នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | ៖ | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | ៖ | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | ៖ | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | ៖ | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jan-2021, 11:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល៖** **សាធារណៈ/Public**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ៖**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ៖**

**ហត្ថលេខា៖**

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជំទាស់ទៅនឹង សាលក្រមនៃសំណុំរឿង ០០២/០២

---

**អ្នកដាក់ឯកសារ៖**

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក ពេជ អង្គ
លោកស្រី Megan HIRST

**ជនជាប់ចោទ៖**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន៖**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

# មាតិកានុទៅ

I. សេចក្តីផ្តើម និងរចនាសម្ព័ន្ធរបស់ចម្លើយតប ....................16

ក. សេចក្តីផ្តើម ....................16

ខ. រចនាសម្ព័ន្ធរបស់ចម្លើយតប ....................20

II. បទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខ ....................20

ក. បទដ្ឋានជាក់លាក់ ....................20

III. អង្គច្បាប់ ....................28

ក. សុពលភាពរបស់សាលក្រម ....................28

ខ. គោលការណ៍នីត្យានុកូលភាព ....................31

IV. សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ....................39

ក. សេចក្តីផ្តើម ....................39

ខ. ចម្លើយតបទៅនឹងមូលដ្ឋាននានា ....................40

គ. ឥទ្ធិពលត្រួតគ្នានៃការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌តាម ការចោទប្រកាន់ ....................72

V. វិធីសាស្ត្រលើភ័ស្តុតាង ....................74

ក. សេចក្តីផ្តើម ....................74

ខ. បន្ទុកនៃភ័ស្តុតាង ....................75

គ. ការវាយតម្លៃភ័ស្តុតាង ....................88

ឃ. ភ័ស្តុតាងជាឯកសារ ....................113

VI. ការទទួលសំណុំរឿង និងវិសាលភាពនៃការជំនុំជម្រះ ....................162

ក. សេចក្តីផ្តើម បរិបទ និងគោលការណ៍ច្បាប់ ....................162

ខ. ការទទួលសំណុំរឿង (ប្រភេទទី ១-៤) ....................164

គ. យុត្តាធិការ (ប្រភេទទី១-៤) ....................181

ឃ. ការអនុវត្តចំពោះមូលដ្ឋាន ....................186

ង. ភ័ស្តុតាងពាក់ព័ន្ធអង្គហេតុ ដែលត្រូវបានចោទប្រកាន់ថា ស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ ....................247

VII. ឧក្រិដ្ឋកម្ម ....................253

ក. សេចក្តីផ្តើម ....................253

ខ. អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត ....................255

គ. ការប្រព្រឹត្តិទៅលើក្រុមគោលដៅ ....................279

ឃ. បទបញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ ....................407

ង. ទីតាំងឧក្រិដ្ឋកម្ម ....................474

VIII. ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ....................547

ក. សេចក្តីផ្តើម ........ 547

ខ. តួនាទី និងមុខងារ ........ 547

គ. សហឧក្រិដ្ឋកម្មរួម ........ 601

ឃ. ការជួយ និងជំរុញ ........ 808

IX. ការសម្រេចដាក់ពិរុទ្ធភាព និង ការដាក់ទោស ........ 828

X. សេចក្តីសន្និដ្ឋាន ........ 842

# មាតិកាលម្អិត

I. សេចក្តីផ្តើម និងរចនាសម្ព័ន្ធរបស់ចម្លើយតប ....16

ក. សេចក្តីផ្តើម ....16

ខ. រចនាសម្ព័ន្ធរបស់ចម្លើយតប....20

II. បទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខ....20

ក. បទដ្ឋានជាក់លាក់ ....20

១. បទដ្ឋានទូទៅ....20

២. កំហុសផ្នែកអង្គច្បាប់ដែលបានចោទប្រកាន់....21

៣. កំហុសផ្នែកអង្គហេតុដែលត្រូវបានចោទប្រកាន់....22

៤. កំហុសផ្នែកនីតិវិធីដែលត្រូវបានចោទប្រកាន់ ....23

៥. ភស្តុតាងហួសពីវិមតិសង្ស័យ....24

៦. សេចក្តីសម្រេចដែលមានសំអាងហេតុ....25

៧. ការបដិសេធចោលភ្លាមៗ ....27

III. អង្គច្បាប់....28

ក. សុពលភាពរបស់សាលក្រម....28

មូលដ្ឋានទី ១៖ អសុពលភាពនៃសាលក្រមដែលបានប្រកាសដោយខុសច្បាប់ទាំងស្រុង....28

ខ. គោលការណ៍នីត្យានុកូលភាព ....31

មូលដ្ឋានទី ៨៥៖ កំហុសពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព ....31

IV. សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌....39

ក. សេចក្តីផ្តើម ....39

ខ. ចម្លើយតបទៅនឹងមូលដ្ឋាននានា....40

មូលដ្ឋានទី ៤៖ ភាពលម្អៀង ឬបុរេវិនិច្ឆ័យរបស់ស្ថាប័នតុលាការ....40

មូលដ្ឋានទី ៨ ៖ សេចក្តីសម្រេចលើការកោះហៅឱ្យចូលមកបង្ហាញខ្លួនបណ្តើរៗ ....44

មូលដ្ឋានទី ៧៖ ការលាតត្រដាងដោយផ្អែកលើភស្តុតាង....48

មូលដ្ឋានទី ១៤៖ ការបំភ្លៃឬការបំផ្លែងភស្តុតាង ....56

មូលដ្ឋានទី ១០៖ សម្ភារៈនានាមកពីសំណុំរឿង០០៣ និង ០០៤....58

មូលដ្ឋានទី ៩៖ ការធ្វេសប្រហែសចំពោះលក្ខណៈពិសេសនៃវិធាន៨៧(៤)....59

មូលដ្ឋានទី ២៣៖ ចម្លើយពីមុនៗ/ចម្លើយពេលក្រោយៗមកទៀត....64

មូលដ្ឋានទី ៦៖ ការកំណត់បទចោទសាជាថ្មីដោយខុសច្បាប់....67

គ. ឥទ្ធិពលត្រួតគ្នានៃការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌តាម ការចោទប្រកាន់....72

V. វិធីសាស្ត្រលើភស្តុតាង....74

ក. សេចក្តីផ្តើម ....................................................................................................................................... 74

ខ. បន្ទុកនៃភ័ស្តុតាង ................................................................................................................................... 75

មូលដ្ឋានទី ១៣៖ ជំនឿឥស្សរចិត្ត និងជំនឿហួសពីវិមតិសង្ស័យ ..................................................................... 75

មូលដ្ឋានទី ១៧៖ បន្ទុកនៃភ័ស្តុតាង .......................................................................................................... 77

មូលដ្ឋានទី ១៩៖ ការសន្និដ្ឋានពង្រីក/ការសន្និដ្ឋានទូទៅ ............................................................................. 80

មូលដ្ឋានទី ១៦៖ ការបំភ្លេចចោលនូវភ័ស្តុតាងដោះបន្ទុក ............................................................................. 83

មូលដ្ឋានទី ១៨៖ អនុមានវិធី/ភ័ស្តុតាងទេសកាល ...................................................................................... 84

គ. ការវាយតម្លៃភ័ស្តុតាង .............................................................................................................................. 88

មូលដ្ឋានទី ១៥៖ ស្តង់ដាពីរនៅក្នុងការប្រើប្រាស់ភ័ស្តុតាងដាក់បន្ទុកនិងដោះបន្ទុក ........................................... 88

មូលដ្ឋានទី ២០៖ ចំនួនភ័ស្តុតាងនិងតម្លៃជាភ័ស្តុតាង ................................................................................... 92

មូលដ្ឋានទី ២១៖ ភាពស៊ីសង្វាក់គ្នា ........................................................................................................... 96

មូលដ្ឋានទី ២២៖ ភាពផ្ទុយគ្នា ................................................................................................................ 100

មូលដ្ឋានទី ២៤៖ ការអានឡើងវិញមុនពេលចូលបង្ហាញខ្លួន ........................................................................ 102

មូលដ្ឋានទី ២៥៖ សំអាងហេតុនៃការនិយាយកុហក ................................................................................... 105

មូលដ្ឋានទី ២៦៖ បុរេវិនិច្ឆ័យវប្បធម៌ ........................................................................................................ 106

មូលដ្ឋានទី ៣២៖ ពាក្យចចាមអារ៉ាម ........................................................................................................ 108

ឃ. ភ័ស្តុតាងជាឯកសារ ............................................................................................................................. 113

១. ការវាយតម្លៃទូទៅ ............................................................................................................................... 113

មូលដ្ឋានទី ៣៦៖ ភ័ស្តុតាងជាឯកសារ និងយថាភាព .................................................................................. 113

២. ចម្លើយរបស់ជនជាប់ចោទ (នាសម័យកាលនោះ និងក្រោយសម័យកាលនោះ) .............................................. 118

មូលដ្ឋានទី ៣១៖ ចម្លើយក្រៅប្រព័ន្ធតុលាការ ............................................................................................ 118

មូលដ្ឋានទី ២៧៖ ចម្លើយ/សៀវភៅរបស់ ខៀវ សំផន .................................................................................. 120

៣. ឯកសារដទៃទៀតនាសម័យកាលនោះ ..................................................................................................... 128

មូលដ្ឋានទី ២៩៖ ឃោសនាការ ................................................................................................................ 128

មូលដ្ឋានទី ១១៖ ភ័ស្តុតាងចេញមកពីប្រវត្តិវិទូដែលមិនបានចូលមកបង្ហាញខ្លួន .............................................. 130

មូលដ្ឋានទី ១២៖ ការទទួលយកបញ្ជីពណ៌ទឹកក្រូចរបស់មន្ទីរ ស-២១ .......................................................... 133

មូលដ្ឋានទី ២៨៖ ភ័ស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម ............................................................ 138

៤. ភ័ស្តុតាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ..................................................................................... 148

មូលដ្ឋានទី ៣០៖ ចម្លើយជាលាយលក្ខណ៍អក្សរ ........................................................................................ 148

មូលដ្ឋានទី ៣៤៖ ការវាយតម្លៃលើចម្លើយនានា ........................................................................................ 155

មូលដ្ឋានទី ៣៣៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ....................................................................... 156

មូលដ្ឋានទី ៣៥៖ ឯកសារដែលទទួលអត្ថប្រយោជន៍ពីសច្ចធារណ៍ ..... 157

៥. ភ័ស្តុតាងអ្នកជំនាញ ..... 159

មូលដ្ឋានទី ៣៧៖ អ្នកជំនាញ ..... 159

VI. ការទទួលសំណុំរឿង និងវិសាលភាពនៃការជំនុំជម្រះ ..... 162

ក. សេចក្តីផ្តើម បរិបទ និងគោលការណ៍ច្បាប់ ..... 162

ខ. ការទទួលសំណុំរឿង (ប្រភេទទី ១-៤) ..... 164

១. កិច្ចស៊ើបសួរ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងការទទួលបានសំណុំរឿងរបស់ ស.ច.ស.អ (ប្រភេទទី១) ..... 166

២. វិសាលភាពនៃរឿងក្តីនេះ៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបណ្តឹងដាក់ជូនទៅ អ.ជ.ស.ដ (ប្រភេទទី ២-៣) ..... 175

៣. ការបកស្រាយដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ប្រភេទទី៣) ..... 179

៤. ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ (ប្រភេទទី ៤) ..... 180

គ. យុត្តាធិការ (ប្រភេទទី១-៤) ..... 181

១. យុត្តាធិការដាច់ខាត ..... 181

២. យុត្តាធិការនីតិវិធី (ប្រភេទទី ១-៤) ..... 182

៣. ការប្តឹងសាទុក្ខលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅ អ.ប.ជ (ប្រភេទី១-២) ..... 183

ឃ. ការអនុវត្តចំពោះមូលដ្ឋាន ..... 186

១. ប្រភេទទី១៖ មូលដ្ឋានពាក់ព័ន្ធនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ ថាមិនមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដូច្នេះស្ថិតនៅក្រៅវិសាលភាពនៃបណ្តឹងដាក់ជូនទៅ ស.ច.ស ..... 186

មូលដ្ឋានទី ៣៨៖ ការអនុវត្តហួសពីវិសាលភាពនៃកិច្ចស៊ើបសួរ ..... 186

មូលដ្ឋានទី ៣៩-៥៩ ..... 192

មូលដ្ឋានទី ៣៩៖ វិសាលភាពភូមិសាស្ត្រនៃបទចោទត្រូវបានកម្រិតត្រឹមឃុំចំនួន ៨ នៅស្រុកត្រាំកក់ 192

មូលដ្ឋានទី ៤០៖ គ្មានបណ្តឹងអំពីការស្លាប់ដែលកើតឡើងក្រៅពីការអត់អាហារ ..... 193

មូលដ្ឋានទី ៤១ ការនិរទេស ..... 193

មូលដ្ឋានទី ៤២ និង៤៧៖ បណ្តឹងចំពោះអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់នៃការបាត់ខ្លួនដោយបង្ខំនៅទំនប់ត្រពាំងថ្ម និងទំនប់ ១ មករា ..... 195

មូលដ្ឋានទី ៤៣៖ ការខ្វះបណ្តឹងចំពោះការប្រហារជីវិតនៅវត្តបារាយណ៍ជាន់ដែក ..... 197

មូលដ្ឋានទី ទី ៤៤៖ គ្មានបណ្តឹងសម្រាប់ការស្លាប់ដោយថៃជន្យ ..... 198

មូលដ្ឋានទី ៤៥៖ គ្មានបណ្តឹងសម្រាប់អង្គហេតុទាក់ទងនឹង “ការរើសអើង” ប្រឆាំងប្រជាជនថ្មីដោយមូលហេតុនយោបាយ ..... 198

មូលដ្ឋានទី ៤៦៖ គ្មានបណ្ដឹងសម្រាប់អង្គហេតុទាក់ទងនឹង "ការរើសអើង" ដោយមូលហេតុសាសនា ...... 199
មូលដ្ឋានទី ៤៨៖ ការធ្វើឱ្យទៅជាទាសករ ...... 200
មូលដ្ឋានទី ៤៩៖ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស ...... 201
មូលដ្ឋានទី ៥០៖ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ...... 201
មូលដ្ឋានទី ៥១, ៥២, ៥៣, ៥៤, ៥៥៖ បណ្ដឹងចំពោះអង្គហេតុដែលបានកើតឡើងនៅក្រាំងតាចាន់ .. 202
មូលដ្ឋានទី ៥៦៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ...... 206
មូលដ្ឋានទី ៥៧៖ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរបស់មនុស្ស ...... 207
មូលដ្ឋានទី ៥៨៖ ការបោសសម្អាត ...... 208
មូលដ្ឋានទី ៥៩៖ គ្មានបណ្ដឹងសម្រាប់អង្គហេតុប្រឆាំងនឹងពុទ្ធសាសិកជននៅត្រាំកក់ ...... 209
២. ប្រភេទទី២៖ មូលដ្ឋានទាក់ទងនឹងអង្គហេតុនានា ដែលចោទប្រកាន់ថាពុំមានការគាំទ្រដោយភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បញ្ចូលទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ...... 210
មូលដ្ឋានទី ៦១៖ បទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ...... 210
មូលដ្ឋានទី ៦២-៦៤ ...... 213
មូលដ្ឋានទី ៦២៖ គ្មានបណ្ដឹងចំពោះការស្លាប់ដោយសារការអត់អាហារនៅឃុំត្រាំកក់ ...... 214
មូលដ្ឋានទី ៦៣៖ គ្មានបណ្ដឹងសម្រាប់ "ការប្រព្រឹត្តដោយរើសអើង" ទាក់ទងនឹង ប្រជាជនថ្មី ...... 215
មូលដ្ឋានទី ៦៤៖ គ្មានបណ្ដឹងសម្រាប់អង្គហេតុនៃការតាមដាន និងការបាត់ខ្លួនអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ...... 216
៣. ប្រភេទទី៣៖ អង្គហេតុដែលម្ចាស់បណ្ដឹងសាទុក្ខអះអាងថានៅក្រៅបណ្ដឹងដាក់ជូនទៅ អ.ជ.ស.ដ ដោយសារការខកខានរបស់ ស.ច.ស មិនបានកំណត់អង្គហេតុទាំងនោះនៅក្នុងដីកាដំណោះស្រាយ ជាអង្គហេតុសំខាន់ដែលកំណត់ប្រភេទតាមផ្លូវច្បាប់ ទំនងនាំទៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ...... 218
មូលដ្ឋានទី ៦០, ៦៥-៨១, ១២៤ និង ១៣៤ ...... 218
មូលដ្ឋានទី ៦០៖ ជនជាតិវៀតណាម ...... 219
មូលដ្ឋានទី ៦៥៖ គ្មានបណ្ដឹងចំពោះការស្លាប់ដោយសារបញ្ហាសុខភាព និងលក្ខខណ្ឌរស់នៅ ...... 223
មូលដ្ឋានទី ៦៦៖ គ្មានបណ្ដឹងចំពោះការស្លាប់ដោយសារការអត់អាហារ នៅខាងក្រៅសំរោង និងតាភេម ...... 224
មូលដ្ឋានទី ៦៧, ៧១, ៧៣, ៧៤៖ បណ្ដឹងអង្គហេតុនៃការរើសអើង ...... 225
មូលដ្ឋានទី ៦៨, ៧២, ៧៥, ៧៦, ៧៧, ១២៤, ១៣៤៖ បណ្ដឹងចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ បីក្រុម ...... 228
មូលដ្ឋានទី ៦៩៖ បណ្ដឹងនៃការស្លាប់នៅក្នុងភូមិ និងមន្ទីរពេទ្យ នៅក្រៅទំនប់ ១ មករា ...... 236

មូលដ្ឋានទី ៧០៖ ការមិនមានបណ្ដឹងអំពីការស្លាប់ ដែលកើតឡើងនៅក្រៅទំនប់១មករា......237

មូលដ្ឋានទី ៧៨៖ ការមិនមានបណ្ដឹង អំពីការសម្លាប់មនុស្សនៅភូមិទ្រា ......237

មូលដ្ឋានទី ៧៩៖ ការមិនមានបណ្ដឹងលើអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ តាមរយៈសហឧក្រិដ្ឋកម្មរួម ......238

មូលដ្ឋានទី ៨០៖ ជនជាតិវៀតណាម......238

មូលដ្ឋានទី ៨១៖ យោធា និងអ្នករដ្ឋការ អតីតរបបសាធារណរដ្ឋខ្មែរ ......239

៤. ប្រភេទទីបួន ៖ មូលដ្ឋានទាក់ទងនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ថា បានដកចេញពីសំណុំរឿង ០០២/០២ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២......241

មូលដ្ឋានទី២ និង ៨២ ដល់៨៤......241

មូលដ្ឋានទី ២៖ ការជំនុំជម្រះដ៏វែងអន្លាយ ក្នុងព្រំដែនដែលអាចរំកិលបាន ......242

មូលដ្ឋានទី ៨២៖ ការមិនមានបណ្ដឹងលើអង្គហេតុ នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់នៃការជម្លៀសប្រជាជនដោយបង្ខំ ......244

មូលដ្ឋានទី ៨៤៖ ជនជាតិវៀតណាម ......245

ង. ភ័ស្តុតាងពាក់ព័ន្ធអង្គហេតុ ដែលត្រូវបានចោទប្រកាន់ថា ស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ ..247

មូលដ្ឋានទី ៣៖ ភ័ស្តុតាងក្រៅវិសាលភាព ប៉ុន្តែពាក់ព័ន្ធ ......247

VII. ឧក្រិដ្ឋកម្ម......253

ក. សេចក្ដីផ្ដើម ......253

ខ. អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត......255

មូលដ្ឋានទី ៨៦៖ ច្បាប់ជាធរមាន៖ គ្មានការបញ្ចូលចេតនាប្រយោល ទៅក្នុងធាតុផ្សំអត្តនោម័តិ ......255

មូលដ្ឋានទី ៨៧ ដល់៩៣៖ អំពើមនុស្សឃាតដោយចេតនាប្រយោល នៅការដ្ឋានត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង និងនៅក្នុងមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល ......266

មូលដ្ឋានទី ៩៤៖ កំហុសឆ្គងពាក់ព័ន្ធ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ ......267

មូលដ្ឋានទី ៩៥, ៩៦៖ មិនមានចេតនារើសអើង ទៅលើពុទ្ធសាសនិកជន និងព្រះសង្ឃ ឬប្រឆាំងជនជាតិចាមឡើយ ......272

មូលដ្ឋានទី ៩៧៖ ការវិភាគដោយខុសឆ្គង ទៅលើនីត្យានុកូលភាពនៃអំពើអមនុស្សធម៌ដទៃទៀត......273

មូលដ្ឋានទី ៩៨៖ ការរំឭកបែបបំប្រួមនៃលក្ខខណ្ឌតម្រូវស្ដីពីអនីត្យានុកូលភាពផ្លូវការ ......276

គ. ការប្រព្រឹត្តិទៅលើក្រុមគោលដៅ......279

១. ពុទ្ធសាសនិកជន......279

មូលដ្ឋានទី ១៨៨៖ ការចោទប្រកាន់ពីគោលនយោបាយ ទាក់ទងនឹងពុទ្ធសាសនិកជន......279

មូលដ្ឋានទី ១០៨៖ មិនមានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា៖ ការប្រព្រឹត្តិស្មើភាព មិនផ្សំបានជាការប្រព្រឹត្តបែបរើសអើង ...... 284

មូលដ្ឋានទី ១០៩៖ មិនមានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ៖ គ្មានភ័ស្តុតាងអំពីផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តរបស់ពុទ្ធសាសនិក ...... 286

២. អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ...... 292

មូលដ្ឋានទី ១៨៧៖ គោលនយោបាយប្រឆាំងនឹងអតីតទាហាន នៃរបបសាធារណរដ្ឋខ្មែរ ...... 292

មូលដ្ឋានទី ១០៦៖ អតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ មិនត្រូវបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយទេ ...... 299

មូលដ្ឋានទី ១២០៖ ការប្រព្រឹត្តិទៅលើអតីតយោធា របបសាធារណរដ្ឋខ្មែរ ...... 304

៣. ជនជាតិចាម ...... 308

មូលដ្ឋានទី ១៨៦៖ គោលនយោបាយចំពោះជនជាតិចាម ...... 309

មូលដ្ឋានទី ១២១៖ គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាម ...... 317

មូលដ្ឋានទី ១២២៖ ការប្រព្រឹត្តិស្មើភាពគ្នា មិនមែនជាធាតុផ្សំ នៃការប្រព្រឹត្តិរើសអើង ...... 320

មូលដ្ឋានទី ១៤១៖ គ្មានការរើសអើងជាក់ស្តែង ចំពោះជនជាតិចាម ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ ...... 321

មូលដ្ឋានទី ១៤៤៖ ភ័ស្តុតាងអំពីការប្រព្រឹត្តមិនខុសគ្នា ពាក់ព័ន្ធនឹងរបបអាហារ និងការកំហិតនានាចំពោះការប្រតិបត្តិសាសនានិងវប្បធម៌ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ...... 323

មូលដ្ឋានទី ១៤៥៖ ការរឹតត្បិតសេរីភាពសាសនា ...... 327

មូលដ្ឋានទី ១៤៦៖ ការចោទប្រកាន់ខុសច្បាប់ ពីការរើសអើងដោយប្រយោល ...... 328

មូលដ្ឋានទី ១៤៧៖ គ្មានចេតនារើសអើង ចំពោះការប្រតិបត្តិសាសនា/វប្បធម៌ ...... 330

មូលដ្ឋានទី ១៣៦៖ ភាពមិនច្បាស់លាស់ និងភាពជាទូទៅ ទាក់ទងនឹងការសម្លាប់មនុស្ស នៅមន្ទីរសន្តិសុខភូមិទ្រា ...... 332

មូលដ្ឋានទី ១៣៧៖ កង្វះភ័ស្តុតាងចំពោះការចោទប្រកាន់ ពីការសម្លាប់មនុស្សនៅវត្តអូរត្រកួន ...... 334

មូលដ្ឋានទី ១៣៨៖ សេចក្តីសន្និដ្ឋានមិនសមហេតុផល អំពីតួលេខនៃការសម្លាប់ដែលបានបង្ហាញ ...... 338

មូលដ្ឋានទី ១៣៩៖ សេចក្តីសន្និដ្ឋានមិនសមហេតុផល អំពីចេតនាសម្លាប់ជនជាតិចាម ក្នុងទ្រង់ទ្រាយធំ ...... 339

មូលដ្ឋានទី ១៤០៖ ការធ្វើទារុណកម្ម ...... 342

មូលដ្ឋានទី ១៤២៖ កំហុសពាក់ព័ន្ធគោលបំណងចម្បង នៃការជម្លៀសប្រជាជន ...... 343

មូលដ្ឋានទី ១៤៣៖ ការបង្ហាញដោយខុសច្បាប់ ពីការចាប់ខ្លួនក្រៅវិសាលភាព នៃការជំនុំជម្រះ ដើម្បីប៉ុនប៉ងបង្ហាញឱ្យឃើញ ពីកម្រិតនៃភាពធ្ងន់ធ្ងរ ដែលជាលក្ខខណ្ឌតម្រូវ ...... 345

មូលដ្ឋានទី ១៤៨៖ ការរំលោភលើសិទ្ធិជាមូលដ្ឋាន ...... 346

មូលដ្ឋានទី ១៤៩៖ ជាចុងក្រោយ កម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើ ដែលកំណត់ការរើសអើងជាក់ស្តែង ...... 348

មូលដ្ឋានទី ៥៖ ការជំនុំជម្រះពីរដង ចំពោះអង្គហេតុដដែល ....................350

មូលដ្ឋានទី ៨៣ និងទី ១៥០៖ ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ ....................351

៤. ជនជាតិវៀតណាម ....................353

i. គោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាម ....................354

មូលដ្ឋានទី ១៨៥៖ គោលនយោបាយចំពោះជនជាតិវៀតណាម ....................354

ii. ការនិរទេសជនជាតិវៀតណាម ....................361

មូលដ្ឋានទី ១៥១៖ ការនិរទេស ....................361

មូលដ្ឋានទី ១០៣ និងទី ១០៤៖ ការនិរទេសជនជាតិវៀតណាម ពីស្រុកត្រាំកក់ (ធាតុផ្សំសត្យានុម័ត) ....................365

មូលដ្ឋានទី ១០៥៖ កំហុសពាក់ព័ន្ធនឹងចេតនា ជម្លៀសជនរងគ្រោះដោយបង្ខំ ឱ្យទៅម្ខាងទៀតនៃព្រំដែនជាតិ ....................372

iii. ការបាត់ខ្លួនជនជាតិវៀតណាមដោយបង្ខំ ....................373

មូលដ្ឋានទី ១១១៖ កំហុសនៅក្នុងការសន្និដ្ឋានអំពីការបាត់ខ្លួនដោយបង្ខំ ចំពោះជនជាតិវៀតណាម ....................373

មូលដ្ឋានទី ១១២៖ អង្គជំនុំជម្រះមានកំហុស ដោយបានសម្រេចថា ខ្មែរក្រោមគឺជាជនរងគ្រោះ នៃការបាត់ខ្លួនដោយបង្ខំ ....................375

iv. អំពើមនុស្សឃាតលើជនជាតិវៀតណាម ....................376

មូលដ្ឋានទី ១៥២៖ កំហុសក្នុងការសន្និដ្ឋាន លើការសម្លាប់ជនជាតិវៀតណាមបួនគ្រួសារ នៅខេត្តស្វាយរៀង ....................376

មូលដ្ឋានទី ១២៨៖ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាមប្រាំមួយនាក់ ....................377

មូលដ្ឋានទី ១៥៥៖ កំហុសក្នុងការសន្និដ្ឋាន អំពីការធ្វើមនុស្សឃាត លើជនជាតិវៀតណាមនៅវត្តខ្សាច់ ....................379

មូលដ្ឋានទី ១៥៦៖ កំហុសក្នុងការសន្និដ្ឋាន អំពីការធ្វើមនុស្សឃាត លើជនជាតិវៀតណាម នៅក្នុងតំបន់ ៥០៥ (ក្រចេះ) ....................380

មូលដ្ឋានទី ១៥៤៖ កំហុសក្នុងការសន្និដ្ឋាន អំពីការធ្វើមនុស្សឃាត លើជនជាតិវៀតណាម នៅក្នុងភូមិភាគបស្ចឹម ....................382

មូលដ្ឋានទី ១៥៣៖ កំហុសក្នុងការសន្និដ្ឋាន លើការសម្លាប់ជនជាតិវៀតណាម នៅតាមសមុទ្រ ....................384

v. ការសម្លាប់រង្គាលជនជាតិវៀតណាម ....................385

មូលដ្ឋានទី ១៥៧៖ ការសម្លាប់រង្គាលជនជាតិវៀតណាម ....................385

vi. ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ....................388

មូលដ្ឋានទី ១៥៨៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ....................388

មូលដ្ឋានទី ១១០៖ កំហុសនានានៅក្នុងការសន្និដ្ឋានអំពីការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ចំពោះជនជាតិវៀតណាម ....................393

មូលដ្ឋានទី ១២៦៖ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ ....395

មូលដ្ឋានទី ១៣០៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ....398

vii. អំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម ....400

មូលដ្ឋានទី ១៥៩៖ អំពើប្រល័យពូជសាសន៍ ....400

ឃ. បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ....407

មូលដ្ឋានទី ១៦០៖ កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាព នៃការរៀបអាពាហ៍ពីពាហ៍ដោយបង្ខំ ក្នុងក្របខណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩....408

មូលដ្ឋានទី ១៧១ និងទី ១៧២៖ ការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ....413

មូលដ្ឋានទី ១៦២៖ គ្មានការព្រមព្រៀង នៅក្នុងច្បាប់ជាតិ ....420

មូលដ្ឋានទី ១៦៥៖ កំហុសពាក់ព័ន្ធនឹងខ្លឹមសារ បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ....423

មូលដ្ឋានទី ១៦៨៖ កំហុសពាក់ព័ន្ធនឹងការផ្សព្វផ្សាយ បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ....432

មូលដ្ឋានទី ១៦៩៖ កំហុសពាក់ព័ន្ធលក្ខខណ្ឌក្រៅបទបញ្ញា ....434

មូលដ្ឋានទី ១៦៧៖ កំហុសពាក់ព័ន្ធនឹងការអនុវត្ត បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ....437

មូលដ្ឋានទី ១៦៦៖ ការបំភ្លៃភ័ស្តុតាងស្តីពី គោលបំណងផ្សេងទៀត ដែលបានចោទប្រកាន់....439

មូលដ្ឋានទី ១៧០៖ ការប្រើការគំរាមកំហែង និងបរិបទបង្ខិតបង្ខំនៅក្នុងប្រទេស....446

មូលដ្ឋានទី ១៦១ ៖ កំហុសក្នុងការពិនិត្យលក្ខណវិនិច្ឆ័យនៃប្រភេទ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងលក្ខណវិនិច្ឆ័យនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដូចបានរៀបរាប់ ....451

មូលដ្ឋានទី ១៦៣ ៖ កំហុសក្នុងការពិនិត្យលើការឈឺចាប់ដែលទទួលរងក្នុងការរៀបអាពាហ៍ពិពាហ៍ 452

មូលដ្ឋានទី ១៦៤ ៖ កំហុសពាក់ព័ន្ធនឹងបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តបទបញ្ញា .459

មូលដ្ឋានទី ១៧៤ ៖ កំហុសដែលពាក់ព័ន្ធនឹងការតាមដានការរួមដំណេក ....459

មូលដ្ឋានទី ១៧៣ ៖ កំហុសពាក់ព័ន្ធនឹងការពិនិត្យលើការទទួលរងការឈឺចាប់ក្នុងបរិបទនៃទំនាក់ទំនងផ្លូវភេទក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ....469

មូលដ្ឋានទី ២៤៤ ៖ ការរៀបអាពាហ៍ពិពាហ៍ ....474

ង. ទីតាំងឧក្រិដ្ឋកម្ម ....474

i. សហករណ៍ និងការដ្ឋានការងារ ....474

១. សហករណ៍ស្រុកត្រាំកក់ ....476

មូលដ្ឋានទី ៩៩ ៖ កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអំពើអកម្ម “នាំឱ្យមានពិរុទ្ធ” ....476

មូលដ្ឋានទី ១០០ ៖ កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងចេតនាប្រយោល ....478

មូលដ្ឋានទី ១០២ ៖ គ្មានភស្តុតាងបង្ហាញពីចេតនាប្រយោលចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និងលក្ខខណ្ឌរស់នៅ ..... 481

មូលដ្ឋានទី ១០១៖ អវត្តមានភស្តុតាងក្នុងកម្រិតតម្រូវនៃការស្លាប់ដែលរងការចោទប្រកាន់ ..... 483

មូលដ្ឋានទី ១០៧ ៖ ប្រជាជនថ្មីមិនត្រូវបានធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 490

២. ទំនប់១មករា ..... 499

មូលដ្ឋានទី ១១៥៖ គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល ..... 499

មូលដ្ឋានទី ១១៦៖ ភាពមិនសមហេតុផលនៃការកត់សម្គាល់ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាតដោយចេតនាប្រយោល ..... 501

មូលដ្ឋានទី ១១៧ ៖ គ្មានភស្តុតាងអំពីចេតនាប្រយោលចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និងលក្ខខណ្ឌរស់នៅ ..... 506

មូលដ្ឋានទី ១១៨ ៖ ការប្រព្រឹត្តលើប្រជាជនថ្មី ..... 509

មូលដ្ឋានទី ១១៩ ៖ ការចោទប្រកាន់ចំពោះការប្រព្រឹត្តលើប្រជាជនថ្មី ..... 513

៣. ទំនប់ត្រពាំងថ្ម ..... 516

មូលដ្ឋានទី ១១៣ ៖ គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល ..... 516

មូលដ្ឋានទី ១១៤៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 520

៤. ព្រលានយន្តហោះកំពង់ឆ្នាំង ..... 522

មូលដ្ឋានទី ១២៣៖ ព្រលានយន្តហោះកំពង់ឆ្នាំង ..... 522

ii. មន្ទីរសន្តិសុខ ..... 525

១. មន្ទីរសន្តិសុខ ស-២១ ..... 526

មូលដ្ឋានទី ១២៥៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 526

២. មន្ទីរសន្តិសុខក្រាំងតាចាន់ ..... 531

មូលដ្ឋានទី ១២៧៖ មន្ទីរសន្តិសុខក្រាំងតាចាន់ ..... 531

៣. មន្ទីរសន្តិសុខភ្នំក្រោល ..... 534

មូលដ្ឋានទី ១៣៣៖ ការធ្វើឱ្យទៅជាទាសករ ..... 534

មូលដ្ឋានទី ១៣១៖ កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាលើ ហ៊ើស ..... 535

មូលដ្ឋានទី ១៣២ ៖ កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាត ដោយចេតនាប្រយោលលើ ទូច ..... 538

មូលដ្ឋានទី ២៥១ ៖ សេចក្តីសន្និដ្ឋានសរុប ..... 541

មូលដ្ឋានទី ១៣៥ ៖ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ..... 542

៤. មន្ទីរសន្តិសុខអូរកន្សែង ..... 544

មូលដ្ឋានទី ១២៩ ៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 544

VIII. ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល........547

ក. សេចក្ដីផ្ដើម........547

ខ. តួនាទី និងមុខងារ........547

មូលដ្ឋានទី ២០៣៖ "សមាជិក" នៃ គណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍........549

មូលដ្ឋានទី ២០៥៖ សមាជិកមន្ទីរ ៨៧០........562

មូលដ្ឋានទី ២០០៖ ការភាន់ច្រឡំទាក់ទងនឹងកន្លែងស្នាក់នៅ កន្លែងការងារ និងការធ្វើដំណើរ........567

មូលដ្ឋានទី ២០១៖ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការ CPNLAF 573

មូលដ្ឋានទី ២០២៖ ប្រធានគណៈប្រធានរដ្ឋ........576

មូលដ្ឋានទី ២០៦៖ ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម........582

មូលដ្ឋានទី ២០៧៖ ការទទួលខុសត្រូវចំពោះក្រសួងការបរទេស........588

មូលដ្ឋានទី ១៩០៖ មជ្ឈិមបក្ស........593

មូលដ្ឋានទី ១៩១ ៖ អង្គការ........596

មូលដ្ឋានទី ១៩៤៖ វចនាសម្ព័ន្ធយោធា និងការប្រាស្រ័យទាក់ទង........598

គ. សហឧក្រិដ្ឋកម្មរួម........601

១. គោលបំណងរួម........603

មូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤ ៖ កំហុសអំពីគោលបំណងរួមដែលចោទប្រកាន់ និងផែនការបដិវត្តសង្គមនិយមរបស់ ប.ក.ក........604

មូលដ្ឋានទី ១៧៨៖ អភិក្រមដែលខុសសម្រាប់ការពិនិត្យលើគោលនយោបាយនានា........624

មូលដ្ឋានទី ១៧៩៖ កំហុសនានាពាក់ព័ន្ធគោលគំនិតស្ដីពីខ្មាំងរបស់ ប.ក.ក........628

មូលដ្ឋានទី ១៨៤៖ កំហុសទាក់ទងនឹង "គោលនយោបាយ" ........647

មូលដ្ឋានទី ១៨០៖ អត្ថិភាពនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន គោលដៅនៃសហករណ៍........662

មូលដ្ឋានទី ១៨១, ១៨៣៖ ការសន្និដ្ឋានខុសអំពីគោលនយោបាយ ប.ក.ក និងកំហុសទាក់ទងនឹង លក្ខណៈឧក្រិដ្ឋនៃគោលនយោបាយនោះ........665

២. ការចូលរួមចំណែកសំខាន់........678

មូលដ្ឋានទី ២២៦៖ កំហុសពាក់ព័ន្ធនឹងការរួមចំណែករបស់ ខៀវ សំផន........680

មូលដ្ឋានទី ២២៧, ២២៨, ២២៩, ២៣០, ២៣១៖ គាំទ្រ និងលើកកម្ពស់គោលបំណងរួម និង គោលនយោបាយនៃគោលបំណងនេះ លើកទឹកចិត្ត ញុះញង់ និងផ្ដល់ធម្មានុរូបចំពោះការ អនុវត្តគោលបំណងរួម ណែនាំ បង្កលទ្ធភាព និងត្រួតត្រាលើការអនុវត្ត........686

មូលដ្ឋានទី ១៩២៖ មន្ទីរ ៨៧០........701

មូលដ្ឋានទី ១៩៨៖ ពីឆ្នាំ ១៩៧០ ដល់ ខែមេសា ឆ្នាំ១៩៧៥........705

មូលដ្ឋានទី ១៩៩៖ ការចូលរួមក្នុងអង្គប្រជុំគណៈកម្មាធិការមជ្ឈិមក្នុងខែមិថុនា ឆ្នាំ១៩៧៤ និង ខែមេសា ឆ្នាំ១៩៧៥ ........ 707

មូលដ្ឋានទី ២០៤៖ វគ្គបណ្ដុះបណ្ដាល ........ 712

មូលដ្ឋានទី ១៨២៖ កំហុសអំពីតួនាទីរបស់ ខៀវ សំផន ទាក់ទងនឹងសហករណ៍ ........ 716

មូលដ្ឋានទី ២២២៖ កំហុសស្ដីពីការដឹងអំពីឧក្រិដ្ឋកម្មទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ........ 720

៣. ចេតនា ........ 722

i. ធាតុផ្សំអត្តនោម័តិសម្រាប់សហឧក្រិដ្ឋកម្មរួម ........ 724

មូលដ្ឋានទី ២២៥៖ ធាតុផ្សំអត្តនោម័តិ៖ ចេតនាប្រព្រឹត្តបទឧក្រិដ្ឋកម្ម ស្ថិតនៅចំចំណុចស្នូលនៃគោលបំណងរួម ........ 724

មូលដ្ឋានទី ២៣២៖ ការរម្លឹកកអំពីកំហុសលើចេតនាចូលរួមគាំទ្រគោលបំណងឧក្រិដ្ឋកម្មរួម ........ 725

មូលដ្ឋានទី ២៣៣៖ ការលើកហេតុផលមិនត្រឹមត្រូវក្នុងការទាញការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋ ........ 726

ii. ការដឹងជាសូចនាករនៃចេតនារបស់ម្ចាស់បណ្ដឹងសាទុក្ខ ........ 728

មូលដ្ឋានទី ២០៨៖ ការប្រែប្រួលកម្រិតនៃការដឹងទៅតាមពេលវេលា ........ 728

មូលដ្ឋានទី ១៩៥៖ គោលការណ៍រក្សាការសម្ងាត់ ........ 729

មូលដ្ឋានទី ១៩៦ និង ១៩៧៖ កុមារភាព យុវវ័យ និងអាជីព ........ 732

មូលដ្ឋានទី ១៩៣៖ ទស្សនាវដ្ដីទង់បដិវត្តន៍/ទស្សនាវដ្ដី យុវជនយុវនារីបដិវត្តន៍ ........ 736

មូលដ្ឋានទី ២២៣៖ ការដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ........ 738

iii. ចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមគោលដៅ ........ 741

មូលដ្ឋានទី ២២០ និង ២៤២៖ ពុទ្ធសាសនិកជន ........ 741

មូលដ្ឋានទី ២៤៣ និង ២២១៖ អតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ........ 746

មូលដ្ឋានទី ២៣៦ និង ២១៨៖ ជនជាតិចាម ........ 751

មូលដ្ឋានទី ២១៩, ២៣៧, ២៣៨, ២៣៩, ២៤០, ២៤១៖ ជនជាតិវៀតណាម ........ 757

iv. ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងអំឡុងពេលបោសសម្អាតផ្ទៃក្នុង និងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានា ........ 772

មូលដ្ឋានទី ២១៦, ២១៧ និង ២៣៥ ........ 772

v. ចេតនាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនៅតាមសហករណ៍ និងការដ្ឋាន ........ 781

មូលដ្ឋានទី ២៣៤៖ សហករណ៍ និងការដ្ឋាន ........ 781

មូលដ្ឋានទី ២១១៖ កំហុសដែលតែងកើតមាននៅគ្រប់ទីកន្លែង ........ 783

មូលដ្ឋានទី ២១២៖ ស្រុកត្រាំកក់ ........ 793

មូលដ្ឋានទី ២១៣៖ ទំនប់ត្រពាំងថ្ម ........ 795

មូលដ្ឋានទី ២១៤៖ ទំនប់ ១ មករា ........ 798

មូលដ្ឋានទី ២១៥៖ ព្រលានយន្តហោះកំពង់ឆ្នាំង ...... 799

vi. ចេតនាប្រព្រឹត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ រួមទាំងការរំលោភសេពសន្ថវៈ ...... 804

មូលដ្ឋានទី ២១០៖ កំហុសស្តីពីការដឹងអំពីឧក្រិដ្ឋកម្មទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ...... 804

ឃ. ការជួយ និងជំរុញ ...... 808

១. ធាតុផ្សំសត្យានុម័តិ ...... 811

មូលដ្ឋានទី ២៤៦៖ គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាត ដោយចេតនាដោយប្រយោល នៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះយោធាកំពង់ឆ្នាំង ...... 811

មូលដ្ឋានទី ២៤៧៖ គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតនៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល ...... 816

២. ធាតុផ្សំអត្តនោម័តិ ...... 818

មូលដ្ឋានទី ២៤៥៖ ការជួយជ្រោមជ្រែង និងការជំរុញ តាមផ្លូវច្បាប់ ...... 818

មូលដ្ឋានទី ២០៩៖ ការដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត ...... 822

មូលដ្ឋានទី ២៤៨៖ គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាដោយប្រយោល នៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង ...... 824

មូលដ្ឋានទី ២៤៩៖ គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាដោយប្រយោល នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល ...... 826

IX. ការសម្រេចដាក់ពិរុទ្ធភាព និង ការដាក់ទោស ...... 828

មូលដ្ឋានទី ២៥២៖ ការបង្ហាញពីភាពលម្អៀងទាក់ទងនឹងគោលដៅការដាក់ទោស ...... 829

មូលដ្ឋានទី ២៥៣៖ កំហុសលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ...... 830

មូលដ្ឋានទី ២៥៤៖ កំហុសពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស ...... 833

មូលដ្ឋានទី ២៥៥៖ កំហុសពាក់ព័ន្ធនឹងស្ថានសម្រាលទោស ...... 837

មូលដ្ឋានទី ២៥៦៖ កំហុសស្តីពីសីលធម៌ល្អ ...... 839

X. សេចក្តីសន្និដ្ឋាន ...... 842

## I. សេចក្តីផ្តើម និងរចនាសម្ព័ន្ធរបស់ចម្លើយតប

### ក. សេចក្តីផ្តើម[1]

1. តទៅនេះ សហព្រះរាជអាជ្ញាសូមឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ **ខៀវ សំផន** ("ម្ចាស់បណ្តឹងសាទុក្ខ")[2] ចំពោះការសម្រេចដាក់ពិរុទ្ធភាពរូបគាត់នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០២ ដែលបានចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[3]។ នៅក្នុងសេចក្តីសម្រេចដែលត្រូវបានប្រកាសយ៉ាងត្រឹមត្រូវ[4] ដោយផ្អែកលើភស្តុតាងរួម និងការលើកឡើងយ៉ាងត្រឹមត្រូវអំពីអង្គច្បាប់ ដែលគោរពយ៉ាងពេញលេញទៅតាមគោលការណ៍នីត្យានុកូលភាព[5] និងសិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[6] អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") បានសម្រេចដាក់ពិរុទ្ធភាពយ៉ាងត្រឹមត្រូវចំពោះម្ចាស់បណ្តឹងសាទុក្ខពីការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម[7] រួមមាន៖ (១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[8] (២) បទប្រល័យពូជសាសន៍ទៅលើជនជាតិ

---

[1] សហព្រះរាជអាជ្ញាសូមទទួលស្គាល់នូវការចូលរួមវិភាគទានយ៉ាងធំធេងរបស់បណ្តាអ្នកច្បាប់ដែលបានប្តេជ្ញាចិត្តក្នុងការតាក់តែង ពិនិត្យ និងកែសម្រួលចម្លើយតបនេះរួមមាន៖ លោក William S. Smith និងលោក សេង ប៊ុនឃាង ជាសហព្រះរាជអាជ្ញារង លោក ស្រ៊ា រតនៈ លោក Vincent de Wilde d'Estmael លោកស្រី Ruth Mary Hackler លោក ពេជ្រ សម្បត្តិ លោកស្រី Nisha Patel លោកស្រី Helen Worsnop លោក Cóman Kenny លោកស្រី Ann Ellefsen-Tremblay លោកស្រី Melissa J. McKay លោក Evan Ritli លោកស្រី Holly Huxtable និងលោកស្រី Isabelle Hayden ព្រមទាំងកម្មសិក្សាការីដែលបានជួយជ្រោមជ្រែងដែលមិនអាចកាត់ថ្លៃបាន។

[2] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ។ សូមមើលផងដែរ មូលដ្ឋានទី ២៥០៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *សេចក្តីសន្និដ្ឋានទូទៅ* កថាខណ្ឌ ២១៤១-២១៤៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨៣ (ភាសាអង់គ្លេស) ទំព័រ ៧៧ (ភាសាបារាំង) ទំព័រ ១១៨ (ភាសាខ្មែរ)។

[3] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២

[4] សូមមើលខាងក្រោម នៅក្នុងចម្លើយតបនេះ ដែលចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងមូលដ្ឋានទី ១ របស់ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានបញ្ចូលក្នុងឧបសម្ព័ន្ធ ក នៃឯកសារនេះ ("*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១")។

[5] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៥។

[6] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤, ៦-១០, ១៤, ២៣។

[7] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦-៤៣០៧។

[8] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការធ្វើមនុស្សឃាតដោយចេតនា ការសម្លាប់រង្គាល ការនិរទេស ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា។ អំពើអមនុស្សធម៌ផ្សេងៗទៀត៖ ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស ការបាត់ខ្លួនដោយបង្ខំ ការជម្លៀសដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។

វៀតណាម (ដោយការសម្លាប់) និង (៣) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[9]។ អ.ជ.ស.ដ ក៏បានរកឃើញផងដែរថា គាត់បានជួយនិងជំរុញ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយ*ចេតនាប្រយោល* នៅតាមទីកន្លែងជាច្រើន[10]។ ចំពោះឧក្រិដ្ឋកម្មទាំងនេះ ដែលឧក្រិដ្ឋកម្មនីមួយៗស្ថិតក្រោម *បណ្ដឹងអំពីអង្គហេតុ*នៃសំណុំរឿង ០០២/០២ ដូចគ្នា[11] ម្ចាស់បណ្ដឹងសាទុក្ខដែលជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតយ៉ាងត្រឹមត្រូវ។ នៅក្នុងបណ្ដឹងសាទុក្ខ ម្ចាស់បណ្ដឹងបានចោទប្រកាន់ជាខ្លឹមសារថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនបានដឹងអ្វីទាំងអស់ មិនបានឃើញអ្វីទាំងអស់ មិនបានឮអ្វីទាំងអស់ មិនបានធ្វើអ្វីទាំងអស់ដើម្បីទាញរូបគាត់ទៅក្នុងឧក្រិដ្ឋកម្មនានាដែលគាត់រងការសម្រេចដាក់ពិរុទ្ធភាព ហើយថា អ.ជ.ស.ដ បានពិនិត្យភ័ស្ដុតាងនៅក្នុងសំណុំរឿង តាមរយៈការធ្វើបុរេវិនិច្ឆ័យក្នុងការសម្រេចដាក់ពិរុទ្ធភាពជាស្រេចទៅហើយ។ ទោះជាយ៉ាងណាក្ដី ការវិភាគភ័ស្ដុតាងជារួមយ៉ាងត្រឹមត្រូវ រួមទាំងសាលក្រមមានសំអាងហេតុរបស់ អ.ជ.ស.ដ ជម្រះអស់នូវការស្រមើស្រមៃនេះហើយ។ ដោយអនុវត្តច្បាប់ត្រឹមត្រូវទៅលើភ័ស្ដុតាងរួម អ.ជ.ស.ដ បានរកឃើញថាម្ចាស់បណ្ដឹងសាទុក្ខមានពិរុទ្ធភាព ដោយផ្អែកលើតួនាទី និងមុខងាររបស់គាត់ និងការប្រព្រឹត្តិរបស់គាត់។ ម្ចាស់បណ្ដឹងសាទុក្ខបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងឧក្រិដ្ឋកម្មទាំងនេះ "តាងនាមឱ្យកម្ពុជាប្រជាធិបតេយ្យ"[12]។ ទាក់ទិននឹងការទទួលខុសត្រូវរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្ម ការសម្រេចទៅតាមគោលបំណងរួមរបស់ ប.ក.ក ការអនុវត្តឱ្យបានលឿននូវបដិវត្តន៍សង្គមនិយម តាមរយៈ "មហាលោតផ្លោះ" ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មចម្បងៗជាទ្រង់ទ្រាយធំ តាមរយៈគោលនយោបាយកម្ទេច ៥ របស់ ប.ក.ក ដែលមានទំនាក់ទំនងមិនអាចផ្ដាច់បានពីគោលបំណងរួម[13]។ ម្ចាស់បណ្ដឹងសាទុក្ខគឺជាមេដឹកនាំជាន់ខ្ពស់នៅក្នុងបក្ស ដែលមានសិទ្ធិបញ្ចេញយោបល់តាមរយៈគោលការណ៍ប្រជាធិបតេយ្យ

---

[9] ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តិដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិរបស់ពួកគេនៅក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ នៅមន្ទីរសន្តិសុខ ស-២១។

[10] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៨ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាតដោយ*ចេតនាដោយប្រយោល* នៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានព្រលានយន្តហោះយោធាកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល)។

[11] សូមមើល ផ្នែក VI៖ *បណ្ដឹងអំពីអង្គហេតុ* និងវិសាលភាពនៃការជំនុំជម្រះ។

[12] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦។

[13] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៥-១៧៨, ១៨៩, ២២៤។

សមូហភាព[14] គាត់មានទំនាក់ទំនងពិសេសជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ជាពិសេស ប៉ុល ពត និង នួន ជា។ តួនាទី និងមុខងាររបស់គាត់រួមមានជា៖ បេក្ខជន បន្ទាប់មកជាសមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មាធិការមជ្ឈិម អ្នកចូលរួមជាទៀងទាត់នៅក្នុងស្ថាប័នបង្កើតគោលនយោបាយថ្នាក់កំពូលគឺគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកមន្ទីរ ៨៧០ ដែលត្រួតពិនិត្យមើលការអនុវត្តនូវសេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង ជាប្រធាននៃគណៈប្រធានរដ្ឋ ដែលតាមរយៈមុខតំណែងនេះ គាត់គឺជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ[15]។

2. ដោយមានចេតនាដែលជាលក្ខខណ្ឌតម្រូវចាំបាច់[16] គាត់បានចូលរួមតាមមធ្យោបាយច្រើនយ៉ាងនៅក្នុងសហឧក្រិដ្ឋកម្មរួម[17] ដោយ៖ គាំទ្រ[18] និងលើកកម្ពស់[19] គោលបំណងរួម ជំរុញ ញុះញង់ និងធ្វើធម្មានុរូបកម្មនូវការអនុវត្តសហឧក្រិដ្ឋកម្មរួមនេះ តាមរយៈគោលនយោបាយរបស់វា[20] ណែនាំឱ្យអនុវត្តតាមរយៈគោលនយោបាយរបស់វា[21] និងជួយ និងគ្រប់គ្រងការអនុវត្តគោលបំណងរួម និងគោលនយោបាយរបស់វា[22]។ ដោយមានការដឹង និងយល់ជ្រួតជ្រាបចាំបាច់[23] គាត់ក៏បានផ្តល់ "ការលើកទឹកចិត្ត"[24] "ជំនួយជាក់ស្តែង"[25] និង "ការគាំទ្រផ្នែកសីលធម៌"[26] ដល់កម្មាភិបាល ប.ក.ក នៅទូទាំងប្រទេស ដែលនាំមកនូវក្តីវិនាសជាទ្រង់ទ្រាយធំ ដែលបណ្តាលឱ្យមានការសម្រេចដាក់ពិរុទ្ធភាពរូបគាត់ តាមរយៈការជួយនិងជំរុញ។

---

[14] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១-៣៩៤, ៣៩៩។

[15] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩០-១៩១, ១៩៤, ២០០-២០៣, ២០៥-២០៧។

[16] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ ផ្នែក ១៨.២.២ *ចេតនា* កថាខណ្ឌ ៤២៧៩-៤៣០៥។

[17] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ ផ្នែក ១៨.២.១៖ *ការចូលរួមចំណែកនៅក្នុងគោលបំណងរួម* កថាខណ្ឌ ៤២៥៧-៤២៧៨។

[18] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧-៤២៦១។

[19] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២-៤២៦៤។

[20] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥-៤២៧០។

[21] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧១-៤២៧៤។

[22] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៥-៤២៧៨។

[23] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៩, ២៤៥, ២៤៨-២៤៩។

[24] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៥ (ជាអ្នកជួយនិងជំរុញនៅតាមសហករណ៍)។

[25] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៧ (ជាអ្នកជួយនិងជំរុញនៅតាមមន្ទីរសន្តិសុខ និងនៅក្នុងបរិបទនៃការបោសសម្អាតផ្ទៃក្នុង)។

[26] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៥ (ជាអ្នកជួយនិងជំរុញនៅតាមសហករណ៍) ៤៣១៧ (ជាអ្នកជួយនិងជំរុញនៅតាមមន្ទីរសន្តិសុខ និងនៅក្នុងបរិបទនៃការបោសសម្អាតផ្ទៃក្នុង)។

3. បណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងត្រូវយកមកអានដោយប្រុងប្រយ័ត្ន។ ដូចដែលនឹងពិភាក្សាលម្អិតនៅក្នុងចម្លើយតបនេះ គាត់វាយតម្លៃទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូង ("សាលក្រម") និងភ័ស្តុតាងជាមូលដ្ឋាននៃសាលក្រមនេះ តាមបែបជ្រើសរើស និងជាផ្នែកៗ បកស្រាយខុស និងយល់ខុសចំពោះការយល់ឃើញទៅលើភ័ស្តុតាង មិនយកចិត្តទុកដាក់ ឬយល់ខុសចំពោះយុត្តិសាស្ត្រផ្នែកព្រហ្មទណ្ឌអន្តរជាតិនៅ អ.វ.ត.ក និង ផ្តល់អត្ថបទដកស្រង់ដែលមិនគាំទ្រដល់ការអះអាងរបស់ខ្លួនទេ។

4. បណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងគួរត្រូវបានបដិសេធចោល ដោយសារជាញឹកញយគាត់មិនបានបំពេញទៅតាមបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខឡើយ រួមមាន ដោយការមិនផ្តល់ការយោងជាក់លាក់ទៅកំណត់ហេតុ ប្រតិចារឹក ភ័ស្តុតាង ឬសាលក្រម ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួន និងបានដាក់ទឡ្ហីករណ៍ដែលមានលក្ខណៈមិនច្បាស់លាស់ មានលក្ខណៈផ្ទុយ និងមានលក្ខណៈស្រពិចស្រពិល ឬមានភាពមិនពេញលេញតាមវិធីផ្សេងទៀត។ ក្រៅពីនេះ គាត់មិនបាន៖ បង្ហាញកំហុសផ្នែកអង្គច្បាប់ដែលមោឃៈសាលក្រមទាំងមូល ឬមួយផ្នែក មិនបានបង្ហាញកំហុសផ្នែកអង្គហេតុដែលនាំឱ្យមានភាពមិនយុត្តិធម៌ជាក់ស្តែង និងមិនបានបង្ហាញពីការបំពានឆន្ទានុសិទ្ធិដែលបង្ខំឱ្យសន្និដ្ឋានថា អ.ជ.ស.ដ មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមផ្លូវតុលាការ នោះទេ។ ចុងក្រោយម្ចាស់បណ្តឹងសាទុក្ខក៏មិនបានបង្ហាញពីការលម្អៀងជាក់ស្តែង ឬការយល់ឃើញថាមានភាពលម្អៀងដោយសមហេតុផលនោះដែរ។ នៅក្នុងចំណុចនេះ ក្នុងការជំទាស់ទៅនឹងភាពមិនលម្អៀងរបស់ចៅក្រម ជាញឹកញយម្ចាស់បណ្តឹងសាទុក្ខបានប្រើប្រាស់ភាសាធ្ងន់ៗ ដែលហួសពីព្រំដែននៃការតស៊ូមតិដែលអាចទទួលយកបាន[27]។

5. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញកំហុសនានាដែលនាំឱ្យមានអន្តរាគមន៍ទៅលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿងនេះទេ ហេតុនេះការសម្រេចដាក់ពិរុទ្ធភាព និងការផ្តន្ទាទោសគួរត្រូវបានតម្កល់។

---

[27] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១៧ (យោងទៅ "ឆន្ទៈទាញ ខៀវ សំផន ឱ្យចូលពាក់ព័ន្ធនៅគ្រប់កម្រិត" របស់ អ.ជ.ស.ដ), ១៤៤១ ("គឺថា សុន្ទរកថារបស់មេដឹកនាំ ប.ក.ក ត្រូវបានកាត់ផ្តាច់ជាប្រព័ន្ធចេញពីបរិបទ និងបកស្រាយដាក់បន្ទុក តាមការចង់បានរបស់អង្គជំនុំជម្រះ ដើម្បីសន្និដ្ឋានថា គោលនយោបាយរបស់ ប.ក.ក មានលក្ខណៈឧក្រិដ្ឋ"), ១៦០០ (អ.ជ.ស.ដ សម្រេចបង្កើតជាគោលនយោបាយមានលក្ខណៈឧក្រិដ្ឋ ដើម្បីធ្វើការផ្តន្ទាទោសឱ្យខាងតែបាន), ១៦០១ ("ការពិនិត្យដោយលម្អៀងទៅលើការទំនាក់ទំនង និងបណ្តាញរដ្ឋបាលរបស់ ប.ក.ក មានគោលដៅទាញ ខៀវ សំផន ឱ្យចូលពាក់ព័ន្ធ "ដោយប្រយោល" ដោយសារតែគ្មានភ័ស្តុតាងបង្ហាញអំពីការចូលរួមចំណែករបស់គាត់ ក្នុងទិដ្ឋភាពនៃគោលបំណងរួម")។

### ខ. រចនាសម្ព័ន្ធរបស់ចម្លើយតប

6. ដើម្បីឱ្យមានភាពងាយស្រួលក្នុងការផ្ដល់ឯកសារយោង សហព្រះរាជអាជ្ញាបានដាក់លេខរៀងជាបន្តបន្ទាប់ទៅលើទទ្បីករណ៍នៃបណ្ដឹងសាទុក្ខរបស់ម្ចាស់បណ្ដឹង ដូចមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ក នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់ ឧបសម្ព័ន្ធដែលមានលេខរៀង ភ្ជាប់មកជាមួយចម្លើយតបនេះមានជាបីភាសា[28]។ ចម្លើយតបនីមួយៗទៅនឹងទទ្បីករណ៍ទាំងនេះនឹងយោងជាលេខរៀងដែលស្របទៅនឹងលេខដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ ក។ ចម្លើយតបដ៏សំខាន់ត្រូវបានរៀបចំជាផ្នែកនានាដូចតទៅ៖ បទដ្ឋាននៃការពិនិត្យលើបណ្ដឹងសាទុក្ខ អង្គច្បាប់ សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ វិធីសាស្ត្រចំពោះភ័ស្តុតាង *បណ្ដឹងអំពីអង្គហេតុ* និងវិសាលភាពនៃការជំនុំជម្រះ ឧក្រិដ្ឋកម្ម ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល និង ការសម្រេចដាក់ពិរុទ្ធភាព និងការផ្ដន្ទាទោស។ ដើម្បីជួយដល់ អ.ជ.ស.ដ ចម្លើយតបក៏រួមបញ្ចូលគ្មានូវខ្លឹមសារនានាដែលបានលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខដែរ។

## II. បទដ្ឋាននៃការពិនិត្យលើបណ្ដឹងសាទុក្ខ

### ក. បទដ្ឋានជាក់លាក់

#### ១. បទដ្ឋានទូទៅ

7. អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) អាច “តម្កល់ ឬ ទុកជាមោឃៈ ឬ កែប្រែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មួយផ្នែក ឬ ទាំងស្រុងបាន ដូចមានចែងក្នុងវិធាន ១១០”[29]។ ទទ្បីករណ៍នៃបណ្ដឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់ អ.ជ.ស.ដ ត្រូវបង្ហាញ “កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈ សាលក្រមនោះ [...] កំហុសនៃអង្គហេតុដែលនាំអោយសាលក្រមលើអង្គសេចក្ដី ឬ សេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌”[30]។ អ.ជ.ត.ក អាចផ្លាស់ប្ដូរការកំណត់ឧក្រិដ្ឋកម្មតាមផ្លូវច្បាប់ ដែល អ.ជ.ស.ដ បានប្រកាន់យក តែមិនអាចបញ្ចូលធាតុផ្សំថ្មីៗ ដែលមិនបានដាក់ជូន អ.ជ.ស.ដ ទេ[31]។ អ.ជ.ត.ក កែតម្រូវកំហុសផ្នែកអង្គច្បាប់ ហើយក៏ផ្ទៀងផ្ទាត់ថាតើ បន្ទុកនៃការបង្ហាញធាតុផ្សំនៃបទចោទត្រូវបានបំពេញ ឬយ៉ាងណា មិន

---

[28] សូមមើល ឧបសម្ព័ន្ធ គ, ឃ, ង។

[29] វិធាន ១០៤(២)។

[30] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៤ *ដកស្រង់* វិធាន ១០៤(១)។

[31] វិធាន ១១០ (២)។

មែនជំនួសការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយការយល់ឃើញរបស់ខ្លួននោះទេ[32]។

## ២. កំហុសផ្នែកអង្គច្បាប់ដែលបានចោទប្រកាន់

8. អ.ជ.ត.ក ធ្វើការពិនិត្យសាជាថ្មីទៅលើកំហុសផ្នែកអង្គច្បាប់ដែលបានចោទប្រកាន់ ដើម្បីកំណត់ថាតើមានការប្រព្រឹត្តកំហុស ទៅលើបញ្ហាអង្គសេចក្តី ឬបញ្ហានីតិវិធី ឬយ៉ាងណា។ មានតែកំហុសផ្នែកអង្គច្បាប់ដែលត្រូវមោឃៈសាលក្រម ឬសេចក្តីសម្រេចប៉ុណ្ណោះ ទើបតម្រូវឱ្យមានអន្តរាគមន៍ពី អ.ជ.ត.ក ដើម្បីកែតម្រូវសេចក្តីសម្រេច ឬសាលក្រមនោះ[33]។ "សាលក្រមមួយដែលអាចចាត់ទុកជាមោឃៈដោយសារកំហុសអង្គច្បាប់ ហើយប្រសិនបើកំហុសនោះមិនឈានទៅដល់មោឃៈសាលក្រមទេ នោះសាលក្រមអាចនឹងត្រូវបានសម្រេចកែប្រែការប្រកាសដាក់ពិរុទ្ធភាពទាំងស្រុង ឬផ្នែកខ្លះ"[34]។ នៅពេលដែល អ.ជ.ត.ក រកឃើញថា អ.ជ.ស.ដ បានអនុវត្តបទដ្ឋានផ្លូវច្បាប់ដែលខុស អ.ជ.ត.ក អនុវត្តនូវបទដ្ឋានផ្លូវច្បាប់ដែលត្រឹមត្រូវ ចំពោះភស្តុតាងនៃកំណត់ហេតុក្នុងករណីចាំបាច់ ហើយកំណត់ថាតើអង្គជំនុំជម្រះជឿជាក់ទៅលើសំអាងនៃអង្គហេតុដែលត្រូវបានជំទាស់នៅចំពោះមុខ ដែរឬទេ មុននឹងបញ្ជាក់ទៅលើអង្គហេតុនោះ[35]។

9. ភាគីដែលចោទប្រកាន់ថាមានកំហុសផ្នែកអង្គច្បាប់ "ត្រូវបង្ហាញកំហុសនោះ ត្រូវមានអំណះអំណាងក្នុងការគាំទ្រដល់ការលើកឡើងនោះ និងត្រូវពន្យល់អំពីមូលហេតុដែលនាំឱ្យសាលក្រមមោឃៈ"[36]។ ទោះបីអំណះអំណាងរបស់ភាគីមិនពេញលេញក្តី ក៏ អ.ជ.ត.ក អាចរកសំអាងហេតុផ្សេងៗទៀត ដើម្បីសន្និដ្ឋានថាមានកំហុសផ្នែកអង្គច្បាប់បានដែរ[37]។ ដើម្បីសម្រេចទៅលើបញ្ហា

---

[32] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៥។

[33] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៦។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៦។

[34] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៩ *ដកស្រង់* សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៧, សាលដីការឿងក្តី *Lubanga* កថាខណ្ឌ ១៩។

[35] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៦។

[36] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៥ *ដកស្រង់* វិធាន ១០៥(៣)។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨៧។

[37] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៥ *ដកស្រង់* សាលដីការឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១០, សាលដីការឿងក្តី *Kambanda* កថាខណ្ឌ ៩៨។

នេះ អ.ជ.ត.ក ក៏នឹងពិនិត្យមើលការយល់ឃើញផ្នែកអង្គច្បាប់របស់ អ.ជ.ស.ដ ដែលជាមូលដ្ឋានចាំបាច់សម្រាប់សេចក្ដីសម្រេចដែលរងការជំទាស់នោះផងដែរ[38]។

10. ការណ៍ដែល អ.ជ.ស.ដ មិនបានលើកឡើង ឬដោះស្រាយនូវភស្តុតាងដោះបន្ទុកសំខាន់ៗ គឺជាកំហុសផ្នែកអង្គច្បាប់។ បញ្ហាគន្លឹះគឺថាតើ កំហុសនេះនាំឱ្យមោឃៈផ្នែកដែលពាក់ព័ន្ធនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ឬយ៉ាងណា[39]។

## ៣. កំហុសផ្នែកអង្គហេតុដែលត្រូវបានចោទប្រកាន់

11. អ.ជ.ត.ក អនុវត្តនូវបទដ្ឋាននៃភាពសមហេតុផល ចំពោះកំហុសផ្នែកអង្គហេតុដែលបានចោទប្រកាន់ គឺថា អង្គជំនុំជម្រះសម្រេចថាតើ ការយល់ឃើញផ្នែកអង្គហេតុរបស់ អ.ជ.ស.ដ គឺជាការយល់ឃើញ ដែលអ្នកវិនិច្ឆ័យទៅលើអង្គហេតុដែលសមហេតុ មិនបានធ្វើ ឬយ៉ាងណា[40] ដោយផ្អែកលើការវាយតម្លៃភស្តុតាងជារួម[41]។ កំហុសផ្នែកអង្គហេតុបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ជាក់ស្ដែង ប្រសិនបើវាប៉ះពាល់ "ធ្ងន់ធ្ងរដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"[42]។ បណ្ដឹងសាទុក្ខជំទាស់ទៅនឹងការសម្រេចដាក់ពិរុទ្ធភាពត្រូវបង្ហាញថា កំហុសផ្នែកអង្គហេតុរបស់ អ.ជ.ស.ដ បង្កើតជាវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ[43]។ ភាគីដែលចោទប្រកាន់អំពីកំហុសនោះត្រូវបង្ហាញពីរបៀបដែលកំហុសឆ្គងផ្នែកអង្គហេតុ ពិតជាបណ្ដាលឱ្យមានភាពមិនយុត្តិធម៌មែន[44]។ អំណះអំណាងនានាដែលត្រឹមតែមិនស្របទៅនឹងសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដោយផ្អែកលើការបកស្រាយចំពោះភស្តុតាងដូចគ្នាតាមវិធីផ្សេងដែលគ្មានមូលដ្ឋាន មិនតម្រូវឱ្យមានអន្តរាគមន៍ពី អ.ជ.ត.ក ឡើយ[45]។

---

[38] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ១៥។

[39] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៤។

[40] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ១៧។

[41] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៨។

[42] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ១៩ *ដកស្រង់* សាលដីការឿងក្ដី *Kupreškić* កថាខណ្ឌ ២៩។

[43] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ១៨។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩១។

[44] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ១៩។

[45] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០។

12. អ.ជ.ត.ក "នឹងមិនប៉ះពាល់ដល់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ"[46] ដែលបានពិនិត្យលើសាក្សីដោយផ្ទាល់ និងមានតួនាទីមួយដែលប្រសើរជាង ក្នុងការវាយតម្លៃលើភាពដែលគួរឱ្យទុកចិត្តបាន និងភាពជឿជាក់បាននៃភ័ស្តុតាង និង សម្រេចទៅលើភ័ស្តុតាងដែលអង្គជំនុំជម្រះយកមកសំអាង[47]។ ការយល់ឃើញផ្នែកអង្គហេតុរបស់ អ.ជ.ស.ដ បានទទួលកម្រិតនៃការយកចិត្តទុកដាក់ "ត្រូវបានប្រើប្រាស់ក្នុងកម្រិតនៃកាតព្វកិច្ច[របស់ខ្លួន]ក្នុងការផ្តល់នូវសំអាងហេតុ"[48]។ ជាវិធានទូទៅ ដើម្បីសម្រេចថាតើ សេចក្តីសន្និដ្ឋានលើអង្គហេតុរបស់ អ.ជ.ស.ដ មានភាពសមហេតុផល ឬយ៉ាងណានោះ ប្រសិនបើភ័ស្តុតាងជាមូលដ្ឋានសម្រាប់យកមកធ្វើសេចក្តីសន្និដ្ឋាននោះមានភាពទន់ខ្សោយ តម្រូវឱ្យមានការផ្តល់សំអាងហេតុថែមទៀតលើសពីមូលដ្ឋានភ័ស្តុតាងដែលគួរឱ្យជឿបាន[49]។

## ៤. កំហុសផ្នែកនីតិវិធីដែលត្រូវបានចោទប្រកាន់

13. កំហុសផ្នែកនីតិវិធីដែលបានចោទប្រកាន់ ដែលបង្កើតជាកំហុសផ្នែកអង្គច្បាប់ ឬកំហុសផ្នែកអង្គហេតុ មានចែងក្នុងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ("វិធាន")[50]។ មានតែកំហុសផ្នែកនីតិវិធីបណ្តាលឱ្យមាន "លទ្ធផលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការមានភាពមិនយុត្តិធម៌ទាំងស្រុង" ទេ ទើបតម្រូវឱ្យមានអន្តរាគមន៍ពី អ.ជ.ត.ក[51]។ ការអនុវត្តឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ ត្រូវបានយកមកពិនិត្យដើម្បីសម្រេចថាតើ អ.ជ.ស.ដ បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងត្រឹមត្រូវ ឬយ៉ាងណា មិនមែនថាតើ អ.ជ.ត.ក យល់ស្របជាមួយ អ.ជ.ស.ដ ឬយ៉ាងណានោះទេ។ វិសាលភាពនៃការពិនិត្យលើបណ្តឹងសាទុក្ខ ចំពោះការអនុវត្តឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ ត្រូវបានកម្រិតជាខ្លាំងនៅពេលពុំមានកំហុសផ្នែកអង្គច្បាប់ ឬការយល់ឃើញផ្នែកអង្គហេតុដែលខុសឆ្គងច្បាស់លាស់។ វិធីសាស្ត្រគួរឱ្យយកចិត្តទុកដាក់ ត្រូវបានយកមកអនុវត្តចំពោះការពិនិត្យនេះ។ ការធ្វើអន្តរាគមន៍ចំពោះបណ្តឹងសាទុក្ខអាចតម្រូវឱ្យមានតែក្នុងករណីដែលមានការបង្ហាញថា ការអនុវត្តឆន្ទានុសិទ្ធិ

---

[46] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៧ *ដកស្រង់* សាលដីការឿងក្តី *Furundžija* កថាខណ្ឌ ៣៧។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨។

[47] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៧ *ដកស្រង់* សាលដីការឿងក្តី *Kupreškić* កថាខណ្ឌ ៣០, ៣២។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩។

[48] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៧ *ដកស្រង់* សាលដីការឿងក្តី *Kupreškić* កថាខណ្ឌ ៣២។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩។

[49] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០។

[50] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០។

[51] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៩ *ដកស្រង់* សាលដីការឿងក្តី *Furundžija* កថាខណ្ឌ ៣៧។

របស់ អ.ជ.ស.ដ មិនសមហេតុផលខ្លាំងពេកដែលបង្ខំឱ្យមានការសន្និដ្ឋានថា អ.ជ.ស.ដ មិនបាន អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនទៅតាមផ្លូវតុលាការឡើយ[52]។ អ.ជ.ត.ក នឹងពិចារណាទៅលើដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងវិធានការនានាដែលត្រូវបានប្រកាន់យក ក្នុងដំណាក់កាលដោះស្រាយបណ្តឹងសាទុក្ខ[53]។

## ៥. ភ័ស្តុតាងហួសពីវិមតិសង្ស័យ

14. ពុំមែនរាល់អង្គហេតុទាំងអស់ត្រូវតែយកមកបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះទេ។ អង្គហេតុទាំងអស់ដែលជាមូលដ្ឋាននៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ឬទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលត្រូវតែបង្ហាញទៅដល់បទដ្ឋាននោះ រួមមាន អង្គហេតុទាំងឡាយ "ដែលសំខាន់ដោយខ្វះពុំបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាព"[54]។ អង្គហេតុផ្សេងទៀតអាចតម្រូវឱ្យបង្ហាញហួសពីវិមតិសង្ស័យ ដោយសារ "តែមានការតវ៉ាក្នុងរឿងក្តី"[55]។

15. ដើម្បីផ្តល់មូលដ្ឋានគាំទ្រដល់ការយល់ឃើញជារួមនៃភ័ស្តុតាងហួសពីវិមតិសង្ស័យទៅលើករណីជាច្រើននៃឧក្រិដ្ឋកម្មមួយ ឧទាហរណ៍ ការធ្វើមនុស្សឃាត ករណីជាក់លាក់ត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ។ ប្រសិនបើពុំមានករណីជាក់លាក់ណាមួយត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យទេនោះ ការយល់ឃើញជារួមមិនត្រូវបានបង្ហាញទេ[56]។ ទោះជាយ៉ាងណាក្តី ការសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតអាចត្រូវបានបញ្ចូល ដោយសារតែពុំអាចកំណត់បាននូវចំនួនមនុស្សស្លាប់សរុប ឬកំណត់អំពីអត្តសញ្ញាណចារីផ្ទាល់ និងជនរងគ្រោះដោយសារពួកគេ[57]។

16. បទដ្ឋានដែលហួសពីវិមតិសង្ស័យត្រូវយកមកអនុវត្ត ដោយផ្អែកលើភ័ស្តុតាងរួម មិនមែនតាមបែបជាផ្នែកៗទេ គឺថា មិនមែនតែផ្នែកនៃភ័ស្តុតាងមួយដាច់តែឯងឡើយ[58]។ នោះគឺថា អ.ជ.ត.ក

---

[52] សូមមើល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំសុំឱ្យចាត់តាំងមេធាវីការពារក្តី រឿងក្តី *S. Milošević* កថាខណ្ឌ ៩-១០។

[53] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០។

[54] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៨ *ដកស្រង់* សាលដីការឿងក្តី *Ntagerura* កថាខណ្ឌ ១៧៤, សាលដីការឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ២១៧។

[55] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៨ *ដកស្រង់* សាលដីការឿងក្តី *Halilović* កថាខណ្ឌ ១២៩។

[56] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤២០។

[57] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤២០ *ដកស្រង់* សាលក្រមរឿងក្តី *Stakić* កថាខណ្ឌ ២០១។

[58] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៨ *ដកស្រង់* សាលដីការឿងក្តី *Ntagerura* កថាខណ្ឌ ១៧៤, សាលដីការឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ២១៧។

សម្រេចថាតើបទដ្ឋាននេះត្រូវបានបំពេញ ឬយ៉ាងណា "ដោយថ្លឹងថ្លែងលើរាល់ភ័ស្តុតាងទាំងអស់បញ្ចូលគ្នាទាក់ទងទៅនឹងអង្គហេតុនោះ"[59]។ ស្រដៀងគ្នាដែរ វិធីសាស្ត្រូមត្រូវបានយកមកប្រើប្រាស់ នៅពេលពិចារណាថាតើ មានភ័ស្តុតាងមិនផ្ទាល់គ្រប់គ្រាន់ ដើម្បីបង្ហាញពីអង្គហេតុចម្បងឱ្យហួសពីវិមតិសង្ស័យពីអង្គហេតុ "ដទៃទៀត" ឬយ៉ាងណា[60]។ ប្រសិនបើមានតែភ័ស្តុតាងមិនផ្ទាល់ រាល់ទំនាក់ទំនងទាំងអស់ត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ[61]។

17. វិធីសាស្ត្រទាំងមូលនេះត្រូវបានពិចារណាជាបឋមពាក់ព័ន្ធនឹងភាពអាចជឿជាក់បាន នៃចំណែកនីមួយៗនៃភ័ស្តុតាង និងភ័ស្តុតាងបញ្ជាក់បន្ថែម។ ទោះជាយ៉ាងណាក្តី ភ័ស្តុតាងហួសពីវិមតិសង្ស័យអាចមិនត្រូវបានបង្ហាញ ដោយត្រឹមតែចំនួនផ្នែកនៃភ័ស្តុតាង ដោយមិនគិតដល់តម្លៃជាភ័ស្តុតាងរបស់វាបានឡើយ[62]។

## ៦. សេចក្តីសម្រេចដែលមានសំអាងហេតុ

18. វិធាន ១០១(១) តម្រូវថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវលើកឡើងនូវសំអាងហេតុ និងសំអាងច្បាប់ដែលគាំទ្រដល់សេចក្តីសម្រេចនោះ។ វិធាន ១០១(៤) តម្រូវថា សាលក្រមត្រូវឆ្លើយតបទៅនឹងសារណាជាលាយលក្ខណ៍អក្សររបស់ភាគីទាំងអស់[63]។

19. ទោះជាយ៉ាងណាក្តី អ.ជ.ស.ដ មិនតម្រូវឱ្យបញ្ជាក់អះអាងគ្រប់ជំហាននៃការផ្តល់សំអាងហេតុរបស់ខ្លួនឱ្យបានលម្អិតនោះឡើយ ហើយអង្គជំនុំជម្រះត្រូវបានសន្មតថា បានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវរាល់ភ័ស្តុតាងទាំងអស់នៅចំពោះមុខខ្លួន ដរាបណាគ្មានការបង្ហាញណាមួយថា អង្គជំនុំជម្រះពុំបានពិចារណាពេញលេញលើភ័ស្តុតាងជាក់លាក់ណាមួយនោះ[64]។ ហេតុនេះ បើមានភ័ស្តុតាងមួយចំនួនពុំត្រូវបានយោងនៅក្នុងការវាយតម្លៃរបស់ អ.ជ.ស.ដ នោះ ពុំមែនមានន័យថា

---

[59] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៨ *ដកស្រង់* សាលដីការឿងក្តី *Lubanga* កថាខណ្ឌ ២២។

[60] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៩ *ដកស្រង់* សាលដីការឿងក្តី *Martić* កថាខណ្ឌ ២៣៤។

[61] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៨ *ដកស្រង់* សាលដីការឿងក្តី *Ntagerura* កថាខណ្ឌ ១៧៥។

[62] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៩។

[63] វិធាន ១០១(១) ("សាលក្រមត្រូវចែកជាពីរផ្នែក៖ ក-ផ្នែកសំអាងហេតុ គឺជាការយល់ឃើញអំពីមូលហេតុខាងអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេច"), ១០១(៤) ("ផ្នែកសំអាងហេតុនៅក្នុងសាលក្រម ត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរដែលបានធ្វើឡើងដោយភាគីទាំងអស់")។

[64] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤ *ដកស្រង់* សាលដីការឿងក្តី *Kalimanzira* កថាខណ្ឌ ១៩៥, សាលដីការឿងក្តី *Simba* កថាខណ្ឌ ១៥២, សាលដីការឿងក្តី *Halilović* កថាខណ្ឌ ១២១, សាលដីការឿងក្តី *Kvočka* កថាខណ្ឌ ២៣។ សូមមើលផងដែរ សាលដីការឿងក្តី *Ngirabatware* កថាខណ្ឌ ៩៧, សាលដីការឿងក្តី *Karera* កថាខណ្ឌ ២១។

ភ័ស្តុតាងនោះពុំត្រូវបានយកមកពិចារណានោះឡើយ[65]។ ទោះជាយ៉ាងណាក្តី ការសន្មតនេះអាចត្រូវបានជំទាស់ នៅពេលដែល អ.ជ.ស.ដ មិនបានលើកឡើងនូវភ័ស្តុតាងនានាដែលជាប់ពាក់ព័ន្ធច្បាស់លាស់ទៅនឹងការយល់ឃើញដែលរងការជំទាស់[66]។ អ.ជ.ស.ដ មានឆន្ទានុសិទ្ធិក្នុងការទទួលយកផ្នែកខ្លះនៃសក្ខីកម្មរបស់សាក្សី និងបដិសេធផ្នែកផ្សេងទៀត ដោយពុំចាំបាច់បញ្ជាក់អះអាងគ្រប់ជំហាននៃការផ្តល់សំអាងហេតុរបស់ខ្លួន ក្នុងការធ្វើការវាយតម្លៃនេះឡើយ[67]។

20. "ពុំមែនរាល់ចំណុចនៃសំអាងហេតុក្នុងសាលក្រម សុទ្ធតែធ្វើឱ្យកិច្ចដំណើរការនីតិវិធីពុំបានប្រព្រឹត្តឡើងដោយត្រឹមត្រូវនោះឡើយ"[68]។ ឧទាហរណ៍ ភ័ស្តុតាងដែលមិនត្រូវបាន "ចងភ្ជាប់ទៅនឹងការយល់ឃើញសំខាន់ៗ"[69] ឬពាក់ព័ន្ធនឹងបញ្ហាមួយដែលមិនមែនជា "ចំណុចសំខាន់" ពុំចាំបាច់លើកឡើងនោះទេ[70]។ អ.ជ.ស.ដ ពុំតម្រូវឱ្យផ្តល់ចម្លើយលម្អិតទៅលើរាល់អំណះអំណាងនីមួយៗដែលបានលើកឡើងក្នុងពេលជំនុំជម្រះទេ។ ផ្ទុយទៅវិញ សេចក្តីសម្រេចនោះត្រូវដោះស្រាយឱ្យច្បាស់លាស់នូវបញ្ហាសំខាន់ៗនៃរឿងក្តី[71]។ វិធីសាស្ត្រ ដែល អ.ជ.ស.ដ យកមកវាយតម្លៃភ័ស្តុតាង និងសម្រេចធ្វើសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុ និងផ្នែកអង្គច្បាប់ ត្រូវតែអាចយល់បាន[72]។ នោះគឺថាសាលក្រមត្រូវតែ "បញ្ជាក់ឱ្យបានច្បាស់លាស់នូវមូលដ្ឋានដែលខ្លួន[បានផ្អែកទៅលើ] នៅក្នុង[សេចក្តីសម្រេច]"[73]។ "ជាអប្បបរមា [អ.ជ.ស.ដ] ត្រូវផ្តល់មូលដ្ឋានដើម្បីគាំទ្រដល់ការយល់ឃើញទាក់ទងទៅនឹងការពិចារណាលើអង្គសេចក្តីដែលពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់ខ្លួន"[74]។

---

[65] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥២។

[66] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥២។

[67] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៧។

[68] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៤៩។

[69] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៤៩។

[70] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥២ *ដកស្រង់* សាលដីការឿងក្តី *Zigiranyirazo* កថាខណ្ឌ ៤៥-៤៦, សាលដីការឿងក្តី *Ntabakuze* កថាខណ្ឌ ១៧១។

[71] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៣ *ដកស្រង់* រឿងក្តី *Taxquet តទល់នឹង ប្រទេសប៊ែលហ្ស៊ិក* កថាខណ្ឌ ៩១។

[72] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៧។

[73] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៣ *ដកស្រង់* រឿងក្តី *Hadjianastassiou តទល់នឹង ប្រទេសក្រិក* កថាខណ្ឌ ៣៣។

[74] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៥ *ដកស្រង់* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំសុំឱ្យដោះលែងបណ្តោះអាសន្ន រឿងក្តី *Milutinović* កថាខណ្ឌ ១១។

21. ចំពោះករណីនេះ នៅពេលដែលរឿងក្តីកំពុងដំណើរការទៅមុខ អ.ជ.ត.ក អាចដោះស្រាយនូវការខ្វះចន្លោះនៅក្នុងសំអាងហេតុរបស់ អ.ជ.ស.ជ ដើម្បីជៀសវាងការរំលោភបំពាននានា។ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ការយល់ឃើញផ្នែកអង្គហេតុត្រូវបានផ្អែកទៅលើសំអាងហេតុមិនគ្រប់គ្រាន់ អ.ជ.ត.ក អាចពិចារណាថា ការយល់ឃើញផ្នែកអង្គហេតុដែលរងការជំទាស់មិនត្រូវបានផ្តល់សំអាងហេតុគ្រប់គ្រាន់ទេ ហេតុនេះវាមានកំហុសឆ្គង ជាជាងសន្និដ្ឋានថាការជំនុំជម្រះពុំមានភាពយុត្តិធម៌[75]។

## ៧. ការបដិសេធចោលភ្លាមៗ

22. ភាគីមិនអាចគ្រាន់តែលើកទឡ្ហីករណ៍ដដែលៗដែលពុំទទួលបានជោគជ័យ ដំណាក់កាលជំនុំជម្រះឡើយ តែត្រូវបង្ហាញថា ការបដិសេធរបស់ អ.ជ.ស.ជ ទៅលើទឡ្ហីករណ៍ទាំងនោះ គឺជាកំហុសមួយដែលត្រូវតែមានអន្តរាគមន៍[76] គឺថា ត្រូវលើកមូលដ្ឋានគាំទ្រថាតើមូលហេតុអ្វីបានជាសេចក្តីសម្រេច ឬការយល់ឃើញនោះ មានកំហុស[77]។ ជាងនេះទៀត "ទឡ្ហីករណ៍ [...] ដែលពុំមានសក្តានុពលធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់អាចត្រូវបានបដិសេធចោល ឬកែប្រែនោះអាចត្រូវបានបដិសេធចោលភ្លាមៗ [...] និងពុំចាំបាច់ត្រូវធ្វើការពិចារណាលើអង្គសេចក្តីឡើយ"[78]។

23. ភាគីម្ចាស់សាទុក្ខគួរផ្តល់ការយោងទៅលើទំព័រប្រតិចារឹក ឬកថាខណ្ឌនានានៅក្នុងសាលក្រមរបស់ អ.ជ.ស.ជ ដែលខ្លួនធ្វើការជំទាស់[79]។ សារណាអាចត្រូវបានបដិសេធចោល ប្រសិនបើ "មានលក្ខណៈមិនច្បាស់លាស់ មានលក្ខណៈផ្ទុយ និងមានលក្ខណៈស្រពិចស្រពិល ឬមានភាពមិនពេញលេញជាផ្លូវការដែលបង្ហាញឱ្យឃើញយ៉ាងជាក់ស្តែង"[80]។ អ.ជ.ត.ក "ឆន្ទានុសិទ្ធិក្នុងការជ្រើសរើសសារណាណាមួយដែលសក្តិសម ក្នុងការទទួលបាននូវការពិនិត្យពិចារណាដោយល្អិត

---

[75] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៨។

[76] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២០។ សូមមើលផងដែរ សាលដីការឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៨។ សាលដីការឿងក្តី *Krajišnik* កថាខណ្ឌ ២៤។

[77] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០២, ៣០៤។

[78] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២០។

[79] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២០។ វិធាន ១០៥(៤)។

[80] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២០ *ដកស្រង់* សាលដីការឿងក្តី *Stakić* កថាខណ្ឌ ១២។ សូមមើលផងដែរ សាលដីការឿងក្តី *Martić* កថាខណ្ឌ ១៤។

ល្អនជាលាយលក្ខណ៍អក្សរ”[81]។ ទទ្ទីករណីដែលមិនមានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចបដិសេធចោលដោយមិនចាំបាច់ផ្តល់សំអាងហេតុលម្អិតឡើយ[82]។

## III. អង្គច្បាប់

## ក. សុពលភាពរបស់សាលក្រម

### *មូលដ្ឋានទី ១៖ អសុពលភាពនៃសាលក្រមដែលបានប្រកាសដោយខុសច្បាប់ទាំងស្រុង*[83]

24. **មូលដ្ឋានទី ១ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ ដោយមិនបានអនុវត្តនីតិវិធីជាកាតព្វកិច្ចដូចមានចែងក្នុងវិធាន**[84]**។**

25. ពុំមានលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី នៅក្នុងវិធាន ១០១, ១០២ និង ១០៧[85] ឬតាមវិធីណាផ្សេងទេ ដែលកំណត់ថាសាលក្រមពុំមានសុពលភាព នៅពេល អ.ជ.ស.ដ ពុំបានផ្តល់សំអាងហេតុជាលាយលក្ខណ៍អក្សរ នៅថ្ងៃដែលប្រកាសសាលក្រម។ អត្ថន័យធម្មតា និងគោលបំណងនៃវិធាន ១០១ និង ១០២ ដែលអានរួមគ្នា តម្រូវឱ្យមានទម្រង់និងខ្លឹមសារនៃសាលក្រមជាលាយលក្ខណ៍អក្សរ[86] ហើយត្រូវធ្វើការប្រកាសសាលក្រមនោះ[87] រួមមានការប្រកាសផ្ទាល់មាត់ដោយសង្ខេបនូវការយល់ឃើញរបស់ អ.ជ.ស.ដ និងការសម្រេចសេចក្តី[88]។ ដូចដែល អ.ជ.ត.ក បានធ្វើការកត់សម្គាល់រួចហើយ អ.ជ.ស.ដ “បញ្ជាក់យ៉ាងច្បាស់ថា “សំអាងហេតុដែលមានអានុភាពផ្លូវច្បាប់មានសរសេរនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងមាន [នៅក្នុងពេលវេលាសមស្របខាងមុខ]”” និងបានបញ្ជាក់បំភ្លឺថា រយៈពេលកំណត់សម្រាប់ការដាក់សេចក្តីជូន

---

[81] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តីឌុច កថាខណ្ឌ ២០។

[82] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តីឌុច កថាខណ្ឌ ២០។

[83] <u>មូលដ្ឋានទី ១៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អសុពលភាពនៃសាលក្រមដែលបានប្រកាសដោយខុសច្បាប់ទាំងស្រុង* កថាខណ្ឌ ៣០-៧៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤ (ភាសាអង់គ្លេស) ទំព័រ ៤ (ភាសាបារាំង) ទំព័រ ៤ (ភាសាខ្មែរ)។

[84] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០។

[85] *ផ្ទុយពី*ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២ ជើងទំព័រ ៤៦។

[86] វិធាន ១០១។

[87] វិធាន ១០២។

[88] វិធាន ១០២(១)។

ដំណឹងពីបណ្ដឹងសាទុក្ខ នឹងត្រូវចាប់ផ្ដើមរាប់មួយថ្ងៃក្រោយពីការជូនដំណឹងពីសាលក្រមជាលាយលក្ខណ៍អក្សរ[89] ដូចបានអនុញ្ញាតទៅតាមវិធាន ១០៧(៤)[90]។ ការធ្វើបែបនេះ អ.ជ.ស.ជ បានការពារសិទ្ធិជាសារវ័ន្តទាំងអស់របស់ជនជាប់ចោទ រួមទាំង សិទ្ធិទទួលបានការជំនុំជម្រះក្ដីជាសាធារណៈដោយគ្មានការពន្យារពេល សិទ្ធិទទួលបានសាលក្រមដែលមានសំអាងហេតុ សិទ្ធិទទួលបានសុចរិតភាពផ្លូវច្បាប់ និងសិទ្ធិប្ដឹងសាទុក្ខ ព្រមទាំង ដោយធានានូវតម្លាភាពនៃកិច្ចដំណើរការនីតិវិធី និងការទទួលបានជាសាធារណៈនូវដំណើរការតាមផ្លូវតុលាការ[91]។

26. ដូចដែលម្ចាស់បណ្ដឹងសាទុក្ខធ្វើការកត់សម្គាល់[92] នៅពេលខ្លះ អង្គជំនុំជម្រះទាំងអស់នៅ អ.វ.ត.ក ពន្យារពេលផ្ដល់សំអាងហេតុជាលាយលក្ខណ៍អក្សរ[93] ហើយ អ.ជ.ត.ក បានបញ្ជាក់ថា ម្យ៉ាង ការពន្យារពេលរវាងការប្រកាសសាលក្រមសង្ខេបនិងផ្នែកសម្រេចសេចក្ដី និងម្យ៉ាងទៀត សំអាងហេតុជាលាយលក្ខណ៍អក្សរ មិនបង្កើតជាការបំពានផ្នែកនីតិវិធីទេ[94]។ ដោយហេតុថា សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងការទទួលបានសាលក្រមជាលាយលក្ខណ៍អក្សរ និងការប្ដឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមនោះមិនត្រូវបានរំលោភបំពានជាក់ស្ដែងនោះ បញ្ហាថាតើ សេចក្ដីសម្រេចមុនៗ អាចត្រូវបានប្ដឹងសាទុក្ខឬយ៉ាងណានោះ ពុំបង្កឱ្យមានផលវិបាកអ្វីទេ[95]។ ការវាយប្រហាររបស់

---

[89] ឯកសារ **E463/1/3** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសាលក្រមសង្ខេប កថាខណ្ឌ ១១ *ដកស្រង់* ឯកសារ **E1/529.1** ប្រតិចារឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ០៩.៣៤.៣៥-០៩.៣៦.០២ ទំព័រ ២ បន្ទាត់ ១៨ ដល់ ទំព័រ ៣ បន្ទាត់ ៦, ១១.៣៧.៥៧ - ចប់ ទំព័រ ៤២ បន្ទាត់ ០៥-១៥។

[90] អនុលោមតាមវិធាន ១០៧(៤) ពេលវេលាកំណត់សម្រាប់ប្ដឹងសាទុក្ខ ចាប់គិតពី "ថ្ងៃប្រកាសសាលក្រម *ឬការជូនដំណឹងពីសាលក្រម* តាមករណីសមស្រប" (គូសបញ្ជាក់បន្ថែម)។

[91] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៩។

[92] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៣៨។

[93] *សូមមើលឧទាហរណ៍* **អ.ជ.ត.ក៖** ឯកសារ **E284/4/7** សេចក្ដីសម្រេចសង្ខេបរបស់ អ.ជ.ត.ក លើបណ្ដឹងសាទុក្ខនៃការបំបែកសំណុំរឿងលើកទី២ *បន្ទាប់មកគឺ* ឯកសារ **E284/4/8** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើបណ្ដឹងសាទុក្ខនៃការបំបែកសំណុំរឿងលើកទី២។ **អ.ប.ជ៖** ឯកសារ **D427/1/26** សាលដីកាលើកទីមួយរបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ *បន្ទាប់មក* ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ។ **អ.ជ.ស.ជ៖** ឯកសារ **E367/7** សេចក្ដីសម្រេចរបស់ អ.ជ.ស.ជ លើឯកសារពាក់ព័ន្ធនឹងសាក្សី 2-TCE-95 *បន្ទាប់មក* ឯកសារ **E367/8** សំអាងហេតុជាលាយលក្ខណ៍អក្សររបស់ អ.ជ.ស.ជ នៃសេចក្ដីសម្រេចលើឯកសារពាក់ព័ន្ធនឹងសាក្សី 2-TCE-95។

[94] ឯកសារ **E50/1/1/4** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើពាក្យសុំដោះលែងរបស់ នួន ជា និង អៀង ធីរិទ្ធិ កថាខណ្ឌ ៣១, ៣៨។ ឯកសារ **E50/3/1/4** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើពាក្យសុំដោះលែងរបស់ ខៀវ សំផន កថាខណ្ឌ ២២។

[95] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៣៨។

ម្ចាស់បណ្ដឹងសាទុក្ខទៅនឹងសុចរិតភាពនៃដំណើរការចេញសេចក្ដីសម្រេច រវាងការប្រកាសសាលក្រម និងការជូនដំណឹងអំពីសំអាងហេតុជាលាយលក្ខណ៍អក្សរ គឺគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ[96] វិធាន ៩៦(១) ធានាថា ការពិភាក្សាសម្រេចសេចក្ដីរបស់ អ.ជ.ស.ដ ធ្វើឡើងជាសម្ងាត់[97] ហើយពុំមានភ័ស្ដុតាងទាល់តែសោះថា សំអាងហេតុរបស់ អ.ជ.ស.ដ មានការផ្លាស់ប្ដូរក្នុងអំឡុងពេលនេះ។

27. ហេតុនេះ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនបាន "គោរព និងអនុវត្តច្បាប់" ហើយថា សាលក្រម "គ្មានមូលដ្ឋាន ដូច្នេះគ្មានតម្លៃគតិយុត្តិ" ពុំមានមូលដ្ឋានទេ[98]។ ទឡ្ហីករណ៍របស់គាត់ដែលថា ការចេញសំអាងហេតុនៅពេលក្រោយមិនអាច "លុបលាងវិការៈ" បាន ហើយថា សំអាងហេតុ "គ្មានសុពលភាព" ត្រូវទុកជាអសារបង់។ នៅពេលម្ចាស់បណ្ដឹងសាទុក្ខលើកឡើងនូវទឡ្ហីករណ៍ទាំងនេះជាបណ្ដឹងសាទុក្ខភ្លាមៗ ក្រោយពេលការប្រកាសសាលក្រមសង្ខេបនៅខែវិច្ឆិកា ឆ្នាំ២០១៨[99] អង្គជំនុំជម្រះនេះបានសន្និដ្ឋានថា ពុំមាន "កាលៈទេសៈណាមួយដែលគួរឱ្យជឿបានថា នឹងរារាំងអង្គជំនុំជម្រះក្នុងការចេញសាលក្រមចុងក្រោយជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ លើអង្គសេចក្ដី"[100]។ ប្រសិនបើ អ.ជ.ស.ដ មិនត្រូវបាន "បង្កើតឡើងដោយច្បាប់"[101] ឬបានបញ្ចប់ភារកិច្ច ឬ ប្រសិនបើសាលក្រមជាលាយលក្ខណ៍អក្សរធ្វើឡើងហួសពីសមត្ថកិច្ច នោះ អ.ជ.ត.ក នឹងមិនធ្វើការយល់ឃើញបែបនេះឡើយ។

28. ក្នុងករណីណាក៏ដោយ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា កំហុសដែលរងការចោទប្រកាន់បណ្ដាលឱ្យមាន "ផលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការមានភាពមិនយុត្តធម៌ទាំងស្រុង" ដោយពិចារណាដល់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងបណ្ដឹងសាទុក្ខនេះផង[102]។ ដូចបានបង្ហាញរួចមកហើយ សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ជាសារវ័ន្តទាំងអស់របស់ម្ចាស់បណ្ដឹងត្រូវបានគោរព។ ការណ៍ដែលម្ចាស់បណ្ដឹងសាទុក្ខមិនត្រូវបានដកហូតសិទ្ធិប្ដឹងសាទុក្ខ សិទ្ធិបញ្ចេញមតិយោបល់ ឬសិទ្ធិការពារក្ដីយ៉ាងមានប្រសិទ្ធភាព គឺស្ដែងចេញឱ្យច្បាស់

[96] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧១-៧៧។

[97] វិធាន ៩៦(១)។

[98] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥១-៥៦។

[99] ឯកសារ E463/1 បណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[100] ឯកសារ E463/1/3 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសាលក្រមសង្ខេប កថាខណ្ឌ ១៥។

[101] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៩។

[102] សូមមើល បទដ្ឋាននៃការពិនិត្យលើបណ្ដឹងសាទុក្ខ (កំហុសផ្នែកនីតិវិធី)។

តាមរយៈបណ្តឹងសាទុក្ខនេះតែម្តង។ កាលៈទេសៈចម្បងតែមួយគត់គឺថា ម្ចាស់បណ្តឹងឧទ្ធរណ៍មានពេលវេលា*ច្រើនជាងមុន*ក្នុងការរៀបចំបណ្តឹងសាទុក្ខរបស់ខ្លួន។ ដូចដែលអង្គជំនុំជម្រះនេះបានសន្និដ្ឋានរួចមកហើយ អ.ជ.ស.ដ មិនបាន "ដកហូតសិទ្ធិរបស់ជនជាប់ចោទក្នុងការពិនិត្យលើអង្គសេចក្តីនៃការដាក់ពិរុទ្ធភាព និងការប្រកាសទោសឡើយ"[103] "ការលើកឡើងអំពីការរំលោភបំពានលើសិទ្ធិផ្នែកនីតិវិធីរបស់ជនជាប់ចោទគ្រាន់តែជាសម្មតិកម្មសុទ្ធសាធ"[104] ហើយ អ.ជ.ត.ក ពុំចាំបាច់ធ្វើអន្តរាគមន៍ "ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះឡើយ"[105]។ ការផ្សព្វផ្សាយនូវសំអាងហេតុជាលាយលក្ខណ៍អក្សររបស់ អ.ជ.ស.ដ និងបណ្តឹងសាទុក្ខប្រឆាំងនឹងសំអាងហេតុទាំងនោះរបស់ម្ចាស់បណ្តឹង បានបញ្ជាក់ថា នេះជារឿងត្រឹមត្រូវ។

## ខ. គោលការណ៍នីត្យានុកូលភាព

### *មូលដ្ឋានទី ៨៥៖ កំហុសពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព*[106]

29. **<u>មូលដ្ឋានទី</u> ៨៥ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ នៅក្នុងការលើកឡើងរបស់ខ្លួនអំពីលក្ខខណ្ឌតម្រូវនៃភាពអាចដឹងជាមុនថាជាបទល្មើស និងភាពអាចដឹងជាមុនថាមានច្បាប់ចែង។**

30. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញកំហុស នៅក្នុងការលើកឡើងរបស់ អ.ជ.ស.ដ អំពីលក្ខខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព[107] ដែលម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ថាបានប្រាសចាកពី *គ្រប់ទិដ្ឋភាពទាំងអស់*ដែលស្របទៅនឹងយុត្តិសាស្ត្រពីមុនៗរបស់ អ.ជ.ត.ក, អ.ប.ជ និងតុលាការមិនអចិន្ត្រៃយ៍ ព្រមទាំងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ *និង* យុត្តិសាស្ត្ររបស់តុលាការ ECtHR នោះទេ។

---

[103] ឯកសារ **E463/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសាលក្រមសង្ខេប កថាខណ្ឌ ១៤។

[104] ឯកសារ **E463/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសាលក្រមសង្ខេប កថាខណ្ឌ ១៨។

[105] ឯកសារ **E463/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសាលក្រមសង្ខេប កថាខណ្ឌ ១៨។

[106] <u>មូលដ្ឋានទី ៨៥៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព* កថាខណ្ឌ ៥៥០-៥៧៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៤ (ភាសាអង់គ្លេស) ទំព័រ ៣១ (ភាសាបារាំង) ទំព័រ ៤៧-៤៨ (ភាសាខ្មែរ)។

[107] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៥០-៥៧៤។

31. ម្ចាស់បណ្ដឹងសាទុក្ខមិនបានតវ៉ាថា អ.ជ.ស.ជ បានសម្រេចដោយត្រឹមត្រូវ ស្របទៅនឹងការអនុវត្ត របស់ អ.ជ.ត.ក[108] អ.ប.ជ[109] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY")[110] និងតុលាការ ECtHR[111] ថា ឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ ត្រូវមាន (១) អត្ថិភាពក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ និង (២) ជនជាប់ចោទអាចដឹងជាមុនថាជាបទល្មើស និងអាចដឹងជាមុនថាមានច្បាប់ចែង នៅពេលប្រព្រឹត្តិអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់[112]។ ទោះជាយ៉ាងណាក្តី គាត់បានទាញសេចក្តីសន្និដ្ឋានដោយខុសឆ្គងថា អ.ជ.ស.ជ ចាំបាច់ត្រូវអនុវត្តតាមលក្ខខណ្ឌនៃភាពអាចដឹងជាមុនថាជាបទល្មើស និងភាពអាចដឹងជាមុនថាមានច្បាប់ចែង ចំពោះ "និយមន័យបច្ចេកទេស"[113] នៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ និងមិនត្រូវបានអនុញ្ញាតឱ្យសំអាងទៅលើ (១) អត្ថិភាពនៃឧក្រិដ្ឋកម្ម ឬទម្រង់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងសម័យប្រជាធិបតេយ្យ (២) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និង (៣) មុខតំណែងរបស់ម្ចាស់បណ្ដឹងសាទុក្ខនៅក្នុងអាជ្ញាគ្រប់គ្រងប្រទេសកម្ពុជា ដើម្បីបង្កើតជាស្ថានភាពនៃភាពអាចដឹងជាមុនថាជាបទល្មើស និងភាពអាចដឹងជាមុនថាមានច្បាប់ចែង[114]។

*ភាពអាចដឹងជាមុនថាមានច្បាប់ចែង*

---

[108] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦១-៧៦២។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តីឌុច កថាខណ្ឌ ៩១, ៩៦-៩៧។

[109] សូមមើលឧទាហរណ៍ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីការបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធិ ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ ១០៥-១០៦។ ឯកសារ **D427/1/30** លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ ២១០-២២០។ ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៣។

[110] សេចក្តីសម្រេចលើការទទួលខុសត្រូវរបស់មេបញ្ជាការ រឿងក្តី *Hadžihasanović* កថាខណ្ឌ ៣៣-៣៥។ សេចក្តីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បង្ខំស្តីពីយុត្តាធិការ រឿងក្តី *Ojdanić* កថាខណ្ឌ ២១, ៣៧។ សាលក្រមរឿងក្តី *Blagojević & Jokić* ជើងទំព័រ ២១៤៥។ សាលក្រមរឿងក្តី *Stakić* កថាខណ្ឌ ៤៣១។

[111] *សូមមើលឧទាហរណ៍ រឿងក្តី Kononov តទល់នឹង ប្រទេសឡេតូនី* កថាខណ្ឌ ១៨៧។ *រឿងក្តី Streletz តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៥១។ *រឿងក្តី K.-H. W. តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៤៦។ *រឿងក្តី Kafkaris តទល់នឹង ប្រទេសស៊ីប* កថាខណ្ឌ ១៣៨, ១៤០។ *រឿងក្តី Vasiliauskas តទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ១៥៤។

[112] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១-៣២។

[113] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៥២, ៥៥៧, ៥៥៩, ៥៦១, ៥៦៣។

[114] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៥០។

32. ដូច អ.ជ.ស.ដ ដែរ[115] អ.ជ.ត.ក បានសម្រេចរួចហើយថា "ទាក់ទងទៅនឹងលក្ខខណ្ឌនៃភាពអាចយល់ដឹងជាមុនថាមានច្បាប់ចែង ក្រៅពីសន្ធិសញ្ញានានា នៅមាន "ច្បាប់នានាដែលបានផ្អែកលើទំនៀមទម្លាប់ ឬគោលការណ៍ទូទៅ អាចយកមកធ្វើជាសំអាងក្នុងការបញ្ជាក់ថា ជនជាប់ចោទអាចយល់ដឹងគ្រប់គ្រាន់ថា មានច្បាប់ចែង""[116] ជាសេចក្តីសម្រេចដែលបានលើកឡើងម្តងហើយម្តងទៀតនៅក្នុងយុត្តាធិការនៃតុលាការ ICTY[117] និងតុលាការ ECtHR[118]។ ជាងនេះទៀត អ.ជ.ត.ក បានបញ្ជាក់ថា មុខតំណែងរបស់ជនជាប់ចោទអាចមានការជាប់ពាក់ព័ន្ធបន្ថែមទៀត *តែមិនចាំបាច់* ក្នុងការកំណត់អំពីភាពអាចដឹងជាមុនថាមានច្បាប់ចែង[119]។ សេចក្តីពិចារណាដូចគ្នាត្រូវបានរកឃើញនៅឯតុលាការ ECtHR[120] និងយុត្តាធិការក្រោយសង្គ្រាមលោកលើកទី២[121]។

33. ហេតុនេះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា គាត់មិនគួរត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ដោយសារគាត់មិនអាចដឹងអំពីករណីយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី២ ជាភាសាមួយដែលយល់ដឹងបាន[122] ពុំមានភាពពាក់ព័ន្ធទេ។ ក្នុងករណីណាក៏ដោយ ការយល់ឃើញរបស់ អ.ជ.ស.ដ បង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខស្ថិតក្នុងតួនាទីយ៉ាងល្អក្នុងការទទួលបានច្បាប់ពាក់ព័ន្ធទាំងអស់។ គាត់មិនត្រឹមតែជាជាមន្ត្រីដឹកនាំរដ្ឋាភិបាលនៅមុន[123] និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ តែគាត់បានសិក្សាច្បាប់នៅប្រទេសបារាំងក្នុងទសវត្សរ៍ឆ្នាំ

---

[115] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១។

[116] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦២។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩៦។

[117] សេចក្តីសម្រេចលើការទទួលខុសត្រូវរបស់មេបញ្ជាការ រឿងក្តី *Hadžihasanović* កថាខណ្ឌ ៣៤។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំស្តីពីយុត្តាធិការ រឿងក្តី *Ojdanić* កថាខណ្ឌ ៤០។

[118] *រឿងក្តី Kononov តទល់នឹង ប្រទេសឡេតូនី* កថាខណ្ឌ ២១៣, ២២៧, ២៣៦-២៣៧។

[119] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦១។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៨០។

[120] សូមមើលឧទាហរណ៍ *រឿងក្តី Kononov តទល់នឹង ប្រទេសឡេតូនី* កថាខណ្ឌ ២៣៨។

[121] សាលក្រមតុលាការ IMT ទំព័រ ២១៩ ("ការកាន់កាប់មុខតំណែងដែលពួកគេទទួលបាននៅក្នុងរដ្ឋាភិបាលប្រទេសអាល្លឺម៉ង់ បណ្តាចុងចោទទាំងនេះ [...] ត្រូវតែបានដឹងអំពីសន្ធិសញ្ញានានាដែលអាល្លឺម៉ង់បានចុះហត្ថលេខា ការដាក់ឱ្យនៅក្រៅច្បាប់នូវការបង្កសង្គ្រាមសម្រាប់ដំណោះស្រាយជម្លោះជាអន្តរជាតិ។ ពួកគេត្រូវតែបានដឹងថា ពួកគេកំពុងធ្វើសកម្មភាពប្រឆាំងនឹងច្បាប់អន្តរជាតិទាំងអស់ នៅពេលពួកគេធ្វើការរៀបចំផែនការលម្អិតពីការលុកលុយ និងការឈ្លានពាន")។

[122] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៧២។

[123] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៧០-៥៧១។

១៩៥០[124] រយៈពេលខ្លី ក្រោយពេលការជំនុំជម្រះក្តីនៅតុលាការ Nuremberg បានដំណើរការ និងមានការចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសារវ័ន្តជាច្រើនទៀត[125]។ នៅឆ្នាំ១៩៥៩ គាត់បានធ្វើបទបង្ហាញនិក្ខេបបទថ្នាក់បណ្ឌិតជាភាសាបារាំងនៅទីក្រុងប៉ារីស[126] ដោយមានការពិភាក្សាយ៉ាងលម្អិតអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ[127] និងយល់ដឹងយ៉ាងស៊ីជម្រៅពីច្បាប់អន្តរជាតិ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[128]។ ម្ចាស់បណ្តឹងសាទុក្ខក៏អាចប្រើប្រាស់ភាសាអង់គ្លេសបានស្ទាត់ជំនាញផងដែរ[129]។

## *ភាពអាចដឹងជាមុនថាជាបទល្មើស*

[124] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៤-៥៦៥។

[125] រួមទាំងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង អនុសញ្ញាសិទ្ធិមនុស្សទ្វីបអឺរ៉ុបឆ្នាំ១៩៥០។

[126] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៧។

[127] ឯកសារ **E3/123** និក្ខេបបទរបស់ ខៀវ សំផន៖ *L'Economie du Cambodge et ses Problemes d'Industrialisation* (សេដ្ឋកិច្ចប្រទេសកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម) EN 00750610, 00750654។

[128] សូមមើល ឯកសារ **E3/8304** FBIS *សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន* ថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៨ EN 00166068 ("តាមវិធីដូចគ្នាដែលហ៊ីត្លែរបានលុកលុយចូលទឹកដីឆេកូស្លូវាគីនៅឆ្នាំ១៩៣៩ ដោយមិនបង្ហាញពីការពិចារណាដល់ច្បាប់អន្តរជាតិណាមួយឡើយ")។ ឯកសារ **E3/549** *សុន្ទរកថារបស់ប្រធានគណៈប្រធានកម្ពុជាប្រជាធិបតេយ្យ ក្នុងសន្និសីទកំពូលលើកទី៥ នៃប្រទេសមិនចូលបក្សសម្ព័ន្ធ* ខែសីហា ឆ្នាំ១៩៧៦ EN 0065902, 05-07 ("[កម្ពុជាប្រជាធិបតេយ្យ] គោរពដាច់ខាតលក្ខការណ៍ដែលប្រទេសនីមួយៗ មានអធិបតេយ្យភាព មិនមានសិទ្ធិអំណាចចាត់ចែង និងសម្រេចកិច្ចការប្រទេសខ្លួន ដោយខ្លួនឯងពេញទី គ្មានការជ្រៀតជ្រែកមកពីខាងក្រៅ" ដោយបន្ថែមថា គាត់គាំទ្រប៉ាឡេស្ទីនក្នុងការទទួលបានសិទ្ធិស្វ័យសម្រេច)។ សូមមើលផងដែរឯកសារ **E3/203** បទសម្ភាសន៍របស់ ខៀវ សំផន ដោយ Stephen Heder ថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៨០ EN 00385399 ("[កម្ពុជាប្រជាធិបតេយ្យ] ជារដ្ឋមួយអធិបតេយ្យភាពដែលសកលលោកទទួលស្គាល់ដែលអង្គការសហប្រជាជាតិទទួលស្គាល់ ហើយយួនវ៉ៃ [កម្ពុជាប្រជាធិបតេយ្យ] ហ្នឹងដោយរំលោភលើច្បាប់អន្តរជាតិ ហើយរំលោភរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ")។

[129] សូមមើល ឯកសារ **E3/4058R** សន្និសិទសារព័ត៌មានដោយ នួន ជា និង ខៀវ សំផន ឆ្នាំ១៩៩៨ EN V00172408-V00172408 (ក្នុងអំឡុងពេលសន្និសិទសារព័ត៌មាន ម្ចាស់បណ្តឹងសាទុក្ខបានអាចសេចក្តីថ្លែងការណ៍នយោបាយមួយជាភាសាអង់គ្លេសយ៉ាងស្ទាត់ជំនាញ។ អ្នកសារព័ត៌មានម្នាក់ដែលប្រើប្រាស់ភាសាអង់គ្លេសបានសួរគាត់មួយសំណួរ ហើយគាត់បានឆ្លើយតបជាភាសាអង់គ្លេសថា "អ្វីដែលកន្លងហួសទៅហើយឱ្យវាហួសទៅចុះ គឺជាដំណោះស្រាយល្អបំផុតសម្រាប់ប្រទេសយើង ដោយសារនេះជាវិធីតែមួយគត់ដែលយើងអាចធ្វើការផ្សះផ្សារជាតិបាន"។ ក្នុងការឆ្លើយតបទៅនឹងសំណួរមួយទៀត គាត់បានលើកឡើងថា៖ "ដូចយើងដឹងហើយថា រាជរដ្ឋាភិបាល [...] កំពុងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្លួនក្នុងការដោះស្រាយបញ្ហានេះ បញ្ហាដែលពាក់ព័ន្ធនឹងបូរណភាពជាតិយើង")។

34. ការសម្រេចរបស់ អ.ជ.ស.ដ ថា ចំពោះឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវដែលអាចដឹងជាមុនថាជាបទល្មើស ជនជាប់ចោទ "ត្រូវមានលទ្ធភាពគ្រប់គ្រាន់ដែលអាចឱ្យខ្លួនយល់ដឹងថាអំពើដែលខ្លួនប្រព្រឹត្តគឺជាបទល្មើសក្នុងន័យដែលគេអាចយល់ដឹងជាទូទៅបាន ដោយពុំចាំបាច់យោងទៅរកបទប្បញ្ញត្តិជាក់លាក់ណាមួយទេ"[130] ហើយថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនេះអាចពាក់ព័ន្ធទៅនឹងការវាយតម្លៃនោះ[131] ដែលស្របទៅនឹងយុត្តិសាស្ត្ររបស់ អ.ជ.ត.ក ដែរ[132]។ អ.ប.ជ[133] តុលាការ ICTY[134] តុលាការ ECtHR[135] និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២[136] ក៏បានបញ្ជាក់ផងដែរថា ភាពធ្ងន់ធ្ងរនៃបទល្មើសមានភាពពាក់ព័ន្ធខ្ពស់ទៅនឹងការកំណត់ពីភាពអាចដឹងជាមុនថាជាបទល្មើស។ វាបំពេញទៅតាមកម្មវត្ថុនិងគោលបំណងនៃគោលការណ៍នីត្យានុកូលភាព ដូចដែល

---

[130] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៥។

[131] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០, ៣២៦, ៦៥១, ៦៥៤, ៦៦១, ៦៧៣, ៦៨៨, ៧០០, ៧១២, ៧២៣។

[132] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦២ ជើងទំព័រ ១៩៨៣។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩៦-៩៧។

[133] ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ ១០៦។ ឯកសារ **D427/1/30** លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ ២៣៥។ ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៥។

[134] សេចក្តីសម្រេចលើការទទួលខុសត្រូវរបស់មេបញ្ជាការ រឿងក្តី *Hadžihasanović* កថាខណ្ឌ ៣៤។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំស្តីពីយុត្តាធិការ រឿងក្តី *Ojdanić* កថាខណ្ឌ ៤២។ សាលក្រមរឿងក្តី *Čelebići* កថាខណ្ឌ ១៧៣។

[135] រឿងក្តី *Groppera Radio AG តទល់នឹង ប្រទេសស្វីស* កថាខណ្ឌ ៦៨។ រឿងក្តី *Kononov តទល់នឹង ប្រទេសឡេតូនី* កថាខណ្ឌ ២៣៨។ រឿងក្តី *S.W. តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ៤៤។ រឿងក្តី *Jorgic តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ១០១, ១០៣-១១៦។

[136] សាលក្រមរបស់តុលាការ IMT ទំព័រ ២១៩ ("គេត្រូវធ្វើការសង្កេតថា ទ្រឹស្តី *មិនមែនជាបទល្មើស មិនគ្មានច្បាប់ចែង* [...] ជាគោលការណ៍ទូទៅផ្នែកយុត្តិធម៌។ ដើម្បីអះអាងថា វាមិនយុត្តិធម៌ក្នុងការដាក់ទណ្ឌកម្មដល់ជនដែលប្រឆាំងនឹងសន្ធិសញ្ញា និងការធានា បានវាយប្រហារទៅលើរដ្ឋជិតខាង ដោយមិនបានព្រមានប្រាប់ជាមុន ជាការមិនពិតទេ ដោយសារថា នៅក្នុងកាលៈទេសៈទាំងនេះ អ្នកវាយប្រហារត្រូវតែដឹងថា គាត់កំពុងធ្វើខុស ហើយវាមិនត្រឹមតែមិនយុត្តិធម៌ក្នុងការដាក់ទណ្ឌកម្មបុគ្គលនោះប៉ុណ្ណោះទេ តែវានឹងមិនយុត្តិធម៌ទេ ប្រសិនបើអំពើខុសឆ្គងរបស់បុគ្គលនោះមិនត្រូវបានដាក់ទណ្ឌកម្មទេ")។ សាលក្រមរឿងក្តី *Justice* ទំព័រ ៩៧៧-៩៧៨ ("ដោយសារបានយកមកអនុវត្តនៅក្នុងវិស័យច្បាប់អន្តរជាតិថា គោលការណ៍ [នីត្យានុកូលភាព] តម្រូវឱ្យមានភ័ស្តុតាងមុនពេលផ្តន្ទាទោសថា ជនជាប់ចោទបានដឹង ឬគួរតែបានដឹងថា នៅក្នុងបញ្ហានានានៃការព្រួយបារម្ភជាអន្តរជាតិ គាត់មានពិរុទ្ធភាពពីការចូលរួមនៅក្នុងប្រព័ន្ធអយុត្តិធម៌ដែលបានរៀបចំនៅថ្នាក់ជាតិ និងការធ្វើទុក្ខបុកម្នេញដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សីលធម៌របស់មនុស្សជាតិ ហើយថា គាត់បានដឹង ឬគួរតែបានដឹងថា គាត់នឹងត្រូវទទួលរងទណ្ឌកម្ម ប្រសិនបើរកឃើញ")។

ម្ចាស់បណ្តឹងសាទុក្ខបានតម្រូវដដែល[137] ដោយធានាថា គាត់អាចដឹងជាមុនថា ការប្រព្រឹត្តរបស់គាត់ជាបទល្មើស។ ការសាកល្បងមិនមែនថាតើម្ចាស់បណ្តឹងសាទុក្ខអាចដឹងយ៉ាងច្បាស់ថា គាត់គួរតែត្រូវបានសម្រេចដាក់ពិរុទ្ធភាព ឬយ៉ាងណាទេ តែផ្ទុយទៅវិញ គឺថាតើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ *អាចដឹងបានជាមុនថាជាបទល្មើស* ឬយ៉ាងណា។ នៅពេលឧក្រិដ្ឋកម្មមួយមានភាពធ្ងន់ធ្ងរជាខ្លាំងរហូតដល់មានភាពខុសច្បាប់ជាក់ស្តែង ពុំតម្រូវឱ្យមានការយល់ដឹងពី "និយមន័យបច្ចេកទេស" ទេ។ ដូចដែល អ.ជ.ស.ដ បានទទួលស្គាល់[138] និងផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[139] ចំណុចនេះនៅតែជាការពិត ដរាបណាការបកស្រាយនាពេលអនាគតទៅលើព្រំដែននៃបទល្មើសមួយ មិនហួសពី "ខ្លឹមសារ" របស់វា ហេតុនេះ អត្ថិភាពនៃភាពមិនប្រាកដប្រជាតាមផ្លូវតុលាការមិនអាចឱ្យគេនិយាយបានថា មិនអាចដឹងជាមុនថាមានការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ[140]។

35. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា គាត់មិនអាចរំពឹងដល់ការអនុវត្តច្បាប់អន្តរជាតិ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យទេ ដោយសារប្រព័ន្ធច្បាប់កម្ពុជាជាប្រព័ន្ធទ្វិកនិយម ក៏ជារឿងធ្វើឱ្យយល់ច្រឡំស្រដៀងគ្នាដែរ[141]។ ការបដិសេធចោលទឡ្ហីករណ៍ដូចគ្នាបេះបិទរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ អ.ជ.ត.ក បានបញ្ជាក់ថា គោលការណ៍នីត្យានុកូលភាពអនុញ្ញាតឱ្យការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មថ្នាក់ជាតិ *ឬ* អន្តរជាតិ នៅពេលដែលប្រព្រឹត្ត[142]។ ហេតុនេះ ដូចដែល អ.ប.ជ បានលើកឡើង បញ្ហាថាតើឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវត្រូវ

---

[137] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៥៤, ៥៥៦, ៥៦៩-៥៧២។

[138] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩ *ដកស្រង់* រឿងក្តី *Vasiliauskas តទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ១៥៥។ រឿងក្តី *Kononov តទល់នឹង ប្រទេសឡេតូនី* កថាខណ្ឌ ១៨៥។ សូមមើលផងដែរ រឿងក្តី *Jorgic តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ១១៤។

[139] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៥៥, ៥៥៧, ៥៦២។

[140] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៦៩-៥៧១។

[141] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៦៨។

[142] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦៣។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩១-៩៥។ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធិ ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ ៩៨។ សូមមើលផងដែរ ICCPR មាត្រា ១៥(១)។ រឿងក្តី *Streletz តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៥១។ រឿងក្តី *K.-H. W. តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៤៦។

បានទទួលស្គាល់នៅក្នុងច្បាប់ជាតិ ឬយ៉ាងណា អាច*ជាប់ពាក់ព័ន្ធ*នឹងការវាយតម្លៃពីភាពអាចដឹងជាមុនថាជាបទល្មើស តែវាមិន*ចាំបាច់ទេ*[143]។

## *យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប*

36. ពុំមានយុត្តិសាស្ត្រណាមួយរបស់តុលាការ ECtHR ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ ផ្ទុយពីគោលជំហរដែលត្រឹមត្រូវទាំងនេះ។ ដូចដែល អ.ជ.ស.ដ បានធ្វើការកត់សម្គាល់[144] ម្ចាស់បណ្តឹងសាទុក្ខបញ្ចូលពីរដំណាក់កាលដែលចាំបាច់ ដើម្បីធានាឱ្យស្របទៅនឹងគោលការណ៍នីត្យានុកូលភាពគឺ៖ ទីមួយ (១) ឧក្រិដ្ឋកម្មមានក្នុងច្បាប់នៅឆ្នាំ១៩៧៥ និង (២) ឧក្រិដ្ឋកម្មនេះអាចដឹងជាមុនថាមានច្បាប់ចែង និងអាចដឹងជាមុនថាជាបទល្មើស។ ទោះបី ជារឿយៗតុលាការ ECtHR ដោះស្រាយដំណាក់កាលទាំងនេះរួមគ្នាក្តី តែតុលាការនេះយល់ថាដំណាក់កាលទាំងពីរនេះដាច់ស្រឡះពីគ្នា[145]។ ហេតុនេះ ផ្ទុយពីការបកស្រាយរបស់ម្ចាស់បណ្តឹងសាទុក្ខ[146] តុលាការជាន់ខ្ពស់នៅក្នុងរឿងក្តី *Vasiliauskas តទល់នឹង ប្រទេសលីទុយអានី* បានរកឃើញនូវការរំលោភបំពានដោយសារ (១) ពុំមានស្ថានភាពជាទំនៀមទម្លាប់ចំពោះអំពើប្រល័យពូជសាសន៍ទៅលើ "ក្រុមនយោបាយ"[147] និង (២) ភាពមិនស្របគ្នានៃការសម្រេចដាក់ពិរុទ្ធភាពចំពោះអ្នកដាក់ពាក្យសុំដោយមាន "ខ្លឹមសារ" ជាអំពើប្រល័យពូជសាសន៍ ដូចមានកំណត់និយមន័យនៅក្នុងច្បាប់ព្រហ្មទណ្ឌ នៅឯពេលវេលាជាក់ស្តែង[148]។ លំនាំស្រដៀងគ្នាបានលេចឡើងនៅគ្រប់ករណីយុត្តិសាស្ត្រទាំងអស់របស់តុលាការ ECtHR ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់[149] ដែលការវាយតម្លៃ

---

[143] ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៥។

[144] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦-២៨។

[145] *សូមមើលឧទាហរណ៍* រឿងក្តី *Kononov តទល់នឹង ប្រទេសឡេតូនី* កថាខណ្ឌ ១៨៧។ រឿងក្តី *Streletz តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៥១។ រឿងក្តី *K.-H. W. តទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៤៦។ រឿងក្តី *Kafkaris តទល់នឹង ប្រទេសស៊ីប* កថាខណ្ឌ ១៣៨, ១៤០។ រឿងក្តី *Vasiliauskas តទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ១៥៤។

[146] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៦៣ *ដកស្រង់* រឿងក្តី *Vasiliauskas តទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ១៦៧-១៨៦, ១៩១។

[147] រឿងក្តី *Vasiliauskas តទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ១៧៨, ១៨១។

[148] រឿងក្តី *Vasiliauskas តទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ១៨៥។

[149] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៥៦។ សូមមើលឧទាហរណ៍ រឿងក្តី *Dragotoniu និង Militaru-Pidhorni តទល់នឹង ប្រទេសរ៉ូម៉ានី* កថាខណ្ឌ ៣៩-៤៨។ រឿងក្តី *Contrada តទល់នឹង ប្រទេសអ៊ីតាលី (លេខ ៣)* កថាខណ្ឌ ៦៤-៧៦។ រឿងក្តី *Žaja តទល់នឹង ប្រទេសក្រូអាត* កថាខណ្ឌ ៩៩-១០៥។

ពីភាពធ្ងន់ធ្ងរមិនពាក់ព័ន្ធ ដោយសារឧក្រិដ្ឋកម្មទាំងនោះមានលក្ខណៈបច្ចេកទេស និង/ឬ ហិរញ្ញវត្ថុខ្ពស់។ ទោះជាយ៉ាងណាក្តី នៅក្នុងករណីដែលឧក្រិដ្ឋកម្មធ្ងន់ធ្ងររហូតដល់ឧក្រិដ្ឋភាពរបស់វាមានភាពជាក់ស្តែង ដោយមិនគិតដល់និយមន័យបច្ចេកទេសនៃបទល្មើសនោះ តុលាការ ECtHR យល់ឃើញថា ពុំមានការបំពានទៅលើគោលការណ៍នីត្យានុកូលភាពទេ[150]។

*ធាតុផ្សំរួមសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*[151]

37. ការរិះគន់របស់ម្ចាស់បណ្តឹងសាទុក្ខចំពោះ អ.ជ.ស.ដ ថាមិនបានពិភាក្សាទៅលើភាពអាចដឹងជាមុនថាមានច្បាប់ចែង និងភាពអាចដឹងជាមុនថាជាបទល្មើស នៃធាតុផ្សំ*រួម*របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ធ្វើឡើងដោយគ្មានមូលដ្ឋាន[152]។ នៅពេល អ.ជ.ស.ដ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ អាចដឹងជាមុនថាមានច្បាប់ចែង និងអាចដឹងជាមុនថាជាបទល្មើស[153] ជាចាំបាច់ ចំណុចនេះបានបញ្ចូលនូវធាតុផ្សំ*រួម*របស់វា។ ក្នុងកាលៈទេសៈណាក៏ដោយ អ.ជ.ត.ក បានបញ្ជាក់រួចមកហើយអំពីភាពអាចដឹងជាមុនថាមានច្បាប់ចែង និងភាពអាចដឹងជាមុនថាជាបទល្មើស នៃធាតុផ្សំ*រួម*របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[154]។ អនុសញ្ញាទីក្រុងហ្សឺណែវចងកាតព្វកិច្ចដល់ប្រទេសកម្ពុជា បន្ទាប់ពីប្រទេសនេះបានចូលជាសមាជិកនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៥៨[155] ហើយធាតុផ្សំ*រួម* មានចែងយ៉ាងច្បាស់នៅក្នុងអនុសញ្ញាទាំងនោះ[156]។

---

[150] សូមមើលឧទាហរណ៍ រឿងក្តី *Kononov តទល់នឹង ប្រទេសឡេតូនី* កថាខណ្ឌ ២៣៨-២៣៩, ២៤៤។

[151] ទាក់ទិននឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខស្តីពីការទទួលខុសត្រូវផ្នែកសហឧក្រិដ្ឋកម្មរួម ចំពោះអំពើអកម្មជាពិរុទ្ធ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៦។

[152] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៦៧ ដកស្រង់ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០០-៣១៦ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ), ៣២៥-៣៥៥ (អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ)។

[153] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០០ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ), ៣២៥-៣២៦ (អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ)។ មុនពេលធ្វើសេចក្តីសន្និដ្ឋានទាំងនោះពាក់ព័ន្ធនឹងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ អង្គជំនុំជម្រះបានរៀបរាប់ច្បាស់លាស់នូវលក្ខខណ្ឌតម្រូវ*រួម*។

[154] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦៤។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩៩-១០៤។

[155] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៥។

[156] ដោយសារពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ១៣០ និង អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ១៤៧។ "បុគ្គលទទួលការការពារ" ត្រូវបានកំណត់និយមន័យនៅត្រង់អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា

## IV. សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌

### ក. សេចក្តីផ្តើម

38. អ.ជ.ស.ដ បានអនុវត្តនូវវិធីសាស្រ្តយ៉ាងត្រឹមត្រូវដើម្បីធានាថា ម្ចាស់បណ្តឹងសាទុក្ខបានទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមមានជាពិសេស៖ ទទួលការវិនិច្ឆ័យដោយតុលាការឯករាជ្យ និងមិនលម្អៀង និងទទួលបានព័ត៌មានអំពីលក្ខណៈ និងមូលហេតុនៃបទចោទនានាប្រឆាំងនឹងរូបគាត់ ទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន និង ទទួលបានឱកាសក្នុងការបង្ហាញការការពារក្តីប្រកបដោយប្រសិទ្ធភាព[157]។ មូលដ្ឋាននីមួយៗក្នុងចំណោមមូលដ្ឋានទាំងប្រាំបីរបស់គាត់[158] ដែលជំទាស់ទៅនឹង៖ ឯករាជភាព និងភាពមិនលម្អៀង[159] ប្រព័ន្ធនៃការជូនដំណឹងពីការជ្រើសរើសសាក្សី[160] សេចក្តីសម្រេចលើការប្រើប្រាស់ភ័ស្តុតាងដែលបានទទួលយកក្នុងសំណុំរឿង ០០២/០១ និងការរម្លឹករឿងរ៉ាវឡើងវិញរបស់សាក្សី[161] ការវាយតម្លៃភ័ស្តុតាង[162] ការបកស្រាយពីកាតព្វកិច្ចដាក់បង្ហាញភ័ស្តុតាងរបស់សហព្រះរាជអាជ្ញា[163] លក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបាននៃភ័ស្តុតាង និងការទទួលយកភ័ស្តុតាងក្នុងអំឡុងពេលជំនុំជម្រះ និងក្រោយពេលបញ្ចប់ការស្តាប់សក្ខីកម្ម[164] និងការសម្រេចដើម្បីកំណត់ឡើងវិញនូវបទល្មើសនៃការសម្លាប់រង្គាលមកជាការធ្វើមនុស្សឃាត[165] របស់ អ.ជ.ស.ដ ត្រូវបរាជ័យ។ ទឡ្ហីករណ៍ទាំងនោះធ្វើឡើងដោយគ្មានមូលដ្ឋាន ដោយសារម្ចាស់បណ្តឹងសាទុក្ខបកស្រាយខុសនូវច្បាប់និងអង្គហេតុរួមដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលបានធ្វើឡើង ព្រមទាំងដំណើរការដែលប្រកាន់យកលើបញ្ហាទាំងនេះ ដើម្បីការពារសិទ្ធិទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ខ្លួន ទាំងនៅមុនពេល និងក្នុងអំឡុងពេលជំនុំជម្រះ។ ហេតុនេះ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខអំពី

---

៤ (ឈ្លើយសឹក) និង អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ៤ (ជនស៊ីវិល)។ សូមមើលផងដែរ អនុសញ្ញាទីក្រុងហ្សឺណែវ មាត្រា ២ ទូទៅ។

[157] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១០-១៥៧។

[158] មូលដ្ឋានទី ៤, ៦, ៧, ៨, ៩, ១០, ១៤ និង ២៣។

[159] មូលដ្ឋានទី ៤។

[160] មូលដ្ឋានទី ៨។

[161] មូលដ្ឋានទី ៧។

[162] មូលដ្ឋានទី ១៤។

[163] មូលដ្ឋានទី ១០។

[164] មូលដ្ឋានទី ៩ និង ២៣។

[165] មូលដ្ឋានទី ៦។

ប្រសិទ្ធភាពរួមនៃការរំលោភបំពានលើសិទ្ធិទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលត្រូវបានចោទប្រកាន់ ត្រូវទុកជាអសារបង់។

## ខ. ចម្លើយតបទៅនឹងមូលដ្ឋាននានា

### *មូលដ្ឋានទី ៤៖ ភាពលម្អៀង ឬបុរេវិនិច្ឆ័យរបស់ស្ថាប័នតុលាការ*[166]

39. **<u>មូលដ្ឋានទី ៤</u> គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ ដោយមិនបានឆ្លើយតប ឬឆ្លើយតបមិនបានគ្រប់គ្រាន់ ចំពោះការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខពីភាពលម្អៀងនៅក្នុងសំណុំរឿង ០០២/០២ ដែលកើតចេញពីការដែល អ.ជ.ស.ដ ចេញសាលក្រមសំណុំរឿង ០០២/០១ ប្រឆាំងនឹងម្ចាស់បណ្តឹងសាទុក្ខ។**

40. <u>មូលដ្ឋាននេះ</u>មិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ មានកំហុសដោយសារមិនពិចារណាដល់ការចោទប្រកាន់ពីអសមត្ថភាពរបស់ខ្លួន ក្នុងការលុបបំបាត់<u>ភាពលម្អៀង</u> ឬបុរេវិនិច្ឆ័យ ក្រោយពេលជំនុំជម្រះសំណុំរឿង ០០២/០១[167] និងមិនដែលងាកចេញពីទស្សនៈតែមួយនៃការជំនុំជម្រះរបស់ខ្លួន ដោយដើរតាមមូលដ្ឋានយោបល់ទូទៅនៅក្នុងសំណុំរឿង ០០២/០១[168]។ ដូចដែល អ.ជ.ស.ដ បានសម្រេចយ៉ាងត្រឹមត្រូវ[169] បញ្ហានេះត្រូវបានដោះស្រាយគ្រប់ជ្រុងជ្រោយរួចទៅហើយ នៅចំពោះមុខក្រុមប្រឹក្សាពិសេសនៃ អ.ជ.ស.ដ[170] បន្ទាប់ពីមានបណ្តឹងជំទាស់ចៅក្រមពីម្ចាស់បណ្តឹងសាទុក្ខ និង នួន ជា[171]។ ដោយសារបញ្ហានេះត្រូវបានលើក

---

[166] <u>មូលដ្ឋានទី ៤៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អគតិភាព ឬបុរេវិនិច្ឆ័យរបស់ស្ថាប័នតុលាការ* កថាខណ្ឌ ១២៧-១៣៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥ (ភាសាអង់គ្លេស) ទំព័រ ៥ (ភាសាបារាំង) ទំព័រ ៥ (ភាសាខ្មែរ)។

[167] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៧។

[168] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៨-១៣៣។

[169] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៥ ("ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋានបែបនេះជាច្រើនត្រូវបានច្រានចោលដោយក្រុមប្រឹក្សាពិសេសនៃអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងការសម្រេចលើបណ្តឹងជំទាស់ចៅក្រម")។

[170] ឯកសារ **E314/12** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិសេសលើបណ្តឹងជំទាស់ចៅក្រម អ.ជ.ស.ដ ទំព័រ ៤។ ក្នុងចំណោមចៅក្រម ៥ រូបដែលទទួលការចាត់តាំង ចៅក្រម Rowan Downing ចៅក្រម Chang-ho Chung ចៅក្រម ហួត វុទ្ធី និង ចៅក្រម ប្រាក់ គឹមសាន សុទ្ធតែជាចៅក្រមនៃ អ.ប.ជ ចំណែកចៅក្រម ធូ មណី ជាចៅក្រមបម្រុងពី អ.ជ.ស.ដ ដោយធានានូវភាពមិនលម្អៀង ក្នុងការដោះស្រាយបញ្ហានេះ។

[171] ឯកសារ **E314/1** សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សា

ឡើងរួចមកហើយ[172] និងត្រូវបានបដិសេធចោលរួចមកហើយ[173] បញ្ហានេះមិនអាចយកមកប្ដឹងសាទុក្ខបានទេ[174]។

41. ក្នុងករណីណាក៏ដោយ ទឡ្ហីករណ៍នេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញនូវភាពលម្អៀងជាក់ស្ដែង នៅក្នុងការផ្ដល់សំអាងហេតុរបស់ អ.ជ.ស.ដ ទាំងនៅក្នុងមូលដ្ឋានផ្សេងទៀត នៅពេលដែលបានការលើកឡើងនូវបញ្ហានេះ[175]។ ដើម្បីបង្ហាញនូវភាពលម្អៀងជាក់ស្ដែង ម្ចាស់បណ្ដឹងសាទុក្ខត្រូវផ្ដល់ភស្ដុតាងគួរឱ្យជឿជាក់បានថា គំនិតរបស់ចៅក្រមមាន ឬអាចមានជាប់ពាក់ព័ន្ធទៅនឹងការគ្រោងទុកជាមុន ក្នុងការដោះស្រាយបញ្ហានានានៅចំពោះមុខខ្លួនជាលក្ខណៈបុរេវិនិច្ឆ័យ[176]។ ម្ចាស់បណ្ដឹងសាទុក្ខត្រូវបង្ហាញថា ការសម្រេចរបស់ អ.ជ.ស.ដ មិនជាប់ពាក់ព័ន្ធពិតប្រាកដទៅនឹងការអនុវត្តន៍ច្បាប់ ឬការវាយតម្លៃពីអង្គហេតុដែលពាក់ព័ន្ធ[177]។

---

ជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤។ ឯកសារ **E314/6** បណ្ដឹងជំទាស់ចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សាខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូរ ឧត្ដារ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។ ឯកសារ **E314/8** បណ្ដឹងជំទាស់ចិត្តសាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។

[172] ឯកសារ **E314/8** បណ្ដឹងជំទាស់ចិត្តសាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ១០ ("មេធាវីការពារក្ដីយោងផងដែរទៅលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី២៩ ខែកញ្ញា ដែលបានរៀបរាប់យ៉ាងលម្អិតពីសេចក្ដីសន្និដ្ឋានរបស់សាលក្រម ដែលច្បាស់ថានឹងមានឥទ្ធិពលទៅលើសំណុំរឿង ០០២/០២ ដោយមូលហេតុថា សេចក្ដីសន្និដ្ឋានទាំងអស់នោះគឺជា "បុរេវិនិច្ឆ័យ" លើពិរុទ្ធភាពរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងអង្គហេតុមួយចំនួនក្នុងសំណុំរឿង ០០២/០២ ដែលមិនទាន់ត្រូវបានពិភាក្សាដេញដោល")។

[173] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាពិសេសលើបណ្ដឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ។

[174] វិធាន ៣៤(៨)។

[175] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ មូលដ្ឋានទី ២, ៣, ៦, ៧, ៨, ១០, ១១, ១២, ១៣, ១៤, ១៥, ១៦, ១៧, ១៩, ២០, ២១, ២២, ២៤, ២៥, ២៦, ២៧, ២៨, ២៩, ៣០, ៣២, ១៦៤, ១៦៥, ១៦៦, ១៧០, ១៧៤, ១៧៦, ១៨១, ១៩៩, ២០២, ២០៤, ២០៦, ២០៧, ២២២, ២២៣, ២៤៤, ២៥០, ២៥២។

[176] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២។

[177] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាពិសេសលើបណ្ដឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ កថាខណ្ឌ ៣៦។ ឯកសារ 11 សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពាក់ព័ន្ធនឹងចៅក្រមតុលាការកំពូលប្រាំមួយរូប កថាខណ្ឌ ១១៩។

42. នៅក្នុងមូលដ្ឋាននេះ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងដោយសារគំនិតខុសឆ្គងរបស់គាត់ដែលថា អ.ជ.ស.ដ ដែលបានសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទនៅក្នុងសំណុំរឿងពីមុនដែលពាក់ព័ន្ធគ្នា មិនអាចវិនិច្ឆ័យដោយមិនលម្អៀងទៅលើសំណុំរឿងមួយទៀតប្រឆាំងនឹងជនជាប់ចោទដដែលនោះទេ។ ច្បាប់មិនគាំទ្រដល់គោលជំហរនេះទេ។ ទោះបីការចោទប្រកាន់ពីភាពលម្អៀងផ្អែកទៅលើការយល់ឃើញតាមផ្លូវតុលាការប្រឆាំងនឹងជនជាប់ចោទក្តី តែដើម្បីកំណត់ថាតើ ការយល់ឃើញតាមផ្លូវតុលាការបានធ្វើបុរេវិនិច្ឆ័យពីពិរុទ្ធភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ ឬយ៉ាងណានោះ ជាការសំខាន់ត្រូវពិនិត្យថាតើចៅក្រមបានសម្រេចនៅក្នុងសំណុំរឿង ០០២/០១ ទៅលើធាតុផ្សំទាំងអស់នៃបទល្មើសមួយក្នុងសំណុំរឿង ០០២/០២ និងបានរកឃើញថាម្ចាស់បណ្តឹងសាទុក្ខមានពិរុទ្ធភាពហួសពីវិមតិសង្ស័យនៃការប្រព្រឹត្តិបទល្មើសនោះ ឬយ៉ាងណា[178]។ ភាពលម្អៀងនឹងមិនអាចរកឃើញឡើយ ដរាបណា អ.ជ.ស.ដ វាយតម្លៃជាថ្មីថាតើ ភស្តុតាងដែលបានយកមកសំអាង បំពេញទៅតាមធាតុផ្សំនៃឧក្រិដ្ឋកម្មនីមួយៗដែលត្រូវបានចោទប្រកាន់ ដែលការទទួលខុសត្រូវព្រហ្មទណ្ឌមិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១[179]។

43. នៅក្នុងករណីនេះ ទោះបីបទចោទពាក់ព័ន្ធនឹងម្ចាស់បណ្តឹងសាទុក្ខដដែល និងមានបញ្ហាខ្លះត្រួតគ្នាក៏ដោយ តែសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ មានភាពខុសគ្នាយ៉ាងច្រើន[180]។ ជាងនេះទៀត សាលក្រមសំណុំរឿង ០០២/០១ មិនបានលើកឡើងនូវបញ្ហាចុងក្រោយនៃការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងបទចោទនានា ដែលបានលើកឡើងនៅក្នុងសំណុំរឿង ០០២/០២ ទេ[181]។ វាមិនគ្រប់គ្រាន់ទេដែលម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា អ.ជ.ស.ដ បាន

---

[178] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិសេសលើបណ្តឹងដិតចិត្តចៅក្រម អ.ជ.ស.ដ កថាខណ្ឌ ៦២។ ឯកសារ **11** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពាក់ព័ន្ធនឹងចៅក្រមតុលាការកំពូលប្រាំមួយរូប កថាខណ្ឌ ៧០។

[179] ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកសំណុំរឿងបន្ថែម និងវិសាលភាព កថាខណ្ឌ ៨៥។ ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិសេសលើបណ្តឹងដិតចិត្តចៅក្រម អ.ជ.ស.ដ កថាខណ្ឌ ៩៦។ ឯកសារ **11** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពាក់ព័ន្ធនឹងចៅក្រមតុលាការកំពូលប្រាំមួយរូប កថាខណ្ឌ ៧១, ៨២។

[180] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិសេសលើបណ្តឹងដិតចិត្តចៅក្រម អ.ជ.ស.ដ កថាខណ្ឌ ៩៣។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកសំណុំរឿងបន្ថែម និងវិសាលភាព កថាខណ្ឌ ៨២ ជើងទំព័រ ១៩៦។ ឯកសារ **11** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស ពាក់ព័ន្ធនឹងចៅក្រមតុលាការកំពូលប្រាំមួយរូប កថាខណ្ឌ ៧១។

[181] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិសេសលើបណ្តឹងដិតចិត្តចៅក្រម អ.ជ.ស.ដ កថាខណ្ឌ ៩៥។

សម្រេចតាមវិធីដូចគ្នាទៅលើបញ្ហាប្រហាក់ប្រហែលគ្នាទៅនឹងបញ្ហានានា ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនៅក្នុងសំណុំរឿង ០០២/០១ ដើម្បីបង្ហាញពីអត្ថិភាពនៃភាពលម្អៀងនោះ[182]។

44. ពិសេសទៅទៀត នៅក្នុងមូលដ្ឋាននេះ ម្ចាស់បណ្ដឹងសាទុក្ខព្យាយាមបង្ហាញពីភាពលម្អៀងនេះ ដោយគ្រាន់តែលើកឧទាហរណ៍ជាក់លាក់មួយគត់ថា នៅក្នុងសំណុំរឿង ០០២/០១ "អង្គជំនុំជម្រះបានសម្រេចរួចហើយ" ពាក់ព័ន្ធនឹងគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ ប.ក.ក[183]។ ទោះជាយ៉ាងណាក្ដី ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងភាពលម្អៀង មិនទទួលបានផលទេ ដោយសារគាត់បកស្រាយមិនបានត្រឹមត្រូវនូវការយល់ឃើញរបស់ អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០១ ដែលស្របទៅនឹងការវិភាគភ័ស្តុតាងរបស់ អ.ជ.ស.ដ[184] ពាក់ព័ន្ធទៅនឹងគោលនយោបាយនៃ "បញ្ញត្តិ" នៃការរៀបអាពាហ៍ពិពាហ៍យ៉ាងទូលំទូលាយ[185] មិនមែនអាពាហ៍ពិពាហ៍ "ដោយបង្ខំ" ដូចដែលម្ចាស់បណ្ដឹងសាទុក្ខចោទប្រកាន់នោះទេ[186]។ ជាងនេះទៀត ការយល់ឃើញនេះមិនអាចបង្កើតជាបុរេវិនិច្ឆ័យបានទេ ដោយត្រឹមតែពាក់ព័ន្ធនឹង "សារតា" នៃសំណុំរឿង ០០២/០១[187] ប៉ុណ្ណោះ ដែលខុសគ្នាស្រឡះពីបញ្ហានៃ "ការទទួលខុសត្រូវព្រហ្មទណ្ឌ" ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងសំណុំរឿង ០០២/០២[188]។ ការពិត អ.ជ.ស.ដ បានលើកឡើងច្បាស់ហើយនៅក្នុងសំណុំរឿង ០០២/០១ ថា "ភ័ស្តុតាងពាក់ព័ន្ធនឹងខ្លឹមសារ និងការអនុវត្តគោលនយោបាយស្តីពីបញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ និង វិសាលភាពនៃការរៀបអាពាហ៍ពិពាហ៍នេះ គឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២"[189]។ ទោះជាយ៉ាងនេះក្តី ទឡ្ហីករណ៍នេះមិនទទួលបានផលទេ ដោយពិចារណាដល់សេចក្តីសម្រេចដែលមានសំអាងហេតុ

[182] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៩, ១៣១។

[183] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣០។

[184] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១២៨-១២៩។

[185] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣០។

[186] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣០។

[187] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៣ ជើងទំព័រ ២៨៧ ("អត្ថិភាពនៃគោលនយោបាយដទៃទៀតត្រូវបានត្រួតពិនិត្យជាលក្ខណៈមូលដ្ឋានតែប៉ុណ្ណោះ។ ការអនុវត្តគោលនយោបាយទាំងនោះ នឹងក្លាយជាប្រធានបទនៃសវនាការនៅពេលអនាគត")។

[188] ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកសំណុំរឿងបន្ថែម និងវិសាលភាព ទំព័រ ២១។

[189] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣០។

របស់ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២/០២ ក្នុងការរកឃើញអត្ថិភាពនៃគោលនយោបាយបញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍[190]។

### *មូលដ្ឋានទី ៨ ៖ សេចក្ដីសម្រេចលើការកោះហៅឱ្យចូលមកបង្ហាញខ្លួនបណ្ដើរៗ*[191]

45. **មូលដ្ឋានទី ៨ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនធ្វើការសម្រេចទៅលើការចូលមកបង្ហាញខ្លួនទាំងអស់នៅពេលចាប់ផ្ដើមសវនាការរយៈពេលជាង ២ ឆ្នាំ និងដោយខកខានមិនបានផ្ដល់សំអាងហេតុគ្រប់គ្រាន់និងទាន់ពេលវេលា សម្រាប់សេចក្ដីសម្រេចនានាលើការចូលបង្ហាញខ្លួនក្នុងកំឡុងពេលសវនាការ។**

46. ម្ចាស់បណ្ដឹងសាទុក្ខផ្ដល់ទឡ្ហីករណ៍ទាំងខុសឆ្គងថា (i) អង្គជំនុំជម្រះសាលាដំបូងរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនលើបញ្ហាពាក់ព័ន្ធនឹងការធ្វើសវនាការ ដោយខកខានមិនបានសម្រេចលើការចូលបង្ហាញ ខ្លួនរបស់សាក្សីនៅពេលចាប់ផ្ដើមសវនាការ[192] និង (ii) ការចោទថារំលោភលើឆន្ទានុសិទ្ធិនេះបណ្ដាលឱ្យមានព្យសនកម្មដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស ពេលវេលា និងធនធានសម្ភារៈសមស្របសម្រាប់ត្រៀមការពារក្ដី និង សច្ចភាពផ្លូវច្បាប់ និងនីតិវិធី[193]។ មិនតែប៉ុណ្ណោះ ម្ចាស់បណ្ដឹងសាទុក្ខលើកទឡ្ហីករណ៍ថា (iii) អង្គជំនុំជម្រះសាលាដំបូង រំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានមិនបានផ្ដល់សំអាងហេតុគ្រប់គ្រាន់ និងទាន់ពេលវេលា សម្រាប់សេចក្ដីសម្រេចដែលបានធ្វើឡើងលើការចូលបង្ហាញខ្លួនក្នុងកំឡុងពេលសវនាការ[194] និង (iv) និង ប្រការនេះបណ្ដាលឱ្យមានព្យសនកម្មដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងការទទួលបានសេចក្ដី សម្រេចដែលមានសំអាងហេតុនិងទទួលបានការជូនដំណឹងអំពីលក្ខណៈនៃមូលដ្ឋានប្រឆាំងនឹងគាត់[195]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថាមានកំហុស

---

[190] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦០-១៧៥។

[191] មូលដ្ឋានទី ៨៖ ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ *សេចក្ដីសម្រេចលើការកោះហៅឱ្យចូលមកបង្ហាញខ្លួនបណ្ដើរៗ* កថាខណ្ឌ ១៧៥ -១៨១។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៦ (ភាសាអង់គ្លេស) ទំព័រ ៦ (ភាសាបារាំង) ទំព័រ ៧-៨ (ភាសាខ្មែរ)។

[192] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៦,១៧៧។

[193] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៧,១៨១។

[194] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៦,១៧៩-១៨០។

[195] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៩-១៨១។

ឆ្គងជាក់ស្តែង ក្នុងការអនុវត្តឆន្ទានុសិទ្ធិ ឬថា កំហុសឆ្គងនោះបណ្តាលឱ្យមានព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ[196]។

47. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ដោយកំហុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានផ្តល់បញ្ជីឈ្មោះសាក្សីពេញលេញដែលត្រូវចូលបង្ហាញខ្លួននៅពេលចាប់ផ្តើមសវនាការ[197]។ ប៉ុន្តែ ទឡ្ហីករណ៍នេះខកខានមិនបានពិចារណាលើការគោរពដែលត្រូវបានផ្តល់ចំពោះឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[198]ជាពិសេសនៅក្នុងរឿងក្តីដែលមានទំហំ និងភាពស្មុគស្មាញបែបនេះ[199] និងការខកខានរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការបង្ហាញកំហុសឆ្គងណាមួយនៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ ជាការពិតណាស់ ដូចដែលបានពន្យល់ដោយអង្គជំនុំជម្រះសាលាដំបូងស្រាប់ហើយ វិធីសាស្រ្តតាមដំណាក់កាលត្រូវបានប្រកាន់យកដោយមូលហេតុនៃ *"ភាពមិនអាចទាយទុកជាមុនបានថាសាក្សីដែលត្រូវបានទាក់ទងនៅពេលចាប់ផ្តើមការជំនុំជម្រះនឹងអាចមានពេលមកផ្តល់សក្ខីកម្មតាមកាលបរិច្ឆេទមួយដ៏យូរនាពេលខាងមុខនិងធនធានមានកម្រិតរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដើម្បីទាក់ទងទៅបុគ្គលដែលត្រូវបានស្នើឡើង"*[200]។ ហេតុដូច្នេះ ការប្រគល់នូវបញ្ជីឈ្មោះលម្អិតរបស់សាក្សីមុនពេលសវនាការ ដូចដែលម្ចាស់បណ្តឹងសាទុក្ខប្រាថ្នាចង់បាននោះ គឺ *"ពុំអាចធ្វើទៅបានឡើយ ហើយក៏ពុំមានភាពចាំបាច់ដែលតម្រូវឱ្យធ្វើដូច្នេះដែរ"*[201]។

---

[196] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧-៩៨, ១០០។

[197] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦-១៧៧។

[198] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣៣។

[199] *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៤, ១០៣, ២៨៦។ ឯកសារ **E51/14** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីវិធានផ្ទៃក្នុង កថាខណ្ឌ ៩។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព កថាខណ្ឌ ៥៩។ ឯកសារ **E459** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ កថាខណ្ឌ ១៣។

[200] ឯកសារ **E363/3** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើ ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ កថាខណ្ឌ ២៦។ *សូមមើលផងដែរ* ឯកសារ **E315** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ អំពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះ កថាខណ្ឌ ៧ ("លើសពីនេះទៀត លំដាប់លំដោយ [...] នៃសាក្សី អាចមានការកែប្រែ ដោយផ្អែកទៅលើកត្តាមួយចំនួន ដូចជាតម្រូវការក្នុងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីសវនាការ និង/ឬវត្តមានរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ព្រមទាំងសុខភាពរបស់ជនជាប់ចោទផងដែរ។")

[201] ឯកសារ **E363/3** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ. លើសំណើ ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ កថាខណ្ឌ ២៦។

48. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខផ្តល់ទឡ្ហីករណ៍ដោយមិនត្រឹមត្រូវដែលថា ការរំលោភឆន្ទានុសិទ្ធិ ដែលបានចោទប្រកាន់នោះបណ្តាលឱ្យមានព្យសនកម្មដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[202]។ ទោះបីយ៉ាងណាក៏ដោយ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញនូវការរំលោភឆន្ទានុសិទ្ធិ រាល់ការពន្យារពេលណាមួយបណ្តាលមកពីវិធីសាស្ត្រតាមដំណាក់កាល គឺមិនអាចត្រូវបានចាត់ទុកថា "មិនចាំបាច់" ឬអសច្ចភាពផ្លូវច្បាប់ឬនីតិវិធីអាចមានព្យសនកម្មឡើយ[203]។ ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ទៀតថា គាត់ "មានការលំបាកដែលបណ្តាលមកពីកង្វះភាពប្រមើលមើលឃើញ ក្នុងរយៈពេលខ្លី និងវែងសម្រាប់ការត្រៀមខ្លួន" ប៉ុន្តែមិនទាំងបានព្យាយាមបង្ហាញឧទាហរណ៍ជាក់ស្តែងណាមួយឡើយ[204]។ ដោយមិនគិតដល់ចំណុចដែលមានសក្តានុពលសម្រាប់ភាពមិនយុត្តិធម៌ អង្គជំនុំ ជម្រះសាលាដំបូងបានប្រកាន់យកដោយភាពបត់បែននូវការការពារសមស្រប។ ឧទាហរណ៍ នៅត្រង់ចំណុចមួយដែលបង្កើតឱ្យមានអសច្ចភាព និងពេលវេលាត្រៀមខ្លួនមិនសមស្របអង្គជំនុំ ជម្រះសាលាដំបូងសម្រេចបញ្ចូនបញ្ជីសាក្សីរួមសម្រាប់ការប្រព្រឹត្តមកលើជនជាតិវៀតណាម និង ចាម ដោយប្រាសចាកពីការអនុវត្តទូទៅរបស់ខ្លួនដែលបោះពុម្ពបញ្ជីឈ្មោះមុនពេលចាប់ផ្តើមជំនុំជម្រះក្នុងវគ្គនីមួយៗ[205]។

49. ជាការផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងកម្រិតលទ្ធភាពរយៈពេលខ្លីនិងវែងរបស់គាត់ក្នុងការត្រៀមសម្រាប់សវនាការ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់នូវការបង្គាប់ច្បាស់មួយលើអង្គសេចក្តីនៃវគ្គសវនាការរយៈពេល ៤ ខែមុនពេលចាប់ផ្តើមសវនាការលើភ័ស្តុតាង[206]។ ពាក់ព័ន្ធនឹងលទ្ធភាពរបស់គាត់ក្នុងរយៈពេលខ្លីក្នុងការត្រៀមសម្រាប់សាក្សីជាក់លាក់មកផ្តល់សក្ខីកម្ម ដូចដែលម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ គឺ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់ជាមុនអំពីវគ្គជំនុំជម្រះនីមួយៗ[207]។ ការណ៍នេះបានផ្តល់ម្ចាស់បណ្តឹងឧទ្ធរណ៍នូវពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមខ្លួនតាំងសំណួរដល់សាក្សី ជាពិសេសដោយហេតុថាសាក្សីត្រូវបានជ្រើសរើសពីបញ្ជីឈ្មោះដែលដាក់ដោយភាគីជូនអង្គជំនុំជម្រះសាលាដំបូង តាំងពីដំបូងនៅក្នុងដំណាក់កាលមុនជំនុំជម្រះ។ មិនតែប៉ុណ្ណោះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ពេលវេលានៃការផ្តល់បញ្ជីឈ្មោះជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង

[202] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦-១៧៨។

[203] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧។

[204] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧។

[205] ឯកសារ **E364/1.1** អ៊ីម៉ែលរបស់អង្គជំនុំជម្រះសាលាដំបូង ជូនដំណឹងអំពីបញ្ជីសាក្សីដែលដាក់បញ្ចូលគ្នា។

[206] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២-១៣។

[207] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ១៧៦។

ជាមុននៃវគ្គជំនុំជម្រះ មិនបានផ្តល់ពេលគ្រប់គ្រាន់ដល់គាត់ក្នុងការត្រៀមខ្លួនតាំងសំណួរដល់សាក្សីជាក់លាក់ទាំងនេះឡើយ[208]។

50. ទីបី ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ដោយពុំមានលក្ខណៈត្រឹមត្រូវថា អង្គជំនុំជម្រះ សាលាដំបូងបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានមិនបានផ្តល់សំអាងហេតុសមស្រប និងទាន់ពេលវេលាសម្រាប់ការសម្រេចរបស់ខ្លួនលើការបង្ហាញខ្លួននៅពេញរយៈពេលជំនុំជម្រះ[209]។ ប៉ុន្តែកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់សំអាងហេតុគឺមិនដាច់ខាតទេ ហើយក៏ មិនតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់អះអាងគ្រប់ជំហាន នៅក្នុងសំអាងហេតុរបស់ខ្លួនដែរ[210]។ នៅក្នុងករណីណាក៏ដោយ ទឡ្ហីករណ៍នេះមិនបានផល ដោយសារតែសំអាងហេតុដ៏ច្រើននិងទាន់ពេលវេលារបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការបង្ហាញខ្លួនដែលទទួលស្គាល់ អនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង[211]។ ផ្ទុយទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា សំអាងហេតុមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់[212] ក្នុងការពន្យល់ផ្សេងៗជាពិសេសពាក់ព័ន្ធទៅនឹង "ការបញ្ជាក់ការពិត" និង "លក្ខណៈជាន់គ្នា" នៃភស្តុតាង[213] អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានគតិយុត្តត្រឹមត្រូវតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង[214] ហេតុដូចនេះពុំមានព្យសនកម្មឡើយ។

51. ជាងនេះទៀត ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីកំហុសឆ្គងអំពីឆន្ទានុសិទ្ធិដោយមូលហេតុនៃការពន្យារផ្តល់សំអាងហេតុ[215] គឺមិនបានផលឡើយ ដោយហេតុថាគាត់ធ្វើមិនដឹងមិនឮដល់លក្ខណៈមិនជាក់ស្តែងនៃការរៀបចំសំអាងហេតុ ក្នុងការជ្រើសរើសសាក្សីដោយចាត់ទុកថាបញ្ជីឈ្មោះសាក្សីមិនប្រាកដប្រជាស្ថិតនៅក្រោមការផ្លាស់ប្តូរឆាប់រហ័ស។ ក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខមិនបង្កើតព្យសនកម្ម នៅក្នុងការពន្យារផ្តល់សំអាងហេតុរបស់អង្គជំនុំជម្រះសាលា

---

208 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥-១៨១។

209 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៩-១៨១។

210 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤,៣៥៩។

211 ឯកសារ **E459** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្ម កថាខណ្ឌ ២២-១៩៥។

212 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០។

213 សូមមើល ឯកសារ **E459** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្ម កថាខណ្ឌ ៩-១០,១៨, ៣០-៤០, ៥២-៦០, ៧៦-៨៩, ១០៥-១៤៥, ១៥២-១៦១, ១៧៨-១៨៦, ១៩០-១៩៥។

214 សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៩។

215 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៩។

ដំបូងសម្រាប់ការសម្រេច ដោយហេតុថាសំអាងហេតុទាំងនោះមិនមានឥទ្ធិពលដល់លទ្ធភាពរបស់គាត់ក្នុងការរៀបចំសម្រាប់សវនាការឡើយ។ ដូចនេះ ភាពពុំសមហេតុផលឬមិនយុត្តិធម៌ដែលជាលក្ខខណ្ឌចាំបាច់គឺ មិនត្រូវបានបង្ហាញឡើយ[216]។

52. ទីបួន ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ថាការរំលោភឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងបានបណ្តាលឱ្យមានព្យសនកម្មដល់សិទ្ធិរបស់គាត់ ក្នុងការទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ និង ទទួលដំណឹងអំពីលក្ខណៈនៃបទចោទប្រឆាំងនឹងគាត់។ ទឡ្ហីករណ៍នេះមិនបានផលឡើយ ពីព្រោះពុំមានភាពមិនគ្រប់គ្រាន់ឬការពន្យារពេលមិនសមហេតុផលឡើយនៅក្នុងការផ្តល់សំអាងហេតុ[217]។ ដោយមិនគិតការណ៍ដែលថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញព្យសនកម្មដោយមូលហេតុនៃការពន្យារពេលផ្តល់សំអាងហេតុ ដែលផ្ទុយទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ[218] ការយោងលើសំណុំរឿង០០២/០២របស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹង "ការបោសសម្អាតផ្ទៃក្នុង" គឺមានលក្ខណៈច្បាស់ពេញរយៈពេលនៃការជំនុំជម្រះទាំងក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឱ្យស៊ើបសួរ និងក្នុងដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះ[219]។

### *មូលដ្ឋានទី ៧៖ ការលាតត្រដាងដោយផ្អែកលើភ័ស្តុតាង*[220]

53. **មូលដ្ឋានទី ៧គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយផ្អែកជ្រុលហួសហេតុលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ឬបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានមិនបានកោះហៅសាក្សី Stephen Heder, Francois Ponchaud, និង Philip Short។**

54. ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ខុសថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយ (i) ផ្អែកលើការវិភាគភ័ស្តុតាងដែលអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ ក្នុងការសន្និដ្ឋានក្នុងសំណុំ រឿង០០២/០២[221] (ii) ផ្តល់ទម្ងន់មិនសមរម្យទៅលើសក្ខីកម្មជាប្រតិចារឹកពីសំណុំរឿង

---

216 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧។

217 *សូមមើល* ចម្លើយតបខាងលើ។

218 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៩។

219 *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៥៨ ។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព កថាខណ្ឌ ៧៤-៧៥។

220 មូលដ្ឋានទី ៧៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការលាតត្រដាងដោយផ្អែកលើភ័ស្តុតាង* កថាខណ្ឌ ១៥៨-១៧៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃបណ្តឹងសាទុក្ខ ទំព័រ ៦ (ភាសាអង់គ្លេស) ទំព័រ ៦ (ភាសាបារាំង) ទំព័រ ៦-៧ (ភាសាខ្មែរ) ។

221 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩។

០០២/០១[222] (iii) ផ្អែកលើសក្ខីកម្មពីសំណុំរឿង០០២/០១ ដោយពុំពិចារណាថាសាក្សីដែលពាក់ព័ន្ធមិនទាន់ត្រូវ បានសួរតទល់[223] (iv) មានកំហុសក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនតាមវិធាន ៨៧(៣) និង ៨៧(៤) ដោយខកខានមិនបានកោះហៅសាក្សី Stephen Heder, Francois Ponchaud, និង Philip Short[224]។ ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខអះអាងថាកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបណ្តាលឱ្យមានព្យសនកម្មលើគាត់ដោយហេតុថាកំហុសទីមួយប៉ះពាល់ដល់សិទ្ធិរបស់គាត់ ក្នុងការទទួលបានសាលក្រមដែលមានសំអាងហេតុ[225] និងកំហុសទី២ ទី៣ និងទី៤ ប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានសវនាការដេញដោលចំពោះមុខសមភាពនៃមធ្យោបាយការពារក្តី និង ការជំនុំជម្រះក្តី[226]។

55. ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលទេ ដោយហេតុថាគាត់លើកឡើងទូទៅផ្អែកលើការអះអាងដែលមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់និងអង្គហេតុដោយមិនវិភាគឡើងវិញលើភស្តុតាងពីក្នុងសំណុំរឿង០០២/០១[227]។ ផ្ទុយទៅនឹងឧទាហរណ៍តែមួយគត់របស់ម្ចាស់បណ្តឹងសាទុក្ខ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថាអង្គជំនុំជម្រះសាលាដំបូងអះអាងដោយខុសថាគាត់បានថ្លែងសុន្ទរកថាចន្លោះថ្ងៃទី១១ ដល់ ១៣ ខែមេសា ឆ្នាំ១៩៧៦ នៅឯសភាតំណាងប្រជាជន[228] មិនអនុញ្ញាតឱ្យមានអន្តរាគមន៍សាទុក្ខទេដោយហេតុថាវាពុំមានឥទ្ធិពលលើសាលក្រមឡើយ។ ឧទាហរណ៍ជាក់ស្តែងមួយនៃកំហុសបែបនេះនឹងមិនគ្រប់គ្រាន់ក្នុងការបង្ហាញលំនាំទូទៅមួយនៃការខកខាននោះទេ ជាពិសេសដោយហេតុថាវាអាចត្រូវបានពន្យល់ដោយត្រឹមតែពិនិត្យមើលនៅក្នុងសវនាការស្មុគស្មាញមួយ[229]។

56. ទីពីរ ខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការវាយតម្លៃរបស់ខ្លួនលើទម្ងន់នៃប្រតិចារឹកនៃសក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១[230]។ ម្ចាស់បណ្តឹងសាទុក្ខ

---

[222] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១-១៦២។

[223] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣-១៧១។

[224] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦-១៧១។

[225] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩, ១៧៤។

[226] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦០, ១៧៤។

[227] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩។

[228] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧។ ផ្ទុយពីឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩៩-១៧០០។

[229] *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០២៣។

[230] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១-១៦២។

មិនត្រឹមតែអះអាងដោយខ្វះការគាំទ្រតាមផ្លូវច្បាប់តែប៉ុណ្ណោះទេ[231] ប៉ុន្តែគាត់ថែមទាំងផ្អែកលើការសន្មត់ក្លែងក្លាយដែលថាគាត់មានសិទ្ធិដាច់ខាតក្នុងការទទួលបានការតទល់ទៀតផង[232]។ ជាងនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានថ្លែងថា រហូតមកដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ សវនាការគឺជា "សវនាការចម្បងតែមួយ" សម្រាប់សំណុំរឿង០០២ទាំងមូល មានន័យថា ភ័ស្តុតាងដែលបានធ្វើសវនាការក្នុងសំណុំរឿង ០០២/០១ មិនតម្រូវឱ្យធ្វើឡើងវិញជាផ្លូវការក្នុងសំណុំរឿង០០២/០២ឡើយ[233]។ មិនតែប៉ុណ្ណោះ ជាផ្លូវការ ការបំបែកសំណុំរឿងមិនប៉ះពាល់ដល់តម្លៃដែលអាចជឿបាននៃសក្ខីកម្មដែលធ្វើសវនាការនៅក្នុងសំណុំរឿង ០០២/០១ ដោយហេតុថា ភ័ស្តុតាងនោះត្រូវបានដឹកនាំដោយភាគីដដែល ត្រូវបានដាក់ឱ្យតទល់គ្នាដោយភាគីដដែល និងដឹកនាំសវនាការដោយចៅក្រមដដែលនៅក្នុងរឿងក្តីទាំងពីរ[234]។ ក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខមិនប៉ុនប៉ងបង្ហាញថាតើកំហុសឆ្គងនេះបដិសេធសាលក្រម ដោយរបៀបណានោះឡើយ[235]។

57. ទីបី ម្ចាស់បណ្តឹងឧកខានមិនបានចង្អុលបង្ហាញកំហុសអង្គច្បាប់ទៅលើការឧកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាលើកង្វះខាតការតទល់នៅពេលវាយតម្លៃភ័ស្តុតាង[236]។ ម្ចាស់បណ្តឹងសាទុក្ខបកស្រាយខុសលើ (i) វិសាលភាពដែលអាចអនុញ្ញាតបានក្នុងការពិនិត្យក្នុងសំណុំរឿង០០២/០១ និង (ii) សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២[237]។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល រហូតមកដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ នៅពេលសំណុំរឿងត្រូវបំបែកជាស្ថាពរ ភ័ស្តុតាងទាំងអស់មានលក្ខណៈធម្មតាចំពោះសំណុំរឿង០០២

[231] សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១-១៦២។ ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោកខៀវ សំផន សំណុំរឿង ០០២/០២ កថាខណ្ឌ៥៥២-៥៥៦។

[232] *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣៣, ២៨៥-២៨៧ ("សិទ្ធិសួរសំណួរទៅកាន់សាក្សីរបស់ភាគីម្ខាងទៀត ត្រូវបានដាក់កំហិតដោយការពន្លឿនកិច្ចដំណើរការនីតិវិធី"។)

[233] ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព កថាខណ្ឌ ៧៥។

[234] ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព កថាខណ្ឌ ៧៥។

[235] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់)។

[236] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣-១៧១។

[237] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣-១៧១។

ទាំងមូល[238] មិនត្រឹមតែ "កម្មវត្ថុនៃសំណុំរឿង០០២/០១" នោះទេ ដូចដែលម្ចាស់បណ្ដឹងសាទុក្ខបានសន្មតទាំងខុសឆ្គង[239]។ ផ្ទុយទៅវិញ ការសម្រេចរបស់ម្ចាស់បណ្ដឹងសាទុក្ខមិនតទល់ពាក់ព័ន្ធនឹងសំណុំរឿង០០២ ទាំងមូលគឺជាការសម្រេចជាយុទ្ធសាស្ត្រ ទោះបីជាត្រូវបានអនុញ្ញាតដោយច្បាប់ក៏ដោយ។ សាក្សីទាំងអស់ដែលម្ចាស់បណ្ដឹងសាទុក្ខថ្លែងថាគាត់សម្រេចមិនតទល់ជាមួយគឺបានផ្ដល់សក្ខីកម្មមុនថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០១៣ ដូច្នេះ ម្ចាស់បណ្ដឹងសាទុក្ខពុំមានហេតុផលក្នុងការកម្រិតការតាំងសំណួររបស់គាត់ ចំពោះសំណុំរឿង០០២/០១ឡើយ[240]។ ការបកស្រាយខុសរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីឱកាសរបស់គាត់ក្នុងការតទល់ គឺត្រូវបានបង្ហាញដោយការណ៍ដែលថាសាក្សីដែលទទួលរងការជំទាស់ផ្ដល់សក្ខីកម្ម ត្រឹមតែពាក់ព័ន្ធនឹងគោលនយោបាយព្រះពុទ្ធសាសនាសម្រាប់រយៈពេលមានកម្រិត[241]។ ផ្ទុយទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខ[242] ការតទល់លើសម្ភារៈមានកម្រិតបែបនេះនឹងមិនតម្រូវការបែងចែកពេលវេលាទូទៅដ៏ច្រើន ដែលមានចំពោះម្ចាស់បណ្ដឹងសាទុក្ខសម្រាប់ការសួរដេញដោលសាក្សីឡើយ។ តាមការពិត ផ្ទុយទៅវិញ ម្ចាស់បណ្ដឹងសាទុក្ខសម្រេចម្ដងហើយម្ដងទៀតមិនធ្វើការ សួរដេញដោលសាក្សីមួយចំនួនទាល់តែសោះ[243] ដែលធ្វើឱ្យអាសាឥតការថាតើគាត់អាចបានបែងចែក ពេលវេលាដល់បញ្ហានានានៃ

---

[238] ឯកសារ E301/9/1/1/3 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពកថាខណ្ឌ ៧៤។

[239] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៤-១៦៥។

[240] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៤ ជើងទំព័រ ១៨៦ ។ សាក្សីដែលត្រូវបានយោង និងកាលបរិច្ឆេទនៃការផ្ដល់សក្ខីកម្មរបស់ពួកគាត់៖ អែម អឿន (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២), ពាន ឃាន (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២), យុន គីម (ថ្ងៃទី១៩, ២០ ខែមិថុនា ឆ្នាំ២០១២), ខៀវ អេន (ថ្ងៃទី១ ខែតុលា ឆ្នាំ២០១២), ហ៊ុន ឈុនលី (ថ្ងៃទី៦,៧ ខែធ្នូ ឆ្នាំ២០១២), ពិន យ៉ាថៃ (ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣), នូ ម៉ៅ (ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣), ស៊ឹម ហោ (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២), អុង ថុងហឿង, ក្លាន វិត (ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១), គឹម វ៉ាន់ឌី (ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២), សួផាន់ សូវណ្ណី (ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣)។

[241] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៤ ជើងទំព័រ ១៨៦។ សាក្សីដែលបានយោង និងរយៈពេលនៃការផ្ដល់សក្ខីកម្មរបស់ពួកគាត់ ពាក់ព័ន្ធនឹងគោលនយោបាយពាក់ព័ន្ធនឹងពុទ្ធសាសនា៖ អែម អឿន (៣នាទី ១៤វិនាទី), ពាន ឃាន (៤នាទី ៥៤វិនាទី), យុន គីម (១៩នាទី ១១វិនាទី), ខៀវ អេន (៧នាទី ៤៤វិនាទី), ហ៊ុន ឈុនលី (៤នាទី ៥២វិនាទី), ពិន យ៉ាថៃ (៥នាទី), នូ ម៉ៅ (៤នាទី ៥៩វិនាទី), ស៊ឹម ហោ (៤នាទី ៥០វិនាទី), អុង ថុងហឿង (២នាទី ២៣វិនាទី) , ក្លាន វិត (៤នាទី ១វិនាទី)), គឹម វ៉ាន់ឌី (២នាទី ៤២វិនាទី), សួផាន់ សូវណ្ណី (២នាទី ១៧វិនាទី)។

[242] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៤-១៦៥។

[243] *សូមមើលឧទាហរណ៍* ឯកសារ E1/128.1 ប្រតិចារឹក ខៀវ អេន ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ម៉ោង១៤.០០.២៤-១៤.០០.៥៤ ទំព័រ៦៨ បន្ទាត់១០-១៣។ សូមមើលផងដែរឯកសារ E1/17.1 ប្រតិចារឹក ក្លាន វិត ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១។

សំណុំរឿង០០២/០២ដែរឬយ៉ាងណា[244]។ ក៏ប៉ុន្តែ នៅពេល យុន គីម ផ្តល់ សក្ខីកម្មលើគោលនយោបាយព្រះពុទ្ធសាសនា[245] (១១ នាទី និង ១៥ វិនាទី) ម្ចាស់បណ្តឹងសាទុក្ខក៏សម្រេច តទល់ជាមួយគាត់លើបញ្ហានោះ (៥ នាទី និង ២០ វិនាទី)[246]។ ដូច្នេះរាល់ព្យសនកម្មណាមួយបង្កឡើងដោយកង្វះការសួរតទល់គឺត្រូវបានសម្រួលដោយការណ៍ដែលថា ម្ចាស់បណ្តឹងសាទុក្ខមាន*ឱកាស*ក្នុងការសួរតទល់ប្រសិនបើគាត់មានបំណងប៉ុន្តែសម្រេចមិនធ្វើដូច្នោះ។

58. ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការដកកាតព្វកិច្ចរបស់ខ្លួនក្នុងការដោះស្រាយចំពោះឱកាសដែលបានបាត់បង់ ក្នុងការសួរតទល់[247] ជាលទ្ធផលនៃការបង្វែរការផ្តោតរបស់ភស្តុតាងក្រោយថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣[248]។ ឧទាហរណ៍ ជាការផ្ទុយទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ[249] អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាតើភាគីមានឱកាសក្នុងការតាំងសំណួរចំពោះ នោម សែ ក្នុងសំណុំរឿង ០០២/០១ដែរឬទេ មុនពេលផ្អែកលើសក្ខីកម្មរបស់គាត់[250]។ ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខមិនអើពើថាអង្គជំនុំជម្រះសាលាដំបូងមិនត្រូវបានតម្រូវឱ្យថ្លែងគ្រប់ធាតុផ្សំនៃសំអាងហេតុឡើយ នៅពេលវាយតម្លៃភស្តុតាង[251] ហើយភស្តុតាងរបស់សាក្សីនីមួយៗដែលរងការជំទាស់ត្រូវបានដកស្រង់ក្នុង

---

ឯកសារ **E1/149.1** ប្រតិចារឹក គីម វ៉ាន់ឌី ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២។ ឯកសារ **E1/199.1** ប្រតិចារឹក សូផាន់ សូវណ្ណី ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣។

[244] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤។

[245] ឯកសារ **E1/88.1** ប្រតិចារឹក យុន គីម ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 11.38.41-11.49.56 ទំព័រ ៥០ បន្ទាត់ ៤ ទំព័រ ៥៣ បន្ទាត់ ៧។

[246] ឯកសារ **E1/89.1** ប្រតិចារឹក យុន គីម ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ម៉ោង ១៤.០១.៣១ - ១៤.០៦.៥១ ទំព័រ ៧៦ បន្ទាត់ ១៩ -ទំព័រ ៧៨ បន្ទាត់ ៣។

[247] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៦៣-១៧១។

[248] ឯកសារ**E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព កថាខណ្ឌ ៧៥។

[249] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣។

[250] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៦០ ("នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យសួរសំណួរមួយចំនួនដល់សាក្សីដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬជាយថាហេតុទៅនឹងវិសាលភាពសំណុំរឿង០០២/០២។ ត្រង់ចំណុចខ្លឹមសារនៃចម្លើយតបដែលត្រូវបានភាគីសួរដេញដោលនៅក្នុងតុលាការនោះ អង្គជំនុំជម្រះបានសំអាងលើចម្លើយរបស់សាក្សី ដើម្បីទាញសេចក្តីសន្និដ្ឋាននៅក្នុងផ្នែកនេះ។") *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១២៨។

[251] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤, ៣៤៩។

ចំណោមភស្តុតាងជាច្រើនដែលស៊ីសង្វាក់គ្នា[252]។ ជាពិសេស ក្នុងចំណោមសក្ខីកម្ម ២៥ ដែលគាំទ្រការសន្និដ្ឋានថាព្រះសង្ឃត្រូវបានផ្សឹកក្រោយឆ្នាំ១៩៧៥ មានតែសក្ខីកម្មចំនួន ៦ ប៉ុណ្ណោះបានមកពីសំណុំរឿង០០២/០១ ពោលគឺសក្ខីកម្ម ១៩ ទៀតត្រូវបានស្ដាប់ក្នុងកំឡុងពេលសំណុំរឿង ០០២/០២[253]។ ជាងនេះទៀត ពាក់ព័ន្ធនឹងការបំផ្លាញវត្តអារ៉ាម មានសក្ខីកម្មចំនួន៣ នៃសក្ខីកម្មចំនួន៧ ប៉ុណ្ណោះត្រូវបានដកស្រង់ចេញពីសាក្សីក្នុងសំណុំរឿង០០២/១[254] ហើយចំពោះការកែប្រែគោលបំណងនៃវត្តអារ៉ាម មានសក្ខីកម្មចំនួន៦នៃសក្ខីកម្មចំនួន២០ ប៉ុណ្ណោះដែលបានដកស្រង់ចេញពីសាក្សីក្នុងសំណុំរឿង០០២/១[255]។ ស្រដៀងគ្នានេះដែរ ដើម្បីគាំទ្រការសន្និដ្ឋានដែលថាការគោរពប្រណិប័តន៍ព្រះពុទ្ធសាសនាត្រូវបានហាមឃាត់ ក្នុងនោះរួមមានទំនៀមទំលាប់ប្រពៃណី អង្គជំនុំជម្រះសាលាដំបូងបានយកមកសំអាងនូវសក្ខីកម្មក្នុងសំណុំរឿង ០០២/០១ សរុបតែ១៦ ប៉ុណ្ណោះដែលត្រូវបានផ្អែកលើ[256]។

59. ទីបួន ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញកំហុសឆ្គងជាក់ស្តែងនៃការប្រើឆន្ទានុសិទ្ធិ របស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនមិនកោះហៅសាក្សី **Stephen Heder, Francois Ponchaud,** និង **Philip Short**[257]។ ខណៈដែលការប្រើឆន្ទានុសិទ្ធិរបស់ អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការកោះហៅសាក្សី ត្រូវបានគ្រប់គ្រងជាអាទិ៍ដោយវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាថា តើភាគីមាន ឱកាសគ្រប់គ្រាន់ក្នុងការតាំងសំណួរចំពោះបុគ្គលដែលត្រូវបានស្នើឡើង ក្នុងសំណុំរឿង០០២/០១ ដែរឬយ៉ាងណា[258]។

60. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាអលទ្ធភាពរបស់គាត់ក្នុងពិនិត្យ **Francois Ponchaud** និង **Philip Short** នៅក្នុងសេចក្តីសម្រេច របស់ខ្លួនមិនកោះហៅពួកគេមកឮបំភ្លឺ[259]។ ក្នុងការបដិសេធសាក្សីថាច្រំដែលក្រោមវិធាន ៨៧(៣)(ក)

---

[252] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥-៤០១៧ ជើងទំព័រ ១៣៣០០-១៣៣១៤, ៣៦៧៩។

[253] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ ជើងទំព័រ ១៣៣០០។

[254] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ ជើងទំព័រ ១៣៣០១។

[255] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ ជើងទំព័រ ១៣៣០២-១៣៣០៦។

[256] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ ជើងទំព័រ ១៣៣០៧-១៣៣១០។

[257] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៦៦-១៧១។

[258] ឯកសារ **E302/5** សេចក្តីណែនាំរបស់ អ.ជ.ស.ដ ស្តីពីនីតិវិធីដើម្បីកោះហៅសាក្សី កថាខណ្ឌ ៨។

[259] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧-១៦៩។

អង្គជំនុំជម្រះសាលាដំបូង មិនត្រឹមតែធ្វើបញ្ជីឈ្មោះតំបន់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ដែលសាក្សីទទួលរងការជំទាស់បានផ្តល់សក្ខីកម្មរួចហើយក្នុងសំណុំរឿង០០២/០១ ប៉ុន្តែ ថែមទាំងកត់សម្គាល់ជាពិសេសនូវរយៈពេលនៃការតាំងសំណួរទៀតផង[260] ដែលលើកឡើងថាតើម្ចាស់បណ្តឹងសាទុក្ខមានឱកាសគ្រប់គ្រាន់ក្នុងការតទល់នឹងសាក្សីទាំងពីរនាក់។ ជាងនេះទៀត ការជ្រើសរើស Stephen Morris ជាអ្នកជំនាញលើប្រធានបទជម្លោះប្រដាប់អាវុធគឺស្ថិតក្នុងរង្វង់ឆន្ទានុសិទ្ធិ របស់អង្គជំនុំជម្រះសាលាដំបូង[261]។ ដោយពិចារណាថា **Stephen Heder** ត្រូវបានអង្គជំនុំជម្រះសាលាដំបូងស្តាប់សក្ខីកម្មរួចហើយ[262] មុនសេចក្តីសម្រេចដែលរងការជំទាស់[263] ការសម្រេចមិនកោះហៅសាក្សីគឺមានហេតុផលច្បាស់ណាស់។

61. ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខបកស្រាយខុសអំពីសម្ភារៈសារធាតុដែលបានលើកមកសំអាងចំពោះការអះអាងរបស់គាត់ដែលថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ដែលមិនកោះហៅ **Philip Short**[264]។ ក្នុងការអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានដកការអនុញ្ញាតក្នុងការពិនិត្យ **Philip Short** ឱ្យបានទូលំទូលាយ ម្ចាស់បណ្តឹងសាទុក្ខថ្លែងដោយមិនត្រឹមត្រូវនូវអសង្គតិភាពមួយ នៅក្នុងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង[265]។ ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងបានតម្រូវភាគីឱ្យផ្តោតលើសម្ភារៈពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ប៉ុន្តែបានអនុញ្ញាតឱ្យអនុវត្តហួសពីវិសាលភាពប្រសិនបើបញ្ហាមួយអ្នកជំនាញមានគុណវុឌ្ឍិដោយឡែកនៅក្នុងការឆ្លើយតបលើចំណុចនោះប៉ុណ្ណោះ[266]។ លក្ខខណ្ឌតម្រូវក្នុងការសាកសួរលើបញ្ហាជំនាញត្រូវបានថ្លឹងថ្លែង

---

[260] ឯកសារ **E408/6/2 5** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីការស្តាប់សក្ខីកម្មរបស់លោក Stephen Heder និងលោក François Ponchaud កថាខណ្ឌ៥-៦។

[261] *សូមមើលឧទាហរណ៍* វិធាន៣១ (១), ៨០ ស្ទួន, ៨៧(៣) នៃវិធានផ្ទៃក្នុង។

[262] *សូមមើល* ឯកសារ **E485.1** Stephen Morris ប្រតិចារឹក ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦។ ឯកសារ **E486.1** Stephen Morris ប្រតិចារឹក ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦។ ឯកសារ **E487.1** Stephen Morris ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦។

[263] ឯកសារ **E408/6/2** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីការស្តាប់សក្ខីកម្មរបស់លោក Stephen Heder និងលោក François Ponchaud។

[264] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧០-១៧១។

[265] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧០។

[266] *ប្រៀបធៀប* ឯកសារ **E215** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការចាត់តាំងអ្នកជំនាញសំណុំរឿង០០២/០១ កថាខណ្ឌ ៤ ("ប៉ុន្តែ ក្នុងគោលបំណងដើម្បីធានាឱ្យមានសវនាការឆាប់រហ័ស និងដោយសារការអនុញ្ញាតឱ្យសួរសំណួរហួសពីវិសាលភាពនៃសំណុំរឿង០០២/១ ដែលជាញឹកញយនាំឱ្យមានការសួរដេញដោលវែងឆ្ងាយនោះ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីថា ការសួរដេញដោលរបស់ខ្លួនគួរតែផ្តោតជាសំខាន់ត្រឹមតែបញ្ហាសាច់រឿងក្នុងសំណុំរឿង ០០២/១ បានហើយ។ *ការសាកសួរបញ្ហានានាដែលហួសពីវិសាលភាពនេះ គួរតែត្រូវកំហិតត្រឹមតែចំណុចណាដែលភាគីយល់ថា អ្នកជំនាញ ឬសាក្សីនោះ មានគុណវុឌ្ឍិដោយ*

សមស្រប ដោយហេតុថាតម្លៃនៃភ័ស្តុតាងនៃសក្ខីកម្មនឹងត្រូវបានពង្រីកនៅក្នុងកម្រិតជំនាញនេះ[267]។ វាកាន់តែសមហេតុ ផលជាងនេះទៀតពីព្រោះអ្នកជំនាញមិនអាចផ្តល់សក្ខីកម្មទាក់ទិនបញ្ហាច្បាប់ស៊ីជម្រៅ ដែលត្រូវបានទុកជូនតុលាការ[268]។ ជាការពិតណាស់ ផ្ទុយទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ[269] ការកាត់បន្ថយឱ្យខ្លីនូវសក្ខីកម្មរបស់ **Philip Short**[270] និងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកឯកសារមួយចំនួន[271] ដែលទាំងពីរករណីទាក់ទិននឹងអំពើប្រល័យពូជសាសន៍នោះ មិនត្រូវបានពន្យល់ត្រឹមតែភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ឡើយ។

---

*ឡែកក្នុងការឆ្លើយតបលើចំណុចនោះតែប៉ុណ្ណោះ។*") (គូសបញ្ជាក់បន្ថែម)។ ឯកសារ **E459** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ កថាខណ្ឌ ១៩៣ ("អង្គជំនុំជម្រះ កត់សម្គាល់ថា Philip Short TCE 92 ស្ថិតក្នុងចំណោមអ្នកជំនាញនានាដែលភាគីបានស្នើសុំកោះហៅមុនការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ដូច្នេះ *អង្គជំនុំជម្រះអនុញ្ញាតឱ្យមានការសួរសំណួរយ៉ាងទូលំទូលាយទៅតាមជំនាញពិសេសរបស់គាត់* ដើម្បីបញ្ចៀសការកោះហៅរូបគាត់ឡើងវិញដោយមិនចាំបាច់") (គូសបញ្ជាក់បន្ថែម)។ ឯកសារ **E1/189.1** ប្រតិចារឹក Philip Short ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 09.03.00-09.06.02 ទំព័រ ១ បន្ទាត់ ១៣-២៣ ("អ្នកជំនាញ Philip Short អាចនឹងត្រូវបានតាំងសំណួរអំពីបញ្ហាទាំងឡាយ ដែលគាត់មានសមត្ថភាព ។ អង្គជំនុំជម្រះសាលាដំបូង បានលើកទឹកចិត្តឱ្យភាគីផ្តោតនូវសំណួរពាក់ព័ន្ធ និងវិសាលភាពនៃការជំនុំជម្រះដែលត្រូវបំបែកជាថ្មីនៅសំណុំរឿង០០២ [...]។ *ដូច្នេះគឺវិសាលភាពគឺអង្គជំនុំជម្រះបើកទូលំទូលាយនៅក្នុងវិសាលភាពនៃសំណុំរឿង០០២* ក៏ពិតមែនប៉ុន្តែអង្គជំនុំជម្រះលើកទឹកចិត្តដល់ភាគីនៅក្នុងការសង្កត់ធ្ងន់ ឬក៏ផ្តោតការយកចិត្តទុកដាក់នៅសំណួរទាំងឡាយដែល ពាក់ព័ន្ធក្នុងវិសាលភាពនៃសំណុំរឿងដែលបានបំបែកមកធ្វើការនៅដំណាក់កាលដំបូងនេះ គឺសំណុំរឿង០០២/០១") (គូសបញ្ជាក់បន្ថែម)។

[267] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣២៨ ("(ii) នៅពេលផ្តល់សក្ខីកម្មលើបញ្ហាក្រៅជំនាញរបស់ខ្លួនសក្ខីកម្មនោះ "នឹងត្រូវចាត់ទុកថាជាមតិផ្ទាល់ខ្លួនរបស់សាក្សីជំនាញ ហើយនឹងត្រូវថ្លឹងថ្លែងសមស្របផងដែរ (បញ្ជាក់ថាមតិថានេះនៅតែអាចត្រូវបានពិចារណាដោយតុលាការអង្គហេតុ)"។

[268] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣២៨-៣២៩។ *សូមមើលផងដែរ* ឯកសារ **E312** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី និង នួន ជា យោងតាមវិធាន៨៧ សុំប្រើប្រាស់ភ័ស្តុតាងក្នុងអំឡុងពេលពិនិត្យលើ Philip Short ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ២។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣០ ("បន្ទាប់ពីពិនិត្យលើឯកសារពាក់ព័ន្ធ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង [E260] អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា សេចក្តីសម្រេចបដិសេធនេះ មានមូលដ្ឋានគ្រប់គ្រាន់")។

[269] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧០។

[270] ឯកសារ **E1/189.1** ប្រតិចារឹក Philip Short ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 1152.32 -11.54.06 ទំព័រ៥៩ បន្ទាត់ ១៥-១៩។

[271] ឯកសារ **E260** ចម្លើយតបរបស់ អ.ជ.ស.ដ ទៅនឹងសំណើតាមវិធាន៨៧ (៤) សុំដាក់ឯកសារជាថ្មីពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញ កថាខណ្ឌ៧-៨។

62. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ទឡ្ហីករណ៍ទី១ ទី២ ទី៣ និងទី៤ ហេតុដូច្នេះ សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការទទួលបានការជំនុំជម្រះ សមភាពនៃមធ្យោបាយតទល់ក្តី និង សវនាការតទល់គ្នាមិនត្រូវបានប៉ះពាល់ឡើយ។ មានសារៈសំខាន់ក្នុងការកត់សម្គាល់ការបំភ្លឺបញ្ជាក់របស់អង្គជំនុំជម្រះតុលាការកំពូលនូវអត្ថន័យនៃសវនាការតទល់គ្នា កិច្ចដំណើរការនីតិវិធីតទល់ចំពោះមុខ៖

> គោលការណ៍កិច្ចដំណើរការនីតិវិធីតទល់ចំពោះមុខតម្រូវមុនគេបង្អស់គឺថា គ្រប់ភាគីត្រូវបានផ្តល់ឱកាសឱ្យផ្តល់យោបល់ទៅលើភស្តុតាងដែលបានដាក់បង្ហាញនៅពេលសវនាការ និងទៅលើសារណារបស់ភាគីដែលធ្វើការជំទាស់ ក្នុងគោលបំណងដើម្បីឱ្យមានឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់តុលាការ។ គោលការណ៍នេះពុំបានតម្រូវថាត្រូវតែផ្តល់ឱកាសឱ្យភាគីក្នុងពេលជាក់លាក់ណាមួយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីឡើយ ឧទាហរណ៍ដូចជា ត្រូវផ្តល់នៅមុនពេលទទួលយកជាភស្តុតាងនិងពុំបានតម្រូវថាភាគីត្រូវតែធ្វើសារណាស្តីពីភស្តុតាងទាំងនោះឡើយ ទោះបីជាភាគីនីមួយៗមានឱកាសធ្វើដូច្នោះក៏ដោយ[272]។

## *មូលដ្ឋានទី ១៤៖ ការបំភ្លៃឬការបំផ្លែងភស្តុតាង*[273]

63. **មូលដ្ឋានទី ១៤ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ឬអង្គហេតុដោយបកស្រាយខុសនិងបំភ្លៃភស្តុតាង។**

64. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូងបកស្រាយខុស ឬបំភ្លៃភស្តុតាងជាក់លាក់ដែលបណ្តាលមកពីវិធីសាស្ត្រលម្អៀងលើភស្តុតាង ហេតុដូច្នេះធ្វើឱ្យការសន្និដ្ឋានអស់សុពលភាពដែលការសន្និដ្ឋាននេះផ្អែកលើភស្តុតាងដែលរងការជំទាស់[274]។ ជាដំបូងម្ចាស់បណ្តឹងសាទុក្ខផ្អែកលើកថាខណ្ឌផ្សេងទៀតនៃសារណារបស់ខ្លួនក្នុងការបង្ហាញឧទាហរណ៍

[272] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៨៥។ នៅក្នុងកថាខណ្ឌ ៤៩៥ អ.ជ.ត.ក ក៏បានយល់ឃើញថាពុំមានការបំពានលើគោលការណ៍នេះ ក្នុងការសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ជាជាងការសំអាងលើសក្ខីកម្មក្នុងតុលាការឡើយ នៅពេលដែល អ.ជ.ស.ដ បានវាយតម្លៃយ៉ាងប្រុងប្រយ័ត្នលើភស្តុតាង និងផ្តល់សំអាងហេតុពេញលេញទៅនឹងមូលហេតុដែលខ្លួនបានសំអាងទៅលើភស្តុតាងនោះ។

[273] <u>មូលដ្ឋានទី ១៤៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការបំភ្លៃ ឬការបំផ្លែងភស្តុតាង* កថាខណ្ឌ២៣២-២៣៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៩ (ភាសាអង់គ្លេស) ទំព័រ ៨ (ភាសាបារាំង) ទំព័រ ១២ (ភាសាខ្មែរ)។

[274] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៣៣-២៣៣។

នៃការបំភ្លៃដែលបានចោទប្រកាន់[275]ពាក់ព័ន្ធនឹងការអនុវត្តបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍[276] ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាគោលនយោបាយ[277] ឯកសារ សុន្ទរកថា[278] និងសក្ខីកម្មរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងពេលសវនាការ[279]។ ប៉ុន្តែឧទាហរណ៍ទាំងនេះនៅតែមិនគ្រប់គ្រាន់ ដោយហេតុថា វាមិនហួសឆ្ងាយពីការមិនយល់ស្របរបស់ម្ចាស់បណ្ដឹងសាទុក្ខទៅនឹងការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង។ ជាទស្សនៈរួមទៅលើភស្តុតាងនិងរម្លឹកឡើងវិញនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃតម្លៃនៃភស្តុតាងដែលអាចជឿជាក់បាន ចម្លើយតបទៅនឹងមូលដ្ឋានទី ២៧ បញ្ជាក់ច្បាស់អំពីការខកខានរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងការបង្ហាញការបកស្រាយខុស ឬការបំភ្លៃភស្តុតាងដែលនាំដល់ការធ្វើឱ្យអស់សុពលភាពនៃផ្នែកពាក់ព័ន្ធនៃសាលក្រម[280] ឬភាពមិនយុត្តិធម៌ជាក់ស្ដែង[281]។

65. ជាងនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខផ្ដល់ត្រឹមតែឧទាហរណ៍មួយប៉ុណ្ណោះដើម្បីគាំទ្រការអះអាងរបស់គាត់៖ ការអះអាងដោយកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាម្ចាស់បណ្ដឹងសាទុក្ខជាអ្នកថ្លែងសុន្ទរកថាបើកសម័យប្រជុំសភានៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦[282]។ ទឡ្ហីករណ៍ របស់ម្ចាស់បណ្ដឹងសាទុក្ខមិនមានហេតុផលក្នុងការអន្តរាគមន៍បណ្ដឹងសាទុក្ខឡើយ ដោយហេតុថា ទឡ្ហីករណ៍នេះពុំមានភស្តុតាងគាំទ្រ និងពុំមានឥទ្ធិពលលើសាលក្រមឡើយ។ គាត់ពុំផ្ដល់ភស្តុតាងគាំទ្រថា ហេតុអ្វីបានជាកំហុសឆ្គងនេះហួសឆ្ងាយពីការត្រឹមតែពិនិត្យមើលទៅលើសាលក្រមនៃការជំនុំជម្រះស្មុគស្មាញមួយ[283]។ ការថ្លែងសុន្ទរកថាដែលរងការជំទាស់គឺជាផ្នែកមួយនៃបណ្ដុំសុន្ទរកថា និងកិច្ចប្រជុំដែលអង្គជំនុំជម្រះសាលាដំបូងផ្អែកលើដើម្បីធ្វើការសន្និដ្ឋានចុងក្រោយថា គោលបំណងរួមមានអត្ថិភាព[284]និងមានចំណែកនៅក្នុងគោលបំណងរួមនេះ[285]។ ហេតុ

---

[275] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៣ ជើងទំព័រ ៣១២ *ដកស្រង់* កថាខណ្ឌ ២៥៧។

[276] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៤៤។

[277] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៩៥-១៣៩៨។

[278] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥២៦-១៥៣៥។

[279] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៣៦-១៥៤០។

[280] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់)។

[281] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[282] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៣។

[283] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១២៩។

[284] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៤ -៣៧៤៣។

[285] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៤. ៣៦៣៦-៣៧៣៧, ៣៧៣៩-៣៧៤៣។

ដូច្នេះ កត្តាកំណត់ចាំបាច់នៃការថ្លែងសុន្ទរកថាដែលរងការជំទាស់ចំពោះការសម្រេចសេចក្ដីចុងក្រោយ[286] និងសក្ដានុពលក្នុងការធ្វើឱ្យសាលក្រមអស់សុពលភាព[287] គឺពុំមានទេ ដែលមិនបណ្ដាលឱ្យមានអសុពលភាព ឬភាពមិនយុត្តិធម៌ជាក់ស្ដែងនោះឡើយ។

66. ជាងនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខប៉ុនប៉ងភ្ជាប់ការចោទថាបកស្រាយខុសពី សំណុំរឿង០០២/០១ ដើម្បីបង្ហាញភាពលម្អៀងបន្តនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងភ័ស្តុតាងដែលគ្របដណ្ដប់សំណុំរឿង០០២/០២[288]។ ប៉ុន្តែទឡ្ហីករណ៍នេះមិនបានទទួលផលឡើយ ដោយហេតុថាការវាយតម្លៃណាមួយលើភ័ស្តុតាងក្នុងសំណុំរឿង០០២/០១ គឺមិនពាក់ព័ន្ធ ពីព្រោះម្ចាស់បណ្ដឹងសាទុក្ខបានខកខានទាំងស្រុងក្នុងការបង្ហាញអំពីបុរេវិនិច្ឆ័យពីសំណាក់អង្គជំនុំជម្រះសាលាដំបូង[289]។

67. ក្នុងករណីណាក៏ដោយ ម្ចាស់បណ្ដឹងមិនបានបង្ហាញថាប្រសិនមានកំហុសឆ្គងកើតឡើង វាមានលក្ខណៈកំណត់ចំពោះការសម្រេចសេចក្ដី ឬវាមិនបានបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ជាក់ស្ដែងឡើយ[290]។

## *មូលដ្ឋានទី ១០៖ សម្ភារៈនានាមកពីសំណុំរឿង០០៣ និង ០០៤*[291]

68. **មូលដ្ឋានទី ១០ គួរត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានកំណត់ថា តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយបកស្រាយខុសទៅលើកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញភ័ស្តុតាងអនុលោមតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ឬថាអង្គជំនុំជម្រះសាលាដំបូងបានរំលោភឆន្ទានុសិទ្ធិនីតិវិធីនៅក្នុងសេចក្ដីសម្រេចបង្ហាញភ័ស្តុតាង។**

69. ម្ចាស់បណ្ដឹងសាទុក្ខលើកទឡ្ហីករណ៍ដោយកំហុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង (i) មានកំហុសអង្គច្បាប់ ដោយបកស្រាយខុសអំពីកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញធាតុផ្សំ

---

[286] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខ ១៩។

[287] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ៩៩។

[288] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៣។

[289] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៤។

[290] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ និងកំហុសអង្គច្បាប់)។

[291] <u>មូលដ្ឋានទី ១០៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ភ័ស្តុតាងមកពីសំណុំរឿង០០៣ និង០០៤* កថាខណ្ឌ ១៩៨-២១៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃ សារណាបណ្ដឹងសាទុក្ខ ទំព័រ ៨ (ភាសាអង់គ្លេស) ទំព័រ ៧ (ភាសាបារាំង) ទំព័រ ៩-១០ (ភាសាខ្មែរ)។

ភ័ស្តុតាង អនុលោមតាមវិធាន៥៣(៤) នៃវិធានផ្ទៃក្នុង[292] និង (ii) រំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយអនុញ្ញាតឱ្យបង្ហាញធាតុផ្សំភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ពីការស៊ើបអង្កេត ក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយមានការធានា "យឺតពេល" និង "មិនគ្រប់គ្រាន់" បណ្តាលឱ្យមានការពន្យារពេលមិនសមស្រប និង ពេលវេលាត្រៀមមិនគ្រប់គ្រាន់[293]។

70. ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយខកខានមិនបានបង្គាប់ឱ្យ "ព្រះរាជអាជ្ញាបង្ហាញតែភ័ស្តុតាងដោះបន្ទុកដែលមានសក្តានុពលនា ពេលអនាគតប៉ុណ្ណោះ" ដូចដែលតម្រូវដោយវិធាន៥៣(៤)នៃវិធានផ្ទៃក្នុង[294]។ ទឡ្ហីករណ៍នេះមិន បានផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខបកស្រាយវិធាន៥៣(៤) នៃវិធានផ្ទៃក្នុងដោយកំហុសឆ្គង។ អង្គជំនុំជម្រះតុលាការកំពូលបានថ្លែងថាវិធាន៥៣(៤)តម្រូវឱ្យព្រះរាជអាជ្ញាបង្ហាញសម្ភារៈទាំងឡាយដែលគ្មានវិរុទ្ធភាពឬដែលអាចប៉ះពាល់ដល់ភាពជឿជាក់នៃភ័ស្តុតាង ដែលក្នុងនោះរួមមានចម្លើយសាក្សីពីមុនៗដែលអាចប៉ះពាល់ដល់ភាពជឿជាក់នៃភ័ស្តុតាង[295]។ ដោយហេតុថាការបង្ហាញភ័ស្តុតាងតាមវិធាន ៥៣(៤) មិនទាក់ទងនឹងការទទួលយកភ័ស្តុតាង[296] ដូច្នេះមូលដ្ឋានដែលអាចផ្អែកសម្រាប់ការចេញសាលក្រម ទឡ្ហីករណ៍របស់គាត់ដែលថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្ហាញបានធ្វើឱ្យអស់សុពលភាពដល់សាលក្រមនោះគឺមិនត្រឹមត្រូវទេ។

### *មូលដ្ឋានទី ៩៖ ការធ្វេសប្រហែសចំពោះលក្ខណៈពិសេសនៃវិធាន៨៧(៤)*[297]

[292] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៨-២០១,២១១-២១៥។

[293] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៨, ២០២-២០៣, ២០៥, ២០៨-២០៩, ២១៥។

[294] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០១។

[295] ឯកសារ F2/4/2 សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយកភ័ស្តុតាងបន្ថែម កថាខណ្ឌ ១៧។

[296] ឯកសារ E363/3 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ កថាខណ្ឌ ៣៦។ (អ.ជ.ស.ដ បញ្ជាក់ថា ភាគី អាចស្នើសុំឱ្យទទួលយកឯកសារដោយផ្ទាល់ ដោយមិនដាក់បង្ហាញ អនុលោមតាមវិធាន៥៣ (៤) នៃវិធានផ្ទៃក្នុង៖ "អង្គជំនុំជម្រះ [...] ត្រូវពឹងផ្អែកលើឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា [...] ដើម្បីកំណត់ថាតើការស្នើសុំឱ្យទទួលយកឯកសារណាមួយគួរត្រូវធ្វើដោយផ្ទាល់ អនុលោមតាមវិធាន៨៧ (៤) នៃវិធានផ្ទៃក្នុង")។

[297] <u>មូលដ្ឋានទី ៩៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ភាពធ្វេសប្រហែសចំពោះលក្ខណៈពិសេសនៃវិធាន ៨៧ (៤)* កថាខណ្ឌ ១៨២-១៨៧។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨ (ភាសាអង់គ្លេស) ទំព័រ ៧ (ភាសាបារាំង) ទំព័រ ៨-៩ (ភាសាខ្មែរ)។

71. **មូលដ្ឋានទី ៩ គួរតែបដិសេធ ដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការទទួលយកភស្តុតាងថ្មី "ច្រើនហួសកម្រិត" នៅក្នុងអំឡុងពេលជំនុំជម្រះ។**

72. ម្ចាស់បណ្ដឹងសាទុក្ខលើកទឡ្ហីករណ៍ដោយខុសឆ្គងថា (i) អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយមិនអើពើដល់លក្ខណៈពិសេសនៃវិធាន៨៧(៤)[298] ដោយអនុញ្ញាតឱ្យទទួលយកភស្តុតាងថ្មីដែលបាននាំដល់កំហុសឆ្គងបន្តបន្ទាប់ទៀតនៅក្នុងការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[299] និងកំហុសឆ្គងនេះបានបណ្ដាលឱ្យមានការទទួលយកភស្តុតាងដែលមិនចាំបាច់បង្កឱ្យមានការពន្យារពេលមិនសមស្រប ភាពមិនប្រាកដប្រជា និង បដិសេធពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្ដី។ ដើម្បីធ្វើឱ្យមានភាពច្បាប់បាច់ក្នុងការអន្តរាគមន៍បណ្ដឹងសាទុក្ខ ម្ចាស់បណ្ដឹងសាទុក្ខត្រូវបង្ហាញកំហុសជាក់ស្ដែង នៅក្នុងការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង និងបង្ហាញថាកំហុសឆ្គងនេះបណ្ដាលឱ្យមានព្យសនកម្មដល់ម្ចាស់បណ្ដឹងសាទុក្ខ[300]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្កើតលក្ខខណ្ឌទាំងពីរ។

73. ទីមួយ ម្ចាស់បណ្ដឹងលើកទឡ្ហីករណ៍ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង[301]។ ប៉ុន្តែគាត់ខកខានមិនបានផ្ដល់ភស្តុតាងគាំទ្រការអះអាងនេះ និងបកស្រាយខុសលើយុត្តិសាស្ត្រដែលមានកម្រិតដែលលើកមកសំអាងលើវិធាន៨៧(៤)[302]។ ជាមូលដ្ឋានសំខាន់ ដោយកែច្នៃវិធាន៨៧(៤) ឱ្យទៅជាមានលក្ខណៈពិសេស ម្ចាស់បណ្ដឹងសាទុក្ខមិនអើពើដល់លក្ខណៈបត់បែននៃវិធាន៨៧(៤) ដែលផ្ដល់យុត្តិកម្មដល់ការទទួលយកដោយឆន្ទានុសិទ្ធិ[303]។

---

[298] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨២-១៨៨។

[299] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៩-១៩០។

[300] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧-៩៨,១០០។

[301] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៣-១៨៩។

[302] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៧-១៨៨។

[303] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៤។ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៤។ ឯកសារ E319/7 សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្ដីពីការទទួលយកឯកសារសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងកំណត់ហេតុនៃការស្ដាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ កថាខណ្ឌ ៨។

74. ម្ចាស់បណ្ដឹងសាទុក្ខបកស្រាយដោយកំហុសឆ្គងដល់អញ្ញត្រកម្មនៃវិធាន៨៧(៤) ថាបណ្ដាលឱ្យវិធាននេះផ្ទាល់មានលក្ខណៈពិសេស[304]។ ក្នុងការបកស្រាយសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ជីឈ្មោះសាក្សីនិងការតវ៉ាអំពីការទទួលយកឯកសារនិងភស្តុតាង[305] ម្ចាស់បណ្ដឹងសាទុក្ខផ្តល់ខ្លឹមសារខុសទៅតាមការយល់ឃើញរបស់ខ្លួន ចំពោះលក្ខណៈវិនិច្ឆ័យនៃប្រយោជន៍យុត្តិធម៌នៅក្នុងវិធាន៨៧(៤)[306] នៅពេលអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងករណីនោះតាមពិតបំភ្លឺបញ្ជាក់ថាលក្ខខណ្ឌនៃប្រយោជន៍យុត្តិធម៌គឺជាអញ្ញត្រកម្មនៅពេល "លក្ខខណ្ឌនៃ វិធាន៨៧(៤) មិនត្រូវ[បាន]បំពេញ"[307]។ មិនតែប៉ុណ្ណោះ ម្ចាស់បណ្ដឹងសាទុក្ខកំណត់លក្ខណៈខុសទៅលើការអនុវត្តលើសំណុំរឿង០០២/០២ នៅពេលគាត់ចោទថាអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃលើភាពទទួលយកបាននៃឯកសារ "ដោយពុំយោងដល់វិធាន៨៧(៤)" ប៉ុន្តែ "ផ្អែកតាមមូលដ្ឋានពិសេស" ដើម្បីចៀសវាងការពន្យារពេលដោយមិនសមស្រប[308]។ ចំណុចចុងក្រោយ ម្ចាស់បណ្ដឹងសាទុក្ខប្រៀបធៀបដោយមិនត្រឹមត្រូវលើលក្ខខណ្ឌតម្រូវតឹងរឹងសម្រាប់វិធាន ៨៧(៤)[309] ដែលមានលក្ខណៈពិសេស ដោយគ្មានការគាំទ្រផ្នែកច្បាប់ ក្រៅតែអំពីទាញទម្លើករណ៍ដោយកំហុសឆ្គងថាការទទួលយកភស្តុតាងទើបរកឃើញថ្មីនៅក្នុងអំឡុងពេលជំនុំជម្រះក្រោយពីមានការស៊ើបអង្កេតដ៏យូរ និងដំណាក់កាលមុនជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគីរៀបចំខ្លួនសម្រាប់ការជំនុំជម្រះ[310]។

---

[304] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៧-១៨៨។

[305] ឯកសារ **E131/1** សេចក្ដីណែនាំរបស់ អ.ជ.ស.ដ ស្ដីពីបញ្ជីឈ្មោះសាក្សី និងការតវ៉ាអំពីការទទួលយកឯកសារ ទំព័រ ៤ EN 00747686។

[306] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៧-១៨៨។

[307] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៣-១៧៤។ *សូមមើលផងដែរ* ឯកសារ **E307/1** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្ដីពីការអនុវត្តវិធាន ៨៧ (៤) កថាខណ្ឌ ៣ ("អង្គជំនុំជម្រះធ្លាប់បានទទួលយកភស្តុតាងថ្មីកាលពីពេលមុនរួចម្ដងហើយជាករណីលើកលែង ទោះបីភស្តុតាងទាំងនោះពុំបានបំពេញលក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងក៏ដោយ ដរាបណាផលប្រយោជន៍នៃយុត្តិធម៌តម្រូវ។") (គូសបញ្ជាក់បន្ថែម)។ *សូមមើលឧទាហរណ៍* ឯកសារ **E363/3** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើសំណើ ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ កថាខណ្ឌ ២៨,៣០។ ឯកសារ **E357/1** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំកែតម្រូវឯកសារពាក់ព័ន្ធនឹងតំបន់៥ កថាខណ្ឌ ២។ ឯកសារ **E276/2** ចម្លើយតបរបស់ អ.ជ.ស.ដ ទៅនឹងសំណើតាមវិធាន៨៧ (៤) កថាខណ្ឌ ២។

[308] ឯកសារ **E307/1/2** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំឱ្យសម្រេច*សាជាថ្មីឡើងវិញ*លើការអនុវត្តវិធាន៨៧ (៤) នៃវិធានផ្ទៃក្នុង កថាខណ្ឌ ១០-១១ (អ.ជ.ស.ដ ថ្លែងថាវាមិនសមស្របឡើយ ក្នុងការបញ្ជាក់មូលហេតុអំពី "ការខកខានក្នុងការដាក់បញ្ចូលឯកសារ [ដែលមានទំហំធំ] ទាំងនោះ នៅក្នុងបញ្ជីឆ្នាំ២០១១ របស់ពួកគេ។")

[309] ឯកសារ **E307/1** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្ដីពីការអនុវត្តវិធាន ៨៧ (៤) កថាខណ្ឌ ៣។

[310] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៧-១៨៨។

75. ដើម្បីបំពេញតាមលក្ខខណ្ឌមានចែងក្នុងវិធាន៨៧(៤) ភាគីត្រូវតែបង្ហាញថាភ័ស្តុតាងថ្មីមិនអាចរកបាន និង/ឬមិនអាចរកបានមុនពេលបើកការជំនុំជម្រះទោះបីជាបានខិតខំប្រឹងប្រែងយ៉ាងសមហេតុផលក្តី និងថាភ័ស្តុតាងនេះអាចនាំទៅដល់ការស្វែងរកការពិត[311]។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធភ័ស្តុតាងដែលមិនបំពេញតាមលក្ខខណ្ឌមានចែងក្នុងវិធាន៨៧(៣) ពោលគឺភ័ស្តុតាងនោះត្រូវតែ "ពាក់ព័ន្ធនឹងអាចជឿទុកចិត្ត*ជាបឋម*"[312]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង "បានងាកចេញយ៉ាងខ្លាំងពីយុត្តិសាស្ត្រនេះ"[313] គឺខកខានមិនបានពិចារណាលើឆន្ទានុសិទ្ធិទូលំទូលាយដែលផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូង តាមរយៈវិធាន៨៧(៤)[314]។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានប្រើឆន្ទានុសិទ្ធិនេះសមស្របតាមច្បាប់កំណត់។ ជាការផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង "ទទួលយកឯកសារក្រាស់ក្រែលទាំងនោះដោយស្វ័យប្រវត្តិ" ដោយបៀបធៀបទាំងមិនត្រឹមត្រូវនូវភាពពាក់ព័ន្ធនិងមានប្រយោជន៍សម្រាប់ស្វែងរកការពិត[315] អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែបានផ្តល់សំអាងហេតុច្បាស់លាស់នោះទេ ប៉ុន្តែថែមទាំងបានអនុវត្តលក្ខខណ្ឌច្បាប់ត្រឹមត្រូវទៀតផង៖ "ភ័ស្តុតាងថ្មីត្រូវតែពាក់ព័ន្ធជាបឋមដើម្បីនាំដល់ការស្វែងរកការពិត"[316]។

---

[311] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៥។

[312] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦។

[313] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩។

[314] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៥ (អ.ជ.ត.ក អានវិធាន៨០ (៣) នៃវិធានផ្ទៃក្នុងជាមួយនឹងវិធាន៨៧ ដើម្បីធ្វើកត់សម្គាល់លើវិធាន៨០ (៣) ថាជា "ឧបករណ៍សម្រាប់គ្រប់គ្រងសំណុំរឿងដែលពុំអាចបដិសេធនូវចំណែក ឬប្រភេទណាមួយនៃភ័ស្តុតាងបានឡើយ")។ កថាខណ្ឌ ១៧៤ (វិធាន៨៧ (៤) ជាឧបករណ៍សម្រាប់ "ថ្លឹងថ្លែងពីតម្រូវការចាំបាច់ក្នុងការគ្រប់គ្រងការជំនុំជម្រះឱ្យបានសមស្រប និងមានភាពបត់បែនបាន នៅពេលដែលតម្រូវឱ្យមានការធានានូវកិច្ចដំណើរការនីតិវិធីដោយត្រឹមត្រូវនោះ")។ *សូមមើលផងដែរ* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៤ ("វិធាន៣៩ [...] ផ្តល់ឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយដល់អង្គជំនុំជម្រះ ក្នុងការកំណត់ផលវិបាកនៃអំឡុងពេលកំណត់ដែលត្រូវធ្វើឡើងដោយអង្គជំនុំជម្រះ")។ ឯកសារ **E319/7** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីការទទួលយកឯកសារសហាករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងកំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ កថាខណ្ឌ ៨។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៤។

[315] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩។

[316] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ២៥ ជើងទំព័រ ៦៤។ ឯកសារ **E190** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ទាក់ទិននឹងឯកសារថ្មី ជើងទំព័រ ៣៨។ សំណុំរឿង ០០១-ឯកសារ **E5/10/2** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ អំពីភាពទទួលយកបាននៃភ័ស្តុតាងថ្មី កថាខណ្ឌ ៦។

76. ម្ចាស់បណ្ដឹងសាទុក្ខលើកទឡ្ហីករណ៍ទាំងមិនត្រឹមត្រូវទៀតថាការទទួលយកភស្តុតាងថ្មីគឺមិនចាំបាច់ ដោយមូលហេតុថាភស្តុតាងដែលបានទទួលយករួចមានចំនួនច្រើនសន្ធឹកសន្ធាប់[317] និងតវ៉ាថា ដោយហេតុថាភស្តុតាងថ្មីមិនត្រូវបានផ្អែកលើមិនអាចប្រកែកបានវា "មិនមានប្រយោជន៍" ឬ "សារៈសំខាន់" ក្នុងប្រយោជន៍យុត្តិធម៌ទេ[318]។ ផ្ដើមចេញពីការផ្ដល់ខ្លឹមសារខុសរបស់ម្ចាស់បណ្ដឹងសាទុក្ខលើវិធាន៨៧(៤)ដែលយោងខាងលើ ទឡ្ហីករណ៍នេះខកខានមិនបានពិចារណាលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកភស្តុតាងនិងថាលក្ខខណ្ឌតម្រូវនៃផលប្រយោជន៍យុត្តិធម៌ពុំពាក់ព័ន្ធ ដោយហេតុថាលក្ខខណ្ឌនៃវិធាន៨៧(៤)ត្រូវបានបំពេញហើយ[319]។ ជាងនេះទៀត ថាតើភស្តុតាងនោះត្រូវបានយោងដោយមិនអាចបដិសេធបាននៅក្នុងសាលក្រមនោះគឺជាការយល់ឃើញក្រោយដើម្បីធ្វើឱ្យអន្តរាយដល់ការប្រើឆន្ទានុសិទ្ធិតុលាការដ៏ទូលំទូលាយជាពិសេស ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងមិនត្រូវបានតម្រូវឱ្យយោងដល់ភស្តុតាងទាំងអស់ ដែលបានផ្អែកលើនោះឡើយ[320]។

77. ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថាអង្គជំនុំជម្រះសាលាដំបូងគួរតែមាន "ការប្រយ័ត្នប្រយ៉ែងជាងនេះ" ក្នុងការទទួលយកភស្តុតាងពេញអំឡុងពេលជំនុំជម្រះ មិនមែននៅចុងបញ្ចប់នៃការជំនុំជម្រះក្ដីនោះ គឺមិនត្រឹមត្រូវទេ[321]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានវាយតម្លៃទៅលើហេតុផលនៅពីក្រោយអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ដែលចេញដោយមូលហេតុនៃការខិតជិតដល់ការបិទបញ្ចប់ការជំនុំជម្រះក្ដីដើម្បីធានាថា ម្ចាស់បណ្ដឹងសាទុក្ខមិនត្រូវបានគ្របដណ្ដប់ដោយភាពមិនប្រាកដប្រជា និងមានពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងភស្តុតាងថ្មីដែលត្រូវបានទទួលយក[322]។

78. ចំពោះទឡ្ហីករណ៍ទីពីររបស់ម្ចាស់បណ្ដឹងសាទុក្ខ គាត់ខកខានមិនបានបង្ហាញថាកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការអនុវត្តវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងបានបណ្ដាលឱ្យមានការ

[317] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩០។

[318] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩១។

[319] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩០។

[320] សូមមើល ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៩, ៣៥២។

[321] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩២។

[322] ឯកសារ E319/47/3 សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំឱ្យទទួលយកកំណត់ហេតុស្ដាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង កថាខណ្ឌ ២៣ ("តម្លៃនៃភស្តុតាងបន្ថែមដែលអាចជួយដល់ការបញ្ជាក់ការពិតត្រូវតែថ្លឹងជាមួយភាពមិនជាក់លាក់ដែលមានតាមរយៈការអនុញ្ញាតឱ្យទទួលយកនូវភស្តុតាងថ្មីមួយចំនួនធំ នៅពេលជិតបិទបញ្ចប់កិច្ចនីតិវិធី នៅពេលដែលភាគីដទៃទៀត មិនអាចមានឱកាសគ្រប់គ្រាន់ដើម្បីវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មាននេះ")។

ពន្យារពេលមិនសមស្រប ភាពមិនប្រាកដប្រជា ឬការបដិសេធសិទ្ធិរបស់គាត់ក្នុងការទទួលបានពេលវេលាសមស្របដើម្បីរៀបចំការការពារក្តីរបស់ខ្លួន។ ម្ចាស់បណ្តឹងសាទុក្ខមានពេលគ្រប់គ្រាន់ចន្លោះពេលនៃការទទួលភស្តុតាងនិងចុងបញ្ចប់នៃការជំនុំជម្រះក្តី ខណៈដែលករណីនៃការទទួលយកភស្តុតាងដែលនាំឱ្យមានព្យសនកម្មដែលម្ចាស់បណ្តឹងសាទុក្ខផ្អែកលើ គឺបានកើតឡើងតាំងពីមុនបិទបញ្ចប់ការជំនុំជម្រះក្តីមកម្ល៉េះ[323]។ មិនតែប៉ុណ្ណោះ ជំហរមិនច្បាស់លាស់របស់ម្ចាស់បណ្តឹងសាទុក្ខថា ការទទួលយក "សៀវភៅទាំងក្បាលៗនៅចុងបញ្ចប់នៃការជំនុំជម្រះ" បានបណ្តាលឱ្យមានការពន្យារពេលមិនសមស្រប[324] មិនអាចបង្កើតបានជាព្យសនកម្មតាមលក្ខខណ្ឌកំណត់ឡើយ ដោយហេតុថាគាត់មិនបានបង្ហាញការទទួលយកដោយមិនត្រឹមត្រូវ ឬពេលវេលាមិនគ្រប់គ្រាន់ក្នុងការឆ្លើយតបឡើយ[325]។ ចំណុចចុងក្រោយ ពេលវេលាដែលបានចំណាយដោយម្ចាស់បណ្តឹងសាទុក្ខនៅក្នុងការជំទាស់ទៅនឹងការអនុវត្តរបស់សហព្រះរាជអាជ្ញា[326] គឺពុំមែនជាហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងអន្តរាគមន៍ឡើយ ប៉ុន្តែគឺជាលទ្ធផលនៃសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការអនុវត្ត អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង[327]។

### *មូលដ្ឋានទី ២៣៖ ចម្លើយពីមុនៗ/ចម្លើយពេលក្រោយៗមកទៀត*[328]

79. **មូលដ្ឋានទី ២៣ គួរតែត្រូវបានបដិសេធដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនទទួលយកចម្លើយរបស់ ឯក**

---

[323] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩។ កាលបរិច្ឆេទ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥,ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ និងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ គឺនៅមុនពេលបញ្ចប់សវនការលើអង្គសេចក្តី នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។

[324] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៤។

[325] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៥។ ឯកសារ E431/5 សំអាងហេតុជាលាយលក្ខណ៍អក្សររបស់ អ.ជ.ស.ជ លើសេចក្តីសម្រេចស្តីពីសក្ខីកម្មរបស់ Kasumi Nakagawa និងលើសំណើសុំឱ្យទទួលយកឯកសារភស្តុតាង កថាខណ្ឌ ២៦-២៨ (វាដូច្នេះមែន នៅពេលដែល អ.ជ.ស.ជ លើកមូលហេតុនៃការទទួលយកសៀវភៅនោះជាផលប្រយោជន៍នៃយុត្តិធម៌ ដោយសារការធ្វើបច្ចុប្បន្នភាព, សៀវភៅបោះពុម្ពផ្សាយថ្មីៗ និងគុណតម្លៃក្នុងការវាយតម្លៃភាពអាចទុកចិត្តបានជាពិសេសនៅពេលដែលវាមានស្រាប់នៅក្នុងសំណុំរឿង ដូចមានចែងនៅក្នុងវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង)។

[326] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦។

[327] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦។

[328] មូលដ្ឋានទី ២៣៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ចម្លើយពីមុនៗ/ចម្លើយពេលក្រោយៗមកទៀត* កថាខណ្ឌ ២៥៥-២៥៦។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃ សារណាបណ្តឹងសាទុក្ខ ទំព័រ ១២ (ភាសាអង់គ្លេស) ទំព័រ ១១ (ភាសាបារាំង) ទំព័រ ១៦ (ភាសាខ្មែរ)។

**ហេន និង ជួន ធី ដែលបានបង្ហាញនៅអំឡុងពេលនៃដំណាក់កាលពិភាក្សាសម្រេចក្នុងសំណុំរឿង ០០២/០២។**

80. ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ដោយមិនត្រឹមត្រូវថា (i)អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបើកឡើងវិញនូវកិច្ចនីតិវិធីក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់ ឯក ហេន និង ជួន ធី[329] (ii) កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបណ្តាលឱ្យមានព្យសនកម្មចំពោះម្ចាស់បណ្តឹងសាទុក្ខដោយហេតុថាគាត់បានបាត់បង់ឱកាសក្នុងការតវ៉ាដោយផ្ទាល់មាត់ទៅលើការសន្និដ្ឋានដែលផ្អែកលើសក្ខីកម្មពីសាក្សីទាំងនោះ[330]។

81. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយងាកចេញពីយុត្តិសាស្ត្ររបស់ខ្លួន ដែលដាក់កាតព្វកិច្ចឱ្យទទួលយកចម្លើយទាំងអស់ពីសំណុំរឿង០០៣និង០០៤ របស់សាក្សីដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២ ដែរ[331]។ ប៉ុន្តែទឡ្ហីករណ៍នេះមិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពង្រីកការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមិនសមស្រប[332] ដែលធ្វើឡើងនៅក្នុងសវនាការលើអង្គសេចក្តី[333] ដល់ដំណាក់កាលពិភាក្សាសម្រេច។ ការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៃការទទួលយកដោយស្វ័យប្រវត្តិនូវចម្លើយសាក្សីដែលបានបង្ហាញខ្លួនគឺជាអញ្ញត្រកម្មទៅនឹងវិធាន ៨៧(៤)[334]។ ក៏ប៉ុន្តែ វិធាន៨៧(៤) អនុវត្តតែ "ក្នុងអំឡុងពេលនៃការជំនុំជម្រះ"តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ការបើកសំណុំរឿងឡើងវិញក្នុងដំណាក់កាលពិភាក្សាសម្រេច ត្រូវបានគ្រប់គ្រងដោយវិធាន៩៦(២) ចំណែកឯការពិចារណាផ្សេងៗគ្នាអាស្រ័យលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ ដូចដែលបានលើកឡើងជាគោលដោយអង្គជំនុំជម្រះតុលាការកំពូល ICTY នៅក្នុងការប្រើឆន្ទានុសិទ្ធិដើម្បីបើករឿងក្តីឡើងវិញ អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិចារណាថាតើតម្លៃដែលគួរឱ្យជឿបាននៃភ័ស្តុតាងមានទម្ងន់លើសការពន្យារពេលដែលបណ្តាលមកពីការបើកកិច្ចដំណើរការនីតិវិធីឡើង

[329] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤៤។

[330] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤៤-២៤៦។

[331] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤៤-២៤៥។

[332] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤៤-២៤៥។

[333] *សូមមើលឧទាហរណ៍* ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៥១។ ឯកសារ E363/3 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើ ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសារ កថាខណ្ឌ ២៥។ ឯកសារ E421/4 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីកាលបរិច្ឆេទកំណត់ តាមវិធាន ៨៧ (៤) កថាខណ្ឌ ១២។

[334] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤៤-២៤៥។

វិញខ្លាំងឬយ៉ាងណា ដោយពិចារណាលើដំណាក់កាលនៃការជំនុំជម្រះដែលមានសំណើ[335]។ ម្ចាស់បណ្តឹងសាទុក្ខមិនប៉ុនប៉ងបង្ហាញកំហុសជាក់ស្តែងរបស់អង្គជំនុំជម្រះសាលាដំបូង ដោយយោងលើលក្ខខណ្ឌតម្រូវនេះ ប៉ុន្តែផ្ទុយទៅវិញ អះអាងដោយមិនត្រឹមត្រូវនូវកំហុសអង្គច្បាប់តាមរយៈការអនុវត្តបទដ្ឋានច្បាប់ខុស។

82. ទីពីរ តាមរយៈការអនុវត្តបទដ្ឋានច្បាប់ត្រឹមត្រូវសម្រាប់ការប្រើឆន្ទានុសិទ្ធិអនុលោមតាមវិធាន៨៦(២) ពុំបង្ហាញឱ្យឃើញកំហុសជាក់ស្តែងឡើយ។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថាកំណត់ហេតុស្តាប់ចម្លើយដែលរងការជំទាស់គួរតែត្រូវបានទទួលយក ដោយបើកកិច្ចដំណើរការនីតិវិធីឡើងវិញ ដោយហេតុថា កំណត់ហេតុស្តាប់ចម្លើយទាំងនេះបង្កផលប៉ះពាល់យ៉ាងខ្លាំងទៅលើការវាយតម្លៃភាពជឿជាក់បាន និងភាពទុកចិត្តបាននៃសក្ខីកម្មរបស់ពួកគេ[336]។ ប៉ុន្តែទោះជាយ៉ាងណា ប្រការនេះមិនត្រូវបានបញ្ជាក់នៅក្នុងខ្លឹមសារនៃចម្លើយណាមួយឡើយ។ ពិតណាស់ កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក ហេន មិនផ្ទុយទៅនឹងចម្លើយនិងសក្ខីកម្មរបស់គាត់ពីលើកមុនទេ[337] ប៉ុន្តែ វាបានបញ្ជាក់បន្ថែមទៅលើលក្ខណៈដាក់បន្ទុកទៅវិញ។ ដូចគ្នានេះដែរ កំណត់ហេតុស្តាប់ចម្លើយ ជួន ធី បានលើកឡើងដូចសក្ខីកម្មរបស់គាត់លើកមុន ទោះបី ជាមានសេចក្តីលម្អិតនៃដំណើររឿងផ្ទាល់ខ្លួនច្រើនជាងក្តី[338]។ ដូច្នេះ ជាការសមហេតុផលដែលអង្គជំនុំ ជម្រះសាលាដំបូងសន្និដ្ឋានថាតម្លៃបន្ថែមណាមួយនៃចម្លើយនានាក្នុងការនាំទៅរកការបង្ហាញការពិត មានទម្ងន់ស្រាលជាងការពន្យារពេលក្នុងការធ្វើដូច្នោះ[339]។ ការណ៍ដែលអង្គជំនុំជម្រះនេះប្រកាន់យក ទស្សនៈទូលាយទៅលើ

---

[335] សាលដីការឿងក្តី *Čelebići* កថាខណ្ឌ ២៨៣ (ក្នុងបរិបទនៃការបើកឡើងវិញនូវកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះតុលាការកំពូល ថ្លែងថា៖ "អង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិក្នុងការទទួលយកភស្តុតាង និងគប្បីពិចារណាថាតើ តម្លៃនៃភស្តុតាងមានលក្ខណៈលម្អៀងជាខ្លាំង ដែលមិនធានាឱ្យមានការជម្រះក្តីដោយយុត្តិធម៌ដែរឬទេ។") កថាខណ្ឌ២៩០ (នៅពេលធ្វើសេចក្តីសម្រេច អ.ជ.ស.ដ គប្បីពិចារណាដំណាក់កាលនៅក្នុងការជំនុំជម្រះដែលភស្តុតាងត្រូវបានស្នើសុំឱ្យទទួលយក និងដំណើរយឺតយ៉ាវជាសក្តានុពល ដែលបណ្តាលឱ្យកើតមានចំពោះការជំនុំជម្រះ)។

[336] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤៦។

[337] *សូមមើល* ឯកសារ **F51/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកភស្តុតាងបន្ថែម ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ កថាខណ្ឌ ២៣-២៨។

[338] *សូមមើល* ឯកសារ **F51/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកភស្តុតាងបន្ថែម ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ កថាខណ្ឌ ៣០-៣៤។

[339] ឯកសារ **F51/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកភស្តុតាងបន្ថែម ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ កថាខណ្ឌ ១៩។ ការដាក់បង្ហាញភស្តុតាង ត្រូវបានធ្វើឡើងនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ នៅពេលដែលការពិភាក្សាបានធ្វើឡើងអស់រយៈពេល១ឆ្នាំ៤ខែ តម្រូវឱ្យមានការជៀសវាងការពន្យាពេលដោយមិនសមស្រប ដែលមានសារៈសំខាន់ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងសាទុក្ខ។

ឆន្ទានុសិទ្ធិពីធម្មជាតិក្នុងការទទួលយកចម្លើយអនុលោមតាមវិធាន១០៤(១)[340] មិនបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងគួរតែបានធ្វើដូច្នោះឡើយ ដោយហេតុថារបបទទួលយកនានាមានលក្ខណៈខុសៗគ្នា។ ដោយពិចារណាលើការគោរពដល់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងបញ្ហានីតិវិធី[341] ជាពិសេស ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងបានមានឱកាសធ្វើឱ្យថ្នឹកនឹងរឿងក្តីជាក់លាក់យ៉ាងហោចណាស់ចំនួន៣ឆ្នាំនោះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញលក្ខខណ្ឌនៃភាពពុំសមហេតុផលឬភាពមិនយុត្តិធម៌[342]។

83. ទីពីរ ជាការផ្ទុយទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ កំហុសឆ្គងណាមួយនៅក្នុងការប្រើឆន្ទានុសិទ្ធិមិនបានបង្កព្យសនកម្មដល់គាត់ឡើយ។ ដើម្បីឱ្យមានការបដិសេធចំពោះការប្រើឆន្ទានុសិទ្ធិនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង លទ្ធផលត្រូវតែមិនយុត្តិធម៌ ដោយពិចារណាទៅលើដំណាក់កាលទាំងអស់នៃកិច្ចនីតិវិធី ក្នុងនោះរួមមានវិធានការដែលប្រកាន់យកនៅអំឡុងពេលនៃបណ្តឹងសាទុក្ខ[343]។ ហេតុដូច្នេះ ដោយហេតុថាចម្លើយដែលរងការជំទាស់បច្ចុប្បន្នត្រូវបានទទួលយកសម្រាប់គោលបំណងនៃបណ្តឹងសាទុក្ខ[344] ម្ចាស់បណ្តឹងសាទុក្ខបានមានឱកាសក្នុងការជំទាស់ទៅនឹងការសន្និដ្ឋាននានានៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ហេតុដូច្នេះ ព្យសនកម្មជាសក្តានុពលណាមួយចេញពីឱកាសដែលបាត់បង់ទៅហើយនោះ គឺត្រូវទុកជាមោឃៈ។

## *មូលដ្ឋានទី ៦៖ ការកំណត់បទចោទសាជាថ្មីដោយខុសច្បាប់*[345]

84. **មូលដ្ឋានទី ៦ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយសន្និដ្ឋានថា ខ្លួនមានសិទ្ធិអំណាចក្នុងការកំណត់បទចោទសាជាថ្មី ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាតនូវ**

[340] ឯកសារ **F51/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើរបស់ខៀវ សំផន សុំដាក់ភ័ស្តុតាងបន្ថែម កថាខណ្ឌ ៣៨។

[341] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧-៩៨។

[342] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧-៩៨។

[343] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសនីតិវិធី)។

[344] *សូមមើល* ឯកសារ **F51/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើរបស់ខៀវ សំផន សុំដាក់ភ័ស្តុតាងបន្ថែម។

[345] <u>មូលដ្ឋានទី ៦៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការកំណត់បទល្មើសសាជាថ្មីខុសច្បាប់* កថាខណ្ឌ ១៣៥-១៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥-៦ (ភាសាអង់គ្លេស) ទំព័រ ៥-៦ (ភាសាបារាំង) ទំព័រ ៦ (ភាសាខ្មែរ)។

**អង្គហេតុដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល[346]។**

85. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកំណត់បទចោទសាថ្មីចំពោះសហការណ៍ត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង ("ទីតាំងទាំង៤")[347] ដោយអនុលោមយ៉ាងពេញលេញទៅនឹងកាតព្វកិច្ចគោរពព្រំដែននៃ *បណ្តឹង* និងការពារសិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ក្នុងករណីណាក៏ដោយម្ចាស់បណ្តឹងសាទុក្ខបច្ចុប្បន្នបានបង្ហាញការការពារក្តីពេញ លេញលើអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធនឹងបទចោទដែលត្រូវបានកំណត់សាជាថ្មី។ ដូច្នេះ វិការៈនីតិវិធីណាមួយនៅក្នុងការកំណត់បទចោទសាជាថ្មីរបស់អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបានដោះស្រាយដោយការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលលើការចោទប្រកាន់របស់អង្គជំនុំជម្រះសាលាដំបូង។

86. ជាការផ្ទុយទៅនឹងការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខ[348] អង្គជំនុំជម្រះសាលាដំបូងមិនបានរំលោភវិធាន៩៨(២)នៃវិធានផ្ទៃក្នុងទេ ដោយដាក់បញ្ចូលធាតុផ្សំណាមួយពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅពេលមានការកំណត់សាជាថ្មីថាជាអំពើមនុស្សឃាតដោយចេតនាប្រយោល ចំពោះអង្គហេតុពាក់ព័ន្ធនឹងការស្លាប់មនុស្សបណ្តាលមកពីលក្ខខណ្ឌរស់នៅ និង/ឬលក្ខខណ្ឌការងារនៅទីតាំងទាំង៤។ ម្ចាស់បណ្តឹងសាទុក្ខផ្អែកដោយខុសឆ្គងលើការប្រៀបធៀបមិនទៀងទាត់លើធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតនិងការសម្លាប់រង្គាល ក្នុងសាលដីកាបណ្តឹងសាទុក្ខនៃសំណុំរឿង

---

346 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៥-១៥៧។

347 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥២-១៥៧ (គោលការណ៍នីត្យានុកូលភាព), ១១៩៤ (សហករណ៍ត្រាំកក់), ១៣៨៨ (ទំនប់ត្រពាំងថ្ម), ១៦៧២ (ទំនប់១មករា), ១៨០៤ (ព្រលានយន្តហោះកំពង់ឆ្នាំង)។ នៅក្នុងផ្នែកសម្រេចសេចក្តីនៃសាលក្រម សហព្រះរាជអាជ្ញា កត់សម្គាល់ថា អ.ជ.ស.ដ បានថ្លែងថាខ្លួនបានកំណត់បទចោទឡើងវិញនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់រង្គាលទៅជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត រួមមានចេតនាដោយប្រយោល ការស្លាប់មនុស្សដែលបានកើតឡើង "ដោយសារតែលក្ខខណ្ឌ និងកាលៈទេសៈដែលជនរងគ្រោះបានទទួល" នៅស-២១ និងមន្ទីរសន្តិសុខភ្នំក្រោល។ ប៉ុន្តែ នៅក្នុងផ្នែកផ្សេងទៀតនៃសាលក្រម អ.ជ.ស.ដ បានរកឃើញថាអង្គហេតុទាំងនោះ ត្រូវបានកំណត់បទចោទនៅក្នុងដីកាដំណោះស្រាយ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៥៦០-២៥៦១ (ស-២១), ២៨១១ (ក្រាំងតាចាន់), ៣១១៥ (ភ្នំក្រោល)។

348 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៦, ១៤៨-១៥២។

០០២/០១[349] ក្នុងការអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលបទចោទថ្មីជាមួយធាតុផ្សំថ្មី គឺចេតនាប្រយោល"[350]។

87. ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មុនពេលចេញសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០១[351] អង្គជំនុំជម្រះសាលាដំបូង[352] អង្គជំនុំជម្រះតុលាការកំពូល[353] និងជាពិសេស ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២របស់សហចៅក្រមស៊ើបអង្កេត[354] សុទ្ធតែបានយល់ធាតុអត្តនោម័តនៃបទសម្លាប់រង្គាលក្នុងការរួមបញ្ចូលចេតនាដោយប្រយោល។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ទើបអង្គជំនុំជម្រះតុលាការកំពូលបំភ្លឺបញ្ជាក់ថាធាតុអត្តនោម័តនៃការ សម្លាប់រង្គាលតម្រូវចេតនាផ្ទាល់ក្នុងការសម្លាប់[355]។ ដូច្នេះ នៅពេលសហចៅក្រមស៊ើបអង្កេត កំណត់ការស្លាប់ដោយសារលក្ខខណ្ឌនានានៅទីតាំងទាំង៤ថាជាការសម្លាប់រង្គាល សហចៅក្រមស៊ើបអង្កេតធ្វើការសន្និដ្ឋានអង្គហេតុពាក់ព័ន្ធទាំងអស់ដែលចាំបាច់ក្នុងការបំពេញ ធាតុផ្សំនៃអំពើមនុស្សឃាតក្នុងនោះរួមមានការសន្និដ្ឋានអង្គហេតុដែលចាំបាច់ក្នុងការសន្និដ្ឋានថា ចារីផ្ទាល់បានប្រព្រឹត្តដោយចេនាប្រយោល[356]។ ដោយទទួលស្គាល់ច្បាស់លាស់ចំណុចនេះ[357] អង្គជំនុំជម្រះសាលាដំបូងនៅតែស្ថិតនៅក្នុងព្រំដែនកំណត់នៃបណ្តឹង ដូចដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអនុវត្តការកំណត់បទចោទសាជាថ្មី។

---

[349] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៩-១៥៤ *ដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ ថាខណ្ឌ ៥១៦-៥២២។

[350] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២។

[351] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ ត្រូវបានប្រកាសនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។

[352] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី ឌុច កថាខណ្ឌ ៣៣៨។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៧-៤២០។

[353] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៣២៣។

[354] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៩។ សូមមើលផងដែរ ជើងទំព័រ ៥២៦៣ ដកស្រង់សាលក្រមរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៥៧២។ សាលក្រមរឿងក្តី *Stakić* កថាខណ្ឌ ៦៣៩ (*សូមមើល* កថាខណ្ឌ៦៤២)។ រឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៤៦។

[355] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥២២, ៥២៥។

[356] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១១-៣១៣ (សហករណ៍ត្រាំកក់), ៣៣៦-៣៤២ (សហករណ៍ត្រពាំងថ្ម), ៣៥៩៣៦០ (ទំនប់១មករា), ៣៩០-៣៩២ (ព្រលានយន្តហោះកំពង់ឆ្នាំង), ១៣៨៧, ១៣៨៩។

[357] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៣-១៥៤ (គោលការណ៍នីត្យានុកូលភាព), ១១៤៤ (សហករណ៍ត្រាំកក់), ១៣៨៨ (ទំនប់ត្រពាំងថ្ម), ១៦៧២ (ទំនប់១មករា), ១៨០៤ (ព្រលានយន្តហោះកំពង់ឆ្នាំង)។

88. អង្គជំនុំជម្រះសាលាដំបូងបានធានាថា ម្ចាស់បណ្តឹងសាទុក្ខបានទទួលការជូនដំណឹងអំពីលទ្ធភាពនៃការកំណត់បទល្មើសសាជាថ្មីនៅផ្អែកលើការសន្និដ្ឋានបទល្មើសសម្លាប់រង្គាលរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០១[358] ដើម្បីធានាថាគាត់បានទទួលដំណឹងពេញលេញអំពីលក្ខណៈនិងមូលហេតុនៃរឿងក្តីប្រឆាំងគាត់ និងអាចការពារក្តីប្រឆាំងនឹងបទចោទដែលបានផ្លាស់ប្តូរ[359]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ ការជូនដំណឹងនេះត្រូវបានផ្តល់ដោយសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ផ្ទាល់ ដែលក្នុងនោះអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការកំណត់បទចោទសាជាថ្មីដូចគ្នាបេះបិទ ក្រោយពីបញ្ជាក់ថា ធាតុអត្តនោម័តអនុវត្តចំពោះការសម្លាប់រង្គាលនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មានកម្រិតខ្ពស់ជាងធាតុអត្តនោម័តដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើនៅក្នុងសាលក្រមសំណុំរឿង០០២/០១ (និងផ្អែកដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២)។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ដោយច្បាស់លាស់ ចំពោះ*ភាគីដដែល* តំណាងដោយ*មេធាវីការពារក្តីដដែល* ពាក់ព័ន្ធនឹង*ដីកាដំណោះស្រាយដដែល* ជាពិសេសការស្លាប់ដែលបានកើតឡើងក្នុង*កាលៈទេសៈស្រដៀងគ្នា*ជាអាទិ៍ដោយសារលក្ខខណ្ឌនិងកាលៈទេសៈដែលដាក់លើជនរងគ្រោះ[360]ថា៖

> វាបើកទូលាយចំពោះ[អង្គជំនុំជម្រះសាលាដំបូង] ហើយក្នុងពេលនេះបានបើកទូលាយ [សម្រាប់អង្គជំនុំជម្រះតុលាការកំពូល] លើបណ្តឹងសាទុក្ខឱ្យកែប្រែប្រភេទបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ (D427) ដែល [សហចៅក្រមស៊ើបអង្កេត] បានចាត់ទុកថាជាបទសម្លាប់រង្គាលជាជាងបទមនុស្សឃាត[361]។

89. ម្ចាស់បណ្តឹងមិនអាចអះអាងគួរឱ្យជឿបានឡើយថា គាត់មិនបានទទួលដំណឹងអំពីការកំណត់បទចោទសាជាថ្មីដដែលនៅក្នុងសំណុំរឿង០០២/០២។

---

[358] មុនខែវិច្ឆិកា ឆ្នាំ២០១៦ មិនមានការតម្រូវឱ្យកំណត់បទចោទនៃអង្គហេតុទាំងហេតុឡើយ ដោយសារការយល់ឃើញជារួមថាធាតុផ្សំអត្តនោម័តិនៃការសម្លាប់រង្គាល រួមបញ្ចូលនូវចេតនាដោយប្រយោលផងដែរ។

[359] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៣-១៥៧ *សូមមើលផងដែរ* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤។ តុលាការសិទ្ធិមនុស្សអឺរ៉ុប មាត្រា៦ (៣)។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី *ឌុច* កថាខណ្ឌ ៤៩៧-៤៩៨ និងជើងទំព័រដែលទាក់ទង។ *សូមមើលផងដែរ* រឿងក្តី *Dallos តទល់នឹងប្រទេសហុងគ្រី* កថាខណ្ឌ ៤៧។ រឿងក្តី *Pélissier and Sassi តទល់នឹងប្រទេសបារាំង* កថាខណ្ឌ ៥១។ រឿងក្តី *Sipavičius តទល់នឹងលីទុយអានី* កថាខណ្ឌ ២៧។

[360] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៦។

[361] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៦២។

90. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខថាអង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចបន្ថែមទៀត ក្នុងការជូនដំណឹងបន្ថែមដល់គាត់ ទោះបីជាមានការថ្លែងច្បាស់លាស់បែបនេះពីអង្គជំនុំជម្រះតុលាការកំពូលក្ដី[362] គឺជាការភ័ន្តច្រឡំ។ ពុំមានលក្ខខណ្ឌតម្រូវពិសេសផ្លូវការអំពីរបៀបដែលជនជាប់ចោទត្រូវបានជូនដំណឹងអំពីលក្ខណៈនិងមូលហេតុនៃការចោទប្រកាន់ចំពោះគាត់ឡើយ[363]។ ជាងនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខមិនមែន "មិនអាចពិភាក្សាដេញដោល" លើការកំណត់ប្រភេទបទចោទសាជាថ្មីនោះទេ[364] ឬដើម្បីការពារខ្លួនប្រឆាំងនឹងបទចោទមនុស្សឃាតដោយរួមបញ្ចូលធាតុអត្តនោម័តទាបជាងនោះឡើយ[365]។ ជាការពិតណាស់ ស្ទើរតែពេញអំឡុងពេលនៃការជំនុំជម្រះ ម្ចាស់បណ្ដឹងសាទុក្ខបានយល់ថាគាត់កំពុងការពារទល់នឹងបទចោទសម្លាប់រង្គាល ដែលកំណត់ថារួមបញ្ចូលធាតុអត្តនោម័តនៃចេតនាប្រយោល។ ម្ចាស់បណ្ដឹងសាទុក្ខសម្រេចធ្វើមិនដឹងមិនឮចំពោះការជូនដំណឹងរបស់អង្គជំនុំជម្រះតុលាការកំពូល និងខកខានចំពោះឱកាសដែលផ្ដល់ជូនគាត់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការដាក់សារណានិងស្នើការបំភ្លឺក្រោយពេលចេញសាលដីកាបណ្ដឹងសាទុក្ខក្នុងសំណុំ០០២/០១[366]។

91. បើទោះជាអង្គជំនុំជម្រះតុលាការកំពូលគិតថាសាលដីកាក្នុងសំណុំរឿង០០២/០១ ពុំមានការជូនដំណឹងគ្រប់គ្រាន់អំពីលទ្ធភាពនៃការកំណត់បទចោទសាជាថ្មីក៏ដោយ ក៏ម្ចាស់បណ្ដឹងសាទុក្ខមានកំហុសឆ្គងដែលតវ៉ាថាកំហុសឆ្គងនីតិវិធី "ធ្វើឱ្យអសុពលភាពដល់សេចក្ដីសម្រេចនោះ"[367]។ ដោយវាយតម្លៃពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីទាំងមូល[368] ក្នុងនោះរួមមានវិធានការដែលត្រូវបានអនុវត្តនៅក្នុងដំណាក់កាលបណ្ដឹងសាទុក្ខ[369] គឺពុំមាន "លទ្ធផលមិនយុត្តិធម៌ទាំងស្រុងនៅក្នុងកិច្ច

---

[362] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៦, ១៣៨-១៤៧, ១៥៦-១៥៧។

[363] រឿងក្ដី *Dallos តទល់នឹងប្រទេសហុងគ្រី* កថាខណ្ឌ ៤៧។ រឿងក្ដី *Pélissier and Sassi តទល់នឹងប្រទេសបារាំង* កថាខណ្ឌ ៥៣។ រឿងក្ដី *Sipavičius តទល់នឹងប្រទេសលីទុយអានី* កថាខណ្ឌ២៨។

[364] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៥។

[365] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៩-១៤៧, ១៥៣-១៦៤, ១៥៧។

[366] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៧ *យោងទៅលើ* ឯកសារ **E449** អនុស្សរណៈរបស់ អ.ជ.ស.ដ កថាខណ្ឌ ៤។

[367] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៥, ១៥៥, ៦៧២, ៧៥៨, ៧៦៨, ៨១៤។

[368] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០។រឿងក្ដី *Dallos តទល់នឹងប្រទេសហុងគ្រី* កថាខណ្ឌ ៤៧។ រឿងក្ដី *Pélissier and Sassi តទល់នឹងប្រទេសបារាំង* កថាខណ្ឌ ៥៣។ រឿងក្ដី *Sipavičius តទល់នឹងប្រទេស លីទុយអានី* កថាខណ្ឌ ២៧។

[369] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០។ រឿងក្ដី *Dallos តទល់នឹងប្រទេសហុងគ្រី* កថាខណ្ឌ ៤៩, ៥២។ រឿងក្ដី *Sipavičius តទល់នឹងប្រទេសលីទុយអានី* កថាខណ្ឌ ៣០។

ដំណើរការនីតិវិធីរបស់តុលាការ”ឡើយ[370]។ ដំណើរការបណ្តឹងសាទុក្ខនេះបានផ្តល់ម្ចាស់បណ្តឹងសាទុក្ខនូវឱកាសក្នុងការការពារក្តីប្រឆាំងនឹងបទចោទ ដែលត្រូវបានកែប្រែនៅចំពោះមុខអង្គតុលាការដែលមានសមត្ថភាពពិនិត្យឡើងវិញ និងបដិសេធការចោទប្រកាន់នានាដែលរងការជំទាស់។ ម្ចាស់បណ្តឹងសាទុក្ខបានដាក់រួចហើយ ដើម្បីជូនអង្គជំនុំជម្រះតុលាការកំពូលពិនិត្យមូលដ្ឋានបណ្តឹងសាទុក្ខដោយតវ៉ាទិដ្ឋភាពច្បាប់ និងអង្គហេតុជាសារធាតុនៃការចោទប្រកាន់ពីបទមនុស្សឃាតពោលគឺគាត់តវ៉ាចំពោះស្ថានភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈមនុស្សឃាត ដែលប្រព្រឹត្តដោយចេតនាប្រយោល[371] និងតវ៉ាមូលដ្ឋានអង្គហេតុនៃការចោទប្រកាន់បទមនុស្សឃាតនៅទីតាំងទាំង៤ ក្នុងនោះរួមមានការអះអាងដែលថាបទដ្ឋានចេតនាប្រយោលមិនត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ[372]។ ហេតុដូច្នេះ វិការៈណាមួយនៅក្នុងការខកខានក្នុងការជូនដំណឹងតាមលក្ខខណ្ឌតម្រូវអាចត្រូវបានដោះស្រាយ ដោយការបញ្ជាក់លើការចោទប្រកាន់ អនុលោមតាមការពិនិត្យរបស់អង្គជំនុំជម្រះនេះ[373]។

## គ. ឥទ្ធិពលត្រួតគ្នានៃការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌តាមការចោទប្រកាន់

92. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងឥទ្ធិពលត្រួតគ្នានៃការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌តាមការចោទប្រកាន់គឺមិនត្រឹមត្រូវទេ[374]។ ដូចដែលបានបង្ហាញរួចហើយ

---

[370] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០។

[371] *សូមមើល* មូលដ្ឋានទី ៨៦ នៃបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៧៥-៦៣៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៤ (ភាសាអង់គ្លេស) ទំព័រ ៣១ (ភាសាបារាំង) ទំព័រ ៤៨ (ភាសាខ្មែរ)។ សូមមើលផងដែរឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ៣៩៤-៤២៩។ស

[372] ពាក់ព័ន្ធនឹងការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងការបំពេញលក្ខខណ្ឌសម្រាប់ធាតុផ្សំអត្តនោម័តិសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត *សូមមើល* មូលដ្ឋាននៃបណ្តឹងសាទុក្ខ មូលដ្ឋានទី ៨៧, ១០០, ១០២ (ត្រាំកក់), ៨៨, ១១៣ (ទំនប់ត្រពាំងថ្ម), ៨៩, ១១៧ (ទំនប់១មករា), ៩០, ១២៣ (ព្រលានយន្តហោះកំពង់ឆ្នាំង)។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨៣-៦៨៥ (ត្រាំកក់), ៧៦០-៧៦២ (ទំនប់ត្រពាំងថ្ម), ៧៨៣-៧៨៦ (ទំនប់១មករា), ៨២២-៨២៤ (ព្រលានយន្តហោះកំពង់ឆ្នាំង)។.

[373] រឿងក្តី *Dallos* *តទល់នឹងប្រទេសហុងគ្រី* កថាខណ្ឌ ៥០-៥២។ រឿងក្តី *Sipavičius* *តទល់នឹងប្រទេសលីទុយអានី* កថាខណ្ឌ ៣០-៣៣។

[374] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧, ៣៣១-៣៣៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៧ (ភាសាអង់គ្លេស)។

ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ការរំលោភណាមួយទៅលើសិទ្ធិណាមួយ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូច្នេះ ពុំមានការបំពានដែលត្រូវតត្រូវឡើយ។ សិទ្ធិរបស់គាត់ទាំងអស់ត្រូវបានការពារ៖ (i) ទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេលមិនសមស្រប[375] (ii) ទទួលមានការជំនុំជម្រះដោយតុលាការដែលគោរពវិសាលភាពនៃយុត្តាធិការ និងដែលបង្កើតឡើងដោយច្បាប់[376] (iii) ទទួលបានការជូនដំណឹងអំពីលក្ខណៈនិងមូលហេតុនៃបទចោទប្រឆាំងនឹងគាត់[377] (iv) សច្ចភាពគតិយុត្តនិងនីតិវិធី[378] (v) តុលាការឯករាជ្យនិងមិនលម្អៀង[379] (vi) សច្ចធារណ៍នៃនិរទោស[380] (vii) មានពេលវេលានិងមធ្យោបាយសមស្របក្នុងការការពារក្តី[381] (viii) ការជំនុំជម្រះក្តីតទល់[382] (ix) ទទួលបានការជំនុំជម្រះ[383] (x) មានការការពារក្តីប្រកបដោយប្រសិទ្ធភាព[384] (xi) តម្លាភាពនៃកិច្ចដំណើរការនីតិវិធី[385] (xii) សេចក្តីសម្រេចដែលមានសំអាងហេតុ និងសាលក្រម ដែលមានសំអាងហេតុ[386] (xiii) សមភាពនៃមធ្យោបាយតទល់ក្តី[387] (xiv) មិនត្រូវបានកាត់សេចក្តី ឬផ្តន្ទាទោសជាថ្មីម្តងទៀត ចំពោះបទល្មើសដែលគាត់ត្រូវបានផ្តន្ទាទោសស្ថាពរ ឬលើកលែងចោទប្រកាន់រួចហើយ[388]។

93. នៅក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានផ្តល់ភ័ស្តុតាងគាំទ្រដល់ការអះអាងរបស់ខ្លួន ដោយពុំមានការពន្យល់ថាតើ "ឥទ្ធិពលត្រូវតគ្នានៃកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលា

[375] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៨, ៩, ១០។

[376] *សូមមើល* ផ្នែកទី៤ បណ្តឹង និងវិសាលភាពនៃការជំនុំជម្រះក្តី។

[377] *សូមមើល* ផ្នែកទី៤ បណ្តឹង និងវិសាលភាពនៃការជំនុំជម្រះក្តី និង ចម្លើយតបទៅនឹងមូលដ្ឋានទី ៦, ៨។

[378] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១, ៨,៩។

[379] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៤, ១៤, ១៧, ២៦-២៧, ១៦៣, ១៦៥-១៦៧, ១៧៣, ១៧៤-១៧៩, ១៨១, ១៨៣, ១៨៥, ១៨៩, ១៨៩, ១៩៩, ២០២-២០៣, ២០៧, ២១៨, ២២, ២៣៦។

[380] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៨។

[381] *សូមមើល* ផ្នែកទី៤.ខ.២ វិសាលភាពនៃរឿងក្តី៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ចម្លើយតបទៅនឹងមូលដ្ឋានទី ៨។

[382] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៨, ៣០, ១៥១, ១៦៣។

[383] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១, ៧។

[384] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១។

[385] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១, ៦។

[386] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១. ៧។

[387] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៧, ១៣១។

[388] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៥, ៨៣, ១៥០។

ដំបូងបានធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃការជំនុំជម្រះក្តីរបស់គាត់នៅក្នុងរបៀបដែលខុសគ្នាពីកត្តាមួយទៅកត្តាមួយយ៉ាងដូចម្តេច” ឡើយ[389]។

## V. វិធីសាស្ត្រលើភស្តុតាង

### ក. សេចក្តីផ្តើម

94. អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តវិធីសាស្ត្រត្រឹមត្រូវក្នុងការវាយតម្លៃភស្តុតាង[390]។ មូលដ្ឋានទាំង ២៥ របស់ម្ចាស់បណ្តឹងសាទុក្ខ[391] ដែលតវ៉ានឹងវិធីសាស្ត្រនេះពុំទទួលផលឡើយ ដោយហេតុថាគាត់ប្រកាន់យកការវិភាគមួយចំណែកៗនៅក្នុងការពិភាក្សាលើភស្តុតាង ដែលជាញឹកញយបកស្រាយមិនត្រឹមត្រូវចំពោះការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង និងភស្តុតាង។ គាត់ថែមទាំងមិនអើពើលក្ខណៈពិសេសដ៏សំខាន់នៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ក្នុងនោះរួមមាន៖ កាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើភស្តុតាងទាំងមូល និងកំណត់ទម្ងន់ភស្តុតាង, ការសន្មត់ថាអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងទាំងអស់, មេធាវីការពារក្តីបាន ផ្តល់ការវាយតម្លៃទូទៅលើភស្តុតាង ក្នុងនោះរួមមានសក្ខីកម្មរបស់សាក្សីដែលខ្លួនមានឱកាសសង្កេតការប្រព្រឹត្តរបស់ពួកគេ, ការដោះស្រាយលើអសង្គតិភាពនៃភស្តុតាងនិងជម្លោះ និងការកំណត់របស់ខ្លួនពាក់ព័ន្ធនឹងភាពអាចជឿទុកចិត្តបាននៃភស្តុតាងទាំងមូល, ការគោរពចំពោះឆន្ទានុសិទ្ធិដែលខ្លួនប្រើ ដើម្បីទទួលឬបដិសេធលក្ខណៈពិសេសដ៏សំខាន់នៃភស្តុតាងដោយគ្មានកាតព្វកិច្ចផ្តល់យុត្តិកម្មលើការកំណត់នោះ, និងថាមិនមែនអង្គហេតុទាំងអស់ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។ ម្ចាស់បណ្តឹងសាទុក្ខ ថែមទាំងមិនបង្ហាញកំហុសឆ្គងណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវការការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល[392]។

---

[389] សាលដីការឿងក្តី *Renzaho* កថាខណ្ឌ ២៥៤។ សហព្រះរាជអាជ្ញា កត់សម្គាល់បន្ថែមទៀតថា នៅពេលដែលវិការៈដែលបានលើកឡើង ត្រូវបានកែតម្រូវរួចហើយ ឬមិនបង្កឱ្យមានព្យសនកម្មទេនោះ បញ្ហានៃចំនួនវិការៈ គ្រាន់តែជាបញ្ហាបន្ទាប់បន្សំ។ បញ្ហាដែលសំខាន់គឺថាតើអានុភាពត្រួតគ្នានៃកំហុសទាំងនោះ បានបង្កព្យសនកម្មច្រើនដល់ម្ចាស់បណ្តឹង សាទុក្ខដែរឬទេ។ សាលដីការឿងក្តី *Nyiramasuhuko* កថាខណ្ឌ ១២៧៧។

[390] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥-១០៩។

[391] មូលដ្ឋានទី ១១-១៣, ១៥-១៩, ២០-២២, ២៤-៣៧។

[392] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់, កំហុសអង្គហេតុ)។

## ខ. បន្ទុកនៃភស្តុតាង

### *មូលដ្ឋានទី ១៣៖ ជំនឿឥតស្សេរចិត្ត និងជំនឿហួសពីវិមតិសង្ស័យ*[393]

95. **មូលដ្ឋានទី ១៣ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានកំណត់ ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយអនុវត្តបទដ្ឋានភស្តុតាងទាបជាងវិមតិ សង្ស័យ។ ការចោទប្រកាន់របស់គាត់ដែលមានលក្ខណៈប្រទាក់ក្រឡាដែលថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គង ដោយទាញសេចក្ដីសន្និដ្ឋានមិនសមហេតុផលតាមរយៈកំហុសភស្តុតាងគួរតែត្រូវបដិសេធភ្លាមៗ ដោយហេតុថាគ្រាន់តែជាការអះអាងដែលគាត់មិនបានផ្ដល់ភស្តុតាងគាំទ្រ។**

96. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខមិនបង្ហាញកំហុសនៅក្នុងការពិភាក្សាអំពីជំនឿឥតស្សេរចិត្តនិងភស្តុតាងហួសពីវិមតិសង្ស័យ។ ទីមួយ ម្ចាស់បណ្ដឹងសាទុក្ខទទួលស្គាល់ថាអង្គជំនុំជម្រះសាលាដំបូង "រំឭកឡើងវិញយ៉ាងត្រឹមត្រូវ" ថាភស្តុតាងហួសពីវិមតិសង្ស័យគឺជាបទដ្ឋានដែលត្រូវតែអនុវត្ត[394]។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងថ្លែងយ៉ាងត្រឹមត្រូវនូវភាសាពាក់ព័ន្ធនឹងបទដ្ឋាននៃភស្តុតាងទាំងជាភាសាអង់គ្លេសនិងភាសាបារាំងនៅក្នុងវិធានផ្ទៃក្នុង[395] រួចហើយបំភ្លឺបញ្ជាក់ថាខ្លួននឹងប្រើបទដ្ឋានភស្តុតាងហួសពីវិមតិសង្ស័យ[396]។ ទីបី ក្រៅពីការពិភាក្សារបស់ខ្លួននៅក្នុងកថាខណ្ឌ ៣៨-៤០ អង្គជំនុំជម្រះសាលាដំបូងពុំប្រើពាក្យ "ជំនឿឥតស្សេរចិត្ត" ក្នុងសំណៅភាសាបារាំងនៅក្នុងសាលក្រមក្នុងការយោងដល់បទដ្ឋានភស្តុតាង ដែលខ្លួនបានអនុវត្ត

---

[393] <u>មូលដ្ឋានទី ១៣</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ជំនឿឥតស្សេរចិត្ត និងជំនឿហួសពីវិមតិសង្ស័យ* កថាខណ្ឌ ២២៧-២៣១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៩ (ភាសាអង់គ្លេស) ទំព័រ ៨ (ភាសាបារាំង) ទំព័រ ១១-១២ (ភាសាខ្មែរ)។

[394] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២២៩។

[395] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨ *ដកស្រង់* វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង សំណៅជាភាសាអង់គ្លេស ក្នុងផ្នែកដែលពាក់ព័ន្ធ៖ "In order to convict, the Chamber must be convinced of an Accused's guilt 'beyond reasonable doubt'."។ សំណៅជាភាសាបារាំង ក្នុងផ្នែកដែលពាក់ព័ន្ធ៖ "*Pour déclarer un accusé coupable, la Chambre doit avoir 'l'intime conviction' de sa culpabilité*"។ សំណៅជាភាសាខ្មែរ ក្នុងផ្នែកដែលពាក់ព័ន្ធ៖ "ដើម្បីផ្ដន្ទាទោសជនចាប់ចោទ អង្គជំនុំជម្រះសាលាដំបូង ត្រូវមានជំនឿ "ដោយគ្មានវិមតិសង្ស័យ" អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។(គូសបញ្ជាក់បន្ថែម)។

[396] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨ (ភាសាអង់គ្លេស) ("បន្ទាប់ពីបានវាយតម្លៃទៅលើភស្តុតាងដែលមានសំអាងហេតុរួច អង្គជំនុំជម្រះ នឹងបកស្រាយវិមតិសង្ស័យដោយផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទ។")។ (ភាសាបារាំង) ("*Ainsi, se fondant sur une analyse raisonnée des éléments de preuve, elle a interprété tout doute quant à la culpabilité des Accusés en faveur de ces derniers*") (គូសបញ្ជាក់បន្ថែម)។

ឡើយ[397]។ ផ្ទុយទៅវិញ នៅក្នុងសាលក្រមជាភាសាបារាំងទាំងមូល អង្គជំនុំជម្រះសាលាដំបូងប្រើពាក្យដែលមានសង្គតិភាពជាមួយភស្តុតាងហួសពីវិមតិសង្ស័យ[398]។

97. ដូចដែលគាត់អនុវត្តនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ទាំងមូល ម្ចាស់បណ្តឹងសាទុក្ខធ្វើឱ្យប្រទាក់ក្រឡាគ្នាជាមួយសារណាដទៃទៀតនៅក្នុងមូលដ្ឋាននៃបណ្តឹងសាទុក្ខនេះ ក្នុងនោះរួមមានចំណុចដែលថាអង្គជំនុំជម្រះសាលាដំបូងបានទាញសេចក្តីសន្និដ្ឋានមិនសមហេតុផល និងប្រព្រឹត្តកំហុសភស្តុតាង[399]។ ក្រៅពីថ្លែងថាសារណាទាំងនេះនឹងត្រូវ "បង្ហាញនៅខាងក្រោមនៅក្នុងសេចក្តីសង្ខេបកំហុសអង្គហេតុ" ម្ចាស់បណ្តឹងសាទុក្ខពុំយោងដល់កថាខ័ណ្ឌនាននៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ឡើយ[400] ដែលធ្វើឱ្យខ្លួនពុំមានលទ្ធភាពក្នុងការឆ្លើយតបដោយផ្ទាល់ទៅនឹងការចោទប្រកាន់គ្មានភស្តុតាងទាំងនេះ។ ការយោងរបស់គាត់ដល់ទស្សនៈជំទាស់នៅក្នុងរឿងក្តី Katanga[401] ក៏មិនបង្កើតកំហុសដែលបានចោទប្រកាន់ទាំងនេះដែរ។ "ការត្រឹមតែអះអាង" ទាំងនេះគួរតែត្រូវ

[397] ក្រៅពីការពិភាក្សានៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨-៤០ (ភាសាបារាំង) (ពាក្យថា "ជំនឿដោយឥស្សរចិត្ត" ត្រូវបានរកឃើញតែម្តងប៉ុណ្ណោះនៅក្នុងសាលក្រម ក្នុងកថាខណ្ឌ ១៨៨៧ ប៉ុន្តែមិនយោងទៅលើបទដ្ឋាននៃការបង្ហាញភស្តុតាងពាក់ព័ន្ធនឹង*ការជឿជាក់ដោយខ្លួនឯង*ឡើយ)៖ "Même en admettant qu'un tel plan ait existé ou que les dirigeants du PCK ait eu *l'intime conviction* de son existence, la Chambre considère que cela ne saurait justifier l'exécution généralisée à S-21, en dehors de toutes garanties procédurales, de cadres et de civils au motif pris de ce qu'ils auraient participé à la préparation ou à la mise en œuvre de ce plan.") (គូសបញ្ជាក់បន្ថែម)។ កថាខណ្ឌ ១៨៨៧ (ភាសាអង់គ្លេស) ("ទោះបីជាមានផែនការបែបនេះ ឬប្រសិនបើមេដឹកនាំ ប.ក.ក. *ជឿជាក់ដោយខ្លួនឯងថា* ផែនការនោះមានអត្ថិភាពក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា អត្ថិភាពនៃផែនការបែបនេះ ឬត្រឹមតែការជឿថា ផែនការដែលមានអត្ថិភាពបែបនេះ មិនអាចជាយុត្តិកម្មចំពោះការសម្លាប់កម្មាភិបាល និងជនស៊ីវិលនៅ ស-២១ ក្រោមការចោទប្រកាន់ថាពួកគេជាប់ពាក់ព័ន្ធក្នុងការរៀបចំ ឬការអនុវត្តផែនការនេះ ដោយមិនបានឆ្លងកាត់ដំណើរការនីតិវិធីច្បាប់ត្រឹមត្រូវនោះទេ។") (គូសបញ្ជាក់បន្ថែម)។

[398] អ.ជ.ស.ដ បានប្រើឃ្លា "*au-delà de tout doute raisonnable*", ឧទាហរណ៍នៅក្នុង ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ (ភាសាបារាំង) កថាខណ្ឌ ៣៨, ៤០, ៧៤, ២៨៧, ៣៣៦, ៣៣៧, ៥៥១, ៦២៨, ១២២២, ១៤២៣, ១៥៧៥, ១៦៥៣, ១៦៦៧, ១៦៨៤,១៧៥៨, ១៧៨០-១៧៨១, ១៧៨៦, ១៧៩២, ១៨៤១, ២៣៤៧, ២៣៧៥, ២៤០១, ២៥៣១, ២៥៦៣, ២៧៤៩,២៨១៩-២៨២០, ២៨៩៦, ២៩២៧, ២៩២៦, ៣០១៥-៣០១៨, ៣០៧៥, ៣១០៨, ៣១១៨, ៣១៧៤, ៣២១១, ៣៣២១, ៣៣៦៧, ៣៤១៦, ៣៤៣៩, ៣៤៦៤, ៣៤៧១, ៣៤៨២, ៣៤៩១, ៣៤៩៩, ៣៥០៥, ៣៥១០, ៤០៧៦, ៤១៥៦, ៤១៩២។ "*il ne fait aucun doute*" ឧទាហរណ៍នៅក្នុងកថាខណ្ឌ ៥៦១, ៦២៨, ៦៥១, ៩៣៨, ៩៤៦ (ភាសាបារាំង)។

[399] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២២៩-៣២១។

[400] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២២៩។

[401] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៣០ *ដកស្រង់* មតិជំទាស់របស់ចៅក្រម Wyngaert ក្នុងរឿងក្តី *Katanga* កថាខណ្ឌ ១៧២។

បានបដិសេធភ្លាមៗ ដោយហេតុថាគ្មានភស្តុតាងគាំទ្រ[402]។ ទោះបី "ការអះអាង" មិនកំណត់ច្បាស់ទាំងនេះត្រូវបានពង្រីកគ្រប់គ្រាន់ នៅក្នុងផ្នែកដទៃទៀតនៃសារណាបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខក៏ដោយ ក៏ប៉ុន្តែការអះអាងទាំងនេះនឹងត្រូវបានលើកឡើងនៅក្នុងផ្នែកដទៃៗទៀតនៃចម្លើយតបនេះ[403]។

## *មូលដ្ឋានទី ១៧៖ បន្ទុកនៃភស្តុតាង*[404]

98. **មូលដ្ឋានទី ១៧ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយលើកឡើងផ្ទុយនឹងខ្លួនឯង នៅក្នុងសំអាងហេតុពាក់ព័ន្ធនឹងបន្ទុកនៃភស្តុតាងនិងមិនគោរពការណ៍ដែលថាបន្ទុកនៃភស្តុតាងស្ថិតនៅលើស្ថាប័នអយ្យការ។ មូលដ្ឋាននេះក៏ខកខានមិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃភស្តុតាងមិនគ្រប់គ្រាន់ផងដែរ។**

99. មូលដ្ឋានដែលពុំមានការបញ្ជាក់ច្បាស់ មិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងគ្រាន់តែអះអាងដោយគ្មានភស្តុតាងគាំទ្រថា អង្គជំនុំជម្រះសាលាដំបូងលើកបន្ទុកភស្តុតាងពីអយ្យការទៅឱ្យមេធាវីការពារក្តីវិញ។ គាត់មិនពន្យល់ថាអង្គជំនុំជម្រះសាលាដំបូងថ្លែងផ្ទុយនឹងខ្លួនឯងឡើយក្នុងការអនុវត្តបន្ទុកនៃភស្តុតាង ។ ឧបសម្ព័ន្ធក ពុំយោងសំអាងដល់កថាខ័ណ្ឌណាមួយឡើយនៅក្នុងសារណារបស់គាត់ ប៉ុន្តែត្រឹមតែយោងសំអាងដល់ "ផ្នែកអង្គហេតុខាងក្រោម"។ នៅក្នុងផ្នែកដែលពាក់ព័ន្ធក្នុងសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ កថាខ័ណ្ឌ២៣៧ ពេលនោះគាត់គ្រាន់តែយោងបន្ថែមដល់កថាខ័ណ្ឌទី១៤២១នៅក្នុងសារណាបណ្តឹងសាទុក្ខ ដែលមិននិយាយដល់កំហុសដែលបានសន្មត់ពាក់ព័ន្ធនឹងបន្ទុកភស្តុតាងឡើយ។ ហើយកថាខ័ណ្ឌផ្សេងៗទៀតដែលគាត់លើកមកសំអាងនៅក្នុងកថាខ័ណ្ឌទី១៤២១ក៏ពុំយោងដល់កំហុសឆ្គងពាក់ព័ន្ធនឹងបន្ទុកភស្តុតាងដែរ[405]។

100. ផ្ទុយទៅវិញ កថាខ័ណ្ឌ១៤២១ នៃបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹង និង កថាខ័ណ្ឌខណ្ឌដែលបានយោងនៅក្នុងនោះ លើកទឡ្ហីករណ៍ដោយមិនត្រឹមត្រូវថាការចោទថាអង្គជំនុំជម្រះសាលាដំបូង

[402] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (ការបដិសេធដោយពុំចាំបាច់ពិចារណាបន្តទៀត)។

[403] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៥។

[404] <u>មូលដ្ឋានទី ១៧៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *បន្ទុកភស្តុតាង* កថាខណ្ឌ ២៣៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១០-១១ (ភាសាអង់គ្លេស) ទំព័រ ៩-១០ (ភាសាបារាំង) ទំព័រ ១៣ (ភាសាខ្មែរ)។

[405] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២១ ជើងទំព័រ ២៦៧៥ *ដកស្រង់*កថាខណ្ឌ ១៧២៣-១៧២៨ របស់ខ្លួន។

វាយតម្លៃមិនត្រឹមត្រូវលើភស្តុតាងតម្រូវឱ្យមានអន្តរាគមន៍បណ្តឹងសាទុក្ខ។ នៅក្នុងកថាខ័ណ្ឌទី ១៤២១ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងថាម្ចាស់បណ្តឹងសាទុក្ខថ្លែងសុន្ទរកថានៅក្នុងសម័យប្រជុំសភាតំណាងប្រជាជនលើកដំបូងចន្លោះថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦[406]។ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមិនតម្រូវឱ្យមានអន្តរាគមន៍បណ្តឹងឧទ្ធរណ៍ឡើយដោយហេតុថាវាពុំមានឥទ្ធិពលលើសាលក្រមទេ។

101. ម្ចាស់បណ្តឹងសាទុក្ខមិនអើពើចំពោះសំអាងហេតុគ្រប់ជ្រុងជ្រោយ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានធ្វើមុនពេលសន្និដ្ឋានថាគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់ ដោយមាន ៩០ ទំព័រនិងរួមទាំងការពិចារណាទៅលើតួនាទី និងមុខងាររបស់ម្ចាស់បណ្តឹងសាទុក្ខ ការដឹង និងការទទួលខុសត្រូវរបស់គាត់ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួមនិងទម្រង់នៃការទទួលខុសត្រូវ ការជួយនិងជំរុញ ដែលទាំងអស់នេះប្រមូលបានពីប្រភពភស្តុតាងនានា[407]។ ហេតុដូច្នេះ ការដកចេញសេចក្តីសន្និដ្ឋានមួយនេះពុំអាចធ្វើឱ្យអសុពលដល់ការសន្និដ្ឋាន និងការចោទប្រកាន់ទាំងនោះឡើយ។

102. ការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងកថាខ័ណ្ឌទី១៧២៣ ថាដើម្បីដាក់ឱ្យម្ចាស់បណ្តឹងទទួលខុសត្រូវ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើការចូលរួមរបស់គាត់នៅក្នុងមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨ "ដោយគ្មានភស្តុតាងបង្ហាញអំពីវត្តមានរបស់គាត់" គឺជាការនាំឱ្យខុសនិងមិនពិត[408]ការនាំខុសសម្រាប់ហេតុផលដែលពិភាក្សានៅក្នុងកថាខណ្ឌ ១០១ ខាងលើ និងមិនពិត នៅក្នុងការណ៍ដែលថាសក្ខីកម្មរបស់សៅសារុន ដែលម្ចាស់បណ្តឹងយោងនៅក្នុងកថាខ័ណ្ឌ១៧២៥[409] គឺពិតជាផ្តល់ការសន្និដ្ឋានសមហេតុផលដែលថាម្ចាស់បណ្តឹងមានវត្តមាននៅក្នុងមហាសន្និបាតបក្សក្នុងឆ្នាំ១៩៧៨[410]។ ចំពោះមហាសន្និបាតបក្សលើកទី៤ អ្វី

---

[406] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២១។ ម្ចាស់បណ្តឹងសាទុក្ខ លើកឡើងវិញនូវការចោទប្រកាន់នេះនៅក្នុងឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩, ២៣៧ (ជើងទំព័រ ៣២៨), ១៦៩៩-១៧០០។ សូមមើលចម្លើយតបទៅនឹងមូលដ្ឋានទី ៧, ១៤, ១៧៦, ២០២។

[407] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦២-៦២៤ (តួនាទី និងមុខងាររបស់ខៀវ សំផន)។ កថាខណ្ឌ ៤២០១-៤៣២៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន)។

[408] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧២៣។ ការចោទប្រកាន់នេះ ក៏ត្រូវបានលើកឡើងផងដែរនៅក្នុងឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១៨, ១៧៤១, ១៧៥០។

[409] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ៣៣៣៩-៣៣៤១។

[410] ឯកសារ E1/84.1 សៅ សារុន, ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 09.48.02-09.49.24 ទំព័រ ១៨ បន្ទាត់ ២២ ("ក្នុងពេលធ្វើបុណ្យខួបបក្ស ប្រហែលជាខែ៩ ក្នុងឆ្នាំ៧៨") (គូសបញ្ជាក់បន្ថែម)។ ម៉ោង 09.51.04-09.52.48 ទំព័រ ២០ បន្ទាត់

ដែលមានសារៈសំខាន់គឺម្ចាស់បណ្តឹងក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម នៅក្នុងឆ្នាំ១៩៧៦ នៅពេលមហាសន្និបាតនោះ[411]។ ម្ចាស់បណ្តឹងសាទុក្ខបានយល់ព្រមថាគាត់ក្លាយជាសមាជិកពេញសិទ្ធិនៅក្នុងឆ្នាំ១៩៧៦[412]។ ការផ្តល់ឋានៈបែបនេះដល់គាត់នៅក្នុងមហាសន្និបាតគឺស្របនឹងតួនាទីរបស់ខ្លួន ពោលគឺ "ការកំណត់មាគ៌ានយោបាយនិងលក្ខន្តិកៈ" របស់បក្ស និងជ្រើសរើស និងចាត់តាំងសមាជិកនៃគណៈកម្មាធិការមជ្ឈិម"[413]។ មានហេតុផលក្នុងការសន្និដ្ឋានថាគាត់មានវត្តមាននៅក្នុងកិច្ចប្រជុំបែបនេះ ដែលឋានៈរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិមត្រូវបានតម្លើង។

103. ដូចគ្នានេះដែរ ការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងមិនរាប់បញ្ចូលចម្លើយរបស់គាត់ថា មានមហាសន្និបាតបក្សចំនួនតែ ៣ ប៉ុណ្ណោះ ដោយមិនរាប់មហាសន្និបាតនៅក្នុងឆ្នាំ១៩៧៨[414] គឺមិនអើពើដល់ភ័ស្តុតាងរបស់ សៅ សារុន និងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកតែមួយផ្នែកនៃសក្ខីកម្មរបស់សាក្សីម្នាក់។

104. ចំណុចចុងក្រោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលហាក់ដូចជាចោទថាចៅក្រមអង្គជំនុំជម្រះសាលាដំបូងមានការលំអៀងឬដោយអសុចិត្ត[415] គឺពុំមានភ័ស្តុតាងគាំទ្រឡើយ និងត្រូវតែបដិសេធ។ ដោយសារ "ការអះអាង" ទាំងនេះមានច្រើនគ្រប់គ្រាន់នៅក្នុងផ្នែកផ្សេងៗទៀតនៃ

៤-៥ ("ចំណែកអ្នកចូលរួមបិទ និងបើកវគ្គ មាន [...] ខៀវ សំផន")។ ម៉ោង 09.54.42-09.56.12 ទំព័រ ២១ បន្ទាត់ ១១-១៦ ("សន្និបាតហ្នឹងជាងដប់ថ្ងៃ [...] សន្និបាតធំមានតំណាងគ្រប់ខេត្តចូលរួម")។ ម៉ោង 09.57.19-09.59.07 ទំព័រ ២២ បន្ទាត់ ២៥ (សមាជិកគណៈមជ្ឈិមត្រូវបានអញ្ជើញឱ្យឡើងលើវេទិកា)។ ម៉ោង 09.59.07-10.01.05 ទំព័រ ២៣ បន្ទាត់ ៧ (សាក្សីស្ថិតនៅចម្ងាយប្រហែល១០ម៉ែត្រពីវេទិកា)។ ម៉ោង 10.02.58-10.04.32 ទំព័រ ២៤ បន្ទាត់ ១០-២១ (សាក្សីបញ្ជាក់ថាសមាជិក ប.ក.ក ទាំងអស់ រួមមាន ប៉ុល ពត, ខៀវ សំផន, នួន ជា, អៀង ធីរិទ្ធិ និងអៀង សារី ព្រមទាំងតំណាងមកពីខេត្ត និងកងពលធំទាំងអស់ បានចូលរួមក្នុងមហាសន្និបាត)។

[411] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៧៤ ជាពិសេស ជើងទំព័រ ១៧៨៩។

[412] *សូមមើលឧទាហរណ៍* ឯកសារ **E3/27** កំណត់ហេតុសួរចម្លើយ ខៀវ សំផន EN 00156751។

[413] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥។

[414] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧២៦។ ពាក់ព័ន្ធនឹងការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខចំពោះពាក្យផ្សេងទៀតដែលបានប្រើដើម្បីពិពណ៌នាសន្និបាតទាំងនេះ គួរកត់សម្គាល់ថានៅក្នុងឯកសារ **E3/27** ដែលគាត់យោងក្នុងជើងទំព័រ ៣៣៤២ ម្ចាស់បណ្តឹងសាទុក្ខ បានប្រើពាក្យ "មហាសន្និបាត" ដែលបន្ទាប់មក គាត់កំណត់នៅសារណាបណ្តឹងសាទុក្ខរបស់គាត់ថាជាសមាជ។

[415] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២១ ("អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាថ្មីម្តងទៀត ពាក់ព័ន្ធនឹងឆន្ទៈទាញ ខៀវ សំផន ឱ្យចូលពាក់ព័ន្ធ"), ("សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដែលចោទជាបញ្ហាកង្វះអនាគតិចំពោះ ខៀវ សំផន")។

សារណាបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹង ការអះអាងទាំងនោះនឹងត្រូវលើកឡើងក្រោមផ្នែកពាក់ព័ន្ធនៃចម្លើយតបនេះ[416]។

### *មូលដ្ឋានទី ១៩៖ ការសន្និដ្ឋានពង្រីក/ការសន្និដ្ឋានទូទៅ*[417]

105. **មូលដ្ឋានទី ១៩ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ឬអង្គហេតុ ដោយការសន្និដ្ឋានពង្រីកឬសន្និដ្ឋានទូទៅលើភ័ស្តុតាង។**

106. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងលើពិរុទ្ធភាពគឺមានកំហុសឆ្គងផ្នែកច្បាប់។ ពិតណាស់ គាត់ខកខានមិនបានបញ្ជាក់ចំៗជាមួយសេចក្តីលំអិតគ្រប់គ្រាន់នូវអ្វីដែលបានចោទថា "កំហុសអង្គច្បាប់ជាច្រើន"[418] និងរបៀបដែលកំហុសទាំងនោះធ្វើឱ្យមោឃភាពដល់សាលក្រមទាំងមូលឬដោយផ្នែក។ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានកំណត់កំហុសអង្គច្បាប់ នៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាង។

107. ចំពោះការចោទរបស់គាត់អំពីកំហុសនៃការវាយតម្លៃមិនគ្រប់គ្រាន់លើភ័ស្តុតាង បង្កើតជាកំហុសអង្គហេតុ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបញ្ជាក់ឱ្យបានជាក់លាក់នូវអ្វីដែលជាការសន្និដ្ឋានពង្រីក/ការសន្និដ្ឋានទូទៅ[419] និងមិនបានបង្ហាញថាតើការសន្និដ្ឋានពង្រីកមិនសមហេតុផលដោយរបៀបណា[420]។ ម្ចាស់បណ្តឹងសាទុក្ខក៏មិនផ្តល់ការយោងឬការពន្យល់ជាជម្រើសថាហេតុអ្វីបានជាពុំមានអង្គជំនុំជម្រះសាលាដំបូងដែលមានហេតុផលអាចបដិសេធការសន្និដ្ឋានជាជម្រើសទាំងនោះ[421]។

108. ម្ចាស់បណ្តឹងសាទុក្ខជាថ្មីម្តងទៀតងាកទៅរកការវាយតម្លៃភ័ស្តុតាងតាមការជ្រើសរើសដោយមិនអើពើថា ការវាយតម្លៃរួមទៅលើភ័ស្តុតាងត្រូវបានតម្រូវក្នុងការកំណត់ថាតើបទដ្ឋានភ័ស្តុតាងហួស

---

[416] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៥។

[417] <u>មូលដ្ឋានទី ១៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការសន្និដ្ឋានពង្រីក/ការសន្និដ្ឋានទូទៅ* កថាខណ្ឌ ២៣៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១១ (ភាសាអង់គ្លេស) ទំព័រ ១០ (ភាសាបារាំង) ទំព័រ ១៩ (ភាសាខ្មែរ)។

[418] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ២៣៩។

[419] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[420] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៩៨។

[421] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០។

ពីវិមតិសង្ស័យត្រូវបានបំពេញដែរឬទេ[422]។ ក្នុងការគាំទ្រដល់ការចោទប្រកាន់ដ៏ច្រើនរបស់ខ្លួន ម្ចាស់បណ្ដឹងសាទុក្ខយោងដល់មូលដ្ឋានបណ្ដឹងសាទុក្ខរបស់គាត់ពាក់ព័ន្ធនឹង អនុមានវិធី/ភ័ស្ដុតាងប្រយោល។ ក៏ប៉ុន្តែវិធីសាស្ត្រមួយចំណែកៗរបស់គាត់ចំពោះភ័ស្ដុតាង និងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងមូលដ្ឋាននេះ ក៏ខកខានមិនបានកំណត់កំហុស ដូចដែលបានពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨[423]។

109. នៅក្នុងឧទាហរណ៍តែមួយរបស់គាត់[424] ម្ចាស់បណ្ដឹងសាទុក្ខយោងដោយមិនជោគជ័យទៅដល់កថាខ័ណ្ឌនានាដែលពាក់ព័ន្ធនឹងសហករណ៍ព្រះវិហារ ដើម្បីលើកទឡ្ហីករណ៍ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលថាគាត់ដឹងអំពីស្ថានភាពនៅទីតាំងសហករណ៍ទូទាំងប្រទេស។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ច្បាស់ថា ក្នុងការកំណត់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងនោះរួមមានការដឹងដែលចាំបាច់ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងត្រឹមត្រូវទៅលើភ័ស្ដុតាងទាំងមូលដែលខ្លួនបានទទួល[425]។ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងគឺមានលក្ខណៈទូលំទូលាយ ដោយពិចារណាដល់សក្ខីកម្មនៅក្នុងតុលាការ ចម្លើយក្រៅតុលាការចម្លើយ និងសំណេររបស់ម្ចាស់បណ្ដឹងសាទុក្ខខ្លួនឯង និងឯកសារផ្សេងៗទៀត[426]។

---

[422] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ, ភ័ស្ដុតាងហួសពីវិមតិសង្ស័យ)។

[423] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៩ ជើងទំព័រ ៣៣៤ *ដកស្រង់* កថាខណ្ឌ ២៣៨ របស់ខ្លួន។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨។

[424] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៩ ជើងទំព័រ ៣៣៦ *ដកស្រង់* កថាខណ្ឌ ១៨២៩-១៨៣៥ របស់ខ្លួន (ការដឹងឮអំពីទីកន្លែងក្នុងសហករណ៍)។

[425] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៣។ (ការវាយតម្លៃរបស់ អ.ជ.ស.ដ លើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្ដឹងសាទុក្ខ ផ្ដែកលើការវាយតម្លៃលើតួនាទី មុខងារ និងការប្រព្រឹត្តរបស់គាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចបានបង្ហាញក្នុងអំឡុងសំណុំរឿង០០២។ អ.ជ.ស.ដ ពិចារណាលើសេចក្ដីថ្លែងការណ៍ទាំងមូល និងការប្រព្រឹត្តរបស់ខៀវ សំផន ក្នុងករណីសមស្រប រួមមានសេចក្ដីថ្លែងការណ៍ធ្វើឡើងក្រោយការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងការវាយតម្លៃវិសាលភាពនៃការដឹងឮក្នុងសម័យនោះអំពីការប្រព្រឹត្តបទឧក្រិដ្ឋ ការចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ និង/ឬចេតនាក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។ *សូមមើលផងដែរ* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧១ (ផ្អែកលើភ័ស្ដុតាងទាំងមូល អ.ជ.ស.ដ អាចធ្វើសេចក្ដីសន្និដ្ឋានរួមបានដោយសមហេតុសមផល)។

[426] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦២-៦២៤ (តួនាទី និងការទទួលខុសត្រូវ), ៤២០១-៤៣១៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌ)។ អ.ជ.ស.ដ យល់ឃើញថា ការដឹងឮក្នុងសម័យនោះ និងការទទួលស្គាល់របស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងឆ្នាំ១៩៨៧ ដែលថាប្រជាជនចំនួន២០.០០០នាក់ បានស្លាប់ដោយសារជំងឺ និងកង្វះម្ហូបអាហារ គឺស្របគ្នាទៅនឹងការដឹងឮរបស់គាត់អំពី "លក្ខខណ្ឌការងារដ៏អាក្រក់នៅតាមសហករណ៍ និងតាមការដ្ឋាន" ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៤២១៦)។ សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋានទី ២០៩, ២២៥, ២៣២, ២៣៣, ២៤៥, ២៤៨, ២៤៩។

110. ការមិនយល់ស្របរបស់ម្ចាស់បណ្តឹងសាទុក្ខជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ មាស វឿន អំពីលក្ខខណ្ឌនានានៅព្រះវិហារពុំមែនជាកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ[427]។ ទីមួយ ម្ចាស់បណ្តឹងសាទុក្ខយល់ស្របថាគាត់បានដឹងអំពីការចាប់ខ្លួនសាច់ញាតិប្រពន្ធគាត់នៅក្នុងខេត្តព្រះវិហារ[428]។ ទីពីរ គាត់ទទួលយកថា សាក្សីនោះផ្តល់សក្ខីកម្មថាបានបញ្ជូនរបាយការណ៍មួយទៅម្ចាស់បណ្តឹងសាទុក្ខដែលក្នុងនោះរួមមានលក្ខខណ្ឌនៅទីនោះ[429] ដោយពុំមានភស្តុតាងផ្ទុយ គេអាចសន្និដ្ឋានប្រកបដោយហេតុផលថានៅក្នុងដំណើរការអនុវត្តការងារជាប្រចាំ លិខិតនោះត្រូវបានប្រគល់ជូនម្ចាស់បណ្តឹងសាទុក្ខ។

111. ទីបី ម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថាសាក្សីបានបញ្ជូនរបាយការណ៍នោះដល់ខ្លួនក្រោយពីខ្លួនសួរគាត់អំពីស្ថានភាពនៅក្នុងខេត្តព្រះវិហារ និងថា សាក្សីមានភារកិច្ចអនុវត្តបទបញ្ជារបស់ ប៉ុល ពត ក្នុងការស៊ើបអង្កេតដើម្បីកំណត់ថា មានប្រជាជនត្រូវបានចាប់ខ្លួនឬដាក់ពន្ធនាគារឬយ៉ាងណា[430]។ គួរកត់សម្គាល់លើពេលវេលា។ សាក្សីនោះអាចត្រូវបានបញ្ជូនទៅស៊ើបអង្កេតក្រោយពេលសាច់ញាតិរបស់ម្ចាស់បណ្តឹងសាទុក្ខត្រូវបានចាប់ខ្លួន ដែលអាចស្របទៅនឹងទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត។ ក្រៅពីរឿងពេលវេលា វាជាការសមហេតុផលក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹកនាំការស៊ើបអង្កេតទៅលើសាក្សី ពីព្រោះគាត់ដឹងថាសាក្សីនោះកាន់តំណែងដែលមានសិទ្ធិអំណាចនៅក្នុងខេត្តព្រះវិហារ[431] ដែលផ្តល់ភស្តុតាងបន្ថែមទៀតអំពីសិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងទំនាក់ទំនងទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត និងតំណែងរបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ម្ចាស់បណ្តឹងសាទុក្ខនោះមិនបានធ្វើដំណើរទៅខេត្តនោះដើម្បីស្វែងយល់អំពីស្ថានភាពនៅទីនោះ ឬស៊ើបអង្កេតអំពីភស្តុតាងរបស់សាច់ញាតិប្រពន្ធគាត់ ឥទ្ធិពលនិងសិទ្ធិអំណាចដែលគាត់មាន។ គាត់មិនចាំបាច់ធ្វើដំណើរទៅទីនោះឡើយ។ សាក្សីបានផ្តល់សក្ខីកម្មថាគេប្រាប់គាត់ថាតំបន់ ១០៣ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម្ចាស់បណ្តឹងសាទុក្ខ[432] ហេតុដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខអាចមានទំនុកចិត្តថាមានអ្នកដែលអាច

[427] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៤-១៨៣៥។

[428] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣១-១៨៣២។

[429] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៤។

[430] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៤។

[431] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៣។ (សាក្សីជាប្រធានតំបន់១០៣ (ព្រះវិហារ))។

[432] ឯកសារ **E1/130.1** មាស វឿន, ប្រតិចារឹក ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ម៉ោង ១៤.២៦.៣០-១៤.២៨.៣៤ ទំព័រ៧៨ បន្ទាត់ ១-ទំព័រ៧៩ បន្ទាត់ ១៣។

ឆ្លៀតពេលរាយការណ៍ទៅម្ចាស់បណ្តឹងសាទុក្ខអំពីស្ថានភាពជាមួយនឹងសមាជិកគ្រួសារខាងប្រពន្ធរបស់គាត់និងផ្តល់ជំនួយដើម្បីដោះស្រាយបញ្ហានោះ[433]។

## *មូលដ្ឋានទី ១៦៖ ការបំភ្លេចចោលនូវភស្តុតាងដោះបន្ទុក*[434]

112. **មូលដ្ឋានទី ១៦ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយបំភ្លេចចោលនូវភស្តុតាងដោះបន្ទុកនៅក្នុងការវាយតម្លៃភស្តុតាង។**

113. មូលដ្ឋាននេះមិនទទួលផលទេ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខមិនកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណា ភស្តុតាង "មានបុគ្គលិកលក្ខណៈ" ល្អ ដូចគ្នានឹងភស្តុតាងដែលបានស្តាប់នៅក្នុងសំណុំរឿង០០២/០១ នៅក្នុងអំឡុងពេលពិចារណាសម្រេចក្នុងរឿងក្តីនេះ[435]។ ម្ចាស់បណ្តឹងសាទុក្ខផ្អែកខុសលើទឡ្ហីករណ៍នៅក្នុងកថាខណ្ឌទី ២១៧៧ ដល់ ២១៨៣ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់ដោយហេតុថាទឡ្ហីករណ៍ទាំងនោះខកខានមិនបានពិចារណាភស្តុតាងដោះបន្ទុក។ ការណ៍ដែលថា អង្គជំនុំជម្រះសាលាដំបូងមិនផ្លាស់ប្តូរការវាយតម្លៃរបស់ខ្លួនទៅលើភស្តុតាងដដែលមិនបង្កើតបានជាការបំភ្លេចចោល ឬមិនអើពើដល់ភស្តុតាងដោះបន្ទុកឡើយ[436]។ អង្គជំនុំជម្រះ

---

[433] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៣។ ឯកសារ **E1/130.1** ប្រតិចារឹក មាស វឿន ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ម៉ោង ១៤.២៦.៣០-១៤.២៨.៣៤ ទំព័រ ៧៨ បន្ទាត់ ១-ទំព័រ ៧៩ បន្ទាត់ ១៣។

[434] <u>មូលដ្ឋានទី ១៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភស្តុតាងដោះបន្ទុក ត្រូវបានបំភ្លេចចោល* កថាខណ្ឌ ២៣៥-២៣៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១០ (ភាសាអង់គ្លេស) ទំព័រ ៩ (ភាសាបារាំង) ទំព័រ ១៣ (ភាសាខ្មែរ)។

[435] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៣៦ ជើងទំព័រ ៣២១ *ដកស្រង់*កថាខណ្ឌ ២១៨៨-២១៨៣ របស់ ខ្លួន។ កត់សម្គាល់ថាកថាខណ្ឌ ២១៧៨ របស់ខ្លួន ជើងទំព័រ ៤១៧៩ និង ៤១៨១ ដកស្រង់សក្ខីកម្មរបស់សាក្សីដដែល ដែលម្ចាស់បណ្តឹងសាទុក្ខ យោងទៅលើ ឯកសារ **F17** សារណាបណ្តឹងសាទុក្ខ សំណុំរឿង០០២/០១ កថាខណ្ឌ ៦៥៦ ជើងទំព័រ ១៣៦១ (*ដកស្រង់* ឯកសារ **E295/6/4** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខៀវ សំផន ក្នុងសំណុំរឿង០០២/០២ កថាខណ្ឌ ២៧៥ ជើងទំព័រ ៨៩១)។ អ.ជ.ត.ក បានច្រានចោលទឡ្ហីករណ៍របស់ម្ចាស់បណ្តឹង សាទុក្ខក្នុងសំណុំរឿង០០២/០១ ដោយយល់ឃើញថា អ.ជ.ស.ដ ពិតជាបានពិចារណាភស្តុតាងស្តីពីអត្តចរិតល្អ។ (*សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១៥-១១១៦)។

[436] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧៩។

សាលាដំបូងគ្រាន់តែមិនចាត់ទុកថា ភស្តុតាងនេះមានលក្ខណៈគ្រប់គ្រាន់ដែលធ្វើឱ្យប៉ះពាល់ដល់ការកំណត់របស់ខ្លួនអំពីការផ្តន្ទាទោសសមស្របនោះឡើយ[437]។

114. មិនតែប៉ុណ្ណោះ ម្ចាស់បណ្តឹងសាទុក្ខកំណត់ប្រភេទភស្តុតាងខុសដែលខ្លួនស្វះស្វែងរកផ្អែកលើ។ សាក្សីដែលត្រូវបានដកស្រង់មកសំអាងអាចបាន "មកផ្តល់សក្ខីកម្មលើអង្គហេតុដែលបានបញ្ជាក់ជាឯកច្ឆន្ទអំពីសីលធម៌ល្អរបស់គាត់"[438] ប៉ុន្តែពួកគេមិនបានធ្វើដូច្នេះឡើយ។ ពួកគេមិនបានផ្តល់ការសក្ខីកម្មដែលសុទ្ធតែសរសើរ" ឡើយ[439]។ ភស្តុតាងនេះមិនកំណត់ថាអង្គជំនុំជម្រះសាលាដំបូងបំភ្លេចភស្តុតាងដោះបន្ទុក និងប្រាកដជាមានគុណភាព ក្នុងការផ្លាស់ប្តូរការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងលើការកំណត់ទោសសមស្របឡើយ ផ្អែកលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលម្ចាស់បណ្តឹងសាទុក្ខត្រូវបានចោទប្រកាន់។ ការផ្អែករបស់ម្ចាស់បណ្តឹងសាទុក្ខលើទឡ្ហីករណ៍ក្នុងកថាខណ្ឌ ៧៥៦ និង ១២៧៩ដល់១២៨០ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់គឺជាការនាំខុសស្រដៀងគ្នា។ ទឡ្ហីករណ៍ទាំងនេះមិនកំណត់ថាអង្គជំនុំជម្រះសាលាដំបូងបំភ្លេចចោលភស្តុតាងដោះបន្ទុកឡើយ[440]។

## ***មូលដ្ឋានទី ១៨៖ អនុមានវិធី/ភស្តុតាងទេសកាល***[441]

115. **មូលដ្ឋានទី ១៨ គួរតែត្រូវបានបដិសេធ ដោយហេតុថាវិធីសាស្ត្រមួយចំណែកៗមិនមែនជាប្រព័ន្ធចំពោះភស្តុតាងមិនកំណត់បានថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គហេតុឬអង្គច្បាប់នៅក្នុងសំអាងហេតុអនុមាននិងការវាយតម្លៃជារួមលើភស្តុតាងឡើយ។**

---

[437] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ជើងទំព័រ ១៩១៩០ (*កត់សម្គាល់សេចក្តីពិចារណាជាមុនរបស់ខ្លួនអំពីសាក្សីបញ្ជាក់អត្តចរិតចំនួនប្រាំនាក់ ដែលបានផ្តល់សក្ខីកម្មតាំងនាមឱ្យម្ចាស់បណ្តឹងសាទុក្ខ*)។ *សូមមើលផងដែរ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៩៩-១១០៣។

[438] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧៩។

[439] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៨០។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៥៦។

[440] ទឡ្ហីករណ៍នៅក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៣៦ ជើងទំព័រ៣២២ *ដកស្រង់*កថាខណ្ឌ៧៥៦របស់គាត់ដែលជំទាស់នឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថាជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ត្រូវបានព័ទ្ធចាប់ និរទេស និង/ឬ បាត់ខ្លួន ពុំលើកឡើងបញ្ហានៃភស្តុតាងដោះបន្ទុកឡើយ និងខកខានមិនបានផ្តល់សំអាងហេតុនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១០៣, ១០៤, ១០៥។ ទឡ្ហីករណ៍នៅក្នុងកថាខណ្ឌ ១២៧៩-១២៨០ របស់គាត់ ដែលជំទាស់នឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថាជនជាតិវៀតណាម ជាជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំ ខកខានមិនបានពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ៨៤, ១១១, ១១២។

[441] <u>មូលដ្ឋានទី ១៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អនុមានវិធី/ភស្តុតាងទេសកាល* កថាខណ្ឌ ២៣៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១១ (ភាសាអង់គ្លេស) ទំព័រ ៩-១០ (ភាសាបារាំង) ទំព័រ ១៣-១៤ (ភាសាខ្មែរ)។

116. ជាពិសេស មូលដ្ឋាននេះមិនទទួលផលឡើយដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខមិនបង្ហាញថាការសន្និដ្ឋានអង្គហេតុផ្អែកលើការពង្រីកដែលធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង គឺមិនសមហេតុផលឡើយ។ ទោះបីជាម្ចាស់បណ្ដឹងសាទុក្ខលើកមកសំអាងដ៏ត្រឹមត្រូវនូវផ្នែកមួយនៃការសម្រេចរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ពាក់ព័ន្ធនឹងការសន្និដ្ឋានទូទៅក៏ដោយ ក៏គាត់បំភ្លេចផ្នែកសំខាន់ៗនៃការសម្រេចនោះដែរ[442]៖ ក្នុងកម្រិតដែលថាការសម្រេចចោទប្រកាន់ផ្អែកលើការសន្និដ្ឋានទូទៅ វាត្រូវតែកំណត់បានហួសពីវិមតិសង្ស័យ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ *បន្ទុកនៃភស្តុតាងនៅតែស្ថិតលើម្ចាស់បណ្ដឹងសាទុក្ខដែលចោទថាមានកំហុសអង្គហេតុ ដើម្បីបង្ហាញថាការពង្រីកធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការឈានដល់ការសន្និដ្ឋាន គឺមិនសមហេតុផលឡើយ*[443] ។ ម្ចាស់បណ្ដឹងសាទុក្ខបានខកខានមិនបានបំពេញបទដ្ឋាននេះទេ។

117. ការអះអាងទូលំទូលាយរបស់ម្ចាស់បណ្ដឹងសាទុក្ខដោយយោងដល់ "ឧទាហរណ៍មួយចំនួន"[444] មិនបង្ហាញថាការចោទប្រកាន់មួយណា ប្រសិនបើមាន ដែលបានផ្អែកលើការសន្និដ្ឋានទូទៅដែលមានកំហុសឆ្គង ឬមិនបង្ហាញថាការសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងមិនសមហេតុផល។ ជាងនេះទៀត តាមការតម្រូវគឺគាត់ពុំផ្ដល់ការសន្និដ្ឋានជាជម្រើស ឬពន្យល់ហេតុអ្វីគ្មានអង្គជំនុំជម្រះសាលាដំបូងណាដែលមិនបញ្ចូលការសន្និដ្ឋានជាជម្រើសផ្សេង[445]។ និយាយរួម គឺគាត់មិនបានផ្ដល់សំអាងហេតុគ្រប់គ្រាន់ឡើយ[446]។

---

[442] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៨ *ដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៩៨។

[443] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៩៨ (គូសបញ្ជាក់បន្ថែម)។

[444] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៨ ជើងទំព័រ ៣៣៣ *ដកស្រង់* កថាខណ្ឌរបស់ខ្លួន ៦៩៥, ៩១០, ១៦១១ និង១៨៨១។

[445] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០។

[446] *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២។ ការពន្យល់ផ្សេងទៀតរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីការបាត់ខ្លួនរបស់ខឿន គឺមិនសមហេតុផលឡើយ។ វាមិនសមស្របទាល់តែសោះក្នុងការពន្យល់ថាគាត់គិតថាការបាត់ខ្លួនភ្លាមៗរបស់ខឿនមិនបានត្រលប់មកវិញក្នុងអំឡុងរយៈពេលពីរឆ្នាំចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺព្រោះតែខឿនបានធ្វើដំណើរច្រើន ជាពិសេស នៅពេលដែលម្ចាស់បណ្ដឹងសាទុក្ខ បានកាន់កាប់ការងារជំនួសខឿន និងទទួលស្គាល់ថា "ការបាត់ខ្លួន" គឺស្មើនឹងការចាប់ខ្លួន។ *សូមមើល* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៦៣ ដកស្រង់ក្នុងកថាខណ្ឌ១៦១១របស់គាត់ដែលត្រូវបានដកស្រង់ក្នុងកថាខណ្ឌ ២៣៨ របស់គាត់។ សូមមើល *បន្ថែម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥ (ខឿន)។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៥។

118. ដោយពិនិត្យមើលភ័ស្តុតាងទាំងអស់ តាមការតម្រូវ[447] "ឧទាហរណ៍" ចំនួន៥របស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលឡើយ ដូចដែលបានពិភាក្សានៅក្នុងផ្នែកផ្សេងទៀតនៃចម្លើយតបនេះ។ ឧទាហរណ៍ទីមួយរបស់គាត់ ដែលចោទថាមានការសន្និដ្ឋានភាន់ច្រឡំលើការជម្លៀសដោយបង្ខំទៅលើប្រជាជនវៀតណាមជាច្រើន ដោយអះអាងទូទៅពុំផ្តល់ភ័ស្តុតាងគាំទ្រ[448] និងដោយគ្មានបញ្ជាក់ច្បាស់លាស់ថាតើកថាខណ្ឌណានៃសាលក្រមដែលគាត់កំពុងជំទាស់[449]។ នៅក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិនិត្យលើភ័ស្តុតាង ក្នុងនោះរួមមានសក្ខីកម្មក្នុងតុលាការ និងកំណត់ហេតុស្តាប់ចម្លើយ មុននឹងធ្វើការសន្និដ្ឋានពាក់ព័ន្ធនឹងការជម្លៀស និងបញ្ជូនចេញដោយបង្ខំ[450]។ ឧទាហរណ៍ទីពីររបស់ម្ចាស់បណ្តឹងសាទុក្ខដែលចោទថាគ្មានភ័ស្តុតាងអំពីវត្តមានជនជាតិចាម និងការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួនក៏មិនជួយបានដូចគ្នាដែរ[451]។ ខណៈដែលម្ចាស់បណ្តឹងសាទុក្ខយោងតែទៅលើកថាខ័ណ្ឌចំនួនពីរនៅក្នុងសាលក្រម[452] អង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃចំនួន១៨ កថាខណ្ឌលើភ័ស្តុតាងក្នុងនោះរួមមានសក្ខីកម្ម ក្នុងតុលាការផងដែរ មុនពេលឈានទៅធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន[453]។

---

[447] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (ក្នុងការវាយតម្លៃកំហុសដែលបានលើកឡើងពាក់ព័ន្ធនឹងភ័ស្តុតាងហួសពីវិមតិសង្ស័យ ត្រូវពិចារណាលើភ័ស្តុតាងទាំងមូល ជាជាងពិចារណាលើផ្នែកនៃភ័ស្តុតាងដែលបានជ្រើសរើសជាកំណាត់ តូចៗ)។ *សូមមើលផងដែរ* ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧១ (អ.ជ.ត.ក ពិនិត្យមើល ភ័ស្តុតាងទាំងមូលដើម្បីសម្រេចថាសេចក្តីសន្និដ្ឋានរួមរបស់ អ.ជ.ស.ដ សមហេតុសមផល)។

[448] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៩៥ (*បានដកស្រង់ជា*ឧទាហរណ៍នៃអង្គហេតុ ក្នុងឯកសារ F54 សារណាបណ្តឹងសាទុក្ខ ជើងទំព័រ៣៣៣)។

[449] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៩៥។

[450] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១០១-១១២៥, ១១៥៦-១១៥៩, ៣៤២៩-៣៤៤០, ៣៥០២-៣៥០៧ (ការបញ្ជូនប្រជាជនវៀតណាមចេញពីប្រទេសកម្ពុជា, ការនិរទេស)។

[451] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១០ (*បានដកស្រង់ជា*ឧទាហរណ៍នៃអង្គហេតុ ក្នុងឯកសារ F54 សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ៣៣៣)។

[452] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១០ ជើងទំព័រ ១៦៥១ (*ដកស្រង់*ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០២), ១៦៥២ (*ដកស្រង់*ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០៦)។

[453] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៩១-៣៣០៨។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣៧។

119. ចំពោះឧទាហរណ៍ទីបីរបស់គាត់ពាក់ព័ន្ធនឹងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានបោសសម្អាត[454]វត្តមានរបស់ម្ចាស់បណ្តឹងសាទុក្ខនៅមន្ទីរស-២១ មិនត្រូវបានតម្រូវឱ្យបង្កើតការទទួលខុសត្រូវរបស់គាត់ក្រោមសហឧក្រិដ្ឋកម្មរួម ឬការការជួយនិងជំរុញ ដែលជាទម្រង់នៃការទទួលខុសត្រូវដែល ម្ចាស់បណ្តឹងសាទុក្ខត្រូវចោទប្រកាន់ពីការបោសសម្អាតនៅមន្ទីរស២១[455]។ ម្ចាស់បណ្តឹងសាទុក្ខក៏ធ្វើមិនអើពើដល់ការវាយតម្លៃដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើភ័ស្តុតាងពាក់ ព័ន្ធនឹងការដឹង និងចេតនារបស់គាត់ផងដែរ[456]។ គាត់មិនបានកំណត់បានភាពមិនសមហេតុផលនៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង គាត់គ្រាន់តែមិនយល់ស្របជាមួយនឹងការវាយតម្លៃភ័ស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង។ ឧទាហរណ៍ទីបួនរបស់ម្ចាស់បណ្តឹងសាទុក្ខដែលជំទាស់កថាខណ្ឌមួយនៃសាលក្រមពាក់ព័ន្ធនឹងការកំណត់គោលដៅលើជនជាតិចាមក៏មិនទទួលផលដែរ[457]។ នៅក្នុងកថាខណ្ឌនោះពុំមានកន្លែងណាមួយដែលអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានមិនច្បាស់លាស់ថា ម្ចាស់បណ្តឹងសាទុក្ខដឹងអំពី "ឧក្រិដ្ឋកម្មមួយចំនួន" តាមការចោទរបស់គាត់ឡើយ[458] ដូច្នេះ ជាថ្មីម្តងទៀតគេទុកឱ្យយើងស្មានថាផ្នែកណាមួយនៃសាលក្រម ដែលគាត់យោងដល់ ប្រសិនបើមាន។ ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខមិនអើពើការវិភាគភ័ស្តុតាងដ៏ទូលំទូលាយដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តដើម្បីធ្វើការសន្និដ្ឋានរបស់ខ្លួន[459]។

---

[454] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១១ (*បានដកស្រង់ជា*ឧទាហរណ៍នៃអង្គហេតុ ក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ៣៣៣)។

[455] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, ផ្នែកទី១៥៖ ច្បាប់ជាធរមាន៖ ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌ ៣៧០២-៣៧១៥, ៣៧២១-៣៧២៤, ៤៣០៦, ៤៣១៦-៤៣១៨, ៤៣២៦-៤៣២៨។.

[456] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦២-៦២៤ (តួនាទី និងមុខងារ), ៤២០១-៤៣១៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌ)។ សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋានទី ២១៦, ២១៧, ២៣៥។

[457] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨១ (*បានដកស្រង់ជា*ឧទាហរណ៍នៃអង្គហេតុ ក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ៣៣៣) ជើងទំព័រ ៣៦៤៤ *ជំទាស់តវ៉ា* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៦។

[458] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨១។

[459] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣៨២២ *ដកស្រង់* ផ្នែកទី ១៣.២.៥.៤ សេចក្តីសន្និដ្ឋានលើគោលនយោបាយ ប.ក.ក កំណត់គោលដៅលើជនជាតិចាម, ផ្នែកទី១៦ គោលបំណងរួម កថាខណ្ឌ ៣៩៨០។ ជើងទំព័រ ១៣៨២៣ *ដកស្រង់*ផ្នែកទី ១៣.២.៥.៤ សេចក្តីសន្និដ្ឋានលើគោលនយោបាយ ប.ក.ក ដែលកំណត់គោលដៅលើជនជាតិចាម។ ជើងទំព័រ ១៣៨២៤ ផ្នែកទី ១៣.៣.៥.២ ភ័ស្តុតាងនៃគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាម។ ផ្នែកទី ១៣.៣.១០.៥ ការប្រព្រឹត្តលើជនជាតិវៀតណាម៖ សំអាងច្បាប់៖ ការអំពើប្រល័យពូជសាសន៍។

## គ. ការវាយតម្លៃភ័ស្តុតាង

### *មូលដ្ឋានទី ១៥៖ ស្តង់ដាពីរនៅក្នុងការប្រើប្រាស់ភ័ស្តុតាងដាក់បន្ទុកនិងដោះបន្ទុក*[460]

120. **មូលដ្ឋានទី ១៥ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខមិនកំណត់បានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុដោយអនុវត្តស្តង់ដាពីរ នៅក្នុងការវាយតម្លៃភ័ស្តុតាងដាក់បន្ទុកដោយប្រៀបធៀបនឹងភ័ស្តុតាងដោះបន្ទុក។**

121. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខបញ្ជាក់មិនគ្រប់គ្រាន់នូវកំហុសអង្គច្បាប់និងអង្គហេតុ ប៉ុន្តែផ្ទុយទៅវិញបានធ្វើការអះអាងទូទៅដែលគ្មានភ័ស្តុតាងគាំទ្រ។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខពុំបានផ្តល់ទឡ្ហីករណ៍ ដើម្បីគាំទ្រការអះអាងរបស់គាត់អំពីកំហុសឡើយ គឺគ្រាន់តែយោងដល់កថាខណ្ឌនានានៅក្នុងសាលក្រម និងសារណាបណ្តឹងសាទុក្ខរបស់គាត់តែប៉ុណ្ណោះ[461]។ ជាការពិតណាស់ ជាការផ្ទុយទៅនឹងការអះអាងដែលគ្មានភ័ស្តុតាងគាំទ្រនេះ អង្គជំនុំជម្រះសាលាដំបូងបានវែកញែកលើភ័ស្តុតាងដោះបន្ទុក ជួនកាលទទួលយក ជួនកាល បដិសេធ[462]។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងកម្រិតដែលការអះអាងរបស់គាត់ត្រូវបានធ្វើឡើងគ្រប់គ្រាន់នោះ ការយោងកថាខណ្ឌទៅសារណាបណ្តឹងសាទុក្ខរបស់គាត់ត្រូវបានវែកញែកនៅក្នុងផ្នែកដទៃទៀតនៃចម្លើយតបនេះ[463]។

---

[460] <u>មូលដ្ឋានទី ១៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ស្តង់ដារពីរ រវាងភ័ស្តុតាងដាក់បន្ទុក និងដោះបន្ទុក*។ កថាខណ្ឌ ២៣៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១០ (ភាសាអង់គ្លេស) ទំព័រ ៩ (ភាសាបារាំង) ទំព័រ ១២ (ភាសាខ្មែរ)។

[461] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១០ (ភាសាអង់គ្លេស) ទំព័រ ៩ (ភាសាបារាំង) *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦, ៣៨, ៤០, ៤៩, ៥៣, ៦០-៦៦, ៦៩, ៧១-៧៣, ១៩៤, ៣៤៤,៣៥១, ៣៥៤, ៤៧០-៤៧២, ៤៧៩។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៣៤, ៣៩២-៣៩៥, ៣៩៧, ៣៤៧១។ ការយោងនៅក្នុងសាលក្រម បង្ហាញពីក្របខ័ណ្ឌរបស់ អ.ជ.ស.ដ សម្រាប់វាយតម្លៃភ័ស្តុតាង ខណៈដែលការយោងក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ គ្រាន់តែបញ្ជូនកថាខណ្ឌបន្ថែមនៃសារណារបស់គាត់ដល់អ្នកអានតែប៉ុណ្ណោះ។ (*ឧទាហរណ៍* កថាខណ្ឌ ២៣៤ ជើងទំព័រ ៣១៦ *ដកស្រង់* កថាខណ្ឌរបស់ខ្លួន កថាខណ្ឌ ២៤១-២៤២, ២៩៣-៣០៥, ៣១២-៣១៣, ៣១៤-៣១៩, ៣២៩-៣៣០,ឧទាហរណ៍នៃអង្គហេតុ ៨១៩,៩២២, ៩៩៩, ១១៩៥, ១២៣៥, ១៣៨៣, ១៥២៩, ១៧៥២ ជើងទំព័រ ៣៤០០ (មិនមានជើងទំព័រ៣៤០០ ក្នុងកថាខណ្ឌ១៧៥២ ទេ។ ជើងទំព័រ ៣៤០០ មាននៅក្នុងកថាខណ្ឌ ១៧៦១))។

[462] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ *ភ័ស្តុតាងដាក់បន្ទុក និងដោះបន្ទុក* កថាខណ្ឌ ១៣៧៣-១៣៧៤ កថាខណ្ឌ ១០០៧, ១១៣៥, ១៣៤៦។

[463] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៣៤ ជើងទំព័រ ៣១៦ *ដកស្រង់* ឯកសារ **F54** សារណាបណ្តឹង សាទុក្ខ កថាខណ្ឌ ២៤១-២៤២ (មូលដ្ឋានទី ២១៖ ភាពស៊ីសង្វាក់គ្នា), ២៩៣-៣០៥ (មូលដ្ឋានទី ៣០៖ ចម្លើយជាលាយលក្ខណ៍អក្សរ-

122. កថាខណ្ឌចំនួនពីរនឹងត្រូវលើកយកមកវែកញែកនៅទីនេះ ពោលគឺកថាខណ្ឌ ៩៩៩ ដែលចោទថា អង្គជំនុំជម្រះសាលាដំបូងផ្អែកដោយខុស ទៅលើច្បាប់ចម្លងមួយនៃឯកសារសម័យអង្គហេតុដែលមាន "តម្លៃភ័ស្តុតាងទាប" និង កថាខណ្ឌ ១៣៨៣ ដែលចោទថាអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តស្តង់ដារពីរ នៅក្នុងការវាយតម្លៃភ័ស្តុតាង។ ការពិនិត្យមើលឡើងវិញលើកថាខណ្ឌទាំងនេះ ការយោង និងកថាខណ្ឌពាក់ព័ន្ធ *ទាំងអស់*នៃសាលក្រមបង្ហាញនូវការខកខានរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តស្តង់ដាពីរនៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើភ័ស្តុតាង។

123. ម្ចាស់បណ្តឹងសាទុក្ខពុំបានបង្ហាញកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ដែលផ្អែកលើរបាយការណ៍របស់កងពលធំលេខ១៦៤ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ ក្នុងការកំណត់អំពើមនុស្សឃាតលើអ្នកនេសាទវៀតណាម និងជនភៀសខ្លួនឡើយ[464]។ ម្ចាស់បណ្តឹងសាទុក្ខក៏ពុំបានបដិសេធការសន្និដ្ឋានពាក់ព័ន្ធនឹងភាពគួរឱ្យជឿជាក់បាន (រួមទាំងយថាភាព) ទៅលើឯកសារសម័យកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា(DC-Cam)[465]។ ម្ចាស់បណ្តឹងសាទុក្ខមានឱកាសស្នើសុំ

---

តម្លៃជាភ័ស្តុតាង), ៣១២-៣១៣ (មូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)), ៣១៤-៣១៩ (មូលដ្ឋានទី ៣៣៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, មូលដ្ឋានទី ៣៤៖ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី), ៣២៩-៣៣០ (មូលដ្ឋានទី ៣៧៖ អ្នកជំនាញ),៨១៩ (មូលដ្ឋានទី ១៣៥៖ អំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំនៅភ្នំក្រោល–សក្ខីកម្មរបស់សៅ សារុន), ៩២២ (មូលដ្ឋាន១៣៩៖ ការសម្លាប់រង្គាល–ការសន្និដ្ឋានមិនសមហេតុផល ទាក់ទងនឹងចេតនានៃការសម្លាប់ជនជាតិចាម – មិនមានភ័ស្តុតាងនៃការចេញបញ្ជា), ១១៩៥ (មូលដ្ឋានទី ១៦៥៖ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ – កំហុសទាក់ទងនឹងលក្ខខណ្ឌពីរនៃការរៀបអាពាហ៍ពិពាហ៍ដែលកំណត់ដោយ ប.ក.ក – ការអះអាងរបស់កម្មាភិបាល ត្រូវបានច្រានចោលដោយមិនសមស្រប), ១២៣៥ (មូលដ្ឋានទី ១៦៦៖ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ – ផ្តល់ភាពជឿជាក់ដោយមិនត្រឹមត្រូវចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប), ១៥២៩ (មូលដ្ឋានទី ១៩៖ "គោលនយោបាយ" មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស – ការបំភ្លៃអត្ថបទ, កំហុសក្នុងការវាយតម្លៃលើរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ), ១១៧៥២ (មូលដ្ឋានទី ២០៣៖ សមាជិកគណៈមជ្ឈិម និងគណៈ អចិន្ត្រៃយ៍), ជើងទំព័រ៣៤០០ (មូលដ្ឋានទី ២០៤៖ កំហុសពាក់ព័ន្ធនឹងខ្លឹមសារនៃវគ្គរៀនសូត្រនយោបាយ)។

[464] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៩៩។

[465] ឯកសារ **E3/997** សេចក្តីរាយការណ៍អំពីទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ជូនបង៨៩ ជ្រាបអំពីសភាពការណ៍សមុទ្រ។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៦ (ការសន្និដ្ឋានបឋមនៃភាពពាក់ព័ន្ធ និងភាពគួរឱ្យទុកចិត្តបានចំពោះឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានទទួលយកដោយ អ.ជ.ត.ក នៅក្នុងឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧៥)។ ឯកសារ **E185** សេចក្តីសម្រេចលើឯកសារសំណុំរឿង០០២/០១ កថាខណ្ឌ ២៤-២៨ (ការសន្និដ្ឋានបឋមនៃភាពពាក់ព័ន្ធ និងភាពគួរឱ្យទុកចិត្តបាន (រួមមាន យថាភាព) នៃឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យដែលមានប្រភពចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា)។

មើលឯកសារដើមដែលផ្តល់ដោយ DC-Cam[466] ដូច្នេះមិនគួរឮនៅពេលនេះថាមានការតវ៉ាថា ឯកសារនេះជាច្បាប់ចម្លងនោះទេ។ ការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងចំនួន ៦ កថាខណ្ឌ ដែលនាំដល់ការសន្និដ្ឋានរបស់ខ្លួន[467] បានឈានដល់ការសន្និដ្ឋានត្រឹមត្រូវ ដោយផ្អែកលើ របាយការណ៍នេះដែលបានដាក់ជូននៅក្នុងដំណើរការធម្មតានៃប្រព័ន្ធរាយការណ៍យោធា។

124. អនុបញ្ញាការកងពលលេខ១ បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងបទបញ្ជាឱ្យចាប់ទូកវៀតណាមដែលចូល ក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងនោះរួមមានទូកដឹកជនភៀសខ្លួនផងដែរ និងចាប់ មនុស្សក្នុងកាណូតទាំងនោះ[468]។ ជាផ្នែកមួយនៃប្រព័ន្ធនេះ ប៉ាក់ សុខ ដែលជាសមាជិកកងពលធំ លេខ១៦៤ បានផ្តល់សក្ខីកម្មថាប្រសិនបើចាប់បាន របាយការណ៍នឹងត្រូវបញ្ជូនទៅកងវរសេនាតូច រួចហើយបញ្ជូនបន្តទៅកងពល ពីមួយថ្នាក់ទៅមួយថ្នាក់ទៀត តាមរយៈខ្សែចង្វាក់នៃការបញ្ជា[469]។ របាយការណ៍ដែលរងការជំទាស់នេះគឺមកពីផ្នែកនយោបាយនៃកងពលធំលេខ១៦៤។ ការរាយការណ៍ នេះគឺស្របទៅនឹងបទបញ្ជាដែលអនុបញ្ញាការបានផ្តល់សក្ខីកម្ម នីតិវិធីដែលកត់សម្គាល់ដោយ ប៉ាក់ សុខ និងជាមួយនឹងប្រភេទព័ត៌មានដែល ប៉ាក់ សុខ បានផ្តល់សក្ខីកម្ម ប្រភេទព័ត៌មានដែលមាននៅ ក្នុងរបាយការណ៍មួយទៀតពីកងពលធំលេខ១៦៤ដែលត្រូវបានទទួលយកជាភស្តុតាង[470]។

125. ការប៉ាន់ស្មានរបស់ម្ចាស់បណ្តឹងសាទុក្ខលើវាសនារបស់ជនដែលគេពន្លិចទូក ដូចដែលបានកត់ត្រា នៅក្នុងរបាយការណ៍ថ្ងៃទី១៩ ខែមីនា ពុំបានបង្ហាញនូវកំហុសឆ្គងឡើយ[471]។ របាយការណ៍នេះ ពុំយោងដល់អ្នកដែលរស់រានមានជីវិតពីការលិចទូកឡើយ។ ដោយហេតុថាបទបញ្ជាគឺត្រូវចាប់ អ្នកដែលនៅលើទូក និងចាប់កាណូត វាជាការសមហេតុផលក្នុងការសន្មតថាអ្នកដែល រស់រានមាន ជីវិតអាចត្រូវបានចាប់ខ្លួននិងការចាប់ខ្លួនរបស់ពួកគេត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍ដូចគ្នា នឹងករណីជនជាតិវៀតណាម ៧៦ នាក់ ដែលយកចេញពីទូកផ្សេងទៀតដែលគេចាប់បានដែរ[472]។

---

[466] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៨។

[467] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥៦-៣៤៦៣, ៣៤៩៤ (សំអាងហេតុ)។

[468] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥៦។

[469] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥៧។ កប៉ាល់នីមួយៗ មានប្រព័ន្ធប្រតិបត្តិការវិទ្យុទាក់ទង ហើយការរាយការណ៍ ត្រូវបញ្ជូនភ្លាមៗ នៅពេលមានការចាប់ឃាត់។ ពេលខ្លះ របាយការណ៍ជាលាយលក្ខណ៍អក្សរ ក៏ត្រូវបាន បញ្ជូនផងដែរ។

[470] ឯកសារ **E3/929** សេចក្តីរាយការណ៍អំពីទូរស័ព្ទសម្ងាត់ ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨។

[471] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៩៨។

[472] ឯកសារ **E3/997** សេចក្តីរាយការណ៍អំពីទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ជូនបង៨៩ ជ្រាបអំពីសភាពការណ៍ សមុទ្រ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ កថាខណ្ឌ ៣។

ផ្ទុយទៅនឹងការប៉ាន់ស្មានរបស់ម្ចាស់បណ្តឹងសាទុក្ខ របាយការណ៍នេះពុំផ្តល់នូវមូលដ្ឋានសម្រាប់សន្និដ្ឋានថាមានវត្តមានកាណូតវៀតណាមជាច្រើនគ្រឿងនៅពេលដែលកាណូតនោះត្រូវបានបាញ់ពន្លិច[473]។ ផ្ទុយទៅវិញ មានតែកាណូតនោះដែលត្រូវលិចប៉ុណ្ណោះត្រូវបានរាយការណ៍នៅពេល និងទីតាំងនោះ[474] ចំណែកឯកាណូតវៀតណាមចំនួនពីរទៀតត្រូវបានចាប់ប៉ុន្មានម៉ោងក្រោយនៅទីតាំងផ្សេង[475]។ ដូច្នេះ វាមិន "អាច" ឡើយថា មនុស្សនៅលើកាណូតត្រូវបានបាញ់ពន្លិកត្រូវបានសង្គ្រោះដោយកាណូតផ្សេងទៀតរបស់វៀតណាមនោះ[476]។

126. *សម្រាប់គោលបំណងវែកញែក* សន្មតថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុង ការផ្អែកលើរបាយការណ៍នេះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ថាកំហុសដែលអាចកើតមានបែបនេះគឺមានលក្ខណៈសំខាន់ខ្លាំងដល់សាលក្រមដែលបានសម្រេចដើម្បីបង្កើតជាភាពមិនយុត្តិធម៌[477]។ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា អំពើមនុស្សឃាតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្កើតពាក់ព័ន្ធនឹងការសម្លាប់ដោយចេតនានៅក្នុងទីតាំងជាច្រើន ក្នុងនោះរួមមានការសម្លាប់ដែលរងការជំទាស់នានានៅក្នុងនេះដែរ[478]។ កំហុសឆ្គងដែលត្រូវបានចោទប្រកាន់នឹងមិនមានសារៈសំខាន់ខ្លាំងចំពោះការសន្និដ្ឋាននោះ ឬបណ្តាលឱ្យមានសាលក្រមផ្សេងទាំងមូលឬដោយផ្នែកឡើយ[479]។

127. ការផ្អែករបស់ម្ចាស់បណ្តឹងសាទុក្ខលើកថាខណ្ឌ ១៣៨៣ នៃសារណាបណ្តឹងសាទុក្ខរបស់គាត់[480] គឺជាការនាំឱ្យខុសស្រដៀងគ្នាដែរ។ គាត់ពុំបានផ្តល់ការយោងដល់ការអះអាងដែលគ្មានភស្តុតាងគាំទ្រថាអង្គជំនុំជម្រះសាលាដំបូងមិនអើពើចម្លើយទាំងអស់របស់កម្មាភិបាល លើកលែងតែចម្លើយ

---

[473] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៩៨។

[474] ឯកសារ **E3/997** សេចក្តីរាយការណ៍អំពីទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ជូនបង៨៩ ជ្រាបអំពីសភាពការណ៍សមុទ្រ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ កថាខណ្ឌ ១។

[475] ឯកសារ **E3/997** សេចក្តីរាយការណ៍អំពីទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ជូនបង៨៩ ជ្រាបអំពីសភាពការណ៍សមុទ្រ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ កថាខណ្ឌ ៣។

[476] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៩៨។

[477] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[478] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៩៩។

[479] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់, កំហុសអង្គហេតុ)។

[480] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ៣១៦ ដកស្រង់កថាខណ្ឌ ១៣៨៣ របស់ខ្លួន ជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ចំនួនប្រាំបី ដែលចោទថា អ.ជ.ស.ដ បានអនុវត្តស្តង់ដារពីរ នៅពេលដែលខ្លួនអនុវត្តលើភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។

ដាក់បន្ទុក និងដែលមានការបញ្ជាក់ ប៉ុន្តែបានទទួលថាគួរជឿទុកចិត្តបានដូចគ្នានឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែរ។ ទឡ្ហីករណ៍នានារបស់គាត់ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់ជំទាស់ភ័ស្តុតាង (អ៊ុំ យឿន[481] ព្រាប សុខឿន[482] និង មុំ វុន[483]) គ្រាន់តែកែសម្រួលទឡ្ហីករណ៍ឡើងវិញដែលមិនជោគជ័យពីការជំនុំជម្រះ ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាបានបដិសេធ និងផ្តល់សំអាងហេតុក្នុងការទទួលភ័ស្តុតាង[484]។ ចំណុចចុងក្រោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា បុគ្គលទាំងនេះ ដូចដើមបណ្តឹងរដ្ឋប្បវេណីដែរ គឺបានផលប្រយោជន៍ក្នុងការចោទប្រកាន់ គួរតែត្រូវបានបដិសេធថាគ្រាន់តែជាការស្មានសុទ្ធសាធ។

## *មូលដ្ឋានទី ២០៖ ចំនួនភ័ស្តុតាងនិងតម្លៃជាភ័ស្តុតាង*[485]

128. **មូលដ្ឋានទី ២០ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយ (i) វាយតម្លៃភ័ស្តុតាងមិនសង្គតិភាព និងមិនគ្រប់គ្រាន់ (ii) វាយតម្លៃភ័ស្តុតាងតាមរបៀបម្តងមួយៗ ឬ(iii) "បន្ថែម" បំណែកៗនៃភ័ស្តុតាងដើម្បីបំពេញលក្ខខណ្ឌបន្ទុកនៃភ័ស្តុតាងហួសពីវិមតិសង្ស័យ។**

129. ម្ចាស់បណ្តឹងសាទុក្ខពុំកំណត់ថាអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានដោយកំហុសឆ្គង ផ្អែកលើការវាយតម្លៃលើភ័ស្តុតាងទាំងមូល ថា "អង្គហេតុទាំងអស់ដែលបង្កើតធាតុផ្សំបទល្មើស និងទម្រង់នៃការទទួលខុសត្រូវព្រមទាំងអង្គហេតុទាំងអស់ដែលសំខាន់មិនអាចខ្វះបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពហួសពីវិមតិសង្ស័យ"[486]។ វិធីសាស្ត្ររបស់គាត់ក្នុងការបង្ហាញភ័ស្តុតាងម្តងមួយៗដាច់ដោយឡែក និងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងក៏បានអនុវត្តវិធីសាស្ត្របង្ហាញភ័ស្តុតាងម្តងមួយៗដាច់ដោយឡែក ឬបង្ហាញថាខ្លួនបាន

---

[481] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៨៦។

[482] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៨៧។

[483] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៨៨។

[484] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៨-៣៦៥៣។

[485] <u>មូលដ្ឋានទី ២០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ចំនួនភ័ស្តុតាង និងតម្លៃជាភ័ស្តុតាង* កថាខណ្ឌ ២៤០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១១ (ភាសាអង់គ្លេស) ទំព័រ ១០ (ភាសាបារាំង) ទំព័រ ១៤-១៥ (ភាសាខ្មែរ)។

[486] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៨។

សន្និដ្ឋានហួសពីវិមតិសង្ស័យផ្អែកលើ "ភ័ស្តុតាងរួម" ដោយពុំគិតពីទម្ងន់នៃភ័ស្តុតាងនីមួយៗឡើយ[487]។

130. ការអះអាងដ៏ទូលាយរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីកំហុសអង្គច្បាប់ពុំមានការគាំទ្រនៅក្នុងកថាខណ្ឌនានានៃបណ្តឹងសាទុក្ខរបស់គាត់ ឬកថាខណ្ឌនានានៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលគាត់លើកយកមកធ្វើជាសំអាងនោះឡើយ[488]។ ឧទាហរណ៍ កថាខណ្ឌ ៤២៧១ ប៉ុន្តែកថាខណ្ឌមួយក្នុងចំណោមកថាខណ្ឌចំនួនបួនដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងទាញសន្និដ្ឋានបានផ្អែកលើការវិភាគយ៉ាងល្អិតល្អន់ពីមុនៗទៅលើភ័ស្តុតាង *ទាំងមូល* ដូចដែលម្ចាស់បណ្តឹងសាទុក្ខចោទថាអង្គជំនុំជម្រះសាលាដំបូងគួរតែធ្វើ[489]។ ការយោងលេខយោងជើងទំព័រដល់ការវិភាគ

---

[487] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១៩។

[488] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤០ ជើងទំព័រ ៣៣៨ សម្រាប់សារណាលើអង្គហេតុ *ដកស្រង់* កថាខណ្ឌ ២០២៦ របស់គាត់ និងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧១ ជើងទំព័រ ១៣៩៣៨-១៣៩៣៩ (ដែលយោងទៅលើកថាខណ្ឌ ៣៣៩០ និង៣៥១៧ នៃសាលក្រមនេះ ហើយកថាខណ្ឌ ៣៥១៧ យោងទៅលើកថាខណ្ឌ ៣៣៨៥, ៣៣៩០, ៣៣៩១, ៣៣៩៦ នៃសាលក្រមនេះដែរ)។ កថាខណ្ឌ ២០២៦ របស់ម្ចាស់ បណ្តឹងសាទុក្ខ ដកស្រង់បន្ថែមនូវកថាខណ្ឌរបស់គាត់ កថាខណ្ឌ១០៧៥, ១៧៥៩, ១៨៩២-១៨៩៤ និងឯកសារ **F51** សំណើរបស់លោក ខៀវ សំផន សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ("សំណើសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម") កថាខណ្ឌ ២០-២៨។

[489] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧១ (ផ្នែកទី ១៨.២.១.៤ *សេចក្តីណែនាំអំពីការអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយរបស់ខ្លួន*), ៤២៧១-៤២៧៤ (ផ្នែករងអំពីការវាយតម្លៃដោយសន្និដ្ឋានលើភ័ស្តុតាងរបស់ អ.ជ.ស.ដ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម), ៣៧២៧-៤៩៧៤ និង ៤២៥៥-៤៣០៨ (ពាក់ព័ន្ធនឹងការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមរបស់ម្ចាស់បណ្តឹងសាទុក្ខ) ជើងទំព័រ ១៣៩៣៨ (*ដកស្រង់* ផ្នែកទី ១៣.៣ *ការប្រព្រឹត្តចំពោះជនជាតិវៀតណាម*) កថាខណ្ឌ ៣៣៩០ ដែលជាកថាខណ្ឌមួយក្នុងចំណោមកថាខណ្ឌជាច្រើននៅក្នុងផ្នែក *ភ័ស្តុតាងនៃគោលនយោបាយមួយកំណត់គោលដៅលើជនជាតិវៀតណាម* កថាខណ្ឌ ៣៣៨២-៣៤១៧) ជើងទំព័រ ១៣៩៣៩ (*ដកស្រង់*ផ្នែកទី១៣.៣ *ការប្រព្រឹត្តចំពោះជនជាតិវៀតណាម* កថាខណ្ឌ ៣៥១៧) ជើងទំព័រ ១៣៩៣៥ (*ដកស្រង់* ផ្នែកទី១៣.៣ *ការប្រព្រឹត្តចំពោះជនជាតិវៀតណាម* ជើងទំព័រ ១១៤៣៧ (សក្ខីកម្មរបស់ ឯក ហេន និងភ័ស្តុតាងដែលបញ្ជាក់អះអាង) ជើងទំព័រ ១១៤៣៦ (*ដកស្រង់*សក្ខីកម្មអំពីវគ្គរៀនសូត្រដែលម្ចាស់បណ្តឹងសាទុក្ខបានចូលរួម នៅពេលដែលគាត់ធ្វើសេចក្តីថ្លែងការណ៍ប្រឆាំងនឹងយួន ឬមិនបានដាក់ខ្លួនគាត់ឱ្យនៅឆ្ងាយ នៅពេលដែលអ្នកផ្សេងទៀត បានធ្វើសេចក្តីថ្លែងការណ៍បែបនោះ) ជើងទំព័រ ១៣៩៣៦ (*ដកស្រង់*ផ្នែកទី ១៣.៣ *ការប្រព្រឹត្តចំពោះជនជាតិវៀតណាម* កថាខណ្ឌ ៣៤០០ (សុន្ទរកថាប្រឆាំងវៀតណាមដោយម្ចាស់បណ្តឹងសាទុក្ខដែលស្របគ្នាទៅនឹងសក្ខីកម្មរបស់ ឯក ហេន) (*សូមមើល* កថាខណ្ឌ ៣៣៩០, ៣៤០៦ (ជើងទំព័រ ១១៨៤), ៣២១៦ (ជើងទំព័រ១១៤៨៤), ៣២១៦ (ជើងទំព័រ ១០៨២៥) និងដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ធុន (*សូមមើល* កថាខណ្ឌ ៣៩៦១)។ ជើងទំព័រ ១៣៩៣៧ (*ដកស្រង់*ផ្នែកទី១៣.៣ *ការប្រព្រឹត្តចំពោះជនជាតិវៀតណាម* កថាខណ្ឌ ៣៤១៦ (វោហារសាស្ត្ររបស់ប.ក.ក ប្រឆាំងនឹងទាហាន វៀតណាម និងការយោងទៅលើយួនដោយមិនរើសមុខ គឺសំដៅទៅលើជាតិពន្ធុវៀតណាមទាំងអស់)។

ភ័ស្តុតាងមុនៗ មានចំនួនច្រើនជងជាងម្ចាស់បណ្តឹងសាទុក្ខរៀបរាប់ និងពុំបានកំណត់នូវកំហុសឆ្គងក្នុងការវាយតម្លៃភ័ស្តុតាងពីសំណាក់អង្គជំនុំជម្រះសាលាដំបូងទេ។ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវតម្រូវឱ្យលើកឡើងសាជាថ្មីនូវការវិភាគ និងការសន្និដ្ឋានពីមុនៗឡើយ ប៉ុន្តែអាចយោងឱ្យបានត្រឹមត្រូវត្រឡប់ទៅវិញតាមរយៈលេខយោងជើងទំព័រ។

131. ការព្រួយបារម្ភរបស់ម្ចាស់បណ្តឹងសាទុក្ខថាប្រភពតែមួយនៃសុន្ទរកថារបស់គាត់គឺសាក្សី ឯក ហេន[490] គឺជាការភាន់ច្រឡំ។ បន្ថែមពីលើប្រភពជាច្រើនដែលមានការបញ្ជាក់ ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន បានផ្តល់សក្ខីកម្មថា ម្ចាស់បណ្តឹងសាទុក្ខបានថ្លែងថា “យើងធ្វើបដិវត្តិន៍ដើម្បីលុបបំបាត់របប លន់ ណល់។ មួយទៀតគឺថាលុបបំបាត់របបនាយទុន សក្តិភូមិ បញ្ញាវន្ត។ គាត់ [ម្ចាស់បណ្តឹងសាទុក្ខ]មិនឱ្យមានទេ”[491]។ ការព្រួយបារម្ភរបស់ម្ចាស់បណ្តឹងសាទុក្ខក៏បង្ហាញអំពីការយល់ខុសរបស់គាត់ទៅលើការវិភាគភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ ដែលអង្គជំនុំជម្រះសាលាដំបូងផ្អែកលើយ៉ាងត្រឹមត្រូវក្នុងការសន្និដ្ឋានតាមការបង្ហាញភ័ស្តុតាងអំពីការដឹង និងចេតនារបស់ ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រព្រឹត្តនៅក្នុងអំឡុងរបបខ្មែរក្រហម[492]។

132. ការផ្អែករបស់ម្ចាស់បណ្តឹងសាទុក្ខលើកថាខណ្ឌបន្ថែមក្នុងបណ្តឹងសាទុក្ខរបស់គាត់ក្នុងការកំណត់កំហុសគឺក៏ជាការភាន់ច្រឡំដូចគ្នាដែរ។ កថាខណ្ឌទាំងនេះ និង *សំណើសុំភ័ស្តុតាងបន្ថែម* ជំទាស់គ្នាជាមួយការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភាពជឿជាក់បានរបស់ ឯក ហេន[493]

[490] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤០ ជើងទំព័រ ៣៣៨ *យោងទៅ*កថាខណ្ឌ ២០២៦។

[491] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦១។ ការលើកឡើងនេះ ធ្វើឱ្យអាសារឥតបានការនូវទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខក្នុងកថាខណ្ឌ ២០២៦ ដែលថាការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថាសេចក្តីថ្លែងការណ៍ ជារបស់ម្ចាស់បណ្តឹងសាទុក្ខនោះ មិនមានប្រភព។ ការដកស្រង់របស់ អ.ជ.ស.ដ ក្នុងកថាខណ្ឌ ៤២៧២ ជើងទំព័រ ១៣៩៤១ ដល់កថាខណ្ឌ ៤២៧២ ត្រូវបានមើលឃើញយ៉ាងច្បាស់ថាជាកំហុសរដ្ឋបាល។

[492] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦២-៦២៤ (តួនាទី និងមុខងារ), ៤២០១-៤៣១៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌ)។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២ និងផ្នែកទី ៨.គ ចេតនា/ការរួមចំណែក (ការរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួម)។

[493] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤០ ជើងទំព័រ ៣៣៨ *ដកស្រង់* កថាខណ្ឌ ២០២៦ របស់គាត់ (ការចូលរួមក្នុងគោលបំណងរួមខុសពីការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម, មតិណែនាំដែលត្រូវបានចោទប្រកាន់) ដែល *ដកស្រង់* កថាខណ្ឌ១០៧៥របស់គាត់ (ធាតុផ្សំអត្តនោម័តិនៃអំពើប្រល័យពូជសាសន៍, ចេតនាក្នុងការបំផ្លាញក្រុមជាតិពន្ធុវៀតណាម, កំហុសពាក់ព័ន្ធនឹងសេចក្តីប្រកាសដែលបានកំណត់ថាជារបស់ថ្នាក់ដឹកនាំ), ១៧៥៩ (មុខងារបន្ទាប់បន្សំផ្សេងទៀត, វគ្គរៀនសូត្រ, ភាពជឿជាក់បានលើឯក ហេន),១៨៩២-១៨៩៤ (ជាតិពុន្ធវៀតណាម, ការទាញសេចក្តីសន្និដ្ឋានពីគោលនយោបាយ ប.ក.ក, ការជម្លៀស)។

មិនអើពើលើការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាងទាំងអស់។ ការពិនិត្យឡើងវិញលើសក្ខីកម្មនិងចម្លើយក្នុងតុលាការរបស់សាក្សីពុំបង្ហាញកំហុសក្នុងការផ្តល់ភាពជឿជាក់បាននៃសក្ខីកម្មរបស់ ឯក ហេន ឡើយ។ ឯក ហេន បានផ្តល់ព័ត៌មានលម្អិត ក្នុងនោះ រួមទាំងអំពីវគ្គរៀនសូត្រដឹកនាំដោយម្ចាស់បណ្តឹងសាទុក្ខ។ គាត់នៅតែមានជំហររឹងដដែលថា ម្ចាស់បណ្តឹងសាទុក្ខគឺជាអ្នកដែលនិយាយថា ប៉ង់ ជាជនក្បត់នៅក្នុងវគ្គរៀនសូត្រនោះ[494]។ នេះជា ចំណុចសំខាន់ ដោយហេតុថាវាជួយឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់កាលបរិច្ឆេទនៃវគ្គរៀនសូត្ររបស់ម្ចាស់បណ្តឹងសាទុក្ខ។ កាលបរិច្ឆេទនានាច្រើនតែមានការច្រឡំជាមួយនឹងការកន្លងទៅនៃពេលវេលា ពីព្រោះភ័ស្តុតាងផ្សេងទៀតបញ្ជាក់ថា ប៉ង់ ត្រូវបានចាប់ខ្លួនរវាងខែមេសា ឆ្នាំ១៩៧៨[495]។ ឯក ហេន បានពន្យល់យ៉ាងច្បាស់ និងសមហេតុផលអំពីភាពមិនស្របគ្នាពាក់ព័ន្ធនឹងរយៈពេលនៃវគ្គរៀនសូត្រ ដោយកត់សម្គាល់ថារយៈពេលនៃវគ្គសិក្សានោះគឺប្រហែល ១ ថ្ងៃ ឬ ១ ព្រឹក ប៉ុន្តែមានវគ្គស្វ័យទិតៀនតាមក្រោយទៀត ដែលមានរយៈពេលប្រហែល១សប្តាហ៍[496]។

133. ភ័ស្តុតាងរបស់ ឯក ហេន ក៏មានសូចនាករផ្ទៃក្នុងនៃការជឿទុកចិត្តផងដែរ។ គាត់និយាយថាគឺនៅក្នុងវគ្គរៀនសូត្រនោះហើយដែលគាត់ដឹងថា ប៉ង់ ជា "ប្រធានមន្ទីរ៨៧០"[497] ដោយពុំមានការបញ្ជាក់ថាគាត់ដឹងអង្គហេតុនេះដោយឯករាជ្យទេ។ ម្ចាស់បណ្តឹងសាទុក្ខផ្អែកលើការអានសក្ខីកម្ម

---

[494] ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក ហេន ឆ.៤៣. ៤៥។ ឯកសារ **E3/474** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក ហេន EN 00205049 (ប៉ង់ត្រូវបានចាប់ខ្លួនដោយសារគាត់ជាជនក្បត់ចូលដៃជាមួយយួន)។ ឯកសារ **E1/217.1** ប្រតិចារឹក ឯក ហេន ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.09.16-11.26.06 ទំព័រ ៣៩-៤៤ បន្ទាត់ ១៤-២៤ (ប៉ង់ត្រូវបានចាប់ខ្លួនដោយសារគាត់ជាជនក្បត់ចូលដៃជាមួយយួន)។

[495] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣១៥ ជើងទំព័រ ៧៨២៣ និងភ័ស្តុតាងដែលបានដកស្រង់។

[496] ឯកសារ **E1/217.1** ប្រតិចារឹក ឯក ហេន ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 15.17.13-15.23.37 ទំព័រ ៩៧-៩៨ បន្ទាត់ ១-១១។

[497] ឯកសារ **E3/474** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក ហេន EN 00205049។ ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក ហេន ឆ.៣៩, ៤៣ (វគ្គរៀនសូត្រជាមួយម្ចាស់បណ្តឹងសាទុក្ខដែលនិយាយអំពីកម្មាភិបាលភូមិភាគឧត្តរដែលបានក្បត់ពួកគេ ហើយក្រោយមក ការក្បត់បានរាលដាលដល់មន្ទីរ៨៧០ ដែលមានប៉ង់ ជា "ប្រធាន"។ ម្ចាស់បណ្តឹងសាទុក្ខបាននិយាយថា ប៉ង់បានក្បត់ពួកគេ)។ ឯកសារ **E1/217.1** ប្រតិចារឹក ឯក ហេន ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.10.24-11.16.44 ទំព័រ ៤០-៤១ បន្ទាត់ ៤-២៣ (សាក្សីរក្សាចម្លើយរបស់គាត់នៅក្នុងកំណត់ហេតុ ស្តាប់ចម្លើយរបស់គាត់ ឯកសារ **E474** ដែលសាក្សីបាននិយាយថាម្ចាស់បណ្តឹងសាទុក្ខ បានប្រាប់អំពីការចាប់ខ្លួនប៉ង់ ប្រធានមន្ទីរ៨៧០) ម៉ោង 14.32.47-14.36.29 ទំព័រទី៨៨-៨៩ បន្ទាត់ ១៨-៨ (ម្ចាស់បណ្តឹងសាទុក្ខបាននិយាយថាប៉ង់ត្រូវបានចាប់ខ្លួន និងបាននិយាយដល់មន្ទីរ៨៧០)។ ជាការកត់សម្គាល់ ម្ចាស់បណ្តឹងសាទុក្ខ គិតថាប៉ង់បានក្លាយជាប្រធានមន្ទីរ៨៧០ (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៥)។

សាក្សីតាមការជ្រើសរើសដើម្បីទាញទឡ្ហីករណ៍ថាការថ្លែងរបស់គាត់ថា "នៅកម្ពុជាគ្មានយួនទេ" គឺមានការបកស្រាយផ្សេងៗគ្នា [ដោយទំនងជាអះអាងថាក្នុងន័យល្អ][498]។ ការអានរួមទៅលើសក្ខីកម្មសាក្សីពាក់ព័ន្ធនឹងការថ្លែងនេះ ជំទាស់ការអះអាងនោះ។ សាក្សីបានផ្តល់សក្ខីកម្មនៅក្នុងបរិបទនៃស្ថានការណ៍នៅពេលដែលម្ចាស់ បណ្តឹងសាទុក្ខថ្លែងថាប៉ង់ គឺជាអ្នកក្បត់ចូលដៃជាមួយយួន។ ឯក ហេន ផ្តល់សក្ខីកម្មថា "កាលពីពេលនោះ យួន ពុំមែនជាមិត្តរបស់យើងទេ ពីព្រោះប្រទេសយើងកាលនុងអត់យួនទេ មានតែខ្មែរ។ ហើយគាត់ [ម្ចាស់បណ្តឹងសាទុក្ខ] ក៏និយាយអំពីបញ្ហានេះដែរ។ គាត់និយាយថាខ្មែរត្រូវតែសាមគ្គីគ្នា ប្រទេសខ្មែរអត់យួនទេ"[499]។ ជាងនេះទៀត ការជំទាស់ទាំងនេះមិនទទួលផលឡើយ ដូចដែលបានពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី២៣ (ការទទួលយកកំណត់ហេតុស្តាប់ចម្លើយគាត់) និង២០៤ (ការរៀននយោបាយរកខ្មាំង)។

## *មូលដ្ឋានទី ២១៖ ភាពស៊ីសង្វាក់គ្នា*[500]

134. **មូលដ្ឋានទី ២១គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុដោយអនុវត្តមិនមានសង្គតិភាពចំពោះក្របខ័ណ្ឌដែលខ្លួនបង្កើតសម្រាប់វាយតម្លៃភស្តុតាងស៊ីចង្វាក់ ជាក្របខ័ណ្ឌមួយដែលម្ចាស់បណ្តឹងសាទុក្ខពុំបដិសេធ។**

135. មូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលឡើយ ដោយហេតុថាជាថ្មីម្តងទៀតគាត់យោងដល់កថាខណ្ឌនានានៅក្នុងសារណារបស់គាត់ដែលពុំផ្តល់ការគាំទ្រ"[501]។ ការផ្អែករបស់គាត់លើកថាខ័ណ្ឌ២៣៨ ទាក់ទិននឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងទេសកាលមិនបានទទួលផល ដោយហេតុថាគាត់មិនអើពើដល់ភាសាដ៏សំខាន់នៅក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០២/០១៖ "ដោយសារតែការដាក់ពិរុទ្ធភាពបានផ្អែកលើការយល់ឃើញជាទូទៅដូច្នេះតម្រូវឱ្យមានការបង្ហាញឱ្យហួសពីវិមតិសង្ស័យ។ [...] ម្ចាស់បណ្តឹងសាទុក្ខដែលចោទថាមានកំហុសអង្គហេតុមានបន្ទុកត្រូវបង្ហាញថា ការគិតដោយស្មានៗរបស់

---

[498] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៦។

[499] ឯកសារ **E1/217.1** ប្រតិចារឹក ឯក ហេន ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.29.00-11.33.02 ទំព័រ ៤៧ បន្ទាត់ ៦-២២។

[500] <u>មូលដ្ឋានទី ២១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភាពស៊ីសង្វាក់គ្នា* កថាខណ្ឌ ២៤១-២៤២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១២ (ភាសាអង់គ្លេស) ទំព័រ ១០-១១ (ភាសាបារាំង) ទំព័រ ១៥ (ភាសាខ្មែរ)។

[501] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៤២ ជើងទំព័រ ៣៤១ (*ដកស្រង់*កថាខណ្ឌរបស់ខ្លួន កថាខណ្ឌ ២៣៨, ៣១២-៣១៣), ៣៤២ (*ដកស្រង់*កថាខណ្ឌ ៧៨១, ៨៦៦)។

តុលាការជាន់ដំបូងក្នុងការផ្ដល់ការយល់ឃើញនោះជាការពុំសមហេតុផល”[502]។ ដូចដែលបានពន្យល់ នៅកន្លែងផ្សេងៗនៃចម្លើយតបនេះ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបំពេញបាននូវបន្ទុកនេះ និងខកខានមិនបានផ្ដល់ការពន្យល់សមហេតុផលជាជម្រើសចំពោះការសន្និដ្ឋានដែលធ្វើឡើងដោយ អង្គជំនុំជម្រះសាលាដំបូង[503]។ ការយោងរបស់គាត់ដល់កថាខណ្ឌ៣១២-៣១៣[504] ពាក់ព័ន្ធនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាងពាក្យចចាមអារ៉ាម មិនទទួលផលដោយមូលហេតុស្រដៀងគ្នាៈ ម្ចាស់បណ្ដឹងសាទុក្ខពុំកំណត់ថា (i) អង្គជំនុំជម្រះសាលាដំបូងខកខានពុំបានអនុវត្តក្របខ័ណ្ឌដែលខ្លួនបានកំណត់សម្រាប់ការវាយតម្លៃបែបនេះ (ii) អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់និងអង្គហេតុនៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើភ័ស្តុតាងនោះ (iii) ពុំមានអ្នករកអង្គហេតុដ៏សមហេតុផលអាចបានផ្អែកលើភ័ស្តុតាងដែលរងការតវ៉ានៅក្នុងការសម្រេចសន្និដ្ឋានដែលរងការតវ៉ានេះឡើយ[505]។

136. ដូចគ្នានេះដែរ ម្ចាស់បណ្ដឹងសាទុក្ខពុំរកឃើញការគាំទ្រនៅក្នុងកថាខណ្ឌ៧៨១ និង ៨៦៦ របស់គាត់ឡើយ[506]។ ទឡ្ហីករណ៍របស់គាត់នៅក្នុងកថាខណ្ឌ៧៨១ ទាក់ទិននឹងការចោទថាខ្វះភ័ស្តុតាងក្នុងការកំណត់ការស្លាប់ដែលបណ្ដាលមកពីឧបទ្ទវហេតុនៅទំនប់១មករា[507] ពុំកំណត់កំហុសនៅក្នុងការផ្អែករបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាងក្នុងតុលាការរបស់សាក្សី[508] និងភ័ស្តុតាង

---

[502] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៣៨ ជើងទំព័រ ៣៣០។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៩៨ (គូសបញ្ជាក់បន្ថែម)។

[503] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨។

[504] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៤២ ជើងទំព័រ ៣៤១ *ដកស្រង់*កថាខណ្ឌ ៣១២-៣១៣។

[505] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២។

[506] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៤២ ជើងទំព័រ ៣៤២ *ដកស្រង់*កថាខណ្ឌ ៧៨១, ៨៦៦។

[507] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១១៦។

[508] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៣៥ *ដកស្រង់* ឯកសារ **E1/339.1** ប្រតិចារឹក នួន ណារុំ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង 11.13.47-11.19.02 ទំព័រ ៤០ បន្ទាត់ ៧-១៤ (ឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្ដីថាតើគាត់ “ធ្លាប់ឃើញមានមនុស្សទទួលរបួស ឬក៏ទទួលគ្រោះថ្នាក់ដែរឬទេ” ដើមបណ្ដឹងរដ្ឋប្បវេណី ដែលកំពុងផ្ដល់សក្ខីកម្មទាក់ទងនឹងហេតុការណ៍នៅទំនប់១មករា បានឆ្លើយតបថាគាត់បានឃើញការបាក់ដីនៅកន្លែងដែលយុវជនកំពុងជីកដី) (គូសបញ្ជាក់បន្ថែម)។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៨ *ដកស្រង់* ឯកសារ **E1/305.1** ប្រតិចារឹក មាស ឡៃហួរ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.40.37-09.42.49 ទំព័រ ១៧ បន្ទាត់ ២-៨ (គាត់បានឃើញដីបាក់សម្លាប់មនុស្សដែលកំពុងជីកដី។) ម៉ោង 10.34.23-10.36.10 ទំព័រ ៣០ បន្ទាត់ ៣-៨ (មានការបាក់ដីនៅកន្លែងមួយដែលមានអ្នកមកពីភូមិផ្សេងធ្វើការ)។

ពាក្យចចាមអារ៉ាមរបស់អ្នកផ្សេងទៀត[509]ពាក់ព័ន្ធនឹងឧបទ្ទវហេតុបាក់ដី ដែលការបាក់ដីខ្លះបណ្តាលឱ្យស្លាប់ដើម្បី "បញ្ជាក់ថាឧបទ្ទវហេតុ[បាក់ដី]បានកើតឡើង"។ សក្ខីកម្មរបស់សាក្សីទាំងនេះនិងរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺមានលក្ខណៈច្បាស់និងឆ្លើយតបអំពីអ្វីដែលពួកគេបានសង្កេត និងអ្វីដែលពួកគេត្រូវបានប្រាប់។ ពួកគេបានផ្តល់ភស្តុតាងគ្រប់គ្រាន់អំពីប្រភពព័ត៌មានរបស់ពួកគេ។ ហ៊ុន សេដ្ឋានី បានផ្តល់សក្ខីកម្មថាសហការីរបស់គាត់ប្រាប់គាត់អំពីការបាក់ដី។ អ៊ុន វ៉ាន់ និយាយថាអ្នកដែលទៅមើលឧបទ្ទវហេតុនោះបានប្រាប់គាត់[510]។ ការអះអាងមិនត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថាភស្តុតាងនេះមិនអាចជាការបញ្ជាក់ការស្លាប់បណ្តាលមកពីការបាក់ដី មិនអើពើទាំងពីថាអង្គជំនុំជម្រះសាលាដំបូងមួយអាចផ្អែកលើពាក្យចចាមអារ៉ាមដែលពុំមានការបញ្ជាក់ដើម្បីកំណត់ធាតុផ្សំបទល្មើស ទោះបីជាភស្តុតាងបែបនេះត្រូវតែបានប្រើប្រាស់ដោយប្រុងប្រយ័ត្ន និងការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០២/០១ ដែលថាភស្តុតាងក្រៅតុលាការ ដែលមានជាធម្មតាមានតម្លៃភស្តុតាងទាប អាចត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ដល់ភស្តុតាងក្នុងតុលាការ[511]។ ការអះអាងនេះក៏មិនអើពើដល់ការណ៍ដែលថាអង្គជំនុំជម្រះសាលាដំបូងមួយអាចផ្អែកលើសាក្សីក្នុងការគាំទ្រការសន្និដ្ឋានមួយ[512] នៅទីនេះយើងមានសាក្សីផ្ទាល់ភ្នែកចំនួនពីរនាក់ដែលឃើញការបាក់ដីយ៉ាងច្បាស់ដែលបង្កការស្លាប់និងរបួស[513]។

---

[509] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៨ *ដកស្រង់* ឯកសារ **E1/305.1** ប្រតិចារឹក ហ៊ុន សិត្ថានី ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.46.36-15.49.15 ទំព័រ ៩៥ បន្ទាត់ ១៩-២៣ (បានឮថាមនុស្សម្នាក់បានស្លាប់ដោយសារការបាក់ដី)។ឯកសារ **E1/309.1** ប្រតិចារឹក អ៊ុត សេង ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 13.42.39-13.45.54 ទំព័រ៥៤ បន្ទាត់ ២៥-ទំព័រ ៥៥ បន្ទាត់ ៥ (សាក្សីបានឮអំពីការបាក់ដីដែលបណ្តាលឱ្យមនុស្សស្លាប់ ដោយសារជីកដីជ្រៅពេក)។ ឯកសារ **E1/307.1** ប្រតិចារឹក អ៊ុន វ៉ន ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.34.36-09.37.13 ទំព័រ ១៤ បន្ទាត់ ១៨-២៣ ម៉ោង 15.21.40-15.23.52 ទំព័រ ៧៩ បន្ទាត់ ២៣-២៥ ម៉ោង 15.21.40-15.23.52 ទំព័រ ៨០ បន្ទាត់ ៤ (អ្នកដែលបានទៅឃើញហេតុការណ៍គ្រោះថ្នាក់នោះ បានប្រាប់គាត់ថា ការបាក់ដីបានសម្លាប់កម្មករមួយចំនួន ហើយមានម្នាក់បានស្លាប់នៅហ្នឹងកន្លែង)។

[510] ឯកសារ **E1/305.1** ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.46.36-15.49.15 ទំព័រ៩៥ បន្ទាត់ ១៩-២៣។ ឯកសារ **E1/307.1** ប្រតិចារឹក អ៊ុន វ៉ន ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.34.36-09.37.13 ទំព័រ ១៤ បន្ទាត់ ១៨-២៣ ម៉ោង 15.21.40-15.23.52 ទំព័រ ៧៩ បន្ទាត់ ២៣-ទំព័រ ៨០ បន្ទាត់ ៤ (ទទួលព័ត៌មានពីអ្នកដែលបានឃើញហេតុការណ៍នោះ)។

[511] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៣០, ៤៣៥។

[512] សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៩៤៩។

[513] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៣៥ *ដកស្រង់* ឯកសារ **E1/339.1** ប្រតិចារឹក នួន ណារុំ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង 11.13.47-11.19.02 ទំព័រ ៤០ បន្ទាត់ ៧-១៤ (ឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី

137. កថាខណ្ឌ៨៦៦របស់ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានកំណត់នូវកំហុសផងដែរ[514]។ កថាខណ្ឌនោះ ដែលពាក់ព័ន្ធនឹងការប្រើកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គលចំនួនពីរនាក់ដែលទទួលមរណភាពទៅហើយ អ៊ឹង ដុស និង សុខ អែល ក្នុងកំណត់ការធ្វើមនុស្សឃាតទៅលើបុរសម្នាក់ឈ្មោះ ហឹស មិនអើពើថាភ័ស្តុតាងបែបនេះអាចត្រូវបានប្រើនៅកន្លែងដែលដូចនៅទីនេះដែរ ដែលអ្នកថ្លែងបានទទួលមរណភាពទៅហើយ[515]។ ពុំមានវិធានភ័ស្តុតាងដាច់ខាតដែលអ្នកវិនិច្ឆ័យឥតលម្អៀងលើអង្គហេតុម្នាក់មិនអាចផ្តន្ទាទោស ដោយឈរលើមូលដ្ឋាននៃភ័ស្តុតាងពីសាក្សីម្នាក់ឬច្រើនដែលមិនត្រូវបានដាក់ឱ្យសួរដេញដោលដោយមេធាវីការពារក្តីឡើយ[516]។ ជាការពិតណាស់ អញ្ញត្រកម្មត្រូវបានអនុញ្ញាតនៅពេល (ii) មានមូលហេតុសមស្របសម្រាប់ការមិនចូលរួមរបស់សាក្សី ដូចក្នុងករណីនៅទីនេះ និង (ii) ក្នុងករណីដែលការផ្តន្ទាទោសត្រូវបានផ្អែកដាច់ខាតឬតែទៅលើភ័ស្តុតាងនោះ ដែលមានកត្តាតុល្យកម្មគ្រប់គ្រាន់ដែលអនុញ្ញាតឱ្យមានការវាយតម្លៃដោយត្រឹមត្រូវលើភ័ស្តុតាង[517]។ អង្គជំនុំជម្រះសាលាដំបូងពិចារណាយ៉ាងត្រឹមត្រូវដល់កាលៈទេសៈនេះ និងបានរម្លឹកដល់ភាពចាំបាច់ក្នុងការប្រយ័ត្នប្រយែងនៅពេលផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ[518]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការប្រយ័ត្នប្រយែងបែបនេះនោះឡើយ នៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើការរៀបរាប់ដែលមាន

---

ថាតើគាត់ "ធ្លាប់ឃើញមានមនុស្សទទួលរបួស ឬក៏ទទួលគ្រោះថ្នាក់ដែរឬទេ" ដើមបណ្តឹងរដ្ឋប្បវេណី ដែលកំពុងផ្តល់សក្ខីកម្មទាក់ទងនឹងហេតុការណ៍នៅទំនប់១មករា បានឆ្លើយតបថាគាត់បានឃើញការបាក់ដីនៅកន្លែងដែលយុវជនកំពុងជីកដី) (គូសបញ្ជាក់បន្ថែម)។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៨ *ដកស្រង់* ឯកសារ **E1/305.1** ប្រតិចារឹក មាស ឡៃហួរ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.40.37-09.42.49 ទំព័រ ១៧ បន្ទាត់ ២-៨ (គាត់បានឃើញដីបាក់សម្លាប់មនុស្សដែលកំពុងជីកដី។) ម៉ោង 10.34.23-10.36.10 ទំព័រ ៣០ បន្ទាត់ ៣-៨ (មានការបាក់ដីនៅកន្លែងមួយដែលអ្នកមកពីភូមិផ្សេងធ្វើការ)។

[514] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣១។

[515] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩០។

[516] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩០។

[517] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩០ *ដកស្រង់*រឿងក្តី *Al-Khawaja & Tahery តទល់នឹង* ចក្រភពអង់គ្លេស កថាខណ្ឌ ១២៧, ១៤៧, រឿងក្តី *Kazakov តទល់នឹងប្រទេសរុស្ស៊ី* កថាខណ្ឌ ២៩ សាលដីការឿងក្តី *Popović* កថាខណ្ឌ ៩០។

[518] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០៩៤។

លក្ខណៈច្បាស់លាស់ លម្អិត និងគួរឱ្យជឿជាក់បានរបស់សាក្សីផ្ទាល់ភ្នែកដែលបានផ្តល់ជូនដោយសាក្សីទាំងនេះ[519]។

138. ម្ចាស់បណ្តឹងសាទុក្ខពុំបានបង្ហាញថាការផ្តន្ទាទោសត្រូវបានផ្អែកដាច់ខាត ឬតែទៅលើភស្តុតាងនេះ[520] ដោយហេតុថាការកាត់ទោសត្រូវបានផ្អែកលើការសម្លាប់ថែមលើគ្នា មិនមែនការសម្លាប់ដោយឡែកៗឡើយ។ ប្រសិនបើគេអាចលើកទឡ្ហីករណ៍ថាវាជាករណីបែបនេះ ការបញ្ជាក់ទៅវិញទៅមក ដែលអាចជឿបាន គឺជាកត្តាតុល្យកម្មគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យមានការវាយតម្លៃត្រឹមត្រូវលើភស្តុតាង[521]។ ដោយការផ្តន្ទាទោសមានលក្ខណៈត្រួតៗគ្នា ទោះបីជាសន្មតកំហុសឆ្គងកាត់បន្ថយចំនួនអ្នកដែលត្រូវគេសម្លាប់មួយចំនួនតូច មិនអាចចាំបាច់ការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលឡើយ។

### *មូលដ្ឋានទី ២២៖ ភាពផ្ទុយគ្នា*[522]

139. **មូលដ្ឋានទី ២២ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការវាយតម្លៃភស្តុតាងពាក់ព័ន្ធនឹងបដិវាទកម្មឬភាពផ្ទុយគ្នានៅក្នុងសក្ខីកម្ម។**

140. ម្ចាស់បណ្តឹងសាទុក្ខទទួលយកក្របខ័ណ្ឌច្បាប់ដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងការវាយតម្លៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ បន្ទាប់មកហាក់ដូចជាមិនអើពើចំពោះកត្តាទាំងអស់ លើកលែងតែភាពមិនស្របគ្នាជាមួយសំណៅផ្សេងៗទៀត[523]។

141. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសន្និដ្ឋានភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន គួរឱ្យជឿបាន ដោយពិចារណាលើសក្ខីកម្ម

[519] ឯកសារ **E3/7703** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ួង ដុស (ការសម្លាប់ដោយការវាយដំទៅលើអ្នកទោសឈ្មោះ ហ៊ើស) EN 00242171-72។ ឯកសារ **E3/7702** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ អ៊ែល (ការសម្លាប់ដោយការ វាយដំទៅលើអតីតប្តីរបស់ប្រពន្ធនាពេលបច្ចុប្បន្នរបស់សុខ អ៊ែល) EN 00239510។

[520] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩០។

[521] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩០។

[522] <u>មូលដ្ឋានទី ២២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភាពផ្ទុយគ្នា* កថាខណ្ឌ ២៤៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១២ (ភាសាអង់គ្លេស) ទំព័រ ១១ (ភាសាបារាំង) ទំព័រ ១៥ (ភាសាខ្មែរ)។

[523] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩ (កត្តានានា រួមមានភាពអាចជឿជាក់ អត្តចរិត ការជំរុញពីខាងក្រៅដែលអាចមាន ការអះអាងបញ្ជាក់ និងកាលៈទេសៈទាំងអស់នៃរឿងក្តីនេះ)។

ទាំងមូលនិងកត្តានានាដែលទាក់ទិនសម្រាប់ការកំណត់មួយ ដូចជាការបញ្ជាក់ជាដើម[524]។ ម្ចាស់បណ្តឹងសាទុក្ខជាថ្មីម្តងទៀតផ្តោតលើការលំបាករបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរម្លឹកឡើងវិញនូវកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដែលបានកើតឡើង ដោយគ្មានពិចារណាថាដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មស្របៗគ្នាពាក់ព័ន្ធនឹងអង្គហេតុពិត ជាពិសេសការណ៍ដែលថាម្ចាស់បណ្តឹងសាទុក្ខមានវត្តមាននៅកន្លែងរៀនសូត្រនយោបាយនៅបុរីកីឡា និងអ្វីដែលគាត់និយាយ នៅក្នុងវគ្គនោះ[525]។ ពីដើមដល់ចប់នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដ៏វែង គាត់បានឆ្លើយ ដោយសមហេតុផល និងត្រង់ៗទៅនឹងការជំទាស់ភាពផ្ទុយគ្នាដែលបានលើកឡើងនៅក្នុងចម្លើយរបស់គាត់ ដោយពន្យល់ជាច្រើនលើកថាគាត់អាចចាំកាលបរិច្ឆេទខុស ប៉ុន្តែការរៀបរាប់របស់គាត់ "គឺជារឿងពិត"[526]។

142. ម្ចាស់បណ្តឹងសាទុក្ខកំណត់ប្រភេទភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីខុសពាក់ព័ន្ធនឹងវគ្គរៀនសូត្រនយោបាយ។ ជាការផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ដើមបណ្តឹងរដ្ឋប្បវេណីពុំបានផ្តល់សក្ខីកម្មថា "អ្នកឧទ្ទេសនាមទាំងអស់បាននិយាយដដែលៗដូចៗគ្នា"[527]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថាអ្នកឧទ្ទេសនាមនៅក្នុងវគ្គនេះ "និយាយភ្ជាប់គ្នាពីមួយទៅមួយ"[528] ម្នាក់ៗ "លើកយកពាក្យពីរបីម៉ាត់" ពីអ្នកឧទ្ទេសនាមពីមុនមុនពេលនិយាយខ្លួនឯង[529]។ ម្ចាស់

[524] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩។

[525] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៤២។

[526] ឯកសារ **E1/116.1** ប្រតិចារឹក អែម អឿន ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ម៉ោង 10.08.58-10.10.15 ទំព័រ ២៥ បន្ទាត់ ៣-៩។ សូមមើលផងដែរ *ឧទាហរណ៍* ឯកសារ **E1/116.1** ប្រតិចារឹក អែម អឿន ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ម៉ោង 09.26.16-10.10.15 ទំព័រ១០-២៥ (កាលបរិច្ឆេទមិនច្បាស់លាស់) ម៉ោង 10.07.01-10.08.58 ទំព័រ ២៤ បន្ទាត់ ១៣-២១ (កាលបរិច្ឆេទជាក់លាក់ គឺក្នុងអំឡុងរដូវវស្សា។ សូមអធ្យាស្រ័យ ខ្ញុំមិនចាំកាលបរិច្ឆេទជាក់លាក់ទេ។ ខ្ញុំមិនយកចិត្តទុកដាក់អំពីកាលបរិច្ឆេទប៉ុន្មានទេ។ ខ្ញុំផ្តោតតែធ្វើយ៉ាងណាដើម្បីឱ្យបានរស់) ម៉ោង 14.59.06-15.01.56 ទំព័រ ៧៧ បន្ទាត់ ១៧-២២ (ហេតុការណ៍ដដែល។ បញ្ហាគឺកាលបរិច្ឆេទមិនបានដាក់ចូលឱ្យបានត្រឹមត្រូវ) ម៉ោង 15.03.15-15.04.00 ទំព័រ ៧៨ បន្ទាត់ ២១-២៤ (មានបញ្ហាចងចាំកាលបរិច្ឆេទជាក់លាក់) ម៉ោង 15.58.38-16.01.24 ទំព័រ ៩៣ បន្ទាត់ ៥-១៣ (ខ្លឹមសារនៃសេចក្តីថ្លែងការណ៍គឺត្រឹមត្រូវ។ ប្រហែលជាមានកំហុសទាក់ទងនឹងកាលបរិច្ឆេទ)។ ឯកសារ **E1/117.1** ប្រតិចារឹក អែម អឿន ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ម៉ោង10.04.02-10.06.39 ទំព័រ ២៣ បន្ទាត់ ២៣-ទំព័រ ២៥ បន្ទាត់ ៤ (សូមអធ្យាស្រ័យ "ការចងចាំមិនមែនដូចជាការថតទុក ហើយក៏មិនមែនដូចការសរសេរទេ ដូច្នេះអាចនឹងមានមុន ឬមានក្រោយ")។

[527] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥៧។

[528] ឯកសារ **E1/113.1** ប្រតិចារឹក អែម អឿន ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 14.30.56-14.32.48 ទំព័រ ៨២ បន្ទាត់ ១៧-ទំព័រ ៨៣ បន្ទាត់ ២។ ឯកសារ **E1/115.1** ប្រតិចារឹក អែម អឿន ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ម៉ោង 09.45.25-11.05.25 ទំព័រ ១៦-២០។

[529] ឯកសារ **E1/113.1** ប្រតិចារឹក អែម អឿន ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 14.32.48-14.35.53 ទំព័រ ៨៣ បន្ទាត់ ១៥-១៩។

បណ្តឹងសាទុក្ខផ្អែកដោយខុសទៅលើការយោងតាមការជ្រើសរើស ដល់ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់គាត់ ក្នុងការបង្ខូចភ័ស្តុតាងរបស់គាត់[530]។ ដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ច្បាស់អំពីកាលៈទេសៈជុំវិញ និងលក្ខណៈបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍របស់គាត់ និងមូលហេតុដែលគាត់នៅតែស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ជាមួយប្រពន្ធទីមួយរបស់គាត់[531]។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងអាចផ្អែកលើសក្ខីកម្មរបស់សាក្សីម្នាក់ក្នុងការកំណត់ការសន្និដ្ឋាន[532] ម្ចាស់បណ្តឹងសាទុក្ខមិនអើពើថាភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺជាប្រភេទមួយនៃប្រភេទជាច្រើនសម្រាប់ការលើកមកយោងសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលរួមបញ្ចូលវាផងដែរ[533]។

## *មូលដ្ឋានទី ២៤៖ ការអានឡើងវិញមុនពេលចូលបង្ហាញខ្លួន*[534]

143. **មូលដ្ឋាន២៤គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់នូវកំហុសអង្គច្បាប់ នៅក្នុងការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យ [អង្គភាពគាំពារជនរងគ្រោះ និងសាក្សី] អនុញ្ញាតឱ្យសាក្សីទាំងអស់ អានឡើងវិញនូវចម្លើយរបស់ពួកគេមុនពេលឡើង ផ្តល់សក្ខីកម្មនៅសវនាការ។**

144. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខមិនអាចបង្ហាញឧទាហរណ៍ណាមួយដែលថាអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តក្របខ័ណ្ឌវាយតម្លៃគ្រប់ជ្រុងជ្រោយដែលបានកំណត់សម្រាប់ការវាយតម្លៃចុងក្រោយរបស់ខ្លួនទៅលើសក្ខីកម្មរបស់សាក្សីដែលបាន

---

[530] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៧២ *ដកស្រង់*ក្នុងកថាខណ្ឌ ១៧៥៨ ជើងទំព័រ ៣៣៩០។

[531] ឯកសារ **E1/113.1** ប្រតិចារឹក អែម អឿន ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 15.53.21-15.59.41 ទំព័រ ១០៣ បន្ទាត់ ២១-ទំព័រ ១០៦ បន្ទាត់ ៥ ម៉ោង 16.01.45-16.04.47 ទំព័រ ១០៧ បន្ទាត់ ១-១០។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥។

[532] សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៩៤៩។

[533] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០៧ (ជើងទំព័រ ១៩០៤), ៣៦២១ (ជើងទំព័រ ១២០៩២), ៣៧៣៩ (ជើងទំព័រ ១២៤៧៣), ៤០១៥ (ជើងទំព័រ ១៣៣០១)។ ខុសពីកថាខណ្ឌដែលបានដកស្រង់ផ្សេងទៀត កថាខណ្ឌ ៣៩៦៧ (ជើងទំព័រ ១៣២០៤) ដកស្រង់តែ អែម អឿន ប៉ុណ្ណោះ ពីព្រោះ អ.ជ.ស.ដ កំពុងដកស្រង់ភ័ស្តុតាងរបស់គាត់ដោយផ្ទាល់។

[534] មូលដ្ឋានទី ២៤៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការអានឡើងវិញមុនពេលចូលបង្ហាញខ្លួន* កថាខណ្ឌ ២៤៧-២៥២។ ឯកសារ **F54.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១២-១៣ (ភាសាអង់គ្លេស) ទំព័រ ១១ (ភាសាបារាំង) ទំព័រ ១៦ (ភាសាខ្មែរ)។

អានចម្លើយរបស់ពួកគេពីមុនៗមុនពេលផ្តល់សក្ខីកម្ម[535]។ ម្ចាស់បណ្តឹងសាទុក្ខក៏ពុំកំណត់មូលដ្ឋានណាមួយក្នុងការបដិសេធការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ផងដែរដែល "ហានិភ័យជាក់ស្តែងបណ្តាលមកពីការអានចម្លើយពីមុននៅក្នុងករណីនេះ មិនខ្លាំងទេ" ដោយផ្អែកមួយផ្នែកលើការពិចារណាដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនៅ ទីនេះ និង ការកំណត់ផ្សេងៗទៀតដែលអនុវត្តស្មើៗគ្នាក្នុងករណីនេះ[536]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបញ្ចេញការមិនយល់ស្របរបស់គាត់ជាមួយនឹងការអនុវត្តមួយដែលអង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថាពុំបង្កើតបានជាកំហុសប៉ុណ្ណោះ[537]។

145. ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានផងដែរក្នុងការកំណត់កំហុសអង្គច្បាប់ត្រង់ថា ភ័ស្តុតាង "តម្រូវឱ្យមានការពិភាក្សាដេញដោលចំពោះមុខក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី"[538]។ គាត់ពុំបង្ហាញថាសាក្សីមិនបាននិយាយផ្ទាល់មាត់ ថាពួកគេមិនត្រូវបានអនុញ្ញាតឱ្យអានចម្លើយដែលបានរៀបចំជាមុន[539]ថាភាគីត្រូវបានបដិសេធ "សិទ្ធិក្នុងការពិនិត្យលើភាពគួរជឿជាក់បានរបស់សាក្សីលើចំណុចនៅក្នុង ឬក្រៅពីចម្លើយមុនៗរបស់គាត់"[540] ឬ "សួរសំណួរបន្ថែម ប៉ុន្តែកម្រិតត្រឹមសំណួរដែលចាំបាច់ដើម្បីបញ្ជាក់អំពីភាពពាក់ព័ន្ធនៃបញ្ហា ដែលមិនទាន់បានឆ្លើយគ្រប់គ្រាន់នៅឡើយនៅក្នុងចម្លើយទាំងនោះឬមិនត្រូវបានអ្នកស៊ើបអង្កេត នៃកសចស សម្ភាសសួរតែប៉ុណ្ណោះ"[541]។ លើកលែងតែសាក្សីមានការចងចាំជារូបភាព បើមិនដូច្នេះទេសក្ខីកម្មក្នុងតុលាការនឹងមិនអាចកែប្រែបានច្រើនដោយការអានចម្លើយមុនៗក្រៅតុលាការឡើយ។

146. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា "តុលាការកំពូលមិនគួរផ្តល់សុពលភាពដល់វិធីសាស្ត្របែបនេះ[ដែលអនុញ្ញាតឱ្យសាក្សីអានឡើងវិញនូវចម្លើយរបស់ពួកគេមុនៗ មុននឹងផ្តល់សក្ខីកម្ម] ដែលប៉ះពាល់ដល់គោលការណ៍សួរដេញដោលផ្ទាល់មាត់"[542] គួរតែបដិសេធថាមិនត្រឹមត្រូវ។ ម្ចាស់បណ្តឹងសាទុក្ខកំពុងស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាឡើងវិញនូវការវិភាគរបស់

[535] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៩, ៥៣ (រួមមាន អត្តចរិត, ភាពមិនស៊ីសង្វាក់ពាក់ព័ន្ធនឹងអង្គហេតុសំខាន់ៗ, ការជំរុញពីខាងក្រៅដែលអាចមាន និងការអះអាងបញ្ជាក់)។

[536] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦៨។

[537] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦៩, ២៦២, ២៦៣។

[538] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥១។

[539] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥១។

[540] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥២។

[541] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥២។

[542] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥០។

ខ្លួនលើយុត្តិសាស្ត្រអន្តរជាតិលើបញ្ហានេះ និងបដិសេធការសន្និដ្ឋានរបស់ខ្លួនដែលងាយទៅរកការអនុវត្តបែបនេះគឺពុំមែនជាកំហុសឆ្គងទេ[543]។ ម្ចាស់បណ្តឹងសាទុក្ខពុំបានកំណត់ការផ្លាស់ប្តូរណាមួយនៅក្នុងការអនុវត្តដែលរងការជំទាស់នៅក្នុងករណីនេះ ឬមូលដ្ឋានណាមួយដែលអាចឱ្យមានការចាំបាច់ពិចារណាឡើងវិញឬបដិសេធជំហររបស់អង្គជំនុំជម្រះតុលាការកំពូលទេ[544]។

147. រឿងក្តី *Lubanga* ពុំគាំទ្រទឡ្ហីករណ៍របស់ម្ចាស់សាទុក្ខឡើយ[545]។ នៅក្នុងការយោងមកសំអាងនូវអ្វីដែលអាចពិព័ណ៌នាថាជាប្រភពអាចទុកចិត្តបាន ម្ចាស់បណ្តឹងសាទុក្ខខកខានពុំបានកត់សម្គាល់ ថា អង្គជំនុំជម្រះ *Lubanga* លើកកម្ពស់ការអនុវត្តការពិនិត្យចម្លើយពីមុនមុនពេលផ្តល់សក្ខីកម្ម[546]។ សេចក្តីសម្រេចនោះមានសារៈសំខាន់ជាពិសេស ដោយហេតុថា "ទម្រង់បែបបទនីតិវិធីរបស់តុលាការ ICC និងទម្រង់ដែលបានយកមកអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក មានចំណុចប្រហាក់ប្រហែលគ្នាខ្លាំងត្រង់ថានៅអ.វ.ត.ក អង្គភាពគាំពារសាក្សីនិងអ្នកជំនាញដែលជាស្ថាប័នអព្យាក្រឹតរបស់តុលាការជាអ្នកផ្តល់ចម្លើយទាំងនោះទៅឱ្យសាក្សីពិនិត្យ"[547]។

148. ជាការផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលអាច "កំណត់ការអានឡើងវិញនូវការសម្រេចពីមុន"[548]ដោយផ្អែកលើការងាយទៅរកវិធាននៃនីតិវិធីដែលបង្កើតក្នុងកម្រិតអន្តរជាតិអនុលោមតាមវិធាន២ នៃវិធានផ្ទៃក្នុង មាត្រា៣៣ថ្មីនៃច្បាប់បង្កើត អ.វ.ត.ក និង មាត្រា១២(១)នៃកិច្ចព្រមព្រៀង អ.វ.ត.ក[549]។ អង្គជំនុំជម្រះសាលាដំបូងអនុវត្តយ៉ាងដូច្នេះយ៉ាងត្រឹមត្រូវនៅក្នុងរឿងក្តីនេះ ដូចដែលខ្លួនបានអនុវត្តនៅក្នុងសំណុំរឿង០០២/០១ និង ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខពុំបានបង្កើតកំហុសឆ្គង ការអនុវត្តបែបនេះគួរតែត្រូវបានលើកកម្ពស់ដោយអង្គជំនុំជម្រះតុលាការកំពូលម្តងទៀត។

---

543 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦៣-២៦៩។

544 ឯកសារ **F2/10/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម ទំព័រ ៣ EN 01202790 (មូលហេតុដែលគួរឱ្យជឿ)។ សេចក្តីសម្រេចរបស់ អ.ជ..ស.ដ ក្នុងរឿងក្តី *Milutinović* ស្តីពីការពិចារណាឡើងវិញលើសំណើរបស់រដ្ឋអាជ្ញាទាក់ទងនឹងសាក្សី K56 កថាខណ្ឌ ២ (កំហុសយ៉ាងច្បាស់នៅក្នុងសំអាងហេតុ, ផលប្រយោជន៍នៃយុត្តិធម៌)។

545 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥១។

546 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦៥ *ដកស្រង់* ២៦៥ សេចក្តីសម្រេចស្តីពីការប្រឹក្សាសាក្សីក្នុងរឿងក្តី *Lubanga* កថាខណ្ឌ ៥១-៥៧។

547 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦៥។

548 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥១។

549 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៦២, ២៦៩។

## ***មូលដ្ឋានទី ២៥៖ សំអាងហេតុនៃការនិយាយកុហក***[550]

149. **មូលដ្ឋានទី ២៥គួរតែត្រូវបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយខកខានមិនបានពិចារណាជាប្រព័ន្ធទៅលើមូលហេតុនៃការនិយាយកុហកនៅក្នុងការវាយតម្លៃលើភស្តុតាងរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ។**

150. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលទេ ដោយហេតុថាគាត់គ្រាន់តែស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលដាក់ជំនួសការវាយតម្លៃភស្តុតាង ដែលខ្លួនពេញចិត្តជាមួយនឹងការវាយតម្លៃភស្តុតាង ធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង[551]។ ការផ្អែករបស់ម្ចាស់បណ្តឹងសាទុក្ខលើ "ការធានាមិនចោទប្រកាន់"[552] ដើម្បីបង្ហាញកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងគឺជាការភាន់ច្រឡំដោយហេតុថាខ្លួនពុំបង្ហាញថាស្តង់ដាពីរត្រូវបានអនុវត្តឡើយ។ មានការទទួលយកជាទូទៅថា មនុស្សកុហក ឬបន្ថយឱ្យនៅតិចបំផុតចំពោះការប្រព្រឹត្តព្រហ្មទណ្ឌឬអំពើដែលសង្គមថ្កោលទោស ដោយហេតុផលផ្សេង ៗក្រៅពីការភ័យខ្លាចការកាត់ទោស ជាអាទិ៍ដូចជាការភ័យខ្លាចស្លាកស្នាមទុយ៌ស ឬវិចារណញាណចំពោះការប្រព្រឹត្តអវិជ្ជមាន។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយផ្អែកថា អតីតកម្មាភិបាលដែលបានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការយល់ព្រមរៀបការ មានទំនោរចង់ "កាត់បន្ថយការទទួលខុសត្រូវរបស់ខ្លួន"[553]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានពិចារណាមួយផ្នែកនៃការពិនិត្យភស្តុតាងមួយភាគធំ ពាក់ព័ន្ធនឹងការយល់ព្រមរៀបការ ក្នុងនោះរួមបញ្ចូលទាំងបរិយាកាសបង្ខិតបង្ខំ ដែលប្រកែកលទ្ធភាពក្នុងការផ្តល់ការយល់ព្រមពិត

---

[550] <u>មូលដ្ឋានទី ២៥</u>៖ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ សំអាងហេតុនៃការនិយាយកុហក កថាខណ្ឌ ២៥៣ ឯកសារ **F54.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៣ (ភាសាអង់គ្លេស) ទំព័រ ១១-១២ (ភាសាបារាំង) ទំព័រ ១៦-១៧ (ភាសាខ្មែរ)។

[551] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៣ *ដកស្រង់*កថាខណ្ឌរបស់ខ្លួន កថាខណ្ឌ ១១៩៤-១១៩៥, ១២៣៣-១២៤២ ដែលដកស្រង់បន្ថែមនូវកថាខណ្ឌរបស់ខ្លួន កថាខណ្ឌ ១៦៧,១១៥៧-១១៨៨, ១២១២-១២១៣, ១២៧១-១២៧២ និងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥៧ (ជើងទំព័រ១១៩៤៣), ៣៥៦៩, ៣៥៧០ (ជើងទំព័រ ១១៩៨០), ៣៦១៣, ៣៦១៧, ៣៦២៣, ៣៦៧៥, ៤២៤៧ (ជើងទំព័រ ១៣៨៦១)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥, ១៦៦, ១៦៩។

[552] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៣។

[553] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២៣។

ប្រាកដ[554] ពុំមែនដោយសារការអនុវត្តស្តង់ដាពីរទេ ដូចដែលបានលើកឡើងនៅក្នុងចម្លើយតប ផ្នែកបទបទបញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍[555]។

151. ការសង្កត់ធ្ងន់របស់ម្ចាស់បណ្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអនុញ្ញាតឱ្យ Francois Panchaud ផ្តល់សក្ខីកម្ម[556] ក៏ជាការភាន់ច្រឡំស្រដៀងគ្នាដែរ ដោយហេតុថាវាមិនបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តស្តង់ដាពីរ ពាក់ព័ន្ធនឹងភ័ស្តុតាងដោះបន្ទុកនិងភ័ស្តុតាងដាក់បន្ទុក។ ទីមួយ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមានមូលដ្ឋានច្បាប់រឹងមាំ។ ក្នុងការឈានទៅចេញសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានរម្លឹកថាបុគ្គលនេះបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ លើប្រធានបទផ្សេងៗគ្នាក្នុងនោះរួមមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែល "ជាផ្នែកនៃភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង ០០២/០២"[557]។ ទីពីរ ម្ចាស់បណ្តឹងសាទុក្ខពុំបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើភ័ស្តុតាងនេះ។

## ***មូលដ្ឋានទី ២៦៖ បុរេវិនិច្ឆ័យវប្បធម៌***[558]

---

[554] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែកទី ១៤.៣.៦.២ ការយល់ព្រម កថាខណ្ឌ ៣៦១៧-៣៦២៥។

[555] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦២, ១៦៧, ១៦៩, ១៧០។ យុត្តិសាស្ត្រអន្តរជាតិ និងវិធាននៃភ័ស្តុតាង ទទួលស្គាល់ថា ចតភាពនៃបរិយាកាសបង្ខិតបង្ខំ និងបរិយាកាសនៃការភ័យខ្លាច ដែលកើតមាននៅក្នុងរឿងក្តីភាគច្រើនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ ធ្វើឱ្យមោឃភាពដល់ការយល់ព្រមពិតប្រាកដ។ *សូមមើលឧទាហរណ៍* សាលដីការឿងក្តី *Kunarac* កថាខណ្ឌ ១៣០ ("វាជាការសំខាន់ក្នុងការកត់សម្គាល់ថាបរិយាកាស [...] ដែលកើតមានស្ទើរតែគ្រប់រឿងក្តីទាំងអស់ ដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាទូទៅមានការបង្ខិតបង្ខំស្ទើរតែទាំងអស់។ *ដូច្នេះអាចនិយាយបានថា ការយល់ព្រមពិតប្រាកដ នឹងមិនអាចកើតមាននោះទេ*។") (គូសបញ្ជាក់បន្ថែម)។ សាលដីការឿងក្តី *Gacumbitsi* កថាខណ្ឌ ១៥៥ (បរិយាកាសបង្ខិតបង្ខំដែលបង្ហាញពីការមិនយល់ព្រម)។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៧៣៦ (ក្នុងករណីនៃការរៀបការដោយបង្ខំ ការគំរាមគំហែងដោយប្រើកម្លាំង ឬការយកប្រយោជន៍ពីកាលៈទេសៈបង្ខិតបង្ខំ **ការយល់ព្រម មិនអាចកើតមាននោះទេ**)។ វិធាននីតិវិធី និងភ័ស្តុតាងនៃតុលាការទាំងនេះ ទទួលស្គាល់បរិយាកាសបង្ខិតបង្ខំដែលជនរងគ្រោះ បានរស់នៅក្នុងអំឡុងពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ។ (វិធាន៩៦ វិធាននីតិវិធី និងភ័ស្តុតាង SCSL, វិធាន៩៦ របស់វិធាននីតិវិធី និងភ័ស្តុតាង វិធាន៩៦ របស់ ICTY, វិធាននីតិវិធី និងភ័ស្តុតាង វិធាន៩៦ របស់ ICTR)។

[556] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៩៥ *ដែលបានដកស្រង់*ក្នុងកថាខណ្ឌ ២៥៣ ជើងទំព័រ ៣៧៣។

[557] ឯកសារ **E408/6/2** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីការស្តាប់សក្ខីកម្មរបស់លោក Stephen Heder និងលោក François Ponchaud កថាខណ្ឌ ៦។

[558] <u>មូលដ្ឋានទី ២៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *បុរេវិនិច្ឆ័យវប្បធម៌* កថាខណ្ឌ២៥៤-២៥៦ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៣ (ភាសាអង់គ្លេស) ទំព័រ ១២ (ភាសាបារាំង) ទំព័រ ១៧ (ភាសាខ្មែរ)។

152. **មូលដ្ឋានទី ២៦ គួរតែត្រូវបានបដិសេធដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុនៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើភ័ស្តុតាងនៅក្នុងបរិបទដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ឬថាចៅក្រមបង្ខូចអង្គហេតុដោយមូលហេតុបុរេវិនិច្ឆ័យ។**

153. មូលដ្ឋាននេះមិនទទួលផល ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំផ្តល់បុរេវិនិច្ឆ័យច្បាប់ និងយុត្តិសាស្ត្រក្នុងការអះអាងថាបុរេវិនិច្ឆ័យគួរតែត្រូវបានទទួលស្គាល់ នៅក្នុងការវាយតម្លៃលើបរិបទដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត។ ក្រោយពីកត់សម្គាល់ថាអង្គជំនុំជម្រះសាលាដំបូង "ផ្អែកតាមណែនាំរបស់ចៅក្រមខ្មែរដែលជាសមាជិក នៅក្នុងការវាយតម្លៃលើភាពជឿជាក់បានរបស់សាក្សីដើម្បីចៀសវាងបុរេវិនិច្ឆ័យវប្បធម៌"[559]។ ម្ចាស់បណ្តឹងសាទុក្ខលើកទឡ្ហីករណ៍ដោយខុសថា "ប្រសិនបើចៅក្រមអន្តរជាតិផ្អែកលើចៅក្រមជាតិដើម្បីចៀសវាងការបកស្រាយខុស ដោយហេតុផលបុរេវិនិច្ឆ័យវប្បធម៌ គឺទាល់តែចៅក្រមជាតិវាយតម្លៃអង្គហេតុនេះដោយផ្អែកលើវប្បធម៌ខ្មែរនៅសម័យអង្គហេតុ"[560]។ ទឡ្ហីករណ៍នេះអាចត្រូវបានកំណត់ថាពុំធ្វើបានល្អ ពីព្រោះ ប្រសិនបើដើរតាមហេតុផលនេះ គឺមានតែចៅក្រមខ្មែរដែលបានរស់នៅក្រោមរបបខ្មែរក្រហមប៉ុណ្ណោះដែលអាចវាយតម្លៃបរិបទនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត។ មូលដ្ឋាននេះក៏មិនទទួលផលដែរ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំបង្ហាញឧទាហរណ៍ដែលបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានបុរេវិនិច្ឆ័យវប្បធម៌ក្នុងការវាយតម្លៃបរិបទនេះ។

154. ឧទាហរណ៍ ម្ចាស់បណ្តឹងសាទុក្ខបកស្រាយខុសលើភ័ស្តុតាងដែលរងការតវ៉ានៅពេលដែលគាត់អះអាងថា "ចៅក្រមដិតដាមទៅដោយបុរេវិនិច្ឆ័យវប្បធម៌ ព្រោះថានៅពេលនិយាយអំពីជីវភាពរស់នៅនិងអំពីអនាម័យ [...] ចៅក្រមចាំថា តែងតែមានរុយជាច្រើនរោមម្ហូបអាហារ"[561]។ ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាងនេះ គឺផ្អែកយ៉ាងត្រឹមត្រូវទៅលើការវិភាគរបស់ខ្លួនទៅលើភ័ស្តុតាងទាំងមូល។ ការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខដែលថាការណ៍នេះកើតឡើងជាធម្មតានៅជនបទគឺជាការមិនអើពើដល់ភាពធ្ងន់ធ្ងរនៃស្ថានភាព។ ម្ចាស់បណ្តឹងសាទុក្ខក៏បំភ្លេចចោលថាការសន្និដ្ឋានអង្គហេតុនេះគឺមិនផ្អែកលើចក្ខុវិស័យសហសម័យ"[562] ប៉ុន្តែ ផ្ទុយ

[559] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៤។

[560] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៥។

[561] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៥ *ដកស្រង់ខុស* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៩៨ ជើងទំព័រ ៤៦៤៨។ ការយោងត្រឹមត្រូវ គឺកថាខណ្ឌ ១៣២៧ ជើងទំព័រ ៤៥៥៨។

[562] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៥។

ទៅវិញ គឺផ្អែកលើភស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលបានឆ្លងកាត់ស្ថានភាពនេះ[563]។ ជាការពិបាកនិយាយថា បុរេវិនិច្ឆ័យវប្បធម៌ទាក់ទិននិងវប្បធម៌ខ្មែរក្នុងឆ្នាំ ១៩៧៥-១៩៧៨ និងមិនចាត់ទុកលក្ខណៈម្ហូបអាហារទាំងនោះជាផ្នែកមួយនៃវប្បធម៌របស់ពួកគេ[564]។

155. ស្រដៀងគ្នានេះដែរ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថាការសន្និដ្ឋានអង្គហេតុត្រូវបានផ្អែកលើការវាយតម្លៃខុសទាំងស្រុងទៅលើភស្តុតាង[565] ឬថាអង្គជំនុំជម្រះសាលាដំបូងកំណត់ប្រភេទអង្គហេតុនៃរឿងក្តីនេះជាមួយទស្សនៈសហសម័យ[566]។ ផ្ទុយទៅនឹងការចោទប្រកាន់តែពុំមានសុពលភាពស្រដៀងគ្នានេះរវាងការផ្សំផ្គុំមុនឆ្នាំ១៩៧៥ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[567] ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងបានបង្ហាញភាពផ្សេងគ្នាសំខាន់ៗជាច្រើន ដែលអនុញ្ញាតឱ្យខ្លួនសន្និដ្ឋានថា "ការផ្សំផ្គុំនៅក្នុងវប្បធម៌កម្ពុជាគឺខុសគ្នាយ៉ាងខ្លាំងទៅនឹងការរៀបការដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[568]។

## ***មូលដ្ឋានទី ៣២៖ ពាក្យចចាមអារ៉ាម***[569]

---

[563] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៤៥៤៨។

[564] ឯកសារ **E1/323.1** ប្រតិចារឹក សែន សុផុន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 15.21.26-15.23.55 ទំព័រ ៧០ បន្ទាត់ ២៣-២៥ ("បើនិយាយពីរុយវិញ រោមបបរឡើងជិតឈើង")។ ឯកសារ **E1/333.1** ប្រតិចារឹក តក់ ប៊ួយ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ម៉ោង 13.49.56-13.52.27 ទំព័រ ៦០ បន្ទាត់ ១៤-១៨ ("អត់មានការគ្របអីទេ គឺនៅហាលវាលណា ពាសពេញដូច្នេះរុយរោម")។ សូមមើលផងដែរឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៨៦ *ដកស្រង់* ឯកសារ **E1/306.1** ប្រតិចារឹក ហ៊ុន សិត្ថានី ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ មោង 09.17.17-09.20.15 ទំព័រ ៧ បន្ទាត់ ៤-១០ ("ដួសមួយវែកណាក៏រុយដែរ។ កាលនោះផ្តិះតែខ្លួនរុយចេញទេ សូម្បីតែដួសឱ្យដោយទឹកសម្លមកជាមួយរុយហ្នឹងក៏គ្មានដែរ ធ្វើម៉េចផ្តិះតែរុយចេញ។ ដួសទៅចែកបន្តិចៗម្នាក់ទៅ។") ឯកសារ **E1/317.1** ប្រតិចារឹក យាន លន់ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 11.27.22-11.30.02 ទំព័រ ៤២ បន្ទាត់ ៧-១០ ("បើនិយាយពីរុយវិញ វាហួសនិយាយតែម្តង គឺខ្មៅទ្រុបលើបាយ លើសម្លហ្នឹងបាទ ហើយឈើនោះក៏ឈឺដោយសារតែរុយវាទុំបាយ ច្រើនណាស់បាទ។")

[565] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៧ *ដកស្រង់*សាលដីកា *Kupreškić* កថាខណ្ឌ ៣០។

[566] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៤០។

[567] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦២។

[568] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៨។ សូមមើលផងដែរ សាលដីការឿងក្តី *Brima* កថាខណ្ឌ ១៩៤។ សូមមើលផងដែរ សាលក្រមរឿងក្តី *Brima* មតិស្របដាច់ដោយឡែករបស់ចៅក្រម Sebutinde កថាខណ្ឌ ៨-១២។ សាលក្រមរឿងក្តី *Brima* មតិជំទាស់ដោយផ្នែករបស់ចៅក្រម Doherty កថាខណ្ឌ ២២-៣៦។

[569] មូលដ្ឋានទី ៣២៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ពាក្យចចាមអារ៉ាម* កថាខណ្ឌ ៣១២-៣១៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៥ (ភាសាអង់គ្លេស) ទំព័រ ១៤ (ភាសាបារាំង) ទំព័រ ២០ (ភាសាខ្មែរ)។

156. **មូលដ្ឋានទី ៣២ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់និងអង្គហេតុក្នុងការវាយតម្លៃនិងផ្អែកលើភស្តុតាងពាក្យចចាមអារ៉ាម។**

157. ម្ចាស់បណ្តឹងសាទុក្ខយល់ស្របដោយត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងបានប្រកាសដោយត្រឹមត្រូវនូវកត្តានានាដើម្បីពិចារណានៅពេលវាយតម្លៃតម្លៃភស្តុតាងពាក្យចចាមអារ៉ាម និងថាភស្តុតាងបែបនេះត្រូវតែពិនិត្យដោយការប្រុងប្រយ័ត្ន[570]។ ប៉ុន្តែគាត់ពុំបានកំណត់បានថាអង្គជំនុំជម្រះសាលាដំបូងមិនបានអនុវត្តលក្ខខណ្ឌទាំងនោះ ឬមានការប្រុងប្រយ័ត្នក្នុងការវាយតម្លៃភស្តុតាងបែបនេះ។ ទឡ្ហីករណ៍របស់គាត់ដែលថាអង្គជំនុំជម្រះសាលាដំបូងជាទូទៅអនុវត្តខុសស្តង់ដានៃការពិនិត្យភស្តុតាង ដោយគ្មានការសំអាង ត្រូវតែបដិសេធ[571]។

158. មូលដ្ឋាននេះពុំទទួលផលឡើយ ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់និងអង្គហេតុ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំបំពេញលក្ខខណ្ឌរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា "ភាគីម្ចាស់បណ្តឹងសាទុក្ខមានកាតព្វកិច្ចបង្ហាញឱ្យឃើញថាពុំមានតុលាការអង្គហេតុសមស្របណាមួយ ដែលអាចយកភស្តុតាងបែបនេះ [ភស្តុតាងពាក្យចចាមអារ៉ាម]មកធ្វើសំអាងហេតុជាក់លាក់នោះឡើយ"[572]។ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានទទួលយកថា ខណៈដែលពាក្យចចាមអារ៉ាមអាចទទួលយកបានប្រសិនបើមានតម្លៃភស្តុតាង ជាការពិតណាស់ភស្តុតាងពាក្យចចាមអារ៉ាមដែលពុំមានការបញ្ជាក់អាចត្រូវបានផ្អែកលើក្នុងការកំណត់ធាតុផ្សំបទល្មើស ប្រសិនបើត្រូវបានពិនិត្យដោយការប្រុងប្រយ័ត្ន[573]។ ដូចដែលបានបង្ហាញខាងក្រោម ម្ចាស់បណ្តឹងសាទុក្ខ ក៏ថ្លែងខុស ឬបកស្រាយមិនត្រឹមត្រូវចំពោះភស្តុតាងភាគច្រើនដែលគាត់យោងទៅលើ តាមរបៀបម្តងមួយៗ និង ខកខានមិនបានពិចារណាពេញលេញទៅលើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

---

[570] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១២ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣។

[571] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤។

[572] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០២ *ដកស្រង់* សាលដីការឿងក្តី *Karera* កថាខណ្ឌ ៣៩, ១៩៦។ សូមមើលផងដែរឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨៩ (ពាក្យចចាមអារ៉ាមអនាមិកតៗគ្នាគឺគួរឱ្យជឿទុកចិត្តបាន។ វាអាចយកមកពិចារណាបាន ផ្អែកលើភស្តុតាងបញ្ជាក់អះអាងបន្ថែម)។

[573] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០២ *ដកស្រង់*សាលដីការឿងក្តី *Gacumbitsi* កថាខណ្ឌ ១៣៣ ជើងទំព័រ ៣២០។ សាលដីការឿងក្តី*Hategekimana* កថាខណ្ឌ ២៧០។

159. ម្ចាស់បណ្តឹងសាទុក្ខលើកកថាខណ្ឌចំនួន១៩មកសំអាងក្នុងសារណារបស់ខ្លួនដែលគាត់លើកទឡ្ហីករណ៍ថាអង្គជំនុំជម្រះសាលាដំបូងលើកឡើងផ្ទុយគ្នានឹងវិធីសាស្ត្ររបស់ខ្លួនដែលបានថ្លែង ក្នុងការវាយតម្លៃភស្តុតាងពាក្យចចាមអារ៉ាម។ ប៉ុន្តែទោះជាយ៉ាងណាក្តី ការអះអាងរបស់ម្ចាស់បណ្តឹងសារទុក្ខគ្រាន់តែចាត់ទុកភស្តុតាងជាពាក្យចចាមអារ៉ាម និងអះអាងថាអង្គជំនុំជម្រះសាលាដំបូងពុំអាចផ្អែកលើវាឡើយ[574]។ ដូចដែលបានកំណត់នៅក្នុងផ្នែកផ្សេងទៀតនៃការឆ្លើយតបនេះ ការអះអាងទាំងនេះពុំបង្កើតជាកំហុសឆ្គងឡើយ[575]។ ឧទាហរណ៍ ពាក់ព័ន្ធនឹងការបញ្ជូនខ្លួនជនជាតិ

---

[574] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ៤៨៤ *ដកស្រង់* កថាខណ្ឌរបស់ខ្លួន កថាខណ្ឌ ៩០៨, ៩១៩, ៩២១, ៩៧១, ៩៧៥, ៩៨៧, ៩៩១-៩៩២, ១០០៤-១០០៥, ១០០៧, ១០១១, ១០១៣-១០១៤, ១០៤៤, ១០៩៥, ១២៦៦, ១៧៦២, ១៨៦៨។

[575] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១២ ជើងទំព័រ ៤៨៤ – ទឡ្ហីករណ៍នៅក្នុងកថាខណ្ឌដែលបានដកស្រង់ខាងក្រោម មិនបានផលទេ ពីព្រោះកថាខណ្ឌទាំងនោះ៖ កថាខណ្ឌ៩០៨ (ការសម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន – បកស្រាយខុសនូវសំអាងហេតុរបស់ អ.ជ.ស.ដ រួមមានភស្តុតាងដោយផ្ទាល់ពីអ្នកភូមិ, សមាជិកកម្លាំងសន្តិសុខនិងឈ្លបដែលថាជនជាតិចាម ត្រូវបានព័ទ្ធចាប់ និងយកទៅវត្ត ជាប្រព័ន្ធ។ មុយ វ៉ាន់នី ជាប្រភពមួយក្នុងចំណោមប្រភពដែលមានការបញ្ជាក់អះអាងផ្សេងទៀត។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣៧)។ កថាខណ្ឌ ៩១៩ (បទបញ្ជាឱ្យចាប់ជនជាតិចាម – បកស្រាយខុសនូវសំអាងហេតុរបស់ អ.ជ.ស.ដ ដែលមិនផ្អែកទាំងស្រុងទៅលើបទបញ្ជាជាក់លាក់។ មិនអើពើថាសំអាងហេតុនោះផ្អែកលើការវាយតម្លៃភស្តុតាងដែលការសម្លាប់ ត្រូវបានចាត់ចែង និងធ្វើឡើងដោយចេតនា យោងតាមគោលនយោបាយ ប.ក.ក។ បកស្រាយខុសនូវសក្ខីកម្មរបស់ យាន នល់)។ *សូមមើល* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៣៩)។ កថាខណ្ឌ ៩២១ (ការសម្លាប់ជនជាតិចាម – បទបញ្ជាពីថ្នាក់លើ ដូចបានផ្តល់សក្ខីកម្មដោយ សយ ឌឿន។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣៩។ កថាខណ្ឌ ៩៧១ (ការជម្លៀសជនជាតិវៀតណាម – ភស្តុតាងរបស់ សៅ សាក់ ត្រូវបានបកស្រាយខុស៖ គាត់បាននិយាយថាគាត់មិនបានឃើញហេតុការណ៍ទាំងនោះទេ ប៉ុន្តែមានគេប្រាប់ថាគ្រួសារជនជាតិវៀតណាមដែលបានបាត់ខ្លួនរៀងរាល់ពីរបីថ្ងៃម្តងនៅក្នុងភូមិ ត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម។ គាត់មិនបានផ្លាស់ប្តូរសក្ខីកម្មរបស់គាត់ទាក់ទងនឹងការនិរទេសនោះទេ ប៉ុន្តែមានគេនិយាយជាបន្តបន្ទាប់ថាជនជាតិវៀតណាម ត្រូវបានយកទៅសម្លាប់ ជាជាងនិរទេសចេញ)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥១។ កថាខណ្ឌ ៩៧៥ (ការជំទាស់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឯម ប៊ុននីម និង ប៊ុន រ៉ើន – សាក្សីទាំងពីរ បញ្ជាក់អះអាងនូវសក្ខីកម្មរបស់សៅ សាក់ និងបាននិយាយថាពួកគេបានឃើញជនជាតិវៀតណាម ត្រូវបានបញ្ជូនពីអន្លង់ទ្រាឱ្យត្រលប់ទៅប្រទេសវៀតណាមវិញ។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥១) កថាខណ្ឌ ៩៨៧ (ការសម្លាប់ជនជាតិវៀតណាមនៅស្វាយរៀង, សក្ខីកម្មរបស់ ស៊ិន ឆែម – គាត់មានមូលដ្ឋាននៃការដឹងឮគ្រប់គ្រាន់ពាក់ព័ន្ធនឹងការចាប់ខ្លួន ឬការសម្លាប់ជនជាតិវៀតណាម រួមទាំងគាត់បានស្គាល់គ្រួសារជនជាតិវៀតណាមនៅក្នុងតំបន់នោះ។ គាត់បានរស់នៅក្បែរ និងបានធ្វើការជាមួយពួកគេ។ គាត់ត្រូវបានប្រាប់ពីការបាត់ខ្លួនរបស់ពួកគេ និងការសម្លាប់ដោយអ្នកដែលរស់នៅក្បែរជនជាតិវៀតណាម។ គាត់ត្រូវបានមេឃុំប្រាប់ថា ស្ត្រីដែលរៀបការជាមួយបុរសខ្មែរ និងកូនៗរបស់ពួកគេ ត្រូវបានយកទៅសម្លាប់)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥២) កថាខណ្ឌ ១០០៤-១០០៥ (ការសម្លាប់ជនជាតិ វៀតណាមនៅក្នុងភូមិភាគបស្ចិម - ហ៊ឹម ដែលជាប្រភពព័ត៌មានអំពីប្រាក់ ឌឿន ស្ថិតនៅក្នុងតំបន់ដែលប្រពន្ធ និងកូនៗរបស់ប្រាក់ ឌឿន ត្រូវបានសម្លាប់ ហើយបានពិពណ៌នាយ៉ាងលម្អិតអំពីវិធី និងមូលហេតុដែលពួកគេត្រូវបានសម្លាប់។ កំហុសអង្គរាវារុទ្ធជាក់ស្តែងទាក់ទងនឹងការសម្លាប់នៅលើកោះតាម៉ូវ។ មិនមានការអន្តរាគមន៍ចំពោះកំហុសនោះទេ ដោយសារតែ អ.ជ.ស.ដ បានរកឃើញដោយសមស្របថាម្ចាស់បណ្តឹងសាទុក្ខទទួលខុសត្រូវក្នុងការសម្លាប់កុមារម្នាក់។ *សូមមើល* ចម្លើយតប

វៀតណាមពីភូមិពោធិចិន្តាំក្នុងខេត្តព្រៃវែង[576]ជាការផ្ទុយទៅនឹង ការអះអាងនេះ ការដឹងរបស់ ដួង អឿន គឺផ្អែកលើការសង្កេតរបស់គាត់ទៅលើម្តាយជនជាតិវៀត ណាមនិងកូនៗរបស់ពួកគេ ឬ បុរសជនជាតិវៀតណាមដែលត្រូវបានយកទៅ ឬបាត់ខ្លួនពីភូមិពោធិចិន្តាំ។ គ្មានជនជាតិវៀតណាម ណាម្នាក់បានត្រឡប់មកភូមិរបស់គាត់ឡើយ។ ប្តីជាខ្មែររបស់ប្រពន្ធជនជាតិវៀតណាមម្នាក់បាន វិលត្រឡប់មកវិញ ប៉ុន្តែមិនមែនប្រពន្ធឬកូនគាត់ទេ។ ប្រភពនៃព័ត៌មានរបស់គាត់ដែលថាប្តីគាត់ ដែលជាជនជាតិវៀតណាមត្រូវបានយកទៅ គឺបានមកពីម្តាយរបស់គាត់ដែលឃើញឈ្លបម្នាក់ យកគាត់ទៅ ហើយមិនឃើញត្រឡប់វិញឡើយ[577]។ ជាងនេះទៀត ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ

---

ទៅនឹងមូលដ្ឋានទី ១៥៤)។ កថាខណ្ឌ ១០០៧, ១០១១ (*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៥ (ការសម្លាប់ជនជាតិវៀតណាមនៅវត្តខ្សាច់), កថាខណ្ឌ ១០១៣-១០១៤ (ការសម្លាប់នៅវត្តខ្សាច់ដែលបញ្ជាដោយថ្នាក់លើ – ស៊ាន ស៊ុង ត្រូវបានមេភូមិប្រាប់ថាបញ្ជាឱ្យសម្លាប់ជនជាតិវៀតណាមគឺមកពីថ្នាក់លើ។ អ្នកភូមិបានប្រាប់ អ៊ី វុន ថាមេភូមិបានទទួលបញ្ជាឱ្យសម្លាប់ពីថ្នាក់លើ។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៥។ កថាខណ្ឌ ១០៤៤ (ជាតិពន្ធុខ្មែរស្រឡាយខាងម្តាយ) *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៨)។ កថាខណ្ឌ ១០៩៥ (សេចក្តីប្រកាសថ្ងៃទី២ ខែមករា – សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង និងការមិនអើពើនឹងភ័ស្តុតាងដោះបន្ទុក។ អតីតទាហានកម្ពុជាប្រជាធិបតេយ្យនោះ គឺមាស វឿន ដែលបានផ្តល់សក្ខីកម្មថាគាត់ត្រូវបានណែនាំឱ្យកម្ទេចជនជាតិ វៀតណាម បន្ទាប់មកបានផ្លាស់ប្តូរសក្ខីកម្មរបស់គាត់ក្នុងតុលាការនៅថ្ងៃបន្ទាប់ ដោយមិនមានការពន្យល់។ សាក្សី ប៉ាក សុខ បានផ្តល់សក្ខីកម្មថានៅវគ្គរៀនសូត្រក្រោយឆ្នាំ១៩៧៦ គាត់ត្រូវប្រាប់ឱ្យសម្លាប់ជនជាតិវៀតណាម រួមទាំងទារក ពីព្រោះពួកគេជាសត្រូវស្នូលពូជ។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៩) កថាខណ្ឌ ១២៦៦ (ការរៀបអាពាហ៍ពិពាហ៍, សៀវភៅសម្តេចសីហនុ, ការរៀបការរបស់នារីវ័យក្មេងជាមួយយោធិនពិការ – បកស្រាយខុសនូវ ភ័ស្តុតាង និងសំអាងហេតុ)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៩)។ កថាខណ្ឌ ១៧៦២ (វគ្គរៀនសូត្រនយោបាយ – បកស្រាយខុសនូវសក្ខីកម្មរបស់ ជា សាយ៖ គាត់ក៏បាននិយាយថាម្ចាស់បណ្តឹងសាទុក្ខ បានដាក់បញ្ចូលការណែនាំអំពីវិធីប្រយុទ្ធប្រឆាំងនឹងខ្មាំងដែលបានបង្កប់ខ្លួន។ អុង ធុងហឿង៖ មិនធ្លាប់បានជួបខៀវ សំផន ទេ មុនពេលគាត់ផ្តល់សក្ខីកម្មក្នុងតុលាករ។ Philip Short៖ រហូតដល់ឆ្នាំ១៩៧៥ ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានគេស្គាល់ថាមានភាពស្មោះត្រង់ និងសុចរិតភាព)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៤, ២៥៦។ *សូមមើលផងដែរ* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០១ (អ.ជ.ស.ដ កត់សម្គាល់ថាការមិនមានឱកាសសួរដេញដោលនៅក្នុងតុលាការចំពោះសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយព្រះបរមរតនកោដ្ឋសម្តេច នរោត្តម សីហនុ នៅក្នុងសៀវភៅរបស់ព្រះអង្គ នាំឱ្យមានការបន្ថយតម្លៃនៃភ័ស្តុតាងនៃសេចក្តីថ្លែងការណ៍ទាំងនោះ)។ កថាខណ្ឌ ១៨០៨ (ការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការសម្លាប់ ជួ ជេត – វាយតម្លៃដោយមិនត្រឹមត្រូវទៅលើភ័ស្តុតាងដែល អ.ជ.ស.ដ ផ្អែកលើ ដែលមិនមែនជាភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៨)។

[576] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៣។

[577] ឯកសារ **E1/381.1** ប្រតិចារឹក ដួង អឿន ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.21.21-0925.30 ទំព័រ ៨ បន្ទាត់ ៥-១១ ម៉ោង 10.41.58-10.45.49 ទំព័រ ៣០ បន្ទាត់ ២-២២ (ម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានប្រាប់គាត់ថាប្តី របស់គាត់ដែលជាជនជាតិវៀតណាម ត្រូវបានឈ្លបយកចេញទៅ ហើយមិនបានត្រឡប់មកវិញទេ) ម៉ោង 09.30.16-09.33.45 ទំព័រ ១០ បន្ទាត់ ២៤-ទំព័រ ១១ បន្ទាត់ ១៥ (តាគី និងយាយម៉ាន់ និងកូនៗរបស់ពួកគាត់មកពីភូមិរបស់គាត់ "បានត្រលប់

សាលាដំបូងគឺថាការបញ្ជូនវៀតណាមចេញពីខេត្តព្រៃវែង គឺត្រូវបានកំណត់ហួសពីវិមតិសង្ស័យ ដែលភូមិពោធិចិន្តាំគ្រាន់តែជាផ្នែកមួយនៃការសន្និដ្ឋានអង្គហេតុជាមូលដ្ឋាន។ ហេតុដូច្នេះ ប្រសិនបើមិនរាប់បញ្ចូលភស្តុតាងនៃការបញ្ជូនចេញនេះ នឹងពុំមានការប៉ះពាល់ដល់ការសន្និដ្ឋានពាក់ព័ន្ធនឹងខេត្តនោះឡើយ។

160. ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបាននិយាយអំពីប្រភពនៃចម្លើយពាក្យចចាមអារ៉ាមក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះក្តី គឺការមិនយកចិត្តទុកដាក់ដោយខុសឆ្គង ដែលគាត់មានឱកាសក្នុងការតាំងសំណួរចំពោះអ្នកដែលបានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងប្រភពដើមនៃចម្លើយណាមួយ[578]។ ឧទាហរណ៍ ម្ចាស់បណ្តឹងសាទុក្ខមិនដែលសួរ ដួង អឿន មួយសំណួរឡើយ ពាក់ព័ន្ធនឹងមូលដ្ឋាននៃការដឹងរបស់គាត់ថាជនជាតិវៀតណាមត្រូវបានបង្ខំឱ្យចេញពីភូមិពោធិចិន្តាំទៅប្រទេសវៀតណាម ឬមិនសួរថាគាត់ដឹងច្រើនកម្រិតណាដែរ[579]។ ផ្ទុយទៅវិញ ម្ចាស់បណ្តឹងបានសួរសំណួរដែលផ្តោតលើតែមុខរបបរបស់ប្តី ដួង អឿន ប៉ុណ្ណោះ[580]ដែលជាការប៉ុនប៉ងមិនត្រឹមត្រូវក្នុងការផ្តល់យុត្តិកម្មនៃការចាប់ខ្លួននិងការបាត់ខ្លួននៃជននេះ[581]។ ក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងមិនអើពើថា តាមពិត ដូចដែលបានកត់សម្គាល់ខាង

ទៅវៀតណាមវិញ" ប៉ុន្តែប្តីបានត្រលប់ទៅវិញ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ) ម៉ោង 09.37.12-09.41.13 ទំព័រ ១៣ បន្ទាត់ ១០-ទំព័រ ១៤ បន្ទាត់ ៧ ម៉ោង 11.00.49-11.05.12 ទំព័រ ៣៨ បន្ទាត់ ៦-២៤ (គ្រួសាររបស់ឡាច នី និងកូនៗត្រូវបានបញ្ជូនចេញ ប៉ុន្តែឡាច នី ត្រូវបានគេទុកជីវិតឱ្យ។ ប្រពន្ធរបស់គាត់ជាជនជាតិ វៀតណាម។ ដួង អឿន មិនបានឃើញគេយកគាត់ចេញទេ។ "គេយកទៅអស់ឃើញ គាត់ក៏ទៅដែរហើយ")។ ម៉ោង09.39.14-09.45.35 ទំព័រ ១៤ បន្ទាត់ ៨-ទំព័រ ១៥ បន្ទាត់ ២៣ (ង៉ាង ក៏ត្រូវបានគេយកចេញទៅដែរ ហើយមិនវិលមកវិញទេ។ ឪពុកម្តាយគាត់ជាជនជាតិវៀតណាម)។ ម៉ោង 11.20.35-11.22.36 ទំព័រ ៤៥ បន្ទាត់ ១៦-១៩ (ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មិនមាននៅសល់ជនជាតិវៀតណាមក្នុងភូមិទេ)។ ម៉ោង 13.49.32-13.54.30 ទំព័រ ៥៥ បន្ទាត់ ២៣ -ទំព័រ ៥៦ បន្ទាត់ ១៨ (នៅពេលឆ្លើយតបទៅនឹងសំណួររបស់ក្រុមមេធាវីការពារក្តីថាតើប្តីរបស់ដើមបណ្តឹង រដ្ឋប្បវេណីជាជនជាតិវៀតណាមតែម្នាក់គត់ដែលរស់នៅភូមិពោធិ៍ចិន្តាំឬ ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយថា ពិតមែន។ ប្តី របស់គាត់មិនព្រមត្រលប់ទៅវិញទេ ទោះបីជាពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានប្រាប់ប្តីគាត់ថា គេរាល់គ្នាបានត្រលប់ទៅវិញហើយក៏ដោយ)។

[578] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១២។

[579] ឯកសារ **E1/381.1** ប្រតិចារឹក ដួង អឿន ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ម៉ោង ១៤.១៦.៥៨-១៤.២៨.៤៤ ទំព័រ ៦៥ បន្ទាត់ ១៣-ទំព័រ ៦៩ បន្ទាត់ ២៣។

[580] ឯកសារ **E1/381.1** ប្រតិចារឹក ដួង អឿន ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ម៉ោង ១៤.១៦.៥៨-១៤.២៨.៤៤ ទំព័រ ៦៥ បន្ទាត់ ១៣-ទំព័រ ៦៩ បន្ទាត់ ២៣។

[581] សូមមើល ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ២១៩១។

លើ ដួង អឿន បានផ្តល់សក្ខីកម្មថាម្តាយរបស់គាត់បានប្រាប់ដើមបណ្តឹងរដ្ឋប្បវេណីថា គាត់ (ម្តាយ) បានឃើញប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវឈ្លបយកទៅ[582]។

## ឃ. ភ័ស្តុតាងជាឯកសារ

### ១. ការវាយតម្លៃទូទៅ

*មូលដ្ឋានទី ៣៦៖ ភ័ស្តុតាងជាឯកសារ និងយថាភាព*[583]

161. **មូលដ្ឋានទី ៣៦ គួរតែត្រូវបានបដិសេធដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ឬអង្គហេតុក្នុងការវាយតម្លៃភ័ស្តុតាងជាឯកសារ និង ឯកសារសហសម័យ។**

162. ជាពិសេស មូលដ្ឋាននេះមិនទទួលផលឡើយដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់និងអង្គហេតុ (i) នៅក្នុងភាពគ្រប់គ្រាន់នៃការវាយតម្លៃលើភ័ស្តុតាងជាឯកសារ ឬ (ii) ដោយកត់សម្គាល់ថា នៅពេលដែលមានឯកសារដើមដែល ជាកម្មសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាភាគីអាចចូលមើលបាន ដើម្បីពិនិត្យយថាភាពនៃឯកសារដើមនិងភាពត្រឹមត្រូវនៃឯកសារថតចម្លង។

163. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលដោយហេតុថាគាត់គ្រាន់តែមិនយល់ស្របចំពោះការវាយតម្លៃភ័ស្តុតាងពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ គាត់ក៏ខកខានមិនបានពិចារណាថា៖ ភ័ស្តុតាងទាំងអស់អាចទទួលយកបានប្រសិនបើមិនហាមឃាត់ដោយវិធានផ្ទៃក្នុង[584] ថាពុំមានតម្រូវការនីតិវិធីក្នុងការកោះហៅសាក្សីមកធ្វើយថាភាពលើឯកសារ[585] ឬថាមានតែឯកសារដើម

---

[582] ឯកសារ **E1/ 381.1** ប្រតិចារឹក ដួង អឿន ប្រតិចារឹក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ម៉ោង ១០.៤៣.៥៨-១០.៤៥.៤៩ ទំព័រ ៣០បន្ទាត់ ៧-១៥។

[583] <u>មូលដ្ឋានទី ៣៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភ័ស្តុតាងជាឯកសារ និងយថាភាព* កថាខណ្ឌ ៣២៣-៣២៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៦ (ភាសាអង់គ្លេស) ទំព័រ ១៥ (ភាសាបារាំង) ទំព័រ ២១-២២ (ភាសាខ្មែរ)។

[584] វិធាន៨៧ (១) នៃវិធានផ្ទៃក្នុង។

[585] ឯកសារ **E185** សេចក្តីសម្រេចលើឯកសារ សំណុំរឿង០០២/០១ កថាខណ្ឌ ២១ (៧) *ដកស្រង់ដោយ* អ.ជ.ត.ក ដោយមិនបដិសេធ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧២ (សេចក្តីសម្រេចលើការជំទាស់)។

ប៉ុណ្ណោះដែលអាចត្រូវបានដាក់នៅក្នុងភស្តុតាង និងថា វាអាស្រ័យលើអង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ទម្ងន់ដែលខ្លួនផ្តល់ចំពោះភស្តុតាងចំពោះមុខខ្លួន និងផ្អែកលើភស្តុតាងទាំងមូល[586]។

164. ទទ្បីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលពាក់ព័ន្ធនឹងការចូលទៅមើលឯកសារដើមដែលច្បាប់ចម្លងនៃឯកសារនោះត្រូវបានប្រើនៅក្នុងរឿងក្តី[587]។ ការព្រួយបារម្ភពាក់ព័ន្ធរបស់គាត់អំពីទីតាំងនៃឯកសារដើមរក្សាទុកនៅ DC-Cam ក៏មិនត្រឹមត្រូវដែរ[588]។ គាត់ពុំចាំបាច់ដឹងថាទីតាំងនោះ ដើម្បីមានឱកាសស្នើសុំពិនិត្យមើលឯកសារដើម និងគាត់មិនបានបង្ហាញថាគាត់បានព្យាយាមដោយមិនជោគជ័យក្នុងការទទួលបានសិទ្ធិចូលមើលឯកសារដើមក្នុងករណីដែលមាន។ ការសម្រេចមិនឆ្លៀតយកឱកាសនេះពុំស្មើនឹងកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងទេ។ អង្គជំនុំជម្រះសាលាដំបូងក៏កត់សម្គាល់ថា នៅក្នុងការវាយតម្លៃរបស់ខ្លួនលើតម្លៃភស្តុតាងរបស់ឯកសារ ខ្លួនបានពិចារណាឧទាហរណ៍ទាំងនោះ ដែលពុំមានឯកសារដើម[589]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថាខ្លួនខកខានមិនបានធ្វើដូច្នេះ។

165. ជាថ្មីម្តងទៀត កថាខណ្ឌនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ និងនៅក្នុងសាលក្រមដែលម្ចាស់បណ្តឹងសាទុក្ខស្វះស្វែងផ្អែកលើ ពុំគាំទ្រទទ្បីករណ៍របស់គាត់ឡើយ។ ទាក់ទិននឹងការទទួលយក និងប្រើប្រាស់ឯកសាររបស់សាស្ត្រាចារ្យ Goscha[590] គាត់ខកខានមិនបានបង្ហាញថាការវាយតម្លៃដ៏ល្អិតល្អន់របស់អង្គជំនុំជម្រះសាលាដំបូងមិនមានលក្ខណៈគ្រប់គ្រាន់[591] និងមិនអើពើចំពោះការថ្លែងរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាខ្លួនអាចប្រើឯកសារបែបនេះសម្រាប់ការបញ្ជាក់បន្ថែមប៉ុណ្ណោះ[592]។ ការតវ៉ារបស់គាត់ទៅលើការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងទទួលយកសៀវភៅបញ្ជីព័ណ៌ទឹកក្រូច[593] គឺជាការភាន់ច្រឡំស្រដៀងគ្នា ដោយហេតុថាជាថ្មីម្តងទៀត

---

[586] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៧។ សូមមើលផងដែរ សាលដីការឿងក្តី *Karera* កថាខណ្ឌ ១៩។ សាលដីការឿងក្តី *Setako* កថាខណ្ឌ ៣១។

[587] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៣។

[588] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៧។

[589] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៧។

[590] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៤ ជើងទំព័រ ៥១៨ *ដកស្រង់* កថាខណ្ឌ ២១៧-២២៥ របស់ខ្លួន។សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋានទី ១១ (ការទទួលយកឯកសារ Goscha)។

[591] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២-៣៥៤ ដាក់បញ្ចូលយោងជើងទំព័រ។

[592] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤។

[593] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៤ ជើងទំព័រ ៥១៨ *ដកស្រង់*កថាខណ្ឌ ២២៦របស់ខ្លួន។ សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋានទី ១២ (ការទទួលយកសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនៅ ស-២១)។

គាត់មិនអើពើចំពោះការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាងនោះ ក្នុងនោះរួមមានការណ៍ដែលថាវាត្រូវបានស្គាល់ដោយសាក្សីម្នាក់ដែលថែរក្សា និងគ្រប់គ្រងវានៅស-២១ ព័ត៌មានពីបុរសម្នាក់ដែលយកវាពីស-២១ និងយកធ្វើជាកម្មសិទ្ធិ រហូតដល់ពេលប្រគល់ជូន អ.វ.ត.ក ឱកាសដែលម្ចាស់បណ្តឹងសាទុក្ខត្រូវធ្វើទឡ្ហីករណ៍ពាក់ព័ន្ធនឹងការទទួលយក និងប្រើ និងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងទៅលើទឡ្ហីករណ៍ទាំងនោះ[594]។ ការទទួលយកសៀវភៅកំណត់ហេតុរួមស-២១[595] ក៏ខកខានមិនបានកំណត់កំហុសនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាងនោះ ដែលរួមបញ្ចូលភ័ស្តុតាងដែលបានបញ្ជាក់[596]។

166. ការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខទៅលើការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសម្ភាសន៍ចំនួនពីរដែលគាត់បានផ្តល់[597] គឺមិនត្រឹមត្រូវទេ។ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើចំនួនភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើ ក្នុងការកំណត់ការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម[598] ដែលមានការបញ្ជាក់ជាច្រើនជាមួយនឹងការសម្ភាសន៍ពីរនេះ។ ការអានដ៏ត្រឹមត្រូវលើការសម្ភាសន៍ទាំងនេះនាំដល់ការសន្និដ្ឋានថា វាជាការផ្អែកភាគច្រើនទៅលើការរម្លឹកឡើងវិញអំពីហេតុការណ៍សហកាល ពុំមែនផ្អែកលើការស្រាវជ្រាវរបស់គាត់ទៅលើស្នាដៃរបស់

---

[594] ឯកសារ **E443/3** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច និងសាក្សីពីររូបពាក់ព័ន្ធនឹង ស-២១។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១២ (ការទទួលយកសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនៅ ស-២១)។

[595] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៤ ជើងទំព័រ ៥១៨ *ដកស្រង់*កថាខណ្ឌ១៤៦៤ របស់ខ្លួន។

[596] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៣១, ២១៣៣-២១៣៤ (ការវាយតម្លៃរបស់ អ.ជ.ស.ដ)។ *សូមមើលផងដែរ* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៤ ជើងទំព័រ ២៧៥៥ (ម្ចាស់បណ្តឹងសាទុក្ខដកស្រង់តែកថាខណ្ឌ ៣៨២២ នៃឯកសារ **E465** ប៉ុណ្ណោះ ដោយមិនគិតពីការវាយតម្លៃរបស់ អ.ជ.ស.ដ ទៅលើ ភ័ស្តុតាងឆ្នាំ១៩៧៨ អំពីទិដ្ឋភាពទូទៅនៃកាលប្បវត្តិក្នុងការកំណត់អត្តសញ្ញាណខ្មាំងរបស់ ប.ក.ក ឆ្នាំ ១៩៧៨ (នៅត្រង់កថាខណ្ឌ ៣៨១៧-៣៨៣៤) និងការយល់ឃើញផ្នែកអង្គហេតុរបស់ អ.ជ.ស.ដ (ត្រង់កថាខណ្ឌ៣៨៣៥-៣៨៦៣) ដែលសៀវភៅកំណត់ត្រារួម គឺភ័ស្តុតាងតែមួយគត់។)

[597] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៤ ជើងទំព័រ ៥១៨ *ដកស្រង់*កថាខណ្ឌ ១៨១៩-១៨២៨, ១៨៧៥ *ដកស្រង់* ឯកសារ **E3/4050**, ឯកសារ **E3/4043** ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយខៀវ សំផន។

[598] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៣ (មូលដ្ឋានសម្រាប់ការវាយតម្លៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខ, ការដឹងឮក្នុងសម័យនោះ ផ្អែកទាំងស្រុងលើសេចក្តីថ្លែងការណ៍ និងអាកប្បកិរិយារបស់គាត់), ៤២០៩ (ការដឹងឮក្នុងសម័យនោះ តាមរយៈការពិនិត្យពិភាក្សាគោលនយោបាយនានា ដែលតាមរយៈគោលនយោបាយទាំងណោះ គោលបំណងរួមត្រូវបានអនុវត្ត), ៤២០៩-៤២១៨ (ការដឹងឮនៅខណៈដែលមានការប្រព្រឹត្ត ឧក្រិដ្ឋកម្ម), ៥៦២-៦២៤ (តួនាទី និងការទទួលខុសត្រូវ), ៤២០១-៤៣១៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌ)។ *សូមមើលផងដែរ* ផ្នែកទី៨.គ.៣ ចេតនា។

អ្នកដទៃឡើយ ដូចជាការទទួលយករបស់គាត់ថាគាត់បានអនុវត្តសេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អំពីការទិញថ្នាំ[599]។ ការតវ៉ារបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីការសន្និដ្ឋានលុបរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្ដីដកស្រង់របស់ខ្លួននៃការសម្ភាសន៍ទាំងនេះ គឺមិនត្រឹមត្រូវស្រដៀងគ្នាដែរ។ វាពុំពាក់ព័ន្ធទៅនឹងសារៈសំខាន់នៃសេចក្ដីដកស្រង់ទេ ក្នុងនោះរួមមានការណ៍ដែលថាដោយមិនគិតពីកង្វះអាហារនិងថ្នាំសង្កូវបានកើតឡើងដោយរបៀបណា របបនោះបានបង្ខំប្រជាជនដែលមានជំងឺ និងដែលដើរស្ទើរតែមិនរួចឱ្យធ្វើការ និងប្រជាជនបានស្លាប់ដោយអត់អាហារ និងខ្វះការថែទាំផ្នែកសុខាភិបាល[600]។ កង្វះសំណួរដែលកត់ត្រាពុំកាត់បន្ថយខ្លឹមសារជាក់ស្ដែងរបស់ចម្លើយឡើយ។

167. ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខទាក់ទិននឹងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៦០ ឆ្នាំ១៩៧១ និងឆ្នាំ១៩៧៦ ក៏មិនត្រឹមត្រូវស្រដៀងគ្នាដែរ[601]។ ទាក់ទិននឹងលក្ខន្តិកៈបក្សឆ្នាំ១៩៧៦ គាត់កំណត់ខុសទៅលើលក្ខណៈនៃការផ្អែករបស់អង្គជំនុំជម្រះសាលាដំបូងលើ នួន ជា ក្នុងការបញ្ជាក់យថាភាពនៃលក្ខន្តិកៈ។ អង្គជំនុំជម្រះសាលាដំបូងពុំបានថ្លែងដោយខុសចំពោះការបញ្ជាក់ពីយថាភាពបែបនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា នួន ជា "[បញ្ជាក់]ថា E3/130 ស្របតាមការរម្លឹកឡើងវិញរបស់គាត់ទៅលើលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ដែលមាន ៨ ជំពូក និង ៣០ មាត្រា"[602] ដែលគាត់បានធ្វើ[603]។ អង្គជំនុំជម្រះសាលាដំបូងក៏កត់សម្គាល់ផងដែរថា នួន ជា មានមតិយោបល់អំពីទស្សនៈនៃ "គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ" ដែលមានចែងក្នុងមាត្រា ៦ នៃលក្ខន្តិកៈឆ្នាំ១៩៧៦[604] ដែលគាត់បានធ្វើ។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងផ្អែកលើសក្ខីកម្មរបស់ ឌុច និង នី កន ក្នុងការបញ្ជាក់យថាភាពនៃលក្ខន្តិកៈឆ្នាំ១៩៧៦[605]។

---

[599] ឯកសារ **E3/4043** ប្រតិចារឹកបទសម្ភាសន៍ជាមួយខៀវ សំផន EN 00786109។

[600] ឯកសារ **E3/4043** ប្រតិចារឹកបទសម្ភាសន៍ជាមួយខៀវ សំផន EN 00786109 *ផ្ទុយពី* ឯកសារ **E3/4050** ប្រតិចារឹកបទសម្ភាសន៍ជាមួយខៀវ សំផន EN 00789062។ សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១, ១៨៣។

[601] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៣៥២ និងជើងទំព័រ៥៣២ *ដកស្រង់* ឯកសារ **E465** កថាខណ្ឌ ៣៤៤, ៣៤៨ (ពិភាក្សាអំពីលក្ខន្តិកៈទាំងនេះ)។ *សូមមើលផងដែរ* កថាខណ្ឌ ៣៤៣ (ពិភាក្សាអំពីលក្ខន្តិកៈទាំងនេះ)។

[602] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៣២៥ ("សេចក្ដីថ្លែងការណ៍ដោយអង្គជំនុំជម្រះនេះ គឺមិនពិតទេ")។

[603] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៤ ជើងទំព័រ ៩៥១ *ដកស្រង់* ឯកសារ **E1/21.1** ប្រតិចារឹក នួន ជា ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ម៉ោង ១០.០៧.២៣-១០.១៦.៣៤ ទំព័រ ២៣ បន្ទាត់ ៤-ទំព័រ ២៤ បន្ទាត់ ១៦។

[604] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៤៤ ជើងទំព័រ ៩៥១ *ដកស្រង់* ឯកសារ **E1/23.1** ប្រតិចារឹកនួន ជា ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ម៉ោង ១០.៥៥.១៧-១១.០៥.៥៥ ទំព័រ ៣២ បន្ទាត់ ១៩-ទំព័រ ៣៦ បន្ទាត់ ៣។

[605] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៤ ជើងទំព័រ ៩៥១។

168. ការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខអំពីលក្ខន្តិកៈឆ្នាំ១៩៦០ គឺពុំត្រឹមត្រូវទេ។ គាត់ក៏ខកខានមិនបានកំណត់ថានៅកន្លែងណាដែលមានសក្ខីកម្មគ្រប់គ្រាន់ ទាក់ទិននឹងផ្នែកពាក់ព័ន្ធនៃឯកសារ ឯកសារនោះត្រូវតែនៅចំពោះមុខតុលាការដើម្បីពិចារណា ដូចនៅទីនេះដែរ[606]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើការពិចារណាទាំងនេះទៅលើបទបញ្ញត្តិពាក់ព័ន្ធនៃសំណៅលក្ខន្តិកៈនោះ មុនដំបូងគេគឺសក្ខីកម្មរបស់ ឌុច[607]ប៉ុន្តែ នួន ជា ក៏បានទទួលស្គាល់អត្ថិភាពនៃលក្ខន្តិកៈឆ្នាំ១៩៦០ ដែរ[608]។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថាខ្លួននឹងប្រើប្រាស់លក្ខន្តិកៈ ឆ្នាំ១៩៧១ ដោយប្រុងប្រយ័ត្ន ហើយនឹងលើកយកខ្លឹមសារនៃកំណត់ហេតុនេះមកធ្វើជាសំអាងហេតុតែក្នុងករណីដែលខ្លឹមសារទាំងនោះត្រូវបានគាំទ្រដោយភស្តុតាងដទៃទៀត[609]។

169. បន្ថែមលើការលើកទឡ្ហីករណ៍ជាថ្មីម្តងទៀតពាក់ព័ន្ធនឹងកំណត់ហេតុគណៈអចិន្ត្រៃយ៍របស់ DC-Cam ដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធនៅក្នុងសំណុំរឿង០០២/០១[610] ម្ចាស់បណ្តឹងសាទុក្ខក៏មិនអើពើ និង ពុំបង្ហាញកំហុសឆ្គងនៅក្នុងការវាយតម្លៃដ៏ទូលំទូលាយទៅលើភាពទុកចិត្ត

---

[606] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៥ ឯកសារ **E185** សេចក្តីសម្រេចលើឯកសារ សំណុំរឿង០០២/០១ កថាខណ្ឌ ៣១។

[607] ឯកសារ **E1/52.1** ប្រតិចារឹក កាំង ហ្គេចអ៊ាវ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ម៉ោង 13.53.32-13.56.58 ទំព័រ ៧០ បន្ទាត់ ៩-ទំព័រ ៧១ បន្ទាត់ ១០ (លក្ខន្តិកៈចំនួន៣ លើកទី១ឆ្នាំ១៩៦០ បានសិក្សាលក្ខន្តិកៈនោះ ហើយក៏របានឃើញលក្ខន្តិកៈឆ្នាំ១៩៧៦ ក្នុងឆ្នាំ១៩៧៦) ម៉ោង 14.05.44-14.09.26 ទំព័រ ៧៤ បន្ទាត់ ៨-ទំព័រ ៧៥ បន្ទាត់ ៩ (ប្រៀបធៀបលក្ខន្តិកៈ ឆ្នាំ១៩៦០ ជាមួយលក្ខន្តិកៈ ឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥)។ ឯកសារ **E1/53.1** ប្រតិចារឹក កាំង ហ្គេចអ៊ាវ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ម៉ោង 09.27.24-09.31.45 ទំព័រ ១០ បន្ទាត់ ២២-ទំព័រ ១១ បន្ទាត់ ១៧ (ភាពខុសគ្នារវាងលក្ខន្តិកៈឆ្នាំ ១៩៧១ និងឆ្នាំ១៩៦៦ (sic) និងភាពខុសគ្នារវាងលក្ខន្តិកៈទាំងពីរនោះ និងលក្ខន្តិកៈ ឆ្នាំ១៩៦០)។ ឯកសារ **E1/62.1** ប្រតិចារឹក កាំង ហ្គេចអ៊ាវ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ម៉ោង 15.18.09-15.19.49 ទំព័រ ៨១ បន្ទាត់ ២២-ទំព័រ ៨២ បន្ទាត់ ៧ (ឆ្នាំ១៩៦០ និងក្រោយមកទៀត – លក្ខន្តិកៈ ចែងយ៉ាងច្បាស់ថាថ្នាក់ក្រោមគោរពបញ្ជាថ្នាក់លើ និងថ្នាក់ដឹកនាំ ជាគណៈមជ្ឈិម។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៣ ជើងទំព័រ ៩៤៦ *ដកស្រង់*ផ្នែកខ្លះ ឯកសារ **E3/10** *ទង់បដិវត្ត* ខែកញ្ញា-តុលា ឆ្នាំ១៩៧៦ EN 00450506 (បង្កើតលក្ខន្តិកៈក្នុងឆ្នាំ១៩៦០)។

[608] ឯកសារ **E1/14.1** ប្រតិចារឹក នួន ជា ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ម៉ោង 14.03.12-14.04.05 ទំព័រ ៨២ បន្ទាត់ ៣-៦។ ឯកសារ **E3/3** សេចក្តីថ្លែងការណ៍របស់ នួន ជា មានចំណែងជើង "ប្រវត្តិនៃការតស៊ូ និងចលនារបស់អ្នកស្រុកស្រែខ្មែរយើងពីឆ្នាំ ១៨៥៤ ដល់ឆ្នាំ១៩៧៩" EN 00184662; ឯកសារ **E1/17.1** ប្រតិចារឹកនួន ជា ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ ម៉ោង 10.14.21 ទំព័រ ២៣ បន្ទាត់ ៣-៩ ម៉ោង 10.19.05-10.23.00 ទំព័រ ២៥ បន្ទាត់ ១-១៦ (សន្និបាតបក្សលើកទីមួយក្នុងឆ្នាំ១៩៦០ អនុម័តលក្ខន្តិកៈ មាន៣០មាត្រា) ។

[609] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៤។.

[610] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៦-៣២៨ សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៦៩-៣៧៥។

បាន (ក្នុងនោះរួមទាំងយថាភាព) នៃកំណត់ហេតុទាំងនេះដែលទទួលបានពីប្រភពផ្សេងៗ[611]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ពាក់ព័ន្ធនឹងឯកសាររបស់ DC-Cam អង្គជំនុំ ជម្រះសាលាដំបូង "ត្រូវ[...]សន្មតថា[ឯកសារទាំងនេះ]មានភាពអាចជឿជាក់បានគ្រប់ គ្រាន់រួមទាំងយថាភាពដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់សេចក្តីសន្និដ្ឋានលើអង្គហេតុដែរឬទេ"[612]។ ម្ចាស់បណ្តឹងសាទុក្ខពុំបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានធ្វើដូច្នេះឡើយ។

## ២. ចម្លើយរបស់ជនជាប់ចោទ (នាសម័យកាលនោះ និងក្រោយសម័យកាលនោះ)

### *មូលដ្ឋានទី ៣១៖ ចម្លើយក្រៅប្រព័ន្ធតុលាការ*[613]

170. **មូលដ្ឋានទី ៣១ គួរតែត្រូវបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំកំណត់ថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់និងអង្គហេតុដែលខ្លួនផ្អែកលើសម្រាប់វាយតម្លៃលើចម្លើយក្រៅប្រព័ន្ធតុលាការ នៅក្នុងការអនុវត្តរបស់ខ្លួនទៅលើក្របខ័ណ្ឌចំពោះភស្តុតាងបែបនេះ ឬនៅក្នុងការវាយតម្លៃរបស់ខ្លួនលើភស្តុតាងនោះ។**

171. ការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលឡើយ ដោយហេតុថាគាត់ (i) គ្រាន់តែដាក់ជំនួសការវាយតម្លៃរបស់គាត់លើភស្តុតាង ជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ (ii) លើកឡើងករណីបំភាន់ដោយគ្មានភស្តុតាងសំអាងថា "គេមិនអាចទទួលយកការសន្និដ្ឋានហួសពីវិមតិសង្ស័យដោយផ្អែកលើភស្តុតាងដែលត្រូវបានគេវិនិច្ឆ័យថា មានតម្លៃជាភស្តុតាងតិចតួចបំផុត"[614] ដោយមិនខ្វល់ថា តម្លៃភស្តុតាងអាចត្រូវបានពង្រឹងដោយភស្តុតាងស្រដៀងគ្នាដូច្នេះហើយ អាចបំពេញបាននូវលក្ខខណ្ឌបន្ទុកនៃភស្តុតាង[615] ហើយក៏មិនអើពើផង ដែរថា "ភស្តុតាងជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានអង្គហេតុទំនងជាមាន*កម្រិតទាប*ជារួម គឺតម្រូវឱ្យមាន

---

[611] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៧-៤៥៣។

[612] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៧។

[613] <u>មូលដ្ឋានទី ៣១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ចម្លើយក្រៅប្រព័ន្ធតុលាការ* កថាខណ្ឌ ៣០៦-៣១១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៥ (ភាសាអង់គ្លេស) ទំព័រ ១៣-១៤ (ភាសាបារាំង) ទំព័រ ១៩-២០ (ភាសាខ្មែរ)។

[614] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០៧។

[615] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤២៤។

សំអាងហេតុបន្ថែម"[616] និង (iii) អះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូងផ្អែកតែទៅលើចម្លើយក្រៅប្រព័ន្ធតុលាការដោយមិនត្រឹមត្រូវ ក្នុងការធ្វើសេចក្តីសន្និដ្ឋានពីពិរុទ្ធភាព [617]។

172. មូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលផលឡើយ ដោយមូលហេតុផ្សេងទៀតដែរ។ គាត់ពុំទទួលបានផលប្រយោជន៍ពីការផ្អែកលើកថាខណ្ឌ១៤២៩-១៤៣០ របស់គាត់ទេដែលវែកញែកកំហុសនៅក្នុងការវាយតម្លៃភស្តុតាងពីសំណាក់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការទំនាក់ទំនង។ នៅក្នុងកថាខណ្ឌទី១៤២៩ គាត់លើកទឡ្ហីករណ៍ជាថ្មីម្តងទៀតដោយមិនត្រឹមត្រូវថា គាត់ត្រូវបាន គេបដិសេធមិនឱ្យចូលពិនិត្យមើលភស្តុតាងដើម និងខ្សែចង្វាក់នៃការថែរក្សា ទុកដាក់ឯកសារ និងលើកឡើងសាជាថ្មីនូវការតវ៉ាមិនជោគជ័យ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះសាលាដំបូងរក្សាគោលជំហរនៃសច្ចធារណ៍នៃភាពអាចជឿទុកចិត្តបាននៃឯកសាររបស់ DC-Cam[618]។ គាត់ពុំបានកំណត់ថាគាត់ត្រូវបានបដិសេធមិនឱ្យចូលពិនិត្យមើលភស្តុតាងដើមឡើយ។ ផ្ទុយទៅវិញ ដូចដែល អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់គាត់ ដែលស្នើអង្គជំនុំជម្រះសាលាដំបូងបង្គាប់មជ្ឈមណ្ឌលសារកម្ពុជាឱ្យបញ្ជូនឯកសារដើមនៃឯកសារទាំងអស់ដែលត្រូវបានដាក់នៅក្នុងសំណុំរឿង ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខអាចស្នើសុំឱ្យគាត់ចូលពិនិត្យឯកសារដើមទាំងនោះបាន[619]។ ការខកខានរបស់គាត់ក្នុងការឆ្លៀតយកប្រយោជន៍ចេញពីឱកាសនេះ ពុំស្មើនឹងកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

---

[616] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ) *ដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០ (គូសបញ្ជាក់បន្ថែម)។

[617] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១១ ជើងទំព័រ ៤៨១ *ដកស្រង់*ជាឧទាហរណ៍នូវកថាខណ្ឌ ៧៣១, ១០៤៤-១០៤៥, ១៤២៩-១៤៣០, ១៥២៥ របស់គាត់។ មិនមានកថាខណ្ឌណាមួយក្នុងសាលក្រម ដែលបានយោងនៅក្នុងឧទាហរណ៍ទាំងនេះ ផ្អែកលើចម្លើយ ឬឯកសារនៅក្រៅតុលាការទេ។ ឯកសារទាំងអស់នេះ ជាផ្នែកមួយនៃការវាយតម្លៃដោយយកចិត្តទុកដាក់នៃភស្តុតាងដោយផ្អែកលើសក្ខីកម្មនៅក្នុងតុលាការ និងប្រភពផ្សេងទៀតនៃភស្តុតាង។ *សូមមើលឧទាហរណ៍* កថាខណ្ឌ ៧៣១ របស់គាត់ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ ដែលជាផ្នែកមួយនៃផ្នែកទី១០.១.៧ ការរស់នៅ និងការងារនៅក្នុងសហករណ៍ (កថាខណ្ឌ៩៦៨-១០៥១) ហើយជាពិសេស ផ្នែកទី ១០.១.៧.៣.២ ការអនុវត្តនៅត្រាំកក់ (កថាខណ្ឌ១០១០-១០១៦)។ ចំពោះកថាខណ្ឌ១០៤៤-១០៤៥ របស់គាត់ គឺពាក់ព័ន្ធនឹងជាតិពន្ធុវៀតណាមជាប់ខ្សែខាងម្តាយ។ *សូមមើល* ផ្នែកទី១៣.៣.៦ នៃសាលក្រម ការកំណត់អត្តសញ្ញាណជនជាតិវៀតណាម និងជាតិពន្ធុវៀតណាមជាប់ខ្សែខាងម្តាយ។ ជាពិសេស ផ្នែកទី១៣.៣.៦.៣ ជាតិពន្ធុ វៀតណាមជាប់ខ្សែខាងម្តាយ (កថាខណ្ឌ ៣៤៣៤-៣៤៣៨)។ សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋានទី ១៣១ និង១៣២ (ការប្រើប្រាស់ចម្លើយក្រៅតុលាការរបស់បុគ្គលដែលបានស្លាប់)។

[618] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២៩។

[619] ឯកសារ **E185** សេចក្តីសម្រេចលើឯកសារ សំណុំរឿង០០២/០១ កថាខណ្ឌ ១៩,២៨។

173. ការយោងរបស់គាត់ដល់កថាខណ្ឌផ្សេងៗទៀតនៃសារណារបស់គាត់ក្នុងកថាខណ្ឌ១៤៣០ជើងទំព័រទី២៧០៣ ពុំគាំទ្រដល់ទឡ្ហីករណ៍របស់គាត់នៅក្នុងមូលដ្ឋាននៃបណ្តឹងសាទុក្ខនេះទេ ដែលយោងដល់តែផ្នែកមួយនៃការវាយតម្លៃលើភ័ស្តុតាងពីសំណាក់អង្គជំនុំជម្រះសាលាដំបូង និងត្រឹមតែជំនួសទស្សនៈរបស់ខ្លួនជាមួយនឹងទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូង។ ការចោទប្រកាន់នៅក្នុងកថាខណ្ឌទាំងនេះក៏ពុំទទួលផលដែរ ដោយមូលហេតុដូចមានចែងពេញលេញនៅក្នុងផ្នែកផ្សេងៗទៀតនៅក្នុងចម្លើយតបនេះ[620]។

## *មូលដ្ឋានទី ២៧៖ ចម្លើយ/សៀវភៅរបស់ ខៀវ សំផន*[621]

174. **មូលដ្ឋានទី ២៧ គួរតែត្រូវបដិសេធដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំបង្ហាញថាអង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសអង្គច្បាប់ឬអង្គហេតុក្នុងការវាយតម្លៃចម្លើយនិងស្នាដៃស្រាវជ្រាវរបស់គាត់។**

175. មូលដ្ឋាននេះពុំទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខពុំផ្តល់ភ័ស្តុតាងគាំទ្រការអះអាងរបស់គាត់ថាអង្គជំនុំជម្រះសាលាដំបូងបានកំណត់ក្របខ័ណ្ឌផ្សេងមួយ សម្រាប់ការវាយតម្លៃចម្លើយនិងសៀវភៅរបស់គាត់[622]។ គាត់ពុំពន្យល់ភាពខុសគ្នាឬថាតើភាពខុសគ្នានោះអាចបង្កើតជាកំហុសអង្គច្បាប់ឬកំហុសអង្គហេតុដោយរបៀបណាឡើយ។ គាត់ក៏ពុំកំណត់ "ការនិយាយជាន់កែងខ្លួនឯង"នៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែរ[623]។ ឧទាហរណ៍ចំនួនពីរ

---

[620] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩០-១០៩១ (អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម) – *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥, ១៤៣០ និងខាងមុខ (មិនអាចពិចារណាបាន ដោយសារតែមិនមានភាពច្បាស់លាស់ ហើយកថាខណ្ឌ ១៤២៩ ពាក់ព័ន្ធចំណុចខាងលើ), ១៥៤២, ១៦២៤-១៦២៦, ១៦២៩, ១៦៤៦, ១៦៤៩, ១៧១១ (កថាខណ្ឌទាំងអស់នេះលើកឡើងអំពីទូរលេខ និងរបាយការណ៍ផ្ញើទៅមេដឹកនាំថ្នាក់លើ, ការមិនយល់ស្របគ្នានូវអត្ថន័យនៃពាក្យ ដូចជាមជ្ឈិមបក្ស, អង្គការ, មន្ទីរ៨៧០ និងការជាប់ទាក់ទងរបស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងការទំនាក់ទំនងទាំងនេះ), ១៧១៤ (ទំនាក់ទំនងការងារ និងការជាប់ទាក់ទងរបស់គាត់ទៅនឹងភ្នំក្រោល។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែកទី៦ (រចនាសម្ព័ន្ធទំនាក់ទំនងការងារ), ផ្នែកទី៨.ខ តួនាទី និង មុខងារ, ផ្នែកទី៨.គ.២ ការចូលរួមយ៉ាងសំខាន់, ផ្នែកទី៨.គ.៣ ចេតនា (ធាតុផ្សំអត្តនោម័តរបស់ម្ចាស់បណ្តឹងសាទុក្ខ), ផ្នែកទី៨.ឃ ការជួយ និងជំរុញ, ផ្នែកទី៨.គ សហឧក្រិដ្ឋកម្មរួម។

[621] <u>មូលដ្ឋានទី ២៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ចម្លើយ/សៀវភៅរបស់ ខៀវ សំផន* កថាខណ្ឌ ២៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៣-១៤ (ភាសាអង់គ្លេស) ទំព័រ ១២ (ភាសាបារាំង) ទំព័រ ១៧-១៨ (ភាសាខ្មែរ)។

[622] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៧។

[623] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៧។ វាមិនមានភាពច្បាស់លាស់នូវអ្វីដែលម្ចាស់បណ្តឹងសាទុក្ខ អះអាងថាជាកំហុសពាក់ព័ន្ធនឹងក្របខ័ណ្ឌសម្រាប់ការវិភាគ ដែលបានប្រើដើម្បីវាយតម្លៃលើចម្លើយ និងសៀវភៅ បោះពុម្ពផ្សាយ

ដែលគាត់ផ្តល់នៅក្នុងកថាខណ្ឌ២៥៧ ពោលគឺ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការវាយតម្លៃលើសក្ខីកម្មរបស់គាត់ក្នុងតុលាការ និងស្នាដៃស្រាវជ្រាវរបស់គាត់ ពុំបង្កើតជាកំហុសឡើយ។ ពុំមានការបង្ហាញកំហុសពាក់ព័ន្ធនឹងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថាខ្លួនគួរផ្អែកលើសក្ខីកម្មមិនទាន់ស្បថរបស់ម្ចាស់បណ្តឹងសាទុក្ខ "ត្រូវមានការប្រយ័ត្នចាំបាច់និងត្រូវបញ្ជាក់គាំទ្រដោយភ័ស្តុតាងផ្សេងៗទៀត"[624]។ ក្នុងឋានៈជាជនជាប់ចោទដែលប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតប្រសិនបើត្រូវបានកំណត់ពិរុទ្ធភាពនោះ និងទំនងជាមានបំណងចង់បន្ថយការទទួលខុសត្រូវរបស់ខ្លួន គាត់មានចេតនាភូតកុហក ដែលធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងមានភាពសមស្របក្នុងការពិចារណាលើសក្ខីកម្មរបស់គាត់ដោយប្រុងប្រយ័ត្ន។ ទន្ទឹមនឹងនេះវាក៏មិនមែនជាកំហុសផងដែរក្នុងការពិចារណាកម្រិត ដែលវាត្រូវបានបញ្ជាក់គាំទ្រដោយភ័ស្តុតាងផ្សេងៗទៀតនោះ ដូចគ្នាទៅនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការវាយតម្លៃសក្ខីកម្មរបស់ នួន ជា[625]។ ជាងនេះទៀត ចេតនាលាក់បាំងនិងការអះអាងបញ្ជាក់គឺជាកត្តាទូទៅដែលអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថាខ្លួននឹងពិចារណានៅក្នុងការវាយតម្លៃភ័ស្តុតាង[626]។

176. ម្ចាស់បណ្តឹងក៏ខកខានផងដែរមិនបានបង្ហាញកំហុស នៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទៅលើឯកសារបោះពុម្ពផ្សាយដែលមានចំណងជើងថា "ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់របបកម្ពុជាប្រជាធិបតេយ្យ"។ អង្គជំនុំជម្រះសាលាដំបូងកំណត់យ៉ាងត្រឹមត្រូវថាខ្លួននឹងផ្អែកលើឯកសារបោះពុម្ពផ្សាយនេះ "នៅក្នុងកម្រិតកំណត់មួយប៉ុណ្ណោះ" និង "នៅត្រង់ចំណុចដែល[ឯកសារបោះពុម្ពផ្សាយនេះ] ផ្តល់ព័ត៌មានអំពីប្រវត្តិសាស្ត្រដែលមិនធ្លាប់ត្រូវបានទទួលស្គាល់ពីមុន និងជាព័ត៌មានប្រវត្តិសាស្ត្រពិសេសរបស់ជនជាប់ចោទ ឬជាព័ត៌មានដែលគាំទ្រដល់ព័ត៌មានដែលអាចជឿជាក់បានដទៃទៀតដែលមាន នៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ"[627]។

របស់ម្ចាស់បណ្តឹងសាទុក្ខទេ។ ក្នុងឧបសម្ព័ន្ធ ក គាត់លើកឡើងថា អ.ជ.ស.ដ បានផ្តល់ក្របខ័ណ្ឌសម្រាប់ការវិភាគចម្លើយនិងសៀវភៅរបស់គាត់ ដែល អ.ជ.ស.ដ ខ្លួនឯង មិនបានគោរព។ (*សូមមើល* ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៣ (ភាសាអង់គ្លេស)។ ផ្ទុយមកវិញ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ កថាខណ្ឌ ២៥៧ គាត់ថ្លែងថា អ.ជ.ស.ដ បង្កើតក្របខ័ណ្ឌសម្រាប់ការវិភាគមួយ *ផ្សេងទៀត* (គូសបញ្ជាក់បន្ថែម)។

[624] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៧ ជើងទំព័រ ៣៨១ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៩៥។

[625] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៩៣។

[626] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩, ៦២, ១៩៥។

[627] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៩៤។

នៅក្នុងការកំណត់នេះ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែកត់សម្គាល់ថាខ្លួននឹងពិចារណាថា ជាចម្លើយរបស់ម្ចាស់បណ្ដឹងសាទុក្ខនូវសារវគ្គទាំងឡាយដែលអាចជារបស់គាត់ ឬវគ្គទាំងឡាយ ដែលបញ្ជាក់ដោយព័ត៌មានដទៃទៀតដែលអាចជឿជាក់បាន។ ម្ចាស់បណ្ដឹងពុំចង្អុលទៅដល់ចំណុចពិសេស ឬដែលមានកំហុសនៅក្នុងវិធីសាស្ត្រនេះឡើយក្នុងការវាយតម្លៃភស្តុតាង។ គាត់មិនបានរកឃើញដោយច្បាស់លាស់គ្រប់គ្រាន់នូវកំហុសអង្គហេតុនៅក្នុងការវាយតម្លៃ និងមិនបានបង្ហាញថាពុំមានតុលាការអង្គហេតុសមស្របណាមួយអាចបានផ្អែកលើវាក្នុងការសន្និដ្ឋានឡើយ។

177. ការពឹងផ្អែករបស់គាត់ទៅលើកថាខណ្ឌផ្សេងៗទៀតនៅក្នុងសារណារបស់ខ្លួន[628] ពុំគាំទ្រដល់ការចោទប្រកាន់របស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងនិយាយជាន់កែងខ្លួនឯង បំភ្លៃ និងបកស្រាយមិនត្រឹមត្រូវនូវចម្លើយ ឬឯកសាររបស់គាត់ ឬប្រើវាតែសម្រាប់គោលបំណងដាក់បន្ទុកប៉ុណ្ណោះ។ កថាខណ្ឌទី ១២៤៤ ដែលពាក់ព័ន្ធនឹងការចោទថាមានកំហុសក្នុងការអនុវត្តបទបញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ មិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខត្រឹមតែយោងដល់កថាខណ្ឌនានានៃសាលក្រមនិងធ្វើការអះអាងថាដោយគ្មានភស្តុតាងគាំទ្រ[629]។ ការផ្អែកលើកថាខណ្ឌ ១៣៩៥-១៣៩៨ ទាក់ទិននឹងកំហុសអង្គហេតុតាមការចោទប្រកាន់ក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាគោលនយោបាយ គឺជាការភាន់ច្រឡំស្រដៀងគ្នា។ គាត់ខកខានមិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរនៅក្នុងការវាយតម្លៃរួមទៅលើភស្តុតាង។ ការវាយតម្លៃនោះ មិនបាន "បដិសេធ" ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយការព្រមព្រៀង ឬមិនអើពើ ឬបកស្រាយមិនត្រឹមត្រូវអំពីភស្តុតាងដែល "បញ្ជាក់អះអាងអំពីគោលការណ៍នេះ"[630]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានដោយត្រឹមត្រូវថា ទោះបីជាមានការប្រើភាសានៅក្នុងឯកសារនេះ និងចម្លើយ និងសក្ខីកម្ម "ដោះបន្ទុក" ក្ដី ប៉ុន្តែភស្តុតាងទាំងមូលបានកំណត់ថា អាពាហ៍ពិពាហ៍ត្រូវបានបង្ខំស្របតាមការណែនាំរបស់ថ្នាក់លើ[631]។ គាត់ក៏ខកខានមិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានអើពើភស្តុតាង

---

[628] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៥៧ ជើងទំព័រ ៣៨៥ *ដកស្រង់* កថាខណ្ឌរបស់ខ្លួន កថាខណ្ឌ ១២៤៤, ១៣៩៥-១៣៩៨, ១៥២៦-១៥៤០។

[629] *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៨។

[630] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៩៧។

[631] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២៦-៣៦៨៥ (ការវិភាគបញ្ហាទាក់ទងនឹងប្រភពភស្តុតាង ការជំទាស់នានារបស់ក្រុមមេធាវីការពារក្ដី និងការជំទាស់របស់ក្រុមមេធាវីការពារក្ដីទៅនឹងភស្តុតាង, ការជូនដំណឹង, ការយល់ព្រម, ការពិនិត្យមើល និងភស្តុតាង "ដោះបន្ទុក" (ឧទាហរណ៍ កថាខណ្ឌ ៣៦១៧-៣៦២៥) និងការយោងទៅលើផ្នែកសារតាប្រវត្តិសាស្ត្រនៃសាលក្រម), ៣៥៨៦-៣៦៩៤ (សំអាងច្បាប់ស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ), ៣៦៩៥-៣៧០១

"ដោះបន្ទុក"។ អង្គជំនុំជម្រះសាលាដំបូងត្រឹមតែវាយតម្លៃ និងបដិសេធចោលភ័ស្តុតាងនោះ ដោយគិតដល់ភ័ស្តុតាង *ទាំងមូល*។

178. កថាខណ្ឌទី ១៥២៦-១៥៤០ របស់គាត់ ពុំបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូងបំភ្លៃឯកសារនិងសុន្ទរកថានោះឡើយ។ ម្ចាស់បណ្តឹងសាទុក្ខពុំបង្ហាញកំហុសពាក់ព័ន្ធនឹង "ការស្វែងយល់" របស់អង្គជំនុំជម្រះ សាលាដំបូងអំពីរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ជាពិសេសមាត្រា១០[632]។ ទោះបីជាមាត្រានេះ ពុំពន្យល់អត្ថន័យនៃពាក្យ "ផ្តន្ទាទោសកម្រិតខ្ពស់បំផុត" ដែលជាភាសាដើមរបស់គណៈកម្មាធិការ មជ្ឈិម[633] ដែលអង្គជំនុំជម្រះសាលាដំបូងបានយោងក្នុងការកំណត់ "គោលជំហររបស់បក្សចំពោះ ការដាក់ទណ្ឌកម្មខ្លាំង"[634] បង្ហាញយ៉ាងច្បាស់៖ សិទ្ធិសម្រេច [កម្ទេច] ក្នុង និងក្រៅជួរបក្ស។ ទឡ្ហីករណ៍របស់ ម្ចាស់បណ្តឹងសាទុក្ខអំពី "ស្តង់ដាពីរ"ក្នុងការវាយតម្លៃរដ្ឋធម្មនុញ្ញក៏មិនទទួលផលដែរ ដោយហេតុថា ជាថ្មីម្តងទៀត គាត់ពុំឃើញគុណតម្លៃថាការវាយតម្លៃលើភាពសមហេតុផលនៃការសន្និដ្ឋានជាក់លាក់ត្រូវបានធ្វើរួចហើយនៅក្នុងបរិបទនៃភ័ស្តុតាងទាំងមូល។ ភ័ស្តុតាងទាំងមូលបញ្ជាក់ច្បាស់នូវភាសាអំពីសេរីភាពសាសនាដែលផ្ទុយទៅនឹងគោលនយោបាយដែលដាក់ចេញ ដោយបក្សកុម្មុយនីស្តកម្ពុជាដែលប្រឆាំងនឹងសាសនានិងមិនអនុញ្ញាតដល់សេរីភាពសាសនាឡើយ[635]។

179. ម្ចាស់បណ្តឹងសាទុក្ខក៏ពុំបានផ្តល់ភ័ស្តុតាងគាំទ្រដល់ការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានប្រើសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមដោយលម្អៀង[636]។ ទឡ្ហីករណ៍របស់គាត់ដំបូងយោងត្រឡប់ទៅការព្រួយបារម្ភរបស់គាត់អំពីយថាភាពនៃឯកសារ[637] ដែលត្រូវ

(ការរំលោភផ្លូវភេទនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍), ៣៥៦៩-៣៥៧១ (ការចូលរួមដោយផ្ទាល់របស់ខៀវ សំផន) ៤០៦២-៤០៦៧ (គោលនយោបាយទាក់ទងនឹងការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍)។ *សូមមើលផងដែរ* ផ្នែកទី ៧.ឃ ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។

[632] ឯកសារ**F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៧-១៥២៩ *ដកស្រង់* ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ មាត្រា១០។

[633] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៥ *ដកស្រង់* ឯកសារ **E3/12** សេចក្តីសម្រេចគណៈកម្មាធិការមជ្ឈិម ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ EN 00182809។

[634] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៥។

[635] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៩ ជើងទំព័រ ២៩០១។

[636] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣០ ជើងទំព័រ ២៩០៣ *ដកស្រង់*កថាខណ្ឌរបស់ខ្លួន កថាខណ្ឌ ១៧១៨-១៧២២។

[637] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១៨ យោងត្រឡប់ទៅកថាខណ្ឌ ១៧១៧ របស់ខ្លួន។

កំចាត់ ដោយការពន្យល់ដោយសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងថាមូលហេតុអ្វីបានជាខ្លួនចាត់ទុកថាឯកសារនេះមានសារៈសំខាន់ ក្នុងនោះរួមមានការវិភាគរបស់ខ្លួនទៅលើ "ប្រភពខ្សែចង្វាក់នៃការរក្សាទុក និងតម្លៃជាភស្តុតាងនៃឯកសារនេះ"[638]។

180. គាត់ពុំបានកំណត់នូវកំហុស ទាក់ទិននឹងការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងឈានដល់ការសន្និដ្ឋានផ្សេងគ្នាមួយអំពី ថាតើម្ចាស់បណ្តឹងសាទុក្ខមានវត្តមាននៅក្នុងកិច្ចប្រជុំមួយរបស់គណៈកម្មាធិការមជ្ឈិមក្នុងខែមិថុនា ឆ្នាំ១៩៧៤ ថាតើសេចក្តីសម្រេចពាក់ព័ន្ធនឹងសិទ្ធិសម្រេចកម្មេចត្រូវបានធ្វើឡើង ដោយគណៈកម្មាធិការមជ្ឈិមឬគណៈកម្មាធិការអចិន្ត្រៃយ៍ ថាតើកិច្ចប្រជុំមួយបានប្រព្រឹត្តទៅ ពាក់ព័ន្ធនឹងការសម្រេចអំពីសិទ្ធិសម្រេចកម្មេច និងថាតើ ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមក្នុងកិច្ចប្រជុំនោះដែរឬទេ[639]។ អង្គជំនុំជម្រះសាលាដំបូងបានបំពេញតួនាទីរបស់ខ្លួនក្នុងការវិនិច្ឆ័យលើ សំណុំរឿង០០២/០២ ដោយផ្អែកលើការពិនិត្យថ្មីៗទៅលើភស្តុតាងនៅចំពោះមុខខ្លួន។ ការពិនិត្យបែបនេះនាំឱ្យមានការសន្និដ្ឋានមួយផ្សេងអំពីកិច្ចប្រជុំក្នុងឆ្នាំ១៩៧៤ គឺជាភស្តុតាងនៃការយកចិត្តទុកដាក់ ពុំមែនជាកំហុសឆ្គងឡើយ[640]។

181. ម្ចាស់បណ្តឹងសាទុក្ខតាមការសារភាពរបស់ខ្លួន គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមចាប់តាំងពីឆ្នាំ១៩៧១ និងបានចូលរួមប្រជុំនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដូច្នេះទោះជាគណៈកម្មាធិការណាក៏ដោយដែលចេញសេចក្តីសម្រេចនោះ គឺមិនសំខាន់ទេ ជាពិសេសដោយហេតុថាសេចក្តីសម្រេចដ៏សំខាន់មួយអាចត្រូវបានផ្ញើជូនគណៈកម្មាធិការមជ្ឈិមប្រសិនបើសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍យ៉ាងហោចណាស់ដើម្បីការផ្សព្វផ្សាយ ដូចដែលម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងបានថ្លែងស្រាប់[641]។ ស្រដៀងគ្នានេះដែរ ថាតើសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំមយយដែលសមាជិកនានាមានវត្តមានផ្ទាល់ ឬតាមវិធីពិគ្រោះពិភាក្សាសេចក្តីសម្រេចនេះអាចត្រូវបានផ្ញើដល់អ្នកដែលពុំមានវត្តមាននៅក្នុងការបំពេញការងារជាប្រចាំ

---

[638] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៦។

[639] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១៨។

[640] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦ ("មិនមានការចម្លងនូវការទទួលខុសត្រូវព្រហ្មទណ្ឌពីសំណុំរឿងមួយទៅសំណុំរឿងមួយទៀតនោះទេ ហើយផ្អែកសំអាងហេតុ មិនត្រូវបានដកស្រង់ពីក្នុងសំណុំរឿង០០២/០១ មកបញ្ចូលក្នុងសំណុំរឿង០០២/០២ នោះដែរ។ ក្នុងបរិបទនេះ ទោះបីជាមានចំណុចរួមគ្នាដោយផ្នែកៗរវាងភស្តុតាងផ្ទាល់មាត់ និងភស្តុតាងជាឯកសារនៅក្នុងសំណុំរឿងនីមួយៗក៏ដោយ តែនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃលើសម្ភារៈទាំងអស់ដែលមាននៅចំពោះមុខនោះ៖ អាចមានការធ្វើសេចក្តីសន្និដ្ឋានផ្សេងគ្នា រួមទាំងទៅលើភស្តុតាង និងអង្គសេចក្តីនានាដែលពាក់ព័ន្ធរួមគ្នា។")

[641] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១០។

ជាពិសេសដោយសារម្ចាស់បណ្តឹងសាទុក្ខមានទំនាក់ទំនងជិតស្និទ្ធជាមួយ ប៉ុល ពត និង នួន ជា ផងនោះ។ ប៉ុន្តែក្នុងចំណុចនេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាការតែងតាំងម្ចាស់បណ្តឹងសាទុក្ខជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម ត្រូវបានប្រកាសជាផ្លូវការដោយគណៈកម្មាធិការមជ្ឈិមនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ជាភ័ស្តុតាងបង្ហាញថាមានកិច្ចប្រជុំមួយនៅថ្ងៃនោះ និងថាម្ចាស់បណ្តឹងសាទុក្ខអាចមានវត្តមានដើម្បីស្តាប់ការប្រកាសពាក់ព័ន្ធនឹងគាត់។ នៅក្នុងការទាញទឡ្ហីករណ៍ថាការដឹង ចេតនា ឬការចូលរួមចំណែករបស់គាត់នៅក្នុងឧក្រិដ្ឋកម្មមិន អាចត្រូវបានទាញសន្និដ្ឋានពីសេចក្តីសម្រេចនានារបស់គណៈកម្មាធិការមជ្ឈិមឬសមាជិកភាពរបស់គាត់ នៅក្នុងគណៈកម្មាធិការមជ្ឈិម[642]ម្ចាស់បណ្តឹងសាទុក្ខមិនអើពើទាល់តែសោះទៅលើមូលដ្ឋាន ដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញពិរុទ្ធភាពរបស់គាត់ក្នុងឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទ ប្រកាន់ផ្អែកលើការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម។ ក្នុងការកំណត់ភ័ស្តុតាងដែលបានបង្ហាញអំពីការទទួលខុសត្រូវរបស់គាត់ហួសពីវិមតិសង្ស័យ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការ វិភាគទាំងមូលលើអង្គច្បាប់និងអង្គហេតុ ដូចដែលបានពិភាក្សាជាលម្អិតនៅក្នុងផ្នែកផ្សេងៗទៀត នៃចម្លើយតបនេះ[643]។

182. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ថា ម្ចាស់បណ្តឹងសាទុក្ខបានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងមហាសន្និបាតបក្សលើកទី៤ ក្នុងខែមករាឆ្នាំ១៩៧៦[644] ក៏ពុំបានកំណត់នូវកំហុសឆ្គងដែលចាំបាច់តម្រូវឱ្យមានការអន្តរាគមន៍របស់អង្គជំនុំជម្រះដែរ។ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើភ័ស្តុតាង និងកំណត់ថាវាគឺជាពេលដែលគាត់ឡើងឋានៈនោះនៅក្នុងគណៈកម្មាធិការមជ្ឈិមគឺស្ថិតក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការដោះស្រាយវិវាទលើភ័ស្តុតាង និងក្នុងការកំណត់ថាភ័ស្តុតាងណាដែលខ្លួនទទួលយក[645]។ ក្នុងករណីណាក៏ដោយ ដូចដែលម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ហើយថា ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងឆ្នាំ១៩៧១ និងបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ វត្តមានរបស់គាត់នៅក្នុងមហាសន្និបាតបក្សលើកទី៤ និង នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការ អចិន្ត្រៃយ៍ អាចជាផ្នែកដ៏សំខាន់មួយនៃតួនាទីដឹកនាំរបស់គាត់នៅ

[642] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១៩។

[643] *សូមមើលឧទាហរណ៍* ផ្នែកទី៨.គ.៣ ចេតនា (ធាតុផ្សំអត្តនោម័តិរបស់ម្ចាស់បណ្តឹងសាទុក្ខ) និងផ្នែកទី៨.គ.២ (ការរួមចំណែកយ៉ាងខ្លាំងក្លាក្នុងសហឧក្រិដ្ឋកម្មរួម)។ *សូមមើលផងដែរ ឧទាហរណ៍* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ ផ្នែកទី១៨.១-១៨.២.៣ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខ ក្រោមសហឧក្រិដ្ឋកម្មរួម)។

[644] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧២០-១៧២២។

[645] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចដែលមានសំអាងហេតុ)។

ក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ជាងនេះទៀត យោងតាមការលើកឡើងរបស់ អៀង សារី បានឱ្យដឹងថានៅត្រឹម "ឆ្នាំ១៩៧៥ [ម្ចាស់បណ្តឹងសាទុក្ខ]ចូលរួមតាមព្រឹត្តិន័យនៅក្នុងកិច្ចការ [គណៈកម្មាធិការមជ្ឈិម]"[646]។ ស្រដៀងគ្នានេះដែរ គាត់លើកទឡ្ហីករណ៍ថាដោយបរាជ័យថាអង្គជំនុំជម្រះសាលាដំបូង "បំភ្លៃ" សេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិមដែលចេញផ្សាយនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ "លើកលែងទោសខ្មាំង ដែលធ្វើសកម្មភាពប្រឆាំងបដិវត្តមុនឆ្នាំ១៩៧៥"[647]។ ម្ចាស់បណ្តឹងសាទុក្ខកំណត់ខុសលើសក្ខីកម្មរបស់ ឌុច។ ឌុច បានផ្តល់សក្ខីកម្មថាគាត់បានពិចារណាលើសេចក្តីណែនាំនេះជាល្បិចបញ្ឆោតឱ្យប្រជាជនស្ងប់ស្ងាត់ ពីព្រោះការបោសសម្អាតបានបន្តកើតមាន[648] ដូចដែលបង្ហាញដោយភស្តុតាងគ្រប់គ្រាន់នៃកំណត់ត្រា។

183. ម្ចាស់បណ្តឹងក៏ខកខានផងដែរក្នុងការកំណត់នូវកំហុសណាមួយ នៅក្នុងការពិនិត្យវាយតម្លៃលើភស្តុតាងពីសំណាក់អង្គជំនុំជម្រះសាលាដំបូងទៅលើសុន្ទរកថារបស់គាត់ ឬថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការទទួលយកភស្តុតាង ដែលត្រូវបានចោទថាមានតម្លៃភស្តុតាងទាប[649]។ ពាក់ព័ន្ធនឹងសុន្ទរកថារបស់គាត់ធ្វើឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ដែលគាត់យោងដល់ការបោសសម្អាតខ្មាំងនោះ វាគួរតែត្រូវបានបកស្រាយដោយមានហេតុផលថាជាបទល្មើសព្រហ្មទណ្ឌ។ បើទោះជាខ្មាំងដែលគាត់និយាយយោងដល់មានលក្ខណៈនយោបាយ ដែលភស្តុតាងបង្ហាញថាខ្មាំងត្រូវបានកំណត់និយមន័យក្នុងន័យកាន់តែទូលាយនោះ[650] ភស្តុតាងនៅក្នុងរឿងក្តីនេះបង្ហាញអ្វីដែលរបប នោះបានប្រព្រឹត្តទៅលើអ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំងនយោបាយ ពោលគឺ ការចាប់ខ្លួន ការធ្វើទារុណកម្ម ការសម្លាប់ ក្នុងចំណោមអំពើឃោរឃៅដទៃទៀត[651]។ ម្ចាស់បណ្តឹងសាទុក្ខបានបញ្ជាក់ច្បាស់នូវអ្វីដែលគាត់មាននៅក្នុងគំនិត ចំពោះសមាជិកនៃរបបចាស់ គឺការសម្លាប់

---

[646] ឯកសារ **E3/573** កំណត់ត្រានៃកិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយលោក Stephen Heder ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៩ EN 00427599។

[647] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣១។

[648] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧១ ជើងទំព័រ ១៣២១៤ *ដកស្រង់* ឯកសារ **E1/55.1** ប្រតិចារឹក កាំង ហ្គេចអ៊ាវ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ម៉ោង ១៥.៤៧.៥១-១៥.៥១.៤៩ ទំព័រ ១០១០ បន្ទាត់ ២១-ទំព័រ ១០៣ បន្ទាត់ ១៨។

[649] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣២-១៥៤០។

[650] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែកទី១៦.៣ (ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត)។

[651] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៦៦-២០៧២ (ការបោសសម្អាត), ២៥៦០-២៦៣៥ (ឧក្រិដ្ឋកម្មនៅស២១), ៣៨៧៥-៣៨៥៩ (វិធីសាស្ត្ររបស់ ប.ក.ក ចំពោះខ្មាំង)។

វង្គាល[652]។ សុន្ទរកថាទាំងនេះដែលធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខបង្ហាញកង្វះភាពត្រឹមត្រូវនៅក្នុងការវាយប្រហារដោយគ្មានមូលដ្ឋានប្រឆាំងនឹងភស្តុតាង ដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន[653] ពោលគឺជាភស្តុតាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលមានគុណភាពដូចគ្នា រួមមានការលុបបំបាត់របប លន់ នល់ លុបបំបាត់ពួកនាយទុន សក្តិភូមិបញ្ញាវន្ត ដែលថាអ្នកដែលក្បត់នឹងបក្ស នឹងត្រូវសម្លាប់ចោល[654]។

184. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងបំភ្លៃសក្ខីកម្មរបស់គាត់លើការទិតៀននិងស្វ័យទិតៀននោះ ក៏ពុំទទួលផលដែរ[655]។ អង្គជំនុំជម្រះសាលាដំបូងបកស្រាយដោយត្រឹមត្រូវលើសក្ខីកម្មរបស់ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងការប្រើស្វ័យទិតៀន ដើម្បីកសាងកំហឹងវណ្ណៈ។ ម្ចាស់បណ្តឹងសាទុក្ខបាននិយាយថាគាត់ត្រូវបានទិតៀននៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម នៅពេលគាត់ត្រូវបានស្នើឱ្យ"ទិតៀននិងស្វ័យទិតៀនដើម្បីកសាងជំហរវណ្ណៈនិងកំហឹងវណ្ណៈ [របស់គាត់]"[656]។ ម្ចាស់បណ្តឹងសាទុក្ខក៏បកស្រាយខុសផងដែរទៅលើការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងកំហឹងវណ្ណៈ។ អង្គជំនុំជម្រះសាលាដំបូងពុំបាន "ប្រើសញ្ញាណទាំងនេះដើម្បីសន្និដ្ឋានថា ការធ្វើស្វ័យទិតៀនអាចនឹងពាក់ព័ន្ធចេតនាក្នុងការរើសអើងប្រជាជនថ្មី" ឡើយ[657]។ ផ្ទុយទៅវិញ វាគឺជាសុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងកម្មវិធីជួបជុំធំៗនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា

---

652 *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៧ (ម្ចាស់បណ្តឹងសាទុក្ខបានកោតសរសើរដល់ការកម្ទេចរបបមុន "ដោយបានប្រកាសប្រាប់" ថា ខ្មាំង "បានដាច់ខ្យល់ទាំងក្តីឈឺចាប់បំផុត"។), ៤២៤៤ (ម្ចាស់បណ្តឹងសាទុក្ខ បានប្រកាសថា "បនក្បត់នៅភ្នំពេញ" មិនអាច "គេចផុតពីការម្ទេចទាំងស្រុង" ដោយបានប្រកាសថា "ចាំបាច់ត្រូវសម្លាប់ជនក្បត់ទាំងប្រាំពីរ" នៃរបបសាធារណរដ្ឋខ្មែរ), ៤៣០២ (ម្ចាស់បណ្តឹងសាទុក្ខ បានធ្វើការអំពាវនាវឱ្យ "កម្ទេច" មន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងអ្នកក្រោមបង្គាប់របស់មន្ត្រីទាំងនោះ។ បន្ទាប់មក បានថ្លែងថា គោលបំណងរបស់បដិវត្តន៍គឺការ "កម្ទេចរបបលន់ នល់" រួមទាំងពួកមូលធន ពួកសក្តិភូមិ និងបញ្ញាវន្ត ដែលកាន់មុខតំណែងទាំងនេះ ហើយអ្នកដែលក្បត់បក្ស ឬបដិវត្តន៍នឹងត្រូវសម្លាប់ចោល)។

653 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៤-១៥៣៥។

654 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦១, ១៣១៨៥ (អ.ជ.ស.ជ បានផ្តល់សេចក្តីពន្យល់ដោយមានសំអាងហេតុពីមូលហេតុដែលខ្លួនយល់ឃើញថាភស្តុតាងនេះអាចជឿជាក់បាន។)

655 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៦-១៥៤០។

656 ឯកសារ **E1/198.1** ប្រតិចារឹកម្ចាស់បណ្តឹងសាទុក្ខ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ម៉ោង១៤.៤៧.១៩- ១៤.៤៩.១៤ ទំព័រ ៨៨ បន្ទាត់១១-១៥។

657 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។

គាត់ "បានផ្តោតគំនុំវណ្ណៈទៅលើប្រជាជនថ្មី"[658]។ ម្ចាស់បណ្តឹងសាទុក្ខបានណែនាំឱ្យគេបង្កើនការងារឱ្យខ្ពស់ ដល់ប្រជាជនថ្មី ដាក់ការងារច្រើននិងឱ្យស៊ីបាយតិចដើម្បីកែមុខកែមាត់សត្រូវស៊ីរូងផ្ទៃក្នុង[659] ប្រុងប្រយ័ត្នខ្ពស់ ចំពោះប្រជាជនថ្មីពីព្រោះពួកគេ "ជាប់កំអែលសក្តិភូមិ" ចំណែកឯជនណាដែលប្រឆាំងនឹងបក្សគឺ ជាខ្មាំងដែលត្រូវតែកម្ទេចចោល[660]។ និយាយរួម "កម្ទេចខ្មាំងគ្រប់រូបភាព"[661]។ ក្នុងបរិបទនៃឧក្រិដ្ឋ កម្មដែលកំពុងត្រូវបានប្រព្រឹត្តប្រឆាំងនឹងខ្មាំងដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាខ្មាំងពិតប្រាកដនិងខ្មាំងតាមការសន្មត ពាក្យទាំងនេះ មិនត្រឹមតែជាវោហាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការជំរុញឱ្យសម្រេចអំពីល្មើសនិងការយល់ព្រមឱ្យមានការប្រព្រឹត្តអំពើល្មើសដែលមានភ័ស្តុតាង គាំទ្រទៀតផង។ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសឆ្គងក្នុងការបកស្រាយភាសានោះ និង ការនាំចូលនូវស្លាកស្នាមទុយ៌សរបស់គាត់ទៅលើខ្មាំង និងការញុះញង់គំនុំវណ្ណៈចំពោះខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មតនោះឡើយ។

## ៣. ឯកសារដទៃទៀតនាសម័យកាលនោះ

### *មូលដ្ឋានទី ២៩៖ ឃោសនាការ*[662]

185. **មូលដ្ឋានទី ២៩ គួរតែត្រូវបានបដិសេធ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានកំណត់កំហុសអង្គហេតុឬអង្គច្បាប់ណាមួយនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាងឃោសនាការឡើយ។**

186. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញនូវកំហុសអង្គច្បាប់ណាមួយនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើឯកសារឃោសនាដែលខ្លួនបានពិចារណាឡើយ។ គាត់មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាថា "សន្ធឹកម្មដែលធ្វើឡើងក្នុងគោលបំណងឃោសនាអាចទទួលបាននូវភាពទុកចិត្តបានតិចតួចប៉ុណ្ណោះ"[663]។ ផ្ទុយទៅវិញ អង្គជំនុំ

[658] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។

[659] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។

[660] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៣។

[661] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៩។

[662] <u>មូលដ្ឋានទី ២៩៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ការឃោសនា* កថាខណ្ឌ២៩១-២៩២ ឯកសារ F54.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៤ (ភាសាអង់គ្លេស) ទំព័រ ១៣ (ភាសាបារាំង) ទំព័រ ១៨ (ភាសាខ្មែរ)។

[663] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩១ ជើងទំព័រ ៤៣៦ *ដកស្រង់* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៥, ៤៧២, ៤៧៩។ *សូមមើលផងដែរ* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥៧។

ជម្រះសាលាដំបូងកត់សម្គាល់ដោយសង្គតិភាពថា ការវាយតម្លៃរបស់ខ្លួននឹងពិចារណាលើលក្ខណៈភ័ស្តុតាងកើតចេញពីឯកសារឃោសនា[664]។ គាត់ក៏ពុំបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូង "បានផ្អែកតែទៅលើឯកសារឃោសនាដើម្បីធ្វើការចោទប្រកាន់"[665]។ ជាការពិតណាស់ កថាខណ្ឌចំនួនពីរដែលគាត់លើកមកសំអាង គឺបដិសេធការអះអាងនេះដោយហេតុថានៅក្នុងកថាខណ្ឌទាំងពីរនេះអង្គជំនុំជម្រះសាលាដំបូង ផ្អែកការសន្និដ្ឋានរបស់ខ្លួនអំពីចេតនាទៅលើភ័ស្តុតាងនៃការរៀបចំបញ្ជីឈ្មោះគោលនយោបាយខ្សែស្រឡាយខាងម្ដាយ ដែលត្រូវបានអនុវត្តចំពោះគ្រួសារចម្រុះ និងការបោះពុម្ពផ្សាយឯកសារសល់ពីរបបនោះនៅក្នុងទស្សនាវដ្ដីទង់បដិវត្តនិងសុន្ទរកថារបស់ឥស្សរជនជាថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅទៅលើជនជាតិវៀតណាម[666]។

187. ការប៉ុនប៉ងរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងការប្រើប្រាស់ការវាយតម្លៃដោយកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសុន្ទរកថាមួយ "ពាក់ព័ន្ធនឹងជនជាតិវៀតណាមនៅក្នុងការប្រារព្ធពិធីមួយក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ" ខកខានមិនបានធ្វើជា "ឧទាហរណ៍ដ៏ច្បាស់" នៃកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងតាមការចោទប្រកាន់នោះទេ[667]។ គាត់ពុំបានបង្ហាញនូវ "ឧទាហរណ៍ដ៏ច្បាស់" ដោយមានលក្ខណៈពិសេសគ្រប់គ្រាន់ដើម្បីអាចយកមកវាយតម្លៃចំពោះការអះអាងរបស់គាត់ឡើយ។ កថាខណ្ឌនានាដែលម្ចាស់បណ្ដឹងសាទុក្ខយោងដើម្បីគាំទ្រការអះអាងនេះ (កថាខណ្ឌ

---

[664] ក្រៅពីឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៦៥, ៤៧២, ៤៧៩ *ត្រូវបានដកស្រង់ក្នុង* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៩១ ជើងទំព័រ ៤៣៦។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨២ (អ.ជ.ស.ដ បង្ហាញការប្រុងប្រយ័ត្នក្នុងការថ្លឹងថ្លែងទម្ងន់ភ័ស្តុតាងនៃប្រភពឯកសារឃោសនារបស់របបកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម)។ កថាខណ្ឌ ៣៧៤៧ (ពិចារណាឃើញថាឯកសារសម្រាប់គោលបំណងទំនាក់ទំនងទៅខាងក្រៅ ឬសម្រាប់ធ្វើជាសម្ភារៈបណ្ដុះបណ្ដាលខាងផ្នែកមនោគមន៍វិជ្ជា រួមមានទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត និងកំណត់ត្រាផ្សេងទៀតនៃការបង្ហាញខ្លួនសាធារណៈរបស់មេដឹកនាំ ប.ក.ក. អាចមានការឃោសនា ហើយនឹងពិចារណាលើចំណុចនេះ នៅពេលធ្វើការវាយតម្លៃលើភ័ស្តុតាងបែបនេះ)។

[665] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៩២។

[666] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៥៥ ជើងទំព័រ ២៩០៨ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥១៥ និងកថាខណ្ឌ ១៥៥៦ ជើងទំព័រ ២៩០៩ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥១៧។ កថាខណ្ឌទាំងនេះ ត្រូវបានដាក់បញ្ចូលក្នុងសេចក្ដីដកស្រង់របស់ម្ចាស់បណ្ដឹង សាទុក្ខ ក្នុងកថាខណ្ឌ ២៩២ ជើងទំព័រ ៤៣៨ ដែលយោងទៅកថាខណ្ឌ ១៥៥១-១៥៦០ របស់ខ្លួន។

[667] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៩២។

១៥៥១-១៥៦០) ពុំបានកំណត់នូវសុន្ទរកថានេះឡើយ[668]។ ហើយកថាខណ្ឌទាំងនេះក៏ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានខកខាកមិនបានអនុវត្តស្តង់ដាត្រឹមត្រូវក្នុងការវាយតម្លៃសម្ភារៈឃោសនានោះឡើយ។ ការអះអាងមិនច្បាស់លាស់បែបនេះមិនសមនឹងទទួលបាននូវការពិចារណាឡើយ[669]។

188. ការយោងរបស់ម្ចាស់បណ្តឹងសាទុក្ខទៅលើការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើភាពអាចជឿជាក់នៃភ័ស្តុតាងដែលមាន “គោលគំនិតឃោសនា”[670] បំភ្លេចនូវការណ៍ដែលថា អង្គជំនុំជម្រះតុលាការកំពូលបន្តសន្និដ្ឋានថា “ភ័ស្តុតាងមូលដ្ឋានបង្ហាញថា ខ្មែរក្រហមមិនត្រឹមតែមិនអើពើចំពោះប្រជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកោតសរសើរការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរដោយប្រើប្រាស់ពាក្យពេចន៍អុចអាលមិនរើសមុខឡើយ”[671]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថាភ័ស្តុតាងនៅក្នុងរឿងក្តីនេះដែល “មានគោលគំនិតឃោសនា” ពុំត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការលើកឡើងដូចគ្នានេះទេ។

### *មូលដ្ឋានទី ១១៖ ភ័ស្តុតាងចេញមកពីប្រវត្តិវិទូដែលមិនបានចូលមកបង្ហាញខ្លួន*[672]

189. **មូលដ្ឋានទី ១១ គួរច្រានចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខពុំបានផ្តល់ភ័ស្តុតាងគាំទ្រដល់ការអះអាងយ៉ាងទូលំទូលាយរបស់ខ្លួនអំពីកំហុសអង្គហេតុចំពោះការយល់ព្រមរបស់ អ.ជ.ស.ដ ទទួលយកកំណត់ហេតុ ប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលកត់ត្រាដោយដៃរបស់សាស្ត្រាចារ្យ Goscha។**

---

[668] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩២ ជើងទំព័រ ៤៣៨-៤៣៩ (*ដកស្រង់*កថាខណ្ឌ ១៥៥១-១៥៦០,១១៩៣ របស់គាត់)។ កថាខណ្ឌ ១៥៥១-១៥៦០ របស់គាត់ យោងទៅលើកំហុសដែលត្រូវបានចោទប្រកាន់ ទាក់ទងនឹងគោលនយោបាយប្រឆាំងប្រជាជនវៀតណាម។ ការចោទប្រកាន់ទាំងនេះ មិនបានពិភាក្សាលម្អិតនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥ (ការកំណត់គោលដៅទៅលើជនជាតិវៀតណាម) ទេ។ ស្រដៀងគ្នានេះដែរ កថាខណ្ឌ១១៩៣ របស់គាត់ បានចោទថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃរបស់ខ្លួនទាក់ទងនឹងការយល់ព្រមក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ការចោទប្រកាន់នេះ ក៏មិនបានពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៦២ និង១៦៥ ដែរ។

[669] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២០។

[670] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩២ *ដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨៣។

[671] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨៤។

[672] <u>មូលដ្ឋានទី ១១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភ័ស្តុតាងចេញមកពីប្រវត្តិវិទូដែលមិនបានចូលបង្ហាញខ្លួន* កថាខណ្ឌ ២១៦-២២៥ *ការប្រើប្រាស់ភ័ស្តុតាងដែលមានតម្លៃតិចតួច* កថាខណ្ឌ ១៤៦៣ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨-៩ (ភាសាអង់គ្លេស) ទំព័រ ៧-៨ (ភាសាបារាំង) ទំព័រ ១០-១១ (ភាសាខ្មែរ)។

190. ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខជ្រើសរើសវិធីសាស្ត្រមិនត្រឹមត្រូវ និងទៅតាមការចង់បានរបស់ខ្លួន ចំពោះសេចក្តីសម្រេចរបស់ អ.ជ.ស.ដ និងការប្រើប្រាស់ភ័ស្តុតាងដែលរងការជំទាស់។ គាត់បានយោងលើកថាខណ្ឌជាច្រើន នៅក្នុងសាលក្រម អ.ជ.ស.ដ[673] ដោយគ្មានការពន្យល់ណាមួយផ្តល់ជាយុត្តិកម្មចំពោះការចោទប្រកាន់របស់គាត់ថា ការប្រើប្រាស់ឯកសាររបស់សាស្ត្រាចារ្យ Goscha "មោឃភាព"[674] ទៅលើការសន្និដ្ឋាននៅក្នុងកថាខណ្ឌនីមួយៗទាំងនោះ ឬការសន្និដ្ឋានទូទៅរបស់ អ.ជ.ស.ដ នោះឡើយ ។ គាត់ពុំបានព្យាយាមបង្ហាញអំពីរបៀបដែលការប្រើប្រាស់ឯកសារដែលរងការជំទាស់នោះ នាំឱ្យមានការយល់ឃើញផ្អែកអង្គហេតុ ដែលគ្មានអ្នកវិនិច្ឆ័យដោយឥតលម្អៀងលើអង្គហេតុណាម្នាក់អាចធ្វើឡើងដូច្នេះឡើយ។

191. ម្ចាស់បណ្តឹងសាទុក្ខ មិនអើពើឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ ចំពោះការទទួលយកភ័ស្តុតាងថ្មីណាមួយ ដែលខ្លួនយល់ថា ជួយដល់ការបញ្ជាក់ការពិត[675]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[676] អ.ជ.ស.ដ បានពន្យល់លម្អិតថាតើខ្លួនបានទាក់ទងជាមួយសាស្ត្រាចារ្យ Goscha ទាក់ទងនឹងសំណុំកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ប.ក.ក ដែលគាត់អាចមាន កិច្ចដែលត្រូវបានផ្តួចផ្តើមឡើងដោយផ្អែកលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលទំនងត្រូវបានជូនដំណឹងទៅម្ចាស់បណ្តឹងសាទុក្ខ[677]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខសំណើសុំនេះគឺសម្រាប់សំណៅថតចំលង*ទាំងស្រុង*នៃកំណត់ហេតុគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ មិនមែន "គ្រាន់តែ...សម្រង់នៃកំណត់ហេតុ"[678] នោះទេ។ អ.ជ.ស.ដ ក៏បានពន្យល់យ៉ាង

---

[673] *សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៣ ជើងទំព័រ ២៧៥៦ (*ដកស្រង់* ឯកសារ **E465** សំណុំរឿង០០២/០២ សាលក្រម កថាខណ្ឌ ៣៨១៤), ២៧៥៣ (*ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨១៤ ជើងទំព័រ ១២៧៤៧-១២៧៤៩), ២៥៧៨ (*ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨០៥)។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨ (ភាសាអង់គ្លេស) *ដកស្រង់* ឯកសារ **E327/4/7** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៤, ៣៥២-៣៥៤, ៣៥៧, ៣៦៤, ៣៧៧, ៤១៥, ៤២១, ៤២៧, ៥០៤, ៥៤៣, ៥៥៤-៥៥៦, ១៤៥៩, ១៧២៣, ១៧៦៣, ២០០៦, ២០១០, ២០១៦, ៣៣៩៧, ៤៧៤០, ៣៨៥០, ៣៨១៤, ៤១២៦។

[674] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨-៩ (ភាសាអង់គ្លេស) ទំព័រ ៧-៨ (ភាសាបារាំង)។

[675] វិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង។

[676] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨-៩ (ភាសាអង់គ្លេស) ទំព័រ ៧-៨ (ភាសាបារាំង)។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧។

[677] ឯកសារ **E327/4/7** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha កថាខណ្ឌ ២។

[678] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៨ (គូសបញ្ជាក់បន្ថែម)។

ពេញលេញអំពីរបៀបដែលការស្រាវជ្រាវនេះ នាំឱ្យខ្លួនបានដឹងអំពីឯកសារផ្សេងទៀត មកពីសាស្ត្រាចារ្យ Goscha ដែលមាននៅក្នុងអ៊ីនធឺណិតនៅក្នុងបណ្ណសារដ្ឋានសាធារណៈ[679]។

192. ផ្ទុយពីទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ[680] អ.ជ.ស.ដ មិនមានកាតព្វកិច្ចមិនអើពើនឹងភស្តុតាងផ្សេងទៀត ដែលជួយដល់ការបញ្ជាក់ការពិត ដែលខ្លួនបានរកឃើញនៅក្នុងពេលស្វែងរកភស្តុតាងជាក់លាក់ណាមួយនោះឡើយ។ ទោះបីជាការអះអាងរបស់គាត់ត្រូវបាន "គេទុកមិនឱ្យដឹងអ្វីទាំងអស់"[681] បន្ថែមលើសំណើរបស់សហព្រះរាជអាជ្ញា ដែលបានជូនដំណឹងក៏ដោយ ក៏ អ.ជ.ស.ដ បានជូនដំណឹងដល់ភាគីទាំងអស់អំពីកិច្ចរបស់ខ្លួនដើម្បីទទួលបានឯកសារ[682] ដោយគ្មានការជំទាស់ពីម្ចាស់បណ្តឹងសាទុក្ខ ហើយបានជូនដំណឹងទៅភាគីថា ឯកសារដែលត្រូវបានជំទាស់ បានបើកឱ្យត្រួតពិនិត្យ ដែលជាការផ្តល់ឱកាសឱ្យពួកគេ ធ្វើសេចក្តីសន្និដ្ឋានអំពីភាពអាចទទួលយកបាន មុនពេលសម្រេចលើបញ្ហានេះ[683]។ ពុំមាន "អសុទ្ធចិត្ត"[684] នៅក្នុងចំណាត់ការដោះស្រាយរបស់ អ.ជ.ស.ដ។ ចំណុចចុងក្រោយ អ.ជ.ស.ដ បានឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដែលបានទទួលយកឯកសារទាំងនេះ[685]។

193. បណ្តឹងតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការទទួលយក និងការប្រើប្រាស់ឯកសារទាំងនេះរបស់ អ.ជ.ស.ដ ក៏គ្មានមូលដ្ឋានដែរ។ អ.ជ.ស.ដ បាន ពន្យល់យ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់អំពីមូលដ្ឋានដែលខ្លួនយកមកសំអាងថា ឯកសារទាំងនេះអាចទទួលយកបាន រួមទាំងភាពពាក់ព័ន្ធ និងតម្រុយនៃភាពអាចទុកចិត្តបាន[686]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ការពិចារណារបស់

---

[679] ឯកសារ E327/4/7 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha កថាខណ្ឌ ២-៣។

[680] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៨ (គាត់ជំទាស់ថា អ.ជ.ស.ដ "បានទៅហួសឆ្ងាយសំណើរបស់សហព្រះរាជអាជ្ញា")។

[681] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៩។

[682] ឯកសារ E327/4/3 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំសំណៅថតចម្លងនៃកំណត់ហេតុរបស់កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧។ ឯកសារ E327/4/7 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha កថាខណ្ឌ ១៨ (ការជូនដំណឹងបណ្តោះអាសន្នអំពីការមិនជំទាស់ពីម្ចាស់បណ្តឹងសាទុក្ខ)។

[683] ឯកសារ E327/4/7 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha កថាខណ្ឌ ៣។

[684] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៩។

[685] ឯកសារ E327/4/7 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha កថាខណ្ឌ ៧-២៨។

[686] ឯកសារ E327/4/7 សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha កថាខណ្ឌ ២០-២៧ (សញ្ញាណផ្សេងៗឬភាពគួរឱ្យទុកចិត្តបាន រួមមាន៖ (១) សាស្ត្រាចារ្យ Goscha បញ្ជាក់ថាគាត់បានចម្លងតាមពាក្យពេចន៍នូវឯកសារដែលគាត់បានរកឃើញនៅក្នុងបណ្ណាល័យកងទ័ពវៀតណាម, (២) លោក Philip Short កត់សម្គាល់ឃើញថាសាស្ត្រាចារ្យ Goscha ជាអ្នក

អ.ជ.ស.ដ លើសំណៅពេញលេញនៃកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ មិនមែនសើៗលំៗនោះឡើយ។ វារួមបញ្ចូលលើសពីភាពសង្វាក់គ្នានៃតួលេខទៅទៀត[687]។ អ.ជ.ស.ដ ក៏ ក៏បានកត់សម្គាល់ផងដែរថា ខ្លួនត្រូវតែពិចារណាកត្តានានា ដែលធ្វើឱ្យប៉ះពាល់ដល់ភាពអាចទុកចិត្តបាននៃឯកសារ និងដែនកំណត់ ដែលខ្លួននឹងកំណត់លើការប្រើប្រាស់ឯកសារទាំងនេះ[688]។ ការពិនិត្យកថាខណ្ឌទាំងពីរឡើងវិញ ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ជាឧទាហរណ៍មកបង្ហាញអំពីកំហុសរបស់ អ.ជ.ស.ដ ក្នុងការប្រើឯកសារ ដែលត្រូវបានជំទាស់ កថាខណ្ឌ ៣៨០៥ និង ៣៨១៤ បញ្ជាក់យ៉ាងច្បាស់ថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញកំហុសនោះទេ។ អ.ជ.ស.ដ កម្រិតការប្រើប្រាស់ខ្លឹមសារនៃឯកសារ ដែលរងការជំទាស់ត្រឹម "កម្មវត្ថុ បរិបទ និងគោលបំណង"។ ការប្រើប្រាស់នេះស៊ីសង្វាក់គ្នាជាមួយភស្តុតាងផ្សេងទៀតនៅចំពោះ អ.ជ.ស.ដ[689]។

### *មូលដ្ឋានទី ១២៖ ការទទួលយកបញ្ជីពណ៌ទឹកក្រូចរបស់មន្ទីរ ស-២១*[690]

194. **មូលដ្ឋានទី ១២ គួរតែត្រូវបានច្រានចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខ ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ ដោយបានទទួលយកបញ្ជីពណ៌ទឹកក្រូចរបស់ ស-២១។**

---

ជំនាញលើបញ្ហានេះ ហើយតាមគាត់ដឹង សាស្ត្រាចារ្យ Goscha គឺជាអ្នកដែលមិនមែនជាជនជាតិ វៀតណាមតែម្នាក់គត់ដែលត្រូវបានអនុញ្ញាតឱ្យធ្វើការនៅទីនោះ, (៣) ឯកសារទាំងនោះត្រូវបានចងក្រងជាកាតាឡុកតាមរយៈលេខ ហើយឯកសារមួយចំនួនមានឈ្មោះអ្នកបកប្រែ និងកាលបរិច្ឆេទនៃការបកប្រែ, (៤) ឯកសារទាំងនោះ ត្រូវបានរក្សាទុកក្នុងសារមន្ទីរមួយ ដែលទំនងជារក្សាបាននូវសុចរិតភាពនៃឯកសារទាំងនេះ ចាប់តាំងពីរបបកម្ពុជា ប្រជាធិបតេយ្យ។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២-៣៥៤។

[687] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២ (អ.ជ.ស.ដ ក៏យល់ឃើញថា កម្មវត្ថុដូចគ្នាត្រូវបានពិភាក្សា ហើយកិច្ចប្រជុំបានចូលរួមដោយគណៈអចិន្ត្រៃយ៍ដូចគ្នាជាច្រើន ហើយ "ជាពិសេស" ធ្វើការសម្រេចពាក់ព័ន្ធនឹងខ្មាំងខាងក្នុង។) ជារួម អ.ជ.ស.ដ យល់ឃើញថាខ្លឹមសារនៃកំណត់ហេតុដែលមានប្រភពពីសាស្ត្រាចារ្យ Goscha រួមមានចំនួនមនុស្សដែលត្រូវបានសម្លាប់ (ពោលគឺ ភាពស៊ីសង្វាក់គ្នានៃតួលេខ) ត្រូវបានបញ្ជាក់ដោយទស្សនាវដ្តីទង់បដិវត្តមួយ លេខ។

[688] ឯកសារ **E327/4/7** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើឯកសារ Goscha កថាខណ្ឌ ២៦ (ព្រមទាំងលើកឡើងថា ឯកសារទាំងនោះ មិនមែនជាឯកសារច្បាប់ដើម និងត្រូវបានសរសេរចម្លងដោយដៃ និងលើកឡើងថាថា អ.ជ.ស.ដ មិនមានឯកសារច្បាប់ដើម ហើយឯកសារបកប្រែជាភាសាវៀតណាម មិនបានផ្ទៀងផ្ទាត់នៅឡើយទេ។) *សូមមើលផងដែរ*ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤។

[689] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨០៥, ៣៨១៤។

[690] <u>មូលដ្ឋានទី ១២</u>៖ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការទទួលយកសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនៃមន្ទីរ ស-២១* កថាខណ្ឌ២២៦ ឯកសារ **F54.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៩ (ភាសាអង់គ្លេស) ទំព័រ ៩ (ភាសាបារាំង) ទំព័រ ១១ (ភាសាខ្មែរ)។

195. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារការអះអាងមិនត្រឹមត្រូវរបស់ម្ចាស់បណ្ដឹងសាទុក្ខថា អ.ជ.ស.ដ មិនបាន "ពិចារណាលើការកត់សម្គាល់របស់មេធាវីការពារក្ដី ចំពោះចន្លោះប្រហោងក្នុងការទទួលយកបញ្ជីនេះជាភ័ស្តុតាង និងចំពោះតម្លៃជាភ័ស្តុតាងដ៏ទាបរបស់វា"[691] ពុំមានមូលដ្ឋាន។ អ.ជ.ស.ដ ពិតជាបានពិចារណាលើទឡ្ហីករណ៍ទាំងនេះ និងបានច្រានចោលយ៉ាងត្រឹមត្រូវ[692]។ ម្ចាស់បណ្ដឹងសាទុក្ខពុំបានបង្ហាញថា គាត់មានពេលវេលាមិនគ្រប់គ្រាន់ដើម្បីសិក្សាទៅលើឯកសារនេះ ហើយ អ.ជ.ស.ដ មានកំហុស ដោយពុំបានកោះហៅសាក្សីចំនួនពីររូបឡើងវិញ និងកោះហៅសាស្ត្រាចារ្យ Heynowski មុនពេលទទួលយកឯកសារនេះ ហើយថាឯកសារនេះមានតម្លៃភ័ស្តុតាងតិចតួច។

196. ការពិនិត្យឡើងវិញអំពីរបៀបដែលឯកសារនេះត្រូវបានទទួលយក គូសបង្ហាញអំពីមូលហេតុ ដែលទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខមិនទទួលបានផលទេ។ នួន ជា បានដាក់សំណើសុំកោះហៅសាស្ត្រាចារ្យ Walter Heynowski មកផ្ដល់សក្ខីកម្មទាក់ទងនឹងឯកសារដើមរបស់ ស-២១ *ក្នុងនោះ* រួមទាំងបញ្ជីពណ៌ទឹកក្រូច ដែលគាត់បានដឹងក្រោយពេលពិនិត្យមើលខ្សែភាពយន្តឯកសារចំណងជើងថា *Die Angkar* ដែលសាស្ត្រាចារ្យបានផលិត[693]។ ក្រោយមក អ.ជ.ស.ដ បានស្នើសុំព័ត៌មានពីសាស្ត្រាចារ្យ Heynowski[694]។ នៅចុងបញ្ចប់ លោកសាស្ត្រាចារ្យបានបញ្ជាក់ជូន អ.ជ.ស.ដ ថា គាត់មានបញ្ជីពណ៌ទឹកក្រូច ហើយគាត់បានយកវាចេញពីបរិវេណមន្ទីរ ស-២១។ គាត់បានផ្ដល់បញ្ជីនេះ និងទំព័ររលុបៗមួយចំនួន ឱ្យទៅ អ.ជ.ស.ដ[695]។

197. នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ អ.ជ.ស.ដ បានជូនដំណឹងដល់ភាគី និង "អញ្ជើញភាគីឱ្យពិនិត្យឯកសារ ដែលអាចរកបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម" ដែលមាននៅអង្គភាពបណ្ណសារ[696] និង "ធ្វើសារណាដោយផ្ទាល់មាត់ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនៅក្នុងសវនាការ

[691] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២២៦។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៦។

[692] ឯកសារ **E443/3** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្ដីពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច និងសាក្សីពីររូបពាក់ព័ន្ធនឹង ស-២១។

[693] ឯកសារ **E412** សំណើទី៤របស់ នួន ជា សុំសាក្សីសម្រាប់វគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២ (ដំណើរការមន្ទីរសន្តិសុខ ស-២១ និងភ័ស្តុតាងជាឯកសារ) កថាខណ្ឌ ៣១-៣២។

[694] ឯកសារ **E443** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើសំណើ នួន ជា សុំស្ដាប់សក្ខីកម្មសាក្សីបន្ថែម កថាខណ្ឌ ១។ ឯកសារ **E443/2.1** លិខិតពីក្រឡាបញ្ជីផ្ញើជូនសាស្ត្រាចារ្យ Heynowski ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។

[695] ឯកសារ **E443/2** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើឯកសាររបស់សាស្ត្រាចារ្យ Heynowski កថាខណ្ឌ ៥-៦។

[696] ឯកសារ **E443/2** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើឯកសាររបស់សាស្ត្រាចារ្យ Heynowski កថាខណ្ឌ ៨។

ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦"[697]។ ម្ចាស់បណ្ដឹងសាទុក្ខពុំបាន ស្នើសុំពេលវេលាបន្ថែមដើម្បីពិនិត្យបញ្ជីពណ៌ទឹកក្រូចមុន ឬក្នុងអំឡុងពេលសវនាការថ្ងៃទី៩ ខែធ្នូ។ នៅក្នុងសវនាការនោះ ម្ចាស់បណ្ដឹងសាទុក្ខ បានស្នើសុំឱ្យកោះហៅសាក្សីចំនួនពីរនាក់ គឺ សួស ធី និង ឌុច[698] និងសាស្ត្រាចារ្យ Heynowski ឱ្យបង្ហាញខ្លួន[699]។ បន្ទាប់ពីបានស្ដាប់សេចក្ដីសង្កេត និងសេចក្ដីសន្និដ្ឋានរបស់ភាគី[700] អ.ជ.ស.ដ បានចេញអនុស្សរណៈមួយនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៦ ដោយបានសម្រេចទទួលយកបញ្ជីពណ៌ទឹកក្រូចជាភស្តុតាង។ អ.ជ.ស.ដ បានរកឃើញថា វា "មានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនាពេលបច្ចុប្បន្ន" និង "មានភាពពាក់ព័បន្ធ និងអាចជឿជាក់បាន (រួមទាំងមានយថាភាព) បំពេញទៅតាមបទដ្ឋាន*ការបញ្ជាក់បឋម*"[701]។ អ.ជ.ស.ដ បានច្រានចោលសេចក្ដីសន្និដ្ឋានរបស់ម្ចាស់បណ្ដឹងសាទុក្ខ ស្នើសុំកោះហៅបុគ្គលទាំងនេះ[702]។

198. ក្នុងអំឡុងពេលប្រមាណ ២,៥ សប្ដាហ៍នៅចន្លោះសវនាការថ្ងៃទី៩ ខែធ្នូ និងពេលចេញអនុស្សរណៈរបស់ អ.ជ.ស.ដ ម្ចាស់បណ្ដឹងសាទុក្ខ មិនបានស្នើសុំឱ្យមានសវនាការបន្ថែម ឬ សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរអំពីបញ្ហានេះ។ គាត់មិនបានជូនដំណឹង អ.ជ.ស.ដ អំពីការបន្តជំទាស់មុនពេលបិទរឿងក្ដីនៅថ្ងៃទី៣១ ខែមករា ទោះបីមានរយៈពេលជិត ២ខែ គិតចាប់ពីសវនាការបឋម ដើម្បីធ្វើដូច្នេះក៏ដោយ ដោយបានជំទាស់ការទទួលយកឯកសារនេះនៅពេលដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលនៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ តែប៉ុណ្ណោះ[703]។

---

[697] ឯកសារ **E443/2** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើឯកសាររបស់សាស្ត្រាចារ្យ Heynowski កថាខណ្ឌ ៩។

[698] ឯកសារ **E1/510.1** ប្រតិចារឹក ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦ ម៉ោង 09.35.40-09.37.57 ទំព័រ ១៧ បន្ទាត់ ២៤-ទំព័រ ១៨ បន្ទាត់ ១៦។

[699] ឯកសារ **E1/510.1** ប្រតិចារឹក ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦ ម៉ោង 09.34.45-09.35.40 ទំព័រ ១៧ បន្ទាត់ ៤-១០។

[700] ឯកសារ **E1/510.1** ប្រតិចារឹក ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦ ម៉ោង 09.15.57-09.46.43 ទំព័រ ៧ បន្ទាត់ ២១-ទំព័រ ២២ បន្ទាត់ ២០។

[701] ឯកសារ **E443/3** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្ដីពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច និងសាក្សីពីររូបពាក់ព័ន្ធនឹង ស-២១ កថាខណ្ឌ ៣។

[702] ឯកសារ **E443/3** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្ដីពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច និងសាក្សីពីររូបពាក់ព័ន្ធនឹង ស-២១ កថាខណ្ឌ ៤។

[703] ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១១៨៥-១១៩៣។

199. ប្រវត្តិសាវតារនេះបញ្ជាក់ច្បាស់ថា ម្ចាស់បណ្ដឹងសាទុក្ខបានតវ៉ាដោយគ្មានមូលដ្ឋានថា ការទទួលយកនេះគឺចំ "ថ្ងៃចុងក្រោយនៃការជំនុំជម្រះ"[704] "ពីរសប្ដាហ៍មុនពេលបញ្ចប់សវនាការលើអង្គសេចក្ដី"[705] ឬ "មានពេលវេលាខ្លីពេចន្លោះពេលដឹកអំពីឯកសារដ៏ធំនេះ និងសវនាការអំពីការទទួលយកឯកសារ"[706]។ អ.ជ.ស.ដ អាចទទួលយកភ័ស្ដុតាងនៅ*ដំណាក់កាលណាមួយ*នៃការជំនុំជម្រះក្ដីដោយអនុលោមតាមវិធាន ៨៧(៤)[707] ហើយម្ចាស់បណ្ដឹងសាទុក្ខ មានពេលវេលាច្រើន មុនពេលបញ្ចប់សំណុំរឿង ដើម្បីវិភាគឯកសារ និងភ័ស្ដុតាងពាក់ព័ន្ធយ៉ាងលម្អិត និងរៀបចំការជំទាស់របស់គាត់ និង/ឬស្នើសុំសវនាការបន្ថែមលើបញ្ហានេះ ឬសម្រាប់ការពិចារណាឡើងវិញលើសេចក្ដីសម្រេចទទួលយកឯកសារ។ ប៉ុន្ដែ គាត់ពុំបានចាត់វិធានការបែបនេះទេ។

200. អំណះអំណាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក៏មិនទទួលបានផលដែរ ដោយសារគាត់មិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុស ដោយសារបានបដិសេធកោះហៅសាក្សី ដែលបានស្នើសុំចំនួន ៣ នាក់ សួស ធី, ឌុច និង Walter Heynowski។ ដូចម្ចាស់បណ្ដឹងសាទុក្ខអះអាងយ៉ាងត្រឹមត្រូវ សួស ធី មានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចបញ្ជាក់យថាភាពនៃសៀវភៅកំណត់ហេតុ[708] ហើយបានបញ្ជាក់មែន[709]។ ឌុច មិនមានព័ត៌មានមានប្រយោជន៍អំពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនោះ

---

[704] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២២៦។

[705] ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១១៨៦។

[706] ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១១៨៥។

[707] វិធាន ៨៧ (៤) នៃបទបញ្ជាផ្ទៃក្នុង។

[708] ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១១៨៦។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៩០។ ឯកសារ **E1/430.1** ប្រតិចារឹក សួស ធី ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.35.22-09.38.00 ទំព័រ ១៤ បន្ទាត់ ១០-១៥។ ឯកសារ **E1/432.1** សួស ធី ប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.15.05-11.17.33 ទំព័រ ៤៤ បន្ទាត់ ៥-១៦ (គាត់គឺជាអ្នករក្សាទុកកំណត់ត្រានៅស-២១ និងទទួលបន្ទុកទុកដាក់ឯកសារភាគច្រើននៅទីនោះ ចាប់ពីចុងឆ្នាំ១៩៧៥ រហូតដល់វៀតណាមចូលរំដោះ)។

[709] ឯកសារ **E1/432.1** ប្រតិចារឹក សួស ធី ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.30.49-14.39.52 ទំព័រ ៧៤ បន្ទាត់ ២៣-ទំព័រ៧៨ បន្ទាត់ ១០ ("សៀវភៅនេះ បើនិយាយរួមគឺសៀវភៅក្ដាប់ចំនួនអ្នកទោសប្រចាំថ្ងៃដែរ ប៉ុន្ដែយូរៗសរុបឱ្យគេ ម្ដង។") ម៉ោង 11.18.44-11.20.48 ទំព័រ ៤៥ បន្ទាត់ ១២-ទំព័រ ៤៦ បន្ទាត់ ១៤ (គាត់បានបញ្ជាក់ថា មិនមានបញ្ហាឱ្យបំផ្លាញចោលមុនពេលវៀតណាមចូលមកដល់ទេ)។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១១៥, ២១២៣, ២៥៤៩ ជើងទំព័រ ៧០៦៦។

ទេ[710]។ ដូច្នេះ សាក្សីទាំងពីរត្រូវបានគេសាកសួរអំពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច ហើយ "មានឱកាសសួរដេញដោលសាក្សីទាំងពីររូបនេះ ក៏ដូចជាខ្លឹមសារនៃបញ្ជីស្រដៀងគ្នានេះយ៉ាងច្រើន"[711] ។ អ.ជ.ស.ដ បានសម្រេចមិនកោះហៅសាស្ត្រាចារ្យ Heynowski ដោយសារតែគិតពីវ័យ និងការលំបាកផ្សេងទៀតទាក់ទងនឹងការផ្ដល់សក្ខីកម្មតាមប្រព័ន្ធវីដេអូ[712]។

201. ម្ចាស់បណ្ដឹងសាទុក្ខ ក៏ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានទទួលយកឯកសារដោយមិនត្រឹមត្រូវ ពីព្រោះវាមាន "តម្លៃជាភស្តុតាងដ៏ទាប"[713]។ សៀវភៅកំណត់ត្រាពណ៌ទឹកក្រូចតាមលក្ខណៈរបស់វា បង្កើតជា "សម្ភារដោយឡែកដ៏កម្រ"[714] ពីព្រោះវាជាឯកសារដើមដ៏កម្រងដែលមានចំនួន ៣៣៥ទំព័រ កត់ត្រាឈ្មោះជាច្រើនដែលបានចូល និងចេញពីមន្ទីរ ស-២១ ក្នុងឆ្នាំ១៩៧៧[715] ក្នុងករណីដែលម្ចាស់បណ្ដឹងសាទុក្ខ អះអាងថាមានបញ្ហាអំពី "កង្វះឯកសារដើមស្ទើរតែទាំងស្រុង"[716]។ ម្យ៉ាងវិញទៀត សៀវភៅកំណត់ត្រានេះត្រូវបានបញ្ជាក់យថាភាពដោយ អ្នកកាន់កាប់កំណត់ហេតុ ដែលបានប្រើប្រាស់ឯកសារនេះជាញឹកញាប់ និងដោយសាស្ត្រាចារ្យ Heynowski ដែលបានលើកឡើងថា គាត់បានយកឯកសារដើមនេះចេញពីបរិវេណមន្ទីរ ស-២១[717]។ លើសពីនេះ សៀវភៅនេះស៊ីសង្វាក់គ្នាជាមួយបញ្ជីក្ដាប់អ្នកជាប់ឃុំប្រចាំថ្ងៃរបស់ ស-២១ ដែលត្រូវបាន

[710] ឯកសារ **E1/438.1** ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.47.10-15.51.50 ទំព័រ ៩១ បន្ទាត់ ១០-ទំព័រ ៩២ បន្ទាត់ ១២ (នៅពេលដែលបង្ហាញឯកសារ ឌុច មិនចំណាំវាទេ ដោយពន្យល់ថា "សៀវភៅបែបនេះ [គាត់] មិនធ្លាប់ឃើញទេ" ពីព្រោះគាត់ "មិនមានព័ត៌មានទាក់ទងនឹងអ្នកទោសចេញចូលទេ")។

[711] ឯកសារ **E443/3** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ស្ដីពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច និងសាក្សីពីររូបពាក់ព័ន្ធនឹង ស-២១ កថាខណ្ឌ ៩។

[712] ឯកសារ **E443/7** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ក្នុងការមិនស្ដាប់សក្ខីកម្ម Walter Heynowski កថាខណ្ឌ ៤ (អ.ជ.ស.ដ សម្រេចថា ដោយសារគាត់មានវ័យចាស់ជរា ការលំបាកផ្នែកបច្ចេកទេសដោយពុំអាចតភ្ជាប់ប្រព័ន្ធសោត ទស្សន៍ពីប្រទេសអាល្លឺម៉ង់ និងលក្ខខណ្ឌនីតិវិធីនៃកិច្ចសហប្រតិបត្តិការតាមផ្លូវតុលាការ ដែលត្រូវចំណាយពេលច្រើននោះ អ.ជ.ស.ដ នឹងមិនស្ដាប់សក្ខីកម្មសាក្សីរូបនោះទេ)។

[713] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២២៦។

[714] ឯកសារ **E1/510.1** ប្រតិចារឹក ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦ ម៉ោង 09.27.53-09.29.33 ទំព័រ ១៣ បន្ទាត់ ១០-១៦ (លោក Koppe មេធាវីការពារក្ដី នួន ជា "ទាំងអស់នេះហើយ វានាំឱ្យយើងទទួលបានសៀវកំណត់ត្រាពណ៌ទឹកក្រូច ដែលមានទម្ងន់ ២ គីឡូ ប្រសិនបើខ្ញុំចាំមិនខុស ហើយមានទំព័រ២០០ទំព័រជាង។ ហើយយើងគិតថា យើងត្រូវការឯកសារនេះ ព្រោះថាទោះបីថាសារមន្ទីរទួលស្លែង មាននូវឯកសារទាំងអស់នោះក៏ដោយ។")

[715] ឯកសារ **E3/10770** សៀវភៅកំណត់ត្រាពណ៌លឿង។

[716] ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១១៨៧។

[717] ឯកសារ **E443/2** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើឯកសាររបស់សាស្ត្រាចារ្យ Heynowski កថាខណ្ឌ ៣។

បញ្ចូលរួចហើយនៅក្នុងសំណុំរឿង ០០២/០២ មុនពេលសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចត្រូវបានរកឃើញ[718]។ ការប្រៀបធៀបរវាងសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច និងបញ្ជីក្តាប់អ្នកជាប់ឃុំប្រចាំថ្ងៃ លាតត្រដាងទិន្នន័យស្ទើរតែដូចគ្នាទាំងស្រុង[719] ដែលអនុញ្ញាតឱ្យ អ.ជ.ស.ដ យល់ឃើញថាឯកសារនេះអាចទុកចិត្តបាន[720]។

202. ចំណុចចុងក្រោយ មូលដ្ឋានទី ១២ ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់។ ភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅ ស-២១ បង្ហាញលើសពីសៀវភៅកំណត់ត្រាពណ៌ក្រូច។ អ.ជ.ស.ដ មានភស្តុតាងជាច្រើនលើសលុប ដែលបង្ហាញលម្អិតនៅក្នុងសាលក្រមចំនួនប្រហែលចំនួន ៣០[721] ដើម្បីធ្វើសេចក្តីសន្និដ្ឋានលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅ ស-២១ ទោះបីជាពុំមានឯកសារនេះក៏ដោយ[722]។

### *មូលដ្ឋានទី ២៨៖ ភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម*[723]

203. **មូលដ្ឋានទី ២៨ គួរត្រូវបានច្រានចោលដោយសារម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ទាក់ទងនឹងការប្រើប្រាស់ភស្តុតាង ដែលបានមកពីការធ្វើទារុណកម្ម។**

204. ជាពិសេសជាងនេះ មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខ ខកខានក្នុងការបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ ដោយបានចោទប្រកាន់អំពី (i) ការប្រើប្រាស់

---

[718] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១២៣ ជើងទំព័រ ៧០៩២ (អ.ជ.ស.ដ បានយោងលើបញ្ជីក្តាប់អ្នកទោសនៅ ស-២១ ជាច្រើន ប៉ុន្តែបញ្ជីខ្លះ មិនមានទំព័រត្រូវគ្នានៅក្នុងសៀវភៅកត់ត្រាពណ៌ទឹកក្រូចទេ។ *ឧទាហរណ៍* ឯកសារ **E3/9968,** ឯកសារ **E39969,** ឯកសារ **E3/9971**)។

[719] *សូមមើលឧទាហរណ៍* បញ្ជីក្តាប់កម្លាំងអ្នកទោសនៅ ស-២១៖ ឯកសារ **E3/9970,** ឯកសារ **E3/9972,** ឯកសារ **E3/9973,** ឯកសារ **E3/9974,** ឯកសារ **E3/9975,** ឯកសារ **E3/10000,** ឯកសារ **E3/10001**។

[720] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១១៩ ("ហេតុដូចនេះ បញ្ជីអ្នកជាប់ឃុំឯទៀតដែលស្ថិតក្នុងប្រភេទបញ្ជីអ្នកជាប់ឃុំទាំង៧ ដែលបានផ្ទៀងផ្ទាត់ និងមានភាពស្រដៀងគ្នាគ្រប់គ្រាន់ជាមួយនឹងឯកសារដែលបានបញ្ជាក់យថាភាព ក៏ត្រូវបានអង្គជំនុំជម្រះយល់ឃើញថា អាចជឿទុកចិត្តបានដែរ") (គូសបញ្ជាក់បន្ថែម), ២៥៥៩។

[721] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៨០-២១៣៥។

[722] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៨០។

[723] <u>មូលដ្ឋានទី ២៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភស្តុតាងទទួលបានតាមរយៈការធ្វើទារុណកម្ម* កថាខណ្ឌ ២៥៨-២៩០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៤ (ភាសាអង់គ្លេស) ទំព័រ ១២-១៣ (ភាសាបារាំង) ទំព័រ ១៨ (ភាសាខ្មែរ)។

ភ័ស្តុតាងមិនត្រឹមត្រូវ ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ក្នុងគោលបំណងមិនទាក់ទងនឹងការបង្ហាញការពិតនៃភ័ស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ពោលគឺ សម្រាប់គោលបំណងតែមួយគត់គឺ តើត្រូវធ្វើចំណាត់ការអ្វីខ្លះផ្អែកតាមរយៈភ័ស្តុតាងនេះ។ (ii) ការប្រើប្រាស់ភ័ស្តុតាង ដែលមាននៅក្នុងសៀវភៅកំណត់ហេតុ ឬ សៀវភៅកំណត់ត្រាសួរចម្លើយនៅ មន្ទីរសន្តិសុខ។ និង (iii) ការប្រើប្រាស់សក្ខីកម្មរបស់ ឌុច ទាក់ទងនឹងការសន្ទនាដែលគាត់បានជជែកជាមួយ ប៉ង់ អំពីការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងការពិភាក្សាអំពីជោគវាសនារបស់ ជូ ជេត។ មូលដ្ឋាននេះក៏ខកខានក្នុងការបង្ហាញព្យសនកម្មដែលបានទទួលរង ឱ្យបានជាក់លាក់ គ្រប់គ្រាន់ ពោលគឺ ការចោទប្រកាន់ថា កំហុសទាំងនោះ "អាចឱ្យ [អ.ជ.ស.ដ] សម្រេចលើធាតុសំខាន់ៗ នៃការជំនុំជម្រះ" និង "ធ្វើមោឃភាពសេចក្តីសន្និដ្ឋានមួយ ចំនួនក្នុងសំអាងហេតុសាលក្រម" មិនបំពេញតាមបទដ្ឋាននៃបណ្តឹងឧទ្ធរណ៍[724]។

## *អនុសញ្ញាស្តីពីទារុណកម្ម*

205. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការប្រើប្រាស់ភ័ស្តុតាងដែលជាប់ប្រឡាក់ប្រឡូកជាមួយនឹងការធ្វើទារុណកម្ម។ ផ្ទុយពីអំណះអំណាងរបស់គាត់ ការប្រើប្រាស់ភ័ស្តុតាងបែបនេះ ពុំត្រូវបានហាមឃាត់ដោយអនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤។ គេត្រូវចងចាំថា ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានផ្តន្ទាទោសពីបទទារុណកម្ម ដូច្នេះ ការលើកលែងមានលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤ អាចអនុវត្តបាននៅក្នុងរឿងក្តីនេះ ពោលគឺ "សេចក្តីថ្លែងការណ៍ណាមួយ ដែលត្រូវបានបង្ហាញថាបានធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្ម មិនត្រូវយកមកប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធី *លើកលែងតែប្រឆាំងនឹងបុគ្គល* [ក្នុងនោះ ម្ចាស់បណ្តឹងសាទុក្ខ] *ដែលត្រូវបានចោទប្រកាន់អំពីទារុណកម្ម ដែលជាភ័ស្តុតាងបង្ហាញថា សេចក្តីថ្លែងការណ៍នោះត្រូវបានធ្វើឡើងមែន*"[725]។ អនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤ មិនត្រូវបានអនុម័ត ដើម្បីការពារអ្នកដែលត្រូវបានផ្តន្ទាទោសពីបទទារុណកម្ម ដើម្បីអនុញ្ញាតឱ្យពួកគេដែលជាអ្នកបង្ករងគ្រោះប្រើប្រាស់អនុសញ្ញា

---

[724] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥៨ *ប៉ុន្តែសូមមើល* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៥ *ឯកស្រង់* វិធាន ១០៥ (៣)។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨៧ (ម្ចាស់បណ្តឹងសាទុក្ខ មិនបានបញ្ជាក់ពីកំហុសដែលបានចោទ ពាក់ព័ន្ធនឹងការសន្និដ្ឋានជាក់លាក់ណាមួយ ហើយក៏មិនបានពន្យល់អំពីមូលហេតុដែលកំហុសទាំងនោះ ធ្វើឱ្យសាលក្រម ពុំមានសុពលភាពនោះទេ។)

[725] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ឆ្នាំ១៩៨៤ មាត្រា១៥ (គូសបញ្ជាក់បន្ថែម)។

នេះដើម្បីជៀសវាងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការធ្វើទារុណកម្មលើជនរងគ្រោះរបស់ពួកគេនោះឡើយ។

206. ការបកស្រាយរបស់ អ.ជ.ស.ដ អំពីការហាមឃាត់ ឃើញមាននៅក្នុងមាត្រា ១៥ គឺស្របនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះថា មាត្រា ១៥ "ពុំកំណត់ជាទូទៅថាត្រូវដកចេញកំណត់ហេតុទាំងមូលជុំវិញការសួរយកចម្លើយពីជនរងគ្រោះនៃការធ្វើទារុណកម្មឡើយ" ដោយបានសម្រេចថា "ព័ត៌មានរបស់បុគ្គលផ្សេងទៀតក្រៅពីជនរងគ្រោះនៃការធ្វើទារុណកម្ម" អាចត្រូវបានប្រើ[726]។ តាមពិត អ.ជ.ស.ដ បានផ្អែកទៅលើការសន្និដ្ឋាននេះ ជាមូលដ្ឋានដើម្បីអាចឱ្យមានការយោងលើព័ត៌មានបែបនេះ នៅក្នុងរឿងក្តីនេះ[727]។

207. ស្រដៀងគ្នានេះដែរ អ.ជ.ស.ដ បានកំណត់យ៉ាងសមស្របថា ខ្លួនអាចប្រើប្រាស់ព័ត៌មានសត្យានុម័តនៅក្នុងចម្លើយសារភាពដែលពុំមែនជាផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយ រួមទាំងកំណត់ត្រាអត្តសញ្ញាណរបស់អ្នកជាប់ឃុំ ដែលត្រូវបានសួរចម្លើយនិងកាលបរិច្ឆេទនៃការចាប់ខ្លួន ការចាប់ដាក់ពន្ធនាគារ និងការប្រហារជីវិត[728]។ អ.ជ.ស.ដ ក៏បានសម្រេចយ៉ាងត្រឹមត្រូវតាមសម្លេងភាគច្រើនលើសលប់ថា ខ្លួនអាចប្រើភ័ស្តុតាងដែលជាប់ទាក់ទងនឹងទារុណកម្ម "ដើម្បីបង្ហាញអង្គហេតុជាជាងការប្រើដើម្បីបញ្ជាក់ការពិតនៃចម្លើយនោះ ប៉ុន្តែភ័ស្តុតាងនេះត្រូវបានប្រើតែក្នុងគោលបំណងដើម្បីកំណត់ថាតើមានអំពើអ្វីដែលបានកើតឡើងដោយផ្អែកលើការណ៍ដែលចម្លើយនោះត្រូវបានធ្វើឡើង" ឧទា. ថាតើ បុគ្គលដែលមានឈ្មោះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយបែបនេះ ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ដែលជាភ័ស្តុតាងបង្ហាញអំពីគោលនយោបាយរដ្ឋដែរឬទេ[729]។ អ.ជ.ស.ដ ពុំបានប្រើប្រាស់ព័ត៌មានបែបនេះ ដើម្បីបង្ហាញ ឬបញ្ជាក់ការពិតនៃចម្លើយដែលបានមកពីការធ្វើទារុណកម្មនោះទេ[730] ដូច្នេះ គ្មានបញ្ហាពាក់ព័ន្ធនឹងភាពអាចទុកចិត្តបាននោះឡើយ[731]។ ការសម្រេចទាំងនេះគឺស្របនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះថា មាត្រា ១៥ មិន

[726] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារ កថាខណ្ឌ ៦៨។

[727] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៦។ ឯកសារ **E350/8** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីភ័ស្តុតាងទទួលបានពីការធ្វើទារុណកម្ម កថាខណ្ឌ កថាខណ្ឌ ៥៩។

[728] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៦។

[729] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៧។

[730] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារ កថាខណ្ឌ ៤០, ៤៧។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៧៧។

[731] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារកថាខណ្ឌ កថាខណ្ឌ ៤២។

អនុញ្ញាតឱ្យដកចេញទាំងស្រុងនូវព័ត៌មាន និងមានបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤ នោះទេ។

208. មូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខ ក៏មិនទទួលបានផលដែរ ដោយសារ អ.ជ.ស.ដ បានសន្និដ្ឋានថា យុត្តិសាស្ត្រនេះមិនមានភាពច្បាស់លាស់ទាក់ទងនឹងការអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មាន ដែលបានមកពីការធ្វើទារុណកម្មក្នុងកាលៈទេសៈ ដែលភ័ស្តុតាងជាប់ទាក់ទងនឹងការធ្វើទារុណកម្ម មិនត្រូវបានបង្ខំដោយអង្គភាព ដែលព្យាយាមប្រើប្រាស់វា ឬក៏ដោយ អ.វ.ត.ក ឬ ដោយនរណាម្នាក់ ដែលដើរតួជាភ្នាក់ងារផ្ទាល់ ឬ ប្រយោល។ ការធ្វើទារុណកម្ម ឬ ការធ្វើបាបក៏មិនត្រូវបង្កលើម្ចាស់បណ្តឹងសាទុក្ខ ឬភាគីទីបីដែលពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌជាមួយម្ចាស់បណ្តឹងសាទុក្ខដើម្បីទទួលបានព័ត៌មាន ឬភ័ស្តុតាងផ្សេងទៀត ដែលក្រោយមកត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងនឹងម្ចាស់បណ្តឹងសាទុក្ខ។ ផ្ទុយមកវិញ ភ័ស្តុតាងដែលជាប់ទាក់ទងនឹងការធ្វើទារុណកម្មត្រូវបានបង្ខំដោយផ្ទាល់ ដោយអ្នកផ្សេងទៀត ដែលបានចូលរួម ឬត្រូវបានប្រើប្រាស់ជាឧបករណ៍នៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានចូលរួម និងដែលបានបង្កើតមូលដ្ឋានសម្រាប់ការផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខ ចំពោះអំពើទារុណកម្ម។

209. យោងតាមហេតុផលដូចគ្នានេះ រឿងក្តីដែលម្ចាស់បណ្តឹងសាទុក្ខបានសំអាង និងដែលអង្គជំនុំជម្រះបានយោងនៅក្នុងសេចក្តីសម្រេច អ.ជ.ត.ក ស្តីពីអញ្ញត្រកម្ម មិនផ្ទុយនឹងការប្រើប្រាស់ភ័ស្តុតាងជាប់ទាក់ទងនឹងទារុណកម្មរបស់ អ.ជ.ស.ដ ដែលរងការជំទាស់នោះទេ។ ភ័ស្តុតាងទាំងនេះអាចញែកដាច់ចេញបាន ដោយសារវាមិនលើកឡើងអំពីកាលៈទេសៈ ដែល អ.ជ.ស.ដ បានសម្រេចថា ខ្លួនអាចប្រើប្រាស់ភ័ស្តុតាងបែបនេះបាន។ គេអាចយល់បានថា ការប្រើប្រាស់ភ័ស្តុតាងបែបនេះក្នុងករណីទាំងនេះ ត្រូវបានគេរកឃើញជារួមថាផ្ទុយនឹងអនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤ និងជាពិសេស មាត្រា ១៥។ ករណីទាំងនេះភាគច្រើន ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ឬធ្វើទារុណកម្ម ឬ ការធ្វើបាប លើជនជាប់ចោទដោយអង្គភាព ឬ ភ្នាក់ងារ ដែលក្រោយមកព្យាយាមប្រើប្រាស់ចម្លើយសារភាព ឬ ព័ត៌មានផ្សេងទៀតដែលទទួលបានតាមវិធីបែបនោះ ប្រឆាំងនឹងជនជាប់ចោទ[732]។ ម៉្យាងវិញទៀត ពួកគេភ្ជាប់ការធ្វើទារុណកម្ម ឬ ធ្វើបាបចំពោះនរណាម្នាក់ ដែល

[732] *សូមមើលឧទាហរណ៍* រឿងក្តី *Gäfgen តទល់នឹងប្រទេសអាល្លឺម៉ង់។ រឿងក្តី* Saunders *តទល់នឹងចក្រភពអង់គ្លេស។ រឿងក្តី Jalloh តទល់នឹងប្រទេសអាល្លឺម៉ង់។ រឿងក្តី Desde តទល់នឹងប្រទេសតួកគី។ រឿងក្តី Huseyn និងអ្នកដទៃទៀត តទល់នឹងប្រទេសអាស៊ែបៃហ្សង់។ រឿងក្តី Ors តទល់នឹងតួកគី។ រឿងក្តី Kolu តទល់នឹងតួកគី។ រឿងក្តី Söylemez តទល់នឹងតួកគី។ រឿងក្តី Rochin តទល់នឹងរដ្ឋកាលីហ្វញ៉ា។ រឿងក្តៅ Harutyunyan តទល់នឹងប្រទេសអាមេនី។ រឿងក្តី A. និងអ្នកដទៃទៀតតទល់នឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។*

ជាប់ទាក់ទងនឹងបទឧក្រិដ្ឋកម្មជាមួយជនជាប់ចោទ ដោយអង្គភាពនោះ ឬភ្នាក់ងាររបស់ពួកគេ[733]។ ក្នុងចំណោមករណីទាំងនោះ គ្មានជនត្រូវចោទណាម្នាក់ត្រូវបានរកឃើញថាមានពិរុទ្ធភាពនោះទេ ដែលបានបង្កើតភ័ស្តុតាងជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មដូចបានចោទប្រកាន់។

210. ក្នុងវិសាលភាពដែលអាចជំទាស់បានថា ការប្រើប្រាស់ភ័ស្តុតាងជាប់ទាក់ទងនឹងការធ្វើទារុណកម្ម ដែលត្រូវបានជំទាស់ "ពុំអាចយកមកការពារបានដោយគ្រាន់តែផ្អែកទៅលើភាសានៃ [មាត្រា ១៥] នេះតែឯងនោះទេ" ដោយមិនគិតពីការពិតដែលថា ម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោសពីបទទារុណកម្ម ការប្រើប្រាស់ភ័ស្តុតាងទាំងនេះ "ត្រូវតែយកមកពិនិត្យផ្ទៀងផ្ទាត់ជាមួយកម្មវត្ថុ និងគោលបំណងនៃវិធានបដិសធភ័ស្តុតាង"[734]។ ចំណុចនេះបង្ហាញថា ការប្រើប្រាស់ភ័ស្តុតាងដែលត្រូវបានជំទាស់ ពុំផ្ទុយនឹងគោលដៅ និងគោលបំណងនោះទេ។ ផ្ទុយទៅវិញ វាជួយជម្រុញដល់គោលដៅ និងគោលបំណងនេះវិញនោះទេ។ គោលដៅ និងគោលបំណងនៃមាត្រា ១៥ នៅក្នុងអនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤ គឺ "ដើម្បីរារាំងការធ្វើទារុណកម្ម និងជាការបង្អាក់ទឹកចិត្តមិនឱ្យប្រើប្រាស់អំពើនេះ ដែលជៀសវាងនូវលទ្ធភាពក្នុងការលើកយកព័ត៌មាន ដែលបានមកពីការធ្វើទារុណកម្មនោះមកបញ្ចូលនៅក្នុងកិច្ចដំណើរការនីតិវិធីជាផ្លូវការណាមួយជាដើម"[735]។ ការប្រើប្រាស់របស់ អ.ជ.ស.ដ ពុំជម្រុញដល់ការលើកទឹកចិត្តបែបនេះ។ ផ្ទុយទៅវិញ វាលុបចោលការលើកទឹកចិត្តបែបនេះ ហើយអត្ថប្រយោជន៍ពីការប្រើប្រាស់ទាំងនេះពុំបានដល់អ្នកធ្វើទារុណកម្មនោះឡើយ។ ការប្រើប្រាស់ទាំងនេះក៏ស្របទៅនឹងគោលដៅ និងគោលបំណងទូលំទូលាយនៃអនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤៖ បំណងដើម្បីបង្ហាញ "បំណងក្នុងការជំរុញឱ្យមានការខិតខំតស៊ូប្រឆាំងនឹងទារុណកម្ម "ឱ្យកាន់តែមានប្រសិទ្ធភាព" ទូទាំងពិភពលោក"[736]។ ការប្រើប្រាស់ទាំងនេះរបស់ អ.ជ.ស.ដ ពុំបានបកស្រាយអនុសញ្ញាស្តីពីទារុណកម្ម ឆ្នាំ១៩៨៤ រួមទាំង មាត្រា ១៥ ក្នុងន័យថា "នាំឱ្យការហាមឃាត់ និងការរារាំងប្រឆាំងនឹងទារុណកម្មចុះខ្សោយ"[737] ឬ ឬធ្វើឱ្យខូចខាតដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ឬ កេរ្តិ៍ឈ្មោះរបស់តុលាការ[738]។

### *ការប្រើប្រាស់សៀវភៅកត់ត្រា និងកំណត់ហេតុសួរចម្លើយ*

[733] *សូមមើលឧទាហរណ៍* រឿងក្តី *Othman តទល់នឹង* ចក្រភពអង់គ្លេស។ រឿងក្តី *Mthembu តទល់នឹងរដ្ឋ*។

[734] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារ កថាខណ្ឌ ៤០។

[735] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារ កថាខណ្ឌ ៤០។

[736] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារ កថាខណ្ឌ ៤០។

[737] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារ កថាខណ្ឌ ៤០។

[738] ឯកសារ **F26/12** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីបញ្ជីឯកសារ កថាខណ្ឌ ៤៥។

211. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសអង្គច្បាប់ ដោយសារបានប្រើប្រាស់ "កំណត់ត្រាសួរចម្លើយ និងបញ្ជីរបស់អ្នកសួរចម្លើយនៃមន្ទីរសន្តិសុខ"[739]។ អ.ជ.ស.ជ បានសម្រេចត្រឹមត្រូវថាសៀវភៅកំណត់ត្រា ឬ បញ្ជីកត់ត្រា អ្នកទោស អាចត្រូវបានប្រើ "ដរាបណាឯកសារទាំងនោះមិនត្រូវបានប្រើដើម្បីបញ្ជាក់ការពិតនៃខ្លឹមសារចម្លើយសារភាពរបស់អ្នកដែលត្រូវទទួលរងអំពើទារុណកម្មទាំងនោះ"[740]។ នេះគឺជាឧទាហរណ៍មួយទៀត ដែលវាជាការសមស្របក្នុងការសំអាងលើការសន្និដ្ឋានរបស់អង្គជំនុំជម្រះថា មាត្រា ១៥ នៃអនុសញ្ញាស្ដីពីទារុណកម្ម ឆ្នាំ ១៩៨៤ មិនតម្រូវឱ្យមានការលុបចោលទាំងស្រុងនោះទេ។ ផ្ទុយទៅវិញ "ព័ត៌មានរបស់បុគ្គលផ្សេងទៀតក្រៅពីជនរងគ្រោះនៃការធ្វើទារុណកម្ម" អាចត្រូវបានយកមកប្រើប្រាស់[741]។ សៀវភៅកំណត់ត្រា និងបញ្ជីកត់ត្រាអ្នកទោស ដែលរងការជំទាស់ ត្រូវបានដកចេញពីការសួរចម្លើយច្រើនជាងចំណារនៅលើការសួរចម្លើយនោះខ្លួនឯង ដែលអង្គជំនុំជម្រះនេះរកឃើញត្រឹមត្រូវថា អាចប្រើប្រាស់បាន។ ឯកសារ ដែលរងការជំទាស់រួមមានព័ត៌មានដូចជា ឧទា. បញ្ជីអ្នកទោសចូល ស-២១ បញ្ជីក្ដាប់អ្នកទោស បញ្ជីសួរចម្លើយ បញ្ជីប្រហារជីវិត [742] កំណត់ត្រា ស-២១ រួមទាំង កំណត់ត្រា ព្រឹត្តិការណ៍ និងការបណ្ដុះបណ្ដាលវគ្គនយោបាយដែលបុគ្គលិកទទួលបាន កំណត់ចំណាំរបស់អ្នកសួរចម្លើយ និងការពិភាក្សាអំពីបច្ចេកទេសសួរចម្លើយជាដើម[743]។

*សក្ខីកម្មរបស់ឌុច*

212. ទីបី នៅក្នុងការជំទាស់តវ៉ាដោយគ្មានមូលដ្ឋានថា អ.ជ.ស.ជ មានកំហុសនៅក្នុងការសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីការសម្លាប់ ជូ ចេត ម្ចាស់បណ្ដឹងសាទុក្ខបានកំណត់ខុសចំពោះភ័ស្ដុតាងដែល អ.ជ.ស.ជ បានយកមកសំអាង ដោយបានអះអាងមិនត្រឹមត្រូវថាជាសក្ខីកម្មជាប់ប្រឡាក់ប្រឡូកនឹងទារុណកម្មរបស់ ឌុច ថា ប៉ង់ បានប្រាប់គាត់ថា ម្ចាស់បណ្ដឹងសាទុក្ខ ត្រូវបាន

---

[739] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៥៨, ២៨៩-២៩០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ១៤ (ភាសាអង់គ្លេស) ទំព័រ ១២-១៣ (ភាសាបារាំង)។

[740] ឯកសារ **E350/8** សេចក្ដីសម្រេចរបស់ អ.ជ.ស.ជ ស្ដីពីភ័ស្ដុតាងទទួលបានពីការធ្វើទារុណកម្ម កថាខណ្ឌ ៣០, ៨៧។

[741] ឯកសារ **F26/12** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៨។

[742] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១១៦។

[743] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៣១។

អញ្ជើញឱ្យចូលរួមកិច្ចប្រជុំស្តីពីជោគវាសនារបស់ ជូ ចេត[744]។ ភ័ស្តុតាងរបស់ Stephen Heder និង Philip Short បង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានប្រគល់ឱ្យធ្វើការស៊ើបអង្កេតយ៉ាងម៉ត់ចត់ដើម្បីកំណត់ថាតើបុគ្គលទាំងនោះជាខ្មាំងឬអត់[745]។ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើនឹងភ័ស្តុតាងរបស់ Stephen Heder ដែលថា ម្ចាស់បណ្តឹងសាទុក្ខត្រូវបានគេបញ្ជូនទៅជួប ជូ ចេត ទាក់ទងនឹងការចោទប្រកាន់របស់ ជូ ចេត ចំពោះអនុប្រធានរបស់គាត់ ប៉ុន្តែ អនុប្រធាននោះបានរួចខ្លួន ផ្ទុយទៅវិញ ជូ ចេត ត្រូវបានគេសម្លាប់ចោល[746]។

213. ស្រដៀងគ្នានេះដែរ ការចោទប្រកាន់ទាក់ទងនឹងការសំអាងរបស់ អ.ជ.ស.ដ លើ ភ័ស្តុតាងរបស់ ឌុច អំពីការសន្ទនារបស់គាត់ជាមួយ ប៉ាំង[747] គឺមិនមានមូលដ្ឋាននោះទេ។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ព័ត៌មានដែលឌុចទទួលបានពី ប៉ាំង អំពីការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងការប្រជុំទាក់ទងនឹងជោគវាសនារបស់ ជូ ចេត គឺជាភ័ស្តុតាងជាប់ទាក់ទងនឹងទារុណកម្ម។ គាត់ក៏មិនបានបង្ហាញថា ប៉ាំង ត្រូវបានឃុំខ្លួននៅ ស-២១ នៅពេលដែលគាត់បានផ្តល់ព័ត៌មាននោះ[748]។ គាត់បានប្រដូចដោយខុសឆ្គងនូវពាក្យពេចន៍ទូទៅនៅក្នុងឯកសាររបស់ UNHCR ដែលគាត់បានយោង[749] ជាមួយពាក្យពេចន៍ជាក់លាក់នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ឌុច

---

[744] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦៧-១៨៦៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៤ (ភាសាអង់គ្លេស) ទំព័រ ១២-១៣ (ភាសាបារាំង)។

[745] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៨ ជើងទំព័រ ១៣៧៩៩។

[746] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៨ ជើងទំព័រ ១៣៨០១ *ដកស្រង់* ឯកសារ **E3/3169** ឯកសារពិភាក្សាស្តីពី "ប៉ុល ពត និងខៀវ សំផន" ដោយ Stephen Heder ទំព័រ ២៦។ សូមមើលផងដែរ ទំព័រ ១៥-១៦ (ម្ចាស់បណ្តឹងសាទុក្ខត្រូវបានបញ្ជូនស៊ើបសួរ)។

[747] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៨៨ ជើងទំព័រ ៤៣០ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៨៦៧-១៨៦៨។

[748] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦៨។

[749] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦៨ ជើងទំព័រ ៣៦២៣ *យោង*ឯកសារ **E3/347** ចម្លើយជនសង្ស័យឌុច, UNHCHR ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ ទំព័រ២-៣ (ភាសាបារាំង) ("*Khieu Samphan II était membre de plein droit du Comité central du Parti communiste du Kampuchea. Du point de vue administratif, il était à la fois chef de l'État et président du bureau du Comité central. À en croire les aveux de Chhim Sam Aok, dit Pang _ après que Pang a eu fini d'écrire ses aveux, je lui ai parlé —, parfois, quand c'était nécessaire, on invitait Khieu Samphan à la réunion (à des réunions sur...) À l'occasion de cette conversation, Pang m'a dit que Vorn Vet, même s'il n'avait pas été appelé ailleurs n'était jamais invité à leurs réunions.")*។ (ការបកប្រែក្រៅផ្លូវការ៖ "ខៀវ សំផន គាត់ជាសមាជិកពេញសិទ្ធិរបស់គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខាងតួនាទីរដ្ឋបានគាត់ជាប្រមុខរដ្ឋ ហើយខាងរដ្ឋបាលដែរ គាត់ជាប្រធានមន្ទីរមជ្ឈិម។ ហើយបើតាមចម្លើយរបស់ ឈឹម សំអ៊ុក ហៅ ប៉ាំង ក្រោយពេលដែល ប៉ាំង សរសេរ

ដែលបានប្រគល់ឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត និងសក្ខីកម្មនៅក្នុងតុលាការរបស់គាត់។ ពាក្យពេចន៍ទូទៅមិនលើកឡើងអំពី ជូ ចេត ឬ ការប្រជុំទាក់ទងនឹងជោគវាសនារបស់គាត់នោះទេ។ សេចក្តីថ្លែងការណ៍ជាក់លាក់ និងសក្ខីកម្មនៅក្នុងតុលាការ ដែលបានធ្វើឡើងដោយស្ថាប័នតុលាការនៃអង្គជំនុំជម្រះនេះ[750] លើកឡើងជាក់លាក់អំពីវត្តមានរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងការប្រជុំនោះ។

214. គ្មានព័ត៌មានណាមួយ ដែល ឌុច បានផ្តល់ទៅស្ថាប័នតុលាការ នៃ អ.វ.ត.ក ពោលគឺ ក.ស.ច.ស និង អ.ជ.ស.ដ បង្ហាញថាបានព័ត៌មានអំពី ប៉ង់ ឱ្យនៅពេលដែល ប៉ង់ កំពុងជាប់ឃុំ។ សក្ខីកម្មរបស់ ឌុច បានបញ្ជាក់យ៉ាងច្បាស់ថា ការសន្ទនារបស់គាត់ជាមួយ ប៉ង់ អំពីវត្តមានរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងអំឡុងពេលពិភាក្សាអំពីជោគវាសនារបស់ ជូ ចេត បានកើតឡើងខណៈពេលដែល ប៉ង់ កំពុងប្រតិបត្តិការក្នុងមុខតំណែងផ្លូវការរបស់គាត់[751]។ ការស្តាប់ចម្លើយរបស់ ក.ស.ច.ស គឺស៊ីសង្វាក់គ្នានឹងករណីហ្នឹង[752]។ កិច្ចស្តាប់ចម្លើយទាំងនោះ ក៏បញ្ជាក់ច្បាស់ដែរថា មុនពេលចាប់ខ្លួន ប៉ង់ បានទៅសួរសុខទុក្ខ ស-២១ ក្នុងមុខនាទីផ្លូវការ ដោយពេលនោះបានផ្តល់ឱកាសដល់គាត់ក្នុងការផ្តល់ភ័ស្តុតាង ដែលមានការជំទាស់ ទៅឱ្យ ឌុច[753]។ ការរៀបរាប់ របស់

---

ចម្លើយចប់ហើយ ខ្ញុំសំណេះសំណាលជាមួយប៉ង់ ក្នុងករណីចាំបាច់ខ្លះ គេក៏អញ្ជើញខៀវ សំផន ឱ្យចូលរួមប្រជុំនឹងគេដែរ [...] ក្នុងពេលសំណេះសំណាលនោះ ប៉ង់បានប្រាប់ថា វ៉ន វ៉េត ទោះបីមិនបានទៅណាក៏ដោយ ក៏គេមិនដែលហៅប្រជុំនឹងគេទេ។")

[750] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩០។

[751] ឯកសារ **E1/55.1** ប្រតិចារឹក កាំង ហ្គេចអ៊ាវ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ម៉ោង 15.24.22-15.27.22 ទំព័រ ៩៣ បន្ទាត់ ១៧-២២ (ឌុច បានសួរប៉ង់ អំពីសេចក្តីសម្រេចក្នុងការចាប់ជូ ចេត នៅពេលប៉ង់ បានមកធ្វើការណែនាំដល់ ឌុច ក្នុងនាមជាមេរបស់ឌុច) ម៉ោង 15.27.22-15.31.20 ទំព័រ ៩៤ បន្ទាត់ ១៥-ទំព័រ ៩៥ បន្ទាត់ ៥ (ប៉ង់ និយាយថាម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំ)។

[752] ឯកសារ **E3/61** កំណត់ហេតុសួរចម្លើយ កាំង ហ្គេចអ៊ាវ EN 00195577 (ប៉ង់ និយាយថាម្ចាស់ បណ្តឹងសាទុក្ខ ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំ)។ ឯកសារ **E3/356** កំណត់ហេតុសួរចម្លើយ កាំង ហ្គេចអ៊ាវ EN 00242901 (ប៉ង់ និយាយថាម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំ)។ ឯកសារ **E3/448** កំណត់ហេតុសួរចម្លើយ កាំង ហ្គេចអ៊ាវ EN 00154910 (ប៉ង់ និយាយថាម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំ)។ ឯកសារ **E3/453** កំណត់ហេតុសួរចម្លើយ កាំង ហ្គេចអ៊ាវ EN 00147584 (ប៉ង់ និយាយថាម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំ)។

[753] ឯកសារ **E1/55.1** ប្រតិចារឹក កាំង ហ្គេចអ៊ាវ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ម៉ោង 15.22.11-15.24.22 ទំព័រ ៩៣ បន្ទាត់ ១-៣ (ឌុច ជួបជាមួយប៉ង់ ញឹកញាប់ណាស់)។ ឯកសារ **E3/448** កំណត់ហេតុសួរចម្លើយ កាំង ហ្គេចអ៊ាវ EN 00154910 (ប៉ង់ និង លឹម មក ស-២១ ញឹកញាប់)។ ឯកសារ **E3/356** កំណត់ហេតុសួរចម្លើយ កាំង ហ្គេចអ៊ាវ EN 00242901 (ប៉ង់ ជាអ្នកទំនាក់ទំនងរវាង ស-២១ និងប៉ុល ពត)។

ឌុច អំពីថាតើ ប៉ង់ បានមកប្រាប់គាត់ដោយរបៀបណាអំពីវត្តមានរបស់ម្ចាស់បណ្ដឹងសាទុក្ខនៅក្នុងកិច្ចប្រជុំពិភាក្សាអំពីជោគវាសនារបស់ ជូ ចេត គឺស៊ីសង្វាក់គ្នា។

215. យោងតាមហេតុផលដែលបានពិភាក្សាខាងលើ ការប្រើប្រាស់ភ័ស្ដុតាងដែលរងការជំទាស់ ពុំរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ម្ចាស់បណ្ដឹងសាទុក្ខនោះឡើយ។ ទាំងម្ចាស់បណ្ដឹងសាទុក្ខ និងគូគនឧក្រិដ្ឋរបស់គាត់ ពុំត្រូវបានគេធ្វើទារុណកម្ម ឬ ការធ្វើបាបដើម្បីទទួលបានចម្លើយសារភាព ឬ ព័ត៌មានផ្សេងទៀតពីពួកគេដែលក្រោយមកត្រូវបានប្រើប្រាស់ប្រឆាំងនឹងម្ចាស់បណ្ដឹងសាទុក្ខក្នុងដំណើរការនីតិវិធីតុលាការផ្លូវការនោះឡើយ។

*ការខកខានមិនបានបង្ហាញអំពីរបៀបដែលកំហុសដូចបានចោទប្រកាន់បានប៉ះពាល់លើសាលក្រម*

216. ទីបួន មូលដ្ឋាននេះក៏មិនទទួលបានផលដែរ ដោយសារម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែអះអាងថាកំហុសដូចបានចោទប្រកាន់ "មោឃភាពសេចក្ដីសន្និដ្ឋានមួយចំនួន"[754] ដោយទុកឱ្យ អ.ជ.ត.ក និងភាគីជំទាស់ ទាយស្មានថា តើសេចក្ដីសន្និដ្ឋានណាខ្លះ។ ប្រសិនបើការយោងមិនច្បាស់បែបនេះត្រូវបានកំណត់ដើម្បីបំពេញតាមស្ដង់ដារបណ្ដឹងឧទ្ធរណ៍ ការប្រើប្រាស់របស់ អ.ជ.ស.ដ ពុំមែនជាប្រភេទដែលអាចទុកចោលការផ្ដន្ទាទោស និងការកាត់ទោសទាំងមូល ឬ ដោយផ្នែកនោះឡើយ។ ដូចបានពិភាក្សាខាងលើ ភ័ស្ដុតាងដែលសំអាងលើការប្រើប្រាស់ដែលរងការជំទាស់ មិនត្រូវបានបង្ខិតបង្ខំពីម្ចាស់បណ្ដឹងសាទុក្ខ ឬ គូគនឧក្រិដ្ឋរបស់គាត់នោះទេ ហើយបន្ទាប់មក ត្រូវបានប្រើប្រឆាំងនឹងគាត់ ហើយក៏មិនត្រូវបានបង្ខិតបង្ខំពីជនរងគ្រោះ ហើយត្រូវបានប្រើប្រឆាំងនឹងជនរងគ្រោះនៃការធ្វើទារុណកម្ម ឬ ការធ្វើបាបនោះដែរ។ ដូច្នេះ ការប្រើប្រាស់ដែលរងការជំទាស់មិនធ្វើឱ្យការហាមឃាត់ និងការទប់ស្កាត់ទារុណកម្ម បាត់បង់អានុភាពនោះទេ ដោយវាជា "ការលើកទឹកចិត្តដល់រដ្ឋនានាឱ្យប្រើវិធីសាស្ត្រ" ស៊ើបអង្កេតផ្អែកលើទារុណកម្ម ឬ ការធ្វើបាប[755]។ វាមិន "បំពេញតាមគោលបំណងក្នុងការបង្ហាញដោយប្រយោលនូវអំពើដែលគួរដាក់ទោសតាមសីលធម៌មានលក្ខណៈស្របច្បាប់ ដែលអំពើនេះអ្នកតាក់តែង [អនុសញ្ញាទារុណកម្មឆ្នាំ១៩៨០] ព្យាយាមតាក់តែង"[756] ឬ "ស្នើសុំបិទបាំងអំពើឃោរឃៅនេះក្រោមសំណាញ់ច្បាប់"[757]។ ដូច្នេះ ពុំចាំបាច់តម្រូវឱ្យមានដំណោះស្រាយទាំងស្រុងនោះទេ។

[754] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៥៨។

[755] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២៦៦។

[756] ឯកសារ F26/12 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើបញ្ជីឯកសារ កថាខណ្ឌ ៤៣។

[757] ឯកសារ F26/12 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើបញ្ជីឯកសារ កថាខណ្ឌ ៤៣។

217. ផ្ទុយទៅវិញ អ.ជ.ត.ក គួរពិចារណាថាតើម្ចាស់បណ្តឹងសាទុក្ខ បានបង្ហាញផលប៉ះពាល់ចាំបាច់នៃកំហុសដូចបានចោទប្រកាន់មកលើសាលក្រមដែរឬទេ ពោលគឺ ថាតើវាបានធ្វើឱ្យសាលក្រមនោះមោឃៈទាំងមូល ឬ មួយផ្នែកដែរឬទេ[758]។ ពុំមានការបង្ហាញបែបនេះឡើយ។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការផ្តន្ទាទោសណាមួយបានធ្វើឡើងដោយផ្អែកសុទ្ធសាធលើភស្តុតាងដែលប្រឡាក់ប្រឡូកនឹងទារុណកម្ម ហើយ អ.ជ.ស.ដ បានសំអាងទាំងស្រុងលើភស្តុតាងដែលបានមកពីការប្រើប្រាស់បែបនោះសម្រាប់ការផ្តន្ទាទោស និងការកំណត់ទោស។ ផ្ទុយមកវិញ អ.ជ.ស.ដ បានពិចារណាលើភស្តុតាងទាំងស្រុងមុនពេលបង្ហាញភស្តុតាង ហួសពីវិមតិសង្ស័យសម្រាប់ផ្តន្ទាទោស រួមទាំង សក្ខីកម្មរបស់អ្នកធ្វើទារុណកម្ម និងអ្នកនៅរស់រានមានជីវិតពីទារុណកម្ម និងភស្តុតាងឯកសារផ្សេងទៀត[759]។

218. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ បានផ្តល់ជាសំណងដល់គាត់។ គោលការណ៍នោះអនុវត្តក្នុងករណីដែលមានវិមតិសង្ស័យពាក់ព័ន្ធនឹងការបង្ហាញភស្តុតាងហួសពីវិមតិសង្ស័យ ដែលករណីនេះពុំបានកើតឡើងឡើយ។ “គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដែលជាគោលការណ៍សន្មតទុកជាមុនថាគ្មានទោស [...] មានតួនាទីចំបងក្នុងការបង្ហាញឱ្យឃើញនូវការយល់ដឹងជាស្វ័យប្រវត្តិក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យ”[760]។ បើនិយាយក្នុងន័យម្យ៉ាងទៀត វាគ្រាន់តែជាគោលការណ៍ដែលពាក់ព័ន្ធនឹងការបង្ហាញអង្គហេតុ ពុំមែនការបកស្រាយអង្គច្បាប់នោះទេ[761]។ ម្យ៉ាងវិញទៀត សម្តែងភាគច្រើននៃ អ.ជ.ស.ដ ពុំមានអ្វីសង្ស័យថា ពាក្យពេចន៍ គោលដៅ និងគោលបំណងនៃអនុសញ្ញាស្តីពីទារុណកម្មឆ្នាំ១៩៨៤ រួមទាំង មាត្រា ១៥ បានអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងជាប់ទាក់ទងនឹងទារុណកម្ម ដែលរងការជំទាស់នោះទេ។ ដូច្នេះគ្មានចន្លោះប្រហោងអ្វីដែលដោះស្រាយនោះឡើយ។

---

[758] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់)។

[759] *សូមមើល* ឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៨០-២៥៥៩, ២៥៨៥-២៥៩៧, ២៦២៣-២៦២៤ (ស-២១ – ពិភាក្សាភស្តុតាង និងការសន្និដ្ឋានអំពីការធ្វើទារុណកម្ម), ៨២៦-៩០២ (កំណត់ត្រាស្រុកត្រាំកក់), ២៦៩៤-២៨១០, ២៨២៨-២៨៣២ (ក្រាំងតាចាន់ – ពិភាក្សាភស្តុតាង និងការសន្និដ្ឋានអំពីការធ្វើទារុណកម្ម), ៣១៨៥-៣៣០៩, ៣៣១៧-៣៣១៩ (ចាម – ពិភាក្សាភស្តុតាង និងការសន្និដ្ឋានអំពីការធ្វើទារុណកម្ម), ៤២០១-៤៣១៩, ៤៣២៦-៤៣២៨ (ពិភាក្សាភស្តុតាង និងការសន្និដ្ឋានអំពីការធ្វើទារុណកម្ម ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខ)។

[760] ឯកសារ **E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីសំណើសុំដោះលែង ខៀវ សំផន កថាខណ្ឌ ៣១។

[761] សាលក្រមរឿងក្តី *Stakić* កថាខណ្ឌ ៥១៦ (គោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ* “អនុវត្តបានតែលើការសម្រេចលើអង្គហេតុតែប៉ុណ្ណោះ ពុំមែនអង្គច្បាប់នោះទេ”)។

## ៤. តំណាងរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី

### *មូលដ្ឋានទី ៣០៖ ចម្លើយជាលាយលក្ខណ៍អក្សរ[762]*

219. **មូលដ្ឋានទី ៣០ គួរច្រានចោលដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសក្នុងការវាយតម្លៃលើចម្លើយជាលាយលក្ខណ៍អក្សរ។**

220. មូលដ្ឋាននេះមិនទទួលបានផលទេ ជាពិសេស ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុស ដោយសារមិនបានអនុវត្តក្របខ័ណ្ឌវាយតម្លៃរបស់ខ្លួននៃកំណត់ហេតុជាលាយលក្ខណ៍អក្សរចំពោះ៖ (i) ការផ្តល់តម្លៃភ័ស្តុតាងនៃកំណត់ហេតុទាំងនេះ[763]។ (ii) ការប្រើប្រាស់ទាក់ទងទៅនឹងសកម្មភាព និងការប្រព្រឹត្តរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលម្ចាស់បណ្តឹងសាទុក្ខ ក៏ហាក់ដូចជាជំទាស់នឹងសេចក្តីសន្និដ្ឋានផ្លូវច្បាប់របស់ អ.ជ.ត.ក អំពី បញ្ហានេះនៅក្នុងសំណុំរឿង ០០២/០១[764] (iii) ការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់[765] និង (iv) កំហុសដដែលៗ ដូចបានចោទប្រកាន់ នៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២[766]។

221. មូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខ មិនទទួលបានផលទេ ដោយសារគាត់ (i) លើកឡើងមិនត្រឹមត្រូវ ឬ បំភាន់អង្គហេតុ ដែល អ.ជ.ស.ជ បានសំអាងទៅលើ និងការយល់ឃើញរបស់ អ.ជ.ស.ជ និង (ii) មិនបង្ហាញជាក់លាក់អំពីព្យសនកម្ម ដែលត្រូវបានចោទប្រកាន់ថាប៉ះពាល់ដល់លក្ខខណ្ឌបទដ្ឋានបណ្តឹងឧទ្ធរណ៍[767]។ ម្ចាស់បណ្តឹងសាទុក្ខ យោងទៅ "សំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ"[768] ដោយមានត្រឹមតែការយោងមិនច្បាស់លាស់ថាតើទៅលើសំអាងហេតុណាខ្លះ ហើយពិតណាស់មិនមានព្យសនកម្មជាក់លាក់ដែលត្រូវបានប៉ះពាល់ដូចបានចោទប្រកាន់ទេ។ ទាក់ទងទៅនឹងបញ្ហាដែលអង្គជំនុំជម្រះនេះ បានសម្រេចរួចហើយនៅក្នុងសំណុំរឿង

---

[762] មូលដ្ឋានទី ៣០៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ សក្ខីកម្មជាលាយលក្ខណ៍អក្សរ កថាខណ្ឌ ២៩៣-៣០៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៤-១៥ (ភាសាអង់គ្លេស) ទំព័រ ១៣ (ភាសាបារាំង) ទំព័រ ១៩ (ភាសាខ្មែរ)។

[763] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩៣-២៩៥។

[764] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩៦-៣០០។

[765] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០១-៣០២។

[766] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០៣-៣០៥។

[767] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់, កំហុសអង្គហេតុ)។

[768] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩៦, ៣០៤។

០០២/០១[769] គាត់គ្រាន់តែមិនយល់ស្របនឹងសេចក្ដីសម្រេចទាំងនោះ ហើយហាក់ដូចជាស្នើសុំការពិចារណាឡើងវិញដោយមិនបានបំពេញតាមបទដ្ឋានសម្រាប់ស្នើសុំការពិចារណាឡើងវិញនោះឡើយ[770]។

222. មូលដ្ឋានទាំងនេះក៏មិនទទួលបានផលដែរ ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសនៅក្នុងវិធីសាស្ត្ររួមរបស់ខ្លួនចំពោះភ័ស្តុតាងជាលាយលក្ខណ៍អក្សរជំនួសឱ្យសក្ខីកម្មក្នុងតុលាការ ដែលវិធីសាស្ត្រមួយនេះ អ.ជ.ត.ក មិនបានរកឃើញថាមានកំហុសនោះទេ[771]។ អ.ជ.ស.ដ បានឆ្លើយតបយ៉ាងច្បាស់លាស់អំពីបញ្ហានានា ដែលទាក់ទងនឹងសេចក្ដីថ្លែងការណ៍នៅក្រៅតុលាការ។ ឧទាហរណ៍ អ.ជ.ស.ដ បានលើកឡើងកត្តានានា ដែលគាំទ្រដល់ការទទួលយក ឬ ការកំណត់តម្លៃភ័ស្តុតាងដែលបានផ្ដល់លើចម្លើយជាលាយលក្ខណ៍អក្សរ ហើយបានសន្និដ្ឋានថា អវត្តមាននៃឱកាសតទល់គ្នា គឺជាកត្តាពិចារណាមួយ ដែលអាចបន្ថយទម្ងន់ដែលត្រូវលើកំណត់ហេតុទាំងនោះ[772]។ អ.ជ.ស.ដ បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវក្នុងការទទួលយកសេចក្ដីថ្លែងការណ៍នៅក្រៅតុលាការ បន្ទាប់ពីបានផ្ដល់ឱកាសឱ្យម្ចាស់ឧទ្ធរណ៍ក្នុងការធ្វើសេចក្ដីសន្និដ្ឋានលើសេចក្ដីថ្លែងការណ៍ទាំងនេះ[773]។ អ.ជ.ស.ដ ក៏ ក៏បានកត់សម្គាល់ការព្រួយបារម្ភរបស់ខ្លួន អំពីតម្លៃភ័ស្តុតាងនៃសេចក្ដីថ្លែងការណ៍នៅក្រៅតុលាការ ដោយបានលើកឡើងថា ខ្លួននឹងពិចារណា "ការកំណត់អត្តសញ្ញាណ ការពិនិត្យលើភ័ស្តុតាង ភាពលម្អៀង ប្រភព

---

[769] *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨៦-២៨៧ (សក្ខីកម្មជាលាយលក្ខណ៍អក្សរជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់ ដែលជាសិទ្ធិពុំមានភាពដាច់ខាត), ២៨៩ (ការប្រើប្រាស់សក្ខីកម្មជាលាយលក្ខណ៍អក្សរសម្រាប់បញ្ជាក់ពីសកម្មភាព និងការប្រព្រឹត្តរបស់ម្ចាស់បណ្ដឹងសាទុក្ខ)។

[770] ម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញមូលហេតុដែលគួរឱ្យជឿ ដើម្បីឱ្យមានការពិចារណាឡើងវិញឡើយ (*សូមមើល* ឯកសារ **F2/10/3** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើរបស់ នួន ជាសុំ ការពិចារណាឡើងវិញ ស្ដីពីការដាក់ ភ័ស្តុតាងបន្ថែម ទំព័រ ៣ EN 01202790។ សេចក្ដីសម្រេចរបស់ អ.ជ..ស.ដ ក្នុងរឿងក្ដី *Milutinović* ស្ដីពីការពិចារណាឡើងវិញលើសំណើរបស់រដ្ឋអាជ្ញាទាក់ទងនឹងសាក្សី K56 កថាខណ្ឌ ២ (កំហុសយ៉ាងច្បាស់ក្នុងសំអាងហេតុ ឬផលប្រយោជន៍នៃយុត្តិធម៌ ដើម្បីជាយុត្តិកម្មសម្រាប់ការពិចារណាឡើងវិញ)។

[771] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨៩។

[772] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៩។ សូមមើលផងដែរឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៧៩។

[773] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៥-៥៦។

និងបុព្វហេតុរបស់បុគ្គលដែលម្ចាស់ភ័ស្តុតាងនោះ ឬ (មិនមានចំណុចទាំងពីរនេះ) ឬ ប្រភពផ្សេងទៀតនៃភ័ស្តុតាង [ក្រៅតុលាការ]"[774]។

223. អ.ជ.ស.ដ ក៏បានផ្តល់ឱកាសឱ្យភាគីជំទាស់តវ៉ាទៅលើភ័ស្តុតាង ហើយនៅក្នុងសវនាការអំពីភាពអាចទទួលយកបាននៃភ័ស្តុតាង បានស្តាប់សេចក្តីសន្និដ្ឋានលម្អិតស្តីពីទម្ងន់ និងតម្លៃនៃភ័ស្តុតាងដែលបានផ្តល់ជូន[775]។ អ.ជ.ស.ដ ក៏ បានកត់សម្គាល់ផងដែរថា បើគ្មានឱកាសសួរដេញដោល ខ្លួននឹងដកចេញសេចក្តីថ្លែងការណ៍ ដែលបង្ហាញសកម្មភាពនិងទង្វើរបស់ជនជាប់ចោទ លើកលែងតែករណីដែលសាក្សីបានទទួលការស្លាប់ ឬ មិនអាចមកផ្តល់សក្ខីកម្ម ហើយ ក្នុងករណីបែបនេះ អ.ជ.ស.ដ នឹងមិនផ្អែកមូលដ្ឋានលើការផ្តន្ទាទោស លើភ័ស្តុតាងនោះទេ ប្រសិនបើតម្លៃភ័ស្តុតាងមានទម្ងន់លើសពីតម្រូវការក្នុងការធានាការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[776]។ ម្ចាស់បណ្តឹងសាទុក្ខខកខានបង្ហាញថា វិធីសាស្ត្រនេះមានកំហុស ឬ អ.ជ.ស.ដ មិនបានគោរពតាមវិធីសាស្ត្រនេះ។

### *តម្លៃភ័ស្តុតាងដែលបានផ្តល់លើ ចម្លើយជាលាយលក្ខណ៍អក្សរ*

224. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលបានផលទេ ទាក់ទងទៅនឹងតម្លៃភ័ស្តុតាង ដែល អ.ជ.ស.ដ បានផ្តល់លើចម្លើយជាលាយលក្ខណ៍អក្សរ ដោយសារហេតុផលមួយចំនួន។ ទី១ ម្ចាស់បណ្តឹងសាទុក្ខ កំណត់មិនត្រឹមត្រូវអំពីការវិភាគរបស់ អ.ជ.ត.ក លើកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដែលគាត់សំអាង។ ជាថ្មីម្តងទៀត គាត់បានចង្អុលយោងលើកថាខណ្ឌតែមួយគត់ក្នុងចំណោមកថាខណ្ឌជាច្រើនដែលវិភាគដោយ អ.ជ.ត.ក ដែលមិនបានបដិសេធចោលភ្លាមៗនូវការសំអាងរបស់ អ.ជ.ស.ដ លើកំណត់ហេតុជាលាយលក្ខណ៍អក្សរនោះឡើយ ប៉ុន្តែពាក់ព័ន្ធនឹងការវិភាគលម្អិតនៃសក្ខីកម្មក្នុងតុលាការ ក៏ដូចជាចម្លើយជាលាយលក្ខណ៍អក្សរ[777]។ គាត់ក៏មិនខ្វល់ពីការយល់ឃើញរបស់ អ.ជ.ត.ក ដែលលើកឡើងថា ចំពោះហេតុផលអំពីចម្លើយ ចម្លើយ

---

[774] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១។ សូមមើលផងដែរឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩៦។

[775] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៥-៥៦, ៦១។ សូមមើលផងដែរឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩៦។

[776] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១-៧២។ សូមមើលផងដែរឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨០, ២៩៦។

[777] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩៥។ សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤២៦-៤៣៥ (ការវាយតម្លៃបញ្ហាជារួមដោយ អ.ជ.ត.ក ត្រូវបានបង្ហាញ)។

ជាលាយលក្ខណ៍អក្សរមិនអាចបង្ហាញឱ្យឃើញនូវការសម្លាប់បុគ្គល ហួសពីមតិសង្ស័យនោះទេ ប៉ុន្តែ អាចត្រូវបានយកមកប្រើប្រាស់សម្រាប់បញ្ជាក់បន្ថែមទៅលើសក្ខីកម្មនៅក្នុងតុលាការ ហើយថា ការយល់ឃើញរបស់ អ.ជ.ស.ជ មិនមែនមិនសមហេតុផលនោះទេ[778]។

225. ទាក់ទងនឹងការធ្វើមនុស្សឃាតទៅលើ ហ៊ើស *អំពើពិរុទ្ធ* នៃការសម្លាប់ ទូច និងការធ្វើមនុស្សឃាត និងសម្លាប់រង្គាលសមាជិកជនជាតិវៀតណាមចំនួន ៦នាក់ នៅក្នុង ក្រុមការពារដែលត្រូវបានការពារ ការវិភាគភស្តុតាងរួម ដែល អ.ជ.ស.ជ បានសំអាង ពុំបានបង្ហាញឱ្យឃើញកំហុសអង្គច្បាប់ ឬ អង្គហេតុនោះទេ ដោយសារ (i) អ.ជ.ស.ជ បានគូសបញ្ជាក់ត្រឹមត្រូវអំពីលក្ខខណ្ឌដែលត្រូវតែបំពេញ ដើម្បីអាចប្រើភស្តុតាងនៅក្រៅតុលាការ (ពាក់ព័ន្ធនឹង ហ៊ើស)[779] (ii) អ.ជ.ស.ជ បានពិចារណាយ៉ាងត្រឹមត្រូវលើ ភស្តុតាងនៅក្រៅ តុលាការ ដែលបានផ្ទៀងផ្ទាត់រួច (ពាក់ព័ន្ធនឹង ទូច) [780] និង (iii) ភស្តុតាងនៃការសម្លាប់នេះត្រូវបានសំអាងលើសក្ខីកម្មនៅក្នុងតុលាការ និង ភស្តុតាងនៃចម្លើយជាលាយលក្ខណ៍អក្សរពីមុនៗ (ពាក់ព័ន្ធនឹងជនជាតិវៀតណាមទាំង ៦ នាក់)[781]។

*ចម្លើយជាលាយលក្ខណ៍អក្សរបង្ហាញអំពីអំពើ និងការប្រព្រឹត្តរបស់ម្ចាស់បណ្តឹងសាទុក្ខ និងការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់*

226. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ដែលចោទប្រកាន់ក្របខ័ណ្ឌច្បាប់ ដែលជាក្របខណ្ឌតែមួយ ដែល អ.ជ.ស.ជ បានរកឃើញថា មិនមានកំហុស បានច្របាច់មូលដ្ឋានទាំងពីរនេះបញ្ចូលគ្នា ដើម្បីឱ្យសម្រេចលើមូលដ្ឋានទាំងពីរនេះរួមគ្នា។ ទឡ្ហីករណ៍របស់គាត់មិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែព្យាយាមលើកបញ្ហាទាំងនេះឡើងវិញ ដែលខ្លួនលើកឡើង

[778] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៣៥។

[779] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩៥ ជើងទំព័រ ៤៤៤ *ដកស្រង់* កថាខណ្ឌ ៨៦៣-៨៦៩។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៨-៧៣។ សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋាន ទី ១៣១ (ការធ្វើមនុស្សឃាតសាក្សីឈ្មោះហ៊ើស)។

[780] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩៥ ជើងទំព័រ ៤៤៤ *ដកស្រង់*កថាខណ្ឌ ៨៧០-៨៧៣។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣២ (កំហុសក្នុងការយល់ឃើញថា ទូច ត្រូវបានធ្វើឃាតដោយប្រយោល)។

[781] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៩៥ ជើងទំព័រ ៤៤៤ *ដកស្រង់*កថាខណ្ឌ ៨៤២-៨៤៧, ១០៥៥។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩២៦។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋាន ទី ១២៨ (ការសម្លាប់), ១៣០ (សមាជិកនៃក្រុមដែលទទួលបានការការពារ)។

ដោយមិនបានជោគជ័យនៅក្នុងសំណុំរឿង ០០២/០១[782]។ ជារួម គាត់ធ្វើដូច្នេះ ដើម្បីស្នើសុំឱ្យ អ.ជ.ត.ក ពិចារណាឡើងវិញនូវសេចក្តីសម្រេចមុនៗ ទាក់ទងនឹងការប្រើប្រាស់ចម្លើយនៅក្រៅតុលាការ ដោយមិនបានបង្ហាញមូលដ្ឋានណាមួយសម្រាប់ការស្នើសុំការពិចារណានោះឡើយ[783]។ ការសំអាងរបស់គាត់លើរឿងក្តី *Bemba* និងមាត្រា ៦៨ និងមាត្រា ៦៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម[784] គឺជាការលើកឡើងខុសបរិបទ ដោយសារអង្គជំនុំជម្រះ បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសំណុំរឿង ០០២/០១ ថា "ពុំបានអនុម័តបទដ្ឋាននៃការទទួលយកចម្លើយក្រៅតុលាការ" ដែលបានរកឃើញនៅក្នុងវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")[785]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបញ្ជាក់អំណះអំណាងរបស់គាត់ទាក់ទងនឹងការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សររបស់ អ.ជ.ស.ដ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់។ ដូច ដែល អ.ជ.ត.ក បានរកឃើញនៅក្នុងសំណុំរឿង ០០២/០១ សិទ្ធិតទល់សាក្សីដាក់បន្ទុក ពុំមែនជាសិទ្ធិដាច់ខាតនោះទេ។ ផ្ទុយទៅវិញ សិទ្ធិនេះអាចត្រូវថ្លឹងថ្លែងជាមួយផលប្រយោជន៍ និងសិទ្ធិផ្សេងទៀត ឧទា. កិច្ចដំណើរការឆាប់រហ័ស[786]។

227. ទីពីរ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ភ័ស្តុតាងទាំងអស់អាចទទួលយកបាន ដែលវាជួយដល់ការស្វែងរកការពិត ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌហាមឃាត់ស្របច្បាប់ និងការពិចារណាផ្សេងទៀត។ នេះរួមបញ្ចូលសេចក្តីថ្លែងការណ៍ក្រៅតុលាការ ការពិចារណាទាក់ទងនឹងការប្រើប្រាស់ ដែល អ.ជ.ស.ដ បានបញ្ជាក់ត្រឹមត្រូវ។ ទីបី ដូចបានពិភាក្សាលម្អិតនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ៣១[787] ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានផ្តន្ទាទោសដោយផ្អែក<u>តែទៅលើ</u>ចម្លើយជាលាយលក្ខណ៍អក្សរ ដោយមិនបានថ្លឹងថ្លែងគ្រប់គ្រាន់ដើម្បីធានាថា

---

[782] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨០-២៨៤។

[783] *សូមមើល* ឯកសារ **F2/10/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើរបស់ នួន ជា សុំការពិចារណាឡើងវិញស្តីពីការដាក់ភ័ស្តុតាងបន្ថែម ទំព័រ ៣ EN 01202790 (មូលហេតុដែលគួរឱ្យជឿ)។ សេចក្តីសម្រេចរបស់ អ.ជ..ស.ដ ក្នុងរឿងក្តី *Milutinović* ស្តីពីការពិចារណាឡើងវិញលើសំណើរបស់រដ្ឋអាជ្ញាទាក់ទងនឹងសាក្សី K56 កថាខណ្ឌ ២ (កំហុសយ៉ាងច្បាស់ក្នុងសំអាងហេតុ ឬផលប្រយោជន៍នៃយុត្តិធម៌ ដើម្បីជាយុត្តិកម្មសម្រាប់ការពិចារណាឡើងវិញ)។

[784] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៨៩ *ដកស្រង់*សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Bemba* ស្តីពី ការទទួលយកភ័ស្តុតាង កថាខណ្ឌ ៧៤-៨១ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៦៩(២)។

[785] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩៧ ជើងទំព័រ ៧១៨។

[786] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៨៦-២៨៧។

[787] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣១ (ចម្លើយក្រៅប្រព័ន្ធតុលាការ/ចម្លើយដែលទទួលបាននៅក្រៅក្របខ័ណ្ឌតុលាការ)។

បណ្តឹងឧទ្ធរណ៍អាចជំទាស់ភ័ស្តុតាងប្រកបដោយប្រសិទ្ធភាព[788]។ ចំណុចចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញកំហុសណាមួយប្រព្រឹត្តដោយ អ.ជ.ស.ដ នៅក្នុង ការប្រើប្រាស់ភ័ស្តុតាងក្រៅតុលាការទាក់ទងនឹងអំពើ និងការប្រព្រឹត្តរបស់គាត់។

### កំហុសរបស់អង្គជំនុំជម្រះ ដែលត្រូវបានចោទប្រកាន់ថាកើតឡើងម្តងទៀត នៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២

228. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ គួរច្រានចោល ដោយសារពុំមានមូលដ្ឋាន។ អ.ជ.ត.ក ពុំបានរកឃើញកំហុសនៅក្នុងក្របខ័ណ្ឌភ័ស្តុតាងទូទៅរបស់ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២/០១ ទេ[789] ហើយម្ចាស់បណ្តឹងសាទុក្ខ ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុស នៅក្នុងការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរ ឬ តម្លៃភ័ស្តុតាងដែលបានផ្តល់លើកំណត់ហេតុទាំងនេះ។ ដូច្នេះ មិនមានកំហុសកើតឡើងម្តងទៀតនោះទេ។ វាគឺជាអំណះអំណាងដែលមិនទទួលបានជោគជ័យនៅក្នុងសំណុំរឿង ០០២/០១ ដែលកំពុងត្រូវបានលើកឡើងម្តងទៀត។ ទាំងរឿងក្តី Prlić និង Katanga[790] ពុំបានជួយដល់ម្ចាស់បណ្តឹងសាទុក្ខនោះទេ ដោយសាររឿងក្តីទាំងពីរនេះផ្អែកលើច្បាប់ខំមិនឡ មិនមែនប្រព័ន្ធស៊ើបអង្កេតដឹកនាំដោយចៅក្រមនោះឡើយ។ នៅ អ.វ.ត.ក មិនចាំបាច់ការពារម្ចាស់បណ្តឹងសាទុក្ខប្រឆាំងនឹង "ភ័ស្តុតាងដែលបានរៀបចំឡើងជំនួសភាគីមួយដែលគូភាគីម្ខាងទៀតមិនអាចធ្វើតេស្ត ឬ ផ្ទៀងផ្ទាត់"[791]។ ផ្ទុយទៅវិញ ភ័ស្តុតាងត្រូវបាន ស.ច.ស ផ្តល់ជូន អ.ជ.ស.ដ ដោយផ្តល់ឱកាសឱ្យម្ចាស់បណ្តឹងសាទុក្ខផ្តល់យោបល់ផងដែរ។

229. ឧទាហរណ៍របស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការគាំទ្រការអះអាងរបស់គាត់ថា អ.ជ.ស.ដ"ប្រើប្រាស់តែចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលការស្តាប់ដើម្បីកំណត់ប្រភេទបទល្មើស និងផ្តន្ទាទោស [គាត់]" មិនបានគាំទ្រការអះអាងនោះទេ[792]។ ដូចបានពិភាក្សាខាងលើ ការយោងលើកថាខណ្ឌ ៨៦៣-៨៧៣ នៃសារណារបស់គាត់ ទាក់ទងនឹងការ

---

[788] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០២ ជើងទំព័រ ៤៦១ *ដកស្រង់* កថាខណ្ឌ ៨៤២-៨៤៧, ១០៥៥ របស់ខ្លួន។ សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩៦។

[789] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩៩។

[790] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០៥ ជើងទំព័រ ៤៧០ សាលក្រមរឿងក្តី *Prlić* កថាខណ្ឌ ៣៨៨ និង និងសេចក្តីសម្រេចរបស់ អ.ជ.ស.ដ ក្នុងរឿងក្តី *Katanga* លើសំណើរបស់រដ្ឋអាជ្ញា កថាខណ្ឌ ៤២។

[791] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០៥ ជើងទំព័រ ៤៧០ *ដកស្រង់* សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ក្នុងរឿងក្តី *Katanga* លើសំណើរបស់រដ្ឋអាជ្ញា កថាខណ្ឌ ៤២។

[792] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០៤។

សម្លាប់ ហ៊ើស និង ទូច គ្មានន័យខ្លឹមសារ ដូចបានរៀបរាប់លម្អិតបន្ថែមនៅក្នុងផ្នែកផ្សេងទៀតនៃចម្លើយតបនេះ[793]។

230. ការយោងផ្សេងទៀតរបស់គាត់ គ្មានប្រយោជន៍ ដោយសារវិធីសាស្ត្រតាមបែបជ្រើសរើសចោះៗក្នុងការសំអាងលើកថាខណ្ឌនៃសាលក្រម អ.ជ.ស.ដ។ ឧទាហរណ៍ គាត់ដកស្រង់ឃ្លាមួយ ដែលទាក់ទងនឹងការផ្លាស់ទីលំនៅជនស៊ីវិលវៀតណាមពីខេត្តព្រៃវែងនៅក្នុងប្រទេសកម្ពុជាទៅកាន់ប្រទេសវៀតណាម[794]។ ការពិភាក្សារបស់ អ.ជ.ស.ដ អំពីភស្តុតាងទាក់ទងនឹងករណីនេះ មាន ៧ កថាខណ្ឌ។ តាមការពិត ការពិភាក្សាអំពីភស្តុតាងនៅក្នុងកថាខ័ណ្ឌ ៣៤៣០ រួមមានការវាយតំលៃលើសក្ខីកម្មក្នុងតុលាការ និងសេចក្តីថ្លែងការណ៍ក្រៅតុលាការ ដែលមានព័តមានលំអិតគ្រប់គ្រាន់ទាក់ទងនឹងប្រភពនៃព័ត៌មានរបស់វា - រួមទាំងការសង្កេតផ្ទាល់ខ្លួន និងអាជ្ញាធរស៊ីវិលក្នុងភូមិ - និងការបញ្ជាក់ផ្ទៀងផ្ទាត់សក្ខីកម្មនៅក្នុងតុលាការ[795]។ ស្រដៀងគ្នានេះដែរ ម្ចាស់បណ្តឹងសាទុក្ខយោងលើកថាខណ្ឌ ៤២៤៨ នៅក្នុងសាលក្រម អ.ជ.ស.ដ តែប៉ុណ្ណោះ ដែលជាំ កថាខណ្ឌមួយក្នុងចំណោមកថាខណ្ឌនានាទាក់ទងនឹងការរៀបចំអាពាហ៍ពិពាហ៍ ហើយកថាខណ្ឌនេះបន្តយោងលើកថាខណ្ឌ ៣៥៦៩-៣៥៧០ និង ៣៦១១ នៅក្នុងសាលក្រម អ.ជ.ស.ដ[796]។ កថាខណ្ឌទាំងនេះរួមមាន ការពិភាក្សាអំពីសក្ខីកម្មក្នុងតុលាការ និងសុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខ ព្រមទាំងកំណត់ហេតុសម្ភាសន៍ដែលបានពិនិត្យផ្ទៀងផ្ទាត់រួច។ ម្ចាស់បណ្តឹងសាទុក្ខដកស្រង់កថាខណ្ឌ ៤២៤៨ ជើងទំព័រលេខ ១៣៨៦៤[797] ដែលយោងបន្តលើកថាខណ្ឌ ៣៥៨៦ ក្នុងនោះមានមួយកថាខណ្ឌក្នុងចំណោម ៥ កថាខណ្ឌ ទាក់ទងនឹងការរៀបចំអាពាហ៍ពិពាហ៍របស់ទាហានពិការ[798] និងរួមបញ្ចូល សក្ខីកម្មក្នុងតុលាការ និងសុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខ ក៏ដូចជាភស្តុតាងនៅក្រៅតុលាការ។

---

[793] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣១ (ការធ្វើមនុស្សឃាតអ្នកទោសឈ្មោះ ហ៊ើស), ១៣២ (កំហុសក្នុងការយល់ឃើញថា ទូច ត្រូវបានធ្វើឃាតដោយប្រយោល)។

[794] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០៤ ជើងទំព័រ ៤៦៨ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២០។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥១ (ការជម្លៀសជនជាតិវៀតណាមពី ព្រៃវែង)។

[795] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៣០។

[796] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤៧-៤២៤៩។

[797] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣០៤ ជើងទំព័រ ៤៦៦។

[798] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៨៦-៣៥៩០។

## *មូលដ្ឋានទី ៣៤៖ ការវាយតម្លៃលើចម្លើយនានា*[799]

231. **មូលដ្ឋានទី ៣៤ គួរតែត្រូវបានច្រានចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការវាយតម្លៃ និងសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលជំនុំជម្រះ។**

232. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ សំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចជឿជាក់បាន ឬ អាចទុកចិត្តបានក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីពិរុទ្ធភាព[800]។ ទី១ ម្ចាស់បណ្តឹងសាទុក្ខសំអាងលើឧទាហរណ៍ដដែលដូចបានលើកឡើងនៅក្នុងមូលដ្ឋានទី ៣៣ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់*ពាក្យស៊ុំ*របស់ដើមបណ្តឹងរដ្ឋប្បវេណី ពុំមែនមែនសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលជំនុំជម្រះនោះឡើយ[801]។ ទីពីរ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងផ្ទុយពីការទទួលស្គាល់របស់គាត់ផ្ទាល់ថា អ.ជ.ស.ដ មានសិទ្ធិសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសន្និដ្ឋានអំពីពិរុទ្ធភាព[802] ដោយបានអះអាងថា សក្ខីកម្មរបស់ អ៊ុច ស៊ុនឡាយ មានតម្លៃតិចតួច ហើយមានភាពលំអៀងធម្មតាព្រោះ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណី[803]។ ដូចដែលបានពន្យល់បន្ថែមខាងក្រោម[804] អ.ជ.ស.ដ បានសំអាងត្រឹមត្រូវលើសក្ខីកម្មរបស់ អ៊ុច ស៊ុនឡាយ ដែលបានឆ្លើយលម្អិត និងអាចជឿជាក់បានអំពីការសម្លាប់សមាជិកគ្រួសាររបស់គាត់ រួមទាំង ប្រពន្ធជនជាតិវៀតណាម និងកូនៗ។

233. ទី៣ ម្ចាស់បណ្តឹងដកស្រង់ជា "ឧទាហរណ៍ដ៏ល្អឥតខ្ចោះ" នៃសក្ខីកម្មរបស់ "ឯក អី (Ek Ei)"[805] ប៉ុន្តែបានយោងលើផ្នែកមួយនៃសារណាបណ្តឹងឧទ្ធរណ៍របស់គាត់ ដែលរួមមានអំណះអំណាងទាក់ទងនឹងភ័ស្តុតាងរបស់ ឯក ហេន និង អែម អឿន[806]។ គ្មានបុគ្គលណាម្នាក់ដែលមានឈ្មោះថា

---

[799] <u>មូលដ្ឋានទី ៣៤</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ការវាយតម្លៃលើចម្លើយ* កថាខណ្ឌ ៣១៧-៣១៩ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៥-១៦ (ភាសាអង់គ្លេស) ទំព័រ ១៤ (ភាសាបារាំង) ទំព័រ ២១ (ភាសាខ្មែរ)។

[800] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៩។

[801] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៩ ជើងទំព័រ ៥០២ *ដកស្រង់*កថាខណ្ឌ ៩៧៨-៩៨០ របស់គាត់។ សូមមើលផងដែរចម្លើយតបទៅនឹងមូលដ្ឋានទី ១៥១ (ការជម្លៀសចេញពីភូមិអង្គរយស)។

[802] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៧-៣១៩។

[803] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៩ ជើងទំព័រ ៥០២ *ដកស្រង់*កថាខណ្ឌ ១០១៥-១០១៦ របស់គាត់។

[804] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៦ (ភ័ស្តុតាងរបស់ អ៊ុច ស៊ុនឡាយ និងការកាប់សម្លាប់នៅក្នុងតំបន់៥០៥)។

[805] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៩។

[806] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៩ ជើងទំព័រ ៥០៣ *ដកស្រង់*កថាខណ្ឌ ១៦៥៤-១៧៦២ របស់គាត់។

ឯក អ៊ី បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ នោះទេ ហើយ ឯក ហេន មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី[807]។ ហេតុដូច្នេះ ការអះអាងខុសរបស់ម្ចាស់បណ្តឹងសាទុក្ខ តាមការសន្មត គឺទាក់ទងនឹង អែម អឿន។ ដូចបានលើកឡើងនៅកន្លែងផ្សេងទៀតនៅក្នុងចម្លើយតបនេះ អ.ជ.ស.ដ បានវាយតម្លៃភ័ស្តុតាងរបស់ អែម អឿន យ៉ាងត្រឹមត្រូវ[808]។ ដូចគ្នានេះដែរ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងសក្ខីកម្មរបស់ ជា ឌៀប[809] មិនបានបង្ហាញឱ្យឃើញនូវកំហុស ដូចរៀបរាប់លំអិតនៅក្នុងផ្នែកផ្សេងទៀតក្នុងចម្លើយតបនេះទេ[810]។

### *មូលដ្ឋានទី ៣៣៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*[811]

234. **មូលដ្ឋានទី ៣៣ គួរត្រូវបានច្រានចោលដោយសារដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញថាការប្រើប្រាស់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយ អ.ជ.ស.ដ ធ្វើឱ្យសាលក្រមមោឃៈ ឬធ្វើឱ្យមានកំហុសក្នុងការស្វែងរកយុត្តិធម៌។**

235. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារការសំអាងដោយ អ.ជ.ស.ដ លើ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងឧប្បត្តិហេតុជាក់លាក់មួយនៃការនិរទេសចេញពីភូមិមួយក្នុងខេត្តព្រៃវែង មិនមោឃៈរកឃើញរបស់ អ.ជ.ស.ដ ថា ការនិរទេសចេញពីខេត្តព្រៃវែងបានកើតឡើងមែន[812]។

236. ទោះបីជាការសំអាងលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយ អ.ជ.ស.ដ ពាក់ព័ន្ធនឹងហេតុការណ៍និរទេសពីភូមិអង្គរយស អាចមានកំហុសក៏ដោយ អ.ជ.ស.ដ បានសន្និដ្ឋានត្រឹមត្រូវថាជនជាតិវៀតណាមត្រូវបាននិរទេសចេញពីភូមិចំនួនពីរផ្សេងទៀតនៅក្នុងខេត្តព្រៃឈើង គឺ ភូមិអន្លង់ទ្រា និងពោធិ៍ចិន្តាំ[813]។ ម្ចាស់បណ្តឹងសាទុក្ខត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទនិរទេស

---

[807] *សូមមើល* ឯកសារ **E1/217.1** ប្រតិចារឹក ឯក ហេន ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ០៩.៣៥.១០-០៩.៥២.៤៧ ទំព័រ១៣ បន្ទាត់ ៦ -ទំព័រទី១៥ បន្ទាត់ ៣។

[808] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២២, ២០៤។

[809] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៩ ជើងទំព័រ ៥០៤ *ដកស្រង់*កថាខណ្ឌ ១២៣៣-១២៤២ របស់គាត់។

[810] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៦។

[811] <u>មូលដ្ឋានទី ៣៣</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* កថាខណ្ឌ ៣១៤-៣១៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៥ (ភាសាអង់គ្លេស) ទំព័រ ១៤ (ភាសាបារាំង) ទំព័រ ២០-២១ (ភាសាខ្មែរ)។

[812] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៦។

[813] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៣០-៣៤០១, ៣៤៣៣-៣៤៣៦, ៣៥០២, ៣៥០៧។

ជនជាតិវៀតណាមចេញពីខេត្តព្រៃវែង[814] មិនមែនដោយសារឧប្បត្តិហេតុដាច់ដោយឡែក នៃការនិរទេសចេញពីភូមិជាក់លាក់នៅក្នុងខេត្តនោះទេ។ ដូច្នេះ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ផ្អែកលើភ័ស្តុតាងទាំងអស់ រួមទាំងសក្ខីកម្ម និងសេចក្តីថ្លែងការណ៍ផ្សេងទៀត របស់អ្នកភូមិទាក់ទងនឹងគ្រួសារវៀតណាម ដែលត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ ជនជាតិវៀតណាមត្រូវបាននិរទេសចេញពីខេត្តព្រៃវែង[815]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា មានកំហុសណាមួយ ដែលបណ្តាលឱ្យសាលក្រមទាំងមូល ឬ មួយផ្នែក មោឃៈ ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌[816]។

### *មូលដ្ឋានទី ៣៥៖ ឯកសារដែលទទួលអត្ថប្រយោជន៍ពីសច្ចធារណ៍*[817]

237. **មូលដ្ឋានទី ៣៥ គួរតែត្រូវបានច្រានចោល ដោយសារម្ចាស់បណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុស អង្គច្បាប់ ឬ អង្គហេតុ តាមរយៈការអនុវត្តក្របខ័ណ្ឌច្បាប់ដូចគ្នាទាក់ទងនឹងឯកសារដែលទទួលបានការសន្មតដែលត្រូវបានតម្កល់ដោយ អ.ជ.ត.ក ក្នុងសំណុំរឿង ០០២/០១។**

238. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងវិញនូវអំណះអំណាងដែលមិនទទួលបានជោគជ័យពីក្នុងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២/០១ ដោយពុំបានផ្តល់មូលដ្ឋានថ្មីណាមួយសម្រាប់ពិចារណាឡើងវិញលើសេចក្តីសន្និដ្ឋាននៅក្នុងរឿងក្តីនេះឡើយ[818]។ លើសពីនេះទៀត ការសំអាងរបស់ម្ចាស់បណ្តឹងសាទុក្ខលើយន្តការដែលនៅសេសសល់របស់តុលាការព្រហ្មទណ្ឌ ("IRMCT") នៃរឿងក្តី *Prlić*[819] មិនត្រូវនឹងបរិបទ។

239. ម្ចាស់បណ្តឹងសាទុក្ខយល់ខុសទាំងស្រុងអំពីការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Prlić*។ គួរកត់សំគាល់ថា អង្គជំនុំជម្រះបានច្រានចោលមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះនៅក្នុងរឿងក្តីនោះ។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបាន "បង្កើតក្របខ័ណ្ឌវាយតម្លៃ

---

[814] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០២, ៣៥០៥-៣៥០៧។

[815] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០៥-៣៥០៧។

[816] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣១៤-៣១៦។

[817] <u>មូលដ្ឋានទី ៣៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ឯកសារដែលទទួលបានសច្ចធារណ៍ថាអាចទទួលយកបាន* កថាខណ្ឌ ៣២០-៣២២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៦ (ភាសាអង់គ្លេស) ទំព័រ ១៥ (ភាសាបារាំង) ទំព័រ ២១ (ភាសាខ្មែរ)។

[818] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៦៩-៣៧៦។

[819] សាលដីការឿងក្តី *Prlić* កថាខណ្ឌ ១២១។

ថាភាពនៃឯកសារហួត់ចត់ជាងនេះ ដើម្បីធានាបទដ្ឋាននៃភ័ស្តុតាង” ឬ “ចាត់ទុកថាវាមិនគ្រប់គ្រាន់ទេក្នុងការទទួលយកយថាភាពនៃភ័ស្តុតាងមួយ ដោយគ្រាន់តែផ្អែកលើសច្ចធារណ៍ដែលអាចជំទាស់បាន ដោយពុំមានលក្ខណៈវិនិច្ឆ័យសត្យានុម័តិណាមួយ”[820]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានកត់សម្គាល់លក្ខណៈវិនិច្ឆ័យ ដែល អ.ជ.ស.ដ បានរកឃើញថាជាការចង្អុលបង្ហាញគ្រប់គ្រាន់នៃភាពអាចទុកចិត្តបានក្នុងរឿងក្តីនោះ - លក្ខណៈវិនិច្ឆ័យដែលស្របនឹងលក្ខណៈវិនិច្ឆ័យទាំងនោះនៅក្នុងរឿងក្តីនេះ[821] - ដោយមិនបានរកឃើញថា លក្ខណៈវិនិច្ឆ័យទាំងនេះជាលក្ខខណ្ឌទាមទារនោះឡើយ។ ទាក់ទងទៅនឹង “សៀវភៅកំណត់ត្រា ស-២១ ពណ៌ទឹកក្រូច”[822] ដែលជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ ដែលលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខ[823] អ.ជ.ស.ដ បានសំអាងមួយផ្នែកលើ សក្ខីកម្មរបស់សាក្សីដែលបានបញ្ជាក់ថា គាត់មានកំណត់ត្រានេះក្នុងដៃហើយបានកាន់កាប់វានៅ មន្ទីរ ស-២១[824]។ សាលក្រមនេះមានស៊ីស្វាក់គ្នាជាមួយឯកសារទាំងអស់ដែលត្រូវបានជំទាស់ដោយម្ចាស់បណ្តឹងសាទុក្ខ[825] តាមរយៈការផ្តល់សក្ខីកម្មរបស់សាក្សីនិងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភ័ស្តុតាងជាឯកសារ។ សំខាន់នោះ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី Prlić បានរំលឹកថា “ការបង្ហាញយថាភាពមិនមែនជាលក្ខខណ្ឌដាច់ដោយឡែកសម្រាប់ការទទួលយកភ័ស្តុតាងឯកសារនោះទេ” [826]។

240. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មិនបានផ្តល់នូវការឆ្លើយតបដែលមានហេតុផលចំពោះការតវ៉ា “ជាច្រើន” របស់គាត់ ចំពោះយថាភាពនៃឯកសារជាក់លាក់ ត្រូវបានបដិសេធដោយកថាខណ្ឌនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់គាត់ដែលគាត់បានសំអាង[827]។ អ.ជ.ស.ដ

---

[820] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២២។

[821] សាលដីការឿងក្តី *Prlić* កថាខណ្ឌ ១២១។ ឯកសារ **E185** សេចក្តីសម្រេចលើឯកសារ សំណុំរឿង០០២/០១ កថាខណ្ឌ ២៥-២៨។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧៣ (ចម្លើយទាក់ទងនឹងដំណើរនៃការរក្សាទុកឯកសារ និងឯកសារដែលបានបញ្ជាក់បន្ថែម *ឧទាហរណ៍* នាយក DC-Cam ចម្លងឯកសារពីឯកសារដើម ពិនិត្យមើលឯកសារដើមដែលម្ចាស់បណ្តឹងសាទុក្ខ មិនបានស្នើ)។

[822] ឯកសារ **E3/10770** របាយការណ៍ប្រចាំអំពីបញ្ជីឈ្មោះអ្នកទោស នៅស-២១ (“សៀវភៅកំណត់ត្រាពណ៌ទឹកក្រូច នៅស-២១”)។

[823] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២២ ជើងទំព័រ ៥០៩ *ដកស្រង់*កថាខណ្ឌ ២២៦ របស់ខ្លួន។

[824] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១២៣។

[825] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២២ ជើងទំព័រ ៥០៩ *ដកស្រង់*កថាខណ្ឌ ១៧-២២៥, ២២៦ របស់ ខ្លួន។

[826] សាលដីការឿងក្តី *Prlić* កថាខណ្ឌ ១២១។

[827] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២២ ជើងទំព័រ ៥០៩ *ដកស្រង់*កថាខណ្ឌ ២១៧-២២៥, ២២៦ របស់ខ្លួន។

បានផ្តល់ចម្លើយតបដែលមានសំអាងហេតុសម្រាប់ការសម្រេចរបស់ខ្លួនទាក់ទងនឹងឯកសារដែលបានពិភាក្សានៅក្នុងកថាខណ្ឌទាំងនេះ[828]។

## ៥. ភស្តុតាងអ្នកជំនាញ

### *មូលដ្ឋានទី ៣៧៖ អ្នកជំនាញ*[829]

241. **មូលដ្ឋានទី ៣៧ គួរត្រូវបានច្រានចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសអង្គច្បាប់ និងអង្គហេតុនៅក្នុងការវាយតម្លៃភស្តុតាងរបស់អ្នកជំនាញ។**

242. ទោះបីជាម្ចាស់បណ្តឹងសាទុក្ខ "យល់ស្របជាមួយនឹងការវិភាគរបស់ [អ.ជ.ស.ជ]"[830] ទាក់ទងនឹងការវាយតម្លៃលើភស្តុតាងជំនាញក៏ដោយ[831] ក៏គាត់ខកខានមិនបានបង្ហាញថា អ.ជ.ស.ជ ពុំបានអនុវត្តក្របខ័ណ្ឌនេះក្នុងការវាយតម្លៃភស្តុតាងទាំងនោះទេ។ ការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ជ មិនបានអនុវត្តក្របខ័ណ្ឌរបស់ខ្លួនសម្រាប់វាយតម្លៃភស្តុតាងជំនាញនិងមិនយកចិត្តទុកដាក់លើភស្តុតាងដោះស្រាយបន្ទុក[832] មិនអាចយកជាការបាន ដោយសារវាមិនត្រឹមត្រូវ ដោយសារវាមិនអើពើថា អ.ជ.ស.ជ ត្រូវតែវិភាគលើភស្តុតាងជាក់លាក់ជាមួយនឹងភស្តុតាង

---

[828] *ជាការឆ្លើយតបទៅនឹង*ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧ (ការជំទាស់ទៅនឹងការទទួលយក ឯកសារដែលមានប្រភពពីសាស្ត្រាចារ្យ Goscha), ២២៥ (ការជំទាស់ទៅនឹងការប្រើប្រាស់ឯកសារទាំងនេះសម្រាប់ការ បញ្ជាក់) *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២-៣៥៤។ *សូមមើលផងដែរ* ឯកសារ **E327/4/7** សេចក្តីសម្រេចរបស់ អ.ជ.ស.ជ លើឯកសារ Goscha។ *ជាការឆ្លើយតបទៅនឹង*ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧, ២២៥ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១១ (សម្រាប់ឆ្នាំ១៩៧៨ និង១៩៧៨ ការប្រើប្រាស់ភស្តុតាងមានតម្លៃតិចតួច)។ *ជាការឆ្លើយតបទៅនឹង*ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២២៦ (ការជំទាស់ទៅនឹងសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនៃ ស-២១ (ឯកសារ **E3/10770**)) *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៦, ២១២៣។ ឯកសារ **E443/3** សេចក្តីសម្រេចរបស់ អ.ជ.ស.ជ ស្តីពីសៀវភៅកំណត់ត្រាពណ៌ទឹកក្រូច និងសាក្សីពីររូបពាក់ព័ន្ធនឹង ស-២១។ ចម្លើយតបទៅនឹងមូលដ្ឋានទី ១២ (ការទទួលយកសៀវភៅកំណត់ត្រាពណ៌ទឹកក្រូចនៃ ស-២១)។

[829] <u>មូលដ្ឋានទី ៣៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អ្នកជំនាញ* កថាខណ្ឌ ៣២៩-៣៣០។ ឯកសារ **F54.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៦-១៧ (ភាសាអង់គ្លេស) ទំព័រ ១៥ (ភាសាបារាំង) ទំព័រ ២២ (ភាសាខ្មែរ)។

[830] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣០។

[831] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣២៩-៣៣០ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៦, ១៩១-១៩៥។

[832] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣០ ជើងទំព័រ ៥៣៥ *យោងទៅ* អ្នកជំនាញ Levine និង អ្នកជំនាញ Nakagawa។

ទាំងអស់[833] ហើយគ្រាន់តែស្នើសុំឱ្យ អ.ជ.ត.ក វាយតម្លៃភ័ស្តុតាងខុសគ្នាចំពោះ អ.ជ.ស.ដ ដោយមិនបង្ហាញកំហុសក្នុងការវាយតម្លៃរបស់ខ្លួន។ ការពិនិត្យពេញលេញបង្ហាញថា អ.ជ.ស.ដ បានវាយតំលៃភ័ស្តុតាងរបស់អ្នកជំនាញទាំងពីរនាក់នេះយ៉ាងត្រឹមត្រូវដោយផ្អែកលើភ័ស្តុតាងទាំងអស់នៅចំពោះមុខខ្លួន ដែលជាលក្ខខណ្ឌទាមទារនៅពេលវាយតម្លៃកំហុសដែលបានចោទប្រកាន់នៅក្នុងបណ្តឹងសាទុក្ខ[834]។

243. ទាក់ទងនឹងសក្ខីកម្មរបស់លោកស្រី Kasumi Nakagawa[835] ម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថា អ.ជ.ស.ដ បំផ្លៃសក្ខីកម្មរបស់គាត់ ឬ មិនបានធ្វើការសន្និដ្ឋានចាំបាច់ពីសក្ខីកម្មនេះ[836]។ វិធីសាស្រ្តជ្រើសរើសតាមការចង់បានរបស់ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានបង្ហាញដោយឧទាហរណ៍មួយដែលម្ចាស់បណ្តឹងសាទុក្ខជ្រើសរើសចម្លើយរបស់អ្នកជំនាញតែមួយផ្នែកប៉ុណ្ណោះ។ ចម្លើយតបដែលបានដកស្រង់ដោយផ្នែកខ្លះគឺត្រង់សំណួររបស់មេធាវីការពារក្តី៖ "ប្រសិនបើខ្ញុំយល់ភ័ស្តុតាងរបស់លោកស្រីមិនខុសនោះទេ ជំហររបស់លោកស្រីផ្អែកតាមការស្រាវជ្រាវគឺថា ប្រជាជនមានលទ្ធភាពបដិសេធមិនរៀបការជាមួយនរណាម្នាក់បាន *ទោះក្នុងករណីអង្គការ "បានបញ្ជា ក៏ដោយ"* " ប៉ុន្តែវាអាស្រ័យខ្លាំងលើអាជ្ញាធរមូលដ្ឋាន? តើត្រឹមត្រូវដែរឬទេ? អ្នកជំនាញបានឆ្លើយតបថា "ចាស, ត្រឹមត្រូវ។ ដូច្នេះហើយទើប ខ្ញុំនិយាយថា ខ្ញុំមិនអាចរកឃើញភ័ស្តុតាងណាមួយបង្ហាញអំពីគោលនយោបាយមជ្ឈិម ដែលបង្ខំប្រជាជនឱ្យរៀបការនោះឡើយ"[837]។ ដោយពិចារណាលើចម្លើយរបស់អ្នកជំនាញនៅក្នុងបរិបទនៃសំណួរ ដែលសំដៅលើ "ការបដិសេធមិនរៀបអាពាហ៍ពិពាហ៍ *ទោះក្នុងករណីអង្គការ "បានបញ្ជាក៏ដោយ"* បានបញ្ជាក់យ៉ាងច្បាស់ថា សំណួរផ្តោតសំខាន់លើ

[833] *សូមមើល* សាលដីការឿងក្តី *Lubanga* កថាខណ្ឌ ២២។ សាលដីការឿងក្តី *Ntagerura* កថាខណ្ឌ ១៧៥។ *សូមមើលផងដែរ* សាលដីការឿងក្តី *Ngirabatware* កថាខណ្ឌ ២០២, ២០៨។ សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៥៥។ សាលដីការឿងក្តី *Martić* កថាខណ្ឌ ២៣៣។

[834] *សូមមើល* បទដ្ឋានសម្រាប់ការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។ សាលដីការឿងក្តី *Setako* កថាខណ្ឌ ៣១៦។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៧។

[835] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣០ *យោងទៅ* កថាខណ្ឌ ១២០៩-១២១០ របស់គាត់ និង ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៣១, ៣៥៣៣ (ការចង្អុលបង្ហាញរបស់ម្ចាស់បណ្តឹងសាទុក្ខទៅលើកថាខណ្ឌនានា នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ និងយោងទៅលើសាលក្រមស្តីពីការផ្តន្ទាទោសចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានលើកឡើងក្នុងផ្នែកទី VII.ឃ. បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍)។

[836] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២០៩។

[837] ឯកសារ **E1/473.1** (Kasumi Nakagawa) ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង ១៤.០៣.៤៤-១៤.០៧.២៩ ទំព័រ ៥៣-៥៤ បន្ទាត់ ៨-២៥, ១-៧ (គូសបញ្ជាក់បន្ថែម)។

អាជ្ញាធរមូលដ្ឋានដែលអនុវត្តបទបញ្ជាពីអង្គការឱ្យរៀបការ មិនមែន លើបញ្ហាចំបងថាតើ មជ្ឈិម ប.ក.ក មាន ឬ គ្មានគោលនយោបាយដែរឬទេនោះឡើយ[838]។

244. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ក៏មិនទទួលបានផលដូចគ្នា នៅពេលសក្ខីកម្មរបស់អ្នកជំនាញលើបញ្ហានេះត្រូវបានពិចារណាជារួម[839]។ អ.ជ.ស.ដ បានយោងសក្ខីកម្មនោះយ៉ាងត្រឹមត្រូវនៅពេលចង្អុលបង្ហាញថា Kasumi Nakagawa មិនអាចសន្និដ្ឋានបានថាមានគោលនយោបាយថ្នាក់ខ្ពស់ដើម្បីរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំដោយសារតែកង្វះភ័ស្តុតាង "ព្រោះវាមិនមែនជាផ្នែកមួយនៃការសិក្សារបស់លោកស្រី"[840] ។ ស្រដៀងគ្នានេះដែរ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ "បដិសេធមិនត្រឹមត្រូវ" លើសក្ខីកម្មរបស់លោកស្រី Peg Levine[841] ក៏ត្រូវចាត់ទុកជាឥតបានការដូចគ្នា។ អ.ជ.ស.ដ មិនដែលបានបដិសេធ ឬ មិនទទួលយកសក្ខីកម្មរបស់អ្នកជំនាញណាមួយដោយគ្មានការវិភាគសមហេតុផលនោះទេ។ ដូចបានកត់សម្គាល់ អ.ជ.ស.ដ បានបង្ហាញភាពស្ទាក់ស្ទើររបស់ខ្លួនទាក់ទងនឹងភ័ស្តុតាងរបស់ Peg Levine[842]។

---

[838] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១០។

[839] ឯកសារ **E1/472.1** (Kasumi Nakagawa) ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង ១៣.៥៥.១១-១៣.៥៧.៣៦ ទំព័រ ៥២-៥៣ បន្ទាត់ ១៧-២៥, ១-១៥ (កម្មវត្ថុ៖ សំណួរថាតើគាត់បានវិភាគលើឯកសារចេញពីមជ្ឈិមបក្សនាសម័យកាលនោះ ឬក៏សេចក្តីថ្លែងការណ៍ចេញពីមេដឹកនាំខ្មែរក្រហមដែរឬអត់ គាត់បានឆ្លើយថា ដោយសារគាត់ចង់ប្រមូលចងក្រមសំឡេងរបស់ស្ត្រី គាត់មិនបានយកមកពិចារណានូវឯកសារគោលនយោបាយ ដែលតុលាការអាចមាននៅក្នុងដៃនោះទេ) ម៉ោង ១៥.០៦.០៧ ទំព័រ ៦៦ បន្ទាត់ ១៦-២០ ("ខ្ញុំមិនមានភ័ស្តុតាងបញ្ជាក់ឱ្យច្បាស់ថា មានគោលនយោបាយចេញពីថ្នាក់លើទៅដើម្បីឱ្យមានការរៀបការបង្ខំឱ្យរៀបការនោះទេ ម៉ោង ១៥.០៩.៤២-១៥.១២.៣០ ទំព័រ ៦៧-៦៨ បន្ទាត់ ២-១១ (មេធាវីការពារក្តី នួន ជា បានជំទាស់ទៅលើមូលដ្ឋានដែលថា អ្នកជំនាញរូបនេះពុំបានសិក្សាស្រាវជ្រាវទៅលើឯកសារគោលនយោបាយ ឯកសារបដិវត្តន៍ ឬឯកសារសម័យកាលនោះណាមួយនោះទេ។ អីចឹង តាមសម្តីគាត់ គាត់មិនមែនជាអ្នកជំនាញទៅលើឯកសារជាក់លាក់ទាំងនោះទេ)។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥, ២៤៤។

[840] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៣៣ ជើងទំព័រ ១១៨៨៣ *យោងទៅ* ឯកសារ **E1/472.1** (Kasumi Nakagawa) ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ៦៦។

[841] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២០៩។

[842] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣០ ជើងទំព័រ ៥៣៥ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៣១ សម្រាប់អ្នកជំនាញ Levine (អ.ជ.ស.ដ មិនមានកាតព្វកិច្ចត្រូវគោរពតាមយោបល់របស់ណាមួយឡើយ។ ឯកសារដែលអ្នកជំនាញមាន គឺមានចំនួនតិចជាងភ័ស្តុតាងទាំងអស់នៅចំពោះមុខ អ.ជ.ស.ដ។ យោបល់របស់អ្នកជំនាញផ្នែកអង្គហេតុ ដែលផ្ទុយនឹងភ័ស្តុតាងដែលមានសារៈសំខាន់ខ្លាំងនៅចំពោះមុខ អ.ជ.ស.ដ នឹងត្រូវបានច្រានចោល) កថាខណ្ឌ ៣៥៣៣ សម្រាប់អ្នកជំនាញ Nakagawa (អ.ជ.ស.ដ នឹងវាយតម្លៃលើភ័ស្តុតាងដោយពិចារណាពីបរិបទនៃភ័ស្តុតាងនៅចំពោះមុខ អ.ជ.ស.ដ)។

## VI. ការទទួលសំណុំរឿង និងវិសាលភាពនៃការជំនុំជម្រះ

### ក. សេចក្តីផ្តើម បរិបទ និងគោលការណ៍ច្បាប់

245. អ.ជ.ស.ដ បានបំពេញកិច្ចក្នុងក្របខ័ណ្ឌសំណុំរឿងដែលខ្លួនទទួលបាន ដើម្បីផ្តន្ទាទោសជនជាប់ចោទពីបទឧក្រិដ្ឋចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២។ ម្ចាស់បណ្តឹងសាទុក្ខតវ៉ានៅក្នុងមូលដ្ឋានចំនួន ៥១ រួមមាន **មូលដ្ឋានទី ២ មូលដ្ឋានទី ៣៨-៨៤ មូលដ្ឋានទី ១២៣-១២៤ និងមូលដ្ឋានទី១៣៤** ថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ដោយផ្តន្ទាទោសគាត់លើអង្គហេតុដែលគាត់អះអាងថា នៅក្រៅសំណុំរឿង ០០២/០២។ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ អះអាងថា អ.ជ.ស.ដ មានកំហុស ដោយសារបានពិចារណាថា ខ្លួនបានទទួលត្រឹមត្រូវចំពោះអង្គហេតុចំនួន ៤ ដូចខាងក្រោម៖

(១) ប្រភេទទី ១៖ អង្គហេតុដែលម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ថា ស.ច.ស ពុំបានទទួលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[843] ឬ ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែមមួយក្នុងចំណោមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមផ្សេងទៀត[844] ("ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម") [845]។

---

[843] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

[844] ឯកសារ **D83** សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិនទៅនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ។ ឯកសារ **D146/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង ដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ឯកសារ **D196** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើចាម។ ឯកសារ **D146/4** សេចក្តីអនុញ្ញាតបន្ថែមដោយអនុលោមតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ឯកសារ **D202** សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

[845] <u>មូលដ្ឋានទី ៣៨ (អង្គច្បាប់), ៣៩-៥៩, ១២៣ (ការអនុវត្ត)</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការអនុវត្តហួសពីវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ* កថាខណ្ឌ ៣៣៤-៤៣៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៨-២៥ (ភាសាអង់គ្លេស) ទំព័រ ១៦-២៣ (ភាសាបារាំង) ទំព័រ ២២-៣៥ (ភាសាខ្មែរ)។

(២) ប្រភេទទី២៖ អង្គហេតុដែលម្ចាស់បណ្តឹងសាទុក្ខអះអាងថាពុំមានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ការដាក់បញ្ចូលក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) [846]។

(៣) ប្រភេទទី៣៖ អង្គហេតុដែលម្ចាស់បណ្តឹងសាទុក្ខអះអាងថានៅក្រៅសំណុំរឿងដែល អ.ជ.ស.ជ ទទួលបាន ចាប់តាំងពី ស.ច.ស ចោទប្រកាន់ថា ពុំបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅចោទប្រកាន់) ដូចបានកំណត់បទចោទ ដែលទំនងជានាំដល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់[847]។ និង

(៤) ប្រភេទទី៤៖ អង្គហេតុដែលត្រូវបានចោទប្រកាន់ថា អ.ជ.ស.ជ បានដកចេញពីក្នុងសំណុំរឿង ០០២/០២ ក្រោយពីបានបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២[848]។

246. ម្ចាស់បណ្តឹងសាទុក្ខអះអាងបន្ថែមទៀតថា អ.ជ.ស.ជ មានកំហុស អង្គច្បាប់ដោយសារបានសំអាងលើ៖

(៥) ភ័ស្តុតាងទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់ថានៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២[849]។

247. ម្ចាស់បណ្តឹងសាទុក្ខផ្អែកលើគោលការណ៍នីតិវិធីដែលយកតាមលំនាំច្បាប់បារាំងដែលពុំបានកំណត់នៅក្នុងច្បាប់ និងវិធានផ្ទៃក្នុង អ.វ.ត.ក ហើយដែលត្រូវបានបកប្រែដោយពុំស៊ីសង្វាក់នៅក្នុងសារណារបស់គាត់ ដែលបានបកប្រែជាភាសាអង់គ្លេស។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីអសច្ចភាព

---

[846] <u>មូលដ្ឋានទី ៦១ (អង្គច្បាប់), ៦២-៦៤ (ការអនុវត្ត)</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *បទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ* កថាខណ្ឌ ៤៣៩-៤៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៥-២៧ (ភាសាអង់គ្លេស) ទំព័រ ២៣-២៤ (ភាសាបារាំង) ទំព័រ ៣៥-៣៧ (ភាសាខ្មែរ)។

[847] <u>មូលដ្ឋានទី ៦០, ៦៥-៨១, ១២៤, ១៣៤ (ការអនុវត្ត)</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កំហុសអង្គហេតុសំខាន់ៗមួយចំនួនដែលត្រូវបានកំណត់ជាបទចោទ កថាខណ្ឌ ៤៥៨-៥៣០, ៨១៤-៨២៤, ៨៨៤-៨៨៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៧-៣២ (ភាសាអង់គ្លេស) ទំព័រ ២៤-២៩ (ភាសាបារាំង) ទំព័រ ៣៧-៤៥ (ភាសាខ្មែរ)។

[848] <u>មូលដ្ឋានទី ២, ៨២-៨៤ (ការអនុវត្ត)</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការដកអង្គហេតុចេញ តាមរយៈការបំបែកកិច្ចដំណើរការនីតិវិធី* កថាខណ្ឌ ៥៣១-៥៤៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៣-៣៤ (ភាសាអង់គ្លេស) ទំព័រ ៣០ (ភាសាបារាំង) ទំព័រ ៤៦-៤៧ (ភាសាខ្មែរ)។

[849] <u>មូលដ្ឋានទី ៣, ១៨០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦, ១២០-១២៥, ៧៥៧, ១៤៨៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥, ៦២ (ភាសាអង់គ្លេស) ទំព័រ ៥, ៥៧ (ភាសាបារាំង) ទំព័រ ៥, ៨៩ (ភាសាខ្មែរ)។

និង ផ្តល់បរិបទចំពោះចម្លើយតបនេះ សហព្រះរាជអាជ្ញាសូមបង្ហាញសាវតារនីតិវិធី គោលការណ៍ និងពាក្យពេចន៍ពាក់ព័ន្ធដោយសង្ខេប។

## ខ. ការទទួលសំណុំរឿង (ប្រធានទី ១-៤)

248. ពាក្យថា ទទួលបានសំណុំរឿង ឃើញមានប្រើបីដងនៅក្នុងវិធានផ្ទៃក្នុង[850] ដោយពុំបានកំណត់និយមន័យ។ នៅក្នុងបរិបទ នៃ អ.វ.ត.ក "ការទទួលបានសំណុំរឿង" អាចកំណត់ជាទិដ្ឋភាពទាក់ទងគ្នាណាមួយ ក្នុងចំណោមក្របខ័ណ្ឌនីតិវិធីរបស់តុលាការ។ ទិដ្ឋភាពទីមួយ វាជាឯកសារដែលបានបញ្ជូនបញ្ហាជាក់លាក់ណាមួយទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីផ្តួចផ្តើមកិច្ចដំណើរការនីតិវិធី៖ ក.ស.ព បានប្តឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទៅ ស.ច.ស[851] និងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ទៅ អ.ជ.ស.ដ[852]។ ក្រោយពីបានចេញសេចក្តីជូនដំណឹងអំពីការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនៅពេលនោះស្ថាប័នតុលាការពាក់ព័ន្ធ បានទទួលសំណុំរឿង ដោយទទួលបានការជូនដំណឹងអំពីវិវាទដែលខ្លួនត្រូវធ្វើការវិនិច្ឆ័យ។ ទីពីរ ការទទួលបានសំណុំរឿង ក៏អាចលើកឡើងអំពីវិសាលភាព

---

[850] វិធានផ្ទៃក្នុង វិធាន ២៣*ស្ទួន*(៣), ៧៤(៣)(ន), ៧៤(៤)(ន)។ សំណៅភាសាអង់គ្លេសចែងថា "បានទទួល" (វិធាន ២៣*ស្ទួន*(៣)) និង "សុំឱ្យប្តឹងទៅ" វិធាន ៧៤(៣)(ន), ៧៤(៤)។

[851] *វាក្យស័ព្ទច្បាប់* ទំព័រ ៩៣២ ("*Saisine*: [...] Action de porter devant un organe une question sur laquelle celui-ci est appelé à statuer." Unofficial translation: "*Saisine*: The action of bringing before a [judicial] organ a question on which it is called to adjudicate."). *សូមមើលផងដែរ Juridictionnaire*, ("Dans le droit de la procédure, la *saisine* est une institution juridique qui permet de *saisir une juridiction*, c'est-à-dire de déférer à une autorité une question qui fait l'objet d'un différend, d'une contestation, de lui renvoyer une affaire. Dans ce mode d'introduction de l'instance, on parle de *saisine* parce que, dès lors que l'avis introductif d'instance ou la requête est déposé au greffe, la juridiction est *saisie*, autrement dit, il y a de sa part appréhension de l'objet du litige sur lequel elle est tenue de statuer. [...] Formalité procédurale, la *saisine* permet à une juridiction de connaître d'un litige." Unofficial translation: "In procedural law, '*saisine*' is a legal institution which makes it possible to seise a court, that is to say, to refer to an authority a question which is the subject of a difference, a dispute; to send it a case. In this mode of initiating proceedings, we speak of '*saisine*' because, as soon as the notice of initiation of proceedings or the request is filed with the registry, the court is seised, in other words, there is on its part, the understanding of the subject of the litigation on which it is held to rule. [...] A procedural formality, the referral allows a court to hear a dispute")។ បកប្រែក្រៅផ្លូវការ៖ "នៅក្នុងច្បាប់នីតិវិធី '*បណ្តឹងអំពីអង្គហេតុ*' ធ្វើឡើងដោយស្ថាប័នច្បាប់ ដែលអាចបង្កលក្ខណៈឱ្យតុលាការទទួលយកវាបាន មានន័យថា បញ្ជូនបញ្ហា គឺវិវាទ ទៅឱ្យសមត្ថកិច្ចមួយដោះស្រាយដោយសារតែកម្មវត្ថុនៃភាពខុសគ្នា។ គឺបញ្ជូនរឿងក្តីទៅឱ្យស្ថាប័ននេះ។ នៅក្នុងទម្រង់នៃការផ្តើមដំណើរការនីតិវិធីបែបនេះ គឺយើងនិយាយពី '*បណ្តឹងអំពីអង្គហេតុ*' ពីព្រោះនៅពេលណាដែលការជូនដំណឹងអំពីការផ្តួចផ្តើមដំណើរការនីតិវិធី ឬសំណើសុំត្រូវបានចុះបញ្ជីជាមួយក្រឡាបញ្ជី មានន័យថា តុលាការបានទទួលបណ្តឹងនោះហើយ។ និយាយម្យ៉ាងទៀតបានថា គឺនៅក្នុងបណ្តឹងនេះ មានការយល់ឃើញអំពីកម្មវត្ថុនៃវិវាទ ដែលខ្លួនត្រូវសម្រេច។ [...] តាមទម្រង់ការនីតិវិធី ការបញ្ជូនមកបែបនេះ គឺអនុញ្ញាតឱ្យតុលាការជំនុំជម្រះលើវិវាទនេះហើយ")។

[852] វិធាន ៦៧(១), ៧៧(១៣), ៧៩(១) នៃវិធានផ្ទៃក្នុង។

នៃរឿងក្តីនៅចំពោះមុខ ស.ច.ស ឬ អ.ជ.ស.ដ ដូចបានកំណត់នៅក្នុងឯកសារពាក់ព័ន្ធ ដែលបាន បញ្ជូនមក[853]។

249. ក្នុងករណីឯកសារមិនត្រូវបានគេបញ្ជូនមកត្រឹមត្រូវ ឬ ក្នុងករណី ដែលអង្គជំនុំជម្រះពិនិត្យលើស អង្គហេតុនៅក្នុងឯកសារដែលបញ្ជូនមក នៅពេលនោះមានការបំពានសំណុំរឿងដែលទទួលបាន។ ម្ចាស់បណ្តឹងសាទុក្ខជារួមប្រើទិដ្ឋភាពចុងក្រោយនេះ។

250. សារណារបស់ម្ចាស់បណ្តឹងសាទុក្ខជាភាសាអង់គ្លេស តែងតែ បន្សល់ទុកពាក្យគ្មានជាភាសាបារាំង ដោយមិនបានបកប្រែ[854]។ ពាក្យជំនួសដូចជា "យុត្តាធិការ"[855] "វិសាលភាព" នៃសំណុំរឿង កិច្ច ស៊ើបសួរស៊ើប ការបញ្ជូនរឿងទៅជំនុំជម្រះ[856] "សំណុំរឿងដែលបានបញ្ជូនមក" បទចោទ[857] ឬការជំនុំជម្រះក្តី[858] ឬក៏ បណ្តឹង ដែល ស.ច.ស ឬ អ.ជ.ស.ដ "ទទួលបាន"[859] គឺជាពាក្យជំនួស

[853] *វាក្យស័ព្ទច្បាប់* ទំព័រ ៩៣៣ ("*Saisine*: [...] Désigne aussi dans la pratique judiciaire, l'ensemble des questions dont une juridiction se trouve saisie, qui sont soumisent à sa connaissance, ou sur renvoi après cassation, et sur lesquelles elle est tenue de répondre aux conclusions des parties. Unofficial translation: "*Saisine*: [...] It also describes in judicial practice, the collection of questions of which a court has been seised, which are submitted to it, or referred to it after an appeal, and on which the court is required to respond to the parties' submissions."។ បកប្រែក្រៅផ្លូវការ៖ "*បណ្តឹងអំពីអង្គហេតុ*"៖ [...] មានការរៀបរាប់នៅក្នុងការអនុវត្តជាក់ស្តែងតាមផ្លូវ តុលាការ ការចងក្រងបណ្តឹងដែលតុលាការបានទទួល តាមរយៈការដាក់ជូនមកខ្លួន ឬបានបញ្ជូនមកខ្លួន ក្រោយពីមានបណ្តឹង ឧទ្ធរណ៍ ហើយដែលតម្រូវឱ្យតុលាការឆ្លើយតបទៅនឹងសារណាទាំងឡាយរបស់ភាគីទាំងអស់")។

[854] *សូមមើលឧទាហរណ៍* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៧៨-៣៧៩, ៣៨២, ៣៨៦, ៣៨៨-៣៨៩, ៣៩១, ៣៩៣, ៣៩៥-៣៩៦, ៣៩៨-៤០០, ៤២០, ៤៩៣, ៥០៤, ៥២៩, ១៤០១-១៤០៣, ១៤០៧, ១៩៤២។

[855] *សូមមើលឧទាហរណ៍* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៨, ៣៥១, ៣៦៧-៣៦៨, ៤២៣, ៤៤៥, ៨១៨។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៨-២៤, ២៦-៣៣ (ភាសាអង់គ្លេស) ទំព័រ ១៦-៣០ (ភាសាបារាំង)។

[856] *សូមមើលឧទាហរណ៍* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១, ៣៣៤, ៣៥២, ៣៥៥, ៣៦៦, ៣៨៨, ៣៩១, ៤៣៦, ៥៣៨, ៨០៦, ១៤-៨៩។

[857] *សូមមើលឧទាហរណ៍* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៤៦, ៤៥៨, ៤៦៦ (ទម្រង់ជាកិរិយាស័ព្ទ), ៥០៥, ៥១០, ៥១៣, ៥១៧-៥១៨, ៥២១, ៥២៣ (បណ្តឹងជាក់ស្តែង), ៥៣០, ៥៩៩។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណា បណ្តឹងសាទុក្ខ ទំព័រ ៤-៥, ១៨-២២, ២៤-២៥, ២៧-៣៣, ៤៥, ៤៨, ៦១-៦២ (ភាសាអង់គ្លេស) ទំព័រ ៤-៥, ១៦-២២, ២៤-៣០, ៤២, ៤៤, ៥៦-៥៧ (ភាសាបារាំង)។

[858] *សូមមើលឧទាហរណ៍* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៦០, ៧២៦។

[859] *សូមមើលឧទាហរណ៍* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៤៩, ៤៥១, ៤៧២, ៤៨៧, ១៥៤៥, ១៥៥១-១៥៥២, ១៥៦៣, ១៥៧៥, ១៥៧៦, ១៥៨៤, ១៥៨៩, ២១៩១។ *សូមមើលផងដែរ* កថាខណ្ឌ ៤៤៣ ("ទាក់ទងនឹងវិសាលភាព នៃបណ្តឹង"), ៤៥១ ("បណ្តឹងជាក់ស្តែង")។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២០ (ភាសា អង់គ្លេស) ទំព័រ ១៨ (ភាសាបារាំង)។

"សំណុំរឿងដែលទទួលបាន" នៅក្នុងសារណារបស់គាត់ និងឧបសម្ព័ន្ធ ក។ អ.ប.ជ និង ស.ច.ស ក៏បានបញ្ជូនការចោទប្រកាន់ "ដែលបានធ្វើឡើងនៅចំពោះ" ស.ច.ស[860] ឬ ក៏បានប្រើពាក្យ "សំណុំរឿងទទួលបាន"[861]។ ដើម្បីចៀសវាងការភ័ន្តច្រឡំ សហព្រះរាជអាជ្ញានឹងប្រើពាក្យដើមជាភាសាបារាំង "*saisine*" (បណ្តឹង) នៅក្នុងចម្លើយតបនេះ។

## ១. កិច្ចស៊ើបសួរ÷ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងការទទួលបានសំណុំរឿងរបស់ ស.ច.ស.អ (ប្រភេទទី១)[862]

251. បណ្តឹងអង្គហេតុ គឺជាអនុប្រភេទនៃបណ្តឹង ដែលសំដៅលើគោលការណ៍ចែងនៅក្នុងវិធានផ្ទៃក្នុង[863] ដែលចៅក្រមស៊ើបសួរ បានទទួលពីព្រះរាជអាជ្ញាស៊ើបអង្កេតនូវ អង្គហេតុប្តឹងនៅក្នុង ដីកា

[860] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣, ៤, ២៩ [កថាខណ្ឌ ៣ (ភាសាបារាំង)៖ "Conformément à la Règle 53, le dossier était transmis, à chaque fois, aux co-procureurs en vue de vérifier l'étendue de la *saisine* des co-juges d'instruction relative à des fait nouveaux et de déterminer la nécessité de saisir les co-juges d'instruction d'un réquisitoire supplétif." (ភាសាអង់គ្លេស)៖ "On each occasion, the case file was forwarded to the Co-Prosecutors pursuant to Internal Rule 53 so that they could ascertain the ambit of the allegations laid before the [CIJs] as regards the new facts and determine whether to seise the [CIJs] by way of a supplementary submission." (ភាសាខ្មែរ)៖ "អនុលោមតាមវិធាន ៥៣ សំណុំរឿងតែងត្រូវបានបញ្ជូនរៀងរាល់លើកទៅសហព្រះរាជអាជ្ញា ដើម្បីផ្ទៀងផ្ទាត់មើលពីវិសាលភាពនៃបណ្តឹងដាក់ទៅសហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងអង្គហេតុថ្មីៗ ដើម្បីកំណត់ពីភាពចាំបាច់ក្នុងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទៅសហចៅក្រមស៊ើបអង្កេត"។ កថាខណ្ឌ ២៩ (ភាសាបារាំង)៖ "Ils soutiennent que les co-juges d'instruction ne sont pas valablement saisis de ces lieux de crimes, qui n'entrent pas dans le champ de la *saisine* telle que délimitée par le Deuxième Réquisitoire introductif." (ភាសាអង់គ្លេស)៖ "The Co-Investigating Judges, they maintain, were not duly seised as regards these crime sites, which fall out with the matters laid before them, as circumscribed by the Second Introductory Submission.") (ភាសាខ្មែរ)៖ "សហមេធាវីការពារក្តីលើកឡើងថា តាមផ្លូវច្បាប់ សហចៅក្រមស៊ើបអង្កេតពុំត្រូវបានស្នើសុំឱ្យស៊ើបសួរលើទីតាំងឧក្រិដ្ឋកម្មទាំងអស់នេះទេ ព្រោះថាវាមិនស្ថិតនៅក្នុងវិសាលភាពនៃបណ្តឹងទៅសហចៅក្រមស៊ើបអង្កេត ដូចដែលត្រូវបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ ឡើយ"]។

[861] *សូមមើលឧទាហរណ៍* ឯកសារ **D404/2/4** សាលដីកាលើកទីពីររបស់ អ.ប.ជ លើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៩, ៤១។ ឯកសារ **D364/1/3** សាលដីការបស់ អ.ប.ជ លើការពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **D22/288** កថាខណ្ឌ ៣។

[862] ម្ចាស់បណ្តឹងសាទុក្ខតវ៉ានៅក្នុងមូលដ្ឋានចំនួន ២២ នៃបណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសដោយសារតែការសម្រេចលើអង្គហេតុហួសពីអង្គហេតុនៃកិច្ចស៊ើបសួរ ដែលបាអនុញ្ញាតតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម៖ **មូលដ្ឋានទី ៣៩-៥៩, ១២៣**។

[863] វិធាន ៥៥(២) ចែងថា៖ "ស.ច.ស ត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកា

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដើម្បីធ្វើការស៊ើបអង្កេត[864]។ នៅក្នុងសំណុំរឿង ០០២ករណីនេះទាមទារឱ្យ ស.ច.ស ស៊ើបអង្កេតរាល់អង្គហេតុដែលបានចោទប្រកាន់នៅក្នុងកថាខណ្ឌ ៣៧-៧២ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[865] រួមជាមួយអង្គហេតុទាំងអស់ដែលត្រូវបានចោទប្រកាន់នៅក្នុងផ្នែកស្តីពីមូលដ្ឋានបទឧក្រិដ្ឋក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[866]។ ស.ច.ស មិនមានកាតព្វកិច្ចត្រូវគោរពតាមការកំណត់

---

លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៣៦។ គោលការណ៍នេះត្រូវបានចែងដូចគ្នានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៥៤ និង ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៨០។

[864] នីតិវិធីព្រហ្មទណ្ឌ ទំព័រ ១១៣ ("Le juge d'instruction est en effet saisi des faits qui lui sont dénoncés par le parquet dans son réquisitoire introductif d'instance [...] On dit qu'il est saisi *in rem* et non *in personam*, c'est-à-dire des faits tels qu'ils apparaissent dans ces actes. Le juge d'instruction ne peut alors pas s'autosaisir en incluant dans sa *saisine* des faits que les autorités de poursuite n'ont peut-être pas voulu poursuivre" Unofficial translation: "The investigating judge is seised of the facts reported to him by the prosecutor in his introductory submission. [...] It is said that the judge is seised *in rem* and not *in personam*, that is to say he is seised of the facts as they appear in these acts. The investigating judge cannot seise himself of facts that the prosecuting authorities may not have wanted to prosecute.")។ បកប្រែក្រៅផ្លូវការ "ចៅក្រមស៊ើបអង្កេតបានទទួលអង្គហេតុ ដែលតំណាងអយ្យការបានរាយការណ៍មកគាត់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ [...]។ គេនិយាយថា ចៅក្រមបានទទួលបណ្តឹងប្រឆាំងនឹងវត្ថុ គឺមិនមែនបណ្តឹងប្រឆាំងនឹងបុគ្គលទេ គឺចង់និយាយថា គាត់បានទទួលអង្គហេតុដែលលេចឡើងនៅក្នុងអំពើទាំងនោះ។ ចៅក្រមស៊ើបអង្កេតមិនអាចទទួលយកអង្គហេតុដោយខ្លួនឯង ដែលអាជ្ញាធរទទួលបន្ទុកចោទប្រកាន់មិនចង់ឱ្យគាត់ធ្វើការចោទប្រកាន់នោះឡើយ"។ *វាក្យស័ព្ទច្បាប់* ទំព័រ ៩៣៣ "*Saisine [...] in rem*: Règle de procédure pénale selon laquelle le juge, en particulier le juge d'instruction, ne peut s'auto-saisir mais doit examiner, mener les investigations et statuer sur tous les faits visés par l'acte de poursuite et seulement ceux-ci." Unofficial translation: "*Saisine in rem*: A rule of criminal procedure according to which the judge, in particular the investigating judge, may not seise himself but must review, conduct investigations and make a decision on all the facts set out in the [introductory submission] and only those facts."។ បកប្រែក្រៅផ្លូវការ៖ "*អង្គហេតុនៅក្នុងបណ្តឹង*"៖ វិធាននៃនីតិវិធីព្រហ្មទណ្ឌដែលចៅក្រម ជាពិសេសចៅក្រមស៊ើបអង្កេតមិនអាចទទួលយកដោយខ្លួនឯងបានទេ ប៉ុន្តែត្រូវតែពិនិត្យឡើងវិញ ធ្វើការស៊ើបអង្កេត និងចេញសេចក្តីសម្រេចទៅលើអង្គហេតុទាំងអស់ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងតែទៅលើអង្គហេតុទាំងនោះតែប៉ុណ្ណោះ")។

[865] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៣៧-៧២។

[866] ឯកសារ **D83** សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិនទៅនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ កថាខណ្ឌ ៥-៩។ ឯកសារ **D146/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង ដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ២, ៤។ ឯកសារ **D196** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើជនចាម កថាខណ្ឌ ២-២៣។ ឯកសារ **D146/4** សេចក្តីអនុញ្ញាតបន្ថែមដោយអនុលោមតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣។ ឯកសារ **D202** សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

បទចោទ ដែលស្នើដោយសហព្រះរាជអាជ្ញានោះទេ[867] ប៉ុន្តែវាគឺជាការណែនាំសម្រាប់កំណត់ការស៊ើបអង្កេតរបស់ខ្លួន[868]។ សំខាន់នោះ គឺជនត្រូវចោទប្រកាន់អាចត្រូវបានចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ដោយផ្អែកតែលើអង្គហេតុទាំងនេះតែប៉ុណ្ណោះ។

252. វិធាន ៥៣ ចែងអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[869] និងចែងអំពីទិដ្ឋភាពពីរប្រភេទដើម្បីឱ្យដីកាសន្និដ្ឋាន មានសុពលភាព ពោលគឺ ផ្នែកនីតិវិធី និងផ្នែកសារធាតុ។ នៅក្នុងផ្នែកទីពីរ វិធានផ្ទៃក្នុង ៥៣(១) ចែងអំពីលក្ខខណ្ឌមួយចំនួនស្តីពីទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[870]។ លើសពីនេះ ផ្នែកដំបូងនៃវិធាន ៥៣(១) ចែងអំពីលក្ខខណ្ឌសារធាតុ ស្តីពីសុពលភាព ពោលគឺ សហព្រះរាជអាជ្ញា មាន "ហេតុផលជឿជាក់" ថា ឧក្រិដ្ឋកម្មនៅក្នុងដែនសមត្ថកិច្ចរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តឡើង[871]។

*ការបកស្រាយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*

253. ម្ចាស់បណ្តឹងសាទុក្ខបកស្រាយខុសអំពីកម្រិតនៃព័ត៌មានលម្អិតដែលតម្រូវឱ្យសរសេរនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដើម្បីកំណត់

---

[867] វិធាន ៦៧(១)។

[868] សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៣៥។

[869] លក្ខខណ្ឌតម្រូវសម្រាប់សុពលភាពនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវអនុវត្តស្មើៗគ្នាចំពោះដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាំងអស់។ *សូមមើល* សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២១៨, ២២២។ ឯកសារ **D250/3/3** ដីកាសម្រេចរួមរបស់ ក.ស.ច.ស លើសំណើរបស់ ក.ស.ព និងមេធាវីដើមតំណាងបណ្តឹងរដ្ឋប្បវេណី ឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងជនជាតិវៀតណាម និងខ្មែរក្រោម កថាខណ្ឌ ៦។

[870] វិធាន ៥៣(១) ចែងថា៖ "ដីកានេះ ត្រូវមានព័ត៌មានដូចខាងក្រោមៈ (ក) សេចក្តីសង្ខេបអំពីអង្គហេតុ (ខ) ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ (គ) បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ (ឃ) ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន និង (ង) កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ")។ សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២១៩។

[871] សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២២០ *យោងទៅ* ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរ សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣៨ (ជាឯកច្ឆន្ទ)។

*បណ្តឹងជាក់ស្តែង* និងកំហុសនៅក្នុងការរិះគន់របស់គាត់ចំពោះការរកឃើញរបស់ អ.ជ.ស.ដ ថា លក្ខខណ្ឌទាមទារចាំបាច់ខុសគ្នារវាង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយ[872]។ ដូចបាន អ.ប.ជ សម្រេច ជាឯកច្ឆ័ន្ទរួចហើយ "កម្រិតនៃលក្ខណៈពិសេសដែលបានទាមទារនៅក្នុងដីកាចោទប្រកាន់ មិនអាចត្រូវបានទទួលស្គាល់ដោយផ្ទាល់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ពីព្រោះ ក.ស.ព ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយមិនមានប្រយោជន៍ពីកិច្ចស៊ើបសួរទាំងមូលនោះទេ"[873]។ តាមពិត ករណី ប្រសិនបើករណីនេះមិនដូច្នេះទេ កិច្ចស៊ើបសួរនឹងធ្វើឡើងជាន់គ្នា[874]។ "សេចក្តីសង្ខេបនៃអង្គហេតុ"[875] និង "ប្រភេទនៃបទល្មើសត្រូវបានកំណត់លក្ខខណ្ឌនៅដំណាក់កាលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ" និង "ភាពពុំច្បាស់លាស់" ចំពោះអង្គហេតុនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ *ពុំបាន*ដកចេញកិច្ចស៊ើបសួរ[876]។ ចៅក្រម អ.ប.ជ បានបញ្ជាក់ថា នៅក្នុងការអនុវត្តជាក់ស្តែង ករណីនេះមានន័យថា សហព្រះរាជអាជ្ញាមិនតម្រូវឱ្យបង្ហាញធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬចំណងទាក់ទងរវាងអំពើជាមូលដ្ឋាន និងធាតុផ្សំចាំបាច់ទូទៅ នៃឧក្រិដ្ឋកម្មពាក់ព័ន្ធនោះឡើយ[877]។

---

[872] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៥១-៣៥២ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦ *យោងជាបន្តបន្ទាប់ទៅលើ* ឯកសារ **D97/14/15** សាលដីកា អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៩២។

[873] ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** ឯកសារ **D97/14/15** សាលដីការ អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៩៥ *យោងទៅ* យុត្តិសាស្ត្រអន្តរជាតិ។ *សូមមើលផងដែរ* សំណុំរឿង ០០៤-ឯកសារ **D345/1/6** សេចក្តីពិចារណារបស់ អ.ប.ជ លើសំណើសុំឱ្យធ្វើមោឃភាពដីកាទាក់ទងនឹងទំនប់កង្គត យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣៩។

[874] ចំណុចដែលបានលើកឡើងដោយចៅក្រមអន្តរជាតិនៃ អ.ប.ជ។ *សូមមើល* សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២២២។

[875] ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីកា អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៩២។

[876] សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៥២។ សំណុំរឿង ០០៣-ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរ សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៤។

[877] សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២២១-២២២។

254. ស.ច.ស មានកាតព្វកិច្ចវិជ្ជមានក្នុងការចេញសេចក្តីសម្រេចទាក់ទងនឹងរាល់អង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[878] រួមទាំង "កាលៈទេសៈជុំវិញអំពើដែលបានលើកឡើង" នៅក្នុងនេះ[879] ដូចជាស្ថានទម្ងន់[880] អង្គហេតុពាក់ព័ន្ធ ទីតាំងដែលអង្គហេតុបានកើតឡើង និងអង្គហេតុដែលជួយដល់ការកំណត់បទចោទ[881]។ ដូច្នេះ ដូចបានពន្យល់ជូន ស.ច.ស[882] ធាតុផ្សំយុត្តាធិការនៃឧក្រិដ្ឋកម្មដែល

---

[878] សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ២៩, ៣៣, ៣៧-៣៨, ១១៥។ ឯកសារ **D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបំភ្លឺអំពីបទចោទ កថាខណ្ឌ ១០។ តុលាការកំពូលបារាំង ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ ៧៦-៩១.៤៤២ ("Le juge d'instruction avait l'obligation d'instruire, puis de statuer par une ordonnance de règlement sur l'ensemble des faits" […] "Le juge est tenu de statuer par ordonnance du règlement sur tous les faits dont il a été régulièrement saisi" Unofficial translation: "The investigating judge has the obligation to investigate and then to render an order covering all the facts. […] The judge is obliged to pronounce on all the facts of which he has been regularly seised"); បកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបសួរ ហើយបន្ទាប់មក ចេញដីកាមួយដែលគ្របដណ្តប់លើអង្គហេតុទាំងអស់"។ […] ចៅក្រមមានកាតព្វកិច្ចសម្រេចលើអង្គហេតុទាំងអស់ ដែលគាត់បានទទួលជាប្រចាំ")។ តុលាការកំពូលបារាំង ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៤ សំណុំរឿងលេខ ០៣-៨៥-៩៨៣ ("le juge d'instruction n'a pas statué, comme il en a le devoir, dans son ordonnance de renvoi, sur tous les faits dont il est saisi" Unofficial translation: "The investigating judge did not rule in his closing order, as he was obliged, on all the facts of which he was seised"). បកប្រែក្រៅផ្លូវការ: "អនុលោមតាមកាតព្វកិច្ចដែលបានប្រគល់ជូន ចៅក្រមស៊ើបអង្កេតមិនសម្រេចលើអង្គហេតុណាទាំងអស់ដែលខ្លួនបានទទួល នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនទេ")។

[879] វិធាន ៥៥(៣)។ សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៣៥។ *សូមមើលបន្ថែម* សំណុំរឿង ០០៣-ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរ សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៥ *យោងទៅ* តុលាការកំពូលបារាំង ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៧ លេខ ៧៥-៩១.២២៤។ សំណុំរឿង ០០៤-ឯកសារ **D345/1/6** សេចក្តីពិចារណារបស់ អ.ប.ជ លើសំណើសុំឱ្យធ្វើមោឃភាពដីកាទាក់ទងនឹងទំនប់កង្ហត យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣៩។

[880] វិធាន ៥៥(៣)។

[881] សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៣៥។ តុលាការកំពូលបារាំង ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៧ លេខ ៧៥-៩១.២២៤ ("S'il est interdit aux juges de statuer sur des faits autres que ceux qui leur sont déférés, il leur appartient de retenir tous ceux qui, bien que non expressément visés dans le titre de la poursuite, ne constituent que des circonstances du fait principal, se rattachant à lui et propre à le caractériser." Unofficial translation: "Whereas judges are barred from adjudicating facts other than those laid before them, it lies with them to draw on all of those facts, which although not expressly stated in the proceedings, constitute mere circumstances of the principal fact, to which they are connected and which they specifically characterise.") បកប្រែក្រៅផ្លូវការ៖ "ក្នុងករណីដែលចៅក្រមត្រូវបានហាមឃាត់មិនឱ្យសម្រេចសេចក្តីលើអង្គហេតុណា ក្រៅពីអង្គហេតុទាំងឡាយដែលបានដាក់ជូននៅចំពោះមុខខ្លួន នោះវាអាស្រ័យលើចៅក្រមដែលត្រូវប្រើប្រាស់អង្គហេតុដែលបង្កើតបានជាកាលៈទេសៈនៃអង្គហេតុចម្បង ដែលជាប់ទាក់ទងនឹងអង្គហេតុទាំងនោះ ហើយដែលចៅក្រមបានកំណត់យ៉ាងច្បាស់លាស់ ទោះបីជាមិនបានបញ្ជាក់ច្បាស់លាស់នៅក្នុងកិច្ចដំណើរការនីតិវិធីក្តី"។ តុលាការកំពូលបារាំង ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ លេខ ១២-៨០.៧៥០ inédit

ត្រូវបានចោទប្រកាន់[883] ឬ ធាតុបរិបទជាក់លាក់មួយចំនួន[884]គឺស្ថិតនៅបណ្តឹងលើអង្គហេតុរបស់ ស.ច.ស។

("lorsqu'une activité délictueuse consiste en une situation d'agissements identiques étroitement liés les uns aux autres qui se développent dans le temps, ces agissements forment une opération unique de sorte que le juge d'instruction est autorisé à informer sur l'ensemble de ces agissements alors même que l'acte de poursuite ne viserait que certains d'entre eux; en l'espèce, le juge d'instruction est saisi de l'ensemble des fausses écritures comptables qui sont le corollaire des faits d'abus de confiance aggravés et leur sont rattachés de manière indivisible". Unofficial translation: "where a criminal activity consists of the same closely-related conduct developed over time, such conduct forms a single operation, and it is therefore permissible for the investigating judge to investigate such conduct in its entirety even if the introductory submission concerns only part of it; in this instance, the Investigating Judge is seised of all the falsified accounting records, which relate to the aggravated breach of trust and are indivisibly linked to it") បកប្រែក្រៅផ្លូវការ៖ "ក្នុងករណីដែលសកម្មភាពឧក្រិដ្ឋ បង្កើតបានជាអំពើទាក់ទងគ្នាយ៉ាងជិតដិតតែមួយ ដែលបានរកឃើញពីពេលមួយទៅពេលមួយ នោះអំពើនោះបង្កបានជា ប្រតិបត្តិការតែមួយ ហើយហេតុដូច្នេះ ចៅក្រមស៊ើបសួរត្រូវបានអនុញ្ញាតឱ្យស៊ើបអង្កេតលើអំពើនោះទាំងស្រុង ទោះបីជាដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពាក់ព័ន្ធតែផ្នែកខ្លះនៃអង្គហេតុនេះក្តី។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវទទួលនូវកំណត់ត្រា រឿងរ៉ាវមិនពិតទាំងអស់ ដែលទាក់ទងនឹងការក្បត់ទំនុកចិត្តយ៉ាងធ្ងន់ធ្ងរ ដែលជាប់ទាក់ទងមិនអាចបំបែកបានទៅនឹងអំពើ នោះ")។ តុលាការកំពូលបារាំង ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៨៦ លេខ ៨៥-៩៣.៤៤៤។ *សូមមើលផងដែរ* សំណុំរឿង ០០៣-ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់ របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៤ "សហចៅក្រមស៊ើបអង្កេតត្រូវកំណត់ព្រំដែននៃការស៊ើបអង្កេតមកត្រឹមអង្គហេតុឧក្រិដ្ឋ ជាសក្តានុពល ដែលកំណត់ដោយសហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែ ទន្ទឹមនឹងនោះ ចៅក្រមទទួលបន្ទុកក្នុងការបង្ហាញកាលៈទេសៈនៃ ការប្រព្រឹត្តឧក្រិដ្ឋកម្ម ជាពិសេស *បង្ហាញទីតាំង*ដែលអំពើនោះបានកើតឡើង")។ សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៥២, ១៦៨-១៦៩, ២០៨។

[882] ឯកសារ **D98/I** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើសុំឱ្យបញ្ជាក់អំពីវិសាលភាព នៃកិច្ចស៊ើបសួរដែលបានស្នើឡើងនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ("សហព្រះរាជអាជ្ញាសូមធ្វើការបញ្ជាក់ថា កិច្ចស៊ើបសួរដែលបានស្នើសុំ គឺមិនកម្រិតត្រឹមតែអង្គហេតុ ទាំងឡាយ ដូចបានកំណត់ជាក់លាក់នៅក្នុងកថាខណ្ឌទី ៣៧ ដល់កថាខណ្ឌទី ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ក្នុងកថាខណ្ឌទី ៥ ដល់កថាខណ្ឌទី ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមប៉ុណ្ណោះទេ ក៏ប៉ុន្តែវាលាតសន្ធឹងដល់គ្រប់ អង្គហេតុទាំងអស់ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានទាំងពីរនេះទៀតផង *ឱ្យតែ*អង្គហេតុទាំងនេះជាជំនួយនៅក្នុងកិច្ច ស៊ើបសួរ ក) ធាតុផ្សំយុត្តាធិការនានាដែលចាំបាច់កំណត់ថាតើ ស្ថានភាពនៃអង្គហេតុនានា ដូចមានចែងជាក់លាក់នៅក្នុង កថាខណ្ឌទី ៣៧ ដល់កថាខណ្ឌទី ៧២ និងកថាខណ្ឌទី ៥ ដល់កថាខណ្ឌទី ២០ រួមបង្កើតទៅជាបទឧក្រិដ្ឋផ្សេងៗដែលស្ថិត នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេនោះ")។

[883] ឯកសារ **D365/2/17** សាលដីកា អ.ប.ជ ស្តីពីការទទួលស្គាល់ភ័ស្តុតាង កថាខណ្ឌ ៥៩, ៦០។ ឯកសារ **D273/3/5** សាលដីកា អ.ប.ជ លើសំណើលើកទី១៨ របស់ នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១៨។

[884] ឯកសារ **D365/2/17** សាលដីកា អ.ប.ជ ពីការទទួលស្គាល់ភ័ស្តុតាង កថាខណ្ឌ ៥៩។ *សូមមើលផងដែរ* ឯកសារ **D273/3/5** សាលដីកា អ.ប.ជ លើសំណើលើកទី១៨ របស់ នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១៨។

255. លើសពីនេះទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម) ត្រូវអានរួមគ្នា[885]។ ការអះអាងថា អ.ជ.ស.ដ មានកំហុសនៅក្នុងការសម្រេចថា បណ្តឹងរបស់ ស.ច.ស ត្រូវបានកំណត់ដោយអង្គហេតុដូចបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម) រួមជាមួយនឹងលេខយោង និងឧបសម្ព័ន្ធអមៈ[886] គឺចាត់ទុកឥតបានការ ហើយផ្ទុយពីវិធីសាស្ត្រ ដែលត្រូវបានទទួលយក និងអនុវត្តដោយចៅក្រម អ.ប.ជ[887]៖ "អង្គហេតុនានាដែលមានក្នុងភស្តុតាងភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្ថិតនៅទាំងស្រុងក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ"[888]។ វិធីសាស្ត្ររបស់ដើមបណ្តឹងសាទុក្ខត្រូវបានច្រានចោលដោយយុត្តិសាស្ត្របារាំង[889] ក្នុងនោះរួមមានយុត្តិសាស្ត្រដែល

---

[885] ក្នុងការសម្រេចអំពីមូលដ្ឋានឧក្រិដ្ឋកម្ម ស.ច.ស គួរតែយកចិត្តទុកដាក់ចំពោះកថាខណ្ឌដែលនៅសេសសល់ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម)។ *សូមមើល* សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៥៦ (យោងទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ២៣, ៣៦), ១៥៨ (យោងទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ២១, ២៣), ១៧៧ (យោងទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៨៦(ក)), ២០៥ (យោងទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៦, ៨២, ៨៦), ២១១ (យោងលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៨៦(ខ))។ ផ្នែកស្តីពី "មូលដ្ឋានឧក្រិដ្ឋកម្ម" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ គឺនៅត្រង់កថាខណ្ឌ ៤៣-៦៦។

[886] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៥១-៣៦៦, ៣៨២-៣៨៣។

[887] សំណុំរឿង ០០៣-ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរ សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៤។ សំណុំរឿង ០០៤-ឯកសារ **D299/3/2** សេចក្តីពិចារណារបស់ អ.ប.ជ លើសំណើសុំការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៥២ និងការចង្អុលបង្ហាញនៅក្នុងសេចក្តីពិចារណានេះ។ សំណុំរឿង ០០៤-ឯកសារ **D263/1/5** សេចក្តីពិចារណារបស់ អ.ប.ជ លើសំណើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបអង្កេតទាក់ទងនឹងវត្តតាមាក់ យោបល់របស់ចៅក្រម Baik និងចៅក្រម Beauvallet លើអង្គសេចក្តីនៃសំណើសុំ កថាខណ្ឌ ៥៨ និង ៦១ *ដែលក្នុងនោះយោងទៅ* សំណុំរឿង ០០៣-ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ ៤២ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួន សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៥០ (*សូមមើលផងដែរ* កថាខណ្ឌ ១៥៦ ចំពោះការអនុវត្តគោលការណ៍នេះ)។

[888] សំណុំរឿង ០០៤-ឯកសារ **D299/3/2** សេចក្តីពិចារណារបស់ អ.ប.ជ លើសំណើសុំការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៥២។ នៅក្នុងសំអាងហេតុរបស់ពួកគាត់ ចៅក្រមទាំងនោះបានយោងទៅលើវិធាន ៥៣(២)។

[889] ទោះបីជាច្បាប់បារាំងមិនអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក ក្តី ក៏ អ.ប.ជ និង អ.ជ.ត.ក បានបញ្ជាក់ពីមុនរួចមកហើយថា ប្រព័ន្ធច្បាប់បារាំងត្រូវបានប្រើប្រាស់ដើម្បីជួយដល់ការបកស្រាយច្បាប់កម្ពុជាផង និង វិធាន ៥៣ និង ៥៥ ផង។ *សូមមើល*

អ.ជ.ស.ជ បានយោង[890] ដែលបានបញ្ជាក់ថា ការយល់ព្រមលើខ្លឹមសារនៃឧបសម្ព័ន្ធមួយ ឬ ច្រើន ដែលដាក់ភ្ជាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូចអ្វីដែលបានរកឃើញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៃសំណុំរឿង ០០២[891] ស្មើនឹងការវិភាគ និងការបញ្ចូលឧបសម្ព័ន្ធ

---

សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ ជើងទំព័រ ៣៨, ៣៩។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៣១។

[890] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧ *យោងទៅ* សំណុំរឿងតុលាការកំពូលបារាំង ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩២ លេខ ៩២-៨៣.៤៦៤ សំណុំរឿងតុលាការកំពូលបារាំង ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៩៨ ព្រឹត្តិប័ត្រព្រហ្មទណ្ឌ លេខ ៩៨-៨២.៦៣៣ ("Lorsque la chambre d'accusation, qui analyse souverainement les pièces annexées au réquisitoire introductif, constate que la *saisine* du magistrat instructeur, quant aux faits, est déterminée par ces pièces, le réquisitoire ne peut être annulé, s'il satisfait en la forme aux conditions essentielles de son existence légale." Unofficial translation: "When the Indictment Chamber, which in its full discretion analyses the documents annexed to the introductory submission, notes that the investigating judge's *saisine*, as to the facts, is determined by these documents, the indictment cannot be canceled, if it satisfies in form the essential conditions of its legal existence")។ បកប្រែក្រៅផ្លូវការ៖ "ស្របតាមឆន្ទានុសិទ្ធិពេញលេញរបស់ខ្លួន នៅពេលដែលអង្គជំនុំជម្រះទទួលបន្ទុកចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ វិភាគលើឯកសារទាំងអស់ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កត់សម្គាល់ឃើញថា *បណ្តឹង*របស់ចៅក្រមស៊ើបអង្កេតចំពោះអង្គហេតុទាំងអស់ ត្រូវបានសម្រេចតាមរយៈឯកសារទាំងអស់នេះ នោះដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចត្រូវបានលុបចោលឡើយ ប្រសិនបើអង្គជំនុំជម្រះយល់ស្របតាមទម្រង់ច្បាប់ទៅលើលក្ខខណ្ឌចាំបាច់នៃអត្ថិភាពតាមផ្លូវច្បាប់របស់ដីកានេះ")។ *សូមមើលផងដែរ* សំណុំរឿងតុលាការព្រហ្មទណ្ឌបារាំង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩១ លេខ ៩១-៨២-៧០៦ ("la *saisine* du magistrat instructeur, quant aux faits, est déterminée par les pièces annexées à ce réquisitoire" Unofficial translation: "the matter laid before the Investigating Judges as regards the facts is defined by the annexures to the submission") បកប្រែក្រៅផ្លូវការ៖ "បញ្ហាដែលបានដាក់ជូននៅចំពោះមុខចៅក្រមស៊ើបអង្កេត ត្រូវបានកំណត់ដោយឧបសម្ព័ន្ធភ្ជាប់ទៅនឹងសំណើសុំនេះ")។ សំណុំរឿងតុលាការព្រហ្មទណ្ឌបារាំង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧២ លេខ ៧២-៩០-៧១៩ ("Le visa, dans le requisitoire introductif, des pièces qui y sont jointes equivaut à une analyse desdites pièces et […] en conséquence, celles-ci determinent par les indications qu'elles contiennent, l'objet exact et l'étendue de la *saisine* du juge d'instruction" Unofficial translation: "the endorsement, in the introductory submission, of its annexes is equivalent to an analysis of those annexes, and as a result, they determine by the evidence they contain, the exact subject and extent of the *saisine* of the investigating judge"។ បកប្រែក្រៅផ្លូវការ៖ "នៅក្នុងដីកាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ការសម្រេចយល់ព្រមលើឧបសម្ព័ន្ធភ្ជាប់នឹងដីកានេះ គឺស្មើនឹងការវិភាគទៅលើឧបសម្ព័ន្ធទាំងនោះ ហើយជាលទ្ធផល តុលាការសម្រេចទៅតាមភស្តុតាងដែលមាននៅក្នុងឧបសម្ព័ន្ធនេះ កម្មវត្ថុពិតប្រាកដ និង*បណ្តឹងលើអង្គហេតុ*របស់ចៅក្រមស៊ើបអង្កេត"។

[891] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ៥៧២ *ដកស្រង់នៅក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧។

ទាំងនោះ។ ក្នុងន័យនេះ ម្ចាស់បណ្តឹងសាទុក្ខបង្កើតភាពខុសគ្នាសិប្បនិម្មិតរវាងអង្គហេតុ[892] និងភ័ស្តុតាង[893]។

256. ទោះជាយ៉ាងនេះក៏ដោយ បណ្តឹងអង្គហេតុ ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពុំត្រូវបានកម្រិតត្រឹមមូលដ្ឋានបទឧក្រិដ្ឋនោះទេ។ សហព្រះរាជអាជ្ញាអាចបើកការស៊ើបអង្កេត "ប្រឆាំងបុគ្គលមួយ ឬ ច្រើនរូប ឬ ប្រឆាំងនឹងអញ្ញត្រជន"[894] និងដូចក្នុងសំណុំរឿង ០០២[895] ក្នុងករណីដីកាទាំងនោះដាក់ឈ្មោះបុគ្គលណាមួយហើយនោះ ស.ច.ស ត្រូវស៊ើបអង្កេតថាតើ បុគ្គលនោះទទួលខុសត្រូវព្រហ្មទណ្ឌលើបទឧក្រិដ្ឋដូចបានចោទប្រកាន់ដែរឬទេ[896]។ អ.ប.ជ ក៏បានបញ្ជាក់ផងដែរថា "ការកំណត់ និងព្រំដែន" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា រួមមាន អង្គហេតុពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ និងពិរុទ្ធភាពរបស់ជនត្រូវចោទ[897]។

---

[892] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៥២, ៣៥៤, ៣៥៨-៣៥៩, ៣៦៣-៣៦៥ ជើងទំព័រ ៥៧៣។

[893] *សូមមើលឧទាហរណ៍* តុលាការកំពូលបារាំង ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៨២ លេខ ៩២-៨៣.៤៦៤ ("il n'est pas contesté que les procès-verbaux d'enquête préliminaire ont été annexés au réquisitoire introductive et que le simple visa, dans ce réquisitoire, des pièces qui y étaient jointes équivaut à une analyse desdites pièces" Unofficial translation: "it is not disputed that the statements from the preliminary investigation were annexed to the introductory submission and that the simple endorsement, in this submission, of the documents which attached to them is equivalent to an analysis of the said documents" បកប្រែក្រៅផ្លូវការ៖ "គេមិនអាចជំទាស់បានឡើយថា ចម្លើយនានាដែលបានមកពីការស៊ើបអង្កេតបឋម ត្រូវបានភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយដែលនៅក្នុងដីការនេះ ការយល់សម្រេចជាធម្មតាទៅលើឯកសារទាំងឡាយដែលបានភ្ជាប់ទៅនឹងចម្លើយទាំងនោះ គឺស្មើនឹងការវិភាគទៅលើឯកសារដែលបានលើកឡើង")។

[894] វិធាន ៥៣(១)។ *សូមមើលផងដែរ* វិធាន ៥៥(៤)។

[895] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១១៤-១១៨, ១២២-១២៤។ *សូមមើលផងដែរ* កថាខណ្ឌ ៨, ៧៥-១១៣។

[896] សហព្រះរាជអាជ្ញាបានបញ្ជាក់ចំណុចនេះយ៉ាងច្បាស់ទៅកាន់ ស.ច.ស នៅក្នុងសំណុំរឿង ០០២ *សូមមើល* ឯកសារ **D98/I** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃកិច្ចស៊ើបសួរដែលបានស្នើឡើងនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។ ឯកសារ **D146/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង ដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៦។

[897] ឯកសារ **D365/2/17** សាលដីកា អ.ប.ជ ស្តីពីការទទួលស្គាល់ភ័ស្តុតាង កថាខណ្ឌ ៤៩ *យោងទៅ* វិធាន ៥៥(៣) កថាខណ្ឌ ៦០ ជើងទំព័រ ១២៦។ ឯកសារ **D274/4/5** សាលដីកាលើកទីមួយរបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ចំពោះការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥៣។

257. ម្ចាស់បណ្តឹងសាទុក្ខតវ៉ានៅក្នុងមូលដ្ឋានចំនួន ២៣ ថា ស.ច.ស មានកំហុស ដោយបានស៊ើបអង្កេត និងសម្រេចលើអង្គហេតុហួសពីបណ្តឹងអង្គហេតុនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (ប្រភេទទី ១)៖ មូលដ្ឋានទី ៣៨-៥៩ មូលដ្ឋានទី ១២៣។

## ២. វិសាលភាពនៃរឿងក្តីនេះ៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបណ្តឹងដាក់ជូនទៅ អ.ជ.ស.ដ (ប្រភេទទី ២-៣)

258. បណ្តឹងដាក់ជូនទៅ អ.ជ.ស.ដ គឺជាលទ្ធផលនៃការចេញដីកាបញ្ជូនរឿងជំនុំជម្រះដោយ ស.ច.ស ក្រោយពេលបិទកិច្ចស៊ើបសួរ ដែលអាស្រ័យលើលទ្ធផលនៃបណ្តឹងឧទ្ធរណ៍ដាក់ជូនទៅ អ.ប.ជ[898]។ ចំពោះការធ្វើមោឃភាព វិធាន ៦៧(២) តម្រូវឱ្យ ស.ច.ស ពិពណ៌នាអង្គហេតុសម្ភារដែលមានភ័ស្តុតាងគ្រប់គ្រាន់[899] និងការកំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមទាំង បទប្បញ្ញត្តិទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ និងលក្ខណៈនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[900]។ ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ធានានូវសិទ្ធិទទួលបានជូនដំណឹងរបស់ជនជាប់ចោទ អំពីលក្ខខណ្ឌ និងមូលហេតុនៃបទចោទដាក់បន្ទុកលើខ្លួន[901] ដោយពិចារណាលើសិទ្ធិរបស់ពួកគេក្នុងការរៀបចំការពារក្តី[902]។

---

[898] វិធាន ៧៩(១)។ *សូមមើលផងដែរ* វិធាន ៧៧(១៣)(ខ) ដែលត្រូវសម្រេចប្តឹងទៅ អ.ជ.ស.ដ ឱ្យទទួលយកសំណុំរឿងក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានកែប្រែដោយ អ.ប.ជ នោះទេ។

[899] វិធាន ៦៧(៣)។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៤៨៥។ សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ លើរឿងក្តី *អ៊ឹម ចែម* កថាខណ្ឌ ៦១-៦២។ អ.ប.ជ បានបង្ហាញ "ភ័ស្តុតាងគ្រប់គ្រាន់" ដើម្បីឈានទៅដល់ "ភវនីយភាព" ឬ "ភាពអាចជឿជាក់បាន" នៃពិរុទ្ធភាព ដែលជាបទដ្ឋានមានកម្រិតទាបជាងការបង្ហាញ "ឱ្យហួសពីវិមតិសង្ស័យ"។ *សូមមើលផងដែរ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

[900] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានបទប្បញ្ញត្តិមួយចែងស្រដៀងគ្នា *សូមមើល* មាត្រា ២៤៧ ("ប្រសិនបើយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ ទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់")។

[901] មាត្រា ៣៥ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ មាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៦(៣)(ក) នៃកតិកាសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៤៧, ៥០។ ឯកសារ **D97/14/15** &

259. ម្ចាស់បណ្ដឹងសាទុក្ខតវ៉ាក្នុងមូលដ្ឋានចំនួន៣ ថា ស.ច.ស មានកំហុសដោយបានសម្រេចថា មានភ័ស្ដុតាងគ្រប់គ្រាន់ចំពោះអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ប្រភេទទី ២)៖ **មូលដ្ឋានទី ៦២-៦៥។**

260. អ.ជ.ស.ជ ត្រូវកម្រិតការសម្រេចរបស់ខ្លួនចំពោះអង្គហេតុទាំងឡាយដែលបានដាក់បញ្ចូលនៅក្នុងដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ[903] ហើយមិនអាចពង្រីកបណ្ដឹងនៃការជំនុំជម្រះ ដូចបានកំណត់នោះឡើយ។ នៅ អ.វ.ត.ក អ.ជ.ស.ជ "បានទទួលសំណុំរឿងផ្អែកទៅតាមលក្ខខណ្ឌនៃភ័ស្ដុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ តាមរយៈ ស.ច.ស និង អ.ប.ជ"[904] និងពាក្យសុំលុបចោល ឬ កែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅដំណាក់កាលជំនុំជម្រះ ពុំបង្កើតជាផ្នែកមួយនៃក្របខ័ណ្ឌច្បាប់នោះឡើយ[905]។ វាអាស្រ័យលើ អ.ជ.ស.ជ ជាអ្នកកំណត់លើបណ្ដឹងដែលខ្លួនបានទទួល ហើយ ដូចបានកត់សម្គាល់ដោយ អ.ជ.ត.ក រួចហើយ ក្នុងករណីមានការភ័ន្តច្រឡំលើករណីនេះ បានកើតឡើងនៅពេលជំនុំជម្រះ ភាគីដែលមានការភាន់ច្រឡំគួរតែស្នើសុំការបញ្ជាក់បំភ្លឺ[906]។ ចំណុចនេះគឺស្របតាមសេចក្ដីណែនាំស្ដីពីការគ្រប់គ្រងការជំនុំជម្រះ ដែលចេញ

---

ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីកា អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣១-៣២។ ឯកសារ **E122** សេចក្ដីសម្រេចរបស់ អ.ជ.ស.ជ លើអញ្ញត្រកម្ម កថាខណ្ឌ ១៦។

[902] មាត្រា ៣៥ ថ្មីនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។ មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៦(៣)(ក) នៃកតិកាសញ្ញាទ្វីបអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស។ រឿងក្ដី *Pélissier និង Sassi តទល់នឹង ប្រទេសបារាំង* កថាខណ្ឌ ៥៤។ រឿងក្ដី *Sipavičius តទល់នឹង* Lithuania កថាខណ្ឌ ២៨។

[903] វិធាន ៩៨(២) ចែងថា៖ "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ")។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥១។

[904] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៥២។

[905] ឯកសារ **E122** សេចក្ដីសម្រេចរបស់ អ.ជ.ស.ជ លើអញ្ញត្រកម្ម កថាខណ្ឌ ១៦។

[906] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៣៧។ នៅក្នុងកថាខណ្ឌដដែលនេះ អ.ជ.ត.ក កត់សម្គាល់ឃើញថា ម្ចាស់បណ្ដឹងសាទុក្ខខកខានពុំបានលើកបញ្ហានេះឡើង រហូតដល់ពេលគាត់ដាក់ដីកាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់គាត់។ ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងថា អ.ជ.ស.ជ បានសម្រេចហួសពី*អង្គហេតុ*នៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងបទចោទនៅក្នុងដំណាក់កាលទីពីរនៃការផ្លាស់ទីលំនៅប្រជាជន។ អ.ជ.ត.ក កត់សម្គាល់ឃើញថា អ.ជ.ស.ជ ពុំបានពន្យល់ឱ្យបានត្រឹមត្រូវអំពីវិសាលភាពនៃដំណាក់កាលទីពីរនៃការផ្លាស់ទីលំនៅប្រជាជននោះទេ និងពុំជឿជាក់ថា ខៀវ សំផន បានទទួលបានការជូនដំណឹងឱ្យបានគ្រប់គ្រាន់អំពីវិសាលភាពនៃបទចោទទាំងនេះឡើយ។ *សូមមើលផងដែរ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦២៨។

ដោយ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២[907] ហើយច្បាប់បារាំងក៏គាំទ្រចំណុចនេះដូចគ្នា ដែលចែងថា តុលាការជំនុំជម្រះទទួលបណ្តឹងអង្គហេតុនៅក្នុងដីកាដំណោះស្រាយដោយពុំអាចកែប្របាន ក្រោយពេលចូលជាស្ថាពរ[908] ហើយត្រូវតែសម្រេចលើអង្គហេតុនីមួយៗ ទោះក្នុងករណីអង្គហេតុទាំងនោះបានដាក់បញ្ចូលដោយមានកំហុសក៏ដោយ[909]។

261. ដូច្នេះ ក្រុមប្រឹក្សា អ.វ.ត.ក ប្រមើលមើលថា រាល់បញ្ហាមុនការជំនុំជម្រះនឹងត្រូវដោះស្រាយមុនពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ចាប់ផ្តើម ក្នុងករណីអាចធ្វើទៅបាន ហើយមិនមែនអាស្រ័យលើ អ.ជ.ស.ដ បើកដំណើរការឡើងវិញនោះទេ។ នៅក្នុងដំណាក់កាលណាមួយក្នុងអំឡុងពេលស៊ើបអង្កេត *មុនពេល* ស.ច.ស ចេញដីកាដំណោះស្រាយ[910] ក្នុងករណីភាគីយល់ឃើញថាផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី ត្រូវចាត់ទុកជាមោឃៈ ភាគីអាចដាក់ពាក្យសុំឱ្យ អ.ប.ជ ពិចារណាឡើងវិញដើម្បីធ្វើមោឃភាព[911]។ ជាពិសេស នីតិវិធីមោឃភាពអាចអនុវត្តបាន ក្នុងករណីភាគីយល់ឃើញថា ស.ច.ស កំពុងស៊ើបអង្កេតនៅក្រៅវិសាលភាពនៃបណ្តឹងជាក់ស្តែង[912]

---

[907] ឯកសារ **E74** សេចក្តីណែនាំស្តីពីការរៀបចំសវនាការ ទំព័រ ២ KH 00660514 ("វាមានភាពច្បាស់លាស់ដែលថា អង្គជំនុំជម្រះត្រូវជំនុំជម្រះទៅតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះយោងទៅលើវិធាន ៦៧(២), ៧៦(៧) និងវិធាន ៨៩(១)(គ)។ នៅពេលអានវិធាននេះបញ្ចូលគ្នា គឺមិនអាចមានមូលដ្ឋានអាចឱ្យអង្គជំនុំជម្រះធ្វើការកែប្រែទៅលើដីកាដែលខ្លួនបានទទួលទេ [...]។ ប្រសិនបើមានភាពមិនច្បាស់លាស់នៅដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះនឹងពិចារណាទៅតាមករណីនីមួយៗ ដោយធ្វើការបកស្រាយអត្ថន័យនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយកាបកស្រាយនេះនឹងចងកាតព្វកិច្ចអង្គជំនុំជម្រះ")។ ឯកសារ **E1/2.1** ប្រតិចារឹកថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១១ ម៉ោង ១៤.៥៩.២៧-១៥.០៤.០១ ទំព័រ ៧៩ បន្ទាត់ ២១ ទំព័រ ៨០ បន្ទាត់ ១៨-១៩។

[908] នីតិវិធីព្រហ្មទណ្ឌ *JurisClasseur* កថាខណ្ឌ ៩៩ *យោងទៅ*សំណុំរឿងតុលាការកំពូលបារាំង ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៥៩ ព្រឹត្តិប័ត្រព្រហ្មទណ្ឌឆ្នាំ១៩៥៩ លេខ ២៥៣។

[909] តុលាការកំពូលបានសម្រេចថា ដីកាដំណោះស្រាយកំណត់អង្គហេតុដែលមិនអាចបដិសេធបាន ដល់សាលាដំបូង សូម្បីតែក្នុងករណីដែលចៅក្រមស៊ើបអង្កេតបានសម្រេចបដិសេធផ្នែកខ្លះ និងបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តី ក៏ប៉ុន្តែបានដាក់បញ្ចូលអង្គហេតុដោយភាន់ច្រឡំ ដើម្បីគាំទ្រដល់ការលែកលែងចោទប្រកាន់ផ្នែកខ្លះ។ តុលាការកំពូលបានសម្រេចថា សាលាដំបូងគួរតែសម្រេចលើអង្គហេតុដែលត្រូវដកចេញ និងមិនត្រូវប្រកាសថា ខ្លួនពុំមានសមត្ថកិច្ចនោះទេ។ *សូមមើល* សំណុំរឿងតុលាការកំពូលបារាំង ចុះថ្ងៃទី១០ ខែ មីនា ឆ្នាំ១៩៩៣ លេខ ៩០-៨៦-៨៥៤។

[910] វិធាន ៧៦(២)។

[911] វិធាន ៧៦។

[912] *សូមមើលឧទាហរណ៍* សំណុំរឿង ០០៣-ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួនសុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ។ សំណុំរឿង ០០៣-ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរ សុំឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ។ សំណុំរឿង ០០៤-ឯកសារ **D345/1/6** សេចក្តីពិចារណារបស់ អ.ប.ជ លើសំណើសុំឱ្យធ្វើមោឃភាពដីកាទាក់ទងនឹងទំនប់កង្អួត។

ប៉ុន្តែបានសម្រេចពុំអនុវត្តចំពោះវិការៈដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[913]។ បន្ទាប់មក វិធាន ៧៦ (៧) ផ្តល់លទ្ធភាពសម្រេចចុងក្រោយដោយគ្មានស្រពិចស្រពិល ចំពោះដំណាក់កាលស៊ើបសួរអង្កេតនៃកិច្ចដំណើរការនីតិវិធី។ វិធាននេះសម្រេចថា ក្រោយពេល ស.ច.ស ចេញដីកាដំណោះស្រាយ "ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុនប្រសិនបើមាន។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ"[914]។

262. ក្នុងករណីមានវិការៈលើទម្រង់នៃ*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ* នាំឱ្យមានការរំលោភបំពានវិធាន ៦៧(២) រហូតមិនអាចឱ្យ អ.ជ.ស.ដ កំណត់ខ្លឹមសារនៃបទចោទ មូលដ្ឋានអង្គហេតុ និងការកំណត់បទចោទបាននោះទេ មានន័យថា អ.ជ.ស.ដ ពុំបានទទួលដីកានេះត្រឹមត្រូវ[915]។ នៅពេលថ្លឹងថ្លែង ថាតើវិការៈមានអត្ថិភាពនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរឬទេនោះ ការវិភាគមិនគួរផ្តោតលើ "ថាតើពាក្យពេចន៍ជាក់លាក់ត្រូវបានប្រើប្រាស់ដែរឬទេ ប៉ុន្តែថាតើជនជាប់ចោទ "ត្រូវបានជូនដំណឹងអំពីលក្ខណៈនៃបទចោទ" ត្រឹមត្រូវដែរឬទេ ដើម្បីអាចឱ្យខ្លួនត្រៀមរៀបចំការពារខ្លួនប្រកបដោយប្រសិទ្ធភាព"[916]។

---

[913] *សូមមើល* សំណុំរឿង ០០៣-ឯកសារ **D158/1** សេចក្តីសម្រេចរបស់ អ.ប.ជ លើវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ កថាខណ្ឌ ១៨ *យោងទៅ* វិធាន ៧៦(២) (ដោយបញ្ជាក់ថា ពាក្យសុំឱ្យធ្វើមោឃភាពអាចមិនត្រូវបានលើកឡើង ឬសម្រេចបានទេ ក្រោយពីការចេញដីកាដំណោះស្រាយ៖ "និយាយតាមនីតិវិធី ពាក្យសុំមោឃភាព ក្រោយពេលមាដីកាដំណោះស្រាយ ពុំមានចែងក្នុងវិធានផ្ទៃក្នុងឡើយ") ហើយវិធាន ៧៦(៤) (អ.ប.ជ ពុំអាចទទួលពាក្យសុំមោឃភាពណាមួយ "ទាក់ទងនឹងដីកាមួយដែលបើកផ្លូវប្តឹងឧទ្ធរណ៍")។ ទោះជាយ៉ាងណាក៏ដោយ អ.ប.ជ បានលើកឡើងថា ខ្លួនអាចពិនិត្យឡើងវិញទៅលើដីកាដំណោះស្រាយ ប្រសិនបើមានការលើកឡើងថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹងអំពីបទចោទ ត្រូវបានដាក់ជូននៅចំពោះមុខខ្លួន *សូមមើល* ជើងទំព័រ ៣៩។

[914] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៥៦។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៨១។

[915] ឯកសារ **E122** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើអញ្ញត្រកម្ម កថាខណ្ឌ ២២។ សូមកត់សម្គាល់ផងដែរ អំពីការវិភាគដែលមាននៅក្នុងផ្នែកនេះ (វិសាលភាពនៃសំណុំរឿង៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបណ្តឹងទៅ អ.ជ.ស.ដ)។

[916] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦២៨។ នៅក្នុងកថាខណ្ឌនោះ អ.ជ.ស.ដ បានកត់សម្គាល់ថាការតវ៉ារបស់ ខៀវ សំផន មិនត្រូវបានលើកឡើងនៅចំពោះមុខ អ.ប.ជ ឡើយ និងបានសម្រេចថា អនុលោមតាមវិធាន ៦៧(២) និង ៧៦(៧) នៃវិធានផ្ទៃក្នុង "នៅពេលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវបានដោះស្រាយចប់រួចរាល់នោះ បញ្ហាពាក់ពាក់ព័ន្ធនឹងទម្រង់នៃដីកាមិនអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានឡើយ"។ *សូមមើលផងដែរ* សេចក្តីសម្រេចលើដីកាបញ្ជូន *Taylor* ទៅជំនុំជម្រះ កថាខណ្ឌ ៧៥។ សាលដីការឿងក្តី *Gacumbitsi* កថាខណ្ឌ ១៦៥ *យោងទៅ* សាលដីការឿងក្តី *Ntakirutimana* កថាខណ្ឌ ៤៧០។

## ៣. ការបកស្រាយដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ប្រភេទទី៣)

263. អ.ជ.ស.ជ មិនមានកំហុសដោយសារ "មិនអើពើ" អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងបណ្តឹងដាក់ជូនខ្លួននោះឡើយ[917]។ យោងតាមលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ៦៧(២) អង្គជំនុំជម្រះបានបញ្ជាក់ថា ជា "ទស្សនទូទៅ" អង្គជំនុំជម្រះមានកាតព្វកិច្ចកម្រិតការសន្និដ្ឋានរបស់ខ្លួនត្រឹមអង្គហេតុដែលបានដាក់បញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[918]។

264. ទាក់ទងនឹងការអនុវត្តគោលការណ៍នេះដោយ អ.ជ.ស.ជ ម្ចាស់បណ្តឹងសាទុក្ខ អះអាងថាការបកស្រាយដីកាដំណោះស្រាយជាលក្ខណៈរួម[919] ដោយ អ.ជ.ស.ជ ធ្វើឡើងមិនត្រឹមត្រូវ ដោយពុំបានដកស្រង់យុត្តិសាស្ត្រផ្លូវច្បាប់ជាមូលដ្ឋានគាំទ្រ[920]។ ជាការពិត ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខផ្ទុយដោយផ្ទាល់ជាមួយយុត្តិសាស្ត្រដែលបានបង្កើតឡើងត្រឹមត្រូវ និងអនុវត្តយ៉ាងស៊ីសង្វាក់គ្នា របស់គ្រប់អង្គជំនុំជម្រះ អ.វ.ត.ក ពោលគឺ អ.ជ.ត.ក នាពេលមុន បានតម្កល់នៅក្នុងសំណុំរឿង ០០២/០១ "ការពិចារណាយ៉ាងជិតដល់លើដីកាដំណោះស្រាយ" របស់ អ.ជ.ស.ជ[921] ហើយ អ.ប.ជ បានយល់ស្របដូចគ្នាចំពោះការបកស្រាយដីកាដំណោះស្រាយ "ជារួម"[922]។ វិធីសាស្ត្រនេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្រជាច្រើនសន្ធឹកសន្ធាប់ពីសាលាក្តីអន្តរជាតិ ដោយបានតម្កល់ថា "នៅក្នុងការវាយតម្លៃលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌនីមួយៗ មិនគួរបកស្រាយ

---

[917] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥៨។

[918] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥០-១៥១។

[919] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៣ ("ដីកាដំណោះស្រាយនឹងត្រូវបានយកមកពិនិត្យជារួមនៅពេលកំណត់បទចោទប្រកាន់ និងអង្គហេតុគាំទ្រជាមូលដ្ឋាន")។ *សូមមើលផងដែរ* កថាខណ្ឌ ៨១២, ១១៦២, ៣១៨៤, ៣៣៥៩។

[920] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៦១។

[921] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៣៥ *យោងទៅ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៥២។ នៅត្រង់ចំណុចនេះ អ.ជ.ត.ក បានច្រានចោលឡើករណ៍ទាំងនោះ ដោយលើកឡើងថា អ.ជ.ស.ជ បានទៅហួសវិសាលភាពនៃករណីរបស់ខ្លួន។ *សូមមើលផងដែរ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ជើងទំព័រ ១៦៨២, ២០៤៣ *យោងទៅ* សាលដីការឿងក្តី *Seromba* កថាខណ្ឌ ២៧, សាលដីការឿងក្តី *Gacumbitsi* កថាខណ្ឌ ១២៣ ("អង្គជំនុំជម្រះគួរតែពិចារណាទៅលើដីកាចោទប្រកាន់ទាំងមូល នៅក្នុងការសម្រេចថាតើវាមានអំណះអំណាងគ្រប់គ្រាន់ចំពោះអង្គហេតុ និងការកំណត់បទចោទតាមផ្លូវច្បាប់លើអង្គហេតុទាំងនោះដែរឬយ៉ាងទេ"។

[922] *សូមមើលឧទាហរណ៍* ឯកសារ **D427/5/10** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៣១។

ដាច់ដោយឡែក ប៉ុន្តែគួរពិចារណាក្នុងបរិបទនៃកថាខណ្ឌផ្សេងទៀតនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[923]។

265. ម្ចាស់បណ្តឹងសាទុក្ខអះអាងនៅក្នុងមូលដ្ឋានចំនួន ២០ ថា អ.ជ.ស.ដ មានកំហុស ដោយបានសម្រេចលើអង្គហេតុនៅក្រៅបណ្តឹង ដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយ (ប្រភេទទី៣)៖ **មូលដ្ឋានទី ៦០ មូលដ្ឋានទី ៦៥-៨១ មូលដ្ឋានទី ១២៤ និងមូលដ្ឋានទី ១៣៤។**

## ៤. ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ (ប្រភេទទី ៤)

266. វិសាលភាពនៃបណ្តឹងមកកាន់ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានកំណត់បន្ថែមតាមការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២។ ដូចម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើង[924] វិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានកំណត់ដោយ អ.ជ.ស.ដ នៅក្នុងសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមរបស់ អ.ជ.ស.ដ[925] និងឧបសម្ព័ន្ធពាក់ព័ន្ធ[926]។

---

[923] *សូមមើលឧទាហរណ៍* សេចក្តីសម្រេច *Ngirabatware* លើសំណើសុំការបដិសេធ កថាខណ្ឌ ២១។ សាលដីកា *Rutaganda* កថាខណ្ឌ ៣០។ យុត្តិសាស្ត្រតុលាការ*មិនអចិន្ត្រៃយ៍*ទទួលស្គាល់ថែមទៀតថា ជនជាប់ចោទអាចទទួលបាន "ការជូនដំណឹងច្បាស់លាស់ និងទាន់ពេលវេលា" អំពីបទចោទប្រឆាំងនឹងគាត់ ពីកថាខណ្ឌផ្សេងៗទៀតនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ *សូមមើល* សាលដីកា *Mrkšić & Šljivančanin* កថាខណ្ឌ ១៣៨ (ក្នុងករណីដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា មិនមានការបញ្ជាក់ច្បាស់លាស់អំពីការជួយ និងជំរុញ ដោយការធ្វេសប្រហែស នោះដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសម្ភារៈអង្គហេតុ និងសំអាងចំពោះការជួយ និងជំរុញ ដោយការធ្វេសប្រហែស ដែលបានផ្តល់ការជូនដំណឹងគ្រប់គ្រាន់។ សាលដីការឿងក្តី *Gacumbitsi* កថាខណ្ឌ ១២៣ (ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញសេចក្តីយោងទៅលើការជួយ និងជំរុញ នៅក្នុងបុព្វកថា ដោយបានពិចារណារួមគ្នាជាមួយនឹងអង្គហេតុនានាថា មានលក្ខណៈគ្រប់គ្រាន់ដល់ការជូនដំណឹង)។ សេចក្តីសម្រេចចំពោះសហឧក្រិដ្ឋកម្មរួមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៧៦ (ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា " អយ្យការបានបំពេញលក្ខខណ្ឌឆ្លើយតបយ៉ាងពេញលេញចំពោះសហឧក្រិដ្ឋកម្មរួមដូចដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយអយ្យការបានផ្តល់ព័ត៌មានលម្អិតដើម្បីជាការជូនដំនឹងដល់ជនជាប់ចោទអំពីរឿងក្តីប្រឆាំងនឹងរូបគាត់ ទោះបីជាអយ្យការមិនដែលបានប្រើឃ្លាថា "សហឧក្រិដ្ឋកម្មរួម" នេះក្តី។

[924] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៣៦។

[925] ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពនៃសំណុំរឿង ០០២/០២។

[926] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២។

267. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងនៅក្នុងមូលដ្ឋានចំនួន ៤ ថា អ.ជ.ស.ដ មានកំហុស ដោយសារ ខកខានមិនបានគោរពតាមបណ្តឹងនៅក្នុងសំណុំរឿង ០០២/០២ ដូចបានកំណត់ក្រោយ ការបំបែក កិច្ចដំណើរការនីតិវិធី៖ **មូលដ្ឋានទី ២ មូលដ្ឋានទី ៨២-៨៤។**

## គ. យុត្តាធិការ (ប្រភេទទី១-៤)

268. យុត្តាធិការសំដៅលើសិទ្ធិអំណាចស្របច្បាប់ដែលផ្តល់ដល់ស្ថាប័នណាមួយ ដើម្បីចាត់ចែង ដំណើរការស្វែងរកយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវដូចបានកំណត់។ ដើម្បីវាយតម្លៃភាព អាចទទួលយកបាននៃការតវ៉ាចំពោះយុត្តាធិការអនុលោមតាមវិធាន ៨៩(១)(ក) (អញ្ញត្រកម្ម ទាក់ទងទៅនឹងយុត្តាធិការ) នៅចំពោះមុខ អ.ជ.ស.ដ និង អ.ជ.ត.ក អ.ជ.ត.ក បានបែង ចែកយុត្តាធិការជាពីរប្រភេទ ពោលគឺ ដាច់ខាត និងនីតិវិធី[927]។

### ១. យុត្តាធិការដាច់ខាត

269. យុត្តាធិការដាច់ខាត នៅ អ.វ.ត.ក មិនអាចត្រូវបានលើកលែង និងជួសជុល នៅពេលរឿងក្តី ដំណើរការទៅមុខបាននោះទេ។ ដោយសារយកលំនាំតាមច្បាប់នីតិវិធីបារាំង អ.ជ.ត.ក បាន សម្រេចថា ការខ្វះធាតុផ្សំយុត្តាធិការដាច់ខាតគឺជាបញ្ហា ដែល "ជាការរារាំងតុលាការមិនឱ្យមាន មូលដ្ឋានផ្លូវច្បាប់ក្នុងការជំនុំជម្រះបទឧក្រិដ្ឋ"[928]។ ក្នុងករណីការខ្វះយុត្តាធិការរារាំងកិច្ចដំណើរការ នីតិវិធី*ពីដំបូង* វាគឺជាធាតុផ្សំដាច់ខាត ហើយអវត្តមានរបស់វានឹងមោឃៈកិច្ចដំណើរនីតិវិធី[929]។ ក្នុងករណីបញ្ហាស្ថិតនៅក្នុងដែនយុត្តាធិការបុគ្គល ទឹកដី ឬ ពេលវេលា របស់ អ.វ.ត.ក ឬ កិច្ច ដំណើរការនីតិវិធី ត្រូវបានរារាំងដោយការលើកលែងទោស ឬ អាជ្ញាយុកាល គឺសុទ្ធតែជាបញ្ហានៃ

---

[927] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៣១។ ការញែកចេញពីគ្នាមិនមាននៅក្នុងច្បាប់កម្ពុជាទេ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៤៤ ចែងថា៖ ("អញ្ញត្រកម្មត្រូវតែលើកឡើងមុនដំណាក់កាលការពារដល់ អង្គសេចក្តី ពុំដូច្នោះទេ ពុំអាចទទួលបានឡើយ")។ ប៉ុន្តែ ការញែកចេញពីគ្នានេះមាននៅក្នុងច្បាប់បារាំង *សូមមើល* ក្រមនីតិវិធី ព្រហ្មទណ្ឌបារាំង មាត្រា ១៧១, ៣០៥-១, ៣៨៥, ៥៨៥-១, ៥៨៥, ៥៩៥, ៨០២ ក៏ដូចជា យុត្តាធិការជាតិដទៃទៀតផងដែរ ទោះបីមានការប្រពាក្យពេជន៍ខុសគ្នា ដូចជា មោឃភាព "ពាក់ព័ន្ធ" និងមោឃភាព "ដាច់ខាត" (ប្រទេសកាណាដា *សូមមើល ឧទាហរណ៍* រឿងក្តី *Gagné*) យុត្តាធិការ "តាមលក្ខខណ្ឌ" និងយុត្តាធិការ "ដាច់ខាត" (ប្រទេសស្រីឡាំងកា *សូមមើល ឧទាហរណ៍* សាលដីកា *Colombo Apothecaries*) អញ្ញត្រកម្ម "ទូទៅ" និងអញ្ញត្រកម្ម "ពិសេស" (ស.រ.អា សូមមើល ឧទាហរណ៍ *Dillard* *តទល់នឹង* រដ្ឋ) ក៏ដោយ។

[928] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច ជើងទំព័រ ៧៨ (គូសបញ្ជាក់បន្ថែម)។

[929] សំណុំរៀង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៣១។

យុត្តាធិការដាច់ខាត[930]។ ធាតុផ្សំយុត្តាធិការដាច់ខាតមិនអាចត្រូវបានលើកលែង ហើយវិការៈទាំងឡាយមិនអាចជួសជុលបានទៅនៅពេលកិច្ចដំណើរការនីតិវិធីដំណើរការទៅមុខ[931]។

## ២. យុត្តាធិការនីតិវិធី (ប្រភេទទី ១-៤)

270. យុត្តាធិការនីតិវិធីសំដៅលើលក្ខខណ្ឌនីតិវិធី ដែលអនុញ្ញាតឱ្យតុលាការអនុវត្តអំណាចរបស់ខ្លួនរួមទាំងសិទ្ធិនីតិវិធីរបស់ជនជាប់ចោទ[932]។ ខុសពីការតវ៉ាចំពោះយុត្តាធិការដាច់ខាត យុត្តាធិការនីតិវិធីនៅ អ.វ.ត.ក អាចត្រូវបានលើកលែងនៅពេលរឿងក្តីដំណើរការទៅមុខ ដោយសារ "*ភាគីទាំងអស់បានយល់ព្រមទៅលើយុត្តាធិការរបស់តុលាការ ដោយសារវិការៈត្រូវបានបញ្ចប់តាមរយៈការប្រព្រឹត្តទៅនៃដំណើរការនីតិវិធី*"[933]។ យុត្តិសាស្ត្រក្នុងស្រុកស្របគ្នា៖ កិច្ចការពារផ្នែកនីតិវិធីរួមជាមួយនឹងការខកខានក្នុងការអនុវត្តសិទ្ធិភ្លាមៗ អាចអនុញ្ញាតឱ្យមានការលើកលែងសិទ្ធិនេះបាន[934]។ ការខកខានរបស់តុលាការក្នុងការទទួលស្គាល់ការលះបង់សិទ្ធិនីតិវិធីស្របច្បាប់ "គឺដើម្បីបម្លែងបុព្វសិទ្ធិទៅជាលក្ខខណ្ឌតម្រូវ"[935]។

---

[930] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី ឌុច កថាខណ្ឌ ៣១។ យុត្តាធិការដទៃទៀតក៏បានលើកឡើងផងដែរថា កម្មវត្ថុអំពីយុត្តាធិការ ជាធាតុផ្សំដាច់ខាត *សូមមើល ស.វ.អា តទល់នឹង* *Anderson* ទំព័រ ៦៥០ ("វាសំខាន់បំផុត នៅក្នុងច្បាប់ព្រហ្មទណ្ឌត្រង់ថា បើតុលាការណាមិនមានយុត្តាធិការលើរឿងក្តីទេ កិច្ចដំណើរការនីតិវិធីរបស់តុលាការនោះត្រូវចាត់ទុកជាមោឃៈ")។

[931] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី ឌុច កថាខណ្ឌ ៣១ *យោងទៅ*សាលដីកា *Colombo Apothecaries* ទំព័រ ៣២៦ *ក៏យោងទៅ*សាលដីកា *Perera* ទំព័រ ៣៦៦។ អ.ជ.ត.ក បានពិចារណាលើការញែកដាច់ពីគ្នារវាង យុត្តាធិការដាច់ខាត និងយុត្តាធិការតាមនីតិវិធី និងរវាងវិការៈផ្នែកយុត្តាធិការទាំងពីរប្រភេទ៖ "កង្វះយុត្តាធិការទៅលើមូលហេតុ ឬទៅលើកម្មវត្ថុ ឬទៅលើភាគី" និង "កង្វះសមត្ថកិច្ច ដោយសារតែការខកខានពុំបានអនុវត្តតាមលក្ខខណ្ឌផ្នែកនីតិវិធី ដែលជាការចាំបាច់សម្រាប់ការអនុវត្តអំណាចដោយតុលាការ"។ កង្វះយុត្តាធិការខាងលើមិនអាចជួសជុលបានឡើយ ចំណែកឯការយល់ព្រម ការលះបង់សិទ្ធិ ឬភាពអកម្មដោយសារតែភាគី អាចហាមឃាត់មិនឱ្យភាគីលើកអំពីកង្វះយុត្តាធិការខាងក្រោមបាន។

[932] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី ឌុច ជើងទំព័រ ៧៨ *យោងទៅ* សាលដីកា *Colombo Apothecaries*។ សាលដីកា *Perera* (ដែលញែកដាច់ពីគ្នានូវប្រភេទរឿងក្តីដែល "តុលាការពុំមានសមត្ថកិច្ចដោះស្រាយ ដោយសារតែពុំគោរពតាមលក្ខខណ្ឌនីតិវិធី ដែលមានសារៈសំខាន់សម្រាប់ការអនុវត្តសិទ្ធិអំណាចរបស់តុលាការ)។ *សូមមើលផងដែរ* កថាខណ្ឌ ៣១។

[933] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី ឌុច កថាខណ្ឌ ៣១។

[934] យុត្តិសាស្ត្រតុលាការជាតិលើកឡើងថា ធាតុផ្សំនីមួយៗ ត្រូវតែយកមកពិចារណានៅក្នុងបរិបទនៃសំណុំរឿង ដើម្បីសម្រេចថាតើការពុំមានធាតុផ្សំរបស់សំណុំរឿងនេះ វារំលោភលើដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់ដែរឬយ៉ាងណា និងថាតើធាតុផ្សំនេះត្រូវបានបោះបង់។ ឧទាហរណ៍ នៅក្នុងទីក្រុងគូបិក (Québec) តុលាការបានញែកចេញពីគ្នារវាងមោឃភាព "ដាច់ខាត" និង មោឃភាព "មិនដាច់ខាត"៖ ក្នុងករណី *Gagné* សាលាឧទ្ធរណ៍បានពិចារណាទៅលើម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើសទត្ថចតាច ទោះបីជាគាត់មានការជំទាស់ទៅនឹងយុត្តាធិការដែនដីនៃសាលាលហុ ដែលស្ថិតនៅក្នុង

## ៣. ការប្តឹងសាទុក្ខលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅ អ.ប.ជ (ប្រភេទទី១-២)

271. ដីកាដំណោះស្រាយបើកផ្លូវឱ្យភាគីទាំងអស់ប្តឹងឧទ្ធរណ៍[936]។ សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍លើរាល់ដីកាសម្រេចរបស់ ស.ច.ស រាប់បញ្ចូលទាំងគ្រប់ផ្នែកនៃដីកាដំណោះស្រាយរបស់

---

តំបន់មួយផ្សេងពីបទល្មើសដែលបានប្រព្រឹត្ត។ សាលាឧទ្ធរណ៍បានសម្រេចថា ចំណុចនេះប្រៀបបាននឹងមោឃភាព "មិនដាច់ខាត" "ដែលត្រូវឈ្នះ ក្នុងករណីដែលមោឃភាពពាក់ព័ន្ធនេះមិនត្រូវបានជំទាស់ នៅក្នុងពេលវេលាសមស្របនេះ [...]។ តាមពិតទៅ ប្រសិនបើគាត់បានទទួលរងព្យសនកម្ម អ្វីដែលម្ចាស់បណ្តឹងសាទុក្ខក្នុងរឿងក្តីនេះគួរធ្វើ ហើយប្រសិនបើមានអវត្តមានយុត្តាធិការពាក់ព័ន្ធក្នុងរឿងក្តីនេះ [...] គាត់គួរតែស្វែងរកការផ្លាស់ប្តូរទីកន្លែង ប្រសើរជាងការស្វែងរកព័ត៌មានដែលបានប្រកាសពីអត្ថិភាព មោឃភាព និងភាពមិនបានការទៅវិញ។ សំណើសុំការផ្លាស់ប្តូរកន្លែងមិនត្រូវដាក់ជូនតុលាការទេ ដូច្នេះ តុលាការដែលផ្តន្ទាទោសលើបទលហុ មានយុត្តាធិការជំនុំជម្រះលើព័ត៌មាននេះ ហើយសាលក្រមដែលតុលាការនេះបានចេញ ត្រូវចាត់ទុកថាមានសុពលភាព" សូមមើល កថាខណ្ឌ ១៩ នៅក្នុងករណី *Immeubles Port Louis Ltée* ទំព័រ ៣២៦-៣២៨ ដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំការធ្វើមោឃភាពតាមផ្លូវច្បាប់ ដោយសារតែម្ចាស់បណ្តឹងបានបង្ហាញពីការមិនយកចិត្តទុកដាក់ ដោយរង់ចាំអស់រយៈពេលប្រាំឆ្នាំ ទើបគាត់ធ្វើការតវ៉ា បោះទោះបីជាមានការដឹងពីច្បាប់នេះក្តី។ តុលាការកំពូលបានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង ដោយការលើកឡើងថា "ក្រៅពីករណីដែលពុំមានយុត្តាធិការទាំងស្រុង ចៅក្រមអាចបដិសេធមិនផ្តល់ ឧបាស្រ័យ ... ចៅក្រមត្រូវតែពិចារណាទៅលើកត្តាមួយចំនួន រួមទាំងចរិតលក្ខណនៃអំពើដែលនាំឱ្យកើតវិវាទ និងចរិតលក្ខណៈនៃអនីត្យានុកូលភាពដែលបានព្រឹត្តឡើង និងផលវិបាករបស់វា។ គាត់ក៏ត្រូវតែពិចារណាលើមូលហេតុនៃការអូសបន្លាយពេលវេលា ចន្លោះពីពេលមានទំនាស់ និងពេលដាក់បណ្តឹង។ ចរិតលក្ខណៈនៃសិទ្ធិដែលបានសំអាង និងឥរិយាបទរបស់ដើមបណ្តឹង គឺជាកត្តាផ្សេងទៀត"។ តុលាការនេះបានកត់សម្គាល់បន្ថែមទៀតថា កង្វះយុត្តាធិការ ការរំលោភបំពានអំណាច និងការរើសអើង គឺជាធាតុផ្សំដាច់ខាត ចំណែកឯ "ភាពមិនប្រក្រតី និងវិការៈផ្លូវការ" មិនដាច់ខាត។ *សូមមើលផងដែរ ស.រ.អា តទល់នឹង* Sorrentino (សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ត្រូវបានលះបង់)។ រឿងក្តី *Morland តទល់នឹង ស.រ.អា* (សិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័សត្រូវបានលះបង់)។ រឿងក្តី *Adams តទល់នឹង ស.រអា* (សិទ្ធិទទួលបានមេធាវីការពារក្តី ត្រូវបានលះបង់។ (សិទ្ធិទទួលបានការជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបានលះបង់)។ រឿងក្តី *Diaz តទល់នឹង ស.រ.អា* (សិទ្ធិទទួលសួរតទល់នឹងសាក្សី ត្រូវបានលះបង់)។

[935] រឿងក្តី *Patton តទល់នឹង ស.រ.អា* ទំព័រ ២៩៨។ នៅទីនោះ តុលាការកំពូលបានរកឃើញថា បទប្បញ្ញត្តិច្បាប់មួយជាក់លាក់ចំនួនផ្តល់សិទ្ធិឱ្យជនជាប់ចោទ ដែលជនជាប់ចោទអាចសម្រេចលះបង់បាន។ តុលាការបានផ្តល់យោបល់ថា ក្នុងករណីដែលសិទ្ធិមួយត្រូវបានលះបង់តាមផ្លូវច្បាប់ នោះវាមិនសមហេតុផលត្រូវទុកឱ្យតុលាការពុំមានអំណាចដើម្បីផ្តល់អានុភាពទៅលើការលះបង់សិទ្ធិនេះនោះទេ *សូមមើល* ទំព័រ ២៩៩ "តុលាការមានសិទ្ធិអំណាចក្នុងការអនុវត្តឆន្ទានុសិទ្ធិប្រកបដោយហេតុផលដើម្បីទទួលយកនូវការលះបង់សិទ្ធិនេះ និងស្របតាមហេតុផលចាំបាច់ ដើម្បីចាប់ផ្តើមដំណើរការឈានដល់ការជំនុំជម្រះ និងការសម្រេចលើរឿងក្តីនេះ"។ ដូចបានចង្អុលបង្ហាញនូវរឿងក្តីមួយពីមុនរួចមកហើយ នៅចំពោះមុខតុលាការកំពូលដូចបានលើកឡើង តុលាការកំពូលបានកត់សម្គាល់ថា "ចុងចម្លើយត្រូវយល់ដឹងពីសិទ្ធិរបស់គាត់ និងអាចទទួលបានជំនួយពីមេធាវីដើម្បីផ្តល់ប្រឹក្សាដល់គាត់ ប្រសិនបើគាត់មានបំណងចង់បាន។ មានបទប្បញ្ញត្តិជាច្រើនសម្រាប់ធានាដល់សន្តិសុខ និងផលប្រយោជន៍របស់គាត់ដែលគាត់អាចមិនប្រើប្រាស់ទាំងស្រុងតែម្តង" *សូមមើល* ទំព័រ ២១១។

[936] វិធាន ៦៧(៥), ៧៣(ក), ៧៤(២) (សហព្រះរាជអាជ្ញា), ៧៤(៣) (ជនជាប់ចោទ), ៧៤(៤) (ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍)។

សហចៅក្រមស៊ើបអង្កេត[937] ក៏ប៉ុន្តែ សិទ្ធិរបស់មេធាវីការពារក្តីក្នុងការប្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ទៅ អ.ប.ជ មានលក្ខណៈកម្រិតជាង។ ជនជាប់ចោទអាចត្រឹមតែប្តឹងឧទ្ធរណ៍លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៤(៣)(ក) បកស្រាយស្របតាមវិធាន ២១ ដែលអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ "តម្កល់យុត្តាធិការរបស់ អ.វ.ត.ក"[938]។ ដូច្នេះ អ.ប.ជ បានតម្កល់សាជាថ្មីថា ខ្លួននឹងទទួលយកការតវ៉ាដូចខាងក្រោមពីជនជាប់ចោទតែប៉ុណ្ណោះ៖ (i) យុត្តាធិការកម្មវត្ថុរបស់ អ.វ.ត.ក ដែលនាំដល់ការរំលោភគោលការណ៍នីត្យានុកូលភាព ប្រសិនបើអនុវត្ត[939] (ii) យុត្តាធិការពេលវេលា ភូមិសាស្ត្រ ឬ បុគ្គល[940] និង (iii) យុត្តាធិការរបស់ អ.វ.ត.ក ដោយផ្អែកលើគោលការណ៍គ្មានការកាត់ទោសពីរដង ការលើកលែងទោស និងការអនុគ្រោះទោស[941] មានន័យថា មានការតវ៉ា "យុត្តាធិការដាច់ខាត"[942]។

272. ការតវ៉ាដូចខាងក្រោមចំពោះដីកាដំណោះស្រាយត្រូវបានចាត់ទុកថាជាបញ្ហាក្រៅយុត្តាធិការ ដូច្នេះមិនអាចទទួលយកបាននៅចំពោះមុខ អ.ប.ជ៖ (i) លក្ខខណ្ឌកំណត់ជាក់លាក់នៃបទឧក្រិដ្ឋ និង

---

[937] វិធាន ៧៤(២)។

[938] ឯកសារ **D427/4/15** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥។ ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៤-៤៥។ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥៩-៦០។ ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីកា អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៩, ២១។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៥។

[939] ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៥-៤៦។ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦០-៦១។ ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីកា អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២៣-២៤។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧-១៣៨។

[940] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៥។ ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីកា អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២២។

[941] ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦២-៦៣, ៦៦-៦៧។

[942] *សូមមើល* ផ្នែក VI.គ. អំពីយុត្តាធិការ (ប្រភេទ ១-៤)។

ទម្រង់នៃការទទួលខុសត្រូវ[943] និងការអនុវត្តនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[944] (ii) វិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[945] រួមទាំង (iii) ការតវ៉ាដោយផ្អែកលើការចោទប្រកាន់ថា អង្គហេតុនានាដែលយកមកវិនិច្ឆ័យដោយ ស.ច.ស ពុំស្ថិតនៅក្នុងបណ្តឹងជាក់ស្តែងដាក់ជូនទៅ ស.ច.ស[946]។ នៅក្នុងសំណុំរឿង ០០២ អ.ប.ជ បានបញ្ជូនបន្តបញ្ហាទាំងនេះទៅ អ.ជ.ស.ជ ដើម្បីពិចារណាលើអង្គសេចក្តីរបស់វា[947]។

---

[943] ឯកសារ សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៥-៤៦។ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦០, ៦២។ សំណុំរឿង ០០៣-ឯកសារ **D158/1** សេចក្តីសម្រេចរបស់ អ.ប.ជ លើវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ កថាខណ្ឌ ១៦។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩។

[944] ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៥-៤៦។ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦០, ៦២។ ឯកសារ **D97/14/15** & ឯកសារ **D97/15/9** & ឯកសារ **D97/16/10** & ឯកសារ **D97/17/6** សាលដីកា អ.ប.ជ សម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២៣។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩។

[945] ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៧។ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយកថាខណ្ឌ ៦៣។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩។

[946] ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥១។ សំណុំរឿង ០០៣-ឯកសារ **D158/1** សេចក្តីសម្រេចរបស់ អ.ប.ជ លើវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ កថាខណ្ឌ ១៩។

[947] ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៧។ ឯកសារ **D427/2/15** & ឯកសារ **D427/3/15** សាលដីកា អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៣។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩។

## ឃ. ការអនុវត្តចំពោះមូលដ្ឋាន

### ១. ប្រភេទទី១÷ មូលដ្ឋានពាក់ព័ន្ធនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ ថាមិនមាននៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដូច្នេះ ស្ថិតនៅក្រៅវិសាលភាពនៃបណ្តឹងដាក់ជូនទៅ ស.ច.ស[948]

*មូលដ្ឋានទី ៣៨៖ ការអនុវត្តហួសពីវិសាលភាពនៃកិច្ចស៊ើបសួរ*[949]

273. **មូលដ្ឋានទី ៣៨ គួរតែត្រូវបានច្រានចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ ដោយពិចារណាថា ការចោទប្រកាន់របស់គាត់ដែលថា អ.ជ.ស.ដ បានទទួលមិនសមស្របលើអង្គហេតុនៅក្នុងដីកាដំណោះស្រាយដែលត្រូវបានចោទប្រកាន់ថា ស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ (អញ្ញត្រកម្មលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) ត្រូវបានរារាំងដោយសារអាជ្ញាយុកាល ក្រោមវិធាន ៨៩(១)[950]។**

274. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារការប៉ុនប៉ងរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការគេចវេសលើការកំណត់លក្ខណៈនៃអញ្ញត្រកម្ម នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ថាជាអញ្ញត្រកម្មដែលបានដាក់យឺតពេល បកស្រាយខុសវិធានផ្ទៃក្នុង និងមើលរំលងយុត្តិសាស្ត្ររបស់ អ.ជ.ត.ក។ ម្យ៉ាងវិញទៀត គាត់ខកខានមិនបាន ផ្តល់នូវមូលដ្ឋានគ្រឹះសមហេតុផលណាមួយសម្រាប់ទទួលយកនៅត្រឹមពេល ដែលគាត់បានលើកឡើងនូវអញ្ញត្រកម្មចំពោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាលើកដំបូងនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧។ ការពិត គាត់មិនបានលើកឡើងបញ្ហាទាំងនេះ នៅពេល អ.ជ.ស.ដ

---

[948] <u>មូលដ្ឋានទី ៣៨ (អង្គច្បាប់), ៣៩-៥៩, ១២៣ (ការអនុវត្ត)</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣៤-៤៣៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៨-២៥ (ភាសាអង់គ្លេស) ទំព័រ ១៦-២៣ (ភាសាបារាំង) ទំព័រ ២២-៣៥ (ភាសាខ្មែរ)។ មូលដ្ឋានទី ១២៣ ដែលលើកឡើងក្នុងសារណាបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្រៅកថាខណ្ឌទាំងឡាយនោះ គឺសំដៅចំពោះបណ្តឹង។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាក៏ឆ្លើយតបទៅតាមនោះ នៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១២៣ តែប៉ុណ្ណោះ។

[949] <u>មូលដ្ឋានទី ៣៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការអនុវត្តហួសពីវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ* កថាខណ្ឌ ៣៣៤-៣៥០ (ភាពអាចទទួលយកបាន), ១១៧, ៣៥១៣៦៦ (វិសាលភាព)។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៨ (ភាសាអង់គ្លេស) ទំព័រ ១៦ (ភាសាបារាំង) ទំព័រ ២២-២៣ (ភាសាខ្មែរ)។

[950] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៨-១៦៥។

បញ្ជាក់ថា សំណុំរឿង ០០២/០២[951] រួមមានផ្នែកនៃដីកាដំណោះស្រាយ ដែលម្ចាស់បណ្តឹងសាទុក្ខកំពុងតវ៉ា[952]។

275. អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អញ្ញត្រកម្មចំពោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមែនជាការជំទាស់យឺតពេលនោះទេ ពីព្រោះ វិធាន ៨៩ (១) "មិនមែនជាយុត្តាធិការលើអង្គហេតុឡើយ តែជាយុត្តាធិការគតិយុត្តិ *(ឬដែនសមត្ថកិច្ច)* របស់ អ.វ.ត.ក ដែលកំណត់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក"[953] ពុំសមហេតុផល ដោយសារហេតុផលចំបងចំនួនពីរ។

276. ទីមួយ នៅពេលអានក្នុងបរិបទរបស់វា ពាក្យថា "យុត្តាធិការ" នៅក្នុងវិធាន ៨៩(១)(ក) មិនត្រូវបានកំណត់ចំពោះយុត្តាធិការ "ច្បាប់" នោះទេ ហើយ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[954] មិនគួរត្រូវបានបកស្រាយតាមរបៀបដូចគ្នានឹងវិធាន ៧៤(៣)(ក) និងវិធាន ៩៨ នោះទេ[955]។ ផ្ទុយទៅវិញ អ្នករៀបចំសេចក្តីព្រាងវិធានផ្ទៃក្នុង បានបែងចែកខុសគ្នារវាង "យុត្តាធិការ*របស់ អ.វ.ត.ក*" នៅក្នុងវិធាន ៧៤(៣)(ក) និងវិធាន ៩៨ និង "ដែនសមត្ថកិច្ច*នៃ អង្គជំនុំជម្រះ*" ក្នុងលក្ខណៈទូលាយជាង នៅក្នុងវិធាន ៨៩(១)(ក)។ យុត្តិសាស្ត្រ អ.ជ.ត.ក គាំទ្រការបកស្រាយដែលបានដាក់បញ្ចូលបែបនេះ។ នៅក្នុងសំណុំរឿង ០០១ អ.ជ.ត.ក បានសម្រេចថា "ទស្សនទាននៃអញ្ញត្រកម្មចំពោះយុត្តាធិការ [អនុលោមតាមវិធាន ៨៩(១)(ក)] ត្រូវយល់ថាពាក់ព័ន្ធនឹងលក្ខណៈនៃវិការៈយុត្តាធិការ ដែលត្រូវបានតវ៉ា" និងរួមបញ្ចូលទាំងធាតុផ្សំយុត្តាធិការ

[951] *សូមមើល* ឯកសារ E301/9/1.1 ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២។ ជាឧទាហរណ៍ សហព្រះរាជអាជ្ញាកត់សម្គាល់យ៉ាងល្អិតល្អន់ថា អ.ជ.ស.ដ បានបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ដោយរាប់បញ្ចូលនូវអង្គហេតុទាំងឡាយ (i) ដែលបានកំណត់ថា ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) នៅការដ្ឋានទំនប់ត្រពាំងថ្ម (កថាខណ្ឌ ៣(៣), ៥(២)(ខ)(១៤))។ (ii) ដែលបានកំណត់ថា ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងនយោបាយ និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) នៅការដ្ឋានទំនប់ ១ មករា (កថាខណ្ឌ ៣(៤), ៥(២)(ខ)(៧), ៥(២)(ខ)(៨), ៥(២)(ខ)(១៤))។ (iii) ដែលបានកំណត់ថា ជាការធ្វើឱ្យទៅជាទាសករ និងការធ្វើទារុណកម្ម នៅមន្ទីរសន្តិសុខក្រាំងតាចាន់ (កថាខណ្ឌ ៣(៧), ៥(២)(ខ)(៣), ៥(២)(ខ)(៦))។ (iv) ដែលបានកំណត់ថា ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅមន្ទីរសន្តិសុខអូរកន្សែង (កថាខណ្ឌ ៣(៨), ៥(២)(ខ)(៩))។ (v) ទាក់ទងនឹងពុទ្ធសាសនិកនៅសហករណ៍ត្រាំកក់ (កថាខណ្ឌ ៣(១០), ៥(២)(ខ)(៨))។

[952] *សូមមើល* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៨០-៣៨៧, ៣៩៣-៣៩៦, ៤០៨-៤១១, ៤២៦។

[953] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣៦។

[954] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣៧-៣៣៨។

[955] វិធាន ៧៤(៣)(ក), ៩៨(៣), ៩៨(៧)។

"ដាច់ខាត" និង "នីតិវិធី"[956]។ ដោយសារអញ្ញត្រកម្មចំពោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជំទាស់នឹងបណ្តឹងមកកាន់ អ.ជ.ស.ដ (ហើយនៅចំពោះមុខខ្លួន ស.ច.ស) បានផ្អែកលើវិការៈដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ និងមិនមែនជាយុត្តាធិការរបស់ អ.វ.ត.ក ខ្លួនឯងទាំងនេះគឺជាការតវ៉ា "យុត្តាធិការនីតិវិធី" យ៉ាងច្បាស់ក្រឡែត។

277. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខមានកំហុសចំពោះការអះអាងរបស់គាត់ថា រយៈពេល ៣០ថ្ងៃ ក្នុងវិធាន ៨៩(១)(ក) អនុវត្តតែចំពោះការតវ៉ាយុត្តាធិការ ("ដាច់ខាត") "ផ្នែកច្បាប់"[957]។ អ.ជ.ស.ដ បានទទួលយកនិយមន័យសាមញ្ញ និងចាំបាច់នៃវិធាន ៨៩(១)៖ អញ្ញត្រកម្ម "ត្រូវលើកឡើង" ក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃ បន្ទាប់ពីដីកាដំណោះស្រាយបានចូលជាស្ថាពរ "*ការខកខានធ្វើដូច្នេះនឹងធ្វើឱ្យអញ្ញត្រកម្មមិនអាចទទួលយកបាន*"[958]។ យុត្តិសាស្ត្រ អ.ជ.ត.ក ផ្ទុយទាំងស្រុងនឹងជំហររបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយបានសម្រេចថា កាលបរិច្ឆេទរយៈពេល ៣០ *ពុំ*អនុវត្តចំពោះការតវ៉ាយុត្តាធិការដាច់ខាត ដោយសារនៅពេលបោះបង់ចោល ភាគីមិនអាចលើកឡើងអំពីយុត្តាធិការ អ.វ.ត.ក ដែល ខ្លួនមិនមាននោះទេ[959]។ ទោះបីជាយ៉ាងក៏ដោយ វា*អនុវត្ត*ចំពោះធាតុផ្សំនៃយុត្តាធិការនីតិវិធី ដែលត្រូវលើកឡើងក្នុងក្របខ័ណ្ឌពេលវេលាដែលមានចែងនៅក្នុងវិធាន ៨៩ (១) ហើយត្រូវបានជួសជុលនៅពេលកិច្ចដំណើរការនីតិវិធីដំណើរការទៅមុខ[960]។

278. ការបកស្រាយវិធាន ៨៩(១) ដើម្បីរារាំងការតវ៉ាដូចជាអញ្ញត្រកម្មចំពោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្រោយកាលបរិច្ឆេទផុតកំណត់រយៈពេល ៣០ថ្ងៃ គឺស្របជាមួយគោលបំណងនៃអញ្ញត្រកម្ម ដែលបានបញ្ជាក់ដោយ អ.ជ.ស.ដ និង អ.ជ.ត.ក ពោលគឺ បញ្ជាក់អំពីបណ្តឹងនៅមុនពេលការជំនុំជម្រះចាប់ផ្តើម និងធានាឱ្យដំណើរការមានរបៀបរៀបរយ និងមានប្រសិទ្ធិភាព[961]។ ដូចបានកត់សម្គាល់រួចមកហើយ[962] ក្របខ័ណ្ឌនៃ អ.វ.ត.ក ប្រមើលមើលឃើញថា បញ្ហាមិនអង្គសេចក្តី នឹងត្រូវដោះស្រាយមុនកិច្ចដំណើរការនីតិវិធីចាប់ផ្តើម ហើយ អ.ជ.ស.ដ នឹងមិនពិចារណា

---

[956] *សូមមើល* ផ្នែកទី VI. គ. យុត្តាធិការ (ប្រភេទ ១-៤)។

[957] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣៦។

[958] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦១។

[959] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៣១, ៣៣-៣៥ ជើងទំព័រ ៧៨។

[960] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៣១។

[961] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦១។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៨។

[962] *សូមមើល* ផ្នែកទី VI.ខ.៣. វិសាលភាពនៃសំណុំរឿង៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង*អង្គហេតុ*របស់ អ.ជ.ស.ដ។

ឡើងវិញនោះទេ ក្នុងករណីអាចធ្វើទៅបាន។ ករណីនេះរួមបញ្ចូលទាំងការពិនិត្យបញ្ចប់ជាស្ថាពរនៃដីកាដំណោះស្រាយ ដែលកំណត់បណ្ដឹងមកកាន់ អ.ជ.ស.ជ[963]។ ទោះបីជា អ.ប.ជ បានកម្រិតមូលដ្ឋានដែលជនជាប់ចោទអាចតវ៉ា ដីកាដំណោះស្រាយ ក៏ដោយ[964] និងបានបញ្ជូនការតវ៉ា ដូចជាអញ្ញត្រកម្មលើ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅ អ.ជ.ស.ជ ក៏ដោយ [965] ករណីនេះមិនដកចេញលក្ខខណ្ឌតម្រូវថា ដីកាដំណោះស្រាយត្រូវបានចេញជាស្ថាពរ មុនពេលចាប់ផ្ដើមការជំនុំជម្រះ។ ដូចគ្នាដែរ យុត្តិសាស្ត្រក្នុងស្រុកបង្ហាញថា ការត្រឹមតែតវ៉ាប្រឆាំងនឹងទម្រង់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ការតវ៉ាដែលស្នើសុំព័ត៌មានបន្ថែម ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវលើកឡើងមុនពេលធ្វើសេចក្ដីសន្និដ្ឋានលើអង្គសេចក្ដី ដែលការខកខានណាមួយ ពោលគឺសិទ្ធិជំទាស់មូលដ្ឋានទាំងនេះ នឹងត្រូវចាត់ទុកថាបានបោះបង់ចោល[966]។

---

963 វិធាន ៧៩(១)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៤៨។

964 *សូមមើល* ផ្នែកទី VI.គ.៣. ការប្ដឹងឧទ្ធរណ៍ទៅ អ.ប.ជ ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

965 ឯកសារ **D427/1/30** សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥១។

966 *ក្រមនីតិវិធីព្រហ្មទណ្ឌ JurisClasseur* កថាខណ្ឌ ៩៩ *យោងទៅ* សំណុំរឿងតុលាការកំពូលបារាំង ចុះថ្ងៃទី១៣ ខែកក្កដា ១៩៤៩៖ ព្រឹត្តិប័ត្រព្រហ្មទណ្ឌឆ្នាំ ១៩៤៩ លេខ ២៤៣។ *សូមមើលផងដែរ* តុលាការកំពូលបារាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ១៩៩៥ លេខ ៩៤-៨១.៣៩៧ ដែលអះអាងថា មោឃភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវតែបានលើកឡើងជាអញ្ញត្រកម្ម។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣២៣។ យុត្តិសាស្ត្រជាតិបញ្ជាក់អះអាងដូចគ្នាទៅនឹង អ.ជ.ត.ក ដែរ នៅក្នុងការញែកដាច់ពីគ្នារវាងធាតុផ្សំដាច់ខាត និងធាតុផ្សំផ្នែកនីតិវិធី (absolute and procedural elements)។ រឿងក្ដី *Lanier តទល់នឹង រដ្ឋ* ម្ចាស់បណ្ដឹងសាទុក្ខត្រូវបានផ្ដន្ទាទោសអំពីបទឧក្រិដ្ឋ និងបានជំទាស់តវ៉ានៅក្នុងបណ្ដឹងសាទុក្ខថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានលើកឡើងពីអង្គហេតុឱ្យបានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យគាត់អំពីបទចោទប្រកាន់មកលើរូបគាត់ទេ។ តុលាការជាន់ខ្ពស់បានញែកដាច់ពីគ្នារវាងការតវ៉ា “ពិសេស” និង “ទូទៅ” ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយលើកឡើងថា ការជំទាស់តវ៉ាពិសេស “ជំទាស់តែទៅលើទម្រង់របស់វា ឬស្វែងរកព័ត៌មានបន្ថែមប៉ុណ្ណោះ ហើយត្រូវតែបានលើកឡើងនៅមុនការជំទាស់តវ៉ាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ [...ហើយ] នឹងត្រូវបានលះបង់ ប្រសិនបើមិនបានលើកឡើងមុនការជំទាស់តវ៉ាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ” ដោយការលើកឡើងថា មុននឹងឈានដល់កំហុសណាមួយជំទាស់នឹងភាពគ្រប់គ្រាន់នៃទម្រង់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះ នោះនឹងត្រូវបានចាត់ទុកថាជាការលះបង់សិទ្ធិ។ *សូមមើលផងដែរ* រឿងក្ដី *Dillard តទល់នឹង រដ្ឋ* កថាខណ្ឌ ២។ ការញែកពីគ្នានេះត្រូវបានបញ្ជាក់យ៉ាងច្បាស់បន្ថែមទៀតនៅក្នុងរឿងក្ដី ស.រ.អា *តទល់នឹង Anderson* ដែលក្នុងរឿងក្ដីនេះ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទបដិសេធពុំព្រមចូលមកក្នុងកំណែនយោធា ស.រ.អា។ ជនជាប់ចោទបានជំទាស់នឹងដីកាបញ្ជូនរូបគាត់ទៅជំនុំជម្រះ លើមូលដ្ឋានចំនួនពីរ៖ ការខកខានរបស់ដីកានេះពុំបានបញ្ជាក់ពីអង្គហេតុឱ្យបានគ្រប់គ្រាន់ដើម្បីបង្កបានជាបទល្មើស ហើយថា តុលាការនេះពុំមានយុត្តាធិការទៅលើកម្មវត្ថុនៃបណ្ដឹងនេះទេ។ តុលាការនេះបានបដិសេធពុំពិចារណាទៅលើទឡ្ហីករណ៍ ទាក់ទងនឹងភាពគ្រប់គ្រាន់នៃអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយយល់ឃើញថា ដីកានេះមានភាពច្បាស់លាស់ហើយ ប៉ុន្តែ បានពិចារណាអំពីទឡ្ហីករណ៍លើយុត្តាធិការដាច់ខាត

279. ម្យ៉ាងវិញទៀត ម្ចាស់បណ្តឹងសាទុក្ខ ខកខានមិនបានពន្យល់អំពីរបៀបដែលបញ្ហាមុនអង្គសេចក្តីដែលត្រូវបានលើកឡើងនៅក្រៅក្របខណ្ឌអញ្ញត្រកម្ម អាចទទួលយកបាននៅចំពោះមុខ អ.ជ.ស.ដ នៅពេលលើកឡើងជាលើកដំបូងបន្ទាប់ពីការបញ្ចប់ការជំនុំជម្រះ។ គាត់ពុំបានចង្អុលយោងវិធាននីតិវិធី ឬ យុត្តិសាស្ត្រគាំទ្រការទទួលយកបាននេះ ក៏ប៉ុន្តែ បែរជាសំអាំងលើការសន្និដ្ឋានខុសនៃការកំណត់លក្ខណៈរបស់ អ.ជ.ស.ដ លើពាក្យសុំស្តីពីការនិរទេស ដែលមាននីតិវិធីដូចគ្នាទៅវិញ[967] ដែលផ្ទុយពីការអះអាងរបស់គាត់[968] អ.ជ.ស.ដ បានចាត់ទុកដូចគ្នាថាជា "អញ្ញត្រកម្ម" [969]។ ការខកខានរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការលើកឡើងនូវបណ្តឹងទាមទារទាំងនេះឱ្យបានទាន់ពេលវេលា ឆ្លុះបញ្ចាំងអំពីការខ្វះការយកចិត្តទុកដាក់របស់គាត់[970]។ ប្រព័ន្ធច្បាប់ "ពោរពេញដោយវិធានដែលតម្រូវឱ្យលើកបញ្ហានានានៅក្នុងពេលជាក់លាក់"[971]។ សាលាក្តី អន្តរជាតិផ្សេងទៀតបានរក

ដោយការធ្វើការវិភាគទៅលើអំណាចដែលបានប្រគល់ដោយកិច្ចព្រមព្រៀង (Act) ដែលដើមបណ្តឹងរងការចោទប្រកាន់ ដោយការសម្រេចថា កិច្ចព្រមព្រៀងនេះចែងយ៉ាងច្បាស់អំពីយុត្តាធិការរបស់តុលាការ ដែលពាក់ព័ន្ធនឹងការរំលោភបំពានចំនួនបីប្រភេទ ទៅនឹងតំបន់ជាក់លាក់ដែលជនស៊ីវិលបានទទួលបញ្ជាឱ្យចូលខ្លួនមកក្នុងកំណែន។

[967] ឯកសារ **E58** ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី កថាខណ្ឌ ១១។

[968] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៤៦។

[969] *សូមមើល* ឯកសារ **E306/5** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ទាក់ទងនឹងយុត្តាធិការលើការនិរទេស (ចំពោះ*អញ្ញត្រកម្ម*បឋមរបស់មេធាវីការពារក្តីទាក់ទងនឹងយុត្តាធិការ គួសបញ្ជាក់បន្ថែម)។ ការកំណត់បែបនេះ ត្រូវបានលើកឡើងមិនិយាយឡើងវិញនៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៣-១៦៤។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ (ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៤៦) ថា អ.ជ.ស.ដ បានកំណត់អញ្ញត្រកម្មនេះថាជា "សំណើសុំធ្វើមោឃភាពផ្នែកជាច្រើននៃដីកាស្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ អាស្រ័យទៅតាមវិការៈដែលធ្វើឱ្យខូចខាតដល់ដីកានេះ" ដោយយោងទៅសេចក្តីសម្រេចមួយផ្សេងរបស់ អ.ជ.ស.ដ ឯកសារ **E122** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើអញ្ញត្រកម្ម កថាខណ្ឌ ២ ដែលទាក់ទងនឹងការតវ៉ាមួយផ្សេងរបស់ អៀង សារី នៅក្នុងផ្នែកមួយផ្សេងនៃ ឯកសារ **E58** ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី ដែលទាក់ទងនឹងបទល្មើសជាតិ។

[970] ឯកសារ **E116** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ២៣។ នៅត្រង់កថាខណ្ឌនេះ អ.ជ.ស.ដ បានកត់សម្គាល់ឃើញថា ក្នុងអំឡុងពេលពីរឆ្នាំ ចន្លោះពីពេលទទួលបានសិទ្ធិចូលមើលសំណុំរឿង និងពេលលើកឡើងនូវការចោទប្រកាន់ទាក់ទងនឹងព័ត៌មាននោះ គឺបានបង្ហាញពីការខ្វះការយកចិត្តទុកដាក់។

[971] រឿងក្តី *Henderson តទល់នឹង Shinseki* ទំព័រ ៤៣៤។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣២៣។ តុលាការកំពូលបារាំង ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៣ លេខ ៩៣-៨២.១៣៣។ សាលដីកាលើរឿងក្តី *Immeubles Port Louis Ltée* ទំព័រ ៣២៨ ("អំពើដោយផ្ទាល់ចំពោះមោឃភាព ត្រូវតែយកមកបង្ហាញនៅក្នុងរយៈពេលមួយសមស្រម")។ សាលដីការឿងក្តី *Colombo Apothecaries ត្រូវបានយកមកសំអាង*នៅក្នុងសំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច ដើងទំព័រ ៧៨ ("ការសុខចិត្តលើក ឬការលះបង់សិទ្ធិមិនលើក ឬអំពើអកម្មណាមួយ នោះ [ភាគី] មិនអាចលើកឡើងនោះទេ")។

ឃើញថា ទោះបីជាមានបណ្តឹងចោទប្រកាន់អំពើទាំងនេះ មានលក្ខណៈធ្ងន់ធ្ងរដូចការប្រមាថតុលាការក៏ដោយ ក៏វាអាចត្រូវបានបដិសេធចោលដោយសារពុំបានដាក់ទាន់ពេលវេលា ក្នុងករណីភាគីណាមួយខកខានមិនបានប្តឹងករណីនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងពេលវេលាសមហេតុផលដោយគ្មានការពន្យល់គ្រប់គ្រាន់អំពីការពន្យាពេល[972]។

280. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដោយគ្មានមូលដ្ឋានដូចគ្នានេះដែរគឺថា ការខកខានរបស់ អ.ជ.ស.ដ ក្នុងការសម្រេចលើអញ្ញត្រកម្មចំពោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅក្នុងសាលក្រម បានរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជូនដំណឹងសមស្របអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងគាត់[973]។ នៅពេលគាត់ទទួលបានសិទ្ធិពិនិត្យមើលសំណុំរឿង ០០២ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧[974] ម្ចាស់បណ្តឹងសាទុក្ខ អាចតាមដានវិសាលភាពនៃការស៊ើបអង្កេតដើម្បីវាយតម្លៃថាតើ ស.ច.សស កំពុងស៊ើបអង្កេតនៅក្នុងដែនវិសាលភាពនៃបណ្តឹងដាក់ស្តែងមកកាន់ខ្លួនដែរឬទេ។ ប៉ុន្តែ គាត់មិនបានដាក់ពាក្យស្នើសុំមោឃភាពអនុលោមតាមវិធាន ៧៦(២) ចំពោះផ្នែកណាមួយនៃការស៊ើបអង្កេតនៅមុនពេលចេញដីកាដំណោះស្រាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០នោះទេ។ បន្ទាប់មក ដោយប្រឈមនឹងដីកាដំណោះស្រាយ ដែលច្បាស់លាស់ និងអនុញ្ញាតឱ្យប្តឹងអនុលោមតាមវិធាន ៦៧(២) ដែលផ្តល់ការជូនដំណឹងពេញលេញ អំពីរឿងក្តីដាក់លាក់ប្រឆាំងនឹងគាត់ និង ដោយទទួលបានអត្ថប្រយោជន៍ពីសេចក្តីសម្រេចដែលបានចេញនៅឆ្នាំ២០១៤ ដោយ អ.ជ.ស.ដ និង អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពនៃសំណុំរឿង ក៏ដូចជា ឧបសម្ព័ន្ធនៃការបំបែកកិច្ចដំណើរការនីតិវិធី ដែលបានបញ្ជាក់យ៉ាងច្បាស់អំពីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២[975] ម្ចាស់បណ្តឹងសាទុក្ខ នៅតែខកខានលើកឡើងអញ្ញត្រកម្មចំពោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវបានរៀបចំឡើង ដើម្បីកែប្រែបណ្តឹងរហូតដល់ថ្ងៃទី២

---

[972] សាលក្រមរឿងក្តី *Taylor* សម្រេចលើសំណើសុំស្តីពីការមាក់ងាយតុលាការ កថាខណ្ឌ ២៥, ២៦។

[973] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៥៩។

[974] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣ *យោងទៅ* ឯកសារ **D42** កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។

[975] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២។ ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និង វិសាលភាពនៃសំណុំរឿង ០០២/០២។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើវិសាលភាព និងការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម។

ខែឧសភាឆ្នាំ ២០១៧ បន្ទាប់ពីការជំនុំជម្រះក្តីលើសំណុំរឿង ០០២ ចំនួន ២វគ្គ ត្រូវបានបញ្ចប់ និង ដោយពុំមានយុត្តិកម្មអ្វីទាំងអស់។

## *មូលដ្ឋានទី ៣៩-៥៩*

281. **មូលដ្ឋានទី ៣៩ ដល់មូលដ្ឋានទី ៥៩ មិនទទួលបានផលទេ ដោយសារ អ.ជ.ស.ដ មានលក្ខណៈត្រឹមត្រូវ ចំពោះការសម្រេចថាត្រូវបានរារាំងដោយសារអាជ្ញាយុកាល អនុលោមតាមវិធាន ៨៩(១)។ *សម្រាប់គោលបំណងវែកញែក* ប្រសិនបើសន្មតថា អ.ជ.ស.ដ មានកំហុសនៅក្នុងការសន្និដ្ឋាននេះ មូលដ្ឋានទាំងនេះ ក៏មិនទទួលបានផលដែរ ដោយសារមូលដ្ឋានទាំងនេះ សំអាងលើការយល់មិនត្រឹមត្រូវលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការពិនិត្យឡើងវិញលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បង្ហាញថា ស.ច.ស បានទទួលយ៉ាងត្រឹមត្រូវនូវសំណុំអង្គហេតុនីមួយៗ ដែលបានលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខ។ ដូច្នេះ គាត់ត្រូវបានចោទប្រកាន់យ៉ាងត្រឹមត្រូវ ផ្អែកលើមូលដ្ឋានទាំងនេះ ហើយ អ.ជ.ស.ដ បើកលទ្ធភាពឱ្យពិចារណាអង្គហេតុទាំងនេះដើម្បីបង្ហាញឧក្រិដ្ឋកម្មពាក់ព័ន្ធ។**

### *មូលដ្ឋានទី ៣៩៖ វិសាលភាពភូមិសាស្ត្រនៃបទចោទត្រូវបានកម្រិតត្រឹមឃុំចំនួន ៨ នៅស្រុកត្រាំកក់*[976]

282. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងអំពី "ស្ថានភាពនៅក្នុងស្រុកត្រាំកក់"[977] និងបានដកស្រង់សល់ពីសម័យនោះអំពីអំពើដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានកើតឡើងនៅក្នុងស្រុកនេះ ប៉ុន្តែនៅក្រៅឃុំទាំង៨ ដែលមានឈ្មោះយ៉ាងច្បាស់[978]។ លើសពីនេះទៀត ឯកសារភ្ជាប់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជា

---

[976] <u>មូលដ្ឋានទី ៣៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *វិសាលភាពទីតាំងភូមិសាស្ត្រលើបទចោទ ត្រូវបានកម្រិតត្រឹមតែប្រាំបីឃុំនៅក្នុងស្រុកត្រាំកក់ទាំងមូល* កថាខណ្ឌ ៣៦៧-៣៦៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៨ (ភាសាអង់គ្លេស) ទំព័រ ១៦ (ភាសាបារាំង) ទំព័រ ២៣-២៤ (ភាសាខ្មែរ)។ សម្រាប់ចំនួនឃុំទាំងអស់នៅក្នុងស្រុកនេះ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៣៦។

[977] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៥៣ (គូសបញ្ជាក់បន្ថែម)។

[978] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៥៣ *យោងទៅឧទាហរណ៍* ឯកសារ **E3/2049** របាយការណ៍មានចំណងជើងថា *បញ្ជីប្រជាជនកម្ពុជាក្រោមដែលស្នាក់នៅឃុំអង្គតាសោម ស្រុកត្រាំកក់* ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ KH 00079100។ ឯកសារ **E3/2052** របាយកាណ៍ជូនទៅបក្សមូលដ្ឋានស្រុកត្រាំកក់នៃ ប.ក.ក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ ១៩៧៧ KH 00082729-30។ ឯកសារ **E3/2050** សេចក្តីរាយការណ៍ជូនអង្គការស្រុកត្រាំកក់ ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៧ KH 00079111។ ឯកសារ **E3/2044** សេចក្តីរាយការណ៍ជូនមន្ទីរអប់រំស្រុកត្រាំកក់អំពីឈ្មោះ ពៅ ផាល់ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ ១៩៧៧ KH 00079148។

ឯកសារមួយ ("ស្ថានភាពនៅក្នុងស្រុកត្រាំកក់") ដែលសង្ខេបភស្តុតាងឯកសារស្តីពីសកម្មភាព ដែលកើតឡើងនៅក្នុងស្រុកត្រាំកក់ ប៉ុន្តែនៅក្រៅឃុំទាំង ៨[979]។

## មូលដ្ឋានទី ៤០៖ គ្មានបណ្តឹងអំពីការស្លាប់ដែលកើតឡើងក្រៅពីការអត់អាហារ[980]

283. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានពិពណ៌នាអំពី "ផែនការជាប្រព័ន្ធ" ដើម្បីធ្វើបាបប្រជាជន នៃសម័យកម្ពុជាប្រជាធិបតេយ្យ ដែលរួមបញ្ចូលទាំង "ការដាក់លក្ខខណ្ឌអមនុស្សធម៌" នៅក្នុង សហករណ៍ និងការដ្ឋានការងារ[981]។ ដីកានេះក៏បានលើកឡើងបន្ថែមទៀតថា ការអនុវត្តច្បាប់ គោលនយោបាយ ប.ក.ក របស់ម្ចាស់បណ្តឹងសាទុក្ខ "នាំឱ្យស្លាប់ប្រជាជន [...]"[982] ហើយ បានផ្តល់ភស្តុតាងនៃពលកម្មដោយបង្ខំ ការធ្វើការងារហួសកម្លាំង របបអាហារ និងការថែទាំ សុខភាពមិនគ្រប់គ្រាន់ និងជំងឺ[983]។ ដីកានេះបានសង្ខេប "លក្ខខណ្ឌនៅតាមឃុំនានា" នៅក្នុង សហករណ៍ត្រាំកក់[984] ដូច្នេះ បានប្តឹង ស.ច.ស ឱ្យស៊ើបអង្កេតទៅលើមូលហេតុ និងផលវិបាក នៃលក្ខខណ្ឌទាំងនោះថាជាផ្នែកនៃ កាលៈទេសៈនៅជុំវិញឃុំទាំងនោះ។

## មូលដ្ឋានទី ៤១ ការនិរទេស[985]

284. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានប្តឹង ស.ច.ស អំពីគោលនយោបាយដែលដំបូងផ្តោត លើការ ដកជនជាតិវៀតណាមមុនពេលវិវត្តន៍ទៅជាការកំទេចបំផ្លាញ[986]។ ម្ចាស់បណ្តឹងសាទុក្ខ

---

[979] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៥៣ ដែលក្នុងនោះ *យោងទៅ* ឯកសារ **D3/I** បញ្ជីរាយឈ្មោះ ឯកសារពីតារាង ១-១០៥, តារាង ៥៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ KH 00194057-00194064 (សំដៅទៅលើឃុំ អង្គតាសោម ឃុំខ្វបត្របែក ក៏ដូចជា ស្រុកត្រាំកក់ទាំងមូលដែលជាស្រុកគំរូ "ទោះបីជាប្រជាជនរាប់ពាន់នាក់ត្រូវស្លាប់ ដោយសារអត់ឃ្លានក៏ដោយ")។

[980] <u>មូលដ្ឋានទី ៤០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពីការស្លាប់ដោយមូលហេតុផ្សេងទៀត ក្រៅពីការ អត់ឃ្លានទេ* កថាខណ្ឌ ៣៧៨-៣៧៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៨-១៩ (ភាសា អង់គ្លេស) ទំព័រ ១៦-១៧ (ភាសាបារាំង) ទំព័រ ២៤ (ភាសាខ្មែរ)។

[981] **ឯកសារ D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៩, ១៤។

[982] **ឯកសារ D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១៦។

[983] **ឯកសារ D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១៤។

[984] **ឯកសារ D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣។

[985] <u>មូលដ្ឋានទី ៤១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការនិរទេស* កថាខណ្ឌ ៣៨០-៣៨៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៩ (ភាសាអង់គ្លេស) ទំព័រ ១៧ (ភាសាបារាំង) ទំព័រ ២៤-២៥ (ភាសាខ្មែរ)។

មិនអើពើឯកសារដែលគាំទ្រ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[987] រួមទាំងចម្លើយសាក្សី ដែលពិពណ៌នាសុន្ទរកថារបស់ប៉ុលពតកាលពីខែឧសភា ឆ្នាំ១៩៧៥ "បណ្តេញជនជាតិភាគតិចវៀតណាមទាំងអស់" ដែលបង្ហាញអំពី "ចេតនារើសអើង"[988]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានគាំទ្របន្ថែមទៀត ដោយរបាយការណ៍ដែល លើកឡើងថា "ប្រសិនបើយួនគ្មានកម្លាំងពីខាងក្នុង វានឹងមិនអាចវាយយើងបាននោះទេ"[989] និងបញ្ជីគ្រួសារដែលត្រូវផ្លាស់ប្តូរជាមួយវៀតណាម[990]។ ម្យ៉ាងវិញទៀត ម្ចាស់បណ្តឹងសាទុក្ខ លើកឡើងដោយមិនត្រឹមត្រូវ[991]ថា ស.ច.ស មានកំហុស ដោយសំអាងលើសំណើជាក់លាក់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សុំស៊ើបអង្កេតលើ "អង្គហេតុជាក់លាក់នៅក្នុងកថាខណ្ឌ ៣៧-៧២ ពាក់ព័ន្ធនឹង [...] ការនិរទេស"[992]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ក.ស.ព ត្រឹមតែស្នើសុំការស៊ើបអង្កេតលើការនិរទេសតាមរយៈដំណាក់កាលចំនួនបី នៃការជម្លៀសដោយបង្ខំ គឺមិនសមហេតុផល[993] ពីព្រោះការជម្លៀសដោយបង្ខំមិនតម្រូវឱ្យឆ្លងកាត់ព្រំដែនជាតិនោះទេ ចំណែកឯការនិរទេស ទាមទារនូវលក្ខខណ្ឌនេះ[994]។

---

[986] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២(ច) (កត់សម្គាល់លើគោលនយោបាយ "រើសអើងប្រឆាំង" និង "សម្លាប់" ជនជាតិវៀតណាម មុនពេលដែលគោលនយោបាយនេះ "បានវិវត្តទៅជាគោលនយោបាយមួយ លុបបំបាត់ប្រជាជនទាំងអស់ដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម")។

[987] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៨១។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៨។

[988] ឯកសារ **D3/IV** ឧបសម្ព័ន្ធ គ៖ ឯកសារភ័ស្តុតាងដទៃទៀត។

[989] ឯកសារ **E3/807** កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និងវរៈសេនាធំឯករាជចុះថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ KH 00052304-05។

[990] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៥៣, ២៤៣ *យោងលើ*ឯកសារ **E3/4082** បញ្ជីដោះដូរអ្នកទោសនៅឃុំអង្គតាសោម KH 00068019-20។

[991] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៨៤។

[992] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៨ *យោងលើ*ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២(គ)។

[993] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៨៤។

[994] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៧១-៦៨៦។

## *មូលដ្ឋានទី ៤២ និង៤៧៖ បណ្ដឹងចំពោះអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់នៃការបាត់ខ្លួនដោយបង្ខំនៅ ទំនប់ត្រពាំងថ្ម និងទំនប់ ១ មករា*[995]

285. ក្នុងការបង្ហាញចំណុចនៃការស៊ើបអង្កេតសម្រាប់ទំនប់ត្រពាំងថ្ម [996] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងយ៉ាងច្បាស់ថា "ពួកអ្នកធ្វើការងារដោយបង្ខំជាច្រើនពាន់នាក់បានស្លាប់" រួមទាំង "មនុស្សប្រមាណច្រើនរយនាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខក្បែរនោះ"[997]។ ក្នុងចំណោមឯកសារដែលគាំទ្រ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានសាក្សីចំនួន ២ នាក់រួមទាំងអតីតចៅហ្វាយស្រុក លើកឡើងជាក់លាក់អំពីការបាត់ខ្លួនពីទំនប់ត្រពាំងថ្ម[998]។ ចំនួនបុគ្គលជាច្រើននាក់ ធ្វើការនៅទីតាំងផ្ទាល់ ហេតុការណ៍នៃការសម្លាប់ដែលគេបានដឹង និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខនីមួយៗនៅក្បែរនោះ សុទ្ធតែបានជូនដំណឹងគ្រប់គ្រាន់ថា ស.ច.ស នឹងស៊ើបអង្កេតការបាត់ខ្លួនដោយបង្ខំ ដែលកើតចេញពីប្រតិបត្តិការនៅទំនប់ត្រពាំងថ្ម។

286. ក្នុងការបង្ហាញចំណុចនៃការស៊ើបអង្កេតសម្រាប់ទំនប់ ១ មករា[999] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កត់សម្គាល់ចំនួនប្រជាជនជាច្រើននាក់ ដែលគេជឿថា បានស្លាប់នៅទីតាំងនោះ រាប់បញ្ចូលទាំងដោយការប្រហារជីវិត ក៏ដូចជា វត្តមាននៃរណ្ដៅសាកសពធំៗ នៅជុំវិញកន្លែងនោះ ដែលទាំងពីរនេះបង្ហាញថាមានបុគ្គលបាត់ខ្លួនពីទីតាំងនោះ[1000]។ លើសពីនេះទៀត ក្នុងចំណោម

[995] <u>មូលដ្ឋានទី ៤២</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ទំនប់ត្រពាំងថ្ម អំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ* កថាខណ្ឌ ៣៨៦-៣៨៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ១៩ (ភាសាអង់គ្លេស) ទំព័រ ១៧ (ភាសាបារាំង) ទំព័រ ២៥ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៤៧</u>៖ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងអំពីអង្គហេតុនៃការបាត់ខ្លួន* កថាខណ្ឌ ៣៩៦។ ឯកសារ **F54.1.1** សារណាបណ្ដឹងសាទុក្ខ ទំព័រ ២១ (ភាសាអង់គ្លេស) ទំព័រ ១៩ (ភាសាបារាំង) ទំព័រ ២៨ (ភាសាខ្មែរ)។

[996] ជាពិសេស ក្នុងការឆ្លើយតបទៅនឹង<u>មូលដ្ឋានទី ៤២</u>។

[997] **ឯកសារ D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៦។

[998] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៦ ជើងទំព័រ ១៦៩ *យោងទៅ*ឯកសារ **E3/5657** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៧ KH 00061334 ("គេហៅទៅរៀនភ្នំពេញបាត់ខ្លួនរហូត ខ្ញុំសោកស្ដាយណាស់កម្លាំង")។ *សូមមើលផងដែរ* ជើងទំព័រ ១៦៥ *យោងលើ*ឯកសារ **E3/5271** រ KH 00279079 ("ក្រោយមក គេបានចាប់ចងអ្នកទាំងនោះបោះដាក់ឡានដូចជ្រូក យកទៅសម្លាប់ចោល")។

[999] ជាពិសេស ក្នុងការឆ្លើយតបទៅនឹង<u>មូលដ្ឋានទី ៤៧</u>។

[1000] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥។

ឯកសារគាំទ្រ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចម្លើយរបស់សាក្សីចំនួន ៣ នាក់ ពិពណ៌នាលម្អិតអំពីការបាត់ខ្លួនពីទំនប់ ១ មករា[1001]។

287. លើសពីនេះទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានកត់សម្គាល់ថា៖ ប.ក.ក បានកម្មាត់ក្រុមគោលដៅ[1002] ប្រតិបត្តិការដោយសម្ងាត់[1003] ហើយឯសមាជិក អ.ជ.ត.ក អាចបញ្ជាឱ្យមានការប្រហារជីវិត តាមអំពើចិត្ត[1004] ដោយពុំបានប្រតិបត្តិការតាមប្រព័ន្ធយុត្តិធម៌ដែលដំណើរការ[1005]។ ដីកានេះលើកឡើងជាក់លាក់ទៀតថា ម្ចាស់បណ្តឹងសាទុក្ខមានសិទ្ធិអំណាចបញ្ជូនបុគ្គលទៅ "ប៉ូលីសសម្ងាត់"[1006]។ កង្វះតម្លាភាពដូចបានលើកឡើង ដំណើរការចាប់ខ្លួន និងសម្លាប់ "ខ្មាំង" និងគោលនយោបាយ បំផ្លាញអ្វីៗ ដែលគេគិតថាជាការគំរាមកំហែងដល់មនោគមវិជ្ជា ប.ក.ក[1007] គ្រប់គ្រាន់អាចផ្តល់ជាការកត់សម្គាល់ថា ស.ច.ស បានទទួលបណ្តឹងឱ្យស៊ើបអង្កេតការបាត់ខ្លួនដោយបង្ខំ នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មជាក់លាក់ ដូចបានចោទប្រកាន់នៅទីតាំងនោះ។

288. នៅទំនប់ត្រពាំងថ្ម និងទំនប់ ១ មករា ស.ច.ស បានទទួលបណ្តឹងឱ្យស៊ើបអង្កេតព្រឹត្តិការណ៍នៃការបាត់ខ្លួនដោយបង្ខំ ស្របតាមការកំណត់របស់សហព្រះរាជអាជ្ញាអំពីចរិកលក្ខណៈអង្គហេតុថាជាអំពើអមនុស្សធម៌ផ្សេងទៀត[1008]។

---

[1001] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥ ជើងទំព័រ ១៥៩, ១៦១ *យោងទៅ* ឯកសារ **E3/8303** កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ អ៊ុត សេង KH 00078623 ("បើ [ខ្មែរក្រហម] ពិនិត្យឃើញថា មានអ្នកណាខ្ជិលច្រអូស គេតែងតែមកហៅអ្នកនោះចេញពីការដ្ឋាន ដោយប្រើពាក្យថាយកទៅរៀនសូត្រ។ ចំពោះអ្នកដលគេយកទៅរៀនសូត្រនោះ មិនដែលឃើញត្រឡប់មកវិញទេ គឺគេយកទៅសម្លាប់ចោល។ [...] គឺគេយកទៅជារៀបរាល់ថ្ងៃ។ [...] ពួកគេមិនដែលឃើញត្រឡប់មកមូលដ្ឋានវិញទេ")។ *សូមមើលផងដែរឯកសារ* **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥ ជើងទំព័រ ១៦១, ១៦៣ *យោងទៅ* ឯកសារ **E3/8303** កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ វណ្ណ ថេង KH 00231632 ("ជននោះនឹងបាត់ខ្លួន និងលែងឃើញតទៅទៀត")។ ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥ ជើងទំព័រ ១៦០, ១៦១, ១៦៣ យោងទៅ ឯកសារ **E3/8303** កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ឱក ហូ KH 00231634 ("ខ្ញុំក៏បានឃើញប្រជាជនបាត់ខ្លួនជារឿងរាល់ថ្ងៃ")។

[1002] *សូមមើលឧទាហរណ៍* ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២(ក), (ខ-ឆ) ១៥។

[1003] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ២៣។

[1004] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ២៥។

[1005] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១៣។

[1006] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៩៣។

[1007] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦។

[1008] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២(គ)។

## *មូលដ្ឋានទី ៤៣៖ ការខ្វះបណ្តឹងចំពោះការប្រហារជីវិតនៅវត្តបារាយណ៍ជាន់ដែក*[1009]

289. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងជាក់លាក់អំពីវត្តបារាយណ៍ជាន់ដែកទាក់ទងទៅនឹងទំនប់ ១ មករា[1010]។ ដូចម្ចាស់បណ្តឹងសាទុក្ខអះអាងមិនត្រឹមត្រូវ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពុំបានប្តឹងចៅក្រមឱ្យស៊ើបអង្កេតតែការស្លាប់ ដែលបានកើតឡើង "នៅទីតាំងផ្ទាល់" នោះទេ[1011]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប្តឹងចៅក្រមស៊ើបអង្កេតតែលើការស្លាប់ ដែលបានកើតឡើង "ដោយសារលទ្ធផលផ្ទាល់" នៃការកើតឡើងនៅទីតាំង ដោយលើកឡើងជាក់លាក់ថា បុគ្គលទាំងនោះត្រូវបានសម្លាប់ចោល ហើយគេជឿថា សាកសពខ្លះបាន "កប់ក្នុងរណ្តៅរួមនៅម៉្តុំវត្តបារាយការណ៍ជាន់ដែក"[1012]។ យោងតាមការអាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងន័យត្រង់ វាបង្ហាញច្បាស់ថា ស.ច.ស បានទទួលបណ្តឹងឱ្យស៊ើបអង្កេតការកាប់សម្លាប់បុគ្គលដែលធ្វើការងារនៅទំនប់ ១ មករា ព្រមទាំងកាលៈទេសៈជុំវិញសាកសពនៅក្នុងផ្នូររួមនៅជិតវត្តបារាយជាន់ដែក។ ម្យ៉ាងវិញទៀត ក្នុងចំណោមឯកសារដែលគាំទ្រ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របាយការណ៍ ក.ស.ព លើកឡើងថា "នៅទំនប់ក្បែរៗនោះ មានវាលពិឃាតដែលស្ថិតខាងក្នុងបរិវេណវត្ត ដែលសាក្សីបានលើកឡើងថា មានប្រជាជនប្រហែល ២០.០០០នាក់ [...] ត្រូវបានសម្លាប់ [...]"[1013]។ ចម្លើយសាក្សីមួយច្បាប់បានបញ្ជាក់ថា "វត្តបារាយណ៍ជាន់ដែកគឺជាកន្លែងកាប់សម្លាប់"[1014]។

---

[1009] មូលដ្ឋានទី ៤៣៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពីការស្លាប់មនុស្សនៅវត្តបារាយណ៍ជាន់ដែកទេ* កថាខណ្ឌ ៣៨៨-៣៩០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ១៩-២០ (ភាសាអង់គ្លេស) ទំព័រ ១៧ (ភាសាបារាំង) ទំព័រ ២៥-២៦ (ភាសាខ្មែរ)។

[1010] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥។

[1011] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៨៩ (លើកឡើងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ "លើកឡើងតែពីការបាត់បង់ជីវិតនៅការដ្ឋាននេះ")។

[1012] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥។

[1013] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៦១, ១៦២ *ដែលយោងទៅ* ឯកសារ **E3/8303** របាយការណ៍របស់ ក.ស.ព ស្តីពីកិច្ចស៊ើបសួរនៅស្ទឹងជីនិត ខេត្តកំពង់ធំ KH 00231627-28។

[1014] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៦១ *ដែលយោងទៅ* ឯកសារ **E3/8303** កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ វណ្ណ ថេង KH 00231630។

### មូលដ្ឋានទី ទី ៤៤៖ គ្មានបណ្តឹងសម្រាប់ការស្លាប់ដោយចៃដន្យ[1015]

290. ស.ច.ស បានទទួលបណ្តឹងជាក់លាក់ឱ្យស៊ើបអង្កេតការស្លាប់នៅទំនប់ ១ មករា ដោយផ្ទាល់ ដែលបណ្តាលមកពី "ការងារហួសកម្លាំង" ដោយសារលក្ខខណ្ឌការងារ និងការរស់នៅ អមនុស្សធម៌នៅទីតាំងនោះ[1016] ក៏ដូចជាសកម្មភាពរបស់ម្ចាស់បណ្តឹងសាទុក្ខនាំដល់ការស្លាប់ពី "ការងារហួសកម្លាំង"[1017]។ ការរកឃើញរបស់ ស.ច.ស ថា លក្ខខណ្ឌនៃការងារហួសកម្លាំងនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្សស្លាប់ គឺស្ថិតនៅក្នុងប្រភេទនៃអង្គហេតុទូលំទូលាយ ទាក់ទងទៅនឹង "ការស្លាប់ដោយសារការងារហួសកម្លាំង" ដូចបានចែងនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូច្នេះ ស.ច.ស បានប្តឹងអង្គហេតុទាំងនេះទៅ អ.ជ.ស.ដ យ៉ាងត្រឹមត្រូវ[1018]។

### មូលដ្ឋានទី ៤៥៖ គ្មានបណ្តឹងសម្រាប់អង្គហេតុទាក់ទងនឹង "ការរើសអើង" ប្រឆាំងប្រជាជនថ្មី ដោយមូលហេតុនយោបាយ[1019]

291. ស.ច.ស បានទទួលគ្រប់កាលៈទេសៈនៃអង្គហេតុដែលបានចោទប្រកាន់នៅទំនប់ ១ មករា។ ដែលជួយក្នុងការកំណត់លក្ខណៈថាជាការធ្វើទុក្ខបុកម្នេញចំពោះប្រជាជនថ្មី ដោយមូលហេតុនយោបាយដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា[1020]។ ម្យ៉ាងវិញទៀត នៅពេលអាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជារួម វាបង្ហាញច្បាស់ថា ស.ច.ស បានទទួលអង្គហេតុដែលបង្ហាញថា "ប.ក.ក ធ្វើការរើសអើងជាលក្ខណៈប្រព័ន្ធ" ប្រឆាំងនឹងប្រជាជនថ្មី ដោយ "បានជំរុញយ៉ាងសកម្មនូវគំនិតដែលថា ប្រជាជនចាស់ ឬ ប្រជាជនមូលដ្ឋាន គឺប្រសើរជាងប្រជាជនថ្មី"[1021]។ "ការរើសអើងជាប្រព័ន្ធ" បណ្តាលឱ្យមានបទឧក្រិដ្ឋ "នៅសហករណ៍ និងការដ្ឋានការងារ"[1022]

---

[1015] <u>មូលដ្ឋានទី ៤៤</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពីការស្លាប់ដោយគ្រោះថ្នាក់* កថាខណ្ឌ ៣៩១-៣៩២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២០ (ភាសាអង់គ្លេស) ទំព័រ ១៧ (ភាសាបារាំង) ទំព័រ ២៦ (ភាសាខ្មែរ)។

[1016] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥។

[1017] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១៦។

[1018] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៣, ១៣៨១-៨៣, ១៣៨៧។

[1019] <u>មូលដ្ឋានទី ៤៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពីអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុនយោបាយចំពោះប្រជាជនថ្មីទេ* កថាខណ្ឌ ៣៩៣-៣៩៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២០ (ភាសាអង់គ្លេស) ទំព័រ ១៨ (ភាសាបារាំង) ទំព័រ ២៦-២៧ (ភាសាខ្មែរ)។

[1020] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២(គ)។

[1021] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២(គ)។

[1022] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១៥។

រួមទាំង ទំនប់ ១ មករា[1023]។ លើសពីនេះទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានគាំទ្រដោយទស្សនាវដ្តី ប.ក.ក ដែលពិពណ៌នាអំពីការរើសអើងជាលក្ខណៈទូទៅលើ ប្រជាជនថ្មីនៅតាមសហករណ៍ និងការដ្ឋានការងារ[1024] ព្រមទាំងចម្លើយរបស់សាក្សីដែលបង្ហាញថា ភាពខុសគ្នារវាងប្រជាជនថ្មី និង ប្រជាជនមូលដ្ឋាន ទាក់ទងទៅនឹងលក្ខខណ្ឌនៅទំនប់ ១ មករា[1025]។

***មូលដ្ឋានទី ៤៦៖ គ្មានបណ្តឹងសម្រាប់អង្គហេតុទាក់ទងនឹង "ការរើសអើង" ដោយមូលហេតុសាសនា***[1026]

292. ស.ច.ស បានទទួលគ្រប់កាលៈទេសៈទាំងអស់នៃអង្គហេតុ ដែលបានចោទប្រកាន់នៅទំនប់ ១ មករា ដែលជួយក្នុងការកំណត់លក្ខណៈជាការធ្វើទុក្ខបុកម្នេញលើជនជាតិចាម ដោយមូលហេតុសាសនា ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា[1027]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានប្តឹងទំនប់ ១ មករា ទៅ ស.ច.ស ព្រមទាំងកាលៈទេសៈជុំវិញសាកសពនៅក្នុងផ្នូររួមនៅជិតវត្តបារាយណ៍ជាន់ដែក[1028]។ ឯកសារគាំ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលដែលលើកឡើងថា ជនរងគ្រោះដែលត្រូវបានសម្លាប់នៅវត្ត

---

[1023] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥។

[1024] *សូមមើលឧទាហរណ៍* ឯកសារ **D3/I** បញ្ជីរាយឈ្មោះឯកសារពីតារាង ១-១០៥, តារាង ៩៤, ៩៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ KH 00194209, 00194217 *យោងទៅ* ឯកសារ **E3/729** *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត* ខែតុលា ឆ្នាំ១៩៧៥ KH 00063401 ("ក្នុងសភាពការស្មុគស្មាញ ដែលប្រជាជនថ្មីជាងពីរលាននាក់ ទើបចុះទៅរស់នៅជនបទ ភ្ជាក់ងារខ្មាំង និងសមាសភាពមិនល្អផ្សេងទៀត ក៏នៅលាយឡំច្របូកច្របល់នៅក្នុងជួរប្រជាជនថ្មីនេះដែរ")។ ឯកសារ **D3/I** តារាង ៩៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ KH 00194223 *ដកស្រង់* ឯកសារ **E3/725** *ទង់បដិវត្តន៍* ខែធ្នូ ឆ្នាំ១៩៧៧-ខែមករា ឆ្នាំ១៩៧៨ KH 00064545-46 (ដែលសង្កត់ធ្ងន់ឱ្យមានការប្រុងប្រយ័ត្នចំពោះសភាសភាពមិនល្អនៅតាមសហករណ៍ និងស្រុក)។

[1025] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៦០, ១៦១, ១៦៣ *ដែលយោងទៅ* ឯកសារ **E3/8303** បទសម្ភាសន៍របស់ ក.ស.ព ជាមួយ ឌិក ហូ KH 00231634 (ដែលនិយាយថា គាត់ "ជាប្រជាជនមូលដ្ឋាន" ដូច្នេះ នៅដើមឆ្នាំ ១៩៧៧ [គាត់] ត្រូវបានពួកខ្មែរឱ្យធ្វើជាប្រធានក្រុម [...] នៅការដ្ឋានសាងសង់ទំនប់ស្ទឹងជីនិត")។

[1026] <u>មូលដ្ឋានទី ៤៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពីអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុសាសនាទេ* កថាខណ្ឌ ៣៩៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២០-២១ (ភាសាអង់គ្លេស) ទំព័រ ១៨-១៩ (ភាសាបារាំង) ទំព័រ ២៧-២៨ (ភាសាខ្មែរ)។

[1027] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២(គ)។

[1028] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥។

បារាយណ៍ជាន់ដែករួមមានប្រជាជន "អ៊ីស្លាម"[1029]។ របាយការណ៍វិភាគ ដែលកត់សំគាល់ថា "ជាពិសេស គេធ្វើទុកបុកម្នេញជនជាតិមូស្លីម" ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏មានទំនាក់ទំនងជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផងដែរ[1030]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងបន្ថែមទៀតថា "ប.ក.ក បានធ្វើការរើសអើងជាលក្ខណៈប្រព័ន្ធ" ប្រឆាំងនឹងជនជាតិចាម ដោយក្នុងនោះ "ហាមពួកគេមិនឱ្យចូលរួមក្នុងសកម្មភាព ឬ ពិធីបុណ្យសាសនាអ៊ីស្លាម និងហាមមិនឱ្យពួកគេមានអត្តបទសាសនាអ៊ីស្លាមជាកម្មសិទ្ធិ"[1031]។

## *មូលដ្ឋានទី ៤៨៖ ការធ្វើឱ្យទៅជាទាសករ*[1032]

293. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បានយោងជាក់លាក់លើភស្តុតាង ដែលពិពណ៌នា អំពីហេតុការណ៍នៃពលកម្មដោយបង្ខំ ដែលអាចកើតមាននៅ ក-១៧ និងគុកភ្នំក្រោល។ ឧទាហរណ៍ សេចក្តីថ្លែងរបស់សាក្សី អ៊ួង ដុស និង ណេត សារ៉ាត គាំទ្រអង្គហេតុដែលលើកឡើងថា "គុកភ្នំក្រោល [គឺជា] អាគារមួយដែលគ្មានជញ្ជាំង និងមានដំបូប្រក់ស្បូវ"[1033] ដែលសាក្សីទាំងពីរលើកឡើងថាទទួលរងពលកម្មដោយបង្ខំនៅគុកភ្នំក្រោល និង ក-១៧។ អ៊ួង ដុស អ្នកទោសនៅគុកភ្នំក្រោល បានលើកឡើងថា "នៅពេលព្រឹក គេឱ្យយើងទៅធ្វើការទាំងដៃជាប់ចំណង"[1034]

---

[1029] ឯកសារ **D3/IV** ឧបសម្ព័ន្ធ គ៖ ឯកសារភស្តុតាងដទៃទៀត៖ KH 00271756-59 *ដកស្រង់* ឯកសារ **E3/8295** របាយការណ៍កំណត់ទីតាំងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្រុកបារាយណ៍ វត្តបារាយជាន់ដែន ឆ្នាំ១៩៧៧ ទំព័រ ៣-៤ KH 0089369-70។

[1030] ឯកសារ **D3/I** បញ្ជីរាយឈ្មោះឯកសារពីតារាង ១-១០៥ និងតារាង ៨១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ KH 00194156។

[1031] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២(ង)។

[1032] <u>មូលដ្ឋានទី ៤៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើឱ្យទៅជាទាសករ* កថាខណ្ឌ ៣៩៧-៣៩៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២១ (ភាសាអង់គ្លេស) ទំព័រ ១៩ (ភាសាបារាំង) ទំព័រ ២៨-២៩ (ភាសាខ្មែរ)។

[1033] ឯកសារ **D202** សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៨។

[1034] *សូមមើលឧទាហរណ៍* ឯកសារ **D202** សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ២០, ២១ *យោងទៅ* ឯកសារ **E3/7703** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ួង ដុស KH 00236746-48។

និង ណោត សារ៉ាត ដែលត្រូវបានឃុំខ្លួននៅ ក-១៧ ពិពណ៌នាថាត្រូវបានគេដឹកទៅកាន់ការដ្ឋានការងារនៅណាងឃីលីក[1035]។

## *មូលដ្ឋានទី ៤៩៖ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស*[1036]

294. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម លើកឡើងថា នៅចុងឆ្នាំ១៩៧៧ មនុស្សជាង ៨០នាក់ជាប់ទាក់ទងនឹងអតីតអនុលេខាឈ្មោះ ខាំ ភួន ត្រូវបានគេឡោមព័ទ្ធ ចាប់ខ្លួន និងឃុំខ្លួន នៅ ក-១១ និងមន្ទីរសន្តិសុខភ្នំក្រោល ហើយក្រោយមកត្រូវបានគេសម្លាប់ចោល[1037]។ ចំណុចនេះត្រូវបានគាំទ្រដោយចម្លើយសាក្សីដែលកត់សម្គាល់ថា ជនជាប់ឃុំនៅភ្នំក្រោលបានប្រឈម "ការសួរចម្លើយអំពីតា ខាំ ភួន" រួមជាមួយ "ការគំរាមកំហែង និងការសម្លុតកំហែងធ្ងន់ធ្ងរ"[1038]។ ដូច្នេះ ស.ច.ស បានទទួលករណីសួរចម្លើយនៅភ្នំក្រោល ដោយសារវាទាក់ទងនឹងកាលៈទេសៈជុំវិញសកម្មភាពដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

## *មូលដ្ឋានទី ៥០៖ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ*[1039]

295. ម្ចាស់បណ្តឹងសាទុក្ខអះអាងថា "មិនមានការបាត់ខ្លួនផ្សេងត្រូវបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹង ក-១១ ឬ ភ្នំក្រោល"[1040] ប៉ុន្តែ សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់គាត់បានកត់សម្គាល់ថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមស្តីពី

---

[1035] *សូមមើលឧទាហរណ៍* ឯកសារ **D202** សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ២២, ២៣ *ដែលយោងទៅ* ឯកសារ **E3/7695** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណោត សារ៉ាត KH 00236716។

[1036] <u>មូលដ្ឋានទី ៤៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្ស* កថាខណ្ឌ ៣៩៩-៤០០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២២ (ភាសាអង់គ្លេស) ទំព័រ ១៩-២០ (ភាសាបារាំង) ទំព័រ ២៩ (ភាសាខ្មែរ)។

[1037] ឯកសារ **D202** សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១០។

[1038] ឯកសារ **E3/7694** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ តួច KH 00236705-06។

[1039] <u>មូលដ្ឋានទី ៥០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួន* កថាខណ្ឌ ៤០១-៤០៣។ ឯកសារ **F54.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២២ (ភាសាអង់គ្លេស) ទំព័រ ១៩-២០ (ភាសាបារាំង) ទំព័រ ២៩ (ភាសាខ្មែរ)។

[1040] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤០១-៤០៣។

"ក-១១" ឬ "ភ្នំក្រោល""[1041]។ ជាការពិត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបានលើកឡើងអំពីការបាត់ខ្លួននៅកន្លែងទាំងនេះ[1042]។ ដូច្នេះ វាបង្ហាញច្បាស់ថា ស.ច.ស និងក្រោយមក អ.ជ.ស.ដ បានទទួលអង្គហេតុទាំងនេះ។

### *មូលដ្ឋានទី ៥១, ៥២, ៥៣, ៥៤, ៥៥៖ បណ្ដឹងចំពោះអង្គហេតុដែលបានកើតឡើងនៅក្រាំងតាចាន់*[1043]

296. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានផ្ដល់សិទ្ធិពិសេសឱ្យបើកការស៊ើបអង្កេតលើអំពើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅមន្ទីរសន្តិសុខក្រាំងតាចាន់[1044]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានប្ដឹងក្រាំងតាចាន់ទៅ ស.ច.ស[1045] ហើយម្ចាស់បណ្ដឹងសាទុក្ខមើលរំលងអង្គហេតុដែលថាខ្លួនក៏លើកឡើងផងដែរថា "មានការឃុំខ្លួនដោយខុសច្បាប់ ការបង្ខំឱ្យធ្វើការងារជាទម្ងន់ ការផ្ដល់ម្ហូបអាហារមិនគ្រប់គ្រាន់ ទុរភិក្សទ្រង់ទ្រាយធំ និងការចាប់ចងតាមទំនើងចិត្តនៅក្នុងសហករណ៍ នៅក្នុងឃុំគួស"[1046]។ ក្រាំងតាចាន់មានទីតាំងស្ថិតនៅឃុំគួស ដូច្នេះហើយដើម្បី

---

[1041] ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១៣៩៨។

[1042] ឯកសារ **D202** សេចក្ដីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៨-១១។

[1043] <u>មូលដ្ឋានទី ៥១</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងអំពីអង្គហេតុនៃការស្លាប់ដោយសារល័ក្ខខ័ណ្ឌនៃការឃុំឃាំងទេ* កថាខណ្ឌ ៤០៤-៤០៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២២ (ភាសាអង់គ្លេស) ទំព័រ ២០ (ភាសាបារាំង) ទំព័រ ២៩-៣០ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៥២</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងអំពីអង្គហេតុនៃការធ្វើឱ្យក្លាយជាទាសករទេ* កថាខណ្ឌ ៤០៨-៤០៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២២-២៣ (ភាសាអង់គ្លេស) ទំព័រ ២០ (ភាសាបារាំង) ទំព័រ ៣០ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៥៣</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងអំពីអង្គហេតុនៃការធ្វើទារុណកម្មទេ* កថាខណ្ឌ ៤១០-៤១១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ**ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២៣ (ភាសាអង់គ្លេស) ទំព័រ ២០ (ភាសាបារាំង) ទំព័រ ៣១ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៥៤</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងអំពីអង្គហេតុនៃការធ្វើបាបទេ* កថាខណ្ឌ ៤១២-៤១៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២៣ (ភាសាអង់គ្លេស) ទំព័រ ២១ (ភាសាបារាំង) ទំព័រ ៣១-៣២ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៥៥</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងអំពីអង្គហេតុនៃការបាត់ខ្លួនទេ* កថាខណ្ឌ ៤១៤-៤១៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២៣-២៤ (ភាសាអង់គ្លេស) ទំព័រ ២១ (ភាសាបារាំង) ទំព័រ ៣២ (ភាសាខ្មែរ)។

[1044] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២។

[1045] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣, ៦០។

[1046] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣។

កំណត់បណ្ដឹងមកកាន់ ស.ច.ស ពាក់ព័ន្ធនឹងក្រាំងតាចាន់ ឱ្យបានត្រឹមត្រូវនោះ អង្គហេតុពាក់ព័ន្ធនឹងក្រាំងតាចាន់គួរត្រូវបានអានរួមគ្នានឹងអង្គហេតុពាក់ព័ន្ធនឹងឃុំគូស[1047]។

297. ទាក់ទងនឹងការស្លាប់ដែលបណ្ដាលមកពីលក្ខខណ្ឌនៃការឃុំខ្លួន[1048] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបញ្ជាក់យ៉ាងច្បាស់ថា ប្រជាជនថ្មីត្រូវបានគេសម្លាប់នៅក្រាំងតាចាន់[1049] ដូចបានទទួលស្គាល់ដោយម្ចាស់បណ្ដឹងសាទុក្ខ[1050]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបញ្ជាក់បន្ថែមទៀតថា ការឃុំឃាំងដោយខុសច្បាប់បានកើតឡើង "នៅឃុំគូស" ដោយរៀបរាប់លម្អិតអំពីលក្ខខណ្ឌទុកឱ្យមនុស្សរាប់ពាន់នាក់ "អត់អាហាររហូតដល់ [ស្លាប់]"[1051]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានកត់សម្គាល់ថា កំណាយនៅក្រាំងតាចាន់បានរកឃើញសាកសពមនុស្សប្រមាណ ២.០០០ នាក់នៅសេសសល់[1052] និងប្រមាណ ១០.០០០ នាក់ទៀតទំនងអាចវត្តមាននៅទីតាំងនោះ[1053] ហើយបានដកស្រង់របាយការណ៍ពីប្រធានក្រាំងតាចាន់ ផ្ញើជូនបក្ស ដោយ បានកត់សម្គាល់ឃើញថាមានប្រជាជនដែល "បានស្លាប់ដោយសារជំងឺ" នៅក្រាំងតាចាន់ជារៀងរាល់ខែ[1054]។

298. ទាក់ទងនឹងការដាក់ឱ្យទៅជាទាសករ[1055] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានអនុញ្ញាតឱ្យ ស.ច.ស. ស៊ើបអង្កេតឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ និងរួមបញ្ចូលអង្គហេតុដើម្បីគាំទ្រដល់ធាតុផ្សំចាំបាច់ ពោលគឺ ការចង្អុលបង្ហាញអំពីភាពជាម្ចាស់ ការគ្រប់គ្រងបរិយាកាសរូបវន្ត ការគំរាមកំហែង និងការរងការធ្វើបាប និងការបំពានយ៉ាងសាហាវ ហើយផ្ទុយការអះអាងរបស់

---

[1047] តាមពិតទៅ អ.ជ.ស.ដ បានប្រើប្រាស់វិធីសាស្ត្រនេះ នៅពេលធ្វើការបកស្រាយលើវិសាលភាពនៃដីកាដំណោះស្រាយទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១២។

[1048] ជាពិសេស ការឆ្លើយតបទៅនឹងមូលដ្ឋានទី ៥១។

[1049] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣។

[1050] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៤០៥។

[1051] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣។

[1052] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០។

[1053] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០។

[1054] *សូមមើលឧទាហរណ៍* ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០ ជើងទំព័រ ២៤៣ *យោងទៅ* ឯកសារ **E3/2109** សេចក្ដីរាយការណ៍អំពីអ្នកទោសក្នុងដំណាច់ខែវិច្ឆិកា ឆ្នាំ១៩៧៧ ERN 00068014-16។ ឯកសារ **E3/4086** សេចក្ដីរាយការណ៍ជូនស.ម អ៊ុំ គិត ស្រុកត្រាំកក់ និងបញ្ជីអ្នកទោសខែកក្កដា ឆ្នាំ KH 00068017។

[1055] ជាពិសេស ការឆ្លើយតបទៅនឹងមូលដ្ឋានទី ៥២។

ម្ចាស់បណ្តឹងសាទុក្ខ ពលកម្មដោយបង្ខំនៅក្រាំងតាចាន់[1056]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងថា "ការឃុំខ្លួនដោយខុសច្បាប់" "ការចាប់ខ្លួនតាមអំពើចិត្ត" និង "ពលកម្មដោយបង្ខំ" បានកើតឡើងនៅក្នុងឃុំគូស[1057] ហើយសំអាងលើ ភ័ស្តុតាងដែលបង្ហាញថា សាកសពត្រូវបានកប់នៅក្នុងរណ្តៅ និង "ផ្នូររួម"[1058]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបន្ថែមទៀតថា ប.ក.ក បានបង្ហាញនូវកម្មសិទ្ធិពេញលេញលើអ្នកជាប់ឃុំនៅក្រាំងតាចាន់តាមរយៈការប្រើទារុណកម្ម និង ការគំរាមកំហែងលើការបាត់ខ្លួន[1059]។

299. ទាក់ទងនឹងការធ្វើទារុណកម្ម[1060] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានស្នើសុំជាក់លាក់ឱ្យស៊ើបអង្កេតលើការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្រាំងតាចាន់[1061]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងយ៉ាងជាក់លាក់ថា អ្នកជាប់ឃុំនៅក្រាំងតាចាន់ ត្រូវបាន "គេដាក់ខ្នោះគ្រប់ពេល"[1062] ហើយ ត្រូវបានគាំទ្រដោយសក្ខីកម្មសាក្សីដែលបានលើកឡើងថា "អ្នកទោសត្រូវបានដាក់ឱ្យដេកជាពីរជួរ និងដាក់ខ្នោះជើងអ្នកទោសជួរទីមួយទល់នឹងគ្នាជាមួយជើងអ្នកទោសជួរទីពីរ"[1063]។ ម្ចាស់បណ្តឹងសាទុក្ខ មើលរំលងភ័ស្តុតាងបន្ថែមដែលគាំទ្រ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រួមមានរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យផ្ញើមកពីលេខាស្រុកទៅប្រធានក្រាំងតាចាន់ បង្គាប់បញ្ជាឱ្យ "សួរ

[1056] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៥២-១៥៤។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច កថាខណ្ឌ ៣៤២។ សំណុំរឿង ០០២ **ឯកសារ D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩២។ សាលក្រម *Kunarac* កថាខណ្ឌ ១១៦-១១៧។ សាលក្រម *Sesay* កថាខណ្ឌ ១៩៧-១៩៩។ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៧(២)(គ)។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ធាតុផ្សំនៃបទល្មើស មាត្រា ៧(១)(គ) ធាតុផ្សំទី ១។

[1057] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣។

[1058] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០ ជើងទំព័រ ២៩៤ *យោងទៅឧទាហរណ៍* ឯកសារ **E3/2063** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *អំពីគំនូសផែនទីអំពីវាលពិឃាតនៃប្រទេសកម្ពុជា* KH 01353565-01353567។ វាសមហេតុផលហើយក្នុងការសន្មតថា រណ្តៅទាំងនេះត្រូវបានអ្នកទោសជីកក្នុងរបបការងារដោយបង្ខំ។

[1059] *សូមមើល* កថាខណ្ឌនានាខាងលើ និងខាងក្រោម នៅក្នុងចម្លើយតបនេះទៅនឹងមូលដ្ឋានទី ៥១, ៥២, ៥៣, ៥៤, ៥៥ (បណ្តឹងស្តីពីអង្គហេតុដែលកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់)។

[1060] ជាពិសេស ការឆ្លើយតបទៅនឹង<u>មូលដ្ឋានទី ៥៣</u>។

[1061] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២។

[1062] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០។

[1063] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០ ជើងទំព័រ ២៩៧ *យោងទៅ* ឯកសារ **E3/2063** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *គំអំពីគំនូសផែនទីអំពីវាលពិឃាតនៃប្រទេសកម្ពុជា* KH 01353564។

ចម្លើយដោយប្រញាប់ប្រញាល់"[1064] និង "បន្ទាប់មក កំទេចពួកគេចោល"[1065] ព្រមទាំងចម្លើយសាក្សី ដែលពិពណ៌នាអំពើទារុណកម្មធ្ងន់ធ្ងរ ដែលបានកើតឡើងនៅក្រាំងតាចាន់[1066]។ ភ័ស្តុតាងបន្ថែមរួមមានចម្លើយសាក្សីដែលពិពណ៌នាមនុស្ស "ស្រែកឱ្យជួយ និងស្រែកថ្ងូរ"[1067] និង មនុស្សត្រូវបានគេវាយ និងបោកនឹងដើមឈើ[1068]។

300. ទាក់ទងទៅនឹងការធ្វើបាប[1069] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានចោទប្រកាន់ថា "អំពើអមនុស្សធម៌ផ្សេងទៀត" ត្រូវបានប្រព្រឹត្តឡើងដោយផ្អែកលើកថាខណ្ឌ ៣៧-៧២[1070]។ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើនឹងភ័ស្តុតាងពាក់ព័ន្ធ ដែលសំអាងលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1071] រួមទាំងភ័ស្តុតាងនៃការធ្វើទារុណកម្ម និងការធ្វើបាបនៅក្រាំងតាចាន់ ដូចបានកត់សម្គាល់ខាងលើ។ លើសពីនេះទៀត នៅក្នុងការយោងទៅលើក្រាំងតាចាន់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបញ្ជាក់យ៉ាងច្បាស់ថា អ្នកជាប់ឃុំ ត្រូវបានគេវាយរហូតដល់ស្លាប់[1072] ហើយអ្នកសួរចម្លើយ និងអ្នកយាម "បានបានសម្លាប់មនុស្សរហូតដល់ ១២,០០០នាក់" ដោយបានប្រហារជីវិតជា

[1064] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០ ជើងទំព័រ ២៤៣ *យោងទៅ* ឯកសារ **E3/2052** របាយកាណ៍ជូនទៅបក្សមូលដ្ឋានស្រុកត្រាំកក់នៃ ប.ក.ក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៧ KH 00082729។

[1065] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០ ជើងទំព័រ ២៤៣ *យោងទៅ* ឯកសារ E3/2012 សេចក្តីរាយការណ៍ពី គិត ជូនទៅ អាន់ KH 00082727។

[1066] ឯកសារ **D3/IV** ឧបសម្ព័ន្ធ គ៖ ឯកសារភ័ស្តុតាងផ្សេងទៀត៖ KH 00271766 *យោងទៅ* ឯកសារ **E3/7483** កិច្ចសំភាសន៍ជាមួយ ស.ម មាន់ សេង KH 00032861 ("គេសួរចម្លើយ ៣ថ្ងៃគេសួរម្តងក្នុងម្តងគេវៃសន្លប់ពីរដង")។

[1067] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០ ជើងទំព័រ ២៤៧ *យោងទៅ* ឯកសារ **E3/2063** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *អំពីគំនូសផែនទីអំពីវាលពិឃាតនៃប្រទេសកម្ពុជា* KH 01353564។

[1068] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០ ជើងទំព័រ ៤៦ *យោងទៅ* ឯកសារ **E3/2063** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ *អំពីគំនូសផែនទីអំពីវាលពិឃាតនៃប្រទេសកម្ពុជា* KH 01353565-01353567។

[1069] ការឆ្លើយតបពិសេសតបទៅនឹងមូលដ្ឋានទី ៥៤។

[1070] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២(គ)។

[1071] *សូមមើលឧទាហរណ៍* ឯកសារ **D3/IV** ឧបសម្ព័ន្ធ គ៖ ឯកសារភ័ស្តុតាងផ្សេងទៀត៖ KH 00032861-00271766 *យោងទៅ* ឯកសារ **E3/7483** កិច្ចសំភាសន៍ជាមួយ ស.ម មាន់ សេង KH 00032862។

[1072] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០។

ទៀងទាត់[1073]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងលម្អិតបន្ថែមអំពីសកម្មភាព ដែលកំពុងកើតឡើងនៅទូទាំងឃុំគួស[1074]។

301. ទាក់ទងនឹងការបាត់ខ្លួន[1075] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងថា ការឃុំខ្លួនដោយខុសច្បាប់ និងការចាប់ខ្លួនតាមអំពើចិត្ត បានកើតឡើងនៅឃុំគួស ហើយខ្មាំងត្រូវបានចាប់ខ្លួន និងសម្លាប់ចោល រួមទាំង ប្រជាជនថ្មី ជាច្រើននាក់ ដែលត្រូវបានបញ្ជូនទៅក្រាំងតាចាន់[1076]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងថាកំណាយនៅក្រាំងតាចាន់ បានរកឃើញសាកសពអ្នកជាប់ឃុំប្រមាណ ២.០០០ នាក់ ជាមួយនឹងលទ្ធភាព ដែលអាចមាន "មនុស្ស ១០.០០០ នាក់ទៀត" នៅក្នុង "ផ្នូររួម"[1077]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានគាំទ្របន្ថែមទៀតដោយភស្តុតាងរបស់សាក្សីមួយចំនួន ដែលបានលើកឡើងថា ប្រជាជននឹងត្រូវបានអញ្ជើញឱ្យ "ហូបស៊ុប" ហើយមិនដែលឃើញវិលត្រឡប់មកវិញនោះទេ ដោយទុកឱ្យក្រុមគ្រួសាររបស់ពួកគេគ្មានព័ត៌មានអំពីកន្លែងដែលពួកគេត្រូវបានគេយកចេញទៅ[1078]។

### *មូលដ្ឋានទី ៥៦៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍*[1079]

302. ស.ច.ស បានទទួលបណ្ដឹងអំពីគ្រប់កាលៈទេសៈទាំងអស់នៃអង្គហេតុដែលត្រូវបានចោទប្រកាន់នៅអូរកន្សែង ដែលជួយនៅក្នុងការកំណត់ចរិកលក្ខណៈថាជាការធ្វើទុក្ខបុកម្នេញលើជនជាតិ

---

[1073] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០។

[1074] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣ ("មានការឃុំខ្លួនដោយខុសច្បាប់ ការបង្ខំឱ្យធ្វើការជាទម្ងន់ ការផ្ដល់ម្ហូបអាហារមិនគ្រប់គ្រាន់ ទុរ្ភិក្សទ្រង់ទ្រាយធំ")។

[1075] ការឆ្លើយតបពិសេសតបទៅនឹងមូលដ្ឋានទី ៥៥។

[1076] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣។

[1077] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦០។

[1078] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣ ជើងទំព័រ ១៥៤ *យោងទៅ* **ឯកសារ D3/I** បញ្ជីរាយឈ្មោះឯកសារពីតារាង ១-១០៥, តារាង ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ KH 00194065 *ដែលយោងទៅ* ឯកសារ **E3/7507** បទសម្ភាសន៍អ្នកស្រី ប៉ូល សុខុម ដោយលោក គ្រេក អេតឈសុន KH 00702056- 00702063។ ឯកសារ **E3/7536** សម្ភាសន៍លោកតា តាំ ដោយលោក គ្រេក អេតឈសុន KH 00283091-00283093។ ឯកសារ **E3/7557** សម្ភាសន៍លោក ឈឿង ផុន ដោយលោក គ្រេក អេតឈសុន KH 00651241- 00651242។

[1079] មូលដ្ឋានទី ៥៦៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍* កថាខណ្ឌ ៤១៦-៤១៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២៤ (ភាសាអង់គ្លេស) ទំព័រ ២១ (ភាសាបារាំង) ទំព័រ ៣២-៣៣ (ភាសាខ្មែរ)។

វៀតណាមដោយមូលហេតុពូជសាសន៍ ដូចបានស្នើឡើងដោយសហព្រះរាជអាជ្ញា[1080]។ ម្ចាស់បណ្តឹងសាទុក្ខ ទទួលស្គាល់ថា ស.ច.ស បានទទួលបណ្តឹងឱ្យស៊ើបអង្កេតការប្រហារជីវិតនៅអូរកន្សែង ហើយបានរកឃើញថាមានជនជាតិវៀតណាមនៅក្នុងចំណោមអ្នកដែលត្រូវបានសម្លាប់[1081]។ លើសពីនេះទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបញ្ជូនឱ្យ ស.ច.ស នូវអង្គហេតុដែលថា "ប.ក.ក បានរើសអើងជាប្រព័ន្ធប្រឆាំងក្រុមគោលដៅរួមទាំង [...] និងសម្លាប់ជនជាតិភាគតិចវៀតណាម" និង "បានបន្តធ្វើនយោបាយរើសអើងប្រឆាំង និងសម្លាប់ជនជាតិភាគតិចវៀតណាម"[1082]។ នាពេលនេះ ម្ចាស់បណ្តឹងសាទុក្ខ អះអាងដោយភាន់ច្រឡំថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចាំបាច់ឱ្យ ស.ច.ស ពិចារណាលើការធ្វើទុក្ខបុកម្នេញ[1083]។

## *មូលដ្ឋានទី ៥៧៖ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស*[1084]

303. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងថា នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ មនុស្សចំនួន ២.០០០នាក់ត្រូវបានសម្លាប់នៅអូរកន្សែង អ្នកខ្លះដោយសារការអត់អាហារ និងខ្លះទៀតត្រូវបានគេប្រហារជីវិត[1085]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានគាំទ្រដោយរបាយការណ៍របស់ DC-Cam ដែលដកស្រង់សំដីរបស់អតីតអ្នកទោសម្នាក់ ដែលបានថ្លែងថា អ្នកទោសត្រូវបានគេផ្តល់អាហារតិចតួច បង្ខំឱ្យដេកគ្មានខោអាវ ដោយជើងជាប់ខ្នោះឈើវែងមួយ ប្រសិនបើពួកគេទៅចូលរួមការប្រជុំបំពាក់បំប៉នយឺត ពួកគេនឹងទទួល "រងទារុណកម្មធ្ងន់ធ្ងរ ដូចជាវាយនឹងស្វាយកាំភ្លើងជាដើម"[1086]។ របាយការណ៍បញ្ជាក់បន្ថែមសំខាន់ទៀតថា អ្នកទោសឈឺ ដែលមិន

---

[1080] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២(គ)។

[1081] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤១៧។

[1082] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២(ច)។

[1083] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤១៧។

[1084] <u>មូលដ្ឋានទី ៥៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស* កថាខណ្ឌ ៤១៨-៤១៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៤ (ភាសាអង់គ្លេស) ទំព័រ ២១-២២ (ភាសាបារាំង) ទំព័រ ៣៣ (ភាសាខ្មែរ)។

[1085] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦៧។

[1086] **ឯកសារ D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ២៧៩, ២៨០ *យោងទៅ* ឯកសារ **E3/2628** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណងជើងថា៖ "*គម្រោងផែនទីខេត្តរតនគិរី* KH 00323342-00323344។

អាចធ្វើការបាន ត្រូវគេចងយកទៅសម្លាប់ចោល[1087] ដូច្នេះបង្ហាញថា មិនមានការព្យាបាលវេជ្ជសាស្ត្រណាមួយត្រូវបានផ្តល់ជូននោះឡើយ។

## *មូលដ្ឋានទី ៥៨៖ ការបោសសម្អាត*[1088]

304. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[1089] ស.ច.ស ពុំត្រូវបានកម្រិតត្រឹមតែការពិចារណាទៅលើការបោសសម្អាតពីរវគ្គនោះទេ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបញ្ជាក់យ៉ាងច្បាស់ថា ម្ចាស់បណ្តឹងសាទុក្ខ "បានបញ្ជា ញុះញង់ និងជំរុញឱ្យមានការបោសសម្អាត និងការប្រហារជីវិតជាទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ដែលជាដំណើរការមួយ "បានបោសសំអាតទូទាំងប្រទេសចាប់តាំងពីឆ្នាំ១៩៧៥ តទៅ"[1090]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យសួរ មានចំណុចយោងជាច្រើនទាក់ទងនឹងការបោសសំអាតផ្ទៃក្នុង ឬ សកម្មភាពដូចការបោសសំអាត[1091] ហើយត្រូវបានគាំទ្រដោយឯកសារ ដែលយោងទៅលើការបោសសំអាតនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ នៅទូទាំងប្រទេស[1092]។ មានទំនាក់ទំនងខុសគ្នារវាងការបោសសំអាត និងការប្រើប្រាស់

---

[1087] **ឯកសារ D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ២៧៩, ២៨០ *ដែលយោងទៅ* ឯកសារ **E3/2628** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណងជើងថា៖ "*គម្រោងផែនទីខេត្តរតនគិរី* " KH 00323351-00323352។

[1088] <u>មូលដ្ឋានទី ៥៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការបោសសម្អាត* កថាខណ្ឌ ៤២០-៤២២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៤ (ភាសាអង់គ្លេស) ទំព័រ ២២ (ភាសាបារាំង) ទំព័រ ៣៣-៣៤ (ភាសាខ្មែរ)។

[1089] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤២០-៤២២។ អ.ជ.ស.ជ បានពិចារណា និងបានបដិសេធការអះអាងនេះ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥ ជើងទំព័រ ៣៦២។

[1090] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៩៧(ឃ)។

[1091] *សូមមើល* ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៣៦ (ការបញ្ជូន "ខ្មាំង" ទាំងនោះមកមន្ទីរសន្តិសុខ ស-២១) កថាខណ្ឌ ៦៤ (ប្រជាជនដែលត្រូវបានគេសន្មត់ថាខ្មាំង ត្រូវបានចាប់ខ្លួន រួចហើយត្រូវបានសម្លាប់ចោលនៅកមន្ទីរសន្តិសុខភ្នំក្រោល នៅចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩) កថាខណ្ឌ ៩៧(ឃ)(១) (មន្ទីរ ៨៧០ មានអំណាចបោសសម្អាតខ្លួនឯងផង មន្ទីរនានា និងប្រជាជនទូទៅផង) កថាខណ្ឌ ៩៧(ឃ)(២) (រៀបរាប់ពីកម្មាភិបាលជាន់ខ្ពស់ និងមានឥទ្ធិពលរបស់ ប.ក.ក ដែលត្រូវបានបោសសម្អាតទូទាំងរបបនេះ)។

[1092] *សូមមើលឧទាហរណ៍* ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៧៩ ជើងទំព័រ ៤៥៥ (យោងទៅលើការបោសសម្អាតដែលកើតឡើងក្នុងភូមិភាគបូព៌ា និងក្នុងតំបន់ស្វ័យត ៥០៥), ៤៥៨ (លើកឡើងពីការបោសសម្អាតទៅលើមន្ទីរ ៨៧០ នៅក្នុងខែតុលា ឆ្នាំ១៩៧៧ និងបន្តរហូតដល់ខែកុម្ភៈ ឬមីនា ឆ្នាំ១៩៧៨)។ កថាខណ្ឌ ៧១ ជើងទំព័រ ២៩៥ *យោងទៅ* ឯកសារ **D3/I** បញ្ជីរាយឈ្មោះឯកសារពីតារាង ១-១០៥, តារាង ៧៤-៧៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ KH 00194146-48 (រៀបរាប់ពីការបោសសម្អាតដែលកើតឡើងក្នុងឆ្នាំ១៩៧៧)។ ជើងទំព័រ ៣៤២ (លើកឡើងជាពិសេសថា ក្នុងឆ្នាំ

យ៉ាងទូលំទូលាយនៃការធ្វើទារុណកម្ម និងអំពើហឹង្សាលើរាងកាយនៅមន្ទីរសន្តិសុខ វាជាផ្នែកមួយនៃប្រព័ន្ធកាប់ សម្លាប់ដែល "ជាលទ្ធផល មានការកើតឡើងនូវការសម្លាប់ជាបន្តបន្ទាប់"[1093]។ វាបង្ហាញច្បាស់ថា ស.ច.ស បានទទួលបណ្តឹងឱ្យស៊ើបអង្កេតការបោសសំអាតរីករាលដាល ផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងឯកសារគាំទ្ររបស់ខ្លួន និងដើម្បីបញ្ជូនអង្គហេតុទាំងនេះទៅ អ.ជ.ស.ដ[1094]។

## *មូលដ្ឋានទី ៥៩៖ គ្មានបណ្តឹងសម្រាប់អង្គហេតុប្រឆាំងនឹងពុទ្ធសាសិកជននៅត្រាំកក់*[1095]

305. អ.ជ.ត.ក បានបញ្ជាក់រួចហើយនូវបណ្តឹងមកកាន់ អ.ជ.ស.ដ ពាក់ព័ន្ធនឹង ការប្រព្រឹត្តលើពុទ្ធសាសនិកជន នៅសហករណ៍ត្រាំកក់[1096]។ លើសពីនេះ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងការយោងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អំពី "លក្ខខណ្ឌនានានៅស្រុកត្រាំកក់រួមទាំង [...] ការធ្វើបាប"[1097] និងតារាង ៥៩ ("លក្ខខណ្ឌនៅក្នុងស្រុកត្រាំកក់") ដែលរួមមានចម្លើយ

---

១៩៧៧ ការរៀបចំបង្កើតតំបន់ ១០៣ ឡើងវិញត្រូវបានប្រកាសឡើង ដូច្នេះ នាំឱ្យការបង្កើតភូមិភាគឧត្តរ និងការចាប់ផ្តើមបោសសម្អាតក្នុងពេលតែមួយទៅលើថ្នាក់ដឹកនាំស្រុក និងតំបន់)។

[1093] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១៥។

[1094] ដោយសារ អ.ជ.ស.ដ បានទទួលអង្គហេតុទាំងនេះយ៉ាងត្រឹមត្រូវ នោះការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសនៅក្នុងសម្រេចលើវិសាលភាពនៃបោសសម្អាត (តាមរយៈសំណើជាបន្ទាន់របស់គាត់សុំឱ្យបញ្ជាក់អំពី*អង្គហេតុ សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤២២) គឺមិនសមហេតុសមផល និងពុំបានស្នើសុំឱ្យមានការធ្វើអន្តរាគមន៍ពី អ.ជ.ត.ក នោះទេ។ លើសពីនេះទៀត ការអះអាងជាបន្តបន្ទាប់របស់ម្ចាស់បណ្តឹងសាទុក្ខ (*សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤២៣-៤២៥) ដែលបានសំអាងទាំងស្រុងទៅលើការលើកឡើងដោយមិនត្រឹមត្រូវរបស់គាត់ថា អ.ជ.ស.ដ ពុំបានទទួលបណ្តឹងលើអង្គហេតុនេះឱ្យបានត្រឹមត្រូវទេ។ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខបង្ហាញកំហុសជាច្រើន ទាក់ទងនឹងការដឹងឮរបស់គាត់ចំពោះការបោសសម្អាត នោះការអះអាងទាំងនោះពុំមានមូលដ្ឋានអ្វីឡើយ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១៦, ២១៧, ២៣៥ (ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងនៃការបោសសម្អាតផ្ទៃក្នុង និងនៅតាមមន្ទីរសន្តិសុខនានា ព្រមទាំងនៅតាមទីតាំងសម្លាប់មនុស្សនានា) (ជាពិសេស មូលដ្ឋានទី ២១៦, ២១៧)។

[1095] <u>មូលដ្ឋានទី ៥៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពីអង្គហេតុប្រឆាំងនឹងពុទ្ធសាសនិក នៅត្រាំកក់ទេ* កថាខណ្ឌ ៤២៦-៤៣៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៥ (ភាសាអង់គ្លេស) ទំព័រ ២២ (ភាសាបារាំង) ទំព័រ ៣៤ (ភាសាខ្មែរ)។

[1096] ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើវិសាលភាព និងការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម កថាខណ្ឌ ៩, ៩១។ *សូមមើលផងដែរ*ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និង វិសាលភាពនៃសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨។ ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២។

[1097] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៥៣។

របស់អតីតព្រះសង្ឃដែលកត់សម្គាល់អំពីការហាមឃាត់ការប្រតិបត្តិព្រះពុទ្ធសាសនា និង ការផ្សឹកព្រះសង្ឃពុទ្ធសាសនានៅក្នុងស្រុកនេះ[1098]។ ដូច្នេះ វាមិនពាក់ព័ន្ធទេថា សហករណ៍ត្រាំកក់ មិនត្រូវបានលើកឡើងច្បាស់នៅក្នុងកថាខណ្ឌ ៧២ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលពិភាក្សាអំពីគោលនយោបាយរបស់ ប.ក.ក នៅទូទាំងប្រទេស ដើម្បីលុបបំបាត់ចោលពុទ្ធសាសនា[1099]។ ប្រសិនបើពាក់ព័ន្ធ អង្គហេតុខាងលើបង្ហាញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានផ្តល់បញ្ជីបើកចំហរ និងមិនមែនជា "សំណាកគំរូ"[1100] នៃទីតាំងនៅពេលគោលនយោបាយនេះត្រូវបានអនុវត្ត "នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ *រួមទាំង* [...]"[1101]។

## ២. ប្រភេទទី២÷ មូលដ្ឋានទាក់ទងនឹងអង្គហេតុនានា ដែលចោទប្រកាន់ថាពុំមានការគាំទ្រដោយភស្តុតាង គ្រប់គ្រាន់សម្រាប់ដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1102]

### *មូលដ្ឋានទី ៦១៖ បទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ*[1103]

306. មូលដ្ឋានទី ៦១ គួរតែត្រូវបានច្រានចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខដើម្បីបង្ហាញថា អ.ជ.ស.ដ "មិនអើពើ" ដោយគ្មានយុត្តិកម្មចំពោះអំណះអំណាងរបស់គាត់ថា អ.ជ.ស.ដ ពុំបានទទួលបណ្តឹងអង្គហេតុជាក់លាក់ ពីព្រោះបទដ្ឋាននៃការបង្ហាញភស្តុតាងសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំត្រូវបានបំពេញនៅក្នុងដីកាដំណោះស្រាយ[1104]។

---

[1098] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជើងទំព័រ ១៥៣ ដែលក្នុងនោះ *យោងទៅ*ឯកសារ **D3/I** បញ្ជីរាយឈ្មោះឯកសារពីតារាង ១-១០៥, តារាង ៥៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ KH 00194057-64 *ដែលយោងលើ* ឯកសារ **E3/7557** បទសម្ភាសន៍របស់ ក.ស.ព ជាមួយ ឈឿន ផុន KH 00651237-00651238។

[1099] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤២៧-៤២៨។

[1100] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤២៩។

[1101] គូសបញ្ជាក់បន្ថែម។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤២៩-៤៣៣។

[1102] <u>មូលដ្ឋានទី ៦១ (អង្គច្បាប់) និង ៦២-៦៤ (ការអនុវត្ត)</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *បទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ* កថាខណ្ឌ ៤៣៩-៤៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៥-២៧ (ភាសាអង់គ្លេស) ទំព័រ ២៣-២៤ (ភាសាបារាំង) ទំព័រ ៣៥-៣៧ (ភាសាខ្មែរ)។

[1103] <u>មូលដ្ឋានទី ៦១៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *បទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ – អង្គច្បាប់* កថាខណ្ឌ ៤៤០-៤៤៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៥ (ភាសាអង់គ្លេស) ទំព័រ ២៣ (ភាសាបារាំង) ទំព័រ ៣៥ (ភាសាខ្មែរ)។

[1104] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៤០-៤៤៤ *យោងទៅ* ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ៩២៤-៩៣១, ៩៤២-៩៤៨, ៩៦៨-៩៦៩ (សហករណ៍ត្រាំកក់),

307. ជាបញ្ហាបឋម សហព្រះរាជអាជ្ញាកត់សំគាល់ថា អ.ជ.ស.ដ ប្រហែលជាយល់ច្រឡំចំពោះ អំណះអំណាង ដែលបានបង្ហាញនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយសារភាពមិនត្រឹមត្រូវនៃការបកប្រែភាសាអង់គ្លេសលើពាក្យ ភ័ស្តុតាងដាក់បន្ទុកដែលមានលក្ខណៈគ្រប់គ្រាន់ "Charges Suffisantes"[1105] ក្នុងអត្ថន័យ នៃ វិធាន ៦៧(៣)។ នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល ម្ចាស់បណ្តឹងសាទុក្ខបានតវ៉ាចំពោះអត្ថិភាពនៃ "ភ័ស្តុតាងដាក់បន្ទុកដែលមានលក្ខណៈគ្រប់គ្រាន់" (ភ័ស្តុតាងគ្រប់គ្រាន់) ទាក់ទងនឹងអង្គហេតុជាក់លាក់[1106]។ ទោះជាយ៉ាងណា សារណាជាភាសាអង់គ្លេសបានយោងស៊ីសង្វាក់គ្នាជាមួយភាពមិនគ្រប់គ្រាន់នៃ "បទចោទ" ផ្ទុយពីភ័ស្តុតាងនៃអង្គហេតុ។ នៅក្នុងសាលក្រមរបស់ខ្លួន អ.ជ.ស.ដ បានសង្ខេបសេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខជាការតវ៉ាលើ "បទចោទ" ដែល ស.ច.ស ខកខានមិនបាន "ប្រមូលអង្គហេតុដែលអាចគាំទ្រ" និងសំណើសុំ "មោឃភាពផ្នែកខ្លះនៃដីដំណោះស្រាយពាក់ព័ន្ធនឹងបទចោទមិនត្រូវបង្ហាញភ័ស្តុតាងគ្រប់គ្រាន់"[1107]។ អ.ជ.ស.ដ បាន

---

១០២២-១០២៨ (ទំនប់ត្រពាំងថ្ម), ១០៩៦-១១០៥ (ព្រលានយន្តហោះកំពង់ឆ្នាំង), ១២៥៤-១២៧១ (ក្រាំងតាចាន់), ២២៦៥-២២៦៧, ២២៨៣-២២៨៧, ២២៨-២២៨៩, ២៣០៦ (អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ)។

[1105] ពាក្យពេចន៍ជាច្រើននៅក្នុងច្បាប់នីតិវិធីបារាំង និង អ.វ.ត.ក ត្រូវបានបកប្រែថា បទចោទ "charges" ជាភាសាអង់គ្លេស។ ស.ច.ស បានធ្វើការកត់សម្គាល់ទៅលើភាពមិនច្បាស់លាស់នេះនៅក្នុងនៅក្នុងសំណៅជាភាសាអង់គ្លេសនៃវិធានផ្ទៃក្នុង (សំណុំរឿង ០០១-ឯកសារ **D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបំភ្លឺអំពីបទ កថាខណ្ឌ ៨ លើកឡើងថា "អង្គហេតុដែលចោទប្រកាន់ 'faits reprochés'" (វិធាន ៦៧(២), *៨៩ស្ទួន*) "ភ័ស្តុតាងដាក់បន្ទុកដែលមានលក្ខណៈគ្រប់គ្រាន់ 'charges suffisantes'" (វិធាន ៦៧(៣), ឬ "ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ (*ជាពិសេស សូមមើល* វិធាន ៥៥(៤), ៥៧ ដែលមានការលំបាកក្នុងការបកប្រែទៅជាភាសាអង់គ្លេស ដោយសារតែមិនមានសញ្ញាណដូចគ្នានៅក្នុងប្រព័ន្ធ Common Law"។ លើសពីនេះទៀត បទចោទដែលបានរៀបរាប់នៅក្នុង "សេចក្តីសម្រេចបញ្ចប់នៃដីកាដំណោះស្រាយ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១៣។ *សូមមើលផងដែរ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥, ១៥៤០ (សហឧក្រិដ្ឋកម្មរួម), ១៥៤៥ (ការរៀបចំផែនការ), ១៥៤៨ (ការញុះញង់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម) ១៥៥១ (ការជួយ និងជំរុញ), ១៥៥៤ (ការបញ្ជា), ១៥៥៩ (ការទទួលខុសត្រូវរបស់ថ្នាក់លើ) កំណត់អំពីឧក្រិដ្ឋកម្មដែលម្ចាស់បណ្តឹងសាទុក្ខទទួលខុសត្រូវ។ ក្នុងន័យនេះហើយ ដែលសាលក្រមកំណត់នៅក្នុង "សេចក្តីសង្ខេបអំពីបទចោទប្រឆាំងនឹងជនជាប់ចោទ" ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤-១៦។ នៅក្នុងសាលក្រមជាភាសាបារាំង។ ក្នុងសំណៅសាលក្រមជាភាសាបារាំង ឃ្លានេះសរសេរថា "Résumé des accusations contre les Accués"។ អ.ជ.ត.ក បានពន្យល់ពីមុនរួចមកហើយចំពោះការចែកដាច់ពីគ្នារវាង "បទចោទ" និង អង្គហេតុ៖ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើវិសាលភាព និងការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម កថាខណ្ឌ ១៨។

[1106] ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ២៩៤-២៩៩។

[1107] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៩។

ច្រានចោលសំណើររបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយហេតុថាខ្លួន "មិនច្បាស់ទេថា តើម្ចាស់បណ្តឹងសាទុក្ខយោងទៅបទចោទដែលមានកង្វះចន្លោះណាមួយឱ្យប្រាកដ"[1108]។

308. ក្នុងករណីណាក៏ដោយ មូលដ្ឋាននេះមិនទទួលបានផលទេ ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់ដែលត្រូវបានចោទប្រកាន់ដោយសារមូលហេតុសំខាន់ពីរ។ ទី១ ម្ចាស់ បណ្តឹងសាទុក្ខបានជំទាស់ជាសាថ្មីចំពោះយុត្តាធិការរបស់ អ.ជ.ស.ដ ក្នុងការកាត់សេចក្តីអង្គហេតុដោយផ្អែកលើការចោទប្រកាន់អំពីវិការៈនៅក្នុងដីកាដំណោះស្រាយដែលស្រពិចស្រពិល និងដែលអាចប្តឹងអនុលោមតាមវិធាន ៦៧(២)។ ទោះបីជាកំហុសដែលត្រូវបានចោទប្រកាន់ទាំងនេះ បង្ហាញច្បាស់ចំពោះម្ចាស់បណ្តឹងសាទុក្ខ នៅពេលដីកាដំណោះស្រាយបានចេញ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ គាត់ពុំបានផ្តល់ហេតុផលសមស្របចំពោះការខកខានក្នុងការលើកឡើងកំហុសទាំងនេះក្នុងរយៈពេលកំណត់ ៣០ ថ្ងៃ យោងតាមវិធាន ៨៩(១)។ ដូច្នេះ វាត្រូវបានរារាំងដោយអាជ្ញាយុកាលក្រោយពេលវេលាផុតកំណត់[1109]។

309. លើសពីនេះទៀត អ.ជ.ស.ដ បានពិនិត្យឡើងវិញនូវសេចក្តីសន្និដ្ឋានទាំងនោះទាក់ទងនឹងរាល់ករណីនៃការចោទប្រកាន់អំពីភ័ស្តុតាងមិនគ្រប់គ្រាន់[1110]។ ក្នុងករណីនីមួយៗ អ.ជ.ស.ដ បាន

---

[1108] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០។

[1109] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៨។

[1110] **<u>សហករណ៍ត្រាំកក់</u>** (i) ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ៩២៤-៩៣១ ត្រូវបានលើកឡើងក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១១, ១១៣៩។ (ii) ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ៩៤២-៩៤៨ ត្រូវបានលើកឡើងក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១៣, ១១៦៩-១១៧១។ (iii) ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ៩៦៨-៩៦៩ ត្រូវបានចាត់ទុកជាឥតបានការដោយឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៣៩-១១៤០, ១១៤៦។ **<u>ត្រពាំងថ្ម</u>** (i) ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ១០២២-១០២៨ (យោងទៅ កថាខណ្ឌ ១០០៩-១០១៦) ត្រូវបានលើកឡើងក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៥២, ១៤០៥។ **<u>ព្រលានយន្តហោះកំពង់ឆ្នាំង</u>** (i) ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ១០៩០-១១០៥ ត្រូវបានចាត់ទុកជាឥតបានការដោយឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៩៤-១៧៩៨។ **<u>ក្រាំងតាចាន់</u>** (i) ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ១២៥៤-១២៧១ ត្រូវបានលើកឡើងក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៣៩-២៨៤៣។ **<u>អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ</u>** (i) ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ២២៨៣-២២៨៧ (*ដោយដាក់បញ្ចូល* កថាខណ្ឌ ២២៦៤-២២៦៧) ត្រូវបានលើកឡើងក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១២, ១១៦៩-

ពិនិត្យមើលថាតើអង្គហេតុត្រូវបានបង្ហាញ "ហួសពីវិមតិសង្ស័យ" ដែរឬទេ អនុលោមតាមវិធាន ៨៧(១) និងមិនត្រឹមតែពិនិត្យមើលថាតើមាន "ភ័ស្តុតាងគ្រប់គ្រាន់ចំពោះបទចោទ" ដែលជាលក្ខខណ្ឌទាមទារចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៦៧ (៣) ដែរឬទេនោះឡើយ[1111]។ នៅក្នុងករណីទាំងពីរនេះ ការពិនិត្យឡើងវិញរបស់ អ.ជ.ស.ជ ចំពោះភ័ស្តុតាងដែលមាននៅក្នុងពេលជំនុំជម្រះ នាំឱ្យមានការសម្រេចឱ្យរួចផុតពីបទចោទ ដែលធ្វើឱ្យបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខលែងចាំបាច់ទៀតហើយ ពាក់ព័ន្ធនឹងការជំទាស់តវ៉ាងទាំងនោះ[1112]។

## *មូលដ្ឋានទី ៦២-៦៤*

310. **អ.ជ.ស.ជ ពុំតម្រូវឱ្យសម្រេចលើមូលដ្ឋានទី ៦២-៦៤ ឡើយ ដោយសារវាត្រូវបានរារាំងដោយអាជ្ញាយុកាលអនុលោមតាមវិធាន ៨៩(១)។ *សម្រាប់គោលបំណងវែកញែក* សន្មតថា អ.ជ.ត.ក សម្រេចលើអង្គសេចក្តីនៃមូលដ្ឋានទាំងនេះ ការពិនិត្យឡើងវិញលើដីកាដំណោះស្រាយបង្ហាញថា ស.ច.ស បានបំពេញលក្ខខណ្ឌបទដ្ឋាននៃការបង្ហាញភ័ស្តុតាងសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

---

១១៧២។ (ii) ផ្នែកសំខាន់ៗនៃឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ២២៨៨-២២៨៩, ២៣០៦ ត្រូវបានលើកឡើងក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១២, ១១៧២។

[1111] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ *អោ អាន* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៤-៨៥។ សំណុំរឿង ០០៤/១-**ឯកសារ D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ លើរឿងក្តី *អ៊ឹម ចែម* កថាខណ្ឌ ៦១-៦២។ អ.ប.ជ បានបង្ហាញ "ភ័ស្តុតាងគ្រប់គ្រាន់" ដើម្បីឈានទៅដល់ "ភវនីយភាព" ឬ "ភាពអាចជឿជាក់បាន" នៃពិរុទ្ធភាព ដែលជាបទដ្ឋានមានកម្រិតទាបជាងការបង្ហាញ "ឱ្យហួសពីវិមតិសង្ស័យ"។ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា នៅដំណាក់មុនការជំនុំជម្រះ ដោយសារមានបណ្តឹងសាទុក្ខនៅចំពោះមុខ អ.ជ.ត.ក នោះកំហុសអង្គហេតុដូចបានលើកឡើង ត្រូវបានពិនិត្យឡើងវិញនៅក្រោមបទដ្ឋាននៃភាពសមហេតុសមផល ដើម្បីសម្រេចថាតើពុំមានអ្នកវិភាគប្រកបដោយហេតុផលណា អាចឈានដល់ការសម្រេចលើអង្គហេតុដែលចោទជាបញ្ហានេះបានទេឬយ៉ាងណា។ *សូមមើលឧទាហរណ៍* ឯកសារ **D427/1/**សាលដីកាលើកទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៣។

[1112] <u>សហករណ៍ត្រាំកក់៖</u> ឯកសារ **E457/6/4/1** កថាខណ្ឌ ៩០៨-៩០៩ ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាមនៅសហករណ៍ត្រាំកក់។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៣៩-១១៤០, ១១៤៦។ <u>ព្រលានយន្តហោះកំពង់ឆ្នាំង៖</u> ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) កថាខណ្ឌ ១០៩៦-១១០៥ ពាក់ព័ន្ធនឹងការសម្លាប់មនុស្សនៅព្រលានយន្តហោះ ឬនៅទីតាំងក្បែរៗនោះ។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៩៤-១៧៩៨។

**អនុលោមតាមវិធាន ៦៧(២)-(៣)។ ដូច្នេះ អ.ជ.ស.ជ បានទទួលបណ្តឹងត្រឹមត្រូវដើម្បីយកមកពិចារណាអង្គហេតុទាំងនេះ នៅក្នុងការបង្ហាញឧក្រិដ្ឋកម្មពាក់ព័ន្ធ។**

***មូលដ្ឋានទី ៦២៖ គ្មានបណ្តឹងចំពោះការស្លាប់ដោយសារការអត់អាហារនៅឃុំត្រាំកក់***[1113]

311. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខត្រូវបានលើកឡើងដោយផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើដីកាដំណោះស្រាយ[1114]។ ទោះបីជា ស.ច.ស បានទទួលបណ្តឹងឱ្យស៊ើបអង្កេតអង្គហេតុនៅក្នុងស្រុកត្រាំកក់ទាំងមូលក៏ដោយ[1115] ក៏ម្ចាស់បណ្តឹងសាទុក្ខ មិនអើពើភ័ស្តុតាងពីក្នុងស្រុកនេះប៉ុន្តែ *បែរជា*ផ្តោតលើ *ក្រៅ*ឃុំសំរោងនិងតាភេម[1116] ដែលបានពិពណ៌នាថា "មានមនុស្សស្លាប់ជាច្រើននាក់ [...] ដោយសារការអត់អាហារ"[1117]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[1118] ភ័ស្តុតាងនេះរួមជាមួយភ័ស្តុតាងបន្ថែមទៀតលើទំហំនៃការស្លាប់ពីការអត់អាហារនៅឃុំសំរោងនិងតាភេម[1119] និងអង្គហេតុដែលថា "[សាក្សី] ស្ទើរទាំងអស់ពិពណ៌នាអំពីកង្វះខាតស្បៀង

---

[1113] <u>មូលដ្ឋានទី ៦២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពីការស្លាប់ដោយសារភាពអត់ឃ្លាន នៅក្នុងឃុំនៃស្រុកត្រាំកក់ទេ* កថាខណ្ឌ ៤៤៥-៤៤៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៦ (ភាសាអង់គ្លេស) ទំព័រ ២៣ (ភាសាបារាំង) ទំព័រ ៣៥៣៦ (ភាសាខ្មែរ)។

[1114] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៤៥-៤៤៧ និង*បានលើកឡើងជាថ្មី* នៅត្រង់ កថាខណ្ឌ ៦៧២។

[1115] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៩។

[1116] ឯកសារ **D427** ដីកាដំណោះស្រាយ ជើងទំព័រ ១២៨៣ *យោងទៅ* ឯកសារ **E3/5835** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក សុត KH 00163522-00163524, 00163525-26 សាក្សីមានវត្តមាននៅស្រែគ្រូ (ឃុំជាងទង) ក្រាំងតាចាន់ (ឃុំគូស) អង្គរកា (ឃុំជាងទង ឬឃុំត្រពាំងខាងជើង) និងអង្គបក្សី (ឃុំជាងទង)។ សម្រាប់ការបញ្ជាក់អត្តសញ្ញាណឃុំទាំងនេះ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៤៦, ២៦៨៣, ៨០៧។ ឯកសារ **E3/2434** សេចក្តីរាយការណ៍របស់មន្ទីរអប់រំស្រុក ១០៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧ KH 00270789។ សម្រាប់ឃុំជាងទង *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៩។

[1117] ឯកសារ **D427** ដីកាដំណោះស្រាយ ជើងទំព័រ ១២៨៣ *យោងទៅ* ឯកសារ **E3/5835** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក សុត KH 00163525-26។

[1118] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៤៦។

[1119] ឯកសារ **D427** ដីកាដំណោះស្រាយ ជើងទំព័រ ១២៨៣ *ដែលក្នុងនោះយោងទៅ* ឯកសារ **E3/7980** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹម ឈៀង KH 00165303 ("មេឃុំនេះអត់អាណិតប្រជាជន ទុកឱ្យប្រជាជនស្លាប់ដោយអត់បាយ")។ ឯកសារ **E3/5519** (D232/67) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក ស៊ីម ឆ.៤៣ (ស. តើលោកមានស្គាល់អ្នកណាដែលស្លាប់ដោយសារកាតអត់បានដែរឬទេ? ឆ. បាទខ្ញុំស្គាល់ មានឈ្មោះ តាប៊ិន, យាម៉ាក, យាយតេង *។ល។*") (គូសបញ្ជាក់បន្ថែម)។

អាហារនៅក្នុងសហករណ៍” ក្នុងស្រុកត្រាំកក់[1120] បង្ហាញថា ការស្លាប់ដោយសារការអត់អាហារ បានកើតឡើងជាលក្ខខណ្ឌបទដ្ឋាននៃភ័ស្តុតាងសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមតាម វិធាន ៦៧(៣)។

## *មូលដ្ឋានទី ៦៣៖ គ្មានបណ្តឹងសម្រាប់ “ការប្រព្រឹត្តដោយរើសអើង” ទាក់ទងនឹង ប្រជាជនថ្មី*[1121]

312. ម្ចាស់បណ្តឹងសាទុក្ខជឿជាក់ថា ការប្រព្រឹត្តដោយការរើសអើងតែមួយគត់ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ទាក់ទង ប្រជាជនថ្មី នៅក្នុងសហករណ៍ត្រាំកក់ គឺជាការបង្ក្រាបសិទ្ធិនយោបាយរបស់ពួកគេ ដោយផ្អែកលើអសមត្ថភាពក្នុងការបំពេញការងារជាប្រធានអង្គភាព[1122]។ ផ្ទុយពីការអះអាងនេះ ស.ច.ស បានរកឃើញថា ប្រជាជនថ្មី ចំណុះឱ្យប្រជាជនមូលដ្ឋាន ដែលត្រូវបានដាក់នៅក្នុងអង្គភាពការងារដែលបានចាត់តាំង បានទទួលរងបញ្ហាសុខភាព និងត្រូវ អប់រំ និងការតាមដាន[1123]។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលង ភ័ស្តុតាងបន្ថែមដែលគួសបញ្ជាក់ ការរកឃើញអង្គហេតុជាក់លាក់ពាក់ព័ន្ធនឹងការប្រព្រឹត្តដោយការរើសអើងលើ ប្រជាជនថ្មី នៅសហករណ៍ ត្រាំកក់៖ យោងតាមគោលនយោបាយ ប.ក.ក នៅថ្នាក់ជាតិ ប្រជាជនត្រូវបានបែងចែកជាប្រភេទដែល “កំណត់កំរិតនៃការចូលរួមរបស់ពួកគេ” នៅក្នុង “មុខងារ” របស់សហករណ៍[1124]។ ប្រជាជនថ្មី ត្រូវបានគេចាត់ថ្នាក់ជា “ជនបញ្ញើ” និងត្រូវបាន “គ្រប់គ្រង” ដោយ

---

[1120] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២ ជើងទំព័រ ១២៨២ *យោងទៅ* កំណត់ហេតុនៃការស្លាប់ចម្លើយខុសៗគ្នាចំនួន ១១ ច្បាប់។

[1121] <u>មូលដ្ឋានទី ៦៣</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងអំពី “ការប្រព្រឹត្តការរើសអើង” លើប្រជាជនថ្មីទេ* កថាខណ្ឌ ៤៤៨-៤៥០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៦ (ភាសាអង់គ្លេស) ទំព័រ ២៣-២៤ (ភាសាបារាំង) ទំព័រ ៣៦ (ភាសាខ្មែរ)។

[1122] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៤៩។

[1123] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១៣, ១១៧០-១១៧១ *ក្នុងនោះយោងទៅ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥-៣០៦, ៣១៣, ៣១៥, ៣១៩, ១៤១៨, ១៤២៤។ ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខមានចេតនាដាក់បញ្ចូលទឡ្ហីករណ៍នានាមកពីកន្លែងណាផ្សេងទៅក្នុងសារណារបស់គាត់ នោះគាត់ខកខានពុំបានបញ្ជាក់ពីបំណងរបស់គាត់នៅក្នុង ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៤៨-៤៥០ ជាមួយនឹងការចង្អុលបង្ហាញបន្ថែមនោះឡើយ។ ទោះជាក្នុងករណីណាក៏ដោយ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៦៧, ៧១, ៧៣, ៧៤៖ ពុំមានបណ្តឹងចំពោះអង្គហេតុនៃ “ការរើសអើង” នោះទេ។

[1124] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥ *យោងទៅឧទាហរណ៍* ឯកសារ **E3/742** *ទង់បដិវត្ត លេខ ពិសេស* សម្រាប់ខែមេសា ឆ្នាំ១៩៧៧ KH 00062997 (“ត្រូវបែងចែកសមាសភាពក្នុងសហករណ៍ឱ្យច្បាស់លាស់ [...]៖ សមាជិកសហករណ៍ពេញសិទ្ធិ [...] -សមាជិកសហករណ៍ត្រៀម [...] -សមាជិកផ្ញើរបស់សហករណ៍”។ *សូមមើលផងដែរ* KH

ប្រជាជនមូលដ្ឋាន ដែលត្រូវបានកំណត់ថា "ពេញសិទ្ធិ" ឬ "ត្រៀម"[1125]។ ការអានរួមគ្នានៃការរកឃើញទាំងនេះបង្ហាញថា ប្រសិនបើ ប្រជាជនថ្មី ត្រូវបានគ្រប់គ្រងដោយប្រជាជនមូលដ្ឋាន យើងនឹងគ្មានឱកាសបង្ហាញជំហរ ក្នុងការកាន់តំណែងខ្ពស់ជាងប្រជាជនមូលដ្ឋាន រួមទាំង មុខតំណែងប្រធានអង្គភាព។ ដូច្នេះ ការធ្វើទុក្ខបុកម្នេញលើ ប្រជាជនថ្មី បានកើតឡើងជាលក្ខខណ្ឌបទដ្ឋាននៃការបង្ហាញភ័ស្តុតាងសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រោយវិធាន ៦៧(៣)។

## *មូលដ្ឋានទី ៦៤៖ គ្មានបណ្តឹងសម្រាប់អង្គហេតុនៃការតាមដាន និងការបាត់ខ្លួនអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ*[1126]

313. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ បានផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើដីកាដំណោះស្រាយ[1127] ដែលមិនអើពើនឹងករណីថា ស.ច.ស បានទទួលបណ្តឹងឱ្យស៊ើបអង្កេតអង្គហេតុនៅទូទាំងស្រុកត្រាំកក់ទាំងមូល[1128]។ ម្ចាស់បណ្តឹងសាទុក្ខ យល់ស្របថា ការចោទប្រកាន់អំពីការបាត់ខ្លួនត្រូវបានបញ្ជាក់ដោយសាក្សីម្នាក់[1129] ប៉ុន្តែមិនយល់ស្របនឹងតម្លៃនៃភ័ស្តុតាង ដោយបានអះអាងថា សាក្សីមិនបានចោទប្រកាន់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ *ពិតជា*បានបាត់ខ្លួនគ្រាន់តែថា ពួកគេ*នឹង*បាត់ខ្លួនប្រសិនបើអត្តសញ្ញាណរបស់ពួកគេពុំត្រូវបានរកឃើញ[1130]។ សាក្សី

---

00062997 "បងចែកយ៉ាងនេះ ទើបមានទស្សនៈនយោបាយច្បាស់លាស់។ តាមរយៈនេះ ក៏មានទស្សនៈចាត់តាំងច្បាស់លាស់ [...]។ រហូតដល់ជ្រើសរើសគណៈកម្មាធិការសហករណ៍ គឺទៅតាមមាគ៌ាចាត់តាំង និងមាគ៌ាវណ្ណៈរបស់បក្ស"។

[1125] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៦ *យោងទៅ* ឯកសារ **E3/5515** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភ្នៅ យ៉ាវ KH 00402458។

[1126] <u>មូលដ្ឋានទី ៦៤</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានភ័ស្តុតាងគាំទ្រអង្គហេតុនៃការបាត់ខ្លួនអតីតទាហាន និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរទេ* កថាខណ្ឌ ៤៥១-៤៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៦ (ភាសាអង់គ្លេស) ទំព័រ ២៤ (ភាសាបារាំង) ទំព័រ ៣៦-៣៧ (ភាសាខ្មែរ)។

[1127] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥១-៤៥៦។

[1128] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៩។

[1129] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥៤។

[1130] ឯកសារ **D427** ដីកាដំណោះស្រាយ ជើងទំព័រ ២១៥៦ *ដែលយោងទៅ* ឯកសារ **E3/4627** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ឌុច KH 00163493 (សៈ ពួក ១៧ មេសាហ្នឹងត្រូវបានឈ្លបចាប់ទៅ ហើយជូនទៅក្រាំងតាចាន់? ឆៈ ខ្ញុំមិនដឹងថាផែនការនេះថ្នាក់សំរេចទេ។ ពេលចូលដល់ហ្នឹង គេឱ្យធ្វើប្រវត្តិរូប បើប្រវត្តិរូបនិយាយថាធ្វើទាហាន អ្នកនោះឯង*ត្រូវ*បាត់ខ្លួន)។ ម្ចាស់បណ្តឹងសាទុក្ខបានឆ្លើយតបនៅក្នុងសំណៅជាភាសាបារាំងនៃឯកសារ **E3/4627** ដែលបានបកប្រែទៅជាភាសាអង់គ្លេសថា "they *had to* disappear" មិនមែនបកប្រែថា "they *would* disappear" នោះទេ។

បន្ថែមបានគាំទ្រដល់ការសម្រេចអំពីការបាត់ខ្លួននៅក្រាំងតាចាន់[1131] ហើយបញ្ជីឈ្មោះអ្នកទោសក្រាំងតាចាន់ គាំទ្រដីកាដំណោះស្រាយបង្ហាញបន្ថែមទៀតថា អ្នកទោសជិត ៥០% បានធ្វើការនៅរបបសាធារណរដ្ឋខ្មែរ[1132]។ ការមិនយល់ស្របរបស់ម្ចាស់បណ្តឹងសាទុក្ខជាមួយនឹងតម្លៃនៃភស្តុតាង[1133] មិនអើពើចំពោះភស្តុតាងតាមបរិបទ និងភស្តុតាងបញ្ជាក់បន្ថែម។ លើសពីនេះទៀតបញ្ហាថា តើភស្តុតាងបែបនេះត្រូវបានចាត់ទុកថាជាភស្តុតាងនៃការបាត់ខ្លួនជាក់ស្តែង ឬក៏ជាភវយីភាពនៃការបាត់ខ្លួននោះ គឺការសម្រេចនៅក្នុងដែនឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ។ ទោះបីជាយ៉ាងក៏ដោយ វាបង្ហាញច្បាស់ថា ការបាត់ខ្លួនបានកើតមាន រហូតដល់កម្រិតបទដ្ឋាននៃការបង្ហាញភស្តុតាងចាំបាច់ អនុលោមតាមវិធាន ៦៧(៣)។

314. ចំពោះភាពគ្រប់គ្រាន់នៃភស្តុតាង ដែលថាអតីតមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ស្ថិតនៅក្រោមការឃ្លាំមើលនោះ[1134] ម្ចាស់បណ្តឹងសាទុក្ខមិនអើពើសាជាថ្មីចំពោះភស្តុតាងជាមូលដ្ឋាន។ គាត់ទទួលស្គាល់ថា ដីកាដំណោះស្រាយត្រូវបានគាំទ្រដោយបញ្ជីឈ្មោះអតីតមន្ត្រីលន់ណុលដែលបានមកដល់ឃុំ និងត្រូវបានបញ្ជូនទៅស្រុកត្រាំកក់[1135] ប៉ុន្តែ ជាឧទាហរណ៍ មិនអើពើរបាយការណ៍ឃុំគូស ដែលជម្រាបអង្គការអំពីវត្តមានរបស់អតីតទាហានលន់នល់ចំនួន ៧ នាក់

---

[1131] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨។ *សូមមើលឧទាហរណ៍* ឯកសារ **E3/5518** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ប៊ាន KH 00408316 (សៈ ពេលប្រជាជនទាំងនោះមកដល់ភូមិ តើគេមានធ្វើប្រវត្តិរូប ឬសម្រិតសម្រាំងប្រវត្តរូអ្វីទេ? ឆៈ បាទ! គឺមាន។ គេដើរធ្វើការស្រាវជ្រាវដើម្បីឱ្យដឹងថា អ្នកណាខ្លះធ្វើគ្រូ ឬតាហាន ឬកម្មករ។ ចំពោះអ្នកដែលគេដឹងថាជាទាហាន ឬគ្រូបង្រៀន អ្នកទាំងនោះត្រូវបានគេចាប់យកទៅបាត់រហូត)។ ឯកសារ **E3/4626** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ KH 00373467 (សៈ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ តើចំនួនអ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់ មានការកើនឡើងដែរឬទេ? ឆៈ ខ្ញុំមិនបានឃើញផ្ទាល់ទេ ប៉ុន្តែ ខ្ញុំអាចដឹងថា ចំនួនអ្នកទោសពិតជាមានការកើនឡើង ដោយសារខ្ញុំឃើញមានការនាំអង្គុយកមក [ពីស្រុក] ផ្គត់ផ្គង់មន្ទីរសន្តិសុខនោះមានការកើនឡើង។ ឯកសារ **E3/5524** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន់ ឆេន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ KH 00414448 (សៈ យើងចង់សួរលោក កាលដែលលោកចូលលេងនៅក្រាំងតាចាន់ចុងឆ្នាំ១៩៧៥។ តើពេលនោះក្រាំងតាចាន់ផ្លាស់ប្តូរយ៉ាងម៉េចដែរ? ឆៈ ទីកន្លែងមិនបានពង្រីកនោះទេ ប៉ុន្តែមានអ្នកទោសច្រើនជាងមុន)។

[1132] ឯកសារ **E457/6/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដែលបានកែប្រែរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៩៣។ ឯកសារ **E457/6/1.2.17** ឧបសម្ព័ន្ធ ឆ.២ ចំណុច ១.៥ *ការគ្រប់គ្រងអ្នកទោសពីដំបូងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។* ឯកសារ **E457/6/1.2.16** ឧបសម្ព័ន្ធ ឆ.១ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់។

[1133] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥៥។

[1134] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥៣។

[1135] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥២-៤៥៣។

ដែលមានការណែនាំឱ្យចាប់ខ្លួនក្រុមនេះ[1136]។ របាយការណ៍ដាច់ដោយឡែកមួយបញ្ជាក់ពីអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរចំនួន ២៥នាក់ និងឋានន្តរសក្តិរបស់ពួកគេ[1137]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ភស្តុតាងគាំទ្រទាំងមូល មិនអាចបំពេញដោយសមហេតុផលចំពោះបទដ្ឋាននៃភស្តុតាង ដែលជាលក្ខខណ្ឌតម្រូវ អនុលោមតាមវិធាន ៦៧ (៣) នោះឡើយ។

## ៣. ប្រភេទទី៣៖ អង្គហេតុដែលម្ចាស់បណ្តឹងសាទុក្ខអះអាងថានៅក្រៅបណ្តឹងដាក់ជូនទៅ អ.ជ.ស.ដ ដោយសារការខកខានរបស់ ស.ច.ស មិនបានកំណត់អង្គហេតុទាំងនោះនៅក្នុងដីកាដំណោះស្រាយ ជាអង្គហេតុសំខាន់ដែលកំណត់ប្រភេទតាមផ្លូវច្បាប់ ពិនិត្យនាំទៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់[1138]

### *មូលដ្ឋានទី ៦០, ៦៥-៨១, ១២៤ និង ១៣៤*

315. មូលដ្ឋានទី ៦០ មូលដ្ឋានទី ៦៥-៨១ មូលដ្ឋានទី ១២៤ និងមូលដ្ឋានទី ១៣៤ គួរត្រូវបានច្រានចោល។ ម្ចាស់បណ្តឹងសាទុក្ខ មិនយល់ស្របជាមួយនឹងការបកស្រាយរបស់ អ.ជ.ស.ដ ចំពោះដីកាដំណោះស្រាយ ប៉ុន្តែខកខានមិនបានពន្យល់អំពីរបៀបដែល អ.ជ.ស.ដ មានកំហុសនៅក្នុងការអានជារួម ទៅលើដីកាដំណោះស្រាយ ដែលពុំមែនជាការអានជាផ្នែកម្តងមួយៗ។ ដីកាដំណោះស្រាយបានកំណត់នូវការពិពណ៌នាជាក់លាក់គ្រប់គ្រាន់អំពីអង្គហេតុសំខាន់ និងការកំណត់បទចោទ ដោយបានផ្តល់ការជូនដំណឹងគ្រប់គ្រាន់ដល់ម្ចាស់បណ្តឹងសាទុក្ខអំពីបណ្តឹងដាក់ជូនទៅ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២។

---

[1136] ឯកសារ **D427** ដីកាដំណោះស្រាយ ជើងទំព័រ ២១៦០ *យោងទៅ* ឯកសារ **E3/2441** សេចក្តីរាយការណ៍ពីឃុំគុស ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00270952 (សេចក្តីរាយការណ៍ជូន*អង្គការ*អំពីអតីតទាហាន លន់ នល់ ចំនួន ៧ នាក់ ដែលពាក់ស័ក្តិ ២ ឬស័ក្តិ ៣) 00270953 (ប្រធានគុកស្រុកឈ្មោះ អាន់ ណែនាំ "ឃុំគុសចាប់ពួក [អានមិនដាច់] ផង")។

[1137] ឯកសារ **E3/2438** សេចក្តីរាយការណ៍ពីឃុំគុស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧ KH 00270811-00270814 (កំណត់អត្តសញ្ញាណប្រជាជនកម្ពុជាក្រោមសរុបចំនួន ៣៥ គ្រួសារ មានសមាជិកសរុប ១៤៩ នាក់ រួមទាំងអតីតទាហានរបបសាធារណរដ្ឋខ្មែរចំនួន ២៥ នាក់ ព្រមទាំងរៀបរាប់ពីឋានន្តរស័ក្តិដែលពួកគេធ្លាប់ពាក់ (អនុសេនីយ៍ អាបារឿដង់ ដោយបីជាន់))។

[1138] មូលដ្ឋានទី ៦០, ៦៥-៨១, ១២៤, ១៣៤ (ការអនុវត្ត)៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥៨-៥៣០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៧-៣២, ៤៥-៤៦, ៤៨ (ភាសាអង់គ្លេស) ទំព័រ ២៤-២៩, ៤១-៤២, ៤៤ (ភាសាបារាំង) ទំព័រ ៣៧-៤៥, ៦៤-៦៥, ៦៨ (ភាសាខ្មែរ)។

## មូលដ្ឋានទី ៦០៖ ជនជាតិវៀតណាម[1139]

316. ជារួម ម្ចាស់បណ្តឹងសាទុក្ខអះអាង[1140]ថា អ.ជ.ស.ដ បកស្រាយខុសលើដីកាដំណោះស្រាយ នៅពេលសម្រេចថា ខ្លួនបានទទួលបណ្តឹងអំពីការកាប់សម្លាប់ជនជាតិវៀតណាមនៅទូទាំងប្រទេស ពោលគឺ នៅខាងក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[1141]។ ប៉ុន្តែ ម្ចាស់បណ្តឹងសាទុក្ខ ខកខាន មិនបានបង្ហាញថា ការបកស្រាយនេះមិនសមហេតុផល ហើយគាត់ក៏មិនបានពន្យល់ពីមូលហេតុ ដែលគាត់ខកខានមិនបានស្នើសុំការបញ្ជាក់បំភ្លឺអំពីបណ្តឹងដាក់ជូនទៅ អ.ជ.ស.ដ នៅមុនពេល ដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលកាលពីខែឧសភា ឆ្នាំ២០១៧។

317. នៅក្នុងការកំណត់បណ្តឹងភូមិសាស្ត្រមកកាន់ខ្លួន អ.ជ.ស.ដ បានយោង និងបកស្រាយយ៉ាងត្រឹមត្រូវលើដីកាដំណោះស្រាយ ដែល ដូចម្ចាស់បណ្តឹងបានអះអាង[1142] បានរៀបរាប់លម្អិតអំពី អង្គហេតុ នៃការកាប់សម្លាប់នៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[1143]។ នៅក្នុងផ្នែកដែលមាន ចំណងជើងថា "ការសម្លាប់ជនស៊ីវិលវៀតណាមនៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង"[1144] ដីកាដំណោះស្រាយបានរកឃើញថា "ការសម្លាប់ជនស៊ីវិលវៀតណាមមិនត្រូវបានកំណត់ចំពោះ តែខេត្តព្រៃវែង និងខេត្តស្វាយរៀងនោះឡើយ"[1145] ដោយសារជនជាតិវៀតណាមត្រូវបានសម្លាប់ នៅវត្តខ្សាច់ ព្រៃដំរីស្រុត និងតំបន់ ៥០៥ ព្រមទាំងទីតាំងឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងវិសាលភាព នៃសំណុំរឿង ០០២/០២ ដូចជា ក្រាំងតាចាន់ ស -២១ និង អូរកន្សែង[1146]។ ផ្នែកពាក់ព័ន្ធនៃ

[1139] មូលដ្ឋានទី ៦០៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ អំពីជនជាតិវៀតណាម កថាខណ្ឌ ៤៣៥-៤៣៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៥ (ភាសាអង់គ្លេស) ទំព័រ ២២-២៣ (ភាសាបារាំង) ទំព័រ ៣៤-៣៥ (ភាសាខ្មែរ)។

[1140] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៣៥, ៤៣៧។ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខបានរៀបរាប់លើមូលដ្ឋានទី ៦០ ថាជាមូលដ្ឋានប្រភេទទី ១ សម្រាប់មូលហេតុដូចបានពន្យល់ខាងក្រោមក្តី ក៏ទឡ្ហីករណ៍ទាំងនោះ គ្រាន់តែជាការបន្ទាប់បន្សំចំពោះអំណះអំណាងរបស់គាត់ដែលថា អ.ជ.ស.ដ បានបកស្រាយខុសទៅលើដីកាដំណោះស្រាយ ក្នុងការកំណត់*អង្គហេតុ*របស់ខ្លួន។

[1141] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥៨, ៣៣៦០។

[1142] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៣៥, ៤៣៨។

[1143] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥៦, ៣៣៥៨ *យោងទៅ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២១៣-២១៥, ៨០២-៨០៣។ *សូមមើលផងដែរ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៥-៨៣១ មានសេចក្តីលម្អិតអំពីការសម្លាប់ជនជាតិវៀតណាមនៅទូទាំងប្រទេសកម្ពុជា។

[1144] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨០២-៨០៤។

[1145] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨០២។

[1146] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨០២-៨០៤។

ដីកាដំណោះស្រាយ ក៏ បានលើកឡើងថា "ការកាប់សម្លាប់ទ្រង់ទ្រាយធំលើជនស៊ីវិលវៀតណាម ត្រូវបានប្រព្រឹត្តនៅទូទាំងខេត្តព្រៃវែង និងខេត្តស្វាយរៀង នៅក្នុងភូមិភាគបូព៌ា។ ភ័ស្តុតាងក៏បង្ហាញផងដែរថា ជនស៊ីវិលវៀតណាមត្រូវបានគេកំណត់មុខសញ្ញា និងត្រូវបានសម្លាប់នៅទូទាំងប្រទេសកម្ពុជា [...] ជាពិសេស នៅក្នុងភូមិភាគឥសាន និងភូមិភាគឧត្តរ"[1147] ហើយការកំណត់គោលដៅចំពោះ ការសម្លាប់ជនជាតិវៀតណាម ដោយផ្អែកលើទ្រឹស្តីនៃការជាប់ខ្សែស្រឡាយខាងម្តាយ "ទំនងត្រូវបានអនុវត្តនៅទូទាំងខេត្តព្រៃវែង និងខេត្តស្វាយរៀង ក៏ដូចជានៅតាមបណ្តាតំបន់នានានៅក្នុងប្រទេស"[1148]។

318. ដីកាដំណោះស្រាយក៏បានរកឃើញ "ការអំពាវនាវផ្ទាល់ ដើម្បីសម្លាប់*រាល់សមាជិកនៃសហគមន៍ប្រជាជនវៀតណាម ដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា*"[1149] កម្មាភិបាលទាំងនោះ "ត្រូវបានស្នើឱ្យស្វែងរក និងសម្លាប់*ប្រជាជនវៀតណាមទាំងអស់នៅក្នុងប្រទេសកម្ពុជា*"[1150] ហើយថា "*វៀតណាមមានគ្រប់ទីកន្លែង* "គ្រប់ៗរូបត្រូវប្រុងប្រយ័ត្ន ដើម្បីរកឱ្យឃើញ និងកំចាត់ចោល""[1151]។

319. នៅក្នុងការជំទាស់អំពីការកំណត់បទចោទចំពោះអង្គហេតុនៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ម្ចាស់បណ្តឹងសាទុក្ខមិនអើពើផ្នែកជាក់លាក់ ដែលកំណត់ "អំពើប្រល័យពូជសាសន៍ដោយការសម្លាប់ជនជាតិវៀតណាម"[1152] "មនុស្សឃាត"[1153] និង "ការសម្លាប់រង្គាល"[1154]។ ដូច អ.ជ.ស.ដ បានពន្យល់[1155] នៅពេលកំណត់អង្គហេតុនៃការសម្លាប់នេះ ស.ច.ស *ពុំបាន* កំណត់បទចោទ

---

[1147] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤។

[1148] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២១៥។

[1149] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៤ (គូសបញ្ជាក់បន្ថែម)។

[1150] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៥ (គូសបញ្ជាក់បន្ថែម)។

[1151] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៧ (គូសបញ្ជាក់បន្ថែម)។

[1152] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣៥, ១៣៤៣-១៣៤៩។

[1153] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣-១៣៨០។ *ជាពិសេស សូមមើល* កថាខណ្ឌ ១៣៧៣ សម្រេចទៅលើការធ្វើមនុស្សឃាត ដែលបានបង្ហាញឡើងដោយអង្គហេតុនានាពាក់ព័ន្ធនឹង "ការប្រព្រឹត្តចំពោះ [...] ជនជាតិវៀតណាម"។

[1154] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១-១៣៩០។ *សូមមើល* ជាពិសេស កថាខណ្ឌ ១៣៨១ សម្រេចទៅលើការសម្លាប់រង្គាល ដែលបានបង្ហាញឡើងដោយអង្គហេតុនានាពាក់ព័ន្ធនឹង "ការប្រព្រឹត្តចំពោះជនជាតិវៀតណាម"។

[1155] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥៦ ជើងទំព័រ ១១៣១៧ *យោងទៅ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣៥, ១៣៥០, ១៣៧៣, ១៣៨១ ហើយដែលពន្យល់ថា "អង្គច្បាប់នៃឧក្រិដ្ឋកម្មប្រល័យ

តែចំពោះការសម្លាប់ដែលកើតឡើងនៅក្នុងខេត្តទាំងពីរនេះទេ[1156]។ តាមការពិត ផ្នែកទាំងនេះគូស បញ្ជាក់ថា៖ "ក្រៅពីតំបន់បូព៌ា *ការសម្លាប់បានធ្វើនៅតាមភូមិភាគផ្សេងៗទៀតក្នុងពេលជាមួយគ្នា*"[1157] "ការកាប់សម្លាប់ប្រជាជនវៀតណាម [...] *បានអនុវត្តទូទៅចាប់តាំងពីឆ្នាំ១៩៧៧មក*"[1158] និង "ការសម្លាប់ [ប្រជាជនវៀតណាម] បានវិវត្តឈានដល់ទ្រង់ទ្រាយធំ និងជាសមូហភាពដែលបង្កដល់ជាការសម្លាប់រង្គាល"[1159]។

320. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខបានទទួលការជូនដំណឹង នៅមុន និងក្នុងអំឡុងពេលនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ដែល អ.ជ.ស.ដ បានយល់ថាខ្លួនបានទទួលអង្គហេតុនៃការសម្លាប់ជនជាតិវៀតណាមនៅទូទាំងប្រទេស។ ចំណុចនេះត្រូវបានលើកឡើងនៅក្នុងឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ដែលកំណត់វិសាលភាពនៃបទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ដោយយោងទៅលើ "ការធ្វើបាបលើជនជាតិវៀតណាម" ទាំងមូល ដោយគ្មានកំណត់[1160]។ ឧបសម្ព័ន្ធបានរួមបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នូវកថាខណ្ឌទាំងអស់ក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាម រួមទាំង*គ្រប់*ផ្នែកទាំងអស់ ដែល ស.ច.ស

---

ពូជសាសន៍ ព្រមទាំងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលដែលជា [ផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] នៅក្នុងដីកាដំណោះស្រាយ មិនបានកំណត់ភូមិសាស្ត្រ និងសំដៅដោយផ្ទាល់ទៅលើអង្គហេតុនោះឡើយ"។

[1156] ចំពោះករណីទាក់ទងនឹងបទចោទស្តីពីការជម្លៀស *សូមមើល* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៧ ("មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការនិរទេស **នៅខេត្តព្រៃវែង ខេត្តស្វាយរៀង** និង **សហករណ៍ស្រុកត្រាំកក់**")។

[1157] ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ *សូមមើល* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៤៧ (គូសបញ្ជាក់បន្ថែម)។

[1158] ទាក់ទងនឹងបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពជាការធ្វើមនុស្សឃាត *សូមមើល* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៨ (គូសបញ្ជាក់បន្ថែម)។

[1159] ទាក់ទងនឹងបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ក្រោមរូបភាពជាការសម្លាប់រង្គាល *សូមមើល* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៦។

[1160] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២ កថាខណ្ឌ ៥(១)(ខ) (បទល្មើសប្រល័យពូជសាសន៍), ៥(២)(ខ)(១) (ការធ្វើមនុស្សឃាត), ៥(២)(ខ)(២) (ការសម្លាប់រង្គាល)។ ប្រៀបធៀប ឧទាហរណ៍ ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២ កថាខណ្ឌ ៥(២)(ខ)(៤) (ការកម្រិតបទចោទស្តីពីការនិរទេសចំពោះ "ការប្រព្រឹត្តលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងស្វាយរៀង")។

បានបង្ហាញថា ការកាប់សម្លាប់នៅក្រៅខេត្តព្រៃវែង និងស្វាយរៀង[1161]។ អ.ជ.ស.ដ បានធ្វើការប្រកាសបន្ថែមទៀតអំពីករណីនេះនៅក្នុងអំឡុងពេលជំនុំជម្រះ[1162]។ ទោះបីជាបានទទួលការជូនដំណឹងបែបនេះក៏ដោយ ក៏ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានស្នើសុំការបញ្ជាក់បំភ្លឺ[1163] នៅមុនពេលដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល[1164] ដែល អ.ជ.ស.ដ បានឆ្លើយតបតាមវិធីបញ្ជាក់បំភ្លឺ*បន្ថែម*នៅក្នុងសាលក្រម[1165]។

---

[1161] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២ ទំព័រ ១-៦ *យោងទៅ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២០៥-២០៧, ២១៣-២១៥ (“អង្គហេតុនៃសហឧក្រិដ្ឋកម្មរួមៗ), ៧៩១-៨៣១ (“អង្គហេតុនៃឧក្រិដ្ឋកម្ម”), ១៣៣៥, ១៣៤៣-១៣៤៩, ១៣៧៣-១៣៨០, ១៣៨១-១៣៩០ (“ផ្នែកអង្គហេតុ”), នៃបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល)។ ចំណែកឯផ្នែកនានានៃដីកាដំណោះស្រាយ ទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម ត្រូវបានដកចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២ តាមរយៈដីកាសម្រេចបំបែកសំណុំរឿង ដែលចំណុចនេះត្រូវបានលើកឡើងយ៉ាងច្បាស់។

[1162] ឯកសារ **E380/2** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែម ទៅលើអង្គហេតុនៃការប្រព្រឹត្តិចំពោះជនជាតិវៀតណាម និងសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធ កថាខណ្ឌ ២១ (*យោងទៅ* ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមដោយ អ.ជ.ស.ដ និងវិសាលភាពនៃសំណុំរឿង ០០២/២ កថាខណ្ឌ (៥(១)(ខ) (បទល្មើសប្រល័យពូជសាសន៍), ៥(២)(ខ)(១) (ការធ្វើមនុស្សឃាត), ៥(២)(ខ)(២) (ការសម្លាប់រង្គាល), កថាខណ្ឌ ២៧។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ (ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៣៧), នៅត្រង់កថាខណ្ឌ ២៧ នៃសេចក្តីសម្រេចនេះ អ.ជ.ស.ដ ពុំបានលើកឡើងថា ខ្លួនបានទទួលបណ្តឹងអំពីការសម្លាប់ជនជាតិវៀតណាម ជាពិសេសនៅក្នុងខេត្តព្រៃវែង និងស្វាយរៀងនោះទេ ប៉ុន្តែ បានរំឭកថា “ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាម ពឹងផ្អែកមួយចំណែកធំទៅលើឧក្រិដ្ឋកម្មជាមូលដ្ឋាន ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងនៅក្នុងខេត្ត ស្វាយរៀង និងព្រៃវែង”)។

[1163] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៣៧។ ដូចបានលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខ (ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៣៦), នៅក្នុងសវនាការ សហព្រះរាជអាជ្ញាទទួលស្គាល់ការយល់ច្រឡំរបស់ខ្លួនទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាមនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង ហើយបើតាមកំហុសឆ្គង គួរតែបានស្នើសុំការបញ្ជាក់បំភ្លឺចំពោះ*អង្គហេតុ*នេះ ប៉ុន្តែ ពុំបានស្នើសុំការបញ្ជាក់បំភ្លឺទ។

[1164] ឯកសារ **E457/6/4/1 E457/6/4/1** កថាខណ្ឌ ១៨៨០-១៨៨៨, ១៨៩៤-១៨៩៦។

[1165] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៦០។

321. ដូចបានពិភាក្សាពីមុនរួចហើយ ចំពោះវិសាលភាពដែលម្ចាស់បណ្ដឹងសាទុក្ខជំទាស់ទៅនឹងវិសាលភាពនៃបណ្ដឹងជាក់ស្ដែងដាក់ជូនទៅ ស.ច.ស អ.ជ.ស.ដ បានពិចារណាករណីទាំងនេះត្រឹមត្រូវថាវាត្រូវបានរារាំងដោយអាជ្ញាយុកាល អនុលោមតាមវិធាន ៨៩ (១)[1166]។

***មូលដ្ឋានទី ៦៥៖ គ្មានបណ្ដឹងចំពោះការស្លាប់ដោយសារបញ្ហាសុខភាព និងលក្ខខណ្ឌរស់នៅ***[1167]

322. ដីកាដំណោះស្រាយប្ដឹង អ.ជ.ស.ដ ចំពោះសំអាងហេតុពាក់ព័ន្ធនឹងគោលនយោបាយ ប.ក.ក[1168] ហើយការអនុវត្តនៅការដ្ឋានការងារនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ អនុលោមតាមតាមសហឧក្រិដ្ឋកម្មរួម[1169]។ អាស្រ័យហេតុនេះ "យោងតាមលក្ខខណ្ឌទូទៅ"[1170] ស.ច.ស បានរកឃើញថាការស្លាប់បានកើតឡើង (i) *ក្នុងទ្រង់ទ្រាយធំ*នៅការដ្ឋានការងារ ដែលខ្លួនបានទទួលបណ្ដឹង[1171] ហើយ (ii) តាមរយៈការបង្កើតលក្ខខណ្ឌដែលនាំមកនូវការបំផ្លាញផ្នែកខ្លះនៃចំនួនប្រជាជន[1172]។

---

[1166] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១១៣១៧។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៨។ សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់បន្ថែមទៅលើការបដិសេធរបស់ ស.ច.ស ចំពោះសំណើសុំឱ្យពិចារណាលើភ័ស្តុតាងថ្មីនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តទៅលើជនជាតិវៀតណាម នៅក្នុងខេត្តកំពង់ឆ្នាំង (ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៤៣៦ ជើងទំព័រ ៧៥៧ *យោងទៅ* ឯកសារ **D250/3/3** ដីកាសម្រេចរួមរបស់ ក.ស.ច.ស លើសំណើរបស់ ក.ស.ព និងមេធាវីដើមតំណាងបណ្ដឹងរដ្ឋប្បវេណី ឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងជនជាតិវៀតណាម និងខ្មែរក្រោម កថាខណ្ឌ ៧-៩) ប៉ុន្តែ រម្លឹកដល់ម្ចាស់បណ្ដឹងសាទុក្ខថា ប្រសិនបើដីកាដំណោះស្រាយ និងដីការងការជំទាស់បានបង្កើតឱ្យមាន "ភាពផ្ទុយគ្នា" ដូចគាត់លើកឡើងមែន (ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៤៣៦), នោះគាត់គួរតែប្រើសិទ្ធិរបស់គាត់ដើម្បីដាក់អញ្ញត្រកម្មជំទាស់នឹងដីកាដំណោះស្រាយ ស្របតាមវិធាន ៨៩(១)។

[1167] <u>មូលដ្ឋានទី ៦៥</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ គ្មានបណ្ដឹងពីការស្លាប់បណ្ដាលមកពីបញ្ហាសុខភាព និងលក្ខខណ្ឌរស់នៅទេ កថាខណ្ឌ ៤៦៥-៤៦៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២៧ (ភាសាអង់គ្លេស) ទំព័រ ២៤-២៥ (ភាសាបារាំង) ទំព័រ ៣៧-៣៨ (ភាសាខ្មែរ)។

[1168] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៨-១៧៧។ *ជាពិសេស សូមមើល* កថាខណ្ឌ ១៦៨-១៦៩, ១៧២-១៧៣, ១៧៥។

[1169] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០២-៤១៣។ *ជាពិសេស សូមមើល* កថាខណ្ឌ ៣១០-៣១៤, ៣៣៤-៣៤៥, ៣៥៨-៣៦៣, ៣៧៦-៣៧៩, ៣៨៩-៣៩២, ៤០៣-៤១០។

[1170] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៣៨។

[1171] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១។

[1172] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨២។

"ល័ក្ខខ័ណ្ឌរួម"[1173]ទាំងនេះ អនុវត្តចំពោះការងារការងារនីមួយៗដែលរៀបរាប់នៅក្នុងដីកាដំណោះស្រាយរួមទាំងសហករណ៍ត្រាំកក់[1174]។

323. ម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ជាក់លាក់ថា អ.ជ.ស.ដ បានសង្ខេបដោយមិនត្រឹមត្រូវនូវការអះអាងរបស់គាត់ថា ខ្លួនមិនបានទទួលអង្គហេតុនៃការស្លាប់ដោយសារបញ្ហាសុខភាព[1175] ប៉ុន្តែខកខានមិនបានបង្ហាញថា តើករណីនេះធ្វើឱ្យមោឃៈដល់ការយល់ឃើញរបស់ អ.ជ.ស.ដ ដែលបានទទួលអង្គហេតុនៃការស្លាប់ក្រៅពីការអត់អាហារនៅសហករណ៍ត្រាំកក់ដោយរបៀបណា។ ម្ចាស់បណ្តឹងសាទុក្ខដកស្រង់មិនត្រឹមត្រូវនូវប្រយោគមួយនៅក្នុងដីកាដំណោះស្រាយ[1176] ដោយមិនអើពើថា នៅក្នុងកថាខណ្ឌដដែលនោះ ស.ច.ស បានលើកឡើងថា ប្រជាជនមានបញ្ហាសុខភាព និងទទួលបានការព្យាបាលវេជ្ជសាស្ត្រមិនគ្រប់គ្រាន់[1177]។ ប្រជាជនដែលស្លាប់ដោយសារការព្យាបាលសុខភាពមិនគ្រប់គ្រាន់កាន់តែស៊ីសង្វាក់គ្នានឹងកំណត់ហេតុនៃការស្លាប់ចម្លើយ ដែលគាំទ្រដល់កថាខណ្ឌនោះ[1178]។

***មូលដ្ឋានទី ៦៦៖ គ្មានបណ្តឹងចំពោះការស្លាប់ដោយសារការអត់អាហារ នៅខាងក្រៅសំរោង និងតាភេម***[1179]

324. ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងឡើងវិញនូវអំណះអំណាងដែលមិនទទួលបានជោគជ័យរបស់គាត់ពីការជំនុំជម្រះមុន[1180] ដោយមិនបានបង្ហាញថា ការបដិសេធរបស់ អ.ជ.ស.ដ លើ

---

[1173] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៧។ ស្ថានភាពរស់នៅ មានដូចជា *ឧទាហរណ៍* ភាពអត់ឃ្លាន គ្មានការថែទាំផ្នែកវេជ្ជសាស្ត្រ និងការបង្ខំឱ្យធ្វើពលកម្ម។

[1174] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤១។

[1175] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៦៧ ជើងទំព័រ ៨២៩ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៣៩។ *ផ្ទុយពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១១។

[1176] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៦៨។

[1177] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៣។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៨៧៩។

[1178] ឯកសារ **D427** ដីកាដំណោះស្រាយ ជើងទំព័រ ១២៩២ *ដកស្រង់* ឯកសារ **E3/5135** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិល ឃៀង KH 00165296។

[1179] <u>មូលដ្ឋានទី ៦៦៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងពីការស្លាប់បណ្តាលមកពីការអត់ឃ្លាន នៅក្រៅឃុំសំរោង និងឃុំតាភេមទេ* កថាខណ្ឌ ៤៧១-៤៧៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៧ (ភាសាអង់គ្លេស) ទំព័រ ២៥ (ភាសាបារាំង) ទំព័រ ៣៨ (ភាសាខ្មែរ)។

ទឡ្ហីករណ៍ទាំងនេះគឺជាកំហុស ដែលចាំបាច់ឱ្យ អ.ជ.ត.ក អន្តរាគមន៍[1181]។ ការអះអាងរបស់គាត់ថា អ.ជ.ស.ជ បានត្រឹមតែទទួលអង្គហេតុនៃការស្លាប់ដោយសារការអត់អាហារនៅសំរោង និងតាភេម[1182] វិតតែមិនទទួលបានផលថែមទៀត ដោយសារតែវាផ្អែកទៅលើការអានដីកាដំណោះស្រាយជាផ្នែកៗដាច់ពីគ្នា។ ស.ច.ស បានកត់សម្គាល់ថា "សាក្សីស្ទើរតែទាំងអស់ពិពណ៌នាអំពីកង្វះអាហារនៅសហករណ៍" ត្រាំកក់ ខណៈសាក្សីខ្លះ "រំលឹកអំពីប្រជាជនស្លាប់ដោយសារអត់អាហារ"[1183]។ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើចំពោះការយោងរបស់ ស.ច.ស មិនត្រឹមតែលើភ័ស្តុតាងជាក់លាក់អំពីការអត់អាហារនៅឃុំសំរោង និងតាភេមនោះទេ ព្រមទាំងសាក្សីដែលរស់នៅក្នុងស្រុកត្រាំកក់*នៅក្រៅឃុំ*ដែលរងការជំទាស់[1184] ដែលបានថ្លែងថា "មានមនុស្សស្លាប់ជាច្រើន [...] ដោយសារការអត់អាហារ"[1185]។ ដូច្នេះ អ.ជ.ស.ជ បានទទួលបណ្តឹងត្រឹមត្រូវដោយបានពិចារណាអំពីការស្លាប់ដោយសារការអត់អាហារនៅទូទាំងស្រុកតាំកក់ទាំងមូល[1186]។

### *មូលដ្ឋានទី ៦៧, ៧១, ៧៣, ៧៤៖ បណ្តឹងអង្គហេតុនៃការរើសអើង*[1187]

[1180] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ៧៧៧, ៨៣៧ ដែលកថាខណ្ឌទាំងពីរនេះ *យោងទៅ* ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ និងបានកែប្រែនៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៩២៤-៩៣១។

[1181] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៧២។

[1182] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៧៣។

[1183] **ឯកសារ D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២ ជើងទំព័រ ១២៨៣។

[1184] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២ ជើងទំព័រ ១២៨៣ *យោងទៅ* ឯកសារ **E3/5835** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក សុត KH 00163522-00163524, 00163525-26 សាក្សីមានវត្តមាននៅស្រែគ្រូ (ឃុំជាងទង) ក្រាំងតាចាន់ (ឃុំគូស) អង្គរកា (ឃុំជាងទង ឬឃុំត្រពាំងខាងជើង) និងអង្គបក្សី (ឃុំជាងទង)។ សម្រាប់ការបញ្ជាក់អត្តសញ្ញាណឃុំទាំងនេះ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៤៦, ២៦៨៣, ៨០៧។ ឯកសារ **E3/2434** សេចក្តីរាយការណ៍របស់មន្ទីរអប់រំស្រុក ១០៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧ KH 00270789។ សម្រាប់ឃុំជាងទង *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៩។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ៨៣៩។

[1185] **ឯកសារ D427** ដីកាដំណោះស្រាយ ជើងទំព័រ ១២៨៣ *យោងទៅ* ឯកសារ **E3/5835** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក សុត KH 00163525-00163526 ។

[1186] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១១, ១១៣៨។

[1187] <u>មូលដ្ឋានទី ៦៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងពីអង្គហេតុនៃ "ការរើសអើង" ចំពោះប្រជាជនថ្មីក្រៅពីការកម្រិតនូវការអនុវត្ត "សិទ្ធិនយោបាយ" មួយចំនួនប៉ុណ្ណោះ* កថាខណ្ឌ ៤៧៥-៤៨០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៨ (ភាសាអង់គ្លេស) ទំព័រ ២៥ (ភាសាបារាំង) ទំព័រ ៣៨-៣៩ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៧១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងពីអង្គហេតុនៃ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការ*

325. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមានកំហុសថា គាត់មិនត្រូវបានចោទប្រកាន់អំពីការរើសអើងប្រជាជនថ្មី នៅត្រាំកក់[1188] ឬ ក្រាំងតាចាន់ ឬ ប្រឆាំងនឹងអតីតមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរនៅទំនប់ ១ មករា និងក្រាំងតាចាន់ ដោយសារគាត់បានចោទប្រកាន់ថា ដីកាដំណោះស្រាយមិនបានដាក់បញ្ចូលអង្គហេតុ នៃ "ការរើសអើង" ហើយដោយសារតែក្រុមជាច្រើន បានប្រឈមនឹងការធ្វើបាបស្រដៀងៗគ្នា[1189]។ ការទទួលស្គាល់ថា មានក្រុមជាច្រើនបានទទួលរងស្ថានភាពលំបាក មិនធ្វើឱ្យបន្ថយលក្ខណៈនៃការរើសអើងចំពោះការធ្វើបាបនោះទេ ដោយសារតាមលក្ខណៈជាក់ស្តែង ក្រុមជាច្រើនអាចត្រូវបានរើសអើងក្នុងពេលដំណាលគ្នា[1190]។ ម្ចាស់បណ្តឹងសាទុក្ខ ក៏មិនអើពើនឹងសេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយដែលថា ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយបានកើតឡើង "នៅគ្រប់ទីតាំង*ស្ទើរតែទាំងអស់*នៅក្នុងវិសាលភាពនៃការស៊ើបអង្កេត" រួមទាំង ទីតាំងនីមួយៗ ដែលបានកត់សម្គាល់ខាងលើ[1191] ព្រមទាំងការសន្និដ្ឋានថា ប្រជាជនថ្មីបានទទួលរងនូវការរើសអើង*ជាក់ស្តែង*នៅទូទាំងប្រទេស[1192] និងថាគោលនយោបាយ

---

*នៃរបបសាធារណរដ្ឋខ្មែរទេ* កថាខណ្ឌ ៤៩០-៤៩២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៩ (ភាសាអង់គ្លេស) ទំព័រ ២៦ (ភាសាបារាំង) ទំព័រ ៤០-៤១ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៧៣</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងពីអង្គហេតុនៃ "ការរើសអើង" ចំពោះប្រជាជនថ្មីទេ* កថាខណ្ឌ ៤៩៥-៤៩៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣០ (ភាសាអង់គ្លេស) ទំព័រ ២៧ (ភាសាបារាំង) ទំព័រ ៤១ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៧៤</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ*គ្មានបណ្តឹងពីអង្គហេតុនៃ "ការរើសអើង" ចំពោះទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទេ* កថាខណ្ឌ ៥០០-៥០៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣០ (ភាសាអង់គ្លេស) ទំព័រ ២៧ (ភាសាបារាំង) ទំព័រ ៤២ (ភាសាខ្មែរ)។

[1188] ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ការរើសអើងដែលត្រូវបានយកមកចោទប្រកាន់នៅស្រុកត្រាំកក់ ត្រូវបានកម្រិតចំពោះ "សិទ្ធិនយោបាយមួយចំនួន" *សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៧៧។

[1189] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៧៨, ៤៩០, ៤៩៧, ៥០២។

[1190] ការចាប់ខ្លួននៅទំនប់ ១ មករា និងមន្ទីរសន្តិសុខក្រាំងតាចាន់គឺ "មិនរើសមុខនោះទេ" ដែលផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ដីកាដំណោះស្រាយលើកឡើងថា ប្រជាជនដែលបាត់ខ្លួនគឺស្ថិតនៅក្នុងចំណោមក្រុមមនុស្សមួយចំនួន *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៩១, ៤៩៨, ៥០២។

[1191] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦ (គូសបញ្ជាក់បន្ថែម)។

[1192] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៣ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៧២ (ប្រជាជនថ្មី គឺជាមនុស្សមួយក្រុម នៅក្នុងស្រទាប់ប្រជាជនទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបាន "ដែលជាលក្ខណៈនយោបាយត្រូវបានចាត់ទុកថាមិនគួរទុកចិត្ត")។ ១៤១៧, ១៤២៤ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៧២ (ក្រុមជា "ខ្មាំង" របស់ ប.ក.ក កម្ពុជា ដូចជា ប្រជាជនថ្មីត្រូវទទួល "ការប្រព្រឹត្តខុសពីគេ" និង "បានស្ថិតនៅក្រោមការប្រព្រឹត្តតឹងរ៉ឹងជាងប្រជាជនចាស់ ក្នុងគោលបំណងលត់ដំឬកំទេចអត្តសញ្ញាណ 'ខ្មាំង' នៅក្នុងចំណោមពួកគេ")។

នៅទូទាំងប្រទេស ដែលកំណត់គោលដៅអតីតមន្ត្រីមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរក្រហម គឺកើតមាននៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ[1193]។ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដដែលនូវទឡ្ហីករណ៍ដែលមិនទទួលបានជោគជ័យពីការជំនុំជម្រះមុន ដោយផ្អែកលើការអានដីកាដំណោះស្រាយមិនបានត្រឹមត្រូវ[1194]។ អ.ជ.ស.ដ ច្រានចោលយ៉ាងត្រឹមត្រូវនូវទឡ្ហីករណ៍នេះ ដោយបានកត់សម្គាល់ថា ការបកស្រាយរបស់ម្ចាស់បណ្តឹងសាទុក្ខ "ពុំបានលើកឡើងខ្លឹមសារសំខាន់"។ ដីកាដំណោះស្រាយបង្កប់ន័យថា ក្រុមគោលដៅមានហានិភ័យជាពិសេសចំពោះ "ការយកទៅអប់រំ ឬ កម្ចាត់ចោល" នៅពេលពួកគេត្រូវបានចាប់ខ្លួនជាក្រុមៗ[1195]។

326. ទាក់ទងទៅនឹងការរើសអើងប្រឆាំង ប្រជាជនថ្មី នៅក្រាំងតាចាន់ និងត្រាំកក់ ដីកាដំណោះស្រាយបានបញ្ជាក់យ៉ាងច្បាស់ថា ប្រជាជនថ្មី ត្រូវបានឃ្លាំមើលយ៉ាងជិតដល់ ហើយនឹងត្រូវចាប់ខ្លួនដោយសារនិយាយប្រឆាំង ប.ក.ក នៅត្រាំកក់[1196] ហើយជាពិសេស ប្រជាជនថ្មី ត្រូវបានចាប់ខ្លួនយកទៅឃុំខ្លួននិងសម្លាប់ខ្លួននៅក្រាំងតាចាន់[1197]។ ក្រោយពេល ប្រជាជនថ្មី បានមកដល់ស្រុកត្រាំកក់ លេខាស្រុក និងឃុំ បានចូលរួមកិច្ចប្រជុំ "ដោយពួកគេត្រូវបានណែនាំថានឹងមានការសម្រិតសម្រាំងក្នុងចំណោមអ្នកដែលត្រូវបានគេជម្លៀស" មកពីភ្នំពេញ[1198]។ ម្ចាស់បណ្តឹងសាទុក្ខ

---

[1193] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២០៨-២០៩។

[1194] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៩០, ៤៩៦, ៤៩៧, ៥០១, ៥០២។ ទឡ្ហីករណ៍នេះត្រូវបានយោងទៅកថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយដែលលើកឡើងថា ខ្មាំងរបស់ ប.ក.ក ដែលត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់ក្នុងលក្ខខណ្ឌពិបាកខ្លាំងនៅតាមសហករណ៍ និងការដ្ឋាន ប៉ុន្តែ មិនរាប់បញ្ចូលនូវភាសាដែលខ្មាំងទាំងនោះត្រូវប្រឈមនឹងការប្រព្រឹត្តិតឹងរ៉ឹង នៅពេលពួកគេត្រូវបានចាប់ខ្លួន *ជាក្រុមៗ* ដើម្បីយកទៅអប់រំឡើងវិញ ឬយកទៅកម្ទេចចោលនៅតាមមន្ទីរសន្តិសុខនានា។

[1195] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៣៥។

[1196] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៩។

[1197] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥០០ ជើងទំព័រ ២១៦៧ *ដែលយោងទៅ* ឯកសារ **E3/7901** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ាង សឿន KH 00163479 ("ស៖ អ្នកទោសមកពីណា? ឆ៖ បែកពីភ្នំពេញមកច្រើន នៅមូលដ្ឋានក៏មាន។ បែកភ្នំពេញហើយ គេយកមនុស្សទៅមូលដ្ឋាន គេហៅពួក ១៧ ហើយគេចម្រាញ់យកមកសម្លាប់")។ ឯកសារ **E3/4627** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀប ឌុច KH 00163493 ("ស៖ អ្នកទោសទាំងនោះគេមកពីណា? ហេតុអ្វីត្រូវឃុំនៅទីនោះ? ឆ៖ ប្រហែលជាភាគច្រើន គឺបងប្អូនដែលជម្លៀសពីទីក្រុង ហៅថា ពួក ១៧ មេសា")។ ឯកសារ **E3/5214** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ សែន KH 00223065-66 ("សួរ៖ តើនៅពេលណាដែលលោកដឹងថា មានការសម្លាប់អ្នកទោសច្រើនជាងគេនៅក្រាំងតាចាន់? ឆ្លើយ៖ គឺនៅក្នុងឆ្នាំ១៩៧៥។ អ្នកទោសដែលគេនាំមកភាគច្រើន គេមិនមានការដាក់ខ្នោះទេ។ គេបញ្ចូលក្នុងគុក រួចហើយ គេហៅចេញទៅវិញ យកទៅសម្លាប់តែម្តង។ អ្នកទោសភាគច្រើនជាអ្នក ១៧ មេសា")។

[1198] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨។

ខ្លួនឯងបានទទួលស្គាល់ថា ដីកាដំណោះស្រាយបានដកស្រង់សាក្សីដែលបានបញ្ជាក់ថាមានការស្រង់ជីវប្រវត្តិនៅស្រុកត្រាំកក់ ដើម្បីឱ្យ ប.ក.ក បោសសម្អាត ប្រជាជនថ្មី និងបញ្ជូនពួកគេទៅក្រាំងតាចាន់[1199] ខណៈមិន អើពើនឹងភស្តុតាងដែលបញ្ជាក់ថា ប្រជាជនថ្មី ត្រូវបានគេចាត់ទុកថាជា "អ្នកទោសធ្ងន់" ហើយត្រូវបានគេធ្វើបាបធ្ងន់ជាងអ្នកទោស "ស្រាល"[1200]។

327. ទាក់ទងនឹងការរើសអើងប្រឆាំងនឹងអតីតមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើនឹងការរកឃើញរបស់ ស.ច.ស ថា មនុស្សជាច្រើននាក់ដែលបានបាត់ខ្លួនពីទំនប់ ១ មករា ទំនងមានទំនាក់ទំនងជាមួយអតីតរបបសាធារណៈខ្មែរ[1201] និងអតីមន្ត្រី និងទាហាន នៃរបបសាធារណរដ្ឋខ្មែរ បានបាត់ខ្លួននៅពេលមកដល់ស្រុកត្រាំកក់ និងត្រូវបានទៅក្រាំងតាចាន់[1202]។ ដីកាដំណោះស្រាយសន្និដ្ឋានបន្ថែមទៀតថា អ្នកដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខដូចជា ក្រាំងតាចាន់ បានប្រឈមនឹងការរើសអើងមុនពេលត្រូវបានចាប់ខ្លួន អប់រំ និងកម្ចាស់ចោល ហើយសកម្មភាពបែបនេះបានបន្តកើតជាអំពើផ្សេងទៀតដែលបានប្រព្រឹត្តឡើងប្រឆាំងពួកគេនៅក្រាំងតាចាន់[1203]។

## ***មូលដ្ឋានទី ៦៨, ៧២, ៧៥, ៧៦, ៧៧, ១២៤, ១៣៤៖ បណ្តឹងចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ បីក្រុម[1204]***

[1199] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៩៧ *យោងទៅ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨។

[1200] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥០០ ជើងទំព័រ ២១៦៧ *យោងទៅ* ឯកសារ **E3/5214** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុយ សែន KH 00223066-67។

[1201] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៦។

[1202] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨ ជើងទំព័រ ២១៥៩។

[1203] **ឯកសារ D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩១៨។

[1204] <u>មូលដ្ឋានទី ៦៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ទំនប់ត្រពាំងថ្ម៖ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ* កថាខណ្ឌ ៤៨២-៤៨៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៨ (ភាសាអង់គ្លេស) ទំព័រ ២៥ (ភាសាបារាំង) ទំព័រ ៣៩ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៧២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *បណ្តឹងកម្រិតត្រឹមក្រុមចំនួនបី នៅក្នុងផ្នែកកំណត់ប្រភេទបទល្មើសនៃដីកាដំណោះស្រាយ* កថាខណ្ឌ ៤៩៣-៤៩៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៩ (ភាសាអង់គ្លេស) ទំព័រ ២៦-២៧ (ភាសាបារាំង) ទំព័រ ៤១ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៧៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *បណ្តឹងកម្រិតត្រឹមក្រុមចំនួនបី នៅក្នុងផ្នែកកំណត់ប្រភេទបទល្មើសនៃដីកាដំណោះស្រាយ* កថាខណ្ឌ ៥០៥-៥១០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣០ (ភាសាអង់គ្លេស) ទំព័រ ២៧-២៨ (ភាសាបារាំង) ទំព័រ ៤២ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៧៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *យុត្តាធិការកម្រិតត្រឹមក្រុមចំនួនបី នៅក្នុងផ្នែកកំណត់ប្រភេទបទល្មើសនៃដីកាដំណោះស្រាយ* កថាខណ្ឌ ៥១១-៥១៣។ ឯកសារ

328. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនបានទទួលបណ្តឹងឱ្យចាត់ទុក "ខ្មាំងពិតប្រាកដ ឬ ខ្មាំងតាមការសន្មតរបស់ ប.ក.ក" ថាជាក្រុមត្រូវបានធ្វើទុក្ខបុកម្នេញ[1205] គឺផ្អែកលើការអានមិនត្រឹមត្រូវលើដីកាដំណោះស្រាយ ហើយមិនមានមូលដ្ឋានច្បាប់គាំទ្រ។ អង្គជំនុំជម្រះនេះបានរកឃើញពីមុនថា "ខ្មាំងពិតប្រាកដ ឬ ខ្មាំងតាមការសន្មតរបស់ ប.ក.ក" គឺជាក្រុមដែលគេអាចញែកចែកដាច់[1206] ទោះបីនៅពេលក្រុមនោះ "អាចមានមនុស្សប្រភេទ*ផ្សេងៗគ្នា*"[1207] ដែលមិនមែនជាក្រុមតែមួយក៏ដោយ[1208]។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ ត្រូវបានគេ "ត្រូវបានយល់ច្បាស់ថា មានការរួមបញ្ចូលស្ថានការណ៍នានា ក្នុងនោះចារីបានកំណត់ក្រុមគោលដៅជាទូទៅ"[1209] ហើយអនុញ្ញាតឱ្យក្រុមដែលធ្វើទុក្ខបុកម្នេញត្រូវបានកំណត់ក្នុងន័យអវិជ្ជមាន (ពោលគឺ មិនមែនជាខ្មែរ) ឬ នៅក្នុងវិធីរួមមួយ (ពោលគឺក្រុមជាមួយមនោគមវិជ្ជា)[1210] ក្នុង

---

**F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣១ (ភាសាអង់គ្លេស) ទំព័រ ២៨ (ភាសាបារាំង) ទំព័រ ៤៣ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៧៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ* កថាខណ្ឌ ៥១៤-៥១៦, ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣១ (ភាសាអង់គ្លេស) ទំព័រ ២៨ (ភាសាបារាំង) ទំព័រ ៤៣ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ១២៤</u>៖ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៥-៤៦ (ភាសាអង់គ្លេស) ទំព័រ ៤១-៤២ (ភាសាបារាំង) ទំព័រ ៦៤-៦៥ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ១៣៤</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ* កថាខណ្ឌ ៨៨៤-៨៨៦, ឯកសារ **F54.1.1** ឧបសម្ព័ន្ធ **ក** នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៨ (ភាសាអង់គ្លេស) ទំព័រ ៤៤ (ភាសាបារាំង) ទំព័រ ៦៨ (ភាសាខ្មែរ)។

[1205] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៨២-៤៨៣, ៤៩៣-៤៩៤, ៥០៥-៥១០, ៥១១-៥១៣, ៥១៤-៥១៦, ៨៨៤-៨៨៦។

[1206] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៧៣, ២៨២។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៦៩។ ដើម្បីសម្រេចថាតើមនុស្សមួយក្រុម អាចឱ្យយល់បានយ៉ាងគ្រប់គ្រាន់សម្រាប់គោលបំណងនៃការធ្វើទុក្ខបុកម្នេញ នោះកត្តាបង្ហាញផ្លូវគឺ *ថាតើចារី*បានកំណត់ក្រុមនោះថាដូចម្តេច *សូមមើល* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៧២-២៧៣។ អ.ជ.ត.ក បានបញ្ជាក់បន្ថែមថា "ដោយខ្មាំងនយោបាយ ត្រូវបានកំណត់តាមគោលនយោបាយមួយ ដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅ ខណៈដែលប្រជាជនដទៃទៀតទទួលបានសេរីភាព នោះមានមូលដ្ឋានក្នុងការយល់ឃើញថា មានអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតយុនយោបាយ") *សូមមើល*សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៨២ ហើយចារីនៃអំពើធ្វើទុក្ខបុកម្នេញអាចកំណត់គោលដៅលើក្រុមប្រមូលផ្តុំ ដែលគ្មានអត្តសញ្ញាណ ឬកម្មវិធីរួមគ្នាណាមួយបាន *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៧៨។

[1207] សំណុំរៀង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៧២ (គូសបញ្ជាក់បន្ថែម)។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៦៩។

[1208] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៧៨។

[1209] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៧៧។

[1210] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៧៨ *យោងទៅ*សាលក្រម *Tadić* កថាខណ្ឌ ៧១៤-៧១៨ សាលក្រម *Ministries* ទំព័រ ៦០៤ សាលក្រម *Kupreškić* កថាខណ្ឌ ៦០២។

របៀបមួយដែលវា "អាចកំណត់គោលដៅលើក្រុមប្រមូលផ្តុំ ដែលគ្មានអត្តសញ្ញាណ ឬ កម្មវិធីរួមគ្នាណាមួយបាន"[1211]។ វិធីសាស្ត្រនេះបានទទួលការ គាំទ្របន្ថែមទៀតដោយសំអាងហេតុ ពីយុត្តិធម៌ក្រោយសង្គ្រាមលោកលើកទី២ ដែលក្នុងនោះ ការធ្វើទុក្ខបុកម្នេញត្រូវបានបង្កើតឡើងប្រឆាំងនឹងមនុស្សមួយក្រុមធំ ដែលត្រូវបានកំណត់គោលដៅថាជា "ខ្មាំង" ដោយពួកណាស៊ី[1212]។

329. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ បណ្តឹងដាក់ជូនទៅ អ.ជ.ស.ដ មិនកម្រិតត្រឹមអតីតមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនខ្មែរ ដែលវិលត្រឡប់មកពីបរទេសវិញនោះទេ[1213]។ ការអានឱ្យបានត្រឹមត្រូវទៅលើដីកាដំណោះស្រាយ បានធ្វើឱ្យ អ.ជ.ស.ដ សន្និដ្ឋាន យ៉ាងត្រឹមត្រូវថា ក្រុមទាំងបីដែលបានរៀបរាប់ខាងលើ ត្រូវបានគេយោងក្នុងពាក្យពេចន៍មិនអាចរាប់អស់ ដោយលើកជាឧទាហរណ៍នៅក្នុងប្រភេទទូលំទូលាយនៃខ្មាំងពិតប្រាកដ ឬ ខ្មាំងតាមការសន្មត[1214]។ ដូច្នេះ អ.ជ.ស.ដ បានទទួលបណ្តឹងឱ្យពិចារណាលើការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងក្រុមនេះ ដែលរួមមាន "បុគ្គលណាដែលមិនយល់ស្របជាមួយនឹងមនោគមន៍វិជ្ជា ប.ក.ក"[1215]។

330. ដីកាដំណោះស្រាយបានបញ្ជាក់ថា គោលនយោបាយសំខាន់មួយក្នុងចំណោមគោលនយោបាយស្នូលទាំង ៥ របស់ ប.ក.ក គឺដើម្បី "សម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម ប.ក.ក [...]

---

1211 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៧៨។

1212 សាលក្រម *Ministries* ទំព័រ ៥៤៧។ ពាក់ព័ន្ធនឹងការបង្កើតជំរុំអប់រំកែប្រែ តុលាការរកឃើញថា កន្លែងអប់រំកែប្រែទាំងនោះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីដាក់ពន្ធនាគារអ្នកទាំងឡាយដែលមិនយល់ស្របជាមួយគោលនយោបាយពួកណាហ្ស៊ី (Nazi) ឬអ្នកទាំងឡាយដែលក្លាយជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញរបស់ពួកណាហ្ស៊ី ដូចជា បុព្វជិតសាសនាកាតូលិក គ្រូគង្វាលសាសនាប្រូតេសស្តង់ ក៏ដូចជា គូប្រឆាំងខាងនយោបាយ ជនជាតិជ្វីហ្វ និងជនបរទេសដែលបានបះបោរប្រឆាំងនឹងក្រុមរបស់ពួកគេ ឬអ្នកដែលបានបំពាននឹងស្ថានភាពឃោរឃៅដែលត្រូវបានយកមកបង្ខំពួកគេឱ្យធ្វើការងារ"។ ដូចគ្នានេះដែរ តុលាការបានសម្រេចថា មធ្យោបាយដែលក្រុមណាហ្ស៊ីបានប្រើប្រាស់តុលាការ និងសាលាជម្រះក្តីនានាយ៉ាងប៉ិនប្រសព្វដើម្បីដកហូតយ៉ាងសម្បើមនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការធ្វើទុក្ខបុកម្នេញជាបន្តទៅលើ "ជនជាតិជ្វីហ្វ និងពួកខ្មាំងដទៃទៀត ព្រមទាំងគូបដិបក្ខនៃពួកសង្គមនិយម" សូមមើល ទំព័រ ៦០២-៦០៤ (ដកស្រង់ពីទំព័រ ៦០៤)។

1213 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៨២, ៤៩៤, ៥០៧, ៥១២, ៥១៥, ៨៨៦។

1214 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧០ (សំដៅលើការប្រើពាក្យ "ដូចជា" ដោយ ស.ច.ស នៅពេលរៀបរាប់ក្រុមដែលបានលើកឡើងទាំងនេះ)។ *សូមមើលផងដែរ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៦៣-១៣៦៤, ១៤១៦-១៤១៨, ១៤២៤ (ដែលក្រុមទាំងនេះត្រូវបាននិយាយសំដៅជាឧទាហរណ៍ដែលស្ថិតនៅក្នុងប្រភេទទូលំទូលាយនៃខ្មាំងពិតប្រាកដ ឬដោយការសន្មត)។

1215 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៨។

តាមរយៈការសម្លាប់ "ខ្មាំង""[1216]។ ស.ច.ស បានរកឃើញថា ប.ក.ក បានចាត់ទុកជា "ខ្មាំង" បុគ្គលណា ដែលមិនយល់ស្របនឹងមនោគមន៍វិជ្ជា ប.ក.ក[1217] រួមទាំង អ្នកទាំងឡាយដែលសង្ស័យថាជាភ្នាក់ងារស៊ើបការណ៍កណ្តាលនៃសហរដ្ឋអាមេរិក (សេ.អ៊ី.អា) ឬ កា.ហ្សេ.បេ ឬ គេញវៀតណាម ("យួន")[1218] បុគ្គលដែលចូលរួមនៅក្នុងសកម្មភាព "អសីលធម៌" ជាប់ទាក់ទងនឹងរបបចាស់[1219] បុគ្គល ដែលមិនយល់ព្រមរៀបការដោយបង្ខំ[1220] និងបុគ្គលដែលមិនបានបំពេញការងារតាមពេលវេលាកំណត់ឱ្យបានទាន់ពេលវេលា[1221]។ ស.ច.ស បានរកឃើញបន្ថែមទៀតថា ប.ក.ក បានអំពាវនាវឱ្យចាប់ខ្លួន សួរចម្លើយ និងកំទេច "ខ្មាំង" របស់ខ្លួន[1222]។ តាមរយៈសំអាងហេតុទាំងនេះ ស.ច.ស បានសម្រេចថា "អាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជាបានកំណត់អត្តសញ្ញាណ "ខ្មាំង" ជាច្រើនក្រុម ដោយសារមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬសន្មតរបស់ក្រុមមនុស្សទាំងនេះ ឬ ដោយសារមូលហេតុនៃការប្រឆាំងរបស់ពួកគេទៅនឹងអ្នកកាន់អំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា [...] "ខ្មាំង" ប្រភេទនេះ កាន់តែមានច្រើនទៅៗ ទៅតាមពេលវេលា។ម្យ៉ាងទៀត ការកំណត់មនុស្សដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយឈរលើមូលដ្ឋាននៃការបំបាត់រាល់បុគ្គលទាំងឡាយណា ដែលមិនយល់ស្របនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាជាក់ស្តែង គឺជាទម្រង់មួយនៃការធ្វើទុក្ខបុកម្នេញដោយសាររមូលហេតុនយោបាយ"[1223]។

331. ទាក់ទងនឹងទំនប់ត្រពាំងថ្ម[1224] ម្ចាស់បណ្តឹងសាទុក្ខមិនខ្វល់នឹងការរកឃើញយ៉ាងច្បាស់ក្រឡែតដោយ ស.ច.ស ដែលក្នុងនោះអតីតទាហាន និងកម្មាភិបាលនៃ ប.ក.ក ត្រូវបានគេដឹងថាធ្វើការប្រមូលប្រវត្តិរូបរបស់អ្នកធ្វើការងារ "ដើម្បីកំណត់អ្នកទាំងឡាយដែលក្រោយមកត្រូវបានចាប់

---

[1216] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៧៨-១៧៩, ១៤១៦-១៤១៨ (នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ "នៅតាមសហករណ៍ និងតាមការដ្ឋានធ្វើការដោយបង្ខំ [...] ខ្មាំងពិត ឬតាមការសន្មតរបស់ ប.ក.ក ត្រូវបានគេបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត [... និង] ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅអប់រំឡើងវិញ ឬយកទៅកម្ទេចចោលនៅតាមមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស" រួមមាន ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង ក្រាំងតាចាន់ អូរកន្សែង ភ្នំក្រោល)។

[1217] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៧។

[1218] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៨០, ១៩០។

[1219] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩១។

[1220] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២២០។

[1221] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១១។

[1222] *សូមមើលឧទាហរណ៍* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៨៣, ១៨៦, ១៨៨-១៩០, ១៩១, ២០២។

[1223] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៧។

[1224] ឆ្លើយតបយ៉ាងជាក់លាក់ទៅនឹងមូលដ្ឋានទី ៦៨។

ខ្លួន ឬ សម្លាប់"[1225]។ ស.ច.ស បានរកឃើញថា កងករណីពិសេសត្រូវបានបង្កើតឡើងនៅតំបន់ត្រពាំងថ្ម សម្រាប់អ្នកដែលត្រូវបានចាត់ទុកថា "មានជំងឺមនោគមន៍"[1226] និងបានបញ្ជាក់ថា "មានការបង្កប់គិញសម្ងាត់ចុះតាមដានត្រួតពិនិត្យនៅតាមកងនានា ដើម្បីស៊ើបសួររកពីជជីវប្រវត្តិ និងសាវតាររបស់អ្នកលើកទំនប់ និងកំណត់ពីអង្គសញ្ញាណរបស់បុគ្គល ដែលត្រូវចាប់ខ្លួន[...] ពួកគេត្រូវបានចោទថាជា "ពួកសេអ៊ីអារបស់អាមេរិកកាំង" ឬ មានទំនាក់ទំនងជាមួយ "យួន"[1227]។

332. ទាក់ទងនឹងក្រាំងតាចាន់[1228] ដីកាដំណោះស្រាយបានបញ្ជាក់លម្អិតថា កម្មករត្រូវបានបញ្ជូនទៅកន្លែងនោះ "លត់ដំ និងកសាងខ្លួន ដោយសារតែខ្លួនមានប្រវត្តិរូប "មិនល្អ" ឬ ជាប់ពាក់ព័ន្ធជាមួយខ្សែក្បត់"[1229] និងរៀបរាប់ក្រុមជាច្រើនដែលត្រូវបានចាត់ទុកថាជា "ខ្មាំង" នៅក្រាំងតាចាន់ រួមទាំង "សមាសធាតុមិនល្អ" ពីកងពលធំលេខ ៥០២ អ្នកពាក់ព័ន្ធនៅក្នុងអង្គភាពកងទ័ពបដិវត្តន៍កម្ពុជាមួយចំនួន និងកងទ័ពមកពីភូមិភាគបូព៌ា[1230]។ ដីកាដំណោះស្រាយលើកឡើងបន្ថែមទៀតថា ខ្មាំង រួមបញ្ចូល កងទ័ពចំនួន ៥,០០០ នាក់ ដែលត្រូវបានបោសសម្អាតពីភូមិភាគបូព៌ា[1231] ត្រូវបាន

---

1225 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៤៣។ ស.ច.ស បាននិយាយសំដៅលើសាក្សីទាំងឡាយដែលបានបញ្ជាក់ថា ប.ក.ក "បានសិក្សាអំពីប្រវត្តិរបស់មនុស្សនោះ តើពីមុនមានធ្លាប់ខូចខិលដែរឬអត់" *ជើងទំព័រ* ១៤៣៣ *យោងលើ* ឯកសារ **E3/5281** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េង ប៊ុនថារ៉ា KH00295963 ហើយ "ប្រសិនបើ [ប.ក.ក] ចង់ចាប់យើង [...] គេតាមដាកសួររកប្រវត្តិឪពុកម្តាយ បងប្អូន ឋាន: វណ្ណ: ឬបុណ្យសក្តិ" ឯកសារ **E3/7323** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង សាមួត KH 00279088។

1226 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣៦។ ស.ច.ស បានបន្តថា៖ ""កងករណី" ត្រូវកំណត់ឱ្យធ្វើការច្រើនជាងគេ ហើយអ្នកដែលគេចាត់ទុកថាមិនអាចអប់រំកែប្រែបាន អ្នកនោះបានបាត់ខ្លួនរហូត ហើយមិនដែលឃើញត្រឡប់មកវិញទេ"។

1227 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៤៦។

1228 ឆ្លើយតបយ៉ាងជាក់លាក់ទៅនឹងមូលដ្ឋានទី ៧២។ ម្ចាស់បណ្តឹងសាទុក្ខនិយាយឡើងវិញអំពីការអះអាងនេះក្នុងមូលដ្ឋានបណ្តឹងសាទុក្ខដាច់ដោយឡែកមួយ (<u>មូលដ្ឋានទី ១២៤</u>)។ ប៉ុន្តែ គាត់ពុំបានដាក់បញ្ចូលទឡ្ហីករណ៍ទាំងនោះដើម្បីគាំទ្រដល់<u>មូលដ្ឋានទី ១២៤</u> នៅត្រង់ចំណុចណាមួយក្នុងសារណារបស់គាត់នោះទេ ហើយដូចដែលម្ចាស់បណ្តឹងសាទុក្ខខ្លួនគាត់ផ្ទាល់បានធ្វើការកត់សម្គាល់ថា "ឧបសម្ព័ន្ធ **ក** មិនមានការចោទប្រកាន់ណាមួយសោះ។ [...] ទឡ្ហីករណ៍ទាំងអស់ ដែលសហព្រះរាជអាជ្ញាត្រូវឆ្លើយតប មាននៅក្នុងសារណាបណ្តឹងសាទុក្ខ ៧៥០ ទំព័រ"។ សហព្រះរាជអាជ្ញាយល់ឃើញថា នេះជាចម្លើយតបគ្រប់គ្រាន់មួយទៅនឹងមូលដ្ឋានទី ៧២ និង ១២៤ *សូមមើល* ឯកសារ **F55/1** ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើសុំបន្ថែមចំនួនទំព័ររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤-៥។

1229 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៨-៣៩២។

1230 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៧, ៣៨៩។

1231 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២៩០ *យោងទៅឧទាហរណ៍* ឯកសារ **E3/5273** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ គីន KH 00282942 (ស៖ "តើលោកដឹងទេ ហេតុអ្វីបានជាគេយកមនុស្សភូមិភាគបូព៌ាមកធ្វើព្រលាន

គេបញ្ជូនទៅ "អប់រំ" ឬ សម្លាប់ចោលនៅក្រាំងតាចាន់[1232] ហើយលក្ខខណ្ឌនៃការរស់នៅ និងការងារអាស្រ័យលើទីតាំងអាស្រ័យលើ "កម្រិតនៃ "ការក្បត់" ដែលគេសន្មតចោទប្រកាន់"[1233]។

333. ទាក់ទងនឹងក្រាំងតាចាន់[1234] ដីកាដំណោះស្រាយបានបញ្ជាក់យ៉ាងច្បាស់ថា ការចាប់ខ្លួនបានកើតឡើងដោយផ្អែកលើប្រវត្តិរបស់ខ្មាំង[1235] ហើយអ្នកទោសត្រូវបានសួរចម្លើយ ការចោទប្រកាន់ថាជាខ្មាំងហើយបានប្រាប់ឱ្យកំណត់ "មេដឹកនាំជនក្បត់"[1236]។ អ្នកដែលជាប់ឃុំរួមមាន "អតីតទាហានសាធារណរដ្ឋខ្មែរ កម្មាភិបាល ប.ក.ក ចិន វៀតណាម និងចាម"[1237]។ ដីកាដំណោះស្រាយពិពណ៌នាអំពីអតីតអ្នកជាប់ឃុំម្នាក់ ដែលត្រូវបានគេសួរថា "តើគាត់គឺជា សេ.អ៊ី.អា អាមេរិក ឬ យួន" និងកត់សំគាល់ថា ប្រជាជនប្រហែលជាត្រូវបានចោទសួរអំពីជាប់ទាក់ទងនឹងរណសិរ្សរួបរួមជាតិកម្ពុជា[1238]។

---

យន្តហោះនេះ? ហេតុអ្វីបានជាគេចាប់ចងមនុស្សទាំងនោះដាក់តាមឡានយកទៅភ្នំពេញ? ឆ៖ ខ្ញុំឮគេនិយាយថា ពួកនេះជាគីញកាហ្សេបេ ឬសេអ៊ីអា។ គេយកពួកនេះមកលត់ដំ ពីព្រោះពួកនេះត្រូវបាគេចោទថាក្បត់ជាមួយ*អង្គការ*។ ខ្ញុំមិនដឹងពីមូលហេតុដែលគេចាប់ចងពួកនេះទេ ប៉ុន្តែ ខ្ញុំឃើញផ្ទាល់នឹងភ្នែកចំនួនពីរដង ដោយគេភ្ជង់កាំភ្លើង និងចងរុញដាក់ឡានចេញទៅ")។

[1232] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២០១, ១៣៧៧។

[1233] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩០។ ក្រុមខ្មាំងក្បត់ធ្ងន់ធ្ងរត្រូវប្រឈមមុខនឹងស្ថានភាពរស់នៅធ្ងន់ធ្ងរ និងជាគោលដៅនៃការសម្លាប់ចោល *សូមមើល* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩០-៣៩២ *ដែលយោងទៅឧទាហរណ៍* ឯកសារ **E3/5530** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោត រិន KH 00418493-94។ ឯកសារ **E3/5280** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម ហឿន KH 00287556-58។ ឯកសារ **E3/7877** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លោកស្រី ទេស ត្រិច KH 00342437-38។ ឯកសារ **E3/467** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ លឿ KH 00170619-20។ ឯកសារ **E3/369** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ម៉ុន KH 00195438-39។ ឯកសារ **E3/471** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យឿន KH ERN 00172081។ ឯកសារ **E3/5276** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត KH 00282954-55។ ឯកសារ **E3/5277** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិល កាន KH 00287545-46។ ឯកសារ **E3/3961** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ ជា KH 00205059។ ឯកសារ **E3/5263** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី KH 00270179-80។

[1234] ឆ្លើយតបយ៉ាងជាក់លាក់ទៅនឹងមូលដ្ឋានទី ៧៥។

[1235] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៧, ៤៩៨, ៥០០។

[1236] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥០៩។ *សូមមើលផងដែរ* កថាខណ្ឌ ៥០៦។

[1237] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥០០។

[1238] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥០៦។

334. ទាក់ទងនឹង អូរកន្សែង[1239] ស.ច.ស បានរៀបរាប់លម្អិតថា អូរកន្សែង ត្រូវបានបង្កើតឡើង ដើម្បីចម្រាញ់ អប់រំ និងបោសសម្អាត "សមាសធាតុប្រឆាំងបដិវត្តន៍""មិនល្អ"[1240]។ ដីកាដំណោះស្រាយកត់សម្គាល់ថា អ្នកទោសត្រូវបានចាប់ខ្លួនពីបទ "រិះគន់" បក្ស[1241] ហើយបានសួរអំពី "បណ្តាញ និងសកម្មភាពរបស់ពួកគេ"[1242]។ ស.ច.ស បាន រកឃើញថាអ្នកជាប់ឃុំ រួមមាន កម្មករសហជីព ជនជាតិភាគតិចចារ៉ាយ កម្មាភិបាលកងពលធំលេខ ៨០១ បញ្ញាវ័ន្ត និងយួន[1243]។

335. ទាក់ទងនឹងភ្នំក្រោល[1244] ស.ច.ស បានលើកឡើងត្រង់ៗថា អ្នកទោសនៅភ្នំក្រោល ត្រូវបាន "ចាប់ខ្លួនក្រោមការសង្ស័យថាជាជនក្បត់នឹងបដិវត្តន៍" ហើយក្រោយពេលចាប់ខ្លួន អ្នកទោសត្រូវសរសេរប្រវត្តិរូបរបស់ខ្លួន[1245]។ ស.ច.ស. បានកត់សម្គាល់ថា អ្នកទោសត្រូវបានបង្ខំឱ្យចូលរួមការប្រជុំ ដែលពួកគេត្រូវបានចោទប្រកាន់ថាជា សេ.អ៊ី.អា[1246] ហើយនៅពេលសួរចម្លើយ ពួកគេត្រូវបានចោទសួរអំពីទំនាក់ទំនងរបស់ពួកគេជាមួយបណ្តាញ សេ.អ៊ី.អា និង/ឬ វៀតណាម[1247]។

336. ដូច្នេះ វាបង្ហាញច្បាស់ថា ស.ច.ស មិនបានកម្រិតការយល់ឃើញរបស់ខ្លួនទៅលើការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅទំនប់ត្រពាំងថ្ម, ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ក្រាំងតាចាន់, អូរកន្សែង, និង ភ្នំក្រោល ត្រឹមតែបីក្រុម ដូចម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនោះទេ។ ផ្អែកលើការយល់ឃើញផ្នែកអង្គហេតុទាំងនេះ អ.ជ.ស.ដ បានទទួលបណ្តឹងយ៉ាងជាក់លាក់ឱ្យពិចារណាទៅលើការធ្វើទុក្ខបុកម្នេញ "ខ្មាំងពិតប្រាកដ ឬ ខ្មាំងតាមការសន្មត" នៅតាមទីតាំងនីមួយៗ និងដើម្បីកំណត់បុគ្គលនានា ដែលរួមបញ្ចូលនៅក្នុងក្រុមនោះ ដោយផ្អែកលើអង្គហេតុនៃសំណុំរឿង ០០២/០២។

337. ដោយទទួលបានយ៉ាងត្រឹមត្រូវនូវសំអាងហេតុ និងសំអាងច្បាប់យ៉ាងជាក់លាក់ទាំងនេះរួចមក អ.ជ.ស.ដ បានពិនិត្យថា តើក្រុមគោលដៅនៃ "ខ្មាំងពិតប្រាកដ ឬ ខ្មាំងតាមការសន្មតរបស់

---

1239 ឆ្លើយតបយ៉ាងជាក់លាក់ទៅនឹងមូលដ្ឋានទី ៧៦។

1240 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥៩១, ៦០៥។

1241 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៦០០-៦០១។

1242 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៦១៣។

1243 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥៩៩, ៦០១, ៦០៣, ៦១៤, ៦១៧។

1244 ឆ្លើយតបយ៉ាងជាក់លាក់ទៅនឹងមូលដ្ឋានទី ៧៧។

1245 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៣៤។

1246 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៣៤។

1247 ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៦៤០។

ប.ក.ក” អាចបែងចែកបានយ៉ាងគ្រប់គ្រាន់ដែរឬទេ នៅទំនប់ត្រពាំងថ្ម ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល ដើម្បីអនុញ្ញាតឱ្យខ្លួនធ្វើការ ពិចារណាថា តើធាតុផ្សំចាំបាច់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ត្រូវបានបង្ហាញដែរឬទេ[1248]។ ដោយសារ ភស្តុតាងច្រើនលើសលប់នៃការធ្វើបាបខុសៗគ្នាទទួលរងដោយបុគ្គលដែលត្រូវបានគេកំណត់ថាមាន “ប្រវត្តិមិនល្អ” អ.ជ.ស.ដ ជឿជាក់ថា “ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក” គឺជាក្រុមជាក់លាក់ នៅតាមការដ្ឋាននីមួយៗ[1249]។ ដូច្នេះ អ.ជ.ស.ដ បានទទួលបណ្តឹងត្រឹមត្រូវដើម្បីពិចារណាថា តើ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ត្រូវបានបង្ហាញប្រឆាំងនឹង “ខ្មាំងពិតប្រាកដ ឬ ខ្មាំងតាមការសន្មតរបស់ ប.ក.ក” នៅទំនប់ត្រពាំងថ្ម ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ក្រាំងតាចាន់ អូរកន្សែង និង ភ្នំក្រោល ដែរឬទេ។

[1248] សម្រាប់ទំនប់ត្រពាំងថ្ម *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤០៧។ នៅក្នុងកថាខណ្ឌដដែលនេះ អ.ជ.ស.ដ កត់សម្គាល់ឃើញថា “ភាពអាចបែងចែកបានរបស់ក្រុមនេះ អាចត្រូវបានវាយតម្លៃដោយពិនិត្យមើលថាតើជនរងគ្រោះស្ថិតនៅក្នុងប្រភេទណាមួយនៃក្រុម ដូចបានកំណត់ដោយថ្នាក់ដឹកនាំបក្សដែរឬទេ”។ សម្រាប់ព្រលានយន្តហោះកំពង់ឆ្នាំង *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨២១។ សម្រាប់ក្រាំងតាចាន់ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៣៨។ សម្រាប់អូរកន្សែង *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨៣។ សម្រាប់មន្ទីរសន្តិសុខភ្នំក្រោល *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៣៩។ កំណត់ចំណាំ៖ ម្ចាស់បណ្តឹងសាទុក្ខនិយាយឡើងវិញអំពីអំណះអំណាងនេះសម្រាប់មន្ទីរសន្តិសុខភ្នំក្រោល *សូមមើល* មូលដ្ឋានទី ១៣៤។ យ៉ាងណាក៏ដោយ គាត់ពុំបានចង្អុលបង្ហាញភស្តុតាងទៅលើមូលដ្ឋាននេះទេ និងគ្រាន់តែយោងទៅលើមូលដ្ឋានទី ៧៧ ប៉ុណ្ណោះ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាយល់ថា នេះគឺជាការគ្រប់គ្រាន់ ចម្លើយតបទៅនឹងមូលដ្ឋានទី ៧៧ និង ១៣៤។

[1249] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤០៧ (អ្នកដែលត្រូវបានគេកំណត់អត្តសញ្ញាណថាជាប្រជាជនថ្មី អតីតទាហាន លន់ នល់, យួន, ភ្នាក់ងារសេ.អ៊ី.អា, សិស្ស និស្សិត បញ្ញវន្ត និងអ្នកដែលគេចាត់ទុកថា បានចូលរួមក្នុងសកម្មភាពប្រឆាំង*អង្គការ* ត្រូវបានគេកំណត់គោលដៅដើម្បីចាប់ខ្លួននៅការដ្ឋានទំនប់ត្រពាំងថ្ម), ១៨២១ (កងទ័ពទាំងឡាយដែលត្រូវបានគេបញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់ថាជាខ្មាំង ដោយសារជំនឿនយោបាយ ឬការប្រឆាំងរបស់ពួកគេទៅនឹង ប.ក.ក ពិតប្រាកដ ឬតាមការសន្មត), ២៨៣៨, ២៩៨៣, ៣១៣៩ (ប.ក.ក បានកំណត់ថាជាខ្មាំងចំពោះ “អ្នកដែលប្រឆាំងបដិវត្តន៍ អ្នកដែលរិះគន់ និងជនក្បត់បដិវត្តន៍ ពួកសក្តិភូមិ ភ្នាក់ងារបរទេស ដូចជាវៀតណាម និងអ្នកដែលចូលដៃជាមួយប្រភេទក្រុមមនុស្សខាងលើផងដែរ”)។

## មូលដ្ឋានទី ៦៩៖ បណ្តឹងនៃការស្លាប់នៅក្នុងភូមិ និងមន្ទីរពេទ្យ នៅក្រៅទំនប់ ១ មករា[1250]

338. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសឆ្គង[1251] ដោយគ្មានការគាំទ្រណាមួយថា ដីកាដំណោះស្រាយកំណត់ឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាតែទៅលើការស្លាប់ ដែលកើតឡើងដោយផ្ទាល់នៅទំនប់ ១ មករា។ ផ្ទុយពីការអះអាងនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ដោយត្រឹមត្រូវថា ដីកាដំណោះស្រាយបានចោទប្រកាន់ម្ចាស់បណ្តឹងសាទុក្ខពីបទសម្លាប់រង្គាល[1252] ដោយផ្អែកលើមូលដ្ឋានថា ប្រជាជនជាច្រើនបានស្លាប់ "ដោយសារតែលក្ខខណ្ឌ" នៅទំនប់១មករា ដូចជា "ការមិនផ្តល់ម្ហូបអាហារ ទីកន្លែងស្នាក់នៅ ការថែទាំផ្នែកវេជ្ជសាស្ត្រ និងអនាម័យ ព្រមទាំងការបាក់កម្លាំង"[1253]។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ថា ស្ថានភាព "បណ្តាលឱ្យមនុស្សឈឺជាច្រើន ដោយសារជំងឺផ្សេងៗ" "មន្ទីរពេទ្យភាគច្រើននៅឆ្ងាយ [...] បុគ្គលិកពេទ្យ [...] មិនមានពេទ្យប្រចាំការនៅការដ្ឋានសាងសង់"[1254] ដោយដកស្រង់ចម្លើយសាក្សីជាច្រើន ដែលបានបញ្ជាក់ថា អ្នកដែលធ្លាក់ខ្លួនឈឺធ្ងន់ ត្រូវបានគេបញ្ជូនចេញពីការដ្ឋាន[1255]។ ដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់បន្ថែមទៀតថា ប្រជាជន "ស្លាប់ដោយសារជំងឺ"[1256]។

---

[1250] <u>មូលដ្ឋានទី ៦៩៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងពីការស្លាប់នៅក្រៅទំនប់១មករា* កថាខណ្ឌ ៤៨៤-៤៨៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ២៨ (ភាសាអង់គ្លេស) ទំព័រ ២៥-២៦ (ភាសាបារាំង) ទំព័រ ៣៩-៤០ (ភាសាខ្មែរ)។

[1251] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៨៥។

[1252] កំណត់ប្រភេទនៃបទល្មើសឡើងវិញ ថាជាអំពើមនុស្សឃាត ដោយមានចេតនាប្រយោល *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦៨, ១៦៧២។

[1253] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦៨ *ដកស្រង់* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៥៩ (កត់សម្គាល់ពីអាហារមិនគ្រប់គ្រាន់ ការស្នាក់នៅមិនសមស្រប និងការខ្វះបរិក្ខារផ្សេង រួមទាំងមុងផង) កថាខណ្ឌ ៣៦៣ (បញ្ជាក់ថា អ្នកខ្លះឈឺស្លាប់) កថាខណ្ឌ ១៣៨១, ១៣៨៧, ១៣៨៩។

[1254] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦០។

[1255] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦០ ជើងទំព័រ ១៥៤១ *ដកស្រង់* ឧទាហរណ៍ ឯកសារ **E3/5267** កំណត់ហេតុស្តាប់ចម្លើយ អ៊ុត សេង ERN 00271410 ឯកសារ **E3/7775** កំណត់ហេតុស្តាប់ចម្លើយ កង អ៊ុត ERN 00229056 ("ក្នុងករណីបើមានអ្នកណាឈឺធ្ងន់ធ្ងរ គេបញ្ជូនទៅមន្ទីរពេទ្យដែលនៅឆ្ងាយ")។ ឯកសារ **E3/5255** កំណត់ហេតុស្តាប់ចម្លើយ ឱ ហួ ERN 00239910 ("ចំពោះអ្នកឈឺធ្ងន់ គេបញ្ជូនទៅពេទ្យស្រុក ឬពេទ្យតំបន់")។

[1256] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៣។

### មូលដ្ឋានទី ៧០៖ ការមិនមានបណ្ដឹងអំពីការស្លាប់ ដែលកើតឡើងនៅក្រៅទំនប់១មករា[1257]

339. ដូចដែលម្ចាស់បណ្ដឹងសាទុក្ខបានទទួលស្គាល់[1258] ដីកាដំណោះស្រាយបានបង្ហាញថា "ភស្តុតាងរឹងមាំ លម្អិតនានាខាងក្រោម"[1259] នឹងត្រូវយកមកធ្វើការពិចារណា សម្រាប់ការកំណត់ប្រភេទនៃបទល្មើសនៅការដ្ឋាននីមួយៗ ដែលមានការកំណត់ពីការសម្លាប់រង្គាល។ ដីកាដំណោះស្រាយបានសម្រេចច្បាស់ថា ធាតុផ្សំគតិយុត្តិនៃការសម្លាប់រង្គាល់ ត្រូវបានកំណត់ពាក់ព័ន្ធទៅនឹងអង្គហេតុទាក់ទងនឹង "ជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ [...] នៅទំនប់១មករា"[1260] "ដោយសារស្ថានភាពរស់នៅ" ដូចជា "ធ្វើការជាទម្ងន់"[1261]។ ការរៀបរាប់អំពីអង្គហេតុសម្ភារៈនៅទំនប់១មករា គឺច្បាស់ក្រឡែត "អ្នកផ្សេងទៀតស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗ ដូចជា រលំថ្មសង្កត់ ឬបាក់ដីលើ"[1262] និងភស្តុតាងជាមូលដ្ឋាននានា បានបង្ហាញថា គ្រោះថ្នាក់បានកើតឡើងដោយសារតែស្ថានភាពនៃលក្ខខណ្ឌធ្វើការជាទម្ងន់[1263] ដូច្នេះហើយគឺស្ថិតក្នុងការកំណត់ប្រភេទនៃបទល្មើសយ៉ាងត្រឹមត្រូវ។

### មូលដ្ឋានទី ៧៨៖ ការមិនមានបណ្ដឹង អំពីការសម្លាប់មនុស្សនៅភូមិទ្រា [1264]

340. ដីកាដំណោះស្រាយបានរៀបរាប់លម្អិតច្បាស់លាស់ពាក់ព័ន្ធនឹងការសម្លាប់ជនជាតិចាមនៅភូមិទ្រា[1265] ហើយបានចោទប្រកាន់ម្ចាស់បណ្ដឹងសាទុក្ខពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល

---

[1257] <u>មូលដ្ឋានទី ៧០៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងពីការស្លាប់បណ្ដាលមកពីគ្រោះថ្នាក់ផ្សេងៗ* កថាខណ្ឌ ៤៨៧-៤៨៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ២៩ (ភាសាអង់គ្លេស) ទំព័រ ២៦ (ភាសាបារាំង) ទំព័រ ៤០ (ភាសាខ្មែរ)។

[1258] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៤៨៨។

[1259] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៣។

[1260] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១។

[1261] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៧។

[1262] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៣។

[1263] សូមមើល ឧទាហរណ៍ ឯកសារ **D427** ដីកាដំណោះស្រាយ ជើងទំព័រ ១៥៦១ *ដកស្រង់* ឯកសារ **E3/5255** កំណត់ហេតុស្ដាប់ចម្លើយ ឱ ហូ ERN 00239909 ("នៅពេលលើកទំនប់ មានករណីដីដាក់សង្កត់លើមនុស្ស ដោយសារពួកគេអស់កម្លាំងពេក ហើយផ្អែកនឹងដី ជាហេតុធ្វើឱ្យដីបាក់សង្កត់ស្លាប់")។

[1264] <u>មូលដ្ឋានទី ៧៨៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញនៅភូមិទ្រា* កថាខណ្ឌ ៥១៧-៥១៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៣១ (ភាសាអង់គ្លេស) ទំព័រ ២៨ (ភាសាបារាំង) ទំព័រ ៤៣-៤៤ (ភាសាខ្មែរ)។

[1265] សូមមើលឧទាហរណ៍ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៨៥-៧៩០។

ជនជាតិចាម ដោយសម្រេចថា ឧក្រិដ្ឋកម្ម "បានកើតឡើងជាពិសេស នៅមន្ទីរសន្តិសុខភូមិទ្រា [...] និងវត្តអូរត្រកួន"[1266]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត នៅភូមិទ្រា[1267] គឺជារឿងបន្ទាប់បន្សំ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខមិនត្រូវបានផ្តន្ទាទោសពីបទអំពីមនុស្សឃាត ដោយសារការស្លាប់នៅភូមិទ្រា ត្រូវបានស្រូបដោយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល់[1268] ជាបណ្តឹងដែលម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់ឡើយ។

## *មូលដ្ឋានទី ៧៩៖ ការមិនមានបណ្តឹងលើអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ តាមរយៈសហឧក្រិដ្ឋកម្មរួម*[1269]

341. ដីកាដំណោះស្រាយបានបញ្ជាក់យ៉ាងច្បាស់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមទាំងម្ចាស់បណ្តឹងសាទុក្ខផង តាមរយៈសហឧក្រិដ្ឋកម្មរួម បានអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ តាមរយៈការផ្លាស់ទីលំនៅប្រជាជន[1270] ហើយជនជាតិចាមគឺជាគោលដៅនៅក្នុងការផ្លាស់ទីលំនៅប្រជាជន[1271]។ សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើជនជាតិចាម ក៏ត្រូវស្ថិតក្រោមបណ្តឹងដែលបានដាក់ក្នុងសំណុំរឿង ០០២/០២ ផងដែរ[1272]។

## *មូលដ្ឋានទី ៨០៖ ជនជាតិវៀតណាម*[1273]

---

[1266] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៦ (គូសបញ្ជាក់បន្ថែម)។

[1267] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥១៨។

[1268] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៣៧, ៤៣៤១(i)។

[1269] <u>មូលដ្ឋានទី ៧៩៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្រោមបទសហក្រិដ្ឋកម្មរួម* កថាខណ្ឌ ៥១៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣១-៣២ (ភាសាអង់គ្លេស) ទំព័រ ២៩ (ភាសាបារាំង) ទំព័រ ៤៤ (ភាសាខ្មែរ)។

[1270] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥(i)(ខ)។

[1271] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២៦៦, ២៦៨, ២៨១។

[1272] ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង កថាខណ្ឌ ៤៣។ ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ២(i), ៣(i), ៥(ii)(ខ)(៧), ៦(i)។

[1273] <u>មូលដ្ឋានទី ៨០៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ជនជាតិវៀតណាម* កថាខណ្ឌ ៥២០-៥២១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣២ (ភាសាអង់គ្លេស) ទំព័រ ២៩ (ភាសាបារាំង) ទំព័រ ៤៤-៤៥ (ភាសាខ្មែរ)។

342. ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបញ្ជាក់ឡើងវិញពីការអះអាងរបស់ខ្លួន ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូង ច្រានចោលរួចទៅហើយនោះ[1274] ថា អង្គហេតុទាំងអស់នេះ មិនស្ថិតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1275] ហើយអះអាងដោយគ្មានការគាំទ្រថា អង្គហេតុដែលបានប្តឹងទៅសហចៅក្រមស៊ើបអង្កេត បានកម្រិតកំណត់ទីតាំងភូមិសាស្ត្រ ដោយមិនរួមបញ្ចូលដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ[1276]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញអំពីកំហុសឆ្គងណាមួយក្នុងការសម្រេចថា ដីកាដំណោះស្រាយបានបញ្ជូនអង្គហេតុទាំងអស់នេះទៅអង្គជំនុំជម្រះសាលាដំបូងឡើយ[1277]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ដោយត្រឹមត្រូវ ដីកាដំណោះស្រាយបានដកស្រង់យ៉ាងលម្អិតនូវកំណត់ត្រាសហសម័យអំពីការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមនៅដែនសមុទ្រ នៅពេលដែលកំណត់អំពីភ័ស្តុតាងនៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងជនជាតិវៀតណាម[1278]។

## *មូលដ្ឋានទី ៨១៖ យោធា និងអ្នករដ្ឋការ អតីតរបបសាធារណរដ្ឋខ្មែរ*[1279]

343. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា ដីកាដំណោះស្រាយមិនបានលើកឡើងថា អតីតអ្នករដ្ឋការ និងយោធារបបសាធារណរដ្ឋខ្មែរ ជាក្រុមជាក់លាក់ឡើយ ដូច្នេះហើយ ក្រុមទាំងនេះមិនស្ថិតក្នុងបណ្តឹងដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលដោះស្រាយឡើយ[1280] ហើយបានបង្ហាញដីកាដំណោះស្រាយដោយខុសឆ្គង[1281]។ ទោះបីជាអតីតយោធារបបសាធារណរដ្ឋខ្មែរ មិនត្រូវបាន

---

[1274] ឯកសារ **E380/2** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំស្តាប់សាក្សីបន្ថែមអំពីជនជាតិវៀតណាម និងកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២១។

[1275] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២០-៥២១។ សូមមើល ឯកសារ **E1/371.1** ប្រតិចារឹក ថេង ផល ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ម៉ោង ០៩.៣២.៤២-០៩.៣៥.៤២ ទំព័រ ១០-១១ បន្ទាត់៨-២។

[1276] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២០។

[1277] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២០-៥២១។

[1278] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥៧ ជើងទំព័រ ១១៣២១។

[1279] <u>មូលដ្ឋានទី ៨១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ* កថាខណ្ឌ ៥២២-៥៣០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣២ (ភាសាអង់គ្លេស) ទំព័រ ២៩ (ភាសាបារាំង) ទំព័រ ៤៥ (ភាសាខ្មែរ)។

[1280] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២៤ ជើងទំព័រ ៩៣៦ *ដកស្រង់* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៤០-៨៤០។

[1281] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២៤ ជើងទំព័រ ៩៣៧ *ដកស្រង់* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៧៤០-៨៤០។ នៅក្នុងកថាខណ្ឌតែមួយនេះ ម្ចាស់បណ្តឹងសាទុក្ខហាក់ដូចជា ជំទាស់លើបណ្តឹងដែលដាក់ជូនទៅ សហចៅក្រមស៊ើបអង្កេត ដោយអះអាងទាំងខុសថា "ពាក់ព័ន្ធនឹងទីតាំងនានាដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ សហចៅក្រម

កំណត់អត្តសញ្ញាណជាក្រុមមួយនៅក្រោមផ្នែក "ការប្រព្រឹត្តិលើក្រុមមនុស្សជាក់លាក់នានា" ក្តី តែដីកាដំណោះស្រាយបានរៀបរាប់យ៉ាងច្រើន ដោយយោងទៅរកការប្រព្រឹត្តិចំពោះពួកគេ ដោយបញ្ជាក់ថា ការកំណត់គោលដៅលើអតីតរបបសាធារណរដ្ឋខ្មែរថាជា "ខ្មាំង" គឺជាគោលនយោបាយចម្បងរបស់បក្សកុម្មុយនីស្តកម្ពុជា[1282]។ លើសពីនេះទៀត ផ្ទុយពីការអះអាងដោយមិនត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងបានទទួលដោះស្រាយបណ្តឹងអំពីការប្រព្រឹត្តិទៅលើអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ *តែនៅ* "ក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ"[1283] ដីកាដំណោះស្រាយបានកំណត់វិសាលភាពពេលវេលានៃគោលនយោបាយ ចាប់តាំងពីមុនឆ្នាំ១៩៧៥ ដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[1284] ហើយបញ្ជាក់យ៉ាងច្បាស់អំពីខ្លឹមសារ ដោយដំបូងចាប់ផ្តើមពីការប្រកាសជាសាធារណៈអំពីចេតនាសម្លាប់មេដឹកនាំជាន់ខ្ពស់របស់របបសាធារណរដ្ឋខ្មែរ នៅក្នុងឆ្នាំ១៩៧៥ ហើយបន្ទាប់មកគឺសេចក្តីសម្រេចជាសម្ងាត់ក្នុងការសម្លាប់សមាជិកថ្នាក់លើនៃរបបនេះ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[1285]។

344. ដោយផ្អែកលើការយល់ខុសចំពោះដីកាដំណោះស្រាយ ទើបម្ចាស់បណ្តឹងសាទុក្ខអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់តាមអំពើចិត្ត ដូច្នេះហើយអង្គជំនុំជម្រះសាលាដំបូងមិនបានទទួល

---

ស៊ើបអង្កេត ពុំធ្លាប់ដែលបានទទួលភារកិច្ច ឱ្យស៊ើបអង្កេតលើគោលនយោបាយ ជាយថាហេតុណាមួយ ដែលគាំទ្រដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ"។ ប៉ុន្តែដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានបញ្ជូនយ៉ាងច្បាស់លាស់ឱ្យ សហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតលើ "ការរើសអើងមានលក្ខណៈជាប្រព័ន្ធ" ទៅលើអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ហើយបានស្នើឱ្យស៊ើបអង្កេតលើ "ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយ ពូជសាសន៍ និងសាសនា មកលើអតីតមន្ត្រីរាជការ នៃរបបសាធារណខ្មែរ" នៅទីតាំងនីមួយៗដែលពាក់ព័ន្ធ ក្នុងសំណុំរឿង០០២/០២ សូមមើល ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២(ក), ១២២(គ)។

[1282] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-១៥៨, ២០៥-២០៦, ២០៨-២០៩, ១៤១៧។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២០ ជើងទំព័រ ១១៨៣៦។

[1283] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២៦-៥២៧។

[1284] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២០ ជើងទំព័រ ១១៨៣៧ *ដកស្រង់* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៨, ២០៨។

[1285] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២០ ជើងទំព័រ ១១៨៣៨ *ដកស្រង់* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២០៨។

ដោះស្រាយបណ្តឹងអំពីគោលនយោបាយប្រឆាំងនឹងអតីតរបបសាធារណរដ្ឋខ្មែរឡើយ[1286]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយគ្មានសុពលភាពថា ដោយសារតែកថាខណ្ឌជាច្រើននៃដីកាដំណោះស្រាយ ដែលបានបង្ហាញពីការប្រព្រឹត្តិទៅលើអតីតយោធា និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ក៏មានបង្ហាញអំពីភស្តុតាងនៃការរើសអើងទៅលើក្រុមដទៃទៀតនោះ មិនមានការរើសអើងប្រឆាំងនឹងអតីតយោធា និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរឡើយ[1287]។ ការយល់សមស្របតែខុសឆ្គងដែលថា ការរើសអើងប្រឆាំងក្រុមជាច្រើន បង្ហាញថា គ្មានការរើសអើងនោះ មិនមានខ្លឹមសារឡើយ។ ដីកាដំណោះស្រាយបានបញ្ជាក់ថា អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរត្រូវបានគេតាមដានយ៉ាងជាប់ ឬត្រូវបានបាត់ខ្លួន[1288] ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងបានទទួលដោះស្រាយបណ្តឹងអំពីទម្រង់នៃការកំណត់គោលដៅជារួម ទៅលើអតីតយោធា និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ។

345. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភស្តុតាងបន្ថែមសម្រាប់ការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូងប្រព្រឹត្តកំហុសឆ្គងយ៉ាងច្បាស់ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការទទួលយកភស្តុតាងទាក់ទងនឹងការប្រព្រឹត្តិទៅលើអតីតយោធា និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ នៅទំនប់ត្រពាំងថ្ម ដោយគ្រាន់តែលើកឡើងវិញថា ដីកាដំណោះស្រាយមិនបានរួមបញ្ចូលគោលនយោបាយកំណត់គោលដៅទៅលើអតីតរបបសាធារណរដ្ឋខ្មែរនោះ[1289]។

## ៤. ប្រភេទទីបួន ÷ មូលដ្ឋានទាក់ទងនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ថា បានដកចេញពីសំណុំរឿង ០០២/០២ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២[1290]

### *មូលដ្ឋានទី២ និង ៨២ ដល់៨៤*

[1286] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២៥-៥២៧ ជើងទំព័រ ៩៣៧, ៩៣៨ *ដកស្រង់* ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង កថាខណ្ឌ ៤៤ ជើងទំព័រ ៩៥។

[1287] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២៦។

[1288] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៩, ៣៦៦, ៤៣២។

[1289] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២៨-៥២៩ ជើងទំព័រ ៩៣៩ *ដកស្រង់* ឯកសារ **E362** សារអេឡិចត្រូនិកស្តីពីការបញ្ជាក់បំភ្លឺ របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើរជូនមេធាវីការពារក្តី ខៀវ សំផន។

[1290] <u>មូលដ្ឋានទី ២, ៨២-៨៤ (សំណើសុំ)</u> ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៥, ៥៣១-៥៤៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤, ៣៣-៣៤ (ភាសាអង់គ្លេស) ទំព័រ ៤, ៣០ (ភាសាបារាំង) ទំព័រ ៤, ៤៦-៤៧ (ភាសាខ្មែរ) ។*កំណត់សម្គាល់*៖ សម្រាប់ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៣ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥០។

346. **មូលដ្ឋានទី២ និង៨២ ដល់៨៤ គួរត្រូវបានច្រានចោល។ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការបកស្រាយសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម ឬឧបសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធី ដែលបញ្ជាក់ពីការពណ៌នាដោយគ្រប់គ្រាន់អំពីអង្គហេតុសម្ភារៈ និងការកំណត់ប្រភេទនៃបទល្មើសដោយអង្គជំនុំជម្រះ ដែលបានផ្តល់នូវការជូនដំណឹងយ៉ាងគ្រប់គ្រាន់ទៅដល់ម្ចាស់បណ្តឹងសាទុក្ខ អំពីបណ្តឹងដែលបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២**

### *មូលដ្ឋានទី ២៖ ការជំនុំជម្រះដ៏វែងអន្លាយ ក្នុងព្រំដែនដែលអាចទំកិលបាន*[1291]

347. ការអះអាងមិនត្រឹមត្រូវរបស់ ម្ចាស់បណ្តឹងសាទុក្ខ ពឹងផ្អែកទៅលើកំហុសឆ្គងក្នុងការបកប្រែ[1292]។ ប្រយោគនៅក្នុងរង្វង់ក្រចក ដែលបញ្ជាក់ថាបទចោទការនិរទេសខ្លួន គឺកម្រិតកំណត់តែត្រឹមខេត្តព្រៃវែង និងស្វាយរៀង[1293] គឺមានតែនៅក្នុងឯកសារជាភាសាបារាំង នៃឧបសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង០០២/០២។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់[1294] ឯកសារជាភាសាអង់គ្លេសនិងភាសាខ្មែរ នៃឧបសម្ព័ន្ធ បានបញ្ជាក់ថាបទចោទនៃការនិរទេសនៅស្រុកត្រាំកក់ គឺស្ថិតក្នុងបណ្តឹងនៃសំណុំរឿង០០២/០២។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[1295]

---

[1291] <u>មូលដ្ឋានទី ២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការជំនុំជម្រះដ៏វែងអន្លាយក្នុងព្រំដែនដែលអាចទំកិលបាន* កថាខណ្ឌ ១១៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤ (ភាសាអង់គ្លេស) ទំព័រ ៤ (ភាសាបារាំង) ទំព័រ ៤ (ភាសាខ្មែរ)។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង នូវបញ្ហានៃភាពខុសគ្នាមួយចំនួន នៅក្នុងបរិបទនៃមូលដ្ឋាននេះ ដែលនឹងត្រូវពិភាក្សានៅក្នុងបរិបទ នៃបញ្ហាដែលពាក់ព័ន្ធនឹងភាពខុសគ្នាទាំងនោះ។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣ (ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ កងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម) ៨៣ និង ១៥០ (ការរំលោភបំពានទៅលើ គោលការណ៍អាជ្ញាអស់ជំនុំ) មូលដ្ឋានទី ១៨០ (អត្ថិភាពនៃគោលនយោបាយ ផ្លាស់ទីលំនៅប្រជាជន៖ គោលដៅនៃសហករណ៍)។

[1292] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៥ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩។

[1293] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៥ *ដកស្រង់* ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ ទំព័រ ៤ (ភាសាបារាំង) ពោលគឺ កថាខណ្ឌ ៥(ii)(ខ) ("Déportation (កថាខណ្ឌ ១៣៩៧-១៤០១) (l'examen sera limité aux mesures ayant visé les Vietnamiens à Prey Veng et à Svay Rieng)")។

[1294] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៥ *ដកស្រង់* ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ ទំព័រ ៣ (ភាសាអង់គ្លេស) (ការនិរទេស (កថាខណ្ឌ ១៣៩៧-១៤០១) (កម្រិតត្រឹមសហករណ៍ត្រាំកក់ និងការប្រព្រឹត្តលើជនជាតិវៀតណាម នៅខេត្តព្រៃវែងនិងស្វាយរៀង") ទំព័រ ៥ (ភាសាខ្មែរ)។

[1295] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៥។

ក្នុងពេលកន្លងមក អង្គជំនុំជម្រះសាលាដំបូង បានអះអាងថាឯកសារឧបសម្ព័ន្ធ ជាភាសាអង់គ្លេស និងភាសាខ្មែរ គឺជាឯកសារដើម ចំណែកឯកសារភាសាបារាំង គឺជាឯកសារបកប្រែ[1296]។ ទីពីរ ឯកសារទាំងបីភាសា សុទ្ធតែយោងទៅរកកថាខណ្ឌដែលអះអាង អំពីបទចោទនៃការនិរទេសនៅស្រុកត្រាំកក់[1297] ព្រមទាំងការសម្រេចលើអង្គហេតុជាមូលដ្ឋានផង[1298]។

348. បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់ថា កំហុសក្នុងការបកប្រែ មានឥទ្ធិពលសំខាន់ខ្លាំង ទៅលើការផ្តន្ទាទោស ដល់កម្រិតដែលបណ្តាលឱ្យមាន ភាពអយុត្តិធម៌ជាក់ស្តែងនោះទេ[1299]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់[1300] ហើយដែលម្ចាស់បណ្តឹងសាទុក្ខបានយល់ស្រប[1301] គាត់អាចលើកឡើងពីភាពខុសគ្នានេះ នៅពេលណាមួយក៏បាន ចាប់ពីពេលដែលអង្គជំនុំជម្រះសាលាដំបូង បានចេញឧបសម្ព័ន្ធនេះនៅក្នុងខែមេសា ឆ្នាំ២០០៤។ ម្ចាស់បណ្តឹងសាទុក្ខបានប្រៀបធៀប ឯកសារជាភាសាអង់គ្លេសនិងភាសាខ្មែរ នៃឧបសម្ព័ន្ធនេះជាមួយឯកសារជាភាសាបារាំង ហើយបានជូនដំណឹងអំពីភាពខុសគ្នា តាំងពីខែសីហា ឆ្នាំ២០១៤មក[1302]។ ទោះជា

---

[1296] ឯកសារ **E301/9/1.1/2** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើរបស់ ខៀវ សំផន សុំកែប្រែឧបសម្ព័ន្ធនៃសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀត ក្នុងសំណុំរឿង ០០២ ("អង្គជំនុំជម្រះសូមបញ្ជាក់ថា អត្ថបទជាភាសាខ្មែរ និងភាសាអង់គ្លេស មានភាពត្រឹមត្រូវ")។ ទាំងនៅក្នុង និងនៅក្នុងសារអេឡិចត្រូនិកជូនដំណឹង អំពីសំណុំរឿង ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារជាភាសាបារាំងមានសម្គាល់ថា "ឯកសារបកប្រែ"។

[1297] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៧ ("មានធាតុផ្សំគ្រប់គ្រាន់នៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការនិរទេស នៅខេត្តព្រៃវែង ខេត្តស្វាយរៀង និងសហករណ៍ស្រុកត្រាំកក់")។

[1298] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣(ii) ("សហករណ៍ត្រាំកក់ (កថាខណ្ឌ ៣០២-៣២១)"។ ការសម្រេចលើអង្គហេតុ ពាក់ព័ន្ធការនិរទេសពីត្រាំកក់ គឺនៅកថាខណ្ឌ ៣២០)។

[1299] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[1300] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩។

[1301] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៥ ("មេធាវីការពារក្តីគួរតែអាចបានដឹងអំពីភាពខុសគ្នានេះ")។ ឯកសារ **E1/525.1** ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង ១០.៤២.០៦-១០.៤៤.០០ ទំព័រ ២៧ បន្ទាត់ ១០-១២ ("ការនោះយើងបានមើលនៅក្នុង ឧបសម្ព័ន្ធនៃដីកាបំបែកបទចោទ ដែលអត់ឃើញមានចំណុចនេះទេ ស្រាប់តែនៅក្នុងភាសាផ្សេងទៀតនោះ ក្រៅពីភាសាបារាំងហ្នឹងឃើញថាមាន")។

[1302] ឯកសារ **E301/9/1.1/1** សំណើមេធាវីការពារក្តីលោក ខៀវ សំផន សុំការបំភ្លឺ និងការកែប្រែឧបសម្ព័ន្ធក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ កថាខណ្ឌ ៣ ("Le 29 juillet 2014 la Défense […] travaillant en français plus qu'en khmer – a par hasard découvert l'existence d'information contenues dans les versions anglaise et khmère de l'annexe ne figurant pas dans la version française de cette annexe." ការបកប្រែក្រៅផ្លូវការៈ "នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ មេធាវីការពារក្តី ដែលបំពេញការងារជាភាសាបារាំង ច្រើន

ក្នុងករណីណាក៏ដោយ ម្ចាស់បណ្ដឹងសាទុក្ខទទួលបានសិទ្ធិក្នុងការជំនុំជម្រះ ទាក់ទងការជម្លៀសជាទូទៅ និងនៅស្រុកត្រាំកក់។ នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ពាក់ព័ន្ធបទចោទជម្លៀសទាំងអស់ ម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង "មិនបានទទួលបណ្ដឹង ពីអង្គហេតុជម្លៀសដែលមានរៀបរាប់ នៅក្នុងកថាខណ្ឌ ១៣៩៧ ដល់១៤០១ នៃដីកាដំណោះស្រាយ ដោយត្រឹមត្រូវតាមនីតិវិធី"[1303]។ នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល បន្ទាប់ពីបានកត់សម្គាល់អំពី កំហុសឆ្គងក្នុងការបកប្រែរួចហើយ ម្ចាស់បណ្ដឹងសាទុក្ខ មិនបានលើកសារណាបន្ថែមទៀតទេ ទាក់ទងការជម្លៀសពិសេសការជម្លៀសពីស្រុកត្រាំកក់[1304]។

## *មូលដ្ឋានទី ៨២៖ ការមិនមានបណ្ដឹងលើអង្គហេតុ នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់នៃការជម្លៀសប្រជាជនដោយបង្ខំ*[1305]

349. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ គឺផ្អែកលើការបកស្រាយមិនត្រឹមត្រូវ ទៅលើសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម របស់អង្គជំនុំជម្រះសាលាដំបូង[1306]។ នៅក្នុងសេចក្ដីសម្រេចនោះ ការយោងរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទាក់ទងការជម្លៀសដោយបង្ខំ ទៅលើជនជាតិចាម នៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ គឺមិនមែនផ្ដាច់មុខ និងមានតែមួយនោះទេ (exclusive nor exclusionary)[1307]

ជាងភាសាខ្មែរ បានរកឃើញដោយថៃដន្យថា មានព័ត៌មានដែលមាននៅក្នុងឧបសម្ព័ន្ធ ជាភាសាអង់គ្លេសនិងភាសាខ្មែរ ប៉ុន្តែមិនមាននៅក្នុងឧបសម្ព័ន្ធជាភាសាបារាំង")។

[1303] ឯកសារ E457/6/4/1 សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៩-២៧៥ (ដកស្រង់ត្រង់កថាខណ្ឌ ២៧៥)។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤១។

[1304] សូមមើល ឯកសារ E1/525.1 ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង ១០.៤២.០៦-១០.៤៤.០០ ទំព័រ ២៧ បន្ទាត់ ១៣ (ពន្យល់ថាកំហុសមិនបានផ្លាស់ប្ដូរ "បញ្ហាទូទៅ" ដែលជាទឡ្ហីករណ៍ចម្បង របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា ការនិរទេសមិនស្ថិតក្នុងបណ្ដឹង សម្រាប់ការស៊ើបសួរតាមផ្លូវតុលាការឡើយ)។

[1305] <u>មូលដ្ឋានទី ៨២</u>៖ ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ *គ្មានបណ្ដឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត/ការជម្លៀសដោយបង្ខំ* កថាខណ្ឌ ៥៣៨-៥៤៣។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៣៣ (ភាសាអង់គ្លេស) ទំព័រ ៣០ (ភាសាបារាំង) ទំព័រ ៤៦ (ភាសាខ្មែរ)។

[1306] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៣៩-៥៤០ *ដកស្រង់* ឯកសារ E301/9/1 សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង កថាខណ្ឌ ៤៣។

[1307] ឯកសារ E301/9/1 សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង កថាខណ្ឌ ៤៣ ("អង្គជំនុំជម្រះកត់សម្គាល់ថា ការផ្លាស់ទីលំនៅ ជនជាតិភាគតិចចាម បង្កើតជាមូលដ្ឋាននៃការចោទប្រកាន់ស្ដីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា *រួមទាំងជាមធ្យោបាយមួយ នៃការអនុវត្តគោលនយោបាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីពីរ) និងការប្រព្រឹត្តចំពោះក្រុមដែលក្លាយជាគោលដៅ*។ អង្គជំនុំជម្រះបាន

ហើយមិនបានកម្រិតបណ្ដឹងលើអង្គហេតុ ទៅអង្គជំនុំជម្រះសាលាដំបូង តែត្រឹមអង្គហេតុដែលអាច កំណត់ប្រភេទនៃបទល្មើស ថាជាការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនានោះទេ។ បន្ថែមលើនេះអង្គជំនុំជម្រះសាលាដំបូង បានបញ្ចូលយ៉ាងច្បាស់នៅក្នុង ឧសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធី៖ (១) ការចោទប្រកាន់ពី ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅលើជនជាតិចាម និងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់នៃការជម្លៀសដោយបង្ខំ នៅក្នុងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ[1308] និង (២) ការសម្រេចលើអង្គហេតុជាមូលដ្ឋាន នៃដីកាដំណោះស្រាយ ដែលអាចអនុវត្តបានចំពោះបទចោទទាំងបី ដោយគ្មានការកម្រិតកំណត់[1309]។

## *មូលដ្ឋានទី ៨៤៖ ជនជាតិវៀតណាម*[1310]

350. ម្ចាស់បណ្ដឹងសាទុក្ខបានបកស្រាយដោយមិនត្រឹមត្រូវ ទៅលើការសម្រេចក្នុងសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង និងទៅលើឧបសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធី ដែលកំណត់នូវបណ្ដឹងនៅក្នុងសំណុំរឿង ០០២/០២។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចថា "ជនជាតិវៀតណាមត្រូវបានដកចេញ ពីក្នុងការពិនិត្យអង្គហេតុ ដែលជាធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ដោយសេចក្ដីសម្រេច

---

ដកចេញនូវអង្គហេតុ នៃ*ការចោទប្រកាន់ទាំងនេះ*ចេញ ដោយផ្អែកលើគោលនយោបាយ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្ត ចំពោះជនជាតិចាម *រួមទាំង*អង្គហេតុស្ដីពីការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុសាសនា ចេញពីវិសាលភាពនៃសំណុំរឿង ០០២/១។ ទោះជាយ៉ាងណាក្ដី ការប្រព្រឹត្តចំពោះជនជាតិចាម និងអង្គហេតុស្ដីពីការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុសាសនា រួមទាំងក្នុងដំណើរការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីពីរ) ត្រូវបានបញ្ចូលក្នុងវិសាលភាព នៃសំណុំរឿង០០២/០២") *(គូសបញ្ជាក់បន្ថែម។ លុបចោលការយោងខាងក្នុង))*។

[1308] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥(២)(ខ)(៧) ("ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ [...] (កម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ (កម្រិតត្រឹមការប្រព្រឹត្តលើជនជាតិចាម)") ៥(២)(ខ)(១៣) ("អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់នៃការជម្លៀសដោយបង្ខំ [...] (ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ (កម្រិតត្រឹមការប្រព្រឹត្តលើជនជាតិចាម))")។

[1309] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣(i) ("ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ (កថាខណ្ឌ ២៦៦, ២៦៨, ២៨១) (កម្រិតត្រឹមតែការប្រព្រឹត្តលើជនជាតិចាម)")។

[1310] <u>មូលដ្ឋានទី ៨៤</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ជនជាតិវៀតណាម* កថាខណ្ឌ ៥៤៧-៥៤៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៣៣-៣៤ (ភាសាអង់គ្លេស) ទំព័រ ៣០ (ភាសាបារាំង) ទំព័រ ៤៧ (ភាសាខ្មែរ)។

បំបែក កិច្ចដំណើរការនីតិវិធី"[1311]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការកំណត់ប្រភេទនៃបទល្មើសនេះ ត្រូវបានដកចេញពីសំណុំរឿង ០០២/០២ ដោយសេចក្តីសម្រេច លើការបំបែកកិច្ចដំណើរការនីតិវិធី[1312] ឬអាចមិនត្រូវបានចោទប្រកាន់[1313] ទាក់ទងអង្គហេតុដែលបានបញ្ចូលនៅក្នុងផ្នែក "ការប្រព្រឹត្តចំពោះជនជាតិវៀតណាម"។ ចំពោះជនរងគ្រោះទាំងអស់ រួមទាំងជនជាតិវៀតណាមផង នៅក្នុងសហករណ៍ត្រាំកក់ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ដោយត្រឹមត្រូវ[1314]ថា បើយោងទៅតាមពាក្យពេចន៍ច្បាស់លាស់ នៃឧបសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធីបណ្តឹងសំណុំរឿង០០២/០២ រួមបញ្ចូល "សហករណ៍ត្រាំកក់ (៣០២-៣២១)"[1315] និងលទ្ធភាពនៃការកំណត់ប្រភេទនៃបទល្មើស ដូចជាអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់នៃការបាត់ខ្លួនដោយបង្ខំ[1316]។ ហេតុដូច្នេះការព្យាយាមរបស់ ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការលុបបំបាត់អង្គហេតុ

---

[1311] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៤៧ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥២។

[1312] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥២ *ដកស្រង់* ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥(ii)(ខ)។

[1313] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១១៣០៥។

[1314] អាន ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៤៧ និងឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៣-៣៤ (ភាសាអង់គ្លេស) ទំព័រ ៣០ (ភាសាបារាំង) ម្ចាស់បណ្តឹងសាទុក្ខ ហាក់ដូចជាបកស្រាយមិនត្រឹមត្រូវ ចំពោះប្រយោគរបស់ អង្គជំនុំជម្រះសាលាដំបូង នៅឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥២ ដែលថាការបាត់ខ្លួនដោយបង្ខំ នៅសហករណ៍ត្រាំកក់ "ពាក់ព័ន្ធនឹងជនរងគ្រោះវៀតណាមនៅតាមទីតាំងទាំងនោះបាន *បើទោះបីជាជនរងគ្រោះផ្សេងទៀតទាំងនេះ មិនទាន់ត្រូវបានបញ្ជាក់ច្បាស់ដូចនោះក៏ដោយ*" (គូសបញ្ជាក់បន្ថែម) ទោះបីជាឯកសារជាភាសាបារាំង "même si cela n'a pas été spécifiquement précisé" អាចបង្កើតនូវភាពស្រពិចស្រពិលក្នុងកម្រិតតូចក្តី តែតាមរយៈបរិបទ និង ឯកសារជាភាសាអង់គ្លេស គឺអង្គជំនុំជម្រះសាលាដំបូងយោងទៅរក ជនរងគ្រោះវៀតណាមដែលមិនទាន់ បានកំណត់អត្តសញ្ញាណច្បាស់លាស់។ អង្គជំនុំជម្រះសាលាដំបូងមិនយល់ស្របថា ខ្លួនបានបញ្ចូលជនរងគ្រោះវៀតណាម ដោយសារការបាត់ខ្លួនដោយបង្ខំ នៅត្រាំកក់ ដោយមិនមានអំណាចគតិយុត្តិ ពីដីកាដំណោះស្រាយ និង ឧបសម្ព័ន្ធបំបែក កិច្ចដំណើរការនីតិវិធីអនុញ្ញាតឱ្យធ្វើឡើយ។

[1315] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣(ii) *យោងទៅ* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០២-៣២១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៤៧។

[1316] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៥២ *ដកស្រង់* ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥(ii)(ខ)។ សូមមើល ជាពិសេស កថាខណ្ឌ ៥(ii)(ខ)(១៤)។

ពាក់ព័ន្ធជនរងគ្រោះជាជនជាតិវៀតណាម នៅស្រុកត្រាំកក់ ពីក្នុងដីកាដំណោះស្រាយ[1317] គឺផ្ទុយទាំងស្រុងជាមួយការបកស្រាយដោយសាមញ្ញ ទៅលើឧបសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធី។

## ខ. ភ័ស្តុតាងពាក់ព័ន្ធអង្គហេតុ ដែលត្រូវបានចោទប្រកាន់ថា ស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២

### *មូលដ្ឋានទី ៣៖ ភ័ស្តុតាងក្រៅវិសាលភាព ប៉ុន្តែពាក់ព័ន្ធ*[1318]

351. **មូលដ្ឋានទី៣ គួរត្រូវបានបដិសេធចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយពឹងផ្អែកទៅលើភ័ស្តុតាង ពាក់ព័ន្ធអង្គហេតុដែលស្ថិតក្រៅវិសាលភាព សំណុំរឿង០០២/០២ ដោយសារតែភាពមិនស្របច្បាប់**

*ភ័ស្តុតាងនៃអំពើដែលស្ថិតក្រៅវិសាលភាព ភូមិសាស្ត្រនិងពេលវេលា នៃដីកាដំណោះស្រាយ*

352. មូលដ្ឋានរងមួយនេះត្រូវតែបដិសេធ ដោយសារតែមិនមានភ័ស្តុតាងគាំទ្រ ហើយគួរត្រូវបានច្រានចោលជារួម[1319]។ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ មិនមានចំណុចណាមួយដែលម្ចាស់បណ្តឹងសាទុក្ខ បានផ្តល់នូវយុត្តិកម្មសម្រាប់ការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គច្បាប់ ក្នុងការសម្រេចថា អង្គជំនុំជម្រះសាលាដំបូង អាចពឹងផ្អែកទៅលើភ័ស្តុតាង ដែលស្ថិតក្រៅវិសាលភាព ពេលវេលានិងភូមិសាស្ត្រ នៃដីកាដំណោះស្រាយ ក្នុងកាលៈទេសៈចំនួនបីគឺ៖ (១) ដើម្បីបញ្ជាក់បំភ្លឺទៅលើបរិបទមួយដែលបានកំណត់ (២) ដើម្បីបង្ហាញដោយការធ្វើសន្និដ្ឋានទៅលើធាតុផ្សំ ជាពិសេសធាតុផ្សំអត្តនោម័ត នៃបទល្មើសដែលបានកើតឡើង

---

[1317] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៤៨-៥៤៩។

[1318] <u>មូលដ្ឋានទី ៣</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អង្គហេតុ"ក្រៅបរិបទ" តែ "ពាក់ព័ន្ធ"* កថាខណ្ឌ ១១៦, ១២០-១២៥, ៧៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥ (ភាសាអង់គ្លេស) ទំព័រ ៥ (ភាសាបារាំង) ទំព័រ ៥ (ភាសាខ្មែរ)។ ម្ចាស់បណ្តឹងសាទុក្ខ*ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០, ១៧៧-១៧៨, ១៨១-១៨៥, ១៨៦-១៨៨, ១៨៩-១៩០។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទាក់ទងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៦-១៨៨ (ការរំលោភសេពសន្ថវៈ ក្រៅការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ត្រូវបានពិភាក្សានៅក្នុងផ្នែកអនុវត្តដែលពាក់ព័ន្ធ នៅផ្នែកខាងក្រោម។

[1319] អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "អង្គជំនុំជម្រះពុំធ្វើការពិចារណា លើអំណះអំណាងដែលគ្រាន់តែលើកឡើងថាសេចក្តីសម្រេចឬសំអាងហេតុ របស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយពុំបានលើកមូលដ្ឋានគាំទ្រ ថាតើមូលហេតុអ្វីបានជាសេចក្តីសម្រេច ឬសំអាងហេតុនេះ មានកំហុសនោះឡើយ" សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០២.

ក្នុងពេលពាក់ព័ន្ធ (៣) ដើម្បីបង្ហាញនូវគំរូយ៉ាងទូលំទូលាយនៃការប្រព្រឹត្ត[1320]។ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែបានយោងឆ្លង ក្នុងលក្ខណៈទូទៅមួយ ទៅរកសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់គាត់ប៉ុណ្ណោះ[1321] ដែលសារណានោះមិនមានការតវ៉ាដោយមានសំអាង នៅត្រង់ចំណុចនេះដូចគ្នា[1322]។ ផ្ទុយទៅវិញ នៅមុនពេលដែលអង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រម ម្ចាស់បណ្ដឹងសាទុក្ខបានរៀបរាប់ថាចំណុចនេះជាគោលការណ៍ "ដែលទទួលស្គាល់ជាទូទៅ" "ហើយអនុវត្តយ៉ាងទូលំទូលាយ" នៅ អ.វ.ត.ក ផងដែរ[1323]។

353. តាមពិតទៅគោលការណ៍នេះ ត្រូវបានទទួលស្គាល់នៅតុលាការ ICTY [1324] តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរវ៉ាន់ដារ ("តុលាការ ICTR")[1325] តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("តុលាការ SCSL")[1326] និងតុលាការព្រហ្មទណ្ឌអន្តរជាតិ[1327]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ "អង្គហេតុដែលថាហេតុការណ៍មួយ កើតឡើងក្រៅវិសាលភាពពេលវេលា [...] មិនបានធ្វើឱ្យហេតុការណ៍នោះ គ្មានភាពពាក់ព័ន្ធដោយស្វ័យប្រវត្តិ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទេ"[1328]។

---

[1320] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០។ សូមមើលផងដែរ ឯកសារ **D300** ដីកាសម្រេចលើសំណើ D153, D172, D173, D174, D178 និង D284 កថាខណ្ឌ ៩-១០។

[1321] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២០-១២៥ ជើងទំព័រ ១៣៦ *ដកស្រង់* ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩-២៩៩។

[1322] ដូចគ្នានេះ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង បានធ្វើការសម្រេចដោយគ្មានសុភវិនិច្ឆ័យ ដែលគ្រាន់ជាការថ្លែងក្នុងតុលាការ (*obiter dicta*) ដែលបណ្ដាលឱ្យមានការពន្យាពេល ដោយមិនសមហេតុផល។ (*សូមមើល* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៦) គឺគ្មានមូលដ្ឋានគាំទ្រ ដោយសារតែគាត់ចង្អុលទៅរក ត្រឹមតែឃ្លាចំនួនបី ដោយមិនបានបង្ហាញថាតើ ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើភ័ស្តុតាងដោះបន្ទុកសក្ដានុពលអាចបណ្ដាលឱ្យមានបុរេនិច្ឆ័យដោយរបៀបណាចំពោះគាត់។

[1323] ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥២-៥៣ ដកស្រង់ ពាក្យសម្ដីផ្ទាល់នៃករណីលើកលែងចំនួនបី និង *ដកស្រង់ សាលដីការឿងក្ដី* *Nahimana* កថាខណ្ឌ ៣១៥។

[1324] សូមមើលឧទាហរណ៍ សេចក្ដីសម្រេចក្នុងរឿងក្ដី *Prlić* លើពេលវេលាសម្រាប់សហឧក្រិដ្ឋកម្មរួម ទំព័រ ៩។

[1325] សូមមើលឧទាហរណ៍ *សាលដីការឿងក្ដី* *Nahimana* កថាខណ្ឌ ៣១៥។

[1326] សូមមើលឧទាហរណ៍ *សាលក្រមរឿងក្ដី* *Taylor* កថាខណ្ឌ ១០១ (ពាក់ព័ន្ធជាមួយ វិសាលភាពពេលវេលា) ១១០ (ពាក់ព័ន្ធវិសាលភាពភូមិសាស្ត្រ)។

[1327] សូមមើលឧទាហរណ៍ *សាលក្រមរឿងក្ដី* *Lubanga* កថាខណ្ឌ ១០២២-១០២៤, ១០២៧, ១៣៥២។ សេចក្ដីសម្រេចទទួលយក របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្ដី *Bemba* កថាខណ្ឌ ១២, ១៩-២០។

[1328] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការទទួលយកភ័ស្តុតាង ក្នុងរឿងក្ដី *Ongwen* កថាខណ្ឌ ៧។

ពុទ្ធសាសនិកជន

354. មូលដ្ឋានរងមួយនេះ ដែលចោទប្រកាន់ពីកំហុសឆ្គងអង្គច្បាប់ នៅក្នុងការប្រើប្រាស់ភ័ស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការប្រព្រឹត្តទៅលើពុទ្ធសាសនិកជន ដែលស្ថិតនៅក្រៅសហករណ៍ត្រាំកក់[1329] ចាំបាច់ត្រូវច្រានចោល ដោយសារតែការសម្រេចលើអង្គហេតុ (និងភ័ស្តុតាងគាំទ្រ) របស់អង្គជំនុំជម្រះសាលាដំបូង ស្ថិតនៅក្នុងវិសាលភាពយ៉ាងត្រឹមត្រូវ នៃសំណុំរឿង០០២/០២ ដូចដែលបានកំណត់ដោយសេចក្តីសម្រេច បំបែកកិច្ចដំណើរការនីតិវិធី និងឧបសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធី[1330]។ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធី វិសាលភាពអង្គហេតុនៃសំណុំរឿង ០០២/០២ រួមមាន (១) នៅក្នុងទីតាំងឧក្រិដ្ឋកម្ម ការប្រព្រឹត្តទៅលើពុទ្ធសាសនិកជន នៅក្នុងសហករណ៍ត្រាំកក់ ព្រមទាំង (២) ការសម្រេចលើអង្គហេតុ ស្តីពីការប្រព្រឹត្តចំពោះ ពុទ្ធសាសនិកជន នៅទូទាំងប្រទេស ដើម្បីកំណត់គោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា[1331]។ តាមរយៈសេចក្តីសម្រេច បំបែកកិច្ចដំណើរការនីតិវិធី ព្រមទាំងការប្រកាសរបស់ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងពេលសវនាការ[1332] ម្ចាស់បណ្តឹងសាទុក្ខបានទទួល ការជូនដំណឹងគ្រប់គ្រាន់ អំពីវិសាលភាព

---

[1329] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦, ១២០-១២៥ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៧-១៧៨។

[1330] ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង។ ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២។

[1331] ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង កថាខណ្ឌ ៣៨ ("សំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីក លើកឡើងពីការប្រព្រឹត្តចំពោះ ពុទ្ធសាសនិក តាមរយៈការបញ្ចូលទីតាំងសហករណ៍ត្រាំកក់ (ដែលមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងទីតាំងនោះ ដោយរួមបញ្ចូលទាំងការធ្វើទុក្ខបុកម្នេញ ដល់ពុទ្ធសាសនិកផង) *រួមទាំងការចោទប្រកាន់ជាទូទៅ នៅក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិក*។")។ ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ២(iv)(គ) ("ផ្នែកអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម [...] គ. ពុទ្ធសាសនិក (កថាខណ្ឌ ២០៥-២០៧, ២១០) (ការអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់)" (គូសបញ្ជាក់បន្ថែម)) កថាខណ្ឌ ៣ (១០) (អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម [...] "ការប្រព្រឹត្តលើពុទ្ធសាសនិក (កថាខណ្ឌ ៧៤០-៧៤៣) (កម្រិតត្រឹមសហករណ៍ត្រាំកក់)។

[1332] ឯកសារ **E1/301.1** ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១៥.៣៥.៥៧-១៥.៥៨.១៤ ទំព័រ ៧៣ បន្ទាត់ ៧-១២ (ជាការឆ្លើយតបចំពោះសំណួររបស់ មេធាវីការពារក្តីផ្ទាល់របស់ខៀវ សំផន ចោទសួរទៅចៅក្រម "ល្អណាស់។ នេះជាការឆ្លើយបំភ្លឺ ខ្ញុំសូមបញ្ជាក់ថា បើតាមការចោទប្រកាន់ គឺថាមានគោលនយោបាយនៅទូទាំងប្រទេស ដែលបានកំណត់គោលដៅលើក្រុមជាក់លាក់មួយចំនួន ទូទាំងប្រទេសកម្ពុជា រួមទាំងពុទ្ធសាសនិក។ អ៊ីចឹងហើយវាពិតជាមានតម្លៃ ដែលយើងត្រូវកំណត់នូវអ្វី ដែលមានចែងនៅក្នុងគោលនយោបាយនោះ")។

នេះ ព្រមទាំងចេតនារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រើប្រាស់ភស្តុតាង នៃការប្រព្រឹត្តទៅលើពុទ្ធសាសនិកជន នៅបណ្តាទីតាំងនានាស្ថិតក្រៅ សហករណ៍ត្រាំកក់។ អង្គជំនុំជម្រះសាលាដំបូង មិនបានអនុវត្តហួស បណ្តឹងដែលដាក់មកអង្គជំនុំជម្រះ ដោយធ្វើការផ្តន្ទាទោសតែចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទៅលើពុទ្ធសាសនិកជននៅសហករណ៍ត្រាំកក់[1333] ហើយពឹងផ្អែកទៅលើភស្តុតាងនៃការប្រព្រឹត្ត នៅទូទាំងប្រទេស ដើម្បីកំណត់ពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[1334]។

## *ខ្មែរក្រោម*

355. មូលដ្ឋានរងនេះដែលបានចោទប្រកាន់ ពីកំហុសអង្គច្បាប់របស់ អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រើប្រាស់ភស្តុតាងពាក់ព័ន្ធខ្មែរក្រោម[1335] ត្រូវតែច្រានចោល ដោយសារតែមូលដ្ឋាននេះ បកស្រាយដោយមិនត្រឹមត្រូវនូវសាលក្រម ហើយយល់ច្រឡំទៅលើអង្គហេតុ ដែលស្ថិតក្រៅវិសាលភាពសំណុំរឿង ០០២/០២ ជាមួយភស្តុតាងដែលប្រើប្រាស់ ដើម្បីបង្ហាញភស្តុតាងនៃអង្គហេតុ ដែលស្ថិតក្នុងវិសាលភាពនោះ។

356. ម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ដោយខុស ពីអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលគាត់អះអាងថា “យោងតាមសេចក្តីសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះមិនត្រូវបាន ស្នើសុំដោយត្រឹមត្រូវឱ្យពិនិត្យ លើអង្គហេតុពាក់ព័ន្ធនឹងខ្មែរក្រោមនោះទេ”[1336]។ ដោយលើកឡើងដដែលៗ អំពីការសម្រេច

---

[1333] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៨, ១០៨៧ (ការផ្សព្វផ្សាយគោលនយោបាយមជ្ឈិមទៅស្រុកត្រាំកក់) កថាខណ្ឌ ១០៩៤-១១០៩ (ការប្រព្រឹត្តលើពុទ្ធសាសនិកនៅស្រុកត្រាំកក់) កថាខណ្ឌ ១១៨០-១១៨៧ (ការបង្ហាញអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមូលហេតុសាសនា នៅក្នុងសហករណ៍ត្រាំកក់) កថាខណ្ឌ ៣១៦៩, ៤០១៨។

[1334] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៨, ៤០១៣។ សូមមើល កថាខណ្ឌ ២៥៧-២៦៤ (ពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា មុនឆ្នាំ១៩៧៥ រួមទាំងការប្រព្រឹត្តទៅលើពុទ្ធសាសនិក ដោយពួកខ្មែរក្រហមនៅក្នុងតំបន់ “រំដោះ”) កថាខណ្ឌ ១០៨៤-១០៩៣ (គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ទៅលើពុទ្ធសាសនិក) កថាខណ្ឌ ៣៨៥០ (ការចាត់ទុកព្រះសង្ឃថាជា “ខ្មាំង”) កថាខណ្ឌ ៤០១៥-៤០២២ (គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ក្នុងការលប់បំបាត់ការប្រតិបត្តិរបស់ពុទ្ធសាសនិក និងការហាមឃាត់ជំនឿពុទ្ធសាសនា នៅក្នុងកម្ពុជាប្រជាធិបតេយ្យ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា)។

[1335] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២០-១២៥, ៧៥៧ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨១-១៨៥, ៨១៦។

[1336] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៧ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១៦។

ដែលស៊ីសង្វាក់គ្នា របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង០០២/០២ ទាំងស្រុង[1337] អ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចគឺ ជាក់លាក់ជាងនេះខ្លាំងណាស់ គឺថាអង្គជំនុំជម្រះសាលាដំបូង មិនបានទទួលបណ្ដឹងដោយត្រឹមត្រូវ អំពីការកំណត់គោលដៅទៅលើខ្មែរក្រោម ក្នុងនាមជាក្រុមជាក់លាក់មួយ ឬជាអនុក្រុមនៃជនជាតិវៀតណាមឡើយ[1338]។

357. ការសម្រេចនេះមិនបានរារាំង អង្គជំនុំជម្រះសាលាដំបូង មិនឱ្យពឹងផ្អែកទៅលើភស្តុតាងទាក់ទងខ្មែរក្រោម ដើម្បីបង្ហាញភស្តុតាងនៃអង្គហេតុ ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង ០០២/០២ ឡើយ រួមទាំងអង្គហេតុអត្ថិភាពនៃជនរងគ្រោះខ្មែរក្រោម នៅទីតាំងឧក្រិដ្ឋកម្មសំណុំរឿង ០០២/០២។ តាមពិតទៅដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ ដីកាដំណោះស្រាយដោយផ្ទាល់ បានយោងទៅរកខ្មែរក្រោម ជាច្រើនលើកច្រើនសារ[1339]។ ម្ចាស់បណ្ដឹងសាទុក្ខ បានគូសបញ្ជាក់ជាទៀងទាត់ និងដោយត្រឹមត្រូវ[1340]ថា អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្ដឹងអំពីអង្គហេតុ មិនមែនភស្តុតាងទេ[1341]។ ភស្តុតាងអាចពាក់ព័ន្ធ ជាមួយអង្គហេតុលើសពីមួយ ដូច្នេះហើយ ភស្តុតាងដែលអាចពាក់ព័ន្ធផងដែរ ជាមួយអង្គហេតុដែលស្ថិតក្រៅវិសាលភាព ក៏អាចត្រូវបានប្រើប្រាស់ដោយស្របច្បាប់ ដើម្បីបង្ហាញភស្តុតាងនៃអង្គហេតុ *ដែលស្ថិតក្នុង*វិសាលភាព[1342]។ ម្ចាស់បណ្ដឹងសាទុក្ខ ត្រូវបានជូនដំណឹងជាទៀងទាត់ អំពីការប្រើប្រាស់ភស្តុតាងដែលបានស្នើនេះ ពាក់ព័ន្ធជាមួយការប្រព្រឹត្តទៅលើខ្មែរក្រោម[1343]។

---

[1337] សូមមើលឧទាហរណ៍ ឯកសារ **E1/304.1** ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១៣.៣៥.៣៩-១៣.៣៨.០៥ ទំព័រ ៤៩ បន្ទាត់ ១១-១៣ ("សំណុំរឿង០០២/០២ មិនបញ្ចូលការចោទប្រកាន់ ទាក់ទងនឹងការកំណត់គោលដៅទៅលើខ្មែរក្រោម ថាជាក្រុមជាក់លាក់មួយនោះទេ។ មានន័យថា ជាការធ្វើទុក្ខបុកម្នេញដែលជា បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម")។

[1338] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៥, ៨១៦។

[1339] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨២, ៨១៦ *ដកស្រង់* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១១១, ២៦៥, ៣២០, ៨១៨, ១៤៦៨, ១៥៨៦។

[1340] វិធានផ្ទៃក្នុង វិធាន ៦៧(២), ៩៨(២)-(៣)។

[1341] សូមមើលឧទាហរណ៍ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២១, ៣៥២-៣៥៣។ ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៦, ៧៣, ៧៦, ៨៤, ៨៧-៨៩, ៩៩។

[1342] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២២៧, ២៣៦។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ៦៦ស្ទួន (៥), ៨៩ ស្ទួនបី ។

[1343] ឯកសារ **E1/304.1** ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១៣.៣៥.៣៩-១៣.៣៨.០៥ ទំព័រ ៤៩ បន្ទាត់ ២១-ទំព័រ ៥០ បន្ទាត់ ១ ("ទោះជាយ៉ាងនេះក្ដី ភស្តុតាងដែលទាក់ទងនឹងខ្មែរក្រោម អាចជាប់ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត នៅក្នុង

358. មូលដ្ឋានរងនេះដែលបានចោទប្រកាន់ ពីកំហុសអង្គច្បាប់ដែល អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រើប្រាស់ភ័ស្តុតាងពាក់ព័ន្ធ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងប្រទេសវៀតណាម[1344] ចាំបាច់ត្រូវតែបដិសេធចោល ដោយសារតែការសម្រេចលើអង្គហេតុ (និងភ័ស្តុតាងគាំទ្រ) របស់អង្គជំនុំជម្រះសាលាដំបូង ស្ថិតនៅក្នុងវិសាលភាពយ៉ាងត្រឹមត្រូវ នៃសំណុំរឿង០០២/០២ ដូចដែលបានកំណត់ដោយសេចក្តីសម្រេច បំបែកកិច្ចដំណើរការនីតិវិធី និងឧបសម្ព័ន្ធបំបែកកិច្ចដំណើរការនីតិវិធី[1345]។ បន្ថែមលើនេះ នៅក្នុងកម្រិតដែល បណ្តឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធជាមួយការចោទប្រកាន់ អំពីការនិរទេសដោយខុសច្បាប់ ប្រជាជនស៊ីវិលទៅកាន់មន្ទីរសន្តិសុខស-២១[1346] បណ្តឹងនេះទៅជាឥតបានការ ដោយសារតែការលើកលែងចោទប្រកាន់ របស់អង្គជំនុំជម្រះសាលាដំបូង ចំពោះបទចោទនេះ[1347]។ល

359. ក្រៅពីអង្គហេតុពាក់ព័ន្ធ បទចោទការនិរទេសដោយខុសច្បាប់ វិសាលភាពនៃសំណុំរឿង ០០២/០២ មិនបានរួមបញ្ចូលនូវអង្គហេតុ ដែលបង្កើតបានជាឧក្រិដ្ឋកម្ម ប្រព្រឹត្តឡើងដោយកងកម្លាំង កងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាមឡើយ បន្ទាប់ពីមានការបំបែកកិច្ចដំណើរការ

---

សំណុំរឿង ០០២/០២ ដូចជាបរិបទប្រវត្តិសាស្ត្រ និងគោលនយោបាយនៃសំណុំរឿងនេះ ឬបទល្មើសដទៃទៀត ដែលត្រូវបានចោទប្រកាន់ ហើយជនរងគ្រោះមួយចំនួនគឺជាខ្មែរក្រោម។ ក្នុងករណីនេះអង្គជំនុំជម្រះអាចអនុញ្ញាតឱ្យធ្វើការដេញដោលបាន [...] អង្គជំនុំជម្រះនឹងមិនបដិសេធ នូវសក្ខីកម្មរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា បុគ្គលម្នាក់ជាខ្មែរក្រោមនោះទេ ពីព្រោះវាទាក់ទងនឹងបញ្ហាដទៃទៀត នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២")។ ឯកសារ **E319/52/4** សេចក្តីសម្រេចលើសំណើចំនួនពីរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) សុំឱ្យទទួលយកឯកសារមួយចំនួន ធ្វើជាឯកសារភ័ស្តុតាង (ឯកសារ E319/51 និង E319/52) កថាខណ្ឌ ១៨។ ឯកសារ **E319/47/3** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង កថាខណ្ឌ ២៥។

[1344] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦, ១២០-១២៥ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៩-១៩០, ៧៧៨។

[1345] ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង។ ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២។

[1346] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៧៤-៧៧៨។

[1347] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦៣៣។

នីតិវិធី[1348] ប៉ុន្តែមានរួមបញ្ចូលនូវអង្គហេតុ កំណត់អំពីអត្ថិភាពនៃ ជម្លោះប្រដាប់អាវុធរវាង កម្ពុជាប្រជាធិបតេយ្យ និងវៀតណាម[1349] ដែលតម្រូវសម្រាប់ការកំណត់ ធាតុផ្សំបន្ទាប់បន្សំ នៃបទចោទការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងម្ចាស់បណ្តឹងសាទុក្ខ[1350]។ នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូង មិនបានអនុវត្តលើវិសាលភាព ដែលស្របច្បាប់នេះទេ ដោយអង្គជំនុំជម្រះមិនបានផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅលើទឹកដីវៀតណាមទេ[1351] ហើយអង្គជំនុំជម្រះប្រើប្រាស់ភ័ស្តុតាង ទាក់ទងការឈ្លានពានរបស់ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ទៅក្នុងប្រទេសវៀតណាម ដើម្បីគ្រាន់តែកំណត់អំពី អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ[1352]។

## VII. ឧក្រិដ្ឋកម្ម

### ក. សេចក្តីផ្តើម

360. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោស ត្រូវបានប្រព្រឹត្តឡើងនៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ ជាមធ្យោបាយដើម្បីសម្រេច គោលដៅចម្បងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការអនុវត្តបដិវត្តសង្គមនិយម យ៉ាងឆាប់រហ័សតាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" ដែលរៀបចំឡើងដើម្បីកសាងការពារប្រទេស ពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុង ឱ្យក្លាយជាសង្គមខ្មែរ ដែលមិនមាន

[1348] ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង កថាខណ្ឌ ៣២ ផ្នែកសម្រេចសេចក្តី។ ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ២-៣, *ជាពិសេស* កថាខណ្ឌ ២(iv)(ខ), ៣(xii)។

[1349] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១(៦) ("ផ្នែកអង្គហេតុ (៦) ជម្លោះប្រដាប់អាវុធ (កថាខណ្ឌ ១៥០-១៥៥)")។

[1350] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥(៣)(ក) ("ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ (កថាខណ្ឌ១៤៧៩) (ក) ធាតុផ្សំ "រួម" (កថាខណ្ឌ ១៤៨០-១៤៩០)")។

[1351] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៩-១៩០។

[1352] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨១-២៨៤, ៣៣៦។

សាសនា និងរូបរួមគ្នាមួយ មានតែវណ្ណៈកម្មករ-កសិករ[1353]។ អង្គជំនុំជម្រះសាលាដំបូង បាន សម្រេចដោយត្រឹមត្រូវផងដែរថា ឧក្រិដ្ឋកម្មទាំងអស់នេះ ត្រូវបានប្រព្រឹត្តឡើងអនុលោមទៅតាម គោលនយោបាយចំនួនប្រាំ ដែលមានទំនាក់ទំនងផ្ទៃក្នុង ជាមួយគោលបំណងរួមរបស់ ម្ចាស់ បណ្តឹងសាទុក្ខ និងសមាជិកដទៃទៀត នៃសហឧក្រិដ្ឋកម្មរួម។

361. ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង អនុលោមទៅតាមគោលនយោបាយចំនួនបី ក្នុងចំណោមគោល នយោបាយចំនួនប្រាំ ត្រូវពិភាក្សានៅក្នុងផ្នែកខាងក្រោម៖ (១) ការផ្លាស់ទីលំនៅប្រជាជន (កម្រិត ត្រឹមជនជាតិចាម, ការផ្លាស់ទីលំនៅដំណាក់កាលទីពីរ) (២) ការកំណត់គោលដៅ ទៅលើក្រុម ជាក់លាក់គឺ ពុទ្ធសាសនិក អតីតរបបសាធារណរដ្ឋខ្មែរ ជនជាតិចាម និងជនជាតិវៀតណាម និង (៣) ការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍ របស់បក្សកុម្មុយនីស្តកម្ពុជា។ ផ្នែកនេះក៏ពិភាក្សា ផងដែរអំពី ឧក្រិដ្ឋកម្មដែលបានកើតឡើង នៅក្រោសហឧក្រិដ្ឋកម្មរួម ដោយសារតែស្ថានភាព អមនុស្សធម៌នៅតាមសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ ដែលម្ចាស់បណ្តឹងសាទុក្ខ បានជួយនិង ជម្រុញ។

362. ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង អនុលោមទៅតាមគោលនយោបាយពីរទៀតដែលនៅសល់ នឹងត្រូវ ពិភាក្សានៅក្នុងផ្នែក ដែលមានចំណងជើងថា សហឧក្រិដ្ឋកម្មរួម៖ គោលបំណងរួមក្នុងការឆ្លើយ តប ចំពោះមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទង (១) ការបង្កើតនិងដំណើរការ សហករណ៍ និងការដ្ឋាន និង(២) ការអប់រំ "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" នៅមន្ទីរសន្តិសុខ និង ទីតាំងសម្លាប់មនុស្ស។

363. ដូចដែលបានរៀបរាប់លម្អិតខាងក្រោម ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះ សាលាដំបូង មានកំហុសអង្គហេតុឬអង្គច្បាប់ ក្នុងការសម្រេចថាគោលនយោបាយ និងឧក្រិដ្ឋកម្ម ទាំងអស់នេះមានអត្ថិភាព និងថាឧក្រិដ្ឋកម្មទាំងអស់នេះ ត្រូវបានប្រព្រឹត្តឡើង អនុលោមទៅតាម គោលនយោបាយទាំងអស់នេះ។

[1353] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

## ខ. អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត

*មូលដ្ឋានទី ៨៦៖ ច្បាប់ជាធរមាន៖ គ្មានការបញ្ចូលចេតនាប្រយោល ទៅក្នុងធាតុផ្សំអត្តនោម័តិ*[1354]

364. **មូលដ្ឋានទី ៨៦ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ក្នុងការសម្រេចថា ធាតុផ្សំអត្តនោម័តិនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើមនុស្សឃាត មានរួមបញ្ចូលចេតនាប្រយោល**[1355]**។**

365. មូលដ្ឋាននេះត្រូវតែច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ លើកឡើងវិញនូវទឡ្ហីករណ៍ ដែលកន្លងមកត្រូវបានអង្គជំនុំជម្រះសាលាដំបូង ច្រានចោលរួចហើយ បន្ទាប់ពីត្រួតពិនិត្យពេញលេញ ទៅលើសារណារបស់គាត់ ក្នុងសំណុំរឿង០០២/០២[1356] និងច្រានចោលដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១[1357]។ ម្ចាស់បណ្តឹងសាទុក្ខ យល់ច្រឡំទៅលើគោលការណ៍ជាធរមាន សម្រាប់ការបង្កើត ICL ព្រមទាំងច្បាប់ និងយុត្តិសាស្ត្រ ដែលបង្ហាញពីធាតុផ្សំអត្តនោម័តិត្រឹមត្រូវ។

*ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឆ្នាំ១៩៧៥ ដល់១៩៧៩*

366. ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មានកំហុសឆ្គងនៅពេលសម្រេចថា យុត្តិសាស្ត្រអន្តរជាតិនៅមុនឆ្នាំ ១៩៧៥ បង្ហាញថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ធាតុផ្សំអត្តនោម័តិ នៃអំពីមនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាននូវធាតុផ្សំចេតនាប្រយោល[1358]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[1359] ថា

---

[1354] <u>មូលដ្ឋានទី ៨៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អង្គច្បាប់៖ គ្មានការបញ្ចូលចេតនាប្រយោលទៅក្នុងធាតុផ្សំអត្តនោម័តិ* កថាខណ្ឌ ៥៧៥-៦៣៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៤ (ភាសាអង់គ្លេស) ទំព័រ ៣១ (ភាសាបារាំង) ទំព័រ ៤៨ (ភាសាខ្មែរ)។

[1355] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៧៥-៦៣៦។

[1356] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣១-៦៥១ *ច្រានចោល* ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៤-៤២៩។

[1357] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៨៧-៤១០ *ច្រានចោល* ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៩-៦២។

[1358] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៦-៦៣៨, ៦៥០។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១០។

ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥ តម្រូវ "ចេតនាដោយផ្ទាល់ក្នុងការសម្លាប់"[1360] គឺមិនមានតម្លៃអ្វីទាំងអស់ ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានដកស្រង់ឯកសារគតិយុត្តិណាមួយ ហើយជាពិសេសមិនមានឧទាហរណ៍ នៃការសម្រេចលើកលែងចោទប្រកាន់ ដោយសារការចង់បានចេតនាដោយផ្ទាល់។

367. ផ្ទុយពីទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខ[1361] ទាំងអង្គជំនុំជម្រះសាលាដំបូង[1362] និងអង្គជំនុំជម្រះកាន់រឿងក្ដីនេះផ្ទាល់[1363] មិនបានបកស្រាយដោយខុសឆ្គង ទៅលើសាលក្រមរឿងក្ដី *គ្រូពេទ្យ* ឡើយ។ ការពិតដែលថាសាលក្រមនេះ មិនមាននិយមន័យច្បាស់លាស់ នៃធាតុផ្សំអត្តនោម័តិ គឺមិនពាក់ព័ន្ធអ្វីឡើយជាមួយ តម្លៃជាគតិយុត្តិរបស់វា[1364]។ ការសម្រេចរបស់តុលាការយោធាអាមេរិក លើអំពើមនុស្សឃាត ក្នុងករណីគ្មានចេតនាដោយផ្ទាល់ក្នុងការសម្លាប់ គឺមានភាពច្បាស់លាស់តាមរយៈសំអាងហេតុរបស់គេ។ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ អំពី "ដំណើរការជំរំនៃរបបណាហ្ស៊ី"[1365] គឺមិនមានភ័ស្ដុតាងគាំទ្រឡើយ ហើយការអះអាងរបស់គាត់ដែលថា ជនជាប់ចោទអាចមានតែចេតនាដោយផ្ទាល់ប៉ុណ្ណោះ ព្រោះ "កំណត់ឱ្យជនជាប់ឃុំទាំងអស់ត្រូវតែស្លាប់" គឺត្រូវបានជំទាស់ដោយ សាលក្រមរឿងក្ដី គ្រូពេទ្យ ដោយផ្ទាល់។ ដូចដែលម្ចាស់បណ្ដឹងសាទុក្ខបានទទួលស្គាល់[1366] អំពើមនុស្សឃាត មិនត្រូវបានចោទប្រកាន់ ចំពោះការពិសោធន៍ចំនួន

---

[1359] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៨១, ៥៨៦, ៥៩០, ៥៩៤-៥៩៥, ៥៩៩-៦០០។ សូមមើលផងដែរ ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥, ៤០៤-៤០៥, ៤២៥។

[1360] ម្ចាស់បណ្ដឹងសាទុក្ខកំណត់និយមន័យចេតនាផ្ទាល់ ដោយហេតុថា "ជននោះបង្កឱ្យកើតផលវិបាកនោះ ឬជននោះមានសតិដឹងថា វានឹងកើតមាននៅក្នុងដំណើរប្រព្រឹត្តធម្មតានៃព្រឹត្តិការណ៍"។ សូមមើល ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៩៤ *ដកស្រង់* លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៣០(២)(ខ)។

[1361] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៨១-៥៨៦។ ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧-៤២០។

[1362] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៣។

[1363] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៥ *ដកស្រង់* សាលក្រមរឿងក្ដីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៨៩-២០៧, ២៣៥-២៤១, ២៥៣-២៦៣, ២៧១, ២៩០។

[1364] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៨៤។ ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៥។

[1365] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៨៥។

[1366] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៨៥។

ប្អូន[1367] ហើយក្នុងករណីដែលត្រូវបានចោទប្រកាន់ អង្គជំនុំជម្រះបានរៀបរាប់ អំពីភ័ស្តុតាងនៃចំនួនអ្នកដែលនៅរស់ជាច្រើន ក្នុងករណីទាំងអស់[1368] លើកលែងតែមួយករណីប៉ុណ្ណោះដែលខុសពីនេះ[1369]។ ចៅក្រមមានភាពច្បាស់លាស់ថា ការស្លាប់គឺគ្រាន់តែជាលទ្ធផល ដែលអាចកើតមានឡើងមួយប៉ុណ្ណោះ[1370] ហើយចារីដឹងត្រឹមថា ជនរងគ្រោះនៃអំពើមនុស្សឃាត "អាចស្លាប់"[1371]។

---

[1367] ការពិសោធន៍ ច, ឆ ឈ និងថ។ សូមមើល សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៦-១៧៧ រំលឹកឡើងវិញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[1368] សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ២៣៦-២៣៧, ២៥៥ ការពិសោធន៍ ក (រយៈកំពស់ខ្ពស់)៖ ការពិសោធន៍ជាច្រើនដុំត្រូវបានធ្វើឡើង ទៅលើអ្នកទោសនៅ Dachau ចំនួន ១៨០ ទៅ២០០ នាក់ ដែលក្នុងនោះមាន៧០ ទៅ៨០នាក់បានស្លាប់) ទំព័រ ២០០-២០១ (ការពិសោធន៍ ខ (ភាពត្រជាក់ដល់កក)៖ "ជាលទ្ធផលមានអ្នកស្លាប់មួយចំនួន") ទំព័រ ២៦៤-២៦៥ (ការពិសោធន៍ គ (ជំងឺគ្រុនចាញ់)៖ "នៅក្នុងពេលពិសោធន៍ មានអ្នកទោសច្រើនរហូតដល់១០០០នាក់ នៅជំរុំប្រមូលផ្តុំ ត្រូវបានប្រើប្រាស់សម្រាប់ការពិសោធន៍ [...] ។ មានការកំណត់ថាមានអ្នកទោស ដែលទទួលរងការពិសោធន៍ ប្រហែល៣០នាក់បានស្លាប់ដោយសារតែលទ្ធផលផ្ទាល់នៃការពិសោធន៍ ហើយជាច្រើននាក់ទៀតមិនអាចទប់ទល់ជាប់ ជាមួយមូលហេតុនៃការពិសោធន៍ ភ្លាមៗក្រោយការពិសោធន៍")។ ទំព័រ ១៩៤ ការពិសោធន៍ ឃ **(Lost (Mustard) Gas)**៖ "អ្នកទោសនៅជំរុំប្រមូលផ្តុំជាង២០០នាក់ [...] ត្រូវបានប្រើប្រាស់សម្រាប់ការពិសោធន៍។ យ៉ាងហោចណាស់មានអ្នកទោស៥០នាក់ [...] បានស្លាប់ជាលទ្ធផលដោយផ្ទាល់ ឬដោយប្រយោល ពីការសាកល្បងដែលពួកគេបានទទួល") ទំព័រ ២១៣ ("អ្នកទោសនៅជំរំប្រមូលផ្តុំជាច្រើន ត្រូវបានយកទៅពិសោធន៍ជាមួយឧស្ម័ននេះ ហើយយ៉ាងតិចបំផុតមានមនុស្សស្លាប់ ចំនួន៥០នាក់")។ ទំព័រ ១៩៣ (ការពិសោធន៍ **(Sulfanilamide)**៖ "មានការបញ្ជាក់ថាមានមនុស្ស ៧៥ នាក់ ត្រូវបានគេពិសោធន៍ជាមួយ [...] ។ មានការបញ្ជាក់ផងដែរថា មានអ្នកទទួលរងការពិសោធន៍បីនាក់បានស្លាប់") ទំព័រ ១៧៧ (ការពិសោធន៍ ជ (ការរាតត្បាតជំងឺខាន់លឿង) ៖ "អ្នកទទួលរងការពិសោធន៍ ត្រូវបានចម្លងនូវជំងឺនេះដោយចេតនា [...] ជាលទ្ធផលអ្នកខ្លះបានស្លាប់ ហើយអ្នកខ្លះទទួលរងការឈឺចាប់និងវេទនាយ៉ាងខ្លាំង") ទំព័រ ២២០, ២៤២-២៤៤ (តុលាការរៀបរាប់លម្អិតអំពីលទ្ធផល នៃការពិសោធន៍ខុសៗគ្នា ក្នុងការសាកល្បងវ៉ាក់សាំងសម្រាប់ការពិសោធន៍ ញ (គ្រុនសន្និ **(Typhus)**)។ តុលាការរកឃើញថា "អ្នកទោសនៅជំរុំប្រមូលផ្តុំ មិនតិចជាង៧២៩នាក់ ត្រូវបានពិសោធន៍ជាមួយជំងឺគ្រុនសន្និ ហើយយ៉ាងហោចណាស់មានមនុស្ស ១៥៤ នាក់បានស្លាប់")។

[1369] នៅក្នុងការពិសោធន៍ ដ (ការពិសោធន៍ថ្នាំពុល) ជនជាប់ចោទបានពិសោធន៍ អ្នកទោសដែលត្រូវប្រហាជីវិត ជាមួយអានុភាពនៃថ្នាំពុល និងអាវុធមានថ្នាំពុល ដែលមានអានុភាពសម្លាប់មនុស្ស។ ក្នុងករណីនេះផ្ទុយពីករណីដទៃផ្សេងទៀត វាហាក់ដូចជាថា ជនជាប់ចោទមានចេតនាផ្ទាល់ ក្នុងការសម្លាប់ជនរងគ្រោះរបស់ពួកគេ។ *សូមមើលឧទាហរណ៍* សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៨, ២៤៥-២៤៧។

[1370] សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៨៣ ("មានការប្រុងប្រយ័ត្នតិចតួចបំផុត ឬក៏គ្មានតែម្តង ដើម្បីការពារ [...] អ្នកដែលត្រូវពិសោធន៍ដើម្បីជៀសផុតពី*លទ្ធភាព* នៃរបួសស្នាម ពិការភាព ឬការស្លាប់។ នៅក្នុងការពិសោធន៍ទាំងអស់ អ្នកដែលត្រូវពិសោធន៍ ទទួលរងការធ្វើទារុណកម្ម ឬឈឺចាប់ខ្លាំងក្លា ហើយពួកគេភាគច្រើនលើសលប់ ទទួលរងរបួសជាអចិន្ត្រៃយ៍ ពិការភាព ឬស្លាប់" ១៨៣ (គូសបញ្ជាក់បន្ថែម))។

ទោះបីជាវិធីសាស្ត្រដែលបានអនុវត្ត មិនអាចការពារបានក៏ដោយ តែគោលបំណងនៃការពិសោធន៍ទាំងអស់នេះ គឺដើម្បីស្វែងរកវិធីសាស្ត្រព្យាបាលឱ្យជោគជ័យ ទៅលើស្ថានភាពគ្រោះថ្នាក់ដល់ស្លាប់ គឺមិនមែនដើម្បីសម្លាប់អ្នកចូលរួមពិសោធន៍ទេ[1372]។

368. បន្ថែមលើនេះ សាលក្រមរឿងក្តី គ្រូពេទ្យ មិនមែនជាយុត្តិសាស្ត្រ ក្រោយសង្គ្រាមលោកលើកទីពីរតែមួយគត់ ដើម្បីគាំទ្របទដ្ឋានចេតនាប្រយោលទេ[1373]។ តុលាការកំពូលអាល្លឺម៉ង់ សម្រាប់តំបន់ចក្រភពអង់គ្លេស បានសម្រេចពីរដងក្នុងឆ្នាំ១៩៤៨ថា ចេតនាប្រយោល បំពេញនូវធាតុផ្សំអត្តនោម័តិ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំងអំពើមនុស្សឃាតផង[1374]។

---

[1371] សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ២៤៤ ("ជនរងគ្រោះទាំងអស់នេះ មិនបានទទួលព័ត៌មានថា [...] ពួកគេ *អាចស្លាប់* [...]។ ជាធម្មតាបុគ្គលម្នាក់ៗមិនបានយល់ព្រម ក្លាយជាវត្ថុពិសោធន៍ពិសេស ជាមួយ*សេចក្តីស្លាប់*ឡើយ ២៤៤ (គូសបញ្ជាក់បន្ថែម))។

[1372] សូមមើលឧទាហរណ៍ សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ២៣៦ (ការពិសោធន៍ ក (រយៈកម្ពស់ខ្ពស់) ត្រូវបានធ្វើឡើង "ដើម្បីកំណត់ពីកម្រិតនៃការធន់ទ្រាំ និងអាចទប់ទល់បានរបស់មនុស្ស នៅរយៈកម្ពស់ខ្ពស់ហួសប្រមាណ" ទំព័រ ២០០-២០១ (ការពិសោធន៍ ខ (ភាពត្រជាក់ដល់កក) ត្រូវបានធ្វើឡើងដើម្បីដោះស្រាយ ("បញ្ហាសំខាន់បំផុតមួយរបស់កងទ័ព") ទំព័រ ២៦៤(ការពិសោធន៍ គ (ជំងឺគ្រុនចាញ់) ត្រូវបានធ្វើឡើង "ក្នុងគោលបំណងស្វែងរកវិធីសាស្ត្រ បង្កើតភាពស៊ាំជាមួយជំងឺគ្រុនចាញ់") ទំព័រ ១៩៥, ២៣៧-២៣៨ (ការពិសោធន៍ ឃ **(Lost (Mustard) Gas)** ត្រូវបានធ្វើឡើង "ដើម្បីស្វែងរកនូវប្រសិទ្ធិភាព នៃការព្យាបាលផ្សេងៗគ្នា ទៅលើស្នាមរបួស ដែលបង្ករឡើងដោយ Lost gas [...]វិធីសាស្ត្រព្យាបាលផ្សេងៗគ្នាត្រូវបានអនុវត្តដើម្បីស្វែងរកវិធីសាស្ត្រមួយ ដែលមានប្រសិទ្ធិភាពបំផុត") ទំព័រ ១៩៣ ((ការពិសោធន៍ **(Sulfanilamide)**"អ្នកត្រូវគេពិសោធន៍ត្រូវបានចម្លងមេរោគដោយចេតនា ហើយ [...] ឱសថផ្សេងៗគ្នាត្រូវបានប្រើប្រាស់ ក្នុងការព្យាបាលការឆ្លង ដើម្បីកំណត់ពីប្រសិទ្ធិភាពរបស់ឱសថនីមួយៗ")ទំព័រ ១៩៤ (ការពិសោធន៍ ជ (ការរាតត្បាតជំងឺខាន់លឿង) ត្រូវបានធ្វើឡើង "ក្នុងគោលបំណងស្វែងរកវ៉ាក់សាំងដែលមានប្រសិទ្ធិភាព ដើម្បីបង្កើតភាពស៊ាំជាមួយ ការរាតត្បាតជំងឺខាន់លឿង") ទំព័រ ២០២, ២១៨-២១៩, ២២១ (ការពិសោធន៍ ញ (គ្រុនសន្និ **(Typhus)**) ត្រូវបានធ្វើឡើង "ក្នុងគោលបំណងកំណត់ប្រសិទ្ធិភាព នៃវ៉ាក់សាំងនានាសម្រាប់ការការពារជំងឺគ្រុនសន្និ")។

[1373] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៦។

[1374] *L.* និង *អ្នកដទៃទៀត* ទំព័រ ២២៩-២៣៤។ ("Der stumme Zuschauer eines Unmenschlichkeitsverbrechens ist nur strafbar, wenn er mitursächlich geworden ist und mindestens Eventualvorsatz der Mitursächlichkeit hatte." ការបកប្រែក្រៅផ្លូវការUnofficial translation៖ "អ្នកទស្សនាដោយស្ងៀមស្ងាត់ ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចដាក់ទណ្ឌកម្មតែក្នុងករណីដែល គាត់បានចូលរួមទទួលខុសត្រូវដោយផ្នែក ហើយយ៉ាងហោចណាស់ មានចេតនាដោយមានលក្ខខណ្ឌ")។ *T.* និង *K.* ទំព័រ ១៩៨-២០២ (ដោយរំឭកឡើងវិញពីលក្ខខណ្ឌ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តុលាការបានពិចារណាថា លក្ខខណ្ឌត្រូវបានបំពេញ ពាក់ព័ន្ធជនជាប់ចោទទាំងពីរ សម្រាប់ការចូលរួមរបស់ពួកគេ ក្នុងការដុតកម្ទេចទាំងវិហារជ្វីហ្វនិងផ្ទះដែលនៅក្បែរៗនោះ ដែលជនជាប់ចោទបានដុតដោយគ្មានញញើត)។

369. ផ្ទុយពីការអះអាងរបស់ ម្ចាស់បណ្ដឹងសាទុក្ខ[1375] អង្គជំនុំជម្រះសាលាដំបូង ត្រូវបានអនុញ្ញាតិឱ្យគាំទ្រ ការវាយតម្លៃរបស់ខ្លួន ទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាមរយៈការស្វែងរក "គោលការណ៍ណែនាំ" បន្ថែម[1376] ពីយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច[1377] ដែលសេចក្ដីសន្និដ្ឋានរបស់តុលាការទាំងនោះ[1378] គឺពឹងផ្អែកផងដែរទៅលើ ការវាយតម្លៃផ្ទាល់របស់ពួកគេ ទៅលើធាតុផ្សំអត្តនោម័តិ នៃអំពើមនុស្សឃាតនៅក្នុងយុគសម័យ មុនឆ្នាំ១៩៧៩[1379]។ ការយោងរបស់ម្ចាស់បណ្ដឹងសាទុក្ខ ទៅលើលក្ខខណ្ឌតម្រូវសម្រាប់ ការគិតទុកជាមុននៅក្នុង យុត្តិសាស្ត្រខ្លះៗរបស់តុលាការ ICTR គឺជាការនាំឱ្យយល់ច្រឡំ[1380]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ អង្គជំនុំជម្រះដែលប្រើប្រាស់លក្ខខណ្ឌតម្រូវនេះ គឺមិនមែនមានន័យថាចង់រក ច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[1381] ហើយតុលាការ ICTY និងអង្គជំនុំជម្រះតុលាការកំពូលខ្លះ របស់

---

[1375] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៨៧។

[1376] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៤-៦៣៥។

[1377] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៥។ សូមមើលផងដែរ *សាលដីការឿងក្ដី Kordić & Čerkez* កថាខណ្ឌ ១១៣ សម្រេចតម្កល់ថា "គ្មានការជំទាស់" *សាលក្រមរឿងក្ដី Kordić & Čerkez* កថាខណ្ឌ ២៣៥-២៣៦។ *សាលក្រមរឿងក្ដី Taylor* កថាខណ្ឌ ៤១២។

[1378] *សាលក្រមរឿងក្ដី Blaškić* កថាខណ្ឌ ២១៧ សម្រេចថា ធាតុផ្សំអត្តនោម័តិ នៃអំពើមនុស្សឃាតរួមមាន "ចេតនា [...] បង្កឱ្យមានការឈឺចាប់រូបរាងកាយធ្ងន់ធ្ងរ ដោយមានការដឹងឮដោយសមហេតុផលថា ការវាយប្រហារប្រហែលជាបណ្ដាលឱ្យមានការស្លាប់" និង *ដកស្រង់* របាយការណ៍របស់ គណៈកម្មាធិការច្បាប់អន្តរជាតិ ស្ដីពីការងារនៃអង្គប្រជុំ លើកទីសែសិបប្រាំបីរបស់ខ្លួន ថ្ងៃទី៦ ខែឧសភា ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ UN Doc. A/51/10 ទំព័រ ៩៦ ("អំពើមនុស្សឃាត [...] ត្រូវបានយល់ដឹងយ៉ាងច្បាស់ និងកំណត់យ៉ាងជាក់ច្បាស់ នៅក្នុងច្បាប់ជាតិរបស់រដ្ឋទាំងអស់")។ សូមមើលផងដែរ *សាលក្រមរឿងក្ដី Akayesu* កថាខណ្ឌ ៥៨៧, ៥៨៩។

[1379] *សូមមើលឧទាហរណ៍ សាលក្រមរឿងក្ដី Čelebići* កថាខណ្ឌ ៤២០-៤៣៩ (វិភាគផងដែរនូវអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ពិធីសារបន្ថែម១ ឆ្នាំ១៩៧៧ និងបទអត្ថាធិប្បាយ [...] ដើម្បីសន្និដ្ឋានថា "ធាតុផ្សំអត្តនោម័តិចាំបាច់ [...] គឺតម្រូវសម្រាប់បង្ហាញ អំពីឧក្រិដ្ឋកម្មនៃការសម្លាប់ និងអំពើមនុស្សឃាតដោយចេតនា ដែលត្រូវបានទទួលស្គាល់នៅក្នុង អនុសញ្ញាទីក្រុងហ្សឺណែវ គឺមានវត្តមានក្នុងករណីដែលមានការបង្ហាញ អំពីចេតនារបស់ជនជាប់ចោទ ក្នុងការសម្លាប់ ឬបង្កឱ្យមានរបួសស្នាមធ្ងន់ធ្ងរ ដោយមិនបានគិតខ្វល់ខ្វាយអំពីជីវិតមនុស្ស")។ ធាតុផ្សំនៃការសម្លាប់ដោយចេតនា គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ហើយអំពើមនុស្សឃាតគឺជា ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដូចគ្នា។ *សូមមើលឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្ដី ឌុច* កថាខណ្ឌ ៤៣១។ *សាលក្រមរឿងក្ដី Brđanin* កថាខណ្ឌ ៣៨០ ជើងទំព័រ ៩០៣។

[1380] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៨៧។

[1381] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩២ *ដកស្រង់ សាលក្រមរឿងក្ដី Kayishema & Ruzindana* កថាខណ្ឌ ១៣៨។

តុលាការ ICTR ក៏មិនអនុវត្តតាមនោះទេ[1382]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូល បានដោះស្រាយទៅលើសារណាដូចគ្នា របស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង០០២/០១ ហើយសម្រេចថាការគិតទុកជាមុន មិនអាចអនុវត្តបានទេ នៅក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥[1383]។

*ការពឹងផ្អែកដោយមានសុពលភាព ទៅលើគោលការណ៍គតិយុត្តិទូទៅ*

370. ម្ចាស់បណ្តឹងសាទុក្ខ យល់ច្រឡំទៅលើគោលបំណង ដែលអង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកទៅលើច្បាប់ជាតិ[1384] ដើម្បីគាំទ្រដល់បទដ្ឋានចេតនាប្រយោល។ ច្បាប់ជាតិមិនមែនជា "ប្រភពចម្បង និងឯករាជ្យ" សម្រាប់ការកំណត់ ធាតុផ្សំអត្តនោម័តិ នៃអំពើមនុស្សឃាត នៅក្នុងឆ្នាំ១៩៧៥ទេ[1385] ហើយច្បាប់ជាតិក៏មិន "ជំនួស" ឬ "ដកចេញ" នូវវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលផ្ទុយនោះឡើយ[1386]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល បានបង្ហាញ យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ គឺជាការចង្អុលបង្ហាញ "រឹងមាំ"[1387] ឬសឹងតែជាស្ថាពរតែម្តង[1388]ថា ធាតុផ្សំអត្តនោម័ត នៃអំពើមនុស្សឃាត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺរួមបញ្ចូលនូវចេតនាប្រយោល។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូង មិនតម្រូវឱ្យស្វែងរក គោលការណ៍គតិយុត្តិទូទៅ ដើម្បីកំណត់ពីស្ថានភាព នៃច្បាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥ឡើយ។ អង្គជំនុំជម្រះគ្រាន់តែត្រូវការបង្ហាញថា សេចក្តីសន្និដ្ឋានរបស់ខ្លួន ទៅលើឋានៈ

---

[1382] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩២។ *សាលដីការឿងក្តី* Đorđević កថាខណ្ឌ ៥៥១-៥៥២។ ចំពោះសាលដីការបស់ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ SCSL បានសម្រេចតម្កល់ការសម្រេចលើពិរុទ្ធភាព នៃអំពើមនុស្សឃាត ដែលមិនតម្រូវឱ្យមានការគិតទុកជាមុនឡើយ សូមមើល ឧទាហរណ៍ *សាលដីការឿងក្តី* Musema, ផ្នែកសម្រេចសេចក្តី, នៅដំណាក់កាលជំនុំជម្រះ អង្គជំនុំជម្រះបានសម្រេចថា "[CIL] តម្រូវថាបទល្មើសជា "អំពើមនុស្សឃាត" គឺមិនមែនជា "ការធ្វើឃាត" ដែលបង្កើតជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ" (*សាលក្រមរឿងក្តី* Musema កថាខណ្ឌ ២១៤)។

[1383] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩២-៣៩៤។

[1384] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៨-៦៥០។ សូមមើលផងដែរ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៦-៤០៩។

[1385] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦១៣។ សូមមើលផងដែរ កថាខណ្ឌ ៦១៨។

[1386] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦០១, ៦១៣។

[1387] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៥។

[1388] សហព្រះរាជអាជ្ញាបានកត់សម្គាល់ ពីការមិនមានសេចក្តីសម្រេចផ្ទុយណាមួយ នៅក្នុងច្បាប់និងយុត្តិសាស្ត្រ ក្រោយសង្គ្រាមលោកលើកទីពីរឡើយ។

នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺ "គាំទ្រ" ដោយច្បាប់ជាតិ[1389]។ ហេតុដូច្នេះ នៅក្នុងការស្វែងរកគោលការណ៍ទូទៅ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តលើអាណត្តិការងាររបស់ខ្លួនទៅទៀត។

371. ទោះជាក្នុងករណីណាក៏ដោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង មិនត្រូវបានអនុញ្ញាតិឱ្យពឹងផ្អែក[1390] ទៅលើគោលការណ៍ទូទៅនៃច្បាប់ជាតិនោះ[1391] គឺបានមើលរំលងទៅលើ ការឯកភាពជាឯកច្ឆន្ទនៅគ្រប់ អង្គជំនុំជម្រះទាំងអស់នៃ អ.វ.ត.ក[1392] រួមទាំងអង្គជំនុំជម្រះតុលាការកំពូល[1393] និងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត[1394] ដែលថា ក្នុងករណីមានការកំណត់ហើយ គោលករណ៍ទូទៅគឺជាប្រភពស្របច្បាប់ និងអាចប្រើប្រាស់បានសម្រាប់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ដោយខុសឆ្គង នូវមាត្រា ៣៨(១)(គ) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីផ្តល់យុត្តិកម្ម[1395] គឺត្រូវបានជំទាស់ដោយប្រភពតែមួយគត់ ដែលម្ចាស់បណ្តឹងសាទុក្ខបានពឹងផ្អែកលើ ដែលប្រភពនោះគាំទ្រថា "មានអត្តសញ្ញាណនៃប្រភពផ្លូវការ រវាងច្បាប់អន្តរជាតិសាធារណៈ និងនីតិព្រហ្មទណ្ឌអន្តរជាតិ"[1396]។ តាមពិតទៅមាត្រា ១៥(២) នៃ

---

[1389] *សាលដីការឿងក្តី* *Tadić* កថាខណ្ឌ ២២៥។ ឯកសារ **D97/14/15** និង ឯកសារ **D97/15/9** និង ឯកសារ **D97/16/10** និងឯកសារ **D97/17/6** សាលដីការបស់អង្គបុរេជំនុំជម្រះ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៤-៨៥។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨០៥។

[1390] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៨។

[1391] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៧៦-៥៨០, ៥៨៨-៥៩១, ៦០០-៦២២។

[1392] សូមមើលឧទាហរណ៍ សហចៅក្រមស៊ើបអង្កេត៖ **ឯកសារ D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០២។ អង្គបុរេជំនុំជម្រះ ៖ ឯកសារ **D97/14/15** និង ឯកសារ **D97/15/9** និងឯកសារ **D97/16/10** និង ឯកសារ **D97/17/6** សាលដីការបស់អង្គបុរេជំនុំជម្រះ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៥៣, ៨៦។ អង្គជំនុំជម្រះសាលាដំបូង៖ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្តី ឌុច* កថាខណ្ឌ ៣០។

[1393] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩២, ៩៦, ១៧៤, ១៨១-១៨២។

[1394] សូមមើលឧទាហរណ៍ តុលាការ **ICTY**៖ *សាលដីការឿងក្តី* *Tadić* កថាខណ្ឌ ២២៥។ *សាលដីការឿងក្តី* *Čelebići* កថាខណ្ឌ ៥៨៣។ *សាលដីការឿងក្តី* *Blaškić* កថាខណ្ឌ ៣៤-៤២។ *សាលក្រមរឿងក្តី* *Furundžija* កថាខណ្ឌ ១៧៧-១៧៨។ *សាលក្រមរឿងក្តី* *Kunarac* កថាខណ្ឌ ៤៣៩។ តុលាការ **SCSL**៖ វិធានភ័ស្តុតាងនិងនីតិវិធីរបស់តុលាការ SCSL វិធាន ៧២ ស្ទួន (៣)។ តុលាការ **ICC**៖ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២១(១)(គ)។

[1395] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦០៦-៦១១ ជំទាស់ចំពោះ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៨។

[1396] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ១០៧៧។ សូមមើលផងដែរ Gerhard Werle, *គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* Asser Press (២០០៥) កថាខណ្ឌ ១២៣ ("ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ កើតចេញពីប្រភពច្បាប់តែមួយ ដូច

កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលបានរួមបញ្ចូលយ៉ាងច្បាស់លាស់ទៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក[1397] បានអះអាងថា ដូច្នេះសិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ មិនត្រូវបានរំលោភបំពានឡើយ[1398]។ ការទាមទាររបស់ ម្ចាស់បណ្តឹងសាទុក្ខ អំពីគោលការណ៍វិមតិសង្ស័យ នឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវរារាំងដល់ការងាកទៅរក គោលការណ៍ទូទៅនោះ[1399] គឺមិនមានអ្វីគាំទ្រឡើយ។ ម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ពីវិមតិសង្ស័យ ដែលត្រូវដោះស្រាយជាប្រយោជន៍ដល់រូបគាត់ឡើយ ហើយម្ចាស់បណ្តឹងសាទុក្ខ មិនបានផ្តល់ការពន្យល់បកស្រាយ ថាតើច្បាប់នេះ ដែលអាចអនុវត្តបានចំពោះបញ្ហាគតិយុត្តិ តែក្នុងករណីដែលនៅមានវិមតិសង្ស័យ ក្រោយពេលប្រើប្រាស់សព្វគ្រប់[1400] នូវច្បាប់បកស្រាយហើយនោះ អាចដកចេញបានដោយរបៀបណា នូវប្រភពដែលស្របច្បាប់ នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

372. ចំពោះខ្លឹមសារនៃគោលការណ៍ទូទៅ ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់ពីកំហុសឆ្គងណាមួយ នៅក្នុងការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលថា ច្បាប់ជាតិនៅក្នុងឆ្នាំ១៩៧៥ កំណត់ថា "នៅពេលដែលបុគ្គលណាម្នាក់ បានប្រព្រឹត្តអំពើដោយស្ម័គ្រចិត្ត និងដោយដឹងថាអំពើនោះ ទំនងជានឹងបណ្តាលឱ្យមាន ការបាត់បង់ជីវិតមនុស្ស អំពើនោះគឺជាការធ្វើមនុស្សឃាត ឬជាឧក្រិដ្ឋកម្មដែលមានស្ថានទម្ងន់ស្រដៀងគ្នា"[1401]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈ "សើៗ"[1402] នោះ គឺមិនមានអ្វីគាំទ្រឡើយ។ ដូចដែលបានតម្រូវ[1403] អង្គជំនុំជម្រះសាលាដំបូង បានស្វែងរកប្រភពរបស់ខ្លួន នៅតាមបណ្តាប្រព័ន្ធច្បាប់

---

នឹងច្បាប់អន្តរជាតិ ដែលទាំងអស់នេះរួមមាន គោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយ ប្រព័ន្ធច្បាប់សំខាន់ៗនានាលើពិភពលោក")។

1397 ច្បាប់ អ.វ.ត.ក មាត្រា ៣៣ ថ្មី។

1398 កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៥(២)។

1399 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦០១, ៦១២, ៦២០, ៦២២។

1400 ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៣១។ *សាលក្រមរឿងក្តី Čelebići* កថាខណ្ឌ ៤១៣។

1401 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៥០។ សូមមើលផងដែរ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៦-៤០៩។

1402 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦២៤។

1403 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៨ *ដកស្រង់* **ឯកសារ D97/15/9** សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម JCE កថាខណ្ឌ ៥៣, ៨៦។

common law[1404] ច្បាប់ស៊ីវិល[1405] ច្បាប់ចម្រុះ[1406] និងច្បាប់ជាតិជាច្រើន។ ជាពិសេសទៅទៀត ម្ចាស់បណ្តឹងសាទុក្ខមិនបាន ធ្វើឱ្យអន់ថយនូវការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធ ប្រទេសឥណ្ឌា ប្រទេសអូស្ត្រាលី និងប្រទេសអង់គ្លេស[1407]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានពន្យល់ថា តើ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មានកំហុសឆ្គងដោយរបៀបណា ដោយការយោងទៅរកធាតុផ្សំអត្តនោម័ត ដែលអាចបំពេញសព្វគ្រប់បាន ដោយការរកឃើញ "ការ មិនអើពើទៅលើអាយុជីវិតមនុស្ស (ប្រទេសអូស្ត្រាលី)"[1408] ឬការដឹងឮថាអំពីនោះគឺ "មាន គ្រោះថ្នាក់ជាក់ច្បាស់ ដែលក្នុងគ្រប់លទ្ធភាពទាំងអស់ អំពើនោះនឹងបណ្តាលឱ្យស្លាប់ ឬរបួសលើ រាងកាយបែបនេះ គឺអាចបណ្តាលឱ្យស្លាប់ (ប្រទេសឥណ្ឌា)"[1409]។ ការវិភាគរបស់ម្ចាស់បណ្តឹង សាទុក្ខ ទៅលើយុត្តិសាស្ត្ររបស់អង់គ្លេស គឺមានកំហុសឆ្គងប្រហែលគ្នា។ នៅក្នុងរឿងក្តី *R តទល់នឹង*. *Hyam* ទាំងមតិភាគច្រើន និងមតិជំទាស់ មិនបានតម្រូវឱ្យមានចេតនាផ្ទាល់ ក្នុងការ សម្លាប់ឡើយ។ មតិជំទាស់ទាំងពីរសម្រេចថា អំពីដោយអាចប្រមើលមើលថា ជីវិតស្ថិតក្នុងគ្រោះ ថ្នាក់ គឺបំពេញបាននូវធាតុផ្សំអត្តនោម័តិ សម្រាប់អំពើមនុស្សឃាត[1410]។

---

[1404] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៩, ៦៤១ រួមបញ្ចូល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៦, ៤០២-៤០៨ ((i) ប្រទេសអង់គ្លេស និងប្រទេស Wales (ii) ប្រទេសអូស្ត្រាលី (iii) ប្រទេសឥណ្ឌា (iv) ប្រទេសសិង្ហបុរី (v) សហរដ្ឋអាមេរិក)។

[1405] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៩, ៦៤១ រួមបញ្ចូលនូវ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៦, ៣៩៩-៤០១ ((i) ប្រទេសប៉ែលហ្សិក (ii) ប្រទេសប៉ូឡូញ) ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៤១ ((i) ប្រទេសអាល្លឺម៉ង់ (ii) ប្រទេសអូទ្រីស្ត (iii) ប្រទេសស្វីស)), ៦៤២ (ប្រទេសហូឡង់), ៦៤៣ (ប្រទេសអ៊ីតាលី), ៦៤៦-៦៤៧ ((i) ប្រទេសរុស្ស៊ី (ii) ប្រទេសជប៉ុន)។

[1406] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤០១។

[1407] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៤៥។

[1408] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ២០១០ *ដកស្រង់* ច្បាប់ព្រហ្មទណ្ឌរបស់ New South Wales ឆ្នាំ១៩០០, ផ្នែក ១៨(ក)។

[1409] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ២០១០ *ដកស្រង់* ក្រមព្រហ្មទណ្ឌឥណ្ឌា ឆ្នាំ១៨៦០ មាត្រា ៣០០។

[1410] *រឿងក្តី R ទល់នឹង Hyam*, [១៩៧៥] AC ៥៥ ទំព័រ ៩៣ (Lord Diplock៖ "ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មមនុស្សឃាត ប្រសិនបើជនល្មើសមិនមានចេតនាសម្លាប់ទេ ជននោះចាំបាច់ត្រូវតែមានចេតនា ឬអាចប្រមើលមើល អំពីផលវិបាកដែលអាច កើតមាន ពីអំពើរបស់គាត់ថា អាចបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស") ទំព័រ ៩៨ (Lord Kilbrandon៖ "ប្រសិនបើបង្ហាញ ភ័ស្តុតាងអំពើមនុស្សឃាត ដោយគ្មានចេតនាក្នុងការសម្លាប់ ក្រុមប្រឹក្សាជំនុំជម្រះចាំបាច់ត្រូវតែជឿជាក់ [...] ថា ជនចាប់ចោទ បានដឹងការ អំពើរបស់ខ្លួន ប្រហែលជាអាចបណ្តាលឱ្យមានការស្លាប់ ហើយមិនមានភាពខុសគ្នាឡើយ ថាតើមានផលវិបាកបែប នេះ កើតឡើងដែរឬអត់នោះ")។

373. សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ថា ប្រភពរបស់អង្គជំនុំជម្រះសាលាដំបូង មិនសព្វគ្រប់នោះឡើយ។ យុត្តាធិការបន្ថែមទៀតជាច្រើននៅក្នុងទ្វីបអាស៊ី[1411] អាហ្វ្រិក[1412] អាមេរិកខាងត្បូង[1413] និងអឺរ៉ុប[1414] គាំទ្រដល់ការសន្និដ្ឋានថា ធាតុផ្សំអត្តនោម័តិ សម្រាប់ការសម្លាប់ដោយចេតនា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាំបាច់ត្រូវកំណត់និយមន័យ "ឱ្យមានលក្ខណៈទូលាយ ដើម្បីរួមបញ្ចូលនូវចេតនាប្រយោល"[1415]។ មិនមែនជាបញ្ហាស្ពាប់រស់នោះទេ[1416] ដែលច្បាប់បារាំងនិងច្បាប់កម្ពុជា មិនបានចែងអំពីចំណុចនេះ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ មិនមានការតម្រូវឱ្យមាន ការអនុវត្តដូចគ្នាទាំងស្រុងនៅថ្នាក់ជាតិឡើយ[1417] ហើយការពឹងផ្អែករបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើលក្ខន្តិកៈទីក្រុងរ៉ូម ដើម្បីលើកទឡ្ហីករណ៍ គឺជាការលើកឡើងដោយខុសឆ្គង[1418]។

*ការមិនអាចអនុវត្តបាននូវគោលការណ៍ច្បាប់ ដែលកំណត់ពីទោសស្រាលជាង (lex mitior)*

374. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសឆ្គងថា ធាតុផ្សំអត្តនោម័តិ នៃចេតនាប្រយោល មិនអាចអនុវត្តបានដោយសារតែវា ត្រូវបានដកចេញដោយមាត្រា ៣០(២)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែល

---

[1411] **ប្រទេសថៃ**៖ ក្រមព្រហ្មទណ្ឌថៃ ឆ្នាំ១៩៥៦, ផ្នែក ៥៩, ២៨៨។ **ប្រទេសប៉ាគីស្ថាន៖** ក្រមព្រហ្មទណ្ឌប៉ាគីស្ថាន ថ្ងៃទី៦ ខែតុលា ឆ្នាំ១៨៦០, ផ្នែក ៣០០។ **ប្រទេសម៉ាឡេស៊ី៖** ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៣៦, ផ្នែក ២៩៩-៣០០។ **អូម៉ង់៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៤ មាត្រា ៨១, ២៣៥។ **ប្រទេសស្រីលង្កា៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែមករា ឆ្នាំ១៨៨៥ មាត្រា ២៩៣-២៩៤។

[1412] **ប្រទេសបុតស្វាណា**៖ ក្រមព្រហ្មទណ្ឌ ថ្ងៃទី១០ ខែមិថុនា ១៩៦៤, ផ្នែក ២០២, ២០៤។ **ប្រទេសហ្គាណា៖** ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៦០, ផ្នែក ១១, ៤៧។ **ប្រទេសកេនយ៉ា៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែសីហា ឆ្នាំ១៩៣០, ផ្នែក ២០៣, ២០៦។ **ប្រទេសលីបេរីយ៉ា**៖ ច្បាប់ព្រហ្មទណ្ឌ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៧៦, ផ្នែក ១៤.១(ខ)។ **ប្រទេសនីហ្សេរីយ៉ា៖** ច្បាប់ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩១៦, ផ្នែក ៣១៥, ៣១៦។ **ប្រទេសម៉ាឡាវី៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៣០, ផ្នែក ២០៩, ២១២។ **ប្រទេសតង់ហ្សានី៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៤៥, ផ្នែក ១៩៦, ២០០។ **ប្រទេសអ៊ូហ្គង់ដា៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥០, ផ្នែក ១៨៨, ១៩១។

[1413] **ប្រទេកូឡុំប៊ី**៖ ក្រមព្រហ្មទណ្ឌសាធារណរដ្ឋកូឡុមប៊ី ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៣៦ (ដូចនៅឆ្នាំ១៩៦៧) មាត្រា ១២, ៣៦២។

[1414] **អតីតប្រទេសយូហ្គោស្លាវី៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែកក្កដា ឆ្នាំ ១៩៥១ មាត្រា ៧(១)-(២), ១៣៥(១)។ **ប្រទេសរ៉ូម៉ានី៖** ក្រមព្រហ្មទណ្ឌសាធារណរដ្ឋសង្គមនិយមរ៉ូម៉ានី ថ្ងៃទី១ ខែមករា ឆ្នាំ១៩៦៩ មាត្រា ១៧, ១៩, ១៧៤។

[1415] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤០៩-៤១០។

[1416] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦២៩។

[1417] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៣៨ និង ការដកស្រង់នៅក្នុងនោះ។

[1418] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២១(១)(គ) មិនបានផ្តល់តម្លៃខ្ពស់ជាងណាមួយ ទៅលើ "ច្បាប់ជាតិរបស់រដ្ឋ ដែលជាធម្មតាអនុវត្ត យុត្តាធិការទៅលើឧក្រិដ្ឋកម្ម"។

ម្ចាស់បណ្ដឹងសាទុក្ខពោលអះអាងថា ជាប្រភពនៃច្បាប់សម្រាប់ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា៩ នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក[1419]។ ជាធាតុផ្សំជាប់មកជាមួយដែលថា គោលការណ៍ច្បាប់កំណត់ពីទោសស្រាលជាង ដែលជាច្បាប់ដែលផ្ដល់ប្រយោជន៍ច្រើនជាង "ចាំបាច់ ត្រូវចងកាតព្វកិច្ចទៅលើ [អ.វ.ត.ក]"[1420]។ ទោះបីជាយ៉ាងនេះក្ដី លក្ខន្តិកៈទីក្រុងរ៉ូម មិនបានផ្ទុះ បញ្ជាំងអំពី ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥ទេ[1421] ហើយកិច្ចព្រមព្រៀងស្ដីពីការ បង្កើត អ.វ.ត.ក[1422] និងយុត្តិសាស្ត្រ[1423] គាំទ្រថាយុត្តាធិការលើរឿងក្ដីរបស់តុលាការនេះ ត្រូវ សម្រេចកំណត់ដោយ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលមិនបានកំណត់និយមន័យ នៃ ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ដោយយោងទៅរកលក្ខន្តិកៈទីក្រុងរ៉ូមឡើយ[1424]។

*ការដឹងថាមានច្បាប់ចែង និងការប្រមើលមើលដឹងថាជាបទល្មើស ត្រូវបានកំណត់*

375. អង្គជំនុំជម្រះបានសម្រេចរួចហើយថា អំពើមនុស្សដោយចេតនាប្រយោល គឺម្ចាស់បណ្ដឹង សាទុក្ខអាចដឹងថាមានច្បាប់ចែង និងអាចប្រមើលមើលដឹងថាជាបទល្មើស[1425]។ ក្នុងកម្រិតដែល ម្ចាស់បណ្ដឹងសាទុក្ខជំទាស់ចំពោះ យុត្តិសាស្ត្រដែលបានកំណត់រួចហើយ តាមរយៈការអះអាង

---

[1419] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៩១, ៥៩៦-៦០០ *ដកស្រង់* កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ៩។

[1420] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ៣៤៦-៣៥១។ បណ្ដឹងសាទុក្ខ *D. Nikolić* SJ កថាខណ្ឌ ៨១។ បណ្ដឹងសាទុក្ខ *Deronjić* SJ កថាខណ្ឌ ៩៧។ *សាលដីការឿងក្ដី Stanišić & Simatović* កថាខណ្ឌ ១២៨។

[1421] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២១។ ការអះអាងពីបទចោទ *Katanga* និង *Ngudjolo Chui* កថាខណ្ឌ ៥០៦-៥០៨។ សាលដីការឿងក្ដី *Šainović* កថាខណ្ឌ ១៦៤៨។ សំណុំរឿង Case ០០៤/២-ឯកសារ **D359/24** និង ឯកសារ **D360/33** សេចក្ដីពិចារណារបស់ អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយ អោ អាន, មតិរបស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៥៧០, ៥៨៨។ សូមមើលផងដែរ ឯកសារ **D193/5/5** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹង ទ្រព្យសម្បត្តិទាំងអស់ ដែលជនជាប់ចោទមាន កថាខណ្ឌ ២៥។

[1422] កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ២(១)។ សូមមើលផងដែរ កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ២(២)។

[1423] *សូមមើលឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ៩៩, ១០៥។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្ដី ឌុច* កថាខណ្ឌ ២៨១។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨, ៣០០-៣០១។

[1424] សូមមើល ច្បាប់ អ.វ.ត.ក មាត្រា ៥។

[1425] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦៥។

បន្ថែមថា វាមិនតំណាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥នោះ[1426] ការវិភាគខាងក្រោមនេះ នឹងបង្ហាញថាចាំបាច់ត្រូវច្រានចោលទឡ្ហីករណ៍នេះ។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានគាំទ្រផងដែរថា គោលការណ៍ទូទៅនៃច្បាប់ជាតិ គឺជនជាប់ចោទអាចដឹងបាន[1427]។ ការសម្លាប់ដោយចេតនាប្រយោល ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ នៅក្នុងប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៥ បើទោះបីជាមិនស្ថិតក្រោមឈ្មោះមនុស្សឃាតក្តី[1428] ហើយដោយសារតែស្ថានទម្ងន់ជាក់ស្តែងនៃបទល្មើស មិនមានវិមតិសង្ស័យឡើយដែលថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីពិរុទ្ធភាពរបស់វា ក្នុងលក្ខណៈ “អាចយល់ដឹងជាទូទៅបាន”[1429]។

## *មូលដ្ឋានទី ៨៧ ដល់៩៣៖ អំពីមនុស្សឃាតដោយចេតនាប្រយោល នៅការដ្ឋានត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង[1430] និងនៅក្នុងមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល*

[1426] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៣៣-៦៣៥។

[1427] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩៦។

[1428] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៤៨-៦៤៩, ៦៥១។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩៧-៣៩៨។

[1429] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦២ ជើងទំព័រ ១៩៨៣។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩៦-៩៧។

[1430] <u>មូលដ្ឋានទី ៨៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពីការដ្ឋានការងារត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង* កថាខណ្ឌ ៦៣៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក ទំព័រ ៣៥ (ភាសាអង់គ្លេស) ទំព័រ ៣២ (ភាសាបារាំង) ទំព័រ ៤៨-៤៩ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៨៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពីការដ្ឋានការងារត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង* កថាខណ្ឌ ៦៣៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៥ (ភាសាអង់គ្លេស) ទំព័រ ៣២ (ភាសាបារាំង) ទំព័រ ៤៩-៥០ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៨៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពីការដ្ឋានការងារត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង* កថាខណ្ឌ ៦៣៧, ៧៦៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៥ (ភាសាអង់គ្លេស) ទំព័រ ៣២ (ភាសាបារាំង) ទំព័រ ៤៩ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៩០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពីការដ្ឋានការងារត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង* កថាខណ្ឌ ៦៣៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៥-៣៦ (ភាសាអង់គ្លេស) ទំព័រ ៣២ (ភាសាបារាំង) ទំព័រ ៥០ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៩១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *នៅក្នុងមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល* កថាខណ្ឌ ៦៣៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក ទំព័រ ៣៦ (ភាសាអង់គ្លេស) ទំព័រ ៥០ (ភាសាខ្មែរ) ទំព័រ ៣២-៣៣ (ភាសាបារាំង)។ <u>មូលដ្ឋានទី ៩២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *នៅក្នុងមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល* កថាខណ្ឌ ៦៣៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៦ (ភាសាអង់គ្លេស) ទំព័រ ៣៣ (ភាសាបារាំង) ទំព័រ ៥០-៥១ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី</u>

376. មូលដ្ឋាននីមួយៗនេះ ត្រូវតែច្រានចោលដោយសារតែពួកគេ ផ្អែកលើការអះអាងដោយខុសឆ្គងថា ធាតុផ្សំអត្តនោម័តិនៃ អំពើមនុស្សឃាតនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនរួមបញ្ចូលនូវចេតនាប្រយោលឡើយ នៅក្នុងឆ្នាំ១៩៧៥។ ដូចដែលបានបង្ហាញពីខាងលើ[1431] ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា និយមន័យនៃធាតុផ្សំអត្តនោម័តិ នៃអំពើមនុស្សឃាត ពង្រីកទៅដល់ចេតនាប្រយោល នៅក្នុងឆ្នាំ១៩៧៥នោះ គឺផ្អែកលើប្រភពច្បាប់ត្រឹមត្រូវ និងវិធានបកស្រាយដែលនៅជាធរមាន។ ការអះអាងដោយគ្មានការគាំទ្រ របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា គាត់អាចត្រូវបានផ្តន្ទាទោសសម្រាប់ការសម្លាប់ តែករណីដែលគាត់មានចេតនាផ្ទាល់ ក្នុងការសម្លាប់[1432] ដោយមិនគិតបន្ថែមទៀតទៅដល់ មាត្រា២៩ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅត្រង់ការជួយ និងជំរុញ។ ហេតុដូច្នេះម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញនូវកំហុសអង្គច្បាប់ណាមួយ ក្នុងការផ្តន្ទាទោសរូបគាត់ ពីបទជួយសម្របសម្រួលដល់អំពើមនុស្សឃាត ដោយមានចេតនាប្រយោល[1433]។

***មូលដ្ឋានទី ៩៤៖ កំហុសឆ្គងពាក់ព័ន្ធ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ[1434]***

377. **មូលដ្ឋានទី ៩៤ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គច្បាប់ នៅពេលលើកឡើងថា ចាំបាច់ត្រូវមានធាតុផ្សំអត្តនោម័តិ ដើម្បីកំណត់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ។**

378. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការបញ្ជាក់ដែលត្រឹមត្រូវ អំពីធាតុផ្សំអត្តនោម័តិ សម្រាប់ការធ្វើទុក្ខបុកម្នេញ គឺរួមមាន "គោលបំណងដក" បុគ្គលទាំងនោះចេញពីសង្គម ឬពីភាពជាមនុស្សជាតិ[1435] បានមើលរំលងបញ្ហាថា អង្គជំនុំជម្រះសាលាដំបូង[1436] បានគោរពតាម

---

<u>៩៣</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *នៅក្នុងមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល* កថាខណ្ឌ ៦៤០។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៦ (ភាសាអង់គ្លេស) ទំព័រ ៣៣ (ភាសាបារាំង) ទំព័រ ៥១ (ភាសាខ្មែរ)។

[1431] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៦។

[1432] *ផ្ទុយពី* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៣៧-៦៤០។

[1433] *សូមមើលឧទាហរណ៍* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣-៤៣៦៦, ៤៣៨៣។

[1434] <u>មូលដ្ឋានទី ៩៤</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ* កថាខណ្ឌ ៦៤១-៦៥៥។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៧ (ភាសាអង់គ្លេស) ទំព័រ ៣៣ (ភាសាបារាំង) ទំព័រ ៥១-៥២ (ភាសាខ្មែរ)។

[1435] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៤២។

យុត្តិសាស្ត្រដែលបានកំណត់ របស់អង្គជំនុំជម្រះតុលាការកំពូល[1437]។ អង្គជំនុំជម្រះតុលាការកំពូលបានអះអាងបញ្ជាក់ថា ទោះបីជាផែនការធ្វើទុក្ខបុកម្នេញ អាចរួមមានការដកចេញនូវក្រុមមនុស្សពីក្នុងសង្គមជាតិក្តី តែគោលបំណងបែបនេះ មិនចាំបាច់ត្រូវកំណត់ "សម្រាប់ជនជាប់ចោទម្នាក់ៗ និងគ្រប់ជនជាប់ចោទទាំងអស់ ទាក់ទិននឹងអំពើធ្វើទុក្ខបុកម្នេញជាក់លាក់ ដែលខ្លួនទទួលរងការផ្តន្ទាទោស"[1438]។ ដោយពឹងផ្អែកទៅលើបណ្តាយុត្តិសាស្ត្រជាច្រើន នៅក្រោយសង្គ្រាមលោកលើកទីពីរ[1439] មានការពន្យល់ថា មិនមានលក្ខខណ្ឌតម្រូវផ្លូវច្បាប់ថា ចារីត្រូវមាន "ចេតនាធ្វើទុក្ខបុកម្នេញ" លើនិងហួសពីចេតនារើសអើង[1440]។

379. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការសម្រេចរបស់អង្គជំនុំជម្រះនានានៃ អ.វ.ត.ក ត្រូវបានធ្វើឱ្យខូចខាតដោយសារតែ លក្ខខណ្ឌតម្រូវ "ការឯកភាពដំបូង" សម្រាប់ធាតុផ្សំបន្ថែមនេះ នៅតុលាការចំពោះកិច្ចនានា[1441]នោះ គឺមិនទទប់ទប់ជាមួយការវិភាគនេះទេ។ ក្នុងចំណោមសាលក្រមទាំងបីនៅតុលាការ ICTY និងតុលាការ ICTR ដែលម្ចាស់បណ្តឹងសាទុក្ខពឹងផ្អែកលើនោះ[1442] មានតែសាលក្រមមួយប៉ុណ្ណោះ ដែលគាំទ្រគោលជំហររបស់គាត់ ហើយសាលក្រមនេះដូចដែលម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់[1443] ត្រូវបានច្រានចោលនៅដំណាក់កាលបណ្តឹងសាទុក្ខ[1444]។ សាលក្រមពីរផ្សេងទៀត មិនមានបញ្ចូល "គោលបំណងដក" ជាធាតុផ្សំសំខាន់នៃ

---

[1436] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៣, ៧១៥។ ការសម្រេចនេះគឺដូចគ្នា នឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០១ និង ០០២/០១៖ សូមមើល សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្តី ឌុច* កថាខណ្ឌ ៣៧៩។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤២៧, ៤២៩។

[1437] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៣៦-២៤០ ជើងទំព័រ ៥១៤។

[1438] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៣៩ ជើងទំព័រ ៥១៤។

[1439] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២២៦, ២៣៦-២៤០ *confirming* សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្តី ឌុច* កថាខណ្ឌ ៣៧៩ បន្ទាប់ពីការត្រួតពិនិត្យផងដែរទៅលើ សាលក្រមរបស់តុលាការយោធាអន្តរជាតិ, សាលក្រមរឿងក្តីក្រសួងយុត្តិធម៌, សាលក្រមរឿងក្តីក្រសួង, សាលក្រមរឿងក្តី *Enigster,* សាលក្រមរឿងក្តី *J* និង *R*, សាលក្រមរឿងក្តី *Greiser*, សាលក្រមរឿងក្តី *Eichmann* Case និង *Barbie*។

[1440] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច ជើងទំព័រ ៥១៤។

[1441] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៤៥-៦៥២។

[1442] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៤៥-៦៤៩ *ដកស្រង់ សាលក្រមរឿងក្តី* Kupreškić កថាខណ្ឌ ៦៣៤។ *សាលក្រមរឿងក្តី* Kordić & Čerkez កថាខណ្ឌ ២១៤, ២១៩, ២២០។ *សាលក្រមរឿងក្តី* Ruggiu កថាខណ្ឌ ២២។

[1443] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៤៨។

[1444] *សាលដីការឿងក្តី* Kordić & Čerkez កថាខណ្ឌ ១១១។ សូមមើលផងដែរ *សាលដីការឿងក្តី* Blaškić កថាខណ្ឌ ១៦៥។

ឧក្រិដ្ឋកម្មឡើយ[1445] ដោយគ្រាន់តែកត់សម្គាល់ថា *លើអង្គហេតុនៃរឿងក្តីជាក់លាក់* ការដកហូតនូវសិទ្ធិជាសារវន្ត "អាចនិយាយបានថា" មានគោលបំណងនោះ[1446]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ យុត្តិសាស្ត្រតុលាការមិនអចិន្ត្រៃយ៍ តាមពិតទៅបានអនុវត្ត "សេចក្តីសម្រេចគ្មានការជំទាស់" នៃធាតុផ្សំការធ្វើទុក្ខបុកម្នេញ រួមទាំង "ចេតនារើសអើង" ប៉ុន្តែមិនមាន "គោលបំណងដក"[1447] ឡើយ។

380. ការយល់ឃើញរបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ[1448] គឺមិនត្រឹមត្រូវនិងមិនពេញលេញ។ បើវិភាគឱ្យបានត្រឹមត្រូវ គឺបង្ហាញដោយស្របគ្នាថា ចេតនាធ្វើទុក្ខបុកម្នេញ "គ្រាន់តែ" ជាចេតនារើសអើង "ប្រឆាំងទៅលើ" ក្រុមជាក់លាក់មួយឬច្រើនប៉ុណ្ណោះ[1449]។ ផ្ទុយទៅវិញ អំពើដែលបានប្រព្រឹត្តឡើង ដោយមានចេតនាលុបបំបាត់ក្រុមគោលដៅមួយ គឺជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[1450]។ ហេតុដូច្នេះ បើទោះបីជាការធ្វើទុក្ខបុកម្នេញ

---

[1445] *សាលក្រមរឿងក្តី* *Ruggiu* កថាខណ្ឌ ២១។ *សាលក្រមរឿងក្តី* *Kupreškić* កថាខណ្ឌ ៦៣៣។

[1446] *សាលក្រមរឿងក្តី* *Ruggiu* កថាខណ្ឌ ២២។ *សាលក្រមរឿងក្តី* *Kupreškić* កថាខណ្ឌ ៦៣៤។ សូមមើល ផងដែរ *សាលក្រមរឿងក្តី* *Kupreškić* កថាខណ្ឌ ៦៣៦, ញែកគ្នារវាង "ត្រឹម" ចេតនារើសអើង ដែលតម្រូវសម្រាប់ង្ហាញ ធាតុផ្សំអត្តនោម័តិ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើធ្វើទុក្ខបុកម្នេញ និងចេតនាបំផ្លាញក្រុម ដែលជាលក្ខខណ្ឌតម្រូវ ដើម្បីបង្ហាញឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយកត់សម្គាល់ថា ចេតនាបង្កការធ្វើទុក្ខបុកម្នេញ អាចកើនឡើងដល់កម្រិត ដែលអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

[1447] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៣៩ ជើងទំព័រ ៥១៤ (*ដកស្រង់* និយមន័យដែលស៊ីចង្វាក់គ្នានៃ ធាតុផ្សំអត្តនោម័តិ ដែលបង្ហាញនៅក្នុងរឿងក្តីដទៃទៀត យ៉ាងហោចណាស់១១រឿងក្តី នៅចំពោះមុខតុលាការមិនអចិន្ត្រៃយ៍ ដែលមិនរួមបញ្ចូល "គោលដៅដកចេញ" ដោយគិតពិចារណាទៅលើរឿងក្តីនីមួយៗ ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ នៅក្នុងបណ្តឹងសាទុក្ខបច្ចុប្បន្ន)។ សូមមើល បន្ថែមសាលដីការឿងក្តី *Popović* កថាខណ្ឌ ៧៣៨។ *សាលដីការឿងក្តី* *Šešelj* កថាខណ្ឌ ១៥៩។

[1448] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៥៣-៦៥៤។

[1449] សាលក្រមរឿងក្តី *RuSHA* ទំព័រ ១៥២ (ពិចារណា "ការដាក់ទណ្ឌកម្មចំពោះ ការរួមភេទជាមួយជនជាតិអាល្លឺម៉ង់, ឆក់ប្លន់ទ្រព្យសម្បត្តិសាធារណៈ និងឯកជន និងការជម្លៀសជនជាតិបរទេស" ហើយសម្រេចថា "ការធ្វើទុក្ខបុកម្នេញទាំងអស់នេះ ដោយមូលហេតុជាតិសាសន៍ គឺធ្វើឡើងជាពិសេសទៅលើជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វ" (គូសបញ្ជាក់បន្ថែម))។ សូមមើលផងដែរសាលក្រម តុលាការយោធាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ទំព័រ ៦៦ (ការធ្វើទុក្ខបុកម្នេញ ត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្ម "សំដៅទៅលើជនជាតិជ្វីហ្វ […] និងប្រឆាំងបុគ្គលណាដែលមានជំនឿនយោបាយ ឬជំនឿផ្លូវចិត្តដែលហាក់ដូចជាប្រឆាំងជាមួយ គោលដៅរបស់ពួកណាហ្ស៊ី")។ សាលក្រមរឿងក្តី ចៅក្រម ទំព័រ ១០៦៣-១០៦៤។

[1450] សូមមើលឧទាហរណ៍ រឿងក្តី *Eichmann* កថាខណ្ឌ ១៦។ សូមមើលផងដែរ សាលក្រម តុលាការយោធាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ទំព័រ ៤៣-៤៤ (អំពើប្រល័យពូជសាសន៍ ត្រូវបានបង្ហាញថាមានចេតនាជាក់លាក់ "ដើម្បីកម្ទេចពូជសាសន៍ វណ្ណៈប្រជាជន និងក្រុមជាតិសាសន៍ ជាតិពន្ធុ ឬសាសនាជាពិសេស")។

*អាច* មាន "គោលបំណងដក"គឺ "ទម្រង់ទាបជាងនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ [...] បង្កើតបានជាផ្នែករួមនៅក្នុង គោលនយោបាយទូទៅរបស់ Reich"[1451]។

381. នៅក្នុងសាលក្រម ក្រសួងយុត្តិធម៌ តុលាការយោធាសហរដ្ឋអាមេរិក បានកត់សម្គាល់ថា ទោះបីជាអំពើរើសអើងរបស់ Rothenberger រួមទាំងការបដិសេធចំពោះជនជាតិជ្វីហ្វ នូវសិទ្ធិទទួលបានការជំនុំជម្រះ ក្នុងបណ្តឹងរដ្ឋប្បវេណី មិនធ្ងន់ធ្ងរដូចអំពើដែលដកជនជាតិជ្វីហ្វចេញ រាប់លាននាក់ក្តី តែអំពើទាំងនោះ "ទោះបែបណាក្តី គឺជាផ្នែកនៃផែនការ ដែលរៀបចំឡើងដោយរដ្ឋាភិបាល សម្រាប់ការធ្វើទុក្ខបុកម្នេញ ទៅលើជនជាតិជ្វីហ្វ [...] ដោយការដកហូតពីពួកគេ នូវមធ្យោបាយសម្រាប់ការរស់នៅ និងសិទ្ធិស្មើគ្នាចំពោះមុខតុលាការ"[1452]។ នៅក្នុងរឿងក្តី *RuSHA* តុលាការបានកត់សម្គាល់អំពី ឯកសារដែលកំណត់ពីបំណងរបស់ Hübner ក្នុងការរក្សាទុកក្រុមដែលត្រូវធ្វើទុក្ខបុកម្នេញ នៅក្នុងតំបន់ឧបសម្ព័ន្ធ និង "ផ្តល់ទីកន្លែងស្នាក់នៅ" សម្រាប់ពួកគេ[1453]។ តុលាការកំពូលជាតិប៉ូឡូញ បានពិចារណាថា "វិធីសាស្ត្រសំខាន់បំផុត" មួយ ដែល Greiser អនុវត្តការធ្វើទុក្ខបុកម្នេញ គឺការរៀបចំការសំដែងតាមដងវិថី ដែលជនជាតិជ្វីហ្វត្រូវបានបង្ខំឱ្យរាំ សំដែងកាយវប្បកម្ម វាយគ្នាទៅវិញទៅមក ឬការកាត់ពុកចង្ការពួកគេចោល[1454]។

---

[1451] សាលក្រមរឿងក្តី ចៅក្រម ពិភាក្សាលើការអនុម័ត និងអនុវត្តច្បាប់ស្តីពីការរើសអើង ។ សូមមើលទំព័រ ២៣, ២៥ ។ នៅត្រង់នោះអង្គជំនុំជម្រះបានបញ្ជាក់ថា "ជនជាប់ចោទខ្លះបានចូលរួម ក្នុងការអនុម័តច្បាប់ និងក្រឹត្យ ដែលមានគោលបំណងសម្លាប់រង្គាល ជនជាតិប៉ូឡូញ និងជ្វីហ្វ នៅក្នុងប្រទេសអាល្លឺម៉ង់ និងនៅទូទាំងទ្វីបអឺរ៉ុប។ ប៉ុន្តែទម្រង់នៃការរើសអើងពូជសាសន៍ដែលស្រាលជាង ត្រូវបានអនុវត្តជាសាកល ដោយអាជ្ញាធររដ្ឋាភិបាល ហើយបង្កើតបានជាផ្នែករួមមួយ នៅក្នុងគោលនយោបាយទូទៅរបស់ *Reich*" (គូសបញ្ជាក់បន្ថែម)។ ការនេះរួមបញ្ចូលផងដែរទាំងការហាមឃាត់ ការរៀបការចម្រុះ និង/ឬ ការរួមភេទរវាងជនជាតិជ្វីហ្វ និងជនជាតិអាល្លឺម៉ង់។ សូមមើល ទំព័រ ១០៦៣។

[1452] សាលក្រមរឿងក្តី ចៅក្រម ទំព័រ ១១១៤ ដោយ "ដោយគ្មានមន្ទិលសង្ស័យ បានប្រើប្រាស់ឥទ្ធិពលរបស់គាត់ ដើម្បីឈានទៅសម្រេចបាន អំពើរើសអើង ដែលផ្តល់ប្រយោជន៍ដល់មន្ត្រីបក្សជាន់ខ្ពស់ ហើយផ្តល់គុណវិបត្តិដល់ជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វ" Rothenberger ត្រូវបានសម្រេចថា បានជួយនិងជម្រុញ ក្នុងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ សូមមើល ទំព័រ ១១១៨ (គូសបញ្ជាក់បន្ថែម)។

[1453] សាលក្រមរឿងក្តី *RuSHA* ទំព័រ ១៥៨("ជនជាតិប៉ូឡូញដែលត្រូវផ្លាស់ទី នៅក្នុងវគ្គនៃការតាំងទីលំនៅ ត្រូវតែចាកចេញពី Warthegau ដោយគ្មានលក្ខខណ្ឌ [...] ដោយសារតែជនជាតិប៉ូឡូញ ប្រហែលជាត្រូវការជាកម្លាំងពលកម្ម នៅពេលក្រោយ")។

[1454] សាលក្រមរឿងក្តី *Greiser* ទំព័រ ៩៣-៩៤ បន្ថែមលើនេះ Greiser ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទធ្វើទុក្ខបុកម្នេញទៅលើប្រជាជនប៉ូឡូញ តាមរយៈបទបញ្ជារដ្ឋបាល និងច្បាប់ ទំព័រ ៧៣ ដែលមិនមាន "គោលដៅដកចេញ" ទេ ប៉ុន្តែ "គឺមានចេតនាដកហូតនូវសិទ្ធិទាំងអស់ ពីជនជាតិប៉ូឡូញ លើកលែងតែសិទ្ធិដែលចាំបាច់ សម្រាប់រក្សាកម្លាំងពលកម្មជនជាតិប៉ូឡូញនៅកម្រិតរវាងកាយអប្បបរមា" សូមមើលទំព័រ ៧៨-៩៣។

382. ផ្ទុយទៅវិញ ម្ចាស់បណ្តឹងសាទុក្ខ ពឹងផ្អែកទៅលើប្រយោគ ដែលបានដកស្រង់មួយចំនួនតូច ពិសេសពីតុលាការយោធាអន្តរជាតិ ដែលមិនបានបង្ហាញថា “គោលបំណងដក” គឺជាធាតុផ្សំតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ការធ្វើទុក្ខបុកម្នេញឡើយ[1455]។ ភាគច្រើននៃរឿងក្តីនោះ ជនជាប់ចោទត្រូវបានចោទប្រកាន់ផងដែរ ពីការប្រព្រឹត្តអំពើប្រល័យពូជសាសន៍[1456] ដែលដូច្នេះហើយ ការយោងទៅរកចេតនារបស់ពួកគេ ក្នុងការដកចេញឬបំផ្លាញក្រុមពាក់ព័ន្ធ អាចត្រូវបានយល់ឃើញថា ជាការបង្ហាញពីចេតនាប្រល័យពូជសាសន៍។ នៅក្នុងរឿងក្តីពីរ ដែលជនជាប់ចោទមិនត្រូវបានចោទប្រកាន់ ពីអំពើដែលបណ្តាលឱ្យមាន ការប្រល័យពូជសាសន៍នោះ តុលាការយោធាអន្តរជាតិ មិនបានតម្រូវឱ្យមាន “គោលបំណងដក” ឡើយ ប៉ុន្តែប្រហែលគ្នានឹងយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ ក៏ដូចជារឿងក្តី *Eichmann* [1457] បានសម្រេចថា គោលបំណងអាចមានអត្ថិភាព ជាលក្ខណៈនៃភ័ស្តុតាង ដោយមិនពឹងផ្អែកការផ្តន្ទាទោស លើបទការធ្វើទុក្ខបុកម្នេញ ទៅលើវត្តមាននៃគោលបំណងនោះឡើយ[1458]។

---

[1455] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៥៤ *ដកស្រង់* សេចក្តីសម្រេចដែលពាក់ព័ន្ធ ជាមួយជនជាប់ចោទរបស់តុលាការយោធានអន្តរជាតិ ចំនួនប្រាំបួនរូប និងរឿងក្តី *Eichmann*។

[1456] នៅឯ Nuremberg, Göring, von Ribbentrop, Frank, Frick, Funk, Seyss-Inquart, និង Bormann ត្រូវបានចោទប្រកាន់តាម “បទចោទទីបី ឧក្រិដ្ឋកម្មសង្គ្រាម” ដោយសារតែបាន “អនុវត្តអំពើប្រល័យពូជសាសន៍ ជាប្រព័ន្ធនិងដោយចេតនាតាមរយៈការសម្លាប់រង្គាល ក្រុមជាតិពន្ធុ និងជនជាតិ ទៅលើប្រជាជនស៊ីវិល នៅតាមតំបន់ដែលគ្រប់គ្រងមួយចំនួន ដើម្បីកម្ទេចពូជសាសន៍ និងវណ្ណៈប្រជាជនជាក់លាក់ និងក្រុមជាតិសាសន៍ ជាតិពន្ធុ និងសាសនា ជាពិសេសជនជាតិជ្វីហ្វ ប៉ូឡូញ និង Gypsies ព្រមទាំងជនជាតិដទៃទៀត” សូមមើល សាលក្រម តុលាការយោធាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ទំព័រ ៤៣-៤៤ ព្រមទាំងការសម្រេចអំពីពិរុទ្ធភាព តាមបទចោទនេះ នៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ ទំព័រ ២៨២ (Göring), ២៨៨ (von Ribbentrop), ២៩៨ (Frank), ៣០១ (Frick), ៣០៧ (Funk), ៣៣០ (Seyss-Inquart), ៣៤១ (Bormann) ។ តុលាការយោធាអន្តរជាតិបានចេញ សំអាងហេតុរបស់ខ្លួន ពាក់ព័ន្ធពិរុទ្ធភាពជាបុគ្គល តាមបទចោទទី៣ (ឧក្រិដ្ឋកម្មសង្គ្រាម រួមទាំង “អំពើមនុស្សឃាតតាមរយៈ អំពើប្រល័យពូជសាសន៍” និង បទចោទទី៤ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំងការធ្វើទុក្ខបុកម្នេញ) នៅក្នុងផ្នែកតែមួយ។ ហេតុដូច្នេះការបង្ហាញនូវចេតនា សម្រាប់អំពើប្រល័យពូជសាសន៍ លេចឡើងជាញឹកញាប់ជាមួយ ការពិចារណារបស់អង្គជំនុំជម្រះ ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ។

[1457] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៥៤, *ដកស្រង់* រឿងក្តី *Eichmann* កថាខណ្ឌ ៥៦, ២០១។ ក្នុងការដកស្រង់រឿងក្តី *Eichmann* កថាខណ្ឌ ៥៦ ម្ចាស់បណ្តឹងសាទុក្ខមើលរំលង គោលបំណងនៃកថាខណ្ឌ ៥៥-៥៨ គឺនិយាយអំពី “សាវតា” ដើម្បីរៀបរាប់អំពីដំណាក់កាលផ្សេងៗ នៃការធ្វើទុក្ខបុកម្នេញទៅលើជនជាតិជ្វីហ្វ “គ្រាន់តែដើម្បីបង្ហាញទីតាំងរបស់ជនជាប់ចោទ និងកម្រិតនៃការទទួលខុសត្រូវជាបុគ្គលរបស់គាត់ នៅក្នុងរបបនៃការធ្វើទុក្ខបុកម្នេញ” កថាខណ្ឌ ៥៦ មិនបាននិយាយពី Eichmann ទាល់តែសោះ ហើយក៏មិនសូវពិភាក្សាអំពីធាតុផ្សំអត្តនោម័តរបស់គាត់ដែរ។ កថាខណ្ឌ ២០១ យោងទៅរកផ្នែកស្តីពី រយៈពេលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែល Eichmann ត្រូវបានផ្តន្ទាទោសបន្ថែមទៀត ពីបទឧក្រិដ្ឋប្រឆាំងប្រជាជនជ្វីហ្វ (អំពើប្រល័យពូជសាសន៍)។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងអង្គហេតុដែលថា ក្នុងករណីតុលាការថ្នាក់ស្រុកមិន

## *មូលដ្ឋានទី ៩៥, ៩៦៖ មិនមានចេតនារើសអើង ទៅលើពុទ្ធសាសនិកជន និងព្រះសង្ឃ ឬប្រឆាំងជនជាតិចាមឡើយ*[1459]

383. មូលដ្ឋានទាំងពីរគួរត្រូវបានបដិសេធចោល ដោយសារតែមិនមានភស្តុតាងគាំទ្រ ហើយគ្រាន់តែជាការលើកឡើងវិញ នូវការអះអាងដោយខុសឆ្គង របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ធាតុផ្សំអត្តនោម័តិ នៃការធ្វើទុក្ខបុកម្នេញ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានចេតនាដកចេញ ឬគោលបំណងដក ក្រុមដែលគេប្រឆាំងចេញពីសង្គមជាតិ។ ដូចដែលបានលើកឡើងពីខាងលើ មិនមានលក្ខខណ្ឌតម្រូវគតិយុត្តិណាដែលថា ចារីត្រូវមាន "ចេតនាធ្វើទុក្ខបុកម្នេញ" ហួសនិងលើសចេតនារើសអើងឡើយ[1460]។

អាចសម្រេច "អំពីចេតនាក្នុងការសម្លាប់រង្គាល ប្រជាជនជ្វីហ្វ" ការផ្តន្ទាទោសលើ Eichmann ត្រូវកម្រិតត្រឹមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលទាំងការធ្វើទុក្ខបុកម្នេញ សូមមើល កថាខណ្ឌ ១៨៥-១៨៦ ហេតុដូច្នេះ ក្នុងការសម្រេចពីពិរុទ្ធភាពរបស់ Eichmann សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ តុលាការមិនបានយោងទៅរក "គោលដៅក្នុងការដកចេញ" ឡើយ សូមមើល *កថាខណ្ឌ* ២៤៤(៥), (៦), ចំណែកក្នុងការផ្តន្ទាទោស Eichmann ពីបទឧក្រិដ្ឋកម្មប្រឆាំងប្រជាជនជ្វីហ្វ តុលាការបានយោងជាពិសេសទៅរក "ចេតនាសម្លាប់រង្គាលប្រជាជនជ្វីហ្វ" សូមមើល កថាខណ្ឌ ២៤៤(១), (២), (៣), (៤)។

[1458] ទោះបីជា Streicher គាំទ្រការសម្លាប់រង្គាលប្រជាជនជ្វីហ្វ តែគាត់ត្រូវបានសម្រេចថា បានប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញ មិនមែនដោយសារតែ "គោលដៅក្នុងការដកចេញ" ជនជាតិជ្វីហ្វពីសង្គម ដាច់ដោយឡែកណាមួយឡើយ ប៉ុន្តែគឺដោយសារតែគាត់បន្តសរសេរនិងបោះពុម្ពផ្សាយការឃោសនា សំដៅប្រឆាំងទៅលើប្រជាជនជ្វីហ្វ ញុះញង់ឱ្យមានអំពើមនុស្សឃាត និងការសម្លាប់រង្គាល ជនជាតិជ្វីហ្វ "នៅពេលដែលជនជាតិជ្វីហ្វនៅភាគខាងកើត ត្រូវបានសម្លាប់ក្រោមស្ថានភាពអាក្រក់បំផុត" សូមមើលសាលក្រមតុលាការយោធាអន្តរជាតិ ទំព័រ ៣០៣-៣០៤ ដូចគ្នានេះ ពិរុទ្ធភាពរបស់ von Schirach គឺអាស្រ័យលើការចូលរួមរបស់គាត់ នៅក្នុងគោលនយោបាយនិរទេស ដែលសំដៅប្រឆាំងទៅលើប្រជាជនជ្វីហ្វនៅក្នុងប្រទេសអូទ្រីស សូមមើល ទំព័រ ៣១៩ សហព្រះរាជអាជ្ញាកត់សម្គាល់ថា នៅក្នុងរឿងក្តីទាំងអស់នេះការដកចេញជនជាតិជ្វីហ្វ ពីសង្គមបច្ចុប្បន្នរបស់ពួកគេ គឺមានជាប់មកជាមួយ ក្នុងអំពើជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការនិរទេស មិនមែនជាលក្ខខណ្ឌតម្រូវធាតុផ្សំអត្តនោម័តផ្សេងឡើយ។

[1459] <u>មូលដ្ឋានទី ៩៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានចេតនារើសអើងចំពោះពុទ្ធសាសនិក និងព្រះសង្ឃ* កថាខណ្ឌ ៦៥៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក ទំព័រ ៣៧ (ភាសាអង់គ្លេស) ទំព័រ ៣៤ (ភាសាបារាំង) ទំព័រ ៥២ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៩៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានចេតនារើសអើងចំពោះជនជាតិចាម* កថាខណ្ឌ ៦៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៧ (ភាសាអង់គ្លេស) ទំព័រ ៣៤ (ភាសាបារាំង) ទំព័រ ៥២ (ភាសាខ្មែរ)។

[1460] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៤។

***មូលដ្ឋានទី ៩៧៖ ការវិភាគដោយខុសឆ្គង ទៅលើនីត្យានុកូលភាពនៃអំពើអមនុស្សធម៌ដទៃទៀត***[1461]

384. **មូលដ្ឋានទី ៩៧ គួរត្រូវបានបដិសេធចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ក្នុងការសម្រេចថា អំពើអមនុស្សធម៌ដទៃទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានដឹងឮថាមានចែង និងអាចប្រមើលមើលដឹងបាន**[1462]

385. ម្ចាស់បណ្ដឹងសាទុក្ខទទួលស្គាល់ថា គាត់ដឹងច្បាស់ថាអំពើប្រភេទណាខ្លះ ដែលអាចធ្វើឱ្យគាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើអមនុស្សធម៌ដទៃទៀត ហើយគាត់បានលើកទឡ្ហីករណ៍ ដែលត្រូវបានវិភាគកន្លងមក ហើយត្រូវបានច្រានចោល ដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ រួចហើយដែរ[1463]។ អង្គជំនុំជម្រះតុលាការកំពូល បានអះអាងរួចហើយថា "មិនមានវិមតិសង្ស័យ" ដែលថាអំពើអមនុស្សធម៌ដទៃទៀត គឺជាឧក្រិដ្ឋកម្មឡើយ បើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥[1464] ជាការសម្រេចដែល ម្ចាស់បណ្ដឹងសាទុក្ខទទួលយក បើទោះបីជាគាត់មានការលើកឡើង ដែលនាំឱ្យយល់ច្រឡំក្ដី[1465]។ ទិដ្ឋភាពយ៉ាងទូលំទូលាយនៃយុត្តិសាស្ត្រ និងលិខិតុបករណ៍អន្តរជាតិ ដែលមាននៅក្នុងឆ្នាំ ១៩៧៥ រួមទាំងបណ្ដាឯកសារ ដែលអង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់នោះ[1466] បានបង្ហាញយ៉ាងច្បាស់ក្រឡែតថា អំពើ

---

[1461] <u>មូលដ្ឋានទី ៩៧</u>៖ ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ *ការវាយតម្លៃពុំត្រឹមត្រូវលើនីត្យានុកូលភាពនៃឧក្រិដ្ឋកម្មដែលជាអំពើអមនុស្សធម៌ផ្សេងៗទៀត* កថាខណ្ឌ ៦៥៩-៦៦៥។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៣៨ (ភាសាអង់គ្លេស) ទំព័រ ៣៤ (ភាសាបារាំង) ទំព័រ ៥៣ (ភាសាខ្មែរ)។

[1462] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៥៩-៦៦៥ *ដកស្រង់* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២៣។

[1463] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧២-៥៩០ នៅកថាខណ្ឌ ៥៨៦ អ.ជ.ត.ក ច្រានចោលការប្រកាន់របស់ នួន ជា ថា អ.ជ.ស.ដ មានកំហុសដោយ រំលោភទៅលើលក្ខខណ្ឌតម្រូវនៃភាពអាចដឹងថាមានច្បាប់ចែង និងភាពអាចប្រមើលដឹងថាជាបទល្មើស ដែលកើតចេញពីគោលការណ៍ នីត្យានុកូលភាព ព្រោះឧក្រិដ្ឋកម្មជាមូលដ្ឋាន មិនមានអត្ថិភាពនៅក្នុង ច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ នៅក្នុងឆ្នាំ១៩៧៥។

[1464] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៦។

[1465] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៦០ ("មេធាវីការពារក្ដីពុំជំទាស់នឹងអត្ថិភាពនៃឧក្រិដ្ឋកម្មដែលជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅសម័យកាលនៃអង្គហេតុនោះទេ") កថាខណ្ឌ ៦៦២ ("អំពើអមនុស្សធម៌ផ្សេងៗទៀត ពុំមែនជាបទឧក្រិដ្ឋ ឬជាប្រភេទឧក្រិដ្ឋកម្មជាក់លាក់នោះទេ")។

[1466] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ ជើងទំព័រ ១៥៦៣-១៥៦៤។

អមនុស្សធម៌ដទៃទៀត តំណាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអាចដឹងឮថាមានចែង និងអាចប្រមើលមើលដឹងបាន នៅក្នុងឆ្នាំ១៩៧៥[1467]។

386. បន្ថែមលើនេះ ដោយទទួលស្គាល់នូវ "ភាពតានតឹងជាក់ស្តែង" នៃប្រភេទដែលនៅសេសសល់ នៃអំពើអមនុស្សធម៌ដទៃទៀត ដែលមាននីត្យានុកូលភាព[1468] អង្គជំនុំជម្រះបានអះអាងរួចហើយថា ផ្ទុយពីសារណាររបស់ម្ចាស់បណ្តឹងសាទុក្ខ[1469] មិនមានលក្ខខណ្ឌតម្រូវថា អំពើជាមូលដ្ឋាន អាចត្រូវកំណត់ថាជាបទល្មើស តាមច្បាប់អន្តរជាតិឡើយ នៅពេលដែលប្រព្រឹត្ត[1470]។ ប៉ុន្តែ ប្រសិនបើអនុវត្តឱ្យបានត្រឹមត្រូវ សញ្ញាណនៃអំពើអមនុស្សធម៌ដទៃទៀត គឺជាក់លាក់ និងច្បាស់លាស់គ្រប់គ្រាន់ ហើយមានភាពស៊ីសង្វាក់ជាមួយ គោលការណ៍ភាពអាចដឹងថាជាបទល្មើស និងមានច្បាប់ចែង[1471] ដែលដូច្នេះម្ចាស់បណ្តឹងសាទុក្ខ អាចដឹងឮ ក្នុងលក្ខណៈ "យល់ដឹងជាទូទៅ" ថាអំពើរបស់គាត់មានលក្ខណៈឧក្រិដ្ឋ[1472]។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា៖

> គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង ត្រូវបានគោរព ប្រសិនបើអំពើប្រព្រឹត្តជាក់លាក់ ដែលត្រូវបានរកឃើញថាជា អំពើអមនុស្សធម៌ផ្សេងៗទៀត រំលោភបំពានលើសិទ្ធិជាសារវ័ន្ត របស់ជនជាប់ចោទ និងមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា ទៅនឹងអំពើជាក់លាក់ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1473]

---

[1467] សូមមើល ធម្មនុញ្ញទីក្រុងឡុងដ៍ មាត្រា ៦(គ) ធម្មនុញ្ញទីក្រុងតូក្យូ មាត្រា ៥(គ)។ ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ មាត្រា II(១)(គ) គោលការណ៍ច្បាប់អន្តរជាតិដែលបានទទួលស្គាល់នៅក្នុងធម្មនុញ្ញតុលាការ Nürnberg និងសាលក្រមរបស់តុលាការនេះ ឆ្នាំ១៩៥០ គោលការណ៍ VI(គ), សាលក្រមរឿងក្តី ក្រសួង ទំព័រ ៣៤៤, ៤៦៧-៤៧៥, ៨៦៥, ៩១១, សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៤-១៨០, ១៩៨, សាលក្រមរឿងក្តី ចៅក្រម ទំព័រ ២៣, ៩៧២, ១២០០, សាលក្រម *High Command* ទំព័រ ៤៦៥, ៥៨០, រឿងក្តី *Gerbsch* ទំព័រ ១៣៤, រឿងក្តី *Eichmann* កថាខណ្ឌ ២០១, ២០៤។ សូមមើលផងដែរ ច្បាប់ (ដាក់ទណ្ឌកម្ម) ពួកណាហ្ស៊ី និងអ្នកសមគំនិតជាមួយណាហ្ស៊ី ១៩៥០ មាត្រា ១(ខ)។

[1468] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៦-៥៧៨។

[1469] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៦៥។

[1470] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤។

[1471] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៨។

[1472] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦២ ជើងទំព័រ ១៩៨៣។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ៩៦-៩៧។

[1473] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៦។

387. ជាផលវិបាក អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់ថា មិនមានភាពចាំបាច់ក្នុងការចែង "ធាតុផ្សំជាក់លាក់" សម្រាប់អំពើទាំងនោះឡើយ[1474]។

388. បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខបានឯកភាពថា គាត់បានដឹងថា អំពើអមនុស្សធម៌ផ្សេងៗទៀត គឺជា "ការពង្រីក" ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមាន ដែលខ្លឹមសារវាគឺត្រូវស្វែងរកដោយប្រើប្រាស់ វិធាននៃការបកស្រាយលើប្រភេទដូចគ្នា[1475]។ តាមពិតទៅ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា វិធាននៃការបកស្រាយលើប្រភេទដូចគ្នា គឺជា "ការធានាដ៏សំខាន់" ទៅលើគោលការណ៍នីត្យានុកូលភាព[1476] ហើយតុលាការយោធាអន្តរជាតិនៅ Nuremberg បានប្រើប្រាស់ទ្រឹស្តីដើម្បីបញ្ជាក់បំភ្លឺទម្រង់នៃ អំពើអមនុស្សធម៌ផ្សេងៗទៀត[1477]។ និយាយម្យ៉ាងវិញទៀត ម្ចាស់បណ្តឹងសាទុក្ខបានដឹងថា គាត់អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ[1478] ចំពោះអំពើ "អមនុស្សធម៌" និង "មានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា" ទៅនឹងអំពើជាក់លាក់ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានបញ្ជាក់បំភ្លឺបន្ថែមដោយយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ[1479] ហើយអំពើដែលមាននៅក្នុងនោះ ដែលបានរំលោភបំពានទៅលើ សិទ្ធិមនុស្សជាមូលដ្ឋាន និងរំលោភបំពានទៅលើច្បាប់ជាធរមាន និងទំនៀម

[1474] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៩។

[1475] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៦១-៦៦២។

[1476] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៨។

[1477] សូមមើលឧទាហរណ៍ សាលក្រមរឿងក្តី *Flick* ទំព័រ ១២១៥, សាលក្រមរឿងក្តី *Farben* ទំព័រ ១១២៩-១១៣០។

[1478] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៦០, ៦៦៣-៦៦៥។

[1479] សូមមើលឧទាហរណ៍សាលក្រមរឿងក្តី ក្រសួង ទំព័រ ៣៤៤, ៩៩១ (ចាត់ទុកថាការឆក់ប្លន់ទ្រព្យសម្បត្តិ គឺជាអំពើអមនុស្សធម៌ ក្នុងករណីដែលអំពើនេះត្រូវបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃអំពើភេរវកម្មទ្រង់ទ្រាយធំ ប្រឆាំងប្រជាជនស៊ីវិល ឬមានជាប់ទាក់ទងជាមួយ អំពើហិង្សាដទៃទៀត ដែលចែងកំណត់ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ), រឿងក្តី *Gerbsch* ទំព័រ ១៣៤ (អំពើធ្វើបាបត្រូវបានគ្របដណ្តប់ដោយពាក្យ "អំពើអមនុស្សធម៌ផ្សេងទៀត") រឿងក្តី *Zuehlke* ទំព័រ ១៤៥ (ការឃុំខ្លួនដោយខុសច្បាប់ "ស្ថិតក្រោមសញ្ញាណនៃ "អំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តទៅលើ ប្រជាជនស៊ីវិល") រឿងក្តី *Eichmann* កថាខណ្ឌ ២០១ ("បណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរ ចំពោះជនជាតិជ្វីហ្វ ទាំងផ្នែករាងកាយ និងស្មារតី ក៏ជាអំពើអមនុស្សធម៌ ដែលប្រព្រឹត្តឡើងប្រឆាំងប្រជាជនស៊ីវិល") ទំព័រ ២០៤ ("ការឆក់ប្លន់ទ្រព្យសម្បត្តិ អាចត្រូវបានចាត់ទុកថាជាអំពើអមនុស្សធម៌នៅក្នុងអត្ថន័យ នៃនិយមន័យ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" តែក្នុងករណីដែលអំពើនេះ ត្រូវបានប្រព្រឹត្តឡើងក្រោមសម្ពាធ នៃអំពើភេរវកម្មទ្រង់ទ្រាយធំ ទៅលើប្រជាជនស៊ីវិល ឬប្រសិនបើមានទំនាក់ទំនង ជាមួយអំពើហិង្សាដទៃផ្សេងទៀត ដែលត្រូវបានកំណត់និយមន័យដោយច្បាប់ថាជា (អំពើអមនុស្សធម៌ផ្សេងទៀត) ឬជាលទ្ធផលនៃអំពើអមនុស្សធម៌ផ្សេងទៀតណាមួយ"), រឿងក្តី *Tarnek* ទំព័រ ៥៤០ ("តុលាការបានបកស្រាយពាក្យ "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលមាននៅក្នុងនិយមន័យនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថាអនុវត្តបានតែចំពោះអំពើអមនុស្សធម៌ផ្សេងទៀតបែបនេះ ដែលមានលក្ខណៈដូចគ្នា និងមានស្ថានទម្ងន់ដូចគ្នា ជាមួយអំពើដែលមានចែងច្បាស់ នៅក្នុងនិយមន័យនោះ")។

ទម្លាប់សង្គ្រាម ដូចជាបទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៨៩៩, បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៩០៧ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩២៩ និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[1480]។ អង្គជំនុំជម្រះដទៃទៀតរបស់ អ.វ.ត.ក[1481] និងតុលាការមិនអចិន្ត្រៃយ៍នានា[1482] បានអះអាងស្របគ្នានូវនីត្យានុកូលភាពនៃ អំពើអមនុស្សធម៌ផ្សេងៗទៀត បន្ទាប់ពីមានការវិភាគមួយ ទៅលើការអនុវត្តរបស់រដ្ឋ ក្រោយសង្គ្រាមលោកលើកទីពីរ អំពីភាពអាចដឹងថាជាបទល្មើស និងមានច្បាប់ចែង។

***មូលដ្ឋានទី ៩៨៖ ការរំពុកបែបបំប្រួមនៃលក្ខខណ្ឌតម្រូវស្តីពីអនីត្យានុកូលភាពផ្លូវការ***[1483]

389. **មូលដ្ឋានទី ៩៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយ "បំប្រួម" ធាតុផ្សំ "អនីត្យានុកូលភាពផ្លូវការ" របស់អង្គជំនុំជម្រះតុលាការកំពូល សម្រាប់ការកំណត់អត្តសញ្ញាណ អំពើអមនុស្សធម៌ផ្សេងៗទៀត**[1484]។

---

[1480] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤។ ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៥។ សាលក្រមរឿងក្តីចៅក្រម ទំព័រ ៣-៤, ១៩, ២៣, ៩៨៥ (ជនជាប់ចោទត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទ "មនុស្សឃាត, ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ អំពើសាហាវយង់ឃ្នង អំពើឃោរឃៅ និង អំពើអមនុស្សធម៌ផ្សេងទៀត ទៅលើមនុស្សរាប់ពាន់នាក់" ជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ក្នុងរឿងក្តីនោះ នៅពេលពិភាក្សាពីបញ្ហា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាការរំលោភបំពានទៅលើច្បាប់អន្តរជាតិ ចៅក្រមបានបញ្ជាក់ថា "បទចោទជាសង្ខេបគឺថា ការចូលរួមដោយចេតនា នៅក្នុងប្រព័ន្ធនៃភាពសាហាវយង់ឃ្នង និងអយុត្តិធម៌ ដែលរៀបចំឡើងដោយរដ្ឋាភិបាល នៅទូទាំងប្រទេស *ដោយរំលោភទៅលើច្បាប់សង្គ្រាម និងមនុស្សជាតិ* (គូសបញ្ជាក់បន្ថែម))។ សាលក្រមរឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ, TWC Vol I ទំព័រ ១៦-១៧, TWC Vol II ទំព័រ ១៧៤-១៨០, ១៩៨ (ឧក្រិដ្ឋកម្មសង្គ្រាម នៃការរៀបចំ "ការពិសោធន៍វេជ្ជសាស្ត្រ" ដោយគ្មានការយល់ព្រមក៏ត្រូវបានចោទប្រកាន់ផងដែរ និងត្រូវបានសម្រេចថាបង្កើតបានជា អំពើអមនុស្សធម៌ផ្សេងទៀត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។ សាលក្រមរឿងក្តីក្រសួង ទំព័រ ៤៦៧-៤៦៨, ៥៥២។

[1481] សូមមើលឧទាហរណ៍ <u>អង្គបុរេជំនុំជម្រះ</u> ៖ ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧១, ៣៨៥-៣៨៨, ៣៩៥-៣៩០, ៣៩៨។ ឯកសារ **D427/2/15** និងឯកសារ **D427/3/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣០-១៣១, ១៥៦-១៥៧, ១៦៥។ <u>អង្គជំនុំជម្រះសាលាដំបូង</u>៖ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្តី ឌុច* កថាខណ្ឌ ៣៦៧។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៣៥។ <u>ក.ស.ច.ស</u>៖ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤។ សំណុំរឿង ០០៣-ឯកសារ **D267** ដីកាដំណោះស្រាយ កថាខណ្ឌ ៥៩-៦១។

[1482] សូមមើលឧទាហរណ៍ *សាលដីការឿងក្តី Stakić* កថាខណ្ឌ ៣១៥។ *សាលក្រមរឿងក្តី Blagojević & Jokić* កថាខណ្ឌ ៦២៤-៦២៦។ *សាលក្រមរឿងក្តី Kupreškić* កថាខណ្ឌ ៥៦២-៥៦៦។

[1483] <u>មូលដ្ឋានទី ៩៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ការរំពុកបែបបំប្រួញនៃល័ក្ខខ័ណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការ កថាខណ្ឌ ៦៦៦-៦៧១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៨ (ភាសាអង់គ្លេស) ទំព័រ ៣៤ (ភាសាបារាំង) ទំព័រ ៥៣ (ភាសាខ្មែរ)។

390. មូលដ្ឋាននេះចាំបាច់ត្រូវច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានពន្យល់ថាតើការដែលអង្គជំនុំជម្រះសាលាដំបូង អនុវត្តនិយមន័យ "បំប្រួម"[1485] នៃ "អនីត្យានុកូលភាពផ្លូវការ" នៅពេលសន្និដ្ឋាន ដោយ*ដកស្រង់ដោយផ្ទាល់* ពីសាលដីការបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០២/០១ ថា "ការវាយតម្លៃថា តើការប្រព្រឹត្តនោះ រំលោភបំពានទៅលើ "សិទ្ធិជាសារវ័ន្តរបស់មនុស្សជាតិ ដូចបានបញ្ជាក់នៅក្នុងលិខិតុបករណ៍ ច្បាប់អន្តរជាតិនោះ" គឺជាវិធីមួយនៃការបង្ហាញ "លក្ខខណ្ឌតម្រូវនៃ អនីត្យានុកូលភាពផ្លូវការជាអន្តរជាតិ""[1486]។

391. ដោយពឹងផ្អែកទៅលើការបកស្រាយលើពាក្យពេចន៍ជ្រុលទៅលើលក្ខណៈខុសៗគ្នា នៃការពិភាក្សារបស់អង្គជំនុំជម្រះតុលាការកំពូល[1487] ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យកំណត់អត្តសញ្ញាណ "ការហាមឃាត់" លើអំពើពាក់ព័ន្ធនានា នៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្ស បន្ថែមពីលើ "សិទ្ធិ" ដែលអំពើនោះបានរំលោភបំពាន[1488]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានលើកឡើង អំពីភាពខុសគ្នាផ្នែកគតិយុត្តិ រវាងការរំលោភបំពានសិទ្ធិ និងការរំលោភបំពានលើការហាមឃាត់ ឬពន្យល់ថាហេតុអ្វីទើបតម្រូវឱ្យមានទាំងពីរ។ ដូចដែលបានបង្ហាញ ដោយឧទាហរណ៍ផ្ទាល់របស់ អង្គជំនុំជម្រះតុលាការកំពូល លិខិតុបករណ៍សិទ្ធិមនុស្សប្រើប្រាស់វិធីសាស្ត្រព្រាងចំនួនពីរ ដែលអាចប្រើប្រាស់ជំនួសគ្នាបាន[1489] ហើយវិធីសាស្ត្រទាំងពីរបានកំណត់និយមន័យ "គោលការណ៍សិទ្ធិមនុស្សទូលាយ" ដែលអំពើអមនុស្សធម៌ផ្សេងៗទៀត

---

[1484] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៦៦-៦៧១។ សូមមើលបន្ថែម ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩៨-១១១៦, ១២៨១-១២៨៧។

[1485] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៥៨, ៦៧១, ១១០៣។

[1486] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២៦ *ដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤។ សូមមើលបន្ថែម កថាខណ្ឌ ៥៨៦ ("អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា គោលការណ៍ គ្មានបទល្មើសបើគ្មានច្បាប់ចែង ត្រូវបានគោរព ប្រសិនបើអំពើប្រព្រឹត្តជាក់លាក់ ដែលត្រូវបានរកឃើញថា ជាអំពើអមនុស្សធម៌ផ្សេងៗទៀតនោះ រំលោភបំពានលើសិទ្ធិជាសារវន្តរបស់ជនរងគ្រោះ" (គូសបញ្ជាក់បន្ថែម))។

[1487] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៦៦, ៦៦៩ *ដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤ ("ក្នុងការកំណត់ "លក្ខខណ្ឌតម្រូវនៃអនីត្យានុកូភាពផ្លូវការ" ត្រូវតែធ្វើឡើងតាមរយៈការកំណត់អត្តសញ្ញាណនៃការបញ្ជាក់ច្បាស់លាស់នូវសិទ្ធិ និងការហាមឃាត់ដែលមានចែងនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស ដែលអនុវត្តបាននៅក្នុងពេលពាក់ព័ន្ធទៅនឹងបទចោទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត")។

[1488] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៦៦, ៦៦៩, ១១០២, ១១០៧, ១២៨២។

[1489] សូមមើលឧទាហរណ៍ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤, *យោងទៅ* សិទ្ធិ និងការហាមឃាត់ដែលមានចែងនៅក្នុង សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស។

អាចរំខាន[1490]។ ជាឧទាហរណ៍ មិនមានភាពខុសគ្នារវាង ការរំលោភបំពានទៅលើសិទ្ធិ រស់រានមានជីវិត ដែលមានចែងនៅក្នុង លិខិតុបករណ៍សិទ្ធិមនុស្សជាច្រើន[1491] ធៀបជាមួយនឹងការហាមឃាត់អំពើមនុស្សឃាត នៅក្នុងមាត្រាបីទូទៅ នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឡើយ។ ការតម្រូវឱ្យអំពើជាក់លាក់មួយ ចាំបាច់ត្រូវមានការហាមឃាត់ច្បាស់លាស់ គឺធ្វើឱ្យខូចខាតដល់គោលបំណង នៃប្រភេទសេសសល់ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត[1492] ដោយដាក់បញ្ចូលឡើងវិញតាមច្រកទ្វាក្រោយ នូវលក្ខខណ្ឌតម្រូវដែល អង្គជំនុំជម្រះតុលាការកំពូល បានដកចេញយ៉ាងជាក់ច្បាស់[1493]។

392. ធាតុផ្សំ "អនីត្យានុកូលភាពផ្លូវការ" មួយ គឺមិនតម្រូវច្បាស់លាស់ឡើយ នៅតុលាការមិនអចិន្ត្រៃយ៍ដើម្បីកំណត់និយមន័យ អំពើអមនុស្សធម៌ផ្សេងៗទៀត[1494] ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់[1495]។ ទោះបីជាយ៉ាងនេះក្តី ក្នុងករណីដែលតុលាការដទៃទៀត រួមទាំងរឿងក្តីដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ បានពិនិត្យមើលទៅលើ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីវាយតម្លៃទៅលើភាពធ្ងន់ធ្ងរ ការវិភាគរបស់ពួកគេ នឹងគាំទ្រទៅលើការបកស្រាយ របស់អង្គជំនុំជម្រះសាលាដំបូង។ ការទាញចេញពីសិទ្ធិ និងការហាមឃាត់ ដោយមិនមានការញែកឱ្យដាច់ពីគ្នា ដើម្បីស្វែងរកអង្គនៃ "សិទ្ធិជាមូលដ្ឋាន ទាក់ទងនឹងមនុស្សជាតិ"[1496] តុលាការមិនបានតម្រូវឱ្យមាន ការហាមឃាត់ទៅលើអំពើដែលស្ថិតជាបញ្ហា ជាក់លាក់ណាមួយឡើយ[1497]។

---

[1490] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៥ (គូសបញ្ជាក់បន្ថែម)។

[1491] សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស មាត្រា ៣។ គណៈកម្មាធិការអឺរ៉ុប សម្រាប់សិទ្ធិមនុស្ស មាត្រា ២។

[1492] *សាលដីការឿងក្តី Brima* កថាខណ្ឌ ១៨៣-១៨៥។ *សាលក្រមរឿងក្តី Kupreškić* កថាខណ្ឌ ៥៦៣។ សូមមើលផងដែរ ការពណ៌នាចំពោះអនុសញ្ញាទីក្រុងហ្សឺណែវទីបួន ទំព័រ ៣៩។

[1493] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤។

[1494] អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY និង SCSL បានដកចេញមូលដ្ឋានសិទ្ធិមនុស្សជាក់ស្តែង សម្រាប់អំពើដែលបង្កើតបានជា អំពើអមនុស្សធម៌ផ្សេងទៀត ដោយតម្រូវត្រឹមតែថា ជាអំពើដែលមានលក្ខណៈ និងស្ថានទម្ងន់ប្រហែលគ្នា ជាមួយអំពើដែលមានចែងច្បាស់ *សូមមើលឧទាហរណ៍ សាលដីការឿងក្តី Krajišnik* កថាខណ្ឌ ៣៣១។ *សាលដីការឿងក្តី Brima* កថាខណ្ឌ ១៩៨-២០០។ *សាលដីការឿងក្តី D Milošević* កថាខណ្ឌ ១០៨-១០៩។

[1495] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤។

[1496] *សាលដីការឿងក្តី Stakić* កថាខណ្ឌ ៣១៥-៣១៧, ជាពិសេស ជើងទំព័រ ៦៤៩។ *សាលក្រមរឿងក្តី Kupreškić* កថាខណ្ឌ ៥៦៦។

[1497] សូមមើលឧទាហរណ៍ *សាលក្រមរឿងក្តី Kupreškić* កថាខណ្ឌ ៥៦៦ (អំពើពេស្យាកម្មដោយបង្ខំ គឺ "ប្រាកដណាស់ថា ជាការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស អនុលោមតាមលិខិតុបករណ៍អន្តរជាតិ ស្តីពីសិទ្ធិមនុស្សភាគច្រើន" ដូច្នេះ

## គ. ការប្រព្រឹត្តិទៅលើក្រុមគោលដៅ

### ១. ពុទ្ធសាសនិកជន

393. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចត្រឹមត្រូវថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ត្រូវបានប្រព្រឹត្តឡើងប្រឆាំងពុទ្ធសាសនិកជន រួមទាំងព្រះសង្ឃនៅក្នុងសហករណ៍ត្រាំកក់[1498] អនុលោមទៅតាមគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅលើពុទ្ធសាសនិកជន នៅទូទាំងប្រទេស ដែលជាប់ទាក់ទងផ្ទៃក្នុង ជាមួយគោលបំណងរួម[1499]។

394. មូលដ្ឋានទាំងបីរបស់ ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងឧក្រិដ្ឋកម្មទាំងអស់នេះ ត្រូវច្រានចោលដោយសារតែពួកគេយល់ច្រឡំទៅលើច្បាប់ ស្តីពីការរើសអើងជាក់ស្តែង, ដោយសារអនុវត្តការបកស្រាយដោយផ្នែកៗទាំងខុសឆ្គង ទៅលើភ័ស្តុតាងឬសាលក្រម និងក្នុងករណីខ្លះមិនបានផ្តល់ភ័ស្តុតាងគាំទ្រអំណះអំណាង[1500]។ ម្ចាស់បណ្តឹងសាទុក្ខបានមើលរំលងជាពិសេស ទៅលើផលវិបាករើសអើង នៃអំពើទៅលើពុទ្ធសាសនិកជន នៅក្នុងសហករណ៍ត្រាំកក់ ផលប៉ះពាល់រួមគ្នានៃអំពើនោះ និងការពិតដែលថាអំពើទាំងនោះ កើតឡើងនៅក្នុងបរិបទ នៃយុទ្ធនាការធ្វើទុក្ខបុកម្នេញទ្រង់ទ្រាយធំ ទៅលើពុទ្ធសាសនិកជន។

#### *មូលដ្ឋានទី ១៨៨៖ ការចោទប្រកាន់ពីគោលនយោបាយ ទាក់ទងនឹងពុទ្ធសាសនិកជន*[1501]

395. **មូលដ្ឋានទី១៨៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការសម្រេចថា មានគោលនយោបាយ**

---

ហើយសម្រេចថា អំពើនេះអាចបង្កើតបានជា អំពើអមនុស្សធម៌ផ្សេងទៀត ដោយមិនតម្រូវនូវការហាមឃាត់ជាក់លាក់ណាមួយអំពី "ពេស្យាកម្មដោយបង្ខំ")។

[1498] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨២-១១៨៧។

[1499] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៣-៤០២២។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៨។

[1500] មូលដ្ឋានទី ១៨៨, ១០៨-១០៩។

[1501] <u>មូលដ្ឋានទី ១៨៨៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ គោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិក កថាខណ្ឌ ១៥៨៦-១៥៩១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៥ (ភាសាអង់គ្លេស) ទំព័រ ៦០ (ភាសាបារាំង) ទំព័រ ៩២ (ភាសាខ្មែរ)។

**ឧក្រិដ្ឋ របស់បក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងពុទ្ធសាសនិកជន ហើយគោលនយោបាយនេះ គឺជាផ្នែកនៃគោលបំណងរួម។**

396. មូលដ្ឋានត្រូវតែច្រានចោលដោយសារ (១) ម្ចាស់បណ្ដឹងសាទុក្ខមិនខ្វល់ថា ភ័ស្តុតាងអ្វីដែលអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកលើ ក្នុងការសម្រេចអំពីអត្ថិភាព នៃគោលនយោបាយប្រឆាំងពុទ្ធសាសនិកជន រួមទាំងព្រះសង្ឃពុទ្ធសាសនា (២) កម្រិតកំណត់ត្រឹមតែ ទឡ្ហីករណ៍ដែលគ្មានមូលដ្ឋាន របស់ម្ចាស់បណ្ដឹងសាទុក្ខ នៅក្នុងមូលដ្ឋានបណ្ដឹងសាទុក្ខដទៃទៀតរបស់គាត់ ដើម្បីលើកទឡ្ហីករណ៍ដោយខុសឆ្គង ថាគោលនយោបាយមិនមានលក្ខណៈឧក្រិដ្ឋ និង (៣) ម្ចាស់បណ្ដឹងសាទុក្ខមិនបានផ្តល់ភ័ស្តុតាង គាំទ្រការអះអាងរបស់គាត់ដែលថា គោលនយោបាយឧក្រិដ្ឋ គឺមិនមែនជាផ្នែកនៃគោលបំណងរួម ដើម្បី "ការពារប្រទេសពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុង ឱ្យក្លាយជាសង្គមខ្មែរ ដែលមិនមានសាសនា និងរួបរួមគ្នាមួយ មានតែវណ្ណៈកម្មករ-កសិករ"[1502]។

397. ទីមួយ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "គោលនយោបាយដែលបង្កើតឡើង ពីគណៈកម្មាធិការមជ្ឈិមបក្ស ក្នុងការលុបបំបាត់អ្នកប្រតិបត្តិពុទ្ធសាសនា និងការហាមឃាត់ការប្រតិបត្តិ ព្រះពុទ្ធសាសនានៅក្នុង កម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាពក្នុងអំឡុងពេល ដែលត្រូវបានចោទប្រកាន់ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" គឺមិនផ្អែកទៅលើអំពើធ្វើទុក្ខបុកម្នេញ ទៅលើពុទ្ធសាសនិកជន នៅក្នុងសហករណ៍ត្រាំកក់ទេ[1503]។ ការសម្រេចនេះផ្អែកលើ (១) ឯកសារបក្សកុម្មុយនីស្តកម្ពុជា ដែលមាន "តម្លៃជាភ័ស្តុតាង"[1504] ដោយពិចារណាទៅលើបរិបទប្រវត្តិសាស្ត្រដែលបក្សកុម្មុយនីស្តកម្ពុជា បានគាប់សង្កត់រួចទៅហើយ ទៅលើព្រះសង្ឃព្រះពុទ្ធសាសនា ឱ្យលាចាកសិក្ខាបទ ហើយចូលបដិវត្តនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[1505] និង (២) "ទម្រង់ស៊ីសង្វាក់គ្នា នៃការប្រព្រឹត្តិនៅតាមទីតាំងឧក្រិដ្ឋកម្ម ដែលបញ្ជាក់ពីអត្ថិភាពនៃគោលនយោបាយដែលមជ្ឈិមបក្ស បានបង្កើតឡើង"[1506]។

---

[1502] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២១។ សូមមើលផងដែរ កថាខណ្ឌ ៤០៦៨។

[1503] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៨៩, ១៥៨៦។

[1504] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៦៥។

[1505] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ *កំណត់សម្គាល់យោងទៅក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ២៦៤ (រួមមានសម្រង់នៅក្នុងនោះ)។ សូមមើលផងដែរ កថាខណ្ឌ ១៩១, ១០៨៥។

[1506] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៦៥ (គូសបញ្ជាក់បន្ថែម)។

398. ហេតុដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខ មិនបានពិចារណាដល់ការពឹងផ្អែកដោយសមហេតុផលរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើ (១) ឯកសារគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ដែលវាយតម្លៃថា យ៉ាងហោចណាស់ព្រះសង្ឃ៩0% បានលាចាកសិក្ខាបទដោយទទួលស្គាល់ពីផលប៉ះពាល់ នៃវត្តអារាមដែលត្រូវបានបោះបង់ចោល ទៅលើការប្រត្តិបត្តិរបស់ពុទ្ធសាសនិកជន និងបានបញ្ជាក់ថា "ស្រទាប់សង្គមពិសេសនេះ លែងនាំឱ្យព្រួយបារម្ភទៀតហើយ" ព្រោះ "ចលនាមិនអាចបញ្ឈប់បាន" ប្រឆាំងពួកគេ បានបណ្តាលឱ្យមាន "ការផ្លាស់ប្តូរខ្លាំង ដូចមើលឃើញក្នុងសង្គមយើង"[1507] (២) ទស្សនាវដ្តី និងសៀវភៅកំណត់ត្រា បក្សកុម្មុយនីស្តកម្ពុជា ដែលរៀបរាប់ថាព្រះសង្ឃគឺជា "វណ្ណៈពិសេស" "អភិជន" និងងាយចាញ់ឧបាយកលខ្លាំង[1508] (៣) ភ័ស្តុតាងនៃកម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជា ដែលចាត់ទុកពុទ្ធសាសនាជាសាសនា "ប្រតិកិរិយា"[1509] និងមិនសមស្របជាមួយបដិវត្ត[1510] និង (៤) ការនិយាយយោង "តិច

[1507] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ *កំណត់សម្គាល់យោងទៅក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ១០៨៨ ជើងទំព័រ ៣៦៣១ *ដកស្រង់* ឯកសារ **E3/99** ឯកសារគោលនយោបាយទី ៦ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥, KH 00072402 (គូសបញ្ជាក់បន្ថែម) និងបញ្ជាក់ឡើងវិញនៅត្រង់ កថាខណ្ឌ ៣៨៥០។ សូមមើលផងដែរ កថាខណ្ឌ ១០៨៥, ១០៨៩, ៣៧៥៧។

[1508] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ *កំណត់សម្គាល់យោងទៅក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ៣៨៥០ (ជើងទំព័រ ១២៨៦១-១២៨៦២ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ៣៧៥០ និង៣៨៣២ ដែលដកស្រង់ឯកសារ **E3/1233** កំណត់ត្រា ពុំមានកាលបរិច្ឆេទ KH 00032934-00032936, ឯកសារ **E3/834** សៀវភៅកត់ត្រារួមរបស់មន្ទីរសន្តិសុខ ស-២១ ចុះខែមេសា-ខែឧសភ ឆ្នាំ១៩៧៨ KH 00077492), ១០៨១ (ជើងទំព័រ ៣៦៣៥ *យោងទៅក្នុងចំណោមផ្សេងទៀត* ឯកសារ **E3/135** *ទង់បដិវត្ត* ចុះខែមិថុនា ឆ្នាំ១៩៧៧ KH 00062806)។ សូមមើលផងដែរ កថាខណ្ឌ ១០៨៤, ១០៨៨, ៣៨៤៦ (រួមទាំង ទំព័រ ១២៨៤៨ *កំណត់សម្គាល់យោងទៅ ក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ៣៧៨៤), ៣៨៨៤។

[1509] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ *កំណត់សម្គាល់យោងទៅក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ១០៩២ (ជើងទំព័រ ៣៦៣៧ *ដកស្រង់* ឯកសារ **E1/56.1** កាំង ហ្គេចអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ទំព័រ ៦-៧), ១០៩០ (ជើងទំព័រ ៣៦៣៣-៣៦៣៤ *ដកស្រង់* ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ KH 00089850-00089851, ឯកសារ **E3/273** កម្រង FBIS *បទយកការណ៍នៅទីក្រុងភ្នំពេញស្តីពីសមាជជាតិលើកទី ៣៖ របាយការណ៍របស់ ខៀវ សំផន* ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ KH 00657450)។ សូមមើលផងដែរ ជើងទំព័រ ៣៧០៣, ១០៨១៩ កថាខណ្ឌ ៣៧៦៣, ៣៨៤៦។

[1510] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ *កំណត់សម្គាល់យោងទៅក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ១១០៨ (ជើងទំព័រ ៣៧០៤ *ដកស្រង់* អត្ថបទសារព័ត៌មានពីរ ទាក់ទង យុន យ៉ាត រដ្ឋមន្ត្រីក្រសួងឃោសនាការ។ សូមមើលផងដែរ កថាខណ្ឌ ៤០២០។

បំផុត" អំពីពុទ្ធសាសនា ឬព្រះសង្ឃ នៅក្នុងឯកសារផ្សព្វផ្សាយ សុន្ទរកថា និងការផ្សព្វផ្សាយនានា របស់បក្សកុម្មុយនីស្តកម្ពុជា នៅក្រោយដើមឆ្នាំ១៩៧៦[1511]។

399. បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយសមហេតុផលថា អត្ថិភាពនៃគោលនយោបាយដែលបង្កើតឡើង ពីគណៈកម្មាធិការមជ្ឈិមបក្ស ត្រូវបានគាំទ្រដោយភ័ស្តុតាង លើសពីសហករណ៍ត្រាំកក់ទៀត។ ដោយផ្អែកលើបណ្តុំយ៉ាងច្រើនលើសលើប់ នៃសក្ខីកម្មក្នុងសវនាការ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីខ្លះ ដែលអង្គជំនុំជម្រះសាលាដំបូង បានដកស្រង់ជាឧទាហរណ៍បង្ហាញ អង្គជំនុំជម្រះសម្រេចថា (១) "ទម្រង់ស្របគ្នានិងជាទ្រង់ទ្រាយធំ នៃការផ្សឹកព្រះសង្ឃដោយបង្ខំ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីបានបណ្តេញព្រះសង្ឃ ចេញពីវត្តអារាមនៅទូទាំងប្រទេសរួចហើយនោះ" (២) "ការបិទ និងកម្ទេចវត្តអារាម នាពេលបន្ទាប់មក ការផ្លាស់ប្តូរការប្រើប្រាស់វត្តអារាម ទៅជាគោលដៅផ្សេងក្រៅពីសាសនា និងការប្រើប្រាស់វត្តអារាម ក្នុងលក្ខណៈប្រមាថមើលងាយ" (៣) ការហាមឃាត់ការប្រតិបត្តិ និងពិធីសាសនារបស់ ពុទ្ធសាសនិក នៅក្នុងអំឡុងពេលវេលា ដែលត្រូវបានចោទប្រកាន់ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង (៤) "សាក្សីត្រូវបានគេប្រាប់ ពីភាពមិនចុះសម្រុងគ្នា រវាងព្រះពុទ្ធសាសនា ជាមួយនឹងបដិវត្តន៍ ហើយបានរៀបរាប់នៅក្នុងតុលាការ អំពីការបំផ្លាញទាំងស្រុង ទៅលើព្រះពុទ្ធសាសនា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[1512]។ ផ្ទុយពីការអះអាងដែលនាំឱ្យយល់ខុស របស់ម្ចាស់បណ្តឹងសាទុក្ខ មិនមានការជំទាស់ចំពោះភ័ស្តុតាងនេះ នៅក្រៅសហករណ៍ត្រាំកក់ឡើង ក្នុងមូលដ្ឋាន ១០៨ និង១០៩ ដែលពាក់ព័ន្ធអំពើធ្វើទុក្ខបុកម្នេញ ប្រឆាំងពុទ្ធសាសនិក នៅក្នុងសហករណ៍ត្រាំកក់[1513]។

400. ជាលទ្ធផល ភ័ស្តុតាងនៃគោលនយោបាយលុបបំបាត់ការប្រតិបត្តិរបស់ពុទ្ធសាសនិក និងការហាមឃាត់ការគោរពព្រះពុទ្ធសាសនា នៅក្នុងអំឡុងពេល ដែលត្រូវបានចោទប្រកាន់ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមានភាពរឹងមាំខ្លាំង ដែលអង្គជំនុំជម្រះសាលាដំបូង មិនចាំបាច់ត្រូវពឹងផ្អែកទៅលើការសម្រេចរបស់ខ្លួន នៅក្នុងសហករណ៍ត្រាំកក់ ដើម្បីទាញសន្និដ្ឋានអំពីអត្ថិភាព នៃគោលនយោបាយបែបនេះឡើយ។ ការពិតដែលថា ទម្រង់នៃការប្រព្រឹត្តដូចគ្នា ប្រឆាំងពុទ្ធសាសនិក

---

[1511] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥ *កំណត់សម្គាល់យោងទៅក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ១០៩១។

[1512] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៥-៤០១៦។

[1513] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨៩, ១៥៩១ (ជើងទំព័រ ៣០៣៥, ៣០៣៨ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ៧៤៣-៧៤៧)។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨-១០៩។

ដែលកើតឡើងនៅក្នុងសហករណ៍ត្រាំកក់ ដូចដែលបានកើតឡើងនៅកន្លែងផ្សេងទៀត នៅក្នុងកម្ពុជាប្រជាធិបតេយ្យ គ្រាន់តែជួយពង្រឹងបន្ថែម ដល់ភាពសមហេតុផល នៃការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើអត្ថិភាពនៃគោលនយោបាយ។

401. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញ អំពីកំហុសឆ្គងណាមួយ នៅក្នុងការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង "យល់ថា គោលនយោបាយកំណត់គោលដៅ ទៅលើពុទ្ធសាសនិកដើម្បីធ្វើបាប មានការប្រព្រឹត្តឧក្រិដ្ឋកម្ម"[1514]។ សម្រាប់សំអាងហេតុដូចបានផ្ដល់ជូនរួចហើយ នៅក្នុងចម្លើយតបនេះ ការអះអាងឡើងវិញរបស់ម្ចាស់បណ្ដឹងសាទុក្ខ ទៅលើមូលដ្ឋាន៥៩, ៩៥, ១០៨ និង ១០៩ មិនបានធ្វើឱ្យខូចខាតដល់ ការសម្រេចដែលសមហេតុផល និងត្រឹមត្រូវតាមគតិយុត្តិរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិក នៅក្នុងសហករណ៍ត្រាំកក់ឡើយ[1515]។ បន្ថែមលើនេះ ម្ចាស់បណ្ដឹងសាទុក្ខ បានមើលរំលងថា អំពើឧក្រិដ្ឋប្រឆាំងពុទ្ធសាសនិក នៅក្នុងស្រុកត្រាំកក់ "ស៊ីសង្វាក់គ្នា" ជាមួយគោលនយោបាយដែលបង្កើតឡើង ពីគណៈកម្មាធិការមជ្ឈិមបក្ស និងការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិកនៅក្រៅស្រុកនេះ[1516]។

402. ទីបី ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែអះអាង ប៉ុន្តែមិនបានពន្យល់ថា ហេតុអ្វីទើបអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការសម្រេចថា អំពើឧក្រិដ្ឋប្រឆាំងពុទ្ធសាសនិក នៅក្នុងសហករណ៍ត្រាំកក់ "ស្ថិតនៅក្នុងគោលបំណងរួម"[1517]។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការលុបបំបាត់

---

[1514] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៨ និងបញ្ជាក់ឡើងវិញនៅត្រង់ កថាខណ្ឌ ៤០២២។ ។ ចំពោះភស្តុតាងដែល អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើ សូមមើល *កថាខណ្ឌ* ៤០១៩ (រួមទាំងការយោងខ្វែង នៅក្នុងនោះផង)។

[1515] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៥៩ (បណ្ដឹង) (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៨៦, ១៥៨៩), ៩៥ (ធាតុផ្សំអត្តនោម័តិ) (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៨៧), ១០៨ (អំពើរើសអើងជាក់ស្ដែង) (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៩០, ១៥៨៨-១៥៨៩), និង ១០៩ (ឥទ្ធិពលលើរាងកាយ និងផ្លូវចិត្ត) (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៨៨-១៥៨៩)។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៩ (រួមទាំងការយោងខ្វែង នៅក្នុងនោះផង)។

[1516] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២០។

[1517] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៨ និងបញ្ជាក់ឡើងវិញនៅត្រង់ កថាខណ្ឌ ៤០២១-៤០២២។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៩១។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨ និង ១៨៩, ១៧៥, ១៧៦, ១៧៧ និង ២៤៤ (កំហុសពាក់ព័ន្ធការចោទពី គោលបំណងរួម និងគម្រោងបដិវត្តសង្គមនិយម របស់បក្សកុម្មុយនីស្តកម្ពុជា)។

ការប្រតិបត្តិរបស់ពុទ្ធសាសនិក នៅទូទាំងស្រុកត្រាំកក់ គឺ "ស៊ីសង្វាក់គ្នា" ជាមួយការហាមឃាត់ព្រះពុទ្ធសាសនា ដោយសារ "មិនចុះសម្រុងគ្នាជាមួយ គោលការណ៍បដិវត្ត"[1518]។ ដោយផ្អែកលើកំណត់ត្រាភ័ស្តុតាង ដែលស៊ីសង្វាក់គ្នាយ៉ាងច្រើនលើសលប់ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយសមហេតុផលថា គោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា កំណត់គោលដៅទៅលើពុទ្ធសាសនិក សម្រាប់ការធ្វើបាប ត្រូវបានអនុវត្តឡើងជាមធ្យោបាយឧក្រិដ្ឋ ដើម្បី "ការពារប្រទេសពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុង ឱ្យក្លាយជាសង្គមខ្មែរ ដែលមិនមានសាសនា និងរូបរួមគ្នាមួយ មានតែវណ្ណៈកម្មករ-កសិករ" ស្របទៅតាមគោលដៅបដិវត្ត របស់បក្សកុម្មុយនីស្តកម្ពុជា[1519]។ ហេតុដូច្នេះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ស្របទៅតាមគោលនយោបាយនេះ ត្រូវស្ថិតនៅក្នុងគោលបំណងរួម[1520]។

### *មូលដ្ឋានទី ១០៨៖ មិនមានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា៖ ការប្រព្រឹត្តិស្មើភាព មិនផ្សំបានជាការប្រព្រឹត្តបែបរើសអើង*[1521]

403. **មូលដ្ឋានទី ១០៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គច្បាប់ ដោយសម្រេចថា ធាតុផ្សំសត្យានុម័ត នៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា ទៅលើពុទ្ធសាសនិកនិងព្រះសង្ឃ នៅក្នុងស្រុកត្រាំកក់ ត្រូវបានកំណត់**

404. មូលដ្ឋាននេះត្រូវច្រានចោល ដោយសារតែទឡ្ហីករណ៍របស់ ម្ចាស់បណ្តឹងសាទុក្ខ បានពឹងផ្អែកទៅលើ ការយល់ច្រឡំលើច្បាប់ ស្តីពីការរើសអើងជាក់ស្តែង និងការបកស្រាយមួយផ្នែកៗ នៃការសម្រេចលើអង្គច្បាប់ របស់អង្គជំនុំជម្រះសាលាដំបូង។

---

[1518] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០១៩។

[1519] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២១។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[1520] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[1521] <u>មូលដ្ឋានទី ១០៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អវត្តមាននៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា៖ ការប្រព្រឹត្តិស្មើភាពមិនផ្សំបានជាការប្រព្រឹត្តិបែបរើសអើង* កថាខណ្ឌ ៧៤៣-៧៤៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤១ (ភាសាអង់គ្លេស) ទំព័រ ៣៧ (ភាសាបារាំង) ទំព័រ ៥៧-៥៨ (ភាសាខ្មែរ)។ ពាក់ព័ន្ធមូលដ្ឋានបណ្តឹងសាទុក្ខ ដែលលើកឡើងវិញ របស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤៣, សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៥៩ (បណ្តឹង) ៩៤ (ច្បាប់ស្តីពីធាតុផ្សំអត្តនោម័តិ នៃការធ្វើទុក្ខបុកម្នេញ)។

405. ម្ចាស់បណ្ដឹងសាទុក្ខ បានចោទប្រកាន់ដោយខុសថា ការរើសអើងជាក់ស្ដែង មិនអាចកើតឡើងបានឡើយ នៅពេលដែលវិធានការណ៍ជាក់លាក់ បានអនុវត្តស្មើភាពគ្នា ចំពោះគ្រប់សមាជិកទាំងអស់នៃក្រុមចម្រុះ[1522]។ ការបកស្រាយនេះគឺខុសផ្នែកគតិយុត្ត ហើយមិនបានពិចារណាទៅលើយុត្តិសាស្ត្រដែលមានកំណត់ស្រាប់របស់ អ.វ.ត.ក ដែលបញ្ជាក់ថា អំពើសកម្មឬអកម្ម "រើសអើងជាក់ស្ដែង" ក្នុងករណីដែលមាន "ផលវិបាកដែលមាន លក្ខណៈរើសអើងជាក់ស្ដែង" ទៅលើសមាជិកនៃក្រុមជាក់លាក់មួយ[1523]។ ហេតុដូច្នេះមិនមានលក្ខខណ្ឌតម្រូវ ផ្នែកគតិយុត្ត ក្នុងការញែកឱ្យដាច់រវាង ការរើសអើង "ផ្ទាល់" ឬ "ប្រយោល"[1524]។ បន្ថែមលើនេះ អំពើសកម្មឬអកម្ម គឺជាការរើសអើងជាក់ស្ដែង " នៅពេលដែល "ជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ *ដោយសារតែជនរងគ្រោះ ជាសមាជិកនៅក្នុងក្រុមណាមួយ* ដែលចារីបានកំណត់ ដោយមូលហេតុជាក់លាក់មួយចំនួន ពោលគឺមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"[1525]។ ហេតុដូច្នេះម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញអំពី កំហុសឆ្គងអង្គច្បាប់ណាមួយ នៅក្នុងការទទួលស្គាល់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរើសអើងជាក់ស្ដែង ត្រូវបានកំណត់ "ដោយមិនគិតថា តើសមភាពនៃលទ្ធផល គឺជាគោលដៅចុងក្រោយដែរឬទេនោះ"[1526] និងដោយពិចារណាទៅដល់ "ផលប៉ះពាល់ខុសៗគ្នា ដែលផ្អែកដោយចៀសមិនផុត លើសាវតារខុសៗគ្នា របស់ប្រជាជន"[1527]។

---

[1522] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៤៥។

[1523] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៦៣, ២៦៧ (គូសបញ្ជាក់បន្ថែម)។ ដើម្បីឈានដល់ការសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូល បានអះអាងនៅត្រង់ កថាខណ្ឌ ២៦៣ ថា "ការសម្រេចលើអង្គហេតុ នៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ដូចដែលបានវិភាគនៅក្នុងផ្នែកខាងលើ បានគាំទ្រដល់ការសម្រេចនេះ ហេតុដូច្នេះបានគាំទ្រថាវាបង្កើតបានជាផ្នែក នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥។

[1524] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៤៤។

[1525] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៧២(ដោយគូសបញ្ជាក់បន្ថែម ហើយលប់ចោលការគូសបញ្ជាក់ដើម) និងបញ្ជាក់ឡើងវិញនៅត្រង់ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៦៧, ៦៩០។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៤។ ជាឧទាហរណ៍ ចំពោះពុទ្ធសាសនិក (១) ព្រះសង្ឃត្រូវបានបង្ខំឱ្យសឹក ហើយបោះបង់ជំនឿរបស់ខ្លួន និង (២) ពុទ្ធរូប គម្ពីរ ចម្លាក់ និងទីសក្ការៈ ដែលជាកន្លែងពិសេសរបស់ពុទ្ធសាសនិកត្រូវបានកម្ទេចចោល ឬប្រើប្រាស់ក្នុងគោលដៅមិនមែនសាសនា។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៣-១១៨៥។

[1526] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៤៥។

[1527] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៥។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៤៤។

406. ដោយអនុវត្តច្បាប់ដោយត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ពុទ្ធសាសនិក[1528] និងព្រះសង្ឃ[1529] ទទួលរងផលវិបាកដែលមានលក្ខណៈរើសអើង នៃគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា ក្នុងការលុបបំបាត់សាសនា ហើយក្លាយជាគោលដៅនៅក្នុងស្រុកត្រាំកក់ *ដោយសារតែជនរងគ្រោះ ជាសមាជិកនៅក្នុងក្រុមសាសនាមួយ*។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងច្រានចោលដោយត្រឹមត្រូវនូវការអះអាងដែលគ្មានមូលដ្ឋានរបស់ នួន ជា ដែលថា មិនមានការរើសអើងជាក់ស្តែងឡើយ ព្រោះពុទ្ធសាសនិកត្រូវបានគេប្រព្រឹត្តចំពោះ ដូចមនុស្សគ្រប់រូបផ្សេងទៀតដែរ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ[1530]។

## *មូលដ្ឋានទី ១០៩៖ មិនមានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ៖ គ្មានភ័ស្តុតាងអំពីផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តរបស់ពុទ្ធសាសនិក*[1531]

407. **មូលដ្ឋានទី ១០៩ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គហេតុ ក្នុងការកំណត់ធាតុផ្សំសត្យានុម័ត នៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា ទៅលើពុទ្ធសាសនិកនិងព្រះសង្ឃ នៅក្នុងស្រុកត្រាំកក់។**

---

[1528] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៦ ("ការបំផ្លិចបំផ្លាញនិមិត្តរូប តំណាងព្រះពុទ្ធសាសនា ការបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបយកកន្លែងគោរពបូជា និងការហាមប្រាមលើការប្រតិបត្តិ ឬជំនឿសាសនា [...] បានរើសអើង ដោយសារពួកគេកំណត់គោលដៅ លើជនទាំងឡាយណា ដែលមានជំនឿនិងមានសារតារ ពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា ដោយផ្អែកទាំងស្រុងលើអត្ថន័យនៃទីកន្លែង និមិត្តរូបតំណាងព្រះពុទ្ធសាសនា និងការប្រតិបត្តិរបស់ប្រជាជនទាំងនោះ")។

[1529] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៣ (ព្រះសង្ឃត្រូវបានប្រមូលដោយ "ចេតនា" ហើយបញ្ជូនទៅវត្តអង្គរកា ដែលនៅទីនោះព្រះសង្ឃត្រូវបាន "បង្ខំ" ឱ្យសឹក ត្រូវបាន "កំណត់អត្តសញ្ញាណ [...] ផ្អែកលើអត្តសញ្ញាណសាសនារបស់ពួកគេ ហើយបានកំណត់គោលដៅ ដោយសារតែពួកគាត់ជាព្រះសង្ឃ") និងបញ្ជាក់ឡើងវិញនៅត្រង់កថាខណ្ឌ ១១៨៥ ("ដោយសារជនរងគ្រោះនៃការប្រព្រឹត្តនេះ គឺជាសមាជិកនៃក្រុមសាសនា (ព្រះសង្ឃ) នោះការប្រព្រឹត្តពិតជាមានការរើសអើងមែន")។

[1530] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៥, ១១៨២។ ជាផ្នែកនៃចម្លើយតបរបស់ខ្លួនចំពោះ នួន ជា អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ឡើងវិញ អំពីការសម្រេចលើអង្គច្បាប់ ពីមុនរបស់ខ្លួន ទៅលើពុទ្ធសាសនិក រួមបញ្ចូលទាំងព្រះសង្ឃ ដែលបានទទួលរងការរើសអើងជាក់ស្តែង។ សូមមើល កថាខណ្ឌ ១១៨៥-១១៨៦។

[1531] <u>មូលដ្ឋានទី ១០៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អវត្តមាននៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា៖ គ្មានភ័ស្តុតាងអំពីផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តរបស់ពុទ្ធសាសនិក* កថាខណ្ឌ ៧៤៣, ៧៤៦-៧៤៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤១ (ភាសាអង់គ្លេស) ទំព័រ ៣៧-៣៨ (ភាសាបារាំង) ទំព័រ ៥៨ (ភាសាខ្មែរ) ។ ពាក់ព័ន្ធមូលដ្ឋានបណ្តឹងសាទុក្ខ ដែលលើកឡើងដដែល របស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុង ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤៣ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៥៩ (បណ្តឹង) ៩៤ (ច្បាប់ស្តីពីធាតុផ្សំអត្តនោម័តិ នៃការធ្វើទុក្ខបុកម្នេញ)។

408. មូលដ្ឋាននេះត្រូវច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង បានធ្វើការវាយតម្លៃមិនសមហេតុផល ទៅលើភ័ស្តុតាងដែលជាមូលដ្ឋាននៃការសម្រេចលើអង្គច្បាប់របស់ខ្លួន ដែលថា "ផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តនៃព្រឹត្តិការណ៍ទាំងនេះ បានរំលោភលើសិទ្ធិជាមូលដ្ឋាន ក្នុងកម្រិតនៃភាពធ្ងន់ធ្ងរស្រដៀងគ្នា ទៅនឹងបទល្មើសផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[1532]។ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញភ័ស្តុតាងថា មិនមានអ្នកជម្រះសេចក្តីលើអង្គហេតុ ដោយសមហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចបែបនេះ ដោយផ្អែកលើការវាយតម្លៃទាំងស្រុង មិនមែនវាយតម្លៃមួយផ្នែកៗ ទៅលើភ័ស្តុតាងនោះ[1533]។ ការតវ៉ាដោយខុសឆ្គងរបស់គាត់ (១) បកស្រាយដោយខុសទៅលើការសម្រេចនេះ (២) កម្រិតត្រឹមតែភ័ស្តុតាងតែមួយ ដែលគាត់ជំទាស់ដោយមិនមានភាពគួរឱ្យជឿជាក់ (៣) មិនបានពិចារណាលើផលប៉ះពាល់រួម នៃអំពើធ្វើទុក្ខបុកម្នេញ ដែលត្រូវបានប្រព្រឹត្តឡើង ប្រឆាំងពុទ្ធិសាសនិកនៅក្នុងស្រុក និង (៤) មើលរំលងថាអំពើទាំងអស់នោះ បានកើតឡើងនៅក្នុងបរិបទ ដែលបក្សកុម្មុយនីស្តកម្ពុជា ជម្រុញដល់យុទ្ធនាការ ធ្វើទុក្ខបុកម្នេញជាទ្រង់ទ្រាយធំ ទៅលើពុទ្ធសាសនិក[1534]។ បន្ថែមលើនេះ ម្ចាស់បណ្ដឹងសាទុក្ខមិនបានជំទាស់ចំពោះការសម្រេចលើអង្គច្បាប់បន្ថែម របស់អង្គជំនុំជម្រះសាលាដំបូង លើស្ថានទម្ងន់នៃអំពើរើសអើងប្រឆាំងនឹងព្រះសង្ឃ[1535] ដែលបង្កើតជាមូលដ្ឋានផងដែរ ដល់ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញ។

409. ដោយពឹងផ្អែកលើសំអាងហេតុ ដែលបង្កើតឡើងដោយ អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងត្រឹមត្រូវអំពីលក្ខខណ្ឌតម្រូវស្ថានទម្ងន់ ដែលអាចបំពេញបានតាមរយៈការត្រួតពិនិត្យលើអំពើពាក់ព័ន្ធ "នៅក្នុងបរិបទ ព្រមជាមួយនឹងផលប៉ះពាល់នានា ដែលបានកើតឡើងដោយអំពើទាំងនោះ"[1536]។ ក្នុងករណីដែលអំពើធ្វើទុក្ខបុកម្នេញនោះ ជាឧក្រិដ្ឋកម្មប្រឆាំង

---

[1532] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៦។

[1533] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[1534] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៦ ជើងទំព័រ ២១៩៨ ដកស្រង់ផងដែរ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៥៩។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៤៦។

[1535] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៧។ សូមមើលផងដែរ កថាខណ្ឌ ១១៨៥ (ស្ថានទម្ងន់នៃ "ការបង្ខំព្រះសង្ឃឱ្យបោះបង់ជំនឿរបស់ខ្លួន [...] ជាពិសេសអ្វីដែលព្រះសង្ឃត្រូវបានបង្ខំឱ្យបោះបង់ចោល")។

[1536] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៦ ជើងទំព័រ ២១៩៨ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៥៦-២៥៩, ២៦១ ។ នេះប្រហែលជាវិធីសាស្រ្ត ក្នុងការសម្រេចថាតើ "អំពើដទៃទៀត" អាចបំពេញបានតាមលក្ខខណ្ឌតម្រូវស្ថានទម្ងន់ដែរឬទេ នៅពេលដែលការត្រួតពិនិត្យជារួម និងទៅតាមបរិបទរបស់អំពើនោះ

មនុស្សជាតិដោយផ្ទាល់ អំពើទាំងអស់នោះគឺ "ពិតជាអំពើដែលមានស្ថានទម្ងន់យ៉ាងខ្លាំង ដែលបណ្តាលឱ្យមានការរំលោភបំពាន លើសិទ្ធិសារវន្ត" ហើយដែល "ឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់នៃបទល្មើសមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[1537]។ នៅក្នុងការវាយតម្លៃថាតើ "អំពើផ្សេងទៀត" (ដូចជាអំពើមិនមានចែងក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) បង្កើតបានជាឧក្រិដ្ឋកម្ម នៃការធ្វើទុក្ខបុកម្នេញដែរឬអត់នោះ[1538] អង្គជំនុំជម្រះមិនគួរផ្តោតទៅលើថាតើអំពើសកម្ម ឬអកម្ម នៃការធ្វើទុក្ខបុកម្នេញជាក់លាក់ណាមួយ បានរំលោភបំពានទៅលើសិទ្ធិមនុស្ស ដែលមានលក្ខណៈជាសារវ័ន្ត ប៉ុន្តែត្រូវផ្តោតទៅលើ "ថាតើអំពើសកម្មឬអកម្ម នៃការធ្វើទុក្ខបុកម្នេញនេះ នៅពេលពិចារណាជារួម និងទៅតាមបរិបទ នាំឱ្យមានការរំលោភទៅលើសិទ្ធិជាសារវ័ន្ត ដោយកំរោល ឬឥតលាក់លៀម ដែលមានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ស្មើគ្នាទៅនឹង បទល្មើសជាមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរឬយ៉ាងណា"[1539]។

410. កម្រិតនៃស្ថានទម្ងន់ កាន់តែធ្ងន់ធ្ងរឡើងនៅពេលដែល "អំពើសកម្ម ឬអកម្ម ដែលមានគោលដៅប្រឆាំងបុគ្គលជាក់លាក់មួយចំនួន ដោយគ្រាន់តែបុគ្គលនោះ ជាសមាជិកនៅក្នុងក្រុមណាមួយនោះ"[1540] ហើយអង្គជំនុំជម្រះត្រូវតែពិចារណាថាតើ អំពើពាក់ព័ន្ធត្រូវបានប្រព្រឹត្តឡើង នៅក្នុងបរិបទ ឬជាផ្នែកមួយនៃព្រឹត្តិការណ៍ដែលកើតឡើងតៗគ្នា នៅក្នុងយុទ្ធនាការធ្វើទុក្ខបុកម្នេញជាទ្រង់ទ្រាយធំជាងមុន ដែលគោលដៅនិងលទ្ធផលចុងក្រោយ មានភាពធ្ងន់ធ្ងរខ្លាំងហួសហេតុ ដែលបានបណ្តាលឱ្យមានការរំលោភបំពាន យ៉ាងធ្ងន់ធ្ងរដែរឬយ៉ាងណា ទៅលើសិទ្ធិជាសារវ័ន្ត[1541]។ នៅគ្រប់ពេលវេលាពាក់ព័ន្ធទាំងអស់ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាដំបូងបានអនុវត្ត លក្ខខណ្ឌតម្រូវគតិយុត្តិ ដែលបានកំណត់យ៉ាងច្បាស់នេះ[1542]។

---

"កំណត់ពីស្ថានទម្ងន់ នៃអំពើនេះទាំងមូល សូមមើល សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៥៧ *ដកស្រង់ សាលក្រមរឿងក្តី Brđanin* ជើងទំព័រ ២៥៨៥។

[1537] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៦១-២៦២។

[1538] អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់ថា លក្ខខណ្ឌតម្រូវស្ថានទម្ងន់ គឺពាក់ព័ន្ធតែជាមួយការសម្រេច ថាតើ "អំពើដទៃទៀត" អាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញដែរឬទេ សូមមើល សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៦១។

[1539] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៥៧។

[1540] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៥៩។

[1541] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៥៩។

[1542] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៩, ១៤១២, ១៦៩១, ៣៣៣១។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១១៩, ១៤៣, និង ១៤៩។

411. ការសម្រេចលើអង្គច្បាប់របស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើស្ថានទម្ងន់នៃអំពើធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិក មិនកម្រិតត្រឹមតែឧទាហរណ៍បង្ហាញ ដូចជាចម្លើយអំពីផលប៉ះពាល់ របស់ជនរងគ្រោះ ប៊ុន សារឿន និងពិធីរៀបអាពាហ៍ពិពាហ៍ មិនត្រូវបានធ្វើឡើងតាមប្រពៃណីខ្មែរឡើយ[1543]។ ការសម្រេចនេះគឺផ្អែកលើភស្តុតាង "ការបំផ្លិចបំផ្លាញនិមិត្តរូប តំណាងព្រះពុទ្ធសាសនា ការបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបយកកន្លែងគោរពបូជា និងការហាមប្រាមលើការប្រតិបត្តិ ឬជំនឿសាសនា"[1544]។ ការអានទាំងស្រុងទៅលើការសម្រេចអង្គច្បាប់ រួមជាមួយការសម្រេចលើអង្គហេតុ និងអង្គច្បាប់កន្លងមក (និងការយោងឆ្លង) បង្ហាញថា ការសម្រេចក៏ផ្អែកផងដែរទៅលើភស្តុតាង ពីអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ទៅលើ "សារៈសំខាន់នៃជំនឿ និងការប្រតិបត្តិសាសនា [...] និងទីកន្លែងរបស់ពួកគេ នៅក្នុងសង្គមកម្ពុជានៅពេលនោះ"[1545] ទំហំនិងរយៈពេលនៃអំពើធ្វើទុក្ខបុកម្នេញនៅក្នុងស្រុកនោះ[1546] និងកម្រិតដែលអំពើទាំងនោះ ជះឥទ្ធិពលទៅលើពុទ្ធសាសនិក[1547]។

412. ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ ពីតួនាទីយ៉ាងសំខាន់របស់ពុទ្ធសាសនា នៅក្នុងប្រទេសកម្ពុជា នៅមុនឆ្នាំ១៩៧៥[1548] រួមទាំង "ពុទ្ធសាសនាបានវេញជាផ្លុងមួយ និងអត្ត

[1543] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤៦។

[1544] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៦។

[1545] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៥។ សូមមើលផងដែរ ជើងទំព័រ ៣៦១៣ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ២៥៧-២៦៤ (ផ្នែក "៣.៤ ពុទ្ធសាសនាក្នុងប្រទេសកម្ពុជា នៅមុនឆ្នាំ១៩៧៥")។

[1546] <u>ទំហំ</u>៖ *ឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៣ (ពាក់ព័ន្ធ (១) ការណែនាំរបស់លេខាស្រុក ឱ្យផ្សឹកព្រះសង្ឃ និង (២) "គំរូទូទៅនៃទូទាំងស្រុងត្រាំកក់" សម្រាប់ការផ្សឹកដោយបង្ខំ "ព្រះសង្ឃរាប់រយអង្គ" ជើងទំព័រ ៤០៣០-៤០៣២ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០៨៧, ១១០៥, ១១៨៤ (ពាក់ព័ន្ធ (១) ពុទ្ធសាសនាត្រូវបានហាមឃាត់ តាមរយៈការបំផ្លាញព្រះពុទ្ធរូប ការប្រមាថមើលងាយលើវត្តអារាម និង "ការលប់បំបាត់ទាំងស្រុង នូវការប្រតិបត្តិព្រះពុទ្ធសាសនា" និង (២) មានការ "វាយប្រហារជាប់ជានិរន្តន៍ នឹងដោយមានការរៀបចំប្រឆាំងនឹងព្រះពុទ្ធសាសនា" ជើងទំព័រ ៤០៣៤-៤០៣៦ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១១០៥, ១១០៧-១១០៨) <u>រយៈពេល</u>៖ ឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៩៤-១០៩៩ (គូសបញ្ជាក់ពីប្រតិបត្តិការជានិរន្ត ដែលមានរយៈពេលច្រើនខែ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើម្បី "បង្ខំព្រះសង្ឃឱ្យសឹក" ១១០៥, ១១០៧-១១០៨ (គូសបញ្ជាក់ពីការវាយប្រហារទៅលើ និមិត្តរូបពុទ្ធសាសនិក និងហាមឃាត់ការប្រតិបត្តិពុទ្ធសាសនា ចាប់ពីថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ រហូតដល់បញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ)។

[1547] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៤-១១៨៧ (រួមទាំងជើងទំព័រ ៤០៣៩, ៤០៤១)។

[1548] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៥៧-២៦៤ (ផ្នែក "៣.៤ ពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា មុនឆ្នាំ១៩៧៥")។

សញ្ញាណជនជាតិខ្មែរ ហើយមានឥទ្ធិពលទៅលើ ស្ទើតែគ្រប់ទិដ្ឋភាពនៃជីវិត”[1549] ហើយព្រះសង្ឃ គឺជា “វណ្ណៈពិសេស”[1550]។ នៅត្រឹមឆ្នាំ១៩៧៦[1551] មានការហាមឃាត់នៅទូទាំងស្រុក លើការគោរពព្រះពុទ្ធសាសនា ការបង្ហាញពីព្រះពុទ្ធសាសនា[1552] ការមិនមានព្រះសង្ឃ[1553] និងការផ្លាស់ប្តូរការប្រើប្រាស់ព្រះពុទ្ធរូប សៀវភៅធម៌ និងវត្តអារាម ទៅជាគោលដៅផ្សេងក្រៅពីសាសនា តាមរយៈការប្រើប្រាស់ ក្នុងលក្ខណៈប្រមាថមើលងាយ[1554]។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលឡើង ឥទ្ធិពលរួមគ្នានៃអំពើទាំងអស់នេះ នៅក្នុងស្រុកត្រាំកក់ គឺមានន័យថាពុទ្ធសាសនិក លែងអាចប្រារព្ធពិធីបុណ្យ

---

[1549] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤៧ *ដកស្រង់* ឯកសារ **E3/20** Elizabeth Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* KH 00232176។

[1550] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៤០៣៧ *កំណត់សម្គាល់យោងទៅ ក្នុងចំណោមផ្សេងទៀត* កថាខណ្ឌ ១០៨៤ ដែលដកស្រង់ឯកសារកម្ពុជាប្រជាធិបតេយ្យផ្សេងៗនៅក្នុងជើងទំព័រ ៣៦១៣។ សូមមើលផងដែរ កថាខណ្ឌ ១០៨៨ ជើងទំព័រ ៣៦៣១ *ដកស្រង់* ឯកសារ **E3/99** ឯកសារគោលនយោបាយទី ៦ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072402។

[1551] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៩៥ ជើងទំព័រ ៣៦៤៧ និង ៣៦៥០ *ដកស្រង់ក្នុងចំណោមផ្សេងទៀត* ឯកសារ **E1/263.1** ឯម ភឿង ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ ១៦, ៤០, ៤៧-៤៨។ សូមមើលផងដែរ កថាខណ្ឌ ៤០១៧។

[1552] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៦ ជើងទំព័រ ៤០៣៨ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១១០៥ និង ១១០៨ ដែលយោងទៅរកសក្ខីកម្ម កំណត់ហេតុស្តាប់ចម្លើយ អត្ថបទសារព័ត៌មាន និងសេចក្តីប្រកាសព័ត៌មាន សូមមើលផងដែរ កថាខណ្ឌ ១១០២-១១០៣ ជើងទំព័រ ៣៦៧៥ (ជាំង ស្រីមុំ) ៣៦៧៩ (សៅ ហ៊ាន) ៣៦៩១ (នាង អ៊ីច) ៣៧០២ (កំណត់ត្រាស្រុកត្រាំកក់)។

[1553] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១០៥ ជើងទំព័រ ៣៦៩១ *ដកស្រង់* ឯកសារ **E1/273.1** ប្រតិចារឹក នាង អ៊ីច ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៥ ទំព័រ ៤៧។ សូមមើលផងដែរ ជើងទំព័រ ៣៦៣១ (ឯកសារគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ៣៦៦១ (ឯម ភឿង) ៣៧០១ (ប៊ុន សារឿន) កថាខណ្ឌ ១១៨៣ (ជើងទំព័រ ៤០២៨ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០៩៤-១០៩៦)។

[1554] <u>និមិត្តរូប និងគម្ពីរ</u> ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៦៨៣ *ដកស្រង់* ឯកសារ **E1/263.1** ឯម ភឿង ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ ៥៤។ សូមមើលផងដែរ ជើងទំព័រ ៣៦៦៩ (រៀល សន) ៣៦៨៤ (សៅ ហ៊ាន), ៣៦៨៦ (ភ្លៅ យ៉ាវ), ៣៦៨៩ (កំណត់សម្គាល់៖ ជើងទំព័រគួរដកស្រង់អំពី ឯកសារ **E1/247.1** ប្រតិចារឹក មាស សុខា ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ទំព័រ ៤៣ ដើម្បីស្របជាមួយជើងទំព័រ នៅក្នុងសាលក្រមជាភាសាខ្មែរ) ៣៦៩៨ (ពេជ្រ ជីម), <u>វត្ត</u>៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១០២, ១១០៥, ១១០៨។ សូមមើលផងដែរ ជើងទំព័រ ៣៦៩៩ (ប៊ុន សារឿន)។

អ្វីបានឡើយ[1555]។ ពួកគាត់ "ដោះស្រាយខ្លួនឯង"[1556] នៅក្នុងអំឡុងពេលបន្តទៀត នៃរបបកម្ពុជាប្រជាធិបតេយ្យ[1557] ដែលបង្ខំឱ្យប្រជាជនមួយចំនួន ត្រូវប្រថុយជីវិតដើម្បីរក្សាជំនឿ លើព្រះពុទ្ធសាសនាដោយសម្ងាត់[1558]។

413. បន្ថែមពីលើឥទ្ធិពលរួមគ្នា ម្ចាស់បណ្តឹងសាទុក្ខ មិនបានស្វែងយល់ថា ការសម្រេចលើអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង លើស្ថានទម្ងន់នៃអំពើធ្វើទុក្ខបុកម្នេញ នៅក្នុងស្រុកនោះ រួមមាននូវភស្តុតាងដែលមានតម្លៃខ្ពស់ ដែលថាអំពើនោះត្រូវបានប្រព្រឹត្តឡើង នៅក្នុងបរិបទនៃយុទ្ធនាការរើសអើងជាទ្រង់ទ្រាយ ប្រឆាំងពុទ្ធសាសនិក[1559] ដែលអនុវត្តឡើងនៅក្នុងស្រុកត្រាំកក់ អនុលោមទៅតាមបញ្ជាខែមេសា ឆ្នាំ១៩៧៥[1560]។

---

[1555] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៩៥ (ជើងទំព័រ ៣៦៥១ *ដកស្រង់* ឯកសារ **E1/263.1** ឯម ភឿង ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ ៤០, ៤៦-៤៨), កថាខណ្ឌ ១១០៥ (ជើងទំព័រ ៣៦៩២ *ដកស្រង់* ឯកសារ **E1/264.1** ភ្លៅ យ៉ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ ៣៦)។ សូមមើលផងដែរ ជើងទំព័រ ៩៤៩៥ (កែវ ច័ន្ទតារា)។

[1556] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៩៥ ជើងទំព័រ ៣៦៥០ *ដកស្រង់* ឯកសារ **E1/263.1** ឯម ភឿង ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ ៤០, ៤៧-៤៨។ សូមមើលផងដែរ កថាខណ្ឌ ១១០៧ (ប៊ុន សារឿន)។ ឯកសារ **E1/402.1** ប្រតិចារឹក Alexander Hinton ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង ១១.១៦.៥៦-១១.២១.១៧ ទំព័រ ៤០ បន្ទាត់ ៧-ទំព័រ ៤២ បន្ទាត់ ៨។

[1557] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១០៥ (ជើងទំព័រ ៣៦៩១ *ដកស្រង់* ឯកសារ **E1/273.1** នាង អ៊ូច ប្រតិចារឹក ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៥ ទំព័រ ៣៧), កថាខណ្ឌ ១១០៨ (ជើងទំព័រ ៣៧០៣-៣៧០៤ *ដកស្រង់ក្នុងចំណោមផ្សេងទៀត* ឯកសារ **E1/259.1** Elizabeth Becker ប្រតិចារឹក ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ ៤២ និង អត្ថបទព័ត៌មាន ទាក់ទង យ៉ុន យ៉ាត រដ្ឋមន្ត្រីឃោសនាការ) សូមមើលផងដែរ ជើងទំព័រ ៣៧០២ (កំណត់ត្រាស្រុកត្រាំកក់) ៣៦៣៧ (កាំង ហ្កេចអ៊ាវ)។

[1558] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៦៩៧ (*ដកស្រង់* ឯកសារ **E1/254.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ទំព័រ ៣១-៣២, ឯកសារ **E1/255.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ ១៣), ជើងទំព័រ ៣៧០២ (*ដកស្រង់* ឯកសារ **E3/8424** កំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៧)។ សូមមើលផងដែរ ឯកសារ **E1/263.1** ប្រតិចារឹក ឯម ភឿង ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង ០៩.៤៥.១៧-០៩.៥៧.០២ ទំព័រ ១៥ បន្ទាត់ ១-៣។ ឯកសារ **E3/5136** កំណត់ហេតុស្តាប់ចម្លើយ ប៊ុល មឿន KH 00165316។

[1559] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៨។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៩៣ (រួមទាំងជើងទំព័រ ៣៦៣៨, ដែលយោងខ្វែងទៅរក "ផ្នែកទីបី៖ បរិបទប្រវត្តិសាស្ត្រ កថាខណ្ឌ ២៦៤ ផ្នែក ១៦.៤.៣.៣ គោលបំណងរួម៖ ការកំណត់គោលដៅទៅលើក្រុមជាក់លាក់៖ ពុទ្ធសាសនិក កថាខណ្ឌ ៤០១៥-៤០១៧"), ១០៨៨-១០៨៩, ៨១៥។

[1560] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨៧ (ជើងទំព័រ ៣៦២៦-៣៦២៧ *ដកស្រង់* ឯកសារ **E1/291.1** ពេជ្រ ជីម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ទំព័រ ៤៨-៥០, ៦៦-៦៧។ ឯកសារ **E1/290.1** ពេជ្រ ជីម

## ២. អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ

414. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ (រួមទាំងមន្ត្រីនិងអតីតយោធា) យោងទៅតាមគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅទៅលើ អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ដែលមានទំនាក់ទំនងផ្ទៃក្នុង ជាមួយគោលបំណងរួម[1561]។

415. មូលដ្ឋានទាំងបីរបស់ម្ចាស់បណ្តឹងសាទុក្ខ[1562] ទាក់ទងនឹងឧក្រិដ្ឋកម្មនេះគួរត្រូវបានច្រានចោលដោយសារតែគាត់បកស្រាយដោយមិនត្រឹមត្រូវទៅលើបណ្តឹង បង្ហាញដោយភាន់ច្រឡំនូវការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១[1563] និងវាយតម្លៃដោយខុសឆ្គង ទៅលើភាពពាក់ព័ន្ធ និងតម្លៃជាភ័ស្តុតាងនៃភ័ស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើ ក្នុងការសម្រេចរបស់ខ្លួន[1564]។

### *មូលដ្ឋានទី ១៨៧៖ គោលនយោបាយប្រឆាំងនឹងអតីតទាហាន នៃរបបសាធារណរដ្ឋខ្មែរ*[1565]

416. **មូលដ្ឋានទី ១៨៧ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុនិងអង្គច្បាប់ ក្នុងការសម្រេចថា មានគោលនយោបាយឧក្រិដ្ឋ របស់បក្សកុម្មុយនីស្តកម្ពុជា ដែលរើសអើងទៅលើអតីតទាហាន និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ហើយគោលនយោបាយនេះ គឺជាផ្នែកនៃគោលបំណងរួម។**

417. មូលដ្ឋាននេះត្រូវច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ដោយ (១) អនុវត្តហួសបណ្តឹង[1566](២)

---

ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ទំព័រ ១១-១២)។ សូមមើលផងដែរ ជើងទំព័រ ៣៦៦៥ (កំណត់ហេតុស្តាប់ចម្លើយ) ៤០៣០។

[1561] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦១។

[1562] មូលដ្ឋានទី ១៨៧, ១០៦ និង ១២០។

[1563] មូលដ្ឋានទី ១៨៧។

[1564] មូលដ្ឋានទី ១៨៧, ១០៦ និង ១២០។

[1565] <u>មូលដ្ឋានទី ១៨៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គោលនយោបាយប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ* កថាខណ្ឌ ១៥៧៨-១៥៨៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៤ (ភាសាអង់គ្លេស) ទំព័រ ៥៩ (ភាសាបារាំង) ទំព័រ ៩២ (ភាសាខ្មែរ)។

[1566] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧៨ ជើងទំព័រ ៣០១៤-៣០១៧។ សូមមើលចម្លើយតបទៅនឹងមូលដ្ឋានទី ៦៤, ៧១, ៧៤, ៨១។

ពឹងផ្អែកលើហេតុការណ៍នៅទួលពោធិ៍ជ្រៃ នៅភូមិភាគពាយ័ព្យ ដើម្បីសន្និដ្ឋានអំពីអត្ថិភាព នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលរើសអើងទៅលើ អតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ[1567] (៣) សម្រេចថាធាតុផ្សំសត្យានុម័ត នៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយទៅលើ អតីតយោធារបបសាធារណរដ្ឋខ្មែរ នៅសហករណ៍ត្រាំកក់[1568] និងទំនប់ ១មករា[1569] និង (៤) ពឹងផ្អែកទៅលើសេចក្តីថ្លែងការណ៍ របស់ម្ចាស់បណ្តឹងសាទុក្ខ ក្រោយពីទទួលបានជ័យជំនះ[1570]។ ការអះអាងទី១ និងទី៣ ត្រូវបានលើកឡើងវិញម្តងទៀត ជាមូលដ្ឋានដាច់ដោយឡែកនៃបណ្តឹងសាទុក្ខ ហើយត្រូវបានបកស្រាយនៅផ្នែកផ្សេង នៃចម្លើយតបនេះ។

418. ការអះអាងទី២ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មានកំហុសឆ្គងក្នុងការវាយតម្លៃ លើសារសំខាន់គតិយុត្តិ នៃការលើកលែងចោទប្រកាន់របស់គាត់ ដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង០០២/០១ ពាក់ព័ន្ធឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅទួលពោធិ៍ជ្រៃ[1571]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយភាន់ច្រឡំថា គាត់ត្រូវបានលើកលែងចោទប្រកាន់ ពីអង្គហេតុពាក់ព័ន្ធឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ[1572] ដែលតាមពិតទៅអង្គជំនុំជម្រះតុលាការកំពូល គ្រាន់តែសម្រេចថា ជាការមិនសមហេតុផលក្នុងការសម្រេចថា "*គោលនយោបាយកំណត់គោលដៅ សម្លាប់*ទាហាន និងអ្នករដ្ឋការ នៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពនៅក្នុងអំឡុងពេល នៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ"[1573]។ អង្គជំនុំជម្រះតុលាការកំពូល បានអះអាងយ៉ាងច្បាស់ គាំទ្រដល់ការសម្រេច ដែលម្ចាស់បណ្តឹងសាទុក្ខបានជំទាស់[1574] ដោយបញ្ជាក់ថា "សមហេតុផលដែលថា យ៉ាងហោចណាស់មានអតីតយោធា និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ចំនួន២៥០នាក់ ត្រូវបានសម្លាប់" នៅទួលពោធិ៍ជ្រៃ[1575]។ ហេតុដូច្នេះ

[1567] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨២។

[1568] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧៩ ជើងទំព័រ ៣០១៨។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៦។

[1569] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧៩ ជើងទំព័រ ៣០១៩។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១២០។

[1570] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨១។

[1571] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨២។

[1572] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨២។

[1573] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧២ (គូសបញ្ជាក់បន្ថែម)។

[1574] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨២។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៦

[1575] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០២។

អង្គជំនុំជម្រះសាលាដំបូង មិនមានកំហុសឆ្គងក្នុងការ ពឹងផ្អែកទៅលើព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួនថា មានគោលនយោបាយរើសអើងទៅលើ អតីតយោធា និង អ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៥[1576]។

419. ការអះអាងទី៤គួរត្រូវបានច្រានចោល ដោយសារតែទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធ ការពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសេចក្តីថ្លែងការណ៍របស់គាត់ ក្រោយពីទទួល បានជ័យជំនះ គឺមានការភាន់ច្រឡំ ហើយមិនគិតផងដែរអំពីភាពរួម នៃភស្តុតាងដែលបង្ហាញពី អត្ថិភាព នៃគោលនយោបាយកំណត់គោលដៅ ទៅលើអតីតយោធានិងអ្នករដ្ឋការ របប សាធារណរដ្ឋខ្មែរ។ ម្ចាស់បណ្តឹងសាទុក្ខ បានលើកទឡ្ហីករណ៍បែបទ្រឹស្តីនិយមថា គាត់គ្រាន់តែចាត់ ទុក ប្រមុខនៃអតីតរបបសាធារណរដ្ឋខ្មែរ ថាជាខ្មាំងប៉ុណ្ណោះ មិនមែនអតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរទាំងអស់ទេ[1577]។ គាត់ពឹងផ្អែកទៅលើ សេចក្តីថ្លែងការណ៍របស់គាត់ ដែល យោងទៅរកប្រមុខ "ពុករលួយ ផ្តាច់ការ និងក្បត់ជាតិបំផុត" ជា "ខ្មាំង" នៅក្នុងសេចក្តីថ្លែង ការណ៍មួយ ដោយមិនបានយោងទៅអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរទាំងអស់ ថាជាជនក្បត់ឡើយ[1578]។ ទោះជាយ៉ាងនេះក្តី ច្បាស់ណាស់ថា គុណនាមទាំងអស់នេះ ដែលគាត់ ជ្រើសរើសប្រើដោយខ្លួនឯង បានសម្តែងឱ្យឃើញពីទំនោររឹះគន់យ៉ាងធ្ងន់ធ្ងរ ទៅលើរបបមុន និង បានពន្យល់ពីមូលហេតុដែល អតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់ ជាគោលដៅ *ជាទូទៅ* ដោយមិនគិតអំពីឋានន្តរសក្តិ ឬតួនាទី។

420. បន្ថែមលើនេះ ហើយសំខាន់ជាងនេះទៅទៀត ម្ចាស់បណ្តឹងសាទុក្ខមិនបានគិតអំពី ភស្តុតាងយ៉ាង ច្រើនលើសលប់ ដែលអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណា នៅពេលដែលម្ចាស់បណ្តឹង សាទុក្ខ បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែក *ជាពិសេស* ទៅលើសេចក្តីថ្លែងការណ៍ របស់ម្ចាស់បណ្តឹងសាទុក្ខ ក្រោយពីទទួលបានជ័យជំនះ ដើម្បីកំណត់ពីការរើសអើងទៅលើ

---

[1576] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៦ ជើងទំព័រ ១៣៣៦៤។

[1577] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨១។

[1578] ឯកសារ **E3/118** FBIS សារអបអរជ័យជម្នះ ធ្វើឡើងនាថ្ងៃទី២១ ខែមេសា របស់ ខៀវ សំផន តាមវិទ្យុទីក្រុងភ្នំពេញ ថ្ងៃ ទី២១ ខែមេសា ឆ្នាំ១៩៧៥ KH 00846160, 00846159 ("ក្រោយវាយប្រយុទ្ធដ៏ស្វិតស្វាញ និងអង់អាចក្លាហានបំផុត ក្រោយពី អត់ធ្មត់នឹងទុក្ខវេទនា និងការលំបាកគ្រប់បែបយ៉ាង ជាមួយវីរភាពដ៏អស្ចារ្យ និងក្រោយពីអត់ធន់នឹងពលីកម្មដ៏អស្ចារ្យ អស់រយៈ ពេលប្រាំឆ្នាំនិងមួយខែមក កងកម្លាំងប្រដាប់អាវុធ ប្រជាជនរំដោះជាតិកម្ពុជា ដ៏ក្លាហានបំផុតរបស់យើង និងប្រជាជនដ៏អស្ចារ្យ របស់យើង បានកម្ទេចទាំងស្រុងនូវសង្គ្រាមឈ្លានពាន ព្រៃផ្សៃបំផុតរបស់ពួកចក្រពត្តិអាមេរិក និងបានកម្ទេចទាំងស្រុងនូវ របបហ្វាស៊ីស ក្បត់ និងពុករលួយបំផុតរបស់ពួកអាក្បត់ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង ប៊ូរេត និងសូស្តែន ហ្វែណង់ដេស" (គូសបញ្ជាក់បន្ថែម))។

អតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ[1579]។ ជាពិសេសអង្គជំនុំជម្រះសាលាដំបូង បានដកស្រង់ព័ត៌មានស្របៗគ្នា អំពីការធ្វើទុក្ខបុកម្នេញទៅលើ អតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ដែលបានកើតឡើងនៅទូទាំងប្រទេស នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[1580]។

421. ម្ចាស់បណ្តឹងសាទុក្ខមើលរំលងថា អង្គជំនុំជម្រះសាលាដំបូង បានកំណត់ពីគោលនយោបាយដែលរងការជំទាស់ ដោយពឹងផ្អែកទៅលើសេចក្តីថ្លែងការណ៍ សេចក្តីណែនាំ និងការប្រជុំដទៃជាច្រើន ដែលបានកើតឡើងនៅក្នុងអំឡុងពេលនោះ នៅកម្រិតខ្ពស់បំផុតនៃ បក្សកុម្មុយនីស្តកម្ពុជា[1581]។ អង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកទៅលើសេចក្តីណែនាំ កិច្ចប្រជុំ និងសេចក្តីថ្លែងការណ៍ចំនួន ២៨ ទាំងនៅមុនបន្តិច និងនៅក្នុងអំឡុង របបកម្ពុជាប្រជាធិបតេយ្យ ដែលទាំងអស់នោះមានពាក់ព័ន្ធជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[1582]។ បើយោងតាម ឌុច អង្គជំនុំជម្រះសាលាដំបូងពិចារណាថា "អតីតអ្នករដ្ឋការ និងអតីតទាហាន ប៉ូលីសរបស់ លន់ នល់ ជាសត្រូវធំសម្រាប់បក្សកុម្មុយនីស្តកម្ពុជា ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥"[1583]។ នៅមុនឆ្នាំ១៩៧៥បន្តិច និងនៅក្នុងឆ្នាំ១៩៧៥ ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើភ័ស្តុតាងក៏បានបង្ហាញផងដែរថា បក្សកុម្មុយនីស្តកម្ពុជាផ្តោតទៅលើ ការចាប់ខ្លួនយោធា និងអ្នករដ្ឋការ ដែលមានបណ្តាសក្តិខ្ពស់[1584]។

422. អង្គជំនុំជម្រះសាលាដំបូងសម្រេចថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា បានពង្រីកជាបន្តបន្ទាប់ ដោយបញ្ចូលផងដែរនូវ អតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរទាំងអស់ រួមជាមួយក្រុមគ្រួសាររបស់ពួកគេ ដោយមិនគិតអំពីឋានៈនិងតួនាទី។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញភ័ស្តុតាងនៃវិសាលភាពយ៉ាងធំនេះ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ឈ្មោះ យង់ សុខុម ដែលបញ្ជាក់ថា អ្នកចូលរួមក្នុងកិច្ចប្រជុំកម្រិតស្រុក នៅក្នុងឆ្នាំ១៩៧៧ បានទទួល

---

[1579] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៨១។

[1580] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២៦-៤០៤៩។

[1581] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២៦-៤០២៩, ៤០៣២, ៤០៣៤, ៤០៣៧-៤០៤០, ៤០៤១ (ជើងទំព័រ ១៣៣៨២, ១៣៣៨៣), ៤០៤៦ (ជើងទំព័រ ១៣៣៩៧), ៤០៤៧ (ជើងទំព័រ ១៣៤០២, ១៣៤០៣)។

[1582] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២៦-៤០២៩, ៤០៣២, ៤០៣៤, ៤០៣៧-៤០៤០, ៤០៤១ (ជើងទំព័រ ១៣៣៨២, ១៣៣៨៣), ៤០៤៦ (ជើងទំព័រ ១៣៣៩៧), ៤០៤៧ (ជើងទំព័រ ១៣៤០២, ១៣៤០៣)។

[1583] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣២។

[1584] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៨។

បញ្ជាឱ្យសម្លាប់ យោធាឬអ្នករដ្ឋការ នៃរបបសាធារណរដ្ឋខ្មែរ[1585]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានពិចារណាផងដែរទៅលើ ទស្សនាវដ្តីទង់បដិវត្តជាច្រើនលេខ នៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ដែលបានបន្ទោសចំពោះភាពខ្វះខាត នៃរបបសម្ភូហភាព ដែលមិនអាចមាននិរន្តរភាពបាន ដោយសារតែអតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ហើយបានលើកសរសើរការលុបបំបាត់អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ហើយបានកំណត់ថា "ក្រុមអានល់" ត្រូវបាន "កម្ទេច"[1586]។

423. បន្ថែមលើនេះ និងសំខាន់ផងដែរនោះ អង្គជំនុំជម្រះសាលាដំបូង ក៏បានពិចារណាផងដែរលើ រយៈពេលយ៉ាងយូរ និងវិសាលភាពភូមិសាស្ត្រដ៏ធំទូលាយ នៃអំពើធ្វើទុក្ខបុកម្នេញ ទៅលើអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ដើម្បីសម្រេចអំពីអត្ថិភាព នៃគោលនយោបាយនេះ។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកទៅលើព័ត៌មាន និងឯកសាររបស់សាក្សីពិសេសៗ ចំនួន៥២នាក់ ដែលរៀបរាប់លម្អិតអំពី ការធ្វើទុក្ខបុកម្នេញ ទៅលើអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ រួមទាំងក្រុមគ្រួសាររបស់ពួកគេ[1587]។ ដោយចាប់ផ្តើមនៅមុនខែមេសា ឆ្នាំ១៩៧៥បន្តិច ការវិភាគទៅលើភ័ស្តុតាង របស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញអំពីភាពស៊ីសង្វាក់គ្នាដ៏គួរឱ្យកត់សម្គាល់ នៃព័ត៌មាននៅក្នុងអំឡុង របបកម្ពុជាប្រជាធិបតេយ្យទាំងមូល[1588]។

424. ចាប់តាំងពីឆ្នាំ១៩៧២ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើសក្ខីកម្មសាក្សីប្រាំបីរូប និងឯកសារផ្សេងទៀតចំនួន១៨ ដែលក្នុងនោះមានព័ត៌មានពីជនភៀសខ្លួន ដើម្បីស្វែងរកការលេចឡើង នូវគោលនយោបាយដែលវងការជំទាស់ ទាក់ទងទៅនឹងយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ[1589]។ ជាឧទាហរណ៍ សក្ខីកម្មរបស់ សូត្រ សាំង បង្ហាញថា "នៅមន្ទីរសន្តិសុខក្រាំងតាចាន់ អ្នកទោសដែលជាអតីតយោធា និងមន្ត្រីរដ្ឋការស៊ីវិល របបលន់ នល់ មានច្រើនជាងមុន" ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥[1590]។ ប្រហែលគ្នានេះ សម្រាប់អំឡុងពេលពីខែ

---

[1585] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០៥៦, ៩០៩៦ ជើងទំព័រ ១៣៣៩៧។

[1586] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០៩៧ ជើងទំព័រ ១៣៩០៣។

[1587] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០២៦-៩០៩៩។

[1588] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០២៦-៩០៩៩។

[1589] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០២៦-៩០៣១ (ឯកសារដកស្រង់នៅក្នុង ជើងទំព័រ ១៣៣៣៥-១៣៣៥៤)។

[1590] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០៣១ ជើងទំព័រ ១៣៣៥៤។

មេសា ដល់ចុងឆ្នាំ១៩៧៥ អង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកទៅលើសក្ខីកម្មសាក្សីចំនួន២៧ កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន២៤ និងឯកសារចំនួន១៧ផ្សេងទៀត បន្ថែមពីលើបញ្ជីឈ្មោះអ្នកទោស ពីមន្ទីរសន្តិសុខស-២១ ដើម្បីកំណត់ពីការតាមស្វែងរកនៅទូទាំងប្រទេស ការបាត់ខ្លួន ការចាប់ខ្លួន និង/ឬការសម្លាប់នាពេលបន្ទាប់មក ទៅលើអតីតសមាជិកជាន់ខ្ពស់នៃកងកម្លាំង និងមន្ត្រីរដ្ឋការស៊ីវិល របបសាធារណរដ្ឋខ្មែរ រួមជាមួយក្រុមគ្រួសារពួកគេ[1591]។ ជាឧទាហរណ៍ ការចាប់ខ្លួន និងការសម្លាប់ អតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ចំនួន២៥០ នៅទួលពោធិ៍ជ្រៃ គឺត្រូវបានរៀបរាប់ដោយសាក្សីចំនួនប្រាំមួយរូប[1592]។

425. លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការអនុវត្តការរើសអើងនេះ នៅតែបន្តរហូតដល់ឆ្នាំ១៩៧៦ ដោយផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន៣ សក្ខីកម្មសាក្សីចំនួន២៥ និងឯកសារផ្សេងទៀតចំនួន៩ រួមទាំងសារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ផ្ញើរជូន ប៉ុល ពត, នួន ជា, អៀង សារី, វ៉ន វ៉េត និងស៊ុន សេន ព័ត៌មានពីជនភៀសខ្លួន ដែលរាយការណ៍ដោយមន្ត្រីសហរដ្ឋអាមេរិក និងអង្គការលើកលែងទោសអន្តរជាតិ[1593]។ ជាឧទាហរណ៍ ព្រំ សារុន បានរំឮកឡើងវិញថា "ក្នុងកាលនោះ ខ្មែរក្រហមបានប្រមូល ក្រុមគ្រួសារទាហាន លន់ នល់ ឱ្យទៅនៅមូលដ្ឋានអូរពងមាន់" មុននឹងសម្លាប់ទាហាន ដែលមានបណ្តាសក្តិធំៗ[1594]។

426. ក្រៅពីនេះ អង្គជំនុំជម្រះសាលាដំបូង អាចរកឃើញថា ការបាត់ខ្លួន ការសម្លាប់ និងការចាប់ខ្លួនកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងឆ្នាំ១៩៧៧ ដោយផ្អែកលើសក្ខីកម្មសាក្សីផ្ទាល់ចំនួនបី សារទូលេខផ្សេងទៀត របស់កម្ពុជាប្រជាធិបតេយ្យ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន៥[1595]។ សារទូលេខកម្ពុជាប្រជាធិបតេយ្យ ពីតំបន់៨០១ ផ្ញើរជូន ប៉ុល ពត, នួន ជា, អៀង សារី, វ៉ន វ៉េត និង ស៊ុន សេន បានរៀបរាប់លម្អិតអំពី ដំណើរការកំណត់អត្តសញ្ញាណ អតីតអ្នករដ្ឋការ នគរបាល និងយោធា[1596]។ ព័ត៌មានរបស់សាក្សីផ្ទាល់ បានបង្ហាញផងដែរអំពី ការចាប់ខ្លួនបងប្រុសរបស់ ព្រាប សុឃឿន និង សៀង ចាន់ធី ការបាត់ខ្លួនរបស់សាច់ញាតិ និងអ៊ំរបស់ ចិច សុផា និងការបាត់ខ្លួននិង

[1591] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣២-៤០៤១ (ឯកសារដកស្រង់នៅក្នុង ជើងទំព័រ ១៣៣៥៥-១៣៣៨៥)។

[1592] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៦ ជើងទំព័រ ១៣៣៦៤។

[1593] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤២-៤០៤៩។

[1594] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៦ ជើងទំព័រ ១៣៣៩៦។

[1595] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤២-៤០៤៩។

[1596] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៨ ជើងទំព័រ ១៣៤០៤។

ការចាប់ខ្លួនទាហាន លន់ នល់[1597]។ បុគ្គលទាំងអស់នេះ គឺសុទ្ធតែជាអតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ឬសមាជិកគ្រួសាររបស់ពួកគេ[1598]។

427. បន្ថែមលើនេះ ការបន្តការអនុវត្តបែបនេះ នៅក្នុងឆ្នាំ១៩៧៨ គឺអង្គជំនុំជម្រះសាលាដំបូង ផ្អែកទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីផ្ទាល់ភ្នែកចំនួន៦នាក់ និងសារទូលេខដទៃទៀត របស់កម្ពុជាប្រជាធិបតេយ្យ និងរបាយការណ៍របស់ កម្ពុជាប្រជាធិបតេយ្យ[1599]។ ជាឧទាហរណ៍ ឈឹម ស្រ៊ន បានបញ្ជាក់ថា "គេសម្លាប់អ្នកដែលជាប់ពាក់ព័ន្ធ និងរបប លន់ នល់ នៅប្រហែលខែ៨ ឆ្នាំ១៩៧៨" ហើយ អ៊ិន ជឿន បានរំឭកឡើងវិញថា ក្មួយប្រុសគាត់និងអ្នកផ្សេងទៀត ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៩ ដោយសារការចោទប្រកាន់ថា ជាកងអារុធហត្ថ (ប៉េអឹម) នៅក្នុងរបប លន់ នល់[1600]។ នៅកម្រិតរចនាសម្ព័ន្ធ របាយការណ៍កម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨ ផ្ញើរជូន "អង្គការ" បានកត់សម្គាល់ពីការសម្រិតសម្រាំងខ្លាំង "ពីអង្គភាពផ្សេងៗ និងចេញពីកងទ័ពជាដើម ព្រមទាំងសមាសភាព១៧មេសា ជារដ្ឋការចាស់ៗ"[1601]។

428. លើសពីនេះទៅទៀត មានកម្រិតនៃភាពស៊ីសង្វាក់គ្នាខ្ពស់ នៅក្នុងចំណោមបណ្តាព័ត៌មានសាក្សី និងឯកសាររាប់សិប ដែលអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកទៅលើ ដើម្បីសម្រេចពីគោលនយោបាយ កំណត់គោលដៅទៅលើ អតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់ នៅពេលវិភាគធៀបទៅនឹង ផ្នែកខ្វែងខាងភូមិសាស្ត្រ របស់កម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូងរកឃើញ អំពីការកំណត់គោលដៅបែបនេះ នៅភូមិភាគពាយ័ព្យ និរតី បូព៌ា បស្ចឹម ព្រៃសាន្ត និងឧត្តរ ព្រមទាំងទីក្រុងភ្នំពេញ[1602]។ ដោយផ្អែកលើកំណត់ភស្តុតាង យ៉ាងច្រើនលើសលប់ ហើយដែលស៊ីសង្វាក់គ្នានេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយសមហេតុផលថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា កំណត់គោលដៅទៅលើ អតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ដើម្បីធ្វើបាប ត្រូវបានអនុវត្តឡើង ជាមធ្យោបាយឧក្រិដ្ឋដើម្បី "ការពារប្រទេស ពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុង ឱ្យក្លាយជាសង្គមខ្មែរ ដែលមិន

[1597] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៦ ជើងទំព័រ ១៣៣៩៧, ១៣៣៩៨។

[1598] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៦ ជើងទំព័រ ១៣៣៩៧, ១៣៣៩៨។

[1599] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៦-៤០៤៩។

[1600] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៦ ជើងទំព័រ ១៣៣៩៨។

[1601] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៨ ជើងទំព័រ ១៣៤០៤។

[1602] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២៦-៤០៤៩។

មានសាសនា និងរួបរួមគ្នាមួយ” យោងទៅតាមគោលដៅបដិវត្ត របស់បក្សកុម្មុយនីស្តកម្ពុជា[1603]។ ដូច្នេះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង អនុលោមទៅតាមគោលនយោបាយនេះ ដើម្បីសម្រេចបាននូវគោលដៅ ត្រូវស្ថិតនៅក្នុងគោលបំណងរួម[1604]។

## *មូលដ្ឋានទី ១០៦៖ អតីតយោធា និងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ មិនត្រូវបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយទេ*[1605]

429. **មូលដ្ឋានទី ១០៦ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ដោយសម្រេចថា ធាតុផ្សំសត្យានុម័ត ត្រូវបានកំណត់សម្រាប់ការធ្វើទុក្ខបុកម្នេញ ដោយមូលដ្ឋាននយោបាយ ទៅលើអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ នៅក្នុងសហករណ៍ត្រាំកក់។**

430. មូលដ្ឋាននេះគួរបដិសេធ ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ បានលើកទឡ្ហីករណ៍ដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុដោយសម្រេចថា (១) មានការចេញបញ្ជាឱ្យស្រាវជ្រាវ និងរកចាប់ខ្លួន អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ (២) ប្រតិបត្តិការសម្លាប់ បានចាប់ផ្ដើមនៅក្នុងខែមេសា ឆ្នាំ១៩៧៧ ទៅលើអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ នៅក្នុងស្រុកត្រាំកក់ និង (៣) ដោយយោងទៅរកកថាខណ្ឌ នៅក្នុងសាលក្រម ពាក់ព័ន្ធក្រាំងតាចាន់ ដើម្បីជាការគាំទ្រ ដល់ការសម្រេចអំពី ការធ្វើទុក្ខបុកម្នេញទៅលើអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ នៅក្នុងស្រុកត្រាំកក់។

431. ទីមួយ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា មិនមានភស្តុតាងដែលមានតម្លៃ ដើម្បីគាំទ្រដល់ការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលថា មានការចេញបញ្ជាឱ្យស្រាវជ្រាវ និងរកចាប់ខ្លួនអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ នៅក្នុងស្រុកត្រាំកក់[1606]។ ម្ចាស់បណ្ដឹងសាទុក្ខមិនទទួលស្គាល់ ភាពជារួម កម្រិត និងគុណភាពនៃភស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែក

---

[1603] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៥៣, ៤០៥៦, ៤០៦០។

[1604] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៥៩-៤០៦១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៨៤។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[1605] មូលដ្ឋានទី ១០៦៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ* កថាខណ្ឌ ៧១៩-៧២៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៤០ (ភាសាអង់គ្លេស) ទំព័រ ៣៧ (ភាសាបារាំង) ទំព័រ ៥៦-៥៧ (ភាសាខ្មែរ)។

[1606] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧២១-៧២៣។

ទៅលើដើម្បីធ្វើការសម្រេចនេះ[1607]។ ការជំទាស់របស់គាត់ទៅលើការសម្រេចនេះ គឺមានត្រឹមតែពីរកថាខណ្ឌ នៅក្នុងសាលក្រម ទាក់ទងសាក្សីចំនួនពីររូបគឺ សេង សឿន និង រៀល សន និង ឯកសារសហសម័យរបស់ បក្សកុម្មុយនីស្តកម្ពុជា។

432. ទោះជាក្នុងករណីណាក៏ដោយ ចំពោះ សេង សឿន ម្ចាស់បណ្តឹងសាទុក្ខ បានវាយតម្លៃដោយខុសឆ្គង ទៅលើតម្លៃនៃភ័ស្តុតាងរបស់ភ័ស្តុតាងគាត់ ដោយលើកទឡ្ហីករណ៍ថា ភ័ស្តុតាងនេះស្ថិតក្រៅវិសាលភាពទីតាំងភូមិសាស្ត្រ នៃការជំនុំជម្រះ[1608]។ មានការកំណត់យ៉ាងច្បាស់ថា ភ័ស្តុតាងដែលស្ថិតក្រៅទីតាំងភូមិសាស្ត្រ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចត្រូវបានប្រើប្រាស់ដើម្បី (១) បញ្ជាក់បំភ្លឺទៅលើបរិបទ (២) កំណត់ដោយទាញយក ធាតុផ្សំនៃអំពើឧក្រិដ្ឋ ដែលកើតឡើងនៅក្នុងអំឡុងពេលជាក់ស្តែង និង (៣) បង្ហាញនូវទម្រង់យ៉ាងជាក់ច្បាស់នៃអំពើ[1609]។ ដូច្នេះភ័ស្តុតាងនៃបញ្ជាឱ្យស្រាវជ្រាវ ចាប់ខ្លួន និងសម្លាប់អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ដែលចេញទៅសមាជិកកងទ័ព នៅក្នុងស្រុកមួយក្នុងតំបន់១៣ គឺច្បាស់ជាមានការពាក់ព័ន្ធ និងមានតម្លៃជាភ័ស្តុតាង ក្នុងការជួយដល់ការបញ្ជាក់បំភ្លឺទៅលើបរិបទ និងធ្វើការកំណត់តាមការទាញសន្និដ្ឋានរួមជាមួយភ័ស្តុតាងដទៃទៀត អំពីការស្រាវជ្រាវនិងចាប់ខ្លួន អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរនៅក្នុងស្រុកត្រាំកក់។ ចំពោះ រៀល សន ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ដោយសារតែសាក្សីមិនអាចផ្តល់ កាលបរិច្ឆេទជាក់លាក់ នៃកិច្ចប្រជុំដែលមានការចេញបញ្ជា ឱ្យស្រាវជ្រាវរកអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ សក្ខីកម្មរបស់គាត់មិនមាន តម្លៃជាភ័ស្តុតាងនោះ [1610] គឺជាការមិនទទួលស្គាល់ថា មិនមែនជារឿងមិនសមហេតុផលនោះទេ ដែលសាក្សីមិនចាំកាលបរិច្ឆេទជាក់លាក់ នៅក្រោយរយៈពេល៤០ឆ្នាំមក។

433. ការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ដោយប្រើប្រាស់ទស្សនាវដ្តីទង់បដិវត្ត របស់បក្សកុម្មុយនីស្តកម្ពុជា (លេខចេញខែកញ្ញា តុលា ឆ្នាំ១៩៧៦) ដើម្បីគាំទ្រដល់សក្ខីកម្មរបស់ រៀល សន ក៏មិនមានខ្លឹមសារនោះដែរ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មិនបានពន្យល់អត្ថន័យនៃឃ្លា "ទំនាស់ស្លាប់រស់" ដូចដែលម្ចាស់បណ្តឹងសាទុក្ខ បាន

[1607] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៥, ១០៦២-១០៦៣, ១០៨០-១០៨១, ២៨១៣-២៨១៤, ២៦៤៣, ២៧៩០, ២៧៩៥-២៨០១, ២៨៤០-២៨៤១។

[1608] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២១។

[1609] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣។

[1610] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២២។

បញ្ជាក់ក្តី[1611] តែអត្ថន័យនៃឃ្លានេះ អាចទាញចេញដោយសមហេតុផល ពីបរិបទរបស់វា។ ដូចដែលបានប្រើប្រាស់ នៅក្នុងទស្សនាវដ្តី ឃ្លា "ទំនាស់ស្លាប់រស់" ត្រូវបានប្រើប្រាស់សម្រាប់រៀបរាប់ ភាពខុសគ្នារវាង "វណ្ណៈអធន" និងយោធានិងអ្នករដ្ឋការ ដែលមិនអាចកែប្រែដោយការអប់រំរៀនសូត្រ[1612]។ ឯកសារបក្សកុម្មុយនីស្តកម្ពុជា បានញែកដាច់ពីគ្នាយ៉ាងច្បាស់ រវាង "ទំនាស់ស្លាប់រស់" និង "ទំនាស់បន្ទាប់បន្សំ"[1613] ដែលទំនាស់បន្ទាប់បន្សំ គឺជា "ទំនាស់ដោយសារការយល់ច្រឡំ" ដែលចាំបាច់ត្រូវ "ដោះស្រាយតាមការអប់រំជាបន្តបន្ទាប់" ចំណែកទំនាស់ស្លាប់រស់គឺជា "ទំនាស់ប្រឆាំង" ដែលចាំបាច់ត្រូវដោះស្រាយដោយ "អនុវត្តផ្តាច់ការវណ្ណៈអធន លើពួកនេះ"[1614]។ ភ័ស្តុតាងនៃឥរិយាបទប្រឆាំង និងកាចសាហាវ ដែលបក្សកុម្មុយនីស្តកម្ពុជាអនុវត្ត ទៅលើជនទាំងឡាយណាដែលពួកគេ ចាត់ទុកថាមិនអាចកែប្រែបាន គឺមានភាពពាក់ព័ន្ធ និងមានតម្លៃជាភ័ស្តុតាងសម្រាប់អង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណា ក្នុងការផ្តល់នូវបរិបទ សម្រាប់សក្ខីកម្មរបស់ រៀល សន អំពីការបោសសម្អាត។ ទស្សនាវដ្តីទង់បដិវត្តលេខមុន និងលេខក្រោយៗ បានផ្តល់នូវបរិបទសម្រាប់អត្ថន័យនៃឃ្លា "ទំនាស់ស្លាប់រស់" ពាក់ព័ន្ធអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ គឺថាដោយសារតែអត្តសញ្ញាណរបស់ពួកគេ បុគ្គលទាំងឡាយណា ដែលមកពីក្រុមនេះ ចាំបាច់ត្រូវសម្លាប់[1615]។

---

[1611] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២៣។ *ផ្ទុយពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៦២។

[1612] ឯកសារ **E3/10** *ទង់បដិវត្ត* ចុះខែកញ្ញា-ខែតុលា ឆ្នាំ១៩៧៦ KH 00063094 ("នៅមូលដ្ឋាន គេទជាទំនាស់ដែលយើងចាប់បាន ភាគច្រើនច្រើនជាអ្នករដ្ឋការ ប៉ូលីស ទាហាន សិស្ស។ មកពីនាយទុន ម្ចាស់ដីវាមិនចេញមុខទេ។ វាជាមេគំនិតតែវាមិនចេញមុខទេ។ ពីកាលវាកាន់អំណាច ក៏វាមិនចេញមុខ។ វាចេញតែលុយ ឱ្យភ្នាក់ងាររដ្ឋការចេញមុខ")។

[1613] ឯកសារ **E3/10** *ទង់បដិវត្ត* ចុះខែកញ្ញា-ខែតុលា ឆ្នាំ១៩៧៦ KH 00063094។

[1614]ឯកសារ **E3/10** *ទង់បដិវត្ត* ចុះខែកញ្ញា-ខែតុលា ឆ្នាំ១៩៧៦ KH 00063095 (គូសបញ្ជាក់បន្ថែម)។

[1615] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៧ ជើងទំព័រ ១៣៤០២៖ ឯកសារ **E3/747** *ទង់បដិវត្ត* ចុះខែសីហា ឆ្នាំ១៩៧៨ KH 00064646 ("តែ ១ ខែប៉ុណ្ណោះ បក្សយើងរំដោះភូមិ-ឃុំ និងទូទាំងប្រទេស បានចំនួន ៧០-៧៥ ភាគរយ។ បើថែមពេលមួយខែទៀត ចលនាបដិវត្តន៍មុខជាបោសសម្អាតពួកអាក្បត់លន់ នល់ អស់រលីងគ្មានសល់") ជើងទំព័រ ១៣៤០៣៖ ឯកសារ **E3/5** *ទង់បដិវត្ត* ចុះខែសីហា ឆ្នាំ១៩៧៥ KH 00063334-00063336 ("ក៏ប៉ុន្តែ បក្សបានវិភាគថាសភាពការណ៍ខ្លាំង មានចក្រពត្តិអាមេរិក មានពួកអាធីរ ក៏ប៉ុន្តែកម្លាំងស្នូលរបស់វា គឺពួកអាក្បត់នៅកម្ពុជា គឺពួកអាណុល [...] សូម្បីតែខាងយោធាក៏ដោយ កាលណោះយើងនៅតិច ឯខ្មាំង វាមានជាង ៤ ម៉ឺននាក់ បើរួមទាំងកងរាជគំរូតផង វាមានជាង ៦ ម៉ឺននាក់។ នេះខាងកងទ័ព។ ឯកងស្ម័គ្រាណ និងជីវពល វាមានច្រើនម៉ឺន ច្រើនសែនទៀត។ ឯយើងវិញ ធំបំផុត គឺអនុសេនាធំ តែយើងវាយបោសតែប៉ុន្មានខែ ខ្មាំងត្រូវខ្ទេច")។ ចំពោះការប្រើប្រាស់ និងការបកស្រាយពាក្យ "ទំនាស់ស្លាប់រស់" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សូមមើលឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០៣ ("ទំនាស់ស្លាប់រស់"

434. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា មិនមានភស្តុតាងគ្រប់គ្រាន់ អំពីប្រតិបត្តិការសម្លាប់ ដែលចាប់ផ្តើមឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៧ នៅស្រុកត្រាំកក់[1616]។ ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខមិនបានគិតអំពី បណ្តុំនៃភស្តុតាងយ៉ាងច្រើនហូរហៀរ ដែលមានរួមសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងកំណត់ត្រាស្រុកត្រាំកក់ ដែលអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកទៅលើ ដើម្បីធ្វើការសម្រេចនេះ[1617]។ ម្ចាស់បណ្តឹងសាទុក្ខកម្រិតទឡ្ហីករណ៍របស់គាត់ តែត្រឹមការអះអាងដោយខុសឆ្គងដែលថា សក្ខីកម្មរបស់ ឃឹម បឿន និងរបាយការណ៍ដែលយកចេញ ពីឃុំជាងទង នៅក្នុងស្រុកត្រាំកក់ ដែលបានផ្តល់ភស្តុតាងផ្ទាល់ អំពីប្រតិបត្តិការសម្លាប់ គឺស្ថិតក្រៅវិសាលភាពភូមិសាស្ត្រ នៃសំណុំរឿង។ ដូចដែលបានរៀបរាប់លម្អិត នៅក្នុងចម្លើយតបចំពោះមូលដ្ឋានទី ៣៩ និងទី ៦៤ ឃុំទាំងអស់នៅក្នុងស្រុកត្រាំកក់ គឺស្ថិតនៅក្នុងបណ្តឹង នៃការស៊ើបអង្កេត និងការជំនុំជម្រះ ហើយជាលទ្ធផល ភស្តុតាងរបស់សាក្សី ឃឹម បឿន និងរបាយការណ៍ពីឃុំជាងទង គឺមានតម្លៃភស្តុតាងខ្ពស់ សម្រាប់ការសម្រេចថា សាក្សីបានទទួល "សេចក្តីណែនាំជាបន្តបន្ទាប់ពីថ្នាក់ស្រុក ឱ្យបោសសម្អាតទាហានឬអ្នករដ្ឋការ ដែលមានបណ្តាសក្តិ"[1618]។

435. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ភស្តុតាងដទៃទៀតដែលបានដកស្រង់ ដើម្បីគាំទ្រដល់ការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងកថាខណ្ឌ ១០៨០ មិនមានតម្លៃជាភស្តុតាងនោះ គឺគ្មានខ្លឹមសារឡើយ ដោយសារតែការអះអាងនេះ មិនបានគិតអំពីខ្លឹមសារនៃភស្តុតាង។ ជាឧទាហរណ៍ របាយការណ៍ពីឃុំពពេល ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ ដែលថា "គ្រួសារទាហានដែលត្រូវអង្គការកម្ទេច និងស្លាប់បាត់១០៦គ្រួសារ មានចំនួន ៣៩៣ នាក់ [...] គ្រួសារទាហានដែលនៅ មានចំនួន ២៣១ គ្រួសារ មានមនុស្សចំនួន ៨៩២ នាក់" បានផ្តល់នូវភស្តុតាងដែលគួរឱ្យទាក់ទាញដោយផ្ទាល់ អំពីប្រតិបត្តិការសម្លាប់មនុស្ស ដែលចាប់ផ្តើមនៅក្នុងខែ

---

រវាងកម្ពុជាប្រជាធិបតេយ្យ និងខ្មាំង "យួន") ៣៨២៩ (ភ្នាក់ងារ KGB CIA និងយួន និង "អាក្បត់លន់ នល់" គឺជា "សត្រូវស្លាប់រស់") ៣៨១៣ ("ទំនាស់បដិបក្ខស្លាប់រស់" ក៏នៅមានក្នុងសង្គមដែលមានសមាសភាព ប្រតិកិរិយា និងប្រឆាំងបដិវត្ត ដែលតាម សួង ស៊ីគឿន គឺជាខ្មាំងបដិវត្ត "បនក្បត់លន់ នល់" និងចក្រពត្តិអាមេរិក) ២១៧៤ (ភ្នាក់ងារ CIA, KGB និងយួនគឺជា "សត្រូវស្លាប់រស់") ៤២៦៩។

[1616] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២៤-៧២៥។

[1617] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៦៣, ១០៨១, ២៦៤៣, ១១៧៥, ១០៦២, ១០៨០, ២៨១៣, ២៨១៤, ២៧៩០, ២៧៩៥-២៨០១, ២៨៤០-៤១។

[1618] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៦៣ *ដកស្រង់* ឯកសារ **E1/296.1** ឃឹម បឿន ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ទំព័រ ៣៨-៣៩។

មេសា ឆ្នាំ១៩៧៧[1619]។ ទោះបីជាយ៉ាងនេះក្តី ឯកសារពីរផ្សេងទៀត ដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកលើ នៅក្នុងកថាខណ្ឌនោះ ដើម្បីគាំទ្រការសម្រេចដែលថា នៅអំឡុងខែមេសា ឬឧសភា ឆ្នាំ១៩៧៧ អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ត្រូវបានចាប់ខ្លួន និងមានផែនការចាប់ខ្លួន នៅក្នុងស្រុកត្រាំកក់[1620]។ សំខាន់ជាងនេះទៀតនោះ សម្រាប់ភ័ស្តុតាងនៃអំពើធ្វើទុក្ខបុកម្នេញដូចជាការចាប់ខ្លួននិងការសម្លាប់ អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ពីខែមេសា ឆ្នាំ១៩៧៧ នៅក្នុងស្រុកត្រាំកក់ ម្ចាស់បណ្តឹងសាទុក្ខមិនបានពិចារណាទាល់តែសោះទៅលើ ការសម្រេចនិងភ័ស្តុតាងគាំទ្រដទៃទៀត ដូចជាភ័ស្តុតាងពាក់ព័ន្ធក្រាំងតាចាន់ ជាមន្ទីរសន្តិសុខស្រុក ដែលអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរជាច្រើន ត្រូវបានសម្លាប់[1621]។ ភាពស៊ីចង្វាក់គ្នានៃភ័ស្តុតាង ពីសាក្សីក្រាំងតាចាន់ និងស្រុកត្រាំកក់ ឯកសារគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជាកម្រិតខ្ពស់ និងកំណត់ត្រាមូលដ្ឋាន របស់បក្សកុម្មុយនីស្តកម្ពុជា ទាំងនៅក្នុងនិងនៅក្រៅស្រុកត្រាំកក់ បានផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូង នូវមូលដ្ឋានដ៏រឹងមាំ ដើម្បីធ្វើការសម្រេចលើភ័ស្តុតាងនេះ។

436. ទីបី ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង បានយោងដោយខុសឆ្គងទៅរកផ្នែកមួយ នៅក្នុងសាលក្រមពាក់ព័ន្ធក្រាំងតាចាន់[1622]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ ដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដោយយោងទៅរកកថាខណ្ឌ ២៦៤៣ នៅក្នុងសាលក្រម ដើម្បីផ្តល់ការគាំទ្រដល់ការសម្រេច របស់អង្គជំនុំជម្រះថា អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ គឺជាគោលដៅនៃការចាប់ខ្លួន និងការសម្លាប់ ចាប់ពីខែមេសា និងខែឧសភា ឆ្នាំ១៩៧៧ នៅក្នុងកថាខណ្ឌ ២៨១៣ ជើងទំព័រ ៩៦២២។ កថាខណ្ឌ ២៦៤៣ បានផ្តល់នូវការយោងទៅរក ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ទាក់ទងអំពើមនុស្សឃាត នៅក្រាំងតាចាន់ ដែលផ្អែកពីការវិភាគលើភ័ស្តុតាង ដែលបានទទួលយកនៅក្នុងសវនាការ។ ទោះបីជាការនេះត្រឹមត្រូវក្តី តែម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា នៅក្នុងជើងទំព័រតែមួយនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងផងដែរទៅរក កថាខណ្ឌ ២៨៤០ និង

---

[1619] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨០ ជើងទំព័រ ៣៥៩៣ *ដកស្រង់* ឯកសារ **E3/2048** កំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ KH 00079090។

[1620] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨០ ជើងទំព័រ ៣៥៩០ (*ដកស្រង់* ឯកសារ **E3/4629** កំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ KH 00079087), ជើងទំព័រ ៣៥៩២ (*ដកស្រង់* ឯកសារ **E3/2050** កំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៧ KH 00079111)។

[1621] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៦៣, ១០៨១, ២៦៤៣, ១០៨០, ១១៧៥, ១០៦២, ២៨១៣, ២៨១៤, ២៧៩០, ២៧៩៥-២៨០១, ២៨៤០-៤១។

[1622] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២៦។

២៨៤១ ដែលកថាខណ្ឌទាំងពីរបានផ្តល់ នូវការសម្រេចលើអង្គហេតុ និងការគាំទ្រផ្នែកភ័ស្តុតាង សម្រាប់ប្រតិបត្តិការសម្លាប់ អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ នៅក្នុងខែមេសា និងខែឧសភា ឆ្នាំ១៩៧៧។

### *មូលដ្ឋានទី ១២០៖ ការប្រព្រឹត្តិទៅលើអតីតយោធា របបសាធារណរដ្ឋខ្មែរ* [1623]

437. **មូលដ្ឋានទី ១២០ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ក្នុងការសម្រេចលើ ធាតុផ្សំសត្យានុម័ត នៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ទៅលើអតីតយោធា របបសាធារណរដ្ឋខ្មែរ នៅទំនប់១មករា។**

438. ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ ដោយមិនមានមូលដ្ឋានថា គ្មានភ័ស្តុតាងណាមួយ ដែលបានដកស្រង់ដើម្បីគាំទ្រដល់ការសម្រេចនេះ ត្រូវបានកំណត់តាមបទដ្ឋានដែលបានតម្រូវ បើជា (១) ការចាប់ខ្លួនឪពុករបស់ ហ៊ុន សិត្ថានី[1624] (២) ការចាប់ខ្លួនក្រុមអតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ដោយផ្អែកទៅលើសក្ខីកម្មរបស់ អ៊ុត សេង[1625] ឬ (៣) ការអនុវត្តការកំណត់អត្តសញ្ញាណ អតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ[1626]។

439. មូលដ្ឋាននេះ ត្រូវច្រានចោលដោយសារមូលហេតុចំនួនបី។ ទីមួយ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបញ្ចូលនូវសក្ខីកម្មសំខាន់ៗចំនួនពីរ ពីតំបន់នៅជុំវិញទំនប់១មករា នៅក្នុងការវិភាគរបស់ខ្លួនទៅលើភ័ស្តុតាង។ អង្គជំនុំជម្រះសាលាដំបូង បានដកស្រង់សក្ខីកម្មរបស់ ប្រាក់ យុត ដែលថា គាត់

---

[1623] មូលដ្ឋានទី ១២០៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ការប្រព្រឹត្តិចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ* កថាខណ្ឌ ៧៩៨-៨០៣។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៤ (ភាសាអង់គ្លេស) ទំព័រ ៤០ (ភាសាបារាំង) ទំព័រ ៦៣ (ភាសាខ្មែរ)។

[1624] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០១ ជើងទំព័រ ១៤៣៦។ ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦២ ជើងទំព័រ ៥៦៥៥ *ដកស្រង់* ឯកសារ E1/306.1 ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ទំព័រ ១៣-១៤, ២៧-៣០។

[1625] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០២ ជើងទំព័រ ១៤៣៧។ ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩០ ជើងទំព័រ ៥៧៤៤ *យោងទៅ* កថាខណ្ឌ ១៦៦២-១៦៦៣។

[1626] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៩៩ ជើងទំព័រ ១៤៣៥។ ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩០ ជើងទំព័រ ៥៧៤៣ *យោងទៅ* កថាខណ្ឌ ១៦៦០, ១៦៦២-១៦៦៣។

និងលេខាស្រុកដទៃទៀត បានរៀបចំបញ្ជីឈ្មោះ អតីតទាហាន លន់ ន់[1627] និងសក្ខីកម្មរបស់ ឱ ហួ ដែលថា ក្នុងនាមជាមេភូមិព្រៃស្រងែ គឺមានការអនុវត្តការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួន អតីតអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ[1628]។

440. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខ បានអនុវត្តម្តងទៀតវិធីសាស្ត្រមួយផ្នែកៗរបស់ខ្លួនទៅលើភ័ស្តុតាង នៅក្នុងការជំទាស់របស់គាត់ ចំពោះតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់ ហ៊ុន សិត្ថានី និង អ៊ុត សេង គឺមិនធ្វើការវាយតម្លៃជារួមតាមការតម្រូវឡើយ។ ម្ចាស់បណ្តឹងសាទុក្ខ បានជំទាស់ដោយបរាជ័យទៅលើសក្ខីកម្មរបស់ ហ៊ុន សិត្ថានី ដោយផ្អែកលើមូលដ្ឋានថា គឺបងប្អូនរបស់គាត់ទេ ដែលបានឃើញផ្ទាល់ការចាប់ខ្លួន ឪពុករបស់ពួកគាត់[1629] ហើយជំទាស់លើសក្ខីកម្មរបស់ អ៊ុត សេង ដោយផ្អែកលើមូលដ្ឋានថា អ៊ុត សេង មិនបានដឹងថាតើ កម្មករដែលបាត់ខ្លួន ត្រូវបានគេសម្លាប់ដែរឬយ៉ាងណា ដោយគាត់បានត្រឹមតែស្តាប់ឮ ពួកកងឈ្លបបានអះអាងថា បានទម្លាក់កម្មករដែលបាត់ខ្លួន ចូលទៅក្នុងអណ្តូង[1630]។ ទោះជាយ៉ាងណាក្តី មានការកំណត់យ៉ាងច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងអាចពឹងផ្អែកទៅលើ សូម្បីត្រឹមភ័ស្តុតាងជាពាក្យចចាមអារាម ដែលមិនមានអ្វីគាំទ្រ ប្រសិនបើអង្គជំនុំជម្រះពឹងផ្អែក ដោយមានការប្រុងប្រយ័ត្ន[1631]។ វិធីសាស្ត្របែបប្រុងប្រយ័ត្នរបស់ អង្គជំនុំជម្រះសាលាដំបូង ត្រូវបានមើលឃើញ នៅពេលឈានដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន បន្ទាប់ពីបានពិចារណាទៅលើសក្ខីកម្មរបស់ ហ៊ុន សិត្ថានី និង អ៊ុត សេង មិនមែនដាច់ដោយឡែក តែពិចារណារួមជាមួយសក្ខីកម្មរបស់ ប្រាក់ យុត, យូ វ៉ាន និង ឱ ហួ[1632]។

441. អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាសក្ខីកម្មរបស់ អ៊ុត សេង "ស្របគ្នាជាមួយនឹងការអនុវត្តជាទូទៅ របស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់អត្តសញ្ញាណ" អតីតយោធានិងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ[1633]។ ក្នុងការពិចារណាទៅលើការអនុវត្តនេះ នៅក្នុងតំបន់ជុំវិញទំនប់

[1627] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦១។ ឯកសារ **E1/378.1** ប្រតិចារឹក ប្រាក់ យុត ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ទំព័រ ២៥-២៨។

[1628] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦០។ ឯកសារ **E1/301.1** ប្រតិចារឹក ឱ ហួ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ទំព័រ ១៣-១៤, ១៤-១៦។

[1629] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០១។

[1630] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០៣។

[1631] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០២។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[1632] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦១។

[1633] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦៣។

១មករា[1634] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ពី សក្ខីកម្មរបស់ ឱ ហួ ដែលជាមេភូមិនៅតំបន់៤២ ហើយដែលបន្ទាប់មកជាប្រធានកងពលកម្ម ដែលបានផ្ដល់សក្ខីកម្មថា ប្រសិនបើរកឃើញអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ នៅក្នុងឃុំ អ្នកទាំងនោះនឹងត្រូវចាប់ខ្លួនយកទៅមន្ទីរសន្តិសុខ ហើយក្រុមគ្រួសារអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរទាំងនោះ ដែលរស់នៅក្នុងភូមិគាត់ ក៏ត្រូវបានកំណត់អត្តសញ្ញាណ ដើម្បីចាប់ខ្លួនផងដែរ[1635]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានកត់សម្គាល់ពីសក្ខីកម្មរបស់ ប្រាក់ យុត ដែលអះអាងពីការអនុវត្ត ការកំណត់គោលដៅនេះ នៅក្នុងតំបន់៤១ ក្បែខាងនោះ ដែលគាត់និងលេខាស្រុកដទៃទៀត បានរៀបចំបញ្ជីឈ្មោះអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ សម្រាប់យកទៅរៀនសូត្រ និងបញ្ជូនបន្តទៅលេខាតំបន់ ប្រសិនបើពួកគេមិនអាចអប់រំបាន[1636]។ យូ វ៉ាន់ ដែលជាអ្នកក្រោមបង្គាប់ ប្រាក់ យុត បានផ្ដល់សក្ខីកម្មអំពីសេចក្ដីណែនាំជាក់លាក់របស់ ប្រាក់ យុត ដោយគាត់បានផ្ដល់សក្ខីកម្មថា ប្រាក់ យុត បានបញ្ជាគាត់ ឱ្យរៀបចំបញ្ជីឈ្មោះអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ព្រមទាំងជនជាតិចាម និងជនជាតិវៀតណាម ហើយអ្នកដែលមានឈ្មោះនៅក្នុងបញ្ជី ត្រូវ "បោសសម្អាត"[1637]។ បន្ថែមលើនេះ ភ័ស្តុតាងរបស់ ហ៊ុន សិត្ថានី ដែលថាកម្មករនៅទំនប់១មករា រួមមានកម្មករមកពីតំបន់៤១ និងតំបន់៤២ ដែលភ័ស្តុតាងនៃការកំណត់គោលដៅទៅលើអតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ មានយ៉ាងច្បាស់លាស់នោះ បានគាំទ្រដល់ការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង លើការអនុវត្តគោលនយោបាយ កំណត់គោលដៅនៅទំនប់១មករា[1638]។

442. ប្រតិចារឹកនៃសក្ខីកម្មរបស់ ហ៊ុន សិត្ថានី បង្ហាញផ្ទុយពីការអះអាងរបស់ ម្ចាស់បណ្ដឹងសាទុក្ខដែលថា "គ្មានភ័ស្តុតាងក្នុងកម្រិតតម្រូវ អំពី ការចាប់ខ្លួន/បាត់ខ្លួន ឪពុករបស់ ហ៊ុន សិត្ថានី"។ គ្មានការជំទាស់ ដោយម្ចាស់បណ្ដឹងសាទុក្ខ តាមរយៈការសួរដេញដោល របស់មេធាវីការពារក្ដីគាត់ ហ៊ុន សិត្ថានីបានផ្ដល់ភ័ស្តុតាង ដែលច្បាស់លាស់ និងគួរឱ្យជឿជាក់ថា៖ ឪពុករបស់គាត់គឺជានាយក

[1634] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦០។

[1635] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦០។

[1636] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦១។

[1637] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៦១។

[1638] ឯកសារ **E1/306.1** ប្រតិចារឹក ហ៊ុន សិត្ថានី ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១០.០៣.៤២-១០.០៦.១៧ ទំព័រ ១៨ បន្ទាត់ ១០-១៣។

សាលានៅក្នុងរបបលន់ នល់[1639] គាត់ជាកម្មករដែលប្រឹងប្រែងធ្វើការ មិនខ្ជិលច្រអូសនៅទំនប់ ១មករា[1640] គាត់បានរំឭក "យ៉ាងច្បាស់" បងស្រីរបស់គាត់បានប្រាប់គាត់ថា បានឃើញឪពុករបស់គាត់ ត្រូវបានពួកខ្មែរក្រហមយកទៅ នៅថ្ងៃទី៥ ខែមេសា[1641] ហើយចាប់ពីពេលដែលបងស្រីបានប្រាប់គាត់មក គាត់ (ហ៊ុន សិត្ថានី) មានការព្រួយបារម្ភ[1642] បងប្អូនគាត់បានប្រាប់គាត់ថា ឪពុកគាត់ត្រូវបានគេយកទៅសម្លាប់ នៅវត្តបារាយជាន់ដែក[1643] ហើយបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានទៅវត្តនោះ ហើយរកឃើញបំណែកអដ្ឋិធាតុ រួមទាំងលលាដ៍ក្បាល នៅតាមរណ្ដៅនិងផ្នូរ[1644]។ ជាលទ្ធផល ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា ជាការមិនសមហេតុផលដែល អង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកទៅលើការសម្លាប់ និងការបាត់ខ្លួនឪពុករបស់ ហ៊ុន សិត្ថានី រួមជាមួយភ័ស្តុតាងដទៃផ្សេងទៀត នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងការសម្រេចថា គោលនយោបាយកំណត់គោលដៅ អតីតយោធានិងអ្នករដ្ឋការ របបសាធារណរដ្ឋខ្មែរ ត្រូវបានអនុវត្តនៅទំនប់១មករា។

443. ទីបី ម្ចាស់បណ្ដឹងសាទុក្ខបានបញ្ជាក់ដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដែលពឹងផ្អែកទៅលើ គោលនយោបាយទូទៅ នៃការរើសអើងប្រឆាំង អតីតយោធានិងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ដើម្បីកំណត់ពីការរើសអើងបែបនេះ នៅទំនប់១មករា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង មិនអាចកំណត់អំពីការរើសអើងបែបនេះ ផ្អែកលើភ័ស្តុតាងដែលទាក់ទងដោយផ្ទាល់ ទៅនឹងទំនប់១មករា[1645]។ ដូចបានកំណត់ពីខាងលើរួចហើយថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយត្រឹមត្រូវទៅលើ សក្ខីកម្មចំនួនបួន ដែលទាក់ទងផ្ទាល់ជាមួយទំនប់១មករា

---

[1639] ឯកសារ **E1/306.1** ប្រតិចារឹក ហ៊ុន សិត្ថានី ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១០.៥៩.២០-១១.០១.៣៣ ទំព័រ ២៦ បន្ទាត់ ២-៣។

[1640] ឯកសារ **E1/306.1** ប្រតិចារឹកហ៊ុន សិត្ថានី ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១០.៥៦.00-១០.៥៩.២០ ទំព័រ ២៥ បន្ទាត់ ៧-១២។

[1641] ឯកសារ **E1/306.1** ប្រតិចារឹកហ៊ុន សិត្ថានី ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង ០៩.៥០.១២-០៩.៥២.៤២ ទំព័រ ១៤ បន្ទាត់ ១-៣។

[1642] ឯកសារ **E1/306.1** ប្រតិចារឹកហ៊ុន សិត្ថានី ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១០.៥០.៥៧-១០.៥៦.00 ទំព័រ ២៤ បន្ទាត់ ២១-២៣។

[1643] ឯកសារ **E1/306.1** ប្រតិចារឹកហ៊ុន សិត្ថានី ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១០.៥០.៥៧-១០.៥៦.00 ទំព័រ ២៤ បន្ទាត់ ១៨-១៩។

[1644] ឯកសារ **E1/306.1** ប្រតិចារឹក ហ៊ុន សិត្ថានី ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១០.៥៦.00-១០.៥៩.២០ ទំព័រ ២៥ បន្ទាត់ ១៣-១៦។

[1645] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៩៩។

ដែលកំណត់ពីការរើសអើងទៅលើ អតីតយោធារបបសាធារណរដ្ឋខ្មែរនោះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវ អំពីការប្រព្រឹត្តិទៅលើ អតីតយោធារបបសាធារណរដ្ឋខ្មែរ នៅទំនប់១មករា ជាផ្នែកនៃគោលនយោបាយទូទៅ ប្រឆាំងអតីតយោធា របបសាធារណរដ្ឋខ្មែរ ដោយបញ្ជាក់បំភ្លឺទៅលើបរិបទនៃព្រឹត្តិការណ៍ នៅទំនប់១មករា[1646]។

## ៣. ជនជាតិចាម

444. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ និងសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការជម្លៀសដោយបង្ខំ ត្រូវបានប្រព្រឹត្តឡើងលើជនជាតិចាម[1647] អនុលោមទៅតាមគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅលើជនជាតិចាម សម្រាប់ការធ្វើបាប ដោយផ្អែកលើអត្តសញ្ញាណរបស់ពួកគេ ដែលមានជាប់ទាក់ទងផ្ទៃក្នុងទៅនឹងគោលបំណងរួម[1648]។

445. មូលដ្ឋានទាំង១៩ របស់ម្ចាស់បណ្តឹងសាទុក្ខ[1649] ពាក់ព័ន្ធឧក្រិដ្ឋកម្មនេះ គួរត្រូវបានច្រានចោល ដោយសារតែបានប្រើប្រាស់វិធីសាស្ត្រមួយផ្នែកៗ ជាច្រើន ហើយដោយខុសឆ្គង ចំពោះភ័ស្តុតាង និងសាលក្រម គ្រាន់តែដើម្បីជំទាស់ជាមួយការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ឬបានយល់ច្រឡំទៅលើច្បាប់ពាក់ព័ន្ធនានា។ ជាពិសេសនោះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខផ្តោតតែទៅលើអំពើឧក្រិដ្ឋជាក់លាក់ ដែលបានប្រព្រឹត្តទៅលើជនជាតិចាម ដាច់ដោយឡែកតែឯង គឺមិនបានពិចារណាទៅលើភាពរួមគ្នា នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ទៅលើជនជាតិចាមនៅទូទាំងប្រទេស និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។ ម្ចាស់បណ្តឹងសាទុក្ខ ក៏បានយល់ច្រឡំ

---

[1646] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០ ជើងទំព័រ ១៥១។

[1647] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣១៤-៣៣១៦, ៣៣៤៣-៣៣៤៨។ ម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់ ចំពោះការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានធ្វើឡើងចំពោះជនជាតិចាម។

[1648] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២២៧-៣២២៨, ៣៩៩៨។ សូមមើលចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៦។

[1649] មូលដ្ឋានទី ៥, ១២១-១២២, ១៣៦-១៤៩, ១៥០, ១៨៦។

និងអនុវត្តដោយខុសឆ្គងសារជាថ្មី ទៅលើច្បាប់ស្តីពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ[1650]។

## *មូលដ្ឋានទី ១៨៦៖ គោលនយោបាយចំពោះជនជាតិចាម*[1651]

446. **មូលដ្ឋានទី ១៨៦ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងលើអង្គហេតុនិងអង្គច្បាប់ ដោយការសម្រេចថា មានគោលនយោបាយឧក្រិដ្ឋរបស់ បក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅលើជនជាតិចាម ហើយនេះគឺជាផ្នែកនៃគោលបំណងរួម។**

447. មូលដ្ឋាននេះគួរច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការ (១) សម្រេចថា មានអត្ថិភាពគោលនយោបាយ កំណត់គោលដៅទៅលើជនជាតិចាម បើទោះបីជា “គ្មាន” ឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលចែងបែបនេះក្តី (២) ដោយផ្តើមចេញពីការកើតឡើងនូវឧក្រិដ្ឋកម្មដើម្បីប៉ុនប៉ងផ្តល់យុត្តិកម្មដល់ទ្រឹស្តីរបស់ខ្លួន ដោយបំភ្លៃភ័ស្តុតាង (៣) លាក់បាំងដោយមិនត្រឹមត្រូវ នូវសក្ខីកម្មរបស់សាក្សីជាច្រើន និងមិនអើពើនឹងចម្លើយ របស់អ្នកជំនាញ និង (៤) សម្រេចដោយមិនសមហេតុផលថា តាមពិតទៅជនជាតិចាមគឺជាគោលដៅ។

448. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយគ្មានមូលដ្ឋានថា “គ្មាន” ឯកសារផ្លូវការណាមួយរបស់ បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងគោលនយោបាយ ប្រឆាំងជនជាតិចាម[1652] និងសារមាន “ភាពវិជ្ជមាន” ចំពោះជនជាតិចាម នៅក្នុងឯកសាររបស់ បក្សកុម្មុយនីស្តកម្ពុជា រួមទាំងរដ្ឋធម្មនុញ្ញរបស់ កម្ពុជាប្រជាធិបតេយ្យ[1653] មានន័យថា ការសម្រេចដោយសមហេតុផលតែមួយគត់គឺ មិនមានគោលនយោបាយ កំណត់គោលដៅលើជនជាតិចាម[1654]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ មិនត្រឹមតែនាំឱ្យយល់ខុសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនបានគិតពិចារណា ទៅលើ

---

[1650] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹងមូលដ្ឋានទី ១២២, ១៤១, ១៤៦, ១៤៧។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

[1651] <u>មូលដ្ឋានទី ១៨៦៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គោលនយោបាយចំពោះជនជាតិចាម* កថាខណ្ឌ ១៥៦១-១៥៧៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៤ (ភាសាអង់គ្លេស) ទំព័រ ៥៩ (ភាសាបារាំង) ទំព័រ ៩១-៩២ (ភាសាខ្មែរ)។

[1652] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦៦-១៥៧១។

[1653] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦៦-១៥៦៨។

[1654] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦៩។

ភាពរួមនៃភ័ស្តុតាង ដែលបង្ហាញពីអត្ថិភាព នៃគោលនយោបាយកំណត់គោលដៅ ទៅលើជនជាតិចាម។

449. ទោះបីជាឯកសារសាធារណៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលយោងទៅជនជាតិចាម ហាក់ដូចជាលែងឃើញមាន នៅក្នុងខែតុលា ឆ្នាំ១៩៧៥ ក្តី[1655] អង្គជំនុំជម្រះសាលាដំបូង បានពិចារណាទៅលើឯកសារផ្ទៃក្នុងក្រោយៗមក ដែលបង្ហាញឱ្យឃើញពីគោលនយោបាយ កំណត់គោលដៅទៅលើជនជាតិចាម។ ជាពិសេស ឯកសារទាំងនោះរួមមាន សារទូរលេខពី សោ ភឹម លេខាភូមិភាគបូព៌ា រាយការណ៍ជូន ប៉ុល ពត អំពីការជម្លៀសជនជាតិចាម[1656]។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយសមហេតុផលថា ទូរលេខចំនួន១៥ បានកំណត់ថា បក្សកុម្មុយនីស្តកម្ពុជា កំណត់គោលដៅយ៉ាងជាក់ច្បាស់ ទៅលើប្រជាជនចាម នៅក្នុងភូមិភាគបូព៌ា និងបង្ហាញអំពីគោលនយោបាយ កំណត់គោលដៅលើជនជាតិចាម ដែលបង្កើតឡើងដោយមជ្ឈិមបក្ស[1657]។ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាបន្ថែមទៀត ទៅលើឯកសារសហសម័យ ដែលមានដូចជាទូរលេខ[1658] កំណត់ហេតុកិច្ចប្រជុំ[1659] និងរបាយការណ៍[1660] ដែលបង្ហាញថា ជនជាតិចាម "ស្ថិតក្រោមការតាមដានយ៉ាងតឹងរ៉ឹង"[1661]។

450. អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាផងដែរទៅលើ ការផ្សព្វផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលទោះបីជាមិនបានបង្ហាញ អំពីជនជាតិចាមជាក់លាក់ក្តី តែបានផ្តល់នូវបរិបទ និងទិដ្ឋភាពយ៉ាងសំខាន់ ទៅលើគោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះក្រុមជនជាតិភាគតិចដូចជាជនជាតិចាមជាដើម។ ជាឧទាហរណ៍ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងយ៉ាងច្បាស់ថា "មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញ កម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាដាច់ខាត"[1662]៕ដោយសង្កត់ធ្ងន់ថា សាសនាបំផ្លិចបំផ្លាញ "ប្រជាជនកម្ពុជា"

---

[1655] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២០៩។

[1656] ឯកសារ **E3/1680** ទូរលេខ១៥ពីសោ ភឹម ផ្ញើរជូនប៉ុល ពត ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ("ទូរលេខ១៥")។

[1657] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១២-៣២១៣។

[1658] ឯកសារ **E3/511** ទូរលេខ៩៤ ថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦។

[1659] ឯកសារ **E3/800** កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ្យ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00064954។

[1660] ឯកសារ **E3/178** សេចក្តីរាយការណ៍របស់ គណៈកម្មាធិការតំបន់៥ ប្រចាំអាទិត្យ ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៧ KH 00275587។

[1661] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៤។

[1662] ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ មាត្រា ២០ KH 00089850។

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញដានចំពោះជនជាតិចាម ទាំងសាសនា ទាំងមិនមែនជាជនជាតិខ្មែរ។ តម្រូវការក្នុងការរក្សា "ជនជាតិកម្ពុជា" ត្រូវបានគូសបញ្ជាក់បន្ថែមទៀត នៅក្នុងឯកសារផ្សេងៗ ដូចជាកំណត់ត្រាសេចក្តីថ្លែងការណ៍ របស់ម្ចាស់បណ្តឹងសាទុក្ខផងដែរ[1663]។

451. ភាពរួមនៃភស្តុតាង មិនត្រឹមតែបង្ហាញយ៉ាងច្បាស់នូវបរិបទមួយដែលថា ជាការមិនអាចជៀសផុតបាន ដែលជនជាតិចាមត្រូវបានកំណត់ជាគោលដៅ ដោយបក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគូសបញ្ជាក់អំពីលក្ខណៈបំភាន់ នៃការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អត្តសញ្ញាណរបស់ជនជាតិចាម "មិនចោទជាបញ្ហាដល់ ប.ក.ក ទេ" និងថាសាររបស់បក្សកុម្មុយនីស្តកម្ពុជាមាន "ភាពវិជ្ជមាន"[1664]។ ជាការមិនសមហេតុផលដែលលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកជនជាតិចាមក្នុងផ្លូវវិជ្ជមាន ដោយផ្អែកលើអវិភាពរបស់ បក្សកុម្មុយនីស្តកម្ពុជាចំពោះលក្ខណៈពិសេសពីរ របស់អត្តសញ្ញាណចាម គឺសាសនារបស់ពួកគេ និងភាពមិនមែនជាជនជាតិខ្មែរ។ តាមពិតទៅ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយសមហេតុផល ក្រោយពេលវាយតម្លៃទៅលើភស្តុតាងជារួមថា សារវិជ្ជមានជាសាធារណៈ របស់បក្សកុម្មុយនីស្តកម្ពុជា និងការការពារសាសនានៅក្នុង រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ គឺ "មិនស្មោះត្រង់" ហើយមិនមានតម្លៃជាភស្តុតាងសោះឡើយ ទាក់ទងគោលនយោបាយលើជនជាតិចាម[1665]។

452. បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់យុត្តិកម្មលើមូលហេតុអ្វីទើបអង្គជំនុំជម្រះសាលាដំបូង មិនអាចពឹងផ្អែកទៅលើភស្តុតាង នៅក្នុងសវនាការ ដើម្បីធ្វើការសម្រេចលើគោលនយោបាយ។ ច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិធ្វើការសម្រេច ផ្អែកលើភស្តុតាងក្នុងសវនាការ បើទោះបីជាគ្មានឯកសារសហសម័យក្តី[1666]។ បន្ថែមពីលើភស្តុតាងជាឯកសារ ដែលបានពិភាក្សាពីខាងលើហើយ អង្គជំនុំជម្រះសាលាដំបូង បានយោងទៅរកសក្ខីកម្មនៅក្នុងពេលសវនាការ របស់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន១០រូប រួមទាំងអតីតកម្មាភិបាល, កំណត់ហេតុស្តាប់ចម្លើយសាក្សី និងអ្នកជំនាញ ពីរបន្ថែមទៀត[1667]។ អង្គជំនុំជម្រះសាលាដំបូង បាន

[1663] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៦។

[1664] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦៦-១៥៦៨។

[1665] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២២៧។

[1666] *សូមមើលឧទាហរណ៍ សាលក្រមរឿងក្តី* Đorđević កថាខណ្ឌ ២០៧៨ (សម្រេចថាការរឹបអូសឯកសារ បង្កើតបានជាគោលនយោបាយជាប្រព័ន្ធ និងមានទ្រង់ទ្រាយធំ បើទោះបីជាគ្មានបទបញ្ជាជាលាយលក្ខណ៍អក្សរក្តី) ដោយសម្រេចអនុញ្ញាតតាមបណ្តឹងសាទុក្ខ នៅក្នុង *សាលដីការឿងក្តី* Đorđević កថាខណ្ឌ ១៥៦។

[1667] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៧-៣២១៩។

សម្រេចដោយសមហេតុផលថា ភ័ស្តុតាងនេះបង្ហាញថា "បក្សកុម្មុយនីស្តកម្ពុជា បានកំណត់គោលដៅជាពិសេស ទៅលើប្រជាជនចាម [...] នៅក្នុងកម្មវិធីមួយដែលរំពឹងថា នឹងដាក់បញ្ចូលប្រជាជនចាម ទៅក្នុងជាតិនិងអត្តសញ្ញាណខ្មែរតែមួយ"[1668]។ ក្រៅពីការចោទប្រកាន់ដោយគ្មានមូលដ្ឋាន ពាក់ព័ន្ធភ័ស្តុតាងរបស់ ឌុច, ម៉ាត់ លី និងសាក្សីអ្នកជំនាញ ដែលនឹងពិភាក្សានៅផ្នែកខាងក្រោម ក្នុងចម្លើយតបនេះ ម្ចាស់បណ្តឹងសាទុក្ខ មិនបានលើកយកបញ្ហាណាមួយ ទាក់ទងភ័ស្តុតាងក្នុងសវនាការ ដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅរក នៅក្នុងសេចក្តីសង្ខេបរបស់ខ្លួន លើភ័ស្តុតាងនៃគោលនយោបាយ កំណត់គោលដៅលើជនជាតិចាម។ ហេតុដូច្នេះម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា បន្ទាប់ពីបានវាយតម្លៃជារួមទៅលើភ័ស្តុតាង ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីអត្ថិភាពនៃគោលនយោបាយ កំណត់គោលដៅលើជនជាតិចាម គឺមិនសមហេតុផល។

453. បន្ទាប់មកម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង "ប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយផ្តើមចេញពីការកើតឡើងនូវឧក្រិដ្ឋកម្ម ដើម្បីប៉ុនប៉ងផ្តល់យុត្តិកម្ម ដល់ទ្រឹស្តីរបស់ខ្លួន ដោយបំភ្លៃភ័ស្តុតាង"[1669]។ ម្ចាស់បណ្តឹងសាទុក្ខយោងទៅការសម្រេចដែលថា ការប្រព្រឹត្តទៅលើជនជាតិចាម បង្ហាញពីគោលដៅរបស់ បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបង្កើតសង្គមមួយ ដែលមិនមានសាសនា រួបរួមគ្នាដោយមិនមានការបែងចែកវណ្ណៈ[1670] ដោយមិនគិតដល់បរិបទ ដែលត្រូវអនុវត្តឡើយ។ អង្គជំនុំជម្រះសាលាដំបូង មិនបានធ្វើការសម្រេចនេះ ដើម្បីកំណត់ពីអត្ថិភាព នៃគោលនយោបាយកំណត់គោលដៅ ទៅលើជនជាតិចាមឡើយ អង្គជំនុំជម្រះសាលាដំបូងសម្រេច ដើម្បីកំណត់ថា គោលនយោបាយកំណត់គោលដៅមានពាក់ព័ន្ធការប្រព្រឹត្តបទឧក្រិដ្ឋ ដែលត្រូវស្ថិតនៅក្នុងសហឧក្រិដ្ឋកម្មរួម[1671]។ ទោះជាក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា សេចក្តីសម្រេចគឺមិនសមហេតុផល។ គាត់

[1668] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៧។

[1669] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦៩-១៥៧១។

[1670] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧០ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៩៣។

[1671] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៩១-៣៩៩៣។ ភាពសមហេតុផលនៃការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ចំពោះឧក្រិដ្ឋកម្ម ត្រូវបានពិភាក្សានៅក្នុង ចម្លើយតបទៅនឹងមូលដ្ឋានទី ១២១-១២២, ១៣៦-១៣៧, ១៣៩-១៤៩។

គ្រាន់តែអះអាងថា "ខុសឆ្គងដោយសារតែគ្មានភស្តុតាងបង្ហាញ អំពីគោលនយោបាយ" និង "ផ្ទុយនឹងការពិតនៃអង្គហេតុ"[1672]។

454. ជាការគួរឱ្យកត់សម្គាល់ ម្ចាស់បណ្តឹងសាទុក្ខ មិនបានលើកឡើងអំពី កំហុសអង្គច្បាប់ណាមួយឡើយ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មិនបានពឹងផ្អែកទៅលើ ការកើតឡើងនូវឧក្រិដ្ឋកម្ម ដើម្បីសម្រេចអំពីអត្ថិភាពនៃគោលនយោបាយក្តី តែអង្គជំនុំជម្រះសាលាដំបូង មិនមានកំហុសឆ្គងឡើយ នៅក្នុងការអនុវត្តបែបនេះ។ តុលាការអន្តរជាតិបានសម្រេចថា ឧក្រិដ្ឋកម្មអាចបង្ហាញឱ្យឃើញ នូវគោលនយោបាយមួយ នៅពេលដែលឧក្រិដ្ឋកម្មនោះ មានលក្ខណៈជាប្រព័ន្ធ ឬបង្ហាញពីទម្រង់ នៃវិធីសាស្ត្រ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[1673]។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចម្តងហើយម្តងទៀតថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងជាប្រព័ន្ធ ប្រឆាំងជនជាតិចាម[1674] ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូង អាចទាញសន្និដ្ឋានដោយសមហេតុផល នូវគោលនយោបាយដោយផ្អែកលើមូលដ្ឋាននេះ។

455. ចំពោះការចោទប្រកាន់ "បំភ្លៃភស្តុតាង" ម្ចាស់បណ្តឹងសាទុក្ខ បានដកស្រង់កថាខណ្ឌ៣២០៧, ៣២១១ និង៣២១៦ នៃសាលក្រម ដោយអះអាងថា "បំប្លែងសម្តីរបស់លោក ខៀវ សំផន ដែលមិនពាក់ព័ន្ធនឹងជនជាតិចាមទាល់តែសោះ"[1675]។ ការនេះមិនពិតនោះទេ។ កថាខណ្ឌ ៣២០៧ និង ៣២១១ មិនបានយោងទៅរក "មតិ" របស់ម្ចាស់បណ្តឹងសាទុក្ខ ជាភស្តុតាងឡើយ ប៉ុន្តែយោងទៅរកផ្នែកនៃ សារណាបញ្ចប់ការពិភាក្សាដេញដោល របស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងជនជាតិចាម[1676]។ កថាខណ្ឌ ៣២១៦ បានដកស្រង់សុន្ទរកថា ដែលថ្លែងដោយម្ចាស់បណ្តឹងសាទុក្ខ ដែល

---

[1672] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧១។

[1673] *សូមមើលឧទាហរណ៍ សាលក្រមរឿងក្តី Brima* កថាខណ្ឌ ២៣១ ("ទំរង់នៃឧក្រិដ្ឋកម្មបង្ហាញឱ្យឃើញពីគោលនយោបាយ")។ ស្ថានភាពស្តីពីសិទ្ធិអំណាចក្នុងការស៊ើបអង្កេត របស់អង្គបុរេជំនុំជម្រះនៃសាធារណៈកូឌីវ័រ កថាខណ្ឌ ១០០ ("កងកម្លាំងគាំទ្រ បានធ្វើសកម្មភាព អនុលោមទៅតាមគោលនយោបាយ [...] ដូចបានបង្ហាញតាមរយៈទម្រង់ជាទូទៅ នៃឧក្រិដ្ឋកម្មដែលក្រុមជាតិពិន្ទុជាក់លាក់មួយ ត្រូវបានកំណត់គោលដៅ [...]។ អង្គជំនុំជម្រះសម្រេចថា លក្ខណៈជាប្រព័ន្ធដែលការវាយប្រហារនេះ ត្រូវបានអនុវត្តឡើង បានបង្ហាញយ៉ាងរឹងមាំ អំពីអត្ថិភាពនៃគោលនយោបាយ ដែលមានការរៀបចំឡើង") (គូសបញ្ជាក់បន្ថែម))។

[1674] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០៨ (អំពើមនុស្សឃាត) ៣៣១៦ (ការដាក់ក្នុងមន្ទីរឃុំឃាំង) ៣៣៣៩ (ការផ្លាស់ទីដោយបង្ខំ)។

[1675] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦៩ ជើងទំព័រ ២៩៩៥។

[1676] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២០៧, ៣២១១ យោងជាពិសេសទៅរកផ្នែកដែលមានចំណងជើងថា "គ្មានឯកសារផ្លូវការស្តីពី គោលនយោបាយជាតិប្រឆាំងនឹងជនជាតិចាម" "ការចោទប្រកាន់ពីគោលនយោបាយ

ក្នុងនោះគាត់បានអំពាវនាវ ឱ្យថែរក្សា "ជាតិសាសន៍កម្ពុជា"។ ពាក្យសម្តីរបស់គាត់មិនត្រូវបាន "បំភ្លៃ" ទេ។ ទោះបីជាគាត់មិនបានលើកឡើងដោយច្បាស់លាស់ អំពីជនជាតិចាម នៅក្នុងសុន្ទរកថានោះក្តី តែច្បាស់ណាស់ថាការថ្លែងនេះ ពាក់ព័ន្ធជាមួយគោលជំហរ របស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះប្រជាជនដែលមិនមែនជាខ្មែរ។

456. ទីបី ម្ចាស់បណ្តឹងសាទុក្ខ បានចោទប្រកាន់ដោយគ្មានមូលដ្ឋាន ដល់អង្គជំនុំជម្រះសាលាដំបូង ថាលាក់បាំងសក្ខីកម្មរបស់សាក្សី[1677] ជាពិសេសភ័ស្តុតាងរបស់ ឌុច និង ម៉ាត់ លី។ ម្ចាស់បណ្តឹងសាទុក្ខ បានចោទប្រកាន់ដោយខុសបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាទៅលើសក្ខីកម្ម របស់អ្នកជំនាញជាច្រើន ជាពិសេសអ្នកជំនាញ Stephen Heder, François Ponchaud, Philip Short និង Henri Locard [1678]។ មិនត្រឹមតែមិន "លាក់បាំង" ភ័ស្តុតាងរបស់សាក្សី និងអ្នកជំនាញទាំងអស់នោះទេ អង្គជំនុំជម្រះសាលាដំបូង បានគូសបញ្ជាក់ពីការបកស្រាយរបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើភ័ស្តុតាងរបស់ពួកគាត់ ដោយកត់សម្គាល់ថា៖

> "ខៀវ សំផន បានយោងទៅសក្ខីកម្មរបស់ ឌុច និងអ្នកដទៃទៀត [...] ដើម្បីលើកឡើងថា ជនជាតិចាម មិនត្រូវបានកំណត់គោលដៅជាក់លាក់ ដោយបក្សកុម្មុយនីស្តកម្ពុជា ដោយសារតែជំនឿសាសនា ឬជាតិពន្ធុរបស់ពួកគេនោះឡើយ ប៉ុន្តែពួកគេត្រូវបានទទួលរង ការប្រព្រឹត្តដូចគ្នានឹងប្រជាជនដទៃផ្សេងទៀត ដែលស្ថិតក្រោមរបប ម៉ាក្សស៊ីស។ មេធាវីការពារក្តី ខៀវ សំផន បានយោងទៅអតីតកម្មាភិបាល របស់បក្សកុម្មុយនីស្តកម្ពុជា [...] ឌុច និង ម៉ាត់ លី រួមទាំងសាក្សី និងអ្នកជំនាញ Philip Short, François Ponchaud, Stephen Heder និង Henri Locard ដែលពួកគាត់ទាំងអស់នោះបានបញ្ជាក់ថា មិនមានគោលនយោបាយកំណត់គោលដៅ ទៅលើជនជាតិចាម ឬមានការស្អប់ខ្ពើមជាក់លាក់ ពីសំណាក់បក្សកុម្មុយនីស្តកម្ពុជា ទៅលើជនជាតិចាមនោះទេ។[1679]

457. អង្គជំនុំជម្រះសាលាដំបូង បានរំឮកដោយត្រឹមត្រូវថា សាក្សីអ្នកជំនាញទាំងអស់នោះ មានមួយចំនួនបានផ្តល់ភ័ស្តុតាងថា ជនជាតិចាមត្រូវបានកំណត់គោលដៅ[1680]។ ជាឧទាហរណ៍ François

---

កំណត់គោលដៅជាពិសេសលើជនជាតិចាម" និង "ការផ្លាស់ទីលំនៅប្រជាជនចាម ក្នុងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីពីរ)"។

[1677] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧២។

[1678] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧៣។

[1679] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២២២។

[1680] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២២៦។

Ponchaud ពន្យល់ថា ពីឆ្នាំ១៩៧៨ "ខ្មែរក្រហមចាប់ពីឆ្នាំ ១៩៧៨ គេរកចាប់ចាម ពីព្រោះថា មូលហេតុដោយសារ មូលហេតុគេជាចាម។ ចាមមិនគោរព-មិនមែនដោយសារមិនគោរព វិន័យ អង្គការ ទេ ប៉ុន្តែដោយសារចាមតែម្តង។ អីចឹងនៅក្នុងភូមិមួយហ្នឹង គេរកចាប់ចាម ហើយ ប្រហែលជាច្បាស់ហើយគឺយកទៅសម្លាប់ ហ្នឹងចាប់ពីឆ្នាំ១៩៧៨"[1681]។ នៅក្នុងសក្ខីកម្មដែលម្ចាស់ បណ្តឹងសាទុក្ខបានដកស្រង់[1682] Stephen Heder បានយោងទៅរក "គោលនយោបាយដំបូងៗ ដែលអាចហៅបានថាប្រឆាំងចាម"[1683]។ បន្ថែមលើនេះ ក្នុងកម្រិតដែលមានភាពពាក់ព័ន្ធ អង្គជំនុំ ជម្រះសាលាដំបូង បានយោងទៅរកភស្តុតាងរបស់ ឌុច និង ម៉ាត់ លី[1684]។ ម្ចាស់បណ្តឹង សាទុក្ខអាចមិនយល់ស្រប ជាមួយការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែគាត់មិនបាន បង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មិនបានគិតទៅដល់ភស្តុតាង ឬធ្វើការសម្រេច ដែលមិនមាន អ្នកវិនិច្ឆ័យអង្គហេតុ ដែលមានសំអាងហេតុណាម្នាក់ អាចធ្វើទៅបាន ដោយផ្អែកលើភស្តុតាងជា រួមនោះ។

458. ទីបួន ម្ចាស់បណ្តឹងសាទុក្ខ បានធ្វើការអះអាងដែលខុសឆ្គង ដដែលៗឡើងវិញ ដែលត្រូវ បកស្រាយលម្អិតនៅផ្នែកផ្សេង នៅក្នុងចម្លើយតបនេះ ទាក់ទងការកំណត់គោលដៅលើជនជាតិ ចាម[1685] និងថាតើ អង្គជំនុំជម្រះសាលាដំបូង បានទទួលបណ្តឹងអំពី ឧក្រិដ្ឋកម្មនៃការជម្លៀស ដោយបង្ខំ ដែរឬយ៉ាងណា[1686]។ ចំពោះការទទួលបណ្តឹង ម្ចាស់បណ្តឹងសាទុក្ខ មិនបានពន្យល់ពី

---

[1681] ឯកសារ **E1/180.1** ប្រតិចារឹក François Ponchaud ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ម៉ោង ១០.២២.១៥-១០.២៤.១០ ទំព័រ ២៦ បន្ទាត់ ១៥-១៨។

[1682] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៧៣។

[1683] ឯកសារ **E1/223.1** ប្រតិចារឹក Stephen Heder ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ១៥.១៣.៤៣-១៥.១៧.០៨ ទំព័រ ៣១ បន្ទាត់ ១៥-ទំព័រ ៣២ បន្ទាត់ ១។

[1684] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៥, ៣២១៩, ៣២២៣, ៣២៣៣, ៣២៥៥ និងជើងទំព័រក្នុងនោះ។ វិធីសាស្ត្រមិនស៊ីចង្វាក់គ្នា របស់ម្ចាស់បណ្តឹងសាទុក្ខ ចំពោះភស្តុតាងនេះ គឺជាការគួរឱ្យកត់ សម្គាល់។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដដែលៗថា ការសម្ភាសន៍ដែលបានធ្វើឡើងនៅក្រៅតុលាការ គឺមានតម្លៃជាភស្តុតាង ទាប ហើយមិនអាចពឹងផ្អែកបានឡើយ (*សូមមើល ឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣១, ៨៨២, ៩៧៤)។ (ភស្តុតាងរបស់ ម៉ាត់ លី គឺស្របគ្នាតែជាមួយ កិច្ចសម្ភាសន៍ដែលធ្វើឡើងក្រៅតុលាការប៉ុណ្ណោះ ដោយសារតែ គាត់បានស្លាប់ នៅក្នុងឆ្នាំ២០០៤ មុនពេលដែលគាត់អាចមានឱកាស មកផ្តល់សក្ខីកម្ម (សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៦ ជើងទំព័រ ១០៨១៨)។ ម្ចាស់បណ្តឹងសាទុក្ខមិនបានពន្យល់ ហេតុអ្វីទើបអង្គ ជំនុំជម្រះសាលាដំបូង គួរពឹងផ្អែកតែទៅលើភស្តុតាងនេះ ជាជាងពឹងផ្អែកទៅលើភស្តុតាង ដែលមាននៅចំពោះមុខខ្លួន។

[1685] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៤១-១៤៨។

[1686] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨២។

ភាពពាក់ព័ន្ធ នៃការអះអាងដោយខុសឆ្គងនេះ ជាមួយការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើគោលនយោបាយកំណត់គោលដៅ លើជនជាតិចាមទេ។

459. ជាចុងក្រោយ ម្ចាស់បណ្ដឹងសាទុក្ខ បានលើកឡើងនូវការអះអាងដែលខុសឆ្គងសាជាថ្មី ដោយបង្អាប់នៅក្នុងមូលដ្ឋានទី ៨៣ និងទី ១៥០ ថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា ជនជាតិចាមត្រូវបានធ្វើទុក្ខបុកម្នេញ នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ បានរំលោភបំពានទៅលើទ្រឹស្ដី អាជ្ញាអស់ជំនុំ[1687]។ ម្ចាស់បណ្ដឹងសាទុក្ខ បានអះអាងដោយខុសបន្ថែមទៀតថា ដោយសារតែអាជ្ញាអស់ជំនុំ អង្គជំនុំជម្រះសាលាដំបូង "មិនអាចយកអង្គហេតុទាំងនេះ មកបង្ហាញអំពីអត្ថិភាព នៃគោលនយោបាយបានឡើយ"[1688]។ ទោះបីជាមានការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មិនបានរំលោភទៅលើទ្រឹស្ដី អាជ្ញាអស់ជំនុំ ហើយក្ដី[1689] ក៏ការនេះមិនពាក់ព័ន្ធឡើយ ដោយសារតែ អាជ្ញាអស់ជំនុំ មិនបានហាមឃាត់ការប្រើប្រាស់អង្គហេតុឡើយ គឺហាមឃាត់ការចោទប្រកាន់ឡើងវិញ ទៅលើបញ្ហាដែលបានសម្រេចជាស្ថាពររួចហើយនោះ[1690]។ អត្ថិភាពនៃគោលនយោបាយ កំណត់គោលដៅលើជនជាតិចាម មិនត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿង ០០២/០១ ឡើយ។

460. ដោយផ្អែកលើកំណត់ត្រាភស្ដុតាងយ៉ាងច្រើន ដែលស៊ីសង្វាក់គ្នា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយសមហេតុផលថា គោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជា ក្នុងការកំណត់គោលដៅលើជនជាតិចាម ត្រូវបានអនុវត្តជាមធ្យោបាយឧក្រិដ្ឋ ដើម្បី "ការពារប្រទេសពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុង ឱ្យក្លាយជាសង្គមខ្មែរ ដែលមិនមានសាសនា និងរួបរួមគ្នាមួយ"[1691] ដែលត្រូវអនុវត្តឡើងតាមរយៈ គោលនយោបាយកំណត់អត្តសញ្ញាណ ចាប់ខ្លួន បំបែក និងកម្ទេច

[1687] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៧៦។

[1688] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៧៦។

[1689] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥០។

[1690] *សូមមើលឧទាហរណ៍* សាលក្រមរឿងក្ដី *Čelebici* កថាខណ្ឌ ២២៨ ("ទ្រឹស្ដីអាជ្ញាអស់ជំនុំ គឺមានដែនកំណត់ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ចំពោះបញ្ហាថាតើនៅពេលដែល ការជំនុំជម្រះលើបុគ្គលម្នាក់នាពេលកន្លងមក ត្រូវបន្តដោយការជំនុំជម្រះផ្សេងទៀត ទៅលើបុគ្គលដដែលនោះ តើបញ្ហាជាក់លាក់មួយ ត្រូវបានជម្រះពេញលេញហើយឬនៅ")។

[1691] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៩០-៣៩៩៨។

ខ្លាំង យោងទៅតាមគោលដៅបដិវត្ត របស់បក្សកុម្មុយនីស្តកម្ពុជា[1692]។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង អនុលោមទៅតាមគោលនយោបាយនេះ ត្រូវស្ថិតនៅក្នុងគោលបំណងរួម[1693]។

## *មូលដ្ឋានទី ១២១៖ គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាម*[1694]

461. **មូលដ្ឋានទី ១២១ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសម្រេចថា ជនជាតិចាមទទួលរង "ការរើសអើងជាក់ស្តែង" នៅទំនប់១មករា។**

462. មូលដ្ឋាននេះគួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង (១) មានកំហុសអង្គច្បាប់ដោយយោងទៅរក ព្រឹត្តិការណ៍នៅក្រៅទំនប់១មករា (២)មានកំហុសអង្គហេតុដោយសម្រេចថា ជនជាតិចាមត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក និងហាមឃាត់មិនឱ្យប្រតិបត្តិជំនឿសាសនារបស់ខ្លួន និងនិយាយភាសាខ្លួន និង (៣) មានកំហុសអង្គហេតុដោយយោងឆ្លងដោយមិនត្រឹមត្រូវ ទៅរកការសម្រេចកន្លងមក។

463. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខ បានលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយយោងទៅរកព្រឹត្តិការណ៍ ដែលកើតឡើងនៅក្រៅ ការដ្ឋានទំនប់១មករា ក្នុងតំបន់ ៤១, ៤២ និង ៤៣[1695]។ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង គ្រាន់តែយោងទៅរកព្រឹត្តិការណ៍នោះ ដើម្បីផ្តល់បរិបទសម្រាប់អំពើ ដែលកើតឡើងនៅទំនប់១មករាប៉ុណ្ណោះ[1696]។ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខ បានអះអាងថា ហេតុការណ៍ទាំងអស់នេះ "មិនអាចប្រើដើម្បី បង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្ម" តែមិនមានការសម្រេចណាមួយ ទៅលើការរើសអើងប្រឆាំងជនជាតិចាម ដែលបាន

---

[1692] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៩៣-៣៩៩៤។

[1693] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[1694] <u>មូលដ្ឋានទី ១២១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាម* កថាខណ្ឌ ៨០៤-៨១២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៥ (ភាសាអង់គ្លេស) ទំព័រ ៤១ (ភាសាបារាំង) ទំព័រ ៦៣-៦៤ (ភាសាខ្មែរ)។

[1695] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០៦។

[1696] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥៤ ("អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តចំពោះជនជាតិចាម នៅការដ្ឋានការងារទំនប់១មករា ចាំបាច់ត្រូវពិនិត្យនៅក្នុងបរិបទ ដែលគេប្រព្រឹត្តចមពោះជនជាតិចាម នៅតាមភូមិនានា ដែលអ្នកទាំងនោះត្រូវបានជ្រើសរើស នៅក្នុងតំបន់៤១ តំបន់៤២ និងតំបន់៤៣") កថាខណ្ឌ ១៦៥៥, ១៦៥៦ ("*ជាមួយនឹងទិដ្ឋភាពនេះ* អង្គជំនុំជម្រះនឹងពិចារណា ទៅលើការប្រព្រឹត្តចំពោះជនជាតិចាម នៅការដ្ឋានការងារទំនប់១មករា") (គូសបញ្ជាក់បន្ថែម)។

កើតឡើងនៅទំនប់១មករា ធ្វើឡើងដោយផ្អែកទៅលើព្រឹត្តិការណ៍ទាំងអស់នេះឡើយ។ តាមពិតទៅ អង្គជំនុំជម្រះសាលាដំបូង មិនបានធ្វើការសម្រេចណាមួយទាល់តែសោះ ទាក់ទងនឹងព្រឹត្តិការណ៍ទាំងអស់នេះ[1697]។

464. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខ បានចោទប្រកាន់ដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ នៅពេលសម្រេចថា ជនជាតិចាមត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក នៅទំនប់១មករា។ ម្ចាស់បណ្តឹងសាទុក្ខ បានកំណត់ដោយចម្លែកហើយខុស នូវសក្ខីកម្មរបស់ អ៊ុំ ជី ដែលថា សាច់ជ្រូកគឺជា "អ្វីដែលពិសេសនិងវិជ្ជមាន សម្រាប់ការផ្តល់សារធាតុចិញ្ចឹមដល់កម្មករ"[1698]។ ខុសឆ្ងាយពី "វិជ្ជមាន" អ៊ុំ ជី បានរៀបរាប់ថា ជនជាតិចាមសុខចិត្តហូបអំបិល ឬហូបតែទឹកសម្ល ដើម្បីជៀសពីការហូបសាច់ជ្រូក[1699]។ ម្ចាស់បណ្តឹងសាទុក្ខ ក៏បានអះអាងផងដែរថា ជនជាតិចាមមានជម្រើស ថាតើត្រូវហូបសាច់ជ្រូក ឬអត់ ព្រោះពួកគេអាចជ្រើសការអត់ហូបអ្វីទាំងអស់បាន[1700]។ ដោយមិនចាំបាច់និយាយអ្វីច្រើន "ជម្រើស" រវាងហូបសាច់ជ្រូក និងដាច់ពោះស្លាប់ គឺមិនមែនជាជម្រើសនោះទេ។ ជាចុងក្រោយ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខ បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូង ក៏បានពឹងផ្អែកទៅលើសក្ខីកម្មរបស់ សៀង សុវិដា និង មាស ឡៃហួរ ដើម្បីសម្រេចថា ជនជាតិចាមត្រូវបានបង្ខំឱ្យហូបសាច់ជ្រូកក្តី តែគាត់មិនបានលើកនូវបញ្ហាណាមួយជាមួយភ័ស្តុតាងរបស់ពួកគេនេះឡើយ។ ហេតុដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា ការសម្រេចដែលថាជនជាតិចាម ត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក ដោយផ្អែកលើភ័ស្តុតាងរបស់ពួកគេ គឺមិនសមហេតុផលនោះទេ។

465. ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយសារតែ ការបង្ខំឱ្យហូបសាច់ជ្រូក និងការហាមឃាត់ការប្រត្តិបត្តិសាសនា ត្រូវអនុវត្តចំពោះមនុស្សគ្រប់គ្នា នៅទំនប់១មករា ដែលដូច្នេះហើយគឺមិនមាន អំពើដែល "រើសអើងជាក់ស្តែង" ឡើយ[1701]។ ទឡ្ហីករណ៍នេះត្រូវបានបង្ហាញរួចហើយថា មិនមានមូលដ្ឋាននោះទេ[1702]។

---

1697 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥៥។

1698 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០៩។

1699 ឯកសារ **E1/326.1** Om Chy ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ១៣.៣០.៤៨-១៣.៣៣.១៨ ទំព័រ ៥០ បន្ទាត់ ២-៣ ("ចាមសម័យហ្នឹង បើអ្នកណាគេកាន់បាន គេអត់ហូបទេ សុខចិត្តៗហូបអំបិល។ បើអ្នកខ្លះគ្នាហេវ ចេះតែហុតទឹកៗទៅប៉ុណ្ណឹងគ្រាន់")។

1700 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨០៩។

1701 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨១០-៨១១។

466. ម្ចាស់បណ្ដឹងសាទុក្ខ អះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុដោយសម្រេចថា ជនជាតិចាមត្រូវបានហាមឃាត់ មិនឱ្យនិយាយភាសាកំណើតខ្លួន។ ការតវ៉ាតែមួយគត់របស់ម្ចាស់បណ្ដឹងសាទុក្ខគឺថា អង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកទៅលើសក្ខីកម្ម របស់សាក្សីតែមួយរូបគត់[1703]។ មិនត្រឹមតែមានការកំណត់យ៉ាងច្បាស់លាស់ថា អាចពឹងផ្អែកទៅលើសាក្សីតែមួយរូប ក្នុងការគាំទ្រដល់ការសម្រេចប៉ុណ្ណោះទេ[1704] ប៉ុន្តែម្ចាស់បណ្ដឹងសាទុក្ខ មិនបានជំទាស់ទៅលើភាពអាចជឿជាក់បាន របស់សាក្សីនោះទេ ដូច្នេះម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថាការសម្រេចនេះមិនសមហេតុផលនោះឡើយ។

467. ទីបី ម្ចាស់បណ្ដឹងសាទុក្ខលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ព្រោះអង្គជំនុំជម្រះសាលាដំបូង បានរំឭកអំពីការសម្រេចដែលថា ជនជាតិចាមត្រូវបានរើសអើង នៅទំនប់១មករា ដោយយោងខ្វែងទៅរកកថាខណ្ឌ ១៦៥៨ ដែលមិនមានលើកឡើងពីការសម្រេចនេះទេ[1705]។ នេះគឺគ្រាន់តែជាកំហុសបច្ចេកទេសប៉ុណ្ណោះ មិនមែនកំហុសអង្គហេតុទេ។ តាមរយៈអត្ថបទសាលក្រម គឺបង្ហាញច្បាស់ថា ចេតនានៃការយោងគឺការសម្រេច នៅក្នុងកថាខណ្ឌ ១៦៥៩ទេ[1706]។

468. ជាចុងក្រោយ និងក្នុងករណីណាក្ដី អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា មានអំពើរើសអើងយ៉ាងទូលំទូលាយ ដែលបានប្រព្រឹត្តទៅលើជនជាតិចាម មិនត្រឹមតែនៅទំនប់១មករាប៉ុណ្ណោះទេ ថែមទាំងនៅតាមទីតាំងផ្សេងៗជាច្រើន នៅទូទាំងប្រទេសកម្ពុជា[1707]។ ហេតុដូច្នេះ ធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ នឹងត្រូវបានបំពេញ បើទោះបីជារកមិនឃើញ ថាមានការប្រព្រឹត្តអំពើរើសអើងនៅទំនប់១មករាក្ដី។

---

[1702] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១២២។

[1703] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨១២។

[1704] *សាលដីការឿងក្ដី Nahimana* កថាខណ្ឌ ៩៤៩។

[1705] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨០៥ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩៥ ជើងទំព័រ ៥៧៥៣។

[1706] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩៥ ("អង្គជំនុំជម្រះ*សន្និដ្ឋាន*ថា [...] ជនជាតិចាម [...] បានទទួលរងនូវការរើសអើង" (គូសបញ្ជាក់បន្ថែម)) កថាខណ្ឌ ១៦៥៩ ("អង្គជំនុំជម្រះ*សម្រេច*ថា ជនជាតិចាមទទួលរងការរើសអើង" (គូសបញ្ជាក់បន្ថែម))។

[1707] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨។

## *មូលដ្ឋានទី ១២២៖ ការប្រព្រឹត្តិស្មើភាពគ្នា មិនមែនជាធាតុផ្សំ នៃការប្រព្រឹត្តិរើសអើង*[1708]

469. **មូលដ្ឋានទី ១២២ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយសម្រេចថា ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានកំណត់ នៅទំនប់១មករា។**

470. មូលដ្ឋាននេះគួរបដិសេធ ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ យល់ខុសទៅលើច្បាប់ ស្ដីពីការរើសអើងជាក់ស្ដែង។ ដូចដែលបានកត់សម្គាល់ពីខាងលើ[1709] មិនមានលក្ខខណ្ឌតម្រូវគតិយុត្តិ ឱ្យញែកដាច់ពីគ្នារវាង ការរើសអើង "ផ្ទាល់" ឬ "ប្រយោល" ឡើយ នៅពេលកំណត់អំពីអត្ថិភាព នៃការរើសអើងជាក់ស្ដែង។ ហេតុដូច្នេះ ការផ្ដល់សាច់ជ្រូកទៅឱ្យក្រុមចម្រុះគ្នា គឺជាការរើសអើងជាក់ស្ដែង ប្រសិនបើ ដូចជាករណីនៅទំនប់១មករា[1710] វាមានផលវិបាករើសអើង សម្រាប់អ្នកទាំងឡាយណា ដែលស្ថិតនៅក្នុងក្រុម ដែលមិនអាចហូបសាច់ជ្រូកបាន។ ប្រហែលគ្នានេះ ការហាមឃាត់ក្រុមមនុស្ស មិនឱ្យគោរពសាសនា ឬនិយាយភាសាណាមួយ គឺជាការរើសអើងជាក់ស្ដែង ប្រសិនបើការហាមឃាត់នោះ ជាការពិតគឺកំណត់គោលដៅ ទៅលើបុគ្គលជាក់លាក់ណាមួយ នៅក្នុងក្រុម។ ទោះជាក្នុងករណីណាក្ដី ដូចដែលបានកត់សម្គាល់ពីខាងលើ[1711] អង្គជំនុំជម្រះសាលាដំបូងបានរកឃើញ អំពើរើសអើងយ៉ាងច្រើន ដែលបានប្រព្រឹត្តឡើងចំពោះជនជាតិចាម នៅតាមទីកន្លែងនានា នៅទូទាំងប្រទេសកម្ពុជា[1712]។ ហេតុដូច្នេះ ធាតុផ្សំសន្យានុម័តនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ត្រូវបានបំពេញ បើទោះបីជាមិនមានការរកឃើញ ការប្រព្រឹត្តអំពើរើសអើង នៅទំនប់១មករាក្ដី។

---

[1708] <u>មូលដ្ឋានទី ១២២</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ការប្រព្រឹត្តិស្មើភាពគ្នា មិនមែនជាធាតុផ្សំនៃការប្រព្រឹត្តិរើសអើង* កថាខណ្ឌ ៨១៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៤៥ (ភាសាអង់គ្លេស) ទំព័រ ៤១ (ភាសាបារាំង) ទំព័រ ៦៤ (ភាសាខ្មែរ)។

[1709] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

[1710] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១២១។

[1711] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១២១។

[1712] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨។ អំពើទាំងនេះរួមមានអំពើដែលបានរកឃើញដោយឡែកថាបង្កើតបានជាបទល្មើសជាក់លាក់ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង, សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៣១។

## *មូលដ្ឋានទី ១៤១៖ គ្មានការរើសអើងជាក់ស្ដែង ចំពោះជនជាតិចាម ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ*[1713]

471. **មូលដ្ឋានទី ១៤១ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ដោយសម្រេចថា ការផ្លាស់ទីលំនៅជនជាតិចាមដោយបង្ខំ គឺជាការរើសអើង ដែលដូច្នេះហើយកំណត់បាន អំពីធាតុផ្សំសត្យានុម័ត នៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ**

472. មូលដ្ឋានត្រូវបដិសេធចោល ចំពោះការចោទប្រកាន់ពី កំហុសអង្គច្បាប់ ព្រោះម្ចាស់បណ្ដឹងសាទុក្ខ បង្ហាញដោយភាន់ច្រឡំ នូវនិយមន័យរបស់អង្គជំនុំជម្រះតុលាការកំពូល ស្ដីពីការរើសអើងជាក់ស្ដែង ដោយយល់ច្រឡំការវិភាគទៅលើអង្គហេតុ នៅក្នុងសំណុំរឿង ០០២/០១ ជាមួយ "ការពិសោធ" ទូទៅនៃការរើសអើង[1714]។ ជាលទ្ធផល ការចោទប្រកាន់លើកំហុសអង្គហេតុ ក៏ត្រូវបដិសេធ ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា ដោយអនុវត្តនូវលក្ខខណ្ឌតម្រូវត្រឹមត្រូវ សម្រាប់ការរើសអើងជាក់ស្ដែង[1715] ការសម្រេចដែលថាការផ្លាស់ទីជនជាតិចាមដោយបង្ខំ គឺជាការរើសអើងនោះ គឺជាការសម្រេចដែលគ្មានអ្នកវិនិច្ឆ័យ ដោយសមហេតុផលណាមួយ អាចឈានដល់ការសម្រេចនោះទេ។

473. ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខ ផ្អែកទៅលើការអះអាងដោយខុសថា អង្គជំនុំជម្រះតុលាការកំពូល បានកំណត់នូវ "ការពិសោធ" ថ្មី សម្រាប់ការរើសអើង នៅក្នុងសាលដីកាសំណុំរឿង ០០២/០១។ ទោះជាយ៉ាងណាក្ដី ដូចដែលបានកត់សម្គាល់ នៅក្នុងចម្លើយតបនេះ មានច្បាប់ដែលបានកំណត់រួចហើយនៅ អ.វ.ត.ក ដែលថា ការរើសអើងជាក់ស្ដែង កើតឡើងនៅពេលដែលជនរងគ្រោះ ត្រូវបានកំណត់គោលដៅ ដោយសារតែសមាជិកភាពរបស់ពួកគេ នៅក្នុងក្រុមមួយដែលកំណត់ដោយចារី ផ្អែកលើមូលដ្ឋានជាក់លាក់[1716]។ "ការពិសោធ" ដែលម្ចាស់បណ្ដឹងសាទុក្ខ បានដកស្រង់នេះ គឺគ្រាន់តែជាការពន្យល់ ទាក់ទងនឹងវិធីសាស្ត្រ ដែលនិយមន័យនៃ "ការរើសអើងជាក់

---

[1713] <u>មូលដ្ឋានទី ១៤១៖</u> ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ *គ្មានការរើសអើងជាក់ស្ដែងចំពោះជនជាតិចាម ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ* កថាខណ្ឌ ៩២៦-៩២៧។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៥០ (ភាសាអង់គ្លេស) ទំព័រ ៤៦ (ភាសាបារាំង) ទំព័រ ៧១ (ភាសាខ្មែរ)។

[1714] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩២៦-៩២៧។

[1715] សូមមើល សំណុំរឿង ០០១-ឯកសារ F28 សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៦៣, ២៦៧, ២៧២។ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៦៧, ៦៩០។

[1716] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

ស្តែង" អាចត្រូវបានកំណត់តាមរយៈ ការផ្លាស់ទីលំនៅប្រជាជនថ្មី នៅក្នុងបណ្តុំអង្គហេតុនៃសំណុំរឿង ០០២/០១[1717]។ តាមពិតទៅការវិភាគនេះ ត្រូវបានកម្រិតកំណត់យ៉ាងច្បាស់ ដោយអង្គជំនុំជម្រះនេះ តត្រឹម "ការធ្វើទុក្ខបុកម្នេញលើ ប្រជាជនថ្មី ដូចមាននៅក្នុង [សំណុំរឿង ០០២/០១]"[1718]។

474. ការផ្លាស់ទីលំនៅជនជាតិចាម ត្រូវបានរកឃើញថាខុសប្លែក ទាំងអង្គហេតុ និងអង្គច្បាប់ ពីការផ្លាស់ទីលំនៅប្រជាជនថ្មី នៅក្នុងសំណុំរឿង ០០២/០១[1719]។ បើទោះបីជាការបំបែកជនជាតិចាមកើតឡើងផងដែរនៅក្នុងបរិបទ នៃការផ្លាស់ទីលំនៅប្រជាជនទ្រង់ទ្រាយធំក្តី តែអង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាតិចាមត្រូវបានកំណត់គោលដៅជាពិសេស សម្រាប់ការផ្លាស់ទីលំនៅ ដោយសារតែពួកគេត្រូវបានចាត់ទុកថាជាខ្មាំង បន្ទាប់ពីមានការបះបោររបស់ជនជាតិចាម[1720]។ ហេតុដូច្នេះ ជនជាតិចាមត្រូវបានកំណត់គោលដៅ សម្រាប់ការផ្លាស់ទីលំនៅ ដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងក្រុម ដែលកំណត់ដោយមូលដ្ឋាននយោបាយ។ ហេតុដូច្នេះ នៅក្នុងសេណារីយ៉ូដែលខុសប្លែកផ្នែកអង្គហេតុ ពីការផ្លាស់ទីលំនៅប្រជាជនថ្មី នៅក្នុងសំណុំរឿង ០០២/០១នោះ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងដោយត្រឹមត្រូវ និងអនុវត្តច្បាប់ដោយត្រឹមត្រូវ ក្នុងការសម្រេចថា ជនជាតិចាមទទួលរង ការរើសអើងជាក់ស្តែង នៅក្នុងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ ដោយសារតែលក្ខណៈដែលពួកគេ ត្រូវបានកំណត់គោលដៅ។

---

[1717] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០១ ដែលត្រូវបានដកស្រង់នៅក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩២៦ ជើងទំព័រ ១៦៨៨។

[1718] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០១ (គូសបញ្ជាក់បន្ថែម)។ ជាងនេះទៀត ប្រសិនបើ អ.ជ.ស.ដ បានអនុវត្ត "ការសាកល្បង" ពីសំណុំរឿង ០០២/០១ ដែលស្នើឡើងដោយម្ចាស់បណ្តឹងសាទុក្ខនោះ ការសាកល្បងនោះអាចមានអានុភាពពេលវាយតម្លៃលើការរើសអើងជាក់ស្តែងប៉ុណ្ណោះ ដរាបណាមានការបញ្ជាក់ពីការសាកល្បងនោះ នៅពេលយកមកអនុវត្តចំពោះអង្គហេតុនៃសំណុំរឿង ០០២/០១។ នេះគឺជាកំហុសមួយ ដោយសារតែភាពខុសគ្នាខ្លាំងនៃអង្គហេតុរវាងការផ្លាស់ទីលំនៅរបស់ប្រជាជនថ្មីនៅក្នុងសំណុំរឿង០០២/០១ និងការផ្លាស់ទីលំនៅរបស់ជនជាតិចាមនៅក្នុងសំណុំរឿង ០០២/០២។

[1719] អ្វីដែលសំខាន់សម្រាប់ការវាយតម្លៃរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០២/០១ គឺការសន្និដ្ឋានថា ការផ្លាស់ទីលំនៅប្រជាជនមូលដ្ឋានទី និងប្រជាជនថ្មីត្រូវបានធ្វើឡើងដោយហេតុផលមួយចំនួន ហើយដូច្នេះ ពុំមានការប្រព្រឹត្តិរើសអើងឡើយ។ សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០២។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា អ.ជ.ស.ដ បានដឹងពីការយល់ឃើញរបស់ អ.ជ.ត.ក មុននឹងខ្លួនបង្ហាញពីភាពខុសគ្នានៃការយល់ឃើញនោះយ៉ាងជាក់ច្បាស់។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២១។

[1720] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២២-៣៣២៣។

## *មូលដ្ឋានទី ១៤៤៖ ភស្តុតាងអំពីការប្រព្រឹត្តមិនខុសគ្នា ពាក់ព័ន្ធនឹងរបបអាហារ និងការកំហិតនានាចំពោះការប្រតិបត្តិសាសនានិងវប្បធម៌ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ*[1721]

475. **មូលដ្ឋានទី ១៤៤ គួរត្រូវបានបដិសេធដោយសារតែ ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស អង្គហេតុនិងអង្គច្បាប់ ក្នុងការសម្រេចរបស់ខ្លួន លើជាតុផ្សំសត្យានុម័ត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា។**

476. មូលដ្ឋាននេះគួរត្រូវបានច្រានចោលដោយសារតែ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គហេតុ ដោយសម្រេចថា (១) ការប្រព្រឹត្តដោយរើសអើងទៅលើជនជាតិចាម ត្រូវបានបង្ហាញថាកើតមាននៅ ទំនប់១មករា (២) បក្សកុម្មុយនីស្តកម្ពុជាអនុវត្តគោលនយោបាយ ដែលកំណត់គោលដៅជាពិសេស ទៅលើជនជាតិចាម ក្នុងនាមជាក្រុមជាតិពិន្ទុ និងសាសនា (៣) ការកំហិតទៅលើជនជាតិចាម គឺជា "ការរើសអើងជាក់ស្តែង" និង (៤) ជនជាតិចាមត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក ហើយគម្ពីគូរ៉ាអានត្រូវបានដុតចោល។

477. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខបានអះអាង ដោយមិនមានអង្គសេចក្តីថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកលើក្នុងការសម្រេច ការប្រព្រឹត្តដោយរើសអើងទៅលើជនជាតិចាម នៅទំនប់១មករា គឺមិនគ្រប់គ្រាន់ ដែលដូច្នេះហើយ មិនគួរត្រូវបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការសម្រេចថាជនជាតិចាម ត្រូវបានធ្វើទុក្ខបុកម្នេញ[1722]។ ប៉ុន្តែដូចដែលបានកត់សម្គាល់រួចហើយ នៅក្នុងចម្លើយតបនេះ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការរើសអើងនៅទំនប់១មករា គឺជាការត្រឹមត្រូវ[1723]។

478. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា មានភស្តុតាងមិនគ្រប់គ្រាន់ ដើម្បីគាំទ្រការសម្រេចអំពីគោលនយោបាយ កំណត់គោលដៅលើជនជាតិចាម[1724]។ បន្ថែមលើនេះ បើទោះបីជា

---

[1721] <u>មូលដ្ឋានទី ១៤៤</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភស្តុតាងអំពីការប្រព្រឹត្តិមិនខុសគ្នា ពាក់ព័ន្ធនឹងរបបអាហារ និងការកំហិតនានាចំពោះការប្រតិបត្តិសាសនា និងវប្បធម៌ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ* កថាខណ្ឌ ៩៣៤-៩៥១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥១ (ភាសាអង់គ្លេស) ទំព័រ ៤៦-៤៧ (ភាសាបារាំង) ទំព័រ ៧២-៧៣ (ភាសាខ្មែរ)។

[1722] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៣៥, ៩៤១។

[1723] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១២១ និង ១២២។

[1724] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៦។

អង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់ឃ្លា "បណ្ដាឆ្នាំដំបូងៗ" នៅក្នុងការពិភាក្សាអំពីការវិវឌ្ឍន៍ នៃគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ចំពោះជនជាតិចាមមានលក្ខណៈផ្ទុយគ្នាក្ដី តែវាមិនបាននាំឱ្យមានភាពអយុត្តិធម៌ជាក់ស្ដែងឡើង។ នៅពេលអានទៅតាមបរិបទ និងរួមជាមួយជើងទំព័រ ច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូង គ្រាន់តែប្រើប្រាស់ឃ្លាបែបនេះ ដើម្បីគូសបញ្ជាក់ពីការកើនឡើង នៃគោលនយោបាយរបស់ បក្សកុម្មុយនីស្ដកម្ពុជា ទៅលើជនជាតិចាម ពីមួយពេលទៅមួយពេលប៉ុណ្ណោះ[1725]។

479. ទីបី ដូចដែលបានកត់សម្គាល់រួចហើយ នៅក្នុងមូលដ្ឋានដទៃទៀតជាច្រើន ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[1726] ទាក់ទងលក្ខខណ្ឌតម្រូវ "ការប្រព្រឹត្តមិនខុសគ្នា" ទៅលើជនជាតិចាម គឺខុសដោយសារតែគាត់យល់ច្រឡំទៅលើ លក្ខខណ្ឌតម្រូវគតិយុត្តិ នៃការរើសអើងជាក់ស្ដែង ដែលកើតឡើងនៅពេលដែលជនរងគ្រោះ ត្រូវបានកំណត់គោលដៅដោយសារតែ សមាជិកភាពរបស់ពួកគេនៅក្នុងក្រុមមួយ ឬនៅពេលដែលសមាជិកនៃក្រុម ទទួលរងផលវិបាកនៃការរើសអើង[1727]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[1728] អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសឆ្គងឡើយ ក្នុងការសន្និដ្ឋានថា ជនជាតិចាមត្រូវបានរើសអើងជាក់ស្ដែង ដោយសារតែពួកគេ "ត្រូវទទួលរងនូវផលប៉ះពាល់ខ្លាំងជាពិសេស" តាមរយៈវិធានការដែលបក្សកុម្មុយនីស្ដកម្ពុជាបានដាក់ដោយបង្ខំដែល "ត្រូវបានបង្ហាញគោលដៅជាពិសេស [លើពួកគេ] នៅក្នុងការអនុវត្តនេះ"[1729]។

480. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា "មានតែការចោទប្រកាន់ពីការបង្ខំឱ្យហូបសាច់ជ្រូក និងការដុតបំផ្លាញគម្ពីគូរ៉ាអានប៉ុណ្ណោះ ដែលអាចបង្កើតបានជាការប្រព្រឹត្តបែបខុសគ្នា"[1730] គឺគ្មានមូលដ្ឋានឡើយ ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខ មិនបានពន្យល់ថាហេតុអ្វីបានជាអំពើរើសអើងដទៃផ្សេងទៀត ដែលរកឃើញថាបានប្រព្រឹត្តទៅលើជនជាតិចាមនោះ មិនបង្កើតបានជា "ការ

---

[1725] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២២៨។

[1726] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៣៩-៩៤២។

[1727] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

[1728] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៤០-៩៤២ *ដែលជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៣២, ៣២៣៣, ៣២៣៨, ៣២៤២, ៣២៥០, ៣៣២៨។

[1729] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៣២, ៣២៤២, ៣២៥០, ៣៣២៨។

[1730] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៤២។

ប្រព្រឹត្តបែបខុសគ្នា” រួមទាំងអំពើនានាដែលអាចកំណត់គោលដៅតែទៅលើជនជាតិចាម ដូចជាការហាមឃាត់ការថ្វាយបង្គំជារៀងរាល់ថ្ងៃ ឬការបំផ្លាញវិហារអ៊ីស្លាមជាដើម[1731]។

481. ទីបួន ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងការបង្ខំឱ្យហូបសាច់ជ្រូក និងការដុតគម្ពីគួរ៉ាន មិនទទួលបានផលឡើយ ដោយសារតែ ម្ចាស់បណ្តឹងសាទុក្ខបកស្រាយមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត នូវភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយមិនបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការវាយតម្លៃភ័ស្តុតាង[1732]។ ជាឧទាហរណ៍ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយខុសឆ្គងថា សុះ មីន មិនបានពន្យល់បកស្រាយ អំពីកាលៈទេសៈដែលជនជាតិចាម ត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក[1733]។ សុះ មីន បានបង្ហាញយ៉ាងច្បាស់ថា ប្រសិនបើជនជាតិចាមមិនហូបសាច់ជ្រូក ពួកគេនឹងត្រូវរងការចោទប្រកាន់ថា មិនព្រមបោះបង់ជំនឿសាសនាខ្លួន ហើយអាចត្រូវបានគេចាត់ទុកថាជាខ្មាំងរបស់អង្គការ[1734] ហើយគាត់បានរំឭកថា ជនជាតិចាមហូបសាច់ជ្រូក ដោយសារតែការភ័យខ្លាច[1735]។ ប្រហែលគ្នានេះ ម្ចាស់បណ្តឹងសាទុក្ខបកស្រាយមិនត្រឹមត្រូវ នូវភ័ស្តុតាងរបស់ឈ្មោះ ហ៊ីម ម៉ាន ដោយលើកឡើងថា ភ័ស្តុតាងរបស់គាត់គឺថា ជនជាតិចាមមិនត្រូវបានបង្ខំឱ្យហូបសាច់ជ្រូកទេ ព្រោះពួកគេមិនត្រូវបានតាមដានឡើយនៅពេលហូបបាយ ដោយមិនពិចារណាថា ហ៊ីម ម៉ាន បានបញ្ជាក់ថាជនជាតិចាម ត្រូវរងការគម្រាមកំហែងបាញ់សម្លាប់ ប្រសិនបើមិនហូបសាច់ជ្រូក[1736]។ ដោយបកស្រាយមិនត្រឹមត្រូវនូវ

[1731] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៤៦។

[1732] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៤៣-៩៤៧។

[1733] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៤៤។

[1734] ឯកសារ **E1/343.1** សុះ មីន ប្រតិចារឹក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ១៤.២០.១៨-១៤.២៣.០៤ ទំព័រ ៥៩ បន្ទាត់ ៤-៨ (“ការបង្ខិតបង្ខំហ្នឹង គឺគេជំរុញឱ្យយើងហូប កាលបើយើងអត់ហូប គេថាយើងនៅកាន់ជឿ គេថាយើងនៅជំនឿសាសនាជំនឿអី។ អ៊ីចឹង គេចោទប្រកាន់ថាយើងហ្នឹងអត់ចោលជំនឿសាសនាអ៊ីចេះអ៊ីចុះ។ អ៊ីចឹងបានន័យថា គេមានការតាមដានទៅមុខទៀត។ អ៊ីចឹងបើសិនជាអ្នកណាហើយមិនហូប ហើយនិយាយឱ្យខ្លី តែប្រឆាំងអ្វីដែលគោលការណ៍របស់គេហ្នឹង គេថាគេចោទថាយើងខ្មាំងហើយ”)។

[1735] ឯកសារ **E1/343.1** សុះ មីន ប្រតិចារឹក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ០៩.២៥.១៣-០៩.២៨.២៣ ទំព័រ ៨ បន្ទាត់ ១១-១៥ (“[កូប សាត់] បញ្ជាឱ្យស៊ីសាច់ជ្រូកសាច់អីហ្នឹង បញ្ជាពីលើមក ពីអង្គការពីលើមក។ គាត់ក៏ហូបដែរ គាត់ខ្លាចគេ។ [...] គាត់ៗជាជនជាតិចាមដែរ [...] ប៉ុន្តែ គាត់ខ្លាចពេកបញ្ជាគេឱ្យស៊ីជាមួយគ្នា គាត់ហូបដែរ ខ្លាចគេ”)។

[1736] ឯកសារ **E1/349.1** ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ១១.១០.១២ ទំព័រ ៣០ បន្ទាត់ ១០-១៥ (“ប៉ុនហូប បាទ បងប្អូនខ្ញុំមានហូបខ្លះហើយ បាទ ពីព្រោះថា មិនហូបទេ អញបាញ់ឯងចោល។ អ៊ីចឹង គេហូបៗដោយទឹកភ្នែកទៅណា។ [...] សាច់ជ្រូច ហូបសាច់ជ្រូកបាទ។ ព្រោះខ្ញុំក៏បានហូបដែរ បានខ្ញុំចេះឆ្លើយអ៊ីចឹង ខ្ញុំបានហូបដែរ បើខ្ញុំមិនហូបទេគេបាញ់ខ្ញុំចោល”)។

ភ័ស្តុតាងរបស់ សុះ មីន និង ហ៊ីម ម៉ាន ហើយនោះ ម្ចាស់បណ្ដឹងសាទុក្ខនៅអះអាងដោយខុសទៀតថា ភ័ស្តុតាងរបស់ ឡិប នាង "គឺជាសក្ខីកម្មតែមួយគត់ ដែលលើកឡើងយ៉ាងពិតប្រាកដពីការគម្រាមកំហែង" ទាក់ទងនឹងការហូបសាច់ជ្រូក[1737] ដែលនេះគឺជាការអះអាងមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត។

482. ការអះអាងរបស់ ម្ចាស់បណ្ដឹងសាទុក្ខដែលថា មិនមានអ្នកវិនិច្ឆ័យប្រកបដោយសំអាងហេតុណាម្នាក់ អាចសម្រេចថា គម្ពីគូរ៉ាអានត្រូវបានដុតចោលនោះ គឺគ្មានអង្គសេចក្ដីដូចគ្នា[1738]។ ការអះអាងនេះពឹងផ្អែកជាចម្បងទៅលើ ការអះអាងទាក់ទងភាពអាចជឿជាក់បាន និងតម្លៃនៃភ័ស្តុតាងរបស់សាក្សី[1739] ដែលការនេះមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង អនុវត្តហួសឆន្ទានុសិទ្ធិរបស់ខ្លួន នៅក្នុងការវាយតម្លៃលើភ័ស្តុតាងឡើយ[1740]។ ម្ចាស់បណ្ដឹងសាទុក្ខបកស្រាយមិនត្រឹមត្រូវបន្ថែមទៀតទៅលើភ័ស្តុតាង ដូចជា មិនគិតទាល់តែសោះទៅលើភ័ស្តុតាង ដែលចង្អុលបង្ហាញថា ការរឹបអូសនិងដុតកម្ទេចគម្ពីគូរ៉ាអាន គឺជាកត្តាមួយដែលនាំទៅដល់ ការបះបោរនៅកោះផល[1741]។

483. ជាចុងក្រោយ ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយពឹងផ្អែក "ទាំងស្រុង" ទៅលើកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយ Nate Thayer ដើម្បីសម្រេចថា "នៅទូទាំងប្រទេស [...] គម្ពីរគូរ៉ាអាន ត្រូវបានរឹបអូស និងដុតបំផ្លាញចោល"[1742]។ ម្ចាស់បណ្ដឹងសាទុក្ខជំទាស់ចំពោះ លក្ខណៈនៃការសម្ភាសន៍ (ដូចជាថាការសម្ភាសន៍ត្រូវបាន "បំពេញដោយដៃ")[1743] ប៉ុន្តែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង អនុវត្តលើសបណ្ដឹងដែលបានដាក់ ដើម្បីឱ្យអង្គជំនុំជម្រះធ្វើការវាយតម្លៃទៅលើភ័ស្តុតាងឡើយ[1744]។ ទោះជាក្នុងករណីណាក្ដី "ការសម្រេច" ដែលរងការជំទាស់ គឺគ្រាន់តែជាការ

[1737] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៤៦។

[1738] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៤៣, ៩៤៨-៩៥០។

[1739] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៤៨-៩៥០។

[1740] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨, ៨៩, ២២៧។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាសំរឿងក្ដី ឌុច កថាខណ្ឌ ១៧។

[1741] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៥២-៣២៥៣។

[1742] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៥០ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៤៩-៣២៥០។

[1743] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៥០។

[1744] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨, ៨៩, ២២៧។

សង្ខេបខ្លឹមសារ នៃកិច្ចសម្ភាសន៍ ដែលពាក់ព័ន្ធតែត្រឹមការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ថា គម្ពីរគូរ៉អានក៏ត្រូវបានដុតបំផ្លាញផងដែរ នៅតាមទីកន្លែងផ្សេងៗ ក្រៅភូមិភាគបូព៌ា និងភូមិភាគកណ្តាល។

## *មូលដ្ឋានទី ១៤៥៖ ការរឹតត្បិតសេរីភាពសាសនា*[1745]

484. **មូលដ្ឋានទី ១៤៥ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយការសម្រេចថា ធាតុផ្សំសត្យានុម័តនៃអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ត្រូវបានកំណត់។**

485. មូលដ្ឋាននេះមិនទទួលផលឡើយ ព្រោះម្ចាស់បណ្តឹងសាទុក្ខ បកស្រាយដោយខុសឆ្គង ទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយលើកឡើងថា ការសម្រេចពីការមិនអាចអនុញ្ញាតបានតាមផ្លូវច្បាប់ ចំពោះការរឹតត្បិតផ្នែកវប្បធម៌ និងសាសនា ទៅលើជនជាតិចាមនោះ គឺទាក់ទងជាមួយការសម្រេចនៅពេលក្រោយ អំពីការរំលោភបំពានទៅលើសិទ្ធិជាសារវន្តប៉ុណ្ណោះ។ ការបកស្រាយបែបនេះ គឺ ម្ចាស់បណ្តឹងសាទុក្ខមិនពិចារណាទាល់តែសោះ ទៅលើការសម្រេចជាក់ស្តែងរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការរំលោភបំពាន ទៅលើសិទ្ធិជាសារវន្តរបស់ជនជាតិចាម[1746]។

486. ទោះបីជាមានការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខក្តី[1747] តែអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចផ្សេងគ្នាទាំងស្រុងលើ (១) ការរើសអើសជាក់ស្តែង ដែលកើតឡើងពីការរិតត្បិត និង (២) ការរំលោភបំពានទៅលើ សេរីភាពនិងសិទ្ធិជាសារវន្ត ដែលត្រូវបានរំលោភបំពានតាមគ្រប់រូបភាព ដោយរាល់អំពើរើសអើងនានា ដែលធ្វើឡើងប្រឆាំងជនជាតិចាម[1748] ដូចដែលបាន

---

[1745] <u>មូលដ្ឋានទី ១៤៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការរឹតត្បិតសេរីភាពសាសនា* កថាខណ្ឌ ៩៥២-៩៥៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥១ (ភាសាអង់គ្លេស) ទំព័រ ៤៧ (ភាសាបារាំង) ទំព័រ ៧៣ (ភាសាខ្មែរ)។

[1746] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨។

[1747] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៣។

[1748] សម្រាប់ការសន្និដ្ឋានអំពីការរើសអើង សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨-៣៣២៩។ សម្រាប់ការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន និងកម្រិតស្ថានទម្ងន់, សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៣០-៣៣៣១។

តម្រូវ[1749]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដោយយល់ច្រឡំ ទៅលើធាតុផ្សំចម្បងនៃការធ្វើទុក្ខបុកម្នេញ[1750] គឺមិនត្រឹមត្រូវទាល់តែសោះ ដូច្នេះហើយគួរត្រូវបានបដិសេធចោល។

487. បន្ថែមលើនេះ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរឹតត្បិតបែបរើសអើង គឺមិនអាចអនុញ្ញាតបាននោះ គឺមានការវិភាគគ្រប់គ្រាន់[1751]។ ដើម្បីគាំទ្រការសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះបានយោង ដូច្នេះគឺបានវិភាគយ៉ាងច្បាស់ ទៅលើមូលដ្ឋានដែលសេរីភាព ក្នុងការសម្តែងការគោរពសាសនា អាចត្រូវបានអនុញ្ញាតឱ្យរឹតត្បិតបាន[1752] ដោយច្រានចោលភាពអាចអនុវត្តបាន នៃមូលដ្ឋានទាំងអស់នេះ ទៅលើ "អង្គហេតុនៃសំណុំរឿង"[1753]។

### *មូលដ្ឋានទី ១៤៦៖ ការចោទប្រកាន់ខុសច្បាប់ ពីការរើសអើងដោយប្រយោល*[1754]

---

[1749] ដូចដែល អ.ជ.ត.ក បានសន្និដ្ឋានកាលពីពេលមុន "ចំណុចសំខាន់បំផុតនៃការវិភាគនេះ គឺមិនមែនផ្ចិតទៅលើការកំណត់ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញជាក់លាក់ *នេះ* រំលោភលើសិទ្ធិមនុស្សដែលជាសិទ្ធិសារវន្តដែរឬយ៉ាងណានោះឡើយ។ ប៉ុន្តែ ស្ថិតនៅលើការកំណត់ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញនេះ នៅពេលដែលពិចារណាជារួម និងទៅតាមបរិបទ នាំឱ្យមានការរំលោភលើសិទ្ធិជាសារវន្ត ដោយកំរោល ឬឥតលាក់លៀម"។ សូមមើល ឯកសារ **F28** សាលដីការឿងក្តីឌុច កថាខណ្ឌ ២៥៦-២៥៨ (ការដកស្រង់នៅក្នុងកថាខណ្ឌ ២៥៧)។ សូមមើល ចម្លើយតបបន្ថែមទៅនឹងមូលដ្ឋានទី ១០៩។

[1750] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៣។

[1751] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥២-៩៥៣។

[1752] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៩-៧២១។ សូមមើល ជាពិសេស កថាខណ្ឌ ៧២០ ("អង្គជំនុំជម្រះយល់ស្រប [...] ថា សេរីភាពសម្តែងពីការគោរពសាសនា ឬជំនឿរបស់ខ្លួន អាចត្រូវបានដាក់កំហិតមួយចំនួន។ ប៉ុន្តែ ការកំហិតទាំងនោះត្រូវតែកំណត់ដោយបញ្ញត្តិច្បាប់ និងមានសារសំខាន់ដល់ការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខភាព សីលធម៌ ឬសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់បុគ្គលផ្សេងទៀត") *ដកស្រង់* ICCPR មាត្រា ១៨(៣)។ ECHR មាត្រា ៩(២)។

[1753] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២១។ សហព្រះរាជអាជ្ញាកត់សម្គាល់បន្ថែមទៀតថា ទោះបីជាមិនត្រូវបានតម្រូវឱ្យធ្វើបែបនេះក្តី ប៉ុន្តែ នៅក្នុងកថាខណ្ឌយោងទាំងនេះ (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៩-៧២១) អ.ជ.ស.ដ ពិតជាបានកំណត់យ៉ាងច្បាស់លាស់ពីសិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភដោយការដាក់កំហិតវប្បធម៌ និងសាសនា។ សូមមើល ចម្លើយតបបន្ថែមទៅនឹងមូលដ្ឋានទី ១៤៨។

[1754] មូលដ្ឋានទី ១៤៦៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការចោទប្រកាន់ខុសច្បាប់ពីការរើសអើងដោយប្រយោល* កថាខណ្ឌ ៩៥៤-៩៥៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥១-៥២ (ភាសាអង់គ្លេស) ទំព័រ ៤៧ (ភាសាបារាំង) ទំព័រ ៧៣ (ភាសាខ្មែរ)។

488. **មូលដ្ឋានទី ១៤៦ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គច្បាប់ ដោយសម្រេចថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញ ទៅលើជនជាតិចាម ដោយមូលហេតុសាសនា ត្រូវបានកំណត់។**

489. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយខុសថា ការប្រព្រឹត្តទៅលើជនជាតិចាម គឺមិនខុសគ្នាឡើយ ដោយមិនពិចារណាទៅលើ ការសម្រេចជាគន្លឹះនានា ដែលផ្ទុយពីទឡ្ហីករណ៍របស់គាត់។ ម្ចាស់បណ្តឹងសាទុក្ខយល់ខុសបន្ថែមទៀត អំពីនិយមន័យផ្លូវច្បាប់ នៃ "ការរើសអើងជាក់ស្តែង"។

490. ទីមួយ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ផ្អែកទៅលើការអះអាងដោយខុសឆ្គងដែលថា ការប្រព្រឹត្តទៅលើជនជាតិចាម គឺមិនខុសគ្នាឡើយ ដូច្នេះគឺ "ការរើសអើងដោយប្រយោល"[1755]។ គាត់មិនបានពិចារណាទាល់តែសោះ ទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើរើសអើងត្រូវបានប្រព្រឹត្តឡើង អនុលោមទៅតាមមគោលនយោបាយ ដែលកំណត់គោលដៅជាពិសេស ទៅលើជនជាតិចាម[1756]។ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខ អាចមិនយល់ស្របជាមួយ ការសម្រេចនេះក្តី តែគាត់មិនបានបង្ហាញថា ការសម្រេចនេះធ្វើឡើងដោយមានកំហុសឡើយ[1757]។ ម្ចាស់បណ្តឹងសាទុក្ខ មិនបានពិចារណាផងដែរថា ផ្ទុយពី "ការប្រព្រឹត្តមិនខុសគ្នា" នោះ អំពើជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថាបានប្រព្រឹត្តនោះ គឺអាចបង្ហាញគោលដៅ*តែទៅលើ*ជនជាតិចាមប៉ុណ្ណោះ ដូចជាការហាមឃាត់ការថ្វាយបង្គំរាល់ថ្ងៃ ការដុតគម្ពីរគូរ៉ាន ការបង្ខំឱ្យនិយាយភាសាខ្មែរ ការបង្ខំឱ្យបោះបង់ចោល សម្លៀកបំពាក់ប្រពៃណីខ្លួន និងការកម្ទេចវិហារអ៊ីស្លាម[1758] ដែលពាក់ព័ន្ធតែលក្ខណៈពិសេសនៃវប្បធម៌ចាមប៉ុណ្ណោះ។

491. ទីពីរ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា[1759] អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងដោយសម្រេចថា អំពើនៃ "ការរើសអើងដោយប្រយោល" គឺជា "អំពើរើសអើងជាក់ស្តែង" ដោយមិនគិតថា មានលក្ខខណ្ឌតម្រូវគតិយុត្តិ ក្នុងការញែកឱ្យដាច់ពីគ្នារវាង ការរើសអើង "ផ្ទាល់" ឬ "ប្រយោល" នៅពេលវាយតម្លៃទៅលើអត្ថិភាព នៃការរើសអើងជាក់ស្តែង ដូចដែលបានកំណត់ពី

---

[1755] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៥។

[1756] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨។

[1757] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៦។

[1758] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨។

[1759] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៤-៩៥៥។

ខាងលើរួចហើយ[1760]។ ដូចដែលបានគូសបញ្ជាក់ពីខាងលើ អំពើមួយអាចអនុវត្តទៅលើប្រជាជនទាំងមូល ហើយនៅតែអាចបង្កើតបានជាអំពើរើសអើងជាក់ស្តែង ប្រសិនបើអំពើនោះមានផលវិបាក ជាការរើសអើងទៅលើក្រុមជាក់លាក់[1761]។

### *មូលដ្ឋានទី ១៤៧៖ គ្មានចេតនារើសអើង ចំពោះការប្រតិបត្តិសាសនា/វប្បធម៌*[1762]

492. **មូលដ្ឋានទី ១៤៧ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គច្បាប់ ដោយសម្រេចថា មានការរឹតត្បិតដែលមានចេតនារើសអើង ទៅលើជនជាតិចាម ដោយសារតែការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ។**

493. មូលដ្ឋាននេះមិនទទួលផលឡើយ ព្រោះ ម្ចាស់បណ្តឹងសាទុក្ខ បកស្រាយមិនត្រឹមត្រូវនូវការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងយល់ច្រឡំទៅលើច្បាប់។ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់សំអាងហេតុ សម្រាប់ការសម្រេចអំពីចេតនា ដោយយោងជាពិសេសទៅលើការមិនមានជើងទំព័រត្រង់ការសម្រេច[1763]។ នៅពេលដែលអានការសម្រេចជារួម និងផ្អែកលើបរិបទ ច្បាស់ណាស់ថា ការអះអាងនេះមិនត្រឹមត្រូវទេ។ ប្រយោគដែលរងការជំទាស់ ចាប់ផ្តើមដោយយោងទៅរកកថាខណ្ឌពីខាងដើម[1764] ដែលសង្ខេបពីការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងចេតនា[1765]។ ការសម្រេចទាំងអស់នេះ គឺមានដាក់ជើងទំព័ររួចហើយ។

494. ម្ចាស់បណ្តឹងសាទុក្ខ ក៏បានអះអាងដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង អនុវត្តដោយខុសនូវចេតនា ពីការសម្រេចរបស់ខ្លួនដែលថា អំពើរើសអើងប៉ះពាល់ដល់ការប្រតិបត្តិសាសនា។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចយ៉ាងច្បាស់ថា អំពើត្រូវបានអនុវត្តឡើងអនុលោមទៅតាមគោលនយោបាយ ដែលបង្ហាញគោលដៅជាពិសេស ទៅលើជនជាតិចាម ជា

---

[1760] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

[1761] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១២២។

[1762] <u>មូលដ្ឋានទី ១៤៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានចេតនារើសអើង ចំពោះការប្រតិបត្តិសាសនា/វប្បធម៌* កថាខណ្ឌ ៩៥៧-៩៥៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥២ (ភាសាអង់គ្លេស) ទំព័រ ៤៧ (ភាសាបារាំង) ទំព័រ ៧៣-៧៤ (ភាសាខ្មែរ)។

[1763] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៨។

[1764] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៩ (“យោងតាមចំណុចដែលបានបង្ហាញខាងលើ...”)។

[1765] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨។

ក្រុមសាសនា[1766]។ ការអះអាងរបស់ ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដោយពឹងផ្អែកទៅលើ "ការរើសអើងដោយប្រយោល" គឺជាការយល់ខុសទៅលើច្បាប់[1767] ដូចដែលបានពិភាក្សា នៅក្នុងចម្លើយតបចំពោះមូលដ្ឋានទី ១៤៦[1768]។ ទោះជាក្នុងករណីណាក្តី អង្គជំនុំជម្រះសាលាដំបូងមិនបានព្យាយាម បង្ហាញប្រភេទ "ការរើសអើងប្រយោលជាក់ស្តែង ដោយមិនមានចេតនារើសអើងឡើយ" ប៉ុន្តែអង្គជំនុំជម្រះបានធ្វើការសម្រេចច្បាស់លាស់ទៅលើចេតនា[1769]។

495. ចំពោះមតិរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុវប្បធម៌ មិនមានអត្ថិភាពនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះ[1770] អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែសម្រេចថាមានចេតនារើសអើង ដោយសារតែការប្រតិបត្តិសាសនានិងវប្បធម៌ របស់ជនជាតិចាម[1771]។ អង្គជំនុំជម្រះសាលាដំបូង មិនបានអះអាងថា មានការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងដាច់ដោយឡែក ឬថាមានអត្ថិភាពនៃឧក្រិដ្ឋកម្មបែបនេះឡើយ។ គ្មានកំហុសអង្គច្បាប់នោះទេ។

496. ជាចុងក្រោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាមានកំហុសដោយសម្រេចថា ជនជាតិចាមត្រូវបានបង្ហាញគោលដៅ ដោយមូលហេតុនយោបាយ និងសាសនា គឺមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ បានសន្មតដោយខុសឆ្គងថា ក្រុមជនរងគ្រោះមិនអាចត្រូវបានបង្ហាញគោលដៅ ជាច្រើនលើកច្រើនសារដោយផ្អែកលើមូលដ្ឋានធ្វើទុក្ខបុកម្នេញផ្សេងៗគ្នាឡើយ[1772]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់ការពន្យល់ ថាហេតុអ្វីទើបបានជាដូច្នេះ។ ក្នុងករណីនេះ ការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា គឺជាបទចោទដាច់ពីគ្នាដែលកើតឡើងពីអង្គហេតុផ្សេងគ្នា ហើយដោះស្រាយចំពោះសកម្មភាពឧក្រិដ្ឋខុសគ្នា[1773]។ ហេតុដូច្នេះ ផ្ទុយពីការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង មិនបាន "ធ្វើការផ្លាស់

[1766] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២២៨, ៣៣២៨។

[1767] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៨។

[1768] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៤៦។

[1769] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨-៣៣២៩។

[1770] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៨។

[1771] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៩។

[1772] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៩។

[1773] **ឯកសារ D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦-១៤១៨ (នយោបាយ), ១៤១៩-១៤២១ (សាសនា)។

ប្តូរមូលហេតុ នៃការធ្វើទុក្ខបុកម្នេញ ក្នុងការវិភាគរបស់ខ្លួន” ហើយមិនបានផ្តល់សំអាងហេតុសម្រាប់ការធ្វើបែបនេះឡើយ[1774]។ ប៉ុន្តែជាការសមស្របទាំងស្រុង បទចោទត្រូវបានពិចារណាដាច់ពីគ្នា ម្តងមួយៗ ហើយសំអាងហេតុពេញលេញ អំពីហេតុផលដែលបទចោទទាំងពីរ ត្រូវបានរកឃើញថាមានភ័ស្តុតាងគ្រប់គ្រាន់ ក៏បានផ្តល់ផងដែរ[1775]។

## *មូលដ្ឋានទី ១៣៦៖ ភាពមិនច្បាស់លាស់ និងភាពជាទូទៅ ទាក់ទងនឹងការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខភូមិទ្រា*[1776]

497. **មូលដ្ឋានទី ១៣៦ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ដោយសម្រេចថា ការសម្លាប់មនុស្សត្រូវបានធ្វើឡើង នៅមន្ទីរសន្តិសុខភូមិទ្រា នៅក្នុងឆ្នាំ១៩៧៨ ដែលដូច្នេះគឺបង្ហាញបានពី ធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាត។**

498. មូលដ្ឋាននេះមិនទទួលផលឡើយ ព្រោះម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង (១) ធ្វើការសម្រេចមិនសមហេតុផល ដោយផ្អែកលើសក្ខីកម្មរបស់ អ៊ុត សេន, នោ សាទះ និង ម៉ាត់ ស (២) ធ្វើការប៉ាន់ប្រមាណមិនសមហេតុផល ដោយគ្មានភ័ស្តុតាង ឬ (៣) មានកំហុសអង្គច្បាប់ ទាក់ទងធាតុផ្សំសត្យានុម័ត នៃអំពើមនុស្សឃាត។

499. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មិនអាចបង្ហាញធាតុផ្សំសត្យានុម័ត នៃអំពើមនុស្សឃាត ដោយផ្អែកតែទៅលើមូលដ្ឋាន នៃសក្ខីកម្មរបស់ឈ្មោះ ម៉ាត់ ស, នោ សាទះ និង អ៊ុត សេន បានទេ[1777]។ ម្ចាស់បណ្តឹងសាទុក្ខបានវាយប្រហារ ទៅលើភាពអាចជឿជាក់ និងភាពអាចទុកចិត្តបានរបស់ នោ សាទះ និង ម៉ាត់ ស[1778] ប៉ុន្តែមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង អនុវត្តហួសបណ្តឹងដែលដាក់មក ដើម្បីឱ្យអង្គជំនុំជម្រះ អាចវាយតម្លៃទៅ

---

[1774] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៥៩។

[1775] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២០-៣៣២៦ (នយោបាយ), ៣៣២៧-៣៣៣២ (សាសនា)។

[1776] <u>មូលដ្ឋានទី ១៣៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ភាពមិនច្បាស់លាស់ និងភាពជាទូទៅ ទាក់ទងនឹងការសម្លាប់នៅមន្ទីរសន្តិសុខភូមិទ្រា* កថាខណ្ឌ ៨៩៤-៨៩៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៨-៤៩ (ភាសាអង់គ្លេស) ទំព័រ ៤៤ (ភាសាបារាំង) ទំព័រ ៦៩ (ភាសាខ្មែរ)។

[1777] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៩៧។

[1778] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៩៦-៨៩៧។

លើភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាន នៃភ័ស្តុតាងឡើយ[1779]។ ជាការគួរឱ្យកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ការពន្យល់ដោយមានសំអាងហេតុ អំពីការវាយតម្លៃរបស់ខ្លួន ទៅលើសាក្សីទាំងអស់នេះ ដោយច្រានចោលទឡ្ហីករណ៍ប្រហែលគ្នានេះ ដែលបានលើកឡើងដោយ ម្ចាស់បណ្តឹងសាទុក្ខ នៅដំណាក់កាលជំនុំជម្រះ[1780]។

500. បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងពាក់ព័ន្ធនឹង ទីតាំងរបស់ អ៊ឹត សេន នៅពេលដែលគាត់បានឃើញហេតុការណ៍សម្លាប់នោះ[1781]។ ទោះបីជាអាចមានការយល់ច្រឡំខ្លះៗ នៅក្នុងសក្ខីកម្មរបស់ អ៊ឹត សេន ទាក់ទងទីកន្លែងជាក់លាក់របស់គាត់ក្តី[1782] តែ អ៊ឹត សេន បានបញ្ជាក់ដោយឥតស្រពិចស្រពិលថា "អាចឃើញអ្វីដែលកើតឡើងយ៉ាងច្បាស់"[1783] ហើយគាត់អាចបង្ហាញអត្តសញ្ញាណ អ្នកជាប់ឃុំឃាំងនោះថាជាចាម មុនពេលដែលគាត់ឃើញពួកគេត្រូវបានសម្លាប់[1784]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់ ចំពោះភ័ស្តុតាងនេះទេ ហើយមិនបានចង្អុលបង្ហាញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនសមហេតុផលនោះឡើយ។

501. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ថា ជាជម្រើសមួយទៀត ការសម្រេចថាជនជាតិចាម ត្រូវបានសម្លាប់នៅភូមិទ្រា គឺជាការប៉ាន់ប្រមាណមិនសមហេតុផល ពីហេតុការណ៍មួយដែល

---

[1779] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[1780] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៧៩-៣២៨០។

[1781] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៩៥។

[1782] ជាការឆ្លើយតបទៅសហព្រះរាជអាជ្ញា អ៊ឹត សេន បាននិយាយថាបានឃើញជនជាតិចាមត្រូវគេសម្លាប់នៅពេលយប់ខណៈពេលគាត់លាក់ខ្លួននៅក្នុងព្រៃគម្ពោត ក្រោយពេលរត់គេចខ្លួន។ នៅពេលសួរដេញដោល គាត់ហាក់ចង់បញ្ជាក់ថា គាត់បានឃើញហេតុការណ៍នៅពេលថ្ងៃ មុនពេលគាត់រត់គេចខ្លួន ប៉ុន្តែ បន្ទាប់មក គាត់ក៏ពណ៌នាភ្លាមៗថា ហេតុការណ៍នេះកើតឡើងនៅពេលយប់ដែរ៖ ឯកសារ **E1/342.1** អ៊ឹត សេន ប្រតិចារឹក ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥, ម៉ោង ១៥.១៦.០២ ទំព័រ ៦៥ បន្ទាត់ ២២-២៤ ("ខ្ញុំរត់ពីផ្ទះហ្នឹងមក ខ្ញុំពួននៅក្នុងសាគូ ដើមសាគូបួនប្រាំគុម្ព ខ្ញុំពួន។ មកពួននៅកន្លែងក្នុងសាគូហ្នឹង ក្បែរផ្លូវវាហ្នឹង វាដើរយកមនុស្សទៅមាត់ទន្លេហ្នឹង ប្រហែល ៥ ម៉ែត្រវាស់ពីផ្លូវទៅខ្ញុំពួននៅកន្លែង") ម៉ោង ១៥.២៣.០០ ទំព័រ ៦៧ បន្ទាត់ ១៧-១៨ ("ខ្ញុំឃើញតែថ្ងៃ ឃើញអីចឹង ដល់យប់មិនឃើញទេ។ ថ្ងៃឃើញដោះខោខ្លីអាវហ្នឹង ដោះខោនៅតែខោខ្លីមួយហ្នឹង ចាប់ពីលើផ្ទះមកបិទភ្នែក ចងភ្នែក ចងដៃ ដោតពួរ")។

[1783] ឯកសារ **E1/342.1** អ៊ឹត សេន ប្រតិចារឹក ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ១៥.២៣.០០-១៥.២៤.០៤ ទំព័រ ៦៧-៦៨ បន្ទាត់ ២៥-១។

[1784] ឯកសារ **E1/342.1** អ៊ឹត សេន ប្រតិចារឹក ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥, ម៉ោង ១៥.០៦.៤៥-១៥.១១.២៥ ទំព័រ ៦៤-៦៥ បន្ទាត់ ១៩-២ ("ឃើញ បាទ ឃើញៗនៅលួចមើលបង្អួចតាមគ្នាមក គ្រប់ផ្ទះកាលនុ៎ង ក្បែរៗផ្ទះ ក្បែរគ្នាហ្នឹង ឃើញមនុស្សនៅនេះហ្នឹង នៅពេញៗផ្ទះ [...] សុទ្ធតែចាមទាំងអស់ ឃើញលួចមើលតាមពីបង្អួចមក ចាមទាំងអស់")។

នោ សាទះ និង ម៉ាត់ ស បានឃើញ[1785]។ ទឡ្ហីករណ៍នេះមិនទទួលផលឡើយ ព្រោះការសម្រេច របស់ អង្គជំនុំជម្រះសាលាដំបូង មិនមែនជាការប៉ាន់ប្រមាណ ពីហេតុការណ៍មួយនោះទេ។ នោ សាទះ និង ម៉ាត់ ស បានផ្តល់ភស្តុតាងអំពីហេតុការណ៍ផ្សេងគ្នា របស់ជនជាតិចាម ដែលត្រូវគេ សម្លាប់ ឬអណ្តែតទឹកស្លាប់នៅក្នុងទន្លេ[1786]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានពិចារណាទាល់តែ សោះផងដែរ ទៅលើភស្តុតាងរបស់ អ៊ីត សេន ដែលគាត់បានឃើញការសម្លាប់មនុស្ស[1787]។ ទោះ ជាក្នុងករណីណាក្តី ម្ចាស់បណ្តឹងសាទុក្ខមិនបានពន្យល់ថា ហេតុអ្វីទើបហេតុការណ៍តែមួយគត់ នៃ ការសម្លាប់ជនជាតិចាម មិនអាចបំពេញបានតាមលក្ខណៈ ធាតុផ្សំសត្យានុម័តនៃអំពើមនុស្ស ឃាត។

502. ទីបី នៅក្នុងសេចក្តីសង្ខេបរបស់គាត់ ទៅលើមូលដ្ឋាននេះ ដែលមាននៅក្នុងឧបសម្ព័ន្ធ ក ម្ចាស់ បណ្តឹងសាទុក្ខហាក់ដូចជាចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយ សម្រេចថា ការសម្លាប់បានបំពេញលក្ខខណ្ឌ ធាតុផ្សំសត្យានុម័ត នៃអំពើមនុស្សឃាត[1788]។ ការ អះអាងនេះមិនមានភស្តុតាងគាំទ្រទេ ដែលដូច្នេះហើយគួរត្រូវបានបដិសេធ[1789]។ ទោះជាក្នុង ករណីណាក្តី ការសម្លាប់មនុស្សបានបំពេញនូវធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតយ៉ាងច្បាស់ ក្រឡែត។ ធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាត គឺជាអំពើសកម្មឬអកម្ម ដែលបណ្តាលឱ្យជនរង គ្រោះស្លាប់[1790]។ បើតាមនិយមន័យ ការសម្លាប់គឺជាអំពើសកម្ម ដែលបណ្តាលឱ្យស្លាប់ជនរង គ្រោះ។

***មូលដ្ឋានទី ១៣៧៖ កង្វះភស្តុតាងចំពោះការចោទប្រកាន់ ពីការសម្លាប់មនុស្សនៅវត្តអូរត្រកួន***[1791]

---

[1785] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៩៨។

[1786] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៧៨-៣២៧៩។

[1787] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៧៦។

[1788] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៩ ("សេចក្តីសន្និដ្ឋានរងការរិះគន់៖ ធាតុផ្សំសត្យានុម័តនៃ បទមនុស្សឃាតត្រូវបានបង្ហាញ ចំពោះការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខភូមិទ្រា នៅឆ្នាំ១៩៧៨")។

[1789] វិធានផ្ទៃក្នុង វិធាន ១០៥(៣)។ សូមមើលផងដែរ បទដ្ឋាននៃការពិនិត្យឡើងវិញ។

[1790] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២៧។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤១២។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្តី ឌុច* កថាខណ្ឌ ៣៣១។

[1791] <u>មូលដ្ឋានទី ១៣៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កង្វះភស្តុតាងចំពោះការចោទប្រកាន់ពីបទមនុស្សឃាត នៅវត្ត អូរត្រកួន* កថាខណ្ឌ ៨៩៩-៩១០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៩ (ភាសាអង់គ្លេស) ទំព័រ ៥៥ (ភាសាបារាំង) ទំព័រ ៦៩-៧០ (ភាសាខ្មែរ)។

503. **មូលដ្ឋានទី ១៣៧ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ដោយសម្រេចថា ជនជាតិចាមត្រូវបានសម្លាប់នៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧ ដែលដូច្នេះគឺបង្ហាញបាន ធាតុផ្សំសត្យានុម័តនៃ អំពើមនុស្សឃាត។**

504. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយមិនសមហេតុផលថា (១) ជនជាតិចាមត្រូវបានចាប់ខ្លួន នៅតាមបណ្ដាភូមិនានា នៅក្នុងស្រុកកងមាស ហើយត្រូវបានគេយកទៅវត្តអូរត្រកួន និង (២) ប្រជាជនជាច្រើន ដែលភាគច្រើនជាជនជាតិចាម ត្រូវបានគេសម្លាប់នៅវត្តអូរត្រកួន ក្នុងឆ្នាំ ១៩៧៧។

505. ទីមួយ ម្ចាស់បណ្ដឹងសាទុក្ខ បកស្រាយមិនត្រឹមត្រូវនូវសាលក្រម ដោយការអះអាងថា អង្គជំនុំជម្រះសាលាដំបូង មិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើការសម្រេចស្ដីពីការចាប់ខ្លួន នៅក្នុងស្រុកកងមាស។ គាត់បានអះអាងដោយភាន់ច្រឡំថា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា "ខ្លួនមានតែ "ភស្តុតាងដែលឮតៗគ្នា""[1792]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា មានភស្តុតាងផ្ទាល់ពីអ្នកភូមិ សមាជិកកងកម្លាំងសន្តិសុខ និងកងឈ្លប អំពីជនជាតិចាម ត្រូវបានគេចាប់ខ្លួនជាប្រព័ន្ធ នៅតាមបណ្ដាភូមិនានា នៅក្នុងស្រុកកងមាស ហើយត្រូវបានគេយកទៅវត្តអូរត្រកួន[1793]។ ម្ចាស់បណ្ដឹងសាទុក្ខក៏បានអះអាងផងដែរថា ភស្តុតាងរបស់សាក្សីផ្ទាល់បួនរូប មកពីឃុំពាមជីកង និងភូមិអង្គរបាន២ គឺមិនគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចថា ប្រជាជនត្រូវបានចាប់ខ្លួន "ដោយមូលហេតុគ្រាន់តែជាចាមប៉ុណ្ណោះ"[1794]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូង មិនបានធ្វើការសម្រេចបែបនេះឡើយ ផ្អែកលើភស្តុតាងរបស់សាក្សីទាំង

---

[1792] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩០០ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០២។

[1793] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០២

[1794] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩០០, ៩០៥។

អស់នេះ[1795] ហើយក៏មិនមានការសម្រេចបែបនេះណាមួយ ពាក់ព័ន្ធទៅនឹងធាតុផ្សំសត្យានុម័ត នៃអំពើមនុស្សឃាតដែរ[1796]។

506. ម្ចាស់បណ្តឹងសាទុក្ខបានអះអាង ដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង "មានកំហុសអង្គច្បាប់" ដោយសម្រេចថា ជនជាតិចាមរាប់រយនាក់ មកពីក្នុងឃុំពាមជីកង ត្រូវបានចាប់ខ្លួនដោយសមាជិកក្រុមដាវវែង នៅដើមឆ្នាំ១៩៧៧[1797]។ ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខ មិនបានផ្តល់ការពន្យល់ណាមួយ ទាក់ទងថាតើ ចោទប្រកាន់ពីកំហុសអង្គច្បាប់អ្វី ដោយម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា ភ័ស្តុតាងមាន "តម្លៃតិចតួច"[1798] និងថា អង្គជំនុំជម្រះសាលាដំបូង គួរទាញសេចក្តីសន្និដ្ឋានផ្សេងពីសក្ខីកម្មសាក្សីដាច់តែឯង[1799] ដែលមិនអាចបង្ហាញថាជា កំហុសអង្គហេតុ ឬកំហុសអង្គច្បាប់ឡើយ។

507. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការសម្រេចថា ភាពច្រើននៃអ្នកដែលត្រូវសម្លាប់ នៅវត្តអូរត្រកួន នៅក្នុងឆ្នាំ១៩៧៧ គឺជនជាតិចាម ព្រោះមានភ័ស្តុតាងថា មានជនជាតិខ្មែរនៅទីនោះដែរ[1800]។ ទឡ្ហីករណ៍មិនសមហេតុផលនេះគឺមិនទទួលផលឡើយ ព្រោះមិនមានកំហុសឆ្គងទេ។ ការសម្រេចដែលថាមានជនជាតិចាមភាគច្រើននោះ បានបង្ហាញដោយច្បាស់ថា ក៏មានវត្តមានអ្នកដែលមិនមែនជាចាមនៅទីនោះដែរ។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា សក្ខីកម្មសាក្សីដែលបញ្ជាក់ថា មានជនជាតិចាមភាគច្រើននោះ គឺ "ផ្អែកលើការព្យួតគ្នា"[1801]។ ផ្ទុយទៅវិញ ទោះបីជាសាក្សី មុយ វ៉ាន់នី ត្រូវបានអ្នកដទៃប្រាប់ថា ពួកទាំងនោះជាជនជាតិចាមក្តី តែគាត់បានឃើញដោយផ្ទាល់ថា ប្រជាជន

[1795] សម្រាប់ការពិភាក្សារបស់ អ.ជ.ស.ដ ទៅលើភ័ស្តុតាងអំពីការបញ្ជាឱ្យកំណត់គោលដៅទៅលើជនជាតិចាម សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៥-៣២៩០។ សូមមើលបន្ថែមទៀត ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៧-៣២២៨។

[1796] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០៦។

[1797] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០១។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៩២។

[1798] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៩៩, ៩០១-៩០២

[1799] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៣-៩០៤។

[1800] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៦។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០៦។

[1801] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៨។

ចាមគឺមានភាគច្រើន[1802]។ ទោះជាក្នុងករណីបែបណាក្តី នេះគឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពិចារណា និងពឹងផ្អែកទៅលើភ័ស្តុតាងចចាមអារាម[1803]។

508. ម្ចាស់បណ្តឹងសាទុក្ខ ក៏បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចថា ភ័ស្តុតាងនៃការសម្លាប់ នៅវត្តអូរត្រកួន ត្រូវបានគាំទ្រដោយសមាជិកនៃកងសន្តិសុខដែលធ្វើការនៅទីនោះ នៅពេលនោះ[1804] ព្រមទាំងបង្ហាញហេតុស្តាប់ចម្លើយសាក្សីមួយចំនួន[1805]។ ជាការចម្លែក ម្ចាស់បណ្តឹងសាទុក្ខ ជំទាស់យ៉ាងខ្លាំងតែទៅលើ សក្ខីកម្មរបស់ឈ្មោះ ហ៊ឹម ម៉ាន ដែលមិនមានជាសមាជិកកងសន្តិសុខ ហើយមិនពិចារណាទាល់តែសោះ ទៅលើបុគ្គលិកសន្តិសុខជាក់ស្តែង ដែលបានផ្តល់ភ័ស្តុតាងគាំទ្រនោះ ដូចជា មុយ វ៉ាន់នី, សេង ស្រ៊ុន និង សំរិត មុយ[1806]។ ចំពោះបង្ហាញហេតុស្តាប់ចម្លើយ ម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែអះអាងថា បង្ហាញហេតុទាំងនោះមានតម្លៃភ័ស្តុតាងទាប ប៉ុន្តែមិនបានពន្យល់ថា ហេតុអ្វីទើបការប្រើប្រាស់កំណត់ហេតុទាំងនោះ ធ្វើជាភ័ស្តុតាងគាំទ្រ ទៅជាកំហុសឆ្គងទៅវិញ[1807]។

509. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុស "អង្គហេតុ និងអង្គច្បាប់" ក្នុងការសម្រេចថា មានភ័ស្តុតាងផ្ទាល់អំពី ជនជាតិចាមត្រូវបានគេចាប់ចង នៅវត្តអូរត្រកួន មុននឹងយកចេញទៅជាក្រុម[1808]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់នូវការពន្យល់ណាមួយ ថាចោទប្រកាន់ពីកំហុសអង្គច្បាប់អ្វី និងអះអាងដោយមិនបានលើកទឡ្ហីករណ៍បន្ថែមណាមួយថា ការសម្រេចនេះ "មិនត្រូវបានបង្ហាញទេ និងមិនគ្រប់គ្រាន់សម្រាប់បង្ហាញឱ្យឃើញ ពីអត្ថិភាពនៃការសម្លាប់ជនជាតិចាម ឱ្យហួសពីវិមតិសង្ស័យបានទេ"[1809]។ ទោះជាក្នុងករណីណាក្តី ការសម្រេចថាជនជាតិចាមត្រូវបានសម្លាប់ មិនមែនទាញយកទាំងស្រុង តែពី

---

[1802] ឯកសារ **E1/373.1** មុយ វ៉ាន់នី ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ម៉ោង ១៣.៤៨.៥៧-១៣.៥៨.១៦ ទំព័រ ៣៥-៣៧ (បានឃើញផ្ទាល់ភ្នែកជនជាតិចាមជាច្រើននាក់មកដល់វត្តអូរត្រកួនតាមកាណូត និងខ្មែរតិចតួចតាមរទេះ) ម៉ោង ១៤.២៥.៤៥-១៤.២៧.៤២ ទំព័រ ៤៨ (បានឃើញផ្ទាល់ភ្នែកជនជាតិចាមគេដាក់នៅក្នុងវិហារនៅវត្តអូរត្រកួន)។

[1803] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[1804] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៧។

[1805] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៩។

[1806] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៩៧-៣២៩៩។

[1807] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៩។

[1808] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១០ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០២។

[1809] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១០។

ភ័ស្តុតាងដែលថា ជនជាតិចាមត្រូវបានចាប់ចងនៅវត្ត មុននឹងយកចេញទៅជាក្រុមនោះឡើយ។ ភ័ស្តុតាងនេះគឺគ្រាន់តែរួមចំណែក ជាមួយភ័ស្តុតាងយ៉ាងច្រើនលើសលប់ដែលថា ជនជាតិចាមត្រូវបានគេសម្លាប់[1810]។

## *មូលដ្ឋានទី ១៣៨៖ សេចក្តីសន្និដ្ឋានមិនសមហេតុផល អំពីតួលេខនៃការសម្លាប់ដែលបានបង្ហាញ*[1811]

510. **មូលដ្ឋានទី ១៣៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ដោយសម្រេចថា ការសម្លាប់មនុស្សបង្កើតបានជា ធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាល ដែលបានប្រព្រឹត្តឡើងនៅវត្តអូរត្រកួន និងភូមិទ្រា។**

511. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុដោយ "បាននិយាយសរុបជាទូទៅ និងដោយបានស្មានលើចំនួនជនរងគ្រោះ" គឺសំអាងលើការអះអាងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេច អំពីការសម្លាប់ដែលកើតឡើង នៅភូមិទ្រា និងវត្តអូរត្រកួន។ ដូចដែលបានពិភាក្សានៅក្នុង ចម្លើយតបចំពោះមូលដ្ឋានទី ១៣៦ និងទី ១៣៧ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមត្រូវបានសម្លាប់ នៅទីតាំងទាំងអស់នេះ គឺជាការមិនសមហេតុផល[1812]។ បន្ថែមលើនេះផ្ទុយពីការ "ស្មាន" លើចំនួន អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយច្បាស់លាស់ថា មិនអាចបង្ហាញនូវចំនួនជាក់លាក់ នៃជនរងគ្រោះដែលត្រូវបានសម្លាប់ នៅទីតាំងទាំងអស់នេះ[1813]។ ទោះជាក្នុងករណីបែបណាក្តី ធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាល មិនបានតម្រូវឱ្យមានការកំណត់អំពីចំនួនមនុស្សស្លាប់ជាក់លាក់ឡើយ[1814]។

---

[1810] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០២។

[1811] <u>មូលដ្ឋានទី ១៣៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *សេចក្តីសន្និដ្ឋានមិនសមហេតុផលអំពីតួលេខនៃការសម្លាប់ដែលបានបង្ហាញ* កថាខណ្ឌ ៩១១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៩ (ភាសាអង់គ្លេស) ទំព័រ ៤៥ (ភាសាបារាំង) ទំព័រ ៧០ (ភាសាខ្មែរ)។

[1812] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣៦ និង ១៣៧។

[1813] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣១១។

[1814] *សាលដីការឿងក្តី Rukundo* កថាខណ្ឌ ១៨៧, ១៨៩។ *សាលក្រមរឿងក្តី Stakić* កថាខណ្ឌ ៦៥៤-៦៥៥។ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨២។

### *មូលដ្ឋានទី ១៣៩៖ សេចក្តីសន្និដ្ឋានមិនសមហេតុផល អំពីចេតនាសម្លាប់ជនជាតិចាម ក្នុងទ្រង់ទ្រាយធំ*[1815]

512. **មូលដ្ឋានទី ១៣៩ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ក្នុងការសម្រេចថា ជាតុផ្សំអត្តនោម័ត នៃឧក្រិដ្ឋកម្មសម្លាប់រង្គាល ត្រូវបានបង្ហាញ ពាក់ព័ន្ធការសម្លាប់នៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧ និងនៅភូមិទ្រា។**

513. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ (១) មិនបានគិតដល់សំអាងហេតុ និងការសម្រេចពាក់ព័ន្ធ របស់អង្គជំនុំជម្រះសាលាដំបូង (២) ធ្វើការជំទាស់ដោយគ្មានភ័ស្តុតាង ចំពោះការវាយតម្លៃទៅលើភ័ស្តុតាង និង (៣) បកស្រាយមិនត្រឹមត្រូវនូវសក្ខីកម្មរបស់សាក្សី។

514. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដោយខុស អំពីការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងទៅលើចេតនា ដោយម្ចាស់បណ្តឹងសាទុក្ខមិនបានពិចារណាទាល់តែសោះ ទៅលើចំណុចសំខាន់នៃសំអាងហេតុរបស់អង្គជំនុំជម្រះ៖ ការសម្រេចដែលថា ការសម្លាប់ជនជាតិចាម "ត្រូវបានរៀបចំ និងដោយមានការគិតទុកជាមុន ដោយប្រុងប្រយ័ត្ន អនុលោមទៅតាម គោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់គោលដៅលើជនជាតិចាម"[1816]។ ម្ចាស់បណ្តឹងសាទុក្ខបែរជាលើកឡើងថា ចេតនាគឺផ្អែកទាំងស្រុងទៅលើភ័ស្តុតាងនៃការបញ្ជា និងកិច្ចប្រជុំជាក់លាក់នានាទៅវិញ[1817] ហើយផ្តោតជាសំខាន់តែទៅលើចំណុចនេះ។

515. ម្ចាស់បណ្តឹងសាទុក្ខ អះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុដោយសម្រេចថា កែ ពក បានបញ្ជាដល់ បាន សៀក ឱ្យកម្ទេចជនជាតិចាមទាំងអស់ នៅក្នុងកិច្ចប្រជុំមួយនៅកំពង់ថ្ម[1818]។ អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចបែបនេះទេ[1819]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា កិច្ចប្រជុំត្រូវបានរៀបចំឡើង ដើម្បីពិភាក្សាអំពីការកម្ទេចខ្មាំង

---

[1815] <u>មូលដ្ឋានទី ១៣៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *សេចក្តីសន្និដ្ឋានមិនសមហេតុផលអំពីចេតនាសម្លាប់ជនជាតិចាម ក្នុងទ្រង់ទ្រាយធំ* កថាខណ្ឌ ៩១២-៩២៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៩-៥០ (ភាសាអង់គ្លេស) ទំព័រ ៤៥ (ភាសាបារាំង) ទំព័រ ៧០-៧១ (ភាសាខ្មែរ)។

[1816] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣១៣។

[1817] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១២។

[1818] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១៣-៩១៤។

[1819] អ.ជ.ស.ដ បានទទួលស្គាល់យ៉ាងជាក់ច្បាស់នូវការបដិសេធរបស់ បាន សៀក ថាគាត់បានចេញបញ្ជានេះ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៧៣។

ហើយក្រោយនោះបានបន្តិច ជនជាតិចាមត្រូវបានផ្លាស់ទី ហើយក៏បានបាត់ខ្លួន[1820]។ មិនមែន "បំភ្លៃ"[1821] នោះទេ ការសម្រេចនេះគឺស្របគ្នាទាំងស្រុង ជាមួយភស្តុតាងរបស់ វ៉ាន់ ម៉ាត់[1822]។ ម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយខុសឆ្គងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដោយមិនបានផ្តល់ "ការយោងណាមួយដែលមានសុពលភាព សម្រាប់គាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួន" ពាក់ព័ន្ធទៅនឹងភូមិភាគកណ្តាល[1823]ប៉ុន្តែតាមពិតទៅ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ការយោង និងសំអាងហេតុលម្អិត[1824] ដែលម្ចាស់បណ្តឹងសាទុក្ខបានត្រឹមតែមិនយល់ស្រប។

516. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខបកស្រាយមិនត្រឹមត្រូវចំពោះការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសក្ខីកម្មរបស់ ប្រាក់ យុត និងសេង ស្រ៊ុន[1825]។ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់សំអាងហេតុលម្អិត ទាក់ទងភាពអាចជឿជាក់បានរបស់ ប្រាក់ យុត[1826] ហើយភស្តុតាងរបស់គាត់ត្រូវបានគាំទ្រយ៉ាងទូលំទូលាយ[1827]។ អង្គជំនុំជម្រះសាលាដំបូង មិនបាន "ដកចេញដោយពុំត្រឹមត្រូវ" នូវភស្តុតាងរបស់ សេង ស្រ៊ុន អំពីបញ្ហាជនជាតិចាម មិនត្រូវបានពិភាក្សានៅកិច្ចប្រជុំនោះទេ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាយ៉ាងច្បាស់លាស់ ទៅលើភស្តុតាងនោះ[1828]។ ទោះក្នុងករណីណាក្តី អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិទទួលយក សក្ខីកម្មមួយផ្នែករបស់សាក្សី ហើយច្រានចោលផ្នែកផ្សេងទៀត[1829]។

517. ចំពោះ យូ វ៉ាន់ ម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែមិនយល់ស្របជាមួយនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើភស្តុតាង ដែលជាចម្បងគឺអំពីអង្គហេតុដែលថា មានការចងក្រងបញ្ជីកំណត់អត្តសញ្ញាណ អ្នកដែលមិនមែនជាជនជាតិខ្មែរ ហើយបន្ទាប់មកអ្នកមិនមែនជាជនជាតិខ្មែរ

---

[1820] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៧៥។

[1821] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១៣។

[1822] ឯកសារ **E1/398.1** វ៉ាន់ ម៉ាត់ តិចារឹក ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៦ ម៉ោង ១០.៥១.២៣ ទំព័រ ២៧ បន្ទាត់ ២ ("ក្រោយពីកិច្ចប្រជុំមក ផែនការគេរៀបចំដឹកជម្លៀសប្រជាពលរដ្ឋចាមនៅហ្នឹងបន្ថែមទៀត")។

[1823] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១៥។

[1824] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៥-៣២៩០។

[1825] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១៦-៩១៨។

[1826] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៩១។

[1827] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៥។

[1828] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៦ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩១៧។

[1829] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ សេចក្តីសម្រេចមានសំអាងហេតុ)។

ត្រូវបានបាត់ខ្លួនជាបន្តបន្ទាប់[1830]។ ការនេះគាំទ្រផងដែរ ទៅលើភ័ស្តុតាងរបស់ ប្រាក់ យុត[1831]។ ម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើង ពីការពិចារណាដែលមិនពាក់ព័ន្ធជាច្រើន ដូចជាបញ្ជីដែលមានឈ្មោះអ្នកមិនមែនជនជាតិចាម ដើម្បីជំទាស់ទៅលើភ័ស្តុតាង។ ប៉ុន្តែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង អនុវត្តហួសពីបណ្ដឹង ដែលប្ដឹងមកអង្គជំនុំជម្រះ ដើម្បីធ្វើការវាយតម្លៃទៅលើភ័ស្តុតាង[1832] ឬថា ភ័ស្តុតាងរបស់ យូ វ៉ាន់ គឺសំខាន់ចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនា។

518. ទីបី ម្ចាស់បណ្ដឹងសាទុក្ខ មានអះអាងដោយខុសឆ្គងថា ភ័ស្តុតាងរបស់ យាន លន់ និង សយ ឌឿន គួរត្រូវបានច្រានចោល ដោយសារជាភ័ស្តុតាងចចាមអារាម[1833]។ អង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការពិចារណាទៅលើភ័ស្តុតាងចចាមអារាម[1834] ហើយម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តលើសឆន្ទានុសិទ្ធិរបស់ខ្លួន ជាពិសេសដោយសារតែភ័ស្តុតាងនេះ មានការគាំទ្រ[1835]។ ម្ចាស់បណ្ដឹងសាទុក្ខ ក៏បានបកស្រាយមិនត្រឹមត្រូវអំពីភ័ស្តុតាងរបស់ សយ ឌឿន ផងដែរ ដោយលើកឡើងថា គាត់ទាយស្មានអំពីប្រភពនៃបញ្ជា[1836] បើទោះបីជា សយ ឌឿន បញ្ជាក់ម្ដងហើយម្ដងទៀតថា គេប្រាប់គាត់ថាបញ្ជា គឺមកពីថ្នាក់លើក្ដី[1837]។

519. ម្ចាស់បណ្ដឹងសាទុក្ខ បានលើកឡើងដោយខុសឆ្គងប្រហែលគ្នា អំពីភ័ស្តុតាងរបស់ សំរិត មុយ ដោយលើកឡើងថា សំរិត មុយ "ស្មាន" ថា ការប្រជុំដែលគាត់បានចូលរួម គឺទាក់ទងជាមួយការ

---

[1830] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៧។

[1831] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៨។

[1832] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨-៨៩, ២២៧។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា កថាខណ្ឌ ១៧។

[1833] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩១៩, ៩២១។

[1834] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[1835] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៥។

[1836] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩២០។

[1837] ឯកសារ **E1/374.1** សយ ឌឿន ប្រតិចារិក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ម៉ោង ១៤.១០.១៥-១៤.១៣.៣០ ទំព័រ ៥៦ បន្ទាត់ ៤ ("[ភាពប្រាប់ថា] ចាប់ដាក់ថ្នាក់លើមក ប្រាប់តាមឃុំហ្នឹង ឃុំមកប្រាប់ខ្ញុំហ្នឹង ប្រាប់បន្តគ្នាអ៊ីចឹង") ម៉ោង ១៥.២២.០០-១៥.២៤.៤៣ ទំព័រ ៧១ បន្ទាត់ ១៨-២០ ("សៈ ដូច្នេះ តើភាពខ្លួនឯងផ្ទាល់ដែលប្រាប់លោកថា "នេះជាបញ្ជាពីថ្នាក់លើដែលខ្ញុំបានទទួល"។ អ៊ីចឹងឬ? ឆៈ បាទ អ៊ីចឹងមែន") ម៉ោង ១៥.២៤.៤៣ ទំព័រ ៧១ បន្ទាត់ ២៤ ("[ភាព] គ្រាន់តែថាប្រាប់ថ្នាក់លើៗ")។

ចាប់ខ្លួនជនជាតិចាម[1838]។ សំរិត មុយ គ្រាន់តែរំឭកថា ចាមត្រូវបានចាប់ខ្លួន ក្រោយការប្រជុំនោះបន្តិច[1839] ដូចដែលបានកត់សម្គាល់ដោយត្រឹមត្រូវ ដោយអង្គជំនុំជម្រះសាលាដំបូង[1840]។

## *មូលដ្ឋានទី ១៤០៖ ការធ្វើទារុណកម្ម*[1841]

520. **មូលដ្ឋានទី ១៤០ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ តាមរយៈការសម្រេចថា ការធ្វើទារុណកម្មត្រូវបានប្រព្រឹត្តឡើង នៅមន្ទីរសន្តិសុខភូមិទ្រា។**

521. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ (១) មិនបានបង្ហាញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមត្រូវបានធ្វើទារុណកម្ម គឺជាការសម្រេចមួយ ដែលគ្មានអ្នកវិនិច្ឆ័យលើអង្គហេតុ ដោយសមហេតុផលណាម្នាក់ អាចសម្រេចដូច្នេះឡើយ និង (២) បកស្រាយមិនត្រឹមត្រូវនូវសក្ខីកម្មសាក្សីដែលខ្លួនជំទាស់។

522. ចំពោះធាតុផ្សំសត្យានុម័តនៃការធ្វើទារុណកម្ម ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា អង្គជំនុំជម្រះសាលាដំបូងមិនអាចពឹងផ្អែក ទៅលើសាក្សីតែមួយរូប ដើម្បីគាំទ្រដល់ការសម្រេច ឱ្យហួសពីវិមតិសង្ស័យឡើយ។ មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែមានការកំណត់យ៉ាងច្បាស់រួចហើយថា អង្គជំនុំជម្រះសាលាដំបូង អាចពឹងផ្អែកទៅលើសាក្សីតែមួយរូប ដើម្បីគាំទ្រដល់ការសម្រេច[1842]។ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា ការសម្រេចដែលថាជនជាតិចាមត្រូវបានវាយដំបែបនេះ គឺជាការសម្រេចមួយដែលគ្មានអ្នកវិនិច្ឆ័យឥតលម្អៀងលើអង្គហេតុណាម្នាក់ អាចសម្រេចដូច្នេះឡើយ។

523. ចំពោះធាតុផ្សំអត្តនោម័ត នៃការធ្វើទារុណកម្ម ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសថា សក្ខីកម្មរបស់ អ៊ុត សេន គឺផ្ទុយគ្នា។ ម្ចាស់បណ្តឹងសាទុក្ខបានវាយប្រហារ ទៅលភាពអាចជឿជាក់បាន នៃភ័ស្តុតាងរបស់សាក្សី ដោយបញ្ជាក់ថា គាត់ត្រូវបានគេទាត់ម្តងហើយម្តងទៀត

---

[1838] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩២៣។

[1839] ឯកសារ **E1/347.1** សំរិត មុយ ប្រតិចារឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ១០.១៣.៣៦-១០.១៩.៤៥ ទំព័រ ២៣-២៤។

[1840] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២៨៦, ៣២៩០។

[1841] <u>មូលដ្ឋានទី ១៤០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទារុណកម្ម* កថាខណ្ឌ ៩២៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥០ (ភាសាអង់គ្លេស) ទំព័រ ៤៥-៤៦ (ភាសាបារាំង) ទំព័រ ៧១ (ភាសាខ្មែរ)។

[1842] *សាលដីការឿងក្តី Nahimana* កថាខណ្ឌ ៩៤៩។

នៅពេលដែលគេសួរគាត់ថា តើគាត់ជាពួកអ៊ីស្លាមមែនឬទេ[1843] ដោយលើកទឡ្ហីករណ៍ថា ភ័ស្តុតាងមានភាពផ្ទុយគ្នា ដោយសារសាក្សីជឿជាក់ថា អ្នកធ្វើទារុណកម្មបានដឹងរួចទៅហើយថា គាត់គឺជាចាម[1844]។ អង្គហេតុនេះតែមួយ មិនបានបង្ហាញផ្ទុយចំពោះ ភ័ស្តុតាងរបស់គាត់ទេ។ ទោះជាក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា "ភាពផ្ទុយគ្នា" បែបនេះ នឹងធ្វើឱ្យប៉ះពាល់ដល់ការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការវាយដំគឺដើម្បីកំណត់អត្តសញ្ញាណ ថាតើអ្នកជាប់ឃុំឃាំងគឺជាចាមមែនឬទេ ដែលដូច្នេះហើយគឺបំពេញបាននូវធាតុផ្សំអត្តនោម័តនៃការធ្វើទារុណកម្ម[1845]។

### *មូលដ្ឋានទី ១៤២៖ កំហុសពាក់ព័ន្ធគោលបំណងចម្បង នៃការជម្លៀសប្រជាជន*[1846]

524. **មូលដ្ឋានទី ១៤២ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ដោយការសម្រេចថា ការផ្លាស់ទីលំនៅជនជាតិចាមដោយបង្ខំ ត្រូវបានធ្វើឡើងដោយចេតនារើសអើង ដែលដូច្នេះបានបង្ហាញ នូវធាតុផ្សំអត្តនោម័តិ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ។**

525. មូលដ្ឋាននេះមិនទទួលផលឡើយ ព្រោះម្ចាស់បណ្តឹងសាទុក្ខ អះអាងដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាទៅលើ "កត្តា" ចំនួនបី ដែលផ្ទុយជាមួយការសម្រេច របស់អង្គជំនុំជម្រះដែលថា ជនជាតិចាមត្រូវបានកំណត់គោលដៅ ដោយមានចេតនារើសអើង។ ម្ចាស់បណ្តឹងសាទុក្ខក៏មិនបាន បង្ហាញផងដែរថា កត្តាទាំងអស់នេះ ចង្អុលបង្ហាញថា ការសម្រេចជាស្ថាពររបស់ អង្គជំនុំជម្រះសាលាដំបូង គឺជាការសម្រេចមួយ ដែលមិនមានអ្នកវិនិច្ឆ័យលើអង្គហេតុ ដោយសមហេតុផលណាម្នាក់ អាចសម្រេចដូច្នេះឡើយ។

526. ជាដំបូង ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូង មិនបានពន្យល់ថាហេតុអ្វី ទើបអង្គជំនុំជម្រះពិចារណាថា "សហគមន៍របស់ពួកគេបែកបាក់" និង "ដើម្បី

---

[1843] ឯកសារ **E1/342.1** អ៊ីត សេន ប្រតិចារឹក ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ១៤.៣៧.១៥-១៤.៣៩.២៨ ទំព័រ ៦១ បន្ទាត់ ៤-៥ ("វាយធាក់ដួលដេក [...] ហើយសួរ សួរថា ខ្មែរ ចាមៗ")។

[1844] ឯកសារ **E1/342.1** អ៊ីត សេន ប្រតិចារឹក ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ១៤.៣៧.១៥-១៤.៣៩.២៨ ទំព័រ ៦១ បន្ទាត់ ៦ ("វាដឹងថាចាមហើយ")។

[1845] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣១៨។

[1846] <u>មូលដ្ឋានទី ១៤២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងគោលបំណងចម្បងនៃការជម្លៀសប្រជាជន* កថាខណ្ឌ ៩២៨-៩៣១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥០ (ភាសាអង់គ្លេស) ទំព័រ ៤៦ (ភាសាបារាំង) ទំព័រ ៧១-៧២។

បន្ថយភាពតានតឹង” គឺជាគោលបំណងធំ សម្រាប់ការបំបែកជនជាតិចាម[1847]។ អង្គជំនុំជម្រះសាលាដំបូង បានពន្យល់យ៉ាងច្បាស់ថា ការនេះត្រូវបានបង្ហាញតាម ទូរលេខ១៥[1848]។ ម្ចាស់បណ្តឹងសាទុក្ខអាចមិនយល់ស្រប ជាមួយការវាយតម្លៃរបស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើទូរលេខ១៥ ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា ការសម្រេចនេះមិនសមហេតុផលឡើយ។

527. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងអំពីការផ្លាស់ទីលំនៅ ជនជាតិចាមដែលរស់នៅតាម ព្រំដែនជាមួយប្រទេសវៀតណាម[1849] ដោយលើកឡើងវិញទាំងស្រុង នូវទឡ្ហីករណ៍ដែលគាត់បានលើកឡើង នៅក្នុងពេលសវនាការ ហើយត្រូវបានបដិសេធនោះ[1850]។ អង្គជំនុំជម្រះសាលាដំបូង មិនត្រឹមតែបានទទួលស្គាល់ពីទឡ្ហីករណ៍នេះប៉ុណ្ណោះទេ[1851] ប៉ុន្តែអង្គជំនុំជម្រះថែមទាំងសម្រេចយ៉ាងច្បាស់ថា អ្នកដែលរស់នៅតាមបណ្តោយដងទន្លេមេគង្គ ត្រូវបានគេកំណត់គោលដៅជាពិសេស លើសអ្នកដែលរស់នៅតាមបណ្តោយព្រំដែន[1852]។ ហេតុដូច្នេះច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូង បានពិចារណាទៅលើក្រុមជនជាតិចាមទាំងពីរ នៅក្នុងសំអាងហេតុរបស់ខ្លួន។ ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែមិនបានបង្ហាញថា សេចក្តីសម្រេចនោះមិនសមហេតុផលនោះឡើយ។

528. ទីបី ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានដោយខុសឆ្គងថា មានចេតនាក្នុងការដាក់ទណ្ឌកម្ម តាមរយៈការផ្លាស់ទីលំនៅជនជាតិចាម[1853]។ អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចបែបនេះទេ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថាការផ្លាស់ទីលំនៅ ជនជាតិចាមនៅភូមិភាគបូព៌ា គឺមានគោលបំណងជាចម្បង ដើម្បី

---

[1847] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩២៨-៩២៩។

[1848] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១២ *ដកស្រង់* ឯកសារ **E3/1680** ទូរលេខ ១៥ របស់ សោ ភឹម ផ្ញើទៅ ប៉ុល ពត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ១៩៧៥។

[1849] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៣០។

[1850] ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២០។

[1851] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១១-៣២១២។

[1852] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១២។

[1853] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៣០។

បន្ថយភាពតានតឹងបន្ទាប់ពីមានការបះបោរ និងដើម្បីបំបែកសហគមន៍របស់ពួកគេ[1854]។ ចំពោះទឡ្ហីករណ៍ទាក់ទងអត្ថិភាពនៃផែនការ ផ្លាស់ទីលំនៅប្រជាជន ដែលបានធ្វើឡើងនៅមុនពេល មានការបះបោររបស់ជនជាតិចាមនោះ ម្ចាស់បណ្តឹងសាទុក្ខជាថ្មីម្តងទៀត បានលើកឡើងម្តងទៀត ទាំងស្រុងនូវទឡ្ហីករណ៍ដែលគាត់បានលើកឡើង នៅក្នុងពេលសវនាការ ហើយត្រូវបានបដិសេធនោះ[1855]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ផែនការដែលមានពីមុនណាមួយ អាចរារាំងអង្គជំនុំជម្រះសាលាដំបូង មិនឱ្យសម្រេចដោយសមហេតុផលថា មានអត្ថិភាពចេតនារើសអើង បន្ទាប់ពីការបះបោរឡើយ។

## *មូលដ្ឋានទី ១៤៣៖ ការបង្ហាញដោយខុសច្បាប់ ពីការចាប់ខ្លួនក្រៅវិសាលភាព នៃការជំនុំជម្រះ ដើម្បីប៉ុនប៉ងបង្ហាញឱ្យឃើញ ពីកម្រិតនៃភាពធ្ងន់ធ្ងរ ដែលជាលក្ខខណ្ឌតម្រូវ*[1856]

529. **មូលដ្ឋានទី ១៤៣ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ក្នុងការវាយតម្លៃរបស់ខ្លួន ទៅលើស្ថានទម្ងន់នៃការធ្វើទុក្ខបុកម្នេញ ដោយរួមបញ្ចូលការចោទប្រកាន់អំពីការចាប់ខ្លួន។**

530. មូលដ្ឋាននេះមិនទទួលផលឡើយ ព្រោះម្ចាស់បណ្តឹងសាទុក្ខ បានអះអាងដោយមិនត្រឹមត្រូវថា ការយោងរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើការចាប់ខ្លួន “មិនច្បាស់លាស់ មិនមានឯកសារយោងគាំទ្រ និងចម្លែក” ទៅក្នុងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ[1857]។ ផ្ទុយទៅវិញ នៅក្នុងកថាខណ្ឌដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូង បានយោងយ៉ាងច្បាស់ទៅលើអំពើ ដែលត្រូវបានចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញ នៅក្នុងដីកាដំណោះស្រាយ[1858] ដែលរួមបញ្ចូល

[1854] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២២។

[1855] ឯកសារ **E457/6/4/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦១១-១៦១៣។

[1856] <u>មូលដ្ឋានទី ១៤៣</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការបង្ហាញដោយខុសច្បាប់ពីការចាប់ខ្លួនក្រៅវិសាលភាពនៃការជំនុំជម្រះ ដើម្បីប៉ុនប៉ងបង្ហាញឱ្យឃើញពីកម្រិតនៃភាពធ្ងន់ធ្ងរដែលជាល័ក្ខខ័ណ្ឌតម្រូវ* កថាខណ្ឌ ៩៣២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥០-៥១ (ភាសាអង់គ្លេស) ទំព័រ ៤៦ (ភាសាបារាំង) ទំព័រ ៧២ (ភាសាខ្មែរ)។

[1857] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៣២។

[1858] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៥ (“*អំពើដែលត្រូវបានចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញ រួមបញ្ចូល* [...] អំពើដែលមិនមែនជាបទល្មើសដោយឡែក (ជាពិសេស ការចាប់ខ្លួន)” (គូសបញ្ជាក់បន្ថែម))។

យ៉ាងប្រត្យក្សនូវការចាប់ខ្លួន ដែលជាអំពើធ្វើទុក្ខបុកម្នេញ[1859]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាយ៉ាងត្រឹមត្រូវ ទៅលើអំពើទាំងអស់នេះ នៅក្នុងការវាយតម្លៃអំពីស្ថានទម្ងន់។

531. ទោះជាក្នុងករណីណាក្តី ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា កំហុសឆ្គងដែលបានចោទប្រកាន់នោះ ធ្វើឱ្យអសុពលភាពទៅដល់សេចក្តីសម្រេចឡើយ ដោយសារតែគាត់មិនបានបង្ហាញថា ភាពធ្ងន់ធ្ងរតាមលក្ខខណ្ឌតម្រូវ ប្រាកដជាមិនត្រូវបានកំណត់ឡើយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនដាក់បញ្ចូលការចាប់ខ្លួន ទៅក្នុងសេចក្តីពិចារណារបស់ខ្លួនទេនោះ។ ដូចដែលបានកត់សម្គាល់នៅផ្នែកផ្សេងក្នុងចម្លើយតបនេះ[1860] អំពើធ្វើទុក្ខបុកម្នេញត្រូវបានពិចារណា សម្រាប់ស្ថានទម្ងន់រួមបញ្ចូលគ្នា។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា អំពើទាំងនោះបានរំលោភបំពាន ទៅលើសិទ្ធិជាសារវ័ន្ត[1861] ហើយបានរួមបញ្ចូលផងដែរ នូវអំពើដែលបង្កើតបានជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយខ្លួនឯងផ្ទាល់[1862]។

## *មូលដ្ឋានទី ១៤៨៖ ការរំលោភលើសិទ្ធិជាមូលដ្ឋាន*[1863]

532. **មូលដ្ឋានទី ១៤៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ដោយសម្រេចថា អំពើដែលប្រព្រឹត្តទៅលើជនជាតិចាម បានរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្ត។**

533. មូលដ្ឋាននេះមិនទទួលផលឡើយ ព្រោះម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយមិនសម្រេចថា អំពើជាក់លាក់ណាមួយបានរំលោភបំពានទៅលើសិទ្ធិជាក់លាក់ណាមួយ ឬថាអំពើដែលធ្វើឡើងចំពោះជនជាតិចាម មិនបានរំលោភបំពានទៅលើ សិទ្ធិជាសារវ័ន្តដែលបានចែងឡើយ។

---

[1859] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ២៦៨។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១១០១៧។

[1860] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៩។

[1861] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៤។

[1862] នេះរួមបញ្ចូលទាំងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃការផ្លាស់ទីលំនៅដោយបង្ខំ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៥, ៣៣៣៥-៣៣៤០។

[1863] <u>មូលដ្ឋានទី ១៤៨</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការរំលោភលើសិទ្ធិជាមូលដ្ឋាន* កថាខណ្ឌ ៩៦០-៩៦១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥២ (ភាសាអង់គ្លេស) ទំព័រ ៤៧-៤៨ (ភាសាបារាំង) ទំព័រ ៧៤ (ភាសាខ្មែរ)។

534. ដូចដែលបានកត់សម្គាល់ពីខាងលើ[1864] អំពើធ្វើទុក្ខបុកម្នេញគឺត្រូវពិចារណារួមគ្នា និងពិចារណាទៅតាមបរិបទ[1865] ហើយដូចដែលអង្គជំនុំជម្រះតុលាការកំពូល បានពន្យល់កន្លងមក "ចំណុចសំខាន់បំផុតនៃការវិភាគនេះ គឺមិនមែនឋិតនៅលើការកំណត់ ថាតើអំពើសកម្ម ឬអកម្ម នៃការធ្វើទុក្ខបុកម្នេញជាក់លាក់នេះ រំលោភលើសិទ្ធិមនុស្សដែលជាសិទ្ធិសារវ័ន្ត ដែរឬយ៉ាងណានោះឡើយ"[1866]។ ដូច្នេះការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា "គ្មានការរឹតត្បិតណាមួយ ក្នុងចំណោមការរឹតត្បិតទាំងឡាយ ដែលត្រូវបានរៀបរាប់ [...] បានរំលោភលើសិទ្ធិជាមូលដ្ឋាន ដែលមានក្នុងបញ្ជី"[1867] គឺមិនត្រឹមត្រូវឡើយ។ ដោយអនុវត្តច្បាប់ដែលត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា អានុភាពរួមគ្នានៃការហាមឃាត់ មិនឱ្យថ្វាយបង្គំ និងនិយាយភាសាកំណើតខ្លួន, ការបង្ខំឱ្យស្លៀកសម្លៀកបំពាក់ និងធ្វើម៉ូតសក់ជាក់លាក់ណាមួយ, ការបង្ខំឱ្យហូបអាហារដែលសាសនាបានហាមឃាត់, ការបំផ្លិចបំផ្លាញទៅលើទីកន្លែងសក្ការៈបូជា និងគម្ពីធម៌សក្តិសិទ្ធិ និងការសម្លាប់ដោយសារតែ ប្រឆាំងចំពោះអំពើបែបនេះ រួមជាមួយអំពើដទៃផ្សេងទៀតទាំងអស់ ដែលប្រព្រឹត្តទៅលើជនជាតិចាម (រួមបញ្ចូលផងដែរ ប៉ុន្តែមិនកម្រិតត្រឹម អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការជម្លៀសដោយបង្ខំ)) បានរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្ត[1868]។

535. ចំពោះមតិរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងការមិនបានសម្រេចថា អំពើនោះបានរំលោភបំពានទៅលើសេរីភាពខាងជំនឿសាសនានោះ[1869] គឺមិនមែនជាកំហុសនោះទេ ដោយសារតែមិនមានការតម្រូវ ឱ្យមានការសម្រេចបែបនេះ ដើម្បីបំពេញបាននូវធាតុផ្សំនៃឧក្រិដ្ឋកម្មឡើយ។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា តម្រូវថា ជនរងគ្រោះត្រូវបានកំណត់ជាគោលដៅ ដោយសារតែសមាជិកភាពរបស់ពួកគាត់ នៅក្នុងក្រុមមួយ ដែលចារីបានកំណត់ ផ្អែកលើមូលដ្ឋានសាសនា[1870] *មិនមែន*ថា អំពើធ្វើទុក្ខបុកម្នេញ បានរំលោភបំពានទៅលើ សេរីភាពខាងជំនឿសាសនាឡើយ។

---

[1864] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៩។

[1865] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៥៦-២៥៩។ សូមមើល ជាពិសេស កថាខណ្ឌ ២៥៧ ("ចំណុចសំខាន់បំផុតនៃការវិភាគនេះ [...] ស្ថិតនៅលើការកំណត់ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញនេះ នៅពេលដែលពិចារណាជារួម និងទៅតាមបរិបទ នាំឱ្យមានការរំលោភលើសិទ្ធិជាសារវន្ត ដោយកំពោល ឬឥតលាក់លៀម")។

[1866] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៥៧ (គូសបញ្ជាក់នៅក្នុងច្បាប់ដើម)។

[1867] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៦០-៦១។

[1868] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៣០-៣៣៣១។

[1869] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៦១។

[1870] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៧២។

ទោះជាយ៉ាងនេះក្តី ច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូង បានពិចារណាថា អំពើដែលប្រព្រឹត្ត ទៅលើជនជាតិចាម *ពិតជា*រំលោភបំពានទៅលើសិទ្ធិជាសារវ័ន្ត ចំពោះសេរីភាពខាងជំនឿសាសនា រួមបញ្ចូលទាំងសិទ្ធិសម្តែងចេញ នូវជំនឿសាសនារបស់បុគ្គល[1871]។

## *មូលដ្ឋានទី ១៤៩៖ ជាចុងក្រោយ កម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើ ដែលកំណត់ការរើសអើងជាក់ស្តែង*[1872]

536. **មូលដ្ឋានទី ១៤៩ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ក្នុងការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរ នៃអំពើធ្វើទុក្ខបុកម្នេញ ដែលប្រព្រឹត្តទៅលើជនជាតិចាម។**

537. មូលដ្ឋាននេះមិនទទួលផលឡើយពាក់ព័ន្ធការចោទប្រកាន់ពីកំហុស ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ បកស្រាយដោយភាន់ច្រឡំ ទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយធ្វើការអះអាង ដែលមិនត្រឹមត្រូវផ្នែកអង្គហេតុ និង/ឬអង្គច្បាប់។

538. ជាបឋម ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើអំពើជាមូលដ្ឋាន នៃការផ្តន្ទាទោសលើបទធ្វើទុក្ខបុកម្នេញ (ដែលដូច្នេះហើយជាប់ពាក់ព័ន្ធជាមួយការវាយតម្លៃលើស្ថានទម្ងន់) គឺមិនកម្រិតត្រឹមតែការរឹតត្បិត ផ្នែកសាសនានិងវប្បធម៌ ដូចបានកំណត់នៅក្នុងកថាខណ្ឌ ៣៣២៨ នៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដូចដែលម្ចាស់បណ្តឹងសាទុក្ខបានអះអាងនោះទេ[1873]។ ប្រហែលគ្នានេះ ការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូង "មិនធ្លាប់ដែលបានចាត់ទុក ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង [ការធ្វើទុក្ខបុកម្នេញ] ការធ្វើទារុណកម្ម ឬអំពើប្រល័យពូជសាសន៍ ថាជាធាតុ

---

[1871] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៨ *យោងទៅ* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៩-៧២១។ ដោយ*ដកស្រង់*ច្បាប់សិទ្ធិមនុស្សអន្តរជាតិ អ.ជ.ស.ដ យល់ឃើញថា "សេរីភាពក្នុងការគិតសតិសម្បជញ្ញៈ និងសាសនា" រួមបញ្ចូលទាំងសិទ្ធិក្នុងការសម្តែងការគោរពសាសនា ឬជំនឿរបស់ខ្លួន ត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិថាជាសិទ្ធិជាមូលដ្ឋានទី (ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២០-៧២១ *ដកស្រង់* ICCPR មាត្រា ១៨។ ECHR មាត្រា ៩)។ អង្គជំនុំជម្រះសម្រេចថា ការកំហិតដែលមិនអាចទទួលយកបានទៅលើសេរីភាពទាំងនេះ ដូចជា ការកំហិតដែលខ្លួនបានសន្និដ្ឋានថាបានដាក់ទៅលើជនជាតិចាម ជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋានទី ដែលត្រូវបានចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។

[1872] <u>មូលដ្ឋានទី ១៤៩</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើដែលកំណត់ការរើសអើងជាក់ស្តែង* កថាខណ្ឌ ៩៦២-៩៦៣។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥២ (ភាសាអង់គ្លេស) ទំព័រ ៤៨ (ភាសាបារាំង) ទំព័រ ៧៤-៧៥ (ភាសាខ្មែរ)។

[1873] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៦៣។

ផ្សំដែលជាមូលដ្ឋាន នៃការប្រព្រឹត្តបែបរើសអើង នៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា ដែលរងការចោទប្រកាន់" គឺជាការបង្ហាញដោយខុសឆ្គងទាំងស្រុង នូវសាលក្រម និងបទចោទ នានាពាក់ព័ន្ធជាមួយសំណុំរឿង ០០២/០២[1874]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញ យ៉ាងច្បាស់ នៅពេលកំណត់អំពីការចោទប្រកាន់ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា ទៅលើជនជាតិចាម បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង០០២[1875] និងម្តងទៀតនៅ ក្នុងសាលក្រម[1876] រួចមក អំពើទាំងអស់ដែលបានប្រព្រឹត្តនៅទូទាំងប្រទេស ក្នុងអំឡុងរបបកម្ពុជា ប្រជាធិបតេយ្យទាំងស្រុង (រួមទាំងក្នុងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ) គឺមានភាព ពាក់ព័ន្ធ។ អំពើទាំងអស់នោះ "រួមមានការបង្ក្រាបលើវប្បធម៌ ទំនៀមទម្លាប់ និងភាសារបស់ជន ជាតិចាម"[1877]។

539. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងពីអំពើរើសអើងថ្មីឡើយ គឺអង្គជំនុំជម្រះ គ្រាន់តែសម្រេចលើអង្គហេតុ[1878] និងអង្គច្បាប់[1879]តែប៉ុណ្ណោះ ទៅលើអង្គហេតុទាំងអស់ ដែលជា មូលដ្ឋាននៃបទចោទ ការធ្វើទុក្ខបុកម្នេញ ហើយបានធ្វើការពិចារណាដោយត្រឹមត្រូវ នៅពេល សម្រេចថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា ត្រូវបានកំណត់[1880]។ ការ

[1874] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៣។

[1875] ឯកសារ **E301/9/1.1** ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាព ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥(ii)(ខ)(៨) ("ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា (កថាខណ្ឌ ១៤១៥, ១៤១៩-១៤២១, ១៤២៣, ១៤២៥) (កម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២ (កម្រិតត្រឹមការប្រព្រឹត្តិ លើជនជាតិចាម)។ [...] ការដ្ឋានទំនប់១មករា និងការប្រព្រឹត្តិលើជនជាតិចាម)។ អង្គហេតុជាក់លាក់ត្រូវបានបញ្ជាក់នៅក្នុង កថាខណ្ឌ ៣(i), (iv) (xi) និងរួមបញ្ចូលអង្គហេតុ *ទាំងអស់*នៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម លើកលែងតែមន្ទីរសន្តិសុខក្រូចឆ្មារ។ សូមមើលផងដែរ ឯកសារ **E301/9/1** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការបំបែកកិច្ច ដំណើរការនីតិវិធីបន្ថែម និងវិសាលភាពសំណុំរឿង កថាខណ្ឌ ៤៣។

[1876] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៨៤, ៣៣២៧, ៣៣៣២។

[1877] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣២៧ *ដកស្រង់* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២០។ តាមពិត នៅក្នុងកថាខណ្ឌដដែលនេះ អ.ជ.ស.ដ បានរៀបរាប់លម្អិតពីការសម្លាប់ និងការផ្លាស់ទីលំនៅ ដោយបង្ខំនៅក្នុងចំណោមអំពើធ្វើទុក្ខបុកម្នេញនានាជាមូលដ្ឋានដែលត្រូវបានចោទប្រកាន់។

[1878] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៨៥-៣៣០៥។

[1879] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣០៥-៣៣២៦, ៣៣៣៣-៣៣៤៨ (កំណត់អំពើនានា ជាមូលដ្ឋានថាជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត អំពើអមនុស្សធម៌ផ្សេងៗទៀត និងឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ក្នុងចំណោមផ្សេងទៀត)។

[1880] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៣១-៣៣៣២។

អះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ឧក្រិដ្ឋកម្មទាំងអស់នេះ មិនត្រូវបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះ[1881] និងថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដោយទាញសន្និដ្ឋាន ចេញពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះ[1882] គឺសុទ្ធតែមិនត្រឹមត្រូវ ផ្អែកលើសំអាងហេតុដូចបានពិភាក្សានៅផ្នែកដទៃផ្សេងទៀត[1883]។

540. ការតវ៉ាបន្ថែមរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង មិនបានកំណត់អត្តសញ្ញាណថាអំពើណាមួយ ដែលបំពេញបានតាមកម្រិតនៃភាពធ្ងន់ធ្ងរតាមការតម្រូវនោះ[1884] គឺជាការយល់ខុសទៅលើច្បាប់។ ដូចដែលបានបង្ហាញរួចមកហើយ អំពើធ្វើទុក្ខបុកម្នេញទាំងអស់ប្រឆាំងទៅនឹងក្រុមគោលដៅមួយ គឺត្រូវបានពិចារណារួមបញ្ចូលគ្នា នៅពេលវាយតម្លៃទៅលើស្ថានទម្ងន់[1885] ហើយការទទួលស្គាល់របស់ អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើជាច្រើនបង្កើតបានជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែង[1886] គឺជាកត្តាកំណត់នៃការវាយតម្លៃនេះ[1887]។ បន្ថែមលើនេះ និងក្នុងគ្រប់ករណីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អំពើប្រព្រឹត្តឡើងប្រឆាំងជនជាតិចាម បានរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្ត[1888]។

### *មូលដ្ឋានទី ៥៖ ការជំនុំជម្រះពីរដង ចំពោះអង្គហេតុដដែល*[1889]

541. **មូលដ្ឋានទី៥គួរត្រូវបានច្រានចោលភ្លាមៗ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញទឡ្ហីករណ៍គាំទ្រ ការចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូង បានរំលោភបំពានទៅលើគោលការណ៍ គ្មានការជំនុំជម្រះពីរដង ចំពោះអង្គហេតុតែមួយ។**

---

[1881] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៣។

[1882] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៣។

[1883] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣៦ (ការធ្វើមនុស្សឃាត), ១៣៨-១៣៩ (ការសម្លាប់រង្គាល), ១៤០ (ការធ្វើទារុណកម្ម), ១៨៦ (គោលនយោបាយចំពោះជនជាតិចាម)។

[1884] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩០៣។

[1885] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៩។ សូមមើល ជាពិសេស សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តីឌុច កថាខណ្ឌ ២៥៦-២៥៩។

[1886] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៣១។

[1887] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៦០-២៦២។

[1888] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៣០។

[1889] មូលដ្ឋានទី ៥៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការជំនុំជម្រះពីរដងចំពោះអង្គហេតុដដែល (Bis in idem)* កថាខណ្ឌ ១៣៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥ (ភាសាអង់គ្លេស) ទំព័រ ៥ (ភាសាបារាំង) ទំព័រ ៦ (ភាសាខ្មែរ)។

542. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែយោងទៅកថាខណ្ឌនៃសារណាបណ្តឹងសាទុក្ខ ដែលគ្រប់ដណ្តប់ដោយមូលដ្ឋានទី ៨២ និងទី៨៣ ដោយមិនបានលើកឡើងនូវទទ្ទីករណ៍ណាមួយ ដើម្បីបង្ហាញពីមូលដ្ឋាននៃបណ្តឹងសាទុក្ខ ដែលដាច់ចេញពីមូលដ្ឋានទាំងពីរនោះឡើយ។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អង្គជំនុំជម្រះតុលាការកំពូលគួរច្រានចោល "ការផ្តន្ទាទោសថ្មីទាំងនេះ" ដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ដោយរំលោភបំពានទៅលើគោលការណ៍ គ្មានការជំនុំជម្រះពីរដង ចំពោះអង្គហេតុតែមួយ ហើយសម្រេចថា ការជំនុំជម្រះមានភាពអយុត្តិធម៌ ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់អំពីការផ្តន្ទាទោសជាក់លាក់ណាមួយ ឬពន្យល់ថាហេតុអ្វីទើបការជំនុំជម្រះអយុត្តិធម៌ឡើយ។ ហេតុដូច្នេះមូលដ្ឋាននេះគួរត្រូវបានបដិសេធភ្លាមៗ[1890]។

### *មូលដ្ឋានទី ៨៣ និងទី ១៥០៖ ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ*[1891]

543. **មូលដ្ឋានទី ៨៣ និងទី ១៥០ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយរំលោភបំពាន ទៅលើទ្រឹស្តីអាជ្ញាអស់ជំនុំ ដោយការសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់អំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ ត្រូវបានប្រព្រឹត្តទៅលើជនជាតិចាម ក្នុងអំឡុងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ។**

544. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែពឹងផ្អែកទៅលើ ការអះអាងដោយមិនត្រឹមត្រូវ របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការជម្លៀសជនជាតិចាមដោយបង្ខំ ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ ជាផ្នែកនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[1892]។ មិនដូច្នោះឡើយ។ អង្គជំនុំ

[1890] វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

[1891] <u>មូលដ្ឋានទី ១៥០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ* កថាខណ្ឌ ៩៦៤-៩៦៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥២-៥៣ (ភាសាអង់គ្លេស) ទំព័រ ៤៨ (ភាសាបារាំង) ទំព័រ ៧៥ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ៨៣</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានបណ្តឹងពីអង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងៗទៀត/ការជម្លៀសដោយបង្ខំ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ* កថាខណ្ឌ ៥៤៤-៥៤៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៣ (ភាសាអង់គ្លេស) ទំព័រ ៣០ (ភាសាបារាំង) ទំព័រ ៤៦-៤៧ (ភាសាខ្មែរ)។ នៅក្នុងមូលដ្ឋានទី ៨៣ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ការជម្លៀសជនជាតិចាមដោយបង្ខំ ត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ជាផ្នែកមួយនៃការជម្លៀសប្រជាជនដំណាក់កាលទី ២ នៅក្នុងទទ្ទីករណ៍ដែលមានលក្ខណៈដូចគ្នាច្រើនជាមួយទទ្ទីករណ៍ដែលមាននៅក្នុងមូលដ្ឋានទី ១៥០។ ដូច្នេះ សហព្រះរាជអាជ្ញាយល់ឃើញថា នេះជាចម្លើយតបគ្រប់គ្រាន់ទៅនឹងមូលដ្ឋានទី ៨៣ និង ១៥០។

[1892] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៦៤-៩៦៥។

ជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១ បានទទួលស្គាល់ថា ការផ្លាស់ទីលំនៅជនជាតិចាមដោយបង្ខំ បង្កើតបានជា "មូលដ្ឋាននៃបទចោទ ទាំងការជម្លៀសដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទី២)"[1893]។ ដោយសារតែបទចោទជាប់ពាក់ព័ន្ធគ្នាពុំអាចញែកចេញពីគ្នាបាន ហើយបទចោទទីពីរ ស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ទើបអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ខ្លួននឹង "មិនធ្វើការសម្រេចត្រង់ចំណុចនេះនៅក្នុងសាលក្រមនេះ [សំណុំរឿង ០០២/០១] ដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំលើប្រជាជនចាម ដែលត្រូវបានចោទប្រកាន់ផងដែរថា ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនានោះទេ"[1894]។ ជាលទ្ធផល ការសម្រេចនេះបានដកចេញ នូវសេចក្តីពិចារណាណាមួយ ទៅលើការផ្លាស់ទីលំនៅប្រជាជនចាមដោយបង្ខំ ពីក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះសាលាដំបូងក៏បាន បដិសេធមិនស្តាប់ផងដែរ ចំពោះសាក្សីណាមួយ នៅក្នុងសំណុំរឿង០០២/០១ លើការផ្លាស់ទីលំនៅជនជាតិចាមដោយបង្ខំ[1895]។ អង្គជំនុំជម្រះសាលាដំបូង មិនអាចរំលោភបំពានលើគោលការណ៍អាជ្ញាអស់ជំនុំឡើយ នៅពេលដែលការផ្លាស់ទីលំនៅជនជាតិចាមដោយបង្ខំ មិនដែលត្រូវបានជំនុំជម្រះនោះ។

545. បន្ថែមលើនេះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ក្នុងការសម្រេច "ការរើសអើងជាក់ស្តែង" ទៅលើជនជាតិចាម នៅក្នុងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ ដែលដូច្នេះហើយ "ត្រូវបានរាប់បញ្ចូលនៅក្នុង ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែលធ្លាប់ត្រូវបានពិនិត្យរួចមកហើយ ដោយចៅក្រមដដែលៗ នៅក្នុងសំណុំរឿង ០០២/០១" គឺគ្មានមូលដ្ឋានទាំងស្រុង[1896]។ ដូចដែលបានពិភាក្សានៅក្នុងចម្លើយតបចំពោះមូលដ្ឋានទី ១៤១ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការសម្រេចរបស់ខ្លួនថា មាន "ការរើសអើងជាក់ស្តែង"[1897]។

546. កំហុសឆ្គងប្រហែលគ្នាគឺនៅក្នុងការដកស្រង់ដោយគ្មានការពន្យល់របស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការរើសអើងទាក់ទងនឹង ការធ្វើទុក្ខបុកម្នេញ

---

[1893] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦២៧។

[1894] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦២៧។

[1895] សូមមើល ឯកសារ **E284/5** សំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺអំពីការរកឃើញទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម ដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ កថាខណ្ឌ ១១។

[1896] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៦៤។

[1897] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៤១។

ទៅលើប្រជាជនថ្មី ដោយមូលហេតុនយោបាយ នៅក្នុងសំណុំរឿង ០០២/០១[1898]។ ក្នុងន័យនេះ ការសម្រេចទាំងអស់នេះ គឺមិនពាក់ព័ន្ធជាមួយបញ្ហា ថាតើការជម្លៀសជនជាតិចាមដោយបង្ខំ ត្រូវបានជំនុំជម្រះដែរឬអត់ ពីពេលមុនកន្លងមក។

## ៤. ជនជាតិវៀតណាម

547. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការនិរទេស ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ តាមរយៈអំពើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ ឬរបួសខ្លាំងដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនា នូវសិទ្ធិទទួលបានការជំនុំជម្រះក្ដី ដោយយុត្តិធម៌និងទៀងទាត់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ទៅលើជនជាតិវៀតណាម[1899] ដែលទាំងអស់នេះត្រូវបានប្រព្រឹត្តឡើង អនុលោមទៅតាមគោលនយោបាយ ដែលមានទំនាក់ទំនងផ្ទៃក្នុងជាមួយគោលបំណងរួម[1900]។

548. មូលដ្ឋានទាំង១៩ របស់ម្ចាស់បណ្ដឹងសាទុក្ខ[1901] ទាក់ទងឧក្រិដ្ឋកម្មទាំងអស់នេះគឺមិនទទួលបានផលឡើយ ដោយសារតែពួកគេប្រើប្រាស់វិធីសាស្ត្រមួយផ្នែកៗ ដោយខុសឆ្គងទៅលើភស្តុតាង ឬសាលក្រម ដោយសារតែមិនបានបកស្រាយ ឬផ្តល់ភស្តុតាងគ្រប់គ្រាន់ ចំពោះការចោទប្រកាន់ពីកំហុសឆ្គង និងគ្រាន់តែមិនយល់ស្របជាមួយ ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើភស្តុតាង។ ជាញឹកញាប់ ម្ចាស់បណ្ដឹងសាទុក្ខ គ្រាន់តែលើកបញ្ជាក់ឡើងវិញ នូវការជំទាស់ដែលមាន នៅក្នុងសេចក្តីថ្លែងបញ្ចប់ការពិភាក្សាដេញដោល ដែលត្រូវបានច្រានចោល ហើយរំឭកឡើងវិញបន្ថែមទៀត នូវការអះអាងដដែលៗ ជាច្រើនលើកច្រើនសារ នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់ ដោយមិនបានបង្ហាញអំពី កំហុសឆ្គងថ្មីឡើយ។ ម្ចាស់បណ្ដឹងសាទុក្ខក៏មិនបានបង្ហាញផងដែរថា កំហុសអង្គហេតុ និងកំហុសអង្គច្បាប់នានា ដែលបានចោទប្រកាន់ នឹងធ្វើឱ្យ

[1898] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៦៥ *ដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៥-៧០៦។

[1899] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៩០-៣៥១៩។

[1900] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៩៩-៤០១២។

[1901] មូលដ្ឋានទី ១០៣-១០៥, ១១០-១១២, ១២៦, ១២៨, ១៣០, ១៥១-១៥៩, ១៨៥។

អសុពលភាពទៅលើសាលក្រម ទាំងស្រុង ឬដោយផ្នែក ឬបណ្តាលឱ្យមានអំពើអយុត្តិធម៌នោះឡើយ[1902]។

### i. គោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាម

### *មូលដ្ឋានទី ១៨៥៖ គោលនយោបាយចំពោះជនជាតិវៀតណាម*[1903]

549. **មូលដ្ឋានទី ១៨៥ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការសម្រេចថា មានគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅទៅលើជនជាតិវៀតណាម ដើម្បីធ្វើបាប និងបំផ្លាញ ហើយថានេះគឺជាផ្នែកនៃគោលបំណងរួម។**

550. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានធ្វើការជំទាស់ ដោយមានភ័ស្តុតាងគាំទ្រ ចំពោះការវាយតម្លៃរបស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើភ័ស្តុតាង ដោយមិនគិតអំពីភ័ស្តុតាងជារួម ដែលបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយ និងគ្រាន់តែមិនយល់ស្របជាមួយ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានធ្វើឡើងអនុលោមទៅតាមគោលនយោបាយនេះ។

551. ការអះអាងដដែលៗរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងការកំណត់អត្តសញ្ញាណ ជនជាតិវៀតណាម តាមរយៈការកំណត់គោលដៅ តាមខ្សែស្រឡាយខាងម្តាយ និងការបង្កើតបញ្ជីនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង គឺគ្មានមូលដ្ឋានទេ[1904]។ សំខាន់ជាងនេះ អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកទៅលើភ័ស្តុតាងសហសម័យ និងសក្ខីកម្មសាក្សីដែលបង្ហាញថា ការអនុវត្តទាំងអស់នេះកើតមានឡើងនៅទូទាំងប្រទេសកម្ពុជា[1905]។

---

[1902] ដូច្នេះ បន្ថែមពីលើមូលដ្ឋានដែលបានពិភាក្សាខាងក្រោម មូលដ្ឋានទី ៤១, ៥៦, ៦០, ៨០, ១០៣-១០៥, ១១០-១១២, ១២៦, ១២៨, ១៣០, ១៥១-១៥៩ និង ១៨៥ ក៏គួរត្រូវបានបដិសេធផងដែរ។

[1903] <u>មូលដ្ឋានទី ១៨៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គោលនយោបាយចំពោះជនជាតិវៀតណាម* កថាខណ្ឌ ១៥៥១-១៥៦០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៤ (ភាសាអង់គ្លេស) ទំព័រ ៥៩ (ភាសាបារាំង) ទំព័រ ៩១ (ភាសាខ្មែរ)។

[1904] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៩។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៨។

[1905] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២០-៣៤២៨។

552. ការអះអាងដដែលៗបន្ថែមទៀត របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា សកម្មភាពនិងសេចក្តីថ្លែងការណ៍ របស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានពន្យល់ដោយជម្លោះរវាង កម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម ហើយថាសេចក្តីថ្លែងការណ៍ របស់បក្សកុម្មុយនីស្តកម្ពុជា តែងតែយោងទៅរកកងទ័ពវៀតណាមនោះ គឺមិនអាចបង្ហាញអំពីភាពលម្អៀង ឬកំហុសឆ្គងណាមួយ នៅក្នុងការបកស្រាយរបស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើភ័ស្តុតាងឡើយ[1906]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូង បានវិភាគភ័ស្តុតាងយ៉ាងច្បាស់លាស់ ដោយផ្តោតទៅលើជម្លោះជាមួយវៀតណាម ដោយចង្អុលបង្ហាញនៅពេលដែលខ្លួន ពិចារណាទៅលើខ្លឹមសារ ដែលយោងទៅរកកងកម្លាំងវៀតណាម ដោយមិនយោងទៅរកជនស៊ីវិលនោះ[1907]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូង បានវិភាគដោយត្រឹមត្រូវផងដែរ នូវឯកសារសហសម័យ ដែលបង្ហាញថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅតែបន្តកំណត់អត្តសញ្ញាណ ជនជាតិវៀតណាមថាជាខ្មាំង ជាពិសេសចាប់ពីខែឧសភា ឆ្នាំ ១៩៧៦[1908]។ ជាឧទាហរណ៍ មាស វឿន ជាអតីតមេបញ្ជាការ កងវរសេនាធំខ្មែរក្រហម ដែលមានតួនាទីជាសន្តិសុខ សម្រាប់ម្ចាស់បណ្តឹងសាទុក្ខ បានផ្តល់សក្ខីកម្មថា ជនជាតិវៀតណាមទាំងអស់ ដោយមិនគិតអំពីឋានៈឬអាយុត្រូវបាន "ចាត់ទុកថាជាខ្មាំង"[1909]។

---

[1906] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៤, ១៥៥៧, ១៥៥៨។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩ (ការបកស្រាយសុន្ទរកថារបស់ ប.ក.ក យោងតាមបរិបទ), ២៧ (ការបកស្រាយទូទៅរបស់ អ.ជ.ស.ដ ពីសុន្ទរកថារបស់ ប.ក.ក)។

[1907] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨៩ *ដកស្រង់* ឯកសារ **E3/741** ឯកសារកម្ពុជាប្រជាធិបតេយ្យ សេចក្តីណែនាំរបស់ ៨៧០ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨។ សូមមើលផងដែរ កថាខណ្ឌ ៣៤១៦។

[1908] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨៩។ នៅក្នុងសារណារបស់ខ្លួន (សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១១-១៤១២) ម្ចាស់បណ្តឹងសាទុក្ខជំទាស់នឹងការយល់ឃើញរបស់ អ.ជ.ស.ដ ដែលថា ជនជាតិវៀតណាមត្រូវបានចាត់ទុកថាជា "សត្រូវស្រួចស្រាវ" របស់ ប.ក.ក មុនឆ្នាំ១៩៧៥ ដោយមិនយល់ស្របជាមួយការវាយតម្លៃរបស់ អ.ជ.ស.ដ ទៅលើសៀវភៅពីរក្បាល។ អ.ជ.ស.ដ មិនត្រូវបានតម្រូវឱ្យធ្វើការបញ្ជាក់ពីរាល់ដំណាក់កាលនៃសំអាងហេតុរបស់ខ្លួនឡើយ (សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចមានសំអាងហេតុ)) ហើយម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការវាយតម្លៃរបស់ អ.ជ.ស.ដ ទៅលើសៀវភៅនោះមិនសមហេតុផល។ លើសពីនេះទៀត ការសន្និដ្ឋានថាជនជាតិវៀតណាមជាសត្រូវ មានភាពស៊ីសង្វាក់ជាមួយនឹងការសន្និដ្ឋាន និងភ័ស្តុតាងដែលត្រូវបានដកស្រង់នៅក្នុងចម្លើយតបនេះ។ សូមមើលផងដែរ ផ្នែកទី VIII.គ. ១ គោលបំណងទូទៅ ជាពិសេស ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩, ១៨៩។

[1909] ឯកសារ **E1/387.1** មាស វឿន ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង ០៩.៥៥.៤៩-០៩.៥៨.៥០ ទំព័រ ១៧ បន្ទាត់ ១៤-២២។

553. ភាសាសាមញ្ញរបស់ម្ចាស់បណ្តឹងសាទុក្ខ ធ្វើឱ្យខូចខាតដល់ការអះអាងដែលថា សេចក្តីថ្លែងការណ៍របស់គាត់ អាចត្រូវបានបកស្រាយថា គ្រាន់ជាការជម្រុញលើកទឹកចិត្ត កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ដើម្បីការពារប្រឆាំងកងទ័ពខ្លាំង[1910]។ អង្គជំនុំជម្រះសាលាដំបូង បានដកស្រង់សេចក្តីថ្លែងការណ៍របស់គាត់ចំនួនពីរ នៅក្នុងឆ្នាំ១៩៧៨ ដែលក្នុងនោះ (១) គាត់បានសច្ចាក្នុងនាមបក្សកុម្មុយនីស្តកម្ពុជាថា កម្ទេចឱ្យអស់រាល់បណ្តា ភ្នាក់ងារពួកឈ្លានពានវៀតណាម ពីក្នុង "អង្គភាពយើង" និងទឹកដីកម្ពុជា និងខ្មាំងគ្រប់ពណ៌សម្បុរ ជាពិសេសខ្មាំងវៀតណាមឈ្លានពានវាតទីនិយម ដើម្បីរក្សាជាតិនិងពូជសាសន៍កម្ពុជា[1911] និង (២) បញ្ជាក់ថា វៀតណាមបាន "ដុតកំហឹងស្នេហាជាតិ"[1912]។ អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានដោយសមហេតុផល ផ្អែកលើបរិបទនិងការយោងទៅរក "ជាតិសាសន៍កម្ពុជា" និង "កំហឹងស្នេហាជាតិ" ថា ពាក្យសម្តីរបស់ម្ចាស់បណ្តឹងសាទុក្ខ គឺកំណត់គោលដៅទៅលើ ជនជាតិវៀតណាមទាំងអស់ ដោយឥតរើសអើង[1913]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានស្តាប់សក្ខីកម្មរបស់ ឯក ហេន ដែលថា ម្ចាស់បណ្តឹងសាទុក្ខបាននិយាយថា "ប្រទេសខ្មែរអត់មានយួន"[1914] នៅក្នុងវគ្គបណ្តុះបណ្តាលមួយ ដែលធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខ។ មនោសញ្ចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងសេចក្តីថ្លែងការណ៍បែបនេះ ត្រូវបានឆ្លុះបញ្ចាំងបន្ថែម នៅក្នុងពាក្យពេចន៍របស់គាត់ ជាមួយសម្តេចសីហនុ ដែលបញ្ជាក់ថា ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា "ញុះញង់ពួកគេឱ្យស្អប់យួន កាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ"[1915]។

---

[1910] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៨។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩ និង ២៧។

[1911] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៩ *ដកស្រង់* ឯកសារ **E3/562** ជំនួបនៅទីក្រុងភ្នំពេញ ប្រារព្ធខួបថ្ងៃទី១៧ ខែមេសា KH 00249989-00249990។

[1912] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០០ *ដកស្រង់* ឯកសារ **E3/169** សុន្ទរកថារបស់សមមិត្ត ខៀវ សំផន នៅក្នុងកិច្ចប្រជុំរំឭកខួបអនុស្សាវរីយ៍ KH S 00704523-00704524។

[1913] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៩-៣៤០០។ សូមមើលផងដែរ កថាខណ្ឌ ៣៤០៦។

[1914] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩០ *ដកស្រង់* ឯកសារ **E1/217.1** ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ១១.២៩.៥៦-១១.៣១.៥៨ ទំព័រ ៤០ បន្ទាត់ ១៣-១៥។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ២០។

[1915] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០១ *ដកស្រង់* ឯកសារ **E3/1819** នរោត្តម សីហនុ *សង្គ្រាម និងក្តីសង្ឃឹម* KH 00349591។

554. ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការសន្និដ្ឋាន ដោយសមហេតុពីភ័ស្តុតាងទាំងអស់ថា ពាក្យ "យួន"[1916] គឺជាពាក្យប្រមាថមើលងាយ ប្រើទាំងចំពោះជនស៊ីវិល និងកងទ័ព[1917]។ អង្គជំនុំជម្រះសាលាដំបូងបកស្រាយពាក្យនេះ ទៅតាមករណីជាក់ស្ដែង ដោយគិតពិចារណាទៅលើកាលៈទេសៈ ដែលពាក្យនេះត្រូវបានប្រើប្រាស់[1918]។ អង្គជំនុំជម្រះពិចារណាថា ពាក្យនេះត្រូវបានប្រើប្រាស់ តាំងពីយូលង់មកហើយ នៅក្នុងប្រទេសកម្ពុជា[1919] ហើយបានទទួលស្គាល់ពីឧទាហរណ៍ ដែលសាក្សីបានប្រើប្រាស់ពាក្យនេះ ដើម្បីយោងទៅរកប្រទេសវៀតណាម ឬជនជាតិវៀតណាម ជាពាក្យទូទៅ[1920]។ ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះក៏បានពិចារណាផងដែរ (១) ឯកសារសហសម័យ និងសក្ខីកម្មក្នុងសវនាការ ដែលពាក្យ "យួន" ត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់កុមារ ឬទារក (២) ទស្សនាវដ្ដីទង់បដិវត្តបញ្ជាក់ថា យួនគឺជា "សត្រូវរបស់ជាតិ" (៣) សក្ខីកម្មផ្សេងៗជាច្រើន ដែលជនជាតិវៀតណាម ត្រូវបានកំណត់ថាជា "សត្រូវស្លូពូជ" របស់ខ្មែរ (៤) ឯកសារដែលរៀបរាប់ "ភ្នាក់ងារ" យួន ថាជាខសត្រូវគ្រោះថ្នាក់បំផុត និង (៥) សៀវភៅខ្មៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបោះពុម្ពនៅក្នុងឆ្នាំ ១៩៧៨ ដែលកំណត់និយមន័យយួនថា "សាហាវ" និងជា "ឈ្មោះដែលប្រជាជនកម្ពុជា ដាក់ឱ្យវៀតណាម"[1921]។

---

[1916] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៨០-១៤៨៥។

[1917] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៨២-១៤៨៥។

[1918] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៧៩, ៣៣៨១ ជាពិសេស ជើងទំព័រ ១១៣៨៦, ១១៣៩៣ (*កត់សម្គាល់ថា* អ.ជ.ស.ដ ក៏បានដកស្រង់ផងដែរនូវចម្លើយរបស់សាក្សីតែមួយឈ្មោះ សៅ សាក់ ដែលមានយោងនៅក្នុងសារណារបស់ម្ចាស់បណ្ដឹងសាទុក្ខ ដែលជាមនុស្សម្នាក់ដែលបានប្រើពាក្យនេះជាទូទៅ)។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨០ ជើងទំព័រ ១១៣៨៨ (បង្ហាញថា ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខត្រូវបានពិចារណា)។

[1919] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៥៣។

[1920] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៧៩, *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៨៣-១៤៨៤។

[1921] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៧៩, ៣៣៨១។ ការជំទាស់របស់ម្ចាស់បណ្ដឹងសាទុក្ខទៅនឹងការពិចារណាលើសៀវភៅ ត្រូវបានលើកយកពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២៤៤ (កំហុសពាក់ព័ន្ធនឹងគោលបំណងរួម និងផែនការបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក) ជាពិសេសនៅក្នុងផ្នែកដែលកត់សម្គាល់ពីការវាយតម្លៃអត្តនោម័តិរបស់ អ.ជ.ស.ដ ទៅលើ "មហាលោតផ្លោះ មហាអស្ចារ្យ" និងបរិបទដែលនាំទៅដល់គោលដៅនេះ។

555. បន្ថែមលើនេះម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ក្នុងការសម្រេចថា សេចក្តីថ្លែងការណ៍ខែមេសា ឆ្នាំ១៩៧៨ របស់ ប៉ុល ពត "មួយទល់នឹង៣០" គឺសំដៅប្រឆាំងទៅលើប្រជាជនវៀតណាមទាំងមូល[1922] មិនមែនប្រទេសវៀតណាម និងកងកម្លាំងវៀតណាមឡើយ[1923]។ សេចក្តីថ្លែងការណ៍នេះ មិនមានអ្វីគួរឱ្យសង្ស័យឡើយថា ប៉ុល ពត ចាត់ទុកជនស៊ីវិលវៀតណាម គឺជាខ្មាំងដែលត្រូវតែសម្លាប់[1924]។ ដោយយោងទៅលើប្រជាជនសរុបរបស់វៀតណាម និងកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត បានសួរថា "យួនមានចំនួន ៥០លាន កម្ពុជាមានតែ៨លាន ម៉េចទៅវាយវាឈ្នះ?"[1925]។ ការយោងដទៃទៀតបង្ហាញច្បាស់ថា ប៉ុល ពត សំដៅទៅលើសង្គ្រាមរវាងប្រជាជន មិនមែនសង្គ្រាមរវាងកងទ័ព និងកងទ័ពទេ៖ "រហូតដល់ថ្ងៃនេះ យើងអនុវត្តបាន១ទល់នឹង៣០ គឺយើងខូចខាត១ យួនត្រូវខូចខាត៣០ [...] ដូច្នេះបើយើងមាន ២លាន យើងវាយវាហួសទៅទៀត ពីព្រោះវាមានតែ៥០លាន"[1926]។ ប្រហែលគ្នានេះ "ត្រូវអនុវត្ត ១ទល់នឹង៣០ឱ្យបាន។ បើអនុវត្តពាក្យស្លោកនេះមិនបាន គឺដណ្តើមជ័យជំនះមិនបាន។ បញ្ហានេះ មិនមែនចោទតែខាងកងទ័ពទេ គឺបក្សទាំងមូល កងទ័ពទាំងមូល *ប្រជាជនទាំងមូល ជ្រួតជ្រាបនូវមាគ៌ានេះ និងទស្សនៈនេះ និងគោលជំហរនេះ*"[1927]។ បន្ថែមលើនេះ ការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ក្នុងការបកស្រាយសេចក្តីថ្លែងការណ៍ ដោយយោងទៅរកសាលដីកាសំណុំរឿង ០០២/០១ គឺជាការបំភាន់[1928] ព្រោះអង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់នៅក្នុងនោះថា និយមន័យនៃពាក្យ "ខ្មាំង" នៅមុនឆ្នាំ១៩៧៥ មិនត្រូវបានបញ្ជាក់បំភ្លឺទេ[1929] ដែលមិនសមស្របជាមួយស្ថានភាពបច្ចុប្បន្ន ដែលអង្គជំនុំជម្រះសាលាដំបូង បានកំណត់យ៉ាងច្បាស់នូវពាក្យ ដែលប្រើប្រាស់សម្រាប់រៀបរាប់ ជនជាតិវៀតណាម។ ដូចដែលម្ចាស់បណ្តឹងសាទុក្ខ បានកត់សម្គាល់អំពីសារសំខាន់ នៃការពិចារណាថាតើ សេចក្តីថ្លែងការណ៍ជាសាធារណៈត្រូវបកស្រាយបែបណាដោយបុគ្គលពាក់ព័ន្ធនោះ[1930] គាត់មិនអាចលុបចោលនូវភ័ស្តុតាងដូចជា

[1922] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០២។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩។

[1923] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៨២។

[1924] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០២។

[1925] ឯកសារ **E3/4604** *ទង់បដិវត្ត* ខែមេសា ឆ្នាំ១៩៧៨ KH 00064712 00៥១៩៨៣៣។

[1926] ឯកសារ **E3/4604** *ទង់បដិវត្ត* ខែមេសា ឆ្នាំ១៩៧៨ KH 00064713, 00064717- 00064718។

[1927] ឯកសារ **E3/4604** *ទង់បដិវត្ត* ខែមេសា ឆ្នាំ១៩៧៨ KH 00064714 (គូសបញ្ជាក់បន្ថែម)។

[1928] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៨៥។

[1929] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៣០។

[1930] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៨៥។

សៀវភៅកំណត់ត្រាពីមន្ទីរសន្តិសុខស-២១ ដែលជនស៊ីវិលជនជាតិវៀតណាមជាច្រើន ត្រូវបានគេសម្លាប់[1931] កំណត់ត្រាបង្ហាញថា មាគ៌ាកំណត់ដោយបក្សប្រឆាំងយួនគឺ "១ទល់នឹង៣០"[1932]។

556. ជាថ្មីម្តងទៀតដោយគ្មានមូលដ្ឋាន ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មិនបានភ្ជាប់ទំនាក់ទំនងរវាង សេចក្តីថ្លែងការណ៍ ទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជនយុវនារីបដិវត្ត ជាមួយនឹងចារីប្រព្រឹត្តឧក្រិដ្ឋកម្ម ប្រឆាំងជនជាតិវៀតណាម[1933]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ មិនបានពិចារណាអំពី ការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើខ្លឹមសារនៃសេចក្តីថ្លែងការណ៍ និងការបោះពុម្ពផ្សាយបែបនេះ ដោយរៀបរាប់លម្អិតដូចជាថា ទស្សនាវដ្តីទង់បដិវត្ត យោងទៅរក "ខ្មាំងយួនបំបាត់ពូជសាសន៍របស់យើង"[1934] និងការប្រើប្រាស់ពាក្យដោយឯកសារបោះពុម្ពផ្សាយ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដូចជា "កម្ចាត់" "កម្ទេច" "វាយឱ្យខ្ទេច" "បោសឱ្យស្អាត" "បោសសម្អាត" "កម្ទេច" "រលំរលាយ" "ធ្វើឱ្យសាបសូន" ដើម្បីរៀបរាប់ពីការប្រព្រឹត្តទៅលើយួន[1935]។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូង បានវិភាគ[1936]ផងដែរទៅលើ ទូរលេខសល់ពីសម័យនោះ ដែលបង្ហាញថាការចាប់ និងការសម្លាប់ជនស៊ីវិលវៀតណាម ត្រូវបានរាយការណ៍ជូនទៅ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[1937]។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូង បានយោងទៅរករបាយការណ៍មួយ ពីមន្ទីរ៤០១ ផ្ញើរជូនអង្គការ ថាខ្លួនបានអនុវត្ត "មាគ៌ាបក្ស មានវិធានការដកហូត សម្រិតសម្រាំង និងបោសសម្អាតជាបន្តបន្ទាប់" ទៅលើ

---

[1931] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦២១។

[1932] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០៥ *ដកស្រង់* ឯកសារ **E3/833** កំណត់ត្រារួម ស-២១ របស់ ម៉ម ណៃ ចុះខែមិថុនា ឆ្នាំ១៩៧៥-ខែតុលា ឆ្នាំ១៩៧៨ KH 00077867-00077868។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១២៦, ១៧៩។

[1933] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៩។

[1934] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០៣ *ដកស្រង់* ឯកសារ **E3/746** *ទង់បដិវត្ត* ចុះខែកក្កដា ឆ្នាំ១៩៧៨ KH 00064487។

[1935] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០៧។

[1936] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤១០-៣៤១១។

[1937] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០៨-៣៤១២។

ខ្លាំង ដោយសម្រិតសម្រាំង "អាណិកជនយួន"[1938]។ ជាលទ្ធផលនៃការសម្រិតសម្រាំងនេះ៖ "បានកម្ទេចជនជាតិយួន ទាំងតូច ទាំងធំ ទាំងចាស់ ទាំងក្មេង អស់ចំនួន ១០០នាក់"[1939]។

557. ប្រហែលគ្នានេះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អត្ថិភាពនៃគោលនយោបាយ គឺជាមធ្យោបាយតែមួយគត់ ក្នុងការបង្ហាញអំពីចេតនា នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ គឺឃ្លាតចាកឆ្ងាយពីការពិត[1940]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែដកស្រង់សេចក្តីសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូងអំពី ធាតុផ្សំអត្តនោម័តិ នៃការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ ហើយមិនពិចារណាទាល់តែសោះ ទៅលើស្ថានទម្ងន់នៃភស្តុតាងដែលបង្ហាញផ្សេងពីនេះ[1941]។

558. បន្ថែមពីលើការគ្រាន់តែលើកឡើងវិញ នូវការអះអាងដ៏ខុសឆ្គងរបស់គាត់ ដែលថា អង្គជំនុំជម្រះសាលាដំបូង (១) ទៅហួសដែនបណ្តឹង[1942] (២) មានកំហុសឆ្គងក្នុងការសម្រេចថា ឧក្រិដ្ឋកម្មបានកើតឡើង[1943] ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយគ្មានមូលដ្ឋានថា ឧក្រិដ្ឋកម្មផ្សេងៗជាច្រើនដែលត្រូវបានធ្វើឡើងប្រឆាំងជនជាតិវៀតណាម គឺមិនមែនជាផ្នែកនៃគោលនយោបាយឡើយ[1944]។ អង្គជំនុំជម្រះសាលាដំបូង បានរៀបរាប់លម្អិតថាតើ ជនជាតិវៀតណាមនៅតាមទីកន្លែងជាច្រើនត្រូវបានគេសម្រិតសម្រាំង និងធ្វើបាបដោយរបៀបណា ដោយសារតែការសន្មតអំពីជាតិសាសន៍របស់ពួកគេ[1945] ហើយអង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានដោយសមហេតុផល ផ្អែកលើភស្តុតាងទាំងអស់ថា គោលនយោបាយដែលបង្កើតឡើង ពីគណៈកម្មាធិការមជ្ឈិមបក្ស ក្នុងការកំណត់គោលដៅលើជនជាតិវៀតណាម សម្រាប់ការធ្វើបាបនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺមានអត្ថិភាពនៅទូទាំងអំឡុងពេលដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1946]។

---

[1938] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤១០ *ដកស្រង់* ឯកសារ **E3/1094** របាយការណ៍ពីមន្ទីរ ៥០១ ជូនអង្គការ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨ KH 00143610។

[1939] ឯកសារ **E3/1094** របាយការណ៍ពីមន្ទីរ ៥០១ ជូនអង្គការ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨ KH 00143610។

[1940] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៥។

[1941] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៥-១៥៥៦។

[1942] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥១។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤១, ៦០, ៨០, ៨៤។

[1943] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥២។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៣ & ១០៤, ១០៥, ១១០, ១១១, ១២៦, ១២៨, ១៣០, ១៥១-១៥៩។

[1944] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៦០។

[1945] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥១៥-៣៥១៦។

[1946] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤១៧។

559. ជាចុងក្រោយ ផ្ទុយពីការអះអាងដោយខុសឆ្គង របស់ម្ចាស់បណ្តឹងសាទុក្ខ[1947] អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា តើការប្រព្រឹត្តទៅលើជនជាតិវៀតណាម ដោយបក្សកុម្មុយនីស្តកម្ពុជាដើរតួនាទីបែបណា ក្នុងការអនុវត្តគោលបំណងរួម ក្នុងនាមជាគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅ និងកម្ទេចជនជាតិវៀតណាម នៅក្នុងប្រទេសកម្ពុជា[1948] ដែលត្រូវអនុវត្តតាមរយៈគោលនយោយ កំណត់អត្តសញ្ញាណ ចាប់ខ្លួន បំបែក និងកម្ទេចខ្លាំង[1949] ដែលជាមធ្យោបាយឧក្រិដ្ឋក្នុងការ "ការពារប្រទេសពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុង ឱ្យក្លាយជាសង្គមខ្មែរ ដែលមិនមានសាសនា និងរូបរួមគ្នាមួយ" យោងទៅតាមគោលដៅបដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា[1950]។

## ii. ការនិរទេសជនជាតិវៀតណាម

### *មូលដ្ឋានទី ១៥១៖ ការនិរទេស*[1951]

560. **មូលដ្ឋានទី ១៥១ គួរត្រូវបានច្រានចោល ដោយសារតែ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងអង្គច្បាប់ និងអង្គហេតុ ក្នុងការសម្រេចថា ជនជាតិវៀតណាមត្រូវបាននិរទេស ពីខេត្តព្រៃវែងនៅក្នុងឆ្នាំ១៩៧៥ និង១៩៧៦។**

561. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធនឹងកំហុសដែលបានចោទប្រកាន់ គឺប្រភេទកំហុសដែលម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញ ព្រោះក្រៅពីការចោទប្រកាន់របស់គាត់ អំពីការមិនបានទទួលបណ្តឹង[1952] ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង នូវបណ្តាការចោទប្រកាន់មិនត្រឹមត្រូវនានា ពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភ័ស្តុតាងនានា។

562. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូង ប៉ាន់ប្រមាណដោយមិនសមហេតុផល ទៅលើភ័ស្តុតាងនៃភូមិចំនួនបី ថាបានបង្ហាញពីជនជាតិវៀតណាម ត្រូវបានប្រមូល

---

[1947] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៣។

[1948] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨២-៣៤១៧។

[1949] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩, ១៨៩។

[1950] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០០៣-៤០០៥, ៤០១២។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[1951] <u>មូលដ្ឋានទី ១៥១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការនិរទេស* កថាខណ្ឌ ៩៦៦-៩៨០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៣ (ភាសាអង់គ្លេស) ទំព័រ ៤៨ (ភាសាបារាំង) ទំព័រ ៧៥ (ភាសាខ្មែរ)។

[1952] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤១។

ផ្តុំ និងជម្លៀសចេញពីភូមិនានា នៅទូទាំងខេត្តព្រៃវែងគឺជាកំហុស[1953]។ ទីមួយ អង្គជំនុំជម្រះសាលាដំបូង បានយោងទៅរកព័ត៌មាននៅក្នុងសំណុំរឿង អំពីហេតុការណ៍បែបនេះ ដែលបានកើតឡើងនៅទូទាំងខេត្ត ហើយបន្ទាប់មកបានផ្តោតទៅលើ "ករណីជាក់ស្តែងនីមួយៗ នៃក្រុមគ្រួសារវៀតណាម ដែលត្រូវបានប្រមូល បញ្ជូនចេញ និងឃើញមានការចាកចេញតាមទូក" នៅតាមភូមិជាក់លាក់មួយចំនួន[1954]។ ទីពីរ មិនមានលក្ខខណ្ឌតម្រូវអំពីចំនួនមនុស្សអប្បបរមា ដើម្បីបង្ហាញភ័ស្តុតាងអំពីបទចោទនិរទេសឡើយ[1955]។

563. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង មិនបានបំភ្លៃភ័ស្តុតាងរបស់ សៅ សាក់ ទេ[1956]។ ទោះបីជា សៅ សាក់ បញ្ជាក់ច្បាស់ថា គាត់មិនបានឃើញហេតុការណ៍ផ្ទាល់ក្តី តែគាត់បានអះអាងថារៀងរាល់ពីរបីថ្ងៃម្តង ក្រុមគ្រួសារវៀតណាមបានបាត់ខ្លួន នៅក្នុងភូមិ ហើយគេបានប្រាប់គាត់ថា គ្រួសារទាំងអស់នោះត្រូវបានបញ្ជូនទៅប្រទេសវៀតណាម[1957]។ សៅ សាក់ មិនបានផ្លាស់ប្តូរភ័ស្តុតាងរបស់គាត់ឡើយ ពាក់ព័ន្ធការនិរទេសជនជាតិវៀតណាម ប៉ុន្តែគាត់បានផ្តល់សក្ខីកម្ម នាពេលក្រោយៗមក ជនជាតិវៀតណាមត្រូវបានគេយកទៅសម្លាប់ ដោយមិនបញ្ជូនទៅប្រទេសវៀតណាមទេ[1958]។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង មិនបានទទួលភ័ស្តុតាងរបស់ សៅ សាក់ ពាក់ព័ន្ធនឹងការនិរទេសជនជាតិវៀតណាម នៅក្នុងឆ្នាំ១៩៧៥ ឬ១៩៧៦ បានឡើយ[1959]។ តាមពិតទៅ សៅ សាក់ បានផ្តល់សក្ខីកម្មថា "កាលពីមុនមក រាប់អានធម្មតា។ ដល់ក្រោយពីព្រឹត្តិការណ៍ទៀតមក គឺគេជម្លៀសប្រជាជន គឺគេរើសតែម្តង រើសដូចថា ឱ្យតែមានជនជាតិវៀតណាម គឺគេប្រមូលតែម្តង"[1960]។

---

[1953] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៦៧-៩៦៨។

[1954] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០៥។

[1955] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៧៥។

[1956] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៦៩-៩៧០។

[1957] ឯកសារ **E1/363.1** សៅ សាក់ ប្រតិចារឹក ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ០៩.៤៣.៣-០៩.៤៤.១៦ ទំព័រ ១២ បន្ទាត់ ១៩-២២។

[1958] ឯកសារ **E1/362.1** សៅ សាក់ ប្រតិចារឹក ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៥.១៩.៣១-១៥.២១.០៥ ទំព័រ ៧៣ បន្ទាត់ ១-៣។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧១។

[1959] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧២។

[1960] ឯកសារ **E1/362.1** សៅ សាក់ ប្រតិចារឹក ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៤.៣២.៣០-១៤.៣៤.៣៦ ទំព័រ ៦៣ បន្ទាត់ ២៣-២៤។ សូមមើលផងដែរ ឯកសារ **E1/363.1** សៅ សាក់ ប្រតិចារឹក ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ០៩.៥៨.១៥-១០.០១.១៥ ទំព័រ ១៨ បន្ទាត់ ១-៣។

564. កំណត់ហេតុស្តាប់ចម្លើយចំនួនពីរ ដែលអង្គជំនុំជម្រះសាលាដំបូងយោង គឺមិនមែនជាមូលដ្ឋានតែមួយ សម្រាប់បង្ហាញថាមានការនិរទេសឡើយ កំណត់ហេតុទាំងនេះគាំទ្រទៅដល់ សក្ខីកម្មរបស់ សៅ សាក់ ជាសាក្សីដែលម្ចាស់បណ្តឹងសាទុក្ខ មានឱកាសក្នុងការសួរដេញដោល[1961]។ ឯម ប៊ុននីម និង ប៊ុន រើន បានប្រាប់ ក.ស.ច.ស នៅក្នុងការស្តាប់ចម្លើយ ដែលធ្វើឡើងសម្រាប់ការជំនុំជម្រះព្រហ្មទណ្ឌ[1962] ថា ពួកគាត់បានឃើញគេបញ្ជូនជនជាតិវៀតណាមពីអន្លង់ទ្រា ត្រឡប់ទៅប្រទេសវៀតណាម[1963]។

565. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ដួង អឿន បានផ្តល់ព័ត៌មានមានកម្រិត និងគ្មានភស្តុតាងគាំទ្រ ទាក់ទងការជម្លៀសជនជាតិវៀតណាម ពីភូមិពោធិ៍ចិន្តាំ[1964] សាក្សីបានផ្តល់សក្ខីកម្ម តាមការដឹងឮផ្ទាល់ខ្លួន អំពីជនជាតិវៀតណាមនៅក្នុងតំបន់ ដែលត្រូវត្រឡប់ទៅប្រទេសវៀតណាម ចាប់ពីឆ្នាំ១៩៧៥ ដោយគាត់បានជម្រុញប្តីរបស់គាត់ ដែលជាជនជាតិវៀតណាម ឱ្យចាកចេញទៅ[1965]។

566. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញផងដែរ អំពីកំហុសឆ្គងណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពិចារណាទៅលើឧបសម្ព័ន្ធ នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយ ដែលរៀបរាប់លម្អិតអំពីការប្រកាស នៅក្នុងភូមិអង្គរយសថា អង្គការចាំបាច់ត្រូវបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ ហើយជាលទ្ធផលក្រុមគ្រួសារ របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានចាកចេញទៅ[1966]។ អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថាឯកសារ "ទទួលបានតម្លៃជាភស្តុតាងតិចតួចបំផុត" ប៉ុន្តែចាត់ទុកថាព័ត៌មាននេះ "អះអាងអំពីអត្ថិភាពនៃការផ្លាស់ទីជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង"[1967]។ ម្ចាស់បណ្តឹងសាទុក្ខបាន

---

[1961] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧៤-៩៧៦។

[1962] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩០។

[1963] ឯកសារ **E3/7760** កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម KH 00296235។ ឯកសារ **E3/7811** កំណត់ហេតុស្តាប់ចម្លើយ ប៊ុន រើន KH 00271361។

[1964] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧៧។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[1965] ឯកសារ **E1/381.1** ដួង អឿន ប្រតិចារឹក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦, ម៉ោង ០៩.២៥.៤៦-០៩.៣១.៣៤ ទំព័រ ៨-៩ បន្ទាត់ ២២-២, ទំព័រ ១០ បន្ទាត់ ១-៥។

[1966] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧៨។

[1967] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៣២។

អនុវត្តដោយខុសឆ្គង នូវគោលការណ៍នៃការគាំទ្រ[1968] ដែលរួមមានការប្រើប្រាស់ ហេតុការណ៍ប្រហាក់ប្រហែលគ្នា ជាពិសេសនៅក្នុងបរិបទ នៃគំរូឬផែនការជាតិទាំងស្រុង[1969]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានពន្យល់ថា ហេតុអ្វីទើបទៅជាបែបនេះ ហើយម្ចាស់បណ្តឹងសាទុក្ខ ក៏មិនបានដកស្រង់អ្វីមួយ ដើម្បីគាំទ្រដល់ទស្សនៈនៃការគាំទ្រ ដ៏ចង្អៀតហើយខុសឆ្គងរបស់គាត់ឡើយ[1970]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយកំណត់តាមគតិយុត្តិ នូវប្រភេទភ័ស្តុតាងនេះថាជាករណីនៃការនិរទេសក្តី[1971] តែអង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវថាករណីដទៃទៀតនៃការនិរទេសជនជាតិវៀតណាម ពីខេត្តព្រៃវែងទៅប្រទេសវៀតណាម ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ[1972]។

567. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញ អំពីកំហុសណាមួយនៅក្នុងការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានស្ថានភាពបង្ខិតបង្ខំនៅក្នុងខេត្តព្រៃវែង ទើបជនជាតិវៀតណាមមិនមានជម្រើសពិតប្រាកដ ក្នុងការចាកចេញ[1973]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការផ្លាស់ទីលំនៅជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង ត្រូវបានបញ្ជាដោយបក្សកុម្មុយនីស្តកម្ពុជា ហើយបានកត់សម្គាល់ថា ការនេះគឺស្របគ្នាជាមួយ ភ័ស្តុតាងនៃហេតុការណ៍ដែលបានកើតឡើង នៅទីកន្លែងផ្សេងៗ នៅក្នុងគោលនយោបាយ ដែលអនុវត្តទូទាំងប្រទេស ក្នុងការបណ្តេញចេញជនជាតិវៀតណាម[1974]។ ភ័ស្តុតាងបែបនេះគឺមិនដូច ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា មានវិសាលភាពទូទៅនោះទេ[1975]។ ប៉ុន្តែហេតុការណ៍ទាំងអស់នេះ កើតឡើងនៅក្នុងកាលៈទេសៈស្លាប់រស់សម្រាប់ជនជាតិវៀតណាម ដូចដែល ប្រាក់ ខន អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានរៀបរាប់ក្នុងពេលផ្តល់សក្ខីកម្មរបស់គាត់៖ “គឺអ្នកមានមុនៗមក អ្នកណារត់ទៅស្រុកទាន់ក៏ទាន់ អ្នកណារត់មិនទាន់គឺសម្លាប់ចោលអស់ហើយ។ តាំងពីសម័យ៧៥មក”[1976]។

---

[1968] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧៩។

[1969] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧៩។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី **២១**។

[1970] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧៩, ២៤១-២៤២។

[1971] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៧៨។

[1972] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០៥។

[1973] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៨៣-៩៨៥។

[1974] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៣៣-៣៤៣៦។

[1975] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៨៥។

[1976] ឯកសារ **E1/424.1** ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង ០៩.១២.០៩-០៩.១៦.១៨ ទំព័រ ៦ បន្ទាត់ ២-៥។

568. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនបានបង្ហាញពីចេតនា ក្នុងការនិរទេសជនជាតិវៀតណាម ពីខេត្តព្រៃវែងនោះ គឺមិនមានអង្គសេចក្តីឡើយ[1977]។ ដោយសារតែទម្ងន់នៃការសម្រេច បង្ហាញថាការផ្លាស់ទីលំនៅដោយបង្ខំទាំងអស់នេះត្រូវបានធ្វើឡើង អនុលោមទៅតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបណ្តេញជនជាតិវៀតណាម ពីប្រទេសកម្ពុជានោះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ គួរត្រូវបានច្រានចោល[1978]។

569. ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ការនិរទេសមិនត្រូវបានបង្ហាញ នៅក្នុងខេត្តស្វាយរៀងឡើយ[1979] ដែលការនេះធ្វើឱ្យការអះអាង របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពាន ទៅលើគោលការណ៍ វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយកត់សម្គាល់ពីលទ្ធភាពដែលថា ការនិរទេសបានកើតឡើងនៅក្នុងខេត្តស្វាយរៀង គឺមិនមានមូលដ្ឋានឡើយ[1980]។

### *មូលដ្ឋានទី ១០៣ និងទី ១០៤៖ ការនិរទេសជនជាតិវៀតណាម ពីស្រុកត្រាំកក់ (ផាតុផ្សំរូបសម្ព័ន្ធ)* [1981]

570. **មូលដ្ឋានទី ១០៣ និងទី ១០៤ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការសម្រេចថា ជនជាតិវៀតណាមត្រូវបានបណ្តេញចេញពីស្រុកត្រាំកក់ ហើយបញ្ជូនទៅប្រទេសវៀតណាម ដោយគ្មានការស្ម័គ្រចិត្ត នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦។**

571. មូលដ្ឋានទាំងនេះមិនទទួលផលឡើយ ពាក់ព័ន្ធការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងអង្គហេតុដោយសារតែម្ចាស់បណ្តឹងសាទុក្ខ (១) គ្រាន់តែបញ្ជាក់ឡើងវិញ នូវការអះអាងដោយខុសឆ្គងរបស់

---

[1977] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៨៥-៩៨៦។

[1978] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៨៦។

[1979] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០៥។

[1980] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៨២។

[1981] <u>មូលដ្ឋានទី ១០៣</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសដោយបានសន្និដ្ឋានថាមានការនិរទេសជនជាតិវៀតណាម* កថាខណ្ឌ ៦៨៦-៧១៤។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៩-៤០ (ភាសាអង់គ្លេស) ទំព័រ ៣៦ (ភាសាបារាំង) ទំព័រ ៥៥-៥៦ (ភាសាខ្មែរ)។ <u>មូលដ្ឋានទី ១០៤</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសដោយបានសន្និដ្ឋានថាមានការនិរទេសជនជាតិវៀតណាម* កថាខណ្ឌ ៦៨៦-៧១៤។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤០ (ភាសាអង់គ្លេស) ទំព័រ ៣៦ (ភាសាបារាំង) ទំព័រ ៥៥-៥៦ (ភាសាខ្មែរ)។

គាត់ ទាក់ទងនឹងបណ្តឹង[1982] (២) គ្រាន់តែអះអាង ប៉ុន្តែមិនផ្តល់ភ័ស្តុតាងគាំទ្រ ការអះអាងរបស់គាត់ដែលថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថាជនជាតិវៀតណាម បានឆ្លងកាត់ព្រំដែនប្រទេសនោះ គឺមិនមានសំអាងហេតុគ្រប់គ្រាន់[1983] (៣) មិនបានបង្ហាញថា ភ័ស្តុតាងជារួមមិនបានបង្ហាញថា ការដែលជនជាតិវៀតណាម នៅក្នុងស្រុកត្រាំកក់ បានឆ្លងកាត់ព្រំដែនជាមួយប្រទេសវៀតណាម គឺជាការទាញសន្និដ្ឋានតែមួយគត់ ដែលសមហេតុផលនោះ[1984] និង (៤) មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង បានបំភ្លៃភ័ស្តុតាង ហើយពឹងផ្អែកលើភ័ស្តុតាង ដែលបានដោយការធ្វើទារុណកម្ម ឬភ័ស្តុតាងដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង[1985]។

572. នៅពេលដំបូង ម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ ពីផ្នែកផ្សេងៗនៃសាលក្រម ហើយបានបង្ហាញផ្នែកទាំងអស់នេះដោយខុសឆ្គងថា ជាការវិភាគជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង ទៅលើការចោទប្រកាន់ពីការនិរទេស។ ជាឧទាហរណ៍ ម្ចាស់បណ្តឹងសាទុក្ខបានលើកយក ការសន្និដ្ឋានអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងផ្នែកទូទៅនៃ "ការប្រព្រឹត្តលើជនជាតិវៀតណាម" ថា "ជនជាតិវៀតណាមជាច្រើន ត្រូវបានប្រមូលផ្តុំក្នុងស្រុកត្រាំកក់ ចាប់ពីចុងឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៦ ដោយពួកគេជាច្រើនត្រូវបានបញ្ជូនចេញ និង/ឬបាត់ខ្លួន"[1986] ហើយបង្ហាញនូវទិដ្ឋភាពដោយបំភាន់ថា អង្គជំនុំជម្រះសាលាដំបូង មិនអាចសម្រេចឱ្យហួសពីវិមតិសង្ស័យបានថា មានការកើតឡើងនូវការនិរទេស ឬការបាត់ខ្លួនដោយបង្ខំ ប៉ុន្តែបែរជាធ្វើការសម្រេចអង្គច្បាប់ ដលនាំទៅដល់ការផ្តន្ទាទោស ដែលដូច្នេះហើយគឺរំលោភបំពាន ទៅលើគោលការណ៍ វិមតិសង្ស័យ នឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ[1987]។

573. ការសម្រេចអង្គច្បាប់ជាក់ស្តែង របស់អង្គជំនុំជម្រះសាលាដំបូង លើការនិរទេស គឺមានភាពច្បាស់លាស់៖ ជនជាតិវៀតណាមយ៉ាងច្រើន ត្រូវបានប្រមូលផ្តុំនៅក្នុងស្រុកត្រាំកក់ ចាប់ពីចុងឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៦។ ការប្រមូលផ្តុំនេះធ្វើឡើងក្នុងបរិយាកាសបង្ខិតបង្ខំ ដែលក្នុងនោះប្រជាជនវៀតណាម ដែលមានវត្តមានរស់នៅ ដោយស្របច្បាប់នៅពេលនោះ មិនមានជម្រើសពិតប្រាកដ

[1982] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី **៥១**។

[1983] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨៨។

[1984] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨៨។

[1985] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨៨។

[1986] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២៥។

[1987] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៩៣។

ឡើយ គឺមានតែការចាកចេញ[1988]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានសម្រេចផងដែរថា មានកិច្ចព្រមព្រៀងគ្នារវាង អាជ្ញាធរវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ ក្នុងការផ្លាស់ប្តូរមនុស្ស ដែលខ្មែរក្រោមត្រូវត្រឡប់មកស្រុកត្រាំកក់ ចំណែកជនជាតិវៀតណាម ត្រូវចាកចេញពីស្រុកវិញ[1989]។ ផ្អែកលើការសម្រេចទាំងនេះ និងការសម្រេចផ្សេងៗទៀត អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានដោយសមហេតុផលថា ជនជាតិវៀតណាមនៅស្រុកត្រាំកក់ ត្រូវបានជម្លៀសឆ្លងព្រំដែន ដោយគ្មានមូលដ្ឋានស្របច្បាប់ឡើយ[1990]។

574. ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា មិនអាចសន្និដ្ឋានបានថា ជនជាតិវៀតណាមត្រូវបាននិរទេស ដោយសារមិនអាចកំណត់បាន ថាមានអ្វីកើតឡើងចំពោះ "ជនជាតិវៀតណាមដែលត្រូវបាន កំណត់អត្តសញ្ញាណយ៉ាងច្បាស់លាស់"[1991] គឺជាការលើកឡើងដែលខុស ដូចគ្នានឹងការអះអាងដែលថា មានការតម្រូវឱ្យបង្ហាញឈ្មោះ ជនរងគ្រោះម្នាក់ៗ នៃការសម្លាប់ដោយរង្គាលនោះដែរ។

575. ចំពោះសក្ខីកម្មសាក្សី ម្ចាស់បណ្តឹងសាទុក្ខ បានពិនិត្យដោយមិនត្រឹមត្រូវ ទៅលើសក្ខីកម្មរបស់សាក្សីមួយចំនួន ដាច់ដោយឡែកពីគ្នា ដោយកម្រិតការវិភាគរបស់គាត់ តែត្រឹមថាតើសាក្សីទាំងនោះ ផ្តល់សក្ខីកម្មថាជនជាតិវៀតណាម បានឆ្លងកាត់ព្រំដែនប្រទេសដែរឬអត់ ហើយមិនគិតអំពីបញ្ហាដែលថា អង្គជំនុំជម្រះសាលាដំបូង តាមពិតទៅ ពឹងផ្អែកលើភ័ស្តុតាងនេះ ដើម្បីបង្ហាញថា ជនជាតិវៀតណាមដែលរស់នៅដោយស្របច្បាប់ នៅក្នុងស្រុកត្រាំកក់ ត្រូវបានចាប់ខ្លួនចាប់ពីចុងឆ្នាំ១៩៧៥ រហូតដល់ដើមឆ្នាំ១៩៧៦ ទៅវិញទេ[1992]។

576. ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូង មិនបានប្រើប្រាស់ដោយទុច្ចរិត ឬបំភ្លៃចម្លើយរបស់ពេជ្រ ជឹម ដើម្បីធ្វើការសន្និដ្ឋានថា ការផ្លាស់ទីលំនៅដោយបង្ខំ ទៅលើប្រជាជនវៀតណាម បានកើតឡើងនៅក្រោយឆ្នាំ១៩៧៥[1993]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការផ្លាស់ទីលំនៅជនជាតិវៀតណាមដោយបង្ខំ បានកើតឡើងនៅក្នុងឆ្នាំ១៩៧% ដោយសារតែខុម និង ជន ដែលជាកម្មាភិបាលស្រុកត្រាំកក់ បានចូលរួមចំណែកក្នុង

[1988] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៥៨។

[1989] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៥៨-១១៥៩។

[1990] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៥៩។

[1991] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៩២។

[1992] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៥៧។

[1993] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៩៨។

ដំណើរការនោះ ដោយអះអាងទាំងខុសឆ្គងថា ភស្តុតាងរបស់ ពេជ្រ ជឹម មិនបានគាំទ្រដល់ចំណុចនេះទេ[1994]។ តាមពិតទៅ ពេជ្រ ជឹម បានឃើញឯកសារមួយចុះកាលបរិច្ឆេទ ដើមខែឧសភា ឆ្នាំ ១៩៧៧ ពីឃុំពពេល ក្នុងស្រុកត្រាំកក់ ដែលរៀបរាប់អំពីការផ្លាស់ប្តូរ ជនជាតិវៀតណាម ជាមួយខ្មែរក្រោម ហើយផ្តល់សក្ខីកម្មថា "គឺប្រធានខុម គាត់ធ្វើជាមួយ ជន ផ្នែកខាងនោះ"[1995]។ ការពន្យល់បន្ទាប់មករបស់ ពេជ្រ ជឹម អំពីតួនាទីរបស់ ជន បង្ហាញយ៉ាងច្បាស់ថា ពេលវេលាដែលចោទជាបញ្ហានោះ គឺនៅក្រោយខែមេសា ឆ្នាំ១៩៧៥ ដោយគាត់បានយោងទៅរក "អ្នកជម្លៀស" ពីភ្នំពេញមកស្រុកត្រាំកក់[1996]។

577. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ សក្ខីកម្មរបស់ ឯក ហឿន មិនមែនមិនច្បាស់លាស់នោះទេ[1997]។ អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា ឯក ហឿន "បានដឹងឮដោយផ្ទាល់ពីការបញ្ជា ឱ្យសម្លាប់ជនជាតិវៀតណាម និងការបញ្ជាឱ្យបញ្ជូនពួកគេទៅវៀតណាម ក្នុងដំណើរការដោះដូរ"[1998]។ ដូចគ្នានេះ ការកំណត់របស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើភស្តុតាងរបស់ ជាំង ស្រីមុំ ថាមិនច្បាស់លាស់ ថាតើប្រជាជនដែលប្រមូលផ្តុំ នៅក្នុងឃុំរបស់គាត់ក្នុងស្រុកត្រាំកក់ គឺជាជនជាតិវៀតណាម ឬបន្លំធ្វើជាជនជាតិវៀតណាម ឬថាតើពួកគេត្រូវបាន បញ្ជូនទៅវៀតណាមដែរឬអត់នោះ គឺជាការមិនគិតពិចារណាទៅដល់ ចំណុចដ៏សំខាន់នៃភស្តុតាងនេះ[1999]។ ជាំង ស្រីមុំ បានផ្តល់សក្ខីកម្មថា នៅក្នុងឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជា "ស្រាវជ្រាវរកជនជាតិវៀតណាម ព្រោះគេនិយាយថា ប្រសិនបើមានវៀតណាម គេនឹងត្រូវបញ្ជូនត្រឡប់ទៅវៀតណាម"[2000] ហើយ "មេកងដើរពីផ្ទះមួយទៅផ្ទះមួយ ដើម្បីកត់ត្រាប្រវត្តិរូបប្រជាជន ហើយគេនិយាយថា អ្នកណាដែលជាប់ទាក់ទងសាច់ញាតិវៀតណាម ឬជាសាច់ញាតិវៀតណាម នឹងត្រូវបញ្ជូនទៅវៀតណាម"[2001]។

---

[1994] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៩៨។

[1995] ឯកសារ **E1/290.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ម៉ោង ១០.៤២.១៥-១០.១៥.២៣ ទំព័រ ១៧ បន្ទាត់ ៨-១៩, សូមមើលផងដែរ ទំព័រ ១៧ បន្ទាត់ ១៨-១៩។

[1996] ឯកសារ **E1/290.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ម៉ោង ១០.៥០.០៨-១០.៥៧.១៦ ទំព័រ ១៨-១៩ បន្ទាត់ ២៤-៩ ទំព័រ ១៩ បន្ទាត់ ១៦-១៧។

[1997] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧០០។

[1998] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១១ (គូសបញ្ជាក់បន្ថែម)។

[1999] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧០២។

[2000] ឯកសារ **E1/254.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ម៉ោង ១១.០៣.៤២ ទំព័រ ៣២ បន្ទាត់ ៩-១០។

[2001] ឯកសារ **E1/254.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ម៉ោង ១១.០៣.៤២-១១.០៧.១៥ ទំព័រ ៣២ បន្ទាត់ ២៣-២៥។

578. ម្ចាស់បណ្ដឹងសាទុក្ខយល់ខុស ទៅលើតម្លៃនៃភ័ស្តុតាង របស់ភ័ស្តុតាងចចាមអារាម ទាក់ទង ជូ គឹមឡូន[2002]។ ទោះបីជាជូ គឹមឡូន មិនបានផ្ដល់សក្ខីកម្មថាតើ គ្រួសារវៀតណាមដែលគេប្រាប់គាត់ថា ត្រូវបានបញ្ជូនត្រឡប់ទៅវៀតណាម[2003] ពិតជាត្រឡប់ទៅប្រទេសវៀតណាមដែរឬអត់នោះក្ដី[2004] តែជាថ្មីម្ដងទៀតភ័ស្តុតាងនេះបានបង្ហាញថា ការប្រមូលផ្ដុំនិងការបញ្ជូនជនជាតិវៀតណាម ពីស្រុកត្រាំកក់ទៅប្រទេសវៀតណាម គឺដឹងឮជាទូទៅ។

579. ការដែលម្ចាស់បណ្ដឹងសាទុក្ខ មិនបានពិចារណាទៅលើភ័ស្តុតាងរបស់ វៀល សន ដោយមិនបានជំទាស់ទៅលើភ័ស្តុតាងដែលថា គ្រួសារវៀតណាមទាំងមូល នៅក្នុងតំបន់របស់គាត់បានបាត់ខ្លួន[2005] បានបង្ហាញបន្ថែមទៀតអំពី វិធីសាស្ត្រមួយផ្នែកៗ របស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងការវាយតម្លៃ។ ផ្ទុយពីការលើកឡើងរបស់ម្ចាស់បណ្ដឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង មិនបានទាញសន្និដ្ឋានចេញតែពីភ័ស្តុតាង របស់សាក្សីបែបនេះ ដោយថាធាតុផ្សំនៃការនិរទេសត្រូវបានបង្ហាញនោះទេ[2006]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង បានវិភាគដោយត្រឹមត្រូវទៅលើភ័ស្តុតាងនេះ នៅក្នុងបរិបទនៃភ័ស្តុតាងដទៃ នៅក្នុងសំណុំរឿង រួមទាំងទស្សនាវដ្ដីទង់បដិវត្ត ដែលនាំទៅដល់ការណ៍ដែលថា នេះគឺជាការទាញសន្និដ្ឋានតែមួយគត់ ដែលសមហេតុផល។

580. ចំពោះទស្សនាវដ្ដីទង់បដិវត្ត អង្គជំនុំជម្រះសាលាដំបូង មិនបានបំភ្លៃអត្ថន័យនៃលេខចេញផ្សាយ ខែមេសា ឆ្នាំ១៩៧៦ ដែលបានប្រកាសថា ជនបរទេសរាប់រយពាន់នាក់ ត្រូវបាន "បោសសម្អាត ឱ្យចេញផុតពីប្រទេសយើង"[2007]។ ការអានដោយធម្មតាទៅលើឯកសារនេះ បង្ហាញយ៉ាងច្បាស់ថា ការនិយាយយោងទៅរក "ជនបរទេស" គឺសំដៅជនជាតិវៀតណាម[2008]។ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែបញ្ជាក់ឡើងវិញ នូវការជំទាស់ដែលបានលើកឡើង នៅសេចក្ដីថ្លែងបញ្ចប់ការពិភាក្សាដេញដោលរបស់គាត់ ទាក់ទងភាពអាចជឿជាក់បាន នៃសក្ខីកម្មអ្នកជំនាញ Alexander

---

[2002] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧០៣។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[2003] ឯកសារ **E1/253.1** ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ម៉ោង ១០.០៨.៥៥ ទំព័រ ២០ បន្ទាត់ ១-២, ទំព័រ ៧៣ បន្ទាត់ ១៤-១៨។

[2004] ឯកសារ **E1/253.1** ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ម៉ោង ១០.០៨.៥៥ ទំព័រ ២០ បន្ទាត់ ៨-៩។

[2005] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧០៣។

[2006] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧០៥។

[2007] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧០៦។

[2008] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧០៦។ សូមមើល ឯកសារ **E3/759** *ទង់បដិវត្ត* ខែមេសា ឆ្នាំ១៩៧៦ KH 00062748។

Hinton[2009]ប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូង បានពិភាក្សាយ៉ាងច្បាស់លាស់ ទៅលើការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខ ចំពោះភាពអាចជឿជាក់បាននៃ សក្ខីកម្មអ្នកជំនាញ Alexander Hinton ហើយបានសន្និដ្ឋានថា អង្គជំនុំជម្រះ "កំណត់ការប្រើប្រាស់របស់ខ្លួន នូវភស្តុតាងរបស់ [គាត់] ត្រឹមការវាយតម្លៃការបកស្រាយត្រឹមត្រូវ នូវអង្គហេតុនានាដែលបានកំណត់ និងត្រឹមការដាក់អង្គហេតុទាំងនេះ បញ្ចូលទៅក្នុងបរិបទនៅពេលចាំបាច់ និងដោយមានការប្រុងប្រយ័ត្ន"[2010]។ អង្គជំនុំជម្រះសាលាដំបូង គោរពតាមវិធីសាស្ត្រនេះ នៅពេលដែលអង្គជំនុំជម្រះ យកសក្ខីកម្មអ្នកជំនាញ Hinton ថាទស្សនាវដ្តីទង់បដិវត្តខែមេសា ឆ្នាំ១៩៧៦ ទាក់ទងជាមួយជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា នៅក្នុងបរិបទប្រវត្តិសាស្ត្រដ៏ទូលំទូលាយ ជាពិសេសការពិតដែលថា ភាសាតែមួយត្រូវបានប្រើប្រាស់ ដើម្បីរៀបរាប់ "ជនបរទេស" នៅក្នុងទស្សនាវដ្តីទង់បដិវត្តលេខខែមេសា ឆ្នាំ១៩៧៦ គឺ "បានប្រើប្រាស់ជាទូទៅ ក្នុងវោហាសាស្ត្ររបស់ បក្សកុម្មុយនីស្តកម្ពុជា ចំពោះជនជាតិវៀតណាម"[2011]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានទទួលស្គាល់ថា កំណត់ត្រាសហសម័យដទៃទៀតទាំងអស់នេះ ដែលខ្លឹមសារនៃកំណត់ត្រាទាំងនេះ ប្រឆាំងជាមួយទឡ្ហីករណ៍របស់គាត់។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខមិនបាន ផ្តល់ភស្តុតាងគាំទ្រចំពោះ ការអះអាងដោយគ្មានមូលដ្ឋានរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់ការប្រុងប្រយ័ត្ន ពាក់ព័ន្ធទស្សនាវដ្តីទង់បដិវត្ត តែក្នុងករណីដែលមានព័ត៌មានដោះបន្ទុក នៅក្នុងនោះប៉ុណ្ណោះ[2012]។

581. ផ្ទុយពីការអះអាងរបស់ ម្ចាស់បណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង មិនបានពឹងផ្អែកតែទៅលើការសម្រេចទាក់ទងការនិរទេស ពីខេត្តព្រៃវែងតែមួយនោះទេ[2013]។ អង្គជំនុំជម្រះសាលាដំបូង បានដកស្រង់ផងដែរនូវភស្តុតាង របស់អតីតកម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជាគឺ ទាត់ ធឿន ដែលបានជូនជនជាតិវៀតណាម ពីបាត់ដំបងទៅប្រទេសវៀតណាម ឈ្មោះហេង ឡៃហ៊ាង ដែលឃើញគេដឹកជនជាតិវៀតណាមចេញតាមឡាននៅខេត្តក្រចេះ ព័ត៌មានរបស់ វ៉ែន វ៉ន ដែលថា ជនជាតិវៀតណាមប្រហែលមួយសែននាក់ ត្រូវបានគេប្រមូលនៅខេត្តពោធិ៍សាត់ ហើយបញ្ជូនត្រឡប់ទៅវៀត

[2009] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧០៧ ជើងទំព័រ ១២៣៥។

[2010] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៧, ៣៣៦៤។

[2011] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨៨។ សូមមើលផងដែរ ឯកសារ **E3/746** *ទង់បដិវត្ត* ខែកក្កដា ឆ្នាំ១៩៧៨ KH 00064486-00064487។ ឯកសារ **E3/727** *ទង់បដិវត្ត* ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ KH 00064566។ ឯកសារ **E3/5720** សេចក្តីថ្លែងការណ៍របស់សមមិត្ត ប៉ុល ពត ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ KH 00225371-00225372។

[2012] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧០៧។

[2013] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧០៨។

ណាម និងឈ្មោះ ជឿង យ៉ាំងចែត ដែលផ្តល់សក្ខីកម្មថា គាត់ត្រូវបាននិរទេសពី កំពង់ឆ្នាំងទៅប្រទេសវៀតណាម[2014]។

582. ចំពោះការផ្លាស់ប្តូរខ្មែរក្រោម ជាមួយជនជាតិវៀតណាម ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា ខ្មែរក្រោមដែលមកពីប្រទេសវៀតណាម ដែលផ្តល់សក្ខីកម្មថា ត្រូវបានគេផ្លាស់ទីលំនៅដោយបង្ខំទៅស្រុកត្រាំកក់ តាមកម្មវិធីផ្លាស់ប្តូរនោះ មិនបានបញ្ជាក់ថា ប្រជាជនវៀតណាមពីស្រុកត្រាំកក់បានឆ្លងព្រំដែនចូលទៅប្រទេសវៀតណាមឡើយ[2015]។ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ហាក់ដូចជាថា នៅក្នុងការផ្លាស់ប្តូរប្រជាជន រវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាមនេះ គឺកម្ពុជាប្រជាធិបតេយ្យ ទទួលខ្មែរក្រោមពីវៀតណាម ចំណែកប្រទេសវៀតណាម មិនទទួលយកជនជាតិវៀតណាមនោះទេ។

583. ម្ចាស់បណ្តឹងសាទុក្ខបានច្រានចោល កំណត់ត្រាសហសម័យស្រុកត្រាំកក់ ដោយផ្អែកលើមូលដ្ឋានថា គាត់ជំទាស់ចំពោះតម្លៃនៃភស្តុតាង របស់កំណត់ត្រាទាំងអស់នោះ[2016]។ ហេតុដូច្នេះម្ចាស់បណ្តឹងសាទុក្ខ មិនបានពិភាក្សាអំពីរបាយការណ៍ ខែឧសភា ឆ្នាំ១៩៧៧ ពីឃុំពពេល ដែលកត់ត្រាចំនួនខ្មែរក្រោមមករស់នៅក្នុងតំបន់ និងបានរៀបរាប់ថាប្រជាជនទាំងអស់នេះ "ដែលយួនដូរឱ្យ"[2017]។ អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា ឯកសារនេះគាំទ្រដល់សក្ខីកម្មរបស់ រី ពៅ ដែលថា ខ្មែរក្រោមត្រូវបានបញ្ជូនទៅឃុំពពេល ជាផ្នែកមួយនៃការផ្លាស់ប្តូរ[2018]។

584. បន្ថែមលើនេះម្ចាស់បណ្តឹងសាទុក្ខ អះអាងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកទៅលើភស្តុតាងដែលទទួលបានដោយទារុណកម្ម ហើយប្រឆាំងជាមួយការសម្រេចផ្ទាល់របស់ខ្លួនកន្លងមក[2019]។ ទីមួយ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់បំភ្លឺថា ប្រយោគដែលបានដកស្រង់ ពីសៀវភៅកំណត់ត្រាក្រាំងតាចាន់ គឺជា "ការពិពណ៌នាមួយ"[2020] ហើយកត់សម្គាល់ថា "ព័ត៌មានសត្យានុម័តមួយចំនួន ដែលមាននៅក្នុងចម្លើយសារភាព មិនមែនជាផ្នែកនៃចម្លើយ ដែលបានមក

[2014] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៣៥។

[2015] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១០។

[2016] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១១។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៦។

[2017] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២៣។

[2018] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២៣។

[2019] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១២-៧១៣។

[2020] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១៥។

ដោយការធ្វើទារុណកម្មនោះទេ។ ហេតុដូច្នេះ វាមិនត្រូវបានដកចេញពីភ័ស្តុតាងនោះឡើយ”[2021]។ ទីពីរ ម្ចាស់បណ្តឹងសាទុក្ខព្យាយាមដោយមិនត្រឹមត្រូវ ក្នុងការដាក់បញ្ចូលគ្នានូវផ្នែកនេះ ជាមួយការជំទាស់របស់អង្គជំនុំជម្រះសាលាដំបូង ទៅលើការប្រើប្រាស់ផ្នែកខ្លះ នៃឯកសារដដែលនេះ នៅក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី ដែលទាក់ទងជាពិសេសជាមួយ អង្គសេចក្តីនៃចម្លើយសារភាព[2022]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុស ហើយគ្មានការពន្យល់ផងដែរថា ការដកស្រង់ពីកំណត់ត្រាក្រាំងតាចាន់ ខែមករា ឆ្នាំ១៩៧៦ មិនបានគាំទ្រដល់ភ័ស្តុតាងរបស់ សាន់ ឡូន ទេ[2023]។ ទោះជាបែបនេះក្តី សាន់ ឡូន បានផ្តល់សក្ខីកម្មថា ជាគោលនយោបាយរបស់ខ្មែរក្រហម ក្នុងការចាប់ខ្លួនជនជាតិវៀតណាមនៅក្នុងឆ្នាំ១៩៧៥[2024] ហើយថាគាត់បានចូលរួម ក្នុងការប្រមូលផ្តុំ និងដឹកជញ្ជូនជនជាតិវៀតណាម “ច្រើន” ពីបណ្តាឃុំនានានៅក្នុងស្រុកត្រាំកក់ ប្រហែលជានៅដើមឆ្នាំ១៩៧៦[2025]។

585. ជាចុងក្រោយ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ភ័ស្តុតាងទាំងអស់ទាក់ទងខ្មែរក្រោម គឺស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២[2026] គឺមិនបានគិតពិចារណាដល់ ការប្រើប្រាស់ដោយត្រឹមត្រូវ របស់អង្គជំនុំជម្រះសាលាដំបូង ទៅលើភ័ស្តុតាងនេះ[2027]។

### *មូលដ្ឋានទី ១០៥៖ កំហុសពាក់ព័ន្ធនឹងចេតនា ជម្លៀសជនរងគ្រោះដោយបង្ខំឱ្យទៅម្ខាងទៀតនៃព្រំដែនជាតិ*[2028]

---

[2021] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៦ *ដកស្រង់* ឯកសារ **E350/8** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើភ័ស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម កថាខណ្ឌ ៩៩។

[2022] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១៣។ សូមមើល ឯកសារ **E1/300.1** វង់ សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១១.២១.៥១-១១.២៩.៣៥ ទំព័រ ២៩-៣១ បន្ទាត់ ២៣-១១។

[2023] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧០១។

[2024] ឯកសារ **E1/384.1** សាន់ ឡូន ប្រតិចារឹក ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ម៉ោង ១៤.២០.៣២-១៤.២៥.៥៩ ទំព័រ ៤៧ បន្ទាត់ ៥-១៤។

[2025] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១៤-១១១៥។

[2026] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១៤។

[2027] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣។

[2028] មូលដ្ឋានទី ១០៥៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងចេតនាជម្លៀសជនរងគ្រោះដោយបង្ខំឱ្យទៅម្ខាងទៀតនៃព្រំដែនជាតិ* កថាខណ្ឌ ៧១៥-៧១៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤០ (ភាសាអង់គ្លេស) ទំព័រ ៣៦ (ភាសាបារាំង) ទំព័រ ៥៦ (ភាសាខ្មែរ)។

586. **មូលដ្ឋានទី ១០៥ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ក្នុងការសម្រេចពីចេតនា ក្នុងការផ្លាស់ទីជនជាតិវៀតណាម ពីស្រុកត្រាំកក់ ដោយឆ្លងកាត់ព្រំដែនប្រទេស។**

587. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធការចោទប្រកាន់ពីកំហុសអង្គហេតុ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែអះអាងថា អង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់ភ័ស្តុតាងតែមួយ ក្នុងការបង្ហាញធាតុផ្សំអត្តនោម័តិ ក្នុងការនិរទេស និងបង្ហាញនូវធាតុផ្សំសត្យានុម័តផងដែរ[2029]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញ អំពីកំហុសឆ្គងណាមួយ នៅក្នុងការដែលអង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកទៅលើភ័ស្តុតាង ដែលបង្ហាញថា៖ ជនជាតិវៀតណាមនៅស្រុកត្រាំកក់ ត្រូវបានចាប់ខ្លួន យោងទៅតាមការណែនាំពី គោលការណ៍ណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា, ការផ្លាស់ប្តូរប្រជាជន ដែលកើតឡើងរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម និងការទទួលស្គាល់ជាសាធារណៈ របស់បក្សកុម្មុយនីស្តកម្ពុជាថា ជនជាតិវៀតណាមត្រូវបាននិរទេសនៅពេលនោះ[2030]។ ភ័ស្តុតាងទាំងនេះជារួម បង្ហាញយ៉ាងច្បាស់អំពីចេតនា ក្នុងការផ្លាស់ទីដោយបង្ខំ ទៅលើជនជាតិវៀតណាម ពីស្រុកត្រាំកក់ ឆ្លងកាត់ព្រំដែនប្រទេស។

588. គួរឱ្យកត់សម្គាល់ផងដែរ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ បានជំទាស់ចំពោះការសម្រេចដែលថា គាត់បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តាមរយៈការសម្លាប់ គាត់បានអះអាងថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្ហាញពីចេតនាតក្នុងការសម្លាប់ មិនមែនចេតនាក្នុងការផ្លាស់ទីលំនៅជនជាតិវៀតណាមទេ[2031] ដែលនេះជាការទទួលស្គាល់យ៉ាងច្បាស់លាស់ ពីការវិវឌ្ឍន៍គោលនយោបាយពីមួយពេលទៅមួយពេល។

### iii. ការបាត់ខ្លួនជនជាតិវៀតណាមដោយបង្ខំ

***មូលដ្ឋានទី ១១១៖ កំហុសនៅក្នុងការសន្និដ្ឋានអំពីការបាត់ខ្លួនដោយបង្ខំ ចំពោះជនជាតិវៀតណាម***[2032]

[2029] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១៦។

[2030] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៥៨។

[2031] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១៧។

[2032] <u>មូលដ្ឋានទី ១១១</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសដោយបានសន្និដ្ឋានថាមានការបាត់ខ្លួនដោយបង្ខំចំពោះជនជាតិវៀតណាម* កថាខណ្ឌ ៧៥៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤២ (ភាសាអង់គ្លេស) ទំព័រ ៣៨ (ភាសាបារាំង) ទំព័រ ៥៩ (ភាសាខ្មែរ)។

589. **មូលដ្ឋានទី ១១១ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានកំណត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ក្នុងការសម្រេចថាជនជាតិវៀតណាម គឺជាជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំ នៅស្រុកត្រាំកក់។**

590. មូលដ្ឋាននេះមិនទទួលផលឡើយ ព្រោះម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែលើកឡើងវិញនូវការអះអាងដោយភាន់ច្រឡំ ទាក់ទងនឹងបណ្តឹង[2033] និងបកស្រាយមិនត្រឹមត្រូវចំពោះការយល់ឃើញនានា។

591. ផ្ទុយពីការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខ ការសម្រេចថាជនជាតិវៀតណាម "ត្រូវបាននិរទេស និង/ឬបាត់ខ្លួន" មិនបានបង្ហាញពីអលទ្ធភាព ក្នុងការសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ជនជាតិវៀតណាមបានបាត់ខ្លួន ឬនិរទេសឡើយ[2034]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាតិវៀតណាមជាច្រើន ត្រូវបានចាប់ខ្លួននៅស្រុកត្រាំកក់ នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៦ ហើយថាក្នុងចំណោមនោះ (១) ភស្តុតាងបានបង្ហាញថាមានមនុស្សបាត់ខ្លួន (២) ការទាញសន្និដ្ឋានដោយសមហេតុផលតែមួយ នៅក្នុងបរិបទនេះគឺថា មនុស្សត្រូវបានគេនិរទេស និង (៣) មនុស្សដែលត្រូវនិរទេស គឺជាជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំ ផ្អែកតាមកាលៈទេសៈ ដែលហេតុការណ៍ទាំងអស់នោះបានកើតឡើង[2035]។ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ហាក់ដូចជាផ្អែកទៅលើសញ្ញាណខុសដូចគ្នាដែលថា ភស្តុតាងតែមួយមិនអាចគាំទ្រ ដល់ការសម្រេចផ្សេងពីគ្នាឡើយ ហើយថាបុគ្គលម្នាក់មិនអាចជាជនរងគ្រោះ នៃការបាត់ខ្លួនដោយបង្ខំ និងការនិរទេសឡើយ[2036]។ ដោយសារតែការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង មិនបណ្តាលឱ្យមានធាតុផ្សំនៃវិមតិសង្ស័យនោះ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ស្តីពីវិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ គឺខុសទាំងស្រុង[2037]។

592. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មិនបានបង្ហាញធាតុផ្សំសំខាន់នៃអំពើអមនុស្សធម៌ផ្សេងទៀត នៃការបាត់ខ្លួនដោយបង្ខំ ទាក់ទងជនជាតិវៀតណាម[2038]។ អង្គជំនុំជម្រះសាលាដំបូង យោងត្រឡប់ទៅរកភស្តុតាង ដែលបានវាយតម្លៃនៅក្នុងផ្នែកនិរទេស ដើម្បី

---

[2033] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៤។

[2034] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៦។

[2035] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១០-១១២៥, ១២០១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៦។

[2036] សូមមើល វិធីសាស្ត្រចំពោះភស្តុតាង។

[2037] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៦។

[2038] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៦។

បង្ហាញថា ជនជាតិវៀតណាមត្រូវបានចាប់ខ្លួន និងបាត់ខ្លួន[2039]។ ចំពោះអ្នកដែលបានបាត់ខ្លួន ប្រាកដណាស់ថាមិនអាចមកផ្តល់សក្ខីកម្មបានទេ ហើយភ័ស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកទៅលើ គឺពិតជាបានបំពេញតាម ធាតុផ្សំគតិយុត្តិនៃអំពើសកម្មឬអកម្មដោយចេតនា របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបណ្តាលឱ្យមាន ការឈឺចាប់ឬរបួសខ្លាំង ដល់រាងកាយនិងផ្លូវចិត្ត ឬ បណ្តាលឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទៅលើសេចក្តីថ្លៃថ្នូរបស់មនុស្ស ហើយមានស្ថានទម្ងន់ ប្រហែលគ្នា ជាមួយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត[2040]។

***មូលដ្ឋានទី ១១២៖ អង្គជំនុំជម្រះមានកំហុស ដោយបានសម្រេចថា ខ្មែរក្រោមគឺជាជនរងគ្រោះ នៃការបាត់ខ្លួនដោយបង្ខំ***[2041]

593. **មូលដ្ឋានទី ១១២ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់និងកំហុសអង្គហេតុ ក្នុងការសម្រេចថា ខ្មែរក្រោមគឺជាជនរងគ្រោះ នៃការបាត់ខ្លួនដោយបង្ខំនៅត្រាំកក់។**

594. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ បង្ហាញដោយភាន់ច្រឡំ ទៅលើការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខអង្គជំនុំជម្រះសាលាដំបូង បានពិចារណាយ៉ាងត្រឹមត្រូវទៅលើភ័ស្តុតាងរបស់ខ្មែរក្រោម[2042]។

595. ម្ចាស់បណ្តឹងសាទុក្ខមិនត្រូវបានចោទប្រកាន់ និងមិនត្រូវបានផ្តន្ទាទោស ពីបទបាត់ខ្លួនដោយបង្ខំ របស់ខ្មែរក្រោម ជាក្រុមឬអនុក្រុមជាក់លាក់ នៃជនជាតិវៀតណាមនៅស្រុកត្រាំកក់ឡើយ[2043]។ ហេតុដូច្នេះនៅក្នុងការសន្និដ្ឋានថា អំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈអំពើដែលចាត់ចំណាត់ថ្នាក់ថាជាការបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញនោះ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាដោយត្រឹមត្រូវទៅលើភ័ស្តុតាងដែលថា គ្រួសារខ្មែរក្រោមទាំងមូល ត្រូវបានបាត់ខ្លួននៅស្រុក

---

[2039] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២០១ ជើងទំព័រ ៤០៩៦។

[2040] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨០។

[2041] <u>មូលដ្ឋានទី ១១២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសដោយបានសន្និដ្ឋានថាមានការបាត់ខ្លួនខ្មែរក្រោមដោយបង្ខំ* កថាខណ្ឌ ៧៥៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤២ (ភាសាអង់គ្លេស) ទំព័រ ៣៨ (ភាសាបារាំង) ទំព័រ ៥៩ (ភាសាខ្មែរ)។

[2042] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៧ ដែលម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ បានសន្និដ្ឋានដោយខ្លួនឯងថា ខ្លួនត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុទាំងនេះ, សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១៦។

[2043] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៧។

ត្រាំកក់ រួមជាមួយភស្តុតាងដែលថា ជនជាតិវៀតណាមនិងអ្នករស់នៅដទៃទៀត នៅក្នុងសហករណ៍បានបាត់ខ្លួនជាបន្តបន្ទាប់ នៅក្នុងអំឡុងរបបនោះ[2044]។

### iv. អំពើមនុស្សឃាតលើជនជាតិវៀតណាម[2045]

### *មូលដ្ឋានទី ១៥២៖ កំហុសក្នុងការសន្និដ្ឋាន លើការសម្លាប់ជនជាតិវៀតណាមបួនគ្រួសារនៅខេត្តស្វាយរៀង*[2046]

596. **មូលដ្ឋានទី ១៥២ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ក្នុងការសន្និដ្ឋានថា ជនជាតិវៀតណាមត្រូវបានសម្លាប់នៅខេត្តស្វាយរៀង។**

597. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ បានពឹងផ្អែកដោយខុស តែទៅលើផ្នែកខ្លះនៃសក្ខីកម្មរបស់ ស៊ិន ឆែម ដោយមិនគិតអំពីបរិបទដែលសាក្សីនោះបានបង្ហាញឡើយ[2047]។

598. ទោះបីជា ស៊ិន ឆែម មិនបានឃើញផ្ទាល់ការចាប់ខ្លួនឬការសម្លាប់ ក្រុមគ្រួសារជនជាតិវៀតណាមក្តី[2048] តែគាត់បានផ្តល់សក្ខីកម្មថា៖ គាត់ស្គាល់គ្រួសារជនជាតិវៀតណាម នៅក្នុងតំបន់នោះតាំងពីមុនឆ្នាំ១៩៧៥[2049], គាត់រស់នៅជិតគ្រួសារជនជាតិវៀតណាម ហើយធ្វើស្រែជាមួយពួកគេផង[2050] គាត់បានឃើញជនជាតិវៀតណាម ត្រូវគេចងដៃទៅក្រោយ[2051] អ្នករស់នៅក្បែរក្រុមគ្រួសារ

---

[2044] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២០១ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៧។

[2045] ទឡ្ហីករណ៍នីមួយៗរបស់ម្ចាស់សាទុក្ខទាក់ទងនឹងបណ្តឹងពីការសម្លាប់មនុស្សមិនត្រូវបានទទួលយកទេ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦០។

[2046] <u>មូលដ្ឋានទី ១៥២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសក្នុងការសន្និដ្ឋានលើការសម្លាប់ជនជាតិវៀតណាមបួនគ្រួសារនៅខេត្តស្វាយរៀង* កថាខណ្ឌ ៩៨៧-៩៩២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៣ (ភាសាអង់គ្លេស) ទំព័រ ៤៨-៤៩ (ភាសាបារាំង) ទំព័រ ៧៦ (ភាសាខ្មែរ)។

[2047] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៨៧, ៩៩០។

[2048] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥៣។

[2049] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ០៩.៣២.៣១ ទំព័រ ៨ បន្ទាត់ ១២-១៨។

[2050] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១០.៤១.៥៦-១០.៤៤.៤៥ ទំព័រ ២១ បន្ទាត់ ១៧-១៧, 14.40.23 ទំព័រ ៥៤ បន្ទាត់ ៧-១០។

វៀតណាមទាំងនោះ ហើយបានឃើញការចាប់ខ្លួនគ្រួសារទាំងនោះ បានប្រាប់គាត់អំពីការបាត់ខ្លួន និងការសម្លាប់ជនជាតិវៀតណាម[2052] មេឃុំបានប្រាប់ថា ក្នុងគ្រួសារដែលរៀបការលាយជាតិសាសន៍គ្នា ប្រពន្ធនិងកូនជនជាតិវៀតណាម ត្រូវគេយកទៅសម្លាប់[2053] គាត់បានឃើញសាកសពគ្រួសារមួយ ដែលមានកូនពីរនាក់ នៅក្នុងរណ្ដៅមួយក្បែរវាលស្រែ ហើយគេប្រាប់គាត់ថា អ្នកទាំងនោះត្រូវបានគេសម្លាប់កាលពីយប់[2054] គេបានប្រាប់គាត់អំពីជនជាតិវៀតណាម ដែលត្រូវគេយកទៅសម្លាប់នៅភូមិផ្សេងទៀត[2055]។

599. បន្ថែមលើនេះ ស៊ិន ឆែម មិនបានលើកឡើងផ្ទុយឡើយ ទាក់ទងពេលវេលានៃការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាម នៅក្នុងឃុំរបស់គាត់។ ម្ចាស់បណ្ដឹងសាទុក្ខពឹងផ្អែកទៅលើ ផ្នែកខ្លះនៃកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ដែលម្ចាស់បណ្ដឹងសាទុក្ខ បានកំណត់ប្រភេទដោយភាន់ច្រលំ ថាជាសក្ខីកម្មក្នុងសវនាការ[2056]។ តាមពិតទៅសក្ខីកម្មរបស់ ស៊ិន ឆែម គឺច្បាស់ថា មេឃុំស្វាយយា ដែលមកជំនួសប្ដីគាត់ ពេលដែលប្ដីគាត់ត្រូវគេសម្លាប់ នៅចុងឆ្នាំ១៩៧៧[2057] បានប្រមូលយកគ្រួសារជនជាតិវៀតណាម[2058]។

### *មូលដ្ឋានទី ១២៨៖ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាមប្រាំមួយនាក់*[2059]

---

[2051] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៥.១៨.០១-១៥.២០.៥២ ទំព័រ ៦០ បន្ទាត់ ១៦-១៧។

[2052] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៥.៥៩.៤០ ទំព័រ ៧១ បន្ទាត់ ១៧-២១។

[2053] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១០.៤៩.៤០-១០.៥២.០៨ ទំព័រ ២៣ បន្ទាត់ ៥-១៧។

[2054] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៥.១៥.៣០-១៥.១៨.០១ ទំព័រ ៦០ បន្ទាត់ ៥-៨។

[2055] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៥.១៨.០១ ទំព័រ ៦០ បន្ទាត់ ១៤-១៧។

[2056] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៩៨៩ ជើងទំព័រ ១៨២៣-១៨២៤។

[2057] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ទំព័រ ១៤ បន្ទាត់ ៣-៧, ទំព័រ ១៥ បន្ទាត់ ១០-១១។

[2058] ឯកសារ **E1/367.1** ស៊ិន ឆែម ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១០.៤៤.៤៥-១០.៤៧.១១ ទំព័រ ២២ បន្ទាត់ ២-៤, ៨-៩។

[2059] មូលដ្ឋានទី ១២៨៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាមប្រាំមួយនាក់* កថាខណ្ឌ ៨៤២-៨៤៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៤៦-៤៧ (ភាសាអង់គ្លេស) ទំព័រ ៤២-៤៣ (ភាសាបារាំង) ទំព័រ ៦៦ (ភាសាខ្មែរ)។

600. **មូលដ្ឋានទី ១២៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ក្នុងការសម្រេចថា ជនជាតិវៀតណាមប្រាំមួយនាក់ ត្រូវបានសម្លាប់នៅអូរកន្សែង។**

601. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែ ម្ចាស់បណ្តឹងសាទុក្ខ បានធ្វើការអះអាងដោយខុសមួយចំនួន ទាក់ទងការប្រើប្រាស់ និងការពឹងផ្អែករបស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើភ័ស្តុតាងរបស់ ឆោម សែ។

602. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូងមិនបានពឹងផ្អែក ការសម្រេចរបស់ខ្លួនតែទៅលើ កំណត់ហេតុស្តាប់ចម្លើយរបស់ ឆោម សែ[2060] ទេ។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ខ្លួនពឹងផ្អែកទៅលើសក្ខីកម្មរបស់ ឆោម សែ ក្នុងសំណុំរឿង ០០២/០១ ជាប្រធានមន្ទីរសន្តិសុខអូរកន្សែង ទាក់ទងអង្គសេចក្តីដែលជាកម្មវត្ថុ នៃការសួរដេញដោលដោយភាគីនានា[2061]។

603. ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញដោយខុស ទៅលើភាពពាក់ព័ន្ធនៃបញ្ហា ដែលអង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឱ្យសួរដេញដោលទៅ ឆោម សែ[2062]។ មេធាវីការពារក្តីបានដឹង អំពីបញ្ហានៅពេលនោះ ដែលទាក់ទងជាមួយ “នយោបាយទាក់ទងទៅនឹងខ្មាំងនៅពេលនោះ [...] សិទ្ធិអំណាច ក្នុងការសម្រេចលើជោគវាសនាខ្មាំង? តើត្រូវដោះលែង ឬក៏ត្រូវប្រហារជីវិត ឬក៏ត្រូវដាក់គុកជាដើម?”[2063]។ បន្ថែមលើនេះ ការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់ នៅអូរកន្សែង បន្ទាប់ពីមានបញ្ជារបស់ ស៊ូ សារឿន គឺត្រូវបានចោទប្រកាន់ជាពិសេស នៅក្នុងដីកាដំណោះស្រាយ ទៅលើម្ចាស់បណ្តឹងសាទុក្ខ ដោយផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ឆោម សែ ដោយ ក.ស.ច.ស ផងដែរ[2064]។ ដូច្នេះប្រាកដណាស់ថា ម្ចាស់បណ្តឹងសាទុក្ខ បានដឹងអំពីភាពពាក់ព័ន្ធ និងសារសំខាន់នៃសក្ខីកម្មរបស់ ឆោម សែ ដែលថា “ដោយឡែកតែរឿងពួកក្រុម៦នាក់ អាហ្នឹងបានបទបញ្ជា

---

[2060] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៤២-៨៤៣។

[2061] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៦០។

[2062] នៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១ សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៤៥។

[2063] ឯកសារ **E1/159.1** ឆោម សែ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ម៉ោង ១៥.១៨.៥១-១៥.២១.៤៣ ទំព័រ ៧៥-៧៦ បន្ទាត់ ២១-១៥ ។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៦០។

[2064] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៦២២ ជើងទំព័រ ២៦៩៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៤៦។

ទៅគឺឱ្យសម្លាប់ដែរ ស៊ូ សារឿន ដែរ ជនក្រៅប្រទេស"[2065]។ ជាលទ្ធផល ការលើកឡើងរបស់ម្ចាស់បណ្ដឹងសាទុក្ខ ដែលថាសេចក្ដីសម្រេចរបស់គាត់ មិនសួរដេញដោល នោម សែ លើបញ្ហាជាក់លាក់នេះ ធ្វើឱ្យសក្ខីកម្មមិនមានតម្លៃជាភ័ស្ដុតាង លើសពីកំណត់ហេតុស្ដាប់ចម្លើយសាក្សីនោះ គឺជាការលើកឡើងដោយខុស[2066]។

***មូលដ្ឋានទី ១៥៥៖ កំហុសក្នុងការសន្និដ្ឋាន អំពីការធ្វើមនុស្សឃាត លើជនជាតិវៀតណាមនៅវត្តខ្សាច់***[2067]

604. **មូលដ្ឋានទី ១៥៥ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចថា ជនជាតិវៀតណាមត្រូវបានសម្លាប់នៅវត្តខ្សាច់។**

605. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធការចោទប្រកាន់ពីកំហុសឆ្គង គឺប្រភេទនៃកំហុសឆ្គងដែលម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញ ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញអំពីកំហុសឆ្គងណាមួយ ក្នុងការសម្រេចដែលថា ការសម្លាប់ជាទ្រង់ទ្រាយធំ ទៅលើជនជាតិវៀតណាម កើតមានឡើងនៅវត្តខ្សាច់ តាមបញ្ជារបស់ថ្នាក់លើ[2068]។

606. ការអះអាងដោយខុសរបស់ម្ចាស់បណ្ដឹងសាទុក្ខ ទាក់ទងការសម្លាប់ យាយ ហាយ និង តា ឃុត[2069] សមាជិកគ្រួសាររបស់ ជុំ[2070] និងអ្នកភូមិមកពីស្រុកជីក្រែង[2071] មិនបានធ្វើឱ្យប៉ះពាល់ដល់សក្ខីកម្ម របស់សាក្សីបីរូប អំពីការសម្លាប់ជាទ្រង់ទ្រាយធំ ទៅលើប្រជាជនវៀតណាមនៅវត្តខ្សាច់ នៅពាក់កណ្ដាល ដល់ចុងឆ្នាំ១៩៧៨ ទេ[2072]។ អ៊ី វុន, ស៊ាន ស៊ង់ និង អ៊ុំ ស៊ន់ បានផ្ដល់សក្ខីកម្មអំពីព័ត៌មានលម្អិតជាគន្លឹះ អំពីការកើតឡើងនូវការសម្លាប់មនុស្សទ្រង់ទ្រាយធំ ដែលកំណត់គោលដៅជាពិសេស ទៅលើជនជាតិវៀតណាម នៅក្នុងឆ្នាំ ១៩៧៨ ដែលថាជនជាតិវៀតណាម

[2065] ឯកសារ **E1/159.1** នោម សែ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ម៉ោង ១៥.៥៣.២១-១៥.៥៥.៥៨ ទំព័រ ៨៥ បន្ទាត់ ១៧-១៨។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៤៦។

[2066] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៤៧។

[2067] <u>មូលដ្ឋានទី ១៥៥</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅវត្តខ្សាច់* កថាខណ្ឌ ១០០៦-១០១៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៥៤ (ភាសាអង់គ្លេស) ទំព័រ ៤៩ (ភាសាបារាំង) ទំព័រ ៧៧ (ភាសាខ្មែរ)។

[2068] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០០៦។

[2069] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០០៧-១០០៨។

[2070] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០០៩-១០១០។

[2071] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០១១-១០១២។

[2072] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៧៧។

ដែលរស់នៅក្នុងតំបន់ និងមកពីខាងក្រៅតំបន់ ត្រូវបានគេសម្លាប់ ហើយថាក្រោយមកគ្មាននៅសល់ ជនជាតិវៀតណាមទៀតទេ នៅក្នុងតំបន់នោះ[2073]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ឬបំពេញកិច្ចដោយមិនសមហេតុផល ក្នុងការពឹងផ្អែកទៅលើសក្ខីកម្មទាំងអស់នេះ ដើម្បីសន្និដ្ឋានថា “”ជនស៊ីវិលវៀតណាមត្រូវនាំទៅសម្លាប់ ក្នុងទ្រង់ទ្រាយធំ នៅចុងឆ្នាំ១៩៧៨ នៅវត្តខ្សាច់ ដោយសារតែជាតិពន្ធុរបស់ពួកគេ”[2074]។

607. បន្ថែមលើនេះ ការបកស្រាយដោយខុសរបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើភ័ស្តុតាងចចាមអារាម[2075] មិនបានបង្ហាញអំពីកំហុសឆ្គងណាមួយ នៅក្នុងការពឹងផ្អែករបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសក្ខីកម្មរបស់ ស៊ាន ស៊ង់ និង អ៊ី វុន ដែលថាការសម្លាប់ជនជាតិវៀតណាម បានធ្វើឡើងយោងទៅតាម បញ្ជាមួយរបស់ថ្នាក់លើ[2076]។ ស៊ាន ស៊ង់ បានអះអាងគាំទ្រនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង ចំពោះចម្លើយកន្លងមករបស់គាត់ ជាមួយ ក.ស.ច.ស ដែលថា មេភូមិបានប្រាប់គាត់ថា មានបញ្ជាមកពីថ្នាក់លើ ឱ្យសម្លាប់ជនជាតិវៀតណាម[2077] ចំណែក អ៊ី វុន បានផ្តល់សក្ខីកម្មថា គាត់បានឮពីអ្នកភូមិថា មេភូមិបានទទួលបញ្ជាឱ្យសម្លាប់ពីថ្នាក់លើ[2078]។ ការវិភាគបែបកម្រិតកំណត់ របស់ម្ចាស់បណ្តឹងសាទុក្ខ ក៏មិនបានធ្វើការពិចារណាទៅលើ រចនាសម្ព័ន្ធឋានានុក្រម ដែលបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានអនុវត្ត និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅលើជនជាតិវៀតណាម នៅពេលដែលមានការសម្លាប់នោះ[2079]។

## *មូលដ្ឋានទី ១៥៦៖ កំហុសក្នុងការសន្និដ្ឋាន អំពីការធ្វើមនុស្សឃាត លើជនជាតិវៀតណាម នៅក្នុងតំបន់ ៥០៥ (ក្រចេះ)*[2080]

[2073] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៧៧-៣៤៨១។

[2074] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៩៥។

[2075] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[2076] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០១៣។

[2077] ឯកសារ **E1/358.1** ស៊ាន ស៊ង់ ប្រតិចារឹក ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ ម៉ោង ០៩.៥៩.២០-១០.២១.១៣ ទំព័រ ២០ បន្ទាត់ ៥-១៣។

[2078] ឯកសារ **E1/368.1** អ៊ី វុន ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៤.០៦.២៥-១៤.០៨.៥៧ ទំព័រ ៤៦ បន្ទាត់ ៥-១១។

[2079] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣, ៣៩១, ៤៨៣, ៣៣៧៧-៣៤១៧។

[2080] <u>មូលដ្ឋានទី ១៥៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅក្នុងតំបន់ ៥០៥ (ក្រចេះ)* កថាខណ្ឌ ១០១៤-១០១៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៤ (ភាសាអង់គ្លេស) ទំព័រ ៤៩-៥០ (ភាសាបារាំង) ទំព័រ ៧៧-៧៨ (ភាសាខ្មែរ)។

608. **មូលដ្ឋានទី ១៥៦ គួរត្រូវបានបដិសេធ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចថា ជនជាតិវៀតណាមត្រូវបានសម្លាប់ នៅតំបន់ ៥០៥ (ក្រចេះ)។**

609. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីកំហុសឆ្គង គឺប្រភេទនៃកំហុសឆ្គង ដែលម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ ធ្វើការអះអាងដោយខុសច្រើនពេក ពាក់ព័ន្ធភ័ស្តុតាងរបស់ ដើមបណ្តឹងរដ្ឋប្បវេណី។

610. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខមានកំហុសឆ្គង ដោយលើកទឡ្ហីករណ៍ថា សក្ខីកម្មរបស់ អ៊ុច ស៊ុនឡាយ អំពីការសម្លាប់ប្រពន្ធ កូន និងសមាជិកដទៃទៀត នៃគ្រួសាររបស់គាត់ មានតម្លៃតិចតួចបំផុត ព្រោះ អ៊ុច ស៊ុនឡាយ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប មានភាពលំអៀង[2081]។ ក្នុងនាមជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនេះ គាត់ស្ថិតក្នុងស្ថានភាពដ៏ប្រសើរ ក្នុងការរាយការណ៍អំពីឧក្រិដ្ឋកម្មនេះ[2082]។

611. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា គ្មានអ្នកវិនិច្ឆ័យលើអង្គហេតុ ប្រកបដោយហេតុផលណាម្នាក់ អាចពឹងផ្អែកទៅលើផ្នែកនានា នៃសក្ខីកម្មរបស់ អ៊ុច ស៊ុនឡាយ ដែលពាក់ព័ន្ធការពួតគ្នា ដើម្បីឈានដល់ការសម្រេចថា សមាជិកក្រុមគ្រួសាររបស់គាត់ និងជនជាតិវៀតណាមដទៃទៀត ត្រូវបានគេសម្លាប់នោះ[2083]។ វិធីសាស្ត្រដោយប្រុងប្រយ័ត្ន និងដោយសមហេតុផលរបស់ អង្គជំនុំជម្រះសាលាដំបូង ចំពោះភ័ស្តុតាងចចាមអារាម ត្រូវបានបង្ហាញដោយសេចក្តីសម្រេច របស់អង្គជំនុំជម្រះ មិនផ្អែកទៅលើសក្ខីកម្មរបស់គាត់ ទាក់ទងហេតុការណ៍មួយផ្សេងទៀត ដែលជនជាតិវៀតណាមគឺជាគោលដៅ[2084]។

612. ផ្ទុយពីការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គង ក្នុងការកំណត់អត្តសញ្ញាណ សមាជិកក្រុមគ្រួសាររបស់ អ៊ុច ស៊ុនឡាយ ដែលត្រូវគេសម្លាប់

---

[2081] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៤។

[2082] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៤។

[2083] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០១៤។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[2084] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៨០។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០១៤។

នោះ[2085] អង្គជំនុំជម្រះសាលាដំបូង បានដកស្រង់សក្ខីកម្មរបស់ អ៊ុច ស៊ុនឡាយ ដែលនៅក្នុងនោះ គាត់បានរៀបរាប់លម្អិតថា មានសមាជិកគ្រួសារគាត់១៣នាក់ ក្រៅពីប្រពន្ធនិងកូនរបស់គាត់ ព្រម ទាំងប្អូនថ្លៃនិងកូនៗ រួចជាមួយកូនៗរបស់ប្អូនគាត់ទៀតនោះ[2086]។ ទោះបីជាអង្គជំនុំជម្រះសាលា ដំបូង ប្រហែលជាអាចមានកំហុស ដោយបញ្ចូលឪពុកម្តាយក្មេករបស់ អ៊ុច ស៊ុនឡាយ ដោយមិន បានកំណត់អំពី មរណភាពរបស់ពួកគាត់ក្តី[2087] តែម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា កំហុស នេះនាំឱ្យអសុពលភាព ទៅលើសាលក្រមទាំងស្រុង ឬដោយផ្នែក ឬបណ្តាលឱ្យមានភាព អយុត្តិធម៌ពិតប្រាកដ[2088]។ សក្ខីកម្មរបស់ អ៊ុច ស៊ុនឡាយ បានរៀបរាប់លម្អិតថា ការសម្លាប់ បងប្អូនបង្កើត របស់ប្រពន្ធគាត់ រួមជាមួយកូនៗ បានធ្វើឡើងនៅកោះទ្រង់[2089]។ ហេតុដូច្នេះការ សម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង បង្ហាញថាយ៉ាងហោចណាស់ សមាជិកគ្រួសារចំនួន ១១នាក់ របស់ អ៊ុច ស៊ុនឡាយ ត្រូវបានសម្លាប់[2090]។

### *មូលដ្ឋានទី ១៥៤៖ កំហុសក្នុងការសន្និដ្ឋាន អំពីការធ្វើមនុស្សឃាត លើជនជាតិវៀតណាម នៅក្នុងភូមិភាគបស្ចិម*[2091]

613. **មូលដ្ឋានទី ១៥៤ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការសម្រេចថា ជនជាតិវៀតណាម ត្រូវបានសម្លាប់ នៅក្នុងភូមិភាគបស្ចិម។**

614. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែ ម្ចាស់បណ្តឹងសាទុក្ខមិនបានវាយតម្លៃដោយត្រឹម ត្រូវទៅលើ ភ័ស្តុតាងរបស់ ប្រាក់ ឌឿន។ ផ្ទុយពីការអះអាងរបស់ ម្ចាស់បណ្តឹងសាទុក្ខ សក្ខីកម្ម

---

[2085] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០១៥។

[2086] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៨៣ *ដកស្រង់* ឯកសារ **E1/394.1** អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ម៉ោង ១៥.២៨.៣៧-១៥.៣២.០១ ទំព័រ ៦៤ បន្ទាត់ ១៧-២៣។

[2087] *ប្រៀបធៀប* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៨៣, ៣៤៨៦ និង ៣៤៨៨។

[2088] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (បទដ្ឋានទូទៅ)។

[2089] ឯកសារ **E1/395.1** អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ ម៉ោង ០៩.៣៤.៣០-០៩.៣៧.០៧ ទំព័រ ១០-១១ បន្ទាត់ ១៩-១១។

[2090] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៨៣-៣៤៨៨ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០១៦-១០១៧។

[2091] <u>មូលដ្ឋានទី ១៥៤</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅក្នុងភូមិភាគបស្ចិម* កថាខណ្ឌ ១០០៣-១០០៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៣-៥៤ (ភាសាអង់គ្លេស) ទំព័រ ៤៩ (ភាសាបារាំង) ទំព័រ ៧៦-៧៧ (ភាសាខ្មែរ)។

របស់ ប្រាក់ ឌឿន អំពីការសម្លាប់ប្រពន្ធនិងកូនរបស់គាត់ មិនតម្រូវឱ្យមានភ័ស្តុតាងគាំទ្រទេ[2092]។ ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខ មិនបានពិនិត្យលើភ័ស្តុតាងជារួម និងក្នុងបរិបទនៃហេតុការណ៍ទេ។ ប្រាក់ ឌឿន មិនបានផ្តល់សក្ខីកម្មថា មេកងឈ្មោះ ហ៊ុម មិនបានឃើញការសម្លាប់ឡើយ[2093]។ ហ៊ុម ដែលនៅត្រង់ម្តុំកន្លែងសម្លាប់នៅពេលនោះ បានរៀបរាប់លម្អិតអំពីមូលហេតុនិងការសម្លាប់ប្រពន្ធជាជនជាតិវៀតណាម និងកូនៗរបស់ ប្រាក់ ឌឿន ហើយបានបន្ទោស ប្រាក់ ឌឿន ថាទៅរៀបការជាមួយស្ត្រីវៀតណាម[2094]។ បន្ថែមលើនេះ ប្រាក់ ឌឿន បានផ្តល់ភ័ស្តុតាងផ្ទាល់ អំពីស្ថានភាពគ្រោះថ្នាក់ដែលកើតមាន ចំពោះជនជាតិវៀតណាមនៅពេលនោះ[2095]។

615. ការយោងរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើ "កូន" របស់ប្រាក់ ឌឿន ដែលត្រូវបានសម្លាប់នៅកោះតាម៉ូវ ហាក់ដូចជាកំហុសវាយអត្ថបទទេ[2096] ព្រោះការពិភាក្សាមុនៗបានកត់សម្គាល់ថា "ប្រាក់ ឌឿន ប្រពន្ធរបស់គាត់ ម្តាយក្មេករបស់គាត់ និងកូនគាត់ម្នាក់ផង" ស្ថិតនៅលើកោះ[2097] ហើយបន្ទាប់មកបានយោងទៅរក "កូនរបស់ ប្រាក់ ឌឿន ផ្សេងទៀត ត្រូវបានគេបញ្ជូន ទៅកន្លែងផ្សេងៗគ្នា"[2098]។ ដូច្នេះបើទោះបីជា អង្គជំនុំជម្រះសាលាដំបូង អាចមានកំហុសពាក់ព័ន្ធ ចំនួនកូនរបស់ប្រាក់ ឌឿន ដែលត្រូវសម្រេចឱ្យហួសពីវិមតិសង្ស័យ ថាត្រូវបានសម្លាប់ក្តី តែម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា កំហុសនេះធ្វើឱ្យអសុពលភាព ដល់សាលក្រមទាំងស្រុង ឬដោយផ្នែកនោះឡើយ[2099]។ អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញនិងសម្រេចដោយត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខទទួលខុសត្រូវ ចំពោះការស្លាប់កូនម្នាក់របស់ ប្រាក់ ឌឿន[2100]។

---

[2092] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០០៤។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២១។

[2093] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០០៤ ជើងទំព័រ ១៨៤៩។

[2094] ឯកសារ **E1/361.1** ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៤.២៨.៥៦-១៤.៣១.២៣ ទំព័រ ៥៨ បន្ទាត់ ៣-៩, ម៉ោង ១៥.២២.២៧-១៥.២៧.១០ ទំព័រ ៦៩-៧០ បន្ទាត់ ១-៦ ។ ឯកសារ **E1/362.1** ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១០.៤៩.០៨-១០.៥២.២៨ ទំព័រ ២៩-៣០ បន្ទាត់ ១៩-១០។

[2095] សូមមើល ឯកសារ **E1/361.1** ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៣.៣៤.៤៣-១៣.៤២.១៣ ទំព័រ ៤០-៤១ បន្ទាត់ ៥-២៣, ម៉ោង ១៣.៥៨.៤៧-១៤.០១.៣៣ ទំព័រ ៤៧ បន្ទាត់ ១១-១៦, ម៉ោង ១៤.០៦.២៤-១៤.០៧.៥៣ ទំព័រ ៤៩-៥០ បន្ទាត់ ២១-៤, ម៉ោង ១៤.១១.៣១ ទំព័រ ៥១ បន្ទាត់ ២០-២២។

[2096] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៧១។

[2097] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៦៦។

[2098] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៦៧។

[2099] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (បទដ្ឋានទូទៅ)។

[2100] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០០៥។

### *មូលដ្ឋានទី ១៥៣៖ កំហុសក្នុងការសន្និដ្ឋាន លើការសម្លាប់ជនជាតិវៀតណាម នៅតាមសមុទ្រ*[2101]

616. **មូលដ្ឋានទី ១៥៣ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុនិងកំហុសអង្គច្បាប់ ក្នុងការសម្រេចថា ជនជាតិវៀតណាម ត្រូវបានសម្លាប់នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ។**

617. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធការពឹងផ្អែករបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើកំណត់ត្រាសហសម័យ របស់បក្សកុម្មុយនីស្តកម្ពុជា និងការសម្រេចរបស់អង្គជំនុំជម្រះថា ជនរងគ្រោះគឺជាជនស៊ីវិល ហើយការសម្លាប់ជាក់លាក់ គឺដោយចេតនានោះ គឺគ្មានមូលដ្ឋានទាំងអស់[2102]។

618. ទីមួយអង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា កំណត់ត្រាសហសម័យ គឺភាគីនានាអាចចូលពិនិត្យបាន នៅពេលមានសំណើ “សុំពិនិត្យយថាភាពចំពោះឯកសារដើម និងភាពត្រឹមត្រូវនៃឯកសារអេឡិចត្រូនិក”[2103] ហើយត្រូវបានទទួលយក “បន្ទាប់ពីមានឱកាសពិភាក្សា ដេញដោលជាសាធារណៈ តាមរយៈសំណើទាំងនោះ”[2104]។ ទឡ្ហីករណ៍ជាទូទៅរបស់ ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងប្រភេទទាំងអស់នៃឯកសារ ដោយមិនមានទឡ្ហីករណ៍ជាក់លាក់ណាមួយ អំពីមូលហេតុអ្វីទើបក្នុងករណីនេះ មិនអាចពឹងផ្អែកបានលើ របាយការណ៍កងពលធំ ១៦៤ នោះ គួរត្រូវបានច្រានចោល[2105]។របាយការណ៍យោងទៅរកការលិចកាណូតមួយ មិនមែនការណូតច្រើនទេ ដូច្នេះការទាយស្មានអំពីសកម្មភាពរបស់ កាណូតដទៃទៀត គឺមិនអាចអះអាងបានឡើយ[2106]។

619. ទីពីរ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលថាការលិចកាណូតនេះ គឺទាក់ទងជាមួយជម្លោះជាមួយវៀតណាម គឺគ្មានមូលដ្ឋានឡើយ[2107]។ របាយការណ៍ដែលចោទនេះ ពាក់ព័ន្ធបញ្ហា “សមុទ្រ” យោងទៅរកព្រឹត្តិការណ៍ចំនួនបី ដែលពាក់ព័ន្ធការលិច ឬការចាប់កាណូតវៀតណាម និង

---

2101 <u>មូលដ្ឋានទី ១៥៣</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសក្នុងការសន្និដ្ឋានលើការសម្លាប់ជនជាតិវៀតណាមនៅតាមសមុទ្រ* កថាខណ្ឌ ៩៩៣-១០០២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៣ (ភាសាអង់គ្លេស) ទំព័រ ៥៩ (ភាសាបារាំង) ទំព័រ ៧៦ (ភាសាខ្មែរ)។

2102 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៩៦។

2103 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៧។

2104 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦។

2105 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៩៩៧, ៣២០-៣២៣។

2106 សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥។

2107 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០០១។

កាណូតចិន ហើយនិយាយពីអ្នកធ្វើដំណើរលើនោះថា "ក្មេងចាស់ប្រុសស្រី"[2108]។ មិនមានការយោងណាមួយ ទៅលើអ្វីដែលអាចបង្ហាញ អំពីទំនាក់ទំនងជាមួយទំនាស់ឡើយ។ ផ្ទុយពីការអះអាងរបស់ ម្ចាស់បណ្តឹងសាទុក្ខ ជាការមិនសមហេតុផលក្នុងការសន្និដ្ឋានថា ជនជាតិវៀតណាមនៅលើកាណូត២២សេសេ ដែលបានលិចនោះ គឺជាកងទ័ពឬអ្នកនេសាទប្រដាប់អាវុធ ដែលចូលរួមក្នុងទំនាស់ឡើយ[2109]។

620. ទីបី ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយមិនត្រឹមត្រូវថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផលណាម្នាក់ អាចសម្រេចថាមានចេតនា ក្នុងការសម្លាប់មនុស្សពីរនាក់ នៅក្នុងហេតុការណ៍ថ្ងៃទី២០ ខែមីនា ដែលបានរៀបរាប់នៅក្នុង របាយការណ៍របស់កងពលធំ ១៦៤ ឡើយ[2110]។ របាយការណ៍បានបញ្ជាក់យ៉ាងច្បាស់ថា ជនជាតិវៀតណាមទាំងក្មេងទាំងចាស់ ត្រូវបានចាប់ចងនៅលើកាណូតតូចមួយ ដែលឃ្លេងឃ្លោង ហើយមានមនុស្សពីរនាក់ធ្លាក់ចូលទៅក្នុងទឹក ហើយរកមិនឃើញវិញទេ[2111]។ កាលៈទេសៈនិងអំពើអកម្ម ក្នុងការជួយសង្គ្រោះ បានបំពេញយ៉ាងច្បាស់ទៅតាមនិយមន័យ នៃការបង្ហាញឆន្ទៈក្នុងការប្រព្រឹត្ត ដោយដឹងថាអំពើសកម្មឬអកម្មរបស់ខ្លួន ទំនងជាបណ្តាលឱ្យជនរងគ្រោះម្នាក់ឬច្រើននាក់ស្លាប់ និងយ៉ាងហោចណាស់បុគ្គលនោះទទួលយកឬជ្រើសរើសយក លទ្ធភាពដែលអាចបណ្តាលឱ្យមានការបាត់បង់ជីវិតនេះ[2112]។

## v. ការសម្លាប់រង្គាលជនជាតិវៀតណាម[2113]

### *មូលដ្ឋានទី ១៥៧៖ ការសម្លាប់រង្គាលជនជាតិវៀតណាម*[2114]

---

[2108] ឯកសារ **E3/997** របាយការណ៍មកពីកងពល ១៦៤ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ KH 00020982។

[2109] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០០១។

[2110] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០០២។

[2111] ឯកសារ **E3/997** របាយការណ៍មកពីកងពល ១៦៤ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ KH 00020982។

[2112] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៥០។

[2113] ទឡ្ហីករណ៍នីមួយៗរបស់ម្ចាស់សាទុក្ខទាក់ទងនឹងបណ្តឹងពីការសម្លាប់មនុស្សមិនត្រូវបានទទួលយកទេ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦០។

[2114] <u>មូលដ្ឋានទី ១៥៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការសម្លាប់រង្គាលជនជាតិវៀតណាម* កថាខណ្ឌ ១០១៨-១០២៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៤ (ភាសាអង់គ្លេស) ទំព័រ ៥០ (ភាសាបារាំង) ទំព័រ ៧៨ (ភាសាខ្មែរ)។

621. **មូលដ្ឋានទី ១៥៧ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុនិងកំហុសអង្គច្បាប់ ក្នុងការសម្រេចថាមានការបង្ហាញអំពីការសម្លាប់រង្គាល ទៅលើជនជាតិវៀតណាម។**

622. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធនឹងកំហុសដែលបានចោទ[2115] ព្រោះម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ពាក់ព័ន្ធ៖ ចំនួននៃការសម្លាប់ ដែលត្រូវគ្រប់គ្រាន់ដើម្បីឈានដល់ លក្ខខណ្ឌតម្រូវនៃការសម្លាប់រង្គាល, ការសម្លាប់នៅតាមទីកន្លែងផ្សេងៗគ្នា ដែលជាផ្នែកនៃប្រតិបត្តិការមនុស្សឃាតតែមួយ និងចំនួនអ្នកស្លាប់តាមការប៉ាន់ប្រមាណ។

623. ទីមួយ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ ថាចំនួនអ្នកស្លាប់ មិនបានឈានដល់ភាពធ្ងន់ធ្ងរចាំបាច់ សម្រាប់ឧក្រិដ្ឋកម្មសម្លាប់រង្គាល គឺគ្មានមូលដ្ឋានគាំទ្រទេ[2116]។ ម្ចាស់បណ្ដឹងសាទុក្ខទទួលស្គាល់ថា មិនមានលក្ខខណ្ឌតម្រូវអប្បបរមា សម្រាប់ចំនួនអ្នកស្លាប់ ដែលតម្រូវសម្រាប់ការកំណត់ប្រភេទនៃបទល្មើសការសម្លាប់ ថាជាការសម្លាប់រង្គាល[2117]។ តាមពិតទៅ អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់អំពីការសម្លាប់រង្គាល នៅក្នុងស្ថានភាពដែលពាក់ព័ន្ធ ការសម្លាប់តិចជាង៦០នាក់[2118]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការសម្លាប់ជនជាតិវៀតណាម៦០នាក់ គឺ "ស្ទើរតែជាចំនួនប៉ាន់ប្រមាណ ក្នុងកម្រិតអប្បរមា លើស្ថានភាពជាក់ស្ដែង" ហើយបានរំឭកអំពីការសម្រេចលើការសម្លាប់រង្គាល នៅអូរកន្សែង និងមន្ទីរសន្តិសុខស-២១ ដែលមានជនជាតិវៀតណាមរាប់រយនាក់[2119]។

624. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា ការសម្លាប់ជនជាតិវៀតណាម នៅតាមទីតាំងផ្សេងៗ គឺជាករណីដាច់ដោយឡែក និងមិនមានពាក់ព័ន្ធគ្នា[2120]។ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែ លើកទឡ្ហីករណ៍ឡើងថា ការសម្លាប់ធ្វើឡើងនៅពេលវេលាខុសៗគ្នា និងទីកន្លែងខុសៗគ្នា[2121] ហើយផ្អែកលើការអះអាងដោយខុសឆ្គងរបស់គាត់ដែលថា ជនជាតិវៀតណាមមិនត្រូវបាន កំណត់គោលដៅជា

[2115] ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា តើការអះអាងរបស់ខ្លួនណាខ្លះជាកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ។
[2116] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០១៩-១០២០។
[2117] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០២០។
[2118] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៥១។
[2119] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៩៩។
[2120] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០២៣-១០២៥។
[2121] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០២៣-១០២៤។

ពិសេស ដោយសារតែពួកគេជាជនជាតិវៀតណាមនោះទេ[2122]។ ច្បាប់ជាធរមានស្តីពីការសម្លាប់រង្គាល ដែលម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់ បានអនុញ្ញាតឱ្យមានការប្រមូលផ្តុំ ហេតុការណ៍ផ្សេងៗគ្នាបាន[2123] ហើយតម្រូវឱ្យមានការពិចារណា ទៅលើការជ្រើសរើសជនរងគ្រោះ និងថាតើការសម្លាប់មានគោលដៅទៅលើក្រុមរួម ឬជនរងគ្រោះម្នាក់ៗ[2124]។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា ការសម្លាប់ផ្សេងៗគ្នានីមួយៗ បានកើតឡើងដោយសារតែជនរងគ្រោះគឺជាជនជាតិវៀតណាម ហើយហេតុការណ៍ទាំងអស់បានកើតឡើង នៅក្នុងបរិបទនៃគោលនយោបាយទូទាំងប្រទេស ក្នុងការសម្លាប់ជនជាតិវៀតណាម[2125]។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានដោយសមហេតុផលថា មាន "ភ័ស្តុតាងយ៉ាងច្រើនលើសលប់ដែលថាការសម្លាប់ទាំងនេះ សុទ្ធតែជាផ្នែកនៃប្រតិបត្តិការ នៃការធ្វើមនុស្សឃាតដូចគ្នា"[2126]។

625. ទីបី ផ្ទុយពីការអះអាងដោយខុស របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង មិនមានមូលដ្ឋានសម្រាប់ ការវាយតម្លៃរបស់ខ្លួនទៅលើ ចំនួនជនជាតិវៀតណាម ដែលត្រូវបានសម្លាប់នោះ[2127] អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ អំពីសំអាងហេតុសម្រាប់ការប៉ាន់ប្រមាណ (បែបអប្បរមា) ត្រឹមពីរនាក់ក្នុងមួយគ្រួសារ និងប្រាំនាក់ក្នុងកាណូតមួយ នៅក្នុងករណីជាក់លាក់នៃការសម្លាប់ ដើម្បីបង្ហាញឱ្យហួសពីវិមតិសង្ស័យ[2128]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបដិសេធ ជាមួយការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងចំនួនជនជាតិវៀតណាម ដែលត្រូវបានសម្លាប់ និងមូលហេតុជាមូលដ្ឋាននៃការសម្លាប់ទាំងនោះ[2129]។

[2122] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០២២។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

[2123] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៥៦។

[2124] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៥១។

[2125] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០០។

[2126] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០០។

[2127] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០២៦-១០២៧។

[2128] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៩៩ ជើងទំព័រ ១១៧៨៧។

[2129] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០១៩-១០២៧។

## vi. ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម

### *មូលដ្ឋានទី ១៥៨៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍*[2130]

626. **មូលដ្ឋានទី ១៥៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុនិងកំហុសអង្គច្បាប់ ក្នុងការសម្រេចថា ជនជាតិវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ នៅខេត្តព្រៃវែង និងស្វាយរៀង។**

627. មូលដ្ឋាននេះមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញអំពីកំហុសណាមួយ ក្នុងការសម្រេចថា (១) ជនជាតិវៀតណាមគឺជាក្រុម ដែលអាចសម្គាល់បានយ៉ាងគ្រប់គ្រាន់ (២) ពួកគេរងការធ្វើទុក្ខបុកម្នេញ ដោយអំពើនៃការនិរទេស ការចាប់ខ្លួន និងការធ្វើមនុស្សឃាត (៣) អំពើទាំងនេះជាការរើសអើងពិតប្រាកដ និង(៤) ជនជាតិវៀតណាមត្រូវបាន កំណត់គោលដៅដោយចេតនា នៅក្នុងខេត្តព្រៃវែងនិងស្វាយរៀង[2131]។

628. ចំពោះការកំណត់អត្តសញ្ញាណ ក្រុមជនជាតិវៀតណាម ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា "ប្រជាជនវៀតណាមដែលរស់នៅ ក្នុងប្រទេសកម្ពុជា" មិនអាចសម្គាល់បានយ៉ាងគ្រប់គ្រាន់ ជាក្រុមពូជសាសន៍មួយនោះ គឺជាការអះអាងគ្មានការការគាំទ្រ[2132]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបញ្ជាក់ ថាតើគាត់ចោទប្រកាន់ពី កំហុសអង្គហេតុ ឬកំហុសអង្គច្បាប់ នៅក្នុងការកំណត់ប្រភេទក្រុមនេះ ដោយអង្គជំនុំជម្រះសាលាដំបូង[2133] ប៉ុន្តែមិនជំទាស់ទាំងទៅលើ ការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង ទៅលើគតិយុត្តិ និងមិនជំទាស់ថាជនជាតិវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា មានអត្តសញ្ញាណពិសេសជាក់លាក់ឡើយ[2134]។ ទឡ្ហីករណ៍របស់គាត់ផ្តោតតែទៅលើ ជើងទំព័រតែមួយគត់ ដែលយោងទៅរកផ្នែកមួយនៃសាលក្រម ដែលរៀបរាប់លម្អិតពាក្យ "ភ្នាក់ងារ សេអ៊ីអា កាហ្សេបេ និងយួន" នៅក្នុងបរិបទនៃគោលនយោបាយប្រឆាំងខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីអះអាងដោយខុសឆ្គងថា អង្គជំនុំជម្រះសាលាដំបូង បានរួមបញ្ចូលជនជាតិ

---

[2130] <u>មូលដ្ឋានទី ១៥៨៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍* កថាខណ្ឌ ១០២៨-១០៥០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៥ (ភាសាអង់គ្លេស) ទំព័រ ៥០ (ភាសាបារាំង) ទំព័រ ៧៨ (ភាសាខ្មែរ)។

[2131] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០២៨។

[2132] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០២៩។

[2133] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០២៩។

[2134] សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០២៩។

កម្ពុជាខ្លះ ទៅក្នុងក្រុមពូជសាសន៍វៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា[2135]។ ការអះអាងដូច្នេះ គឺម្ចាស់បណ្តឹងសាទុក្ខមិនបានពិចារណា ទៅលើការពិភាក្សាយ៉ាងលម្អិត របស់អង្គជំនុំជម្រះសាលាដំបូង ទៅលើក្រុមជនជាតិវៀតណាម នៅពេលវាយតម្លៃលើភ័ស្តុតាង នៃគោលនយោបាយកំណត់គោលដៅ[2136]។ ជាលទ្ធផល ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងមិនបាន ញែកដាច់ពីគ្នាជាប្រព័ន្ធ រវាងជនស៊ីវិលវៀតណាម នៅក្នុងប្រទេសកម្ពុជា និងអ្នករស់នៅក្នុងប្រទេសវៀតណាម កងទ័ពវៀតណាម និងភ្នាក់ងារយួន គឺមិនមានការគាំទ្រឡើយ ដោយការយោងតែមួយគត់ ទៅលើសាលក្រមនោះ[2137]។

629. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញ អំពីកំហុសណាមួយនៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសេចក្តីថ្លែងការណ៍ "១ទល់នឹង៣០"[2138] ហើយការអះអាងរបស់គាត់ដែលថា ការអំពាវនាវរបស់ ប៉ុល ពត ឱ្យកម្ទេចជនស៊ីវិលវៀតណាម គឺដូចជាមិនរួមបញ្ចូល ជនជាតិវៀតណាមរស់នៅក្នុងខេត្តព្រៃវែង និងស្វាយរៀងនោះ គឺគ្មានការគាំទ្រ និងមិនមានមូលដ្ឋានឡើយ[2139]។

630. ចំពោះការធ្វើទុក្ខបុកម្នេញ តាមរយៈអំពើនិរទេស ការចាប់ខ្លួន និងមនុស្សឃាតនោះ ម្ចាស់បណ្តឹងសាទុក្ខមិនបានធ្វើឱ្យខូចខាត ដល់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងអំពើជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញ ដែលប្រព្រឹត្តទៅលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែងនិងស្វាយរៀង[2140]។ ដូចដែលនឹងរៀបរាប់លម្អិត ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញ អំពីកំហុសណាមួយនៅក្នុងការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាម (១) ត្រូវបាននិរទេសពីព្រៃវែង នៅក្នុងឆ្នាំ១៩៧៥ និង១៩៧៦[2141] (២) ត្រូវបានសម្លាប់នៅខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៨[2142]។

---

[2135] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០២៩។

[2136] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨២-៣៤១៧។

[2137] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣១។

[2138] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

[2139] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣០។

[2140] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៣-១០៣៦។

[2141] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៣។

[2142] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥២។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៣។

631. ក្រៅពីនេះ ម្ចាស់បណ្តឹងសាទុក្ខបានបញ្ជាក់ដោយខុស លើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធការចាប់ខ្លួននៅក្នុងខេត្តព្រៃវែង ចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៩[2143]។ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការសម្លាប់មិនអាចបង្ហាញបាន តាមបទដ្ឋានគតិយុត្តិតាមការតម្រូវ មិនបានរារាំងអង្គជំនុំជម្រះ មិនឱ្យពឹងផ្អែកទៅលើភស្តុតាងដដែលនេះ ក្នុងការបង្ហាញ “ការផ្លាស់ទីលំនៅ ឬការចាប់ខ្លួនជនជាតិវៀតណាមម្នាក់ៗ ដែលបន្ទាប់មកត្រូវបានគេយកទៅហើយលែងឃើញត្រឡប់មកវិញ”[2144]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានដកចេញនូវការសម្រេចពាក់ព័ន្ធនានា នៅពេលដែលអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចអំពីការចាប់ខ្លួនណាមួយ ដែលបានកើតឡើងនៅក្នុងខេត្តស្វាយរៀង ចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩[2145]។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា “ការចាប់ខ្លួនក្នុងឆ្នាំ១៩៧៨ [...] គឺជាលទ្ធផលនៃការអនុវត្តជាប្រព័ន្ធ” នៅក្នុងខេត្តស្វាយរៀង “ នូវគោលនយោបាយទូទាំងប្រទេស ក្នុងការសម្លាប់ជនជាតិវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជានៅពេលនោះ”[2146]។

632. ចំពោះការរើសអើងជាក់ស្តែង ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់សំអាងហេតុណាមួយ ពីមូលហេតុអ្វី និងថាតើជនជាតិវៀតណាម ដែលជាជនរងគ្រោះនៃការនិរទេស ការចាប់ខ្លួន និងមនុស្សឃាត នៅខេត្តព្រៃវែងនិងស្វាយរៀង ត្រូវកំណត់ជាគោលដៅដោយរបៀបណា[2147]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានគិតដល់ ការសម្រេចដែលថាឧក្រិដ្ឋកម្មទាំងអស់នេះ បានកើតឡើងនៅក្នុងបរិបទនៃ “ការកំណត់គោលដៅជាប្រព័ន្ធ លើបុគ្គលជនជាតិវៀតណាម ដោយសារតែការសន្មត ពីជាតិសាសន៍របស់ពួកគេ”[2148]។ ក្រៅពីនេះការលើកឡើងរបស់ ម្ចាស់បណ្តឹងសាទុក្ខដែលថា អាចមានមូលហេតុដទៃទៀត ដែលជនជាតិវៀតណាមត្រូវបានចាប់ខ្លួននោះ គឺម្ចាស់បណ្តឹងសាទុក្ខមិនគ្រាន់តែ មិនគិតអំពីភស្តុតាងប៉ុណ្ណោះទេ ប៉ុន្តែថែម

---

2143 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៤។

2144 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៤។

2145 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៥។

2146 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥៣។ សូមមើលផងដែរ កថាខណ្ឌ ៣៥១២។

2147 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៧។

2148 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥១៣។

ទាំងមិនបានបង្ហាញថា ហេតុអ្វីទើបការនិរទេស និងការសម្លាប់ជនជាតិវៀតណាម មិនគួរត្រូវបាន ចាត់ទុកថាជាការរើសអើងជាក់ស្តែងនោះ[2149]។

633. ចំពោះការកំណត់គោលដៅដោយចេតនា ទៅលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង បន្ថែមពីលើការណ៍ដែលគាត់មិនបាន ធ្វើឱ្យខូចខាតដល់ការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបង្កើតបញ្ជីអត្តសញ្ញាណ ជនជាតិវៀតណាមហើយនោះ[2150] ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយខុសថា ការកំណត់អត្តសញ្ញាណ ជនជាតិវៀតណាមតាមបញ្ជី មិនមាននៅខេត្តព្រៃវែងនិងស្វាយរៀងទេ[2151] ដែលដូច្នេះគឺជាការបង្ហាញដោយខុស ទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[2152]។ ផ្នែកនៃសាលក្រម ដែលវិភាគទៅលើវិធីសាស្ត្រដែលបក្សកុម្មុយនីស្តកម្ពុជា កំណត់អត្តសញ្ញាណជនជាតិវៀតណាម ដើម្បីកំណត់គោលដៅលើពួកគេ បានយោងទៅរកភ័ស្តុតាងរបស់ សៅ សាក់ ដែលផ្តល់សក្ខីកម្មថា "តាមភូមិអីប្រហែលជាគេធ្វើស្ថិតិ [...] ប្រហែលជាគេធ្វើស្ថិតិបានថ្នាក់លើដឹងថា កូនខ្មែរ កូនយួនអីចឹងណា ប្រហែលជាអីចឹងហើយភូមិឃុំ គេហ្នឹងចុះធ្វើស្ថិតិ"[2153] ព្រមទាំង សៀង ចាន់ចី ដែលផ្តល់សក្ខីកម្មថា មេសហករណ៍នៅក្នុងតំបន់គាត់ ក្នុងខេត្តស្វាយរៀង "គេប្រធានសហករណ៍ គឺវាបានដឹងច្បាស់ហើយ [...] ព្រោះអីដូចគ្រួសារខ្ញុំអីចឹង គេដឹងថាជីតាខ្ញុំអីចឹង វៀតណាមអីចឹង គេដឹង"[2154]។ បន្ថែមលើនេះ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ការបង្កើតបញ្ជីនៅផ្នែកផ្សេងទៀត ក្នុងប្រទេសកម្ពុជា គឺមានភាពពាក់ព័ន្ធក្នុងការវាយតម្លៃ ទៅលើចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង[2155]។ វិធីសាស្ត្រតាមរបៀបម្តងមួយៗរបស់ម្ចាស់បណ្តឹងសាទុក្ខ គឺមិនបានពិនិត្យទៅលើភ័ស្តុតាងជារួម ហើយជាការខុសឆ្គងគឺមិនអើពើចំពោះការសម្រេចនានាអំពីផែនការបក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅលើជនជាតិវៀតណាម នៅទូទាំងប្រទេស។

---

[2149] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៣៨-១០៣៩។

[2150] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

[2151] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៤០។

[2152] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៤០។

[2153] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២០ ជើងទំព័រ ១១៥៣១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៤១។

[2154] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២០ ជើងទំព័រ ១១៥៣១។

[2155] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៤២។

634. ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញផងដែរពីកំហុសណាមួយនៅក្នុង ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការកំណត់គោលដៅ តាមខ្សែស្រឡាយខាងម្ដាយ ទៅលើជនជាតិវៀតណាម[2156]។ ការអះអាងដែលមិនគួរឱ្យជឿ របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា សាក្សីជាច្រើនដែលបានផ្ដល់សក្ខីកម្មលើហេតុការណ៍នៅទូទាំងប្រទេសកម្ពុជា សុទ្ធតែទាញយកសេចក្ដីសន្និដ្ឋានដោយផ្ទាល់ខ្លួនថា បក្សកុម្មុយនីស្ដកម្ពុជាពិចារណា ជាតិពន្ធុត្រូវបន្តតាមរយៈម្ដាយ[2157]។ វិធីសាស្ត្រដែលខុសឆ្គង របស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងការវាយតម្លៃទៅលើភ័ស្តុតាង ត្រូវបានបង្ហាញតាមរយៈការព្យាយាមរបស់គាត់ ក្នុងការបង្ខូចដល់ការដឹងឮរបស់ ដួង អឿន, ស៊ិន ឆែម និង ឡាច គ្រី លើការកំណត់គោលដៅតាមខ្សែស្រឡាយខាងម្ដាយ[2158]។ ទោះជាបែបនេះក្ដី ពួកគាត់ម្នាក់ៗបានផ្ដល់សក្ខីកម្ម តាមការដឹងឮផ្ទាល់ខ្លួន និង/ឬ បទពិសោធន៍ពីបក្សកុម្មុយនីស្ដកម្ពុជា ដែលយកម្ដាយនិងកូនជនជាតិវៀតណាមទៅ សម្រាប់គ្រួសារដែលរៀបការចម្រុះសាសន៍គ្នា[2159]។ បន្ថែមលើនេះ សក្ខីកម្មដែលថា "មួយចំនួនខ្លះកាត់ដូចគ្នា តែគេនៅរស់" មិនបានបដិសេធចំពោះ ការកំណត់គោលដៅ តាមខ្សែស្រឡាយម្ដាយទេ[2160] ដោយសារតែសាក្សីបន្ទាប់មក បានផ្ដល់សក្ខីកម្មថា "ជាម្ដាយមុនដំបូងកម្មេចម្ដាយហ្នឹងទៅ ចាប់ម្ដាយហ្នឹងទៅ រយៈក្រោយមកទៀត ក៏ចាប់កូនកាត់ទៀត មិនត្រឹមកូនកាត់ ចាប់ទាំងចៅកាត់ហ្នឹងទៅទៀត"[2161]។ បន្ថែមលើនេះ ដោយផ្ទុយពីការលើកឡើងដោយខុសឆ្គង របស់ម្ចាស់បណ្ដឹងសាទុក្ខ[2162] សំណើរបស់ រស់ ញឹម ទៅមន្ទីរ៨៧០ ស្នើសុំការណែនាំពាក់ព័ន្ធ "បាតុភាព" "ពួកយួនដែលមានប្ដីខ្មែរ មានខ្មែរបានប្រពន្ធយួន ហើយកូនកាត់យួនតើឱ្យសំរេចយ៉ាងណា?" នៅក្នុងខែឧសភា ឆ្នាំ១៩៧៨[2163] បានបង្ហាញថា កម្មាភិបាលបានចាត់ទុកក្រុមគ្រួសារកាត់វៀតណាម គឺជាបញ្ហាដែលទាមទារនូវដំណោះស្រាយ ដូចជាសេចក្ដីសម្រេច "ប្រមូល"[2164]។

---

[2156] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៤៣។

[2157] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៤៣។

[2158] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៤៤។

[2159] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២៤-៣៤២៥។

[2160] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៤៥។

[2161] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២៤ ជើងទំព័រ ១១៥៤៧។

[2162] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៤៧។

[2163] ឯកសារ **E3/863** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ KH 00076286-00076287 *ដកស្រង់*នៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២៦។

[2164] ឯកសារ **E3/863** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ KH 00076286-00076287។

635. ម្ចាស់បណ្តឹងសាទុក្ខបានយោងដោយបំភាន់ តែទៅរកសេចក្តីសន្និដ្ឋាន របស់អង្គជំនុំជម្រះសាលាដំបូង លើធាតុផ្សំអត្តនោម័ត នៅពេលលើកឡើងថា គាត់ "មិនអាច" ដឹងថាការបោះផ្សាយណាមួយ របស់ទស្សនាវដ្តីទង់បដិវត្ត និងសុន្ទរកថាថ្នាក់ដឹកនាំ របស់បក្សកុម្មុយនីស្តកម្ពុជា ដែលអង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើនោះទេ[2165]។ តាមពិតទៅ អង្គជំនុំជម្រះសាលាដំបូង បានរៀបរាប់លម្អិតអំពី ការបោះផ្សាយទស្សនាវដ្តីទង់បដិវត្ត និងអំពីសុន្ទរកថា នៅពេលដែលវាយតម្លៃទៅលើភ័ស្តុតាង អំពីគោលនយោបាយកំណត់គោលដៅ លើជនជាតិវៀតណាម ព្រមទាំងអំពីថាតើការបោះផ្សាយ និងសុន្ទរកថាទាំងអស់នេះ ពាក់ព័ន្ធដោយរបៀបណា ទៅលើជនជាតិវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា[2166]។ អង្គជំនុំជម្រះសាលាដំបូង បានពន្យល់យ៉ាងត្រឹមត្រូវថា ការបោះផ្សាយនិងសុន្ទរកថាទាំងអស់នេះ បានបង្ហាញដោយរបៀបណា នូវគោលនយោបាយកំណត់គោលដៅ នៅទូទាំងប្រទេស ទៅលើជនជាតិវៀតណាម ដោយបដិសេធចោលនូវការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ភ័ស្តុតាងបែបនេះមិនពាក់ព័ន្ធ ជាមួយខេត្តព្រៃវែងនិងស្វាយរៀងនោះ[2167]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាទៅលើជម្លោះជាមួយប្រទេសវៀតណាម នៅពេលបកស្រាយសេចក្តីថ្លែងការណ៍ របស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខ ទទួលស្គាល់ពីបណ្តាករណីដែល អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើជម្លោះនោះ[2168]។ និយាយដោយខ្លីទៅ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ ហើយមិនបានបង្ហាញអំពីកំហុសណាមួយនោះឡើយ។

### *មូលដ្ឋានទី ១១០៖ កំហុសនានានៅក្នុងការសន្និដ្ឋានអំពីការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ចំពោះជនជាតិវៀតណាម*[2169]

---

[2165] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៤៩ *យោង*ទៅតែ ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥១៣។

[2166] សូមមើល ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩២-៣៤១៧។

[2167] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៤៩។

[2168] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៥០។

[2169] មូលដ្ឋានទី ១១០៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសដោយបានសន្និដ្ឋានថាមានការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ចំពោះជនជាតិវៀតណាម* កថាខណ្ឌ ៧៤៨-៧៥៥។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤១ (ភាសាអង់គ្លេស) ទំព័រ ៣៨ (ភាសាបារាំង) ទំព័រ ៥៨-៥៩ (ភាសាខ្មែរ)។

636. **មូលដ្ឋានទី ១១០ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការសម្រេចថាជនជាតិវៀតណាម ត្រូវរងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ នៅក្នុងស្រុកត្រាំកក់។**

637. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធការចោទអំពីកំហុសអង្គហេតុនិងកំហុសអង្គច្បាប់ ព្រោះក្រៅពីការលើកឡើងវិញសារជាថ្មី ដោយគ្មានសុពលភាពអំពី បណ្តឹងដែលបានបំពាននោះ[2170] ម្ចាស់បណ្តឹងសាទុក្ខ (១) គ្រាន់តែបញ្ជាក់ថា ធាតុផ្សំសត្យានុម័ត នៃការធ្វើទុក្ខបុកម្នេញ មិនត្រូវបានបង្ហាញ ដោយបានលើកឡើងវិញនូវការអះអាងដែលខុសរបស់គាត់ ដែលថាមិនមានការបង្ហាញ អំពីការនិរទេសជនជាតិវៀតណាម ពីស្រុកត្រាំកក់ នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦[2171] និង (២) អះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មិនមានភ័ស្តុតាងអំពីចេតនាណាមួយក្នុងការរើសអើងលើជនជាតិវៀតណាម ដោយសារតែមូលហេតុពូជសាសន៍របស់ពួកគេ នៅក្នុងស្រុកត្រាំកក់ក្នុងឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៦ ឡើយ។

638. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា គាត់ត្រូវទាយស្មានថាតើ អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើភ័ស្តុតាងអ្វី ដើម្បីបង្ហាញពីធាតុផ្សំអត្តនោម័តិ នៃការធ្វើទុក្ខបុកម្នេញនោះ គឺជាការបំភាន់[2172]។ កថាខណ្ឌនៅក្នុងសេចក្តីសន្និដ្ឋាននៃផ្នែកពាក់ព័ន្ធ នៅក្នុងសាលក្រម ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ គឺធ្វើឡើងបន្ទាប់ពីមាន ការវិភាគយ៉ាងលម្អិតអំពី ការប្រព្រឹត្តទៅលើជនជាតិវៀតណាម នៅក្នុងស្រុកត្រាំកក់[2173]។ ទាំងអស់នេះរួមមាន សក្ខីកម្មពាក់ព័ន្ធៈ ស្រុកត្រាំកក់បានទទួលរបាយការណ៍ អំពីចំនួនជនជាតិវៀតណាម ដែលចូលរួមក្នុងការអនុវត្ត ការបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ នូវជនជាតិវៀតណាមដែលរស់នៅក្នុងតំបន់[2174] ការណែនាំពីលេខាភូមិភាគ ពាក់ព័ន្ធការប្រព្រឹត្តចំពោះជនជាតិវៀតណាម[2175] ការចូលរួមដោយផ្ទាល់នៅក្នុងប្រតិបត្តិការ ដឹកជញ្ជូនជនជាតិវៀតណាម "យ៉ាងច្រើន" ពីស្រុកត្រាំកក់ ដែលនៅពេលនោះមេឃុំ

---

[2170] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤១, ៥៦។

[2171] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤៩-៧៥០។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៣ & ១០៤ (ការនិរទេសជនជាតិវៀតណាមចេញពីត្រាំកក់ (ធាតុផ្សំសត្យានុម័តិ)), ១០៥។

[2172] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥១។

[2173] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១០-១១២៥។

[2174] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១០។

[2175] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១០-១១១១។

នៅតំបន់នីមួយៗ បានប្រាប់ប្រជាជនថា ពួកគេត្រូវបញ្ជូនត្រឡប់ទៅប្រទេសវៀតណាម[2176] និង បញ្ជីដែលត្រូវរក្សាទុកនៅមន្ទីរឃុំ អំពីនរណាជាជនជាតិវៀតណាម និងជាកូនចៅខ្មែរក្រោម[2177]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានរៀបរាប់លម្អិតអំពី ការពឹងផ្អែកទៅលើទស្សនាវដ្តីទង់បដិវត្ត លេខចេញនៅខែមេសា ឆ្នាំ១៩៧៦[2178] ដែលរៀបរាប់អំពីជនជាតិវៀតណាម ក្នុងន័យអវិជ្ជមាន និង និយាយសំដៅទៅរក ការបណ្តេញពួកគេចេញ[2179]។

## *មូលដ្ឋានទី ១២៦៖ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍*[180]

639. **មូលដ្ឋានទី ១២៦ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចថា ជនជាតិវៀតណាមត្រូវរងការធ្វើទុក្ខបុកម្នេញ នៅមន្ទីរសន្តិសុខស-២១។**

640. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធកំហុសដែលបានចោទ គឺប្រភេទនៃកំហុសដែលម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញ ព្រោះទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាង គឺគ្មានមូលដ្ឋាន។

641. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង បានបញ្ចូលក្រុមផ្សេងៗគ្នាទៅជាក្រុមតែមួយ នៅពេលយោងទៅរកជនជាតិវៀតណាម និងគ្រាន់តែបានសម្រេចថា ជនជាតិវៀតណាមត្រូវបានឃុំឃាំង នៅមន្ទីរសន្តិសុខស-២១[2181]។ ជាដំបូង អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា រួមទាំងក្រុមគ្រួសារដែលព្យាយាមរត់ចេញពីប្រទេស និងកូនៗពួកគេ មកពីខេត្តស្វាយរៀង ភូមិភាគនិរតី និងកំពង់សោម ត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខស-២១[2182]។ ទីពីរ ម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងដោយខុសអំពីច្បាប់ នៅ

---

[2176] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១៣។

[2177] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២២។

[2178] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១១៨។

[2179] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៣ & ១០៤ (ការនិរទេសជនជាតិវៀតណាមចេញពីត្រាំកក់ (ធាតុផ្សំសត្យានុម័តិ))។

[2180] <u>មូលដ្ឋានទី ១២៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍* កថាខណ្ឌ ៨២៨-៨៣៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៦ (ភាសាអង់គ្លេស) ទំព័រ ៤២ (ភាសាបារាំង) ទំព័រ ៦៥-៦៦។

[2181] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣០។

[2182] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៦៥, ២៤៧៨, ២៤៨១។

ពេលដែលអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយបញ្ចូលជនជាតិវៀតណាម មកពីប្រទេសវៀតណាម ទៅក្នុងក្រុមដែលរងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាន៍ នៅមន្ទីរសន្តិសុខ ស-២១[2183]។

642. បន្ថែមលើនេះ ការអះអាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែក យ៉ាងខ្លាំងទៅលើទ្រឹស្តីខ្មែរស្រឡាយខាងម្តាយ ពាក់ព័ន្ធពូជសាសន៍ នៅពេលកំណត់អត្តសញ្ញាណជនជាតិវៀតណាម នៅមន្ទីរសន្តិសុខស-២១ គឺខុស[2184]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកផងដែរទៅលើសក្ខីកម្មរបស់សន្តិសុខមន្ទីរសន្តិសុខស-២១ ដែលថា ពួកគេត្រូវបានបង្រៀន នៅក្នុងវគ្គរៀនសូត្រថា ជនជាតិវៀតណាមគឺជា "សត្រូវស្នូរពូជ"[2185]។

643. ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសថា មិនមានការធ្វើទុក្ខបុកម្នេញទេ ព្រោះជនជាតិវៀតណាមត្រូវបានប្រព្រឹត្តដូចគ្នានឹងអ្នកជាប់ឃុំឃាំងដទៃដែរ[2186] ដោយមិនគិតទៅដល់ភ័ស្តុតាងដែលថា ជនជាតិវៀតណាមត្រូវបាននាំយកមក មន្ទីរសន្តិសុខស-២១ ដើម្បីឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់*ដោយសារតែ*ពួកគេ គឺជាជនជាតិវៀតណាមនោះ។ ការដែលមានមានជនរងគ្រោះដទៃទៀត ដែលទទួលរងការប្រព្រឹត្តគួរឱ្យខ្លាចប្រហែលគ្នានោះ មិនបានផ្លាស់ប្តូរការណ៍ដែលថា ជនជាតិវៀតណាមគឺជាគោលដៅ និងរងការរើសអើងដោយសារតែ ពូជសាសន៍របស់ពួកគេឡើយ[2187]។ បន្ថែមលើនេះ ការណ៍ដែលជនជាតិវៀតណាម ត្រូវទទួលការប្រព្រឹត្តខុសពីគេ ត្រូវបានបង្ហាញតាមអង្គហេតុដែលថា ឌុច ជាទូទៅទទួលបានព័ត៌មានអំពីការមកដល់របស់អ្នកជាប់ឃុំជាជនជាតិវៀតណាម, "ចម្លើយសារភាព" របស់ពួកគេ ត្រូវបានកត់ត្រានិងផ្សព្វផ្សាយតាមវិទ្យុ

---

[2183] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨ អំពើមួយជាការរើសអៀង នៅពេលដែលជនរងគ្រោះត្រូវបានកំណត់ជាគោលដៅ ដោយសារតែពួកគេជាសមាជិកនៅក្នុងក្រុមណាមួយ*ដែលចារីបានកំណត់* ។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៤។

[2184] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣០។

[2185] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៦៩។

[2186] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣២។

[2187] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣១-៨៣២។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

និង/ឬ បោះពុម្ពផ្សាយលើឯកសារ កម្ពុជាប្រជាធិបតេយ្យ[2188] និងការណ៍ដែលអ្នកទោសជនជាតិវៀតណាម ត្រូវបានគេចម្រាញ់សម្រាប់ វិធីសាស្ត្រសួរចម្លើយ ដែលធ្ងន់ធ្ងរជាងគេ[2189]។

644. លើសពីនេះទៀត ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា ជនជាតិវៀតណាមត្រូវបានចាត់ទុកថាជា "ទាហាន"[2190] ឬ "គិញ"[2191] ដោយមិនចាត់ទុកថាជាផ្នែក នៃក្រុមជនជាតិវៀតណាមនោះ គឺជាការមិនគិតដោយចេតនា ទៅលើភ័ស្តុតាងជារួម ដែលអង្គជំនុំជម្រះសាលាដំបូង បានវិភាគដូចជា (១) សក្ខីកម្មរបស់ ឌុច ដែលថា ជនស៊ីវិលវៀតណាមត្រូវបានបង្ខំ ឱ្យឆ្លើយសារភាពថាពួកគេគឺជាគិញ និង (២) នៅពេលដែលទាហានវៀតណាម ត្រូវបាននាំយកមកមន្ទីរសន្តិសុខស-២១ ក្រោយពេលផ្ទុះជម្លោះជាមួយប្រទេសវៀតណាមនោះ ជនស៊ីវិលវៀតណាមត្រូវបានឃុំឃាំង នៅពេលវេលាខុសគ្នា[2192]។ ម្ចាស់បណ្ដឹងសាទុក្ខក៏គេចមិនផ្ដល់ព័ត៌មានលម្អិត ថាតើការអះអាងរបស់គាត់ដែលថា ជនជាតិវៀតណាមនៅមន្ទីរសន្តិសុខស-២១ គឺជា "ទាហាន" ឬ "គិញ" អាចពន្យល់បានដោយរបៀបណា ចំពោះការសម្លាប់កុមារវៀតណាមនៅទីនោះ[2193]។

645. ជាចុងក្រោយម្ចាស់បណ្ដឹងសាទុក្ខ បានបង្ហាញដោយខុសនូវ សាលក្រមនិងសាលដីកា សំណុំរឿង ០០១ ដោយអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេច ហើយអង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ថា ការធ្វើទុក្ខបុកម្នេញជនជាតិវៀតណាម នៅមន្ទីរសន្តិសុខស-២១ គឺដោយមូលហេតុនយោបាយសុទ្ធសាធ[2194]។ ការពិតគឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ បានចោទប្រកាន់ ឌុច ពីបទធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ លើអ្នកជាប់ឃុំឃាំង[2195] ដូច្នេះ ឌុច មិនអាចត្រូវបានផ្ដន្ទាទោសពីបទ ធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមដោយមូលហេតុពូជសាសន៍ឡើយ[2196]។ ទោះក្នុងករណីណាក្ដី ការសម្រេចលើអង្គហេតុ គឺមាន

---

[2188] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៦២។

[2189] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៦៩។

[2190] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៣១។

[2191] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៣២។

[2192] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៦០-២៤៨៤។

[2193] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៧៨-២៤៧៩។

[2194] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៣៣-៨៣៤។

[2195] សូមមើល សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្ដី ឌុច* កថាខណ្ឌ ១១ ជើងទំព័រ ១៥។

[2196] ទាក់ទងនឹងការបកស្រាយខុសរបស់ម្ចាស់បណ្ដឹងសាទុក្ខទៅលើការបញ្ជាក់របស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០១ ថា "ខណៈពេលដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងកម្ទេចដោយមិនរើសមុខ" សូមមើល

លក្ខណៈពិសេសសម្រាប់សំណុំរឿងនីមួយៗ ហើយអង្គជំនុំជម្រះសាលាដំបូង មិនមានកាតព្វកិច្ច ត្រូវគោរពតាមការសម្រេចនានារបស់អង្គជំនុំជម្រះ*ណាមួយ* នៅក្នុងសំណុំរឿងផ្សេងទៀត*ណាមួយ* នោះឡើយ[2197]។ ដូច្នេះ ការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ គួរយក "សំអាងហេតុនេះ" មកពិចារណា គឺមិនត្រឹមត្រូវឡើយ[2198]។

## *មូលដ្ឋានទី ១៣០៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍*[2199]

646. **មូលដ្ឋានទី ១៣០ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចថា ជនជាតិវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញ នៅមន្ទីរសន្តិសុខអូរកន្សែង។**

647. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធនឹងកំហុសឆ្គងដែលបានចោទប្រកាន់ ដែលប្រភេទនៃកំហុសនេះ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញ ព្រោះម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែលើកឡើងវិញនូវការអះអាងដោយខុសរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសម្រេចថាជនជាតិវៀតណាម ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ[2200] ហើយម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញ អំពីកំហុសណាមួយនៅក្នុងការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនស៊ីវិលជនជាតិវៀតណាមប្រាំមួយនាក់ ត្រូវបានសម្លាប់នៅអូរកន្សែង ដោយសារតែការសន្មតអំពីពូជសាសន៍របស់ពួកគេ។

---

ចម្លើយតបទៅនឹងមូលដ្ឋានទី ៦៨, ៧២, ៧៥, ៧៦, ៧៧, ១២៤, និង ១៣៤៖ បណ្ដឹងពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ ក្រុមចំនួន ៣។

[2197] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៣៥។

[2198] ម្ចាស់បណ្ដឹងសាទុក្ខក៏យល់ខុសលើចម្លើយរបស់ ឌុច ទាក់ទងនឹងសំអាងហេតុរបស់ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០១ផងដែរ។ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៣៣ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្ដី ឌុច* កថាខណ្ឌ ៣៨៦ ដែលបញ្ជាក់ថា "*ជនជាប់ចោទបញ្ជាក់*ថា គោលនយោបាយ ប.ក.ក ទាក់ទងនឹងជនជាតិវៀតណាម និងជនជាតិភាគតិច ឬក្រុមសាសនាផ្សេងៗទៀត ចាត់ទុកបុគ្គលទាំងនេះថាជា "គីញ" ដែលប្រឆាំងនឹងបក្ស" (គូសបញ្ជាក់បន្ថែម)។

[2199] <u>មូលដ្ឋានទី ១៣០</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍* កថាខណ្ឌ ៨៥៩-៨៦១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៤៧ (ភាសាអង់គ្លេស) ទំព័រ ៤៣ (ភាសាបារាំង) ទំព័រ ៦៧ (ភាសាខ្មែរ)។

[2200] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១២៨។

648. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើមូលហេតុរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការចាប់ខ្លួននិងសម្លាប់ ជនស៊ីវិលវៀតណាម គឺមិនដូចចំពោះអ្នកដែលត្រូវបានកំណត់គោលដៅ ថាជាខ្មាំងនយោបាយតាមការសន្និដ្ឋានឡើយ[2201]។ ម្ចាស់បណ្តឹងសាទុក្ខបកស្រាយដោយខុស នូវការយោងរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះការចាប់ខ្លួននិងការសម្លាប់ គិញវៀតណាម និងទាហានធីវគីតាមការសន្និដ្ឋាន នៅមន្ទីរសន្តិសុខស-២១ ថាមានន័យថា អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាការសម្លាប់នេះដូចគ្នា (ដែលអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថាគឺជាការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ) ជាមួយស្ថានភាពនៃជនស៊ីវិលវៀតណាមទាំងប្រាំមួយរូប[2202]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង បានញែកដាច់ពីគ្នានូវបរិបទខុសគ្នា នៃករណីសម្លាប់ដែលផ្សេងគ្នាទាំងអស់នេះ[2203]។ ម្ចាស់បណ្តឹងសាទុក្ខដាក់បញ្ចូលដោយខុស នូវការសម្រេចដែលថា ជនជាតិវៀតណាមត្រូវបានចាត់ទុកថាជា "ខ្មាំង" និងត្រូវបានកំណត់គោលដៅ ដោយសារតែការសន្និដ្ឋានអំពីពូជសាសន៍ពួកគេ ជាមួយការសម្រេចដែលថា ក្រុមដទៃទៀតត្រូវបានចាត់ទុកផងដែរថាជា "ខ្មាំង" ហើយកំណត់គោលដៅ ដោយផ្អែកលើមូលហេតុនយោបាយ[2204]។

649. បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការពិចារណាថាជនរងគ្រោះជនជាតិវៀតណាម គឺជាជនស៊ីវិលនោះឡើយ។ ម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ដោយផ្នែកៗ នូវកំណត់ហេតុស្តាប់ចម្លើយរបស់ ឆោម សែ[2205] ដែលលើកឡើងថាជនជាតិវៀតណាមទាំងប្រាំមួយរូប ដែលត្រូវបានចាប់ខ្លួននៅសមរភូមិអូរយ៉ាដាវ ប៉ុន្តែបែរជាលប់សម្តី ឆោម សែ ដែលរៀបរាប់ថា ជនជាតិវៀតណាមទាំងប្រាំមួយនាក់នោះគឺជា "ជនស៊ីវិល"[2206]។

---

[2201] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៦០។

[2202] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៦០។

[2203] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨២-២៩៩៣។

[2204] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨៣, ២៩៨៥, ២៩៩៦។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៤។

[2205] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៦១។

[2206] ឯកសារ **E3/405** កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ KH 00401303។

### vii. អំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម

### *មូលដ្ឋានទី ១៥៩៖ អំពើប្រល័យពូជសាសន៍*[2207]

650. **មូលដ្ឋានទី ១៥៩ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការសម្រេចថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមជនជាតិវៀតណាម ត្រូវបានកំណត់។**

651. មូលដ្ឋាននេះមិនទទួលផលឡើយ ពាក់ព័ន្ធនឹងការចោទប្រកាន់ អំពីកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ជំទាស់ទៅនឹងធាតុផ្សំសត្យានុម័ត និងអត្តនោម័តិ នៃអំពើប្រល័យពូជសាសន៍។

652. នៅពេលដំបូង ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែលើកឡើងវិញ នូវការអះអាងដោយខុសរបស់គាត់ ទាក់ទងនឹងបណ្ដឹង[2208] និងការកំណត់អំពីការសម្លាប់ ជនជាតិវៀតណាម នៅអូរកន្សែង ស្វាយរៀង ក្រចេះ កំពង់ឆ្នាំង វត្តខ្សាច់ និងនៅសមុទ្រ[2209]។ ផ្ទុយពីការអះអាងដោយខុស របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង មិនបានកំណត់ប្រភេទនៃការស្លាប់ របស់ជនជាតិវៀតណាមនៅ មន្ទីរសន្តិសុខស-២១[2210] នោះ អង្គជំនុំជម្រះសាលាដំបូង បានធ្វើការសម្រេចអង្គហេតុយ៉ាងច្បាស់លាស់ លើការសម្លាប់ជនជាតិវៀតណាមនៅ មន្ទីរសន្តិសុខស-២១[2211] ហើយផ្នែកកំណត់ប្រភេទនៃបទល្មើស មិនបានញែកដាច់ពីគ្នា រវាងប្រភេទនៃជនរងគ្រោះឡើយ[2212]។

653. ម្ចាស់បណ្ដឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសថា ជនរងគ្រោះជនជាតិវៀតណាម ដោយការសម្លាប់នៅមន្ទីរសន្តិសុខស-២១, អូរកន្សែង និងនៅសមុទ្រ គឺមិនមែនជាផ្នែកនៃក្រុមជនជាតិវៀតណាមដែលត្រូវការពារឡើយ តាមគោលបំណងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ[2213]។

---

[2207] <u>មូលដ្ឋានទី ១៥៩</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *អំពើប្រល័យពូជសាសន៍* កថាខណ្ឌ ១០៥១-១០៩៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៥៥ (ភាសាអង់គ្លេស) ទំព័រ ៥០ (ភាសាបារាំង) ទំព័រ ៧៨-៧៩ (ភាសាខ្មែរ)។

[2208] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៥១។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦០។

[2209] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៥២-១០៥៣។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១២៨, ១៥២, ១៥៣, ១៥៤, ១៥៥, ១៥៦។

[2210] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៥២។

[2211] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៦០-២៤៧១, ២៤៨០។

[2212] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៥៦០-២៥៦៩។ សូមមើលផងដែរ កថាខណ្ឌ ២៥៧៧។

[2213] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៥៥-១០៥៧។

ទស្សនៈទានរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះក្រុមជាតិពន្ធុ ជាតិសាសន៍ និងពូជសាសន៍របស់ជនជាតិវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា ក្នុងនាមជាក្រុមដែលទទួលបានការការពារ គឺច្បាស់ណាស់មិនបានដកចេញនូវជនជាតិវៀតណាម ដែលចូលមកក្នុងប្រទេសកម្ពុជា ពីប្រទេសវៀតណាម ហើយត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជាឡើយ[2214]។

654. ចំពោះធាតុផ្សំអត្តនោម័តិ ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងមិនបាន កំណត់ជាក់លាក់ថាតើ ចេតនាក្នុងការបំផ្លាញជនជាតិវៀតណាម "ទាំងស្រុងឬដោយផ្នែក" នោះ គឺគ្មានមូលដ្ឋានដូចគ្នា[2215]។ មិនមានភាពស្រពិចស្រពិលឡើយ នៅក្នុងការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលថា ភស្តុតាងបង្ហាញ "ចេតនាជាក់លាក់ក្នុងការបំផ្លាញ ក្រុមជនជាតិវៀតណាមយ៉ាងជាក់ច្បាស់"[2216]។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសថា ចំនួននៃការសម្លាប់ជនជាតិវៀតណាម ដែលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ គឺមិនគ្រប់គ្រាន់សម្រាប់បង្ហាញភស្តុតាង អំពីចេតនាក្នុងការបំផ្លាញ ផ្នែកដ៏សំខាន់នៃក្រុមបានឡើយ[2217]។ ម្ចាស់បណ្តឹងសាទុក្ខរួមបញ្ចូលដោយមិនត្រឹមត្រូវ នូវធាតុផ្សំអត្តនោម័តិ និងធាតុផ្សំសត្យានុម័ត។ មិនមានលក្ខខណ្ឌតម្រូវចំនួនជនរងគ្រោះ ដើម្បីបង្ហាញពីអំពើប្រល័យពូជសាសន៍ទេ[2218] ហើយចេតនាជាក់លាក់ត្រូវបានកំណត់ ដោយយោងទៅរកភស្តុតាងជារួម ដែលរួមមានផងដែរនូវការសម្លាប់ ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័ត[2219]។ យោងតាមសំអាងហេតុដដែលនេះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវការនូវទិន្និន័យប្រជាសាស្ត្រ ដើម្បីបង្ហាញអំពីឧក្រិដ្ឋកម្មនោះ គឺជាការមិនត្រឹមត្រូវ[2220]។

[2214] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤១៩។

[2215] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៥៩។

[2216] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥១៨។

[2217] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៥៩-១០៦៣។

[2218] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៩៦។ សាលដីការឿងក្តី *Karadžić* កថាខណ្ឌ ២៣ (គ្មានសារសំខាន់ខាងតួលេខដើម្បីបង្ហាញឱ្យឃើញធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍)។ ទាក់ទងនឹងធាតុផ្សំអត្តនោម័តិ ដូចមានបញ្ជាក់នៅក្នុងយុត្តិសាស្ត្រដែលម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងផ្ទាល់បានដកស្រង់នោះ "ប្រសិនបើត្រូវគិតដំបូងគេដល់សារៈសំខាន់ខាងតួលេខនៃក្រុមដែលត្រូវបានកំណត់គោលដៅ គេមិនអាចឈប់ត្រឹមនេះបានទេ"។ សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៦១ *ដកស្រង់* សាលដីការឿងក្តី *Krstić* កថាខណ្ឌ ១២។

[2219] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨០១-៨០៣។

[2220] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៦៤។

655. ម្ចាស់បណ្ដឹងសាទុក្ខបានកំណត់ប្រភេទ នៃការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយខុសឆ្គង តាមរយៈការលើកឡើងថា អង្គជំនុំជម្រះពឹងផ្អែកជាសំខាន់ ឬសឹងតែទាំងស្រុង ទៅលើអត្ថិភាពនៃគោលនយោបាយ កំណត់គោលដៅលើជនជាតិវៀតណាម ដើម្បីបង្ហាញពីចេតនា[2221]។ រួមជាមួយការអះអាងដែលគ្មានមូលដ្ឋាន និងដដែលៗ ទាក់ទងគោលនយោបាយនោះ[2222] ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងដោយកំហុសថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីអត្ថិភាពនៃគោលនយោបាយ កំណត់គោលដៅលើជនជាតិវៀតណាម ទាក់ទងនឹងក្រុមដទៃផ្សេងទៀត ដែលមិនមែនជាក្រុមជនជាតិវៀតណាម ដែលជាគោលដៅនៃការបំផ្លាញ[2223]។

656. ពាក់ព័ន្ធនឹងមូលដ្ឋានសម្រាប់ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាអំពើប្រល័យពូជសាសន៍បានកើតឡើងនោះ ម្ចាស់បណ្ដឹងសាទុក្ខបានធ្វើការអះអាង ដោយគ្មានការគាំទ្រជាច្រើនថា អង្គជំនុំជម្រះសាលាដំបូងបំភ្លៃភ័ស្តុតាង[2224]។ ជាឧទាហរណ៍ម្ចាស់បណ្ដឹងសាទុក្ខ បានអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មិនបានគាំទ្រដល់ការសម្រេចថា ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា បានទទួលការចាប់អារម្មណ៍ ដោយសារតែការធ្លាក់ចុះនូវទំនាក់ទំនង រវាងបក្សកុម្មុយនីស្តកម្ពុជា និងវៀតណាម បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៧៣[2225]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកផងដែរទៅលើ ទស្សនាវដ្ដីទង់បដិវត្ត ដែលរៀបរាប់ពីកងកម្លាំងខ្មែរក្រហម "បញ្ចេញទាំងអាណិកជនវៀតណាម" និងអ្នកដទៃទៀត នៅក្នុងពេលវាយប្រយុទ្ធនៅបាណាម ក្នុងឆ្នាំ១៩៧៣[2226]។

657. ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែលើកឡើងម្ដងទៀត នូវការអះអាងដោយខុសរបស់គាត់ ពាក់ព័ន្ធការបកស្រាយលើទស្សនាវដ្ដីទង់បដិវត្តលេខខែមេសា ឆ្នាំ១៩៧៦[2227]។ អង្គជំនុំជម្រះសាលាដំបូង មិនបានបកស្រាយឯកសារនេះ ដោយពិនិត្យមើលលើទស្សនាវដ្ដីទង់បដិវត្តពីឆ្នាំ១៩៧៨ និងឆ្នាំ

[2221] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៦៥។

[2222] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៦៥-១០៦៦។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

[2223] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៦៦។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៤។

[2224] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៦៨-១០៧៨។

[2225] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៦៨-១០៦៩។

[2226] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨៤ *ដកស្រង់* ឯកសារ **E3/25** *ទង់បដិវត្ត* ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ ១៩៧៧, KH 00063040។

[2227] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៧០-១០៧១។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៣ & ១០៤ (ការនិរទេសជនជាតិវៀតណាមចេញពីត្រាំកក់ (ធាតុផ្សំសត្យានុម័តិ))។

១៩៧៩ឡើយ[2228] ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងគួសបញ្ជាក់ ពីការបន្តនូវការប្រើប្រាស់ពាក្យពេចន៍ប្រមាថមើលងាយតែមួយ របស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការពណ៌នាជនជាតិវៀតណាមជារហូតមកទេ[2229]។

658. ផ្ទុយពីការកំណត់ដោយខុសរបស់ម្ចាស់បណ្តឹងសាទុក្ខ[2230] អង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកលើភ័ស្តុតាងរបស់ សុន សេន ដែលបញ្ជាក់ពាក់ព័ន្ធ ការវែកមុខខ្មាំងបង្កប់ថា វៀតណាមបានព្យាយាមវាយប្រហារបក្សទាំងពីខាងក្នុង និងខាងក្រៅ ហើយត្រូវបានបណ្តេញចេញពីទឹកដីកម្ពុជា[2231]។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខបានយោងទៅរកសក្ខីកម្មមួយក្នុងចំណោមសក្ខីកម្មជាច្រើន ដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកទៅលើ ពាក់ព័ន្ធនឹងវៀតណាម ដែលត្រូវបានពណ៌នាថាជាខ្មាំង និងបានអះអាងដោយខុសថា ការណ៍នេះទាក់ទងជាមួយរដ្ឋវៀតណាម មិនមែនជនជាតិវៀតណាម នៅក្នុងប្រទេសកម្ពុជាទេ[2232]។ ប៉ុន្តែសក្ខីកម្មរបស់ អ៊ំ ដារ មិនគ្រាន់តែយោងទៅរកមហិច្ឆិតារបស់វៀតណាម ក្នុងការលេបទឹកដីកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថា "បញ្ចូលនូវចារកម្មរបស់វា ដើម្បីរំលោភបំពានមកលើទឹកដីកម្ពុជាប្រជាធិបតេយ្យយើង"[2233]។

659. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីភាពមិនស៊ីចង្វាក់គ្នានៅក្នុងសក្ខីកម្ម និងចម្លើយរបស់ ឯក ហេន ត្រូវបានពិភាក្សារួចហើយ[2234] ដោយម្ចាស់បណ្តឹងសាទុក្ខ មិនបានធ្វើឱ្យខូចខាតឡើយដល់តម្លៃជាភ័ស្តុតាងនៃភ័ស្តុតាងរបស់ ឯក ហេន ដែលថា គាត់បានចូលរួមវគ្គបណ្តុះបណ្តាល ដែលក្នុងវគ្គនោះម្ចាស់បណ្តឹងសាទុក្ខបញ្ជាក់ថា ខ្មែរត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន[2235]។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាង ដោយគ្មានការគាំទ្រថា កំណត់ត្រារបស់ អៀង សារី យោងទៅរកខ្មាំងត្រូវបានគាស់រំលើងឫសគល់ គឺមិនអាចសំដៅទៅ

---

[2228] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧២។

[2229] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨៨ ជើងទំព័រ ១១៤២៣។

[2230] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៣។

[2231] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៩៥។

[2232] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៤។

[2233] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩០ ជើងទំព័រ ១១៤៣៦។

[2234] ឯកសារ **F51/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកស្តុតាងបន្ថែម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ កថាខណ្ឌ ២៣-២៨។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ២០។

[2235] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៥។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩០ ជើងទំព័រ ១១៤៣៧។

ដល់ជនជាតិវៀតណាមនោះ[2236] ដោយមិនគិតអំពីភ័ស្តុតាងដែលថា ឃ្លានេះត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់អំពីការសម្លាប់ គ្រួសារជនជាតិវៀតណាម[2237]។

660. ម្ចាស់បណ្តឹងសាទុក្ខកំណត់ដោយខុសនូវប្រភេទ នៃការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយអះអាងដោយខុសថា "ភ្នាក់ងារ" វៀតណាម សំដៅតែទៅលើខ្មែរជាសមាជិក កម្ពុជាប្រជាធិបតេយ្យ[2238] មិនមែនជនជាតិវៀតណាមនោះ គឺត្រូវបានប្រឆាំងដោយភ័ស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកលើ[2239]។ ការពឹងផ្អែករបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើសក្ខីកម្មរបស់ មាស វឿន នៅត្រង់ចំណុចនេះ គឺជាការគួរឱ្យឆ្ងល់មួយ ដោយសារតែ មាស វឿន បានផ្តល់សក្ខីកម្មថា ប្រជាជនវៀតណាមទាំងអស់ ដោយមិនគិតអំពីឋានៈ ឬអាយុរបស់ពួកគេ ត្រូវបានចាត់ទុកជា "សត្រូវ"[2240]។ ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា លើកលែងតែពាក្យជនជាតិវៀតណាម ដែលមានការបង្ហាញយ៉ាងច្បាស់នូវវោហាសាស្ត្របែបប្រឆាំងវៀតណាមនោះ ភ័ស្តុតាងបែបនេះគួរត្រូវបានចាត់ទុកថា យោងសំដៅទៅលើជម្លោះកងទ័ពនោះ គឺជាការលើកឡើងដែលគ្មានមូលដ្ឋានឡើយ[2241]។

661. បន្ថែមពីលើការលើកឡើងម្តងទៀត នូវការអះអាងដោយខុសឆ្គងរបស់គាត់ ពាក់ព័ន្ធសារសំខាន់នៃជម្លោះប្រដាប់អាវុធជាមួយវៀតណាមនោះ[2242] ការប្រើប្រាស់បញ្ជីសម្រាប់កំណត់អត្តសញ្ញាណជនជាតិវៀតណាម និងការកំណត់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅលើជនជាតិវៀតណាមដោយផ្អែកលើទ្រឹស្តីនៃជាតិពន្ធុ តាមខ្សែស្រឡាយខាងម្តាយ[2243] ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់

[2236] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៦។

[2237] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២៥។ សូមមើលផងដែរ ជើងទំព័រ ១១៥៤៦ *ដកស្រង់* ឯកសារ **E3/9801** កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន KH 01097673 ជើងទំព័រ ១១៥៤៧ *ដកស្រង់* ឯកសារ **E1/395.1** អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ ម៉ោង ០៩.១៤.៤៦-០៩.១៨.០០ ទំព័រ ៥-៦ បន្ទាត់ ១០-៥។

[2238] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៤, ១០៧៦។ សូមមើលផងដែរ កថាខណ្ឌ ១០៨៦-១០៨៧។

[2239] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៧។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣០៧, ៣៤៦៦។

[2240] ឯកសារ **E1/387.1** មាស វឿន ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង ០៩.៥៥.៤៩-០៩.៥៨.៥០ ទំព័រ ១៧ បន្ទាត់ ១៤-២២។ សូមមើលផងដែរ ឯកសារ **E319/23.3.44** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ KH 00955488។

[2241] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៨។

[2242] សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩, ១៨៥។

[2243] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩០។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៨។

ភ័ស្តុតាងគាំទ្រ ការអះអាងរបស់គាត់ដែលថា សារព័ត៌មាន Foreign Broadcast Information Service ("FBIS") និងឯកសារសេចក្តីសង្ខេបរបស់ World Broadcasts ("SWB") ដែលអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកទៅលើ គឺមិនពិតប្រាកដ ហើយខ្លឹមសាររបស់ឯកសារទាំងអស់នេះ មិនអាចទម្លាក់ទៅលើ បក្សកុម្មុយនីស្តកម្ពុជាបានឡើយ[2244]។ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់អំពីប្រភព និងសារសំខាន់នៃឯកសារទាំងអស់នេះ ហើយបានកត់សម្គាល់ថា ឯកសារទាំងនេះត្រូវបានពឹងផ្អែក តែក្នុងករណីដែលមានការគាំទ្រគ្រប់គ្រាន់ប៉ុណ្ណោះ[2245]។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយសមហេតុផលថា កំណត់ត្រានៃការផ្សព្វផ្សាយនាសម័យកាលនោះ ពីទីក្រុងភ្នំពេញ បានឆ្លុះបញ្ចាំងពីទម្រង់និងខ្លឹមសារ នៃវោហាសាស្ត្រដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងជនជាតិវៀតណាម ដែលជាសត្រូវ ហើយត្រូវកម្ចាត់ចេញពីប្រទេសកម្ពុជា[2246]។ ស្រដៀងគ្នានេះដែរ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងតម្លៃជាភ័ស្តុតាងនៃកំណត់ត្រានៃសុន្ទរកថា ខែមេសា ឆ្នាំ១៩៧៨ របស់គាត់ នៅក្នុងឯកសារ SWB នាសម័យកាលនោះ គឺគ្មានមូលដ្ឋានឡើយ[2247] ហើយការអះអាងដោយខុសឆ្គងរបស់គាត់ដែលថា ខ្លឹមសារនៃសុន្ទរកថារបស់គាត់ និងរបស់ ប៉ុល ពត អំពី "១ទល់នឹង៣០" អាចត្រូវបានពិចារណា តែនៅក្នុងបរិបទកងទ័ពតែប៉ុណ្ណោះនោះ គឺត្រូវបានពិភាក្សាពីខាងលើរួចហើយ[2248]។

662. ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា ការអំពាវនាវរបស់បក្សកុម្មុយនីស្តកម្ពុជា ឱ្យការពារ "ពូជសាសន៍" ខ្មែរ ពីពួកយួន នៅក្នុងទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជន យុវនារីបដិវត្ត គឺមានចេតនាដើម្បីជម្រុញ កងទ័ពកម្ពុជា[2249]។ ការព្យាយាមរបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការបំភាន់ការញុះញង់ម្តងហើយម្តងទៀត ដើម្បីបំផ្លាញជនជាតិវៀតណាម ដែលត្រូវបកស្រាយថាជនស៊ីវិលគ្រប់វ័យ ត្រូវបានកំណត់គោលដៅ និងត្រូវសម្លាប់ នៅ

---

[2244] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៧៩។

[2245] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៦៩-៤៧២។

[2246] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៨។

[2247] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៨០។

[2248] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៨១, ១០៨៣-១០៨៥។

[2249] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៨៨។

ទូទាំងប្រទេសកម្ពុជា ថាគ្រាន់តែជាការឃោសនានៅពេលសង្គ្រាមនោះ ធ្វើឱ្យខូចខាតដល់ភាពអាចជឿជាក់បាន[2250]។

663. ចំពោះទូរលេខនិងភស្តុតាងដែលម្ចាស់បណ្តឹងសាទុក្ខ បានលើកទឡ្ហីករណ៍ថា ស្ថិតក្រៅវិសាលភាពនៃសំណុំរឿងនោះ ម្ចាស់បណ្តឹងសាទុក្ខបានធ្វើការ អះអាងដោយបំភាន់ជាបន្តបន្ទាប់[2251]។ ទីមួយ អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់យ៉ាងច្បាស់ថា ទូរលេខមួយចំនួនបានកត់ត្រា ពីចំនួនស្លាប់នៃជនស៊ីវិល និងកងទ័ព ឬយោងជាសំខាន់ទៅលើកងកម្លាំងវៀតណាម[2252]។ ទីពីរ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ទូរលេខដែលអង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកទៅលើ គឺគ្រាន់តែពាក់ព័ន្ធ តែជាមួយបរិបទកងទ័ពនោះ គឺត្រូវបានបង្ហាញថាខុស ដោយសារ (១) សំណើរបស់ រស់ ញឹម ទៅមន្ទីរ៨៧០ សុំគោលករណ៍ណែនាំ សម្រាប់ក្រុមគ្រួសារចម្រុះខ្មែរវៀតណាម និង (២) របាយការណ៍របស់ភូមិភាគបស្ចិម ដែលបញ្ជាក់ថាខ្លួនបានគោរពតាម មាគ៌ាបក្សក្នុងការសម្រិតសម្រាំង និងបោសសម្អាត "អាណិកជនយួន" ហើយបានសម្លាប់ប្រជាជនវៀតណាម ១០០នាក់ "ទាំងតូច ទាំងធំ ទាំងចាស់ ទាំងក្មេង"[2253]។ បន្ថែមលើនេះ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់ភស្តុតាងគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ការយោងទៅរកជនជាតិវៀតណាម ថាជា "ខ្មាំងសូរពូជ" និង "សត្រូវប្រចាំជាតិរបស់យើង តាំងពីដើមរហូតឥឡូវ និងទៅខាងមុខយូរអង្វែងទៀត" នៅក្នុងសេចក្តីប្រកាសថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៩ គឺកម្រិតត្រឹមតែកងកម្លាំងទ័ព របស់វៀតណាមនោះ[2254]។

664. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសថា ហេង ឡៃហ៊ាង ដែលចូលខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧១ ហើយជាសមាជិកគណៈកម្មាធិការឃុំ នៅក្នុងខេត្តក្រចេះរហូតដល់ឆ្នាំ ១៩៧៧[2255] មិនបានដឹងអំពីគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា[2256]។ ការអះអាងរបស់

[2250] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៨៩។

[2251] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩០-១០៩៣។

[2252] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩០។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០៨, ៣៤១១។

[2253] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០៩-៣៤១០។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩២-១០៩៣។

[2254] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩៤ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤១២។

[2255] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤១៤។

[2256] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩៥។

ម្ចាស់បណ្តឹងសាទុក្ខ ដែលថាសក្ខីកម្មរបស់សាក្សី មិនមានភាពសត្យានុម័តិ ដោយសារតែគាត់បាត់បង់សមាជិកគ្រួសារ នៅក្នុងរបបនោះ គឺជារឿងគួរឱ្យសោកស្តាយ[2257]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មិនបានគិតអំពីសក្ខីកម្មរបស់អតីតកងទ័ពកម្ពុជាប្រជាធិបតេយ្យដែលថា មិនមានគោលនយោបាយសម្លាប់ជនស៊ីវិលឡើយ[2258]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានលើកពីសាក្សី មាស វឿន ដែលមានតួនាទីជាសន្តិសុខ របស់ម្ចាស់បណ្តឹងសាទុក្ខ ដែលបានផ្តល់សក្ខីកម្មថា "អីចឹងតាមអង្គការអីចឹង ឱ្យតែជនជាតិវៀតណាមត្រូវកម្ទេចអីចឹង។ បើកាលណាគេឱ្យទៅហើយ យើងមិនព្រមទៅ"[2259]។ ទោះបីជាគាត់ព្យាយាមកែសម្រួលសក្ខីកម្មនេះនៅពេលព្រឹកថ្ងៃបន្ទាប់ក្តី សាក្សីមិនបានផ្តល់ការពន្យល់ ដែលគួរឱ្យជឿជាក់បានសម្រាប់ការផ្លាស់ប្តូរភ្លាមៗ នៃព័ត៌មានរបស់គាត់។ ទោះបីជាយ៉ាងណាក្តី ប៉ាក់ សុខ ក៏បានផ្តល់សក្ខីកម្មថា នៅវគ្គរៀនសូត្រក្នុងកងពលធំ ១៦៤ "សត្រូវយួនហ្នឹងគឺថា សម្លាប់អត់មានទុកសូម្បីកូនង៉ែតមួយក៏អត់ឱ្យមានដែរ ព្រោះសត្រូវយួន គឺសម្លាប់ចោលតែម្តង។ [...] ទទួលផែនការច្បាស់លាស់តែម្តង"[2260]។

## ឃ. បទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍

665. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀត តាមរយៈអំពើដែលអាចចាត់ចំណាត់ថ្នាក់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានប្រព្រឹត្តឡើងអនុលោមតាម គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ក្នុងការគ្រប់គ្រងការរៀបអាពាហ៍ពិពាហ៍[2261] ដែលមានទំនាក់ទំនងផ្ទៃក្នុង ជាមួយគោលបំណងរួម នៃការអនុវត្តបដិវត្តសង្គមនិយម[2262]។ មូលដ្ឋានទាំង១៦ របស់ម្ចាស់បណ្តឹងសាទុក្ខ[2263] ទាក់ទងនឹងបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍គឺមិនទទួលផលឡើយ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ អនុវត្តវិធីសាស្ត្រ

---

[2257] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩៥។

[2258] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩៥។

[2259] ឯកសារ **E1/386.1** មាស វឿន ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង ១៥.៥៥.៥១-១៥.៥៨.៥១ ទំព័រ ៧៣ បន្ទាត់ ៥-១១ (គូសបញ្ជាក់បន្ថែម)។

[2260] ឯកសារ **E1/369.1** ប៉ាក់ សុខ ប្រតិចារឹក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១៣.៣៤.១៧-១៣.៣៧.៤៥ ទំព័រ ៣៩ បន្ទាត់ ១០-១១។

[2261] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨០-៣៧០១។

[2262] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២៦-៤០៦៧។

[2263] មូលដ្ឋានទី ១៦០-១៦៩, ១៧១-១៧៤, ២៤៤។

មួយផ្នែកៗ ចំពោះភ័ស្តុតាង ហើយមិនគិតអំពីបរិយាកាស នៃការភ័យខ្លាចនិងកាលៈទេសៈបង្ខិតបង្ខំ ដែលការរៀបការទាំងនោះបានរៀបចំឡើយ ដែលធ្វើឱ្យការយល់ព្រមដោយពិតប្រាកដ គឺមិនអាចធ្វើទៅបាន។ ជាពិសេស ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ផ្តោតទៅលើអង្គហេតុដែលថា ការយល់ព្រមគឺជាគោលការណ៍នៃបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ហើយមិនបានពិចារណាទៅលើភ័ស្តុតាងជារួមដែលចង្អុលបង្ហាញថា ការណ៍នេះគឺជាទម្រង់ការទទេរស្អាត[2264]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានព្យាយាមជាបន្តបន្ទាប់ ដើម្បីធ្វើការប្រៀបធៀបរវាងបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំបែបប្រពៃណី ដែលនាំឱ្យមានកំហុសមួយចំនួន នៅក្នុងការវិភាគរបស់គាត់អំពីលក្ខណៈនិងអានុភាពនៃឧក្រិដ្ឋកម្ម[2265]។

## *មូលដ្ឋានទី ១៦០៖ កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាព នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងក្របខណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩*[2266]

666. **មូលដ្ឋានទី ១៦០ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលអះអាងគាំទ្រថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងក្របខណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត គឺគោរពទៅតាមគោលការណ៍នីត្យានុកូលភាព[2267]។**

667. មូលដ្ឋាននេះត្រូវបានអះអាងដោយផ្អែកលើការសន្មតដោយខុសជាច្រើន និងមើលរំលងទៅលើការអះអាងគាំទ្រយ៉ាងសំបូរបែប នៅក្នុងច្បាប់អន្តរជាតិដែលថា ការរៀបការដោយបង្ខំ រំលោភទៅលើសិទ្ធិមនុស្សជាមូលដ្ឋាន ក្នុងការរៀបការនិងបង្កើតក្រុមគ្រួសារដោយស្ម័គ្រចិត្ត។ ដូចដែលបានពន្យល់កន្លងមក[2268] ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យសម្រេច (១) ការហាមឃាត់ជាក់លាក់ ចំពោះការរៀបការដោយបង្ខំ នៅក្នុងច្បាប់

---

[2264] មូលដ្ឋានទី ១៦២, ១៦៣, ១៦៥, ១៦៧-១៦៩

[2265] មូលដ្ឋានទី ១៦៣, ១៦៧, ១៧៣។

[2266] <u>មូលដ្ឋានទី ១៦០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងក្របខណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩* កថាខណ្ឌ ១០៩៨-១១១៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៥ (ភាសាអង់គ្លេស) ទំព័រ ៥១ (ភាសាបារាំង) ទំព័រ ៧៩ (ភាសាខ្មែរ)។

[2267] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩៨-១១១៦, ១១៣១-១១៥៩។

[2268] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៥, ៨៦, ៩៧, ៩៨។

អន្តរជាតិនៅឆ្នាំ១៩៧៥[2269] និង (២) ការរៀបការដោយបង្ខំ ត្រូវបានកំណត់ប្រភេទជាបទល្មើស ហើយមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ជាតិឬច្បាប់អន្តរជាតិ នៅត្រឹមឆ្នាំ១៩៧៥[2270] គឺជាការអះអាងដែលខុស។ អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តដោយត្រឹមត្រូវ ក្នុងការគោរពតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា អង្គជំនុំជម្រះចាំបាច់ត្រឹមតែសម្រេចថា អំពើនោះបានរំលោភបំពានទៅលើ "សិទ្ធិជាសារវ័ន្តរបស់ [ជនរងគ្រោះ] និងមានសភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា ទៅនឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[2271]។ ដូចដែលបានកត់សម្គាល់កន្លងមក ម្ចាស់បណ្ដឹងសាទុក្ខយល់ស្របថា នៅក្នុងឆ្នាំ១៩៧៥ គឺអាចប្រមើលមើលដឹងថាមានច្បាប់ចែងថា អំពើដែលមានលក្ខណៈ និងសភាពធ្ងន់ធ្ងរប្រហាក់ប្រហែល នឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចនាំឱ្យមានការចោទប្រកាន់ព្រហ្មទណ្ឌសម្រាប់អំពើអមនុស្សធម៌ផ្សេងទៀត[2272]។

668. ចំពោះ "អនីត្យានុកូលភាពផ្លូវការ" អង្គជំនុំជម្រះសាលាដំបូង បានបំពេញអាណត្តិរបស់ខ្លួនយ៉ាងច្បាស់ ដើម្បីកំណត់អំពី "សិទ្ធិមូលដ្ឋាន" ដែលត្រូវបានរំលោភបំពាន ដោយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅពេលដែលអង្គជំនុំជម្រះសម្រេចថា សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ដោយសេរី គឺមានចែងនៅក្នុងសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស[2273]។ ម្ចាស់បណ្ដឹងសាទុក្ខមិនបានពន្យល់ថា ហេតុអ្វីទើបលិខិតុបករណ៍សិទ្ធិមនុស្ស ជាមូលដ្ឋានបំផុតនេះ[2274] ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដោយគ្មានមតិប្រឆាំង[2275] មិនមានភាពគ្រប់គ្រាន់ ឬថាតើការស្រាវជ្រាវ "ស៊ីជម្រៅ"[2276] ជាងនេះអ្វី ដែលអង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យបំពេញនោះ។ ការលើកឡើងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា លិខិតុបករណ៍តែមួយ គឺតម្រូវឱ្យ

---

[2269] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៩៨, ១១០០-១១០៣, ១១០៨-១១១១, ១១១៦, ១១៣១, ១១៤៩។

[2270] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៩៩, ១១១២-១១១៤, ១១១៦, ១១៣២-១១៤៧។

[2271] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៦។ សូមមើល បន្ថែមទៀត ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៨, ៥៨០, ៥៨៤-៥៨៥។

[2272] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៧។

[2273] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៤៣ *ដកស្រង់* UDHR មាត្រា ១៦(២)។

[2274] ទោះបីជា UDHR មិនមែនជាសន្ធិសញ្ញាដែលចងកាតព្វកិច្ចក្ដី ក៏រដ្ឋសមាជិកអង្គការសហប្រជាជាតិត្រូវបានអំពាវនាវឱ្យជួយលើកតម្កើង និងផ្សព្វផ្សាយសន្ធិសញ្ញានេះដែរ។ ប្រទេសកម្ពុជាបានក្លាយជារដ្ឋសមាជិកនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥។

[2275] UDHR ត្រូវបានអនុម័តដោយសំឡេងចំនួន ៤៨ សំឡេង អនុបវាទ ៨ សំឡេង។ សូមមើល របាយការណ៍ផ្លូវការនៃកិច្ចប្រជុំពេញអង្គមហាសន្និបាតលើកទី១៨៣ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ឯកសារ A/PV.183 ទំព័រ ៩៣៣។

[2276] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១០៣-១១០៥។

មានការគាំទ្រនោះ[2277] គឺមិនសមហេតុផល និងមិនមានអ្វីជាសំអាងឡើយ។ អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង ក៏បានយោងទៅរកសេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស នៅពេលបង្ហាញថា តើ លក្ខណៈវិនិច្ឆ័យនៃ "អនីត្យានុកូលភាពផ្លូវការ" អាចត្រូវបានបំពេញដោយរបៀបណា[2278]។

669. ទោះជាក្នុងករណីណាក្តី មានច្បាប់អន្តរជាតិជាច្រើនលើសលប់ ដែលបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខមានកំហុស ក្នុងការអះអាងរបស់គាត់ដែលថា សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស គឺជាលិខិតុបករណ៍តែមួយគត់ ដែល "និយាយច្បាស់ដល់ការរៀបអាពាហ៍ពិពាហ៍" នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ[2279]។ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៥៧ កម្ពុជាបានចូលជាហត្ថលេខី នៃ អនុសញ្ញាបន្ថែម ស្តីពីការលប់បំបាត់ទាសភាព ដែលអំពាវនាវឱ្យរដ្ឋជាសមាជិក លប់បំបាត់ឬបោះបង់ចោល ការអនុវត្តដែលនារីត្រូវបានសន្យា ឬប្រគល់ឱ្យក្នុងការរៀបការ ដោយគ្មានសិទ្ធិក្នុងការបដិសេធ[2280]។ នៅក្នុងឆ្នាំ១៩៦២ អនុសញ្ញាស្តីពីការព្រមព្រៀង ក្នុងការរៀបអាពាហ៍ពិពាហ៍ អាយុកំណត់សម្រាប់ការរៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអាពាហ៍ពិពាហ៍ បានបញ្ជាក់ថា "ការរៀបអាពាហ៍ពិពាហ៍ មិនអាចធ្វើឡើងដោយស្របច្បាប់ឡើយ ប្រសិនបើគ្មានការឯកភាពពេញលេញ និងដោយសេរី ពីភាគីទាំងពីរ"[2281]។

670. នៅពេលយោងទៅរកបទប្បញ្ញត្តិផ្សេងៗ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[2282] ម្ចាស់បណ្តឹងសាទុក្ខមិនបានគិតដល់ថា នៅក្នុងខែធ្នូ ឆ្នាំ១៩៦៦ ពាក្យពេចន៍សឹងតែដូចគ្នាជាមួយពាក្យពេចន៍ ដែលមានចែងនៅក្នុង សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស ក៏មានប្រើនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[2283] និង ICESCR[2284] ដែល

[2277] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១០៥។

[2278] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៤។

[2279] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១០៨, ១១៤១។

[2280] អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ចោលទាសភាព ការជួញដូរទាសករ អង្គការចាត់តាំង និងការអនុវត្តដែលមានលក្ខណៈប្រហាក់ប្រហែលនឹងទាសភាព (ចូលជាធរមាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៧) មាត្រា ១(គ)។

[2281] អនុសញ្ញាតស្តីពីការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ អាយុអប្បបរមា និងការចុះសំបុត្រអាពាហ៍ពិពាហ៍ (ចូលជាធរមាននៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៦៤) (អារម្ភកថានៃអនុសញ្ញានេះរម្លឹកពីមាត្រា ១៦ នៃ UDHR ហើយមាត្រា ១ ចែងថា "រាល់ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងក្រោមបរិយាកាសព្រមព្រៀងដោយសេរីដោយភាគីទាំងសងខាង")។

[2282] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១០៨ *ដកស្រង់* ICCPR មាត្រា ១៧។

[2283] ICCPR មាត្រា ២៣(៣) ("គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រម ដោយសេរី និងពេញលេញពីអនាគតប្តី-ប្រពន្ធឡើយ")។ អនុសញ្ញានេះចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ហើយនៅត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អនុសញ្ញាមានរដ្ឋភាគីចំនួន ២៨ និងភាគីហត្ថលេខីចំនួន ២៥។

ចូលជាធរមាននៅក្នុងបណ្តាខែដំបូងៗ នៃរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៦៧ សេចក្តីប្រកាសស្តីពីការ លប់បំបាត់ការរើសអើងលើស្ត្រី ដែលបានអនុម័តិជាឯកច្ឆន្ទដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៦៧ បានប្រកាសថា "ស្ត្រីត្រូវមានសិទ្ធិដូចបុរស ក្នុងការជ្រើសរើសដោយសេរីនូវគូស្រករ ហើយឈានចូលចំណងអាពាហ៍ពិពាហ៍ តែនៅពេលដែលខ្លួនយល់ព្រមពេញលេញ និងដោយសេរីប៉ុណ្ណោះ"[2285]។ អនុសញ្ញាស្តីពីការលប់បំបាត់ រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី ដែលទាមទារប្រហែលគ្នា នូវការយល់ព្រមពេញលេញ និងដោយសេរី ក្នុងការរៀបអាពាហ៍ពិពាហ៍[2286] គឺស្ថិតក្នុងការចរចាររហូតពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2287] មុនពេលបើកឱ្យចុះហត្ថលេខា នៅក្នុងខែធ្នូ ឆ្នាំ១៩៧៩ ហើយផ្តល់សច្ចាប័នដោយ អៀង សារី នៅក្នុងខែតុលា ឆ្នាំ១៩៨០[2288]។

671. នៅឆ្នាំ១៩៧៥ លិខិតុបករណ៍ក្នុងតំបន់ ក៏បានទទួលស្គាល់ផងដែរពីសារសំខាន់នៃការយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍[2289]។ ទោះបីជាមិនមានការចែងជាក់ច្បាស់ អំពីការរៀបអាពាហ៍ពិពាហ៍ក្តី[2290] តែបទបញ្ញាទីក្រុងឡាអេឆ្នាំ១៨៩៩[2291] និងឆ្នាំ១៩០៧[2292] និងអនុសញ្ញាទីក្រុងហ្សឺណែវIV[2293] សុទ្ធតែតម្រូវឱ្យមានការគោរពចំពោះសិទ្ធិគ្រួសារ។

---

[2284] ICESCR មាត្រា ១០(១) "ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយមានការយល់ព្រមដោយសេរីរបស់អនាគតប្តី-ប្រពន្ធ")។ អនុសញ្ញានេះចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦ ហើយនៅត្រឹមខែមេសា ឆ្នាំ១៩៧៥ អនុសញ្ញាមានរដ្ឋភាគីចំនួន ២៥ និងភាគីហត្ថលេខីចំនួន ២៨។

[2285] សេចក្តីប្រកាសស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (កំណត់ត្រាបោះឆ្នោត ១១១-០-០ មិនបានកត់ត្រា) មាត្រា ៦(២)(ក)។ សូមមើលផងដែរ មាត្រា ១១(១)-(២)។

[2286] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ មាត្រា ១៦។

[2287] សូមមើល អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ៖ ប្រវត្តិនីតិវិធី។ អាចរកបាននៅលើគេហទំព័រ៖ https://legal.un.org/avl/pdf/ha/cedaw/cedaw_ph_e.pdf។

[2288] សូមមើល 1249 UNTS 89។

[2289] ACHR មាត្រា ១៧(៣) (ចូលជាធរមាននៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨) ("គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រម ដោយសេរី និងពេញលេញពីអនាគតប្តី-ប្រពន្ធឡើយ")។ សូមមើលផងដែរ ECHR (ចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៥៣) មាត្រា ៨, ១២។

[2290] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១១១។

[2291] អនុសញ្ញាឆ្នាំ១៨៩៩ ស្តីពីសង្គ្រាមផ្លូវគោក ឧបសម្ព័ន្ធ៖ បទបញ្ញា មាត្រា ៤៦។

[2292] អនុសញ្ញាឆ្នាំ១៩០៧ ស្តីពីសង្គ្រាមផ្លូវគោក ឧបសម្ព័ន្ធ៖ បទបញ្ញា មាត្រា ៤៦។

[2293] GC IV មាត្រា ២៧។

672. លើសពីនេះទៀត ទោះបីជាមិនមានការតម្រូវ ដើម្បីធានាពីអនុលោមភាពជាមួយនឹងគោលការណ៍នីត្យានុកូលភាព ដោយផ្អែកលើច្បាប់អន្តរជាតិជាច្រើនក្តី តែភាពធ្ងន់ធ្ងរនៃអំពើ និងភាពអាចដឹងថាជាបទល្មើស សម្រាប់ការចោទប្រកាន់ព្រហ្មទណ្ឌ ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានគាំទ្របន្ថែមទៀត តាមរយៈការពិនិត្យពិច័យទៅលើច្បាប់ជាតិ នៅក្នុងឆ្នាំ១៩៧៥។ ផ្ទុយពីសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ[2294] ការកំណត់ប្រភេទជាបទល្មើស សម្រាប់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងច្បាប់ជាតិ គឺមិនមែនជាព្រឹត្តិការណ៍ថ្មីៗដែលពិសេសនោះឡើយ។ នៅមុនពេលខ្មែរក្រហមចាប់ផ្តើម យុទ្ធនាការការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួន បណ្តារដ្ឋនៅទូទាំងពិភពលោក រួមទាំងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍[2295] ដូចជាសិង្ហបុរី និងហ្វីលីពីន[2296] បានចាប់ផ្តើមកំណត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាប្រភេទបទល្មើស[2297]។ បន្ថែមលើនេះ ការចាប់ពង្រត់ និងការឃុំឃាំងនារី ក្នុងគោលបំណងដើម្បីរៀបអាពាហ៍ពិពាហ៍ ត្រូវបានកំណត់ប្រភេទថាជាបទល្មើស នៅទូទាំងទ្វីបអាស៊ី[2298] ព្រមទាំងទ្វីបអឺរ៉ុប[2299] ទ្វីបអាហ្វ្រិក[2300] ទ្វីបអាមេរិកខាងត្បូង[2301] និងទ្វីបអូសេអានី[2302]។

---

[2294] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៣៧-១១៤១។

[2295] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៣៣-១១៣៥។

[2296] **ប្រទេសសិង្ហបុរី៖** ធម្មនុញ្ញស្ត្រី ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៦១ មាត្រា ៣៦។ **ប្រទេសហ្វីលីពីន៖** ក្រមព្រហ្មទណ្ឌដែលបានកែសម្រួលរួច ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៣០ មាត្រា ៣៥០។

[2297] **ប្រទេសប៊ុលហ្គារី៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៦៨ មាត្រា ១៧៧(១)។ **ប្រទេសហ្គាណា៖** ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៦០, ផ្នែក ១០៩។ **ប្រទេសន័រវេ៖** ក្រមព្រហ្មទណ្ឌរដ្ឋប្បវេណីទូទៅ ថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩០២ លេខ ១០, ផ្នែក ២២២។ **សាធារណរដ្ឋសង្គមនិយមសហព័ន្ធសូវៀតរុស្ស៊ី៖** ក្រមព្រហ្មទណ្ឌសាធារណរដ្ឋសង្គមនិយមសហព័ន្ធសូវៀតរុស្ស៊ី បោះពុម្ពផ្សាយនៅ *Soverskaya Yustitsiya* (តុលាការសូវៀត) លេខ ១៧ ខែធ្នូ ឆ្នាំ១៩៦០ (ចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៦១) មាត្រា ២៣៣។ សូមមើលផងដែរ **ប្រទេសអាហ្គានីស្ថាន៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៦ មាត្រា ៥១៧(១)។

[2298] **ប្រទេសឥណ្ឌា៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី៦ ខែតុលា ឆ្នាំ១៨៦០ មាត្រា ៣៦៦។ **ប្រទេសសិង្ហបុរី៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៨៧២ មាត្រា ៣៦៦។ ប្រទេសឥណ្ឌូនេស៊ី៖ ក្រមព្រហ្មទណ្ឌឥណ្ឌូនេស៊ី ឆ្នាំ១៩១៥ (ជាមួយនឹងការកែសម្រួលនៅឆ្នាំ១៩៧៦) មាត្រា ៣៣២។ **ប្រទេសជប៉ុន៖** ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩០៧ មាត្រា ២២៥, ២២៦-២(៣)។ **ប្រទេសបង់ក្លាដេស៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី៦ ខែតុលា ឆ្នាំ១៨៦០ មាត្រា ៣៦៦។ **ប្រទេសប៉ាគីស្ថាន៖** ក្រមព្រហ្មទណ្ឌប៉ាគីស្ថាន ថ្ងៃទី៦ ខែតុលា ឆ្នាំ១៨៦០, ផ្នែក ៣៦៥B។ **ប្រទេសកូរ៉េខាងត្បូង៖** ក្រមព្រហ្មទណ្ឌកូរ៉េ ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៥៣ មាត្រា ២៩១។ **ប្រទេសម៉ាឡេស៊ី៖** ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៣៦, ផ្នែក ៣៦៦។ **ប្រទេសភូមា៖** ក្រមព្រហ្មទណ្ឌ (ច្បាប់ឥណ្ឌា XLV ឆ្នាំ១៨៦០) ថ្ងៃទី១ ខែឧសភា ឆ្នាំ១៨៦១ មាត្រា ៣៦៦។ **ប្រទេសស្រីលង្កា៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែមករា ឆ្នាំ១៨៨៥ មាត្រា ៣៥៧។

[2299] **ប្រទេសប៊ុលហ្គារី៖** ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៦៨ មាត្រា ១៧៧(២)។ **ប្រទេសអ៊ីតាលី៖** ក្រមព្រហ្មទណ្ឌអ៊ីតាលី ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៣០ មាត្រា ៥២២។ **ប្រទេសអូទ្រីស៖** ច្បាប់ព្រហ្មទណ្ឌអូទ្រីស ឆ្នាំ១៨៥២ & ១៩៤៥ មាត្រា

673. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខយល់ច្រឡំ ទៅលើគោលបំណងដែល អង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការ SCSL និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបាន កំណត់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អាចចាត់ទុកថាជា អំពើអមនុស្សធម៌ផ្សេង ទៀត[2303]។ អង្គជំនុំជម្រះសាលាដំបូង មិនបានអះអាងថា រឿងក្តីទាំងអស់នេះតំណាងឱ្យ ច្បាប់ អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥ ទេ។ ប៉ុន្តែការយោងទាំងអស់នេះ បង្កើតបានជាផ្នែកនៃ ការស្រាវជ្រាវ ដោយប្រុងប្រយ័ត្នរបស់ខ្លួន ទៅលើច្បាប់និងយុត្តិសាស្ត្រពាក់ព័ន្ធនានា ក្នុងការបង្ហាញថាតើ *ជា គោលការណ៍* ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អាចមានសភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែលនឹង អំពើជាក់លាក់នៅក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬទេ។ អង្គជំនុំជម្រះសាលាដំបូង មានភាព ច្បាស់លាស់ណាស់ថា ទាំងអស់នេះមិនអាចជំនួសការសម្រេចថាតើ ការអនុវត្តការរៀបអាពាហ៍ ពិពាហ៍ *នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* អាចបំពេញបានតាមបទដ្ឋាននេះដែរឬអត់នោះ[2304] ដែលជាការវាយតម្លៃលើអង្គហេតុភាគច្រើន ដែលអង្គជំនុំជម្រះសាលាដំបូង បានអនុវត្តដោយ លម្អិត[2305]។

## *មូលដ្ឋានទី ១៧១ និងទី ១៧២៖ ការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត*[2306]

---

៧៦, ៩៦ (បទប្បញ្ញត្តិបន្ថែមនៅឆ្នាំ១៩៥៣)។ <u>**ប្រទេសក្រិក៖**</u> ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៥១ មាត្រា ៣២៥, ៣២៧(១) (បទប្បញ្ញត្តិបន្ថែមនៅឆ្នាំ១៩៦០)។

[2300] <u>**ប្រទេសបុតស្វាណា**</u>៖ ក្រមព្រហ្មទណ្ឌ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៦៤, ផ្នែក ១៤៤។ <u>**ប្រទេសអ៊ូហ្គាន់ដា៖**</u> ច្បាប់ក្រមព្រហ្មទណ្ឌ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥០, ផ្នែក ១២៦។ <u>**ប្រទេសនីហ្សេរីយ៉ា៖**</u> ច្បាប់ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩១៦, ផ្នែក ៣៦១។ <u>**ប្រទេសតង់ហ្គានី៖**</u> ក្រមព្រហ្មទណ្ឌ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៤៥, ផ្នែក ១៣៣។ <u>**ប្រទេសម៉ាឡាវី៖**</u> ក្រមព្រហ្មទណ្ឌ ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៣០, ផ្នែក ១៣៥។

[2301] <u>**ប្រទេសកូឡុំប៊ី៖**</u> ក្រមព្រហ្មទណ្ឌសាធារណរដ្ឋកូឡុំប៊ី ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៣៦ (ត្រឹមឆ្នាំ១៩៦៧) មាត្រា ៣៤៩។

[2302] <u>ប្រទេសប៉ាពួញូវហ្គីណេ៖</u> ច្បាប់ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៧៤ មាត្រា ៣៥០។

[2303] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១០៥-១១០៦, *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៤៤-៧៤៧ *យោងទៅ* សាលដីការឿងក្តី *Brima* កថាខណ្ឌ ១៨២, ១៨៦, ១៩២, ១៩៥-១៩៦, ២០០, សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៧៣៥-៧៣៦ ការបញ្ជាក់ពីបទចោទ *Ongwen* កថាខណ្ឌ ៨៨-៩១, ៩៣-៩៤។

[2304] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៤៦, ៧៤៩។ សូមមើល បន្ថែមទៀត ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨០, ៥៨៦។

[2305] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២៧, ៧៤០-៧៤៩, ៣៥៣៦-៣៦៩៤។

[2306] <u>មូលដ្ឋានទី ១៧១ និង ១៧២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការរំលោភ សេពសន្ថវៈដែលប្រព្រឹត្ត ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ចន្លោះពីឆ្នាំ១៩៧៥*

674. **មូលដ្ឋានទី ១៧១ និងទី១៧២ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបាន បង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ក្នុងការអះអាងថា ការប្រព្រឹត្តដែលអាច ចាត់ទុកថាជា ការរំលោភសេពសន្ថវៈ ដែលដែលប្រព្រឹត្តឡើងក្នុងបរិបទ នៃការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ បានគោរពទៅតាមគោលការណ៍នីត្យានុកូលភាព[2307]។**

675. មូលដ្ឋានទាំងនេះខុស ដោយសារតែអំពើដែលអាចចាត់ទុក ថាជាការរំលោភសេពសន្ថវៈ នៅក្នុង បរិបទណាក្តី គឺបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើសិទ្ធិមនុស្សជាមូលដ្ឋាន គឺជាការប្រមាថ មើលងាយទាំងស្រុង ទៅលើសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ការព្យាយាមរបស់ម្ចាស់ បណ្តឹងសាទុក្ខ ក្នុងការកំណត់ប្រភេទ "ការរំលោភសេពសន្ថវៈក្នុងនាមសហព័ទ្ធ" ថាជាករណី លើកឡើង ដែលមិនមានជាបទឧក្រិដ្ឋនេះ គឺបានមើលរំលងមិនត្រឹមតែ លក្ខណៈបន្ទាបបន្ថោតជា មូលដ្ឋាន នៃអំពើដែលបង្ខំបុគ្គលម្នាក់ ឬប្តីប្រពន្ធ ឱ្យរួមភេទ ដោយគ្មានការព្រមព្រៀងពីពួកគេ ប៉ុណ្ណោះទេ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍ ដែលម្ចាស់បណ្តឹងសាទុក្ខ ព្យាយាមធ្វើឱ្យស្របច្បាប់ សម្រាប់ការរំលោភសេពសន្ថវៈនោះ ក៏ជាការបង្ខំផងដែរ។

676. ជាថ្មីម្តងទៀត[2308] អង្គជំនុំជម្រះសាលាដំបូង មិនបានតម្រូវឱ្យសម្រេចថា (១) មានការហាមឃាត់ ជាក់ច្បាស់ចំពោះ "ការរំលោភសេពសន្ថវៈ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" នៅក្នុងច្បាប់អន្តរជាតិនៅត្រឹមឆ្នាំ ១៩៧៥ [2309] ឬ (២) "ធាតុផ្សំសំខាន់" សម្រាប់អំពើជាមូលដ្ឋាន នៃអំពើអមនុស្សធម៌ដទៃទៀត[2310]។ លក្ខខណ្ឌនេះគឺថាតើ អំពើបានរំលោភបំពាន ទៅលើ "សិទ្ធិជា សារវ័ន្ត និងមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា ទៅនឹងអំពើជាក់លាក់នៅក្នុង ឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ"[2311]។

---

*ដល់ឆ្នាំ១៩៧៩ និងកំហុសពាក់ព័ន្ធនឹងការពិនិត្យលើល័ក្ខខ័ណ្ឌតម្រូវនៃលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែល (ផ្នែកទី ១)* កថាខណ្ឌ ១២៨១-១៣០០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៩ (ភាសាអង់គ្លេស) ទំព័រ ៥៤ (ភាសាបារាំង) ទំព័រ ៨៤-៨៥ (ភាសាខ្មែរ)។

[2307] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៨១-១៣០០។

[2308] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៥, ៨៦, ៩៧, ៩៨។

[2309] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៨១-១២៨២, ១២៨៤-១២៨៥។

[2310] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៩១-១៣០០។

[2311] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨៦។ សូមមើល បន្ថែមទៀត ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៨, ៥៨០, ៥៨៤-៥៨៥។

677. មិនមានការចោទសួរថា ការរំលោភសេពសន្ថវៈ បានរំលោភបំពានទៅលើ "សិទ្ធិជាសារវ័ន្ត" របស់ជនរងគ្រោះ ដែលត្រូវបានការពារតាម ច្បាប់អន្តរជាតិ ឬថាវាមានសភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែលគ្នា ទៅនឹងអំពើជាក់លាក់នៅក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះដែរ។ ដូចដែលម្ចាស់បណ្ដឹងសាទុក្ខបានយល់ស្រប[2312] ការរំលោភសេពសន្ថវៈ ព្រមទាំងអំពើហិង្សាផ្លូវភេទដទៃទៀតត្រូវបានហាមឃាត់ដោយលិខិតុបករណ៍សិទ្ធិមនុស្ស ដែលនៅជាធរមាននៅមុន ឬនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងក្រម Lieber ឆ្នាំ១៨៦៣[2313] អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[2314] ពិធីសារបន្ថែម I និង II ឆ្នាំ១៩៧៧[2315]។ សាលក្រមឆ្នាំ១៩៤៨ របស់តុលាការ IMTFE បានផ្ដន្ទាទោសជនជាប់ចោទពីបទឧក្រិដ្ឋកម្មសង្គ្រាម ចំពោះការរំលោភសេពសន្ថវៈនៅ Nanking ដែលក្នុងពេលនោះកងទ័ពបានប្រព្រឹត្តការរំលោភសេពសន្ថវៈ យ៉ាងហោចណាស់ ២០០០០ ដង[2316]។

678. ការបង្ខំបុគ្គលឱ្យរួមភេទ ដោយគ្មានការយល់ព្រមពេញលេញ និងដោយសេរី ដែលផ្ទុយទៅនឹងសិទ្ធិមនុស្សជាមូលដ្ឋាន ក៏ត្រូវបានកំណត់នៅមុនឆ្នាំ១៩៧៥ ដែរ នៅក្នុងការហាមឃាត់អំពើពេស្យាកម្មដោយបង្ខំ នៅក្នុងអនុសញ្ញាឆ្នាំ១៩៥០ ស្ដីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការកេញប្រវ័ញ្ចលើពេស្យាកម្ម របស់បុគ្គលដទៃ[2317] និងអនុសញ្ញាទីក្រុងហ្សឺណែវ IV[2318]។ ការនេះត្រូវបានគាំទ្រដោយសារចែងបញ្ចូលទៅក្នុង លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការ SCSL [2319]។ តាមពិតទៅ អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្ដី *Kupreškić* បានបញ្ជាក់

---

[2312] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៨៤។

[2313] ក្រម Lieber មាត្រា ៤៤។

[2314] GC IV មាត្រា ២៧-២។

[2315] ពិធីសារបន្ថែម I មាត្រា ៧៦(១)។ ពិធីសារបន្ថែម II មាត្រា ៤(២)(ង) ("ដោយមិនធ្វើឱ្យប៉ះពាល់ដល់ភាពទូទៅនៃអ្វីដែលបានរៀបរាប់ខាងដើម អំពើខាងក្រោមនេះដែលប្រឆាំងនឹងបុគ្គលដូចមានបញ្ជាក់នៅក្នុងកថាខណ្ឌ I ត្រូវបាន និងនៅតែត្រូវបានហាមឃាត់ មិនថានៅពេលណា និង*នៅកន្លែងណា*នោះទេ [...] (ង) ការធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់បុគ្គល ជាពិសេសការប្រព្រឹត្តិបន្ទុះបង្អាប់ ឬថោកទាប ការរំលោភសេពសន្ថវៈ ពេស្យាចារដោយបង្ខំ និងរាល់ទម្រង់នៃការបៀតបៀនកេរ្តិ៍ខ្មាស់" (គូសបញ្ជាក់បន្ថែម))។

[2316] សាលក្រម IMTFE ទំព័រ ៤៩៤-៤៩៧, ៥៦៣-៥៦៤, ៥៧២-៥៧៣។

[2317] អនុសញ្ញាស្ដីពីការលុបចោលការជួញដូរមនុស្ស និងការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ, Lake Success, ញូវយ៉កថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៥០, 96 UNTS 271 (ចូលជាធរមានថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥១)។

[2318] GC IV មាត្រា ២៧-២។

[2319] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៧(១)(ធ)។ លក្ខន្តិកៈតុលាការ SCSL មាត្រា ២(ធ)។

ថា អំពើពេស្យាកម្មដោយបង្ខំគឺ "ប្រាកដណាស់ថាជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរ ទៅលើសេចក្តីថ្លៃថ្នូរបស់មនុស្ស អនុលោមតាមលិខិតុបករណ៍អន្តរជាតិ ស្តីពីសិទ្ធិមនុស្សភាគច្រើន"[2320]។

679. តាំងពីដើមឆ្នាំ១៩៤៥ ការរំលោភសេពសន្ថវៈ ត្រូវបានចែងនៅក្នុងអំពើជាក់លាក់នៅក្នុង ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០[2321] ហើយដែលបច្ចុប្បន្ននេះត្រូវក្លាយជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងរឹងមាំ នៅក្នុងលក្ខន្តិកៈនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងអស់[2322]។ អង្គជំនុំជម្រះនេះបានគាំទ្រអះអាងកន្លងមកហើយថា ការរំលោភសេពសន្ថវៈ អាចចាត់ទុកផងដែរថាជា ការធ្វើទារុណកម្ម ជាអំពើជាក់លាក់ដែលមានចែងក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងករណីដែលធាតុផ្សំការធ្វើទារុណកម្មត្រូវបានបង្ហាញ[2323]។

680. ផ្ទុយពីការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខ[2324] សភាពធ្ងន់ធ្ងរនៃអំពើមិនថមថយឡើយ តាមរយៈការពិតដែលថា ការរួមភេទដោយគ្មានការព្រមព្រៀងនេះ បានកើតឡើងនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ និងជាពិសេសបំផុតនោះ គឺការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អំពើនេះមិនខុសពីការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូ និងកិត្តិយសបុគ្គលរបស់ជនរងគ្រោះឡើយ។ តាមពិតទៅអង្គជំនុំជម្រះតុលាការកំពូល[2325] ដូចគ្នានឹងអង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ ICTY[2326] បានកត់សម្គាល់ថា អំពើជាក់លាក់មួយចំនួន រួមទាំងការរំលោភសេពសន្ថវៈ ត្រូវបានចាត់ទុកដោយសារលក្ខណៈនៃអំពើនោះថា បង្កនូវការឈឺចាប់និងព្យសនកម្មធ្ងន់ធ្ងរ។ ម្ចាស់បណ្តឹងសាទុក្ខយោងទៅរក សាលក្រមរបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស នៅក្នុងរឿងក្តី *S.W. តទល់នឹង*

---

[2320] សាលក្រមរឿងក្តី *Kupreškić* កថាខណ្ឌ ៥៦៦។

[2321] CCL លេខ ១០ មាត្រា II(១)(គ)។

[2322] **<u>តុលាការ ICTY</u>**៖ លក្ខន្តិកៈតុលាការ ICTY មាត្រា ៥(ឆ)។ សាលដីកាឿងក្តី *Kunarac* កថាខណ្ឌ ១៧៩។ **<u>តុលាការ ICTR</u>**៖ លក្ខន្តិកៈតុលាការ ICTR មាត្រា ៣(ឆ)។ *សាលក្រមរឿងក្តី* *Akayesu* កថាខណ្ឌ ៥៩៦។ **<u>តុលាការ SCSL</u>**៖ លក្ខន្តិកៈតុលាការ SCSL មាត្រា ២(ឆ)។ សាលក្រមរឿងក្តី *Sesay* កថាខណ្ឌ ១៤៤។ **<u>តុលាការ ICC</u>**៖ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៧(១)(ឆ)។

[2323] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២០៧-២០៨, ២១១។ សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្តី ឌុច* កថាខណ្ឌ ៣៥៥, ៣៦៦។ *សាលក្រមរឿងក្តី Akayesu* កថាខណ្ឌ ៦៨៧។

[2324] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៨២, ១២៨៤, ១២៨៨, ១២៩១-១៣០០។

[2325] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២០៧ *តម្កល់* សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្តី ឌុច* កថាខណ្ឌ ៣៥៥។

[2326] សាលដីការឿងក្តី *Kunarac* កថាខណ្ឌ ១៥០។ សូមមើលផងដែរ *សាលក្រមរឿងក្តី* *Furundžija* កថាខណ្ឌ ១៨៣។

*ចក្រភពអង់គ្លេស*[2327] ប៉ុន្តែគាត់មើលរំលងភាពច្បាស់លាស់ ដែលតុលាការបានបង្ហាញនូវសេចក្តីស្អប់ខ្ពើមយ៉ាងខ្លាំងរបស់ខ្លួន ចំពោះបញ្ហានិទណ្ឌភាព សម្រាប់ការរំលោភសេពសន្ថវៈ ក្នុងអាពាហ៍ពិពាហ៍ ហើយបានអះអាងពីភាពអាចប្រមើលដឹងថា មានការផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះការរំលោភសេពសន្ថវៈលើសហព័ទ្ធ បើទោះបីជាមិនមានការហាមឃាត់ជាក់ច្បាស់ក្តី៖

> លក្ខណៈបន្ទាបបន្ថោកយ៉ាងសំខាន់ នៃការរំលោភសេពសន្ថវៈ គឺបង្ហាញយ៉ាងជាក់ច្បាស់ដែលលទ្ធផល [...] គឺថាអ្នកដាក់ពាក្យសុំ អាចត្រូវបានផ្តន្ទាទោសពីបទ ការប៉ុនប៉ងរំលោភសេពសន្ថវៈ ដោយមិនគិតអំពីទំនាក់ទំនង រវាងគាត់ជាមួយជនរងគ្រោះ មិនអាចនិយាយបានថា ដោយអញ្ញត្រកម្មនៅក្នុងកម្មវត្ថុ និងគោលបំណងនៃមាត្រា ៧ របស់អនុសញ្ញា គឺធានាថាមិនមាននរណាម្នាក់ គួរត្រូវស្ថិតក្រោមការជំនុំជម្រះ ការផ្តន្ទាទោស ឬការដាក់ទណ្ឌកម្ម តាមអំពើចិត្ត [...]។ លើសពីនេះទៀត ការបោះបង់ចោលនូវគំនិតដែលមិនអាចទទួលយកបាន ដែលថាប្តីមាននិទណ្ឌភាពពីការចោទប្រកាន់ លើការរំលោភប្រពន្ធគាត់ គឺស្របគ្នាមិនត្រឹមតែជាមួយ ទស្សនៈបែបអរិយធម៌នៃអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងគេនោះគឺស្របតាម គោលដៅជាសារវ័ន្តនៃអនុសញ្ញាដែលធាតុផ្សំសំខាន់បំផុតគឺ ការគោរពសេចក្តីថ្លៃថ្នូរបស់មនុស្ស និងសេរីភាពរបស់មនុស្ស[2328]។

681. ទោះក្នុងករណីណាក្តី ម្ចាស់បណ្តឹងសាទុក្ខមានកំហុសឆ្គង ក្នុងការចាត់ទុក "ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ដូចគ្នានិង "ការរំលោភសេពសន្ថវៈសហព័ទ្ធ"។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហេតុផលតែមួយគត់ដែលជនរងគ្រោះ ស្ថិតក្នុងចំណងទាក់ទងសហព័ទ្ធ គឺដោយសារតែពួកគេគឺជា ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ តាមពិតទៅគោលដៅស្ពាពរនៃ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺដើម្បីបង្កើតចំនួនប្រជាជន របស់កម្ពុជាប្រជាធិបតេយ្យ[2329]។ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មិនអនុញ្ញាតឱ្យចារី ក្លាយជាម្ចាស់នៃនិទណ្ឌភាពផ្ទាល់ខ្លួនពួកគេឡើយ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច "ជាគោល

---

[2327] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៩៩ *ដកស្រង់រឿងក្តី S.W. តទល់នឹងចក្រភពអង់គ្លេស។*

[2328] រឿងក្តី *S.W. តទល់នឹងចក្រភពអង់គ្លេស* កថាខណ្ឌ ៤៤។

[2329] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៦។

ការណ៍ទូទៅមួយដែលថាចារីមិនអាចផ្អែកទៅលើស្ថានភាពនានា ដែលបានកើតឡើងដោយសារតែអំពើខុសច្បាប់ផ្ទាល់ខ្លួន នៅក្នុងការផ្តល់យុត្តិកម្មចំពោះអំពើជាក់លាក់នោះឡើយ”[2330]។

682. បញ្ហានេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្ររបស់តុលាការ អ.វ.ត.ក តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការ SCSL។ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ គឺ*នៅក្នុងការយោងលើការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* អង្គបុរេជំនុំជម្រះបានរៀបរាប់ អំពីរំលោភសេពសន្ថវៈនេះថា “ជាអំពើគួរឱ្យស្អប់ខ្ពើម និងធ្វើឱ្យរន្ធត់ជាខ្លាំងដល់មនុស្សគ្រប់រូប” និងជា “ការរំលោភធ្ងន់ធ្ងរ ដល់បូរណភាពរាងកាយជនរងគ្រោះ”[2331]។ អង្គបុរេជំនុំជម្រះបានបន្តគាំទ្រការពិតដែល សហចៅក្រមស៊ើបអង្កេត បានកំណត់ប្រភេទថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការរំលោភសេពសន្ថវៈ ដែលអាចកំណត់ប្រភេទបន្ថែមទៀតផងដែរថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ដទៃទៀត[2332]។ អង្គបុរេជំនុំជម្រះ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏បានពិចារណាការរួមភេទដោយបង្ខំ នៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាការរំលោភសេពសន្ថវៈដែរ[2333]។ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ SCSL បានកំណត់ប្រភេទការរំលោភផ្លូវភេទ ថាជាឧក្រិដ្ឋកម្មសង្គ្រាមនៃអំពើសាហាវយង់ឃ្នង ទៅលើសេចក្តីថ្លៃថ្នូផ្ទាល់ខ្លួន[2334] និងជាអំពើអមនុស្សធម៌ដទៃទៀត នៃទាសភាពផ្លូវភេទ[2335]។

---

[2330] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០១ ជើងទំព័រ ២០៧៥។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៥០ (មិនត្រូវបានរំខានលើបណ្តឹងឧទ្ធរណ៍។ សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៤៥)។ *សាលដីការឿងក្តី Stakić* កថាខណ្ឌ ២៨៧។

[2331] ឯកសារ **D427/2/15** & **D427/3/15** សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥០។

[2332] **ឯកសារ D427/1/30** សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧២។ ឯកសារ **D427/2/15** & **D427/3/15** សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤។ សូមមើល បន្ថែមទៀត សំណុំរឿង ០០៤/១-**ឯកសារ D308/3** IC ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៥៩។

[2333] ការបញ្ជាក់ពីបទចោទ *Ongwen* កថាខណ្ឌ ១១១-១១២, ១១៤-១១៥, ១៣៦-១៣៩។ នៅកថាខណ្ឌ ១៣៧ (“[ស្ត្រី និងកុមារី] ត្រូវបានបញ្ជូនឱ្យទៅធ្វើជា “ភរិយា” របស់យុទ្ធជន LRA ដោយពួកគេគ្មានសិទ្ធិជ្រើសរើស និងត្រូវបានរំលោភសេពសន្ថវៈជាប្រចាំដោយ “ស្វាមី” របស់ពួកគេ នៅក្នុងរយៈពេលវែង”)។

[2334] *សាលដីការឿងក្តី Brima* កថាខណ្ឌ ១៨១-២០២។

[2335] សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៧៣៦-៧៤០។ សូមមើល ជាពិសេស កថាខណ្ឌ ៧៣៦ (ដោយទើបតែរកឃើញថា ស្ត្រីជាជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះបន្តថា៖ ““ដោយសារតែបរិស្ថានហិង្សា ប្រទូស្តរាយ និង

683. ជាចុងក្រោយ ដូចដែលម្ចាស់បណ្តឹងសាទុក្ខបានយល់ស្រប មានការទទួលស្គាល់ជាសាកលថា ការរៀបអាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយគ្មានការព្រមព្រៀង គឺមោឃៈ ឬអាចធ្វើមោឃភាពបាន ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខមានកំហុសនៅក្នុងការជំទាស់របស់គាត់ថា ការវិវឌ្ឍន៍នេះបានកើតមានតាំងពីឆ្នាំ១៩៧៥[2336]។ សហព្រះរាជអាជ្ញាសូមលើកឡើងថា ដោយទទួលស្គាល់នូវព្យសនកម្មជាមូលដ្ឋាន ចំពោះសេចក្តីថ្លៃថ្នូរបស់មនុស្ស ដែលបណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ ដោយមិនស្ម័គ្រចិត្ត គឺជាគោលការណ៍ទូទៅនៃច្បាប់នៅឆ្នាំ១៩៧៥ដែលថា ការរៀបអាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយគ្មានការយល់ព្រម ឬតាមរយៈការបង្ខំ គឺមោឃៈ ឬអាចធ្វើមោឃភាពបាន។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺផ្ទុយទៅនឹងគោលការណ៍ជាសាកល ដែលទទួលស្គាល់ទាំងប្រព័ន្ធច្បាប់ស៊ីវិលនិងច្បាប់ Common Law ព្រមទាំងច្បាប់ព្រះវិហាកាតូលិក[2337] និងច្បាប់អ៊ីស្លាម[2338] ហើយអាចឃើញមាននៅក្នុងច្បាប់ស៊ីវិល នៅទូទាំងទ្វីបអាស៊ី[2339] ទ្វីបអាហ្វ្រិក[2340] ទ្វីបអឺរ៉ុប[2341]

---

បង្ខិតបង្ខំដែលស្ត្រីទាំងនេះស្ថិតនៅ [...] ទំនាក់ទំនងផ្លូវភេទជាមួយពួកឧទ្ទាម ទោះក្នុងកាលៈទេសៈណាក៏ដោយ [...] មិនអាចជា និងមិនមែនជាការយល់ព្រមទេ ដោយសារតែភាពមិនប្រាកដប្រជា និងភាពស្ថិតនៅក្រោមអំណាចដែលពួកគេរស់នៅក្នុងការបង្ខាំងខ្លួន"។ ការបង្ខាំងខ្លួននេះនឹងធ្វើឱ្យប៉ះពាល់ដល់ការយល់ព្រមនៅក្នុងកាលៈទេសៈដែលគេកំពុងពិចារណា")។

2336 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៣៨។

2337 ក្រមច្បាប់ Canon ឆ្នាំ១៩១៧ មាត្រា ១០៨៧ (បកប្រែក្រៅផ្លូវការ៖ "ការរៀបអាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយការបង្ខំ ឬរងការភ័យខ្លាចពីខាងក្រៅ និងដោយអយុត្តិធម៌ ត្រូវបានចាត់ទុកជាមោឃៈ នៅពេលដែលបុគ្គលម្នាក់ត្រូវបានបង្ខំឱ្យជ្រើសរើសយកការរៀបអាពាហ៍ពិពាហ៍ដើម្បីឱ្យគេចផុតវា")។

2338 The Holy Qur'an, ឃ្លា ៤:២០៖ ("មិនស្របច្បាប់ទេដែលអ្នកឱ្យស្ត្រីស្នងមរតកផ្ទុយនឹងឆន្ទៈរបស់គេ")។ ប្រទេសមួយចំនួនចែងយ៉ាងជាក់ច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញថា Sharia ជាប្រភពគោលការណ៍នៃច្បាប់។ សូមមើលឧទាហរណ៍ រដ្ឋធម្មនុញ្ញសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប ឆ្នាំ១៩៧១ មាត្រា ២។ រដ្ឋធម្មនុញ្ញសាធារណរដ្ឋអារ៉ាប់ស៊ីរី ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧១ មាត្រា ៧។

2339 **__ប្រទេសថៃ៖__** ក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណី ឆ្នាំ១៩៣៤, ផ្នែក ១៤៤៥(៤), ១៤៩១។ **__ប្រទេសឥណ្ឌា៖__** ច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍ហិណ្ឌូ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៥៥, ផ្នែក ១២(១)(គ)។ ច្បាប់ស្តីពីការរៀបពាហ៍ពិពាហ៍ពិសេស ឆ្នាំ១៩៥៤, ផ្នែក **២៥**(iii)។ ការរៀបអាពាហ៍ពិពាហ៍ជនជាតិចាមត្រូវបានគ្រប់គ្រងដោយច្បាប់ Sharia ដែលចាត់ទុកការរៀបអាពាហ៍ពិពាហ៍ក្រោមការបង្ខិតបង្ខំជាមោឃៈ។ **__ប្រទេសអ៊ីរ៉ាក់៖__** ច្បាប់ស្តីពីស្ថានភាពផ្ទាល់ខ្លួន ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៩ មាត្រា ៦។

2340 **__ប្រទេសទុយនេស៊ី៖__** ក្រមស្តីពីស្ថានភាពផ្ទាល់ខ្លួន ឆ្នាំ១៩៥៦ មាត្រា ៣, ៩។ **__ប្រទេសនីហ្សេរីយ៉ា៖__** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍, ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧០, ផ្នែក ៣(១)(ឃ)(i)។ **__ប្រទេសតង់ហ្សានី៖__** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ ឆ្នាំ១៩៧១, ផ្នែក៣៨(១)(ង)។ **__ប្រទេសកេនយ៉ា៖__** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍, ថ្ងៃទី១ ខែមករា ឆ្នាំ១៩៤១, ផ្នែក ១៤ (បទប្បញ្ញត្តិបន្ថែមនៅឆ្នាំ១៩៥២)។

2341 **__ប្រទេសបារាំង__**៖ ក្រមរដ្ឋប្បវេណីបារាំង មាត្រា ១៤៦ (តាំងពីថ្ងៃទី២៧ ខែមីនា ឆ្នាំ១៨០៣)។ **__ប្រទេសប៊ែលហ្ស៊ិក៖__** ក្រមរដ្ឋប្បវេណីប៊ែលហ្ស៊ិក មាត្រា ១៤៦ (តាំងពីថ្ងៃទី២១ ខែមីនា ឆ្នាំ១៨០៤)។ **__ប្រទេសអាល្លឺម៉ង់ និងអូទ្រីស៖__** ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងការលែងលះ ថ្ងៃទី**១ ខែសីហា ឆ្នាំ១៩៣៨ មាត្រា ៣៩**(១) (បកប្រែក្រៅផ្លូវការ)៖ (ប្តី-ប្រពន្ធអាចស្នើសុំ

ទ្វីបអាមេរិក[2342] និងទ្វីបអូសេអានី[2343]។ ហេតុដូច្នេះ គឺអាចប្រមើលមើលដឹងថា ប្រភេទនៃការរៀបអាពាហ៍ពិពាហ៍ ដែលបានអនុវត្តនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចចាត់ទុកថាជាការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ។ ក្នុងន័យនេះ ម្ចាស់បណ្ដឹងសាទុក្ខក៏មានកំហុសផងដែរ ក្នុងការអះអាងរបស់គាត់ដែលថា ច្បាប់ជាតិកម្ពុជានៅមុនឆ្នាំ១៩៧៥ មិនតម្រូវឱ្យមានការយល់ព្រម ពីអនាគតស្វាមីភរិយាឡើយ[2344]។ ម្ចាស់បណ្ដឹងសាទុក្ខមើលរំលង[2345] ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ដែលត្រូវបានជំនួស នៅមុនរបបខ្មែរក្រហម ហើយក្រមនេះនៅជាធរមាន យ៉ាងហោចណាស់ចន្លោះពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ១៩៧០ ហើយចែងនៅត្រង់មាត្រា ១១៤ ថា "ការរៀបអាពាហ៍ពិពាហ៍ គឺជាការសន្យាជាឱឡារិក ដោយបុរស និងនារី ដែលយល់ព្រមរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ"[2346]។

## *មូលដ្ឋានទី ១៦២៖ គ្មានការព្រមព្រៀង នៅក្នុងច្បាប់ជាតិ*[2347]

684. **មូលដ្ឋានទី ១៦២ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុណាមួយ នៃការសម្រេចថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុង**

---

បញ្ចប់ចំណងអាពាហ៍ពិពាហ៍ ប្រសិនបើខ្លួនត្រូវបានបង្ខំឱ្យយល់ព្រមរៀបអាពាហ៍ពិពាហ៍ដោយការគំរាម")។ **<u>ប្រទេសអង់គ្លេស និងវែលស៍៖</u>** ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៣, ផ្នែក ១២(១)(គ)។ **<u>ប្រទេសអេស្ប៉ាញ៖</u>** ក្រមរដ្ឋប្បវេណី ឆ្នាំ១៨៨៩ មាត្រា ១០១។ **<u>សាធារណរដ្ឋសង្គមនិយមសហព័ន្ធសូវៀតរុស្ស៊ី៖</u>** ច្បាប់សាធារណរដ្ឋសង្គមនិយមសហព័ន្ធសូវៀតរុស្ស៊ីស្ដីពីការអនុម័តក្រមសាធារណរដ្ឋសង្គមនិយមសហព័ន្ធសូវៀតរុស្ស៊ីស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៦៩ មាត្រា ១៥, ៤៣។

[2342] **<u>ប្រទេសប្រេស៊ីល</u>** ៖ ក្រមរដ្ឋប្បវេណីសហរដ្ឋប្រេស៊ីល ថ្ងៃទី១ ខែមករា ឆ្នាំ១៩១៦ មាត្រា ១៨៣, ២០៩។ **<u>ប្រទេសម៉ិចស៊ិក៖</u>** ក្រមរដ្ឋប្បវេណីសហព័ន្ធ ឆ្នាំ១៩២៨ មាត្រា ២៤៥។ **<u>ប្រទេសឈីលី៖</u>** ច្បាប់អាពាហ៍ពិពាហ៍រដ្ឋប្បវេណី ថ្ងៃទី១០ ខែមករា ឆ្នាំ១៨៨៤ មាត្រា ៣២-៣៣។ **<u>ប្រទេសប៉េរូ៖</u>** ក្រមរដ្ឋប្បវេណី ឆ្នាំ១៩៣៦ មាត្រា ១៤៨។ **<u>ប្រទេសកូស្ដារីកា៖</u>** ក្រមស្ដីពីគ្រួសារ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៤ មាត្រា ១៥(១)។ **<u>ប្រទេសគុយបា៖</u>** ក្រមស្ដីពីគ្រួសារ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៥ មាត្រា ៤៥(២)។

[2343] **<u>ប្រទេសអូស្ត្រាលី៖</u>** ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៥៩, ផ្នែក ១៨(ឃ)(i)។

[2344] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១១៣ *ដកស្រង់* ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០។

[2345] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១១៣។

[2346] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩៥៣-១៩៧០ មាត្រា ១១៤។ សូមមើលផងដែរ ច្បាប់ស្ដីពីគ្រួសារ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ មាត្រា ៤ ("បុរស និងនារីដែលមានអាយុពេញលក្ខណៈច្បាប់មានសិទ្ធិពេញលេញក្នុងការសម្រេចអាពាហ៍ពិពាហ៍។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ")។

[2347] <u>មូលដ្ឋានទី ១៦២</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានការព្រមព្រៀង នៅក្នុងច្បាប់ជាតិ* កថាខណ្ឌ ១១១៩-១១៣០, ១១៥០-១១៥៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៥៦ (ភាសាអង់គ្លេស) ទំព័រ ៥១-៥២ (ភាសាបារាំង) ទំព័រ ៨០ (ភាសាខ្មែរ)។

**វប្បធម៌កម្ពុជា នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ គឺផ្អែកលើការទុកចិត្តគ្នារវាងឪពុកម្ដាយ និងកូន ហើយម្ចាស់បណ្ដឹងសាទុក្ខ ក៏មិនបានបង្ហាញថា ការណ៍នេះនាំទៅដល់កំហុសឆ្គងជាផលវិបាក ក្នុងការបង្ហាញថាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាអំពើអមនុស្សធម៌ផ្សេងទៀត ដោយសារតែអំពើនេះមិនបានឈានដល់កម្រិតធ្ងន់ធ្ងរដូចគ្នានឹងអំពើជាក់លាក់នានានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។**

685. ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញ អំពីកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុ តាមរយៈការដែលអង្គជំនុំជម្រះសាលាដំបូង បានយោងទៅលើសញ្ញាណ នៃសង្គមសាស្ត្រ-មនុស្សសាស្ត្រ ដែលថាការរៀបអាពាហ៍ពិពាហ៍នៅមុន របបកម្ពុជាប្រជាធិបតេយ្យ គឺផ្អែកលើ "ជំនឿទុកចិត្តគ្នាទៅវិញទៅមក រវាងឪពុកម្ដាយ និងកូន" មិនមែនផ្អែកលើក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ទេ[2348]។ ម្ចាស់បណ្ដឹងសាទុក្ខ ក៏មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មិនបានពិចារណាលើផលប៉ះពាល់នៃសម្ពាធលើការយល់ព្រម នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ដែលបណ្ដាលឱ្យមានការមិនគិតពិចារណា ដោយលម្អៀង ទៅលើភ័ស្តុតាងដោះបន្ទុក ពាក់ព័ន្ធការវាយតម្លៃលើភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្ម[2349]។ ការព្យាយាមក្នុងការរួមបញ្ចូល ការប្រតិបត្តិការរៀបអាពាហ៍ពិពាហ៍ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការមិនគិតអំពីកាលៈទេសៈបង្ខិតបង្ខំយ៉ាងច្បាស់ក្រឡែត ដែលបង្ហាញចេញនៅពេលដែល បក្សកុម្មុយនីស្តកម្ពុជានៅកាន់អំណាចនោះ។ ការបដិសេធការរៀបការ ដែលស្នើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា អាចបណ្ដាលឱ្យមានការគម្រាមកំហែង ដោយអំពើហឹង្សា ត្រូវទទួលរងការចោទប្រកាន់ ប្រកបដោយគ្រោះថ្នាក់

[2348] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១១៩-១១២១ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៨។ ម្ចាស់បណ្ដឹងសាទុក្ខអះអាងថា ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ តម្រូវឱ្យមានការយល់ព្រមរបស់ឪពុកម្ដាយ ដើម្បីរៀបចំពិធីអាពាហ៍ពិពាហ៍ដែលមានសុពលភាពស្របច្បាប់ ដែលនេះជាការដាក់កំហិតលើអនាគតប្ដីប្រពន្ធដែលធ្វើឱ្យ "គេពិបាកជឿ" ថា ពួកគេអាចមានសិទ្ធិសេរីភាពបដិសេធការរៀបអាពាហ៍ពិពាហ៍ដែលបានស្នើឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមមើល ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១២២-១១២៣ *ដកស្រង់* កថាខណ្ឌ ១១១៣-១១១៤ ដែលដកស្រង់ក្រមរដ្ឋប្បវេណីកម្ពុជា (ឆ្នាំ១៩២០) មាត្រា ១២៥ ("អនីតិជនអាចនឹងរៀបអាពាហ៍ពិពាហ៍បានលុះត្រាណាតែឪពុកម្ដាយអនុញ្ញាតយល់ព្រមផង"), មាត្រា ១៣៣ ("ប្រុស និងស្រី ជានីតិជន ហើយចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នានោះ ក៏ត្រូវឱ្យបានអនុញ្ញាតពីបុព្វញាតិទាំងឡាយនោះ ដូចអនីតិជនដែរ")។ *កត់សម្គាល់ថា* ម្ចាស់បណ្ដឹងសាទុក្ខមិនចាប់អារម្មណ៍ថា ក្រមរដ្ឋប្បវេណីឆ្នាំ១០៩២០ ត្រូវបានជំនួសមុនរបបខ្មែរក្រហម ហើយក្រមរដ្ឋប្បវេណីជាធរមាន ចន្លោះពីឆ្នាំ ១៩៥៣ ដល់និងឆ្នាំ១៩៧០ ចែងនៅមាត្រា ១១៤ ថា "ដែលហៅថាអាពាហ៍ពិពាំហ៍គឺជាកិច្ចសន្យាយ៉ាងឧឡារិកមួយដែលប្រុសម្នាក់ និងស្ត្រីម្នាក់ប្ដេជ្ញាគ្នាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នា")។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧១ និង ១៧២។

[2349] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១២៤-១១៣០, ១១៥៤។

ជាច្រើន ត្រូវបញ្ជូន ទៅរៀនសូត្រ ត្រូវផ្លាស់ទីទៅទីកន្លែងផ្សេង ឬត្រូវសម្លាប់[2350]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ដោយត្រឹមត្រូវថា "វាពិតជាពិបាកក្នុងការមើលឃើញថា វិធានការបដិវត្តទាំងអស់នោះ អាចប្រដូចទៅនឹងឥរិយាបទ របស់ឪពុកម្ដាយចំពោះកូនៗ"[2351]។ បន្ថែមលើនេះមិនមានភ័ស្តុតាងដែលថា ការយល់ព្រមដែលត្រូវផ្ដល់ដោយស្របច្បាប់ដោយ "ប្រព័ន្ធគ្រួសារដែលមានការយកចិត្តទុកដាក់ និងដំណើរការត្រឹមត្រូវនោះ ត្រូវបានប្រគល់ដោយស្ម័គ្រចិត្តទៅឱ្យបក្ស(អង្គការ) នោះឡើយ"[2352]។ តាមពិតទៅកាលៈទេសៈប្រហាក់ប្រហែលគ្នានឹងកាលៈទេសៈនៅរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានកំណត់ប្រភេទ នៅក្នុងរឿងក្ដីផ្សេងទៀតថាជា "ការបង្ខិតបង្ខំជាទូទៅ" ដែលធ្វើឱ្យគ្មានការយល់ព្រមពិតប្រាកដ[2353]។ ដោយសារតែភាពខុសគ្នាខ្លាំង នៃការរៀបចំការរៀបអាពាហ៍ពិពាហ៍ ទាំងនេះហើយ ទើបអង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយត្រឹមត្រូវថា សម្ពាធនៅក្នុងការរៀបអាពាហ៍ពិពាហ៍ បែបប្រពៃណី នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ គឺមិនពាក់ព័ន្ធជាមួយបញ្ហានៃការយល់ព្រម *នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ*[2354]។ ម្ចាស់បណ្ដឹងសាទុក្ខមិនបានប្រឆាំង ចំពោះសច្ចធារណ៍ដ៏ខ្លាំងក្លា នៃភាពមិនលម្អៀង

[2350] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៨។ សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២០-៣៦២២, ៣៦២៤-៣៦២៥ និងការដកស្រង់ទាំងអស់ដែលមានក្នុងកថាខណ្ឌទាំងនេះ។ អ.ជ.ស.ដ បានស្ដាប់ភ័ស្តុតាងរបស់បុគ្គលពីរនាក់ប៉ុណ្ណោះ ដែលបានបដិសេធមិនរៀបការ ដោយគ្មានបញ្ហាគ្រោះថ្នាក់អ្វីឡើយ ដោយសន្និដ្ឋានថា ស្ថានភាពទាំងនេះជាករណីលើកលែង និងអាចថាដោយសារកាលៈទេសៈជាក់លាក់នោះ។ ភ័ស្តុតាងភាគច្រើនលើសលប់បង្ហាញថា ពួកគេមិនអាចបដិសេធការរៀបការដោយមិនទទួលរងបញ្ហានោះឡើយ។

[2351] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៩។

[2352] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៨។

[2353] សាលដីការឿងក្ដី *Kunarac* កថាខណ្ឌ ១៣០-១៣២ (កាលៈទេសៈដែលមានប្រៀបនៅក្នុងរឿងក្ដីភាគច្រើនដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្ទើរតែមានលក្ខណៈបង្ខិតបង្ខំជាសកល។ មានន័យថាមិនអាចមានការព្រមព្រៀងពិតប្រាកដទេ)។ ទាក់ទងនឹងរឿងក្ដីអាពាហ៍ពិពាហ៍ដោយបង្ខំជាពិសេស សូមមើល ឧទាហរណ៍ សាលក្រមរឿងក្ដី *Sesay* កថាខណ្ឌ ១៤៦៨-១៤៧០ (ស្ត្រីជាច្រើននាក់ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយការគំរាមកំហែង បំភិតបំភ័យ បោកបញ្ឆោត និងតាមរយៈទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំដែលផ្អែកលើការភ័យខ្លាច និងស្ថានភាពអស់សង្ឃឹមរបស់ជនរងគ្រោះ)។ សាលក្រមរឿងក្ដី *Brima* កថាខណ្ឌ ៧១២ ("គ្មានការព្រមព្រៀងណាអាចត្រូវបានទាញចេញដោយសារតែបរិស្ថាននៃហិង្សា និងការបង្ខិតបង្ខំ")។

[2354] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៨ (គូសបញ្ជាក់បន្ថែម)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១២៣-១១២៤។ ជាលទ្ធផលនៃបរិបទផ្ទុយគ្នាខ្លាំងទាំងនេះ អ.ជ.ស.ដ មិនមាន "កាតព្វកិច្ច" ត្រូវកំណត់និយមន័យនៃការបង្ខិតបង្ខំ ដោយសារវាពាក់ព័ន្ធនឹងរយៈពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ "ដើម្បីឱ្យយល់បរិបទនៃបទល្មើសដែលបានចោទប្រកាន់"។ លើសពីនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មិនបានពិចារណាលើភ័ស្តុតាងរបស់ Kasumi Nakagawa ស្ដីពីសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចរបស់ស្ត្រីទេ ប៉ុន្តែ ដោយសារតែប្រការនេះពាក់ព័ន្ធនឹង

របស់តុលាការ ដើម្បីបង្ហាញពីភាពលម្អៀងជាក់ស្តែងឡើយ[2355]។ ហេតុដូច្នេះម្ចាស់បណ្តឹងសាទុក្ខ មិនអាចផ្តល់ភ័ស្តុតាងគាំទ្រ ដល់កំហុសឆ្គងណាមួយបានឡើយ។

686. អាស្រ័យហេតុនេះ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើស្ថានទម្ងន់ គួរត្រូវបានធ្វើមោឃភាព ដោយសារតែការអនុវត្ត នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ[2356]។ ទឡ្ហីករណ៍អង្គហេតុដែលនៅសេសសល់ របស់ម្ចាស់បណ្តឹងសាទុក្ខ នឹងត្រូវពិភាក្សានៅផ្នែកផ្សេងៗ នៃចម្លើយតប គឺត្រង់ផ្នែកដែលគាត់ បានលើកជាពិសេសនូវការអះអាងទាំងនេះ[2357]។

## *មូលដ្ឋានទី ១៦៥៖ កំហុសពាក់ព័ន្ធនឹងខ្លឹមសារ បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*[2358]

687. **មូលដ្ឋានទី ១៦៥ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ដោយសារមិនបានសន្និដ្ឋានថា ការយល់ព្រមរៀបអាពាហ៍ពិពាហ៍ គឺជាគោលការណ៍សំខាន់ នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។**

688. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូង បានបកស្រាយដោយមិនត្រឹមត្រូវ ហើយលាក់បាំងភ័ស្តុតាង ឯកសារនាសម័យកាលនោះ ដែលអះអាងបញ្ជាក់ថា ការយល់ព្រមគឺជាផ្នែកមួយ នៃគោលការណ៍រៀបអាពាហ៍ពិពាហ៍ របស់បក្សកុម្មុយនីស្តកម្ពុជា[2359]នោះ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាទៅលើគោលនយោបាយ របស់បក្ស

---

ការអនុវត្តការរៀបអាពាហ៍ពិពាហ៍នៅសម័យមុនរបបកម្ពុជាប្រជាធិបតេយ្យ វាមិនមានភាពពាក់ព័ន្ធជាមួយនឹងបញ្ហាការព្រមព្រៀងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទេ។ សូមមើល ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦៨ ដែលបង្ហាញថា អ.ជ.ស.ដ បានពិចារណាលើភ័ស្តុតាងមុនរបបកម្ពុជាប្រជាធិបតេយ្យរបស់គាត់។

[2355] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤ ទាក់ទងនឹង បន្ទុកភ័ស្តុតាងរបស់ម្ចាស់បណ្តឹងសាទុក្ខដើម្បីបង្ហាញពីភាពលម្អៀងពិតប្រាកដ។

[2356] *ផ្ទុយពី* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១២៦, ១១៥៤។

[2357] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥ (ទាក់ទងនឹង អត្ថិភាពនៃគោលនយោបាយនៃការព្រមព្រៀងរបស់ ប.ក.ក និងភាពជាតំណាងនៅថ្នាក់ជាតិនៃភ័ស្តុតាង)។

[2358] <u>មូលដ្ឋានទី ១៦៥</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងខ្លឹមសារបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* កថាខណ្ឌ ១១៩១-១២១៥។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៧ (ភាសាអង់គ្លេស) ទំព័រ ៥២ (ភាសាបារាំង) ទំព័រ ៨១-៨២ (ភាសាខ្មែរ)។

[2359] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៩៣, ១២១២។

កុម្មុយនីស្តកម្ពុជា ស្តីពីការយល់ព្រម ដូចមានបង្ហាញនៅក្នុង សីលធម៌១២ប្រការ[2360] និងបាន ត្រួតពិនិត្យលើសក្ខីកម្ម ដែលបានរៀបរាប់អំពីករណី ដែលបុគ្គលអាចជ្រើសរើសដៃគូររបស់ខ្លួន បាន[2361]។ ទោះបីជាភ័ស្តុតាងនេះពិតជាបង្ហាញថា ការយល់ព្រមគឺគោលការណ៍មួយ នៃគោល ការណ៍រៀបអាពាហ៍ពិពាហ៍ក្តី តែនៅចំពោះមុខខ្លួន អង្គជំនុំជម្រះសាលាដំបូង មានភ័ស្តុតាងយ៉ាង ច្រើនដែលបង្ហាញថា ក្នុងការអនុវត្ត ការគោរពតាមការណែនាំរបស់អង្គការ ទទួលបានអាទិភាព លើសការជ្រើសរើសផ្ទាល់ខ្លួន[2362]។ ការវាយតម្លៃយ៉ាងលម្អិត ទៅលើការផ្សំផ្គុំទាំងអស់ គឺជា តួនាទីរបស់អង្គការ ហើយសេចក្តីសម្រេចរបស់អង្គការ ត្រូវតែគោរពតាម[2363]។ ជាលទ្ធផល មិនមែនរាល់ការរៀបអាពាហ៍ពិពាហ៍ ដែលបានស្នើឡើងដោយបុគ្គល ឬសូម្បីតែផ្សំផ្គុំឡើងដោយ អាជ្ញាធរ សុទ្ធតែត្រូវបានអនុម័តយល់ព្រមនោះទេ ហើយការរៀបអាពាហ៍ពិពាហ៍ ត្រូវបាន អនុញ្ញាតតែក្នុងករណីដែលរកឃើញថា ស្របទៅតាមផលប្រយោជន៍សមូហភាព[2364]។ តាមពិត ទៅបុគ្គលម្នាក់ៗ មិនអាចបដិសេធ ការស្នើរៀបអាពាហ៍ពិពាហ៍ឡើយ ដូច្នេះហើយទើបគោល

---

[2360] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤២ (ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ បញ្ជាក់ថា ការរៀបអាពាហ៍ពិពាហ៍ត្រូវផ្អែកលើគោលការណ៍ទាំងពីររបស់បក្ស៖ "ទីមួយ សាមីខ្លួនទាំងសងខាងយល់ព្រម។ ទីពីរ សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ"។

[2361] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៩៩-៣៦០០។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹង សាទុក្ខ កថាខណ្ឌ ១១៩៣។

[2362] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤៤-៣៥៤៥ និងនិងការដកស្រង់ទាំងអស់ដែលមានក្នុង កថាខណ្ឌទាំងនេះ (ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តជាច្រើនបញ្ជាក់ថា សេចក្តីសម្រេចរបស់អង្គការមានសារៈសំខាន់ជាង មនោសញ្ចេតនាផ្ទាល់ខ្លួនដែល "ផ្ទុយទៅនឹងគោលជំហរមនោគមន៍វិជ្ជាត្រឹមត្រូវ") ជើងទំព័រ ១១៩២៧ (សេចក្តីសម្រេចដែលត្រូវ បានអនុម័តនៅក្នុងពេលប្រជុំមហាជន ដែលម្ចាស់បណ្តឹងសាទុក្ខបានឡើងថ្លែងសុន្ទរកថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានបញ្ចូលការប្តេជ្ញាចិត្តក្នុងការ "ដាក់ប្រយោជន៍គ្រួសារ និងផ្ទាល់ខ្លួនទាំងស្រុងជាប្រយោជន៍រួមរបស់ជាតិ វណ្ណៈ ប្រជាជន និងបដិវត្ត") ជើងទំព័រ ១១៩២៩ (*ដកស្រង់* ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តមួយចំនួន រួមមានការប្តេជ្ញាចិត្តរបស់យុវជន យុវនារីក្នុងការផ្តល់អាទិភាពទៅលើប្រយោជន៍របស់បក្ស និង "កុំរវីរវល់ ឬជំពាក់ជំពិននឹងបញ្ហាកំប៉ិកកំប៉ុក ជុំវិញអត្តាខ្លួន ជុំវិញបុគ្គលខ្លួន")។

[2363] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤១ ("ចំពោះការជ្រើសរើសគូស្រករ បុគ្គលត្រូវគោរព វិន័យអង្គការជាដាច់ខាត")។

[2364] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤១, ៣៥៤៣ *ដកស្រង់* ឯកសារ **E3/775** លោក ទស្សនៈបដិវត្ត និងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៥ KH 00407100-00407101 ("ត្រូវគោរពអង្គការវិន័យដាច់ខាត។ ក្នុងបញ្ហាកសាងគ្រួសារនេះ បើអង្គការ សមូហភាព ពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាង ណា ត្រូវគោរពតាមដាច់ខាត កុំទោមនស្ស កុំថ្នាំងថ្នាក់។ ព្រោះមានតែអង្គការ មានតែសមូហភាពទេ ដែលអាចពិនិត្យមើលបាន ហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយបាន")។

ការណ៍យល់ព្រម នៅក្នុងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្លាយជាទម្រង់ផ្លូវការ ទទេស្អាត[2365]។ ហេតុដូច្នេះមិនអាចនិយាយបានទេថា អង្គជំនុំជម្រះសាលាដំបូង "ច្រានចោល" គោលការណ៍ ឬបង្ហាញត្រឹមមួយផ្នែក នៅក្នុងការវាយតម្លៃរបស់ខ្លួន ទៅលើភស្តុតាងនោះ[2366]។ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ទម្ងន់ទៅលើភស្តុតាងទាំងអស់ នៅចំពោះមុខខ្លួន ដើម្បីសម្រេចថាការយល់ព្រម គឺមិនត្រូវបានផ្តល់អាទិភាពឡើយ នៅក្នុងការអនុវត្តជាក់ស្តែង[2367]។

689. បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសថា អង្គជំនុំជម្រះសាលាដំបូង បានលាក់បាំងដោយចេតនា នូវផ្នែកខ្លះនៃភស្តុតាងរបស់សាក្សី ដែលបង្ហាញថាការយល់ព្រម គឺជាផ្នែកនៃគោលនយោបាយ រៀបអាពាហ៍ពិពាហ៍របស់ បក្សកុម្មុយនីស្តកម្ពុជា[2368]។ ដោយបានលើកឡើងដដែលៗ នៅក្នុងមូលដ្ឋានជាច្រើនរួចហើយនោះ[2369] ទឡ្ហីករណ៍នេះមិនបានគិតដល់ថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិ ក្នុងការទទួលឬបដិសេធផ្នែកខ្លះ នៃសក្ខីកម្មរបស់សាក្សី ដោយផ្អែកលើទិដ្ឋភាពជារួមនៃភស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះ[2370]។ បន្ថែមលើនេះ សាក្សីជាច្រើនដែលម្ចាស់បណ្តឹងសាទុក្ខ បានកំណត់អត្តសញ្ញាណថា បានអះអាងគាំទ្រពីសារសំខាន់នៃការយល់ព្រម ក៏បានផ្តល់សក្ខីកម្មផងដែរអំពី បរិយាកាសភ័យខ្លាចគ្រប់ពេល ដែលធ្វើឱ្យមនុស្សជាច្រើន មិនអាចមានការយល់ព្រមពិតប្រាកដបានឡើយ[2371] ដែលការណ៍នេះគាំទ្រដល់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

---

[2365] អសមត្ថភាពរបស់បុគ្គលក្នុងការបដិសេធការរៀបអាពាហ៍ពិពាហ៍ដោយគ្មានផលវិបាកធ្ងន់ធ្ងរ (សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៩) ដែលបញ្ជាក់យ៉ាងច្បាស់ថា ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្ត និងសុន្ទរកថា មិនមែនគ្រាន់ជា "ការរំឭក" ឬ "ការអំពាវនាវ" ឱ្យកម្មាភិបាលវ័យក្មេងពិចារណាឱ្យបានហ្មត់ចត់ និងប្រុងប្រយ័ត្នចំពោះការជ្រើសរើសគូស្រករបស់ពួកគេទេ (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១៣-១៤១២) ហើយក៏មិនមែនជា "ទស្សនៈថ្មីនៃទំនាក់ទំនងបុរស-ស្ត្រី ដែលបង្កើតឡើងដោយមនោគមន៍វិជ្ជាបដិវត្តន៍ [... ដែលបង្ហាញ] ពីឆន្ទៈផ្តល់ជូនស្ត្រីនូវតួនាទីផ្សេងពីប្រពៃណី គឺតាមរយៈការរៀបអាពាហ៍ពិពាហ៍តែមួយគត់" (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១២)។

[2366] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤ ទាក់ទងនឹង បន្ទុកភស្តុតាងរបស់ម្ចាស់បណ្តឹងសាទុក្ខដើម្បីបង្ហាញពីភាពលម្អៀងពិតប្រាកដ។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១១។

[2367] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤៨។

[2368] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៩៣។

[2369] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥, ១៦៦, ១៦៧, ១៧០, ១៧៣។

[2370] សូមមើល សាលដីការឿងក្តី *Setako* កថាខណ្ឌ ៣១។ សាលដីការឿងក្តី *Ngirabatware* កថាខណ្ឌ ៩៧។ សាលដីការឿងក្តី *Karera* កថាខណ្ឌ ២១។

[2371] ឯកសារ **E1/113.1** ឯម អឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង ១៥.៥៣.១៦-១៥.៥៦.៣៦ ទំព័រ ៩០ បន្ទាត់ ៧-២១ (រួមបញ្ចូលទាំងសក្ខីកម្មនេះ៖ "គឺរឿងពិត គឺបិទសិទ្ធិមនុស្សប្រើប្រាស់មិនបានទេ ព្រោះគេតម្រូវឱ្យខ្ញុំយកប្រពន្ធៗ

690. ម្ចាស់បណ្តឹងសាទុក្ខក៏បានអះអាងដោយខុសថា អតីតកម្មាភិបាលដែលផ្តល់សក្ខីកម្មអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ស្តីពីការយល់ព្រម ត្រូវបានអង្គជំនុំជម្រះសាលាដំបូងច្រានចោលនូវសក្ខីកម្មរបស់ពួកគេ ដោយមិនសមហេតុផល ដោយសារតែពួកគេហាក់ដូចជាព្យាយាមបន្ថយជាអតិបរមា នូវការទទួលខុសត្រូវរបស់ខ្លួន[2372]។ ច្បាស់ណាស់ថា អង្គជំនុំជម្រះ

---

ហើយចង្អុលចំដែលមនុស្សដែលខ្ញុំអត់ស្រឡាញ់។ អ៊ីចឹង ខ្ញុំប្រកែកចុះ ប្រកែកឡើង [...] ទទួលទោស។ គេដកចេញពីពេទ្យឱ្យខ្ញុំទៅការដ្ឋាន [...] ខ្ញុំសម្រេចចិត្តថា បើខ្ញុំមិនយកជីវិតខ្ញុំអត់ដឹងថា ខ្ញុំរស់ឬស្លាប់។ អ៊ីចឹងដាច់ចិត្តបង្ខំៗចិត្តទទួលពាក្យបង្ខំនេះថាត្រូវព្រមទទួល")។ សូមមើលផងដែរ ឯកសារ **E1/76.1** នី កន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ ម៉ោង ១៥.៣៣.២៦-១៥.៣៦.២៨ ទំព័រ ៧៤-៧៥ បន្ទាត់ ២៤-៤ (នី កន ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់ដើម្បីគាំទ្រគំនិតថា ការព្រមព្រៀងគឺជាសីលធម៌មួយក្នុងចំណោមសីលធម៌ទាំង ១២ តាមពិត មិនបានយោងទៅសីលធម៌ទាំង ១២ ទេ និងគ្រាន់តែលើកឡើងថា សីលធម៌ចែងថា "កុំលួច ហើយកុំខិលខូច ខុសប្រពៃណី")។ ឯកសារ **E1/346.1** សេន ស្រ៊ុន ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង ១១.៥១.៤០-១១.៥២.៥៤ ទំព័រ ៤៦ បន្ទាត់ ៨-១១ ("ចំពោះខ្ញុំអ៊ីចេះ ពីរឿងខ្ញុំវាដោយឡែក ក៏ប៉ុន្តែ *រឿងអ្នកដទៃទៀតគឺអត់បានស្ម័គ្រចិត្តទេ*។ ដូចរឿងខ្ញុំ ខ្ញុំបាន បើនិយាយទៅ ខ្ញុំប្រពន្ធខ្ញុំដែលអាប៉ុលពត ឱ្យរៀបការហ្នឹង គឺបានចាស់ទុំអីចូលស្តីដណ្តឹងអ៊ីចឹងទៅណា") (គូសបញ្ជាក់បន្ថែម)។ ឯកសារ **E1/394.1** សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ម៉ោង ១០.៤៩.៤៧-១០.៥២.៥៥ ទំព័រ ២៦ បន្ទាត់ ១៩-២១ ("គាត់ប្រាប់ គាត់ថាបងអ្អែង គេស្នើឱ្យរៀបការហើយ ខ្ញុំថា អ៊ូ! មិនដឹងការស្អីទេ ឱ្យរៀបការស្អីទេ ខ្ញុំមិនទៅការទេ។ គាត់ថា អ្អែងទៅការដែរអី ខ្ញុំថាខ្ញុំមិនទេ។ ទៅៗកុំអើយ ក្រែងលោនេះ អ្អែងតែអ៊ីចឹងខ្លាចគេយកវ៉ៃចោលទៀត ឱ្យបងទៅការទៅ ហើយទៅការបងទៅ។ គាត់ប្រាប់អ៊ីចឹង")។ ឯកសារ **E1/387.1** អ៊ិន យឿង ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង ១៤.១៥.១១-១៤.១៨.១៣ ទំព័រ ៥៧ បន្ទាត់ ៥-៦ ("គេចង់ការ ព្រោះគេចង់ត្រឡប់ទៅសហករណ៍វិញ។ នៅសហករណ៍ការងារស្រាលជាង គឺគ្រាន់តែជូនកាលទៅ គ្រាន់តែរែកបាយ។ អ៊ីចឹង គេចង់ការដើម្បីទៅធ្វើការនៅតាមសហករណ៍វិញ")។ ឯកសារ **E1/465.1** សេង សឿន ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១០.០៣.២២-១០.០៦.០០ ទំព័រ ១៨ បន្ទាត់ ១៣-២៣ ("ស៖ អ្នកស៊ើបអង្កេតក៏សួរលោកតទៅទៀតថា៖ តើគេតែងតែយល់ព្រមក្នុងការរៀបការនេះមែនទេ? លោកឆ្លើយតបទៅវិញ៖ អ្នកខ្លះអាចមិនសប្បាយចិត្ត ប៉ុន្តែអ្នកខ្លះសប្បាយចិត្ត ហើយអ្នកដែលមិនសប្បាយចិត្ត មិនហ៊ានបដិសេធឡើយ។ ហើយជាចុងក្រោយ អ្នកស៊ើបអង្កេតក៏សួរលោកបន្ថែមទៀតថា៖ ហេតុអ្វីបានជាគេមិនហ៊ានបដិសេធ? លោកថា៖ គេខ្លាចរបបខ្មែរក្រហមសម្លាប់គេ។" ដូច្នេះលោកនឹកឃើញឡើងវិញទេថា អ្នកខ្លះនុ៎ង ទោះបីជាមិនសប្បាយចិត្ត ក៏មិនហ៊ានប្រកែកដែរ ព្រោះខ្លាចខ្មែរក្រហមសម្លាប់? ឆ. បាទៗ ចម្លើយរបស់ខ្ញុំដែលថានេះគឺពិតហើយ ព្រោះខ្ញុំ ដូចថាវានៅក្នុងជួរហ្នឹង វាដូចជាពិត មិនដែលនិយាយភូតភរអីទេហ្នឹង។ ហ្នឹងខ្ញុំបានជូនដំណឹងទៅថា របបហ្នឹង គេធ្វើអ៊ីចឹងមែន គ្រាន់តែត្រឹមថា ទោះបីស្រឡាញ់ប៉ុនណា អាហ្នឹងអត់អីទេ។ ប៉ុន្តែមិនប្រកែក តែហ៊ានតែប្រកែក ដឹងតែបាត់ខ្លួនតែប៉ុណ្ណឹងឯង")។ ឯកសារ **E1/469.1** ណុប ងឹម ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង ១១.១៧.០៥-១១.១៨.០៣ ទំព័រ ៣៩ បន្ទាត់ ១៩-២០ ("ប៉ុន្តែការជំនាន់ហ្នឹង វាស្រឡាញ់គ្នា បានយើងការឱ្យ បានអ្នកនៅហ្នឹងការឱ្យ កូនប្រជាជនណ៎ះ! ការឱ្យ អត់មានបង្ខំដូចយើងនៅអង្គភាពទេ")។ ឯកសារ **E1/464.1** យស ផល ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១១.០៩.២៤-១១.១១.៤៩ ទំព័រ ២៩ បន្ទាត់ ១២-១៣។

[2372] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៩៤។ ម្ចាស់បណ្តឹងសាទុក្ខផ្អែកលើលិខិតធានាមិនចោទប្រកាន់សាក្សីដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួនថា សក្ខីកម្មរបស់កម្មាភិបាលត្រូវបានផ្តល់ទម្ងន់ដោយមិនត្រឹមត្រូវ ប៉ុន្តែ ការផ្អែកលើលិខិតធានាមិនចោទប្រកាន់សាក្សីនេះ មិនបានបង្ហាញពីកំហុសអង្គច្បាប់ទេ (សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៥)។

សាលាដំបូង មិនបានច្រានចោលភ័ស្តុតាងរបស់ពួកគេ ដោយសារតែមូលដ្ឋាននេះតែមួយទេ។ ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង បានសម្រេចយ៉ាងច្បាស់លាស់ថា "បរិយាកាសនៃការភ័យខ្លាចជាទូទៅ ដែលបង្កើតឡើងដោយអាជ្ញាធរ និង/ឬ ការគំរាមកំហែងប្រឆាំងនឹងបុគ្គលទាំងនោះ ធ្វើឱ្យពួកគេត្រូវគោរពតាមអង្គការ និងមិនអនុញ្ញាតឱ្យពួកគេជំទាស់នឹងបញ្ហា ឱ្យរៀបការនេះទេ។ ដូច្នេះ *បើទោះបីជាភ័ស្តុតាងដែល កម្មាភិបាលបានផ្តល់មក*ថា តាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា គូស្រករដែលត្រូវរៀបការ ត្រូវតែយល់ព្រមរៀបការក៏ដោយ [...] ការយល់ព្រមនោះធ្វើឡើងដោយមិនពិតប្រាកដឡើយ"[2373]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែស្នើដល់អង្គជំនុំជម្រះតុលាការកំពូល ឱ្យបកស្រាយឡើងវិញនូវអង្គហេតុ ដែលអង្គជំនុំជម្រះសាលាដំបូង បានពិចារណារួចហើយនោះ[2374]។ បន្ថែមលើនេះ កម្មាភិបាលដែលម្ចាស់បណ្តឹងសាទុក្ខ បានដកស្រង់មកនោះ ពួកគេខ្លួនឯងផ្ទាល់ គឺជាជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយជាជាងការអះអាងគាំទ្រថា ការយល់ព្រមគឺជាគោលការណ៍ដែលត្រូវគោរពតាមយ៉ាងម៉ឺងម៉ាត់នោះ ពួកគេគ្រាន់តែអះអាងថា បទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ ដែលមិនគួរឱ្យចង់បានរបស់ពួកគេ គឺមិនដូចអ្នកដទៃទេឡើយ[2375]។

691. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងសាក្សីដទៃទៀតក៏ខុសដែរ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបដិសេធការបង្ហាញខ្លួន របស់ François Ponchaud នៅសវនាការសំណុំរឿង ០០២/០២ គឺមានមូលដ្ឋានច្បាស់លាស់តាមផ្លូវច្បាប់ ហើយអង្គជំនុំជម្រះសាលាដំបូងបានរំឭកថា សាក្សីបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ លើប្រធានបទជាច្រើនរួមទាំង ការរៀបអាពាហ៍ពិពាហ៍ ដែលសក្ខីកម្មទាំងនេះនៅជាផ្នែកនៃភ័ស្តុតាង ដែល

---

ទឡ្ហីករណ៍នេះត្រូវបានលើកឡើងម្តងហើយម្តងទៀតនៅក្នុងសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៦, ១៦៩, ១៧៥។

[2373] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២៣ (គូសបញ្ជាក់បន្ថែម)។

[2374] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៨៦-៣៥៩១ (បង្ហាញថា អ.ជ.ស.ដ បានពិចារណាលើភ័ស្តុតាងរបស់អតីតកម្មាភិបាល ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍របស់យុទ្ធជន កម្មាភិបាល និងកងទ័ពពិការ ដែលត្រូវបានគេសួរយោបល់អំពីការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ ប៉ុន្តែ អ.ជ.ស.ដ បានសន្និដ្ឋានថា នេះដោយសារតែឋានៈពិសេសរបស់ពួកគេ។ ការអនុវត្តទូទៅគឺថា បុគ្គលគ្មានសិទ្ធិជ្រើសរើសអ្នកដែលខ្លួនចង់រៀបការជាមួយឡើយ) កថាខណ្ឌ ៣៦១៧ (អ.ជ.ស.ដ បានពិចារណាលើភ័ស្តុតាងរបស់ ពេជ្រ ជីម ដែលថា ចាំបាច់ត្រូវមានការព្រមព្រៀងដើម្បីរៀបការ ប៉ុន្តែ គាត់បានទទួលស្គាល់ថា "មានភាពខុសគ្នានៅក្នុងការអនុវត្ត")។

[2375] ដូចដែលបានបញ្ជាក់ដោយផ្ទាល់ដោយម្ចាស់បណ្តឹងសាទុក្ខ នេះជាករណីសម្រាប់ ណុប ធីម និង សេង សឿន ដែលកម្មាភិបាលថ្នាក់ខ្ពស់ សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៩៧។

មាននៅក្នុងសំណុំរឿង ០០២/០២[2376]។ ការអះអាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយមិនបានទាញសន្និដ្ឋានដែលចាំបាច់ ពីសក្ខីកម្មអ្នកជំនាញ ត្រូវបានបង្ហាញនៅផ្នែកផ្សេងៗ ក្នុងចម្លើយតបនេះ ថាជាការអះអាងដែលមិនមានមូលដ្ឋាន[2377]។

*ការចោទពីការមិនពិចារណាទៅលើ "ភាពជាតំណាង" នៃភ័ស្តុតាង*

692. ម្ចាស់បណ្តឹងសាទុក្ខបានជ្រើសរើសយកអ្វីដែលគាត់បានហៅជាទូទៅថា "វិធីសាស្ត្រស្ថិតិ" ដើម្បីលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកច្រើនហួសហេតុ ទៅលើភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពីផ្នែករៀបអាពាហ៍ពិពាហ៍ នៅក្នុងសវនាការជំនុំជម្រះ ហើយមិនបានទទួលស្គាល់ភ័ស្តុតាង ពីផ្នែកដទៃទៀត ដែលម្ចាស់បណ្តឹងសាទុក្ខបានចោទថា ប្រសិនបើពិចារណាឱ្យបានត្រឹមត្រូវ គឺនឹងបង្ហាញថាការយល់ព្រម គឺជាគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា[2378]។ "វិធីសាស្ត្រស្ថិតិ" នេះ ត្រូវបានលើកឡើងជាច្រើនដង នៅក្នុងសារណារបស់គាត់ ដោយលើកទឡ្ហីករណ៍ដដែលៗថា អង្គជំនុំជម្រះសាលាដំបូង មិនបានវាយតម្លៃទៅលើភ័ស្តុតាងជារួម មុនពេលឈានដល់សេចក្តីសន្និដ្ឋាននានារបស់ខ្លួន ដែលការនេះបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានភាពលម្អៀង[2379]។ ប៉ុន្តែវិធីសាស្ត្រនេះគឺសំអាងលើ ការសន្មតដែលខុសមួយចំនួន ហើយពោពេញ

---

[2376] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៩៥។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៥។ សូមមើលផងដែរ ឯកសារ **E1/179.1** François Ponchaud ប្រតិចារឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ម៉ោង ១៣.៤៥.៥០-១៣.៤៨.០៦ ទំព័រ ៥១-៥២ បន្ទាត់ ១៣-២។

[2377] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២០៩។

[2378] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៩៦-១២០៨។

[2379] សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៧៧-១១៨៨ (អះអាងថា ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមានសភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ ហើយវាក៏មិនតំណាងឱ្យប្រទេសទាំងមូលដែរ៖ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ភ័ស្តុតាងនៅលើសំណុំរឿងក្រៅវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ បង្ហាញឱ្យឃើញថាមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ពីរឿងរ៉ាវរបស់ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ម្ចាស់បណ្តឹងសាទុក្ខបានយោងទៅវគ្គសហករណ៍ត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម ក៏ដូចជា "វគ្គផ្សេងទៀតក្នុងសំណុំរឿង ០០២/០២" ប្រតិចារឹកសំណុំរឿង ០០២/០១ និងកំណត់ហេតុស្តាប់ចម្លើយដែលគាំទ្រដល់ដីកាដំណោះស្រាយ និងយកចេញពីសំណុំរឿង ០០៣ និង ០០៤ ដោយអះអាងថា អ្វីដែលម្ចាស់បណ្តឹងសាទុក្ខបានយោងទៅសុទ្ធតែបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍មិនត្រូវបានបង្ខំទេ ប៉ុន្តែ "ត្រូវបានរៀបចំ" ហើយការឈឺចាប់មិនអាចត្រូវបានបង្ហាញឱ្យឃើញទេ) កថាខណ្ឌ ១១៩៦-១២០៨ (អះអាងថា អ.ជ.ស.ដ មិនបានពិចារណាទៅលើ "បទពិសោធន៍ផ្សេងទៀត" នៃការរៀបអាពាហ៍ពិពាហ៍ ដូចជា ការរៀបអាពាហ៍ពិពាហ៍ដោយការរៀបចំ និងបានបដិសេធដោយមិនត្រឹមត្រូវនូវសក្ខីកម្មរបស់អតីតកម្មាភិបាលដែលបានបញ្ជាក់អះអាងថា ការយល់ព្រមជាគោលនយោបាយរបស់ ប.ក.ក។ ម្ចាស់បណ្តឹងសាទុក្ខយោងទៅវគ្គសហករណ៍ត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងវគ្គ "ផ្សេងទៀត" ដោយអះអាងថា វគ្គសហករណ៍

ទៅដោយកំហុសឆ្គង ដែលធ្វើឱ្យអសុពលភាព ចំពោះការសន្និដ្ឋានដែលវិធីសាស្ត្រនេះត្រូវគាំទ្រនោះ។ ការអះអាងជាច្រើនរបស់ គឺពិភាក្សាជាចម្បងនៅទីនេះ ដោយមិនពិភាក្សានៅផ្នែកទាំងមូលនោះទេ ដើម្បីផ្តល់នូវភាពច្បាស់លាស់ និងជៀសវាងការច្រំដែលគ្នា។

693. កំហុសឆ្គងធំបំផុតនៅក្នុងការវិភាគរបស់ម្ចាស់បណ្តឹងសាទុក្ខ គឺការញែកគ្នាដោយខុសឆ្គងរវាងការរៀបអាពាហ៍ពិពាហ៍ "ផ្សំផ្គុំ" ដោយអាជ្ញាធរ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2380]។ ដូចដែលបានពិភាក្សាពីខាងលើ បុគ្គលជាច្រើនដែលម្ចាស់បណ្តឹងសាទុក្ខ កំណត់ប្រភេទថា "យល់ព្រម" រៀបអាពាហ៍ពិពាហ៍នោះ តាមការពិតទៅគឺពួកគាត់ មិនបានយល់ព្រមទេ[2381]។ ហេតុដូច្នេះ

ត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងវគ្គជំនុំជម្រះ "ផ្សេងទៀត" បង្ហាញថា ការយល់ព្រមជាគោលការណ៍របស់ ប.ក.ក) កថាខណ្ឌ ១២៧៣-១២៧៨ (អះអាងថា ភ័ស្តុតាងទាំងអស់មិនបង្ហាញពីគោលនយោបាយថ្នាក់ជាតិនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ៖ ម្ចាស់បណ្តឹងសាទុក្ខអះអាថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដោយខកខានមិនបានពិចារណាទៅលើភាពខុសគ្នាក្នុងការអនុវត្តគោលនយោបាយ នៅពេលពិនិត្យភ័ស្តុតាងទាំងមូល។ ម្ចាស់បណ្តឹងសាទុក្ខយល់ឃើញថា វគ្គជំនុំជម្រះផ្សេងៗដើម្បីសន្និដ្ឋានពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានតិចតួច។ ឧទាហរណ៍ ពេលពិនិត្យមើលសក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ក្រៅវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ម្ចាស់បណ្តឹងសាទុក្ខរកឃើញថា ការរៀបអាពាហ៍ពិពាហ៍ ១៩% ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដូចគ្នាដែរ ការវិភាគរបស់ម្ចាស់បណ្តឹងសាទុក្ខទៅលើកំណត់ហេតុស្តាប់ចម្លើយដែលគាំទ្រដល់ដីកាដំណោះស្រាយ រកឃើញថា ការរៀបអាពាហ៍ពិពាហ៍ ៣៤% ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ១៣២៥-១៣៤០ (អះអាងថា កម្រិតនៃការឈឺចាប់ដែលតម្រូវសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនត្រូវបានបំពេញទេ ទាក់ទងនឹងការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ម្ចាស់បណ្តឹងសាទុក្ខជំទាស់នឹងភ័ស្តុតាងនៅក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ និងវគ្គជំនុំជម្រះផ្សេងៗ ដោយអះអាងថា ពុំមានធាតុផ្សំអង្គហេតុ និងការសន្និដ្ឋានថា ការឈឺចាប់ដែលទទួលរង អាចប្រៀបប្រដូចនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សផ្សេងទៀតបាន មិនត្រូវបានបង្ហាញឱ្យឃើញឡើយ។ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងម្តងហើយម្តងទៀតពីការអះអាងរបស់គាត់ថា ការរៀបអាពាហ៍ពិពាហ៍ភាគច្រើនមិនត្រូវបានបង្ខំទេ ហើយមានសាក្សីតិចតួចដែលបានផ្តល់សក្ខីកម្មពីការឈឺចាប់) កថាខណ្ឌ ១៣៥៦-១៣៦០ (ទាក់ទងនឹង ការអនុវត្តថ្នាក់ជាតិនៃការតាមដានការរួមដំណេក៖ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ខណៈដែលបុគ្គ ៧៩% នៅក្នុងវគ្គស្តីការរៀបអាពាហ៍ពិពាហ៍បានផ្តល់សក្ខីកម្មថាត្រូវគេតាមដាន មានតែបុគ្គល ១៦% មកពីវគ្គជំនុំជម្រះផ្សេងទៀត ផ្តល់សក្ខីកម្មដូចគ្នា។ ម្ចាស់បណ្តឹងសាទុក្ខក៏បានវិភាគលើកំណត់ហេតុស្តាប់ចម្លើយដែលគាំទ្រដល់ដីកាដំណោះស្រាយ និងយកចេញពីសំណុំរឿង ០០២/០១, ០០៣ និង ០០៤ និងសន្និដ្ឋានថា ពុំមានការអនុវត្តថ្នាក់ត្រូវបានបង្ហាញឱ្យឃើញទេ)។

[2380] សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៨២-១១៨៣, ១២០១-១២០៤, ១២៧៥, ១២៧៧។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៣, ១៦៧។

[2381] សូមមើលឧទាហរណ៍ ឯកសារ **F54.1.2** ឧបសម្ព័ន្ធ ខ១ ដែលម្ចាស់បណ្តឹងសាទុក្ខបានកំណត់ថា ការរៀបអាពាហ៍ពិពាហ៍របស់សាក្សី កង អ៊ុត ជាការរៀបអាពាហ៍ពិពាហ៍ "ដោយមិនបង្ខំ"។ ទោះជាយ៉ាងនេះក្តី កង អ៊ុត បានបញ្ជាក់យ៉ាងច្បាស់ថា "ខ្ញុំមិនប៊ានជំទាស់ទេ។ បើយើងជំទាស់ គេថាយើងប្រឆាំង។ ប្រឆាំងនឹងអង្គការ" (សូមមើល ឯកសារ **E1/322.1** កង អ៊ុត ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង ១០.៥៩.៥៦-១១.០១.៥២ ទំព័រ ២៦ បន្ទាត់ ១៣-១៤)។ ស្រដៀងគ្នានេះដែរ ឯកសារ **F54.1.7** ឧបសម្ព័ន្ធ ៦ខ ចាត់ អ៊ិន យឿង ក្នុងចំណោមអ្នកដែលរៀបការ "ដោយការរៀបចំ"។ ទោះជាយ៉ាងនេះក្តី

ទម្រង់ណាមួយ ដែលទាញចេញពីការកំណត់ប្រភេទដោយខុស របស់ម្ចាស់បណ្ដឹងសាទុក្ខនេះ គឺជាទម្រង់ដែលខុស។ លើសពីនេះទៀត ជារឿងសមហេតុផលដែលថា សក្ខីកម្មដែលផ្ដល់នៅក្នុងផ្នែកការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺមានជនរងគ្រោះច្រើនដោយគោលនយោបាយ ហើយដែលអាចផ្ដល់សក្ខីកម្មបានយ៉ាងលម្អិត អំពីគោលដៅ ព័ត៌មានលម្អិត និងផលប៉ះពាល់នៃគោលនយោបាយ ហើយនេះគឺជាហេតុផលចម្បង ដែលពួកគាត់ត្រូវបានកោះអញ្ជើញ[2382]។ តាមពិតទៅ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា ដើមបណ្ដឹងរដ្ឋប្បវេណី "ទទួលបានតួនាទីយ៉ាងសំខាន់ ក្នុងការពណ៌នាអំពីព្រឹត្តិការណ៍ ដែលបង្កើតបានជាមូលដ្ឋាន ក្នុងការចោទប្រកាន់"[2383]។ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាភ័ស្តុតាង របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយត្រឹមត្រូវ នៅពេលធ្វើការសម្រេចលើអង្គហេតុ ហើយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានអនុញ្ញាតឱ្យពិចារណា ទៅលើសក្ខីកម្មនានារបស់ ដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងពិរុទ្ធភាពរបស់ជនជាប់ចោទ[2384]។

694. នៅក្នុងការវិភាគទាំងស្រុងរបស់គាត់ ម្ចាស់បណ្ដឹងសាទុក្ខបានសន្និដ្ឋាន ដោយស៊ីចង្វាក់គ្នាទាំងខុសឆ្គងថា ដោយសារតែទំនាក់ទំនងខ្លះៗ បានវិវឌ្ឍន៍ទៅតាមពេលវេលា ដែលនាំឱ្យមានសេចក្ដីស្នេហា និងការពេញចិត្ត[2385] ឬដោយសារតែបុគ្គលមួយចំនួន មិនបានបង្ហាញដោយត្រង់ថា អាពាហ៍ពិពាហ៍ ឬទំនាក់ទំនងផ្លូវភេទរបស់ពួកគេ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ បង្កនូវការឈឺចាប់ចំពោះខ្លួន[2386] ទើបការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនអាចត្រូវបានមើលឃើញថា បណ្ដាលឱ្យមានកម្រិតនៃការឈឺចាប់ ដូចបានតម្រូវចំពោះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃអំពើអមនុស្សធម៌ដទៃទៀត។ ទោះបីជាយ៉ាងនេះក្ដី ដូចដែលបានបង្ហាញនៅក្នុង

---

ច្បាស់ណាស់ថា ការយល់ព្រមរបស់គាត់កើតចេញពីបរិស្ថានបង្ខិតបង្ខំ។ គាត់យល់ព្រមរៀបការ ដើម្បីអាចចាកចេញពីកងចល័ត ដែលលក្ខខណ្ឌពិបាកខ្លាំង និងគ្មានអាហារគ្រប់គ្រាន់សម្រាប់ហូប (សូមមើល ឯកសារ **E1/387.1** អ៊ិន យឿង ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង ១៤.១៥.១១-១៤.១៨.១៣ ទំព័រ ៥៧ បន្ទាត់ ៥-៩)។

[2382] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២០០, ១២០៣ (អះអាងថា អ្នកដែលបានផ្ដល់សក្ខីកម្មនៅក្នុងវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ១០០% ជាជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ធៀបនឹងវគ្គសហករណ៍ត្រាំកក់ និងទំនប់ត្រពាំងថ្ម ដែលចំនួននៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ "ធ្លាក់ចុះយ៉ាងខ្លាំង")។

[2383] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣១២។

[2384] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣១២។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១៩៥។

[2385] ឯកសារ **F54**សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១៧៨, ១១៨០, ១១៨២, ១១៨៦-១១៨៧។

[2386] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១៧៨, ១១៨១, ១១៨៣, ១១៨៥-១១៨៧។

ចម្លើយតប ចំពោះមូលដ្ឋានទី ១៦៣ និងទី ១៧៣ ការអះអាងទាំងអស់នេះគឺខុស។ ហេតុដូច្នេះ ការពិចារណាលើករណី នៅក្នុងផ្នែកដទៃទៀតនៃសវនាការ ដែលសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ទំនាក់ទំនងបានវិវឌ្ឍន៍ ឬសាក្សីត្រូវបានកោះអញ្ជើញ ឱ្យមកផ្តល់សក្ខីកម្មអំពីបញ្ហាដទៃទៀត មិនបានបញ្ជាក់ដោយច្បាស់លាស់ថា គូស្រកពួកគាត់ទទួលរងការឈឺចាប់ដោយសារតែការរួមដំណេក[2387] ឬការពិតដែលថា ស្ត្រីមួយចំនួនមិនបានចាត់ទុកថា ខ្លួនគាត់ត្រូវបានគេរំលោភនោះ[2388] គឺជះឥទ្ធិពលតិចតួចដល់ការធ្វើឱ្យខូចខាត ដល់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការឈឺចាប់ដែលបណ្តាលមកពី ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេករបស់ពួកគេ។

695. ជាចុងក្រោយ នៅពេលអនុវត្ត “វិធីសាស្ត្រស្ថិតិ” ចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សី ក្នុងសំណុំរឿង ០០៣ និង០០៤ ដើម្បីបង្ហាញថា ៦៥% នៃការរៀបអាពាហ៍ពិពាហ៍ ត្រូវបានធ្វើឡើងដោយបង្ខំនោះ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាង ដោយគ្មានភ័ស្តុតាងគាំទ្រថា អ្នកស៊ើបអង្កេតប្រើប្រាស់សំណួរនាំមុខ ដូច្នេះចម្លើយទាំងនោះត្រូវទទួលបាន តម្លៃជាភ័ស្តុតាងតិចតួចប៉ុណ្ណោះ[2389]។ នៅពេលដែលមានការជំទាស់ប្រហែលគ្នា ប៉ុន្តែមានលក្ខណៈជាក់លាក់ខ្លាំងជាងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលជាច្រើន ដែលត្រូវបានលើកឡើងនៅក្នុងសំណុំរឿងដទៃទៀត អង្គបុរេជំនុំជម្រះបានធ្វើការត្រួតពិនិត្យយ៉ាងម៉ត់ចត់ ហើយរកមិនឃើញនូវភាពខុសឆ្គងបែបនេះទេ[2390]។ សម្រាប់សំអាងហេតុទាំងអស់នេះ ការវិភាគរបស់ម្ចាស់បណ្តឹងសាទុក្ខ គឺពុំមានមូលដ្ឋានឡើយ។

[2387] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣២៩។

[2388] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៧២។

[2389] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៧៧។

[2390] អ.ប.ជ បានវាយតម្លៃលើសំណើសុំធ្វើមោឃភាពផ្នែកខ្លះនៃកំណត់ហេតុស្តាប់ចម្លើយដែលរងការជំទាស់ ដែលត្រូវបានចោទប្រកាន់ថាមានភាពលម្អៀង ឬការលេចឡើងនូវភាពលម្អៀង រួមបញ្ចូលទាំងតាមរយៈការប្រើប្រាស់សំណួរនាំមុខដោយអ្នកស៊ើបអង្កេត។ ក្នុងចំណោមចន្លោះប្រហោងចំនួន ៣៨៦ ដែលត្រូវបានចោទប្រកាន់ ពុំមានរកឃើញកំហុសណាមួយឡើយ។ សូមមើល សំណុំរឿង ០០៤/២-ឯកសារ **D338/1/5** សាលដីការបស់ អ.ប.ជ លើអ្នកស៊ើបអង្កេតបីរូប កថាខណ្ឌ ១០, ១៨, ២០ (សច្ចធារណ៍នៃភាពអាចទុកចិត្តបានដែលត្រូវបានភ្ជាប់មកជាមួយនឹងកិច្ចស៊ើបសួរ ដែលតម្រូវឱ្យមានលក្ខខណ្ឌតឹងរ៉ឹងមួយដើម្បីជំទាស់) កថាខណ្ឌ ២១-២២។

## *មូលដ្ឋានទី ១៦៨៖ កំហុសពាក់ព័ន្ធនឹងការផ្សព្វផ្សាយ បទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍*[2391]

696. **មូលដ្ឋានទី ១៦៨ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ ដោយសារពឹងផ្អែកទៅលើភ័ស្តុតាង ពាក់ព័ន្ធការទំនាក់ទំនងព័ត៌មានរវាងថ្នាក់លើនិងថ្នាក់ក្រោមបក្ស ដើម្បីបង្ហាញពីអត្ថិភាព នៃគោលនយោបាយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។**

697. ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសថា អង្គជំនុំជម្រះសាលាដំបូង "មានចេតនាបំភ្លេចចោល" សក្ខីកម្មទាក់ទងការយល់ព្រម រៀបអាពាហ៍ពិពាហ៍ របស់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្មផងដែរ អំពីការណែនាំពីថ្នាក់លើ សម្រាប់ការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍[2392]។ ម្ចាស់បណ្តឹងសាទុក្ខបានជំទាស់ដោយខុសថា វិធីសាស្ត្របែបជ្រើសរើសរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះភ័ស្តុតាងនេះ តម្រូវឱ្យមានការច្រានចោល ការសម្រេចទាក់ទងការណែនាំពីអាជ្ញាធរថ្នាក់លើ និងការសម្រេចដែលទូទៅជាងនេះដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាផ្នែកនៃគោលនយោបាយរៀបចំមួយ របស់បក្សកុម្មុយនីស្តកម្ពុជា[2393]។ ដោយមិនបានបង្ហាញអំពីការវាយតម្លៃ "លម្អៀង" ឬ "ឱកាសនិយម" ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង បានប្រើប្រាស់ដោយត្រឹមត្រូវ នូវឆន្ទានុសិទ្ធរបស់ខ្លួន ក្នុងការទទួលយកឬច្រានចោល ចំនុចជាក់លាក់នានា នៃសក្ខីកម្មរបស់សាក្សីដោយផ្អែកលើទិដ្ឋភាពរួមនៃភ័ស្តុតាង ដែលនៅចំពោះមុខអង្គជំនុំជម្រះ[2394]។ ដូចដែលបានកត់សម្គាល់កន្លងមក អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើភ័ស្តុតាងនៃការយល់ព្រម ដូចជាភ័ស្តុតាងដែលផ្តល់ដោយ សាក្សីដែលបានដកស្រង់[2395] ហើយអង្គជំនុំជម្រះសាលាដំបូង ក៏ពិចារណាផងដែរទៅលើ សក្ខីកម្មរបស់ពួកគាត់ (និងសក្ខីកម្មរបស់អ្នកដទៃជាច្រើន) ទាក់ទង

---

[2391] មូលដ្ឋានទី ១៦៨៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងការផ្សព្វផ្សាយបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍* កថាខណ្ឌ ១២៤៥-១២៤៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៨ (ភាសាអង់គ្លេស) ទំព័រ ៥៣ (ភាសាបារាំង) ទំព័រ ៨៣ (ភាសាខ្មែរ)។

[2392] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៤៥-១២៤៦។

[2393] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៤៥-១២៤៦ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៤-៣៦០៧, ៣៦៩០-៣៦៩៣។

[2394] សូមមើល សាលដីការឿងក្តី *Setako* កថាខណ្ឌ ៣១។ សាលដីការឿងក្តី *Ngirabatware* កថាខណ្ឌ ៩៧។ សាលដីការឿងក្តី *Karera* កថាខណ្ឌ ២១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៤៦។

[2395] សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦១៧, ៣៦១៩, ៣៦២៣។

បរិយាកាសនៃភាពភ័យខ្លាច ភាពចាំបាច់ក្នុងការគោរពតាមមាគ៌ាបក្ស និងតួនាទីរបស់ថ្នាក់លើ ក្នុងការអនុញ្ញាតចំពោះការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវរៀបចំឡើង ដោយអាជ្ញាធរមូលដ្ឋាន[2396]។ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺផ្អែកដោយសមហេតុផលលើភស្តុតាង ហើយម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញអំពីកំហុសណាមួយឡើយ។

698. ម្ចាស់បណ្តឹងសាទុក្ខ បកស្រាយមិនត្រឹមត្រូវចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅពេលដែលគាត់លើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូង ដកស្រង់តែរបាយការណ៍ចំនួនពីរពីថ្នាក់ក្រោម ដើម្បីគាំទ្រការសន្និដ្ឋានដែលថា មានការណែនាំឱ្យរៀបចំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលចេញដោយ និងមានការអនុម័តយល់ព្រម ពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[2397]។ ការសម្រេចតែមួយដែល របាយការណ៍ទាំងពីរនេះគាំទ្រ បានសម្រេចដោយត្រឹមត្រូវថា "ព័ត៌មានទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ត្រូវបានបញ្ជូនទៅថ្នាក់លើ តាមរយៈរបាយការណ៍"[2398]។ ការសម្រេចដែលមានលក្ខណៈទូលំទូលាយ ទាក់ទងការណែនាំ និងការយល់ព្រមរបស់ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគាំទ្រយ៉ាងរឹងមាំដោយ ភស្តុតាងជាច្រើនផ្សេងទៀតក្រៅពីរបាយការណ៍។ សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បានរំឭកថា ថ្នាក់លើចេញគោលការណ៍ណែនាំ អំពីការរៀបអាពាហ៍ពិពាហ៍ ហើយត្រូវបញ្ជូនចុះទៅក្រោម ចំណែកព័ត៌មានលម្អិត ទាក់ទងការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ គឺទុកឱ្យថ្នាក់ក្រោម ហើយការផ្សំផ្គុំដែលបាន

---

[2396] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦០៣-៣៦០៩។ សូមមើលផងដែរ ភស្តុតាងមកពីសាក្សីដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់៖ ឯកសារ **E1/476.1** ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង ១១.១៦.១៩-១១.១៩.២៧ ទំព័រ ៣៣ បន្ទាត់ ៩-២៣ (ដោយសារភ័យខ្លាច ប្រជាជនស៊ីវិលត្រូវគោរពតាមមាគ៌ា/បទបញ្ជារបស់បក្ស រួមទាំងនៅក្នុងករណីរៀបអាពាហ៍ពិពាហ៍ផងដែរ)។ ឯកសារ **E1/465.1** សេង សឿន ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១០.០៣.២២-១០.០៦.០០ ទំព័រ ១៨ បន្ទាត់ ១២-២៣ (បញ្ជាក់អះអាងចម្លើយកាលពីលើកមុនដែលថា ប្រសិនបើបដិសេធមិនរៀបអាពាហ៍ពិពាហ៍ ពួកគេនឹងបាត់ខ្លួន។ អ្នកដែលជំទាស់ក៏អាចត្រូវគេសម្លាប់ផងដែរ)។ ឯកសារ **E1/466.1** សេង សឿន ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១១.២១.៣២-១១.២៣.២០ ទំព័រ ៣៩ បន្ទាត់ ១-១៧ (គ្មានវិធានការណាមួយត្រូវបានចាត់ដើម្បីកំណត់ការព្រមព្រៀងមុនពិធីរៀបការ ហើយអនាគតប្តី-ប្រពន្ធជាច្រើនមិនត្រូវបានគេជូនដំណឹងជាមុនថា ពួកគេនឹងរៀបការនោះទេ)។ ឯកសារ **E1/310.1** ស៊ូ សឿន ប្រតិចារឹក ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង ១៥.២៤.២៨-១៥.២៧.០០ ទំព័រ ៦៥ បន្ទាត់ ៥-៩ (ការណែនាំឱ្យរៀបចំអាពាហ៍ពិពាហ៍ចេញពីថ្នាក់លើ និងត្រូវបានបញ្ជូនតាមថ្នាក់ទៅថ្នាក់ក្រោម)។

[2397] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៤៧ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៨, ៣៦៩៣។

[2398] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៨។

ស្មើឡើងណាមួយ ចាំបាច់ត្រូវសម្រេចដោយផ្ទាក់លើ[2399]។ ហេតុដូច្នេះការសម្រេច ដែលរងការជំទាស់ទាំងពីរ គឺសមហេតុផល។

### *មូលដ្ឋានទី ១៦៩៖ កំហុសពាក់ព័ន្ធលក្ខខណ្ឌក្រៅបទបញ្ញា*[2400]

699. **មូលដ្ឋានទី ១៦៩ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការវាយតម្លៃ ទៅលើភស្តុតាង ឬការសម្រេចរបស់ខ្លួនស្តីពីការរៀបចំការរៀបអាពាហ៍ពិពាហ៍។**

700. ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយបំភាន់ថា ការយល់ព្រមពីអាជ្ញាធរជាន់ខ្ពស់ សម្រាប់រាល់ការរៀបអាពាហ៍ពិពាហ៍ទាំងអស់ គឺជាការអនុវត្តទូទៅ នៅក្នុងបណ្តាប្រទេសដទៃ ហើយមិនមែនជាភស្តុតាង នៃការខិតខំប្រឹងប្រែង ក្នុងការរៀបចំអាពាហ៍ពិពាហ៍ ដោយគ្មានការយល់ព្រមពីអនាគតគូស្រករទាំងពីរឡើយ[2401]។ ប៉ុន្តែ មិនដូចបណ្តាប្រទេសដទៃឡើយ លក្ខខណ្ឌតម្រូវការយល់ព្រមជាបុគ្គល នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាទម្រង់ផ្លូវការទទេរស្អាត[2402]។ ទោះបីជាអនាគតគូស្រក ត្រូវបានកម្មាភិបាលមូលដ្ឋាន តម្រូវឱ្យ "យល់ព្រម" រៀបអាពាហ៍ពិពាហ៍ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ក្តី ការនេះមិនបាន និងមិនអាចមានន័យថា ការជាយល់ព្រមពិតប្រាកដ ដោយសារតែលក្ខណៈបង្ខិតបង្ខំ យ៉ាងច្បាស់ក្រឡែតនៃរបបនោះ[2403]។ បន្ថែមលើនោះ ដូចដែល

---

[2399] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៤-៣៥៧៦, ៣៥៩២-៣៥៩៨, ៣៦៩៣។

[2400] <u>មូលដ្ឋានទី ១៦៩</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌក្រៅបទបញ្ញា* កថាខណ្ឌ ១២៤៨-១២៥៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៨ (ភាសាអង់គ្លេស) ទំព័រ ៥៣ (ភាសាបារាំង) ទំព័រ ៨៤ (ភាសាខ្មែរ)។

[2401] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៤៩-១២៥០ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៩៨, ៣៦០២, ៣៦៩៣។ សូមមើលផងដែរ កថាខណ្ឌ ១២៥២-១២៥៣ ដែលបញ្ជាក់ថា "អ្វីដែលថ្មីដែលមិនដែលមានពីមុនមក" គឺការដែលរបបកម្ពុជាប្រជាធិបតេយ្យផ្តល់អាទិភាពដល់ការយល់ព្រមរៀបអាពាហ៍ពិពាហ៍របស់បុគ្គលជាជាងការយល់ព្រមរបស់ឪពុកម្តាយ។

[2402] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៥៧ ("ការទទួលបានការព្រមព្រៀង គឺជាទិដ្ឋភាពសំខាន់មួយនៃការផ្តល់សុពលភាពដល់ការរៀបអាពាហ៍ពិពាហ៍")។

[2403] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦១៤-៣៦១៥ (បុគ្គលមិនត្រូវបានសួរយោបល់មុនរៀបអាពាហ៍ពិពាហ៍ទេ) កថាខណ្ឌ ៣៦១៩ (សាក្សីពណ៌នាថា ការរៀបការត្រូវបានបង្ខំ ឬដោយមិនស្ម័គ្រចិត្ត) កថាខណ្ឌ ៣៦២០ (បុគ្គលជាច្រើនយល់ព្រមរៀបកាដោយសារខ្លាច) កថាខណ្ឌ ៣៦២១-៣៦២២ (ការប្រើប្រាស់ការគំរាមកំហែង រួមទាំងការគំរាមសម្លាប់) កថាខណ្ឌ ៣៦២៣ (បរិយាកាសនៃការភ័យខ្លាចទូទៅមិនអនុញ្ញាតឱ្យពួកគេជំទាស់នឹងបញ្ហាទេ) កថាខណ្ឌ ៣៦២៤ (ការគំរាមកំហែងដែលបានអនុវត្ត) កថាខណ្ឌ ៣៦២៥ (សន្និដ្ឋានថា "មិនអាចមានការយល់ព្រម

បានពិភាក្សានៅផ្ទែកដទៃ ការយល់ព្រមតែមួយគត់ ដែលមានតម្លៃគឺការយល់ព្រម ពីថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា៖ ការណែនាំរបស់អង្គការ គឺជាការណែនាំស្ថាពរ ទោះបីជាបុគ្គលម្នាក់បានយល់ព្រមពិតប្រាកដ ឬមិនពិតប្រាកដក៏ដោយ[2404]។

701. ផ្ទុយពីការអះអាងបន្ទាប់របស់ម្ចាស់បណ្តឹងសាទុក្ខ ការសម្រេចលើអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ក្នុងករណីភាគច្រើន ឪពុកម្តាយមិនមានវត្តមានក្នុងពិធីរៀបការ" គឺមានការគាំទ្រដោយភស្តុតាងជាច្រើនដែលថា ឪពុកម្តាយមិនត្រូវបានអនុញ្ញាត ឱ្យដើរតួនាទីបែបប្រពៃណី ឬជាញឹកញាប់គឺគ្មានតួនាទីអ្វីសោះ នៅក្នុងការរៀបអាពាហ៍ពិពាហ៍ កូនៗរបស់ពួកគាត់[2405]។ ការពិតដែលថាម្ចាស់បណ្តឹងសាទុក្ខ បានកំណត់អំពីករណីមួយចំនួនតូច ដែលឪពុកម្តាយមានវត្តមាននៅពិធីរៀបអាពាហ៍ពិពាហ៍ មិនបានបង្ហាញពីកំហុសឡើយ ព្រោះឧទាហរណ៍ទាំងនេះ ស្របគ្នាជាមួយការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលប្រើប្រាស់ "ភាគច្រើន" ដើម្បីទទួលស្គាល់ថា ក្នុងករណីខ្លះ ឪពុកម្តាយបានចូលរួមពិធីរៀបអាពាហ៍ពិពាហ៍[2406]។

702. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយគ្មានមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មិនគួរទាញសន្និដ្ឋានជាទូទៅ ពីភស្តុតាងរបស់ ឯក ហឿន និង ស៊ូ សុធាវីឡើយ ព្រោះពួកគេគឺជាករណីហួសហេតុ នៃការរៀបអាពាហ៍ពិពាហ៍ជាក្រុម[2407]។ បើទោះបីជាហួសហេតុ ប៉ុន្តែករណីពួកគេមិនមែនខុសប្លែកពីគេឡើយ ហើយករណីទាំងនេះគ្រាន់តែ ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញ ពីទំហំដែលអាច

---

ពិតប្រាកដឡើយ") កថាខណ្ឌ ៣៦៧៣-៣៦៧៤ (ការអនុវត្តបែបបង្ខិតបង្ខំនៅត្រាំកក់) កថាខណ្ឌ ៣៦៧៦ (ការអនុវត្តបែបបង្ខិតបង្ខំនៅទំនប់ត្រពាំងថ្ម) ៣៦៧៧-៣៦៧៨ (ការអនុវត្តបែបបង្ខិតបង្ខំនៅទំនប់១មករា)។

[2404] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥។

[2405] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៥១-១២៥៤ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៩០-៣៦៩១, ៣៦៩៣ (ដកស្រង់ការសន្និដ្ឋាននៅកថាខណ្ឌ ៣៦៩១)។ សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៧២-៣៥៨០ (អាជ្ញាធរទទួលខុសត្រូវលើការសម្រិតសម្រាំងប្រត្តិរូប និងផ្សំផ្គុំ ដែលជាតួនាទីជាប្រពៃណីរបស់ឪពុកម្តាយ) កថាខណ្ឌ ៣៦១២ (ភស្តុតាងដែលបញ្ជាក់ថា ឪពុកម្តាយ "ពុំបានចូលរួមពិគ្រោះយោបល់ ឬបានទទួលដំណឹង" អំពីការរៀបអាពាហ៍ពិពាហ៍កូនរបស់ពួកគេទេ) កថាខណ្ឌ ៣៦៣៩, ៣៦៩១ (បុគ្គលបង្ហាញពីការមិនសប្បាយចិត្ត ដោយសារឪពុកម្តាយរបស់ពួកគេអវត្តមាន)។

[2406] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៥៤, ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានបដិសេធជាលក្ខណៈប្រព័ន្ធនូវសក្ខីកម្មរបស់អតីតកម្មាភិបាល។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦១២-៣៦១៣។

[2407] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៥៥ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៣១-៣៦៣២, ៣៦៩១។

ឈានទៅដល់ប៉ុណ្ណោះ។ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក៏មានភស្តុតាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី យ៉ាងច្រើនលើសលប់ ដែលបង្ហាញថាពិធីរៀបអាពាហ៍ពិពាហ៍ជាសមូហភាពត្រូវបានប្រើប្រាស់ក្នុងលក្ខណៈជាប្រព័ន្ធ និងទូលំទូលាយបែបនេះ ដែលអាចច្រានចោលទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា មានកម្មាភិបាលមូលដ្ឋានតែពីរបីនាក់ប៉ុណ្ណោះ ដែលបានប្រើប្រាស់សិទ្ធិសម្រេចរបស់ខ្លួន សម្រាប់ការអនុវត្តជាក់ស្តែង[2408]។ ការពន្យល់របស់ ពេជ្រ ជឹម ដែលថា ការរៀបអាពាហ៍ពិពាហ៍ជាសមូហភាព ត្រូវបានរៀបចំឡើយដោយសារតែ "មនុស្សច្រើនទៅៗចង់រៀបការ" ត្រូវបានច្រានចោលប្រហែលគ្នានេះ ដោយភស្តុតាងយ៉ាងច្រើន អំពីគូស្រករដែលត្រូវបានជូនដំណឹង អំពីការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ នៅពេលដែលពួកគេទៅដល់កន្លែងពិធី ឬនៅមុនពិធីបន្តិច។ ដូច្នេះជាការសមហេតុផល ហើយស្ថិតក្នុងឆន្ទានុសិទ្ធិ របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដកចេញនូវការពន្យល់របស់គាត់[2409]។

703. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនូវទឡ្ហីករណ៍ដោយខុសឆ្គងថា ដោយពិចារណាទៅលើកង្វះខាតភាពរួមគ្នា នៃការអនុវត្តនៅពិធីរៀបអាពាហ៍ពិពាហ៍នោះ មិនមានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចធ្វើការសន្និដ្ឋានថា បក្សកុម្មុយនីស្តកម្ពុជាបានចេញ គោលការណ៍ណែនាំជាក់លាក់ អំពី ការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ឡើយ[2410]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ ការខុសប្លែកគ្នាក្នុងការអនុវត្ត នៅទូទាំងភូមិភាគនានា ប៉ុន្តែការវាយតម្លៃជារួមទៅលើភស្តុតាង បានបង្ហាញច្បាស់ពីភាពរួមគ្នា ក្នុងលក្ខណៈពិសេសជាមូលដ្ឋាន នៃពិធីរៀប

---

[2408] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៣១-៣៦៣២ និងការដកស្រង់ទាំងអស់ដែលមានក្នុងកថាខណ្ឌទាំងនេះ, កថាខណ្ឌ ៣៥៨៧-៣៥៨៨, ៣៥៩៧ (ទាក់ទងនឹង ពិធីរៀបការជាសមូហភាពដែលត្រូវបានរៀបចំឡើងតាមការណែនាំរបស់លេខាភូមិភាគនិរតី តាម៉ុក)។ សូមមើលផងដែរ ឧបសម្ព័ន្ធ I១-I៤ នៃឯកសារ **E457/6/1** សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះអាជ្ញា (ដែលបង្ហាញបន្ថែមទៀតពីការអនុវត្តជាទូទៅនៃការរៀបចំពិធីរៀបការជាសមូហភាព)។

[2409] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦១៤-៣៦១៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៥៥។

[2410] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៥៦-១២៥៧ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤៨, ៣៦៣៣-៣៦៣៥។

អាពាហ៍ពិពាហ៍[2411]។ ការអះអាងដែលនៅសេសសល់ របស់ម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញ អំពីកំហុសឡើយ[2412]។

## *មូលដ្ឋានទី ១៦៧៖ កំហុសពាក់ព័ន្ធនឹងការអនុវត្ត បទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍*[2413]

704. **មូលដ្ឋានទី ១៦៧ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុក្នុងការសម្រេចថា ពិធីរៀបអាពាហ៍ពិពាហ៍ ដែលរៀបចំឡើងដោយអាជ្ញាធរ គឺគោរពទៅតាមសេចក្ដីណែនាំពីខាងលើ ហើយថាទាំងបុរសនិងស្ត្រី ត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។**

705. ម្ចាស់បណ្ដឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសថា អង្គជំនុំជម្រះសាលាដំបូង មិនគិតពិចារណាអំពី ឯកសារគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជាដែលក្រើនរំលឹក ដល់កម្មាភិបាលអំពីភាពចាំបាច់ ក្នុងការពិចារណាអំពី "សេចក្ដីត្រូវការរបស់ប្រជាជន ក្រោមការគ្រប់គ្រងរបស់ខ្លួន" ហើយអនុវត្តមាគ៌ាបក្សដោយមិនត្រឹមត្រូវ[2414]។ ទោះបីជា "សេចក្ដីត្រូវការរបស់ប្រជាជន" ពិតជាផ្នែកមួយនៃលក្ខន្តិកៈ បក្សកុម្មុយនីស្តកម្ពុជាក្តី តែឯកសារនិងសេចក្ដីថ្លែងការណ៍នានា ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញយ៉ាងច្បាស់ថា គោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវតែអនុវត្តចាប់ពីថ្នាក់លើ រហូតដល់ថ្នាក់ក្រោម គឺដើម្បីផល

[2411] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២៦-៣៦២៩, ៣៦៣១, ៣៦៣៣-៣៦៣៥ (ជាទូទៅ ការប្ដេជ្ញាចិត្តត្រូវបានធ្វើឡើង ហើយអាជ្ញាធរចូលរួម) កថាខណ្ឌ ៣៦៣៦-៣៦៣៨ (មិនអនុវត្តតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ) កថាខណ្ឌ ៣៦៣៩-៣៦៤០ (ជាទូទៅ ក្រុមគ្រួសារអវត្តមាន) កថាខណ្ឌ ៣៦៤០-៣៦៤១។

[2412] ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខនៅក្នុងឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៤៨ *ដែលជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៩៣, មិនលម្អិត និងបំប្លែងការសន្និដ្ឋាន។ អ.ជ.ស.ដ មិនបានសន្និដ្ឋានថា ការប្រើប្រាស់ការគំរាមកំហែងដើម្បីបង្ខំប្រជាជនឱ្យរៀបអាពាហ៍ពិពាហ៍ ជា "ការណែនាំពីថ្នាក់ដឹកនាំនយោបាយរបស់ ប.ក.ក" ប៉ុន្តែ ផ្ទុយទៅវិញ "អាជ្ញាធរបានប្រើប្រាស់ការគំរាមកំហែង ដើម្បីបង្ខំបុគ្គលទាំងនោះឱ្យរៀបការ ហើយបានចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តដំណើរការតាមដានផងដែរ"។ ទាក់ទងនឹងការបដិសេធរបស់ម្ចាស់បណ្ដឹងសាទុក្ខនៅក្នុងកថាខណ្ឌ ១២៥៨ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២៥, ៣៦៤០-៣៦៤១ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែបង្ហាញថា គាត់មិនយល់ព្រម ដោយពុំធ្វើការបកស្រាយពីការអះអាងរបស់គាត់។

[2413] <u>មូលដ្ឋានទី ១៦៧</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងការអនុវត្តបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍* កថាខណ្ឌ ១២៤៣, ១២៧១-១២៨០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៥៨ (ភាសាអង់គ្លេស) ទំព័រ ៥៣ (ភាសាបារាំង) ទំព័រ ៨២-៨៣ (ភាសាខ្មែរ)។

[2414] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៤៣, ១២៧១-១២៧២ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤០-៣៦៤១។

ប្រយោជន៍បដិវត្ត មិនមែនដើម្បីផលប្រយោជន៍ប្រជាជនទេ[2415]។ ជាដំបូង បក្សកុម្មុយនីស្តកម្ពុជា បានបោះផ្សាយគោលនយោបាយរបស់ខ្លួន អំពីការកសាងគ្រួសារ នៅក្នុងទស្សនាវដ្ដីទង់បដិវត្ត លេខចេញខែកុម្ភៈ ឆ្នាំ១៩៧៤ ហើយបោះផ្សាយឡើងវិញនៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ ដោយផ្ទុះបញ្ចាំងពីសារសំខាន់ដែលបក្សផ្ដល់ សម្រាប់ការអនុវត្តដោយពេញលេញ លើគោលនយោបាយនេះ នៅទូទាំងប្រទេស[2416]។ ទស្សនាវដ្ដីទង់បដិវត្តលេខបន្តបន្ទាប់ បានផ្ដល់គោលការណ៍ណែនាំ អំពីការដែលបុគ្គលម្នាក់ៗគួរជ្រើសរើសគូស្រករដោយរបៀបណា ដើម្បី "ស្របជាមួយនឹងផលប្រយោជន៍សមូហភាព"[2417]។ សេចក្ដីសម្រេចដែលបានអនុម័ត នៅក្នុងពេលប្រជុំមហាជន "ដាក់ប្រយោជន៍គ្រួសារនិងផ្ទាល់ខ្លួនទាំងស្រុង ជាប្រយោជន៍រួមរបស់ជាតិ"[2418]។ ទោះបីជាមានការខុសប្លែក បន្តិចបន្តួចនៅតាមតំបន់ក្ដី តែទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អាជ្ញាធរមូលដ្ឋាន មិនបានអនុវត្តមាគ៌ាបក្សដោយត្រឹមត្រូវនេះ គឺជាការបំភាន់។ ការអនុវត្តការផ្សំផ្គុំ ការរៀបចំ និងការប្រារព្ធពិធី រៀបអាពាហ៍ពិពាហ៍ គឺមានភាពប្រហែលគ្នាខ្លាំង នៅទូទាំងប្រទេស ដែលបានបង្កើតនូវទំរង់ដែលបង្ហាញយ៉ាងច្បាស់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាផ្នែកមួយនៃគោលនយោបាយកណ្ដាល របស់បក្សកុម្មុយនីស្តកម្ពុជា[2419]។ ទឡ្ហីករណ៍ដែលនៅសល់របស់ ម្ចាស់បណ្ដឹងសាទុក្ខ ដែលបានពិភាក្សានៅផ្នែកដទៃទៀត ក្នុងចម្លើយតបនេះ ក៏ពុំមានមូលដ្ឋានដែរ[2420]។

---

[2415] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤០-៣៥៤៨។

[2416] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤០ (បង្ហាញលម្អិតពីខ្លឹមសារនៃទស្សនាវដ្ដីយុវជននិងយុវនារីបដិវត្តដែលលើកឡើងពីទស្សនៈបដិវត្តន៍ស្ដីពីការកសាងគ្រួសារ ដោយចាត់ទុកបញ្ហាគ្រួសារជាផ្នែកមួយបេះមិនដាច់ពីបញ្ហាប្រទេសជាតិទាំងមូល)។

[2417] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤២-៣៥៤៣។

[2418] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤៨ ជើងទំព័រ ១១៩២៧។

[2419] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២៩-៣៦៤០ (ការអនុវត្តរួមរួមមានការរៀបចំពិធីជាសមូហភាព មិនគោរពតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ និងពុំមានវត្តមានរបស់ឪពុកម្ដាយ)។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៩។

[2420] សម្រាប់ទឡ្ហីករណ៍នៅសេសសល់របស់ម្ចាស់បណ្ដឹងសាទុក្ខនៅក្នុងឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៧៣-១២៨០, សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥ (កថាខណ្ឌ ១២៧៣-១២៧៨ ទាក់ទងនឹងការអះអាងដែលថា អ.ជ.ស.ដ មិនបានពិចារណាលើភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿង), ៣៧ (កថាខណ្ឌ ១២៧៩ ទាក់ទងនឹងការប្រព្រឹត្តិរបស់ អ.ជ.ស.ដ ចំពោះភស្តុតាងរបស់អ្នកជំនាញស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ), ១៦៨ (កថាខណ្ឌ ១២៨០ ទាក់ទងនឹងភស្តុតាងដែលបានផ្អែកលើ ដើម្បីសន្និដ្ឋានថា ប.ក.ក មានបំណងអនុវត្តបទបញ្ជាស្ដីពីការរៀបអាពាហ៍ពិពាហ៍)។

## *មូលដ្ឋានទី ១៦៦៖ ការបំភ្លៃភស្តុតាងស្តីពី គោលបំណងផ្សេងទៀត ដែលបានចោទប្រកាន់*[2421]

706. **មូលដ្ឋានទី ១៦៦ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឬមានលម្អៀង ក្នុងការវាយតម្លៃរបស់ខ្លួន ទៅលើភស្តុតាងទាក់ទងនឹងគោលបំណងនៃគោលនយោបាយ រៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។**

707. ម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់ដោយគ្មានមូលដ្ឋាន អំពីកំហុសឆ្គងជាច្រើន ដើម្បីជំទាស់ចំពោះការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលថា បក្សកុម្មុយនីស្តកម្ពុជា មានគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលគ្រប់គ្រងលើទំនាក់ទំនងផ្លូវភេទ ដើម្បីបង្កើនចំនួនប្រជាជន[2422]។ ប៉ុន្តែការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញភស្តុតាងគាំទ្រ ដែលអាចបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង ឈានដល់ការសម្រេចមួយ ដែលមិនមានចៅក្រមប្រកបដោយ វិចារណញ្ញាណណាម្នាក់ អាចសម្រេចបែបនេះនោះឡើយ។

708. **ការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅលើទំនាក់ទំនង៖** ម្ចាស់បណ្តឹងសាទុក្ខបានជំទាស់ចំពោះការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលថា គោលនយោបាយស្តីពីការ រៀបអាពាហ៍ពិពាហ៍ របស់បក្សកុម្មុយនីស្តកម្ពុជា គ្រប់គ្រងទៅលើទំនាក់ទំនងផ្លូវភេទបុរសស្ត្រី ទាំងនៅមុនពេលរៀបការ និងក្រោយពេលរៀបការ[2423]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសថា អង្គជំនុំជម្រះសាលាដំបូងគួរសម្រេចថា ការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា នៅមុនពេលរៀបអាពាហ៍ពិពាហ៍ គឺស្របជាមួយប្រពៃណីខ្មែរ ដែលហាមឃាត់ទំនាក់ទំនងផ្លូវភេទ ក្រៅចំណងអាពាហ៍ពិពាហ៍[2424]។ ជាថ្មីម្តងទៀត ការព្យាយាមបញ្ចូលគ្នា នូវការប្រតិបត្តិការរៀប

---

[2421] <u>មូលដ្ឋានទី ១៦៦</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងគោលបំណងរបស់ ប.ក.ក* កថាខណ្ឌ ១២១៦-១២៤២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៧ (ភាសាអង់គ្លេស) ទំព័រ ៥២-៥៣ (ភាសាបារាំង) ទំព័រ ៨២ (ភាសាខ្មែរ)។

[2422] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១៦ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤៩-៣៥៦៣។

[2423] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១៧ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥៩-៣៥៦៣, ៣៦៦២-៣៦៦៣, ៣៦៦៩។

[2424] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១៨។ ម្ចាស់បណ្តឹងសាទុក្ខក៏បានចោទប្រកាន់ដោយភាន់ច្រឡំ អ.ជ.ស.ដ ថាបានលាក់បាំងភស្តុតាងអំពីគោលការណ៍សីលធម៌របស់បក្ស និងបដិសេធគោលកាណ៍សីលធម៌នៅត្រឹម "ការការពារបដិវត្តន៍"។ ទោះជាយ៉ាងនេះ កថាខណ្ឌមួយក្នុងចំណោមកថាខណ្ឌនៃសាលក្រមដែលម្ចាស់បណ្តឹងសាទុក្ខជំទាស់ដោយផ្ទាល់ ផ្ទុយនឹងការអះអាងរបស់គាត់ ដោយសារតែកថាខណ្ឌនោះលើកឡើងពីការពណ៌នារបស់ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តពីសីលធម៌ទាំង ១២ ប្រការ ថាជា "ក្រិត្យវិន័យរបស់បក្ស" និងកត់សម្គាល់ថា ការរំលោភស្ត្រី ប៉ះពាល់ដល់

អាពាហ៍ពិពាហ៍ នៅរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយការប្រតិបត្តិការរៀបអាពាហ៍ពិពាហ៍ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការមិនគិតពិចារណាអំពីភ័ស្តុតាង នៃបរិយាកាសដែលបុគ្គលម្នាក់ៗរស់នៅ ស្ថិតក្រោមការភ័យខ្លាចជាប្រចាំ ថាត្រូវស្លាប់ដោយសារតែសកម្មភាពរបស់ខ្លួន។ មិនត្រឹមតែទំនាក់ទំនងបុរសនារី ដែលសូម្បីទំនាក់ទំនងមិនមែនផ្លូវភេទ ក្រៅអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាជា ការងាកចេញពីគោលដៅ កសាងជាតិឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែទំនាក់ទំនងនេះថែមទាំងត្រូវបានចាត់ទុកថាជា កំហុសសីលធម៌ដែលអាចត្រូវទទួលទណ្ឌកម្ម តាមរយៈការរៀនសូត្រ ឬអាចដល់សម្លាប់[2425]។ មិនអាចឡើយដែលចាត់ទុកការនេះថាជា "ការបន្តប្រពៃណីខ្មែរ។

709. ប្រហែលគ្នានេះ ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញដោយបំភាន់នូវភ័ស្តុតាង នៅពេលដែលជំទាស់ចំពោះការសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការលែងលះ។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[2426] អង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណា ទៅលើកិច្ចសម្ភាសន៍របស់ ប៉ុល ពត ដែលបញ្ជាក់ថា ការលែងលះអាចធ្វើទៅបាន ប៉ុន្តែវាត្រូវបានប្រឆាំងដោយបរិបទ ក្នុងការថ្លែងប្រកាសនេះ ដែលបង្ហាញថាវាជាការឃោសនា[2427]។ ការថ្លែងនេះក៏ផ្ទុយផងដែរ ពីភ័ស្តុតាងដែលអាចជឿជាក់បាន ដែលរៀបរាប់អំពីបរិយាកាសភ័យខ្លាចគ្រប់ទីកន្លែង ដែល

---

សីលធម៌នារី-បុរស "ប្រពៃណីស្អាតស្អំនិងបរិសុទ្ធរបស់ប្រជាជន" និងបដិវត្តន៍។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦០ (គូសបញ្ជាក់បន្ថែម)។

[2425] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦២-៣៥៦៣ និងការដកស្រង់ទាំងអស់ដែលមានក្នុងកថាខណ្ឌទាំងនេះ។ ម្ចាស់បណ្តឹងសាទុក្ខក៏ជំទាស់ផងដែរទៅនឹងការសន្និដ្ឋានថា កំហុសសីលធម៌ត្រូវបានរាយការណ៍ទៅមជ្ឈិមបក្ស ដោយអះអាងថា "មជ្ឈិមបក្ស" មានលក្ខណៈទូលាយ និងបង្កើតឱ្យមានទំនាក់ទំនងសិប្បនិម្មិតរវាងម្ចាស់បណ្តឹងសាទុក្ខនិងអង្គហេតុ (សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២១៩)។ ការអះអាងនេះក៏មានលើកឡើងនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៩០ ដែរ។

[2426] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២០ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៦៩។

[2427] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៦៦-៣៦៦៨ (នៅក្នុងកិច្ចសម្ភាសន៍ជាមួយប្រតិភូសមាគមបែលហ្ស៊ិក-កម្ពុជា ប៉ុល ពត បញ្ជាក់ថា "ភាគីពាក់ព័ន្ធនោះមិនចាំបាច់ឡើងតុលាការទេ"។ ដោយនៅពេលនោះ មិនមានតុលាការទេ នេះបានអនុញ្ញាតឱ្យ អ.ជ.ស.ដ សន្និដ្ឋានថា ជាការយល់ខុស)។

បុគ្គលម្នាក់ៗមិនអាចបង្ហាញ អំពីការមិនពេញចិត្តជាមួយ គូស្រកដែលបានជ្រើសរើសឡើយ ដែលច្បាស់ណាស់ថាមិនអាចមានការលែងលះ[2428]។

710. **គោលដៅបង្កើនចំនួនប្រជាជន៖** ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសម្រេចថា គោលដៅមួយនៅក្រោយបទបញ្ជា ស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺជម្រុញកំណើនប្រជាជន[2429]។ ផ្ទុយពីការអះអាងរបសម្ចាស់បណ្តឹងសាទុក្ខ ការសម្រេចទៅលើការទៅសួរសុខទុក្ខប្តីប្រពន្ធ មិនបានប្រឆាំងជាមួយការសម្រេចនេះទេ[2430] ការសម្រេចពីការសួរសុខទុក្ខ គ្រាន់តែបង្ហាញថាគោលដៅនៃការបង្កើនចំនួនប្រជាជន ត្រូវតែរួមគ្នាជាមួយគោលដៅកសាងហេដ្ឋារចនាសម្ព័ន្ធជាតិឱ្យបានឆាប់រហ័ស។ ដើម្បីសម្រេចគោលដៅទាំងពីរ បក្សត្រូវប្រើប្រាស់ការគ្រប់គ្រងដាច់ខាត ដើម្បីកុំឱ្យប៉ះពាល់ដល់គោលដៅណាមួយ។ បក្សសម្រេចបែបនេះបាន តាមរយៈការតាមដានដោយម៉ត់ចត់ ទៅលើគូស្រកដែលទើបរៀបការថ្មីថ្មោង ដើម្បីធានាថាពួកគេផ្សំដំណេក នៅក្នុងអំឡុងពេលវេលាដ៏ខ្លី ដែលពួកគេនៅជាមួយគ្នា[2431] ហើយវាបង្កើតបានជាប្រព័ន្ធ នៃការសួរសុខទុក្ខរយៈពេលខ្លី សម្រាប់ទំនាក់ទំនងបន្តទៀត ដែលដើរតួនាទីបំពេញតាមគោលដៅ នៃការបង្កើតចំនួនប្រជាជន ដោយមិនងាកចេញពីការផលិត[2432]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញ ពីកំហុសក្នុងការវាយតម្លៃជារួម របស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

711. **កំហុសក្នុងការវាយតម្លៃភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង៖** ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយខុសថា ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើឯកសារនិងសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា បានលប់ចេញដោយខុសឆ្គង នូវការលើកឡើងអំពីគោលបំណង របស់

2428 សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៦៨ (បុគ្គលត្រូវបានតម្រូវឱ្យលាក់បាំងការដែលពួកគេរស់នៅមិនចុះសម្រុងគ្នា ឬមិនស្រឡាញ់គ្នា។ ការភ័យខ្លាចគេស្តីបន្ទោស បញ្ជូនទៅរៀនសូត្រ ឬសម្លាប់ធ្វើឱ្យពួកគេមិនហ៊ានសុំការលែងលះ)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២០។

2429 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២១-១២២២ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥៨, ៣៦៦២-៣៦៦៤, ៣៦៩០-៣៦៩១, ៣៦៩៦-៣៦៩៨។

2430 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៦៣។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២២។

2431 សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤១-៣៦៤៧, ៣៦៥៤, ៣៦៥៦-៣៦៥៧, ៣៦៦០-៣៦៦២។

2432 សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៦២-៣៦៦៥។ សូមមើលផងដែរ ឯកសារ **E3/20** Elizbeth Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* KH 00232298 (រៀបរាប់ពីតុល្យភាពនេះថា ជួនកាលដែលពេលខ្លះហាក់ដូចជា "លែងស្រឡាញ់ ឬជាប់ចិត្ត")។

បក្សកុម្មុយនីស្តកម្ពុជា ក្នុងការសម្រេចបានគោលដៅ កំណត់ប្រជាជន តាមការលើកស្ទួយជីវភាពប្រជាជន និងសុខភាពប្រជាជន[2433]។ ដូចដែលបានពិភាក្សានៅផ្នែកផ្សេងៗ ក្នុងចម្លើយតបនេះហើយ សកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា បានបង្ហាញច្បាស់លាស់ជាង "គោលបំណង" ដែលបានលើកឡើងរបស់ខ្លួន ព្រោះភ័ស្តុតាងជាច្រើនបង្ហាញថា ជាច្រើនលើកច្រើនសារ បក្សសុខចិត្តលះបង់សុខុមាលភាពប្រជាជន ដើម្បីផ្តល់អាទិភាពដល់ គោលដៅបដិវត្ត[2434]។ នេះគឺជាការពិតផងដែរ ចំពោះគោលដៅកំណើនប្រជាជន ដែលជារួមគឺបង្កការឈឺចាប់ ចំពោះអ្នកដែលទទួលរងនូវគោលដៅនេះ ក្នុងលក្ខណៈមួយជាប្រព័ន្ធ និងក្នុងទ្រង់ទ្រាយធំ ដែលអាចពន្យល់បានតែម្យ៉ាងគត់ ដោយសារគោលនយោបាយ ដែលបង្កើតឡើងពីថ្នាក់មជ្ឈឹម ដែលមានការគាំទ្រពីកម្រិតខ្ពស់បំផុត[2435]។ ជាចុងក្រោយម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងដោយខុសថា មូលហេតុតែមួយដែលដើមបណ្តឹងរដ្ឋប្បវេណី ទទួលរងការឈឺចាប់ពីគោលដៅ បង្កើនចំនួនប្រជាជននោះ គឺដោយសារតែមិនមានការថែទាំ និងថ្នាំសង្កូវ សម្រាប់ស្ត្រីមានផ្ទៃពោះប៉ុណ្ណោះ[2436]។ ទោះបីជាការនេះប្រាកដណាស់ថា ជាប្រភពនៃការឈឺចាប់ក្តី ប៉ុន្តែជារឿងអយុត្តិធម៌ ដែលបំភ្លេចចោលនូវបរិបទទាំងស្រុង ដែលអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកដោយត្រឹមត្រូវទៅលើ សម្រាប់ការសម្រេចរបស់ខ្លួន[2437]។ ការអះអាងដទៃទៀតរបស់ ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងសក្ខីកម្មរបស់អតីតកម្មាភិបាល

[2433] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២៣-១២២៤ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤៩-៣៩៥៥។

[2434] សូមមើលឧទាហរណ៍ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១, ១៨៣ (ម្ចាស់បណ្តឹងសាទុក្ខអះអាងថា គោលបំណងមួយក្នុងចំណោមគោលបំណងនៃការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ គឺដើម្បីកែលម្អជីវភាពរស់នៅរបស់ប្រជាជនឱ្យបានប្រសើរឡើង ប៉ុន្តែ ប្រការនេះត្រូវបានបង្ហាញថាខុស តាមរយៈការនាំចេញអង្ករក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់របស់បក្ស ដើម្បីបង្កើតមូលធន ទោះបីជាមានបញ្ហាខ្វះស្បៀងក្នុងប្រទេស និងការតម្រូវនូវលក្ខខណ្ឌអមនុស្សធម៌ ទោះបីជាវាប៉ះពាល់ដល់កម្មករក៏ដោយ)។

[2435] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៩, ២៩៦, ៣១៧, ៣២១, ៣៦៣១, ៣៦៩០។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២៤ (អះអាងថា អ.ជ.ស.ដ បានបំភ្លេចចោលភ័ស្តុតាងរបស់ "កម្មាភិបាលដែលធ្វេសប្រហែសនឹងតួនាទីរបស់ខ្លួនក្នុងការ [...] បម្រើប្រជាជន")។

[2436] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៣២។

[2437] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧៩-៣៦៨២ (ទាក់ទងនឹងផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) កថាខណ្ឌ ៣៦៨៣-៣៦៨៥ (ទាក់ទងនឹង ផលប៉ះពាល់នៃការរួមដំណេកដោយបង្ខំ) កថាខណ្ឌ ៤៤៥២ (ទាក់ទងនឹងការប៉ះទង្គិចធ្ងន់ធ្ងរដែលដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់បានទទួលរង ក្រោយការបង្ខំរួមភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ សូមមើល ជាពិសេស ភ័ស្តុតាងរបស់ សយ ណារឿន ដែលបញ្ជាក់យ៉ាងច្បាស់ថា ការឈឺចាប់របស់គាត់មិនបណ្តាលមកពីកង្វះការថែទាំវេជ្ជសាស្ត្រ ដូចដែលម្ចាស់បណ្តឹងសាទុក្ខបានអះអាងនោះទេ)។ សូមមើល បន្ថែមទៀត ភ័ស្តុតាងដែលបញ្ជាក់ថា កង្វះការថែទាំស្ត្រីមានផ្ទៃពោះសមស្របជាកំហុសរបស់

និងការចោទពីការពឹងផ្អែកជ្រុល ទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី មកពីផ្នែកការរៀបអាពាហ៍ពិពាហ៍ នៃសវនាការ ត្រូវបានបង្ហាញថាគ្មានមូលដ្ឋាន នៅផ្នែកដទៃក្នុងចម្លើយតបនេះ[2438]។

## *ភាពអាចជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប*

712. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសម្រេចថា សក្ខីកម្មរបស់ ជា ឌៀប គឺអាចជឿជាក់បាន ជាពិសេសក្នុងការបង្ហាញអំពី ការចូលរួមដោយផ្ទាល់របស់ ខៀវ សំផន នៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2439]។ ការអះអាងរបស់គាត់ដែលថា ការពឹងផ្អែករបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើចម្លើយរបស់ ជា ឌៀប "បានរំលោភលើវិធានទាំងអស់ស្តីពី ការវាយតម្លៃភស្តុតាង" ត្រូវបានច្រានចោលដោយផ្ទាល់ ដោយយុត្តិសាស្ត្រដែលបានកំណត់ថា អ្នកវិនិច្ឆ័យលើអង្គហេតុ អាចពឹងផ្អែកទៅលើសាក្សីតែម្នាក់ ដើម្បីគាំទ្រការសម្រេច បើទោះបីជាមិនមានការគាំទ្រក្តី[2440]។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានសម្រេចយ៉ាងច្បាស់ផងដែរថា អង្គជំនុំជម្រះសាលាដំបូង អាចពឹងផ្អែកទៅលើសក្ខីកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការសម្រេចលើពិរុទ្ធភាព[2441]។

---

ប.ក.ក មួយផ្នែក៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣១២-១៣១៩ (ទាក់ទងនឹង វិធីសាស្ត្ររបស់ ប.ក.ក ទាក់ទងនឹងការថែទាំសុខភាព រួមទាំងជំហារមនោគមវិជ្ជាក្នុងការបដិសេធជំនួយវេជ្ជសាស្ត្រពីបរទេសលើកលែងតែប្រទេសចិន ដោយខ្លាចថា ជំនួយបែបនេះមានលក្ខខណ្ឌមិនអាចទទួលយកបាន) កថាខណ្ឌ ៣៩១៣ (គ្រូពេទ្យត្រូវបានជំនួសដោយអ្នកគ្មានជំនាញ ដែលគ្មានសមត្ថភាព ឬគ្មានការបណ្តុះបណ្តាល)។

[2438] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥, *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២៥-១២៣២។ ការដែលថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានគ្រប់គ្រងនៅថ្នាក់ជាតិ (សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧០) ជំទាស់នឹងការអះអាងបន្ថែមទៀតថា អ.ជ.ស.ដ មិនពិចារណាលើសក្ខីកម្មដែលបញ្ជាក់ថា កម្មាភិបាលទទួលខុសត្រូវ ធ្វេសប្រហែសនឹងតួនាទីរបស់ខ្លួនក្នុងការបម្រើប្រជាជន (ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២២៤)។

[2439] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៣៣-១២៤២ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥៧, ៣៥៦៩, ៣៥៧០ (ជើងទំព័រ ១១៩៨០), ៤២៤៧។

[2440] *សាលដីការឿងក្តី* *Nahimana* កថាខណ្ឌ ៩៤៩ (កត់សម្គាល់ផងដែរថា ចៅក្រមជំនុំជម្រះ "អាចវាយតម្លៃភាពអាចជឿទុកចិត្តបានរបស់សាក្សី និងភាពអាចជឿជាក់នៃភស្តុតាងដែលបានបង្ហាញ")។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៣៣-១២៣៤។

[2441] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣១៣។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៣៥ (យោងទៅការដែល ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី គាត់មិនត្រូវបានតម្រូវឱ្យធ្វើសច្ចាប្រណិធានទេ)។

713. ចំពោះការអះអាងដែលជាក់លាក់ជាងនេះ របស់ម្ចាស់បណ្ដឹងសាទុក្ខ ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា ភស្តុតាងដាក់បន្ទុករបស់ ជា ឌៀប គឺមាន "លក្ខណៈយឺត" ដែលដកស្រង់ដោយគ្មានមូលដ្ឋានគតិយុត្តិគាំទ្រដល់ការលើកឡើងថា ព្រះរាជអាជ្ញាមិនតម្រូវឱ្យពន្យល់ថា ហេតុអ្វីទើបចម្លើយនាពេលក្រោយរបស់គាត់ មានព័ត៌មានបែបនេះ[2442]។ សំខាន់បំផុតនោះ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានសួរដេញដោលយ៉ាងច្រើន លើបញ្ហានេះនៅក្នុងសវនាការ ហើយគាត់បានពន្យល់ថា គាត់មិនចាំថានរណាដែលជួយគាត់ បំពេញទម្រង់ចំនួនពីរដំបូងរបស់គាត់ទេ ហើយគាត់មិនចាំថាតើ គាត់បាននិយាយដែរឬអត់ ថាបានឃើញម្ចាស់បណ្ដឹងសាទុក្ខ នៅក្នុងការប្រជុំនោះ ប៉ុន្តែប្រសិនបើគាត់បំពេញទម្រង់ដោយខ្លួនឯង គាត់នឹងបញ្ចូលព័ត៌មានដូចដែលគាត់បានបញ្ចូលនៅពេលដែលគាត់ធ្វើជាមួយមេធាវីរបស់គាត់ នៅក្នុងឆ្នាំ២០១៤ហើយ[2443]។ អង្គជំនុំជម្រះសាលាដំបូង បានវិនិច្ឆ័យលើអាកប្បកិរិយាដែលស្ដែងចេញ និងភាពសមទំនងរបស់គាត់ ក្នុងការពន្យល់បកស្រាយ ហើយសម្រេចថាគាត់អាចជឿជាក់បាន តាមរយៈការវិនិច្ឆ័យម៉ត់ចត់ គឺមិនមែនជាមនុស្សដែលព្យាយាមឆ្លើយដាក់ ម្ចាស់បណ្ដឹងសាទុក្ខតាមគ្រប់រូបភាព ដូចដែលបានលើកឡើង ក្នុងទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខនោះឡើយ[2444]។ ប្រហែលគ្នានេះ ការជំទាស់ចំពោះភស្តុតាងរបស់ ជា ឌៀប ក្នុងការកំណត់អត្តសញ្ញាណ គឺខុស ដោយសារតែមានការបដិសេធដោយចេតនាមិនទទួលស្គាល់នូវភាពខុសគ្នារវាង "ជួប" នរណាម្នាក់ដោយផ្ទាល់ ហើយនិង "ឃើញ" នរណាម្នាក់ និងត្រូវបានគេប្រាប់ថាជានរណា ដែលធ្វើឱ្យស្គាល់នៅពេលក្រោយមក[2445]។

714. ទឡ្ហីករណ៍ដទៃទៀតរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក៏ពុំមានមូលដ្ឋានដែរ។ ជាឧទាហរណ៍ ការតវ៉ារបស់គាត់ ពាក់ព័ន្ធភស្តុតាងរបស់ ជា ឌៀប ស្ដីពីវគ្គរៀនសូត្រនៅបុរីកីឡា ដែលមិនបានពិចារណាថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្អែកលើ ភស្តុតាងរបស់គាត់ នៅត្រង់ចំណុចនេះដើម្បីធ្វើសេចក្ដីសម្រេចណាមួយឡើយ[2446]។ ម្ចាស់បណ្ដឹងសាទុក្ខក៏ហាក់ដូចជាចង់លើកឡើងថា

---

[2442] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៣៥។

[2443] សូមមើល ឯកសារ **E1/467.1** ជា ឌៀប ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១១.១៧.៤៥-១១.៤៦.៥៤ ទំព័រ ៤៣-៥៣ បន្ទាត់ ១៣-៥ ជាពិសេស ទំព័រ ៥១-៥២ បន្ទាត់ ៩-៨។

[2444] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៩។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៣៥។

[2445] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៣៦ ជើងទំព័រ ២៣៣៧។

[2446] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៣៧។ *កត់សម្គាល់ថា* អ.ជ.ស.ដ ផ្អែកលើភស្តុតាងរបស់ ជា ឌៀប ពាក់ព័ន្ធនឹងការប្រជុំនៅវត្តឧណ្ណាលោម មិនមែនបុរីកីឡា ដែលគាត់អះអាងថា ហ៊ូ នឹម និង ហ៊ូ យន់ ត្រូវបានគេកាត់ទោសនៅទីនោះ។ ជាជាងមានមន្ទិលសង្ស័យលើវិធីសាស្ត្ររបស់ អ.ជ.ស.ដ នេះបង្ហាញពីការយកចិត្តទុកដាក់របស់ អ.ជ.ស.ដ ដែល

ឯកសារដែលបញ្ជាក់អំពីឧត្តមគតិរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានទទួលយកត្រឹមតម្លៃជាក់ស្តែង និងដាច់ដោយឡែកប៉ុណ្ណោះ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង បានវាយតម្លៃយ៉ាងសមស្រប ទៅលើភ័ស្តុតាងជារួម មុនពេលធ្វើការសម្រេចថា វ័យសម្រាប់ការរៀបអាពាហ៍ពិពាហ៍ មានការប្រែប្រួលក្នុងការអនុវត្តជាក់ស្តែង[2447]។ ការប្រឆាំងជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខ ជាមួយភ័ស្តុតាងរបស់ កម្មាភិបាលដទៃទៀតក្នុងក្រសួង ត្រូវបានជំទាស់ដោយភ័ស្តុតាង[2448]។ ជាចុងក្រោយភ័ស្តុតាងរបស់ ជា ឌៀប អំពីវគ្គរៀនសូត្ររបស់ម្ចាស់បណ្តឹងសាទុក្ខ នៅវត្តឧណ្ណាលោម ត្រូវបានគាំទ្រមួយផ្នែកដោយ រស់ ស៊ុយ និងសម្តេច នរោត្តម សីហនុ ហើយត្រូវបានអង្គជំនុំ

---

បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីទទួលយកផ្នែកខ្លះនៃភ័ស្តុតាងរបស់សាក្សី ដែលខ្លួនយល់ថាអាចជឿជាក់បាន និងច្រានចោលទិដ្ឋភាពណាដែលខ្លួនយល់ថាមិនអាចជឿជាក់បាន ដោយមិនចាំបាច់បង្ហាញពីគ្រប់ដំណាក់កាលនៃសំអាងហេតុរបស់ខ្លួនឡើយ។ សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចមានសំអាងហេតុ)។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០៧ ជើងទំព័រ ១៩០៤ សម្រាប់ភ័ស្តុតាងដែលស៊ីសង្វាក់ជាមួយភ័ស្តុតាងរបស់គាត់។

[2447] ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ភ័ស្តុតាងផ្ទុយនឹង "ស្មារតី និងសេចក្តីណែនាំ ក្នុងឯកសារបោះពុម្ពផ្សាយផ្លូវការរបស់ ប.ក.ក" មានលក្ខណៈប្រហាក់ប្រហែលនឹងទឡ្ហីករណ៍ផ្សេងទៀតនៅក្នុងសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ ឧទាហរណ៍ ពាក់ព័ន្ធនឹងបទបញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ និងមូលហេតុដែលបានបញ្ជាក់នៅពីក្រោយគោលនយោបាយរបស់ ប.ក.ក ដែលត្រូវបានអនុវត្តតាមរយៈការប្រព្រឹត្តិបទក្រិដ្ឋ (សូមមើល *ឧទាហរណ៍* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩, ១៨១, ១៨៣)។ សូមមើល បន្ថែមទៀត ភ័ស្តុតាងជាច្រើនដែល អ.ជ.ស.ដ ផ្អែកលើ ដើម្បីធ្វើការសន្និដ្ឋានអំពី "អាយុរៀបការ" នៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៨១-៣៥៨៤ ដែលពិចារណាលើភ័ស្តុតាងថា ម្ចាស់បណ្តឹងសាទុក្ខបានបញ្ជាក់ថា នារីវ័យក្មេងមិនគួររៀបការឆាប់ពេកទេ ប៉ុន្តែទម្ងន់នៃភ័ស្តុតាងបង្ហាញថា អាយុចន្លោះពី ១៦ ទៅ ៦០ ឆ្នាំ។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៣៨។

[2448] ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ជា ឌៀប ជំទាស់នឹងភ័ស្តុតាងមកពីមន្ត្រីក្រសួងផ្សេងទៀត។ ទោះជាយ៉ាងនេះក្តី ភ័ស្តុតាងរបស់ ផាន់ ហ៊ឹម គ្រាន់តែបញ្ជាក់ថា គាត់មិនបានដឹងពីការណែនាំឱ្យរៀបការ ១០០ គូក្នុងមួយខែ ហើយថាការណែនាំនេះមិនត្រូវបានផ្តល់នោះទេ។ សូមមើល ឯកសារ **E1/467.1** ផាន់ ហ៊ឹម ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១៥.០១.១៤-១៥.០៣.២២ ទំព័រ ៧៦-៧៧ បន្ទាត់ ១៦-៥។ សូមមើលផងដែរ ភ័ស្តុតាងរបស់គាត់ថា ខ្លួនគាត់ផ្ទាល់ត្រូវបានគេបង្ខំឱ្យរៀបការនៅក្នុងពិធីមួយជាមួយ ២០ គូផ្សេងទៀត (ឯកសារ **E1/467.1** ផាន់ ហ៊ឹម ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១៤.២២.១០-១៤.២៥.២៧ ទំព័រ ៧០-៧១ បន្ទាត់ ១៧-៥ ១៥, ម៉ោង ១៥.០៨.៤៨-១៥.១១.១៥ ទំព័រ ៧៩ បន្ទាត់ ៧-៨)។ ប៊ិត ហឿន ផ្តល់សក្ខីកម្មថា សម្រាប់ប្រជាជនសាមញ្ញ "ឱ្យតែអង្គការចាប់រៀបគឺត្រូវតែរៀបការ" (សូមមើល ឯកសារ **E1/502.1** ប៊ិត ហឿន ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង ១១.២១.៤១-១១.២៣.៤២ ទំព័រ ៣២ បន្ទាត់ ១៨) ដែលបញ្ជាក់យ៉ាងច្បាស់ថា សូម្បីនៅថ្នាក់ក្រសួង អ្នករដ្ឋការក៏បានចូលរួម ឬដឹងថា ការរៀបការនេះត្រូវបានរៀបចំឡើង។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៣៩ ("ការងាកចេញពីបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍បានកើតឡើងជាសំខាន់ នៅតំបន់ឆ្ងាយពីទីក្រុងភ្នំពេញ")។ អ.ជ.ស.ដ ក៏មានភ័ស្តុតាងផ្សេងទៀតអំពីវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំដែលបានដាក់នៅចំពោះមុខខ្លួន ដែលបង្ហាញយ៉ាងច្បាស់ថា គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍គឺដើម្បីបង្កើនចំនួនប្រជាជន។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥៦។

ជម្រះសាលាដំបូង វិភាគដោយគ្រប់គ្រាន់[2449]។ និយាយដោយខ្លី មិនមានការជំទាស់ណាមួយរបស់ម្ចាស់បណ្តឹងសាទុក្ខ អាចធ្វើឱ្យខូចខាតដល់ការពឹងផ្អែក ទៅលើភ័ស្តុតាងរបស់ ជា ឡៀប ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។

### *មូលដ្ឋានទី ១៧០៖ ការប្រើការគំរាមកំហែង និងបរិបទបង្ខិតបង្ខំនៅក្នុងប្រទេស*[2450]

715. **មូលដ្ឋានទី ១៧០ គួរត្រូវបានច្រានចោល ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុក្នុងការសម្រេចថា ប្រជាជនមិនមានជម្រើសក្នុងការរៀបអាពាហ៍ពិពាហ៍។**

716. ស្ថានទម្ងន់នៃភ័ស្តុតាងបង្ហាញយ៉ាងច្បាស់ថា បរិយាកាសនៃភាពភ័យខ្លាចជាទូទៅ បានបដិសេធចំពោះការយល់ព្រមពិតប្រាកដ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2451]។ ទោះបីជាយ៉ាងនេះក្តី ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺផ្អែកលើការត្រួតពិនិត្យដោយមិនត្រឹមត្រូវ ទៅលើភ័ស្តុតាង[2452]។ ម្ចាស់បណ្តឹងសាទុក្ខបានជំទាស់ចំពោះភាពជាតំណាងទូទៅនៃភ័ស្តុតាងរបស់បុគ្គល ដែលមិនអាចបដិសេធសំណើរៀបការ ដោយមិនមានផលវិបាកអវិជ្ជមាន[2453] ត្រូវបានពិភាក្សានៅផ្នែកដទៃក្នុងចម្លើយតបនេះ[2454] ហើយសក្ខីកម្មរបស់បុគ្គលជាក់លាក់ ត្រូវពិភាក្សានៅផ្នែកខាងក្រោម។

---

[2449] អ.ជ.ស.ដ មានសិទ្ធិផ្អែកលើភ័ស្តុតាងក្រៅតុលាការ ហើយម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញនូវកំហុសណាមួយលើការផ្អែកលើភ័ស្តុតាងរបស់ រស់ ស៊ុយ ពាក់ព័ន្ធនឹងប្រការនេះទេ (សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣០) *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៤០។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៩-៣៥៧១, ៣៥៨៦, ៤២៤៨។

[2450] <u>មូលដ្ឋានទី ១៧០</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការប្រើការគំរាមកំហែង និងបរិបទបង្ខិតបង្ខំនៅក្នុងប្រទេស* កថាខណ្ឌ ១២៥៩-១២៧០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៨-៥៩ (ភាសាអង់គ្លេស) ទំព័រ ៥៤ (ភាសាបារាំង) ទំព័រ ៨៤ (ភាសាខ្មែរ)។

[2451] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២១-៣៦២២ (ការប្រើប្រាស់ការគំរាមកំហែងដោយអាជ្ញាធរ រួមទាំងការគំរាមសម្លាប់) កថាខណ្ឌ ៣៦២៣ (បរិយាកាសនៃការភ័យខ្លាចទូទៅមិនអនុញ្ញាតឱ្យពួកគេជំទាស់នឹងបញ្ហាទេ) កថាខណ្ឌ ៣៦២៤ (ការគំរាមកំហែងដែលបានអនុវត្ត) កថាខណ្ឌ ៣៦២៥ (សន្និដ្ឋានថា "មិនអាចមានការយល់ព្រមពិតប្រាកដឡើយ") កថាខណ្ឌ ៣៦៧៣-៣៦៧៤ (ការអនុវត្តបែបបង្ខិតបង្ខំនៅត្រាំកក់) កថាខណ្ឌ ៣៦៧៦ (ការអនុវត្តបែបបង្ខិតបង្ខំនៅទំនប់ត្រពាំងថ្ម) កថាខណ្ឌ ៣៦៧៧-៣៦៧៨ (ការអនុវត្តបែបបង្ខិតបង្ខំនៅទំនប់១មករា)។

[2452] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៥៩។

[2453] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦០-១២៦១។

[2454] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥។

*ការបកស្រាយមិនត្រឹមត្រូវនូវសក្ខីកម្មរបស់ មុំ វុន*

717. ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសថា សេចក្តីសង្ខេបនៃការបកស្រាយមិនត្រឹមត្រូវនូវភស្តុតាងគឺ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរំលោភសេពសន្ថវៈ ក្រៅអាពាហ៍ពិពាហ៍ ដែលដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានចោទប្រកាន់ គឺជាលទ្ធផលនៃការបដិសេធមិនរៀបអាពាហ៍ពិពាហ៍របស់គាត់[2455]។ ទឡ្ហីករណ៍នេះខុស ដោយសារតែម្ចាស់បណ្តឹងសាទុក្ខ ស្នើដល់អង្គជំនុំជម្រះតុលាការកំពូល ឱ្យយកការវាយតម្លៃរបស់ខ្លួន មកជំនួសការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមិនបានបង្ហាញអំពីកំហុសណាមួយឡើយ។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ព្រះរាជអាជ្ញាបានផ្តល់ព័ត៌មានដល់ ដើមបណ្តឹងរដ្ឋប្បវេណីឡើយ នៅពេលដែល មុំ វុន ភ្ជាប់ការរំលោភសេពសន្ថវៈលើរូបគាត់ ជាមួយការបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍ តាំងពីមុនពេលដែលសហព្រះរាជអាជ្ញា បានសួរដេញដោលគាត់ទៅទៀត[2456]។ បន្ថែមលើនេះ អង្គហេតុដែលថាដើមបណ្តឹងរដ្ឋប្បវេណី មិនបានដឹងអំពីហេតុការណ៍ផ្សេងទៀតប្រហែលគ្នានឹងហេតុការណ៍ដែលគាត់ជួប គឺមិនមានភាពពាក់ព័ន្ធឡើយ ហើយមិនបានធ្វើឱ្យថមថយ នូវសុពលភាពនៃសក្ខីកម្មរបស់គាត់ដែរ[2457]។

*ការចោទពីកំហុសនានាពាក់ព័ន្ធនឹងការសម្រេច ស្តីពីការរៀបអាពាហ៍ពិពាហ៍កម្មាភិបាលនិង យុទ្ធជនពិការ*

718. ម្ចាស់បណ្តឹងសាទុក្ខបានជំទាស់ដោយខុសផងដែរ ចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរៀបអាពាហ៍ពិពាហ៍ កម្មាភិបាលឬយុទ្ធជនពិការ ដែលមានអភ័យឯកសិទ្ធិជ្រើសរើសគូស្រករបស់ពួកគេ គឺមិនមានការយល់ព្រមពិតប្រាកដឡើយ[2458]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយភាន់ច្រឡំថា អង្គជំនុំជម្រះសាលាដំបូង ពឹងផ្អែកលើ "ករណីទូទៅ" ដើម្បីសន្និដ្ឋានថា ករណីកិច្ចបម្រើជាតិ និងការគោរពអង្គការវិន័យ ដោយឥតលក្ខខណ្ឌ ធ្វើឱ្យយុទ្ធជន

[2455] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦២-១២៦៣ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២១ (ជើងទំព័រ ១២០៩៤), ៣៦៥៨, ៣៦៩០។

[2456] ឯកសារ **E1/475.1** មុំ វុន ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង ១១.១៧.០៥-១១.២៤.៤១ ទំព័រ ៣៧-៣៩ បន្ទាត់ ១៩-២។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៣។

[2457] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៣។

[2458] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៥-១២៦៧ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៨៦-៣៥៩០។

ពិការមិនចាំបាច់ត្រូវការ ការយល់ព្រមដោយសេរីឡើយ[2459]។ ទីមួយម្ចាស់បណ្ដឹងសាទុក្ខ បាន ជំទាស់ដោយខុស ចំពោះការពឹងផ្អែកលើ "សុន្ទរកថាមិនបញ្ជាក់ច្បាស់" របស់ម្ចាស់បណ្ដឹងសាទុក្ខ[2460]។ ផ្ទុយពីការអះអាងរបស់គាត់ សុន្ទរកថានេះមិនមែន "មិនបញ្ជាក់ច្បាស់"នោះទេ ព្រោះសាលក្រមបង្ហាញច្បាស់ ក្នុងការយោងរបស់ខ្លួន ទៅរកសុន្ទរកថាមួយដែលថ្លែង នៅកិច្ចប្រជុំដែលដឹកនាំដោយ ម្ចាស់បណ្ដឹងសាទុក្ខ នៅក្នុងកិច្ចប្រជុំនោះ ម្ចាស់បណ្ដឹងសាទុក្ខបាន "បង្គាប់ឱ្យក្រសួងរៀបចំអាពាហ៍ពិពាហ៍"[2461]។ ទីពីរម្ចាស់បណ្ដឹងសាទុក្ខ ជំទាស់ចំពោះការពឹងផ្អែក លើសៀវភៅរបស់សម្ដេច នរោត្តម សីហនុ ធ្វើជាភស្តុតាងគាំទ្រ[2462]។ ផ្ទុយទៅវិញ តាមពិតទៅអង្គជំនុំជម្រះសាលាដំបូង បានដឹងអំពីតម្លៃជាភស្តុតាង របស់សៀវភៅនោះ ហើយបានពិចារណាលើចំណុចនេះនៅក្នុងសាលក្រម[2463]។ សក្ខីកម្មសវនការបន្ថែម និងទស្សនាវដ្ដីយុវជន យុវនារីបដិវត្តជាច្រើន ដែលម្ចាស់បណ្ដឹងសាទុក្ខមិនបានលើកឡើង ក៏ត្រូវបានអង្គជំនុំជម្រះសាលាដំបូង យកមកធ្វើការពិចារណាផងដែរ ដែលបង្ហាញយ៉ាងច្បាស់ថា ស្ត្រីត្រូវបានរំពឹងថា ត្រូវលះបង់រូបរាងកាយខ្លួន ដើម្បីមូលហេតុ "ស្នេហាជាតិ" និងដើម្បីផលប្រយោជន៍បដិវត្ត ហើយការណែនាំនេះគឺចេញពីថ្នាក់លើខ្ពស់បំផុត[2464]។

719. ម្ចាស់បណ្ដឹងសាទុក្ខបានចោទប្រកាន់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង ទុកចោលនូវសក្ខីកម្មដែលផ្ទុយនិងការសម្រេចរបស់ខ្លួន[2465]។ ប៉ុន្តែការពិនិត្យឱ្យម៉ត់ចត់ទៅលើភស្តុតាង ដែលម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើង ដើម្បីគាំទ្រដល់ការអះអាងនេះ បានបង្ហាញសារជាថ្មីថា ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការបកស្រាយភស្តុតាងតាមបែបផ្សេងប៉ុណ្ណោះ។ ក្នុងករណីខ្លះ ម្ចាស់បណ្ដឹងសាទុក្ខបានផ្ដល់ ការបកស្រាយជាជម្រើស ដែលមិន

[2459] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៦៤។

[2460] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៦៥។

[2461] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៩។

[2462] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៦៦។

[2463] ពេលពិភាក្សាអំពីសៀវភៅនេះ អ.ជ.ស.ដ ទទួលស្គាល់ថា ម្ចាស់បណ្ដឹងសាទុក្ខមិនមានឱកាសសួរដេញដោលចំពោះសេចក្ដីថ្លែងការណ៍ដែលបានធ្វើឡើងនៅក្នុងសៀវភៅនេះ ដែល "ជាហេតុនាំឱ្យមានការបន្ថយទម្ងន់លើសេចក្ដីថ្លែងការណ៍នេះ" (សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥០១)។

[2464] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៨៦-៣៥៨៩ (តាម៉ុក បានបង្កើតគោលនយោបាយដែលតម្រូវឱ្យកងយុទ្ធជនពិការនាំនារី (ជនស៊ីវិលធម្មតាពីចម្ការម្រេចនៅកំពត) មករៀបការជាមួយកងទ័ពពិការ។ ពិធីរៀបការចំនួនពីរត្រូវបានសាក្សីជាច្រើនលើកឡើង)។

[2465] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១២៦៦។

មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចអនុវត្តឡើយ[2466] ដូចជាការអះអាងរបស់គាត់ដែលថា ស៊ូ សុធារី បានបញ្ជាក់ថា ការរៀបអាពាហ៍ពិពាហ៍ កងទ័ពពិការ មិនមែនជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[2467]។ ម្ចាស់បណ្តឹងសាទុក្ខ បានលុបចោលយ៉ាងស្រួល នូវអង្គហេតុដែល ស៊ូ សុធារី បានផ្តល់សក្ខីកម្មថា មិនមាននារីណាដែលចូលរួម ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ទាំងអស់នេះ ហ៊ានបដិសេធឡើយ[2468]។ ដោយផ្អែកលើភ័ស្តុតាងយ៉ាងច្រើន អំពីលទ្ធភាពនៃផលវិបាកយ៉ាងធ្ងន់ធ្ងរ ចំពោះការបដិសេធ[2469] ជាការសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការទទួលយកផ្នែកខ្លះ នៃសក្ខីកម្មរបស់សាក្សី និងច្រានចោលផ្នែកខ្លះទៀត ដោយមិនបានបញ្ជាក់ នូវគ្រប់ដំណាក់កាលនៃ សំអាងហេតុរបស់ខ្លួន ក្នុងការវាយតម្លៃនេះ[2470]។

720. ម្ចាស់បណ្តឹងសាទុក្ខបានជ្រើសយកវិធីសាស្ត្របែបជ្រើសរើស ដែលមិនត្រឹមត្រូវដដែល ក្នុងការជំទាស់ចំពោះភ័ស្តុតាង ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ កម្មាភិបាលបុរសដែលអាចជ្រើសរើសភរិយារបស់ខ្លួន ឬត្រូវបានគេពិភាក្សានៅពេលផ្សំផ្គុំ ដោយលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការសម្រេចរបស់ខ្លួនដែលថា ស្ត្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ដោយមិនមានការសាកសួរ អំពីការយល់ព្រមរបស់ពួកគេ[2471]។ ភ័ស្តុតាងដែលម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងនោះ សឹងតែមិនបានបង្ហាញអំពីកំហុសឆ្គងណាមួយ ដោយសារតែ

---

[2466] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៦ (ចម្លើយរបស់ ណុប ង៉ឹម ត្រូវបានដកស្រង់មិនត្រឹមត្រូវដោយម្ចាស់បណ្តឹងសាទុក្ខ ដែលអះអាងថា គាត់យល់ព្រមរៀបការ ពីព្រោះគាត់ "ចាស់ៗ" ហើយ។ ការអានសក្ខីកម្មគ្រប់ជ្រុងជ្រោយបង្ហាញថា ណុប ង៉ឹម បានពន្យល់ថា មើលលើអាយុរបស់គាត់ ការរត់គេចខ្លួនគឺមានហានិភ័យច្រើន (សូមមើល ឯកសារ **E1/469.1** ណុប ង៉ឹម ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង ១៥.៤៨.២៩-១៥.៥០.១៧ ទំព័រ ៨៣ បន្ទាត់ ២៣-២៥)។

[2467] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៩។

[2468] ឯកសារ **E1/462.1** ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១៥.៤៧.៣៧-១៥.៥០.០១ ទំព័រ ៨១ បន្ទាត់ ១-២ ("ដែលខ្ញុំឃើញជនពិការមក យុទ្ធជនខាងមុខពិការហ្នឹងមករៀបការហ្នឹង គេគ្មានបង្ខំទេ គេទៅប្រាប់មកនារីហ្នឹងរៀបចំខ្លួនមការមួយយុទ្ធជនហ្នឹង។ ហើយអត់មានអ្នកណាហ៊ានប្រកែក")។

[2469] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥។

[2470] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចមានសំអាងហេតុ)។

[2471] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៨ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៩១។

ភ័ស្តុតាងនេះ គ្រាន់តែបង្ហាញថា ស្ត្រីនៅក្នុងករណីទាំងអស់នេះ មិនបាន និងមិនអាចយល់ព្រម ដោយសេរីឡើយ[2472]។

*កំហុសដែលរងការចោទប្រកាន់ដែលមាននៅក្នុងការវាយតម្លៃលើភស្តុតាងរបស់ អ.ជ.ស.ដ ស្តីពីការ ប្រកែកមិនរៀបការ*

721. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានការភាន់ច្រឡំនៅក្នុងការវាយតម្លៃលើភ័ស្តុតាងរបស់ខ្លួនក្នុងការសន្និដ្ឋានថា ករណីប្រកែកដោយគ្មានគ្រោះថ្នាក់ដល់ខ្លួន គឺជាករណីលើកលែង[2473]។ សំខាន់បំផុត ម្ចាស់បណ្តឹងសាទុក្ខបានដេញដោលលើការបកស្រាយសក្ខីកម្មរបស់ ឯម ភឿង និង សុន វុត ដែលអាចបដិសេធការរៀបការរបស់ពួកគេបាន។ ទោះជាយ៉ាងណាក៏ដោយ ភ័ស្តុតាងដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង មិនបានគាំទ្រសេចក្តីសន្និដ្ឋាននេះឡើយ ហើយគ្រាន់តែជាការពន្យល់ជំនួសអំពីអង្គហេតុប៉ុណ្ណោះ។ តាមពិត ក្នុងករណីរបស់ សុន វុត ការរៀបរាប់របស់ម្ចាស់បណ្តឹងសាទុក្ខផ្ទុយស្រឡះពីភ័ស្តុតាងនោះ ព្រោះគាត់បានលើកឡើងយ៉ាងច្បាស់ថា "ផុតពីនោះ គេអត់តវ៉ាបាន" និង "យើងអត់គោរពអង្គការចាត់តាំងយ៉ាងណាគឺត្រូវតាមអង្គការ"[2474]។ ម្ចាស់បណ្តឹងសាទុក្ខពិតជាភាន់ច្រឡំរវាងលទ្ធភាពក្នុងការពន្យារពេលរៀបការដោយបង្ខំ និងលទ្ធភាពបដិសេធការរៀបការនោះ ដែលនេះជាបុព្វសិទ្ធិដែលភស្តុតាងជារួមបង្ហាញច្បាស់ថាគ្មានអត្ថិភាពទេ[2475]។

---

[2472] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៨ ជើងទំព័រ ២៤១៦ (ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានពិនិត្យសក្ខីកម្មរបស់ ប្រាក់ យុត ទាំងស្រុងទេ។ ពេលសួរដេញដោលពីចម្លើយផ្ទុយគ្នារបស់គាត់អំពីការរៀបការរបស់គាត់ គាត់បានឆ្លើយបំភ្លឺថា "គាត់អ្នកដឹកនាំខ្ញុំទៅហើយ ខ្ញុំគិតអ៊ីចឹងវិញទេ។ បើការគ្រប់គ្រងទាំងអស់នៅក្នុងតំបន់ ៣៥ គាត់គ្រប់គ្រងទាំងអស់ ហើយបើខ្ញុំប្រឆាំង ហាក់ដូចជាខ្ញុំហ្នឹងមិនគោរព។ អ៊ីចឹងខ្ញុំតាមគាត់ទៅ ការបណ្តោយ ទោះបីខ្ញុំស្រឡាញ់មិនស្រឡាញ់ក៏ត្រូវតែយកដែរ" សូមមើល ឯកសារ **E1/378.1** ប្រាក់ យុត ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ម៉ោង ១១.២០.០៥-១១.២១.៣១ ទំព័រ ៣២ បន្ទាត់ ២០-២២។ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ ជាម គីម ម្ចាស់បណ្តឹងសាទុក្ខអះអាងខុសថាការរៀបអាពាហ៍ត្រូវបាន "រៀបចំ" មិនមែនបង្ខំទេ (សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥)) ជើងទំព័រ ២៤១៧ (ឯកសារ **E1/502.1** ប៊ិត ហឿន ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង ១១.១៨.២១-១១.២១.៥១ ទំព័រ ៣២ បន្ទាត់ ៩-១៦ បញ្ជាក់ថា "ប្រុសគេស្នើយើង យើងមិនពេញចិត្ត ក៏យើងត្រូវតែយក" ហើយ "ប្រកែកតទៅទៀត ខ្លាចហើយ")។

[2473] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១២៦៩ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២៥។

[2474] ឯកសារ **E1/411.1** សុន វុត ប្រតិចារឹក ថ្ងៃទី៣៩ ខែមីនា ឆ្នាំ២០១៦ ១៤.៣៨.០៤-១៤.៤១.៣០ ទំព័រ ៥៩ បន្ទាត់ ១៦-១៨។

[2475] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២១-៣៦២២ (ការគំរាមកំហែងដោយអាជ្ញាធរ រួមទាំងការគំរាមសម្លាប់) កថាខណ្ឌ ៣៦២៣ (បរិយាកាសនៃការភ័យខ្លាចទូទៅ មិនអនុញ្ញាតឱ្យពួកគេជំទាស់នឹងបញ្ជាឱ្យរៀបការ

## *មូលដ្ឋានទី ១៦១ ៖ កំហុសក្នុងការពិនិត្យលក្ខណវិនិច្ឆ័យនៃប្រភេទ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងលក្ខណវិនិច្ឆ័យនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដូចបានរៀបរាប់*[2476]

722. **គួរច្រានចោលមូលដ្ឋានទី ១៦១ ព្រោះថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានការភាន់ច្រឡំក្នុងការសន្និដ្ឋានថា មាន *ធាតុផ្សំសត្យានុម័តិ* នៃអំពើអមនុស្សធម៌ផ្សេងទៀត ក្នុងទម្រង់ជាការរៀបការដោយបង្ខំ**

723. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានធ្វើការវិភាគមិនបានពេញលេញលើភស្តុតាងដែលធ្វើឱ្យ អ.ជ.ស.ដ ប្រព្រឹត្តកំហុសជាច្រើន ដូចជា ការលើកឡើងថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្ម នៅមុនពេលកើតហេតុ ក្រោយពេលកើតហេតុ ឬនៅពេលកើតហេតុ[2477]។ ដូចបានលើកឡើងនៅផ្នែកផ្សេងៗទៀតនៃចម្លើយតបនេះ អ.ជ.ស.ដ បានព្យាយាមបំពេញអាណត្តិរបស់ខ្លួនយ៉ាងពេញលេញ ក្នុងការវិភាគទៅលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាអំពើអមនុស្សធម៌ផ្សេងទៀត[2478] អនុវត្តយ៉ាងត្រឹមត្រូវតាមយុត្តិសាស្ត្រយ៉ាងច្បាស់របស់អង្គជំនុំជម្រះតុលាការកំពូល ដែលកំណត់ថា ជាករណីចាំបាច់ដែលថា អំពើនេះរំលោភបំពានលើ "សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ និងមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[2479]។ ក្នុងការអនុវត្តតាមវិធានការទាំងនេះ អ.ជ.ស.ដ សន្និដ្ឋានថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាការរំលោភបំពានសិទ្ធិរៀបអាពាហ៍ពិពាហ៍ដោយសេរី ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[2480] បន្ទាប់មកបានធ្វើការវាយតម្លៃអង្គហេតុលម្អិតដើម្បីកំណត់ថាតើ ការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែល

---

នេះទេ) កថាខណ្ឌ ៣៦២៤ (ការគំរាមកំហែងដោយផ្ទាល់) កថាខណ្ឌ ៣៦២៥ (គឺថា មិនអាចមានការយល់ព្រមពិតប្រាកដឡើយ) កថាខណ្ឌ ៣៦៧៣-៣៦៧៤ (ការអនុវត្តបែបបង្ខិតបង្ខំនៅស្រុកត្រាំកក់) កថាខណ្ឌ ៣៦៧៦ (ការអនុវត្តបែបបង្ខិតបង្ខំនៅទំនប់ត្រពាំងថ្ម) កថាខណ្ឌ ៣៦៧៧-៣៦៧៨ (ការអនុវត្តបែបបង្ខិតបង្ខំនៅទំនប់ ១ មករា)។

[2476] <u>មូលដ្ឋានទី ១៦១</u> ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសក្នុងការពិនិត្យលក្ខណៈវិនិច្ឆ័យនៃប្រភេទ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដូចបានរៀបរាប់* កថាខណ្ឌ ១១១៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៩ (ភាសាអង់គ្លេស) ទំព័រ ៥១ (ភាសាបារាំង) ទំព័រ ៨០-៨១ (ភាសាខ្មែរ)។

[2477] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១១៨។

[2478] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៥, ៩៧, ៩៨, ១៦០។

[2479] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦០ *ដោយយកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨០។

[2480] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៤៣ *ដោយយកស្រង់* UDHR មាត្រា ១៦ (២)។

មានចែងកំណត់ដែរឬទេ[2481]។ មិនត្រូវការការបញ្ជាក់អ្វីបន្ថែមទៀតឡើយ។ ការអះអាងដោយភាន់ច្រឡំថែមទៀតរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ដ ព្យាយាមលុបកំហុសដែលរងការចោទប្រកាន់ទាំងនេះ ដោយធ្វើការបែងចែកសិប្បនិម្មិតរវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏ត្រូវបានច្រានចោលក្នុងផ្នែកផ្សេងទៀតផងដែរ[2482]។ ដូច្នេះ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានវាយតម្លៃមិនត្រឹមត្រូវលើភស្តុតាងនេះ ដើម្បីសន្និដ្ឋានថា លក្ខណៈ និងភាពធ្ងន់ធ្ងរនៃអំពើនេះ ដែលប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ជួយដល់ការ កំណត់*ធាតុផ្សំសត្យានុម័តិ* នៃអំពើអមនុស្សធម៌ផ្សេងទៀត។

*មូលដ្ឋានទី ១៦៣ ៖ កំហុសក្នុងការពិនិត្យលើការឈឺចាប់ដែលទទួលរងក្នុងការរៀបអាពាហ៍ពិពាហ៍*[2483]

724. **គួរច្រានចោលមូលដ្ឋានទី ១៦៣ ព្រោះថា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសនៅពេលដែល អ.ជ.ស.ដ សន្និដ្ឋានថា ការចោទប្រកាន់ផ្នែកអង្គហេតុពីអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានភាពធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចែងកំណត់។**

725. ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងដោយគ្មានមូលដ្ឋានថា ការវិភាគសមហេតុផលទៅលើភស្តុតាងពាក់ព័ន្ធនឹងរបៀបរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ មិនអនុញ្ញាតឱ្យ អ.ជ.ស.ដ សន្និដ្ឋានថា ការឈឺចាប់ជាទូទៅមានកម្រិតដូចគ្នានឹងការឈឺចាប់ដែលបណ្ដាលមកពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចែងកំណត់ទេ[2484]។ ការអះអាងរបស់គាត់មើលរំលងអង្គហេតុដែលថា ភាពធ្ងន់ធ្ងរនៃអំពើមួយត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ[2485] ខណៈដែលអង្គហេតុទាំងនោះត្រូវឆ្លងកាត់

---

[2481] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២៧, ៧៤០-៧៤៩, ៣៥៣៦-៣៦៩៥។

[2482] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១១៨។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦២។

[2483] មូលដ្ឋានទី ១៦៣ ៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *កំហុសក្នុងការពិនិត្យលើការឈឺចាប់ដែលទទួលរងក្នុងការរៀបអាពាហ៍ពិពាហ៍* កថាខណ្ឌ ១១៥៦-១១៥៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៥៦ (ភាសាអង់គ្លេស) ទំព័រ ៥២ (ភាសាបារាំង)។

[2484] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១៦៣ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨១។

[2485] សំណុំរឿង ០០១-ឯកសារ **E188** *សាលក្រមរឿងក្ដី ឌុច* កថាខណ្ឌ ៣៦៩។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៣៨។ សំណុំរឿង ០០៤-ឯកសារ **D257/1/8** សេចក្ដីពិចារណាលើសំណើសុំឱ្យ អ.ប.ជ ធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទស្សនៈរបស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៦។ សាលដីការឿងក្ដី *Kordić &Čerkez* កថាខណ្ឌ ១១៧។ សាលក្រមរឿងក្ដី *Lukić & Lukić* កថាខណ្ឌ ៩៦១។

ការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរជារួម[2486]។ តាមពិត អ.ជ.ស.ដ បានកត់សម្គាល់យ៉ាងត្រឹមត្រូវពីចំណុចនេះតាមរយៈសេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ "រួមគ្នាបានបង្កើតជាការឈឺចាប់ទាំងខាងផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិដែលជាជនរងគ្រោះទាំងនោះ"[2487] និង "យល់ឃើញថា អំពើនេះមានភាពធ្ងន់ធ្ងរដូចទៅនឹងបទល្មើសដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមានចែងដែរ"[2488]។ គ្មានលក្ខខណ្ឌតម្រូវឱ្យជនរងគ្រោះត្រូវទទួលរងផលប៉ះពាល់យូរអង្វែងឡើយ ទោះបីជាចំណុចនេះអាចពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃអំពើទាំងនេះក៏ដោយ[2489]។

726. ការវាយតម្លៃលើភាពធ្ងន់ធ្ងរជារួមរបស់ អ.ជ.ស.ដ បានបង្ហាញយ៉ាងច្បាស់ថា បុរស និងស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទទួលរងការឈឺចាប់ខាងផ្លូវកាយ និងផ្លូវចិត្ត ដែលនៅតែដិតដាម[2490]។ ជនរងគ្រោះបានលើកឡើងថា ពួកគាត់យំ និងញ័រទទ្រើកដោយសារការ ភ័យខ្លាចក្នុងពិធីរៀបអាពាហ៍ពិពាហ៍ និងបានរម្លឹកពីការអន់ចិត្ត ការសោកស្ដាយ ការឈឺចិត្ត និងការខកចិត្ត ប៉ុន្តែអត់ហ៊ាននិយាយ[2491]។ ជនរងគ្រោះខ្លះមានវ័យក្មេង និងមិនទាន់ត្រៀមខ្លួន រៀបការនៅឡើយទេ[2492]។ ជនរងគ្រោះផ្សេងទៀតត្រូវបានបង្ខំឱ្យរៀបការម្ដងទៀតក្នុងពេលដែលពួកគាត់នៅសោកស្ដាយចំពោះការបាត់បង់ដៃគូរបស់ខ្លួននៅឡើយ[2493]។ ពួកគេ

[2486] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៩០។

[2487] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៩១ (គូសបញ្ជាក់បន្ថែម)។

[2488] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៩២។

[2489] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្ដី ឌុច កថាខណ្ឌ ៣៦៩។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៣៩។ សាលដីការឿងក្ដី *Vasiljević* កថាខណ្ឌ ១៦៥។ សាលក្រមរឿងក្ដី *Lukić & Lukić* កថាខណ្ឌ ៩៦១ ជើងទំព័រ ២៨៨៧។

[2490] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧៩-៣៦៨២, ៣៦៩២។

[2491] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧៩ និងការដកស្រង់ទាំងអស់នៅក្នុងនោះ។ សូមមើលផងដែរ ឯកសារ **E3/9614** Theresa De Langis *និងអ្នកផ្សេងទៀត កែប្រែខ្លួនប្រាណដូចខ្មោច* ERN 01212418 ("ការខកចិត្តជាការឆ្លើយតបខាងផ្លូវអារម្មណ៍ទូទៅ [...] ដែលបានបាត់បង់ឱកាសក្នុងការដាក់ការគ្រប់គ្រងលើការសម្រេចចិត្តដ៏ធំមួយក្នុងជីវិត ដូចជា អាពាហ៍ពិពាហ៍ជាដើម និងមិនបានឱ្យក្រុមគ្រួសារ និងជីដូនជីតាផ្ដល់សុពលភាព និងបំពេញឱ្យត្រឹមត្រូវតាមច្បាប់លើការសម្រេចចិត្តដ៏ធំក្នុងជីវិតនោះ")។

[2492] *សូមមើលឧទាហរណ៍*ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២២៧៤ (ប៉ែន សុចាន់, អែម អឿន ង៉ែតចាត) កថាខណ្ឌ ៣៥៨៣។ សូមមើលផងដែរឯកសារ **E1/466.1** ជា ឌៀប ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦, ១៥.១១.៣៥-១៥.១៣.៣៩ ទំព័រ ៧៣ បន្ទាត់ ៨-១៧។

[2493] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨០ និងការដកស្រង់ទាំងអស់នៅក្នុងនោះ។

មានការឈឺចាប់ផ្លូវចិត្តយ៉ាងខ្លាំងដោយសារតែការរៀបការមិនទៅតាមប្រពៃណី និងមិនមានឪពុកម្តាយនៅក្នុងពិធីនេះ ទេ។ ជនរងគ្រោះខ្លះជឿថា អាពាហ៍ពិពាហ៍នេះមិនផ្តល់សុភមង្គល ឬមានអារម្មណ៍ថាមិនទទួលបានការការពារឡើយ[2494]។ ការបង្ខំឱ្យរួមដំណេកជាមួយនរណាម្នាក់ដែលពួកគេមិនស្គាល់ ឬមិនស្រឡាញ់ ជាពិសេស បន្ទាប់ពីការបង្ខំឱ្យរៀបការ ក៏បានបង្កផលប៉ះពាល់ធ្ងន់ធ្ងរ និងយូរអង្វែងផងដែរ[2495]។ ជនរងគ្រោះជាច្រើននៅតែយល់ថាទទួលរងភាពអាម៉ាស់យ៉ាងខ្លាំង ឬស្តីបន្ទោសខ្លួនឯង និងនៅតែភ័យខ្លាចថា ពួកគេ ឬកូនៗរបស់ពួកគេ នឹងប្រឈមនឹងការរើសអើង ដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ[2496]។

727. ផ្អែកតាមភស្តុតាងនេះ ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការឈឺចាប់មិនមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ឡើយ ដោយសារតែជនរងគ្រោះខ្លះចាប់ចិត្តស្រឡាញ់គ្នា គឺជាការប្រើប្រាស់ទស្សនៈបែបចង្អៀតលើភ័ស្តុតាងនោះ[2497]។ ឧទាហរណ៍ ការលើកឡើងថា ការអះអាងរបស់ វ៉ា លីមហ៊ាន់ មិនអាចចាត់ទុកជាការឈឺចាប់ ព្រោះគាត់បានចាប់ចិត្តស្រឡាញ់ប្តីរបស់គាត់ ជាការមិនគិតគូរពីការប៉ះទង្គិចផ្លូវចិត្ត និងផលប៉ះពាល់ជារួមនៃអាពាហ៍ពិពាហ៍នោះ[2498]។ តាមពិត គាត់បានបញ្ជាក់រួចហើយថា គាត់ភ័យខ្លាចថាគាត់នឹងត្រូវបានគេយកទៅសម្លាប់ ប្រសិនបើគាត់ប្រកែកមិនរៀបការ[2499] ហើយការមានអារម្មណ៍ស្រឡាញ់នៅពេលក្រោយមកទៀត មិនបានលុបការប៉ះពាល់ផ្លូវចិត្ត ដែលគាត់បានឆ្លងកាត់នៅក្នុងព្រឹត្តិការណ៍ទាំងនោះ ឬដែលនៅជិតដាមរហូតមកនោះទេ[2500]។

728. ការខកខានរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងកាពិចារណាពីភ័ស្តុតាងនេះទាំងមូល ត្រូវបានបង្ហាញបន្ថែមទៀតតាមរយៈការលើកឡើងរបស់គាត់ពាក់ព័ន្ធនឹងអង្គហេតុដែលថា "ការតូចចិត្ត" មិនអាច

---

[2494] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨១ និងការដកស្រង់ទាំងអស់នៅក្នុងនោះ។

[2495] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៣-៣៦៨៥, ៣៦៩១-៣៦៩២។

[2496] *សូមមើលឧទាហរណ៍* ឯកសារ **E457/6/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/២ កថាខណ្ឌ ៦២៤ និងភ័ស្តុតាងដែលបានដកស្រង់នៅក្នុងនោះ។

[2497] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦៤។

[2498] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦៤ ជើងទំព័រ ២១៦៣។

[2499] ឯកសារ **E3/9756** កំណត់ហេតុស្តាប់ចម្លើយ វ៉ា លីមហ៊ាន់ ERN 01025625 ("ការចាប់ដៃរបស់ខ្ញុំធ្វើឡើងពីរបីថ្ងៃ បន្ទាប់ពីឆេន បានប្រាប់ខ្ញុំ។ ខ្ញុំមិនហ៊ានបដិសេធបញ្ជារបស់គាត់ទេ ពីព្រោះគាត់បានព្រមានខ្ញុំថា បើអ្នកឯងបដិសេធ អ្នកឯងនឹងត្រូវស្លាប់ដូចបងអ្នកឯង")។

[2500] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៧១, ១១៧៤ (សក្ខីកម្មរបស់ សួន យឹម, សុម ប៉ែត, យស ផល និង គល់ ប៊ិន សុទ្ធតែត្រូវបានម្ចាស់បណ្តឹងសាទុក្ខដេញដោលដោយភាន់ច្រឡំ)។

បណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើផ្លូវចិត្តដែលមានផលប៉ះពាល់រយៈពេលយូរឡើយ[2501]។ នៅពេលពិចារណាជារួមពីសក្ខីកម្មរបស់សាក្សីរូបនេះដែលលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខ វាបង្ហាញយ៉ាងច្បាស់ថា ការតូចចិត្តដែលពួកគេបានរៀបរាប់ គឺនៅជិតដាមជារឿងរហូត ប៉ុន្តែមានតែផ្នែកមួយនៃផលប៉ះពាល់នោះប៉ុណ្ណោះ។ តាមពិត មុំ វុន ក៏បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេចាប់រំលោភ ជាឧប្បត្តិហេតុមួយដែលគាត់ជឿថាពាក់ព័ន្ធនឹងការប្រកែកមិនរៀបការ[2502]។ យី ឡែស្រូវ ប្រឈមនឹងការភ័យខ្លាច ការគំរាមកំហែង និងការបង្ខិតបង្ខំឱ្យរៀបការ[2503] ដូច ឃិន វ៉ាត ដែរ[2504]។

729. ក្រៅពីការខកខានមិនបានពិចារណាពីភស្តុតាងនេះទាំងមូល ម្ចាស់បណ្តឹងសាទុក្ខក៏បានលើកឡើងដោយមិនត្រឹមត្រូវផងដែរ។ គាត់លើកឡើងថា មាស សារ៉ាន មិនបានរងការឈឺចាប់ដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ ព្រោះវាមិនបានបង្កជាបញ្ហាក្នុងពេលដែលគាត់រៀបការលើកទីពីរឡើយ។ ម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់ដោយមិនទំនងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ "ទាមទារឱ្យមានសំណងចំពោះការឈឺចាប់របស់គាត់ដោយសារតែការសម្លាប់ប្តីរបស់គាត់" ដោយបញ្ជាក់ថា គាត់ចាត់ទុកប្តីគាត់ ជាអ្នកទទួលខុសត្រូវលើការឈឺចាប់របស់គាត់ មិនមែនរបបនោះឡើយ[2505]។ ចំណុចនេះមិនពិតនោះទេ។ ទោះបីជាមានភាពខុសគ្នារវាងការបកប្រែជាភាសាអង់គ្លេស និងភាសាបារាំង ប៉ុន្តែ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរភាសានេះបានបញ្ជាក់យ៉ាងច្បាស់ថា គាត់ទាមទារសំណងចំពោះការប៉ះទង្គិចផ្លូវចិត្តដោយសារការសម្លាប់ប្តីរបស់គាត់ ដែលគេបង្ខំឱ្យគាត់រៀបការជាមួយនោះ[2506]។ យ៉ាងណា

---

[2501] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦៤។

[2502] ឯកសារ **E1/475.1** មុំ វុន ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦, ១១.១៧.០៥-១១.២០.២៩ ទំព័រ ៣៧ បន្ទាត់ ២០-ទំព័រ ៣៨ បន្ទាត់ ៩។

[2503] ឯកសារ **E1/334.1** យី ឡែស្រូវ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥, ១៤.០៦.០៨-១៤.១០.០០ ទំព័រ ៤៨ បន្ទាត់ ៦ ("គេថាបើខ្ញុំអត់ទៅ ប្រយ័ត្នគេយកទៅវៃចោលទាំងគ្រួសារ")។

[2504] ឯកសារ **E1/325.1** ឃិន វ៉ាត ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥, ១៥.៣៦.៤២-១៥.៤០.៣៥ ទំព័រ ៦៨ បន្ទាត់ ៦-១១ ("គេប្រាប់ខ្ញុំថា "ឥឡូវត្រូវតែទៅការ បើមិនការទេ អង្គការអត់ទទួលខុសត្រូវទេ" [...] ហើយប្តីខ្ញុំគាត់និយាយថា "បើមិនស្រឡាញ់ខ្ញុំទេ ក៏ហ៊ីចុះ តែកុំប្រាប់គេអី បើមិត្តឯងប្រាប់គេ មុខជាស្លាប់ហើយ [..]។ ហើយខ្ញុំក៏បង្ខិតបង្ខំដែរ ខ្ញុំទទួលយកពីគាត់យកប្តីហ្នឹងតាមគេ")។

[2505] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦៤ ជើងទំព័រ ២១៦៣។

[2506] ឯកសារ **E3/6190** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស សារ៉ាន ERN 00521240 ("ព្យសនកម្មលើរូបរាងកាយ [...] ប្តី ប្អូន ស្លាប់ដោយសារអត់អាហារ និងសម្លាប់ដោយគ្មានកំហុស")។

ក៏ដោយ ចំណុចនេះមិនបង្ហាញថា គាត់យល់ថាប្តីរបស់គាត់ជា "ចារីសំខាន់" នៃការឈឺចាប់របស់គាត់នោះទេ។ តាមពិត វាបង្ហាញអត្ថន័យផ្ទុយពីនេះវិញទេ។

*កំហុសដែលរងការចោទប្រកាន់នៅក្នុងការវាយតម្លៃរបស់ អ.ជ.ស.ដ លើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី*

730. ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានខកខានមិនពិចារណាពី "បទពិសោធន៍ និងអារម្មណ៍ចម្រុះរបស់ដើមរដ្ឋប្បវេណី" ដែលស្តែងឡើងក្នុងអត្ថន័យ និងភាពផ្ទុយគ្នានៅក្នុងភស្តុតាងនេះ[2507]។ យ៉ាងណាក៏ដោយ គាត់មិនបានបង្ហាញទឡ្ហីករណ៍ដែលអាចជំទាស់នឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ឡើយ ប៉ុន្តែបែរជាគ្មានផ្តល់អ្វីក្រៅពីការបកស្រាយជំនួស និងជាញឹកញាប់ មិនសមហេតុផល ទៅលើអង្គហេតុដដែលៗនេះ។ ឧទាហរណ៍ គាត់លើកឡើងថា អ.ជ.ស.ដ មិនបានបញ្ជាក់ថា អ៊ុំ យឿន បានរួមរស់ជាមួយប្តីរបស់គាត់វិញក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[2508]។ យ៉ាងណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ច្បាស់ថា ការសម្រេចចិត្តដំបូងក្នុងការរៀបការជាមួយប្តីរបស់គាត់ មិនមែនជាជម្រើសផ្ទាល់ខ្លួនឡើយ ព្រោះប្តីគាត់បានរំលោភ គាត់ក្រោយពេលរៀបការ ហើយគាត់បានរួមរស់ជាមួយប្តីវិញដោយសារតែសម្ពាធគ្រួសារ[2509]។ ការបញ្ជាក់អះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនអើពើលើអង្គហេតុដែលថា ង៉ែត ចាត និង ជា ឡៀប មិនបាននិយាយថា ពួកគាត់ឈឺចាប់ធ្ងន់ធ្ងរបំផុតដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2510] ក៏គ្មានមូលដ្ឋានដែរ។ គ្មានលក្ខខណ្ឌតម្រូវឱ្យការឈឺចាប់នេះត្រូវតែមានភាពធ្ងន់ធ្ងរជាងការឈឺចាប់ដោយសារឧក្រិដ្ឋកម្មផ្សេងទៀត ដែលពួកគាត់ជាជន

[2507] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦៦-១១៦៨ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧៩។

[2508] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦៩។

[2509] *សូមមើលឧទាហរណ៍* ឯកសារ **E1/461.1** អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦, ១៥.៤១.២២-១៥.៤៩.១០ ទំព័រ ៧២ បន្ទាត់ ២០-២១-ទំព័រ ៧៤ បន្ទាត់ ២-៣ (ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេប្រាប់ថា គាត់ត្រូវតែរៀបគ្រួសារ ហើយគាត់ប្រកែក ព្រោះគាត់មានកូនទៅហើយ ប៉ុន្តែគេថា អត់ទេ ត្រូវតែរៀប បើមិនរៀបទេ "គេមានវិធានការផ្សេង"។ គាត់អត់ហ៊ាននិយាយទេ ព្រោះកន្លងមក គាត់មានការខ្លាច ព្រោះនៅនុង ប្រកែកអត់បាន ដឹងតែបាត់ខ្លួន), ១៥.៥៣.៥៤-១៥.៥៥.៥៨ ទំព័រ ៧៥ បន្ទាត់ ២២-ទំព័រ ៧៦ បន្ទាត់ ៨ (ដែលពិភាក្សាពីមូលហេតុដែលគាត់មិនចង់រៀបការជាមួយប្តីរបស់គាត់)។ ឯកសារ **E1/462.1** អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦, ០៩.៣១.១៨ ទំព័រ ១២ បន្ទាត់ ៤-៥ (ឪពុកម្តាយ ឪពុកម្តាយក្មេក និងចាស់ទុំក្នុងភូមិ ទទូចឱ្យគាត់ទទួលយកប្តីគាត់វិញ ហើយពួកគាត់ក៏បានរស់ជួបជុំគ្នា), ០៩.៣៧.០៤ ទំព័រ ១៤ បន្ទាត់ ២-៩ (គាត់ត្រូវបានប្តីរំលោភ)។

[2510] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៦៩។

រងគ្រោះនោះទេ។ អ្វីដែលត្រូវការជាចាំបាច់គឺការកំណត់ថាតើការរៀបអាពាហ៍ពិពាហ៍ក្នុងរបប កម្ពុជាប្រជាធិបតេយ្យ មានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចែង[2511]។

731. ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានការភាន់ច្រឡំលើអង្គហេតុ និង អង្គច្បាប់ តាមរយៈការប្រើប្រាស់សក្ខីកម្មរបស់ ស៊ូ សុធារី ដើម្បី "គាំទ្រដល់ការសន្និដ្ឋានជាទូទៅរបស់ខ្លួនអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ដោយលើកឡើងថា ស៊ូ សុធារី "ឈឺចាប់បំផុតពីការរំលោភបំពានផ្លូវភេទ ដោយសារតែជាភេទទីបី" ដែលបណ្ដាលមកពីវប្បធម៌ខ្មែរ មិនមែនរបបកម្ពុជាប្រជាធិបតេយ្យទេ[2512]។ ទោះជាយ៉ាងណាក៏ដោយ គេមិនអាចលើកឡើងថា អ.ជ.ស.ដ ផ្អែកលើសក្ខីភាពរបស់ ស៊ូ សុធារី តែម្នាក់នោះទេ។ អ.ជ.ស.ដ បានដកស្រង់សក្ខីកម្មយ៉ាងតិចចំនួនប្រាំ ដើម្បីសន្និដ្ឋានថា "ពួកគាត់ភាគច្រើនបានរម្លឹកថា ពួកគាត់យំ ហើយអន់ចិត្ត សោកស្ដាយ និងភ័យខ្លាចនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់ពួកគាត់"[2513]។ បទពិសោធន៍របស់គាត់ មិនមែនជាករណីលើកលែងឡើយ។

732. "ភាពផ្ទុយគ្នាច្បាស់ក្រឡែត" ដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានចោទប្រកាន់ មិនអាចតទល់នឹងការពិនិត្យពិច័យ ឬធ្វើឱ្យមានការដេញដោលភ័ស្តុតាងរបស់ អែម អឿន បានឡើយ។ ឧទាហរណ៍ គាត់បានលើកឡើងដោយភាន់ច្រឡំថា អែម អឿន មិនមែនជាជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយដោយសារតែភាពមិនស៊ីសង្វាក់គ្នាជាច្រើន សក្ខីកម្មរបស់គាត់មានតម្លៃជាភ័ស្តុតាងតិចតួចបំផុត[2514]។ អង្គហេតុដែលថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចជ្រើសរើសថ្ងៃរៀបការរបស់ខ្លួន ប៉ះពាល់តិចតួចដល់សក្ខីកម្មរបស់គាត់ផ្សេងៗទៀត ដែលគាត់បានរម្លឹកយ៉ាងច្បាស់ថាអាពាហ៍ពិពាហ៍របស់គាត់ធ្វើឡើងដោយការបង្ខំ និងបង្កជាការឈឺចាប់[2515]។

---

[2511] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦១។

[2512] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១៧០ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧៩។

[2513] សូមមើល ឯកសារ **E 465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧៩។

[2514] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១១៧២។

[2515] *សូមមើលឧទាហរណ៍* ឯកសារ **E1/113.1** អែម អឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២, ១៥.៥៣.១៦-១៥.៥៦.៣៦ ទំព័រ ៨៩ បន្ទាត់ ២៤-ទំព័រ ៩០ បន្ទាត់ ២៤, ១៥.៥៩.២៤-១៦.០៣.១២ ទំព័រ ៩១ បន្ទាត់ ២៤-ទំព័រ ៩៣ បន្ទាត់ ១៦។

733. ពាក់ព័ន្ធនឹង មុំ រុន ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញភ័ស្តុតាងដែលអាចដេញដោលសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្តីពីភាពអាចជឿជាក់បានរបស់គាត់ឡើយ[2516] ដោយលើកឡើងម្តងហើយម្តងទៀតពីការអះអាងដដែលៗពីមុនមក ដែល អ.ជ.ស.ដ បានពិចារណា និងបដិសេធ រួចហើយ[2517]។ ចំពោះ ប៉ូ ឌីណា អង្គហេតុដែលថា គាត់មិនបានរៀបការម្តងទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនលុបការពឹងផ្អែករបស់ អ.ជ.ស.ដ លើភ័ស្តុតាងរបស់ ប៉ូ ឌីណា ឡើយ[2518]។ ដូចដែល អ.ជ.ស.ដ បានកត់សម្គាល់ ប៉ូ ឌីណា បានផ្តល់សក្ខីកម្មថា គាត់បានបាត់បង់ប្តី កូន និងឪពុកម្តាយ និងបានប្រកែកមិនរៀបការម្តងទៀត ដែលធ្វើឱ្យគាត់ប្រឈមនឹងការវាយដំយ៉ាងធ្ងន់ធ្ងរ និងការចាប់ដាក់គុក[2519]។ ច្បាស់ណាស់ថា ចំណុចនេះពិពណ៌នាពីអារម្មណ៍ដ៏លំបាករបស់គាត់នៅពេលគិតពីការត្រូវរៀបការម្តងទៀត ដែលផ្ទុយពីឆន្ទៈរបស់គាត់ ព្រោះគាត់នៅសោកស្តាយចំពោះការបាត់បង់ប្តី ហើយនេះជាអ្វីដែល អ.ជ.ស.ដ សន្និដ្ឋាន[2520]។ ទទ្បីករណ៍ផ្សេងទៀតរបស់ម្ចាស់បណ្តឹងសាទុក្ខ ក៏មិនបានបង្ហាញភ័ស្តុតាងគួរឱ្យជឿជាក់ ដូចលើកឡើងក្នុងផ្នែកផ្សេងទៀតនៃចម្លើយតបនេះដែរ[2521]។

---

[2516] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៧៣ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៩, ៣៦៨០។

[2517] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៨-៣៦៤៩។ *សូមមើលផងដែរ* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ២១៨៤។ អ.ជ.ស.ដ យល់ឃើញដោយត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខមានឱកាសប្រឈមមុខជាមួយ មុំ រុន លើបញ្ហានៃភាពអាចជឿជាក់ចិត្តបានក្នុងតុលាការ បញ្ជាក់ថា អ.ជ.ស.ដ ផ្អែកលើសក្ខីកម្មក្នុងតុលាការជាជាងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងកត់សម្គាល់ថា ជាទូទៅ ភាពមិនស៊ីសង្វាក់គ្នាលេចឡើងក្នុងខ្លឹមសារលម្អិតនៃព្រឹត្តិការណ៍នានាដែលកើតឡើងជាង ៣០ ឆ្នាំមកហើយ។

[2518] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៧៣ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨០។

[2519] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២២៧៩។

[2520] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨០។

[2521] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥ (យោង ការយល់ព្រមក្លាយជាផ្នែកមួយនៃគោលនយោបាយ ប.ក.ក និងភាពជាតំណាងថ្នាក់ជាតិនៃភ័ស្តុតាង ដែលត្រូវបានលើកឡើងក្នុង ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៥៧-១១៥៨, ១១៧៦-១១៨៨), មូលដ្ឋានទី ១៦២ (យោង ការប៉ុនប៉ងរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការដាក់បញ្ចូលការរៀបអាពាហ៍ពិពាហ៍បែបប្រពៃណីជាមួយនឹងបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍ក្រោមរបប ក.ប.ធ ដូចការលើកឡើងក្នុង ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៥៩-១១៦២)។

### *មូលដ្ឋានទី ១៦៤ ៖ កំហុសពាក់ព័ន្ធនឹងបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តបទបញ្ញា* [2522]

734. **គួរច្រានចោលមូលដ្ឋានទី ១៦៤ ព្រោះថា ម្ចាស់បណ្តឹងសាទុក្ខមិនបានលើកឡើងពីកំហុសក្នុងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលកំណត់ថាមាន *ធាតុផ្សំអត្តនោម័តិ* សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈអំពើ ដែលចាត់ទុកថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។**

735. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញច្បាស់ពីបំណងរបស់ខ្លួន ក្នុងការចោទប្រកាន់លើមូលដ្ឋាននេះឡើយ ព្រោះឧបសម្ព័ន្ធ ក ជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ពាក់ព័ន្ធនឹង*ធាតុផ្សំអត្តនោម័តិ* សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2523] ខណៈដែលសារណារបស់គាត់លើកឡើងដដែលៗពី *ធាតុផ្សំសត្យានុម័តិ* [2524]។ តាមពិត ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានលើកទឡ្ហីករណ៍សំខាន់ក្នុងការអះអាងថា គាត់គ្មាន*ធាតុផ្សំអត្តនោម័តិ* ចាំបាច់ ដោយគ្រាន់តែលើកឡើងថា "អ.ជ.ស.ដ បានប្រព្រឹត្តកំហុសជាច្រើនក្នុងការសន្និដ្ឋានអំពីចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ" ដោយមិនផ្តល់ការយោងទៅភ័ស្តុតាង ឬឯកសារសំអាងឡើយ[2525]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានលើកឡើងច្បាស់ពីកំហុស កុំថាឡើយដល់ទៅការបញ្ជាក់ពីកំហុសនោះ។ ដូច្នេះគួរច្រានចោលមូលដ្ឋាននេះ។

### *មូលដ្ឋានទី ១៧៤ ៖ កំហុសដែលពាក់ព័ន្ធនឹងការតាមដានការរួមដំណេក* [2526]

---

[2522] <u>មូលដ្ឋានទី ១៦៤ ៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តបទបញ្ញា* កថាខណ្ឌ ១១៨៩-១១៩០។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៧ (ភាសាអង់គ្លេស) ទំព័រ ៥២ (ភាសាបារាំង) ទំព័រ ៨១ (ភាសាខ្មែរ)។

[2523] ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨១ (ភាសាខ្មែរ) ដោយកត់សម្គាល់ថា សេចក្តីសន្និដ្ឋានរងការរិះគន់គឺថាតើឥរិយាបថដោយចេតនានោះ ដែលពិចារណាដោយអង្គជំនុំជម្រះ បង្កើតជា*ធាតុផ្សំអត្តនោម័តិ* ចំពោះឧក្រិដ្ឋកម្មនោះ ឬទេ។

[2524] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៨៩ *ដោយដកស្រង់* កថាខណ្ឌ ៦៥៨-៦៦៥។

[2525] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១១៨៩។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានយោងតាមផ្នែកផ្សេងទៀតនៃសារណារបស់គាត់ដែលអាចធ្វើជាមូលដ្ឋាននៃការអះអាងរបស់គាត់។

[2526] <u>មូលដ្ឋានទី ១៧៤ ៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសដែលពាក់ព័ន្ធនឹងការតាមដានការរួមដំណេក* កថាខណ្ឌ ១៣៩១-១៣៩៨។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៩-៦០ (ភាសាអង់គ្លេស) ទំព័រ ៥៥ (ភាសាបារាំង) ទំព័រ ៨៦ (ភាសាខ្មែរ)។

736. **គួរច្រានចោលមូលដ្ឋានទី ១៧៤ ព្រោះថា ម្ចាស់បណ្ដឹងសាទុក្ខមិនបានលើកឡើងថា អ.ជ.ស.ដ មានកំហុសក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា ការរួមដំណេកធ្វើឡើងក្រោមការបង្ខិតបង្ខំ ដោយសារតែវិធានការតាមដាន ដែលធ្វើឱ្យមានការចាប់រំលោភមនុស្សយ៉ាងតិចម្នាក់។**

737. ម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា ការត្រួតពិនិត្យគ្រប់ជ្រុងជ្រោយលើភស្តុតាងនេះមិនអាចឱ្យ អ.ជ.ស.ដ សន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា បន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍ជាទូទៅ ប្ដីប្រពន្ធ ត្រូវបានគេតាមដានដើម្បីឱ្យប្រាកដថា ពួកគេបានរួមដំណេកបានឡើយ[2527]។ សំខាន់បំផុត គាត់បានផ្ដល់ទឡ្ហីករណ៍ជាច្រើនដែលបញ្ជាក់ថា អ.ជ.ស.ដ ធ្វើសេចក្ដីសន្និដ្ឋានដោយផ្អែកលើបទពិសោធន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការរៀបអាពាហ៍ពិពាហ៍ បកស្រាយខុសពីសក្ខីកម្មរបស់ពួកគេ មើលរំលងភស្តុតាងផ្សេងទៀត និងខកខានមិនបានពិចារណាថាតើការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងរបស់ពួកគេតំណាងឱ្យភ័ស្តុតាងទាំងមូលឬយ៉ាងណា។ ទឡ្ហីករណ៍នីមួយៗត្រូវបានពិនិត្យមើលដូចខាងក្រោម ប៉ុន្តែ ចាំបាច់ត្រូវកត់សម្គាល់តាំងពីដំបូងថា ទឡ្ហីករណ៍គោលធ្វើឱ្យមានការភាន់ច្រឡំ ព្រោះថា សេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ រួមទាំងភស្តុតាងពីការរៀបអាពាហ៍ពិពាហ៍ និងសក្ខីកម្មរបស់បុគ្គលយ៉ាងតិច ១០ នាក់មកពីផ្នែកផ្សេងៗនៃការជំនុំជម្រះ[2528]។

*គោលដៅនៃការតាមដាន*

738. ម្ចាស់បណ្ដឹងសាទុក្ខមិនបានផ្ដល់ភ័ស្តុតាងដែលអាចគាំទ្រដល់ទឡ្ហីករណ៍របស់គាត់ដែលថា មិនអាចបង្ហាញថា គោលដៅនៃការតាមដានគឺដើម្បីធានាថា ប្ដីប្រពន្ធថ្មីថ្មោងបានរួមដំណេកនោះទេ[2529]។ ផ្ទុយទៅនឹងការអះអាងរបស់គាត់ ភ័ស្តុតាងដែលទទួលបានពី អ៊ុំ យឿន, ព្រាប សុខឿន, ជុំ សាមឿន, មាស ឡៃហួរ, ហេង ឡៃប៉ាង និង ជាំង ស្រីមុំ មិនបង្ហាញពី "បទពិសោធចម្រុះ" នោះទេ វាមានទំនាក់ទំនងយ៉ាងច្បាស់ទៅនឹងការយាមល្បាតរបស់ឈ្លបដើម្បីឃ្លាំមើលការរួមដំណេក

[2527] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៤៣ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៤, ៣៦៥៩។

[2528] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៥-៣៦៦១ ជើងទំព័រ ១២១៨៦-១២២២៨ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥។

[2529] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៤៥ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤១-៣៦៤៤។

ដោយបង្ខំ[2530]។ ការអះអាងបន្ថែមរបស់គាត់ដែលថា ឥទ្ធិពលដែលការតាមដានបែបនេះមានទៅលើប្ដីប្រពន្ធថ្មីថ្មោង មានភាពខុសគ្នាពីករណីមួយទៅករណីមួយ ក៏មិនមានភាពពាក់ព័ន្ធផងដែរ[2531]។ បុគ្គលខ្លះបានបង្ខំខ្លួនឯងឱ្យរក្សាភាពស្ងៀមស្ងាត់[2532] ខណៈពេលដែលបុគ្គលផ្សេងទៀតបានបង្ខំខ្លួនឯងឱ្យមានទំនាក់ទំនងផ្លូវភេទ[2533]។ សេណារីយ៉ូទាំងពីរនេះ បង្ហាញយ៉ាងច្បាស់ថា ការតាមដានបានបង្កឱ្យមានការភ័យខ្លាច និងមានបរិយាកាសបង្ខិតបង្ខំ។

[2530] ឯកសារ E1/462.1 អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦, ០៩.១៨.៤០-០៩.២០.០៨ ទំព័រ ៧ បន្ទាត់ ១៥-១៧ ("ហើយដល់ពេលយប់ឡើង គេមិនឱ្យអ្នកការពារហ្នឹងការពារចំពោះនាងខ្ញុំផង ហើយមកមើល តើរួមដំណេកឬអត់ បើសិនជាអត់មានរួមដំណេកទេ គេអាចមានធ្វើវិធានការផ្សេងទៀត")។ ឯកសារ E1/487.1 ព្រាប សុខឿន ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦, ១៤.៣១.១៥-១៤.៣៣.៣១ ទំព័រ ៥៩ បន្ទាត់ ២១-២៣ ("សម័យហ្នឹងបើនិយាយភាពជូរចត់ ការហើយគេតាមដាន គេនៅពី គេអើតមើលតាមបង្អួច គេឈរពីចំហៀង គេតាមដានយើងគ្រប់ជំហាន ឱ្យយើងការរួចឱ្យយើងរស់នៅជាមួយគ្នា។ គេតាមពិនិត្យគ្រប់បែបយ៉ាង គឺថាបើយប់ហ្នឹងគឺទាល់តែភ្លឺ")។ ឯកសារ E1/321.1 ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥, ១៤.២៩.៤៤-១៤.៣២.៤៤ ទំព័រ ៥២ បន្ទាត់ ២៤-ទំព័រ ៥៣ បន្ទាប់ ២ ("ចាស មានឈ្លបគេតាមដានហ្នឹង គេៗអត់បានចង់ធ្វើអីទេ ព្រោះខ្ញុំអត់បានដឹងគេកាន់អារុធឬអីទេ ព្រោះខ្ញុំឮតែសម្រឹបជើងដើរចាស។ [...] គេចង់ដឹងថា យើងចុះសម្រុងអត់")។ ឯកសារ E1/305.1 មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥, ០៩.៤៨.២៨-០៩.៥០.៤៥ ទំព័រ១៤ បន្ទាត់ ១៨-១៩ ("ក្រែងលោគេមកមើលយើង យើងចុះដំណេកនឹងគ្នាឬក៏អត់ អីអ៊ីចឹងទៅណា បានគេចេះតែមក")។ ឯកសារ E1/476.1 ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦, ០៩.៥៣.០១-០៩.៥៤.៤៧ ទំព័រ ១៤ បន្ទាត់ ២៣-២៥ ("ចាស បញ្ហាហ្នឹងគឺមានចំពោះអ្នកដែលត្រូវគ្នាអ៊ីចឹងទៅ គេមិនមានការតាមដានទេ។ ចំពោះខ្ញុំអ្នកដែលមិនពេញចិត្តនឹងគ្នា មិនចុះសម្រុងគ្នាគឺគេតាមដាន ស៊ើបអង្កេត លួចស្ដាប់ លួចយកព័ត៌មានជាហូរហែ ដើម្បីហៅទៅអប់រំ និងព្រមាន")។ ឯកសារ E1/254.1 ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥, ១៥.៤៥.២០-១៥.៤៦.៥២ ទំព័រ ៧៣ បន្ទាត់ ២-៤ ("ចាស កាលឈ្លបមកហ្នឹង គឺគេមកលបមើលហ្នឹង គេលបស្ដាប់គ្រាន់ថាក្រែងយើងហ្នឹងមិនចុះដំណេកជាមួយគ្នា។ អ៊ីចឹងយើង សកម្មភាពអីយើងសម្ងំអត់មានធ្វើអីទាំងអស់ យើងខ្លាច យើងចេះតែសម្ងំទៅ")។

[2531] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៤៦។

[2532] *សូមមើលឧទាហរណ៍* ឯកសារ E1/489.1 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦, ០៩.០៦.៣៩-០៩.០៨.៥១ ទំព័រ ៣ បន្ទាត់ ១២-១៥ ("អត់ហ៊ាននិយាយអី គិតអីទេ ខ្លាចៗគេ ព្រោះអីឃើញឈ្លបដើរតាមផ្លូវកៀនៗជញ្ជាំងផ្ទះដែលខ្ញុំដេកហ្នឹង ហើយខ្លាចគេឮ ខ្លាចគេស្ដាប់ដឹងអ៊ីចឹង ខ្លាចថាខ្ញុំហ្នឹងមិនគោរពបដិវត្តន៍អ៊ីចឹងទៅ។ ខ្ញុំខ្លាចគេយកទៅបញ្ជូនខ្ញុំទៅលើ ខ្ញុំមិនដឹងទៅណា ខ្ញុំចេះតែខ្លាចអ៊ីចឹង ចេះអ៊ីចឹង ដេកស្ងៀមអ៊ីចឹងពីរនាក់គាត់អ៊ីចឹងទៅ")។

[2533] *សូមមើលឧទាហរណ៍* ឯកសារ E1/488.1 កុល ណែម ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦, ១៥.០៧.១៦-១៥.០៨.៥៦ ទំព័រ ៧៧ បន្ទាត់ ៤-៨ ("មានតែគេចាំតាមដានយើង។ បើយើងអត់បានរួមដំណេកជាមួយហ្នឹង គឺគេតាមដានយើងរហូតហ្នឹង។ ហ្នឹងហើយ មានតែប៉ុណ្ណឹង យើងខ្លាចគេ ដូច្នេះយើងត្រូវរួមដំណេក បាន៣ថ្ងៃបានរួមដំណេក យូរដែរ។ បាទ មិនមែនថា អូ! ភ្លាមៗរួមដំណេកទេ នៅគិតច្រើន បាទ នៅគិតច្រើន។ ៣ថ្ងៃបានៗរួមដំណេក។ បើមិនរួម គេមក។ មានអ្នកតាមដានមករហូត។ ខ្ញុំអស់ប៉ុណ្ណឹង")។ ឯកសារ E1/254.1 ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥, ១០.៤០.៤៩-១០.៤៤.១៣ ទំព័រ ២៦ បន្ទាត់ ៤-៦ ("ចាស ពេលនោះខ្ញុំត្រូវតែស្ម័គ្រចិត្ត បើកាលណាយើងកើតមានបញ្ហា ខ្លាចវាមានគ្រោះថ្នាក់ ព្រោះក្នុងការ

739. ម្ចាស់បណ្ដឹងសាទុក្ខក៏មិនបានបង្ហាញផងដែរថា សក្ខីកម្មរបស់ ជា ឌៀប[2534] និង ណុប ងឹម[2535] ត្រូវបានបកស្រាយដោយមិនត្រឹមត្រូវ និងមិនអាចទុកចិត្តបាននៅត្រង់ចំណុចនេះ។ ការពិតដែលថា សក្ខីកម្មរបស់ ជា ឌៀប គ្រាន់តែជាសក្ខីកម្មដើម្បីបង្ហាញថា ការតាមដានដែលបានកើតមានឡើង នៅក្នុងក្រសួងរបស់គាត់ មិនមានភាពពាក់ព័ន្ធទេ ដោយសារ អ.ជ.ស.ដ មិនបានសន្និដ្ឋានទាក់ទង នឹងការតាមដាននៅក្រសួងនានាឡើយ។ ដូចគ្នានេះដែរ អ.ជ.ស.ដ មិនបានពឹងផ្អែកលើសក្ខីកម្ម របស់ ណុប ងឹម នោះទេសម្រាប់សេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា ការតាមដានការរៀបការត្រូវ បានធ្វើឡើងទៅតាមបញ្ជាពីអាជ្ញាធរ[2536]។

*ការរាយការណ៍អំពីការរួមដំណេកទៅថ្នាក់លើ និងតួនាទីរបស់ឈ្លប*

740. ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញភ័ស្ដុតាងណាមួយដែលអាចបញ្ជាក់ទឡ្ហីករណ៍របស់គាត់បាន ឡើយទាក់ទងទៅនឹងសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ឈ្លបបានរាយការណ៍សកម្មភាព តាមដានរបស់ពួកគេទៅកាន់អាជ្ញាធរ។ ការចោទប្រកាន់របស់គាត់ដែលថា ការរៀបរាប់ពី ព្រឹត្តិការណ៍ដំណើររឿងរបស់ រី ពៅ គួរត្រូវបានពិចារណាដោយប្រុងប្រយ័ត្នជាងនេះដោយសារថា រចនាសម្ព័ន្ធរាយការណ៍ដែលគាត់បានពិពណ៌នា តម្រូវឱ្យមាន "ការធ្វើដំណើរទៅច្រើនកន្លែង"[2537] នោះ គ្មានអ្វីលើសពីការប៉ាន់ស្មាននោះទេ។ អង្គហេតុដែលថា រចនាសម្ព័ន្ធរាយការណ៍មានភាពស្មុគ ស្មាញនោះ មិនបានបង្ហាញថា រចនាសម្ព័ន្ធរាយការណ៍នេះមិនអនុវត្តនោះទេ។ ដូចគ្នានេះដែរ ទាក់ទង នឹងភ័ស្ដុតាងរបស់ ហេង ឡៃហ៊ាង ម្ចាស់បណ្ដឹងសាទុក្ខកំពុងធ្វើការងារលើផ្នែកភាសា[2538]។ ភ័ស្ដុតាងរបស់គាត់បញ្ជាក់សក្ខីកម្មផ្សេងទៀតដែលព័ត៌មានត្រូវបានប្រមូល និងរាយការណ៍ឡើង

ភ័យខ្លាចមានឈ្លបនៅពីក្រោមអ៊ីចឹង។ ខ្ញុំដូចថា សម្រួលចិត្តដាក់ចិត្ត ក្នុងចិត្តថាវាជៀសវាងប្ដីប្រពន្ធ ពីថ្ងៃនេះទៅវាជៀសវាងប្ដីប្រពន្ធឥត១ជៀសវាងមិនផុត អ៊ីចឹងខ្ញុំត្រូវតែសម្រួលចិត្ត")។

[2534] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៤៧។

[2535] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៤៨។

[2536] សូមមើល ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៣ (ដោយពិភាក្សាអំពីភ័ស្ដុតាងដែលបង្ហាញថា ឈ្លបដែលបានតាមដានប្ដីប្រពន្ធបានរាយការណ៍ទៅកាន់អាជ្ញាធរ និងដោយលើកឡើងភ័ស្ដុតាងដែលបង្ហាញថា ពួកគេត្រូវបានចាត់តាំងឱ្យតាមដានប្ដីប្រពន្ធ។ ណុប ងឹម មិនត្រូវបានដកស្រង់សំដីឡើយ)។ *ផ្ទុយពី* ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៤៨។

[2537] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៤៩-១៣៥០ *ដោយដកស្រង់* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៣។

[2538] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៥១។

ទៅកាន់ខ្សែសង្វាក់នៃការបញ្ជា[2539]។ មិនថារបាយការណ៍បែបនេះត្រូវបានបញ្ជូនទៅកាន់អង្គភាព ឬយ៉ាងណានោះទេ "អ្នកគ្រប់គ្រង" ឬ "អ្នកទទួលខុសត្រូវជាន់ខ្ពស់" មិនមានការពាក់ព័ន្ធឡើយ ដោយសារ អ.ជ.ស.ដ មិនធ្លាប់បានលើកឡើងថា មន្ត្រីជាន់ខ្ពស់របស់ ប.ក.ក បានទទួលរបាយការណ៍បែបនេះដោយផ្ទាល់នោះទេ[2540]។

741. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មិនអើពើនឹងភ័ស្តុតាងទាក់ទងនឹងតួនាទីពិតរបស់ឈ្លបនៅក្នុងសហគមន៍[2541] ដោយបង្ហាញសក្ខីកម្មរបស់ នាង អ៊ួច និង យាន លន់ ដើម្បីលើកឡើងថា ឈ្លបបានត្រឹមតែឃ្លាំមើលសហគមន៍ និងផ្តល់សន្តិសុខប៉ុណ្ណោះ[2542]។ ទោះជាយ៉ាងណា សក្ខីកម្មរបស់ពួកគេចូលរួមចំណែកបានតិចតួចដល់ការជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានដែលត្រូវបានគាំទ្រដោយភ័ស្តុតាងយ៉ាងច្រើនដែលបង្ហាញថា ឈ្លបកំពុងតាមដានប្តីប្រពន្ធ។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែចង់បានការពន្យល់ផ្សេងមួយទៀតអំពីអង្គហេតុប៉ុណ្ណោះ។

*កំហុសដែលត្រូវបានចោទប្រកាន់ក្នុងការវាយតម្លៃរបស់ អ.ជ.ស.ដ ទៅលើសក្ខីកម្មរបស់ ឌុច*

742. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មិនបានពិចារណាលើសក្ខីកម្មរបស់ ឌុច ដែលថា មានតែ "កម្មាភិបាលខូច" ប៉ុណ្ណោះដែលតាមដានប្តីប្រពន្ធដូចដែលត្រូវបានបង្ហាញដោយអង្គហេតុថា កម្មាភិបាលឈ្មោះ ប៉ាង ត្រូវបានដាក់ទណ្ឌកម្មដោយសារឥរិយាបថបែបនេះរបស់គាត់[2543]។ សាលក្រមច្រានចោលការអះអាងនេះដោយផ្ទាល់។ អ.ជ.ស.ដ បានលើកឡើងយ៉ាងច្បាស់ថា "ផ្ទុយទៅនឹងចម្លើយរបស់ ឌុច ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបង្ហាញថា គូស្វាមីភរិយាទើបរៀបការត្រូវបានគេឃ្លាំមើលដើម្បីឱ្យដឹងថា តើពួកគាត់បានរួមដំណេកឬអត់" ខណៈពេលដែល "ប៉ាង មិនត្រូវបានចាប់ខ្លួន [ដោយសារការស្នើឱ្យអ្នកនៅក្រោមបង្គាប់របស់គាត់តាមដានប្តីប្រពន្ធថ្មីថ្មោង] ប៉ុន្តែ [ដោយសារជាផ្នែកមួយនៃ] ការបោសសម្អាតមនុស្សទ្រង់ទ្រាយធំពីមន្ទីពេទ្យ ព-៧៨"[2544]។ ចំណុចនេះត្រូវបានគាំទ្រដោយការសរសេរបញ្ចូល

---

[2539] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៣ *ជាពិសេស* ជើងទំព័រ ១២១៨៣។

[2540] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៥១។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៤ (អ.ជ.ស.ដ យល់ឃើញថា ប្តីប្រពន្ធត្រូវបានតាមដានជាញឹកញាប់ ដើម្បីប្រាដកថា ពួកគេបានរួមដំណេក)។

[2541] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៥២។

[2542] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៥២, ១៣៥៤។

[2543] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៥៣។

[2544] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤១ ជើងទំព័រ ១២១៧៧។

នៅក្នុងសៀវភៅកត់ត្រាចូលផ្សេងៗរបស់មន្ទីរ ស-២១[2545]។ ដូច្នេះ អ.ជ.ស.ដ បានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីភាពមិនស៊ីសង្វាក់គ្នានៃភស្តុតាង ដោយពិចារណាលើភាពអាចទុកចិត្តបាន និងភាពអាចជឿជាក់បាន*ទាំងស្រុង* និងបានទទួល និងបានច្រានចោលលក្ខណៈពិសេសជាមូលដ្ឋាននៃភស្តុតាងដោយផ្អែកលើការវាយតម្លៃរួម[2546]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញនោះទេថា អ.ជ.ស.ដ មានការភាន់ច្រឡំនោះ។

*ឥទ្ធិពលនៃបរិយាកាសបង្ខិតបង្ខំទៅលើការរួមដំណេកដោយបង្ខំ*

743. បន្ថែមទៅលើការជំទាស់ទៅនឹងអត្ថិភាពនៃគោលនយោបាយតាមដាន ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា អ.ជ.ស.ដ មានការភាន់ច្រឡំក្នុងការសន្និដ្ឋានថា បរិយាកាសនេះគឺជាបរិយាកាសដែលបុគ្គលមានអារម្មណ៍ថា ពួកគេត្រូវបានបង្ខំឱ្យមានទំនាក់ទំនងផ្លូវភេទជាមួយប្តីប្រពន្ធរបស់ពួកគេ[2547]។ ដំបូង គាត់លើកឡើងថា អ.ជ.ស.ដ បកស្រាយមិនត្រឹមត្រូវលើចម្លើយរបស់ ប្រាក់ យុត, ជាំង ស្រីមុំ និង ម៉ម សឿន[2548]។ ក្នុងករណីនីមួយៗ គាត់ត្រឹមតែបង្ហាញការបកស្រាយជំនួសអង្គហេតុដែលត្រូវបានពិចារណារួចហើយដោយ អ.ជ.ស.ដ។ អ្វីដែលបង្ហាញនោះគឺការដែលថាម្ចាស់បណ្តឹងសាទុក្ខខ្លួនគាត់ផ្ទាល់ទទួលស្គាល់ថា ជាំង ស្រីមុំ និង ម៉ម សឿន បានលើកឡើងពីភាពភ័យខ្លាចត្រូវគេសម្លាប់ ប្រសិនបើមិនបានរួមដំណេកក្រោយអាពាហ៍ពិពាហ៍[2549] ដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីបរិយាកាសបង្ខិតបង្ខំ។ សក្ខីកម្មរបស់ ប្រាក់ យុត ត្រូវបានបកស្រាយដោយមិនត្រឹមត្រូវដូចគ្នាដោយម្ចាស់បណ្តឹងសាទុក្ខ ដែលលើកឡើងថា អ.ជ.ស.ដ មិនបានអើពើទៅនឹងសក្ខីកម្មដ៏សំខាន់របស់គាត់ ដែលថាក្នុងតួនាទីរបស់គាត់ជាគណៈស្រុក គាត់មិនបានបញ្ជូនប្តីប្រពន្ធឱ្យទៅទទួលទណ្ឌកម្មដោយសារការមិនបានរួមដំណេកឡើយ[2550]។ គាត់មិនបានទទួលស្គាល់ដោយផ្ទាល់នោះទេថា នៅមុនពេលដកស្រង់សក្ខីកម្មត្រង់ចំណុចនេះ ប្រាក់ យុត បានលើកឡើងយ៉ាងច្បាស់ថា "ខ្ញុំអត់មានវិធានការអីដែលធ្វើឱ្យគូស្រករទាំងពីរនាក់នោះបាត់បង់អីទេ *មានតែ*

[2545] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤១ ជើងទំព័រ ១២១៧៧។

[2546] សាលដីការឿងក្តី *Setako* កថាខណ្ឌ ៣១។

[2547] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៦១។

[2548] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៦៥-១៣៦៦។

[2549] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៦៦។

[2550] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៦៥។

*ការអប់រំនៅក្នុងស្រុក* ដើម្បីឱ្យគូស្រករទាំងពីរនោះចេះយល់ចិត្ត យល់គំនិតគ្នា"[2551]។ ភ័ស្តុតាងជាច្រើននៅចំពោះមុខ អ.ជ.ស.ដ បង្ហាញថា ការអប់រំជាញឹកញាប់ត្រូវបានប្រើប្រាស់ធ្វើជាការគំរាមកំហែង ហើយជាញឹកញាប់មានការពាក់ព័ន្ធនឹងការដាក់ទោសទណ្ឌចំពោះជនទាំងឡាយណាដែលមិនអនុលោមតាមគោលនយោបាយរបស់ ប.ក.ក[2552]។

744. ទាក់ទងនឹងភ័ស្តុតាងក្នុងអំឡុងវគ្គសវនាការពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសមួយចំនួនក្នុងការវាយតម្លៃរបស់ខ្លួនទៅលើសក្ខីកម្មរបស់ សយ ណារឿន, អ៊ុំ យឿន, ជា ឡៀប, កុល ណែម, ប៉ែន សុចាន់ និងអ្នកជំនាញ Kasumi Nakagawa[2553]។ គាត់មិនបានលើកឡើងទឡ្ហីករណ៍បន្ថែមទៀតឡើយទាក់ទងនឹង សយ ណារឿន, ជា ឡៀប ឬ កុល ណែម លើសពីប្រយោគនេះ។ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរដែលនៅសល់ គាត់លើកឡើងទឡ្ហីករណ៍ជាច្រើនដែលបកស្រាយមិនត្រឹមត្រូវចំពោះភ័ស្តុតាងនេះ និងមិនអើពើទៅនឹងសច្ចធារណ៍ដែលថា អ.ជ.ស.ដ បានវាយតម្លៃភ័ស្តុតាងទាំងអស់ដែលបានដាក់នៅចំពោះមុខខ្លួន[2554]។ គាត់លើកឡើងថា ការរំលោភសេពសន្ថវៈទៅលើ ប៉ែន សុចាន់ និង អ៊ុំ យឿន គួរត្រូវបានចាត់ទុកថាជាការលើកលែង និងមានភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយស្តីពីការព្រមព្រៀងរបស់ ប.ក.ក[2555]។ ដូចដែលមានការលើកឡើងនៅកន្លែងផ្សេង គាត់មិនបានលើកឡើងចំណុចនេះឡើយ ហើយត្រឹមតែលើកឡើងដដែលៗនូវទឡ្ហីករណ៍មិនត្រឹមត្រូវដែលថា គោលការណ៍សីលធម៌របស់ ប.ក.ក បានជំរុញឱ្យមានទំនាក់ទំនងដែលមានការព្រមព្រៀង[2556]។

745. ទាក់ទងនឹងសាក្សីដែលជាអ្នកជំនាញ Kasumi Nakagawa ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដោយមិនត្រឹមត្រូវថា គាត់បាននិយាយអំពីការរំលោភអំណាចដោយ*អាជ្ញាធរមូលដ្ឋាន* "ដែលគាត់បានវិភាគថាជាបរាជ័យរបស់អាជ្ញាធរថ្នាក់លើ ក្នុងការដាក់ឱ្យអនុវត្ត "គោលនយោបាយដើម្បីការពារស្ត្រី""[2557]។ ទោះជាយ៉ាងណា សក្ខីកម្មរបស់គាត់ដែលបានដកស្រង់ពេញលេញដោយម្ចាស់បណ្តឹង

[2551] ឯកសារ **E1/378.1** ប្រាក់ យុត ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦, ១៣.៤៧.២៧-១៣.៥១.៤៤ ទំព័រ ៤០ បន្ទាត់ ១៤-១៥ (គូសបញ្ជាក់បន្ថែម)។

[2552] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩, ១៨៤។

[2553] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៦៧, ១៣៧០។

[2554] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចដែលសមហេតុផល)។

[2555] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៦៨-១៣៦៩។

[2556] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៣។

[2557] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៧០ (គូសបញ្ជាក់បន្ថែម)។

សាទុក្ខ បង្ហាញពីការគាំទ្រច្បាស់លាស់ដល់សេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា មិនមានគោលនយោបាយបែបនេះអនុវត្តឡើយ ដោយសារ*អាជ្ញាធរថ្នាក់លើ* "ពិតជាមានគោលនយោបាយតឹងរ៉ឹងមែន ហើយអ្នកណាក៏ដឹងពីគោលនយោបាយនេះដែរ។ ខ្ញុំដឹងថា ថ្នាក់លើមិនបានអនុវត្តគោលនយោបាយហ្នឹងទេ"[2558]។

746. ម្ចាស់បណ្ដឹងសាទុក្ខក៏ចង្អុលបង្ហាញទៅកាន់ភ័ស្តុតាងដែលត្រូវបានចោទប្រកាន់ថា អ.ជ.ស.ដ "មិនបានអើពើ"។ គាត់លើកឡើងថា អ.ជ.ស.ដ មិនបានកត់សម្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរៀបការមិនសមតាមបំណងរបស់ពួកគេ (ណុប ធីម, ផាន់ ហ៊ីម និង សេង សឿន) មិនបានលើកឡើងពីការរួមដំណេកក្រោមការបង្ខិតបង្ខំឡើយ[2559]។ ទឡ្ហីករណ៍របស់គាត់ មិនអើពើទៅនឹងសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា នៅទីណាដែលការព្រមព្រៀងរៀបការមិនមែនជាការព្រមព្រៀងពិតប្រាកដ ការរួមដំណេកត្រូវបានបង្ខំ *យ៉ាងពិតប្រាកដ*[2560]។ ម្ចាស់បណ្ដឹងសាទុក្ខចង្អុលបង្ហាញបន្ថែមទៅនឹងសក្ខីកម្មរបស់ ជាំង ស្រីមុំ, ណុប ធីម និង សេង សឿន ដោយលើកឡើងថា ពួកគាត់ "មិនមាន "អារម្មណ៍ភ័យខ្លាច" ឬ "បានយល់ព្រមរួមភេទ [...] ពីព្រោះពួកគាត់ជាប្ដីប្រពន្ធនឹងគ្នាហើយ"[2561]។ ដូចដែលបានលើកឡើងនៅកន្លែងផ្សេង ការអះអាងដែលថា ការរៀបការបានធ្វើឱ្យទំនាក់ទំនងផ្លូវភេទរបស់ពួកគេមានភាពជាធម្មតាវិញនោះ គ្មានមូលដ្ឋានទេ[2562]។

747. សក្ខីកម្មរបស់ ព្រាប សុខឿន និង ប្រាក់ ខឿន ត្រូវបានបកស្រាយខុសបន្ថែមទៀតទាក់ទងនឹងចំណុចនេះ។ ម្ចាស់បណ្ដឹងសាទុក្ខបង្ហាញការរំលោភសេពសន្ថវៈរបស់ ព្រាប សុខឿន ថាជាអំពើស្ម័គ្រចិត្តពីប្ដីរបស់គាត់[2563]។ ទោះជាយ៉ាងណា សក្ខីកម្មរបស់គាត់បង្ហាញយ៉ាងច្បាស់ថា "គាត់ធ្វើ

---

[2558] ឯកសារ **E1/473.1** Kasumi Nakagawa ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦, ១៤.១៣.២៣-១៤.១៥.៣០ ទំព័រ ៥៦ បន្ទាត់ ២១-២៣ ("ពិតជាមានគោលនយោបាយតឹងរ៉ឹងមែន [ប្រឆាំងនឹងការរំលោភសេពសន្ថវៈ] ហើយអ្នកណាក៏ដឹងពីគោលនយោបាយនេះដែរ។ ខ្ញុំដឹងថា ថ្នាក់លើមិនបានអនុវត្តគោលនយោបាយហ្នឹងទេ គឺគោលនយោបាយគេមានដើម្បីការពារស្ត្រី ក៏ប៉ុន្តែគេប្រើគោលនយោបាយនេះដើម្បីវាយប្រហារទៅលើស្ត្រីទៅវិញ")។ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧០ ជើងទំព័រ ២៥៩៤។

[2559] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧១-១៣៧២។

[2560] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៦១។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៣ (ដោយពិភាក្សាថា រាល់អំពើចាប់រំលោភសេពសន្ថវៈ បង្កើតឱ្យមានការឈឺចាប់ ឬរបួសស្នាមដោយមិនចាំបាច់ស្ដែងចេញច្បាស់ឡើយ)។

[2561] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧២។

[2562] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៣។

[2563] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧២។

នេះគាត់ទៅតាមអង្គការវិន័យទេ ដើម្បីកុំឱ្យយើងនេះជួបការស្លាប់"[2564]។ ទោះជាគាត់ក៏បញ្ជាក់ផងដែរ "ថា មិនមានអ្នកណាម្នាក់បញ្ជាពួកគេ" នោះ វានៅតែច្បាស់ពីសក្ខីកម្មរបស់គាត់ទាំងស្រុងថា កាលៈទេសៈនោះគឺថា មិនមានអ្នកណាម្នាក់អាចបដិសេធបានទេ។

748. ប្រាក់ ឌឿន ក៏ត្រូវបានរាយការណ៍ដោយមិនត្រឹមត្រូវផងដែរដោយម្ចាស់បណ្ដឹងសាទុក្ខ ខណៈពេលផ្ដល់សក្ខីកម្មថា ប្ដីប្រពន្ធមិនត្រូវបានដាក់ទោសដោយសារការមិនរួមដំណេក[2565]។ តាមពិត សក្ខីកម្មរបស់គាត់បង្ហាញផ្ទុយពីនេះថា "បាទដែលខ្ញុំបានឮច្បាស់ [ប្ដីប្រពន្ធដែលត្រូវបានចាប់ខ្លួន] គឺអត់មានដាក់ទណ្ឌកម្មទេ គឺគ្រាន់តែយកទៅណែនាំជាលើកទី១ ដែលអង្គការបានស្រលាញ់ ហើយនិងជួយសម្រួលដោះស្រាយពីត្រឹមថ្ងៃហ្នឹង យកចិត្តទុកដាក់ជាមួយគ្នា ដើម្បីរស់រានមានជីវិតដេកនៅជាមួយគ្នា កុំឱ្យមានពាក្យធំ ពាក្យតូច កុំឱ្យបន្ទោសទៅដល់អង្គការថាអ៊ីចេះ ថាអ៊ីចុះ តែបន្តិចទៅគេចាប់ខ្លួនហើយ។ អ្នកទាំងពីរនាក់ហ្នឹង ខ្ញុំក៏បានដើរឆ្ងាយ ដឹងជាស្លាប់ ដឹងជាបាត់យ៉ាងម៉េច ក៏ខ្ញុំបានលែងទៅកាប់សសរដែរ ក៏ពាក្យហ្នឹងបញ្ចប់ត្រឹមហ្នឹងទៅ"[2566]។ ដោយត្រូវបានគំរាមបញ្ជូនទៅរៀនសូត្រ បុគ្គលដែលជាកម្មវត្ថុចំពោះការរៀបការដោយបង្ខំ មិនអាចជំទាស់ទៅនឹងរៀបការលើសពីអ្វីដែលពួកគេអាចធ្វើបានតាមរយៈការជំទាស់ទៅនឹងការរួមដំណេកដោយបង្ខំនោះទេ។

749. ម្ចាស់បណ្ដឹងសាទុក្ខក៏លើកឡើងផងដែរថា អ.ជ.ស.ដ មិនបានអើពើទៅនឹងសេចក្ដីសន្និដ្ឋានរបស់ Pag Levine ដែលបានអះអាងថា "នៅក្នុងប៉ាន់គំរូ [ស្រាវជ្រាវ] របស់ខ្ញុំ មិនមានអ្នកណាម្នាក់ត្រូវបានគេគំរាមកំហែងថា បើអ្នកឯងមិនធ្វើតាមសំណើគេហ្នឹងទេ គឺថាអ្នកឯងត្រូវសម្លាប់ចោលនោះ"[2567]។ បើទោះជាមានការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខក្ដី ក៏ចម្លើយនេះតែងឯងមិនបង្ហាញថា "ក្នុងការអនុវត្តវិធីសាស្ត្រមិនជ្រើសរើស និងមិនលម្អៀង យើងឈានដល់ការធ្វើសេចក្ដីសន្និដ្ឋានផ្សេង"[2568]។ ការពិត គាត់ក៏បានផ្ដល់សក្ខីកម្មផងដែរថា អ្នកឆ្លើយតបចំនួន ៧៦ នាក់ក្នុងចំណោម ១៩២ នាក់ក្នុងការសិក្សារបស់គាត់ បានរាយការណ៍ថា ការរួមភេទត្រូវបានបង្គាប់បញ្ជា ហើយ

---

[2564] ឯកសារ **E1/488.1** ព្រាប សុខឿន ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦, ១៣.៥១.៥១-១៣.៥៣.៥២ ទំព័រ ៥៨ បន្ទាត់ ១០-១៥។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៨៧។

[2565] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧២។

[2566] ឯកសារ **E1/361.1** ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥, ១៥.៥៨.៥៥ ទំព័រ ៨១ បន្ទាត់ ៣-៧។

[2567] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧៣ ជើងទំព័រ ២៦០១ *ដោយលើកឡើង* ឯកសារ **E1/480.1** Peg Levine ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦, មុន ១៥.៥១.២៤។

[2568] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧៣។

១៩នាក់ បានរាយការណ៍អំពីការអនុវត្តតាមការបង្គាប់បញ្ជា[2569]។ ហេតុដូចនេះ អ.ជ.ស.ដ បាន ចាត់វិធានការយ៉ាងច្បាស់លាស់ក្នុងដែនឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីកំណត់ថា តើផ្នែកនៃភ័ស្តុតាង ណាមួយដែលត្រូវទទួលយក និងថាតើផ្នែកណាមួយដែលត្រូវច្រានចោល ដោយផ្អែកលើការវាយ តម្លៃរួមលើភ័ស្តុតាងដែលបានដាក់នៅចំពោះមុខខ្លួន ដែលក្នុងចំណោមនោះ ភ័ស្តុតាងរបស់ Peg Levine គឺជាផ្នែកតូចមួយ។

750. ម្ចាស់បណ្តឹងសាទុក្ខបន្ទាប់មកជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា គេត្រូវ លាក់បាំងការមិនរួមភេទ ដើម្បីបញ្ចៀសផលវិបាកធ្ងន់ធ្ងរ[2570] ដោយត្រឹមតែលើកឡើងដដែលៗនូវ ទឡ្ហីករណ៍មិនត្រឹមត្រូវទាក់ទងនឹងភាពពាក់ព័ន្ធនៃបរិបទប្រពៃណីខ្មែរ ដែលត្រូវបានលើកឡើងរួច ហើយនៅកន្លែងផ្សេងក្នុងចម្លើយតបនេះ[2571]។ ជាចុងក្រោយ គាត់ជំទាស់ទៅនឹងសេចក្តីសន្និដ្ឋាន ដែលថា នៅពេលបុគ្គលមិនបានរួមដំណេក ពួកគេត្រូវបានកោះហៅដោយអាជ្ញាធរ ដោយអះអាង ថា អ.ជ.ស.ដ មិនបានអើពើទៅនឹងសក្ខីកម្មរបស់កម្មាភិបាលដែលបានបញ្ជាក់ថា គោលបំណង នោះគឺដើម្បីផ្តល់ការណែនាំដល់ប្តីប្រពន្ធ មិនមែនស្តីបន្ទោសទេ[2572]។ ទោះជាយ៉ាងណា សក្ខីកម្ម មួយចំនួនដែលម្ចាស់បណ្តឹងសាទុក្ខដកស្រង់មកគាំទ្របញ្ជាក់ថា បុគ្គលម្នាក់ៗត្រូវបានយកទៅ រៀនសូត្រ[2573]។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងទាំងស្រុងលើការគំរាមកំហែងពីការយកទៅអប់រំ។

---

[2569] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៥៤។

[2570] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៧៤ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤៧។

[2571] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦២។

[2572] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣៧៥-១៣៧៦ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៥៦។

[2573] *សូមមើលឧទាហរណ៍* ឯកសារ **E1/412.1** សុន វុត ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦, ០៩.១៥.១១-០៩.១៧.៤០ ទំព័រ ៥ បន្ទាត់ ៦-៨ (បាទ អានេះគេតាមថ្នាក់លើ គេយក [ប្តីប្រពន្ធថ្មីថ្មោងដែលមិនរួមដំណេក] ទៅអប់រំ។ បើស្រីមិនស្រលាញ់ ប្រុសស្រលាញ់ អានេះគេអប់រំ អប់រំស្រី។ ថាយើងមិនគោរពទៅតាមអង្គការ បទបញ្ជាការរៀបចំគូ ប្រគូឱ្យយើងមិនគោរព គឺគេ អប់រំ ឱ្យយើងស្តាប់បទបញ្ជារបស់អង្គការ")។ ឯកសារ **E1/376.1** យូ វ៉ាន់ ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦, ១៥.៣៨.៤១-១៥.៤២.០១ ទំព័រ ៥០ បន្ទាត់ ១៦ ("គឺបានណែនាំគេទៅ ដូចគេព្រមទៅ នៅទាល់សព្វថ្ងៃ"); ឯកសារ **E1/378.1** ប្រាក់ យុត ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦, ១៣.៤៧.២៧-១៤.៥១.៤៤ ទំព័រ ៤០ បន្ទាត់ ១៤-១៧ ("ខ្ញុំ ចំពោះគូស្រករ មិនរួមដំណេក ខ្ញុំអត់មានវិធានការអីដែលធ្វើឱ្យគូស្រករទាំងពីរនាក់នោះបាត់បង់អីទេ *មានតែការអប់រំនៅក្នុងស្រុក* ដើម្បីឱ្យគូ ស្រករទាំងពីរនោះចេះយល់ចិត្ត យល់គំនិតគ្នា ព្រោះយើងការរួចហើយ តែថាឱ្យយកគូស្រករទាំងពីរនាក់នោះ ខ្ញុំជាចៅហ្វាយ ស្រុកដែលគាត់មិនបានរួមដំណេក ហើយយកគាត់ធ្វើបាបធ្វើទោស គឺអត់មាន")។ ឯកសារ **E1/361.1** ប្រាក់ ខឿន ប្រតិចារឹក ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥, ១៥.៥៨.៥៥ ទំព័រ ៨១ បន្ទាត់ ៣-៧ ("បាទដែលខ្ញុំបានឮច្បាស់ [ប្តីប្រពន្ធដែលត្រូវបានចាប់ខ្លួន] គឺអត់

*កំហុសដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងធាតុផ្សំសត្យានុម័តិនៃអំពើរំលោភសេពសន្ថវៈ*

751. ជាចុងក្រោយ បន្ថែមលើការជំទាស់ទៅនឹងអង្គហេតុជុំវិញការតាមដានបុគ្គល ម្ចាស់បណ្ដឹងសាទុក្ខក៏ជំទាស់ទៅនឹងសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ជ ទាក់ទងនឹងធាតុផ្សំសត្យានុម័តិនៃអំពើរំលោភសេពសន្ថវៈ[2574]។ បើទោះជាផ្នែកសារណារបស់ម្ចាស់បណ្ដឹងសាទុក្ខវែងអន្លាយ ម្ចាស់បណ្ដឹងសាទុក្ខត្រឹមតែលើកឡើងពីទឡ្ហីករណ៍ដែលមិនមានមូលដ្ឋាន និងមិនត្រឹមត្រូវមួយចំនួនប៉ុណ្ណោះដែលមាននៅ កន្លែងផ្សេងក្នុងបណ្ដឹងសាទុក្ខរបស់គាត់[2575]។

***មូលដ្ឋានទី ១៧៣ ៖ កំហុសពាក់ព័ន្ធនឹងការពិនិត្យលើការទទួលរងការឈឺចាប់ក្នុងបរិបទនៃទំនាក់ទំនងផ្លូវភេទក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍[2576]***

752. **មូលដ្ឋានទី ១៧៣ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសតាមរយៈការសន្និដ្ឋានថា ស្ត្រីប្រឈមនឹងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ និងរយៈពេលយូរដោយសារការបង្ខំឱ្យរួមដំណេក ក្នុងគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។**

*កំហុសដែលរងការចោទប្រកាន់របស់ អ.ជ.ស.ជ ចំពោះការផ្អែកលើសក្ខីកម្មរបស់ ជាំង ស្រីមុំ*

753. ម្ចាស់បណ្ដឹងសាទុក្ខបានជំទាស់មិនត្រឹមត្រូវចំពោះសេចក្ដីសន្និដ្ឋានថា យ៉ាងហោចណាស់ក៏មានការរំលោភផ្លូវភេទបានកើតឡើងម្ដងដែរនៅក្នុងសហករណ៍ស្រុកត្រាំកក់ ដោយលើកឡើងថា អ.ជ.ស.ជ មិនអាចពឹងផ្អែកដោយសមហេតុផលលើសក្ខីកម្មរបស់ ជាំង ស្រីមុំ ដើម្បីពិចារណាថាមាន*ធាតុផ្សំសត្យានុម័តិ* និងមិនអាចពឹងផ្អែកលើការសន្និដ្ឋានថាមានការឈឺចាប់កម្រិតធ្ងន់ធ្ងរ ដែលអាចឱ្យកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀតបាន

---

មានដាក់ទណ្ឌកម្មទេ គឺគ្រាន់តែយកទៅណែនាំជាលើកទី១ ដែលអង្គការបានស្រលាញ់ ហើយនិងជួយសម្រួលដោះស្រាយពីត្រឹមថ្ងៃហ្នឹង យកចិត្តទុកដាក់ជាមួយគ្នា ដើម្បីរស់រានមានជីវិតដេកនៅជាមួយគ្នា កុំឱ្យមានពាក្យធំ ពាក្យតូច កុំឱ្យបន្ទោសទៅដល់អង្គការថាអ៊ីចេះ ថាអ៊ីចុះ តែបន្តិចទៅគេចាប់ខ្លួនហើយ។ អ្នកទាំងពីរនាក់ហ្នឹង ខ្ញុំក៏បានដើរឆ្ងាយ ដឹងជាស្ងាត់ ដឹងជាបាត់យ៉ាងម៉េច ក៏ខ្ញុំបានលែងទៅកាប់សរសរដែរ ក៏ពាក្យហ្នឹងបញ្ចប់ត្រឹមហ្នឹងទៅ”)។

[2574] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៣៧៨-១៣៩៨។

[2575] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៣, ១៦១, ១៦៣។

[2576] <u>មូលដ្ឋានទី ១៧៣</u> ៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងការពិនិត្យលើការទទួលរងការឈឺចាប់ក្នុងបរិបទនៃទំនាក់ទំនងផ្លូវភេទក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍* កថាខណ្ឌ ១៣០១-១៣៤០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៥៩ (ភាសាអង់គ្លេស) ទំព័រ ៥៤-៥៥ (ភាសាបារាំង) ទំព័រ ៨៥-៨៦ (ភាសាខ្មែរ)។

ឡើយ[2577]។ ការពិនិត្យល្អិតល្អន់លើទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ប៉ុណ្ណោះ ដោយមិនបានផ្តល់នូវភស្តុតាងណាមួយដែលអាចជម្រុញឱ្យមានការពិនិត្យមើលលើបណ្តឹងសាទុក្ខនោះឡើយ។ គ្មានចំណុចណាមួយក្នុងអង្គច្បាប់ ឬអង្គហេតុ ដែលគាំទ្រដល់ការអះអាងថា "ការក្លាយជាប្តីប្រពន្ធជាផ្លូវការធ្វើឱ្យការរួមភេទគឺជារឿងធម្មតា និងស្របច្បាប់" នោះទេ[2578]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងវិញពីសក្ខីកម្មរបស់ ជាំង ស្រីមុំ តាមរបៀបដែលច្រានចោលទាំងស្រុងនូវអង្គហេតុដែលថា បរិយាកាសបែបបង្ខិតបង្ខំមិនអាចឱ្យមានការយល់ព្រមពិតប្រាកដបានឡើយ[2579]។

754. ការរៀបអាពាហ៍ពិពាហ៍ ឬការរួមដំណេក ប្រហែលជាមិនមានការយល់ព្រមពិតប្រាកដឡើយ។ តាមការគូសបញ្ជាក់ដោយម្ចាស់បណ្តឹងសាទុក្ខ ខណៈដែល ជាំង ស្រីមុំ បានផ្តល់សក្ខីកម្មថា "ការរួមដំណេក គាត់អត់មានបង្ខំយើងទេ"[2580] ម្ចាស់បណ្តឹងសាទុក្ខមិនអើពើសក្ខីកម្មរបស់ ជាំង ស្រីមុំ ដែលថា "ខ្ញុំគិតថា គ្មានជម្រើសអីផ្សេងក្រៅពីប្តីប្រពន្ធ។ បើកាលណាបើខ្ញុំមិនយកគ្នា (...) ខ្ញុំនឹងបាត់បង់ជីវិត"[2581]។ ជាំង ស្រីមុំ បានគូសបញ្ជាក់ផងដែរអំពីឥទ្ធិពលនៃការតាមដានដោយឈ្លបម្នាក់លើការសម្រេចចិត្តរួមដំណេក[2582]។ អង្គហេតុដែលថា ក្រោយមកគាត់មានអារម្មណ៍ចំពោះប្តីរបស់គាត់ មិនប៉ះពាល់ដល់អត្ថិភាពនៃការឈឺចាប់ឡើយ។ ដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសក្នុងការប្រើប្រាស់សក្ខីកម្ម របស់ ជាំង ស្រីមុំ ឡើយ។

### *ការយល់ព្រមក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

755. ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងមិនត្រឹមត្រូវថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានជារួមថា បើការយល់ព្រមរៀបអាពាហ៍ពិពាហ៍មិន"ពិត" ការរួម

[2577] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣០៣ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៧៤។

[2578] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣០៥។

[2579] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥, ១៦៧។

[2580] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣០៤។

[2581] ឯកសារ **E1/254.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.43.16 ទំព័រ ២៦ បន្ទាត់ ៩-១៥។

[2582] ឯកសារ **E1/254.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥, ម៉ោង 10.45.59 ទំព័រ ២៦ បន្ទាត់ ២៣-ទំព័រ ២៧ បន្ទាត់ ១ ("ពេលនោះ ចិត្តវាអត់ទាន់មានចិត្តស្រឡាញ់ប្តីទេ ប៉ុន្តែក្នុងការខ្លាចៗ ដូចថាមានឈ្លបមួយផង មួយណានឹកឃើញថា ប្តីក៏លួងលោមថា យើងជៀសផុតមិនប្តីប្រពន្ធ យើងអ្វីមានតែប្តីប្រពន្ធទេ មិនបាច់មានការលាក់លៀមអីទេ យើងជៀសផុតប្តីប្រពន្ធមិនរួចទេ។ អ៊ីចឹងខ្ញុំចេះតែស្តាប់គេផង ក្នុងការខ្លាចមិនៗហ៊ានប្រកែក ព្រោះអីឈ្លបគេមកស្តាប់ដើម្បីថាយើងហ្នឹងមានការប្រកែក មិនចុះសម្រុង")។

ដំណេកក៏ត្រូវបានធ្វើឡើងដោយបង្ខំដែរ ដោយសារតែជនរងគ្រោះប្រព្រឹត្តដោយសារការភ័យខ្លាចបាត់បង់ជីវិត ឬសន្តិសុខផ្លូវកាយ ហើយមិនបានយល់ព្រមពិតប្រាកដឡើយ ឬដោយសារតែពួកគេរងការបង្ខំផ្លូវកាយឱ្យរួមដំណេកជាមួយប្តី[2583]។ ដើម្បីគាំទ្រដល់ការលើកឡើងនេះ ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញមិនត្រឹមត្រូវពីសក្ខីកម្មរបស់ ព្រាប សុខឿន, អ៊ុំ យឿន, មុំ វុន, ប៉ែន សុចាន់, ស៊ូ សុធាវី, ណុប ធីម និង ជា ឌៀប ដោយលាបពណ៌សក្ខីកម្មរបស់ពួកគេថា "ចម្លែក" និង "ខុសពីធម្មតា" តាមរយៈការលើកឡើងដដែលៗពីទឡ្ហីករណ៍មិនត្រឹមត្រូវថា ការយល់ព្រមគឺជាផ្នែកមួយនៃគោលនយោបាយរបស់ ប.ក.ក[2584] ដោយមិនអើពើបរិយាកាសបែបបង្ខិតបង្ខំដែលធ្វើឱ្យគេមិនអាចផ្តល់ការយល់ព្រមបាន[2585] និងបានជំទាស់មិនត្រឹមត្រូវលើភាពអាចជឿជាក់បានរបស់ពួកគេ ទោះបីជា អ.ជ.ស.ដ បានលើកឡើងលម្អិតពីបញ្ហានេះរួចហើយក្តី[2586]។

756. ការបកស្រាយភ័ស្តុតាងដែលមិនត្រឹមត្រូវបំផុតដោយម្ចាស់បណ្តឹងសាទុក្ខ គឺពាក់ព័ន្ធនឹងសក្ខីកម្មរបស់ អ៊ុំ យឿន។ ផ្អែកតាមម្ចាស់បណ្តឹងសាទុក្ខ ប្តីរបស់ អ៊ុំ យឿន "បានធ្វើឱ្យគាត់សោយទុក្ខ" ហើយចុងបញ្ចប់ ពួកគាត់ "បានស្រឡាញ់គ្នាតាមធម្មតា"[2587]។ ទោះជាយ៉ាងណា សក្ខីកម្មរបស់គាត់បានបង្ហាញយ៉ាងច្បាស់ពីទិដ្ឋភាពមួយដែលខុសគ្នាស្រឡះ។ គាត់បានផ្តល់សក្ខីកម្មថាមិនធ្លាប់មានអារម្មណ៍ចំពោះប្តីរបស់គាត់[2588] ដើម្បីជំទាស់នឹងបំណងនៃការរួមដំណេកនៅយប់ដំបូង និង

[2583] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣០៦ *ដោយជំទាស់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៥៩, ៣៦៦១។

[2584] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៥។

[2585] ឯកសារ **E1/469.1** ណុប ធីម ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦, ម៉ោង 11.09.05-11.13.12 ទំព័រ ៣៧ បន្ទាត់ ២៤-២៥ ("ការហើយបានពីរបីយប់ គឺចេះតែតាមដានដែរ។ ការបានហើយ ២ យប់ ៣ យប់ហ្នឹងណា គេតាមដានយើងហើយ ហើយអត់ៗមានអីក៏សុខស្រួលគ្នាទៅ ក៏អត់មានបញ្ហាអីទៅ"), ១២.១២.២៥ ទំព័រ ៣៨ បន្ទាត់ ៩ ("មិនចង់យកចង់តែរត់ចោលទេ តែធ្វើម៉េចចេះតែទ្រាំទៅ។ ខ្ញុំនិយាយដូចដដែលៗ")។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦២។

[2586] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៥៧-៣៦៥៩។

[2587] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣០៧។

[2588] ឯកសារ **E1/462.1** អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦, ម៉ោង 13.39.08 ទំព័រ ៤៧ បន្ទាត់ ២-៧ ("ស ៖ បាទ។ ក្នុងអំឡុងពេលដែលលោកៗស្រីរួមរស់ជាមួយប្តីលោកស្រី តើប្តីលោកស្រីមានបង្ហាញអាការៈថាស្រឡាញ់លោកស្រីដែរឬទេ? ឆ ៖ ចាស ចុងក្រោយបំផុតមក វាដូចថាផុតនេះហើយ ចុងក្រោយបំផុតមក វានៅថាថ្នាក់ថ្នមហ្នឹងដែរ ប្រពន្ធ ប្តីប្រពន្ធ ប៉ុនខ្ញុំធម្មតា តែប៉ុណ្ណឹង។ ទោះបីតែឥឡូវ បាត់ងាប់ទៅ ក៏ខ្ញុំនៅតែធម្មតាប៉ុណ្ណឹងដែរ អត់មានដូចថានិយាយអីអ៊ីចេះអ៊ីចុះ ហើយតវែងឆ្ងាយ ដូចខ្ញុំនិយាយខាងៗលើអ៊ីចឹង ថាខ្ញុំអត់ចេះរញ៉េរញ៉ៃកច្រើនទេ។ សូម្បីតែប្តីខ្ញុំក៏អត់សូវអ្នកនិយាយច្រើនដែរ")។

មានអារម្មណ៍ថា "គាត់ចង់ចាប់រំលោភបង្ខំ"[2589] ហើយចុងក្រោយ គាត់ត្រូវបានកម្មាភិបាលម្នាក់ទៀតរំលោភ ដើម្បីជាការដាក់ទណ្ឌកម្មលើការប្រកែកមិនរួមដំណេកពីដំបូង[2590]។ ការសម្រេចចិត្តរបស់គាត់ក្នុងការរួមរស់ និងរស់នៅជាមួយប្តីរបស់គាត់ក្រោយរបបនេះគឺដោយសារសម្ពាធពីគ្រួសារ និងចាស់ៗក្នុងភូមិ[2591]។ ការអះអាងថា "ការក្លាយជាប្តីប្រពន្ធជាផ្លូវការធ្វើឱ្យការរួមភេទគឺជារឿង ធម្មតា និងស្របច្បាប់"[2592] ដោយផ្អែកលើសក្ខីកម្មដូច្នេះ គឺគ្មានអង្គសេចក្តីឡើយ។ គាត់ប្រហែលជាមិនយល់ព្រមទទួលយកអាពាហ៍ពិពាហ៍នោះ ខ្លាំងជាងយល់ព្រមទទួលយកការរួមដំណេកដោយបង្ខំ។ អង្គហេតុដែលថា គាត់ "មិនបានលើកឡើងពីការឈឺចាប់" ក្នុងសក្ខីកម្មរបស់គាត់ ក៏មិនពាក់ព័ន្ធផងដែរ[2593] ព្រោះមានការកំណត់យ៉ាងច្បាស់ថា អំពើជាក់លាក់តែមួយគត់នៃការរំលោភសេពសន្ថវៈបង្កើតជាការឈឺចាប់ ឬព្យសនកម្មដោយមិនចាំបាច់មានការបញ្ជាក់ច្បាស់[2594]។

757. ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងមិនត្រឹមត្រូវថា អ.ជ.ស.ដ "គួរណាតែវាយតម្លៃលើភាពធ្ងន់ធ្ងរនៃការឈឺចាប់របស់ស្ត្រី ដែលកើតចេញពីការរួមភេទជាមួយប្តីក្នុងបរិបទវប្បធម៌ខ្មែរ នៅពេលកើតហេតុដែលក្នុងនោះ (...) ស្ត្រីត្រូវគោរពប្រណិប័តន៍ប្តីក្នុងការរស់នៅប្រចាំថ្ងៃ និងការរួមភេទ"[2595]។ ទឡ្ហីករណ៍នេះ គឺជាការលើកឡើងវិញដដែលៗពីការអះអាងដោយគ្មានមូលដ្ឋានរបស់ម្ចាស់បណ្តឹង

[2589] ឯកសារ **E1/462.1** អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦, ម៉ោង 09.10.01-09.11.02 ទំព័រ ៤ បន្ទាត់ ២៣-២៥-ទំព័រ ៥ បន្ទាត់ ៣-៤ ("ចាស នៅពេលនោះ គ្មានបាននិយាយអីវែងឆ្ងាយទេចាស។ ទៅដល់សង្គ្រប់យកតែម្តង។ រួចដល់ទៅនាងខ្ញុំ ដំណើរនាងខ្ញុំរៀងខ្លាចដែរ ហើយខ្លាំងដែរ ប្រតាយគ្នាទៅ គេចេញទៅប្រាប់នឹងប្រធានគេវិញ។ ព្រោះប្រធានគេហ្នឹងប្រធានយោធាផ្ទាល់ ចាស។ ខ្ញុំមិនពេញចិត្ត ហើយមនុស្សនោះចូលទៅគ្មានការលួងលោមសិន អាពេលទៅដល់ទឹងណាត់ទឹងណែងហ្មង។ របៀបដូចថា មនុស្សចង់ចាប់រំលោភបង្ខំហ្មង ចាស")។

[2590] ឯកសារ **E1/462.1** អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦, ម៉ោង 09.13.12 ទំព័រ ៥ បន្ទាត់ ២២-២៤-ទំព័រ ៦ បន្ទាត់ ៤-៧ ("ហៅទៅចូលបន្ទប់មួយរៀងស្ងាត់តែឯង។ ដល់ទៅហៅនាងខ្ញុំទៅដល់ វា ទៅដល់សួរថា "ម៉េចបានមិនព្រមយកគេអ៊ីចឹង?" ហើយ (សមមិត្ត ផាន់) គ្មានសួរអីវែងទេ (សមមិត្ត ផាន់) ប្រតាយប្រតប់ជាមួយខ្ញុំ ចាប់រំលោភខ្ញុំនៅហ្នឹងនៅឯង (...)។ (សមមិត្តផាន់) និយាយថា បើសិនជាគេចាប់ហើយ បើសិននិយាយតទៅផ្សេងទៀត គេអាចបំបិទមាត់យើងចេញ គេបាញ់យើងគ្រវាត់ចោល ហើយគេរ៉ៃចោលអ៊ីចឹងទៅ។ ចំណែកប្តីត្រូវតែយកវិញ។ ឱ្យរៀបការជាមួយប្តីហ្នឹងហើយ ហើយឱ្យយកប្តីហ្នឹងវិញទៅ អត់មាននេះទេ គេចាប់រំលោភហើយកុំឱ្យនិយាយប្រាប់អ្នកណាឱ្យសោះ")។

[2591] ឯកសារ **E1/462.1** អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥, ម៉ោង 09.31.18-09.32.44 ទំព័រ ១២ បន្ទាត់ ៤-១៣។

[2592] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣០៥។

[2593] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣០៤។

[2594] សាលក្រមរឿងក្តី *Čelebići* កថាខណ្ឌ ៤៨៦, ៤៩៥-៤៩៦។ សាលដីការឿងក្តី *Kunarac* កថាខណ្ឌ ១៥១។

[2595] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣២០។

សាទុក្ខដែលថា ការរៀបអាពាហ៍ពិពាហ៍ក្រោមរបប កម្ពុជាប្រជាធិបតេយ្យ គឺដូចគ្នានឹងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំមុនរបប កម្ពុជាប្រជាធិបតេយ្យ[2596]។ គ្មានភ័ស្តុតាងជាក់ស្តែងដើម្បីបង្ហាញថា ការរួមភេទលើកដំបូងរបស់ស្ត្រីជាមួយបុរសដែលខ្លួនមិនស្គាល់ ឬស្គាល់មិនសូវច្បាស់ គឺដូចគ្នានោះទេ មិនចំពោះថាការរួមភេទនោះ បានកើតឡើងក្នុងក្របខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំពីឪពុកម្តាយ ឬពីអាជ្ញាធររបប កម្ពុជាប្រជាធិបតេយ្យឡើយ ហើយម្ចាស់បណ្តឹងសាទុក្ខក៏មិនបានដកស្រង់មូលដ្ឋានណាមួយសម្រាប់ការអះអាងនេះដែរ[2597]។ តាមពិត អ.ជ.ស.ដ បានពិចារណាពីភាពពាក់ព័ន្ធនៃបរិបទសង្គម និងវប្បធម៌កម្ពុជា នៅពេលវាយតម្លៃផលប៉ះពាល់នៃការបង្ខំឱ្យរួមដំណេកលើបុគ្គល និងយល់ថា ស្ត្រីដែលបាត់បង់ព្រហ្មចារីដោយសារការរៀបអាពាហ៍ពិពាហ៍ ដែលមិនត្រូវបានរៀបចំឡើងដោយឪពុកម្តាយ ប្រឈមនឹងការឈឺចាប់បន្ថែមទៀត ដោយសារតែវប្បធម៌ខ្មែរឱ្យតម្លៃលើភាពបរិសុទ្ធរបស់ស្ត្រី[2598]។

758. ទោះបីជាមានការអះអាងម្តងហើយម្តងទៀតរបស់ម្ចាស់បណ្តឹងសាទុក្ខក៏ដោយ ក៏អង្គហេតុដែលថា បុគ្គលមិនបានលើកឡើងច្បាស់ពីការឈឺចាប់ដែលបណ្តាលមកពីការរួមដំណេក ឬក្រោយមកមានអារម្មណ៍ចំពោះប្តី/ប្រពន្ធរបស់ខ្លួន ពុំមានភាពពាក់ព័ន្ធគ្នានោះទេ។ អំពើជាក់លាក់តែមួយគត់នៃការរំលោភសេពសន្ថវៈ បង្កើតជាការឈឺចាប់ ឬព្យសនកម្មដោយមិនចាំបាច់មានការបញ្ជាក់ច្បាស់[2599]។ សម្រាប់ហេតុផលដូចគ្នានេះ អង្គហេតុដែលថា បុរសមិនបានលើកឡើងពីការឈឺចាប់របស់ប្រពន្ធមិនមានន័យថាគ្មានការឈឺចាប់នោះទេ។ ចំណុចចុងក្រោយ អង្គហេតុដែលថា ស្ត្រីមួយចំនួនមិនចាត់ទុកថា ពួកគាត់ត្រូវបានគេចាប់រំលោភ មិនច្រានចោលអង្គហេតុដែលថា បរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដែលកើតឡើងនៅពេលក្រោយមកទៀត គឺមិនអាចមានការយល់ព្រមពិតប្រាកដនោះទេ[2600]។ ដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានលើកឡើងពីសំអាងហេតុជាមូលដ្ឋាន ឬភាពលម្អៀងរបស់ អ.ជ.ស.ដ ឡើយ និងគ្រាន់តែបានលើកឡើងវិញពីការអះអាងដែលមិនត្រឹមត្រូវប៉ុណ្ណោះ។

---

[2596] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦២។

[2597] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣២០-១៣២២។

[2598] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៤-៣៦៨៥។

[2599] សាលដីការឿងក្តី *Kunarac* កថាខណ្ឌ ១៥១។

[2600] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧០។

## មូលដ្ឋានទី ២៤៤ ៖ ការរៀបអាពាហ៍ពិពាហ៍[2601]

759. **មូលដ្ឋានទី ២៤៤ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គហេតុ ឬអង្គច្បាប់ក្នុងការសន្និដ្ឋានថា យោងតាមគោលនយោបាយរបស់ ប.ក.ក ម្ចាស់បណ្តឹងសាទុក្ខមានបំណងប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ[2602]។**

760. ក្នុងកថាខណ្ឌចំនួន ៣០០ ដែលលើកឡើងពីការជំទាស់សេចក្តីសន្និដ្ឋានទាំងនេះក្នុងសារណារបស់គាត់[2603] ម្ចាស់បណ្តឹងខកខានមិនបានបង្ហាញថា សេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ មិនត្រឹមត្រូវ ឬមិនសមហេតុផលឡើយ។ កថាខណ្ឌទាំង ៥ នៃមូលដ្ឋាននេះ គ្រាន់តែលើកឡើងវិញពីការអះអាងមិនត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ និងមិនផ្តល់ទឡ្ហីករណ៍ថ្មី ឬទឡ្ហីករណ៍សំខាន់ណាមួយឡើយ[2604]។

### ខ. ទីតាំងឧក្រិដ្ឋកម្ម

#### i. សហករណ៍ និងការដ្ឋានការងារ

761. អ.ជ.ស.ដ យល់ឃើញយ៉ាងត្រឹមត្រូវថា មានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងទៀត (ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ) និងការធ្វើមនុស្សឃាតនៅតាមសហករណ៍ និងការដ្ឋានការងារ[2605] ដោយយោងតាមគោលនយោបាយរបស់ ប.ក.ក ដើម្បីបង្កើត និងប្រតិបត្តិការទីតាំងទាំងនេះក្នុងគោលបំណងកសាង ការពារប្រទេស

---

[2601] <u>មូលដ្ឋានទី ២៤៤</u> ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តបទបញ្ជា* កថាខណ្ឌ ២១១៤-២១១៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨០-៨១ (ភាសាអង់គ្លេស) ទំព័រ ៧៥ (ភាសាបារាំង) ទំព័រ ១១៦ (ភាសាខ្មែរ)។

[2602] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤៨-៤២៤៩, ៤៣០៣-៤៣០៥។

[2603] សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១០៩៨-១៣៩៨។

[2604] ឯកសារ **F54**សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១១៤-២១១៨ *ដោយដកស្រង់* កថាខណ្ឌរបស់គាត់ ១០៩៨-១៣៩៨។

[2605] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២០ (ការធ្វើមនុស្សឃាត), ៣៩២២-៣៩២៧ (ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)។

ប្រឆាំងនឹងខ្មាំង និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយជាសង្គមខ្មែររួបរួមគ្នាមួយ ដែលមានតែវណ្ណៈកម្មករ-កសិករ[2606]។ គោលនយោបាយឧក្រិដ្ឋនេះពាក់ព័ន្ធគ្នានឹងគោលបំណងរួម[2607]។ ក្រៅពីនេះ អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថាមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបណ្តាលមកពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅបែបអមនុស្សធម៌នៅតាមសហករណ៍ និងការដ្ឋានការងារ[2608]។

762. មូលដ្ឋានទាំង ១៣ របស់ម្ចាស់បណ្តឹងសាទុក្ខ[2609] ដែលពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋានការងារ មិនអាចយកជាសំអាងបានទេ ព្រោះមូលដ្ឋានទាំងនោះអនុវត្តវិធីសាស្ត្រជាផ្នែកៗដែលមិនត្រឹមត្រូវលើភស្តុតាង ហើយសេចក្តីសម្រេច លើកឡើងមិនត្រឹមត្រូវពីការយល់ឃើញផ្នែកអង្គហេតុពាក់ព័ន្ធ និងប្រហាក់ប្រហែលនឹងការខ្វែងគំនិតធម្មតាទៅនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ។ សំខាន់បំផុត ម្ចាស់បណ្តឹងសាទុក្ខបានដេញដោលម្តងហើយម្តងទៀតលើសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្តីពី*ធាតុផ្សំសត្យានុម័តិ* និង*ធាតុផ្សំអត្តនោម័តិ* នៃការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តដោយចេតនាប្រយោល ដោយខកខានមិនបានទទួលស្គាល់ថា អ.ជ.ស.ដ មិនចាំបាច់គូសបញ្ជាក់ពីបទប្បញ្ញត្តិព្រហ្មទណ្ឌដែលកំណត់ថា ចារីត្រូវចាត់វិធានការដើម្បីកែប្រែ ឬកែលម្អលក្ខខណ្ឌដែលគំរាមកំហែងអាយុជីវិតដែលពួកគេផ្ទាល់ជាអ្នកបង្កើតឡើងនៅតាមសហករណ៍ និងការដ្ឋានការងារនោះទេ។ ការខកខានរបស់ពួកគេក្នុងការកាត់បន្ថយលក្ខខណ្ឌទាំងនេះ គ្រាន់តែជាការបន្តអនុវត្តអំពើឧក្រិដ្ឋដ៏សកម្មរបស់ខ្លួន ដែលពួកគេមានភារកិច្ចមិនអាចបោះបង់បាន[2610]។ ម្ចាស់បណ្តឹងសាទុក្ខបានវាយប្រហារបន្ថែមទៀតលើសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្តីពីការធ្វើទុក្ខបុកម្នេញនយោបាយលើប្រជាជនថ្មី និង "ខ្មាំង" និងការវាយតម្លៃរបស់ខ្លួនលើភស្តុតាងទូទៅ ដោយមិនអើពើបរិមាណដ៏ច្រើននៃភស្តុតាងដែលមានតម្លៃខ្ពស់ក្នុងសំណុំរឿង ដែលគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ[2611]។

[2606] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៨-៣៩១៩, ៣៩២៨។

[2607] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៧-៣៩២៨។

[2608] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៥, ១៣៨៨, ១៦៧២, ១៨០៤។

[2609] មូលដ្ឋានទី ៩៩-១០២, ១០៧, ១១៣-១១៩, ១២៣។

[2610] មូលដ្ឋានទី ៩៩-១០២, ១១៣, ១១៥-១១៧, ១២៣។

[2611] មូលដ្ឋានទី ១០៧, ១១៤, ១១៨-១១៩។

## ១. សហករណ៍ស្រុកត្រាំកក់

### *មូលដ្ឋានទី ៩៩ ៖ កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអំពើអកម្ម "នាំឱ្យមានពិរុទ្ធ"* [2612]

763. **មូលដ្ឋានទី ៩៩ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ ប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការសន្និដ្ឋានថាមាន*ធាតុផ្សំសត្យានុម័តិ* នៃការធ្វើមនុស្សឃាតពាក់ព័ន្ធនឹងការស្លាប់ដោយសារលក្ខខណ្ឌរស់នៅក្នុងសហករណ៍ស្រុកត្រាំកក់[2613]។**

764. មូលដ្ឋាននេះមិនទទួលបានផលទេ ព្រោះម្ចាស់បណ្តឹងសាទុក្ខមើលរំលងទំនាក់ទំនងទៅវិញ ទៅមក រវាងអំពើសកម្មដែលជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ជ ស្តីពី*ធាតុផ្សំ សត្យានុម័តិ* នៃការធ្វើមនុស្សឃាត[2614] ហើយម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់[2615] និងអំពើ អកម្ម។ ទឡ្ហីករណ៍របស់គាត់គ្មានសុភវិនិច្ឆ័យទាល់តែសោះ។

765. អ.ជ.ស.ជ មិនចាំបាច់បញ្ជាក់ពីបទប្បញ្ញត្តិព្រហ្មទណ្ឌណាមួយដែលកំណត់ថា ចារីផ្ទាល់ត្រូវលើកឡើងពីលក្ខខណ្ឌដែល "អាចប្រមើលមើលឃើញថា (...) នឹងបង្កឱ្យមានមនុស្សស្លាប់"[2616] ជាលក្ខខណ្ឌដែលពួកគេបានបង្កើតឡើងនៅទីតាំងឧក្រិដ្ឋកម្មនោះ[2617]។ ដូច្នេះ ការខកខានរបស់ពួកគេក្នុង

---

[2612] <u>មូលដ្ឋានទី ៩៩</u> ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអំពើអកម្ម "នាំឱ្យមានពិរុទ្ធ"* កថាខណ្ឌ ៦៧៣-៦៧៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៨ (EN) ទំព័រ ៣៥ (ភាសាបារាំង) ទំព័រ ៥៤ (ភាសាខ្មែរ)។

[2613] ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដដែលពីការអះអាងមិនត្រឹមត្រូវនេះពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗនៅស្រុកត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៩, ១១៣, ១១៥ និង ១២៣។

[2614] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៤។ ពាក់ព័ន្ធនឹងការខកខានមិនចាត់វិធានការ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១០០។

[2615] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៤-១១៤៥។ ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខមានបំណងចង់ដេញដោលអំពើសកម្មរបស់អាជ្ញាធរតាមរយៈមូលដ្ឋានបណ្តឹងសាទុក្ខផ្សេងទៀតរបស់គាត់ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានគូសបញ្ជាក់ពីចេតនារបស់គាត់ក្នុង ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៧២-៦៧៥ ដោយមាន កំណត់សម្គាល់យោងទៅកថាខណ្ឌផ្សេងទៀតក្នុងសារណារបស់គាត់។ម្យ៉ាងវិញទៀត *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ១០១ និង ១០៧។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១០០ (និងការដកស្រង់ទាំងអស់នៅក្នុងនោះ)។

[2616] លក្ខខណ្ឌនៃកង្វះអាហារ កង្វះអាហារូបត្ថម្ភ ការងារហួសកម្រិត ជំងឺ និងកង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២ និង *ត្រូវបានលើកឡើងម្តងទៀត* ក្នុងជើងទំព័រ ១៣១០១។ សូមមើលផងដែរ កថាខណ្ឌ ១១៤៥, ១៤៤៤។

[2617] ឯកសារ **E465**សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៤។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៧៤។

ការ "ចាត់វិធានការសមស្របដើម្បីកែប្រែ ឬកាត់បន្ថយ"[2618] លក្ខខណ្ឌទាំងនោះ មិនមែនជាអំពើអកម្មដាច់ដោយឡែកដែលអាចបង្កជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ប៉ុន្តែផ្ទុយទៅវិញ ជាការបន្តអំពើសកម្មរបស់ពួកគេ[2619]។

766. ក្នុងករណីណាក៏ដោយ វាជាច្បាប់ទូទៅដែលមានភារកិច្ចស្របច្បាប់ក្នុងការបោះបង់ការប្រព្រឹត្តបទឧក្រិដ្ឋ។ ភារកិច្ចរបស់ចារីក្នុងការប្រព្រឹត្ត *កើតចេញ*ពីអំពើឧក្រិដ្ឋដ៏សកម្មរបស់ពួកគេ ជាអំពើដែលពួកគេមានកាតព្វកិច្ចមិនអាចបញ្ឈប់បាន[2620]។ ដោយសារតែចារីផ្ទាល់នៅស្រុកត្រាំកក់ជាអ្នកបង្កើតលក្ខខណ្ឌទាំងនោះ ចំណុចនេះមានន័យថា ពួកគេមានតួនាទីកែប្រែ ឬកាត់បន្ថយលក្ខខណ្ឌទាំងនោះ និងមានកាតព្វកិច្ចធ្វើដូច្នេះ។

767. ដូច្នេះ អ.ជ.ស.ដ មិនចាំបាច់កំណត់ច្បាស់ពីលក្ខណៈ និងវិសាលភាពនៃកាតព្វកិច្ចក្នុងការចាត់វិធានការឡើយ[2621]។ អ្វីដែលជាសុភវិនិច្ឆ័យផងដែរនោះគឺអ្វីដែលជាលក្ខខណ្ឌចាំបាច់ក្នុងការកែលម្អស្ថានភាពមួយដែលគេបង្កើតឡើង និង/ឬរក្សាទុក។ ឧទាហរណ៍ ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃកង្វះអាហារដែលបានបង្កើតឡើង[2622] អ.ជ.ស.ដ យល់ថា ឃុំ និងសហករណ៍បានកំណត់របបអាហារ[2623]

---

[2618] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៤។

[2619] ពាក់ព័ន្ធនឹងការរួមចំណែករបស់ម្ចាស់បណ្ដឹងសាទុក្ខដល់ការប្រព្រឹត្តអំពើមនុស្សឃាតរបស់ចារី ដោយមាន*ចេតនាប្រយោល* *សូមមើល* ផ្នែក ៧ ឃ.ការជួយ និងជំរុញ ក្នុងសារណាបណ្ដឹងសាទុក្ខនេះដែលពាក់ព័ន្ធនឹងមូលដ្ឋានទី ២៤៦-២៤៧ (*ធាតុផ្សំសត្យានុម័តិ*), ២៤៥, ២០៩, ២៤៨-២៤៩ (*ធាតុផ្សំអត្តនោម័តិ*)។

[2620] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៤។ អង្គជំនុំជម្រះតុលាការកំពូល ICTY ទទួលស្គាល់ការប្រព្រឹត្តដោយអំពើអកម្មដែលចារីមានសមត្ថភាព និងខកខានមិនបានស្រោចស្រង់លក្ខខណ្ឌដែលបានបង្កើតលើជនរងគ្រោះ ដូចជា អំពើសកម្ម ដែលបង្កើតបានជាឧក្រិដ្ឋកម្មអន្តរជាតិ។ សូមមើល សាលដីការឿងក្តី *Čelebići* កថាខណ្ឌ ៣៤២-៣៤៣ ដែលលើកឡើងថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ បណ្ដាលមកពីបុគ្គល "ដែលមានអំណាច ឬសមត្ថកិច្ចក្នុងការដោះលែងអ្នកទោស ខកខានមិនបានធ្វើដូច្នេះ ទោះបីជាដឹងថាគ្មានមូលដ្ឋានសមហេតុផលសម្រាប់ការឃុំឃាំងពួកគេ ឬដឹងថា លែងមានមូលហេតុទាំងនោះក៏ដោយ"។ អ.ជ.ស.ដ បានបដិសេធករណីនេះ *in casu* ព្រោះថាឆ្មាំគុកធម្មតាម្នាក់គ្មានអំណាចគ្រប់គ្រាន់ក្នុងការដាក់កាតព្វកិច្ចឱ្យគាត់អនុវត្តឡើយ។ ទោះជាយ៉ាងណា អំណាចរបស់ចារីនៅស្រុកត្រាំកក់ក្នុងការបង្កើតលក្ខខណ្ឌដោយខ្លួនឯង មានន័យថា ពួកគេមានតួនាទីកែប្រែលក្ខខណ្ឌទាំងនោះ និងមានកាតព្វកិច្ចធ្វើដូច្នោះ។

[2621] *ផ្ទុយពី*ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៧៤។

[2622] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២ និង *ត្រូវបានលើកឡើងម្ដងទៀត* ក្នុងជើងទំព័រ ១៣១០១។ សូមមើលផងដែរ កថាខណ្ឌ ១១៤៥, ១៤៤៤។

[2623] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១០។

ប៉ុន្តែមិនមែនកំណត់ទៅតាមបរិមាណដែលបានកំណត់ឡើយ[2624]។ វាជាបន្ទុករបស់អាជ្ញាធរពាក់ព័ន្ធក្នុងការកំណត់របបអាហារទៅតាមបរិមាណដែលបានកំណត់ និងមិនត្រូវផ្តល់អាហារតិចជាងបរិមាណដែលបានកំណត់ដល់ប្រជាជនថ្មី[2625] ដែលកំពុងរងគ្រោះខ្លាំងជាងគេ និងស្លាប់ដោយសារកង្វះអាហារូបត្ថម្ភនោះទេ[2626]។ ក្រៅពីនេះ នៅថ្នាក់ស្រុក អតីតសមាជិកគណៈស្រុក ឈ្មោះ ពេជ្រ ជឹម បានផ្តល់ភ័ស្តុតាងស្តីពីការខកខានរបស់គណៈស្រុក ក្នុងការដាក់ទណ្ឌកម្មលើការផ្តល់របបអាហារបែបរើសអើង[2627] ទោះបីជាមានវិធានការដាក់ទណ្ឌកម្មអ្នកដែលលួចអាហារក្តី[2628]។

768. ដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មិនបានផ្តល់ការវិភាគអង្គច្បាប់សមស្របលើភ័ស្តុតាង និងមូលហេតុសម្រាប់ការកំណត់ពី*ធាតុផ្សំសត្យានុម័ត*នៃការធ្វើមនុស្សឃាតឡើយ[2629]។

### *មូលដ្ឋានទី ១០០ ៖ កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងចេតនាប្រយោល*[2630]

---

[2624] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៣។

[2625] *សូមមើលឧទាហរណ៍*ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៤ (រី ពៅ, មាស សុខា), ១០១៦ (រួមទាំង ពេជ្រ ជឹម)។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៧ (ការធ្វើទុក្ខបុកម្នេញប្រជាជនថ្មី)។

[2626] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦, ១០៤៥។ សូមមើលផងដែរ កថាខណ្ឌ ១០២០ (សឹម ឈឿង), ១០៣៧ (ជូ គឹមឡន)។

[2627] ឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 14.01.04 ទំព័រ ៤២ បន្ទាត់ ២២-ទំព័រ ៤៣ បន្ទាត់ ១។ សូមមើលផងដែរ ម៉ោង 09.57.00-09.59.18 ទំព័រ ១៥ បន្ទាត់ ១១-១២, ១៤-១៥, ១៨, ទំព័រ ១៥ បន្ទាត់ ២៥-ទំព័រ ១៦ បន្ទាត់ ១-២, ៣។ ពាក់ព័ន្ធនឹងលេខាស្រុកដែលច្រានចោលការឈឺចាប់របស់ប្រជាជនដោយសារជំងឺហើម រាក និងមិនមានអាហារូបត្ថម្ភ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤៦ *ដោយដកស្រង់ក្នុងចំណោមចំណុចផ្សេងទៀត* ឯកសារ **E1/278.1** រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥, ម៉ោង 10.51.49 ទំព័រ ២៥ បន្ទាត់ ៣-៤។ សូមមើលផងដែរ ឯកសារ **E1/278.1** រៀល សន ប្រតិចារឹក ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៥, ម៉ោង 10.47.33-10.49.20 ទំព័រ ២៤ បន្ទាត់ ២-៣, ១០។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៤, ១០២៩ (យ៉ែម ឌុន្នី), ១០៤៥។

[2628] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៧, ១០២៩ (អៀម យេន)។ សូមមើលផងដែរឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 14.01.04 ទំព័រ ៤២ បន្ទាត់ ២២-ទំព័រ ៤៣ បន្ទាត់ ១។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៥ (ប៊ុន សារឿន)។

[2629] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៧៤-៦៧៥។

[2630] <u>មូលដ្ឋានទី ១០០ ៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងចេតនាប្រយោល* កថាខណ្ឌ ៦៧៥-៦៧៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៩ (ភាសាអង់គ្លេស) ទំព័រ ៣៥ (ភាសាបារាំង) ទំព័រ ៥៤ (ភាសាខ្មែរ)។

769. **មូលដ្ឋានទី ១០០ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ ប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការប្រើប្រាស់ជម្រើស “X” ឬ “Y” ដើម្បីកំណត់ថាមាន*ធាតុផ្សំអត្តនោម័តិ*សម្រាប់ការធ្វើមនុស្សឃាត*ដោយចេតនាប្រយោល* ពាក់ព័ន្ធនឹងលក្ខខណ្ឌរស់នៅក្នុងសហករណ៍ស្រុកត្រាំកក់។**

770. មូលដ្ឋាននេះមិនទទួលបានផលទេ ព្រោះការអះអាងដោយគ្មានមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញពីកំហុសអង្គច្បាប់ក្នុងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ជ ដែលថាមាន*ធាតុផ្សំអត្តនោម័តិនៃចេតនាប្រយោល*សម្រាប់ការធ្វើមនុស្សឃាត ដែលចារីសំខាន់ ពោលគឺអាជ្ញាធរស្រុកត្រាំកក់ បានប្រព្រឹត្ត “ដោយដឹងថា លក្ខខណ្ឌទាំងនេះអាចនឹងធ្វើឱ្យមានមនុស្សស្លាប់ *ឬ* គាត់ទទួលយកលទ្ធភាពដែលអាចឱ្យស្លាប់មនុស្សនេះ”[2631]។ ការដឹងថា ទំនងជានឹងមានការស្លាប់[2632] និងការទទួលយកលទ្ធភាពដែលថា ការស្លាប់នឹងបណ្តាលមកពីសកម្មភាពរបស់បុគ្គលម្នាក់[2633] សុទ្ធតែបំពេញ*ធាតុផ្សំអត្តនោម័តិ*។ យុត្តិសាស្ត្រយ៉ាងច្រើនរបស់ អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិបញ្ជាក់ថា ក្នុងករណីដែលការយល់ឃើញផ្នែកអង្គហេតុណាមួយនៃការយល់ឃើញផ្នែកអង្គហេតុដែលមានសុពលភាពជាច្រើន មានភាពគ្រប់គ្រាន់នៅក្នុងការកំណត់ពីធាតុផ្សំដ៏សំខាន់មួយ គេអាចកំណត់ការសន្និដ្ឋានអង្គហេតុទាំងនោះជាជម្រើស ដោយមិនបង្ហាញច្បាស់ពីការសន្និដ្ឋានអង្គហេតុមួយដាច់តែឯង[2634]។

---

[2631] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ១១៨១ *ដោយដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៥ (គូសបញ្ជាក់បន្ថែម)។

[2632] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៨៧ (គូសបញ្ជាក់ក្នុងកថាខណ្ឌ ៤១០), ៣៩៥។

[2633] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩០ *ដោយដកស្រង់ សាលក្រមរឿងក្តី* Stakić កថាខណ្ឌ ៥៨៧។ សូមមើលផងដែរ កថាខណ្ឌ ៤០៩ (“ការធ្វើឱ្យមនុស្សស្លាប់ដោយចេតនាក្នុងកម្រិតទាបជាងចេតនាដោយផ្ទាល់ ប៉ុន្តែខ្ពស់ជាងការមិនអើពើនោះ (ដូចជា *ចេតនាប្រយោល* ឬការធ្វេសប្រហែស) គឺជាការទទួលខុសត្រូវព្រហ្មទណ្ឌ និងត្រូវបានចាត់ទុកថាជាការធ្វើមនុស្សឃាតដោយចេតនា”)។

[2634] សូមមើលឧទាហរណ៍សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី ឌុច កថាខណ្ឌ ៥២៦, ៥៣១។ សាលក្រមរឿងក្តី *Đorđević* កថាខណ្ឌ ២១៣៩ និងត្រូវបានបញ្ជាក់ក្នុងសាលដីការឿងក្តី *Đorđević* កថាខណ្ឌ ១៩២ (“អង្គជំនុំជម្រះតុលាការកំពូលយល់ថា សេចក្តីសន្និដ្ឋានជាជម្រើសមានភាពច្បាស់លាស់ ហើយអង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការចេញសេចក្តីសន្និដ្ឋានទាំងនោះ”)។ សាលក្រមរឿងក្តី *Galić* កថាខណ្ឌ ៣១៧, ៥៩៦ និងត្រូវបានបញ្ជាក់ក្នុងសាលដីការឿងក្តី *Galić* កថាខណ្ឌ ១៤០។ សាលក្រមរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៥៥១ (“ការវាយប្រហារកើតមានជាទូទៅ ឬជាប្រព័ន្ធ”) និងត្រូវបានបញ្ជាក់ក្នុងសាលដីការឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៩៩-១០៣។

771. ការពិនិត្យមើលជារួមលើសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ បង្ហាញថា អាជ្ញាធរស្រុកត្រាំកក់ប្រព្រឹត្តដោយ*ចេតនាប្រយោល* ព្រោះការស្លាប់បណ្ដាលមកពីលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារ (ឧទាហរណ៍ កង្វះអាហារ ការងារហួសកម្រិត និងកង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ) ត្រូវបានគេ "ដឹងច្បាស់" ក្នុងស្រុកត្រាំកក់ ហើយអាជ្ញាធរបានបន្តរក្សាលក្ខខណ្ឌទាំងនេះ "ក្នុងរយៈពេលយ៉ាងយូរ រួមទាំងរយៈពេល *ក្រោយឥទ្ធិពលទាំងនេះមានភាពច្បាស់លាស់*"[2635]។

772. ជាឧទាហរណ៍ អាជ្ញាធរស្រុកត្រាំកក់ដឹងថា របបអាហារត្រូវបានបែងចែកមិនគ្រប់គ្រាន់[2636] ហើយអាជ្ញាធរទាំងនោះបានចុះតាមការដ្ឋានការងារ[2637] ដើម្បីសង្កេតមើលលក្ខខណ្ឌការងារដ៏លំបាកដែលកំណត់លើកម្មករដែលទទួលបានរបបអាហារមិនគ្រប់គ្រាន់[2638]។ ទោះបីជាបានមើលឃើញយ៉ាងច្បាស់នូវរាងកាយដែលខ្វះអាហារូបត្ថម្ភ ការស្លាប់ដែលបណ្ដាលមកពីកង្វះអាហារូបត្ថម្ភ[2639] និងអាជ្ញាធរដែលដាក់ទណ្ឌកម្មលើអ្នកលួចអាហារ ឬមិនសម្រេចការងារតាមផែនការកំណត់ក៏ដោយ[2640] ក៏អាជ្ញាធរបានទទួលយកលទ្ធភាពនៃការស្លាប់បន្ថែមទៀតនៅពេលពួកគេ

---

[2635] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២០, ១១៤២ (ការគូសបញ្ជាក់បន្ថែម និង*ត្រូវបានលើកឡើងម្ដងទៀត* ក្នុងជើងទំព័រ ១៣១០១)។ *ផ្ទុយពី*ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៧៧។

[2636] ស្រុកដែលផ្ដល់ការបែងចែកអាហារជារួមដល់ឃុំ ទទួលបានរបាយការណ៍ស្ដីពីកង្វះស្បៀងអាហារ។ ឃុំ និងសហករណ៍មិនបានកំណត់របបអាហារទៅតាមបរិមាណកំណត់ឡើយ។ មានការដឹងឮ និងសង្កេតឃើញជាទូទៅ ហើយសូម្បីតែ ពេជ្រ ជឹម ដែលជាគណៈស្រុកក៏ដឹងដែរថា ប្រជាជនមូលដ្ឋានទទួលបានអាហារច្រើនជាងប្រជាជនផ្សេងទៀត។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១០, ១០១២-១០១៤, ១០១៦។ សូមមើលផងដែរ កថាខណ្ឌ ៩៥៥ (វត្តមានរបស់អាជ្ញាធរក្នុងស្រុកត្រាំកក់), ១០០៩ (គោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់របបអាហារបែបរើសអើង), ១០១១ (នុត នូវ)។

[2637] *ឧ.* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៥៥។

[2638] <u>ការធ្វើឱ្យទៅជាទាសករ៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២២-១០២៣, ១០៣៤ (មាស សុខា)។ សូមមើលផងដែរ កថាខណ្ឌ ១០៦០ (ប្រសិនបើកម្មករតវ៉ា ទណ្ឌកម្មគឺការប្រហារជីវិត), ១១៥០-១១៥៣។ <u>កិច្ចការបែបអមនុស្សធម៌៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៨, ១០២០, ១០៣៤។ សូមមើលផងដែរ កថាខណ្ឌ ១០៤៤ ជើងទំព័រ ៣៤៩០។ <u>ធ្វើការច្រើនម៉ោង៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៩-១០២០។ <u>ការសម្រេចការងារតាមផែនការកំណត់៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៨។

[2639] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ (រៀល សន និងត្រូវបានលើកឡើងម្ដងទៀតក្នុងកថាខណ្ឌ ១០៤៥), ១០២០ (ឯក ហឿន, សឹម ឈៀង), ១០៣៧ (ជូ គឹមឡុន) ជើងទំព័រ ៣២៨៣។

[2640] <u>ការដាក់ទណ្ឌកម្មលើការលួចអាហារ៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៧, ១០២៩ (អៀម យេន)។ សូមមើលផងដែរឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 14.01.04 ទំព័រ ៤២ បន្ទាត់ ២២-ទំព័រ ៤៣ បន្ទាត់ ១។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៥ (ប៊ុន សារឿន)។ <u>ទណ្ឌកម្មជាការដកហូតអាហារ៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៨, ១០២៣។

សម្រេចមិនអនុវត្តវិធានការសមស្របដើម្បីស្រោចស្រង់ស្ថានភាពនេះ[2641]។ ការថែទាំវេជ្ជសាស្ត្រនៅតែមិនអាចប្រើប្រាស់បាន[2642] និងមិនគ្រប់គ្រាន់[2643]។ នៅពេលលេខាស្រុកទទួលបានរបាយការណ៍មួយស្តីពីមូលហេតុដែលធ្វើឱ្យប្រជាជនមានជំងឺ គាត់បានសម្រេចមិនជំរុញឱ្យមានការដាក់របាយការណ៍ស្តីពីស្ថានភាពដ៏អាក្រក់បន្តទៀតឡើយ[2644]។ ដូច្នេះ ចំនួនអ្នកស្លាប់ "បានកើនឡើងយ៉ាងខ្លាំងនៅពេលចុងក្រោយនៃរបបនោះ"[2645]។

## *មូលដ្ឋានទី ១០២ ៖ គ្មានភស្តុតាងបង្ហាញពីចេតនាប្រយោលចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និងលក្ខខណ្ឌរស់នៅ*[2646]

---

[2641] សូមមើលឧទាហរណ៍ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៦ (*ដោយដកស្រង់ ក្នុងចំណោមចំណុចផ្សេងទៀត* ឯកសារ **E1/278.1** រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥, ម៉ោង 10.51.49 ទំព័រ ២៥ បន្ទាត់ ៣-៥)។ ឯកសារ **E1/278.1** រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥, ម៉ោង 10.47.33-10.49.20 ទំព័រ ២៤ បន្ទាត់ ២-៣ ទំព័រ ២៤ បន្ទាត់ ១០។ សូមមើលផងដែរឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៤, ១០២៩ (យ៉ែម ឌុន្នី ), ១០៥៥។ សម្រាប់ការខកខានផ្សេងទៀតក្នុងការមិនចាត់វិធានការសមស្របដើម្បីកែប្រែ ឬកាត់បន្ថយលក្ខខណ្ឌនេះ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៦, ១០១៦, ១០២៩ (យ៉ែម ឌុន្នី), ១០៥៦។ ឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 09.57.00-09.59.18 ទំព័រ ១៥ បន្ទាត់ ១១-១២, ១៤-១៥, ១៨, ទំព័រ ១៥ បន្ទាត់ ២៥-ទំព័រ ១៦ បន្ទាត់ ១-២, ៣, ម៉ោង 14.01.04 ទំព័រ ៤២ បន្ទាត់ ២៤-ទំព័រ ៤៣ បន្ទាត់ ១។

[2642] អាជ្ញាធរបានបដិសេធសំណើសុំការព្យាបាលវេជ្ជសាស្ត្រ និងបានចោទប្រកាន់អ្នកឈឺថាមានបញ្ហាសតិអារម្មណ៍ ឬជាខ្មាំង។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥០។

[2643] គ្មានបទពិសោធន៍ផ្នែកវេជ្ជសាស្ត្រ ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤០-១០៤៣។ ឱសថមិនគ្រប់គ្រាន់ ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤២, ១០៥៦, ១០៥០។ ការបន្ថយរបបអាហារសម្រាប់អ្នកជំងឺក្នុងមន្ទីរពេទ្យ ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤៧។

[2644] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៦។

[2645] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៣, ១០៥៧ (*ដោយដកស្រង់ ក្នុងចំណោមចំណុចផ្សេងទៀត* ឯកសារ **E1/279.1** រៀល សន ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥, ម៉ោង 13.49.18-13.51.35 ទំព័រ ៣៨ បន្ទាត់ ២-១៤)។ សូមមើលផងដែរ កថាខណ្ឌ ១០៤៧ (*ដោយដកស្រង់* ឯកសារ **E1/278.1** រៀល សន ប្រតិចារឹក ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០១៥, ម៉ោង 15.39.07 ៦៦ បន្ទាត់ ២-៣), ១០៥០ (*ដោយដកស្រង់* ឯកសារ **E1/262.1** រី ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥, ម៉ោង 10.48.03 ទំព័រ ២៧ បន្ទាត់ ៣-៤, ៥-៦)។

[2646] មូលដ្ឋានទី ១០២ ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានភស្តុតាងបង្ហាញពីចេតនាប្រយោលចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និងលក្ខខណ្ឌរស់នៅ* កថាខណ្ឌ ៦៨៣-៦៨៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៩ (ភាសាអង់គ្លេស) ទំព័រ ៣៦ (ភាសាបារាំង) ទំព័រ ៥៥ (ភាសាខ្មែរ)។ កំណែដើមនៃសារណាបណ្តឹងសាទុក្ខប្រើពាក្យ "dol éventuel" ដែលគួរបកប្រែថា "*ចេតនាប្រយោល*" មិនមែន "កាស្លាប់" ទេ។

773. **មូលដ្ឋានទី ១០២ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គហេតុតាមរយៈការសន្និដ្ឋានថាមាន*ធាតុផ្សំអត្តនោម័តិ*នៃការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល*ដោយសារលក្ខខណ្ឌរស់នៅក្នុងសហករណ៍ស្រុកត្រាំកក់។**

774. មូលដ្ឋាននេះមិនទទួលបានផលទេ ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់មូលដ្ឋានដល់ការចោទប្រកាន់របស់ខ្លួនដែលថា អ.ជ.ស.ដ បានវាយតម្លៃមិនសមហេតុផលលើភ័ស្តុតាងដែលជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់ខ្លួន[2647]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដែលផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើសាលក្រមនេះ និងគ្មានភ័ស្តុតាងបញ្ជាក់។

775. ទីមួយ ការកត់សម្គាល់របស់ អ.ជ.ស.ដ ពីកត្តាខាងក្រៅដែលអាចរួមចំណែកដល់កង្វះស្បៀងអាហារ និងកង្វះសម្ភារបរិក្ខារពេទ្យក្នុងស្រុកត្រាំកក់[2648] មិនរារាំងចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ មិនឱ្យលើកឡើងពី*ធាតុផ្សំអត្តនោម័តិ*របស់អាជ្ញាធរស្រុកត្រាំកក់ សម្រាប់ការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌទាំងនោះឡើយ[2649]។ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើថា (១) លក្ខខណ្ឌដែលគ្របដណ្តប់*លើសពី*កង្វះស្បៀងអាហារ និងសម្ភារៈបរិក្ខារវេជ្ជសាស្ត្រដើម្បីដាក់បញ្ចូលប្រជាជនដែល "ត្រូវបានបង្ខំដោយចេតនាឱ្យធ្វើការក្នុងបរិយាកាសមួយដែលមានការគ្រប់គ្រងការគំរាមកំហែង ការភ័យខ្លាច (...) និងការរើសអើងដោយមានផលវិបាកយ៉ាងធ្ងន់ធ្ងរបំផុតដល់អ្នកដែលបានតវ៉ាប្រឆាំង[2650] និង (២) "ការវាយតម្លៃភ័ស្តុតាង*ទាំងអស់* (ដែលម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់)[2651] បង្ហាញយ៉ាងច្បាស់ថា" អាជ្ញាធរ "មានចេតនាបង្កើត" លក្ខខណ្ឌទាំងនេះ "ក្នុងរយៈពេលយ៉ាងយូរ" ដែលធ្វើឱ្យប្រជាជន "គ្មានជម្រើសអ្វីផ្សេងក្រៅតែពីទទួលយកជោគវាសនាដែលខ្លួនមាន រួមទាំងនៅពេលដែលលទ្ធផលអាចប្រមើលឃើញថានឹងបង្កឱ្យមានមនុស្សស្លាប់"[2652]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញពីមូលហេតុថាហេតុអ្វីគ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់យល់ថា កម្រិត និងភាពធ្ងន់ធ្ងរនៃវិធានការរបស់អាជ្ញាធរស្រុកត្រាំកក់ ដោយមិនគិតពីកត្តាខាងក្រៅ បំពេញ*ធាតុផ្សំអត្តនោម័តិ*នៃការធ្វើមនុស្សឃាត។

[2647] *ផ្ទុយពី*ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៣៩។

[2648] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៥។

[2649] *ផ្ទុយពី*ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨៥។

[2650] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៥, ១១៤៤។ សូមមើលផងដែរ កថាខណ្ឌ ១១៤២។

[2651] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០០ (និងការដកស្រង់ទាំងអស់នៅក្នុងនោះ) និងមូលដ្ឋានទី ១០១។

[2652] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៥ (គូសបញ្ជាក់បន្ថែម), ១១៤៤។

776. ទីពីរ សេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា អាជ្ញាធរស្រុកត្រាំកក់ បានបន្តរក្សា "លក្ខខណ្ឌទាំងនេះក្នុងរយៈពេលយ៉ាងយូរ *រួមទាំង*រយៈពេលក្រោយឥទ្ធិពលទាំងនេះមានភាពច្បាស់លាស់" មិនទាមទារឱ្យ អ.ជ.ស.ដ ត្រូវកំណត់ពេលដែល*ធាតុផ្សំសត្យានុម័ត* និង*ធាតុផ្សំអត្តនោម័ត*របស់អាជ្ញាធរទាំងនោះត្រូវបានបង្ហាញឡើយ[2653]។ អ.ជ.ស.ដ យល់ថា *ធាតុផ្សំអត្តនោម័ត*នៃឧក្រិដ្ឋកម្មនេះគ្របដណ្ដប់លើរយៈពេលទាំងមូលនៅមុនពេល និងក្រោយពេលដែលឥទ្ធិពលនៃឧក្រិដ្ឋកម្មនេះមានភាពច្បាស់លាស់។ ចំណុចនេះត្រូវបានគាំទ្រដោយសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ឧទាហរណ៍ (១) មានកង្វះស្បៀងអាហាររហូតដល់ពេលប្រមូលផលស្រូវនៅឆ្នាំ ១៩៧៦-១៩៧៧ [2654] និងកើតមានបន្តទៀតនៅពេលបន្ទាប់[2655] ហើយ (២) ប្រជាជនថ្មី (ដែលត្រូវបានជម្លៀសពីទីក្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) ចាញ់ប្រៀបប្រជាជនមូលដ្ឋាន នៅពេលពួកគេទៅដល់សហករណ៍ស្រុកត្រាំកក់[2656] ហើយការចាញ់ប្រៀបនេះបន្តរហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧៨[2657]។

### *មូលដ្ឋានទី ១០១៖ អវត្តមានភ័ស្តុតាងក្នុងកម្រិតតម្រូវនៃការស្លាប់ដែលវងការចោទប្រកាន់*[2658]

777. **មូលដ្ឋានទី ១០១ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គហេតុនៅក្នុងសេចក្ដីសន្និដ្ឋានថាមាន *ធាតុផ្សំសត្យានុម័ត* នៃការធ្វើមនុស្សឃាតដោយសារលក្ខខណ្ឌរស់នៅក្នុងសហករណ៍ស្រុកត្រាំកក់។**

778. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ វាយតម្លៃដោយមិនសមស្របទៅលើបរិមាណដ៏ច្រើននៃភ័ស្តុតាងដែលមានតម្លៃខ្ពស់ ដែលរារាំង

---

[2653] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៥ (គូសបញ្ជាក់បន្ថែម)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៨៥។

[2654] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០១៣។

[2655] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៣។

[2656] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៨០-៩៨៥ (គោលនយោបាយ), ៩៩၀-១០០១, ១០០៤ (ការអនុវត្ត)។

[2657] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៧។

[2658] <u>មូលដ្ឋានទី ១០១៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *អវត្តមានភ័ស្តុតាងក្នុងកម្រិតតម្រូវនៃការស្លាប់ដែលវងការចោទប្រកាន់* កថាខណ្ឌ ៦៧៨-៦៨២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៣៩ (ភាសាអង់គ្លេស) ទំព័រ ៣៥ (ភាសាបារាំង) ទំព័រ ៥៥ (ភាសាខ្មែរ)។ ទាក់ទងនឹងមូលដ្ឋានបណ្ដឹងសាទុក្ខសាជាថ្មីរបស់ម្ចាស់បណ្ដឹងសាទុក្ខនៅឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៦២ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៩-៤០, ៦២, ៦៥-៦៦ (វិសាលភាពបណ្ដឹង) និង ៨៦ (ច្បាប់ស្ដីពីការធ្វើឃាតកម្ម*ដោយចេតនាប្រយោល*)។

ដល់សេចក្ដីសន្និដ្ឋានដែលរងការជំទាស់[2659]។ ទឡ្ហីករណ៍មិនត្រឹមត្រូវរបស់ម្ចាស់បណ្ដឹងសាទុក្ខជាផ្នែកមួយនៃភ័ស្ដុតាង និងមិនអើពើទៅនឹង (i) ភ័ស្ដុតាងបន្ថែមទាក់ទងនឹងលក្ខខណ្ឌរស់នៅ *និង* លក្ខខណ្ឌការងារលំបាកឃោរឃៅយ៉ាងច្រើន ដែល អ.ជ.ស.ដ បានយល់ឃើញថាត្រូវបានប្រព្រឹត្តទៅលើប្រជាជន[2660] ដែលត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅក្នុងស្រុកត្រាំកក់[2661] និង (ii) ផលប៉ះពាល់រួមគ្នាដែលលក្ខខណ្ឌទាំងនេះបានបង្កឡើងទៅលើសុខភាពរបស់ប្រជាជន ហើយជាចុងក្រោយទៅលើការស្លាប់របស់ពួកគាត់[2662]។ ភ័ស្ដុតាងបន្ថែមនោះមានការពាក់ព័ន្ធនឹង (i) កង្វះអាហារ និងការស្លាប់ដោយសារកង្វះអាហារ[2663] (ii) លក្ខខណ្ឌការងារ[2664] (iii) ការគ្រប់គ្រង

---

2659 សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

2660 សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៤-១១៤៥។

2661 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៧៩។

2662 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២ និងសេចក្ដីដកស្រង់នៅក្នុងនេះ។

2663 កង្វះអាហារធ្ងន់ធ្ងរមុន និងក្រោយការប្រមូលផលឆ្នាំ១៩៧៦-១៩៧៧ ដែលបង្កឱ្យមានមនុស្សស្លាប់៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១១-១០១២ (ផ្អែកតាម ពេជ្រ ជឹម, នុត នូវ, សៅ វ៉ន, ឯក ហឿន, ជូ គឹមឡន, ឯម ភឿង, ឡង់ វ៉ុន), ១០១៣ (កំណត់ត្រាស្រុកត្រាំកក់ ជើងទំព័រ៣២២៥ និង ៣២២៨), ១០១៤ (អ៊ឹម សាវឿន, ភ្លៅ យ៉ារ, ថាន់ ធីម, របាយការណ៍ស្រុកត្រាំកក់, រៀល សន, រី ពៅ, សៅ ប៊ាន, មាស សុខា)។ អាហារជាទូទៅតិចជាងបរិមាណដែលចាំបាច់សម្រាប់រក្សាជីវិតប្រជាជន៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ ជើងទំព័រ ៣២៦១ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០០៨ (ផ្អែកតាមគណៈអចិន្ត្រៃយ៍របស់ ប.ក.ក និងកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ទស្សនាវដ្ដីរបស់ ប.ក.ក ផែនការសេដ្ឋកិច្ចឆ្នាំ១៩៧៧-១៩៨០ របស់ ប.ក.ក)។ ប្រជាជនថ្មីបានទទួលអាហារតិចជាងប្រជាជនមូលដ្ឋាន៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ (ផ្អែកតាម ពេជ្រ ជឹម, កែវ ចាន់ដារ៉ា, តាក សាន់, ជូ គឹមឡន, រៀល សន)។ ប្រសិនបើម្ចាស់បណ្ដឹងសាទុក្ខមានបំណងជំទាស់ទៅនឹងសេចក្ដីសន្និដ្ឋាននេះ ទាក់ទងនឹងប្រជាជនថ្មី តាមរយៈមូលដ្ឋានបណ្ដឹងសាទុក្ខផ្សេងទៀតរបស់គាត់ គាត់ខកខានមិនបានបង្ហាញបំណងរបស់គាត់ក្នុងឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៧៨-៦៨២ ជាមួយកំណត់សម្គាល់យោងទៅកថាខណ្ឌផ្សេងទៀតក្នុងសារណារបស់គាត់។ ម្យ៉ាងវិញទៀត *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៧។ ការស្លាប់៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤៥-១០៤៧ (ផ្អែកតាម រៀល សន)។ សូមមើលផងដែរ កថាខណ្ឌ ១០១២។

2664 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៤។ សូមមើល កថាខណ្ឌ ១០១៨ (ផ្អែកតាម សៅ ប៊ាន, ប៊ុន សាវឿន, តាក សាន់, អៀម យេន), ១០១៩ (កំណត់ត្រាស្រុកត្រាំកក់, ឯម ភឿង, សៅ ប៊ាន, ជាំង ស្រីមុំ, មាស សុខា, ភ្លៅ យ៉ារ), ១០២០ (ផ្អែកតាម រី ពៅ, នុត នូវ ជើងទំព័រ ៣២៧៩, រៀល សន), ១០២៩ (ផ្អែកតាម យែម ឌុន្នី), ១០៤៥ (ផ្អែកតាម រៀល សន), ១០៤៧ (ផ្អែកតាម រៀល សន)។

ប្រជាជន រួមទាំងតាមរយៈការដាក់ទោសទណ្ឌនានាដូចជា ការដកហូតអាហារ និងបង្កើនបន្ទុកការងារ[2665] និង (iv) ការថែទាំផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់[2666] ជាដើម។

779. លើសពីនេះទៀត ការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងវត្ថុតាងពាក់ព័ន្ធនឹងការកើតមានកង្វះអាហារ (ដែលម្ចាស់បណ្តឹងសាទុក្ខមិនលើកឡើងថាជាផ្នែកមួយនៃការផ្តន្ទាទោសពីបទអំពើអមនុស្សធម៌ផ្សេងទៀតរបស់គាត់ ដោយសារការរំលោភបំពានលើសេចក្តីថ្លៃថ្នូរបស់មនុស្ស)[2667] ការស្លាប់ដោយសារការបង្អត់អាហារ និងការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់ មិនត្រូវបានរកឃើញឡើយ ពីព្រោះគាត់បកស្រាយមិនត្រឹមត្រូវអំពីភ័ស្តុតាងនោះ និងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលពាក់ព័ន្ធ។

780. ទាក់ទងនឹងការកើតមានកង្វះអាហារ ដែលបង្កមកពីអំពើសកម្ម និងអកម្មរបស់អាជ្ញាធរក្នុងស្រុកត្រាំកក់[2668] ម្ចាស់បណ្តឹងសាទុក្ខ ដេញដោលដែលពុំអាចឱ្យជឿបានទៅនឹងការវាយតម្លៃរបស់ អ.ជ.ស.ដ លើផ្នែកចំនួនពីរនៃភ័ស្តុតាង។ គាត់មិនបានបង្ហាញថា តើហេតុអ្វីបានជាមិនមានអ្នកជម្រះហេតុសមស្រប ដែលអាចទាញសេចក្តីសន្និដ្ឋានពីរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ដែលភូមិភាគនិរតីកំពុងសំដៅលើអាហារ នៅពេលភូមិភាគនេះនិយាយថា "ឃុំខ្លះមានការខ្វះខាត ឬស្រុកខ្លះខ្វះខាត [ក្នុងខេត្តតាកែវ]"[2669]។ កង្វះអាហារដែលត្រូវបានរាយការណ៍ត្រូវបានកត់ត្រា

---

[2665] ការដកហូតអាហារ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២៣ (ផ្អែកតាម ប៊ុន សារឿន, អ៊ុម វណ្ណៈ, តាក សាន់) រួមទាំងកំណត់សម្គាល់យោងទៅជើងទំព័រ ៣២៩៥ ដល់កថាខណ្ឌ ១០០៩ ផ្អែកតាមទស្សនាវដ្តី ប.ក.ក និងសៀវភៅកំណត់ហេតុរបស់ អៀង សារី)។ សូមមើលផងដែ កថាខណ្ឌ ១០១៨ (អៀម យេន), ១០៥៧ (រួមទាំងជើងទំព័រ ៣៤៩៤, ៣៤៩៦, ៣៤៩៨)។ បង្កើនបន្ទុកការងារ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២៩ (ផ្អែកតាម យែម ឌុន្នី)។ ទោសទណ្ឌផ្សេងទៀត៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២២ (ផ្អែកតាម ខៀវ សំផន), ១០២៩ (ផ្អែកតាម ជាំង ស្រីមុំ, សៅ ហ៊ាន, ខៀវ នៅ, អៀម យេន), ១០៣០ (ផ្អែកតាមកំណត់ត្រាស្រុកត្រាំកក់ និងសៀវភៅកំណត់ត្រាក្រាំងតាចាន់) រួមទាំងកំណត់សម្គាល់យោងទៅជើងទំព័រ ៣៣២៩, ៣៣៣១, ដល់កថាខណ្ឌ ៨៦៦, ៨៩១។ សូមមើលផងដែរ កថាខណ្ឌ ១០៣៩។

[2666] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤០-១០៤៣, ១០៤៦ (ផ្អែកតាម រៀល សន), ១០៥០ (ផ្អែកតាម រៀល សន, អ៊ុម សារឿន, ជួន គឹមឡូន, រីពៅ)។

[2667] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៩៥, ១១៩៧, ១១៩៩។

[2668] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២, ១១៤៤, ១១៤៥។

[2669] ឯកសារ **E3/853** សេចក្តីរាយការណ៍ជូនអង្គការពីភូមិភាគនិរតី ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ KH 00052828 ដែលមានភាពស្របគ្នាជាមួយនឹងឯកសារភាសាខ្មែរ និង KH ក្នុងសាលក្រមជាភាសាខ្មែរ។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៧៨។

នៅក្នុងចំណងជើងរង ដែលសរសេរថា "បញ្ហាជីវភាពប្រជាជន"[2670] និងទាក់ទងទៅនឹង "សភាពការណ៍សេដ្ឋកិច្ច" និង "ផែនការកសិកម្មដើមឆ្នាំ១៩៧៧"[2671]។ សេចក្តីថ្លែងការណ៍នេះក៏ត្រូវបានបញ្ជាក់ផងដែរក្នុងចំណោមនោះដោយកំណត់ត្រារបស់ស្រុកត្រាំកក់មួយចំនួន[2672]។

781. លើសពីនេះ ម្ចាស់បណ្តឹងសាទុក្ខព្រងើយកន្តើយក្នុងការបង្ហាញអំពីរបៀបដែល អ.ជ.ស.ដ បំភ្លៃសក្ខីកម្មរបស់ នាង អ៊ួច *ហៅ* តាសាន តាមរយៈសេចក្តីសន្និដ្ឋានថា សាក្សី "បានបញ្ជាក់ថា កង្វះអាហារបែបនេះគឺដោយសារតែកំហុសប្រធានសហករណ៍"[2673]។ នាង អ៊ួច បានលើកឡើងថា (i) ប្រធានឃុំ/សហករណ៍បានរៀបចំអាហារសម្រាប់ប្រជាជន/អ្នកធ្វើការរបស់ពួកគេ (ii) ប្រធានខ្លះមិន "សម្របសម្រួល" ឬ "ដោះស្រាយ" អាហារបានល្អឡើយ ហើយ (iii) "អ៊ីចឹង" ការបរាជ័យរបស់ពួកគេបានបង្កឱ្យប្រជាជនទទួលបានអាហារមិនគ្រប់គ្រងក្នុងសហករណ៍មួយចំនួន[2674]។

782. ទាក់ទងនឹងការស្លាប់ដោយសារការបង្អត់អាហារ[2675] ម្ចាស់បណ្តឹងសាទុក្ខជាថ្មីម្តងទៀតជំទាស់ដោយមិនទទួលជោគជ័យទៅនឹងការវាយតម្លៃរបស់ អ.ជ.ស.ដ ទៅលើភ័ស្តុតាងចំនួនពីរ។ អ.ជ.ស.ដ បានយល់ឃើញដោយសមហេតុផលថា រៀល សន បានផ្តល់សក្ខីកម្មថា ការស្លាប់ដោយសារការបង្អត់អាហារ "បានកើនឡើងយ៉ាងខ្លាំងនៅពេលចុងក្រោយនៃរបបនោះ"[2676]។ ក្នុងអំឡុងពេល

---

[2670] ឯកសារ **E3/853** សេចក្តីរាយការណ៍ជូនអង្គការពីភូមិភាគនិរតី ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ KH 00052828។ សហព្រះរាជអាជ្ញាកត់សម្គាល់ការបកប្រែជាភាសាអង់គ្លេស និងភាសាបារាំងសម្រាប់ចំណងជើងរងនៅក្នុងឯកសារដើមជាភាសាខ្មែរ។ ការអានរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យបង្ហាញថា កង្វះអាហារត្រូវបានពិភាក្សាទាក់ទងនឹង "សភាពការណ៍" និង "ជីវភាពរស់នៅ" របស់ប្រជាជន។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣០៤៩ *ដោយដកស្រង់ក្នុងចំណោមនោះ* ឯកសារ **E3/179** សេចក្តីរាយការណ៍ពីមន្ទីរ ៥៦០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ KH 0000 8498-00008499 និងឯកសារ **E3/1179** សេចក្តីរាយការណ៍ពីមន្ទីរ ៥៦០ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ KH 00214272។

[2671] ឯកសារ **E3/853** សេចក្តីរាយការណ៍ជូនអង្គការពីភូមិភាគនិរតី ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ KH 00052825-000 52826។

[2672] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣២២៥, ៣២២៨។

[2673] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៣។ សូមមើលផងដែរ កថាខណ្ឌ ១០១៦ រួមទាំងជើងទំព័រ ៣២៥៣។

[2674] ឯកសារ **E1/274.1** នាង អ៊ួច ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥, ម៉ោង 09.33.23-09.35.55 ទំព័រ ៩ បន្ទាត់ ១៧-ទំព័រ ១០ បន្ទាត់ ៦។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ប្រតិចារឹកភាសាខ្មែរជួយបញ្ជាក់បំភ្លឺភាពមិនស៊ីចង្វាក់គ្នាមួយចំនួនដែលកើតមានរវាងសំណៅបកប្រែជាភាសាអង់គ្លេស និងបារាំង។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៧៩។

[2675] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២, ១១៤៤-១១៤៥។

[2676] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៣។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៧៩។

ផ្តល់សក្ខីកម្មរបស់គាត់ រៀល សន បានរៀបរាប់លម្អិតអំពីការកើនឡើងយ៉ាងគំហុកនេះដែលគាត់បានលើកឡើងនៅក្នុងចម្លើយរបស់គាត់ដែលផ្តល់ទៅឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា។ គាត់បានពន្យល់ទៅកាន់ អ.ជ.ស.ដ ថា កំណើនការស្លាប់នេះគឺដោយសារ "ប្រជាជនមិនមានអ្វីហូប"[2677]។

783. លើសពីនេះទៀត អ.ជ.ស.ដ បានយល់ឃើញដោយសមហេតុផលថា "ជាំង ស្រីមុំ បានផ្តល់សក្ខីកម្មថា [...] ប្រជាជនបានស្លាប់ដោយសារខ្វះអាហារូបត្ថម្ភ"[2678]។ អ.ជ.ស.ដ បានទទួលស្គាល់ទំនាក់ទំនងមូលហេតុរវាងអាហារមិនគ្រប់គ្រាន់ និងការស្លាប់ ពីព្រោះវាមានទំនាក់ទំនងនឹង (i) ជាំង ស្រីមុំ បាននិយាយជាច្រើនដងថា មានអាហារមិនគ្រប់គ្រាន់[2679] និង (ii) ជាំង ស្រីមុំ ដែលលើកឡើងថា "អាហារប្រចាំថ្ងៃហ្នឹងវាមិនដែលបានហូបគ្រប់គ្រាន់ [...] ដល់ពេលជួបប្រទះអាហារហ្នឹងចេះតែហូប" នៅពេលដែលពួកគេអាចហូបបាន ហើយ "អ្នកខ្លះទៅស្ទះជាខ្យល់ ឬមួយបែកក្រពះស្លាប់"[2680]។

784. ទាក់ទងនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា អ្នកធ្វើការមាន "បញ្ហាយ៉ាងខ្លាំងក្នុងការទទួលបានអាហារ ហើយប្រជាជនខ្លះបានស្លាប់ដោយសារកង្វះអាហារនេះ"[2681] នោះ ការអះអាងគ្មានមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខ មិនអើពើនឹងការវាយតម្លៃរួមរបស់ អ.ជ.ស.ដ ទៅលើភ័ស្តុតាង[2682]។ ដូចគ្នាទៅនឹងសេចក្តីសន្និដ្ឋានដំបូងរបស់ អ.ជ.ស.ដ ផងដែរ ទាក់ទងនឹងអាហារមិនគ្រប់គ្រាន់នៅក្នុងស្រុកត្រាំកក់ និងការបង្កឱ្យមនុស្សស្លាប់ដោយសារកង្វះអាហារនេះ[2683] សក្ខីកម្មរបស់ ឯក ហឿន ដែលបានធ្វើការឱ្យស្រុកនេះ បានអះអាងថា អ្នកធ្វើការក៏ជួបប្រទះការ

---

[2677] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៣។ សូមមើលផងដែរ ឯកសារ **E1/278.1** រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥, ម៉ោង 11.09.00-11.13.41 ទំព័រ ២៩ បន្ទាត់ ៣-១៣។

[2678] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៥។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៧៩។

[2679] ឯកសារ **E1/254.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥, ម៉ោង 09.34.22-09.36.44ទំព័រ ១១ បន្ទាត់ ២-៣, ៥-៧, ១១.១០.១៤-១១.១១.៥១ ទំព័រ ៣៤ បន្ទាត់ ២។

[2680] ឯកសារ **E1/254.1** ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥, ម៉ោង 09.34.22-09.36.44 ទំព័រ ១១ បន្ទាត់ ២-៨ (គូសបញ្ជាក់បន្ថែម)។

[2681] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២។

[2682] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨០។

[2683] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២ រួមទាំងជើងទំព័រ ៣៨៨០-៣៨៨២ និង *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០២០ ("ភ័ស្តុតាងទាំងអស់ [..] បានកំណត់ថា" "ការស្លាប់ជាច្រើន [...] គឺជាស្ថានភាព [...] ទូទៅនៅក្នុងស្រុកត្រាំកក់")។

ស្លាប់ដោយសារអត់អាហារដែរ។ អ្នកធ្វើការ "ហូបអត់គ្រប់គ្រាន់" ហើយការស្លាប់បានកើតមានឡើងនៅការដ្ឋាន[2684]។ ស៊ឹម ឈៀង ដែលបានរស់នៅ និងធ្វើការនៅសហករណ៍មួយ បានលើកឡើងនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់គាត់ថា គាត់បានទទួលអាហារមិនគ្រប់គ្រាន់ និងថា បើទោះជាក្នុងពេលស្គមរីងរៃ និងអស់កម្លាំងក៏ដោយ ក៏គាត់ត្រូវបាន "គេឱ្យនៅតែធ្វើការបន្តទៀត" និង "បានឃើញយ៉ាងហោចណាស់មានមនុស្សម្នាក់បានស្លាប់ដោយសារការអត់អាហារ"[2685]។ ដោយសារភ័ស្តុតាងដែលស៊ីចង្វាក់គ្នារបស់ប្រជាជន/អ្នកធ្វើការ ដែលទទួលបានអាហារមិនគ្រប់គ្រាន់ និងការឈានទៅរកការស្លាប់ដោយសារកង្វះអាហារនេះ[2686] អ.ស.ជ.ដ បានពឹងផ្អែកយ៉ាងសមស្របទៅលើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលស៊ីចង្វាក់គ្នា "ជាច្រើន" ដែលបានផ្តល់ "ព័ត៌មានលម្អិត និងព័ត៌មានជាក់លាក់" របស់ប្រជាជន រួមទាំងអ្នកធ្វើការ "ដែលស្លាប់ដោយសារ" លក្ខខណ្ឌផ្សេង រួមទាំង "ខ្វះអាហារ" ផងដែរ[2687]។

785. ទាក់ទងនឹងការស្លាប់ដោយសារការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់[2688] វាមិនច្បាស់លាស់នោះទេថា តើម្ចាស់បណ្តឹងសាទុក្ខកំពុងចោទប្រកាន់ថាបណ្តាលមកពីកំហុងអង្គច្បាប់ អង្គហេតុ ឬមកពីកំហុសទាំងពីរ[2689]។ ក្នុងករណីដែលគាត់មិនអើពើនឹងភាសាសាមញ្ញនៃសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា "ប្រជាជនបានស្លាប់នៅក្នុងមន្ទីរពេទ្យស្រុក រួមទាំងនៅតាមទីកន្លែងផ្សេងៗ

---

[2684] ឯកសារ **E1/298.1** ឯក ហឿន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 15.55.50-15.58.05 ទំព័រ ៧៦ បន្ទាត់ ២៣។ សូមមើលផងដែរ ម៉ោង 15.53.56-15.55.50 ទំព័រ ៧៥ បន្ទាត់ ២០-២១, ម៉ោង 15.53.56-15.55.50 ទំព័រ ៧៦ បន្ទាត់ ១០-១១។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨២០, ១០២០។

[2685] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២០។ ឯកសារ **E3/7980** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម ឈៀង KH 00165302។

[2686] សូមមើលផងដែរ ភ័ស្តុតាងដែលជាមូលដ្ឋាននៃការសន្និដ្ឋានលើអង្គហេតុនៅឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៧៩ ("ប្រជាជននៅក្នុងស្រុកត្រាំកក់ត្រូវបានកំណត់ឱ្យបំពេញការងារ"), ១០៤៧ ("ការរៀបរាប់ពីបទពិសោធដោយផ្ទាល់របស់ រៀល សន [...] ថា ប្រជាជនបានស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ" នៅមន្ទីរពេទ្យស្រុក "មានភាពស៊ីចង្វាក់គ្នា ហើយសមស្របនិងអាចជឿជាក់បាន")។

[2687] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២០ រួមទាំងជើងទំព័រ ៣២៨៣។

[2688] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២, ១១៤៤-១១៤៥។

[2689] បណ្តឹងរបស់ម្ចាស់បណ្តឹងសាទុក្ខចាប់ផ្តើមដោយការចោទប្រកាន់ថាជា "កំហុសអង្គច្បាប់" ប៉ុន្តែក្រោយមកមិនលើកឡើងច្បាស់លាស់នោះទេថា តើកំហុសនោះគឺជាអ្វី ហើយបញ្ចប់បណ្តឹងរបស់គាត់ជាមួយនឹងពាក្យថា "គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់"។ សូមមើល ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៥៤ ("កំហុស៖ ការអនុវត្តច្បាប់មិនត្រឹមត្រូវ").

ទៀតដែរ ដោយសារតែកង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ”[2690]។ ភាសានោះមិនកំណត់ការស្លាប់ចំពោះអ្នកទាំងឡាយណាដែលនៅមន្ទីរពេទ្យស្រុកនោះទេ ហើយដូច្នេះផ្ទុយទៅនឹងការលើកឡើងរបស់ម្ចាស់បណ្ដឹងសាទុក្ខ មិនមានការពឹងផ្អែក “តែទៅលើ” ភស្តុតាងដែលទទួលបានមកពី រៀល សន ដែលជាអតីតអនុប្រធានមន្ទីរពេទ្យនេះនោះទេ[2691]។

786. ដោយសន្មតថា សេចក្ដីសន្និដ្ឋានដែលថា ប្រជាជនស្លាប់ដោយសារការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់បានពឹងផ្អែកតែទៅលើ រៀល សន នោះ ម្ចាស់បណ្ដឹងសាទុក្ខមិនបានពន្យល់នោះទេថាតើហេតុអ្វីបានជាវាមិនមានហេតុផល ដើម្បីបញ្ជាក់ភាពអាចកើតមានអ្នកជំងឺស្លាប់ដោយសារលក្ខខណ្ឌនេះ។ រៀល សន បានលើកឡើងថា “ការរៀបរាប់ពីបទពិសោធដោយផ្ទាល់ [...] អំពីសម្ភារនៅក្នុងមន្ទីរពេទ្យ រួមទាំងការផ្គត់ផ្គង់អាហារដែលថាមិនគ្រប់គ្រាន់ មានភាពស៊ីចង្វាក់គ្នាហើយសមស្របនិងអាចជឿជាក់បាន”[2692] ដែលម្ចាស់បណ្ដឹងសាទុក្ខមិនជំទាស់។ លើសពីនេះទៀត ភាពអាចកើតមាននៃការស្លាប់បែបនេះ ត្រូវបានបញ្ជាក់ដោយភស្តុតាងដែលស៊ីចង្វាក់គ្នាផ្សេងទៀត[2693] និងសុភវិនិច្ឆ័យ។

---

[2690] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២ (គូសបញ្ជាក់បន្ថែម)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៨២។

[2691] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥០ (ទាក់ទងនឹងការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់ រួមទាំង រី ពៅ ផងដែរនោះដែលលើកឡើងថា “មិនមាននរណាម្នាក់ត្រូវបានគេបញ្ជូនទៅគ្លីនិកឡើយ។ បើប្រជាជនធ្លាក់ខ្លួនឈឺ ឬស្លាប់ដោយសារតែអត់អាហារ គេចាត់ទុកថា នេះគឺជា “កង់ប្រវត្តិសាស្ត្រ””), ១០២០ (ទាក់ទងនឹងមនុស្សដែលស្លាប់ដោយសារសុខភាពមិនល្អ ដោយផ្អែកតាម ឯក ហឿន, ស៊ឹម ឈៀង និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនទៀត)។ សូមមើលផងដែរឯកសារ **E1/277.1** នុត នូវ ប្រតិចារឹក ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥, ម៉ោង 10.14.38-10.33.52 ទំព័រ ២១ បន្ទាត់ ១២-២២។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៨២។

[2692] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤២ *កំណត់សម្គាល់យោងទៅ* ជើងទំព័រ ៣៨៨៤ ដល់កថាខណ្ឌ ១០៤៧ (*សម្គាល់៖* សេចក្ដីសន្និដ្ឋានរួមនៃភស្តុតាងរបស់ រៀល សន មានមូលដ្ឋានលើកថាខណ្ឌ ១០៤០-១០៤៧)។ សូមមើលផងដែរ ជើងទំព័រ ៣៤២៦ ទាក់ទងនឹងថ្នាំមិនគ្រប់គ្រាន់ ដើម្បីព្យាបាលជំងឺរាករូស និងហើម។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៦៨២។

[2693] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥០ (ទាក់ទងនឹងការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់ រួមទាំង រី ពៅ ផងដែរនោះដែលលើកឡើងថា “មិនមាននរណាម្នាក់ត្រូវបានគេបញ្ជូនទៅគ្លីនិកឡើយ។ បើប្រជាជនធ្លាក់ខ្លួនឈឺ ឬស្លាប់ដោយសារតែអត់អាហារ គេចាត់ទុកថា នេះគឺជា “កង់ប្រវត្តិសាស្ត្រ””), ១០២០ (ទាក់ទងនឹងមនុស្សដែលស្លាប់ដោយសារសុខភាពមិនល្អ ដោយផ្អែកតាម ឯក ហឿន, ស៊ឹម ឈៀង និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនទៀត)។ សូមមើលផងដែរឯកសារ **E1/277.1** នុត នូវ ប្រតិចារឹក ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥, ម៉ោង 10.14.38-10.33.52 ទំព័រ ២១ បន្ទាត់ ១២-២២។

### *មូលដ្ឋានទី ១០៧ ៖ ប្រជាជនថ្មីមិនត្រូវបានធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*[2694]

787. **មូលដ្ឋានទី ១០៧ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុងអង្គហេតុ តាមរយៈសេចក្តីសន្និដ្ឋានថាមាន *ចេតនាប្រកាន់ពូជសាសន៍* សម្រាប់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងប្រជាជនថ្មីនៅក្នុងស្រុកត្រាំកក់។**

788. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានធ្វើការវាយតម្លៃដោយមិនសមស្របទៅលើភ័ស្តុតាងដែលមានតម្លៃខ្ពស់ ដែលរារាំងដល់សេចក្តីសន្និដ្ឋានដែលរងការជំទាស់។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចធ្វើសេចក្តីសន្និដ្ឋានបែបនេះ ដោយផ្អែកលើការវាយតម្លៃជារួមនៃភ័ស្តុតាង ដែលផ្ទុយទៅនឹងការវាយតម្លៃជាផ្នែកៗ[2695]។ បណ្តឹងដែលមិនត្រឹមត្រូវរបស់គាត់ ដែលត្រូវបានលើកឡើងខាងក្រោម មិនអើពើនឹង (i) ភ័ស្តុតាង និងសេចក្តីសន្និដ្ឋានដែលពាក់ព័ន្ធ រួមទាំងការបែងចែកជាប្រភេទ និងការបំបែកប្រជាជនថ្មីបែបរើសអើសរបស់ ប.ក.ក ដែល "ត្រូវបានជ្រួតជ្រាបយ៉ាងទូលំទូលាយ និងត្រូវបានគេស្គាល់ និងអនុវត្តយ៉ាងទូលំទូលាយនៅទូទាំងស្រុកត្រាំកក់"[2696] និង (ii) ដែលការរើសអើង*តាមព្រឹត្តន័យ* បានកើតមានឡើងដោយសារការបែងចែកជាប្រភេទជាប្រជាជនថ្មី ពោលគឺជាក្រុមគោលដៅនៃ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" ដែលត្រូវបានកំណត់ដោយ ប.ក.ក ដោយមូលហេតុនយោបាយ[2697] ដោយមិនគិតថាតើមនុស្សផ្សេងទៀតបានទទួលរងផលប៉ះពាល់ដោយអំពើដូចគ្នាទាំងនោះដែរ ឬយ៉ាងណា[2698]។

---

[2694] <u>មូលដ្ឋានទី ១០៧ ៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ប្រជាជនថ្មីមិនត្រូវបានធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ* កថាខណ្ឌ ៧២៧-៧៤២។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤០-៤១ (ភាសាអង់គ្លេស) ទំព័រ ៣៧ (ភាសាបារាំង) ទំព័រ ៥៧ (ភាសាខ្មែរ)។ ទាក់ទងនឹងមូលដ្ឋានបណ្តឹងសាទុក្ខសាជាថ្មីរបស់ម្ចាស់បណ្តឹងសាទុក្ខនៅឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២៧ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៩, ៦៣ និង ៦៧, ៧១, ៧៣, ៧៤ (វិសាលភាពនៃបណ្តឹងសម្រាប់អង្គហេតុនៃការរើសអើង)។

[2695] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[2696] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៧ ជើងទំព័រ ៤០០៨ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០០៤-១០០៧។ សូមមើលផងដែរ កថាខណ្ឌ ៩៨០-១០០៣, ១០០៥។

[2697] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៤, ៧១៨, ១១៧៤, ១១៧៨។ *ផ្ទុយពី* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣៣-៧៣៤, ៧៣៧, ៧៣៩, ៧៤១។

[2698] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

789. ម្ចាស់បណ្តឹងសាទុក្ខមិនបានដឹងថា អ.ជ.ស.ដ *ពិតជា* ពិចារណាលើភ័ស្តុតាងដោះបន្ទុក[2699] ដែលបានបង្ហាញថា មាន "ការកំណត់យ៉ាងទូលំទូលាយអំពីរបបអាហារស្មើគ្នាសម្រាប់ប្រជាជនផ្សេងៗ"[2700] មុនពេល អ.ជ.ស.ដ បានសន្និដ្ឋានថា ប្រជាជនថ្មីបានទទួលអាហារតិចជាងប្រជាជនផ្សេងទៀតនៅក្នុងស្រុក[2701]។ អ.ជ.ស.ដ បានដាក់បន្ទុកបន្ថែមទៀតទៅលើសក្ខីកម្មដោះបន្ទុក ពីព្រោះការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងទាំងនោះ (i) "គួរឱ្យជឿជាក់"[2702] និង (ii) មានភាពស៊ីចង្វាក់គ្នាទៅនឹងឯកសារសហកាលដែលមានតម្លៃខ្ពស់ ពីរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែល "ប.ក.ក បានកំណត់របបអាហារផ្សេងៗគ្នាសម្រាប់ប្រភេទមនុស្សខុសៗគ្នា ដោយផ្អែកលើវណ្ណៈរបស់ពួកគេ" ដែលម្ចាស់បណ្តឹងសាទុក្ខមិនជំទាស់[2703]។

790. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខជំទាស់តែសក្ខីកម្មដាក់បន្ទុកតែពីរប៉ុណ្ណោះក្នុងចំណោមសក្ខីកម្មដាក់បន្ទុកទាំងនេះ ពោលគឺសក្ខីកម្មរបស់ តាក សាន់ និងសក្ខីកម្មរបស់ ពេជ្រ ជឹម ដោយធ្វើការអះអាងដែលពុំអាចឱ្យជឿបាន ដែលមិនអើពើទៅនឹងការគោរពដែលត្រូវបានផ្តល់ជូនដល់ការវាយតម្លៃនៃភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាននៃភ័ស្តុតាងដែលដាក់នៅចំពោះមុខខ្លួន[2704]។ ការជំទាស់តវ៉ាដែលពុំមានមូលដ្ឋានសំអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងភាព

---

[2699] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៤ (សៅ ប៉ាន), ១០១៦ (ពេជ្រ ជឹម, ជាំង ស្រីមុំ)។ ភ័ស្តុតាងរបស់ នាង អ៊ួច ដែលថា "ផ្ទះបាយខ្លះមិនមានអាហារគ្រប់គ្រាន់សម្រាប់ឱ្យប្រជាជនហូប" *មិនមែន* ជាការដោះបន្ទុកទេ ពីព្រោះ អ.ជ.ស.ដ បានយល់ឃើញថា វា *ស្ថិត* នៅក្នុងបរិយាកាសទូទៅនៃការដែលមិនមានអាហារគ្រប់គ្រាន់ក្នុងស្រុកត្រាំកក់ ដែលប្រជាជនថ្មីបានទទួលអាហារតិចជាងប្រជាជនផ្សេងទៀត។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣២៥៣ (*ដកស្រង់ ក្នុងចំណោមនោះ* ឯកសារ **E1/274.1** នាង អ៊ួច ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥, ម៉ោង 09.33.23-09.35.55 ទំព័រ ៩ បន្ទាត់ ១៨-១៩), កថាខណ្ឌ ១០១៦ ("បរិមាណអាហារជាទូទៅនៅក្នុងស្រុកត្រាំកក់តិច ជាង [...] បរិមាណដែលមេដឹកនាំ ប.ក.ក បានទទួលស្គាល់យ៉ាងច្បាស់ថា ចាំបាច់សម្រាប់រក្សាជីវិតប្រជាជន"), ១១៤២។ សូមមើលផងដែរ បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចដែលមានសំអាងហេតុ)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣០។

[2700] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦។

[2701] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៧ (សេចក្តីសន្និដ្ឋានលើអង្គច្បាប់)។ សូមមើលផងដែរ កថាខណ្ឌ ១០១៦ (ការសន្និដ្ឋានលើអង្គហេតុ)។

[2702] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ (ការសន្និដ្ឋានលើអង្គហេតុ)។

[2703] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៩។ សូមមើលផងដែរ កថាខណ្ឌ ១០០៨, ១១៧៧ (ជើងទំព័រ ៤០០៤ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០០៩)។

[2704] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២៩។

អាចជឿជាក់បានរបស់ តាក សាន់ គឺមិនបានអើពើដែលថា ភ័ស្តុតាងរបស់គាត់ផ្អែកទៅលើ អ្វីដែលគាត់បានឃើញ និងបានជួបប្រទះនៅពេលគាត់ និងប្រជាជនថ្មីផ្សេងទៀតហូបជាមួយ ប្រជាជនមូលដ្ឋាន[2705]។ ទាក់ទងនឹង ពេជ្រ ជឹម ម្ចាស់បណ្តឹងសាទុក្ខខកខានក្នុងការយល់ដឹងថា សាក្សីបាន "ចុះពិនិត្យមើលឃើញ" ប្រជាជនថ្មីដែលទទួលបានអាហារតិច*នៅក្នុង*ស្រុក[2706] *នៅពេលដែល*គាត់នៅជាគណៈស្រុក[2707] និងបានដឹងថា "ហើយដែលឃ្លានជាងគេ បងប្អូនមកថ្មី មានម្នាក់គាត់ហូបដល់សន្លប់"[2708]។ ការរើងអើងនេះមិនមែនជាការសម្ងាត់ទេ ប៉ុន្តែអាចសង្កេតមើលឃើញ និងត្រូវបានដឹងដោយ ពេជ្រ ជឹម និងមនុស្សផ្សេងទៀតដែលបានរស់នៅក្នុងស្រុក និងបានផ្តល់សក្ខីកម្មអំពីអង្គហេតុនេះ ដែលសក្ខីកម្មចំនួនពីរក្នុងចំណោមសក្ខីកម្មរបស់អ្នកទាំងនោះ ម្ចាស់បណ្តឹងសាទុក្ខមិនជំទាស់ឡើយ[2709]។ វាមិនពាក់ព័ន្ធនោះទេថា តើអ្នកណាបានកំណត់ការបែងចែកមិនស្មើគ្នា ដែល ពេជ្រ ជឹម បានឃើញ ពីព្រោះវាគឺជាគោលនយោបាយរបស់ ប.ក.ក ដើម្បីកំណត់របបអាហារផ្សេងគ្នាសម្រាប់ប្រភេទមនុស្សផ្សេងគ្នា[2710] ហើយ ពេជ្រ ជឹម បានផ្តល់ភ័ស្តុតាង

---

[2705] ឯកសារ **E1/286.1** តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥, ម៉ោង 14.12.18-14.16.54 ទំព័រ ៣៧ បន្ទាត់ ៤-៥, ៨, ១១-១២, ១៧-១៩។

[2706] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣២៥២ *ដោយដកស្រង់* ឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 14.01.04-14.03.30 ទំព័រ ៤២ បន្ទាត់ ១៩-ទំព័រ ៤៣ បន្ទាត់ ៣។

[2707] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១៨។ ការទទួលខុសត្រូវរបស់ ពេជ្រ ជឹម រួមមានការទទួលខុសត្រូវលើសេដ្ឋកិច្ច និងផលិតកម្ម និង "ដល់សព្វឃុំ មើលរាល់ថ្ងៃ" តាមរយៈការចុះទៅពិនិត្យមើលដល់ទីកន្លែងផ្ទាល់ និងរបាយការណ៍។ សូមមើល ឯកសារ **E1/289.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥, ម៉ោង 15.24.34-15.26.39 ទំព័រ ៦០ បន្ទាត់ ៣-៤។ ឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 09.38.45-09.41.41 ទំព័រ ១១ បន្ទាត់ ១២-១៣, ម៉ោង 14.26.27-14.28.57 ទំព័រ ៤៨ បន្ទាត់ ១៦-១៩ (ការផ្គត់ផ្គង់អាហារនៅមន្ទីរពេទ្យស្រុក), ម៉ោង 09.53.27-09.55.20 ទំព័រ ១៤ បន្ទាត់ ១៤-១៦ (ចុះទៅពិនិត្យមើលភូមិគុស), ម៉ោង 09.47.03-09.50.37 ទំព័រ ១៣ បន្ទាត់ ២-៥, ១០-១២, ២៤-២៥-ទំព័រ ១៤ បន្ទាត់ ១-២ (ចុះទៅពិនិត្យមើលអង្គភាពដែលខ្វះខាតអាហារ), ក្រោយម៉ោង 10.10.25-10.12.46 ទំព័រ ១៨ បន្ទាត់ ១៩-២២, ម៉ោង 10.12.46-10.36.40 ទំព័រ ១៩ បន្ទាត់ ១៣-១៤, ម៉ោង 09.41.46-09.44.45 ទំព័រ ១២ បន្ទាត់ ៣-៥ (ការរាយការណ៍របស់ស្រុកត្រឹមត្រូវទៅកាន់ថ្នាក់លើពីផ្នែកសេដ្ឋកិច្ច ដោយមានជំនួយពីប្រធានកង)។

[2708] ឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ២០១៥, ម៉ោង 13.46.26-13.50.41 ទំព័រ ៣៩ បន្ទាត់ ១៥-១៦ (គូសបញ្ជាក់បន្ថែម)។

[2709] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ (កែវ ចាន់ដារ៉ា, តាក សាន់, ជូ គឹមឡូន)។ ម្ចាស់បណ្តឹងសាទុក្ខមិនជំទាស់ទៅនឹងភ័ស្តុតាងរបស់ កែវ ចាន់ដារ៉ា និង ជូ គឹមឡូន។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧២៩។

[2710] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣២៦០ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០០៩។

ដែលបង្ហាញពីការការខុកខានរបស់គណៈស្រុកក្នុងការចាត់វិធានការសមស្រប ដើម្បីបង្ការ និងដាក់ទោសទណ្ឌដល់ការរើសអើងជាក់ស្តែង[2711]។

791. ដោយសារការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងបែបសក្ខីកម្មមួយចំនួន អំពីភាពខុសគ្នាក្នុងការទទួលបានអាហារ ដែលស្របតាមគោលនយោបាយស្តីពីរបបអាហាររបស់ ប.ក.ក ដែលបានលើកឡើងខាងលើ និងភ័ស្តុតាងនៃផលវិបាកពីការគំរាមដល់ជីវិតសម្រាប់ប្រជាជនថ្មី ប្រសិនបើពួកគេព្យាយាមសុំអាហារបន្ថែមនោះ[2712] ម្ចាស់បណ្តឹងសាទុក្ខខុកខានក្នុងការយល់ដឹងថា អ.ជ.ស.ដ បានពឹងផ្អែកលើបទសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជារបស់ រៀល សន ដើម្បី "*គាំទ្របន្ថែមទៀត*" ដល់ភ័ស្តុតាងបែបសក្ខីកម្ម និងឯកសារដែលខ្លាំង[2713]។ ការបកស្រាយភ័ស្តុតាងយ៉ាងតឹងរ៉ឹងផ្សេងទៀតរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងបទសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញបន្ថែមទៀតថាមិនមានកំហុសនៅក្នុងការប្រើប្រាស់ភ័ស្តុតាងរបស់ អ.ជ.ស.ដ សម្រាប់សេចក្តីសន្និដ្ឋានកាន់តែទូលំទូលាយអំពី "*ភាពខុសគ្នាក្នុងការទទួលបានអាហារ*"[2714] នោះទេ។

792. ម្ចាស់បណ្តឹងសាទុក្ខយល់ច្រឡំទៅលើការយល់ឃើញផ្នែកអង្គច្បាប់របស់ អ.ជ.ស.ដ ដែលថាប្រជាជនថ្មី "ជាពិសេស បានរងគ្រោះ និងស្លាប់ដោយសារជំងឺកង្វះអាហារូបត្ថម្ភ ខណៈដែលប្រជាជនមូលដ្ឋានហាក់ដូចជាមិនខ្វះអាហារូបត្ថម្ភទេ" ដោយផ្អែក "ទាំងស្រុង" លើបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[2715]។ ការរងគ្រោះរបស់ប្រជាជនថ្មី ក៏ផ្អែកផងដែរលើសក្ខីកម្មដូចដែលបានបញ្ជាក់ខាងលើ ដែលថា ប្រជាជនថ្មីបានទទួលអាហារតិចជាងប្រជាជនមូលដ្ឋានក្នុងបរិយាកាសដែលអាហារ "បានតិចជាង [...] បរិមាណដែលមេដឹកនាំ ប.ក.ក បានទទួលស្គាល់

[2711] ឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 09.57.00-10.01.36 ទំព័រ ១៥ បន្ទាត់ ១១-១២, ១៤-១៥, ១៨-១៩-ទំព័រ ១៦ បន្ទាត់ ១-៣, ម៉ោង 14.01.04-14.03.30 ទំព័រ ៤២ បន្ទាត់ ២៤-២៥-ទំព័រ ៤៣ បន្ទាត់ ១-៤។

[2712] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៤៩៣-៣៤៩៧ (អ៊ឹម វណ្ណៈ, ភ្លៅ យ៉ាវ, កំណត់ត្រាស្រុកត្រាំកក់, អ៊ឹម សារឿន)។ សូមមើលផងដែរ ជើងទំព័រ ៣៤៩៨។

[2713] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ (គូសបញ្ជាក់បន្ថែម)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣១។

[2714] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣១ (គូសបញ្ជាក់បន្ថែម)។

[2715] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៧។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ៣១ ដែលផ្ទុយពី ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣១។

យ៉ាងច្បាស់ថាចាំបាច់សម្រាប់រក្សាជីវិតប្រជាជននោះ"[2716]។ លើសពីនោះទៀត ប្រជាជនថ្មីដែលស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ ក៏បានផ្អែកលើសក្ខីកម្មរបស់ រៀល សន អតីតអនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់ផងដែរ[2717]។

793. ម្ចាស់បណ្តឹងសាទុក្ខបកស្រាយសាលក្រមនេះយ៉ាងចង្អៀត ក្នុងការជំទាស់ដោយខុសឆ្គងទៅនឹងការយល់ឃើញផ្នែកអង្គច្បាប់របស់ អ.ជ.ស.ដ ដែលថា "លក្ខខណ្ឌការងារប្រែប្រួលអាស្រ័យលើប្រភេទបុគ្គល ដោយបុគ្គលពេញសិទ្ធិជាទូទៅមានលក្ខខណ្ឌការងារប្រសើរជាង"[2718]។ កំណត់សម្គាល់យោងនៃការសន្និដ្ឋាននេះ ទៅលើការយល់ឃើញផ្នែកអង្គហេតុរបស់ អ.ជ.ស.ដ អំពីលក្ខខណ្ឌការងារទូទៅនៅក្នុងស្រុកត្រាំកក់ ដែលម្ចាស់បណ្តឹងសាទុក្ខមិនបានឱ្យតម្លៃនោះ មិនពាក់ព័ន្ធទាំងស្រុងទៅនឹងប្រជាជនថ្មីនោះឡើយ[2719] និងត្រូវបកស្រាយការយល់ឃើញផ្នែកអង្គហេតុរបស់ អ.ជ.ស.ដ ក្នុងបរិបទទូលាយ ពាក់ព័ន្ធនឹងការកំណត់ប្រភេទប្រជាជនរបស់ ប.ក.ក និងការអនុវត្តការងារកំណត់ប្រភេទប្រជាជននៅក្នុងស្រុកនេះ[2720]។

---

[2716] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៦ ជើងទំព័រ ៣២៦១ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០០៨។ សូមមើលផងដែរ ជើងទំព័រ ៤០០៥ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០១៦។

[2717] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣២៥៩ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០៤៧។ ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខចង់ដេញដោលលើភ័ស្តុតាងរបស់ រៀល សន ក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤៧ តាមរយៈមូលដ្ឋានបណ្តឹងសារទុក្ខរបស់ខ្លួនផ្សេងទៀតវិញនោះ ម្ចាស់បណ្តឹងសាទុក្ខនឹងមិនអាចបញ្ជាក់ពីចេតនារបស់ខ្លួនក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣១ ដោយមានកំណត់សម្គាល់យោងទៅកថាខណ្ឌផ្សេងទៀតក្នុងសារណារបស់ខ្លួន។ ម្យ៉ាងវិញទៀត *សូមមើលផងដែរ* មូលដ្ឋានទី ១០១ (ការស្លាប់ដោយសារលក្ខខណ្ឌនានា)។

[2718] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៧។ បណ្តឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ រួមមានកំហុសអង្គច្បាប់ដែលត្រូវបានចោទប្រកាន់ ដែលគាត់មិនបានបង្ហាញភ័ស្តុតាង។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបានលើកឡើងថា អ.ជ.ស.ដ "បានប្រព្រឹត្តកំហុសអង្គច្បាប់ [...] ដោយពុំបានចង្អុលបង្ហាញថា តើលក្ខខណ្ឌអាក្រក់ជាងសម្រាប់ប្រជាជនថ្មីបែបដូចម្តេចទៅ" ដោយមិនបានពន្យល់ថា តើបណ្តឹងតវ៉ារបស់គាត់បង្កើតបានជាកំហុសអង្គច្បាប់ដែរឬទេ។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣២-៧៣៤។

[2719] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣៣ (មាស សុខា) ៧៣៤ (ឯក ហឿន)។

[2720] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចំណុច ១០.១.៧.៤ ៖ លក្ខខណ្ឌការងារ, ១០.១.៧.២ ៖ ការកំណត់ប្រភេទប្រជាជន ៖ ប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងប្រជាជនបញ្ញើ។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣២ (សៅ ហ៊ាន, ប៊ុន សារឿន, តាក សាន់, អៀម យេន) ៧៣៤ (រី ពៅ, នុត នូវ)។

794. ជាផ្នែកមួយនៃបរិបទទូលាយ អ.ជ.ស.ដ យល់ឃើញថា (i) គណៈកម្មាធិការអចិន្ត្រៃយ៍តម្រូវឱ្យប្រជាជនថ្មី "រណបសហករណ៍"[2721] (ii) ប្រជាជនថ្មីត្រូវបានកំណត់ប្រភេទជា "ប្រជាជនបញ្ញើ" នៅក្នុងស្រុកនេះ[2722] (iii) ប្រជាជនថ្មីត្រូវបានដាក់ក្នុងសហករណ៍ដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន[2723] និង (iv) "តួនាទីដែលមានអំណាច ឬតួនាទីក្នុងការត្រួតពិនិត្យ [ដូចជា ប្រធានកង ឬប្រធានក្រុមនៅក្នុងកងមួយ] ក៏ត្រូវបានរក្សាទុកសម្រាប់តែសមាជិកពេញសិទ្ធិប៉ុណ្ណោះ ដូចជាប្រជាជនមូលដ្ឋាន ដែលត្រូវបានចាត់ទុកថាមានប្រវត្តិរូបស្អាតល្អជាដើម"[2724]។ អ.ជ.ស.ដ បានកំណត់សក្ខីកម្មមួយចំនួន ដែល*ក្នុងចំណោមនោះ* បានចង្អុលបង្ហាញថា សមាជិកពេញសិទ្ធិគ្រប់គ្រងការងាររបស់ប្រជាជនថ្មី និងធ្វើឱ្យប្រជាជនទាំងនោះប្រឹងប្រែងធ្វើការ[2725]។ ជាពិសេស រី ពៅ ដែលជាខ្មែរកម្ពុជាក្រោមមកពីប្រទេសវៀតណាម ដែលបានធ្វើការជាមួយប្រជាជនថ្មី បាននិយាយថា អ្នកគ្រប់គ្រងរបស់ពួកគាត់ " [...] គេបញ្ជាលើយើង ទាំងពីការធ្វើការ ទាំងពីដេក ដើរឈរ អង្គុយ ប្លុករួមទាំងអស់នៅលើគេហ្នឹង" [2726]។ ការពិតដែលថា សមាជិកពេញសិទ្ធិជាទូទៅមានលក្ខខណ្ឌការងារប្រសើរជាងប្រជាជនថ្មី ត្រូវបានចង្អុលបញ្ជាក់បន្ថែមដោយសក្ខីកម្មពាក់ព័ន្ធនានា ដែល អ.ជ.ស.ដ បានកត់សម្គាល់ឃើញថាជាផ្នែកមួយនៃការយល់ឃើញផ្នែកអង្គហេតុរបស់ខ្លួនអំពីលក្ខខណ្ឌការងារទូទៅនៅក្នុងស្រុកនេះ រួមបញ្ចូលទាំងកងយុវជនចល័តផងដែរ[2727] និងត្រូវបានបញ្ជាក់ដោយសក្ខីកម្ម និងរបាយការណ៍ផ្សេងៗទៀតរបស់ស្រុកត្រាំកក់[2728]។

---

[2721] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៨១ (ទាក់ទិននឹងឯកសារ **E3/216** កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ KH 00008488)។ សូមមើលផងដែរ កថាខណ្ឌ ១១៧៦។

[2722] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៩៨, ១១៧៦។ សូមមើលផងដែរ កថាខណ្ឌ ១០០៤។

[2723] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៩៩។ សូមមើលផងដែរ កថាខណ្ឌ ១០០០-១០០៥, ១១៧៦។

[2724] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៤, ១០០២។ សូមមើលផងដែរ កថាខណ្ឌ ៩៩៦, ១០០៥។

[2725] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣១៦៨។ សូមមើលផងដែរ កថាខណ្ឌ ១០០៥។

[2726] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣១៦៨ *ដោយដកស្រង់ ក្នុងចំណោមនោះ* ឯកសារ **E1/262.1** រី ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥, ម៉ោង 09.44.28-09.47.04 ទំព័រ ១២-១៣ បន្ទាត់ ២៤-២។ សូមមើលផងដែរ ម៉ោង 09.41.21-09.44.28 ទំព័រ ១២ បន្ទាត់ ៤-១០, ១៤-១៥, ម៉ោង 13.55.58-13.58.15 ទំព័រ ៥០-៥១ បន្ទាត់ ៣-១០, ម៉ោង 13.58.45-14.00.12 ទំព័រ ៥១-៥២ បន្ទាត់ ១-៥។

[2727] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១៨ (*ឧទាហរណ៍* សៅ ប៊ាន, តាក សាន់, អៀម យេន), ១០១៩ (*ឧទាហរណ៍* ឯម គឿង), ១០២០ (*ឧទាហរណ៍* រី ពៅ, នុត នូវ)។

[2728] <u>លក្ខណៈនៃការងារ៖</u> *ឧទាហរណ៍* ឯកសារ **E1/288.1** អ៊ុំ វណ្ណៈ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 15.27.45-15.30.00 ទំព័រ ៧៥ បន្ទាត់ ១១ (*សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ

795. ស្រដៀងគ្នានេះដែរ ការជំទាស់ដោយគ្មានមូលដ្ឋានចំពោះការយល់ឃើញផ្នែកអង្គច្បាប់របស់ អ.ជ.ស.ដ អំពីការប្រព្រឹត្តដ៏រន្ធត់លើប្រជាជនថ្មី ព្រងើយកន្តើយដល់ផលប៉ះពាល់នៃការរើសអើងដែលបានប្រព្រឹត្តចំពោះពួកគេតាមរយៈការបំបែកចេញ និងដាក់នៅក្រោមបង្គាប់របស់ប្រជាជនមូលដ្ឋាន[2729]។ អ.ជ.ស.ដ បានសម្រេចនៅក្នុងការយល់ឃើញផ្នែកអង្គហេតុរបស់ខ្លួនថា "គោលបំណងច្បាស់លាស់នៃការបែងចែកប្រជាជន [...] គឺដើម្បីពង្រឹងការគ្រប់គ្រងទៅលើ"ពួកគេ[2730]។ ប្រជាជនថ្មី "គឺជាខ្មាំង ហើយមិនមានតម្លៃដូចជាប្រជាជនមូលដ្ឋានទេ ហើយប្រជាជនមូលដ្ឋានត្រូវបានណែនាំឱ្យតាមឃ្លាំមើលប្រជាជនថ្មី"[2731]។ ដូច្នេះ ការបំបែកប្រជាជនថ្មីចេញ គឺដើម្បី "កុំឱ្យមានការយល់ច្រឡំបន្តទៀត" នៅពេល "វាយតម្លៃទៅលើអំពើ និងអាកប្បកិរិយារបស់មនុស្សម្នាក់ៗ"[2732]។

796. អាស្រ័យហេតុនេះ អ.ជ.ស.ដ មានហេតុផលសមស្របក្នុងការពឹងផ្អែកលើសក្ខីកម្មរបស់ អ៊ឹម វណ្ណៈ និង តាក សាន់ អំពីការធ្វើទុក្ខទោស ពីព្រោះពួកគេបានចង្អុលបង្ហាញថា ពួកគេ និងប្រជាជនថ្មីផ្សេងទៀតនៅក្នុងអង្គភាពដែលត្រូវបានបំបែកចេញ ត្រូវបានអ្នកគ្រប់គ្រងកំណត់គោលដៅដោយប្រើប្រាស់ភាព "ពេញសិទ្ធិ" របស់ខ្លួនក្នុងការដកហូតអាហារ ដែលជាការគំរាមកំហែង ឬការដាក់ទណ្ឌកម្មចំពោះការធ្វើការងារមិនគ្រប់ផែនការកំណត់[2733]។ អំពើរើសអើងនេះបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើប្រជាជនថ្មី ពីព្រោះ ដូចបានពន្យល់ផ្នែកខាងលើ របបអាហាររបស់ពួកគេ គឺតិច

---

៣១៧៦)។ ឯកសារ **E1/252.1** ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥, ម៉ោង 11.22.03-11.24.19 ទំព័រ ៣៩ បន្ទាត់ ១៣-១៥។ <u>ភាពតឹងតែងនៃការងារ</u>៖ *ឧទាហរណ៍* ឯកសារ **E1/252.1** ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥, ម៉ោង 11.22.03-11.24.19 ទំព័រ ៣៩ បន្ទាត់ ១៥-១៦។ ឯកសារ **E3/2441** របាយការណ៍រវាងឃុំ និងស្រុក និងក្រាំងតាចាន់ KH 00270961, 00270958។ ឯកសារ **E1/283.1** អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥, ម៉ោង 09.15.59-09.20.00 ទំព័រ ៥ បន្ទាត់ ២០-២១។

[2729] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៣៥-៧៣៨។

[2730] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៥។ សូមមើលផងដែរ កថាខណ្ឌ ៩៨៣ (សមាជិករបស់សហករណ៍ទទួលខុសត្រូវក្នុងការចាត់ចែងការងារអប់រំដល់អ្នកដែលត្រូវបានគេជម្លៀសមក និងលត់ដំពួកគេ), ១០២៣។

[2731] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៧ (ដោយធ្វើការសង្ខេបភ័ស្តុតាងរបស់ ឃឹម ហឿន)។

[2732] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៨៩, ៩៩៦។

[2733] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២៣ ដោយរួមបញ្ចូលទាំងជើងទំព័រ ៣២៩០-៣២៩១។ ទាក់ទិននឹង អ៊ឹម វណ្ណៈ និង តាក សាន់ ដែលជាផ្នែកមួយនៃប្រជាជនថ្មី *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨២៤-៨២៥។ ឯកសារ **E1/286.1** តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥, ម៉ោង 14.12.18-14.14.04 ទំព័រ ៣៧ បន្ទាត់ ៤-៥។ *ផ្ទុយពី* **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៣៥។

ជាងរបបអាហាររបស់ប្រជាជនមូលដ្ឋាន ហើយពួកគេត្រូវបានបង្ខំឱ្យធ្វើការខ្លាំងជាងសមាជិកពេញសិទ្ធិ។

797. លើសពីនេះទៀត ផ្ទុយពីការអះអាងមិនត្រឹមត្រូវរបស់ម្ចាស់បណ្ដឹងសាទុក្ខ[2734] ការអានជារួមលើភ័ស្តុតាងរបស់ រី ពៅ ចង្អុលបង្ហាញថា ប្រជាជនថ្មីនៅក្នុងអង្គភាពរបស់គាត់ ត្រូវបានចាត់ទុកថាជា "ទាសករគ្មានតម្លៃ" ពីព្រោះពួកគេធ្វើការងារដោយបង្ខំ[2735] នៅក្នុងបរិយាកាសដែលប្រជាជនមូលដ្ឋានជាប្រធានកងដែលមានសមាជិក ៥០ នាក់ ឬប្រធានក្រុមនៅក្នុងកងទាំងនោះ[2736] ត្រួតពិនិត្យមើលគ្រប់ចលនារបស់ពួកគេ រួមទាំងរបបអាហារដែលពួកគេអាចបរិភោគទៀតផង[2737]។ ការណ៍នេះត្រូវបានបញ្ជាក់ដោយ អ៊ឹម វណ្ណៈ ដែលបាននិយាយថា គាត់បានទទួលរងការវាយដំពីសំណាក់កុមារមូលដ្ឋាន ដោយសារការស្វែងរកអាហារបន្ថែម និងទៅលេងឪពុកម្ដាយរបស់គាត់ និងថា ប្រជាជនថ្មីផ្សេងទៀតនៅក្នុងកងរបស់គាត់ក៏ទទួលរងការវាយដំផងដែរ[2738]។ ដោយពិចារណាលើភ័ស្តុតាងនេះ បណ្ដឹងផ្សេងៗទៀតរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីសក្ខីកម្មរបស់ រី ពៅ មិនមានមូលដ្ឋានច្បាស់លាស់ទេ[2739]។

798. ចុងបញ្ចប់ ម្ចាស់បណ្ដឹងសាទុក្ខមិនបានចង្អុលបង្ហាញថា ការយល់ឃើញផ្នែកអង្គច្បាប់របស់ អ.ជ.ស.ដ ដែលថា "ប្រជាជនថ្មី [...] និងអ្នកផ្សេងទៀត ដែលគេយល់ថា មានការគំរាមកំហែងដល់ ប.ក.ក ត្រូវបានគេកំណត់គោលដៅ ដោយមានការចាប់ខ្លួនពីបទមានគំនិត ពាក្យសម្ដី ឬការ

---

[2734] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៣៧។

[2735] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៧ ជើងទំព័រ ៤០០៧ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ១០២៣។ ឯកសារ **E1/262.1** រី ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥, ម៉ោង 09.41.21-09.44.28 ទំព័រ ១២ បន្ទាត់ ៥-៦, ម៉ោង 10.00.17-10.01.56 ទំព័រ ១៧ បន្ទាត់ ១៩-២០ ទំព័រ ១៨ បន្ទាត់ ២-៣។

[2736] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២៣។ ឯកសារ **E1/262.1** រី ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥, ម៉ោង 09.44.28-09.47.04 ទំព័រ ១២ បន្ទាត់ ២៣-២៥, ម៉ោង 13.55.58-13.58.15 ទំព័រ ៥១ បន្ទាត់ ៧-៨។

[2737] ឯកសារ **E1/262.1** រី ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥, ម៉ោង 09.41.21-09.44.28 ទំព័រ ១២ បន្ទាត់ ៤-១០, ម៉ោង 09.44.28-09.47.04 ទំព័រ ១៣ បន្ទាត់ ១-២។

[2738] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២៣។ ឯកសារ **E1/288.1** អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥, ម៉ោង 13.46.56-13.54.18 ទំព័រ ៤៩ បន្ទាត់ ១-២៥ ទំព័រ ៥០ បន្ទាត់ ៣-៥, ម៉ោង 14.17.50-14.23.12 ទំព័រ ៥៨ បន្ទាត់ ៨-១៨ ទំព័រ៥៩ បន្ទាត់ ១-៣, ម៉ោង 14.36.10-14.37.53 ទំព័រ ៦៤ បន្ទាត់ ១-២។

[2739] ទាក់ទិននឹងបណ្ដឹងតវ៉ារបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អាកប្បកិរិយារបស់ប្រជាជនមូលដ្ឋានដែល ពៅ រី បានពិពណ៌នា គឺផ្ទុយទៅនឹងគោលនយោបាយរបស់ ប.ក.ក *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៣៧។

ប្រព្រឹត្តដោយសោះអង្គើយ ដែលគេចាត់ទុកថា ផ្ទុយទៅនឹងបដិវត្តន៍" មិនធ្វើឱ្យឃ្លាតឆ្ងាយពីការពិត ដែលថា ប្រជាជនថ្មីបានទទួលរងនូវការរើសអើង*តាមព្រឹត្តិហេតុ* (ជាក់ស្តែង)*ឡើយ*[2740]។ ដូចបាន រៀបរាប់ នៅខាងលើ ស្ថានភាពដាក់ប្រជាជនថ្មីនៅក្រោមបង្គាប់ប្រជាជនមូលដ្ឋាន និងការណែនាំ របស់ស្រុកដល់ឃុំឱ្យប្រជាជនមូលដ្ឋានតាមឃ្លាំមើលប្រជាជនថ្មីដោយសារតែពួកគេគឺជាខ្មាំង[2741] បណ្តាលឱ្យប្រជាជនថ្មីត្រូវបានគេតាមដានជាពិសេស និង "ងាយនឹងត្រូវគេចាប់ខ្លួនបំផុត" [2742]។

799. ហេតុដូចនេះ អ.ជ.ស.ដ បានពឹងផ្អែកដោយសមហេតុផលទៅលើសក្ខីកម្មរបស់ ថាន់ ធីម និង វង សារុន ពីព្រោះពួកគេបានផ្តល់ភ័ស្តុតាងថា ប្រជាជនថ្មីត្រូវបានតាមដាន "រហូត" ដោយសារ ប្រភេទថ្នាក់ទាបរបស់ពួកគេ[2743]។ ថាន់ ធីម ក៏បានលើកឡើងផងដែរថា ប្រជាជនមូលដ្ឋាន "អត់ ដែល" ទុកចិត្តពួកគេឡើយ ហើយតាមសួរពួកគេរហូត[2744]។ គ្មានចៅក្រមមានវិចារណញ្ញាណ ណាម្នាក់នឹងយល់ឃើញថា ភ័ស្តុតាងតាមរយៈការឮតពីគេរបស់ វង សារុន មានតម្លៃតិចតួចបំផុត [2745] នោះទេ ជាពិសេសដោយសារ អ.ជ.ស.ដ បានទទួលស្គាល់ភ័ស្តុតាងផ្សេងទៀត ដែលរួមមាន កំណត់ត្រាស្រុកត្រាំកក់ ដែលបញ្ជាក់អំពីគាត់ និងភ័ស្តុតាងរបស់ ថាន់ ធីម[2746]។ ទាក់ទងនឹងភាព ងាយរងគ្រោះរបស់ប្រជាជនថ្មីទៅនឹងការចាប់ខ្លួន ម្ចាស់បណ្តឹងសាទុក្ខក៏មើលរំលងផងដែរចំពោះ

---

[2740] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣៩-៧៤១។

[2741] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៧ (ដោយធ្វើការសង្ខេបភ័ស្តុតាងរបស់ ឃឹម ហឿន)។

[2742] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨០។

[2743] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៥។ ឯកសារ **E1/289.1** ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥, ម៉ោង 10.34.06-10.36.53 ទំព័រ ២១ បន្ទាត់ ១៧-២៥-ទំព័រ ២២ បន្ទាត់ ១។ ឯកសារ **E1/300.1** វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 13.54.24-13.57.06 ទំព័រ ៤៤ បន្ទាត់ ១៤-១៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤០។

[2744] ឯកសារ **E1/289.1** ថាន់ ធីម ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥, ម៉ោង 10.34.06-10.36.53 ទំព័រ ២១ បន្ទាត់ ១៧-២៥-ទំព័រ ២២ បន្ទាត់ ១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤០។

[2745] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។ អ.ជ.ស.ដ ក៏បានដឹងថា ប.ក.ក បានប្រតិបត្តិការក្នុង វប្បធម៌សង្គមមួយ។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២, ៣៦២, ៣៩៨, ៤៥៩, ៦២៣។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤០។

[2746] *ឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៥ (ជាំង ស្រីមុំ) ជើងទំព័រ ៣៤៧១ (ឯកសារ **E3/2441** កំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00270961 ទាក់ទងនឹងប្រជាជនថ្មីដែលត្រូវ បានតាមដាននៅពេលគាត់ដេក), ៣៤៨០, ៣៥៩១ (ការណែនាំពីឃុំឱ្យបែងចែករវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីនៅពេល តាមដាន)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣៩-៧៤១។

ការទទួលស្គាល់របស់ អ.ជ.ស.ដ នូវកំណត់ត្រាស្រុកត្រាំកក់ដែលមានតម្លៃខ្ពស់[2747] និងភស្តុតាងដែលពាក់ព័ន្ធផ្សេងទៀត[2748]។

## ២. ទំនប់១មករា

### *មូលដ្ឋានទី ១១៥៖ គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល*[2749]

800. **មូលដ្ឋានទី ១១៥ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការសន្និដ្ឋានថា មានធាតុ*ផ្សំសត្យានុម័តិ*នៃការធ្វើមនុស្សឃាតពាក់ព័ន្ធនឹងការស្លាប់ដោយសារលក្ខខណ្ឌរស់នៅនៅទំនប់១មករា។**

801. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងជាថ្មីនូវការអះអាងមិនត្រឹមត្រូវរបស់គាត់ទាក់ទងនឹង *វិសាលភាពនៃបណ្តឹង* ភាពស្របច្បាប់នៃការកំណត់អង្គហេតុឡើងវិញថាជាការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល* និងភាពអាចអនុវត្តបាននៃការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល* នៅសម័យអង្គហេតុ[2750]។ អ.ជ.ស.ដ បានទទួលយកដោយសមស្រប[2751] និងបានចាត់វិធានការក្នុងដែនសិទ្ធិអំណាចរបស់ខ្លួនក្នុងការកំណត់អង្គហេតុទាំងនេះឡើងវិញ[2752] និងនិយមន័យរបស់ *ធាតុផ្សំអត្តនោម័តិ* នៃការធ្វើមនុស្សឃាតថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលលាតសន្ធឹងដល់ *ចេតនាដោយប្រយោល* ក្នុងឆ្នាំ១៩៧៥[2753]។

802. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា *ធាតុផ្សំសត្យានុម័តិ* នៃការធ្វើមនុស្សឃាតនៅទំនប់១មករា មិនត្រូវបានបំពេញនោះ មានភាពផ្ទុយគ្នាពីសុភវិនិច្ឆ័យ និងមានមូលដ្ឋានលើការបកស្រាយសាលក្រមមិនត្រឹមត្រូវ។ គាត់ចោទប្រកាន់ថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសតាមរយៈការ

---

[2747] សូមមើល ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៣៤៧១ (ឯកសារ E3/2441 កំណត់ត្រាស្រុកត្រាំកក់ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00270961) កថាខណ្ឌ ១០៦៤, ១០៨១។ *ផ្ទុយពី* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៤១។

[2748] *ឧទាហរណ៍* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៥៥ (ចាន់ ធីម, ជាំង ស្រីមុំ)។

[2749] <u>មូលដ្ឋានទី ១១៥៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល* កថាខណ្ឌ ៧៦៨-៧៧១។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៣ (ភាសាអង់គ្លេស) ទំព័រ ៣៩ (ភាសាបារាំង) ទំព័រ ៦០-៦១ (ភាសាខ្មែរ)។

[2750] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៦៨។។

[2751] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦៨ និង ៧០។

[2752] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦។

[2753] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៦, ៨៧-៩៣។

សន្និដ្ឋានថាមានអំពើអកម្មនាំឱ្យមានពិរុទ្ធ ខណៈពេលដែលខកខានមិនបានកំណត់លក្ខណៈ និងវិសាលភាពនៃភារកិច្ចដែលត្រូវបំពេញ[2754]។ តាមពិត និងដូចដែលម្ចាស់បណ្ដឹងសាទុក្ខបានទទួលស្គាល់[2755] អ.ជ.ស.ដ បានយល់ឃើញថា *ធាតុផ្សំសត្យានុម័តិ* នៃការធ្វើមនុស្សឃាតនៅទំនប់១មករា ត្រូវបានបំពេញដោយអំពើឧក្រិដ្ឋកម្មវិជ្ជមាន ("ការដាក់ឱ្យអ្នកធ្វើការទទួលរងនូវលក្ខខណ្ឌដែលបណ្ដាលឱ្យពួកគេស្លាប់") និងការខកខានមិនបានបញ្ឈប់អំពើទាំងនេះតាមរយៈការចាត់ "វិធានការសមស្របដើម្បីផ្លាស់ប្ដូរ ឬលុបបំបាត់លក្ខខណ្ឌបែបនេះ"[2756]។ ម្ចាស់បណ្ដឹងសាទុក្ខចោទប្រកាន់បន្ថែមទៀតថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គច្បាប់ដោយខកខានមិនបានកំណត់លក្ខណៈស្របច្បាប់ថា តើហេតុអ្វីបានជាវិធានការដែលធ្វើឡើងដោយចារីផ្ទាល់ ដើម្បីធ្វើឱ្យលក្ខខណ្ឌនៅទំនប់១មករា មានភាពប្រសើរឡើង មានភាពមិនគ្រប់គ្រាន់ ដោយមិនបានដកស្រង់ភ័ស្ដុតាងនៃវិធានការបែបនេះណាមួយឡើយ[2757]។ អ.ជ.ស.ដ បានធ្វើសេចក្ដីសន្និដ្ឋានទូលំទូលាយអំពីលក្ខខណ្ឌដែលត្រូវបានដាក់នៅទំនប់១មករា និងបានយល់ឃើញដោយសមហេតុផលថាលក្ខខណ្ឌទាំងនេះបានបង្កឱ្យមានការស្លាប់អ្នកធ្វើការពីប្រាំមួយទៅដប់នាក់ ការស្លាប់ដែលបង្កឡើងដោយឧប្បត្តិហេតុ និងការស្លាប់អ្នកធ្វើការក្នុងចំនួនច្រើន[2758]។ អវត្តមានវិធានការសមស្របដើម្បីផ្លាស់ប្ដូរលក្ខខណ្ឌទាំងនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ នូវអំពើដែលគ្មានការរារាំងដែលបានដាក់ចេញដោយអាជ្ញាធរការដ្ឋាន ដូច្នេះបានបង្កឱ្យមានការស្លាប់ពេញមួយអំឡុងពេលនៃការសាងសង់ទំនប់នេះ។

---

[2754] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៧០។ ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងជាថ្មីនូវការអះអាងមិនត្រឹមត្រូវនេះទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ គឺស្រុកត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង។ សូមមើលចម្លើយតបទៅនឹងមូលដ្ឋានទី ៩៩, ១១៣, ១១៥ និង ១២៣។

[2755] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៧០ *ដោយដកស្រង់* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧២។

[2756] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧២។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៩។

[2757] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៧១។ ប្រសិនបើម្ចាស់បណ្ដឹងសាទុក្ខមានបំណងសំដៅដល់ការជំនួសកម្មាភិបាលភូមិភាគកណ្ដាលដោយកម្មាភិបាលភូមិភាគនិរតី គាត់ខកខានមិនបានធ្វើដូច្នេះទេ។ ដោយមិនគិតពីបញ្ហានេះ អ.ជ.ស.ដ បានយល់ឃើញថា ការតែងតាំងកម្មាភិបាលភូមិភាគនិរតី មិនបានធ្វើឱ្យស្ថានភាពនានាមានភាពប្រសើរឡើងវិញឡើយនៅទំនប់១មករា ប៉ុន្តែត្រូវបានចាត់ទុកដោយមនុស្សជាច្រើនថាកាន់តែមានស្ថានភាពឃោរឃៅឡើង។ *សូមមើល* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥១៩។

[2758] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១១៦។ សូមមើលផងដែរឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៣៥, ១៦០៦-១៦១០, ១៦២៦, ១៦២៩។

## *មូលដ្ឋានទី ១១៦៖ ភាពមិនសមហេតុផលនៃការកត់សម្គាល់ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាតដោយចេតនាប្រយោល*[2759]

803. **មូលដ្ឋានទី ១៦៦ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ បានប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការសន្និដ្ឋានថា *មានធាតុផ្សំសត្យានុម័តិ* នៃឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល* នៅទំនប់១មករា។**

*ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខទាក់ទងនឹងការស្លាប់របស់អ្នកធ្វើការពីប្រាំមួយទៅដប់នាក់*[2760]

804. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ជ បានប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការសន្និដ្ឋានថា អ្នកធ្វើការពីប្រាំមួយទៅដប់នាក់បានស្លាប់នៅទំនប់១មករា ដោយសារលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅ[2761] នោះ ផ្អែកទៅលើការអានសាលក្រមតាមបែបជ្រើសរើស និងមិនអើពើចំពោះការយល់ឃើញផ្នែកអង្គហេតុដែលពាក់ព័ន្ធ។ ដោយផ្អែកលើភស្តុតាងទាំងមូល អ.ជ.ស.ជ បានយល់ឃើញថា យ៉ាងហោចណាស់អ្នកធ្វើការចំនួនពីប្រាំមួយទៅដប់នាក់ "បានស្លាប់ដោយសារតែធ្វើការងារធ្ងន់ របបអាហារមិនគ្រប់គ្រាន់ និងស្ថានភាពមិនអំណោយផល ដូចជា បរិស្ថានគ្មានអនាម័យ និងឱសថមិនគ្រប់គ្រាន់ និងគ្មានប្រសិទ្ធភាព។ អ្នកធ្វើការត្រូវបានបង្ខំឱ្យធ្វើការងារហួសដែនកំណត់ជាមនុស្ស ហើយមិនទទួលបានអាហារ និងការព្យាបាលត្រឹមត្រូវគ្រប់គ្រាន់នៅពេលដែលពួកគេធ្លាក់ខ្លួនឈឺ"[2762]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា ភស្តុតាង

---

[2759] <u>មូលដ្ឋានទី ១១៦៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ភាពមិនសមហេតុផលនៃការកត់សម្គាល់ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាតដោយចេតនាប្រយោល* កថាខណ្ឌ ៧៧២-៧៨២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៤៣ (ភាសាអង់គ្លេស) ទំព័រ ៣៩ (ភាសាបារាំង) ទំព័រ ៦១ (ភាសាខ្មែរ)។

[2760] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៧៣-៧៧៨។

[2761] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៧៣។

[2762] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧០ *ដោយដកស្រង់* កថាខណ្ឌ ១៦២៦, ១៦២៩។ ភស្តុតាងបង្ហាញថា យ៉ាងហោចណាស់អ្នកធ្វើការប្រាំមួយនាក់បានស្លាប់ *សូមមើល* ជើងទំព័រ ៥៥២៩-៥៥៣១ *ដោយដកស្រង់* ឯកសារ **E1/306.1** ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 14.11.46-14.14.08 ទំព័រ ៤៥ បន្ទាត់ ៩-២២ (ដោយលើកឡើងថា គាត់បានឃើញបុរសវ័យក្មេង*ម្នាក់* បានស្លាប់ដោយសារជំងឺដែលឆ្លងពីទំនប់១មករា "គឺខ្ញុំឃើញ ខ្ញុំដឹងនឹងភ្នែកហ្នឹងណា")។ សូមមើលផងដែរ ជើងទំព័រ ៥៥៤៣ *ដោយដកស្រង់* ឯកសារ **E1/305.1** មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 13.46.46-13.49.31 ទំព័រ ៤៣ បន្ទាត់ ១១-១៣ (ដោយលើកឡើងថា មេកងរបស់គាត់បានប្រាប់គាត់ថា អ្នកនេះស្លាប់ពីព្រោះគាត់មិនអាចព្យាបាលបាន)។ ឯកសារ **E1/307.1** អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.30.00-09.36.43 ទំព័រ ១០ បន្ទាត់ ៦-១៧ (ដោយលើកឡើងថា អ្នកធ្វើការ *ពីរនាក់* ក្នុងក្រុមរបស់គាត់បានធ្លាក់ខ្លួនឈឺ ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ហើយបានបាត់ខ្លួន) និង *សូមមើល* ជើងទំព័រ ៥៥៣៣, ឯកសារ **E1/309.1**

"បានត្រឹមចង្អុលបង្ហាញថា អ្នកជំងឺត្រូវបានជម្លៀសចេញ"[2763]នោះ ភស្តុតាងបង្ហាញពីការស្លាប់៖ សាក្សីម្នាក់បានឃើញអ្នកធ្វើការម្នាក់ "ឃើញ [...] នឹងភ្នែក [របស់គាត់]" បន្ទាប់ពីអ្នកធ្វើការរូបនោះ "ឈឺពីការដ្ឋានមកតើ! ឈឺបន្តិចម្តងៗ [...] បានទៅជាទ្រុឌទ្រោម"[2764] ហើយសាក្សីម្នាក់ទៀតបានផ្តល់សក្ខីកម្មថា អ្នកធ្វើការពីរនាក់នៅក្នុងកងរបស់គាត់បានស្លាប់ដោយសារជំងឺ[2765]។ សាក្សីបន្ថែមទៀតបានលើកឡើងថា អ្នកជំងឺមួយចំនួនមកពីទំនប់១មករា "គឺបញ្ជូនទៅមន្ទីរពេទ្យ [...] ស្លាប់នៅនឹងកន្លែងពេទ្យហ្នឹងទៅ"[2766] និងបានបញ្ជាក់បំភ្លឺថា អ្នកធ្វើការដែលមិនអាចព្យាបាលបានត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ដោយសារអាជ្ញាធរមិនចង់ឱ្យមានសាកសពនៅការដ្ឋាន[2767]។

805. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខមិនទទួលបានផលទេ ដោយសារការអះអាងទាំងនោះមិនបានបំពេញនូវបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខទាល់តែសោះ ពោលគឺគ្រាន់តែមិនឯកភាពជាមួយនឹងទម្ងន់ដែលផ្តល់ទៅលើភស្តុតាងប៉ុណ្ណោះ[2768]។ អង្គជំនុំជម្រះបានដកស្រង់សាក្សី

---

អ៊ុត សេង ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 11.16.09-11.19.49 ទំព័រ ៣១ បន្ទាត់ ១២ (ដោយលើកឡើងថា មនុស្ស *ពីរ* នាក់ដែលគាត់ស្គាល់នៅក្នុងកងធ្វើការងាររបស់គាត់បានស្លាប់ដោយសារជំងឺ)។

[2763] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៧៣។

[2764] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៦ ជើងទំព័រ ៥៥២៩-៥៥៣១ *ដោយដកស្រង់* ឯកសារ **E1/306.1** ហ៊ិន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 14.11-46-14.14.08 ទំព័រ ៤៥ បន្ទាត់ ៩-២២។

[2765] ឯកសារ **E1/309.1** អ៊ុត សេង ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 11.16.09-11.19.49 ទំព័រ ៣១ បន្ទាត់ ១២។ នៅកថាខណ្ឌ ១៦២៦ អ.ជ.ស.ដ បានកត់សម្គាល់ថា អ៊ុត សេង មិនបានបញ្ជាក់ទីកន្លែងដែលអ្នកធ្វើការបានស្លាប់ទេ។

[2766] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៩ ជើងទំព័រ ៥៥៤៣ *ដោយដកស្រង់* ឯកសារ **E1/326.1** អ៊ុំ ជី ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥, ម៉ោង 13.33.18-13.35.19 ទំព័រ ៥១ បន្ទាត់ ១៩-២០។

[2767] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៩ ជើងទំព័រ ៥៥៤៣ *ដោយដកស្រង់* ឯកសារ **E1/305.1** មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 10.00.03-10.02.45 ទំព័រ ១៨ បន្ទាត់ ១២-១៥ ("គេអត់ឱ្យងាប់នៅការដ្ឋានទេ កុំឱ្យពួកចល័តអីឃើញអ៊ីចឹង បាក់ស្មារតី គេបញ្ជូនទៅពេទ្យឆ្ងាយៗបាត់")។ ក្នុងជើងទំព័រដូចគ្នា ភស្តុតាងនេះត្រូវបានបញ្ជាក់ដោយឯកសារ **E3/7775** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង អ៊ុត, KH 00229056 ("ក្នុងករណីបើមានអ្នកណាឈឺធ្ងន់ធ្ងរ គេបញ្ជូនទៅមន្ទីរពេទ្យដែលនៅឆ្ងាយពីការដ្ឋាន គេមិនទុកឱ្យស្លាប់នៅទីនោះទេ")។

[2768] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៧៤-៧៧៧។ ឧទាហរណ៍ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ស៊ូ សឿន ខ្វះភាពអាចជឿជាក់បាន បើទោះជាការពិតគឺថា អ.ជ.ស.ដ បានផ្តោតសំខាន់លើភាពអាចជឿជាក់បានរបស់គាត់នៅក្នុងសាលក្រមក្តី ដោយកត់សម្គាល់ថា អង្គជំនុំជម្រះនឹងផ្តល់ "ទម្ងន់តិចតួច" ដល់សក្ខីកម្មរបស់គាត់អំពីលក្ខខណ្ឌ និងភាពលំបាកដែលអ្នកធ្វើការបានប្រឈមនៅទំនប់១មករា, *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៨៤។ ដោយគ្មានអង្គសេចក្តី ម្ចាស់បណ្តឹងសាទុក្ខអះអាងបន្ថែមថា អ.ជ.ស.ដ "បានបំភ្លៃ" សក្ខីកម្មរបស់ អ៊ុន រ៉ន ប៉ុន្តែមិនបានបង្ហាញការបំភ្លៃណាមួយនោះទេ។

ផ្សេងគ្នាចំនួនប្រាំមួយនាក់ និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនពីរក្នុងការសន្និដ្ឋានថា "មនុស្សតិចតួចទេដែលបានស្លាប់ដោយសារជំងឺ ឬរងរបួសនៅការដ្ឋានការងារទំនប់១មករា ប៉ុន្តែជាធម្មតាអ្នកជំងឺដែលមានជំងឺធ្ងន់ត្រូវបានបញ្ជូនត្រលប់ទៅភូមិរបស់ពួកគេវិញ ឬទៅកាន់រោងព្យាបាលក្នុងមូលដ្ឋាន ហើយក្រោយមកបានស្លាប់ដោយសារតែមិនអាចព្យាបាលបាន"[2769]។ ការពិនិត្យមើលជារួមទៅលើភ័ស្តុតាងរបស់ អ.ជ.ស.ដ បាននាំឱ្យមានការសន្និដ្ឋានដោយសមហេតុផលថា យ៉ាងហោចណាស់មានអ្នកធ្វើការពីប្រាំមួយទៅដប់នាក់បានស្លាប់នៅទំនប់១មករា ដោយសារលក្ខខណ្ឌនានា ហើយអ្នកធ្វើការផ្សេងទៀតបានទទួលរងជោគវាសនាដូចគ្នានៅរោងព្យាបាល និងមន្ទីរពេទ្យ បន្ទាប់ពីបានឆ្លងកាត់ស្ថានភាពដ៏អាក្រក់របស់ការដ្ឋាននេះ[2770]។ ការមិនឯកភាពរបស់ម្ចាស់បណ្តឹងសាទុក្ខជាមួយនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ មិនគ្រប់គ្រាន់នោះឡើយក្នុងការច្រានចោលការយល់ឃើញផ្នែកអង្គហេតុ ហើយការអះអាងទាំងនេះគួរត្រូវបានបដិសេធចោល។

*ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងការស្លាប់ដែលបង្កឡើងដោយឧប្បត្តិហេតុ*[2771]

806. ម្ចាស់បណ្តឹងសាទុក្ខជាថ្មីម្តងទៀតបកស្រាយមិនត្រឹមត្រូវនូវភ័ស្តុតាងទាំងមូល ដោយអះអាងថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសតាមរយៈការធ្វើការសន្និដ្ឋានថា ឧប្បត្តិហេតុមួយចំនួនបានបង្កឱ្យមនុស្សស្លាប់នៅការដ្ឋាន[2772]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ភ័ស្តុតាងរបស់ មាស ឡៃហួរ មានលក្ខណៈ "ទូទៅ"[2773] នោះ គាត់ត្រូវបានសួរដោយផ្ទាល់ថា តើគាត់បានឃើញឧប្បត្តិហេតុនៅទំនប់១មករាដែរឬអត់ ហើយគាត់បានឆ្លើយវិជ្ជមាន ដោយបានផ្តល់សក្ខីកម្មច្បាស់លាស់ និងជាក់លាក់ថា "ខ្ញុំធ្លាប់ឃើញ ខ្ញុំទៅរែកដីនៅការដ្ឋាន ដូចដីអ៊ីចឹងយើងកាប់ទៅ អ្នកនៅកាប់ពីក្រោមអ៊ីចឹងទៅវារលំដីពីលើមកសង្កិនងាប់ [...] ភូមិគេហ្នឹងឯងដីធ្លាក់ពីលើមកសង្កត់ងាប់ទៅ។ អ្នកកាប់មិនមែនអ្នករែកទេ"[2774]។ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើថែមទៀតទៅនឹងការយល់ឃើញផ្នែកអង្គហេតុដែលពាក់ព័ន្ធ៖ ក្រៅពីសាក្សីចំនួនបួននាក់ដែលបានបញ្ជាក់ពីការស្លាប់

[2769] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៩ ជើងទំព័រ ៥៥៤៣។

[2770] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៣០។

[2771] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៧៩-៧៨១។

[2772] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៧៩។

[2773] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៨០។

[2774] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៣៥, ១៦២៧-១៦២៨ ជើងទំព័រ ៥២៣៦, ៥៥៣៤, ៥៥៣៥, ៥៥៣៨ *ដោយដកស្រង់* ឯកសារ **E1/305.1** មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.40.00-09.44.55 ទំព័រ ១២ បន្ទាត់ ១៩-ទំព័រ ១៣ បន្ទាត់ ៨។

ដែលបានបង្កឡើងដោយឧប្បត្តិហេតុនានានោះ[2775] ឱ ហូ បានផ្តល់សក្ខីកម្មថា "តែវាច្រើនបាក់ដីសង្កិនងាប់"[2776] និងបានផ្តល់ការពិពណ៌នាលម្អិតទាក់ទងនឹងមូលហេតុដែលបណ្តាលឱ្យដីបាក់[2777]។ ជាចុងក្រោយ ក្នុងការអះអាងថា ភ័ស្តុតាងរបស់ នួន ណារុំ មិនអាចត្រូវបានយកមកប្រើប្រាស់ដើម្បីបង្ហាញពីការស្លាប់ដោយសារឧប្បត្តិហេតុនោះ[2778] ម្ចាស់បណ្តឹងសាទុក្ខបកស្រាយមិនត្រឹមត្រូវនូវការពឹងផ្អែករបស់ អ.ជ.ស.ដ ទៅលើភ័ស្តុតាងនេះ ដែលប្រើប្រាស់ដើម្បីបង្ហាញថា ការបាក់ដីបានកើតមានឡើងពិតប្រាកដ[2779]។

807. ការវាយតម្លៃរួមរបស់ អ.ជ.ស.ដ ទៅលើភ័ស្តុតាងបានឈានទៅរកការសន្និដ្ឋានដោយសមហេតុផលថា "គ្រោះថ្នាក់ជាច្រើនបណ្តាលមកពីការប្រកួតប្រជែងរវាងអ្នកធ្វើការ ដែលបានកើតមានឡើងនៅការដ្ឋាន ដូចជាច្រាំងដីបានបាក់ និងកប់ពីលើអ្នកធ្វើការបណ្តាលឱ្យមួយចំនួនបានស្លាប់"[2780]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខមិនអើពើនឹងភ័ស្តុតាងទាំងមូល បង្កើតឱ្យមានត្រឹមតែការមិនឯកភាពគ្នាជាមួយសេចក្តីសន្និដ្ឋានប៉ុណ្ណោះ ហើយដូច្នេះគួរត្រូវបានច្រានចោល[2781]។

---

[2775] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៣៥, ១៦២៧, ១៦២៨ ជើងទំព័រ ៥២៣៦, ៥៥៣៤, ៥៥៣៥, ៥៥៣៨ *ដោយដកស្រង់* ឯកសារ **E1/305.1** ហ៊ិន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ទំព័រ ៧០-៧១។ ឯកសារ **E1/307.1** អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.33.17-09.39.23 ទំព័រ ១១ បន្ទាត់ ៨-១៥, ម៉ោង 15.22.38-15.25.00 ទំព័រ ៦១ បន្ទាត់ ១៤-២២។ ឯកសារ **E1/309.1** អ៊ិត សេង ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 13.41.34-13.46.00 ទំព័រ ៣៩ បន្ទាត់ ១២-១៥។ ឯកសារ **E1/322.1** កង អ៊ុត ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 09.44.19-09.49.08 ទំព័រ ១៣ បន្ទាត់ ១៥-១៧។

[2776] ឯកសារ **E1/301.1** ឱ ហូ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 11.31.25-13.30.34 ទំព័រ ៣៤ បន្ទាត់ ១១-១២, *ដកស្រង់* ក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៧ ជើងទំព័រ ៥៥៣៥។

[2777] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៧ ជើងទំព័រ ៥៥៣៥ *ដោយដកស្រង់* ឯកសារ **E1/302.1** ឱ ហូ ប្រតិចារឹក ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 10.08.25-10.32.12 ទំព័រ ១៨ បន្ទាត់ ២១-ទំព័រ ១៩ បន្ទាត់ ៨ ("ដីដែលវាបាក់នោះគឺអីចេះ ពេលដែលយើងធ្វើការយប់ ពេលយើងធ្វើការយប់ ក្រុមនីមួយៗហ្នឹងសុទ្ធតែចង់ប្រឡងប្រណាំងណាស់។ គេច្រោះដីខាងក្រោមឱ្យប្រហោងទៅ [...] អាដីហ្នឹងវាបាក់មក [...] បើដីវាមួយផ្ទាំងធំប្រហែលជាមួយឡាន ពីរឡានហ្នឹងណា")។

[2778] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៨១។

[2779] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦២៨ ("នួន ណារុំ បានផ្តល់ភ័ស្តុតាងថា គាត់បានឃើញការបាក់ដីនៅរណ្តៅដែលយុវជនមួយចំនួនកំពុងជីក") ជើងទំព័រ ៥២៣៦ (ដែល អ.ជ.ស.ដ កត់សម្គាល់ថា នួន ណារុំ បានផ្តល់សក្ខីកម្មថា "គាត់បានឃើញការបាក់ដីនៅក្បែររណ្តៅដែលយុវជនខ្លះកំពុងជីក")។

[2780] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧០។

[2781] សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ២១។

## *ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងចំនួនអ្នកស្លាប់*[2782]

808. នៅក្នុងការអះអាងថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុតាមរយៈការសន្និដ្ឋានថា ចំនួនអ្នកធ្វើការយ៉ាងច្រើននៅទំនប់១មករា បានស្លាប់ដោយសារលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារ[2783] នោះ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើចំពោះការយល់ឃើញផ្នែកអង្គហេតុដែលពាក់ព័ន្ធ និងសមហេតុផល អំពីលក្ខខណ្ឌទាំងនេះនៅទំនប់១មករា[2784]។ អ.ជ.ស.ដ ជឿជាក់ថា ក្នុងអំឡុងពេលសាងសង់ទំនប់នេះ ចំនួនអ្នកធ្វើការនៅការដ្ឋានការងារទំនប់១មករា "មានចំនួនរាប់ម៉ឺននាក់"[2785] និងបានកត់សម្គាល់ថា "អ្នកធ្វើការយ៉ាងច្រើននៅការដ្ឋាន [...] មិនទទួលបាននូវអាហារអនាម័យ និងការព្យាបាលផ្នែកវេជ្ជសាស្ត្របានត្រឹមត្រូវនោះឡើយ"[2786]។ ដោយផ្អែកលើ "ភ័ស្តុតាងច្រើន និងជាទូទៅស៊ីចង្វាក់គ្នា" ដែលបង្ហាញពីលក្ខខណ្ឌនៃការរស់នៅនៅការដ្ឋានការងារទំនប់១មករា[2787] អ.ជ.ស.ដ បានធ្វើការសន្និដ្ឋានទាក់ទងនឹង (i) "បរិស្ថានគ្មានអនាម័យដ៏សែនគ្រោះថ្នាក់"[2788] ដែល "ធ្វើឱ្យមានជំងឺ និងធ្វើឱ្យអ្នកធ្វើការនៅការដ្ឋានការងារទំនប់១មករា កាន់តែលំបាកវេទនាខ្លាំងថែមទៀត"[2789] (ii) អាហារ "មិនគ្រប់គ្រាន់"[2790] ដែលធ្វើឱ្យអ្នកធ្វើការ "ខ្វះជីវជាតិ និង

---

[2782] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៨២។

[2783] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៨២។

[2784] បើទោះជា អ.ជ.ស.ដ មិនបានរួមបញ្ចូលការដកស្រង់សំដីបន្ទាប់ពីខ្លួនបានសន្និដ្ឋានថា ចំនួនមនុស្សស្លាប់យ៉ាងច្រើនបានកើតមានឡើងក្តី ក៏ អ.ជ.ស.ដ មិនត្រូវបានតម្រូវឱ្យបញ្ជាក់ឱ្យបានច្បាស់លាស់នូវសំអាងហេតុគ្រប់ជំហានលម្អិតឡើយ *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចដែលមានសំអាងហេតុ)។ អ.ជ.ស.ដ បានសំដៅដល់ "ស្ថានភាពដ៏អាក្រក់" នៅទំនប់១មករា ក្នុងកថាខណ្ឌ ១៦៧០ រួមទាំង *ក្នុងចំណោមនោះ* "ធ្វើការងារធ្ងន់ របបអាហារមិនគ្រប់គ្រាន់ និងស្ថានភាពមិនអំណោយផល ដូចជា បរិស្ថានគ្មានអនាម័យ និងឱសថមិនគ្រប់គ្រាន់ និងគ្មានប្រសិទ្ធភាព" ជាមួយនឹងសម្រង់សំដីចំពោះភ័ស្តុតាងដែលពាក់ព័ន្ធ។ អ.ជ.ស.ដ បានធ្វើការសន្និដ្ឋានលើអង្គហេតុលើលក្ខខណ្ឌនីមួយៗនៃលក្ខខណ្ឌទាំងនេះនៅទូទាំងផ្នែកនៃសាលក្រមទាក់ទងនឹងទំនប់១មករា។

[2785] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៩៩។

[2786] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧០។

[2787] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៨៥។

[2788] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៩៦។ អ.ជ.ស.ដ បានយល់ឃើញថា៖ អ្នកធ្វើការបានឆ្លងជំងឺរាករូសពីទឹក ដែលបានបង្កឱ្យមនុស្សមួយចំនួនស្លាប់ (*សូមមើល* កថាខណ្ឌ ១៥៩៧) អ្នកធ្វើការត្រូវបានបង្ខំឱ្យបន្ទោរបង់នៅក្នុងព្រៃ (*សូមមើល* កថាខណ្ឌ ១៥៩៨) អ្នកធ្វើការមិនត្រូវបានផ្តល់ជូនសម្លៀកបំពាក់សមស្រប ឬមធ្យោបាយដើម្បីបោកសម្លៀកបំពាក់នោះទេ ដែលនាំឱ្យមានចៃ "ច្រើន" (*សូមមើល* កថាខណ្ឌ ១៦០០-១៦០១) និងមិនមានសំឡីអនាម័យសម្រាប់ស្ត្រី (*សូមមើល* កថាខណ្ឌ ១៦០២)។

[2789] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦០៣។

ស្គមកំព្រីង"[2791] និង (iii) ការព្យាបាលផ្នែកវេជ្ជសាស្ត្រ "បានទទួលត្រឹមតែ [ថ្នាំអាចម៍ទន្សាយ និង សេរ៉ូមវីតាមីនបេ១ និងបេ១២]"[2792] និង "គ្មានប្រសិទ្ធភាព"[2793]។ ជារួម អ.ជ.ស.ដ បានយល់ឃើញថា លក្ខខណ្ឌរស់នៅ"មិនល្អទេ និងមិនគ្រប់គ្រាន់ដើម្បីទ្រទ្រង់អ្នកធ្វើការឱ្យអាចបំពេញការងារដែលពួកគេត្រូវធ្វើ"[2794] ហើយដូច្នេះបានសន្និដ្ឋានដោយសមហេតុផលថា អ្នកធ្វើការយ៉ាងច្រើនបានស្លាប់ដោយសារលទ្ធផលនេះ[2795]។

## *មូលដ្ឋានទី ១១៧ ៖ គ្មានភស្តុតាងអំពីចេតនាប្រយោលចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និងលក្ខខណ្ឌរស់នៅ*[2796]

809. **មូលដ្ឋានទី ១១៧ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គហេតុតាមរយៈការសន្និដ្ឋានថា *មានធាតុផ្សំអត្តនោម័តិ* នៃការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល* នៅទំនប់១មករា។**

810. ម្ចាស់បណ្តឹងសាទុក្ខមិនអើពើចំពោះការយល់ឃើញផ្នែកអង្គហេតុដែលពាក់ព័ន្ធ តាមរយៈការលើកឡើងដោយមិនត្រឹមត្រូវថា ភស្តុតាងដែលពឹងផ្អែកលើដើម្បីបង្ហាញឱ្យឃើញ *ធាតុផ្សំអត្តនោម័តិ* មានតម្លៃតិចតួចបំផុត[2797]។ ដោយផ្អែកលើសក្ខីកម្មដែលទទួលបានពី "សាក្សីជាច្រើន" អ.ជ.ស.ដ

---

[2790] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៩៥។ អ.ជ.ស.ដ បានយល់ឃើញថា "ប្រជាជនជួបប្រទះការអត់ឃ្លាន" (*សូមមើល* កថាខណ្ឌ ១៥៨៦) និងត្រូវបានផ្តល់ជូន "របបអាហារស្តួចស្តើង" (*សូមមើល* កថាខណ្ឌ ១៥៩២)។ សូមមើលផងដែរ កថាខណ្ឌ ១៥៨៧-១៥៩៤។

[2791] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៨៦។

[2792] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦០៧។

[2793] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦០៨។ អ.ជ.ស.ដ បានយល់ឃើញបន្ថែមថា បុគ្គលិកពេទ្យ "បានទទួលការបណ្តុះបណ្តាលតិចតួចណាស់" (*សូមមើល* កថាខណ្ឌ ១៦១០) និងថា បុគ្គលិកដែលធ្លាក់ខ្លួនឈឺ ត្រូវបានបង្ខំឱ្យបន្តធ្វើការ (*សូមមើល* កថាខណ្ឌ ១៥៣៩, ១៥៥៧, ១៥៥៨, ១៦០៦, ១៦១០)។

[2794] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦១០។

[2795] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧០។

[2796] មូលដ្ឋានទី ១១៧៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានភស្តុតាងអំពីចេតនាប្រយោលចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និងលក្ខខណ្ឌរស់នៅ* កថាខណ្ឌ ៧៨៣-៧៨៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៣ (ភាសាអង់គ្លេស) ទំព័រ ៣៩-៤០ (ភាសាបារាំង) ទំព័រ ៦១-៦២ (ភាសាខ្មែរ)។

[2797] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៨៤។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានដកស្រង់បន្ថែមនូវកថាខណ្ឌ ១៥០៤ ក្នុងការធ្វើការសន្និដ្ឋានរបស់ខ្លួនអំពី*ធាតុផ្សំអត្តនោម័តិ សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ជើងទំព័រ ៥៦៧៦។

បានយល់ឃើញថា ទំនប់១មករា គឺជា "សមរភូមិក្តៅ"[2798] មួយ។ សក្ខីកម្មនេះមានទំនាក់ទំនងទៅនឹងភស្តុតាងជាឯកសារដែលត្រូវបានពឹងផ្អែកលើ ដើម្បីបង្ហាញឱ្យឃើញពីការដឹងឮរបស់មជ្ឈិមបក្សអំពីលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារដ៏អាក្រក់នៅទំនប់៖ ឯកសាររបស់ ប.ក.ក បានពិពណ៌នាអំពីអ្នកធ្វើការដែលធ្វើការយ៉ាងលំបាក "ទាំងយប់ទាំងថ្ងៃយ៉ាងសស្រាក់សស្រាំបំផុត" សម្រាប់គម្រោងនានា រួមទាំងទំនប់១មករា[2799] ជាមួយនឹងជីវភាពប្រជាជន "ខ្វះខាត"[2800]។ ម្ចាស់បណ្តឹងសាទុក្ខមិនអើពើថែមទៀតទៅលើការយល់ឃើញផ្អែកអង្គហេតុដ៏ទូលំទូលាយរបស់ អ.ជ.ស.ដ អំពី កែ ពក និងការដឹងឮរបស់ថ្នាក់លើអំពីលក្ខខណ្ឌទាំងនេះនៅទំនប់១មករា[2801]។ ដោយផ្អែកលើភស្តុតាងទាំងមូល អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា មេដឹកនាំនៅការដ្ឋាន និងនៅក្នុងមជ្ឈិមបក្សបានដឹងឮអំពីលក្ខខណ្ឌរស់នៅដ៏លំបាកលំបិនទាំងនេះ ប៉ុន្តែបានបន្តដាក់លក្ខខណ្ឌការងារដ៏អាក្រក់នានា ដែលបានបង្ហាញថា "កម្មាភិបាលត្រៀមខ្លួនរួចរាល់ដើម្បីទទួលយកហានិភ័យដែលថា អ្នកធ្វើការអាចនឹងស្លាប់"[2802] ក្នុងអំឡុងពេលសាងសង់ទំនប់១មករា។ ដូច្នេះ អ.ជ.ស.ដ បានយល់ឃើញដោយសមហេតុផលថា "ការទទួលយកហានិភ័យនៃការស្លាប់របស់អ្នកធ្វើការដែលបណ្តាលមកពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌនៃការរស់នៅដ៏អាក្រក់ និងមិន

---

[2798] ឯកសារ **E465** សំណុំរឿង ០០២/០២ កថាខណ្ឌ ១៥០៤។ "សមរភូមិក្តៅ" គឺជាការដ្ឋានដែលមានពេលវេលាកំណត់តឹងរ៉ឹងក្នុងការបញ្ចប់ការងារ។ អ.ជ.ស.ដ បានរួមបញ្ចូលការយោងទៅនឹងសក្ខីកម្មដោយលើកឡើងថា ការដ្ឋានត្រូវបានសំដៅថាជា "សមរភូមិក្តៅ" នៅតាមមេក្រូដែលគេចាក់នៅការដ្ឋាន *សូមមើល* ឯកសារ **E1/306.1** ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 14.35.38-14.39.35 ទំព័រ ៥១ បន្ទាត់ ១០-២០។

[2799] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៥៥៧៥ *ដោយដកស្រង់* ឯកសារ **E3/287** កម្រងសារព័ត៌មាន FBIS *សេចក្តីអត្ថាធិប្បាយស្តីពីការបញ្ចប់ការងារធារាសាស្ត្រនៅរដូវប្រាំង* ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៧ EN 00168139-40, ដែលត្រូវបានដកស្រង់នៅក្នុង ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥០៦។

[2800] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៣៩ ជើងទំព័រ ៥៥៧៤ *ដោយដកស្រង់* ឯកសារ **E3/170** *ទង់បដិវត្តន៍* ខែតុលា-ខែវិច្ឆិកា ឆ្នាំ១៩៧៧, KH 00064775។

[2801] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៣០-១៦៤០ ដោយសន្និដ្ឋានថា កែ ពក បានដឹងពីលក្ខខណ្ឌទាំងនេះ ដោយសារ "ការមើលការខុសត្រូវរបស់គាត់" (*សូមមើល* កថាខណ្ឌ ១៦៣១) ថា គាត់បានជូនដំណឹងទៅមជ្ឈិមបក្សអំពី "ការលំបាកមួយចំនួន" ដែលបានជួបប្រទះនៅការដ្ឋានការងារទំនប់១មករា (*សូមមើល* កថាខណ្ឌ ១៦៣៣), និងថា មជ្ឈិមបក្ស "ថ្ងៃកំណត់បញ្ចប់ទំនប់នៅតែតម្រូវឱ្យអ្នកធ្វើការគោរពតាម ជាហេតុនាំមានគ្រោះថ្នាក់ដល់ជីវិតអ្នកធ្វើការជាច្រើននាក់" (*សូមមើល* កថាខណ្ឌ ១៦៤០)។

[2802] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧១។

មានសុវត្ថិភាពនោះ”[2803] បានបំពេញ *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតក្នុងទម្រង់ *ចេតនាដោយប្រយោល*[2804]។

811. ម្ចាស់បណ្ដឹងសាទុក្ខក៏បានលើកឡើងដោយគ្មានមូលដ្ឋានផងដែរថា អ.ជ.ស.ដ ខកខានមិនបានវាយតម្លៃភ័ស្តុតាងទាក់ទងនឹង “ពេលវេលា”[2805] នៃភ័ស្តុតាងនោះ ដោយអះអាងថា សេចក្ដីសន្និដ្ឋានអំពី *ធាតុផ្សំអត្តនោម័តិ* របស់ អ.ជ.ស.ដ ផ្អែកទៅលើអង្គហេតុនានាដែលត្រូវបានគេដឹងឮតែបន្ទាប់ពី *ធាតុផ្សំសត្យានុម័តិ* ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ហើយដូច្នេះ ការស្លាប់មិនបានកើតមានឡើង ដោយមានចេតនាឧក្រិដ្ឋឡើយ[2806]។ ការអះអាងនេះមិនទទួលបានផលទេ ដោយសារ អ.ជ.ស.ដ បានយល់ឃើញយ៉ាងច្បាស់ថា ការស្លាប់នៅទំនប់១មករា បានកើតមានឡើងព្រមគ្នាជាមួយនឹងការដឹងឮរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីលក្ខខណ្ឌអមនុស្សធម៌។ ម្ចាស់បណ្ដឹងសាទុក្ខទទួលស្គាល់ពីកង្វះអាហារក្នុងទ្រង់ទ្រាយធំនៅការដ្ឋាន[2807] ហើយ “បង្ខំឱ្យគ្នាធ្វើការអត់បាយ ដើរខ្លួនឯងមិនចង់រួចផង”[2808] និងថា ស្ថានភាពកាន់តែយ៉ាប់យ៉ឺន ដោយសារគោលបំណងរបស់ ប.ក.ក[2809]។ អ.ជ.ស.ដ បានយល់ឃើញថា ការសាងសង់ទំនប់១មករា បានចាប់ផ្ដើមនៅចន្លោះឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ និងត្រូវបានបញ្ចប់នៅដើមឆ្នាំ១៩៧៨[2810]។ ការអានយ៉ាងសាមញ្ញនូវភាសាររបស់ អ.ជ.ស.ដ បង្ហាញថា *ធាតុផ្សំអត្តនោម័តិ* បានលាតសន្ធឹងដល់រយៈកាលទាំងមូលនៃការសាងសង់ទំនប់នេះ ដោយសារការដាក់ជាហូរហែរនូវលក្ខខណ្ឌការងារ និងរស់នៅដ៏លំបាកលំបិន[2811]៖ “អ្នកធ្វើការបានទទួលសម្ភារចាំបាច់ក្នុងកម្រិតអប្បបរមា ដើម្បីរស់ និងដើម្បីសម្រេចគោលដៅនៃការសាងសង់ទំប់ [...] កម្មាភិបាលត្រៀមខ្លួនរួចរាល់ដើម្បីទទួលយកហានិភ័យដែលថាអ្នកធ្វើការអាចនឹងស្លាប់ក្នុងដំណើរការសាងសង់”[2812]។ អ.ជ.ស.ដ បានធ្វើការសន្និដ្ឋានលើអង្គ

[2803] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧២។

[2804] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៧២។

[2805] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៨៥។

[2806] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៧៨៥-៧៨៦។

[2807] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១១-៤២១២។

[2808] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៤ *ដោយដកស្រង់* ឯកសារ **E3/4043** ប្រតិចារឹកបទសម្ភាសជាមួយលោក ខៀវ សំផន ដែលគ្មានកាលបរិច្ឆេទ, KH 00780959-00780960។

[2809] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១១-៤២១២។

[2810] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៣០, ១៤៤៧។

[2811] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥០៤-១៥២៦ (ការពិចារណាអំពីម៉ោងធ្វើការ), ១៥២៧-១៥៤១ (ការពិចារណាអំពីលក្ខខណ្ឌការងារ និងផែនការការងារ), ១៥៨៦-១៦១៥ (ការពិចារណាអំពីលក្ខខណ្ឌនៃការរស់នៅ)។

[2812] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៧១។

ហេតុ ដោយសំដៅដល់ការដឹងឮរបស់មជ្ឈិមបក្សអំពីលក្ខខណ្ឌទាំងនេះនៅទូទាំងការដ្ឋានសាងសង់ទំនប់នេះ ដោយកត់សម្គាល់អំពីដំណើរទស្សនកិច្ចរបស់ ប៉ុល ពត ទៅកាន់ទំនប់១មករានៅចន្លោះចុងឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨[2813] ការបើកសម្ពោធនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧[2814] និងដំណើរទស្សនកិច្ចពីសំណាក់គណៈប្រតិភូបរទេសនៅចន្លោះឆ្នាំ១៩៧៧ ដល់ខែមីនា ឆ្នាំ១៩៧៨[2815] ដែល "បានជូនដំណឹងដល់គណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក អំពីលក្ខខណ្ឌទូទៅនៅការដ្ឋានការងាររួមទាំងនៅការដ្ឋានការងារទំនប់ ១ មករា ផងដែរ"[2816]។

## *មូលដ្ឋានទី ១១៨ ៖ ការប្រព្រឹត្តលើប្រជាជនថ្មី*[2817]

812. **មូលដ្ឋានទី ១១៨ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសក្នុងការវាយតម្លៃភស្តុតាងដែលជាមូលដ្ឋាននៃការសន្និដ្ឋានថាមាន*ធាតុផ្សំសត្យានុម័ត* សម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយលើប្រជាជនថ្មីនៅទំនប់ ១ មករា។**

813. មូលដ្ឋាននេះមិនទទួលបានផលទេ ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់ដែលបានចោទប្រកាន់ថា ភស្តុតាងដែលបានដកស្រង់ក្នុងសាលក្រម កថាខណ្ឌ ១៦៤២-១៦៤៨ មិនអាចបង្កើតនូវលំនាំនៃការប្រព្រឹត្តបែបរើសអើងបានឡើយ[2818]។ អ.ជ.ស.ដ បានផ្អែកយ៉ាងត្រឹមត្រូវលើភស្តុតាងដែលស្ថិតនៅក្រៅវិសាលភាពពេលវេលា និងវិសាលភាពភូមិសាស្ត្រនៃដីកាដំណោះស្រាយដើម្បីសន្និដ្ឋានអំពីលំនាំនេះ[2819] ដូច្នេះហើយបានរកឃើញបរិបទមួយនៃ "ការបំបែក និងការធ្វើបាបប្រជាជនថ្មី"[2820] ដែលគួសបញ្ជាក់ពីភស្តុតាងជាក់លាក់នៃការរើសអើង*ជាក់ស្តែង* ដែលទទួលរងនៅទំនប់ ១ មករា។

---

[2813] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៨៩។

[2814] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៨៤។

[2815] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៩១-១៥៩៦។

[2816] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៩៧។

[2817] <u>មូលដ្ឋានទី ១១៨ ៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការប្រព្រឹត្តលើប្រជាជនថ្មី* កថាខណ្ឌ ៧៨៧-៧៩០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៣ (ភាសាអង់គ្លេស) ទំព័រ ៤០ (ភាសាបារាំង) ទំព័រ ៦២ (ភាសាខ្មែរ)។

[2818] ឯកសារ **F54 សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ៧៨៩។

[2819] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣។

[2820] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤៩។

814. មូលដ្ឋាននេះមិនទទួលបានផលទេ ពាក់ព័ន្ធនឹងកំហុសអង្គហេតុដែលរងការចោទប្រកាន់ ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសន្និដ្ឋាននេះគឺជាការសន្និដ្ឋានមួយដែលថា គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់ អាចធ្វើការវាយតម្លៃជារួមលើភ័ស្តុតាង ដែលផ្ទុយពីការវាយតម្លៃជាផ្នែកៗនោះឡើយ។ ទោះបីជាមានការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខស្តីពីការប្រព្រឹត្តដោយស្មើភាពជាមួយប្រជាជនថ្មី និងប្រជាជនមូលដ្ឋានក្តី[2821] ក៏ការវាយតម្លៃភ័ស្តុតាងដោយ អ.ជ.ស.ដ បានបង្ហាញពីភាពខុសគ្នាប្រកបដោយអត្ថន័យជាច្រើន ដែលកំណត់ពីការរើសអើង*ជាក់ស្តែង*[2822]។ ប្រជាជនថ្មី គឺជា"សមាសភាពមិនល្អ"[2823]។ ពួកគេត្រូវបានស៊ើបការណ៍[2824] និងតាមដានដោយកងឈ្លបនៅតាមមូលដ្ឋាន[2825] និងមានការដើរប្រមូលប្រវត្តិរូបដើម្បីបែងចែកពួកគេជាប្រជាជនថ្មី[2826]។ ផ្អែកលើប្រវត្តិរូបរបស់ពួកគេ ពួកគេត្រូវបានចាប់ខ្លួន[2827] និងបាត់ខ្លួន ឬត្រូវបានគេសម្លាប់[2828]។

---

[2821] ឯកសារ **F54 សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ៧៩០។

[2822] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤១-១៦៥៣។

[2823] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤៨។ សូមមើលផងដែរ កថាខណ្ឌ ១៦៤១ ជើងទំព័រ ៥៥៧៦ *ដោយដកស្រង់* កថាខណ្ឌ ៩៨០-៩៩៥ ជើងទំព័រ ៥៥៧៧ *ដោយដកស្រង់* កថាខណ្ឌ ៣៨៣៩, ៣៨៤៥-៣៨៤៦, ៣៨៤៨។

[2824] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤២ ជើងទំព័រ ៥៥៨២ (*ដោយដកស្រង់* ឯកសារ **E1/301.1** ឱ ហ្វ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.57.47-10.02.17 ទំព័រ ១៥ បន្ទាត់ ៩-២៣, ម៉ោង 10.43.18 ទំព័រ ២១ បន្ទាត់ ២១-ទំព័រ ២២ បន្ទាត់ ៣), ៥៥៩៦-៥៥៩៧ (*ដោយដកស្រង់* ឯកសារ **E1/309.1** អ៊ុត សេង ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 09.29.21 ទំព័រ ៨ បន្ទាត់ ២៤-ទំព័រ ៩ បន្ទាត់ ៣)។

[2825] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៥៦០១ *ដោយដកស្រង់* ឯកសារ **E1/309.1** អ៊ុត សេង ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 09.33.16 ទំព័រ ៩ បន្ទាត់ ២៣-ទំព័រ ១០ បន្ទាត់ ៤, ម៉ោង 09.44.22 ទំព័រ ១៣ បន្ទាត់ ៩-១៣។

[2826] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤៦។ ជើងទំព័រ ៥៦០៤ *ដោយដកស្រង់* ឯកសារ **E1/317.1** យាន លន់ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦, ម៉ោង 13.47.47 ទំព័រ ៤៥ បន្ទាត់ ១៤-២០។

[2827] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤៣ ជើងទំព័រ ៥៥៩០ (*ដោយដកស្រង់* ឯកសារ **E1/306.1** ហ៊ុន សុគ្គានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ទំព័រ ១៣-១៤, ២៥) កថាខណ្ឌ ១៦៤៦ ជើងទំព័រ ៥៦០៣ (*ដោយដកស្រង់* ឯកសារ **E1/317.1** យាន លន់ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 13.47.47-13.53.10 ទំព័រ ៤៥ បន្ទាត់ ១៤-២០), ៥៦០៥-៥៦០៦ (*ដោយដកស្រង់* ឯកសារ **E3/7322** កំណត់ហេតុស្តាប់ចម្លើយ យាន លន់, KH 00321786) កថាខណ្ឌ ១៦៤៧ ជើងទំព័រ ៥៦០៨ (*ដោយដកស្រង់* ឯកសារ **E1/317.1** យាន លន់ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 13.53.10-13.56.30 ទំព័រ ៤៥ បន្ទាត់ ២៤-ទំព័រ ៤៦ បន្ទាត់ ៨)។

[2828] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤៣ ជើងទំព័រ ៥៥៩០-៥៥៩៥ (*ដោយដកស្រង់* ឯកសារ **E1/306.1** ហ៊ុន សុគ្គានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.48.02-09.52.42 ទំព័រ ១៣ បន្ទាត់ ៨-ទំព័រ ១៤ បន្ទាត់ ៩, ម៉ោង 10.47.11-10.56.00 ទំព័រ ២៤ បន្ទាត់ ១៨-ទំព័រ ២៥ បន្ទាត់ ២០, ម៉ោង 11.01.33-11.13.12 ទំព័រ ២៧

នៅទំនប់ ១ មករា ប្រជាជនមូលដ្ឋានទទួលបានសិទ្ធិពិសេស[2829] និងអាចកាន់តួនាទីជាអ្នកគ្រប់គ្រង[2830]។ ប្រជាជនថ្មីប្រឈមនឹងទណ្ឌកម្មតឹងរ៉ឹង[2831] និងរស់នៅក្នុងបរិយាកាសនៃ "ការភ័យខ្លាចជាដរាប"[2832]។

815. ការអះអាងមិនត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការកត់សម្គាល់ដោយ អ.ជ.ស.ដ ថា ប្រជាជនថ្មី និងប្រជាជនមូលដ្ឋានប្រឈមនឹងការប្រព្រឹត្តដូចគ្នាមួយចំនួន ធ្វើឱ្យមានការសន្និដ្ឋានទៅលើការរើសអើង មិនសមហេតុផលនោះ[2833] ក៏មិនទទួលបានផលដែរ។ ការទទួលស្គាល់ដោយ អ.ជ.ស.ដ ថា ទាំងប្រជាជនថ្មី និងប្រជាជនមូលដ្ឋានសុទ្ធតែទទួលរងលក្ខខណ្ឌលំបាកនៅទំនប់ ១ មករា មិនធ្វើឱ្យប៉ះពាល់ដល់តថភាពដែលថា ប្រជាជនថ្មីប្រឈមនឹងការរើសអើង*ជាក់ស្តែង* ដោយខ្មែរក្រហមក្នុងការពន្លឿនរបៀបវារៈនយោបាយរបស់ ប.ក.ក នោះទេ។ ផ្អែកលើកំណត់ត្រា

---

បន្ទាត់ ១៤-ទំព័រ ២៩ បន្ទាត់ ១០) កថាខណ្ឌ ១៦៤៤ ជើងទំព័រ ៥៦០០ (*ដោយដកស្រង់* ឯកសារ **E1/309.1** អ៊ុត សេង ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 09.21.27-09.24.05 ទំព័រ ៦ បន្ទាត់ ២២-ទំព័រ ៧ បន្ទាត់ ១២) កថាខណ្ឌ ១៦៤៦ ជើងទំព័រ ៥៦០៧ (*ដោយដកស្រង់* ឯកសារ **E3/7322** កំណត់ហេតុស្តាប់ចម្លើយ យាន លន់, KH 00321786)។

[2829] ប្រជាជនមូលដ្ឋានអាចស្នើសុំធ្វើការនៅកន្លែងជាក់លាក់ មានសិទ្ធិទទួលបានសម្លៀកបំពាក់ និងស្បែកជើងថ្មី និងត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងពិធីផ្លូវការ។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥២ ជើងទំព័រ ៥៦១៩ (*ដោយដកស្រង់* ឯកសារ **E1/305.1** ហ៊ុន សុត្ថានី ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 15.53.16-15.59.35 ទំព័រ ៧៣ បន្ទាត់ ៣-១៧), ៥៦២០ (*ដោយដកស្រង់* ឯកសារ **E1/309.1** អ៊ុត សេង ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 10.03.42-10.07.27 ទំព័រ ១៩ បន្ទាត់ ២-៩, ម៉ោង 11.16.09-11.19.49 ទំព័រ ៣១ បន្ទាត់ ១០-២០), ៥៦២៤ (*ដោយដកស្រង់* ឯកសារ **E1/306.1** ហ៊ុន សុត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 14.30.00-14.33.32 ទំព័រ ៥០ បន្ទាត់ ២-៩), ៥៦២៥ (*ដោយដកស្រង់* ឯកសារ **E1/305.1** ហ៊ុន សុត្ថានី ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 15.46.17-15.53.16 ទំព័រ ៧២ បន្ទាត់ ៧-១០), ៥៦២៧ (*ដោយដកស្រង់* ឯកសារ **E1/307.1** អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.45.54-09.51.24 ទំព័រ ១៤ បន្ទាត់ ១៥-ទំព័រ ១៥ បន្ទាត់ ៧), ៥៦២៩ (*ដោយដកស្រង់* ឯកសារ **E1/308.1** សៀង សុវិដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 10.45.32-10.48.40 ទំព័រ ២៧ បន្ទាត់ ១០-១៣, ម៉ោង 11.22.10-11.24.10 ទំព័រ ៣៩ បន្ទាត់ ១-៥)។

[2830] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥២ ជើងទំព័រ ៥៦១៧ (*ដោយដកស្រង់* ឯកសារ **E1/339.1** នួន ណារុំ ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥, ម៉ោង 10.33.32-10.36.04 ទំព័រ ២០ បន្ទាត់ ២៣-ទំព័រ ២១ បន្ទាត់ ១), ៥៦២៩ (*ដោយដកស្រង់* ឯកសារ **E1/308.1** សៀង សុវិដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥, ម៉ោង 10.45.32-10.48.40 ទំព័រ ២៧ បន្ទាត់ ១០-១៣, ម៉ោង 11.22.10-11.24.10 ទំព័រ ៣៩ បន្ទាត់ ១-៥)។

[2831] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥២ ជើងទំព័រ ៥៦២១ (*ដោយដកស្រង់* ឯកសារ **E1/301.1** ឱ ហ្វូ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.39.20-09.45.12 ទំព័រ ១១ បន្ទាត់ ១០-ទំព័រ ១២ បន្ទាត់ ១៦), ៥៦២២ (*ដោយដកស្រង់* ឯកសារ **E1/306.1** ហ៊ុន សុត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.28.07-09.30.11 ទំព័រ ៨ បន្ទាត់ ១៨-ទំព័រ ៩ បន្ទាត់ ៥)។

[2832] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥៣, ១៦៨៨។

[2833] ឯកសារ **F54 សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ៧៩១។

ភ័ស្តុតាង អ.ជ.ស.ដ បានសន្និដ្ឋានដោយសមហេតុផលថា ទោះបីជាស្ថានភាពដ៏លំបាកនៅទំនប់ ១ មករា ប៉ះពាល់ដល់ប្រជាជនគ្រប់រូប ប៉ុន្តែប្រជាជនថ្មីប្រឈមនឹងការលំបាកខ្លាំងជាងប្រជាជនមូលដ្ឋាន ដោយសារ ប.ក.ក បែងចែកប្រជាជនជាប្រភេទ[2834]។ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ដ ខកខានមិនបានបកស្រាយភ័ស្តុតាងរបស់សាក្សី ៦ នាក់ ដែល អ.ជ.ស.ដ ពេញចិត្ត មិនបានបំពេញបទដ្ឋាននៃការពិនិត្យបណ្ដឹងសាទុក្ខឡើយ[2835]។

816. ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងថា អ.ជ.ស.ដ "បានដកចេញបែបជ្រើសរើស" នូវសក្ខីកម្មរបស់ អ៊ុំ ជី និង ឱ ហូ[2836] ប៉ុន្តែមិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសក្នុងការផ្អែកលើផ្នែកនានានៃសក្ខីកម្មនេះ ប៉ុន្តែបដិសេធសក្ខីកម្មផ្សេងទៀត។ អ.ជ.ស.ដ មានឆន្ទានុសិទ្ធិក្នុងការទទួលយកផ្នែកណាមួយនៃសក្ខីកម្មរបស់សាក្សីថាអាចជឿទុកចិត្តបាន និងអាចជឿជាក់បាន និងបដិសេធផ្នែកផ្សេងទៀត[2837]។ អ.ជ.ស.ដ លើកឡើងពីសក្ខីកម្មទាំងនេះដោយកត់សម្គាល់ពីតួនាទីជាអ្នកគ្រប់គ្រងរបស់សាក្សីទាំងនេះនៅទំនប់ ១ មករា[2838]។

817. ជាថ្មីម្ដងទៀត ម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើងដោយគ្មានមូលដ្ឋាន[2839] ពាក់ព័ន្ធនឹងការពឹងផ្អែករបស់ អ.ជ.ស.ដ លើសក្ខកម្មរបស់ ឱ ហូ ដែលថា ប្រជាជនថ្មីត្រូវបានគេស្ដីបន្ទោសនៅពេលប្រព្រឹត្តកំហុសតូចតាច និងប្រសិនបើពួកគេប្រព្រឹត្តកំហុសធ្ងន់ធ្ងរ មេឃុំមិនអាចធានាសុវត្ថិភាពរបស់ពួកគេបានទេ[2840]។ អ.ជ.ស.ដ បានវាយតម្លៃដោយការគោរពចំពោះភាពអាចជឿទុកចិត្ត

[2834] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥៣។

[2835] សូមមើល សាលដីការឿងក្ដី *Boškoski & Tarčulovski* កថាខណ្ឌ ១៨។ សាលដីការឿងក្ដី *Krajišnik* កថាខណ្ឌ ២៧, សាលដីការឿងក្ដី *Martić* កថាខណ្ឌ ១៩។

[2836] ឯកសារ **F54 សារណាបណ្ដឹងសាទុក្ខ** កថាខណ្ឌ ៧៩១។

[2837] សូមមើល ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៧។ សាលដីការឿងក្ដី *Karemera & Ngirumpatse* កថាខណ្ឌ ៤៦៨ *ដោយដកស្រង់* សាលដីការឿងក្ដី *Kajelijeli* កថាខណ្ឌ ១៦៧។

[2838] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥១ *ដោយដកស្រង់* កថាខណ្ឌ ១៥២៦, ១៥៤០ ("អ៊ុំ ជី និង ឱ ហូ គឺជាថ្នាក់លើដែលមានចិត្តចង់បន្ថយការទទួលខុសត្រូវរបស់ខ្លួនពាក់ព័ន្ធនឹងការធ្វើបាប ឬការរើសអើងក្រុមជាក់លាក់")។

[2839] ឯកសារ **F54 សារណាបណ្ដឹងសាទុក្ខ** កថាខណ្ឌ ៧៩៤។

[2840] ឯកសារ **E465**សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥២ ជើងទំព័រ ៥៦២១ *ដោយដកស្រង់* ឯកសារ **E1/301.1** ឱ ហូ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.39.20-09.45.12 ទំព័រ ១១ បន្ទាត់ ១០-ទំព័រ ១២ បន្ទាត់ ១៦ *ដោយបញ្ជាក់* ឯកសារ **E3/5255**, KH 00239911 ("ប្រជាជនបញ្ញើគឺងាយនឹងគេចាប់កំហុស យកទោសជាងប្រជាជនផ្សេងទៀត")។

បាន និងភាពអាចជឿជាក់បាននៃភ័ស្តុតាងពាក់ព័ន្ធ[2841]។ សក្ខីកម្មបន្ថែមទៀតបានគាំទ្រអង្គហេតុនេះ[2842] ហើយ អ.ជ.ស.ដ យល់ថា ប្រជាជនថ្មី "ងាយត្រូវបានគេស្តីបន្ទោសជាង"[2843]។

818. ការពិនិត្យជារួមរបស់ អ.ជ.ស.ដ លើភ័ស្តុតាងនេះ បានធ្វើឱ្យមានការសន្និដ្ឋានដោយសមហេតុផលថា "ស្ថានភាពងាយរងគ្រោះ" របស់ប្រជាជនថ្មីគឺ "កាន់តែមានភាពធ្ងន់ធ្ងរឡើង" ដោយសារអំពើរើសអើង "ជាច្រើន"[2844]។ ការមិនយល់ស្របរបស់ម្ចាស់បណ្តឹងសាទុក្ខ[2845] ទៅនឹងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មនៅសេសសល់ ដែលត្រូវបានប្រើប្រាស់ក្នុងការសន្និដ្ឋានពីការរើសអើង *ជាក់ស្តែង* មិនប៉ះពាល់ដល់ភាពសមហេតុផលរបស់ អ.ជ.ស.ដ ឡើយ ហើយការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការអះអាងទាំងនេះជាការភាន់ច្រឡំ គួរត្រូវបានច្រានចោល។

### *មូលដ្ឋានទី ១១៩ ៖ ការចោទប្រកាន់ចំពោះការប្រព្រឹត្តលើប្រជាជនថ្មី*[2846]

819. **មូលដ្ឋានទី ១១៩ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គហេតុ ឬអង្គច្បាប់ក្នុងការសន្និដ្ឋានថាមាន*ធាតុផ្សំសត្យានុម័ត* សម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយលើប្រជាជនថ្មីនៅទំនប់ ១ មករា។**

820. មូលដ្ឋាននេះមិនទទួលបានផលទេ ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់ និងអង្គហេតុដែលបានចោទប្រកាន់ ព្រោះម្ចាស់បណ្តឹងសាទុក្ខ (i) មិនបានពន្យល់ថាតើការដែល អ.ជ.ស.ដ យោងតាមសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា ធ្វើមោឃភាពសេចក្តីសម្រេចនេះដោយរបៀបណា (ii) មិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គច្បាប់ ឬអង្គហេតុក្នុងការសន្និដ្ឋានថា ការ

---

[2841] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨, ៨៩, ២២៧។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៧។

[2842] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ 1652 ជើងទំព័រ 5622 *ដោយដកស្រង់* ឯកសារ **E1/306.1** ហ៊ុន សុគ្គានី ប្រតិចារិក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥, ម៉ោង 09.30.11 ទំព័រ ៩ បន្ទាត់ ១-២ ("រឿងនេះគឺថាប្រជាជនចាស់គេខុសអីបន្តិចបន្តួច គេអាចតវ៉ា គេតតាំងគ្នាទៅ គេអនុគ្រោះឱ្យគ្នាទៅ។ បើអ្នកថ្មីវិញ គឺមិនអាចមានប៉ុន្មានសរសៃសក់ក៏មិនបានដែរ")។

[2843] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៨៨។

[2844] ឯកសារ **E465**សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៨៨។

[2845] ឯកសារ **F54** **សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ៧៩៣, ៧៩៥, ៧៩៦។

[2846] មូលដ្ឋានទី ១១៩ ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការចោទប្រកាន់ចំពោះការប្រព្រឹត្តលើប្រជាជនថ្មី* កថាខណ្ឌ ៧៩៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៤ (EN) ទំព័រ ៥០ (FR) ទំព័រ ៦២-៦៣ (ភាសាខ្មែរ)។

ប្រព្រឹត្តលើប្រជាជនថ្មីគឺជាការរំលោភសិទ្ធិជាមូលដ្ឋាន និង (iii) គ្រាន់តែបានអះអាង ប៉ុន្តែមិនបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសក្នុងការកំណត់កម្រិតនៃភាពធ្ងន់ធ្ងរសម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ។

821. ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គច្បាប់ តាមរយៈការបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា ដោយគ្មានប្រភពច្បាប់សម្រាប់គាំទ្រការលើកឡើងនេះ[2847] ប៉ុន្តែមិនបានទទួលស្គាល់ថា អ.ជ.ស.ដ គ្រាន់តែបានលើកឡើងជាពាក្យពេចន៍ផ្សេងទៀតថា ភស្តុតាងដែលបញ្ជាក់ថា ប្រជាជនថ្មីទទួលបានការប្រព្រឹត្តខុសគ្នា ជាកត្តាចាំបាច់ក្នុងការវិភាគថាតើក្រុមមួយទទួលរងការរើសអើង *ជាក់ស្តែង* ឬយ៉ាងណា[2848]។ ការអានដោយអន្លើរៗលើសាលក្រមនេះដោយម្ចាស់បណ្តឹងសាទុក្ខ មិនអើពើការលើកឡើងថា សេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្តីពីការធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មីនៅទំនប់ ១ មករា មិនផ្អែកលើសិទ្ធិទទួលបានការប្រព្រឹត្តស្មើភាពគ្នាឡើយ ប៉ុន្តែផ្អែកលើការរំលោភសិទ្ធចម្រុះ ដូចជា "សិទ្ធិជាមូលដ្ឋានពាក់ព័ន្ធនឹងការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន សេរីភាព និងសន្តិសុខ និងការរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត ឬខុសច្បាប់ ដូចមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[2849]។

822. បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការសន្និដ្ឋានថា ការប្រព្រឹត្តដែលបានពិពណ៌នាក្នុងកថាខណ្ឌ ១៦៥៣ នៃសាលក្រមនេះស្មើនឹងការរំលោភសិទ្ធជាមូលដ្ឋាន និងបន្តលើកឡើងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការខកខានមិនបានកំណត់អំពីកម្រិតនៃភាពធ្ងន់ធ្ងរចាំបាច់ ដើម្បីឱ្យការរើសអើងជាក់ស្តែងមួយដែលរំលោភលើសិទ្ធិជាមូលដ្ឋាន អាចត្រូវបានកំណត់បានថាជា

[2847] ឯកសារ F54 **សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ៧៩៧ *ដោយដកស្រង់* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៨៩។

[2848] សូមមើល ឯកសារ F28 សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៥៦-២៥៨។ សូមមើល *ចម្លើយតបបន្ថែមទៀតទៅនឹងមូលដ្ឋានទី ១០៩*។ ម្ចាស់បណ្តឹងសាទុក្ខក៏មិនបានលើកឡើងផងដែរថា សិទ្ធិមិនទទួលរងការរើសអើង គួសបញ្ជាក់ពីឧបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗទាំងអស់ (*សូមមើល ឧ.* UDHR បុព្វថា មាត្រា ១ (សេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើភាព), ២ (សិទ្ធិមិនទទួលរងការរើសអើង), ៧ (សិទ្ធិទទួលបានសមភាពនៅចំពោះមុខច្បាប់)។ ICCPR បុព្វកថា មាត្រា ២ (១) (សិទ្ធិមិនទទួលរងការរើសអើង), ២៦ (សិទ្ធិទទួលបានសមភាពនៅចំពោះមុខច្បាប់) និងគឺជាខ្លឹមសារនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ។

[2849] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩១ *ដោយដកស្រង់* GC IV, មាត្រា ៣(១)(ក), UDHR, បុព្វកថា, មាត្រា ១, ៣, ៩, ២២, ២៣(៣), ICCPR, មាត្រា ៦, ៩(១), ១០, ECHR, មាត្រា ២, ៥, ACHPR, មាត្រា ៤-៦, ACHR, មាត្រា ៤-៧, សាលដីការឿងក្តី *Kordić និង Čerkez* កថាខណ្ឌ ១០៦។

ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ[2850]។ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីកំហុសអង្គហេតុ ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញមិនត្រឹមត្រូវពីសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ តាមរយៈការអានសាលក្រមនេះដោយអន្លើរៗ ដោយមិនអើពើថា សេចក្តីសន្និដ្ឋាននោះផ្អែកលើការរំលោភសិទ្ធិចម្រុះ[2851]។ ការវិភាគរបស់ អ.ជ.ស.ដ លើអំពើបែបរើសអើងចំពោះប្រជាជនថ្មី បង្ហាញពីការរំលោភយ៉ាងច្បាស់ក្រឡែតលើសិទ្ធពាក់ព័ន្ធនឹងការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន សេរីភាព និងសន្តិសុខ និងការរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត ឬខុសច្បាប់ ដែលត្រូវបានលើកឡើងយ៉ាងសមហេតុផលដោយ អ.ជ.ស.ដ[2852]។

823. កំហុសអង្គច្បាប់ដែលរងការចោទប្រកាន់ មិនអាចយកជាសំអាងបានទេ ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញច្បាស់ថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសក្នុងការអនុវត្តច្បាប់ឡើយ។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនយល់ស្របនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ។ ម្ចាស់បណ្តឹងសាទុក្ខបានបកស្រាយដោយមិនត្រឹមត្រូវលើការពិចារណាសមស្របពីសិទ្ធិជាមូលដ្ឋាន និងគ្រាន់តែបានអះអាងថា អំពើបែបរើសអើងដែលលើកឡើងដោយ អ.ជ.ស.ដ មិនឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរចាំបាច់ដើម្បីបំពេញ*ធាតុផ្សំសត្យានុម័តិ*នៃការធ្វើទុក្ខបុកម្នេញ ដោយមិនបានកំណត់ពីកំហុសក្នុងបទដ្ឋាននេះ ឬបញ្ជាក់ពីបទដ្ឋានជាជម្រើសមួយឡើយ។

824. ក្នុងចំណោមអំពើបែបរើសអើងផ្សេងទៀត អ.ជ.ស.ដ យល់ថា ប្រជាជនថ្មីនៅទំនប់ ១ មករា ត្រូវបានស្តីបន្ទោសយ៉ាងងាយចំពោះបទល្មើស ឬកំហុសឆ្គងនានា ត្រូវបានបង្ខំឱ្យលាក់បាំងអត្តសញ្ញាណរបស់ខ្លួន និងរស់នៅក្នុងការភ័យខ្លាចជាដរាបខ្លាចត្រូវបានចាប់ខ្លួន ឬអប់រំកែប្រែដោយសារតែការស៊ើបការណ៍ និងការបាត់ខ្លួនរបស់ប្រជាជនថ្មីផ្សេងទៀត[2853]។ អ.ជ.ស.ដ មិនបានកំណត់អំពើទាំងនេះជា “សិទ្ធិជាមូលដ្ឋាន” ទៅតាមការអះអាងមិនត្រឹមត្រូវដោយម្ចាស់បណ្តឹង

---

[2850] ឯកសារ **F54 សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ៧៩៧។

[2851] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩១។

[2852] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩១។ ឧទាហរណ៍ ការសន្និដ្ឋានថា ប្រជាជនថ្មីត្រូវបានគេស៊ើបការណ៍ (*សូមមើល* ជើងទំព័រ ៥៥៨២, ៥៥៩០-៥៥៩៧, ៥៦០១) និងត្រូវបានចាប់ខ្លួន (*សូមមើល* ជើងទំព័រ ៥៥៩០, ៥៦០៣, ៥៦០៥-៥៦០៦, ៥៦០៨) រំលោភលើសិទ្ធិរបស់ពួកគេពាក់ព័ន្ធនឹងការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន សេរីភាព និងសន្តិសុខ និងការរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត ឬខុសច្បាប់។ ដូចគ្នានេះដែរ ការសន្និដ្ឋានថា ប្រជាជនថ្មីត្រូវបានបាត់ខ្លួន ឬសម្លាប់ (*សូមមើល* ជើងទំព័រ ៥៥៩០-៥៥៩៥, ៥៦០០, ៥៦០៧) ជាការរំលោភសិទ្ធិរស់រានមានជីវិតរបស់ពួកគេ។ សម្រាប់ខ្លឹមសារលម្អិត *សូមមើលផងដែរ* កថាខណ្ឌ ១៦៤១-១៦៥៣។

[2853] ឯកសារ **E465**សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៥៣។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១១៨។

សាទុក្ខនោះទេ[2854] ប៉ុន្តែផ្ទុយទៅវិញ បានពិចារណាយ៉ាងត្រឹមត្រូវថា អំពើទាំងនេះគឺជាអំពើនៃការធ្វើទុក្ខបុកម្នេញដែលធ្វើឱ្យមានការរំលោភសិទ្ធិជាមូលដ្ឋាន[2855]។

825. អ.ជ.ស.ដ បានលើកឡើងយ៉ាងត្រឹមត្រូវពីកម្រិតនៃភាពធ្ងន់ធ្ងរ[2856]។ តាមរយៈការវិភាគសមស្រប ដោយពិចារណាពីអំពើទាំងនេះ "រួមគ្នា" និង "ជាពិសេសនៅក្នុងបរិបទ" ដែលអំពើទាំងនេះត្រូវបានប្រព្រឹត្ត អង្គជំនុំជម្រះជឿជាក់ថា ការរំលោភសិទ្ធដែលបណ្តាលមកពីការប្រព្រឹត្តបែបរើសអើងចំពោះប្រជាជនថ្មី "រួមបញ្ចូលគ្នាឡើងដល់កម្រិតធ្ងន់ធ្ងរស្រដៀងគ្នាដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[2857]។

## ៣. ទំនប់ត្រពាំងថ្ម

### *មូលដ្ឋានទី ១១៣ ៖ គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល*[2858]

826. **មូលដ្ឋានទី ១១៣ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈការសន្និដ្ឋានថាមាន*ធាតុផ្សំសត្យានុម័តិ* និង*ធាតុផ្សំអត្តនោម័តិ* នៃការធ្វើមនុស្សឃាតដោយចេតនាប្រយោលពាក់ព័ន្ធនឹងការស្លាប់ ដែលបណ្តាលមកពីលក្ខខណ្ឌរស់នៅនៅទំនប់ត្រពាំងថ្ម។**

827. មូលដ្ឋាននេះមិនទទួលបានផលទេ ព្រោះម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងដដែលៗពីការអះអាងមិនត្រឹមត្រូវរបស់ខ្លួន ពាក់ព័ន្ធនឹងភាពស្របច្បាប់នៃការកំណត់បទចោទប្រកាន់ឡើងវិញថាជាការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល*[2859] និងភាពអាចអនុវត្តបាននៃការធ្វើមនុស្សឃាត

---

[2854] ឯកសារ F54 **សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ៧៩៧។

[2855] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩១។ ការវិភាគសមស្របគឺមិនមែនថាតើអំពើនៃការធ្វើទុក្ខបុកម្នេញផ្ទាល់បានរំលោភសិទ្ធិមនុស្សជាមូលដ្ឋាននោះទេ ប៉ុន្តែជាការវិភាគថាតើអំពើនៃការធ្វើទុក្ខបុកម្នេញបណ្តាលឱ្យមានការបំពារបំពានយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិជាមូលដ្ឋាន នៅពេលពិចារណារួមគ្នា ឬនៅក្នុងបរិបទ។

[2856] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៦, ១៦៩១។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៩។

[2857] ឯកសារ **E465**សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៩១។

[2858] <u>មូលដ្ឋានទី ១១៣ ៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល* កថាខណ្ឌ ៧៥៨-៧៦២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤២ (EN) ទំព័រ ៣៨-៣៩ (ភាសាបារាំង) ទំព័រ ៦០ (ភាសាខ្មែរ)។

[2859] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៨។

*ដោយចេតនាប្រយោល*[2860]។ អ.ជ.ស.ដ បានប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួនក្នុងការកំណត់បទចោទប្រកាន់ឡើងវិញ[2861] និង*ធាតុផ្សំអត្តនោម័តិ*នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាតដែលត្រូវបានប្រព្រឹត្ត*ដោយចេតនាប្រយោល*នៅឆ្នាំ ១៩៧៥[2862]។

828. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា គ្មាន*ធាតុផ្សំសត្យានុម័តិ*នៃការធ្វើមនុស្សឃាតនៅទំនប់ត្រពាំងថ្ម គឺគ្មានសុភវិនិច្ឆ័យទាល់តែសោះ និងផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើសាលក្រមនេះ ព្រោះម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសតាមរយៈការសន្និដ្ឋានពីអំពើអកម្មនាំឱ្យមានពិរុទ្ធ ដោយមិនបានកំណត់ពីប្រភេទ និងវិសាលភាពនៃកាតព្វកិច្ចក្នុងការចាត់វិធានការ[2863]។ តាមពិត និងផ្អែកតាមការទទួលស្គាល់របស់ម្ចាស់បណ្តឹងសាទុក្ខ[2864] អ.ជ.ស.ដ យល់ថាមាន*ធាតុផ្សំសត្យានុម័តិ* នៃការធ្វើមនុស្សឃាតនៅទំនប់ត្រពាំងថ្មតាមរយៈអំពើឧក្រិដ្ឋដ៏សកម្ម ("ការដាក់លក្ខខណ្ឌលើអ្នកធ្វើការ (...) ដែលបង្កឱ្យពួកគេស្លាប់") ជាជាង "អំពើអកម្ម"។ "ការគ្មានឆន្ទៈ (របស់អាជ្ញាធរការដ្ឋាន) ក្នុងការកែប្រែម៉ោងធ្វើការ និងលក្ខខណ្ឌការងារ ឬលក្ខខណ្ឌនៃការរស់នៅទៅតាមតម្រូវការរបស់អ្នកធ្វើការ ព្រមទាំងឆន្ទៈក្នុងការមិនផ្តល់តំហែទាំសុខភាពជាមូលដ្ឋានសមស្របផងដែរ"[2865] គឺគ្រាន់តែជាការខកខានមិនបញ្ឈប់ និងជាលទ្ធផលបន្តអនុវត្តអំពើសកម្មទាំងនេះ។

829. អ្វីដែលគួរឱ្យកត់សម្គាល់គឺម្ចាស់បណ្តឹងសាទុក្ខមិនបានដេញដោលការវាយតម្លៃរបស់ អ.ជ.ស.ដ លើភ័ស្តុតាង ឬសេចក្តីសន្និដ្ឋានអង្គហេតុ ដែលបង្កើតបានជាមូលដ្ឋាននៃការសេចក្តីសន្និដ្ឋានអង្គច្បាប់ដែលរងការជំទាស់[2866]។ *ក្នុងចំណោមចំណុចផ្សេងទៀត* សេចក្តីសន្និដ្ឋានអង្គហេតុទាំងនេះ

---

[2860] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៦១។

[2861] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦។

[2862] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨០ និង ៨៧-៩៣។

[2863] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៩។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដដែលៗពីការអះអាងដោយមិនត្រឹមត្រូវនេះពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗនៅស្រុកត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៩, ១១៣, ១១៥ និង ១២៣។

[2864] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៥៩ *ដោយដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៨។

[2865] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៨។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៩។

[2866] ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខ ចង់ដេញដោលលើសេចក្តីសន្និដ្ឋានអង្គហេតុតាមរយៈមូលដ្ឋានបណ្តឹងសាទុក្ខរបស់ខ្លួនផ្សេងទៀតវិញនោះ ម្ចាស់បណ្តឹងសាទុក្ខនឹងមិនអាចបញ្ជាក់ពីចេតនារបស់ខ្លួនក្នុង ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ

រួមមាន (i) អ្នកធ្វើការមិនទទួលបានអាហារ ទឹកពិសាគ្រប់គ្រាន់ និងធ្លាក់ខ្លួនឈឺដោយសារទឹកមិនស្អាត[2867] (ii) អ្នកធ្វើការមិនទទួលបានការរស់នៅគ្រប់គ្រាន់ ធ្លាក់ខ្លួនឈឺញឹកញាប់ ហើយអ្នកធ្វើការខ្លះបានស្លាប់ដោយសារជំងឺ[2868] (iii) អ្នកធ្វើការដែលមានជំងឺត្រូវបានចោទប្រកាន់ថា "មានជំងឺសតិអារម្មណ៍" និងទទួលបានថ្នាំដែលគ្មានប្រសិទ្ធភាព ហើយត្រូវបានព្យាបាលដោយគ្រូពេទ្យអសមត្ថភាព[2869] (iv) លក្ខខណ្ឌការងារមានលក្ខណៈបង្ខំឱ្យបំពេញតាមលក្ខខណ្ឌ និងរួមបញ្ចូល*ក្នុងចំណោមចំណុចផ្សេងទៀត* ការពឹងផ្អែកទាំងស្រុងលើកម្លាំងពលកម្មដោយដៃសុទ្ធសាធ[2870] ការតម្រូវឱ្យធ្វើការដោយមិនគិតពីលក្ខខណ្ឌអាកាសធាតុ[2871] ការតម្រូវឱ្យធ្វើការច្រើនម៉ោង (ក្នុងករណីខ្លះ ត្រូវធ្វើការទាំងថ្ងៃទាំងយប់)[2872] និងការកំណត់ផែនការការងារដ៏លំបាក[2873] និង (v) អ្នកធ្វើការបានស្លាប់ស្ទើរតែរៀងរាល់ថ្ងៃបន្ទាប់ពីដួលលើដី[2874]។ ការគ្មានឆន្ទៈក្នុងការកែប្រែលក្ខខណ្ឌទាំងនេះគ្រាន់តែជាការបង្ហាញពីអំពើយ៉ាងរលូនរបស់អាជ្ញាធរការដ្ឋាននោះ ដែលបានកំណត់លក្ខខណ្ឌទាំងនេះ និងបណ្តាលឱ្យមានមនុស្សស្លាប់ក្នុងអំឡុងពេលសាងសង់ទំនប់ទាំងមូល។

830. ក្រៅពីនេះ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃ*ធាតុផ្សំអត្តនោម័តិ*[2875]តាមរយៈការសន្និដ្ឋានថា អាជ្ញាធរនៅទំនប់ត្រពាំងថ្មស្ម័គ្រចិត្តដាក់លក្ខខណ្ឌបែបនេះ

---

៧៥៨-៧៦២ ដោយមានកំណត់សម្គាល់យោងទៅកថាខណ្ឌផ្សេងទៀតក្នុងសារណារបស់គាត់។ ក្នុងករណីណាក៏ដោយ មូលដ្ឋានបណ្តឹងសាទុក្ខផ្សេងទៀតរបស់គាត់មិនបានដេញដោលសេចក្តីសន្និដ្ឋានអង្គហេតុ *ទាំងអស់* ដែលគួសបញ្ជាក់ពីសេចក្តីសន្និដ្ឋានដែលរងការជំទាស់ក្នុងមូលដ្ឋានទី ១១៣ ឡើយ។

[2867] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៩៨, ១៣០១។

[2868] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣០៨, ១៣២០, ១៣៧៥។

[2869] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣២១-១៣២២។

[2870] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៩៦។

[2871] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៧០។

[2872] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៧៨-១២៨០។

[2873] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៨៨។

[2874] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៧៥, ១៣៨៥។ ដោយពិចារណាពីសេចក្តីសន្និដ្ឋានទាំងអស់នេះ អ.ជ.ស.ដ "យល់ឃើញថា ការស្លាប់នៃអ្នកដែលដួលនៅការដ្ឋានគឺដោយសារតែការងារហួសកម្លាំង បាក់កម្លាំង និងខ្វះអាហារ។ អ្នកដែលស្លាប់ដោយសារជំងឺគឺបណ្តាលមកពីលទ្ធផលនៃការធ្វើការធ្ងន់ និងលក្ខខណ្ឌនៃការរស់នៅគ្មានសុខុមាលភាព ដែលបន្ថែមពីលើកង្វះតំហែទាំសុខភាពជាមូលដ្ឋានសមស្រប។ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់លក្ខខណ្ឌទាំងនេះបង្កឱ្យអ្នកធ្វើការស្លាប់នៅការដ្ឋានការងារនេះ" (*សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៤ និងការដកស្រង់នៅក្នុងនោះ)។

[2875] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៦១។

ដោយដឹងថា វានឹងបណ្តាលឱ្យជនរងគ្រោះស្លាប់ ឬព្រមទទួលយកលទ្ធភាពនៃផលវិបាកដែលអាចបណ្តាលឱ្យមានការស្លាប់បែបនេះ[2876]។ ផ្ទុយទៅវិញ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែធ្វើការអះអាងដោយគ្មានមូលដ្ឋានភ័ស្តុតាង និងផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើសេចក្តីសន្និដ្ឋានអង្គច្បាប់របស់ អ.ជ.ស.ដ ស្តីពីការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

831. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងមិនត្រឹមត្រូវថា កត្តាដែលហួសពីការគ្រប់គ្រងរបស់អាជ្ញាធរ និងអត្ថិភាពនៃ "បុរេលក្ខខណ្ឌ" បានផ្តល់ទំនាក់ទំនងធម្មតារវាងលក្ខខណ្ឌដែលបានដាក់ និងផលប៉ះពាល់របស់វាលើអ្នកធ្វើការ។ ដូច្នេះ គេមិនអាចបញ្ជាក់បានដើម្បីរារាំងចៅក្រមមានវិចារណញ្ញាណណាម្នាក់មិនឱ្យកំណត់*ធាតុផ្សំអត្តនោម័តិ*របស់អាជ្ញាធរ សម្រាប់ការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌនានាបានឡើយ[2877]។ ទោះជាយ៉ាងណា ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់រកកត្តាខាងក្រៅ ឬបុរេលក្ខខណ្ឌណាមួយនោះទេ និងបន្តមិនអើពើផ្នែកសំខាន់ៗនៃសេចក្តីសន្និដ្ឋានអង្គច្បាប់របស់ អ.ជ.ស.ដ។

832. អ.ជ.ស.ដ យល់ថា អាជ្ញាធរ "ស្ម័គ្រចិត្តដាក់" លក្ខខណ្ឌ "ក្នុងរយៈពេលយូរ" ដោយមានបំណង "ប្រើអ្នកធ្វើការឱ្យអស់ពីលទ្ធភាពការងារ (...) ដោយមិនខ្វល់ពីសុខុមាលភាពរបស់ពួកគេ ហើយព្រមទទួលយកហានិភ័យថានឹងអាចមានមនុស្សស្លាប់ ដើម្បីសម្រេចគោលដៅរបស់ខ្លួន[2878]។ អ.ជ.ស.ដ បានកត់សម្គាល់បន្ថែមទៀតពី "ការគ្មានឆន្ទៈ" របស់អាជ្ញាធរក្នុងការកែប្រែលក្ខខណ្ឌទាំងនេះដើម្បីពិចារណាពីតម្រូវការរបស់អ្នកធ្វើការ[2879]។ ផ្អែកតាមសេចក្តីសន្និដ្ឋានខាងលើ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថាហេតុអ្វីគ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់យល់ថា កម្រិត និងភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់អាជ្ញាធរ បញ្ជាក់ឱ្យហួសពីវិមតិសង្ស័យនូវចេតនាប្រព្រឹត្តអំពើមនុស្សឃាត។

833. ក្រៅពីនេះ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសតាមរយៈការមិនបញ្ជាក់ពី "វិសាលភាពពេលវេលា" នៃភ័ស្តុតាងដែល អ.ជ.ស.ដ យកជាសំអាងក្នុងការកំណត់ថាមាន*ធាតុផ្សំអត្តនោម័តិ*[2880]។ អ.ជ.ស.ដ យល់ឃើញថា ការងារសាងសង់នៅទំនប់

---

[2876] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៩។

[2877] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៦១។

[2878] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៩, ១៣៨៧។

[2879] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៨។

[2880] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៦១។

ត្រពាំងថ្ម បានចាប់ផ្តើមឡើងនៅចន្លោះដើមឆ្នាំ ១៩៧៦ និងដើមឆ្នាំ ១៩៧៧[2881] យល់ឃើញថាមានសកម្មភាពខ្លាំងបំផុតនៅក្នុងអំឡុងឆ្នាំ ១៩៧៧[2882] និងយល់ឃើញថា ទំនប់ត្រពាំងថ្មត្រូវបានបញ្ចប់ស្ទើរតែទាំងស្រុងនៅដំណាច់ឆ្នាំ ១៩៧៧ ឬពាក់កណ្តាលឆ្នាំ ១៩៧៨[2883]។ អ.ជ.ស.ដ បានបន្តលើកឡើងទៀតថា អាជ្ញាធរបានដាក់លក្ខខណ្ឌទាំងនេះ "ក្នុងរយៈពេលយូរ រួមទាំងក្រោយពីអាជ្ញាធរនៅការដ្ឋានការងារដឹងច្បាស់អំពីផលប៉ះពាល់លើពួកគេក៏ដោយនោះ"[2884]។ ការបកស្រាយធម្មតាលើភាសារបស់ អ.ជ.ស.ដ គួសបញ្ជាក់ថាមាន*ធាតុផ្សំអត្តនោម័តិ* នៅទូទាំងអំឡុងពេលសាងសង់ទំនប់នេះ។ ចំណុចនេះត្រូវបានគាំទ្របន្ថែមទៀតដោយសេចក្តីសន្និដ្ឋានអង្គហេតុរបស់ អ.ជ.ស.ដ ដែលយោងតាមរបាយការណ៍ស្តីពីស្ថានភាពរស់នៅដ៏លំបាកនៅទំនប់ត្រពាំងថ្ម ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦[2885]។ *ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍* និងអត្ថបទបណ្តាញផ្សព្វផ្សាយដែលគួសបញ្ជាក់ពីការខ្វះទឹកនៅទំនប់ត្រពាំងថ្មចាប់ពីពាក់កណ្តាលរហូតដល់ដំណាច់ឆ្នាំ ១៩៧៧[2886] ដំណើរទស្សនកិច្ចផ្តល់ព័ត៌មានដោយស្ថិតក្រោមការឃ្លាំមើលទៅកាន់ទំនប់នេះនៅអំឡុងឆ្នាំ១៩៧៧ និងដើមឆ្នាំ ១៩៧៨ ដែលមន្ត្រី ប.ក.ក បានផ្តល់ព័ត៌មានមិនពិតស្តីពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅដល់គណៈប្រតិភូការទូត និងអ្នកសារព័ត៌មាន[2887] និងរបាយការណ៍ និងទូរលេខរបស់ ប.ក.ក ដែលពិភាក្សាពីស្ថានភាពរស់នៅដ៏លំបាកនៅទំនប់ត្រពាំងថ្មចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៨ រួមទាំងរបាយការណ៍ជាច្រើនដែលផ្ញើដោយមន្ទីរ ៥៦០ នៅភូមិភាគពាយ័ព្យទៅមន្ទីរ ៨៧០ នៅមជ្ឈិមបក្ស[2888]។

## *មូលដ្ឋានទី ១១៤៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*[2889]

---

[2881] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២២០។

[2882] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២២០, ១២៦២។

[2883] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២២១។

[2884] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៩។

[2885] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣០៧។

[2886] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៨៥។

[2887] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២១៦, ១២១៧, ១២២២, ១២៥៣។

[2888] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៣៩-១២៤៨, ១៣១៨។

[2889] មូលដ្ឋានទី ១១៤៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ* កថាខណ្ឌ ៧៦៣-៧៦៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤២-៤៣ (ភាសាអង់គ្លេស) ទំព័រ ៤០ (ភាសាបារាំង) ទំព័រ ៦០ (ភាសាខ្មែរ)។

834. **មូលដ្ឋានទី ១១៤ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ បានប្រព្រឹត្តកំហុសក្នុងការវាយតម្លៃភ័ស្តុតាងដែលមានមូលដ្ឋានលើការសន្និដ្ឋានថា មាន *ធាតុផ្សំសត្យានុម័ត* នៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅទំនប់ត្រពាំងថ្ម។**

835. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមានមូលដ្ឋានលើការបកស្រាយមិនត្រឹមត្រូវនូវភ័ស្តុតាង និងអំពើអកម្មនៃការសន្និដ្ឋានលើអង្គហេតុដែលពាក់ព័ន្ធ ហើយហេតុដូចនេះ គួរត្រូវបានច្រានចោល[2890]។ ជាពិសេស ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខមានមូលដ្ឋានទាំងស្រុងលើការបកស្រាយដីកាដំណោះស្រាយមិនត្រឹមត្រូវរបស់គាត់ និងមិនឆ្លុះបញ្ចាំងឱ្យឃើញពីភ័ស្តុតាងទាំងមូលដែលខ្លួនផ្អែកលើ ក្នុងការបង្ហាញពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[2891]។ អ.ជ.ស.ជ ដែលបានទទួលយកដោយសមស្រប[2892] បានយល់ឃើញថា ក្រុមដែលបានរងការធ្វើទុក្ខបុកម្នេញនៅទំនប់ត្រពាំងថ្ម គឺជា "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក"[2893]។ ការច្រានចោលរបស់ម្ចាស់បណ្តឹងសាទុក្ខនូវការសន្និដ្ឋានលើអង្គហេតុ និងការសន្និដ្ឋានលើអង្គច្បាប់ទូលំទូលាយរបស់ អ.ជ.ស.ជ អំពីការធ្វើទុក្ខបុកម្នេញទៅលើខ្មាំងរបស់ ប.ក.ក មិនឃ្លាតឆ្ងាយពីសេចក្តីសន្និដ្ឋានដោយសមហេតុផលដែលថា (i) ខ្មាំងរបស់ ប.ក.ក គឺជាកម្មវត្ថុចំពោះការរើសអើង *តាមព្រឹត្តន័យ*[2894] (ii) ការប្រព្រឹត្តបែបរើសអើងនេះ

[2890] សូមមើល សាលដីការឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៨។ សាលដីការឿងក្តី *Krajišnik* កថាខណ្ឌ ១៨។ សាលដីការឿងក្តី *Martić* កថាខណ្ឌ ១៧។

[2891] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧៦៣-៧៦៧ (ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមានមូលដ្ឋានទាំងស្រុងលើសម្មតិកម្មខុសដែលថា អ.ជ.ស.ជ បានទទួលយកតែអំពើនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងប្រជាជនថ្មី)។

[2892] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦៨, ៧២, ៧៥, ៧៦, ៧៧, ១២៤, ១៣៤ (*វិសាលភាពនៃបណ្តឹង* សម្រាប់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ)។

[2893] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤០៧, ១៤១៣។

[2894] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤០៩, ១៤១០។ សូមមើលផងដែរ កថាខណ្ឌ ១២៦៨ (*ដោយដកស្រង់* សាក្សីចំនួនបួននាក់ដែលបានផ្តល់សក្ខីកម្មថា អ្នកដែលមិនត្រូវបានគេចាត់ទុកថាខិតខំប្រឹងប្រែងធ្វើការ ត្រូវបានដាក់នៅក្នុងកងពិសេស ដែលមានលក្ខខណ្ឌការងារកាន់តែលំបាក), ១៣៤៥ (*ដោយដកស្រង់* សាក្សីចំនួនប្រាំមួយនាក់ដែលបានផ្តល់សក្ខីកម្មថា ប្រជាជនមូលដ្ឋានត្រូវបានផ្តល់តួនាទីជាអ្នកដឹកនាំ), ១៣៦២-១៣៦៧ (សាក្សីចំនួនបីនាក់បានផ្តល់ព័ត៌មានលម្អិតអំពីការចាប់ខ្លួន និងសម្លាប់ប្រជាជន ដែលត្រូវបានគេចាត់ទុកថាជាខ្មាំងរបស់ ប.ក.ក)។

បានរំលោភសិទ្ធិជាមូលដ្ឋាន[2895] និង (iii) ការរំលោភសិទ្ធិទាំងនេះបានឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរចាំបាច់ ដើម្បីបំពេញ *ធាតុផ្សំសត្យានុម័តិ* នៃការធ្វើទុក្ខបុកម្នេញ[2896]។

## ៩. ព្រលានយន្តហោះកំពង់ឆ្នាំង

### *មូលដ្ឋានទី ១២៣៖ ព្រលានយន្តហោះកំពង់ឆ្នាំង* [2897]

836. **មូលដ្ឋានទី ១២៣ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុស តាមរយៈការកំណត់ឡើងវិញនូវឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលថាជាការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល* នៅព្រលានយន្តហោះកំពង់ឆ្នាំង។**

837. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខគ្រឹមតែលើកឡើងជាថ្មីនូវការអះអាងមិនត្រឹមត្រូវរបស់គាត់ទាក់ទងនឹង *វិសាលភាពនៃបណ្តឹង*[2898] ភាពស្របច្បាប់នៃការកំណត់អង្គហេតុឡើងវិញថាជាអំពើមនុស្សឃាត *ដោយចេតនាប្រយោលភាព*[2899] និងភាពអាចអនុវត្តបាននៃការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល* នៅសម័យអង្គហេតុ[2900]។ ទឡ្ហីករណ៍ទាំងនេះមិនអាចយកជាសំអាងបានទេ ដោយសារ អ.ជ.ស.ដ បានទទួលយកដោយសមស្រប បានចាត់វិធានការក្នុងដែនសិទ្ធិអំណាចរបស់ខ្លួនក្នុងការកំណត់ឡើងវិញនូវអង្គហេតុទាំងនេះ[2901] និងនិយមន័យរបស់*ធាតុផ្សំអត្តនោម័តិ* នៃការធ្វើមនុស្សឃាតថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលលាតសន្ធឹងដល់ *ចេតនាដោយប្រយោល* ក្នុងឆ្នាំ១៩៧៥[2902]។

[2895] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤១១។

[2896] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤១២។

[2897] មូលដ្ឋានទី ១២៣៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ព្រលានយន្តហោះកំពង់ឆ្នាំង* កថាខណ្ឌ ៨១៤-៨២៤។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៥ (ភាសាអង់គ្លេស) ទំព័រ ៤១ (ភាសាបារាំង) ទំព័រ ៦៤ (ភាសាខ្មែរ)។

[2898] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨១៨។

[2899] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨១៤។

[2900] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨២២។

[2901] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៦។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០៣-១៨០៤។

[2902] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៦។

838. ទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខទាក់ទងនឹង *វិសាលភាពនៃបណ្ដឹង* មិនទទួលបានផលទេ ដោយសារហេតុផលដូចដែលបានលើកឡើងខាងលើ[2903]។ ទឡ្ហីករណ៍នេះក៏មិនអាចយកជាសំអាងបានផងដែរ ដោយសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានស្នើឡើងយ៉ាងពិសេសឱ្យមានការស៊ើបអង្កេតមួយទៅក្នុង *ដែលក្នុងចំណោមនោះ* ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅព្រលានយន្តហោះកំពង់ឆ្នាំង[2904]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកឡើងថា អ្នកធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង "អត់បាយបន្តិចម្ដងៗ" ត្រូវបានបង្ខំឱ្យធ្វើ "ការងារធ្ងន់" និងត្រូវបានយកទៅសម្លាប់ និងបានបាត់ខ្លួន[2905]។ លើសពីនេះទៀត តារាងបញ្ជីឯកសារទី ៥២ របស់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះកត់សម្គាល់អំពីភ័ស្តុតាងរបស់សាក្សីជាច្រើន ដែលពិពណ៌នាអំពីកង្វះអាហារ ការងារដែលបង្កឱ្យហត់នឿយខ្លាំង និងលក្ខខណ្ឌដ៏វេទនាផ្សេងៗទៀតនៅព្រលានយន្តហោះកំពង់ឆ្នាំង[2906]។ ដូច្នេះ ស.ច.ស បានទទួលយកដោយសមស្រប ដើម្បីស៊ើបអង្កេតបន្ថែមទៀតទៅលើលក្ខខណ្ឌទាំងនេះនៅព្រលានយន្តហោះកំពង់ឆ្នាំង និងចោទប្រកាន់ម្ចាស់បណ្ដឹងសាទុក្ខពីបទការស្លាប់ដែលបង្កឡើងដោយលក្ខខណ្ឌទាំងនេះ[2907]។

839. ម្ចាស់បណ្ដឹងសាទុក្ខអះអាងទាំងមិនត្រឹមត្រូវបន្ថែមទៀតថា អ.ជ.ស.ដ បានខកខានមិនបានកំណត់ភារកិច្ចស្របច្បាប់ ដើម្បីអនុវត្តការងារ ហើយដូច្នេះបានប្រព្រឹត្តកំហុសនៅក្នុងការបង្ហាញពី*ធាតុផ្សំសត្យានុម័ត*នៃការធ្វើមនុស្សឃាត[2908]។ ការពិត និងដូចដែលត្រូវបានទទួលស្គាល់ដោយម្ចាស់បណ្ដឹងសាទុក្ខ[2909] អ.ជ.ស.ដ បានយល់ឃើញថា *ធាតុផ្សំសត្យានុម័ត* នៃការធ្វើមនុស្សឃាតនៅព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានគាំទ្រដោយអំពើឧក្រិដ្ឋកម្មវិជ្ជមាន៖ "លក្ខខណ្ឌផ្សេងៗត្រូវ

[2903] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៨។

[2904] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២។

[2905] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៧។

[2906] ឯកសារ **D3** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៧ *ដោយដកស្រង់ តារាងបញ្ជីឯកសារទី ៥២ ស្ថានភាពនៅការដ្ឋានសាងសង់អាកាសយានដ្ឋានខេត្តកំពង់ឆ្នាំង* ទំព័រ ៩៧-៩៩។

[2907] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១-១៣៩០។

[2908] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨២១។ ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងជាថ្មីនូវការអះអាងមិនត្រឹមត្រូវនេះទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៩, ១១៣, ១១៥ និង ១២៣។

[2909] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨២២ *ដោយដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០៥។

បានកំណត់ឡើងដែលនាំឱ្យមនុស្សជាច្រើននាក់ស្លាប់ រួមទាំងការដាក់ប្រជាជនឱ្យស្ថិតក្នុងលក្ខខណ្ឌការងារដែលគ្មានសុវត្ថិភាព និងការបង្ខំពួកគេឱ្យធ្វើការរយៈពេលយូរ ដោយគ្មានម្ហូបអាហារគ្រប់គ្រាន់"[2910]។ ដូច្នេះ ការណ៍ដែល "ពុំមានវិធានការសមស្របសម្រាប់ផ្លាស់ប្តូរ ឬជួយបន្ធូរបន្ថយលក្ខខណ្ឌបែបនេះ" មិនមែនជាអំពើអកម្មដាច់ដោយឡែកមួយនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺជាការខកខានមិនបានបញ្ឈប់អំពើទាំងនេះ[2911]។

840. អ.ជ.ស.ដ បានលើកឡើងថា លក្ខខណ្ឌនៅព្រលានយន្តហោះកំពង់ឆ្នាំង រួមមានការបំបែកថ្មដែលខ្មាតត្រូវអ្នកធ្វើការដោយសារការបំផ្ទុះដែលពាក់ព័ន្ធនឹងការងារ[2912] កង្វះឧបករណ៍ការពារ និងការកើតមានឡើងឧប្បត្តិហេតុបណ្តាលឱ្យស្លាប់[2913] និងការធ្វើការហួសកម្លាំង និងការបង្អត់អាហារ[2914]។ អាជ្ញាធរការដ្ឋាន បានដឹងពីលក្ខខណ្ឌនៅព្រលានយន្តហោះកំពង់ឆ្នាំងនៅទូទាំងរយៈពេលទាំងមូលនៃការសាងសង់ព្រលានយន្តហោះនេះ ប៉ុន្តែមិនមានឆន្ទៈកែសម្រួលលក្ខខណ្ឌទាំងនេះ និង "ការមិនអើពើអំពីជោគវាសនារបស់អ្នកធ្វើការ"[2915] ដូច្នេះ បំពេញ*ធាតុផ្សំអត្តនោម័តិ* តាមការតម្រូវ[2916]។ អ.ជ.ស.ដ បានយល់ឃើញថា ការស្លាប់នៅព្រលានយន្តហោះកំពង់ឆ្នាំងអាចចៀសវាងបាន ប្រសិនបើអាជ្ញាធរ"កែប្រែកាលវិភាគការងារ ឬធ្វើឱ្យលក្ខខណ្ឌនៃការរស់នៅ និងសុវត្ថិភាពមានភាពប្រសើរឡើងវិញ" ប៉ុន្តែពួកគេមានចេតនាមិនធ្វើដូច្នេះ[2917]។ លើសពីនេះទៀត ម្ចាស់បណ្តឹង

[2910] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០០។

[2911] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០៤។ លើសពីនេះ ទាក់ទងនឹងព្រលានយន្តហោះកំពង់ឆ្នាំង ដោយសារលក្ខណៈមូលដ្ឋានយោធា អ.ជ.ស.ដ បានពឹងផ្អែកលើយុត្តិសាស្ត្រដែលបង្ហាញពីអត្ថិភាពនៃភារកិច្ចថែទាំចំពោះទាហាន ដើម្បីធានា "ថា កិច្ចការ និងវិន័យរបស់ពួកគេ មិនឱ្យលើសពីកម្រិតនៃការឈឺចាប់ដែលមានមកជាមួយស្រាប់ចំពោះមុខងាររបស់ពួកគេ"។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៣៤ *ដោយដកស្រង់ រឿងក្តី Quispialaya Vilcapoma តទល់នឹងប្រទេសប៉េរូ* តុលាការសិទ្ធិមនុស្សអឺរ៉ុបអន្តរអាមេរិក សាលក្រម ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៥ (ស៊េរី C លេខ ៣០៨) កថាខណ្ឌ ១២៤ (បកប្រែក្រៅផ្លូវការ)។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៩។

[2912] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៥៥, ១៨០១។

[2913] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៥៥-១៧៥៦, ១៧៦០, ១៨០១។

[2914] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៥៨, ១៨០០, ១៨០២។

[2915] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០០។

[2916] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០៥។

[2917] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៣២, ១៨៣៥។

សាទុក្ខខកខានមិនបានកំណត់កត្តាខាងក្រៅដែលចាត់ទុកថា ទំនាក់ទំនងហេតុ និងផលរវាងលក្ខខណ្ឌទាំងនេះ និងការស្លាប់នៅព្រលានយន្តហោះកំពង់ឆ្នាំងគ្មានសុពលភាព[2918]។

841. ម្ចាស់បណ្ដឹងសាទុក្ខក៏ចោទប្រកាន់ដោយមិនត្រឹមត្រូវផងដែរថា អ.ជ.ស.ដ មិនបានវាយតម្លៃ "ភ័ស្តុតាងឱ្យបានច្បាស់លាស់ទាក់ទងនឹងពេលវេលា"[2919]។ អ.ជ.ស.ដ បានយល់ឃើញថា ការសម្រេចចិត្តចាប់ផ្ដើមការសាងសង់នៅព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៅក្នុងខែមេសា ឆ្នាំ១៩៧៦ ហើយការសាងសង់បានចាប់ផ្ដើមនៅពាក់កណ្ដាលឆ្នាំ១៩៧៦ និងបានបន្តរហូតដល់ខែមករា ឆ្នាំ១៩៧៩[2920]។ ក្នុងការវាយតម្លៃលក្ខខណ្ឌនានានៅព្រលានយន្តហោះកំពង់ឆ្នាំង អ.ជ.ស.ដ បានពឹងផ្អែកលើសក្ខីកម្មដែលទទួលបានពីសាក្សីដែលបានធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង នៅទូទាំងរយៈកាលទាំងស្រុងនៃការសាងសង់របស់ព្រលាននេះ[2921] និងបានបញ្ជាក់ថា ស្ថានភាពប្រកបដោយគ្រោះថ្នាក់ និងអមនុស្សធម៌ត្រូវបានរក្សា "រយៈពេលយូរ" រួមទាំងបន្ទាប់ពីផលប៉ះពាល់អវិជ្ជមានទៅលើអ្នកធ្វើការបានលេចឡើងច្បាស់លាស់[2922]។ ដូច្នេះការអានដ៏សាមញ្ញនៃភាសារបស់ អ.ជ.ស.ដ បង្ហាញថា *ធាតុផ្សំអត្តនោម័តិ* នៃអំពើមនុស្សឃាតបានលាតសន្ធឹងដល់រយៈកាលទាំងស្រុងនៃការសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

### ii. មន្ទីរសន្តិសុខ

842. អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថា ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ អំពើអមនុស្សធម៌ផ្សេងៗទៀត (ការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ) ការធ្វើទណ្ឌកម្ម កាធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខនានាអនុលោមតាមគោលនយោបាយរបស់ ប.ក.ក ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន

[2918] *ផ្ទុយពី* ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨២៣។

[2919] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨២៣។

[2920] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣-១៧២៤។

[2921] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៣១ *ដោយដកស្រង់ឧទាហរណ៍* ឯកសារ E1/321.1 ហ៊ឹម ហន ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 11.10.09-11.17.09 ទំព័រ ៣១-៣២។ ឯកសារ E3/5810 កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ប្រតិចារឹក ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ម៉ោង 11.22.26-11.28.12 ទំព័រ ៣៩-៣៩។ ឯកសារ E3/369 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កុយ ម៉ុន KH 00195436-38។

[2922] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨០៥។

ដាក់ឱ្យនៅដាច់ដោយឡែក និង "កម្ទេច" ខ្មាំងប្រភេទធ្ងន់ធ្ងរបំផុតនៅមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស និងដើម្បីអប់រំ "សមាសភាពមិនល្អ"[2923]។ គោលនយោបាយឧក្រិដ្ឋនេះមានទំនាក់ទំនងសំខាន់ទៅនឹងគោលបំណងរួម[2924]។ លើសពីនេះទៀត អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្ត ដោយសារការដាក់លក្ខខណ្ឌអមនុស្សធម៌នៅមន្ទីរសន្តិសុខទាំងនេះ[2925]។

843. មូលដ្ឋានចំនួនប្រាំបីរបស់ម្ចាស់បណ្តឹងសាទុក្ខ[2926] ទាក់ទងនឹងមន្ទីរសន្តិសុខ មិនទទួលបានផលទេ ដោយសារមូលដ្ឋានទាំងនេះកំណត់មិនត្រឹមត្រូវនូវភ័ស្តុតាងដែល អ.ជ.ស.ដ បានពិចារណា[2927] ពឹងផ្អែកលើការទាយស្មាន[2928] មិនឆ្លើយតបទៅនឹងបទដ្ឋានដែលតម្រូវសម្រាប់ការពិនិត្យបណ្តឹងសាទុក្ខឡើងវិញ[2929] និងខកខានមិនបានបង្ហាញការអះអាងដែលធានាដល់ការអន្តរាគមន៍របស់ អ.ជ.ត.ក[2930]។ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខយល់ខុស និងប្រើប្រាស់មិនត្រឹមត្រូវនូវទិដ្ឋភាពសំខាន់ៗនៃច្បាប់ស្តីពីការធ្វើទុក្ខបុកម្នេញ[2931]។

## ១. មន្ទីរសន្តិសុខ ស-២១

### *មូលដ្ឋានទី ១២៥៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ* [2932]

[2923] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧៦ (ការធ្វើមនុស្សឃាត), ៣៩៧៨-៣៩៨៣ (ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ), ៣៩៨៥-៣៩៨៦ (អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)។ សូមមើលផងដែរ កថាខណ្ឌ ៣៩៨៧។

[2924] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧៣, ៣៩៨៧។

[2925] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៥៦៨, ២៨១៥, ៣១១៦។

[2926] មូលដ្ឋានទី ១២៥, ១២៧, ១២៩, ១៣១-១៣៣, ១៣៥, ២៥១។

[2927] មូលដ្ឋានទី ១៣៣។

[2928] មូលដ្ឋានទី ១៣១។

[2929] មូលដ្ឋានទី ១៣៥។

[2930] មូលដ្ឋានទី ១២៧, ១៣២, ២៥១។

[2931] មូលដ្ឋានទី ១២៥, ១២៩។

[2932] មូលដ្ឋានទី ១២៥៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ* កថាខណ្ឌ ៨២៥-៨២៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៦ (ភាសាអង់គ្លេស) ទំព័រ ៤២ (ភាសាបារាំង) ទំព័រ ៦៥ (ភាសាខ្មែរ)។

844. **មូលដ្ឋានទី ១២៥ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ បានប្រព្រឹត្តកំហុសអង្គហេតុ ឬអង្គច្បាប់ តាមរយៈការសន្និដ្ឋានថា "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក" គឺជាក្រុមដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់ និងថា ពួកគេបានរងគ្រោះដោយសារការរើសអើង *តាមព្រឹត្តន័យ* នៅមន្ទីរសន្តិសុខ ស-២១។**

845. មូលដ្ឋាននេះមិនទទួលបានផលទេ ទាក់ទងនឹងកំហុសដែលត្រូវបានចោទប្រកាន់ ពោលគឺជាប្រភេទកំហុសដែលម្ចាស់បណ្តឹងសាទុក្ខមិនបញ្ជាក់ច្បាស់លាស់ ដោយសារគាត់មិនអើពើនឹងយុត្តិសាស្ត្រដែលពាក់ព័ន្ធរបស់ អ.វ.ត.ក និងបកស្រាយមិនត្រឹមត្រូវនូវសេចក្តីសន្និដ្ឋាននេះរបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០១។

846. ផ្ទុយទៅនឹងការអះអាងដែលមិនត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ[2933] "សត្រូវពិតប្រាកដ ឬសត្រូវតាមការសន្មតរបស់ ប.ក.ក" អាចបង្កើតបានជាក្រុមដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់[2934]។ ហេតុដូច្នេះ អ.ជ.ស.ជ មិនបានប្រព្រឹត្តកំហុសនោះទេក្នុងការសន្និដ្ឋានថា ប្រភេទខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតបាន "រីករាលដាលថែមទៀតពីពេលមួយទៅពេលមួយ" ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ[2935] និងថា អ្នកទោសរបស់មន្ទីរសន្តិសុខ ស-២១ ជាច្រើនបានធ្លាក់ចូលទៅក្នុងប្រភេទទាំងនោះ[2936]។ សេចក្តីសន្និដ្ឋានទាំងនេះ មានមូលដ្ឋានលើភ័ស្តុតាងដែលមានតម្លៃខ្ពស់ ដែលមានលើកឡើងនៅក្នុងសាលក្រម[2937] ដែល អ.ជ.ស.ជ បានកំណត់តារាងកាលប្បវត្តិច្បាស់លាស់មួយនៃសញ្ញាណខ្មាំងរបស់ ប.ក.ក និងប្រភេទមនុស្សច្បាស់លាស់ដែលធ្លាក់ចូលទៅក្នុងក្រុមគោលដៅនៃខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក[2938]។

---

[2933] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨២៥។

[2934] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៧៣។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៦៩។ សូមមើលផងដែរសំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៨២។ សូមមើលចម្លើយតបទៅនឹងមូលដ្ឋានទី ៦៨, ៧២, ៧៥, ៧៦, ៧៧, ១២៤ និង ១៣៤ (*វិសាលភាពនៃបណ្តឹង* សម្រាប់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ បីក្រុម)។

[2935] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០០ ជើងទំព័រ ៨៧៨៩ *កំណត់សម្គាល់យោងទៅ* កថាខណ្ឌ ៣៧៤៤-៣៨៦៣ (ផ្នែក ១៦.៣៖ ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត)។ សូមមើល *ជាពិសេស* កថាខណ្ឌ ៣៨៣៩។

[2936] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០០, ២៦០២។ សូមមើលផងដែរ កថាខណ្ឌ ២៥៧៧។

[2937] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៤-៣៧៤៨។

[2938] សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៤-៣៨៦៣ (ផ្នែក ១៦.៣៖ ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត)។ សូមមើលផងដែរ កថាខណ្ឌ ២៦០០, ២៦០២។

847. ម្ចាស់បណ្ដឹងសាទុក្ខក៏លើកឡើងដែលពុំអាចធ្វើឱ្យជឿបានផងដែរថា សេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា អ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ "ត្រូវបានចាប់ខ្លួនក្នុង *ទ្រង់ទ្រាយធំ* [...] ជាពិសេសក្នុងពេលបោសសម្អាត និងក្នុងពេលមានជម្លោះជាមួយនឹងវៀតណាមឡើងកម្ដៅខ្លាំង" បង្ហាញថា ពួកគេត្រូវបានកំណត់គោលដៅ ដោយគ្មានការរើសអើង ជាជាងត្រូវបានរើសអើងទៅតាមជាក់ស្ដែង[2939]។ ដូចដែលបានបង្ហាញខាងលើដែលត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូល និងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវដោយ អ.ជ.ស.ដ "អំពើសកម្ម ឬអកម្ម គឺជាការរើសអើងជាក់ស្ដែង នៅពេលដែល "ជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះជាសមាជិកនៅក្នុងក្រុមណាមួយ ដែលថាវីបានកំណត់ដោយមូលហេតុជាក់លាក់មួយចំនួន"[2940]។ វាមិនមែនជាចំនួនមនុស្សគោលដៅដែលកំណត់ថា តើមនុស្សទាំងនោះគឺជាកម្មវត្ថុចំពោះការរើសអើង *តាមព្រឹត្តន័យ* ឬអត់នោះទេ។ ប្រសិនបើដូច្នេះមែន ចំនួនជនរងគ្រោះបង្ហាញពីលក្ខណៈជាប្រព័ន្ធ និងមានការចាត់តាំងថា តើខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក ណាម្នាក់ដែលត្រូវបានកំណត់គោលដៅ[2941]។

848. លើសពីនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខបកស្រាយមិនត្រឹមត្រូវនូវសេចក្ដីសន្និដ្ឋាននេះរបស់ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០១ ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅមន្ទីរសន្តិសុខ ស-២១ ដើម្បីគាំទ្រដល់ការអះអាងមិនត្រឹមត្រូវរបស់គាត់ថា អ្នកទោសក្នុងសំណុំរឿង ០០២/០២ ត្រូវបានកំណត់គោលដៅដោយគ្មានការរើសអើង[2942]។ ដោយពិចារណាទៅលើសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០១ ថា "នៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ "ដំណើរការបោសសម្អាតខ្លាំងរបស់អង្គការ បានធ្វើឱ្យបុគ្គលមួយចំនួនមានការភ័យខ្លាចមិនទុកចិត្ត

---

[2939] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០១ (គូសបញ្ជាក់លើអត្ថបទដើម)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨២៦។

[2940] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។ សូមមើលផងដែរ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៧២ (គូសបញ្ជាក់លើអត្ថបទដើមត្រូវបានលុបចោល)។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៦៧, ៦៩០។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧១៤។

[2941] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៥៤៨, ៣៩៨២។ សូមមើលផងដែរ កថាខណ្ឌ ២៥៦៣ (ការសម្លាប់នៅមន្ទីរសន្តិសុខ ស-២១), ២៥៦៨ (ការធ្វើបាបនៅមន្ទីរសន្តិសុខ ស-២១), ២៦០២ (គោលនយោបាយរបស់ ប.ក.ក កំណត់គោលដៅទៅលើគូបដិបក្ខនយោបាយតាមការសន្មត), ៣៩៥៨ (ការសម្លាប់ជាប្រព័ន្ធរបស់ ប.ក.ក)។

[2942] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨២៦ (ជើងទំព័រ ១៤៨៣-១៤៨៤ *ដោយដកស្រង់* សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៧៧, ២៨៣), ៨២៧។

គ្នា និងកាប់សម្លាប់គ្នាពេញផ្ទៃប្រទេស""។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានបញ្ជាក់ថា "ដោយខ្មាំងនយោបាយ ត្រូវបានកំណត់តាមគោលនយោបាយមួយដែលប្រើប្រាស់លក្ខណៈវិនិច្ឆ័យទូទៅ នៅខណៈដែលប្រជាជនដទៃទៀតទទួលបានសេរីភាព ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការយល់ឃើញថា មានអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ"[2943]។ គោលការណ៍នីត្យានុកូលភាពដែលត្រូវបានបំពេញក្នុងសំណុំរឿង ០០១ គឺថា ការកំណត់គោលដៅដោយគ្មានការរើសអើងមិនបំពេញធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញដែលចាំបាច់នោះទេ។ ទោះជាយ៉ាងណា ការសន្និដ្ឋានលើអង្គហេតុទាក់ទងនឹងថា តើការកំណត់គោលដៅពិតជាគ្មានការរើសអើងឬអត់នោះ គឺអាស្រ័យលើករណីនីមួយៗ និងដូចដែលម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថាជា "សំណុំរឿងពីរផ្សេងគ្នា"[2944]។

849. ដោយផ្អែកភស្តុតាងដែលមានតម្លៃខ្ពស់យ៉ាងច្រើនសន្ធឹកសន្ធាប់[2945] អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ បានយល់ឃើញដោយសមហេតុផលថា "ទិសដៅនៃប្រតិបត្តិការរបស់មន្ទីរសន្តិសុខ ស-២១ គឺតម្រង់ទៅរកខ្មាំងនយោបាយពិតប្រាកដ ឬតាមសន្មតរបស់ ប.ក.ក" ដែលជាក្រុមដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់[2946]។ ជនរងគ្រោះរួមមានអ្នកបន្ទះបង្អាប់បដិវត្តន៍សង្គមនិយម អ្នករិះគន់ ឬប្រឆាំងនឹងបក្ស អតីតខ្មែរក្រហម និងប្រជាជនថ្មី[2947] ដែលត្រូវបាន

[2943] សំណុំរឿង ០០១-ឯកសារ F28 សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៨២។

[2944] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨២៧។ វាមានតម្លៃគួរឱ្យកត់សម្គាល់ថា នៅបណ្តឹងសាទុក្ខ ឌុច នៅតែមានពិរុទ្ធភាពពីបទការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ដែល *គាត់បានដឹង* ថាការពិតគឺជាខ្មាំងរបស់បក្ស និងថា ការផ្តន្ទាទោសរបស់គាត់ពីបទការធ្វើទុក្ខបុកម្នេញត្រូវបានច្រានចោល *តែ* សម្រាប់អ្នកទោសដែលគាត់មិនបានជឿថាការពិតគឺជាខ្មាំងតែប៉ុណ្ណោះ ហើយដូច្នេះអ្នកទាំងនោះគឺជាមនុស្សដែលគាត់បានកំណត់គោលដៅដោយគ្មានការរើសអើង។ សូមមើល សំណុំរឿង ០០១-ឯកសារ F28 សាលដីការឿងក្តី ឌុច កថាខណ្ឌ ២៨៣ ("ពាក់ព័ន្ធនឹងអំពើនានាដែលបានប្រព្រឹត្តទៅលើបុគ្គលទាំងនេះ [...] អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ដោយបានកំណត់អំពើទាំងនេះថាជាអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ") (គូសបញ្ជាក់បន្ថែម), ២៨៤, ២៧៧។ ដោយមិនគិតពីបញ្ហានេះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញអំពីរបៀបដែលការសន្និដ្ឋានលើអង្គហេតុពីសំណុំរឿង ០០១ រារាំងដល់ការសន្និដ្ឋានអំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅមន្ទីរសន្តិសុខ ស-២១ ក្នុងសំណុំរឿង ០០២/០២។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ៦៨, ៧២, ៧៥, ៧៦, ៧៧, ១២៤ និង ១៣៤ (*វិសាលភាពនៃបណ្តឹង* សម្រាប់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយៈ បីក្រុម)។

[2945] សូមមើល ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៨៦-២១៣៤ (ផ្នែក ១២.២.៣ ការពិចារណាជាទូទៅលើភស្តុតាង)។

[2946] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០១។

[2947] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០០, ២៤៨៥-២៤៩២, ២២៣០។

កំណត់អត្តសញ្ញាណ និងចាប់ខ្លួន *ពីព្រោះ* ពួកគេត្រូវបាន "កំណត់ឈ្មោះពួកគេថាជា ខ្មាំង ជាជនក្បត់ ឬជាគិញ និងត្រូវបានគេមើលឃើញថាជាខ្មាំងនយោបាយរបស់ ប.ក.ក និងបដិវត្តន៍"[2948]។ នៅពេញមួយរយៈពេលនៃការឃុំឃាំងរបស់ពួកគេនៅមន្ទីរសន្តិសុខ ស-២១ ពួកគេ "ត្រូវបានចាត់ទុកជាខ្មាំងផ្ទៃក្នុង ឬខ្មាំងខាងក្រៅ ដែលមានទំនាក់ទំនងតាមការសន្មតថាជា CIA ឬ KGB ឬគិញវៀតណាម"[2949]។

850. លើសពីនេះទៀត អ.ជ.ស.ដ បានយល់ឃើញដោយសមហេតុផលពីភ័ស្តុតាងថា ជនរងគ្រោះទាំងនេះ "ត្រូវបានចាប់ខ្លួន ឃុំខ្លួន ត្រូវគេធ្វើបាបយ៉ាងធ្ងន់ធ្ងរ និងដាក់ឱ្យរស់នៅក្នុងស្ថានភាពលំបាកវេទនា ហើយទីបំផុតត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ គឺជាលទ្ធផលដោយផ្ទាល់នៃឋានៈតាមការសន្មតរបស់ពួកគេថាជាខ្មាំងរបស់ ប.ក.ក"[2950]។ ឧទាហរណ៍ "បុគ្គលិកមន្ទីរសន្តិសុខ ស-២១ ទាំងអស់ ត្រូវគេបង្រៀនឱ្យទទួលស្គាល់ និងមានភាព "ដាច់ខាត" ក្នុងការកម្ទេច "ខ្មាំង" និងដឹងថា អ្នកដែលអង្គការចាប់គឺសុទ្ធតែជាខ្មាំង"[2951]។ "អ្នកសួរចម្លើយត្រូវបានណែនាំថា កុំឱ្យអាណិតអាសូរ ទន់ជ្រាយជាមួយនឹង "ខ្មាំង" បើទោះបីជាខ្មាំងទាំងនោះគឺជាឪពុកម្តាយរបស់ពួកគេក៏ដោយ"[2952]។ ជនរងគ្រោះដែលស្ថិតក្នុងក្រុមគោលដៅ ត្រូវបានតម្រូវឱ្យទទួលស្គាល់ទោសកំហុសរបស់ពួកគេ[2953]។ អ្នកទាំងឡាយណាដែលត្រូវបានសួរចម្លើយ "ទទួលរងការគាបសង្កត់ ឬការធ្វើបាបទាំងផ្លូវកាយ និងផ្លូវចិត្ត ដើម្បីទទួលបានចម្លើយសារភាពអំពីខ្សែបណ្តាញក្បត់ ដែលបានសន្មតរួចទៅហើយនោះ"[2954]។ បន្ទាប់មក សមាជិករបស់ក្រុមគោលដៅ

---

[2948] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០១។

[2949] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០២។

[2950] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០២។ សូមមើលផងដែរ កថាខណ្ឌ ២៦០១។ សម្រាប់ប្រភេទបន្ថែមនៃខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក នៅមន្ទីរសន្តិសុខ ស-២១។ *សូមមើលឧទាហរណ៍* កថាខណ្ឌ ២៦០០, ២៤៨៦។ សូមមើលផងដែរ កថាខណ្ឌ ២៥៣១។

[2951] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៦៣។ សូមមើលផងដែរ កថាខណ្ឌ ២១៦៩, ២៤០២។

[2952] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៦៣។ សូមមើលផងដែរ កថាខណ្ឌ ២១៦៩, ២៣៩៥។

[2953] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៦៣។ សូមមើលផងដែរ កថាខណ្ឌ ២១៦៩, ២២៣៦, ២៣៧២, ២៣៨៩។

[2954] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦០១ *កំណត់សម្គាល់* ក្នុងជើងទំព័រ ៨៧៩២ *យោងទៅ ក្នុងចំណោមនោះ* កថាខណ្ឌ ២៣២៨។ សូមមើលផងដែរ កថាខណ្ឌ ២៣២៧, ២៣៨៧, ២៣៨៩, ២៣៩៦-២៣៩៧។

ត្រូវទទួលរងការកម្ទេច[2955]។ ដូចគ្នានេះដែរ អ្នកទោសសំខាន់ៗមកពីក្នុង ប.ក.ក ដែលត្រូវបានរក្សាទុកក្នុងគុកពិសេសនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានដាក់ក្នុង "លក្ខខណ្ឌមួយដែលអាចឱ្យពួកគេនៅមានជីវិតបានយូរគ្រប់គ្រាន់ និងអាចផ្តល់ចម្លើយសារភាពចប់សព្វគ្រប់មុនពេលសម្លាប់ពួកគេនៅពេលក្រោយមកនោះ"[2956]។

## ២. មន្ទីរសន្តិសុខក្រាំងតាចាន់

### *មូលដ្ឋានទី ១២៧៖ មន្ទីរសន្តិសុខក្រាំងតាចាន់* [2957]

851. **មូលដ្ឋានទី ១២៧ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ បានប្រព្រឹត្តកំហុសក្នុងការសន្និដ្ឋានថា អំពើនៃការបាត់ខ្លួនដោយបង្ខំអាចត្រូវបានប្រព្រឹត្តឡើងលើសពីម្តងលើមនុស្សតែម្នាក់។**

852. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ជ បានប្រព្រឹត្តកំហុសក្នុងការបកស្រាយ ឬការអនុវត្តច្បាប់របស់ខ្លួន។ គាត់ត្រឹមតែមិនយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ជ ប៉ុណ្ណោះ។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានផ្តល់អំណាចស្របច្បាប់ណាមួយ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា អំពើនៃការបាត់ខ្លួនដោយបង្ខំគឺជា "ការប្រព្រឹត្តបែបឧក្រិដ្ឋបន្តជាប់រហូត"[2958] ហើយដូច្នេះមិនអាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មពីរដាច់ដោយឡែកគ្នាបានទេ។ ទីមួយ នៅពេលដែលអ្នកជាប់ឃុំបានបាត់ខ្លួនដំបូងពីសហករណ៍ ដែលត្រូវយកទៅឃុំឃាំងនៅក្រាំងតាចាន់ និងទីពីរនៅពេលដែលពួកគេបានបាត់ខ្លួនពីការឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលគេយកទៅសម្លាប់[2959]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញបន្ថែមទៀតថា សេចក្តីសន្និដ្ឋានដែលពាក់ព័ន្ធរបស់ អ.ជ.ស.ជ ពិតជាបង្កឱ្យមានយុត្តិនិសេធក្នុងកាលៈទេសៈមួយចំនួន ដែលសេចក្តីសន្និដ្ឋាននេះមិនមានសារៈសំខាន់ចំពោះ

---

[2955] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៤៩, ២២៣៦, ២២៤៥, ២៣៥០, ២៥០៤។ ការមិនសម្លាប់កើតមានយ៉ាងកម្រ។ សូមមើល កថាខណ្ឌ ២៣៥០, ២៥៦៦, ២៦០១ (ជើងទំព័រ ៨៧៩៥ *កំណត់សម្គាល់យោងទៅ ក្នុងចំណោមនោះ* កថាខណ្ឌ ២៤៥១)។ សូមមើលផងដែរ កថាខណ្ឌ ២៣៦២។

[2956] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២៥៦, ២២៥៨។

[2957] <u>មូលដ្ឋានទី ១២៧</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ក្រាំងតាចាន់* កថាខណ្ឌ ៨៣៧-៨៤០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៦ (ភាសាអង់គ្លេស) ទំព័រ ៤២ (ភាសាបារាំង) ទំព័រ ៦៦ (ភាសាខ្មែរ)។

[2958] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣៧-៨៣៨។

[2959] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣៩។

សាលក្រមដែលសម្រេចបាន ដែលម្ចាស់បណ្តឹងសាទុក្ខបានប្រព្រឹត្តអំពើនៃការបាត់ខ្លួនដោយបង្ខំដំបូងទៅលើអ្នកដែលត្រូវបានគេយកទៅមន្ទីរសន្តិសុខក្រាំងតាចាន់[2960]។

853. អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ការបាត់ខ្លួនដោយបង្ខំដែលជាឧក្រិដ្ឋកម្មមួយ ពុំមាន "ធាតុផ្សំ និងនិយមន័យជាក់លាក់ស្របច្បាប់"[2961] នៅឡើយទេនៅក្នុងឆ្នាំ ១៩៧៥។ ហេតុដូច្នេះ ការវិភាគអង្គច្បាប់សមស្របដើម្បីបង្ហាញពីឧក្រិដ្ឋកម្ម គឺដើម្បីបញ្ជាក់ឱ្យឃើញពីធាតុផ្សំនិត្យានុកូលនៃឧក្រិដ្ឋកម្មក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ពោលគឺ៖ (i) អំពើសកម្ម ឬអកម្មដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ii) អំពើសកម្ម ឬអកម្មដែលបណ្តាលឱ្យមានការឈឺចាប់ និងព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង (iii) អំពើសកម្មឬអកម្មដែលបានប្រព្រឹត្តដោយចេតនា[2962]។ អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថា "អំពើជាក់លាក់នៃការបាត់ខ្លួនដោយបង្ខំអាចត្រូវបានប្រព្រឹត្តលើសពីម្តងលើមនុស្សតែម្នាក់ ដោយសារតែធាតុផ្សំចាំបាច់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានបំពេញក្នុងពេលនីមួយៗ"[2963]។

854. អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថា ការបាត់ខ្លួនដោយបង្ខំបានកើតមានឡើងនៅក្នុងករណីដំបូង នៅពេលដែលអ្នកជាប់ឃុំត្រូវបានចាប់ខ្លួននៅក្នុងឃុំ និងការដ្ឋានរបស់ពួកគេ និងបានបាត់ខ្លួនទៅកាន់មន្ទីរសន្តិសុខក្រាំងតាចាន់[2964]។ សមាជិកគ្រួសារមិនត្រូវបានផ្តល់ដំណឹងណាមួយនោះទេទាក់ទងនឹងទីកន្លែងដែលមនុស្សជាទីស្រលាញ់របស់ពួកគេស្ថិតនោះ[2965]។ នៅពេលដាក់ក្នុងមន្ទីរឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ អង្គជំនុំជម្រះបានរកឃើញបន្ថែមទៀតនូវអំពើនៃការបាត់ខ្លួនដោយបង្ខំ ខណៈពេលដែលបុគ្គលបានបាត់ខ្លួនពីអ្នកជាប់ឃុំជាមួយគ្នារបស់ពួកគេ ដែលជាញឹក

[2960] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦ (អ.ជ.ស.ដ បានយល់ឃើញថា តាមរយៈសហឧក្រិដ្ឋកម្មរួម ម្ចាស់បណ្តឹងសាទុក្ខបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំនៅសហករណ៍ត្រាំកក់)។

[2961] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/១ កថាខណ្ឌ ៥៨៩។

[2962] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/១ កថាខណ្ឌ ៥៨០។

[2963] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៥៤។

[2964] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៥៣ ជើងទំព័រ ៩៧៤១ *ដោយដកស្រង់* ផ្នែក ១០.១.១៣.១០៖ សហករណ៍ត្រាំកក់៖ ការសន្និដ្ឋានលើអង្គច្បាប់៖ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

[2965] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៥៦។

ញាប់ត្រូវបានគេយកទៅសម្លាប់ក្រោមការបោកបញ្ឆោតថា "ពួកគេនឹងត្រូវបញ្ជូនទៅផ្ទះវិញ"[2966]។ សកម្មភាពរបស់ឆ្មាំដែលបានអនុវត្តការបាត់ខ្លួនលើកទីពីរពីមន្ទីរសន្តិសុខក្រាំងតាចាន់ បានបង្កើតបានជាឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំបន្ថែមទៀត ដោយសារ "ចំណុចទាំងនេះជាការប្រព្រឹត្តដោយចេតនា និងជាក់ស្តែងរបស់តួអង្គបន្ថែមទៀត ក្រោយពីការបាត់ខ្លួនមនុស្សដំបូងពីសហករណ៍"[2967]។

855. សេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ត្រូវបានគាំទ្រដោយលក្ខណៈដាច់ដោយឡែកនៃឧក្រិដ្ឋកម្មចំនួនពីរទៅលើមនុស្សតែម្នាក់។ ចារីផ្ទាល់ម្នាក់ផ្សេងទៀតបានប្រព្រឹត្តអំពើបាត់ខ្លួនពីមជ្ឈដ្ឋានទីពីរ នាពេលក្រោយមកទៀត។ សំខាន់ជាងនេះ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងដីកាដំណោះស្រាយ "ក្រៅពីជនរងគ្រោះផ្ទាល់ ការបាត់ខ្លួនដោយបង្ខំ [...] បានធ្វើឱ្យឈឺចាប់ផងដែរដល់អ្នកដែលជាសាក្សីនៃអំពើនោះ ដោយសារតែការភ័យខ្លាច និងភាពមិនច្បាស់លាស់ដែលបណ្តាលមកពីការបាត់ខ្លួនទាំងនេះ"[2968]។ អំពើដាច់ដោយឡែកដែលបានធ្វើឱ្យឈឺចាប់ដល់ក្រុមមនុស្សពីរផ្សេងគ្នាពោលគឺក្រុមទីមួយគឺជាអ្នកដែលត្រូវបានទុកនៅក្នុងឃុំ និងការដ្ឋានបន្ទាប់ពីមានការបាត់ខ្លួនដំបូង ហើយក្រុមទីពីរគឺជាអ្នកដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលត្រូវបានទុកដោយគ្មានជំនួយ នៅពេលដែលអ្នកជាប់ឃុំជាមួយគ្នារបស់ពួកគេបានបាត់ខ្លួនពីមន្ទីរក្រាំងតាចាន់[2969]។

856. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា មានការរឹតបន្តឹងទៅលើថា តើអំពើនេះអាចត្រូវបានប្រព្រឹត្តទៅលើមនុស្សតែម្នាក់បានប៉ុន្មានដងនោះ ត្រូវបានធ្វើឡើងដោយគ្មានមូលដ្ឋានច្បាប់ណាមួយឡើយ។ ជំនួសមកវិញ ម្ចាស់បណ្តឹងសាទុក្ខពឹងផ្អែកលើចំណែកសម្រង់សំដីបែបជ្រើសរើស និងនាំឱ្យមានការយល់ខុសពីក្រុមការងារទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ឬមិនស្ម័គ្រចិត្ត ដើម្បីគាំទ្រដល់គោលជំហររបស់គាត់[2970]។

857. ម្ចាស់បណ្តឹងសាទុក្ខ ពឹងផ្អែកមិនត្រឹមត្រូវលើសេចក្តីសន្និដ្ឋានរបស់ក្រុមការងារនេះដែលថា បើទោះបីជាមាន "គោលការណ៍នៃអានុភាពមិនប្រតិសកម្ម" ប្រសិនបើមនុស្សម្នាក់ត្រូវបានផ្តន្ទាទោសពី

[2966] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨០៩, ២៨៥៥។

[2967] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៥៤។

[2968] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៦០។

[2969] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៥៥ ("អង្គហេតុ និងវិធិសាស្ត្រនៃការសម្លាប់ បញ្ជាក់ពីការបដិសេធទាំងស្រុងនូវជំនួយពីអ្នកជាប់ឃុំដូចគ្នា ក្រុមគ្រួសារ ឬមិត្តភក្តិ ឱ្យទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ជាធរមាន និងការធានាផ្អែកនីតិវិធីច្បាប់អន្តរជាតិ"), ២៨៥៦-២៨៥៨។

[2970] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣៧។

បទការបាត់ខ្លួនដោយបង្ខំក្តី ក៏តុលាការមិនគួរបំបែកឧក្រិដ្ឋកម្មនេះ ដើម្បីពិចារណាតែលើអង្គហេតុទាំងនេះនោះដែរ បន្ទាប់ពីលិខិតុបករណ៍ច្បាប់ដើម្បីផ្តន្ទាទោសបុគ្គលត្រូវបានអនុម័ត[2971]។ សេចក្តីសន្និដ្ឋានទាំងនេះមិនមានការពាក់ព័ន្ធឡើយនៅទីនេះ ដោយសារសេចក្តីសន្និដ្ឋានទាំងនេះត្រឹមតែអនុវត្តចំពោះតែបុគ្គលម្នាក់ដែលបានបាត់ខ្លួននៅក្នុងឱកាសមួយ ដែលប្រព្រឹត្តដោយចារីម្នាក់ នៅក្នុងរយៈកាលដែលការប្រព្រឹត្តត្រូវបានធ្វើឱ្យខុសច្បាប់។ សេណារីយោបច្ចុប្បន្នមានភាពផ្សេងគ្នា ដោយសារវាសំដៅទៅលើមនុស្សម្នាក់ដែលបានបាត់ខ្លួននៅក្នុងឱកាសពីរដាច់ដោយឡែកពីគ្នា ពីមជ្ឈដ្ឋានពីរផ្សេងគ្នា ដែលប្រព្រឹត្តដោយចារីផ្ទាល់ពីរនាក់ផ្សេងគ្នា។ ផ្ទុយទៅនឹងការអះអាងដែលនាំឱ្យមានការយល់ខុសរបស់ម្ចាស់បណ្តឹងសាទុក្ខ ក្រុមការងារនេះមិនបានធ្វើសេចក្តីសន្និដ្ឋានឡើយទាក់ទងនឹងអំពើដាច់ដោយឡែកពីគ្នាដែលត្រូវបានប្រព្រឹត្តលើមនុស្សតែម្នាក់ដោយចារីផ្ទាល់ផ្សេងគ្នា។

## ៣. មន្ទីរសន្តិសុខភ្នំក្រោល

### *មូលដ្ឋានទី ១៣៣៖ ការធ្វើឱ្យទៅជាទាសករ*[2972]

858. **មូលដ្ឋានទី ១៣៣ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសតាមរយៈការសន្និដ្ឋានថា ការធ្វើឱ្យទៅជាទាសករត្រូវបានបំពេញនៅមន្ទីរសន្តិសុខភ្នំក្រោល។**

859. ដំបូងឡើយ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ស.ច.ស និងបន្ទាប់មក អ.ជ.ស.ដ មិនបានទទួលយកអង្គហេតុដែលពាក់ព័ន្ធនឹងមន្ទីរ ក-១៧ និងគុកភ្នំក្រោល មិនមានមូលដ្ឋានឡើយ [2973]។ ទីពីរ ទាក់ទងនឹងបញ្ហាភស្តុតាងគ្រប់គ្រាន់ មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខកំណត់មិនត្រឹមត្រូវនូវភស្តុតាងនៃការធ្វើឱ្យក្លាយជាទាសករនៅមន្ទីរ ក-១៧ ហេតុដូចនេះ មិនរាប់បញ្ចូលទាំងភស្តុតាងដែលពាក់ព័ន្ធពីមន្ទីរ ក-១៧ និងគុកភ្នំក្រោល។ ផ្ទុយពី

---

[2971] របាយការណ៍ក្រុមការងារទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ឬមិនស្ម័គ្រចិត្ត A/HRC/16/48 ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ៣៩-៥។

[2972] <u>មូលដ្ឋានទី ១៣៣៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើឱ្យទៅជាទាសករ* កថាខណ្ឌ ៨៨០-៨៨៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៨ (ភាសាអង់គ្លេស) ទំព័រ ៤៤ (ភាសាបារាំង) ទំព័រ ៦៨ (ភាសាខ្មែរ)។

[2973] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤៨។

ទទួឡីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ ពិចារណាយ៉ាងត្រឹមត្រូវលើភ័ស្តុតាងនៃការធ្វើឱ្យទៅជាទាសករនៅទីតាំងទាំងបីនេះ ដើម្បីគាំទ្រដល់ការផ្តន្ទាទោសរបស់ខ្លួន។

860. អ.ជ.ស.ដ បានយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរ ក-១៧ ត្រូវបានបង្ខំឱ្យជាន់គ្រាប់ក្រចៅជាច្រើនម៉ោងក្នុងអំឡុងពេលដែលពួកគេស្ថិតនៅក្នុងរបបនៃការជាប់ខ្នោះជាទូទៅ[2974]។ អ្នកទោសផ្សេងទៀត ត្រូវបានបង្ខំឱ្យបោកស្រូវ និងស្ទូងស្រូវស្របតាមកាលវិភាគការងារដែលត្រូវបានគ្រប់គ្រង។ មិនមានភ័ស្តុតាងដែលបង្ហាញថា អ្នកជាប់ឃុំបានទទួលការទូទាត់សំណងចំពោះការងារដ៏លំបាករបស់ពួកគេឡើយ ហើយពួកគេមានការភ័យខ្លាចត្រូវគេសម្លាប់ ប្រសិនបើពួកគេមិនគោរពតាមបញ្ជានៅពេលពួកគេធ្វើការនៅភ្នំក្រោល។ អ្នកជាប់ឃុំត្រូវទទួលរងការឈឺចាប់ផ្លូវចិត្តដោយសារតែការប្រព្រឹត្តបែបនេះ[2975]។ ដូច្នេះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ការផ្តន្ទាទោសនេះមានមូលដ្ឋានជាចម្បងតែលើភ័ស្តុតាងមិនគ្រប់គ្រាន់ និងមិនអាចបញ្ជាក់បានពីមន្ទីរ ក-១១ ពោលគឺជាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណៃម និងកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់សាក្សី អ៊ូម ម៉ុល ដែលបានស្លាប់នោះ[2976] គ្មានមូលដ្ឋានឡើយ។ ម្ចាស់បណ្តឹងសាទុក្ខបានខកខានមិនបានបង្ហាញកំហុសអង្គច្បាប់ណាមួយក្នុងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ការធ្វើឱ្យទៅជាទាសករបានកើតមានឡើងនៅមន្ទីរ ក-១៧ និងគុកភ្នំក្រោលដោយគ្មានវិមតិសង្ស័យ។

### *មូលដ្ឋានទី ១៣១៖ កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាលើ ហឿស*[2977]

861. **មូលដ្ឋានទី ១៣១ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ តាមរយៈការសន្និដ្ឋានថា ធាតុផ្សំនៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានកំណត់។**

862. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា កំហុស អង្គច្បាប់ដែលត្រូវបានចោទប្រកាន់មានមូលដ្ឋានលើប្រភពអង្គច្បាប់ដែលមិនសមស្រប ឬវិធានបក

---

[2974] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១២១។

[2975] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១២១។

[2976] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៨១-៨៨៣។

[2977] <u>មូលដ្ឋានទី ១៣១៖</u> ឯកសារ **F54** *កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាលើ ហឿស* កថាខណ្ឌ ៨៦៣-៨៦៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៧ (ភាសាអង់គ្លេស) ទំព័រ ៤៣ (ភាសាបារាំង) ទំព័រ ៦៧ (ភាសាអង់គ្លេស)។

ស្រាយមិនអាចអនុវត្តបាន។ មូលដ្ឋាននេះក៏មិនទទួលបានផលផងដែរ ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា ការសន្និដ្ឋានលើអង្គហេតុមានមូលដ្ឋានលើភ័ស្ដុតាងដែលមិនអាចទទួលយកបានដោយចៅក្រមជំនុំជម្រះមានវិចារណញ្ញាណណាម្នាក់ ថា ការវាយតម្លៃនៃភ័ស្ដុតាងមិនត្រឹមត្រូវទាំងស្រុង ឬថា ភ័ស្ដុតាងដោះបន្ទុកត្រូវបានដកចេញដោយចេតនា។

863. ទាក់ទងនឹងកំហុសអង្គច្បាប់ដែលត្រូវបានចោទប្រកាន់ ម្ចាស់បណ្ដឹងសាទុក្ខជំទាស់ដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ សំអាងសេចក្ដីសន្និដ្ឋានរបស់ខ្លួនមិនត្រឹមត្រូវលើការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងជាលាយលក្ខខណ៍អក្សររបស់សាក្សីចំនួនពីរនាក់គឺ អ៊្លូង ឌុស និង សុខ អ៊ែល ដែលមិនបានបង្ហាញខ្លួននៅតុលាការ ដែលរំលោភគោលការណ៍សមភាពនៃកម្លាំង និងវិធានស្ដីពីភ័ស្ដុតាង[2978]។ ដូចដែលបង្ហាញក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២១ និង ៣០ វាសមហេតុផលសម្រាប់ អ.ជ.ស.ដ ដើម្បីពឹងផ្អែកលើចម្លើយ និងដើមបណ្ដឹងរដ្ឋប្បវេណី អ៊្លូង ឌុស និង សុខ អ៊ែល ដែលអ្នកទាំងពីរបានបញ្ជាក់ពី "អត្តសញ្ញាណរបស់ជនរងគ្រោះ លក្ខណៈនៃការវាយប្រហារទៅលើជនរងគ្រោះ ស្ថានភាពនៃការស្លាប់ រួមជាមួយនឹងការប្រព្រឹត្តនាពេលបន្ទាប់ទៅលើសាកសពរបស់ជនរងគ្រោះ"[2979]។

864. ទាក់ទងនឹងកំហុសអង្គហេតុដែលត្រូវបានចោទប្រកាន់ ម្ចាស់បណ្ដឹងសាទុក្ខជំទាស់ទៅនឹងតម្លៃនៃភ័ស្ដុតាងដែលត្រូវបានផ្ដល់ជូនដោយ អ៊្លូង ឌុស និង សុខ អ៊ែល ដោយអះអាងថា មាន "គម្រូយសត្យានុម័តិបង្ហាញពីលទ្ធភាពនៃការសមគំនិតគ្នារវាងរឿងរ៉ាវនានា"[2980]។ ទឡ្ហីករណ៍នេះមិនទទួលបានផលទេ ជាចម្បងដោយសារតែ អ.ជ.ស.ដ ត្រូវបានសន្មតថាបានវាយតម្លៃយ៉ាងសមស្របទៅលើភ័ស្ដុតាងទាំងអស់[2981]។ ក្ដីបារម្ភរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា បទសម្ភាសត្រូវបានធ្វើឡើងនៅថ្ងៃតែមួយ ក្នុងភូមិតែមួយ នៅម៉ោងសិក្ខាសាលាតែមួយនោះ[2982] មិនច្រានចោលសច្ចធារណ៍នេះឡើយ ដោយសារទឡ្ហីករណ៍នេះត្រឹមតែជាការប៉ាន់ស្មានប៉ុណ្ណោះ ដែលបង្ហាញថាគ្មានការឃុបឃិតគ្នា ឬភាពមិនសមស្របផ្សេងៗឡើយ។

[2978] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៦៤។

[2979] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១០០។

[2980] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៦៦។

[2981] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥២។

[2982] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៦៦។

865. ម្ចាស់បណ្តឹងសាទុក្ខក៏ជំទាស់ផងដែរថា អ.ជ.ស.ជ លុបចោលដោយចេតនានូវភស្តុតាងដោះបន្ទុក ដែលពាក់ព័ន្ធនឹងការធ្វើមនុស្សឃាតអ្នកទោសឈ្មោះ គួច និង ហ៊ើស[2983]។ ទោះជាយ៉ាងណា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញទឡ្ហីករណ៍ណាមួយដែលថា អ.ជ.ស.ជ បានដំណើរការដោយចេតនាជាមួយនឹងបំណងមិនល្អ ឬបានចូលរួមក្នុងការប្រព្រឹត្តបែបព្យាបាទ ដែលតម្រូវឱ្យមានដើម្បីឆ្លើយតបទៅនឹងកម្រិតកំណត់ខ្ពស់សម្រាប់ការពិនិត្យបណ្តឹងសាទុក្ខឡើងវិញនោះទេ[2984]។ ឆន្ទានុសិទ្ធិនោះត្រូវបានអនុវត្តដោយមិនត្រឹមត្រូវ ឬក្នុងរបៀបមួយដែលម្ចាស់បណ្តឹងសាទុក្ខមិនឯកភាពជាមួយ ដែលទំនងជាករណីនៅទីនេះ ដែលមិនគ្រប់គ្រាន់ដើម្បីសន្និដ្ឋានប្រកបដោយសមហេតុផលថាជាបំណងអាក្រក់។ លើសពីនេះទៀត ការខកខានរបស់ អ.ជ.ស.ជ ក្នុងការសំដៅជាក់លាក់ទៅកាន់ភស្តុតាងដោះបន្ទុក មិនធ្វើឱ្យសេចក្តីសន្និដ្ឋាននេះក្លាយជាមោឃៈដោយស្វ័យប្រវត្តិនោះទេ[2985]។ សំខាន់ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់ភស្តុតាង ដែលនឹងបង្កឱ្យមានការសង្ស័យដោយសមហេតុផលទៅលើសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ជ ទាក់ទងនឹងការធ្វើមនុស្សឃាតចំនួនពីរ។ ការពិតដែលថា ចាន់ ទូយ *ហៅ* ចាន់ គួច និង នេត សារ៉ាត មិនបានឃើញការសម្លាប់ណាមួយដោយផ្ទាល់ភ្នែកដែលសូម្បីតែ អ.ជ.ស.ជ ក៏បានកត់សម្គាល់ និងបានពិចារណាផងដែរ នៅក្នុងសាលក្រមដរាបណាមានការពាក់ព័ន្ធនឹង ចាន់ ទូយ នោះ[2986] មិនស្ថិតនៅក្នុងការដោះបន្ទុក

---

[2983] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៧៦-៨៧៩។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣២។

[2984] *Bemba Gombo* Second Corrected Musamba សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥២ កថាខណ្ឌ ៥៤ *ដោយដកស្រង់* សាលក្រមរបស់តុលាការកំពូលប្រទេសប៊ែលហ្សិក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ១៦៖ "កិច្ចស៊ើបសួរដែលត្រូវបានជំទាស់បង្កើតបានជាការស្វែងរកព័ត៌មានដែលជាការប្រមូលព័ត៌មានបែបព្យាបាទ និងដោយគ្មានភស្តុតាងណាមួយ និងភស្តុតាងបទល្មើសដែលមិនមែនជាកម្មវត្ថុនៃការបញ្ជូនក្នុងបរិបទនៃការស៊ើបអង្កេតរបស់តុលាការ។ ភាពមិនប្រក្រតីដែលត្រូវបានប្រព្រឹត្តឡើងមិនមែនជាលទ្ធផលនៃការប្រព្រឹត្តដែលអាចជំទាស់បាន ដែលអាចលើកលែងទោសបាន និងដែលអាចអភ័យទោសបាននោះទេ ហើយក៏មិនមែនជាលទ្ធផលនៃការព្រងើយកន្តើយ ឬការធ្វេសប្រហែសដែលអាចលើកលែងទោសបាននោះដែរ ប៉ុន្តែវាគឺជាសកម្មភាពចេតនារបស់ជនដែលទទួលខុសត្រូវលើការស៊ើបអង្កេត"។ (ការបកប្រែក្រៅផ្លូវការ)។

[2985] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥២។

[2986] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១០៩ (ទាក់ទងនឹង ចាន់ ទូយ)។

ខ្លួនឯងនោះទេ[2987]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញនោះទេថា សេចក្តីសន្និដ្ឋាននេះគឺជាសេចក្តីសន្និដ្ឋានមួយដែលគ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់អាចធ្វើទៅបានឡើយ[2988]។

## *មូលដ្ឋានទី ១៣២ ៖ កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាត ដោយចេតនាប្រយោលលើ ខូច* [2989]

866. **មូលដ្ឋានទី ១៣២ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ និងអង្គហេតុតាមរយៈការសន្និដ្ឋានថាមានការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល*។**

867. មូលដ្ឋាននេះមិនទទួលបានផលទេ ព្រោះម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបានលើកឡើងដដែលៗនូវការអះអាងមិនត្រឹមត្រូវពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃការធ្វើមនុស្សឃាត *ដោយចេតនាប្រយោល*[2990]។ លើសពីនេះ ម្ចាស់បណ្តឹងសាទុក្ខមិនអាចបង្ហាញថា អ.ជ.ស.ដ ប្រព្រឹត្តកំហុសអង្គច្បាប់តាមរយៈ (i) ការផ្អែក*ទាំងស្រុង* លើកំណត់ហេតុរបស់មនុស្សម្នាក់ដែលបានស្លាប់ដើម្បីផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខពីបទធ្វើមនុស្សឃាត (ii) ការប្រើប្រាស់កំណត់ហេតុរបស់មនុស្សម្នាក់ដែលបានស្លាប់សម្រាប់ជាមូលដ្ឋាននៃការផ្តន្ទាទោស (iii) ការមិនបានផ្តល់មូលហេតុលម្អិតនៅពេលផ្អែកលើភស្តុតាងដែលមិនត្រូវបានសួរដេញដោល និង (iv) បំភ្លេចចោលដោយចេតនានូវភស្តុតាងដោះបន្ទុកនៃការធ្វើមនុស្សឃាត[2991] និងមិនបានបង្ហាញថា ប្រសិនបើមានកំហុសដែលរងការចោទប្រកាន់ណាមួយមែននោះ វានឹងធ្វើឱ្យសាលក្រមនេះមោឃៈ។

868. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខបកស្រាយមិនត្រឹមត្រូវពីសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ តាមរយៈការលើកឡើងថា អ.ជ.ស.ដ ផ្អែក “ទាំងស្រុង” លើកំណត់ហេតុរបស់មនុស្សម្នាក់ដែលបានស្លាប់

---

[2987] សាលដីការឿងក្តី *Kvočka* កថាខណ្ឌ ២៣ (ប្រសិនបើ អ.ជ.ស.ដ មិនសំដៅដល់ភស្តុតាងដែលត្រូវបានផ្តល់ជូនដោយសាក្សីបើទោះជាវាផ្ទុយនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួនក្តី ក៏មានការសន្មតថា អ.ជ.ស.ដ បានវាយតម្លៃ និងដាក់បន្ទុកលើភស្តុតាងនេះផងដែរ ប៉ុន្តែ អ.ជ.ស.ដ បានយល់ឃើញថា ភស្តុតាងនេះមិនបានរារាំងខ្លួនមិនឱ្យសម្រេចបានសេចក្តីសន្និដ្ឋានជាក់ស្តែងរបស់ខ្លួននោះទេ)។

[2988] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[2989] <u>មូលដ្ឋានទី ១៣២ ៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាប្រយោលលើ ខូច* កថាខណ្ឌ ៨៧០-៨៧៥។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃបណ្តឹងសាទុក្ខ ទំព័រ ៤៧ (ភាសាអង់គ្លេស) ទំព័រ ៤៣ (ភាសាបារាំង) ទំព័រ ៦៧-៦៨ (ភាសាខ្មែរ)។

[2990] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៧៤-៨៧៥។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៦។

[2991] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣១។

ដើម្បីបញ្ជាក់ពីការធ្វើមនុស្សឃាតអ្នកទោសម្នាក់។ គ្មានគោលការណ៍ស្របច្បាប់ដែលតម្រូវឱ្យមានការគាំទ្រផ្ទាល់ដោយការស្លាប់ដើម្បីបញ្ជាក់ពីការធ្វើមនុស្សឃាតឡើយ ហើយការស្លាប់របស់ជនរងគ្រោះ អាចត្រូវបានសន្និដ្ឋានតាមរយៈភ័ស្តុតាងទាំងអស់នៅចំពោះមុខ អ.ជ.ស.ដ[2992]។ តាមពិត អង្គហេតុស្តីពីការស្លាប់របស់ ទូច ត្រូវបានគាំទ្រដោយភ័ស្តុតាងប្រយោលនៃលក្ខខណ្ឌដ៏លំបាកក្នុងគុក[2993]។ ខណៈដែល អ.ជ.ស.ដ មិនបានឮភ័ស្តុតាងបន្ថែមក្នុងតុលាការស្តីពីលក្ខខណ្ឌនៅមន្ទីរ ក-១១ ឬគុកភ្នំក្រោល អ.ជ.ស.ដ បានលើកឡើងយ៉ាងត្រឹមត្រូវថា អ.ជ.ស.ដ បានទទួលយកអង្គហេតុទាំងនេះ ព្រោះវាពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល *ទាំងមូល*[2994]។ ជារួម ភ័ស្តុតាងនេះបានផ្តល់ការគាំទ្រដល់ការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងរបស់ សុខ អ៊ែល។

869. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ សុខ អ៊ែល មិនអាចផ្តល់មូលដ្ឋាននៃការផ្តន្ទាទោសសម្រាប់ការស្លាប់របស់ ទូច បានទេ ព្រោះ ទូច មិនត្រូវបានមេធាវីការពារក្តីដេញដោល។ គ្មានវិធានដាច់ខាតនៃភ័ស្តុតាងដែលថា ចៅក្រមមានវិចារណញ្ញាណម្នាក់មិនអាចផ្តន្ទាទោសដោយផ្អែកលើភ័ស្តុតាងពីសាក្សីម្នាក់ ឬច្រើននាក់ដែលត្រូវបានមេធាវីការពារក្តីដេញដោលនោះទេ[2995]។ ទោះជាយ៉ាងណា ក្នុងករណីនេះ អ.ជ.ស.ដ បានផ្អែកលើភ័ស្តុតាងនៃកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ សុខ អ៊ែល ដោយហេតុថា ភ័ស្តុតាងនោះគាំទ្រ ឬផ្ទុយទៅនឹងភ័ស្តុតាងអំពីលក្ខខណ្ឌនៃការឃុំខ្លួនដែលបានរៀបរាប់នៅក្នុងសវនាការ[2996]។

870. ទីបី ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មិនបានផ្តល់សំអាងហេតុលម្អិតទៅតាមភាពចាំបាច់ នៅពេលផ្អែកលើភ័ស្តុតាងដែលមិនត្រូវបានសួរដេញដោល[2997]។ សំណួរ

---

[2992] សាលដីការឿងក្តី *Kvočka* កថាខណ្ឌ ២៦០។

[2993] អ.ជ.ស.ដ បានធ្វើការសន្និដ្ឋានសរុបពីការដាក់ខ្នោះអ្នកជាប់ឃុំ ការទុកឱ្យអ្នកជាប់ឃុំស្ថិតក្នុងលក្ខខណ្ឌគ្មានអនាម័យ និងការឃុំខ្លួនទាបជាងបទដ្ឋានអប្បបរមា ការតម្រូវឱ្យមានរបបការងារ ការផ្តល់អាហារមិនគ្រប់គ្រាន់ ការសួរចម្លើយអ្នកជាប់ឃុំ ការសួរចម្លើយអ្នកជាប់ឃុំ និងការធ្វើបាបលើរូបរាងកាយម្តងម្កាលក្រៅពីពេលសួរចម្លើយ។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១០១ (ការស្លាប់របស់ ទូច), ៣១០២ (លក្ខខណ្ឌអ្នកជាប់ឃុំនៅមន្ទីរ ក-១១ និង ក-១៧)។

[2994] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៤៨។

[2995] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២១។

[2996] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០៩៤។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ៣០។

[2997] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៧២។

របស់ម្ចាស់បណ្តឹងសាទុក្ខថាតើ អ.ជ.ស.ដ សន្និដ្ឋានដោយរបៀបណាថា ទូច បានស្លាប់ដោយសារលក្ខខណ្ឌក្នុងគុក នៅពេលដែលភស្តុតាងនេះមិនអាចឱ្យគេកំណត់អត្តសញ្ញាណអ្នកទោសដែលលើកឡើងនោះឱ្យបានប្រាកដ និងគ្មានការបញ្ជាក់បន្ថែមនោះ[2998] មិនធ្វើឱ្យមានកំហុសអង្គច្បាប់ ឬអង្គហេតុឡើយ។ ពាក់ព័ន្ធនឹងអត្តសញ្ញាណ ម្ចាស់បណ្តឹងសាទុក្ខមិនបានពន្យល់ពីរបៀបដែលកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ សុខ អ៊ែល "មិនអាចឱ្យគេកំណត់អត្តសញ្ញាណអ្នកទោសដែលលើកឡើងនោះឱ្យបានប្រាកដនោះទេ"[2999]។ សុខ អ៊ែល បានរៀបរាប់ឈ្មោះ និងកំណត់អត្តសញ្ញាណជាតិពន្ធុរបស់អ្នកទោសនេះ[3000]។

871. ចុងបញ្ចប់ ម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់មិនត្រឹមត្រូវថា ភ័ស្តុតាងដោះបន្ទុកដែលត្រូវបានដេញដោលក្នុងតុលាការដែលពាក់ព័ន្ធនឹងការធ្វើមនុស្សឃាតនៅមន្ទីរសន្តិសុខភ្នំក្រោល ត្រូវបាន អ.ជ.ស.ដ បំភ្លេចចោលដោយចេតនា[3001]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់មូលដ្ឋានដល់ទឡ្ហីករណ៍ដែលថា អ.ជ.ស.ដ បានធ្វើប្រតិបត្តិការដោយចេតនាមិនល្អ ឬពាក់ព័ន្ធនឹងការប្រព្រឹត្តបែបព្យាបាទ នៅពេលច្រានចោលភ័ស្តុតាងចាំបាច់ ដើម្បីបំពេញកម្រិតខ្ពស់សម្រាប់ការពិនិត្យបណ្តឹងសាទុក្ខ[3002]។ សំខាន់បំផុត ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់រកភស្តុតាងដែលអាចបង្កជាមន្ទិលសង្ស័យសមហេតុផលលើសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ នោះទេ[3003]។ អង្គហេតុដែលថា ចាន់ ទូយ *ហៅ* ចាន់ តូច និង ណេត សារ៉ាត មិនបានមើលឃើញការសម្លាប់ដោយផ្ទាល់ ជាចំណុចដែលត្រូវបានកត់សម្គាល់ដោយ អ.ជ.ស.ដ និងត្រូវបានពិចារណាក្នុងសាលក្រមនេះដែលពាក់ព័ន្ធនឹង ចាន់ ទូយ[3004] មិនអាចដោះបន្ទុកបានឡើយ[3005]។ អ.ជ.ស.ដ មានឆន្ទានុសិទ្ធិក្នុងការ

[2998] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៧២។

[2999] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៧២។

[3000] ឯកសារ **E3/7702** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ អ៊ែល, KH 00236728 ("ខ្ញុំបានឃើញអ្នកទោសម្នាក់ឈ្មោះ ទូច ជនជាតិពួង បានដេកស្លាប់ធ្លាក់ក និងលៀនអណ្តាត។ ហើយខ្ញុំក៏ប្រាប់អ្នកយាមឱ្យយកចេញទៅ ថាគាត់បានស្លាប់ហើយ")។

[3001] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៧៦-៨៧៩ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៣១។

[3002] សេចក្តីសម្រេចបន្ទាន់បង្គំរឿងក្តី *Muvunyi* ជើងទំព័រ ៨៦។

[3003] សូមមើល ចម្លើយតបនឹងមូលដ្ឋានទី ១៣១។

[3004] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១០៩ (ពាក់ព័ន្ធនឹង ចាន់ ទូយ)។

[3005] សាលដីការឿងក្តី *Kvočka* កថាខណ្ឌ ២៣ (ប្រសិនបើ អ.ជ.ស.ដ មិនផ្អែកតាមភ័ស្តុតាងដែលផ្តល់ដោយសាក្សីណាម្នាក់ ទោះបីជាភស្តុតាងនោះផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ក្តី ក៏គេត្រូវសន្មតថា អ.ជ.ស.ដ បានវាយតម្លៃ និងថ្លឹងថ្លែងភ័ស្តុតាងនោះ ប៉ុន្តែយល់ឃើញថា ភ័ស្តុតាងនោះមិនអាចរារាំងមិនឱ្យ អ.ជ.ស.ដ ធ្វើសេចក្តីសន្និដ្ឋានជាក់ស្តែងបានឡើយ)។

វាយតម្លៃភាពមិនស៊ីសង្វាក់គ្នាក្នុងភស្តុតាងនោះ និងពិចារណាថាតើភស្តុតាង *ទាំងមូល*អាចជឿជាក់ និងអាចទុកចិត្តបាន និងទទួលយក ឬបដិសេធលក្ខណៈជាមូលដ្ឋាននៃភស្តុតាងនោះ[3006]។

872. ក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឡើយថា ប្រសិនបើ អ.ជ.ស.ដ មានកំហុស កំហុសនោះនឹងធ្វើឱ្យសាលក្រមនេះមោឃៈ។ ការកែប្រែសាលក្រមដោយអំពើមនុស្សឃាតមួយនៅភ្នំក្រោល មិនប៉ះពាល់ដល់សុពលភាពនៃការសន្និដ្ឋានលើពិរុទ្ធភាពនៃការសម្លាប់រង្គាលនៅមន្ទីរ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខអូរកន្សែង ឬការធ្វើមនុស្សឃាតនៅសហករណ៍ស្រុកត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់ ១ មករា និងព្រលានយន្តហោះកំពង់ឆ្នាំងទេ[3007]។ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃកំហុសអង្គច្បាប់ទៅលើទោសទណ្ឌបែបនេះ ការកែប្រែសេចក្តីសន្និដ្ឋាននេះនឹងមិនធ្វើឱ្យមានមោឃភាពទៅលើការសម្រេចរបស់ អ.ជ.ស.ដ លើការផ្តន្ទាទោសនេះ ដែលមានលក្ខណៈជារួម និងឆ្លុះបញ្ចាំងនូវអំពើឧក្រិដ្ឋទាំងមូលនោះឡើយ។ ដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឡើយថា តើកំហុសបែបនេះនឹងធ្វើឱ្យមានមោឃភាពលើការផ្តន្ទាទោសសម្រាប់អំពើមនុស្សឃាត ឬការដាក់ទោសនេះដោយរបៀបណា។

## *មូលដ្ឋានទី ២៥១ ៖ សេចក្តីសន្និដ្ឋានសរុប*[3008]

873. **មូលដ្ឋានទី ២៥១ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថាសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ លើពិរុទ្ធភាពរបស់ម្ចាស់បណ្តឹងសាទុក្ខសម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលនៅភ្នំក្រោល បង្កជាកំហុសអង្គច្បាប់ដែលធ្វើឱ្យសាលក្រមនេះមោឃៈ។**

874. មូលដ្ឋាននេះមិនទទួលបានផលទេ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់នៅពេលធ្វើការផ្តន្ទាទោសសម្រាប់ការសម្លាប់រង្គាលនៅភ្នំក្រោល និងមានការសន្និដ្ឋាននៅផ្នែកផ្សេងទៀតថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការសម្លាប់រង្គាលមិនត្រូវបានបង្ហាញនោះទេ" ក៏ដោយ[3009]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា កំហុសនេះធ្វើឱ្យសាលក្រមនេះមោឃៈនោះឡើយ[3010]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ប្រសិនបើកំហុស

[3006] សាលដីការឿងក្តី *Setako* កថាខណ្ឌ ៣១។

[3007] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៤១។

[3008] <u>មូលដ្ឋានទី ២៥១ ៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *សេចក្តីសន្និដ្ឋានសរុប* កថាខណ្ឌ ២១៤១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨៣ (ភាសាអង់គ្លេស) ទំព័រ ៧៧ (ភាសាបារាំង) ទំព័រ ១១៨-១១៩ (ភាសាខ្មែរ)។

[3009] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១១៨។

[3010] សូមមើល បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់)។

នោះមិនទាន់ទៅដល់មោឃៈសាលក្រមទេ នោះសាលក្រមអាចនឹងត្រូវបានសម្រេចកែប្រែប្រកាសដាក់ពិរុទ្ធភាពទាំងស្រុង ឬផ្នែកខ្លះ[3011]។ ដោយសារតែ អ.ជ.ស.ដ បានផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខសម្រាប់ការសម្លាប់រង្គាលនៅមន្ទីរ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខអូរកន្សែង ការកែប្រែសាលក្រមនេះពាក់ព័ន្ធនឹងការសម្លាប់រង្គាលនៅមន្ទីរសន្តិសុខភ្នំក្រោលមិនប៉ះពាល់ដល់សុពលភាពនៃមូលដ្ឋានពិរុទ្ធភាព សម្រាប់ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលនៅទីតាំងទាំងនេះឡើយ[3012]។

875. ពាក់ព័ន្ធនឹងផលប៉ះពាល់នៃកំហុសអង្គច្បាប់ទៅលើទោសទណ្ឌបែបនេះ នៅពេលសម្រេចអំពីទោសឱ្យបានសមស្របសម្រាប់ឧក្រិដ្ឋកម្ម*ទាំងអស់*ដែលត្រូវបានប្រព្រឹត្ត អ.ជ.ស.ដ បានលើកឡើងថាភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះគឺជា “លក្ខណៈវិនិច្ឆ័យសំខាន់” និងផ្អែកលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីកំណត់រកកត្តា ដែលពាក់ព័ន្ធនឹងការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម[3013]។ ការកែប្រែសាលក្រមនេះពាក់ព័ន្ធនឹងការសម្លាប់រង្គាលនៅមន្ទីរសន្តិសុខភ្នំក្រោលមិនធ្វើឱ្យមានមោឃភាពទៅលើការសម្រេចរបស់ អ.ជ.ស.ដ ឡើយ។ អ.ជ.ស.ដ បានលើកឡើងយ៉ាងច្បាស់ពីទំហំយ៉ាងធំធេង និងភាពសាហាវយង់ឃ្នងនៃឧក្រិដ្ឋកម្មទាំងនេះ និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទាំងនេះនៅមន្ទីរសន្តិសុខផ្សេងទៀត[3014]។

### *មូលដ្ឋានទី ១៣៥ ៖ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ*[3015]

876. **មូលដ្ឋានទី ១៣៥ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃភស្តុតាងដែលជាមូលដ្ឋាននៃការសន្និដ្ឋានថា មានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត (តាមរយៈការបាត់ខ្លួនដោយបង្ខំ) នៅមន្ទីរសន្តិសុខភ្នំក្រោល។**

---

[3011] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៩។

[3012] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៤១។

[3013] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៤៩។

[3014] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៦១-៤៣៧៦។

[3015] <u>មូលដ្ឋានទី ១៣៥ ៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ* កថាខណ្ឌ ៨៨៧-៨៩១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៨ (ភាសាអង់គ្លេស) ទំព័រ ៥៥ (ភាសាបារាំង) ទំព័រ ៦៨-៦៩ (ភាសាខ្មែរ)។

877. មូលដ្ឋាននេះមិនទទួលបានផលទេ ព្រោះម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញពីកំហុសណាមួយនៅក្នុងការពិចារណាទៅលើភ័ស្តុតាងរបស់ អ.ជ.ស.ដ នោះឡើយ។ ទីមួយ ទឡ្ហីករណ៍មិនត្រឹមត្រូវរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលពាក់ព័ន្ធនឹង*បណ្ដឹង*ដាក់ជូន អ.ជ.ស.ដ អំពីអង្គហេតុដែលសាក្សី ចាន់ ទូយ និង អ្លូង ដុស បានលើកឡើង[3016] គឺលែងចាំបាច់ទៀតហើយ ដោយសារថា ហេតុផលត្រូវបានលើកឡើងរួចហើយនៅកថាខណ្ឌផ្សេងទៀតក្នុងចម្លើយតបនេះ[3017]។

878. ទីពីរ ការចោទប្រកាន់របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនបានបង្ហាញភ័ស្តុតាងផ្ទាល់និងមិនផ្អែកលើ "អ្វីក្រៅតែពីការឮគេនិយាយតគ្នា"[3018] គឺគ្មានមូលដ្ឋានសំអាងទាល់តែសោះ។ ការទទួលស្គាល់ជារួម គឺ អ.ជ.ស.ដ អាចផ្អែកលើភ័ស្តុតាងដែលឮគេនិយាយតគ្នាដែលគ្មានមូលដ្ឋានដើម្បីកំណត់ពីឧក្រិដ្ឋកម្មមួយ ឱ្យតែ អ.ជ.ស.ដ ធ្វើការវិភាគភ័ស្តុតាងយ៉ាងប្រុងប្រយ័ត្ន[3019]។ ការវិភាគយ៉ាងប្រុងប្រយ័ត្ន និងសមហេតុផលដោយ អ.ជ.ស.ដ ត្រូវបានបង្ហាញឡើងតាមរយៈការការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ភ័ស្តុតាងដែលឮគេនិយាយតគ្នា បានផ្ដល់ការរៀបរាប់ព្រឹត្តិការណ៍ដំណើររឿងដែលស៊ីសង្វាក់គ្នា និងមានការបញ្ជាក់បន្ថែម តែចំពោះការយកអ្នកទោសចេញពីមន្ទីរ ក-១៧ ដោយគ្មានការពន្យល់ប៉ុណ្ណោះ មិនមែនចំពោះជោគវាសនាចុងក្រោយរបស់អ្នកទោសទាំងនោះឡើយ[3020]។

879. ក្នុងករណីណាក៏ដោយ ម្ចាស់បណ្ដឹងសាទុក្ខត្រូវបង្ហាញថា គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់អាចផ្អែកលើភ័ស្តុតាងដែលឮគេនិយាយតគ្នា ក្នុងការចេញសេចក្ដីសន្និដ្ឋានជាក់លាក់មួយនោះឡើយ[3021]។ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែបានអះអាងថា អ.ជ.ស.ដ "ពុំបានបង្ហាញពីភ័ស្តុតាងផ្ទាល់ណាមួយទេ ហើយការផ្ដន្ទាទោសផ្អែកតែលើការនិយាយសរុបជាទូទៅ"[3022]។ គ្មានការពន្យល់បន្ថែមទៀតស្ដីពីរបៀបដែលសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ មានភាពមិនសមហេតុផលហួសពី

---

[3016] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៨៨។

[3017] អ.ជ.ស.ដ បានទទួលយកអង្គហេតុនៅមន្ទីរ ក-១១, មន្ទីរ ក-១៧ និងគុកភ្នំក្រោល និងមានភ័ស្តុតាងជាក់លាក់ដើម្បីបញ្ជាក់ពីការបាត់ខ្លួនដោយបង្ខំនៅទីតាំងទាំងនេះ។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៥០។

[3018] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៨៩។

[3019] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[3020] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០៩១។

[3021] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ *ដោយដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០២ *ដោយយោងតាម* សាលដីការឿងក្ដី *Karera* កថាខណ្ឌ ៣៩, ១៩៦។

[3022] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៨៩។

អង្គហេតុដែលថា ភ័ស្តុតាងនោះជាពាក្យចចាមអារ៉ាម និងមិនបំពេញលក្ខណៈវិនិច្ឆ័យចាំបាច់សម្រាប់ការពិនិត្យបណ្តឹងសាទុក្ខឡើយ[3023]។

880. ទីបី ម្ចាស់បណ្តឹងសាទុក្ខ បានចោទប្រកាន់ដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ បានរំលោភលើវិធានស្តីពីភ័ស្តុតាង តាមរយៈការផ្អែកលើសក្ខីកម្មរបស់ សៅ សារុន ដើម្បីសម្រេចថា ការបាត់ខ្លួនទាំងឡាយដែលកើតឡើងនៅមន្ទីរសន្តិសុខ គឺជាលទ្ធផលនៃអំពើរបស់អាជ្ញាធរ ក.ប.ធ ឬដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពី ប.ក.ក[3024]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ មានឆន្ទានុសិទ្ធិក្នុងការសម្រេចថា ផ្នែកណាខ្លះនៃសក្ខីកម្មអាចជឿទុកចិត្តបាន និងផ្នែកណាខ្លះមិនអាចជឿទុកចិត្តបាន[3025]។ ក្រៅពីនេះ ទោះបីជាគ្មានកាតព្វកិច្ចត្រូវអនុវត្តក្តី[3026] ក៏ អ.ជ.ស.ដ បានបរិយាយដោយស៊ីសង្វាក់គ្នា និងជាបន្តបន្ទាប់នូវសំអាងហេតុរបស់ខ្លួននៅគ្រប់ពេលដែល អ.ជ.ស.ដ បដិសេធ ឬទទួលយកផ្នែកនានានៃសក្ខីកម្មរបស់ សៅ សារុន ដោយបង្ហាញច្បាស់ពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងសមហេតុផល[3027]។ *សម្រាប់គោលបំណងនៃការវែកញែក* ប្រសិនបើសក្ខីកម្មរបស់ សៅ សារុន ត្រូវបានបដិសេធចោល ការសន្និដ្ឋានដែលរងការជំទាស់នេះ ត្រូវបានគាំទ្រដោយសាក្សីផ្សេងទៀតយ៉ាងតិច ២ នាក់[3028]។

## ៤. មន្ទីរសន្តិសុខអូរកន្សែង

### *មូលដ្ឋានទី ១២៩ ៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ*[3029]

881. **មូលដ្ឋានទី ១២៩ គួរត្រូវបានច្រានចោល ព្រោះម្ចាស់បណ្តឹងសាទុក្ខមិនបានលើកឡើងពីកំហុសអង្គច្បាប់ក្នុងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថាមានការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយនៅមន្ទីរសន្តិសុខអូរកន្សែង។**

---

[3023] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ពាក្យចចាមអារ៉ាម)។

[3024] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ 890-891.

[3025] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៧។

[3026] សូមមើល សាលដីការឿងក្តី *Ngirabatware* កថាខណ្ឌ ៩៧។ សាលដីការឿងក្តី *Karera* កថាខណ្ឌ ២១។

[3027] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០៣៩-៣០៤១, ៣០៥៣, ៣០៦៥, ៣០៧៧-៣០៧៨, ៣០៨០-៣០៨១, ៣០៩០-៣០៩២, ៣១៦២, ៣៣៨៨។

[3028] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៦២។

[3029] មូលដ្ឋានទី ១២៩ ៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ* កថាខណ្ឌ ៨៤៨-៨៥៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៤៧ (ភាសាអង់គ្លេស) ទំព័រ ៤៣ (ភាសាបារាំង) ទំព័រ ៦៦-៦៧ (ភាសាខ្មែរ)។

882. មូលដ្ឋាននេះមិនទទួលបានផលទេ ព្រោះម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា (i) អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា អ្នកដែលបានជាប់ឃុំនៅមន្ទីរសន្តិសុខអូរកន្សែង ជាប្រភេទ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក" ដែលមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាន និង (ii) ជនជាតិចារ៉ាយ ១០០ នាក់, ផន ថុល, មឿង ចាន់ឌី និងអ្នកជាប់ឃុំដែលជាកងទ័ព មិនទទួលរងការរើសអើងក្នុងមន្ទីរសន្តិសុខអូរកន្សែង។

883. ម្ចាស់បណ្ដឹងសាទុក្ខយល់ឃើញថា ក្រុមដែលបានកំណត់ថាស្ថិតក្នុងប្រភេទខ្មាំងរបស់ ប.ក.ក មិន "កំណត់យ៉ាងតឹងរ៉ឹងនូវអ្វីដែលគេហៅថាជាក្រុម ដែលមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាននោះទេ"[3030] ដោយមិនអើពើថា ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក អាចបង្កើតបានជាក្រុមដែលមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាន[3031]។ ក្នុងការសន្និដ្ឋានថា ក្រុមនេះមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាននៅមន្ទីរសន្តិសុខអូរកន្សែង អ.ជ.ស.ដ បានពិនិត្យយ៉ាងសមស្របលើភស្តុតាងនៃគោលបំណង និងគោលនយោបាយមនោគមន៍វិជ្ជារបស់ ប.ក.ក ចំពោះខ្មាំង ស្ថានភាពជម្លោះប្រដាប់អាវុធរវាង ក.ប.ធ និងសាធារណ រដ្ឋសង្គមនិយមវៀតណាម ការវិវត្តនៃគោលនយោបាយរបស់ ប.ក.ក ចំពោះជនជាតិវៀតណាម និងខ្មាំងផ្សេងទៀត និងការបោសសម្អាតផ្ទៃក្នុង[3032]។ ភស្តុតាងនេះបានផ្ដល់លទ្ធភាពឱ្យ អ.ជ.ស.ដ សន្និដ្ឋានបានថា ប.ក.ក ផ្ដោតលើ "ខ្មាំងប្រឆាំងបដិវត្តន៍ អ្នកបង្កគ្រោះថ្នាក់ និងជនក្បត់បដិវត្តន៍ ពួកសក្តិភូមិ និងអ្នកចូលរួមនៅក្នុងការអនុវត្តបែបសក្តិភូមិ ជនជាតិវៀតណាម គិញបរទេស និងអ្នកឃុបឃិតនៅក្នុងប្រភេទផ្សេងៗដូចបានលើកឡើងខាងលើ"[3033]។ អ.ជ.ស.ដ រកឃើញ "ករណីជាច្រើនដែលប្រជាជនបានទទួលរងការធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត"[3034] ជាការសន្និដ្ឋានដែលអាចធ្វើឡើងយ៉ាងសមហេតុផលតាមរយៈការប្រៀបធៀបរវាងក្រុមដែលអាចកំណត់អត្តសញ្ញាណបាន។

---

[3030] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ៨៤៩។

[3031] សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ២៧៣, ២៨២។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៦៩។ ពាក់ព័ន្ធនឹងការបកស្រាយមិនត្រឹមត្រូវដោយម្ចាស់បណ្ដឹងសាទុក្ខលើការលើកឡើងរបស់ អ.ជ.ស.ដ ក្នុងសំណុំរឿង ០០១ ថា "ខណៈដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាត"។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១២៥។

[3032] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨៣។

[3033] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨៣។

[3034] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨៤។

884. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនគួរឱ្យជឿជាក់បានឡើយថា លក្ខខណ្ឌនៃការឃុំឃាំងប្រែប្រួលទៅតាមអ្នកទោសដែលប្រព្រឹត្តកំហុសធ្ងន់ កំហុសស្រាល និងជាស្ត្រី និងកុមារ *មិនមែន* ទៅតាមអ្នកទោសដែលគេសន្មតថាជាខ្មាំងនោះទេ។ ដូច្នេះ គេមិនអាចកំណត់ថា ជនជាតិចាវ៉ាយ, ផន ផុល, មៀង ចាន់ឌី និងអ្នកជាប់ឃុំដែលជាកងទ័ពប្រឈមនឹងលក្ខខណ្ឌពិបាកខ្លាំងជាងអ្នក ផ្សេងទៀតបានឡើយ[3035]។ ទោះជាយ៉ាងណា ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ មើលរំលងការ សន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ក្រុមទាំងនេះបានក្លាយជាគោលដៅ និងងាយប្រឈមនឹងការចាប់ខ្លួន *ដោយសារតែ*សមាជិកភាពរបស់ពួកគេក្នុងក្រុមខ្មាំងដែលកំណត់ដោយ ប.ក.ក[3036]។ បុគ្គលទាំងនេះ "បានទទួលរងនូវការធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាង ប្រជាជនផ្សេងទៀត នៅពេលពួកគេជាប់ឃុំនៅមន្ទីរសន្តិសុខអូរកន្សែង"[3037]។ អង្គហេតុដែលថា អ្នកទោសផ្សេងទៀតនៅមន្ទីរសន្តិសុខអូរកន្សែងក៏ត្រូវបានសួរចម្លើយ និងបញ្ជូនយកទៅសម្លាប់ ផងដែរនោះ មិនប៉ះពាល់ដល់ការសន្និដ្ឋាននេះឡើយ[3038]។

---

[3035] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៨៥៤-៨៥៨។

[3036] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៥០ ("ជនជាតិចាវ៉ាយត្រូវបានចាប់ខ្លួនដោយផ្អែកលើទំនាក់ទំនងរបស់ពួកគេជាមួយនឹងក្រុមដែលមិនមែនជាជនជាតិខ្មែរ ជាជាងសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមជាតិសាសន៍ ឬជាតិពន្ធនោះ បើទោះបីជាពួកគេជាជនជាតិចាវ៉ាយ ឬជនជាតិវៀតណាមក៏ដោយ។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះយល់ឃើញថា ពួកចាវ៉ាយត្រូវបានចាប់ខ្លួន ដោយសារតែការយល់ឃើញរបស់កងពល ៨០១ និងលេខាភូមិភាគឦសានថា ពួកគេគឺជា "ខ្មាំងខាងក្រៅ"), ២៩៨៧ ("កម្មករចម្ការកៅស៊ូម្នាក់ឈ្មោះ ផន ផុល ត្រូវបានចាប់ខ្លួន ឃុំខ្លួន សួរចម្លើយអំពីការប្រើប្រាស់បច្ចេកទេសព្យាបាលដើមកៅស៊ូ "តាមបែបសក្តិភូមិ" ហើយត្រូវទទួលរងការអប់រំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់គាត់ក្នុងនាមជាមនុស្សនៅមន្ទីរសន្តិសុខអូរកន្សែង"), ២៩៨៨ ("ដោយសារតែទីតាំងលំនៅដ្ឋានរបស់គាត់នៅជិតព្រំដែនប្រទេសវៀតណាម ហើយរៀបការជាមួយនឹង ផន ផុល ដែលគេសន្មតថាជាខ្មាំងនោះ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា សាក្សី មៀង ចាន់ឌី ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងទទួលរងការធ្វើបាប និងការដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងអ្នកផ្សេងទៀតដោយសារតែឋានៈជាខ្មាំងតាមការសន្មត"), ២៩៨៩ ("អង្គជំនុំជម្រះពិចារណាលើការមើលឃើញទៅលើកងទ័ពទាំងនេះថាបានទាក់ទងជាមួយនឹងអ្នកប្រយុទ្ធជាខ្មាំងនៅតាមព្រំដែន ក.ប.ធ និងវៀតណាម និង "ខ្មាំងផ្ទៃក្នុង" ឬកងទ័ពប្រឆាំងបដិវត្តន៍នៅក្នុងជួរយោធាដោយសារជម្លោះប្រដាប់អាវុធដែលបានបន្តកើតឡើងជាមួយនឹងវៀតណាម។ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំជាកងទ័ពត្រូវបានចាប់ខ្លួន ឃុំខ្លួន និងទទួលរងការធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកជាងអ្នកផ្សេងទៀត ដោយសារតែឋានៈជាខ្មាំងតាមការសន្មតរបស់ពួកគេ")។

[3037] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៨៤។

[3038] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨។

## VIII. ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល

### ក. សេចក្តីផ្តើម

885. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមដោយមានចេតនាពេញលេញនៅក្នុងផែនការឧក្រិដ្ឋ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ និងបានជួយ និងជ្រោមជ្រែងដល់ការប្រព្រឹត្តិរបស់ពួកគេដោយចេតនា។ នៅក្នុងបណ្តឹងសាទុក្ខនេះ ម្ចាស់បណ្តឹងរិះគន់ អ.ជ.ស.ដ ចំពោះការមើលមិនពេញលេញចំពោះគោលនយោបាយឧក្រិដ្ឋយ៉ាងច្បាស់ក្រឡែតរបស់ ប.ក.ក។ បន្ទាប់មក គាត់បានបន្តធ្វើមិនដឹងរឿង ដោយថា គាត់គ្រាន់តែជាប្រមុខរដ្ឋ ដែលមានតែនាម តែគ្មានអំណាច គ្មានឥទ្ធិពល ឬគ្មានចេតនាក្នុងការបង្កើត និងរក្សាគោលនយោបាយទាំងនោះឡើយ និងបានចូលរួមនៅក្នុងការអនុវត្តគោលនយោបាយទាំងនោះឡើយដោយមិន ដឹងខ្លួន។ នៅក្នុងផ្នែកនេះ ចម្លើយតបនឹងលាតត្រដាងឱ្យឃើញថា តាមរយៈការបំភ្លៃយុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់ និងការមិនដឹងអំពីការទទួលខុសត្រូវរបស់អ្នកដែលរៀបចំឱ្យមានឧក្រិដ្ឋ កម្មអន្តរជាតិ ដោយមានបុព្វសិទ្ធិ និងការផ្តាច់ចេញពីអំណាចនោះ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដោយមិនត្រឹមត្រូវ និងអនុវត្តខុសចំពោះកត្តាកំណត់នៃច្បាប់ស្តីពី សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវចំពោះការជួយ និងការជំរុញ។ ផ្នែកនេះក៏នឹងបង្ហាញថា វិធីសាស្ត្របង្ហាញ ដោយផ្នែករបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះភ័ស្តុតាង និងការចោទប្រកាន់អំពីភាពលម្អៀង ខកខានមិនបានលើកឡើងពីវិមតិសង្ស័យណាមួយទៅលើការសន្និដ្ឋានរបស់ អ.ជ.ស.ដ ទាក់ទងនឹងការ ទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់គាត់ទេ។

### ខ. តួនាទី និងមុខងារ

886. អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានកាន់តួនាទី និងមុខងារជាក់លាក់នៅក្នុង ប.ក.ក[3039] ដែលធ្វើឱ្យគាត់ដឹងអំពី (i) គោលនយោបាយដែល ប.ក.ក បានបង្កើតឡើង និងអនុវត្ត និង (ii) ឧក្រិដ្ឋកម្មនៅក្នុង *បណ្តឹង* នៃសំណុំរឿង ០០២/០២ អាចនឹងត្រូវបានប្រព្រឹត្ត កំពុងប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្តរួចហើយ[3040]។ លើសពីនេះទៀត តួនាទី និងមុខងារទាំងនោះបានផ្តល់ឱ្យគាត់នូវឱកាស និងសិទ្ធិអំណាចដ៏ល្អក្នុងការចូលរួមចំណែកជាសំខាន់ទៅក្នុង

[3039] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦២-៦២៤។

[3040] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៥, ៣៩៦៥ (ជើងទំព័រ ១៣១៩១-១៣៩១៣), ៤០៥៨, ៤២០៨, ៤២២៥, ៤២៣០, ៤២៥០, ៤៣២៥។

គោលបំណងរួមនោះ[3041] និងលើការជួយ និងការជំរុញឧក្រិដ្ឋកម្មនានា[3042]។ មូលដ្ឋានចំនួន ១០ របស់ម្ចាស់បណ្តឹងសាទុក្ខ[3043] ដែលជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ទាក់ទងនឹងតួនាទី និងមុខងាររបស់គាត់ បរាជ័យ ដោយហេតុថា មូលដ្ឋានទាំងនោះប្រើវិធីសាស្ត្របង្ហាញតាមផ្នែក ដោយមិនត្រឹមត្រូវចំពោះភ័ស្តុតាង ឬសាលក្រម បំភ្លៃការសន្និដ្ឋាន និង គ្រាន់តែជាការបកស្រាយឡើងវិញទៅលើភ័ស្តុតាងដែល អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវរួចទៅហើយនោះ។ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដដែលៗ និងដោយមិនត្រឹមត្រូវថា រូបគាត់គ្មានអំណាច ឬឥទ្ធិពលនៅក្នុង ប.ក.ក និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឡើយ ដោយមិនគិតពីទម្ងន់នៃភ័ស្តុតាងដែលបង្ហាញពីមុខតំណែងសំខាន់របស់គាត់នៅក្នុងថ្នាក់ដឹកនាំបក្ស[3044]។

887. ម្ចាស់បណ្តឹងសាទុក្ខ "បានគាំទ្រ លើកទឹកចិត្ត ដោយប្រយោល បង្កើតនូវធម្មានុរូប [...] និង [...] បានជួយសម្រួលដល់" គោលបំណងរួម រួមទាំងគោលនយោបាយឧក្រិដ្ឋរបស់របបនេះ តាមរយៈការកាន់កាប់មុខតំណែងសំខាន់ៗជាបន្តបន្ទាប់របស់គាត់នៅក្នុង ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងវិសាលភាពនៃការចោទប្រកាន់ទាំងមូល[3045]។ តាមរយៈវត្តមានជាប្រចាំរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដែលបញ្ហាសំខាន់ៗ ដូចជា ជោគវាសនារបស់ខ្មាំង[3046] និងការអនុវត្តគោលនយោបាយទាក់ទងនឹងសហករណ៍ និងការដ្ឋាន ត្រូវបានពិភាក្សា[3047]នោះ ម្ចាស់បណ្តឹងសាទុក្ខ "បានផ្តល់លទ្ធភាពដោយផ្ទាល់ និងគ្រប់គ្រង"[3048] ការអនុវត្តជាបន្តបន្ទាប់នៃគោលនយោបាយឧក្រិដ្ឋប្រឆាំងនឹងប្រជាជនកម្ពុជាប្រជាធិបតេយ្យ[3049] និង "បានគាំទ្រផ្នែកសីលធម៌" បន្ថែមទៀត ចំពោះការធ្វើសេចក្តីសម្រេចរបស់ ប.ក.ក ដែលបានបន្តជំរុញដល់ ការរៀបចំផែនការ និងការអនុវត្តគំនិតផ្តួចផ្តើមឧក្រិដ្ឋកម្ម[3050]។ ក្នុងនាមជាសមាជិកម្នាក់នៃគណៈ

---

[3041] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៩, ៣៣៨៧, ៣៥៥០-៣៥៥១, ៣៥៧០ (ការបង្កើនចំនួនប្រជាជន), ៣៧៤២ (ជើងទំព័រ ១២៤៨៩), ៣៧៧៣ (ទាប៊ាន លន់ នល់), ៣៨២៣ (ខ្មាំងវៀតណាម) ៣៨៩៧, ៣៩០៩, ៣៩១៦ (គោលនយោបាយឧក្រិដ្ឋទាក់ទងនឹងសហករណ៍) ៣៩៦០ (ការគៀបសង្កត់ខ្មាំង) ៤២៦២, ៤២៦៥, ៤៣១៥។

[3042] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១២-៤៣១៩។

[3043] មូលដ្ឋានទី ១៩០-១៩១, ១៩៥, ២០០-២០៣, ២០៥-២០៧។

[3044] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២៤, ៤២២៤។

[3045] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧។

[3046] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣១៦។

[3047] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៣។

[3048] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៨។

[3049] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៧-៤២៧៨។

[3050] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៣។

កម្មាធិការមជ្ឈិម ម្ចាស់បណ្តឹងសាទុក្ខបានមានវត្តមាន និងបានចូលរួមចំណែកក្នុងសន្និបាតបក្ស ដែលបានអនុម័តិគោលនយោបាយពាក់ព័ន្ធនឹងមាគ៌ានយោបាយរួម[3051] ក៏ដូចជា សេចក្តីសម្រេច ប្រគល់ "សិទ្ធិកម្ទេច" ជូនទៅថ្នាក់ក្រោម ប.ក.ក ផងដែរ[3052]។

888. ក្នុងនាមជាសមាជិកនៃមន្ទីរ ៨៧០ និងជាអ្នកមើលការខុសត្រូវលើពាណិជ្ជកម្ម និងជំនួញនៃរបប កម្ពុជាប្រជាធិបតេយ្យ ម្ចាស់បណ្តឹងសាទុក្ខ "បានជួយឱ្យរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដំណើរការទៅដោយរលូន ក្នុងទិសដៅបំផ្លាញប្រជាជនរបស់ខ្លួន"[3053]។ ម្ចាស់បណ្តឹងសាទុក្ខ ក្នុងនាមជាអ្នកនយោបាយកម្ពុជាដែលទទួលបានការគោរព ជាមុខមាត់តំណាងរាជរដ្ឋាភិបាល រួបរួមជាតិកម្ពុជា (GRUNK) និងរបបកម្ពុជាប្រជាធិបតេយ្យ និងជា "អ្នកធានាក្រមសីលធម៌" របស់របបកម្ពុជាប្រជាធិបតេយ្យ "[បាន]គាំទ្រ និង [បាន]ផ្តល់នូវធម្មានុរូប" ចំពោះការអនុវត្ត គោលបំណងរួម ទាំងនៅក្នុងស្រុក និងលើឆាកអន្តរជាតិ[3054]។ តាមរយៈការចូលរួម និង "ដឹកនាំ វគ្គបំពាក់បំប៉ន" នៅតាមអង្គមីទ្ទីង និងវគ្គសិក្សាអប់រំ ដែលមានបំណងបង្កើតការគាំទ្រគោល នយោបាយ ប.ក.ក ម្ចាស់បណ្តឹងសាទុក្ខ "បានផ្សព្វផ្សាយជាសាធារណៈ បានបញ្ជាក់ [...] គាំទ្រ" និង "បានបន្តគោរពតាម" មាគ៌ាបក្ស[3055]។ តាមរយៈសុន្ទរកថាជាសាធារណៈ និងសេចក្តីថ្លែង ការណ៍របស់គាត់ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ម្ចាស់បណ្តឹងសាទុក្ខក៏បានលើក ទឹកចិត្ត និងបានញុះញង់ "ដោយបើកចំហរ និងយ៉ាងសកម្ម" ឱ្យអនុវត្តគោលនយោបាយរបស់ ប.ក.ក ស្តីពីដំណើរការសហករណ៍ និងការដ្ឋាន បទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក៏ដូចជា ការចាប់ខ្លួន និងសម្លាប់ខ្មាំងផងដែរ[3056]។

### *មូលដ្ឋានទី ២០៣៖ "សមាជិក" នៃ គណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍*[3057]

---

[3051] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦០។

[3052] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦០។

[3053] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៦។

[3054] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥, ៤៣១៤, ៤៣៨៣។

[3055] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២, ៤២៧១-៤២៧៣។

[3056] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៤, ៤២៦៥-៤២៧០។ *សូមមើលផងដែរ* កថាខណ្ឌ ៤២៦៦-៤២៦៩។

[3057] <u>មូលដ្ឋានទី ២០៣៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *"សមាជិក" នៃគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍* កថាខណ្ឌ ១៧០៤-១៧៥៤។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៩-៧០ (អង់គ្លេស) ទំព័រ ៦៤-៦៥ (បារាំង) ទំព័រ ៩៨-៩៩ (ខ្មែរ)។

889. **មូលដ្ឋានទី ១៣១ គួរត្រូវបានច្រានចោលដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គហេតុ នៅក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខគឺជាផ្នែកមួយនៃក្រុមតូចដែលជាសមាជិក ប.ក.ក ដែលទទួលបានព័ត៌មានច្បាស់លាស់**

890. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ ខកខានមិនបានបង្ហាញថា (i) គាត់គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម[3058] (ii) គាត់បានចូលរួមក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើន ដែលបញ្ហាសំខាន់ៗត្រូវបានពិភាក្សា និងសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើងនៅទីនោះ[3059] និង (iii) គាត់បានចូលរួមក្នុងការប្រជុំ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ស្របតាមគោលការណ៍មជ្ឈការនិយមប្រជាធិបតេយ្យ ដែលបានផ្តល់ឱ្យគាត់នូវឱកាសចូលរួមចំណែកក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត[3060]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយមិនត្រឹមត្រូវថា ការវាយតម្លៃភ័ស្តុតាងរបស់ អ.ជ.ស.ដ មិនសមហេតុផល និងលម្អៀង[3061]។

*អ.ជ.ស.ដ បានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីសមាជិកភាពរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុង គណៈកម្មាធិការមជ្ឈិម*

891. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម ក្នុងពេលសន្និបាតបក្ស លើកទីបួន ក្នុងខែមករា ឆ្នាំ១៩៧៦[3062]។ ម្ចាស់បណ្តឹងសាទុក្ខបំភ្លៃសក្ខីកម្មរបស់ Stephen Heder ដែលបានពន្យល់យ៉ាងច្បាស់ថា "មានសន្និបាតបក្សមួយក្នុងខែមករា ឆ្នាំ៧៦ តាមខ្ញុំដឹងគឺ [...] [ម្ចាស់បណ្តឹងសាទុក្ខ] បានឡើងតំណែងពីសមាជិកត្រៀមរួច ទៅជាសមាជិកពេញសិទ្ធិ"[3063]។

---

[3058] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៣៤, ៦០០, ៦០៤។

[3059] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០១-៦០៤។

[3060] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០-៣៩១, ៣៩៩, ៦០៤, ៤៣២២, ៤២៥៩។

[3061] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៩-៧០ (អង់គ្លេស) ទំព័រ ៦៤-៦៥ (បារាំង) ទំព័រ ៩៨-៩៩ ខ្មែរ)។

[3062] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧២០-១៧២១ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥, ៥៣៤, ៦០០, ៣៧៣៨។

[3063] ឯកសារ **E1/223.1** Stephen Heder ប្រតិចារឹក ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.09.22-11.11.33 ទំព័រ ៣១ ជួរ៨-៩។

ម្ចាស់បណ្ដឹងសាទុក្ខខ្លួនគាត់ផ្ទាល់ដឹងថា គាត់បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនៅចន្លោះឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦[3064]។

892. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានពង្រីកអំណាចរបស់គណៈកម្មាធិការមជ្ឈិម ដើម្បីភ្ជាប់រូបគាត់ទៅនឹងឧក្រិដ្ឋកម្មនានានៅតាមរយៈការដឹកនាំរបស់គាត់[3065]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាសបណ្ដឹងសាទុក្ខ[3066] អ.ជ.ស.ដ ផ្អែកលើភ័ស្ដុតាងទាំងមូល មិនមែនផ្អែកលើតែលក្ខន្តិកៈ ប.ក.ក ឆ្នាំ១៩៧១ តែប៉ុណ្ណោះទេ[3067] ដើម្បីសន្និដ្ឋានថា គណៈកម្មាធិការមជ្ឈិមមានការទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តគោលនយោបាយបក្ស[3068] និងមានអំណាចតែងតាំង[3069]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានទទួលស្គាល់ទម្ងន់ភ័ស្ដុតាងដែលបង្ហាញថា គណៈកម្មាធិការមជ្ឈិមបានត្រួតពិនិត្យ និងបានអនុវត្តគោលនយោបាយ ប.ក.ក ទាក់ទង នឹងការដ្ឋាន[3070] សហករណ៍[3071] មន្ទីរសន្តិសុខ[3072] ការបោសសម្អាត[3073] និងវិធានការប្រឆាំង

---

[3064] ឯកសារ **E1/198.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 14.42.06- 14.44.38 ទំព័រ ៦៤ បន្ទាត់ ១៩-២០។ *សូមមើលផងដែរ* ឯកសារ **E3/573** កំណត់ត្រាបទសម្ភាសន៍ អៀង សារី ដោយ Stephen Heder, KH 00640499 ("ខៀវ សំផន បានក្លាយជាសមាជិកគណៈកម្មាធិការមជ្ឈិមក្នុងឆ្នាំ១៩៧៦ ប៉ុន្តែតាមការពិត គាតបានចូលប្រឡូកក្នុងកិច្ចការគណៈកម្មាធិការមជ្ឈិមតាំងពីឆ្នាំ ១៩៧៥ [ឯកសារបកប្រែខ្មែរបកខុសថា ១៩៧៧] មកម្ល៉េះ")។

[3065] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ១៧០៦។

[3066] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧១០។ អំណះអំណាងស្រដៀងនេះត្រូវបានបដិសេធដោយ អ.ជ.ត.ក ក្នុងសំណុំរឿង០០២/០១។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ១០៤៥-១០៤៧។

[3067] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧០៨-១៧០៩។

[3068] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥, ៦០០។

[3069] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៧។

[3070] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២២៤, ១៤៧៦, ៣៩២២។

[3071] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៧១។

[3072] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៧០។

[3073] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៦៤, ១៤៦៨, ២២៧៨។

នឹងក្រុមជាក់លាក់[3074] តាមរយៈការចេញសារាចរណែនាំ និងសេចក្តីសម្រេច[3075] ការផ្សព្វផ្សាយផែនការការងារនៅតាមភូមិភាគ និងតំបន់ និងតាមរយៈវគ្គបណ្តុះបណ្តាល[3076]។

893. ទាក់ទងទៅនឹងអំណាចតែងតាំងរបស់គណៈកម្មាធិការមជ្ឈិម ម្ចាស់បណ្តឹងសាទុក្ខមើលរំលងផ្នែកនៃភស្តុតាងជាច្រើនស្តីពីការតែងតាំងធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម[3077]។ គាត់ក៏ខកខានមិនបានបង្ហាញថា វាមិនសមហេតុផលនោះទេ ដែល អ.ជ.ស.ដ សន្និដ្ឋានថា គណៈកម្មាធិការមជ្ឈិមបានតែងតាំងគាត់ជាប្រធានគណៈប្រធានរដ្ឋនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជនបានបញ្ជាក់ជាផ្លូវការលើការតែងតាំងនោះនៅក្នុងខែមេសា ឆ្នាំ១៩៧៦[3078]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខមិនត្រឹមត្រូវទេ ដែលថា អ.ជ.ស.ដ បានចេញការសន្និដ្ឋានផ្ទុយគ្នាក្នុងការសន្និដ្ឋាន (i) គណៈកម្មាធិការមជ្ឈិមបានតែងតាំងគាត់ជាប្រធានគណៈប្រធានរដ្ឋ និង (ii) សន្និដ្ឋានថា "រដ្ឋមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកក្រសួងរាយការណ៍ និងទទួលការណែនាំពីគណៈកម្មាធិការមជ្ឈិម"[3079] ការសន្និដ្ឋានទាំងពីរនេះមិនពេញលេញទេ ដោយហេតុថា ប្រធាននៃរបបកម្ពុជាប្រជាធិបតេយ្យមិនមែនជាសមាជិករដ្ឋាភិបាលទេ[3080] ហើយទោះបីជាគាត់ត្រូវរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ក៏ដោយ ក៏គណៈកម្មាធិការមជ្ឈិមពិតជាបានធ្វើសេចក្តីសម្រេចចិត្តមួយចំនួនដែរ[3081]។ ឧទាហរណ៍ គណៈកម្មាធិការអចិន្ត្រៃយ៍គឺជាសាខាប្រតិបត្តិជាន់ខ្ពស់របស់គណៈ

---

[3074] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨២៨។

[3075] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៩៦៨, ២៧៧០, ៣៨២៨។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ គណៈកម្មាធិការមជ្ឈិមបានចេញគោលការណ៍ណែនាំទាក់ទងនឹងតម្រូវការចាំបាច់លុបបំបាត់ខ្មាំងរបស់ ប.ក.ក ដូចជា ភ្នាក់ងារ សេ.អ៊ី.អា និង កា.ហ្សេ.បេ ជនជាតិវៀតណាម និងបានផ្សព្វផ្សាយសារាចរបន្ថែមទៀតដោយមានការណែនាំអំពីបញ្ហានេះ។

[3076] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៩៧៦-១៩៨០។

[3077] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៥១៤, ៥៩០។ គណៈកម្មាធិការមជ្ឈិមបានតែងតាំងជាឧទាហរណ៍ ប្រធានគណៈប្រធានរដ្ឋ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ។

[3078] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៦៩៣ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩០។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧។

[3079] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥១៦។

[3080] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥១២, ៥១៥-៥១៦, ៥១៨-៥១៩។ ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ មាត្រា ១១ (កម្ពុជាប្រជាធិបតេយ្យមានគណៈប្រធានរដ្ឋ ដែលជ្រើសរើស និងតែងតាំងដោយសភាតំណាងប្រជាជន "រាងរាល់ប្រាំឆ្នាំម្តង")។

[3081] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៥៧។ *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៤៧។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣។

កម្មាធិការមជ្ឈិម ហើយសមាជិករបស់ខ្លួនក៏ត្រូវបានតែងតាំងដោយគណៈកម្មាធិការមជ្ឈិមផ្ទាល់ផងដែរ[3082]។ ដូចដែល អ.ជ.ស.ដ បានសន្និដ្ឋាន[3083] និងបានតម្កល់ដោយ អ.ជ.ត.ក នៅក្នុងសំណុំរឿង០០២/០១[3084] អង្គហេតុដែលថា តាមការអនុវត្ត គណៈកម្មាធិការអចិន្ត្រៃយ៍ធ្វើការត្រួតត្រាយ៉ាងមានប្រសិទ្ធភាពលើ ប.ក.ក មិនបានបដិសេធថា សេចក្ដីសម្រេចមួយចំនួនតាមពិតបានធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិមនោះឡើយ។

894. ទីបី ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានសន្និដ្ឋានថា គាត់បានដឹងមានគោលបំណង និងបានចូលរួមក្នុងឧក្រិដ្ឋកម្ម ដោយសារតែការរួមចំណែកនៃសេចក្ដីសម្រេចជាច្រើនដែលបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ទៅកាន់គណៈកម្មាធិការមជ្ឈិម[3085]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងសន្និដ្ឋានថា គាត់ បានដឹងអំពីសេចក្ដីសម្រេចបិទផ្សារ បញ្ឈប់ការប្រើប្រាស់លុយ និងបង្កើតសហករណ៍នៅក្នុង តំបន់រំដោះដែលផ្ដួចផ្ដើមធ្វើឡើងក្នុងខែឧសភា ឆ្នាំ១៩៧២ និងបានបញ្ជាក់មួយឆ្នាំក្រោយមក[3086]។ ទឡ្ហីករណ៍របស់គាត់ដែលថា វាគឺជាសេចក្ដីសម្រេចមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ មិនមែនគណៈកម្មាធិការមជ្ឈិមនោះ មិនមានមូលដ្ឋានទេ[3087]។ ប្រសិនបើ អ.ជ.ស.ដ មិនបានផ្ដល់សំអាងហេតុច្បាស់លាស់សម្រាប់ការពឹងផ្អែកច្រើនលើសក្ខីកម្មរបស់ Philip Short ជាងសក្ខីកម្មរបស់ នួន ជា លើបញ្ហានេះ[3088] ខ្លឹមសារនៃទង់បដិវត្តបង្ហាញថា សេចក្ដីសម្រេចខែឧសភា ឆ្នាំ១៩៧២ -

[3082] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៦ (សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាស្ថាប័នធ្វើសម្រេចកំពូលរបស់ ប.ក.ក "ត្រូវបានជ្រើសរើសចេញពីគណៈកម្មាធិការមជ្ឈិមដែលជាស្ថាប័នសមាជិកច្រើនជាង") ៣៥៥ (គណៈកម្មាធិការមជ្ឈិម "មានភារកិច្ចអនុវត្តមាគ៌ានយោបាយ និងលក្ខន្តិកៈរបស់បក្សនៅក្នុង ប.ក.ក ទាំងមូល") ៣៥៧ ("ទោះបីជាលក្ខន្តិកៈ ប.ក.ក ផ្ដល់អំណាចប្រតិបត្តិការខ្ពស់បំផុតទៅឱ្យគណៈកម្មាធិការមជ្ឈិមក៏ដោយ ក៏ការត្រួតត្រាពិតប្រាកដទៅលើ ប.ក.ក ត្រូវបានអនុវត្តដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណៈកម្មាធិការមជ្ឈិម [...] គណៈកម្មាធិការមជ្ឈិមមានតួនាទីចាត់តាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍")។

[3083] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៥៥, ៣៥៧។ *សូមមើលផងដែរ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៤៧។

[3084] ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ១០៤៧។

[3085] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧១៣, ១៧១៩។

[3086] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៤២០៧។

[3087] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧១៤។

[3088] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២៧ (*យោង* **E3/9** សៀវភៅនិពន្ធដោយ Philip Short មានចំណងជើងថា *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* EN 00396428 (*សូមមើលផងដែរ* EN 00396427, 00396430) *ត្រូវបានបញ្ជាក់ក្នុង* ឯកសារ **E1/190.1** Philip Short ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 11.12.34-11.19.01

ឧសភា ឆ្នាំ១៩៧៣ ត្រូវបានធ្វើឡើងដោយបក្សទាំងមូល រួមទាំងគណៈកម្មាធិការមជ្ឈិមផង និង មិនមែនតែគណៈកម្មាធិការអចិន្ត្រៃយ៍តែឯងនោះទេ[3089]។ *សម្រាប់គោលបំណងវែកញែក* ប្រសិន បើសេចក្តីសម្រេចទាំងនេះជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបាន បង្ហាញថា វាមិនសមហេតុផលក្នុងសន្និដ្ឋានថា គាត់បានដឹងអំពីសេចក្តីសម្រេចដ៏សំខាន់ទាំងនេះ ដោយផ្អែកលើមុខតំណែងរបស់គាត់នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិ កម្ពុជា (GRUNK) និង រណបកម្ពុជាប្រជាធិបតេយ្យ មុខងារ និងទំនាក់ទំនងជិតស្និទរបស់គាត់ជាមួយមេដឹកនាំ ប.ក.ក[3090]។

895. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា តាមរយៈសមាជិកភាពរបស់គាត់ក្នុងគណៈកម្មាធិការមជ្ឈិម ដែលគាត់បានយល់ព្រមតាមសេចក្តី សម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ពាក់ព័ន្ធជាពិសេសទៅនឹងការតែងតាំងទៅក្នុងរដ្ឋាភិបាល ការបង្កើតប្រព័ន្ធរាយការណ៍ និងអំណាចនៃការអនុវត្ត[3091]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងម្តង ហើយម្តងទៀតពីការអះអាងដែលគ្មានការគាំទ្រ[3092]ថា សេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ មិនចេញមកពីគណៈកម្មាធិការមជ្ឈិមទេ ដូច្នេះ មិនមានតម្លៃភ័ស្តុតាងបញ្ជាក់ឡើយ[3093]។ ម្ចាស់ បណ្តឹងសាទុក្ខក៏បានលើកឡើងដោយមិនត្រឹមត្រូវផងដែរថា អ.ជ.ស.ដ បានសន្និដ្ឋាននៅក្នុងសំណុំ

---

ទំព័រ ៣០ បន្ទាត់១៨ - ទំព័រ៣២ បន្ទាត់១៦) ២៣៩ (*យោង* ឯកសារ **E1/35.1** នួន ជា ប្រតិចារឹក ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ ម៉ោង 09.14.46-09.20.30 ទំព័រ ៣ បន្ទាត់ ២២ - ទំព័រ ៤ បន្ទាត់ ១៧)។

[3089] ឯកសារ **E169/4/1.1.2** *ទស្សនាវដ្តីទង់បដិវត្ត* ខែធ្នូ ឆ្នាំ១៩៧៥-មករា ឆ្នាំ១៩៧៦ KH 00809847-48 ("សន្និបាតមជ្ឈិមបក្ស ខែ៥ ឆ្នាំ១៩៧២ [...] បក្សបានបើកឆាករៀបចំសហករណ៍ជាជំហានដំបូង។ [...] ដល់ពាក់កណ្តាលឆ្នាំ១៩៧៣ មជ្ឈិមបក្ស បើកសន្និបាតទៀត")។ ឯកសារ **E3/10** *ទស្សនាវដ្តីទង់បដិវត្ត* ខែកញ្ញា-តុលា ១៩៧៦ KH 00063072 ("បក្សពិនិត្យឃើញ សភាពការណ៍យ៉ាងនេះ [...] ក៏សម្រេចបិទផ្សារនៅក្នុងតំបន់រំដោះក្នុងឆ្នាំ១៩៧២។") 00063072 ("ក្នុងពាក់កណ្តាលឆ្នាំ១៩៧៣ បក្សសម្រេចចាត់តាំងសហករណ៍ទូទាំងប្រទេស")។ *សូមមើលផងដែរ* **E3/166** *ទស្សនាវដ្តីទង់បដិវត្ត* ខែកុម្ភៈ-មីនា ១៩៧៦ KH 00063229 (សំដៅលើវិធានការ "បក្ស" ក្នុងពាក់កណ្តាលឆ្នាំ១៩៧២ និង ១៩៧៣) 00063195។ ឯកសារ **E3/50** របាយការណ៍ស្តីពីខួបនៃការរៀបចំសហករណ៍ កសិករ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ KH 00442209 ("ឆ្នាំ៧២-៧៣ បក្សលើកវិធានការ [...] ផ្តាច់ឯកជនលក់ដូរ ក្តាប់ពាណិជ្ជកម្ម [...] ចាត់តាំងសហករណ៍")។

[3090] *See e.g.* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៥៦៥-៥៦៦, ៥៧២-៥៨០, ៤២០៧, ៤២៥៧។

[3091] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១៤, ៤១៦, ៥៩៦, ៣៧៣៩, ៣៨៥៥-៣៨៥៦, ៣៨៩៩, ៤២៥៩-៤២៦០។ កត់សម្គាល់ថា ម្ចាស់បណ្តឹងសាទុក្ខត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋក្នុងពេលប្រជុំគណៈកម្មាធិការ មជ្ឈិមថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៥៩៦។

[3092] ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ កថាខណ្ឌ ៤៩៧-៥០១។ ការអះអាងទាំងនេះត្រូវបានបដិសេធ ដោយ អ.ជ.ត.ក ក្នុង ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ១០៤៥-១០៤៧។

[3093] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧១៧។

រឿង០០១ ថា សេចក្តីសម្រេចនេះបានចេញដោយគណៈកម្មាធិការអចិន្ត្រៃយ៍[3094]។ ផ្ទុយទៅវិញ អ.ជ.ស.ដ បានសន្និដ្ឋានក្នុងសំណុំរឿង០០១ ថា វាគឺជាសេចក្តីណែនាំដ៏សំខាន់ចេញពីគណៈកម្មាធិការមជ្ឈិម[3095] ជាការសន្និដ្ឋានដែលមានបញ្ជាក់ក្នុងសំណុំរឿង០០២/០២ ផងដែរ[3096]។

896. ម្ចាស់បណ្តឹងសាទុក្ខខកខានក្នុងការង្ហាញទៀតថា អ.ជ.ស.ដ មានកំហុស ដោយផ្អែកលើការប្រជុំខែមិថុនា ឆ្នាំ១៩៧៤ ដែលនៅក្នុងអង្គប្រជុំនោះ គណៈកម្មាធិការមជ្ឈិមបានអនុម័តទាំងផែនការសម្រាប់ការវាយសម្រុកចុងក្រោយចូលទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងសេចក្តីសម្រេចឈប់ទទួលបក្ខជនថ្មី ដើម្បីទប់ស្កាត់កុំឱ្យគិញជ្រៀតចូល[3097]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3098] អ.ជ.ស.ដ បានវាយតម្លៃយ៉ាងត្រឹមត្រូវលើភ័ស្តុតាង

[3094] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១៧។

[3095] ឯកសារ **E188** សាលក្រមសំណុំរឿង០០១ កថាខណ្ឌ ១០២-១០៣ (អ.ជ.ស.ដ បានភ្ជាប់សេចក្តីសម្រេចនេះទៅនឹងគណៈកម្មាធិការមជ្ឈិមទោះបីមតិយោបល់របស់អ្នកជំនាញ Philip Short)។

[3096] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១៤, ៤១៦, ៥៣៦, ៥៩៦, ៩៧១, ១១២៦, ២០៦៨, ២២៧៨, ២២៨៤, ៣០៤៨, ៣៧៣៩, ៣៧៧១, ៣៨៩៩, ៣៩៥៥, ៤១២៥, ៤២៥៩-៤២៦០។ ឯកសារនេះផ្ទាល់ (E3/12, ៣០ មីនា ១៩៧៦) គឺជាមានចំណងជើងច្បាស់ក្រឡែតថា "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" (គូសបញ្ជាក់បន្ថែម)។

[3097] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១៥-១៧១៦។

[3098] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧១៥ (*ទស្សនាវដ្តីទង់បដិវត្ត*ពិភាក្សាអំពីសេចក្តីសម្រេចពាក់កណ្តាលឆ្នាំ១៩៧៤ ឈប់ទទួលសមាជិកបក្ស មិនសំដៅលើគណៈកម្មាធិការមជ្ឈិមទេ តែសំដៅលើ "បក្ស") ១៥១៦ (យោងតាមម្ចាស់បណ្តឹងសាទុក្ខ នួន ជា បានផ្តល់សក្ខីកម្មថា វាគឺជាវគ្គប្រជុំពិសេសរបស់គណៈកម្មាធិការអចិន្ត្រៃយ៍)។ កត់សម្គាល់ថា សក្ខីកម្មគុណការរបស់ នួន ជា មិនស៊ីចង្វាក់គ្នាទេ ដោយហេតុថាគាត់បានអះអាងពីរដងថា វាជាអង្គប្រជុំគណៈមជ្ឈិម ក្រោយមកថា វាគឺជាវគ្គប្រជុំពិសេសរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងចុងក្រោយថាវាប្រមូលផ្តុំទាំងសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម។ *សូមមើល* ឯកសារ **E1/14.1** នួន ជា ប្រតិចារឹក ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ម៉ោង 14.53.02-14.54.34 ទំព័រ៦ ៨ បន្ទាត់ ១-២ ("ចុងឆ្នាំ១៩៧៤ គណៈមជ្ឈិមបក្សមិនពេញអង្គមួយបានប្រជុំទៀត គឺធ្វើសេចក្តីសម្រេចវាយរំដោះភ្នំពេញ ក្នុងឆ្នាំ១៩៧៥") ម៉ោង 14.53.02-14.54.34 បន្ទាត់ ១៩-២០ ទំព័រ ៧៣ បន្ទាត់ ៣ ទំព័រ ៧៤, បន្ទាត់ ៨ ("ការប្រជុំ អចិន្ត្រៃយ៍ បក្សមិនពេញអង្គមួយ នៅពាក់កណ្តាលឆ្នាំ១៩៧៤") ម៉ោង 15.31.16-15.32.52, ទំព័រ៧៨ បន្ទាត់៥-៦ ("អង្គប្រជុំបានមានមតិ ឱ្យសមាជិកមជ្ឈិមបក្សដែលបានចូលរួមប្រជុំទៅពិភាក្សាជាមួយគណៈភាគ [...] ឱ្យច្បាស់ថាតើភូមិភាគណាមានលទ្ធភាពទទួលយកប្រជាជន អ្នកជម្លៀសប៉ុន្មាននាក់?")។ ឯកសារ **E1/22.1** នួន ជា ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ម៉ោង 09.06.42-09.07.38, ទំព័រ ២ បន្ទាត់ ២-៤ ("អំពីការជម្លៀសប្រជាជន ខ្ញុំសូមបញ្ជាក់ដូចតទៅនេះ៖ មានការប្រជុំគណៈអចិន្ត្រៃយ៍រួមជាមួយសមាជិកមជ្ឈិមមិនពេញអង្គខ្លះ នៅពាក់កណ្តាលឆ្នាំ១៩៧៤") ម៉ោង 09.08.30-09.10.05 ទំព័រ ២ បន្ទាត់ ២៤ ទំព័រ ៣ បន្ទាត់ ១។

*ទាំងមូល* រួមទាំងទស្សនាវដ្តី *ទង់បដិវត្ត* មុនពេលកំណត់ថា អង្គប្រជុំនេះគឺជា ការប្រជុំគណៈកម្មាធិការមជ្ឈិម និងមិនមែនជាអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទេ[3099]។

897. ទីបួន ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ អំពីវត្តមានរបស់គាត់នៅក្នុងសន្និបាតបក្សលើកទីបួន និងទីប្រាំ មិនត្រឹមត្រូវ[3100]។ ដូចបានបង្ហាញខាងលើ ម្ចាស់បណ្តឹងសាទុក្ខបានទទួលការតែងតាំងជាសមាជិកពេញសិទ្ធិក្នុ ងពេលសន្និបាតបក្សលើកទីបួន[3101] ដូច្នេះ ជាការសមហេតុផលក្នុងការសន្និដ្ឋានថាគាត់មានវត្តមាននោះ[3102]។ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានពិចារណាភាពភស្តុតាងជារួម នៅពេលជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ អំពីវត្តមានរបស់គាត់នៅក្នុងសន្និបាតបក្សលើកទីប្រាំផងដែរ[3103]។ សៅ សារុន លើកឡើងថា គាត់បានឃើញម្ចាស់បណ្តឹងសាទុក្ខក្នុងចំណោមមេដឹកនាំ ប.ក.ក នៅក្នុងសន្និបាតបក្សដែលបង្រួបបង្រួមតំបន់ កងពល ទាំងអស់ និងគណៈកម្មាធិការមជ្ឈិម ដែលកន្លែងគាត់បានតែងតាំងជាលេខាតំបន់ ១០៥[3104]។ ឌុច បានអះអាងថា គោលបំណងសំខាន់នៃសន្និបាតបក្សលើកទីប្រាំ គឺដើម្បីតែងតាំងលេខាតំបន់ (និងតំបន់ស្វយ័ត) ថ្មី ដើម្បីជំនួសលេខាជាច្រើនដែលត្រូវ

---

[3099] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ២៣០ (ជើងទំព័រ ៥៤៧-៥៤៩) ៣៨៨០, ៤០២ (ជើងទំព័រ ១២០៤) ៣៩៤០។ ភស្តុតាងដែលបានយោងសំអាងបង្ហាញថា ការប្រជុំនោះគឺជាអង្គប្រជុំគណៈមជ្ឈិម៖ ឯកសារ **E3/11** *ទង់បដិវត្ត* ខែកញ្ញា ឆ្នាំ១៩៧៧ KH 00063162 (“គណៈកម្មាធិការមជ្ឈិមបក្សរបស់យើង ក្នុងអង្គសន្និបាតរបស់ខ្លួន នៅខែមិថុនា ឆ្នាំ១៩៧៤បានសម្រេចដាច់ខាត វាយខ្ទាំងផ្តាច់ព្រ័ត្ររំដោះភ្នំពេញ […] តាមទិសអប់រំរបស់មជ្ឈិមបក្ស”)។ ឯកសារ **E3/9** សៀវភៅនិពន្ធដោយ Philip Short មានចំនងជើងថា *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់* 00336465-66 (បានពន្យល់ថា ប៉ុល ពត បានបើកការប្រជុំ គណៈមជ្ឈិម ក្នុងខែមេឃ ខែកញ្ញា ឆ្នាំ១៩៧៤ ដើម្បីធ្វើការសម្រេចសំខាន់ៗទាក់ទងនឹង ការជម្លៀសប្រជាជនចេញពីទីក្រុង លុយ និងការឯកភាពបក្ស)។ *សូមមើលផងដែរ* ឯកសារ **E3/5** *ទង់បដិវត្ត* ខែសីហា ឆ្នាំ១៩៧៨ KH 00063336។ ឯកសារ **E3/25** *ទង់បដិវត្ត* ខែធ្នូ ឆ្នាំ១៩៧៦-មករា ឆ្នាំ១៩៧៧ KH 00063036 (“យើង […] បក្ស”), 00063044។ ឯកសារ **E3/746** *ទង់បដិវត្ត* ខែកក្កដា ឆ្នាំ១៩៧៨ KH 00064487 (“បក្សយើង”)។ ឯកសារ **E3/747 [E3/166]** *ទង់បដិវត្ត* ខែសីហា មីនា ឆ្នាំ១៩៧៦ KH 005063226-27 (“បក្ស”)។

[3100] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧២៤-១៧២៥ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៩, ៤២៥៧, ៤២៥៩-៤២៦០។

[3101] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥, ៥៧៤, ៦០០។ *សូមមើលផងដែរ* **E3/573** កំណត់ត្រាបទសម្ភាសន៍ អៀង សារី ដោយ Stephen Heder, KH 00640499-00640500។

[3102] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧។

[3103] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧២៥។

[3104] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥ ឯកសារ **E1/84.1** សៅ សារុន ប្រតិចារិក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 09.45.27-09.47.05 ទំព័រ ១៤ បន្ទាត់ ៥ ទំព័រ ១៤ បន្ទាត់ ១៧ ម៉ោង 10.07.44-10.18.22 ទំព័រ ២១ បន្ទាត់ ១-ទំព័រ ២៣ បន្ទាត់ ១៦។

បានបោសសម្អាត[3105]។ កំណត់ហេតុកិច្ចប្រជុំសន្និបាតបក្សលើកទីប្រាំក៏គាំទ្របញ្ជាក់ថា ម្ចាស់បណ្តឹងសាទុក្ខមានវត្តមាននៅក្នុងសន្និបាតនេះ ដោយសារគាត់ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការសេដ្ឋកិច្ចនៃគណៈកម្មាធិការមជ្ឈិម[3106]។

*អ.ជ.ស.ដ បានវាយតម្លៃយ៉ាងត្រឹមត្រូវលើការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍*

898. ម្ចាស់បណ្តឹងសាទុក្ខជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើមុខតំណែងពិសេសរបស់គាត់ក្នុងបក្ស ដោយបានអះអាងថា អ្នកមិនមែនជាសមាជិកផ្សេងទៀតក៏បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ[3107]។ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានពិចារណាលើភ័ស្តុតាងទាំងអស់។ ក្រៅពីការចូលរួមជាប្រចាំ និងដ៏សកម្មរបស់គាត់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ អ.ជ.ស.ដ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខកាន់មុខនាទីដ៏សំខាន់នៅក្នុង ប.ក.ក និង រាជរដ្ឋាភិបាលរួបរួមជាតិ (GRUNK)/កម្ពុជាប្រជាធិបតេយ្យ និងថា គាត់បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយមេដឹកនាំ ប.ក.ក ជាពិសេស ប៉ុល ពត និង នួន ជា[3108]។ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានចូលរួមក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើន ដែលបញ្ហាសំខាន់ៗត្រូវបានពិភាក្សា ហើយសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង[3109]។

899. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មិនមានសំអាងហេតុត្រឹមត្រូវក្នុងការសន្និដ្ឋានថា គាត់មានវត្តមាន និងបានចូលរួមជាប្រចាំក្នុងការប្រជុំគណៈកម្មាធិការ

[3105] ឯកសារ **E3/55** កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ម៉ោង 14.05.23-14.08.57 ទំព័រ ៥៦ បន្ទាត់ ៩-១២។ ឌុច ក៏បានលើកឡើងថា កែ ពក បានប្រាប់គាត់ថា ខៀវ សំផន មានវត្តមាននៅពេលដែល វន វ៉េត ត្រូវបានចាប់ខ្លួន (ទោះបីជាគាត់អះអាងថាវាគឺជាការប្រជុំគណៈកម្មាធិការមជ្ឈិមក៏ដោយ)៖ ឯកសារ **E3/394** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00398227។

[3106] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥២ ជើងទំព័រ ១២៥៨៦ *យោង* ឯកសារ **E3/816** កំណត់ហេតុនៃអង្គប្រជុំសន្និបាតបក្សលើកទីប្រាំ ចុះថ្ងៃទី១-២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ KH 00800744-46។

[3107] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥៦។

[3108] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩, ៤២៣០។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០០។

[3109] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០៤, ៦២៤, ៤២០៨, ៤៣៨២។

អចិន្ត្រៃយ៍[3110]។ ទទ្បីករណ៍របស់គាត់ខកខានមិនបានកំណត់កំហុសណាមួយនៅក្នុងការ សន្និដ្ឋានរបស់ អ.ជ.ស.ដ តែផ្ទុយទៅវិញផ្តល់នូវការបកស្រាយផ្សេងចំពោះភ័ស្តុតាងដែលបាន វាយតម្លៃរួចហើយដោយ អ.ជ.ស.ដ[3111]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា កំណត់ហេតុកិច្ចប្រជុំចំនួន ២២ ដែលទទួលយកដោយ អ.ជ.ស.ដ មានបញ្ជីឈ្មោះអ្នកចូលរួម បញ្ជីឈ្មោះ ១៦ បានកត់ត្រាឈ្មោះ "សមមិត្ត ហែម" (ម្ចាស់បណ្តឹងសាទុក្ខ) ថា មានវត្តមាន ដែលធ្វើឱ្យគាត់ជាអ្នកដែលមានវត្តមានច្រើនជាងគេបំផុត បន្ទាប់ពី នួន ជា និង ប៉ុល ពត[3112]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3113] និងដូចដែលបានពន្យល់ក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ៣៦[3114] មិនមានកំហុសក្នុងការពឹងផ្អែកលើកំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នោះទេ ដោយសារពួកវាមានយថាភូត និងមានតម្លៃបញ្ជាក់ភ័ស្តុតាងសំខាន់។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថាការធ្វើបទអន្តរាគមរបស់គាត់ក្នុងពេលប្រជុំមិនទាក់ទងទៅនឹងឧក្រិដ្ឋកម្មជាក់លាក់នោះ មិនមានការពាក់ព័ន្ធឡើយ[3115] ដោយហេតុថា ការចូលរួមរបស់គាត់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនចាំបាច់ថាត្រូវតែចូលរួមផ្ទាល់នោះទេ ការចូលរួមដោយប្រយោលក៏រាប់ចូលដែរ[3116]។

900. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មិនអាចសន្និដ្ឋានអំពីការដឹងចេតនា ឬការចូលរួមចំណែកណាមួយក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈវត្តមានរបស់គាត់ក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើននោះបានទេ[3117]។ គាត់ជំទាស់ជាពិសេសទៅនឹងការពឹងផ្អែករបស់ អ.ជ.ស.ដ លើវត្តមានរបស់គាត់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើនអំពីការសង់ព្រលានយន្តហោះកំពង់ឆ្នាំង[3118]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3119] អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា

[3110] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧៣១, ១៧៣៧ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧, ៣៥៧, ៤៨៤, ៦០២, ៣៧៤០។

[3111] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៣៧, ១៧៤៦។

[3112] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០២។

[3113] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៣២។

[3114] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៦ (យថាភាព និងតម្លៃបញ្ជាក់ភ័ស្តុតាងនៃការប្រជុំគណៈអចិន្ត្រៃយ៍ចំនួន ២២)។

[3115] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៣៧។

[3116] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៦ (ការវាយតម្លៃរបស់ អ.ជ.ស.ដ លើការចូលរួមចំណែកសំខាន់)។

[3117] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៤០។

[3118] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៤១-១៧៤២។

[3119] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧៤២។

ម្ចាស់បណ្ដឹងសាទុក្ខបានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ (i) ក្នុងខែតុលា ឆ្នាំ១៩៧៥ អំពីការសង់ព្រលានយន្តហោះ[3120] និង (ii) ក្នុងខែឧសភា ឆ្នាំ១៩៧៦ អំពីការរៀបចំព្រលានយន្តហោះ[3121]។ ដូចបានរៀបរាប់លម្អិតក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២១៥ អ.ជ.ស.ដ មិនបានផ្អែកទាំងស្រុងលើវត្តមានរបស់គាត់នោះទេ ប៉ុន្តែ លើភស្តុតាងជារួម ដើម្បីសន្និដ្ឋានថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃគោលនយោបាយ ដែលផ្ដោតលើការបង្កើត និងប្រតិបត្តិការព្រលានយន្តហោះកំពង់ឆ្នាំង[3122]។

901. ម្ចាស់បណ្ដឹងសាទុក្ខក៏ជំទាស់ទៅនឹងការពឹងផ្អែករបស់ អ.ជ.ស.ដ លើវត្តមានរបស់គាត់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍អំពីកសិកម្ម គ្រោះរាំងស្ងួត និងឧស្សាហកម្ម ក្នុងការសន្និដ្ឋានថារូបគាត់បានចូលរួមចំណែកក្នុងការជំរុញគោលបំណងរួម[3123]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[3124] អ.ជ.ស.ដ បានវាយតម្លៃសេចក្ដីថ្លែងការណ៍ក្រៅតុលាការរបស់ អៀង សារី រួមជាមួយនឹងភស្តុតាងគាំទ្របញ្ជាក់ផ្សេងទៀត ដើម្បីសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខបានចូលរួមក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍អំពីកសិកម្ម គ្រោះរាំងស្ងួត និងឧស្សាហកម្ម[3125]។ គាត់ក៏មើលរំលងការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើវត្តមានរបស់គាត់ក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៅ (i) ថ្ងៃទី៣០ ខែឧសភា ឆ្នាំ៩៧៦ ស្ដីពីការទទួលបានស្រូវជាដាច់ខាតពីមូលដ្ឋានក្នុងចំនួនពី ៣០ ភាគរយ ទៅ ១០០ ភាគរយ[3126] និង (ii) នៅក្នុងខែមិថុនា ឆ្នាំ១៩៧៦[3127] ស្ដីពីការលំបាកក្នុងការសម្រេចបានតាមគោលដៅស្រូវបីតោនក្នុងមួយហិចតា ត្រឹមចុងឆ្នាំ។

---

[3120] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣ ជើងទំព័រ ៥៨៣៤។ កំណត់ហេតុនៃអង្គប្រជុំបង្ហាញថាគាត់ត្រូវបានតែងតាំងក្នុងអង្គប្រជុំនេះឱ្យទទួលខុសត្រូវរណសិរ្ស រាជរដ្ឋាភិបាល ពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ។ *សូមមើល* ឯកសារ **E3/182** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019108។

[3121] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣។ កំណត់ហេតុនៃអង្គប្រជុំបញ្ជាក់ថា គាត់ត្រូវបានតែងតាំងក្នុងពេលអង្គប្រជុំនេះ ឱ្យទទួលខុសត្រូវគណៈប្រតិភូកូរេខាងជើង។ *សូមមើល* ឯកសារ **E3/235** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១៩-២១ ខែមេសា ឆ្នាំ១៩៧៦ KH 00019144។

[3122] *សូមមើ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១៥។

[3123] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៤៤ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៨១, ៤២៥៨។

[3124] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៤៤។

[3125] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៩-៣៨៩១។

[3126] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៨ ជើងទំព័រ ១៣៨៩៣ *យោង* ឯកសារ **E3/224** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៦ KH 00000773។

*អ.ជ.ស.ជ បានវាយតម្លៃយ៉ាងត្រូវលើគោលការណ៍មជ្ឈការនិយមប្រជាធិបតេយ្យ*

902. ដោយគ្មានមូលដ្ឋាន ម្ចាស់បណ្ដឹងសាទុក្ខអះអាងថា អ.ជ.ស.ជ បានសន្និដ្ឋានខុសថា គាត់មានឱកាសចូលរួមក្នុងពេលប្រជុំគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍[3128]។

903. ទាក់ទងនឹងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងដោយមិនត្រឹមត្រូវថា មិនមានភ័ស្ដុតាងអំពីវត្តមានរបស់គាត់ ឬការធ្វើអន្តរាគមន៍របស់គាត់ទេ[3129]។ ដូចបានលើកឡើងខាងលើ ម្ចាស់បណ្ដឹងសាទុក្ខបានចូលរួមក្នុងការប្រជុំគណៈកម្មាធិការមជ្ឈិម ដូចជា ការប្រជុំមួយដែលធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១០៩៦ ក៏ដូចជា សន្និបាតបក្ស[3130]។ ម្ចាស់បណ្ដឹងសាទុក្ខបានមើលរំលងថែមទៀតថា ក្នុងនាមជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម ចន្លោះឆ្នាំ ១៩៧១ និង ១៩៧៦[3131] គាត់អាចចូលរួមក្នុងការប្រជុំពិភាក្សារបស់គណៈកម្មាធិការមជ្ឈិម ដែលឈានដល់សេចក្ដីសម្រេច និងឥទ្ធិពលលើអ្នកដទៃ ខណៈដែលពីខែមករា ឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ គាត់អាចទាំងចូលរួម និងទាំងបោះឆ្នោត[3132]។ គាត់ក៏ខកខានមិនបានទទួលស្គាល់ផងដែរថា អៀង សារី បានថ្លែងថានៅ "ឆ្នាំ១៩៧៥ [ម្ចាស់បណ្ដឹងសាទុក្ខ] បានចូលរួម*តាមព្រឹត្តន័យ* ក្នុងកិច្ចការគណៈកម្មាធិការមជ្ឈិម"[3133]។

904. ទាក់ទងនឹងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ម្ចាស់បណ្ដឹងសាទុក្ខ លើកឡើងដោយគ្មានអង្គមូលដ្ឋានថា អ.ជ.ស.ជ មិនអាចសន្និដ្ឋានថា គាត់មានលទ្ធភាពចូលរួមបានទេ ដោយសារគាត់មិនមែនជាសមាជិកផ្លូវការទេ[3134]។ ជាថ្មីម្ដងទៀត ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានទទួលស្គាល់ភ័ស្ដុតាងជារួម។ អ.ជ.ស.ជ បានសន្និដ្ឋានថា គាត់បានចូលរួមយ៉ាងសកម្មក្នុងការប្រជុំជាច្រើន

---

[3127] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០១ ជើងទំព័រ ១៣០៨ *យោង* ឯកសារ **E3/226** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ KH 0017155។

[3128] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៤៩។

[3129] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៥០។

[3130] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៩-៤២៦០ *យោងទៅ* កថាខណ្ឌ ៦០០, ៣៨៩៩, ៣៧៧១, ៣៩៥៥, ៤២២៩ និងយោងទៅផ្នែក ៥.១.១ (សន្និបាតបក្ស) ផ្នែក៥.១.៩ (មជ្ឈការនិយមប្រជាធិបតេយ្យ)។

[3131] ឯកសារ **E3/8380** លក្ខន្តិកៈ ប.ក.ក ឆ្នាំ១៩៧១ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៧២ KH 00283497 (មាត្រា៣)។ *សូមមើលផងដែរ* ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៩៩៧ (ម្ចាស់បណ្ដឹងសាទុក្ខ "មានសិទ្ធិចូលរួមក្នុងការពិភាក្សារបស់គណៈកម្មាធិការនេះ" "ទោះបីជាគាត់មិនមានសិទ្ធិសម្រេចជាផ្លូវការក៏ដោយ")។

[3132] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០០។

[3133] ឯកសារ **E3/573** កំណត់ត្រាបទសម្ភាសន៍ អៀង សារី ដោយ Stephen Heder ចុះថ្ងៃទី៤ ខែមករា ឆ្នាំ១៩៩៩ KH 00640499។

[3134] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៥១។

តាមរយៈការធ្វើរបាយការណ៍ និងការធ្វើបទបង្ហាញ[3135]។ តាមរយៈការចូលរួមយ៉ាងសកម្ម និងការបញ្ចេញសំឡេងរបស់គាត់ ជាការសមហេតុផលសម្រាប់ អ.ជ.ស.ដ ក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់ដែលជិតស្និទ្ធនឹង ប៉ុល ពត និង នួន ជា យ៉ាងហោចណាស់ មានលទ្ធភាព មានឥទ្ធិពលលើសេចក្តីសម្រេចដែលបានធ្វើឡើង ជាពិសេសដោយផ្អែកលើគោលការណ៍មជ្ឈការនិយមប្រជាធិបតេយ្យរបស់ ប.ក.ក[3136]។

905. ម្ចាស់បណ្តឹងសាទុក្ខខកខានផងដែរក្នុងការបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា តាមគោលការណ៍មជ្ឈការនិយមប្រជាធិបតេយ្យ សេចក្តីសម្រេចបានធ្វើឡើងជាសមូហភាព មិនមែនដោយ ប៉ុល ពត ផ្តាច់មុខតែម្នាក់ឯងនោះទេ[3137]។ ដូចគ្នាក្នុងសំណុំរឿង ០០២/០១ ដែរ ទទ្បីករណ៍គ្មានមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខបរាជ័យ[3138]។ ម្ចាស់បណ្តឹងសាទុក្ខខកខានទៀតក្នុងការបង្ហាញថា កំណត់ហេតុប្រជុំទាំងនោះ ផ្ទុយទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា សេចក្តីសម្រេចត្រូវបានធ្វើឡើងជាសមូហភាព[3139]។ អង្គហេតុដែលថា ប៉ុល ពត និង/ឬ នួន ជា បានធ្វើការកត់សម្គាល់/លើកមតិយោបល់ជាច្រើននៅក្នុងកំណត់ហេតុកិច្ចប្រជុំចំនួន ២៣[3140] ដែល អ.ជ.ស.ដ បានចាត់ទុកថាមានយថាភូត និងមានតម្លៃបញ្ជាក់ភ័ស្តុតាងសំខាន់[3141] មិនផ្ទុយទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា សេចក្តីសម្រេចត្រូវបានធ្វើឡើងជាសមូហភាពឡើយ[3142]។

---

[3135] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០២។

[3136] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២។ *សូមមើលផងដែរ* ទាក់ទងនឹងលទ្ធភាពរបស់គាត់ក្នុងការមានលទ្ធភាពលើអ្នកដទៃក្នុងបរិបទផ្សេង កថាខណ្ឌ ៤៣២០, ៤៣៨៣។

[3137] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥២ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧។

[3138] ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ១០៥០។

[3139] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥២។

[3140] *សូមមើលផងដែរ* ឯកសារ **E3/218** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ KH 00000751។ ឯកសារ **E3/223** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៦ KH 00000829។ ឯកសារ **E3/225** កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ KH 00000837។ ឯកសារ **E3/226** កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ KH 00017147។ **E3/1733** កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019108-09។

[3141] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៩-៣៥០ ជើងទំព័រ ៩៦៥, ៩៦៩។

[3142] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥៣។

## *មូលដ្ឋានទី ២០៥៖ សមាជិកមន្ទីរ ៨៧០*[3143]

906. **មូលដ្ឋានទី ២០៥ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុនៅក្នុងការសម្រេចរបស់ខ្លួន ទាក់ទងនឹងសមាជិកភាពរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងមន្ទីរ ៨៧០។**

907. មូលដ្ឋាននេះបរាជ័យទាក់ទងនឹងកំហុសអង្គហេតុដែលបានចោទប្រកាន់ថា ម្ចាស់បណ្តឹងសាទុក្ខបានក្លាយជាសមាជិកម្នាក់នៃមន្ទីរ ៨៧០ ប្រហែល ឬ នៅក្នុងខែតុលា ឆ្នាំ១៩៧៥[3144]។ អ.ជ.ស.ដ បានពឹងផ្អែកលើភស្តុតាងយ៉ាងសន្ធឹកសន្ធាប់ រួមទាំងភស្តុតាងដែលម្ចាស់បណ្តឹងសាទុក្ខបានដាក់ផងក្នុងការកំណត់ថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមជាមួយមន្ទីរ ៨៧០ ប្រហែលក្នុងខែតុលា ឆ្នាំ១៩៧៥[3145] មិនមែនក្នុងខែ មីនា-មេសា ឆ្នាំ១៩៧៦ ដូចគាត់តវ៉ានោះទេ[3146]។

---

[3143] មូលដ្ឋានទី ២០៥៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *សមាជិកមន្ទីរ ៨៧០* កថាខណ្ឌ ១៧៦៣-១៧៦៩, ១៦៣៧-១៦៣៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧០ (ភាសាអង់គ្លេស) ទំព័រ ៦៥ (ភាសាបារាំង) ទំព័រ ៩៩-១០០ (ភាសាខ្មែរ)។

[3144] ម្ចាស់បណ្តឹងសាទុក្ខយល់ច្រឡំចំពោះសាលក្រម ដោយនិយាយថា គាត់បានក្លាយជាសមាជិកមន្ទីរ ៨៧០ នៅក្នុងខែតុលា ឆ្នាំ១៩៧៥ ដែលការពិត អ.ជ.ស.ដ បានរកឃើញថា "ប្រហែល" នៅក្នុងខែតុលា ឆ្នាំ១៩៧៥៖ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤, ៦០៨។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦៣, ១៧៦៧។ យើងត្រូវកត់សំគាល់ថា អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងច្រំដែលទាំងមិនជោគជ័យ យកពីសំណុំរឿង ០០២/០១។ សូមមើល សំណុំរឿង **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១៧ *ទាត់ចោល* ឯកសារ **F17** សារណាបណ្តឹងសាទុក្ខ សំណុំរឿង ០០២/០១ កថាខណ្ឌ ៥៥១-៥៥៣។

[3145] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០៨ (ជើងទំព័រ ១៩០៩), ៣៦៤ (ជើងទំព័រ ១០៤០) *ឯកសារទាំងពីរយោង* ឯកសារ **E3/182** កំណត់ហេតុការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019108។ ឯកសារ **E3/37** កំណត់ហេតុសួរចម្លើយ ខៀវ សំផន KH 00156676។ ឯកសារ **E3/112** លិខិតរបស់ ខៀវ សំផន ជូន ក.ស.ច.ស។ ឯកសារ **E3/18** សៀវភៅនិពន្ធដោយ ខៀវ សំផន មានចំណងជើងថា៖ "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ ទំព័រ ៦៥-៦៦។ នេះភស្តុតាងនេះបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ថា គាត់បានក្លាយជាសមាជិកម្នាក់នៃសមាជិកទាំងពីររបស់មន្ទីរ៨៧០ ប្រហែលនៅក្នុងខែតុលា ឆ្នាំ១៩៧៦ ថាមន្ទីរ ៨៧០ គឺជាមន្ទីរមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ថាគាត់នៅក្នុងមន្ទីរនេះ ទទួលខុសត្រូវលើការរៀបចំបញ្ជីតម្លៃ និងការបែងចែកទំនិញនៅក្នុងប្រទេស (និងធានាលើការនាំចូលទំនិញ) ជាកិច្ចការដែលបានចាត់តាំងច្បាស់លាស់មកឱ្យគាត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងខែតុលា ឆ្នាំ១៩៧៥ (ទទួលបន្ទុកខាង "ពាណិជ្ជកម្មសម្រាប់ការងារគណនី និងតម្លៃ")។

[3146] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦៦-១៧៦៧។

908. មូលដ្ឋាននេះក៏បរាជ័យផងដែរទាក់ទងនឹងកំហុសអង្គហេតុដែលបានចោទប្រកាន់ថា អ.ជ.ស.ដ បានកំណត់ខុសថា ឌឿន គឺជា "អ្នកកាន់មុខតំណែងមុន" របស់ម្ចាស់បណ្តឹងសាទុក្ខមន្ទីរ៨៧០ [3147]។ អ.ជ.ស.ដ បានពិនិត្យយ៉ាងហ្មត់ចត់លើភស្តុតាងនេះ ហើយបន្ទាប់ពីបានបដិសេធលើសក្ខីកម្មចំនួនប្រាំមួយដែលឱ្យដឹងថាម្ចាស់បណ្តឹងសាទុក្ខបានក្លាយជាប្រធានមន្ទីរ៨៧០ ក្រោយការចាប់ខ្លួន ឌឿន រួចមក[3148] ក៏បានសន្និដ្ឋានថា ខ្លួនមិនអាចកំណត់បានឡើយ ថាតើម្ចាស់បណ្តឹងសាទុក្ខបានកាន់មុខតំណែងជាថ្នាក់ដឹកនាំនៅមន្ទីរ៨៧០ លើសពីសមាជិកភាពរបស់គាត់[3149]។ ការប្រើពាក្យ "អ្នកកាន់មុខតំណែងមុន" នៅក្នុងកថាខណ្ឌដែលរងការជំទាស់[3150] ដូច្នេះ អាចត្រូវបានបកស្រាយតាមតក្កវិជ្ជាថា ជាកំហុសផ្នែកបោះពុម្ព ឬជាការច្រឡំដែលបណ្តាលមកពីអង្គហេតុថា ឌឿន ការពិតគឺជា "អ្នកកាន់មុខតំណែងមុន" របស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងគណៈ កម្មាធិការពាណិជ្ជកម្ម [3151]។ ក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា កំហុស ផ្នែកបោះពុម្ពនេះគឺជារឿងសំខាន់បំផុតដល់សេចក្តីវិនិច្ឆ័យដែលបានសម្រេច ដែលជាហេតុនាំឱ្យមានការខុសឆ្គងរបស់តុលាការនោះទេ[3152]។

---

[3147] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦៨-១៧៦៩ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៦។

[3148] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១២ (អ.ជ.ស.ដ ច្រានចោលសក្ខីកម្មរបស់ ឌុច ត្រង់ចំណុចនេះ), ៦១៣-៦១៤) (អ.ជ.ស.ដ ផ្តល់តម្លៃភរនីយភាពបន្តិចបន្តួចទៅលើកំណត់សំគាល់នៃបទសម្ភាសន៍របស់ Heder ជាមួយ វ៉ាន់ រិទ្ធិ និង អៀង សារី តែគ្មានផ្តល់តម្លៃលើសក្ខីកម្មផ្ទាល់មាត់របស់ ភី ភួន ទេ), ៦១៥ (អ.ជ.ស.ដ ផ្តល់តម្លៃបន្តិចបន្តួចទៅលើសក្ខីកម្មរបស់អ្នកជំនាញ Philip Short និង David Chandler អំពីការចូលជំនួសមុខតំណែង ឌឿន ដោយ ខៀវ សំផន)។

[3149] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤, ៦១៦។ សូមមើលផងដែរ កថាខណ្ឌ ៤២២៥ (ម្ចាស់បណ្តឹងសាទុក្ខនៅតែ "ជាសមាជិកម្នាក់ក្នុងចំណោមសមាជិកពីរបីនាក់នៃមន្ទីរ ៨៧០ ក្រោយការបាត់ខ្លួន ឌឿន"), ៤២៥៧, ៤២៧៦ (*'សមាជិក'* មន្ទីរ ៨៧០)។

[3150] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៦ ("ទម្រង់នៃការទទួលខុសត្រូវច្បាស់លាស់របស់ ខៀវ សំផន នៅក្នុងមន្ទីរ ៨៧០ គឺខុសគ្នាពី*អ្នកកាន់មុខតំណែងមុនៗ* របស់គាត់ [...]។ ជាលទ្ធផលនៃភាពកម្រនៃភស្តុតាងទាក់ទងនឹងមុខងាររបស់គាត់នៅក្នុងមន្ទីរ ៨៧០ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ខៀវ សំផន បានធ្វើជាប្រធាននៃមន្ទីរ ៨៧០ ឬ ការពិតជា "កម្មាភិបាលដឹកនាំ" ម្នាក់នៅក្នុងមន្ទីរនេះឡើយ") (គូសបញ្ជាក់បន្ថែម)។

[3151] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥ ដែលបែងចែករវាងសមាជិកភាពរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងមន្ទីរ៨៧០ និងតួនាទីរបស់គាត់នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម ដែលមើលការខុសត្រូវលើកិច្ចការរបស់ក្រសួងនេះ និងធានាចំពោះ "ការទទួលខុសត្រូវរបស់អ្នកកាន់មុខតំណែងមុនរបស់គាត់ [ឌឿន] នៅតែត្រូវបានបំពេញនៅក្រោយការដកគាត់ចេញ" (គូសបញ្ជាក់បន្ថែម)។

[3152] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦៨។

909. ម្ចាស់បណ្តឹងសាទុក្ខអះអាងទាំងគ្មានមូលដ្ឋានទៀតថា អ.ជ.ស.ជ មានកំហុសដោយសារមិនបានបែងចែកឱ្យដាច់ពីគ្នារវាងអំណះអំណាងទាក់ទងនឹងអត្ថន័យនៃលេខកូដ"៨៧០" និង "មន្ទីរ ៨៧០"[3153]។ ផ្ទុយពីទឡ្ហីករណ៍ខុសរបស់គាត់អំពីភាពមិនច្បាស់លាស់ដែលបានចោទប្រកាន់ ទាក់ទងនឹងអាសយដ្ឋានពិតប្រាកដនៃរបាយការណ៍ ឬទូរលេខមួយចំនួន[3154] ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការពឹងផ្អែករបស់ អ.ជ.ស.ជ លើឯកសារទាំងនេះក្នុងការវាយតម្លៃអំពីតួនាទីរបស់គាត់នៅក្នុងមន្ទីរ ៨៧០ និងការរួមចំណែករបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម គ្មានហេតុ ផលទេ[3155]។ អ.ជ.ស.ជ ពិតជាបានបែងចែកដាច់ពីគ្នារវាងអត្ថន័យខុសៗគ្នានៃ "៨៧០"[3156] និង បានធ្វើការសន្និដ្ឋានដោយមានហេតុផលថា សមាជិកភាពរបស់មន្ទីរ ៨៧០ បានផ្តល់លទ្ធភាពដល់គាត់ក្នុងចូលពិនិត្យព័ត៌មានសម្ងាត់សំខាន់ៗនានា ដែលរួមទាំង ព័ត៌មានអំពីឧក្រិដ្ឋកម្មនានាផង ដូចជា ការចាប់ខ្លួន និងការធ្វើមនុស្សឃាត ជាដើម នៅក្នុងទម្រង់ជារបាយការណ៍ និងទូរលេខ ដែលត្រូវបានបញ្ជូនពីភូមិភាគ និងតំបន់ស្វយ័តនានា ហើយដែលដាក់អាសយដ្ឋានច្បាស់លាស់ទៅកាន់ "មន្ទីរ ៨៧០"[3157]។ ដោយផ្អែកលើសក្ខីកម្មរបស់ នួន ជា សំផង់ អ.ជ.ស.ជ បានបំភ្លឺបន្ថែមថា ទូរលេខនានា

[3153] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣៧។

[3154] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣៨ (ម្ចាស់បណ្តឹងសាទុក្ខចោទថា របាយការណ៍ និងទូរលេខនានា មិនដាក់អាសយដ្ឋានអ្នកទទួលតែមន្ទីរ ៨៧០ ទេ ប៉ុន្តែភាគច្រើនអាសយដ្ឋានសរសេរថា "គណៈ ៨៧០ *អង្គការ* ៨៧០ មន្ទីរ ៨៧០ ឬ ជូនកាល បង")។

[3155] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣៧-១៦៣៩ (កត់សំគាល់ថា "មន្ទីរ ៨៧០" បានបកប្រែខុសនៅក្នុងកថាខណ្ឌ ១៦៣៧ ថា "ប៊ូរ៉ូ ៨៧០" នៅក្នុងការបកប្រែជាភាសាអង់គ្លេសនៃសារណាបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសា*ទុក្ខ។ សូមមើលផងដែរ* កថាខណ្ឌ ១៧៦៨ (ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ជ និយាយសរុបនៅពេលអង្គជំនុំជម្រះនេះរកឃើញថា គាត់មានលទ្ធភាពចូលពិនិត្យទូរលេខ និងរបាយការណ៍នានាដោយសារតែសមាជិកភាពរបស់គាត់នៅក្នុងមន្ទីរ៨៧០។ អំណះអំណាងនេះ គឺគ្មានមូលដ្ឋានឡើយ)។

[3156] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២ (ការប្រើខុសៗគ្នានៃ "៨៧០" ដោយរបបកម្ពុជាប្រជាធិបតេយ្យ និងការយល់ខុសៗគ្នាដោយសាក្សី), ៣៦៣ (ការបែងចែកដាច់ពីគ្នារវាង គណៈ ៨៧០ និង មន្ទីរ ៨៧០), ៣៦៥ (ការពិភាក្សាថាតើ មន្ទីរ ៨៧០ និង ប៊ូរ៉ូ ៨៧០ បង្កើតបាននូវអង្គតែមួយ), ៣៦៧ (ការបែងចែកដាច់ពីគ្នារវាងមន្ទីរ ៨៧០ និង ស-៧១), ៤៩២ (ទូរលេខនានាដែលបានសរសេរថា "ចម្លងជូនមន្ទីរ" គឺត្រូវបានបញ្ជូនទៅមន្ទីរ ៨៧០)។

[3157] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២ (របាយការណ៍នានាដែលបានបញ្ជូនដោយមេដឹកនាំភូមិភាគ និងមេដឹកនាំតំបន់ស្វយ័តទៅកាន់មន្ទីរ ៨៧០), ៣៨៦ (សំបុត្ររបស់មន្ទីរ ៨៧០ បញ្ជាឱ្យមេដឹកនាំកងពល ១១៧ & តំបន់ ៥០៥ ឡើងមកភ្នំពេញ ជាទីកន្លែងដែលពួកគេត្រូវបានចាប់ខ្លួន), ៤៩៣, ៦១០ (ទូរលេខនានាដែលផ្ញើទៅអ្នកទទួល ម-៨៧០ នៅឆ្នាំ១៩៧៧ និង ១៩៧៨), ១២៤០-១២៤៨ (របាយការណ៍នានារបស់ ប.ក.ក ដែលបានបញ្ជូនដោយ ម-៥៦០ ទៅមន្ទីរ៨៧០ ទាក់ទងនឹងការអត់បាយ និងលក្ខខណ្ឌអាក្រក់ផ្សេងៗទៀតនៅក្នុងតំបន់ ៥ រួមទាំងនៅទំនប់ត្រពាំងថ្ម), ១២៤២-១២៤៤ (សក្ខីកម្មតុលាការរបស់ សុន អេម អំពីរបាយការណ៍ដែលបានបញ្ជូនពីមន្ទីរ ម-៥៦០ ដែលបានប្រើពាក្យ "មន្ទីរ

ដែលមានសរសេរសំគាល់ថា បានចម្លងជូន "មន្ទីរ" ត្រូវបានបញ្ជូនយ៉ាងមានប្រសិទ្ធភាពទៅកាន់ "មន្ទីរ ៨៧០"[3158]។

910. ម្ចាស់បណ្តឹងសាទុក្ខមិនតវ៉ាចំពោះការរកឃើញរបស់ អ.ជ.ស.ដ ដែលថា (i) មន្ទីរ ៨៧០ គឺជាអង្គមួយដែលទទួលខុសត្រូវលើការពិនិត្យការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ទេ (ជា "ស្ថាប័នប្រតិបត្តិ" របស់គណៈកម្មាធិការនេះ)[3159] (ii) វានៅបន្តធ្វើប្រតិបត្តិការក្រោយការចាប់ខ្លួនរបស់ ខឿន ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧[3160] និង (iii) ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯង ធ្លាប់បានធ្វើការប្រាស្រ័យទំនាក់ទំនងជាមួយជាមួយថ្នាក់ក្រោមតាមរយៈទូរលេខ ដែលបានបញ្ជូនពីមន្ទីរ ៨៧០ [3161]។ លើសពីនេះទៀត ទោះបីជាគាត់អះអាងថា គាត់បានដឹងអំពីតួនាទីពិតប្រាកដរបស់គាត់តែនៅពេលក្រោយឆ្នាំ១៩៧៩ ក៏ដោយ ក៏ម្ចាស់បណ្តឹងសាទុក្ខធ្លាប់បានសារភាពក្នុងពេលនៃកិច្ចស៊ើបសួរថា តួនាទីរបស់មន្ទីរ ៨៧០ គឺដើម្បី "តាមដានលើសមាជិកបក្សដែលគេសង្ស័យ សម្រាប់គណៈកម្មាធិការអចិន្ត្រៃយ៍"[3162]។

---

៨៧០" សរសេរនៅលើស្រោមសំបុត្រ មិនមែនជាឯកសារទេ), ១២៥០, ១៤៥៩, ១៤៦៦ (កែ ពក រាយការណ៍អំពីខ្មាំង និងពួកក្បត់ទៅកាន់មន្ទីរ ៨៧០), ១៩៩៦ (ការប្រាស្រ័យទំនាក់ទំនងរបស់ សោ ភិម ជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ តាមរយៈមន្ទីរ ៨៧០), ៣០៣៥, ៣០៤០, ៤០៤៨ (របាយការណ៍អំពីការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមមុនៗជូនមន្ទីរ ៨៧០), ៤០៧១ (កែ ពក និង រស់ ញឹម បានរាយការណ៍ជូនមន្ទីរ ៨៧០ អំពីការកសាង និងស្ថានភាពការងារនៅការដ្ឋាន ទំនប់១មករា និងទំនប់ត្រពាំងថ្ម)។ សូមមើលផងដែរ ទូរលេខចម្លងជូនមន្ទីរ ៨៧០ ដែលបានយោង ជាអាទិ៍ នៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៧៨១៣, ១០០៣៩, ១១៥០៦, ១២៩៩៩។

[3158] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៩២ *យោង* សក្ខីកម្មគុលាការសំខាន់ៗរបស់ នង សុផង់ (ដែលជាអ្នកសរសេរលេខកូដ និងបកប្រែទូរលេខ នៅសាលាសុធារស ក្នុងទីក្រុងភ្នំពេញ ចាប់ពីឆ្នាំ១៩៧៥ មក) និង ឌុច។ សូមមើលឧទាហរណ៍ ទូរលេខ និងរបាយការណ៍នានាដែលបានចម្លងជូន "មន្ទីរ" នៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២១៦ (ជើងទំព័រ ១២៥១), ១២៤៧ (ជើងទំព័រ ៤២៦៨), ១២៥៣ (ជើងទំព័រ ៤២៨៥), ៣០៣៥ (ជើងទំព័រ ១០២៦៨)។

[3159] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៣-៣៦៤, ៦០៨, ២១៨៨ ជើងទំព័រ ៧៣៤៩។

[3160] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤, ៦១០, ៤២៧៦។

[3161] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៩៣, ៤២៧៦។

[3162] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២០ *យោង* ឯកសារ **E3/557** កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ KH 00153232-33។ ឯកសារ **E3/37** កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156677-78។ កថាខណ្ឌ ៤២២០ ត្រូវបានទុកចោលដោយម្ចាស់បណ្តឹងសាទុក្ខនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ពេលធ្វើការពិភាក្សាអំពីតួនាទីរបស់មន្ទីរ ៨៧០)។ *សូមមើលផងដែរ* ចម្លើយតបទៅនឹង ១៩២។

911. លើសពីនេះទៀត ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខក៏បរាជ័យដែរ ដោយហេតុថា សមាជិកភាពមន្ទីរ ៨៧០ របស់គាត់ គ្រាន់តែជាចំណុចមួយប៉ុណ្ណោះនៅក្នុងចំណោមកត្តាជាច្រើនទៀត[3163] ដែល អ.ជ.ស.ដ បានពឹងផ្អែកដើម្បីស្វែងរកភស្តុតាងមកបញ្ជាក់ថា ម្ចាស់បណ្តឹងសាទុក្ខពិតជាបានដឹងអំពីឧក្រិដ្ឋកម្មនានា[3164] និងបានចូលរួមចំណែកក្នុងក្រិដ្ឋកម្មទាំងនោះក្នុងនាមជាអ្នកចូលរួមប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម[3165]។

[3163] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨៩ (ការរួមចំណែករបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មនានា និងការចូលរួមប្រព្រឹត្តនៅក្នុង JCE បានធ្វើឡើងក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិម សមាជិកមន្ទីរ ៨៧០ ប្រធានគណៈប្រធានរដ្ឋ និងមន្ត្រីថ្នាក់ខ្ពស់បំផុតនៃ GRUNK), ៣៤០ (ម្ចាស់បណ្តឹងសាទុក្ខ បានដឹងអំពីឋានៈជនរងគ្រោះនៅ ស-២១ដែលទទួលបាននូវការការពារ អាស្រ័យដោយសមាជិកភាពរបស់នៅគាត់គណៈកម្មាធិការមជ្ឈិម និងមន្ទីរ៨៧០ និងថែមទាំងដោយសារជំហរពិសេសរបស់គាត់នៅក្នុងបក្ស ក្នុងនាមជាអ្នកដែលបានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមជា ច្រើន), ៤២២៥ (ការយល់ដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការចាប់ខ្លួន ខឿន គឺអាស្រ័យដោយបានបង្ហាញខ្លួន និងចូលរួមដោយផ្ទាល់ជាប្រចាំនៅក្នុងអង្គប្រជុំជាច្រើនរបស់គណៈកម្មាធិការមជ្ឈិម ដោយសារសម្ព័ន្ធភាពជិតស្និទ្ធជាមួយ ប៉ុល ពត និង នួន ជា, ការគ្រប់គ្រងលើការទទួលខុសត្រូវនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម និងការពិតដែលគាត់នៅតែរក្សាបានជាសមាជិកនៃមន្ទីរ៨៧០ រហូតដល់ពីរឆ្នាំបន្ទាប់ពីការបាត់ខ្លួន ខឿន), ៤២៥៧ (ការគាំទ្ររបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះគោលនយោបាយនានារបស់ ប.ក.ក ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិម ប្រធានគណៈប្រធានរដ្ឋ ការចូលរួមដោយផ្ទាល់ជាប្រចាំក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ជាកន្លែងដែលសេចក្តីសម្រេចសំខាន់ៗនានាត្រូវបានធ្វើឡើង សមាជិកភាពមន្ទីរ ៨៧០ និងការគ្រប់គ្រងកិច្ចការពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ចាប់ពីខែតុលា ឆ្នាំ១៩៧៦ មក), ៤២០៨ (ម្ចាស់បណ្តឹងសាទុក្ខមានការយល់ដឹងជាបន្តបន្ទាប់អំពីការវិវឌ្ឍន៍នៃផែនការ ការអនុវត្តផែនការ និងភាវនីយភាពដែលថាឧក្រិដ្ឋកម្មនានានឹងត្រូវកើតមានឡើងដោយសារភាពជិតស្និទ្ធរបស់គាត់ជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត ការចូលរួមផ្ទាល់ក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ការធ្វើដំណើរទៅទាំងតំបន់រំដោះ ការចេញសេចក្តីថ្លែងការនានា ការបង្ហាញខ្លួននៅក្នុងវគ្គរៀនសូត្រ និងវគ្គបំពាក់បំប៉នមនោគមវិជ្ជាផ្សេងៗ), ៤២២៦ (ការយល់ដឹងអំពីការចាប់ខ្លួន "ជនក្បត់" ដូចបានបង្ហាញភស្តុតាងជាក់ស្តែងនៅក្នុងសុន្ទរកថារបស់ នួន ជា និងម្ចាស់បណ្តឹងសាទុក្ខនៅឯវគ្គរៀនសូត្រនយោបាយក្នុងឆ្នាំ១៩៧៦), ៤២២៩, ៤២៥៣, ៤២៧៧។ អំពីការប្រជុំ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៨ ("ខៀវ សំផន បានបង្ហាញខ្លួន និងចូលរួមដោយផ្ទាល់ជាប្រចាំនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ជាពេលដែលកិច្ចការស្នូលចំពោះគោលបំណងរួមត្រូវបានពិភាក្សា" រួមទាំងការកំណត់អត្តសញ្ញាណ និងការបោសសម្អាតខ្មាំង), ៣៤០, ៤២០៨, ៤២២០, ៤២២២-៤២២៣, ៤២២៥-៤២២៦, ៤២២៨, ៤២៥៧, ៤២៧៧, ៤៣៨២។

[3164] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០, ៤២២៥, ៤២០៨ និង កថាខណ្ឌ ៤២០៤-៤២៥៤ ដែលមានលក្ខណៈទូទៅជាង (ចំណេះដឹងពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវ), ៤៣៨២។

[3165] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧-៤២២៨, ៤៣៨៩ និង កថាខណ្ឌ ៤២៥៥-៤៣០៨ ដែលមានលក្ខណៈទូទៅជាង (ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម), ៤៣២៦, ៤៣៨២-៤៣៨៣។ សូមមើលផងដែរ កថាខណ្ឌ ៤២៣០-៤២៣៦។

### *មូលដ្ឋានទី ២០០៖ ការភាន់ច្រឡំទាក់ទងនឹងកន្លែងស្នាក់នៅ កន្លែងការងារ និងការធ្វើដំណើរ*[3166]

912. **មូលដ្ឋានទី ២០០ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសនៅក្នុងការសម្រេចរបស់ខ្លួន ទាក់ទងនឹងភាពជិតស្និទ្ធរបស់ម្ចាស់បណ្តឹងសាទុក្ខជាមួយមេដឹកនាំ ប.ក.ក និងទស្សនកិច្ចរបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ឬក្នុងប្រើប្រាស់សេចក្តីសម្រេចទាំងនេះ ដើម្បីធ្វើការវិភាគទៅលើការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់គាត់។**

913. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខបានឱ្យដឹងទាំងមិនត្រឹមត្រូវថា អ.ជ.ស.ដ មានការភាន់ច្រឡំក្នុងការសម្រេចរបស់ខ្លួនថា គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយ ប៉ុល ពត, នួន ជា និងមេដឹកនាំ ប.ក.ក ដទៃទៀតនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ដោយសារកន្លែងស្នាក់នៅ និងកន្លែងធ្វើការងាររបស់គាត់ស្ថិតនៅចន្លោះមន្ទីរ ក-១ និង ក-៣[3167]។ ម្ចាស់បណ្តឹងសាទុក្ខតវ៉ាថា ក្រោយការចាកចេញពី ក.១ គាត់ "រស់នៅ ក.៣ ជាកន្លែងដែល នួន ជា និង អៀង សារី មកតែម្តងម្កាល ចំណែក ប៉ុល ពត ស្នាក់នៅជាប្រចាំនៅ ក.១"[3168]។ ម្ចាស់បណ្តឹងសាទុក្ខធ្វើមិនយកចិត្តទុកដាក់លើភ័ស្តុតាងទាំងមូលដែលបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខបានរក្សាសម្ព័ន្ធភាពជិតស្និទ្ធនៅកម្ពុជាប្រជាធិបតេយ្យជាមួយ ប៉ុល ពត[3169], នួន ជា[3170] និង អៀង សារី[3171] រួមទាំងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ប៉ុល

[3166] <u>មូលដ្ឋានទី ២០០៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសទាក់ទងនឹងទីកន្លែងស្នាក់នៅ កន្លែងធ្វើការ និងការធ្វើដំណើរ* កថាខណ្ឌ ១៦៨៣-១៦៨៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៩-៧០ (អង់គ្លេស) ទំព័រ ៦៤ (បារាំង) ទំព័រ ៩៧ (ខ្មែរ)។

[3167] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨៤ *ផ្ទុយពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៤, ៥៨៩។

[3168] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨៤ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៤។

[3169] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩ (ជើងទំព័រ ១៨៤៥), ៦០២ *សូមមើលផងដែរ* ឯកសារ **E3/4044** កិច្ចសម្ភាសន៍ ខៀវ សំផន KH 00784357 ("ដឹងច្បាស់ណាស់ និយាយគ្នាធម្មតា")។ ឯកសារ **E1/55.1** កាំង ហ្គេកអាវ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ម៉ោង 11.53.19-11.54.46, ទំព័រ ៤៣-៤៤ បន្ទាត់ ២-៣ (ម្ចាស់បណ្តឹងសាទុក្ខគឺជា "ប្រធានមន្ទីររបស់ ប៉ុល ពត។ ជាកូនសិស្សដែល ប៉ុល ពត បង្រៀន")។ ឯកសារ **E3/355** ។កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ KH 00239835 ("ខៀវ សំផន មានទំនាក់ទំនងជាពិសេសជាមួយ ប៉ុល ពត ដែលខ្ញុំគិតថា ប៉ុល ពត ស្រឡាញ់គាត់ខ្លាំងណាស់ ហើយប្រហែលជាចង់ឱ្យគាត់ក្លាយជាអ្នកបន្តវេនពីគាត់ទៀតផង")។ ឯកសារ **E3/9** សៀវភៅនិពន្ធដោយ Philip Short មានចំណងជើងថា *ប៉ុល ពតៈ ប្រវត្តិនៃសុបិនអាក្រក់មួយ* EN 00396544 ("ប៉ុល មានការទុកចិត្តកាន់តែខ្លាំងឡើងទៅលើគាត់។ គាត់ពេញចិត្តចំពោះភាពអត់ធ្មត់ និងឧស្សាហ៍ព្យាយាមរបស់គាត់ និងការពិតដែលថា នៅពេលគាត់ត្រូវបានការងារ គាត់នឹងអនុវត្តការងារនោះទាល់តែបានសម្រេច"), EN 00396521 ("សំផន ក៏មានការទុកចិត្តផ្តល់បេសកកម្មទាំងឡាយដែល

ពត, នួន ជា និងម្ចាស់បណ្ដឹងសាទុក្ខ តែងតែចូលរួមបរិភោគអាហារជាមួយគ្នានៅ ក.៣[3172] និងត្រូវបានគេឃើញនៅជាមួយគ្នាជាញឹកញាប់ទៀតផង[3173]។ ម្ចាស់បណ្ដឹងសាទុក្ខបានទទួល

---

ប៉ុល ពត គិតថា ជារឿងរសើបដែលអ្នកផ្សេងពិបាកនឹងធ្វើបាន"), ឯកសារ **E1/58.1** កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២ ម៉ោង 14.13.28-14.15.00 បន្ទាត់ ១៤-១៥ ទំព័រ ៤៦ ("ប៉ុល ពត ឱ្យគាត់ដឹង គាត់ឮ ឱ្យគាត់ទុកដាក់ គាត់ជាអ្នកទទួលខុសត្រូវខាងឯកសារ។ ឯកសារទាំងប៉ុន្មាននៅលើដៃគាត់")។

[3170] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៤, ៥៨៩, ៦០២ (កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍), ៦០៧ (បាឋកថានៅក្នុងវគ្គរៀនសូត្រនយោបាយជាមួយ នួន ជា)។ *សូមមើលផងដែរ* ឯកសារ **E3/278** FBIS, ថ្នាក់ដឹកនាំគោរពវិញ្ញាណក្ខន្ធលោក ជូ តេ នៃសាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៦ KH 00663912។ ឯកសារ **E3/491** ក្រសួងការបរទេសបារាំង *ការពិនិត្យមើលកម្ពុជា ខែកញ្ញា ឆ្នាំ១៩៧៦* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00704452។ ឯកសារ **E3/299** BBC SWB, *ដំណើរទស្សនកិច្ចរបស់ ណេ វិន (Ne Win) មកកាន់ប្រទេសកម្ពុជា* ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ KH S 00704487-90។ ឯកសារ **E3/1414** BBC SWB, *ទស្សនកិច្ចរបស់ប្រធានាធិបតីរ៉ូម៉ានី មកកាន់ប្រទេសកម្ពុជា* ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៨ KH S 00644675-76។ ឯកសារ **E3/485** រដ្ឋមន្ត្រីក្រសួងការបរទេសបារាំង *ព័ត៌មាន និងសក្ខីកម្មអំពីប្រទេសកម្ពុជា* ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៧ KH 00524035-39។

[3171] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៧។

[3172] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩។ សូមមើលឧទាហរណ៍ ឯកសារ **E1/126.1** នឹម សែម ទី២៥ ខែកញ្ញា ឆ្នាំ២០១២ ម៉ោង 14.11.37-14.14.19 ទំព័រ ៦០ បន្ទាត់ ១-៨។ ឯកសារ **E1/55.1** កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ម៉ោង 13.32.07-13.41.53 ទំព័រ ៤៨ បន្ទាត់ ២៤-ទំព័រ ៤៩ បន្ទាត់ ១៥ (បានឮពី សុន សេន ថាពួកគេហូបបាយនៅ ក-៣ នៅក្នុងរោងបាយរួម)។ ឯកសារ **E1/205.1** សូ សុជាតិ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង15.44.39-15.46.56 ទំព័រ ៧៥ បន្ទាត់ ១-១៣ (គាត់បានឃើញ ប៉ុល ពត, នួន ជា និងម្ចាស់បណ្ដឹងសាទុក្ខហូបបាយជាមួយ គ្នា)។ ឯកសារ **E1/206.1** សូ សុជាតិ ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង 09.29.30-09.40.59 ទំព័រ ១០ បន្ទាត់ ៤-ទំព័រ ១៣ បន្ទាត់ ៣។ ឯកសារ **E1/98.1** រ៉ោម គុន ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 14.01.53-14.07.59 ទំព័រ ៥២ បន្ទាត់ ១២-ព័រ ៥៣ បន្ទាត់ ១២ (ប៉ុល ពត, នួន ជា និងម្ចាស់បណ្ដឹងសាទុក្ខធ្វើការជាមួយគ្នានៅមន្ទីរដែលនៅជិតគ្នា ជួបគ្នាញឹកញាប់ និងហូបអាហារពេលព្រឹក អាហារថ្ងៃត្រង់ជាមួយគ្នា)។

[3173] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩, ៣៨៨៤ ជើងទំព័រ ១៨៤១, ១៨៤៣, ១៨៤៥, ១២៩៦០ *យោង* ឯកសារ **E1/97.1** រ៉ោម គុន ហៅ ភី ភួន ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 13.39.57-14.12.13 ទំព័រ ៥១ បន្ទាត់ ១ ទំព័រ ៥៣ បន្ទាត់ ១១ ទំព័រ ៧២ បន្ទាត់ ១៨ ទំព័រ ៧៣ បន្ទាត់ ១២។ ឯកសារ **E3/24** កំណត់ហេតុស្តាប់ចម្លើយ ភី ភួន KH 00204069 (ប៉ុល ពត, នួន ជា, ខៀវ សំផន និង សុន សេន ធ្វើការជាមួយគ្នាជារៀងរាល់ថ្ងៃ)។ ឯកសារ **E1/205.1** សូ សុជាតិ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង 14.32.49-14.35.55 ទំព័រ ៥៩ បន្ទាត់ ២៣-ទំព័រ ៦០ បន្ទាត់ ៧។ (ម្ចាស់បណ្ដឹងសាទុក្ខតែងតែនៅជាមួយ ប៉ុល ពត, នួន ជា, គាត់ និង នួន ជា ជាអ្នកទទួលខុសត្រូវពេល ប៉ុល ពត អវត្តមាន)។ ឯកសារ **E1/156.1** ស រី ប្រតិចារឹក ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ ម៉ោង 09.41.40-09.47.09 ទំព័រ ១០ បន្ទាត់ ១៣-ទំព័រ ១១ បន្ទាត់ ២៥។

ស្គាល់ថា ប៉ុល ពត, នួន ជា និងខ្លួនគាត់ "មិនដែលធ្វើអ្វីដោយឡែកពីគ្នាទេ"[3174]។ ស រី ដែលធ្លាប់ធ្វើការនៅ ក-១ បានផ្តល់សក្ខីកម្មថា គាត់ធ្លាប់ឃើញ នួន ជា, អៀង សារី និងម្ចាស់បណ្តឹងសាទុក្ខទៅមន្ទីររបស់ ប៉ុល ពត នៅ ក-១ ស្ទើរតែរាល់ថ្ងៃ និងបានកត់សម្គាល់ថា ម្ចាស់បណ្តឹងសាទុក្ខមកញឹកញាប់ជាងអ្នកផ្សេងទៀត[3175]។ លើសពីនេះទៀត ដោយផ្អែកលើភ័ស្តុតាងដែលគួរជឿទុកចិត្តបំផុត អ.ជ.ស.ដ សន្និដ្ឋានដោយមានសំអាងហេតុថា ម្ចាស់បណ្តឹងសាទុក្ខ (i) បានចាកចេញពី ប-៥ ហើយបានចូលភ្នំពេញជាមួយ ប៉ុល ពត និង នួន ជា នៅចុងខែមេសា ឆ្នាំ១៩៧៥ ជាកន្លែងដែលពួកគេបានស្នាក់នៅ និងធ្វើការជាមួយគ្នាជាលើកដំបូងដោយជោគជ័យនៅស្ថានីយរថភ្លើង ក្រសួងហិរញ្ញវត្ថុ និងវត្តព្រះកែវមរកត[3176]; (ii) បានរស់នៅ និងធ្វើការជាមួយ ប៉ុល ពត និងមេដឹកនាំផ្សេងទៀតជាច្រើនខែនៅ ក-១[3177] និង (iii) បានរស់នៅ និងធ្វើការនៅ ក-៣ ជាមួយ នួន ជា,

[3174] ឯកសារ **E3/3198** ប្រតិចារឹកនៃសេចក្តីថ្លែងការជាវីដេអូរបស់ ខៀវ សំផន KH 00800763។ ឯកសារ **E3/3197R** សេចក្តីថ្លែងការជាវីដេអូរបស់ ខៀវ សំផន ម៉ោង 00.38.48-00.42.42។

[3175] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៤, ជើងទំព័រ ១៥២៧ (*យោង* ឯកសារ **E1/156.1** ស រី, ប្រតិចារឹក ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ ម៉ោង 15.42.29-15.44.25 ទំព័រ ៧២ បន្ទាត់ ២២-ទំព័រ ៧៣ បន្ទាត់ ៩។ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៨៤៦ (យោងសាក្សី ស រី, អឿន តាន់ និង ឡេង ឈឿន)។

[3176] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៨៤១ *យោង* ឧទាហរណ៍ ឯកសារ **E3/27** កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ KH 00156615-16 ("នួន ជា និង ប៉ុល ពត បាននាំខ្ញុំពីឧត្តុងមកភ្នំពេញ។ ពួកគេនាំខ្ញុំទៅអាគារស្ថានីយរថភ្លើង ហើយយើងបានស្នាក់នៅទីនោះមួយខែ មុនចេញទៅវត្តព្រះកែវមរកត ហើយបន្ទាប់មកទៀតមុខទន្លេបាសាក់")។ ទាក់ទងនឹងជីវិត និងការងាររបស់ម្ចាស់បណ្តឹងសាទុក្ខនៅ ប-៥ ជាមួយ នួន ជា និង ប៉ុល ពត *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨១, ៥៨៤-៥៨៥, ជើងទំព័រ ១៨២២, ១៨៣២។

[3177] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៨៤៣-១៨៤៤។

សុន សេន និង វន វ៉េត[3178] ព្រមទាំងជាមួយ អៀង សារី ដោយគាត់ក៏មានមន្ទីរមួយនៅ ប-១ ផងដែរ[3179]។

914. ម្ចាស់បណ្តឹងសាទុក្ខក៏អះអាងទាំងគ្មានមូលដ្ឋានផងដែរថា អ.ជ.ស.ដ មានការភាន់ច្រឡំតាមរយៈការនិយាយសរុបអំពីអ្វីដែលម្ចាស់បណ្តឹងសាទុក្ខគួរតែបានដឹងអំពីផែនការ និងភាវនីយភាពនៃឧក្រិដ្ឋកម្មនានា ដោយសារភាពជិតស្និទ្ធរបស់គាត់ជាមួយនឹងមេដឹកនាំ ប.ក.ក ដែលផ្ទុយពី គោលការណ៍រក្សាការសម្ងាត់[3180]។ អ.ជ.ស.ដ មិនបានសន្និដ្ឋានសរុបទេ។ គោលការណ៍រក្សាការសម្ងាត់មិនអនុវត្តចំពោះមេដឹកនាំដូចម្ចាស់បណ្តឹងសាទុក្ខនេះទេ[3181]។ ម្ចាស់បណ្តឹងសាទុក្ខ និងមេដឹកនាំ ប.ក.ក ដទៃទៀត ពិតជាបានជួបគ្នាជាប្រចាំ ទាំងជាផ្លូវការនៅគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការបញ្ឈរ និងទាំងនៅឯកិច្ចប្រជុំសមាជបក្ស ជាទីកន្លែងគោលនយោបាយនានាត្រូវគេពិភាក្សា និងសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង និងនៅក្នុងអំឡុងនៃការប្រមូលផ្តុំធំ និងវគ្គរៀនសូត្រនានា

---

[3178] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨១, ៥៨៤-៥៨៥, ជើងទំព័រ ១៨២២, ១៨៣២។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៨៤៣-១៨៤៤ និងសេចក្តីយោងនៅក្នុងនោះ រួមទាំង ឯកសារ **E3/37** កំណត់ហេតុសួរចម្លើយ ខៀវ សំផន ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156676 ("ខ្ញុំនៅក-៣ បន្ទាប់ពីនៅ ក-១ បានពីរបីខែ [...]។ តាមពិត មេដឹកនាំភាគច្រើននៅ ក-៣, អៀង សារី, សុន សេន, នួន ជា។ ចំណែក ប៉ុល ពត មានម្តងនោះគាត់នៅ ក-៣ [...]។ គាត់ក៏នៅ ក-១ ដែរ។ កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គឺបានធ្វើឡើងញឹកញាប់នៅ មន្ទីរ ក-១ ប៉ុន្តែជួនកាលនៅមន្ទីរ ក-៣ នៅផ្ទះ ប៉ុល ពត និងអាចនៅផ្ទះបាយ")។ ឯកសារ **E1/208.1** ឡេង ឈឿង ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង 09.42.45-09.48.43 ទំព័រ ១២ បន្ទាត់ ១-ទំព័រ ១៣ បន្ទាត់ ៧ ម៉ោង 09.56.40-10.01.37 ទំព័រ ១៥ បន្ទាត់ ២១-ទំព័រ ១៦ បន្ទាត់ ២១។ ផ្ទុយពី ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨៥។

[3179] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៨៤៤ *យោង* ឯកសារ **E3/37** កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156676 ("តាមពិត មេដឹកនាំភាគច្រើននៅ ក-៣, អៀង សារី, សុន សេន, នួន ជា")។ ឯកសារ **E1/71.1** ពាន យាន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ម៉ោង 14.14.59-14.17.12, ទំព័រ ៣៩ បន្ទាត់ ១៥-២២ (ក-៣ គឺជាមន្ទីររួម ជាកន្លែងដែល ប៉ុល ពត, ខៀវ សំផន, អៀង សារី និង សុន សេន ធ្វើការ)។ ឯកសារ **E1/208.1** ឡេង ឈឿង ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង 09.42.45-09.48.43, ទំព័រ ១២ បន្ទាត់ ១-ទំព័រ ១៣ បន្ទាត់ ៧ ម៉ោង 09.56.40-10.01.37 ទំព័រ ១៥ បន្ទាត់ ២១-ទំព័រ ១៦ បន្ទាត់ ២១។ (ខៀវ សំផន, នួន ជា និង អៀង សារី មានផ្ទះនៅ ក-៣)។ ឯកសារ **E1/86.1** អឿន តាន, ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 11.14.12-11.16.08, ព័រ ៣៥ បន្ទាត់ ១-ទំព័រ ៨ បន្ទាត់ ៣៦ (ខៀវ សំផន និង នួន ជា ស្នាក់នៅ ក-៣ ចំណែក ប៉ុល ពត និង អៀង សារី នៅ ក-១ និង ប.១ ពួកគេជួបគ្នានៅ ក-១)។

[3180] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨៥។

[3181] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៥ (គោលការណ៍រក្សាការសម្ងាត់)។

របស់ ប.ក.ក[3182] ឬក្នុងពេលប្រមូលផ្តុំជាផ្លូវការ ដូចជានៅ ក-១ និង ក-៣ ជាដើម ជាទីកន្លែងដែលពួកគេរស់នៅ និងធ្វើការ។ អាស្រ័យដោយមូលហេតុទាំងនេះ យើងគ្មានមន្ទិលអ្វីទាំងអស់ ដូច អ.ជ.ស.ដ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខមិនត្រឹមតែជិតស្និទ្ធខាងផ្លូវកាយជាមួយមេដឹកនាំ ប.ក.ក ដទៃទៀតប៉ុណ្ណោះទេ ប៉ុន្តែ ដោយសារគាត់ជាសមាជិកម្នាក់នៃគណៈកម្មាធិការមជ្ឈិម និង មន្ទីរ៨៧០ គាត់ថែមទាំងជាអ្នកចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ផង ជាប្រធានគណៈប្រធានរដ្ឋផង ជាមន្ត្រីថ្នាក់ខ្ពស់បំផុតនៃចលនា GRUNK ផង និងជាអ្នកទទួលខុសត្រូវលើកិច្ចការពាណិជ្ជកម្មផង គាត់គឺជាផ្នែកមួយនៃស្ថាប័នប្រតិបត្តិជាន់ខ្ពស់របស់ ប.ក.ក គឺ មជ្ឈិមបក្ស[3183]។ ដូច្នេះ អ.ជ.ស.ដ បានសម្រេចយ៉ាងសមស្របថា ម្ចាស់បណ្តឹងសាទុក្ខមានការយល់ដឹងជាបន្តបន្ទាប់អំពីការវិវឌ្ឍនៃផែនការ ការអនុវត្តផែនការទាំងនោះ និងភវនីយភាពនៃឧក្រិដ្ឋកម្មនានាដែលនឹងកើតឡើង[3184]។

---

[3182] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥, ៣៥៧, ៣៩៥, ៦០០-៦០៤, ៦០៧, ៦២៤។ *សូមមើលផងដែរ* កថាខណ្ឌ ៤២៥៣, ៤២៥៧-៤២៦០, ៤២៦២, ៤២៧១-៤២៧៣។

[3183] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧ (ការគាំទ្ររបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះគោលនយោបាយ ប.ក.ក ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិម ជាប្រធានគណៈប្រធានរដ្ឋ ជាអ្នកចូលរួមដោយផ្ទាល់ជាប្រចាំនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ជាកន្លែងដែលសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង ជាសមាជិកភាពនៃមន្ទីរ ៨៧០ និងការគ្រប់គ្រងកិច្ចការពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យចាប់ពីខែតុលា ឆ្នាំ១៩៧៦ មក), ៤២៥៨។

[3184] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៨ (ម្ចាស់បណ្តឹងសាទុក្ខមានការយល់ដឹងជាបន្តបន្ទាប់អំពីការវិវឌ្ឍន៍នៃផែនការ ការអនុវត្តផែនការ និងភវនីយភាពនៃឧក្រិដ្ឋកម្មនានាដែលនឹងកើតឡើង អាស្រ័យដោយភាពជិតស្និទ្ធរបស់គាត់ជាមួយសមាជិកជាន់ខ្ពស់ដទៃទៀត ជាអ្នកចូលរួមដោយផ្ទាល់ជាប្រចាំនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ការធ្វើដំណើរទូទៅតំបន់រំដោះ ការចេញសេចក្តីថ្លែងការផ្សេងៗ ការធ្វើឧទ្ទេសនាមនៅក្នុងវគ្គរៀនសូត្រ និងការបំពាក់បំប៉នមនោគមន៍វិជ្ជា), ៤៣៨៩ (ការរួមចំណែករបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្ម និងការចូលរួមប្រព្រឹត្តិនៅក្នុង JCE ដែលបានធ្វើឡើងក្នុងនាមសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកមន្ទីរ៨៧០ ប្រធានគណៈប្រធានរដ្ឋ និងជាមន្ត្រីថ្នាក់ខ្ពស់បំផុតនៃ GRUNK) ៣៤០ (ម្ចាស់បណ្តឹងសាទុក្ខ បានដឹងអំពីឋានៈជនរងគ្រោះនៅ ស-២១ ដែលទទួលបាននូវការការពារ អាស្រ័យដោយសមាជិកភាពរបស់គាត់នៅគណៈកម្មាធិការមជ្ឈិម និងមន្ទីរ ៨៧០ និងថែមទាំងដោយសារជំហរពិសេសរបស់គាត់នៅក្នុងបក្ស ក្នុងនាមជាអ្នកដែលបានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមជាច្រើន), ៤២២៥ (ការយល់ដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការចាប់ខ្លួន ឌឿន គឺអាស្រ័យដោយបានបង្ហាញខ្លួន និងចូលរួមដោយផ្ទាល់ជាប្រចាំនៅក្នុងអង្គប្រជុំរបស់គណៈកម្មាធិការមជ្ឈិម ដោយសារសម្ព័ន្ធភាពជិតស្និទ្ធជាមួយ ប៉ុល ពត និង នួន ជា, ការគ្រប់គ្រងលើការទទួលខុសត្រូវនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម និងការពិតដែលគាត់នៅតែរក្សាបានជាសមាជិកនៃមន្ទីរ៨៧០ រហូតដល់ពីរឆ្នាំបន្ទាប់ពីការបាត់ខ្លួន ឌឿន), ៤២២៦ (ការយល់ដឹងអំពីការចាប់ខ្លួន "ជនក្បត់" ដូចដែលបានបង្ហាញភ័ស្តុតាងនៅក្នុងសុន្ទរកថារបស់ នួន ជា និង ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងវគ្គរៀនសូត្រនយោបាយក្នុងឆ្នាំ១៩៧៦), ៤២២៩, ៤២៥៣, ៤២៧៧, ៤៣៨២។

915. ទីពីរ មូលដ្ឋាននេះក៏បរាជ័យផងដែរ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា ការសម្រេចរបស់ អ.ជ.ស.ដ ទាក់ទងនឹងការចុះពិនិត្យតាមការដ្ឋានរបស់គាត់ មិនសមហេតុផលនោះទេ។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានពិចារណាលើការចុះពិនិត្យតាមការដ្ឋាននានានៅតាមជនបទថាជា "ជាទម្លាប់ជាធម្មតាមួយ" ទៅហើយនោះ អ.ជ.ស.ដ បានបញ្ជាក់ច្បាស់ថា ម្ចាស់បណ្តឹងសាទុក្ខបានចុះពិនិត្យតាមការដ្ឋាននៅក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ ១៩៧៦[3185]។ លើសពីនេះទៀត ដោយជំទាស់នឹងការសម្រេចដោយសមស្របរបស់ អ.ជ.ស.ដ ដែលថា គាត់បានសង្កេតឃើញលក្ខខណ្ឌនៃការរស់នៅ និងការធ្វើការងារទាបរបស់កម្មករ-កសិករ រួមទាំងគ្រោះទុរ្ភិក្ស ជំងឺ និងរោគាផ្សេងៗ នៅក្នុងអំឡុងនៃការចុះពិនិត្យរបស់គាត់នេះ[3186] ម្ចាស់បណ្តឹងសាទុក្ខមិនយកចិត្តទុកដាក់លើសេចក្តីប្រកាសរបស់ សម្តេច សីហនុ ក្នុងឆ្នាំ ២០០០ ដែលសម្តេចបានបញ្ជាក់ពីអ្វីដែលសម្តេចទតឃើញក្នុងអំឡុងនៃការធ្វើដំណើររបស់ព្រះអង្គជាមួយម្ចាស់បណ្តឹងសាទុក្ខនៅពេលនោះថា៖

> ខ្ញុំធ្វើដំណើរទៅទូទាំងប្រទេសកម្ពុជាជាមួយលោក ខៀវ សំផន។ ខ្ញុំបានឃើញមានជំរំឃុំខ្លួន គេធ្វើការទាំងថ្ងៃទាំងយប់ នៅពេលព្រះចន្ទរះគេមិនអាចដេក គឺគេមិនអនុញ្ញាតឱ្យដេក គឺគេត្រូវធ្វើការ។ ខ្ញុំឃើញអ្វីៗដែលប្រជាជនហូប គឺមិនមានបាយគ្រប់គ្រាន់ទេ គេលាយជាមួយពោត និងអ្វីៗជាមួយសណ្តែក ហើយជាមួយស្លឹកឈើ គេអាចនឹងលាយដើមចេកផងដែរ។ របបអាហារគឺអាក្រក់ណាស់[3187]។

916. ទោះជាមានការទទួលស្គាល់អំពីការចុះពិនិត្យតាមប្រឡាយ និងទំនប់នានា រួមទាំងទំនប់អាងត្រពាំងថ្មផងដែរនោះ[3188] ម្ចាស់បណ្តឹងសាទុក្ខបរាជ័យផងដែរ ដែលមិនទូលស្គាល់ថា អ៊ឹម ចែម បាន

---

[3185] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០៦។ ផ្ទុយពី ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨០។

[3186] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨៦ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៥។

[3187] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥ ជើងទំព័រ ១៣៩២០ *យោង* ឯកសារ **E3/3113R** សង្គ្រាមព្រៃ, ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០០០ EN V00172509 ម៉ោង 00.29.32-00.30.26។ ឯកសារ **E3/9** សៀវភៅនិពន្ធដោយ Philip Short មានចំណងជើងថា *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ* EN 00396541។

[3188] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៥៤ ជើងទំព័រ ៤២៨៦ *យោង* ឯកសារ **E1/198.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 10.06.45-10.09.13 ទំព័រ ១៦ បន្ទាត់ ២១-ទំព័រ ១៧ បន្ទាត់ ៦។ ឯកសារ **E3/18** ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ* KH 00103875-76។

និយាយថា ម្ចាស់បណ្ដឹងសាទុក្ខធ្លាប់ចុះមកមើលកម្មករនៅទំនប់អាងត្រពាំងថ្មដោយផ្ទាល់ និង បានប្រាប់ឱ្យកម្មករខំប្រឹងធ្វើការ[3189]។

### *មូលដ្ឋានទី ២០១៖ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការ CPNLAF*[3190]

917. **មូលដ្ឋានទី ២០១ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្ដឹងសាទុក្ខបរាជ័យមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុក្នុងការសម្រេចរបស់ខ្លួនថា សមាជជាតិ/ចលនា FUNK ទាំងបី ក្នុងឆ្នាំ១៩៧៥ ដែលត្រូវបានគេរាយការណ៍ថា គាត់បានធ្វើជាអធិបតីនោះ បានផ្ដល់ធម្មានុរូបដល់គោលនយោបាយរបស់ ប.ក.ក ជាអន្តរជាតិ និងថា គាត់បានចូលរួមក្នុងកិច្ចប្រជុំ និងការប្រមូលផ្ដុំយោធាសំខាន់ៗ។**

918. ទីមួយ មូលដ្ឋាននេះបរាជ័យ ដោយសារម្ចាស់បណ្ដឹងសាទុក្ខតវ៉ាទាំងមិនត្រឹមត្រូវថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្ដីពីភាពមិនប្រាកដប្រជានៃការកើតមានសមាជជាតិចំនួនពីរក្នុងខែមេសា និងខែធ្នូ ឆ្នាំ១៩៧៥ និងសមាជរបស់ FUNK មួយនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥[3191] បានរារាំងមិនអាចធ្វើការសម្រេចបានថា ការចូលរួមរបស់គាត់ដូចបានចោទប្រកាន់ក្នុងសមាជទាំងនេះ ក្នុងអំឡុងពេលដែលសេចក្ដីសម្រេចនានាត្រូវបានអនុមតិ បានផ្ដល់ធម្មានុរូបទៅលើរបៀបវារៈរបស់ ប.ក.ក ជាអន្តរជាតិ[3192]។ ម្ចាស់បណ្ដឹងសាទុក្ខយល់ច្រឡំចំពោះការសម្រេចរបស់ អ.ជ.ស.ដ ហើយខ្លួនបរាជ័យក្នុងការកំណត់ឱ្យឃើញអំពីការភាន់ច្រឡំផ្នែកអង្គហេតុណាមួយ។ តាមពិត ប្រសិនបើ អ.ជ.ស.ដ មិនបានធ្វើការសន្និដ្ឋានថា សមាជទាំងបីក្នុងឆ្នាំ១៩៧៥នេះ ពិតជាបានកើតឡើងមែន ឬ

---

[3189] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៥៤, ជើងទំព័រ ៤២៨៦ *យោង* ឯកសារ E3/5657 បទសម្ភាសន៍ DC-Cam ជាមួយ អ៊ឹម ចែម KH 00061333 ("ចិន ហើយហ្នឹងអ៊ំ ខៀវ សំផន ក៏ធ្លាប់មកមើល។ [...] ប៉ុល ពត មិនសូវទៅទេ ប៉ុន្តែបើអ៊ំ ខៀវ សំផន អាហ្នឹងគាត់ទៅ។ [...] គាត់មានយោបល់ឃើញកម្លាំងនៅក្រោមទំនប់ចឹងហើយមានស្រូវមានអី គាត់ [ខៀវ សំផន] ថាខំធ្វើតទៅទៀត")។

[3190] <u>មូលដ្ឋានទី ២០១៖</u> ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ, *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា (CPNLAF)* កថាខណ្ឌ ១៦៩០-១៦៩១។ ឯកសារ F54.1.1 សារណាបណ្ដឹងសាទុក្ខ ឧបសម្ព័ន្ធ ក, ទំព័រ ៦៩ (អង់គ្លេស) ទំព័រ ៦៤ (បារាំង) ទំព័រ ៩៨ (ខ្មែរ)។

[3191] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ, កថាខណ្ឌ ១៦៩០ *យោង* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៣។

[3192] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៩០ *យោង* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៥, ៤២៦២។

ថា ម្ចាស់បណ្ដឹងសាទុក្ខពិតជាបានធ្វើជាអធិបតីយ៉ាងមានប្រសិទ្ធភាពនៅក្នុងសមាជទាំងនោះ[3193] ដូច្នេះ វាមិនរារាំង អ.ជ.ស.ដ មិនឱ្យធ្វើការសម្រេចប្រកបដោយហេតុផលផ្សេងទៀតឡើយ រួមទាំងការសម្រេចថា (i) ខ្លឹមសារនៃសេចក្ដីប្រកាសជាផ្លូវការ និងសេចក្ដីសម្រេចនានារបស់សមាជ ត្រូវបានរាយការណ៍ថា ត្រូវបានអនុមតិ ដែលឆ្លុះបញ្ចាំងអំពីគោលនយោបាយរបស់ ប.ក.ក នៅពេលនោះ[3194] និងត្រូវបានបញ្ជាក់បន្ថែមដោយ ប៉ុល ពត[3195] ម្ចាស់បណ្ដឹងសាទុក្ខ[3196] និងតាមរយៈការពិតដែលថា រដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវបានចោទថា ត្រូវបានសម្រេចនៅក្នុងសមាជជាតិ ខែធ្នូ ដែលត្រូវបានប្រកាសឱ្យប្រើក្នុងខែមករា ឆ្នាំ១៩៧៦ នោះដែរ[3197] (ii) សេចក្ដីប្រកាសជាផ្លូវការ និងសេចក្ដីសម្រេចនានា ត្រូវបានប្រកាសតាមវិទ្យុជាផ្លូវការ[3198] ហើយ

---

[3193] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១២ (ជើងទំព័រ ១២៣៤), ៥៨១ (ជើងទំព័រ ១៨២០), ៥៩៣ (ជើងទំព័រ ១៨៦០), ៣៧៣៥ (ជើងទំព័រ ១២៤៥៨), ៣៨៩៧ (ជើងទំព័រ ១២៩៩១), ៤២៦២ (ជើងទំព័រ ១៣៩០៨)។

[3194] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៣, ៣៧៣៥, ៤២៦២ (ជើងទំព័រ ១៣៩០៨), ៣៨៩៧។

[3195] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៤ ជើងទំព័រ ១២៩៦១ *យោង* ឯកសារ **E3/5713** *កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយអ្នកកាសែត យូហ្គោស្លាវី* ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ KH 00775903 (បន្ទាប់ពី "សមាជជាតិពិសេសរួចមក នៅចុងខែមេសា ឆ្នាំ១៩៧៥" ប.ក.ក បានកំណត់ថា "កសាងសង្គម[កម្ពុជា]មួយមានរុងរឿង និងសប្បាយ [...] គ្មានវណ្ណៈជិះជាន់គេ ឬគ្មានវណ្ណត្រូវគេជិះជាន់ គ្មានអ្នកជិះជាន់គេ គ្មានអ្នកត្រូវគេជិះជាន់ គឺជាសង្គមមួយដែលប្រជាជនទាំងអស់រួមគ្នាប្រកបការងារបង្កបង្កើនផល និងការពារជាតិ")។

[3196] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨១ ជើងទំព័រ ១៨២១ *យោង* ឯកសារ **E3/273** FBIS, *របាយការណ៍របស់ ខៀវ សំផន* ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ KH 00657434-53 (នៅក្នុងសុន្ទរកថារបស់គាត់ ម្ចាស់បណ្ដឹងសាទុក្ខ បានយោងសំដៅសមាជជាតិ និងសមាជ FUNK ទាំងបីក្នុងឆ្នាំ១៩៧៥ ដែលធ្វើឡើងក្នុងខែកុម្ភៈ ខែមេសា និងខែធ្នូ ឆ្នាំ១៩៧៥ និងខ្លឹមសារនៃសមាជទាំងនេះ ដែលបានបង្ហាញពីការយល់ដឹងលើខ្លឹមសាររដ្ឋធម្មនុញ្ញ ហើយបានប្រកាសអំពីការប្ដេជ្ញាចិត្តកសាងសង្គមមួយដែលគ្មានវណ្ណៈ គ្មានការជិះជាន់ គឺជាសង្គមមួយដែលទាំងអស់រួមគ្នាប្រកបការងារបង្កបង្កើនផល និងការពារជាតិ – ដែលជាការឆ្លុះបញ្ចាំងឥតខ្ចោះទៅលើមាគនយោបាយរបស់ ប.ក.ក ក្នុងពេលនោះ), កថាខណ្ឌ ៤០២៧, ជើងទំព័រ ១៣៣៤០ ("អង្គជំនុំមិនអាចសន្និដ្ឋានកំណត់បានថាតើ "សមាជជាតិ"នេះ បានកើតឡើងមែន ឬអត់នោះទេ ប៉ុន្តែបានទទួលស្គាល់ថា សេចក្ដីសម្រេចនានាដូចដែលបានចោទប្រកាន់ថាបានឈានដល់សម្រេចនៅក្នុងនោះ គឺជាតំណាងនៃសេចក្ដីប្រកាសផ្សេងៗដែលបានធ្វើឡើងដោយ ខៀវ សំផន")។

[3197] សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១២ (ជើងទំព័រ ១២៣៤-១២៣៥ *យោង* ឯកសារ **E3/273** FBIS, *វិចារណកថាវិទ្យុសាទរចំពោះការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញថ្មី* ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៦ EN 00167822។ ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, ៣៧៣៨ (ជើងទំព័រ ១២៤៦៥)។

[3198] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣១ ជើងទំព័រ ៥៥៦ (*យោង* ឯកសារ **E3/117** & **E3/488** FBIS *ខៀវ សំផន ធ្វើជាអធិបតីក្នុងសមាជ NUFC៖* សេចក្ដីថ្លែងការ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ EN 00663978-83), ៤១២ (ជើងទំព័រ ១២៣៤ *យោង* ឯកសារ **E3/273** FBIS, *សេចក្ដីរាយការណ៍របស់ទីក្រុងភ្នំពេញ ស្ដីពីសមាជជាតិលើកទី៣៖ របាយការណ៍របស់ ខៀវ សំផន* ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ KH 00657434-53, ៥៨១ (ជើងទំព័រ ១៨១៩), ៥៩៣

(iii) ការសន្និដ្ឋានអំពីទេពកោសល្យ និងប្រជាប្រិយភាពរបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះព្រឹត្តិការណ៍ដូច្នេះ (រួមទាំងសេចក្តីប្រកាសជាផ្លូវការ និងសុន្ទរកថាដែលពិភាក្សាលើសេចក្តីប្រកាសទាំងនោះ)[3199] ដែលធ្វើឡើងដោយរបបនេះ បានរួមចំណែកដល់ការផ្តល់ការជឿជាក់ និងធម្មានុរូបដល់គោលនយោបាយរបស់ ប.ក.ក ទាំងថ្នាក់ជាតិ និងអន្តរជាតិ[3200]។ ម្ចាស់បណ្តឹងសាទុក្ខ ក្នុងនាមជាឧបនាយករដ្ឋមន្ត្រី GRUNK និងតំណាង FUNK បានទទួលយក ដូចបានប្រកាសតាមវិទ្យុជាផ្លូវការ ដូច្នេះក្នុងនាមជាប្រធាន និង/ឬ ជាអ្នកចូលរួមប្រព្រឹត្តដ៏លេចធ្លោម្នាក់នៅក្នុងសមាជទាំងនោះមែន ដូច្នេះ គាត់បានជួយលើកកម្ពស់ តម្កល់ និងអនុមតិលើមាគ៌ានយោបាយ និងគោលបំណងរួមរបស់ ប.ក.ក[3201]។

919. មូលដ្ឋាននេះក៏រាជ័យផងដែរ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់ភ័ស្តុតាងលើអ្វីដែលគាត់អះអាងថា អ.ជ.ស.ដ មានការភាន់ច្រឡំអំពីការសន្និដ្ឋានថា គាត់បានចូលរួមក្នុងកិច្ចប្រជុំ និងការប្រមូលផ្តុំយោធាសំខាន់ៗ (ក្នុងឆ្នាំ១៩៧៥)[3202]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ មិនដែលសន្និដ្ឋានថា ធាតុផ្សំផ្នែកអង្គហេតុនេះបង្កើតបានជាភ័ស្តុតាងដែលនាំឱ្យអង្គជំនុំជម្រះសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខបានជួយលើកកម្ពស់ តម្កល់ និងអនុមតិលើគោលបំណងរួមរបស់ ប.ក.ក ឡើយ[3203]។

---

(ជើងទំព័រ ១៨៥៨ *យោង* ឯកសារ **E3/118** FBIS, *'សមាជជាតិពិសេស' រក្សាទុកសម្តេច សីហនុ ប៉ែន នុត* ថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥ EN 00167012)។ *សូមមើលផងដែរ* កថាខណ្ឌ ៤០២៨ (ជើងទំព័រ ១៣៤៤២), ៤០៤៧ (ជើងទំព័រ ១៣៣៩៩) (កថាខណ្ឌទាំងពីរយោងប្រភព ប.ក.ក ផ្សេងទៀត ដែលយោងសំដៅសេចក្តីសម្រេចនានាដែលបានយកពីសមាជជាតិលើកទីពីរ ទាក់ទងនឹងជនក្បត់ និងការអំពាវនាវឱ្យប្រជាជនដើរតាមពួកគេ)។

3199 សូមមើលឧទាហរណ៍ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៥៧០-៥៧១, ៥៧៧, ៥៨២, ៦២៤។

3200 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៥៩៣ *សូមមើលផងដែរ* កថាខណ្ឌ ៥៩៨, ៤០២៧ (ជើងទំព័រ ១៣៣៤០), ៤២៦២។

3201 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២។

3202 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩១។

3203 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩១ ជើងទំព័រ ៣២៦២ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២។ តាមពិត ម្ចាស់បណ្តឹងសាទុក្ខបកស្រាយខុសចំពោះសាលក្រមរបស់ អ.ជ.ស.ដ ដោយហេតុថា អ.ជ.ស.ដ មិនបានយោងនៅកន្លែងណាមួយឡើយនៅក្នុងកថាខណ្ឌ ៤២៦២ អំពីការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងការប្រមូលផ្តុំយោធាសំខាន់ៗដូចបានរៀបរាប់ក្នុងកថាខណ្ឌ ៥១០ ប៉ុន្តែមាននិយាយតែអំពីការចូលរួមក្នុងសមាជជាតិ ការជួបប្រជុំនៅវត្តព្រះកែវមរកត និងអំពើនិងការប្រព្រឹត្តរបស់គាត់ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ពីឆ្នាំ១៩៧៦-១៩៧៩ តែប៉ុណ្ណោះ។ ការប្រៀបធៀបដែលម្ចាស់បណ្តឹងសាទុក្ខធ្វើជាមួយសម្តេចនរោត្តម សីហនុ (ដែលព្រះអង្គមិនដែលចូលរួមក្នុងសមាជជាតិ/

920. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញឱ្យឃើញថា ជាការមិនសមស្របដែល អ.ជ.ស.ដ សន្និដ្ឋានថា ក្នុងនាមជាឧបនាយករដ្ឋមន្ត្រី GRUNK ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការកងកម្លាំងរំដោះជាតិប្រជាជនកម្ពុជា ("CPNLAF") គាត់បានផ្តល់ធម្មានុរូបដល់ការអនុវត្តគោលបំណងរួម ទាំងថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈ (i) ការលើកសរសើររដ្ឋធម្មនុញ្ញថ្មីដែលមិនផ្តល់សិទ្ធិគោរពជំនឿផ្សេងៗថាជា "សាសនាប្រតិកិរិយា"[3204] និងបានលើកកម្ពស់គោលបំណងរបស់ ប.ក.ក ក្នុងការផ្លាស់ប្តូរប្រជាជនទាំងមូលទៅជាសង្គមកម្មករ-កសិករ ដោយប្រជាជនទាំងអស់នឹងតស៊ូ និងការពារប្រទេស[3205] និង (ii) កំពុងតែបានបង្ហាញខ្លួនក្នុងនាមប្រធានសមាជជាតិ[3206]។ តាមរយៈមុខតំណែងរបស់ខ្លួន គាត់ក៏បានជួយការពាររចនាសម្ព័ន្ធដែលមានតែសម្បក FUNK និង GRUNK នេះ ដែលបានបិតបាំងប្រតិបត្តិការរបស់ ប.ក.ក[3207] *ជាអាទិ៍* ការប្រឆាំងនឹងពុទ្ធសាសនាជិកជនជាដើម[3208]។

## *មូលដ្ឋានទី ២០២៖ ប្រធានគណៈប្រធានរដ្ឋ*[3209]

921. **គួរច្រានចោលមូលដ្ឋានទី ២០២ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការវិភាគរបស់ខ្លួនអំពី ការតែងតាំងគាត់ តួនាទី និងសុទ្ធរកថារបស់គាត់ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ និងការពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់។**

922. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសតាមរយៈការសន្និដ្ឋានថា រូបគាត់ត្រូវបានតែងតាំងដោយគណៈកម្មាធិការមជ្ឈិមនៅក្នុងអង្គប្រជុំថ្ងៃទី៣០ ខែមីនា ឆ្នាំ ១៩៧៦ របស់ខ្លួន (ហើយត្រូវបានបញ្ជាក់ជាផ្លូវការដោយសភាតំណាងប្រជាជន នៅពាក់កណ្តាលខែមេសា) មិនមែនដោយគណៈកម្មាធិការអចិន្ត្រៃយ៍ទេ បើទោះជា អ.ជ.ស.ដ បានទទួលស្គាល់ថា

---

GRUNK ឬនៅក្នុងកិច្ចប្រជុំនៅវត្តព្រះកែវមរកត ជាមួយម្ចាស់បណ្តឹងសាទុក្ខ ម្តងណាសោះនោះ ព្រមទាំងត្រូវបានបង្ខាំងឱ្យនៅតែក្នុងព្រះបរមរាជវាំងចាប់តាំងពីឆ្នាំ១៩៧៦ មក) គឺមិនពាក់ព័ន្ធគ្នាឡើយសូម្បីតែបន្តិច។

[3204] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤១។

[3205] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៩, ៤២៦២។

[3206] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២។

[3207] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៨។

[3208] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤១, ៤២៧៥។

[3209] <u>មូលដ្ឋានទី ២០២៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ប្រធានគណៈប្រធានរដ្ឋ* កថាខណ្ឌ ១៦៩២-១៧០៣។ ឯកសារ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៦ (អង់គ្លេស) ទំព័រ ៦៤ (បារាំង) ទំព័រ ៩៨ (ខ្មែរ)។

ក្រោយពេលដែលរដ្ឋាភិបាលត្រូវបានបង្កើតឡើង រដ្ឋមន្ត្រីត្រូវរាយការណ៍ និងទទួលការណែនាំពីគណៈកម្មាធិការអចិន្ត្រៃយ៍ក៏ដោយ[3210]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា សេចក្តីសម្រេចលើការតែងតាំងនោះត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍[3211]។ ទោះជាយ៉ាងណា ម្ចាស់បណ្តឹងសាទុក្ខបកស្រាយខុសអំពីឋានៈរបស់ប្រធានរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារគាត់មិនមែនជាសមាជិករដ្ឋាភិបាលទេ[3212]។ ចំណងជើងនៃសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បញ្ជាក់យ៉ាងច្បាស់ថា ឯកសារនេះត្រូវបានចេញដោយគណៈកម្មាធិការមជ្ឈិម[3213] បញ្ជូនទៅកាន់អ្នកមានសិទ្ធិអំណាចពិតប្រាកដរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្រោយពេលបង្កើតគណៈប្រធានរដ្ឋ ហើយរដ្ឋាភិបាលមិនបដិសេធការតែងតាំងដំបូងរបស់គណៈកម្មាធិការមជ្ឈិមទេ[3214]។

923. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ សន្និដ្ឋានមិនស្របគ្នាទេ ដោយចាត់ទុកមុខតំណែងរបស់ប្រធានថាជា "និមិត្តរូបភាគច្រើន" ខណៈដែលនៅតែពឹងផ្អែកលើមុខតំណែងនេះក្នុងការសន្និដ្ឋានលើការទទួលខុសត្រូវរបស់គាត់ និងបានចាត់ទុកវាជាស្ថានទម្ងន់ទោស ប៉ុន្តែខកខានមិនបានបង្ហាញថាតើ អ.ជ.ស.ដ មានកំហុសដោយរបៀបណា[3215]។ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា អ.ជ.ស.ដ មិនយកចិត្តទុកដាក់ទៅលើចំណុចដែលថា ប.ក.ក "មិនទុកចិត្ត" គាត់ ដែលត្រូវ

---

[3210] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩៣ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩១៤-៩១៦, ៥៩០។ *សូមមើល* ឯកសារ **E3/12** សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00000762។

[3211] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩៣។

[3212] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩១២, ៩១៥-៩១៦, ៩១៨-៩១៩។ ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ មាត្រា ១១ (កម្ពុជាប្រជាធិបតេយ្យមានគណៈប្រធានរដ្ឋរួមទាំងប្រធាន ដែលជ្រើសរើស និងតែងតាំងឡើងដោយសភាតំណាងប្រជាជន "រៀងរាល់ប្រាំឆ្នាំម្តង")។

[3213] **E3/12** សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ វានៅតែមិនច្បាស់ថាតើ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ទៅនឹងអង្គហេតុដែលថា សេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ត្រូវបានចេញដោយគណៈកម្មាធិការមជ្ឈិម គឺមិនមែនដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ឬយ៉ាងណា។

[3214] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៥៧។ *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៤៧។ ទាក់ទងនឹងអំណាចតែងតាំងរបស់គណៈកម្មាធិការមជ្ឈិម។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣។

[3215] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩៤, ១៧០៣ *យោងទៅ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៨១ និង ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៩ (ភារកិច្ចការទូត និងការតម្លើងឋានៈទូទៅនៃមាគ៌ា ប.ក.ក)។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៧ (រៀបរាប់លម្អិតពីមុខងារការទូត និងពិធីការផ្សេងៗ) ៥៩៨ (ម្ចាស់បណ្តឹងសាទុក្ខថ្លែងសុន្ទរកថាលើកកម្ពស់ និងគាំទ្រគោលនយោបាយ ប.ក.ក ទាំងអស់) ៤២៤២, ៤២៥៧, ៤២៦២, ៤២៦៥, ៤២៦៨, ៤៣៨៩។

បានបញ្ជាក់ដោយការតែងតាំងអនុប្រធានពីររូបរបស់គាត់ និងការតម្លើងឋានៈឃើតក្នុងឆ្នាំ១៩៧៦ ជាសមាជិកពេញសិទ្ធិរបស់គណៈម្ចាធិការមជ្ឈិម[3216]។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងមាត្រា១១ នៃរដ្ឋធម្មនុញ្ញរបបកម្ពុជាប្រជាធិបតេយ្យ ដែលកំណត់ឱ្យមានអនុប្រធានពីររូប[3217] និងថា អ្នកដែលត្រូវបានតែងតាំងជា "អនុប្រធាន" សោ ភឹម និង វស់ ញឹម មិនដែលបានបំពេញតួនាទីនេះនោះទេនៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ហើយចុងក្រោយត្រូវបានបោសសំអាត[3218]។ គាត់ក៏បានមើលរំលងថា នៅចន្លោះឆ្នាំ១៩៧១ និង ១៩៧៦ មិនមានសន្និបាតបក្សដើម្បីតម្លើងឋានៈគាត់ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមទេ[3219]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនឯកភាពទៅនឹងការបកស្រាយទៅលើភ័ស្តុតាងរបស់ អ.ជ.ស.ដ ដែលបង្ហាញថា គាត់មានទំនាក់ទំនងជិតស្និទ្ធ និងជាទីទុកចិត្តជាមួយនឹងមេដឹកនាំ ប.ក.ក ផ្សេងៗទៀត ព្រមទាំង មានមុខងារជាច្រើនផ្សេងទៀតរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា ជាសមាជិកគណៈកម្មាធិការមជ្ឈិម អ្នកមានវត្តមាន និងអ្នកចូលរួមក្នុងអង្គប្រជុំគណៈគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកមន្ទីរ ៨៧០ អ្នកត្រួតពិនិត្យបញ្ហាពាណិជ្ជកម្ម និងអ្នកធ្វើបាឋកថានៅក្នុងវគ្គបណ្តុះបណ្តាលនយោបាយ[3220]។ ម្ចាស់បណ្តឹងសាទុក្ខបានតវ៉ាដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ ខកខានមិនបានពន្យល់ថាតើ "មាគ៌ា ប.ក.ក" ដែលគាត់ត្រូវបានតែងតម្លើងឋានៈជាប្រធាននោះ ជាអ្វី ហើយផ្តល់ការបកស្រាយរបស់គាត់មិនត្រឹមត្រូវអំពីគោលនយោបាយដែលមិនមានលក្ខណៈឧក្រិដ្ឋ[3221]។ ទោះជាយ៉ាងណាក៏ដោយ គាត់មើលរំលងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ទាក់ទងនឹងគោលដៅនៃគោលបំណងរួម គោលនយោបាយឧក្រិដ្ឋដែលមានទំនាក់ទំនងគ្នា និងវិន័យដែលត្រូវបានជំរុញ

[3216] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៦៩៤។

[3217] ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ មាត្រា ១១។

[3218] សោ ភឹម ធ្វើអត្តឃាតភ្លាមៗ មុនពេលការចាប់ខ្លួនគាត់ ចំណែក វស់ ញឹម វិញត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរ ស-២១។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៨, ៣៧៤, ៣៧៨, ៥៥៨, ១២៣១, ២០៥១-២០៥៤, ២២២០ ផ្នែក ១២.១.៥ (ព្រឹត្តិការណ៍ឆ្នាំ ១៩៧៧ - កងពល ៣១០ និងភូមិភាគពាយ័ព្យ (វស់ ញឹម) ផ្នែក ១២.១.៦ (ព្រឹត្តិការណ៍ឆ្នាំ ១៩៧៨ - ភូមិភាគបូព៌ា និង សោ ភឹម) ផ្នែក ១២.២.៨.៤ (ការចាប់ខ្លួន វស់ ញឹម)។

[3219] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២៦, ៣៤៥ ("សន្និបាតបក្សត្រូវរៀបចំធ្វើរៀងរាល់បួនឆ្នាំម្តង [...] តួនាទីរបស់សន្និបាតគឺដើម្បី [...] ជ្រើសតាំងសមាជិកគណៈកម្មាធិការមជ្ឈិម") ៣៥៥, ៥៧៤, ៦០០។

[3220] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០០។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩, ៥៩៤, ៥៩៦-៥៩៩, ៦០០-៦០៤, ៦០៧-៦០៨, ៦១៦-៦២១, ៦២៤, ៤២០៧-៤២០៨, ៤២២៥, ៤២៣០, ៤២៥៣, ៤២៥៧-៤២៦០, ៤២៦២, ៤២៧២-៤២៧៣, ៤២៧៥-៤២៧៧, ៤៣១៣។

[3221] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩៦។

នៅក្នុងលក្ខន្តិកៈ ប.ក.ក និងមជ្ឈិមបក្ស[3222] រួមទាំង ម្ចាស់បណ្តឹងសាទុក្ខនៅ ក្នុងសុន្ទរកថា និងបាឋកថានានារបស់គាត់ *ជាអាទិ៍* ស្តីពីការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន[3223] និងការកំណត់អត្តសញ្ញាណខ្មាំង និងជនក្បត់[3224]។

924. ទីបី ម្ចាស់បណ្តឹងសាទុក្ខលើកឡើងពីកំហុសអង្គហេតុជាច្រើនទាក់ទងនឹងសុន្ទរកថា/សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់គាត់ ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ ដែលគាត់អះអាងដោយមិនត្រឹមត្រូវថា មានឥទ្ធិពលលើសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្តីពីការរួមចំណែករបស់គាត់ក្នុងគោលបំណងរួម[3225]។

925. ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ មានកំហុសក្នុងការពឹងផ្អែកលើសុន្ទរកថាមួយ ដែលគាត់ធ្វើមុនពេលតែងតាំងគាត់ជាប្រធានគណៈប្រធានរដ្ឋ[3226] ដើម្បីសន្និដ្ឋានថា ក្នុងឋានៈជាប្រធានគាត់បានគាំទ្រ "គោលនយោបាយរបស់ ប.ក.ក ដូចជា ការបង្កើតសហករណ៍ របបហូបចុក ពលកម្មកុមារ និងការដ្ឋាន"[3227]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានទទួលស្គាល់ថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ មិនពឹងផ្អែកទាំងស្រុងលើសុន្ទរកថាខែមករា ឆ្នាំ១៩៧៦ របស់គាត់ទេ ប៉ុន្តែក៏ផ្អែកលើសុន្ទរកថារបស់គាត់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ដែលពេលនោះ គាត់បានលើកទឹកចិត្តឱ្យកម្មករ "តស៊ូឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត" លើសពីឆ្នាំមុន ដើម្បី "បំពេញបានលើសពីឆ្នាំ១៩៧៧" ដោយបន្ថែមថា "ឥឡូវយើងអាចចិញ្ចឹមប្រជាជនយើងតាមការបែងចែករបបអាហារបានគ្រប់គ្រាន់ពីរដ្ឋ" និងបានធ្វើយុត្តិកម្មលើការប្រើប្រាស់កម្លាំងពលកម្មកុមារដើម្បីបំពេញផែនការបក្ស ដោយបញ្ជាក់ថា កុមាររីករាយក្នុងការ "រើសជីធម្មជាតិ ជួយកសាងទំនប់ និង

[3222] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៤៥, ៣៥៥, ៤១៦, ៤៧៧, ៥៩៩, ៦២៤, ១០៥៦, ៣៤០០, ៣៥៤៧, ៣៦១៨, ៣៧៣៤-៣៧៤២, ៣៧៦៥, ៣៨៤៣, ៣៨៧៧, ៣៩៥៥, ៤០៨០, ៤១៣៣, ៤១៥៨, ៤២៥៧-៤២៦៣, ៤២៦២, ៤២៦៥។

[3223] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៦ (ជើងទំព័រ ១៣០៦៧) ៣៤០០, ៣៨៧៧, ៤២៦៣, ៤២៦៥-៦៨, ៤២៧២។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨២។

[3224] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០៧, ៣៣៩៩-៣៤០០, ៣៩៦០, ៣៩៦៧, ៤០២៧, ៤២៦៩, ៤២៧១-៤២៧៣, ៤២៨៥, ៤២៩២, ៤៣០៦។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៤។

[3225] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩៨-១៧០៣។

[3226] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧០២។

[3227] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៨។

ឃឿនទំនប់ការពារទឹក ជីកអាងស្តុកទឹក និងជីកប្រឡាយ"[3228]។ ទោះជាយ៉ាងណាក៏ដោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញពីកំហុសណាមួយទេ ដោយហេតុថា អ.ជ. ស.ដ បានពិនិត្យលើទិដ្ឋភាពទូទៅនៃសុន្ទរកថាទាំងនោះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនត្រឹមតែសុន្ទរកថាដែលធ្វើឡើងក្នុងពេលគាត់ជាប្រធាននោះឡើយ។

926. ម្ចាស់បណ្តឹងសាទុក្ខអះអាងទៀតថា អ.ជ.ស.ដ មានកំហុសក្នុងការពឹងផ្អែកលើឯកសារ FBIS ដែលមិនមានការបញ្ជាក់គាំទ្រ ទាក់ទងនឹងបទសម្ភាសន៍មួយដែលធ្វើប្រតិចារឹកក្នុងខែកញ្ញា ឆ្នាំ ១៩៧៦[3229] ប៉ុន្តែខកខានមិនបានបង្ហាញពីផលប៉ះពាល់របស់វាលើសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ អំពីការរួមចំណែករបស់គាត់ក្នុងគោលបំណងរួម។ វិធីសាស្ត្រមួយលើកឡើងតាមផ្នែករបស់ម្ចាស់បណ្តឹងសាទុក្ខមិនយកចិត្តទុកដាក់ទៅលើភ័ស្តុតាងជារួមទាក់ទងនឹងការដឹងរបស់គាត់ថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងពុទ្ធសាសនិក[3230]។ តាមពិត សេចក្តីថ្លែងរបស់គាត់លើចំណុចដែលថា "ទោះបីព្រះសង្ឃព្រះពុទ្ធ

---

[3228] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៨ ជើងទំព័រ ១៨៧៩ *យោង* ឯកសារ **E3/201** សុន្ទរកថា ខៀវ សំផន ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292814, 00292805, 00292810-11។ *សូមមើលផងដែរ* ឯកសារ **E3/200** BBC SWB *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292803-15។ ឯកសារ **E3/712** សារព័ត៌មានអន្តរជាតិ (International Herald Tribune), *ប្រមុខដឹកនាំកម្ពុជាសន្យាថានឹងប្រឹងប្រែងធ្វើការ និងមានវិន័យបន្ថែមទៀត* ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៧ KH S 00725084-86។ ឯកសារ **E3/3376** សារព័ត៌មាន New York Times *អ្នកដឹកនាំកម្ពុជា លើកពីការរីកចម្រើន* ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៧ KH 00729008-10។ ឯកសារ **E3/709** សារព័ត៌មាន The Sunday Star *ប្រធានរដ្ឋកម្ពុជាសរសើរសង្គមដែលគ្មានគ្រឿងចក្រ* ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ KH S 00716250-53។

[3229] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧០១ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤១, ៤២៥៣ (*យោង* ឯកសារ **E3/608** FBIS *លោក ខៀវ សំផន ត្រូវបានសម្ភាសន៍អំពីការប្រហារជីវិតនានាដែលជាបញ្ហាប្រទេសជាតិ* KH 00635928-32)។ បទសម្ភាសន៍ ឯកសារ E3/608 បានធ្វើឡើងនៅកូឡំបូ និង ស្រីឡាំងកា (ទំនងជានៅក្នុងខែសីហា ឆ្នាំ១៩៧៦ ក្នុងពេលសន្និសីទកំពូលលើកទីប្រាំនៃបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធ៖ *សូមមើលឧទាហរណ៍* ឯកសារ **E3/279** FBIS *ខៀវ សំផន ចាកចេញ, ខៀវ សំផន ថ្លែងសន្ទរកថានៅសន្និសីទកំពូលនៃប្រទេសមិនចូលបក្សសម្ព័ន្ធ គណៈប្រតិភូត្រឡប់មកវិញ* KH 00663923-25, 00663926-30។ ឯកសារ **E3/549** សុន្ទរកថា ខៀវ សំផន ចុះថ្ងៃទី១៦-១៩ ខែសីហា ឆ្នាំ១៩៧៦ KH 00065894-95) និងបានបោះពុម្ពផ្សាយក្នុងកាសែតអ៊ីតាលីឈ្មោះ *Famiglia Cristiana* នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់មក នៅក្នុងសារព័ត៌មាន FBIS (អាស៊ី និងប៉ាស៊ីហ្វិច) នៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៦។

[3230] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤០, ៤២៤៣, ៤២៥០-៤២៥៤។

សាសនាក៏មានភារកិច្ច និងកាតព្វកិច្ចត្រូវធ្វើការដែរ"[3231] ហើយ "ជនក្បត់ទាំងនោះដែលស្ថិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ត្រូវបានកាត់ទោសប្រហារជីវិតហើយ"[3232] គ្រាន់តែជាផ្នែកពីរក្នុងចំណោមភ័ស្តុតាងជាច្រើនដែល អ.ជ.ស.ជ ផ្អែកលើតែប៉ុណ្ណោះ។

927. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ជ បានភ្ជាប់គាត់ខុសទៅនឹងសុន្ទរកថាដែលធ្វើឡើងក្នុងចន្លោះថ្ងៃទី១១ និង ទី១៣ ខែមេសា ឆ្នាំ១៩៧៦ នៅក្នុងសភាតំណាងប្រជាជន[3233] មិនតម្រូវឱ្យមានបណ្តឹងសាទុក្ខទេ ដោយហេតុថា វាមិនមានឥទ្ធិពលលើសាលក្រមឡើយ។ ទីមួយ ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមក្នុងសម័យប្រជុំលើកទីមួយនៃសភាតំណាងប្រជាជន ដែលក្នុងពេលនោះ សុន្ទរកថារបស់គាត់ត្រូវបានធ្វើឡើងដោយប្រធានគ្មានឈ្មោះនៃសន្និសិទនោះ ហើយសេចក្តីសម្រេចជាឯកច្ឆ័ន្ទលើការតែងតាំង និងគោលនយោបាយ ត្រូវបានធ្វើឡើង និងទទួលបានការគាំទ្រដោយរដ្ឋសភា រួមទាំងម្ចាស់បណ្តឹងសាទុក្ខផង[3234]។ ទីពីរ អ.ជ.ស.ជ បានសន្និដ្ឋានថា ត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងរហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មេដឹកនាំ ប.ក.ក រួមទាំងម្ចាស់បណ្តឹងសាទុក្ខ មានគោលបំណងរួមគ្នាក្នុងការអនុវត្តបដិវត្តសង្គមនិយមក្នុងប្រទេសកម្ពុជាឱ្យបានឆាប់រហ័សតាមរយៈ "មហាលោតផ្លោះមហាអស្ចារ្យ"[3235]។ ផ្ទុយទៅនឹងការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខ ការសន្និដ្ឋានរបស់ អ.ជ.ស.ជ មិនបានផ្អែកទាំងស្រុងលើតែសុន្ទរកថាធ្វើចន្លោះថ្ងៃទី១១ និង ១៣ ខែមេសា ឆ្នាំ១៩៧៦ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្អែកលើ (i) ការចូលរួមរបស់គាត់ក្នុងអង្គប្រជុំគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលពិភាក្សាអំពីការអនុវត្តមាគ៌ានយោបាយបក្ស[3236] ក៏ដូចជា សន្និបាតបក្ស[3237] (ii) វត្តមាន និង

---

[3231] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤១ ជើងទំព័រ ១៣៨៤៤។

[3232] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៣ ជើងទំព័រ ១៣៨៧៥។

[3233] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧, ១៧៦។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩៩-១៧០០។

[3234] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ *យោង* ឯកសារ **E3/165** ឯកសារស្តីពីអង្គប្រជុំសន្និបាតទី១ ក្នុងកាលសម័យទី១ ចុះថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ KH 00053630-45 (ពិភាក្សាអំពីមាគ៌ាបក្សក្នុងការការពារ និងកសាងប្រទេស "ឱ្យបានឆាប់រហ័ស តាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ" KH 00053636, 44)។

[3235] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៣។

[3236] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦, ៣៧៤០។

[3237] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៨, ៣៧៤២។

បាឋកថារបស់គាត់នៅក្នុងអង្គប្រជុំអំពីគោលនយោបាយ ប.ក.ក[3238] និង (iii) សុន្ទរកថាជាច្រើនរបស់គាត់ ដែលក្នុងនោះគាត់បានជំរុញ បញ្ជាក់ គាំទ្រ និងឯកភាពទៅលើមាគ៌ាបក្ស[3239]។

928. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ទៅនឹងការពឹងផ្អែករបស់ អ.ជ.ស.ដ លើសុន្ទរកថារបស់គាត់នៅក្នុងពិធីខួប ១៧ មេសា ក្នុងឆ្នាំ១៩៧៦, ១៩៧៧, ១៩៧៨[3240] និងសុន្ទរកថានានាអំពីការឈ្លានពានរបស់វៀតណាម[3241] ប៉ុន្តែខកខានមិនបានផ្តល់ការបញ្ជាក់គាំទ្រទៅលើការអះអាងរបស់ខ្លួន។ ការគ្រាន់តែចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខអំពីការវាយតម្លៃភ័ស្តុតាងដោយលម្អៀង និងដោយផ្អែករបស់ អ.ជ.ស.ដ មិនគ្រប់គ្រាន់សម្រាប់បង្ហាញពីកំហុសក្នុងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ឡើយ។

### *មូលដ្ឋានទី ២០៦៖ ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម*[3242]

929. **គួរច្រានចោលមូលដ្ឋានទី ២០៦ ព្រោះម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុក្នុងការសន្និដ្ឋានថា គាត់បានធ្វើការត្រួតពិនិត្យជាច្រើន និងបានដឹងអំពីការជួញដូរ និងពាណិជ្ជកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យក្នុងចន្លោះខែតុលា ឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៩។**

930. មូលដ្ឋាននេះគួរត្រូវបានច្រានចោល ព្រោះថាម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃភ័ស្តុតាង និងការសន្និដ្ឋានថា រូបគាត់បានត្រួតពិនិត្យច្រើនលើកិច្ចការពាណិជ្ជកម្ម និងការធ្វើជំនួញរបស់របបកម្ពុជាប្រជាធិបតេយ្យ និងបានដឹងច្បាស់លើបញ្ហាទាំងអស់នោះ ទាំងនៅក្នុងស្រុក និងក្រៅស្រុក[3243]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា

---

[3238] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០, ៦០៧, ៣៣៩០, ៥៣១៧, ៣៧៣៦, ៣៧៣៩, ៣៩៦៨, ៤២០៨, ៤២៥៣, ៤២៦២, ៤២៧១។

[3239] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៤, ៣៧៤២ ជើងទំព័រ ១២៤៨៩។

[3240] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧០២។

[3241] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៨ ជើងទំព័រ ១៨០០។

[3242] <u>មូលដ្ឋានទី ២០៦៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការគ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម* កថាខណ្ឌ ១៧៧០-១៧៩៨។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧១ (អង់គ្លេស) ទំព័រ ៦៥ (បារាំង) ទំព័រ ១០០ (ខ្មែរ)។

[3243] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧០, ១៧៧៦-១៧៩៨ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៩-៦២១។ ស្រដៀងទៅនឹងអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ (ទាក់ទងនឹងការមើលរំលងរបស់ជនជាប់ចោទ តួនាទីរបស់ វ៉ាន់ រិត តម្លៃបញ្ជាក់ភ័ស្តុតាងរបស់សាក្សី ស គឹមល្អុត អវត្តមានសិទ្ធិអំណាចសម្រេចដែលលើក

អ.ជ.ស.ដ មានកំហុសក្នុងការពឹងផ្អែកលើ (i) របាយការណ៍ជាច្រើនដែលបញ្ជូនមកគាត់ ដោយគណៈកម្មាធិការពាណិជ្ជកម្ម (ii) សេចក្តីណែនាំចេញពីគាត់ទៅកាន់គណៈកម្មាធិការពាណិជ្ជកម្ម (iii) ទស្សនកិច្ចរបស់គាត់ទៅកាន់ឃ្លាំងរដ្ឋ និង (iv) ការបណ្តុះបណ្តាលរបស់គាត់ ស្តីពីការគ្រប់គ្រងឃ្លាំងឱ្យបានល្អ[3244]។

931. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ការវាយតម្លៃរបស់ អ.ជ.ស.ដ លើរបាយការណ៍ពាណិជ្ជកម្មដែលផ្ញើមកកាន់គាត់ មានភាពលម្អៀង និងមិនសមហេតុផល[3245] ដោយមិនបានបង្ហាញអំពីភាពលម្អៀង ឬកំហុសទាំងនោះរបស់ អ.ជ.ស.ដ ឡើយ[3246]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយគ្មានមូលដ្ឋានថា របាយការណ៍ផ្ញើមកគាត់ដោយគណៈកម្មាធិការពាណិជ្ជកម្ម ទាក់ទងតែទៅនឹងការធ្វើជំនួញប៉ុណ្ណោះ នៅក្នុង "មុខការមានកម្រិត" នៃភារកិច្ចរបស់គាត់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ដូច្នេះមិនបង្ហាញអំពីសិទ្ធិអំណាចត្រួតពិនិត្យច្រើននោះទេ[3247]។ របាយការណ៍ដ៏ច្រើននេះដែលគាត់បានទទួលមិនមែនកម្រិតត្រឹមតែការលក់ទំនិញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខជាប់ពាក់ព័ន្ធនឹងបញ្ហាទាក់ទងនឹងពាណិជ្ជកម្មជាច្រើន[3248] រួមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយសាធារណៈរដ្ឋប្រជាមានិតកូរ៉េ (PRK)[3249] ផលិតកម្មស្រូវក្នុង

---

ឡើង ការនិយាយសរុប ឬការបំភ្លៃរបស់ អ.ជ.ស.ដ ដែលបានចោទប្រកាន់) ត្រូវបានបដិសេធដោយ អ.ជ.ត.ក ក្នុងសំណុំរឿង ០០២/០១៖ ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ១០១៨ ("ខៀវ សំផន បានត្រឹមតែលើកឡើងនូវជម្រើសនៃការបកស្រាយភស្តុតាងប៉ុណ្ណោះ ប៉ុន្តែពុំបានបង្ហាញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសទេ") *ដោយបដិសេធ* ឯកសារ **F17** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៥៥-៥៥៩។

[3244] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧០, ១៧៧៦-១៧៩៨ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៩-៦២១។

[3245] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧១, ១៧៨៥។

[3246] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៥។

[3247] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៨៧, ១៧៩០។

[3248] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៦១៩ *យោង* ឯកសារ **E3/2059** ស្ថិតិនាំចូល (ពីខែមករា ដល់កញ្ញា) និងស្ថិតិនាំចេញក្នុងឆ្នាំ ១៩៧៨ (ពីខែមករា ដល់ខែកញ្ញា) KH 00088795-99។ ឯកសារ **E3/3533** ស្ថិតិនាំចេញ គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៨ KH 00187947, 00187956។

[3249] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៨-៦១៩ ជើងទំព័រ ១៩៥១, ១៩៥៥ *យោង* ឯកសារ **E3/304** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00003035-37។ ឯកសារ **E3/2041** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00091073-74។

របបកម្ពុជាប្រជាធិបតេយ្យ[3250] និងការតម្លើងរោងចក្រផលិតថ្នាំបុរាណរបស់ចិន[3251]។ ដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា គាត់បានអនុវត្តសិទ្ធិអំណាចនៃការត្រួតពិនិត្យច្រើនក្នុងតួនាទីនេះ មិនសមហេតុផលនោះឡើយ។

932. ម្ចាស់បណ្តឹងសាទុក្ខបរាជ័យបន្ថែមទៀតក្នុងការបង្ហាញថា អ.ជ.ស.ដ មានកំហុស តាមរយៈការសន្និដ្ឋានថា នៅចុងខែតុលា ឆ្នាំ១៩៧៦ ខ្សែបណ្តាញរាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម បានប្តូរពី ខឿន មកគាត់នោះទេ[3252]។ អង្គហេតុដែលថា ខឿន នៅតែផ្តល់សុន្ទរកថានៅចំពោះមុខគណៈប្រតិភូពាណិជ្ជកម្មយូហ្គោស្លាវីនៅដើមឆ្នាំ១៩៧៧ ក្នុងនាមជាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម មិនផ្ទុយគ្នាទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា របាយការណ៍ពេលនេះត្រូវបញ្ជូនទៅកាន់ម្ចាស់បណ្តឹងសាទុក្ខនោះឡើយ[3253]។ តាមពិតនោះ ម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់ទេថា របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្មត្រូវបានបញ្ជូនមកកាន់គាត់នៅចុងឆ្នាំ១៩៧៦[3254]។ គាត់ថែមទាំងមិនជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ក្នុងចំណោមឯកសារទាំងអស់ដែលមានចំពោះមុខ ទាក់ទងនឹងបញ្ហាពាណិជ្ជកម្ម មានតែមួយចំនួនប៉ុណ្ណោះត្រូវបានបញ្ជូនទៅ

[3250] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៩ ជើងទំព័រ ១៩៥៦ *យោង* ឯកសារ **E3/3511** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៧ ទំព័រ ១-៣ KH 00187941-43។

[3251] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៩ ជើងទំព័រ ១៩៥៥ *យោង* ឯកសារ **E3/3510** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧ KH 00003096។

[3252] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧៤ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៨។

[3253] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧៤។

[3254] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៧៤ *យោងទៅ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៨, ៤២២៥។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែក ៨.៣.៤.២ (ខៀវ សំផន៖ ការត្រួតពិនិត្យពាណិជ្ជកម្ម រួមទាំងកថាខណ្ឌ ៦១៨-២០ ជើងទំព័រ ១៩៥១, ១៩៥៥-៥៩, ១៩៦៣) *យោងឧទាហរណ៍* ឯកសារ **E3/2040** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **E3/2041** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧។ ឯកសារ **E3/2042** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **E3/304** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **E3/3413** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ **E3/3564** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ឯកសារ **E3/3457** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨។ ឯកសារ **E3/3510** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ឯកសារ **E3/1616** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧។ ឯកសារ **E3/3516** បញ្ជីស្នើទិញ ចុះខែកុម្ភៈ ឆ្នាំ១៩៧៨។ ឯកសារ **E3/3461** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ **E3/3534** គណៈកម្មាធិការពាណិជ្ជកម្ម បញ្ជីសម្ភារនាំចូល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៨។

វន វ៉េត ដែលទទួលខុសត្រូវផ្នែកសេដ្ឋកិច្ច ហើយមិនបញ្ជូនមកម្ចាស់បណ្តឹងសាទុក្ខទេ[3255]។ ផ្ទុយមកវិញ អ.ជ.ស.ដ បានសន្និដ្ឋានថា វន វ៉េត ជាញឹកញាប់ត្រូវបានចម្លងជូននៅក្នុងរបាយការណ៍ក្នុងនាមជាអ្នកទទួលបន្ទាប់[3256] ឬមិនត្រូវបានបញ្ជូនទាល់តែសោះនៅក្នុងរបាយការណ៍មួយចំនួនដែលត្រូវបានបញ្ជូនទៅកាន់ម្ចាស់បណ្តឹងសាទុក្ខដោយគណៈកម្មាធិការពាណិជ្ជកម្ម[3257]។ ការអះអាងរបស់គាត់ថា អ.ជ.ស.ដ និយាយសរុបក្នុងការសន្និដ្ឋានថា វន វ៉េត ជាញឹកញាប់ត្រូវបានបញ្ចូលជាអ្នកទទួលបន្ទាប់[3258] មើលរំលងរបាយការណ៍ជាច្រើនដែល អ.ជ.ស.ដ យោងនោះបានបញ្ជាក់យ៉ាងច្បាស់លាស់ថា មកកាន់គាត់ និងគ្រាន់តែចម្លងជូនទៅ វន វ៉េត តែប៉ុណ្ណោះ[3259]។ ការគ្រាន់តែអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានទទួលជាបន្តបន្ទាប់នូវរបាយការណ៍ និងលិខិតស្តីពីបញ្ហាពាណិជ្ជកម្ម បន្ទាប់ពី វន វ៉េត ត្រូវចាប់ខ្លួន[3260] មិនបានបំពេញតាមបទដ្ឋាននៃការពិនិត្យបណ្តឹងសាទុក្ខឡើងវិញទេ។

---

[3255] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២០ ជើងទំព័រ ១៩៦១។

[3256] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២០ ជើងទំព័រ ១៩៦០។

[3257] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៨-៦១៩ ជើងទំព័រ ១៩៥១, ១៩៥៥-១៩៥៦ *យោង* ឯកសារ **E3/2040** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦ KH 00003041-44។ ឯកសារ **E3/2041** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00091073-74។ ឯកសារ **E3/2042** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00003038-40។ ឯកសារ **E3/1616** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧ KH 00003145-46។ ឯកសារ **E3/3533** គណៈកម្មាធិការពាណិជ្ជកម្ម ស្ថិតិនាំចេញ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៨ KH 00187947-56។ ឯកសារ **E3/1640** គណៈកម្មាធិការពាណិជ្ជកម្ម លិខិតទៅកាន់ស្ថានទូតយូហ្គោស្លាវី ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៨ KH 00278403-04។ ឯកសារ **E3/311** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៧ KH 00069482។

[3258] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៨៩។

[3259] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៦១៨-៦១៩ ជើងទំព័រ ១៩៥១, ១៩៥៤, ១៩៥៨ *យោង* ឯកសារ **E3/3457** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ KH 00188521-22។ ឯកសារ **E3/3461** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៨ KH 00188537-38។ ឯកសារ **E3/1615** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ខែកញ្ញា ឆ្នាំ១៩៧៧ KH 00067709។ ឯកសារ **E3/325** របាយការណ៍គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ KH 00069487-96។

[3260] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៧៨៩។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២០ ជើងទំព័រ ១៩៦៣។

933. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសក្នុងការសន្និដ្ឋានថា គណៈកម្មាធិការពាណិជ្ជកម្មជាញឹកញាប់បានស្នើសុំសេចក្ដីណែនាំពីគាត់[3261] ព្រោះគាត់គ្រាន់តែលើកឡើងពីការបកស្រាយភ័ស្តុតាងតាមបែបផ្សេង ដោយមិនបានបង្ហាញថា ការបកស្រាយរបស់ អ.ជ.ស.ជ មិនសមហេតុផលនោះទេ។ ម្ចាស់បណ្ដឹងសាទុក្ខក៏បានលើកឡើង ដោយគ្មានការគាំទ្រផងដែរថា សំណើសុំការណែនាំដែលផ្ញើមកកាន់គាត់ក្នុងរបាយការណ៍ទាំងនោះ គ្រាន់តែជាទម្រង់ផ្លូវការប៉ុណ្ណោះ[3262]។

934. ទីបី ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានទៅមើលឃ្លាំងរដ្ឋជាមួយ វ៉ាន់ រិត ដែលជាកន្លែងគាត់ត្រួតពិនិត្យផលិតផលសម្រាប់នាំចេញ[3263]។ គាត់អះអាងថា អ.ជ.ស.ជ មានកំហុសក្នុងការពឹងផ្អែកលើចម្លើយ យ៉ិន គុជ[3264] ប៉ុន្តែខកខានមិនបានទទួលស្គាល់ថា អ.ជ.ស.ជ បានយោងចម្លើយរបស់សាក្សីនេះក្នុងនាមជាប្រភពបន្ថែម និងបានសំអាងជាសំខាន់លើសក្ខីកម្មក្នុងតុលាការរបស់ រស់ ស៊ុយ និង ស៊ឹម ហោ[3265]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញពីការរំលោភបំពានឆន្ទានុសិទ្ធិណាមួយនៅក្នុងការវាយតម្លៃភ័ស្តុតាងរបស់ អ.ជ.ស.ជ ដែលបានផ្ដល់ឱ្យដោយ រស់ ស៊ុយ និង ស៊ឹម ហោ នោះទេ។ គាត់គ្រាន់តែស្នើសុំឱ្យ អ.ជ.ត.ក ដាក់ជំនួសវិញនូវការវាយតម្លៃភ័ស្តុតាងតាមគាត់ចង់បាន ជំនួយឱ្យការវាយតម្លៃរបស់ អ.ជ.ត.ក។

935. ទីបួន ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានធ្វើការប្រជុំជាមួយកម្មករ និងកម្មាភិបាលពាណិជ្ជកម្ម បានណែនាំពួកគេពីការដឹកនាំ វិន័យ និងសីលធម៌ និងបានប្រកាសថា "ពួកអ្នកដែលខ្ជិលធ្វើការ"[3266] ជាខ្មាំងរបស់បក្ស។ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខថា អ.ជ.ស.ជ មានកំហុសក្នុងការលើកឡើងថា សក្ខីកម្មរបស់ ប៊ិត ណា ទទួលការបរាជ័យ ដោយសារការអះអាងទាំងនេះគ្រាន់តែមិនស្របទៅនឹងការវាយតម្លៃភ័ស្តុតាង

---

[3261] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៧៧-១៧៨០, ១៧៨៥-១៧៩០ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៩ ជើងទំព័រ ១៩៥៥។

[3262] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៧៩។

[3263] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៩១។

[3264] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៩៣។

[3265] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២០ ជើងទំព័រ ១៩៦៤។

[3266] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ១៧៩៤ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២០ ជើងទំព័រ ១៩៦៥។

របស់ អ.ជ.ស.ដ តែប៉ុណ្ណោះ ផ្អែកលើការមិនទទួលស្គាល់របស់គាត់ទៅលើឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់ អ.ជ.ស.ដ ក្នុងការវាយតម្លៃភាពអាចជឿជាក់ និងជឿទុកចិត្តបាននៃភ័ស្តុតាង[3267]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយមិនត្រឹមត្រូវថា សក្ខីកម្មរបស់ ប៊ិត ណា មិនមានការគាំទ្របញ្ជាក់ឡើយ[3268] មើលរំលងថា រស់ ស៊ុយ[3269] និង ស៊ឹម ហោ[3270] ក៏បានរៀបរាប់ថា ពួកគេបានចូលរួមក្នុងវគ្គសម្រាប់កម្មាភិបាលសេដ្ឋកិច្ច ដែលដឹកនាំដោយម្ចាស់បណ្តឹងសាទុក្ខ ដែលបានផ្តល់ការណែនាំលើរបៀបដែលត្រូវធានាឱ្យមានការគ្រប់គ្រងឃ្លាំងបានល្អ[3271] និងបានពិភាក្សាលើស្ថានភាពនយោបាយក្នុងប្រទេសកម្ពុជា[3272]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3273] មិនមានភាពផ្ទុយគ្នានៅក្នុងចម្លើយពីមុនរបស់ ប៊ិត ណា ដែលថា ម្ចាស់បណ្តឹងសាទុក្ខបានបរិហារពីឥរិយាបទខ្ជិលច្រអូសនៅក្នុងពេលប្រជុំរបស់គាត់ឡើយ។

936. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា មិនមានហេតុផលក្នុងការសន្និដ្ឋានថា តាមរយៈតួនាទីរបស់គាត់ជាអ្នកត្រួតពិនិត្យគណៈកម្មាធិការពាណិជ្ជកម្ម គាត់ (i) បានលើកកម្ពស់ និងបានណែនាំការអនុវត្តគោលបំណងរួម ដោយដឹកនាំវគ្គមនោគមន៍វិជ្ជាសម្រាប់កម្មាភិបាលនៅក្រសួងពាណិជ្ជកម្ម[3274] (ii) បានត្រួតត្រាការអនុវត្តគោលបំណងរួម ដោយបានផ្តល់លទ្ធភាពដោយផ្ទាល់ ធ្វើឱ្យការធ្វើជំនួញ និងពាណិជ្ជកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យដំណើរការទៅ

---

[3267] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧។

[3268] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៩៤។

[3269] ឯកសារ **E1/184.1** រស់ ស៊ុយ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ម៉ោង 11.06.36-11.09.58 ទំព័រ ៣១ បន្ទាត់ ១៣-២៥ ម៉ោង 11.17.49 ទំព័រ៣៤ បន្ទាត់២៣-ទំព័រ៣៥ បន្ទាត់ ១២ ម៉ោង 11.33.27-11.38.49 ទំព័រ៣៨ បន្ទាត់ ២៣-ទំព័រ ៤០ បន្ទាត់៥ ម៉ោង 11.38.49-11.48.35 ទំព័រ ៤០ បន្ទាត់១៨-ទំព័រ៤៣ បន្ទាត់៧។ ឯកសារ **E3/4594** បទសម្ភាសន៍ DC-Cam ជាមួយ រស់ ស៊ុយ KH 00008336។

[3270] ឯកសារ **E1/207.2** ស៊ឹម ហោ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង 14.16.31- 14.25.11 ទំព័រ ១៤ បន្ទាត់ ៨-ទំព័រ១៦ បន្ទាត់២២។ ឯកសារ **E3/4623** បទសម្ភាសន៍ DC-Cam ជាមួយ ស៊ឹម ហោ KH 00055251-52។

[3271] **E1/184.1** រស់ ស៊ុយ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ម៉ោង 11.06.36-11.09.58 ទំព័រ ៣១ បន្ទាត់ ១៣-១៧, ម៉ោង 11.17.49-11.19.29 ទំព័រ ៣៤ បន្ទាត់ ២៣- ទំព័រ ៣៥ បន្ទាត់ ៦។

[3272] ឯកសារ **E1/184.1** រស់ ស៊ុយ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ម៉ោង 11.33.27-11.38.49 ទំព័រ ៣៨ បន្ទាត់២៣-ទំព័រ ៤០ បន្ទាត់ ៥។ ឯកសារ **E3/4623** បទសម្ភាសន៍ DC-Cam ជាមួយ ស៊ឹម ហោ KH 00055251-52។ ឯកសារ **E1/207.2** ស៊ឹម ហោ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង 14.16.31- 14.25.11 ទំព័រ ១៤ បន្ទាត់ ៨-ទំព័រ១៦ បន្ទាត់ ២២។

[3273] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៩៦។

[3274] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២, ៤២៧២។

បានយ៉ាងរលូន[3275] និង (iii) បានដឹងអំពីកង្វះខាតស្បៀង[3276] និងហេតុការណ៍ដែលបានកើតមាននៅក្នុងក្រសួងពាណិជ្ជកម្ម ដូចជា ការបោសសម្អាត[3277] និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលគាត់បានណែនាំ[3278]។

### *មូលដ្ឋានទី ២០៧៖ ការទទួលខុសត្រូវចំពោះក្រសួងការបរទេស*[3279]

937. **មូលដ្ឋានទី ២០៧ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ក្នុងការសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខអាចបានផ្ដល់ជំនួយបណ្ដោះអាសន្នទៅឱ្យក្រសួងការបរទេស ("MFA") និងពិតជាបានទទួលលិខិតពីអង្គការលើកលែងទោសអន្តរជាតិ។**

938. ទីមួយ មូលដ្ឋាននោះបរាជ័យ ដោយហេតុថាម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា ការវាយតម្លៃភ័ស្តុតាងរបស់ អ.ជ.ស.ដ មកពីសក្ខីកម្មរបស់ សាឡុត បាន, ឡុង នរិន្ទ និង សួង ស៊ីគឿន ដែលបានប្រើដើម្បីគាំទ្រការសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខអាចបានផ្ដល់ជំនួយដ៏មានកម្រិតទៅឱ្យក្រសួងការបរទេសនោះ មានលក្ខណៈដោយផ្នែក និងមិនគ្រប់គ្រាន់[3280]។ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែមិនយល់ស្របជាមួយនឹងការបកស្រាយភ័ស្តុតាងរបស់ អ.ជ.ស.ដ ដោយមិនបានបង្ហាញថាតើការសន្និដ្ឋាននេះមិនសមហេតុផលដោយរបៀបណានោះទេ។ ចំពោះ សាឡុត បាន *ហៅ* សូ ហុង ម្ចាស់បណ្ដឹងសាទុក្ខតវ៉ាដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ បានបំភ្លៃ និងបានបំភាន់សក្ខីកម្មរបស់គាត់ ក្នុងការសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខបានធ្វើការប្រជុំនៅក្រសួងការបរទេសអំពីជន

---

[3275] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៦។

[3276] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២៨ ជើងទំព័រ ១៩៥១ *យោង* ឯកសារ **E3/2041** របាយការណ៍ពីគណៈកម្មាធិការពាណិជ្ជកម្ម ផ្ញើជូនបង ហែម ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00091074 (កត់សម្គាល់ថាប្រជាជនកម្ពុជាកំពុង "ខ្វះខាតស្បៀង" នៅឆ្នាំនោះ។)។

[3277] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥ ជើងទំព័រ ១៣៧៨៦-១៣៧៨៧។

[3278] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៧០, ៤២២៧, ៤២៧៣។

[3279] *<u>មូលដ្ឋានទី ២០៧៖</u>* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ការទទួលខុសត្រូវរបស់ក្រសួងការបរទេស* កថាខណ្ឌ១៧៩៩-១៨០៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧១ (អង់គ្លេស) ទំព័រ ៦៥-៦៦ (បារាំង) ទំព័រ ១០១ (ខ្មែរ)។

[3280] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨០២។ ចំពោះភាពលម្អៀង *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៤។ ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ១១២។

បរទេស ខណៈដែលតាមពិតនោះគាត់បានជួបតែ "ផ្នែកបញ្ញាជន" ប៉ុណ្ណោះ[3281]។ ម្ចាស់បណ្តឹងសាទុក្ខបានលុបចោលផ្នែកនៃសក្ខីកម្មរបស់ សាឡុត បាន ដែលផ្នែកនោះបានលើកឡើងយ៉ាងច្បាស់ថា គាត់បានឃើញម្ចាស់បណ្តឹងសាទុក្ខជួប "ខាងផ្នែកបញ្ញាជន ទាក់ទងខាងបរទេស"[3282] ដែលស្របទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ។ ចំពោះ ឡុង នរិន្ទ ម្ចាស់បណ្តឹងសាទុក្ខ កត់សម្គាល់ដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មើលរំលងថា ម្ចាស់បណ្តឹងសាទុក្ខមិនអាចធ្វើការសម្រេចក្នុងពេលអវត្តមាន អៀង សារី នោះទេ ប៉ុន្តែអាចបានតែស្វាគមន៍ភ្ញៀវតែប៉ុណ្ណោះ [3283]។ ចំណុចនេះមិនពាក់ព័ន្ធទេ ដោយហេតុថា អ.ជ.ស.ដ មិនដែលសន្និដ្ឋានថា ម្ចាស់បណ្តឹង សាទុក្ខជំនួស អៀង សារី នៅពេលគាត់អវត្តមាន ឬធ្វើការសម្រេចចិត្តណាមួយឡើយ ផ្ទុយទៅវិញ គាត់ផ្តល់ជំនួយដ៏មានកម្រិតយូរៗម្តង[3284]។ ភស្តុតាងនេះ រួមផ្សំជាមួយនឹងសក្ខីកម្មរបស់ សួង ស៊ីគឿន ដែលថ្លែងថា គាត់បានជួបជាមួយម្ចាស់បណ្តឹងសាទុក្ខពីរដងនៅក្រសួងការបរទេស ដើម្បី ពិភាក្សាការធ្វើសេចក្តីព្រៀងអត្ថបទសារព័ត៌មាន[3285] ផ្តល់មូលដ្ឋានសមហេតុផល ឥតលម្អៀង និង សំខាន់ក្នុងការគាំទ្រការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខបានផ្តល់ជំនួយខ្លះដល់ ក្រសួងការបរទេស ទោះបីជាមានកម្រិតក្តី។

939. ទីពីរ មូលដ្ឋាននេះក៏បរាជ័យផងដែរទាក់ទងនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងថា ឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល និងអតីតទាហ៊ានខ្មែរក្រហម តាមរយៈលិខិតពីរផ្ញើមកកាន់គាត់[3286] និងរបាយការណ៍ជាសាធារណៈពីរច្បាប់[3287]

---

[3281] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០២ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២៣។

[3282] ឯកសារ **E1/68.1** សាឡុត បាន *ហៅ* សូ ហុង ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ម៉ោង 11.13.48-11.15.28 ទំព័រ ៣២ បន្ទាត់ ១០-១១។

[3283] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០២។

[3284] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២៣។

[3285] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០២។

[3286] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៥៨ ជើងទំព័រ ១៣៤០៥ *យោង* ឯកសារ **E3/4520** របាយការណ៍អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ១៩៧៥-១៩៧៦ KH 00634978-00634980 (រៀបរាប់អំពីលិខិតដែលបានផ្ញើនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៦ ទៅកាន់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងការសម្លាប់ក្រៅផ្លូវតុលាការ និងស្នើសុំឱ្យមានការស៊ើបអង្កេត)។ ឯកសារ **E3/3864** លិខិតអង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ KH 00323619-22។

[3287] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៥៨ ជើងទំព័រ ១៣៤០៦ *យោង* ឯកសារ **E3/3311** សេចក្តីប្រកាសព័ត៌មានរបស់អង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ KH 00591041-42 និង

ដែលសុទ្ធតែមកពីអង្គការលើកលែងទោសអន្តរជាតិ ក្នុងឆ្នាំ១៩៧៦ - ១៩៧៨[3288]។ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ដោយគ្មានមូលដ្ឋានចំពោះការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា គាត់មិនអាចមើលរំលងរបាយការណ៍ទាំងនេះទេ ផ្អែកលើទំនាក់ទំនងរឹងមាំរបស់គាត់ជាមួយ អៀង សារី និង ក្រសួងការបរទេស[3289]។

940. អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវ ផ្អែកលើភស្តុតាងជារួមថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីលិខិត និងរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ និងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3290]។ មានហេតុផលសមរម្យក្នុងការសន្និដ្ឋានថា លិខិតដែលផ្ញើមកម្ចាស់បណ្តឹងសាទុក្ខ គាត់បានទទួលក្នុងថ្ងៃធ្វើការងារធម្មតារបស់គាត់ ដូចគ្នាទៅនឹងលិខិតសារតាំងពីអ្នកការទូតផ្សេងទៀត ដែលផ្ញើមកកាន់ម្ចាស់បណ្តឹងសាទុក្ខក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ[3291]។ ភស្តុតាងបង្ហាញទៀតថា របាយការណ៍អង្គការលើកលែងទោសអន្តរជាតិ បានកើតចេញពីសកម្មភាពរបស់រដ្ឋាភិបាល ប.ក.ក។ ក្រោយសេចក្តីសម្រេចខែកញ្ញា ឆ្នាំ១៩៧៨ របស់ អ.ស.ប ដើម្បីធ្វើការស៊ើបអង្កេតលើស្ថានភាពសិទ្ធិមនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលកើតចេញពីរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ[3292] អៀង សារី បានផ្ញើកំណត់សម្គាល់ពីរ (i) មួយទៅ កាន់អគ្គលេខាអង្គការសហប្រជាជាតិ ("UNSG") ដែលក្នុងនោះគាត់បានបរិហារថា "នៅលើ ឆាកអន្តរជាតិ មានយុទ្ធនាការ [...] បង្កាច់បង្ខូច" ធ្វើឡើងក្រោមបញ្ហា "សិទ្ធិមនុស្ស" ដោយពួកចក្រពត្តិនិយម ពួកវាតទីនិយម និងពួកទេសានុពន្ធនិយម រួមទាំងចក្រភពអង់គ្លេសផង[3293] និង (ii) លិខិតមួយទៀតទៅកាន់អនុគណៈកម្មាការ អ.ស.ប ស្តីពីការទប់ស្កាត់ការរើសអើង និងការពារជនជាតិភាគតិច ដែលបានចាត់ទុកសេចក្តីសម្រេចរបស់ខ្លួនក្នុងស៊ើបអង្កេតរបបកម្ពុជាប្រជាធិប

---

ឯកសារ **E3/4492** កាសែត Los Angeles Times *ប្រទេសកម្ពុជា៖ ប្រជាជនកម្ពុជាដែលប្រឈមនឹងការវិនាសសាបសូន្យ* ចេញផ្សាយថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៨ KH 00722242-44។ *សូមមើលផងដែរ* ឯកសារ **E3/4521** UN ECOSOC *សារណាពីអង្គការលើកលែងទោសអន្តរជាតិក្រោមសេចក្តីសម្រេចលេខ៩ (XXXIV)* ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៨ KH 00664701។

[3288] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥០។

[3289] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០៣។

[3290] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥០។

[3291] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៧ ជើងទំព័រ ១៨៧១, ១៨៧៤។

[3292] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៣៤។

[3293] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨២៥ ជើងទំព័រ ១២៧៨៤ *យោង* ឯកសារ **E3/1385** សេចក្តីថ្លែងការណ៍របស់ អៀង សារី ទៅកាន់អគ្គលេខា អ.ស.ប ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ KH 00333906-920។

តេយ្យថា "ជាការគាំទ្រដល់សកម្មភាពរបស់ពួកក្បត់ និងពួកចក្រពត្តិអាមេរិក"[3294]។ ក្នុងខែតុលា ឆ្នាំ១៩៧៨ អៀង សារី ក៏បានអញ្ជើញអគ្គលេខា អ.ស.ប មកទស្សនាប្រទេសផងដែរ ដើម្បីមើលការពិតទាក់ទងនឹងការចោទប្រកាន់ពីបញ្ហាសិទ្ធិមនុស្ស[3295]។ ក្នុងឋានៈជាប្រមុខរដ្ឋ ដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រសួងការបរទេស និងទទួលខុសត្រូវទទួលស្វាគមន៍គណៈប្រតិភូបរទេស[3296] មិនទំនងទេថា ម្ចាស់បណ្តឹងសាទុក្ខមិនបានដឹងអំពីលិខិត និងរបាយការណ៍ទាំងនេះ ដោយផ្អែកលើតម្រូវការចាំបាច់សម្រាប់គាត់ក្នុងការត្រៀមខ្លួនឆ្លើយតបក្នុងកម្រិតណាមួយ ប្រសិនបើបញ្ហានោះត្រូវបានលើកឡើងដោយប្រតិភូបរទេស។ លើសពីនេះទៀត ផ្អែកលើភ័ស្តុតាងជាច្រើន អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខ និង អៀង សារី មានទំនាក់ទំនងរឹងមាំតាំងពីទសវត្សរ៍ឆ្នាំ១៩៥០[3297] និងថា ពួកគេធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធមុន និងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងផ្នែកការទូត និងការបរទេស ដោយបានទៅ ទស្សនកិច្ចប្រទេសនានា[3298] ចូលរួមប្រជុំជាច្រើន[3299] និងការទទួលស្វាគមន៍គណៈប្រតិភូបរទេស[3300]។

---

[3294] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៣៤ ជើងទំព័រ ១២៨១៦ *យោង* ឯកសារ **E3/4605** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៨ KH 00813070-71។

[3295] ឯកសារ **E3/627** កាសែត Los Angeles Times *ប្រធានអង្គការសហប្រជាជាតិត្រូវបានអញ្ជើញឱ្យមកទស្សនកិច្ចប្រទេសកម្ពុជាដើម្បីពិនិត្យមើលបញ្ហាសិទ្ធិមនុស្ស* ចេញផ្សាយថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៨ KH 00712911-12។ ឯកសារ **E3/654** កាសែត International Herald Tribune *កម្ពុជាអញ្ជើញអ្នកអង្កេតការណ៍បស្ចិមប្រទេសមកបំពេញទស្សនកិច្ចដើម្បីប្រឆាំងនឹងការរិះគន់* KH S 00720231-32។

[3296] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៧។

[3297] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៥, ៥៧៣។ *សូមមើលផងដែរ* ឯកសារ **E3/111** បទសម្ភាសន៍ អៀង សារី ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧២ KH 00711435-36។ ឯកសារ **E3/659** បទសម្ភាសន៍ អៀង ធីរិទ្ធ ចុះខែតុលា ឆ្នាំ១៩៨០ KH 00471100-02។

[3298] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៣៤, ៥៩៧។ *សូមមើលផងដែរ ឧទាហរណ៍* ឯកសារ **E3/488** FBIS, *AKI ស្វាគមន៍សមាគមមិត្តភាព និងទំនាក់ទំនងរវាងសាធារណៈរដ្ឋប្រជាធិបតេយ្យវៀតណាម និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា* ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៥ KH 00663976។ ឯកសារ **E3/113** *ទីភ្នាក់ងារសារព័ត៌មានកម្ពុជា លេខ ៦៩៣* ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៤ KH S 00704555-68។ ឯកសារ **E3/114** *ទីភ្នាក់ងារសារព័ត៌មានកម្ពុជា លេខ ៦៩៦* ចុះថ្ងៃទី៧-៨ ខែមេសា ឆ្នាំ១៩៧៤ KH S 00662250-56។ ឯកសារ **E3/115** *ទីភ្នាក់ងារសារព័ត៌មានកម្ពុជា លេខ ៧០៨* ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៤ KH 00597966-70។ ឯកសារ **E3/3312** *សេចក្តីសង្ខេបសារព័ត៌មាន EA ថ្ងៃទី៣០ ខែមេសា* ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៤ KH 00740847។ ឯកសារ **E3/3724** *លោកនាយករដ្ឋមន្ត្រី ជូ (Chou) ជួប ខៀវ សំផន* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧៥ KH S 00656241-43។ ឯកសារ **E3/273** FBIS *គណៈប្រតិភូលាវជួបជាមួយរដ្ឋាភិបាលកម្ពុជា* ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៥, EN 00167585។ ឯកសារ **E3/278** FBIS *សាររំលែកទុក្ខផ្ញើជូនចំពោះសាធារណរដ្ឋប្រជាមានិតចិន ក្នុងឱកាសមរណភាពរបស់ឯកឧត្តម ជូ តេ (Chu Te)* ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៦ KH 00663907-09។

ពួកគេក៏រស់នៅក្បែរគ្នានៅ ក-៣ ផងដែរ[3301] និងដូចបានឃើញខាងលើ ម្ចាស់ បណ្តឹងសាទុក្ខបានផ្តល់ជំនួយមួយចំនួនដល់ក្រសួងការបរទេស ក្នុងពេលដែល អៀង សារី អវត្តមាន។ ទំនាក់ទំនងដ៏រឹងមាំនេះ ក៏ដូចជាតម្រូវការចាំបាច់សម្រាប់ម្ចាស់បណ្តឹងសាទុក្ខក្នុងការទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ពីសំណាក់អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដើម្បីបំពេញមុខងារការទូតរបស់គាត់ឱ្យបានគ្រប់គ្រាន់ ក្នុងនាមជាប្រធាន បានធ្វើឱ្យរូបគាត់ចៀសមិនផុតពីការដឹងឮអំពីលិខិត និងរបាយការណ៍ទាំងអស់នេះឡើយ[3302]។

---

[3299] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៣, ៥៩៧។ *សូមមើលផងដែរ* ឯកសារ **E3/1238** *ទីភ្នាក់ងារសារព័ត៌មានកម្ពុជា លេខ ៦៩១* ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៤ KH 00702017-25។ ឯកសារ **E3/5** *ទង់បដិវត្ត* លេខ៨ សីហា ១៩៧៥ KH 00063324 (ការប្រមូលផ្តុំកងទ័ពនៅពហុកីឡដ្ឋានជាតិអូឡាំពិក)។ ឯកសារ **E3/89** បទសម្ភាសន៍ជាមួយ អៀង សារី ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ KH 00062453 (ការប្រជុំនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥)។ ឯកសារ **E3/182** កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍របស់ ប.ក.ក ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019108។ ឯកសារ **E3/1372** BBC/SWB ចុះនៅខែធ្នូ ឆ្នាំ១៩៧៧ KH 00652313។ ឯកសារ **E3/3741** *អ្នកការទូតនិយាយថារាជធានីរបស់ប្រទេសកម្ពុជាជា "ទីក្រុងខ្មោច"* ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៨ KH 00707424-26។ ឯកសារ **E3/1413** BBC/SWB *ដំណើរទស្សនកិច្ចនៅអាស៊ីអាគ្នេយ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេសយូហ្គូស្លាវី* ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៨ KH S 00651230។ ឯកសារ **E3/1252** BBC/SWB, *ប្រធានាធិបតីរ៉ូម៉ានីមកដល់ប្រទេសកម្ពុជា* ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨ KH S 00723819-20។

[3300] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៧, ១៩៩៥, ជើងទំព័រ ១៨៧២-១៨៧៣។ *សូមមើលផងដែរ* ឯកសារ **E3/273** FBIS *អៀង សារី រៀបចំពិធីជប់លៀងជូនមន្ត្រីការទូត* ចុះថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ KH 00657431-33។ ឯកសារ **E3/277** FBIS *លោក ខៀវ សំផន ទទួលស្វាគមន៍ឯកអគ្គរដ្ឋទូតបរទេស* ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៦ KH 00663901-02។ ឯកសារ **E3/491** *ក្រសួងការបរទេសសាធារណរដ្ឋបារាំង-ពង្សាវតារខ្មែរ (ខែកញ្ញា ឆ្នាំ១៩៧៦)* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00704452។ ឯកសារ **E3/1339** FBIS *ប្រេសិតឡាវរៀបចំពិធីជប់លៀងដើម្បីប្រារព្ធពិធីបុណ្យជាតិសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ* ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៧ KH 00721336។

[3301] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៣៤។ *សូមមើលផងដែរ* ឯកសារ **E3/37** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156676។ ឯកសារ **E1/208.1** ឡុង ឈឿង ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង 09.28.08-09.30.37 ទំព័រ ៨ បន្ទាត់ ២០ -ទំព័រ ៩ បន្ទាត់ ៧។ ឯកសារ **E3/5748** កំណត់ ហេតុស្តាប់ចម្លើយ ឌុច ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ KH 00153461។ ឯកសារ **E1/71.1** ពាន ឃាន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ម៉ោង 15.57.43-15.59.25 ទំព័រ ៥៨ បន្ទាត់ ១១-១៨។

[3302] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥០, ៤២៥៣។ *សូមមើលផងដែរ* កថាខណ្ឌ ៤៨៤ ជើងទំព័រ ១៥២៧ *យោង* ឯកសារ **E1/66.1** សាឡុត បាន *ហៅ* សូ ហុង ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ទំព័រ ៦១ (បញ្ជាក់ថា អៀង សារី, នួន ជា, ខៀវ សំផន បានជួបគ្នានៅមន្ទីរ ក.១)។

## *មូលដ្ឋានទី ១៩០៖ មជ្ឈិមបក្ស*[3303]

941. **គួរច្រានចោលមូលដ្ឋានទី ១៩០ ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសដោយការប្រើប្រាស់ពាក្យ "មជ្ឈិមបក្ស" ក្នុងវិធីដែលម្ចាស់បណ្ដឹងសាទុក្ខត្រូវបានបញ្ចូលក្នុងស្ថាប័នសមូហភាពមិនច្បាស់លាស់មួយ ដែលជាការរៀបចំធ្វើឱ្យរូបគាត់មានទំនាក់ទំនងទៅនឹងសេចក្ដីសម្រេចទាំងអស់របស់ ប.ក.ក។**

942. ស្របជៀងគ្នាទៅនឹងសំណុំរឿង ០០២/០១[3304] មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការកំណត់និយមន័យនៃពាក្យ "មជ្ឈិមបក្ស"។ ផ្អែកតាមភ័ស្តុតាងជាសក្ខីកម្ម និងភ័ស្តុតាងឯកសារ[3305] អ.ជ.ស.ដ បានសន្និដ្ឋានថា "មជ្ឈិមបក្ស" សំដៅលើស្ថាប័នប្រតិបត្តិជាន់ខ្ពស់របស់ ប.ក.ក ដែលមានមូលដ្ឋាននៅភ្នំពេញ រួមទាំង គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការយោធា មន្ទីរ៨៧០ និងមន្ទីររដ្ឋាភិបាល (ស-៧១)[3306]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍សន្និដ្ឋានដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានចេញការសន្និដ្ឋានផ្ទុយគ្នាទាក់ទងនឹងទំនាក់ទំនងរបស់គាត់ទៅនឹងមជ្ឈិមបក្ស[3307]។ តាមពិត អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងស៊ីសង្វាក់គ្នាថា រូបគាត់គឺជាមេដឹកនាំជាន់ខ្ពស់ ដែលមានតួនាទីពិសេសនៅក្នុងមជ្ឈិមបក្ស ឬ ប.ក.ក ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិមម្នាក់ ដែលមានវត្តមាន និងបានចូលរួមក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើន[3308]។ ម្ចាស់បណ្ដឹង

---

[3303] ទទ្ធីករណ៍ ១៩០៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *មជ្ឈិមក្ស* កថាខណ្ឌ ១៦១៨-១៦៣២។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៦៦ (អង់គ្លេស) ទំព័រ ៦១ (បារាំង) ទំព័រ ៩៣ (ខ្មែរ)។

[3304] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧២ *បានបដិសេធ* ឯកសារ **F17** សារណាបណ្ដឹងសាទុក្ខសំណុំរឿង០០២/០១ កថាខណ្ឌ ១៤០-១៤១, ១៤៤។

[3305] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៦០ ជើងទំព័រ ១០២៦-១០២៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦១៩-១៦២០។

[3306] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦១។

[3307] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៣១ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៨។ (ម្ចាស់បណ្ដឹងសាទុក្ខបំភ្លៃការសន្និដ្ឋានរបស់ អ.ជ.ស.ដ ក្នុងកថាខណ្ឌ ៤២០៨ នៃសាលក្រម។ ដោយលើកឡើងថា គាត់កៀកទៅនឹងមជ្ឈិមបក្ស អ.ជ.ស.ដ មិនមានន័យថា គាត់មិនមែនជាផ្នែកមួយនៃមជ្ឈិមបក្សទេ ប៉ុន្តែគ្រាន់តែមានន័យថា ភាពកៀកកិតផ្នែករូបវន្ត និងភាពជិតស្និទ្ធរបស់គាត់ ទៅនឹងមេដឹកនាំ ប.ក.ក ផ្សេងទៀត ដែលមានមូលដ្ឋានស្ថិតនៅ ក-១ និង ក-៣ នៅភ្នំពេញ "ជួយឱ្យ ខៀវ សំផន ដឹងជាបន្តបន្ទាប់អំពីការបង្កើតផែនការ ការអនុវត្តផែនការ និងភរនីយភាពដែលថា ឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ បានកើតឡើង")។

[3308] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦២៤ ("ដោយមិនគិតពីអំណះអំណាងរបស់គាត់ ដែលថាគាត់មិនបានប្រើប្រាស់តួនាទីណាមួយ នៅក្នុងគណៈកម្មាធិការ *មជ្ឈិមបក្ស*នោះ អង្គជំនុំជម្រះរកឃើញថា

សាទុក្ខអះអាងថែមទៀតថា អ.ជ.ស.ដ មិនគិតគូរដល់ភ័ស្តុតាងដោះបន្ទុកពី អឿន តាន ទេ[3309]។ ទោះជាយ៉ាងណា សក្ខីកម្មរបស់គាត់មិនគាំទ្រដល់ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខនោះទេ ដោយផ្ទុយទៅវិញបានបង្ហាញថា រូបគាត់គឺជាផ្នែកមួយនៃថ្នាក់ដឹកនាំ និងបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹង ប៉ុល ពត, អៀង សារី, និង នួន ជា នៅមុនពេល និងក្នុងអំឡុងពេលនៃរបប កម្ពុជាប្រជាធិបតេយ្យ[3310]។

943. ម្ចាស់បណ្តឹងសាទុក្ខខកខានផងដែរក្នុងការបង្ហាញពីកំហុសណាមួយ ក្នុងការប្រើប្រាស់ពាក្យ "មជ្ឈិមបក្ស"[3311] របស់ អ.ជ.ស.ដ។ គាត់អះអាងដោយមិនត្រឹមត្រូវថា ក្នុងការសន្និដ្ឋានថា ភូមិភាគ និងតំបន់ស្វយ័តបានរាយការណ៍ផ្ទាល់ទៅមជ្ឈិមបក្ស អ.ជ.ស.ដ បានមើលរំលង ភ័ស្តុតាងដែលបង្ហាញថា គាត់មិនមែនជាអ្នកទទួលរបាយការណ៍ផ្ទាល់ទេ[3312]។ ម្ចាស់បណ្តឹង សាទុក្ខខកខានមិនបានទទួលស្គាល់ថា ទូរលេខជាច្រើនដែលផ្ញើទៅកាន់មជ្ឈិមបក្ស "ចម្លងជូន មន្ទីរ"[3313] ដែល អ.ជ.ស.ដ បានសន្និដ្ឋានថា គឺជា "មន្ទីរ ៨៧០"[3314] ដែលម្ចាស់បណ្តឹងសាទុក្ខ គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិកដ៏តិចតួច[3315]។

---

ខៀវ សំផន មិនគ្រាន់តែស្ថិតនៅក្នុងក្រុមនៃសមាជិក ប.ក.ក ដែលទទួលបានព័ត៌មានពេញលេញ ដោយសារតែសមាជិកភាព របស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះទេ ប៉ុន្តែ ខៀវ សំផន ថែមទាំងស្ថិតនៅក្នុងតួនាទីមួយដែលមានភាពលេចធ្លោ ខ្លាំងនៅក្នុងបក្ស ដោយសារវត្តមានរបស់គាត់នៅឯកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលពិភាក្សាបញ្ហាសំខាន់ៗ ហើយសេចក្តី សម្រេចត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំនោះ") (គូសបញ្ជាក់បន្ថែម) ៤២៣៦ ("ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់ដែលមានឋានៈ ពិសេសនៅក្នុងមជ្ឈិមបក្ស") ៣៤០, ៦០៤, ៦២៤, ៤២៣០, ៤២៣៧, ៤៣១៦។

[3309] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២៤។

[3310] ឯកសារ **E1/86.1** អឿន តាន ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 11.14.12-11.24.08 ទំព័រ ៣៦ បន្ទាត់ ១- ទំព័រ ៣៩ បន្ទាត់ ៩ ម៉ោង 11.44.29-11.49.17 ទំព័រ ៤៥ បន្ទាត់ ៥-ទំព័រ ៤៦ បន្ទាត់ ១៤ ម៉ោង 15.44.50-15.47.16 ទំព័រ ៨៣ បន្ទាត់ ១២-២៤។

[3311] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២១-១៦៣១។

[3312] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២៥ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៧។

[3313] *សូមមើលឧទាហរណ៍* ឯកសារ **E3/888** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ KH 00020876។ ឯកសារ **E3/889** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ KH 00020877។ ឯកសារ **E3/914** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ KH 00020926។ ឯកសារ **E3/949** ទូរលេខកម្ពុជាប្រជាធិប តេយ្យ ចុះថ្ងៃទី៩-១០ ខែឧសភា ឆ្នាំ១៩៧៨ EN 00003533។ ឯកសារ **E3/978** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៧ KH 00020884។ ឯកសារ **E3/996** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ KH 00001084។ ឯកសារ **E3/1077** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ KH 00296228។ ឯកសារ

944. ម្ចាស់បណ្តឹងសាទុក្ខក៏លើកឡើងដោយមិនត្រឹមត្រូវថែមទៀតថា អ.ជ.ស.ដ បានបំភ្លៃភ័ស្តុតាងក្នុងការគាំទ្រការសន្និដ្ឋានរបស់ខ្លួនថា មានប្រព័ន្ធប្រាស្រ័យទាក់ទងរវាងភូមិភាគ និងមេដឹកនាំ ប.ក.ក ដោយមិនបានពន្យល់ថាតើ អ.ជ.ស.ដ បានបំភ្លៃភ័ស្តុតាងនោះដោយរបៀបណានោះទេ[3316]។ អ.ជ.ស.ដ បានកត់សម្គាល់ថា ទូរលេខបញ្ជូនពីភូមិភាគ ឬតំបន់ស្វយ័តទៅកាន់មជ្ឈិមបក្សជាទូទៅត្រូវបានបញ្ជូនទៅ "មន្ទីរ ៨៧០" ឬ *អង្គការ*[3317] ប៉ុន្តែ ក៏បានសន្និដ្ឋានថា បញ្ជីឈ្មោះអ្នកទទួលនៅលើទូរលេខជាច្រើនបានបញ្ជាក់ថា សំណៅទាំងនោះត្រូវបានបញ្ជូនទៅកាន់មេដឹកនាំ ប.ក.ក ជាច្រើន និងទៅកាន់មន្ទីរ ៨៧០[3318]។ អ.ជ.ស.ដ ក៏បានពិចារណាផងដែរលើភ័ស្តុតាងរបស់សាក្សីដែលបានផ្តល់សក្ខីកម្មថា មន្ទីរទូរលេខ ប.ក.ក របស់មជ្ឈិមបក្ស រួមទាំង ក-១៨ ដែលជាមន្ទីរមួយស្ថិតនៅក្នុងសាលាសុទ្ធារស និង ក-១ ត្រូវបានបង្កើតឡើងនៅភ្នំពេញក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ សម្រាប់ការទំនាក់ទំនងយូរអង្វែង និងថា ប្រព័ន្ធនេះនៅតែដំណើរការរហូតដល់វៀតណាមមកដល់ក្នុងឆ្នាំ១៩៧៩[3319]។

---

**E3/1144** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00069447។ ឯកសារ **E3/1209** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៦ KH 00597809។ ឯកសារ **E3/254** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ KH 00020972 (លើកឡើងថា មន្ទីរ ៨៧០ បានទទួលរបាយការណ៍ពីភូមិភាគបូព៌ា)។

[3314] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៤៩២, ៦០៨, ៦១៦ ជើងទំព័រ ១៥៥៣ *យោង* ឯកសារ **E1/120.1** នង សុផង់ ប្រតិចារឹក ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ ម៉ោង 11.28.04-11.31.04 ទំព័រ ៣១ បន្ទាត់ ១-១៩ (បានលើកឡើងថា ចំណារ "ដាក់នៅមន្ទីរ" នៅក្នុង "មួយសន្លឹកហ្នឹងគឺគេសម្គាល់ទុកនៅមន្ទីរ ៨៧០") ម៉ោង 13.53.43-13.56.57 ទំព័រ ៤៧ បន្ទាត់ ១-១០។ ឯកសារ **E3/37** កំណត់ហេតុស្តួរចម្លើយ ខៀវ សំផន KH 00156676 ("[មន្ទីរ ៨៧០] មានសមាសភាពតែពីរនាក់ទេ គឺ ខឿន និងខ្ញុំ)។

[3315] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៦៤, ៦០៨, ៦១៦។ ឯកសារ **E3/37** កំណត់ហេតុស្តួរចម្លើយ ខៀវ សំផន KH 00156676 ("[មន្ទីរ ៨៧០] មានសមាសភាពតែពីរនាក់ទេ គឺ ខឿន និងខ្ញុំ)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៥។

[3316] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ១៦២៩ *យោង*ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩៩, ៣៩៦២-៣៩៦៣។

[3317] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៩២។

[3318] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩, ៤៩២។

[3319] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៥៧ (*យោង* ភ័ស្តុតាងសក្ខីកម្មរបស់ នង សុផង់ និង គង់ សុខា)។

945. គួរច្រានចោលអំណះអំណាងផ្សេងទៀតរបស់គាត់ទាក់ទងនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើ (i) ទំនាក់ទំនងខ្សែទទឹងនៅក្នុងមជ្ឈិមបក្ស[3320] (ii) ផែនការរបស់គណៈកម្មាធិការមជ្ឈិមក្នុងការជម្លៀសប្រជាជនចេញពីភ្នំពេញ[3321] និង (iii) សេចក្តីណែនាំរបស់មជ្ឈិមបក្សទាក់ទងនឹងម៉ោងធ្វើការនៅ ទំនប់១មករា[3322] ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញពីកំហុសណាមួយក្នុងការប្រើប្រាស់ពាក្យ "មជ្ឈិមបក្ស" របស់ អ.ជ.ស.ដ ដែលធ្វើឱ្យមានការពាក់ព័ន្ធដោយមិនត្រឹមត្រូវទៅនឹង ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់។

## *មូលដ្ឋានទី ១៩១ ៖ អង្គការ*[3323]

946. **គួរច្រានចោលមូលដ្ឋានទី ១៩១ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រើពាក្យ "*អង្គការ*" តាមវិធីមួយដែលគាត់ត្រូវបានរៀបចំឱ្យមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្ម។**

947. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខអានសាលក្រមតែផ្នែកខ្លះ[3324] ដោយលើកឡើងថា អ.ជ.ស.ដ គួរផ្តល់សំអាងហេតុ និងបរិបទ បន្ថែមទៀត ក្នុងការបកស្រាយពាក្យ

[3320] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២១-១៦២៣ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៣-៤៨៤។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញពីកំហុសណាមួយទេ តែគ្រាន់តែមិនឯកភាពជាមួយការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា គណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍បានជួបជាប្រចាំ និងថា ប៉ុល ពត និង នួន ជា បានជួបគ្នានៅម្ទីរ ក-១ និង ក-៣។ ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខអះអាងទាក់ទងនឹងឯកសារ Goscha ថាពួកវាខ្វះភាពអាចជឿជាក់បាន និងហេតុដូច្នេះ មិនអាចប្រើដើម្បីបង្ហាញពីការប្រជុំញឹកញាប់របស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បានទេ។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១១ (ការទទួលយកឯកសារ Goscha)។

[3321] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២៧ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៧៩។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមក្នុងការបញ្ចប់ផែនការជម្លៀសប្រជាជនចេញពីភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៩។

[3322] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦២៨ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៧៧, ១៥០៩, ៣៩១១។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា ការសន្និដ្ឋាននេះមិនបង្កើតបានទេ ដោយសារ សេចក្តីណែនាំមកពី "អង្គភាពនានាដែលត្រូវបានកំណត់អត្តសញ្ញាណ" និងមិនមានប្រភពណាសំដៅលើពាក្យ "មជ្ឈិមបក្ស" ទេ។ គាត់មើលរំលងថា អ.ជ.ស.ដ បានសន្និដ្ឋានថា "មជ្ឈិមបក្ស" សំដៅលើស្ថាប័នប្រតិបត្តិជាន់ខ្ពស់ជាច្រើន របស់ ប.ក.ក ដែលមានមូលដ្ឋាននៅភ្នំពេញ ដែលរួមទាំងគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម គណៈកម្មាធិការយោធា មន្ទីរ ៨៧០ និងមន្ទីររដ្ឋាភិបាល (ស-៧១) និងហេតុដូច្នេះ បានថ្លែងយ៉ាងត្រឹមត្រូវថា គឺ "មជ្ឈិមបក្ស" ដែលបានចេញការណែនាំទាក់ទងនឹងម៉ោងពេល ធ្វើការនៅការដ្ឋានទំនប់ ១ មករា។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦១១។

[3323] មូលដ្ឋានទី ១៩១៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អង្គការ* កថាខណ្ឌ ១៦៣៣-១៦៣៦។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៦ (អង់គ្លេស) ទំព័រ ៦១ (បារាំង) ទំព័រ ៩៣-៩៤ (ខ្មែរ)។

*អង្គការ*[3325]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានបង្ហាញពីភាពខុសគ្នានៃនិយមន័យរបស់ ប.ក.ក នៃពាក្យ*អង្គការ* ដែលសំដៅលើបក្ស និងការប្រើប្រាស់ពិតប្រាកដនៃពាក្យនេះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[3326]។ ក្នុងបរិបទទំនាក់ទំនងជាលាយលក្ខណ៍អក្សរ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងស៊ីសង្វាក់គ្នាថា ទូរលេខ និងរបាយការណ៍ បានបញ្ជូនដោយមានចំណារថា "*អង្គការ*" ទៅកាន់មជ្ឈិមបក្ស[3327] និងផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3328] មិនមែន ប៉ុល ពត ទេ[3329]។ នៅពេលដែល អ.ជ.ស.ដ សន្និដ្ឋានជារួមថា វាត្រូវបានបញ្ជូនទៅកាន់ ប៉ុល ពត គឺដោយសារតែទូរលេខនោះបញ្ជាក់ថា វាត្រូវបញ្ជូនទៅ "បងប៉ុល"[3330] ឬ "បងប៉"[3331] មិនមែន*អង្គការ* ទេ។

948. ម្ចាស់បណ្តឹងសាទុក្ខក៏អះអាងមិនត្រឹមត្រូវផងដែរថា អ.ជ.ស.ដ បានប្រើពាក្យ *អង្គការ* ជាពាក្យជំនួសនៃពាក្យគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍[3332]។ អំណះអំណាងរបស់

---

[3324] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (សំអាងហេតុ)។

[3325] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣៥។ ការអះអាងស្រដៀងគ្នាត្រូវបានបដិសេធដោយ អ.ជ.ត.ក ក្នុងសំណុំរឿង ០០២/០១ (ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧២ *បដិសេធ* ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ១៤៤)។

[3326] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩។

[3327] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៩១ (ជើងទំព័រ ១៥៤៤-១៥៤៦), ៤៩២, ៣៨៩៩ (ជើងទំព័រ ១២៩៩៩) កថាខណ្ឌ ៣៩៦៦ (ជើងទំព័រ ១៣១៨០) កថាខណ្ឌ ៣៩៦ (ជើងទំព័រ ១៣១៨៧-១៣១៨៨)។

[3328] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៣៤ ជើងទំព័រ ៣១១៧ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៦ ជើងទំព័រ ១៣០៦៥។

[3329] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨ ជើងទំព័រ ១១៦៦, ១១៦៨។ សួត ទៀង និង ឌុច ពេលខ្លះបានប្រើពាក្យ *អង្គការ* សំដៅលើ ប៉ុល ពត ប៉ុន្តែមិនមែនក្នុងបរិបទនៃទំនាក់ទំនងរវាងភូមិភាគ/តំបន់ស្វយ័ត្ត និងមជ្ឈិមបក្សទេ។

[3330] ឯកសារ **E3/154** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ KH 00008494។ ឯកសារ **E3/885** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00020867។ ឯកសារ **E3/886** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00052846-48។ ឯកសារ **E3/1062** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ១៩៧៨ KH 00052864។

[3331] ឯកសារ **E3/244** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៣ ខែកមរា ឆ្នាំ១៩៧៨ KH 00001052-53។ ឯកសារ **E3/921** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៨ KH 00020943-44។ ឯកសារ **E3/922** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៨ KH 00020945។ ឯកសារ **E3/988** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧ KH 00020918។

[3332] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៦ (អង់គ្លេស) ទំព័រ ៦១ (បារាំង) ទំព័រ ៩៣-៩៤ (ខ្មែរ)។

គាត់ផ្អែកលើការអះអាងមិនត្រឹមត្រូវថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើការជាប់ពាក់ព័ន្ធរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងយុទ្ធនាការកំណត់អត្តសញ្ញាណ និងលុបបំបាត់ខ្សែរយៈខ្មាំង[3333] និងការតាមដាន និងការអនុវត្តគោលនយោបាយ ប.ក.ក ដោយគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍[3334] ផ្អែកទាំងស្រុងលើទូរលេខដែលបញ្ជូនទៅ*អង្គការ* ដូច្នេះ មិនបានពិចារណាភ័ស្តុតាងទាំងអស់ដែល អ.ជ.ស.ដ ផ្អែកលើទេ[3335]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញពីកំហុសណាមួយក្នុងនិយមន័យរបស់ អ.ជ.ស.ដ និងការប្រើប្រាស់ពាក្យ *អង្គការ* ដែល អាចនាំឱ្យមោឃភាពការសន្និដ្ឋានថា គាត់បានលើកទឹកចិត្ត និងជំរុញការអនុវត្តគោលបំណងរួម តាមរយៈការលើកកម្ពស់ប្រជាជនទូទៅឱ្យ "បំពេញ ឬបំពេញលើស" ផែនការសេដ្ឋកិច្ចបួនឆ្នាំរបស់*អង្គការ*[3336] និងបានអំពាវនាវឱ្យប្រជាជនបោះបង់ចោលមនោសញ្ចេតនាផ្ទាល់ខ្លួនដើម្បីជាប្រយោជន៍*អង្គការ*[3337]។

## *មូលដ្ឋានទី ១៩៤៖ វចនាសម្ព័ន្ធយោធា និងការប្រាស្រ័យទាក់ទង*[3338]

949. **គួរច្រានចោលមូលដ្ឋានទី ១៩៤ ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា មានទំនាក់ទំនងផ្អែកឋានានុក្រមរវាងយោធា គណៈកម្មាធិការមជ្ឈិម និងមជ្ឈិមបក្ស។**

---

[3333] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៣៤ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦២។

[3334] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៣៤ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៤។

[3335] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ១៥៤៨។ <u>ការជាប់ពាក់ព័ន្ធរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងយុទ្ធនាការកំណត់អត្តសញ្ញា និងលុបបំបាត់ខ្សែបណ្ដាញខ្មាំង៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០៣, ២៣១៣, ៣៧៦៩-៣៧៧០ (អង្គប្រជុំគណៈអចិន្ត្រៃយ៍ដែលម្ចាស់បណ្ដឹងសាទុក្ខបានចូលរួម "សមមិត្ត ហែម" ក្នុងនោះពិភាក្សាអំពីខ្មាំង ៣៧៧៥ (អង្គប្រជុំគណៈអចិន្ត្រៃយ៍ដែលម្ចាស់បណ្ដឹងសាទុក្ខបានចូលរួម) ៣៩៥៥-៣៩៦៥, ៣៩៦៧-៣៩៧២,៤២០៨, ៤២១៩-៤២៣៥, ៤២៥៨, ៤២៦០-៤២៦១, ៤២៦៩-៤២៧០, ៤២៧២, ៤២៧៣, ៤២៨៣-៤២៨៧។ <u>តួនាទីរបស់គណៈកម្មាធិកាមជ្ឈិមក្នុងការត្រួតពិនិត្យ និងអនុវត្តគោលនយោបាយរបស់ ប.ក.ក៖</u> ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥, ៣៩៦១។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣។

[3336] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៧។

[3337] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៨, ៤៣០៤។

[3338] <u>ទូទ្បីករណ៍ទី ១៩៤៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *វចនាសម្ព័ន្ធយោធា និងការប្រាស្រ័យទំនាក់ទំនង* កថាខណ្ឌ ១៦៤៤-១៦៤៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៦៧ (អង់គ្លេស) ទំព័រ ៦២ (បារាំង) ទំព័រ ៩៥-៩៦ (ខ្មែរ)។

950. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបង្ហាញពីកំហុសណាមួយ និងគ្រាន់តែលើកឡើងវិញពីការជំទាស់របស់ខ្លួនទៅនឹងការកំណត់និយមន័យរបស់ អ.ជ.ស.ដ នៃពាក្យមជ្ឈិមបក្ស ដែលរួមទាំងគណៈកម្មាធិការយោធា[3339]។ ទោះបីជា អ.ជ.ស.ដ ទទួលស្គាល់ថា ម្ចាស់បណ្តឹងសាទុក្ខមិនមានសិទ្ធិអំណាចយោធាផ្នែកប្រតិបត្តិក៏ដោយ[3340] ក៏ទោះជាយ៉ាងណាបានសម្រេចថា រូបគាត់បានដឹងអំពីបញ្ហាយោធាជាក់លាក់តាមរយៈវត្តមានរបស់គាត់នៅក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍[3341] អង្គប្រជុំធំៗ ឬការជួបជុំនៅភ្នំពេញ[3342] និងរបាយការណ៍ពីភូមិភាគមកកាន់មជ្ឈិមបក្ស ទាក់ទងនឹងស្ថានការណ៍ "ការពារជាតិ"[3343]។

951. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា បញ្ហាយោធាត្រូវបានរាយការណ៍ទៅកាន់មជ្ឈិមបក្ស[3344]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា របាយការណ៍ពី សុន សេន និង កងពល ៩២០ ដែលបញ្ជូនទៅកាន់*អង្គការ* បញ្ជូនទៅតែ ប៉ុល ពត ប៉ុណ្ណោះ[3345]។ ដូចបានកត់សម្គាល់ខាងលើ ពាក្យ *អង្គការ* មិនសំដៅជាពិសេសលើតែ ប៉ុល ពត នោះទេ ប៉ុន្តែសំដៅលើមជ្ឈិមបក្ស[3346] ហើយលើសពីនេះទៀត ផ្អែកលើការពិនិត្យភ័ស្តុតាង*ទាំងមូល* ទូរលេខភាគច្រើនបានចម្លងជូនទៅកាន់មេដឹកនាំ ប.ក.ក ជាច្រើន និងមន្ទីរ ៨៧០[3347]។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងការសន្និដ្ឋានពាក់ព័ន្ធបន្ថែមទៀត ដូចជាអង្គហេតុដែលថា សុន សេន បានជូនដំណឹងទៅមេដឹកនាំ ប.ក.ក អំពីកិច្ចការយោធា និង បញ្ហា

---

[3339] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤៤, ៤៦១-៤៦២។ *សូមមើល* ចម្លើយតបទៅនឹមូលលដ្ឋានទី ១៩០។

[3340] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៩៥។

[3341] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៨ (ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមកិច្ចប្រជុំជាច្រើន ដែលព្រលានយន្តហោះកំពង់ឆ្នាំត្រូវបានពិភាក្សា) ៥០៨ (សុន សេន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលរូបគាត់បានរាយការណ៍ពីកិច្ចការយោធា និងការការពារជាតិ *យោង* ឯកសារ **E3/229** អង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ **E3/217** អង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ១៩៧៦)។ *សូមមើល* ចម្លើយតបទៅនឹងមូលលដ្ឋានទី ២១៥។

[3342] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥១០ ជើងទំព័រ ១៥៩៦។

[3343] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦២-៣៩៦៤។

[3344] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤៦-១៦៤៧ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥០៨, ៣០៤៧, ៤០៧០។

[3345] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤៦-១៦៤៨។ *សូមមើល* ចម្លើយតបទៅនឹងមូលលដ្ឋានទី ១៩១។

[3346] *សូមមើល* ចម្លើយតបទៅនឹងទឡ្ហីករណ៍១៩១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤៦។

[3347] *សូមមើល* ចម្លើយតបទៅនឹងមូលលដ្ឋានទី ១៩០។

ទាក់ទងនឹងការការពារជាតិ[3348]។ ម្ចាស់បណ្ដឹងសាទុក្ខក៏មើលរំលងផងដែរនូវសក្ខីកម្មគួរ ឱ្យជឿជាក់របស់ សៅ សារុន[3349] ដែលលើកឡើងយ៉ាងច្បាស់ថា "កងពលគេមានសិទ្ធិ [បាន] រាយការណ៍ទៅមជ្ឈិម"[3350]។

952. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា តាមរយៈការបង្កើតកងទ័ពបដិវត្តកម្ពុជា កងពលយោធាភូមិភាគជាច្រើនត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម និងជាពិសេស សេនាធិការ[3351]។ ម្ចាស់បណ្ដឹងសាទុក្ខបំភ្លៃសក្ខីកម្ម[3352] ដោយហេតុថា គង់ គីម, ឡាញ់ ដុស និង Stephen Heder ពិតជាបានលើកឡើងថា អង្គភាពយោធាជាក់លាក់ ("កងពលមជ្ឈិម") ស្ថិតនៅក្រោមសេនាធិការ[3353]។ ម្ចាស់បណ្ដឹងសាទុក្ខក៏ខកខានមិនបានពិចារណាលើភស្តុតាងទាំងអស់ដែល អ.ជ.ស.ដ ផ្អែកលើ ដោយមិនបានពិចារណាសក្ខីកម្មរបស់ ឌុច ដែលកត់សម្គាល់អំពីឋានានុក្រមយោធាទាក់ទងនឹងសេនាធិការ និង គណៈកម្មាធិការមជ្ឈិម[3354] ក៏ដូចជា ភស្តុតាងឯកសារដែលគាំទ្រការសន្និដ្ឋានថា ការបង្កើតកងទ័ពបដិវត្តកម្ពុជា បាននាំឱ្យកងពលយោធាមួយចំនួនស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម[3355]។

---

[3348] ការសន្និដ្ឋាននេះផ្អែកលើកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥០៨ ជើងទំព័រ ១៥៨៨។

[3349] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០៤០ *យោង* ឯកសារ **E1/83.1** សៅ សារុន ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 10.12.13-10.13.23 ទំព័រ ២២ បន្ទាត់ ២២-ទំព័រ ២៣ បន្ទាត់ ១។

[3350] ឯកសារ **E1/83.1** សៅ សារុន ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 10.12.13-10.13.23 ទំព័រ ២២ បន្ទាត់ ២២-២៣។

[3351] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៤៥ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤ *សូមមើលផងដែរ* កថាខណ្ឌ ៤២៧។

[3352] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៤៥។

[3353] *សូមមើល* **E1/138.1** គង់ គីម ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 15.34.54-15.49.49 ទំព័រ ៩១ បន្ទាត់ ១៤-ទំព័រ ៩៥ បន្ទាត់ ៩។ ឯកសារ **E3/70** កំណត់ហេតុស្ដាប់ចម្លើយ ឡាញ់ ដុស ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ KH 00404633-35។ ឯកសារ **E1/222.1** Stephen Heder ប្រតិចារឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 14.06.49-14.08.44 ទំព័រ ៥៥ បន្ទាត់ ២៣- ទំព័រ ៥៦ បន្ទាត់ ៥។

[3354] ឯកសារ **E1/53.1** កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ម៉ោង 10.13.11-10.15.16 ទំព័រ ១៩ បន្ទាត់ ១-៥។

[3355] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤ ជើងទំព័រ ១២៨២ *យោង* ឯកសារ **E3/49** អត្ថបទនិពន្ធដោយ Timothy Carney មានចំណងជើងថា "*ការរៀបចំអំណាច*" នៅក្នុង Karl Jackson (កែសម្រួល) *កម្ពុជា*

## គ. សហឧក្រិដ្ឋកម្មរួម

953. អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ តាមរយៈសហឧក្រិដ្ឋកម្មរួម[3356] ដែលជាលទ្ធផល (i) ការចូលរួមរបស់គាត់ក្នុងគោលបំណងរួម[3357] ដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលរូបគាត់ត្រូវបានផ្តន្ទាទោសអនុលោមតាមសហឧក្រិដ្ឋកម្មរួម[3358]។ (ii) ការចូលរួមចំណែកក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ[3359] និង (iii) ចេតនាចូលរួមរបស់គាត់ជាមួយសមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងទៀតក្នុងការចូលរួមក្នុងគោលបំណងរួម និងប្រព្រឹត្តឧក្រិដ្ឋកម្មជាមូលដ្ឋាន និងដែលគ្របដណ្តប់ដោយគោលបំណងនោះ[3360]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវទៀតថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងអនុលោមតាមគោលនយោបាយ ប.ក.ក ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងគោលបំណងរួម[3361]។

---

*១៩៧៥-១៩៧៨៖ ការណាត់ជួបនឹងសេចក្តីស្លាប់* EN 00105137 (ភាសាអង់គ្លេស)។ ឯកសារ **E3/1593** សៀវភៅនិពន្ធដោយ Benedict Kiernan មានចំណងជើងថា *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និងអំពើប្រល័យ ពូជសាសន៍ក្នុងប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម ឆ្នាំ ១៩៧៥-៧៩* KH 006637498-99។ *សូមមើលផងដែរ* ឯកសារ **E3/5** *ទង់បដិវត្តន៍* ខែសីហា ឆ្នាំ១៩៧៥ KH 003557569។ ឯកសារ **E3/405** កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.១។ ឯកសារ **E3/407** កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.៤។ ឯកសារ **E1/159.1** ឆោម សែ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ម៉ោង 13.50.36-14.05.57, 14.09.51-14.13.52។

[3356] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦។

[3357] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦។

[3358] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦, ៤៣៣១។

[3359] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦។

[3360] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៩-៤៣០៥។

[3361] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨។ សហព្រះរាជអាជ្ញាកត់សម្គាល់ពីភាពមិនច្បាស់លាស់របស់ អ.ជ.ស.ដ នៅក្នុងការប្រើប្រាសពាក្យ "គោលបំណងរួម" ក្នុងការយោងទៅលើទាំង (i) គោលបំណងចំបងនៃគោលបំណងរួម (*សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៨, ៣៩៨៧, ៣៩៩៨, ៤០១២, ៤០២២, ៤០៦១, ៤០៦៧, ៤០៦៨, ៤២៥៦) និង (ii) គោលបំណងឧក្រិដ្ឋរួមទាំងមូល*គឺ* គោលបំណងចំបង និងមធ្យោបាយឧក្រិដ្ឋ គឺជាគោលនយោបាយទាំងប្រាំដែល ប.ក.ក បានស្វែងរកដើម្បីសម្រេចបាននូវគោលបំណងចំបងនោះ (*សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០៨-៣៧១២, ៤០៦៨, ៤០៧៣)។ ប្រសិនបើមិនដកស្រង់ពី អ.ជ.ស.ដ ទេ សហព្រះរាជអាជ្ញានឹងប្រើពាក្យទាំងអស់នេះ - ដូចដែល អ.ជ.ត.ក ប្រើក្នុង ឯកសារ

954. ក្នុងការជំទាស់ទៅនឹងការផ្តន្ទាទោសគាត់ផ្អែកលើការទទួលខុសត្រូវតាមទម្រង់សហឧក្រិដ្ឋកម្មរួម ការវិភាគផ្នែកច្បាប់របស់ម្ចាស់បណ្តឹងសាទុក្ខលើធាតុផ្សំសហឧក្រិដ្ឋកម្មរួមកំណត់ត្រឹមទម្រង់សហឧក្រិដ្ឋកម្មរួម ដែលគោលបំណងរួម*បង្កើតបានជា* ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3362] ជាជាងការពិចារណាទម្រង់សហឧក្រិដ្ឋកម្មរួម ដែលរូបគាត់គឺជាសមាជិកម្នាក់ *ជាប់ពាក់ព័ន្ធក្នុង* ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3363]។ ដូចដែលបានសម្រេចពីមុនដោយ អ.ជ.ត.ក និងដូចដែលម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់[3364] គោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋឡើយ ដែលឧក្រិដ្ឋកម្មគឺជា*មធ្យោបាយ* ដើម្បីសម្រេចបានគោលដៅលាក់កំបាំងនោះ[3365]។ ដូច្នេះ គោលដៅក្នុងការសម្រេចបានបដិវត្តន៍សង្គមនិយម ត្រូវតែវាយតម្លៃរួម ជាមួយនឹងមធ្យោបាយ ដែលប្រើដើម្បីសម្រេចបានគោលដៅនោះ គឺ គោលនយោបាយ ប.ក.ក ដែលជាប្រធានបទនៃសំណុំរឿង០០២/០២[3366]។

955. ក្នុងសារណារបស់គាត់ទាំងមូល ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងពីការបកស្រាយភាន់ច្រឡំ និងមិនត្រឹមត្រូវថែមទៀតអំពីគោលបំណងរួម ដោយការយោង*តែ* ទៅលើគោលដៅរបស់វា ដោយមើលរំលងមធ្យោបាយ។ ទោះជាយ៉ាងណាក៏ដោយ ការព្យាយាមរបស់គាត់ក្នុងការបំបែកគោលនយោបាយចេញពីបដិវត្ត នាំឱ្យមានការបែងចែកដោយមិនត្រឹមត្រូវ និងក្លែងក្លាយ ដោយហេតុថា គោលបំណងរួម *រួមទាំង* គោលដៅ និងមធ្យោបាយ។ មិនមានត្រង់ណានៅក្នុងអំណះអំណាងដ៏វែងអន្លាយរបស់គាត់[3367] បានពន្យល់ពីរបៀបដែលការកំណត់របស់ អ.ជ.ស.ដ ថា ភាពឧក្រិដ្ឋនៃសហឧក្រិដ្ឋនោះត្រូវបានបង្ហាញនៅក្នុងគោលនយោបាយទាំងនោះថា "*មានទំនាក់ទំនងយ៉ាងជិត*

---

**F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៨៩, ៨០៧-៨០៨, ៨១៥-៨១៦ – ក្នុងន័យទីពីរ ត្រង់ចំណុចដែល "គោលបំណងរួម" គ្របដណ្តប់ទាំងគោលបំណងចំបង *និង* មធ្យោបាយឧក្រិដ្ឋដើម្បីសម្រេចបានគោលបំណងនោះ។

[3362] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៩។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៤ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨-៤០៧៥។

[3363] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០៨-៣៧០៩ (គោលបំណងរួមត្រូវមានគោលដៅចម្បង (មួយក្នុងចំណោម) គោលដៅចំបងនានារបស់វា នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ (*ពោលគឺ* "ស្មើនឹង") ឬត្រូវបានគិតទុកជាមុនថា ការប្រព្រឹត្តបទឧក្រិដ្ឋ គឺជាមធ្យោបាយសម្រេចគោលដៅ ដែលគោលដៅនោះមិនតម្រូវថាត្រូវតែមានលក្ខណៈឧក្រិដ្ឋនោះឡើយ (*ពោលគឺ* "ជាប់ពាក់ព័ន្ធ"))។

[3364] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៤១-១៩៤២, ១៩៥១។

[3365] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៨៩, ៨០៧-៨១០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៣០០។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ៧៦, ៨០។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៤៦។

[3366] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨១៥។

[3367] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៧៥, ១៩៨១-២០០០។

*ស្និទ្ធជាមួយនឹងគោលបំណងរួម ហើយមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម*"[3368] អាចបរាជ័យក្នុងការបំពេញលក្ខខណ្ឌតម្រូវដែលថា គោលបំណងរួម*ជាប់ពាក់ព័ន្ធ* ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ វាអាចផ្ទុយទៅនឹងហេតុផលសមរម្យ ហើយដូចដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង[3369] នៅក្នុងសំណុំរឿង ០០២/០១ ដែល អ.ជ.ត.ក បានជំទាស់ទៅនឹងការកំណត់បែបនេះរួចទៅហើយ[3370]។

956. ដូចបានរៀបរាប់លម្អិតខាងក្រោម ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ និងអង្គច្បាប់ នៅក្នុងការសន្និដ្ឋានរបស់ខ្លួនពាក់ព័ន្ធនឹងគោលបំណងរួម ការចូលរួមចំណែកដ៏សំខាន់របស់គាត់ក្នុងឧក្រិដ្ឋកម្ម និងចេតនារបស់គាត់ក្នុងការចូលរួមក្នុងឧក្រិដ្ឋកម្មដែលជាមូលដ្ឋាននៃគោលបំណងរួមទេ។

## ១. គោលបំណងរួម

957. អ.ជ.ស.ដ បានវិភាគយ៉ាងត្រឹមត្រូវលើគោលដៅនៃគោលបំណងរួមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈ "មហាលោតផ្លោះមហាអស្ចារ្យ" ដែលត្រូវបានបង្កើតឡើងដើម្បីកសាងប្រទេស ការពារប្រទេសពីខ្មាំង និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយជាសង្គមខ្មែរដែលមិនមានសាសនា និងរួមគ្នាមួយ មានតែវណ្ណៈកម្មករ-កសិករ[3371]។ លើសពីនេះទៀត ផ្អែកលើឯកសារភស្តុតាងជាច្រើន អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា គោលនយោបាយឧក្រិដ្ឋទាំងប្រាំ[3372] ដែលជាមធ្យោបាយដើម្បីសម្រេចបានគោលដៅ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងគោលបំណងរួម។

958. មូលដ្ឋានចំនួន ១០ របស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងទៅនឹងគោលបំណងរួម បរាជ័យ[3373]។ ទោះជាគាត់ព្យាយាមបង្ហាញខ្លួនគាត់ថាជាអ្នកដែលស្មោះត្រង់ទៅនឹងផែនការនយោបាយដ៏មនុស្សធម៌ ដែលមានគោលបំណងតែធ្វើឱ្យបានល្អបំផុតសម្រាប់ប្រជាជនកម្ពុជានោះ អំណះអំណាងរបស់គាត់មើលរំលងលើវិសាលភាពនៃភស្តុតាង ហើយគ្រាន់តែជំទាស់នឹងសេចក្តីសន្និដ្ឋានរបស់

---

[3368] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨ (គូសបញ្ជាក់បន្ថែម)។

[3369] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៨៧-១៩៩០។

[3370] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨១៥។ *សូមមើលបន្ថែមទៀត* កថាខណ្ឌ ៨១៦ ("និយាយម្យ៉ាងទៀត ដោយសារតែគោលបំណងនេះ ត្រូវបានសម្រេចតាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋ ដែលកើតចេញពីគោលនយោបាយ គោលដៅនៃការកសាងបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា គឺជាបទឧក្រិដ្ឋពិតប្រាកដមែន")។

[3371] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨។

[3372] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៣-៤០៧៤។

[3373] ទទ្បីករណ៍ ១៧៥-១៧៩, ១៨០-១៨១, ១៨៣-១៨៤, ១៨៩។

អ.ជ.ស.ដ។ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខអះអាងយ៉ាងមុតមាំ និងមិនត្រឹមត្រូវថា ដោយសារតែគោលដៅចម្បងនៃគោលបំណងរួមមិនមានតម្លៃស្មើទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម គាត់ត្រូវបានផ្តន្ទាទោសខុសចំពោះការទទួលខុសត្រូវតាមទម្រង់សហឧក្រិដ្ឋកម្មរួម ហើយ អ.ជ.ស.ដ ពិតជាតាំងចិត្តចោទប្រកាន់គាត់។ ការយល់ខុសនេះបណ្តាលឱ្យគាត់ចោទប្រកាន់ អ.ជ.ស.ដ ដដែលៗអំពីភាពលម្អៀង ដែលចោទប្រកាន់មិនរើសមុខថា អ.ជ.ស.ដ បានមើលរំលងបរិបទ និងភស្តុតាងដោះបន្ទុក និងបានបំភ្លៃច្បាប់ដើម្បីផ្តន្ទាទោសគាត់ ដោយមិនបានបដិសេធសច្ចធារណ៍នៃអនាគតិតុលាការ[3374]។

## *មូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤ ៖ កំហុសអំពីគោលបំណងរួមដែលចោទប្រកាន់ និងផែនការបដិវត្តសង្គមនិយមរបស់ ប.ក.ក*[3375]

959. **មូលដ្ឋាននីមួយៗក្នុងចំណោមមូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, និង ២២៤ បរាជ័យ ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ (i) កំណត់និយមន័យខុសនៃពាក្យ "គោលបំណងរួម" ក្នុងសហឧក្រិដ្ឋកម្មរួម[3376] (ii) មានកំហុសក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មស្ថិតនៅ**

---

[3374] *សូមមើល* ចម្លើយតបទៅនឹងមូលលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤។

[3375] <u>មូលលដ្ឋានទី ១៨៩៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសទាក់ទងនឹងគោលបំណងរួមដែលបានចោទប្រកាន់* កថាខណ្ឌ ១៥៩៣-១៦០៣។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៥ (អង់គ្លេស) ទំព័រ ៦០ (បារាំង) ទំព័រ ៩២-៩៣ (ខ្មែរ)។ <u>មូលលដ្ឋានទី ១៧៥៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងផែនការបដិវត្តសង្គមនិយមរបស់ ប.ក.ក* កថាខណ្ឌ ១៣៩៩-១៤០៧។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃ សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងអង្គច្បាប់* ទំព័រ ៦១ (អង់គ្លេស) ទំព័រ ៥៦ (បារាំង) ទំព័រ ៨៦-៨៧ (ខ្មែរ)។ មូលលដ្ឋានទី<u>១៧៦៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសទាក់ទងនឹងខ្លឹមសារ "បដិវត្តន៍សង្គមនិយម"* កថាខណ្ឌ ១៤០៩-១៤២៧។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦១ (អង់គ្លេស) ទំព័រ ៥៦ (បារាំង) ទំព័រ ៨៧ (ខ្មែរ)។ មូលលដ្ឋានទី<u>១៧៧៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការផ្សព្វផ្សាយផែនការនយោបាយនៃ "បដិវត្តន៍សង្គមនិយម"* កថាខណ្ឌ ១៤២៨-១៤៣៧។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃ សារណាបណ្តឹងសាទុក្ខ ទំព័រ ៦១-៦២ (អង់គ្លេស) ទំព័រ ៥៦-៥៧ (បារាំង) ទំព័រ ៨៧-៨៨ (ខ្មែរ)។ <u>មូលលដ្ឋានទី ២២៤៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ចរិតឧក្រិដ្ឋនៃគោលបំណងស្ថិត ត្រង់ធាតុផ្សំសត្យានុម័តិ* កថាខណ្ឌ ១៩៣៨-១៩៥៦ និង *លំដាប់លំដោយព្រឹត្តិការណ៍នៃ JCE និងនិយមន័យគោលបំណងរួម* កថាខណ្ឌ ១៩៦៦-២០០០, ២០០៥-២០០៧។ ឯកសារ **F54.1.1** ឧបសម្ពន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៥ (អង់គ្លេស) ទំព័រ ៧០ (បារាំង) ទំព័រ ១០៨ (ខ្មែរ)។ សម្គាល់៖ ទិដ្ឋភាពនៃមូលលដ្ឋានទី ២២៤ ដែលទាក់ទងនឹងការចូលរួមចំណែករបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងគោលបំណងរួម ត្រូវបានឆ្លើយតបក្នុងបរិបទនៃមូលលដ្ឋានទី ២២៦។

[3376] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៨, ៤០៦៨-៤០៧៤។ ម្ចាស់បណ្តឹងសាទុក្ខធ្វើឱ្យជឿនជឿនទៅមុខម្តងហើយម្តងទៀតនូវការបកស្រាយខុសនៃឃ្លា "គោលបំណងរួម" ផ្តោតតែទៅលើធាតុផ្សំដែលទាក់ទងនឹងទៅនឹង *គោលដៅ* នៃការសម្រេចបានបដិវត្តន៍សង្គមនិយម ខណៈដែលមើលរំលងធាតុផ្សំទាក់ទងនឹង *មធ្យោបាយ* ដែលគោលដៅនោះ

**ក្រោមគោលបំណងរួម (iii) បកស្រាយភស្តុតាងមិនត្រឹមត្រូវ ឬធ្វើការសន្និដ្ឋានមិនសមហេតុផល (iv) លម្អៀងក្នុងការពិនិត្យភស្តុតាង ឬ (v) ទៅហួសពី *បណ្តឹង* របស់ខ្លួន[3377]។**

*អ.ជ.ស.ដ បានកំណត់និយមន័យគោលបំណងរួមយ៉ាងត្រឹមត្រូវ[3378]*

960. អ.ជ.ស.ដ បានណែនាំមួយផ្នែកដោយពាក្យពេចន៍របស់ម្ចាស់បណ្តឹងសាទុក្ខ បានកំណត់និយមន័យគោលបំណងរួមយ៉ាងត្រឹមត្រូវ[3379] ដែលថាជាការអនុវត្តបដិវត្តន៍សង្គមនិយមឱ្យបានឆាប់រហ័សនៅកម្ពុជា តាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" ដែលបានរៀបចំឡើងដើម្បីកសាងប្រទេស ការពារប្រទេសពីខ្មាំង និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយជាសង្គមខ្មែរដែលមិនមានសាសនា និងរួមគ្នាមួយមានតែវណ្ណៈកម្មករ-កសិករ[3380]។ អ.ជ.ស.ដ ទទួលស្គាល់ថា បដិវត្តន៍សង្គមនិយម

---

ត្រូវបានសម្រេច។ ដូចក្នុងករណីនេះ ត្រង់ចំណុចដែល JCE ដែល*ពាក់ព័ន្ធទៅនឹង* ការប្រព្រឹត្តឧក្រិដ្ឋកម្មអាចមានគោលដៅចំបងមិនមានលក្ខណៈឧក្រិដ្ឋ តែនៅតែមានលក្ខណៈឧក្រិដ្ឋ ក្នុងករណីដែលឧក្រិដ្ឋកម្មគឺជា*មធ្យោបាយ* ក្នុងការសម្រេចបានគោលដៅបង្កប់នោះ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨ *យោង*ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៨៩, ៨០៧-៨១០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៣០០។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ៧៦, ៨០។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៩៦។

[3377] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩០១-១៩០២។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ បានទៅហួស*បណ្តឹង*របស់ខ្លួន គឺមិនត្រឹមត្រូវទេ *សូមមើល* ផ្នែក VI. *បណ្តឹង* និងវិសាលភាពនៃការជំនុំជម្រះ។ ខណៈដែលចៅក្រមទទួលបានបណ្តឹងយ៉ាងត្រឹមត្រូវ ពួកគេអាចពិចារណាលើអង្គហេតុ ដែលម្ចាស់បណ្តឹងសាទុក្ខជំទាស់ (*សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ២៦៩២ *យោង* កថាខណ្ឌរបស់គាត់ ៣៨០-៥៩៩ *ដែលឆ្លើយតបទៅ*ក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ៩១-៨៤ ខាងលើ) ក្នុងការកំណត់គោលបំណងរួម។ ការអះអាងរបស់គាត់ថា អ.ជ.ស.ដ កំណត់ប្រភេទខុសនៃបទល្មើសរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏បរាជ័យផងដែរ ដោយហេតុថា អ.ជ.ស.ដ បានលើកឡើងយ៉ាងច្បាស់ថា ការប្រើប្រាស់ភស្តុតាងនៃការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងការគាំទ្របទចោទព្រហ្មទណ្ឌណាមួយ "គឺជាការកំណត់ប្រភេទបទល្មើសឡើងវិញចំពោះអង្គហេតុ [...] មិនអាចធ្វើទៅបាន" (*សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៨) និង ហេតុដូច្នេះ បានកំណត់យ៉ាងត្រឹមត្រូវនូវការប្រើប្រាស់របស់ខ្លួនចំពោះភស្តុតាងនេះ។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩០៧, ១៩០២ ជើងទំព័រ ២៦៤៦ *យោង* កថាខណ្ឌ ១២៦២-១២៦៣។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣, ១៧០។

[3378] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ២២៤។ *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៣, ១៩០០, ១៩២៤, ១៩២៦, ១៩២៧, ១៩៣៨-១៩៥៦, ១៩៦៦-២០០០, ២០០៤-២០០៧។

[3379] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៤-១៥៩៥។

[3380] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៣, ៤០៦៨។ *សូមមើលផងដែរ* កថាខណ្ឌ ៣៧៣៥-៣៧៤២ *ជាពិសេស* ៣៧៣៥ (មាគ៌ានយោបាយ ប.ក.ក គឺត្រូវបង្កើតសង្គមគ្មានវណ្ណៈ ការពារប្រទេស) ៣៧៣៦ (នៅក្នុងកិច្ចប្រជុំ ១០ថ្ងៃ នៅវត្តប្រាក់ អាទិភាពផ្តល់ឱ្យទៅលើការកសាងប្រទេសឱ្យបានឆាប់ និងការពារប្រទេស ដោយការបង្កើតសហករណ៍ និងការសាងសង់ទំនប់ និងប្រឡាយ។ នៅកិច្ចប្រជុំមួយផ្សេងទៀត ប៉ុល ពត និង មេដឹកនាំជាន់ខ្ពស់ផ្សេងទៀត បាន

នេះផ្ទាល់ មិនជាឧក្រិដ្ឋទេ[3381] ហើយបន្ទាប់មកធ្វើការវិភាគភ័ស្តុតាងជាច្រើនដើម្បីកំណត់ថាតើវាទោះជាយ៉ាងណា*ជាប់ពាក់ព័ន្ធក្នុង* ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬយ៉ាងណា[3382] ដោយវាពិតជាជាប់ពាក់ព័ន្ធមែន[3383]។ ដោយយោងទៅលើការរីករាលដាលនៃឧក្រិដ្ឋកម្ម វិធីសាស្ត្រស្រដៀងគ្នាដែលប្រើដើម្បីអនុវត្តឧក្រិដ្ឋកម្មទាំងអស់នោះ កណ្តាប់ដៃដែកដែលមេដឹកនាំប្រើលើថ្នាក់ក្រោមរបស់ខ្លួន វចនាសម្ព័ន្ធទំនាក់ទំនងតាមឋានានុក្រម និងផ្សេងពីគ្នា និងសេចក្តីថ្លែងការណ៍ និងសកម្មភាពដែលបង្កភាពភ័យខ្លាច និងការស្អប់ខ្ពើមចំពោះក្រុមជាក់លាក់ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងសមហេតុផលថា គោលបំណងរួមត្រូវបានអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលដោយខ្សែបណ្តាញរដ្ឋបាលទាំងមូលរបស់បក្ស តាមរយៈការអនុវត្តគោលនយោបាយប្រាំ[3384]។ គោលនយោបាយទាំងអស់នេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងគោលបំណងរួម និងជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលម្ចាស់បណ្តឹងសាទុក្ខត្រូវផ្តន្ទាទោស[3385]។ ដោយសារតែការអនុវត្តគោលបំណងរួមមិនអាចចែកដាច់ពីឧក្រិដ្ឋកម្ម ដូច្នេះវាមានលក្ខណៈឧក្រិដ្ឋ[3386]។

961. ការផ្តោតរបស់ម្ចាស់បណ្តឹងសាទុក្ខលើគោលបំណងរួមមិនមែនជាឧក្រិដ្ឋដែលបានចោទឡើងនេះ និងថា ឧក្រិដ្ឋកម្ម "ចាកឆ្ងាយ" ពីគោលបំណងរួម[3387] មានភាពអរូបី មិនពាក់ព័ន្ធ និងមើលរំលង

---

ណែនាំអំពីក្រុមខ្មាំង និងការប្រព្រឹត្តរបស់ពួកគេ) ៣៧៣៩ (ម្ចាស់បណ្តឹងសាទុក្ខបានលើកម្ពស់គោលដៅនៃការសម្រេចបានមហាលោតផ្លោះមហាអស្ចារ្យ) ៣៧៤១ (នៅក្នុងការប្រជុំថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ដែលរាយការណ៍បានចូលរួមដោយសមាជិកគណៈមជ្ឈិម ប៉ុល ពត បានបញ្ជាក់ពីការអភិវឌ្ឍន៍រដ្ឋកម្មករ-កសិករ ដោយផ្អែកលើសមូហភាពនិយម និងការតស៊ូវណ្ណៈសង្គមនិយម ភាពចាំបាច់ក្នុងការការពារ និងកសាងប្រទេសឱ្យបានឆាប់រហ័សតាមរយៈសហករណ៍ និងការផ្តួចផ្តើមការងារកសាង និងការប្រឆាំងនឹងចក្រពត្តិនិយម សក្តិភូមិនិយម មូលធននិយម ប្រតិកិរិយា សមាសភាពប្រឆាំងនឹងបដិវត្តន៍ និងខ្មាំងជារួម) ៣៧៤២ (មាគ៌បក្សនេះត្រូវបានគាំទ្រដោយមេដឹកនាំជាន់ខ្ពស់ រួមទាំងម្ចាស់បណ្តឹងសាទុក្ខ)។

[3381] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៣។

[3382] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែក ១៦.៣ (ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត) ១៦.៤ (ការអនុវត្តគោលបំណងរួម) ជាពិសេស ១៦.៤.១.២, ១៦.៤.២.២, ១៦.៤.៣.១.២, ១៦.៤.៣.២.២, ១៦.៤.៣.៣.២, ១៦.៤.៣.៤.២ និង ១៦.៤.៤.២ ដែលទាំងអស់នេះពិភាក្សាអំពីភាពឧក្រិដ្ឋនៃគោលនយោបាយនោះ។

[3383] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៨, ៤០៦៨-៤០៧៤។

[3384] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨។ អត្ថិភាព និងការអនុវត្តគោលនយោបាយត្រូវបានលម្អិតខាងក្រោម *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨, ១៧៩, ១៨០, ១៨១, ១៨៣, ១៨៥-១៨៨។

[3385] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨-៤០៧៤។

[3386] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[3387] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២៥-១៤២៦, ១៤៣២, ១៥៩៤-១៥៩៥, ១៥៩៨។

ការពិត។ ប.ក.ក ផ្តោតលើការធានាឱ្យមានការត្រួតត្រាទាំងស្រុង ស្របតាមមនោគមន៍វិជ្ជារបស់ខ្លួន ដូច្នេះ មេដឹកនាំ ប.ក.ក ប្រកាន់ខ្ជាប់នូវបេសកកម្មនៃការធ្វើមនោគមន៍វិជ្ជា ការធ្វើមីទ្ទីងនៅចំពោះមុខមនុស្សរាប់ពាន់នាក់ និងវគ្គអប់រំសម្រាប់កម្មាភិបាល ដែលក្នុងនោះ គោលបំណងរួមត្រូវបានធ្វើម្តងហើយម្តងទៀត *ជាអនន្តភាព*[3388] ការអនុវត្តវិធានការញុះញុងបដិវត្តន៍ដើម្បីសម្រេចបានគោលបំណងរួម[3389] បង្គាប់ឱ្យរាល់ស្ថាប័នរដ្ឋទាំងអស់ស្ថិតក្រោមបក្ស[3390] និង "ប្រឆាំងដាច់ខាត" វណ្ណប្រឆាំងបដិវត្ត[3391]។ ម្ចាស់បណ្តឹងសាទុក្ខស្ថិតនៅក្នុងចំណោមមេដឹកនាំបក្ស ដែលបានចូលរួមក្នុងការធ្វើការឃោសនាឥតឈប់ឈរអំពីគោលបំណងរួម បានធ្វើសន្ទរកថាពីថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ ដើម្បីគាំទ្រមាគ៌ាបក្ស[3392]។

962. មេដឹកនាំ ប.ក.ក មានភាពច្បាស់លាស់ហួសកម្រិតនៅក្នុងវិធីរបស់ខ្លួនដើម្បីសម្រេចបានគោលបំណងរួម។ មិនថាវាធ្វើឱ្យ "បោះជំហានលើដំណើរបដិវត្តន៍សង្គមនិយម"[3393] ធ្វើឃោធូបនីយកម្ម "កាន់តែខ្ពស់ និងឆាប់រហ័សថែមទៀត"[3394] "វាយសម្រុក"[3395] "ការពារ និងកសាងប្រទេស ឱ្យបានឆាប់រហ័ស"[3396] ឬ បន្ត "ខិតខំ [...] យ៉ាងឆាប់រហ័ស"[3397] ឬយ៉ាងណា បក្សបានព្យាយាម

[3388] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦, ៣៧៤១។

[3389] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ ១២៤៧០ (សភា "សភាសម្រេចជាឯកច្ឆ័ន្ទ ក្នុងការប្រមូល "ប្រជាជនទាំងមូល" មកបង្កបង្កើនផលស្រូវឱ្យបានច្រើនជាអតិបរមា "ឱ្យកាន់តែខ្ពស់ និងឆាប់រហ័សថែមទៀត" ដើម្បីកសាងប្រទេសឱ្យសម្រេចបាន "មហាលោតផ្លោះមហាអស្ចារ្យ"")។

[3390] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ("នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈកម្មាធិការមជ្ឈិម ប.ក.ក បានប្រកាសពីអង្គការរដ្ឋទាំងអស់ រួមទាំងរដ្ឋាភិបាលដែលស្ថិតក្រោមបក្ស")។

[3391] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៨-៣៧៣៩។

[3392] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤២ ជើងទំព័រ ១២៤៨៩ និងការយោងសំអាងទាំងអស់ក្នុងនោះ។

[3393] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៨ ជើងទំព័រ ១២៤៦៦ និងការយោងសមអាងទាំងអស់នៅក្នុងនោះ។

[3394] **E3/165** ឯកសារស្តីពីអង្គប្រជុំសន្និបាតរបស់សភា ចុះថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ KH 00053639, 00053644, *យោងក្នុង*ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ ១២៤៧០។

[3395] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ ១២៤៧១, ១២៤៧២ និងការយោងសំអាងទាំងអស់នៅក្នុងនោះ។

[3396] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦, ៣៧៤១ ជើងទំព័រ ១២៤៥៩, ១២៤៨៣ និងការយោងសំអាងទាំងអស់នៅក្នុងនោះ។

[3397] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៨ ជើងទំព័រ ១២៤៦៦ *យោង* **E3/130** លក្ខន្តិកៈ ប.ក.ក គ្មានកាលបរិច្ឆេទ (មាត្រា ១-៥)។

ដើម្បីសម្រេចបាន "សន្ទុះមហាលោតផ្លោះ"[3398]។ ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងផ្ទាល់បានណែនាំអំពីការសម្រេចបានគោលដៅនេះ មិនមែនតាមរយៈមធ្យោបាយបែបមនុស្សធម៌ទេ ប៉ុន្តែតាមរយៈការបំពេញមាគ៌ាបក្ស "*ដាដាច់ខាត*"[3399]។ ដូចដែលបានបង្ហាញនៅក្នុងចម្លើយតបនេះ ភាពដាច់ខាតនោះខ្ពស់ខ្លាំងពេក ហើយប្រជាជនកម្ពុជាទាំងមូលត្រូវបានបង្ខំឱ្យធ្វើដើម្បីសម្រេចបាន។

963. ក្នុងការលើកឡើងអំពីគោលបំណងរួម អង្គជំនុំជម្រះបានផ្អែកជាពិសេសលើសក្ខីកម្មផ្ទាល់របស់ម្ចាស់បណ្តឹងសាទុក្ខ[3400] សក្ខីកម្មមកពីសាក្សីជាច្រើន[3401] បទសម្ភាសន៍ សុន្ទរកថា និងសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹសាទុក្ខ និងមេដឹកនាំ ប.ក.ក ផ្សេងទៀត[3402] ការស្តាប់ចម្លើយសាក្សី[3403] និងឯកសារសហកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ *ជាអាទិ៍* ដូចជា លក្ខន្តិកៈ ប.ក.ក កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ការបោះពុម្ពឃោសនារបស់ ប.ក.ក និងរបាយការណ៍សារព័ត៌មាន FBIS[3404]។ ដើម្បីផ្តល់បរិបទចំពោះការបង្កើតគោលបំណងរួម អ.ជ.ស.ដ ក៏បានពិនិត្យមើលឯកសារសហកាល ការបោះពុម្ពផ្សាយ និងសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយ

---

[3398] ឯកសារ **E3/165** ឯកសារស្តីពីអង្គប្រជុំសន្និបាតរបស់សភា ចុះថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ KH 00053644 *យោងក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ ១២៤៧០។

[3399] ឯកសារ **E1/115.1** អែម អឿន ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ម៉ោង 11.22.43-11.25.05 ទំព័រ ៤១ បន្ទាត់ ២៤-ទំព័រ ៤២ បន្ទាត់ ១៣ (គូសបញ្ជាក់បន្ថែម) *យោងក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ ១២៤៧៣។

[3400] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦ ជើងទំព័រ ១២៤៥៦ និងការយោងសំអាងទាំងអស់ខាងក្នុងនោះ។

[3401] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦ ជើងទំព័រ ១២៤៦១ *យោង* ឯកសារ **E1/82.1** សៅ សារុន ប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 13.41.14-13.45.00 ទំព័រ ៤៩ បន្ទាត់ ១៣-ទំព័រ ៥០ បន្ទាត់ ៤ ។ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ ១២៤៧៣ *យោង* ឯកសារ **E1/100.1** រ៉ូចាម តុន ហៅ ភី ភួន ប្រតិចារឹក ថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ ម៉ោង 15.31.10-15.33.20 ទំព័រ ៧៦ បន្ទាត់ ១-ទំព័រ ៧៦ បន្ទាត់ ១១។ ឯកសារ **E1/124.1** ជា សាយ ប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ម៉ោង 10.17.58-10.31.32 ទំព័រ ២៦ បន្ទាត់ ១៣-ទំព័រ ៣០ បន្ទាត់ ៩។ កថាខណ្ឌ ៣៩៤៣ ជើងទំព័រ ១៣១៤៩ *យោង* ឯកសារ **E1/502.1** ប៊ិត ហឿន ហៅ ប៊ិត ណា ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ 10.40.54-10.43.57ទំព័រ ២២ បន្ទាត់ ២-ទំព័រ ២២ បន្ទាត់ ១៤។

[3402] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៤, ៣៧៣៥, ៣៧៤២ ជើងទំព័រ ១២៤៥៦, ១២៤៥៧, ១២៤៨៩ និងការយោងសំអាងទាំងអស់ខាងក្នុងនោះ។

[3403] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦ ជើងទំព័រ ១២៤៦១ និងការយោងសំអាងទាំងអស់ខាងក្នុងនោះ។

[3404] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦៥ (ជើងទំព័រ១២៥៤៧-១២៥៥០) ៣៧៣៧ (ជើងទំព័រ១២៤៦៤) ៣៧៣៩ (ជើងទំព័រ១២៤៧១-១២៤៧២) និងការយោងសំអាងទាំងអស់ខាងក្នុងនោះ។

ម្ចាស់បណ្តឹងសាទុក្ខ និងមេដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងទៀតដែលចុះកាលបរិច្ឆេទមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[3405]។

964. ដើម្បីកំណត់ពីចំណងទាក់ទងរវាង "ការពិតនៅនឹងកន្លែង" និង សេចក្តីណែនាំរបស់ ប.ក.ក[3406] អ.ជ.ស.ដ ក៏បានធ្វើការពិនិត្យដ៏ហ្មត់ចត់លើរដ្ឋបាលរបស់ ប.ក.ក និង រចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទង[3407] ដោយបានពិនិត្យទូរលេខ របាយការណ៍ ឯកសារឆ្លើយឆ្លងផ្លូវការ អត្ថបទ និងសុន្ទរកថា[3408] ក៏ដូចជា សក្ខីកម្មបញ្ជាក់ដែលពន្យល់ពីរបៀបដែលប្រព័ន្ធប្រាស្រ័យទាក់ទងដំណើរការ រួមទាំងការផ្សព្វផ្សាយព័ត៌មាន និងអត្ថន័យនៃពាក្យពេចន៍ដែលមានក្នុងឯកសារ[3409]។ ភស្តុតាងបញ្ជាក់ច្បាស់ថា ព័ត៌មានត្រូវបានបញ្ជូនឡើងលើពីថ្នាក់ក្រោមទៅថ្នាក់លើ ជាផ្នែកមួយនៃប្រព័ន្ធទំនាក់ទំនងជាធម្មតា[3410] និងថា បក្សបានប្រើទម្រង់នៃការទំនាក់ទំនងជាច្រើនដើម្បីផ្សព្វផ្សាយសេចក្តីណែនាំត្រឡប់ទៅថ្នាក់ក្រោមតាមខ្សែសង្វាក់នៃការបញ្ជា[3411]។

---

[3405] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៣ *យោង* កថាខណ្ឌ ១៩៦-២០៤, ២០៦, ២០៨-២១០, ២១២, ២១៤-២១៥, ២២០-២២៣, ២២៦-២២៧, ២២៩-២៣០, ២៣៥។ *សូមមើល* ការយោងសំអាងទាំងអស់ខាងក្នុងនោះ។

[3406] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៣៧។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៨៣-១២៨៧ (អ.ជ.ស.ដ ទទួលស្គាល់ថា មាន "ភាពប្រែប្រួល" នៅថ្នាក់មូលដ្ឋាន នៅទំនប់ត្រពាំងថ្ម ដែលនាំឱ្យមានលក្ខណ្ឌលំបាកខ្លាំងសម្រាប់កម្មករ ប៉ុន្តែក៏បានសន្និដ្ឋានថា មជ្ឈិមបក្សបានដឹងអំពីលក្ខណ្ឌទាំងនេះ និងមិនបានធ្វើអ្វីដើម្បីផ្លាស់ប្តូរ ឬដោះស្រាយស្ថានភាពនោះទេ) ១៥០៩, ៣៩៣១។ ការវិភាគដ៏ទូលំទូលាយលើរចនាសម្ព័ន្ធទំនាក់ទំនង ធ្វើឱ្យការពិចារណាមួយចំណែកម្តងៗបែបប្រឌិតរបស់ម្ចាស់បណ្តឹងសាទុក្ខលើលំហូរនៃព័ត៌មាន និងអំណះអំណាងរបស់គាត់ដែលថាការផ្សព្វផ្សាយព័ត៌មានមិនមានប្រសិទ្ធិភាព ដោយសារការគ្របដណ្តប់របស់វិទ្យុទាប ឬការមិនចេះអក្សរនោះ កាន់តែគ្មានអង្គសេចក្តីដូចគ្នាដែរ *សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៣៤, ១៤៣៦។

[3407] ការឆ្លើយតបជាពិសេសទៅនឹងមូលដ្ឋានទី ១៧៧។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦០-៣៦៥ (មជ្ឈិមបក្ស, មន្ទីរ ៨៧០, គណៈ ៨៧០) ៣៨៨-៣៨៩ (*អង្គការ*) ៤៥៥-៥១៦ (រចនាសម្ព័ន្ធទំនាក់ទំនង) ៥៤២ (ជាពិសេស ភស្តុតាងក្នុង ជើងទំព័រ ១៦៩០) ៦០៧, ១៤៧៦-១៤៨០, ២១៦១-២១៨០, ៣៣៩០ (ជាពិសេស ភស្តុតាងក្នុង ជើងទំព័រ ១១៤៣៦) ៣៥៥៦, ៤០៣៨, ៤០៨០, ៤១២៩, ៤២០៨, ៤២៧១។

[3408] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២៨។

[3409] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ២៦៩៤ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៦៩-៤៧២។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៧៩ (ប្រយ័ត្នប្រយែងអំពីការឃោនាដែលអាចមាននៅក្នុង*ទង់បដិវត្តន៍ និងយុវជនយុវនារីបដិវត្តន៍*) ៣៥-៨២ (ភស្តុតាងទូទៅ និងគោលការណ៍នីតិវិធី ជាពិសេស កថាខណ្ឌ ៥៥-៥៩ អំពី គោលការណ៍ទាំងនេះពាក់ព័ន្ធនឹងភស្តុតាងឯកសារ)។

[3410] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨២-៥០១, ៥០៧-៥១៦។

[3411] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៥៥-៤៧៩។

965. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីគោលបំណងមនុស្សធម៌ និងកម្មាភិបាលមិនស្មោះត្រង់[3412] ពិតជាមើលរំលង ឬជាញ៉ីកញ៉ាប់លើកឡើងមិនត្រឹមត្រូវពីឯកសារភ័ស្តុតាងដ៏សំខាន់នេះ។ ថាតើឧក្រិដ្ឋកម្មត្រូវបានគ្របដណ្តប់ដោយគោលបំណងរួមឬយ៉ាងណា ជាសំខាន់គឺជាបញ្ហាអង្គហេតុ ដែលត្រូវវាយតម្លៃផ្អែកលើកាលៈទេសៈពាក់ព័ន្ធ រួមទាំងគោលដៅរួមរបស់គោលបំណងរួម និងលទ្ធភាពដែលវាអាចសម្រេចបានតែតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3413]។ លើសពីនេះទៀត អ.ជ.ស.ដ បានសម្រេចយ៉ាងត្រឹមត្រូវថា ចំណុចនេះអាចត្រូវបានបង្ហាញដោយភ័ស្តុតាងទេសកាល[3414]។ ការត្រួតពិនិត្យដ៏ហ្មត់ចត់របស់ អ.ជ.ស.ដ លើឯកសារ *ទាំងមូល* បញ្ជាក់ពីទម្រង់នៃការប្រព្រឹត្តិដែលអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយដែលបានកំណត់អត្តសញ្ញាណ[3415]

[3412] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៤-១៥៩៥ (ឧក្រិដ្ឋកម្មជាការដើរខុសគន្លង) ១៥៩៥ (ការពន្យល់បែបមនុស្សធម៌សម្រាប់គោលនយោបាយ– *ប៉ុន្តែ សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៦៦-៣៩២៩ (សហករណ៍ និងការដ្ឋាន) និង ចម្លើយតបទៅនឹងមូលលដ្ឋានទី ១៨១, ១៨៣) ១៥៩៦ (សុន្ទរកថារបស់មេដឹកនាំជាន់ខ្ពស់ ប.ក.ក ដែលជាការឆ្លើយតបទៅនឹងការវាយប្រហារយោធា – *ប៉ុន្តែ សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨២, ៥៩៨, ៦០៧ (តួនាទី និងមុខងារ សុន្ទរកថា) ៤២០២-៤២៤៦ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខ រួមទាំងសុន្ទរកថារបស់គាត់ ការបោះពុម្ពផ្សាយ) ៤២៥៧-៤២៧៧ (ការចូលរួមចំណែកក្នុង JCE) និង ចម្លើយតបទៅនឹងមូលលដ្ឋានទី ២៧, ១៥៩, ១៧៧-១៧៩, ១៨៥, ២២២) ១៥៩៧ (ការជំទាស់ទៅនឹងការកំណត់ប្រភេទបទល្មើសនៃការប្រព្រឹត្តលើក្រុមផ្តោតគោលដៅ ដូចជាជនជាតិចាម ពុទ្ធសាសនិក និងអតីតមន្ត្រីខ្មែរសាធារណៈ និងប្រជាជនថ្មី - *ប៉ុន្តែ សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៣៤-៣៩៦៥, ៣៩៧៣-៣៩៨៧ (មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស) ៣៧៤៤-៣៨៦៣ (ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត) ៣៩៨៨-៤០៦១ (ការកំណត់គោលដៅលើក្រុមជាក់លាក់) ៤០៦៨-៤០៧៤ (គោលបំណងរួម និងការអនុវត្តក្នុង JCE) និង ចម្លើយតបទៅនឹងមូលលដ្ឋានទី ១៧៩, ១៨៤)។

[3413] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨០៨។

[3414] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៥៤-៥៦។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា “ការទទួលខុសត្រូវកើតឡើងនៅពេលដែលសមាជិក នៃសហឧក្រិដ្ឋកម្មរួមមិនបានចាត់វិធានការទប់ស្កាត់ឱ្យមានប្រសិទ្ធិភាពចំពោះការកើតឡើងនៃបទឧក្រិដ្ឋថ្មី ហើយពួកគេនៅតែបន្តអនុវត្តគោលបំណងរួមនេះ បោះទោះបីជាពួកគេបានដឹងហើយថាបទឧក្រិដ្ឋថ្មីត្រូវបានដាក់បញ្ចូលបន្ថែមនៅក្នុងការអនុវត្តផែនការរួមក៏ដោយ” (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០៩ ជើងទំព័រ ១២៣៦១)។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងថា ការសន្និដ្ឋាននៅក្នុងរឿងក្តី *Krajišnik* ដែល អ.ជ.ស.ដ សំអាងលើ ត្រូវវានតម្កល់នៅដំណាក់កាលឧទ្ធរណ៍ (សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ១៦៣, ១៧០-១៧១) និងបានអនុវត្តនៅក្នុងរឿងក្តីនានានៃតុលាការ ICTY (សាលក្រមក្នុងរឿងក្តី *Prlić* កថាខណ្ឌ ២១២។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៨០២-៨០៣។ សាលក្រមក្នុងរឿងក្តី *Popović* កថាខណ្ឌ ១០២៨)។

[3415] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែក ១៦.៣ (ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត) ១៦.៤ (ការអនុវត្តគោលបំណងរួម)។

ដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដូចគ្នា តាមរបៀបដូចគ្នា ដែលបាន ប្រព្រឹត្តឡើងនៅក្នុងរចនាសម្ព័ន្ធ ប.ក.ក ទាំងមូល និងនៅតាមគ្រប់ទីកន្លែងទាំងអស់នៅក្នុង *បណ្តឹង*។ ចំណុចនេះត្រូវបានរាយការណ៍ជាប្រចាំទៅកាន់ថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលក្នុងនោះ ម្ចាស់បណ្តឹងសាទុក្ខគឺជាសមាជិក ហើយជាការឆ្លើយតប ថ្នាក់លើបានផ្តល់សេចក្តីណែនាំ និង ទិសដៅ[3416]។ ភាពស្រដៀងគ្នា ទំហំ និងរយៈពេលនៃឧក្រិដ្ឋកម្ម ដោយថ្នាក់លើបានដឹង មិនបានដាក់ទណ្ឌកម្ម តែបែរជាគាំទ្រឧក្រិដ្ឋកម្មទាំងអស់នោះ អាចពន្យល់បានយ៉ាងសមហេតុ ផលថាជាការអនុវត្តគោលនយោបាយថ្នាក់លើ ដែលបានបង្កើតឡើងដើម្បីអនុវត្តគោលបំណងរួម។ ត្រង់ចំណុចនេះ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីកំហុសអង្គច្បាប់នៅក្នុងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ចំណងទាក់ទងមួយត្រូវតែបង្ហាញឱ្យឃើញរវាងសមាជិកសហឧក្រិដ្ឋកម្មរួម និងចារីផ្ទាល់ណាម្នាក់ ដែលមិនស្ថិតក្រោមសហឧក្រិដ្ឋកម្មរួម គ្រាន់តែជាការយល់ច្រឡំចំពោះសាលក្រមតែប៉ុណ្ណោះ[3417]។

966. ផ្ទុយទៅនឹងការអះអាងដែលជាញឹកញាប់លើកឡើងដដែលៗរបស់ម្ចាស់បណ្តឹងសាទុក្ខ ការពិនិត្យភ័ស្តុតាងរបស់ អ.ជ.ស.ដ មានលក្ខណៈហ្មត់ចត់ សត្យានុម័តិ និងមានហេតុផលត្រឹមត្រូវ។ អ.ជ.ស.ដ បានអនុវត្តច្បាប់យ៉ាងត្រឹមត្រូវក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋកម្មរួម[3418]។ ម្ចាស់បណ្តឹង

[3416] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែក. ៥.១ (រចនាសម្ព័ន្ធ ប.ក.ក) ផ្នែក. ៦ (រចនាសម្ព័ន្ធទំនាក់ទំនង)។

[3417] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៥២-១៩៥៣ ម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានរបស់ខ្លួនថា "អ្នកចូលនៅក្នុងសហឧក្រិដ្ឋកម្មរួម អាចតម្រូវឱ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយចារី [ផ្ទាល់] ដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ប្រសិនបើត្រូវបានរកឃើញថា ឧក្រិដ្ឋកម្មទាំងនោះ អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ យ៉ាងហោចណាស់ទៅលើអ្នកចូលរួមណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម ហើយអ្នកចូលរួមនោះអាចប្រើប្រាស់*ចារី [ផ្ទាល់]* ដើម្បីសម្រេចគោលបំណងនោះ" (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧១១ (គូសបញ្ជាក់បន្ថែម))។ នៅពេលយោងទៅ "ចារី [ផ្ទាល់]" អ.ជ.ស.ដ គ្រាន់តែមានន័យដូចគ្នាបះបិតទៅនឹងការចង់បានរបស់ម្ចាស់បណ្តឹងសាទុក្ខ ថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ "នីមួយៗ" ណាម្នាក់ក្នុងន័យទូទៅត្រូវតែសន្មត់ថាជាសមាជិក JCE ដែលធ្វើសកម្មភាពអនុលោមតាមគោលបំណងរួម។ ទោះជាយ៉ាងណា មិនមានលក្ខខណ្ឌតម្រូវត្រូវបង្ហាញអំពីអត្តសញ្ញាណជាច្បាស់លាស់នៃចារីផ្ទាល់នីមួយៗ។ វាគ្រប់គ្រាន់ក្នុងការសំដៅទៅលើប្រភេទ ឬក្រុមចារី (*សូមមើល*សាលដីកាក្នុងរឿងក្តី *Martić* កថាខណ្ឌ១៦៩។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១១៦។ *សូមមើលផងដែរ* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៤២០)។

[3418] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០១-៤៣០៨ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខផ្អែកលើ JCE) ៤៣២៦-៤៣២៧។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩០-១៩១, ១៩៤, ២០២-២០៣, ២០៥-២០៦ (តួនាទី និងមុខងារ)។ មូលដ្ឋានទី ១៩៣, ១៩៥-១៩៧, ២០៨-២០៩, ២១១-២១៧, ២២០-២២៣, ២៣២-២៣៦, ២៣៨-២៤៣ (ការដឹងឮ និងចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខ)។

សាទុក្ខមិនត្រូវបានផ្តន្ទាទោសចំពោះការចូលរួមរបស់គាត់ក្នុងសហគ្រាសមនុស្សធម៌ ដើម្បីធ្វើឱ្យជីវិតប្រជាជនកម្ពុជា និងជនបរទេសក្នុងប្រទេសកម្ពុជាប្រសើរឡើងនោះឡើយ ហើយការសហការមនុស្សធម៌ដែលលើកឡើងនោះមិនក៏មិនមានអត្ថិភាពដែរ ផ្អែកលើតថភាពជាក់ស្តែងនៃរបបនោះ។ ដូចបានរៀបរាប់លម្អិតនៅក្នុងចម្លើយតបនេះ[3419] ម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោសតាមរយៈសហឧក្រិដ្ឋកម្មរួម ដោយសារតែការចូលរួមចំណែកសំខាន់ៗជាច្រើនមុខក្នុងគោលបំណងរួមរបស់ ប.ក.ក ដែលជាប់ពាក់ព័ន្ធយ៉ាងច្បាស់លាស់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3420]។

## *អ.ជ.ស.ដ បានវិភាគជាសត្យានុម័តិអំពីគោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យ និងបរិបទដែលនាំឱ្យមានគោនយោបាយនេះ*[3421]

967. អ.ជ.ស.ដ បានលើកឡើងយ៉ាងស៊ីសង្វាក់អំពីគោលបំណងរួមនៅក្នុងសាលក្រមទាំងមូល[3422] ហើយការលើកឡើងដោយគ្មានមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខថា ការប្រើប្រាស់របស់

---

[3419] *សូមមើល* ផ្នែក VIII.**ខ** តួនាទី និងមុខងារ, ផ្នែក VIII.**គ**.២ ការចូលរួមចំណែកសំខាន់, ផ្នែក VIII.**គ**.៣ ចេតនា, ផ្នែក VIII.**ឃ** ការជួយ និងជម្រុញ។

[3420] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[3421] *ទាក់ទងនឹង* ទង្វីករណ៍ ១៨៩, ១៧៦, ១៧៧។ *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៥-១៥៩៩, ១៤១៦, ១៤៣១, ១៤៣៦។

[3422] *ទាក់ទងនឹង* ទង្វីករណ៍ ១៨៩។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១, ៣៧៤៣, ៣៩១៨, ៤០៦៨, ៤១១៧, ៤២៥៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥៩ ("ការប្រែប្រួលជាច្រើន" របស់ អ.ជ.ស.ដ ក្នុងការកំណត់និយមន័យគោលបំណងរួម "បង្ហាញពី" ភាពលម្អៀងរបស់ខ្លួន ធ្វើឱ្យខ្លួន "ដើម្បីដាក់បញ្ចូលនូវគោលនយោបាយឧក្រិដ្ឋ" ទៅក្នុងគោលបំណងរួម)។ ម្ចាស់បណ្តឹងសាទុក្ខសន្មត់គំនិតព្យាបាទ ជាដដែលៗទៅលើ អ.ជ.ស.ដ នៅក្នុងសារណារបស់ខ្លួន ទោះបីជាត្រូវបានប្រមានប្រឆាំងនឹងភាសាមិនគួរសមនោះនៅក្នុងឯកសារ **F51/3** សេចក្តីសម្រេចលើការទទួលយកភស្តុតាងបន្ថែម កថាខណ្ឌ ៣៩។ *សូមមើលផងដែរ* ឧទាហរណ៍ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៤១ (សុន្ទរកថារបស់មេដឹកនាំ ប.ក.ក ត្រូវបានដកស្រង់ខុសបរិបទ "បកស្រាយដាក់បន្ទុកតាមការចង់បានរបស់អង្គជំនុំជម្រះ ដើម្បីសន្និដ្ឋានថា គោលនយោបាយរបស់ ប.ក.ក មានលក្ខណៈឧក្រិដ្ឋ" ១៤៤៦ ("តាមរយៈការច្របល់បញ្ចូលគ្នាដោយចេតនា រវាងខ្មាំងយោធា និងខ្មាំងជាគូបដិបក្ខនយោបាយ អង្គជំនុំជម្រះបានលាក់បាំងបរិបទនៃជម្លោះប្រដាប់អាវុធ និងពាក្យពេចន៍ម៉ាក្សនិយមនៅសម័យនោះ") ១៦០០ (អ.ជ.ស.ដ បានសម្រេចបង្កើតគោលនយោបាយឧក្រិដ្ឋដើម្បីផ្តន្ទាទោស) ១៦០១ (គោលបំណងនៃការពិនិត្យលម្អៀងរបស់ អ.ជ.ស.ដ ទៅលើការទំនាក់ទំនង និងបណ្តាញរដ្ឋបាលរបស់ ប.ក.ក មានគោលដៅ "ដោយប្រយោល" ទម្លាក់កំហុសលើ ខៀវ សំផន ដោយសារមិនអាចមានភស្តុតាងបញ្ជាក់ពីការចូលរួមចំណែករបស់គាត់ ក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម)។

អ.ជ.ស.ដ នូវពាក្យ “គោលបំណងចម្បង” នាំឱ្យមានភាពលម្អៀង[3423] មិនបានពិចារណាថា អ.ជ.ស.ដ គ្រាន់តែអនុវត្តតាមពាក្យពេចន៍ដែលបានបង្កើតឡើងដោយ អ.ជ.ត.ក តែប៉ុណ្ណោះ[3424]។ វាក៏ច្បាស់ផងដែរតាមរយៈការវិភាគភស្តុតាងដែលថា អ.ជ.ស.ដ មិនបានវាយតម្លៃគោលបំណងរួមតែតាមរយៈ “ជ្រុង ‘នៃការតស៊ូប្រឆាំងនឹងខ្មាំង’” នោះទេ[3425]។ អ.ជ.ស.ដ បានពិចារណាម្តងហើយម្តងទៀតអំពីកម្លាំងជំរុញ “គម្រោងបដិវត្តន៍សង្គមនិយម”[3426] និងជាពិសេស បានចែកដាច់ពីគ្នារវាងខ្មាំងយោធា និងខ្មាំងមនោគមន៍វិជ្ជា ដែលមិនមានទំនាក់ទំនងជាមួយនឹងទំនាស់ ប៉ុន្តែត្រូវបានចាប់ខ្លួនដោយសារតែពួកគេត្រូវបានគេយល់ឃើញថាប្រឆាំងនឹងមនោគមន៍វិជ្ជា ប.ក.ក[3427]។ តថភាពជាក់ស្តែងដែលបានបង្ហាញដោយភស្តុតាងនោះគឺថា ការអនុវត្តរបស់ ប.ក.ក នូវគោល

---

[3423] *ទាក់ទងនឹង* ទឡ្ហីករណ៍ ១៧៦។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២៦។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៩, ១៨៣។

[3424] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០៨-៣៧០៩ ជាពិសេស ជើងទំព័រ ១២៣៥៦ *យោង* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨០៧-៨០៨។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២៦។ ទោះជាយ៉ាងណា សេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ផ្អែកលើការវាយតម្លៃភស្តុតាងសត្យានុម័តិ និងការវិភាគមួយជំហានម្តងៗ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៩ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣២, ៣៨៦៤។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៣។

[3425] *ទាក់ទងនឹង*មូលដ្ឋានទី ១៨៩។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៣។

[3426] *ទាក់ទងនឹង*មូលដ្ឋានទី ១៧៦។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៩ (ការបែងចែកទំនិញនាំចូល) ៩០៨ (ផ្នែកនៃផលិតកម្មរបស់សហករណ៍ត្រូវបានបញ្ជូនទៅឱ្យរដ្ឋសម្រាប់គ្រឿងចក្រ និងរបស់របរផ្សេងទៀត) ១០១១ (ជំនួយពីចិននៅក្នុងស្រុកត្រាំកក់) ១៣១៣-១៣១៤ (កម្មវត្ថុ ម៉ាស៊ីនទទួលបានពីចិន) ១៣១៨, ១៣៩៧, ១៥៩៤ (ការនាំចេញស្រូវដើម្បីផ្តល់ហិរញ្ញប្បទានទំនើបកម្មកសិកម្មរបស់ប្រទេសកម្ពុជា) ១៦៧៨, ១៧៦៣, ៣៨៧០ (សេចក្តីសន្និដ្ឋានអំពី កសិកម្មគឺជាមធ្យោបាយដែលមានតែមួយគត់នៃការបង្កើតទុន) ៣៨៩០, ៣៨៩៣ (បំពេញគោលដៅសេដ្ឋកិច្ចឱ្យបានឆាប់រហ័ស ដែលជាគន្លឹះដើម្បីពង្រឹងជីវភាពរស់នៅ និងត្រូវសម្រេចបានដោយគ្មានជំនួយបរទេស) ៣៩០៧, ៣៩១៤ (កម្មវត្ថុ សរុបទំនិញនាំចេញ និងនាំចូលរបស់កម្ពុជាប្រជាធិបតេយ្យ) ៣៩១៦ (ការរៀបចំសេដ្ឋកិច្ចឡើងវិញ) ៤២១៤ (ម្ចាស់បណ្តឹងសាទុក្ខមានភារកិច្ចទិញម៉ាស៊ីនពីបរទេស ដែលបានអនុម័តដោយគណៈអចិន្ត្រៃយ៍) ៤២៦៦ (ម្ចាស់បណ្តឹងសាទុក្ខ អំពាវនាវឱ្យមានការបង្កើនទិន្នផល សម្រាប់ការនាំចេញស្រូវឱ្យបានច្រើនដើម្បីបង្កើតទុន) ជើងទំព័រ ១៤៥៩ (ភ្ញៀវចិន និងកូរ៉េបានជួយភ្ជាប់ខ្សែទូរស័ព្ទ) ៥១០០ (កម្មវត្ថុ ត្រាក់ទ័រ និងឡានដឹកទំនិញពីប្រទេសយូហ្គោស្លាវី) ៥២១០។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១៨។

[3427] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥២, ៣៧៦៤ (កម្មវត្ថុ ខ្មាំងយោធា) ៣៧៦៥ (លក្ខន្តិកៈ ប.ក.ក ឆ្នាំ១៩៧៦ កម្មវត្ថុ អាកប្បកិរិយា និង មនោគមវិជ្ជាប្រឆាំងបដិវត្តន៍) ៣៧៧០, ៣៨៣៥ (អត្ថន័យនៃពាក្យខ្មាំង អាស្រ័យលើបរិបទដែលវាត្រូវបានពិភាក្សា) ៣៨៤៧-៣៨៥៥, ៣៨៦៣។

បំណងរួមជាប់ពាក់ព័ន្ធនឹងការលុបបំបាត់ក្រុមខ្មាំង ដែលត្រូវបានកំណត់និយមន័យយ៉ាងទូលំទូលាយ[3428]។

968. ទោះបីជាការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខផ្សេងពីនេះ អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវអំពីជម្លោះប្រដាប់អាវុធ ដែល ប.ក.ក ជួបប្រឈម បានចែកដាច់ពីគ្នារវាងខ្មាំងយោធា និងខ្មាំងមិនមែនយោធា និងបានពិចារណាអំពីវិធីសាស្ត្រ ម៉ាក្ស-លេនីន របស់ ប.ក.ក ឆ្ពោះទៅកាន់កុម្មុយនីស្ត[3429]។ អ.ជ.ស.ដ បានកត់សម្គាល់ម្តងហើយម្តងទៀតលើសារសំខាន់រួមរបស់ ប.ក.ក ដែលបានកំណត់លើឯករាជ្យភាពពីវៀតណាម[3430] មិនបានបញ្ចិតបញ្ចៀងថា ប្រតិកម្មរបស់ ប.ក.ក ទៅនឹងភាពប្រទូសរ៉ាយខាងយោធាជាមួយប្រទេសជិតខាងរបស់ខ្លួន គ្រាន់តែជា "ការខ្លាចស្រមោលខ្លួនឯងរបស់បក្ស"[3431]នោះទេ។ ឯកសារយោងនៅក្នុងសាលក្រមទាំងមូលបាន

---

[3428] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៤០ (ប្រភេទខ្មាំង) ៣៨៤២ (ខ្មាំងខាងក្នុង *ជំនួស*ខ្មាំងខាងក្រៅ) ៣៨៤៥-៣៨៤៦ (ខ្មាំង អាកប្បកិរិយាប្រឆាំងបដិវត្តន៍)។

[3429] *ទាក់ទងនឹង*មូលដ្ឋានទី ១៨៩។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៩៩-៣៨០៣ (ខ្មាំងពិតប្រាកដ ឬខ្មាំងសន្មត) ៣៨៣៦-៣៨៤៥ (ជម្លោះប្រដាប់អាវុធ អំពីវិធីសាស្ត្រ ម៉ាក្ស-លេនីន ឆ្ពោះទៅកាន់កុម្មុយនីស្ត) ៣៩៣០-៣៩៨៧ (មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស) ៣៩៨៩-៤០១២ (ក្រុមដែលបានកំណត់ជាគោលដៅ - ប្រជាជនចាម និង វៀតណាម) ៤០២៣-៤០៦១ (អតីតទាហ៊ានសាធារណរដ្ឋខ្មែរ)។ *សូមមើលផងដែរ* កថាខណ្ឌ ២៩៦, ៣១៨, ២៩៨៣, ២៩៩៦, ៣១៣៩ (ជម្លោះប្រដាប់អាវុធ)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៨ ជើងទំព័រ ៣០៤៦។

[3430] *ទាក់ទងនឹង* ទង្វីករណ៍ ១៧៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១៦ (លើកឡើងថា អ.ជ.ស.ដ "មិនអាចប្រកែកបានថា ឯករាជ្យគឺជាស្នូលសម្រាប់ ប.ក.ក" ឬគិតពីបរិបទឆ្នាំ១៩៧៥)។ ជាងនេះទៀត អ.ជ.ស.ដ មិនបានផ្អែកការសន្និដ្ឋានរបស់ខ្លួនអំពីគោលនយោបាយប្រឆាំងនឹងវៀតណាមទាំងស្រុងតែទៅលើ ទំនាក់ទំនងមុនខែមេសា ឆ្នាំ១៩៧៥ រវាងប្រទេសទាំងពីរទេ។ *ផ្ទុយពី* ១៦១៣ ប៉ុន្តែគ្រាន់តែវិភាគវាជាផ្នែកមួយនៃបរិបទប្រវត្តិសាស្ត្រ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៨២។ អ.ជ.ស.ដ មានការប្រុងប្រយ័ត្នថា សៀវភៅ Black Paper (សៀវភៅខ្មៅ) មានការឃោសនា និងដូច្នេះប្រយ័ត្នក្នុងវាយតម្លៃរបស់វា *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨២, ២៤៧៤ ជើងទំព័រ ៧៣៣។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១០។

[3431] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ២០២ (កត់សម្គាល់ការខិតខំប្រឹងប្រែងរបស់បក្ស នៅចុងឆ្នាំ១៩៥៩ ក្នុងការបង្កើតបក្សមួយដែលគ្មានឥទ្ធិពលវៀតណាម) ២០៤ (បក្សត្រូវបានកំណត់ឈ្មោះឡើងវិញថាជាបក្សពលករកម្ពុជា ដើម្បី "បញ្ជាក់ឯករាជ្យភាពរបស់ខ្លួន និងការងាកចេញពីកុម្មុយនីស្តវៀតណាម" ២២៦ (មាគ៌ាដ៏មានភាពបទបែននៃទំនាក់ទំនងល្អជាមួយវៀតណាមត្រូវបានផ្លាស់ប្តូរក្នុងឆ្នាំ១៩៧១ នៅពេលដែលមេដឹកនាំ ប.ក.ក "បានសម្រេចថា វៀតណាមគឺជា "សត្រូវស្រួចស្រាវ" យូរអង្វែងរបស់កម្ពុជា" ២២៨ (អំពី ទំនាក់ទំនងកាន់តែយ៉ាប់យឺន) ២៣០ (នួន ជា និង ខៀវ សំផន ទាំងពីរនាក់បានទទួចថា ចាំបាច់ត្រូវរំដោះភ្នំពេញមុនពេលវៀតណាមខាងជើងវាយយកបានសៃហ្គន់ដើម្បីទប់ស្កាត់មិនឱ្យវៀតណាមគ្រប់គ្រងកម្ពុជា) ២៤០, ១៣១៣ (ស្វ័យម្ចាស់ការត្រូវបានចាត់ទុកថាជាគោលការណ៍ដែលរកបានដើម្បីធានាឯករាជ្យភាព និងអធិបតេយ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យ) ៣៣៨២, ៣៣៨៥ ជើងទំព័រ ៤១០។ *ផ្ទុយពី*

បដិសេធទៀតថា អ.ជ.ស.ដ មិនបានខកខានក្នុងការពិចារណាថា ធនធានរបស់ប្រទេសត្រូវបានបំផ្លិចបំផ្លាញ ឬមិនអើពើនឹងសារៈសំខាន់នៃសមូហភាព និងការបង្កើនការផលិតដើម្បីរស់ឡើយ[3432]។

969. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ បានបដិសេធមិនឱ្យគាត់ពិភាក្សាជំទាស់ទៅនឹងភ័ស្តុតាងទាក់ទងនឹងផែនការនយោបាយរបស់ ប.ក.ក[3433] មានភាពផ្ទុយគ្នា តាមរយៈការយោងទៅឱកាសជាច្រើនដែលផ្តល់ឱ្យគាត់ ដើម្បីធ្វើការបញ្ចេញមតិលើភ័ស្តុតាងបែបនោះ មុនពេលសវនាការបានចាប់ផ្តើម និងនៅក្នុងការជំនុំជម្រះទាំងមូល[3434]។ មិនមានអ្វីផ្សេងទៀតដែល អ.ជ.ស.ដ បានកំណត់នោះទេ[3435]។

### *ការផ្សព្វផ្សាយព័ត៌មានត្រូវបានធ្វើឡើងតាមវិធីខុសៗគ្នា និងយ៉ាងទូលំទូលាយ*[3436]

---

ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១៦ (មិនបង្ហាញពីផ្នែកណាដែលបញ្ជាក់ថា អ.ជ.ស.ដ តម្កល់ទស្សនៈ "ការខ្លាចស្រមោលខ្លួនឯង" នោះទេ)។

[3432] *ទាក់ទងនឹង*មូលដ្ឋានទី ១៧៦។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២០-១៤២៥ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៨-៣៧៣៩។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២៩, ៣៣៨២ (អំពី ការខូចខាតដែលបណ្តាលមកពីការទម្លាក់គ្រាប់បែករបស់ ស.រ.អ) ២៤០, ៩៤០, ៩៧១, ៣៨៨៤ (អំពី មេដឹកនាំ - ប្រមូលផ្តុំធនធានធនធានពលកម្ម ដែលបង្កើនផលិតផលកម្ម ដើម្បីកសាងប្រទេសឱ្យបានឆាប់រហ័ស) ២៤១ (សង្គ្រាមស៊ីវិលបាននាំឱ្យមានកង្វះខាតទំនិញប្រើប្រាស់ និងអតិថរណា) ១៣១២ (សង្គ្រាមបានប៉ះពាល់ប្រព័ន្ធសុខាភិបាល) ១៤១៨, ១៨៣២ (ធនធានពិបាករកដោយសារសង្គ្រាម ប៉ុន្តែអាជ្ញាធរអាចកាត់បន្ថយផលប៉ះពាល់បានល្អជាងនោះ)។ *សូមមើលផងដែរ ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៨១ ជាពិសេសទាក់ទងនឹងមូលហេតុមនុស្សធម៌ដែលនៅពីក្រោយគោលនយោបាយសហករណ៍។

[3433] *ទាក់ទីងនឹង*មូលដ្ឋានទី ណ៍ ១៧៥។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤០៥។

[3434] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦-៣៧, ៥៧-៥៩, ១៤៣-១៤៨, ៣៧៣១, ៣៩៣២, ៣៩៥៦។

[3435] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ១៨៥ ("គោលការណ៍ស្តីពីកិច្ចដំណើរការនីតិវិធីតទល់ចំពោះមុខតម្រូវមុនគេបង្អស់គឺថា គ្រប់ភាគីត្រូវបានផ្តល់ឱកាសឱ្យផ្តល់យោបល់ទៅលើភ័ស្តុតាងដែលបានដាក់បង្ហាញនៅពេលសវនាការ និងទៅលើសារណារបស់ភាគីដែលធ្វើការជំទាស់ ក្នុងគោលបំណងដើម្បីឱ្យមានឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់តុលាការ។ គោលការណ៍នេះពុំបានតម្រូវ [...] ថាភាគីត្រូវតែធ្វើសារណាស្តីពីភ័ស្តុតាងទាំងនោះឡើយ") ៤៩៥ (សន្និដ្ឋានថា មិនមានការរំលោភបំពានលើគោលការណ៍នេះនៅក្នុងការពឹងផ្អែករបស់ អ.ជ.ស.ដ លើកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មក្នុងតុលាការដែល អ.ជ.ស.ដ បានវាយតម្លៃយ៉ាងប្រុងប្រយ័ត្នលើភ័ស្តុតាង និងបានផ្តល់យោបល់មានហេតុផលលើមូលហេតុដែលផ្អែកលើភ័ស្តុតាងនោះ)។

[3436] *ផ្ទុយពី* មូលដ្ឋានទី ១១៧។

970. ម្ចាស់បណ្តឹងសាទុក្ខវាយប្រហារចំពោះការសន្និដ្ឋានដ៏សមហេតុផលរបស់ អ.ជ.ស.ដ ដែលថា ទស្សនាវដ្តីបដិវត្ត ប.ក.ក ត្រូវបានគេចែកចាយយ៉ាងទូលំទូលាយ[3437] ផ្អែកទៅលើតែមួយផ្នែកនៃសក្ខីកម្មរបស់សាក្សីតែម្នាក់ និងធ្វើគិតគូរដល់សក្ខីកម្មរបស់សាក្សីដដែលនេះ និងសាក្សីដទៃទៀតដែលផ្តល់សក្ខីកម្មថា ទស្សនាវដ្តីទង់បដិវត្ត/យុវជនយុវនារីបដិវត្ត ត្រូវបានផ្សព្វផ្សាយនៅទូទៅប្រទេស[3438]។ ការព្យាយាមរបស់គាត់មិនទទួលស្គាល់ពីឥទ្ធិពលដ៏រីករាលដាល និងមនោគមន៍វិជ្ជាដែលកើតចេញពីឥទ្ធិពលនេះ[3439] គឺជាការលាក់បាំងនូវការពិតដែលមានភ័ស្តុតាងបញ្ជាក់ជាច្រើន។ ឧទាហរណ៍ ដើម្បីបង្ហាញពីភាពខុសគ្នា គាត់យោងទៅសាក្សីម្នាក់ដែលបានផ្តល់សក្ខីកម្មថា "វិន័យនៅកន្លែងមួយអាចធូន់ជាងកន្លែងមួយផ្សេងទៀត" ប៉ុន្តែ គាត់ក៏បាននិយាយដែរថា "*ផែនការ* គឺស្រដៀងគ្នានៅគ្រប់ទីកន្លែង *ទាំងអស់*"[3440]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អនក្ខរភាព មានន័យថា មានមនុស្សតិចតួចដែលចេះអាន និងយល់អំពីសារនៅក្នុងទស្សនាវដ្តីទាំងនេះ ប៉ុន្តែគាត់មិនគិតថា ខ្លឹមសារនៃទស្សនាវដ្តីទាំងនេះថា ត្រូវបានគេយកទៅបង្រៀនជាទៀងទាត់នៅក្នុងវគ្គរៀនសូត្រនានា និយាយឱ្យចំគឺដើម្បីជួយដល់ពួកកម្មាភិបាល និងជនស៊ីវិលបានយល់ដឹងអំពីមាគ៌ារបស់បក្ស[3441]។ ជាចុងក្រោយ កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដែលគាត់អះអាងថា បង្ហាញពីការលំបាកក្នុងការប្រាស្រ័យទាក់ទងគ្នានោះ[3442] តាមពិតគឺជាការបង្ហាញអំពីការពិភាក្សាគ្នាយ៉ាងទូលំទូលាយដោយផ្អែកលើព័ត៌មានផ្សេងៗ ដែលបានរាយការណ៍ពីប្រភពជាច្រើននៅទូទាំងប្រទេស ដោយបានស្នើឱ្យមានរបាយកាណ៍អំពី

---

[3437] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៣៥ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៧៥។ សូមមើល ចម្លើយតបទៅនឹងចន្ទ្រីករណ៍ ១៩៣ (ទស្សនាវដ្តីទង់បដិវត្តន៍/យុវជន យុវនារីបដិវត្តន៍)។

[3438] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៧៤ (កត់សំគាល់ថា សាក្សីដដែល ដែលមិនអាចធ្វើការប៉ាន់ប្រមាណឱ្យបានច្បាស់អំពីចំនួនដែលបានបោះពុម្ព តាមពិតគាត់បានរម្លឹកឡើងវិញថា"បានឃើញ លេខផ្សាយនីមួយៗ 'គរជាគីប' ដែលគេបានរៀបចំដើម្បីចែកចាយ", ៤៧៥ ជើងទំព័រ ១៤៩០-១៤៩២ និងភ័ស្តុតាងដែលបានយោងនៅក្នុងនោះ។ ផ្ទុយពី ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៣៥ (ទាក់ទងនឹងសាក្សី គីម វុន)។

[3439] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៣៦ *ជំទាស់នឹង* សេចក្តីសន្និដ្ឋានដែលថា គាត់មិនបានបញ្ជាក់ចំៗទេ។

[3440] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៧១០ *យោង* ឯកសារ **E1/178.1** François Ponchaud, ប្រតិចារឹក ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ ម៉ោង 16.03.58-16.08.57 ទំព័រ ៧១ បន្ទាត់ ១០-បន្ទាត់ ២១ (គូសបញ្ជាក់បន្ថែម)។

[3441] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៧៥, ៤៧៧ (និយាយឱ្យចំគឺភ័ស្តុតាងជើងទំព័រ ១៥០១), ១០២៨, ២១៦៥, ២២០៧, ២៩០៧។

[3442] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៧១១ *យោង* ឯកសារ **E3/232** កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ KH 00017121-23។

សភាពការណ៍ប្រចាំសប្តាហ៍ ដើម្បីឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍បានដឹង និងបង្កលទ្ធភាពឱ្យគណៈកម្មាធិការនេះអាចចេញសេចក្តីណែនាំបានទាន់ពេលវេលា[3443]។

971. ម្ចាស់បណ្តឹងសាទុក្ខតវ៉ាថែមទៀតអំពីវិសាលភាពនៃការផ្សព្វផ្សាយព័ត៌មាន ដោយអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានថ្លែងថា ចម្លើយសារភាពរបស់ទាហានវៀតណាម ត្រូវបានគេផ្សាយយ៉ាងទូលំទូលាយទៅដល់ប្រជាជនទាំងមូល[3444]។ តាមពិត អ.ជ.ស.ដ បានដឹងថា ប្រជាជនកម្ពុជាធម្មតាមិនមានសិទ្ធិស្តាប់វិទ្យុដោយសេរីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយគ្រាន់តែបានសន្និដ្ឋានថា ចម្លើយសារភាពដូច្នេះត្រូវបាន "ផ្សាយយ៉ាងហោចណាស់មួយផ្នែកជាភាសាវៀតណាម"[3445]។

*អ.ជ.ស.ដ បានធ្វើការវិភាគយ៉ាងត្រឹមត្រូវលើសេចក្តីថ្លែងជាផ្លូវការនានា*[3446]

972. ម្ចាស់បណ្តឹងសាទុក្ខតវ៉ាដដែលៗថា គាត់ត្រូវបានបដិសេធលទ្ធភាពចូលពិនិត្យភ័ស្តុតាងដើមទាំងអស់នៅក្នុងសំណុំរឿង និងថា អ.ជ.ស.ដ មានកំហុសក្នុងការផ្តល់ការសន្មតចំពោះយថាភូតលើឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា[3447] ដែល អ.ជ.ស.ដ និង អ.ជ.ត.ក បានបដិសេធដូច្នេះជាថ្មីម្តងទៀតគួរតែត្រូវបានបដិសេធ[3448]។ ទាក់ទងនឹងទូរលេខ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានពឹងផ្អែកលើការផ្លាស់ប្តូរទូរលេខ "មូលដ្ឋាន" ជាភ័ស្តុតាងនៃគោលនយោបាយជាតិ ដែលគ្មានតឹកតាងបញ្ជាក់ថា ព័ត៌មានទាំងនោះ "បានទៅដល់ភ្នំពេញ"

---

[3443] ឯកសារ **E3/232** កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦។

[3444] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៣៤។

[3445] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៦៦, ៤៦៨។ *សូមមើលផងដែរ* កថាខណ្ឌ ២៤៧២-២៤៧៣, ៣៤៥៧។

[3446] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៧៧។

[3447] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២៩។

[3448] ភាគីអាចមិនគ្រាន់តែបាននិយាយឡើងវិញនូវអំណះអំណាងដែលមិនបានជោគជ័យនៅក្នុងពេលសវនាការលើបណ្តឹងសាទុក្ខ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៧, ២០។ ភាគីដែលជំទាស់នឹងយថាភូតនៃឯកសារណាមួយត្រូវផ្តល់សំអាងអំពីសច្ចធារណ៍នៃនិរទោស*ជាបឋម*, សំណុំរឿង ០០១-ឯកសារ **F28** សាលដីការឿងក្តី ឌុច កថាខណ្ឌ ១៧, ២០។ *សូមមើលផងដែរ* ទឡ្ហីករណ៍ ១៥, ៣១, ៣៥។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧៥។ *សូមកត់សំគាល់* ថាម្ចាស់បណ្តឹងសាទុក្ខមិនបានបញ្ជាក់ថា គាត់បានបញ្ជូនសមាជិកណាម្នាក់នៃក្រុមការពារក្តីរបស់គាត់ទៅ DC-cam ដើម្បីពិនិត្យយថាភូតនៃឯកសារដែលរងការជំទាស់ទេ ទោះបីមានការបង្ហាញរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង០០២/០១ ថា នេះជាជំហានមួយដែលអាចធ្វើបានដើម្បីបញ្ជាក់ពីសច្ចធារណ៍ក៏ដោយ។

ឡើយ[3449]។ លើសពីកំហុសអង្គហេតុដែលម្ចាស់បណ្ដឹងសាទុក្ខមាន កថាខណ្ឌនានាដែលគាត់លើកយោងដើម្បីគាំទ្រដល់ការអះអាងរបស់គាត់នោះ[3450] ក៏មិនបានបញ្ជាក់ឱ្យបានច្បាស់ចំៗអំពីកំហុសឬអង្គសេចក្ដីដែលគេបានធ្វើដូច្នោះនោះដែរ ដូចបានពិភាក្សានៅកន្លែងផ្សេងទៀតក្នុងចម្លើយតបនេះ[3451]។ ម្ចាស់បណ្ដឹងសាទុក្ខក៏ខកខានមិនបញ្ជាក់ចំៗពីអ្វីដែលកើតចេញពី "សេចក្ដីសន្និដ្ឋានអវិជ្ជមាន" ដែលនាំឱ្យមានការខុសឆ្គងរបស់តុលាការពិតប្រាកដ ឬមោឃៈដល់សាលក្រមនោះដែរ[3452]។

### *អ.ជ.ស.ដ បានវាយតម្លៃជាសត្យានុមតិលើឯកសារ ប.ក.ក*[3453]

973. ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា ការវាយតម្លៃរបស់ អ.ជ.ស.ដ លើឯកសាររបស់ ប.ក.ក ត្រូវបានធ្វើឡើងដោយចោះៗ ឬតែមួយផ្នែកជាប្រព័ន្ធនោះទេ[3454]។ ទីមួយ ឧទាហរណ៍នានាដែលគាត់បានលើកយោងដោយសង្ខេបនោះ បានបង្ហាញថា គ្មានមូលដ្ឋាននៅក្នុងវាក្យខណ្ឌនានានៅក្នុងចម្លើយតបដែលគាត់បានលើកនោះទេ[3455]។ ទីពីរ ការអះអាងរបស់គាត់ដែលថា កំណត់ហេតុ

---

[3449] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣០។ ការអះអាងរបស់គាត់ធ្វើមិនដឹងមិនឮចំពោះការវិភាគយ៉ាងទូលំទូលាយរបស់ អ.ជ.ស.ដ អំពីរចនាសម្ព័ន្ធនៃការប្រាស្រ័យទំនាក់ទំនងដូចបានកត់សំគាល់ខាងលើ ព្រមទាំងបណ្ដាញនៃការប្រាស្រ័យនៅក្នុងរចនាសម្ព័ន្ធនោះ រួមទាំងបង្ហូរព័ត៌មានចេញចូលពីថ្នាក់លើនិងថ្នាក់ក្រោម ដូចបានតម្រូវដោយលក្ខន្តិកៈ ប.ក.ក។ សូមមើល ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៥៥-៥១៦។ ឯកសារ **E3/130** លក្ខន្តិកៈ ប.ក.ក គ្មានកាលបរិច្ឆេទ មាត្រា ៦។

[3450] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣០ ជើងទំព័រ ១៤៣០ *យោង* កថាខណ្ឌរបស់គាត់ ១០៩០-១០៩១, ១៥៤២, ១៦១៤, ១៦២៤-១៦២៦, ១៦២៩, ១៦៣៤, ១៦៤៦, ១៦៤៩, ១៧១១។

[3451] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៩ (*យោង* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១០៩០-១០៩១), ១៨៤ (*យោង* កថាខណ្ឌ ១៥៤២), ១៩០, ២១៦ (*យោង* កថាខណ្ឌ ១៦១៤), ១៩០ (*យោង* ១៦២៤-១៦២៦, ១៦២៩), ១៩១ (*យោង* កថាខណ្ឌ ១៦៣៤), ២០៥ (*យោង* កថាខណ្ឌ ១៦៣៩), ១៩៤ (*យោង* កថាខណ្ឌ ១៦៤៦, ១៦៤៩), ២០៣ (*យោង* កថាខណ្ឌ ១៧១១)។

[3452] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣០ (និយាយដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានប្រើប្រាស់ឯកសារទាំងនេះ ក្នុងន័យត្រឹមតែទាញសេចក្ដីសន្និដ្ឋានអវិជ្ជមានលើគោលនយោបាយ ប.ក.ក)។

[3453] *ពាក់ព័ន្ធនឹងមូលដ្ឋានទី* ១៧៧។

[3454] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣០-១៤៣១, ១៤៣៣, ១៤៣៥, ១៤៣៧។

[3455] ចំពោះការចោទប្រកាន់ដែលបានយោងដោយសង្ខេបនៅក្នុង ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣១ *សូមមើល* មូលដ្ឋានទី ១៩៣ (ការខកខានក្នុងការបង្ហាញឱ្យឃើញអំពី ការប្រើទស្សនាវដ្ដីទង់បដិវត្តន៍/យុវជនយុវនារីបដិវត្តន៍ "ដោយចោះៗ"), ១៥៩ (ការខកខានក្នុងការបង្ហាញឱ្យឃើញអំពី "ការសន្និដ្ឋានពង្រីក" មិនត្រឹមត្រូវចំពោះសុន្ទរកថាដែលពាក់

កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ មិនអាចត្រូវបាន "វិភាគថាជាផ្នែកនៃយុទ្ធនាការនៃការប្រាស្រ័យទាក់ទង"[3456]នោះ មិនគិតគូរថា មិនមែនកំណត់ហេតុទាំងនោះទៅវិញទេដែលត្រូវបានផ្សព្វផ្សាយនោះ ដូចម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើង តាមពិតគឺ *សេចក្ដីសម្រេចទានា* របស់គណៈកម្មាធិការអចិន្ត្រៃយ៍ទៅវិញទេដែលគេបានផ្សព្វផ្សាយ[3457]។ ដូច្នេះ សេចក្ដីសម្រេចដែលបញ្ជាឱ្យមានការផ្សាយតាមវិទ្យុឱ្យបានញឹកញាប់អំពីការបោះឆ្នោត[3458]ដើម្បីលុបបំបាត់គំនិតដែលថា របបកម្ពុជាប្រជាធិបតេយ្យគឺជារបបផ្ដាច់ការនោះ ត្រូវបានវិភាគយ៉ាងសមស្របក្នុងបរិបទនៃយុទ្ធនាឃោសនាអំពីការប្រាស្រ័យទាក់ទង។

974. លើសពីនេះទៀត ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនគិតគូរដោយមិនត្រឹមត្រូវ ទៅលើផ្នែកមួយនៃកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដដែលនេះដែលបញ្ជាក់ថា រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ "ត្រូវឱ្យប្រជាជនដឹង" នោះ មិនបានផ្ដល់ភស្តុតាងថា អ.ជ.ស.ដ មិនយកគិតគូរដល់ភស្តុតាងនេះ ឬថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដោយសារអង្គជំនុំជម្រះមិនទទួលយកអ្វីៗគ្រប់យ៉ាងដែលមានក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ថាពិតនោះទេ[3459]។ និយាយឱ្យចំជាងនេះទៀត មិនមានការបញ្ជាក់ថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការសម្រេចពីអត្ថិភាពនៃគោលនយោបាយមួយដែលផ្ដោតគោលដៅលើចាមដោយសារតែជាតិសាសន៍ ឬសាសនា[3460]ឡើយ ដោយហេតុថា ការសម្រេចនេះបានពឹងផ្អែកលើ

---

ព័ន្ធនឹងជនជាតិវៀតណាម), ១៦៥ (*យោង* មាត្រាមួយនៃទស្សនាវដ្ដីយុវជនយុវនារីបដិវត្តន៍ ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដែល "គ្មានអ្វីក្រៅពីការឃោសនា")។

[3456] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣២។

[3457] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣២ (កំណត់ហេតុនៃកិច្ចប្រជុំទាំងនេះពាក់ព័ន្ធតែអំពីសមាជិក ប.ក.ក ប៉ុណ្ណោះ ហើយវាមិនធ្វើទំនាក់ទំនងខាងក្រៅទេ)។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៤៦៦ *យោង* ឯកសារ **E3/231** កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ KH 00017124-25 ("ក្នុងខែ៣ ១៩៧៦ គណៈអចិន្ត្រៃយ៍បានបញ្ជាឱ្យមានការផ្សាយតាមវិទ្យុឱ្យបានញឹកញាប់អំពី "ការបោះឆ្នោត" ខាងមុខ" ដោយធ្វើការសង្កេតថា បើមិនផ្សាយសោះ វា[ខ្មាំង]ថាយើងផ្ដាច់ការ គ្មានប្រជាធិបតេយ្យ")។

[3458] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៤១៣ និងភស្តុតាងដែលបានយោងនៅក្នុងនោះ ទាក់ទងនឹងការបំភាន់របស់គណៈអចិន្ត្រៃយ៍អំពីសភាតំណាងប្រជាជន និងការបោះឆ្នោត។

[3459] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣២។ *សូមមើលផងដែរ* មូលដ្ឋានទី ១៧៩ (បរាជ័យក្នុងការបង្ហាញអំពីការបកស្រាយដោយអនាគតិលើរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ)។

[3460] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣២២៨។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៣២។

ការវាយតម្លៃលើភ័ស្តុតាងទាំងមូល និងហួត់ចត់[3461]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ផ្នែកដែលរងការជំទាស់ធ្វើឱ្យសេចក្តីសម្រេចរបស់ អ.ជ.ស.ដ ទាក់ទងនឹងគោលនយោបាយ ប.ក.ក គ្មានមូលហេតុ ឬបង្ហាញថា អ.ជ.ស.ដ បានធ្វើការវាយតម្លៃដោយចោះៗចំពោះឯកសារ ប.ក.ក នោះឡើយ។

*អ.ជ.ស.ដ បានធ្វើសេចក្តីសម្រេចប្រកបដោយហេតុផល ដោយផ្អែកលើការអនុវត្តច្បាប់ដោយអនាគតិក្នុងការវាយតម្លៃលើភ័ស្តុតាងយ៉ាងត្រឹមត្រូវ និងសត្យានុមតិ*[3462]

975. ម្ចាស់បណ្តឹងសាទុក្ខក៏តវ៉ាទាំងគ្មានមូលដ្ឋានផងដែរអំពីអនាគតិរបស់ អ.ជ.ស.ដ លើចំណុចដែលគាត់គ្រាន់តែមិនយល់ស្របជាមួយនឹងការសន្និដ្ឋានដែលបានសម្រេច បន្ទាប់ពីមានការវាយតម្លៃលើភ័ស្តុតាងសមហេតុផលមួយ[3463]។ គាត់មិនបានបង្ហាញថា អ.ជ.ស.ដ "បានលាក់" ភ័ស្តុតាងដោះបន្ទុក"ទាំងអស់"ទេ[3464]។ ទោះបីអង្គជំនុំជម្រះមិនតម្រូវឱ្យផ្តល់យុត្តិកម្មអំពីមូលហេតុដែលខ្លួនទាត់

---

[3461] អ.ជ.ស.ដ បានពឹងផ្អែកការសម្រេចរបស់ខ្លួនលើការវាយតម្លៃភ័ស្តុតាងទាំងមូល ដែលបានបង្ហាញដដែលៗថា បទប្បញ្ញត្តិរដ្ឋធម្មនុញ្ញភាគច្រើន (រួមទាំងការការពារសាសនាផង) មិនបានសម្រេចទាំងស្រុងឡើយ ឬមិនត្រូវបានគោរព ឬមានលក្ខណៈវៀចវេរ ខណៈភ័ស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់បានបង្ហាញថា ឥស្លាម ត្រូវបានចាត់ទុកថា "ជាសាសនាប្រតិកិរិយា" ដែលត្រូវ "ហាមឃាត់ជាដាច់ខាត"។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣២២៨។ ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៤១, ៤១២-៤១៣, ៤១៧, ១០៩៣, ៣២១៥, ៣២២៧, ៣២៣០-៣២៣១, ៣២៣៤-៣២៣៦, ៣២៤២, ៣២៧៥, ៣២៧៩, ៣២៨៥, ៣២៨៧-៣៣០៤, ៤២៤១។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៦។

[3462] *ពាក់ព័ន្ធនឹង* ទឡ្ហីករណ៍ ១៨៩, ១៧៥, ១៧៦, ១៧៧។ ការទាមទាររបស់ម្ចាស់បណ្តឹងសាទុក្ខអំពីអនាគតិ មាននៅទូទាំងវាក្យខណ្ឌនេះទាំងមូល ហើយសារណាបណ្តឹងសាទុក្ខរបស់គាត់គ្មានមូលដ្ឋាន ដោយសារខកខានមិនបានជំនះទៅលើសច្ចធារណ៍នៃអនាគតិតុលាការដ៏ខ្លាំង (*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៩)។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤០៥-១៤០៦, ១៤៣៥, ១៤៣៧, ១៥៩៣-១៥៩៤, ១៥៩៨-១៦០១, ១៦០៣។

[3463] *ពាក់ព័ន្ធនឹង* ទឡ្ហីករណ៍ ១៧៥, ១៧៦, ១៨៩។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១៧ ជើងទំព័រ ២៦៦៩ (ម្ចាស់បណ្តឹងសាទុក្ខទាមទារថា ការកំណត់ចារិកលក្ខណៈរបស់ អ.ជ.ស.ដ អំពីការគាបសង្កត់របស់បក្សលើអាគតដ្ឋានរបស់វាបានបង្ហាញថាមានភាពលំអៀង ពេលដែលការសម្រេចនេះមានភ័ស្តុតាងគាំទ្រយ៉ាងរឹងមាំ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧៤១ ជើងទំព័រ ១២៤៨៤-១២៤៨៥, ១៤៣៣ (ម្ចាស់បណ្តឹងសាទុក្ខទាមទារថា អ.ជ.ស.ដ បានធ្វើការវាយតម្លៃលើកំណត់ហេតុកិច្ចប្រជុំ ឯកសារនានារបស់ FBIS/SWB និង ផ្នែកខ្លះនៃទូរលេខ "ផ្សេងទៀត"), ១៥៩៣-១៥៩៤, ១៥៩៨-១៦០១, ១៦០៣។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៩។

[3464] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៨៩។ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៩។

ចោលភស្តុតាងខ្លះ និងពឹងផ្អែកលើភស្តុតាងដទៃទៀត[3465] ក៏ការឈានដល់ការសម្រេចសាលក្រមមួយដែលត្រឹមត្រូវយុត្តិធម៌ បានបញ្ជាក់យ៉ាងច្បាស់ថា អ.ជ.ស.ដ បានពិចារណាលើភស្តុតាងដោះបន្ទុកសក្តានុពល ស្របតាមគោលការណ៍ដែលខ្លួនត្រូវអនុវត្ត[3466] និងបានធ្វើសេចក្តីសម្រេចដែលមានលក្ខណៈអនុគ្រោះចំពោះម្ចាស់បណ្តឹងសាទុក្ខ[3467]។ អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ដូចជាអំណះអំណាងទាក់ទងនឹងការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ជាដើម គឺជាការយល់ច្រឡំ ដោយសារគាត់មិនបានបង្ហាញពីកំហុសដែលតំណាងឱ្យអភិក្រមដាក់បន្ទុកណាមួយ[3468]។ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានបង្ហាញផងដែរថា អ.ជ.ស.ដ បានបំពានឆន្ទានុសិទ្ធរបស់ខ្លួននៅពេលអង្គជំនុំជម្រះនេះ បានធ្វើការវាយតម្លៃលើភាពទុកចិត្តបាន និងភាពជឿជាក់បាននៃភស្តុតាង និងពេលសម្រេចលើភស្តុតាងដែលអង្គជំនុំជម្រះសន្និដ្ឋានថា គួរឱ្យជឿជាក់បានជាងគេ[3469]។ ម្ចាស់បណ្តឹងសាទុក្ខបានធ្វើការទាមទារជាច្រើនដែលសុទ្ធសឹងជាការបញ្ជាក់ឡើងវិញពីអ្វីដែលបាន

---

[3465] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤, ៤៩៥។ សាលដីការឿងក្តី *Ngirabatware* កថាខណ្ឌ ៩៧។ សាលដីការឿងក្តី *Karera* កថាខណ្ឌ ២១។ សាលដីការឿងក្តី *Setako* កថាខណ្ឌ ៣១។

[3466] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៦៥។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ១៣៧៣ (យោង ទំនប់ត្រពាំងថ្ម), ៣៣៧៨ (សក្ខីកម្មផ្តល់ថា សុទ្ធរកថា "មួយទល់នឹង ៣០" គឺមានន័យលើកទឹកចិត្តដល់កងទ័ព), ៣៣៧៩ (អ.ជ.ស.ដ ពន្យល់ពីមូលហេតុដែលខ្លួនធ្វើការសន្និដ្ឋានលើភស្តុតាងនេះថាមិនគាំទ្រដល់ការយល់ឃើញរបស់ខ្លួន), ៣៤០៤ (អ.ជ.ស.ដ ពន្យល់ពីមូលហេតុដែលឯកសារដាក់ឱ្យនៅដាច់ពីគេដែលអំពាវនាវឱ្យមានមិត្តភាពជាមួយវៀតណាម មិនមានវមតិសង្ស័យ ទាក់ទងនឹងការកំណត់គោលដៅលើជនជាតិវៀតណាម), ៣៤២៧ (អ.ជ.ស.ដ ពន្យល់ពីមូលហេតុនៃឧទាហរណ៍ទាំងបីអំពីកូនៗរបស់បុរសជនជាតិវៀតណាមម្នាក់មិនមែនជាគោលដៅនោះ មិនបានហៅការកំណត់គោលដៅដែលផ្អែកលើជាតិពន្ធុខាងម្តាយ ជាចំណោទទេ), ៣៦១៧ (ការព្រមព្រៀងក្នុងអាពាហ៍ពិពាហ៍)។

[3467] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៦៤ (មិនយល់ស្របថា ម្ចាស់បណ្តឹងសាទុក្ខបានចូលជំនួស ខឿន ធ្វើជាប្រធានមន្ទីរ ៨៧០), ៥៩៥ (យល់ស្របថា ម្ចាស់បណ្តឹងសាទុក្ខគ្មានសិទ្ធិអំណាចលើប្រតិបត្តិការយោធា), ១១៣៥ (មិនយល់ស្របថា ម្ចាស់បណ្តឹងសាទុក្ខបានចុះទៅពិនិត្យការដ្ឋានប្រឡាយ អូរចំបក់ ស្រុកត្រាំកក់ ក្នុងឆ្នាំ ១៩៧៧), ១៣៨៧, ១៦៦៧ (មិនយល់ស្របថា មានការសម្លាប់រង្គាលបានកើតឡើងនៅទំនប់ត្រពាំងថ្ម និងទំនប់ ១មករា), ៣១៣៥ (យល់ស្របថា គ្មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីទារុណកម្មនៅមន្ទីរសន្តិសុខភ្នំក្រោល), ៣៨៥៥ (យល់ស្របថា សេចក្តីយោងនានារបស់ ប.ក.ក សំដៅទីភ្នាក់ងារព័ត៌មានចារកម្មបរទេស មិនត្រូវបានគេធ្វើឡើងត្រឹមត្រូវតាមអត្ថន័យដើម), ៤៣៩០, ៤៣១៩ (គ្មានការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះអំពើប្រល័យពូជសាសន៍ចាម នៅក្រមទម្រង់នៃការទទួលខុសត្រូវណាមួយឡើយ)។

[3468] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៨៩។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៩ ជើងទំព័រ ៣០៤៩ *យោង* កថាខណ្ឌរបស់គាត់ ១១៨៩-១២៨០។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៤-១៧០ (បទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍)។

[3469] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៨៩។ *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧-៩៨, សេចក្តីសម្រេចលើការចាត់តាំងមេធាវីការពារក្តី AC ក្នុងរឿងក្តី *S. Milošević* កថាខណ្ឌ៩-១០)។

បង្ហាញរួចហើយក្នុងចម្លើយតបនេះ ដែលសុទ្ធតែឥតខ្លឹមសារ[3470]។ ជាចុងក្រោយ ម្ចាស់បណ្ដឹងសាទុក្ខទាមទារទាំងគ្មានមូលដ្ឋានថា អ.ជ.ស.ដ បានរំលោភលើគោលការណ៍នីត្យានុកូលភាព[3471]។ ដូចបានបង្ហាញក្នុងចម្លើយតបនេះ ច្បាប់ដែល អ.ជ.ស.ដ បានអនុវត្ត មានចែងកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មុនពេលដែលឧក្រិដ្ឋកម្មនានាដែលរងការជំទាស់ ត្រូវបានប្រព្រឹត្ត[3472]។

976. ការទាមទារដែលមិនត្រឹមត្រូវរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីអនាគតិ ត្រូវបានលើកជាឧទាហរណ៍នៅក្នុងការជំទាស់របស់គាត់ទៅនឹងសេចក្ដីពិចារណាលើដំណោះស្រាយមួយដែលគេបានរាយការណ៍ ដែលត្រូវបានសម្រេចថា តំណាងឱ្យមាគ៌ារបស់បក្ស[3473]។ ម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានសន្និដ្ឋានថា គាត់បាន "ធ្វើជាអធិបតីក្នុងសមាជ(ខ្លះ)"[3474] ខណ: អ.ជ.ស.ដ បានថ្លែងយ៉ាងប្រុងប្រយ័ត្នថា នៅចន្លោះថ្ងៃទី២៥ និង២៧ ខែមេសា ឆ្នាំ១៩៧៥ ម្ចាស់បណ្ដឹងសាទុក្ខត្រូវបានគេ "រាយការណ៍ថា" បានធ្វើជាអធិបតីនៅក្នុងសមាជជាតិពិសេស

---

[3470] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៧៦។ ការទាមទាររបស់គាត់ទាក់ទងនឹងសុន្ទរកថា ថ្ងៃទី១១ មេសា ១៩៧៦ (*សូមមើល* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤២១) ត្រូវបានលើកនៅចម្លើយតបទៅនឹងទមូលដ្ឋានទី ១៧។ *សូមមើលផងដែរ* មូលដ្ឋានទី ២៧, ១៨៤, ២០៣ (កាលបរិច្ឆេទសមាជលើកទីបួន ពេលដែលម្ចាស់បណ្ដឹងសាទុក្ខបានក្លាជាសមាជិកពេញសិទ្ធិនៃគណ:កម្មាធិការមជ្ឈិម) *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២២៧៥)។ ដូចគ្នានេះដែរ ការតវ៉ាទាក់ទងនឹងការពឹងផ្អែករបស់ អ.ជ.ស.ដ លើភស្តុតាងរបស់ អែម អឿន និង អែក ហេន (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤២៤) ត្រូវបានពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២០៤ ហើយការជំទាស់របស់គាត់ទាក់ទងនឹងការអនុវត្តត្រឹមត្រូវរបស់ អ.ជ.ស.ដ ទាក់ទងនឹងការយល់ដឹងរបស់ ប.ក.ក ចំពោះពាក្យ "បរិសុទ្ធ" ថាមានការពាក់ព័ន្ធទៅនឹងផ្នែកនៃការរើសអើងជាតិពន្ធុនោះ ក៏ត្រូវបានដោះស្រាយនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩ (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤២៧)។

[3471] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៨៩។ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៩៩ ជើងទំព័រ ៣០៨៤ *យោង* កថាខណ្ឌរបស់គាត់ ៦៤២-៦៥៧ (ទាក់ទងនឹង ធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ)។

[3472] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៥-៩៦ (ការធ្វើទុក្ខបុកម្នេញ)។

[3473] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៧៦។ ការសម្រេចទាក់ទងនឹងមាគ៌ាបក្ស ត្រូវបានផ្ដល់សំអាងបន្ថែមតាមរយ:ភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧៣៥ (ថ្លែងថា សមាជបានប្រកាសអំពីការប្ដេជ្ញាចិត្តថ្មីរបស់រដ្ឋាភិបាលចំពោះសង្គមគ្មានវណ្ណ: ដែលខំប្រឹងកសាង និងការពារប្រទេសប្រទេស), ៣៧៣៧-៣៧៣៩, ៣៨៨៤ (ជាពិសេស ភស្តុតាងដែលបានយោងនៅក្នុងជើងទំព័រ ១២៩៦១), ៤២៦២។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០១។

[3474] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៧៦។ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤១៧ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៥។

ដោយកត់សំគាល់ថា មិនប្រាកដថាតើ វាបានកើតឡើងមែនឬអត់[3475]។ ដោយសារការផ្សព្វផ្សាយ និងអត្ថបទសារព័ត៌មានរបស់ ប.ក.ក បានរាយការណ៍អំពីអធិបតីភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងអង្គប្រជុំនោះ និងភ័ស្តុតាងផ្សេងទៀតដែលបានបញ្ជាក់ថា ការប្រជុំនោះពិតជាបាន *កើតឡើង* មែន[3476] ការសន្និដ្ឋានសំខាន់នេះមិនត្រូវបានគេបញ្ជាក់ថាមិនសមហេតុផលនោះទេ[3477]។

977. ម្ចាស់បណ្តឹងសាទុក្ខទាមទារថា អ.ជ.ស.ដ មានភាពលំអៀង ដោយសារមិនយកវិធីសាស្ត្រដែលខ្លួនបានកំណត់សម្រាប់ខ្លួនឯង មកធ្វើការវិភាគទៅលើគោលបំណងរួម[3478]។ គាត់ខកខានមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ ទោះក្នុងមធ្យោបាយណាក៏ដោយ តម្រូវឱ្យដើរតាមលំដាប់នៃព្រឹត្តិការណ៍ជាក់លាក់នៅពេលធ្វើការវិភាគ ឬកំណត់លើការសន្និដ្ឋានរបស់ខ្លួន។ លំដាប់លំដោយដែល អ.ជ.ស.ដ បានជ្រើសរើសមិនបានបង្ហាញពីអនាគតិណាមួយទេ ហើយម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងបរាជ័យក្នុងការជំទាស់ទៅលើសច្ចធារណ៍ខ្លាំងនៃអនាគតិតុលាការ[3479]។

---

[3475] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧៣៥ (*កត់សំគាល់* ថា អ.ជ.ស.ដ ក៏បានយោងកថាខណ្ឌ ៥៩៣ ក្នុងជើងទំព័រ ១២៤៥៨ ដែរ)។

[3476] ជាការបន្ថែមលើភ័ស្តុតាងដែលបានយោងនៅក្នុងកថាខណ្ឌសាលក្រមដែលរកការជំទាស់ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៥៩៣ (ជាពិសេស អត្ថបទសារព័ត៌មានដែលបានយោងនៅក្នុងជើងទំព័រ ១៨៥៨ ដែលរាយការណ៍អំពីគណៈអធិបតីភាពរបស់ម្ចាស់បណ្តឹងសាទុក្ខនៃកិច្ចប្រជុំនេះ), ១០៨៦ (ពិភាក្សាលើភ័ស្តុតាងដែលបង្ហាញឱ្យឃើញថា សមាជពិសេស បានធ្វើឡើងនៅថ្ងៃកាលបរិច្ឆេទទាំងនោះ)។ ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បុព្វកថា (ពិភាក្សាអំពីដំណោះស្រាយរបស់សមាជជាតិពិសេស ដែលបានធ្វើឡើងនៅថ្ងៃទី២៥-២៧ មេសា ១៩៧៥)។ ការខកខានរបស់ ប៉ុល ពត មិនបាននិយាយឈ្មោះម្ចាស់បណ្តឹងសាទុក្ខ ជូនអ្នកសារព័ត៌មានយូហ្គោស្លាវី នៅពេលពិភាក្សាអំពីសមាជនេះ មិនបានធ្វើឱ្យការសម្រេចនេះគ្មានហេតុផលនោះឡើយ បើតាមស្មារតីនៃភ័ស្តុតាងទាំងស្រុង។ (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១៧)។

[3477] *ពាក់ព័ន្ធនឹង* មូលដ្ឋានទី ១៧៦។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១៧។

[3478] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤០៤ (សង្ខេបវិធីសាស្ត្រ អ.ជ.ស.ដ ដែលបានថ្លែង - ពិតជាបានចោទ*ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៧៥។ថា គោលបំណងរួមបានកើតឡើងមែន ដោយពិនិត្យលើគោលនយោបាយនានាដើម្បីអនុវត្តគោលបំណងរួម គឺជាមូលដ្ឋានឧក្រិដ្ឋកម្មដែលជាប់ជំពាក់ពីគោលនយោបាយនានា ដូច្នេះវាបានជួយបន្ថែម ឬអនុវត្តទៅលើគោលបំណងរួមនោះ), ១៤០៦។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៧៣២។

[3479] *ពាក់ព័ន្ធនឹង*មូលដ្ឋានទី ១៧៥។ *សូមមើលឧទាហរណ៍* សេចក្តីសម្រេចចំនួន ១១ របស់អង្គចៅក្រមពិសេស ទាក់ទងនឹងចៅក្រមសាលាឧទ្ធរណ៍ទាំងប្រាំមួយរូប កថាខណ្ឌ ៦៤។ *សាលដីការឿងក្តី Karemera & Ngirumpatse កថាខណ្ឌ ២៤*។

## *មូលដ្ឋានទី ១៧៨៖ អភិក្រមដែលខុសសម្រាប់ការពិនិត្យលើគោលនយោបាយនានា*[3480]

978. **មូលដ្ឋានទី ១៧៨ បរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសនៅក្នុងការសម្រេចថា គោលបំណងនយោបាយរបស់ ប.ក.ក ត្រូវបានអនុវត្តតាមរយៈគោលនយោបាយចំនួនប្រាំ ដែលពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។**

979. ច្បាស់ណាស់ថា អ.ជ.ស.ដ បានសន្និដ្ឋានថា គោលនយោបាយនៃការជម្លៀសប្រជាជន (ចំពោះតែចាម ការជម្លៀសប្រជាជនដំណាក់កាលទី២) មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងបដិវត្តន៍ ធ្វើជាមធ្យោបាយមួយដើម្បី "ត្រួតត្រា" និង "ចាប់មនុស្ស"[3481] ដើម្បីបំពេញគោលបំណងនៃការការពារប្រទេសប្រឆាំងនឹងខ្មាំង និងការផ្លាស់ប្តូរដាច់ខាតលើប្រជាជនដើម្បីក្លាយជាសង្គមខ្មែរមួយ ដែលគ្មានសាសនា និងគ្មានការបែងចែកវណ្ណៈ ក្នុងបរិបទនៃបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក[3482]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ប.ក.ក បានបញ្ជាឱ្យមានការបញ្ជូនដោយបង្ខំដើម្បី "បំបែកចាម"[3483] និងថា ក្រោយការបញ្ជូន ពួកគេត្រូវបានបង្ខំឱ្យរស់នៅក្នុងចំណោមប្រជាជនខ្មែរ និងត្រូវអនុវត្តតាមទំនៀមទម្លាប់ខ្មែរ[3484] "ដើម្បីឱ្យសហគមន៍ពួកគេបែកបាក់"[3485] ធ្វើដូច្នេះ ដើម្បីពួកគេ "សម្របខ្លួនទាំងស្រុង" [...] ទៅក្នុងជាតិខ្មែរ និងអត្តសញ្ញាណខ្មែរតែមួយ"[3486]។ អ.ជ.ស.ដ បានសន្និដ្ឋានប្រកបដោយហេតុផលថា គោលនយោបាយនេះរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3487]។

980. អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងច្បាស់ដោយគ្មានការយល់ច្រឡំថា គោលនយោបាយបង្កើត និងដាក់ឱ្យដំណើរការសហករណ៍ និងការដ្ឋាន មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងបដិវត្តន៍ ដោយសារវាធ្វើឡើងដើម្បី "ត្រួតត្រា" និង"ចាប់មនុស្ស"[3488] ដើម្បី"បំពេញគោលដៅសេដ្ឋកិច្ច និងមនោគមន៍វិជ្ជា"

---

[3480] ទទ្ចីករណ៍ ១៧៨៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អភិក្រមខុសសម្រាប់ពិនិត្យគោលនយោបាយ* កថាខណ្ឌ ១៤៣៨-១៤៤៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦២ (អង់គ្លេស) ទំព័រ ៥៧ (បារាំង) ទំព័រ ៨៨ (ខ្មែរ)។

[3481] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៨៦៦-៣៨៦៧, ៣៩៩១។

[3482] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៩៩៥, ៣៩៩៧។

[3483] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣២៦២។

[3484] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣២៦១, ៣២៦៣, ៣២៦៤។

[3485] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣២៦៨។

[3486] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣២១៧។

[3487] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៣ & ១៥០, ១៤២។

[3488] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៨៧៧។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨៦៦-៣៨៦៧។

ក្នុងបរិបទនៃបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក[3489]។ អ.ជ.ស.ដ បានសន្និដ្ឋានថា គោលនយោបាយនេះបានគាំទ្រលើគ្រប់គោលដៅនៃគោលបំណងរួមទាំងអស់ ដូចជា ដើម្បីកសាងប្រទេស ការពារប្រទេសពីខ្មាំង និងផ្លាស់ប្តូរដាច់ខាតលើប្រជាជនដើម្បីក្លាយជាសង្គមកម្មក-កសិករ ដែលគ្មានការបែងចែកវណ្ណៈ[3490]។ អ.ជ.ស.ដ បានសន្និដ្ឋានថា សហករណ៍គឺជា "ឧបករណ៍ចម្បងសម្រាប់ការតស៊ូវណ្ណៈ" ដែលនឹង "ត្រួសត្រាយផ្លូវឱ្យមានសង្គមនិយមថ្មីមួយ"[3491] និងបានកត់សំគាល់ថា ប៉ុល ពត បានធ្វើអត្ថាធិប្បាយអំពីការជម្លៀសប្រជាជនដោយបង្ខំទៅកាន់ជនបទនេះថាជា"កត្តាដ៏សំខាន់មួយដើម្បីជោគជ័យបដិវត្តន៍"[3492]។ សហករណ៍បានបន្ត "ដកហូតធនធានមនុស្ស និងធនធានសេដ្ឋកិច្ចចេញពីខ្មាំង"[3493] និង "[បាន]ផ្លាស់ប្តូរប្រព័ន្ធកសិកម្មរបស់ប្រទេស[3494]។ អ.ជ.ស.ដ បានសន្និដ្ឋានប្រកបដោយហេតុផលថា គោលនយោបាយនេះរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3495]។

981. អ.ជ.ស.ដ បានសន្និដ្ឋានថា គោលនយោបាយបង្កើត និងដាក់ឱ្យដំណើរការមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យដាច់ពីគេ និងកម្ទេចខ្មាំង និងអប់រំ "សមាសធាតុមិនល្អ" មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងបដិវត្តន៍ និងជាមធ្យោបាយច្បាស់ក្រឡែតមួយសម្រាប់បំពេញបំណងនៃការការពារប្រទេស ប្រឆាំងនឹងខ្មាំង និងដើម្បីផ្លាស់ប្តូរសង្គមជាដាច់ខាត ក្នុងបរិបទនៃបដិវត្តសង្គមនិយមរបស់ ប.ក.ក[3496]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខ "បានណែនាំឱ្យកម្មាភិបាលឱ្យកែប្រែអាកប្បកិរិយា *ដើម្បីសម្រេចគោលដៅ*

---

[3489] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៩១៦។

[3490] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៨។

[3491] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៧៥។

[3492] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨១។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨៨៤ ("អាទិភាពរបស់បក្ស គឺកសាងប្រទេសដោយពឹងផ្អែកលើខ្លួនឯង ឯករាជ្យ និងមិនមានវណ្ណៈ ហើយត្រូវការការពារប្រទេសពីខ្មាំង។ [ម្ចាស់បណ្តឹងសាទុក្ខ]បានពន្យល់ថាដើម្បីកសាងប្រទេសឱ្យបានលឿន និងដើម្បីដោះស្រាយបញ្ហាខ្វះស្បៀងអាហារដោយសារសង្គ្រាមស៊ីវិល យើងត្រូវបង្ខំប្រជាជនឱ្យចូលរួមក្នុងសហករណ៍"), ៣៨៨៥។

[3493] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៧៩។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨៧៥, ៣៨៧៨, ៣៨៩៨។

[3494] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៩។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨៧៩, ៣៩០១, ៣៩០៧។

[3495] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១ និង ១៨៣។

[3496] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧៣, ៣៩៧៦, ៣៩៧៨-៣៩៨១, ៣៩៨៣, ៣៩៨៥-៣៩៨៧។

*បក្ស* និងកំណត់អត្តសញ្ញាណខ្មាំង"[3497] និងបានកត់សំគាល់លើសក្តីកម្មរបស់គាត់ "ថា របប កសាងរបស់បក្សតាមរយៈការប្រជុំទិតៀន និងស្វ័យទិតៀន គឺជាមូលដ្ឋានគ្រឹះខាងសតិអារម្មណ៍ សម្រាប់ការតស៊ូវណ្ណៈ"[3498]។ អ.ជ.ស.ដ ក៏បានសន្និដ្ឋានផងដែរថា ដំណើរការមន្ទីរសន្តិសុខ គឺជា "ការអនុវត្តទូទាំងប្រទេស"[3499] ដែលមានមន្ទីរសន្តសុខយ៉ាងហោចណាស់ ២០០ កំពុងដំណើរការ នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ[3500] និងថា ប្រព័ន្ធថ្កោលទោសខ្មាំងដោយដាក់ក្នុងមន្ទីរឃុំឃាំង និងសម្លាប់ចោលនេះ ស្របតាមរដ្ឋធម្មនុញ្ញ និងត្រូវបានអនុវត្តអនុលោមតាមក្រឹត្យរបស់បក្ស[3501]។ អ.ជ.ស.ដ បានសន្និដ្ឋានប្រកបដោយហេតុផលថា គោលនយោបាយនេះរួមមានការប្រព្រឹត្តិឧក្រិដ្ឋ កម្ម[3502]។

982. អ.ជ.ស.ដ ក៏បានសន្និដ្ឋានផងដែរថា គោលនយោបាយផ្តោតគោលដៅលើក្រុមជាក់លាក់ រួមមាន ចាម វៀតណាម ពុទ្ធសាសនិកជន និងកម្មាភិបាលខ្មែរក្រហមមុនៗ មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹង បដិវត្តន៍ និងត្រូវបានអនុមតិឡើងដើម្បីសម្រេចបាននូវគោលបំណងនៃការការពារប្រទេសប្រឆាំង នឹងខ្មាំង និងដើម្បីផ្លាស់ប្តូរសង្គមជាដាច់ខាត ក្នុងបរិបទនៃបដិវត្តសង្គមនិយមរបស់ ប.ក.ក[3503]។ ក្រុមដែលត្រូវបានគេកំណត់គោលដៅថា "ខ្មាំង" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន កម្មាភិបាលខ្មែរក្រហមមុនៗ ចាម ជនស៊ីវិលវៀតណាម កម្មាភិបាល ប.ក.ក ដែល"ក្បត់" និងអ្នក ផ្សេងទៀតដែលជាប់ខ្សែជាមួយពួកគេ ត្រូវបានគេចាត់ទុកថាជាការគំរាមកំហែងដល់គោលបំណង នយោបាយ និងមនោគមន៍វិជ្ជារបស់បដិវត្តន៍[3504] រួមទាំងគោលបំណងសេដ្ឋកិច្ចរបស់ពួកគេផង

[3497] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៤២ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* កថាខណ្ឌ ៣៩៦០ (ម្ចាស់បណ្តឹងសាទុក្ខអំពាវនាវឱ្យបក្ស "បោសសម្អាត" ខ្មាំង)។

[3498] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។

[3499] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៩។

[3500] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៤។

[3501] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៥។

[3502] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៤។

[3503] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៩៣, ៣៩៩៤, ៣៩៩៦, ៣៩៩៧, ៤០០៣-៤០០៥, ៤០០៧-៤០០៩, ៤០១១, ៤០២១, ៤០៥៣, ៤០៥៦, ៤០៦០។

[3504] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤១០, ១៤៦៦, ១៦៤២-១៦៤៣, ១៦៤៦-១៦៤៧, ១៦៦០-១៦៦៣, ១៦៩០, ១៩២៩, ១៩៤៥, ២០១៦-២០២១, ២០៣០-២០៣៨, ២០៦៩, ២០៧២, ២៤២៩-២៣៣៥, ២៤៧៨, ២៤៨០, ២៤៨២, ២៤៨៦-២៤៩០, ២៤៩២, ២៥២៧, ២៥៣១, ៣២១៩, ៣២២៨, ៣២៧៤-៣២៨១, ៣២៨៥-៣៣០៤, ៣៣០៦-៣៣០៨, ៣៣១១-៣៣១៣, ៣៣៨៩-៣៣៩០, ៣៣៩៦, ៣៣៩៨, ៣៤០២, ៣៤០២, ៣៤០៧-៣៤១០, ៣៤១៦-៣៤១៧, ៣៧៤៤, ៣៧៥២, ៣៧៨៩-៣៧៩០, ៣៨៤៧, ៣៨៦០, ៣៩២៤-៣៩២៥។

[3505]។ អ.ជ.ស.ដ បានសន្និដ្ឋានបន្ថែមទៀតអំពីបំណងរបស់ ប.ក.ក ក្នុងការរក្សា "ពូជសាសន៍កម្ពុជា" និងបង្កើតជាតិ និងអត្តសញ្ញាណខ្មែរតែមួយដែលគ្មានការបែងចែកវណ្ណៈនេះ ស្របគ្នានឹងអាទិភាពរបស់បក្សដើម្បីការពារប្រឆាំងនឹងខ្មាំងទាំងអស់[3506]។ អ.ជ.ស.ដ បានសន្និដ្ឋានប្រកបដោយហេតុផលថា គោលនយោបាយនេះរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3507]។

983. អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងច្បាស់ថា គោលនយោបាយរបស់ ប.ក.ក អំពីបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍ មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងបដិវត្តន៍ និងគាំទ្រលើគ្រប់គោលដៅនៃគោលបំណងរួមៈ កសាងប្រទេស ការពារប្រទេសប្រឆាំងនឹងខ្មាំង និងការផ្លាស់ប្តូរសង្គមជាដាច់ខាត[3508]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ប.ក.ក "បានចាត់ទុកគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍ជាស្នូលក្នុងការកសាងសង្គមមួយថ្មី ស្របតាមមនោគមន៍វិជ្ជានៃបដិវត្តន៍សង្គមនិយមរបស់ខ្លួន" ដោយ*អង្គការ* ស្ថិតនៅពីលើឪពុកម្តាយជាផ្នែកមួយនៅក្នុង "ទម្រង់នៃសង្គមថ្មី"[3509]។ អ.ជ.ស.ដ បានពិចារណាលើសក្ខីកម្ម បានបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខបានធ្វើបាឋកថាស្តីពីបទបញ្ជានៃអាពាហ៍ពិពាហ៍ "ដើម្បីឱ្យគូស្វាមីភរិយាអាចបង្កើតកូន និងមានកម្លាំងកាន់តែច្រើនដើម្បីការពារប្រទេស"[3510]។ អ.ជ.ស.ដ ក៏បានធ្វើការកត់សំគាល់លើការឃោសនារបស់ ប.ក.ក ដោយថ្លែងថា "ការកសាងគ្រួសារ" គឺជាការ "បេះមិនដាច់ពីបញ្ហាប្រទេសនិងប្រជាជនទាំងមូល [...] ដើម្បីធ្វើបដិវត្តន៍សម្រេចភារកិច្ចដ៏ឧត្តុងឧត្តម[...] ហើយឈានទៅកសាងសង្គមនិយម និងកុម្មុយនីស្ត

---

[3505] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥៥, ៣៧៥៧, ៣៧៥៩, ៣៧៧២។

[3506] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៦-៣២១៩, ៣២២៨, ៣២៨៦, ៣៣៨៧, ៣៣៩០, ៣៤០០, ៣៤១២, ៤០១៥។

[3507] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៧។ *សូមមើលជាទូទៅ វាក្យខណ្ឌ VII៖ ឧក្រិដ្ឋកម្ម៖ គ. ការប្រព្រឹត្តចំពោះក្រុមគោលដៅ*។

[3508] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៦។

[3509] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៣៩។ *សូមមើលផងដែរ* កថាខណ្ឌ ៣៦១០ (គោលដៅមួយក្នុងចំណោមគោលដៅបដិវត្តន៍ជាច្រើនទៀត គឺការធ្វើឱ្យយុវជនយុវនារី បោះបង់ចោលកម្មសិទ្ធិឯកជន ដែលយោងតាមមនោគមន៍វិជ្ជារបស់ ប.ក.ក គឺរួមទាំងទំនាក់ទំនងជាមួយឪពុកម្តាយរបស់ពួកគេផងដែរ")។

[3510] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៩។ *សូមមើលផងដែរ* កថាខណ្ឌ ៣៣៥០-៣៣៥២ ដែលរៀបរាប់ពីសមាជិកជាច្រើននៃថ្នាក់ដឹកនាំបក្ស ដោយនិយាយពីគោលដៅបង្កើនចំនួនប្រជាជនឱ្យបានឆាប់រហ័ស, ៣៥៥៦-៣៥៥៧ ជាអ្វីដែល អ.ជ.ស.ដ យោងសំដៅសាក្សីជាច្រើន ដែលបាននិយាយថា គេប្រាប់ឱ្យពួកគេបង្កើតកូនឱ្យបានច្រើនតាមដែលអាចធ្វើបានសម្រាប់*អង្គការ* ទាំងបង្កើនចំនួនប្រជាជននៅតាមខេត្ត ដោយសារវៀតណាមមានប្រជាជនច្រើនជាង។

និយម"[3511]។ អ.ជ.ស.ដ បានសន្និដ្ឋានប្រកបដោយហេតុផលថា គោលនយោបាយនេះរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3512]។

984. ភាពសមហេតុផលនៃការសម្រេចរបស់ អ.ជ.ស.ដ ដែលថា គោលនយោបាយនីមួយៗនៃគោលនយោបាយទាំងប្រាំដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការធ្វើបដិវត្តន៍សង្គមនិយមនៅក្នុងកម្ពុជាប្រជាធិតេយ្យនោះ គឺជាភ័ស្តុតាងយ៉ាងច្បាស់ក្រឡែត[3513]។ យើងច្បាស់ណាស់ថា បដិវត្តន៍សង្គមនិយមរបស់ ប.ក.ក ជាចំណុចស្នូលរបស់វា គឺជារឿងឧក្រិដ្ឋ ដោយសាររចនាឡើងដើម្បីសម្រេចគោលដៅ តាមរយៈគោលនយោបាយនានារបស់បក្សដែលពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងគោលបំណងរួម។

### *មូលដ្ឋានទី ១៧៩៖ កំហុសនានាពាក់ព័ន្ធគោលគំនិតស្តីពីខ្មាំងរបស់ ប.ក.ក*[3514]

985. **គួរច្រានចោលមូលដ្ឋានទី ១៧៩ ដោយសារម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានប្រព្រឹត្តលើអង្គច្បាប់ និងអង្គហេតុ ពេលអង្គជំនុំជម្រះនេះបានសន្និដ្ឋានថា គោលនយោបាយរបស់ ប.ក.ក ត្រូវបានបង្ហាញតាមរយៈការវាយប្រហារប្រឆាំងនឹង "ខ្មាំង" ដែលជាគោលគំនិតមួយដែលបានវិវឌ្ឍន៍ជាបន្តបន្ទាប់។**

986. ក្រោយការពិនិត្យលើភ័ស្តុតាងទាំងមូល អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមនៅកម្ពុជាឱ្យបានលឿនតាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" ជនណាក៏

---

[3511] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤០ *យោង* ឯកសារ **E3/775** យុវជនយុវនារីបដិវត្តន៍ ខែមិថុនា ឆ្នាំ១៩៧៥ KH 00407098-99។ អ.ជ.ស.ដ ក៏បានកត់សំគាល់ផងដែរថា ការជ្រើសរើសប្តីប្រពន្ធគឺត្រូវធ្វើឡើងដោយមានបទបញ្ញាដូចជា "ដើម្បីធានានូវជ័យជម្នះនៃការតស៊ូវណ្ណៈ ចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យអ្នកដែលជាកម្លាំងវណ្ណៈអធន មានភាពស្អាតស្អំតាមដែលអាចធ្វើទៅបាន" *សូមមើល* កថាខណ្ឌ ៣៥៥៩។

[3512] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៨, ១៦៧, ១៦៦។

[3513] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៨, ៣៧៤៣។ *សូមមើលផងដែរ* កថាខណ្ឌ ៣២៦០-៣២៦៨, ៣៩៩១, ៣៩៩៥, ៣៩៩៧ (ការជម្លៀសប្រជាជន ដំណាក់កាលទី២ (កំហិតចំពោះតៃចាម)), ៣៩១៩-៣៩២៨ (ការបង្កើតការដ្ឋាន និងសហករណ៍), ៣៩៧៣-៣៩៨៧ (ការបង្កើត និងការដាក់ឱ្យដំណើរការនូវមន្ទីរសន្តិសុខ/គោលនយោបាយចំពោះខ្មាំង), ៣៩៩១-៣៩៩៨, ៤០០១-៤០១២, ៤០១៨-៤០២២, ៤០៥០-៤០៦១ (ការកំណត់គោលដៅលើក្រុមជាក់លាក់ ចាម វៀតណាម ពុទ្ធសាសនិកជន និងកម្មាភិបាលខ្មែរក្រហមមុនៗ), ៤០៦៤-៤០៦៧ (បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍), ៤០៦៨-៤០៧៥ (ការសម្រេចផ្នែកច្បាប់ស្តីពីការអនុវត្តគោលបំណងរួម)។

[3514] មូលដ្ឋានទី ១៧៩៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងគោលគំនិតស្តីពីខ្មាំងរបស់ ប.ក.ក* កថាខណ្ឌ ១៤៥៨-១៤៨៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦២ (អង់គ្លេស) ទំព័រ ៥៧ (បារាំង) ទំព័រ ៨៨ (ខ្មែរ)។

ដោយដែលគេយល់ថា ប្រឆាំងនឹងបដិវត្តន៍ ទោះជាការពិត ឬជាមនោគមន៍វិជ្ជាក៏ដោយ នឹងត្រូវបានចាត់ទុកថា"ខ្មាំង"[3515]។ អ្នកដែលជាប់ពាក់ព័ន្ធ ឬដែលគេគិតថា ជាប់ពាក់ព័ន្ធជាមួយក្រុមដែលតវ៉ានឹងគំនិតបដិវត្តជាងគេ ងាយរងគ្រោះទៅនឹងការចាត់ទុកថា "ខ្មាំង"[3516]ផងដែរ។ ព្រឹត្តិការណ៍ជាក់ស្តែងត្រូវបានគេបង្កើតឡើងសម្រាប់អ្នកដែលត្រូវធ្លាក់ចូលក្នុងជំពូកនេះ ធ្វើដូច្នេះគឺដើម្បីឱ្យគោលគំនិតនេះវិវឌ្ឍន៍ជាបន្តបន្ទាប់ សម្រាប់ឆ្លើយតបទៅនឹងមនុស្សដែលពាក់ព័ន្ធ ឬដែលគេគិតថាពាក់ព័ន្ធនៅក្នុង "អាកប្បកិរិយាប្រឆាំងបដិវត្តន៍"[3517]។ ដូចបានពិភាក្សាលម្អិតក្នុងចម្លើយតបនេះ ខ្មាំងត្រូវបានចាប់ដាក់គុក សួរចម្លើយ ធ្វើទារុណកម្ម ទទួលរងលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗ បង្ខំឱ្យធ្វើការយ៉ាងលំបាក និងជារឿយៗត្រូវបាត់ខ្លួន ឬពិឃាដ ទាំងអស់នេះសុទ្ធតែបានធ្វើឡើងមិនមែនតាមរយៈដំណើរការត្រឹមត្រូវឡើយ[3518]។

987. ភ័ស្តុតាងបង្ហាញយ៉ាងច្បាស់ថា មនុស្សភាគច្រើនបំផុតដែលត្រូវបានចាត់ទុកថា "ខ្មាំង" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាខ្មាំងនយោបាយ និងមនោគមន៍វិជ្ជានៅក្នុងប្រទេសកម្ពុជា មិនមែនជាខ្មាំងយោធាទេ។ ចុងក្រោយបង្អស់ ខ្មាំងទាំងនេះរួមមាន កម្មាភិបាលខ្មែរក្រហមមុនៗ ចាមជនស៊ីវិលវៀតណាម កម្មាភិបាល ប.ក.ក ដែល "ក្បត់" និងអ្នកផ្សេងទៀតដែលជាប់ពាក់ព័ន្ធជាមួយពួកគេ ដែល ប.ក.ក បានកំណត់គោលដៅថាខ្មាំង[3519]។ ក្នុងជំពូកនេះក៏រាប់បញ្ចូល អ្នកដែល

---

[3515] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៩, ៣៧៤៤, ៣៧៦០, ៣៧៦៣, ៣៧៦៥-៣៧៦៦, ៣៧៩៣, ៣៨១០, ៣៨១២, ៣៨៣៩, ៣៨៤៥។

[3516] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៦៦, ១៦៤១, ១៦៤៤, ៣២១៤, ៣៧៤៤, ៣៧៩៧, ៣៨៣៩, ៣៨៤៥-៣៥៤៦, ៣៨៤៨។

[3517] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៥, ១០៦០, ១៨៩២, ១៨៩៤-១៨៩៦, ១៨៩៨, ២៨៣៨, ៣២២៨, ៣៧៤៤, ៣៧៥២, ៣៧៦៣, ៣៧៦៥, ៣៧៧២, ៣៧៧៩, ៣៧៨៤, ៣៧៩៣ (ការប្រឆាំងនយោបាយ គឺស្មើនឹងសកម្មភាពខ្មាំង), ៣៨៣៩-៣៨៤០, ៣៨៤៤, ៣៨៤៦។

[3518] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៤។

[3519] *មមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤១០, ១៤៦៦, ១៦៤២-១៦៤៣, ១៦៤៦-១៦៤៧, ១៦៦០-១៦៦៣, ១៦៩០, ១៩២៩, ១៩៤៥, ២០១៦-២០២១, ២០៣០-២០៣៨, ២០៦៩, ២០៧២, ២៣២៩-២៣៣៥, ២៤៧៨, ២៤៨០, ២៤៨២, ២៤៨៦-២៤៩០, ២៤៩២, ២៥២៧, ២៥៣១, ៣២១៩, ៣២២៨, ៣២៧៤-៣២៨១, ៣២៨៥-៣៣០៤, ៣៣០៦-៣៣០៨, ៣៣១១-៣៣១៣, ៣៣៨៩-៣៣៩០, ៣៣៩៦, ៣៣៩៨, ៣៤០២, ៣៤០៧-៣៤១០, ៣៤១៦-៣៤១៧, ៣៧៥២, ៣៧៨៩-៣៧៩០, ៣៨៤៧, ៣៨៦០, ៣៩២៤-៣៩២៥។

មិនត្រូវបានចាត់ទុកថាប្រឆាំងនឹងបដិវត្តន៍ ឬភាពជឿនលឿនរបស់បដិវត្តន៍ផងដែរ ដូចជា អ្នកលួចអាហាររបស់សមូហភាព ឬអ្នកសម្តែងការមិនពេញចិត្តចំពោះរបបនេះជាដើម[3520]។

988. ភ័ស្តុតាងដែលនាំឱ្យ អ.ជ.ស.ដ ឈានដល់ការសន្និដ្ឋានទាំងនេះ មានច្រើនណាស់ រឹងមាំ និងមានភាពចម្រុះ។ ភ័ស្តុតាងទាំងនោះរួមមាន កំណត់ហេតុនៃកិច្ចប្រជុំរបស់ថ្នាក់លើ សេចក្តីឆ្លើយឆ្លងជាផ្លូវការ ដូចជា របាយការណ៍ និងទូរលេខ ការបោះពុម្ពផ្សាយរបស់ ប.ក.ក សុន្ទរកថា កំណត់ត្រាគុកដែលនៅសេសសល់ និងសក្ខីកម្មរបស់សាក្សីពីប្រភពជាច្រើន រួមទាំងជនរងគ្រោះ និងអតីតកម្មាភិបាល[3521]។ ភ័ស្តុតាងទាំងនេះបង្ហាញពីលំនាំនៅទូទាំងប្រទេសដែលមានលក្ខណៈរីករាលដាលយ៉ាងខ្លាំង និងត្រូវបានគេអនុវត្តស្រដៀងៗគ្នា ដែលគ្មានអ្វីអាចពន្យល់បាន ក្រៅតែអំពីការអនុវត្តគោលនយោបាយជាតិដែលបានជួយឧបត្ថមដោយមេដឹកនាំថ្នាក់ខ្ពស់បំផុតរបស់ ប.ក.ក ជាពិសេស ទាក់ទងនឹងឋានានុក្រមរដ្ឋបាល និងការរាយការណ៍ ដែលតម្រូវឱ្យមានការប្រកាន់ឱ្យបានខ្ជាប់ខ្ជួនចំពោះមាគ៌ាបក្ស[3522]។

989. ក្នុងមូលដ្ឋាននេះ ម្ចាស់បណ្តឹងសាទុក្ខលើកពីបញ្ហាបរិបទដែលគាត់ចោទថាអាចនឹងធ្វើឱ្យមានការផ្លាស់ប្តូរក្នុងការវិភាគរបស់ អ.ជ.ស.ដ ប្រសិនបើបញ្ហាទាំងនោះត្រូវបានពិចារណាត្រឹមត្រូវ[3523] និងការប្រើប្រាស់អភិក្រមតាមផ្នែក ដើម្បីជំទាស់ទៅនឹងតម្លៃភស្តុតាងនៃផ្នែកនីមួយៗនៃភ័ស្តុតាង។ អំណះអំណាងរបស់គាត់ខកខានក្នុងការដកចេញនូវចំណុចខ្លាំងពីកំណត់ហេតុជាភ័ស្តុតាង ដោយសារអំណះអំណាងទាំងនេះបំពានលើយុត្តិសាស្ត្រដែលបានកំណត់ បកស្រាយខុសចំពោះការវិភាគរបស់ អ.ជ.ស.ដ ឬ មិនគិតគូរលើភ័ស្តុតាងទាំងមូល។ ជាលទ្ធផល ម្ចាស់បណ្តឹងសាទុក្ខខកខានក្នុងការបង្ហាញឱ្យឃើញពីកំហុសណាមួយដែលនឹងនាំឱ្យមានអន្តរាគមន៍ពី អ.ជ.ត.ក រួមទាំង ការសម្រេចទាក់ទងនឹងចេតនារបស់គាត់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋប្រឆាំងនឹង "ខ្មាំង" និង

---

[3520] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨០, ១១៥៣, ១១៧៧, ១៣៦៣, ១៣៦៧, ១៤០៩-១៤១០, ១៦៤៨, ១៦៥២, ១៦៨៨, ៣៤២៦, ៣៧៤៤, ៣៧៩៣, ៣៨៤៦, ៣៨៤៨-៣៨៥០, ៣៨៥៧។

[3521] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២០៨, ១៤៣៨, ១៧១៧, ២០៨៦-២០៨១, ២១១៥-២១១៩, ២៦៤៤-២៦២៧, ២៨៦០-៨២៦២, ៣០២០-៣០២១, ៣៣៦១-៣៣៦២, ៣៧៤៤-៣៧៤៥, ៣៧៤៧-៣៧៤៨។

[3522] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៤-២៩៦, ៣១៧-៣២២, ៣៩០-៣៩១, ៣៩៧, ៤៩២-៥០១, ៥០៧-៥១៦, ៣៣០៤, ៣៥៤៧, ៣៩៧៤-៣៩៧៦, ៤០៤៥, ៤០៥៦, ៤០៥៩, ៤០៨១, ៤២០៧-៤២០៨។

[3523] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៤៦, ១៤៥០, ១៤៥៨, ១៤៦០-១៤៦១, ១៤៦៥, ១៤៦៧-១៤៧៨, ១៤៨៥, ១៤៨៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦២ (អង់គ្លេស) ទំព័រ ៥៧ (បារាំង)។

ការសម្រេចដែលថា "ការកម្ទេចខ្មាំង" តាមរយៈអំពើមនុស្សឃាត គឺជាមធ្យោបាយ មួយដែលធ្វើឱ្យគោលបំណងបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក ត្រូវតែសម្រេចបាន[3524]។

*អ.ជ.ស.ដ បានរៀបចំភស្តុតាងត្រឹមត្រូវនៅក្នុងបរិបទរបស់ខ្លួន*

990. **មុនឆ្នាំ១៩៧៥ និងក្នុងឆ្នាំ១៩៧៥៖** ម្ចាស់បណ្តឹងសាទុក្ខតវ៉ាដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ ខកខានមិនបានដាក់សុន្ទរកថា និងឯកសារទៅតាមបរិបទរបស់វាឱ្យបានត្រឹមត្រូវទេ ដោយចោទថា ធ្វើដូច្នេះនាំឱ្យអង្គជំនុំជម្រះនេះយល់ខុសទៅលើមូលដ្ឋានគោលនយោបាយ និងនាំឱ្យមានការយល់ជាទូទៅមិនត្រឹមត្រូវ និងលំអៀងអំពីខ្មាំង[3525]។ គាត់ពឹងផ្អែកលើតែឧទាហរណ៍មួយគត់ គឺបញ្ជាឱ្យសម្លាប់អតីតទាហាន លន់ នល់ ចំនួន ១៧ នាក់ ដើម្បីគាំទ្រលើអំណះអំណាងរបស់គាត់ដែលថា អ.ជ.ស.ដ បានប្រើប្រាស់ខុសចំពោះឯកសារផ្ទៃក្នុងរបស់កងទ័ពបដិវត្តកម្ពុជាពាក់ព័ន្ធនឹងសេចក្តីសម្រេចនៅមូលដ្ឋានដែលមិនបង្ហាញអំពីគោលនយោបាយរបស់ ប.ក.ក[3526]។ យ៉ាងណាមិញ បញ្ជានេះ ដែលបានចុះហត្ថលេខាដោយសមមិត្ត ពិន បង្ហាញយ៉ាងច្បាស់ថា តាមរូបភាពរបស់វា គឺបក្សជាអ្នកធ្វើសេចក្តីសម្រេចឱ្យសម្លាប់[3527]។ ក្រៅអំពីពាក្យជៀមជាមផ្សេងទៀតរបស់ម្ចាស់បណ្តឹងសាទុក្ខ គ្មានភស្តុតាងបង្ហាញ ឬសូម្បីតែសង្ស័យថា សមមិត្ត ពិន "ជាផ្នែកនៃអ្នកតស៊ូ" ក៏គ្មានផង[3528]។ ជាចុងក្រោយ អ.ជ.ស.ដ បានពិចារណាថា ការបញ្ជាឱ្យសម្លាប់ត្រូវបានគាំទ្របន្ថែមដោយសក្ខីកម្មរបស់ ឌុច ហើយក៏បានផ្អែកការសម្រេចរបស់ខ្លួនទាក់ទងនឹង

---

[3524] *ផ្ទុយពី* ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦២ (អង់គ្លេស) ទំព័រ ៥៧ (បារាំង)។

[3525] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៤០-១៩៤២, ១៩៤៥-១៩៤៧, ១៩៥០-១៩៥២។

[3526] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៥៤។

[3527] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៥៤ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥២ ជើងទំព័រ ១២៥១៧ *យោង* ឯកសារ **E3/832** សេចក្តីសម្រេចចិត្ត ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៥ KH 00068914 និងកត់សំគាល់ថា មានតែ ពិន ទេដែលបានចុះហត្ថលេខាលើបញ្ជានេះ និងគ្មានចម្លងជូននរណាម្នាក់ដែរ។ ប៉ុន្តែបញ្ជានេះ បានបញ្ជាក់យ៉ាងច្បាស់ថា *"បក្សបានពិនិត្យ និងសម្រេចកម្ទេច [ទាំង១៧ នាក់]*។ ស្នើសមមិត្តអនុវត្តតាម*គោលការណ៍របស់បក្ស"* (គូសបញ្ជាក់បន្ថែម)។

[3528] តាមពិត ពិន គឺជាមនុស្សជាទីទុកចិត្តរបស់បក្ស នៅទូទាំងរបបនេះ រួមទាំងក្នុងខែធ្នូ ឆ្នាំ១៩៧៨ នៅពេលគាត់ដឹកនាំកងទ័ពនៅសមរភូមិ ភូមិភាគបូព៌ាផង។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៥៨៤៧។

គោលនយោបាយ ប.ក.ក ទៅលើកម្ពុជាភិបាលខ្មែរក្រហមមុនៗ នៅពេលធ្វើការវាយតម្លៃលើភ័ស្តុតាងទាំងមូល[3529]។

991. ទាក់ទងនឹងការបែងចែករវាងខ្មាំងមនោគមន៍វិជ្ជា និងខ្មាំងយោធា ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់ភ័ស្តុតាង ឬសូម្បីតែបង្ហាញអត្តសញ្ញាណថាតើ នៅត្រង់ចំណុចណា ឬរបៀបណាដែល អ.ជ.ស.ដ ត្រូវបានចោទថា ខកខានមិនបានធ្វើការបែងចែករវាងខ្មាំងទាំងពីរនៅក្នុងពេលវេលានៃឆ្នាំ១៩៧៥ ដូចបានពិភាក្សានៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍នោះ[3530]។ ដោយគ្មានការបង្ហាញដូច្នេះ ការអះអាងតែម្យ៉ាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសនោះ គឺជាការបរាជ័យ។ ស្រដៀងគ្នានេះដែរ ការអះអាងតែម្យ៉ាងរបស់ម្ចាស់បណ្តឹងសាទុក្ខលើភ័ស្តុតាងតែមួយ ដែលថា អ.ជ.ស.ដ មានកាតព្វកិច្ចទទួលស្គាល់ថា ប្រជាជនថ្មី និងព្រះសង្ឃ មិនត្រូវបានចាត់ទុកថាជាខ្មាំងឡើយ[3531]។ ចំណុចនេះមិនត្រឹមតែខកខានមិនបានបំពេញបទដ្ឋានសើរើបណ្តឹងសាទុក្ខប៉ុណ្ណោះទេ ថែមទាំងបកស្រាយខុសចំពោះការសម្រេចរបស់ អ.ជ.ស.ដ ទាក់ទងនឹងក្រុមទាំងពីរនេះផងដែរ ដូចបានពិភាក្សានៅកន្លែងផ្សេងទៀតនៅក្នុងចម្លើយតបនេះ[3532]។

---

[3529] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៨៧ (បញ្ហាដែលមានការបញ្ជាក់បន្ថែមដោយសក្ខីកម្ម ឌុច ថា ពិន និង ហ៊ី ទាំងពីរនាក់បានប្រាប់គាត់ថា ទាហាន លន់ នល់ ត្រូវបានកម្ទេចជាប្រព័ន្ធ), ៨៥៩-៨៦១, ៨៦៣-៨៦៧, ១០៦២-១០៦៣, ១០៧៧, ១០៨០, ១១៧៥, ១៦៦០-១៦៦៣, ១៦៩០, ២៤៨៦-២៤៩២, ២៧៩១, ២៧៩៥-២៨០១, ២៨៣៩-២៨៤១, ៣៩៨២, ៤០៣៩-៤០៤៩។

[3530] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៤ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៦ ជើងទំព័រ ១២៤៩៥ ដែលយោងកំណត់ត្រាប្រចាំថ្ងៃរបស់ អៀង សារី គ្របដណ្តប់ពីឆ្នាំ១៩៧៥-១៩៧៩ មិនមែនឆ្នាំ១៩៧៥ ទេ។

[3531] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៤ *ជំទាស់នឹង* (*យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥៧ ជាផ្នែកនៃពហុកថាខណ្ឌ ទិដ្ឋភាពទូទៅនៃកាលប្រវត្តិនៃភ័ស្តុតាងអំពីខ្មាំងពិត និងអ្នកដែលគេយល់ថាខ្មាំង ទាក់ទងនឹងឆ្នាំ១៩៧៥ កថាខណ្ឌ ៣៧៤៤-៣៧៤៨, ៣៧៥១-៣៧៦៣), ១៤៧៧ (មិនមានយោងអ្វីទាំងអស់)។

[3532] ប.ក.ក មើលឃើញព្រះពុទ្ធសាសនា និងការអនុវត្តពុទ្ធសាសនា មានវិសមិតភាពនឹងបដិវត្តន៍ ដូច្នេះការធ្វើជាសង្ឃត្រូវបានកំណត់គោលដៅដោយផ្អែកលើអត្តសញ្ញាណសាសនារបស់ពួកគាត់។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨៨, ១០៩៣, ១០៩៨-១១០០, ១១០៣-១១០៨, ៣៧៥៧ (កត់សំគាល់ថា ៩០-៩៥% នៃព្រះសង្ឃបានបោះបង់ចោលភាពជាសង្ឃរបស់ខ្លួន ហើយការអនុវត្តខាងសាសនាបានបាត់បង់រហូតដល់ "ស្រទាប់ពិសេស" នេះនៃសង្គម ដូច្នេះស្រទាប់ពិសេសនេះមិនមានអ្វីគួរឱ្យព្រួយបារម្ភទេ), ៣៨៥០, ៤០១៥-៤៩២២។ ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៨, ១៨៨។ ប.ក.ក បានយោងសំដៅលើប្រជាជនថ្មីថាជា ប្រភេទមនុស្សខុសគេដែលគ្មានតម្លៃ និងវិសមិតភាពនឹងគោលដៅមនោគមន៍វិជ្ជារបស់ ប.ក.ក ដូច្នេះពួកគេមានហានិភ័យងាយនឹងត្រូវបានចាត់ទុកថា ខ្មាំង ជាងប្រជាជនមូលដ្ឋាន និងកំណត់គោលដៅដោយមូលហេតុនយោបាយ។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ

992. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ជ គួរទទួលទណ្ឌកម្មចំពោះ "ការវាយតម្លៃដោយលំអៀងទាំងស្រុង" លើរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យនោះ គឺជាការមិនគិតគូរដល់ការពិត[3533]។ អ.ជ.ស.ជ បានវាយតម្លៃយ៉ាងត្រឹមត្រូវលើឯកសារនេះ អមជាមួយឯកសារផ្សេងទៀត ដោយបានបង្ហាញឱ្យឃើញថា បទប្បញ្ញត្តិភាគច្រើនក្នុងរដ្ឋធម្មនុញ្ញនេះមិនបានសម្រេចទាំងស្រុងឡើយ ឬមិនត្រូវបានគោរព ឬមានលក្ខណៈវៀចវេរ[3534]។

993. ការអះអាងផ្សេងទៀតរបស់ម្ចាស់បណ្ដឹងសាទុក្ខក៏បរាជ័យដែរ។ អ.ជ.ស.ជ *មិនធ្លាប់* អះអាងថាពាក្យថា "មេក្បត់ លន់ នល់" មានប្រភពចេញពី ប.ក.ក ទេ[3535] អង្គជំនុំជម្រះនេះគ្រាន់តែបានធ្វើ

---

១០៨០, ១១៧៤, ១១៧៧, ១៣៨០, ១៣៨២-១៣៨៤, ១៦៤១ (ជើងទំព័រ ៥៥៧៧), ១៦៥៣, ៣៨៤៨, ចម្លើយតបទៅនឹងមូលដ្ឋានទី ១១៨-១១៩។

[3533] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៥៥ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦៣។

[3534] សម្រាប់ភស្តុតាងគាំទ្រដល់ការសម្រេចនៅក្នុង ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦៣ ដែលថា "កម្រិតខ្ពស់បំផុតនៃទណ្ឌកម្មដែលបានដាក់ចំពោះសកម្មភាពប្រទូសរ៉ាយ" ដូចបានគូសបញ្ជាក់នៅក្នុងឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា១០ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៤-២៥០ (មុនឆ្នាំ១៩៧៥), ២៩៤-២៩៥, ៣៥៨, ៣៧៦-៣៧៧, ៣៧៩-៣៨២, ៣៨៦, ២០៦៩, ២០៧២, ២១៣៥-២១៤៣, ២១៤៩, ២១៦១-២១៨០, ២២៣៣-២២៤៣, ២២៥៥-២២៦០, ២២៦៥-២៣២៨, ២៣៥០-២៣៥១, ២៣៧៧-២៣៩៩, ២៤០២, ២៤១២-២៤២៣, ២៥០២-២៥១៨, ២៥២២-២៥៣១, ២៧១៤-២៧២៩, ២៧៤២-២៧៧៤។ សម្រាប់ភស្តុតាងផ្ទុយនឹងមាត្រា២០ នៃរដ្ឋធម្មនុញ្ញ ដែលធានា "សិទ្ធិសេរីភាពខាងសាសនា" *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦៤ (មុនឆ្នាំ១៩៧៥), ១០៨៧-១១០៩, ៣២១៥, ៣២៣០-៣២៥០។ សម្រាប់ការធានាផ្សេងទៀតនៅក្នុងរដ្ឋធម្មនុញ្ញដែលមិនធ្លាប់បានដាក់ឱ្យអនុវត្តសោះ *សូមមើល* ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា៥-៧ ទាក់ទងនឹង អំណាចគឺនៅលើសភាតំណាងប្រជាជន ផ្ទុយពីភស្តុតាងដែលថា មានតែមុខ (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១២-៤១៥, ៤១៩, ៥៣៧, ៥៩៦។ ឯកសារ **E3/259** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា៩ ទាក់ទងនឹងយុត្តិធម៌ដែលត្រូវគ្រប់គ្រងតាមប្រព័ន្ធច្បាប់កម្ពុជាប្រជាធិបតេយ្យ មិនដែលកើតមានទេ (*សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៦, ៤១២-៤១៣, ៤១៧-៤១៨។ *សូមមើលផងដែរ* ភស្តុតាងអំពីកិច្ចខិតខំប្រឹងប្រែងរបស់ ប.ក.ក ក្នុងលាក់កំបាំងការងារផ្ទៃក្នុងរបស់ខ្លួនពីសាធារណជន (ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៤២, ៤១៣, ៣៩៣៨, ៣៦២, ៤២០៨, ៤២៦៨)។ *សូមមើលបន្ថែម* ចម្លើយតបទៅនឹងទឡ្ហីករណ៍ ១៧៧ ទាក់ទងនឹងការចោទប្រកាន់របស់ម្ចាស់បណ្ដឹងសាទុក្ខដែលថា អ.ជ.ស.ជ បានប្រើបទដ្ឋានទ្វេភាពដើម្បីធ្វើការវិភាគទៅលើរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។

[3535] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៥៦។ អ.ជ.ស.ជ មិនបានអះអាងលើចំណុចនេះនៅក្នុងកថាខណ្ឌដែលរងការជំទាស់ ឬនៅក្នុងសេចក្ដីយោងផ្សេងទៀតទៅនឹងឃ្លានេះទេ។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥៥, ៣៧៧៣, ៣៨១៣, ៣៨២៩, ៣៨៤៧, ៤១០៧, ៤១៦៨។

ការកត់សំគាល់ថា ទង់បដិវត្តន៍ ចុះខែសីហា ឆ្នាំ១៩៧៥ បានប្រើឃ្លានេះដដែលៗតែប៉ុណ្ណោះ[3536]។ លើសពីនេះ អ.ជ.ស.ដ បានពិចារណាលើបរិបទនៃពេលវេលា ពេលដែលអង្គជំនុំជម្រះថ្លែងថា FUNK បានថ្កោលទោស លន់ នល់ ថា ជាជនម្នាក់ក្នុងចំណោមជនក្បត់ទាំងប្រាំពីរ ដែលមានការទទួលខុសត្រូវចំពោះការធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ[3537]។ ស្រដៀងគ្នានេះ អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ ពិនិត្យលើឯកសារចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ថា មិនត្រូវនឹងបរិបទនោះ ក៏ជាការអះអាងដែលគ្មានមូលដ្ឋាន ដោយហេតុថា ខ្លួនបកស្រាយខុសចំពោះខ្លឹមសារនៃឯកសារ[3538]។ ដូចដែលឯកសារនេះពិតជាបានពិភាក្សាពីសារសំខាន់នៃសហករណ៍ដូចម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់ក្តី[3539] វាមិនបានកម្រិតកិច្ចពិភាក្សាឱ្យនៅត្រឹមតែក្នុងឆ្នាំ១៩៧០នោះទេ។ ផ្ទុយទៅវិញ វាបានសង្កត់ធ្ងន់អំពីសារសំខាន់ជាយុទ្ធសាស្ត្រចំពោះការកសាង ទាំងក្នុងពេល "បច្ចុប្បន្ន និងទៅអនាគត"[3540] ដោយជឿនលឿនពី ជាមូលដ្ឋានបង្អែកទៅជា"ការការពារប្រទេសខ្លាំង" ដែល "ខ្មាំងណាក៏ចូលមិនចុះ"[3541]។ ការដាក់បញ្ចូលឯកសារនេះពីសំណាក់ អ.ជ.ស.ដ ទៅក្នុងផ្នែកទិដ្ឋភាពទូទៅនៃកាលប្រវត្តិរបស់ខ្លួនចំពោះការយល់ដឹងអំពីខ្មាំងរបស់ ប.ក.ក ក្នុងឆ្នាំ១៩៧៦ ជាការសមហេតុផល និងតំណាងយ៉ាងត្រឹមត្រូវលើខ្លឹមសារនៃឯកសារ។

---

[3536] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥៥។

[3537] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣១។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៦ (ដែលថ្លែងថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសមួយផ្នែកដោយសារ "បរិបទនេះមានសារសំខាន់ជាមូលដ្ឋានដែលត្រូវបង្ហាញ")។

[3538] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៦ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៧៦ (ដែលពិភាក្សា ឯកសារ **E3/50** ខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ទំព័រ ២-៤, ១០)។

[3539] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៦។

[3540] *សូមមើលឧទាហរណ៍* ឯកសារ **E3/50** ខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ទំព័រ ១០ ("សហករណ៍ មិនគ្រាន់តែជាមូលដ្ឋានបង្អែក ដើរតួនាទីសំខាន់ ក្នុងការសម្រេចមហាជ័យជំនះថ្ងៃ១៧ មេសា ១៩៧៥ កន្លងមកទេ។ សហករណ៍ ធានានូវមហាជ័យជំនះ នៃមហាបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម ពេលនេះ និងទៅអនាគត")។

[3541] *សូមកត់សំគាល់ថា* សម្រង់នេះមាននៅក្នុងវាក្យខណ្ឌដែលមានចំណងជើងថា "សហករណ៍ ជាកម្លាំងការពារប្រទេសបច្ចុប្បន្ន និងទៅអនាគតទៀត"។ *សូមមើល* ឯកសារ **E3/50** ខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ទំព័រ ១២។

994. **១៩៧៦ ដល់ ១៩៧៨៖** ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុដោយសារមិនដាក់សក្ខីកម្មរបស់ ឌុច ទៅក្នុងបរិបទត្រឹមត្រូវនោះ ក៏បរាជ័យដែរ[3542]។ ភ័ស្តុតាងលើសលប់អំពីសិទ្ធិអំណាចដ៏ទូលំទូលាយរបស់មជ្ឈិមបក្ស លើការសម្រេចផ្សេងៗរបស់ ស-២១ បង្ហាញថា អំណះអំណាងរបស់គាត់ទាក់ទងនឹងប្រសិទ្ធភាពនៃការរក្សាការសម្ងាត់ចំពោះសកម្មភាពរៀនសូត្រនៅ ស-២១ ចំពោះការទទួលខុសត្រូវដោយផ្ទាល់របស់យោធាលើ ស-២១ ដូចដែលបានចោទប្រកាន់[3543] និងចំពោះសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចស្វ័យភាពរបស់ សុន សេន នៅទីនោះ គឺជារឿងមិនពិត[3544]។ ការអះអាងមិនពិតទាំងនេះ គឺដោយសារយើងមានភ័ស្តុតាងបញ្ជាក់ថា ជាឧទាហរណ៍ (i) សុន សេន គ្រប់គ្រង ស-២១ តាមសមត្ថកិច្ចរបស់គាត់ក្នុងនាមជាបុគ្គលនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ មិនមែនក្នុងមុខតំណែងសេនាធិការរបស់គាត់ទេ; [3545] (ii) ឌុច គ្រាន់តែបានទទួលបញ្ជា និងបញ្ជូនរបាយការណ៍អំពីសន្តិសុខ ពីនិងទៅគណៈកម្មាធិការអចិន្ត្រៃយ៍, "៨៧០" ឬ *អង្គការ* ប៉ុណ្ណោះ ដែលបើតាមការអនុវត្តជាក់ស្តែងត្រូវបានកំហិតត្រឹម សុន សេន, នួន ជា និង ប៉ុល ពត និង ប៉ង់ ដែលជាប្រធាន ស-៧១ តែនៅពេលណាមានការណែនាំរបស់ នួន ជា;[3546] (iii) ឌុច មិនត្រូវបានអនុញ្ញាតឱ្យបញ្ជូនរបាយការណ៍ ឬចម្លើយសារភាព ស-២១ ទៅគណៈកម្មាធិការសេនាធិការឡើយ;[3547] (iv) មានតែគណៈអចិន្ត្រៃយ៍ប៉ុណ្ណោះអាចផ្សព្វផ្សាយឯកសារ ស-២១ ទៅកាន់ថ្នាក់លើរបស់អ្នកសារភាព;[3548] (v) ថ្នាក់លើរបស់ ឌុច គឺជាអ្នក

---

[3542] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦០។

[3543] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៤ ទាក់ទងនឹងអំណះអំណាងមិនត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការត្រួតត្រារបស់យោធាលើ ស-២១ ជាពិសេស ការរកឃើញរបស់ អ.ជ.ស.ដ ដែលថា ការទទួលខុសត្រូវតែមួយគត់របស់សេនាធិការ គឺផ្តល់ការគាំទ្រផ្នែកប្រតិបត្តិការ ចំណែកគណៈកម្មាធិការអចិន្ត្រៃយ៍ជាអ្នកចេញសេចក្តីណែនាំផ្សេងៗទាក់ទងនឹងបញ្ហាសន្តិសុខ ដូចជាការសួរចម្លើយ និងការសម្លាប់ជាដើម។

[3544] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦០ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦៧-៣៧៦៨។

[3545] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៨៨, ២១៩៧-២១៩៨, ២២០៩។

[3546] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦២, ២១៨៣, ២១៨៦, ២១៨៩-២១៩០, ២១៩៧, ២១៩៩-២២០២, ២២០៦, ២២០៩-២២១៥, ២២១៧, ២២២០-២២២៤, ២២២៦-២២៣២, ២២៦១-២២៦២, ២២៦៨, ២២៧០, ២២៧៣-២២៧៥, ២២៧៩, ២២៨១, ២២៨៧-២២៨៩, ២៣១១, ២៣១៦-២៣១៨, ២៣២៣, ២៣៣១-២៣៣២, ២៤១២, ២៤៥២, ២៤៥៧, ២៤៦២, ២៤៦៧, ២៤៧៣, ២៤៧៥, ២៤៩៧-២៤៩៨, ២៥០៣, ២៥០៩, ២៥២៧, ២៥៥៥-២៥៥៧។

[3547] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២១៧។ *សូមមើលផងដែរ* កថាខណ្ឌ ២១៨៩, ២១៩១, ២១៩៧។

[3548] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២៧៧, ២២២៥, ២២៣៣-២២៣៥។

បានទទួលដំណឹងអំពីចម្លើយសារភាពរបស់អ្នកទោស ជាអ្នកដែលបានទទួលដំណឹងពេញលេញអំពីការប្រើទារុណកម្មនៅក្នុងពេលសួរចម្លើយនៅ ស-២១ និងបានណែនាំ ឌុច ពីរបៀបដែលត្រូវចាត់ការបន្ត;[3549] និង (vi) មជ្ឈិមបក្សមានសិទ្ធិចំពោះព័ត៌មានសម្ងាត់ ដែលថ្នាក់ក្រោមមិនមាន[3550]។ តាមស្មារតីនៃភ័ស្តុតាងទាំងនេះ ការសម្រេចរបស់ អ.ជ.ស.ដ មិនអាចនិយាយថា មិនសមហេតុនោះឡើយ[3551]។

995. អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ ខកខានមិនបានពិចារណាលើបរិបទនៃវាក្យសព្ទនោះ ក៏គ្មានមូលដ្ឋានដែរ។ ទាក់ទងនឹងនិយមនៃពាក្យ "កម្ទេច" អ.ជ.ស.ដ បានទទួលស្គាល់យ៉ាងច្បាស់ថា អត្ថន័យគឺអាស្រ័យលើបរិបទដែលគេប្រើ[3552]។ យ៉ាងណាមិញ តាមឯកសារ និងសាក្សីជាច្រើនមកពីទូទាំងប្រទេស បានបញ្ជាក់យ៉ាងច្បាស់ថា ពាក្យថា "កម្ទេច" ត្រូវបានគេយល់យ៉ាងទូលំទូលាយថា "សម្លាប់" ឬ "ពិឃាដ" សូម្បីនៅក្រៅ ស-២១[3553]។ ការសន្និដ្ឋានរបស់

[3549] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២០២, ២២២០-២២២៩, ២២៣២-២២៣៣, ២២៧៣-២២៧៥, ២២៨០-២២៨២, ២២៨៦-២២៨៩, ២២៩១, ២៣០៦, ២៣១១, ២៣១៣-២៣១៨, ២៣២១, ២៣២៣, ២៣៧៣, ២៤១២-២៤២៣, ២៤៩១, ២៥៨៩។

[3550] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦០, ៣៧៩៣, ៣៨៦២, ៣៩៥៨។ *សូមមើល* ចម្លើយតបទៅនឹង ទទ្បីករណ៍ ១៩៥ (គោលការណ៍រក្សាការសម្ងាត់)។

[3551] *សូមមើលបន្ថែម* ចម្លើយតបទៅនឹង ទទ្បីករណ៍ ១៨៤ ទាក់ទងនឹងអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការរកឃើញជាទូទៅអំពីសេចក្តីសម្រេចឃោឃាជាក់លាក់នៅ ស-២១ និងមន្ទីរសន្តិសុខផ្សេងទៀត(*ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦២)។

[3552] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨០១, ៣៨៥៨, ៣៨៩៦ (ឧទាហរណ៍ជាតួរយ៉ាងមួយដែលបរិបទនេះហាក់ដូចជាបានកើតឡើងមែនជាមួយនឹងការឱ្យនិយមន័យរបស់ ពេជ ជឹម)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦០-១៤៦១ (ដោយអះអាងថា ពាក្យថា "កម្ទេច" មានន័យសម្លាប់នៅតែមន្ទីរ ស-២១ ដោយឱ្យដឹងថា ទីកន្លែងផ្សេងទៀត មានន័យថា "បំបាត់ផ្នែកគំនិត[វណ្ណៈ]" ដូចបានពន្យល់ដោយ ពេជ ជឹម)។

[3553] *សូមមើលឧទាហរណ៍* **មន្ទីរសន្តិសុខក្រាំងតាចាន់៖** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨៧១, ២៦៦៩-២៦៧០, ២៧៧២ ("អ្នកយាមឈ្មោះ វ៉ាន់ សឿន បានផ្តល់សក្ខីកម្មថា គេចាក់ភ្លេងឮៗតាម 'កូនធុងបាសពីរតូចៗ' នៅពេល 'គេធ្វើការបោសសម្អាត[កម្ទេចអ្នកទោស]ហ្នឹងតែម្តង'")។ [...] ហ៊ិន គឹមសេង បានប្រាប់ ក.ស.ច.ស ថា គេចាក់ភ្លេងតាមឧបករណ៍បំពងសំឡេងនៅពេលសម្លាប់អ្នកជាប់ឃុំ")។ **ត្រាំកក់៖** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៣៤ ជើងទំព័រ ១០០៣៨ *យោង* ឯកសារ **E1/405.1** ជិន គឹមធុង ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ម៉ោង 15.17.38-15.19.43 ទំព័រ ៦០ បន្ទាត់ ២៣-ទំព័រ ៦១ បន្ទាត់ ១៣ ([មានអ្នកទោស]"រយនាក់ហ្នឹង[បានស្លាប់] ដោយសារខ្ញុំសរុបទាំងអ្នកដែលត្រូវគេកម្ទេច ទាំងអ្នកដែលមានជំងឺឈឺស្លាប់នៅក្នុងមន្ទីរឃុំឃាំង។ ហើយការសរុបជាភាគរយ ខ្ញុំសុំជម្រាបត្រឹមពាក្យថា អ្នកដែលស្លាប់ដោយជំងឺ គឺមានចំនួនតិចជាងអ្នកដែលត្រូវកម្ទេច")។ **ទំនប់ ១ មករា៖** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៥៣៧២ *យោង* ឯកសារ **E3/7765** កំណត់ហេតុស្តាប់ចម្លើយ យិន ដួត KH 00321793-94

អ.ជ.ស.ដ បានពឹងផ្អែកយ៉ាងសមហេតុផលលើភស្តុតាងទាំងនេះ។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ បានដកចេញពាក្យ "*ភាពបរិសុទ្ធ*" ពីបរិបទ ដើម្បីពិចារណាលើទស្សនៈរើសអើងពូជសាសន៍ប្រឆាំងនឹងចាម និងវៀតណាមនោះ ក៏ជាការអះអាងគ្មានមូលដ្ឋានដូចគ្នា[3554]។ ដូចម្ចាស់បណ្តឹងសាទុក្ខយល់ស្របដែរថា អ.ជ.ស.ដ បានទទួលស្គាល់ទាំងស្រុងអំពីការយល់ដឹងដែលបានពន្យល់តាមរយៈលក្ខន្តិកៈ ប.ក.ក ក្នុងការរក្សាបក្សឱ្យស្អាតស្អំ[3555]។ ក៏ប៉ុន្តែ ភស្តុតាងជាសក្ខីកម្ម និងជាឯកសារដ៏សន្ធឹកសន្ធាប់បានបង្ហាញយ៉ាងច្បាស់ថា នេះមិនមែនជាការអនុវត្តតែមួយចំពោះពាក្យ "*ភាពបរិសុទ្ធ*"នោះទេ ដោយហេតុថា ប.ក.ក បានកំណត់ដើម្បីបង្កើតសង្គមខ្មែរមួយ

---

("អ្នកទោសត្រូវបានកម្ទេចនៅពេលមេឃងងឹត។ អ្នកយាមជាទូទៅបានជីករណ្តៅនៅពាក់កណ្តាលថ្ងៃមុនពេលកម្ទេចអ្នកទោស។ អ្នកទោសត្រូវបានប្រាប់ឱ្យអង្គុយចុះលើដីមានចម្ងាយពី ៤ ទៅ ៥ ម៉ែត្រពីរណ្តៅ។ គេវាយអ្នកទោសពីក្រោយចំក្បាល ដោយវាយនឹងដំបងឫស្សី ឬត្បូងចប។ បន្ទាប់ គេអូសសាកសពយកទៅកប់នៅក្នុងរណ្តៅ")។ **<u>ព្រលានយន្តហោះកំពង់ឆ្នាំង៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៨៦, ជើងទំព័រ ៦១០៥។ **<u>ស្រុក ត្រាំកក់៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨០, ជើងទំព័រ ៤៦៧៨ *យោង* ឯកសារ **E3/9010** បទសម្ភាសន៍ **DC-Cam** ជាមួយ ជុំ សេង KH 00730784 ("វៃចោលហើយ ហើយយកទៅវៃចោលបើថាយ៉ាងណាទៅ គឺប្រាប់វរៈ ព្រឹកឡើងគឺប្រធានវរៈ ប្រាប់ថា បងអើយ! អានោះខ្ញុំកំចាត់ចោលហើយ")។ **<u>ចាម៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៩ (ភស្តុតាងរបស់ សុះ រំលី), ៣២៩៨ ជើងទំព័រ ១១២០៦ *យោង* ឯកសារ **E1/346.1** សេង ស្រ៊ុន ប្រតិចារិក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង 11.11.04-11.15.48, ទំព័រ ៣៣ បន្ទាត់ ២៣ - ទំព័រ ៣៤ បន្ទាត់ ១៦ ("ពេលដែលខ្ញុំនាំ [ជនជាតិចាម ទៅកាន់វត្តអូរត្រកួន]") ទៅហើយ [...] ខ្ញុំជួបឈ្មោះ មឿន ហ្នឹងខ្ញុំថា ម៉េច មឿន បងប្អូនពួកចាម គេចាប់យកមកល្ងាចមិញនោះ ម៉េចទៅហើយ? គាត់ថា អូ! វៃចោលអស់យប់មិញទៅហើយ គ្មានសល់មួយទេ វៃទាំងយប់ហ្នឹងតែម្តង។ វៃទល់តែម៉ោងជិតពីរជណ្តប់ បានអស់។ រួចខ្ញុំសួរបញ្ជាក់ថា [...] អត់មានសល់ខ្លះទេ ថារឿងបងប្អូនចាម អត់មានសល់ទេ គេយកមកសម្លាប់ក្នុងពេលយប់តែមួយហ្នឹងដែរ")។ **<u>ជនជាតិវៀតណាម:</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២៤, ៣៤៦៧ ជើងទំព័រ ១១៦៩៦ *យោង* ឯកសារ **E1/361.1** ប្រាក់ ឌឿន ប្រតិចារិក ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 15.19.53-15.27.10 ទំព័រ ៦៨ បន្ទាត់ ១៨ - ទំព័រ ៦៩ បន្ទាត់ ២២ ("គេបានប្រាប់ខ្ញុំថា គេយក[វៀតណាមទាំងនោះ]ទៅសម្លាប់ហើយ គេយកអត់ទុកទេ គេប្រាប់ត្រង់។ មកព្រឹកឡើងបានគេប្រាប់យើងថា គេយកទៅកម្ទេចហើយ។ គេអត់ថា "សម្លាប់"ទេ គេថា "កម្ទេច"។ បាទ អង្គាល់នៅសម័យហ្នឹងគេប្រាប់ថាកម្ទេច។ [...] ប្រធានកងខ្ញុំបាទ គឺថាបានបញ្ជាក់ថា ព្រឹកឡើងបានប្រាប់ខ្ញុំថា ពូតាំងស្មារតីទៅ ព្រោះប្រពន្ធកូនអត់មានកើតមកវិញទៀតទេ។ អង្គការបានកម្ទេចហើយ")។ **<u>អតីតកម្មាភិបាលខ្មែរក្រហម:</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥២ *យោង* ឯកសារ **E3/832** សេចក្តីសម្រេចចិត្ត ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៥ KH 00068914។

[3554] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤២៧, ១៤៥៩ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៣។ ម្ចាស់បណ្តឹងសាទុក្ខតវ៉ាទាំងខុសថា ពាក្យនេះ មានន័យតែម្យ៉ាងថា ប.ក.ក និងសមាជិកបក្សម្នាក់ៗត្រូវតែស្អាតបរិសុទ្ធ "ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង" ជានិច្ច។

[3555] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៩ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦៥។

ដែលគ្មានការបែងចែកវណ្ណៈ"[3556]។ ការបកស្រាយរបស់ អ.ជ.ស.ដ បានកើតចេញពី ប.ក.ក ដែលបង្ខំឱ្យចាម បោះបង់ចោលការអនុវត្តវប្បធម៌ និងសាសនារបស់ខ្លួន ដើម្បីបញ្ចូលជាមួយខ្មែរ[3557] តាមរយៈការបំបែក ការកំណត់គោលដៅ និងជាចុងក្រោយ ការកម្ទេចសហគមន៍ចាម បន្ទាប់ពីមានក្រុមចាមតូចៗមិនព្រមធ្វើតាម[3558] ព្រមទាំងការសម្លាប់ជនជាតិវៀតណាមដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ជាពិសេស គឺដើម្បី "ថែរក្សា" "ពូជសាសន៍កម្ពុជា" ពេលដែលសង្គ្រាមជាមួយវៀតណាមបានផ្ទុះឡើង[3559]។

996. ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានមើលរំលងផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម លើ "ប្រតិកម្មជាផ្លូវការ"របស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៧[3560]។ អ.ជ.ស.ដ បានរៀបរាប់យ៉ាងច្បាស់លាស់អំពីបរិបទនៃភាពប្រទូសរ៉ាយខាងយោធានានានៅក្នុងការវិភាគរបស់ខ្លួនលើឯកសារទាំងនេះ[3561]។

---

[3556] *សូមមើលឧទាហរណ៍* ឯកសារ **E1/301.1** ឌិ ហ្វូ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.05.13-10.11.17 ទំព័រ ១៦ បន្ទាត់ ២៣ - ទំព័រ ១៧ បន្ទាត់ ២០។ ឯកសារ **E1/302.1** ឌិ ហ្វូ ប្រតិចារឹក ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ទំព័រ ៤៣ បន្ទាត់ ៥-៧ ("ក្នុងប្រទេសកម្ពុជា យើងមានតែប្រជាជនតែមួយទេ គឺខ្មែរតែម្តង។ គ្មានអ្នកថ្មី គ្មានអ្នកចាស់ គ្មានចាម គ្មានជ្វាអីទេ គឺខ្មែរទាំងអស់")។

[3557] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៧-៣២១៩, ៣២២៨, ៣២៣២-៣២៥០, ៣២៥២-៣២៥៣។

[3558] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៩, ៣២២១-៣២២៨, ៣២៥១-៣២៦៨, ៣២៧២-៣៣០៤។

[3559] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០២, ៣៤០៦-៣៤០៧, ៣៤១០ (ពិភាក្សាលើទូរលេខ ចុះខែសីហា ឆ្នាំ១៩៧៨ ពីគណៈភូមិភាគបស្ចិម រាយការណ៍ជូនអង្គការថា ជាផ្នែកនៃប្រតិបត្តិការ "សម្រិតសម្រាំង"របស់ខ្លួន ក្នុងកន្លងមក ពួកគេបានកម្ទេច "ប្រជាជនវៀតណាម ១០០ - ទាំងតូចទាំងធំ ទាំងក្មេង ទាំងចាស់"), ៣៤២០-៣៤២៨, ៣៤៥២-៣៤៦១, ៣៤៦៦-៣៤៧១, ៣៤៧៧-៣៤៨៨, ៤២៣៧-៤២៣៨។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥ (គោលនយោបាយ ប.ក.ក ក្នុងការកំណត់គោលដៅជនជាតិវៀតណាម)។

[3560] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៥។

[3561] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៧ ("អង្គជំនុំជម្រះបានកត់សម្គាល់ថា នៅពេលអាននៅក្នុងបរិបទជាមួយនឹងជម្លោះប្រដាប់អាវុធដែលកំពុងបន្តអនុវត្ត សេចក្តីណែនាំទាំងនេះសំដៅជាចម្បងលើកងកម្លាំងប្រដាប់អាវុធវៀតណាម"), ៣៣៩៨, ៣៤០២ ("អង្គជំនុំជម្រះទទួលស្គាល់ថា សុន្ទរកថារបស់ ប៉ុល ពត ក្នុងខែមេសា ឆ្នាំ១៩៧៨ ដែលលើកឡើងថា គោលនយោបាយ "មួយ ត្រូវវាយយួនឱ្យបាន ៣០" របស់ ប.ក.ក ពាក់ព័ន្ធចម្បងនឹងកងទ័ព ហើយមានបំណង "បំផុសដល់កម្មាភិបាល យុទ្ធជន ឱ្យមានទឹកចិត្ត និងលើកស្ទួយខាងស្មារតីឱ្យមានស្មារតីត្រៀមប្រយុទ្ធ"), ៣៤១១ ("អង្គជំនុំជម្រះបានកត់សម្គាល់ថា សេចក្តីថ្លែងការណ៍នេះត្រូវបានធ្វើឡើងក្នុងអំឡុងពេលមានការវាយលុកខាងកងទ័ពដ៏សំខាន់មួយដោយកងទ័ពវៀតណាម។ ដូច្នេះ នៅពេលអានក្នុងបរិបទរួម អង្គជំនុំជម្រះយល់ឃើញថា សេចក្តីណែនាំ

យ៉ាងណាក៏ដោយ ការអះអាងរបស់គាត់ថា មានតែកាសន្និដ្ឋានទាក់ទងនឹងការគ្រប់គ្រងរបស់ សុន សេន ប៉ុណ្ណោះដែលអាចទាញចេញយ៉ាងត្រឹមត្រូវពីកំណត់ហេតុអង្គប្រជុំយោធានោះ[3562] មើលរំលងភ័ស្តុតាងជាច្រើនដែលបញ្ជាក់ថាយោធាស្ថិតក្រោម ប.ក.ក ទាំងស្រុង ហើយ សុន សេន បានអនុវត្តបទបញ្ជារបស់បក្ស និងបានគាំទ្រមាគ៌ានយោបាយរបស់បក្សយ៉ាងស៊ីសង្វាក់គ្នានៅក្នុងអង្គប្រជុំទាំងនេះ[3563]។ លើសនេះទៀត អ.ជ.ស.ដ បានពិចារណាការកើនឡើងនៃភាពប្រទូសសារ៉ាយនៅពេលវាយតម្លៃសុន្ទរកថាបុណ្យខួប១៧មេសាចំនួនពីរ ដែលម្ចាស់បណ្តឹងសាទុក្ខនិយាយថាអង្គជំនុំជម្រះគួរពិចារណាវា[3564]។ ជាចុងក្រោយ ការជំទាស់របស់គាត់ទៅនឹងការវាយតម្លៃសុន្ទរកថាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៧[3565] គ្មានអ្វីលើសពីការជំទាស់ទៅនឹងវិធីដែល អ.ជ.ស.ដ រៀបចំសាលក្រមរបស់ខ្លួននោះឡើយ។ អ.ជ.ស.ដ បានបង្ហាញដដែលៗថា ខ្លួនបានដឹងយ៉ាងច្បាស់

ទាំងនេះ សំដៅជាចម្បងទៅលើកងកម្លាំងប្រដាប់អាវុធវៀតណាម"), ៣៤១៣។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៣៥-៣៨៣៦។

[3562] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៦។

[3563] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៨ (ប.ក.ក ជាអង្គការកំពូលរបស់កងទ័ព), ៣៧៨៩-៣៧៩០, ៣៧៩៩, ៣៨០៤ (គាំទ្រមាគ៌ាបក្ស)។ ឯកសារ **E3/130** លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា មាត្រា ៤ (សង្កត់ន័យលើសារៈសំខាន់នៃបញ្ហាមាគ៌ាបក្សនីមួយៗ), ៦ (ប.ក.ក ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យ-ប្រមូលផ្តុំ តម្រូវ ឱ្យថ្នាក់ក្រោមគោរពថ្នាក់លើ អង្គការថ្នាក់ផ្សេងៗគោរពអង្គការមជ្ឈិម ថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើ និង ថ្នាក់លើត្រូវផ្តល់សេចក្តីណែនាំដល់ថ្នាក់ក្រោមជាទិសការងារផ្សេងៗ), ២៧ (កងទ័ពបដិវត្តកម្ពុជាទាំង៣ប្រភេទត្រូវ "ស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខ ដាច់ខាត និងគ្រប់ផ្នែក" របស់បក្សកុម្មុយនិស្តកម្ពុជា), ២៨ (កងទ័ពបដិវត្តកម្ពុជាមានការចាត់តាំងតាមប្រជាធិបតេយ្យ-ប្រមូលផ្តុំ)។ ឯកសារ **E3/1733** ការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019109 (ការពារប្រទេស ចាត់ចែងតាមមជ្ឈិម)។ ឯកសារ **E3/222** ការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ (រាយការណ៍ខាងកិច្ចការពារប្រទេសជូនដល់គណៈអចិន្ត្រៃយ៍)។ ម្ចាស់បណ្តឹងសាទុក្ខ (សមមិត្ត ហែម) មានវត្តមាន។ ឯកសារ **E3/12** សេចក្តីសម្រេចរបស់ គណៈមជ្ឈិម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00000758 (អនុញ្ញាតឱ្យសេនាធិការសម្រេច "កំទេច" បុគ្គលនៅក្នុង "កងទ័ពមជ្ឈិម")។ ឯកសារ **E3/739** *ទង់បដិវត្ត* ខែកក្កដា ឆ្នាំ១៩៧៦ KH 00062942 ("ផ្តាច់មុខ គឺមានតែបក្សដឹកនាំកងទ័ព គ្មានអង្គការណាផ្សេងទៀត ឬបុគ្គលផ្សេងទៀតដឹកនាំទេ")។ ឯកសារ **E3/5724** កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច KH 00680803 ("អគ្គសេនាធិការទទួលបន្ទុកអនុវត្តតាមបញ្ជារបស់ ប៉ុល ពត ហើយ សុន សេន ជាអ្នកអនុវត្តបញ្ជាទាំងនោះ")។

[3564] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩២-៣៣៩៤ (ពិភាក្សាពីសុន្ទរកថាដូចដែលបានពិភាក្សានៅក្នុងដាក់ឱ្យរងនូវការចោទប្រកាន់ កថាខណ្ឌ ៣៨០៦-៣៨០៧ ហើយបន្ទាប់មក បានថ្លែងថា "*ដោយសារជម្លោះយោធាជាមួយវៀតណាមកាន់តែធ្ងន់ធ្ងរឡើង*" រួមទាំងកត្តាផ្សេងៗទៀត "អង្គជំនុំជម្រះយល់ឃើញថា ការសំដៅដល់ "ប្រភេទខ្មាំងទាំងអស់" នៅក្នុងសុន្ទរកថាខាងលើ តាមពិតបានរួមបញ្ចូលសំដៅដល់វៀតណាមថា ជា "សត្រូវសួពូជ") (គូសបញ្ជាក់បន្ថែម)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៧។

[3565] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៨។

អំពីសភាពនៃជម្លោះនៅចុងឆ្នាំ១៩៧៧[3566] និងថា ខ្លួនមិនតម្រូវឱ្យលើកឡើងរាល់ចំណុចលម្អិតនៃសំអាងហេតុរបស់ខ្លួន សម្រាប់ការសន្និដ្ឋានជាក់លាក់នីមួយៗដែលខ្លួនបានធ្វើនោះឡើយ[3567]។ ការជំទាស់ជារួមរបស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងសុន្ទរកថាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ និងឯកសារនានាបរាជ័យដោយមូលហេតុស្រដៀងគ្នានេះ[3568]។

997. ម្ចាស់បណ្តឹងសាទុក្ខបំភ្លើសទៅលើសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្តីពីសុន្ទរកថាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ អំពី "មួយទល់នឹងសាមសិប" របស់ប៉ុល ពត ដោយអះអាងមិនត្រឹមត្រូវថា ការវិភាគរបស់ អ.ជ.ស.ដ លើសុន្ទរកថានេះមានភាពលម្អៀង[3569]។ តាមពិត អ.ជ.ស.ដ ទទួលស្គាល់បរិបទដែលម្ចាស់បណ្តឹងសាទុក្ខថាខ្លួនបានជំទាស់នោះ ដោយបានស្និដ្ឋានថា សុន្ទរកថារបស់ ប៉ុល ពត *ជាសំខាន់* ទាក់ទងទៅនឹងទាហានវៀតណាម និងមានបំណង "បំផុសដល់កម្មាភិបាល យុទ្ធជន ឱ្យមានទឹកចិត្ត និងលើកស្ទួយខាងស្មារតីឱ្យមានស្មារតីត្រៀមប្រយុទ្ធ"[3570]។ ទោះជាយ៉ាងណា នៅពេលដែល អ.ជ.ស.ដ ពិនិត្យមើលភ័ស្តុតាង*ទាំងមូល*[3571] ខ្លួនបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ប៉ុល ពត បានពង្រីកគោលនយោបាយ "មួយ ត្រូវវាយយួនឱ្យបាន ៣០" ហួសឆ្ងាយពីកងកម្លាំង យោធារបស់សាធារណៈរដ្ឋសង្គមនិយមវៀតណាមទៅទៀត ដើម្បីគ្របដណ្តប់លើជនស៊ីវិល ផងដែរ[3572]។

---

[3566] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨០, ២៨៨-២៩០, ២០២៩, ៣៣៩៦។

[3567] បទដ្ឋានក្នុងការពិនិត្យឡើងវិញ (សេចក្តីសម្រេចមានសំអាងហេតុ)។

[3568] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៩-១៤៧០ ធ្វើការជំទាស់ដូចគ្នាដែលបានលើកឡើងពីសុន្ទរកថាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៧ និង ខកខានចំពោះហេតុផលដូចគ្នាដូចដែលបានថ្លែងនៅខាងលើនេះ។

[3569] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៧០-១៤៧១ ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើឯកសារ **E465 E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨២៥។

[3570] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០២។

[3571] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩១៨-៩១៩។ សាលដីការឿងក្តី *Lubanga* កថាខណ្ឌ ២២។ សាលដីការឿងក្តី *Ntagerura* កថាខណ្ឌ ១៧៤។ *សូមមើលផងដែរ* សាលដីការឿងក្តី *Ngirabatware* កថាខណ្ឌ ២០២, ២០៨។ សាលដីការឿងក្តី *Martić* កថាខណ្ឌ ២៣៣។

[3572] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០២, ៣៨២៥។ *កត់សំគាល់ដោយឡែកថា* អ.ជ.ស.ដ បានពិចារណាសេចក្តីយោងរបស់ ប៉ុល ពត នៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ទាំងមូល ទៅកាន់ប្រជាជនទាំងអស់នៅក្នុងប្រទេសទាំងពីរ បណ្តាលឱ្យវាបញ្ចប់ទៅដោយគោលនយោបាយ "មួយត្រូវវាយយួនឱ្យបាន ៣០" អនុវត្តចំពោះប្រជាជនវៀតណាមទាំងមូល មិនមែនគ្រាន់តែជាកងកម្លាំងរបស់សង្គមនិយមប្រជាមានិតវៀតណាមនោះទេ។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងទឡ្ហីករណ៍១៨៥។

### *អ.ជ.ស.ដ បានពិចារណាអំពីមនោគមន៍វិជ្ជាម៉ាក្សសម័យរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលវាយតម្លៃភ័ស្តុតាង*

998. ការរិះគន់របស់ម្ចាស់បណ្តឹងសាទុក្ខលើការបរាជ័យដោយការសន្មតរបស់ អ.ជ.ស.ដ ក្នុងការពិចារណាឱ្យបានត្រឹមត្រូវលើឯកសារដែលបានវិភាគ ក្នុងបរិបទនៃវាក្យសព្ទម៉ាក្សដែលប្រើក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ មិនមានមូលដ្ឋានឡើយ[3573]។ អំណះអំណាងមិនត្រឹមត្រូវមួយផ្តោតលើប្រយោគមួយដែលកំណត់ប្រភេទអត្ថន័យនៃពាក្យ "ខ្មាំង" ដែលបានប្រើនៅក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាក់លាក់មួយ[3574]។ *សម្រាប់គោលបំណងវែកញែក* ទោះបីជាការកំណត់ប្រភេទរបស់ អ.ជ.ស.ដ បកស្រាយខុសពីអត្ថន័យនៃពាក្យ "ខ្មាំង" នៅក្នុងចំណុចជាក់លាក់នេះក៏ដោយ ក៏ការវិភាគភ័ស្តុតាងដ៏ច្រើនរបស់ខ្លួន និងការសន្និដ្ឋានជាច្រើនទាក់ទងនឹងខ្មាំងពិតប្រាកដ និងអ្នកដែលត្រូវបានគេគិតថាជាខ្មាំង[3575] បដិសេធផលប៉ះពាល់ណាមួយលើការសន្និដ្ឋានណាដែលនឹងធ្វើឱ្យសាលក្រមក្លាយមោឃៈ ឬនាំឱ្យមានភាពខុសឆ្គងពិតប្រាកដរបស់តុលាការ[3576]។

999. ការប្រើប្រាស់ការចោទប្រកាន់ដោយគ្មានការគាំទ្រជាច្រើនរបស់ម្ចាស់បណ្តឹងសាទុក្ខ ក៏គ្មានមូលដ្ឋានដែរ។ ឧទាហរណ៍ មានឯកសារជាច្រើនផ្ទុយទៅនឹងការអះអាងរបស់គាត់ថា គ្មានឯកសារណាអាចនាំឱ្យមានការសន្និដ្ឋានថា ប.ក.ក ជំទាស់ទៅនឹងអ្នកដែល "បានជឿ ឬ គាំទ្រ

---

[3573] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៧៣-១៤៧៩។ *កត់សំគាល់ថា* កថាខណ្ឌ ១៤៧៤ និង ១៤៧៥ មិនជំទាស់ទៅនឹងការរកឃើញយ៉ាងជាក់លាក់នោះទេ។

[3574] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៧៣, ជើងទំព័រ ២៧៧៧ *ដោយលើកឡើងពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦៨។ *កត់សំគាល់ថា* ការដកស្រង់នេះពិតជាមាននៅក្នុងកថាខណ្ឌ ៣៧៦៩ នៃសាលក្រម ដែលយោងទៅដល់ឯកសារ **E3/231** កំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦។

[3575] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៤-៣៨៦៣។

[3576] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៦៩ ជាពិសេស បានពឹងផ្អែកលើសាលក្រមប្រាំបីដង ដែលក្នុងម្តងៗ ទៅលើការពិភាក្សាអង្គហេតុនៅក្នុងកថាខណ្ឌ និងភ័ស្តុតាងគាំទ្ររបស់វា មិនមែនទៅលើការសំគាល់ថាជា "ខ្មាំង" របស់ អ.ជ.ស.ដ នោះទេ។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៤៧០ (យោង ការផ្សព្វផ្សាយតាមវិទ្យុ), ១២៥៩២ (យោង ប៊ូ ផាត *ហៅ* ហង្ស), ១២៨២៦ (យោង ប្រទេសថៃ គឺជាខ្មាំងមួយ), ១២៨៣១ (យោង ប្រទេសឡាវ ជាខ្មាំងមួយ), ១២៨៤៥ (សកម្មភាពអ្នកលួចរត់ទៅផ្ទះ និងលួចរត់ចោលការងារ ត្រូវបានចាត់ទុកថាជា "សកម្មភាពខ្មាំង"), ១២៨៩៦ (ការពិភាក្សាអំពីប្រព្រឹត្តិកម្មលើខ្មាំងជាក់លាក់ ត្រូវបានធ្វើឡើងនៅក្នុងកំរិតខ្ពស់តែប៉ុណ្ណោះ), ១៣៤៨៣ (នួន ជា បន្តទទួលបានព័ត៌មានជាប្រចាំស្តីពីសកម្មភាពខ្មាំង), ១៣៤៨៦ (សកម្មភាពខ្មាំងត្រូវបានពិភាក្សាជាច្រើនលើកច្រើនសានៅក្នុងអំឡុងពេលកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍)។

ពួកសន្តិភាព និយម ឬ ពួកសេរីនិយម”[3577]។ ស្រដៀងគ្នាដែរ គាត់មិនបានផ្តល់ភ័ស្តុតាងណាមួយ ឬការសន្និដ្ឋានជំទាស់ជាក់លាក់ណាមួយ ដើម្បីអះអាងថា វណ្ណៈសង្គម និងទ្រឹស្តីនៃសង្គ្រាមវណ្ណៈ អាចត្រូវបានវិភាគតែថាជាការប្រយុទ្ធប្រឆាំងនឹងក្រុមដែលបានកំណត់អត្តសញ្ញាណដោយអង្គជំនុំជម្រះប៉ុណ្ណោះ ដោយគួរឱ្យភ្ញាក់ផ្អើល ផ្អែកលើកថាខណ្ឌមួយនៅក្នុងដីកាដំណោះស្រាយ ដែលពិភាក្សាអំពីប្រភេទអ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់ទៅវិញ[3578]។ ការអះអាងដោយគ្មានការគាំទ្ររបស់គាត់ត្រូវតែបដិសេធចោល[3579]។

1000. ការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងការវាយតម្លៃរបស់ អ.ជ.ស.ដ លើពាក្យ “យួន” ត្រូវបានដោះស្រាយនៅកន្លែងផ្សេងទៀតក្នុងចម្លើយតបនេះ[3580] ប៉ុន្តែមានបញ្ហាមួយចំនួនត្រូវលើកឡើងនៅទីនេះ។ ផ្ទុយទៅនឹងការអះអាងខុសរបស់គាត់[3581] អ.ជ.ស.ដ បានទទួលស្គាល់យ៉ាងជាក់លាក់ថា ពាក្យនេះ នៅពេលនោះ ត្រូវបានប្រើមានលក្ខណៈទូទៅជាង ដូច្នេះ បានបានធ្វើការវិភាគមួយករណីម្តងៗ ដើម្បីកំណត់ការប្រើប្រាស់របស់វា ក្នុងបរិបទនៃឯកសារដែលកំពុងវិភាគ[3582]។

---

[3577] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨០៨ (ដោយដកស្រង់ពីលក្ខណៈ “សេរីរើ និយមក្បត់បដិវត្ត” នៅក្នុងទង់បដិវត្ត ខែមិថុនា ឆ្នាំ១៩៧៧)។ ឯកសារ **E3/5** *ទង់បដិវត្ត* ខែសីហា ឆ្នាំ១៩៧៥ KH 00063318 (ពីកណ្តាលឆ្នាំ៧៣ មកដើមឆ្នាំ ៧៥៖ “កំចាត់គិញ ចារកម្ម សន្តិសម្ព័ន្ធបាន”)។ ឯកសារ **E3/25** *ទង់បដិវត្ត* ធ្នូ-មករា ១៩៧៦-៧៧ KH 00063039 (“វាយខ្លាំងដោយកំចាត់សង្គ្រាមចារកម្ម សង្គ្រាមចិត្តសាស្ត្រ និងសន្តិសម្ព័ន្ធ របស់វា”)។ ឯកសារ **E3/723** សេចក្តីណែនាំរបស់ ៨៧០ មិនមានកាលបរិច្ឆេទ KH 00052517។ ឯកសារ **E3/196** សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជា ជូនចំពោះបក្សកុម្មុយនិស្តកម្មករដែណឺម៉ាក ខែកក្កដា ១៩៧៨ KH 00224468 (នួន ជា៖ “សត្រូវ ទាំងពួកចក្រពត្តិនិយម ទាំងពួកនិយមការកែប្រែ ព្រមទាំងយួនបន្តវាយប្រហារយើង”)។ ឯកសារ **E3/807** កំណត់ហេតុនៃការប្រជុំលេខា-អនុលេខា កងពល និងវរៈសេនាធំឯករាជ ថ្ងៃទី ១-៣-៧៧ KH 00052306 (“ព្រឹត្តិការណ៍បញ្ជាក់ថា ខ្មាំងជាសេ-អ៊ី-អា ជាយួន ជាសេរីរើ វាបន្តធ្វើសកម្មភាពដើម្បីបំផ្លាញបដិវត្តយើង ខ្លាំងក្លាណាស់”)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៧៦។

[3578] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៧៦, ជើងទំព័រ ២៧៨២ *ដោយលើកឡើងពី* ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ៥០០។

[3579] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៧៧។ ម្ចាស់បណ្តឹងសាទុក្ខបានថ្លែងយ៉ាងសង្ខេបថា “អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាខ្មាំងតែក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធជាមួយ លន់ នល់ ប៉ុណ្ណោះ” ហើយ “ប្រជាជនថ្មី និងព្រះសង្ឃមិនធ្លាប់ត្រូវបានចាត់ទុកជាខ្មាំងទាល់តែសោះ” ដោយគ្មានលើឡើងពីភ័ស្តុតាងគាំទ្រអ្វីទាល់តែសោះ។

[3580] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

[3581] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៨៣-១៤៨៥។

[3582] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៧៩-៣៣៨១។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

ផ្ទុយនឹងការចោទប្រកាន់គ្មានការគាំទ្ររបស់គាត់ដែរ[3583] អ.ជ.ស.ដ បានពិនិត្យយ៉ាងច្បាស់លាស់ពីកាលៈទេសៈជុំវិញការប្រើប្រាស់របស់ ប.ក.ក នៃពាក្យ "យួន" ឬ ទម្រង់ណាមួយនៃ "ខ្មាំង" វៀតណាម យ៉ាងហោចណាស់ចំនួនប្រាំបីដងនៅក្នុងការវាយតម្លៃរបស់ខ្លួនលើឯកសារទាំងនោះ មុនពេលធ្វើសេចក្តីសន្និដ្ឋានអំពីអត្ថន័យនោះ[3584]។ ដោយបានធ្វើការពិចារណាយ៉ាងប្រុងប្រយ័ត្នលើភស្តុតាងទាំងអស់រួចមក អ.ជ.ស.ដ បានកត់សម្គាល់ថា ទោះបីជាពាក្យ "យួន" ពេលខ្លះ ត្រូវបានប្រើសំដៅលើវៀតណាម ឬជនជាតិវៀតណាមក្នុងពាក្យពេចន៍ទូទៅក៏ដោយ ក៏ជាញឹកញាប់ ប.ក.ក បានប្រើពាក្យនេះដើម្បីសំដៅប្រមាថទៅលើជាតិពន្ធុវៀតណាមទាំងអស់ និងកាន់តែមានលក្ខណៈក្តៅឡើងនៅពេលដែលជម្លោះប្រដាប់អាវុធមានសភាពខ្លាំងក្លាឡើង[3585]។

1001. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថា អ.ជ.ស.ដ បានភ្ជាប់ដោយចេតនានូវពាក្យ "ភ្នាក់ងារវៀតណាម" ទៅនឹង "ជនជាតិវៀតណាម" ដើម្បីសន្និដ្ឋានថា មានគោលនយោបាយឧក្រិដ្ឋប្រឆាំងនឹងប្រជាជនវៀតណាម[3586]។ អំណះអំណាងនេះគ្រាន់តែប៉ុនប៉ងបន្ថយភស្តុតាងជាច្រើនលើសលប់នៃព្រឹត្តិការណ៍ស្រដៀងគ្នានេះក្នុងប្រទេសទាំងមូល ដែលបង្ហាញពីគោលនយោបាយ ប.ក.ក ប្រឆាំងនឹងវៀតណាម រួមបញ្ចូលទាំង ការផ្តោតលើខាងមាតា និងការធ្វើបញ្ជីដើម្បីកំណត់អត្តសញ្ញាណ និងផ្តោតគោលដៅលើមនុស្សដែលមានដើមកំណើតវៀតណាម[3587] ការសម្លាប់កុមារជនជាតិវៀតណាមដែលតាមវិធីណាក៏ដោយ មិនអាចចាត់ទុកថាជាភ្នាក់ងារវៀតណាម[3588] និងការសម្លាប់អ្នកនេសាទ និងជនភៀសខ្លួនវៀតណាមដែលចាប់បាននៅសមុទ្រ[3589]។

*អ.ជ.ស.ដ បានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីតម្លៃបញ្ជាក់ភស្តុតាងនៅចំពោះមុខខ្លួនទាក់ទងនឹងខ្មាំង*

---

[3583] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៨០-១៤៨១។

[3584] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៧-៣៤០០, ៣៤០២, ៣៤១១-៣៤១៣, ៣៤១៦។

[3585] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៧៩, ៣៣៨១, ៣៣៩៦-៣៤១៦។

[3586] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៨៦-១៤៨៧ ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៥១-៣៨៥៥។ ការជំទាស់ជាក់លាក់របស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើពួកវៀតណាម ត្រូវបានលើកឡើងនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៥៩, ១៨៥។

[3587] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២០-៣៤២៨, ៣៥០៣, ៣៥១០។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

[3588] *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៧៨, ២៦២១, ៣៤២៤-៣៤២៥, ៣៤៨៣-៣៤៨៥, ៣៤៨៧, ជើងទំព័រ ១១៣៨៧។

[3589] *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៥៦-៣៤៦១, ៣៤៩៣។

1002. ម្ចាស់បណ្តឹងសាទុក្ខក៏អះអាងគ្មានមូលដ្ឋានផងដែរថា អ.ជ.ស.ដ មានកំហុសក្នុងការធ្វើការសន្និដ្ឋានជារួមអំពីគោលនយោបាយមួយ[3590] ចេញពីសៀវភៅកត់ត្រាគ្មានកាលបរិច្ឆេទចំនួនពីររបស់របបកម្ពុជាប្រជាធិបតេយ្យ[3591] គឺ "សៀវភៅបណ្ដុំកំណត់ត្រានៅ ស.២១"[3592] និង "សៀវភៅកំណត់ហេតុរបស់ អៀង សារី"[3593] ដោយមិនមានការបញ្ជាក់ពីយថាភូត។ ទោះជាយ៉ាងណាក៏ដោយ អ.ជ.ត.ក និង យុត្តិសាស្ត្រអន្តរជាតិបានបញ្ជាក់ថា យថាភូតមិនផ្អែកលើវត្ថុមានមួយ ក្នុងចំណោមកត្តាមួយ ឬច្រើននោះទេ ឱ្យតែភ័ស្តុតាងដែលពិចារណាជារួម កំណត់ថា ឯកសារនោះជាឯកសារពិត[3594]។ អ.ជ.ស.ដ បានអនុវត្តតាមវិធីសាស្ត្រនេះយ៉ាងត្រឹមត្រូវ ដោយបានបញ្ជាក់អត្តសញ្ញាណកត្តាជាច្រើនសម្រាប់ឯកសារនីមួយៗ ដែលខ្លួនជឿជាក់ថាជាការបញ្ជាក់យថាភូតគ្រប់គ្រាន់[3595]។ ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីកត្តាដែលគាត់

---

[3590] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៥០, ១៤៥១, ១៤៥៣-១៤៥៨, ១៤៦៣-១៤៦៤។

[3591] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៥១, ១៤៥៣ ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥០ (*លើកឡើងពី* ឯកសារ **E3/1233** សៀវភៅកំណត់ត្រាកម្ពុជាប្រជាធិបតេយ្យស្ដីពីការបែងចែកវណ្ណៈ និងការតស៊ូវណ្ណៈក្នុងសង្គមកម្ពុជា, មិនមានកាលបរិច្ឆេទ), ៣៧៥១ (*លើកឡើងពី* ឯកសារ **E3/1235** សៀវភៅកំណត់ហេតុកម្ពុជាប្រជាធិបតេយ្យក្រោមចំណងជើងថា៖ ទស្សនៈសភាពការណ៍កម្ពុជា ក្រោយថ្ងៃ ១៧ មេសា ១៩៧៥, មិនមានកាលបរិច្ឆេទ)។

[3592] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៦៤ ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨២២ (*លើកឡើងពី* ឯកសារ **E3/834** សៀវភៅបណ្ដុំកំណត់ត្រានៅស.២១, ខែមេសា ឆ្នាំ១៩៧៨ ដល់ ខែធ្នូ ឆ្នាំ១៩៧៨)។

[3593] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៥៨, ១៤៦៤ ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៦, ៣៧៧៨, ៣៨០៣ (*ទាំងអស់នេះលើកឡើងពី* ឯកសារ **E3/522** សៀវភៅកំណត់ហេតុរបស់ អៀង សារី, មិនមានកាលបរិច្ឆេទ)។

[3594] *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩៦-២៩៧។ សាលក្រមរឿងក្ដី *Orić* កថាខណ្ឌ ២៧ ("ចន្លោះប្រហោងនៅក្នុងខ្សែសង្វាក់គ្រប់គ្រងមិនដាច់នោះទេ ឱ្យតែភ័ស្តុតាងទាំងមូលបង្ហាញហួសពីវិមតិសង្ស័យថា ភ័ស្តុតាងដែលមានចម្ងល់មួយផ្នែកនោះគឺជាអ្វីដែលវាបានសំដៅទៅដល់") *បានលើកឡើងដោយ* អនុគ្រោះដល់សាលក្រមរឿងក្ដី *Taylor* កថាខណ្ឌ ៣៨៣។ សាលដីការឿងក្ដី *Đorđević* កថាខណ្ឌ ៣៩៥ (ដោយសង្កេតឃើញថា អ.ជ.ស.ដ បានវាយតម្លៃដោយប្រុងប្រយ័ត្ននៅលើសៀវភៅក្រុមការងារ ដែលមានមូលដ្ឋានទាំងស្រុងនៅលើភ័ស្តុតាង ជាក់ស្តែងក្នុងការពិចារណាភ័ស្តុតាងបញ្ជាក់បន្ថែម)។ សាលក្រមរឿងក្ដី *Taylor* កថាខណ្ឌ ៣៩១-៣៩២ ("សាក្សីដែលផ្ដល់សក្ខីកម្មផ្ទាល់ពិស្ដារ និង បញ្ជាក់បន្ថែម បានជួយដល់ការឆ្លើយថាភាព ដល់ភ័ស្តុតាងជាឯកសារ")។

[3595] **<u>សៀវភៅកំណត់ត្រាកម្ពុជាប្រជាធិបតេយ្យដែលមិនមានកាលបរិច្ឆេទ៖</u>** *សូមមើល* ឯកសារ **E185** សេចក្ដីសម្រេចលើឯកសារនៅក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៧, ១៥ (v), ២១, ២៣, ២៥-២៨ (វិធីសាស្ត្ររបស់ DC-Cam ដែលមិនបានផ្ដល់មូលហេតុអ្វីដែលត្រូវភ័យខ្លាចថាឯកសារត្រូវបានឃុបឃិត ធ្វើឱ្យខុសពីភាពដើម ឬ ក្លែងបន្លំ), ៣៦ (ឯកសារពាក់ព័ន្ធត្រូវបានចុះនៅក្នុងឧបសម្ព័ន្ធ ខ, ឯកសារ E185.2)។ *សូមមើលបន្ថែមទៀតថា* ផ្នែកនៃឯកសារ **E3/1233** ដែលបានលើកឡើង

ចង់បានថាជាកត្តាកំណត់ មិនបង្ហាញថា ការវិភាគ ឬការសន្និដ្ឋានរបស់ អ.ជ.ស.ដ ខុសច្បាប់ ឬមិនសមហេតុផលឡើយ។ ស្រដៀងគ្នានេះដែរ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការកំណត់ទម្ងន់របស់ខ្លួនទៅលើ (i) វគ្គសិក្សាដែលបានសង្ខេបក្នុងសៀវភៅរបស់ Ben Kiernan[3596] (ii) ឯកសារចំនួនពីរដែលចម្លងដោយសាស្ត្រាចារ្យ Goscha[3597] និង (iii) សំណៅពង្រាងនៃលក្ខន្តិកៈ ប.ក.ក[3598]។ អ.ជ.ស.ដ បានលើក ឡើងពីកង្វល់ដូចគ្នានឹងការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខដែរអំពីឯកសារទាំងអស់នេះ និង បាន

---

ដោយ អ.ជ.ស.ដ ត្រង់កថាខណ្ឌ ៣៧៥០ នៃសាលក្រម គឺជាផ្នែកក្នុង ដែលត្រូវគ្នា និងដែលបញ្ជាក់បន្ថែម ដោយ *ឧទាហរណ៍* ឯកសារ **E3/138** អារម្មណ៍ជាមូលដ្ឋាន និងជាយុទ្ធសាស្ត្រដើម្បីសមមិត្តក្នុងបក្ស មិនមានកាលបរិច្ឆេទ KH 00442427 (ពិភាក្សាអំពីវណ្ណៈកសិម្មករ កសិករ និង នាយទុន ក៏ដូចជាពីរប្រភេទផ្សេងទៀតនៃវណ្ណៈសក្តិភូមិ៖ ពួកម្ចាស់ដី និង ពួកអភិជន)។ ឯកសារ **E3/146** *យុវជន-យុវនារី បដិវត្ត* សីហា-កញ្ញា ១៩៧៤ KH 00283409-10 (យោង ពួកសក្តិភូមិមានពីរប្រភេទ។ ពួកសក្តិភូមិ “អភិជន” ជារួមមាន ស្តេច និង មន្ត្រីជាន់ខ្ពស់, KH 00283410-16 (វណ្ណៈផ្សេងៗទៀត))។ ឯកសារ **E3/5** *ទង់បដិវត្ត* សីហា ១៩៧៥ KH 00063322-23 (ជារួមមាន វណ្ណៈសក្តិភូមិ នាយទុន គហបតី និង បញ្ញាវន្ត)។ **សៀវភៅកំណត់ត្រារួម ស.២១ ដែលបានស្នើឡើង៖** *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៩១, ២១៣១, ២១៣៣, ២១៧០។ **សៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ អៀង សារី៖** *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៦។ *សូមមើលផងដែរ* ភ័ស្តុតាងដែលបញ្ជាក់បន្ថែមនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃ ក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៤២ (ជើងទំព័រ ២៨៩៦, ២៨៩៧) (ដោយបានបញ្ជាក់បន្ថែមលើឯកសារ **E3/522** សៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ អៀង សារី មិនមានកាលបរិច្ឆេទ EN 00003285), ១៨៩១, ៣៧៤៦ (ជើងទំព័រ ១២៤៩៧), ជើងទំព័រ ១២៩០, ១៤២៨, ៣២០២-៣២០៣, ៦៣២០, ១២៥៨៩, ១២៦៧៧។

[3596] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៨ *ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៩១ ជើងទំព័រ ១២៦៤២ (*លើកឡើងពី* ឯកសារ **E3/8** លោក B. Kiernan “សង្ខេបលទ្ធផលនៃវគ្គរៀនសូត្រឆ្នាំ១៩៧៦” នៅក្នុង*គំរោងផែនការអនាគតរបស់ ប៉ុល ពត៖ ឯកសារដឹកនាំសម្ងាត់ពីកម្ពុជាប្រជាធិបតេយ្យ* ឆ្នាំ១៩៧៦-១៩៧៧ ខែកញ្ញា ឆ្នាំ១៩៧៦ EN 00104082)។

[3597] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៦៣ *ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨០៥ (*លើកឡើងពី* ឯកសារ **E3/10693** កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និងវរៈសេនាធំឯករាជ ថ្ងៃទី ៣-៤-៧៧), ៣៨១៤ (*លើកឡើងពី* ឯកសារ **E3/10686** កំណត់ហេតុនៃសន្និសីទរវាងកម្ពុជា និងប្រទេសចិន នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧)។

[3598] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៥៣ *ដោយបានដាក់ឱ្យរងនូវការចោទប្រកាន់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៩ (*លើកឡើងពី* ឯកសារ **E3/8380** សេចក្តីព្រាងនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឆ្នាំ១៩៧១ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៧២)។

ពិនិត្យដោយប្រុងប្រយ័ត្ន[3599] ដោយយោង តែនៅពេលដែលភស្តុតាងផ្សេងទៀត ស្របទៅនឹងខ្លឹមសាររបស់វាប៉ុណ្ណោះ[3600]។ នេះគឺជាឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ ក្នុងការធ្វើដូច្នោះ[3601]។

---

[3599] **<u>*សង្ខេបលោក* Ben Kiernan៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៦៣២៩ (អ.ជ.ស.ដ រំលឹកពីអវត្តមានក្នុងការសួរដេញដោលលោក Ben Kiernan ដែលមិនបានផ្តល់សក្ខីកម្ម ដោយចាត់ទុកថា ទស្សនៈរបស់គាត់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់), កថាខណ្ឌ ៣៧៩១ (មិនមានសេចក្តីសង្ខេបដើមជាភាសាខ្មែរនៃវគ្គរៀនសូត្រឆ្នាំ១៩៧៦ ដូច្នេះ បានចាត់ទុកថាភស្តុតាងនេះមានការប្រុងប្រយ័ត្នយ៉ាងត្រឹមត្រូវ)។ **<u>*ឯកសាររបស់* Goscha៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨០៥, ៣៨១៤។ *សូមមើលផងដែរ* កថាខណ្ឌ ៣៥១-៣៥៤ បង្ហាញពីការប្រុងប្រយ័ត្នរបស់ អ.ជ.ស.ដ ជាមួយនឹង ឯកសារផ្សេងៗទៀតដែលបានផតចម្លងស្រដៀងគ្នាដោយលោកសាស្ត្រាចារ្យ Goscha។ **<u>*សេចក្តីព្រាងនៃលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា៖*</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤៤ (លក្ខន្តិកៈឆ្នាំ១៩៧៦ រក្សាទុកភាសាដដែលជាច្រើន ទៅនឹងលក្ខន្តិកៈឆ្នាំ១៩៧១, អ្នកនិពន្ធនៃកំណត់សម្គាល់ឆ្នាំ១៩៧២ ដែលមានសេចក្តីព្រាងលក្ខន្តិកៈឆ្នាំ១៩៧១ គឺមិនត្រូវបានស្គាល់នោះឡើយ ដូច្នេះ អ.ជ.ស.ដ បានចាត់ទុកលក្ខន្តិកៈឆ្នាំ១៩៧១ ដោយប្រុងប្រយ័ត្ន ក៏ប៉ុន្តែនឹងត្រូវពឹងផ្អែកលើខ្លឹមសារនៃកំណត់សម្គាល់ទាំងនេះ បើសិនជាបានបញ្ជាក់បន្ថែម)។

[3600] **<u>*សង្ខេបលោក* Ben Kiernan៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ៤១៧០។ *កត់សម្គាល់ថា* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២៨៨១ គឺជាការរកឃើញមួយតែប៉ុណ្ណោះថាបានគាំទ្រដល់ការដាក់ឱ្យរងនូវការចោទប្រកាន់លើសាលក្រម កថាខណ្ឌ ៣៧៩១ (ពិភាក្សាតែការសង្ខេបរបស់លោក Kiernan ប៉ុណ្ណោះ) និងមានមូលដ្ឋាននៅលើភស្តុតាងយ៉ាងទូលំទូលាយបន្ថែមទៅលើការសង្ខេបរបស់លោក Kiernan។ **<u>*ឯកសាររបស់* Goscha៖</u>** បានដាក់ឱ្យរងនូវការចោទប្រកាន់លើសាលក្រម កថាខណ្ឌ ៣៨០៥ មិនបានលើកឡើងនៅក្នុងការរកឃើញណាមួយ ហើយគ្រាន់តែត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃទិដ្ឋភាពទូទៅតាមកាលប្បវត្តិរបស់ អ.ជ.ស.ដ ប៉ុណ្ណោះ ដោយការបង្ហាញថាមានភាពលេចជ្រងោដែលរបបកម្ពុជាប្រជាធិបតេយ្យបានផ្តល់ឱ្យដល់ប្រធានបទស្តីពីខ្មាំង (*តាម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៤)។ *កត់សម្គាល់ផងដែរ* អ.ជ.ស.ដ បានលើកឡើងពីសាលក្រមដែលរងការចោទប្រកាន់ កថាខណ្ឌ ៣៨១៤ តែកាលណាបានរួមផ្សំដោយភស្តុតាងបញ្ជាក់បន្ថែមប៉ុណ្ណោះ (*សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៥៧៩, ១២៨២៤, ១២៨៣០, ១២៨៤០, ១២៨៦៤, ១២៨៦៦-១២៨៦៨)។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២៨៦៦ លើកឡើងពីកថាខណ្ឌ ៣៨១៤ ដោយសារតែប្រភពតែមួយគត់របស់វា ការពិនិត្យពិច័យយ៉ាងជិតដិតបង្ហាញថា ការយោងគ្រាន់តែផ្តល់ជាឧទាហរណ៍មួយដែលបញ្ជាក់បន្ថែមទៅនឹងប្រភពជាច្រើន ដែលបានលើកឡើងនៅក្នុងជើងទំព័រ ១២៨៦៤។ **<u>*សេចក្តីព្រាងនៃលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា៖*</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦ (ភាពខុសគ្នារវាងសំណៅទាំងពីរនៃលក្ខន្តិកៈ) ជើងទំព័រ ៥៣៦, ៩៤៩-៩៥០, ៩៥២, ៩៥៤-៩៥៥, ៩៩៧, ១០០១, ១០០៣ *អានរួមជាមួយនឹង* ១០០៤, ១០២១ (*សូមមើលផងដែរ* ឯកសារ **E3/130** លក្ខន្តិកៈ ប.ក.ក មាត្រា ២៧-២៨), ១១៧១-១១៧៤ (*សូមមើលផងដែរ* ឯកសារ **E3/130** លក្ខន្តិកៈ ប.ក.ក មាត្រា ៦(៤)), ១១៩០, ១១៩៣-១១៩៦, ១២១៨-១២១៩។ ចំណែកឯសាលក្រមដែលរងការចោទប្រកាន់ កថាខណ្ឌ ៣៧៤៩ *លើកឡើងពី* សេចក្តីព្រាងនៃលក្ខន្តិកៈ ប.ក.ក កថាខណ្ឌបន្ទាប់គឺ ៣៧៥០ និងភស្តុតាងដែលបានលើកឡើងនៅក្នុងនោះ គឺត្រូវគ្នាខាងផ្ទៃក្នុង និងបញ្ជាក់បន្ថែមជាផ្នែកពិភាក្សាពីចក្រពត្តិនិយម ពួកសក្តិភូមិនិយម និង ពួកនាយទុន។ *សូមមើលផងដែរ* ឯកសារ **E3/522** សៀវភៅកំណត់ហេតុរបស់ អៀង សារី EN 00003329 (ដោយកំណត់ប្លុក "ពួកចក្រពត្តិអាមេរិក" រួមទាំងពួកចក្រពត្តិអាល្លឺម៉ង់ខាងលិច និងជប៉ុន

## *មូលដ្ឋានទី ១៨៤៖ កំហុសទាក់ទងនឹង "គោលនយោបាយ"*[3602]

**1003. គួរច្រានចោលមូលដ្ឋានទី ១៨៤ ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ប.ក.ក មានគោលនយោបាយកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យនៅដាច់ដោយឡែក និងកម្ទេចសត្រូវប្រភេទធ្ងន់ធ្ងរបំផុតនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅក្នុងប្រទេសទាំងមូល និងកសាង "សមាសភាពមិនល្អ" និងថា គោលនយោបាយនេះត្រូវបានអនុវត្តដោយខ្សែបណ្ដាញរដ្ឋបាលរបស់បក្សទាំងមូល។**

1004. ផ្អែកលើការវាយតម្លៃជារួមលើភស្តុតាង អ.ជ.ស.ដ បានសន្និដ្ឋានថា ប.ក.ក មានគោលនយោបាយកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យនៅដាច់ដោយឡែក និង "កម្ទេច" ខ្មាំងប្រភេទធ្ងន់ធ្ងរបំផុត នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស និងកសាង "សមាសភាពមិនល្អ"[3603]។ អង្គជំនុំជម្រះក៏សន្និដ្ឋានទៀតថា គោលនយោបាយនេះជាប់ទាក់ទងជាពិសេសទៅនឹងគោលបំណងរួម និងជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការវាយប្រហារប្រឆាំងនឹងភាពថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ) ដូច្នេះ ធ្វើឱ្យគោលនយោបាយនោះមានលក្ខណៈឧក្រិដ្ឋ[3604]។

1005. ការសន្និដ្ឋានទាំងនេះផ្អែកលើភស្តុតាងស៊ីសង្វាក់គ្នា និងលម្អិតដ៏ច្រើនសន្ធឹកសន្ធាប់មកពីប្រភពជាច្រើន រួមទាំង ភស្តុតាងជាបញ្ជីដែលប្រើដើម្បីកំណត់អត្តសញ្ញាណក្រុមខ្មាំងជាក់លាក់ដើម្បីចាប់ខ្លួន ឯកសារពន្ធនាគាររាប់រយ ឯកសារឆ្លើយឆ្លងពីមន្ត្រីមូលដ្ឋានស្នើសុំ និងទទួលការណែនាំពីថ្នាក់លើ របាយការណ៍ពីថ្នាក់ក្រោមទៅកាន់ថ្នាក់លើអំពីការប្រើទារុណកម្មក្នុងពេលសួរចម្លើយ

---

"ពួកគេមានចេតនាបំផ្លាញយើងជានិច្ច" ហើយ "ពួកគេជាសត្រូវរបស់យើងយ៉ាងពិតប្រាកដ"), 00003331 (កត់សំគាល់ថា ចក្រពត្តិអាមេរិក "នៅតែមានមិនបាត់" ហើយស៊ីរូងបង្កប់ផ្ទៃក្នុង)។

[3601] *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៩៦។ សាលដីការឿងក្ដី *Haraqija & Morina* កថាខណ្ឌ ៦១-៦២។

[3602] <u>មូលដ្ឋានទី ១៨៤៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹង "គោលនយោបាយ"* កថាខណ្ឌ ១៥៤៣-១៥៥០ រួមបញ្ចូលទាំង *កំហុសពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ* កថាខណ្ឌ ១៥២៣-១៥៤២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ *"គោលនយោបាយ" មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស* ទំព័រ ៦៣-៦៤ (អង់គ្លេស), ទំព័រ ៥៨-៥៩ (បារាំង), ទំព័រ ៩០-៩១ (ខ្មែរ)។

[3603] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៥, ៣៩៧២, ៣៩៨៧។

[3604] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧៤-៣៩៧៦, ៣៩៧៨-៣៩៨១, ៣៩៨២-៣៩៨៣, ៣៩៨៥-៣៩៨៧។

របាយការណ៍អង្គិរិជ្ជាស្តីពីសាកសពមនុស្សដែលរកឃើញនៅជើងឯក និងក្រាំងតាចាន់ និងសក្ខីកម្មសវនាការរបស់អ្នករស់រានមានជីវិត និងអតីតកម្មាភិបាល ប.ក.ក ដែលរៀបរាប់ពីភាពភ័យខ្លាចដដែលៗជាច្រើន[3605]។ ភស្តុតាងបង្កើតបានជាទម្រង់នៃឧក្រិដ្ឋកម្មនៅទូទាំងប្រទេស ដែលមានលក្ខណៈរីករាលដាលខ្លាំង និងត្រូវបានធ្វើឡើងស្រដៀងគ្នានៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានា ដែលមិនអាចបង្កើតបានជាផាតុផ្សំមនុស្សធម៌ដោយឯកឯងបានឡើយ ប៉ុន្តែ ដើម្បីតែការអនុវត្តគោលនយោបាយជាតិដែលគាំទ្រដោយថ្នាក់ខ្ពស់បំផុតរបស់បក្សប៉ុណ្ណោះ[3606]។ ភស្តុតាងក៏បង្ហាញផងដែរថា ម្ចាស់បណ្តឹងសាទុក្ខគឺជាផ្នែកមួយនៃក្រុមតូចមួយក្នុងចំណោមមេដឹកនាំដែលកំណត់គោលនយោបាយ ប.ក.ក នេះ និងបានដឹងយ៉ាងច្បាស់លាស់ អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដើម្បីអនុវត្តគោលនយោបាយនោះ[3607]។

1006. ជាការសំខាន់ត្រូវកត់សម្គាល់ថា ម្ចាស់បណ្តឹងសាទុក្ខពីមុនបានទទួលស្គាល់ថា ភាគច្រើននៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលបានកើតឡើង ឬទំនងជានឹងកើតឡើងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៃសំណុំរឿង០០២/០២[3608]។ ទោះជាយ៉ាងណា ពេលនេះគាត់អះអាងថា (i) ឧក្រិដ្ឋកម្មទាំងនោះមិនមែនជាផ្នែកនៃគោលបំណងរួម ដែលគាត់បានយល់ព្រមចូលរួមនោះឡើយ។ ឧក្រិដ្ឋកម្មទាំងនេះជា "ការដើរខុសគន្លង" ដែលចាំបាច់សម្រាប់ផានាប្រតិបត្តិការរបស់របបនោះ[3609] និងថា អ.ជ.ស.ដ (ii) បានប្រើគោលនយោបាយ ដើម្បីភ្ជាប់គាត់ខុសទៅនឹង

---

[3605] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨២៦, ៨៤០-៨៧២, ៩០២, ១១២២-១១២៥, ២០៨៦-២០៩១, ២១១៥-២១១៩, ២១១៩, ២៤១១-២៤២៣, ២៥៣២-២៥៤០, ២៦៤៤-២៦៤៧, ២៧០៥, ២៧៧៧-២៧៨៥, ២៨០៣-២៨០៤, ២៨០៨, ២៨៦០-២៨៦២, ៣០២០-៣០២១, ៣០៣៥-៣០៣៦, ៣២៨៧-៣២៩០, ៣៧៤៤-៣៧៤៥, ៣៧៤៨។

[3606] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៤-២៩៦, ៣១៧-៣២២, ៣៣០៤, ៣៩៧៤-៣៩៧៦, ៣៩៧៨-៣៩៨២, ៣៩៨៥-៣៩៨៧, ៤០៤៥, ៤០៥១, ៤០៥៦, ៤០៥៨-៤០៦១, ៤០៨១, ៤២០៨។

[3607] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១-៣២២, ៣៤០, ៣៦៤, ៦០០-៦០៤, ២៣១៣, ៣៧៦៩-៣៧៧០ (ការប្រជុំគណៈអចិន្ត្រៃយ៍ (ចូលរួមដោយម្ចាស់បណ្តឹងសាទុក្ខ "សមមិត្ត ហែម") ដែលនៅក្នុងនោះពួកខ្មាំងត្រូវបានពិភាក្សា), ៣៧៧១ (សេចក្តីសំរេចរបស់គណៈមជ្ឈិម ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ពាក់ព័ន្ធនឹងសិទ្ធិក្នុងការកំទេច), ៣៧៧៥ (ការប្រជុំគណៈអចិន្ត្រៃយ៍ចូលរួមដោយម្ចាស់បណ្តឹងសាទុក្ខ), ៣៩៥៥-៣៩៦៥, ៣៩៦៧-៣៩៧២, ៤២០៨, ៤២១៩-៤២៣៥, ៤២៥៧-៤២៦១, ៤២៦៩-៤២៧០, ៤២៧២, ៤២៧៧, ៤២៨៣-៤២៨៧។

[3608] ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១១៩៦, ១២១៤, ១៣០៤, ១៣៤៨, ១៤១១, ១៤៣៩, ១៤៤២។

[3609] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៧។

ឧក្រិដ្ឋកម្ម ពីព្រោះគាត់មិនទទួលខុសត្រូវចំពោះមន្ទីរសន្តិសុខទេ[3610] និង (iii) បានឱ្យទម្ងន់មិនត្រឹមត្រូវចំពោះតម្លៃជាភ័ស្តុតាង និងបរិបទនៅក្នុងការវិភាគរបស់ខ្លួន ដើម្បីសន្និដ្ឋានថាមានគោលនយោបាយ[3611]។ អំណះអំណាងទាំងអស់នេះមិនមានមូលដ្ឋានដូចបានរៀបរាប់លម្អិតខាងក្រោម។

1007. **អំណះអំណាងស្តីពីការដើរខុសគន្លងនេះបរាជ័យ៖** ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ប.ក.ក មានគោលនយោបាយចាប់ខ្លួន និងសម្លាប់ខ្មាំងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ឬថា អ.ជ.ស.ដ បានកំណត់បទចោទឧក្រិដ្ឋកម្មនៅតាមមន្ទីរសន្តិសុខជាគោលនយោបាយ ប.ក.ក[3612] ជាជាងការដើរខុសគន្លងដែលគាត់លើកឡើង[3613]។ ភ័ស្តុតាងបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅតាមមន្ទីរសន្តិសុខ គឺជាធាតុផ្សំដ៏សំខាន់នៃគោលនយោបាយដ៏យូរអង្វែងរបស់ ប.ក.ក ក្នុងការការពារខ្លួនប្រឆាំងនឹងខ្មាំង ទាំងខ្មាំង ពិត ឬតាមការសន្មត ដើម្បីឱ្យបដិវត្តសង្គមនិយមរបស់ខ្លួនអាចទទួលបានជោគជ័យ។ អ.ជ.ស.ដ បានរៀបរាប់លម្អិតអំពីការប្រុងប្រយ័ត្នរបស់ ប.ក.ក ក្នុងការការពារខ្លួនប្រឆាំងនឹងជ្រាបចូលរបស់ "ខ្មាំង" តាំងពីមុនឆ្នាំ ១៩៧៥ តាមរយៈការចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់គិញដែលសង្ស័យ ហើយកម្មាភិបាលត្រូវបានណែនាំឱ្យធ្វើសកម្មភាពទាំងនោះដោយលាក់ការសម្ងាត់បំផុត ដើម្បីកុំឱ្យប្រជាជនភ័យខ្លាចបក្ស[3614]។ អ.ជ.ស.ដ ក៏បានពិនិត្យភ័ស្តុតាងជាច្រើន ដែលបង្ហាញថាគោលនយោបាយនេះបានបន្តក្នុងរបបទាំងមូល រួមទាំងភ័ស្តុតាងអំពីការប្រតិបត្តិការរបស់មន្ទីរសន្តិសុខជាង ២០០ ទូទាំងប្រទេស ដើម្បីឃុំឃាំង និង "កម្ទេច" ខ្មាំងទាំងនោះ និងជាការកសាង "សមាសភាពមិនល្អ" នៅតាមមន្ទីរសន្តិសុខ ឬលត់ដំដើម្បីរំសាយនិន្នាការ "ប្រឆាំងបដិវត្ត" របស់ពួកគេ[3615]។ ដូចបានរៀបរាប់ខាងលើ ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ផ្អែកលើភ័ស្តុតាងស្របគ្នា

---

[3610] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៨, ១៥៥០។

[3611] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៣-១៥៤២។

[3612] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៧ ដោយអះអាងថា ពួកគេមិនទាក់ទងនឹងគោលបំណងរួមដែលបានកំណត់ នៅក្នុងការបង្កើតបដិវត្តសង្គមនិយម នោះទេ។

[3613] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៧, ១៥៩៩។ *សូមមើលផងដែរ* ជើងទំព័រ ២៩៤០ ដោយលើកឡើងពីឯកសារ E457/6/4/1 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១៩៦៩-១៩៧៩ ជាក់ស្តែងកថាខណ្ឌ ១៩៧៩ (បានប៉ុនប៉ងផ្តួលរំលំ និងបានធ្វើផែនការតស៊ូដែលចាំបាច់ត្រូវកំណត់អត្តសញ្ញាណ និងបោសសំអាតពួកខ្មាំង។ គោលបំណងរួមតែមួយគត់ គឺបង្កើតបដិវត្តសង្គមនិយមដែលចំពោះរឿងនេះ ឧក្រិដ្ឋកម្មនានាមិនមានទាក់ទងនោះទេ)។ *សូមមើលផងដែរ* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៣២។

[3614] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៩៤-២៥០, ២១៣៥, ៣៩៣៤-៣៩៤១, ៣៩៩៧។

[3615] *សូមមើលឧទាហរណ៍* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៩៦, ២០៣៨, ២១២៨, ២១៣៦-២១៤៣, ២១៤៩, ២១៦១-២១៨០, ២៧០៣, ២៧៤៣, ២៧៧១, ២៨៨៧-២៨៨៩, ២៨៩៨-២៩០០, ២៩០៧-២៩០៨, ២៩៩៩-

និងលម្អិតជាច្រើនសន្លឹកសន្ធាប់មកពីប្រភពជាច្រើន ដែលបង្កើតបានជាទម្រង់នៃឧក្រិដ្ឋកម្ម ដែលមានលក្ខណៈរីករាលដាល និងត្រូវបានអនុវត្តស្រដៀងគ្នា ដែលអាចត្រូវបានពន្យល់តែសម្រាប់ការអនុវត្តគោលនយោបាយជាតិដែលគាំទ្រដោយថ្នាក់លើបំផុតរបស់បក្សតែប៉ុណ្ណោះ មិនមែនសម្រាប់ធាតុផ្សំមនុស្សធម៌ដោយឯកឯងនោះទេ[3616]។

1008. **ការអះអាងអំពី "ទំនាក់ទំនងបែបច្នៃប្រឌិត" បរាជ័យ៖** ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គោលនយោបាយចាប់ និងសម្លាប់ខ្មាំងត្រូវបានអនុវត្តដោយខ្សែបណ្តាញរដ្ឋបាលទាំងមូលរបស់បក្ស រួមទាំងរូបគាត់[3617]។ គាត់បានអះអាងដោយមិនត្រឹមត្រូវថា គាត់មិនគួរត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅតាមមន្ទីរសន្តិសុខទេ ដោយហេតុថា ទីតាំងទាំងនោះស្ថិតក្រោមការគ្រប់គ្រងរបស់យោធា ឬស្រុក ហើយគាត់មិនមានសិទ្ធិអំណាចនៅទីនោះទេ[3618]។ អ.ជ.ស.ដ បានពិចារណាយ៉ាងប្រុងប្រយ័ត្នលើអំណះអំណាងនេះ[3619] និងបានសន្និដ្ឋានថា តួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខ តាមពិត មានកម្រិតទាក់ទងនឹង *ការមើលការខុសត្រូវ* មន្ទីរសន្តិសុខទាំងអស់នេះ[3620]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានធ្វើការបែងចែកដាច់ពីគ្នាជាសំខាន់។ ទម្ងន់នៃភស្តុតាងបញ្ជាក់ថា ការទទួលខុសត្រូវតែមួយគត់របស់យោធាគឺត្រូវផ្តល់ការគាំទ្រដល់ប្រតិបត្តិការរបស់ ស-២១ ខណៈដែល *សេចក្តី*

---

២៩៥០, ៣០៤៨-៣០៤៩, ៣០៥៩-៣០៦៥, ៣៧៥១-៣៨៣៤, ៣៨៣៩-៣៨៦៣, ៣៩៤២-៣៩៤៣, ៣៩៤៤-៣៩៥៤ (ប្រតិបត្តិការលើមន្ទីរសន្តិសុខជាង ២០០ កន្លែង), ៣៩៥៥-៣៩៦៥ (ឯកសាររបស់បក្ស និង "ការកំទេច" ពួកខ្មាំង), ៣៩៦៦-៣៩៧២ (អប់រំកសាងពួក "សមាសភាពមិនល្អ")។

[3616] ដូចដែលបានពិភាក្សា និងបានលើកឡើងនៅក្នុងកថាខណ្ឌដំបូងៗ នៃមូលដ្ឋាននេះ។

[3617] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៨ (ម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ អ.ជ.ស.ដ ដែលបានកំណត់គោលនយោបាយប្រឆាំងនឹងខ្មាំងថាបានកំណត់ "ក្រោមរូបភាពជាច្រើន និងដោយប្រែប្រួល" នាំឱ្យ "ផ្សារភ្ជាប់តាមបែបសិប្បនិម្មិត") មកលើរូបគាត់ទៅនឹងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅឯមន្ទីរសន្តិសុខផ្សេងៗ។

[3618] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៨ ជើងទំព័រ ២៩៤៤។ ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) កថាខណ្ឌ ១៤៦៧, ១៤៨០-១៤៨៦។

[3619] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៨៥, ៣៩៣២។ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ថា អ.ជ.ស.ដ គ្រាន់តែរំលឹកឡើងវិញជាផ្នែកប៉ុណ្ណោះនូវអំណះអំណាងរបស់គាត់ (ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៨) ប៉ុន្តែថាការណ៍នេះមិនចាំបាច់តម្រូវទេ (*សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៣, ២០៧) ឬមិនត្រឹមត្រូវនោះទេ (*សូមមើលជាក់ស្តែង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣១២០ កត់សំគាល់ថា កថាខណ្ឌ ១៤៦៩-១៤៨៦ នៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានលើកឡើងនៅក្នុងផ្នែក ១៨.១.២.២ នៃសាលក្រម)។

[3620] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៩ (គូសបញ្ជាក់បន្ថែម)។

*ណែនាំទាក់ទងនឹងបញ្ហាសន្តិសុខ* ដូចជាការសួរចម្លើយ និងការសម្លាប់ មកពីគណៈកម្មាធិការមជ្ឈិមទាំងស្រុង[3621] ដែលម្ចាស់បណ្ដឹងសាទុក្ខមានទំនាក់ទំនងសំខាន់។ ស្រដៀងគ្នានេះដែរ ទោះបីជាមន្ទីរសន្តិសុខអូរកន្សែងស្ថិតក្រោមការគ្រប់គ្រងរបស់យោធាក៏ដោយ ច្បាស់ណាស់ថា កន្លែងនេះត្រូវបានប្រើប្រាស់សម្រាប់ការស្វែងរកខ្មាំងរបស់មជ្ឈិមបក្ស[3622] ហើយទោះបីជា ភ្នំក្រោលបានដំណើរការក្រោមការគ្រប់គ្រងរបស់អាជ្ញាធរតំបន់ ១០៥ ក៏ដោយ ក៏អាជ្ញាធរទាំងនេះរាយការណ៍ផ្ទាល់ទៅមជ្ឈិមបក្សនៅមន្ទីរ ៨៧០[3623] ដែលម្ចាស់បណ្ដឹងសាទុក្ខជាសមាជិកនោះ។ ជាចុងក្រោយ ទោះបីជាមន្ទីរសន្តិសុខក្រាំងតាចាន់គឺជាមន្ទីរសន្តិសុខថ្នាក់ស្រុក តំបន់១៣ ជាប់ពាក់ព័ន្ធខ្លាំងក្នុងការសម្រេចពីជោគវាសនារបស់អ្នកទោស និងជាប្រចាំបានបញ្ជូនព័ត៌មានទៅលេខាភូមិភាគ/សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ តាម៉ុក អំពីសកម្មភាពនានានៅទីតាំងនោះ[3624]។

1009. ផ្ទុយទៅនឹងការអះអាងរបស់គាត់ ការទទួលខុសត្រូវរបស់ម្ចាស់បណ្ដឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មទាំងអស់នេះមិនផ្អែកលើសិទ្ធិអំណាចយោធា ឬថ្នាក់ស្រុកនោះទេ តែផ្ទុយទៅវិញផ្អែកលើសមាជិកភាពរបស់គាត់ក្នុងក្រុមតូចមួយនៃមេដឹកនាំ ប.ក.ក ដែលបានដឹងច្បាស់លាស់នៅក្នុងមជ្ឈិមបក្ស ការចូលរួមរបស់គាត់ក្នុងអង្គប្រជុំ ដែលសម្រេចពីជោគវាសនារបស់កម្មាភិបាល ការចូលរួមចំណែករបស់គាត់ក្នុងការស៊ើបអង្កេត និងបោសសម្អាតអ្នកផ្សេងទៀត និងការចូលរួមរបស់គាត់ក្នុងប្រព័ន្ធមួយដែលគាត់បានដឹងថាកំពុងចាប់ និងសម្លាប់កម្មាភិបាល ប.ក.ក និងប្រជាជនរបបកម្ពុជាប្រជាធិបតេយ្យ[3625]។ អ.ជ.ស.ដ មិនចាំបាច់ "ភ្ជាប់ទំនាក់ទំនងតាមបែបច្នៃប្រឌិត"

---

[3621] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៨៦-២១៨៧, ២១៩១។ នេះគឺជាសេចក្ដីសន្និដ្ឋានសមហេតុសមផលមួយដែលមានមូលដ្ឋាននៅលើ, *ក្នុងចំណោមនោះ,* ភស្តុតាងដែលបានលើកឡើងនៅក្នុងចម្លើយតបទៅនឹងទទ្បីករណ៍ ១៧៩ ដែលពិភាក្សាពីបញ្ហានេះ ដែលបង្ហាញថាគឺគណៈអចិន្ត្រៃយ៍ - មិនមែនអគ្គសេនាធិការនោះទេ - ដែលគ្រប់គ្រងលើមន្ទីរ ស.២១។ បន្ថែមទៅលើភស្តុតាងដែលបានលើកឡើងនៅក្នុងនោះ *សូមមើលបន្ថែមទៀត* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២២៣ (កត់សំគាល់ថា នៅពេលដែល ស៊ូ ម៉េត (ដែលជាសមាជិកនៃអគ្គសេនាធិការ) បានសរសេរទៅកាន់ ឌុច ពាក់ព័ន្ធនឹងការបញ្ជូនអ្នកទោសបួននាក់ទៅកាន់ស.២១, ជាជាងការណែនាំ ឌុច ឱ្យធ្វើនូវអ្វីដែលត្រូវធ្វើ ស៊ូ ម៉េត បានថ្លែងថា គាត់ត្រូវសួរយោបល់ពីអង្គការពាក់ព័ន្ធនឹងសកម្មភាពជាបន្តទៀត)។

[3622] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៧២-២៨៨៤, ២៨៩៨-២៩០០, ២៩០៦, ២៩៣៥-២៩៣៦, ២៩៥៧-២៩៥៨, ២៩៦០។

[3623] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៧, ៤៨៩, ៣០២៨-៣០២៩, ៣០៣១, ៣០៣៤-៣០៤៩, ៣០៦៥, ៣០៧៦-៣០៨០, ៣១៦២។

[3624] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧០២-២៧០៩, ២៨២០, ២៨៣៨។

[3625] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០, ៣៥០, ៣៥៥, ៣៦៤, ៦០០-៦០៤, ២៣១៣, ៣៧៦៩-៣៧៧០ (ការប្រជុំគណៈអចិន្ត្រៃយ៍ (ចូលរួមដោយម្ចាស់បណ្ដឹងសាទុក្ខ "សមមិត្ត ហែម") ដែលនៅ

រវាងម្ចាស់បណ្តឹងសាទុកទៅនឹងឧក្រិដ្ឋកម្មតាមមន្ទីរសន្តិសុខទេ។ ភស្តុតាងបង្ហាញយ៉ាងគ្រប់គ្រាន់ថា ការចូលរួមចំណែករបស់គាត់ "មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ" ជាមួយនឹងឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទីនោះ[3626]។

1010. ក្នុងការព្យាយាមបន្ថែមទៀតដើម្បីជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលភ្ជាប់គាត់ទៅនឹងឧក្រិដ្ឋកម្ម ម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់ដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសដោយខកខានមិនបានសន្និដ្ឋានថា ការសម្ងាត់នៅជុំវិញប្រតិបត្តិការមន្ទីរសន្តិសុខ បានរារាំងមិនឱ្យដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទីនោះ ដែលអាចបដិសេធការសន្និដ្ឋានដែលថា គោលបំណងរួមបាននាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ[3627]។ អ.ជ.ស.ដ បានទទួលស្គាល់ថា ការសម្ងាត់គឺជាលក្ខណៈនៃប្រតិបត្តិការរបស់មន្ទីរសន្តិសុខ[3628] និងបានកត់សម្គាល់លើការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា គាត់មិនបានដឹង មិនបានឃើញ និងមិនបានស្តាប់អ្វីទាំងអស់ដោយសារតែភាពសម្ងាត់នោះ[3629]។ ប៉ុន្តែ ដូចបានពិភាក្សាជាលម្អិតនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៥ ទម្ងន់នៃភស្តុតាងបង្ហាញថា មេដឹកនាំជាន់ខ្ពស់ ប.ក.ក រួមទាំងម្ចាស់បណ្តឹងសាទុក្ខ បានទទួលព័ត៌មានសម្ងាត់អំពីឧក្រិដ្ឋកម្មតាមមន្ទីរសន្តិសុខ ដែលកម្មាភិបាលថ្នាក់ក្រោមមិនបានដឹង[3630]។ ការជំទាស់ផ្សេងទៀតរបស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងការដឹងរបស់គាត់ ក៏មាន

---

ក្នុងនោះ គេបានពិភាក្សាអំពីខ្មាំង), ៣៧៧១ (សេចក្តីសំរេចរបស់គណៈមជ្ឈិម ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ពាក់ព័ន្ធនឹងសិទ្ធិក្នុងការកំទេច), ៣៧៧៥ (ការប្រជុំគណៈអចិន្ត្រៃយ៍ចូលរួមដោយម្ចាស់បណ្តឹងសាទុក្ខ), ៣៩៥៥-៣៩៦៥, ៣៩៦៧-៣៩៧២, ៤២០៨, ៤២១៩-៤២៣៥, ៤២៥៨, ៤២៦០-៤២៦១, ៤២៦៩-៤២៧០, ៤២៧២, ៤២៧៧, ៤២៨៣-៤២៨៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៨។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩០-១៩២, ១៩៥, ២០០, ២០៣-២០៥, ២១៦-២១៧, ២៣៥។

[3626] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៩, ៤២៨៤។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៨។

[3627] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៥០, ជើងទំព័រ ២៩៤៩ *ដាក់ឱ្យរងនូវការចោទប្រកាន់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧៨-៣៩៨១, ៣៩៨៣, ៣៩៨៥-៣៩៨៧។

[3628] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១៧១, ២១៨៣, ២២១៧, ២២៥៧-២២៥៩, ២៤០៤, ៣៧៦០, ៣៧៩៣, ៣៨៦២, ៣៩៣៨-៣៩៣៩, ៣៩៥៨។

[3629] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០២។

[3630] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦០ (នៅឯការប្រជុំគណៈចិន្ត្រៃយ៍មួយ គេបានពិភាក្សាគ្នាថា ចាន់ ចក្រី *ហៅ* មាន និង ផាន ត្រូវបានស៊ើបរឿងនេះ ហើយត្រូវឱ្យស្ងៀមស្ងាត់មែនទែន), ៣៧៩៣ (នៅក្នុងកិច្ចប្រជុំមួយរបស់លេខា និងអនុលេខារបស់កងពល និងកងវរសេនាធំ សុន សេន បានសង្ខេបពីព្រឹត្តិការណ៍ថ្មីៗជុំវិញការចាប់ខ្លួន និងការសារភាពពីកម្មាភិបាលដឹកនាំមួយចំនួន "ដោយគាត់បានសង្កត់ធ្ងន់ថា គ្រប់គ្នាត្រូវរក្សាការសម្ងាត់

ពិភាក្សា នៅកន្លែងផ្សេងទៀត ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានអនុវត្តច្បាប់មិនត្រឹមត្រូវ ឬថា ការសន្និដ្ឋានរបស់ខ្លួនមិនអាចធ្វើឡើងបានដោយអ្នកស្វែងរកការពិតដ៏មានហេតុផលណាម្នាក់[3631]។

1011. ស្រដៀងគ្នានេះដែរ ការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការភ្ជាប់ទៅនឹងខ្សែបណ្តាញរដ្ឋបាលរបស់ ប.ក.ក ទាំងមូល[3632] ក៏បរាជ័យផងដែរ ដោយសារតែគាត់មិនបានបង្ហាញពីកំហុសណាមួយនៅក្នុងការបកស្រាយរបស់ អ.ជ.ស.ដ នៃសារដែលបានផ្ញើទៅកាន់មន្ទីរ ៨៧០ ឬ *អង្គការ* ដែលបានភ្ជាប់គាត់ទៅនឹងខ្សែបណ្តាញនោះ[3633]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសដោយការប្រដូចស្វ័យទិះទៀនទៅនឹងការកសាង (ការបន្ទោសកំហុស) ត្រូវតែបរាជ័យផងដែរ ដោយសារតែខ្វះការគាំទ្រ[3634]។ ចំណុចត្រូវបានធ្វើឱ្យអស់ភាពជឿជាក់បន្ថែមទៀតដោយភស្តុតាងដែលបង្ហាញថា ស្វ័យទិទានត្រូវបានប្រើដើម្បីជួយកំណត់ថា អ្នកណា "ល្អ" ឬ "មិនល្អ" ដែលជាញឹកញាប់បណ្តាលឱ្យមាន ឬត្រូវបានប្រើជាមួយការគំរាមកំហែង ការបាត់ខ្លួន និងការចាត់តាំងការងារ[3635]។

1012. តម្លៃជាភស្តុតាង និងបរិបទដែលជំទាស់ បរាជ័យ ៖ ការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងការពឹងផ្អែករបស់ អ.ជ.ស.ដ លើសក្ខីកម្មរបស់ ឌុច ទាក់ទងនឹងខ្មាំងបីប្រភេទ មើលរំលងបរិបទ

---

និងមិនត្រូវឱ្យព័ត៌មាននេះលេចធ្លុះដល់កម្មាភិបាលថ្នាក់ក្រោមនោះទេ"), ៣៨៦២ ("ព័ត៌មានលម្អិតអំពីដំណោះស្រាយចំពោះសកម្មភាពរបស់ខ្មាំង និងវិធីសាស្ត្រជាក់លាក់ក្នុងការដោះស្រាយជាមួយខ្មាំង ត្រូវបានពិភាក្សានៅក្នុងចំណោមថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក តែប៉ុណ្ណោះ [...]។ ការពិភាក្សាទាំងនេះត្រូវបានរក្សាជាការសម្ងាត់"), ៣៩៥៨ ("ទោះបីជាមានគោលការណ៍រក្សាការសម្ងាត់របស់បក្សក៏ដោយ ក៏ការកម្ទេចខ្មាំងត្រូវបានរាយការណ៍យ៉ាងច្រើនក្នុងជួរបក្ស")។

[3631] *សូមមើលយ៉ាងជាក់លាក់* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩២, ១៩៥, ២១៦, ២១៧, ២៣៥។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ២៩៤៨ *យោងយ៉ាងជាក់ច្បាស់* ទៅលើកថាខណ្ឌ ១៨៤៩-១៨៧៨ របស់គាត់។

[3632] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៩។

[3633] *សូមមើល* ចម្លើយតបទៅនឹងទឡ្ហីករណ៍ ១៩០, ១៩១, ២០៥, ២២៥, ២៤៥ ដោយបានលើកឡើងពីអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងកថាខណ្ឌ ១៦១៦-១៦៣៩ របស់គាត់ ដែលគាត់បានយោងយ៉ាងជាក់ច្បាស់នៅក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ២៩៤៤។

[3634] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤៩ ជើងទំព័រ ២៩៤៥ *ដោយបានលើកឡើងពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៨, ៣៩៧២។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបានយោងទៅដល់កថាខណ្ឌនានាដែលបានដាក់ឱ្យរងនូវការចោទប្រកាន់ប៉ុណ្ណោះ។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងទឡ្ហីករណ៍ ១៧៩ (ស្វ័យទិះទៀន)។

[3635] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២៨-១០២៩, ១២៩១, ១២៩៥, ១៣២១, ១៥៥៣, ១៥៥៥, ១៥៥៨, ១៥៦០, ១៦៧៧ ១៧១១។

នៃភ័ស្តុតាងផ្ទុយ ដោយការកំណត់ខុសត្រឹមរយៈពេលក្នុងឆ្នាំ ១៩៧៦[3636]។ ក្នុងការឆ្លើយតបទៅនឹងសំណួរដ៏ទូលំទូលាយរបស់មេធាវីការពារក្តី នួន ជា ស្តីពីការដកស្រង់មួយចេញពីកំណត់ហេតុនៃអង្គប្រជុំឆ្នាំ ១៩៧៦[3637] ឌុច បានផ្តល់ចម្លើយតបជាលម្អិត ដោយបានគូសបញ្ជាក់ពីដើមកំណើតនៃក្រុមខ្មាំងទាំងនោះពីឆ្នាំ ១៩៦០[3638]។ ការពិចារណាថា ឌុច មានការប្រុងប្រយ័ត្នក្នុងការសិក្សាអំពីមាគ៌ាបក្សក្រោយពេលគាត់ចូលរួមក្នុង ប.ក.ក ក្នុងឆ្នាំ១៩៦៤[3639] អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវលើសក្ខីកម្មរបស់គាត់ ដែលសន្និដ្ឋានចេញពីចំណេះដឹងមុនរបបកម្ពុជាប្រជាធិបតេយ្យរបស់គាត់ អំពីអង្គហេតុដែលគាត់បានផ្តល់សក្ខីកម្ម[3640]។ ការលើកឡើងតាមការស្មានរបស់ម្ចាស់បណ្តឹងសាទុក្ខថា ឌុច បានដឹងតាមរយៈការអានសំណុំរឿង[3641] មិនបង្កើតបានជាកំហុសនោះទេ[3642]។

1013. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញកំហុសណាមួយនៅក្នុងការប្រើប្រាស់របស់ អ.ជ.ស.ដ នូវភ័ស្តុតាងទាក់ទងនឹងព្រឹត្តិការណ៍មុនខែមេសា ឆ្នាំ១៩៧៥ ដើម្បីបង្ហាញពីគោលនយោបាយប្រឆាំងនឹងខ្មាំង ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស ក្នុងការការពិចារណាលើភ័ស្តុតាងជាច្រើន ដែលបង្ហាញថា គោលនយោបាយនេះបានបន្តនៅទូទាំងរបបទាំងមូល ដូច្នេះ

---

[3636] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៤ ("ទោះយ៉ាងណា ឌុច បានអត្ថាធិប្បាយលើកំណត់ហេតុនៃកិច្ចប្រជុំយោធាមួយ ដែលលើកឡើងពីខ្មាំងបីប្រភេទ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦")។

[3637] ឯកសារ **E1/441.1** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.45.01-13.47.14 ទំព័រ ៤៣ បន្ទាត់ ៧-១៨ (មេធាវីបានសួរប្រសិនបើ ឌុច នៅចងចាំការបែងចែកខ្មាំងជាបីប្រភេទនេះ)។

[3638] ឯកសារ **E1/441.1** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.47.14-13.52.56 ទំព័រ ៤៣ បន្ទាត់ ២០-ទំព័រ ៤៤ បន្ទាត់ ៨។

[3639] ឯកសារ **E3/5798** កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 13.45.09-13.54.14 ទំព័រ៤៣ បន្ទាត់ ១៧-២១។

[3640] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ១៧ (កំរិតនៃសេចក្តីគោរព ដែលការរកឃើញខាងអង្គហេតុរបស់ អ.ជ.ស.ដ បានប្រឹងប្រែងផ្តល់ឱ្យ)។

[3641] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៤។

[3642] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៨០-២០៨២។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៤។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២១៨, ២៤៩៩, ជើងទំព័រ ១២៧១, ៧៤២៥, ៧៤៦៨, ៨១០៧ ដោយបង្ហាញពីវិធីសាស្ត្រប្រុងប្រយ័ត្នរបស់ អ.ជ.ស.ដ ទៅលើភ័ស្តុតាងរបស់ ឌុច។

បង្កើតបានជាទម្រង់ដ៏ច្បាស់លាស់មួយនៃការប្រព្រឹត្ត[3643]។ គាត់ក៏មិនបានបង្ហាញផងដែរថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា មានមន្ទីរសន្តិសុខយ៉ាងហោចណាស់ ២០០ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[3644] ផ្ទុយទៅវិញ គាត់គ្រាន់តែលើកឡើងពីអង្គហេតុដែល អ.ជ.ស.ដ បានពិចារណាមុនពេលធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន[3645]។ ផ្ទុយទៅនឹងការបង្ហាញរបស់គាត់[3646] អ.ជ.ស.ដ បានពិនិត្យភស្តុតាងក្នុងសំណុំរឿងយ៉ាងឯករាជ្យទាក់ទងនឹងអត្ថិភាពនៃមន្ទីរសន្តិសុខក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ បានពិនិត្យផ្ទៀងផ្ទាត់ការសន្និដ្ឋានរបស់ខ្លួន និងផ្អែកលើតែភស្តុតាងណាដែលអាចជឿជាក់បាន និងនៅពេលណាដែលអាចធ្វើបាន ជាភស្តុតាងដែលអាចបញ្ជាក់បាន[3647]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា សេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលផ្អែកលើការវិភាគដ៏ប្រុងប្រយ័ត្ននោះ មិនត្រឹមត្រូវនោះទេ។

1014. ម្ចាស់បណ្តឹងសាទុក្ខចោទមិនត្រឹមត្រូវថា អ.ជ.ស.ដ បានបំភ្លៃអត្ថន័យនៃមាត្រា ១០ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ដោយបកស្រាយខុសនូវឃ្លា "ផ្តន្ទាទោសកម្រិតខ្ពស់បំផុត" ថាមានន័យថា ស្លាប់[3648]។ ដូចបានគូសបញ្ជាក់នៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២៧ ការអះអាងរបស់គាត់មើលរំលងពាក្យពេចន៍ធម្មតានៃសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែល អ.ជ.ស.ដ បានយោង ដែលបានបញ្ជាក់យ៉ាងច្បាស់អំពីអត្ថន័យនេះគឺ

---

[3643] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៥ *ដោយដាក់ឱ្យវងនូវការជំទាស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៣៤-៣៩៤១។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨០ ដោយពិភាក្សាអំពីករណីយុត្តិសាស្ត្រដែលអនុញ្ញាតឱ្យប្រើប្រាស់មានកម្រិតនៃភស្តុតាងក្រៅវិសាលភាពពេលវេលា។

[3644] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៥ *ដោយដាក់ឱ្យវងនូវការជំទាស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៤។

[3645] *សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៥។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៤៩ (យោង វិធីសាស្ត្ររបស់ DC-Cam និងការទទួលស្គាល់ការទាក់ទងគ្នាពីមុនរបស់លោក Craig Etcheson ជាមួយនឹង DC-Cam និង ក.ស.ព), ៣៩៥១, ៣៩៥៣ (ការខ្វល់ខ្វាយពីការប្រមូលរកឃើញដោយផ្ទាល់ខ្លួនរបស់លោក Henri Locard និងការទុកចិត្តរបស់ អ.ជ.ស.ដ ទៅលើពួកវា តែនៅពេលណាដែលបានបញ្ជាក់បន្ថែមប៉ុណ្ណោះ)។

[3646] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៥ (ចោទប្រកាន់ថា អ.ជ.ស.ដ បានទុកចិត្តតែទៅលើការងាររបស់ DC-Cam មួយតែប៉ុណ្ណោះ)។

[3647] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៤៨, ៣៩៥៣-៣៩៥៤។

[3648] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៧-១៥២៩ *ដោយដាក់ឱ្យវងនូវការជំទាស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៥។

សិទ្ធិ "កម្មេច" ខាងក្នុង និងខាងក្រៅជួរបក្ស[3649]។ ភ័ស្តុតាងជាច្រើនអំពី "ជនក្បត់" ដែលត្រូវបានសម្លាប់ដោយមូលហេតុកំហុសដែលគេជឿថា "ធ្ងន់ធ្ងរ" ប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ[3650] បញ្ជាក់ពីភាពត្រឹមត្រូវនៃការបកស្រាយរបស់ អ.ជ.ស.ដ។ ផ្អែកលើភ័ស្តុតាង នៅចំពោះមុខខ្លួន ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការបកស្រាយរបស់ អ.ជ.ស.ដ មិនត្រឹមត្រូវ។ ភាសានៃសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដូចគ្នានេះ បដិសេធការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានបំភ្លៃឯកសារក្នុងការធ្វើការសន្និដ្ឋានរបស់ ខ្លួនអំពីអំណាចក្នុងការបញ្ជាការសម្លាប់នៅក្នុងអំឡុងពេលបោសសម្អាត[3651]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា គាត់មិនមានទំនាក់ទំនងទៅនឹងឯកសារនោះ ក៏បរាជ័យផងដែរ ដោយហេតុថា គាត់គឺជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនៅពេលសេចក្តីសម្រេចនោះ[3652]។ អំណះអំណាង *ចោទបកវិញ (tu quoque)* ដែលគ្មានការគាំទ្ររបស់គាត់[3653] ដែលមិនមែនជា ការការពារដ៏មាន

---

[3649] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៥ *ដោយលើកឡើងពី* ឯកសារ **E3/12** សេចក្តីសម្រេចរបស់គណៈមជ្ឈិម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦, EN 00182809។

[3650] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៨៦, ១៨៩៣-១៨៩៦, ១៨៩៩, ១៩២៩, ១៩៩៤-១៩៩៥, ២០១៣-២០១៤, ២០១៧, ២០២២-២០២៣, ២០៣០-២០៣១, ២០៣៣-២០៣៥, ២០៣៧-២០៣៨, ២០៤១, ២០៥៦, ២០៧២, ២១២៨, ២១៧៨-២១៧៩, ២២៦៥, ២២៦៧, ២២៧០, ២២៧៥-២២៧៧, ២២៨១-២២៨៣, ២២៨៩, ២២៩៥-២២៩៨, ២៣០២-២៣០៤, ២៣០៨-២៣១២, ២៣១៦-២៣១៨, ២៣២០, ២៣២២-២៣២៧។

[3651] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣០ *ដោយដាក់ឱ្យវង់នូវការជំទាស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៥-៣៩៥៦ *ដោយលើកឡើងពី* ឯកសារ **E3/12**។ ម្ចាស់បណ្តឹងសាទុក្ខមិនបានពន្យល់ពីរបៀបដែល អ.ជ.ស.ដ បានធ្វើឱ្យឯកសារខុសពីភាពដើមនោះទេ ដោយគ្រាន់តែថាវាត្រូវបានយោងនៅពាសពេញសាលក្រម។

[3652] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣០។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៧៦ (ម្ចាស់បណ្តឹងសាទុក្ខបានក្លាយទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមរបស់ ប.ក.ក នៅក្នុងសន្និបាតលើកទីបួន ឆ្នាំ១៩៧៦), ៣៩៣ (សន្និបាតបក្សលើកទីបួនត្រូវបានធ្វើឡើងនៅខែមករា ឆ្នាំ១៩៧៦)។ ឯកសារ **E1/198.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 14.42.41-14.44.52 ទំព័រ ៨៧ បន្ទាត់ ២-៤ ("ខ្ញុំជាសមាជិកត្រៀមរហូតដល់ចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ នៅពេលដែលខ្ញុំបានក្លាយទៅជាសមាជិកពេញសិទ្ធិ")។ ឯកសារ **E3/27** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន EN 00156751។ ឯកសារ **E1/223.1** លោក Stephen Heder ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.08.55-11.11.28 ទំព័រ ៤៣ បន្ទាត់ ២-៦។ ឯកសារ **E3/573** កិច្ចសម្ភាសន៍ជាមួយ អៀង សារី ដោយ Stephen Heder ឆ្នាំ១៩៩៩ EN 00427599។ ឯកសារ **E3/20** *នៅពេលដែលសង្គ្រាមរលត់ទៅ* EN 00237887 (សន្និបាតបក្ស លើកទីបួន នៅខែមករា ឆ្នាំ១៩៧៦)។

[3653] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៨ (ដោយអះអាងថា ការដាក់ទោសយ៉ាងធ្ងន់ធ្ងរចំពោះរាល់ការធ្វើឱ្យប៉ះពាល់ដល់ជាតិ គឺជាចម្លើយតបតាមផ្លូវច្បាប់ ហើយវា"គ្រប់គ្រាន់"បាត់ទៅហើយ ដោយគ្រាន់តែយោងលើក្រមព្រហ្មទណ្ឌជាតិដើម្បីវាយតម្លៃពីរឿងនេះ)។

សុពលភាពតាមច្បាប់មនុស្សធម៌អន្តរជាតិ[3654] មិនបានពិចារណាថាមនុស្សទាំងអស់ សូម្បីតែជនក្បត់ដែលគេសង្ស័យ ទទួលបានការធានានូវសិទ្ធិជាមូលដ្ឋាន ដែលបានបដិសេធដោយរបបកម្ពុជាប្រជាធិបតេយ្យ[3655]។ ជាចុងក្រោយ ភ័ស្តុតាងបដិសេធការអះអាងរបស់ម្ចាស់ បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានអនុវត្តបទដ្ឋានត្រូតគ្នា ក្នុងការវិភាគរដ្ឋធម្មនុញ្ញ[3656]។

1015. ម្ចាស់បណ្តឹងសាទុក្ខជំទាស់មិនត្រឹមត្រូវថា អ.ជ.ស.ដ មិនគួរពឹងផ្អែកលើការវាយតម្លៃរបស់ ឌុច អំពីសេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិម ខែមិថុនា ឆ្នាំ១៩៧៨ ដែលបានលើកលែងទោស "ខ្មាំង" មួយចំនួន ដោយសារតែបរិបទនៅពាក់កណ្តាលឆ្នាំ ១៩៧៨[3657]។ អ.ជ.ស.ដ ពិតជាបានពិចារណាលើបរិបទនោះ ប៉ុន្តែ ខ្លួនក៏បានពិចារណាអំពីបញ្ជីឈ្មោះអ្នកទោស ស-២១ ផងដែរ ដែលបានបញ្ជាក់ថា ការចាប់ខ្លួនបានបន្តកើតមាននៅទូទាំងប្រទេសក្រោយខែមិថុនា ឆ្នាំ១៩៧៨ សក្ខីកម្មរបស់សាក្សីអំពីការបន្តចាប់ខ្លួនមនុស្សនៅទំនប់ ១ មករា ភ័ស្តុតាងឯកសារ និងសក្ខីកម្មអំពីការបន្តបញ្ជូនអ្នកទោសចូលក្នុងមន្ទីរឃុំឃាំង និងការសម្លាប់នៅក្រាំងតាចាន់ និងភ័ស្តុតាងដែលថា "យួន" និង ចាម ត្រូវបានដកចេញពីអ្វីដែលគេហៅថា ការលើកលែងទោសរបស់ ប.ក.ក នោះ[3658]។ ផ្អែកលើភ័ស្តុតាងនេះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការពឹងផ្អែករបស់ អ.ជ.ស.ដ លើមតិរបស់ ឌុច មិនត្រឹមត្រូវទេ ដែលថា សេចក្តីណែនាំនោះគឺជាឧបាយកល។

---

[3654] *សូមមើលឧទាហរណ៍* សាលដីការឿងក្តី *D. Milošević* កថាខណ្ឌ ២៥០ *ដោយលើកឡើងពី* សាលដីការឿងក្តី *Martić* កថាខណ្ឌ ១១១ សាលដីការឿងក្តី *Kupreškić* កថាខណ្ឌ ២៥។

[3655] *សូមមើលឧទាហរណ៍* មាត្រា ៦, ៩, ១៤ នៃ ICCPR។ មាត្រា ៧-១១ នៃ UDHR។ មាត្រា ២, ៦ នៃ ECHR។ មាត្រា ៤, ៨ នៃ ACHR។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៦, ៤១៧-៤១៨, ១៨៨៧, ១៩៣១។

[3656] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៩។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៥ និង ១៧៩។

[3657] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣១ *ដោយដាក់ឱ្យរងនូវការជំទាស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧១។

[3658] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៦៨, ២៧៧០, ៣៤០៤, ៣៨២៨, ៣៩៧១។ *កត់សំគាល់ថា* ឯកសារ **E3/764** និងឯកសារ **E3/763** គឺជាឯកសារដូចគ្នា ហើយថា សេចក្តីណែនាំរបស់គណៈមជ្ឈិម នៅខែមិថុនា ឆ្នាំ១៩៧៨ នេះ គឺមិនអនុវត្តចំពោះពួកជនដែលប្រឆាំងនឹងបក្ស ពីឆ្នាំ១៩៧៥-១៩៧៨ នោះទេ និងមានចេតនាបន្តសកម្មភាពប្រឆាំងបក្ស ដូច្នេះ "ប.ក.ក ត្រូវតែកំចាត់"។ (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨២៨, ៣៩៧១ *ដោយលើកឡើងពី* ឯកសារ **E3/764 (E3/763)** សេចក្តីណែនាំរបស់គណៈមជ្ឈិម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ EN 00275218។

1016. ទាក់ទងនឹងសុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧[3659] កថាខណ្ឌនៃសាលក្រមដែលគាត់ជំទាស់នោះ គ្រាន់តែលើកឡើងថា ម្ចាស់បណ្តឹងសាទុក្ខ "បានបន្ទរការអំពាវនាវឱ្យ "កម្ទេច" ខ្មាំង នៅក្នុងសុន្ទរកថាថ្លែងក្នុងឱកាសខួបលើកទី ២ នៃថ្ងៃ "រំដោះ" ១៧ មេសា ១៩៧៥" និងបានដកស្រង់សម្រង់ចេញពីសុន្ទរកថារបស់គាត់[3660]។ ម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញពីការសន្និដ្ឋានណាមួយ ដែលកំណត់ប្រភេទសុន្ទរកថារបស់គាត់ថា "មានលក្ខណៈឧក្រិដ្ឋ" ឬ ថា អ.ជ.ស.ដ បានបំភ្លៃអត្ថន័យរបស់វានោះទេ[3661]។

1017. អ.ជ.ស.ដ ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានពឹងផ្អែកខុសលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ទាក់ទងនឹងសុន្ទរកថាឆ្នាំ ១៩៧៧ នៅផ្សារច្បារអំពៅ[3662]។ អ.ជ.ស.ដ បានកត់សម្គាល់សំណួរជាច្រើនរបស់មេធាវីការពារក្តីរបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការខកខានមិនបានរៀបរាប់ពីសុន្ទរកថារបស់គាត់ពីមុន និងថា ព្រាប ឆុន បានពន្យល់យ៉ាងគួរឱ្យជឿជាក់ និងយ៉ាងស៊ីសង្វាក់គ្នាអំពីកាលៈទេសៈនានា ដែលរូបគាត់បានផ្តល់ចម្លើយបឋម រួមទាំងការដែលថា គេមិនបានសួរគាត់អំពីម្ចាស់បណ្តឹងសាទុក្ខ និងបានព្យាយាមកំណត់ចម្លើយរបស់គាត់ត្រឹមសំណួរដែលបានសួរ[3663]។ អ.ជ.ស.ដ មានការប្រុងប្រយ័ត្នអំពីកាលៈទេសៈនានាដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱ្យ ហើយ ដោយសារសក្ខីកម្មដ៏គួរឱ្យជឿជាក់របស់ ព្រាប ឆុន ក្រោមការសួរដេញដោលដោយភាគីបដិបក្ខយ៉ាងហ្មត់ចត់ អង្គជំនុំជម្រះបានពឹងផ្អែកយ៉ាងសមហេតុផលលើភស្តុតាងរបស់គាត់[3664]។ ដោយបានទទួលស្គាល់អំពីសំណើមិនត្រឹមត្រូវតាមពេលវេលា[3665] អ.ជ.ស.ដ បានកត់សម្គាល់យ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខមិនទទួលរងព្យសនកម្មទេ ដោយហេតុថា គាត់មានពេលគ្រប់គ្រាន់ក្នុងការ

---

[3659] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣២-១៥៣៣។

[3660] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦០។

[3661] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០ (អំណះអំណាងដែលគ្រាន់តែមិនយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ដោយមានមូលដ្ឋាននៅលើការបកស្រាយដែលមិនមានអំណះអំណាងមួយផ្សេងទៀតទៅលើភស្តុតាងដូចគ្នា គឺមិនគ្រប់គ្រាន់នោះទេក្នុងការទាត់ចោលការរកឃើញខាងអង្គហេតុ)។

[3662] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៤-១៥៣៥ *ដោយដាក់ឱ្យរងនូវការជំទាស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦១។

[3663] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣១៨៥។

[3664] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣១៨៥។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ១៧។

[3665] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៥។

រៀបចំសម្រាប់ការសួរសំណួរ[3666]។ ជាចុងក្រោយ អ.ជ.ស.ជ បានកំណត់ការប្រើប្រាស់របស់ខ្លួន ចំពោះសុន្ទរកថានោះត្រឹមភ័ស្តុតាងគោលនយោបាយសហឧក្រិដ្ឋកម្មរួម ទាក់ទងនឹងការកម្ទេច "ខ្មាំង" ដែលស្ថិតក្នុង *បណ្តឹង* នៃរឿងក្តីនេះ[3667]។

1018. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ជ បានបំភ្លៃសក្ខីកម្មអំពីការធ្វើស្វ័យទិទាន ដើម្បីបង្កើតចេតនារើសអើងប្រឆាំងនឹងប្រជាជនថ្មី[3668] បំភ្លៃការប្រើប្រាស់របស់ អ.ជ.ស.ជ នូវការលើកឡើងរបស់គាត់។ អ.ជ.ស.ជ គ្រាន់តែលើកឡើងថា ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ថា ការប្រជុំស្វ័យទិទានគឺជាមូលដ្ឋានមនោគមន៍វិជ្ជាចំពោះការតស៊ូវណ្ណៈ រួមទាំងការបង្កើត "កំហឹងវណ្ណៈ"[3669]។ ចេនារើសអើងចំពោះប្រជាជនថ្មីមិនមែន "និយាយសរុប" ចេញពីសក្ខីកម្មនេះទេ ត្រូវបានបង្ហាញដោយសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន[3670] និងភ័ស្តុតាងបន្ថែមជាច្រើនសន្ធឹកសន្ធាប់ទៀត[3671]។ ដូចគ្នានេះដែរ ការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ជ បានមើលរំលងវោហារសាស្រ្តនយោបាយនៃសុន្ទរកថារបស់គាត់ស្តីពីការតស៊ូវណ្ណៈ[3672] មើលរំលងឧទាហរណ៍នានាដែល អ.ជ.ស.ជ ដាក់វោហារសាស្រ្តនយោបាយទៅក្នុងបរិបទ[3673]។

---

[3666] ឯកសារ **E436/1** សេចក្តីសំរេចរបស់ អ.ជ.ស.ជ លើសំណើសុំស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបន្ថែមទៀត កថាខណ្ឌ ៥។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣ និងប្រភពច្បាប់ដែលបានលើកឡើងនៅក្នុងនោះ (ភាគីនានាអាចស្នើសុំដាក់បញ្ចូលភ័ស្តុតាងនៅដំណាក់កាលណាក៏បាន ហើយបើសិនជាមិនសមនឹងពេលវេលា អាចត្រូវបានទទួលក្នុងផលប្រយោជន៍នៃយុត្តិធម៌)។ អ.ជ.ស.ជ កត់សម្គាល់លើ ផ្នែកសវនាការពាក់ព័ន្ធ នៅមិនទាន់ចាប់ផ្តើមនៅឡើយទេ។

[3667] *សូមមើល* ចម្លើយតបទៅនឹងទឡ្ហីករណ៍ ១៨០។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៤។

[3668] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៦-១៥៤០ *ដោយដាក់ឱ្យវងនូវការជំទស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។

[3669] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។

[3670] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៦។

[3671] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៧៦-១១៧៨, ១៣៤៨, ១៤០៩-១៤១១, ១៦៨៨-១៦៨៩, ២៨៣៩-២៨៤៣, ៣៩៦៦-៣៩៦៨។

[3672] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៣៩-១៥៤០ *ដោយដាក់ឱ្យវងនូវការជំទស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៧០។

[3673] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៧ ("នៅពេលអាននៅក្នុងបរិបទជាមួយនឹងជម្លោះប្រដាប់អាវុធដែលកំពុងបន្តអនុវត្ត សេចក្តីណែនាំទាំងនេះសំដៅជាចម្បងលើកងកម្លាំងប្រដាប់អាវុធវៀតណាម"), ៣៤១១, ៣៤១៣, ៣៨៣៦, ៣៨៥៥ ("ភ័ស្តុតាងដែលសំដៅទៅភ្នាក់ងារ CIA, KGB និងវៀតណាម ត្រូវបានប្រើ

1019. ទាក់ទងនឹងការវាយតម្លៃរបស់ អ.ជ.ស.ដ លើទស្សនាវដ្ដី *ទង់បដិវត្តន៍* និង *យុវជនយុវនារីបដិវត្តន៍* ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានគាំទ្រការខ្វល់ខ្វាយរបស់គាត់ ទាក់ទងនឹងការប្រើប្រាស់របស់ អ.ជ.ស.ដ នូវឯកសារទាំងអស់នេះ។ គាត់មិនបានផ្ដល់ឧទាហរណ៍ណាដែលបង្ហាញថា អ.ជ.ស.ដ មិនបានពិចារណាអំពីលក្ខណៈឃោសនារបស់ទស្សនាវដ្ដីទាំងនោះ ដូចដែលខ្លួនថាបានធ្វើដូច្នោះ[3674] ឬថា អ.ជ.ស.ដ បានកំណត់ខុសនូវអត្ថបទអំពីការប្រយុទ្ធបែបមនោគមន៍វិជ្ជាក្នុងកម្រិតមួយ ដូចគ្នានឹងការប្រយុទ្ធបែបយោធា[3675]។ គាត់ក៏បំភ្លៃលក្ខណៈនៃការពឹងផ្អែករបស់ អ.ជ.ស.ដ លើទស្សនាវដ្ដី *ទង់បដិវត្តន៍* ដោយបានអះអាងថា អ.ជ.ស.ដ បានលើកឡើងថា "ទស្សនាវដ្ដីទាំងនេះជំរុញការកម្ទេចខ្មាំង តាមរយៈមន្ទីរសន្តិសុខ" នៅពេលដែលជាក់ស្ដែងនោះ អ.ជ.ស.ដ បានសង្កេតឃើញថា ទស្សនាវដ្ដី *ទង់បដិវត្តន៍* "បានពន្យល់ថា ឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ជាពិសេស មានការបោសសម្អាត និង "ការកម្ទេច" ខ្មាំងជាប្រព័ន្ធ"[3676]។ ចំណុចនេះបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីខ្លឹមសារនៃទស្សនាវដ្ដី *ទង់បដិវត្តន៍* ហើយក៏ត្រូវបានបញ្ជាក់ដោយភ័ស្តុតាងជាច្រើន[3677]។ ស្រដៀងគ្នានេះដែរ ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ការកម្ទេចខ្មាំងដែលបានរាយការណ៍យ៉ាងទូលំទូលាយនៅក្នុងជួរបក្ស ពឹងផ្អែកយ៉ាងសមហេតុផលលើភ័ស្តុតាងទាក់ទងនឹងការចែកចាយ និងការប្រើប្រាស់ទស្សនាវដ្ដីទាំងនោះ ក៏ដូចជា ភ័ស្តុតាងផ្សេងៗទៀតផងដែរ[3678]។

---

ប្រាស់ក្នុងគោលបំណងវាយប្រហារខាងវោហាសាស្ត្រតែប៉ុណ្ណោះ"), ៣៨៥៨ (បរិបទកំណត់និយមន័យនៃពាក្យថា "កម្ទេច" អាចមានន័យថាឬមួយ "សម្លាប់" ឬមួយ បំបាត់ផ្ទត់គំនិត)។

[3674] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៤១។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៥, ៤៧២, ៤៧៩, ៣៧៤៧។ *សូមមើលផងដែរ* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤។ ចម្លើយតបទៅនឹងមូលដ្ឋានទី ២៩, ១៩៣។

[3675] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៤១។

[3676] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥៤១ *ដោយដាក់ឱ្យរងនូវការជំទស់លើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥៨-៣៩៥៩។

[3677] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៩៣, ១៨៩៦, ១៨៩៩, ១៩២៩-១៩៣១, ១៩៤១, ១៩៤៥, ១៩៥៣, ២០១៣-២០១៤, ២០១៧, ២០៦៩, ២០៧២, ២២០៤-២២០៦, ២២២៣-២២២៤, ២២៣៣, ២២៤២, ២២៤៣, ២២៦៤, ២២៦៦-២២៧១, ២២៧៣-២២៧៩, ២២៨១-២២៨៤, ២២៨៦, ២២៨៩-២២៩២, ២២៩៥-២៣០០, ២៣០២-២៣០៣, ២៣០៧, ២៣១៨, ២៣៣២, ២៥៤៣-២៥៤៤, ២៥៤៦-២៥៥១, ២៥៧៨, ២៧១៥, ២៨៨៥-២៨៨៦, ២៨៩៨-២៩០០, ៣០៤៨-៣០៤៩, ៣០៥៤, ៣០៥៦-៣០៥៨, ៣០៦០-៣០៦២។

[3678] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៦៦ (កម្មវិធីវិទ្យុផ្សាយសម្លេងបានរាយការណ៍អំពីបញ្ហាមួយចំនួនដូចជា ការចាប់ខ្លួន និងអ្នកដែលត្រូវបានគេចាត់ទុកថាជាខ្មាំង), ៤៧៤-៤៧៥ (ការចែកចាយទស្សនាវដ្ដី *ទង់បដិវត្ត* និង *យុវជន-យុវនារីបដិវត្ត* នៅក្នុង ប.ក.ក), ៤៧៧ (*ទង់បដិវត្ត* និង *យុវជន-យុវនារីបដិវត្ត* ត្រូវបានប្រើ

1020. អំណះអំណាងដែលនៅសេសសល់របស់ម្ចាស់បណ្តឹងសាទុក្ខក៏បរាជ័យផងដែរ។ គាត់អះអាងថា ទូរលេខ និងរបាយការណ៍ ដែលបញ្ជូនមក*អង្គការ* បានបដិសេធការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ បានតាមដានការអនុវត្តគោលនយោបាយរបស់ ប.ក.ក ដោយសារ "លក្ខណៈសម្ងាត់" ដែលខ្មាំងត្រូវបានរៀបរាប់នៅក្នុងរបាយការណ៍ ប៉ុន្តែ ឯកសារជាច្រើនដែលគាត់ជំទាស់នោះមានឈ្មោះ ឬព័ត៌មានបញ្ជាក់អត្តសញ្ញាណផ្សេងទៀតអំពី "ខ្មាំង" និងបទល្មើសដែលចោទប្រកាន់ពួកគេ[3679]។ ជាចុងក្រោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងការប្តូរយុទ្ធសាស្ត្រនៅចន្លោះឆ្នាំ ១៩៦៦ និង ពេលចាប់ផ្តើមនៃភាពប្រទូស្តរ៉ាយក្នុងឆ្នាំ១៩៦៧ គ្រាន់តែផ្តល់ជាការពន្យល់បែបផ្សេងអំពីអង្គហេតុប៉ុណ្ណោះ និងទទួលស្គាល់ថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ មានភាពត្រឹមត្រូវ[3680]។

---

ប្រាស់សម្រាប់គោលបំណងអប់រំ នៅក្នុងវគ្គអប់រំ ឬរៀនសូត្រនយោបាយរបស់ ប.ក.ក), ១៩០៤ (ការចាប់ខ្លួន អឿន មេបញ្ជាការកងពល៣១០ ត្រូវបានប្រកាសឡើងនៅក្នុងអង្គប្រជុំមួយនៅភ្នំពេញ នៅពេលដែលខ្សែអាត់សំឡេងសារភាពរបស់គាត់ និងរបស់ កុយ ធួន ត្រូវបានចាក់ផ្សាយ), ១៩១៨-១៩១៩, ១៩២៤, ២០៥៤ ("សាកសពរបស់ សោ ភឹម ត្រូវបានដង្ហែរជុំវិញដើម្បីបង្ហាញថាគាត់បានស្លាប់ ហើយថាការចោទប្រកាន់នានាដែលថាគាត់ជាមនុស្សក្បត់នោះ គឺពិតមែន"), ២២៣៥, ៣៩៦២-៣៩៦៥។

[3679] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៤២ *ដោយដាក់ឱ្យរងនូវការជំទាស់លើ* ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៤។ *សូមមើលឧទាហរណ៍* ឯកសារ **E3/1179** ទូរលេខកម្ពុជាប្រជាធិបតេយ្យ របាយការណ៍ពី ម.៥៦០ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ KH 00214271 (ឈ្មោះ អាសុខ ជាអ្នកគូរប្លង់ផ្ទះថ្មនៅភ្នំពេញ បានដាក់ឈើក្នុងបេតុង។ អាឈួន ប្រ.ជមូលដ្ឋាន ដែលបាន "បំផុស" ប្រ.ជឱ្យរត់ទៅថៃអស់១៥នាក់។ អាប៉ិច អ្នកដែលបានសារភាព (បន្ទាប់ពីយោធាបាញ់ និងត្រូវបានសួរសចម្លើយមក) ថាវាមកលួចកាំភ្លើង រួចរត់ទៅថៃ។ មនុស្សប្រាំបីនាក់ នៅស្រុកអូរជ្រៅ ប៉ុនប៉ងរត់ទៅសៀម។ ពួក ១៧ មេសា បួននាក់នៅសង្កាត់ផ្គាំ បានរត់។ កុមារ "ឆ្កួត" ម្នាក់ បំរុងលួចកាំភ្លើងដើម្បីយកទៅឱ្យខ្សែចាត់តាំង៦នាក់ ហើយកុមារនោះត្រូវបានវាយចោល។ នៅតំបន់៦ មានអ្នករត់ ២៥នាក់។ អ្នកក្បត់ម្នាក់ឈ្មោះ អារស់ ត្រូវបានកំទេច)។ ឯកសារ **E3/1144** ទូរលេខកម្ពុជាប្រជាធិបតេយ្យ របាយការណ៍ កង ចាប *ហៅ* សែ គោរពជូនគណៈ ៨៧០ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00069447-48 (ពួកខ្មាំងនៅតាមមូលដ្ឋាន មន្ទីរ ក្រសួង និងមន្ទីរយោធា ដែលបង្កប់ ស៊ីរូងផ្ទៃក្នុង តាមរយៈចារកម្ម ឬជាសកម្មភាពប្រឆាំងបដិវត្ត ត្រូវបានបោសសម្អាត ដោយរួមទាំងអតីតមន្ត្រីរាជការ ប៉ូលីស និង ទាហាន នៃរបបមុន)។ ឯកសារ **E3/952** ទូរលេខកម្ពុជាប្រជាធិបតេយ្យ របាយការណ៍ កែ ពក "គោរពជូនបង ប៉ុល ជាទីគោរព" ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ KH 00000766 (អតីតទាហានដែលធ្វើការជាមួយចាម និងអតីតប្រធានក្រុម សហករណ៍បានធ្វើការផ្សព្វផ្សាយប្រឆាំងបដិវត្ត និងបំផ្លាញដំណាំ)។

[3680] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២៣ (យល់ព្រមថា "អាចមានការសន្និដ្ឋានសមហេតុផល*មួយផ្សេងទៀត ក្រៅពី*វិធីការសន្និដ្ឋានពីភាពហិង្សានៃចលនាបដិវត្ត" (គូសបញ្ជាក់បន្ថែម))។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ១៧ (ម្ចាស់បណ្តឹងសាទុក្ខត្រូវតែបង្ហាញថា មិនមានអ្នកវិភាគប្រកបដោយហេតុផលណាមួយលើអង្គហេតុ អាចរកឃើញ ដូចដែល អ.ជ.ស.ដ ធ្លាប់បានសម្រេចនោះទេ)។

## *មូលដ្ឋានទី ១៨០៖ អត្ថិភាពនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន គោលដៅនៃសហករណ៍*[3681]

1021. មូលដ្ឋានទី ១៨០ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ បានប្រើប្រាស់ខុសនូវភស្តុតាងដែលស្ថិតនៅក្រៅវិសាលភាព ដើម្បីកំណត់ប្រភេទគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន ថាមានលក្ខណៈឧក្រិដ្ឋ។

1022. បន្ទាប់ពីធ្វើការពិនិត្យមើលភស្តុតាងទាំងមូល អ.ជ.ស.ជ បានសន្និដ្ឋានថា ការ "ក្តាប់" និង "ដណ្តើមប្រជាជន" គឺជា "*មាគ៌ាយុទ្ធសាស្ត្រ* សំខាន់" របស់ ប.ក.ក[3682]។ យុទ្ធសាស្ត្រនេះរួមមានការបម្លាស់ទីប្រជាជន *ដ៏ច្រើន* ទៅកាន់សហករណ៍ (ពោលគឺ ការដណ្តើមប្រជាជន) ដែលជាកន្លែងបក្សអាចប្រើការគ្រប់គ្រងជាអតិបរមា ដើម្បីប្រើកម្លាំងពលកម្មមនុស្សយ៉ាងមានប្រសិទ្ធភាព និងដើម្បីសម្រេចបានគោលដៅកសាង និងផលិតកម្មដែលមានមហិច្ឆតាខ្ពស់របស់បក្ស[3683]។

1023. អត្ថិភាពនៃយុទ្ធសាស្ត្រនេះផ្អែកលើភស្តុតាងបញ្ជាក់ជាច្រើន។ ភស្តុតាងទាំងនោះរួមមាន ភស្តុតាងដែលបក្សបានចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រក្នុង ឆ្នាំ១៩៧៣ នៅតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ប.ក.ក ការផ្លាស់ទីប្រជាជនទៅកាន់សហករណ៍ ដើម្បីបង្កើនផលិតកម្មកសិកម្ម ទាំងមុន

---

[3681] មូលដ្ឋានទី ១៨០៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អត្ថិភាពនៃគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជន គោលដៅរបស់សហករណ៍* កថាខណ្ឌ ១៩៨៩-១៩៩៣។ ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ ក ទំព័រ ៦២ (អង់គ្លេស) ទំព័រ ៥៧ (បារាំង) ទំព័រ ៨៩ (ខ្មែរ)។

[3682] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៧៧ (គូសបញ្ជាក់បន្ថែម) *យោង ជាអាទិ៍* ឯកសារ **E3/748** *ទង់បដិវត្តន៍* ខែតុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ KH 00063240។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៩១ បានថ្លែងថា "អង្គជំនុំជម្រះបានបង្កើតគោលនយោបាយថ្មី ហៅថា "ក្តាប់" និង "ដណ្តើមប្រជាជន"" ។

[3683] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៦, ៩៤០, ៩៦៩, ៩៨៣ (មនុស្សជាងពីលាននាក់ត្រូវបានដាក់បញ្ចូលទៅនឹងសហករណ៍) ១០២៣ (ស្បៀងអាហារត្រូវបានប្រើជាមធ្យោបាយក្តាប់ប្រជាជន និងសហករណ៍ត្រូវបានរៀបចំប្រើប្រាស់ការគ្រប់គ្រង) ៣៨៧៧ (ម្ចាស់បណ្តឹងសាទុក្ខបញ្ជាក់ថា សហករណ៍មុនឆ្នាំ ១៩៧៥ អនុញ្ញាតឱ្យ ប.ក.ក បានក្តាប់ប្រជាជន) ៣៨៨៣ (មណ្ឌលប្រជាជនត្រូវបានជម្លៀសចេញ) ៣៨៨៥ (ការរៀបចំប្រជាជនតាមវិសាស្ត្រទៅក្នុងសហករណ៍នឹងបង្កើនផលិតភាព) ៣៨៨៧ (គណៈកម្មធិការអចិន្ត្រៃយ៍បានកត់សម្គាល់ថា តួនាទីរបស់សហករណ៍គឺ "ដើម្បីស្រូបប្រជាជនថ្មីចេញពីទីក្រុងទាំងអស់") ៣៨៨៩ (គោលបំណងរបស់បក្សសម្រាប់ផលិតកម្ម ដែលសង្កត់ធ្ងន់លើល្បឿន) ៣៨៩០ (កម្លាំងពលកម្មគឺជាប្រភេទតែមួយគត់របស់បក្ស និងទាមទាឱ្យមានការបែងចែកជាយុទ្ធសាស្ត្រ) ៣៨៩២ (កម្លាំងពលកម្មនឹងត្រូវរៀបចំសម្រាប់គម្រោងបន្តបន្ទាប់ នៅពេលដែលសហករណ៍ត្រូវបានពង្រីកត្រឹមត្រូវដើម្បីផ្តល់កម្លាំងពលកម្ម ពួកគេអាចចៀវាងមិនឱ្យមានការផ្លាស់ទីលំនៅប្រជាជន) ៣៨៩៣, ៣៩០០-៣៩០៣, ៣៩០៨, ៣៩១៥-៣៩១៧.

និងក្នុងអំឡុងរបបនោះ[3684]។ ភ័ស្តុតាងនេះរួមបញ្ចូលទាំងភ័ស្តុតាងដែលបង្ហាញពីការគ្រប់គ្រងដាច់ខាតរបស់ ប.ក.ក លើរាល់ទិដ្ឋភាពនៃជីវិតក្នុងសហករណ៍ និងការដ្ឋាន[3685]។ ភ័ស្តុតាងក៏រួមបញ្ចូលទាំង ការប្រើប្រាស់របស់បក្សនូវសុន្ទរកថា វគ្គសិក្សា និងការបោះពុម្ពផ្សាយរបស់ ប.ក.ក ដើម្បីបញ្ជាក់អំពីតម្រូវការក្នុងការខិតខំធ្វើការ បំពេញតាមរបបការងារ និងសម្រេចបានផែនការរបស់បក្ស[3686]។ ការខិតខំប្រឹងប្រែងទាំងនេះមានគោលបំណងបញ្ចូលមនោគមន៍វិជ្ជាដល់មហាជនអំពីផ្នត់គំនិតបដិវត្តន៍ ដែលផ្តោតជាពិសេសលើផលិតកម្មដ៏ឆាប់រហ័ស។

1024. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងខុស មើលរំលង ឬបំភ្លៃ ច្បាប់ពាក់ព័ន្ធ និង/ឬការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដើម្បីជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ លើយុទ្ធសាស្ត្រនេះ។ ទីមួយ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងខុសថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ដោយការយោងទៅភ័ស្តុតាងដែលស្ថិតនៅក្រៅវិសាលភាពពេលវេលា ដើម្បីបង្ហាញពីហេតុជំរុញការផ្លាស់ទីលំនៅរបស់ប្រជាជន និងដើម្បីសន្និដ្ឋានថា មានផែនការ "ដើម្បីគ្រប់គ្រង និងដណ្តើមប្រជាជន"[3687]។ យុត្តិសាស្ត្របានបង្ហាញយ៉ាងច្បាស់ថា ភ័ស្តុតាងនៅក្រៅរយៈពេលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចត្រូវបានប្រើដើម្បីបញ្ជាក់ពីបរិបទ បង្ហាញតាមការសន្និដ្ឋានពីធាតុផ្សំនៃអំពើឧក្រិដ្ឋ ដូចជាចេតនាដែលបានកើតឡើងក្នុងអំឡុងរយៈពេលនៃដីការបញ្ជូនរឿងទៅជំនុំជម្រះ ឬបង្ហាញពីលំនាំនៃការអនុវត្តដោយចេតនា[3688]។ អ.ជ.ស.ដ បានកំណត់ដោយត្រឹមត្រូវអំពីការប្រើប្រាស់របស់ខ្លួន

---

[3684] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣៦-២៤៣។ *សូមមើលជាពិសេស* កថាខណ្ឌ ២៤៣ ទាក់ទងនឹងការបែងចែកប្រជាជនទៅតាមសហករណ៍ ដែលនៅពេលនោះត្រូវបានធ្វើឡើងដើម្បីផ្តាច់ប្រជាជនចេញពីកងកម្លាំងរបស់ លន់ នល់។

[3685] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១, ១៨៣។

[3686] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៦៦, ៩៧៩, ១២២១, ១២៧៦, ១២៨៩, ១២៩៥, ១៤៧៩, ១៤៨៥, ១៥០៤, ១៥០៦-១៥០៧, ១៥១៧, ១៥៥៦-១៥៥៧, ១៧៦១, ៣៧៣៩, ៣៨៨៩, ៣៩១៦, ៣៩២៦, ៤២១៤។

[3687] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៨៩។

[3688] *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២៣៦។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ជើងទំព័រ ១៩៥។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៣១៥។ សេចក្តីសម្រេចក្នុងរឿងក្តី *Prlić* ស្តីពីក្របខណ្ឌពេលវេលា JCE ទំព័រ ៩។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ១០១។ សាលក្រមក្នុងរឿងក្តី *Lubanga* កថាខណ្ឌ ១០២២-១០២៤, ១០២៧, ១៣៥២។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣។

នូវភស្តុតាងមុនឆ្នាំ ១៩៧៥ ត្រឹមតែគោលបំណងដែលបានអនុញ្ញាតទាំងអស់នេះតែប៉ុណ្ណោះ[3689]។ ទីពីរ គាត់លើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានបង្កើតគោលនយោបាយថ្មីមួយ ប៉ុន្តែខកខានមិនបានបង្ហាញពីការសន្និដ្ឋានណាមួយ ដែលក្នុងនោះ អ.ជ.ស.ដ លើកឡើងពី "ការគ្រប់គ្រង និងការដណ្តើម" ថាជាគោលនយោបាយពិតប្រាកដ មិនមែនជាមាគ៌ាយុទ្ធសាស្ត្រទេនោះ[3690]។ ទីបី គាត់បានចោទប្រកាន់ អ.ជ.ស.ដ អំពីការបំភ្លៃគោលដៅរបស់សហករណ៍ ដើម្បីសន្និដ្ឋានថាគោលដៅនោះមានលក្ខណៈឧក្រិដ្ឋ[3691]។ គាត់មិនត្រឹមតែយល់ខុសអំពីមូលដ្ឋាន ដែល អ.ជ.ស.ដ បានផ្អែកក្នុងការសន្និដ្ឋានថា គោលនយោបាយនោះមានលក្ខណៈឧក្រិដ្ឋប៉ុណ្ណោះទេ[3692] ប៉ុន្តែការអានសាលក្រមយ៉ាងត្រឹមត្រូវបង្ហាញថា វាមិនមែនជាការបំភ្លៃទេ តែផ្ទុយទៅវិញ ការប្រើប្រាស់របស់ អ.ជ.ស.ដ នៃ "ការគ្រប់គ្រង" និង "ការដណ្តើមប្រជាជន" នោះ គ្រាន់តែជាការឆ្លុះបញ្ចាំងពីភាសាដដែលៗដែលមេដឹកនាំ ប.ក.ក រួមទាំងម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងផង បានប្រើ[3693]។

1025. ម្ចាស់បណ្តឹងសាទុក្ខក៏យល់ច្រឡំចំពោះ*បណ្តឹង* នៃសំណុំរឿង ០០២/០២ អះអាងខុសថា ការផ្លាស់ទីលំនៅប្រជាជនត្រូវបានដកចេញទាំងស្រុង ហេតុដូច្នេះ អ.ជ.ស.ដ មានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយការយោងទៅភស្តុតាងស្តីពីការផ្លាស់ទីលំនៅប្រជាជន ដែលបានធ្វើឡើងក្រោយ

---

[3689] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០, ៣៨៧៧-៣៨៨៣។ *សូមមើលឧទាហរណ៍* ដែល អ.ជ.ស.ដ លើកឡើង "នៅក្នុង*គំរូនៃការប្រព្រឹត្ត*ដែលបន្តមាន បន្ទាប់ពីការជម្លៀសរាជធានីភ្នំពេញ" នៅពេលពិភាក្សាអំពីភស្តុតាងស្តីពីការផ្លាស់ប្តូរទីលំនៅប្រជាជននៅក្នុង កថាខណ្ឌ ៣៨៨៣ (គូសបញ្ជាក់បន្ថែម)។

[3690] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៩១ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្នែក ១៦.៤.១។ តាមពិត ការសន្និដ្ឋាននៅក្នុងផ្នែកដែលគាត់ជំទាស់ កំណត់អត្តសញ្ញាណយ៉ាងស៊ីចង្វាក់ និងត្រឹមត្រូវនូវគោលនយោបាយនោះ ថាជាគោលនយោបាយដើម្បី "បង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន" ដូចដែលបានកំណត់និយមន័យក្នុងឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧។ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៦៦-៣៨៦៧, ៣៩១៨-៣៩១៩, ៣៩២៨ *ផ្ទុយពី* កថាខណ្ឌ ៣៨៧៧ ("មាគ៌ាយុទ្ធសាស្ត្រសំខាន់នៃបដិវត្តន៍")។

[3691] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៩១។

[3692] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១, ១៨៣។ ស្រដៀងគ្នានេះដែរ ការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខដែលជំទាស់ទៅនឹងការរើសអើងប្រឆាំងនឹងជនជាតិចាម ត្រូវបានបង្ហាញត្រង់កន្លែងផ្សេងទៀតនៅក្នុងចម្លើយតបនេះថាធ្វើឡើងដោយគ្មានអង្គសេចក្តី និងត្រូវបានពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៤១ ត្រង់ចំណុចដែលគាត់បញ្ជាក់អំពីទង្វើករណ៍របស់គាត់។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៩២-១៩៩៣។

[3693] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៧៧-៣៨៧៨, ៣៨៩៥, ៣៨៩៨។

ពេលដួលរលំនៃទីក្រុងភ្នំពេញ[3694]។ ទោះជាយ៉ាងណាក៏ដោយ អ.ជ.ស.ដ បានប្រកាន់ខ្ជាប់ទៅនឹងការកំណត់នៃសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម[3695] ដោយបានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះពឹងផ្អែកលើភស្តុតាងស្តីពីការផ្លាស់ទីលំនៅប្រជាជន តែដើម្បីវិភាគពីគោលដៅនៃគោលនយោបាយមនោគមន៍វិជ្ជាប៉ុណ្ណោះ ខណៈដែលការពិចារណារបស់ខ្លួនលើភស្តុតាងផ្នែកអង្គហេតុនៃ*ការអនុវត្ត* ការផ្លាស់ទីលំនៅប្រជាជន កំណត់ត្រឹមតែជនជាតិចាមទេ[3696]។ វិធីសាស្ត្រនេះស្របទៅនឹងទស្សនៈរបស់ អ.ជ.ត.ក ថា គោលនយោបាយទាំងប្រាំរបស់ ប.ក.ក មិនមានលក្ខណៈដាច់ដោយឡែកច្បាស់លាស់ចំពោះករណីណាមួយឡើយ[3697]។ វាក៏ស្របទៅនឹងវិធានផ្ទៃក្នុងផងដែរ ដែលចែងថា ត្រង់ចំណុចដែលវិសាលភាពនៃការជំនុំជម្រះត្រូវបានកាត់បន្ថយ ភស្តុតាងទាក់ទងនឹងអង្គហេតុដែលត្រូវបានដកចេញ អាចប្រើជាសំអាងបាន ប្រសិនបើពាក់ព័ន្ធទៅនឹងអង្គហេតុដែលនៅសល់[3698]។ អ.ជ.ស.ដ ពិតជាស្ថិតក្នុងបណ្តឹងរបស់ខ្លួន នៅពេលដែលពឹងផ្អែកលើភស្តុតាងស្តីពីការផ្លាស់ទីលំនៅប្រជាជន ដើម្បីបញ្ជាក់ពី "អង្គហេតុដែលនៅសល់" ទាក់ទងនឹងគោលនយោបាយរបស់ ប.ក.ក ក្នុងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន ដើម្បីសម្រេចបានគោលបំណងរួម។

## *មូលដ្ឋានទី ១៨១, ១៨៣៖ ការសន្និដ្ឋានខុសអំពីគោលនយោបាយ ប.ក.ក និងកំហុសទាក់ទងនឹងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយនោះ*[3699]

[3694] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៨៩, ១៤៩១ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៦៧, ៣៨៨៣, ៣៩១៦, ៣៩១៨-៣៩២៩។ សហព្រះរាជអាជ្ញាបានលើកឡើងនៅកន្លែងផ្សេងថា *ផ្ទុយពី* ទស្សនៈរបស់ម្ចាស់បណ្តឹងសាទុក្ខ *បណ្តឹង* នៃសំណុំរឿង ០០២/០២ រួមបញ្ចូលការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីររបស់ជនជាតិចាម (*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៨២)។

[3695] ឯកសារ **E301/9/1.1** ឧបសម្ពន្ធនៃសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពបន្ថែមរបស់ អ.ជ.ស.ដ នៃ សំណុំរឿង ០០២/០២ ទំព័រ ១ (បានបញ្ជាក់យ៉ាងជាក់លាក់ *ជាអាទិ៍* ថា ឯកសារ **D៤២៧** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-១៥៩, ១៦០-១៦៣, ១៦៥, ១៦៧, ១៦៨-១៧៧ ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ទាំងអស់)។

[3696] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៦៧ (គូសបញ្ជាក់បន្ថែម)។

[3697] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២២៧។ *សូមមើលផងដែរ* **E301/9/1** ឧបសម្ពន្ធនៃសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពបន្ថែមរបស់ អ.ជ.ស.ដ នៃ សំណុំរឿង ០០២/០២ កថាខណ្ឌ ៤២ (*កត់សម្គាល់* ថា ភស្តុតាងស្តីពីគោលនយោបាយ JCE អាចមិនត្រូវបានពិនិត្យពេញលេញនៅក្នុងសំណុំរឿង ០០២/០១ ដោយសារតែវិសាលភាពមានកម្រិតនៃការជំនុំជម្រះនោះ និងអាចពាក់ព័ន្ធក្នុងបរិបទសំណុំរឿង ០០២/០២)។

[3698] វិធានផ្ទៃក្នុង ៨៩ *ស្ទួន*(៣)។

[3699] <u>មូលដ្ឋានទី ១៨១៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការសន្និដ្ឋានខុសអំពីគោលនយោបាយ ប.ក.ក* កថាខណ្ឌ ១៤៩៥-១៥១០; **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ពន្ធ ក ទំព័រ ៦៣ (អង់គ្លេស) ទំព័រ ៥៧-៥៨ (បារាំង) ទំព័រ ៨៩ (ខ្មែរ)។

1026. **មូលដ្ឋានទី ១៨១ និង ១៨៣ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ ឬ អង្គហេតុ (i) ក្នុងការសន្និដ្ឋានថា គោលនយោបាយបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន រួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងគោលបំណងរួម ឬ (ii) នៅក្នុងការវាយតម្លៃជារួមរបស់ខ្លួនអំពីគោលនយោបាយនោះ។**

1027. ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន គឺជាផ្នែកសំខាន់នៃគោលដៅរបស់ ប.ក.ក អនុលោមតាមគោលបំណងរួម ដើម្បីធ្វើបដិវត្តន៍សង្គមនិយមឱ្យបានឆាប់រហ័សក្នុងប្រទេសកម្ពុជាតាមរយៈ "មហាលោតផ្លោះមហាអស្ចារ្យ" ដោយសារតែសហករណ៍ និងការដ្ឋាន បម្រើឱ្យគោលបំណងជាច្រើន។ ទីមួយ និងសំខាន់ជាងគេ សហករណ៍ និងការដ្ឋានគឺជាកម្លាំងជំរុញដែលគាំទ្រដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ដើម្បីផ្តល់ស្បៀងសម្រាប់បំពេញតម្រូវការក្នុងស្រុក និងសម្រាប់ការនាំចេញទៅក្រៅប្រទេសដើម្បីបង្កើតទុន[3700]។ សហករណ៍ និងការដ្ឋានក៏ត្រូវបានគេមើលឃើញថាជាមធ្យោបាយក្នុងការបំផ្លាញប្រព័ន្ធវណ្ណៈសង្គមផងដែរ ដោយបង្ខំឱ្យអតីតអ្នករស់នៅទីក្រុងឱ្យក្លាយទៅជាកម្មករ-កសិករ និងបានជំនួសកម្មសិទ្ធិឯកជនដោយសមូហភាពវិញ[3701]។ លើសពីនេះទៀត ប.ក.ក បានប្រើរចនាសម្ព័ន្ធគ្រប់គ្រងទីតាំងទាំងនោះ ដើម្បីគាស់រម្លើង "ខ្មាំង" ដោយតម្រូវឱ្យប្រជាជនបំពេញប្រវត្តិរូបជាប្រចាំ និងតាមដានពួកគេចំពោះអាកប្បកិរិយាប្រឆាំងនឹងបដិវត្តន៍ ដែលធ្វើឱ្យមានការបាត់ខ្លួន និងការកាប់សម្លាប់[3702]។ ការដ្ឋានព្រលាន

---

*កត់សម្គាល់* ម្ចាស់បណ្តឹងសាទុក្ខរៀបរាប់អំពីកំហុសដែលបានចោទប្រកាន់ដែលជាប់ទាក់ទងនឹងការចូលរួមរបស់គាត់ក្នុងអង្គប្រជុំ ប-៥ នៅខែមេសា ឆ្នាំ ១៩៧៥ (*សូមមើល* កថាខណ្ឌ ១៤៩៤) ប៉ុន្តែមិនបានផ្តល់ឯកសារគាំទ្រពួកវានៅក្នុងផ្នែកនេះទេ។ *សូមមើល* ចម្លើយតបទៅនឹងទឡ្ហីករណ៍ ១៩៩។ <u>មូលដ្ឋានទី ១៨៣៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសទាក់ទងនឹងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយ* កថាខណ្ឌ ១៥១៨-១៥២២។ ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ ក ទំព័រ ៦៣ (អង់គ្លេស) ទំព័រ ៥៨ (បារាំង) ទំព័រ ៩០ (ខ្មែរ)។

[3700] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤០, ៩៤០, ៩៦៨-៩៧១, ៩៧៥, ១៤៤៨-១៤៥០, ៣៧៣៧, ៣៧៣៩, ៣៧៤១, ៣៧៤៣, ៣៨៧៣, ៣៨៨៤-៣៨៨៥, ៣៨៨៩-៣៨៩០, ៣៨៩២-៣៨៩៣, ៣៩១៨។

[3701] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤១, ២៧៦, ២៧៩, ៩៤០, ៩៨១, ៩៨៦-៩៨៧, ៣៨៧៤, ៣៨៧៦, ៣៨៩៤, ៣៨៩៦។

[3702] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៥៩-៩៦១, ៩៦៤, ៩៩៧, ១០០៥, ១០២៨, ១០៣១-១០៣២, ១០៥៥, ១០៧០-១០៨០, ១១១៧, ១១២១-១១២៣, ១១៥០, ១១៥២, ១១៧៥, ១១៩៨, ១២០១-១២០៣, ១៣៣៥-១៣៣៩, ១៣៤៥, ១៣៥៣-១៣៥៦, ១៣៥៩-១៣៧១, ១៤០៧, ១៤០៩-១៤១០, ១៤២៤-១៤២៦, ១៥៣៨, ១៥៤២-១៥៥១, ១៥៦១-១៥៦៧, ១៥៧២, ១៥៧៤, ១៥៧៦, ១៥៨០, ១៦៤៤-១៦៤៨, ១៦៦០-១៦៦៣, ១៦៨២, ១៧៦៨, ១៧៧០, ១៧៧១-១៧៧៨, ៣៨៩៨។

យន្តហោះកំពង់ឆ្នាំងខុសពីទីតាំងផ្សេងៗទៀត ដោយវាមានគោលបំណងពង្រឹងហេដ្ឋារចនាសម្ព័ន្ធយោធារបស់ប្រទេស ក៏ដូចជាត្រូវបានប្រើសម្រាប់ការកសាង និងការលត់ដំ "សមាសភាពមិនល្អ" មកពីកងទ័ពបដិវត្តន៍កម្ពុជា តាមរយៈពលកម្មធ្ងន់ធ្ងរ[3703]។

1028. ភស្តុតាងដ៏ច្រើននៅក្នុងសំណុំរឿងបង្ហាញពីរូបភាពច្បាស់លាស់អំពីលក្ខណ្ឌរស់នៅ និងការងារនៅតាមទីកន្លែងទាំងអស់នេះ។ អតីតព្រះករុណាព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បានប្រៀបធៀបទីកន្លែងទាំងនេះទៅនឹង "ជំរំឃុំខ្លួន" ក្រោយពេលបានធ្វើដំណើរទស្សនកិច្ចរបស់ព្រះអង្គជាមួយម្ចាស់បណ្តឹងសាទុក្ខទៅកាន់ទីជនបទនៅចុងឆ្នាំ ១៩៧៥-ដើមឆ្នាំ១៩៧៦[3704] ដែលបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីការគ្រប់គ្រងផ្តាច់ការរបស់ ប.ក.ក លើរាល់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ប្រជាជនក្រោមការត្រួតត្រារបស់ពួកគេ។ ដោយផ្តោតតែលើការសម្រេចឱ្យបានឆាប់រហ័សនូវគោលដៅផលិតកម្មរបស់ថ្នាក់ដឹកនាំ ទោះក្នុងតម្លៃណាក៏ដោយ កម្មាភិបាល ប.ក.ក បានបង្ខំប្រជាជនឱ្យធ្វើការច្រើនម៉ោង ដោយធ្វើពលកម្មដ៏លំបាកក្នុងលក្ខខណ្ឌអាក្រក់ក្រៃលែង[3705]។ អ្នកដែលបរាជ័យមិនបានបំពេញតាមការកំណត់ផលិតកម្មដ៏ច្រើនរបស់បក្ស ឬ "មិនខំប្រឹងធ្វើការ" ត្រូវទទួលរងទណ្ឌកម្ម[3706]។ ប្រជាជនរងការឈឺចាប់ និងស្លាប់ដោយបាក់កម្លាំង របបអាហារតិចតួចស្តួចស្តើង ការថែទាំសុខភាពមិនគ្រប់គ្រាន់ កង្វះអនាម័យជាមូលដ្ឋាន និងទីកន្លែងស្នាក់មិនមានស្តង់ដា[3707]។ សមាជិកគ្រួសារត្រូវបានបំបែកចេញពីគ្នា ហើយជាញឹកញាប់មិន

---

[3703] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣, ១៧៣១-១៧៣៥ ("សមាសភាពមិនល្អ" រួមបញ្ចូលមនុស្សដែលគេសន្មតថាមានទំនាក់ទំនងជាមួយនឹងរបបចាស់ ជនជាតិវៀតណាម ឬមេដឹកនាំដែលបានចាប់ខ្លួនថាជាជនក្បត់) ១៧៤១, ១៧៥៦ ("សមាសភាពមិនល្អ" រួមមានមនុស្សដែលប្រវត្តិរូបមិនល្អ ពោលគឺ មនុស្សមកពីភូមិភាគបូព៌ា) ១៧៦១, ១៨១១, ១៨២១-១៨២៤ (ទាហ៊ានដែលបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំ "ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់ថាជាខ្មាំងដោយសារតែជំនឿនយោបាយពិតប្រាកដ ឬតាមការសន្មតរបស់ពួកគេ ឬការប្រឆាំងនឹង ប.ក.ក")។

[3704] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥ *យោង* **E3/113R** *សង្គ្រាមទ័ពព្រៃ (Jungle War)*, EN V00172509, 00:២៩:៣២-00:៣០:២៦។

[3705] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៩, ១០១៨-១០២០, ១១៤៥, ១១៩៦-១១៩៨, ១២៧០-១២៩០, ១២៩៦, ១៣៩៩, ១៤១៥-១៤១៦, ១៥០៤, ១៥១១-១៥១៩, ១៥២៤-១៥២៩, ១៥៣៥, ១៦០៦, ១៦១៦, ១៦១៨, ១៦២៧-១៦២៨, ១៧៣៧, ១៧៣៩, ១៧៤២, ១៧៤៥, ១៧៥៥-១៧៥៧, ១៧៦១, ៣៩០៥-៣៩១៤។

[3706] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០២៣, ១២៩១-១២៩៥, ១៣៣២, ១៣៧២, ១៥៣២-១៥៤១, ១៥៥២, ១៥៥៥, ១៥៥៨, ១៥៦២, ១៧៤៤, ១៧៤៦។

[3707] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១១-១០១៦, ១០២០, ១០៣៧, ១០៤៣-១០៤៧, ១០៥០, ១១៤២, ១១៤៥, ១១៩៥-១១៩៧, ១២៣១, ១២៩៧-១២៩៨, ១៣០០-១៣០៦, ១៣០៨-១៣១០,

អនុញ្ញាតឱ្យជួបមុខគ្នា[3708]។ កណ្តាប់ដៃដែករបស់ ប.ក.ក ត្រូវបានប្រើនៅគ្រប់ទិដ្ឋភាពនៃជីវិត រួមទាំងការកំណត់អំពីអ្វីដែលប្រជាជនអាចបរិភោគ និងទីកន្លែងត្រូវបរិភោគ ទីកន្លែងដែលពួកគេអាចទៅបាន របៀបពួកគេគួរស្លៀកពាក់ និងពេលណាដែលគូស្រករអាចជួបមុខគ្នាបាន[3709]។

1029. បន្ទាប់ពីពិនិត្យយ៉ាងទូលំទូលាយលើភ័ស្តុតាងរួចមក អ.ជ.ស.ដ បានសន្និដ្ឋានថា គោលនយោបាយបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងគោលបំណងរួម និងមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ជាមធ្យោបាយមួយក្នុងការសម្រេចបានគោលបំណងនោះ ដូច្នេះធ្វើឱ្យវាមានលក្ខណៈឧក្រិដ្ឋ[3710]។ ឧក្រិដ្ឋកម្មទាំងអស់នេះ ដែលស្ថិតនៅក្នុងគោលបំណងរួម ជាមធ្យោបាយដែលសម្រេចគោលបំណងនោះ រួមមាន ការធ្វើមនុស្សឃាត ការដាក់ឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការវាយប្រហារប្រឆាំងនឹងភាពថ្លៃថ្នូររបស់មនុស្ស និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[3711]។ ភ័ស្តុតាងបង្ហាញថា ឧក្រិដ្ឋកម្មទាំងនេះបានធ្វើឡើងនៅតាមសហករណ៍ និងការដ្ឋាន ក្នុងលក្ខណៈមួយដែលមានការកើនឡើង និងជាប្រព័ន្ធ ដែលជាការអនុវត្តគោលនយោបាយថ្នាក់ជាតិ និងមានបានផ្សព្វផ្សាយនៅកម្រិតខ្ពស់បំផុត[3712]។ ការសន្និដ្ឋានទាំងអស់នេះផ្អែកលើភ័ស្តុតាងជាច្រើន ដែលរួមមានសក្ខីកម្ម និងចម្លើយរបស់សាក្សីជាច្រើន និងអតីតកម្មាភិបាល ប.ក.ក ឯកសារសហកាលដូចជា កំណត់ហេតុអង្គប្រជុំ និងរបាយការណ៍ដែលលើកឡើងអំពីផលិតកម្ម លក្ខខណ្ឌផ្សេងៗ

---

១៣២០-១៣២៩, ១៣៧៥-១៣៧៦, ១៣៨៩, ១៤១៥-១៤១៦, ១៥៨៥-១៦១០, ១៦២៤-១៦២៦, ១៦៨០-១៦៨១, ១៧៤៧-១៧៥៤, ១៧៥៨, ៣៩០៨។

[3708] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៣៣-១០៣៩, ១១៥១, ១៦១១, ១៦១៤, ១៦៧៩។

[3709] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៦, ១០០៨-១០០៩, ១០២៤, ១០៣៣, ១០៣៥, ១១៥០-១១៥១, ១៣០២-១៣០៦, ១៣១១, ១៣៣០-១៣៣១, ១៣៣៣-១៣៣៤, ១៣៩៨, ១៥៤៤, ១៥៩៣, ១៦០០-១៦០១, ១៦១៦-១៦២៣, ១៦៧៩, ១៧៦៩។

[3710] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៩, ៣៩២៨។

[3711] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៥, ១១៥៥, ១១៧៩, ១១៩៩, ១២០៤, ១៣៧៨-១៣៨០, ១៣៩០, ១៤០២, ១៤១៣, ១៤២១, ១៤២៩, ១៦៦៦, ១៦៧៣, ១៦៨៤, ១៦៩២, ១៧០៧, ១៧១២, ១៨០៦, ១៨១៧, ១៨២៨, ១៨៣៧, ១៨៤៦, ៣៩១៩-៣៩២៨។

[3712] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៧, ៣១៩, ៣២១-៣២២, ៣៩២៩, ៤០៨១។

និងការខ្វះខាត និងសុន្ទរកថា និងការឃោសនារបស់បក្សដែលជំរុញឥតឈប់ឈរឱ្យប្រជាជនធ្វើការឱ្យកាន់តែខ្លាំង និងផលិតឱ្យបានកាន់តែច្រើន[3713]។

### *អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា គោលនយោបាយសហករណ៍មានការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតក្រោមគោលបំណងរួម (មូលដ្ឋានទី ១៨៣)*

1030. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា ដោយសារតែគោលនយោបាយសហករណ៍មានគោលបំណង ដូចជា ការសម្រេចបាននូវម្ចាស់ការខាងស្បៀងអាហារ (តាមរយៈ សមូហភាពនិយម) អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថាវាមានលក្ខណៈឧក្រិដ្ឋ[3714]។ ដើម្បីបញ្ជាក់ឱ្យច្បាស់ ហើយដូចដែលបានបង្ហាញរួចហើយ អ.ជ.ស.ដ ឯកភាពថា គោលដៅចម្បងនៃបដិវត្តន៍សង្គមនិយមមិនមានលក្ខណៈឧក្រិដ្ឋទេ[3715]។ គោលបំណងរួមមិនមែនជាគោលបំណងដែល *ស្មើនឹង* ការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទេ ប៉ុន្តែជាគោលបំណងដែល *មាន* ការប្រព្រឹត្តិឧក្រិដ្ឋកម្មជាច្រើន ដែលធ្វើឱ្យគោលបំណងរួមនោះមានលក្ខណៈឧក្រិដ្ឋ[3716]។ ការសន្និដ្ឋាននេះត្រូវបានគាំទ្រដោយភ័ស្តុតាងជាច្រើន[3717]។ នៅសហករណ៍ត្រាំកក់ ទំនប់១មករា និងទំនប់ត្រពាំងថ្មប្រជាជនត្រូវបានដាក់ឱ្យទៅជាទាសករ ដើម្បីជួយបំពេញគោលដៅសេដ្ឋកិច្ចរបស់បក្ស[3718] ខណៈដែលព្រលានយន្តហោះកំពង់ឆ្នាំង កម្មករត្រូវបានដាក់ឱ្យទៅជាទាសករ ដើម្បីជួយជ្រោមជ្រែងយុទ្ធសាស្ត្រយោធារបស់របបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការកសាងវាលយន្តហោះ[3719]។ នៅក្នុងទីតាំងនីមួយៗ កម្មករត្រូវបានផ្តល់ "របបអាហារមិនគ្រប់គ្រាន់" និង "ធ្វើការប្រកបដោយគ្រោះថ្នាក់" ដែលត្រូវបានចាត់ទុកថាសំខាន់សម្រាប់កម្មាភិបាល ប.ក.ក ក្នុងការគ្រប់គ្រងលើ

---

[3713] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨១៧-៨២៥, ៩០២, ៩៥២, ១០១២-១០១៣, ១២០៨-១២១៨, ១២៣៨-១២៥៣, ១២៥៦, ១២៨៥, ១៣០៦-១៣០៧, ១៤៣៨-១៤៤៤, ១៤៧២-១៤៨០, ១៤៨៨, ១៤៩៥, ១៥០៥-១៥០៩, ១៥១៧, ១៥៣០-១៥៣១, ១៥៥២-១៥៦០, ១៦៣១-១៦៤០, ១៧១៧-១៧២០, ៣៨៨៩, ៣៨៩៩-៣៩០២, ៣៩០៥-៣៩០៧, ៣៩១១-៣៩១៤, ៣៩១៦។

[3714] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥២០-១៥២២ (តវ៉ាថា គោលដៅនោះមិន "បណ្តាលឱ្យ" មានឧក្រិដ្ឋកម្មទេ)។

[3715] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៣។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨។

[3716] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៩។

[3717] *សូមមើល* សេចក្តីផ្តើមនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១, ១៨៣។

[3718] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២២។

[3719] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៣។

កម្មករ និងការអនុវត្តគោលដៅបដិវត្តន៍ បើទោះជាធ្វើឱ្យមាន "ការបាក់កម្លាំង ភាពស្គមស្គាំង កង្វះអាហារូបត្ថម្ភ ជំងឺ និងការស្លាប់"[3720]។ ការគ្រប់គ្រងផ្ដាច់ការនៅទីតាំងទាំងអស់នេះ ផ្ដល់លទ្ធភាពបន្ថែមទៀតឱ្យ ប.ក.ក ផ្ដាច់ទំនាក់ទំនង កំណត់អត្តសញ្ញាណ និងកម្ទេចខ្មាំង[3721]។ តាមពិតនោះ នៅតាមទីកន្លែងនីមួយៗ អ្នកដែលបានបាត់ខ្លួនត្រូវបានកំណត់អត្តសញ្ញាណថាជាខ្មាំង ដោយកម្មាភិបាល ប.ក.ក[3722] ហើយនៅទំនប់ត្រពាំងថ្ម និង ទំនប់១មករា ខ្មាំងត្រូវបានសម្លាប់[3723]។ ដោយពិចារណាលើទំហំ និងរយៈពេលនៃអំពើឃោរឃៅដែលបានប្រព្រឹត្តឡើង ដើម្បីអនុវត្តគោលនយោបាយនោះ អ.ជ.ស.ដ បានសន្និដ្ឋានត្រឹមត្រូវថា គោលបំណងដែលបានលើកឡើងថាដើម្បីធ្វើឱ្យលក្ខខណ្ឌរស់នៅបានប្រសើរឡើងនោះ មិនត្រូវបានគាំទ្រដោយភ័ស្តុតាងនោះទេ[3724]។ ទឡ្ហីករណ៍ដែលមិនទទួលបានជោគជ័យ ដដែលៗរបស់ម្ចាស់បណ្ដឹងសាទុក្ខ[3725] និងការបកស្រាយឡើងវិញលើភ័ស្តុតាង ដែល អ.ជ.ស.ដ បានពិចារណាអស់រយៈពេលយ៉ាងយូរនោះ មិនបង្ហាញអំពីកំហុសឡើយ[3726]។

---

[3720] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៦។

[3721] ដូចដែលបានពិភាក្សានៅក្នុង សេចក្ដីផ្ដើមនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១, ១៨៣។

[3722] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៧។

[3723] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២០។

[3724] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៩។ ទឡ្ហីករណ៍គ្មានការគាំទ្ររបស់ម្ចាស់បណ្ដឹងសាទុក្ខថា ការធ្វើបាបប្រជាជនមិនមែនជាផ្នែកមួយនៃគោលបំណងរួម ប៉ុន្តែផ្ទុយទៅវិញជា "ការប្រព្រឹត្តខុសទិសដៅ" ដូចជា អសមត្ថភាពការគ្រប់គ្រងមិនល្អ និង "ការងាកទៅរកភាពផ្ដាច់ការ" របស់កម្មាភិបាលនៅតាមសហករណ៍ និងការដ្ឋាន (*សូមមើល* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥២១-១៥២២) ក៏បរាជ័យដោយមូលហេតុស្រដៀងគ្នា និងដោយសារគ្មានភាពច្បាស់លាស់។

[3725] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥២១ ("ការធ្វើបាបប្រជាជនមិនត្រូវបានដាក់បញ្ចូលក្នុងគោលបំណងរួមនោះទេ [...] គោលដៅកែលម្អជីវភាពប្រជាជន ដើម្បីធានាឱ្យមានការចូលរួមក្នុងផែនការបដិវត្តន៍")។

[3726] ទឡ្ហីករណ៍របស់ចម្ងាស់បណ្ដឹងសាទុក្ខទាក់ទងនឹង *បណ្ដឹង* ក៏បរាជ័យផងដែរ។ អ.ជ.ស.ដ បានទទួលយ៉ាងត្រឹមត្រូវ ហើយភ័ស្តុតាងសំខាន់ៗត្រូវបានបង្ហាញសម្រាប់រាល់ឧក្រិដ្ឋកម្មទាំងអស់នៅក្នុងសហករណ៍ និងការដ្ឋាននៃសំណុំរឿង ០០២/០២ (*ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥១៨-១៥១៩)។ *សូមមើលចម្លើយតបទៅនឹងមូលដ្ឋានទី* ៣៩, ៤២-៤៣, ៤៥-៤៧, ៥៩, ៦៣-៦៤, ៦៨, ៧១-៧២, ៩៤, ១០៦-១០៧, ១១៤, ១១៨-១២០។ ខណៈដែលម្ចាស់បណ្ដឹងសាទុក្ខយោងទៅរាល់ទម្រង់ទាំងអស់នៃការធ្វើទុក្ខបុកម្នេញនៅក្នុងមូលដ្ឋាននេះនៅក្នុងសារណារបស់គាត់ (*សូមមើល* កថាខណ្ឌ ១៥១៩) អ.ជ.ស.ដ គ្រាន់តែពិចារណាលើការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាផ្នែកមួយនៃគោលនយោបាយសហករណ៍ ខណៈដែលការធ្វើទុក្ខបុកម្នេញលើក្រុមជាតិពន្ធុ និងសាសនាស្ថិតក្រោមគោលនយោបាយ "ការកំណត់គោលដៅលើក្រុមជាក់លាក់" (*សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៤-៣៩២៥, ៣៩៩៦, ៣៩៩៨, ៤០០៥, ៤០១២, ៤០១៩-៤០២២)។

## *ការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើគោលនយោបាយសហករណ៍ ប.ក.ក បានផ្អែកយ៉ាងត្រឹមត្រូវលើការវាយតម្លៃលើភស្តុតាងទាំងមូល (មូលដ្ឋានទី ១៨១)*

1031. ម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានលាក់បាំងអង្គហេតុដែលថា ប.ក.ក បានចេញសេចក្តីណែនាំឱ្យមេដឹកនាំសហករណ៍បង្កើនជីវភាពរស់នៅរបស់ប្រជាជន ហេតុដូច្នេះ បង្ហាញតែភស្តុតាងដាក់បន្ទុកក្នុងការវាយតម្លៃរបស់ខ្លួនលើគោលនយោបាយសហករណ៍[3727]។ ការអះអាងនេះពិតជាខុសទាំងស្រុង ដោយហេតុថា អ.ជ.ស.ដ បានទទួលស្គាល់យ៉ាងច្បាស់ថា យោងតាមបក្ស ការបង្កើនជីវភាព និងការរស់នៅរបស់ប្រជាជន "ត្រូវបានផ្សារភ្ជាប់ យ៉ាងជិតស្និទ្ធទៅនឹងការបំពេញគោលដៅសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងដែលបាន និងកំពុងធ្វើ" ហើយអង្គជំនុំជម្រះបានសន្និដ្ឋានថា មានភស្តុតាងខ្លះបង្ហាញពីចេតនារបស់មជ្ឈិមបក្សចង់ "រក្សាកម្លាំងពលកម្មរបស់ប្រជាជនឱ្យមានសុខភាពល្អ"[3728]។ លើសពីនេះទៀត សាលក្រមបានលើកឡើងជាច្រើនអំពីឯកសារ ប.ក.ក ដែលលើកឡើងអំពីគោលដៅរបស់បក្សក្នុងការពង្រឹងលក្ខខណ្ឌរស់នៅរបស់ប្រជាជន[3729] និងបានកត់សម្គាល់លើសារណារបស់មេធាវីការពារក្តីលើចំណុចនេះ[3730]។

---

[3727] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០១-១៥០៤ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៩-៣៨៩១, ៣៨៩៣, ៣៩០០, ៣៩១០-៣៩១១, ៣៩៩៨ (គួរតែជាកថាខណ្ឌ ៣៨៩៨)។

[3728] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩៣, ៣៩១៣ (*សូមមើលផងដែរ* កថាខណ្ឌ ១៣១៤, ១៣១៦)។

[3729] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២៤៧០, ១២៩៣១ (ដកស្រង់ការដកស្រង់ដូចគ្នាពីឯកសារ **E3/166** ដែលម្ចាស់បណ្តឹងសាទុក្ខអះអាងនៅក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០២, ជើងទំព័រ ២៨៣៣ ថា អ.ជ.ស.ដ *គួ*បានគូសបញ្ជាក់) ១២៩៨១ (*សូមមើល* ភស្តុតាងដែលបានយោងខាងក្នុងនោះ និងការកត់សម្គាល់របស់ អ.ជ.ស.ដ ថា "ការផ្សព្វផ្សាយអំពីបដិវត្តន៍ជាវិធីសាស្ត្រមួយក្នុងការដោះស្រាយបញ្ហាជីវភាពប្រជាជនក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ") ១៣០៣៩ (ដកស្រង់សុន្ទរកថារបស់ នួន ជា មួយដែលបានលើកឡើងថា "យើងត្រូវតែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ជាប្រចាំ [...] ដើម្បីកសាងប្រទេសរបស់យើងឱ្យឆាប់រហ័ស និងលើកកម្ពស់កម្រិតជីវភាពប្រជាជនយើង") ១៣០៥៩, ១៣០៦៥ (ដកស្រង់ឯកសារ **E3/2728** និង **E3/294** កម្មវត្ថុ ការដោះស្រាយជីវភាពប្រជាជន និងការកាត់បន្ថយកង្វះខាតស្បៀងអាហារ) ១៣០៦៧ (ដកស្រង់ឯកសារ **E3/275** ដូចដែលបានលើកឡើងថា "ភារកិច្ចជាក់ស្តែង បន្ទាន់មួយចំនួនទៀតត្រូវធ្វើ" បានរួមបញ្ចូលការផលិតស្រូវ "ឱ្យដល់កម្រិតខ្ពស់បំផុត" ដើម្បីជួយលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជន ឱ្យបានខ្ពស់ និងឆាប់រហ័សដូចដែលអាចធ្វើបាន)។ កថាខណ្ឌ ៤២៦៥ (យោងទៅសុន្ទរកថាមួយ ធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខ ដែលក្នុងនោះគាត់បានអំពាវនាវឱ្យមហាជនធ្វើការជាសមូហភាព ដើម្បីបង្កើនការផលិត និងការពារប្រទេស ដោយធានាថាក្នុងរយៈពេលពីមួយឆ្នាំ ទៅពីរឆ្នាំ ជីវភាពរបស់ប្រជាជននឹងបានប្រសើរឡើងបន្តិចម្តងៗ)។

[3730] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៤៨, ១៦៩៩-១៧០១, ៣៨៦៩-៣៨៧០, ៣៩២៩។

1032. ទោះជាយ៉ាងណា ការវាយតម្លៃជារួមរបស់ អ.ជ.ស.ដ លើឯកសារភស្តុតាងបានបង្ហាញថា បក្សបានដឹងថា កម្មករត្រូវបានបង្ខំឱ្យធ្វើការច្រើនម៉ោងខុសពីធម្មតា ដោយគ្មានសម្រាក "ថែមទាំងធ្វើការក្រៅម៉ោងលើសពីម៉ោងធម្មតា"[3731] ថា សូម្បីតែនៅក្នុងគ្រោះរាំងស្ងួត និងខ្វះខាតស្បៀងអាហារ ក៏កម្លាំងពលកម្មដែលមានទាំងអស់ត្រូវបានជំរុញឱ្យសម្រេចគោលដៅ និងបើអាចធ្វើទៅបាន ឱ្យលើសពីគោលដៅសេដ្ឋកិច្ចរបស់បក្ស[3732] និងថា មជ្ឈិមបក្សទទួលបានដំណឹងពេញលេញអំពីលក្ខខណ្ឌរស់នៅ និងកង្វះស្បៀងអាហារ ប៉ុន្តែ ម្តងហើយម្តងទៀតមិនបានឆ្លើយតបឱ្យបានគ្រប់គ្រាន់ ផ្ទុយទៅវិញបែរជានាំចេញស្រូវក្នុងបរិមាណដ៏ច្រើន ដើម្បីបង្កើតទុន[3733]។ តាមរយៈភស្តុតាងបែបនេះ ការអះអាងដែលថា សហករណ៍ និងការដ្ឋាន ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់លក្ខខណ្ឌរស់នៅ ត្រូវបានសន្និដ្ឋានដោយសមហេតុផលថាមិនទទួលបានការគាំទ្របញ្ជាក់ឡើយ[3734]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញពីកំហុសឡើយ។

*អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា បរិមាណការងារកំណត់បាននាំឱ្យមានលក្ខខណ្ឌការងារអមនុស្សធម៌ (មូលដ្ឋានទី ១៨១)*

1033. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានសន្និដ្ឋានខុសថា ការនាំចេញស្រូវ និងបរិមាណកំណត់ ត្រូវបាន "កំណត់ក្នុងក្របខណ្ឌនៃគោលនយោបាយដែលមិនខ្វល់ពីប្រជាជន" ដោយចោទប្រកាន់ថា មិនបានគិតអំពីភស្តុតាងដែលថា ការនាំចេញផ្នែកកសិកម្មគឺជាមធ្យោបាយបំពេញបន្ថែមលើកង្វះខាតផលិតផលដែលប្រជាជនត្រូវការ[3735]។ តាមពិតនោះ អ.ជ.ស.ដ យល់ឃើញពីមូលហេតុសេដ្ឋកិច្ចដែលជំរុញការផលិតនៅក្នុងសហករណ៍ និងការដ្ឋាន ដោយសន្និដ្ឋានថា "ប.ក.ក បាននាំចេញអង្គដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីបង្កើតទុន" និងបានកត់សម្គាល់ពីសម្ភារនានាដែល ប.ក.ក បានទទួលក្នុងការដោះដូរនោះ[3736]។ ទោះជាយ៉ាងណា ភស្តុតាងនេះមិនបានប្តូរ

---

[3731] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១០-៣៩១១. *សូមមើលផងដែរ* កថាខណ្ឌ ១២៧៧, ១២៨៤-១២៨៧, ១៥០៥-១៥០៩។

[3732] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០៥-៣៩០៦ និងភស្តុតាងយោងខាងក្នុងនោះ។

[3733] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៣-៣៩១៤ និងភស្តុតាងយោងខាងក្នុងនោះ។

[3734] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៩។

[3735] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០៦ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០១-៣៩០៨។

[3736] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៤ (ដែលកត់សម្គាល់ផងដែរលើការនាំចូល និងនាំចេញសរុបរបស់កម្ពុជាប្រជាធិបតេយ្យ។ ការនាំចូលរួមមានវាយនភណ្ឌ ឥន្ធនៈ ថ្នាំសង្កូវ ថ្នាំសម្លាប់សត្វល្អិត និងគ្រឿងបន្លាស់

ការសន្និដ្ឋានផ្អែកលើភ័ស្តុតាងដែលថា ការកំណត់បរិមាណផលិតកម្មរបស់ ប.ក.ក ធ្វើឱ្យមានឧក្រិដ្ឋកម្ម ដូចជា លក្ខខណ្ឌការងារអមនុស្សធម៌ ដែលបក្សភាគច្រើនមិនបានដោះស្រាយ ដោយសារតែការផ្តោតទៅលើផលិតកម្មឆាប់របាស[3737]។

1034. ម្ចាស់បណ្តឹងសាទុក្ខក៏ចោទប្រកាន់ដោយមិនត្រឹមត្រូវផងដែរថា អ.ជ.ស.ដ បានមើលរំលងភ័ស្តុតាងដែលថា ប.ក.ក គ្រាន់តែមានបំណងនាំចេញស្រូវដែលលើសប៉ុណ្ណោះ[3738]។ បើទោះជា ចំណុចជាច្រើននៅក្នុងសាលក្រមលើកឡើងថា អ.ជ.ស.ដ *ពិតជាបាន* ពិចារណាលើភ័ស្តុតាងទាំងនោះ[3739] វិធានការដែលបក្សបានអនុវត្តមានសារសំខាន់ជាងពាក្យពេចន៍របស់ខ្លួន។ ចំពោះ ភ័ស្តុតាងដ៏ច្រើនលើសលប់ ដែលថា ប.ក.ក បាននាំចេញស្រូវក្នុងបរិមាណដ៏ច្រើនទៅកាន់ប្រទេសផ្សេងៗ បើទោះជាមានគ្រោះអត់ឃ្លាននៅក្នុងស្រុក[3740] ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញពីកំហុសឡើយ។

1035. ម្ចាស់បណ្តឹងសាទុក្ខហាក់ដូចជាបន្ទោសថា ការផ្គត់ផ្គង់ស្បៀងអាហារមិនគ្រប់គ្រាន់របស់បក្សគឺដោយសារតែរបាយការណ៍មិនពិតពីមូលដ្ឋាន ដែលបានបិតបាំងការខ្វះខាតទាំងនោះ ដែលធ្វើឱ្យ

---

ម៉ាស៊ីន)។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៩, ៩៦៨, ១៣១៣-១៣១៤, ១៣១៨, ១៤៥៤, ១៥៩៤, ១៦៧៨, ៣៩០១, ៣៩០៧, ៤២១៤, ៤២៦៦។

[3737] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០៩-៣៩១៤។ ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៦, ១៨៣។*សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៧៥-៩៧៩, ១០១០-១០១៦, ១០២០, ១០២៣, ១០៤៥, ១០៤៧, ១១៩៩, ១២៨៤-១២៨៧, ១៣០០-១៣០១, ១៣០៦-១៣០៧, ១៣១២-១៣១៩, ១៣២៣-១៣២៤, ១៥០៦-១៥០៩, ១៥១១-១៥១៩, ១៥៣០-១៥៣៦, ១៦០៥, ១៦០៩-១៦១០, ១៦៣៣-១៦៣៤, ១៦៤០, ១៦៧១, ១៧០៥, ១៧៤៥-១៧៤៦, ១៧៥៤។ *សូមមើលបន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៨, ៩០, ១០១, ១១៣, ១១៥-១១៧, ១២៣។

[3738] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០៧។

[3739] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៥២ (យោងសុន្ទរកថា ដែល នួន ជា បានប្រកាស "យើងនៅសល់ស្រូវជាង ១៥០.០០០ តោន សម្រាប់នាំចេញ") ជើងទំព័រ ១៩៥២ (យោងសក្ខីកម្មរបស់ម្ចាស់បណ្តឹងសាទុក្ខ "បានលើកឡើងពីការនាំចេញអង្ករដែលនៅសល់ទៅកាន់ប្រទេសជាមិត្ត ដើម្បីដោះដូរយកផលិតផលកសិកម្ម" និង "បានលើកឡើងពីការដោះដូរផលិតផលកសិកម្មដែលលើពីតម្រូវការជាមួយឱសថ") ៣២០៩ (យោងភ័ស្តុតាងរបស់ ភ្នៅ យ៉ារ ថាស្រូវត្រូវបានរក្សាទុកនៅឃុំ ហើយស្រូវដែលលើត្រូវបញ្ជូនទៅថ្នាក់លើ) ៤៩៧៨ (យោងការចេញផ្សាយរបស់ទស្សនាវដ្តីទង់បដិវត្តន៍ខែកញ្ញា ឆ្នាំ១៩៧៧ ដែលបានរាយការណ៍ថា ពួកគេមាន "ស្បៀងគ្រប់គ្រាន់" សម្រាប់ប្រជាជន និងមានលទ្ធភាពនាំចេញ "ស្រូវរាប់ពាន់តោន" ដើម្បីបង្កើតទុន។

[3740] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១០-១០១៣, ១០៤៧, ១១៤២, ១១៩៥, ១១៩៩, ១៣០១, ១៤៤៨-១៤៥៤, ១៥៨៦-១៥៩៥, ១៦៣៦-១៦៤០, ១៦៧៨, ១៦៨១, ១៩៥៣, ៣៩០០, ៣៩០៧, ៣៩១៣-៣៩១៤, ៤២៧៦។

មេដឹកនាំ ប.ក.ក មិនបានដឹងពិតប្រាកដពីស្ថានភាពនោះ[3741]។ អ.ជ.ស.ដ បានទទួលស្គាល់ថា របាយការណ៍មិនពិតបានកើតមានមែន[3742] ប៉ុន្តែ របាយការណ៍ទាំងនោះតិចជាងភស្តុតាងដែលបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់ (i) បានទទួលរបាយការណ៍ផ្ទាល់ដែលលើកឡើងអំពីកង្វះខាតស្បៀង (ii) បានទៅពិនិត្យមើលទីតាំងទាំងនោះដោយផ្ទាល់ និងបានឃើញលក្ខខណ្ឌទាំងនោះ[3743] និង (iii) បានទទួលស្គាល់ពីកង្វះខាតស្បៀង[3744]។ ការឃោសនារបស់ ប.ក.ក ក៏បានយោងទៅលើចំណុច

[3741] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០៧-១៥០៩។ ម្ចាស់បណ្តឹងសាទុក្ខអះអាងបន្តទៀតថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា "មេដឹកនាំ ប.ក.ក ដឹងពីអ្វីដែលបានកើតឡើងនៅតាមសហករណ៍" (*សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០៨)។ ចំណុចនេះបំភ្លៃសការសន្និដ្ឋាននោះ ដែលគ្រាន់តែលើកឡើងថា ការសាងសង់ និងផលិតកម្ម "ត្រូវបានកម្មាភិបាលភូមិភាគផ្តល់ដំណឹងជាទៀតទាត់ទៅមជ្ឈិមបក្ស" (*សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩៩)។

[3742] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០១០ (ឃុំត្រាំកក់បានរាយការណ៍ខុសអំពីទិន្នផលស្រូវ ដើម្បីទទួលបានស្រូវច្រើនទៀតសម្រាប់ខ្លួនឯង) ១២១៦-១២១៧, ១២៥១-១២៥២ (របាយការណ៍បោកប្រាស់) ១២៦០ (មានតែកម្មករមានសុខភាពល្អទេដែលបានអនុញ្ញាតឱ្យឈរក្បែរភ្ញៀវទស្សនាទំនប់ត្រពាំងថ្ម) ១៤៩៦, ១៦៣៦-១៦៣៧។ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ទៅនឹងការពឹងផ្អែករបស់ អ.ជ.ស.ដ លើ មាស វឿន ក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីលក្ខខណ្ឌនានានៅក្នុងសហករណ៍ (*សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០៩) ប៉ុន្តែ*សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[3743] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៥៥, ១២៣៨-១២៥៩, ១៤៨៦-១៤៩៧, ១៦៣១, ១៦៣៣-១៦៣៥, ១៦៤០, ១៦៧១, ១៧០៥-១៧០៦, ៣៩១២-៣៩១៣ និងភស្តុតាងយោងខាងក្នុងនោះ។ ឯកសារ **E3/2041** របាយការណ៍ពីគណៈកម្មាធិការពាណិជ្ជកម្ម ទៅកាន់បង ហែម ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00091074 (*កត់សម្គាល់* ថា ប្រជាជនកម្ពុជាកំពុងប្រឈមមុខនឹង "កង្វះខាតស្បៀង" នៅឆ្នាំនោះ)។

[3744] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០០ និងភស្តុតាងយោងខាងក្នុងនោះ។ *សូមមើលផងដែរ* ឯកសារ **E3/232** កំណត់ហេតុអង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ KH 00017122 (បានលើកឡើងថា ពួកគេត្រូវតែប្រុងប្រយ័ត្នចំពោះរបបអាហារក្នុងខែសីហា និង កញ្ញា "ច្រើនខ្វះខាត" ដោយសារការខ្វះខាត "នឹងប៉ះពាល់ដល់សុខភាព ខាតកម្លាំងពលកម្ម")។ ឯកសារ **E3/223** កំណត់ហេតុអង្គប្រជុំនៃ គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៦ KH 00000832 (ដែលបានរាយការណ៍ពីការសន្និដ្ឋានរបស់ ប៉ុល ពត ថា គោលនយោបាយនៅតែរួមបញ្ចូលការដោះស្រាយ "បញ្ហាស្បៀង")។ ឯកសារ **E3/294** សារព័ត៌មាន FBIS, *សេចក្តីសន្និដ្ឋាននៃសុន្ទរកថារបស់ ប៉ុល ពត នៅអង្គប្រជុំថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៨* EN 00170165 (ភាសាអង់គ្លេស) (ប៉ុល ពត កត់សម្គាល់ "បញ្ហាស្បៀង" នៅក្នុងឆ្នាំ ១៩៧៥-១៩៧៧ ទាំងមូល)។ ឯកសារ **E3/781** ពិនិត្យការក្តាប់ និងការអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072396-97។

នេះដែរ[3745]។ ដូច្នេះ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា មេដឹកនាំ ប.ក.ក បានដឹងអំពីកង្វះខាតទាំងនេះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[3746]។

*អ.ជ.ស.ដ បានលើកឡើងយ៉ាងត្រឹមត្រូវអំពីឯកសារ ប.ក.ក ទាក់ទងនឹងសហករណ៍ (មូលដ្ឋានទី ១៨១)*

1036. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានលើកឡើងដោយមិនត្រឹមត្រូវអំពីឯកសារ ប.ក.ក ទាក់ទងនឹងសហករណ៍ ដើម្បីគាំទ្រដល់ការរើសអើងប្រឆាំងនឹងប្រជាជនថ្មី ឬថាអង្គជំនុំជម្រះបានមើលរំលងភ័ស្តុតាងដោះបន្ទុក ដែលផ្តល់យុត្តិកម្មដល់គោលនយោបាយនោះ និងបង្ហាញពី "ការព្រួយបារម្ភជាប្រចាំចំពោះប្រជាជន" របស់ ប.ក.ក[3747]។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងទៅលើសំអាងហេតុពាក់ព័ន្ធ ដោយផ្តោតលើភ័ស្តុតាងតែមួយផ្នែក ដោយមិនបានរៀបរាប់ថាតើការដកស្រង់ខ្លះដែលគាត់យោងសំអាង លុបទៅលើឯកសារភ័ស្តុតាងទាំងមូល ដែល អ.ជ.ស.ដ សំអាងលើដើម្បីធ្វើការសន្និដ្ឋានរបស់ខ្លួន។ ការពិនិត្យភ័ស្តុតាងតាមជ្រើសរើសរបស់ម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែបញ្ជាក់ថា អ.ជ.ស.ដ ខកខានមិនបានបកស្រាយភ័ស្តុតាងតាមលក្ខណៈដែលគាត់ចង់បាន។ គាត់បរាជ័យក្នុងការបញ្ជាក់ថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើគោលនយោបាយរបស់ ប.ក.ក ស្តីពីសហករណ៍ គឺជាការសន្និដ្ឋានដែលអ្នកវិនិច្ឆ័យលើអង្គហេតុដ៏មានហេតុផល អាចសន្និដ្ឋានបែបនេះ ឬក៏ថា ការសន្និដ្ឋានទាំងនោះមានភាពលម្អៀង[3748]។

1037. ឧទាហរណ៍ ផ្ទុយទៅនឹងការវិភាគដ៏ទូលំទូលាយរបស់ អ.ជ.ស.ដ លើគោលនយោបាយសហករណ៍ ម្ចាស់បណ្តឹងសាទុក្ខបានជ្រើសរើសការដកស្រង់បីចេញពីឯកសារផ្សេងៗ ដែល អ.ជ.ស.ដ បានធ្វើការពិចារណា[3749]។ ចំពោះការដកស្រង់ទីមួយ គាត់អះអាងថា អ.ជ.ស.ដ បានបង្ហាញពីការលម្អៀង ដោយមិនអើពើលើការរៀបរាប់របស់ឯកសារអំពីកង្វះខាតដោយគ្រោះ

---

[3745] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០៦ ជើងទំព័រ ១៣០២៣ *យោងឯកសារ* **E3/135** *ទង់បដិវត្តន៍* ខែមិថុនា ឆ្នាំ១៩៧៧ KH 00062811 (*កត់សម្គាល់* កង្វះខាតស្បៀង និងថារបបអាហាររបស់កម្មករមួយចំនួនក្នុងរដូវវស្សា "អាចមានកន្លែងខ្លះថយបន្តិច នាំឱ្យប្រជាជន*អាក់*សន្ទាបន្តិចដែរ")។ ឯកសារ **E3/170** *ទង់បដិវត្តន៍* ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧ KH 00064762 (ទទួលស្គាល់ការខ្វះខាតស្បៀងមួយចំនួនក្នុងឆ្នាំ ១៩៧៦) 00064769 (លើកឡើងថា "ប្រជាជនខ្វះខាតយើងថាធម្មតា" ក្នុងឆ្នាំ១៩៧៥-១៩៧៧ និង "ឆ្នាំ ៧៨ ប្រជាជនខ្វះខាត យើងថាធម្មតា")។

[3746] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៣។

[3747] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥៩៤-១៥៩៥។

[3748] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១០។

[3749] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ជើងទំព័រ ២៨២១, ២៨២៣, ២៨២៩។

មហន្តរាយ ដែលផ្តល់យុត្តិកម្មលើការតម្រូវឱ្យមនុស្សរាល់គ្នាធ្វើការ[3750]។ ទោះបីជាមានហេតុផលផ្នែកមនុស្សធម៌ ម្ចាស់បណ្តឹងសាទុក្ខហាក់ដូចជាយល់ច្រឡំលើហេតុជំរុញ ដែលមិនមែនជាធាតុផ្សំ *នៃ* ការទទួលខុសត្រូវ និងមិនមែនជាការការពារ *ចំពោះ* ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មឡើយ[3751]។ ដូចដែលបានពិភាក្សារួចហើយ សកម្មភាពទាំងនេះគឺជាឧក្រិដ្ឋកម្មដែលបានធ្វើឡើងដើម្បីអនុវត្តគោលនយោបាយនោះ ដូចជា ការដាក់កម្មករឱ្យទៅជាទាសករ ដែលបញ្ជាក់ពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងរឿងក្តីនេះ។ ការខកខានរបស់ អ.ជ.ស.ដ ក្នុងការលើកឡើងពីការដកស្រង់ដែលលើកឡើងអំពីហេតុផលផ្នែកមនុស្សធម៌នៅក្នុងឯកសារមួយ មិនបង្ហាញពីភាពលម្អៀង ឬកំហុសនោះទេ[3752]។ ឯកសារទីពីរ ដែលយោងសំអាងដោយម្ចាស់បណ្តឹងសាទុក្ខ បរាជ័យមិនបានបង្ហាញថា អ.ជ.ស.ដ មានការយល់ច្រឡំណាមួយទាក់ទងនឹងការប្រើពាក្យ "ខ្មាំង" នោះឡើយ ដោយហេតុថា អ.ជ.ស.ដ បានកត់សម្គាល់យ៉ាងត្រឹមត្រូវថា ឯកសារដែលរងការជំទាស់នោះសំដៅទៅលើសមិទ្ធផលមុនឆ្នាំ១៩៧៥ របស់បក្ស[3753]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់ការពន្យល់បន្ថែមទៀតអំពីមូលហេតុដែលភ័ស្តុតាងជាច្រើន ដែល អ.ជ.ស.ដ ពឹងផ្អែកដើម្បីធ្វើការសន្និដ្ឋានរបស់ខ្លួនលើការប្រព្រឹត្តិលើ "ខ្មាំង" នៅក្នុងសហករណ៍ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ[3754] គួរត្រូវបានបដិសេធនោះទេ។

---

[3750] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៩៦ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៥ ដែលតាមលំដាប់លំដោយ យោងឯកសារ **E3/729** *ទង់បដិវត្តន៍* ខែតុលា ឆ្នាំ១៩៧៥ KH 00063400។

[3751] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៤៨-៧៤៩ (ដែលក្នុងនោះម្ចាស់បណ្តឹងសាទុក្ខបានសន្និដ្ឋានថា អំពើជាក់លាក់មិនត្រូវបានប្រព្រឹត្តឡើងដោយមានចេតនាដែលតម្រូវទេ ដោយហេតុថា គោលបំណងនោះគឺត្រូវបង្កើតគ្រួសារ (ហេតុជំរុញមនុស្សធម៌) ហើយ អ.ជ.ស.ដ បានកត់សម្គាល់ថា គាត់ហាក់ដូចជាយល់ច្រឡំរវាងហេតុជម្រុញ និង ចេតនា) ៣៧០៨-៣៧១២ (ធាតុផ្សំ JCE គោលបំណងរួម)។

[3752] ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា "អង្គជំនុំជម្រះមិនបានយកចិត្តទុកដាក់លើគោលបំណងរបស់ ប.ក.ក តាមរយៈការបង្កើតសហករណ៍" បរាជ័យដោយសារមូលហេតុដូចគ្នានេះ។ *សូមមើល*ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៩៩។

[3753] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤៩៧។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២៩៣៣។ ជាងនេះទៀត អ.ជ.ស.ដ ពេញចិត្តក្នុងការពិចារណាភ័ស្តុតាងនេះក្នុងការបង្ហាញពីគំរូច្បាស់លាស់នៃទង្វើ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣។

[3754] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៤៨ (ប្រជាជនថ្មីជាទូទៅមិនត្រូវបានគេទុកចិត្ត និងប្រឈមមុខនឹងការចោទប្រកាន់ថាជាខ្មាំងច្រើនជាងប្រជាជនមូលដ្ឋាន ប៉ុន្តែមានការបញ្ជាក់មួយចំនួនមិនមានការកំណត់ "ក្រុមគោលដៅដាច់ខាត" លើប្រជាជនថ្មីទេ") ៣៨៨៧ (គណៈកម្មាធិការអចិន្ត្រៃយ៍បានការប្រុងប្រយ័ត្នចំពោះតម្រូវការប្រុងប្រយ័ត្ននៅក្នុងសហករណ៍ ដែលស្រូបយកប្រជាជនថ្មី រួមបញ្ចូលទាំង "ពួកអានេះ" និង "សមាសភាពអាក្រក់")

1038. ឯកសារទីបីក៏ខកខានមិនបានង្ហាញពីកំហុសណាមួយផងដែរ។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា អ.ជ.ស.ដ មានកំហុសអង្គហេតុ ដោយខកខានមិនបានបកស្រាយភ័ស្តុតាងតាមលក្ខណៈជាក់លាក់ និងជ្រើសរើសតាមការចង់បាននូវប្រយោគតែមួយក្នុងឯកសារមួយ ដោយតវ៉ាអំពីលំដាប់លំដោយរបស់វានៅក្នុងសាលក្រម[3755]។ ទោះជាយ៉ាងណា កថាខណ្ឌនៃសាលក្រមដែលគាត់ជំទាស់នោះ មិនបានធ្វើការសន្និដ្ឋានអំពីការប្រព្រឹត្តិមិនល្អលើប្រជាជនថ្មីទេ ដោយគ្រាន់តែលើកឡើងថា ប.ក.ក អះអាងថា ការបែងចែកវណ្ណៈត្រូវបានដោះស្រាយ និងរាល់ សកម្មភាពសេដ្ឋកិច្ចទាំងអស់កំពុងត្រូវបានអនុវត្តដោយ "វណ្ណៈកម្មករ-កសិករ"[3756]។ ទោះបីជាមានការអះអាងពីការសាមគ្គីគ្នានេះក្តី ការបែងចែកដាច់ពីគ្នារវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី នៅតែកើតមាន ហើយការសន្និដ្ឋានក្រោយមកទៀតរបស់ អ.ជ.ស.ដ ថា ប្រជាជនថ្មីជាទូទៅ មិនត្រូវបានគេទុកចិត្ត និងប្រឈមនឹងការចោទប្រកាន់ថាជាខ្មាំង ត្រូវបានគាំទ្រដោយភ័ស្តុតាងជាច្រើន[3757]។ ការ

---

៣៨៩៦, ៣៨៩៨ (ខ្មាំងបានបន្តសកម្មភាពរបស់ពួកគេនៅក្នុងសហករណ៍) ៣៩០៨ ("វណ្ណៈជិះជាន់ជាច្រើន" បាន "ដណ្តើមអំណាច" នៅក្នុងសហករណ៍មួយចំនួន)។

[3755] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០០ *យោង* **E3/99** ឯកសារគោលនយោបាយ លេខ ៦ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072400-03។

[3756] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩៤។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥០០ (បានថ្លែងថា អ.ជ.ស.ដ បានពិចារណាថា "ការបែងចែករវាងប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន មានន័យថា ប្រជាជនថ្មីទទួលបានការយកចិត្តទុកដាក់តិចជាងប្រជាជនមូលដ្ឋាន")។

[3757] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៤៨។ *សូមមើលឧទាហរណ៍* **<u>សហករណ៍ត្រាំកក់៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០០៧ (ស្រុកបានណែនាំឃុំថា ប្រជាជនថ្មីគឺជាខ្មាំង និងមិនមានតម្លៃដូចប្រជាជនមូលដ្ឋាន ដែលទទួលបានការណែនាំឱ្យតាមដានពួកគេ) ១០១៦ (ប្រជាជនថ្មីជាទូទៅទទួលបានអាហារតិចជាង) ១០៨០ (ប្រជាជនថ្មីងាយនឹងត្រូវចាប់ខ្លួនជាង) ១១៧១, ១១៧៧។ *សូមមើលបន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ១០៧ (ការធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មី នៅក្នុងស្រុកត្រាំកក់)។ **<u>ការដ្ឋានទំនប់ត្រពាំងថ្ម៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៤៥, ១៤០៩ (ប្រជាជនថ្មីត្រូវបានបដិសេធមិនឱ្យកាន់កាប់មុខតំណែងដឹកនាំ ដែលផ្ទុយទៅវិញគេផ្តល់ឱ្យប្រជាជនមូលដ្ឋាន ហើយប្រជាជនមូលដ្ឋានត្រូវតាមដានសកម្មភាពរបស់ប្រជាជនថ្មី) ១៣៤៨ (ប្រជាជនថ្មីត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួន និងការសម្លាប់)។ *សូមមើលបន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ១១៤ (ការប្រព្រឹត្តបែបរើសអើងប្រឆាំងនឹងប្រជាជនថ្មី នៅការដ្ឋានទំនប់ត្រពាំងថ្ម)។ **<u>ការដ្ឋានទំនប់ ១មករា៖</u>** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៤៩-១៦៥៣។ *សូមមើលបន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ១១៨, ១១៩ (ការធ្វើបាបប្រជាជនថ្មីធៀបទៅនឹងប្រជាជនមូលដ្ឋាននៅការដ្ឋានទំនប់ ១មករា។ *កត់សម្គាល់ផងដែរ* ថាចម្លាស់បណ្តឹងសាទុក្ខយោងឯកសារ **E3/99** ឯកសារគោលនយោបាយលេខ ៦ អំពីការក្តាប់ និងការអនុវត្តនយោបាយប្រមូលកម្លាំងរបស់រណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស (ឯកសារទី៦) ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072400-03 ដើម្បីបង្ហាញថា ប.ក.ក បានដឹងជាមុនពីសម្ព័ន្ធភាពរវាងប្រជាជនថ្មី និងប្រជាជនចាស់ ប៉ុន្តែឯកសារដូចគ្នានេះបានបន្តលើកឡើងថា "[ប្រជាជនថ្មី] ក្តាប់គេខាងសតិអារម្មណ៍នយោបាយ និងចាត់តាំង" ក្នុង KH 00072404។

អះអាងមិនគ្រប់គ្រាន់របស់ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា ការសន្និដ្ឋាននោះមិនត្រឹមត្រូវ។

1039. ចុងក្រោយ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខទាក់ទងនឹងការប្រើប្រាស់របស់ អ.ជ.ស.ដ នូវសៀវភៅរបស់ Ben Kiernan និងនិក្ខេបបទរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក៏ដូចជា *បណ្ដឹង* អំពីសហករណ៍ក្រៅពីស្រុកត្រាំកក់ ដូចបានបង្ហាញនៅកន្លែងផ្សេងទៀតនៅក្នុងបណ្ដឹងសាទុក្ខនេះ គ្មានមូលដ្ឋានទេ[3758]។ ការតវ៉ាដោយគ្មានការគាំទ្ររបស់គាត់អំពីការប្រើប្រាស់របស់ អ.ជ.ស.ដ នូវកំណត់ហេតុស្ដាប់ចម្លើយដែលមានតម្លៃភស្តុតាងទាប មិនបំពេញបទដ្ឋាននៃការពិនិត្យឡើងវិញនៃបណ្ដឹងសាទុក្ខទេ[3759]។

## ២. ការចូលរួមចំណែកសំខាន់

1040. អ.ជ.ស.ដ បានសន្និដ្ឋានត្រឹមត្រូវថា ម្ចាស់បណ្ដឹងសាទុក្ខបានចូលរួមក្នុងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ផ្អែកលើការលើកឡើងអំពីច្បាប់ដោយត្រឹមត្រូវ និងតាមការវាយតម្លៃជារួមលើតួនាទី មុខងារ និងការប្រព្រឹត្តិរបស់ម្ចាស់បណ្ដឹងសាទុក្ខ និង ភស្តុតាងជាមូលដ្ឋានដ៏រឹងមាំ[3760]។ មូលដ្ឋានទី ១៣ របស់ម្ចាស់បណ្ដឹងសាទុក្ខ[3761] ទាក់ទងនឹង ការចូលរួម

---

[3758] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៩៨-១៤៩៩។ *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩ (សៀវភៅរបស់ Ben Kiernan) ១៩៦, &១៩៧ (និក្ខេបបទរបស់ម្ចាស់បណ្ដឹងសាទុក្ខ) ៣ (ការប្រើប្រាស់ភស្តុតាងក្រៅវិសាលភាពភូមិសាស្ត្រ ដើម្បីបង្ហាញពីគំរូច្បាស់លាស់នៃទង្វើ) ៣៩ (*បណ្ដឹង*នៃសហករណ៍ត្រាំកក់) ១៨០ (ភស្តុតាងនៃការផ្លាស់ទីលំនៅប្រជាជន)។

[3759] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៤៩៨ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៥។ *សូមមើលផងដែរ* បទដ្ឋាននៃការពិនិត្យឡើងវិញ (កំហុសផ្នែកអង្គហេតុ)។

[3760] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦ ("តាងនាមឱ្យកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានគាំទ្រ និងជំរុញគោលបំណងរួម និងលើកទឹកចិត្ត ញុះញង់ និងផ្ដល់ភាពស្របច្បាប់ដល់ការអនុវត្តគោលបំណងរួមនេះតាមរយៈគោលនយោបាយឧក្រិដ្ឋ។ ក្រៅពីនេះ គាត់បានណែនាំកម្មាភិបាលពីការអនុវត្តគោលបំណងទាំងនោះ ទន្ទឹមនឹងការផ្ដល់លទ្ធភាព និងការគ្រប់គ្រង។ ដូចគ្នានេះដែរ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានចូលរួមចំណែកយ៉ាងច្រើនក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយកម្មាភិបាល ប.ក.ក") ៤២០៣ ("ការវាយតម្លៃលើការទទួលខុសត្រូវរបស់ ខៀវ សំផន នឹងអាស្រ័យលើការវាយតម្លៃរបស់អង្គជំនុំជម្រះអំពី តួនាទី ភារកិច្ច និងការប្រព្រឹត្តរបស់គាត់ [...] នៅក្នុងការវាយតម្លៃទៅលើទំហំនៃ [...] ការចូលរួមចំណែករបស់គាត់លើឧក្រិដ្ឋកម្ម [...] អង្គជំនុំជម្រះនឹងពិចារណាលើសុន្ទរកថាទាំងស្រុង និងអំពើរបស់ ខៀវ សំផន រួមទាំងសុន្ទរកថាដែលបានធ្វើឡើងបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើចាំបាច់") ៤២៥៧-៤២៧៨ (រៀបរាប់លម្អិតពីរបៀបដែលម្ចាស់បណ្ដឹងសាទុក្ខ នៅក្នុងតួនាទី មុខងារ និងការប្រព្រឹត្តជាច្រើនរបស់គាត់ បានគាំទ្រ និងបានលើកកម្ពស់គោលបំណងរួម និងបានលើកទឹកចិត្ត បានញុះញង់ បានធ្វើជម្មានរូប និងបានណែនាំ បានផ្ដល់លទ្ធភាព និងបានត្រួតត្រាការអនុវត្តនោះតាមរយៈគោលនយោបាយរបស់ខ្លួន)។

ចំណែករបស់គាត់ចំពោះសហឧក្រិដ្ឋកម្មរួម បរាជ័យ ដោយហេតុថា លើកឡើងពីទឡ្ហីករណ៍ផ្សេងៗ ដែលខ្វះការពាក់ព័ន្ធ លើកឡើងម្តងទៀតអំពីអ្វីដែលបានលើកឡើងនៅពេលជំនុំជម្រះ មិនមានការគាំទ្រ ឬបង្ហាញតែពីការជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ផ្អែកលើការបកស្រាយផ្សេងទៅលើភ័ស្តុតាងដដែលនោះ។ លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខប្រើវិធីសាស្ត្រមួយផ្នែកម្តងៗ ទាំងទៅលើសាលក្រម និងលើភ័ស្តុតាងដែលគាំទ្រ ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមចំណែកសំខាន់ក្នុងគោលបំណង រួម។

1041. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខបំភ្លៃ និងប្រើមិនត្រឹមត្រូវនូវច្បាប់ដែលពាក់ព័ន្ធ។ ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម ម្ចាស់បណ្តឹងសាទុក្ខមិនចាំបាច់ជាប់ពាក់ព័ន្ធក្នុងការរៀបចំគោលបំណងរួម ឬ ផ្ទុយទៅនឹងការអះអាងជាច្រើនរបស់គាត់ ជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មជាក់លាក់នោះទេ។ ដូចដែលភ័ស្តុតាងបញ្ជាក់ គាត់ពិតបានធ្វើ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបានចូលរួមចំណែកក្នុងការអនុវត្តគោលបំណងរួម ដែលនាំឱ្យមានអានុភាពផ្ទាល់ ឬប្រយោលលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3762]។ ការចូលរួមចំណែករបស់ម្ចាស់បណ្តឹងសាទុក្ខអាចជាប់ពាក់ព័ន្ធទាំងស្រុង ឬដោយផ្នែក តាមរយៈអំពើអកម្ម[3763]។ ការចូលរួមចំណែករបស់គាត់មិនចាំបាច់ជា *លក្ខខណ្ឌតម្រូវដាច់ខាត (sine qua non)* សម្រាប់ការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយ ឬជាការចូលរួមចំណែក*ដ៏ច្រើន* នោះទេ[3764] ប៉ុន្តែ វាត្រូវតែសំខាន់ ដូចដែលបានបញ្ជាក់ដោយ

---

[3761] មូលដ្ឋានទី ១៨២, ១៩២, ១៩៨, ១៩៩, ២០៤, ២២២, ២២៤, ២២៦-២៣១។

[3762] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨៣-៩៨៥។ **F97/14/15 & D97/15/9 & D97/16/10 & D97/17/6** សាលដីការបស់ អ.ប.ជ ស្តីពី JCE កថាខណ្ឌ ៣៨។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៧, ២២៩។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៤១០, ១៨៨០, ១៨៨២, ១៩៨២, ១៩៨៨។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៦១១។

[3763] សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៨៧, ៤២១។ ផ្ទុយទៅនឹងការសម្រេចរបស់ អ.ជ.ស.ដ (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០៣, ៣៧១០) សហព្រះរាជអាជ្ញាសន្និដ្ឋានថា នៅពេលដែលបង្ហាញអំពីការចូលរួមចំណែករបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម តាមរយៈការខកខានក្នុងការធ្វើសកម្មភាពរបស់គាត់ អត្ថិភាពនៃកាតព្វកិច្ចផ្លូវច្បាប់ក្នុងការចាត់វិធានការ ដែលទាញចេញពីវិធាននៃច្បាប់ព្រហ្មទណ្ឌ *មិនតម្រូវ*នោះទេ (*សូមមើលឧទាហរណ៍* សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៣៩៤, ១៤៨៨, ២០៨០។ សាលដីកាក្នុងរឿងក្តី *Stanišić & Župljanin* កថាខណ្ឌ ១១០)។ បញ្ហាវាសាមញ្ញទេ ថាតើ ផ្អែកលើភ័ស្តុតាង ការបរាជ័យក្នុងការចាត់វិធានការ គឺជាការចូលរួមចំណែកសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឬយ៉ាងណា។ ការបរាជ័យក្នុងការទប់ស្កាត់ការកើតមានឡើងនូវឧក្រិដ្ឋកម្មត្រូវបានពិចារណា ក្នុងករណីដែលជនជាប់ចោទមានអំណាច និងឥទ្ធិពលខ្លះ ឬមានសិទ្ធិអំណាចលើចារី ដែលសមល្មមនឹងទប់ស្កាត់ ឬបញ្ឈប់ការរំលោភបំពាន ប៉ុន្តែបានខកខានមិនអនុវត្តអំណាចនោះ (សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៤៨៧, ១៥៣០)។

[3764] សំណុំរឿង០០១-ឯកសារ **E188** សាលក្រម ឌុច កថាខណ្ឌ ៥០៨។ ឯកសារ **E៣១៣** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩២។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨១០, ៩៨០។ សាលដីកាក្នុងរឿងក្តី *Kvočka*

ភ័ស្តុតាងដូច្នោះ[3765]។ សារសំខាន់នេះត្រូវបានកំណត់យ៉ាងត្រឹមត្រូវនៅក្នុងនេះ តាមករណីនីមួយៗ ដោយពិចារណាលើកត្តាជាច្រើន រួមទាំង ទំហំ ភាពធ្ងន់ធ្ងរ និងវិសាលភាពនៃផែនការរួម និង ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង មុខតំណែង *តាមនីតិន័យ* ឬ*តាមព្រឹត្តិន័យ* របស់ម្ចាស់បណ្តឹង សាទុក្ខ កម្រិត និងឥទ្ធិពលនៃការចូលរួមរបស់គាត់ ការថ្លែងជាសាធារណៈដែលពាក់ព័ន្ធរបស់គាត់ និងការខំប្រឹងប្រែងណាមួយក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម[3766]។

### *មូលដ្ឋានទី ២២៦៖ កំហុសពាក់ព័ន្ធនឹងការរួមចំណែករបស់ ខៀវ សំផន*[3767]

1042. **មូលដ្ឋានទី ២២៦ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខ បរាជ័យមិនបានបង្ហាញឱ្យ ឃើញថា អ.ជ.ស.ដ មានកំហុសផ្នែកច្បាប់ ឬអង្គហេតុ ចំពោះការសម្រេចដែលថា ការរួម**

---

កថាខណ្ឌ ៩៨។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤០១។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៣០។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៣៧៨។ សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ៣០៣។

[3765] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨០; ឯកសារ **E៣១៣** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩២។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រម ឌុច កថាខណ្ឌ ៥០៨។ **F97/14/15 & D97/15/9 & D97/16/10 & D97/17/6** សាលដីការបស់ អ.ប.ជ ស្តីពី JCE កថាខណ្ឌ ៣៨។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤២៧, ៤៣០, ៤៣២។ សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ៣០៣។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៦១១។

[3766] ឯកសារ **E៣១៣** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩៣។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨០។ សាក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២៩២, ៣១១។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១០១, ១៩២។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៦៤២។ អ.ជ.ត.ក បានសម្រេចថា (ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨២ *យោង* សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២១៦-២១៧) ប្រភេទនៃការប្រព្រឹត្តខាងក្រោម ដែលបង្កើតបានជាការចូលរួមចំណែកសំខាន់ក្នុង JCE គឺ៖ “ក) ការរៀបចំ ការផ្តួចផ្តើមគំនិត ការលើកកម្ពស់ ការចូលរួមក្នុង និង/ឬ ការលើកទឹកចិត្តការបង្កើត និងការអនុវត្ត [...] គោលនយោបាយរបស់រដ្ឋាភិបាល ដែលមានគោលបំណងពន្លឿន គោលដៅរបស់ [JCE]។ (ខ) ការចូលរួមក្នុងការបង្កើត គាំទ្រ ឬថែរក្សា [...] ស្ថាប័នរដ្ឋនៅថ្នាក់ [ជាតិ] តំបន់ ក្រុង និងមូលដ្ឋាន [...] តាមរយៈនោះ [គាត់] អាចអនុវត្តគោលដៅរបស់ [JCE]។ (គ) គាំទ្រ លើកទឹកចិត្ត ជួយជ្រោមជ្រែង ឬ ចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មានដើម្បី [...] ទទួលបានការគាំទ្រដល់ [JCE] និងការចូលរួមក្នុងការសម្រេចបានគោលដៅ របស់ [JCE]។ (ឃ) ការដឹកនាំ ការញុះញង់ ការលើកទឹកចិត្ត និងការផ្តល់សិទ្ធិអំណាច [...] កងកម្លាំងឱ្យចាត់វិធានការដើម្បី ពន្លឿនគោលដៅរបស់ [JCE]។ [...] (ង) ជាប់ពាក់ព័ន្ធក្នុងការគាំទ្រ ឬការជួយជ្រោមជ្រែង កិច្ចខិតខំប្រឹងប្រែងដែលផ្តោតលើ តំណាងរបស់សហគមន៍អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងសាធារណជន ដែលបដិសេធ ឬផ្តល់ឱ្យនូវព័ត៌មានមិនពិតអំពី ឧក្រិដ្ឋកម្ម”)។

[3767] មូលដ្ឋានទី ២២៦៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសទាក់ទងនឹងការរួមចំណែករបស់ ខៀវ សំផន* កថាខណ្ឌ ២០០៨-២០១១។ *សូមមើលផងដែរ* កថាខណ្ឌ ១៦០៤-១៦១៥, ១៩៤២-១៩៤៥, ១៩៥៧-១៩៦២, ២០០១-២០០៣។ ឯកសារ **F54** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៦ (អង់គ្លេស), ទំព័រ ៧០ (បារាំង), ទំព័រ ១០៩ (ខ្មែរ)។

**ចំណែកដ៏សំខាន់របស់គាត់ចំពោះគោលបំណងរួម ដែលជាធាតុផ្សំចាំបាច់មួយនៃធាតុផ្សំសត្យានុម័តិនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានបង្ហាញច្បាស់រួចទៅហើយ។**

1043. ទីមួយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ បានពឹងផ្អែកការសម្រេចរបស់ខ្លួនទាក់ទងនឹងការគាំទ្ររបស់គាត់ចំពោះផ្នែកផ្សេងៗនៃគោលនយោបាយនានា ដោយសារតែការការចូលរួមរបស់គាត់ជាមួយនឹងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នោះ[3768] គឺជាការលើកឡើងខុសច្បាស់ក្រឡែតនៅក្នុងសាលក្រម ព្រោះថា មិនគិតគូរអំពីការសន្និដ្ឋានជាច្រើនរបស់ អ.ជ.ស.ដ អំពីការរួមចំណែកដ៏សំខាន់របស់ម្ចាស់បណ្តឹងសាទុក្ខទៅក្នុងគោលបំណងរួម[3769]។ ប្រាកដណាស់ ទំនាក់ទំនងជាពិសេសរបស់គាត់ជាមួយនឹង ប.ក.ក រួមទាំង ការចូលរួមរបស់គាត់ផង បានផ្តល់ឱ្យគាត់នូវ មូលដ្ឋាន សិទ្ធិអំណាច និងការយល់ដឹង ដែលនាំឱ្យគាត់បានចូលរួមចំណែកដ៏សំខាន់នេះ តែទោះជាយ៉ាងណា គឺនេះជាការប្រព្រឹត្តិដោយស្ម័គ្រចិត្តរបស់គាត់ ដែលបានចូលរួមចំណែកយ៉ាងសំខាន់។ ដូចដែល អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវដែរ ម្ចាស់បណ្តឹងសាទុក្ខបានរួមចំណែកដល់គោលបំណងរួមនេះ តាមរយៈ "ការផ្តល់លទ្ធភាព និងការត្រួតត្រាដោយផ្ទាល់លើការអនុវត្តគោលបំណងរួម តាមរយៈ គោលនយោបាយផ្សេងៗ"[3770] រួមទាំង "ការផ្តល់លទ្ធភាពដោយផ្ទាល់ ដែលធ្វើឱ្យរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យដំណើរការទៅដោយរលូន ក្នុងទិសដៅបំផ្លាញប្រជាជនខ្លួនឯង" តាមរយៈ សមាជិកភាពនៃមន្ទីរ ៨៧០ របស់គាត់[3771] និងតាមរយៈការរួមចំណែកដល់ការបោសសម្អាតកម្មាភិបាលនានា[3772]។

1044. អ.ជ.ស.ដ បានសន្និដ្ឋានទៀតថា ម្ចាស់បណ្តឹងសាទុក្ខបានរួមចំណែកទៅគោលបំណងរួមតាមរយៈ "ការណែនាំយ៉ាងសកម្ម"[3773] "ការលើកទឹកចិត្ត និងការញុះញង់"[3774] ដល់ការអនុវត្តតាមរយៈគោលនយោបាយផ្សេងៗរបស់ ប.ក.ក ដោយ "ប្រើមុខឋានៈជាន់ខ្ពស់របស់ខ្លួនក្នុងការធ្វើឱ្យគោល

---

[3768] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០០៨។

[3769] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧-៤២៧៨, ៤៣០៦។

[3770] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៨។ *សូមមើលបន្ថែម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៥-៤២៧៨។

[3771] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៦។

[3772] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៧។

[3773] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៤។ *សូមមើលបន្ថែម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧១-៤២៧៤។

[3774] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧០។ *សូមមើលបន្ថែម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥-៤២៧០។

បំណងរួមនេះទៅជាធម្មានុរូប"[3775]។ ម្ចាស់បណ្តឹងសាទុក្ខ "បានឃោសនាយ៉ាងសកម្មអំពីសេចក្តីអំពាវ នាវបែបរោហាសាស្ត្ររបស់ ប.ក.ក ឱ្យមានការប្រព្រឹត្តិបែបអើងទៅលើជនជាតិវៀតណាម នៅក្នុង ប្រទេសកម្ពុជា"[3776] និងបានបង្រៀនដោយផ្ទាល់អំពីការដកវៀតណាមទាំងអស់ចេញពីប្រទេស កម្ពុជា[3777]។ គាត់បានថ្លែងជាសាធារណៈអំពីតម្រូវការចាំបាច់ក្នុងការ "កម្ទេចរបប លន់នល់"[3778] នៅពេលជាមួយគ្នាកំពុងតែបិទបាំងឧក្រិដ្ឋកម្មដែលបាន និងកំពុងប្រព្រឹត្តប្រឆាំងនឹង "អតីតខ្មែរក្រហម"[3779]។ គាត់បានលើកទឹកចិត្តឱ្យមានការប្តេជ្ញាចិត្តក្នុងការបំពេញផែនការការងាររបស់ បក្សលើការងារកសាង និងបង្កបង្កើនផល[3780] "ទោះក្នុងតម្លៃណាក៏ដោយរបស់កម្មករ"[3781]។ គាត់បានលើកកម្ពស់គោលនយោបាយប្រជាជនរបស់ ប.ក.ក[3782] និងបានណែនាំឱ្យក្រសួងនានារៀបចំឱ្យមានការរៀបការ[3783]។

1045. អ.ជ.ស.ដ ក៏បានសន្និដ្ឋានផងដែរថា ម្ចាស់បណ្តឹងសាទុក្ខបានរួមចំណែកដល់គោលបំណងរួមតាមរយៈ "ការគាំទ្រជាសាធារណៈ"[3784] និងក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ "ការចូលរួមយ៉ាងសកម្មយ៉ាងខ្លាំងក្លា និងការលើកទឹកចិត្ត ការទទួលស្គាល់ និងការយល់ព្រមជាសាធារណៈលើគោលនយោបាយនេះនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ"[3785]។ ម្ចាស់បណ្តឹងសាទុក្ខបានធ្វើសកម្មភាពទាំងនេះតាមរយៈ *មានជាអាទិ៍* សមាជិកភាពពេញសិទ្ធិរបស់គាត់នៃគណៈកម្មាធិការមជ្ឈិម ការចូលរួមដោយផ្ទាល់នៅក្នុងសមាជបក្ស តួនាទីរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ ការបង្ហាញខ្លួន និងចូលរួមដោយផ្ទាល់ជាប្រចាំនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសមាជិកភាពរបស់

[3775] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧០។ *សូមមើលបន្ថែម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥-៤២៧០។

[3776] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៩។

[3777] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧១។

[3778] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧២។

[3779] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៨។

[3780] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥-៤២៦៨, ៤២៧៣។

[3781] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៣។

[3782] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៨។

[3783] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៣។

[3784] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦១។ *សូមមើលបន្ថែម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧-៤២៦១។

[3785] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៤។ *សូមមើលបន្ថែម* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២-៤២៦៤។

នៃមន្ទីរ ៨៧០[3786]។ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ គាត់បាន "បន្តគោរពតាមមាគ៌ាបក្ស ដោយបានដឹកនាំវគ្គបំពាក់បំប៉ននៅក្នុងអង្គមីទ្ទីង និងវគ្គសិក្សាអប់រំ"[3787]។ ម្ចាស់បណ្តឹងសាទុក្ខបានកោតសរសើរជាសាធារណៈអំពីជោគជ័យរបស់ ប.ក.ក[3788] រួមទាំងនៅក្រុមប្រិពិភពលោកខាងក្រៅ ។ គាត់បាន "បិទបាំងព្រឹត្តិការណ៍នៅខាងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបដិសេធការប្រព្រឹត្តិឧក្រិដ្ឋកម្មទ្រង់ទ្រាយធំទាំងនេះ"[3789]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសន្និដ្ឋានណាមួយនៃការសម្រេចទាំងនេះ គឺជាការសន្និដ្ឋានដែលអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលអាចសន្និដ្ឋានបែបនេះនោះទេ[3790]។ ការអះអាងមិនត្រឹមត្រូវច្បាស់ក្រឡែតរបស់គាត់ដែលថា អ.ជ.ស.ដ ខកខានមិនបាន "កំណត់សកម្មភាពជាក់លាក់ណាមួយ [...] ដែលបញ្ជាក់ថា គាត់ចូលរួមចំណែកក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម" គួរត្រូវបានបដិសេធចោល[3791]។

1046. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3792] ដូចដែល អ.ជ.ត.ក បានបដិសេធក្នុងសំណុំរឿង ០០២/០១[3793] អ្វីដែលតម្រូវនោះគឺថា គាត់បានចូលរួមប្រព្រឹត្តតាមមធ្យោបាយសំខាន់ៗមួយចំនួនក្នុងការសម្រេចគោលបំណងរួម[3794] ដែលធ្វើឱ្យមានអនុភាពដោយផ្ទាល់ និងប្រយោល ទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា[3795]។ ហេតុដូចនេះ ការរួមចំណែកដ៏សំខាន់ *មិន*ចាំបាច់ ទាល់តែមានការ

---

[3786] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧-៤២៦១។

[3787] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២។

[3788] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៣។

[3789] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៧។

[3790] *សូមមើល* ចម្លើយតបទៅនឹង មូលដ្ឋានទី ២២៧-២៣១។

[3791] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០០៨។

[3792] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦០៤-១៦១៥, ១៩៤៣-១៩៤៥, ១៩៦០-១៩៦២, ២០០២-២០០៣, ២០០៨-២០១១ (ម្ចាស់បណ្តឹងសាទុក្ខតវ៉ាថា ការរួមចំណែកតែមួយគត់នៅក្នុងការប្រតិបត្តិគោលបំណងរួមមិនមែនព្រហ្មទណ្ឌដែលបានចោទ មានកង្វះទំនាក់ទំនងគាប់ជូនទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម) *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧១០, ៤២៥៥-៤២៥៦។

[3793] ឯកសារ **E465** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៧៦-៩៨៥។

[3794] ឯកសារ **D97/14/15 & D97/15/9 & D97/16/10 & D97/17/6** សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពី **JCE** កថាខណ្ឌ ៣៨។ ឯកសារ **E188** សាលក្រមរឿងក្តី ឌុច កថាខណ្ឌ ៥០៨។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ៦៩៣។ សាលដីការឿងក្តី *Tadić* កថាខណ្ឌ ២២៩(iii)។ សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ៤២៧។ សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៣៧៨។ សាលដីការឿងក្តី *Krajišnik* កថាខណ្ឌ ២១៨។ សាលដីការឿងក្តី *Simba* កថាខណ្ឌ ២៥០។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៦១១, ១០៣៤។

[3795] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨៣-៩៨៤ (ដូច អ.ជ.ត.ក បានពន្យល់ នៅត្រង់កថាខណ្ឌ៩៨៤ ថា "សូម្បីតែសកម្មភាពដែលមើលពីខាងក្រៅពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក៏ដោយ ក៏អាចលើកយកមកពិចារណា

ប្រព្រឹត្តិឧក្រិដ្ឋកម្មជាក់លាក់ណាមួយឡើយ ហើយក៏មិនមែនជា*កត្តាចាំបាច់បំផុត* សម្រាប់ការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយនោះដែរ[3796]។ ដោយសារតែឥទ្ធិពលដោយប្រយោលនៃការរួមចំណែកដ៏សំខាន់ចំពោះគោលបំណងឧក្រិដ្ឋ លើការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានោះ គ្មានការរំលោភគោលការណ៍នៃការទទួលខុសត្រូវជាបុគ្គលឡើយ"[3797] ហើយក៏គ្មាន "ការផ្តាច់ចំណងពាក់ព័ន្ធ"[3798] រវាងជនជាប់ចោទ និងឧក្រិដ្ឋកម្ម ដូចម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់នោះដែរ។

1047. លើសពីនេះទៀត អង្គហេតុដែលថា គោលដៅចុងក្រោយនៃគោលបំណងរួមមិនមែនជាឧក្រិដ្ឋកម្មនោះ មិនមានភាពពាក់ព័ន្ធទេ[3799] ដោយសារ អ.ជ.ស.ដ បានបង្ហាញរួចហើយថា គោលបំណងនេះ *មាន* ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3800]។ បើទោះជាការអនុវត្តយ៉ាងឆាប់រហ័សនូវបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជាតាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" មិនមាន ជាគោលបំណងសំខាន់ការប្រព្រឹត្តិឧក្រិដ្ឋកម្មបែបនេះក្តី[3801] អ.ជ.ស.ដ សន្និដ្ឋានថា ការអនុវត្តយ៉ាងជោគជ័យនោះ គឺអាស្រ័យទៅលើការអនុវត្តគោលនយោបាយឧក្រិដ្ឋទាំងប្រាំ[3802]។ ដូច្នេះ អ.ជ.ស.ដ ពិតជាបានភ្ជាប់យ៉ាងត្រឹមត្រូវនូវអំពើរបស់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា តាមរយៈការវាយតម្លៃអំពីការគាំទ្រ និងការលើកកម្ពស់របស់គាត់ចំពោះគោលបំណងរួម[3803] និងការរួមចំណែករបស់គាត់ដល់ការអនុវត្តឧក្រិដ្ឋកម្មទាំងនោះ[3804]។

---

បានដែរ នៅពេលកំណត់ ថាតើជនជាប់ចោទបានរួមចំណែកយ៉ាងសកម្មដែរឬយ៉ាងណា" ពីព្រោះសកម្មភាពនេះអាចជំរុញ និងគាំទ្រការប្រព្រឹត្តបទឧក្រិដ្ឋបាន បើទោះបីជាសកម្មភាពនោះត្រឹមតែប្រយោលក៏ដោយ")។

[3796] ឯកសារ **E465** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧១០, ជើងទំព័រ ១២៣៦៤-១២៣៦៥។

[3797] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦០៤-១៦១៥, ១៩៤២-១៩៤៥។

[3798] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៤៥។

[3799] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៤២, ១៩៦០, ១៩៦២, ២០០២, ២០១០-២០១១។

[3800] ឯកសារ **E465** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៩២៨, ៣៩៨៧, ៣៩៩៨, ៤០១២, ៤០២២, ៤០៦១, ៤០៦៧, ៤២៥៦។ *សូមមើលបន្ថែម* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤។

[3801] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤៣។

[3802] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៨។ *សូមមើលផងដែរ* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៧៨។

[3803] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧-៤២៦៤។

[3804] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥-៤២៧៨។

1048. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា ការរួមចំណែកអាចធ្វើបានតាមរយៈអំពើអកម្មដែលអាចនាំឱ្យមានពិរុទ្ធ[3805] ក៏ត្រូវបរាជ័យដូចគ្នាដែរ។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានពឹងផ្អែកលើភាពអកម្មនៅក្នុងការសម្រេចរបស់ខ្លួនទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមទេ ដូច្នេះ មិនបានបង្ហាញថា តើកំហុសដែលបានចោទប្រកាន់នោះប៉ះពាល់ដល់សាលក្រមដោយវិធីណាទេ[3806]។ ទោះក្នុងករណីក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសម្រេចថា ការចូលរួមប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម អាចតាមរយៈអំពើអកម្មដែលដែលអាចនាំឱ្យមានពិរុទ្ធ[3807]។ តាមពិត ចំណុចនេះត្រូវបានទទួលស្គាល់តាំងពីក្រោយសង្គ្រាមលោកលើកទី ២ ពេលដែលច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ពីការទទួលខុសត្រូវចំពោះអំពើអកម្ម[3808]។ យុត្តិសាស្ត្រពីសាលាក្តី *ចំពោះកិច្ច* នានាក្រោយមក បានបញ្ជាក់ថា ជនជាប់ចោទអាចនឹងត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម តាមរយៈ "*សកម្មភាព ឬអំពើអកម្ម* ណាមួយដែលរួមចំណែកដល់គោលបំណងឧក្រិដ្ឋរួម"[3809]។

---

[3805] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៥៨-១៩៥៩ *ជំទាស់នឹង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០៣។

[3806] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (ការបដិសេធដោយសង្ខេប, កំហុចផ្នែកច្បាប់)។

[3807] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៥៨-១៩៥៩។

[3808] អនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ មាត្រា ១៣ ("អំពើខុសច្បាប់ ឬអំពើអកម្មណាមួយ តាមអំណាចឃាត់ខ្លួន ដែលបណ្តាលឱ្យស្លាប់ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពឈ្លើយសឹកដែលកំពុងជាប់ឃុំឃាំង ត្រូវបានហាមឃាត់ និងត្រូវបានចាត់ទុកថា ជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានេះ")។ បទវិចារណកថា អំពីអនុសញ្ញាទីក្រុងហ្សឺណែវលើកទី៣ ទំព័រ ៦២៦ (ការសម្លាប់ដោយចេតនា "ហាក់ដូចជាគ្រប់ដណ្តប់លើកំហុសនៃអំពើអកម្ម"។ បទវិចារណកថា អំពីអនុសញ្ញាទីក្រុងហ្សឺណែវលើកទី៤ ទំព័រ ៥៩៧ (ការសម្លាប់ដោយចេតនា "ហាក់ដូចជាគ្រប់ដណ្តប់លើករណីនៃការស្លាប់កើតឡើងតាមរយៈកំហុសនៃអំពើអកម្ម"។ ដូចគ្នានេះផងដែរ គោលបំណងនៃការផ្តល់បញ្ជីនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ គឺដើម្បីជាការជូនដំណឹងទៅជនល្មើសសក្តានុពលៈ "វាក៏ជាគំនិតប្រាប់ឱ្យដឹងអំពីការព្រមានដល់ជនល្មើសសក្តានុពលនូវបញ្ជីបទឧក្រិដ្ឋច្បាស់លាស់មួយថា អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋនឹងត្រូវស្វែងរកនៅគ្រប់ប្រទេសទាំងអស់")។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១១(២) (ហាក់ដូចជាទទួលស្គាល់ចំពោះការទទួលខុសត្រូវនៃអំពើអកម្មៈ គ្មានជនណាម្នាក់នឹងត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌណាមួយឡើយ ដោយផ្អែកលើសកម្មភាព ឬអំពើអកម្មណាមួយដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ [...] នៅពេលបទល្មើសនោះត្រូវបានប្រព្រឹត្ត")។

[3809] សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៩៥, ១៨៧, ជើងទំព័រ ៥០៣។ សាលដីកាក្នុងរឿងក្តី *Stanišić & Župljanin* កថាខណ្ឌ ១១០។

### *មូលដ្ឋានទី ២២៧, ២២៨, ២២៩, ២៣០, ២៣១៖ គាំទ្រ និងលើកកម្ពស់គោលបំណងរួម និងគោលនយោបាយនៃគោលបំណងនេះ លើកទឹកចិត្ត ញុះញង់ និងផ្តល់ធម្មានុរូបចំពោះការអនុវត្តគោលបំណងរួម ណែនាំ បង្កលទ្ធភាព និងត្រួតត្រាលើការអនុវត្ត*[3810]

1049. **មូលដ្ឋានទី ២២៧-២៣១ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខបរាជ័យមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ចំពោះការសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខ: (i) បានគាំទ្រជាសាធារណៈចំពោះគោលបំណងរួម នៅទូទាំងសម័យកម្ពុជាប្រជាធិតេយ្យ (មូលដ្ឋានទី ២២៧); (ii) ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ "បានចូលរួមលើកកម្ពស់ បញ្ជាក់ យល់ព្រមយ៉ាងសកម្ម យ៉ាងខ្លាំងក្លា និងជាសាធារណៈលើគោលបំណងរួម ទាំងនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ" (មូលដ្ឋានទី ២២៨); (iii) បានលើកទឹកចិត្ត និងញុះញង់ឱ្យមានការអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយនានារបស់ ប.ក.ក ដោយប្រើមុខតំណែងជាន់ខ្ពស់របស់ខ្លួន ក្នុងការផ្តល់ធម្មានុរូប ទាំងនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ" (មូលដ្ឋានទី ២២៩); (iv) បានផ្តល់ការណែនាំយ៉ាងសកម្មអំពីការអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយនានារបស់ ប.ក.ក (មូលដ្ឋានទី ២៣០); និង (v) បានផ្តល់លទ្ធភាព និងត្រួតត្រាដោយផ្ទាល់លើការអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយនានារបស់ ប.ក.ក (មូលដ្ឋានទី ២៣១)។**

---

[3810] <u>មូលដ្ឋានទី ២២៧៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការផ្តល់ការគាំទ្រដល់គោលបំណងរួមដូចបានចោទប្រកាន់* កថាខណ្ឌ ២០១២-១៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៦ (អង់គ្លេស), ទំព័រ ៧១ (បារាំង), ទំព័រ ១០៩-១១០ (ខ្មែរ)។ <u>មូលដ្ឋានទី ២២៨៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការលើកស្ទួយដល់គោលបំណងរួមដូចបានចោទប្រកាន់* កថាខណ្ឌ ២០១៨-២០២០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៧ (អង់គ្លេស), ទំព័រ ៧១ (បារាំង), ទំព័រ ១១០ (ខ្មែរ)។ <u>មូលដ្ឋានទី ២២៩៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការលើកទឹកចិត្ត ការញុះញង់ និង ការផ្តល់ធម្មានុរូបដល់ការអនុវត្តគោលបំណងរួមដូចបានចោទប្រកាន់* កថាខណ្ឌ ២០២១-២០២៤។ *សូមមើលផងដែរ* កថាខណ្ឌ ១៦៨៦-១៦៩០ & ២១៣០ (ការចុះពិនិត្យដល់ទីកន្លែង)។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៧ (អង់គ្លេស), ទំព័រ ៧២ (បារាំង), ទំព័រ ១១០ (ខ្មែរ)។ <u>មូលដ្ឋានទី ២៣០៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការណែនាំលើការអនុវត្តគោលបំណងរួមដូចបានចោទប្រកាន់* កថាខណ្ឌ ២០២៥-២០២៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៧ (អង់គ្លេស), ទំព័រ ៧២ (បារាំង), ទំព័រ ១១០-១១១ (ខ្មែរ)។ <u>មូលដ្ឋានទី ២៣១៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការជួយសម្រួល និងការត្រួតត្រាលើការអនុវត្តគោលបំណងរួមដូចបានចោទប្រកាន់* កថាខណ្ឌ ២០២៥-២០២៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៧ (អង់គ្លេស), ទំព័រ ៧២ (បារាំង), ទំព័រ ១១១ (ខ្មែរ)។ (ចំណងជើង ១៨.២.១.៥ នៃ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ ការប្រើពាក្យ "ផ្តល់លទ្ធភាព និងការត្រួតត្រាលើការអនុវត្ត។

1050. ម្ចាស់បណ្តឹងសាទុក្ខជំទាស់ថា កំហុសទាំងប្រាំ ដែលបានចោទប្រកាន់នេះ រួមមាន កំហុសតូចៗ ចំនួន ១៦ ទៀត ដែល អ.ជ.ស.ដ បានបង្កើតឡើង។ ភាគច្រើន ម្ចាស់បណ្តឹងសាទុក្ខមិនបាន បង្ហាញទទ្បីករណ៍ថ្មីណាមួយទាក់ទងនឹងកំហុស និងកំហុសតូចៗទាំងនេះទេ ក្រៅតែអំពីការយោង ទៅផ្នែកសំខាន់ៗផ្សេងទៀតនៅក្នុងសារណារបស់គាត់។ ផ្អែកលើមូលហេតុដូចបានកំណត់យ៉ាង ពិស្តារនៅក្នុងផ្នែកផ្សេងទៀតនៃចម្លើយតបនេះ កំហុសដែលបានចោទប្រកាន់ទាំងនេះ មិនបាន បង្ហាញទេ ពាក់ព័ន្ធនឹងការសន្និដ្ឋានខាងក្រោមរបស់ អ.ជ.ស.ដ ដែលថា ម្ចាស់បណ្តឹងសាទុក្ខ៖

(ក) បានផ្តល់ការគាំទ្រដល់ ប.ក.ក និងគោលនយោបាយបក្ស យ៉ាងហោចណាស់តាំងពីឆ្នាំ ១៩៦៧[3811] (មូលដ្ឋានទី ២២៧)។ ទទ្បីករណ៍នេះបរាជ័យ ដោយសារ អ.ជ.ស.ដ បាន ផ្តល់សំអាងហេតុយ៉ាងលម្អិតសម្រាប់ការសម្រេចរបស់ខ្លួន ដោយផ្អែកលើភស្តុតាងដ៏ច្រើន សន្ធឹកសន្ធាប់ ហើយម្ចាស់បណ្តឹងសាទុក្ខខានមិនបានបង្ហាញពីកំហុសនៃអង្គហេតុដែល អាចថាការសម្រេចទាំងនេះថាគ្មានមូលហេតុសមស្រប និងនាំឱ្យមានការខុសឆ្គោយរបស់ តុលាការ[3812]។

(ខ) បានផ្តល់ការគាំទ្រដល់គោលបំណងរួម ដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទោះបីគោលដៅ បដិវត្តន៍របស់ ប.ក.ក ខ្លួនវាផ្ទាល់ មិនមែនមានលក្ខណៈឧក្រិដ្ឋក៏ដោយ[3813] (មូលដ្ឋានទី

[3811] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០១២ *យោង* កថាខណ្ឌ ១៦៦០-១៦៦៤ (សមាជិក ប.ក.ក), ១៧០៤-១៧៥៣ (សមាជិកគណៈកម្មាធិការមជ្ឈិម/គណៈកម្មាធិការអចិន្ត្រៃយ៍)។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧។

[3812] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៩៨ (១៩៧០-១៩៧៥), ១៩០ (ការជម្លៀសប្រជាជន), ១៩៩ (កិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិម ឆ្នាំ១៩៧៤-១៩៧៥), ២០៤ (វគ្គបំពាក់បំប៉ន), ១៩២ (តួនាទីនៅក្នុងសហករណ៍), ២២២ ("គោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍), ២០៣ ("សមាជិក"គណៈកម្មាធិការមជ្ឈិម/គណៈកម្មាធិការអចិន្ត្រៃយ៍), ២០០ (ទីកន្លែងការងារ និងភាពជិតស្និទ្ធជាមួយមេដឹកនាំ), ១៩០ (មជ្ឈិមបក្ស), ១៩១ (អង្គការ), ២០៥ (មន្ទីរ ៨៧០), ២០៦ (គណៈកម្មាធិការពាណិជ្ជកម្ម), ១៩៦ & ១៩៧ (សមាជិក ប.ក.ក), ២០២ (ប្រធានគណៈប្រធានរដ្ឋ)។

[3813] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០១៣ *យោង* កថាខណ្ឌ ៤២៥៧ (ម្ចាស់បណ្តឹងសាទុក្ខអះអាងថា មុខងារជាបន្តរបស់គាត់នៅក្នុងមុខតំណែងនៃ ប.ក.ក/កម្ពុជាប្រជាធិបតេយ្យ មិនអាចនាំទៅដល់ការសម្រេចថា គាត់បានផ្តល់ ការគាំទ្រដល់គោលបំណងរួមទាំងមូលដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ), កថាខណ្ឌ ២០១៥ ជើងទំព័រ ៣៨៨៦ *យោង* កថាខណ្ឌ ១៤៨៩-១៥២២ ("គោលនយោបាយ" ស្តីពីសហករណ៍ និងការដ្ឋាន) (ម្ចាស់បណ្តឹងសាទុក្ខតវ៉ាថា ការយល់ ស្របជាមួយទិសដៅបង្កបង្កើនផលស្រូវឱ្យបានបីតោនក្នុងមួយហិកតា ការអនុមតិជាសាធារណៈនូវរដ្ឋធម្មនុញ្ញរបស់កម្ពុជា ប្រជាធិបតេយ្យ និងឆន្ទៈក្នុងការផ្លាស់ប្តូរប្រជាជនទាំងមូលទៅក្នុងសង្គមកម្មករ-កសិករ មិនអាចកំណត់បានថា គាត់គាំទ្រចំពោះ ទិដ្ឋភាពឧក្រិដ្ឋណាមួយនៃគោលបំណងរួមឡើយ)។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧-៤២៥៩។

២២៧)។ យ៉ាងណាមិញ ទឡ្ហីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្ដឹងសាទុក្ខ មិនបាន បង្ហាញភ័ស្តុតាងអំពីកំហុសណាមួយ ទាក់ទងនឹងចរិកលក្ខណៈនៃគោលនយោបាយខុសៗ គ្នានៃគោលបំណងរួម[3814]។

(គ) បានផ្ដល់ការគាំទ្រដល់គោលបំណងរួម តាមរយៈការបង្ហាញខ្លួន និងចូលរួមដោយផ្ទាល់ នៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំនានា ពាក់ព័ន្ធនឹងមាគ៌ានយោបាយរួមរបស់ ប.ក.ក ការកំណត់ អត្តសញ្ញាណ និងការបោសសម្អាតខ្មាំង និងលក្ខខណ្ឌផ្សេងៗនៅក្នុងសហករណ៍ និង ការដ្ឋាន រួមទាំងនៅពេលានយន្តហោះកំពង់ឆ្នាំង[3815](មូលដ្ឋានទី ២២៧)។ ទឡ្ហីករណ៍ នេះបរាជ័យ ដោយសារម្ចាស់បណ្ដឹងសាទុក្ខ មិនបានបង្ហាញភ័ស្តុតាងអំពីកំហុសណាមួយ ទាក់ទងនឹងការវាយតម្លៃលើភ័ស្តុតាងលើសលប់ ដែលគាំទ្រដល់ការបង្ហាញខ្លួន និងចូលរួម ដោយផ្ទាល់របស់គាត់នៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំ ប.ក.ក ជាកន្លែងដែលគោលនយោបាយ នានាត្រូវបានអនុមតិ និងសម្រេចទៅលើការបោសសម្អាត[3816]។

(ឃ) ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិម បានផ្ដល់ការអនុមតិលើការធ្វើប្រតិភូកម្ម “សិទ្ធិកម្ទេច” ក្នុងជួរ ប.ក.ក បានរួមចំណែកដល់ការបោះពុម្ពផ្សាយអនុស្សរណៈឆ្នាំ១៩៧៨ ដែលរើសអើងប្រឆាំងនឹងជនជាតិវៀតណាម និងបានចូលរួមក្នុងសមាជបក្សលើកទី ៥ ពេលដែល វន វ៉ែត ត្រូវបានចាប់ខ្លួនបញ្ជូនទៅ ស-២១[3817] (មូលដ្ឋានទី ២២៧)។

---

[3814] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤ (គោលបំណងរួម), ១៨០, ១៨២ (“គោលនយោបាយ” ស្ដីពីសហករណ៍ និងការដ្ឋាន), ១៨៤ (គោលនយោបាយស្ដីពីមន្ទីរសន្តិសុខ), ១៨៨ (គោលនយោបាយចំពោះពុទ្ធសាសនិកជន), ១៨៧ (គោលនយោបាយប្រឆាំងកម្មាភិបាលខ្មែរក្រហមមុនៗ)។

[3815] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០១៤ *យោង* កថាខណ្ឌ ១៨៦៧-១៨៦៨ (ជូ ជេត), ១៨១៦-១៨៤៨ (សហករណ៍ និង ការដ្ឋាន), ១៧៤៩-១៧៥៣ (មជ្ឈិមដ្ឋានប្រជាធិបតេយ្យ), ១៦៩០-១៨០៣ (កំហុសទាក់ទងនឹងតួនាទីនៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ)។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៨-៤២៥៩។

[3816] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ២០៣ (“សមាជិក”គណៈកម្មាធិការមជ្ឈិម/គណៈកម្មាធិការអចិន្ត្រៃយ៍), ១៩៤ (វចនាសម្ព័ន្ធ និងការប្រាស្រ័យទំនាក់ទំនងយោធា), ១៩៨ (១៩៧០-១៩៧៥), ១៩២ (តួនាទីនៅក្នុងសហករណ៍), ២០១ (កិច្ចប្រជុំនានាក្នុងឆ្នាំ១៩៧៤-១៩៧៥), ១៩៦ & ១៩៧ (សមាជិក ប.ក.ក), ២១៦, ២១៧, ២៣៥ (ចំណេះដឹងអំពីការបោសសម្អាត), ២១១ (ចំណេះដឹងអំពីសហករណ៍ និង ការដ្ឋាន)។

[3817] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០១៦, ជើងទំព័រ ៣៨៨៧, ៣៨៨៩, ៣៨៩១-៣៨៩២ *យោង* កថាខណ្ឌ ១៧០៤-១៧៥៣ (សមាជិកគណៈកម្មាធិការមជ្ឈិម/គណៈកម្មាធិការអចិន្ត្រៃយ៍), ៨២៨-៨៣៥ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍), ១៨៥១-១៨៥៣ (កង្វះការយល់ដឹងអំពីឧក្រិដ្ឋកម្ម ស-២១), ១៨៦៩-១៨៧១។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦០។

ទទ្បីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភស្តុតាងអំពីកំហុសណាមួយទាក់ទងនឹងការវាយតម្លៃលើភស្តុតាងគាំទ្រសមាជិកភាពរបស់គាត់ នៅក្នុងគណៈកម្មាធិការមជ្ឈិម និងសេចក្តីសម្រេច សេចក្តីណែនាំ និង*អនុស្សរណៈ* ដែលគណៈកម្មាធិការមជ្ឈិមបានចេញ និងការចូលរួមរបស់គាត់ក្នុងសមាជបក្សលើកទី៥[3818]។

(ង) ត្រូវបានបញ្ចេញឱ្យដឹងឈ្មោះថាជាប្រធានសមាជជាតិពិសេស ខែមេសា ឆ្នាំ១៩៧៥ ក្នុងរបាយការណ៍នានាដែលពិពណ៌នាយ៉ាងលម្អិតពីគោលដៅបដិវត្តន៍ ប.ក.ក[3819] (មូលដ្ឋានទី ២២៨)។ ទទ្បីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភស្តុតាងអំពីកំហុសណាមួយដែល អ.ជ.ស.ដ បានប្រព្រឹត្ត នៅក្នុងសេចក្តីសម្រេចដែលថា ទោះបីមានមន្ទិលផ្សេងៗទាក់ទងនឹងការប្រារព្ធសមាជជាតិពិសេសនេះក្តី ការលើកឡើងពីការទទួលខុសត្រូវលើម្ចាស់បណ្តឹងសាទុក្ខចំពោះព្រឹត្តិការណ៍នេះ នៅក្នុងការផ្សាយតាមវិទ្យុជាផ្លូវការ និងការទទួលយករបស់គាត់ចំពោះការលើកឡើងនេះ បានផ្តល់ធម្មានុរូបដល់មាគ៌ាគោលនយោបាយ ប.ក.ក ជាអន្តរជាតិ[3820]។

(ច) បានចូលរួមក្នុងកិច្ចប្រជុំនានាដែលធ្វើឡើងនៅវត្តព្រះកែវមរកត នៅភ្នំពេញ ក្នុងខែឧសភា ឆ្នាំ១៩៧៥ ដែលជាការងារសំខាន់ៗជាមូលដ្ឋានសម្រាប់បដិវត្តន៍សង្គមនិយមតាមរយៈគោលនយោបាយនានា ដែលរួមមាន ការជម្លៀសប្រជនជន ឬការបង្កើតសហករណ៍ និងការដ្ឋានជាដើម[3821](មូលដ្ឋានទី ២២៨)។ ទទ្បីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខ មិនបានបង្ហាញភស្តុតាងអំពីកំហុសណាមួយដែល អ.ជ.ស.ដ បានប្រព្រឹត្តក្នុងការវាយតម្លៃលើភស្តុតាងដែលគាំទ្រដល់ការសម្រេចថា ការសម្រេច "គោលដៅបដិវត្តន៍

---

[3818] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ២០៣ (សមាជិកគណៈកម្មាធិការមជ្ឈិម/គណៈកម្មាធិការអចិន្ត្រៃយ៍), ១៨៤ (គោលនយោបាយមន្ទីរសន្តិសុខ), ២១៦, ២១៧ & ២៣៥ (ការយល់ដឹងអំពីការបោសសម្អាត)។

[3819] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០១៨ (ជើងទំព័រ ៣៨៩៦) *យោង* កថាខណ្ឌ ១៦៩០-១៦៩១។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២, ៣៧៣៥។

[3820] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ២០១ (កិច្ចប្រជុំនានាក្នុងឆ្នាំ ១៩៧៤-១៩៧៥), ១៧៦ (ខ្លឹមសារនៃ "បដិវត្តន៍សង្គមនិយម")។

[3821] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០១៩ (ជើងទំព័រ ៣៨៩៨) *យោង* កថាខណ្ឌ ១៧៥៤-១៨០៣ (មុខងារដែលនៅសេសសល់ ជាវាក្យខណ្ឌមួយហាក់ដូចជាមិនមានការពាក់ព័ន្ធណាមួយទៅនឹងកិច្ចប្រជុំនៅវត្តព្រះកែវមរកត), ១៤៩០-១៥២២ ("គោលនយោបាយ" អំពីសហករណ៍ និងការដ្ឋាន)។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២។

សង្គមនិយមដែលគ្មានលក្ខណៈឧក្រិដ្ឋ” មានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ដែលស្ថិតនៅក្នុងគោលបំណងរួម[3822]។

(ឆ) ក្នុងនាមប្រធានគណៈប្រធានរដ្ឋ បានអនុមតិ និងលើកស្ទួយគោលបំណងនៃការសម្រេចបាន “មហាលោតផ្លោះមហាអស្ចារ្យ” ក្នុងការកសាង និងការពារប្រទេស[3823](មូលដ្ឋានទី ២២៨)។ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានភ្ជាប់ដោយមិនត្រឹមត្រូវទៅសុន្ទរកថាមួយដែលបានធ្វើឡើងនៅឯសភាតំណាងប្រជាជន នៅចន្លោះថ្ងៃទី ១១ និង១៣ ខែមេសា ឆ្នាំ១៩៧៦ ទៅនឹងម្ចាស់បណ្តឹងសាទុក្ខនោះ មិនតម្រូវឱ្យមានកិច្ចអន្តរាគមន៍ពី អ.ជ.ត.ក ទេ ដោយសារវាមិនមានការប៉ះពាល់ដល់សាលក្រម ឬជាការសម្រេចលើអង្គហេតុសំខាន់ឡើយ។ អ.ជ.ត.ក បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានអនុមតិ និងលើកស្ទួយមាគ៌ាគោលនយោបាយ ប.ក.ក មែន មិនត្រឹមតែក្នុងនាមជាប្រធានគណៈប្រធានរដ្ឋដែលបានថ្លែង និងអនុមតិសុន្ទរកថាប៉ុណ្ណោះទេ ថែមទាំងក្នុងនាមជាអ្នកចូលរួមក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងសមាជបក្ស ក្នុងនាមជាអ្នកបង្រៀន និងអ្នកចូលក្នុងវគ្គបំពាក់បំប៉ន និងថា កំហុសដែលបានចោទនេះនឹងធ្វើឱ្យមានការខុសឆ្គោយរបស់តុលាការ[3824]។

(ជ) នៅក្នុងសុន្ទរកថា បានកោតសើរសើរអំពីជ័យជំនះរបស់ ប.ក.ក និងបានលើកទឹកចិត្តឱ្យមហាជនគាំទ្រ*កម្មវិធី* របស់អង្គការ ក្នុងកសាង និងការពារកម្ពុជាប្រជាធិបតេយ្យ[3825] (មូលដ្ឋានទី ២២៨)។ ទឡ្ហីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខ មិនបាន

---

[3822] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៨១, ២៨៣ & ១៨០ (គោលនយោបាយស្តីពីសហករណ៍ និងការដ្ឋាន), ២៤៦ (ធាតុផ្សំសត្យានុម័តិនៃការជួយនិងជំរុញដោយចេតនាប្រយោល) នៃការធ្វើមនុស្សឃាតនៅសហករណ៍ និងការដ្ឋាន), ២២០ & ២៤២ (ពុទ្ធសាសនិកជន), ២២១ (កម្មាភិបាលខ្មែរក្រហមមុនៗ, ចំណេះដឹង), ២៤៣ (កម្មាភិបាលខ្មែរក្រហមមុនៗ, ចេតនា)។

[3823] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២០ (ជើងទំព័រ ៣៩០០) *យោង* កថាខណ្ឌ ១៤០៨-១៤៣៧, ១៧៥៤-១៨០៣, ១៤៩០-១៥២២។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២, ៣៧៣៩។

[3824] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ២០២ (ប្រធានគណៈប្រធានរដ្ឋ), ២០៣ (សមាជិកគណៈកម្មាធិការមជ្ឈិម/គណៈកម្មាធិការអចិន្ត្រៃយ៍)។ *សូមមើលផងដែរ* ២៣៤ (សហករណ៍ និងការដ្ឋាន, ចេតនា), ១៧ (បន្ទុកនៃភ័ស្តុតាង), ១៧៦ (ខ្លឹមសារនៃបដិវត្តន៍សង្គមនិយម)។

[3825] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២០ (ជើងទំព័រ ៣៩០១) *យោង* កថាខណ្ឌ ១៧៥៤-១៨០៣ (មុខងារដែលនៅសេសសល់។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៣ *យោងក* ថាខណ្ឌ ៣៧៤២, ៥៩៨, ៤២៧១-៤២៧៤។

បង្ហាញភ័ស្តុតាងអំពីកំហុសណាមួយថា ខ្លឹមសារនៃសុន្ទរកថារបស់គាត់អំពីគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក ត្រូវបានមួលបង្កាច់ ឬបំភ្លៃដោយ អ.ជ.ស.ដ ទេ[3826]។

(ឈ) បានផ្តល់ការគាំទ្រដល់ការលុបបំបាត់ពុទ្ធសាសនា ដោយការបង្ហាញសាធារណជននូវឥរិយាបថ "បំភាន់" ក្នុងគោលបំណងរក្សារូបភាពធម្មតា[3827] (មូលដ្ឋានទី ២២៩)។ ទឡ្ហីករណ៍នេះបរាជ័យ ដោយហេតុថា អ.ជ.ស.ដ បានផ្តល់សំអាងហេតុយ៉ាងលម្អិតផ្អែកលើភ័ស្តុតាងជាច្រើនសម្រាប់សេចក្តីសម្រេចដែលមានសំអាងហេតុ ដែលបញ្ជាក់ថា គាត់បានគាំទ្រដល់ការបំបាត់ពុទ្ធសាសនា ទោះបីជាគាត់បដិសេធក៏ដោយ[3828]។

(ញ) បានបដិសេធជាសាធារណៈ និងព្យាយាមបិទបាំងឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងកម្មាភិបាលខ្មែរក្រហមមុនៗ[3829] (មូលដ្ឋានទី ២២៩)។ ទឡ្ហីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភ័ស្តុតាងណាមួយដែលថា អ.ជ.ស.ដ បាន

---

[3826] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ២០២ (ប្រធានគណៈប្រធានរដ្ឋ), ២០៤ (វគ្គបំពាក់បំប៉ន), ១៨២ (សហករណ៍ និងការដ្ឋាន), ២៤៣ (កម្មាភិបាលខ្មែរក្រហមមុនៗ, ចេតនា), ២១៩ (ជនជាតិវៀតណាម, ចំណេះដឹង), ២៣៤ (សហករណ៍ និងការដ្ឋាន, ចេតនា), ២១៦, ២១៧ & ២៣៥ (មន្ទីរសន្តិសុខ, ចេតនា), ១៨៥ (គោលនយោបាយស្តីពីជនជាតិវៀតណាម), ១៦៦ (ភ័ស្តុតាងស្តីពីការរៀបអាពាហ៍ពិពាហ៍)។ ជាការបន្ថែម ម្ចាស់បណ្តឹងសាទុក្ខ មិនតវ៉ាចំពោះការរកឃើញយ៉ាងសំខាន់ដែលថា "គាត់បានបន្តគោរពមាគ៌ាបក្ស ដោយបានដឹកនាំវគ្គបំពាក់បំប៉ននៅក្នុងអគ្គមីទ្ទីង និងវគ្គសិក្សាអបរំ" ក្នុងគោលដៅ "បង្កើតការគាំទ្រគោលនយោបាយ ប.ក.ក" (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦២)។

[3827] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២៣ *យោង* កថាខណ្ឌ ១៩១០-៩២០, ២០៩៤។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៨ (ម្ចាស់បណ្តឹងសាទុក្ខបានជំរុញឱ្យប្រជាជនទូទៅផ្ទេរចេតនាចំពោះឪពុកម្តាយរបស់ខ្លួនមកអង្គការ ដោយលើកទឹកចិត្តឱ្យមានការរៀបចំការរៀបអាពាហ៍ពិពាហ៍ប្រឆាំងនឹងទំនៀមទម្លាប់ព្រះពុទ្ធសាសនាដើម្បីបង្កើនចំនួនប្រជាជនកម្ពុជាប្រជាធិបតេយ្យឱ្យបានឆាប់រហ័ស និងបានគាំទ្រក្នុងការលុបបំបាត់ព្រះពុទ្ធសាសនា), *យោង* កថាខណ្ឌ ៤២៤០-៤២៤២, ៤២៤៨)។

[3828] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ២២០ & ២៤២ (ពុទ្ធសាសនិកជន, ចំណេះដឹង), ១៨៨ (គោលនយោបាយចំពោះពុទ្ធសាសនិកជន), ១០៩ (ការធ្វើទុក្ខបុកម្នេញពុទ្ធសាសនិកជន, ធាតុផ្សំសត្យានុម័តិ)។

[3829] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២៣ *យោង* កថាខណ្ឌ ១៩២១-១៩២៧, ២០៩៩-២១១៣។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៨ (ម្ចាស់បណ្តឹងសាទុក្ខបានបដិសេធ និងស្វែងរកជាសាធារណៈដើម្បីបិទបាំងឧក្រិដ្ឋកម្មប្រឆាំងកម្មាភិបាលខ្មែរក្រហមមុនៗ"), *យោង* កថាខណ្ឌ ៤២៥២-៤២៥៣។

ប្រព្រឹត្តកំហុសក្នុងការវាយតម្លៃលើភ័ស្តុតាងអំពីអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងកម្មាភិបាលខ្មែរក្រហមមុនៗ និងការយល់ដឹង ព្រមទាំងចេតនារបស់គាត់អំពីឧក្រិដ្ឋកម្មទាំងនោះ[3830]។

(ង) បានញុះញង់ឱ្យមានការស្អប់ខ្ពើមប្រឆាំងនឹងជនជាតិវៀតណាមនៅក្នុងសុន្ទរកថានានា[3831] (មូលដ្ឋានទី ២២៩)។ ទឡ្ហីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភ័ស្តុតាងណាមួយដែលថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការសម្រេចដែលថាម្ចាស់បណ្តឹងសាទុក្ខបានញុះញង់យ៉ាងសកម្មឱ្យប្រជាជនស្អប់ជនជាតិវៀតណាម បានលើកទឹកចិត្តឱ្យមាន "ការប្រព្រឹត្តិដោយរើសអើង" ព្រមទាំងបានសន្យា និងអំពាវឱ្យកម្ទេចពួកគេ និងភ្នាក់ងាររបស់ពួកគេ ដោយសារ "ការម្ទេចពួកគេ គឺជាការចាំបាច់ដើម្បីថែរក្សា "ជាតិ និងពូជសាសន៍កម្ពុជាជារៀងរហូត"[3832]។

1051. អាស្រ័យដូចបានលើកឡើងយ៉ាងលម្អិតនៅក្នុងផ្នែកផ្សេងៗទៀតនៃចម្លើយតបនេះ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានបង្ហាញផងដែរអំពីអត្ថិភាពនៃកំហុសផ្សេងៗទៀត ដែលខ្លួនបានចោទថា អ.ជ.ស.ដ បានប្រព្រឹត្តនៅក្នុងការវាយតម្លៃលើភ័ស្តុតាង ជាពិសេស ៖

(ក) ក្នុងការយល់ដឹងអំពីគោលនយោបាយស្តីពីសហករណ៍ និងការដ្ឋាន និងការបកស្រាយលើភ័ស្តុតាងទាក់ទងនឹងចំណុចទាំងនេះ រួមទាំង ការចុះពិនិត្យដល់ទីកន្លែងរបស់ម្ចាស់បណ្តឹងសាទុក្ខ និងសេចក្តីថ្លែងការណ៍ក្រោយកម្ពុជាប្រជាធិបតេយ្យ[3833] (មូលដ្ឋានទី ២២៩)។

---

[3830] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៨៧ (គោលនយោបាយចំពោះកម្មាភិបាលខ្មែរក្រហមមុនៗ"), ១០៦ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើកម្មាភិបាលខ្មែរក្រហមមុនៗ"), ២២១ (កម្មាភិបាលខ្មែរក្រហមមុនៗ, ចំណេះដឹង), ២២១ (កម្មាភិបាលខ្មែរក្រហមមុនៗ, ចេតនា)។

[3831] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២៣ *យោងឧទាហរណ៍* កថាខណ្ឌ ១០៥៨-១០៩៧, ១៥៥១-១៥៦០, ១៨៨០-១៩០៩, ២០៧៥-២០៩០។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៩ *យោង* កថាខណ្ឌ ៣៣៩៤, ៣៣៩៩, ៣៤០១, ៣៤០៤, ៣៤០៦, ៣៤០៨។

[3832] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៨៥ (គោលនយោបាយលើជនជាតិវៀតណាម), ២១៩ (ជនជាតិវៀតណាម, ចំណេះដឹង), ២៤០ (ចេតនានៃអំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិវៀតណាម)។

[3833] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២១-២០២២ (ជើងទំព័រ ៣៩០៥, ៣៩១០) *យោង* កថាខណ្ឌ ១៣៩៩-១៦០៣, ២១៣០, ១៨១៦-១៨៤៨។ *សូមមើលផងដែរ* កថាខណ្ឌ ១៦៨០-១៦៨៩។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៥-៤២៦៦ (ម្ចាស់បណ្តឹងសាទុក្ខបានលើកទឹកចិត្តដល់ការងារសមូហភាពនៅតាមមូលដ្ឋាន រោងចក្រ និងការដ្ឋានសំណង់ "តាមជំហានដែលមិនធ្លាប់សម្រេចបានពីមុនមក") និងបានបន្តធ្វើដូច្នេះរហូតដល់ចុងនៃរបបនេះ ទោះបីជាគាត់ដឹងអំពី "ស្ថានភាពដ៏គួររន្ធត់ របបការងារដែលមានសភាពអាប់អួ និងអាហារមិនគ្រប់គ្រាន់" អនាម័យ និង សុខភាពជាមូលហេតុក៏ដោយ) *យោង* វាក្យខណ្ឌ ១៦ *គោលបំណងរួម* រួមទាំង កថាខណ្ឌ ៣៨៩៧, ៣៩០៩, ៣៩១៦, ៣៩១៩-៣៩២៧

ទទ្បីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភ័ស្តុតាងណាមួយទាក់ទងនឹងគោលបំណងរួម និងគោលនយោបាយនានារបស់វាទេ រួមទាំង គោលនយោបាយស្តីពីសហករណ៍ និងការដ្ឋាន ឬ ការបកស្រាយរបស់ អ.ជ.ស.ជ លើភ័ស្តុតាងទាំងនោះ[3834]។

(ខ) ក្នុងការពឹងផ្អែកលើសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ[3835] (មូលដ្ឋានទី ២២៩)។ ទទ្បីករណ៍នេះបរាជ័យ ដោយសារមិនបានបង្ហាញពីកំហុសទាក់ទាក់ទងនឹងការប្រើប្រាស់តិចតួចរបស់ អ.ជ.ស.ជ លើសេចក្តីថ្លែងការណ៍របស់សម្តេច សីហនុ ធ្វើជាភ័ស្តុតាងបញ្ជាក់ទៅលើប្រធានបទជាក់លាក់មួយចំនួន[3836]។

(គ) ក្នុងការវាយតម្លៃលើសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងបញ្ហាគ្រួសារ ផែនការបង្កើនប្រជាជន និងការរៀបអាពាហ៍ពិពាហ៍[3837] (មូលដ្ឋានទី ២៣០)។ ទទ្បីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញភ័ស្តុតាងណាមួយរបស់ អ.ជ.ស.ជ ក្នុងការប្រើប្រាស់ និងវាយតម្លៃលើសេចក្តីថ្លែងការណ៍កម្ពុជាប្រជាធិបតេយ្យរបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅលើប្រធានទាំងនេះទេ ដែលជាផ្នែកមួយនៃអភិក្រមវាយតម្លៃលើភ័ស្តុតាងទាំងមូលរបស់ អ.ជ.ស.ជ[3838]។

---

(វាក្យខណ្ឌ ១៦.៤.១.២ *ឧក្រិដ្ឋភាពនៃគោលនយោបាយ*), ៤២១៤-៤២១៧, ១៥០៨។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៧ (ម្ចាស់បណ្តឹងសាទុក្ខបានចេញសេចក្តីថ្លែងការណ៍នានាដែលចាប់បង្ខំប្រជាជនទូទៅឱ្យ "បំពេញឱ្យបាន ឬឱ្យលើស" នូវផែនការសេដ្ឋកិច្ចបួនឆ្នាំរបស់អង្គការ និង "ទ្រទ្រង់ គ្រប់ស្ថានការណ៍" តាមការកំណត់របស់បក្ស រួមទាំងការនាំចេញអង្ករ), *យោង* កថាខណ្ឌ ៣៧៤២។

[3834] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤ (គោលបំណងរួម), ១៨១ & ១៨៣, ២១១ (គោលនយោបាយស្តីពីសហករណ៍ និងការដ្ឋាន និងតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខ), ២០០ (ការចុះពិនិត្យដល់ទីកន្លែង), ២៧, ២១៧ (ការប្រើប្រាស់សេចក្តីថ្លែងការណ៍ក្រោយកម្ពុជាប្រជាធិបតេយ្យ)។

[3835] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២១ *យោង* កថាខណ្ឌ ២៩៣-៣០៥។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០១, ៣៥៧១, ៣៥៨៦, ៤២៤៨, ៤២៦៩, ៦០៦)។

[3836] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ២១០, ២២២, ១៧០ (បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍), ១៨៥ (ជនជាតិវៀតណាម), ២០០ (លក្ខខណ្ឌផ្សេងៗនៅតាមសហករណ៍ និងការដ្ឋាន)។

[3837] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២២-២០២៣ *យោង* កថាខណ្ឌ ១០៩៨-៣៩៨។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥២២-៧០១, ៤០៦២-៤០៦៧។

[3838] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៦៦ (ផែនការបង្កើនចំនួនប្រជាជន), ១៧០ (ការគំរាមកំហែង និងការបង្ខិតបង្ខំ), ២១០ & ២២២ (ចំណេះដឹងអំពីឧក្រិដ្ឋកម្ម)។

(ឃ) ទាក់ទងនឹងសេចក្ដីណែនាំរបស់ម្ចាស់បណ្ដឹងសាទុក្ខស្ដីពីការអនុវត្តគោលបំណងរួម[3839] (មូលដ្ឋានទី ២៣០) ក្នុងការពឹងផ្អែកលើភ័ស្ដុតាងសក្ខីកម្មដែលត្រូវបានចោទថាទទួលបានក្រៅក្របខណ្ឌច្បាប់[3840] ដែលត្រូវចោទថាមិនអាចឱ្យទុកចិត្តបាន[3841] មួលបង្កាច់[3842] ឬជាភ័ស្តុតាងមានតែរបាយការណ៍ FBIS និង SWB[3843]។ ទឡ្ហីករណ៍នេះបរាជ័យ ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានធ្វើឱ្យខូចតម្លៃភាពនៃសក្ខីកម្មរបស់ នៅ សារុន, ឯក ហេន, អែម អឿន, ព្រាប ឌុន, ប៊ិត ណា និង ជា ដៀប និងរបាយការណ៍របស់ FBIS និង SWB ដែល អ.ជ.ស.ដ បានយោងដល់ដើម្បីគាំទ្រដល់ការសម្រេចរបស់ខ្លួនទាក់ទងនឹងសេចក្ដីណែនាំរបស់ម្ចាស់បណ្ដឹងសាទុក្ខ ស្ដីពីការអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយនានារបស់ ប.ក.ក[3844]ទេ។

---

[3839] ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ អ.ជ.ស.ដ បានធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវថា តាមរយៈសុន្ទរកថាជាសាធារណៈនិងសេចក្ដីថ្លែងការណ៍ជាច្រើនក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ម្ចាស់បណ្ដឹងសាទុក្ខបានណែនាំឱ្យកម្មាភិបាលនិងប្រជាជន ប.ក.ក អនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយនានារបស់ ប.ក.ក រួមទាំង ការនិរទេស និងការកម្ទេចជនជាតិវៀតណាម (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧១) ការស្រាវជ្រាវរក "ខ្មាំង" ជាពិសេសក្នុងចំណោមកម្មាភិបាលខ្មែរក្រហមមុនៗ ពួកក្បត់ ជនបង្កប់ អ្នកខ្ជិលធ្វើការ និងប្រជាជនថ្មី (កថាខណ្ឌ ៤២៧២-៤២៧៣), ភាពចាំបាច់ក្នុងការបំពេញទិសដៅបង្កបង្កើនផល ទោះក្នុងតម្លៃណាក៏ដោយ (កថាខណ្ឌ ៤២៧៣) និងការរៀបការរៀបអាពាហ៍ពិពាហ៍នៅតាមក្រសួងនានា (កថាខណ្ឌ ៤២៧៣)។

[3840] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០២៥ *យោង* កថាខណ្ឌ ១៨៩៤ (នៅ សារ៉េម)។

[3841] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០២៥ *យោង* កថាខណ្ឌ ១០៨០-១០៨២, ១៨៩៨-១៩០២ (ភាពជឿជាក់បាននៃឯកសារដែលបានផ្សព្វផ្សាយដោយ "*le Comité des Patriotes du Kampuchéa Démocratique*"), ២០២៦ *យោង* កថាខណ្ឌ ១០៧៥, ១៧៥៩, ១៨៩២-១៨៩៤ (ឯក ហេន), ២០២៧ (ជើងទំព័រ ៣៩៣២) *យោង* កថាខណ្ឌ ១៥៣៤-១៥៣៥ (ព្រាប ឌុន), ២០២៨ (ជើងទំព័រ ៣៩៤០) *យោង* កថាខណ្ឌ ១២៣៣-១២៤២, ១៨១៥, ១៩២៩, ១៩៣៦, ២០២៨, ២១១៧ (ជា ដៀប)។

[3842] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០២៧ (ជើងទំព័រ ៣៩៣៦) *យោង* កថាខណ្ឌ ១៧៩៤-១៧៩៧ (ប៊ិត ណា)។

[3843] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០២៨ (ជើងទំព័រ ៣៩៣៧-៣៩៣៨) *យោង* កថាខណ្ឌ១៨៩៨-១៩០២។

[3844] *សូមមើលឧទាហរណ៍* មូលដ្ឋានទី ២១៩, ២៣៧ (ភាពជឿជាក់បានរបស់ នៅ សារ៉េម), ២០, ២៣, ៣៤, ១៥៩, ២០៤, ២០៤ & ២១៩, ២៣៧ (ភាពជឿជាក់បានរបស់ ឯក ហេន), ២២, ៣៤, ១៨៤, ១៦៣, ២០៤, ២១៧ (ភាពជឿជាក់បានរបស់ អែម អឿន), ១៨៤, ២៧, ២៤៣ (ភាពជឿជាក់បានរបស់ ព្រាប ឌុន), ២០៦ (ភាពជឿជាក់បានរបស់ ប៊ិត ហឿន ហៅ ប៊ិត ណា), ១៦៦, ២៥, ៣៤, ១៧៣, ១៧៤, ២១០, ១៦៦ (ភាពជឿជាក់បានរបស់ ជា ដៀប) (*សូមមើលផងដែរ* ឯកសារ **F51/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ

(ង) ទាក់ទងនឹងការផ្តល់លទ្ធភាពរបស់ម្ចាស់បណ្តឹងសាទុក្ខឱ្យរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យដំណើរការយ៉ាងរលូនក្នុងទិសដៅបំផ្លាញប្រជាជន និងកម្មាភិបាលខ្លួនឯង"[3845] (មូលដ្ឋានទី ២៣០) ក្នុងការពឹងផ្អែកមិនត្រឹមត្រូវលើ មុខងាររបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទិននឹងមន្ទីរ ៨៧០ និងពាណិជ្ជកម្ម[3846] តួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការនាំចេញអង្ករ ទោះបីមានកង្វះស្បៀងអាហារក៏ដោយ[3847] ការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងកិច្ចប្រជុំនានា ដែលមានការធ្វើសេចក្តីសម្រេចស្តីពីការបោសសម្អាត រួមទាំងការបោសសម្អាត កងចាប ផង[3848] និងការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មធំៗ ទោះបីជាគាត់បដិសេធក៏ដោយ[3849]។ ទឡ្ហីករណ៍នេះបរាជ័យដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសណាមួយនៅក្នុងការសន្និដ្ឋានរបស់ខ្លួនដែលថា គាត់បានផ្តល់លទ្ធភាព និងត្រួតត្រាលើការអនុវត្តគោលបំណងរួម ក្នុងទិសដៅបំផ្លាញប្រជាជនខ្លួនឯង តាមរយៈគោលនយោបាយនានារបស់ ប.ក.ក[3850]។

---

២០១៩ កថាខណ្ឌ ២៣-២៨។ ទាក់ទងនឹងភ័ស្តុតាង FBIS និង BBC/SWB *សូមមើល* ចម្លើយតបទៅនឹង មូលដ្ឋានទី ១៥៩, ២០២, ២៣០, ២២០, ២២១ និង ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤ (គោលបំណងរួម)។

[3845] ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានធានាថា ការទទួលខុសត្រូវរបស់ ឌឿន នៅតែត្រូវបានបំពេញនៅក្រោយការដកគាត់ចេញ និងថា សហករណ៍បានផ្តល់អង្ករឱ្យមកមជ្ឈិមបក្សសម្រាប់នាំចេញក្នុងចំនួនមួយដ៏ធំ) (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៦ *យោង* កថាខណ្ឌ ៤២២៥, ៦១៩, វាក្យខណ្ឌ ១០.១.៧.៣, ១១.២.១៧.១, កថាខណ្ឌ ១៤៥០-១៤៥១, ៣៩០៨, ៣៩១២-៣៩១៣, ៣៩២៦) ថា ម្ចាស់បណ្តឹងសាទុក្ខបានចុះពិនិត្យមើលដោយផ្ទាល់ចំពោះផលិតផលសម្រាប់នាំចេញ និងបានគ្រប់គ្រងលើការនាំចេញនាំចូលទំនិញ (កថាខណ្ឌ ៤២៧៦ *យោង* កថាខណ្ឌ ៦១៩-៦២១, ៣៩០៩, ៣៩១៤), វាក្យខណ្ឌ ៨.៣.៤.២, បានរួមចំណែកដល់ការស្រាវជ្រាវ និងការបោសសម្អាតកម្មាភិបាល ប.ក.ក និងបានចូលរួមក្នុងកិច្ចប្រជុំនានាដែលមានការ សម្រេចលើវាសនារបស់មនុស្សផ្សេងទៀត (កថាខណ្ឌ ៤២៧៧ *យោង* កថាខណ្ឌ ៤២១៩, ៤២២១-៤២៣០, ៤២៣៤) និងបានបិទបាំងព្រមទាំងបដិសេធចំពោះឧក្រិដ្ឋធំៗនៅក្នុងកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៤២៧៧, ៤២៥៣)។

[3846] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២៩ (ជើងទំព័រ ៣៩៤៤-៣៩៤៦) *យោង* កថាខណ្ឌ ១៧៦៣-១៧៩៨។

[3847] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២៩ (ជើងទំព័រ ៣៩៤៨) *យោង* កថាខណ្ឌ ១៥០៦-១០, ១៩៩០-១៥២២, ១៧៧០-១៧៩៨។

[3848] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣០ (ជើងទំព័រ ៣៩៥១) *យោង* កថាខណ្ឌ ១៨៥១-១៨៥៣, ១៨៥៧-១៨៧៨។

[3849] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣០ (ជើងទំព័រ ៣៩៥៥) *យោង* ចំណងជើង **III** ទាំងមូល (កថាខណ្ឌ ១៨០៥-១៩៣៧។

[3850] ទាក់ទងនឹងមុខងាររបស់ម្ចាស់បណ្តឹងសាទុក្ខនៅមន្ទីរ ៨៧០ និងពាណិជ្ជកម្ម *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩២, ២០៥, ១៩០ (តួនាទីនៅ ៨៧០ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២១, ២១៦-២១៧), ២០៦, ២១៧ (ការគ្រប់គ្រង

1052. ចំពោះកំហុសនីមួយៗក្នុងចំណោមកំហុសទាំង ១៦ ដែលត្រូវបានលើកឡើងនៅកន្លែងផ្សេងទៀតនៃចម្លើយតបនេះ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ មិនអាចឱ្យវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផល ឈានដល់ការសម្រេចនេះបាន ដោយផ្អែកលើការវាយតម្លៃលើភស្តុតាងទាំងមូលនោះទេ។

1053. អំណះអំណាងថ្មីទាំងបីរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីកំហុសអង្គហេតុក្នុងមូលដ្ឋានទី ២៣០-២៣១ ក៏បរាជ័យដែរ។

1054. ទីមួយ ក្នុងមូលដ្ឋានទី ២៣០ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដោយបានយោងទៅសុន្ទរកថា ខែមេសា ឆ្នាំ១៩៧៨ របស់គាត់ ដែលត្រូវបាន *"Le Comité des Patriotes du Kampuchéa Démocratique en France"* សរសេរឡើងវិញ ដោយអះអាងថា មិនគួរឱ្យទុកចិត្តបាន ហើយបានលើកឡើងថា សម្រង់ដែលបានយោងនេះ មិនលើកឡើងអំពីការនិរទេស និងការកម្ទេចជនជាតិវៀតណាមទេ[3851]។ ថ្វីត្បិត អ.ជ.ស.ដ មានការយល់ច្រឡំតិចតួចអំពីកាលបរិច្ឆេទក្តី[3852] ភស្តុតាងនេះបង្ហាញថា សុន្ទរកថានេះ ត្រូវបានធ្វើឡើងយ៉ាងមានប្រសិទ្ធ

ពាណិជ្ជកម្ម)។ ពាក់ព័ន្ធនឹងតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការនាំចេញអង្ករ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១-១៨២, ២០៦, ២១១, ២៣៤។ ទាក់ទងនឹងការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងកិច្ចប្រជុំនានាដែលមានការសម្រេចអំពីការបោសសម្អាត *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣, ២១៧, ២១៥, ២៤៧, ២៣៥, ១៩២។ ទាក់ទងនឹងចំណេះដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខស្តីពីឧក្រិដ្ឋកម្មខ្នាតធំ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៨ (ចំណេះដឹងទូទៅ), ១៩៣ (ទស្សនាវដ្តីទង់បដិវត្តន៍/យុវជន យុវនារីបដិវត្តន៍), ២២៣ (ចំណេះដឹងដែលថា បទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត), ១៩៥ (ការសម្លាប់), ២១៨-២២១ (ចាម វៀតណាម ពុទ្ធសាសនិកជន កម្មាភិបាលខ្មែរក្រហមមុនៗ), ២១៧ (ការបោសសម្អាត), ២១១-២១៦ (សហករណ៍ និងការដ្ឋាន រួមទាំង ត្រាំកក់ ទំនប់អាងត្រពាំងថ្ម ទំនប់ ១មករា ព្រលានយន្តហោះកំពង់ឆ្នាំង ភ្នំក្រោល), ២១១ (ការរៀបអាពាហ៍ពិពាហ៍)។

[3851] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០២៥ (និយាយពីឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧១ *យោង* កថាខណ្ឌ ៣៤០០ ដែលយោង ឯកសារ **E3/169** *សុន្ទរកថារបស់ ខៀវ សំផន ក្នុងសន្និបាតមហាជន,* ១៧ មេសា ១៩៧៨ EN 00280396)។

[3852] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៩-៣៤០០ (សាលក្រមបានបែងចែកខុសរវាងសុន្ទរកថាទាំងពីរដែលបានប្រកាសយ៉ាងជោគជ័យដោយ ខៀវ សំផន នៅថ្ងៃទី១៥ និង ១៧ ខែមេសា ឆ្នាំ១៩៧៨ នៅក្នុងកថាខណ្ឌ ៣៣៩៩ និង ៣៤០០ ដែលសុន្ទរកថាទាំងនេះ គឺជាសុន្ទរកថាពិសេសប្លែកពីគេដែលបានធ្វើឡើងនៅមុននៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ដែលបន្ទាប់មកក៏មានដំណោះស្រាយនានាត្រូវបានអនុមតិដោយអ្នកចូលរួមនៅក្នុងកិច្ចប្រជុំ ដែលមានវត្តមានម្ចាស់បណ្តឹងសាទុក្ខផង នៅក្នុងឱកាសនៃខួបលើកទី៣ ដែលបានប្រារព្ធឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលមើលទៅដូចជាច្របូកច្របល់។ *សូមមើលផងដែរ* ឯកសារ **E295/6/1.4** ឧបសម្ព័ន្ធ ៤ នៃសារណាស្ថាពររបស់ ក.ស.ព *កាលប្បវត្តិ ខៀវ សំផន* ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨, EN 00948530-31។

ភាពដោយម្ចាស់បណ្ដឹងសាទុក្ខនៅក្នុងមីទ្ទីង ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ដែលជាថ្ងៃប្រារព្ធពិធីជ័យជំនះ ១៧ មេសា ១៩៧៥ និងត្រូវបានសរសេរឡើងវិញទាំងស្រុងក្នុងប្រភពពីរផ្សេងទៀត (FBIS[3853] និង *Comité des Patriotes*[3854]) និងការដកស្រង់មួយផ្នែកធំដោយ BBC/SWB[3855] ខណៈសម្រង់ផ្សេងៗទៀតក៏ត្រូវបានប្រើប្រាស់ ឬសង្ខេបក្នុងកម្មវិធីបារាំងមួយផងដែរ[3856] និងដោយ Stephen Heder[3857]។ ដោយសារប្រភពទាំងនេះបានធ្វើការផលិតឡើងវិញនូវសុន្ទរកថានេះ បានដាក់បញ្ចូលខ្លឹមសារដូចគ្នាបេះបិទទៅនឹងសុន្ទរកថានេះ ហើយនឹងសុន្ទរកថាដែលផ្សាយតាមវិទ្យុ ដូច្នេះ ប្រភពផ្សេងទាំងនេះបានបន្ថែមភ័ស្តុតាងឱ្យគ្នាទៅវិញទៅមក អាស្រ័យហេតុនេះ អាចទុកចិត្តបាន មានតែការបកប្រែជាភាសាអង់គ្លេស និងបារាំងប៉ុណ្ណោះ ដែលមានភាពខុសគ្នាបន្តិចបន្តួច។ ការពាក់ព័ន្ធនៃសុន្ទរកថានេះមានភាពច្បាស់លាស់ គឺថា ម្ចាស់បណ្ដឹងសាទុក្ខបានអំពាវនាវដោយឥតលាក់លៀមឱ្យមានការកម្ទេចជនជាតិវៀតណាមទាំងអស់ (និងចារកម្មវៀតណាម) ពីទឹកដីកម្ពុជា[3858]។ គោលជំហរនេះត្រូវបានបង្ហាញម្ដងហើយម្ដងទៀតនៅក្នុងសេចក្ដីសម្រេចនានាដែលបានធ្វើឡើងយ៉ាងឆាប់រហ័សក្រោយសុន្ទរកថារបស់គាត់ ដោយបញ្ជាក់ពី

---

[3853] ឯកសារ **E3/1361** FBIS, *ខួបលើកទី៣ ដែលបានប្រារព្ធឡើងនៅក្នុងកិច្ចប្រជុំមហាជនក្នុងពេលប្រារព្ធខួប នៅថ្ងៃទី១៥ ខែមេសា: សេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន - ជំណោះស្រាយដែលបានអនុមតិ* ១៧ មេសា ១៩៧៨ EN 00168813-22 (ការប្រមូលផ្ដុំមហាជនដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨។ ការផ្សាយតាមវិទ្យុនៅថ្ងទី១៦ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ FBIS ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨)។

[3854] ឯកសារ **E3/169** *សុន្ទរកថារបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំមហាជនក្នុងពេលប្រារព្ធខួប* ចុះថ្ងៃទី១៥ មេសា ឆ្នាំ១៩៧៨ EN 00280389-99។

[3855] ឯកសារ **E3/562** BBC/SWB, ការប្រមូលផ្ដុំនៅភ្នំពេញ គួស បញ្ជាក់ខួប ១៧ មេសា, ១៥ មេសា ១៩៧៨ KH 00249989-90 (សុន្ទរកថាដែលបានថ្លែងដោយម្ចាស់បណ្ដឹងសាទុក្ខ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ប៉ុន្តែរបាយការណ៍បានបោះពុម្ពផ្សាយនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨)។

[3856] ឯកសារ **E3/2671** ទូរលេខអន្តរជាតិបារាំង *កាលប្បវត្តិកម្ពុជា (ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៨)* ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៧៨, KH 008077744-76។

[3857] ឯកសារ **E3/3169** Stephen Heder, *ប៉ុល ពត និង ខៀវ សំផន* KH 00711395-400។

[3858] ឯកសារ **E3/1361** FBIS, *ខួបលើកទី៣ ដែលបានប្រារព្ធឡើងនៅក្នុងកិច្ចប្រជុំមហាជនក្នុងពេលប្រារព្ធខួប នៅថ្ងៃទី១៥ ខែមេសា: សេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន - ជំណោះស្រាយដែលបានអនុមតិ* ១៧ មេសា ១៩៧៨ ("យើងទាំងអស់គ្នាប្ដេជ្ញាចិត្តមោះមុត លះបង់ឥតរួញរា [...] តស៊ូយ៉ាងស្វិតស្វាញ និងយ៉ាងក្លៀវក្លា ដើម្បីកម្ទេចពួកខ្មាំងឈ្លានពាន ជាពិសេស ពួកយួនឈ្លានពានវាតទី លេបទឹកដី ឱ្យអស់ចេញពីទឹកកម្ពុជា"), 00168819 ("ការពារជាតិសាសន៍កម្ពុជាឱ្យបានជោគជ័យ")។ *សូមមើល* ផងដែរ ឯកសារ **E3/169** *សុន្ទរកថារបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំមហាជនក្នុងពេលប្រារព្ធខួប* EN 00280392 ("កម្ទេចឱ្យអស់ជារៀងរហូតចេញពីកម្ពុជា នូវខ្មាំងឈ្លានពាន ជាពិសេស វៀតណាម"), 00280398។ ឯកសារ **E3/562** BBC/SWB, ការប្រមូលផ្ដុំនៅភ្នំពេញ គួស បញ្ជាក់ខួប ១៧ មេសា, ១៥ មេសា ១៩៧៨ KH 00249989-90។

ឆន្ទៈរបស់ថ្នាក់ដឹកនាំ ប.ក.ក ដោយឥតងាករេ ក្នុងការ "បណ្ដេញចេញឱ្យអស់ពីទឹកដីកម្ពុជា" ពួកវៀតណាម និងភ្នាក់ងារវៀតណាម និង "កម្ទេច" ពួកគេ ដើម្បីថែរក្សាការពារ "ជាតិសាសន៍កម្ពុជាជារៀងរហូត"[3859]។ អ.ជ.ស.ដ បានធ្វើការបកស្រាយយ៉ាងត្រឹមត្រូវលើឯកសារ ប.ក.ក នេះ ដែលផ្ដោតគោលដៅលើជនជាតិវៀតណាមទាំងអស់ដោយរើសអើង[3860]។

1055. ទីពីរ ក្នុងមូលដ្ឋានទី ២៣០ ម្ចាស់បណ្ដឹងសាទុក្ខបានបង្ហាញយ៉ាងត្រឹមត្រូវថា អ.ជ.ស.ដ ខកខានមិនបានកំណត់សំអាងហេតុឱ្យបានត្រឹមត្រូវថា[3861] ក្នុងឆ្នាំ១៩៧៧ ម្ចាស់បណ្ដឹងសាទុក្ខ "បានណែនាំដោយផ្ទាល់ទៅមហាជនថា គោលបំណងនៃបដិវត្តន៍ គឺដើម្បី "លុបបំបាត់របប លន់ នល់ [...] លុបបំបាត់ពួកមូលធន ពួកសក្ដិភូមិ [និង] បញ្ញវន្ត"[3862]។ ការស្វែងរកដោយប្រើពាក្យគន្លឹះនៅក្នុងសាលក្រមបានបង្ហាញឱ្យឃើញភ្លាមថា ប្រភពនោះគឺ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ដែលត្រូវបានដក់ស្រង់សំដីក្នុងកថាខណ្ឌ ៣៩៦១ នៃសាលក្រម ជាប្រភពនៃសេចក្ដីថ្លែងនេះ[3863] ព្រមទាំងបានពិពណ៌នាដោយម្ចាស់បណ្ដឹងសាទុក្ខក្នុងបន្ទាត់ជាប់គ្នានោះថា ខ្វះភាពជឿបាន[3864]។

1056. ទីបី ម្ចាស់បណ្ដឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវនៅក្នុងមូលដ្ឋានទី ២៣១ ថា អ.ជ.ស.ដ មានកំហុសក្នុងការផ្អែកលើការប្រើប្រាស់មិនស្របទៅនឹងទស្សនទាននៃពាក្យ "យល់ព្រមដោយនៅស្ងៀម" ចំពោះការធ្វើបាបជនស៊ីវិល[3865]។ ម្ចាស់បណ្ដឹងសាទុក្ខបានយោងដោយមិនត្រឹមត្រូវទៅ

---

[3859] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៩ *យោង* ឯកសារ **E3/1361** FBIS, ខួបលើកទី៣ ដែលបានប្រារព្ធឡើងនៅក្នុងកិច្ចប្រជុំមហាជន នៅថ្ងៃទី១៥ ខែមេសា: ដំណោះស្រាយដែលបានអនុមតិ ១៧ មេសា ១៩៧៨ EN 00168820 (ការការពារជាតិ, បដិវត្តន៍ ៤, ៥, ៩, ១០, ១៧)។ ឯកសារ **E3/562** BBC/SWB, ការប្រមូលផ្ដុំនៅភ្នំពេញ គួសបញ្ជាក់ខួប ១៧ មេសា, ១៥ មេសា ១៩៧៨ KH 00249989-90។

[3860] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២
កថាខណ្ឌ ៣៣៩៩-៣៤០០។

[3861] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០២៦ (ចង្អុលប្រាប់អង្គហេតុនៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧២ ជើងទំព័រ ១៣៩៤១ ដែលយោងខុសត្រឡប់ទៅកថាខណ្ឌ៤២៧២ នៅក្នុងចលនាសារាចរ)។

[3862] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧២។

[3863] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៩៦១ (ព្រាប ឆុន បានផ្ដល់សក្ខីកម្មថា "ក្នុងការថ្លែងសុន្ទរកថាទៅកាន់ក្រុមអ្នកជម្លៀសមកពីភូមិភាគបូព៌ានៅផ្សារច្បារអំពៅ ក្នុងឆ្នាំ១៩៧៧ ខៀវ សំផន បាននិយាយថា: យើងធ្វើបដិវត្តន៍នេះ ដើម្បីលុបបំបាត់របប លន់ នល់។ មួយទៀត គឺថាលុបបំបាត់របបនាយទុន សក្ដិភូមិ បញ្ញវន្ត។ គាត់ [ខៀវ សំផន] មិនឱ្យមានទេ")។ *សូមមើល* ចម្លើយតបទៅនឹង មូលដ្ឋានទី ២០។

[3864] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០២៧។

[3865] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០៣០។

ផ្នែកមួយនៃសារណារបស់គាត់ ដែលមិនទាក់ទងទៅនឹងការធ្វើបាបដែលបង្កទៅលើជនស៊ីវិល "*នៅក្នុងសហករណ៍ និងការដ្ឋាន*" ដូចដែល អ.ជ.ស.ដ បានបញ្ជាក់ឡើយ ប៉ុន្តែ ទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុង ជាពិសេសការប្រព្រឹត្តលើខ្មាំងនៅតាមមន្ទីរសន្តិសុខ[3866]។ ទទ្ធីករណ៍ថ្មីប្លែកដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនោះ គឺថា ក្នុងនាមជាកម្មាភិបាលមាន "មុខតំណែងពិសេសនៅក្នុង ប.ក.ក" និងមានវត្តមានជាប្រចាំនៅក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍[3867] គាត់មិនបានផ្តល់ "ការយល់ព្រមដោយនៅស្ងៀម" ចំពោះការធ្វើបាបដែលបានលើកឡើងនេះទេ ពីព្រោះគេមិនអាចបញ្ជាក់ពីការយល់ព្រមដោយនៅស្ងៀមឡើយ[3868]។ ទោះជាយ៉ាងណា ដូចបានរៀបរាប់លម្អិតនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨២ អ.ជ.ស.ដ បានបញ្ជាក់ថា ម្ចាស់បណ្តឹងសាទុក្ខបានសារភាពជាសាធារណៈពីការដឹងនៅពេលនោះរបស់គាត់អំពីការចាប់ខ្លួន ការឃុំខ្លួន និងការធ្វើបាបជនស៊ីវិល និងថា បញ្ហានេះត្រូវបានបញ្ជាក់ដោយសាក្សី មាស វឿន[3869]។ លើសពីនេះទៀត នៅក្នុងប្រព័ន្ធដែលប្រើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ អ.ជ.ស.ដ បានសន្និដ្ឋានថា អ្នកចូលរួមម្នាក់ៗក្នុងអង្គប្រជុំគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ រួមទាំងម្ចាស់បណ្តឹងសាទុក្ខផង មានសិទ្ធិបញ្ចេញគំនិត និងមតិយោបល់ មុនពេលមានការសន្និដ្ឋានរួមដោយលេខាគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍[3870]។ ដូចដែល អ.ជ.ស.ដ បានបង្ហាញ នួន ជា បានពន្យល់នៅពេលសវនាការថា ប្រសិនបើសមាជិកនៅតែមិនពេញចិត្តនៅដំណាក់កាលនោះ ពួកគេអាចបង្ហាញការជំទាស់បន្តទៀត និងលើកពីសំណើ ហើយបន្ទាប់មកការពិភាក្សានឹងបន្តធ្វើរហូតទាល់តែឈានដល់ការឯកភាពគ្នា[3871]។ ដូចដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង ទាក់ទងនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ "បើមានសំឡេងតែមួយប្រឆាំងមិនឱ្យជម្លៀសនោះ ក៏អត់ជម្លៀសកើត

[3866] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣០ (យោងដោយខុសឆ្គងទៅកថាខណ្ឌ ១៨៤៩-១៨៧៨) (គូសបញ្ជាក់បន្ថែម)។

[3867] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៧។

[3868] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣០។

[3869] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣១-៣៥។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨៨៥, ៣៨៩៦, ៣៩០០, ៣៩០៨, ៣៩១៣, ៣៩២០-៣៩២៧, ៣៩៦៧, ៤២០៨, ៤២១០-៤២១៨, ៤២៥៣, ៤២៦៥, ៤២៧២-៤២៧៣។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨២, ២១១។

[3870] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១-៣៩២, ៣៩៧។

[3871] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២ *ដោយលើកឡើងពី* ឯកសារ **E1/23.1** នួន ជា ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ទំព័រ 33-36។

ទេ”[3872]។ *អំណះអំណាងផ្ទុយមកវិញ (A contrario)* ការនៅស្ងៀមនៅក្នុងអង្គប្រជុំគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍បែបនោះ ដែលគោលនយោបាយ និងសេចក្ដីសម្រេចមានលក្ខណៈឧក្រិដ្ឋ រួមទាំងអំពីការចាប់ខ្លួនមនុស្ស ត្រូវបានពិភាក្សា មានន័យថា ព្រមទទួលយក និងគាំទ្រ[3873] ហេតុដូច្នេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង[3874]។

---

[3872] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៣ ជើងទំព័រ ១១៧៩ *ដោយលើកឡើងពី* ឯកសារ **E3/4051** ប្រតិចារឹក ខៀវ សំផន មិនមានកាលបរិច្ឆេទ EN 00788872។

[3873] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៣ *ដោយលើកឡើងពី* ឯកសារ **E3/18** ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះនិងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* KH 00103843-44 (“ប៉ុន្តែដោយម្នាក់ៗដាក់ជំនឿឥតព្រំដែនលើ ប៉ុល ពត *គេច្រើនតែទទួលមតិវិភាគ និង ការលើកស្នើវិធានការរបស់ ប៉ុល ពត ដោយមិនសូវបានជជែកវែកញែកអ្វីជ្រៅជ្រះហ្មត់ចត់ទេ។* ជំនឿនេះក៏ហាក់ដូចជាមិនរង្គោះរង្គើទេ ក្រោយពេលមានការចាប់ចងសមាជិកគណៈមជ្ឈិមណាមួយ ឬ ក្រោយមកទៀត មានការចាប់សមាជិកគណៈអចិន្ត្រៃយ៍ក៏ដោយ។ ការបាត់មុខអ្នកទាំងអស់នោះម្ដងមួយៗ *ហាក់ដូចជា* បានត្រូវសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀត ដែលគេដឹងរឿង*ចាត់ទុកជា* ករណីដាច់ពីគ្នា ហើយជាវិធានការត្រឹមត្រូវ”) (គូសបញ្ជាក់បន្ថែម), ៤២៥៩ (តាមរយៈសមាជិកភាពនៃគណៈអចិន្ត្រៃយ៍ និងការចូលរួមចំណែកនៅក្នុងសន្និបាតបក្សរបស់គាត់ ម្ចាស់បណ្ដឹងសាទុក្ខបានយល់ព្រមទៅនឹងគោលនយោបាយ និងបទបញ្ជានានា ដែលបានអនុវត្ត), ៤២៨៦ (“នៅពេលការពារវិធីសាស្ត្ររបស់ ប៉ុល ពត ថាមានភាពចាំបាច់ក្នុងកាលៈទេសៈបែបនោះ គាត់បានយល់ស្របដោយប្រយោលឱ្យមានការ ចាប់ខ្លួនតាមទំនើងចិត្តនិងដោយសម្ងាត់ ការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ ចំពោះមេដឹកនាំ ប.ក.ក”)។

[3874] តុលាការ ICTY បានសម្រេចយ៉ាងទៀងទាត់ថា ជនជាប់ចោទអាចចូលរួមនៅក្នុង JCE ដោយអំពើអកម្ម (សាលក្រម *Milutinović* កថាខណ្ឌ ១០៣ *ដោយលើកឡើងពី* សាលក្រម *Kvočka* កថាខណ្ឌ ៣០៩) ហើយថា ស្ថានភាពដឹកនាំដែលមិនអាចជំនួសបានរបស់ជនជាប់ចោទ និងការយល់ស្របដោយស្ងាត់ស្ងៀមនៃវិធានការនានាដែលជំរុញផែនការរួម ប្រយុទ្ធប្រឆាំងដើម្បីរកឱ្យឃើញថា ការចូលរួមចំណែករបស់គាត់គឺសំខាន់ ជាពិសេសនៅក្នុងអវត្តមាននៃការប៉ុនប៉ងណាមួយដើម្បីបង្អាក់ដំណើរការប្រព្រឹត្តទៅដ៏មានប្រសិទ្ធិភាពនៃ JCE (សាលក្រម *Milutinović* កថាខណ្ឌ ១០៥។ សាលក្រម *Kvočka* កថាខណ្ឌ ៣០៩, ៣១១។ *សូមមើលផងដែរ* សាលក្រម *Prlić* កថាខណ្ឌ ១៤៨៧, ១៥៣០)។ គោលជំហរនេះត្រូវបានគាំទ្រទាំងស្រុងដោយករណីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II ដែលបានបង្កើតឡើងនូវគោលការណ៍ដែលថា ជនចាប់ចោទអាចត្រូវបានដាក់ឱ្យរងនូវការទទួលការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះការខកខានរបស់ខ្លួនដែលមិនបានជំទាស់ទៅនឹងប្រតិបត្តិការឧក្រិដ្ឋ តាមរបៀបមួយបែបដូច្នោះដើម្បីបណ្ដាលឱ្យខ្លួនមានជោគជ័យ។ *សូមមើលឧទាហរណ៍* សាលក្រម *Einsatzgruppen* ទំព័រ ៥៧២ (ផ្ដន្ទាទោស Fendler នៅលើមូលដ្ឋានដែលថា គាត់បានដឹងថាការសម្លាប់មនុស្សត្រូវបានធ្វើឡើង និងខកខានមិនបានធ្វើអ្វីសោះ ទោះបីជាខ្លួននៅក្នុងឋានៈជាមន្ត្រីជាន់ខ្ពស់ទីពីរនៅក្នុង Kommando ដែលថាទស្សនៈរបស់គាត់អាចនឹងត្រូវបានដឹងឮ), ៥៨០-៥៨១ (**សម្រេចឱ្យ** Rühl រួចទោស ពីព្រោះគាត់មិនបានចូលរួមនៅក្នុងចំណែកណាមួយដែលជា “ប្រតិបត្តិការណ៍ ឬឋានៈតូចទាបរបស់គាត់ ជាស្វ័យប្រវត្តិ ចូលទៅក្នុងកន្លែងដែលមិនមានការជំទាស់តាមបែបណាមួយ ដែលបណ្ដាលឱ្យឈានដល់ជោគជ័យនៃបញ្ហាប្រតិបត្តិការណ៍”)។ តុលាការក៏បានរកឃើញផងដែរ (ទំព័រ ៥៨០) ថា “វាមិនត្រូវបានបង្កើតឡើងឱ្យហួសពីវិមតិសង្ស័យ ដែលថាគាត់ត្រូវនៅក្នុងឋានៈមួយដែលត្រូវគ្រប់គ្រង ការពារ ឬ កែប្រែភាពធ្ងន់ធ្ងរនៃ [កម្មវិធី Sonderkommando របស់គាត់]”។ *សំណុំរឿងរបស់ Pohl* ទំព័រ ១០០២-១០០៤ (“មាន “ធាតុផ្សំនៃអំពើប្រព្រឹត្តសកម្មមួយ

ទាក់ទងនឹងការធ្វើបាបជនស៊ីវិលនៅតាមសហករណ៍ និងការដ្ឋាន ដែលគាត់បានដឹងយ៉ាងពេញលេញ[3875] ការនៅស្ងៀមមិនព្រមប្រើសិទ្ធិអំណាចរបស់គាត់ក្នុងការទប់ស្កាត់ ឬបញ្ឈប់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម (ដូចដែលគាត់បានធ្វើតាមពេល ដើម្បីជួយសមាជិកគ្រួសារសាច់ថ្លៃរបស់គាត់នៅក្នុងភូមិភាគឧត្តរថ្មី)[3876] បានបង្ហាញឱ្យឃើញពីការយល់ព្រមរបស់គាត់។

### *មូលដ្ឋានទី ១៩២៖ មន្ទីរ ៨៧០*[3877]

1057. **មូលដ្ឋានទី ១៩២ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គហេតុ ដោយសន្និដ្ឋានថា ក្នុងនាមជាសមាជិកមន្ទីរ ៨៧០ ម្ចាស់បណ្ដឹងសាទុក្ខបានចូលរួមចំណែកដល់ឧក្រិដ្ឋកម្ម តាមរយៈការចូលរួមក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក និងបានដឹងអំពីការចាប់ខ្លួន និងការសម្លាប់ ឿន។**

---

ដែលបញ្ជាក់យ៉ាងច្បាស់នៅក្នុងពាក្យ "យល់ព្រម""។ តុលាការ បានបន្ថែមថា "នៅក្នុងករណីដែលបុគ្គលមួយ ដែលមានអំណាច ឬមានសិទ្ធិ ត្រូវចាប់ផ្ដើម ឬបញ្ឈប់នូវអំពើឧក្រិដ្ឋ ការដឹងឮពីអង្គហេតុនេះដែលរួមគ្នាជាមួយនឹងភាពស្ងាត់ស្ងៀម អាចត្រូវបានបកស្រាយថាជា ការយល់ព្រម")។

[3875] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៥ (ម្ចាស់បណ្ដឹងសាទុក្ខទទួលស្គាល់អវត្តមាននៃសេរីភាពនៅក្នុងសហករណ៍), ៣៨៩៦-៣៨៩៧ ("សមាសភាពមិនល្អ" ក្នុងចំណោមប្រជាជនថ្មី), ៣៩០០ (ប៉ុល ពត ពោលពីកង្វះខាតស្បៀងអាហារ ពីជំងឺ ពីទីជំរកមិនគ្រប់គ្រាន់), ៣៩០៨-៣៩០៨ (ស្បៀងអាហារមិនគ្រប់គ្រាន់ មានជំងឺ និង ស្លាប់ដោយសារកង្វះអាហាររូបត្ថម), ៣៩១២ (របាយការណ៍ពីកង្វះខាតស្បៀងអាហារដោយពួកលេខាភូមិភាគ), ៣៩១៣ (ម្ចាស់បណ្ដឹងសាទុក្ខបានដឹងពីលក្ខខណ្ឌរស់នៅតាមមូលដ្ឋាន រួមមាន កង្វះខាតស្បៀងអាហារ បញ្ហាសុខភាព និង កង្វះឱសថ), ៣៩១៦, ៣៩២០-៣៩២៧, ៤២០៨, ៤២១០-៤២១៨, ៤២៣២-៤២៣៤។ ការណ៍នេះច្បាស់លាស់ផងដែរពីខ្លឹមសារនៅក្នុងសុន្ទរកថានានារបស់គាត់ស្ដីពីលក្ខខណ្ឌការងារនៅក្នុងសហករណ៍ និងតាមការដ្ឋាននានា ហើយនិងភាពចាំបាច់ក្នុងការកំណត់អត្តសញ្ញាណពួកខ្មាំងរបស់ ប.ក.ក ក្នុងចំណោមពួកកម្មករ ជាពិសេស ក្នុងចំណោមប្រជាជនថ្មី (*សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៣, ៤២៦៥ (កម្លាំងពលកម្ម "ទាំងថ្ងៃទាំងយប់ [...] **ក៏**ដោយមិនសម្រាក"។ ទទួលស្គាល់ពីម៉ោងការងារមិនទៀងទាត់។ សីហានុ រៀបរាប់ពីការដឹងឮដ៏គួរឱ្យរន្ធត់របស់ម្ចាស់បណ្ដឹងសាទុក្ខ), ៤២៧២-៤២៧៣, ៣៩៦៧)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨២, ២១១។

[3876] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣២-៣៤ (ម្ចាស់បណ្ដឹងសាទុក្ខទទួលស្គាល់នៅក្នុងលិខិតចំហរមួយនូវការដឹងឮសហការនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងការឃុំគ្រងជនស៊ីវិលមិនបានល្អជាក់ស្ដែង នៅព្រះវិហារ។ អន្តរាគមន៍របស់ មាស វឿន ដើម្បីដោះលែងបង(/ប្អូន)ស្រីថ្លៃរបស់ម្ចាស់បណ្ដឹងសាទុក្ខ), ៤២១៦, ៤២៨៦។

[3877] <u>មូលដ្ឋានទី ១៩២៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *៨៧០*, កថាខណ្ឌ ១៧៦៣-១៧៦៩។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៦៦-៦៧ (អង់គ្លេស) ទំព័រ ៦១-៦២ (បារាំង) ទំព័រ ៩៩-១០០ (ខ្មែរ)។

1058. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3878] គោលការណ៍នៃការសម្លាប់មិនអនុវត្តចំពោះម្ចាស់បណ្តឹងសាទុក្ខទេ ហើយគាត់បានដឹង និងប្រកាន់ខ្ជាប់ទៅនឹងគោលនយោបាយរបស់ ប.ក.ក ក្នុងការលុបបំបាត់ជនទាំងឡាយណាដែលត្រូវបានចាត់ទុកថាជាខ្មាំង[3879]។ ការប្រព្រឹត្តិលើខ្មាំងត្រូវបានធ្វើដោយសម្ងាត់ខ្ពស់បំផុត សម្រាប់តែកម្មាភិបាលថ្នាក់ទាប ប្រជាជនធម្មតា ឬជនបរទេសតែប៉ុណ្ណោះ។ លើសពីនេះទៀត អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីការចាប់ខ្លួន និងការស្លាប់របស់កម្មាភិបាលជាន់ខ្ពស់ ប.ក.ក តាមរយៈការប្រជុំ ឬឯកសារកម្ពុជាប្រជាធិបតេយ្យដែលគាត់បានមើល[3880] ផ្ទុយទៅនឹងអ្វីដែលគាត់បានអះអាង[3881]។ ការអះអាងបច្ចុប្បន្នរបស់ម្ចាស់បណ្តឹងសាទុក្ខថាមិន "បានឃើញ" ការចាប់ខ្លួន ប៉ុន្តែ គ្រាន់តែ "បានឃើញ" ការបាត់ខ្លួនសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មិនពិតទាល់តែសោះ[3882]។ ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់យ៉ាងច្បាស់លាស់នៅចំពោះមុខ ស.ច.ស ថា ពាក្យ "បាត់ខ្លួន" របស់កម្មាភិបាលជាន់ខ្ពស់នៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្មើទៅនឹង "ការចាប់ខ្លួន" និងថា "គ្រប់គ្នា [ពោលគឺ សមាជិកផ្សេងទៀតនៃ

---

[3878] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៥០-១៦៥១, ១៨៥៩។

[3879] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៥ (គោលការណ៍សម្លាប់)។

[3880] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២០-៤២២៤ (ជាទូទៅ ការដឹងឮពីការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលជាន់ខ្ពស់), ៤២២៥-៤២៣០ (ការដឹងឮពីជោគវាសនារបស់កម្មាភិបាលជាន់ខ្ពស់មួយចំនួន៖ សឿ វ៉ាស៊ី *ហៅ* ឌឿន, ចាន់ ចក្រី, សួស នៅ, កុយ ធួន, កែវ មាស, ហ៊ូ នឹម, ជូ ជេត *ហៅ* ស៊ី, វន វ៉េត, សោ ភឹម និង វ៉ឹង ផែម), ៤២៣១-៤២៣៥ (ការដឹងឮពីការបោសសម្អាតថ្នាក់ទាប និងការដាក់ក្នុងមន្ទីរឃុំឃាំង ហើយនិង ការឃុំគ្រងជនស៊ីវិលមិនបានល្អ), ៣៩៥៨ ("ទោះបីជាមានគោលការណ៍រក្សាការសម្ងាត់របស់បក្សក៏ដោយ ក៏ការកម្ទេចខ្មាំងត្រូវបានរាយការណ៍យ៉ាងច្រើនក្នុងជួរបក្ស"), ៤២៥៣ ("ខៀវ សំផន បានចូលរួម និងបង្រៀននៅក្នុងវគ្គអប់រំ និងមីទ្ទីងមហាជន ដែលនៅពេលនោះអំពើដែលត្រូវបានចាត់ទុកថាមានលក្ខណៈឧក្រិដ្ឋប្រឆាំងទៅលើខ្មាំង ប.ក.ក ត្រូវបានយកទៅពិភាក្សា លើកទឹកចិត្ត និងញុះញង់"), ៤២៧៧, ៤២៨៤-៤២៨៥។ វាមិនជាបញ្ហាអ្វីទេដែលថាសេចក្តីថ្លែងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការបាត់ខ្លួន ការចាប់ខ្លួន និង ការបោសសម្អាតខ្មាំង ត្រូវបានធ្វើឡើងនៅក្រោយខែមករា ឆ្នាំ១៩៧៩ ឱ្យតែវាច្បាស់ថាគាត់បានដឹងឮពីដំណឹងនោះនៅពេលនោះ។

[3881] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៥៨-១៨៥៩។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២០ (ខៀវ សំផន "បានលើកឡើងថា គាត់ពុំបានដឹងអំពីការចាប់ខ្លួនណាមួយមុនឆ្នាំ១៩៧៩ឡើយ")។

[3882] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៥៨ *យោងដល់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២០។

គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍] ហាក់ដូចជាយល់ស្រប"[3883] ការចាប់ខ្លួនទាំងនោះនៅពេលនោះ និងបានចាត់ទុកពួកវាថា "ហាក់ដូចជាវិធានការត្រឹមត្រូវ"[3884]។

1059. មូលដ្ឋាននេះក៏បរាជ័យផងដែរ ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ដោយការសន្និដ្ឋានថា គាត់បានដឹងច្បាស់អំពីការចាប់ខ្លួន និងការសម្លាប់ ខឿន[3885]។ ទីមួយ ម្ចាស់បណ្ដឹងសាទុក្ខបានទទួលស្គាល់ថា ខឿន គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម[3886] រដ្ឋមន្ត្រីពាណិជ្ជកម្ម និងប្រធានមន្ទីរ ៨៧០[3887] និងថា ដូចបានបង្ហាញខាងលើ នៅពេល

---

[3883] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២០ ជើងទំព័រ ១៣៧៦៩ *លើកឡើងពី* ឯកសារ **E3/210** កំណត់ហេតុស្ដាប់ចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156690-91 ("ខ្ញុំបានឃើញសមាជិកមួយចំនួនរបស់គណៈកម្មាធិការមជ្ឈិម *បាត់ខ្លួន* ម្ដងមួយៗ [...] ទោះជាយ៉ាងណាក៏ដោយ ខ្ញុំ មិនដឹងទាល់តែសោះអំពីទំហំនៃ*ហេតុការណ៍* នោះ [...] ទាក់ទងនឹង*ការបាត់ខ្លួន* នៃសមាជិកនៃគណៈកម្មាធិការមជ្ឈិម និង គណៈអចិន្ត្រៃយ៍ គ្រប់គ្នាហាក់ដូចជាយល់ស្រប ប៉ុន្តែខ្ញុំវិញ ខ្ញុំមិនដឹងពីទំហំរបស់*វា* ទេ") ("គូសបញ្ជាក់បន្ថែម"), ៤២២១ ជើងទំព័រ ១៣៧៧០ *លើកឡើងពី* ឯកសារ **E3/203** បទសម្ភាស ខៀវ សំផន ដោយលោក Stephen Heder ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៨០ KH 00385409 (ការប្រើពាក្យថា "យើង" ដើម្បីរៀបរាប់ពីការប្រយុទ្ធប្រឆាំងជាមួយនឹងពួកក្បត់ជាតិ, "ការគ្រប់គ្រង" យ៉ាងពេញលេញរបស់ពួកគេ និងការវាយឱ្យចុះចាញ់), ៤២២២ ជើងទំព័រ ១៣៧៧៤ *លើកឡើងពី* ឯកសារ **E3/4023** បទសម្ភាស ខៀវ សំផន មិនមានកាលបរិច្ឆេទ KH 00784640 (ថ្នាក់លើ "គិតគូរចាប់ចងតែកម្មាភិបាលណាដែលប្រព្រឹត្តខុស")។ ឯកសារ **E3/630** បទសម្ភាស ខៀវ សំផន ដោយវិទ្យុសម្លេងសហរដ្ឋអាមេរិក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ KH 00766098 (យោងតាម ខៀវ សំផន ការចាប់ខ្លួនកម្មាភិបាលសំខាន់ៗ ប្រហែលមនុស្ស "រាប់រយនាក់" ប៉ុណ្ណោះ មិនមែន "រាប់ពាន់នាក់" ទេ)។

[3884] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៣ *លើកឡើងពី* ឯកសារ **E3/18** ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ* ទំព័រ ៧១-៧២ KH 00103843-44 (ជំនឿនេះក៏ហាក់ដូចជាមិនរង្គោះរង្គើទេ "ក្រោយពេលមានការចាប់ចងសមាជិកគណៈមជ្ឈិមណាមួយ ឬ ក្រោយមកទៀត មានការចាប់សមាជិកគណៈអចិន្ត្រៃយ៍ក៏ដោយ។ ការបាត់មុខអ្នកទាំងអស់នោះម្ដងមួយៗ ហាក់ដូចជាបានត្រូវសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀត ដែលគេដឹងរឿងចាត់ទុកជាករណីដាច់ពីគ្នា ហើយជាវិធានការត្រឹមត្រូវ")។

[3885] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៦២-១៨៦៣។ អ.ជ.ស.ដ បានប្រើប្រាស់ពាក្យ "បានដឹងអំពីការចាប់ខ្លួន និងការសម្លាប់ ខឿន នាពេលក្រោយមក" និងបាន "ដឹងថា ខឿន ត្រូវបានគេបោសសម្អាត" (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥) ខណៈដែលម្ចាស់បណ្ដឹងសាទុក្ខប្រើប្រាស់ពាក្យ "បានដឹងអំពីការចាប់ខ្លួន និងការសម្លាប់ ខឿន" (ឯកសារ **F54.1.1** កឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៦៦-៦៧ (អង់គ្លេស) ទំព័រ ៦១-៦២ (បារាំង)។ *ផ្ទុយពី* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៦២ ("ដឹងថា ខឿន ត្រូវបានបោសសម្អាត")។

[3886] ឯកសារ **E3/27** កំណត់ហេតុស្ដាប់ចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ EN 00539266។ ឯកសារ **E3/203** បទសម្ភាស ខៀវ សំផន ដោយលោក Stephen Heder ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៨០ EN 00424016។ *សូមមើលផងដែរ* ឯកសារ **E3/356** កំណត់ហេតុស្ដាប់ចម្លើយ ឌុច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ EN 00242903-04។ ឯកសារ **E3/9** Philip Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* EN 00396426។ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥ ជើងទំព័រ ៩៩៧។

ដែលកម្មាភិបាលដ៏សំខាន់របស់ ប.ក.ក "បាត់ខ្លួន" វាមានន័យថាគាត់ត្រូវបាន "ចាប់ខ្លួន"។ ទីពីរ ក្នុងនាមជាសាមជិកម្នាក់ក្នុងចំណោមពីរនាក់ ឬពីរបីនាក់ ដែលនៅរស់ក្នុងមន្ទីរ ៨៧០[3888] ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងជាអ្នកត្រួតពិនិត្យបញ្ហាពាណិជ្ជកម្ម[3889] ម្ចាស់បណ្ដឹងសាទុក្ខពិតជាបានកត់សម្គាល់អំពី "ការបាត់ខ្លួន"[3890] ឌឿន រយៈពេលជិតពីរឆ្នាំ មិនមែនតែដោយសារគាត់ធ្វើការជិតស្និទ្ធជាមួយ ឌឿន ទេ[3891] ប៉ុន្តែ ក៏ដោយសារតែគាត់ទទួលទានអាហារជាប្រចាំជាមួយ ឌឿន នៅ ក-៣[3892]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្ដឹងសាទុក្ខបានធានាដោយផ្ទាល់ពីការទទួលខុសត្រូវពាណិជ្ជកម្មរបស់ ឌឿន ថានៅតែបំពេញបានក្រោយពេលបោសសម្អាតគាត់[3893]។ ទីបី អ.ជ.ស.ដ បានបញ្ជាក់ថា ឌឿន និង កម្មាភិបាល ប.ក.ក ដែលត្រូវបានបោសសម្អាតផ្សេងទៀត (រួមទាំង ចាន់ ចក្រី, ស្លួស នៅ, កុយ ធួន, ជូ ជេត និង កែវ មាស) ត្រូវបានដាក់ឈ្មោះនៅក្នុង *ទស្សនាវដ្ដីទង់បដិវត្តន៍* ក្នុងឆ្នាំ១៩៧៨ និងត្រូវ បាន

---

[3887] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៦៤-១៧៦៩, ១៨៦២-១៨៦៣។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២៩២។

[3888] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤, ៤២២៥។

[3889] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥ (ម្ចាស់បណ្ដឹងសាទុក្ខបានសន្មតចំពោះតួនាទីនៃការមើលខុសត្រូវរបស់ ឌឿន នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម នៅត្រឹមចុងខែតុលា ឆ្នាំ១៩៧៦), ៤២៧៦។ ម្ចាស់បណ្ដឹងសាទុក្ខត្រូវតែបានកត់សម្គាល់ថា នៅត្រឹមខែតុលា ឆ្នាំ១៩៧៦ របាយការណ៍នានារបស់ក្រសួងពាណិជ្ជកម្មត្រូវបានលើកឡើងចំពោះរូបគាត់ ហើយលែងចំពោះរូប ឌឿន ទៀតហើយ៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៨, ជើងទំព័រ ១៩៥១។

[3890] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤ (មន្ទីរ ៨៧០ បានបន្តធ្វើប្រតិបត្តិការនៅក្រោយការចាប់ខ្លួន ឌឿន នៅម៉ុខែកុម្ភៈ ឆ្នាំ១៩៧៧)។

[3891] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥, ៦១០។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤ (*លើកឡើងពី* សេចក្ដីថ្លែងការជាផ្លូវការចំនួនពីររបស់ម្ចាស់បណ្ដឹងសាទុក្ខនៅ អ.វ.ត.ក ហើយសៀវភៅមួយក្នុងចំណោមសៀវភៅរបស់គាត់ ថ្លែងថា ឌឿន អវត្តមានជាញឹកញាប់ដោយសារការធ្វើដំណើរ), ៤២២៥ (ម្ចាស់បណ្ដឹងសាទុក្ខអះអាងថា ការរកឃើញនៅក្រោយខែមករា ឆ្នាំ១៩៧៩ ថា ឌឿន ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ នោះ មិនមានន័យអ្វីទេ)។

[3892] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥, ជើងទំព័រ ១៣៧៨១ (*លើកឡើងពី* ភរិយារបស់ម្ចាស់បណ្ដឹងសាទុក្ខ សូ សុជាតិ៖ ឯកសារ **E1/206.1** សូ សុជាតិ ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ទំព័រ ១០-១៥ ដែលបាននិយាយនៅក្នុងខ្លឹមសារថា ម្ចាស់បណ្ដឹងសាទុក្ខបរិភោគអាហារជាច្រើនលើកច្រើនសារជាមួយនឹង ឌឿន នៅ ក.៣ រហូតទាល់តែគាត់លែងឃើញមក ហើយលោកស្រីបានសម្រេចថា ឈប់រៀបចំម្ហូបអាហារសម្រាប់ ឌឿន ទៀតហើយ)។ *សូមមើលផងដែរ* ឯកសារ **E3/16** ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា* KH 00380459-60 ជើងទំព័រ ១៩៣។

[3893] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥។

ចាត់ទុកថាជាជនក្បត់មានទំនាក់ទំនងជាមួយ សេ.អ៊ី.អា និង/ឬ "យួន"[3894]។ ចំណុចនេះបង្ហាញថា ការចាប់ខ្លួន និងការសម្លាប់ ឌឿន ត្រូវបានគេដឹងយ៉ាងច្បាស់នៅក្នុងជួរ ប.ក.ក ជា អង្គហេតុ ដែលកាន់តែច្បាស់ទៅទៀតចំពោះម្ចាស់បណ្តឹងសាទុក្ខ ដែលមានសិទ្ធិចូលរួមក្នុងអង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង ប៉ុល ពត និង នួន ជា[3895]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា សំអាងហេតុរបស់ អ.ជ.ស.ដ ទាក់ទងនឹង ការចាប់ខ្លួន និងការសម្លាប់ ឌឿន ជាការស្មាន ឬជាសំអាងហេតុដែលមិនមានអ្នកវិនិច្ឆ័យអង្គហេតុណាម្នាក់អាចឈានទៅសម្រេចដូច្នេះនោះទេ។

## *មូលដ្ឋានទី ១៩៨៖ ពីឆ្នាំ ១៩៧០ ដល់ ខែមេសា ឆ្នាំ១៩៧៥*[3896]

1060. **មូលដ្ឋានទី ១៩៨ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ក្នុងការសន្និដ្ឋានថា តាមរយៈមុខងារ និងសកម្មភាពរបស់គាត់ ម្ចាស់បណ្តឹងសាទុក្ខបានដើរតួរនាទីយ៉ាងសំខាន់ក្នុងការប្រមូលផ្តុំការគាំទ្របដិវត្តនៅចន្លោះឆ្នាំ១៩៧០ និង ឆ្នាំ១៩៧៥ ហេតុដូច្នេះ បានជួយពង្រឹងភាពស្របច្បាប់របស់ ប.ក.ក។**

1061. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញពីកំហុសណាមួយនៅក្នុងការវាយតម្លៃរបស់ អ.ជ.ស.ដ លើភ័ស្តុតាង ដោយការផ្អែកលើតួនាទីរបស់គាត់ក្នុងការធានាដល់សាធារណជនអំពីផែនការរបស់ ប.ក.ក និងការអំពាវនាវរបស់គាត់ឱ្យមានការតស៊ូហិង្សាប្រឆាំងនឹងរបប លន់ នល់ ដើម្បីសន្និដ្ឋានថា គាត់បានធ្វើឱ្យចលនា ប.ក.ក មានភាពស្របច្បាប់[3897]។

---

[3894] *សូមមើលផងដែរ* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២២៩២, ជើងទំព័រ ៧៧៥៥ (*លើកឡើងពី* ឯកសារ E3/727 *ទង់បដិវត្ត* ឧសភា-មិថុនា ១៩៧៨ KH 00064566៖ "ក្បាលដែលត្រូវវាយ គឺសេអ៊ីអា យួន និងកាសេបេ។ តាំងពី ៧៥ មក កំឡាំងដែលវាយយើងសុទ្ធតែសេអ៊ីអា និងយួន។ អាចក្រី អាឈូក អាធុច អាឌឿន អាភឹម អាស៊ី អាកែវមាស អាជ័យ ទាំងអស់សុទ្ធតែសេអ៊ីអា។ គ្រាន់តែសេអ៊ីអាមួយ វាធ្ងន់ខាងអាមេរិក អាមួយវាធ្ងន់ខាងយួនជាង")។ *សូមមើលផងដែរ* ឯកសារ E1/437.1 ឌុច ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ទំព័រ ១១។ ខៀវ សំផន អាចចូលមើលទស្សនាវដ្តី *ទង់បដិវត្ត* បាន៖ ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៣។

[3895] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥។ *សូមមើលផងដែរ* កថាខណ្ឌ ៤២៨៤។

[3896] <u>មូលដ្ឋានទី ១៩៨៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ពីឆ្នាំ១៩៧០ ទៅដល់ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥* កថាខណ្ឌ ១៦៦៥-៦៨។ ឯកសារ F54.1.1 ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧១ (អង់គ្លេស) ទំព័រ ៦៣ (បារាំង) ទំព័រ ៩៦-៩៧ (ខ្មែរ)។

[3897] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦៨ *លើកឡើងពី* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨២។

1062. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់មានតួនាទីនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (FUNK/GRUNK) នៅក្នុងការធានាដល់សាធារណជនអំពីផែនការរបស់ ប.ក.ក មិនមានការបញ្ជាក់គាំទ្រទេ[3898]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា អ.ជ.ស.ដ បានលើកឡើងលើសអំពីតួនាទីរបស់គាត់នៅក្នុង FUNK/GRUNK[3899] និងមិនបានគិតគូរដល់បរិបទនៃការតែងតាំងគាត់ជាអនុនាយករដ្ឋមន្ត្រី ដោយមិនបានបង្ហាញបន្ថែមទៀតទៅលើចំណុចណាដែលមានកំហុសនោះ។

1063. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានកំហុសក្នុងការផ្អែកលើសេចក្តីថ្លែងរបស់គាត់ក្នុងនាមជាអនុនាយករដ្ឋមន្ត្រី ដើម្បីសន្និដ្ឋានថា គាត់ផ្តល់ភាពស្របច្បាប់ដល់ចលនារបស់ ប.ក.ក[3900]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានជំទាស់ថា គាត់បានបរិហារ "បនក្បត់ទាំង ៧ នាក់" នៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ជំរុញឱ្យផ្តួលរំលំពួកគេ និងបានអំពាវនាវឱ្យមាន "បំផ្លាញ" និង "សម្លាប់ចោល"[3901] ពួកគេ ប៉ុន្តែ គ្រាន់តែអះអាងថា អ.ជ.ស.ដ មិនអាចផ្អែកលើភស្តុតាងទាំងនេះបានទេ ដោយសារតែវាត្រូវបានធ្វើឡើងក្នុងពេលមានសង្គ្រាម[3902]។ អង្គហេតុដែលថា សុន្ទរកថាទាំងអស់នេះត្រូវបានធ្វើឡើងក្នុងពេលជម្លោះ មិនបានធ្វើឱ្យការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដែលថា គាត់បានអំពាវនាវឱ្យមានការតស៊ូហិង្សាប្រឆាំងនឹងរបប លន់ នល់ និងការសម្លាប់មេដឹកនាំរបស់របបនោះ មិនត្រឹមត្រូវនោះទេ។ ចំពោះទឡ្ហីករណ៍ផ្សេងៗទៀតរបស់គាត់ ម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់ថា អ.ជ.ស.ដ មិនគិតគូរទៅលើផ្នែកផ្សេងៗនៃភស្តុតាង ទាក់ទងនឹងលក្ខណៈនៃសុន្ទរកថារបស់គាត់ជាទូទៅ និងតួនាទីរបស់គាត់ក្នុងការទំនាក់ទំនងរបស់ FUNK/GRUNK[3903] ប៉ុន្តែ ខកខានមិនបានបង្ហាញថាតើវាផ្ទុយគ្នាដោយវិធីណាទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ។ តាមពិត អង្គហេតុដែលថា សម្តេច សីហនុ ក៏មានតួនាទីនៅក្នុងការទំនាក់ទំនងរបស់ FUNK/GRUNK ដែរនោះ មិនកាត់បន្ថយកិច្ចខិតខំប្រឹងប្រែងផ្ទាល់របស់ម្ចាស់បណ្តឹងសាទុក្ខទេ។ ស្រដៀងគ្នានេះដែរ អង្គហេតុដែលថា សាក្សីបានលើកឡើងថា សុន្ទរកថាមួយចំនួនរបស់គាត់

[3898] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦៦ *លើកឡើងពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨២។

[3899] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦៦។

[3900] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦៦។

[3901] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨១, ជើងទំព័រ ១៨១៨។

[3902] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦៧។

[3903] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦៧, ជើងទំព័រ ៣២១០-៣២១១។

មានលក្ខណៈជាក់លាក់នោះ មិនផ្លាស់ប្តូរអង្គហេតុដែលថា សុន្ទរកថាដែលគាត់បានធ្វើអំពីរបប លន់ នល់ មានលក្ខណៈហិង្សានោះឡើយ។

1064. ជាចុងក្រោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ជ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានធ្វើឱ្យចលនា ប.ក.ក មានភាពស្របច្បាប់ នៅចន្លោះឆ្នាំ១៩៧០ និង ខែមេសា ឆ្នាំ ១៩៧៥[3904] មើលរំលងភស្តុតាងទាំងស្រុងដែល អ.ជ.ស.ជ ពឹងផ្អែកលើ ដូចជា តួនាទីរបស់គាត់ ក្នុងការរៀបចំ និងផ្សព្វផ្សាយសម្ភារៈឃោសនា ការបំពេញកាតព្វកិច្ចការទូតរបស់គាត់ និងតួនាទី របស់គាត់ក្នុងការទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ[3905]។

## *មូលដ្ឋានទី ១៩៩៖ ការចូលរួមក្នុងអង្គប្រជុំគណៈកម្មាធិការមជ្ឈិមក្នុងខែមិថុនា ឆ្នាំ១៩៧៤ និង ខែមេសា ឆ្នាំ១៩៧៥[3906]*

1065. **មូលដ្ឋានទី ១៩៩ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសផ្អែកអង្គហេតុ ក្នុងការសន្និដ្ឋានថា គាត់បានផ្តល់ការយល់ព្រមក្នុងការ ជម្លៀសប្រជាជននៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ និងនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ជាបន្តបន្ទាប់មកទៀត**

1066. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថា ការវាយតម្លៃរបស់ អ.ជ.ស.ជ លើភស្តុតាងទាក់ទងនឹងអង្គប្រជុំខែមិថុនា ឆ្នាំ១៩៧៤ និង ខែមេសា ឆ្នាំ១៩៧៥ អំពី ការជម្លៀសប្រជាជនចេញពីភ្នំពេញ មានលក្ខណៈលម្អៀង ឬមិនសមហេតុផល[3907]។

1067. ទាក់ទងនឹងអង្គប្រជុំខែមិថុនា ឆ្នាំ១៩៧៤ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា ការ ពិនិត្យរបស់ អ.ជ.ស.ជ លើការសន្និដ្ឋានរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ លើការចូលរួម របស់ គាត់ក្នុងអង្គប្រជុំនោះ បង្ហាញថា អ.ជ.ស.ជ មានភាពលម្អៀង[3908] ប៉ុន្តែ ខកខានមិនបានបដិសេធ

---

[3904] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៦៨។

[3905] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨២។

[3906] <u>មូលដ្ឋានទី ១៩៩៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការចូលរួមនៅក្នុងកិច្ចប្រជុំគណៈមជ្ឈិម ខែមិថុនា ឆ្នាំ១៩៧៤ និង ខែមេសា ឆ្នាំ១៩៧៥* កថាខណ្ឌ ១៦៦៩-១៦៨២។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៨ (អង់គ្លេស) ទំព័រ ៦៣ (បារាំង) ទំព័រ ៩៧ (ខ្មែរ)។

[3907] ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៨ (អង់គ្លេស) ទំព័រ ៦៣ (បារាំង) ទំព័រ ៩៧ (ខ្មែរ)។

[3908] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧០។

សច្ចធារណ៍នៃអនាគតតុលាការ[3909]។ តាមពិត សំអាងហេតុរបស់ អ.ជ.ស.ដ ទាក់ទងនឹងការប្រជុំនេះមិនបានបង្ហាញពីភាពលម្អៀងណាមួយទេ ដោយសារវាគ្រាន់តែកែតម្រូវសំអាងហេតុពីមុនរបស់ខ្លួន ដោយសារតែសាលដីកាសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ[3910]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3911] អ.ជ.ត.ក មិនបានសន្និដ្ឋានថា អ.ជ.ស.ដ លម្អៀងនោះទេ តែផ្ទុយទៅវិញ ថា អ.ជ.ស.ដ បានពឹងផ្អែកខុសលើផ្នែកនៃសក្ខីកម្មរបស់ ភី ភួន ទាក់ទងនឹងអង្គប្រជុំខែមេសា ឆ្នាំ១៩៧៥ ដើម្បីសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានឯកភាពជាមួយនឹងផែនការជម្លៀសប្រជាជនចេញពីភ្នំពេញ នៅក្នុងកិច្ចប្រជុំខែមិថុនា ឆ្នាំ១៩៧៤[3912]។ អ.ជ.ស.ដ បានទទួលស្គាល់កំហុសនោះនៅក្នុងសំណុំរឿង ០០២/០២[3913] បានពិនិត្យមើលសក្ខីកម្មរបស់ ភី ភួន ដោយ គិតពីភស្តុតាង*ទាំងមូល*[3914] និងក្រោយមក បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមតែ ក្នុងអង្គប្រជុំខែមេសា ឆ្នាំ១៩៧៥ ប៉ុណ្ណោះ មិនមែនក្នុងអង្គប្រជុំខែមិថុនា ឆ្នាំ១៩៧៤ ទេ[3915]។

1068. ទាក់ទងនឹងអង្គប្រជុំខែមេសា ឆ្នាំ១៩៧៥ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនយល់ស្របទៅនឹងការវិភាគភស្តុតាងរបស់ អ.ជ.ស.ដ ដែលផ្អែកលើការអះអាងមិនត្រឹមត្រូវចំនួនបី ហើយការអះអាងនីមួយបរាជ័យមិនបង្ហាញពីកំហុសណាមួយឡើយ។

1069. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃលើភាពអាចជឿជាក់បានរបស់ ភី ភួន។ ម្ចាស់បណ្តឹងសាទុក្ខបញ្ជាក់ឡើងវិញពីការអះអាងដែល អ.ជ.ត.ក[3916] បានបដិសេធ ថា អ.ជ.ស.ដ បានមើលរំលងភស្តុតាងដែលផ្ទុយទៅនឹងសក្ខីកម្មរបស់ ភី ភួន ហេតុដូច្នេះ មានកំហុសក្នុងការសន្និដ្ឋានថាគាត់អាចឱ្យជឿបាន។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែស្នើសុំឱ្យ អ.ជ.ត.ក វាយតម្លៃភស្តុតាងនេះឡើងវិញ ដូច្នេះ មើលរំលងទាំងកម្រិតដ៏ខ្ពស់នៃការគោរព ដែលផ្តល់ឱ្យ អ.ជ.ស.ដ ក្នុងការវាយតម្លៃលើភាពអាចជឿជាក់ និងទុកចិត្ត

---

[3909] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៤ (ការចោទប្រកាន់ដោយលំអៀង)។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២។

[3910] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៨៣៩ លើកឡើងពី ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០៩, ជើងទំព័រ ២៦៧៤។

[3911] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧០។

[3912] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០៩, ជើងទំព័រ ២៦៧៥។

[3913] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៨។

[3914] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៤-៥៨៧។

[3915] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៨។

[3916] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១១។

បាននៃភ័ស្តុតាង[3917] និងសំអាងហេតុដ៏ច្រើនដែល អ.ជ.ស.ដ បានផ្តល់[3918]។ តាមពិត អ.ជ.ស.ដ បានសន្និដ្ឋានថា សក្ខីកម្មរបស់ ភី ភួន មានភាពស៊ីសង្វាក់គ្នា និងច្បាស់លាស់ថា មេដឹកនាំ ប.ក.ក បានធ្វើការប្រជុំមួយនៅក្នុងខែមេសា ឆ្នាំ១៩៧៥ អំពីការជម្លៀសប្រជាជនចេញពីភ្នំពេញ ដែលម្ចាស់បណ្តឹងសាទុក្ខបានចូលរួម ហើយគាត់បានឯកភាពជាមួយនឹងសេចក្តីសម្រេចធ្វើការជម្លៀសនេះ[3919]។

1070. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ ខកខានមិនបានដោះស្រាយសក្ខីកម្មរបស់ សាឡុត បាន និង អឿន តាន ទាក់ទងនឹងពេលវេលារបស់ ភី ភួន នៅ ប-៥[3920] និងអសមត្ថភាពរបស់គាត់ក្នុងការស្តាប់ឮកិច្ចសន្ទនានៅក្នុងពេលប្រជុំ[3921] មិនគ្រប់គ្រាន់ក្នុងការបង្ហាញថា ការវាយតម្លៃរបស់ អ.ជ.ស.ដ លើភាពអាចជឿជាក់បានរបស់ ភី ភួន មិនត្រឹមត្រូវនោះទេ។ តាមពិត ការអានដោយយកចិត្តទុកដាក់នៃសក្ខីកម្មរបស់ ភី ភួន បង្ហាញថា មិនមានភាពផ្ទុយគ្នាបែបនោះទេ រវាង សាឡុត បាន និង ភី ភួន ចំពោះពេលវេលារបស់គាត់នៅ ប-៥[3922]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានទទួលស្គាល់ថា សាក្សីទាំងពីរនេះបានបញ្ជាក់ថា ភី ភួន បានធ្វើការជានីរសារ និងទទួលខុសត្រូវខាងម្ហូបអាហារនៅ ប-៥[3923]។ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា អ្នកយាមមិនអាចស្តាប់ឮការសន្ទនានៅក្នុងអង្គប្រជុំទេ ដោយសារតែចម្ងាយ ដែលជាធម្មតា ពួកគេត្រូវឈរឆ្ងាយពីមេដឹកនាំ ប.ក.ក។ ការអះអាងនេះមើលរំលងសក្ខីកម្មរបស់ ភី ភួន ដែលនៅក្នុងនោះ គាត់បានពន្យល់ថា ការដឹងរបស់គាត់អំពីខ្លឹមសារនៃការសន្ទនាទាំងនោះ មិនផ្អែកទាំងស្រុងលើអង្គហេតុថា គាត់បានយាមការប្រជុំនោះទេ ប៉ុន្តែ ផ្អែកផងដែរលើហេតុផលដែលថា គាត់ទទួលខុសត្រូវលើ

---

[3917] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩។

[3918] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៣-៥៨៨។

[3919] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៦, ៥៨៨។ *សូមមើលផងដែរ* ឯកសារ **E1/97.1** រ៉ចាម គុន *ហៅ* ភី ភួន ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 09.38.15-09.56.01 ទំព័រ ១២-១៨ ម៉ោង 10.09.04-10.22.08 ទំព័រ ២១-២៥។ ឯកសារ **E3/24** កំណត់ហេតុស្តាប់ចម្លើយ ភី ភួន EN 00223584។ ឯកសារ **E1/98.1** ភី ភួន ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 13.37.44-13.42.02 ទំព័រ ៥៧ បន្ទាត់ ៦-១៣ ម៉ោង 15.20.31-15.24.06 ទំព័រ ៨៣-៨៣។

[3920] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧៧។

[3921] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧៨។

[3922] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧៨។

[3923] ឯកសារ **E1/68.1** សាឡុត បាន *ហៅ* សូ ហុង ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ម៉ោង 11.28.03-11.30.40 ទំព័រ ៤៦ បន្ទាត់ ២០-២៤។ ឯកសារ **E1/97.1** រ៉ចាម គុន *ហៅ* ភី ភួន ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 09.33.36-09.35.59 ទំព័រ ១១ បន្ទាត់ ១០-១៩ ម៉ោង 10.26.50-10.29.38 ទំព័រ ២៧ បន្ទាត់ ១៥-២៣។

ការផ្តល់អាហារឱ្យអ្នកចូលរួមក្នុងអង្គប្រជុំនោះ[3924]។ ភី ភួន បានបញ្ជាក់ទៀតថា គាត់អាចមើលឃើញដប៉ាក្រាមដែលពួកគេគួរលើក្តាខៀន ក្នុងពេលប្រជុំខែមេសា ឆ្នាំ១៩៧៥[3925]។

1071. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា នួន ជា និងសក្ខីកម្មរបស់ម្ចាស់បណ្តឹងសាទុក្ខ ក៏ដូចជា សេចក្តីថ្លែងការណ៍របស់ អៀង សារី ស្របគ្នាទៅនឹងការរៀបរាប់របស់ ភី ភួន ទាក់ទងនឹងអង្គប្រជុំខែមេសា ឆ្នាំ១៩៧៥ នៅ ប-៥ ប៉ុន្តែ បរាជ័យមិនបានបង្ហាញទឡ្ហីករណ៍ណាមួយដែលបង្ហាញថា ការសន្និដ្ឋាននោះមិនត្រឹមត្រូវ[3926]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនយល់ស្របទៅនឹងការសន្និដ្ឋាននោះ និងលើកឡើងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ ខកខានមិនបានផ្តល់សំអាងហេតុសម្រាប់ការទទួលយកភ័ស្តុតាងរបស់ ភី ភួន ដោយផ្អែកលើភ័ស្តុតាងផ្ទុយគ្នានេះ[3927]។ ការអានសំអាងហេតុរបស់ អ.ជ.ស.ដ ដ៏ត្រឹមត្រូវ បង្ហាញថា ខ្លួនបានទទួលស្គាល់ភ័ស្តុតាងផ្ទុយគ្នាមួយចំនួន ស្តីពីការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងអង្គប្រជុំខែមេសា ឆ្នាំ១៩៧៥[3928] ប៉ុន្តែ នៅតែទទួលយកភ័ស្តុតាងរបស់ ភី ភួន ដោយសារតែអង្គជំនុំជម្រះសន្និដ្ឋានថា សក្ខីកម្មរបស់គាត់ អាចជឿជាក់បានផ្អែកលើ "ការបរិយាយស៊ីសង្វាក់គ្នា និងមានភាពច្បាស់លាស់ អំពីការប្រជុំខែមេសា ឆ្នាំ១៩៧៥"[3929] និងស្របគ្នាជាមួយនឹងសាក្សីជាច្រើន។ សាក្សីទាំងអស់នេះបញ្ជាក់ថា (i) មានការប្រជុំមួយក្នុងខែមេសា ឆ្នាំ១៩៧៥[3930] (ii) ប៉ុល ពត បើកមន្ទីរមួយនៅ ប-៥ ដើម្បីរៀបចំការរំដោះភ្នំពេញ[3931] (iii) ម្ចាស់បណ្តឹងសាទុក្ខនៅ ប-៥ ដើម្បីតាមដានការវាយសម្រុកចុងក្រោយនោះជាមួយនឹង ប៉ុល ពត, នួន ជា, និងលេខា ភូមិភាគផ្សេង

---

[3924] ឯកសារ **E1/97.1** រ៉ចាម តុន *ហៅ* ភី ភួន ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 09.33.36-09.35.59 ទំព័រ 11 បន្ទាត់ 10-19។

[3925] ឯកសារ **E1/97.1** រ៉ចាម តុន *ហៅ* ភី ភួន ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 09.33.36-09.35.59 ទំព័រ 11 បន្ទាត់ 10-19។

[3926] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧៩។

[3927] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៧៩។

[3928] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៣។

[3929] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៤។

[3930] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៥។

[3931] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៥ ជើងទំព័រ ១៨៣១។

ទៀត[3932] និង (iv) មានការប្រជុំមួយនៅដើមខែមេសា ឆ្នាំ១៩៧៥ ដែលពិភាក្សាពីការជម្លៀសប្រជាជនចេញពីភ្នំពេញ[3933]។

1072. ទីបី ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនមានមូលដ្ឋានថា អ.ជ.ស.ដ បានមើលរំលងភ័ស្តុតាងដោះបន្ទុកអំពីអវត្តមានរបស់គាត់ក្នុងការចូលរួមក្នុងសេចក្តីសម្រេចអំពីការជម្លៀសប្រជាជនចេញពីភ្នំពេញ[3934]។ ភ័ស្តុតាងដែលម្ចាស់បណ្តឹងសាទុក្ខយោងមិនគាំទ្រការអះអាងរបស់គាត់ទេ។ ឧទាហរណ៍ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា គាត់មិនអាចបោះឆ្នោតបានទេ ក្នុងនាមជាសមាជិកបក្ស[3935] ដោយបានយោងទៅលក្ខន្តិកៈ ប.ក.ក ឆ្នាំ១៩៧៦ ដែលមិនត្រូវបានអនុវត្តក្នុងឆ្នាំ ១៩៧៥[3936] ពីព្រោះ ដូចដែល អ.ជ.ស.ដ បានសន្និដ្ឋាន[3937] វាត្រូវបានអនុម័តិក្នុងសន្និបាតបក្សលើកទី៤ ក្នុងខែមេសា ឆ្នាំ១៩៧៦។ ផ្ទុយទៅវិញ លក្ខខន្តិកៈ ប.ក.ក ឆ្នាំ១៩៧១ បានចែងថា "សិទ្ធិផ្សេងៗឯទៀត [របស់បក្ខជនត្រៀម] សុទ្ធតែដូចបក្ខជនពេញសិទ្ធិដែរ"[3938]។ ស្រដៀងគ្នានេះដែរ ម្ចាស់បណ្តឹងសាទុក្ខយោងសក្ខីកម្មរបស់ សាឡុត បាន ដើម្បីគាំទ្រការអះអាងរបស់ខ្លួនដែលថា គាត់មិនជាប់ពាក់ព័ន្ធក្នុងបញ្ហាយោធាទេ ដោយមើលរំលងអង្គហេតុដែលថា សាឡុត បាន បានឃើញគាត់ចូលរួមក្នុងការប្រជុំនៅ ប-៥ ដែលជាកន្លែងដែលគាត់បានផ្តល់ជំនួយលើការចុះបញ្ជីអាវុធយុទ្ធភ័ណ្ឌ[3939]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3940] អៀង សារី មិនបានរៀបរាប់នៅក្នុងខែធ្នូ ឆ្នាំ១៩៨៦ ថា ម្ចាស់បណ្តឹងសាទុក្ខជាប់ពាក់ព័ន្ធក្នុងការសម្រេចជម្លៀសប្រជាជនចេញពីភ្នំពេញទេ[3941]។

---

[3932] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៥ ជើងទំព័រ ១៨៣២។ *សូមមើលផងដែរ* ឯកសារ **E1/68.1** សាឡុត បាន *ហៅ* សូ ហុង ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ម៉ោង 11.23.53-11.28.03, ទំព័រ 45 បន្ទាត់ 14-22។

[3933] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣៣, ៥៨៥ (ជើងទំព័រ ៥៦១, ១៨៣៣)។

[3934] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨១-១៦៨២។

[3935] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣ (ប្រជាធិបតេយ្យប្រមូលផ្តុំ)។

[3936] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨១ ជើងទំព័រ ៣២៣៩។

[3937] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៨។

[3938] ឯកសារ **E3/8380** លក្ខន្តិកៈ ប.ក.ក ឆ្នាំ១៩៧១ មាត្រា ៣។

[3939] ឯកសារ **E1/68.1** សាឡុត បាន *ហៅ* សូ ហុង ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ម៉ោង 11.23.53-11.28.03, ទំព័រ 45 បន្ទាត់ 14-22។

[3940] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៨២។

[3941] ឯកសារ **E3/89** បទសម្ភាសន៍ អៀង សារី ដោយលោក Stephen Heder ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៨៦ EN 00417627។

## *មូលដ្ឋានទី ២០៤៖ វគ្គបណ្តុះបណ្តាល*[3942]

1073. **មូលដ្ឋានទី ២០៤ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសផ្នែកអង្គហេតុ ក្នុងការសន្និដ្ឋានថា គាត់បានចូលរួម និងបានបង្រៀន នៅក្នុងវគ្គសិក្សានយោបាយ ដែលផ្តោត*ជាអាទិ៍* លើការកំណត់អត្តសញ្ញាណ "ខ្មាំង" និង "ជនក្បត់"។**

1074. ទទ្បីករណ៍នេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញពីកំហុសណាមួយក្នុងផ្នែកអង្គហេតុ និងអង្គច្បាប់នៅក្នុងការសន្និដ្ឋានរបស់ អ.ជ.ស.ជ លើ (i) សេចក្តីថ្លែងរបស់គាត់អំពីខ្មាំង និងជនក្បត់ ឬ (ii) តួនាទីរបស់គាត់ក្នុងអំឡុងពេលសិក្សានយោបាយ និងខ្លឹមសាររបស់ពួកវា។

*អ.ជ.ស.ជ បានវាយតម្លៃយ៉ាងត្រឹមត្រូវលើសេចក្តីថ្លែងរបស់ម្ចាស់បណ្តឹងសាទុក្ខ អំពីខ្មាំង និងជនក្បត់*

1075. ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ជ បានភ្ជាប់គាត់ខុសទៅនឹងសេចក្តីថ្លែងអំពីការកំណត់អត្តសញ្ញាណ "ខ្មាំង" និង ការប្រម៉ាញ់រក "ជនក្បត់"[3943] ដោយការពឹងផ្អែកលើសាក្សីពីររូប ដែលត្រូវបានចោទថាមិនមានភាពគួរឱ្យជឿជាក់ និងអាចទុកចិត្តបាន។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញពីកំហុសណាមួយនៅក្នុងការវាយតម្លៃរបស់ អ.ជ.ស.ជ អំពីភាពអាចជឿជាក់ និងទុកចិត្តបានរបស់ អែម អឿន និង ឯក ហេន ដោយពិចារណាលើការគោរព ដែលត្រូវបានផ្តល់ឱ្យ អ.ជ.ស.ជ ក្នុងការវាយតម្លៃភ័ស្តុតាងនៅចំពោះមុខខ្លួន[3944]។

1076. ទាក់ទងនឹងសក្ខីកម្មរបស់ អែម អឿន ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ជ មានកំហុសដោយមើលរំលងព័ត៌មានផ្ទុយគ្នា ដែលប៉ះពាល់ដល់ភាពអាចជឿជាក់បានរបស់គាត់[3945]។ ដូចបានបង្ហាញនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២២ អ.ជ.ស.ជ បានពិចារណាលើសក្ខីកម្មរបស់ អែម អឿន យ៉ាងត្រឹមត្រូវថាអាចជឿជាក់បាន[3946]។ ភាពផ្ទុយគ្នាដែលលើកឡើង

---

[3942] <u>មូលដ្ឋានទី ២០៤</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *វគ្គរៀនសូត្រ* កថាខណ្ឌ ១៧៥៤-១៧៦២, ១៩២៨-១៩៣១។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧០ (អង់គ្លេស) ទំព័រ ៦៥ (បារាំង) ទំព័រ ៩៩ (ខ្មែរ)។

[3943] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥៥។

[3944] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[3945] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥៨។

[3946] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២។

ដោយម្ចាស់បណ្ដឹងសាទុក្ខ[3947] គឺជាផ្នែកបន្ទាប់បន្សំបើធៀបទៅនឹងចម្លើយសំខាន់របស់ អែម អឿន ដែលថា ម្ចាស់បណ្ដឹងសាទុក្ខបានបង្រៀននៅបុរីកីឡា បានលើកទឹកចិត្តឱ្យអ្នកចូលរួមកំណត់អត្តសញ្ញាណជនក្បត់ និងខ្មាំង[3948]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[3949] ការវាយតម្លៃរបស់ អ.ជ.ស.ដ លើសក្ខីកម្មរបស់ អែម អឿន មានភាពសមហេតុផល ដោយសារតែសាក្សីបានផ្ដល់សក្ខីកម្មស៊ីសង្វាក់គ្នា និង លម្អិត លើទីកន្លែង និងប្រធានបទដែលម្ចាស់បណ្ដឹងសាទុក្ខបានពិភាក្សាក្នុងអំឡុងពេលវគ្គសិក្សានយោបាយដែលបានចូលរួម[3950] និងបានបញ្ជាក់ដោយសាក្សីផ្សេងទៀត[3951]។

1077. ទាក់ទងនឹងសក្ខីកម្មរបស់ ឯក ហេន ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងថា គាត់ផ្ដល់ព័ត៌មានច្របូកច្របល់អំពីពេលវេលានៃការប្រជុំនៅបុរីកីឡា និងអត្តសញ្ញាណរបស់វាគ្មិនដែលបរិហារអំពីខ្មាំង[3952]។ ដូចដែលបានបង្ហាញនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២០ អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវលើសក្ខីកម្មរបស់ ឯក ហឿន ថាអាចជឿជាក់បាន។ ឯក ហឿន មានភាពស៊ីសង្វាក់គ្នាលើសភាពនៃសេចក្ដីថ្លែងរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងអំឡុងពេលវគ្គសិក្សានយោបាយដែលគាត់បង្រៀននៅបុរីកីឡា។ ចំពោះពេលវេលាវិញ គាត់បានលើកឡើងថា ម្ចាស់បណ្ដឹងសាទុក្ខ និង នួន ជា បានផ្ដល់ការបណ្ដុះបណ្ដាលពីរដាច់ដោយឡែកពីគ្នាក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨ ការសិក្សាមួយដែល (i) នួន ជា បាននិយាយអំពីខ្មាំងនៅក្នុងភូមិភាគឧត្តរ និងបាននិយាយអំពីអំពើក្បត់ជាតិរបស់ កុយ ធួន[3953] និងការសិក្សាមួយទៀតដែល (ii) ម្ចាស់បណ្ដឹងសាទុក្ខបាននិយាយអំពីរបប

---

[3947] ភាពផ្ទុយគ្នាបានលើកឡើងទាក់ទងនឹងកាលៈទេសៈនៃមរណភាពរបស់ម្ដាយលោក អែម អឿន (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៥៨) និង ថិរៈវេលាជាក់លាក់នៃវគ្គរៀនសូត្រដែលត្រូវបានធ្វើឡើង (ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៥៧-១៧៥៨)។

[3948] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៥៨។

[3949] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៥៧។

[3950] ឯកសារ **E1/115.1** អែម អឿន ប្រតិចារឹក ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១២ ម៉ោង 10.10.31-10.31.05 ទំព័រ 25-33 ម៉ោង 11.18.00-11.23.53 ប្រតិចារឹក ២៣។ ឯកសារ **E1/113.1** អែម អឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 14.22.12-15.07.54 ទំព័រ 80-87 ម៉ោង 15.35.36-15.43.37 ទំព័រ 97-99។

[3951] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ **១២៤៧៣** *លើកឡើងពី* ឯកសារ **E1/73.1** ពាន ឃាន ប្រតិចារឹក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ ម៉ោង 10.14.52 -10.24.01 ទំព័រ 22-25។ ឯកសារ **E1/217.1** ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ទំព័រ 40-48, 63, 78-82, 87-88, 90-98។

[3952] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៥៩។

[3953] ឯកសារ **E1/217.1** ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.37.13-11.43.46 ទំព័រ 50-51។ ឯកសារ **E3/474** កំណត់ហេតុស្ដាប់ចម្លើយ ឯក ហេន EN 00205049-50។

ការងារ[3954] និងគិញវៀតណាម និងបានផ្តល់យុត្តិកម្មនៃការចាប់ខ្លួន ប៉ង់ ថា "ដោយសារគាត់ជា ប៉ង់ អ្នកក្បត់សហការជាមួយយួន ចូលដៃជាមួយយួន"[3955]។ នៅពេលវាយតម្លៃសក្ខីកម្មរបស់គាត់ ក្នុងបរិបទភ័ស្តុតាង អ.ជ.ស.ដ ប្រាកដថា ការបណ្តុះបណ្តាលដែល ផ្តល់ឱ្យដោយ នួន ជា និង ដោយម្ចាស់បណ្តឹងសាទុក្ខ បានធ្វើឡើងក្នុងឆ្នាំ១៩៧៦ និង ១៩៧៨ ដោយសារតែ កុយ ធួន ត្រូវបាន ចាប់ខ្លួនក្នុងឆ្នាំ ១៩៧៦[3956] ហើយ ប៉ង់ ក្នុងឆ្នាំ១៩៧៨[3957]។ ម្ចាស់បណ្តឹងសាទុក្ខបរាជ័យក្នុងការ បង្ហាញថា ការយល់ច្រឡំរបស់សាក្សីអំពីឆ្នាំដែលគាត់បាន ចូលរួមក្នុងការបណ្តុះបណ្តាលរបស់ ម្ចាស់បណ្តឹងសាទុក្ខ បានធ្វើឱ្យការពឹងផ្អែករបស់ អ.ជ.ស.ដ លើសក្ខីកម្មរបស់គាត់មិនត្រឹមត្រូវ[3958]។

### *អ.ជ.ស.ដ បានវាយតម្លៃយ៉ាងត្រឹមត្រូវលើតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងអំឡុងពេលបង្រៀន នយោបាយ និងខ្លឹមសាររបស់ការបង្រៀនទាំងនោះ*

1078. ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ មានកំហុសក្នុងការផ្អែកលើការចូលរួមរបស់គាត់ក្នុង វគ្គបង្រៀននយោបាយ ដើម្បីសន្និដ្ឋានថា គាត់បានចូលរួមចំណែកក្នុងគោលបំណងរួម[3959]។

1079. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខបានអះអាងដោយមិនត្រឹមត្រូវថា ការលើកឡើងរបស់គាត់នៅក្នុងការ ប្រជុំទាំងអស់នេះមិនមានអ្វីទាក់ទងនឹងគោលនយោបាយរបស់ ប.ក.ក ទេ ប៉ុន្តែជាទូទៅ អំពី ផែនការសេដ្ឋកិច្ច[3960]។ វិធីសាស្ត្រមួយផ្នែកម្តងៗរបស់ម្ចាស់បណ្តឹងសាទុក្ខ[3961] ខកខានមិនបាន ពិចារណាលើភ័ស្តុតាងជារួម។ តាមពិត ម្ចាស់បណ្តឹងសាទុក្ខមើលរំលងទម្ងន់នៃភ័ស្តុតាង ដែល អ.ជ.ស.ដ សំអាងលើ ក្នុងការសន្និដ្ឋានថា ការបង្រៀនរបស់គាត់ទាក់ទងទៅនឹងការកំណត់ អត្តសញ្ញាណ "ខ្មាំង" និងស្វែងរក "ជនក្បត់"[3962]។ ទាំង អែម អឿន និង ឯក ហឿន បានផ្តល់

---

[3954] ឯកសារ **E1/217.1** ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.18.47-11.21.13 ទំព័រ 43 បន្ទាត់ 1-21។ ឯកសារ **E3/474** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន EN 00205049។ ឯកសារ **E3/4635** ឯក ហេន កំណត់ហេតុរបស់ DC-Cam EN 00662014។

[3955] ឯកសារ **E1/217.1** ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 11.26.06-11.28.02 ទំព័រ 45 បន្ទាត់ 17-20 ម៉ោង 11.29.00-11.33.02 ទំព័រ 47-48។

[3956] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៩។

[3957] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១៣៩។

[3958] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៥៩។

[3959] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦០-១៧៦២។

[3960] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦០។

[3961] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៦០-១៧៦២។

[3962] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០៧ ជើងទំព័រ ១៩០៥។

សក្ខីកម្មថា គាត់បានទទួចឱ្យសិក្ខាកាមកំណត់អត្តសញ្ញាណខ្មាំងបង្កប់ ផ្អែកលើវិធីសាស្ត្រ ជាក់លាក់ និងមិនត្រូវអនុវត្តតាមឧទាហរណ៍របស់ពួកក្បត់ ដែលឃុបឃិតជាមួយវៀតណាមទេ[3963]។ ម្ចាស់បណ្ដឹងសាទុក្ខក៏មើលរំលងសក្ខីកម្មរបស់ ភី ភួន ផងដែរ ដែលបានលើកឡើងថា ម្ចាស់បណ្ដឹងសាទុក្ខបានផ្ដល់វគ្គបណ្ដុះបណ្ដាលមួយនៅ ក-១៥ ដែលបានពិភាក្សាអំពីស្ថានភាពនយោបាយខាងក្នុង និងខាងក្រៅ និង "ខ្មាំងទូទៅ"[3964]។ ម្ចាស់បណ្ដឹងសាទុក្ខក៏បានបំភ្លៃភ័ស្តុតាងផងដែរ។ ឧទាហរណ៍ គាត់អះអាងថា អ.ជ.ស.ដ បានផ្អែកដោយមិនត្រឹមត្រូវលើសក្ខីកម្មរបស់ ពាន ឃាន ដែលអះអាងថា គាត់បានលើកឡើងថា វគ្គនយោបាយគឺនិយាយតែអំពីគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ "ប្រទេសធ្វើម៉េចឱ្យរីកចម្រើន"[3965] ដែលតាមពិតនោះ គាត់ក៏បានលើកឡើងផងដែរថា បទបង្ហាញរបស់ម្ចាស់បណ្ដឹងសាទុក្ខ និងមេដឹកនាំផ្សេងទៀតនៅបុរីកីឡា មានការណែនាំឱ្យកំណត់អត្តសញ្ញាណខ្មាំងបង្កប់ រួមទាំងភ្នាក់ងារ សេ.អ៊ី.អា និង កា.ហ្សេ.បេ និងជនជាតិវៀតណាម ដើម្បីការពារប្រទេសពីការឈ្លានពានរបស់វៀតណាម ឬការត្រឡប់មកវិញរបស់ចក្រពត្តិអាមេរិក[3966]។

1080. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃលើតួនាទីរបស់គាត់ក្នុងពេលប្រជុំទាំងនេះ ដោយអះអាងថា គាត់មិនបាននិយាយអ្វីច្រើនទេ[3967]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញពីកំហុសណាមួយទេ និងគ្រាន់តែស្នើឱ្យមានការបកស្រាយផ្សេងលើភ័ស្តុតាង ដែល អ.ជ.ស.ដ ផ្អែកលើ[3968]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្ដឹងសាទុក្ខបានបង្រៀន និងបានមានវត្តមាននៅក្នុងវគ្គបណ្ដុះបណ្ដាល ដែល

---

[3963] <u>អែម អឿន</u>៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៤២-៣៩៤៣, ៣៩៦៧។ <u>ឯក ហេន</u>៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩០ *សូមមើលផងដែរ* កថាខណ្ឌ ៣២១៦ (ជើងទំព័រ ១០៨២៥)។

[3964] ឯកសារ **E1/96.1** *ភី ភួន* ប្រតិចារឹក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 14.25.02-14.34.24 ទំព័រ 77-79។ ឯកសារ **E1/100.1** *ភី ភួន* ប្រតិចារឹក ថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ ម៉ោង 15.26.35-15.35.43 ទំព័រ 94-96។ ម្ចាស់បណ្ដឹងសាទុក្ខក៏បានធ្វើជាមិនអើពើនឹងសក្ខីកម្មរបស់លោកស្រី ប៊ិត ណា ដែលបានថ្លែងថាគាត់បានចូលរួមយ៉ាងសកម្មជាមួយនឹង ប៉ុល ពត និង នួន ជា នៅក្នុងវគ្គនយោបាយ ដោយបានណែនាំឱ្យស្រាវជ្រាវរកខ្មាំងផ្ទៃក្នុង (ឯកសារ **E1/502.1** លោកស្រី ប៊ិត ធឿន *ហៅ* ប៊ិត ណា ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង 10.08.26-10.45.14 ទំព័រ 22-23, 25, 28)។

[3965] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៦២ ជើងទំព័រ ៣៤០៦។

[3966] ឯកសារ **E1/73.1** ពាន ឃាន ប្រតិចារឹក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ ម៉ោង 10.08.24-10.24.01 ទំព័រ 20-24។

[3967] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៦១។

[3968] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៧៦១-១៧៦២។

មេដឹកនាំ ប.ក.ក បាននិយាយអំពីខ្មាំងខាងក្នុងប្រទេស និងខ្មាំងដែលបង្កប់ក្នុងបក្ស[3969] ដោយបានកំណត់ឈ្មោះថាជា ខ្មាំងវៀតណាម "ភ្នាក់ងារ" វៀតណាម[3970] និងអតីតទាហានសាធារណរដ្ឋខ្មែរ[3971] និងការចាំបាច់ត្រូវ "ស្វែងរក" និង "ចម្រាញ់" និង "សម្រិតសម្រាំង" ទាហានដែលបង្កប់ក្នុងរបបមុន[3972]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តាច់ខ្លួនគាត់ចេញពីយោបល់ដែលបានធ្វើឡើងដោយមេដឹកនាំ ប.ក.ក ផ្សេងទៀតទេ។

### *មូលដ្ឋានទី ១៨២៖ កំហុសអំពីតួនាទីរបស់ ខៀវ សំផន ទាក់ទងនឹងសហករណ៍*[3973]

1081. **មូលដ្ឋានទី ១៨២ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុក្នុងការសន្និដ្ឋានថា គាត់បានជំរុញ បានគាំទ្រ និង/ឬ បានយល់ស្របនឹងគោលដៅក្នុងការបំពេញគោលបំណងសេដ្ឋកិច្ច និងមនោគមន៍វិជ្ជា និងថា គាត់បានដឹងអំពីការធ្វើបាបប្រជាជន និងអំពីឧក្រិដ្ឋកម្ម ដូច្នេះ បានបង្ហាញថា គាត់មាន*ធាតុផ្សំអត្តនោម័តិ* ដែលតម្រូវសម្រាប់ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍ និងការដ្ឋាន។**

1082. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខមើលរំលងលើវិធីសាស្ត្រពិនិត្យរួមលើភស្តុតាងទាំងមូលរបស់ អ.ជ.ស.ដ និងមិនបានបង្ហាញថា ការវាយតម្លៃរបស់ អ.ជ.ស.ដ មិនសមហេតុផល ទាក់ទងនឹង (i) សុន្ទរកថា/សេចក្តីថ្លែងការណ៍របស់គាត់ និង (ii) ការចូលរួមចំណែករបស់គាត់ក្នុងគោលនយោបាយឧក្រិដ្ឋ។

1083. ទាក់ទងនឹងសុន្ទរកថា/សេចក្តីថ្លែងការណ៍ផ្ទាល់របស់គាត់ ម្ចាស់បណ្តឹងសាទុក្ខវាយតម្លៃសេចក្តីថ្លែងមួយចំនួនដោយមិនត្រឹមត្រូវក្នុងលក្ខណៈដាច់ដោយឡែក ក្នុងគោលបំណងបង្ហាញថា មិនមានឯកសារមួយណាមានភាពគ្រប់គ្រាន់ដើម្បីបង្ហាញពីការដឹងរបស់គាត់ថា ឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងនៅតាមសហករណ៍ទេ[3974]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍

---

[3969] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៨។

[3970] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥១៧។

[3971] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៨ ជើងទំព័រ ១៣៣៧៣។

[3972] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៨, ៤០៥៤។

[3973] <u>មូលដ្ឋានទី ១៨២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសអំពីតួនាទីរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងសហករណ៍* កថាខណ្ឌ ១៥១១-១៧។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៣ (អង់គ្លេស) ទំព័រ ៥៨ (បារាំង) ទំព័រ ៨៩-៩០ (ខ្មែរ)។

[3974] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១១-១៥១៣។

ផ្អែកទាំងស្រុងលើសេចក្ដីថ្លែងការណ៍ *ប្រតិសកម្ម* របស់គាត់[3975] ដោយសារគាត់មើលរំលង ភ័ស្តុតាងទាំងអស់ដែល អ.ជ.ស.ដ បានពឹងផ្អែកលើ[3976]។

1084. ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[3977] សុន្ទរកថាជាច្រើនរបស់គាត់បង្ហាញថា គាត់បានជំរុញ គាំទ្រ និង/ឬយល់ស្របនឹងគោលនយោបាយឧក្រិដ្ឋ ទាក់ទងនឹងសហករណ៍[3978]។ ឧទាហរណ៍ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ គាត់បាននិយាយទៅកាន់ប្រជាជនអំពី "ការបង្កបង្កើនផល" ប្រមូលផលស្រែពីរដងក្នុងមួយឆ្នាំ "ធ្វើការទាំងថ្ងៃទាំងយប់ [...] ឥតឈប់សម្រាក និងធ្វើការលះបង់ដ៏ច្រើនឥតគណនា"[3979]។ នៅក្នុងសុន្ទរកថាខែមេសា ឆ្នាំ១៩៧៨ គាត់បានប្រកាសថា ដោយហេតុថា គោលដៅប្រមូលផលផលិតកម្មដំណាំស្បៀងបីតោន ក្នុងមួយហិកតាត្រូវបានបំពេញ បក្សបានបង្កើនការនាំចេញស្រូវ និងបានសម្រេចបង្កើនគោលដៅផលិតកម្ម និងការនាំចេញកាន់តែច្រើនថែមទៀត[3980]។ នៅក្នុងសុន្ទរកថាខែមករា ឆ្នាំ១៩៧៩ ម្ចាស់បណ្ដឹងសាទុក្ខបានបញ្ជាក់ថា ប្រជាជន "កំពុងតស៊ូយ៉ាងស្វាហាប់បង្កបង្កើនផលឱ្យដល់កម្រិតអតិបរមា ជួយទ្រទ្រង់*គ្រប់ស្ថានការណ៍* ម្ចាស់ការ ផ្គត់ផ្គង់ស្បៀង *តាមការកំណត់របស់បក្ស*"[3981]។

1085. ទាក់ទងនឹងការចូលរួមចំណែករបស់គាត់ក្នុងគោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ ម្ចាស់បណ្ដឹងសាទុក្ខចោទប្រកាន់ដោយគ្មានមូលដ្ឋានពីកំហុសអង្គហេតុជាច្រើននៅក្នុងការសន្និដ្ឋាន

[3975] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥១១។

[3976] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១ (ការដឹងឮពីឧក្រិដ្ឋកម្មនៅក្នុងសហករណ៍ និងនៅតាមការដ្ឋាននានា)។

[3977] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥១៣។

[3978] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៦ ជើងទំព័រ ១៣០៦៧ (បានលើកឡើងពីគ្រប់ប្រភព) *សូមមើលផងដែរ* ជើងទំព័រ ១៣០៧២។

[3979] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៦ ជើងទំព័រ ១៣០៦៧ *លើកឡើងពី* ឯកសារ **E3/118** FBIS *លោក ខៀវ សំផន ថ្ងៃទី២១ ខែមេសា សារជ័យជំនះនៅតាមវិទ្យុទីក្រុងភ្នំពេញ* ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ EN 00166994-95។

[3980] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០៩ ជើងទំព័រ ១៣០៤១ *លើកឡើងពី* ឯកសារ **E3/169** *សុន្ទរកថារបស់សមមិត្ត ខៀវ សំផន នៅក្នុងឱកាសពិធីបុណ្យខួប* ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ EN 00280393, 400។ ឯកសារ **E3/1361** FBIS *សុន្ទរកថារបស់ ខៀវ សំផន* ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ EN 00168816។

[3981] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៦ ជើងទំព័រ ១៣០៦៧ *លើកឡើងពី* ឯកសារ **E3/296** FBIS *សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាល អំពាវនាវស្វែងរកជំនួយដើម្បីប្រយុទ្ធនឹងការឈ្លានពាន របស់សាធារណរដ្ឋសង្គមនិយមវៀតណាម (SRV)* ចុះថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ EN 00169295 (សេចក្ដីថ្លែងការណ៍អានដោយម្ចាស់បណ្ដឹងសាទុក្ខ) (គូសបញ្ជាក់បន្ថែម)។

របស់ អ.ជ.ស.ជ[3982]។ ការអះអាងរបស់គាត់ភាគច្រើនលើកឡើងវិញពីការអះអាងមិនត្រឹមត្រូវ ដែលបានធ្វើឡើងនៅក្នុងមូលដ្ឋានទី ២០០, ២០១, ២០២ និង ២០៣ ដែលត្រូវបានលើកឡើងជាលម្អិតនៅក្នុងផ្នែកផ្សេងៗទៀតនៃចម្លើយតបនេះ។

1086. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ជ មានកំហុសក្នុងការសន្និដ្ឋានថា គាត់គឺជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ[3983]។ គាត់បានលើកឡើងវិញពីការអះអាងមិនត្រឹមត្រូវនេះថា មុខងាររបស់គាត់ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋគ្រាន់តែជាពិធីការ[3984] និងកាត់បន្ថយសារសំខាន់នៃការចូលរួមរបស់គាត់ក្នុងអង្គប្រជុំគណៈម្ចាធិការអចិន្ត្រៃយ៍[3985]។

1087. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ជ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹងអំពីរបាយការណ៍ស្តីពីទស្សនៈកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ទៅកាន់ភូមិភាគពាយ័ព្យ[3986] ដែលបានសន្និដ្ឋានថា តួនាទីរបស់សហករណ៍ក្នុងការស្រូបយកប្រជាជនថ្មីទាំងអស់ រួមបញ្ចូលទាំង "ពួកអានេះ" និង "សមាសភាពអាក្រក់"[3987]។ វាមានភាពសមហេតុផលសម្រាប់ អ.ជ.ស.ជ ក្នុងការធ្វើការសន្និដ្ឋាននេះ[3988] មិនមែនដោយសារតែអតីតភាពរបស់គាត់នៅក្នុងបក្សប៉ុណ្ណោះទេ តែថែមទាំងដោយសារតែគាត់បានចូលរួមដោយផ្ទាល់ក្នុងការបង្កើតផែនការ និងគោលនយោបាយ ដែលបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍នោះ[3989]។ ដូចដែល អ.ជ.ស.ជ បានសន្និដ្ឋាន ប៉ុល ពត, នួន ជា, ម្ចាស់បណ្តឹងសាទុក្ខ, អៀង សារី និង សុន សេន បានជួបគ្នាជាប្រចាំក្រោយខែមេសា ឆ្នាំ១៩៧៥ ជាមួយនឹងលេខាភូមិភាគ និងតំបន់ ដើម្បីពិភាក្សាអំពីគោលនយោបាយ និងផែនការដើម្បីអភិវឌ្ឍប្រទេស រួមទាំងការបង្កើតសហករណ៍[3990] ហើយម្ចាស់បណ្តឹងសាទុក្ខបាន

[3982] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១៤។

[3983] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១៤។ *មិនទៀតលើ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៤។

[3984] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០២ (ប្រធានគណៈប្រធានរដ្ឋ)។

[3985] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣ (ការចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍)។

[3986] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១៥ *ដែលរិះគន់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៨។

[3987] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៧។

[3988] ក៏ដូចជាការសន្និដ្ឋានទាក់ទងនឹងការដឹងឮរបស់គាត់អំពីឯកសារគោលនយោបាយ ខែកញ្ញា ឆ្នាំ១៩៧៥៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩១។

[3989] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៨, ៤២២៥។

[3990] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៨៤ (*យោងទំព័រ* ១២៩៦០, ១២៩៦២-១២៩៦៣) ៣៨៨៥។

ចូលរួមក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើន រួមទាំងការប្រជុំមួយដែលធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ដែលបានពិភាក្សាពីបញ្ហាកសិកម្ម គ្រោះរាំងស្ងួត និងឧស្សាហកម្ម[3991]។

1088. ទីបី ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹងអំពីលក្ខខណ្ឌរស់នៅតាមមូលដ្ឋាន ដោយយោងទៅលើរបបរាយការណ៍មានលក្ខណៈជាប្រព័ន្ធ[3992] និងបានរៀបរាប់ឡើងវិញពីការអះអាងថា សហករណ៍ និងការដ្ឋាន បានបង្កើតឡើងដោយមានគោលបំណងសំខាន់បំផុតដើម្បីពង្រឹងជីវភាពរស់នៅ[3993]។ ការអះអាងនេះមិនត្រឹមត្រូវ[3994] និងមើលរំលងភស្តុតាងទាំងអស់ដែលគាំទ្រការសន្និដ្ឋានរបស់ អ.ជ.ស.ដ[3995]។

1089. ទីបួន ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[3996] និងដូចបានរៀរាប់លម្អិតក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២០១[3997] អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមចំណែកក្នុងគោលនយោបាយសហករណ៍ដែលមានលក្ខណៈឧក្រិដ្ឋ ដូចដែលគាត់ត្រូវបានរាយការណ៍ក្នុងការផ្សាយតាមវិទ្យុថា បង្ហាញរដ្ឋធម្មនុញ្ញថ្មី ក្នុងអំឡុងពេលសមាជជាតិ ខែធ្នូ ឆ្នាំ១៩៧៥[3998] ថា បានពន្យល់ថា ប្រជាជនពិតជាបានធ្វើការជាសមូហភាពនៅតាមស្រែចម្ការ និងបានអំពាវនាវទៅកាន់ប្រជាជនឱ្យ "រួមគ្នាបង្កបង្កើនផលដើម្បីកសាង និងការពារប្រទេស"[3999]។

---

[3991] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩១ *ជើងទំព័រ* ១២៩៧៧។

[3992] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១៦ *ដែលរិះគន់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៣។ *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១-១៥។

[3993] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១៦។

[3994] ទឡ្ហីករណ៍នេះបានធ្វើឡើងក្នុងពេលជំនុំជម្រះ ត្រូវបានបដិសេធដោយ អ.ជ.ស.ដ នៅក្នុង ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៩។

[3995] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១ (ទទួលស្គាល់ថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង)។

[3996] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៥១៧។

[3997] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ២០១ (បានចូលរួមក្នុងសន្និបាតជាតិក្នុងឆ្នាំ១៩៧៥)។

[3998] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩៧ *ជើងទំព័រ* ១២៩៩១-១២៩៩២។

[3999] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩៧ *ជើងទំព័រ* ១២៩៩១ *យោង* **E3/273** កម្រងសារព័ត៌មាន FBIS *របាយការណ៍ ខៀវ សំផន* ចុះថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៦ KH 00657436-53 (ត្រង់ 00657447៖ "គ្រប់គ្នាធ្វើការនៅតាមស្រែចំការ ពីព្រោះកម្មករយោង អនុវត្តប្រព័ន្ធការងារសមូហភាព")។ **E3/1356** សារព័ត៌មាន FBIS *សមាជជាតិត្រូវបានប្រារព្ធឡើង ហើយរដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័ត* ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៥ EN 0066389294។

### *មូលដ្ឋានទី ២២២៖ កំហុសស្តីពីការដឹងអំពីឧក្រិដ្ឋកម្មទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍*[4000]

1090. **មូលដ្ឋានទី ២២២ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ក្នុងការសន្និដ្ឋានថា គាត់បានផ្តល់ការណែនាំទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ដែលជាផ្នែកមួយនៃគោលនយោបាយបង្កើនចំនួនប្រជាជន នៅក្នុងកិច្ចប្រជុំមួយនៅវត្តឧណ្ណាលោម និងថា គាត់បានលើកកម្ពស់គោលនយោបាយនេះដោយផ្ទាល់នៅក្នុងសុន្ទរកថានានារបស់គាត់ ដើម្បីបង្ហាញថា គាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ ក្នុងនាមជាសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួម។**

1091. មូលដ្ឋាននេះបរាជ័យ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា (i) គាត់ "បានអប់រំដល់កម្មាភិបាលពីភាពចាំបាច់ក្នុងការផ្តាច់ខ្លួនចេញពីឪពុកម្តាយ ហើយបង្គាប់ឱ្យគ្រប់ក្រសួងត្រូវរៀបចំអាពាហ៍ពិពាហ៍" សម្រាប់យុវជនទាំងអស់ ដើម្បីឱ្យគូស្រករអាចបង្កើតកូនដើម្បីបង្កើន "កម្លាំងដើម្បីការពារប្រទេស"[4001] និង (ii) គាត់បានលើកកម្ពស់គោលនយោបាយបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យឱ្យបានឆាប់រហ័ស[4002]។

1092. ទាក់ទងនឹងសេចក្តីណែនាំលើការរៀបអាពាហ៍ពិពាហ៍ ដែលគាត់ផ្តល់ឱ្យនៅក្នុងកិច្ចប្រជុំនៅវត្តឧណ្ណាលោម នៅចុងឆ្នាំ១៩៧៥ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសំអាងរបស់ អ.ជ.ស.ដ លើសក្ខីកម្មរបស់ ជា ឡៀប ដែលខ្លួនពិចារណាថា "អាចជឿជាក់បាន និងមានភាពស្របគ្នា"[4003] មិនត្រឹមត្រូវនោះឡើយ[4004]។ គាត់គ្រាន់តែយោងទៅលើមូលដ្ឋានទី ១៦៦ នៃសារណា

---

[4000] <u>មូលដ្ឋានទី ២២២៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសទាក់ទងនឹងការដឹងឮអំពីឧក្រិដ្ឋកម្មនៅក្នុងក្របខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍* កថាខណ្ឌ ១៩២៨-១៩៣១។ ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៧៥ (អង់គ្លេស)ទំព័រ ៧០ (បារាំង)ទំព័រ ១០៧ (ខ្មែរ)។

[4001] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤៧ *ជើងទំព័រ* ១៣៨៦០ *យោងទៅ* កថាខណ្ឌ ៣៥៦៩។

[4002] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤៨ *ជើងទំព័រ* ១៣៨៦៣-១៣៨៦៤, *យោងទៅ* កថាខណ្ឌ ៣៥៥១, ៣៥៨៦។

[4003] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៩។

[4004] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៩។

បណ្តឹងសាទុក្ខរបស់គាត់[4005] និងបានរៀបរាប់ឡើងវិញពីទឡ្ហីករណ៍មុនរបស់គាត់ ដែលមិនទទួលបានជោគជ័យនៅចំពោះមុខ អ.ជ.ស.ដ[4006]។

1093. ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4007] សក្ខីកម្មអាចជឿជាក់បានរបស់ ជា ឌៀប មិនមែនជាភ័ស្តុតាងតែមួយគត់ ដែលបង្ហាញពីការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានទទួលស្គាល់សុន្ទរកថានៅពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៨ របស់គាត់ ដែលនិយាយឡើងវិញពីការអប់រំរបស់គាត់នៅវត្តឧណ្ណាលោម ដោយបានលើកទឹកចិត្តប្រជាជនឱ្យ "តម្កល់ប្រយោជន៍ជាតិ វណ្ណៈ ប្រជាជន និងបដិវត្តន៍ធំជាងប្រយោជន៍គ្រួសារ"[4008]។

1094. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានគាំទ្រគោលនយោបាយបង្កើនប្រជាជន។ ការអះអាងដោយគ្មានការគាំទ្ររបស់ម្ចាស់បណ្តឹងសាទុក្ខនេះបរាជ័យក្នុងការបង្ហាញថា អ.ជ.ស.ដ បានបំភ្លៃសុន្ទរកថារបស់គាត់នៅពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៨ ដែលក្នុងពេលនោះ គាត់បានថ្លែងថា សមាជិកបក្សគួរខិតខំ "អនុវត្តឱ្យបានល្អនូវផែនការបង្កើនបរិមាណប្រជាជនឱ្យដល់កម្រិតអតិបរារបស់ខ្លួន ដើម្បីសម្រេចតាមគោលដៅឱ្យមានប្រជាជនពី១៥ ទៅ ២០ លាននាក់ ក្នុងរយៈពេលពី១០ ទៅ១៥ឆ្នាំខាងមុខ"[4009]។

1095. មូលដ្ឋាននេះក៏បរាជ័យផងដែរ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានភាពលម្អៀងនៅក្នុងការវាយតម្លៃលើភ័ស្តុតាងរបស់ខ្លួន។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4010] ក្នុងសំណុំរឿង០០២/០១ អ.ជ.ស.ដ មិនដែលបានសម្រេចលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានយកឈ្នះលើសច្ចធារណ៍ដ៏រឹងមាំនៃអនាគតិរបស់ចៅក្រមទេ។ អ.ជ.ស.ដ បានធ្វើការយ៉ាងត្រឹមត្រូវ ដោយលើកឡើងថា "មិនមានការ

[4005] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៩ *យោងទៅ* កថាខណ្ឌ ១២៣៣-១២៤២។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៦ (ជា ឌៀប)។

[4006] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៩ *ជើងទំព័រ* ១១៩៧៩។

[4007] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៩។

[4008] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៧០ *យោង* **E3/202** *សុន្ទរកថារបស់ ខៀវ សំផន* គ្មានកាលបរិច្ឆេទ KH 00287221-22។

[4009] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥១ *ជើងទំព័រ* ១១៩៣១។

[4010] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៨។

ចម្លងនូវការទទួលខុសត្រូវព្រហ្មទណ្ឌពីសំណុំរឿងមួយទៅសំណុំរឿងមួយទៀតនោះទេ ហើយផ្អែកសំអាងហេតុមិនត្រូវបានដកស្រង់ចេញពីក្នុងសំណុំរឿង ០០២/០១ មកបញ្ចូលក្នុងសំណុំរឿង ០០២/០២ នោះទេ”[4011] ដោយបានបន្ថែមទៀតថា “ទោះបីជាមានចំណុចរួមគ្នាដោយផ្នែកៗរវាងភ័ស្តុតាងផ្ទាល់មាត់ និងភ័ស្តុតាងជាឯកសារនៅក្នុងសំណុំរឿងនីមួយៗក៏ដោយ តែនៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងវាយតម្លៃលើសម្ភារទាំងអស់ដែលមាននៅចំពោះមុខខ្លួន”[4012]។

## ៣. ចេតនា

1096. ដូចដែលតម្រូវដោយលក្ខខណ្ឌតម្រូវ*ធាតុផ្សំអត្តនោម័តិ* នៃសហឧក្រិដ្ឋកម្មរួម I[4013] អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមជាមួយនឹងអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមផ្សេងទៀត ទាំងចេតនាប្រព្រឹត្តបទឧក្រិដ្ឋដោយមានគោលបំណងរួម និងទាំងចេតនាចូលរួមក្នុងគោលបំណងរួម ដែលជាប់ពាក់ទៅនឹងការប្រព្រឹត្តិរបស់ពួកគេ[4014]។ មូលដ្ឋានទាំង ៣១ របស់ម្ចាស់បណ្តឹងសាទុក្ខ[4015] ទាក់ទងនឹងចេតនារបស់គាត់ បរាជ័យ ដោយហេតុថា មូលដ្ឋានទាំងនេះប្រើវិធីសាស្ត្រមួយផ្នែកម្តងៗមិនត្រឹមត្រូវ ទាំងទៅលើភ័ស្តុតាង និងទាំងទៅលើសាលក្រម និងផ្អែកលើការយល់ច្រឡំលើច្បាប់ដែលពាក់ព័ន្ធ។

1097. ជាពិសេស ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខផ្ទុយទៅនឹងយុត្តិសាស្ត្រដែលបានបង្កើតថា មិនមានលក្ខខណ្ឌតម្រូវថា ម្ចាស់បណ្តឹងសាទុក្ខមានគោលបំណងចំពោះឧក្រិដ្ឋកម្ម ឬហេតុការណ៍ជាក់លាក់នោះទេ[4016] ហើយការដឹងអំពីឧក្រិដ្ឋកម្មក៏មិនមែនជាធាតុផ្សំសម្ភារបន្ថែមទៅលើចេតនា

---

[4011] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦។

[4012] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦ *ជើងទំព័រ* ៨៣។ *សូមមើល*ចម្លើយតបទៅមូលដ្ឋានទី ៥។

[4013] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៥៣-១០៥៤។ ឯកសារ **D97/15/9** សាលដីកា អ.ប.ជ ស្តីពី JCE កថាខណ្ឌ ៣៧, ៣៩។ សាលក្រម *ឌុច* សំណុំរឿង០០១-ឯកសារ **E188** កថាខណ្ឌ ៥០៩។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩០, ៦៩៥។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ១៩៦, ២២០, ២២៨។ សាលដីកា ក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៣៦៥។ សាលដីកា ក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៤៧០។ សាលដីកា ក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៣៦៩។ សាលដីកា ក្នុងរឿងក្តី *Munyakazi* កថាខណ្ឌ ១៦០។សាលដីកា ក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤៧៤-៤៧៥។ *សូមមើលផងដែរ* សាលដីកា ក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៧៧១-១៧៧២, ២៣៧២, ២៤២២។

[4014] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៩-៤៣០៥។

[4015] មូលដ្ឋានទី ១៩៣, ១៩៥-១៩៧, ២០៨, ២១០-២២១, ២២៣, ២២៥, ២៣២-២៤៣។

[4016] សាលដីកា ក្នុងរឿងក្តី *Prlić* កថាខណ្ឌ ២០៧៤ (*ជើងទំព័រ* ៧១០៦)។ សាលដីកា ក្នុងរឿងក្តី *Stanišić & Župljanin* កថាខណ្ឌ ៩១៧។ សាលដីកា ក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៩០៦។

នោះដែរ[4017]។ អ.ជ.ស.ជ *បានសន្និដ្ឋាន* អំពីចេតនារបស់ម្ចាស់បណ្ដឹងសាទុក្ខ *ជាអាទិ៍* ចេញពីការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម និងការចូលរួមជាបន្តបន្ទាប់ក្នុងផែនការរួម[4018]។ ក្នុងការទាញសេចក្ដីសន្និដ្ឋាននេះ អ.ជ.ស.ជ មិនតម្រូវឱ្យសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីហេតុការណ៍ឧក្រិដ្ឋ*ជាក់លាក់* នោះទេ[4019]។ ចេតនានោះអាចត្រូវបានបង្ហាញតាមរយៈការធ្វើ មិនដឹងមិនឮដោយចេតនារបស់ជនជាប់ចោទ ក៏បានបង្ហាញយ៉ាងច្បាស់ផងដែរ[4020]។ ក៏មិនមានការតម្រូវដែរថា

---

[4017] សាលដីកា ក្នុងរឿងក្ដី *Šainović* កថាខណ្ឌ ១៤៩១។ សាលដីកា ក្នុងរឿងក្ដី *Prlić* កថាខណ្ឌ ២០៧៤ (*ជើងទំព័រ* ៧១០៦)។ សាលដីកា ក្នុងរឿងក្ដី *Sesay* កថាខណ្ឌ ៨២៣។

[4018] *សូមមើលឧទាហរណ៍* សាលដីកា ក្នុងរឿងក្ដី *Tolimir* កថាខណ្ឌ ៤៧៤ ("[ដើម្បីបង្ហាញថា បុគ្គលម្នាក់បានរួមចំណែកក្នុងគោលបំណងរួម] វាគ្រប់គ្រាន់ថា [គាត់] ដឹងថា ឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្តតាមផែនការរួម និងចូលរួមដោយដឹងឮនៅក្នុងវិធីមួយដែលជួយជ្រោមជ្រែងដល់ប្រព្រឹត្តឧក្រិដ្ឋកម្ម ឬដែលអនុញ្ញាតឱ្យផែនការឧក្រិដ្ឋកម្មដំណើរការយ៉ាងមានប្រសិទ្ធិភាព ឬយ៉ាងមានប្រសិទ្ធិផល")។ សាលដីកា ក្នុងរឿងក្ដី *Prlić* កថាខណ្ឌ ១៨០០ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍រំលឹក [...] ថា *ធាតុផ្សំអត្តនោម័តិ* ដែលតម្រូវសម្រាប់ការផ្ដន្ទាទោសក្រោមទម្រង់ JCE I អាចទាញការសន្និដ្ឋានចេញពី ការដឹងរបស់បុគ្គលនោះអំពីផែនការរួម រួមជាមួយនឹងការចូលរួមជាបន្តបន្ទាប់របស់គាត់ក្នុង JCE ប្រសិនបើនេះគឺជាការទាញការសន្និដ្ឋានដ៏សមហេតុសមផលតែមួយគត់ដែលភ័ស្ដុតាងមាន") ១៨០២។ សាលដីកា ក្នុងរឿងក្ដី *Popović* កថាខណ្ឌ ១៦៥២។

[4019] សាលដីកា ក្នុងរឿងក្ដី *Prlić* កថាខណ្ឌ ១៨០២ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនជឿជាក់លើសារណារបស់ Stojićs ដែលថា ការដឹងពីឧក្រិដ្ឋកម្មដែលជាធម្មតាមទទួលបានពីរបាយការណ៍ក្រោយអង្គហេតុ មិនអាចគាំទ្រការសន្និដ្ឋានថា គាត់មានចេតនាដែលត្រូវការក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលជាបញ្ហានោះទេ។ [...] អង្គជំនុំជម្រះ [បានរកឃើញ] ថា Stojić [...] បានដឹងពីឧក្រិដ្ឋកម្ម [...] ក្នុងន័យនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍រំលឹកថា វាមិនចាំបាច់ទេថា អ្នកចូលរួមក្នុង JCE ត្រូវដឹងអំពីឧក្រិដ្ឋកម្មជាក់លាក់ ដែលបានប្រព្រឹត្តឡើង ដើម្បីដាក់ឱ្យទទួលខុសត្រូវចំពោះវា។")។ សាលដីកា ក្នុងរឿងក្ដី *Tolimir* កថាខណ្ឌ ៤៧៤ ("អ្នកចូលរួមក្នុង JCE មិនចាំបាច់ដឹងអំពីឧក្រិដ្ឋកម្មនីមួយៗ ដែលបានប្រព្រឹត្តឡើង ដើម្បីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ")។

[4020] *សូមមើលឧទាហរណ៍* សាលក្រមតុលាការ IMT ទំព័រ ៣០៥-៣០៧ ("Funk បានតវ៉ាថា គាត់មិនបានដឹងថា Reichsbank បានទទួលសម្ភារប្រភេទនេះទេ [របស់របរផ្ទាល់ខ្លួនដែលយកពីជនរងគ្រោះ ដែលបានសម្លាប់នៅជំរុំលត់ដំ]។ អង្គជំនុំជម្រះដឹងថា គាត់បានដឹងពីអ្វីដែលទទួលបាន *ឬធ្វើជាបិទភ្នែកមិនឃើញអ្វីដែលកំពុងធ្វើឡើង*" (គូសបញ្ជាក់បន្ថែម)។ ផ្អែកលើមូលដ្ឋាននេះ តុលាការ IMT បានសន្និដ្ឋានថា Funk មានពិរុទ្ធ *ជាអាទិ៍* ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។ រឿងក្ដី *Eichmann* កថាខណ្ឌ ១១៥, ២៤៤ (បានសន្និដ្ឋានថា Eichmann មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនជ្វីស (Jewish) (អំពើប្រល័យពូជសាសន៍) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងផ្នែកដែលផ្អែកលើមូលដ្ឋានដែលថា គាត់បានធ្វើមិនដឹងមិនឮដោយចេតនានូវការប្រមាទអំពីលក្ខណៈឧក្រិដ្ឋនៃការនិរទេសជនជាតិជ្វីសរាប់ពាន់នាក់ពីប្រទេសហុងហ្គារី និងបានបញ្ជាឱ្យជំនួយការរបស់គាត់ឱ្យធ្វើដូចគ្នានេះ)។ *រឿងក្ដី R ទល់នឹង Finta* [១៩៩៤] ១ S.C.R. ៧០១ ទំព័រ ៧០៦ ("ម្យ៉ាងវិញទៀត លក្ខខណ្ឌតម្រូវនៃ *ធាតុផ្សំអត្តនោម័តិ* នៃ [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] និងឧក្រិដ្ឋកម្មសង្គ្រាមអាចបំពេញបាន ប្រសិនបើគេរកឃើញថា ជនជាប់ចោទមានចេតនាមិនអើពើនឹងអង្គហេតុ កាលៈទេសៈ ដែលអាននាំឱ្យសកម្មភាពរបស់គាត់មានការប្រព្រឹត្តបទល្មើសទាំងអស់នេះ")។

ម្ចាស់បណ្តឹងសាទុក្ខមានការសាទរ ឬទទួលបានការពេញចិត្តពីឧក្រិដ្ឋកម្មនោះទេ ហើយក៏មិនតម្រូវថា ឧក្រិដ្ឋកម្មទាំងនោះត្រូវបានផ្តួចផ្តើមឡើងដោយគាត់ផ្ទាល់នោះដែរ[4021]។

## i. ធាតុផ្សំអត្តនោម័តិសម្រាប់សហឧក្រិដ្ឋកម្មរួម

### *មូលដ្ឋានទី ២២៥៖ ធាតុផ្សំអត្តនោម័តិ៖ ចេតនាប្រព្រឹត្តបទឧក្រិដ្ឋកម្មស្ថិតនៅចំចំណុចស្នូលនៃគោលបំណងរួម[4022]*

1098. **មូលដ្ឋានទី ២២៥ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសណាមួយក្នុងការលើកឡើងអំពីច្បាប់ស្តីពី*ធាតុផ្សំអត្តនោម័តិ* សម្រាប់សហឧក្រិដ្ឋកម្មរួម។**

1099. ផ្ទុយទៅនឹងការលើកឡើងដដែលៗរបស់ម្ចាស់បណ្តឹងសាទុក្ខ[4023] អ.ជ.ស.ជ បានលើកឡើងអំពីនិយមន័យត្រឹមត្រូវនៃ*ធាតុផ្សំអត្តនោម័តិ*សម្រាប់សហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នានៅ អ.វ.ត.ក[4024]។ ម្ចាស់ណ្តឹងសាទុក្ខគ្រាន់តែកត់សម្គាល់ពីការប្រើឃ្លាខុសគ្នាដោយតុលាការផ្សេងៗទៀត ដោយមិនបានបង្ហាញថា វាបង្កើតបានជាការខុសគ្នាណាមួយនៅក្នុងអត្ថន័យនោះទេ[4025]។ នៅពេលដែលវិភាគលើ*ធាតុផ្សំអត្តនោម័តិ* របស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ជ

---

[4021] សាលដីកា ក្នុងរឿងក្តី *Popović ជើងទំព័រ* ២៩៧១។ សាលដីកា ក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១០០។

[4022] <u>មូលដ្ឋានទី ២២៥៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ធាតុផ្សំអត្តនោម័តិ៖ ចេតនាប្រព្រឹត្តបទឧក្រិដ្ឋកម្មរួមទៅចំស្នូលនៃគោលបំណងរួម* កថាខណ្ឌ ១៩៦៣-១៩៦៥។ ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៧៦ (អង់គ្លេស) ទំព័រ ៧០-៧១ (បារាំង)ទំព័រ ១០៩ (ខ្មែរ)។

[4023] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦៣-១៩៦៥។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងវិញនូវទឡ្ហីករណ៍ដែលត្រូវបានបដិសេធដោយ អ.ជ.ត.ក ក្នុងសំណុំរឿង ០០២/០១៖ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៥៣ ("ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា [អ.ជ.ស.ជ] មានកំហុសដោយបានលើកឡើងថា ជនជាប់ចោទប្រាកដជាមានចេតនាចូលរួមក្នុងគោលបំណងរួម ដែលខុសគ្នាពីការធ្វើឱ្យសម្រេចគោលបំណងរួម និងការប្រព្រឹត្តបទឧក្រិដ្ឋនោះ [អ.ជ.ត.ក] ពិចារណាឃើញថា ការលើកឡើងនេះមានកំហុសអង្គច្បាប់។")។

[4024] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧១២ ("ជនជាប់ចោទត្រូវមានចេតនាចូលរួមនៅក្នុងគោលបំណងរួម ហើយអ្នកចូលរួមផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួម ត្រូវមានចេតនានេះផងដែរ។ ជាមួយគ្នានេះដែរ អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវតែបង្ហាញថា មានចេតនាដូចគ្នានឹងអ្នកចូលរួមផ្សេងទៀតនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ") *ត្រូវបានបញ្ជាក់*នៅក្នុងឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៥៣។ *សូមមើលផងដែរ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩៤។

[4025] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦៣-១៩៦៤ *ជើងទំព័រ* ៣៨១៤។ សាលក្រមនីមួយៗដែលបានយោងដោយម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា ជនជាប់ចោទត្រូវមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងគោលបំណងរួម

មិនបាន "ទាញការសន្និដ្ឋានថា មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ដោយគ្រាន់តែផ្អែកលើការចូលរួមក្នុងគម្រោង"[4026] ប៉ុន្តែ ផ្ទុយទៅវិញបានលើកឡើងយ៉ាងជាក់លាក់ថាតើ គាត់បានធ្វើសកម្មភាពដោយមានចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងគោលបំណងរួម ឬយ៉ាងណា[4027]។

## *មូលដ្ឋានទី ២៣២៖ ការរម្លឹកកអំពីកំហុសលើចេតនាចូលរួមគាំទ្រគោលបំណងឧក្រិដ្ឋកម្មរួម*[4028]

1100. **មូលដ្ឋានទី ២៣២ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ជ មានកំហុសក្នុងការសន្និដ្ឋានថា គាត់មានចេតនាគាំទ្រគោលបំណងរួម ដែលមានលក្ខណ:ឧក្រិដ្ឋ។**

1101. ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងអំពីកំហុសជាច្រើន ទាក់ទងនឹងចេតនារបស់គាត់ក្នុងការគាំទ្រគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ប៉ុន្តែការចោទប្រកាន់ទាំងអស់នេះត្រូវបានកំណត់និយមន័យខុស និងគ្មានមូលដ្ឋាន[4029]។ គាត់មិនបានបញ្ជាក់ថាតើ គាត់កំពុងចោទប្រកាន់អំពីកំហុសអង្គច្បាប់ ឬអង្គហេតុ មើលរំលងបទដ្ឋាននៃការពិនិត្យឡើងវិញដែលតម្រូវ និងបរាជ័យទាំងស្រុងក្នុងការបង្ហាញថាតើ ទឡ្ហីករណ៍ដែលគាត់លើកឡើងអាចធ្វើឱ្យសាលក្រមទៅជាមោឃ: ឬនាំឱ្យមានការខុសឆ្គងរបស់តុលាការពិតប្រាកដដោយរបៀបណានោះទេ។

---

និង "មានចេតនាចូលរួមក្នុងផែនការរួមដែលមានបំណងលើការប្រព្រឹត្តរបស់ពួកវា"។ *សូមមើលឧទាហរណ៍* សាលដីកា *Popović* កថាខណ្ឌ ១៣៦៩។ ម្ចាស់បណ្តឹងសាទុក្ខមិនបង្ហាញថាតើការវិភាគនៅក្នុងសាលក្រមនេះ ខុសពីការវិភាគដែលបានធ្វើឡើងដោយ អ.ជ.ស.ជ ដោយរបៀបណាទេ ហើយក៏មិនបានពន្យល់ថាតើពួកវាគាំទ្រការអះអាងមិនត្រឹមត្រូវរបស់គាត់យ៉ាងដូចម្តេច ដែលថាច្បាប់តម្រូវឱ្យជនជាប់ចោទមានចេតនាចូលរួមក្នុង "ការ**សម្រេចបាន**ទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម" (គូសបញ្ជាក់បន្ថែម) (ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦៣)។

[4026] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៦៥។

[4027] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៩។ *សូមមើលផងដែរ* កថាខណ្ឌ ៤២៨២, ៤២៨៧, ៤២៨៩, ៤២៩៣-៤២៩៥, ៤២៩៨, ៤៣០០, ៤៣០២, ៤៣០៥។ ក្នុងការវិភាគដែលត្រូវបានវាស់ស្ទង់របស់ខ្លួន អ.ជ.ស.ជ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខ មិនមានចេតនាដែលតម្រូវ ដើម្បីផ្តោលទោសដោយការទទួលខុសត្រូវតាមរយ: JCE ចំពោះឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមទេ *សូមមើល* កថាខណ្ឌ ៤២៩០។

[4028] <u>ទឡ្ហីករណ៍ ២៣២៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការរំលឹកអំពីកំហុសលើចេតនាចូលរួមក្នុងគោលបំណងឧក្រិដ្ឋកម្មរួម* កថាខណ្ឌ ២០៣១-២០៣២; ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៧៨ (អង់គ្លេស)ទំព័រ ៧២ (បារាំង)ទំព័រ ១១១ (ខ្មែរ)។

[4029] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣១-២០៣២។

1102. ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4030] អ.ជ.ស.ដ មិនមានកំហុសក្នុងការកំណត់និយមន័យលើគោលបំណងរួម[4031] ឬមានកំហុសក្នុងការសន្និដ្ឋានថា គោលបំណងរួមមានគោលនយោបាយឧក្រិដ្ឋនោះ[4032]។ លើសពីនេះទៀត ទោះបីជាចាំបាច់ត្រូវបង្ហាញថា ជនជាប់ចោទបានធ្វើការចូលរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងរួមក៏ដោយ ក៏មិនចាំបាច់បង្ហាញថាការចូលរួមចំណែកជាក់លាក់នោះមានលក្ខណៈឧក្រិដ្ឋនោះទេ[4033]។ ដូច្នេះ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4034] អ.ជ.ស.ដ មិនត្រូវបានតម្រូវឱ្យបង្ហាញពីចេតនារបស់គាត់ក្នុងការចូលរួមក្នុង "លក្ខណៈឧក្រិដ្ឋ" នៃគោលបំណងរួមទេ[4035] និងបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា គាត់បានធ្វើការចូលរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងរួម[4036]។

### *មូលដ្ឋានទី ២៣៣៖ ការលើកហេតុផលមិនត្រឹមត្រូវក្នុងការទាញការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋ*[4037]

1103. **មូលដ្ឋានទី ២៣៣ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា សេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខមាន*ធាតុផ្សំអត្តនោម័តិ* ដែលតម្រូវ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មសហឧក្រិដ្ឋកម្មរួម គឺជាការសន្និដ្ឋានដែលមិនមានអ្នកវិនិច្ឆ័យលើអង្គហេតុសមហេតុផលណាអាចធ្វើឡើយ។**

1104. ក្នុងការជំទាស់ទៅនឹងសំអាងហេតុរបស់ អ.ជ.ស.ដ ទាក់ទងនឹងចេតនារបស់គាត់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋកម្មរួម ម្ចាស់បណ្តឹងសាទុក្ខមិនបានលើកទឡ្ហីករណ៍សំខាន់របស់ខ្លួនទេ ដោយគាត់គ្រាន់តែលើកឡើងវិញពីការអះអាងមិនត្រឹមត្រូវ ដែលមាននៅកន្លែងផ្សេងទៀត

---

[4030] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣១ *យោង* កថាខណ្ឌ ១៥៣៨-១៦០៣។

[4031] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤។ *សូមមើល* ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥៣, ៤០៦៨។

[4032] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨-១៨០, ១៨១ & ១៨៣, ១៨២, ១៨៤-១៨៨។

[4033] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៥។

[4034] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣២ *យោង* កថាខណ្ឌ ១៥៩៣-១៦០៣, ២០០១-២០៣០, ១៩៦៣-១៩៦៥។

[4035] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៦ និង ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤។

[4036] *សូមមើល* ផ្នែក VIII.គ.២. ការចូលរួមសំខាន់។

[4037] មូលដ្ឋានទី ២៣៣៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *វិចារណកិច្ចមិនត្រឹមត្រូវក្នុងការទាញការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋ* កថាខណ្ឌ ២០៣៣-២០៣៨។ ឯកសារ F54.1.1 សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៧៨ (អង់គ្លេស)ទំព័រ ៧២-៧៣ (បារាំង)ទំព័រ ១១២ (ខ្មែរ)។

ក្នុងសារណារបស់គាត់[4038] ដោយមិនបានផ្តល់ការយោងណាទៅភ័ស្តុតាង ឬឯកសារសំអាងច្បាប់ណាមួយទេ[4039]។

1105. ច្បាស់ណាស់ថា គោលបំណងរួម ពឹងផ្អែក "ជាមូលដ្ឋាន" លើការអនុវត្តគោលនយោបាយទាំងប្រាំ ដោយគោលនយោបាយនីមួយៗមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4040]។ ការលើកឡើងម្តងហើយម្តងទៀត គ្មានទីបញ្ចប់របស់ម្ចាស់បណ្តឹងសាទុក្ខពីការអះអាងមិនត្រឹមត្រូវ ដែលជំទាស់ទៅនឹងការសន្និដ្ឋាននេះ មិនបានធ្វើឱ្យការសន្និដ្ឋានបាត់បង់ភាពត្រឹមត្រូវរបស់ខ្លួនបន្តិចណាទេ[4041]។ ច្បាស់ផងដែរនោះគឺថា ផ្អែកលើការអនុវត្តច្បាប់ដ៏ត្រឹមត្រូវ[4042] "តាមរយៈការរៀបចំ អនុវត្ត ត្រួតត្រា និងរួមចំណែកដល់គោលនយោបាយទាំងប្រាំ"[4043] ម្ចាស់បណ្តឹងសាទុក្ខមានចេតនាធ្វើឱ្យមានគោលបំណងរួម[4044] និងជាពិសេសនោះ មានចេតនាឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៃគោលនយោបាយទាំងប្រាំ ដែលជាប់ទាក់ជាពិសេសទៅនឹងគោលបំណងរួមដែលចូលរួម ដូចដែលបានពិភាក្សាជាលម្អិតនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងចេតនាខាងក្រោម[4045]។ ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញយ៉ាងស៊ីសង្វាក់គ្នាអំពីចេតនារបស់គាត់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលជាមូលដ្ឋាននៃគោលបំណងរួម តាមវិធីជាច្រើន តាមរយៈ "ភាពរីករាយ" របស់គាត់ចំពោះផែនការរបស់ ប.ក.ក "[ការ]ការពារវិធីសាស្ត្ររបស់ ប៉ុល ពត" របស់គាត់ ឬការគាំទ្រ "ឥតងាករេ" និង "ស្មោះត្រង់" របស់គាត់ចំពោះគោលនយោបាយរើសអើងរបស់បក្ស[4046]។

[4038] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣៤, *ជើងទំព័រ* ៣៩៦២ *យោង* កថាខណ្ឌ ១៩៨១-២០០០។

[4039] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣៣, ២០៣៥-២០៣៨។

[4040] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨. *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៨, ១៨៩, ១៧៥, ១៧៦, ១៧៧ & ២២៤ (គោលបំណងរួម)។

[4041] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៣៤ *យោង* កថាខណ្ឌ ១៩៨១-២០០០។

[4042] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៥។

[4043] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៧៣។

[4044] *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ២៣២។

[4045] *សូមមើលជាពិសេស* ផ្នែក VIII.ឃ.៣. ចេតនា (ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមផ្តោតគោលដៅ។ ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងពេលបោសសំអាតផ្ទៃក្នុង និងនៅតាមទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។ ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនៅតាមសហករណ៍ និងការដ្ឋាន។ ចេតនាធ្វើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ រួមទាំងការរំលោភសេពសន្ថវៈ)។

[4046] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨១, ៤២៨៦, ៤២៩៨, ៤៣០០។ *សូមមើល*ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៣, ២២៣។

### ii. ការដឹងជាសូចនាករនៃចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខ

### *មូលដ្ឋានទី ២០៨៖ ការប្រែប្រួលកម្រិតនៃការដឹងទៅតាមពេលវេលា*[4047]

1106. **មូលដ្ឋានទី ២០៨ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានក្នុងការបង្ហាញថា ក្នុងការលើកឡើងថា កម្រិតការដឹងដែលជាលក្ខខណ្ឌតម្រូវប្រែប្រួលតាមពេលវេលាដែលការទទួលខុសត្រូវព្រហ្មទណ្ឌកើតមានឡើង អ.ជ.ស.ដ មានកំហុសអង្គច្បាប់ដែលធ្វើឱ្យសាលក្រមក្លាយជា មោឃៈ។**

1107. ពាក្យពេចន៍ដែល អ.ជ.ស.ដ បានប្រើ អាចមិនសូវច្បាស់[4048]។ ប៉ុន្តែ ដូចដែលម្ចាស់បណ្តឹងសាទុក្ខខ្លួនគាត់ផ្ទាល់បានទទួលស្គាល់[4049] មានភាពច្បាស់លាស់ពីបរិបទ និងការយោងផ្ទាល់របស់អង្គជំនុំជម្រះ[4050] ថា អ.ជ.ស.ដ គ្រាន់តែលើកឡើងថា ទម្រង់ខុសៗគ្នានៃការទទួលខុសត្រូវព្រហ្មទណ្ឌតម្រូវឱ្យមានប្រភេទខុសៗគ្នានៃការដឹង ដើម្បីគាំទ្រដល់*ធាតុផ្សំអត្តនោម័តិ* ដែលតម្រូវ និងថាការដឹងបែបនេះអាចកើតមានមុនពេល ដំណាលគ្នា ឬក្រោយពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ដូច្នេះការលើកឡើងរបស់ អ.ជ.ស.ដ នេះមិនមានកំហុសទេ។

1108. ក្នុងសាលក្រមទាំងមូល អ.ជ.ស.ដ បានលើកឡើង[4051] និងបានអនុវត្ត[4052] យ៉ាងត្រឹមត្រូវនូវ*ធាតុផ្សំអត្តនោម័តិ* សម្រាប់សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវចំពោះការជួយ និងជំរុញ។ តាមពិតទោះបីជាម្ចាស់បណ្តឹងសាទុក្ខបកស្រាយសាលក្រមមិនត្រឹមត្រូវ គាត់ហាក់ដូចជាទទួលស្គាល់ថា

---

[4047] <u>មូលដ្ឋានទី ២០៨៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការប្រែប្រួលកម្រិតនៃការដឹងទៅតាមពេលវេលា* កថាខណ្ឌ ១៨០៤-១៨០៧។ ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៧១ (អង់គ្លេស)ទំព័រ ៦៦ (បារាំង)ទំព័រ ១០១ (ខ្មែរ)។

[4048] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៥។ កត់សម្គាល់ថា ការបកប្រែជាភាសាអង់គ្លេសនៃប្រយោគនេះក្នុង ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០៤ អានមិនត្រឹមត្រូវថា "កម្រិតនៃការដឹងតាមការតម្រូវមានការប្រែប្រួល អាស្រ័យថាតើ*អំពើ* ដែលចោទប្រកាន់លើជនជាប់ចោទ កើតឡើងនៅមុន ក្នុងពេល ឬ ក្រោយពេល ប្រព្រឹត្តឧក្រិដ្ឋកម្ម" (គូសបញ្ជាក់បន្ថែម)។

[4049] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០៧ ("[អ.ជ.ស.ដ] ហាក់ដូចជាចង់និយាយថា កម្រិតនៃការដឹងតាមការតម្រូវមានការប្រែប្រួល ទៅតាមទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់")។

[4050] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៥, *ជើងទំព័រ* ១៣៧២៦ *យោងឆ្លងទៅ* កថាខណ្ឌ ៣៧១៥, ៣៧១៧, ៣៧១៩-៣៧២០, ៣៧២២, ៣៧២៥។

[4051] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧១២ (JCE) ៣៧២២ (ការជួយ និងជំរុញ) *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៥ (JCE), ២៤៥ (ការជួយ និងជំរុញ)។

[4052] *សូមមើល* ផ្នែក VIII.គ.៣. ចេតនា ផ្នែក VIII.ឃ.២ *ធាតុផ្សំអត្តនោម័តិ*។

អ.ជ.ស.ដ បានលើកឡើងថា ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម តម្រូវឱ្យមានចេតនាផ្ទាល់ ខណៈដែលការជួយ និងជំរុញ ត្រូវការការដឹងថាឧក្រិដ្ឋកម្មអាចត្រូវបានប្រព្រឹត្តឡើង និងថាការប្រព្រឹត្តិរបស់គាត់ជួយ ឬជ្រោមជ្រែងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4053]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការលើកឡើងនេះមានផលប៉ះពាល់ណាមួយលើសេចក្តីសម្រេចចុងក្រោយរបស់ អ.ជ.ស.ដ នោះទេ ឬក៏ថា អ.ជ.ស.ដ ខកខានមិនបានបង្ហាញថា គាត់មាន *ធាតុផ្សំ អត្តនោម័តិ* ដែលតម្រូវ សម្រាប់ឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលគាត់ត្រូវបានផ្តន្ទាទោស។

## *មូលដ្ឋានទី ១៩៥៖ គោលការណ៍រក្សាការសម្ងាត់*[4054]

1109. **មូលដ្ឋានទី ១៩៥ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ដោយការសន្និដ្ឋានថា “គោលការណ៍រក្សាការសម្ងាត់” អនុវត្តម្តងម្កាលតែប៉ុណ្ណោះទៅលើម្ចាស់បណ្តឹងសាទុក្ខ។**

1110. មូលដ្ឋាននេះគួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនឯកភាពជាមួយនឹង អ.ជ.ស.ដ លើផលប៉ះពាល់នៃគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក លើការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីឧក្រិដ្ឋកម្ម។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងពីការបកស្រាយលើភស្តុតាងតាមរបៀបផ្សេង ដោយមិនបានបង្ហាញថាតើ អ.ជ.ស.ដ មានកំហុសរបៀបណា ជាវិធីសាស្ត្រមិនត្រឹមត្រូវដែល អ.ជ.ត.ក បានជំទាស់នៅក្នុងសំណុំរឿង ០០២/០១[4055]។

1111. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខដកស្រង់ការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើគោលការណ៍រក្សាការសម្ងាត់ក្រៅបរិបទ។ ដូចនៅក្នុងសំណុំរឿង០០២/០១[4056] ម្ចាស់បណ្តឹងសាទុក្ខមិនលើកឡើងពីការសន្និដ្ឋានដ៏ច្រើនដែលមាននៅក្នុងផ្នែកផ្សេងៗនៃសាលក្រម ពាក់ព័ន្ធនឹងបញ្ហានេះ[4057]។

---

[4053] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០៥-១៨០៦ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧១៥, ៣៧២២។

[4054] <u>មូលដ្ឋានទី ១៩៥៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *គោលការណ៍រក្សាការសម្ងាត់* កថាខណ្ឌ ១៦៥០-៥១។ ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៦៧-៦៨ (អង់គ្លេស)ទំព័រ ៦២ (បារាំង)ទំព័រ ៩៥-៩៦ (ខ្មែរ)។

[4055] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧១ ដែលបានបដិសេធការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹង “គោលការណ៍រក្សាការសម្ងាត់” ដែលបានលើកឡើងក្នុង ឯកសារ **F17** សារណាបណ្តឹងសាទុក្ខ សំណុំរឿង ០០២/០១ កថាខណ្ឌ ១៤៥-១៤៩. *សូមមើលផងដែរ* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០។

[4056] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧១។

[4057] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០២-៥៤ (ស្តីពីការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខ), ៤២-៤៥៤, ៣៩២៧, ៣៩៥៨, ៣៩៦៨, ៣៩៨៦, ៤២០៨, ៤២៨១។

ជាលទ្ធផល ការវាយតម្លៃរបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះផលប៉ះពាល់នៃគោលការណ៍រក្សាការសម្ងាត់ មិនពេញលេញទេ ហើយម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ទាក់ទងនឹងគោលការណ៍រក្សាការសម្ងាត់ ជាការសន្និដ្ឋានដែលអ្នកវិនិច្ឆ័យលើអង្គហេតុមានហេតុផលណាម្នាក់មិនអាចមាន ផ្អែកលើការវាយតម្លៃភ័ស្តុតាងជារួមទេ[4058]។

1112. អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវថា ពីឆ្នាំ១៩៧៥-១៩៧៩ រចនាសម្ព័ន្ធប្រតិបត្តិការ គោលដៅ និងសកម្មភាពពិតប្រាកដរបស់ ប.ក.ក តាមពិតត្រូវបានបិទបាំងដោយការសម្ងាត់ ដោយថ្នាក់ដឹកនាំរបស់ ប.ក.ក ដើម្បីការពារបក្សពីការជ្រៀតចូលរបស់ខ្មាំង មិនឱ្យប្រជាជនធម្មតា និងកម្មាភិបាលថ្នាក់ទាបដឹង និងធ្វើឱ្យពួកគេគោរពតាមសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំដោយគ្មានសង្ស័យ[4059]។ អ.ជ.ស.ដ ក៏បានសន្និដ្ឋានយ៉ាងត្រឹមត្រូវផងដែរថា មេដឹកនាំ ប.ក.ក រួមទាំងម្ចាស់បណ្តឹងសាទុក្ខផង មិនស្ថិតក្រោមគោលការណ៍រក្សាការសម្ងាត់ទេ[4060] តែផ្ទុយទៅវិញ បានគាំទ្រ និងបានចូលរួមក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលក្នុងពេលនោះ ការពិភាក្សាត្រូវបានធ្វើឡើងអំពីអ្វីដែលគួររក្សាការសម្ងាត់[4061]។ តម្រូវការរក្សាការសម្ងាត់ដាច់ខាតអំពីការកំណត់អត្តសញ្ញាណខ្មាំង ប.ក.ក និងគំរូនៃការចាប់ខ្លួន និងសម្លាប់ពួកគេ ក្នុងការសម្រេចបន្ថែមទៀតលើគោលបំណងរួម ក៏ត្រូវបានឯកភាពលើផងដែរ[4062]។

---

[4058] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០២-០៣។

[4059] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤២, ៣៦២, ៣៧៩៣, ៣៩២៧, ៣៩៣៨-៣៩, ៣៩៨៦, ៤១៣៤។

[4060] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៨, ៤២៨១, ៤២៨៥។

[4061] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១២៩, ៤១៣៤។ ទោះបីជាកថាខណ្ឌទាំងអស់នេះទាក់ទងជាសំខាន់ទៅនឹង នួន ជា ពួកវាក៏អនុវត្តបានដូចគ្នាចំពោះម្ចាស់បណ្តឹងសាទុក្ខ ដោយហេតុថាគាត់មានវត្តមាន និងបានចូលរួមក្នុងការប្រជុំភាគច្រើនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

[4062] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨១, ៣៩៣៧, ៣៩៣៨, ៤១៣៤, ៣៩៨៦។ *សូមមើលផងដែរ* ឯកសារ **E3/1733** កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥, *ដែលបានយោងក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៦០ *ជើងទំព័រ* ១២៥៣៦។ ឯកសារ **E3/229** កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ទាក់ទងនឹងបញ្ហាការពារប្រទេស ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ KH 00000714-15 *ដែលបានយោងក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១៣៤ *ជើងទំព័រ* ១៣៥៨៥។

1113. សក្ខីកម្មដែលម្ចាស់បណ្ដឹងសាទុក្ខបានដកស្រង់[4063] មិនគាំទ្រការអះអាងរបស់គាត់ថា អ.ជ.ស.ដ ធ្វើការស្មានក្នុងការសន្និដ្ឋានថា គោលការណ៍រក្សាការសម្ងាត់មិនអនុវត្តចំពោះសមាជិកបក្សទាំងអស់ រួមទាំងកម្មាភិបាលថ្នាក់ខ្ពស់បំផុតទេ។ ភស្តុតាងនេះបានមកពីកម្មាភិបាល ប.ក.ក ដែលមានឋានៈទាបជាងម្ចាស់បណ្ដឹងសាទុក្ខច្រើននៅក្នុងឋានានុក្រម ហេតុដូច្នេះ ផ្នែកជាច្រើនត្រូវស្ថិតក្រោមការសម្ងាត់នោះ។ សាក្សីទាំងអស់នេះមិនបានចូលរួមក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម ដែលបានធ្វើសេចក្ដីសម្រេចសំខាន់ៗនោះទេ ពួកគេមិនត្រូវបានទុកចិត្តឱ្យរស់នៅ និងធ្វើការក្បែរទៅនឹង ប៉ុល ពត និង នួន ជា នៅ ក-១ និង ក-៣ នៅក្នុង របបទាំងមូលទេ ហើយពួកគេមិនមែនជាសមាជិក ឬមានតួនាទីដឹកនាំនៅក្នុងមន្ទីរ ៨៧០ នោះទេ។ អ.ជ.ស.ដ បានសំអាងយ៉ាងត្រឹមត្រូវលើចំណុចទាំងអស់នេះ និងកត្តាផ្សេងទៀត[4064] នៅក្នុងការសន្និដ្ឋានថា គោលការណ៍រក្សាការសម្ងាត់មិនអនុវត្តចំពោះម្ចាស់បណ្ដឹងសាទុក្ខទេ និងថា ដោយទទួលបានបានការទុកចិត្តពីមេដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងទៀត គាត់ "ដឹងជាបន្តបន្ទាប់អំពីការបង្កើតផែនការ ការអនុវត្តផែនការ និងភវនីយភាពដែលថា ឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ បានកើតឡើង"[4065]។

1114. ស្រដៀងគ្នានេះដែរ ការដកស្រង់សក្ខីកម្ម ដែលជ្រើសរើសតាមការចង់បាន ដោយម្ចាស់បណ្ដឹងសាទុក្ខ បរាជ័យមិនបានបង្ហាញថា គាត់ទទួលបានព័ត៌មានសម្ងាត់បំផុតដ៏តិចតួចនៅ ក-១ និង ក-៣[4066]។ តាមពិត ដូចដែលម្ចាស់បណ្ដឹងសាទុក្ខបានទទួលស្គាល់ ប៉ុល ពត, នួន ជា និងខ្លួនគាត់ផ្ទាល់ "អត់មានអីដោយឡែក" នោះទេ[4067]។

---

[4063] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៥០ *ជើងទំព័រ* ៣១៧២ *យោង* ឌុច, សៅ សារុន, សាឡុត បាន, អៀង ផាន និង ឈូក រិន។

[4064] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៨ (ដែលបានកត់សម្គាល់អំណាចរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងការចេញសេចក្ដីថ្លែងការលើបញ្ហាសំខាន់ៗ មានសិទ្ធិពិសេសចំពោះសេចក្ដីថ្លែងដែលធ្វើឡើងដោយសមាជិកមជ្ឈិមបក្ស ចូលរួម និងបង្រៀននៅតាមវគ្គបណ្ដុះបណ្ដាល និងវគ្គមនោគមវិជ្ជា ដែលការអនុវត្តគោលនយោបាយឧក្រិដ្ឋបានពិភាក្សា ទទួលសារាចរ ប.ក.ក គ្រប់គ្រងគណៈកម្មាធិការពាណិជ្ជកម្ម និងធ្វើដំណើរក្នុងប្រទេស) ៣៩៦៨, ៤២៨៥, ៥៨៩-៦២៥។

[4065] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៨។

[4066] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៥១ *ជើងទំព័រ* ៣១៧៥៖ ការដកស្រង់សក្ខីកម្មរបស់ អឿន តាន, ស វី និង នង សូផង់ ដែលបានយោងសំអាង គ្រាន់តែបង្ហាញថា ទូរលេខត្រូវបានបញ្ជូននៅ ក-១ ទៅកាន់ ប៉ុល ពត និង នួន ជា។ ប៉ុន្តែ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩ ("ក្នុងអំឡុងពេលស្នាក់នៅ ក-៣ ខៀវ សំផន បន្តរក្សាទម្លាប់ស្និទ្ធស្នាលរបស់គាត់ជាមួយ ប៉ុល ពត និង នួន ជា (ដូចដែលគាត់បានអនុវត្តតាំងពីឆ្នាំ១៩៧០)។ គាត់បានទៅលេងញឹកញាប់នៅមន្ទីរ ក-១ ដែល ប៉ុល ពត នៅតែបន្តស្នាក់នៅទីនោះនៅឡើយ")។ *សូមមើលផងដែរ* ឯកសារ

## *មូលដ្ឋានទី ១៩៦ និង ១៩៧៖ កុមារភាព យុវវ័យ និងអាជីព*[4068]

1115. **មូលដ្ឋានទាំងពីរគួរត្រូវច្រានចោល ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ នៅក្នុងការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹង (i) និក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ (ii) ទំនាក់ទំនងផ្ទាល់ខ្លួនរបស់គាត់ជាមួយនឹងបុគ្គលនានា ដែលក្រោយមកបានកាន់មុខតំណែងសំខាន់នៅក្នុង ប.ក.ក (iii) ការគាំទ្ររបស់គាត់ចំពោះគោលបំណងរួម តាំងពីឆ្នាំ១៩៦៧ និង (iv) ការដឹងរបស់គាត់អំពីលទ្ធភាពនៃឧក្រិដ្ឋកម្មដែលមានតាំងពីឆ្នាំ ១៩៦៩។**

1116. មូលដ្ឋានទាំងពីរនេះបរាជ័យ ដោយហេតុថា អ.ជ.ស.ដ មិនបានធ្វើការសន្និដ្ឋានផ្អែកទាំងស្រុងលើសកម្មភាព ឬនិក្ខេបបទរបស់ម្ចាស់បណ្តឹងសាទុក្ខមុនឆ្នាំ១៩៧០ ទេ ទាក់ទងនឹងការគាំទ្ររបស់ម្ចាស់បណ្តឹងសាទុក្ខលើគោលបំណងរួម អតីតភាពក្នុងចំណោមថ្នាក់ដឹកនាំ ប.ក.ក ឬការដឹងអំពីលទ្ធភាពនៃឧក្រិដ្ឋកម្មក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[4069]។ ផ្ទុយទៅនឹងការអះអាងរបស់

---

**E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៤ *ជើងទំព័រ* ១៥២៧ (*យោង* នឹម សែម ដែលថ្លែងថា ប៉ុល ពត, នួន ជា និង ម្ចាស់បណ្តឹងសាទុក្ខ បានទទួលទានអាហាររួមគ្នានៅ ក-៣។ ស វី ដែលបានបញ្ជាក់ថា ម្ចាស់បណ្តឹងសាទុក្ខ បានទៅមើល ក.១ ញឹកញាប់ជាងមេដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងទៀត។ សាឡុត បាន ដែលបានថ្លែងថា អៀង សារី, នួន ជា និងម្ចាស់បណ្តឹងសាទុក្ខបានជួបគ្នានៅ ក-១)។

[4067] **E3/3198** ប្រតិចារឹកនៃសេចក្តីថ្លែងក្នុងវីដេអូរបស់ ខៀវ សំផន KH 00807463។ **E3/3197R** សេចក្តីថ្លែងក្នុងវីដេអូរបស់ ខៀវ សំផន ម៉ោង ០០.៣៨.៤៨-០០.៤២.៤២។

[4068] <u>មូលដ្ឋានទី ១៩៦៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កុមារភាព យុវវ័យ និងអាជីព* កថាខណ្ឌ ១៦៥២-១៦៥៩, ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៦៨ (អង់គ្លេស)ទំព័រ ៦៣ (បារាំង)ទំព័រ ៩៦ (ខ្មែរ)។ <u>មូលដ្ឋានទី ១៩៧៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *សមាជិក ប.ក.ក* កថាខណ្ឌ ១៦៦០-៦៤ ឯកសារ **F54.1.1** សារណាបណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ កទំព័រ ៦៨ (អង់គ្លេស) ទំព័រ ៦៣ (បារាំង) ទំព័រ ៩៦ (ខ្មែរ)។

[4069] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៧-៤២០៨, ៤២៥៧, ៥៧៤-៥៧៨, ៥៨២, ២១៩-២២១, ២២៦-២២៧, ២៣១-២៣២ (ទាក់ទងនឹងគោលនយោបាយ គោលបំណងរួម និងឧក្រិដ្ឋកម្មមួយចំនួនចន្លោះ ឆ្នាំ១៩៧០ និង ១៩៧៥ ប៉ុន្តែ *មិន* ផ្តោតលើរយៈកាល *មុន* ឆ្នាំ១៩៧០), ២១១, ៥៧២-៥៧៣ (បានរៀបរាប់លម្អិតអំពីការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខជាមួយ តាម៉ុក ក្នុងព្រៃ *ម៉ាគី* (*maquis*) និងការបញ្ចូលគាត់ជាសមាជិក ប.ក.ក ក្នុងឆ្នាំ១៩៦៩ ប៉ុន្តែមិនបានទាញការសន្និដ្ឋានណាមួយទាក់ទងនឹងឧក្រិដ្ឋកម្ម និងគោលបំណងរួមរបស់កម្ពុជាប្រជាធិបតេយ្យទេ) ៥៦៧-៥៦៨, ៣៨៨៤, ៤២០៦ (បានរៀបរាប់អំពីនិក្ខេបបទ ប៉ុន្តែបានកត់សម្គាល់ថា វាមិនបានគាំទ្រការលុបបំបាត់លុយ ឬសម្បត្តិឯកជនទេ និងមិនមែនជាផែនការសម្រាប់គោលនយោបាយ ប.ក.ក ទេ)។ ម្ចាស់បណ្តឹងសាទុក្ខចម្លងតាមអំណះអំណាងបង្ហាញក្នុងឯកសារ **F17** សារណាបណ្តឹងសាទុក្ខ សំណុំរឿង ០០២/០១ កថាខណ្ឌ ២៣៧-២៤៦ ទល់នឹងឯកសារ **E313** សាលក្រម សំណុំរឿង ០០២/០១ កថាខណ្ឌ ៩៦៥ ("ត្រឹមឆ្នាំ១៩៦៩ នៅពេលដែលគាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានដឹងយ៉ាងច្បាស់អំពីគោលបំណងរួម [...] ព្រមទាំងការវិវត្តន៍ [...] និងបានឯកភាពទៅនឹងគោលបំណងរួមនេះ")។ ប៉ុន្តែ ក្នុង

ម្ចាស់បណ្ដឹងសាទុក្ខ[4070] វាមិនសំខាន់ទេថាតើ អ.ជ.ស.ដ អាចមិនមានភាពស៊ីសង្វាក់គ្នាទាក់ទង នឹងឆ្នាំដែលម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីគោលនយោបាយមួយចំនួនរបស់ ប.ក.ក ឬយ៉ាងណា នោះ[4071]។

1117. ម្ចាស់បណ្ដឹងសាទុក្ខមិនបានជំទាស់អំពីការចូលព្រៃ *ម៉ាគី* របស់គាត់ក្នុងឆ្នាំ១៩៦៧ និងបានក្លាយជា សមាជិក ប.ក.ក ក្នុងឆ្នាំ១៩៦៩[4072]ទេ។ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បាន ប្រព្រឹត្តកំហុសដែលសន្និដ្ឋានថា ខ្លឹមសារនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់បានឆ្លុះបញ្ចាំងពី "ការ ជឿជាក់ជាវិជ្ជមានរបស់គាត់ចំពោះគោលនយោបាយរបស់ ប.ក.ក ស្ដីពីសមូហភាវូបនីយកម្មដែល រួមមានតាមរយៈការជំរុញដាក់ឱ្យប្រជាជនស្ថិតនៅក្រោមគំនិតផ្ដួចផ្ដើមនៃការបង្កបង្កើនផលជូន រដ្ឋ"ទេ[4073]។ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែមិនយល់ស្របជាមួយការសន្និដ្ឋានរបស់ អ.ជ.ស.ដ ទាក់ ទងនឹងនិក្ខេបបទរបស់គាត់ និងផ្ដល់ទឡ្ហីករណ៍ដដែលៗដែល អ.ជ.ត.ក បានបដិសេធក្នុងសំណុំ រឿង ០០២/០១[4074]។ យ៉ាងណាមិញ អ.ជ.ស.ដ បានធ្វើការសម្រេចប្រកបដោយហេតុផល ដោយ ផ្អែកលើអភិក្រមច្បាស់លាស់អំពីនិក្ខេបបទរបស់ម្ចាស់បណ្ដឹងសាទុក្ខ ដោយទទួលស្គាល់ថា ទោះបី មិនមែនជាផែនការសម្រាប់គោលនយោបាយរបស់ ប.ក.ក ក៏ដោយ[4075] ក៏មានចំណុចខ្លះជាចំណុច រួមជាប់ទាក់ទងនឹងគោលនយោបាយនានាដែលចុងក្រោយ ត្រូវបានអនុមតិដោយ ប.ក.ក ដែរ[4076]។

---

ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ អ.ជ.ស.ដ មិនដែលសន្និដ្ឋានតាមវិធីដែលបង្ហាញដោយម្ចាស់បណ្ដឹងសាទុក្ខ ក្នុងឯកសារ **F54.1.1** សារណាបណ្ដឹងសាទុក្ខ ឧបសម្ពន្ធ កទំព័រ ៦៨ នោះទេ។

[4070] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៦០។

[4071] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១១, ២២០, ៥៧២-៧៣, ៤២០៧, ៤២៥៧។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២១២, ៣៩៣៤។

[4072] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៦៦១-១៦៦៣, ២០១២។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៦, ៥៧២-៥៧៣, ៤២០៧, ៤២៥៧។

[4073] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៦។

[4074] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ១០០២, ជើងទំព័រ ២៦២៤ (*យោង* ឯកសារ **F17** សារណាបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ២៤៦-២៤៨ ដែលពិភាក្សាពីខ្លឹមសារនៃនិក្ខេបបទរបស់គាត់), ១០០៥។ *សូមមើលផងដែរ* ឯកសារ **F17** សារណាបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ២៤៧-២៤៨។

[4075] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៨, ៤២០៦។

[4076] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៧-៥៦៨ (សំណើររបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងការគ្រប់ គ្រងផ្ដាច់មុខលើពាណិជ្ជក្រៅប្រទេស ខ្លួនទីពឹងខ្លួន ការផ្ទេរមូលធនពីវិស័យពាណិជ្ជកម្មទៅកសិកម្ម និងឧស្សាហកម្ម ការរៀបចំ កសិករទៅជាក្រុមជួយគ្នាទៅវិញទៅមក និងសហករណ៍), ៣៨៨៤ (អ.ជ.ស.ដ ប្រៀបធៀបគោលជំហររបស់ម្ចាស់បណ្ដឹង សាទុក្ខក្នុងឆ្នាំ១៩៧៥ ទាក់ទងនឹងភាពចាំបាច់ក្នុងការបង្ខំប្រជាជនឱ្យចូលរួមក្នុងសហករណ៍ដើម្បីកសាងប្រទេស ទៅនឹងខ្លឹមសារ

1118. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដោយសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីអនាគតមេដឹកនាំ ប.ក.ក មួយចំនួន ខណៈកំពុងសិក្សានៅប្រទេសបារាំង ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និង/ឬ ក្រោយពួកគេវិលត្រឡប់មកកម្ពុជាវិញនៅក្នុងឆ្នាំ១៩៥៩[4077]។ ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខផ្តល់ទឡ្ហីករណ៍ដដែលៗដែល អ.ជ.ត.ក បានបដិសេធក្នុងសំណុំរឿង ០០២/០១ លើបញ្ហានេះ[4078]។ អ.ជ.ស.ដ មិនបានប្រព្រឹត្តកំហុសនៅក្នុងការសន្និដ្ឋានផ្អែកលើការសន្និដ្ឋានដែលថា ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញនូវ *"ការគាំទ្រដល់គោលបំណងរួម"*[4079]នោះទេ។ អ.ជ.ស.ដ គ្រាន់តែបានលើកឡើងថា ម្ចាស់បណ្តឹងសាទុក្ខបានផ្តល់ "*ការគាំទ្រ* ចំពោះ ប.ក.ក និងគោលនយោបាយនានារបស់បក្សនេះ យ៉ាងហោចណាស់តាំងពីឆ្នាំ១៩៦៧"[4080] ហើយបានយោងទៅគោលនយោបាយនានាដែលត្រូវបានធ្វើរៀបចំឡើង ដាក់ឱ្យសាកល្បង និងអនុវត្តនៅក្នុងតំបន់ "រំដោះ" នៅចន្លោះឆ្នាំ១៩៦៩ និងខែមេសា ឆ្នាំ១៩៧៥ និង "បានអនុវត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដើម្បីសម្រេចបាននូវគោលបំណងរួម និងបានចូលរួមពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម"[4081]។ អ.ជ.ស.ដ មិនដែលសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានគាំទ្រចំពោះ "គោលបំណងរួម" ដោយផ្អែកតែលើទំនាក់ទំនងរបស់គាត់តែមួយជាមួយមេដឹកនាំ ប.ក.ក ដែលត្រូវបានបង្កើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ឬនៅក្នុងប្រទេសបារាំង ឬនៅចន្លោះពេលនៃការវិលត្រឡប់របស់គាត់មកកម្ពុជាវិញ និងឆ្នាំ១៩៧០ នោះទេ។ ទោះក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខបានជួប អៀង សារី, អៀង ធីរិទ្ធិ, សុន សេន, អ៊ុក សាគុន និង ហ៊ូ យន់ នៅទីក្រុងប៉ារីស ក្នុងក្រុមម៉ាក្សឡេនីន (១៩៥៣-១៩៥៩)[4082] បក្សកុម្មុយនីស្តបារាំង

---

នៃនិក្ខេបបទរបស់គាត់ អំពីការជួយគ្នាទៅវិញទៅមក និងសហករណ៍), ៤២០៦ (សំណើរបស់ម្ចាស់បណ្តឹងសាទុក្ខដើម្បីផ្លាញ់ផ្លាលវណ្ណៈមូលធនពីសកម្មភាពដែលគ្មានប្រយោជន៍ទៅជាការលើកទឹកចិត្តឱ្យពួកគេចូលរួមក្នុងការបង្កបង្កើនផល និងការរៀបចំសហករណ៍តាមរយៈកញ្ចប់វិធានការដ៏តឹងរ៉ឹងបំផុត)។

[4077] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៥២-១៦៥៩, ១៦៦២។

[4078] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ១០០២, ១០០៥។ *សូមមើលផងដែរ* ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ២៣៧-២៤៥។

[4079] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៥៨ (គូសបញ្ជាក់បន្ថែម)។

[4080] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៧ (គូសបញ្ជាក់បន្ថែម)។

[4081] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៧-៤២០៨។

[4082] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៥៦៥-៥៦៦, ៥៧៣។ *សូមមើលផងដែរ* ឯកសារ **E295/6/1.4** ឧបសម្ព័ន្ធ ៤ របស់ ក.ស.ព ទៅនឹងសារណាសារណាចុងក្រោយក្នុងសំណុំរឿង ០០២/០១ ("កាលប្បវត្តិ ខៀវ សំផន របស់ ក.ស.ព") EN 00948464-66។

(១៩៥៥-១៩៥៧)[4083] ឬសហភាពនិស្សិតខ្មែរ (UEK) ទេ[4084] ហើយក៏មិនបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការសម្រេចថា កាសែត “L'Observateur” ដែលគាត់បានចោទប្រកាន់ទាំងមិនត្រឹមត្រូវថា អ.ជ.ស.ដ បានហៅថា “កុម្មុយនីស្ត” នោះ[4085] គឺមួយផ្នែកបានទទួលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីប្រជាជនដែលចូលរួមជាមួយចលនាកុម្មុយនីស្តនៅប្រទេសកម្ពុជា[4086]។

1119. ជាចុងក្រោយ និងទោះបីជាក្នុងករណីណាក៏ដោយ មូលដ្ឋានទី ១៨៦ និង១៨៧ ក៏បរាជ័យដែរ ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថាតើ កំហុសអង្គហេតុដែលបានចោទប្រកាន់ទាក់ទងនឹងព្រឹត្តិការណ៍នានាមុនឆ្នាំ១៩៧០ អាចនឹងធ្វើឱ្យប៉ះពាល់ដល់ការសម្រេចរបស់ អ.ជ.ស.ដ ពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ និងធ្វើឱ្យមានការខុសឆ្គាយរបស់តុលាការជាក់ ស្ដែង ដោយរបៀបណានោះទេ[4087]។ ដូចទៅនឹងសំណុំរឿង ០០២/០១ ដែរ[4088] ការយោងដែលបាន លើកឡើងទៅនឹងនិក្ខេបបទថ្នាក់បណ្ឌិតរបស់ម្ចាស់បណ្ដឹងសាទុក្ខ និងសកម្មភាពនានាមុនឆ្នាំ១៩៧០ មិនបានផ្ដល់ជាមូលដ្ឋានសម្រាប់បញ្ជាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ឡើយ ហើយ អ.ជ.ស.ដ បានប្រើប្រាស់វាដើម្បីតែការបង្ហាញពីបរិបទនៃផ្នត់គំនិត និងការ

---

[4083] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៥ *យោង* ឯកសារ **E3/18** ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* KH 00103827 (សារភាពថា គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តបារាំង ប៉ុន្តែគាត់មិនបានបន្តសមាជិកភាពរបស់គាត់ទេនៅក្រោយឆ្នាំ១៩៥៧ ដោយសារការពិត សកម្មភាពរបស់បក្សនេះផ្ដោតជាចំបងទៅលើបញ្ហាផ្ទៃក្នុងរបស់ប្រទេសបារាំង មិនមែនដោយសារវាជាកុម្មុយនីស្តទេ)។ ឯកសារ **E1/21.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១ ម៉ោង 14.28.39-14.36.20, ទំព័រ ៥១ បន្ទាត់ ២១–ទំព័រ ៥២ បន្ទាត់ ២១ (ពន្យល់អំពីជាប់ចិត្តជាមួយបក្សកុម្មុយនីស្តបារាំង ក្នុងឆ្នាំ១៩៥៥ ប៉ុន្តែក្រោយមកបានជ្រើសរើសមិនបន្តសមាជិកភាពរបស់គាត់ជាមួយបក្សនេះ ដោយសារការប្រជុំនិយាយតែពីនយោបាយបារាំង)។

[4084] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៦។

[4085] អ.ជ.ស.ដ មិនបានហៅថា ការបោះពុម្ពផ្សាយកុម្មុយនីស្តទេ គឺហៅថា “កាសែតភាសាបារាំង” ដែល “មានការរិះគន់លើទិដ្ឋភាពនយោបាយរបស់សម្ដេច នរោត្តម សីហនុ ខណៈមានការគាំទ្រឥតលាក់លៀមចំពោះគោលនយោបាយអព្យាក្រឹតភាពរបស់ព្រះអង្គ”៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៩។

[4086] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦៩ (ទាក់ទងនឹងការឧបត្ថមថវិកាដោយ អៀង ធីរិទ្ធិ ហើយនឹង ជួន ប្រសិទ្ធិ, ប៊ូ ផាត, ហ៊ូ នឹម និង ហ៊ូ យន់ ផងដែរ)។ ម្ចាស់បណ្ដឹងសាទុក្ខខ្លួនគាត់ផ្ទាល់ បានសារភាពថា ប្រភពមួយចំនួនរបស់គាត់ គឺកុម្មុយនីស្តៈ ឯកសារ **E1/21.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ម៉ោង 14.38.53-14.41.47, ទំព័រ ៥៣ បន្ទាត់ ១៦-២១។ *សូមមើលផងដែរ* ឯកសារ **E295/6/1.4** ឧបសម្ព័ន្ធ ៤ របស់ ក.ស.ព ទៅនឹងសារណាសារណាចុងក្រោយក្នុងសំណុំរឿង ០០២/០១ (“កាលប្រវត្តិ ខៀវ សំផន របស់ ក.ស.ព”) EN 00948466 និងប្រភពដែលបានយោងនៅក្នុងនោះ។

[4087] *សូមមើល* បទដ្ឋានស្ដីពីការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់)។

[4088] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ១០០៥។

ចូលរួមរបស់ គាត់នៅក្នុង ប.ក.ក និងពីរបៀបដែលម្ចាស់បណ្តឹងសាទុក្ខបានទទួលទំនុកចិត្តជាបណ្តើរៗពីថ្នាក់ដឹកនាំបក្ស និងបានក្លាយជាមេដឹកនាំម្នាក់ ដែលក្រោយមក បានជួយជំរុញគោលនយោបាយនានា និងឧក្រិដ្ឋកម្មរបស់ ប.ក.ក។

### *មូលដ្ឋានទី ១៩៣៖ ទស្សនាវដ្ដីទង់បដិវត្តន៍/ទស្សនាវដ្ដី យុវជនយុវនារីបដិវត្តន៍*[4089]

1120. **មូលដ្ឋានទី ១៩៣ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខបរាជ័យមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ និងច្បាប់នៅក្នុងការសម្រេចរបស់ខ្លួនដែលថា ម្ចាស់បណ្តឹងសាទុក្ខមានលទ្ធភាពទទួលបានទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជន យុវនារី បដិវត្តន៍ និងថា តាមរយៈនេះ គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។**

1121. ជារួម មូលដ្ឋាននេះដូចគ្នានឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជន យុវនារី បដិវត្តន៍ នៅក្នុងសំណុំរឿង ០០២/០១ ដែរ[4090] ដែល អ.ជ.ត.ក បានបដិសេធចោលយ៉ាងត្រឹមត្រូវ[4091]។ ដូចគ្នាទៅនឹងសំណុំរឿង ០០២/០១ ដែរ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខគួរត្រូវបានបដិសេធចោល ដោយសារ អ.ជ.ស.ដ មិនបានសន្និដ្ឋានថា ការយល់ដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខបានពឹងផ្អែកលើតែ ឬជាសំខាន់ទៅលើ ទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជន យុវនារីបដិវត្តន៍ នោះទេ។ ទោះក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបញ្ជាក់គាំទ្រការអះអាងជាក់ជាក់លាក់របស់ខ្លួនទាក់ទងនឹងលទ្ធភាពទទួលបាន និងការដឹងអំពីទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជន យុវនារី បដិវត្តន៍ ឡើយ។

1122. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញភ័ស្តុតាងអំពីការអះអាងរបស់ខ្លួនថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដោយសន្និដ្ឋានថា សមាជិកបក្សទាំងអស់សុទ្ធតែមានលទ្ធភាពទទួលបានទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជន យុវនារីបដិវត្តន៍ រួមទាំងនៅថ្នាក់ស្រុក និងឃុំ[4092]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ប.ក.ក បានធានា តាមរយៈមធ្យោបាយផ្សេងៗ ថាសមាជិករបស់ខ្លួនបានដឹងអំពីខ្លឹមសារនៃទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជន យុវនារី

---

[4089] <u>មូលដ្ឋានទី ២៩៣៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ ទស្សនាវដ្តី ទង់បដិវត្តន៍/យុវជន យុវនារីបដិវត្តន៍ កថាខណ្ឌ ១៦៩១-១៦៩៣។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៦៧ (អង់គ្លេស), ទំព័រ ៦២ (បារាំង), ទំព័រ ៩៤-៩៥ (ខ្មែរ)។

[4090] ឯកសារ F17 សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៩២-៤៩៤, ៤៩៦។

[4091] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ១០៧២។

[4092] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៩២។

បដិវត្តន៍ និងបានដឹងអំពីគោលនយោបាយនានារបស់ ប.ក.ក ដែលមាននៅក្នុងនោះ ដោយសារទស្សនាវដ្តីទាំងនេះត្រូវបានប្រើប្រាស់ជាញឹកញាប់សម្រាប់អប់រំក្នុងវគ្គរៀនសូត្រ ឬបំពាក់បំប៉ននានារបស់ ប.ក.ក ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ[4093]។ លើសពីនេះទៀត ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ ពិតជាយល់ថា ទោះបីជាមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយយ៉ាងណាក្តី[4094] ក៏មិនមែនមានន័យថា គ្រប់សមាជិកទាំងអស់សុទ្ធតែទទួលបានទស្សនាវដ្តីទាំងនេះដែរ"[4095]។

1123. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការសម្រេចថា គាត់មានលទ្ធភាពទទួលបានយ៉ាងមានប្រសិទ្ធភាពនូវទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជនយុវនារី បដិវត្តន៍ទាំងអស់នេះ ឬបានអានអត្ថបទជាក់លាក់ដើម្បីធ្វើការសន្និដ្ឋានលើការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម[4096] រួមទាំងអំពីវាសនារបស់ខ្មាំង[4097]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4098] អ.ជ.ស.ដ មិនមែនធ្វើការស្មានក្នុងការសម្រេចរបស់ខ្លួនថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ រួមទាំង ចាន់ ចក្រី, សួស នៅ *ហៅ* ឈូក, កែវ មាស និង កុយ ធួន តាមរយៈទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជនយុវនារី បដិវត្តន៍នេះទេ។ អ.ជ.ស.ដ បានបង្ហាញយ៉ាងលម្អិតអំពីប្រភពព័ត៌មានជាច្រើន ក្រៅពីទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជនយុវនារី បដិវត្តន៍ ដែលតាមរយៈនោះ ម្ចាស់បណ្តឹងសាទុក្ខ គួរតែ

---

[4093] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៧៧, ១០២៦, ៣៧៤៧។ *សូមមើលផងដែរ* ឯកសារ **E1/502.1** ប៊ិត ហឿន ហៅ ប៊ិត ណា ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង 10.06.44-10.13.00, ទំព័រ១៧ បន្ទាត់ ៩-ទំព័រ ១៩ បន្ទាត់ ២ (ប៊ិត ហឿន ហៅ ប៊ិត ណា បានផ្តល់សក្ខីកម្មថា នាងបានចូលរួមវគ្គពីរដង ដែលមាន ប៉ុល ពត, នួន ជា និង ម្ចាស់បណ្តឹងសាទុក្ខ ជាអ្នកធ្វើឧទ្ទេសនាម និង "គេបង្រៀនទស្សនាវដ្តី *ទង់នបដិវត្តន៍*")។

[4094] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៧៩។

[4095] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៧៥។

[4096] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤៣។ អ.ជ.ស.ដ មិនបានរកឃើញថា ម្ចាស់បណ្តឹងសាទុក្ខបានអានអត្ថបទជាក់លាក់ណាមួយទេ ប៉ុន្តែគ្រាន់តែបាននិយាយថា ទស្សនាវដ្តី ទង់បដិវត្តន៍/យុវជន យុវនារីបដិវត្តន៍ មានចំពោះម្ចាស់បណ្តឹងសាទុក្ខ តាមស្មារតីនៃមុខតំណែងនៃការទទួលខុសត្រូវរបស់គាត់៖ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៦, ៤២៥៣។

[4097] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤១, ១៦៤៣។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៣, ៤២២៦។

[4098] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤៣, ១៨៦៥, ១០៨៦ (ជាកន្លែងដែលម្ចាស់បណ្តឹងសាទុក្ខសារភាពថា ចក្រី, សោ ភឹម, ឌឿន និង ជ័យ ត្រូវបានចាត់ទុកនៅទស្សនាវដ្តីទង់បដិវត្តន៍ ចេញផ្សាយខែ ឧសភា-មិថុនា និង កក្កដា ឆ្នាំ១៩៧៦ ថាជា "ភ្នាក់ងារ" វៀតណាម)។

បានដឹងអំពីការចាប់ខ្លួនទាំងនោះ[4099]។ ផ្ទុយពីអភិក្រមវាយតម្លៃលើភ័ស្តុតាងតាមផ្នែករបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវលើភ័ស្តុតាងទាំងមូល មុននឹងធ្វើការសម្រេចប្រកបដោយហេតុផល[4100]។

1124. ទីបី ការអះអាងររបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការសម្រេចថា សេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងវិញអំពីអត្ថបទនៃទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជនយុវនារី បដិវត្តន៍ ពាក់ព័ន្ធនឹងការប្រព្រឹត្តិដោយរើសអើងប្រឆាំងនឹងខ្មាំងវៀតណាម និងទីភ្នាក់ងារវៀតណាមនោះ គ្មានមូលដ្ឋានបញ្ជាក់គាំទ្រឡើយ[4101]។ ការអះអាងរបស់គាត់ទាក់ទងនឹងបរិបទនៃសុន្ទរកថារបស់គាត់ ត្រូវបានលើកមកដោះស្រាយនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥[4102]។

1125. ការអះអាងផ្សេងៗទៀតរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងលទ្ធភាពទទួលយកបានភ័ស្តុតាង និងតម្លៃនៃភ័ស្តុតាងនៃទស្សនាវដ្តីទង់បដិវត្តន៍/ទស្សនាវដ្តី យុវជនយុវនារី បដិវត្តន៍ ត្រូវបានលើកមកដោះស្រាយនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២៩ និង ១៧៧[4103]។

### *មូលដ្ឋានទី ២២៣៖ ការដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត*[4104]

1126. **មូលដ្ឋានទី ២២៣ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខបរាជ័យមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុនៅក្នុងការសម្រេចរបស់ខ្លួនដែលថា តាមរយៈការចូលរួមវគ្គរៀនសូត្រ និងការប្រមូលផ្តុំរបស់គាត់ ជាទីកន្លែងដែលការប្រព្រឹត្តិឧក្រិដ្ឋកម្មត្រូវបានពិភាក្សា អនុមតិ និងអនុវត្ត និងលទ្ធភាពរបស់គាត់ក្នុងការទទួលបានឯកសារនានារបស់ ប.ក.ក នោះម្ចាស់បណ្តឹងសាទុក្ខបានដឹងថា ឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្ត។**

---

[4099] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៦។

[4100] *សូមមើល* បទដ្ឋានស្តីពីការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[4101] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦៤១។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៩។ *សូមមើលផងដែរ* កថាខណ្ឌ ៣៤០៦-៣៤០៧, ៣៥១៣, ៣៨១៩-៣៨២០, ៣៨២៤, ៣៨២៩, ៣៨៣៣។

[4102] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៩ និង ១៨៥។

[4103] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៩ និង ១៧៧។

[4104] <u>មូលដ្ឋានទី ២២៣៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ចំណេះដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត* កថាខណ្ឌ ១៩៣៦-១៩៣៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ៧៥(អង់គ្លេស), ទំព័រ៧០(បារាំង), ទំព័រ១០៧(ខ្មែរ)។

1127. មូលដ្ឋាននេះបរាជ័យ ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា ការសម្រេចរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្មនានានៅក្រោយឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត ដែលបណ្ដាលឱ្យមានការខុសឆ្គោយរបស់តុលាការជាក់ស្ដែង ដែលជាកត្តាសំខាន់បំផុតនៃការសម្រេចសាលក្រម[4105]។ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញពីការផ្ដន្ទាទោសណាមួយ ដែល អ.ជ.ស.ដ មិនអាចកំណត់ធ្វើបាន បើគ្មានការសម្រេចដូចនេះទេ។ តាមពិត អ.ជ.ស.ដ ជាក់ស្ដែងមិនបានពឹងផ្អែកការសម្រេចរបស់ខ្លួនលើចំណុចដែលថា ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្មនានា នៅក្រោយពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងដើម្បីកំណត់អំពីការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មណាមួយ ដែលគាត់ត្រូវបានកាត់ឱ្យជាប់ទោសនោះទេ។ ផ្ទុយទៅវិញ គេមិនធ្វើដូច្នោះទេ ដោយហេតុថា អ.ជ.ស.ដ បានកំណត់រួចហើយថា ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្មនីមួយៗក្នុងពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង[4106]។

1128. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខជាច្រើនផ្សេងទៀតដែលថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដោយសារតែការខកខានមិនបានបង្ហាញការដឹងរបស់គាត់ទាក់ទងនឹងឧក្រិដ្ឋកម្មនានានោះ ក៏បរាជ័យដោយសារមូលហេតុដូចគ្នានេះដែរ[4107]។ អ.ជ.ស.ដ មិនចាំបាច់ធ្វើដូច្នេះទេ ដោយសារអង្គជំនុំជម្រះនេះបានកំណត់រួចហើយថា គាត់មានការដឹងនៅពេលនោះអំពីឧក្រិដ្ឋកម្មជាក់លាក់នីមួយៗនៃឧក្រិដ្ឋកម្មទាំងនេះ[4108] ហើយអង្គជំនុំជម្រះមិនបានពឹងផ្អែកលើការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មទាំងនោះ នៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ ដើម្បីកំណត់ទៅលើការទទួលខុសត្រូវរបស់គាត់ទេ។

---

[4105] *សូមមើល* បទដ្ឋានស្ដីពីការពិនិត្យឡើងវិញ (កំហុសអង្គច្បាប់ កំហុសអង្គហេតុ)។

[4106] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៩-៤២៤៩។

[4107] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩៣៣ ("អង្គជំនុំជម្រះមិនបានបង្ហាញអំពីចំណេះដឹងរបស់គាត់ក្រោយអង្គហេតុនៃឧក្រិដ្ឋកម្មជាក់លាក់ណាមួយដែលគាត់ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ទេ"), ១៩៣៤ ("មិនមានបញ្ជាក់ថាតើគោលនយោបាយណាមួយដែលគាត់ពាក់ព័ន្ធទេ និងកាន់តែតិចចំពោះឧក្រិដ្ឋកម្មដែលគាត់បានដឹងតាមរយៈសុន្ទរកថាទាំងនេះ"), ១៩៣៥(អង្គជំនុំជម្រះមិនបានបង្ហាញហួសពីវិមតិសង្ស័យថាគាត់បានដឹងអំពីឧក្រិដ្ឋកម្មជាក់លាក់ដែលបានប្រព្រឹត្តនោះទេ"), ១៩៣៧ ("លទ្ធភាពទទួលបានការបោះពុម្ពផ្សាយទង់បដិវត្តន៍ដូចបានចោទប្រកាន់ មិនអនុញ្ញាតឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខមានចំណេះដឹងអំពីឧក្រិដ្ឋកម្មជាក់លាក់" នោះឡើយ)។

[4108] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៩-៤២៤៩។

1129. ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងឧក្រិដ្ឋកម្មអំពីបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ដែលម្ចាស់បណ្តឹងសាទុក្ខផ្តល់សារសំខាន់ជាពិសេសនោះ[4109] ក៏បរាជ័យ អាស្រ័យដោយមូលហេតុដូចគ្នា។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា "ទាក់ទងទៅនឹងបទបញ្ញាស្តីពីការរៀបការ [អ.ជ.ស.ដ] បានសន្និដ្ឋានថា [ម្ចាស់បណ្តឹងសាទុក្ខ] *បានដឹង* អំពីឧក្រិដ្ឋកម្ម បន្ទាប់ពីឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តរួចហើយ"នោះ[4110] អ.ជ.ស.ដ បានកំណត់រួចហើយថា ម្ចាស់បណ្តឹងសាទុក្ខមានការដឹងនៅពេលនោះអំពីឧក្រិដ្ឋកម្មទាំងនេះ[4111]។ អ.ជ.ស.ដ មិនបានយោង ឬពឹងផ្អែកសេចក្តីសម្រេចរបស់ខ្លួនលើការដឹងរបស់គាត់ចំពោះឧក្រិដ្ឋកម្មទាំងនេះ នៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ ដើម្បីកំណត់លើការទទួលខុសត្រូវរបស់គាត់ទេ[4112]។ ការសន្និដ្ឋាននេះគ្មានអ្វីដែលសំខាន់សម្រាប់សាលក្រមឡើយ។

1130. ការចោទប្រកាន់ផ្សេងៗទៀតរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលបានធ្វើឡើងនៅក្នុងមូលដ្ឋាននេះ សុទ្ធតែគ្មានមូលដ្ឋាន និងត្រូវបានដោះស្រាយរួចហើយនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានផ្សេងទៀត ឬគ្មានភ័ស្តុតាង ដូច្នេះ គួរត្រូវបានបដិសេធចោល។ ការអះអាងរបស់គាត់ដែលថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុស នៅក្នុងការសម្រេចរបស់ខ្លួន ទាក់ទងនឹងលិខិតដែលបានបញ្ជូនមក គាត់ដោយអង្គការលើកលែងទោសអន្តរជាតិ[4113] ត្រូវបានលើកមកដោះស្រាយនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២០៧[4114]។ ការជំទាស់របស់គាត់ទៅនឹងការសម្រេចរបស់ អ.ជ.ស.ដ អំពីការ ដឹងនៅពេលនោះរបស់គាត់អំពីឧក្រិដ្ឋកម្ម[4115] ត្រូវបានលើកមកដោះស្រាយនៅកន្លែងផ្សេង[4116]។ ការអះអាងរបស់គាត់ទាក់ទងនឹងលទ្ធភាពទទួលបានទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តី យុវជនយុវនារីបដិវត្តន៍[4117] ត្រូវបានលើកមកដោះស្រាយនៅក្នុងមូលដ្ឋានទី ១៩៣[4118]។ ជាចុងក្រោយ ភាព

---

[4109] មូលដ្ឋានទី ២២៣ ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ ក ហាក់ដូចជាពាក់ព័ន្ធតែជាមួយនឹងការសន្និដ្ឋានរបស់ អ.ជ.ស.ដ ទាក់ទងនឹងបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ប៉ុណ្ណោះ៖ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៥។

[4110] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៣៦ (គូសបញ្ជាក់បន្ថែម)។

[4111] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤៧-៤២៤៩។

[4112] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៣-៤៣០៥។

[4113] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៣២។

[4114] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៧។

[4115] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៣២ (ទាក់ទងនឹងចំណេះដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត "ជាផ្នែកនៃការបង្កើត និងដំណើរការនៃសហករណ៍ និងការដ្ឋាន ហើយនឹងការបោសសម្អាតផ្ទៃក្នុង"), ១៩៣៦ (ទាក់ទងនឹងចំណេះដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីឧក្រិដ្ឋកម្មនៃបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍)។

[4116] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១០-២១៥។ *សូមមើល* វាក្យខណ្ឌ **VIII**.គ.៣ ចេតនា។

[4117] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៣៤។

ពាក់ព័ន្ធនៃការអះអាងរបស់គាត់ថា "សុន្ទរកថាស្តីពីការបង្កើនចំនួនប្រជាជន ពាក់ព័ន្ធជាមួយគោលបំណងនៃការកែលម្អស្ថានភាពរស់នៅរបស់ប្រជាជន" នោះ មិនមានភាពច្បាស់លាស់ទេ[4119]។ ការជំរុញទឹកចិត្តរបស់ម្ចាស់បណ្តឹងសាទុក្ខ មានការពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម និងទោះជាយ៉ាងណាក៏ដោយ គេអាចបង្ហាញឱ្យឃើញបានតែតាមរយៈថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ[4120]។

### iii. ចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមគោលដៅ

### *មូលដ្ឋានទី ២២០ និង ២៤២៖ ពុទ្ធសាសនិកជន*[4121]

1131. **មូលដ្ឋានទី ២២០ និង ២៤២ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខបរាជ័យមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ និងអង្គហេតុ នៅក្នុងការសម្រេចដែលថាគាត់មាន*ធាតុផ្សំអត្តនោម័តិ* ដែលតម្រូវ សម្រាប់ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួមសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនាប្រឆាំងនឹងពុទ្ធសាសនិកជន។**

1132. មូលដ្ឋាននេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខ (i) យល់ច្រឡំចំពោះ*ធាតុផ្សំអត្តនោម័តិ* ដែលតម្រូវសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម និង (ii) មិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសនៅក្នុងការសម្រេចរបស់ខ្លួនទាក់ទងនឹងការដឹង និងចេតនារបស់គាត់ទេ។

1133. ទីមួយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខយល់ច្រឡំចំពោះច្បាប់[4122]។ ផ្ទុយពីការអះអាងរបស់គាត់[4123] ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម មិនតម្រូវឱ្យមានការដឹងអំពីអំពើឧក្រិដ្ឋជាក់

---

[4118] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៣។

[4119] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៣៧។

[4120] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១០ និង ១៦៦។

[4121] មូលដ្ឋានទី ២២០៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ពុទ្ធសាសនិកជន* កថាខណ្ឌ ១៩១០-១៩២០។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៤ (អង់គ្លេស), ទំព័រ ៦៩ (បារាំង), ទំព័រ ១០៦ (ខ្មែរ)។ មូលដ្ឋានទី ២៤២៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ពុទ្ធសាសនិកជន* កថាខណ្ឌ ២០៩១-២០៩៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨០ (អង់គ្លេស), ទំព័រ ៧៥ (បារាំង), ទំព័រ ១១៥ (ខ្មែរ)។

[4122] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៩៧-២០៩៨។

[4123] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩១២-១៩១៧។

លាក់ណាមួយទេ[4124]។ លើសពីនេះទៀត *ធាតុផ្សំអត្តនោម័តិ* សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ មិនតម្រូវឱ្យមានចេតនាក្នុងការដាក់ឱ្យឯកោ ឬទាត់ចេញក្រុមណាមួយពីសង្គម[4125] នោះទេ។

1134. ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ ខកខានមិនបានបង្ហាញភ័ស្តុតាងចំពោះការសម្រេចរបស់ខ្លួនទាក់ទងនឹង*ធាតុផ្សំអត្តនោម័តិ*[4126]។ ការអះអាងរបស់គាត់ ត្រូវតែច្រានចោល ដោយសារម្ចាស់បណ្ដឹងសាទុក្ខប្រើអភិក្រមវាយតម្លៃភ័ស្តុតាងតាមផ្នែកដែលមិនត្រឹមត្រូវ ហើយខកខានមិនបានអានសេចក្ដីសន្និដ្ឋានរបស់ អ.ជ.ស.ដ រួមគ្នាជាមួយនឹងសេចក្ដីសម្រេចខាងអង្គហេតុជាមូលដ្ឋាន[4127]។ ផ្ទុយពីការជំទាស់របស់ម្ចាស់បណ្ដឹងសាទុក្ខ អ.ជ.ស.ដ បានផ្ដល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់ការសន្និដ្ឋានរបស់ខ្លួនថា "ការគាំទ្រឥតងាករេរបស់គាត់ចំពោះគោលនយោបាយរបស់ ប.ក.ក និងការបិទបាំងជាច្រើនលើកច្រើនសារនូវការអនុវត្តគោលនយោបាយទាំងនោះ បង្ហាញពីចេតនារបស់គាត់ក្នុងការលុបបំបាត់ព្រះពុទ្ធសាសនានៅកម្ពុជា"[4128]។

1135. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខថា អ.ជ.ស.ដ មិនមានភ័ស្តុតាងបញ្ជាក់ចំពោះការសន្និដ្ឋានរបស់ខ្លួនដែលថា គាត់បានដឹង និងគាំទ្រចំពោះគោលនយោបាយរបស់ ប.ក.ក នោះ បានមិនគិតគូរចំពោះការសម្រេចរបស់ អ.ជ.ស.ដ លើសកម្មភាពរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក្រោយថ្ងៃជ័យជំនះរបស់ ប.ក.ក ក្នុងខែមេសា ឆ្នាំ១៩៧៥[4129]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ក្នុងខែឧសភា ឆ្នាំ១៩៧៥ ម្ចាស់បណ្ដឹងសាទុក្ខបានចូលរួមកិច្ចប្រជុំនៅវត្តព្រះកែវមរកត ជាកន្លែងដែលគោលនយោបាយនានារបស់បក្សត្រូវបានសម្រេច រួមទាំង ផែនការបិទវត្តទាំងអស់ និងការផ្សឹកព្រះសង្ឃទាំងអស់ផង[4130]។ នៅចន្លោះថ្ងៃទី២០ និង២៥ ខែឧសភា ឆ្នាំ១៩៧៥ គោលនយោបាយទាំងនេះ ត្រូវបានលើកឡើងនៅក្នុងពេលប្រមូលផ្ដុំរបស់ពួកកម្មាភិបាល[4131] ដែលម្ចាស់បណ្ដឹងសាទុក្ខបាន

[4124] *សូមមើល* វាក្យខណ្ឌ VIII.គ.៣ ចេតនា។

[4125] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៥។

[4126] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩១០-១៩២០, ២០៩២-២០៩៦។

[4127] *សូមមើល* វាក្យខណ្ឌ VIII.គ.៣ ចេតនា។

[4128] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៨។

[4129] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩១០-១៩២០, ២០៩៣។

[4130] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦។

[4131] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦, ជើងទំព័រ ១២៤៦០។ *សូមមើលផងដែរ* ឯកសារ **E1/82.1** សៅ សារុន ប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 11.30.48-11.36.40, ទំព័រ ៣៧ បន្ទាត់ ៩-ទំព័រ ៣៨ បន្ទាត់ ៦ *ដោយបញ្ជាក់អះអាងលើ* ឯកសារ **E3/367** កំណត់ហេតុស្ដាប់ចម្លើយ សៅ សារុន KH 00251437 ("ក្នុងការប្រជុំនេះ

ចូលរួម[4132]។ ប៉ុល ពត បានសារភាពជាសាធារណៈថា បក្សកំពុងតែព្យាយាម "លុបបំបាត់" ពុទ្ធសាសនា ហើយមធ្យោបាយដើម្បីធ្វើដូច្នេះគឺឱ្យព្រះសង្ឃលើកទំនប់ និងធ្វើការងារ"[4133] ជាអ្វីដែលម្ចាស់ បណ្ដឹងសាទុក្ខបានបញ្ជាក់ជាសាធារណៈ[4134]។ ក្នុងខែមករា ឆ្នាំ១៩៧៦ ម្ចាស់បណ្ដឹងសាទុក្ខបានធ្វើបទបង្ហាញអំពីរដ្ឋធម្មនុញ្ញថ្មីដែលហាមឃាត់ "សាសនាប្រតិកិរិយា" (ដែលព្រះពុទ្ធសាសនាត្រូវ បានចាត់ទុកជាសាសនាប្រតិកិរិយា)[4135] និងបានពន្យល់អំពីមូលហេតុដែលនាំឱ្យមានការហាមឃាត់នេះថា មកពីមានភាពចាំបាច់ក្នុងការប្រឆាំង "តាមគ្រប់រូបភាព" ចំពោះជនណាដែលប្រើ សាសនាដើម្បីធ្វើវិទ្ធង្សនាចំពោះរបបនេះ"[4136]។ គណៈប្រតិភូអន្តរជាតិត្រូវបានជូនដំណឹងថា ព្រះពុទ្ធសាសនាលែងមានការគោរពពទៀតហើយ និងត្រូវ "បានចាត់ទុកថាមិនត្រូវធាតុគ្នាជាមួយនឹងបដិវត្តន៍"[4137]។

1136. អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងសមហេតុផលថា ម្ចាស់បណ្ដឹងសាទុក្ខបានណែនាំអំពីការរៀបចំអាពាហ៍ពិពាហ៍ដោយគ្មានវត្តមានព្រះសង្ឃ និង "តាមរបៀបមួយដែលវិសមិតភាពនឹងប្រពៃណីនៃពុទ្ធសាសនាជាមូលដ្ឋាន"[4138]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[4139] អ.ជ.ស.ដ មិនបានពឹងផ្អែកលើ "ការស្មានដែលគ្មានមូលដ្ឋាន" ទេ និងបានលើកអំពីភាពជឿជាក់បានចំពោះសក្ខីកម្ម

---

អ្នក ឧទ្ទេសនាមបើកវត្តមាន នួន ជា និង ប៉ុល ពត [...] អ្នកទាំងពីរនាក់នេះ និយាយអំពី [...] បិទវត្តអារាម")។ ឯកសារ **E3/1593** Ben Kiernan, *របប ប៉ុល ពត* KH 00637442 (គោលនយោបាយត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំ រួមមាន៖ "(៤) ផ្សឹកលោកសង្ឃកាន់សាសនាព្រះពុទ្ធទាំងអស់ ហើយដាក់ឱ្យធ្វើស្រែទាំងអស់")។ ឯកសារ **E3/1568** សេចក្ដីថ្លែងការណ៍ ជា ស៊ីម ថ្ងៃទី៣ ខែធ្នូ ១៩៩១ KH 00713927 និងកំណត់សំគាល់បទសម្ភាសន៍ដើម ឯកសារ **E3/5593** EN 00419371-72 (បញ្ជាក់អះអាងថា ចំណុចមួយក្នុងចំណោមប្រាំបីចំណុច ប៉ុល ពត និង នួន ជា បាននិយាយអំពី "ផ្សឹកលោកសង្ឃទាំងអស់")។ ឯកសារ **E1/291.1** ពេជ្រ ជឹម ប្រតិចារិក ថ្ងៃទី២៣ មេសា ២០១៥ ត្រង់ 14.31.05-14.34.02, ទំព័រ ៤៩ បន្ទាត់ ២៣ -ទំព័រ ៥០ បន្ទាត់ ៤ (ខុម ជាលេខាស្រុកត្រាំកក់ បានចូលរួមប្រជុំខែឧសភា ឆ្នាំ១៩៧៥ និងបានកោះកម្មាភិបាលថ្នាក់ស្រុកមកប្រជុំ ពេលដែលគាត់ត្រឡប់ទៅវិញ ដើម្បីផ្សព្វផ្សាយអំពីផែនការ: "ស៖ តើលោកចាំដែរទេថា ថាតើគាត់និយាយបញ្ហាមួយចំនួនអំពីការផ្សឹក ឬក៏ការឱ្យព្រះសង្ឃលាចាកសិក្ខាបទហ្នឹង តើគាត់បាននិយាយដែរទេ? ឆ៖ គាត់និយាយ [...] គាត់មាននិយាយ និយាយ ហើយអនុវត្ត គាត់ហ្នឹងនាំគ្នាធ្វើតែម្ដង នាំធ្វើគ្រប់ឃុំធ្វើទៅ")។

[4132] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦, ជើងទំព័រ ១២៤៦០។

[4133] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៩២។

[4134] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤១, ជើងទំព័រ ១៣៨៤៤។

[4135] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១០៨។

[4136] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០២០ *យោង* កថាខណ្ឌ ១០៩០។

[4137] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១០៨។

[4138] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៧, ៤២៤២ *យោង* កថាខណ្ឌ ៣៥៦៩-៣៥៧០។

[4139] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩១៨។

របស់ ជា ជៀប ដែលថា ម្ចាស់បណ្តឹងសាទុក្ខបានបង្រៀនកម្មាភិបាលអំពីភាពចាំបាច់នៃអាពាហ៍ពិពាហ៍ដែលមានការរៀបចំ[4140] ជាភស្តុតាងដែលត្រូវបានបញ្ជាក់បន្ថែមដោយសាក្សី រស់ ស៊ុយ និងសម្តេច នរោត្តម សីហនុ[4141]។ អ.ជ.ស.ដ បានសន្និដ្ឋានថា សក្ខីកម្មរបស់សាក្សីស៊ុយសង្វាក់គ្នាជាមួយនឹង "ការផ្សព្វផ្សាយមនោគមន៍វិជ្ជារបស់ ប.ក.ក រួមទាំង សុន្ទរកថាថ្លែងដោយ [ម្ចាស់បណ្តឹងសាទុក្ខ]"[4142]។

1137. ស្រដៀងគ្នានេះដែរ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសនៅក្នុងការសម្រេចដែលថា សេចក្តីថ្លែងការណ៍គាំទ្រព្រះពុទ្ធសាសនាគឺជា "ល្បិចដោះខ្លួន" និងជា "ការលាក់បាំងប្រក្រតីភាព"[4143]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានពិចារណាលើការសម្រេចជាមូលដ្ឋានរបស់ អ.ជ.ស.ដ អំពីតួនាទីរបស់គាត់ក្នុងនាមជាឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាល GRUNK ដែលបានជួយពង្រឹងកម្លាំង FUNK និង GRUNK ដែលបិទបាំងប្រតិបត្តិការរបស់ ប.ក.ក"[4144] រួមទាំងអ្នកដែលប្រឆាំងនឹងកាន់ព្រះពុទ្ធសាសនា។ ទាក់ទងនឹងការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជនឱ្យចំជាងនេះទៀត[4145] គឺ អ.ជ.ស.ដ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមក្នុងការបង្ហាញមុខមាត់ FUNK តាមរយៈការអនុមតិកម្មវិធីនយោបាយផ្លូវការរបស់ FUNK ដែលបានប្រកាសថា "សាសនាព្រះពុទ្ធ គឺជា និងនៅតែសាសនារបស់រដ្ឋ"[4146]។ ម្ចាស់បណ្តឹងសាទុក្ខនៅតែរក្សាស្ថានភាពធម្មតា រហូតដល់ខែមេសា ឆ្នាំ១៩៧៥ តាមរយៈការលើកសរសើរព្រះសង្ឃដែលបានចូលរួមចំណែកក្នុងបដិវត្តន៍[4147] និងតាមរយៈការថ្វាយបង្គំដល់ព្រះសង្ឃ[4148]។

1138. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ វាមិនមែនជាការមិនសមហេតុផលដែល អ.ជ.ស.ដ បានពឹងផ្អែកលើរបាយការណ៍របស់ FBIS នោះ ដោយហេតុថា ភស្តុតាងត្រូវបានបញ្ជាក់បន្ថែម

---

[4140] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៥៦៩។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងទស្សីរណ៍ ១៦៦។

[4141] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៧០-៣៦៧១, ៣៥៨៦។

[4142] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៩០។

[4143] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩១៤-១៩២០, ២០៩៤ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤១, ៤២៩៧។

[4144] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៨, ៤២៩៧។

[4145] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៨៤-១០៨៦។

[4146] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤០។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦៣, ១០៨៤។

[4147] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៧ *យោង* កថាខណ្ឌ ៤២៤០។

[4148] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤០, ជើងទំព័រ ១៣៨៣៦។

ដោយប្រភពឯករាជ្យនានា[4149] និងរបាយការណ៍ផ្សេងទៀតអំពីសេចក្តីថ្លែងការណ៍របស់គាត់[4150]។ តាមរយៈការផ្តល់សំអាងហេតុរបស់ អ.ជ.ស.ដ យើងច្បាស់ណាស់ថា អ.ជ.ស.ដ បានពិចារណាលើភាពជឿជាក់បាន និងតម្លៃភស្តុតាងនៃភ័ស្តុតាងនៅចំពោះមុខខ្លួន[4151]។ អ.ជ.ស.ដ ក៏បានពិចារណាយ៉ាងច្បាស់លាស់លើភ័ស្តុតាងរបស់ម្ចាស់បណ្តឹងសាទុក្ខផងដែរដែលថា "គាត់មិនដឹងអ្វីសោះទាក់ទងនឹងការប្រតិបត្តិសាសនា ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ" និងបានច្រាលចោលយ៉ាងត្រឹមត្រូវលើភ័ស្តុតាងនោះដោយផ្អែកលើភ័ស្តុតាងផ្ទុយសំខាន់ៗ[4152]។

1139. លើសពីនេះទៀត ទាក់ទងនឹងត្រាំកក់ ម្ចាស់បណ្តឹងសាទុក្ខអះអាងទាំងគ្មានមូលដ្ឋានថា អ.ជ.ស.ដ ខកខានមិនបានបង្ហាញភ័ស្តុតាងចំពោះការសន្និដ្ឋានរបស់ខ្លួនទេ និងបានពឹងផ្អែកទាំងខុសលើសុទ្ធរកថា និងឯកសារនានាដែលមានចុះកាលបរិច្ឆេទមុនសម័យកម្ពុជាប្រជាធិបតេយ្យ និងមិនមាននិយាយអំពីត្រាំកក់[4153]។ ដូចបានពិភាក្សានៅកន្លែងផ្សេង[4154] អ.ជ.ស.ដ បានផ្តល់មូលហេតុគ្រប់គ្រាន់លើការសន្និដ្ឋានរបស់ខ្លួនថា អំពើនៃការធ្វើទុក្ខបុកម្នេញដែលបានប្រព្រឹត្តនៅត្រាំកក់ នៅក្នុងបរិបទនៃយុទ្ធនាការធ្វើទុក្ខបុកម្នេញទ្រង់ទ្រាយធំប្រឆាំងនឹងពុទ្ធសាសនិក គឺជាអំពើដែលម្ចាស់បណ្តឹងសាទុក្ខបានដឹង[4155]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានដឹងផងដែរអំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅត្រាំកក់[4156]។ ម្ចាស់បណ្តឹងសាទុក្ខធ្វើមិនដឹងមិនឮទៀតថា អ.ជ.ស.ដ អាចនឹងពឹងផ្អែក

---

[4149] កំណត់ហេតុ FBIS ស្តីពីសេចក្តីថ្លែងការណ៍ជាផ្លូវការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលអះអាងថា ឧបាសក/ឧបាសិកានៃពុទ្ធសាសនាបានចូលរួមសមាជជាតិពិសេស ជាតំណាងឱ្យសង្ឃនោះ គឺត្រូវបានបញ្ជាក់បន្ថែមដោយប្រភពឯករាជ្យនានាដូចជា ឯកសារ **E3/2290** New York Times, *កម្ពុជាហាមមូលដ្ឋានទ័ពបរទេស គេជឿថា វិធានការនេះសំដៅលើក្រុងហាណូយ,* ២៩ មេសា ១៩៧៥, KH 00758352-55។ ឯកសារ **E3/3722** The Guardian, *កម្ពុជារៀបចំ "មហាសន្និបាតពិសេស,* ២១ ឧសភា ១៩៧៥ KH S 00656237-40។

[4150] *សូមមើលឧទាហរណ៍* ឯកសារ **E3/116** សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់, ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ១៩៧២ KH 00003067-68 (អំពាវនាវចំពោះ "ព្រះសង្ឃគ្រប់ព្រះអង្គជាទីគោរព" សាមគ្គីជាធ្លុង១ ជាមួយកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា: ដើម្បីវាយកម្ទេចពួកអាក្បត់)។

[4151] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤១, ជើងទំព័រ ១៣៨៤៣។

[4152] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤០។

[4153] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩១៦-១៩១៧។

[4154] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៩៥, ១០៨, ១០៩។

[4155] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

[4156] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១២។

លើភ័ស្តុតាងក្រៅវិសាលភាពដែនដី ឬពេលវេលានៃរឿងក្តីនេះ តាមកាលៈទេសៈជាក់ស្តែង ឧទាហរណ៍ ដើម្បីវាយតម្លៃលើទម្រង់នៃអំពើប្រព្រឹត្តដោយចេតនាណាមួយ"[4157]។

### *មូលដ្ឋានទី ២៤៣ និង ២២១៖ អតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់* [4158]

1140. **មូលដ្ឋានទី ២៤៣ និង ២២១ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្តឹងសាទុក្ខបរាជ័យមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសនៅក្នុងការសម្រេចដែលថា គាត់មាន *ធាតុផ្សំអត្តនោម័តិ* ដែលតម្រូវសម្រាប់ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញ និងការធ្វើមនុស្សឃាត ប្រឆាំងនឹងអតីតមន្ត្រីរដ្ឋការ លន់ នល់[4159]។**

1141. មូលដ្ឋានទី ២៤៣ និង ២២១ បរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខ (i) មិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខមាន *ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើភ័ស្តុតាងទាំងអស់នៅចំពោះមុខខ្លួន (ii) បង្កើតការអះអាងខុស ទាក់ទងនឹងភ័ស្តុតាងផ្នែកខ្លះ និង (iii) ធ្វើការអះអាងផ្លូវច្បាប់ខុសដដែលៗ ដែលបានលើកនៅកន្លែងផ្សេងៗក្នុងសារណារបស់គាត់។

1142. ទីមួយ ម្ចាស់បណ្តឹងសាទុក្ខលើកពីបញ្ហាជាក់លាក់នៅក្នុងសេចក្តីសម្រេច[4160] ប៉ុន្តែ ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានកំណត់ទាំងមិនសមហេតុផលថា ម្ចាស់បណ្តឹងសាទុក្ខមាន *ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ទាក់ទងនឹង

---

[4157] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០, ៨១៥។

[4158] <u>មូលដ្ឋានទី ២៤៣៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អតីតទាហាន និងមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ* កថាខណ្ឌ ២០៩៩-២១១៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨០ (អង់គ្លេស), ទំព័រ ៧៥ (បារាំង), ទំព័រ ១១៥-១១៦ (ខ្មែរ)។ <u>មូលដ្ឋានទី ២២១៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *អតីតមន្ត្រីរដ្ឋការ លន់ នល់* កថាខណ្ឌ ១៩២១-១៩២៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៤-៧៥ (អង់គ្លេស), ទំព័រ ៦៩ (បារាំង), ទំព័រ ១០៦-១០៧ (ខ្មែរ)។

[4159] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨០។

[4160] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៧, ២១០៩-២១០៧ (ម្ចាស់បណ្តឹងសាទុក្ខតវ៉ាថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសនៅក្នុងការសន្និដ្ឋានថា គាត់គឺជា "អ្នកគាំទ្រឥតងាករេចំពោះគោលនយោបាយរើងអើងរបស់បក្ស", ជាពិសេសចេតនាដាក់អតីតមន្ត្រីរដ្ឋការ លន់ នល់ "ឱ្យស្ថិតនៅក្រោមការប្រព្រឹត្តមិនអនុគ្រោះ" និងបានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងអតីតមន្ត្រីរដ្ឋការ លន់ នល់)។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងអតីតមន្ត្រីរដ្ឋការ លន់ នល់[4161] នោះទេ។

1143. អ.ជ.ស.ដ បានពិចារណាលើភ័ស្តុតាងសំខាន់ៗជាច្រើន បានបង្ហាញឱ្យឃើញថា ម្ចាស់បណ្តឹងសាទុក្ខមិនត្រឹមតែបានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងអតីតមន្ត្រីរដ្ឋការ លន់ នល់ ប៉ុណ្ណោះទេ គាត់មានចេតនាធ្វើឱ្យឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងផងដែរ។ អ.ជ.ស.ដ បានកំណត់ថា "ការសម្រេចសម្លាប់" អតីតមន្ត្រីរដ្ឋការ លន់ នល់ ត្រូវបានធ្វើឡើងដោយថ្នាក់ដឹកនាំ ប.ក.ក ប្រហែល ឬនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ នៅភ្នំពេញ[4162]។ ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញវត្តមានក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៅក្នុងវគ្គបំពាក់បំប៉ន និងការប្រមូលផ្តុំមហាជនជាទីកន្លែងដែលកម្មាភិបាលត្រូវបានណែនាំឱ្យរើសអើងប្រឆាំងអតីតមន្ត្រីរដ្ឋការ លន់ នល់[4163]។ ម្ចាស់បណ្តឹងសាទុក្ខបានសរសើរជាសាធារណៈចំពោះការបំផ្លាញសាធារណរដ្ឋខ្មែរ ដោយសរសើរថា "ពួកខ្មាំងបានដាច់ខ្យល់ស្លាប់ ទាំងក្តីឈឺចាប់បំផុត"[4164]។ ទូរលេខដែលមាននៅចំពោះមុខ អ.ជ.ស.ដ បានបញ្ជាក់ថា ការចាប់ខ្លួនអតីតមន្ត្រីរដ្ឋការ លន់ នល់ ត្រូវបានគេរាយការណ៍ជាប្រចាំទៅមន្ទីរ ៨៧០ នៅក្នុងឆ្នាំ១៩៧៦ និង១៩៧៧ ខណៈម្ចាស់បណ្តឹងសាទុក្ខ ជាសមាជិកមន្ទីរនោះ"[4165]។ ម្ចាស់បណ្តឹងសាទុក្ខបានបង្គាប់ជាសាធារណៈនៅចុងឆ្នាំ ១៩៧៧ ឱ្យមហាជន "កម្ទេចរបប លន់ នល់"[4166]។

1144. អ.ជ.ស.ដ បានពិចារណាឃើញផងដែរថា អតីតមន្ត្រីរដ្ឋការ លន់ នល់ ត្រូវបាន "លើកឡើងជាច្រើននៅក្នុងទស្សនាវដ្តីរបស់ ប.ក.ក"[4167] ជាខ្លឹមសារដែលម្ចាស់បណ្តឹងសាទុក្ខបានដឹង[4168]។ ការបោះពុម្ពផ្សាយជាច្រើននៃទស្សនាវដ្តីទង់បដិវត្តន៍បានបង្គាប់ឱ្យពួកកម្មាភិបាលកំណត់អត្តសញ្ញាណ

---

[4161] ម្ចាស់បណ្តឹងសាទុក្ខតវ៉ាថា តុលាការត្រូវតែដោះលែងគាត់ឱ្យរួចខ្លួនពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ *ដោយមូលហេតុសាសនា* និងការធ្វើមនុស្សឃាតប្រឆាំងនឹងអតីតទាហាននៃរបបសាធារណរដ្ឋ"៖ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៥ (គូសបញ្ជាក់បន្ថែម)។ អ.ជ.ស.ដ មិនបានរកឃើញថា ម្ចាស់បណ្តឹងសាទុក្ខមានពិរុទ្ធចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទាក់ទងនឹងអតីតមន្ត្រីរដ្ឋការ លន់ នល់ ទេ)។

[4162] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៥៣។

[4163] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៨-៤០៤១, ៤០៥៤។

[4164] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៣៧។

[4165] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៤៨។

[4166] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧២។

[4167] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៤៧។

[4168] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៣។

និងសម្លាប់អតីតមន្ត្រីរដ្ឋការ លន់ នល់[4169]។ ទស្សនាវដ្តីទង់បដិវត្តន៍បានលើកឡើងពីអតីតមន្ត្រីរដ្ឋការ លន់ នល់ ដោយហៅពួកគេថា "អាក្បត់"[4170] និងបានលើកឡើងវិញពីសុន្ទរកថារបស់ ប៉ុល ពត ដែលនិយាយអំពី "ខ្មាំង" ប.ក.ក និងបានយោងដល់ "បនក្បត់" លន់ នល់[4171]។ ទស្សនាវដ្តីទង់បដិវត្តន៍ ច្បាប់ចេញផ្សាយខែតុលា ឆ្នាំ១៩៧៦ បានរៀបរាប់ថា ""ទំនាស់ស្លាប់រស់" ជាមួយអ្នករដ្ឋការ ប៉ូលីស ទាហាន និងនិស្សិត ដែលមិនអាចអប់រំកែប្រែបាន"[4172]។ លើសពីនេះទៀត នៅក្នុងឆ្នាំ ១៩៧៨ ប៉ុល ពត បាននិយាយសំដៅដល់អតីតមន្ត្រីរដ្ឋការ លន់ នល់ ជាសាធារណៈថា "ជាមេក្លោង" ដែលជាប់ខ្សែខ្មាំងអាមេរិក[4173]។ ដោយមានការកត់សំគាល់អំពីកង្វល់ទាក់ទងនឹងការប្រព្រឹត្តិចំពោះអតីតមន្ត្រីរដ្ឋការ លន់ នល់ និងដោយមានការគាំទ្រពីគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ លិខិតពាក់ព័ន្ធត្រូវបានបញ្ជូនទៅឱ្យម្ចាស់បណ្តឹងសាទុក្ខដោយអង្គការលើកលែងទោសអន្តរជាតិ ដែលស្នើឱ្យមានការស៊ើបអង្កេតលើបញ្ហានេះ[4174]។

1145. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានបង្កើត "ទំនាក់ទំនងសិប្បនិម្មិត" រវាង "ការអំពាវនាវ" របស់គាត់ ដើម្បីញុះញង់ឱ្យមានឧក្រិដ្ឋកម្មប្រឆាំងអតីតមន្ត្រីរដ្ឋការ លន់ នល់ ក្នុងឆ្នាំ១៩៧២ និងឧក្រិដ្ឋកម្មដែលបានកើតឡើងនៅ ស-២១ និងក្រាំងតាចាន់ នោះ គ្មានមូលដ្ឋានទេ[4175]។ ម្ចាស់បណ្តឹងសាទុក្ខធ្វើមិនដឹងមិនឮចំពោះភ័ស្តុតាងដែល អ.ជ.ស.ដ បានពឹងផ្អែក ដែលបានកំណត់ថា ម្ចាស់បណ្តឹងសាទុក្ខបានបន្តញុះញង់ឱ្យមានការធ្វើទុក្ខបុកម្នេញលើអតីតមន្ត្រីរដ្ឋការ លន់ នល់ និងការអំពាវនាវចំៗឱ្យមានការកម្ទេចពួកគេនៅក្រោយឆ្នាំ១៩៧២ នៅទូទាំងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យទាំងមូល។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញចេតនារបស់ខ្លួនស៊ីសង្វាក់គ្នា ក្នុងការធ្វើទុក្ខបុកម្នេញ និងសម្លាប់អតីត

---

[4169] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤២-៤០៤៣, ៤០៤៧។

[4170] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៥៥ *យោង* ឯកសារ **E3/5** ទង់បដិវត្តន៍ ចុះខែសីហា ១៩៧៥ KH 00063330, 00063333, កថាខណ្ឌ ៣៨២៩ *យោង* ឯកសារ **E3/746** *ទង់បដិវត្តន៍* កក្កដា ១៩៧៨, KH 00064490-91។

[4171] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨១៣។

[4172] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៦២ *យោង* ឯកសារ **E3/10** ទង់បដិវត្តន៍ ចុះខែកញ្ញា-តុលា ១៩៧៦ KH 00063093-94។

[4173] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨១៨។

[4174] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៤៨។ *សូមមើលផងដែរ* ចម្លើយតបទៅនឹង មូលដ្ឋានទី ២០៧។

[4175] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១១១។

មន្ត្រីរដ្ឋការ លន់ នល់ នៅទូទាំងសហករណ៍ ការដ្ឋាន[4176] និងមន្ទីរសន្តិសុខ[4177] តាមរយៈ ការគាំទ្រ "ឥតងាករេ" របស់គាត់ចំពោះគោលនយោបាយរើសអើងរបស់បក្ស[4178] និងការញុះញង់ឱ្យមានការចាប់ខ្លួន ការបាត់ខ្លួន ការរើសអើង និងការសម្លាប់យ៉ាងរីករាលដាលទៅលើអតីតមន្ត្រីរដ្ឋការ លន់ នល់ នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងនៅទូទាំងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ[4179]។

1146. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខធ្វើការអះអាងមិនត្រឹមត្រូវជាច្រើនទាក់ទងនឹងផ្នែកខ្លះនៃភស្តុតាង ដោយខកខានមិនបានពិចារណាលើភស្តុតាងទាំងមូលដែលគាំទ្រដល់ការសន្និដ្ឋានរបស់ អ.ជ.ស.ដ។ ម្ចាស់បណ្តឹងសាទុក្ខបានពិចារណាលើបញ្ហាទាក់ទងនឹងភស្តុតាងសារព័ត៌មាន FBIS ប៉ុន្តែ មើលរំលងថា អ.ជ.ស.ដ បានបង្ហាញថា ភស្តុតាងដែលមាននៅក្នុងឯកសារសារព័ត៌មាន FBIS "ដ៏សំខាន់" និងអាចផ្អែកលើបាន នៅពេលណាវាស្របគ្នាគ្រប់គ្រាន់ជាមួយនឹងភស្តុតាងផ្សេងៗទៀត[4180]។ សេចក្តីថ្លែងរបស់គាត់ទាក់ទងនឹងការលុបបំបាត់អតីតសមាជិកជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ មានភាពស្របគ្នាជាមួយនឹងភស្តុតាងផ្សេងៗទៀត[4181]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានបញ្ជាក់ការយោងសំអាងមិនត្រឹមត្រូវនូវពាក្យបោះពុម្ពខុសតិចតួច[4182] និងការអះអាងមិនពិតថា អ.ជ.ស.ដ ខកខានមិនបានយោងត្រឹមត្រូវទៅសេចក្តីថ្លែងការណ៍មួយ ដែលធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខថា "គោលបំណងនៃបដិវត្តន៍ គឺដើម្បី "លុបបំបាត់របប លន់ នល់ [...]" ប្រសិនបើពួកគេក្បត់បក្ស ឬបដិវត្តន៍ ពួកគេនឹងត្រូវគេសម្លាប់ចោល"។ កថាខណ្ឌដែលរងការជំទាស់នេះសំដៅលើកថាខណ្ឌ ៤២៧២ នៃសាលក្រម ដែលតាមពិត សំដៅលើកថាខណ្ឌ ៣៩៦១

---

[4176] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៤។

[4177] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៧។

[4178] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០០។

[4179] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៥៩។

[4180] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៦៩-៤៧២។

[4181] ឯកសារ **E3/3169** ឯកសារពិភាក្សាស្តីពី៖ "ប៉ុល ពត និង ខៀវ សំផន" ដោយ Stephen Heder ទំព័រ ១៥ (ថ្លែងថា "ក្នុងអំឡុងពេល ៤ខែដំបូងក្នុងឆ្នាំ ១៩៧៥ លោក ខៀវ សំផន បានបង្ហាញសារជាលើកទីពីរ ដល់អ្នកទាំងឡាយដែលបានកំពុងប្រយុទ្ធប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាថា មានតែថ្នាក់ដឹកនាំកំពូលទាំង ៧ រូបក្នុងចំណោមពួកគេប៉ុណ្ណោះ ដែលនឹងត្រូវប្រហារជីវិត បន្ទាប់ពីទទួលបានជ័យជម្នះ")។

[4182] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៣។ ម្ចាស់បណ្តឹងសាទុក្ខកត់សម្គាល់ថា នៅក្នុងកថាខណ្ឌ ៤២៤៤ នៃសាលក្រម អ.ជ.ស.ដ បានយោងសុន្ទរកថាមួយដោយម្ចាស់បណ្តឹងសាទុក្ខ ដែលបានធ្វើឡើងក្នុងឆ្នាំ១៩៧២ បានលើកឡើងដោយខុសឆ្គង ដោយយោងទៅកាន់កថាខណ្ឌ ៤០៧៣ នៅពេលដែលវាត្រូវអានកថាខណ្ឌ ៤០២៦ *លើកឡើងពី* ឯកសារ **E3/116** សេចក្តីអំពាវនាវរបស់ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧២ KH 00003068។

ដែលភ័ស្តុតាងបង្ហាញលើកដំបូង។ ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងផ្ទាល់សំដៅលើកថាខណ្ឌ ៣៩៦១ នៃសាលក្រម ត្រង់ចំណុចដែលបញ្ជាក់ច្បាស់ថា ភ័ស្តុតាងបានមកពីសក្ខីកម្មរបស់ ព្រាប ធុន[4183]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនយល់ស្របជាមួយនឹងការវាយតម្លៃរបស់ អ.ជ.ស.ដ លើភ័ស្តុតាងរបស់ ព្រាប ធុន។

1147. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសតាមរយៈការពិចារណាលើភ័ស្តុតាងស្តីពីការប្រព្រឹត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខ មុនខែមេសា ឆ្នាំ១៩៧៥[4184]។ ដូចដែល អ.ជ.ត.ក បានលើកឡើងនៅក្នុងសំណុំរឿង០០២/០១ មិនមានអ្វីខុសទេក្នុងការពិចារណាលើការប្រព្រឹត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខមុនរបបកម្ពុជាប្រជាធិបតេយ្យ ត្រង់ចំណុចដែលការចូលរួមចំណែករបស់គាត់ "គឺជាផ្នែកនៃបណ្តុំក្នុងការអនុវត្តផែនការសហឧក្រិដ្ឋកម្មរួមដែលបានបន្តអស់មួយរយៈពេល" និង "បានចេញជាផ្លែផ្កា" នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងយុត្តាធិការពេលវេលារបស់តុលាការ[4185]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបាន "បានអំពាវនាវជាសាធារណៈឱ្យកម្ចាត់សមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាលរបបសាធារណរដ្ឋខ្មែរ និង អ្នកក្រោមបង្គាប់របស់ពួកគេ" តាំងពីឆ្នាំ១៩៧២ និងថា គំរូនៃអាកប្បកិរិយានេះ បានបន្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[4186] ដែលបានបញ្ជាក់ពីការចូលរួមយ៉ាងស៊ីសង្វាក់គ្នារបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះគោលបំណងរួម[4187]។

1148. ទីបី ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខយោងទៅលើទ្រឹស្តីករណ៍មិនត្រឹមត្រូវ ដែលថា អ.ជ.ស.ដ បានរំលោភលើគោលការណ៍ *គ្មានការជំនុំជម្រះពីរដងសម្រាប់អង្គហេតុដដែល (non bis in idem)*[4188] ដែលការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានចេតនាដកបុគ្គលចេញពីសង្គម[4189] និងថា គាត់

[4183] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១១០ ជើងទំព័រ ៤០៦៤ ("សូមមើលសំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦១ កំណត់សម្គាល់ជើងទំព័រលេខ ១៣១៨៥ យោងដល់សក្ខីកម្មរបស់ ព្រាប ធុន ដែលបានលើកឡើងអំពីសុន្ទរកថាដែលត្រូវបានសន្មតថាជារបស់លោក ខៀវ សំផន នៅឆ្នាំ១៩៧៧")។

[4184] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២១, ២១០១-២១០២, ២១០៩។

[4185] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ២១៧។

[4186] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦០, ៤២៤៤-៤២៤៥។

[4187] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤៤-៤២៤៥។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០២ (អ.ជ.ស.ដ បានពិចារណាលើគំរូសុន្ទរកថាដែលបានធ្វើឡើងដោយម្ចាស់បណ្តឹងសាទុក្ខនៅដើមឆ្នាំ១៩៧២ ថាត្រូវបាន "ផ្ទុះបញ្ចាំង" ដោយសុន្ទរកថាក្នុងឆ្នាំ១៩៧៧)។

[4188] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៤, ២១០៣, ២១០៩។

[4189] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១១២។

គ្រាន់តែបានចូលរួមក្នុង "គោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋចំពោះ" តែប៉ុណ្ណោះ[4190]។ ទទ្ទីករណ៍ទាំងនេះពិតជាមិនត្រឹមត្រូវតាមផ្លូវច្បាប់ទេ ដូចបានពិភាក្សាត្រង់កន្លែងផ្សេងទៀត[4191]។ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខបានធ្វើឱ្យការអះអាងរបស់គាត់ចុះខ្សោយ ទាក់ទងនឹងគោលការណ៍ *គ្មានការជំនុំជម្រះពីរដងសម្រាប់អង្គហេតុដដែល* ដោយបានបញ្ជាក់ថា អ.ជ.ត.ក "បានពិចារណាថា "ការប្រហារជីវិតមេដឹកនាំសំខាន់ៗនៃរបបសាធារណរដ្ឋខ្មែរ ជាផ្នែកមួយនៃគោលបំណងរួម*ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីភ្នំពេញ*""[4192]។ អង្គហេតុទាំងអស់នេះមិនត្រូវ បានពិភាក្សាទេ ទាក់ទងនឹងព្រឹត្តិការណ៍ក្រោយមកទៀត ដូច្នេះ អ.ជ.ស.ដ មិនបានជំនុំជម្រះម្ចាស់បណ្តឹងសាទុក្ខឡើងវិញចំពោះឧក្រិដ្ឋកម្មទាំងអស់នោះទេ។

### *មូលដ្ឋានទី ២៣៦ និង ២១៨៖ ជនជាតិចាម*[4193]

1149. **មូលដ្ឋានទី ២៣៦ និង ២១៨ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ដោយការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខមាន *ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួមទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាម។**

1150. មូលដ្ឋានទី ២៣៦ និង ២១៨ បរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខ (i) យល់ច្រឡំអំពី *ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម (ii) បំភ្លៃសាលក្រម និង (iii) ខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាម។

1151. ទីមួយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខយល់ច្រឡំអំពី *ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវ។ គាត់បានអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ ខកខានមិនបានវាយតម្លៃអំពីចេតនា

---

[4190] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១០៧។

[4191] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៥ (*ការកាត់ក្តីពីរដង*) ៩៤ (ការធ្វើទុក្ខបុកម្នេញ) ១៨៣, ២១៨ (គោលបំណងរួមមិនមែនឧក្រិដ្ឋកម្ម)។

[4192] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១០៣ *លើកឡើងពី* ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៥៩ (គូសបញ្ជាក់បន្ថែមដោយម្ចាស់បណ្តឹងសាទុក្ខ)។

[4193] <u>មូលដ្ឋានទី ២៣៦៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ជនជាតិចាម* កថាខណ្ឌ ២០៦២-២០៧៤។ ឯកសារ F54.1.1 ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៨-៧៩ (អង់គ្លេស) ទំព័រ ៧៣ (បារាំង) ទំព័រ ១១៣ (ខ្មែរ)។ <u>មូលដ្ឋានទី ២១៨៖</u> ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ជនជាតិចាម* កថាខណ្ឌ ១៨៧៩-១៨៨៥។ ឯកសារ F54.1.1 ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៤ (អង់គ្លេស) ទំព័រ ៦៨-៦៩ (បារាំង) ទំព័រ ១០៥ (ខ្មែរ)។

របស់គាត់ "ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នីមួយៗ"[4194] នៅពេលដែល អ.ជ.ស.ដ ពិតជាបានវាយតម្លៃយ៉ាងត្រឹមត្រូវលើចេតនារបស់គាត់ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នីមួយៗ[4195]។ ការអះអាងដោយគ្មានមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសដោយការធ្វើការសន្និដ្ឋាន "ជាលក្ខណៈទូទៅ" អំពីការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីឧក្រិដ្ឋកម្ម[4196] មើលរំលងផងដែរថា ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម មិនតម្រូវឱ្យមានការដឹងថាអំពើឧក្រិដ្ឋជាក់លាក់ត្រូវបានប្រព្រឹត្តឡើងទេ[4197]។

1152. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខអះអាងគ្មានមូលដ្ឋានថា អ.ជ.ស.ដ មិនអាចទាញការសន្និដ្ឋានលើចេតនារបស់គាត់ចេញពីគោលនយោបាយរបស់ ប.ក.ក ក្នុងការចាប់ខ្លួន ដាក់ឱ្យនៅឯកោ និង "កម្ទេច" ខ្មាំង[4198] ពីអត្ថិភាពនៃគោលនយោបាយរើសអើងដែលផ្តោតលើជនជាតិចាម[4199] និងពីការចូលរួមជាបន្តបន្ទាប់របស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមបានទេ[4200]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានគាំទ្រការអះអាងរបស់គាត់ថា ចេតនាមិនអាចត្រូវបានទាញការសន្និដ្ឋានចេញពីការសន្និដ្ឋានទាំងនេះ ហើយគាត់បានផ្អែកលើការអះអាងមិនត្រឹមត្រូវ ដែលត្រូវបានលើកឡើងនៅកន្លែងផ្សេងទៀត[4201]។ ទោះជាយ៉ាងណា វិធីសាស្ត្រតាមផ្នែក និងផ្តុយគ្នារបស់ម្ចាស់បណ្តឹងសាទុក្ខបានបំភ្លៃសាលក្រម[4202]។ អ.ជ.ស.ដ មិនបានបង្ហាញពីចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខតាមរយៈការ

---

[4194] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៦៥, ២០៦៩-២០៧៤។

[4195] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៩-៤២៩០។

[4196] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨១, ២០៦៥។

[4197] *សូមមើល* ផ្នែក VIII.គ.៣. ចេតនា។

[4198] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៦៣-២០៦៥។

[4199] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៦៦។

[4200] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៦៧។

[4201] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៦៤-២០៦៥ (និយាយឡើងវិញនូវការអះអាងរបស់គាត់ដែលថា អ.ជ.ស.ដ បានខុសឆ្គងនៅក្នុងការរកឃើញថាគាត់បានគាំទ្រដល់គោលនយោបាយរបស់ខ្មាំង), ២០៧៣ (និយាយឡើងវិញនូវការអះអាងរបស់គាត់ដែលថា ការធ្វើទុក្ខបុកម្នេញតម្រូវឱ្យមានចេតនាមួយដែលបញ្ចេញបុគ្គលពីសង្គម), ២០៦៨ (និយាយឡើងវិញនូវការអះអាងរបស់គាត់ដែលថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងជនជាតិចាម ត្រូវបានរាំងខ្ទប់ដោយ*អាជ្ញាអស់ជំនុំ*)។ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៧, ២៣៤, ៨៣, ១៥០។

[4202] ឧទាហរណ៍ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ បានខុសឆ្គងនៅក្នុងការរកឃើញថា ចេតនាឧក្រិដ្ឋរបស់ម្ចាស់បណ្តឹងសាទុក្ខ "*នៅលើមូលដ្ឋានតែមួយ*" នៃការផ្សារភ្ជាប់ការប្រតិបត្តិលើជនជាតិចាមនៅតាមមន្ទីរសន្តិសុខ ទៅនឹង គោលនយោបាយខ្មាំងរបស់ ប.ក.ក។ ក្រោយមក មានកថាខណ្ឌចំនួនបីដែលគាត់បានជំទាស់ដោយអះអាងថា "ការប្រើប្រាស់ឈ្នាប់ផ្សារភ្ជាប់ឃ្លា "អាស្រ័យហេតុនេះ" បញ្ជាក់ថា [អ.ជ.ស.ដ] បានទាញការសន្និដ្ឋានពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋរបស់ [របស់ម្ចាស់បណ្តឹងសាទុក្ខ]

សន្និដ្ឋានទាំងអស់នេះដាច់ដោយឡែកពីគ្នានោះទេ។ ផ្ទុយទៅវិញ អ.ជ.ស.ដ បានពិចារណាលើការសន្និដ្ឋានជារួមរបស់ខ្លួនថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាម គឺជាការអនុវត្តគោលនយោបាយទាំងអស់នោះ[4203]។

1153. ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខបំភ្លៃសំអាងហេតុរបស់ អ.ជ.ស.ដ ដោយអះអាងថា ចេតនារបស់គាត់មិនត្រូវបានបង្ហាញឱ្យឃើញទេ ដោយហេតុថា ឧក្រិដ្ឋកម្មនេះ "មិនមានជាប់ទាក់ទងនឹងគោលនយោបាយប្រឆាំងខ្មាំង និងគោលនយោបាយរើសអើងដោយមូលហេតុសាសនា"[4204]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានពិចារណាថា ក្នុងការបង្ហាញពីចេតនារបស់គាត់ អ.ជ.ស.ដ បានយោងជាពិសេសទៅលើការសន្និដ្ឋានរបស់ខ្លួនលើការអនុវត្តគោលនយោបាយ ដែលផ្តោតលើការបំបែកជនជាតិចាម[4205]។

1154. ទីបី ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសតាមរយៈការទាញការសន្និដ្ឋានលើការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាមចេញពីមុខតំណែងរបស់គាត់ ការគាំទ្ររបស់គាត់ចំពោះគោលបំណងរួម និងការដឹងរបស់គាត់អំពីការអនុវត្តគោលនយោបាយនានា ដែលផ្តោតលើការបង្កើតសង្គមខ្មែរដែលមិនមានសាសនា និងរួមគ្នាមួយ មានតែវណ្ណៈកម្មករ-កសិករ[4206]។ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់អំពីកំហុសអង្គច្បាប់[4207] គាត់ខកខានមិនបានផ្តល់ការគាំទ្រណាមួយដល់កាចោទប្រកាន់ទាំងអស់នោះទេ។ ទាក់ទងនឹងកំហុសផ្នែកអង្គហេតុដែលចោទប្រកាន់ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងថា អាចមានការសន្និដ្ឋានផ្សេងពីនេះ[4208]។ គាត់ខកខានមិនបានបង្ហាញថា ការសន្និដ្ឋានដែលរងការជំទាស់នោះ គឺជាការសន្និដ្ឋានមួយដែលមិនមានអ្នកវិនិច្ឆ័យលើអង្គហេតុណាអាច

ចេញពីអត្ថិភាពនៃគោលនយោបាយរើសអើងនានា"៖ *សូមមើល* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៦៣, ២០៦៦។

[4203] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៩។

[4204] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៦៨។

[4205] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៩។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣៩៩៧ (ដោយការយោងនិងយោងផ្សេងទៀតទៅកាន់ការរកឃើញរបស់ អ.ជ.ស.ដ ស្តីពីការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងគោលបំណងរួម)។

[4206] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨០, ១៨៨១, ១៨៨៣, ១៨៨៤, ១៨៨៥។

[4207] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨១។

[4208] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨១, ១៨៨៣, ១៨៨៤។

សម្រេចដូចនេះទេ[4209]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម *នៅជាប់ជាមួយ* នឹងគោលនយោបាយរបស់ ប.ក.ក[4210]។ អង្គជំនុំជម្រះក៏បានសន្និដ្ឋានស្រដៀងគ្នាថា គោលបំណងរួមរបស់សហឧក្រិដ្ឋកម្មរួម មានទំនាក់ទំនង*ជាពិសេស* (មិនមែនគ្រាន់តែ*ដោយយោងប្រយោល* ទេ)[4211] ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម[4212]។ ផ្អែកលើការសន្និដ្ឋានរបស់ខ្លួនថា ម្ចាស់បណ្តឹងសាទុក្ខបានដឹង និងបានគាំទ្រគោលបំណងរួម និងគោលនយោបាយ ដែលមានចំណងទាក់ទងជាពិសេស និងជាប់ជាមួយនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម[4213] វាជាការសមហេតុផលដែល អ.ជ.ស.ដ បានសន្និដ្ឋានថា គាត់មិនត្រឹមតែបានដឹងអំពីឧក្រិដ្ឋកម្មទាំងអស់នេះទេ ប៉ុន្តែថែមទាំងមានបំណងឱ្យឧក្រិដ្ឋកម្មទាំងនេះកើតឡើងទៀតផង។

1155. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋាន និងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ "បានប្រព្រឹត្តកំហុសអង្គហេតុ ទាក់ទងនឹងភស្តុតាងនីមួយក្នុងចំណោមភស្តុតាងទេសកាលទាំងឡាយ ដែលខ្លួនយកមកធ្វើជាសំអាង ដើម្បីទាញសេចក្តីសន្និដ្ឋានទាក់ទងនឹងការដឹងរបស់ [ម្ចាស់បណ្តឹងសាទុក្ខ] ដោយពុំបានពន្យល់ថា ហេតុអ្វីបានជាសេចក្តីសន្និដ្ឋាននោះ គឺជា*សេចក្តីសន្និដ្ឋាន* សមហេតុសមផលតែមួយគត់"[4214] ដោយមិនផ្តល់ការគាំទ្រការអះអាងរបស់គាត់ថា ការសន្និដ្ឋានសមហេតុសមផលផ្សេងទៀតបើកចំហរទាក់ទងនឹងការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ក្នុងករណីណាក៏ដោយនេះគឺជាបទដ្ឋានមិនត្រឹមត្រូវអនុវត្តចំពោះការអះអាងជាក់លាក់ ដែលម្ចាស់បណ្តឹងសាទុក្ខធ្វើឡើង។ ទោះជា*ការសន្និដ្ឋាន* ដែលការផ្តន្ទាទោសមួយណាផ្អែកលើ ត្រូវតែជាការសន្និដ្ឋានសមហេតុសមផលតែមួយគត់ ដែលអាចផ្អែកលើភស្តុតាងជារួម បទដ្ឋាននៃភាពសមហេតុសមផល[4215] អនុវត្តលើ*ការសន្និដ្ឋាននីមួយៗ* ដែលអាចរួមគ្នានាំទៅដល់សេចក្តីសន្និដ្ឋាននេះ[4216]។ ការអះអាងដោយ

[4209] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[4210] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៦។

[4211] *ប្រៀបធៀប* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨៥។

[4212] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៨៨-៣៩៩៨។

[4213] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៦២-៦២៤, ៣៧៣៣-៣៧៣៤, ៤២០៨។

[4214] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨១ (គូសបញ្ជាក់បន្ថែម)។

[4215] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសអង្គហេតុ)។

[4216] *សូមមើលឧទាហរណ៍* សាលដីការឿងក្តី *Stakić* កថាខណ្ឌ ២១៩ ("កាលណាការជំទាស់នៅលើបណ្តឹងសាទុក្ខគឺជាការទាញសេចក្តីសន្និដ្ឋានដើម្បីបង្កើតអង្គហេតុមួយ ដែលនៅលើអង្គហេតុនោះការផ្តន្ទាទោសបានពឹងផ្អែកលើនោះ បទដ្ឋានគឺគ្រាន់តែត្រូវបានពេញចិត្ត បើសិនជាការទាញសេចក្តីសន្និដ្ឋាននោះគ្រាន់តែជាការសមហេតុសមផលមួយដែលថា អាចត្រូវបានទាញចេញពីភស្តុតាងដែលបានដាក់បង្ហាញ"), កថាខណ្ឌ ២១៩ ជើងទំព័រ ៤៧០ ("ទាក់ទងទៅនឹងការរកឃើញរបស់អង្គជំនុំជម្រះ

គ្មានការបញ្ជាក់គាំទ្ររបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មិនបានបង្ហាញយ៉ាងសមហេតុសមផលថា ប.ក.ក បានចាត់វិធានការជាក់លាក់ផ្តោតលើជនជាតិចាមក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យនោះ ក៏បរាជ័យផងដែរ[4217]។ ការយោងរបស់ម្ចាស់បណ្តឹងសាទុក្ខទៅលើមូលដ្ឋានទីមួយនៃបណ្តឹងសាទុក្ខរបស់គាត់ទាក់ទងនឹងជនជាតិចាម ដែលការយោងភាគច្រើនមិនពាក់ព័ន្ធទៅនឹងការអះអាងដែលបានធ្វើឡើង[4218] ខ្វះភាពជាក់លាក់ដែលជាលក្ខខណ្ឌសម្រាប់កិច្ចអន្តរាគមបណ្តឹងសាទុក្ខ និងគួរត្រូវបានច្រានចោលភ្លាមៗ។ ក្នុងករណីណាក៏ដោយ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការសន្និដ្ឋានណាមួយរបស់ អ.ជ.ស.ដ ទាក់ទងនឹងជនជាតិចាម មិនសមហេតុសមផលឡើយ[4219]។

1156. ម្ចាស់បណ្តឹងសាទុក្ខក៏ចោទប្រកាន់មិនត្រឹមត្រូវផងដែរថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ និងអង្គច្បាប់ ដោយ "យល់ថា ការបង្ហាញឱ្យឃើញថា [ម្ចាស់បណ្តឹងសាទុក្ខ] "បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការថែរក្សា "ផ្តែផ្តាបដិវត្តន៍ និងជាតិសាសន៍កម្ពុជាឱ្យបានជារៀងរហូត"" ដោយមិនបានផ្តល់ការដកស្រង់សំអាងឡើយ[4220]។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានផ្តល់ការដកស្រង់សំអាង[4221] ហើយសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខលើការថែរក្សាជាតិសាសន៍កម្ពុជា ត្រូវបានបញ្ជាក់ដោយប្រភពជាច្រើន[4222]។

---

សាលាដំបូងស្តីពីអង្គហេតុ ដែលនៅលើអង្គហេតុនោះការផ្តន្ទាទោសមិនបានពឹងផ្អែកលើនោះទេ អង្គជំនុំជម្រះតុលាការកំពូលនឹងលើកពេលឱ្យចំពោះការរកឃើញនានារបស់អង្គជំនុំជម្រះសាលាដំបូង កាលណាការរកឃើញទាំងនោះសមហេតុសមផល")។

[4217] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨២។

[4218] ឧទាហរណ៍ ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខ រួមទាំង មូលដ្ឋានទី នានាពាក់ព័ន្ធនឹង*អាជ្ញាអស់ជំនុំ* (មូលដ្ឋានទី ៨៣ និង ១៥៣) និង *បណ្តឹង* (មូលដ្ឋានទី ៤៦, ៧៨, ៧៩) ដែលមិនត្រូវទៅនឹងភាពសមហេតុសមផលនៃការរកឃើញរបស់ អ.ជ.ស.ដ ពាក់ព័ន្ធនឹងវិធានការនានាដែលផ្តោតទៅលើជនជាតិចាម។

[4219] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៥, ៨២-៨៣, ១២១-១២២, ១៤១-១៥០, ១៨៦។

[4220] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨២ *លើកឡើងពី* ឯកសារ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៦។

[4221] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៦ ជើងទំព័រ ១៣៨២៣ (ដោយការយោង និងយោងផ្សេងទៀតទៅកាន់ផ្នែក ១៣.២.៥.៤), ៣២១៦ ជើងទំព័រ ១០៨២៥។

[4222] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣២១៦ ជើងទំព័រ ១០៨២៥ *លើកឡើងពី* ឯកសារ **E3/294** FBIS *សីហនុចូលរួម ខៀវ សំផន ថ្លែងទៅកាន់ពិធីលៀងសាយភោជន៍បក្សកុម្មុយនិស្តកម្ពុជា* ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៨ KH 00702823។ ឯកសារ **E3/169** *សុន្ទរកថារបស់សមមិត្ត ខៀវ សំផន ក្នុងសន្និបាតមហាជននាឱកាសពិធីបុណ្យខួប* ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ KH 01507850 ("យើងត្រូវការពារប្រទេស បដិវត្តន៍ អំណាច ប្រជាជន កងទ័ព បក្ស និងពូជសាសន៍កម្ពុជា")។ ឯកសារ **E3/562** BBC/SWB *ជំនួបនៅទីក្រុងភ្នំពេញ សំគាល់ថ្ងៃទី១៧ មេសា ជាថ្ងៃបុណ្យខួប* ចុះថ្ងៃទី១៥

1157. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសដោយការសំអាងលើការគាំទ្ររបស់គាត់ "ចំពោះផែនការរួមមិនមែនឧក្រិដ្ឋ ដើម្បីសន្និដ្ឋានថា គាត់បានដឹងអំពីការអនុវត្តគោលនយោបាយ [...] ដោយពុំបានពន្យល់ថា តើវាជាសេចក្តីសន្និដ្ឋានសមហេតុសមផលតែមួយដែលអាចមាន"[4223]។ អ.ជ.ស.ដ តាមពិតនោះ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខ "បានគាំទ្រគោលបំណងរួម *និង* ដឹងអំពីការអនុវត្តគោលនយោបាយ"[4224] អង្គជំនុំជម្រះមិនបានទាញការសន្និដ្ឋានការដឹងអំពីការអនុវត្តគោលនយោបាយ ចេញពីការគាំទ្រគោលបំណងរួមទេ។ ការយោងរបស់ម្ចាស់បណ្តឹងសាទុក្ខទៅ "ផែនការរួមមិនមែនឧក្រិដ្ឋ" ក៏មិនត្រឹមត្រូវផងដែរ ដោយហេតុថា វាត្រូវបានបង្ហាញយ៉ាងច្បាស់ថា គោលបំណងរួមមានលក្ខណៈឧក្រិដ្ឋប្រសិនបើវាមានទំនាក់ទំនងជាពិសេសទៅនឹងគោលនយោបាយ ដែលការអនុវត្តគោលនយោបាយទាំងនោះ នាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4225] ដូចដែល អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងសមហេតុសមផលថាវាពិតជាដូច្នោះមែន[4226]។

1158. ជាចុងក្រោយ ការចោទប្រកាន់ដោយគ្មានមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីភាពលម្អៀង ក៏ត្រូវតែបដិសេធចោលផងដែរ[4227]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់ភស្តុតាងណាមួយដែលបង្ហាញថា ការសន្និដ្ឋាននោះលម្អៀងនោះទេ និងមិនបានជម្រះសច្ចធារណ៍នៃអនាគតិរបស់តុលាការដែលចៅក្រមត្រូវមាននោះដែរ[4228]។

ខែមេសា ឆ្នាំ១៩៧៨ KH 00249989 ។ ឯកសារ **E1/217.1** លោកស្រី ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ១១.២៩.៥៦-១១.៣១.៥៨ ទំព័រ ៤០ បន្ទាត់ ១៤-១៥ ("ព្រោះអីជំនាន់ នុ៎ងគឺគាត់ [ម្ចាស់បណ្តឹងសាទុក្ខ] បានលើកឡើងអ៊ីចឹងដែរ គាត់ថា "យើងត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន គឺមានតែខ្មែរ ខ្មែរនិងខ្មែរចេះស្រឡាញ់គ្នា" គឺមានអ៊ីចឹង") ។ *សូមមើលផងដែរ* ឯកសារ **E3/4162** BBC SWB *ពិធីជប់លៀងបុណ្យខួប៖ សម្តេចសីហនុ វត្តមាន* ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៨ KH S 00649984-88។ ឯកសារ **E3/9** Philip Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* EN 00396544។ ឯកសារ **E3/2738** ទីភ្នាក់ងារព័ត៌មានបារាំង *រូបថតរបស់ សម្តេច សីហនុ ក្នុងសារព័ត៌មានចិន* ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៨ KH 00723738។

[4223] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨៤។

[4224] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៦ (គូសបញ្ជាក់បន្ថែម)។

[4225] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧៥។

[4226] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០៦៨។

[4227] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨៣។

[4228] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៤។

## *មូលដ្ឋានទី ២១៩, ២៣៧, ២៣៨, ២៣៩, ២៤០, ២៤១៖ ជនជាតិវៀតណាម*[4229]

1159. **មូលដ្ឋានទី ២១៩, ២៣៧, ២៣៨, ២៣៩, ២៤០, និង ២៤១ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ និងអង្គច្បាប់ ដោយសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខមាន *ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេស ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាម។**

1160. មូលដ្ឋានរបស់ម្ចាស់បណ្ដឹងសាទុក្ខទាក់ទងនឹង*ធាតុផ្សំអត្តនោម័តិ* របស់គាត់ សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាម បរាជ័យ ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខជាដដែលៗ (i) យល់ច្រឡំចំពោះ*ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម និងការជួយ និងជំរុញ (ii) ពឹងផ្អែកលើការអះអាងមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសតាមរយៈការសន្និដ្ឋានលើគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាម និងការភ្ជាប់ប្រទេសវៀតណាមទៅនឹងជាតិពន្ធុវៀតណាម និង (iii) ធ្វើការអះអាងដោយគ្មានមូលដ្ឋានទាក់ទងនឹងភ័ស្តុតាងអំពីសុន្ទរកថាប្រកាន់ពូជសាសន៍របស់គាត់ប្រឆាំងនឹងជនជាតិវៀតណាម។ ការអះអាងនីមួយៗរបស់ម្ចាស់បណ្ដឹងសាទុក្ខមិនមានមូលដ្ឋានទេ។

[4229] <u>មូលដ្ឋានទី ២១៩៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *ជនជាតិវៀតណាម* កថាខណ្ឌ ១៨៨៦-១៩០៩។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៤ (អង់គ្លេស) ទំព័រ ៦៩ (បារាំង) ទំព័រ ១០៥-១០៦ (ខ្មែរ)។ <u>មូលដ្ឋានទី ២៣៧៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានចេតនានិរទេស* កថាខណ្ឌ ២០៧៥-២០៧៦។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៩ (អង់គ្លេស) ទំព័រ ៧៣-៧៤ (បារាំង) ទំព័រ ១១៣ (ខ្មែរ)។ <u>មូលដ្ឋានទី ២៣៨៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត និងការសម្លាប់រង្គាល* កថាខណ្ឌ ២០៧៧-២០៨០។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៩ (អង់គ្លេស) ទំព័រ ៧៤ (បារាំង) ទំព័រ ១១៣-១១៤ (ខ្មែរ)។ <u>មូលដ្ឋានទី ២៣៩៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍* កថាខណ្ឌ ២០៨១-២០៨៥។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៩ (អង់គ្លេស) ទំព័រ ៧៤ (បារាំង) ទំព័រ ១១៤ (ខ្មែរ)។ <u>មូលដ្ឋានទី ២៤០៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយអំពើមនុស្សឃាត* កថាខណ្ឌ ២០៨៦-២០៨៨។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៩ (អង់គ្លេស) ទំព័រ ៧៤ (បារាំង) ទំព័រ ១១៤ (ខ្មែរ)។ <u>មូលដ្ឋានទី ២៤១៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *គ្មានចេតនាប្រព្រឹត្តអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ* កថាខណ្ឌ ២០៨៩-២០៩០។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃ សារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៩ (អង់គ្លេស) ទំព័រ ៧៤ (បារាំង) ទំព័រ ១១៤-១១៥ (ខ្មែរ)។

1161. ទីមួយ ផ្ទុយទៅនឹងការអះអាងច្រំដែលៗរបស់ម្ចាស់បណ្តឹងសាទុក្ខ[4230] មិនជាការចាំបាច់ដែលគាត់ត្រូវមានចេតនាឱ្យមាន ឬបានដឹងអំពីអំពើឧក្រិដ្ឋជាក់លាក់ ដើម្បីឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម[4231]។ ស្រដៀងគ្នានេះ អ.ជ.ស.ដ មិនត្រូវបានតម្រូវឱ្យធ្វើការកំណត់ទីកន្លែងដែលម្ចាស់បណ្តឹងសាទុក្ខស្ថិតនៅទេ នៅចំពេលនៃអំពើឧក្រិដ្ឋជាក់លាក់ ឬអ្វីដែលគាត់បានលើកឡើងថា នៅមុនពេល ក្នុងអំឡុងពេល ឬក្រោយពេលព្រឹត្តិការណ៍[4232]។

1162. ម្ចាស់បណ្តឹងសាទុក្ខក៏បានអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហេតុដូច្នេះ តាមតក្កវិជ្ជា មិនអាចសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្មឡើយ[4233]។ ប៉ុន្តែ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុស ក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាម[4234]។

1163. ទីពីរ ការអះអាងច្រំដែលៗរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានលើអត្ថិភាពនៃគោលនយោបាយចំពោះជនជាតិវៀតណាម និងដោយភ្ជាប់ការអំពាវនាវប្រឆាំងនឹងខ្មាំងរដ្ឋវៀតណាម ជាមួយនឹងការអំពាវនាវប្រឆាំងនឹងប្រជាជនជាតិពន្ធុវៀតណាមនៅកម្ពុជា មិនមានមូលដ្ឋានទេ[4235] ដូចដែលបានពិភាក្សានៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥[4236]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសំអាងលើសុន្ទរកថារបស់

---

[4230] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨៨-១៨៨៩, ១៨៩៤, ១៩០៣, ២០៧៦។

[4231] *សូមមើល* ផ្នែក VIII.គ.៣. ចេតនា។

[4232] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨៩។ នៅក្នុងករណីណាក៏ដោយ អ.ជ.ស.ដ ប្រាកដជាបានធ្វើការកឃើញថា ម្ចាស់បណ្តឹងសាទុក្ខណាបាននិយាយអ្វី និងនៅពេលណា៖ *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០ ("*ទំនងជានៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩* ខៀវ សំផន បានជួបជាមួយនឹង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ ហើយ ខៀវ សំផន បានណែនាំ ឌុច ថាបុគ្គលិកមន្ទីរសន្តិសុខ ស-២១ មិនគួរតក់ស្លុតចំពោះការវាយប្រហាររបស់វៀតណាមចូលក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យនោះទេ និងថាបុគ្គលិកទាំងអស់គួរបន្តធ្វើការងារតាមធម្មតា" (គូសបញ្ជាក់បន្ថែម)), ៣៤០៦ ("*ពេញមួយឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩* ប៉ុល ពត និង ខៀវ សំផន បានបន្តសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការការពារ និងថែរក្សាជោគជ័យនៃបដិវត្តន៍ និង "ពូជសាសន៍កម្ពុជា" ពីវៀតណាម "រាតទីនិយម" និង "ទេសានុពន្ធន៍និយម"" (គូសបញ្ជាក់បន្ថែម))។

[4233] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨៦។

[4234] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៤១, ៥៦, ៦០, ៨០,៨៤, ១០៣-១០៥, ១១០-១១២, ១២៦, ១២៨, ១៣០, ១៥១-១៥៩, ១៨៥, ២១៩, ២៣៧-២៤១។

[4235] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩៦, ១៩០០, ១៩០១, ១៩០២, ២០៧៩, ២០៨៣, ២០៨៦។

[4236] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨៥។

គាត់ក្នុងខែមេសា ឆ្នាំ១៩៧៧[4237] និងឆ្នាំ១៩៧៨[4238] ដោយមើលរំលងថា ចំណុចនេះត្រូវបានបញ្ជាក់ដោយប្រភពឯករាជ្យផ្សេងទៀត។

1164. ទីបី ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងភ័ស្តុតាងជាក់លាក់ខ្លះអំពីសុន្ទរកថាប្រកាន់ពូជសាសន៍របស់ម្ចាស់បណ្តឹងសាទុក្ខប្រឆាំងនឹងជនជាតិវៀតណាម មិនមានមូលដ្ឋានទេ។ ម្ចាស់បណ្តឹងសាទុក្ខកត់សម្គាល់ថា[4239] ពាក្យពេចន៍ជាក់លាក់ "ស្អាតជាអចិន្ត្រៃយ៍" ដែល អ.ជ.ស.ដ បានលើកឡើង[4240] បានមកពីទស្សនាវដ្តី *ទង់បដិវត្តន៍*[4241] មិនមែនសុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខទេ។ ទោះជាយ៉ាងណា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការកំណត់អត្តសញ្ញាណខុសនៃពាក្យពេចន៍ទាំងនេះ គឺជាការខុសឆ្គោយពិតប្រាកដរបស់តុលាការ ដែលមានសារៈសំខាន់ខ្លាំងចំពោះសាលក្រមចុងក្រោយនោះ[4242]។ ពាក្យ "ស្អាតជាអចិន្ត្រៃយ៍" នេះផ្ទាល់មិនមែនជាកត្តាកំណត់ចំពោះការសន្និដ្ឋាននេះទេ ជាពិសេស ផ្អែកលើទម្ងន់នៃភ័ស្តុតាងដែលបង្ហាញថា គាត់ពិតជាបានគាំទ្រគំនិតនិរទេសជនជាតិវៀតណាមប្រាកដមែន។ ជាការពិត គួរកត់សម្គាល់ផងដែរថា ពាក្យ "ស្អាតជាអចិន្ត្រៃយ៍" មានកត់ត្រានៅក្នុង "លេខពិសេស" នៃទស្សនាវដ្តី

[4237] *សូមមើល* ឯកសារ **E3/200** BBC SWB *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប* ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ ១៩៧៧ KH 00292803-14។ ឯកសារ **E3/286** FBIS *មេដឹកនាំបរទេសបន្តផ្ញើសារជូនពរក្នុងឱកាសទិវាបុណ្យជាតិ* ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ១៩៧៧ EN 00168203-11។ ឯកសារ **E3/3376** កាសែត New York Times៖ អ្នកដឹកនាំកម្ពុជាលើកពីការ រីកចម្រើន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៧ KH 00729008។ ឯកសារ **E3/712** កាសែត International Herald Tribune៖ *អ្នកដឹកនាំប្រទេសកម្ពុជា ប្តេជ្ញាធ្វើការងារពលកម្មឱ្យបានកាន់តែខ្លាំង និងមានវិន័យតឹងរ៉ឹងជាងមុន* ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ ១៩៧៧ KH S 00725084។ ឯកសារ **E3/709** កាសែត The Sunday Star៖ *ប្រមុខរដ្ឋកម្ពុជា កោតសរសើរអំពីសង្គមដែលមិនប្រើគ្រឿងចក្រ* ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ KH S 00716250។

[4238] *សូមមើល* ឯកសារ **E3/1361** FBIS *សុន្ទរកថារបស់សមមិត្ត ខៀវ សំផន នាឱកាសពិធីបុណ្យខួបលើកទី៣ ថ្ងៃ១៥ ខែមេសា* ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ EN 00168813-22។ ឯកសារ **E3/1389 & E3/562** SWB មិទ្ទិញនៅក្រុងភ្នំពេញរំលឹកខួបទិវាជ័យជំនះ១៧មេសា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ KH S 00679973-82។ ឯកសារ **E3/2671** ទូរលេខអន្តរជាតិពីរដ្ឋមន្ត្រីក្រសួងការបរទេសបារាំង ទៅកាន់ស្ថានទូតបារាំង ក្រោមចំណងជើងថា "កាលប្បវត្តិកម្ពុជា ថ្ងៃទី១៥ ខែកុម្ភៈ - ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៨" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៨ KH 00807774-77។ ឯកសារ **E3/3169** សៀវភៅនិពន្ធដោយលោក Stephen Heder ក្រោមចំណងជើងថា ប៉ុល ពត និង ខៀវ សំផន KH 00711396-402។ ឯកសារ **E3/169 & E3/202** *សុន្ទរកថារបស់សមមិត្ត ខៀវ សំផន នាឱកាសពិធីបុណ្យខួបលើកទី៣* ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ KH S 00704515-27។

[4239] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩៥, ២០៨០។

[4240] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៨។

[4241] ឯកសារ **E3/742** ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៧ EN 00478502។

[4242] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសខាងអង្គច្បាប់ កំហុសខាងអង្គហេតុ)។

*ទង់បដិវត្តន៍* ដែលមានការដកស្រង់ចេញពីសុន្ទរកថា ដែលធ្វើឡើងដោយ "កម្មាភិបាលតំណាងបក្ស" នៅក្នុងអង្គប្រជុំរម្លឹកខួបលើកទីពីរនៃជ័យជំនះរបស់ ប.ក.ក ក្នុងខែមេសា ឆ្នាំ១៩៧៧[4243]។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនៅក្នុងអង្គមីទ្ទីងរម្លឹកខួបលើកទីពីរនេះ ហេតុដូច្នេះ ទោះបីជាគាត់មិនបានលើកឡើងពាក្យនេះដោយខ្លួនគាត់ផ្ទាល់ វាអាចថា គាត់យ៉ាងហោចណាស់បានផ្តល់ការគាំទ្រដោយប្រយោលចំពោះអ្វីដែលបានលើកឡើងនោះ[4244]។

1165. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា វាជាការមិនសមហេតុសមផលសម្រាប់ អ.ជ.ស.ដ ក្នុងការផ្អែកលើឯកសារពីរដែលមានការដកស្រង់សុន្ទរកថាមួយ ដែលម្ចាស់បណ្តឹងសាទុក្ខបានធ្វើនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ពីព្រោះខ្លឹមសាររបស់ឯកសារទាំងនោះខុសគ្នា[4245]។ ដោយហេតុថា ឯកសារទាំងនេះគឺជាការប្រតិចារឹកដោយផ្នែកនៃសុន្ទរកថានោះ វាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេថា ខ្លឹមសាររបស់វាខុសគ្នានោះទេ។ ច្បាស់ណាស់ថា ឯកសារទាំងនេះដកស្រង់ និងបកប្រែផ្នែកខុសគ្នានៃសុន្ទរកថានោះ។ ចំណុចនេះមិនមានត្រង់ណាបង្ហាញថា អ.ជ.ស.ដ ប្រាសចាកពីឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការវាយតម្លៃលើការទទួលខុសត្រូវ និងទម្ងន់នៃភ័ស្តុតាងនៅចំពោះមុខខ្លួនទេ[4246]។

1166. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ បានយោងទៅកថាខណ្ឌ ៣៤០៧ ជាភ័ស្តុតាងបញ្ជាក់ពីការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ គឺជាការបំភ្លៃសំអាងហេតុរបស់ អ.ជ.ស.ដ។ ទោះបីជា អ.ជ.ស.ដ ពិតជាបានយោងទៅកថាខណ្ឌ ៣៤០៧ នេះជាការយោងទៅកថាខណ្ឌ ៣៤០៦។ កថាខណ្ឌ ៣៤០៧ ផ្តល់បរិបទឱ្យការសន្និដ្ឋាននៅក្នុងកថាខណ្ឌ ៣៤០៦ តាមរយៈការរៀបរាប់លម្អិតអំពីភាសាដែលបានប្រើនៅក្នុងឯកសារបោះពុម្ពពេលនោះរបស់ ប.ក.ក ក្នុងការសំដៅទៅលើជនជាតិវៀតណាម។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4247] គ្មានត្រង់ ណាដែល អ.ជ.ស.ដ សន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានសរសេរឯកសារបោះពុម្ពផ្សាយ ទាំងអស់នេះទេ ឬ "បានអានទស្សនាវដ្តីទាំងនេះគ្រប់ច្បាប់នោះដែរ"។ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានបញ្ជាក់

---

[4243] ឯកសារ **E3/742** ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៧ EN 00478492-507។

[4244] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៣។

[4245] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៩៨។

[4246] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសខាងអង្គហេតុ)។

[4247] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩០១។

គាំទ្រការអះអាងរបស់ខ្លួនផងដែរថា អ.ជ.ស.ដ បានបំភ្លៃភស្តុតាងនេះ ដោយគាត់គ្រាន់តែលើកឡើងពីការបកស្រាយផ្សេងតែប៉ុណ្ណោះ[4248]។

*ការនិរទេសជនជាតិវៀតណាម*

1167. ការអះអាងជាក់លាក់របស់ម្ចាស់បណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការនិរទេសជនជាតិវៀតណាមក៏បរាជ័យផងដែរ។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងសមហេតុសមផលថា ម្ចាស់បណ្តឹងសាទុក្ខមានចេតនាឱ្យមានការនិរទេសជនជាតិវៀតណាម។ ដូចដែលម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងបានកត់សម្គាល់[4249] ការសន្និដ្ឋានរបស់ អ.ជ.ស.ដ អំពីចេតនាផ្អែកលើសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខអំពីជនជាតិវៀតណាម និង "យោងតាមការអំពាវនាវរបស់ ខៀវ សំផន ឱ្យបញ្ជូនជនជាតិវៀតណាមពីប្រទេសកម្ពុជាត្រឡប់ទៅប្រទេសវៀតណាមវិញ នៅដើមរបបកម្ពុជាប្រជាធិបតេយ្យ"[4250]។ ចំណុចនេះរួមមានភស្តុតាងអំពីការថ្លែងជាសាធារណៈរបស់គាត់ថា "ប្រទេសខ្មែរអត់មានយួន គឺមានតែខ្មែរ"[4251] និងថា ជនជាតិវៀតណាមនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ[4252]។ ដូចដែលបានពន្យល់ខាងលើ មិនចាំបាច់ទេថាតើម្ចាស់បណ្តឹងសាទុក្ខពិតជាបានដឹងថា ជនជាតិវៀតណាមត្រូវបាននិរទេស "ពីត្រាំកក់ និងព្រៃវែង នៅចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦"[4253] ឬយ៉ាងណានោះទេ។

1168. ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា ភស្តុតាងដែល អ.ជ.ស.ដ បានផ្អែកលើ ជាពិសេសសក្ខីកម្មរបស់ ឯក ហេន និងបទសម្ភាសន៍ក្រៅតុលាការរបស់ នៅ សារឹម[4254] ខ្វះភាពអាចជឿ

---

[4248] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩០១។

[4249] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៧៥។

[4250] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩២ *លើកឡើងពី* ផ្នែក ១៨.១.២.៣.២។

[4251] ឯកសារ **E1/217.1** លោកស្រី ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ១១.២៩.៥៦-១១.៣១.៥៨ ទំព័រ ៤០ បន្ទាត់ ១៤-១៥។

[4252] ឯកសារ **E3/6934** ប្រតិចារឹកនៃបទសម្ភាសន៍អ្នកស្រី នៅ សារឹម ដោយវិទ្យុសម្លេងសហរដ្ឋអាមេរិកភាសាខ្មែរ KH 01326477 ("លោក ខៀវ សំផន ក៏លើកអំពីដំណោះស្រាយរឿងយួន (ប្រជាជនវៀតណាម) ដែរនៅក្នុងប្រទេសកម្ពុជា [...]។ គាត់និយាយថា ពួកវៀតណាមបាននិយាយថា ពួកគេមិនចេះធ្វើស្រែ [...]។ លោក ខៀវ សំផន និយាយទៀតថា ប្រជាជនទាំងឡាយរស់នៅក្នុងប្រទេសកម្ពុជា ត្រូវធ្វើស្រែ តែអ្នកដែលមិនចេះធ្វើស្រែ ជាពិសេស ជនជាតិវៀតណាម ត្រូវបញ្ជូនទៅប្រទេសវៀតណាមវិញ។ ដូច្នេះ ខ្មែរក្រហមបានរៀបចំគម្រោងការបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ")។

[4253] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៧៦។ *សូមមើល* ផ្នែក VIII.គ.៣. ចេតនា។

[4254] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩០។

ជាក់បាន និងមានតម្លៃភ័ស្តុតាងទាប[4255]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងគ្មានមូលដ្ឋានថា សក្ខីកម្ម របស់ ឯក ហេន គួរត្រូវបានដកចេញ ដោយសារតែ "ភាពផ្ទុយគ្នាជាច្រើន និងបញ្ហានៃការចងចាំ" ឬ ត្រូវបានបកស្រាយតាមវិធីមួយតាមការចង់បានរបស់គាត់[4256]។ ម្ចាស់បណ្តឹងសាទុក្ខមិនបាន បញ្ជាក់គាំទ្រដល់ការអះអាងទាំងអស់នេះនៅក្នុងសារណារបស់គាត់ទេ ហើយក៏មិនបានផ្តល់ ឯកសារយោងណាមួយទៅនឹងភ័ស្តុតាងនេះផ្ទាល់ដែរ។ គាត់គ្រាន់តែយោងតាមរយៈជើងទំព័រ ទៅកាន់សារណាពីមុនដែលគាត់បានធ្វើ ទាក់ទងនឹងសាក្សីនេះ។ ក្នុងករណីណាក៏ដោយ សារណា របស់គាត់បរាជ័យមិនបានបង្ហាញថា អ.ជ.ស.ដ បានទៅហួសឆ្ងាយពីការគោរពដែលផ្តល់ឱ្យ ក្នុងការវាយតម្លៃលើទម្ងន់ ភាពអាចជឿទុកចិត្តបាន និងភាពអាចជឿជាក់បាននៃភ័ស្តុតាងនោះ ទេ[4257]។ ចំពោះការបកស្រាយផ្សេងទៀតនៃភ័ស្តុតាងរបស់ ឯក ហេន ម្ចាស់បណ្តឹងសាទុក្ខមិនបាន ពន្យល់ពីមូលហេតុដែល អ.ជ.ស.ដ គួរបកស្រាយសាររបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងន័យតែមួយ គត់ថា "ឱ្យចេះសាមគ្គី និងរួបរួមគ្នា"[4258] ខណៈដែលបដិសេធភ័ស្តុតាងច្បាស់លាស់របស់ ឯក ហេន ដែលថា ម្ចាស់បណ្តឹងសាទុក្ខបាននិយាយថា "ប្រទេសខ្មែរអត់មានយួន គឺមានតែខ្មែរ"[4259]។ គ្រាន់តែអះអាងថា អ.ជ.ស.ដ ខកខានមិនបានបកស្រាយភ័ស្តុតាងតាមរបៀបជាក់លាក់ណាមួយ មិនគ្រប់គ្រាន់ដើម្បីបង្ហាញអំពីកំហុសទេ[4260]។

1169. ម្ចាស់បណ្តឹងសាទុក្ខក៏អះអាងគ្មានមូលដ្ឋានផងដែរថា អ.ជ.ស.ដ មានកំហុសក្នុងការប្រើប្រាស់ របស់ខ្លួននូវបទសម្ភាសន៍របស់ នៅ សារីម[4261]។ ផ្ទុយទៅនឹងការអះអាងរបស់គាត់ បទសម្ភាសន៍ របស់ នៅ សារីម មិនមែនមិនអាចទទួលយកបាននោះទេ ហើយក៏មិនមែនត្រូវបានប្រើដោយគ្មាន ការអនុញ្ញាតដើម្បីរាយការណ៍អំពីអំពើរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលជាមូលដ្ឋានតែមួយគត់ សម្រាប់ការផ្តន្ទាទោសនោះទេ។ អ.ជ.ស.ដ បានប្រើបទសម្ភាសន៍នេះដាច់តែឯងនោះទេ ប៉ុន្តែប្រើ វា *ជាអាទិ៍* ជាមួយនឹងសក្ខីកម្មក្នុងតុលាការរបស់ ឯក ហេន និងភ័ស្តុតាងពីសម័យនោះនៃសុន្ទរកថា នានារបស់ម្ចាស់បណ្តឹងសាទុក្ខ។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានបង្កើត

[4255] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩៣-១៨៩៤, ២០៧៥។

[4256] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩៣។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០។

[4257] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសខាងអង្គហេតុ)។

[4258] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩៣។

[4259] ឯកសារ **E1/217.1** លោកស្រី ឯក ហេន ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង ១១.២៩.៥៦-១១.៣១.៥៨ ទំព័រ ៥០ បន្ទាត់ ១៤-១៥។

[4260] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសខាងអង្គហេតុ)។

[4261] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩៤។

កំហុសណាមួយ ដោយការប្រើភស្តុតាងនេះ ឬថា អង្គជំនុំជម្រះបានទៅហួសឆ្ងាយពីការគោរព ដែលផ្តល់បានផ្តល់ឱ្យខ្លួន ក្នុងការវាយតម្លៃលើទម្ងន់ ភាពអាចជឿទុកចិត្ត និងភាពអាចជឿជាក់បាន នៃភស្តុតាង[4262]។ លើសពីនេះទៀត ផ្ទុយទៅនឹងអ្វីដែលម្ចាស់បណ្តឹងសាទុក្ខបានអះអាង ទោះបីជា ឯក ហេន និង នៅ សារឹម បានចូលរួមក្នុងវគ្គសិក្សានៅឆ្នាំខុសគ្នាក៏ដោយ ក៏ភស្តុតាងរបស់ នៅ សារឹម នៅតែបញ្ជាក់ដោយអង្គហេតុទូទៅដែលទាញចេញពីសក្ខីកម្មរបស់ ឯក ហេន ថា ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនៅវគ្គសិក្សាអំពីការបណ្តេញជនជាតិវៀតណាមចេញពីកម្ពុជា។

1170. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា ទោះបីជាសេចក្តីថ្លែងការណ៍របស់គាត់បង្ហាញពីគោលបំណងរួម នៅតែមិនអាចទាញការសន្និដ្ឋានថា គាត់បានដឹងអំពីការនិរទេស ចំណុចនេះបំភ្លៃសំអាងហេតុរបស់ អ.ជ.ស.ដ។ អ.ជ.ស.ដ មិនត្រឹមតែបានសន្និដ្ឋានថា សេចក្តីថ្លែងការណ៍របស់គាត់ឆ្លុះបញ្ចាំងពីគោលបំណងរួមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសន្និដ្ឋានថា គាត់បានគាំទ្រជាចំហរឱ្យមានការបណ្តេញជនជាតិវៀតណាមចេញ ដោយការអំពាវនាវដែលបាន "ឆ្លុះបញ្ចាំងអំពីខ្លឹមសារសំខាន់ បែបបទ *និងការអនុវត្តចុងក្រោយ* នៃគោលបំណងរួមស្តីពីការនិរទេសប្រជាជនវៀតណាមទាំងអស់"[4263]។

1171. ការជំទាស់របស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុស ដោយការបកស្រាយមិនត្រឹមត្រូវលើភស្តុតាង និងបំភ្លៃសេចក្តីថ្លែងជាសាធារណៈរបស់ម្ចាស់បណ្តឹងសាទុក្ខនោះ គ្មានមូលដ្ឋានទេ។ ចំពោះការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា កថាខណ្ឌ ៣៤០០ មិនគាំទ្រដល់ការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានគាំទ្រឱ្យមានការនិរទេសជនជាតិវៀតណាម វាមានភាពច្បាស់លាស់នៅពេលអានដោយគិតទៅបរិបទថា អ.ជ.ស.ដ មានចេតនាយោងទៅកថាខណ្ឌមុន គឺកថាខណ្ឌ ៣៣៩៩។ កថាខណ្ឌ ៣៣៩៩ *ពិតជា* គាំទ្រការសន្និដ្ឋានដែលបានធ្វើនៅក្នុងកថាខណ្ឌ ៤២៧១ ដែលក្រោយមកត្រូវបានយោងក្នុងកថាខណ្ឌ ៤២៣៧។ ក្នុងកថាខណ្ឌ ៣៣៩៩ អ.ជ.ស.ដ បានដកស្រង់សុន្ទរកថាដែលម្ចាស់បណ្តឹងសាទុក្ខបានអាន ដែលគាត់បានសន្យាថា "*បណ្តេញចេញ និងកម្ទេចឱ្យអស់* ពួកឈ្លានពាន ពួកវាតទីនិយមវៀតណាម សាហាវព្រៃផ្សៃ *ឱ្យចេញផុតពីទឹកដីកម្ពុជា*" និង "កម្ទេចឱ្យអស់រាល់បណ្តាញភ្នាក់ងារពួកឈ្លានពាន ពួកវាតទីនិយមវៀតណាម សាហាវព្រៃផ្សៃ*ឱ្យចេញផុតពីទឹកដីកម្ពុជា*"[4264]។ នៅក្នុងករណីណាក៏ដោយ ទោះបីជា អ.ជ.ស.ដ

---

[4262] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសខាងអង្គហេតុ)។

[4263] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៧ (គូសបញ្ជាក់បន្ថែម)។

[4264] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩៩ *លើកឡើងពី* ឯកសារ **E3/562** *ជំនួបនៅទីក្រុងភ្នំពេញ សំគាល់ថ្ងៃទី១៧ មេសា ជាថ្ងៃបុណ្យខួប* ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ KH 00249989 (គូសបញ្ជាក់បន្ថែម)។

មិនមានន័យយោងទៅ កថាខណ្ឌ ៣៣៩៩ ក៏ដោយ ក៏ច្បាស់ណាស់ថា ភ័ស្តុតាងនេះត្រូវបាន ពិចារណាដោយ អ.ជ.ស.ដ រួចហើយ នៅពេលដែលអង្គជំនុំជម្រះធ្វើការសន្និដ្ឋានរបស់ខ្លួន ទាក់ទងនឹងការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ។

1172. ទាក់ទងនឹងកថាខណ្ឌ ៤២៧១ ម្ចាស់បណ្តឹងសាទុក្ខបំភ្លៃសំអាងហេតុរបស់ អ.ជ.ស.ដ។ ទោះជា អ.ជ.ស.ដ ពិតជាយោងឆ្លងទៅជើងទំព័រ ១១៤៧ ក្នុងថាខណ្ឌ ៤២៧១ ផ្នែកពាក់ព័ន្ធនៃជើងទំព័រ ១១៤៣៧ គឺជាភ័ស្តុតាងរបស់ នៅ សារឹម មិនមែនសក្ខីកម្មរបស់ ឯក ហេន ទេ។ ចំណុច នេះច្បាស់លាស់ណាស់ នៅពេលដែលអានដោយគិតពីបរិបទ ដោយសារវាគឺជាការដកស្រង់មួយ ចេញពីបទសម្ភាសន៍របស់ នៅ សារឹម ដែលត្រូវបានដាក់ក្នុងជើងទំព័រ។ ដោយសារតែវាជា ភ័ស្តុតាងរបស់ នៅ សារឹម ដែលកំពុងត្រូវបានពិភាក្សា នៅពេលដែល អ.ជ.ស.ដ សំដៅលើ ការបង្រៀនរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ អ.ជ.ស.ដ មិនបានមានកំហុស ដោយការចុះកាលបរិច្ឆេទភ័ស្តុតាងរបស់ ឯក ហេន ទៅឆ្នាំ១៩៧៥ ឬ ១៩៧៦ នោះទេ[4265]។ អ.ជ.ស.ដ ពិតជាបានយោងទៅសក្ខីកម្មរបស់ ឯក ហេន ក្រោយមកទៀតក្នុងកថាខណ្ឌ ៤២៧១ ប៉ុន្តែ ខ្លួនបានចុះកាលបរិច្ឆេទយ៉ាងច្បាស់នូវវគ្គសិក្សាដែលគាត់បានចូលរួម ដែលបានធ្វើឡើង "បន្ទាប់ពីការផ្លាស់ប្តូរគោលនយោបាយ ប.ក.ក ចំពោះជនជាតិវៀតណាមនៅឆ្នាំ១៩៧៧"[4266]។

## *ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាម*

1173. ការអះអាងជាក់លាក់របស់ម្ចាស់បណ្តឹងសាទុក្ខចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើមនុស្ស ឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាម ក៏បរាជ័យផងដែរ។ ម្ចាស់បណ្តឹងសាទុក្ខអះអាង ថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ពាក្យពេចន៍ និងសកម្មភាពរបស់គាត់ បង្ហាញពីការប្រមាថ ជនជាតិវៀតណាមនោះ មិនបង្ហាញថា គាត់មានចេតនាសម្លាប់ពួកគេទេ ដែលជាការបំភ្លៃ សាលក្រម[4267]។ អ.ជ.ស.ដ បានសន្និដ្ឋានថា "ពាក្យពេចន៍ និងសកម្មភាព [របស់ម្ចាស់បណ្តឹង សាទុក្ខ] [...] ស្តែងឱ្យឃើញពីការស្អប់ខ្ពើមរបស់គាត់ចំពោះជនជាតិវៀតណាម *និង* ចេតនា ផ្ទាល់ក្នុងការសម្លាប់ពួកគេជាលក្ខណៈទ្រង់ទ្រាយធំនៅប្រទេសកម្ពុជា"[4268]។ អ.ជ.ស.ដ មិនបាន ទាញការសន្និដ្ឋានលើចេតនាសម្លាប់ ចេញពីការប្រមាថរបស់គាត់ចំពោះជនជាតិវៀតណាមទេ

[4265] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៩៣។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០។

[4266] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៣៩០, ៤២៧១។

[4267] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៧៧។

[4268] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៣ (គូសបញ្ជាក់បន្ថែម)។

ប៉ុន្តែ បានសន្និដ្ឋានថា គាត់មានទាំងការប្រមាថលើជនជាតិវៀតណាម និងចេតនាផ្ទាល់ក្នុងការសម្លាប់ពួកគេ។

1174. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុស ដោយមិនបានពន្យល់ "ថាតើពាក្យសម្តីរបស់ ខៀវ សំផន អនុញ្ញាតឱ្យបង្ហាញថា [ម្ចាស់បណ្តឹងសាទុក្ខ] មានចេតនាសម្លាប់ជនជាតិវៀតណាម នៅទីកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើងដែរឬទេ" យល់ច្រឡំចំពោះ*ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល[4269]។ ការធ្វើមនុស្សឃាតតម្រូវឱ្យមានចេតនាឱ្យមានការសម្លាប់ជនរងគ្រោះ[4270]។ ការសម្លាប់រង្គាលតម្រូវឱ្យមានតែ "ចេតនាផ្ទាល់ក្នុងការសម្លាប់ក្នុងទ្រង់ទ្រាយធំ"[4271]។ ទាំងការធ្វើមនុស្សឃាត និងទាំងការសម្លាប់រង្គាល មិនតម្រូវឱ្យមានចេតនាឱ្យមានការសម្លាប់ជនរងគ្រោះនៅកន្លែងជាក់លាក់ ដែលការសម្លាប់ជាក់ស្តែងបានកើតឡើងនោះទេ។ ដូចដែលបានពិភាក្សាខាងលើ ជនជាប់ចោទអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ទោះបីជាគាត់មិនមានចេតនា ឬមិនដឹងពីព័ត៌មានលម្អិតនៃអំពើឧក្រិដ្ឋជាក់លាក់ (ដូចជាទីកន្លែង) ក៏ដោយ[4272]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងសមហេតុសមផលថា ម្ចាស់បណ្តឹងសាទុក្ខទាំងមានចេតនាចូលរួមក្នុងគោលបំណងរួម[4273] និងទាំងមាន "ចេតនាផ្ទាល់ក្នុងការសម្លាប់ [ជនជាតិវៀតណាម] ជាលក្ខណៈទ្រង់ទ្រាយធំនៅប្រទេសកម្ពុជា"[4274] ដូច្នេះបំពេញបាននូវ *ធាតុផ្សំអត្តនោម័តិ* នៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

## *ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនជាតិសាសន៍លើជនជាតិវៀតណាម*

1175. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខផ្តោតជាក់លាក់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍លើជនជាតិវៀតណាម ក៏បរាជ័យផងដែរ។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មិនបានកំណត់អត្តសញ្ញាណភ័ស្តុតាងណា

[4269] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៧៧, ២០៨០។

[4270] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៨៧ ("ចេតនារបស់ជនជាប់ចោទ ឬជនណាម្នាក់ ឬច្រើននាក់ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ទាំងការសម្លាប់ ឬទាំងការបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរ ផ្នែករូបកាយដោយមានហេតុផលដឹងថា អំពើសកម្ម ឬអំពើអកម្មនោះ មុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស") ៤១០។

[4271] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥២២។

[4272] *សូមមើល* ផ្នែក VIII.គ.៣. ចេតនា។

[4273] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧៩។

[4274] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៣។

មួយអំពីចេតនារើសអើងរបស់គាត់ប្រឆាំងនឹងជនជាតិវៀតណាម[4275] និងខកខានមិនបានពន្យល់ថា តើវាជាការរើសអើងពូជសាសន៍ដែលគាត់មានចេតនា ដោយរបៀបណា[4276] ការសន្និដ្ឋានរបស់ អ.ជ.ស.ដ អំពីចេតនារើសអើងដោយមូលហេតុជាតិសាសន៍ មានភាពសមហេតុសមផល និង បានពន្យល់យ៉ាងពេញលេញ។ អ.ជ.ស.ដ បានសន្និដ្ឋានថា ពាក្យពេចន៍ និងសកម្មភាពរបស់ម្ចាស់ បណ្តឹងសាទុក្ខក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញឱ្យឃើញពីចេតនាចូលរួមរបស់ គាត់ក្នុងការសម្លាប់ជនជាតិវៀតណាមក្នុងទ្រង់ទ្រាយធំ ដោយបានយោងទៅភ័ស្តុតាងដែលបាន ដកស្រង់នៅក្នុងកថាខណ្ឌ ៤២៣៨ ដើម្បីគាំទ្រដល់ការសន្និដ្ឋាននេះ[4277]។ ចេតនារបស់ម្ចាស់ បណ្តឹងសាទុក្ខក្នុងការរើសអើងដោយមូលហេតុជាតិសាសន៍ ត្រូវបានបង្ហាញដោយចេតនាក្នុងការ សម្លាប់នេះ[4278]។ សំអាងហេតុនេះស្របគ្នាជាមួយនឹងសេចក្តីសម្រេចពីតុលាការអន្តរជាតិផ្សេង ទៀត។ ឧទាហរណ៍ ក្នុងរឿងក្តី *Kvočka* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានពន្យល់ ថា "ប្រសិនបើគម្រោងឧក្រិដ្ឋជាប់ពាក់ព័ន្ធនឹងការសម្លាប់សមាជិកនៃក្រុមជាតិពន្ធុជាក់លាក់ ហើយសមាជិកនៃក្រុមជាតិពន្ធុនោះមាន សាសនា ពូជសាសន៍ ឬក្រុមនយោបាយខុសពីសហចារី *ការណ៍នោះបង្ហាញពីចេតនារើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា*"[4279]។ ហេតុដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខបរាជ័យមិនបានបង្ហាញថា ការសន្និដ្ឋានរបស់ អ.ជ.ស.ដ អំពី ចេតនារើសអើង គឺជាការសន្និដ្ឋានដែលអ្នកវិនិច្ឆ័យលើអង្គហេតុដ៏មានហេតុផលណាអាចបានធ្វើ។

1176. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ ខកខានមិនបានបង្ហាញថា ម្ចាស់បណ្តឹង សាទុក្ខមានចេតនាប្រព្រឹត្តការធ្វើទុក្ខបុកម្នេញពូជាសាសន៍នៅក្នុងស្រុកត្រាំកក់ និងខេត្តព្រៃវែង[4280] បរាជ័យ ដោយហេតុថា ការអះអាងនេះប្រើវិធីតាមផ្នែកចំពោះសាលក្រម និងយល់ច្រឡំច្បាប់។ អ.ជ.ស.ដ មិនត្រូវបានតម្រូវឱ្យបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខមានចេតនាធ្វើទុក្ខបុកម្នេញលើ ជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍នោះទេ ទាក់ទងនឹងអំពើរើសអើងជាក់លាក់ នីមួយៗ និងទីតាំងឧក្រិដ្ឋកម្មជាក់លាក់នីមួយៗ។ អ.ជ.ស.ដ គ្រាន់តែត្រូវបង្ហាញថា ម្ចាស់បណ្តឹង

[4275] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៨២។

[4276] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៨៥។

[4277] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤០០២-៤០០៣, ៤២៩៣ ជើងទំព័រ ១៤០០១។

[4278] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៣ ("ម្យ៉ាងវិញទៀត អង្គជំនុំជម្រះយល់ឃើញថា ចេតនាសម្លាប់នេះកើតចេញពីចេតនាជាក់លាក់របស់ ខៀវ សំផន ក្នុងការរើសអើងជនជាតិវៀតណាមដោយសារមូលហេតុជាតិសាសន៍")។

[4279] សាលក្រមរឿងក្តី *Kvočka* កថាខណ្ឌ ២៨៨ (គូសបញ្ជាក់បន្ថែម)។

[4280] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៨៥។

សាទុក្ខមានចេតនាជាក់លាក់ជាមួយនឹងសមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងទៀត ក្នុងការប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍។ អង្គជំនុំជម្រះបានសន្និដ្ឋានយ៉ាងសមហេតុសមផលថា ចំណុចនេះត្រូវបានបង្ហាញដោយចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការសម្លាប់ជនជាតិវៀតណាម ដូចដែលបានពិភាក្សាខាងលើ។ ក្នុងករណីណាក៏ដោយ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការធ្វើទុក្ខបុកម្នេញពូជសាសន៍លើជនជាតិវៀតណាមនៅស្រុកត្រាំកក់ និងខេត្តព្រៃវែង ត្រូវបានបង្ហាញនៅក្នុងសាលក្រមទាំងមូល។ ឧទាហរណ៍ អ.ជ.ស.ដ បានសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញពូជសាសន៍ត្រូវបានបង្ហាញទាក់ទងនឹងការនិរទេសជនជាតិវៀតណាមនៅស្រុកត្រាំកក់[4281]។ អង្គជំនុំជម្រះក៏បានសន្និដ្ឋានទៀតថា ម្ចាស់បណ្តឹងសាទុក្ខមានចេតនាធ្វើការនិរទេសទាំងអស់នេះ[4282]។ ហេតុដូច្នេះ អង្គជំនុំជម្រះសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខពិតជាមានចេតនារើសអើងជាតិសាសន៍នៅស្រុកត្រាំកក់។

1177. ការអះអាងរបស់ម្ចាស់ណ្តឹងសាទុក្ខថា អ.ជ.ស.ដ “គ្មានភស្តុតាងបង្ហាញថា [គាត់] មានចេតនាសម្លាប់ជនជាតិវៀតណាមដែលមានដើមកំណើតជាវៀតណាមនោះទេ” មិនត្រឹមត្រូវទេ[4283] ដូចបានពិភាក្សាខាងលើ ក្នុងចម្លើយតបទៅនឹងការអះអាងរបស់គាត់ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

*អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម*

1178. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម ក៏បរាជ័យផងដែរ។ ម្ចាស់បណ្តឹងសាទុក្ខបំភ្លៃសំអាងហេតុរបស់ អ.ជ.ស.ដ និងមិនបានអានការសន្និដ្ឋានរបស់ អ.ជ.ស.ដ ស្តីពីចេតនាប្រល័យពូជសាសន៍ក្នុងបរិបទ នៅពេលដែលអះអាងថា អ.ជ.ស.ដ ខកខានមិនបានបញ្ជាក់ថាតើ “ពាក្យពេចន៍ ឬសកម្មភាព” មួយណា ដែលបង្ហាញពីចេតនាប្រល័យពូជសាសន៍របស់គាត់[4284]។ ការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើចេតនាប្រល័យពូជសាសន៍នៅក្នុងកថាខណ្ឌ ៤២៩៤ បានមកពី និងយោងទៅលើ ការសន្និដ្ឋានរបស់ខ្លួនលើចេតនា

[4281] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៨៨-១១៩២។

[4282] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩២។

[4283] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៨១។

[4284] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៨៦។

មនុស្សឃាតរបស់គាត់នៅក្នុងកថាខណ្ឌ ៤២៩៣[4285]។ កថាខណ្ឌ ៤២៩៣ យោងទៅ "ពាក្យពេចន៍ និងសកម្មភាព [របស់ម្ចាស់បណ្ដឹងសាទុក្ខ] ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ" ដោយការយោងឆ្លងទៅកថាខណ្ឌ ៤២៣៨[4286]។ ហេតុដូច្នេះ នៅពេលដែលការសន្និដ្ឋានរបស់ អ.ជ.ស.ដ លើចេតនារបស់ម្ចាស់បណ្ដឹងសាទុក្ខ ត្រូវបានអានដោយគិតពីបរិបទ ច្បាស់ថា "ពាក្យពេចន៍ និងសកម្មភាព" ដែលបានយោងដោយ អ.ជ.ស.ដ គឺជាពាក្យពេចន៍ និងសកម្មភាពដែលបានពិភាក្សាក្នុងកថាខណ្ឌ ៤២៣៨[4287] ដោយរួមទាំងសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ម្ចាស់បណ្ដឹងសាទុក្ខ ដែលអំពាវនាវថា ជនជាតិវៀតណាម "បោសសម្អាត" "សម្លាប់ឱ្យអស់" និង "កម្ទេចឱ្យសាបសូន្យ"[4288]។ សេចក្ដីថ្លែងការណ៍ទាំងនេះបង្ហាញយ៉ាងច្បាស់អំពីចេតនាប្រល័យពូជសាសន៍។

1179. ម្ចាស់បណ្ដឹងសាទុក្ខអះអាងថា អ.ជ.ស.ដ ប្រើខុសនូវបទសម្ភាសន៍ ឆ្នាំ២០០៧ ជាមួយគាត់ ដើម្បីបង្ហាញពីចេតនាប្រល័យពូជសាសន៍របស់គាត់ ក៏បំភ្លៃសំអាងហេតុរបស់ អ.ជ.ស.ដ ផងដែរ[4289]។ អ.ជ.ស.ដ មិនបានផ្អែកលើបទសម្ភាសន៍នេះ ដើម្បីបង្ហាញពីចេតនាប្រល័យពូជសាសន៍របស់ម្ចាស់បណ្ដឹងសាទុក្ខទេ។ អ.ជ.ស.ដ បានសន្និដ្ឋានថា ចេតនារបស់គាត់បានបង្ហាញតាមរយៈ "ពាក្យពេចន៍ និងសកម្មភាព [របស់គាត់] *ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ*"[4290]។ បទសម្ភាសន៍គ្រាន់តែត្រូវបានយោងនៅក្នុងជើងទំព័រ ដើម្បីបង្ហាញពី "កំហឹងយូរអង្វែង" របស់ម្ចាស់បណ្ដឹងសាទុក្ខចំពោះជនជាតិវៀតណាមតែប៉ុណ្ណោះ[4291]។ លើសពីនេះទៀត ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខថា អ.ជ.ស.ដ "មិនបានចម្លងឡើងវិញ" បទសម្ភាសន៍នេះ គួរត្រូវច្រានចោលផងដែរ ដោយសារគាត់មិនបានពន្យល់ពីមូលហេតុដែលតម្រូវឱ្យ អ.ជ.ស.ដ ធ្វើប្រតិចារិកបទសម្ភាសន៍នេះ បន្ថែមលើការរៀបរាប់អំពីភស្តុតាង និងការយោងសំអាងវាដោយមានការយោងលើ

---

[4285] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៤ (អ.ជ.ស.ដ ចាប់ផ្ដើមដោយពាក្យកិរិយាវិសេសន៍ "ម្យ៉ាងវិញទៀត" ដូច្នេះវាបានភ្ជាប់យ៉ាងច្បាស់ទៅនឹងការសន្និដ្ឋានដែលបានធ្វើឡើងនៅក្នុងកថាខណ្ឌ ៤២៩៣។ អ.ជ.ស.ដ ក៏បានកត់សម្គាល់ផងដែរថាការរកឃើញរបស់ខ្លួនគឺ "យោងតាមការសន្និដ្ឋានរបស់ខ្លួនក្នុងកថាខណ្ឌខាងដើម")។

[4286] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៣ ជើងទំព័រ ១៤០០១។

[4287] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៨ យោងផ្នែក ១៣.៣៖ ការប្រព្រឹត្តលើជនជាតិវៀតណាម ដែលការយោងសំអាងពេញលេញសម្រាប់សុន្ទរកថារបស់ម្ចាស់បណ្ដឹងសាទុក្ខ ត្រូវបានផ្ដល់នៅក្នុងកថាខណ្ឌ ៣៤០៦-៣៤០៧។

[4288] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៨។

[4289] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២០៨៧-២០៨៨។

[4290] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៤ (គូសបញ្ជាក់បន្ថែម)។

[4291] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៤ ជើងទំព័រ ១៤០០២។

កំណត់គ្រាពេលវេលា។ ការខកខានរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងការលើកឡើងទៅកាន់ អ.ជ.ស.ជ នៃបញ្ហាបកប្រែភាសាណាមួយ ទាក់ទងនឹងភ័ស្ដុតាងនេះ បញ្ជាក់ថា មិនមាននោះទេ។

1180. ពាក្យពេចន៍ និងសកម្មភាពរបស់ម្ចាស់បណ្ដឹងសាទុក្ខ ដែល អ.ជ.ស.ជ[4292] បានពិចារណាថា គ្រប់គ្រាន់ក្នុងការបញ្ជាក់ពីចេតនាប្រល័យពូជសាសន៍របស់គាត់នេះ ត្រូវបានកំណត់យ៉ាងច្បាស់ដោយយុត្តិសាស្ត្រអន្តរជាតិ។ ក្នុងរឿងក្ដី *Krstić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានកត់សម្គាល់ថា ចេតនាប្រល័យពូជសាសន៍ ជាធម្មតាមិនអាចជាភ័ស្ដុតាងផ្ទាល់ទេ ប៉ុន្តែ ជាញឹកញាប់ទាញការសន្និដ្ឋានចេញពីអង្គហេតុ និងកាលៈទេសៈនៃរឿងក្ដី[4293]។ អង្គហេតុទាំងនេះមិនចាំបាច់ត្រូវជា*ធាតុផ្សំសត្យានុម័តិ* នៃឧក្រិដ្ឋកម្មទេ[4294]។ កត្តានានាពាក់ព័ន្ធទៅនឹងការវិភាគនេះ អាចមានការប្រព្រឹត្តិអំពើខុសឆ្គងផ្សេងទៀត ដែលផ្ដោតជាប្រព័ន្ធប្រឆាំងនឹងក្រុមដូចគ្នា (ថាតើបានធ្វើឡើងដោយជនល្មើសដដែល ឬជនដទៃ ឬយ៉ាងណា) ការកំណត់គោលដៅជាប្រព័ន្ធលើជនរងគ្រោះ ដោយផ្អែកលើសមាជិកភាពរបស់ពួកគេក្នុងក្រុមជាក់លាក់ ការអនុវត្តជាដដែលៗនូវអំពើបំផ្លិចបំផ្លាញ និងរើសអើង ការប្រើប្រាស់ភាសាដែលប្រមាថ ចំពោះសមាជិកនៃក្រុមដែលបានកំណត់គោលដៅ[4295] សុន្ទរកថា ឬគម្រោងការដែលជាមូលដ្ឋាន និងជាយុត្តិកម្មចំពោះអំពើដែលមានបំណងធ្វើឱ្យអន្តរាយដល់មូលដ្ឋាននៃក្រុមដែលបានផ្ដោតគោលដៅនោះ[4296] និងគោលនយោបាយដែលបណ្ដាលឱ្យមានអំពើទាំងនោះ[4297]។ កត្តាទាំងអស់នេះត្រូវបានបង្ហាញទាំងអស់នៅ

---

[4292] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៨, ៤២៩៤។

[4293] សាលដីការឿងក្ដី *Karadžić* លើវិធាន ៩៨*ស្ទួន* កថាខណ្ឌ ៨០ *យោង* សាលដីការឿងក្ដី *Gacumbitsi* កថាខណ្ឌ ៤០, សាលដីការឿងក្ដី *Rutaganda* កថាខណ្ឌ ៥២៥, សាលដីការឿងក្ដី *Kayishema & Ruzindana* កថាខណ្ឌ ១៥៩។

[4294] សាលដីការឿងក្ដី *Tolimir* កថាខណ្ឌ ២៥៤។ សាលដីការឿងក្ដី *Krstić* កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* រឿងក្ដី*ប្រទេសក្រូអាស៊ី តទល់នឹង ប្រទេសស៊ែប៊ី* កថាខណ្ឌ ១៦២-១៦៣, ៤៧៨។ *ប្រទេសបូស្នី តទល់នឹង ប្រទេសស៊ែប៊ី* កថាខណ្ឌ ១៩០។

[4295] សាលក្រមរឿងក្ដី *Karadžić* កថាខណ្ឌ ៥៥០។ សាលដីការឿងក្ដី *Karadžić* លើវិធាន ៩៨*ស្ទួន* កថាខណ្ឌ ៨០។ សាលដីការឿងក្ដី *Tolimir* កថាខណ្ឌ ២៤៦។ សាលដីការឿងក្ដី *Popović* កថាខណ្ឌ ៤៦៨។ សាលដីការឿងក្ដី *Hategekimana* កថាខណ្ឌ ១៣៣។ សាលដីការឿងក្ដី *Jelisić* កថាខណ្ឌ ៤៧។ សាលដីការឿងក្ដី *Seromba* កថាខណ្ឌ ១៧៦។ សាលដីការឿងក្ដី *Gacumbitsi* កថាខណ្ឌ ៤០-៤១។ របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១៥២។

[4296] សាលដីការឿងក្ដី *Gacumbitsi* កថាខណ្ឌ ៤៣។ សាលដីការឿងក្ដី *Kamuhanda* កថាខណ្ឌ ៨១-៨២។ សាលក្រមរឿងក្ដី *Karadžić* កថាខណ្ឌ ៥៥០។ សាលក្រមរឿងក្ដី *Tolimir* កថាខណ្ឌ ៧៤៥។

[4297] សាលដីការឿងក្ដី *Seromba* កថាខណ្ឌ ១៧៦។

ក្នុងរឿងក្តីនេះ[4298] ដែលគាំទ្រដល់ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខបានប្រព្រឹត្តដោយមានចេតនាប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម។

1181. ជាចុងក្រោយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ "បានមើលរំលង" ថា ចេតនាប្រល័យពូជសាសន៍ តម្រូវឱ្យមានចេតនាកម្ទេចក្រុមមួយ "ទាំងមូល ឬមួយផ្នែក" ពិតជាខុសទាំងស្រុង[4299]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខមាន "ចេតនាប្រល័យពូជសាសន៍ [...] ក្នុងការកម្ទេចជនជាតិវៀតណាម *ក្នុងនាមជាក្រុមជាតិសាសន៍ ជនជាតិ និងជាតិពន្ធុ*"[4300]។ ការសន្និដ្ឋានអំពីចេតនាប្រល័យពូជសាសន៍ក្នុងការកម្ទេចក្រុមមួយ ពាក់ព័ន្ធជាចាំបាច់នូវការសន្និដ្ឋានពីចេតនាកម្ទេចក្រុមនោះ "ទាំងមូល ឬមួយផ្នែក" ថាតើពាក្យពេចន៍ជាក់លាក់ទាំងនោះត្រូវបានប្រើ ឬមិនត្រូវបានប្រើ។ លើសពីនេះទៀត ច្បាស់ណាស់ថា អ.ជ.ស.ដ បានដឹងអំពីលក្ខខណ្ឌតម្រូវនេះ ដូចដែលខ្លួនបានលើកឡើងពីចំណុចនេះនៅក្នុងការពិភាក្សារបស់ខ្លួនអំពី*ធាតុផ្សំអត្តនោម័តិ* នៃអំពើប្រល័យពូជសាសន៍[4301]។

*ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវប្រឆាំងនឹងជនជាតិវៀតណាម*

1182. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវប្រឆាំងនឹងជនជាតិវៀតណាម ក៏បរាជ័យផងដែរ។ ម្ចាស់បណ្តឹងសាទុក្ខអះអាងសើៗថា អ.ជ.ស.ដ មិនអាចទាញការសន្និដ្ឋានអំពីចេតនាចេញពីការដឹងរបស់គាត់អំពីឋានៈដែលទទួលបានការអនុញ្ញារបស់អ្នកទោសជនជាតិវៀតណាម[4302] ការគាំទ្ររបស់គាត់ចំពោះក្របខណ្ឌបដិវត្តន៍[4303] និងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម[4304]បានទេ។ ផ្ទុយទៅវិញ អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវលើការសន្និដ្ឋានរបស់ខ្លួន ទាក់ទងនឹងការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីឋានៈដែលទទួលបានការការអនុញ្ញាតរបស់អ្នកទោសជនជាតិវៀតណាមនៅ ស-២១ ការគាំទ្រ

[4298] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៨៨-៣៩៩៨។ *១៣.៣ ការប្រព្រឹត្តលើជនជាតិវៀតណាម*។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានដែលមានចំណងជើងថា *ការប្រព្រឹត្តលើក្រុមជនជាតិ៖ ជនជាតិវៀតណាម* និងចម្លើយតបទៅនឹងមូលដ្ឋានទី ២១៩, ២៣៧, ២៣៨, ២៣៩, ២៤១។

[4299] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៨៧។

[4300] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៤ (គូសបញ្ជាក់បន្ថែម)។

[4301] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៩៧-៨០៥។

[4302] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៨៩។

[4303] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៩០។

[4304] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៩០។

របស់គាត់ចំពោះក្របខណ្ឌប្រជិវត្តន៍ទាក់ទងនឹងខ្លាំង និងចេតនាចូលរួមចំណែករបស់គាត់ក្នុងការជំរុញឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋកម្មរួម[4305]។ នៅពេលដែលពិចារណារួមគ្នា ច្បាស់ ណាស់ថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងថា ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវកំពុងត្រូវបានធ្វើឡើងប្រឆាំងនឹងអ្នកទោសជនជាតិវៀតណាមនៅមន្ទីរ ស-២១ ដែលជាផ្នែកមួយនៃផែនការរួម និងទោះជាយ៉ាងណា បានបន្តចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនោះ។ សេចក្តីសន្និដ្ឋានដ៏សមហេតុសមផលតែមួយគត់ដែលអាចធ្វើចេញពីចំណុចនេះ គឺថា ម្ចាស់បណ្តឹងសាទុក្ខមានចេតនាប្រព្រឹត្តការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹងអ្នកទោសជនជាតិវៀតណាមនៅមន្ទីរ ស-២១។

1183. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់ "បានដឹងអំពីឋានៈដែលត្រូវទទួលបានការការពាររបស់ជនជាតិវៀតណាមនៅមន្ទីរសន្តិសុខ ស-២១ ហើយបានដឹងអំពីការធ្វើបាបពួកគេ"[4306]។ ការអះអាងដដែលៗរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់មានមុខតំណែងពិសេសនៅក្នុង ប.ក.ក មិនត្រឹមត្រូវទេ[4307]។ ចំពោះការអះអាងរបស់គាត់ទាក់ទងនឹង "គោលការណ៍រក្សាការសម្ងាត់"[4308] ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកឡើងថា ការសន្និដ្ឋានផ្សេងគួរត្រូវបានធ្វើ ដោយមិនបានបង្ហាញអំពីកំហុសណាមួយរបស់ អ.ជ.ស.ដ[4309]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងភ័ស្តុតាងនៃការប្រជុំរវាង ឌុច និងម្ចាស់បណ្តឹងសាទុក្ខ និងការដឹងរបស់គាត់អំពីចម្លើយសារភាព រូបថត និងភាពយន្តអំពីឈ្លើយសឹកវៀតណាម គួរត្រូវបានច្រានចោលផងដែរ[4310]។ ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអះអាងថា អ.ជ.ស.ដ គួរបានសន្និដ្ឋានផ្សេងពីនេះ។

---

[4305] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៩៥។

[4306] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣៩។

[4307] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣។

[4308] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩០៤-១៩០៥។

[4309] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧១។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៥។

[4310] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩០៦-១៩០៩។

## iv. ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងអំឡុងពេលបោសសម្អាតផ្ទៃក្នុង និងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានា

### *មូលដ្ឋានទី ២១៦, ២១៧ និង ២៣៥*[4311]

1184. **មូលដ្ឋានទី ២១៦, ២១៧ និង ២៣៥ គួរត្រូវបានច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ម្ចាស់បណ្តឹងសាទុក្ខមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបង្ខំឱ្យបាត់ខ្លួន ក្នុងអំឡុងពេលបោសសម្អាតផ្ទៃក្នុង និងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។**

1185. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃលើឧក្រិដ្ឋកម្មទាំងអស់នេះ។ ផ្អែកលើការពណ៌នាត្រឹមត្រូវអំពីច្បាប់[4312] និងការពិនិត្យទាំងមូលលើឯកសារភស្តុតាងដ៏ទូលំទូលាយ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខមានចេតនាឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងអឡុងពេលបោសសំអាត និងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនឹងសំណុំរឿង០០២/០២[4313]។

1186. ម្ចាស់បណ្តឹងសាទុក្ខបានរួមចំណែកចំពោះការបោសសម្អាត[4314] *ជាអាទិ៍* តាមរយៈការផ្តល់វគ្គសិក្សានយោបាយ ដែលមានបំណងស្វែងរកជនក្បត់ និងខ្មាំង និងនៅក្នុងសុន្ទរកថាសាធារណៈជាច្រើនរបស់គាត់ បានលើកទឹកចិត្តឱ្យកម្មាភិបាលឱ្យកំណត់អត្តសញ្ញាណខ្មាំង និងញុះញង់ឱ្យ

---

[4311] <u>មូលដ្ឋានទី ២១៦៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *មន្ទីរសន្តិសុខនានា* កថាខណ្ឌ ១៨៤៩-១៨៥៦។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៣ (អង់គ្លេស) ទំព័រ ៦៨ (បារាំង) ទំព័រ ១០៤-១០៥ (ខ្មែរ)។ <u>មូលដ្ឋានទី ២១៧៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងពេល នៃការបោសសម្អាត* កថាខណ្ឌ ១៨៥៧-១៨៧៨។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៣-៧៤ (អង់គ្លេស) ទំព័រ ៦៨ (បារាំង) ទំព័រ ១០៥ (ខ្មែរ)។ <u>មូលដ្ឋានទី ២៣៥៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស និង ការបោសសម្អាត* កថាខណ្ឌ ២០៥៣-២០៦១។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៨ (អង់គ្លេស) ទំព័រ ៧៣ (បារាំង) ទំព័រ ១១២-១១៣ (ខ្មែរ)។

[4312] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៥។ *សូមមើលផងដែរ* ផ្អែក VIII.គ.៣. ចេតនា។

[4313] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៣-៤២៨៧, ៤៣០៦។

[4314] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៩។

ស្អប់ខ្ពើមពួកគេ[4315]។ គាត់បានធ្វើដូច្នេះនៅពេលគាត់បានដឹងច្បាស់ថា ឧក្រិដ្ឋកម្មកំពុងត្រូវបានធ្វើឡើងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានានៅទូទាំងប្រទេស។ ចេតនារបស់គាត់ដែលថា ឧក្រិដ្ឋកម្មទាំងអស់នេះត្រូវបានប្រព្រឹត្តឡើង ត្រូវបានបង្ហាញបន្ថែមទៀតដោយអង្គហេតុដែលថា គាត់មានលទ្ធភាព "ក្នុងការរារាំងការប្រព្រឹត្តដ៏ឃោរឃៅ និងការកាប់សម្លាប់ជនរួមជាតិខ្លួន" និង "ជ្រើសរើសប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ដើម្បីទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម" នៅពេលដែលសមស្របតាមផលប្រយោជន៍ផ្ទាល់ខ្លួនគាត់[4316] ប៉ុន្តែ មិនបានចាត់វិធានការជាបន្តបន្ទាប់នៅពេលណាមួយផ្សេងទៀត ដើម្បីអន្តរាគមន៍ក្នុងអំពើឃោរឃៅ ដែលកំពុងកើតឡើងចំពោះប្រជាជនកម្ពុជាទេ។

## ***<u>ការបោសសម្អាតផ្ទៃក្នុង</u>***

### *ការបោសសម្អាតនៅថ្នាក់ខ្ពស់*

1187. ម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុស ដោយការពឹងផ្អែកលើ និងការបំភ្លៃចម្លើយមុនរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងការបញ្ជាក់ពីការដឹងរបស់គាត់អំពីការបោសសម្អាតកម្មាភិបាលថ្នាក់ខ្ពស់នៅពេលទាំងនោះ[4317]។ អ.ជ.ត.ក បានបញ្ជាក់ថា អ.ជ.ស.ដ អាចពឹងផ្អែកលើការដឹងក្រោយអង្គហេតុ ធ្វើជាធាតុផ្សំ នៅពេលកំណត់ថាតើ ម្ចាស់បណ្តឹងសាទុក្ខមានចេតនាដែលជាលក្ខខណ្ឌតម្រូវ នៅពេលឧក្រិដ្ឋកម្មកើតឡើងឬទេ[4318] ដូចដែលខ្លួនបានអនុវត្តនៅក្នុងករណីនេះ។ លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានបំភ្លៃការលើកឡើងរបស់គាត់។ គាត់អះអាងមិនពិតពីការដឹងរបស់គាត់អំពី "ការបាត់ខ្លួន" សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ មិនបានបង្ហាញពីការដឹងរបស់អំពីការបោសសម្អាតសមាជិកទាំងនោះទេ[4319] ទោះបីជាយ៉ាងណា គាត់បានទទួលស្គាល់យ៉ាងច្បាស់ពីមុនមកថា នៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ ពាក្យថា "បាត់ខ្លួន" កម្មាភិបាលជាន់ខ្ពស់ មានន័យស្មើទៅនឹង

---

[4315] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៤, ២២៧, ២២៨, ២២៩, ២៣០ &២៣១។

[4316] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៦។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣២-៤២៣៤ (ម្ចាស់បណ្តឹងសាទុក្ខបានធានាលើការដោះលែងបង(ប្អូន)ថ្លៃស្រីរបស់គាត់ពីមន្ទីរសន្តិសុខមួយនៅភូមិភាគឧត្តរ)។

[4317] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៥៨-១៨៦១, ១៨៦៥។ *សូមមើលផងដែរ* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១០។

[4318] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៨២។

[4319] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៥៨, ១៨៦០។

"ការចាប់ខ្លួន"[4320]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានទទួលស្គាល់ផងដែរថា គាត់បានដឹងថា អ្នកដែលគេចាត់ទុកថាជាភ្នាក់ងារវៀតណាម ត្រូវបានបោសសម្អាតចេញពីគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយបានអះអាងថា តាមយោបល់របស់គាត់ "ពាក់កណ្តាល [នៃគណៈកម្មាធិការអចិន្ត្រៃយ៍]" ត្រូវបានបោសសម្អាតនោះ តាមពិតសំដៅទៅលើ "ភ្នាក់ងារវៀតណាម" ដែល "បង្កប់នៅក្នុងជួរគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍"[4321]។ ភស្តុតាងដែលបានយោងដោយម្ចាស់បណ្តឹងសាទុក្ខបានបញ្ជាក់បន្ថែមទៀតលើការដឹងរបស់គាត់ ដោយកត់សម្គាល់ថា "យើងដោះស្រាយពួកនេះបានជាមូលដ្ឋាន"[4322]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនឯកភាពជាមួយនឹងការវិភាគភស្តុតាងរបស់ អ.ជ.ស.ដ ទេ។ គាត់ខកខានមិនបានផ្តល់ភស្តុតាងបញ្ជាក់ថា ការសន្និដ្ឋាននោះគឺជាការសន្និដ្ឋានដែលមិនមានអ្នកវិនិច្ឆ័យអង្គហេតុណាអាចធ្វើបាន ផ្អែកលើការវាយតម្លៃភស្តុតាងទាំងមូល មិនមែនការវាយតម្លៃតែមួយផ្នែកនៃភស្តុតាងនោះទេ[4323]។

1188. ម្ចាស់បណ្តឹងសាទុក្ខមិនឯកភាពទៅនឹងការវាយតម្លៃរបស់ អ.ជ.ស.ដ លើភស្តុតាង ដែលបង្ហាញថា គាត់បានដឹងថា ឌឿន ត្រូវបានបោសសម្អាត[4324]។ ដូចបានរៀបរាប់លម្អិតនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ១៩២ អ.ជ.ស.ដ ពឹងផ្អែកជាច្រើនលើការបង្ហាញពីការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការចាប់ខ្លួន និងការសម្លាប់ ឌឿន[4325]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងថា ឌឿន ត្រូវបានបោសសម្អាត ដោយសារតែម្ចាស់បណ្តឹងសាទុក្ខនៅតែជាសមាជិកម្នាក់ក្នុងចំណោមសមាជិកដ៏តិចតួចនៃមន្ទីរ ៨៧០[4326] សេចក្តីសម្រេចស្តីពីការចាប់ខ្លួនបានធ្វើឡើងដោយគណៈកម្មាធិការពាណិជ្ជកម្ម ដើម្បីបោសសម្អាត "ពួកខ្មៅមួយចំនួនពីក្រសួងចេញ" នៅពេលនោះ[4327] ហើយរបាយការណ៍លែងត្រូវបានបញ្ជូនទៅ ឌឿន ទៀតហើយ ប៉ុន្តែ

---

[4320] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩២។

[4321] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦០។

[4322] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២១។

[4323] *សូមមើល* បទដ្ឋាននៃការពិនិត្យមើលឡើងវិញ (កំហុសផ្នែកអង្គហេតុ)។

[4324] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦២-១៨៦៣។

[4325] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩២។

[4326] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥។

[4327] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥ *យោង* ឯកសារ **E3/962** សេចក្តីសំរេចរបស់គណៈក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦ KH 00068577។ ឯកសារ **E3/174** សេចក្តីសំរេចរបស់គណៈក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦ KH 00068728។ ឯកសារ **E3/846** របាយការណ៍របស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦ KH 00021305-08។

បញ្ជូនមកម្ចាស់បណ្ដឹងសាទុក្ខវិញ[4328] ដោយហេតុថា ម្ចាស់បណ្ដឹងសាទុក្ខទទួលរ៉ាប់រង មុខនាទីត្រួតពិនិត្យនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម ក្នុងពេលអវត្តមានរបស់ ឌឿន[4329]។ ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខថា គាត់មិនបានភ្ញាក់ផ្អើលអំពីអវត្តមានរបស់ ឌឿន ចាប់ពីឆ្នាំ១៩៧៧ នោះទេ ដោយហេតុថា គាត់ "ធ្វើដំណើរច្រើន" នៅពេលមួយដែលម្ចាស់បណ្ដឹងសាទុក្ខ បានដឹងថា កម្មាភិបាលជាន់ខ្ពស់កំពុងត្រូវបានចាប់ខ្លួន "ម្ដងមួយៗ"[4330] មិនមានភាពអាចជឿជាក់បាន និងត្រូវបាន អ.ជ.ស.ដ បដិសេធចោលយ៉ាងត្រឹមត្រូវ[4331]។

1189. ទាក់ទងនឹងការដឹងរបស់គាត់អំពី ចាន់ ចក្រី, ឈូក, កែវ មាស និង កុយ ធួន ម្ចាស់បណ្ដឹងសាទុក្ខលើកការចោទប្រកាន់របស់ឡើងវិញថា អ.ជ.ស.ដ មានកំហុស ដោយពឹងផ្អែកលើសក្ខីកម្មមិនស៊ីសង្វាក់គ្នាដែលចោទប្រកាន់ អែម អឿន[4332]។ ទោះជាយ៉ាងណា ដូចបានបង្ហាញនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២២ អ.ជ.ស.ដ បានពិចារណាយ៉ាងត្រឹមត្រូវលើសក្ខីកម្មរបស់ អែម អឿន ថាអាចជឿជាក់បាន[4333]។ លើសពីនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថាតើ អ.ជ.ស.ដ បានធ្វើ "សេចក្ដីសន្និដ្ឋានដាច់ខាត" ដោយរបៀបណា ក្នុងការសន្និដ្ឋានថាម្ចាស់បណ្ដឹងសាទុក្ខបានអានទស្សនាវដ្ដី *ទង់បដិវត្តន៍* ដែលបានយោងទៅលើការបោសសម្អាតទាំងអស់នេះ[4334]។ មិនត្រឹមតែ *ទង់បដិវត្តន៍* នោះទេដែលបានបោះពុម្ព និងបញ្ជូនទៅក្រសួង និងមន្ទីរនានារបស់កម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈិមបក្ស ថែមទាំងបានសរសេរដោយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ផង[4335]។ ជាចុងក្រោយ ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងជាថ្មីម្ដងទៀតថា អ.ជ.ស.ដ មានកំហុសក្នុងការពឹងផ្អែកលើសៀវភៅរបស់ម្ចាស់បណ្ដឹងសាទុក្ខ[4336] ដើម្បី

[4328] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៦១៨ ជើងទំព័រ ១៩៥១។

[4329] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥។

[4330] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥, ៤២២០ *យោង* ឯកសារ **E3/210** កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156689-91។

[4331] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៥ *យោង* ឯកសារ **E3/37** កំណត់ហេតុសួរ ចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156675។

[4332] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៦៤។

[4333] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២ និង ២០៤។

[4334] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៦៥។

[4335] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៧៤-៤៧៥។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៣។

[4336] ឯកសារ **E3/16** ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា* KH 00380221។

បង្ហាញពីការដឹងរបស់គាត់អំពីការបោសសម្អាត[4337]។ ផ្ទុយទៅនឹងអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានប្រុងប្រយ័ត្នការពឹងផ្អែករបស់ខ្លួនលើសៀវភៅរបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយបានកត់សម្គាល់ថា ខ្លួនបានពិចារណាលើសៀវភៅនេះ "ក្នុងកម្រិតកំណត់មួយ" ដោយសារការយោងរបស់វាទៅស្នាដៃរបស់អ្នកនិពន្ធផ្សេងទៀត[4338]។ អ.ជ.ស.ដ ក៏បានពឹងផ្អែកលើភ័ស្តុតាងបន្ថែមទៀតមកពី អែម អឿន ដែលបានផ្តល់សក្ខីកម្មថា ម្ចាស់បណ្តឹងសាទុក្ខបានបរិហារ ចាន់ ចក្រី នៅក្នុងវគ្គសិក្សាមួយ[4339] និងការទទួលស្គាល់ពីម្ចាស់បណ្តឹងសាទុក្ខថា ចាន់ ចក្រី និង ឈូក ត្រូវបានចាប់ខ្លួន ក្រោយមានសេចក្តីសម្រេចមួយរបស់ ប៉ុល ពត[4340]។

1190. ទាក់ទងនឹងការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីការចាប់ខ្លួន និងការសម្លាប់ ហ៊ូ នឹម អ.ជ.ស.ដ បានពិចារណាលើលិខិតមួយ ដែលសរសេរដោយ ហ៊ូ នឹម ផ្ញើទៅកាន់ម្ចាស់បណ្តឹងសាទុក្ខ។ ផ្ទុយទៅនឹងអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4341] អ.ជ.ស.ដ បានទទួលស្គាល់ថា វាមិនច្បាស់ទេថាតើ ម្ចាស់បណ្តឹងសាទុក្ខបានទទួលលិខិតនោះឬអត់[4342]។ ប៉ុន្តែ អ.ជ.ស.ដ ក៏បានពិចារណាលើទំនាក់ទំនងជិតស្និទ្ធរបស់ម្ចាស់បណ្តឹងសាទុក្ខជាមួយនឹង ហ៊ូ នឹម និង ចម្លើយរបស់ម្ចាស់បណ្តឹងសាទុក្ខទៅកាន់ ស.ច.ស ទាក់ទងនឹងការសម្លាប់ ហ៊ូ នឹម[4343]។ ការដកស្រង់បំភាន់របស់ម្ចាស់បណ្តឹងសាទុក្ខលើផ្នែកជាក់លាក់នៃចម្លើយនេះ តែមិនបានធ្វើឱ្យប៉ះពាល់ដល់ការសន្និដ្ឋានដែលថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងថា ហ៊ូ នឹម ត្រូវបានសម្លាប់ ក្រោយពេលបង្ហាញការជំទាស់ទៅនឹងគោលនយោបាយរបស់ ប.ក.ក[4344]។ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខអះអាងថា ចម្លើយនេះមានទម្ងន់តិចតួច ដោយហេតុថា វាធ្វើឡើងនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[4345]

---

[4337] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦៥។

[4338] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៩៥។

[4339] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៦។

[4340] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៦។

[4341] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦៦។

[4342] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៧។

[4343] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៧។

[4344] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៧ *យោង* ឯកសារ **E3/37** កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156678 (ម្ចាស់បណ្តឹងសាទុក្ខបានថ្លែងថាគាត់ "មិនអាចបង្ហាញការមិនយល់ស្របរបស់យើង [ជាមួយនឹងសេចក្តីសម្រេចនានារបស់ ប.ក.ក] ជាសាធារណនោះទេ [...] ខ្ញុំមិនអាចនៅរស់រានមានជីវិតបានទេ ប្រសិនបើខ្ញុំហ៊ាន [...] ឧទាហរណ៍ របស់ ហ៊ូ នឹម ជាភ័ស្តុតាងស្រាប់")។

[4345] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៦៦។

ចម្លើយនេះបង្ហាញយ៉ាងច្បាស់ពីជំនឿរបស់ម្ចាស់បណ្ដឹងសាទុក្ខនៅពេលនៃឧក្រិដ្ឋកម្មនោះថា ប្រសិនបើគាត់និយាយប្រឆាំងនឹងបក្ស គាត់នឹងត្រូវគេសម្លាប់ដូច ហ៊ូ នឹម ដែរ។

1191. ចំពោះការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីការបោសសម្អាត ជូ ជេត, វន វ៉េត, សោ ភឹម និង រឹង ឆែម[4346] អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ភ័ស្តុតាងចចាមអារាមត្រូវបានបញ្ជាក់គាំទ្រ ដោយការទទួលស្គាល់ដាច់ដោយឡែកពីគ្នារបស់ម្ចាស់បណ្ដឹងសាទុក្ខផ្ទាល់ ជាមួយ Stephen Heder, អ៊ា ម៉េងទ្រី, និង លឿង សុភ័ក្ត ថា គាត់បានដឹងថា វន វ៉េត, សោ ភឹម និង ជូ ជេត ទាំងអស់គ្នាត្រូវបានចាត់ទុកថាជាខ្មាំងវៀតណាមដោយ ប.ក.ក[4347]។ ម្ចាស់បណ្ដឹងសាទុក្ខព្យាយាមបំភ្លៃការសន្និដ្ឋានរបស់ អ.ជ.ស.ដ ដោយលើកឡើងថា វន វ៉េត ត្រូវបានចាប់ខ្លួន*ក្រោយ* សន្និបាតបក្សលើកទីប្រាំ ហេតុដូច្នេះ ម្ចាស់បណ្ដឹងសាទុក្ខមិនបានមានវត្តមាននៅពេលចាប់នេះទេ[4348]។ ម្ចាស់បណ្ដឹងសាទុក្ខដកស្រង់ភ័ស្តុតាងពី កែ ពក ដូចគ្នានឹង អ.ជ.ស.ដ ថា ការចាប់ខ្លួនបានកើតឡើងនៅពេលព្រឹក ខណៈពេលដែល "បញ្ចប់មហាសន្និបាត"[4349]។ គាត់បានមើលរំលងការពន្យល់របស់ កែ ពក ថា មូលហេតុដែលគាត់ត្រូវបានស្នើសុំឱ្យស្នាក់នៅ ក្រោយពេលការប្រជុំសភាបិទបញ្ចប់ គឺដើម្បីទស្សនាខ្សែវីដេអូអំពីការចាប់ខ្លួន ដូច្នេះបានកើតឡើងមុនពេលនោះ។ គាត់ក៏បានអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មិនអាចប្រើចម្លើយរបស់ ឌុច ដែលថា កែ ពក បានប្រាប់គាត់អំពីរឿងនេះទេ[4350]។ ទោះជាយ៉ាងណា ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ បានបំភ្លៃភ័ស្តុតាងរបស់ កែ ពក[4351] ឬថា អង្គជំនុំជម្រះបានទៅហួសឆ្ងាយវិសាលភាពដ៏ទូលំទូលាយដែលផ្ដល់ឱ្យខ្លួនក្នុងការពិចារណា និងពឹងផ្អែកលើភ័ស្តុតាងចចាមអារាម[4352]។

*ការបោសសម្អាតនៅថ្នាក់ទាប*

[4346] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៨-៤២៣០។

[4347] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៨-៤២២៩។

[4348] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៧០។

[4349] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៧០។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២១ ជើងទំព័រ ៧៨៤៨។

[4350] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២១ ជើងទំព័រ ៧៨៤៧។

[4351] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៧០។

[4352] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣២ (ភ័ស្តុតាងចចាមអារាម)។

1192. អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹងអំពីការបោសសម្អាតកម្មាភិបាលថ្នាក់ទាប ក៏បរាជ័យផងដែរ។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4353] ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងពីការបោសសម្អាតកម្មាភិបាលថ្នាក់ទាប និងលក្ខខណ្ឌរស់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺផ្អែកលើភ័ស្តុតាងជាច្រើន មិនមែនសក្ខីកម្មរបស់ មាស វឿន ទេ[4354]។ អ.ជ.ស.ដ ក៏មិនមានកំហុសដោយការយោងទៅអំពើដែលបានកើតឡើងនៅខេត្តព្រះវិហារនោះទេ[4355]។

1193. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខលើកឡើងម្តងទៀតពីអំណះអំណាងរបស់គាត់ថា អ.ជ.ស.ដ មានកំហុសដោយការផ្អែកលើចម្លើយដែលគាត់ធ្វើឡើងដោយគ្មានកាលបរិច្ឆេទ និងយោងតែផ្នែកជាក់លាក់នៃចម្លើយនោះ[4356]។ ទោះជាយ៉ាងណា ជាការសន្មត អ.ជ.ស.ដ បានវាយតម្លៃ និងថ្លឹងថ្លែងលើភ័ស្តុតាងទាំងអស់ដែលបានបង្ហាញ មិនមានការបញ្ជាក់ណាមួយថា ផ្នែកជាក់លាក់មួយនៃភ័ស្តុតាងត្រូវបានមើលរំលងទាំងស្រុងនោះទេ[4357]។ ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានមិនបានបដិសេធសច្ចធារណ៍នៃយថាភូត *ជាបឋម* នៃឯកសារទាំងអស់នេះផងដែរ[4358]។

1194. នៅក្នុងការសន្និដ្ឋានលើការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានផ្អែកលើប្រភពដែលបានថ្លឹងថ្លែងត្រឹមត្រូវជាច្រើន។ ជាពិសេស ភ័ស្តុតាងនេះរួមមានទាំងការសារភាពដោយផ្ទាល់របស់ម្ចាស់បណ្តឹងសាទុក្ខថា "យើងតាមដាន" នៅពេលត្រួតពិនិត្យការចាប់ខ្លួន ដូច្នេះ អ្នករាល់គ្នាដែលត្រូវបានសម្លាប់ គឺជាជនក្បត់[4359] "យើងខ្ញុំដោះស្រាយពួកនេះបានជាមូលដ្ឋាន"[4360] និងការដឹងរបស់គាត់អំពីវិធីដែល ប៉ុល ពត ចាប់កម្មាភិបាល។

## <u>មន្ទីរសន្តិសុខ</u>

---

[4353] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៧៤, ១៨៧៨។

[4354] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[4355] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៦, ៤២៣២, ៤២៣៤។

[4356] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៧៥-១៨៧៦។

[4357] *សូមមើល* បទដ្ឋាននៃការពិនិត្យមើលឡើងវិញ (កំហុសផ្នែកអង្គហេតុ)។

[4358] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧៥។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ៣៦។

[4359] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២១, ៤២២៨ *យោង* ឯកសារ **E3/3169** Stephen Heder *ប៉ុល ពត និង ខៀវ សំផន* ឆ្នាំ១៩៩១ ទំព័រ ៥០-៥៤ KH 00711412-16។

[4360] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២១ *យោង* ឯកសារ **E3/203** ខៀវ សំផន សម្ភាស ដោយ Stephen Heder ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៨០ KH 00385409-10។

1195. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងភ័ស្តុតាងដែលថា គាត់មិនដឹងអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅតាមមន្ទីរសន្តិសុខដូចដែលគាត់បានចោទប្រកាន់នោះ[4361] គាត់យល់ច្រឡំអំពី *ធាតុផ្សំអត្តនោម័តិ* ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម និងការជួយ និងជំរុញ។ *ធាតុផ្សំអត្តនោម័តិ* សម្រាប់ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម មិនតម្រូវ ឱ្យមានការដឹងអំពីហេតុការណ៍ឧក្រិដ្ឋជាក់លាក់ណាមួយទេ[4362] ហើយ អ.ជ.ស.ដ ក៏មិនបានកំណត់អំពី *ធាតុផ្សំអត្តនោម័តិ* ក្នុងរបៀបនេះដែរ។

1196. ទោះក្នុងករណីណាក៏ដោយ ផ្ទុយពីការអះអាងដោយគ្មានមូលដ្ឋានភាគច្រើនរបស់ម្ចាស់បណ្តឹងសាទុក្ខ[4363] អ.ជ.ស.ដ ពិតជាបានធ្វើការសន្និដ្ឋានដែលមានហេតុផល ដែលសន្និដ្ឋានថា យើងគ្មានមន្ទិលទេថា ម្ចាស់បណ្តឹងសាទុក្ខ ពិតជាដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខនានា។ ឧទាហរណ៍ ទាក់ទងនឹង ស-២១ អ.ជ.ស.ដ បានសន្និដ្ឋានថា *មានជាអាទិ៍* ម្ចាស់បណ្តឹងសាទុក្ខ គួរតែបានដឹងអំពី ស-២១ អាស្រ័យដោយគោលជំហរពិសេសប្លែកពីគេរបស់គាត់ នៅក្នុងបក្ស ជាផ្នែកនៃក្រុមតូចមួយនៃមេដឹកនាំ ប.ក.ក ដ៏ល្បីល្បាញនៅមជ្ឈិមបក្ស[4364]។ ម្ចាស់បណ្តឹងសាទុក្ខបានជួប ឌុច និងបានណែនាំគាត់ថា បុគ្គលិក ស-២១ ត្រូវបន្តធ្វើការជាធម្មតាក្នុងពេលប្រឈមមុខជាមួយវៀតណាម ដែលកំពុងរុលចូលក្នុងទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ[4365]។

---

[4361] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៩-១៨៥៦ (ជាឧទាហរណ៍ "ដោយសារគ្មានការដឹងឮអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មនៅ ស-២១ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា "ខៀវ សំផន បានដឹងឮគ្រប់ពេលពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយចារីផ្ទាល់"នោះ គួរត្រូវបានទុកជាមោឃៈ (កថាខណ្ឌ ១៨៥៣), "ប៉ុន្តែ អង្គជំនុំជម្រះមិនធ្លាប់បានបង្ហាញថា ខៀវ សំផន បានដឹងឮអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះទេ [...] ដូច្នេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញពីចេតនាដោយផ្ទាល់ណាមួយ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដូចបានបង្ហាញនៅខាងលើឡើយ" (កថាខណ្ឌ ១៨៥៣)។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៦, ៥៧២-៥៧៣, ៤២០៧, ៤២៥៧។

[4362] *សូមមើល* វាក្យខណ្ឌ **VIII**.គ.៣ ចេតនា។

[4363] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៩-១៨៥៦។ *សូមមើលផងដែរ* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦១០-១៦១៥។

[4364] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០, ២៣៧៣។ *សូមមើលផងដែរ* កថាខណ្ឌ ៤២៣០ (ការចាប់ខ្លួន និងសម្លាប់ ភួង នៅ ស-២១), ៤២៧៧ (តួនាទីក្នុងការចាប់ខ្លួន និងសម្លាប់ កង ចាប)។

[4365] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០, ២៣៧៣, ២៥៥៧, ២៥៥៨។

អ.ជ.ស.ដ ក៏បានបង្ហាញយ៉ាងសមហេតុផលផងដែរថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងថា ពួកកាហ្សេបេ កំពុងតែប្រព្រឹត្តប្រឆាំងនឹងអ្នកទោសវៀតណាមនៅទីនោះ[4366]។

1197. ចំពោះមន្ទីរសន្តិសុខក្រាំងតាចាន់ អ.ជ.ស.ដ បានសន្និដ្ឋានថា *ជាអាទិ៍* របាយការណ៍អំពីការស្លាប់ត្រូវបានបញ្ជូនទៅថ្នាក់លើនៃខ្សែសង្វាក់នៃការបញ្ជាទៅ *"បក្ស"*[4367] និងថា ស្រុកត្រាំកក់ (ជាស្រុកដែលមន្ទីរសន្តិសុខក្រាំងតាចាន់ស្ថិតនៅ) ត្រូវបានផ្តល់ "ទង់ក្រហមកិត្តិយសរបស់គណៈកម្មាធិការមជ្ឈិម" ជាស្រុកគំរូ ដោយគណៈកម្មាធិការមជ្ឈិម[4368] និងថា ម្ចាស់បណ្តឹងសាទុក្ខ ទំនងជាបានចុះមកស្រុកនេះជាមួយ តាម៉ុក[4369] ដែលគេដឹងថា បានចុះមកពិនិត្យមើលមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយត្រូវបាន "គេជូនដំណឹងអំពីប្រតិបត្តិការរបស់កន្លែងនេះ"[4370]។ ទាក់ទងនឹងអ្នករកន្សែង អ.ជ.ស.ដ បានសន្និដ្ឋានថា របាយការណ៍ស្តីពីដំណើរការបោសសម្អាតផ្ទៃក្នុង នៅទូទាំងភូមិភាគទាំងមូល និងនៅក្នុងជួរកងពល ៨០១ ត្រូវបានបញ្ជូនទៅមជ្ឈិមបក្សដោយផ្ទាល់[4371]។

1198. ស្រដៀងគ្នានេះ អ.ជ.ស.ដ បានសន្និដ្ឋានថា មន្ទីរសន្តិសុខភ្នំក្រោល បានធ្វើប្រតិបត្តិការនៅក្រោមការត្រួតត្រារបស់តំបន់ ដែលបានរាយការណ៍ដោយផ្ទាល់ជូនមជ្ឈិមបក្សដែលស្ថិតនៅឯមន្ទីរ ៨៧០ ដែលម្ចាស់បណ្តឹងសាទុក្ខគឺជាសមាជិក[4372]។ លើសពីនេះទៀត អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មថា "ថ្នាក់តំបន់មិនមានសិទ្ធិអំណាចក្នុងការបញ្ជាឱ្យចាប់ខ្លួននោះទេ។ សេចក្តីសម្រេចលើការចាប់ខ្លួន

---

[4366] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤១។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៤០, ៤២៣៩។

[4367] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨៦០ ជើងទំព័រ ២៥៦០ *យោង* ឯកសារ **E3/2924** កំណត់ហេតុស្រុកត្រាំកក់ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៧ KH 00082726, 2814 (ទាក់ទងនឹង "បញ្ជាឱ្យកម្ទេចពីតំបន់ និងស្រុក")។ **E1/274.1** នាង អ៊ិច ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.09.50-09.12.13, ទំព័រ ៣ បន្ទាត់ ២១-២២។

[4368] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២៦។

[4369] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៣៧។

[4370] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧០៨-២៧០៩។ ឯកសារ **E3/4626** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម KH 00373469-70 *បញ្ជាក់អះអាងដោយ* ឯកសារ **E1/290.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៥ ម៉ោង 14.23.02-14.30.05, ទំព័រ ៤១ បន្ទាត់ ១៩-ទំព័រ ៤២ បន្ទាត់ ៤។

[4371] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៨៨៥។

[4372] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៨៧, ៤៨៩, ៣០២៨-៣០២៩, ៣០៣១, ៣០៣៤-៣០៤៧, ៣០៦៥, ៣០៧៦-៣០៨០, ៣១៦២។

និងឃុំខ្លួនស្ថិតនៅលើមជ្ឈិមបក្ស"[4373]។ ម្ចាស់បណ្ដឹងសាទុក្ខចោទប្រកាន់នៅក្នុង ឧបសម្ព័ន្ធ ក ថា អ.ជ.ស.ដ បានបំភ្លៃភ័ស្តុតាង ដើម្បីបង្ហាញដោយមិនត្រឹមត្រូវអំពីការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំក្រោល តាមរយៈការសន្និដ្ឋានជាទូទៅរបស់ខ្លួនទាក់ទងនឹងការ បោសសម្អាត[4374] ប៉ុន្តែខកខានមិនបានបញ្ជាក់គាំទ្រទៅលើទឡ្ហីករណ៍របស់គាត់បន្ថែមទៀត នៅក្នុង សារណារបស់គាត់ និងមិនបានពន្យល់ពីអ្វីដែលជាភ័ស្តុតាងដែល អ.ជ.ស.ដ បាន "បំភ្លៃ"[4375]។

## v. ចេតនាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនៅតាមសហករណ៍ និងការដ្ឋាន

### *មូលដ្ឋានទី ២៣៤៖ សហករណ៍ និងការដ្ឋាន*[4376]

1199. **មូលដ្ឋានទី ២៣៤ គួរត្រូវបានបដិសេធ ដោយសារម្ចាស់បណ្ដឹងសាទុក្ខបរាជ័យមិនបានបង្ហាញឱ្យ ឃើញថា អង្គជំនុំជម្រះ បានប្រព្រឹត្តកំហុសនៅក្នុងការសម្រេចដែលថា គាត់មានចេតនាប្រព្រឹត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ការវាយប្រហារប្រឆាំងនឹងសេចក្ដី ថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំនៅតាមសហករណ៍ និងការដ្ឋាន។**

1200. គោលនយោបាយ ប.ក.ក ក្នុងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន ត្រូវបានរក ឃើញថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4377]។ អង្គជំនុំជម្រះបានពន្យល់យ៉ាងត្រឹមត្រូវអំពីច្បាប់ស្ដីពី *ធាតុផ្សំអត្តនោម័តិ* សម្រាប់សហឧក្រិដ្ឋកម្មរួម[4378] និងផ្អែកលើកំណត់ហេតុភ័ស្តុតាងដ៏ច្រើនសន្ធឹក សន្ធាប់ ដែលរួមមានទាំងការលើកឡើងរបស់ម្ចាស់បណ្ដឹងសាទុក្ខខ្លួនឯងផង បានសន្និដ្ឋានថា គាត់ មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះនៅតាមសហករណ៍ និងការដ្ឋាន ដែលពាក់ព័ន្ធទៅនឹងសំណុំ រឿង ០០២/០២"[4379]។

---

[4373] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០៧៧ ជើងទំព័រ ១០៤០២ *យោង* ឯកសារ **E1/152.1** ផាន វ៉ាន់ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ម៉ោង 09.53.14-09.58.30, ទំព័រ ១៣ បន្ទាត់ ៤-ទំព័រ ១៤ បន្ទាត់ ១៨។

[4374] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៣។

[4375] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៤៩-១៨៥០។

[4376] <u>មូលដ្ឋានទី ២៣៤៖</u> ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *សហករណ៍ និងការដ្ឋាន* កថាខណ្ឌ ២០៣៩-២០៥២។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧៨ (អង់គ្លេស), ទំព័រ ៧៣ (បារាំង), ទំព័រ ១១២ (ខ្មែរ)។

[4377] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១, ១៨៣។

[4378] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៥។

[4379] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១-២១៥។

1201. ម្ចាស់បណ្តឹងសាទុក្ខបានបង្ហាញចេតនារបស់គាត់ក្នុងការចូលរួមប្រព្រឹត្តគោលបំណងរួម តាមរយៈឋានៈខ្ពង់ខ្ពស់របស់គាត់ និងការចូលរួមសំខាន់ៗនៅក្នុងបក្ស ហើយនឹងការគាំទ្រឥតងាករេរបស់គាត់ចំពោះគោលនយោបាយ[4380]។ ក្នុងនាមជាសមាជិកម្នាក់នៃគណៈកម្មាធិការមជ្ឈិម និងជាអ្នកចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដោយទៀងទាត់ ម្ចាស់បណ្តឹងសាទុក្ខគឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលតែពីរបីនាក់ដែលបានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ ប.ក.ក ដែលរួមមាន ការបង្កើត ការតាមដាន និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច ព្រមទាំងការផ្សព្វផ្សាយសេចក្តីណែនាំផ្សេងៗ និងលើកទិសដៅការងារទូទាំងប្រទេស[4381]។ ម្ចាស់បណ្តឹងសាទុក្ខមិនចាប់អារម្មណ៍នឹង "ការផ្លាស់ប្តូរសង្គម"[4382] តាមធម្មតាទេ គាត់ជំរុញជាសាធារណៈ ចំពោះគោលនយោបាយ និងការកំណត់ការងារដែលមានលក្ខណៈមិនប្រាកដនិយម[4383] ដោយអំពាវនាវឱ្យបំពេញឱ្យបាន *"ទោះក្នុងតម្លៃណាក៏ដោយ"*។ តាមការលើកឡើងផ្ទាល់ខ្លួនគាត់ ការសម្រេចបាន "មហាលោតផ្លោះ មហាអស្ចារ្យ" ចាំបាច់ត្រូវដាក់ឱ្យបំពេញការងារ និងការរស់ នៅក្នុងស្ថានភាពលំបាកនេះ[4384]។ ម្ចាស់បណ្តឹងសាទុក្ខបានធ្វើឱ្យមានប្រព័ន្ធឃោរឃៅនេះយ៉ាងសកម្ម តាមរយៈការគ្រប់គ្រងការនាំចេញអង្ករ ដោយដឹងយ៉ាងច្បាស់ថា ប្រជាជនដែលកំពុងត្រូវបានបង្ខំឱ្យធ្វើការ ក្នុងនាមជាគោលនយោបាយ ប.ក.ក កំពុងតែអនុវត្តនៅក្នុងស្ថានភាពលំបាក ខណៈដែលពួកគេកំពុងតែស្លាប់ជាបណ្តើរៗដោយសារតែកង្វះអាហារ និងថ្នាំសង្កូវ[4385]។

1202. ម្ចាស់បណ្តឹងសាទុក្ខមានចេតនាថែមទៀតក្នុងការរើសអើងចំពោះខ្មាំងរបស់បក្ស ដោយមូលហេតុនយោបាយ។ គោលនយោបាយ ប.ក.ក ក្នុងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន មិនមែនធ្វើឡើងដោយសារមូលហេតុសេដ្ឋកិច្ចតែមួយមុខទេ វាក៏មានមុខងារជាមធ្យោបាយមួយក្នុងការអនុវត្តគោលនយោបាយសន្តិសុខ និងសង្គមរបស់ ប.ក.ក ក្នុងការ "ការពារប្រឆាំងនឹងខ្មាំង" និង "ផ្លាស់ប្តូរប្រជាជនយ៉ាងគំហុក"[4386]ផងដែរ។ សហករណ៍បំរើឱ្យ "ការជម្រះបន្តិចម្តងៗនូវ

---

[4380] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៦-២០៧។

[4381] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣។

[4382] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២០៤៣។

[4383] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨២។

[4384] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[4385] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១

[4386] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១។

កាកសំណល់នៃទស្សនៈចក្រពត្តិ សក្តិភូមិ-នាយទុន"[4387] ដូច្នេះហើយ ទើបចាំបាច់ត្រូវមានការបែងចែករវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី[4388]។ អ្នកដែលគេចាត់ទុកថាខ្មាំង និងខ្មាំងពិតប្រាកដនៃ ប.ក.ក "រួមមាន ប្រជាជនថ្មី អតីតអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ ជនក្បត់ អ្នកដែលប្រឆាំងនឹងបដិវត្តន៍ ហើយនឹងអ្នករារាំងបដិវត្តន៍ផ្សេងទៀតដែលគេចាត់ទុកថា មិនអាចបំពេញគោលដៅបដិវត្តន៍" អ្នកទាំងនេះត្រូវបានកំណត់គោលដៅជាប្រព័ន្ធ តាមរយៈប្រព័ន្ធសហករណ៍[4389]។ ម្ចាស់បណ្តឹងសាទុក្ខបានជំរុញការប្រព្រឹត្តិមិនស្មើភាពនេះ តាមរយៈការបើកវគ្គបង្រៀន និងបំពាក់បំប៉ននយោបាយ ដែលបានធ្វើឡើងដើម្បីជីករុករកជនក្បត់ និងខ្មាំង[4390] ហើយគាត់បានសារភាពថា "ការកសាងតាមរយៈការប្រជុំទិតៀន និងស្វ័យទិតៀន គឺជាមូលដ្ឋានគ្រឹះនៃសតិអារម្មណ៍សម្រាប់ការតស៊ូវណ្ណៈ"[4391]។

1203. ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញឱ្យឃើញថា ការសម្រេចប្រកបដោយហេតុផលរបស់ អ.ជ.ស.ដ មានកំហុស ទាក់ទងនឹងចេតនាក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋរបស់គាត់ក្នុងនាមសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំនៅតាមសហករណ៍ និងការដ្ឋាន ដូច្នេះ ការដាក់ពិរុទ្ធ និងការកំណត់ទោសគាត់ចំពោះឧក្រិដ្ឋកម្មទាំងនេះត្រូវតែតម្កល់[4392]។

## *មូលដ្ឋានទី ២១១៖ កំហុសដែលតែងកើតមាននៅគ្រប់ទីកន្លែង*[4393]

[4387] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩១ ជើងទំព័រ ១២៩៩០ *យោង* ឯកសារ E3/729 ទង់បដិវត្តន៍ តុលា ១៩៧៥ KH 00063407-410។ *សូមមើលផងដែរ* កថាខណ្ឌ ៩៨០-៩៨១ និងសេចក្តីយោងនៅខាងក្នុងនោះ។

[4388] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១។

[4389] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៤។

[4390] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៤, ២១១។

[4391] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៦៧។

[4392] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨២, ៤៣០៦, ៤៣២៦-៤៣២៧។

[4393] មូលដ្ឋានទី ២១១៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសដែលតែងកើតមានជាធម្មតានៅគ្រប់ទីកន្លែងទាំងអស់* កថាខណ្ឌ ១៨១៦-១៨៤០។ *សូមមើលផងដែរ* កថាខណ្ឌ ១៦០៤-១៦១៥។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧២ (អង់គ្លេស), ទំព័រ ៦៧ (បារាំង), ទំព័រ ១០២-១០៣ (ខ្មែរ)។

1204. **ម្ចាស់បណ្តឹងសាទុក្ខ បរាជ័យមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសនៅក្នុងការសម្រេចថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ជាផ្នែកមួយនៃគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋាននោះទេ។**

1205. មូលដ្ឋាននេះបរាជ័យ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានប្រព្រឹត្តខុស (i) ដែលសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីអង្គហេតុដែលថា ឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្ត ជាផ្នែកមួយនៃគោលនយោបាយនេះ[4394] (ii) មួលបង្កាច់ភ័ស្តុតាងនៅចំពោះមុខខ្លួន ហើយប្រើអភិក្រមកាត់បន្ថយ ដើម្បីសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខដឹងអំពីឧក្រិដ្ឋកម្ម[4395] (iii) ពឹងផ្អែកលើអង្គហេតុទាក់ទងនឹងលក្ខខណ្ឌនៅតាមសហករណ៍នៅព្រះវិហារ ដែលស្ថិតនៅក្រៅសេចក្តីសន្និដ្ឋានរបស់ អ.ជ.ស.ដ[4396] និង (iv) ពឹងផ្អែកទាំងស្រុងលើសៀវភៅរបស់ម្ចាស់បណ្តឹងសាទុក្ខ[4397] សម្រាប់ធ្វើការសន្និដ្ឋានអំពីការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនថ្មី[4398]។

*អ.ជ.ស.ដ បានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្ម*

1206. ទីមួយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងការសម្រេចរបស់ អ.ជ.ស.ដ អំពីការដឹងរបស់គាត់ចំពោះឧក្រិដ្ឋកម្ម ត្រូវតែបរាជ័យ។ ដូចបានពិភាក្សាខាងលើ[4399] ម្ចាស់បណ្តឹងសាទុក្ខយោងដោយមិនត្រឹមត្រូវទៅលើផ្នែកសន្និដ្ឋានមួយនៃសាលក្រម[4400] ថាមានការសម្រេចទាំងស្រុងរបស់ អ.ជ.ស.ដ អំពីការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4401]។ ម្ចាស់បណ្តឹងសាទុក្ខមិនយកចិត្តទុកដាក់ទៅលើការសម្រេចរបស់ អ.ជ.ស.ដ ទាក់ទងនឹងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មផ្សេងៗនៅក្នុងសាលក្រមទាំងមូល។ ការវាយតម្លៃឱ្យបានត្រឹមត្រូវលើការសម្រេចរបស់ អ.ជ.ស.ដ អំពី

---

[4394] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨១៦-១៨២៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧២។

[4395] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨១៦-១៨២៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧២។

[4396] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨២៩-១៨៣០។

[4397] ឯកសារ **E3/16** ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា* KH 00380347-48។

[4398] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៦-១៨៣៨។

[4399] *សូមមើល* វាក្យខណ្ឌ **VIII**.គ.៣ ចេតនា។

[4400] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ១៨.១.២៖ *ការដឹងឮស្របគ្នានឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម*។

[4401] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨១៦-១៨៤០។

ការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ តម្រូវឱ្យមានការពិចារណាលើសំអាងហេតុរបស់ អ.ជ.ស.ដ *ទាំងមូល*។

1207. ស្រដៀងគ្នានេះ ការអះអាងមិនត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ ខកខានមិនបាន បង្ហាញភ័ស្តុតាងអំពីទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងទីតាំងទាំងនោះ ដោយសារអង្គជំនុំជម្រះមិនបានផ្តល់មូលហេតុផ្សេងៗទៅតាម "ទីតាំងនីមួយៗ"[4402]។ ម្ចាស់បណ្តឹងសាទុក្ខមិនបាន ផ្តល់ប្រភពដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា អ.ជ.ស.ដ គួរតែបង្កើតសំអាងហេតុរបស់ខ្លួនដោយផ្អែកលើរចនាសម្ព័ន្ធ "ទីតាំងនីមួយៗ"[4403]។ នៅក្នុងផ្នែកនៃសាលក្រមដែលគាត់យោង ម្ចាស់បណ្តឹងសាទុក្ខក៏គិតគូរទៅចំណុចថា អ.ជ.ស.ដ បានយោងផ្នែកប្រាំមួយផ្សេងទៀតនៃសាលក្រមដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន រួមទាំង យ៉ាងហោចណាស់ផ្នែកពីរទៀត ដែលនិយាយអំពីទីតាំងឧក្រិដ្ឋកម្មជាក់លាក់[4404]។ លើសពីនេះទៀត អ.ជ.ស.ដ "មិនតម្រូវឱ្យបញ្ជាក់ច្បាស់លាស់គ្រប់ជំហាននៃការផ្តល់សំអាងហេតុរបស់ខ្លួនឱ្យពិស្តារនោះទេ"[4405]។

1208. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសផ្នែកច្បាប់ ដោយសារការខកខានមិនបានបង្ហាញច្បាស់លាស់អំពីទំនាក់ទំនងរវាងខ្លួនគាត់ ទីតាំងឧក្រិដ្ឋកម្ម និងបទឧក្រិដ្ឋ[4406]។ អ.ជ.ស.ដ បានកំណត់យ៉ាងសំខាន់ ហ្មត់ចត់ និងច្បាស់លាស់នូវទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងទីតាំងឧក្រិដ្ឋកម្មជាក់លាក់នីមួយៗ[4407]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា ការសម្រេចរបស់ អ.ជ.ស.ដ "បំពានលើវិធានទាក់ទងនឹងសិទ្ធិលើភ័ស្តុតាង"[4408] ដោយគ្មានការពន្យល់ថាតើវិធានណាដែលត្រូវបានរំលោភនោះទេ។

1209. ផ្ទុយពីការអះអាងរបស់គាត់ដែលថា "គ្មានធាតុផ្សំភវនីយភាព" ដែលបញ្ជាក់អំពីការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ[4409] អ.ជ.ស.ដ បានពឹងផ្អែកលើកត្តា

---

[4402] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤០។

[4403] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤០។ *សូមមើលផងដែរ* កថាខណ្ឌ ១៦០៤-១៦១៥។

[4404] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣៧៤០-១៣៧៤២, ១៣៧៤៤-១៣៧៤៥, ១៣៧៥-១៣៧៥៥, ១៣៧៦៥។

[4405] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ (សេចក្តីសម្រេចដែលមានសំអាងហេតុ)។

[4406] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦០៤-១៦១៥, ១៨៤០។

[4407] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១២, ២១៣, ២១៤, ២១៥។

[4408] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៩។

[4409] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៨-១៨៤០។

ជាច្រើនដែលជារួមបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខមានការដឹងនៅពេលនោះអំពីស្ថានភាពរស់នៅតាមសហករណ៍ និងការដ្ឋាន។ ដោយពិចារណាលើ "របបរាយការណ៍ជាប្រព័ន្ធតាមខ្សែបណ្តោយក្នុងជួរ ប.ក.ក"[4410] សក្ខីកម្មរបស់សាក្សី សេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងផ្ទាល់[4411] គោលជំហររបស់គាត់នៅក្នុងបក្ស និងទំនាក់ទំនងជិតស្និទ្ធជាមួយមេដឹកនាំជាន់ខ្ពស់[4412] ការគាំទ្រជាសាធារណៈរបស់គាត់ចំពោះគោលបំណងរួម[4413] និងឯកសារកាលពីជំនាន់ នោះ អ.ជ.ស.ដ ពិតជាបានបង្ហាញយ៉ាងត្រឹមត្រូវអំពីការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងស្ថានភាពរស់នៅតាមសហករណ៍ និងការដ្ឋាន[4414]។

1210. ភស្តុតាងអំពីការដឹងនេះ រួមមាន សេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងផង ដែលបានទទួលស្គាល់ថា ជាទូទៅ ម្ហូបអាហារ "មិនមានច្រើនទេ"[4415] និងថា ប្រជាជននៅតាមសហករណ៍ និងការដ្ឋាន "មិនមានសេរីភាព"[4416] និងថា ស្ថានភាពបានធ្លាក់ចុះ "ពីព្រោះអ្វីៗត្រូវតែឱ្យលឿន" [4417]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានទទួលស្គាល់ផងដែរថា "ឆ្នាំ១៩៧៨ ដោយគ្រោះរាំងស្ងួត ដែលបណ្តាលឱ្យខូចខាតផលដំណាំដ៏សំខាន់ៗ ហើយ [...] សង្គ្រាមជាមួយវៀតណាមក៏កាន់តែរីកខ្លាំងឡើង [...] កម្លាំងយើងមាននៅពេលនោះ គឺមានតែកម្លាំងមនុស្សហ្នឹងឯង"[4418]។ គាត់ផ្តល់សក្ខីកម្ម

[4410] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៩១៣។

[4411] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ១០២២ *យោង* **E3/4049** បទសម្ភាសន៍ជាមួយ ខៀវ សំផន គ្មានកាលបរិច្ឆេទ KH 00780962-63។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ១២៥៤, ៤២១៣, ៤២២១, ៤២១៧ *យោង* ឯកសារ **E3/16** ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា* ទំព័រ ២៣៥-២៣៦ KH 00380469-71 ("នេះជាគោលការណ៍ប្រុងប្រយ័ត្នកុំឱ្យភ្នាក់ងាររបស់ប្រទេសខ្លះ អាចចូលមកស៊ីរូងរដ្ឋអំណាចបដិវត្តន៍កម្ពុជាបាន។ ដូច្នេះត្រូវតែក្តាប់ប្រវត្តិរូបរបស់ម្នាក់ៗ។ ហើយដើម្បីកម្មាភិបាល កសិករ ងាយក្តាប់ប្រវត្តិរូបម្នាក់ៗ វិធីដែលងាយបំផុត គឺការបែងចែកជាប្រជាជនចាស់ ប្រជាជនថ្មី")។

[4412] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២០៨។

[4413] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២៦២។

[4414] *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១ & ១៨៣, ១៨២។

[4415] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២១១ *យោង* **E1/197.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 14.56.04-14.58.09, ទំព័រ ៧០ បន្ទាត់ ២-៦។

[4416] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៨៨៥ ជើងទំព័រ ១២៩៦៦។

[4417] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៨៨៥ ជើងទំព័រ ៤២១១ *យោង* ឯកសារ **E3/4043** បទសម្ភាន៍ជាមួយ ខៀវ សំផន, គ្មានកាលបរិច្ឆេទ KH 00780959។

[4418] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៨៨៥ ជើងទំព័រ ៤២១០ *យោង* **E1/528.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង 10.43.39-10.48.33, ទំព័រ ២៤ បន្ទាត់ ១០-១២។

បន្ថែមថា សហករណ៍ត្រូវបានចាត់តាំងឡើង "ដើម្បីរួមគ្នាប្រយុទ្ធធ្វើស្រែឱ្យបាន *មិនថាមានអ្វីកើតឡើងនោះទេ*"[4419]។ សុន្ទរកថាកាលពីជំនាន់នោះបង្ហាញជាក់ស្ដែងអំពីការដឹងរបស់គាត់ថា "ប្រជាជនទាំងអស់" ធ្វើការ "គ្មានពេលសម្រាក"[4420] ថ្វីត្បិតមានការខ្វះខាតម្ហូបអាហារ ហើយការបង្កបង្កើនផល និងការកសាងមានការកើនឡើងក្ដី[4421]។ បទសម្ភាសន៍នៅក្រោយសម័យកម្ពុជាប្រជាធិបតេយ្យបានបង្ហាញថា គាត់បានដឹងថា "ដូច្នេះ ធ្វើៗទាំងអ្នកឈឺ ទាំងអ្នកជា" រួមទាំង "អ្នកឈឺល្មមៗក៏ធ្វើនឹងគេដែរ"[4422]។ ម្ចាស់បណ្ដឹងសាទុក្ខបានរៀបរាប់ពីរបៀបដែល "ប្រជាជនត្រូវបានបង្ខំឱ្យគ្នាធ្វើ អត់បាយ ដើរខ្លួនឯងមិនរួច ក៏ឱ្យទៅធ្វើទៀត" និងបានសារភាពថា គាត់ទទួលខុសត្រូវក្នុងការទិញថ្នាំសង្កូវពីបរទេស ដើម្បីប្រយុទ្ធប្រឆាំងនឹងកង្វះថ្នាំសង្កូវសម្រាប់ប្រជាជននៅតាមសហករណ៍ និងការដ្ឋាន" [4423]។

1211. ភ័ស្តុតាងផ្សេងទៀតអំពីការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខ រួមមាន ការគាំទ្រជាសាធារណៈរបស់គាត់ចំពោះគោលនយោបាយ ប.ក.ក រួមទាំង "ការរំដោះ" ភ្នំពេញ ការបង្កើត "សហករណ៍ របបហូបចុក ពលកម្មកុមារ និងការដ្ឋានការងារ"[4424] និងការបង្រៀនរបស់គាត់ពីរបៀបកំណត់អត្ត

[4419] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៨៨៥ ជើងទំព័រ ៩២១០ *យោង* **E1/528.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង 10.48.33-10.57.25, ទំព័រ ២៤ បន្ទាត់ ២៣-២៤ (គូសបញ្ជាក់បន្ថែម)។

[4420] *សូមមើលឧទាហរណ៍ដែលបានយោងនៅក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៩០៦-៣៩១៦ រួមទាំងឯកសារ **E3/200** សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292806-08។ ឯកសារ **E3/169** សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ KH 01507853-54។ ឯកសារ **E3/1361** FBIS, *ខួបលើកទី៣ ដែលបានប្រារព្ធឡើងនៅក្នុងកិច្ចប្រជុំមហាជនក្នុងពេលប្រារព្ធខួប នៅថ្ងៃទី១៥ ខែមេសា: សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន* - ១៦ មេសា ១៩៧៨ EN 00168820-21។ ឯកសារ **E3/562** BBC/SWB, ការប្រមូលផ្តុំនៅភ្នំពេញ គូស បញ្ជាក់ខួប ១៧ មេសា, ១៦ មេសា ១៩៧៨ KH 00249989-90។ ឯកសារ **E3/200** SWB BBC, *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292806-08។

[4421] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៩១៦ *យោង* **E3/118** FBIS, សារជ័យជំនះរបស់ ខៀវ សំផន ថ្ងៃទី២១ មេសា ១៩៧៥ KH 00846160-63 (យោង "ប្រជាជនទាំងអស់" លើកទំនប់ ជីកប្រឡាយ និងអាងស្តុកទឹក បង្កបង្កើនផលឱ្យបានពីរដងក្នុងមួយឆ្នាំ "ដោយមិនគិតយប់ឬថ្ងៃ [...] ដោយគ្មានសម្រាក")។

[4422] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៤ *យោង* ឯកសារ **E3/4050** បទសម្ភាន៍ជាមួយ ខៀវ សំផន, គ្មានកាលបរិច្ឆេទ KH 00786553។

[4423] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៤ *យោង* ឯកសារ **E3/4043** បទសម្ភាន៍ជាមួយ ខៀវ សំផន, គ្មានកាលបរិច្ឆេទ KH 00780959-60។

[4424] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៥៩៨។

សញ្ញាណខ្លាំង និងស្រាវជ្រាវជនក្បត់ រួមទាំងប្រជាជនថ្មី និប្រជាជនវៀតណាម[4425]។ ដោយសារមុខតំណែង និងការទទួលខុសត្រូវរបស់គាត់ ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីសេចក្ដីណែនាំផ្សេងៗដែលបានដាក់ទៅលើកម្មករ ទាក់ទងនឹងការកំណត់បរិមាណការងារ ម៉ោង និងលក្ខខណ្ឌការងារ[4426]។ កំណត់សំគាល់មួយក្នុងទង់បដិវត្តន៍ឆ្នាំ ១៩៧៦ បានលើកឡើងថា "ឆ្នាំ៧៦ ប្រជាជនខ្វះខាត យើងថាធម្មតា ឆ្នាំ៧៧ ប្រជាជនខ្វះខាត យើងថាធម្មតា ឆ្នាំ៧៨ ប្រជាជនខ្វះខាត យើងថាធម្មតា"[4427]។ ឯកសារកាលពីជំនាន់នោះបញ្ជាក់ថា ម្ចាស់បណ្ដឹងសាទុក្ខត្រូវបានជូនដំណឹងអំពី "របាយការណ៍ស្ដីពីបរិមាណស្រូវអង្ករដែលបានបញ្ជូនទៅឃ្លាំងរដ្ឋ [...] និងរបាយការណ៍ស្ដីពីការនាំចេញស្រូវអង្ករ និងទំនិញផ្សេងៗទៀត" តាមចំនួនកំណត់[4428]។ អ.ជ.ស.ដ បានសន្និដ្ឋានថា ថ្វីបើ "មានការកំហិតជាក់ស្ដែង" ក្ដី ក៏ ប.ក.ក នៅតែទទូចឱ្យមានទិន្នផលច្រើន ថែមទៀត រួមទាំងការបង្កើនការបង្កបង្កើនផលស្រូវ និងការកសាងទំនប់ ប្រឡាញឱ្យបានច្រើន បន្ថែមទៀត[4429]។ ម្ចាស់បណ្ដឹងសាទុក្ខបានទទួលស្គាល់ថា គាត់មានភារកិច្ចចែកចាយសម្ភារ និងផលិតផលទៅតាមបណ្ដាភូមិភាគ[4430] ហើយ អ.ជ.ស.ដ បានស្ដាប់សក្ខីកម្មដែលបញ្ជាក់ថា ម្ចាស់បណ្ដឹងសាទុក្ខបានចុះពិនិត្យមើលឃ្លាំងផលិតផលសម្រាប់នាំចេញ និងបានប្រជុំជាមួយកម្មករ ជាទីកន្លែងដែលគាត់បានថ្កោលទោស "ពួកដែលខ្ជិលធ្វើការ" ថាជាខ្មាំង[4431]។

---

[4425] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៦០៧, ៣៩៦៧, ៤២២១។ ទោះបីខ្លឹមសារនៃសុន្ទរកថារបស់គាត់ត្រូវបាន "អានឱ្យកត់ត្រាដោយ ប៉ុល ពត"ក្ដី ក៏ម្ចាស់បណ្ដឹងសាទុក្ខ "ជាទូទៅ គាត់យល់ស្របតាមអ្វីដែលគាត់បាននិយាយ"។ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៥៩៨។

[4426] *សូមមើល* វាក្យខណ្ឌ **VIII.ខ.** តួនាទី និង មុខងារ។

[4427] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ១៦៣៨។

[4428] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៦១៩។

[4429] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ១៥១៧ *យោង* ឯកសារ **E3/201** សុន្ទរកថាដោយ ខៀវ សំផន នៅថ្ងៃប្រជុំប្រារព្ធខួប ថ្ងៃទី១៥ មេសា នៅភ្នំពេញ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៧ KH 00292807 (របាយការណ៍អំពី ខៀវ សំផន ដែលបានថ្លែងថា គម្រោងជីកប្រឡាញ និងការដ្ឋានសាងសង់ជាច្រើនកំពុងតែត្រូវបានពន្លឿនយ៉ាងឆាប់រហ័ស និងថា "នៅទូទាំងប្រទេស ការដ្ឋានសាងសង់ទាំងអស់នឹងបំពេញតាមផែនការឆ្នាំ១៩៧៧នៅដំណាច់ខែឧសភានេះ"), ៣៩០៥ *យោង* ឯកសារ **E3/139** *ទង់បដិវត្តន៍* ខែវិច្ឆិកា ១៩៧៦, KH 00064960-61។

[4430] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៦១៩។

[4431] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៦២០ *យោង* ឯកសារ **E1/502.1** ប៊ិត ហឿន ហៅ ប៊ិត ណា ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង 10.06.44-10.49.35 ទំព័ ១៧ បន្ទាត់ ៩-ទំព័ ២៣ បន្ទាត់ ២៣, ម៉ោង 10.50.40-11.00.11, ទំព័ ២៤ បន្ទាត់ ២៥-ទំព័ ២៧ បន្ទាត់ ៤។

1212. ការអះអាងរបស់របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា វត្តមានរបស់គាត់ក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ មិនអាចកំណត់បានអំពីការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មនានានោះ គ្មានមូលដ្ឋានទេ[4432]។ គាត់និយាយបញ្ជាក់ខ្លួនឯងថា "កិច្ចការសំខាន់ៗសុទ្ធតែបានសម្រេចក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍"[4433]។ ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងពេលដែលការអនុវត្តគោលនយោបាយស្តីពីសហករណ៍ និងការដ្ឋាន ត្រូវបានពិភាក្សា និងតាមដាន[4434]។ ជាច្រើនទសវត្សរ៍ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលខុសស្រឡះពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា គាត់គ្មានការដឹងនៅពេលនោះ ម្ចាស់បណ្តឹងសាទុក្ខនៅតែថា គាត់ប្តេជ្ញាបំពេញមុខនាទីរបស់ខ្លួន "ដោយអស់ពីចិត្តពីថ្លើម"[4435] និងបន្តផ្ញើខ្លួនផ្ញើប្រាណជាមួយបក្ស[4436]។

*ការបំភ្លៃភស្តុតាង និងការប្រើប្រាស់សំអាងហេតុកាត់បន្ថយដែលបានចោទប្រកាន់*

1213. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុស ដោយសារពឹងផ្អែកលើសេចក្តីថ្លែងការណ៍ក្រោយកម្ពុជាប្រជាធិបតេយ្យ និងធ្វើការសន្និដ្ឋានទូទៅដោយបំភ្លៃបទសម្ភាសន៍ និងមិនគិតគូរដល់ភស្តុតាងដោះបន្ទុក[4437]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែបានអះអាងថា អ.ជ.ស.ដ ខកខានមិនបានពិចារណាលើភស្តុតាងដែលពាក់ព័ន្ធប៉ុណ្ណោះ ដោយមិនបានបង្ហាញថា គ្មានអ្នកវិនិច្ឆ័យលើអង្គហេតុដែលសមហេតុផល អាចនឹងឈានដល់ការសន្និដ្ឋានដូចគ្នានឹង អ.ជ.ស.ដ នោះទេ[4438]។

---

[4432] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧៤២។

[4433] ឯកសារ **E3/205** សំបុត្រចំហររបស់ ខៀវ សំផន ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ KH 00002795-96 *ដែលបានយោងនៅក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២៣២។

[4434] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤៣១៣។

[4435] ឯកសារ **E3/205** សំបុត្រចំហររបស់ ខៀវ សំផន ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ KH 00002794 *ដែលបានយោងនៅក្នុង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២៣២។

[4436] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២១០ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៣៨៨៥ ជើងទំព័រ ៤២១០ *យោង* **E1/528.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង 10.43.39-10.48.33, ទំព័រ ២៤ បន្ទាត់ ១៥-១៨ (ម្ចាស់បណ្តឹងសាទុក្ខផ្តល់ទិដ្ឋភាពពីអ្វីដែល "មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាសង្ឃឹម" ថានឹងធ្វើបាននៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្កើតសហករណ៍), ៤២២១ *យោង* ឯកសារ **E3/203** បទសម្ភាសន៍ ខៀវ សំផន ជាមួយ Stephen Heder, ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៨០ KH 00385410 ("យើងខ្ញុំ [បក្ស] ដោះស្រាយពួកនេះបានជាមូលដ្ឋាន")។

[4437] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨១៦។

[4438] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ។

1214. ដូចសំណុំរឿង ០០២/០១[4439]ដែរ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដោយសារពឹងផ្អែកលើចម្លើយក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្ហាញភ័ស្តុតាងអំពីការដឹងនៅពេលនោះរបស់ម្ចាស់បណ្តឹងសាទុក្ខនោះ គ្មានមូលដ្ឋានទេ។ បើទោះជាមានការចោទជាបញ្ហាច្រើនចំពោះ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២/០២ ក្នុងការពឹងផ្អែកលើសេចក្តីថ្លែងការណ៍ជាក់លាក់ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យក៏ដោយ[4440] ក៏គាត់នៅតែខកខានមិនបានបង្ហាញឱ្យឃើញថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃ និងប្រើប្រាស់ភ័ស្តុតាងនេះ[4441]។ ជាការសន្និដ្ឋាន អ.ជ.ស.ដ បានវាយតម្លៃ និងថ្លឹងថ្លែងលើភ័ស្តុតាងទាំងអស់ដែលបានបង្ហាញ ដូច្នេះ មិនមានសញ្ញាណអំពីការមិនគិតគូរទាល់តែសោះទៅលើភ័ស្តុតាងណាមួយទេ[4442]។ ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញអំពីសញ្ញាណដូច្នេះទេ ហើយ អ.ជ.ស.ដ មិនមានកាតព្វកិច្ចក្នុងការផ្តល់យុត្តិកម្មពីមូលហេតុដែលអង្គជំនុំជម្រះបដិសេធផ្នែកខ្លះ និងប្រើផ្នែកខ្លះនៃភ័ស្តុតាងឡើយ[4443]។ សេចក្តីថ្លែងការណ៍ដែលរងការជំទាស់នេះ មិនមែនជាភ័ស្តុតាងតែមួយគត់ដែលត្រូវបានពឹងផ្អែកសម្រាប់ការបង្ហាញអំពីការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខប៉ុណ្ណោះទេ ដូចបានពិភាក្សាខាងលើ។

1215. ម្ចាស់បណ្តឹងសាទុក្ខក៏ខកខានផងដែរក្នុងការបង្ហាញឱ្យឃើញថា អ.ជ.ស.ដ បានមិនគិតគូរដល់ភ័ស្តុតាងដោះបន្ទុកដែលមាននៅក្នុងសេចក្តីថ្លែងរបស់គាត់។ អ.ជ.ស.ដ ទទួលស្គាល់ថា ម្ចាស់បណ្តឹងសាទុក្ខបានធ្វើសេចក្តីថ្លែងផ្ទុយគ្នាទាក់ទងនឹងការដឹងរបស់គាត់ និងបានធ្វើការកត់សំគាល់ថា ការអះអាងដែលគាត់ជំទាស់គឺជាភ័ស្តុតាងដោះបន្ទុក[4444]។ លើសពីនេះទៀត សេចក្តីថ្លែងដែលម្ចាស់បណ្តឹងសាទុក្ខអះអាងថា "ត្រូវបានលុបចោលដោយចេតនា" នោះ មិនបានបង្ហាញឱ្យឃើញពីកង្វះការដឹងនៅជំនាន់នោះអំពីឧក្រិដ្ឋកម្មនោះទេ គ្រាន់តែរៀបរាប់យ៉ាងសាមញ្ញអំពីការចង់បាន

---

[4439] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៨២។

[4440] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨១៧-១៨២៧។

[4441] *សូមមើលឧទាហរណ៍* ចម្លើយតបទៅនឹងមូលដ្ឋានទី ២២៧, ២២៨, ២២៩, ២៣០, ២៣១ (ការគាំទ្រ និងការលើកស្ទួយគោលបំណងរួម និងគោលនយោបាយនានា)។

[4442] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ។

[4443] *សូមមើល* បទដ្ឋាននៃការពិនិត្យឡើងវិញ។

[4444] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២១០ ("នៅក្នុងតុលាការ ខៀវ សំផន អះអាងថាគាត់មិនដឹងថា ការកសាងប្រទេសនេះនាំឱ្យមាន "ការបាត់បង់ដីធំធេងដូច្នេះទេ" នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ")។

របស់ម្ចាស់បណ្ដឹងសាទុក្ខឱ្យ "តាមស្វែងរក" ភស្តុតាងស្ដីពីស្ថានភាពមិនល្អនៅក្នុងអំឡុងរបប កម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ[4445]។

1216. ចំពោះសេចក្ដីថ្លែងទាំងពីរដែលម្ចាស់បណ្ដឹងសាទុក្ខអះអាងថា (i) ត្រូវបានធ្វើឡើងក្រោយព្រឹត្តិការណ៍ និង (ii) គ្មានយថាភូត[4446]នោះ ចំណុចសម្រាប់ភាគីដែលជំទាស់នឹងយថាភូតរបស់ឯកសារដែលត្រូវបានសន្មតតាមផ្លូវតុលាការថា យថាភូត *ជាបឋម* ដែលអាចជំទាស់ទៅនឹងសច្ចធារណ៍នេះបាន[4447]។ ម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានបង្ហាញដូច្នេះទេ គាត់គ្រាន់តែបានទាញអំណះអំណាងដដែលៗដែល អ.ជ.ស.ដ បានធ្វើរួចហើយតែប៉ុណ្ណោះ ដែលបានធ្វើការកត់សំគាល់ថាសក្ខីកម្មរបស់ម្ចាស់បណ្ដឹងសាទុក្ខ "ត្រូវមានការប្រុងប្រយ័ត្ន និងពិនិត្យលើភស្តុតាងគាំទ្រផ្សេងទៀត"[4448]។ ម្ចាស់បណ្ដឹងសាទុក្ខជំទាស់ដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ លំអៀង ឬ ស្មានចំពោះការសម្រេចថា ពាក្យសំដីដែលបានប្រើនៅក្នុងសេចក្ដីថ្លែងក្នុងចំណោមសេចក្ដីថ្លែងទាំងនេះថា "បានបង្ហាញពីការដឹងដ៏ទូលំទូលាយរបស់ [ម្ចាស់បណ្ដឹងសាទុក្ខ] ចំពោះស្ថានភាពការងារនៅការដ្ឋាន"[4449]។ គាត់ខកខានមិនបានបង្ហាញថា សេចក្ដីថ្លែងទាំងនេះមានភស្តុតាងដោះបន្ទុកទេ និងទោះជាក្នុងករណីណាក៏ដោយ ចំណុចនេះមិនត្រូវបាន អ.ជ.ស.ដ ពិចារណា ទេ[4450]។

## *ភស្តុតាងពីព្រះវិហារ*

1217. ម្ចាស់បណ្ដឹងសាទុក្ខជំទាស់ទាំងមិនត្រឹមត្រូវថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុស ដោយសារបានពឹងផ្អែកលើអង្គហេតុស្ដីពីលក្ខខណ្ឌនៅសហករណ៍នៅព្រះវិហារដែលស្ថិតនៅក្រៅការសន្និដ្ឋានរបស់អង្គជំនុំជម្រះនេះ[4451]។ អ.ជ.ស.ដ មិនបានពឹងផ្អែកលើសកម្មភាពដែលបានកើតឡើងនៅព្រះវិហារ ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនៅទីនោះ ប៉ុន្តែ អង្គជំនុំជម្រះ គ្រាន់តែបានសន្និដ្ឋានថា សេចក្ដីថ្លែងរបស់ម្ចាស់បណ្ដឹងសាទុក្ខ ទាក់ទងនឹងតំបន់នោះ បញ្ជាក់អំពី "ការដឹងនៅ

---

4445 ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨១៧-១៨១៩។

4446 ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨១៩-១៨២៨។

4447 ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៧៥។

4448 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ១៩៤ (គូសបញ្ជាក់បន្ថែម)។

4449 ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨២០ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១៣៧៥៧។

4450 ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨២១-១៨២៣, ១៨២៥។

4451 ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨២៩-១៨៣០។

ពេលនោះអំពីការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើបាបជនស៊ីវិល” ជាទូទៅ និងបានបង្ហាញពី “ឥទ្ធិពល និងសិទ្ធិអំណាច” របស់គាត់[4452]។

1218. ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងដែលថា ការលើកឡើងរបស់គាត់ត្រូវបានមួលបង្កាច់ ហើយតាមពិតទៅបានបញ្ជាក់ថា គាត់មិនបានដឹងអំពីស្ថានភាពទាំងនោះ[4453] គាត់ខ្លួនឯងនិយាយថា “បានដឹងអំពីការចាប់ខ្លួនដោយចៃដន្យ”[4454] និងជឿថា វាជាការកើតឡើងដាច់ដោយឡែក[4455] ដោយម្ចាស់បណ្តឹងសាទុក្ខនិយាយថា បងប្អូនគាត់ក៏ត្រូវបានចាប់ខ្លួនជាមួយនឹងប្រជាជនផ្សេងទៀតដែរ”[4456] ហើយបានសារភាពថា គាត់បានដឹងរឿងនេះ “នៅពាក់កណ្តាលឆ្នាំ ១៩៧៨” [4457]។ ម្ចាស់បណ្តឹងសាទុក្ខនិយាយថា គាត់បានស្នើសុំរបាយការណ៍អំពីហេតុការណ៍នោះ ហើយ មាស វឿន បានផ្តល់សក្ខីកម្មថា គាត់បានបញ្ជូនរបាយការណ៍តាមសំណើ[4458]។ ទោះបីជាការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ គួរឱ្យជឿក៏ដោយ គាត់មិនបានព្យាយាមធ្វើឱ្យប្រាកដថា មិនមានការប្រព្រឹត្តិការចាប់ចងតាមទំនើងចិត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីគាត់បានដឹងហេតុការណ៍ទាំងនេះក្នុងឆ្នាំ១៩៧៨ នោះ។

### *ការដឹងអំពីការរើសអើងប្រឆាំងនឹងប្រជាជនថ្មី*

1219. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុស ដោយសារបានពឹងផ្អែកលើសៀវភៅរបស់ម្ចាស់បណ្តឹងសាទុក្ខ[4459] ដើម្បីកំណត់អំពីការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនថ្មី[4460]។ ម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថា ផ្ទុយពីការអះអាងរបស់ខ្លួនឯង អ.ជ.ស.ដ បានដឹងច្បាស់ថា សៀវភៅនេះបានពឹងផ្អែក “នៅក្នុងកម្រិតកំណត់មួយប៉ុណ្ណោះ”

---

[4452] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២១៦, ៤២៣២, ៤២៣៤។

[4453] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣១។

[4454] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣១។

[4455] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣២-១៨៣៣។

[4456] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣២។

[4457] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២៣២។

[4458] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២៣៣ *យោង* **E1/130.1** មាស វឿន ប្រតិចារឹក ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 14.04.36 -14.13.35, ទំព័រ ៥៦ បន្ទាត់ ១-ទំព័រ ៥៧ បន្ទាត់ ១១។

[4459] ឯកសារ **E3/16** ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* KH 00380347-48។

[4460] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៦-១៨៣៧។

ដោយសារសេចក្តីយោងរបស់វាទៅនឹងការងាររបស់អ្នកនិពន្ធផ្សេងទៀត[4461]។ បន្ទាប់មកទៀត គាត់ជំទាស់ដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានប្រើ "តែ" សៀវភៅនេះ ដើម្បីស្វែងរកភ័ស្តុតាង មកបញ្ជាក់ថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីការប្រព្រឹត្តិតាមទំនើងចិត្តចំពោះប្រជាជនថ្មី[4462]។ ម្ចាស់បណ្តឹងសាទុក្ខធ្វើមិនដឹងមិនឮចំពោះភ័ស្តុតាងសំខាន់ៗដែល អ.ជ.ស.ដ បានពឹងផ្អែក[4463] រួមទាំងភ័ស្តុតាងបញ្ជាក់ថាគាត់បានលើកទឹកចិត្តឱ្យកម្មាភិបាលចាត់តាំងការងារថែមទៀតដល់ ប្រជាជនថ្មី និងឱ្យដកហូតម្ហូបអាហារពីពួកគេ[4464] និង "បានទទូចឱ្យកម្មាភិបាលកំណត់អត្តសញ្ញាណខ្មាំង [...] ជំរុញឱ្យចងកំហឹង និង "ប្រុងប្រយ័ត្ន" ប្រឆាំងនឹងពួកគេ ហើយបានព្រមានថា ជនក្បត់នឹងត្រូវសម្លាប់"[4465]។

## *មូលដ្ឋានទី ២១២៖ ស្រុកត្រាំកក់*[4466]

1220. **មូលដ្ឋានទី ២១២ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅស្រុកត្រាំកក់ ដែលជាផ្នែកមួយនៃគោលនយោបាយផ្តោតលើការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន។**

1221. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានផ្អែកលើភ័ស្តុតាងមិនគ្រប់គ្រាន់[4467]។ ម្ចាស់បណ្តឹងសាទុក្ខផ្អែកលើអំណះអំណាងមិនត្រឹមត្រូវថា អ.ជ.ស.ដ ត្រូវបានតម្រូវឱ្យយោងទៅលើទីតាំងជាក់លាក់នៅក្នុងស្រុកត្រាំកក់នេះ[4468] នៅក្នុង

---

[4461] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៧ *យោង* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ១៩៥។

[4462] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៣៨។

[4463] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤៣ & ២២១។

[4464] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២៨១។

[4465] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ វាក្យខណ្ឌ ៤២៨៥។

[4466] <u>មូលដ្ឋានទី ២១២៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *សហករណ៍ត្រាំកក់* កថាខណ្ឌ ១៨៤១។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧២ (អង់គ្លេស) ទំព័រ ៦៧ (បារាំង) ទំព័រ ១០៣ (ខ្មែរ)។

[4467] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤១។

[4468] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤១។

ផ្នែកជាក់លាក់មួយនៃសាលក្រម។ ដោយសារតែម្ចាស់បណ្ដឹងសាទុក្ខខកខានមិនបានគាំទ្រមូលដ្ឋានរបស់ខ្លួននេះបន្ថែមទៀត[4469] មូលដ្ឋានគួរបានច្រានចោលភ្លាមៗ។

1222. ទាក់ទងនឹងផ្នែកនៃសាលក្រមដែលរងការជំទាស់ អ.ជ.ស.ដ បានយោងទៅលើភ័ស្តុតាងដែលអង្គជំនុំជម្រះយល់ថា "បង្ហាញអំពីការដឹងដ៏ទូលំទូលាយរបស់គាត់ចំពោះស្ថានភាពការងារនៅឯការដ្ឋានការងារជាច្រើនទៀត"[4470] ក៏ដូចជា ទៅលើការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងសហករណ៍ត្រាំកក់[4471]។ ការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ដែលជាផ្នែកមួយនៃគោលនយោបាយស្ដីពីសហករណ៍ និងការដ្ឋាន ត្រូវបានបង្ហាញតាមរយៈការពឹងផ្អែករបស់ អ.ជ.ស.ដ លើភ័ស្តុតាងជាច្រើន រួមទាំងការទទួលស្គាល់របស់ម្ចាស់បណ្ដឹងសាទុក្ខខ្លួនឯងផ្ទាល់ គោលនយោបាយ និងឯកសាររបស់ ប.ក.ក និងមុខតំណែងពិសេសរបស់ម្ចាស់បណ្ដឹងសាទុក្ខនៅក្នុងបក្ស[4472]។ អ.ជ.ស.ដ ក៏បានសន្និដ្ឋានដែរថា ប្រជាជនស្រុកត្រាំកក់ ត្រូវបាន "ធ្វើឱ្យទៅជាទាសករ ក្នុងគោលបំណងកសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដ៏ធំ [...] ស្របតាមផែនការសេដ្ឋកិច្ចរបស់ ប.ក.ក"[4473] ដោយបានកត់សម្គាល់ពីការយោងរបស់ម្ចាស់បណ្ដឹងសាទុក្ខទៅអង្គហេតុដែលថា គេបាន "ពង្រីកសហករណ៍ទូទាំងប្រទេស [...] លើកទំនប់ ជីកប្រឡាយបង្ហូរទឹកចូលស្រែ"[4474]។

1223. អ.ជ.ស.ដ បានសន្និដ្ឋានជាច្រើន ដែលតាមរយៈការសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះអាចទាញការសន្និដ្ឋានយ៉ាងសមហេតុសមផលអំពីការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីលក្ខខណ្ឌ នៅស្រុកត្រាំកក់ ដែលរួមមាន ខ្សែសង្វាក់នៃការបញ្ជាតាមឋានានុក្រមដែលបានបង្កើតឡើង ដែលតាមរយៈ

[4469] ម្ចាស់បណ្ដឹងសាទុក្ខពឹងផ្អែកលើកថាខណ្ឌ ៤២៨៣-៤២៨៧ នៃសាលក្រមដើម្បីគាំទ្រមូលដ្ឋាននេះ។ ផ្នែកនេះមានចំណងជើងថា *មន្ទីរសន្តិសុខ ទីកន្លែងសម្លាប់មនុស្ស និង ការបោសសម្អាតផ្ទៃក្នុង* ហើយជាទូទៅ វាមិនទាក់ទងនឹងត្រាំកក់ ឬសហករណ៍នានានោះទេ៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨៤១ *លើកឡើងពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៨៣-៤២៨៧។

[4470] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៤ ជើងទំព័រ ១៣៧៥៧។

[4471] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១០-៤២១១ ជើងទំព័រ ១៣៧៤៥, ១៣៧៥២។

[4472] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១ & ១៨៣, ១៨២, ២១១។

[4473] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២២។

[4474] ឯកសារ **E1/528.1** ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង ១០.៤៨.៣៣-១០.៥៧.២៥ ទំព័រ ២៤ បន្ទាត់ ២៥ - ទំព័រ ២៥ បន្ទាត់ ៣។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០៦។

នេះ ព័ត៌មានអំពីលក្ខខណ្ឌនៅត្រាំកក់ត្រូវបានផ្តល់ជូនទៅបក្ស និង *អង្គការ*[4475] ការផ្តល់ឱ្យនូវ "ទង់ក្រហមកិត្តិយសរបស់គណៈកម្មាធិការមជ្ឈិម" ដែលជា ("កិត្តិយសខ្ពង់ខ្ពស់បំផុតរបស់ ប.ក.ក") ទៅឱ្យកម្មាភិបាលស្រុកត្រាំកក់ ដោយគណៈកម្មាធិការមជ្ឈិម ដែលក្នុងនោះ ម្ចាស់បណ្តឹងសាទុក្ខគឺជាសមាជិក[4476] និងបានបង្ហាញសហករណ៍ត្រាំកក់ទៅកាន់ប្រតិភូអន្តរជាតិ ក៏ដូចជា ការពណ៌នាសំខាន់របស់វានៅក្នុងទស្សនាវដ្តី *ទង់បដិវត្តន៍*[4477]។ អ.ជ.ស.ដ បានកត់សម្គាល់បន្ថែមទៀតថា ម្ចាស់បណ្តឹងសាទុក្ខទំនងជាបានទៅទស្សនាស្រុកនោះ[4478] និងបានធ្វើការសន្និដ្ឋានទាក់ទងនឹងទំនាក់ទំនងជិតស្និទ្ធរបស់ម្ចាស់បណ្តឹងសាទុក្ខជាមួយនឹង តាម៉ុក[4479] ដែលបានមកមើលស្រុកត្រាំកក់ជាប្រចាំ និងបានដឹងអំពីឧក្រិដ្ឋកម្មនៅទីនោះ[4480]។

## *មូលដ្ឋានទី ២១៣៖ ទំនប់ត្រពាំងថ្ម*[4481]

1224. **មូលដ្ឋានទី ២១៣ គួរត្រូវបានច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលបានធ្វើឡើងនៅទំនប់ត្រពាំងថ្ម ដែលជាផ្នែកមួយនៃគោលនយោបាយផ្តោតលើការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន។**

1225. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុស (i) ក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅទំនប់ត្រពាំងថ្ម "នៅពេលអង្គហេតុកើតឡើង"[4482] (ii) ដោយការបង្កើត "សេចក្តីសន្និដ្ឋានជាទូទៅមួយ" អំពីការដឹងតាមរយៈ

---

[4475] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៨៥៦, ៨៦៨, ៨៩៦, ៩៧៩។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩០ និង ១៩១។

[4476] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២៦-១១២៩។

[4477] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២៧-១១២៩។

[4478] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១១៣៧។

[4479] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០៤ (តាម៉ុក បានបញ្ចូលម្ចាស់បណ្តឹងសាទុក្ខទៅក្នុង ប.ក.ក នៅឆ្នាំ១៩៦៩)។

[4480] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩០៥, ៩៥៥, ១១១០-១១១១។

[4481] <u>មូលដ្ឋានទី ២១៣៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ទំនប់ត្រពាំងថ្ម* កថាខណ្ឌ ១៨៤២-១៨៤៤។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧២ (អង់គ្លេស) ទំព័រ ៦៧ (បារាំង) ទំព័រ ១០៣ (ខ្មែរ)។

[4482] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤២។

"ការវិនិច្ឆ័យបែបអនុមាន"[4483] និង (iii) ដោយ "បំភ្លេចចោលដោយចេតនានូវភ័ស្តុតាងដោះបន្ទុក"[4484]។

1226. ម្ចាស់បណ្តឹងសាទុក្ខយល់ច្រឡំលើការដឹងដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម[4485]។ ម្ចាស់បណ្តឹងសាទុក្ខមិនចាំបាច់ត្រូវបានដឹងអំពីឧក្រិដ្ឋកម្មជាក់លាក់ដែលត្រូវបានប្រព្រឹត្តឡើងនៅពេលព្រឹត្តិការណ៍នោះ ដើម្បីទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ[4486]។

1227. ទីពីរ វិធីសាស្រ្តតាមផ្នែករបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះភ័ស្តុតាង មិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសអង្គច្បាប់ណាមួយនៅក្នុងសំអាងហេតុ និងការវាយតម្លៃលើភ័ស្តុតាងជារួមរបស់ខ្លួននោះទេ[4487]។ ដូចបានរៀបរាប់ខាងលើ ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ដែលជាផ្នែកមួយនៃគោលនយោបាយផ្តោតលើការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន ត្រូវបានបញ្ជាក់គាំទ្រដោយភ័ស្តុតាងជាច្រើន។[4488]

1228. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខបានអះអាងមិនត្រឹមត្រូវថា "គ្មានភ័ស្តុតាងណាមួយដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង អាចឱ្យសន្និដ្ឋានបានថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីតាំងទំនប់ត្រពាំងថ្ម"[4489]។ ម្ចាស់បណ្តឹងសាទុក្ខមើលរំលងភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលបង្ហាញពីការដឹងរបស់គាត់អំពីលក្ខខណ្ឌនៅទំនប់ត្រពាំងថ្ម រួមទាំង ការដឹងរបស់ ថ្នាក់ដឹកនាំជាន់ខ្ពស់អំពីលក្ខខណ្ឌមិនល្អ[4490] ដូចជា ជំងឺ[4491] និងកង្វះស្បៀង និងថ្នាំសង្កូវ[4492] គណៈ

---

[4483] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤២។

[4484] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៨៤។

[4485] ម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៅទំនប់ត្រពាំងថ្ម ដោយអនុលោមតាម ទាំងសហឧក្រិដ្ឋកម្មរួម (JCE) ទាំងការទទួលខុសត្រូវក្នុងការជួយ និងជំរុញ (A&A)៖ *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦ (JCE), ៤៣១៨, ៤៣២៨ (A&A)។

[4486] *សូមមើល* ផ្នែក VIII.គ.៣ ចេតនា (អ.ជ.ស.ដ *បានសន្និដ្ឋាន* យ៉ាងត្រឹមត្រូវពីចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខចេញពី *ក្នុងចំណោមនោះ* ការដឹងឮរបស់គាត់ពីឧក្រិដ្ឋកម្មនានា និងការបន្តចូលរួមចំណែកនៅក្នុងផែនការរួម)។

[4487] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨។

[4488] មូលដ្ឋានទី ១៨១ & ១៨៣, ១៨២, ២១១។

[4489] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៤។

[4490] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣០៧។

[4491] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣១៧។

[4492] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៥៦, ១២៥៩។ អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦០៧ ដែលថាការរកឃើញរបស់ អ.ជ.ស.ដ ដែលថាគាត់បានដឹងឮពី

ប្រតិភូអន្តរជាតិដែលម្ចាស់បណ្ដឹងសាទុក្ខទទួលខុសត្រូវទទួលស្វាគមន៍[4493] បានទៅមើលទំនប់ត្រពាំងថ្ម និងបានទទួលការឃោសនារៀបរាប់លម្អិតអំពីលក្ខខណ្ឌនៅទីនោះ[4494] ការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខថា ការសាងសង់ត្រូវបានធ្វើឡើងដោយគ្មានគ្រឿងចក្រ[4495] ការលើកទឹកចិត្តរបស់ម្ចាស់បណ្ដឹងសាទុក្ខឱ្យកម្មាភិបាលអនុវត្តគោលនយោបាយមជ្ឈិមបក្ស "គ្រប់ពេលវេលាទាំងអស់" និងការទទូចរបស់គាត់ថា កម្លាំងពលកម្មត្រូវ "ខិតខំធ្វើការទាំងយប់ទាំងថ្ងៃ" "គ្មានឈប់សម្រាក"[4496] ការពណ៌នាអំពីកង្វះខាតទឹក និងលក្ខខណ្ឌរស់នៅមិនល្អនៅក្នុង ទស្សនាវដ្ដី *ទង់បដិវត្តន៍* និងរបាយការណ៍ ប.ក.ក ទូរលេខទៅកាន់មន្ទីរ ៨៧០ និងអត្ថបទសារព័ត៌មាន[4497] និងថា កម្លាំងពលកម្មពី ១០.០០០ ទៅ ២០.០០០ នាក់ រួមទាំងកុមារ ត្រូវប្រើនៅកន្លែងសាងសង់នោះ[4498]។

1229. ទីបី ម្ចាស់បណ្ដឹងសាទុក្ខចោទប្រកាន់ថា អ.ជ.ស.ដ "បានលុបចោលដោយចេតនា" នូវធាតុផ្សំដោះបន្ទុក និងបានបង្ហាញផ្ទុយនឹងខ្លួនឯង ដោយសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីលក្ខខណ្ឌនៅទំនប់ត្រពាំងថ្ម ខណៈដែលសន្និដ្ឋានថា "រដ្ឋអំណាចមូលដ្ឋានបានប៉ុនប៉ងលាក់បាំង

---

របាយការណ៍របស់គណៈអចិន្ត្រៃយ៍ដែលបានកត់ត្រានូវកង្វះខាតទាំងនេះថា "មិនសមហេតុផល និងលម្អៀង" គឺមិនមានសំអាងហេតុនោះទេ ហើយដូច្នេះ ត្រូវតែបដិសេធចោល។ បន្ថែមលើនេះ ម្ចាស់បណ្ដឹងសាទុក្ខត្រូវទទួលខុសត្រូវចំពោះការផ្គត់ផ្គង់ថ្នាំពេទ្យ ហើយគួរតែត្រូវបានដឹងឮអំពីលក្ខខណ្ឌទាំងនេះ៖ *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[4493] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២២២, ១២៥៨-១២៥៩។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[4494] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២១៦, ១២១៧, ១២២២, ១២៥៣។

[4495] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៨៦ ជើងទំព័រ ៤៤៣៣ *លើកឡើងពី* ឯកសារ **E3/201** សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួបនៅភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292806-08។

[4496] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៤។

[4497] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៣៩, ១២៤០, ១២៤៤-១២៤៨, ១២៥០, ១២៨៥, ១៣១៨។

[4498] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៦២ *លើកឡើងពី* ឯកសារ **E3/771** *ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត ខែកក្កដា-ខែសីហា ឆ្នាំ១៩៧៧* KH 00376344-46 (រាយការណ៍ថាមានកម្មកររាប់ម៉ឺននាក់), ១២៦៥ *លើកឡើងពី* ឯកសារ **E3/230** កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ អំពីបញ្ហាសេដ្ឋកិច្ច ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ KH 00000712 (ដោយស្នើឱ្យសុំយក "កុមារធំទង់ៗ ពីមូលដ្ឋានបន្ថែម ហើយប្រគល់ទៅឧស្សាហកម្មចាត់ចែង"), ឯកសារ **E3/226** កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ KH 00017158-59 (ប៉ុល ពត ពិភាក្សាអំពីការប្រើប្រាស់កម្លាំងកុមារ)។

ទិដ្ឋភាពមួយចំនួន” អំពីលក្ខណ្ឌទាំងនោះ[4499]។ ទោះជាយ៉ាងណា ម្ចាស់បណ្តឹងសាទុក្ខខ្លួនគាត់ផ្ទាល់ទទួលស្គាល់ថា អ.ជ.ស.ដ រៀបរាប់ពេញលេញអំពីភ័ស្តុតាងដែលគាត់ចាត់ទុកថា “ដោះបន្ទុក”[4500]។ អ.ជ.ស.ដ បានពិចារណាថែមទៀតលើបញ្ហាជាក់លាក់ដែល នួន ជា និងសហព្រះរាជអាជ្ញាបានលើកឡើង ទាក់ទងនឹងការចុះមើលទីតាំងឧក្រិដ្ឋកម្ម[4501] និងបានកត់សម្គាល់ថាខ្លួនបាន “វាយតម្លៃរាល់ព័ត៌មានទាំងអស់ដែលមាននៅចំពោះមុខខ្លួន រួមទាំងទស្សនកិច្ចរបស់មេដឹកនាំ ប.ក.ក នៅទីតាំងឧក្រិដ្ឋកម្មជាក់លាក់ផងដែរ”[4502]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនឯកភាពតាមការសន្និដ្ឋានរបស់ អ.ជ.ស.ដ។ គាត់ខកខានមិនបានបង្ហាញថា ការសន្និដ្ឋានទាក់ទងនឹងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម គឺជាការសន្និដ្ឋានមួយដែលមិនមានអ្នកវិនិច្ឆ័យអង្គហេតុណាម្នាក់អាចធ្វើបាន ផ្អែកលើការវាយតម្លៃលើភ័ស្តុតាងទាំងមូលនេះទេ[4503]។

## *មូលដ្ឋានទី ២១៤៖ ទំនប់ ១ មករា*[4504]

1230. **មូលដ្ឋានទី ២១៤ គួរត្រូវបានច្រានចោល ដោយហេតុថាម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុ ដោយសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅ ទំនប់ ១ មករា ដែលជាផ្នែកមួយនៃគោលនយោបាយផ្តោតលើការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន។**

1231. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញបង្ហាញថា អ.ជ.ស.ដ បានពឹងផ្អែកលើភ័ស្តុតាងមិនគ្រប់គ្រាន់[4505]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែលើកការអះអាងដែលមិនត្រឹមត្រូវរបស់ខ្លួនម្តងទៀតថា អ.ជ.ស.ដ មានកំហុសដោយសារមិនបានយោងទៅទំនប់ ១

---

[4499] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៣-១៨៤៤ *លើកឡើងពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៦០, ៤២១៣។ *សូមមើលផងដែរ* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦០៦។

[4500] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៣ *លើកឡើងពី* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៥៤។

[4501] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៦១។ គួរឱ្យកត់សំគាល់ថា ម្ចាស់បណ្តឹងសាទុក្ខមិនបានដាក់សារណាណាមួយទាក់ទងទៅនឹងដំណើរទស្សនៈកិច្ចរបស់គាត់ទៅកាន់ទំនប់ត្រពាំងថ្មនោះទេ សូម្បីតែសារណាត្រូវបានធ្វើឡើងទាំងដោយ នួន ជា និងទាំង សហព្រះរាជអាជ្ញា។

[4502] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៦១។

[4503] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ។

[4504] <u>មូលដ្ឋានទី ២១៤៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ទំនប់១មករា* កថាខណ្ឌ ១៨៤៥។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧២-៧៣ (អង់គ្លេស) ទំព័រ ៦៧ (បារាំង) ទំព័រ ១០៣-១០៤ (ខ្មែរ)។

[4505] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៥។

មករា នៅក្នុងផ្នែកជាក់លាក់នៃសាលក្រម[4506]។ គាត់អះអាងឱ្យធ្វើឱ្យមានការភាន់ច្រឡំថា "ពុំមានភ័ស្តុតាងណាមួយត្រូវបានបង្ហាញទាក់ទងនឹងទីតាំងនេះទេ"[4507] ដោយមើលរំលងការសន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងអំពីការដឹងរបស់គាត់ដែលបានធ្វើឡើងនៅក្នុងផ្នែកផ្សេងទៀតនៃសាលក្រមនេះ[4508]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលម្ចាស់បណ្តឹងសាទុក្ខបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការនេះជាប្រចាំ[4509] ទទួលបានដំណឹងយ៉ាងជាក់លាក់អំពីលក្ខខណ្ឌនៅទំនប់ ១ មករា[4510]។ ការសន្និដ្ឋានរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃគោលនយោបាយផ្តោតលើការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន ត្រូវបានបញ្ជាក់គាំទ្រដោយឯកសារភ័ស្តុតាងជាច្រើន[4511]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់អំណះអំណាងបន្ថែមទៀត ដើម្បីគាំទ្រដល់មូលដ្ឋាននេះឡើយ។ ដោយសារតែមូលដ្ឋាននេះមិនមានការបញ្ជាក់គាំទ្រ គួរតែច្រានចោលមូលដ្ឋាននេះភ្លាមៗ។

### *មូលដ្ឋានទី ២១៥៖ ព្រលានយន្តហោះកំពង់ឆ្នាំង* [4512]

1232. **មូលដ្ឋានទី ២១៥ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ដែលជាផ្នែកមួយនៃគោលនយោបាយផ្តោតលើការបង្កើត និងប្រតិបត្តិការព្រលានយន្តហោះកំពង់ឆ្នាំង។**

1233. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ បានបំភ្លៃភ័ស្តុតាង ដើម្បីបញ្ជាក់ពីការដឹងរបស់គាត់ចំពោះឧក្រិដ្ឋកម្មនៅព្រលានយន្តហោះកំពង់ឆ្នាំង មិនមានមូលដ្ឋានទេ។ គាត់បានចោទប្រកាន់ដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ មានកំហុសដោយ (i) ខកខានមិនបានយោងទៅភ័ស្តុតាងជាក់លាក់ណាមួយ[4513] (ii) ប្រើវិធីសាស្ត្របែបអនុមាន និង

---

[4506] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៥។

[4507] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៥។

[4508] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៨០-១៤៩៧, ១៥១៧-១៥១៨, ៤២១០-៤២១៨, ៤២៥១, ៤២៨០-៤២៨២, ៤៣០៦, ៤៣១៣-៤៣១៥។ *សូមមើលបន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១, ២១៧។

[4509] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣។

[4510] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៨៣-១៤៩៧។

[4511] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨១ & ១៨៣, ១៨២, ២១១។

[4512] <u>មូលដ្ឋានទី ២១៥៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ព្រលានយន្តហោះកំពង់ឆ្នាំង* កថាខណ្ឌ ១៨៤៦-១៨៤៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧៣ (អង់គ្លេស) ទំព័រ ៦៧-៦៨ (បារាំង) ទំព័រ ១០៤ (ខ្មែរ)។

[4513] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៦។

ផ្អែកលើភស្តុតាង "ខុសបរិបទ"[4514] និង (iii) សន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខមានការទទួលខុសត្រូវចំពោះព្រលានយន្តហោះកំពង់ឆ្នាំង[4515]។

1234. ទីមួយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា អ.ជ.ស.ដ មិនបានយោងទៅភស្តុតាងណាមួយទាក់ទងនឹងការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីទីតាំងនោះ មិនត្រឹមត្រូវទេ។ អ.ជ.ស.ដ បានធ្វើការវិភាគលើភស្តុតាងទាំងមូល ដើម្បីធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងពីឧក្រិដ្ឋកម្មដែលបានធ្វើឡើងនៅតាមការដ្ឋាន រួមទាំងនៅព្រលានយន្តហោះកំពង់ឆ្នាំង[4516]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា លក្ខណៈពិសេសនៃទីតាំងព្រលានយន្តហោះកំពង់ឆ្នាំង ធ្វើឱ្យការសន្និដ្ឋានជារួមរបស់ អ.ជ.ស.ដ លើការដ្ឋាន មិនមានសុពលភាពទេ[4517]។ ទោះជាយ៉ាងណា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថាតើ ព្រលានយន្តហោះកំពង់ឆ្នាំងខុសពីគម្រោងសាងសង់ទ្រង់ទ្រាយធំផ្សេងៗទៀត ដែលគាត់បានគាំទ្រជាសាធារណៈនោះ ដោយរបៀបណា[4518] និងសារៈសំខាន់នៃភាពខុសគ្នាទាំងនោះ។

1235. ទីពីរ អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងបរិបទបរាជ័យ ដោយហេតុថា គាត់មិនបានបង្ហាញថា ការលើកឡើងរបស់គាត់ត្រូវបានអាន "ខុសបរិបទ"[4519]។ អំណះអំណាងរបស់គាត់ទាក់ទងនឹង "វិធីសាស្ត្របែបអនុមានញែក" នៅក្នុងការវិភាគភស្តុតាង[4520] ក៏បរាជ័យផងដែរ។ ដូចបានបញ្ជាក់នៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២១១[4521] ម្ចាស់បណ្តឹងសាទុក្ខខកខានក្នុងការបង្ហាញថាតើ ការពិចារណារបស់ អ.ជ.ស.ដ លើពាក្យពេចន៍ផ្ទាល់របស់គាត់ ជាមួយនឹងភស្តុតាងផ្សេងៗទៀតនោះ គឺជា "វិធីសាស្ត្របែបអនុមានញែក" ដែលនាំឱ្យមានការខុសឆ្គងរបស់តុលាការដោយរបៀបណា[4522]។

---

[4514] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៧។

[4515] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៧-១៨៤៨។

[4516] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[4517] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៧។

[4518] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៣។

[4519] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៧។

[4520] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៧។

[4521] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[4522] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ (កំហុសខាងអង្គច្បាប់ កំហុសខាងអង្គហេតុ)។

1236. ទីបី អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា ព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានសាងសង់ឡើងជាចម្បងសម្រាប់ប្រើជាទីតាំងយោធា ហេតុដូច្នេះ "មិនត្រូវអ្វីបន្តិចសោះ" ទៅនឹងការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ ក៏បរាជ័យផងដែរ[4523]។ អ.ជ.ស.ដ បានបង្ហាញយ៉ាងត្រឹមត្រូវថា ទោះបីជាព្រលានយន្តហោះកំពង់ឆ្នាំងដើមឡើយមានបំណងធ្វើជាផែនការយោធា[4524] នៅពេលដែលការបោសសម្អាតភូមិភាគឧត្តរ និងភូមិភាគបូព៌ា បានចាប់ផ្តើម ការដ្ឋាននោះក្រោយមកត្រូវប្រើប្រាស់ជាកន្លែងរបស់ប្រជាជនដែលគេចាត់ទុកថាជា "ខ្មាំង" ដែលត្រូវបានបញ្ជូនទៅកាន់ព្រលានយន្តហោះកំពង់ឆ្នាំង ដើម្បី "លត់ដំ និងកសាង"[4525]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា "មូលដ្ឋាននៃការបង្កើតការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង គឺការការពារប្រទេស ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រយោធារបស់កម្ពុជាប្រជាធិបតេយ្យ"[4526] ប៉ុន្តែការសាងសង់នេះបានងាកចេញពីគោលបំណងនេះ ហើយត្រូវបានធ្វើឡើងផងដែរដើម្បី "សម្រេចគោលបំណងរួមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមឱ្យបានឆាប់ តាមរយៈ "មហាលោតផ្លោះមហាអស្ចារ្យ" ក្នុងចំណោមគោលបំណងផ្សេងៗ ដែលក្នុងនោះមាន ការការពារប្រទេសប្រឆាំងនឹងខ្មាំង" ដែលរួមទាំងកម្មាភិបាលផ្ទៃក្នុងរបស់ ប.ក.ក[4527]។ មន្ទីរសេនាធិការបានតាមដានត្រួតពិនិត្យដំណើរការសាងសង់របស់ព្រលានយន្តហោះកំពង់ឆ្នាំង និងរាយការណ៍អំពីស្ថានភាពនៅក្នុងភូមិភាគបស្ចិម ដែលរួមទាំងថា ព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានបញ្ជូនទៅកាន់ "*អង្គការ* ថ្នាក់លើ"[4528]។

1237. លើសពីនេះទៀត អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា ព្រលានយន្តហោះកំពង់ឆ្នាំងពេលខ្លះបានដំណើរការហួសពីការគ្រប់គ្រងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ មិនត្រូវបានបញ្ជាក់គាំទ្រដោយភស្តុតាងទេ។ តាមតួនាទីខ្ពស់របស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងបក្ស ម្ចាស់បណ្តឹងសាទុក្ខទទួលបានដំណឹងអំពីដំណើរវិវឌ្ឍន៍នៅព្រលានយន្តហោះកំពង់ឆ្នាំង ក្នុងពេលសាងសង់ទាំងមូល ដោយហេតុថា គណៈកម្មាធិការអចិន្ត្រៃយ៍បានពិចារណាទៅលើការសាងសង់ព្រលានយន្តហោះនេះតាំងពីដើមខែតុលា ឆ្នាំ១៩៧៥ ក្នុងអំឡុងពេលប្រជុំមួយ ដែលម្ចាស់បណ្តឹងសាទុក្ខមាន

---

[4523] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨៤៧-១៨៤៨។

[4524] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៣៥។

[4525] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៣៥។

[4526] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៣។

[4527] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២៣។

[4528] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៧។

វត្តមានផងដែរ[4529]។ កាន់តែប៉ះពាល់ដល់អំណះអំណាងរបស់ម្ចាស់បណ្ដឹងសាទុក្ខទៀតនោះគឺថា របាយការណ៍ទៅកាន់អង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ពីព្រលានយន្តហោះកំពង់ឆ្នាំងបានបន្តមានក្នុងឆ្នាំ ១៩៧៦ ពេញ[4530]។ ក្នុងខែឧសភា ឆ្នាំ១៩៧៦ ម្ចាស់បណ្ដឹងសាទុក្ខមានវត្តមាននៅក្នុងអង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដែលពិភាក្សាអំពីព្រលានយន្តហោះកំពង់ឆ្នាំង ជាពិសេសដោយតាមកំណត់ហេតុ មានការមកដល់នៃក្រុមខែដីនៅព្រលានយន្តហោះកំពង់ឆ្នាំង ដើម្បីចាប់ផ្ដើមការសាងសង់[4531]។ កងពល ៥០២ បានដឹកនាំការសាងសង់ព្រលានយន្តហោះ កំពង់ឆ្នាំងក្រោមបញ្ជារបស់ ស៊ូ ម៉េត[4532]។ ស៊ូ ម៉េត រស់នៅក្នុងក្រុងភ្នំពេញ និងមានការប្រជុំ ជាប្រចាំជាមួយ សុន សេន និង ឌុច[4533]។ ការទទួលខុសត្រូវរបស់ ស៊ូ ម៉េត ដែលរួមទាំងការត្រួតពិនិត្យព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានពិភាក្សាក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍[4534]។

1238. អ.ជ.ស.ដ ក៏បានបញ្ជាក់ផងដែរថា “គណៈប្រតិភូជាន់ខ្ពស់មួយចំនួនបានចុះពិនិត្យការដ្ឋាន” ព្រលានយន្តហោះកំពង់ឆ្នាំង[4535]។ របាយការណ៍ស្ដីពីស្ថានភាពនៅភូមិភាគបស្ចិម ដែលរួមទាំងព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានបញ្ជូនទៅ “*អង្គការ* ថ្នាក់លើ” ហើយ អ.ជ.ស.ដ បានសន្និដ្ឋានថា យ៉ាងហោចណាស់នៅក្នុងអង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដែលម្ចាស់បណ្ដឹងសាទុក្ខបានចូលរួម សុន សេន បានរាយការណ៍អំពីដំណើរវិវឌ្ឍន៍ការងារនៅវាលយន្តហោះនេះ[4536]។ ផ្ទុយទៅនឹងអំណះអំណាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[4537] វត្តមានរបស់ម្ចាស់បណ្ដឹង

[4529] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣ *លើកឡើងពី* ឯកសារ **E3/182** ការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019125 (ម្ចាស់បណ្ដឹងសាទុក្ខបានមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ)។

[4530] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣ *លើកឡើងពី* ឯកសារ **E3/229** កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ អំពីបញ្ហាការពារប្រទេស ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ KH 00000718 (ម្ចាស់បណ្ដឹងសាទុក្ខបានមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ)។

[4531] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៤ *លើកឡើងពី* ឯកសារ **E3/222** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ KH 00000771 (កំណត់ហេតុនៃអង្គប្រជុំមួយ ដែលនៅក្នុងនោះម្ចាស់បណ្ដឹងសាទុក្ខបានមានវត្តមាន ដោយបានបញ្ជាក់ថា ពួកខែដី ក៏មកដល់ហើយដែរ)។«

[4532] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៦។

[4533] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៦។

[4534] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៦ *លើកឡើងពី* ឯកសារ **E3/224** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៦ KH 00000775 (រាយការណ៍ថា ខាងនិរតី និងខាងត្បូងភ្នំពេញជាកន្លែងសមមិត្តម៉េត និងសមមិត្តពឹន)។

[4535] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៨៨។

[4536] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៧, ៤២៥៨។

សាទុក្ខនៅក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលពិភាក្សាពីការសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងនោះ មានការពាក់ព័ន្ធ។ គេអាចទាញការសន្និដ្ឋានយ៉ាងសមហេតុសមផលបានថា នៅក្នុងការប្រជុំទាំងអស់នេះ ដំណើរការវិវឌ្ឍន៍នៃការសាងសង់ រួមទាំង ម៉ោងពេលធ្វើការ លក្ខខណ្ឌការងារ និងស្ថានភាព "ខ្មាំង" ត្រូវបានពិភាក្សា ដោយហេតុថា របាយការណ៍ដែលនៅសល់ពីភូមិភាគបស្ចិមទៅកាន់ "*អង្គការ*" បានពិភាក្សាអំពីខ្មាំងប៉ុនប៉ងរត់ចេញពីព្រលានយន្តហោះកំពង់ឆ្នាំង ក៏ដូចជា បញ្ហាផ្សេងទៀត ទាក់ទងនឹងការបោសសម្អាត វគ្គរៀនសូត្រ និងសន្តិសុខ នៅទូទាំងភូមិភាគបស្ចិម[4538]។

1239. អ.ជ.ស.ដ បានធ្វើការសន្និដ្ឋានសមស្របផងដែរថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីលក្ខខណ្ឌនានានៅព្រលានយន្តហោះកំពង់ឆ្នាំង ខណៈដែលការដ្ឋានបានប្តូរពីទីតាំងយោធាតែមួយមុខ ទៅជាកន្លែងកសាង និងលត់ដំសម្រាប់យោធាដែលបានបោសសម្អាត អនុលោមតាមគោលនយោបាយ ប.ក.ក ដែលបានបង្កើតឡើង ប្រឆាំងនឹង "ខ្មាំង"[4539]។ ម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីការបោសសម្អាតនៅភូមិភាគបូព៌ា[4540] ដែលក្នុងអំឡុងពេលនោះ "យុទ្ធជនប្រហែល ៥.០០០ នាក់" ត្រូវបានបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង[4541] និង "កម្មាភិបាល ភូមិភាគបូព៌ាមិនដឹងចំនួនពិតប្រាកដ ត្រូវបានដកបញ្ជូនទៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង ដើម្បីធ្វើការអប់រំកសាងខ្លួន ឬលត់ដំ"[4542]។ អ.ជ.ស.ដ បានធ្វើការសន្និដ្ឋាន ដោយផ្អែកលើ "តួនាទី និងឋានៈពិសេសរបស់ ខៀវ សំផន នៅក្នុងបក្ស និងភាពស្និទ្ធស្នាលជាមួយ ប៉ុល ពត និង នួន ជា" នៅពេលមាន "ការបោសសម្អាតដ៏ច្របូកច្របល់លើបុគ្គលិក [ភូមិភាគបូព៌ា]"[4543]។ ក្នុងពាក្យ

---

[4537] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៤១៨។

[4538] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៧ ជើងទំព័រ ៥៨៥៣ *លើកឡើងពី* ឯកសារ **E3/1094** គោរពជូនអង្គការជាទីគោរពស្នេហានឹករលឹក ពីម.៤០១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨ KH 00143604-05 (របាយការណ៍ពីការប៉ុនប៉ងរបស់បុគ្គលរត់គេចចេញពីព្រលានយន្តហោះ ក៏ដូចជាបញ្ហាមួយចំនួនទាក់ទងនឹងសន្តិសុខ សហករណ៍ ការបោសសម្អាត វគ្គអប់រំ និង ផលិតផលកសិកម្មនៅក្នុងតំបន់ និងស្រុកនានា នៅភូមិភាគបស្ចិម)។

[4539] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៧៩, ១៨១ & ១៨៣។

[4540] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៩ (ម្ចាស់បណ្តឹងសាទុក្ខ "បានផ្តល់នូវការរៀបរាប់ពន្យល់លម្អិតយ៉ាងសមហេតុផលអំពីការបោសសម្អាត គណៈកម្មាធិការភូមិភាគបូព៌ា"), ៤២៨៤ (ម្ចាស់បណ្តឹងសាទុក្ខបានដឹងឮពីការបោសសម្អាត "មេបញ្ជាការកងពល ១៧០ ឈ្មោះ ចាន់ ចក្រី និងលេខាតំបន់ ២៤ ឈ្មោះ សួស នៅ *ហៅ* ឈូក")។

[4541] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៣៧។ មេបញ្ជាការរបស់យុទ្ធជនទាំងនេះត្រូវបានចាប់បញ្ជូនទៅមន្ទីរសន្តិសុខ ស.២១។

[4542] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២០៣៨។

[4543] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣០។

ពេចន៍ផ្ទាល់របស់គាត់ ម្ចាស់បណ្តឹងសាទុក្ខបានកត់សម្គាល់ថា កម្មាភិបាលបានចាត់តាំងឱ្យធ្វើការក្រោមអ្នកដែលត្រូវបានបោសសម្អាត "ត្រូវចាប់នឹងគេទៅ ដែល ថា គេថាអី ខ្សែ ឬមួយក៏សមាសភាព" ដែលនាំឱ្យមានការចាប់ខ្លួន "ជាច្រើន"[4544]។ មិនអាចទៅរួចទេដែលថា ម្ចាស់បណ្តឹងសាទុក្ខមិនបានដឹងអំពីការបោសសម្អាតទាំងអស់នេះ និងគោលនយោបាយប្រឆាំងនឹងខ្មាំង ដែលតាមរយៈគោលនយោបាយនេះ កម្មាភិបាលបានទទួលរងការលំបាកវេទនានៅព្រលានយន្តហោះកំពង់ឆ្នាំងនេះ។

1240. ជាលទ្ធផល ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គហេតុនៅក្នុងការពិចារណារបស់ខ្លួនលើភ័ស្តុតាងនៅចំពោះមុខខ្លួន ដែលរួមទាំងការទទួលស្គាល់របស់ម្ចាស់បណ្តឹងសាទុក្ខ។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា សំអាងហេតុនេះគឺជាសំអាងហេតុដែលមិនមានអ្នកវិនិច្ឆ័យអង្គហេតុណាអាចធ្វើបាន ដោយផ្អែកលើការវាយតម្លៃលើភ័ស្តុតាងទាំងមូល មិនមែនការវាយតម្លៃលើភ័ស្តុតាងតាមផ្នែកនោះទេ[4545]។

### vi. ចេតនាប្រព្រឹត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ រួមទាំងការរំលោភសេពសន្ថវៈ

***មូលដ្ឋានទី ២១០៖ កំហុសស្តីពីការដឹងអំពីឧក្រិដ្ឋកម្មទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[4546]***

1241. **មូលដ្ឋានទី ២១០ គួរត្រូវច្រានចោល ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ការដឹងដែលជាលក្ខខណ្ឌតម្រូវនៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តឡើង ដោយសារតែគោលនយោបាយនេះ។**

1242. មូលដ្ឋាននេះបរាជ័យ ដោយហេតុថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ "[បាន] វិនិច្ឆ័យជាមុនចំពោះអង្គហេតុ" ដែលជាលទ្ធផលនៃការសន្និដ្ឋានថាដែលខ្លួនបានធ្វើឡើងក្នុងសំណុំរឿង០០២/០១[4547] "ផ្អែកលើសក្ខីកម្ម [...] តែមួយ"[4548] និង "បានប្រព្រឹត្តកំហុសផងដែរក្នុង

[4544] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣១ *លើកឡើងពី* ឯកសារ **E3/4041** បទសម្ភាសន៍ជាមួយ ខៀវ សំផន មិនមានកាលបរិច្ឆេទ KH 00782543។

[4545] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ។

[4546] <u>មូលដ្ឋានទី ២១០៖</u> ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីឧក្រិដ្ឋកម្មនៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍* កថាខណ្ឌ ១៩២៨-១៩៣១។ ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧១-៧២ (អង់គ្លេស) ទំព័រ ៦៦ (បារាំង) ទំព័រ ១០២ (ខ្មែរ)។

[4547] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៨។

ការបកស្រាយភ័ស្តុតាងទេសៈកាលៈ"[4549]។ ម្ចាស់បណ្តឹងសាទុក្ខដកស្រង់កថាខណ្ឌ ១៥៨ នៃសារណាបណ្តឹងសាទុក្ខដើម្បីគាំទ្រមូលដ្ឋាននេះ[4550]។ ភាគច្រើននៃកថាខណ្ឌទាំងអស់នេះមិនពាក់ព័ន្ធទៅនឹងមូលដ្ឋាននេះទេ ហើយត្រូវបានលើកឡើងនៅកន្លែងផ្សេងទៀត[4551]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានផ្តល់ការគាំទ្រអំណះអំណាងរបស់ខ្លួន ដើម្បីគាំទ្រមូលដ្ឋាននេះ ហេតុដូច្នេះ គួរតែបានច្រានចោលមូលដ្ឋាននេះភ្លាមៗ។

1243. ទោះក្នុងស្ថានការណ៍ណាក៏ដោយ ដូចបានពិភាក្សាក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ៤ ម្ចាស់បណ្តឹងសាទុក្ខបានខកខានមិនបានបង្ហាញថា អ.ជ.ស.ដ "[បាន]វិនិច្ឆ័យជាមុនចំពោះអង្គហេតុ" នៃសំណុំរឿង ០០២/០២ ជាលទ្ធផលនៃការសន្និដ្ឋានទាក់ទងនឹងបទបញ្ជានៃការរៀបការដែលបានធ្វើក្នុងសំណុំរឿង ០០២/០១[4552]។ លើសពីនេះទៀត អំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខទាក់ទងនឹងសក្ខីកម្មរបស់ ជា ឌៀប ក៏មិនត្រឹមត្រូវដែរ ដូច្នេះត្រូវបរាជ័យ[4553]។ អំណះអំណាងមិនត្រឹមត្រូវនេះទាក់ទងនឹងសក្ខីកម្មរបស់ ជា ឌៀប មានភាពច្រំដែល ហើយត្រូវបានលើកឡើងនៅក្នុងកន្លែងផ្សេងក្នុងចម្លើយតបនេះ[4554]។

1244. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា ទាំងភ័ស្តុតាងនេះ និងទាំង "[ការ]ជាប់ទាក់ទងជាមួយពាណិជ្ជកម្ម" របស់គាត់ មិនបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខគាំទ្រការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ ឬថា គាត់បានដឹងអំពីបញ្ហានេះទេ[4555]។ វិធីសាស្ត្រពិនិត្យមួយផ្នែករបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះភ័ស្តុតាងនេះ បរាជ័យមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសនៅក្នុងសំអាងហេតុបែបអនុមានញែករបស់ខ្លួន និងការវាយតម្លៃលើភ័ស្តុតាងទាំងមូលរបស់ខ្លួននោះ

---

4548 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៩។

4549 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៩-១៩៣០។

4550 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៨ ជើងទំព័រ ៣៧៥៦។

4551 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៩ (ជើងទំព័រ ៣៧៥៩ *លើកឡើងពី* កថាខណ្ឌ ១២៣៣-១២៤២ (មូលដ្ឋានទី ២៣០, ១៥, ២១, ២២, ២៥, ២៦)), ១៩៣០ (ជើងទំព័រ ៣៧៦២ *លើកឡើងពី* កថាខណ្ឌ ១២២១-១២៣២ (មូលដ្ឋានទី ១៦៦, ២៥៥)), ១៩៣០ (ជើងទំព័រ ៣៧៦៣ *លើកឡើងពី* កថាខណ្ឌ ១៦៥២-១៨០៣ (មូលដ្ឋានទី ១៩៦, ១៩០)), ១៩៣១ (ជើងទំព័រ ៣៧៦៥ *លើកឡើងពី* កថាខណ្ឌ ១២៥៥-១២៨០ (មូលដ្ឋានទី ១៦៧, ១៦៨, ១៦៩, ១៧០, ១៦៥, ១៦២))។

4552 *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ៤។

4553 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩២៩។

4554 *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៦។

4555 ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩៣០។

ឡើយ[4556]។ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ភ័ស្តុតាងរបស់សាក្សីខាងលើ ស៊ីសង្វាក់គ្នាជាមួយនឹង "មនោគមន៍វិជ្ជារបស់ ប.ក.ក រួមទាំង សុន្ទរកថាថ្លែងដោយ [ម្ចាស់បណ្ដឹងសាទុក្ខ]" ដែលនៅក្នុងនោះ គាត់បានទទួលថា មានភារកិច្ចបំរើបដិវត្តន៍ និងគោរពតាមវិន័យបក្សដោយឥតលក្ខខណ្ឌ[4557]។ ដូចបានបញ្ជាក់នៅកន្លែងផ្សេងទៀត អ.ជ.ស.ដ បានសន្និដ្ឋានថា សេចក្ដីណែនាំទៅកាន់កម្មាភិបាលមូលដ្ឋានចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចេញមកពីថ្នាក់លើ[4558]។ តាមរយៈការវិភាគលើភ័ស្តុតាងទាំងមូល អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា អនុលោមតាមការណែនាំរបស់ម្ចាស់បណ្ដឹងសាទុក្ខ អាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងដោយគ្រប់ក្រសួងទាំងអស់[4559]។

1245. ម្ចាស់បណ្ដឹងសាទុក្ខបានអះអាងដោយគ្មានមូលដ្ឋានថា ទំនាក់ទំនងរបស់គាត់ជាមួយនឹង "មជ្ឈិមបក្ស" មិនបង្ហាញពីការដឹងណាមួយ ដោយហេតុថា "របាយការណ៍ទាំងពីរ" ដែល អ.ជ.ស.ដ បានពឹងផ្អែក មិនលើកឡើងពីការដឹងរបស់គាត់ទេ[4560] ហើយការវិភាគដែលធ្វើឡើងដោយ អ.ជ.ស.ដ ដើម្បីគាំទ្រការសន្និដ្ឋានរបស់ខ្លួនអំពីការដឹង មិនបានយោងទៅរបាយការណ៍នោះទេ[4561]។ ផ្ទុយទៅវិញ អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាគោលនយោបាយដែលបានបង្កើតឡើងដោយ ប.ក.ក ដែលបានប្រើជាមធ្យោបាយក្នុងការបង្កើនចំនួនប្រជាជន ដូចដែលបក្ស (រួមទាំងម្ចាស់បណ្ដឹងសាទុក្ខ)[4562] បានអនុម័តជាសាធារណៈ និងបានពិភាក្សានៅក្នុងការចេញផ្សាយរបស់ទស្សនាវដ្ដី *ទង់បដិវត្តន៍*[4563]។ អំណះអំណាងរបស់

---

[4556] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៨។

[4557] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៩០។

[4558] *សូមមើល* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៨។ ឯកសារ **E1/290.1** ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ម៉ោង ១៣.៥៧.០៨-១៤.០០.៣៦ ទំព័រ ៣៤ បន្ទាត់ ៣-៤ ("ពីលើៗគ្រាន់តែយល់ព្រមឱ្យធ្វើ ធ្វើយ៉ាងម៉េចក៏ធ្វើទៅ ជាក្រុមក៏បាន ជារាយក៏បាន ស្រេចយើងពិគ្រោះគ្នាទេ")។ ឯកសារ **E1/297.1** លោកស្រី ខឹម បឿន ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ១៥.០៣.៤៩-១៥.០៧.១៨ ទំព័រ ៥៤ បន្ទាត់ ៥-៦ ("តើអ្នកស្រីយល់ស្របតាមសក្ខីកម្មរបស់លោក ពេជ្រ ជឹម នេះទេ? ឆ៖ ចាស ខ្ញុំយល់ស្រប")។

[4559] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៩។

[4560] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩៣១។

[4561] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៩៣១ ជើងទំព័រ ៣៧៦៦ *យោងទៅកាន់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៤៧-៤២៤៩, ៤៣០៣-៤៣០៨, ៤៣២៦-៤៣២៧។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦៨។

[4562] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥០-៣៥៥៥។

[4563] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៥៤-៣៥៥៥។

ម្ចាស់បណ្ដឹងសាទុក្ខក៏មើលរំលងអង្គហេតុដែលថា អ.ជ.ស.ដ បានយោងទៅលើការប្រជុំនានា ដែលពិភាក្សាលើគោលនយោបាយ និងការអនុវត្តគោលនយោបាយនៅក្នុងស្រុកជាច្រើន[4564]។ អំណះអំណាងរបស់ម្ចាស់បណ្ដឹងសាទុក្ខក៏ខកខានមិនបង្ហាញថា ការវាយតម្លៃរបស់ អ.ជ.ស.ដ លើភ័ស្តុតាង មានកំហុសទាំងស្រុង ឬថា សំអាងហេតុនេះគឺជាសំអាងហេតុមួយដែលមិនមាន អ្នកវិនិច្ឆ័យអង្គហេតុមានហេតុផលណាបានធ្វើ ផ្អែកលើការវាយតម្លៃលើភ័ស្តុតាងទាំងមូល មិន មែនលើការវាយតម្លៃលើភ័ស្តុតាងមួយផ្នែកទេ[4565]។

1246. ជាចុងក្រោយ ម្ចាស់បណ្ដឹងសាទុក្ខក៏ខកខានមិនផ្ដល់ការគាំទ្រអំណះអំណាងរបស់គាត់ដែលថា អ.ជ.ស.ដ បានសន្និដ្ឋានមិនត្រឹមត្រូវថា ពីឆ្នាំ១៩៧៤ ប.ក.ក បានចាប់ផ្ដើមរៀបចំការរៀប អាពាហ៍ពិពាហ៍កម្មាភិបាល[4566]។ ម្ចាស់បណ្ដឹងសាទុក្ខយោងតែទៅលើសារណាបណ្ដឹងសាទុក្ខ របស់គាត់ និងសក្ខីកម្មដាច់ដោយឡែក ក្នុងការបញ្ជាក់ថា "ពុំមានភ័ស្តុតាង" ទាក់ទងនឹងការ រៀបអាពាហ៍ពិពាហ៍ដោយបង្ខំមុនឆ្នាំ ១៩៧៥[4567]។ ម្ចាស់បណ្ដឹងសាទុក្ខមើលរំលងភ័ស្តុតាងដែល ថា គោលនយោបាយស្ដីពីការកសាងគ្រួសារ ត្រូវបានប្រកាសជាលើកដំបូងក្នុងទស្សនាវដ្ដី *ទង់ បដិវត្តន៍* ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៤[4568] ហើយសក្ខីកម្មរបស់សាក្សីបញ្ជាក់ភ័ស្តុតាងអំពីគោលនយោ បាយច្បាស់លាស់មួយនៅមុនឆ្នាំ ១៩៧៥[4569] ដែលក្រោយមក បានបន្តអនុវត្តនៅទូទាំងរបបកម្ពុជា ប្រជាធិបតេយ្យ។ លើសពីនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខផ្អែកលើអំណះអំណាងដែលគ្មានការគាំទ្រ ថា គោលនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា (FUNK) ក្នុងការលុបបំបាត់ពហុពន្ធភាព "ផ្ទុយ" ទៅនឹងគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលនាំឱ្យ មានការរំលោភ សេពសន្ថវៈរវាងប្ដីប្រពន្ធ[4570]។ អំណះអំណាងនេះមានកំហុសជាមូលដ្ឋាន ដោយហេតុថាការលុប បំបាត់ពហុពន្ធភាព ប្រើសម្រាប់តែកំណត់ឱ្យបុរសមានប្រពន្ធតែម្នាក់ប៉ុណ្ណោះ។ គោលនយោបាយ នេះមិនអាចបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលនាំឱ្យមានការរំលោភសេពសន្ថវៈរវាង ប្ដីប្រពន្ធនោះឡើយ។

---

[4564] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៦៧។

[4565] *សូមមើល* បទដ្ឋានក្នុងការពិនិត្យឡើងវិញ។

[4566] ឯកសារ **F54.1.1** ឧសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៧២។ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨១២។

[4567] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨១៣។

[4568] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥៤០-៣៥៤២។

[4569] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៣។

[4570] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ១៨១៤។

## ឃ. ការជួយ និងជំរុញ

1247. អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្ដឹងសាទុក្ខបានជួយ និងជំរុញឱ្យមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយ*ចេតនាដោយប្រយោល* ដែលបានប្រព្រឹត្តនៅ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះយោធាកំពង់ឆ្នាំង មន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល[4571]។ មូលដ្ឋានទាំង ៦ របស់ម្ចាស់បណ្ដឹងសាទុក្ខ[4572] ពាក់ព័ន្ធនឹង ការទទួលខុសត្រូវរបស់គាត់ក្រោមទម្រង់ជាការជួយ និងជំរុញ មិនទទួលបានផលទេ ដោយ សារគាត់មិនយកចិត្តទុកដាក់ចំពោះការយល់ឃើញពាក់ព័ន្ធនានា ប្រកាន់យកវិធីសាស្ត្រពិនិត្យ ភស្តុតាង និងសាលក្រមជាផ្នែកៗ និង យល់ខុសចំពោះច្បាប់ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃ ធាតុផ្សំសត្យានុម័តិ[4573] និងធាតុផ្សំអត្តនោម័តិ[4574]។

1248. ភស្តុតាងនៅក្នុងសំណុំរឿងនេះបង្ហាញពីធាតុផ្សំសត្យានុម័តិ ចំពោះការទទួលខុសត្រូវក្រោមទម្រង់ ជាការជួយ និងជំរុញ គឺថា ម្ចាស់បណ្ដឹងសាទុក្ខផ្ដល់ការជួយជ្រោមជ្រែងជាក់ស្ដែង ការលើកទឹក ចិត្ត ឬការគាំទ្រខាងផ្នែកស្មារតី ដល់ការបង្កើត និងប្រតិបត្តិទៅតាមគំនិតផ្ដួចផ្ដើមឧក្រិដ្ឋកម្មរបស់ មជ្ឈិមបក្ស[4575] និងជួយ និងជំរុញដល់កម្មាភិបាល ប.ក.ក ក្នុងការអនុវត្តគោលនយោបាយ[4576] ដែលមានឥទ្ធិពលយ៉ាងធំធេងទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ[4577]។

1249. ម្ចាស់បណ្ដឹងសាទុក្ខពុំចាំបាច់ចូលរួមចំណែកដោយផ្ទាល់ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយជាក់ លាក់ទេ[4578]។ ហើយក៏ពុំតម្រូវឱ្យមានផែនការ ឬការព្រមព្រៀងរវាងម្ចាស់បណ្ដឹងសាទុក្ខ និង

[4571] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១២-៤៣១៨។

[4572] មូលដ្ឋានទី ២០៩, ២៤៥-២៤៩។

[4573] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤៧។

[4574] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៩, ២៤៥, ២៤៨-២៤៩។

[4575] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៣, ៤៣១៧។

[4576] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៤។

[4577] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្ដី *ឌុច* កថាខណ្ឌ ៥៣៣។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីការឿងក្ដី *Blaškić* កថាខណ្ឌ ៤៦។ សាលដីការឿងក្ដី *Šainović* កថាខណ្ឌ ១៦៤៩។ សាលដីការឿងក្ដី *Popović* កថាខណ្ឌ ១៧៣២, ១៧៨៣។ សាលដីការឿងក្ដី *Taylor* កថាខណ្ឌ ៣៦៨។

[4578] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៣។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៧-៧១០។ សាលដីការឿងក្ដី *Taylor* កថាខណ្ឌ ៤៨១។ សាលដីការឿងក្ដី *Šainović* កថាខណ្ឌ ១៦៤៩, ១៦៦៣។ សាលដីការឿងក្ដី *Popović* កថាខណ្ឌ ១៧៥៨។ សាលដីការឿងក្ដី *Stanišić & Simatović* កថាខណ្ឌ ១០៦, ១០៨។ *ផ្ទុយពី* ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៣៣, ២១៣៥។ សូមមើល *បន្ថែមទៀត* ចម្លើយតបទៅនឹង

អាទិចារីដែរ[4579]។ ការពិត អាទិចារីមិនចាំបាច់ដឹងឮពីការចូលរួមចំណែករបស់ម្ចាស់បណ្តឹងសាទុក្ខនោះទេ[4580]។ ទោះបីទង្វើរបស់ម្ចាស់បណ្តឹងសាទុក្ខត្រូវតែមានអានុភាពធំធេងទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ[4581] តែពុំមានលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងរវាងហេតុនិងផល ឬថា ទង្វើនេះគឺជាលក្ខខណ្ឌមុនឧក្រិដ្ឋកម្មនោះទេ[4582]។ ទង្វើដែលបង្កើតជាការជួយ និងជំរុញ អាចកើតមុនពេល ក្នុងអំឡុងពេល ឬក្រោយពេលការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4583] ហើយនៅកន្លែងមួយផ្សេងពីឧក្រិដ្ឋកម្ម[4584]។ ប្រសិនបើទង្វើរបស់ម្ចាស់បណ្តឹងសាទុក្ខជាការយល់ស្រប និងការលើកទឹកចិត្តដោយតុណ្ហីភាពដល់ឧក្រិដ្ឋកម្មទាំងនោះ បើសិនទង្វើនេះចូលរួមចំណែកយ៉ាងធំធេងដល់ឧក្រិដ្ឋកម្មទាំងនោះ[4585] វាជាការគ្រប់គ្រាន់ហើយ។ ទោះបីសិទ្ធិអំណាចរបស់ម្ចាស់បណ្តឹងសាទុក្ខគឺជាកត្តាមួយនៅក្នុងកាលៈទេសៈទាំងនោះក្តី តែមិនចាំបាច់ត្រូវបង្ហាញថាគាត់មានសិទ្ធិអំណាចទៅលើចារីផ្ទាល់

---

មូលដ្ឋានទី ២៤៦។

[4579] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២២។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី *ឌុច* កថាខណ្ឌ ៥៣៤។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីការឿងក្តី *Tadić* កថាខណ្ឌ ២២៩(ii)។ សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ២៦៣។ សាលដីការឿងក្តី *Seromba* កថាខណ្ឌ ៥៧។

[4580] សាលដីការឿងក្តី *Tadić* កថាខណ្ឌ ២២៩(ii)។ សាលដីការឿងក្តី *Kalimanzira* កថាខណ្ឌ ៨៧។ សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ២៦៣។

[4581] *សូមមើលឧទាហរណ៍* សាលដីការឿងក្តី *Tadić* កថាខណ្ឌ ២២៩(iii)។ សាលដីការឿងក្តី *Gotovina & Markač* កថាខណ្ឌ ១២៧។ សាលដីការឿងក្តី *Ntawukulilyayo* កថាខណ្ឌ ២១៤។ សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៤៨១។

[4582] សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៧៤០, ១៧៨៣។ សាលដីការឿងក្តី *Ndahimana* កថាខណ្ឌ ១៤៩។ សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៥២២។ *ផ្ទុយពី* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៣១។ សូមមើល *បន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤៦។

[4583] ដូចដែល អ.ជ.ស.ដ បានកត់សម្គាល់ (ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៣) ដោយសារលក្ខខណ្ឌតម្រូវសំខាន់បំផុតគឺថាថា ការជួយជ្រោមជ្រែង ការលើកទឹកចិត្ត ឬការគាំទ្រខាងផ្នែកស្មារតី ត្រូវមានអានុភាពធំធេងលើការប្រព្រឹត្តិបទឧក្រិដ្ឋ លក្ខខណ្ឌតម្រូវនេះមិនអាចបំពេញបានទេ នៅពេលការជួយជ្រោមជ្រែងបានផ្តល់*ផ្តាច់មុខ*ក្រោយពេលប្រព្រឹត្ត។ ទោះជាយ៉ាងណាក្តី ដរាបណាលក្ខខណ្ឌតម្រូវនៃអានុភាពធំធេងត្រូវបានបំពេញ ធ្វើការរៀបចំ*នៅមុនពេល ឬក្នុងអំឡុងពេល*ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ការជួយជ្រោមជ្រែងដែលផ្តល់ក្រោយហេតុការណ៍នោះ អាចគ្រប់គ្រាន់។

[4584] សាលដីការឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ៨១។ សាលដីការឿងក្តី *Ntagerura* កថាខណ្ឌ ៣៧២។ សាលដីការឿងក្តី *Fofana & Kondewa* កថាខណ្ឌ ៧២។

[4585] សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៦៨៧។ សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ២៧៣, ២៧៧ (យោងទៅ "អ្នកមើលស្ងៀមស្ងាត់")។ សាលដីការឿងក្តី *Ndahimana* កថាខណ្ឌ ១៤៧។ សាលដីការឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ២០១-២០២ (យោងទៅ "អ្នកមើលយល់ស្រប")។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៥៤១។ *ផ្ទុយពី* ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៣៤។ សូមមើល *បន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤៧។

នោះទេ[4586]។ ជនជាប់ចោទក៏អាចជួយ និងជំរុញដោយអំពើអកម្មដែរ ប្រសិនបើមានការបង្ហាញថា ជនជាប់ចោទបានធ្វើសកម្មភាព នោះការប្រព្រឹត្តិឧក្រិដ្ឋកម្មនឹងពុំសូវមានភាពធំធេងទេ[4587]។

1250. ធាតុផ្សំអត្តនោម័តិសម្រាប់ការទទួលខុសត្រូវក្រោមទម្រង់ជាការជួយ និងជំរុញ ក៏ត្រូវបានបញ្ជាក់ផងដែរ ដែលក្នុងនោះភស្តុតាងបង្ហាញថាម្ចាស់បណ្តឹងសាទុក្ខបានដឹងឮ នៅពេលគាត់ផ្តល់ការជួយជ្រោមជ្រែង ដែលថាអំពើមនុស្សឃាតដោយ*ចេតនាដោយប្រយោល*ទំនងជានឹង[4588] ត្រូវបានប្រព្រឹត្ត ហើយថា ទង្វើរបស់គាត់បានជួយជ្រោមជ្រែង ឬបានសម្រួលដល់ការប្រព្រឹត្តិអំពើមនុស្សឃាតទាំងនេះ[4589]។ ក្រៅពីនេះ ភស្តុតាងបានបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងឮពីធាតុផ្សំសំខាន់នៃឧក្រិដ្ឋកម្ម រួមទាំងស្ថានភាពផ្លូវចិត្តរបស់ចារី តែគាត់មិនចាំបាច់រួមចំណែកនូវចេតនារបស់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទេ[4590]។ ហើយក៏ពុំតម្រូវឱ្យគាត់ដឹងឮពីឧក្រិដ្ឋកម្មច្បាស់លាស់ដែលបានប្រព្រឹត្តដោយអាទិចារីដែរ ដោយសារគាត់បានដឹងថា ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មមួយចំនួនទំនងជានឹងត្រូវបានប្រព្រឹត្ត ហើយឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងនោះពិតជាបានប្រព្រឹត្តមែន[4591]។ ពុំមានលក្ខខណ្ឌតម្រូវតាមច្បាប់បន្ថែមទៀតថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងនូវព័ត៌មានលម្អិតទាំងអស់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនាពេលបន្ទាប់នោះ

---

[4586] សាលដីការឿងក្តី *lagojević & Jokić* កថាខណ្ឌ ១៩៥។ សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៦៧២។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៥៤១។

[4587] សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៨១២, ១៧៤១។ សាលដីការឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ៤៩, ៩៧, ១០០, ១៤៦។ សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៤៨២។ សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៦៧៩, ១៦៨២ ជើងទំព័រ ៥៥១០។

[4588] ផ្ទុយពី ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២០-២១២៣។ សូមមើល *បន្ថែមទៀត* ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤៥។

[4589] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី *ឌុច* កថាខណ្ឌ ៥៣៥។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីការឿងក្តី *Blaškić* កថាខណ្ឌ ៤៥-៤៦, ៤៩-៥០។ សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៧៣២។ សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៤៨២។

[4590] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៧៧២។ សាលដីការឿងក្តី *Ndahimana* កថាខណ្ឌ ១៥៧។ សាលដីការឿងក្តី *Brima* កថាខណ្ឌ ២៤៤។ សូមមើលផងដែរ សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៧៧៣ ("កម្រិតនៃការដឹងឮពាក់ព័ន្ធនឹងព័ត៌មានលម្អិតអំពីឧក្រិដ្ឋកម្មនោះត្រូវបានតម្រូវឱ្យស្របទៅនឹងធាតុផ្សំអត្តនោម័តនៃការជួយ និងជំរុញ នឹងអាស្រ័យទៅលើកាលៈទេសៈនានានៃរឿងក្តី រួមទាំងទំហំនៃឧក្រិដ្ឋកម្ម និងប្រភេទនៃការជួយជ្រោមជ្រែងដែលផ្តល់ឱ្យ")។

[4591] សាលដីការឿងក្តី *Blaškić* កថាខណ្ឌ ៥០។ សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៧៧២។ សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៤៨២។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៥៤៦។

ទេ[4592]។ ទោះជាយ៉ាងណាក្តី គាត់បានដឹងពួពី "ធាតុផ្សំសំខាន់ៗ" នៃឧក្រិដ្ឋកម្មនោះ[4593] ដែលជាលក្ខខណ្ឌតម្រូវ (ឧទាហរណ៍ ថា មនុស្សត្រូវបានសម្លាប់) តែមិនមែនព័ត៌មានលម្អិតនៃអំពើព្រហ្មទណ្ឌជាក់លាក់នោះទេ (ឧទាហរណ៍ ទីកន្លែង ពេលវេលា និងជនរងគ្រោះ)។

## ១. ធាតុផ្សំសត្យានុម័តិ

### *មូលដ្ឋានទី ២៤៦៖ គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាត ដោយចេតនាដោយប្រយោល នៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះយោធាកំពង់ឆ្នាំង*[4594]

1251. មូលដ្ឋានទី **២៤៦ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ និងផ្នែកអង្គហេតុក្នុងការសន្និដ្ឋានថា ធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតដោយ*ចេតនាដោយប្រយោល* ត្រូវបានបង្ហាញក្រោមទម្រង់ជាការជួយ និងជំរុញ នៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងនៅព្រលានយន្តហោះយោធាកំពង់ឆ្នាំង។**

1252. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ និងផ្នែកអង្គហេតុ ក្នុងការយល់ឃើញថា គាត់ (១) បានគាំទ្រផ្នែកស្មារតី និងបានជំរុញដោយផ្ទាល់ដល់ការធ្វើសេចក្តីសម្រេចចិត្ត ចំពោះការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាននានា[4595] (២) បានជំរុញ និងបានគាំទ្រផ្នែកស្មារតីដល់កម្មាភិបាល ប.ក.ក

---

[4592] សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៩៩៣។

[4593] សូមមើលឧទាហរណ៍ សាលក្រមរឿងក្តី *Farben* ទំព័រ ១១៥៣ ("គេមិនអាចប្រើប្រាស់រចនាសម្ព័ន្ធស្ថាប័នដើម្បីសម្រេចបាននូវអំពើនិទណ្ឌភាពពីការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើខុសច្បាប់ដែលគាត់បានដឹកនាំ ផ្តល់យោបល់ *ជួយ* បញ្ជា ឬ*ជំរុញ*ទេ។ តែភស្តុតាងត្រូវបង្ហាញពីសកម្មភាពរបស់តួអង្គដែលយើងបានចង្អុលបង្ហាញ *ដោយបានដឹងពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មនោះ*។ [...] នៅក្នុងករណីមួយចំនួន គោលនយោបាយត្រូវបានបង្កើតឡើងដោយគ្មានការបង្ហាញច្បាស់លាស់ថា *ធាតុផ្សំអង្គហេតុសំខាន់ៗដែលចាំបាច់ដើម្បីឱ្យគោលនយោបាយនេះមានលក្ខណៈព្រហ្មទណ្ឌត្រូវបានបង្ហាញ*" (គូសបញ្ជាក់បន្ថែម))។ សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៧៧២។ សាលដីការឿងក្តី *Haradinaj* កថាខណ្ឌ ៥៨។ សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៤៨២។ សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៤០៤, ៤២២។

[4594] <u>មូលដ្ឋានទី ២៤៦</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាត ដោយចេតនាដោយប្រយោល នៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះយោធាកំពង់ឆ្នាំង* កថាខណ្ឌ ២១២៥-៣១។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨១ (ភាសាអង់គ្លេស) ទំព័រ ៧៦ (ភាសាបារាំង) ទំព័រ ១១៦-១១៧ (ភាសាខ្មែរ)។

[4595] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៣។

ក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ទោះក្នុងតម្លៃណាក៏ដោយ[4596] និង (៣) ចូលរួមចំណែកយ៉ាងធំធេងដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

### *អ.ជ.ស.ដ យល់ឃើញយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានផ្តល់ការគាំទ្រផ្នែកស្មារតី និងការលើកទឹកចិត្តដោយតុណ្ហីភាពដល់ការសេចក្តីសម្រេចចិត្ត*

1253. ទីមួយ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ចំពោះការយល់ឃើញរបស់ខ្លួន[4597] ជាការមិនយកចិត្តទុកដាក់ចំពោះវិធីសាស្ត្រនៃពិនិត្យទៅលើភស្តុតាងរួមរបស់ អ.ជ.ស.ដ ដើម្បីបង្ហាញពីការយល់ឃើញរបស់ខ្លួន។ ការផ្តល់សំអាងហេតុគ្រប់គ្រាន់មិនតម្រូវឱ្យលើកឡើងដដែលៗនូវភស្តុតាងទាំងអស់ ដែលអង្គជំនុំជម្រះបានទទួលយកដើម្បីបង្ហាញពីការយល់ឃើញរបស់ខ្លួនទេ[4598]។ ការពិត ការយល់ឃើញពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តិនៃការជួយ និងជំរុញ ត្រូវយកមកអានរួមគ្នាជាមួយការយល់ឃើញផ្នែកអង្គហេតុជាមូលដ្ឋាន។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4599] អ.ជ.ស.ដ បានលើកឡើងយ៉ាងច្បាស់គ្រប់គ្រាន់នូវមូលដ្ឋាននៃការយល់ឃើញរបស់ខ្លួនថា តាមរយៈការចូលរួម និងការរួមចំណែករបស់គាត់នៅក្នុងការប្រជុំជាច្រើនរបស់ ប.ក.ក ម្ចាស់បណ្តឹងសាទុក្ខ "បានគាំទ្រផ្នែកសីលធម៌ និងលើកទឹកចិត្តដោយតុណ្ហីភាពដល់ការធ្វើសេចក្តីសម្រេចចិត្ត ដែលជំរុញបន្ថែមនូវការរៀបចំផែនការ និងការអនុវត្តគំនិតផ្តួចផ្តើមឧក្រិដ្ឋកម្ម"[4600]។ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនបានពន្យល់ថាអ្វីទៅជាគំនិតផ្តួចផ្តើមឧក្រិដ្ឋកម្ម និងទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និង ព្រលានយន្តហោះយោធាកំពង់ឆ្នាំង[4601] ជាការមិនយកចិត្តទុកដាក់ចំពោះការយល់ឃើញរបស់ អ.ជ.ស.ដ អំពីគំនិតផ្តួចផ្តើមជាច្រើនដែលបានបណ្តាលឱ្យមានការស្លាប់កម្មករ ដោយសារលក្ខខណ្ឌលំបាកលំបិន[4602] ដូចជាៈ ផែនការដែលមិនអាចធ្វើបានគឺ "ធ្វើស្រែបីតោនក្នុងមួយហិចតា"[4603] គំនិតផ្តួចផ្តើមផ្នែកធារាសាស្ត្រពាក់ព័ន្ធនឹងការ

---

[4596] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៤។

[4597] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២៦-២៧។

[4598] សូមមើល បទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខ (សេចក្តីសម្រេចដែលមានសំអាងហេតុ)។

[4599] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២៦-២៧។

[4600] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៣។

[4601] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២៦-២៧។

[4602] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២១។

[4603] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៧២, ៩៧៩, ២៤៤៨, ៣៨៩៩, ៣៩០៤, ៣៩២២, ៤២៥៩។

លើកភ្លឺស្រែ ជីកប្រឡាយ សាងសង់ទំនប់ទឹក និងអាងស្តុកទឹកដោយកម្លាំងកម្មកររាប់ម៉ឺននាក់ដែលហូបចុកមិនគ្រប់គ្រាន់ "តាមជំហានដែលមិនធ្លាប់សម្រេចបានពីមុនមក"[4604] ឬការសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង ក្រោមលក្ខខណ្ឌលំបាកលំបិន និងគ្មានសុវត្ថិភាព[4605]។

1254. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា ការលើកទឹកចិត្តដោយតុណ្ហីភាពត្រូវបានកម្រិតត្រឹមតែស្ថានភាពដែលជនជាប់ចោទមានវត្តមាននៅកន្លែងកើតហេតុប៉ុណ្ណោះ[4606]។ ម្ចាស់បណ្តឹងសាទុក្ខមិនយកចិត្តទុកដាក់ចំពោះយុត្តិសាស្ត្រអន្តរជាតិ ដែលសម្រេចស្របគ្នាថា "អំពើនៃការជួយ និងជំរុញអាចត្រូវបានធ្វើឡើងនៅឯពេលវេលា និងកន្លែងមួយដែលដាច់ពីឧក្រិដ្ឋកម្មជាក់ស្តែង"[4607]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលពន្យល់នៅក្នុងរឿងក្តី *Taylor* ថា៖ "ទោះបីជនជាប់ចោទអាចនៅឆ្ងាយពីការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ តែការពិត គាត់អាចនៅក្នុងក្បែរ និងធ្វើទំនាក់ទំនងជាមួយអ្នកបញ្ជា និងដឹកនាំការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[4608]។ ច្បាប់កំណត់ច្បាស់ថា បុគ្គលម្នាក់អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការជួយ និងជំរុញដល់ឧក្រិដ្ឋកម្មមួយ ដោយទង្វើដែលជាការព្រមព្រៀង និងការលើកទឹកចិត្តដោយតុណ្ហីភាពចំពោះឧក្រិដ្ឋកម្មនោះ ដរាបណាទង្វើនោះបានចូលរួមចំណែកយ៉ាងធំធេងដល់ឧក្រិដ្ឋកម្មនោះ"[4609]។

*អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតីដល់កម្មាភិបាល ប.ក.ក ក្នុងការអនុវត្តគោលនយោបាយ ទោះក្នុងតម្លៃណាក៏ដោយ*

---

[4604] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៦៦ *ដកស្រង់* ឯកសារ **E3/273** FBIS *របាយការណ៍របស់ខៀវ សំផន* ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ EN 00167816។

[4605] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣, ១៧២៧, ១៧៥៥-៦០, ៣៩០៨, ៤២៥៨។

[4606] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២៨ *ដកស្រង់* សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ២៧៧។ ទោះជាយ៉ាងណាក្តី រឿងក្តី *Brđanin* មិនបានលើកឡើងថា ចំពោះទង្វើដែលជាការព្រមព្រៀង និងការលើកទឹកចិត្តដោយតុណ្ហីភាពចំពោះឧក្រិដ្ឋកម្ម វាត្រូវពាក់ព័ន្ធនឹងវត្តមាននៅកន្លែងកើតហេតុនោះទេ៖ រឿងក្តីនេះគ្រាន់តែពិភាក្សាទៅលើរឿងក្តីនានាដែលការព្រមព្រៀង ឬការលើកទឹកចិត្តដោយតុណ្ហីភាពត្រូវបានរកឃើញថាជាមូលដ្ឋានចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយផ្អែកលើសិទ្ធិអំណាចរបស់ជនជាប់ចោទ រួមជាមួយវត្តមានរបស់គាត់ នៅឯ/ឬ ជិតកន្លែងកើតហេតុ។

[4607] សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៤៨០ *ដកស្រង់* សាលដីការឿងក្តី *Fofana & Kondewa* កថាខណ្ឌ ៧២។ សាលដីការឿងក្តី *Kalimanzira* កថាខណ្ឌ ៨៧ ជើងទំព័រ ២៣៨។ សាលដីការឿងក្តី *Mrkšić* និងជនដទៃទៀត កថាខណ្ឌ ៨១។ សាលដីការឿងក្តី *B. Simić* កថាខណ្ឌ ៨៥។ សាលដីការឿងក្តី *Blaškić* កថាខណ្ឌ ៤៨។

[4608] សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៤៨០។

[4609] សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៦៩៧។ សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ២៧៣។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៥៤១។ សាលក្រមរឿងក្តី *Furundžija* កថាខណ្ឌ ២៣២-៣៥។

1255. ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញទឡ្ហីករណ៍ថ្មីៗទេ[4610] តែគាត់ត្រឹមតែយោងទៅការធ្វើទឡ្ហីករណ៍របស់ខ្លួននៅក្នុងមូលដ្ឋានទី ២១១ និង ២២៩ ពាក់ព័ន្ធនឹងទស្សនកិច្ចរបស់គាត់ទៅតាមសហករណ៍ និងការដ្ឋាន និង សេចក្តីថ្លែងការណ៍របស់គាត់ស្តីពីកម្លាំងពលកម្ម។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ជាការមិនសមហេតុផលដែល អ.ជ.ស.ដ សន្និដ្ឋានថា គាត់បានលើកទឹកចិត្ត និងគាំទ្រផ្នែកស្មារតីដល់កម្មាភិបាល ប.ក.ក ក្នុងការអនុវត្តគោលនយោបាយទោះក្នុងតម្លៃណាក៏ដោយ នោះទេ។ ដូចដែល អ.ជ.ស.ដ បានយល់ឃើញយ៉ាងត្រឹមត្រូវថា តាមរយៈសុន្ទរកថា ការណែនាំ និងបាឋកថារបស់គាត់ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឹកចិត្តឱ្យប្រជាជនខិតខំធ្វើការងារ "ទាំងយប់ទាំងថ្ងៃ" និង "ហូបតិច"[4611] ដើម្បីកសាងប្រទេស និងជំរុញឱ្យពួកគេបំពេញឱ្យបាន ឬ "បំពេញឱ្យលើស" ផែនការសេដ្ឋកិច្ចរបស់ ប.ក.ក "នៅគ្រប់កាលៈទេសៈទាំងអស់" ទោះបីគាត់បានសង្កេតឃើញលក្ខខណ្ឌយ៉ាងលំបាកវេទនាបំផុត នៅពេលគាត់ចុះធ្វើទស្សនកិច្ចទៅដល់ទីកន្លែងក៏ដោយ[4612]។

*អ.ជ.ស.ដ បានយល់ឃើញដោយត្រឹមត្រូវថា ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមចំណែកយ៉ាងធំធេងចំពោះឧក្រិដ្ឋកម្ម*

1256. ម្ចាស់បណ្តឹងសាទុក្ខយល់ខុសអំពីបទដ្ឋានគតិយុត្តិដើម្បីបង្ហាញពីការចូលរួមយ៉ាងធំធេង ដោយធ្វើការអះអាងដោយគ្មានដកស្រង់ឯកសារយោងតាមផ្លូវច្បាប់ថា "ពុំមានការបង្ហាញទំនាក់ទំនងហេតុផលណាមួយសោះ"[4613]។ ច្បាប់មិនតម្រូវឱ្យមានទំនាក់ទំនងហេតុផលទេ[4614]។

1257. ដោយមិនយកចិត្តទុកដាក់ដល់វិធីសាស្ត្រពិនិត្យភស្តុតាងរួមរបស់ អ.ជ.ស.ដ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ថា អ.ជ.ស.ដ មិនបានពន្យល់ពីរបៀបដែលការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតីរបស់

---

[4610] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២៩-៣០។

[4611] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៩ ជើងទំព័រ ១២៤៧៣។

[4612] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៤ ជើងទំព័រ ១៤០២៦-២៧។

[4613] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៣១។

[4614] សាលដីការឿងក្តី *Blaškić* កថាខណ្ឌ ៤៣, ៤៨។ សាលដីការឿងក្តី *Blagojević & Jokić* កថាខណ្ឌ ១៨៧។ សាលដីការឿងក្តី *B. Simić* កថាខណ្ឌ ៨៥។ សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៧៤០, ១៧៨៣។ សាលដីការឿងក្តី *Ndahimana* កថាខណ្ឌ ១៤៩។ សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៥២២។ គោលជំហរនេះត្រូវបានគាំទ្រយ៉ាងពេញលេញដោយយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ដែលបានបង្ហាញជាគោលការណ៍ថា ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការដែលមិនបានជំទាស់ទៅនឹងប្រតិបត្តិការឧក្រិដ្ឋកម្ម តាមវិធីដូចជាការចូលរួមចំណែកក្នុងការធ្វើឱ្យប្រតិបត្តិការនោះបានទទួលជោគជ័យ។ សូមមើលឧទាហរណ៍ សាលក្រមរឿងក្តី *Einsatz-gruppen* ទំព័រ ៥៧២, ៥៨០-៥៨១។ *រឿងក្តី Pohl Case* ទំព័រ ១០០២-៤ (ត្រូវបានដកស្រង់យ៉ាងពេញលេញនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ២២៧-២៣១)។

គាត់ មានឥទ្ធិពលយ៉ាងធំធេងទៅលើការស្លាប់កម្មករ[4615]។ ផ្អែកលើភស្តុតាងរួម អ.ជ.ស.ដ បាន សន្និដ្ឋានយ៉ាងត្រឹមត្រូវថា ការជួយជ្រោមជ្រែង និងការគាំទ្រផ្នែកស្មារតីរបស់ម្ចាស់បណ្តឹងសាទុក្ខ បានរួមចំណែកយ៉ាងធំធេង និងបានជួយសម្រួលដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជា ទម្រង់នៃអំពើមនុស្សឃាត (ដោយ *ចេតនាដោយប្រយោល*) នៅតាមសហករណ៍ និងការដ្ឋាន។ ការ ពិត ម្ចាស់បណ្តឹងសាទុក្ខបានចូលរួម និងរួមចំណែកក្នុងការប្រជុំជាច្រើនរបស់ថ្នាក់ដឹកនាំ ប.ក.ក ស្តីពីផលិតកម្មស្រូវ[4616] ការបង្កើតសហករណ៍[4617] ការសាងសង់រចនាសម្ព័ន្ធធារាសាស្ត្រ[4618] ព្រលានយន្តហោះយោធា[4619] និងវឌ្ឍនភាពនៃផែនការទាំងនោះ[4620]។ គាត់បានថ្លែងសុន្ទរកថាជា ច្រើនផងដែរ ក្នុងការលើកកម្ពស់គោលដៅរបស់ ប.ក.ក ក្នុងការកែប្រែប្រជាជនទាំងមូលទៅជា សង្គមកម្មករ-កសិករ[4621]។ ទោះបីបានដឹងឮពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក៏ដោយ[4622] ក៏ម្ចាស់ បណ្តឹងសាទុក្ខបានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតី ដោយជំរុញកម្លាំងពលករ "ខិតខំ ធ្វើការទាំងយប់ទាំងថ្ងៃ" និង "គ្មានឈប់សម្រាក" ដើម្បីកសាងប្រទេស ជំរុញឲ្យប្រជាជនបំពេញ ទៅតាមផែនការផលិតកម្មដែលមិនប្រាកដនិយមរបស់ ប.ក.ក[4623] ដើម្បីនាំចេញអង្ករក្នុងបរិមាណ យ៉ាងច្រើន ទោះបីប្រជាជនរងការអត់ឃ្លានក៏ដោយ[4624]។

---

[4615] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៥។

[4616] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩០១ *ដកស្រង់* ឯកសារ **E3/226** កំណត់ហេតុប្រជុំការងារ សង្គមកិច្ច សុខាភិបាល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ EN 00017155, កថាខណ្ឌ ៩៦៨ *ដកស្រង់* ឯកសារ **E3/224** កំណត់ ហេតុនៃអង្គប្រជុំ គណៈអចិន្ត្រៃយ៍ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៦ EN 00000774-775, កថាខណ្ឌ ៣៨៩១។

[4617] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦។

[4618] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៣៦។

[4619] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៣ *ដកស្រង់* ឯកសារ **E3/182** ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៧៥ EN 00019108។

[4620] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧២៧ *ដកស្រង់* ឯកសារ **E3/222** កំណត់ហេតុនៃអង្គប្រជុំ គណៈអចិន្ត្រៃយ៍ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ EN 00000771។ កថាខណ្ឌ ៣៥៥, ៣៦៤, ១៤៧៤, ១៤៥៨។

[4621] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨៩៧។

[4622] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩១៦។

[4623] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៤។

[4624] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៩៤-៩៥, ៣៩០៧, ៣៩០៩, ៣៩១៤, ៤២៦៥-៦៦, ៤២៧៦។ *សូមមើលផងដែរ* កថាខណ្ឌ ៦១៩, ៦២១, ៣៨៨៩។

## *មូលដ្ឋានទី ២៤៧៖ គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតនៅមន្ទីរ ស-២១ ក្រាំងតាចាន់ និង ភ្នំក្រោល*[4625]

1258. មូលដ្ឋានទី **២៤៧ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ និងផ្នែកអង្គហេតុក្នុងការសន្និដ្ឋានថា ធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតដោយ** ***ចេតនាដោយប្រយោល*** **ត្រូវបានបង្ហាញក្រោមទម្រង់ជាការជួយ និង ជំរុញ នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល។**

1259. មូលដ្ឋាននេះមិនទទួលបានផលទេ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ និងផ្នែកអង្គហេតុ ក្នុងការសន្និដ្ឋានថា ការជួយជ្រោមជ្រែងជាក់ស្តែង និងការគាំទ្រផ្នែកស្មារតីរបស់គាត់ដល់ “មជ្ឈិមបក្ស” ក្នុងការបង្កើត និងប្រតិបត្តិគោលនយោបាយបោសសម្អាត បានបង្កើតជាការចូលរួមចំណែកយ៉ាងធំធេងក្នុងការប្រព្រឹត្តិដោយ *ចេតនាដោយប្រយោល* នូវអំពើមនុស្សឃាត ដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ។

1260. ម្ចាស់បណ្តឹងសាទុក្ខយល់ខុសចំពោះបទដ្ឋានគតិយុត្តិដែលតម្រូវឱ្យមានធាតុផ្សំសត្យានុម័តិ ចំពោះការជួយ និងជំរុញ ដោយលើកជាទឡ្ហីករណ៍ថា ការជួយជ្រោមជ្រែងជាក់ស្តែង និងការគាំទ្រផ្នែកស្មារតីត្រូវតែ “ផ្តល់ជាពិសេសដល់ការប្រព្រឹត្តិបទល្មើសមនុស្សឃាត [...] មិនមែនចូលរួមចំណែកក្នុងការបង្កើត និងអនុវត្តគោលនយោបាយនោះទេ”[4626]។ ការអះអាងដែលគ្មានមូលដ្ឋានគាំទ្ររបស់ម្ចាស់បណ្តឹងសាទុក្ខ[4627] គឺពុំត្រឹមត្រូវទេ។ “គោលដៅជាក់លាក់” មិនមែនជាធាតុផ្សំនៃការទទួលខុសត្រូវក្រោមទម្រង់ជាការជួយ និងជំរុញ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[4628]។ ដូចដែល អ.ជ.ស.ដ បានសម្រេចយ៉ាងត្រឹមត្រូវអនុលោមទៅតាមយុត្តិសាស្រ្តអន្តរជាតិ អ្វីៗទាំងអស់ដែលត្រូវបានតម្រូវឱ្យបំពេញទៅតាមលក្ខខណ្ឌនៃធាតុផ្សំសត្យានុម័តិ គឺថា ជនជាប់ចោទបានផ្តល់

---

[4625] <u>មូលដ្ឋានទី ២៤៧</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតនៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល* កថាខណ្ឌ ២១៣២-៣៦។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨១ (ភាសាអង់គ្លេស) ទំព័រ ៧៦ (ភាសាបារាំង) ទំព័រ ១១៧ (ភាសាខ្មែរ)។

[4626] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៣៣, ២១៣៥។ *សូមមើលផងដែរ* កថាខណ្ឌ ១៦០៤-១៦១៥។

[4627] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៣៣, ២១៣៥។

[4628] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៧-១០។ សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៤៨១។ សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៦៤៩, ១៦៦៣។ សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៧៥៨។ សាលដីការឿងក្តី *Stanišić & Simatović* កថាខណ្ឌ ១០៦, ១០៨។

ការជួយជ្រោមជ្រែងជាក់ស្តែង ឬការគាំទ្រផ្នែកស្មារតីដែលមានឥទ្ធិពលយ៉ាងធំធេងទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4629]។

1261. ម្ចាស់បណ្តឹងសាទុក្ខអះអាងថា អ.ជ.ស.ដ មិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ចំពោះការយល់ឃើញរបស់ខ្លួន[4630] តែមិនយកចិត្តទុកដាក់ម្តងទៀតដល់វិធីសាស្ត្រពិនិត្យភស្តុតាងរួមរបស់ អ.ជ.ស.ដ។ អ.ជ.ស.ដ បានផ្តល់ព័ត៌មានលម្អិតអំពីមូលដ្ឋាននៃការយល់ឃើញរបស់ខ្លួនថា គាត់បានផ្តល់ការជួយជ្រោមជ្រែងជាក់ស្តែង និងការគាំទ្រផ្នែកស្មារតីដល់ "មជ្ឈិមបក្ស" និងបានចូលរួមចំណែកយ៉ាងធំធេងដល់អំពើមនុស្សឃាតដោយ *ចេតនាដោយប្រយោល* នៅតាមមន្ទីរសន្តិសុខ[4631]។ ម្ចាស់បណ្តឹងសាទុក្ខមិនយកចិត្តទុកដាក់ដល់ការយល់ឃើញរបស់ អ.ជ.ស.ដ អំពីការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំ ប.ក.ក ដែលសម្រេចទៅលើជោគវាសនារបស់ខ្មាំង[4632] ព្រមទាំងការអំពាវនាវរបស់គាត់ឱ្យសម្លាប់ពួកក្បត់[4633]។ ការពិត អ.ជ.ស.ដ បានយល់ឃើញក្នុងចំណោមនោះថា (១) គាត់បានចូលរួមក្នុងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលសម្រេចលើជោគវាសនារបស់ ជូ ជេត *ហៅ* ស៊ី[4634] (២) គាត់បានធ្វើការស៊ើបអង្កេតដើម្បីសម្រេចថាតើ បុគ្គលទាំងនេះគឺជាខ្មាំង ឬយ៉ាងណា[4635] (៣) គាត់បានដឹកនាំការអប់រំនយោបាយដែលគាត់បានធ្វើបាឋកថាលើការកំណត់ "ខ្មាំង" និងលាតត្រដាង "ជនក្បត់"[4636] (៤) គាត់បានដាស់តឿនប្រជាជនឱ្យស្វែងរក

---

[4629] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២២។ *សូមមើលឧទាហរណ៍* សាលដីការឿងក្តី *Tadić* កថាខណ្ឌ ២២៩(iii)។ សាលដីការឿងក្តី *Gotovina & Markač* កថាខណ្ឌ ១២៧។ សាលដីការឿងក្តី *Ntawukulilyayo* កថាខណ្ឌ ២១៤។ សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៤៨១។

[4630] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៣២-៣៦ ជាពិសេស ២១៣៣។

[4631] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៧។

[4632] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៦ ជើងទំព័រ ១៤០៣០ *យោងទៅ* កថាខណ្ឌ ៤២២១-៣៤។

[4633] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៦ *យោងទៅ* កថាខណ្ឌ ៤២៧២។

[4634] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៨។ សូមមើលផងដែរ ចម្លើយតបទៅនឹងមូលដ្ឋានទី ២៨ (ភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម), ២១៧ (ការដឹងឮពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្នុងអំឡុងពេលនៃការបោសសម្អាត)។

[4635] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២២៨។

[4636] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧២ *យោងទៅ* កថាខណ្ឌ ៦០៧។

"ខ្មាំងផ្ទៃក្នុង" និងអ្នកដែលប្រឆាំង ឬរារាំងដល់បដិវត្តន៍[4637] និង (៥) គាត់បានណែនាំដល់កម្មាភិបាលនៅក្រសួងពាណិជ្ជកម្មដើម្បីថ្កោលទោស "អ្នកខ្ជិលធ្វើការថាជាខ្មាំងរបស់បក្ស"[4638]។

## ២. ធាតុផ្សំអត្តនោម័តិ

### *មូលដ្ឋានទី ២៤៥៖ ការជួយជ្រោមជ្រែង និងការជំរុញ តាមផ្លូវច្បាប់*[4639]

1262. **មូលដ្ឋានទី ២៤៥ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ដោយសន្និដ្ឋានថា ធាតុផ្សំអត្តនោម័តិចំពោះការជួយ និងជំរុញ រួមទាំងការដឹងឮថា "ឧក្រិដ្ឋកម្មទំនងជានឹងប្រព្រឹត្ត"។**

1263. ម្ចាស់បណ្តឹងសាទុក្ខបានបញ្ចូលទិដ្ឋភាពពីរដាច់ពីគ្នានៃធាតុផ្សំអត្តនោម័តិចំពោះការជួយ និងជំរុញ នៅពេលគាត់លើកឡើងថា ដោយសារជនជាប់ចោទអាចធ្វើសកម្មភាពដោយ "អំពើដែលគាត់បានធ្វើចូលរួមចំណែក [...] [ក្នុង] ការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ដោយចារីបង្គោលនោះ" ចាំបាច់ត្រូវមានលក្ខខណ្ឌតម្រូវមួយដែលគាត់ត្រូវដឹងឮថាឧក្រិដ្ឋកម្ម*នឹង*ប្រព្រឹត្ត មិនមែនគ្រាន់តែ "ទំនងជានឹង" ប្រព្រឹត្តនោះទេ[4640]។

1264. ការដឹងឮពីភាពទំនងថាឧក្រិដ្ឋកម្មនឹងប្រព្រឹត្ត និងការដឹងឮពីការចូលរួមចំណែកក្នុងការជួយជ្រោមជ្រែងរបស់ជនជាប់ចោទដល់ឧក្រិដ្ឋកម្មទាំងនោះ គឺជាធាតុផ្សំផ្នែកផ្លូវចិត្តពីរដាច់ពីគ្នា។ អ.ជ.ស.ដ បានបែងចែកច្បាស់រវាងទង្វើទាំងនោះ នៅពេលអង្គយជំនុំជម្រះយល់ឃើញថា ជនជាប់ចោទ "ត្រូវតែបានដឹងថា បទឧក្រិដ្ឋមួយអាចនឹងត្រូវបានប្រព្រឹត្តឡើង ហើយអំពើរបស់ខ្លួននេះបានជួយ ឬសម្រួលដល់ការប្រព្រឹត្តបទឧក្រិដ្ឋនោះ"[4641]។ ទម្រង់ផ្សេងទៀតនៃការសាកល្បងដូចគ្នានេះដែល

---

[4637] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧២ *យោងទៅ* កថាខណ្ឌ ៣៩៤២-៤៣។

[4638] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៧២ *យោងទៅ* កថាខណ្ឌ ៦២០។

[4639] <u>មូលដ្ឋានទី ២៤៥</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការជួយជ្រោមជ្រែង និងការជំរុញ តាមផ្លូវច្បាប់* កថាខណ្ឌ ២១២០-២១២៣។ *សូមមើលផងដែរ* កថាខណ្ឌ ១៦០៤-១៦១៥។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨១ (ភាសាអង់គ្លេស) ទំព័រ ៧៥ (ភាសាបារាំង) ទំព័រ ១១៦ (ភាសាខ្មែរ)។

[4640] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២០-២១២៣ *ដកស្រង់* ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧-៨៩។

[4641] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២២ (គូសបញ្ជាក់បន្ថែម) *ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧០៤។

បានផ្តល់ដោយ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០១ គូសបញ្ជាក់នូវភាពខុសគ្នានេះកាន់តែច្បាស់ថា៖

> ការទទួលខុសត្រូវចំពោះ [ការជួយ និងជំរុញ] ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម តម្រូវឲ្យបង្ហាញភស្តុតាងថា ជនជាប់ចោទ *បានដឹងថាឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្ត* ហើយដែលឧក្រិដ្ឋកម្មនោះពិតជាប្រព្រឹត្តមែន ហើយជនជាប់ចោទ *បានដឹងថា*អំពើរបស់ខ្លួនបានជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ[4642]។

1265. ហេតុនេះ ទីមួយ ជនជាប់ចោទត្រូវដឹងថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មគឺ "ប្រហែល" ឬ "ទំនងជា"។ ទីពីរ គាត់ត្រូវបានដឹង ពោលគឺ ដឹងថា ការជួយជ្រោមជ្រែងរបស់គាត់នឹងជួយសម្រួលដល់ឧក្រិដ្ឋកម្មនោះ*ប្រសិនបើវាកើតឡើង*។ ចំណុចទីមួយទទួលស្គាល់ថា មិនអាចមានភាពប្រាកដប្រជាដាច់ខាតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនាពេលអនាគតទេ ដោយសារអាចមានព្រឹត្តិការណ៍មិនបង្អាក់។ ចំណុចនេះពាក់ព័ន្ធជាពិសេស នៅពេលដែលមានការផ្តល់ការជួយជ្រោមជ្រែងនៅពេលវេលា និង/ឬ ទីកន្លែងមួយដែលនៅឆ្ងាយពីឧក្រិដ្ឋកម្ម[4643]។ ទោះបីយុត្តិសាស្ត្រមួយចំនួន[4644] លុបចោលការយោងដោយផ្ទាល់ដល់ចំណុចទីមួយនេះក្តី តែមានការទទួលស្គាល់នៅក្នុងអង្គហេតុថា ជនជាប់ចោទអាចទទួលខុសត្រូវត្រឹមតែជាចារីបន្ទាប់បន្សំប៉ុណ្ណោះ *ប្រសិនបើ*ឧក្រិដ្ឋកម្មនោះកើតឡើង[4645]។ គាត់មិនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែល "នឹងទំនង" តែការពិតមិនបានកើតឡើងនោះទេ។

1266. យុត្តិសាស្ត្រជាច្រើនពីតុលាការ*មិនអចិន្ត្រៃយ៍* ព្រមទាំងករណីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ គាំទ្រដល់ការសម្រេចរបស់ អ.ជ.ស.ដ។ ដូចដែលសាលដីការឿងក្តី *Blaškić* ដែល

---

[4642] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី *ឌុច* កថាខណ្ឌ ៥៣៥ (គូសបញ្ជាក់បន្ថែម)។

[4643] សូមមើលឧទាហរណ៍ សាលដីការឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ៨១។ សាលដីការឿងក្តី *Ntagerura* កថាខណ្ឌ ៣៧២។ សាលដីការឿងក្តី *Fofana & Kondewa* កថាខណ្ឌ ៧២។

[4644] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២១ *ដកស្រង់* ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨ *ដែលដកស្រង់ពី* សាលដីការឿងក្តី *Rukundo* កថាខណ្ឌ ៥៣។ សាលដីការឿងក្តី *Kalimanzira* កថាខណ្ឌ ៨៦។ សាលដីការឿងក្តី *Ntawukulilyayo* កថាខណ្ឌ ២២២។ សាលដីការឿងក្តី *Gotovina & Markač* កថាខណ្ឌ ១២៧។ សាលដីការឿងក្តី *Lukić & Lukić* កថាខណ្ឌ ៤២៧, ៤៤០, ៤៥៨។

[4645] សូមមើល *បន្ថែមទៀត* សាលដីការឿងក្តី *Tadić* កថាខណ្ឌ ២២៩(i)។ សាលដីការឿងក្តី *Lukić & Lukić* កថាខណ្ឌ ៤២៨, ៤៤០ ("មានការលើកឡើងយ៉ាងត្រឹមត្រូវថា ធាតុផ្សំអត្តនោម័តនៃការជួយ និងជំរុញតម្រូវថា អ្នកជួយ និងជំរុញដឹងថា អំពើរបស់គាត់នឹងជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយចារីចម្បង"។ នៅទីនេះ ការប្រើពាក្យ "នឹង" បង្ហាញពីលក្ខខណ្ឌ៖ ជនជាប់ចោទដឹងថា វា "នឹងជួយក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម" *ប្រសិនបើឧក្រិដ្ឋកម្មនោះកើតឡើង*)។

អ.ជ.ស.ដ បានដកស្រង់[4646] បានលើកឡើងយ៉ាងត្រឹមត្រូវថា មានលទ្ធផលជាការទទួលខុសត្រូវនៅពេលជនជាប់ចោទ "ដឹងថាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មមួយចំនួន *ប្រហែលជានឹងប្រព្រឹត្តឡើង* ហើយការពិត ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងនោះបានប្រព្រឹត្តមែន"[4647]។ សាលដីការឿងក្តី *Blaškić* បានដកស្រង់ (និងបានធ្វើសំអាង) សាលក្រមរឿងក្តី *Furundžija* សម្រាប់សំណើនេះ ដែលបានធ្វើការសិក្សាយ៉ាងយូរទៅលើសំណុំរឿងនានាក្រោយសង្គ្រាមលោកលើកទី២[4648]។ ផ្ទុយពីការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ[4649] ចាប់ពីពេលនោះមក រឿងក្តី *Blaškić* ត្រូវបានយកមកធ្វើជាគំរូ និងអនុវត្តតាមនៅក្នុងសាលដីកាជាបន្តបន្ទាប់នៅតុលាការ ICTY និងតុលាការ SCSL[4650]។

1267. យុត្តិសាស្រ្តបន្ថែមទៀតយោងទៅការដឹងឮរបស់ជនជាប់ចោទ អំពីឧក្រិដ្ឋកម្មដែលបាន *ប៉ុនប៉ង*[4651] តែបើតាមនិយមន័យ ការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនច្បាស់លាស់ទេ រហូតដល់ពេលកើតឡើងជាក់ស្តែង។ ដូចដែលតុលាការ IMT យល់ឃើញថា៖

> ហ៊ីត្លែរមិនអាចធ្វើសង្គ្រាមឈ្លានពានតែម្នាក់ឯងទេ។ គាត់ត្រូវមានការសហការពីរដ្ឋបុរស មេដឹកនាំយោធា អ្នកការទូត និងអ្នកជំនួញ។ នៅពេលពួកគេ *ផ្តល់ការសហការជាមួយគាត់ ដោយដឹងឮអំពីគោលបំណងរបស់គាត់* ពួកគេបានចូលរួម

---

[4646] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២២។

[4647] សាលដីការឿងក្តី *Blaškić* កថាខណ្ឌ ៥០ *ដកស្រង់* សាលក្រមរឿងក្តី *Furundžija* កថាខណ្ឌ ២៤៦ (គូសបញ្ជាក់បន្ថែម)។ នៅក្នុងសាលដីកាដដែលនោះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក៏បានគាំទ្រ *ផងដែរ*ដល់ទម្រង់នៃធាតុផ្សំអត្តនោម័តចំពោះការជួយ និងជំរុញ ដូចតទៅ៖ "នៅក្នុងករណីជួយ និងជំរុញ ធាតុផ្សំផ្លូវចិត្តចាំបាច់គឺការដឹងថា អំពើដែលអ្នកជួយ និងជំរុញបានប្រព្រឹត្ត គឺជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មជាក់លាក់របស់ចារីចម្បង" (សាលដីការឿងក្តី *Blaškić* កថាខណ្ឌ ៤៥)។ ការណ៍ដែលថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY គាំទ្រដល់ទម្រង់ទាំងពីរនេះដំណាលគ្នាបង្ហាញច្បាស់ថា អ្វីដែលតម្រូវឱ្យជនជាប់ចោទត្រូវ*ដឹង*គឺថា អំពើរបស់គាត់នឹងជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ។ គាត់ *មិន*តម្រូវឱ្យ*ដឹង*ថាឧក្រិដ្ឋកម្មនោះនឹងប្រព្រឹត្តទេ គ្រាន់តែតម្រូវឱ្យគាត់យល់ថាឧក្រិដ្ឋកម្មនោះ*ប្រហែលជា*នឹងប្រព្រឹត្ត ហើយថា ប្រសិនបើវាជាការពិត នោះអំពើរបស់គាត់នឹងជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះហើយ។

[4648] សាលក្រមរឿងក្តី *Furundžija* កថាខណ្ឌ ២៣៦-២៤៩។

[4649] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២១។ ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨។

[4650] សូមមើលឧទាហរណ៍ សាលដីការឿងក្តី *Šainović* កថាខណ្ឌ ១៧៧២។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៥៤៦។ សាលដីការឿងក្តី *B. Simić* កថាខណ្ឌ ៨៦។ សាលដីការឿងក្តី *Haradinaj* កថាខណ្ឌ ៥៨។

[4651] សូមមើលឧទាហរណ៍ សាលដីការឿងក្តី *Nahimana* កថាខណ្ឌ ៤៨២ ("ពុំចាំបាច់ត្រូវដឹងឮពីឧក្រិដ្ឋកម្មជាក់លាក់ដែល *ប៉ុនប៉ងប្រព្រឹត្ត* និងព្រឹត្តិការណ៍នៃការប្រព្រឹត្តិទេ")។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៥៤៦។

ជាភាគីនៃផែនការដែលគាត់បានផ្តួចផ្តើមឡើង។ ពួកគេមិនត្រូវបានចាត់ទុកជាអ្នកគ្មានពិរុទ្ធភាពបានទេ ដោយសារហ៊ីត្លែរប្រើប្រាស់ពួកគេ ប្រសិនបើ*ពួកគេបានដឹងពីអ្វីដែលខ្លួនកំពុងធ្វើ*[4652]។

1268. ការពិត ក្រោយសង្គ្រាមលោកលើកទី២ តុលាការនានាបានបញ្ជាក់ច្បាស់ថា ក្នុងការយល់ឃើញថា ចុងចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ "ការចូលរួមដោយដឹងឮ" នោះ[4653] ពុំតម្រូវឱ្យមានការដឹងឮថា ឧក្រិដ្ឋកម្មជាក់លាក់មួយប្រាកដជានឹងប្រព្រឹត្តឡើង ដោយមានការជួយជ្រោមជ្រែងពីពួកគេ[4654] នោះទេ។ ការដឹងឮជាទូទៅថាឧក្រិដ្ឋកម្មមួយ ឬច្រើន ត្រូវបានរៀបចំផែនការ ឬកំពុងប្រព្រឹត្ត ហើយទំនងជានឹងប្រព្រឹត្តនាពេលអនាគត ជាការគ្រប់គ្រាន់ហើយ។ ឧទាហរណ៍ តុលាការ IMT យល់ឃើញថា Von Schirach មានពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចាំបាច់តម្រូវឱ្យគាត់ដឹងឮជាមុនពីឧក្រិដ្ឋកម្មនានាដែលនឹងប្រព្រឹត្តចំពោះជនជាតិជ្វីហ្វ នៅពេលគាត់ចូលរួមក្នុងការនិរទេសពួកគេទេ។ ចៅក្រមបានសំអាងទៅលើការដឹងឮរបស់គាត់ "ថា ក្តីសង្ឃឹមដែលជនជាតិជ្វីហ្វអាចមាន គឺសោកនាដកម្មនៅកន្លែងជួបជុំប៉ែកខាងកើត" និងអង្គហេតុដែលថា នៅក្នុងការិយាល័យគាត់ មានព្រឹត្តិប័ត្រនានាដែលពិពណ៌នាអំពីការសម្លាប់រង្គាលជនជាតិជ្វីហ្វ[4655]។

1269. ស្រដៀងគ្នាដែរ នៅក្នុងសាលក្រមរឿងក្តី *Justice* តុលាការយោធាអាមេរិកបានសម្រេចដាក់ពិរុទ្ធភាព Klemm ដោយសារគាត់ធ្វើសកម្មភាពដោយបានដឹងឮជាទូទៅអំពី "គោលនយោបាយ និងវិធីសាស្ត្រ" របស់ថ្នាក់ដឹកនាំណាហ្ស៊ី ក្នុងការគ្រប់គ្រងសកម្មភាពឧក្រិដ្ឋជាច្រើន[4656]។ តុលាការនេះក៏បានសម្រេចដាក់ពិរុទ្ធភាព Flick ផងដែរ ដែលជាអ្នកជំនួយដែលបានផ្គត់ផ្គង់ប្រាក់កាសដល់ Himmler ក្នុងនាមជាចារីបន្ទាប់បន្សំ ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយពួក SS (Schutzstaffel)[4657] ដោយផ្អែកលើមូលដ្ឋានថា នាពេលមួយគាត់បានជួយជ្រោមជ្រែង នៅពេល

[4652] សាលក្រមតុលាការ IMT ទំព័រ ២២៦ (គូសបញ្ជាក់បន្ថែម)។

[4653] សូមមើលឧទាហរណ៍ សាលក្រមរឿងក្តី *Justice* ទំព័រ ១០៩៣។

[4654] *ផ្ទុយពី* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦០៩-១៦១៥។

[4655] សាលក្រមតុលាការ IMT ទំព័រ ៣១៨-៣១៩។

[4656] សាលក្រមរឿងក្តី *Justice* ទំព័រ ១០៩៤ (ក្នុងចំណោមអង្គហេតុផ្សេងទៀត គាត់ "បានដឹងឮអំពីការបំពារបំពាននៅតាមជំរុំប្រមូលផ្តុំ។ គាត់បានដឹងឮពីការអនុវត្តការសួរចម្លើយធ្ងន់ធ្ងរ។ គាត់បានដឹងឮពីការធ្វើទុក្ខបុកម្នេញ និងការបង្ក្រាបទៅលើជនជាតិជ្វីហ្វ និងជនជាតិប៉ូឡូញ និងពួកជីបស៊ី។ តាមរយៈភស្តុតាងនានា ត្រូវតែបានសន្មតថាបានដឹងពីមូលដ្ឋានទូទៅនៃនីតិវិធី Nacht und Nebel នៅក្រោមក្រសួងយុត្តិធម៌")។

[4657] សាលក្រមរឿងក្តី *Flick* ទំព័រ ១២១៦។

"សកម្មភាពឧក្រិដ្ឋ" របស់ពួក SS ត្រូវបានដឹងឮជាទូទៅ[4658]។ នៅក្នុងរឿងក្តី *Einsatzgruppen*[4659] តុលាការបានសម្រេចថា Klingelhöfer នឹងមានពិរុទ្ធភាពជាចារីបន្ទាប់បន្សំ ប្រសិនគាត់បានស្វែងរក វាយតម្លៃ និងបញ្ជូនបញ្ជីឈ្មោះមន្ត្រីបក្សកុម្មុយនីស្តទៅឱ្យពួក SS ដោយដឹងឮថា មន្ត្រីទាំងនោះនឹងត្រូវយកទៅសម្លាប់ *ប្រសិនបើគេរកឃើញ*[4660]។ ដោយសារជនរងគ្រោះទាំងនោះមិនត្រូវបានរកឃើញ ឧក្រិដ្ឋកម្មប្រឆាំងពួកគេគ្រាន់តែ "ទំនងជា" កើតឡើង នៅពេលមានអំពើជួយជ្រោមជ្រែងនោះ។

1270. ហេតុនេះ ទម្រង់របស់ អ.ជ.ស.ដ មានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបានបង្ហាញយ៉ាងច្បាស់នៅត្រឹមសម័យកាលក្រោយសង្គ្រាមលោកលើកទី២។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខថា លក្ខខណ្ឌតម្រូវនៅក្នុងមាត្រា ២៥(៣)(គ) នៃលក្ខន្តិកៈទីក្រុងរ៉ូមដែលថាជនជាប់ចោទធ្វើសកម្មភាព "ដើម្បីជួយសម្រួល" ដល់ឧក្រិដ្ឋកម្មមួយ គួរច្រានចោលបទដ្ឋានដែលបានបង្កើតឡើងនេះ[4661] គឺជាការយល់ច្រឡំ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL បានសម្រេចថា "លក្ខន្តិកៈទីក្រុងរ៉ូមពុំមានចំណងកាតព្វកិច្ចទៅលើធាតុផ្សំអត្តនោម័តនៃការទទួលខុសត្រូវក្រោមទម្រង់ជា [ការជួយ និងជំរុញ] ទៅតាម [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] ទេ"[4662]។

## ***មូលដ្ឋានទី ២០៩៖ ការដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត***[4663]

1271. **មូលដ្ឋានទី ២០៩ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការយល់ឃើញថា គាត់បានដឹងឮអំពីភាវនីយភាពនៃឧក្រិដ្ឋកម្ម។**

---

[4658] សាលក្រមរឿងក្តី *Flick* ទំព័រ ១២១៦-១២២៣ (ចំណុចទាំងនេះរួមមាន ការធ្វើទុក្ខបុកម្នេញ និងការសម្លាប់រង្គាលជនជាតិជ្វីហ្វ អំពើឃោរឃៅ និងការសម្លាប់នៅតាមជំរុំប្រមូលផ្តុំ ការប្រើប្រាស់ការគ្រប់គ្រងធ្ងន់ធ្ងរទៅលើទឹកដីដែលបានកាន់កាប់ ការគ្រប់គ្រងកម្មវិធីពលកម្មរបស់ទាសករ និងការធ្វើបាប និងអំពើមនុស្សឃាតពួកឈ្លើយសឹក)។

[4659] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២២។

[4660] សាលក្រមរឿងក្តី *Einsatzgruppen* ទំព័រ ៥៦៩ (គូសបញ្ជាក់បន្ថែម)។

[4661] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១២១។ ឯកសារ **F17** សារណាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨។

[4662] សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៤៣៥។

[4663] <u>មូលដ្ឋានទី ២០៩</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *ការដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត* កថាខណ្ឌ ១៨០៨-១៨១១។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៧១ (ភាសាអង់គ្លេស) ទំព័រ ៦៦ (ភាសាបារាំង) ទំព័រ ១០១-១០២ (ភាសាខ្មែរ)។

1272. អ.ជ.ស.ជ បានលើកឡើងយ៉ាងត្រឹមត្រូវនូវច្បាប់អំពីធាតុផ្សំអត្តនោម័តិចំពោះការជួយ និង ជំរុញ[4664]។ ម្ចាស់បណ្តឹងសាទុក្ខជំទាស់ចំណុចនេះ ដោយមិនបានលើកឡើងនូវទឡ្ហីករណ៍លើអង្គសេចក្តី ឬដកស្រង់ប្រភពឯកសារច្បាប់នានាទេ[4665] ដោយគ្រាន់តែយោងទៅកំហុសពីរចំណុចដែលបានចោទប្រកាន់ ដែលកំហុសទាំងនោះយោងត្រឡប់ទៅរកកំហុសដែលបានចោទប្រកាន់នេះវិញតែប៉ុណ្ណោះ[4666]។ ការអះអាងនេះមិនសក្តិសមនឹងបង្ហាញពីកំហុសដែលនាំឲ្យមោឃៈសាលក្រម ឬ ធ្វើឲ្យភាពមិនយុត្តិធម៌ជាក់ស្តែងនោះទេ។

1273. ម្ចាស់បណ្តឹងសាទុក្ខបានដឹងឮជាយូរមកហើយថា ឧក្រិដ្ឋកម្មទំនងជានឹងប្រព្រឹត្ត ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ តាមរយៈការអនុវត្តគោលការណ៍របស់ ប.ក.ក។ សកម្មភាពនានារបស់គាត់មុនសម័យកម្ពុជាប្រជាធិបតេយ្យបង្ហាញពីការដឹងឮនេះ ទោះបីផ្តល់នូវបរិបទនៃទស្សនៈរបស់គាត់ និងការចូលរួមក្នុងបក្ស ដោយបង្ហាញនូវដំណើរវឌ្ឍនភាពតាមរយៈឋានៈនៅក្នុងបក្ស ដោយសារ ចុងក្រោយគាត់ក្លាយជាមេដឹកនាំតែម្តង[4667]។ ចំណុចនេះបង្ហាញច្បាស់តាមរយៈជោគវាសនារបស់អ្នកផ្សេងដែលគេចាត់ទុកថាមិនបានគាំទ្រឲ្យបានពេញលេញដល់គោលបំណង និងមធ្យោបាយរបស់បក្ស ដើម្បីសម្រេចទៅតាមគោលបំណងទាំងនោះដែលថា គាត់បានឡើងឋានៈដោយសារគាត់គាំទ្រដោយស្មោះអស់ពីដួងចិត្ត ដល់មធ្យោបាយនានាដែលអនុវត្តតាមគោលបំណងរបស់បក្ស។ ម្ចាស់បណ្តឹងសាទុក្ខក៏បានដើរតួនាទីសំខាន់ផងដែរ ក្នុងការគាំទ្រចលនារបស់ ប.ក.ក ចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ដែលផ្តល់ធម្មានុរូបកម្មដល់បក្ស និងគោលនយោបាយរបស់បក្សឆ្ពោះទៅខែមេសា ឆ្នាំ១៩៧៥ ដែលបានត្រួសត្រាយផ្លូវដល់ការផ្លាស់ទីលំនៅប្រជាជន និងឧក្រិដ្ឋកម្មនានាដោយសារដំណើរការនេះ[4668]។

1274. ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ម្ចាស់បណ្តឹងសាទុក្ខទទួលបានអំណាចច្រើនជាងមុន ហេតុនេះបានដឹងឮច្រើនជាងមុននូវភវនីយភាពនៃឧក្រិដ្ឋកម្ម។ គាត់ជាបុគ្គលម្នាក់ក្នុងចំណោម

[4664] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២២។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤៥។

[4665] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០៨-១៨១១។

[4666] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨០៨ ជើងទំព័រ ៣៥០៣ *ដកស្រង់* កថាខណ្ឌ ២១៣៧-២១៤០, កថាខណ្ឌ ២១៣៨ ជើងទំព័រ ៤១០៧ *យោងទៅ* កថាខណ្ឌ ១៨០៨-១៨១០, កថាខណ្ឌ ២១៤០ ជើងទំព័រ ៤១១១ *យោងទៅ* កថាខណ្ឌ ១៨០៨-១៨១៥។

[4667] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៦, ១៩៧។

[4668] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៩៨, ១៩៩។

បុគ្គលមួយចំនួនតូចដែលបានចូលរួមក្នុងដំណើរការសម្រេចចិត្តរបស់បក្ស[4669]។ ជាមុខងារមួយនៃតួនាទីជាន់ខ្ពស់របស់គាត់ គាត់៖ ត្រួតពិនិត្យបញ្ហាពាណិជ្ជកម្ម និងការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចូលរួមប្រជុំទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ថ្លែងសុន្ទរកថាកោតសរសើរដល់ការអនុវត្តគោលនយោបាយ រៀបចំវគ្គបណ្តុះបណ្តាលនយោបាយដោយផ្តោតលើការកំណត់មុខសញ្ញា "ខ្មាំង" និង ទទួលលិខិតទាក់ទងពីបណ្តាអង្គការអន្តរជាតិធំៗដែលថ្កោលទោសដល់ស្ថានភាពលំបាកលំបិកនៅសម័យកម្ពុជាប្រជាធិបតេយ្យ[4670]។ តាមរយៈទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត និង នួន ជា[4671] ព្រមទាំងការចុះធ្វើទស្សនកិច្ចជារឿយៗទៅតាមការដ្ឋាន[4672] និងដឹងឮជាបន្តបន្ទាប់អំពីឧក្រិដ្ឋកម្មនានា និងលក្ខខណ្ឌយ៉ាងអមនុស្សធម៌[4673] ដែលបំផ្លិចបំផ្លាញប្រជាជនទាំងមូល[4674]។

1275. ម្ចាស់បណ្តឹងសាទុក្ខប្រើប្រាស់វិធីសាស្ត្រជាផ្នែកៗចំពោះការផ្តល់សំអាងហេតុរបស់ អ.ជ.ស.ដ នៅពេលគាត់ជំទាស់ទៅនឹងការយល់ឃើញសមហេតុផលរបស់ អ.ជ.ស.ដ ដែលថា គាត់បានដឹងឮពីភរនីយភាពនៃឧក្រិដ្ឋកម្ម ហេតុនេះការសម្រេចដាក់ពិរុទ្ធភាពរូបគាត់ចំពោះឧក្រិដ្ឋកម្មទាំងនោះត្រូវមានសុពលភាព[4675]។

## ***មូលដ្ឋានទី ២៤៨៖ គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាដោយប្រយោល នៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង[4676]***

1276. **មូលដ្ឋានទី ២៤៨ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ ឬផ្នែកអង្គហេតុ ក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបាន**

---

[4669] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៣។

[4670] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២០១-២០២, ២០៤-២០៧។

[4671] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៨៩, ៤២២៥។

[4672] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១២៥៤, ៤២១៣។

[4673] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២០០។

[4674] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១៤, ៤២៦៥, ៤៣១៤។

[4675] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៨។

[4676] មូលដ្ឋានទី ២៤៨៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាដោយប្រយោល នៅត្រាំកក់ ទំនប់ ១ មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង* កថាខណ្ឌ ២១៣៧-២១៣៩។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨១-៨២ (ភាសាអង់គ្លេស) ទំព័រ ៧៦ (ភាសាបារាំង) ទំព័រ ១១៧-១១៨ (ភាសាខ្មែរ)។

**ធាតុផ្សំអត្តនោម័តិចាំបាច់ចំពោះការជួយ និងជំរុញ ក្រោមទម្រង់ជាអំពើមនុស្សឃាតដោយ*ចេតនាដោយប្រយោល* នៅតាមការដ្ឋាន និងសហករណ៍។**

1277. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខជំទាស់ទៅនឹងការយល់ឃើញរបស់ អ.ជ.ស.ដ ពាក់ព័ន្ធនឹងចេតនារបស់គាត់ចំពោះការធ្វើមនុស្សឃាតតាមរយៈការជួយ និងជំរុញ ដោយ*ចេតនាដោយប្រយោល* នៅតាមការដ្ឋាន និងសហករណ៍ ធ្វើឡើងដោយមិនត្រឹមត្រូវ និងគ្មានមូលដ្ឋាន ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានលើកជាទឡ្ហីករណ៍ដែលមានមូលដ្ឋាន[4677]។ ម្ចាស់បណ្ដឹងសាទុក្ខគ្រាន់តែប្រាប់អ្នកអានដោយយោងត្រឡប់ទៅការចោទប្រកាន់ពីកំហុសឆ្គងមួយទៀតប៉ុណ្ណោះ ដែលប្រាប់អ្នកអានឱ្យយោងត្រឡប់មកការចោទប្រកាន់ពីកំហុសឆ្គងនេះវិញ[4678]។ ការអះអាងបែបនេះមិនបង្ហាញពីកំហុសឆ្គងមួយដែលធ្វើឱ្យមោឃៈសាលក្រម ឬបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ជាក់ស្ដែងនោះទេ។

1278. ការចូលរួមយ៉ាងធំធេងរបស់ម្ចាស់បណ្ដឹងសាទុក្ខទៅក្នុងគោលនយោបាយរបស់ ប.ក.ក ក្នុងគោលបំណងបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន ត្រូវបានបង្ហាញយ៉ាងច្បាស់[4679] ដោយសារទំនាក់ទំនងរបស់គាត់ទៅនឹងការដ្ឋាននីមួយៗ[4680]។ ផ្អែកលើការបញ្ជាក់យ៉ាងត្រឹមត្រូវពីច្បាប់[4681] និងកំណត់ហេតុភស្តុតាងជាច្រើន អ.ជ.ស.ដ បានវាយតម្លៃយ៉ាងសមហេតុផលអំពីធាតុផ្សំអត្តនោម័តរបស់ម្ចាស់បណ្ដឹងសាទុក្ខចំពោះអំពើមនុស្សឃាត តាមរយៈការជួយ និងជំរុញ ដោយ*ចេតនាដោយប្រយោល* ដោយពិចារណាដល់តួនាទី និងការទទួលខុសត្រូវរបស់គាត់នៅក្នុងបក្ស ភាពជិតស្និទ្ធរបស់គាត់ជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត ការគាំទ្ររបស់គាត់ជាសាធារណៈចំពោះគោលនយោបាយ របៀបរបបរាយការណ៍ជាប្រព័ន្ធរបស់ ប.ក.ក និង សុន្ទរកថារបស់គាត់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសេចក្ដីថ្លែងការណ៍របស់គាត់ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ[4682]។ ក្នុងនាមជាអ្នកចូលរួមជាប្រចាំ និងអ្នករួមចំណែកក្នុងការប្រជុំរបស់គណៈ

---

[4677] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៣៧-២១៣៩។

[4678] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៣៨ ជើងទំព័រ ៤១០៧ *ដកស្រង់* កថាខណ្ឌ ១៨០៨-១៨១០, កថាខណ្ឌ ១៨០៨ ជើងទំព័រ ៣៥០៣ *យោងទៅ* កថាខណ្ឌ ២១៣៧-២១៤០។

[4679] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២១១។

[4680] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២១២-២១៥។

[4681] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ៨៦។

[4682] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២០៦-៤២០៨, ៤២១០-១១, ៤២១៤, ៤៣១៣-៤៣១៤។

កម្មាធិការអចន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម និងមហាសន្និបាតបក្ស ម្ចាស់បណ្តឹងសាទុក្ខមានវត្តមាននៅពេលដាក់ជូនរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តគោលបំណងរួម រួមមាននៅតាមសហករណ៍ និងការដ្ឋាន[4683]។ ម្ចាស់បណ្តឹងសាទុក្ខបានដឹងឮពីការខ្វះខាតថ្នាំពេទ្យ និងស្បៀងអាហារ និងលក្ខខណ្ឌយ៉ាងអមនុស្សធម៌ ដែលបណ្តាលឲ្យបាត់បង់ជីវិតជាច្រើនសន្ធឹកសន្ធាប់[4684]។ ដោយបានដឹងឮយ៉ាងច្បាស់នូវចំនួនមនុស្សស្លាប់ គាត់បែរជាបង្ហាញសេចក្តីសាទរចំពោះការអនុវត្តគោលនយោបាយនេះ ជាសេចក្តីសាទរដែលបន្តរហូតមកដល់សព្វថ្ងៃ បើផ្អែកទៅលើសក្ខីកម្មរបស់គាត់ផ្ទាល់។

1279. ម្ចាស់បណ្តឹងសាទុក្ខមិនបានដាក់ទឡ្ហីករណ៍នានាដែលបង្ហាញថា ការយល់ឃើញរបស់ អ.ជ.ស.ដ ជាការមិនត្រឹមត្រូវដែលថា គាត់មានធាតុផ្សំអត្តនោម័តិចាំបាច់ចំពោះការជួយ និងជំរុញ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយ *ចេតនាដោយប្រយោល* ដែលបានប្រព្រឹត្តទៅតាមការដ្ឋាន និងសហករណ៍ ហេតុនេះការសម្រេចដាក់ពិរុទ្ធភាពរូបគាត់ចំពោះឧក្រិដ្ឋកម្មទាំងនេះត្រូវតែតម្កល់។

### *មូលដ្ឋានទី ២៤៩៖ គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាដោយប្រយោល នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល*[4685]

1280. **មូលដ្ឋានទី ២៤៩ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសក្នុងការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខមានធាតុផ្សំអត្តនោម័តិចំពោះការការជួយ និងជំរុញ នៃការធ្វើមនុស្សឃាតដោយ *ចេតនាដោយប្រយោល* នៅតាមមន្ទីរសន្តិសុខ។**

1281. ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខប្រឆាំងនឹងការយល់ឃើញរបស់ អ.ជ.ស.ដ ពាក់ព័ន្ធនឹងចេតនារបស់គាត់ចំពោះការជួយ និងជំរុញ នៃអំពើមនុស្សឃាតដោយ *ចេតនាដោយប្រយោល*នៅតាមមន្ទីរសន្តិសុខធ្វើឡើងដោយមិនត្រឹមត្រូវ និងគ្មានមូលដ្ឋាន ដោយសារម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែអ្នកអានដោយយោងត្រឡប់ទៅការចោទប្រកាន់ពីកំហុសឆ្គងមួយទៀតប៉ុណ្ណោះ ដែលប្រាប់អ្នក

---

[4683] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៥៨, ៤៣១៣។

[4684] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១២, ៤២១៦។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៤ ជើងទំព័រ ១៤០៧ *យោងទៅ* កថាខណ្ឌ ៤២១៣-៤២១៦។

[4685] មូលដ្ឋានទី ២៤៩៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាដោយប្រយោល នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល* កថាខណ្ឌ ២១៤០។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨២ (ភាសាអង់គ្លេស) ទំព័រ ៧៦ (ភាសាបារាំង) ទំព័រ ១១៨ (ភាសាខ្មែរ)។

អានឲ្យយោងត្រឡប់មកការចោទប្រកាន់ពីកំហុសឆ្គងនេះវិញ[4686]។ ការអះអាងបែបនេះមិនបង្ហាញពីកំហុសឆ្គងមួយដែលធ្វើឲ្យមោឃៈសាលក្រម ឬបណ្តាលឲ្យភាពមិនយុត្តិធម៌ជាក់ស្តែងនោះទេ។

1282. ការចូលរួមយ៉ាងធំធេងរបស់ម្ចាស់បណ្តឹងសាទុក្ខទៅក្នុងគោលនយោបាយរបស់ ប.ក.ក ដើម្បីកំណត់មុខសញ្ញា ចាប់ខ្លួន ដាក់ឲ្យនៅដាច់ពីគេ និង "កម្ទេច" ខ្មាំង ត្រូវបានបង្ហាញយ៉ាងច្បាស់[4687]។ ផ្អែកលើការបញ្ជាក់យ៉ាងត្រឹមត្រូវពីច្បាប់[4688] និងការពិនិត្យទៅលើកំណត់ហេតុភស្តុតាងរួមជាច្រើន អ.ជ.ស.ដ បានវាយតម្លៃយ៉ាងសមហេតុផលអំពីចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះការជួយ និងជំរុញ នៃការធ្វើមនុស្សឃាតដោយ *ចេតនាដោយប្រយោល* នៅតាមមន្ទីរសន្តិសុខ និងនៅក្នុងបរិបទនៃការបោសសម្អាតផ្ទៃក្នុង ដោយពិចារណាដល់តួនាទី និងការទទួលខុសត្រូវរបស់គាត់នៅក្នុងបក្ស ការដឹងឮរបស់គាត់ពីស្ថានភាពនៃការចាប់ខ្លួន ការគាំទ្ររបស់គាត់ជាសាធារណៈចំពោះគោលនយោបាយ សុន្ទរកថារបស់គាត់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីថ្លែងការណ៍របស់គាត់ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ[4689]។ អ.ជ.ស.ដ បានពិចារណាថែមទៀតថា គាត់បានអំពាវនាវពីការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើបាប និងការសម្លាប់ខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មតរបស់ ប.ក.ក និងការដឹងឮរបស់គាត់ទូទៅអំពីការធ្វើបាបខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មតរបស់ ប.ក.ក ដោយការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយកម្មាភិបាល ប.ក.ក នៅទូទាំងប្រទេស[4690]។ អំពើរបស់គាត់មាន "ឥទ្ធិពលយ៉ាងច្រើន" លើការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយកម្មាភិបាល ប.ក.ក[4691] ហើយវាបង្ហាញច្បាស់ថា ការអនុវត្តគោលនយោបាយនោះទំនងជាបណ្តាលឲ្យមានការស្លាប់នៅតាមមន្ទីរសន្តិសុខ និងក្នុងអំឡុងពេលបោសសម្អាត[4692]។ ដោយការដឹងឮយ៉ាងពេញលេញពីភវនីយភាពនៃផលវិបាកដែលបណ្តាលឲ្យមានការស្លាប់បែបនេះ ម្ចាស់បណ្តឹងសាទុក្ខបានបន្តផ្តល់ការជួយជ្រោមជ្រែងជាក់ស្តែង និងការគាំទ្រផ្នែកស្មារតីដល់ ប.ក.ក ក្នុងការបង្កើត និងប្រតិបត្តិនូវគោលនយោបាយនេះ ដែលជួយ និងជួយសម្រួល

[4686] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៤០ ជើងទំព័រ ៤១១១ *ដកស្រង់* កថាខណ្ឌ ១៨០៨-១៨១៥, កថាខណ្ឌ ១៨០៨ ជើងទំព័រ ៣៥០៣ *យោងទៅ* កថាខណ្ឌ ២១៣៧-២១៤០។សារណាបណ្តឹងសាទុក្ខ

[4687] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២១៦, ២១៧ និង ២៣៥។

[4688] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៤៥។

[4689] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២១៦, ២១៧ និង ២៣៥។

[4690] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៦។

[4691] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៧។

[4692] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២០៩។

ដល់ការប្រព្រឹត្តិអំពើមនុស្សឃាតដោយ *ចេតនាដោយប្រយោល* នៅតាមមន្ទីរសន្តិសុខ និងនៅក្នុងបរិបទនៃការបោសសម្អាតផ្ទៃក្នុង[4693]។

1283. ម្ចាស់បណ្ដឹងសាទុក្ខមិនបានលើកឡើងនូវទឡ្ហីករណ៍ ដែលបង្ហាញកំហុសឆ្គងក្នុងការយល់ឃើញរបស់ អ.ជ.ស.ដ ដែលថា គាត់មានធាតុផ្សំអត្តនោម័តិចាំបាច់ចំពោះការជួយ និងជំរុញនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃអំពើមនុស្សឃាតដោយ *ចេតនាដោយប្រយោល* ដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ ហេតុនេះការសម្រេចដាក់ពិរុទ្ធភាពដល់រូបគាត់ចំពោះឧក្រិដ្ឋកម្មទាំងនេះត្រូវតែតម្កល់[4694]។

## IX. ការសម្រេចដាក់ពិរុទ្ធភាព និង ការដាក់ទោស

1284. អ.ជ.ស.ដ បានធ្វើការដាក់ទោសជាឯកត្តបុគ្គលយ៉ាងត្រឹមត្រូវសមហេតុផល ដោយពិចារណាដល់បរិបទ និងទម្រង់នៃឧក្រិដ្ឋកម្មដែលម្ចាស់បណ្ដឹងសាទុក្ខបានប្រព្រឹត្ត[4695]។ មូលដ្ឋានចំនួន ៥ របស់ម្ចាស់បណ្ដឹងសាទុក្ខ[4696] ពាក់ព័ន្ធនឹងការដាក់ទោសរូបគាត់មិនបានបង្ហាញថា អ.ជ.ស.ដ បានបំពានទៅលើឆន្ទានុសិទ្ធិធំធេងរបស់ខ្លួនទេ[4697]។ ស្របទៅនឹងសារណាទាំងមូលរបស់គាត់ គាត់បានធ្វើការចោទប្រកាន់ពីភាពលម្អៀងប្រឆាំង អ.ជ.ស.ដ ដោយមិនបានដកចេញនូវសច្ចាធារណ៍នៃភាពអនាគតិរបស់តុលាការនោះទេ។ ជាថ្មីម្ដងទៀត ការអះអាងរបស់គាត់ផ្អែកលើការអានសាលក្រមបែបជ្រើសរើស ដែលមិនបានលើកឡើងនូវការយល់ឃើញពាក់ព័ន្ធ ទាក់ទិននឹងកាលៈទេសៈពិសេសនៃសំណុំរឿងនេះទេ។ ដូចដែលនឹងពន្យល់ខាងក្រោម ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញពីកំហុសណាមួយរបស់ អ.ជ.ស.ដ ដែលតម្រូវឲ្យមានអន្តរាគមន៍ពី អ.ជ.ត.ក ពាក់ព័ន្ធនឹងការដាក់ទោសរូបគាត់ទេ។

[4693] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៧។

[4694] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣១៧-៤៣១៨, ៤៣២៨។

[4695] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៥០-៤៣៧៦, ៤៣៨២-៤៣៨០, ៤៣៨៩-៤៣៩១, ៤៣៩៦-៤៤០៣។

[4696] មូលដ្ឋានទី ២៥២-២៥៦។

[4697] អ.ជ.ត.ក បានគូសបញ្ជាក់អំពីឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទៅលើការដាក់ទោស និងការពិនិត្យដោយយកចិត្តទុកដាក់លើបណ្ដឹងសាទុក្ខ *សូមមើល* សំណុំរឿង ០០១-ឯកសារ **E188** សាលដីការឿងក្ដី ឌុច កថាខណ្ឌ ៣៥៤។ សូមមើលផងដែរ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១០៧។ សាលដីការឿងក្ដី *D. Milošević* កថាខណ្ឌ ២៩៧។

## *មូលដ្ឋានទី ២៥២៖ ការបង្ហាញពីភាពលម្អៀងទាក់ទងនឹងគោលដៅការដាក់ទោស*[4698]

1285. **មូលដ្ឋានទី ២៥២ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មានកំហុសផ្នែកអង្គច្បាប់ ឬបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការកំណត់អំពោះគោលបំណងនៃការដាក់ទោស។**

1286. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានកំហុសក្នុងការលើកឡើងពីគោលបំណងនៃការដាក់ទោស និងអះអាងបន្ថែមថា គោលបំណងដែលត្រូវបានបញ្ជាក់ បង្ហាញពីភាពលម្អៀងមកលើរូបគាត់[4699]។ អ.ជ.ត.ក ធ្លាប់បានពិចារណាដល់ការបញ្ជាក់ដោយច្បាប់នេះ ដោយបានសម្រេចថាវាជាការសមរម្យ ហើយយល់ឃើញថា "ពុំមានការបង្ហាញ" ថាវាជាការសម្តែងនូវភាពលម្អៀងរបស់អង្គជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទឡើយ[4700]។

1287. ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយខុសឆ្គងថា អ.ជ.ស.ដ មិនបានពិចារណាដល់គោលការណ៍នៃការដាក់ទោស ដោយធ្វើការដាក់ទោសធ្ងន់ធ្ងរហួសហេតុ និងធ្វើជាគំរូ ដែលបានធ្វើឱ្យប៉ះពាល់ដល់ការញញើត និងការសងសឹកជាឯកត្តបុគ្គល[4701]។ នៅទីនេះ គាត់បានលើកជាទឡ្ហីករណ៍ "បែបស្រពិចស្រពិល" ដូចគ្នាទៅនឹងទឡ្ហីករណ៍ដែល អ.ជ.ត.ក បានបដិសេធនៅក្នុងបណ្តឹងសាទុក្ខដែលមិនជោគជ័យប្រឆាំងនឹងការដាក់ទោសក្នុងសំណុំរឿង ០០២/០១[4702]។ ការអះអាងរបស់គាត់មិនគួរឱ្យជឿជាក់បានទេ ដោយសារក្នុងសំណុំរឿង ០០២/០២ អ.ជ.ស.ដ បានយោងយ៉ាងច្បាស់ទៅដល់ការដាក់ទោសជាឯកត្តបុគ្គល ដែលឆ្លុះបញ្ចាំងនូវពិរុទ្ធភាពរបស់ជនជាប់ចោទ ដោយមានគោលដៅចម្បងគឺការធ្វើឱ្យញញើត និងការផ្តន្ទាទោស ស្របទៅនឹងច្បាប់នៅ អ.វ.ត.ក និងតុលាការមិនអចិន្ត្រៃយ៍នានា[4703]។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការដាក់

---

[4698] <u>មូលដ្ឋានទី ២៥២</u>៖ ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ *ការបង្ហាញពីភាពលម្អៀងទាក់ទងនឹងគោលដៅការដាក់ទោស* កថាខណ្ឌ ២១៤៥-២១៤៨។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨៤ (ភាសាអង់គ្លេស) ទំព័រ ៧៨ (ភាសាបារាំង) ទំព័រ ១១៩ (ភាសាខ្មែរ)។

[4699] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៤៥។

[4700] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១០។

[4701] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៤៦-២១៤៨។

[4702] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១០។

[4703] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៤៨។ នៅទីនោះ អ.ជ.ស.ដ កត់សម្គាល់ថា ការដាក់ទោសមានគោលបំណង "ឱ្យមានការញញើត [...] និងការផ្តន្ទាទោស ដែលមិនមែនជាការសងសឹក" ហើយថា "ត្រូវតែមានលក្ខណៈឯកត្តបុគ្គល និងសមាមាត្រ" *សូមមើល* ជើងទំព័រ ១៤០៨៦ និង ១៤០៨៧ និងការអត្ថបទដកស្រង់នៅក្នុងជើងទំព័រទាំងនោះ។ ការពន្យល់ច្បាស់ផ្នែកច្បាប់ស្របទៅនឹងគោលបំណងនៃការដាក់ទោសដែលបានលើកឡើងនៅក្នុងសំណុំរឿង ០០១ និង

ទោសរូបគាត់មានភាពធ្ងន់ធ្ងរហួសហេតុ អនុលោមទៅតាមកាលៈទេសៈទាំងអស់ដែលពាក់ព័ន្ធនោះទេ[4704] ហើយគាត់ក៏មិនបានបង្ហាញនូវកំហុសផ្នែកច្បាប់ ការបំពានឆន្ទានុសិទ្ធិ ឬភាពលម្អៀងរបស់ អ.ជ.ស.ដ តាមរយៈការលើកឡើងរបស់ខ្លួនអង្គជំនុំជម្រះ ស្តីពីគោលបំណងនៃការដាក់ទោស។

## *មូលដ្ឋានទី ២៥៣៖ កំហុសលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត*[4705]

1288. **មូលដ្ឋានទី ២៥៣ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសពាក់ព័ន្ធ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលវាយតម្លៃពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។**

*ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងការបញ្ចូលភស្តុតាងនៅក្រៅវិសាលភាព*[4706]

1289. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយមិនត្រឹមត្រូវថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសដែលធ្វើឱ្យមោឃៈសាលក្រម នៅពេលកំណត់អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដោយបញ្ចូលការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលគាត់មិនត្រូវបានចោទប្រកាន់[4707]។ ការអះអាងនេះផ្អែកលើអំណានសាលក្រមដោយមិនត្រឹមត្រូវ ដែលមិនយកចិត្តទុកដាក់ចំពោះការយល់ឃើញនានាដែលពាក់ព័ន្ធ។ ដូចដែលម្ចាស់បណ្តឹងសាទុក្ខកត់សម្គាល់គឺថា អ.ជ.ស.ដ បានលើកឡើងយ៉ាងត្រឹមត្រូវនូវច្បាប់ស្តីពីការកំណត់អំពីភាពធ្ងន់ធ្ងរ៖ អង្គជំនុំជម្រះត្រូវពិចារណាពី "កាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ ក៏

---

សំណុំរឿង ០០២/០១ ព្រមទាំងក្រមព្រហ្មទណ្ឌកម្ពុជា *សូមមើល* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៦៧។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី *ឌុច* កថាខណ្ឌ ៥៨០-៥៨១។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៩៦។ គោលការណ៍ទាំងនេះឆ្លុះបញ្ចាំងបន្ថែមទៀតនៅក្នុងយុត្តិសាស្ត្រពីតុលាការមិនអចិន្ត្រៃយ៍ ដែលកត់សម្គាល់ថា ការញញើត និងការសងសឹកគឺជាគោលដៅចម្បងនៃការដាក់ទោស ហើយថា ការស្តារនីតិសម្បទាគឺជាគោលដៅបន្ទាប់បន្សំ ដោយសារគោលបំណងខុសៗគ្នានៃប្រព័ន្ធអន្តរជាតិ និងជាតិ *សូមមើលឧទាហរណ៍* សេចក្តីសម្រេចរឿងក្តី *Brima* កថាខណ្ឌ ១៤-១៧។ សាលដីការឿងក្តី *Čelebici* កថាខណ្ឌ ៨០៦។ សាលដីការឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១០៧៣-១០៨៣។ សាលដីការឿងក្តី *Aleksovski* កថាខណ្ឌ ១៨៥។

[4704] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៥៣, ២៥៤, ២៥៥, ២៥៦។

[4705] មូលដ្ឋានទី ២៥៣៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត* កថាខណ្ឌ ២១៤៩-២១៥៧។ ឯកសារ F54.1.1 ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨៤ (ភាសាអង់គ្លេស) ទំព័រ ៧៨ (ភាសាបារាំង) ទំព័រ ១១៩ (ភាសាខ្មែរ)។

[4706] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៤៩-២១៥១។

[4707] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៥០-២១៥១។

ដូចជា ទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទក្នុងបទល្មើសនេះ"[4708]។ កាលៈទេសៈទាំងនេះបញ្ចូល "ភាពសាហាវព្រៃផ្សៃ" នៃបទល្មើស[4709]។

1290. ក្នុងការកំណត់អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម អ.ជ.ស.ដ បានពិចារណាអំពីលក្ខខណ្ឌនានាដែលអ្នកជាប់ឃុំនៅតាមមន្ទីរសន្តិសុខបានទទួលរង និង បានកត់សម្គាល់ថា "អ្នកខ្លះត្រូវបានគេរំលោភផ្លូវភេទ" ដោយដកស្រង់ករណីវាយប្រហារផ្លូវភេទមួយហួសពីវិមតិសង្ស័យនៅក្រាំងតាចាន់[4710]។ ទោះបីជីកាដំណោះស្រាយមិនបានចោទប្រកាន់ពីការរំលោភផ្លូវភេទ ឬអំពើហិង្សាផ្លូវភេទផ្សេងទៀតនៅក្រាំងតាចាន់ក៏ដោយ តែអំពើទាំងនេះពាក់ព័ន្ធនឹងការពិនិត្យទៅលើលក្ខខណ្ឌទូទៅនៅក្រាំងតាចាន់[4711] ហើយការពិត វាឆ្លុះបញ្ចាំងអំពី "ផ្នែកផ្សេងៗនៃលក្ខខណ្ឌ"[4712]។ ម្ចាស់បណ្តឹងសាទុក្ខត្រូវបានរកឃើញបន្ថែមថាបានដឹងឮនាសម័យនោះនូវការធ្វើបាបប្រជាជនស៊ីវិល នៅតាមមន្ទីរសន្តិសុខ[4713]។ ហេតុនេះ និងផ្ទុយពីការអះអាងរបស់គាត់[4714] ក្នុងការពិចារណាថា ការរំលោភផ្លូវភេទគឺជាផ្នែកមួយនៃលក្ខខណ្ឌនានានៅតាមមន្ទីរសន្តិសុខ អ.ជ.ស.ដ បានកម្រិតយ៉ាងត្រឹមត្រូវនូវការពិចារណារបស់ខ្លួនចំពោះការដាក់ទោសត្រឹមតែបញ្ហានានា ដែលបានបង្ហាញហួសពីវិមតិសង្ស័យប្រឆាំងនឹងម្ចាស់បណ្តឹងសាទុក្ខ។ ការសន្មត *ដោយស្មានៗ*ថា ភស្តុតាងនេះត្រូវបានយកមកពិចារណាដោយមានកំហុសនោះ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការយល់ឃើញណាផ្សេងពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មត្រូវបានធ្វើឡើង ដោយគ្មានភស្តុតាងនេះទេ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាច្រើនផ្សេងទៀតត្រូវបានបញ្ជាក់ និងបង្ហាញ។

*ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងតួនាទីរបស់គាត់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម*[4715]

---

4708 ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៥០ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៤៩។

4709 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៤៩ ជើងទំព័រ ១៤០៩១ *ដកស្រង់* ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៦៨, សំណុំរឿង ០០១-ឯកសារ F28 សាលដីការឿងក្តី ឌុច កថាខណ្ឌ ៣៧៥, ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១៨។ សូមមើលផងដែរ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៦២។

4710 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៦៥ *ដកស្រង់* កថាខណ្ឌ ២៧៣៨។

4711 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៦៤១, ២៧៣៤, ២៧៣៨។

4712 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ២៧៣៨។

4713 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២៣២-៤២៣៤។

4714 ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៥១។

4715 ឯកសារ F54 **សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ២១៥២-២១៥៧។

1291. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានកំហុសក្នុងការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដោយពិចារណាដល់ទម្រង់ និងកម្រិតនៃការចូលរួមរបស់គាត់[4716]។ ក្នុងការដាក់ទោសម្ចាស់បណ្តឹងសាទុក្ខ អ.ជ.ស.ដ បានពិចារណាថា គាត់ជា "តួអង្គសំខាន់មួយដែលទទួលខុសត្រូវលើការបង្កើតគោលនយោបាយបក្សដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២"[4717]។ ដោយកត់សម្គាល់អំពីការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម[4718] ព្រមទាំងតួនាទីរបស់គាត់ក្នុងនាមជាអ្នកជួយ/អ្នកជំរុញ[4719] អ.ជ.ស.ដ បានរកឃើញថា ការចូលពាក់ព័ន្ធរបស់ម្ចាស់បណ្តឹងសាទុក្ខទៅក្នុងឧក្រិដ្ឋកម្ម "មានលក្ខណៈធំធេង និងមានឥទ្ធិពលខ្លាំងក្លា"[4720]។ ម្ចាស់បណ្តឹងសាទុក្ខព្យាយាមកាត់បន្ថយតួនាទីរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម[4721] ដោយមិនយកចិត្តទុកដាក់ដល់ការយល់ឃើញយ៉ាងធំធេងស្តីពីការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មនោះ ដែលត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំនួន ១៣ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរចំនួន ៤ និងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម[4722]។

1292. ជាងនេះទៀត ដោយហេតុថា "ទោសសមស្របជានិច្ចកាលនឹងត្រូវកំណត់ដោយផ្អែកលើអង្គហេតុនេះរឿងក្តីជាក់លាក់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទនីមួយៗ"[4723] នោះ ការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងដោយគ្មានមូលដ្ឋានទេ។ ការអះអាងរបស់ម្ចាស់បណ្តឹង

---

[4716] ឯកសារ F54 **សារណាបណ្តឹងសាទុក្ខ** កថាខណ្ឌ ២១៥២។

[4717] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨២។

[4718] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨២ ("គាត់បានអនុវត្តកិច្ចការសេដ្ឋកិច្ចសំខាន់ៗនៃគោលបំណងរួមនេះ"), ៤៣៨៣ ("គាត់បានអំពាវនាវជាសាធារណៈឱ្យកម្ចាត់ចោលសមាជិកជាន់ខ្ពស់នៃបណ្តាញរដ្ឋបាលរបបសាធារណរដ្ឋខ្មែរ"), ៤៣៨៤ ("ម្ចាស់បណ្តឹងសាទុក្ខ "បានផ្សព្វផ្សាយជាចំហនូវគោលនយោបាយរបស់បក្ស ក្នុងការបង្កើនចំនួនប្រជាជននៅកម្ពុជាប្រជាធិបតេយ្យឱ្យបានឆាប់រហ័ស ធ្វើឱ្យខូចនូវប្រពៃណីរបស់ពុទ្ធសាសនិក និងធ្វើឱ្យគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានលក្ខណៈជាធម្មតា")។

[4719] *សូមមើលឧទាហរណ៍* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨៣ ("ខៀវ សំផន បានគាំទ្រយ៉ាងសកម្មចំពោះការប្រើប្រាស់សហករណ៍និងការដ្ឋានការងារ បើទោះបីជាគាត់បានដឹងឮអំពីភាពអត់អាហារនិងជំងឺដែលជាបញ្ហាកំពុងកើតមានក្តី" ដែលពាក់ព័ន្ធមិនត្រឹមតែចំពោះការផ្សព្វផ្សាយរបស់គាត់អំពីគោលនយោបាយប៉ុណ្ណោះទេ តែពាក់ព័ន្ធដល់ការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាអ្នកជួយ/អ្នកជំរុញដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយ *ចេតនាដោយប្រយោល*នៅតាមសហករណ៍ និងការដ្ឋានផងដែរ)។

[4720] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨៥។

[4721] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៥៥។

[4722] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣០៦-៤៣០៧។

[4723] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១២។

សាទុក្ខមិនអាចជឿជាក់បានទាល់តែសោះ ដោយសារវាផ្អែកលើតែការប្រៀបធៀបរវាងការដាក់ទោសដោយតុលាការផ្សេងទៀត ក្នុងសំណុំរឿងផ្សេងទៀត[4724] ដែល អ.ជ.ត.ក ធ្លាប់បានយល់ឃើញពីមុនមកថា "ពុំសមស្របក្នុងការបង្ហាញថា ជាកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីដាក់ទោសសមស្របណាមួយឡើយ"[4725]។

## *មូលដ្ឋានទី ២៥៤៖ កំហុសពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស*[4726]

1293. **មូលដ្ឋានទី ២៥៤ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសពាក់ព័ន្ធ ដែលធ្វើឱ្យមោឃៈការដាក់ទោស នៅក្នុងការវាយតម្លៃរបស់ខ្លួនពីការថ្លឹងថ្លែង និងការអនុវត្តស្ថានទម្ងន់ទោស។**

### *ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងការរំលោភបំពានមុខតំណែងមានសិទ្ធិអំណាច និងឥទ្ធិពលរបស់គាត់*[4727]

1294. ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខថា អង្គជំនុំជម្រះមានកំហុសក្នុងការសន្និដ្ឋានថា ការរំលោភបំពានមុខតំណែងមានសិទ្ធិអំណាចរបស់គាត់ បង្កើតជាស្ថានទម្ងន់ មិនទទួលបានផលទេ[4728] ដោយសារវាផ្អែកលើអំណានសាលក្រមបែបជ្រើសរើស និងបកស្រាយខុសនូវសិទ្ធិអំណាចដែលម្ចាស់បណ្ដឹងសាទុក្ខបានអនុវត្តជាក់ស្ដែង។ អ.ជ.ស.ដ ធ្វើការយល់ឃើញពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិអំណាចរបស់ម្ចាស់បណ្ដឹងសាទុក្ខ ដោយផ្អែកលើការចូលរួមចំណែករបស់គាត់ទៅក្នុងឧក្រិដ្ឋកម្ម ទទួលបានតួនាទីផ្លូវការជាច្រើន "រួមមាន ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម សមាជិកមន្ទីរ ៨៧០ ប្រធានគណៈប្រធានរដ្ឋ និងជាកម្មាភិបាលជាន់ខ្ពស់នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា"[4729]។ ទាំងការបកស្រាយខុសរបស់ម្ចាស់បណ្ដឹងសាទុក្ខចំពោះការយល់ឃើញ

---

[4724] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៥៣, ២១៥៤, ២១៥៦។

[4725] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១២។

[4726] <u>មូលដ្ឋានទី ២៥៤</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស* កថាខណ្ឌ ២១៥៨-២១៦៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៨៤ (ភាសាអង់គ្លេស) ទំព័រ ៧៨ (ភាសាបារាំង) ទំព័រ ១២០ (ភាសាខ្មែរ)។

[4727] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៥៨-២១៦២។

[4728] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៥៨។

[4729] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨៩។

របស់ អ.ជ.ស.ដ[4730] ទាំងការយល់ឃើញរបស់គាត់ថាបុគ្គលផ្សេងគ្នានៅចំពោះមុខតុលាការខុសគ្នាបានទទួលការវាយតម្លៃផ្សេងគ្នាអំពីស្ថានទម្ងន់ និងស្ថានសម្រាល[4731] មិនគ្រប់គ្រាន់ក្នុងការបង្ហាញពីកំហុសដែលអាចវិនិច្ឆ័យបានក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ នៅត្រង់ចំណុចនេះទេ។

1295. ម្ចាស់បណ្តឹងសាទុក្ខអះអាងបន្ថែមថា អ.ជ.ស.ដ រាប់ពីរដងអំពីការរំលោភបំពានសិទ្ធិអំណាចរបស់គាត់ធ្វើជាស្ថានទម្ងន់ ព្រមទាំងការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម[4732]។ អង្គជំនុំជម្រះសាលាដំបូងមាន "ឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើកត្តាណាមួយដែលមានភាពសមស្របជាង ក្នុងការកំណត់អំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ឬស្ថានទម្ងន់ទោសនោះ"[4733] ហើយម្ចាស់បណ្តឹងសាទុក្ខមានបន្ទុកក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានរាប់ពីរដងចំពោះស្ថានទម្ងន់នៅចំពោះមុខដែលមិនអាចទទួលយកបាន[4734]។ អ.ជ.ស.ដ បានលើកឡើងយ៉ាងត្រឹមត្រូវថា "អង្គហេតុដូចគ្នាមិនអាចយកមកប្រើប្រាស់សម្រាប់ការបង្ហាញពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មផង និងស្ថានទម្ងន់ទោសផងបានទេ"[4735] ហេតុនេះបញ្ជាក់ថា "មានការទទួលស្គាល់ថា ការរាប់ពីរដងមិនអាចអនុញ្ញាតបានទេ"[4736]។

---

[4730] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៥៨ ជើងទំព័រ ៤១៤៣-៤១៤៥ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣២០ (នៅពេល អ.ជ.ស.ដ បានសម្រេចថា ម្ចាស់បណ្តឹងសាទុក្ខគ្មានការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពនៅមុនពេល ឬក្នុងអំឡុងពេលប្រព្រឹត្តបទល្មើស ហេតុនេះគាត់មិនទទួលខុសត្រូវក្រោមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើទេ), កថាខណ្ឌ ៥៩៣ (ដែលមិនស្របទៅនឹងទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ តែផ្ទុយទៅវិញវាតំណាងឲ្យការយល់ឃើញរបស់អង្គជំនុំជម្រះថា តាមរយៈតួនាទីរបស់គាត់ក្នុងនាមជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ម្ចាស់បណ្តឹងសាទុក្ខបានធ្វើធម្មានុរូបកម្មដល់របៀបវារៈរបស់ ប.ក.ក ជាអន្តរជាតិ), កថាខណ្ឌ ៥៩៦-៥៩៩ (នៅពេល អ.ជ.ស.ដ សម្រេចថា ការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ "គឺជាភារកិច្ចការទូតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងការផ្សព្វផ្សាយទូទៅអំពីមាគ៌ា ប.ក.ក ប៉ុណ្ណោះ")

[4731] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៥៩។

[4732] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៦០។

[4733] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧៨ *ដកស្រង់* សាលក្រមរឿងក្តី *Popović* កថាខណ្ឌ ២១៣៨, សាលដីការឿងក្តី *Vasiljević* កថាខណ្ឌ ១៥៧។

[4734] សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៦៨៧។ សាលដីការឿងក្តី *Deronjić* កថាខណ្ឌ ១០៧។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ១២៣៤។

[4735] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៥០។

[4736] សូមមើល សាលដីការឿងក្តី *Deronjić* កថាខណ្ឌ ១០៧។ នៅទីនោះ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថាទោះបី អ.ជ.ស.ដ បានពិចារណាដល់ស្ថានទម្ងន់ និងភាពធ្ងន់ធ្ងរនៅក្រោមចំណងជើងតែមួយក៏ដោយ តែមានភាពដាច់ស្រឡះ

1296. ដើម្បីគាំទ្រដល់ការចោទប្រកាន់ពីកំហុសនេះ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងពីការយល់ឃើញរបស់ អ.ជ.ស.ដ ថា "ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិម និងជាអ្នកចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ [គាត់]បានចូលរួមពិភាក្សានិងសម្រេចទៅលើបញ្ហាសំខាន់ៗដូច្នេះហើយគាត់មានតួនាទីខ្ពស់នៅក្នុងបក្ស"[4737]។ នេះជាការលើកឡើងដែលមិនអាចប្រកែកបានអំពីតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងការវិភាគពីភាពធ្ងន់ធ្ងរ ហេតុនេះពុំមានកំហុសឆ្គងនោះទេ។ ម្ចាស់បណ្តឹងសាទុក្ខកត់សម្គាល់បន្ថែមពីការលើកឡើងរបស់ អ.ជ.ស.ដ ថា ម្ចាស់បណ្តឹងសាទុក្ខ "បានប្រើតំណែងមានឥទ្ធិពលរបស់គាត់ដើម្បីគាំទ្រ ហើយតាមរយៈការគាំទ្រនេះ គឺគាត់បានផ្តល់ភាពស្របច្បាប់ដល់ការអនុវត្តគោលនយោបាយរបស់ ប.ក.ក" នៅពេលពិភាក្សាអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម[4738]។ ទោះបីឃ្លោងឃ្លារបស់ អ.ជ.ស.ដ មិនល្អឥតខ្ចោះក្តី តែអង្គជំនុំជម្រះមួយអាចពិចារណាយ៉ាងត្រឹមត្រូវនូវទិដ្ឋភាពផ្សេងៗនៃអំពើ និងទង្វើរបស់បុគ្គលម្នាក់ ក្នុងការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃទង្វើពិរុទ្ធជារួម ដោយមិនរាប់ពីរដងនូវកត្តាដដែលនោះដែលមិនអាចទទួលយកបាននោះទេ[4739]។ ជាងនេះទៀត អ.ជ.ស.ដ បានបញ្ជាក់ច្បាស់ថា ការវាយតម្លៃរបស់ខ្លួនពីភាពធ្ងន់ធ្ងរ "បានពិចារណាអំពីចំនួន និងភាពងាយរងគ្រោះរបស់ជនរងគ្រោះ ទំហំ និងភាពសាហាវយង់ឃ្នងនៃឧក្រិដ្ឋកម្ម នៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីភាពធ្ងន់ធ្ងរដែលកើតចេញពីឧក្រិដ្ឋកម្មទាំងនេះ"[4740] ដោយមិនបានលើកឡើងពីការរំលោភបំពានសិទ្ធិអំណាចទេ[4741]។

ពីគ្នារវាងចំណុចទាំងពីរនេះ និងមានការទទួលស្គាល់ថា ការរាប់ពីរដងមិនអាចទទួលយកបានទេ។ ហេតុនេះ អង្គជំនុំជម្រះបានបដិសេធចោលបណ្តឹងសាទុក្ខ ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញនូវការយល់ឃើញជាក់លាក់នៅក្នុងការដាក់ទោស "ដែលបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាបន្ថែមទៀត [ទៅលើស្ថានទម្ងន់] ថាជាផ្នែកនៃភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម"។

[4737] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨២ (ផ្នែក ២០.២.៥ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម, ផ្នែក ២០.២.៥.៤ តួនាទីរបស់ ខៀវ សំផន) *ជំទាស់* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៦០។

[4738] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៦១ ជើងទំព័រ ៤១៤៨ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨៣។

[4739] សាលដីការឿងក្តី *Taylor* កថាខណ្ឌ ៦៨៧។

[4740] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨០។

[4741] ក្រុមខណ្ឌនេះបង្ហាញពីភាពខុសគ្នារវាងសំណុំរឿងដែលកំពុងពិភាក្សា ពីសំណុំរឿងដែលម្ចាស់បណ្តឹងសាទុក្ខយកមកសំអាងដើម្បីគាំទ្រ គឺសាលដីការឿងក្តី *M. Nikolić ត្រូវបានដកស្រង់នៅក្នុង* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៦២។ នៅទីនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អ.ជ.ស.ដ បាន "លើកឡើងយ៉ាងច្បាស់ [...] ថា អង្គជំនុំជម្រះបានពិចារណាមិនត្រឹមតែទៅលើមុខតំណែងនៃសិទ្ធិអំណាចរបស់គាត់ប៉ុណ្ណោះទេ តែក៏បានពិចារណាផងដែរទៅលើតួនាទីរបស់គាត់ជាស្ថានទម្ងន់" ដោយប្រើពាក្យ "តួនាទី" នៅក្នុងការពិចារណាទាំងទៅលើភាពធ្ងន់ធ្ងរ និងស្ថានទម្ងន់ *សូមមើល* កថាខណ្ឌ ៦០-

1297. បើការសន្មតបែបស្មានៗថា អ.ជ.ត.ក យល់ឃើញថា កត្តានេះត្រូវបានរាប់ពីរដងក៏ដោយ ក៏មូលដ្ឋាននេះនៅតែមិនទទួលបានផលដដែល ដោយសារម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា ការចោទប្រកាន់ពីកំហុសធ្វើឱ្យមោឃៈដល់ការដាក់ទោស[4742]។ ការរាប់ពីរដងទៅលើកត្តាតែមួយមានឥទ្ធិពលតិចតួចទៅលើការសម្រេចរបស់ អ.ជ.ស.ដ ពាក់ព័ន្ធនឹងការដាក់ទោសសមរម្យចំពោះឧក្រិដ្ឋកម្ម*ទ្វេ*ដែលបានប្រព្រឹត្ត[4743] និងមានឥទ្ធិពលតិចតួចមិនអាចធ្វើឱ្យមោឃៈដល់ការដាក់ទោសបានទេ ដោយពិចារណាទៅដល់កត្តាទាំងអស់ដែលពាក់ព័ន្ធ[4744]។

*ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសេចក្តីពិចារណាអំពីកម្រិតនៃការអប់រំ*[4745]

1298. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានកំហុសក្នុងការពិចារណាអំពីកម្រិតនៃការអប់រំរបស់គាត់ ថាជាស្ថានទម្ងន់ ដោយមិនបានផ្តល់យុត្តិកម្មឱ្យបានគ្រប់គ្រាន់[4746]។ អ.ជ.ត.ក ធ្លាប់បានយល់ឃើញថា "ការអប់រំខ្ពង់ខ្ពស់" របស់បុគ្គលណាម្នាក់អាចត្រូវបាន

---

៦១ ជើងទំព័រ ១៦៤។ នៅក្នុងសំណុំរឿងនេះ អ.ជ.ស.ដ បានដកការរំលោភបំពានសិទ្ធិអំណាចចេញពីសេចក្តីសង្ខេបអំពីកត្តានានាដែលបានយកមកពិចារណា ក្នុងការបង្ហាញពីភាពធ្ងន់ធ្ងរ។ សូមមើលផងដែរ សាលដីការឿងក្តី *Deronjić* កថាខណ្ឌ ១០៧, ១១០។

[4742] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៩។

[4743] *សូមមើលឧទាហរណ៍* សាលដីការឿងក្តី *D. Milošević* កថាខណ្ឌ ៣៣៦ (ទោះបីអង្គជំនុំជម្រះសាលាដំបូង "ជាច្រើនលើកច្រើនសា [...] បានពិចារណាទៅលើអង្គហេតុដូចគ្នា នៅពេលវាយតម្លៃទាំងទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងស្ថានទម្ងន់ក្តី" ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កត្តាទាំងនេះពាក់ព័ន្ធក្នុងការកំណត់ការដាក់ទោស "ហើយសូម្បីតែនៅពេលពិចារណាឱ្យបានត្រឹមត្រូវតែមួយដងគត់ក្តី ក៏នៅតែតម្រូវឱ្យមានការដាក់ទោសស្របទៅនឹងការដាក់ទោសដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងដែរ" ហេតុនេះពុំតម្រូវឱ្យមានការកាត់បន្ថយការដាក់ទោសទេ)។

[4744] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៦១-៤៣៦៧, ៤៣៨២-៤៣៨៦, ៤៣៨៩-៤៣៩១, ៤៣៩៦-៤៣៩៩។ កត្តានានាក្នុងចំណោមនោះរួមមាន៖ "ចំនួនជនរងគ្រោះយ៉ាងច្រើន ហើយនិងអង្គហេតុដែលថា ជនរងគ្រោះជាច្រើនងាយទទួលរងគ្រោះបំផុត ព្រមទាំងផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃឧក្រិដ្ឋកម្មលើជនរងគ្រោះនិងសាច់ញាតិរបស់ពួកគេ និងទំហំដ៏ធំធេង រួមជាមួយភាពសាហាវយង់ឃ្នងនៃឧក្រិដ្ឋកម្មទាំងអស់នេះ" *សូមមើល* កថាខណ្ឌ ៤៣៦២, ចេតនា "ដើម្បីបំផ្លាញរចនាសម្ព័ន្ធសង្គមរបស់សង្គមកម្ពុជា" *សូមមើល* កថាខណ្ឌ ៤៣៦៩, "ភាពធ្ងន់ធ្ងរនៃអំពើប្រល័យពូជសាសន៍" *សូមមើល* កថាខណ្ឌ ៤៣៧០, "ព្យសនកម្មខាងផ្លូវកាយ ផ្លូវចិត្ត និងស្មារតីយ៉ាងធ្ងន់ធ្ងរ" ដល់ជនរងគ្រោះ *សូមមើល* កថាខណ្ឌ ៤៣៧២, "ការចូលរួម [របស់ម្ចាស់បណ្តឹងសាទុក្ខ ទៅក្នុងឧក្រិដ្ឋកម្មទាំងនេះ] មានលក្ខណៈធំធេង និងមានឥទ្ធិពលខ្លាំងក្លា" *សូមមើល* កថាខណ្ឌ ៤៣៨៥, ម្ចាស់បណ្តឹងសាទុក្ខមានចំណេះដឹងខ្ពង់ខ្ពស់ ដែលឱ្យគាត់ "ដឹងអំពីផលវិបាកទាំងឡាយដែលកើតចេញពីសកម្មភាពរបស់គាត់" *សូមមើល* កថាខណ្ឌ ៤៣៩០, និងពុំមានស្ថានសម្រាល ឬសាក្សីបញ្ជាក់ពីអត្តចរិតទេ *សូមមើល* កថាខណ្ឌ ៤៣៩៨-៤៣៩៩។

[4745] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៦៣-២១៦៧។

[4746] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៦៣, ២១៦៦។

ពិចារណាថាជាស្ថានទម្ងន់[4747] ហើយ អ.ជ.ស.ដ បានផ្ដល់យុត្តិកម្មនូវភាពពាក់ព័ន្ធនៃការអប់រំរបស់គាត់ទៅនឹងឧក្រិដ្ឋកម្ម ដោយសម្រេចយ៉ាងច្បាស់ថា សាវតាររបស់ម្ចាស់បណ្ដឹងសាទុក្ខជាអ្នកច្បាប់ និងជាសេដ្ឋកិច្ចវិទូអាចឱ្យគាត់ "ដឹងអំពីផលវិបាកទាំងឡាយដែលកើតចេញពីសកម្មភាពរបស់គាត់"[4748]។ ម្ចាស់បណ្ដឹងសាទុក្ខបានសំអាងដោយមិនត្រឹមត្រូវបន្ថែមទៀតទៅលើការប្រៀបធៀបនៃការដាក់ទោសនៅក្នុងសំណុំរឿងផ្សេងទៀត[4749] ទោះបីទទួលស្គាល់ថា ការផ្ដល់ទម្ងន់ដល់ស្ថានទម្ងន់ រួមមានការអប់រំរបស់បុគ្គលណាម្នាក់ ត្រូវយកមកវាយតម្លៃដោយគិតទៅដល់កាលៈទេសៈពិសេសនៃរឿងក្ដីណាមួយ[4750] ក៏ដោយ។

## *មូលដ្ឋានទី ២៥៥៖ កំហុសពាក់ព័ន្ធនឹងស្ថានសម្រាលទោស*[4751]

1299. **មូលដ្ឋានទី ២៥៥ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសពាក់ព័ន្ធ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលវាយតម្លៃថ្លឹងថ្លែង និងការអនុវត្តស្ថានសម្រាល ចំពោះការដាក់ទោសដល់ម្ចាស់បណ្ដឹងសាទុក្ខ។**

*ការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងការសហការរបស់គាត់ជាមួយ អ.វ.ត.ក*[4752]

1300. ម្ចាស់បណ្ដឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា ការដាក់ទោសរូបគាត់គួរត្រូវបានកាត់បន្ថយដោយសារការសហការរបស់គាត់ជាមួយ អ.វ.ត.ក[4753]។ អ.ជ.ស.ដ យល់ឃើញយ៉ាងត្រឹមត្រូវថា ការចូលរួមរបស់ម្ចាស់បណ្ដឹងសាទុក្ខជាមួយ អ.វ.ត.ក "មិនលើសពីលក្ខខណ្ឌតម្រូវអប្បបរមាតាមផ្លូវច្បាប់នៅក្នុងសវនាការរបស់តុលាការ" ហេតុនេះវាពុំមែនជាស្ថានសម្រាលទោស ឬស្ថាន

---

[4747] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១៩។

[4748] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩០ ជើងទំព័រ ១៤១៧៦ *ដកស្រង់* កថាខណ្ឌ ៥៦៤-៥៦៩ (នៅពេល អ.ជ.ស.ដ យល់ឃើញថា ម្ចាស់បណ្ដឹងសាទុក្ខបានសិក្សាច្បាប់ និងសេដ្ឋកិច្ច ផ្ដោតលើកំណែទម្រង់សេដ្ឋកិច្ចនៅកម្ពុជា ក្លាយជាមេដឹកនាំ*ក្រុមម៉ាក្សនិយម* កាលនៅជានិស្សិត ហើយថា និក្ខេបបទរបស់គាត់ស្ដីពីកំណែទម្រង់សេដ្ឋកិច្ចនៅកម្ពុជា "បង្ហាញជាមុននូវទិដ្ឋភាពនៃមនោគមន៍វិជ្ជារបស់ ប.ក.ក")។

[4749] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៦៥។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៥៣។

[4750] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៦៤។

[4751] <u>មូលដ្ឋានទី ២៥៥</u>៖ ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ *កំហុសពាក់ព័ន្ធនឹងស្ថានសម្រាលទោស* កថាខណ្ឌ ២១៦៨-២១៧៧។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខ ទំព័រ ៨៤-៨៥ (ភាសាអង់គ្លេស) ទំព័រ ៧៨ (ភាសាបារាំង) ទំព័រ ១២០ (ភាសាខ្មែរ)។

[4752] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៦៨-២១៧១។

[4753] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៧១។

ទម្ងន់ទោស ក្នុងគោលបំណងនៃការដាក់ទោសរូបគាត់ឡើយ[4754]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែមិនយល់ស្របទៅនឹងការវាយតម្លៃរបស់ អ.ជ.ស.ដ ចំពោះការចូលរួមរបស់គាត់ប៉ុណ្ណោះ[4755]។ ម្ចាស់បណ្តឹងសាទុក្ខអះអាងថែមទៀតថា អ.ជ.ស.ដ មិនបានពិចារណាពីការទទួលស្គាល់របស់គាត់ចំពោះការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[4756] ខណៈមិនអើពើដែលថា "ការសូមទោស" នីមួយៗដែលគាត់បានធ្វើនោះ អមទៅដោយយុត្តិកម្មរបស់គាត់ចំពោះការឈឺចាប់របស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម និងការកាត់បន្ថយនូវតួនាទីរបស់គាត់ ចំពោះការឈឺចាប់នោះ[4757]។

*ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងវ័យចាស់ជរា និងសុខភាពរបស់គាត់*[4758]

1301. ម្ចាស់បណ្តឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា អ.ជ.ស.ដ មានកំហុសដោយមិនបានផ្តល់សំអាងហេតុ ចំពោះការវាយតម្លៃរបស់ខ្លួនអំពីវ័យចាស់ជរារបស់គាត់ថា ជាស្ថានសម្រាលទោស[4759]។ ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខមិនអាចទទួលយកបានទេ។ ទីមួយ ការអះអាងទាំងនោះមានភាពផ្ទុយគ្នា ដោយទទួលស្គាល់ថា អ.ជ.ស.ដ បានផ្តល់ "ស្ថានសម្រាលទោសតិចតួចបំផុត"[4760] ដល់វ័យចាស់ជរារបស់គាត់ ដោយក្រោយមកទៀតអះអាងថា អង្គជំនុំជម្រះ "មិនគិតថាវ័យចាស់ជរារបស់គាត់ជាស្ថានសម្រាលទោស"[4761]។ ទីពីរ ភាពពាក់ព័ន្ធនៃការពិចារណាទៅដល់វ័យចាស់ជរានៅក្នុងសេចក្តីសម្រេចបំបែកសំណុំរឿង ០០២[4762] មានភាពមិនច្បាស់លាស់ ជាពិសេស ដូចដែលម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថា ដោយសារ អ.ជ.ស.ដ ពិតជាបានផ្តល់ការថ្លឹងថ្លែងខ្លះដល់វ័យចាស់ជរារបស់គាត់នៅក្នុងការដាក់ទោសរូបគាត់។ ចុងក្រោយ ការអះអាងរបស់គាត់ ក្នុងការគាំទ្រដល់ការបន្ថយទោស ដោយសារវ័យចាស់ជរា សំអាងម្តងទៀតទៅលើការប្រៀបធៀបអំពីការដាក់ទោសដោយតុលាការផ្សេងទៀត នៅក្នុងសំណុំរឿងផ្សេង[4763]។

---

[4754] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩៧ ជើងទំព័រ ១៤១៨៦។

[4755] *សូមមើលឧទាហរណ៍* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៦៩។

[4756] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧០។

[4757] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៤៥។

[4758] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧២-២១៧៧។

[4759] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧២។

[4760] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧២ *ដកស្រង់* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩៨។

[4761] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧៤។

[4762] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧២។

[4763] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧៣-២១៧៤។ សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ២៥៣។

1302. ទាក់ទិននឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អ.ជ.ស.ដ មិនបានពិចារណាដល់សុខភាពរបស់គាត់[4764] អ.ជ.ស.ដ បានកត់សម្គាល់យ៉ាងត្រឹមត្រូវថា សុខភាពមិនល្អត្រូវបានយកមកពិចារណាជាស្ថានសម្រាលទោស តែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ[4765]។ ដោយពិចារណាដល់មតិយោបល់របស់អ្នកជំនាញវេជ្ជសាស្ត្រស្តីពីសុខភាពរបស់ម្ចាស់បណ្តឹងសាទុក្ខ[4766] ដែលបានយល់ឃើញក្នុងចំណោមនោះថា "ចង្វាក់បេះដូង ភាពស្តេកស្តាំង ដង្ហើម និងចលនាបេះដុំ [របស់គាត់] មានភាពធម្មតា"[4767] គាត់ "ហាត់ប្រាណនៅពេលល្ងាច អាចដើរបានដោយគ្មានជំនួយទប់ ហើយអាចអាន និងរៀបចំឯកសារបាន"[4768] "ស្ថានភាពស្មារតី [របស់គាត់] មានសភាពធម្មតា [...] ការចងចាំរយៈពេលខ្លី ការផ្តង់អារម្មណ៍ និងការផ្តោតអារម្មណ៍របស់គាត់ល្អប្រសើរទាំងអស់សម្រាប់វ័យគាត់"[4769] អ.ជ.ស.ដ បានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា "កាលៈទេសៈនៃរឿងក្តី" ពុំមានលក្ខណៈពិសេស ដែលតម្រូវឲ្យយកការពិចារណាពីសុខភាពមិនល្អមកធ្វើជាស្ថានសម្រាលទោសទេ[4770]។

## *មូលដ្ឋានទី ២៥៦៖ កំហុសស្តីពីសីលធម៌ល្អ*[4771]

---

[4764] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧៥-២១៧៧។

[4765] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩៨ *ដកស្រង់* សេចក្តីសម្រេចដាក់ទោសរឿងក្តី *Simić* កថាខណ្ឌ ៩៧-៩៨, សាលក្រមរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៨៤៨។ អ.ជ.ស.ដ នៃរឿងក្តី *Simić* បញ្ចេញយោបល់ថា "បញ្ហានានាដែលពាក់ព័ន្ធនឹងសុខភាពមិនល្អរបស់ពិរុទ្ធជនជាធម្មតា គួរតែជាបញ្ហាដែលយកមកពិចារណា ក្នុងការអនុវត្តទោសដែលត្រូវវាស់វែង។ ហេតុនេះ មានតែក្នុងកាលៈទេសៈពិសេស ឬករណី "ដោយកម្រ" ប៉ុណ្ណោះ ដែលសុខភាពមិនល្អត្រូវបានពិចារណាជាស្ថានសម្រាលទោស", អ.ជ.ស.ដ នៃរឿងក្តី *Kordić and Čerkez* កានកត់សម្គាល់ថា សុខភាពមិនល្អអាចត្រូវបានពិចារណាជាស្ថានសម្រាលទោសបាន តែ "កត្តាទាំងនេះនឹងមានភាពខុសៗគ្នាទៅតាមកាលៈទេសនៃរឿងក្តីនីមួយៗ ដោយអាស្រ័យទៅតាម "កាលៈទេសៈជាឯកត្តបុគ្គល""។

[4766] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩៨ *ដកស្រង់* ឯកសារ **E460/5** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសម្បទារបស់ ខៀវ សំផន។

[4767] ឯកសារ **E460/5** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសម្បទារបស់ ខៀវ សំផន កថាខណ្ឌ ៣។

[4768] ឯកសារ **E460/5** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសម្បទារបស់ ខៀវ សំផន កថាខណ្ឌ ៥។

[4769] ឯកសារ **E460/5** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសម្បទារបស់ ខៀវ សំផន កថាខណ្ឌ ៦។

[4770] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩៨។

[4771] <u>មូលដ្ឋានទី ២៥៦</u>៖ ឯកសារ F54 សារណាបណ្តឹងសាទុក្ខ *កំហុសស្តីពីសីលធម៌មិនល្អ* កថាខណ្ឌ ២១៧៨-២១៨៣។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខ ទំព័រ ៨៥ (ភាសាអង់គ្លេស) ទំព័រ ៧៩ (ភាសាបារាំង) ទំព័រ ១២០-១២១ (ភាសាខ្មែរ)។

1303. **មូលដ្ឋានទី ២៥៦ គួរត្រូវបានបដិសេធចោល ដោយសារម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ បានប្រព្រឹត្តកំហុសពាក់ព័ន្ធ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលថ្លឹងថ្លែងដល់សាក្សីបញ្ជាក់អត្តចរិត ក្នុងការដាក់ទោសដល់ម្ចាស់បណ្ដឹងសាទុក្ខ។**

1304. ម្ចាស់បណ្ដឹងសាទុក្ខអះអាងដោយគ្មានមូលដ្ឋានថា នៅក្នុងសំណុំរឿង ០០២/០២ អ.ជ.ស.ដ មានកំហុសដោយមិនបានធ្វើការថ្លឹងថ្លែងទៅលើសាក្សីបញ្ជាក់អត្តចរិត ដែលបាននិយាយក្នុងនាមរូបគាត់ នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០១[4772]។ អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២/០២ កត់សម្គាល់ថា អ.ជ.ស.ដ នៅក្នុងសំណុំរឿង ០០២/០១ បានស្ដាប់សក្ខីកម្មពីសាក្សីប្រភេទនេះចំនួន ៥ នាក់ ដោយបានផ្ដល់ការថ្លឹងថ្លែងតិចតួចដល់ការដាក់ទោស[4773] ហើយត្រូវបានតម្កល់នៅដំណាក់កាលបណ្ដឹងសាទុក្ខទៅ អ.ជ.ត.ក[4774]។ នៅក្នុងបណ្ដឹងសាទុក្ខនេះ ម្ចាស់បណ្ដឹងសាទុក្ខបានយោងទៅសាក្សីដដែលទាំងនេះ[4775]។ ដូចបានកត់សម្គាល់ខាងលើ[4776] ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មិនបានពិចារណាទៅលើចម្លើយសាក្សីទាំងនេះទេ។ ការណ៍ដែលថា អ.ជ.ស.ដ មិនបានផ្លាស់ប្ដូរការវាយតម្លៃភស្តុតាងពីមុនរបស់ខ្លួន ពុំមែនជាកំហុសឆ្គងទេ។ ម្ចាស់បណ្ដឹងសាទុក្ខមិនបានបង្ហាញថា អ.ជ.ស.ដ មិនយកចិត្តទុកដាក់ចំពោះភស្តុតាងនោះទេ។ អង្គជំនុំជម្រះគ្រាន់តែយល់ឃើញថា ភស្តុតាងនេះមិនគ្រប់គ្រាន់ធ្វើឱ្យប៉ះពាល់ទៅដល់ការសម្រេចដាក់ទោសត្រឹមត្រូវនោះទេ[4777]។

1305. ក្រៅពីនេះ ម្ចាស់បណ្ដឹងសាទុក្ខកំណត់មិនបានត្រឹមត្រូវនូវភស្តុតាងនានាដែលគាត់មានបំណងយកមកធ្វើជាសំអាង។ សាក្សីដែលត្រូវបានដកស្រង់ អាចបានមក "ផ្ដល់សក្ខីកម្មលើអង្គហេតុដែល

---

[4772] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៧៨។

[4773] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩៩ ជើងទំព័រ ១៤១៩០។

[4774] ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១៥-១១១៦។

[4775] ឯកសារ F54 សារណាបណ្ដឹងសាទុក្ខ កថាខណ្ឌ ២១៧៨ ជើងទំព័រ ៤១៧៩, ៤១៨១ *ដកស្រង់* សក្ខីកម្មរបស់សាក្សីដដែល ដែលម្ចាស់បណ្ដឹងសាទុក្ខបានយោងនៅក្នុង ឯកសារ F17 សារណាបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៥៦ ជើងទំព័រ ១៣៦១ *យោងទៅ* ឯកសារ E295/6/4 សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ២០៨ ជើងទំព័រ ៣៤៨-៣៤៩។

[4776] សូមមើល ចម្លើយតបទៅនឹងមូលដ្ឋានទី ១៦។

[4777] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៩៩ ជើងទំព័រ ១៤១៩០ *យោង* សេចក្ដីពិចារណាពីមុនរបស់ខ្លួនទៅសាក្សីបញ្ជាក់អត្តចរិត ៥ នាក់ ដែលបានផ្ដល់សក្ខីកម្មក្នុងនាមម្ចាស់បណ្ដឹងសាទុក្ខ។ សូមមើលផងដែរ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៩៩-១១០៣។

បានបញ្ជាក់ជាឯកច្ឆ័ន្ទអំពីសីលធម៌ល្អរបស់គាត់”[4778] តែសាក្សីទាំងនោះមិនបានផ្តល់សក្ខីកម្ម “សុទ្ធតែស្ញើចសរសើរ”[4779] នោះទេ។ ឧទាហរណ៍ សាក្សី François Ponchaud បានផ្តល់សក្ខីកម្មថា ក្នុងអំឡុងឆ្នាំ១៩៧០ គាត់ស្ញើចសរសើរម្ចាស់បណ្តឹងសាទុក្ខ តែ “ក្រោយមកជារឿងផ្សេង”[4780]។ សាក្សី Philip Short បានផ្តល់សក្ខីកម្មថា ម្ចាស់បណ្តឹងសាទុក្ខធ្វើអ្វីទៅតាមគេប្រាប់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយ *រហូតដល់ឆ្នាំ១៩៧៥* គាត់មានកេរ្តិ៍ឈ្មោះជាមនុស្សស្មោះត្រង់ និងមានសុចរិតភាព[4781]។ សាក្សី នួរ ហ៊ាន់ បានផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយយោងទៅសុភាសិតខ្មែរថាៈ “ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់” ហើយនៅពេលម្ចាស់បណ្តឹងសាទុក្ខទៅរស់នៅជាមួយពួកខ្មែរក្រហមចិត្តខ្មៅ គាត់ក្លាយត្រីស្អុយនឹងគេដែរ។ គាត់ក៏បានបានផ្តល់សក្ខីកម្មផងដែរថា ម្ចាស់បណ្តឹងសាទុក្ខមិនស្រឡាញ់ជាតិខ្លួនទេ ផ្ទុយទៅវិញគាត់បំផ្លាញជាតិឯង[4782]។

1306. សាក្សីផ្សេងទៀតបានទទួលស្គាល់ថា គាត់មិនបានដឹងឮពីសកម្មភាពរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬមិនមានទំនាក់ទំនងជាមួយគាត់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ និង/ឬ មិនបានស្គាល់ម្ចាស់បណ្តឹងសាទុក្ខដោយផ្ទាល់ទេ[4783]។ ភស្តុតាងនេះពិតជាមិន

[4778] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៧៩។

[4779] ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២១៨០។

[4780] ឯកសារ **E1/178.1** សាក្សី François Ponchaud ប្រតិចារឹក ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤, ម៉ោង ០៩.៣៦.៥២-០៩.៣៨.៤៨ ទំព័រ ៩ បន្ទាត់ ២២។

[4781] ឯកសារ **E1/189.1** សាក្សី Philip Short ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៤, ម៉ោង ១១.៣៥.៤២-១១.៣៧.១០ ទំព័រ ៤១ បន្ទាត់ ១៩ ដល់ ទំព័រ ៤២ បន្ទាត់ ៧។

[4782] ឯកសារ **E1/199.1** សាក្សី នួរ ហ៊ាន់ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣, ម៉ោង ១០.២៩.៣៦-១០.៣២.០២ ទំព័រ ៣១ បន្ទាត់ ១-១៥, ម៉ោង ១៣.៥២.៥៥-១៣.៥៤.៥៣ ទំព័រ ៦៥ បន្ទាត់ ១៣-២៥។

[4783] សូមមើលឧទាហរណ៍ ឯកសារ **E1/194.1** សាក្សី ព្រំ ស៊ូ ប្រតិចារឹក ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣, ម៉ោង ១៤.៤១.២៩-១៤.៤៣.៤៤ ទំព័រ ៦៥ បន្ទាត់ ៧-២២, ម៉ោង ១៥.២០.៤៨-១៥.២៥.៤៥ ទំព័រ ៧១ បន្ទាត់ ១១-ទំព័រ ៧២ បន្ទាត់ ១៩ (លើកឡើងថា គាត់មិនបានដឹងពីតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យទេ មិនបានទាក់ទងជាមួយគាត់ពីឆ្នាំ១៩៦៧-១៩៩០ មិនបានដឹងឮពីសុន្ទរកថា ការសង្កេតផ្ទាល់ និងការវិភាគរបស់សាក្សីជាការស្មានៗដោយផ្អែកលើអ្វីដែលគាត់បានដឹងពីម្ចាស់បណ្តឹងសាទុក្ខកាលពីអតីតកាល និងអ្វីដែលគាត់បានឃើញ និងបានឮពីសាក្សីចាប់ពីឆ្នាំ២០០០ មក)។ ឯកសារ **E1/203.1** សាក្សី សុខ អឿ ប្រតិចារឹក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣, ម៉ោង ១៣.៣៣.៥៧-១៣.៣៩.០១ ទំព័រ ៦០ បន្ទាត់ ៨ ដល់ ទំព័រ ៦១ បន្ទាត់ ១៤, ម៉ោង ១៣.៤៨.១៩-១៣.៥០.០៦ ទំព័រ ៦៤ បន្ទាត់ ១១-២០, ម៉ោង ១៤.៤៩.៣០-១៤.៥៤.៤៦ ទំព័រ ៧៧ បន្ទាត់ ១៥ ដល់ ទំព័រ ៧៩ បន្ទាត់ ១ (អង្គរក្សរបស់ម្ចាស់បណ្តឹងសាទុក្ខក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ បាននិយាយថា គាត់ធ្លាប់បាននិយាយជាមួយម្ចាស់បណ្តឹងសាទុក្ខអំពីអ្វីដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ទេ មិនបានដឹងពីទង្វើរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យទេ)។ ឯកសារ **E1/103.1** សាក្សី អ៊ុង

គ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរការកំណត់របស់ អ.ជ.ស.ដ អំពីការដាក់ទោសសមស្របនោះទេ ជាពិសេសទាក់ទិននឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលម្ចាស់បណ្តឹងសាទុក្ខត្រូវបានសម្រេចដាក់ពិរុទ្ធភាព។ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញនូវកំហុសដែលអាចវិនិច្ឆ័យបានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ ក្នុងការវាយតម្លៃទៅលើចម្លើយរបស់សាក្សីទាំងនេះ ដែលត្រូវបានយកមកពិចារណាពីមុនដោយ អ.ជ.ស.ដ និង អ.ជ.ត.ក ក្នុងសំណុំរឿង ០០២/០១ នោះទេ។ ហេតុនេះ ពុំតម្រូវឱ្យមានអន្តរាគមន៍ពី អ.ជ.ត.ក ឡើយ។

## X. សេចក្តីសន្និដ្ឋាន

1307. សរុបមក សហព្រះរាជអាជ្ញាសូមអះអាងដោយគោរពថា ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញកំហុសឆ្គងដែលតម្រូវឱ្យមានអន្តរាគមន៍លើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿងនេះទេ។ អ.ជ.ស.ដ បានសម្រេចដាក់ពិរុទ្ធភាពដល់ម្ចាស់បណ្តឹងសាទុក្ខទៅតាមផ្លូវច្បាប់ និងសមហេតុផល ថា បានប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម (១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (២) អំពើប្រល័យពូជសាសន៍ និង (៣) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃការជួយ និងជំរុញដល់អំពើមនុស្សឃាតដោយ*ចេតនាដោយប្រយោល*។ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានរកឃើញថាបានចូលរួមយ៉ាងទូលំទូលាយ និងយ៉ាងធំធេងទៅក្នុងឧក្រិដ្ឋកម្មទាំងនេះ[4784] ម្ចាស់បណ្តឹងសាទុក្ខត្រូវបានដាក់ទោសយ៉ាងត្រឹមត្រូវឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ ហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំដោយគោរពដល់ អ.ជ.ត.ក មេត្តា៖

(១) **បដិសេធ** បណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខទាំងមូល។ និង

(២) **តម្កល់** ការសម្រេចផ្តន្ទាទោស និងការដាក់ទោសដោយ អ.ជ.ស.ដ នៅក្នុងសាលក្រមរបស់ខ្លួន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

សូមលោកចៅក្រមមេត្តាទទួលយកចម្លើយតបនេះដោយក្តីគោរព

---

ថុងហឿន ប្រតិចារឹក ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២, ម៉ោង ១៤.០២.២៧-១៤.០៤.១៩ ទំព័រ ៦១ បន្ទាត់ ២៤ ដល់ ទំព័រ ៦២ បន្ទាត់ ១៤ (លើកឡើងថាមិនដែលជួបម្ចាស់បណ្តឹងសាទុក្ខដោយផ្ទាល់ទេ រហូតដល់ពេលមកផ្តល់សក្ខីកម្ម)។

[4784] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៨៥។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោកស្រី Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | |